TEP-YOK et THAO-KUN

Membres de la commission culturelle

DICTIONNAIRE

FRANÇAIS-KHMER

1ère partie

A - J

50.000 mots

1ère édition

1962

Librairie BOUT-NEANG

N° 176, Rukhak Vithei Khemarak Phoumin

PHNOM-PENH

Tous droits réservés

ការយល់ឃើញ

សៀវភៅ វចនានុក្រម ភាគ១-២ របស់លោក [illegible] និង លោក [illegible] នេះ មានសារៈសំខាន់ណាស់ សម្រាប់កុលបុត្រ-កុលធីតា [illegible] ដែលត្រូវការ [illegible] ។

[illegible] ពិនិត្យមើលសៀវភៅលោក [illegible] [illegible] [illegible] [illegible], នេះ [illegible] [illegible] [illegible] [illegible] [illegible] [illegible] [illegible] [illegible] [illegible] [illegible] ។

[illegible] [illegible] [illegible] [illegible] [illegible] [illegible] [illegible] ។ [illegible] [illegible] [illegible] [illegible] [illegible] [illegible], [illegible] [illegible] [illegible] [illegible] [illegible] ៥ [illegible] "[illegible] [illegible] [illegible] [illegible] ([illegible]) [illegible] [illegible]" ។ [illegible] [illegible] [illegible] ។

ថ្ងៃទី ៨ មិថុនា ២៥០៩ / ១៩៦៦

សម្ដេចព្រះមហាសុមេធាធិបតី
ជ. ណ. ជោតញ្ញាណោ

[signature]

បុព្វយោគ

សៀវភៅវចនានុក្រមបារាំង-ខ្មែរនេះ យើងខ្ញុំបានរៀបរៀងឡើង ដោយមានគោលបំណងពីរគឺ :

១– ជួយជនរួមជាតិយើងក្នុងការសិក្សាភាសាបារាំង ឬក្នុងការប្រែអត្ថបទពីភាសាបារាំងជាភាសាខ្មែរ ;

២- ជួយលើកស្ទួយអក្សរសាស្ត្រយើង ។

x
x x

ដើម្បីសម្រេចគោលបំណងខាងលើនេះ យើងខ្ញុំបានខិតខំរចនាសៀវភៅនេះឱ្យប្រកបដោយលក្ខណៈដូចតទៅនេះ :

ក– **ការប្រែន័យផ្សេងៗនៃពាក្យបារាំង** គឺន័យខាងគណិតសាស្ត្រ, តាកសាស្ត្រ, នីតិសាស្ត្រ, វិទ្យាសាស្ត្រ, នយោបាយ, បច្ចេកទេស, យោធា ។ល។ សម្រាប់ប្រើឲ្យទៅតាមកម្រិតនៃអត្ថបទ ។

យើងខ្ញុំសុំលើកតែពាក្យពីរមកធ្វើជាឧទាហរណ៍ជូនដូចខាងក្រោម :

mine ខាងយោធា មានន័យថា "គ្រាប់បែកកប់" ខាងឧស្សាហកម្មថា "អណ្ដូងរ៉ែ" ;

brut មានន័យថា "កម្រោល" បំពោះមនុស្ស ឬ សត្វ គឺសត្វ "កម្រោល" ឬ "គ្មានការអប់រំ" (bête brute), បំពោះវត្ថុផ្សេងៗ គឺ

វត្ថុ «មិនទាន់រចនា» (matière brute); មិនទាន់ច្នៃ (diamant brut); រីឯ eau brute, poids brut គប្បីប្រែថា «ទឹកអសិទ្ធ, ទម្ងន់សរុប» ពុំគួរថា «ទឹកគ្មានការអប់រំ, ទម្ងន់គ្មានការអប់រំ» ឡើយ ។

ខ_ **ការប្រែសំនួនសេចក្តី** ។ លក្ខណៈនេះសំខាន់ណាស់ ព្រោះពាក្យនីមួយៗ កាលប្រើដាច់ឡែកមានន័យផ្សេង លុះប្រើក្នុងសំនួនសេចក្តីរមែងមានន័យផ្សេង ឧទាហរណ៍ :

– donner un coup de main ជួយ (មិនមែនវាយមួយដៃទេ)

– jeter l'argent par la fenêtre ចាយខ្ជះខ្ជាយ (មិនមែនបោះប្រាក់តាមបង្អួចទេ) ។

សូម្បីតែសំនួនសេចក្តីដដែលទៀត ក៏មានន័យខុសៗគ្នាដែរ តាមកាលៈទេសៈ ឧទាហរណ៍ « ordre du jour » ខាងនយោបាយ មានន័យថា «របៀបការៈ» (ឧ. របៀបការៈនៃរដ្ឋសភា, នៃសម័យប្រជុំ), ខាងយោធាមានន័យថា «ការបញ្ជា» (ឧ. ការបញ្ជានៃឧត្តមសេនីយ «ក»)

គ_ **ការប្រែសុភាសិត** ។ សុភាសិតនេះគួរជាទីចាប់អារម្មណ៍នៃអ្នកប្រាជ្ញណាស់ ព្រោះជាកញ្ចក់អាចឆ្លុះមើលវប្បធម៌ និងអារ្យធម៌នៃជនជាតិណាមួយបាន ។ ក្នុងការប្រែសុភាសិតនេះ យើងខ្ញុំបានស្រាវជ្រាវរកសុភាសិតខ្មែរ ដែលមានន័យស្មើនឹងសុភាសិតបារាំង, ពិតមែនតែមានសេចក្តីខុសគ្នា ឧទាហរណ៍:

– chercher midi à quatorze heures អន្ទង់ថ្ងៃរកឆ្នាំងថ្ងៃ

– se trouver entre l'enclume et le marteau ចុះទឹកក្រពើ ឡើងលើខ្លា

– il faut battre le fer pendant qu'il est chaud ធ្វើស្រែទាន់ក្តៅដី ។ល។

ឃ- **ការប្រែតាមតម្លៃពាក្យ** ។ ក្នុងការប្រែនេះ យើងខ្ញុំបានស្រាវជ្រាវរកពាក្យខ្មែរដែលមានន័យស្មើនឹងពាក្យបារាំង បើពាក្យបារាំងជាពាក្យថ្លៃថ្នូរ ឬជាពាក្យសម្រាប់ប្រើក្នុងកាព្យឃ្លោង ឬ ក៏ជាពាក្យធម្មតា យើងខ្ញុំក៏រកពាក្យខ្មែរដែលមានលក្ខណៈដូចគ្នាដែរ ឧទាហរណ៍ :

– courroux ក្រោធ

– colère កំហឹង ។

បើពាក្យបារាំងជាពាក្យសាមញ្ញ យើងខ្ញុំក៏រកពាក្យខ្មែរសាមញ្ញដែរ ឧទាហរណ៍:

– prendre la poudre d'escampette ដាក់មេជាយ

– écrire comme un chat សរសេរអក្សរដូចជើងក្តាម ។

ចំពោះរឿងនេះ យើងខ្ញុំសូមអភ័យទោសជាមុន អំពីសំណាក់អស់លោកដែលយល់ថាមិនគួរយកពាក្យសាមញ្ញ ពាក្យផ្សារ មកដាក់

ក្នុងសៀវភៅបែបនេះ ។

x

x x

ឯវិធីរៀបរៀងសៀវភៅនេះ មានដូចតទៅ :

ក– យើងខ្ញុំបានប្រមូលពាក្យទាំងអម្បាលម៉ាន ដែលគណៈកម្មការវប្បធម៌បានប្រែហើយ យកមកដាក់ទាំងអស់ ;

ខ– យើងខ្ញុំបានយកពាក្យដែលគណៈកម្មការវប្បធម៌បានប្រែហើយ ធ្វើជាឫសគល់ ដើម្បីប្រែពាក្យដែលមានសន្ទានជាមួយគ្នា ;

គ– ក្រៅពីនេះ យើងខ្ញុំបានស្រាវជ្រាវរកពាក្យបុរាណនិងពាក្យខ្មែរសុទ្ធៗ ដោយឥតមានរួញរានឹងសួរអ្នកស្រែចំការ, ជាងឈើ, ជាងដែក, ជាងទង, អ្នកនេសាទ, អ្នកបរទេះសេះ ឬកូនក្មេងតូចតាច ។ ល ។ ដើម្បីរកពាក្យត្រូវឡើយ ;

ឃ– ចំពោះពាក្យខ្លះទៀត ដែលជនសាមញ្ញស្គាល់មិនជាក់ហើយ ដែលមិនទាន់មានក្នុងវចនានុក្រមខ្មែរ យើងខ្ញុំបានចូលទៅគាល់សម្ដេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ ទូលសួរបញ្ជាក់ន័យនិងអត្ថាធិប្បាយ ដូចជាពាក្យ "គ្រាវ" (សម្ងំផ្លាស់នៅពេលឡើងខ្លួន) និង "ស្រឡៀវខន" ជាដើម ។

x

x x

ក្នុងការរៀបរៀងនេះ សូម្បីយើងខ្ញុំបានយកចិត្តទុកដាក់យ៉ាងណា ក៏គង់នៅមានសេចក្ដីខាតខុសលើសលស់ខ្លះមិនខាន សមដូចសុភាសិតថា "ដំរីជើងបួនជួនមានភ្លាត់ អ្នកប្រាជ្ញបេះស្អាតជួនមានភ្លេច" ។

តាំងក្នុងការកែវិញ្ញាសាទៀត ទោះបីយើងខ្ញុំបានធ្វើជាច្រើនដង ច្រើនសារទឹងដោយម៉ត់ចត់ដូចម្ដេច ក៏គង់នៅមានចន្លោះជាច្រើនអន្លើ ។ ដើម្បីលុបលាងកំហុសនេះ យើងខ្ញុំសូមកែលើសៀវភៅនេះឲ្យស្រេច ទើបបញ្ចេញលក់ ។

ម្យ៉ាងទៀត ក្នុងពេលដែលសៀវភៅនេះបោះពុម្ពហួសទៅហើយ គណៈកម្មការវប្បធម៌បានប្រែពាក្យថ្មីទៅទៀត ឬបានលើកពាក្យខ្លះដែលប្រែរួចហើយ ប៉ុន្តែមានន័យមិនសូវច្បាស់លាស់យកមកពិនិត្យប្រែឡើងវិញ ។ ដើម្បីជូនលោកអ្នកជ្រាបនូវពាក្យទាំងនោះ យើងខ្ញុំបានធ្វើភាគពិសេសមួយជូនជាប់មកនេះ ។

x

x x

ជាពិសេស យើងខ្ញុំសូមបញ្ជាក់ថា សៀវភៅនេះគ្មានអានុភាពធ្វើឲ្យលោកអ្នកប្រែភាសាក្លាយទៅជាម៉ាស៊ីនបានឡើយ ពោលគឺពាក្យដែលប្រែទាំងប៉ុន្មាន មិនអាចយកទៅប្រើគ្រប់អត្ថបទបានទេ ពាក្យទាំងនេះគ្រាន់តែជាគោល ។ ដូច្នេះ លោកអ្នកប្រែភាសាត្រូវរើសរកជម្រៅ

សេចក្ដីនៃអត្ថបទដើមសិន សឹមប្រែសម្រួលពាក្យទីមួយ ៗ ឲ្យសមតាមន័យក្នុងអត្ថបទនោះ ។

ការប្រែភាសាជាការលំបាកបំផុត ព្រោះធម្មតាពាក្យរបស់ប្រជាជាតិពីរដែលមានអារ្យធម៌នឹងវប្បធម៌ខុសគ្នា ពុំដែលមានន័យត្រូវគ្នាដោយសុទ្ធសាធឡើយ ហើយការរកពាក្យខ្មែរឲ្យមានតម្លៃស្មើនឹងពាក្យបារាំង ក៏ជាការកម្រណាស់ ។ ដូច្នេះ ការប្រែភាសាតែងតែមានសេចក្ដីល្អៀងឃ្លៀងឃ្លាតពីន័យដើមខ្លះជាធម្មតា សមតាមភាសិតបារាំងថា «traduire c'est trahir» ។

x

x x

នៅទីបញ្ចប់ យើងខ្ញុំសូមអភ័យទោសអំពីសំណាក់លោកអ្នកអាន ដោយមានការចាំបាច់ តម្រូវឲ្យបែងចែកសៀវភៅនេះជាពីរភាគ ដើម្បីចៀសវាងកុំឲ្យក្រាស់ពេក នាំឲ្យមិនល្អមើលផង ដោយហេតុបច្ចេកទេសខាងពេងពុម្ពផង ។

ឆ.យ. ង៉ង ឌ.ក.

ពាក្យបំប្រួញប្រើក្នុងសៀវភៅនេះ

a.	adjectif
Abrév.	abréviation
Absol.	absolument
Abusiv.	abusivement
Acoust.	acoustique
Adm.	administration
adv.	adverbe
Aéron.	aéronautique
Agric.	agriculture
Alg.	algèbre
Anat.	anatomie
Apic.	apiculture
Arbor.	arboriculture
Archit.	architecture
Arg.	argot
Arithm.	arithmétique
Art cul.	art culinaire
Arts graph.	arts graphiques
Astr.	astronomie
Autom.	automobile
Av.	aviation
Biol.	biologie
Bot.	botanique
Bx-arts	beaux-arts
Chass.	chasse
Ch. de fer	chemin de fer
Chim.	chimie
Chir.	chirurgie
Chorégr.	chorégraphie
Cin.	cinéma
Com.	commerce
Comptab.	comptabilité
cf.	conférez
conj.	conjonction
Constr.	construction
Cordon.	cordonnerie
Cosm.	cosmographie
Cout.	couture
Cuis.	cuisine
dénigr.	dénigrement
Dr.	droit
Ebénist.	ébénistrerie
Econ. dom.	économie domestique
Econ. pol.	économie politique
Econ. rur.	économie rurale
Equit.	équitation
Escr.	escrime
Esthét.	esthétique
Ethn.	ethnologie
f.	féminin
Fam.	familier
Fig.	figuré
Fin.	finances
Géogr.	géographie
Géol.	géologie
Géom.	géométrie
Gram.	grammaire
Gynéc.	gynécologie
Hist.	histoire
Hist. nat.	histoire naturelle
Hortic.	horticulture
Hyg.	hygiène
Ichtyol.	ichtyologie
Iconogr.	iconographie
indéf.	indéfini
Ind.	industrie
int.	interjection
interr.	interrogatif
inv.	invariable
Ironiq.	ironiquement
Jard.	jardinage
Jeux	jeux
Joaill.	joaillerie
Just.	justice
lat.	latin
Littér.	littérature
Loc.	locution
Loc. adj.	locution adjective
Loc. adv.	locution adverbiale
Loc. conj.	locution conjonctive
Loc. div.	locutions diverses
Loc. fam.	locution familière
Loc. lat.	locution latine
Loc. pré.	locution prépositive
Loc. prov.	locution proverbiale
Log.	logique
m.	masculin
Manèg.	manège
Mar.	marine

Math.	mathématiques
Mécan.	mécanique
Méd.	médecine
Menuis.	menuiserie
Métall.	métallurgie
Météor.	météorologie
Microbiol.	microbiologie
Mil.	militaire
Min.	mines
Minér.	minéralogie
Mus.	musique
Myth.	mythologie
n.	nom
n.f.	nom féminin
n.f. pl.	nom féminin pluriel
n.m.	nom masculin
n.m. pl.	nom masculin pluriel
n. pr.	nom propre
Obstétr.	obstétrique
Opt.	optique
Ornith.	ornithologie
Par anal.	par analogie
Par dénigr.	par dénigrement
Par exag.	par exagération
Par ext.	par extention
Par iron.	par ironie
Par plais.	par plaisanterie
Path.	pathologie
Pêch.	pêche
Pédag.	pédagogie
Peint.	peinture
Péjor.	péjoratif
Pharm.	pharmacie
Phil.	philosophie
Phonét.	phonétique
Phot.	photographie
Phys.	physique
Physiol.	physiologie
pl.	pluriel
Poét.	poétique
Pol.	politique
Pop.	populaire
poss.	possessif
pr.	pronom
préf.	préfixe
pré.	préposition
Procéd.	procédure
Prov.	proverbe
Psych.	psychologie
relat.	relatif
Relig.	religion
Sc.	sciences
scol.	scolaire
Sculpt.	sculpture
Serrur.	serrurerie
sing.	singulier
Sociol.	sociologie
Spécialem.	spécialement
Subst.	substantif
Sylv.	sylviculture
Techn.	technologie
Théâtr.	théâtre
Théol.	théologie
Trav. publ.	travaux publics
Typogr.	typographie
v.	verbe
Vén.	vénerie
Vétér.	art vétérinaire
Verr.	verrerie
v.i.	verbe intransitif
v. impers.	verbe impersonnel
v.pr.	verbe pronominal
v.t.	verbe transitif
v.t. ind.	verbe transitif indirect
Zool.	zoologie

★

★ ★

ព.	ពាក្យ	ព.ផ.	ពាក្យផ្ទុយ	រ.ស.	រាជសព្ទ	ឬ.	ឬបន:
ព.អ.	ពាក្យអង់គ្លេស	ម.ព.	មើលពាក្យ	ឧ.	ឧទាហរណ៍		

ពាក្យដែលគណៈកម្មការវប្បធម៌ទើបនឹងបានប្រែ

ពាក្យបារាំង	ទំព័រ	ពាក្យប្រែថ្មី
abandon *n.m.*	១	*Dr.* ការបោះបង់ ។ abandon de biens ការបោះបង់ទ្រព្យ ។ abandon d'enfant ការបោះបង់កូន ។ abandon de famille ការបោះបង់គ្រួសារ ។ abandon d'infirme ការបោះបង់មនុស្សពិការ ។ abandon du domicile conjugal ការបោះបង់លំនៅសង្វាស
ab irato *loc. lat.*	"	នាពិភេធ (ដោយកំហឹង, ពីកំហឹង) ។ acte ab irato លិខិតនាពិភេធ (លិខិតធ្វើក្នុងពេលកំហឹង)។ action ab irato បណ្ដឹងនាពិភេធ
abordage *n.m.*	៥	*Mar.* នាភសង្ឃ័ដ [—ស័ង-ឃ័ត] (ការប៉ះទង្គិចរវាងនាវាពីរ, ការឡើងវាយលុកនាវា)
absolution *n.f.*	៦	អសាធន [អ:-សា-ធន់] (សេចក្ដីសម្រេចរបស់តុលាការ ដែលកាត់ឲ្យមនុស្សជាប់ចោទរួចខ្លួន ព្រោះមានកាលទេសៈណាមួយនាំឲ្យផុតពីទោស ទោះបីមានពិរុទ្ធលើរូបមនុស្សនោះក៏ដោយ)
abstentionnisme *n.m.*	៧	អនុបវាទនិយម
abus *n.m.*	៧	ទុរុបយោគ (អំពើលោភ, ការប្រព្រឹត្តហួសប្រមាណ) ។ abus d'autorité ទុរុបយោគអាជ្ញា ។ abus de blanc-seing ទុរុបយោគលើហត្ថលេខាណាត ។ abus des passions d'un mineur ទុរុប-

ពាក្យបារាំង	ទំព័រ	ពាក្យប្រែថ្មី
analyse *n.f.*	៤៥	*Math.* analyse vectorielle វិភាគទិសយុត្ត
angulaire *a.*	៤៨	pierre angulaire ថ្មឥន្ទកីល [–អិន-ទ:-កិល]
animateur, trice *n.*	"	ជីវតាលក៍ [--វ:-តាល]
animation *n.f.*	"	ជីវបលតា [—វ:-ប:-ល:-ណា]
animé,e *a.*	"	ជីវបល [— វ:-បល់]
animisme *n.m.*	"	ជីវបលនិយម [--វ:-ប:-ល:-]
annales *n.f. pl.*	"	សេសិកប្រវត្តិ [សែ-សិ-ក:-]
annaliste *n.m.*	"	អ្នកសេសិកប្រវត្តិ
annexion *n.f.*	៤៩	ទេសានុពន្ធ
annexionnisme *n.m.*	"	ទេសានុពន្ធនិយម [--ព័ន-ធ:-]
anticipation *n.f.*	៥១	កាលាទិករណ៍ [កា-ឡា-ទិ-ករ]
anticyclone *n.f.*	"	ប្រតិចក្រភិត [ប្រ-តិ-ចក្រ:-ភិត]
antimilitarisme *n.m.*	៥២	ប្រតិយោធនិយម
antimilitariste *a.&n.*	៥២	អ្នកប្រតិយោធនិយម
antithèse *n.f.*	៥៣	ប្រតិនិក្ខេបបទ [—និក-ខេ-ប៉:-]
anthropophagie *n.f.*	"	មនុស្សភក្សា
anthropophage *a.&n.*	"	មនុស្សភ័ក្ស
arrêt *n.m.*	៦៩	*Dr.* សាលដីកា (ការវិនិច្ឆ័យនៃតុលាការជាន់ខ្ពស់)
assistance *n.f.*	៧៨	*Adm.* ថ្នាក់ឧបការី។, assistance des hôpitaux ថ្នាក់ឧបការីនៃមន្ទីរពេទ្យ
auteur *n.m.*	៨២	*Dr.* អ្នកប្រព្រឹត្ត ។ auteur principal

ពាក្យបារាំង	ទំព័រ	ពាក្យប្រែថ្មី
		អ្នកប្រព្រឹត្តដើមកេទ៌ ។ ជនក [ជៈ នក់] (អ្នកបង្កើត គឺ ឪពុក, ជីតា ។ល។) ។ auteur commun ជនករួម
autoritaire *r.&a.*	៩៣	អាជ្ញាព្រឹត្ត
autoritarisme *n.m.*	៩៤	អាជ្ញានិយម
blanc-seing *n.m.*	១៥១	ហត្ថលេខាលាត
cannibale *a.&n.*	២២៨	ពោរិសាទ [ពោ រ៉ុ–]
cannibalisme *n.m.*	"	ពោរិសាទនិយម [ពោ-រ៉ុ-សា-ទៈ–]
capitalisation *n.f.*	២៣១	មូលធនកម្ម [មូលៈ-ធនៈ–]
classificateur *n.m.*	៣០៦	វគ្គការី [វ៉ក-គី-កា-រ៉ី-]
classifier *v.t.*	"	វគ្គក្រឹត [វ៉ក -គី–]
clef *n.f.*	៣០៧	clef de voûte សិលាប្រធាន
co-action *n.f.*	៣១២	*Dr.* ការប្រព្រឹត្តរួម
co-auteur *n.m.*	"	អ្នកនិពន្ធរួម ។ *Dr.* អ្នកប្រព្រឹត្តរួម
collatéral,e,aux *a.*	៣១៩	collatéraux directs សាខាញាតិផ្ទាល់
collectivisation *n.f.*	៣២០	សមូហភាវកម្ម
collision *n.f.*	៣២១	សង្ឃដ្ឋនកម្ម [ស័ង-ឃ័ត:-ឋៈ–],ការជល់ទង្គិច
combattant *n.m.*	៣២៥	យុទ្ធជន
concitoyen *n.*	៣៤៦	សហពលរដ្ឋ [សៈ-ហៈ-ពល់–]
concubin,e *a.&n.*	៣៤៧	អនីតិសង្វាសី-សិនី
concussion *n.f.*	៣៤៨	រីតិក្រម
consécration *n.f.*	៣៦១	ឧទ្ទិសកម្ម [អ៊ុត-ទ៌-សៈ–]
conseil *n.m.*	៣៦២	conseil de Prud'hommes ក្រុមប្រឹក្សានិយោជន៍

ពាក្យបារាំង	ទំព័រ	ពាក្យប្រែ
constance *n.f.*	៣៦៧	ថិរភាព
contre-rail *n.m.*	៣៦២	*Ch. de fer* ររណបបីស្ទូប
corrompre *v.t.*	៤០០	សូក
corrompu,e *n.*	"	អ្នកស៊ីសំណូក
corrupteur,trice *a.& n.*	៤០១	អ្នកសូក
corruption *n.f.*	"	សំណូក។ corruption active សំណូកសកម្ម។ corruption passive សំណូកអកម្ម
cynique *a.*	៤៦០	អលជ្ជី
cynisme *n.m.*	"	អលជ្ជីនិយម
cynophile *a.*	"	សុនខភក្តិ (ដែលស្រឡាញ់ឆ្កែ)
délinquant,e *n.*	៥២០	ទោសករ [-សៈ-]
délit *n.m.*	៥២១	ទោសកម្ម [-សៈ-]
détenu,e *n.*	៥៨១	អ្នកជាប់ឃុំ
droit *n.m.*	៦៧៤	នីតិ, នីតិសាស្ត្រ។ droit administratif នីតិរដ្ឋបាល ។ droit civil នីតិបវេណី ។ droit constitutionnel នីតិធម្មនុញ្ញ ។ droit économique នីតិ ឬ សិទ្ធិសេដ្ឋកិច្ច ។ droit international នីតិអន្តរជាតិ ។ droit international privé នីតិអន្តរជាតិឯកជន ។ droit international public នីតិអន្តរជាតិសាធារណៈ ។ droit naturel នីតិធម្មជាតិ ។ droit national នីតិជាតិ ។

ពាក្យបារាំង	ទំព័រ	ពាក្យប្រែថ្មី
		droit pénal នីតិព្រហ្មទណ្ឌ ។ droit privé នីតិឯកជន ។ droit public នីតិសាធារណជន។ droit social នីតិ ឬ សិទ្ធិសង្គម
enfant *n.*	៧៦២	enfant naturel កូនក្រៅច្បាប់
explicite *a.*	៨៦៦	ភិទិក [ភិ-ទិក]
exproprier *v.t.*	៨៦៩	អស្សាមីក្រឹត [អ័ស-សា-មុី-]
flagrant,e *a.*	៩៣១	ជាក់ស្តែង ។ flagrant délit ទោសកម្មជាក់ស្តែង
fruit *n.m.*	៩៨១	fruit civil ផលបវេណី ។ fruit naturel ផលធម្មជាតិ
gamme *n.f.*	៩៩៤	*Mus.* សទ្ទមាលា។ gamme majeure សទ្ទមាលាជេដ្ឋា ។ gamme mineure សទ្ទមាលាកនិដ្ឋា

a *n.m.* អក្សរទីមួយនៃអក្ខរក្រមឡាតាំង ។ prouver par a + b ពន្យល់ដោយគណិតសាស្ត្រ ឬដោយច្បាស់លាស់ ។ ne savoir ni A ni B មិនចេះ ឆ ខ្វាក់។de A jusqu'à Z ពីដើមដល់ចុង

à *pré.* ឯ, ទៅ, នា, កាន់, ដល់, នឹង ។ maison à vendre ផ្ទះត្រូវការលក់

abaca *n.m.* ចេកអាបាកា

abaissant,e *a.* សម្រាប់បន្ទាប,សម្រាប់ទម្លាក់ចុះ ។ *Fig.*ដែលធ្វើឲ្យថោកទាប

abaisse *n.f.* ផែនម្សៅ (ស្រោបនំ)

abaisse-langue *n.m.inv.* ស្លាបព្រាសង្កត់អណ្ដាត (ប្រើក្នុងពេទ្យ)

abaissement *n.m.* ការទម្លាក់ចុះ, ការបន្ទាបឬបន្ថោក។*Fig.*ការដាក់ខ្លួន;ការបំបាក់មុខ;ការបញ្ចុះ(តម្លៃ);ភាពអាប់ឱន

abaisser *v.t.* បន្ទាប,ទម្លាក់ចុះ.ពង្រួតចុះ, បញ្ចុះ។*Fig.*បំបាក់មុខ។s'abaisser *v.pr.*ធ្លាក់ចុះ,ចុះទាប;ដាក់ឬបន្ទាបខ្លួន

abaisseur *a.&n.m.* អនោនទ្ធ

abajoue *n.f.* ថ្ពក់ថ្ពាល់។*Fig.*ថ្ពាល់ហុំ

abalourdir *v.t.* ធ្វើឲ្យងឹងងោង ឬ ឲ្យល្ងេល្ងើ

abandon *n.m.* ការបរិច្ចាគ,ការលះបង់, ការបំភ្លេច;បរិច្ចត្តភាព,ភាពលះបង់, ការតែលតោល(ឥតពំនាក់ពំនឹង)។ à l'abandon *loc.adv.*ដោយគ្មានថែទាំ

abandonnataire *n.Dr.*បរិច្ចត្តគ្រាហក (អ្នកទទួលទ្រព្យដែលគេលះបង់ឲ្យខ្លួន)

abandonnateur, trice *n. Dr.* បរិច្ចាគី-គិនី [ប៉ះ-រិច-ចា–] (អ្នកលះបង់ទ្រព្យសម្បត្តិឲ្យអ្នកដទៃ)

abandonné,e *n.* បរិច្ចត្តបុគ្គល(អ្នកត្រូវបោះបង់,អ្នកឥតពំនាក់ពំនឹង)

abandonnement *n.m.* ការបរិច្ចាគ; ការលះបង់

abandonner *v.t.* បរិច្ចាគ; លះបង់; ប្រហែស;ប្រគល់។ s'abandonner *v.pr.* បណ្ដោយខ្លួន; អស់សង្ឃឹម

abaque *n.m.* ក្បាច់នព្វន្ត; សណ្ដោក្បាលសសរ

abarticulaire *a. Méd.* ក្រៅសន្លាក់

abasourdir *v.t.* ពន្លឹង ។ *Fig.* បំភាំង

abasourdissant,e *a.* ដែលពន្លឹង, ដែលបំភាំង

abasourdissement *n.m.* ការពន្លឹង។ *Fig.* ការបំភាំង, ភាពភ័ន្តភាំង

abat ឬ **abas** *n.m.* ភ្លៀងធំ

abat *n.m.* ការសម្លាប់

abâtardir *v.t.* ធ្វើឲ្យក្លាយ ឬ ខូច ។ s'abâtardir *v.pr.* ក្លាយ ឬ ខូច

abâtardissement *n.m.* ការក្លាយ(ឧ. abâtardissement d'une race)

abat-faim *n.m. inv.* អាហារសម្រន់

abat-foin *n.m.inv.* ព្រង់ទម្លាក់ស្មៅ

abat-jour *n.m.inv.* ឆាងចង្កៀង

abat-son *n.m.inv.* របាំងសូរ

abattable *a.* អាចកាប់ ឬ សម្លាប់បាន; អាចផ្ដួល ឬ រំលំបាន

abattage *n.m.* ការសម្លាប់; ការរំលំ

abattant *n.m.* បន្ទះសម្លប

abattée *n.f.* ភាគវេគចលនា(ចលនានៃនាវាដែលនាំឲ្យក្បាលងាកចេញពីមុខខ្យល់)

abattement *n.m.* អវិសារទភាព, ទុព្វលភាព, ភាពខ្សោយ; ការបន្ថយបរិមាណ

abatteur *n.m.* អ្នករំលំឈើ ។ abatteur de besogne អ្នកធ្វើការច្រើន

abattis *n.m.* បរិមាណវត្ថុដែលគេរំលំ ឬ សត្វព្រៃដែលគេសម្លាប់; ក្បាល-ចុងស្លាប-ក- ជើងនៃមាន់ទា ។ *Art mil.* គ្រឿងការពារធ្វើដោយគំនរឈើដើម្បីទប់ល្បឿនសត្រូវ ។ *Pop.* ដៃ ជើង

abattoir *n.m.* ទីសត្តឃាត [សាត់-តៈ-ឃាត], រោងសម្លាប់សត្វ

abattre *v.t.* ផ្ដួល; រំលំ; រុះរើ; សម្លាប់, បាញ់; ទម្លាក់ ។ *Fig.* ធ្វើឲ្យខ្សោយ; ធ្វើឲ្យអស់កម្លាំង; ធ្វើឲ្យថយកម្លាំងចិត្ត; បំបាក់; បង្អន់ ។ s'abattre *v.pr.* ដួល, រលំ; សង្គ្រុប; ស្ងប់ ។ *Prov.* petite pluie abat grand vent ហេតុតូច ច្រើនតែរម្ងាប់កំហឹងធំ

abattu,e *a.* ដែលរលំ,ដែលដួល ។ *Fig.* ដែលអស់កម្លាំង; ដែលអស់កម្លាំងចិត្ត

abat-vent *n.m.inv.* របាំងខ្យល់;គំរប

បំពង់ភ្លើង

abat-voix *n.m.inv.* ពិតានក្រែព្រះធម៌

abbatial,e,aux *a.* នៃអ្នកបួស, នៃវត្ត

abbaye *n.f.* វត្តនៃសាសនាគ្រិស្ត (ដែលមានអប្បេ ឬ អប្បេសម្នាក់គ្រប់គ្រង)

abbé *n.m.* អប្បេ (បព្វជិតមេវត្តនៃសាសនាគ្រិស្ត)

abbesse *n.f.* អប្បេស (ដូនជីមេវត្តនៃសាសនាគ្រិស្ត)

A B C *n.m.* សៀវភៅអក្ខរវិធី, ចំណេះជាន់ដំបូងនៃវិទ្យាសាស្ត្រឬសិល្បៈអ្វីមួយ

abcéder *v.i.* ក្លាយជាបូស

abcès *n.m.* បូស

abdicataire *n. & a.* ដែលដាក់រាជ្យ; ការដាក់ធុរៈ

abdication *n.f.* ការដាក់រាជ្យឬដាក់ធុរៈ

abdiquer *v.t.* ដាក់រាជ្យ, បោះបង់ចោល

abdomen *n.m.* ពោះ

abdominal,e, aux *a.* នៃពោះ

abduction *n.f.Méd.* អបចាល [អៈ-ប៉ៈ-]

abécédaire *a.* នៃអក្ខរវិធី ។ *n.m.* សៀវភៅរៀនអានដំបូង

abecquer *v.t.* បញ្ចុកក្នុងចំពុះ (ឲ្យចំណីបក្សី)

abeille *n.m.* ឃ្មុំ ។ reine d'abeille មេឃ្មុំ

abeiller, ère *a.* នៃឃ្មុំ ។ *n.m.* សំបុកឃ្មុំ

aberrant,e *a.* ដែលឃ្លាតចេញ, ដែលភ្លាត់

aberration *n.f. Fig.* ការភ្លាំងភ្លាត់, ការច្រឡំ, ការភ័ន្ត

aberrer *v.i.* ភ្លាំងភ្លាត់, ច្រឡំ, ភ័ន្ត

abêtir *v.t.* ធ្វើឲ្យភ្លីភ្លើ ។ *v.i.* & s'abêtir *v.pr.* ទៅជាភ្លីភ្លើឬល្ងង់ខ្លៅ

abhorrer *v.t.* ស្អប់

abîme *n.m.* រហេមស្ថាន, អន្លង់ជ្រៅ ។ *Fig.* អ្វីៗដែលហួសហេតុ ឬ ដែលមើលមិនធ្លុះ ។ être sur le bord de l'abîme ហៀបនឹងវិនាស

abîmer *v.t.* បំផ្លាញ; ធ្វើឲ្យខូច; ធ្វើឲ្យវិនាស ។ s'abîmer *v.pr.* លិចក្នុងអន្លង់ជ្រៅ; រលំ ។ *Fig.* សាប៉ូ; ខូច; វិនាស

ab intestat *loc.adv.* ម.ព. intestat

abject, e *a.* គួរទាត់ចោល; ថោកទាប

abjection *n.f.* សេចក្ដីថោកទាប

abjurable *a.* គួរបោះបង់

abjuration *n.f.* ការបោះបង់សាសនា។ *Fig.* ការបោះបង់លទ្ធិឬមតិ ។ល។

abjurer *v.t.* បោះបង់សាសនា ។ *Fig.* បោះបង់មតិ ឬ លទ្ធិ

ablatif, ive *a.* ដែលមានលក្ខណ ទិប វិភត្តិទី ៥ ។ *n.m.* បញ្ចមីវិភត្តិ, វិភត្តិទី ៥ (វេយ្យាករណ៍)

ablation *n.f.* ការកាត់ចោល

abluer *v.t.* លាងស្បែក ឬ ក្រដាសដោយថ្នាំដើម្បីឲ្យអស់ធូលី ឬ ឲ្យឃើញអក្សរច្បាស់

ablution *n.f.* ស្នានកិច្ច, ស្នានពិធី, ការជំរះកាយ, ពិធីជំរះកាយ

ablutionner *v.t.* លាង, ជំរះ

abnégation *n.f.* ការលះបង់

aboi *n.m.* សំឡេងឆ្កែព្រុស ។ *n.m.pl.* ដំណើរភ្លាន់ទ័លច្រក ។ *Fig.* ដំណើរអស់សង្ឃឹម ។ être aux abois ទ័លច្រក, ទ័លព្រាជ្ញ

aboiement *n.m.* សំឡេងឆ្កែព្រុស ។ *Fig.* សំរែកដែលឲ្យខាន; សំរែករខ្ចើន

abolir *v.t.* លុបចោល; បំបិទលែងឲ្យមាន; កំទេចចោល

abolitif, ive *a.* ដែលលុបចោល

abolition *n.f.* និរាក្រឹត, ការបំបិទលែងឲ្យមាន

abominable *a.* អប្រិយ, សំអប់, គួរឲ្យស្អប់; អាក្រក់ណាស់

abominablement *adv.* ដោយអប្រិយ; ដោយគួរឲ្យស្អប់

abomination *n.f.* សំអប់; របស់អាក្រក់ណាស់

abominer *v.t.* ស្អប់

abondamment *adv.* ដោយសម្បូណ៌

abondance *v.t.* សម្បូណ្ណភាព, ភាពសម្បូណ៌ ។ *Fig.* parler avec abondance និយាយរួសរាន់ ។ parler d'abondance និយាយដោយឥតព្រាងទុក ។ corne d'abondance និមិត្តរូបនៃភាពសម្បូណ៌ (ស្នែងច្រកពេញដោយផ្លែឈើនឹងផ្កា)

abondant, e *a.* សម្បូណ៌

abonder *v.i.* មានសម្បូណ៌, ជាល់ ។ abonder dans le sens de quelqu'un យល់ស្របតាម

abonné, e *n.* អ្នកជាវប្រចាំ

abonnement *n.m.* ការជាវប្រចាំ

abonner *v.t.* ជាវប្រចាំ (ឲ្យគេ) ។ s'abonner *v.pr.* ជាវប្រចាំ (យកខ្លួនឯង)

abonnir *v.t.* ធ្វើឲ្យរឹតតែល្អ ។ *v.i.* រឹតតែល្អ ។ s'abonnir *v. pr.* រឹតតែប្រសើរ

abord *n.m.* ការឡើងគោក, ការចូលចត; របៀបទទួល ។ *pl.* ទីជិតខាង ។ d'abord, de premier abord,

de prime abord, tout d'abord *loc.adv.* ដើមដំបូង, មុនដំបូង, ដើមឡើយ

abordable *a.* អាចចូលចតបាន; អាចចូលជិតបាន ។ *Fig.* រាក់ទាក់

abordage *n.m.* ការវាយប្រហារនាវា, ការទង្គិចគ្នានៃនាវា

abordé,e *a.* & *n.* ដែលត្រូវវាយប្រហារ

abordée *n.f.* ការឡើងគោក, ការចូលចត ។ à l'abordée, d'abordée *loc. adv.* ដើមដំបូង

aborder *v.i.* ឡើងគោក ។ *v.t.* ចូលជិត, ចូលចត; វាយប្រហារនាវា; ជួប; ទង្គិច (នាវា); ប្រហារ; ចូលតវ៉ា ។ *Fig.* aborder une question ផ្ដើមចរចាអំពីបញ្ហាមួយ ។ s'aborder *v.pr.* ចូលរកគ្នា

abordeur *a.m.* ដែលវាយប្រហារ

aborigène *a.&n.* ទេសវាសី -សិនី, អ្នកកើតក្នុងស្រុក ។ *n.m.pl.* អ្នកស្រុក (ផ្ទុយនឹងអ្នកបំណូល)

abornement *n.m.* ការបោះគោលដី

aborner *v.t.* បោះគោលដី

abortif,ive *a.* ដែលរលូត, ដែលធ្វើឲ្យរលូត

aboucher *v.t.* តចុងភ្ជាប់គ្នា, នាំឲ្យជួបមាត់គ្នា ។ s'aboucher *v.pr.* ជួបមាត់, ទាក់ទង

about *n.m.* ចុងសំរាប់តភ្ជាប់

aboutage *n.m.* ការចងតខ្សែ

aboutement *n.m.* ភាពឬការតភ្ជាប់គ្នា

abouter *v.t.* តភ្ជាប់គ្នា

aboutir *v.i.* មានចុងម្ខាងទៅដល់ ។ *Fig.* នាំទៅ, មានលទ្ធផល

aboutissant, e *a.* ដែលទៅដល់, ដែលមានលទ្ធផល ។ *n.m.pl.* អ្វីៗដែលភ្ជាប់ ឬ ដែលទាក់ទង

aboutissement *n.m.* លទ្ធផល, ការបានសំរេច ។ *Méd.* ការឡាយ(បូស)

aboyant,e *a.* ដែលព្រុស

aboyer *v.i.* ព្រុស ។ *Fig.* ស្រែកឡូ; តាមធ្វើឲ្យរំខាន

aboyeur,euse *a.* ដែលព្រុស

abracadabrant, e *a.* *Fam.* ប្លែកអស្ចារ្យ

abraser *v.t.* សឹកដោយកកិតគ្នា

abrasif *a.&n.m.* របស់សម្រាប់ខាត់

abrasion *n.f.* ការបន្សឹកដោយកកិតគ្នា

abrégé *n.m.* សេចក្ដីសង្ខេបឬបំប្រួញ ។ en abrégé *loc.adv.* ដោយសង្ខេប ។ écrire en abrégé សរសេរបំប្រួញ

abrégement *n.m.* ការសង្ខេប

abréger *v.t.* សង្ខេប, បំប្រួញ

abreuvage ឬ **abreuvement** *n.m.* ការឲ្យផឹក

abreuver *v.t.* ឲ្យផឹក, បំផឹក, ស្រោច ។ *Fig.* ធ្វើឲ្យពិបាកចិត្ត ។ s'abreuver *v.pr.* ផឹក

abreuvoir *n.m.* កន្លែងឲ្យសត្វផឹកទឹក

abréviateur,trice *n.* សង្ខេបក-បិកា, អ្នកបំប្រួញ

abréviatif, ive *a.* ដែលបំប្រួញ

abréviation *n.f.* ការបំប្រួញ, ពាក្យ ឬ សេចក្ដីបំប្រួញ

abréviativement *adv.* ដោយបំប្រួញ

abri *n.m.* ជំរក, ទីកំបាំង ។ *Fig.* ទីជ្រក ។ à l'abri de *loc.pré.* បានសុខ, ផុតភ័យ

abriter *v.t.* បាំង, បិទបាំង, ឲ្យមានជំរក ។ s'abriter *v.pr.* ជ្រក

abrogatif,ive *a.* ដែលលុបចោល

abrogation *n.f.* និរាករណ៍, ការលុបចោល

abrogatoire *a.* សំរាប់លុបចោល

abrogeable *a.* អាចលុបចោលបាន

abroger *v.t.* លុបចោល (ច្បាប់)

abrupt, e *a.* ចោតគ្រោង ។ *Fig.* ទ្រគោះ

abruptement *adv.* ដោយចោតគ្រោង

abruti,e *a.&n.* ដែលទៅជាល្ងីល្ងើ

abrutir *v.t.* ធ្វើឲ្យអប្បប្រាជ្ញ ឬ ល្ងីល្ងើ ។ s'abrutir *v.pr.* ទៅជាល្ងីល្ងើ

abrutissant, e *a.* ដែលធ្វើឲ្យល្ងីល្ងើ

abrutissement *n.m.* ភាពល្ងីល្ងើ, ភាពអប្បប្រាជ្ញ

abrutisseur,euse *a.&n.* ដែលធ្វើឲ្យអប្បប្រាជ្ញ

abscisse *n.f.* *Geom.* ភុជតា [ភុ-ជៈ-]

absence *n.f.* អវត្តមាន, [អៈ-វ័ត-តៈ-ម៉ាន], ភាពនៅឆ្ងាយ, ការមិននៅ ។ *Fig.* ការនៅខ្វះ, ការធ្វេស

absent, e *a.* អវត្តមាន,មិននៅ ។ *Fig.* ដែលធ្វេស

absentéisme *n.m.* អវត្តមាននិយម

absentéiste *a.&n.* អ្នកអវត្តមាននិយម

absenter (s') *v.pr.* មិននៅ, បាត់មុខ

absolu,e *a.* ផ្ដាច់ការ, ដាច់ខាត

absolument *adv.* ដោយដាច់ខាត

absolution *n.f.* ការលើកទោស

absolutisme *n.m.* សម្បូណ៌ាញានិយម, លទ្ធិផ្ដាច់ការ

absolutiste *a.* នៃសម្បូណ៌ាញានិយម, នៃលទ្ធិផ្ដាច់ការ ។ *n.* អ្នកសម្បូណ៌ាញានិយម, អ្នកកាន់លទ្ធិផ្ដាច់ការ

absolutoire *a.* ដែលលើកទោស

absorbable *a.* អាចជ្រាប ឬ ស្រូបបាន

absorbant, e *a.* ដែលស្រូប ។ *Fig.* ដែលឲ្យរវល់ជាប់ ។ *n.m.* សារជាតិដែលស្រូប ឬ បឺត (ដូចជាសំឡី)

absorbement *n.m.* ភាពគំនិតរវល់គិត

absorber *v.t.* ស្រូប, បឺត, ជ្រាប, លេប, បរិភោគ, ផឹក ។ *Fig.* បង្ហិន, ឲ្យរវល់ខ្លាំង ។ s'absorber *v.pr.* ត្រូវជ្រាប ឬ ស្រូប, រវល់ខ្លាំង

absorbeur,euse *a.* ដែលស្រូប,ដែលបឺត,ដែលជ្រាប

absorption *n.f.* ការស្រូប,ការបឺត,ការជ្រាប,ការលេប

absorptivité *n.f.* គុណភាពដែលស្រូប-បឺត ឬ ជ្រាប

absoudre *v.t.* លើកទោស,ឲ្យរួចបាប

abstème *a.&n.* ដែលតមស្រា

abstention *n.f.* អនុបភាព, ការតម

abstentionniste *n.* អ្នកអនុបភាពនិយម

abstergent,e *a.&n.* ថ្នាំលាងដំបៅ

absterger *v.t. Méd.* លាងដំបៅ

abstersif, ive *a. Méd.* សំរាប់លាងដំបៅ

abstersion *n.f. Méd.* ការលាងដំបៅ

abstinence *n.f.* ការតម (អាហារ)

abstinent, e *a.* ដែលចេះប្រមាណក្នុងការបរិភោគ

abstraction *n.f.* អរូបកម្ម ។ faire abstraction de ធ្វើអរូបកម្ម (មិនគិតដល់) ។ *pl.* ឈាម្ត

abstraire *v.t.* មិនគិតដល់ ។ s'abstraire *v.pr.* រវល់ខ្លាំង

abstrait, e *a.* អរូបី [អ:-រូ-ប៉ី], ដែលឥតរូប; ពិបាកយល់; ដែលរវល់ខ្លាំង ។ l'abstrait *n.m.* អរូប

abstraitement *adv.* ដោយអរូបី

abstrus, e *a.* ពិបាកយល់

absurde *a.* មិនទំនង

absurdement *adv.* ដោយមិនទំនង

absurdité *n.f.* ភាពមិនទំនង, អ្វីៗ មិនទំនង

abus *n.m.* ការរំលោភ, ការបំពាន; ការកាន់ច្រឡំ ។ abus d'autorité ការរំលោភអំណាច ។ abus de confiance ការក្បត់សេចក្ដីទុកចិត្ត។ abus de droit ការរំលោភច្បាប់។ *pl.* អំពើអយុត្តិធម៌

abuser *v.t.* បញ្ឆោត, ឆបោក ។ *v.i.* រំលោភ, បំពាន ។ s'abuser *v.pr.* ច្រឡំ, ភ័ន្ត

abuseur, euse *n.&a.* អ្នកឆបោក;

អ្នករំលោភ

abusif, ive *a.* ខុសច្បាប់; ហួសហេតុ

abusivement *adv.* ដោយខុសច្បាប់; ដោយហួសហេតុ

abyssal, e, aux *a.* អត់គម្ពីរ, ជ្រៅហួសប្រមាណ, នៃជាតសមុទ្រជ្រៅ

abysse *n.m.* ជាតសមុទ្រជ្រៅ

abyssinien, enne ឬ **abyssin, e** *a. & n.* នៃប្រទេសអាប៊ីស៊ីនី

acabit *n.m.* ភាពល្អ ឬ អាក្រក់ ។ *Fig. & Fam.* ចរិត ។ homme d'un bon acabit មនុស្សចរិតល្អ

académicien *n.m.* សមាជិកបណ្ឌិតសភា, សមាជិកវិទ្យាគារ

académicienne *n.f.* សមាជិកាបណ្ឌិតសភា ឬ វិទ្យាគារ

académie *n.f.* បណ្ឌិតសភា; វិទ្យាគារ

académie *n.f.* រូបភាពសិល្បការ, គំរូរូប ។ *Fam.* ខ្លួន

académique *a.* សំរាប់បណ្ឌិតសភា ឬ វិទ្យាគារ

acariâtre *a.* រញ៉ាំរញ៉ូវ

acariâtreté *n.f.* ចរិតរញ៉ាំរញ៉ូវ

accablant, e *a.* ពិបាកទ្រាំទ្រ, ធ្ងន់

accablement *n.m.* សេចក្ដីស្រុបស្រៅ, ភាពខ្សោយពេក

accabler *v.t.* ធ្វើឱ្យទ្រាំទ្រមិនបាន ។ *Fig.* ផ្ទុកលើនាទម្ងន់; បំពេញ

accalmie ឬ **accalmée** *n.f.* ការស្ងប់ក្នុងមួយកាល ឬ មួយគ្រា ។ *Fig.* ពេលសម្រាក (ក្នុងមួយកាលមួយគ្រា)

accaparement *n.m.* ការប្រមូលទំនិញ (ដើម្បីដំឡើង ឬ បញ្ចុះថ្លៃ)

accaparer *v.t.* ប្រមូលទំនិញ; ដណ្ដើមយកម្នាក់ឯង

accapareur, euse *n.* អ្នកប្រមូលទំនិញ

accéder *v.i.* ទៅដល់, ឡើងកាន់ ។ *Fig.* យល់ព្រម

accélérando *adv. Mus.* ពន្លឿន

accélérateur, trice *a.* ដែលពន្លឿន ។ *n.m.* ប្រដាប់ពន្លឿន

accélération *n.f.* ការកើននៃល្បឿន; ការបង្ខំឱ្យលឿន

accéléré *n.m.* ល្បិចពន្លឿន (ធ្វើឱ្យចលនាខ្សែភាពយន្តលឿនជាងការពិត)

accélérer *v.t.* ពន្លឿន, បង្កើនល្បឿន, បង្ខំឱ្យលឿន

accent *n.m.* ការសង្កត់សំឡេង, របៀបនិយាយដោយឡែក (ឧ.ខ្មែរស្រុកក្រោមមានរបៀបនិយាយដោយឡែក), សំនៀង; សញ្ញា

accentuation *n.f.* របៀបសង្កត់ពាក្យក្នុងការនិយាយ ឬ ក្នុងការអាន, របៀបដាក់សញ្ញា; អ្វីៗ ដែលលេចធ្លោឡើង

accentué, e *a.* ដែលមានសញ្ញា ។ *Fig.* ច្បាស់

accentuer *v.t.* ដាក់សញ្ញា; និយាយសង្កត់ពាក្យ; ធ្វើឲ្យលេចធ្លោឡើង ។ s'accentuer *v.pr.* កើន

acceptabilité *n.f.* ភាពអាចព្រមទទួលបាន

acceptable *a.* អាចព្រមទទួលបាន ; គួរព្រមទទួល

acceptant, e *n.&a.* អ្នកព្រមទទួល

acceptation *n.f.* ស៊ីការ, ការព្រមទទួល ។ acceptation d'une traite ស៊ីការរូបិយាណត្តិ

accepter *v.t.* ព្រមទទួល ។ សុខចិត្ត; ធ្វើស៊ីការ ។ accepter un don ព្រមទទួលអំណោយ ។ accepter une lettre de change ធ្វើស៊ីការរូបិយាណត្តិ

accepteur *n.m.* អ្នកធ្វើស៊ីការរូបិយាណត្តិ

acception *n.f.* ការយល់មុខ, ការលំអៀង ។ *Gram.* ន័យរបស់ពាក្យ ។ acception propre អត្ថានុរូប ។ acception figurée អត្ថបដិរូប

accès *n.m.* ការចូល;ផ្លូវចូល,មាត់ច្រក។ accès de fièvre ពេលគ្រុន ។ accès de colère ពេលខឹង

accessibilité *n.f.* ភាពអាចចូល ឬ អាចទៅដល់បាន; លក្ខណ្ឌដើម្បីចូលកាន់មុខងារមួយបាន

accessible *a.* អាចចូលជិតឬទៅដល់បាន

accession *n.f.* ការទៅដល់; ការឡើងកាន់; ការចូលរួបរួមជាមួយ

accessit *n.m.* រង្វាន់រង

accessoire *a.* បន្ទាប់បន្សំ, បរិភារ,មិនសំខាន់ ។ *n.m.* ឧបសាធន (គ្រឿងបន្ទាប់បន្សំ) ; គ្រឿងតាំងកន្លែងលេងល្ខោន

accessoirement *adv.* ដោយបន្ទាប់បន្សំ

accessoiriste *n.m.* អ្នកតាំងកន្លែងលេងល្ខោន

accident *n.m.* គ្រោះថ្នាក់, ឧបទ្ទវហេតុ។ accident de terrain ភាពដីខ្ពស់ទាប ។ *Mus.* គ្រោះ ។ Par accident *loc. adv.* ដោយដួន

accidenté,e *a.* ដែលរងគ្រោះថ្នាក់; មិនស្មើ ។ terrain accidenté ដីខ្ពស់ទាប ។ *Fig.* vie acciden-

lée ដីភាពប្រកបដោយការប្រែប្រួល

accidentel, elle *a.* ដែលមានដោយផ្ទួន, ដែលគ្មានប្រុងទុក

accidentellement *adv.* ដោយផ្ទួន

accidenter *v.t.* ធ្វើឲ្យមានភាពខ្ពស់ទាប

accise *n.f.* ពន្ធមិនចំពោះលើគ្រឿងបរិភោគ

acclamateur *n.m.* អ្នកអបអរសាទរ

acclamatif, ive *a.* ដែលសំដែងសេចក្ដីអបអរសាទរ

acclamation *n.f.* សម្រែកអបអរសាទរ ។ Par acclamation *loc. adv.* ដោយសម្រែកអបអរសាទរ ។ loi votée par acclamation ច្បាប់អនុម័តដោយសម្រែកអបអរសាទរ

acclamer *v.t.* ស្រែកអបអរសាទរ ; តាំងដោយស្រែកអបអរសាទរ

acclimatable *a.* អាចផ្សាំនឹងអាកាសធាតុថ្មីបាន

acclimatation *n.f.* ការផ្សាំនឹងអាកាសធាតុថ្មី

acclimatement *n.m.* ភាពស៊ាំនឹងអាកាសធាតុថ្មី

acclimater *v.t.* ផ្សាំនឹងអាកាសថ្មី ។ s'acclimater *v.pr.* ស៊ាំនឹងអាកាសធាតុថ្មី

accointance *n.f.* ការសេពគប់

accointer (s') *v.pr.* សេពគប់

accolade *n.f.* ការឱប ។ *Gram.* វ៉ាត់ (វណ្ណយុត្ត : {)

accolader *v.t.* វ៉ាត់ (ប្រើវណ្ណយុត្ត ហៅថាវ៉ាត់)។s'accolader *v.pr.* ឱបគ្នា

accolement *n.m.* ការផ្គោប ឬ ភ្ជាប់គ្នា

accoler *v.t.* ឱប ក ។ accoler deux noms សរសេរឈ្មោះពីរទន្ទឹមគ្នា ។ accoler la vigne ចងដើមទំពាំងបាយជូរភ្ជាប់នឹងជន្ទល់

accommodable *a.* អាចសំរួលបាន

accommodage *n.m.* ការផ្សំគ្រឿងម្ហូប

accommodant, e *a.* ដែលមានអារម្មណ៍ល្អ, ស្រួលទាក់ទង

accommodation *n.f.* ការសំរួល,ការស្រុះស្រួល។*Anat.* សុរិតា។ accommodation de l'œil សុរិតានៃភ្នែក

accommodement *n.m.* ការសំរួល, ការសំរុះសំរួល, ការស្រុះស្រួលគ្នា

accommoder *v.t.* ផ្សំ, សំរុះសំរួល; ផ្សំគ្រឿង; ត្រូវចិត្ត។*Anat.* ធ្វើសុរិតា។ cette maison m'accommode ផ្ទះនេះត្រូវចិត្តខ្ញុំ ។ s'accommoder *v.pr.* ស្រួលចិត្ត; ពេញចិត្ត

accompagnateur, trice *n.* អ្នកតាម

(ដោយច្រៀង ឬ ដោយភ្លេង)

accompagnement *n.m.* ការតាមជូន;គ្រឿងបន្ទាប់បន្សំ ។ *Mus.* ការតាម

accompagner *v.t.* តាម, ជូន; លើកតម្លៃ ។ *Mus.* តាម

accompli,e *a.* រួចស្រេច,បានសម្រេច; ឥតខ្ចោះ; ពេញលេញ

accomplir *v.t.* បំពេញ ; ប្រតិបត្តិ ; បង្ហើយ

accomplissement *n.m.* ការបង្ហើយ, ការសម្រេច

accord *n.m.* ការយល់ព្រម, ដំណើរត្រូវគ្នា; កិច្ចព្រមព្រៀង។*Gram.* សម្ពន្ធ ។ accord à l'amiable កិច្ចព្រមព្រៀងដោយស្រុះស្រួល ។ *Mus.* សមង្គី; accord parfait សមង្គីមនោរម្យ ។ d'accord *loc.adv.* យល់ព្រម

accordable *a.* អាចធ្វើឲ្យត្រូវគ្នាបាន

accordage, accordement *n.m.* ការផ្សំភ្លេង (រឹតខ្សែគ្រឿងភ្លេងឲ្យត្រូវគ្នា)

accordailles *n.f.pl.* ការចែចូវ

accordant,e *a.* ត្រូវគ្នា

accordéon *n.m.* អ័កគ័រដេអុង ។ en accordéon ជាផ្នត់អង្កាញ់ (ដូចអ័កគ័រដេអុង)

accordéoniste *n.* អ្នកលេងអ័កគ័រដេអុង

accorder *v.t.* សំរុះសំរួល; ព្រមឲ្យ; អនុញ្ញាត; ផ្សំសំឡេង (ភ្លេង) ។ s'accorder *v.pr.* ព្រមព្រៀងគ្នា, មូលមាត់គ្នា

accort,e *a.* រួសរាយ

accortement *adv.* ដោយប្រសប់

accostable *a.* ស្រួលចូល, ស្រួលឡើង

accostage *n.m.* ការចូលចត, ការអែបជិតគ្នា

accoster *v.t.* ចូលជិត ។ *Mar.* ចូលចត, អែបជិតគ្នា

accotement *n.m.* ជាយថ្នល់

accoter *v.t.* ផ្អែក ឬ ច្រត់ម្ខាង ។ s'accoter *v. pr.* ផ្អែក

accouardir *v.t.* បន្លាច ។ s'accouardir *v.pr.* ខ្លាច

accouchée *n.f.* ប្រសូតិកា,ស្ត្រីទើបនឹងឆ្លងទន្លេ

accouchement *n.m.* ប្រសូតិកម្ម, ការឆ្លងទន្លេ, ការសម្រាលកូន

accoucher *v.i.* ឆ្លងទន្លេ;សម្រាលកូន ។ *Fig.* បង្កើត (ដោយគំនិត) ។ *v.t.* ជួយបង្កើតកូន

accoucheur, euse *n.* ឆ្មប

accoudement *n.m.* ការច្រត់កែងដៃ; ការឲ្យឈរជិតគ្នា

accouder (s') *v.pr.* ច្រត់កែងដៃ; ឈរជិតគ្នា (កែងដៃប៉ះគ្នា)

accoudoir *n.m.* ផ្អក់ដៃ

accouplement *n.m.* ការរួមសង្វាស; ការបង្កាត់កូន; ការពាក់គ្នា; ការផ្គួ

accoupler *v.t.* ផ្គួ; ផ្ទឹម; បង្កាត់កូន ។ s'accoupler *v.pr.* រួមសង្វាស; ពាក់គ្នា

accourci *n.m.* ការសង្ខេប

accourcir *v.t.* សង្ខេប, បង្រួញឲ្យខ្លី

accourcissement *n.m.* ការបង្រួញឲ្យខ្លី

accourir *v.i.* រត់មកយ៉ាងលឿន

accoutrement *n.m.* សំលៀកបំពាក់ប្លែក

accoutrer *v.t.* ឲ្យស្លៀកពាក់ប្លែក ។ s'accoutrer *v.pr.* ស្លៀកពាក់យ៉ាងបំឡែក

accoutumance *n.f.* ទំលាប់

accoutumé, e *a.* ធម្មតា ។ à l'accoutumée *loc.adv.* ដូចធម្មតា

accoutumer *v.t.* ទំលាប់ ។ *v.i.* ធ្លាប់ ។ s'accoutumer *v.pr.* ធ្លាប់

accouver *v.t.* រៀបចំសំបុកឲ្យក្រាបពង ។ *v.i.* ក្រាបពង ។ s'accouver *v.pr.* ចាប់ក្រាប

accréditement *n.m.* ការតាំងទូត

accréditer *vt.* ធ្វើឲ្យទុកចិត្ត ឬ ឲ្យជឿ; តែងតាំងអ្នកការទូត; បើកឥណទាន ។ s'accréditer *v.pr.* មានគេចូលចិត្ត, មានគេជឿ; សាយភាយ

accréditeur *n.m.* អ្នកធានា

accrêté,e *a.* ដែលមានសិរ ឬ កំពូល

accroc *n.m.* រង្វះរហែក ។ *Fig.* ឧបសគ្គ, ការសៅហ្មង

accrochage *n.m.* ការទង្គិចគ្នា; ការផ្តក់, ការព្យួរ ។ *Art mil.* ការតើបតយុទ្ធ ។ ជម្លោះ; ឧបសគ្គ

accrochement *n.m.* ការផ្តក់

accrocher *v.t.* ព្យួរ, ផ្តក់; ទង្គិចគ្នា; បញ្ឈប់; បង្ខំឲ្យប្រយុទ្ធ; បានដោយឧបាយកល ។ s'accrocher *v.pr.* ផ្តក់, ប្រតោង; ជំពាក់ ។ *Fig.* រំខាន

accroire (faire) *v.t.* ធ្វើឲ្យជឿការមិនពិត ។ en faire accroire à quelqu'un បង្ខំឲ្យជឿ ។ s'en faire accroire អួតអាងខ្លួនពេក

accroissement *n.m.* ការដុះដាល, ការចំរើន, ការកើន

accroitre *v.t.* ដុះដាល, ធ្វើឲ្យចំរើន ។

v.i. & s'accroître *v.pr.* បានចម្រើន

accroupetonner (s') *v.pr.* អង្គុយច្រហោង

accroupi,e *a.* ដែលអង្គុយច្រហោង

accroupir (s') *v.pr.* អង្គុយច្រហោង

accroupissement *n.m.* កិរិយាបថអង្គុយច្រហោង

accru *n.m.* លំពង់ឫស

accrue *n.f.* ការកើននៃដីដោយទឹកជយ, ការកើននៃព្រៃដោយឫសឈើដុះចូលក្នុងដីជិតខាង

accu *n.m. Fam.* ពាក្យបំប្រួញនៃ accumulateur

accueil *n.m.* បដិគមន៍, បដិគមនាការ, ការទទួល ។ faire accueil ទាក់ទទួល, ទទួលដោយរាក់ទាក់

accueillant, e *a.* រាក់ទាក់

accueillir *v.t.* ធ្វើបដិគមន៍, ទទួល

accul *n.m.* អំពើឬកន្លែងទាល់ច្រក

acculement *n.m.* ភាពទាល់ច្រក, ការផ្ទប់ឲ្យទាល់ច្រក

acculer *v.t.* ផ្ទប់ឲ្យទាល់ច្រក ។ *Fig.* ផ្ចាញ់ ។ *v.i* ប៉ះក្បាល(នាវា) ។ s'acculer *v.pr.* ផ្អែក

accumulateur, trice *a.&n.* អ្នកប្រមូល ។ *n.m.* សមាច័យករ, ធុងអាគុយ (ប្រដាប់ប្រមូលថាមពលអគ្គិសនី ហើយបញ្ចេញជាចរន្ត)

accumulation *n.f.* សមាច័យ, ការប្រមូល

accumuler *v.t.* គរជាគំនរ, ប្រមូល

accusable *a.* អាចចោទប្រកាន់បាន

accusateur,trice *n.&a.* អ្នកចោទប្រកាន់

accusatif,ive *a.* នៃទុតិយាវិភត្តិ ។ *n.m.* ទុតិយាវិភត្តិ, វិភត្តិទី២

accusation *n.f.* ការចោទប្រកាន់

accusatoire *a.* ដែលរាយរាប់ហេតុនៃការចោទប្រកាន់

accusé,e *n.* អ្នកត្រូវចោទ ។ accusé de réception លិខិតទទួល

accuser *v.t.* ចោទប្រកាន់; ប្រាប់ត្រង់; ជាសញ្ញា ។ *Fig.* ស, បង្ហាញ ។ *Com.* accuser réception ឲ្យដំណឹងទទួល ។ s'accuser *v.pr.* ទទួលខុស

acérage *n.m.* ការថែប (ប៉ះដែកល្អលើដែកអន់ដើម្បីឲ្យមុត)

acérain,e *a.* ដូចដែកថែប

acerbe *a.* ជូរចត់ (មិនឆ្ងាញ់, មិនពីរោះ)

acerbité *n.f.* ភាពជូរចត់

acère *a.& n.m.* គ្មានស្នែង, គ្មានពុក, គ្មានកេក្ខាការ

acéré,e *a.* ថែប; មុត, ស្រួច ។ *Fig.* ដែលធ្វើឲ្យឈឺចាប់

acérer *v.t.* ថែប (ប៉ះដែកល្អលើដែកអន់ដើម្បីឲ្យមុត) ។ *Fig.* ធ្វើឲ្យមុត

acescence *n.f.* ភាពទើបនឹងឡើងជូរ

acescent,e *a.* ដែលទើបនឹងឡើងជូរ

acétylène *n.m.* អាសេទីឡែន(ភ្នុគុត)

achalandage *n.m.* ការរកអតិថិជន, ការរកអ្នកទិញ

achalandé,e *a.* ដែលមានអ្នកទិញច្រើន ។ *Fam.* ដែលមានទំនិញច្រើន

achalander *v.t.* រកអ្នកទិញ។ *Fam.* ផ្ដល់ទំនិញ

acharné,e *a.* ចចេស, មានះ

acharnement *n.m.* សេចក្ដីចចេសៈ, មានះ ។ *Fig.* ទោសៈ

acharner *v.t.* ពន្យុះ ។ s'acharner *v.pr.* មានមានះ

achat *n.m.* ការទិញ; របស់ទិញ

acheminement *n.m.* ការដំរង់ឆ្ពោះទៅ; វឌ្ឍនភាព, ការចំរើន

acheminer *v.t.* ដំរង់ឆ្ពោះទៅ ។ s'acheminer *v.pr.* ដើរឆ្ពោះទៅ

achetable *a.* ដែលអាចទិញបាន

acheter *v.t.* ទិញ។ *Fig.* បាន(ដោយប្ដូរនឹងអ្វីមួយ); សូក

acheteur,euse *n.* អ្នកទិញ

achevé,e *a.* ពេញលក្ខណៈ

achèvement *n.m.* ការបង្ហើយ, ភាពហើយស្រេច

achever *v.t.* ធ្វើឲ្យស្រេច, បង្ហើយ

achoppement *n.m.* ឧបសគ្គ , ការជំពប់។ pierre d'achoppement ឧបសគ្គដែលរាំង

achopper *v.i.* ជំពប់ ។ *Fig.* s'achopper à *v.pr.* មិនបានសម្រេចដោយមានឧបសគ្គ

acide *a.* ជូរ ។ *n.m.* ទឹកក្រូតឬអាស៊ីដ។ acide gras ទឹកក្រូត ឬ អាស៊ីដខ្លាញ់ ឬ ប្រេង

acidifiable *a.* អាចទៅជាអាស៊ីដបាន

acidification *n.f.* ការធ្វើឲ្យទៅជាអាស៊ីដ

acidifier *v.t.* ធ្វើឲ្យទៅជាអាស៊ីដ ។ s'acidifier *v.pr.* ទៅជាអាស៊ីដ

acidimètre *n.m.* អាស៊ីដមាត្រ

acidimétrie *n.f.* អាស៊ីដមាត្រវិធី

acidité *n.f.* ភាពជូរ ឬ រសជាតិជូរ ។ acidité du sol ភាពជូរនៃដី

acidule ឬ **acidulé,e** *a.* ជូរបន្តិចៗ

aciduler *v.t.* ធ្វើឲ្យឡើងជូរបន្តិចៗ

acier *n.m.* ដែកថែប

aciérage *n.m.* ឬ **aciération** *n.f.* ការធ្វើឲ្យទៅជាដែកថែប

aciérer *v.t.* ធ្វើឲ្យទៅជាដែកថែប; ថែប

aciéreux, euse *a.* នៃដែកថែប; ដូចដែកថែប

aciérie *n.f.* រោងចក្រដែកថែប

aciériste *n m.* អ្នកឯកទេសដែកថែប

acné *n.f.* មុន (រោគសើស្បែក)

acompte *n.m.* ប្រាក់រំដោះ (ប្រាក់សងបន្តិចម្ដងៗដរាបដល់រួចប្រាក់ជំពាក់)

acoquiner *v.t.* ធ្វើឲ្យជាប់ចិត្ត ។ s'acoquiner *v.pr.* ជាប់ចិត្តពេក

à-côté *n.m.* ទាយអាយ, ភាយរង

acotylédone ឬ **acotylédoné,e** *a.* អពីជបត្ត (ដែលគ្មានស្រទាប់គ្រាប់)

à-coup *n.m.* ភាពមានមួយលើកៗ; ដំណើរកញ្ឆក់ៗ ឬ ទប់ៗ

acoustique *a.* នៃសូរ, នៃការឮ ។ cornet acoustique ប្រដាប់ពង្រីកសូរ (សំរាប់មនុស្សថ្លង់) ។ *n.f.* ទ្រឹស្ដីសូរ, សូរសាស្ត្រ

acquéreur *n.m.* អ្នកទិញ, អ្នកជាវ

acquérir *v.t.* ទិញ,ជាវ; ទទួលលទ្ធកម្ម; បាន; ជាប់ចិត្ត

acquiescement *n.m.* ការយល់ព្រម

acquiescer *v.i.* យល់ព្រម

acquis *n.m.* ចំណេះ; ពិសោធន៍; ទ្រព្យរបស់

acquisition *n.f.* លទ្ធកម្ម,ការឬវត្តបាន

acquisivité *n.f.* ការចង់បាន

acquit *n.m.* និមុត្តិ (ការជ្រះស្រឡះ, ការដោះបន្ទុករួចស្រេចហើយ) ។ pour acquit ដើម្បីនិមុត្តិ ។ par manière d'acquit *loc.adv.* ដោយធ្វេសប្រហែស ។ par acquit de conscience, pour l'acquit de sa conscience ជាគម្រប់កិច្ច

acquit-à-caution *n.m.* និមុត្តិធានា

acquittable *a.* អាចឲ្យរួចខ្លួនបាន

acquittement *n.m.Fin.* និមុត្តិកិច្ច; ការសងបំណុល ។ *Just.* ទោសនិមុត្ត, ការដោះលែង

acquitter *v.t.* ធ្វើនិមុត្តិកិច្ច, ឲ្យរួចខ្លួន, ដោះលែង ។ s'acquitter *v.pr.* ដោះជំពាក់; បំពេញករណីយកិច្ចខ្លួន

âcre *a.* ក្អាប, ហាង ។ *Fig.* រញ៉ាំរញ៉ូវ

âcrement *adv.* យ៉ាងក្អាប ឬ ហាង

âcreté *n.f.* ភាពក្អាប ឬ ហាង

acrimonie *n.f.* ភាពហាង ។ *Fig.* សំដីចាក់ដោត; សេចក្ដីរញ៉ាំរញ៉ូវ

acrimonieusement *adv.* ដោយចាក់ដោត; ដោយរញ៉ាំរញ៉ូវ

acrimonieux,euse *a.* រញ៉ាំរញ៉ូវ

acrobate *n.* អ្នកលេងសៀក

acrobatie *n.f.* សៀក; ការយកឫកពិបាក

acrobatique *a.* នៃសៀក

acte *n.m.* កិច្ច, អំពើ; សារលិខិត ។ *Théât.* ឈុត ។ donner acte ចេញលិខិតកត់សំគាល់តាមផ្លូវច្បាប់ ។ prendre acte កត់សំគាល់ទុក ។ faire acte de présence បង្ហាញមុខមួយភ្លែត ។ acte de gestion កិច្ចចាត់ចែងការ ។ acte de vente សារលិខិតលក់ ។ acte constitutif សារលិខិតដាបតិដ្ឋាប័ន ។ acte légalisé សារលិខិតពេញច្បាប់ ។ acte sous seing privé ម. ព. sous seing ។ acte en brevet លិខិតសារការីគិតដើម ។ acte notarié លិខិតសារការី ។ acte de terrorisme ភេរវកម្ម ។ acte de transaction កិច្ចសម្រុះសម្រួល ។ acte de commerce ពាណិជ្ជកិច្ច ។ acte de commerce par nature ពាណិជ្ជកិច្ចដោយធម្មជាតិ ។ acte de commerce par la forme ពាណិជ្ជកិច្ចដោយលក្ខណរូប ។ acte de commerce par accessoires ពាណិជ្ជកិច្ចដោយឧបសាធន ។ acte d'amnistie កិច្ចលើកលែងទោស

acteur,trice *n.* តួល្ខោន,តានការ-ការី

actif,ive *a.* សកម្ម,ភាងវៃ,រហ័សរហួន ។ *Gram.* កត្តុវាចក: (ម.ព. verbe ផង)។ *n.m.* ទ្រព្យសកម្ម (សំរាប់ហៅទ្រព្យសម្បត្តិដែលបុគ្គលនីមួយ ៗ មានមិនថាផ្ទះសម្បែង ស្រែចំការ ។ ល ។) citoyen actif ពលរដ្ឋសកម្ម (មានសិទ្ធិបោះឆ្នោត) ។ remède actif ឱសថពូកែ ។ dettes actives បំណុលសកម្ម (បំណុលដែលយើងជាម្ចាស់) ។ l'actif net សកម្មសុទ្ធ ។ l'active *n.f.* ទ័ពសកម្ម

action *n.f.* កិច្ច, អំពើ; កម្ម; ហ៊ុន, ភាគទុន; ការប្ដឹងតុលាការ ។ action sociale សង្គមកិច្ច ។ action civile បទរដ្ឋប្បវេណី ។ action publique បទអាជ្ញា

actionnable *a.* អាចចោទប្រកាន់បាន

actionnaire *a.* អ្នកចូលហ៊ុន

actionner *v.t.* ប្ដឹងតុលាការ; ជម្រុញ; ធ្វើឲ្យកម្រើក, ធ្វើឲ្យដើរ

activement *adv.* ដោយរហ័សរហួន

activer *v.t.* តឿន, បង្ខំការ

activité *n.f.* សកម្មភាព ។ en activité ក្នុងដំណែង

actualité *n.f.* បច្ចុប្បន្នភាព, រឿងបច្ចុប្បន្ន

actuel,elle *a.* បច្ចុប្បន្ន, ដែលមានក្នុងពេលឥឡូវនេះ

actuellement *adv.* ក្នុងបច្ចុប្បន្នកាល, សព្វថ្ងៃ, ឥឡូវនេះ

acuité *n.f.* តិក្ខណភាព [តិក-ខៈ-ណៈ-], ភាពស្រួច ឬ មុត

aculé,e *a.* ដែលមានទ្រនិច (ដូចជាឃ្មុំ, ស្រាំង)

adage *n.m.* បុរាណភាសិត, វាក្យភេទ, វាក្យបទេស

adaptable *a.* ដែលអាចឲ្យមានលំនាំតាម; ដែលអាចផ្សំ ឬ តម្រូវបាន

adapteur, trice *n.* អ្នកយកលំនាំតាម; អ្នកផ្សំ ឬ តម្រូវ

adaptation *n.f.* ការយកលំនាំតាម; ការផ្សំ ឬ ការតម្រូវ

adapter *v.t.* យកលំនាំតាម;ផ្សំ;តម្រូវ ។ s'adapter *v.pr.* មានលំនាំត្រូវ, ត្រូវល្មម

additif, ive *a.* បូរណត្ថ [បូ-រៈ-ណ័ត], ដែលសំរាប់បូកបន្ថែម ។ *n.m.* បូរណត្ថ, សេចក្ដី ឬ អ្វីៗ ដែលបន្ថែម

addition *n.f.* លេខបូក, ការបូករួម, វត្ថុបូកបន្ថែម

additionnable *a.* ដែលអាចបូក ឬ បន្ថែមបាន

additionnel, elle *a.* ដែលបន្ថែមលើ ។ centimes additionnels អាករបន្ថែម

additionner *v.t.* បូក, រួម, បញ្ចូល

additionneuse *n.f.* ម៉ាស៊ីនបូកលេខ

adduction *n.f.* ការបង្ហូរទឹក ។ *Méd.* ឧបបាល

adénite *n.f.* កូនកណ្ដុរ (ឈ្មោះរោគ)

adepte *n.* និកាយព័ន្ធ,បក្សពន្ធ; អ្នកចូលចិត្ត; អ្នកជឿ ឬ កាន់តាម

adéquat,e *a.* ពេញលេញ; ជួនល្មម; ត្រឹមត្រូវ; សម

adhérence *n.f.* សដ្ឋិភាព,ការលោយជាប់គ្នា

adhérent, e *a.* សដ្ឋិក, ដែលលោយ ឬ ស្អិតជាប់ ។ *n.m.* សដ្ឋិក (អ្នកចូលក្នុងបក្ស ឬ និកាយ)

adhérer *v.i.* ស្អិតជាប់ ។ *Fig.* យល់ព្រម

adhésif, ive *a.* សដ្ឋិត, ដែលលោយជាប់, ដែលស្អិតជាប់

adhésion *n.f.* សដ្ឋិកម្ម, ការកួលគ្នា; ការរួបរួម; ភាពស្អិតជាប់ ។ *Fig.* ការយល់ព្រម

adhésivement *adv.* ដោយស្អិតជាប់

adhésivité *n.f.* សដ្ឋិភាព, គុណភាពដែលធ្វើឲ្យស្អិតជាប់ ; ការអាចសម្រឹងស្មារតីលើគំនិតមួយបាន

ad hoc *loc.lat.* ចំពោះលើ, ដែលត្រូវចំលើ, សំរាប់ប្រើលើ

adieu *int.* សុំលា !

adipeux,euse *a.* ដែលមានសណ្ឋានជាខ្លាញ់

adipose *n.f.* រោគខ្លាញ់ច្រើនពេក

adiposité *n.f.* ភាពខ្លាញ់ច្រើនពេក

adirer *v.t. Dr.* បាត់, វង្វេង (របស់) (ច្រើនប្រើតែជា participe passé: titre adiré)

adjacence *n.f.* ភាពជាប់គ្នា (ប៉ះគ្នា)

adjacent,e *a.* ជាប់គ្នា (ប៉ះគ្នា)

adjectif,ive *a.* នៃគុណនាម ។ *n.m.* គុណនាម ឬ គុណសព្ទ ។ adjectif qualificatif បកតិគុណនាម ។ adjectif comparatif វិសេសគុណនាម ។ adjectif superlatif អតិវិសេសគុណនាម ។ adjectif numéral cardinal បកតិសំខ្យា ។ adjectif numéral ordinal បូរណសំខ្យា

adjectivement *adv.* ជាគុណសព្ទ

adjoindre *v.t.* បន្ថែមជាជំនួយ

adjoint,e *a.&n.* ជំនួយ, ភូលួយ,រង

adjonction *n.f.* ការបន្ថែមជាជំនួយ

adjudant *n.m.* ព្រិន្ទបាលទោ [ព្រិន-ទៈ-បាល] ។ adjudant chef ព្រិន្ទបាលឯក

adjudicataire *n.* អ្នកដេញថ្លៃបាន

adjudicateur,trice *n.* អ្នកដាក់លក់ដេញថ្លៃ

adjudicatif, ive *a.* ដែលដាក់លក់ដេញថ្លៃ

adjudication *n.f.* ការដេញថ្លៃ, ការដេញថ្លៃបាន

adjuger *v.t.* ដេញថ្លៃ , កាត់សេចក្ដីឲ្យ (វិនិច្ឆ័យសេចក្ដីឲ្យគូក្ដីម្ខាងបានរបស់ជាប់វិវាទ) , ព្រមឲ្យក្រោយដែលបានដេញថ្លៃលក់

adjuration *n.f.* ការសែកមន្តអាគមដេញខ្មោចបិសាច; ការអង្វរករ

adjurer *v.t.* សែកមន្តអាគមដេញ ឬ ប្រើបិសាច; អង្វរករ

admettre *v.t.* បើកឲ្យចូល.ទទួល;ទុកជាត្រូវ; យល់ព្រម

administrateur,trice *n.* អភិបាល, អ្នកត្រួតត្រា ឬ គ្រប់គ្រង; អ្នករាជការរដ្ឋបាល

administratif,ive *a.* នៃរាជការ, នៃអភិបាល

administration *n.f.* អភិបាល, ទីអភិបាល; រដ្ឋបាល; ការត្រួតត្រា ។ administration intérieure អន្តោភិបាល ។ administration légale ការអភិបាលនីត្យានុកូល ។ conseil d'administration ម.ព. conseil

administrativement *adv.* តាមទម្រង់រាជការ ឬ តាមបទបញ្ជារាជការ

administré,e *n.* អ្នកនៅក្រោមការត្រួតត្រា ឬ ក្រោមអភិបាល

administrer *v.t.* អភិបាល, គ្រប់គ្រង, ត្រួតត្រា;រក្សា;ឲ្យផឹកឬឲ្យលេប(ឱសថ); វាយ។ administrer une preuve ជូនភស្តុតាងដល់តុលាការ ។ s'administrer *v.pr.* យកខ្លួនឯង

admirable *a.* គួរសរសើរ,គួរស្ងើច, គួរកោត; ឥតខ្ចោះ

admirablement *adv.* ដោយគួរស្ងើច;ដោយឥតខ្ចោះ

admirateur, trice *n.* អ្នកសរសើរ, អ្នកស្ងើច

admiratif, ive *a.* ដែលសំដែងសេចក្ដីកោត ឬ សេចក្ដីសរសើរ ។ point admiratif ឧទានសញ្ញា

admiration *n.f.* ការសរសើរ, ការស្ងើច,ការកោត, ការស្ញប់ស្ញែង

admirativement *adv.* ដោយការសរសើរ, ដោយស្ងើច

admirer *v.t.* សរសើរ, ស្ងើច, កោត

admis,e *a.*&*n.* ដែលប្រឡងជាប់

admissibilité *n.f.* ប្រវេសនីយភាព, ភាពគួរឲ្យជាប់បាន ។ épreuve d'admissibilité វិញ្ញាសាប្រវេសនីយភាព

admissible *a.* ប្រវេសនីយ, គួរឲ្យជាប់; ដែលប្រឡងជាប់ខាងវិញ្ញាសាសរសេរ ; គួរឲ្យទទួល; គួរទុកជាត្រូវ

admission *n.f.* ប្រវេសន៍, ការទទួល, ការទុកជាត្រូវ; ការប្រឡងជាប់ ។ admission exceptionnelle អញ្ញត្រប្រវេសន៍,ការទទួលជាពិសេស ។ admission temporaire ប្រវេសន៍កាលិក (ការទទួលបណ្ដោះអាសន្ន) ។ admission à la retraite d'office ការដាក់ឲ្យនិវត្តន៍ដោយឥតសុំ

admonestation *n.f.* ការស្តីបន្ទោស

admonester *v.t.* ស្តីបន្ទោស

admoniteur,trice *n.* អ្នកព្រមាន

adolescence *n.f.* តរុណវ័យ, តរុណភាព, វ័យ ឬ ភាពពេញជំទង់

adolescent,e *a.&n.* តរុណ, តរុណី, មនុស្សពេញជំទង់

adonner (s') *v.pr.* ប្រព្រឹត្ត, ធ្វើ, ជ្អិញចិត្ត; ផ្តេកផ្តួល ។ s'adonner à l'étude ជ្អិញចិត្តខាងការសិក្សា ។ s'adonner aux plaisirs ជ្អិញចិត្តខាងសប្បាយ

adoptable *a.* គួរចិញ្ចឹមជាកូន, គួរយកជាការ, គួរយល់ព្រម

adoptant, e *n.* អ្នកទទួលចិញ្ចឹម(ជាកូន)

adopté, e *n.* អ្នកដែលគេចិញ្ចឹម(ជាកូន)

adopter *v.t.* ចិញ្ចឹមជាកូន ។ *Fig.* ចាប់យក, យកជាការ, យល់ព្រម

adoptif, ive *a.* ការចិញ្ចឹមជាកូន។ fils adoptif កូនចិញ្ចឹម។ père adoptif ឪពុកចិញ្ចឹម ។

adoption *n.f.* ការចិញ្ចឹមជាកូន

adorable *a.* គួរធ្វើសក្ការៈ; ល្អឆ្នើម

adorablement *adv.* ដោយគួរធ្វើសក្ការៈ

adorateur,trice *n.* អ្នកធ្វើសក្ការៈ; អ្នកស្រឡាញ់ហួសពេក

adoration *n.f.* សក្ការៈ; ស្នេហាខ្ពង់ខ្ពស់

adorer *v.t.* ធ្វើសក្ការៈ; ស្នេហាខ្ពង់ខ្ពស់, ស្រឡាញ់ណាស់

ados *n.m.* ដីអាចម៍បំណះ; រង (រងដំឡូង)

adossé,e *a.* ដែលដាក់ខ្នងទល់គ្នា

adossement *n.m.* ការដាក់ផ្អែក

adosser *v.t.* ដាក់ផ្អែក ។ s'adosser *v.pr.* ផ្អែក

adoucir *v.t.* បន្ទាប(វត្ថុល្វីងឬប្រៃ); ខាត់លោហធាតុ ។ *Fig.* ធ្វើឲ្យស្រាក ឬ ឲ្យសមរម្យ; ធ្វើឲ្យទ្រាំទ្របាន

adoucissage *n.m.* ការខាត់លោហធាតុ

adoucissant,e *a.* ដែលធ្វើឲ្យស្រាក ឬ ឲ្យស្ងប់, ដែលធ្វើឲ្យទ្រាំទ្របាន

adoucissement *n.m.* ការបន្ទាប; ដំណើរអាកាសធាតុប្រែទៅជាល្អ ។ *Fig.* ការស្រាកទុក្ខ

adresse *n.f.* ប៉ិនដៃ, ការប៉ិនប្រសប់;អាសយដ្ឋាន [–សៈ-យ័ត–] (ទីដែលអាស្រ័យនៅ);ទីលំនៅ។ *Fig.* à l'adresse de quelqu'un ចំពោះអ្នកណាមួយ

adresser *v.t.* ផ្ញើឆ្ពោះ។ adresser

la parole à quelqu'un និយាយទៅកាន់ ។ s'adresser (à quelqu'un) *v.pr.* និយាយទៅកាន់, ជូនបណ្ដឹង

adroit, e *a.* ប៉ិនប្រសប់ ។ *Fig.* ដែលមានឧបាយកល

adroitement *adv.* ដោយប៉ិនប្រសប់, ដោយឧបាយកល

adulateur,trice *a.&n.* ដែលបញ្ចើចបញ្ចើ, អ្នកបញ្ចោរ

adulation *n.f.* ការបញ្ចើចបញ្ចើ

adulatoire *a.* នៃការបញ្ចើចបញ្ចើ

aduler *v.t.* បញ្ចើចបញ្ចើ

adulte *a.&n.* ពេញវ័យ,មនុស្សពេញវ័យ

adultérateur *n.m.* អ្នកក្លែង

adultération *n.f.* ការក្លែង ·

adultère *a.&n.* អតិចារី, អតិចារិនី (ដែលផិតក្បត់ចិត្តស្វាមី ឬ ក្បត់ចិត្តភរិយា) ។ *n.m.* អតិចរិយា (ការផិតក្បត់ចិត្តស្វាមី ឬ ក្បត់ចិត្តភរិយា)

adultérer *v.t.* ក្លែង

adultérin,e *a.&n.* អតិចារជាត,ដែលកើតអំពីអតិចរិយា (កូនកើតពីការផិតក្បត់)

adultérinité *n.f.* ភាពកូនកើតអំពីអតិចរិយា

ad valorem *loc.lat.* តាមតម្លៃ

advenir *v.i.* មកដល់ដោយចៃដន្យ ។ advienne que pourra ទៅជាយ៉ាងណាទៅចុះ

adventice *a.* ដែលមកឯង, ដែលដុះឯង (ម.ព. plante)

adventif,ive *a. Bot.* ដែលដុះក្រៅពីកន្លែងធម្មតា ។ racine adventive ឫសព្រយុង ។ *Dr.* biens adventifs ទ្រព្យដែលប្រពន្ធរកបានតាំងពីការមក

adverbe *n.m.* កិរិយាវិសេសន៍

adverbial,e,aux *a.* នៃកិរិយាវិសេសន៍ ។ locution adverbiale និបាតសព្ទកិរិយាវិសេស

adverbialement *adv.* ជាកិរិយាវិសេសន៍

adversaire *n.m.* គូប្រឆាំង, សត្រូវ

adverse *a.* ដែលប្រឆាំង ។ partie adverse គូក្ដីប្រឆាំង ។ fortune adverse ភ័ព្វអាក្រក់

adversité *n.f.* គ្រោះកាច

adynamie *n.f.* អថាមភាព, ភាពគ្មានកម្លាំងកាយ

adynamique *a.* អថាមវន្ត, អថាមវន្តី, ខ្សោយ, ដែលអស់កម្លាំង

aération *n.f.* ឬ **aérage** *n.m.* ការបញ្ចូលខ្យល់

aéré,e *a.* ដែលមានខ្យល់ចេញចូល

aérer *v.t.* បញ្ចូលខ្យល់

aéricole *a.* ដែលដុះលើអាកាស

aérien,enne *a.* ដែលជាខ្យល់, ដែលដើរដោយខ្យល់, ដែលនៅលើអាកាស។ *Fig.* ស្រាល (ដូចខ្យល់)

aérifère *a.* ដែលនាំខ្យល់ ។ tube aérifère បំពង់ខ្យល់

aérification *n.f.* ការធ្វើឲ្យរលាយទៅជាខ្យល់(គឺធ្វើវត្ថុរឹងឬរាវឲ្យទៅជាខ្យល់), ភាពរលាយទៅជាខ្យល់

aérifier *v.t.* ធ្វើឲ្យរលាយទៅជាខ្យល់

aériforme *a.* ដែលមានរូបសណ្ឋានដូចខ្យល់

aériser *v.t.* ម.ព. **aérifier**

aérobie *a.* អាកាសជីវី(អតិសុខុមប្រាណដែលរស់ដោយសារខ្យល់អាកាស)

aérobus *n.m.* យន្តហោះបន្ទុក

aéro-club *n.m.* សមាគមអាកាសយាន

aréodrome *n.m.* បំណតឬដំណាក់អាកាសយាន

aérogare *n.f.* ស្ថានីយអាកាសយាន

aérolithe *n.m.* កេតុ, ថ្មអាចម៍ផ្កាយ (ឈ្មោះថ្មមានពន្លឺដែលធ្លាក់ចុះពីអាកាសមកលើផែនដី)

aérolithique *a.* នៃកេតុ(ថ្មអាចម៍ផ្កាយ)

aérologie ឬ **aérographie** *n.f.* អាកាសវិជ្ជា

aéromètre *n.m.* អាកាសមាត្រ (ប្រដាប់វាស់ឃនភាពខ្យល់)

aérométrie *n.f.* អាកាសមាត្រវិធី

aéromoteur *n.m.* យន្តដើរដោយខ្យល់

aéronautique *a.* នៃវិជ្ជាអាកាសចរណ៍។ *n.f.* វិជ្ជាអាកាសចរណ៍ (វិជ្ជាធ្វើអាកាសយាន និង ក្រាប់ចរតាមអាកាសយាន)

aéronaval, e, als *a.* នៃអាកាសនាវាចរណ៍

aéronef *n.m.* គ្រឿងអាកាសយាន

aéroplane *n.m.* អាកាសយាន

aéroport *n.m.* អាកាសយានដ្ឋាន,កំពង់បំណតអាកាសយាន

aéroporté, e *a.* ដែលដឹកនាំដោយអាកាសយាន

aéropostal,e,aux *a.* ប្រៃសណីយអាកាសចរណ៍

aérostat *n.m.* គោមហោះ

aérothérapie *n.f.* ការព្យាបាលរោគដោយប្រើខ្យល់

affabilité *n.f.* មនុញ្ញភាព,ភាពរួសរាយ ឬ រាក់ទាក់

affable *a.* មនុញ្ញ (ដែលមានសំដីនិងកិរិយាធ្វើឲ្យអ្នកផងស្រួលក្នុងចិត្តជានិច្ចនៅវេលាប្រស្រ័យ), រួសរាយ, រាក់ទាក់

affablement *adv.* ដោយមនុញ្ញភាព, ដោយរាក់ទាក់

affadir *v.t.* បន្សាប, ធ្វើឲ្យខ្ចើម

affaiblir *v.t.* ធ្វើឲ្យខ្សោយ

affaiblissant,e *a.* ដែលធ្វើឲ្យខ្សោយ

affaiblissement *n.m.* ការថយកម្លាំង, ការថយសកម្មភាព

affaire *n.f.* ការកិច្ច,កិច្ចរវល់,កិច្ចការ; ក្ដី; ការជំនួញ ។ *pl.* អីវ៉ាន់, សំលៀកបំពាក់; ជំនួញ; អត្ថប្រយោជន៍ (របស់រដ្ឋឬរបស់ឯកជន) ។ avoir affaire à quelqu'un មានការនិយាយគ្នា។ avoir affaire avec quelqu'un មានការទាក់ទងនឹង ។ j'en fais mon affaire ខ្ញុំទទួលការកិច្ចនេះ។ il fait mon affaire មនុស្សនេះឬរបស់នេះត្រូវចិត្តខ្ញុំ ។ faire son affaire à quelqu'un ធ្វើទោស, សម្លាប់ ។ se tirer d'affaire បានលទ្ធផលល្អ ; ដោះកុនរួចខ្លួន ។ affaires étrangères ការបរទេស

affairé,e *a.* ដែលមានកិច្ចរវល់, ដែលរវល់ច្រើន , ដែលហាក់ដូចជារវល់ច្រើន

affairement *n.m.* ភាពរវល់

affairer (s') *v.pr.* ប្រញាប់ប្រញាល់

affaissement *n.m.* ភាពស្រុត។*Fig.* ភាពអស់កម្លាំង, ភាពស្រយុតស្រយង់

affaisser *v.t.* សំរុត,បន្ទ្រាម ។ *Fig.* ធ្វើឲ្យអស់កម្លាំង ។ s'affaisser *v.pr.* ស្រុត, ទ្រោម

affaitage, affaitement *n.m.* ការផ្សាំងបក្សីពា

affaiter *v.t.* ផ្សាំងបក្សីពា

affaler *v.t.* *Mar.* ទម្លាក់។ s'affaler *v.pr.* ទៅជិតឆ្នេរពេក (នាវា) ។ *Fam.* ទម្លាក់ខ្លួន

affamé,e *a.* ដែលឃ្លាន។ *Fig.* លោភ

affamer *v.t.* បង្អត់អាហារ

affameur,euse *n.&a.* អ្នកបង្អត់អាហារ

affectable *a.* ប្រើអីយ, ងាយធ្វើឲ្យរំជួលចិត្ត ; ដែលបញ្ជាំបាន

affectation *n.f.* ការប៉ុរុងសំរាប់ ; ការធ្វើឫកពា

affecté, e *a.* ក្លែង ; ដែលធ្វើឫកពា; ហួសហេតុ

affecter *v.t.* ប្រើច្រើន ; ធ្វើឫកពា; ក្លែង ; មានរូបរាងដោយឡែក ; បំរុងសំរាប់; ធ្វើឲ្យរំជួលចិត្ត ។ s'affecter *v.pr.* ពិបាកចិត្ត

affectibilité *n.f.* ប្រេមីយភាព, ភាពងាយធ្វើឲ្យរំជួលចិត្ត

affectif,ive *a.* ប្រេមាការ, ដែលសំដែងមិត្តភាព

affection *n.f.* ប្រេម័ន,សេចក្ដីស្នេហា, មិត្តភាព; ជម្ងឺ

affectionné,e *a.* ប្រិយប្រិយ, ដែលគេស្រឡាញ់, ដែលគេចូលចិត្ត, ភក្ដី

affectionnément *adv.* ដោយស្រឡាញ់, ដោយរាប់អាន

affectionner *v.t.* ស្រឡាញ់

affectivité *n.f.* ប្រេមាការ

affectueusement *adv.* ដោយប្រេមវត្ត, ដោយមិត្តភាព, ដោយស្នេហា

affectueux,euse *a.* ប្រេមវត្ត,ដែលមានសេចក្ដីស្រឡាញ់,ប្រកបដោយមិត្តភាព

affectuosité *n.f.* ប្រេមវត្តភាព, ភាពអ្នកមានសេចក្ដីស្រឡាញ់

afférent, e *a.* បច្ចេកភាគ, ដែលត្រូវបានដល់ម្នាក់ៗ

affermable *a.* ដែលអាចប្រវាស់បាន

affermage *n.m.* ការប្រវាស់ដី ; ការបង់ភាស៊ី ; ការតែងលក់

affermataire *n.* អ្នកទទួលប្រវាស់ដី

affermateur, trice *n* អ្នកមានដីប្រវាស់ឲ្យគេ

affermer *v.t.* ប្រវាស់ដី; បង់ភាស៊ី; តែងលក់; ទិញភាស៊ី

affermir *v.t.* ពង្រឹង, ធ្វើឲ្យជាប់

affermissement *n.m.* ការពង្រឹង; ភាពបានរឹង

affichable *a.* អាចបិទប័ណ្ណប្រកាសបាន

affichage ឬ **affichement** *n.m.* ការបិទប័ណ្ណប្រកាស

affiche *n.f.* ប័ណ្ណប្រកាស ។ *Fig.* សញ្ញាខាងបរិយា

afficher *v.t.* បិទប័ណ្ណប្រកាស។ *Fig.* បញ្ចេញអាការៈ,សំដែង។ s'afficher *v.pr.* បញ្ចេញឬកឲ្យគេឃើញ

afficheur *n.m.* អ្នកបិទប័ណ្ណប្រកាស

affidé, e *a.* ដែលគេទុកចិត្ត ។ *n.* ចារបុរស, អ្នកស៊ើបការសម្ងាត់

affilage *n.m.* ការសម្លៀង

affilé, e *a.* មុត ។ *Fig.* avoir la langue bien affilée និយាយច្រើន ។ d'affilée *loc.adv.* រហូត, ឥតឈប់,ឥតដាច់

affiler *v.t.* សម្លៀង

affileur *n.m.* អ្នកសម្លៀង

affiliation *n.f.* ការចូលរួម (ក្នុងសហជីវកម្ម ឬ សមាគមសម្ងាត់) ; ការ

បញ្ចូលឈ្មោះ

affilié, e *a.&n.* ដែលចូលក្នុងសាជីវកម្ម ឬ សមាគមសម្ងាត់

affilier *v.t.* បញ្ចូលឈ្មោះ ។ s'affilier *v.pr.* ចូលជាសមាជិក

affiloir *n.m.* ប្រដាប់សម្លៀង

affin, e *a.* ដូចគ្នា ។ *n.m.* បងប្អូន

affinage ឬ **affinement** *n.m.* បរិសោធន៍, ការធ្វើឲ្យឆ្ងារ ឬ ឲ្យសុទ្ធ

affiner *v.t.* បរិសោធ, ធ្វើឲ្យឆ្ងារ-ឲ្យសុទ្ធ ឬ ឲ្យម៉ដ្ឋ; ប្រមោក (សូត្រ)

affinerie *n.f.* បរិសោធនដ្ឋាន

affineur *n.m.* បរិសោធនករ

affinité *n.f.* ពន្ធភាព, ភាពដូចគ្នា; ដំណើរទាក់ទងគ្នា

affinoir *n.m.* ស្និតសិតធ្មៃ

affirmatif, ive *a.* ដែលពោលអះអាង; វិជ្ជមាន ។ *n.f.* វិជ្ជមានកម្ម

affirmation *n.f.* ការពោលអះអាង

affirmativement *adv.* ដោយពោលអះអាង

affirmer *v.t.* ពោលអះអាង

affistoler ឬ **afistoler** *v.t.* តែងខ្លួនឲ្យដោយមិនសម ។ s'affistoler *v.pr.* ស្លៀកពាក់ល្អដើតឆាយ

affixe *n.m.* បុព្វបរបទ [បុប-ពា-ប៉ះ-រៈ-បត់]

affleurement *n.m.* ការដាក់ស្មើកំពស់គ្នា, ភាពនៅសើៗ ឬ នៅប៉ប្រះ

affleurer *v.t.* ដាក់ស្មើកំពស់គ្នា ។ *v.i.* នៅសើៗ, នៅប៉ប្រះ; នៅស្មើគ្នា

afflictif,ive *a.* នៃទណ្ឌកម្មលើរូបកាយ peine afflictive ម.ព. peine

affliction *n.f.* ទុក្ខព្រួយ, ទុក្ខវេទនា

affligé,e *a.* ដែលមានភេគឬមានទុក្ខព្រួយ

affligeant,e *a.* ដែលធ្វើឲ្យឈឺចាប់ ឬ ឲ្យមានទុក្ខព្រួយ

affliger *v.t.* ធ្វើឲ្យឈឺចាប់ ឬ ឲ្យមានទុក្ខព្រួយ

afflouer *v.t.* ស្ទូរ (ទូក-នាវា)

affluence *n.f.* ភាពកុះករ, ភាពដោរជន់ ។ *Fig.* ភាពសម្បូណ៌

affluent,e *a.&n.m.* ដៃទន្លេ

affluer *v.i.* ហូរចាក់ទៅ ។ *Fig.* មានសម្បូណ៌, មកដល់ច្រើន

afflux *n.m.* ការដោរឡើង (ឈាម)

affolant,e *a.* ដែលធ្វើឲ្យឡប់ស្មារតី

affolé,e *a.&n.* ដែលឡប់ស្មារតី

affolement *n.m.* ភាពឡប់ស្មារតី

affoler *v.t.* ធ្វើឲ្យឆ្កួត, ធ្វើឲ្យឡប់ស្មារតី

affouillement *n.m.* ចម្រោះ(ទឹក)

affouiller *v.t.* ច្រោះ (ទឹកភ្លៀងច្រោះដី)

affouragement ឬ **affourragement** *n.m.* ការដាក់ស្មៅឲ្យសត្វ

affourager ឬ **affourrager** *v.t.* ដាក់ស្មៅឲ្យសត្វ

affourcher *v.t.* ចតនាវា

affranchi,e *a.&n.* ដែលបានរួចជាអ្នកជា (ទាសៈ-ទាសី)

affranchir *v.t.* ឲ្យរួចជាអ្នកជា; ឲ្យរួចពន្ធ; បិទតែមប្រៃសណីយ៍; ឲ្យរួចអំពី...

affranchissable *a.* គួរឲ្យរួចជាអ្នកជា

affranchissement *n.m.* ការដោះលែង,ការបិទតែមប្រៃសណីយ៍

affranchisseur *n.m.* អ្នកដោះលែង

affres *n.f.pl.* ការតក់ស្លុត (មរណភ័យ)

affrètement *n.m.* នាវាការវេតកិច្ច (កិច្ចសន្យាជួលដឹកនាំតាមសមុទ្រ), ការជួលនាវា

affréter *v.t.* ជួលនាវា

affréteur *n.m.* នាវាការវេតក៍, អ្នកទទួលជួលនាវា (ផ្ទុយនឹងពាក្យ fréteur)

affreusement *adv.* ដោយគួរឲ្យខ្លាច

affreux,euse *a.* គួរខ្លាច; អាក្រក់ណាស់; កាចណាស់

affriander *v.t.* ធ្វើឲ្យចង់

affricher *v.t.* បោះបង់ដីឲ្យទៅជាព្រៃ

affriolant,e *a.* គួរឲ្យចង់ណាស់

affrioler *v.t.* ធ្វើឲ្យចង់; ធ្វើឲ្យឃ្លាន

affront *n.m.* ប្រមាថ,ដំណើរខូចកិត្តិយស

affrontement *n.m.* ការដាក់ប្រផស់មុខគ្នា

affronter *v.t.* ដាក់ប្រផស់មុខគ្នា ។ *Fig.* ពុះពារ

affronterie *n.f.* ការពុះពារ

affronteur,euse *n.* មនុស្សឥតអៀនខ្មាស; អ្នកបញ្ឆោតគេ

affruiter *v.i.* មានផល ។ *v.t.* ដាំរុក្ខផល, ដាំឈើមានផ្លែ ។ **s'affruiter** *v.pr.* ឲ្យផ្លែ

affublement *n.m.* សំលៀកបំពាក់ខុសបែប

affubler *v.t.* ស្លៀកពាក់ឲ្យដោយខុសបែប ។ **s'affubler** *v.pr.* ស្លៀកពាក់យ៉ាងចំឡែកឬគួរឲ្យអស់សំណើច

affût *n.m.* ជើងទ្រកាំភ្លើងធំ; ខ្ទះ ។ *Fig.* être à l'affût ឃ្លាំមើល, ឈ្លប

affûtage *n.m.* ការសម្លៀង ឬ សម្រួច

affûter *v.t.* សម្លៀង; កល់កាំភ្លើងធំ

affûteur *n.m.* អ្នកសម្លៀង; អ្នកបាញ់ពីលើខ្ទះ

afghan,e *a.* នៃប្រទេសអ័ហ្វហានីស្ថាន ។

n. ជនជាតិអ័ហ្វហ្គានីស្ថាន

afin que ឬ **de** *loc.conj.* ឬ *pré.* ដើម្បីនឹង

afistoler *v.t.* ម.ព. affistoler

à fortiori *loc.lat.* ម.ព. fortiori (à)

africain,e *a.* នៃទ្វីបអាហ្វ្រិក ។ *n.* ជនជាតិអាហ្វ្រិក

agaçant,e *a.* ដែលឲ្យសង្កៀរ ។ *Fig.* ដែលធ្វើឲ្យក្ដាញ់

agacement *n.m.* ការសង្កៀរ (ធ្មេញ, ត្រចៀក, ។ល។) ។ *Fig.* ការក្ដាញ់

agacer *v.t.* ធ្វើឲ្យសង្កៀរ ។ *Fig.* ធ្វើឲ្យក្ដាញ់ ឬ ឲ្យខឹង

agacerie *n.f.* ឫកម៉ូកម៉ក់

agaillardir *v.t.* ធ្វើឲ្យរឹតតែសប្បាយ

agalactie ឬ **agalaxie** *n.f.* ទាស់គ្មានទឹកដោះ (រោគរបស់ស្ត្រី)

agar-agar *n.m.* ជាហ្វួយ

age *n.m.* ចន្ទោល

âge *n.m.* អាយុ, វ័យ, វ័យចាស់ ។ âge ingrat វ័យជំទង់ ។ Moyen Age ម.ព. moyen ។ les quatre âges យុគទាំងបួន : l'âge d'or ក្រឹតយុគ (យុគមាស, អាយុមាស : ពួកមនុស្សក្នុងយុគនេះមានអាយុវែងៗ មានសេចក្ដីសុខច្រើន) ; l'âge d'argent ត្រេតយុគ ឬ ត្រេតាយុគ (យុគប្រាក់, អាយុប្រាក់ : ពួកមនុស្សក្នុងយុគនេះមានអាយុវែងយ៉ាងមធ្យម ទាំងសេចក្ដីសុខក៏យ៉ាងមធ្យម) ; l'âge d'airain ទ្វាបរយុគ (យុគសំរិទ្ធ : ក្នុងយុគនេះអាយុមនុស្សទាំងសេចក្ដីសុខយ៉ាងអន់) ; l'âge de fer កលិយុគ (យុគដែក : យុគយើងសព្វថ្ងៃនេះឯង, ពួកមនុស្សមានអាយុនិងសេចក្ដីសុខតិចណាស់) ។

âgé,e *a.* ដែលមានអាយុ; ចាស់

agence *n.f.* នាទីភ្នាក់ងារ, ដំណែងភ្នាក់ងារ, ទីភ្នាក់ងារ ។ agence de voyage ទីភ្នាក់ងារគមនាគារ

agencement *n.m.* ការរៀបចំ

agencer *v.t.* រៀបចំ

agenda *n.m.* ទិនានុលេខន៍

agenouillement *n.m.* ការលុតជង្គង់

agenouiller (s') *v.pr.* លុតជង្គង់

agenouilloir *n.m.* ជើងម៉ាសំរាប់លុតជង្គង់

agent *n.m.* ភ្នាក់ងារ ។ agent de brigade ភ្នាក់ងារតម្រួត ។ *ch. de fer* agent de dédoublement ភ្នាក់ងារទុតិយការ ។ agent de police ឬ agent ភ្នាក់ងារប៉ូលីស ។

agent de liaison ភ្នាក់ងារសម្ពន្ធ។ agent technique វិស្វកររង ។ agent de paiement ភ្នាក់ងារបើកប្រាក់

agglomératif,ive *a.* ដែលផ្ដុំ

agglomération *n.f.* អាកិណ្ណភូមិ; ការផ្ដុំ; ភាពផ្ដុំគ្នា

agglomérer *v.t.* ប្រមូល, ផ្ដុំ

agglutinant,e *a.* ស្អិត

agglutinatif,ive *a.* ដែលបិទភ្ជាប់

agglutination *n.f.* ការបិទភ្ជាប់, ការស្អិតជាប់,ការតភ្ជាប់ឡើងវិញ

agglutiner *v.t.* បិទភ្ជាប់ ។ s'agglutiner *v.pr.* ស្អិតជាប់គ្នា

aggravant,e *a.* ដែលធ្វើឲ្យធ្ងន់ ។ circonstance aggravante ស្ថានទម្ងន់ទោស

aggravation *n.f.* គារុកម្ម, ការធ្វើឲ្យធ្ងន់

aggraver *v.t.* ធ្វើឲ្យកាន់តែធ្ងន់, ធ្វើឲ្យកាន់តែដុនដាប

agile *a.* ស្រាល, រហ័ស, ទន់ភ្លន់

agilement *adv.* យ៉ាងស្រាល, យ៉ាងរហ័ស, យ៉ាងទន់ភ្លន់

agilité *n.f.* ភាពស្រាល-រហ័សឬទន់ភ្លន់

agio *n.m.* អតិប្រមាណ (ឧ.ឧបមាប្រាក់រៀលក្រដាស បើតាមច្បាប់មានតម្លៃស្មើនឹងសាច់ប្រាក់សុទ្ធ ទម្ងន់ ២៥ ក្រាម ។ ដោយមានហេតុផ្សេង ៗ ប្រាក់ក្រដាសនោះចុះតម្លៃមកនៅស្មើនឹងសាច់ប្រាក់សុទ្ធទម្ងន់ ៥ ក្រាមវិញ ។ តម្លៃទឹកប្រាក់ខុសគ្នា ២០ ក្រាមនេះ គេហៅថា «agio», «អតិប្រមាណ» គឺប្រមាណដែលលើសកំណត់)

agiotage *n.m.* អតិប្រមាណកម្ម

agioter *v.i.* ប្រព្រឹត្តអតិប្រមាណកម្ម

agioteur,euse *n.* អតិប្រមាណករ

agir *v.t.* ធ្វើ, ប្រព្រឹត្ត; ប្ដឹង ។ Il s'agit de គឺជា

agissant,e *a.* ដែលធ្វើ, ដែលប្រព្រឹត្ត, ដែលនាំរំជើបរំជួល, សកម្ម

agissements *n.m.pl.* ការប្រព្រឹត្ត, មារយាទ (ខាងខូច)

agitant,e *a.* ដែលធ្វើឲ្យញ័រទទ្រើក

agitateur,trice *n.* អ្នកនាំរំជើបរំជួល។ *n.m.* ប្រដាប់កូរ

agitation *n.f.* កោលាហល, ការរំជើបរំជួល;ដំណើរញ័រទទ្រើក។agitation populaire ប្រជាកោលាហល ។ *Fig.* សេចក្ដីរំជើបរំជួលក្នុងចិត្ត

agité,e *a.&n.* ដែលច្រើលច្រាស់

agiter *v.t.* បក់, អង្រួន, ក្រឡុក, កំរើក,

ទទោក ។ *Fig.* ធ្វើឲ្យរំដើបរំជួល, បំបះបំបោរ; នាំដែក

agnat *n.m.* ញាតិសាច់ថ្លៃ

agnation *n.f.* ពួកញាតិសាច់ថ្លៃ

agneau *n.m.* កូនចៀមឈ្មោល ។ *Fig.* មនុស្សស្លូត ។ l'agneau sans tache ព្រះយេស៊ូ

agnelage ឬ **agnèlement** *n.m.* រដូវចៀមកើតកូន

agnelée *n.f.* ចំនួនកូនចៀមកើតម្ដង

agneler *v.t.* កើតកូន (ចៀម)

agnelet *n.m.* កូនចៀមតូច

agnelle *n.f.* កូនចៀមញី

agonie *n.f.* មរណាសន្នកាល, មរណវេលា, ការរកខ្យល់, ការស្លូឈាម ។ *Fig.* ទុក្ខវេទនា;ដំណើរជិតផុត-ជិតចប់

agonir *v.t.* **agonir d'injures** ជេរប្រទេចខ្លាំង ។ agonir de sottises ធ្វើផ្ដេសផ្ដាសខ្លាំង (កុំជា agoniser)

agonisant,e *a.&n.* មរណាសន្ន, ដែលជិតស្លាប់, ដែលជិតផុតដង្ហើម, ដែលស្លូឈាម

agoniser *v.t.* ជិតស្លាប់,ជិតផុតដង្ហើម

agrafe *n.f.* កន្ទាស់

agrafer *v.t.* ក្ទាស់ ។ *Pop.* ក្របួច ក

agrafeuse *n.f.* មាស៊ីនក្ទាស់

agrainer *v.t.* បាចគ្រាប់ (ស្រូវ ឬ គ្រាប់អ្វីផ្សេងទៀត) ឲ្យសត្វស៊ី

agraire *a.* នៃដី, នៃក្សេត្រ

agrandir *v.t.* ធ្វើឲ្យធំ,ពង្រីក ។ *Fig.* លើកឋានៈ

agrandissement *n.m.* ការពង្រីក, ការបង្កើន; រូបថតពង្រីក

agrandisseur *n.m.* ប្រដាប់ពង្រីករូបថត

agraphie *n.f.* អលេខនា (រោគសរសេរមិនកើត)

agréable *a.* រមណីយ,ដែលជាទីគាប់ចិត្ត, គួររីករាយ ។ *n.m.* រមណីយវត្ថុ

agréablement *adv.* ដោយរមណីយ ឬ គួររីករាយ

agréé *n.m.* ប្រតិស្រុត(អ្នកធានារឿងក្ដី)

agréer *v.t.* ទទួល, ព្រមតាម ។ *v.i.* គាប់ចិត្ត

agrégat *n.m.* ខន្ធ,ការផ្ដុំវត្ថុទៃពីគ្នា

agrégatif,ive *a.* ដែលភ្ជាប់,ដែលផ្ដុំ ។ *Fam.* បេក្ខជនមហាបរិញ្ញាប័ត្រ

agrégation *n.f.* ខន្ធុប្បាទ, សំយោគកម្ម, ការចូលក្នុងអង្គការណាមួយ; មហាបរិញ្ញាប័ត្រ ។ *Par ext.* ការជុំ,ការផ្ដុំ

agrégé, e *n.* អ្នកមហាបរិញ្ញា

agréger *v.t.* ឲ្យចូលក្នុងអង្គការណា

មួយ ។ *Phy.* ភ្ជាប់គ្នា

agrément *n.m.* ប្រតិស្រពណ៍, សេចក្ដីយល់ព្រម, ការគាប់ចិត្ត, ការប្ដេជ្ញា ។ *Pl.* លំអ

agrémenter *v.t.* លំអ

agrès *n.m. pl.* នាវិកភ័ណ្ឌ; ឧបករណ៍

agresseur *n.m.* អ្នកបង្កអធិករណ៍, អ្នកល្បានពាន

agressif,ive *a.* ដែលបង្កអធិករណ៍, ដែលឈ្លានពាន

agression *n.f.* ការបង្កអធិករណ៍, អំពើឈ្លានពាន

agressivement *adv.* ដោយល្បានពាន

agressivité *n.f.* ភាពជាអ្នកបង្កអធិករណ៍, ភាពជាអ្នកឈ្លានពាន

agreste *a.* នៃជនបទ, គំរាំង

agrestement *adv.* ដោយគំរាំង

agricole *a.* នៃក្សេត្រកម្ម, នៃកសិកម្ម ។ ingénieur agricole វិស្វករកសិកម្ម

agriculteur *n.m.* កសិករ, អ្នកស្រែចំការ

agricultural, e,aux *a.* នៃកសិកម្ម

agriculture *n.f.* កសិកម្ម, ក្សេត្រកម្ម

agriffer *v.t.* ចាប់យកដោយក្រញ៉ាំ ។ s'agriffer *v.pr.* ខ្ទាំ, ក្រសោប

agripper *v.t.* ឆក់ ។ s'agripper *v.pr.* តោង

agrippeur,euse *n. Fam.* អ្នកឆក់

agrologie *n.f.* ក្សេត្រភូមិវិទ្យា

agronome *n.m.* ក្សេត្រវិទ

agronomie *n.f.* ក្សេត្រវិទ្យា

agronomique *a.* នៃក្សេត្រវិទ្យា

agroupement *n.m.* ការប្រជុំគ្នា, ភាពជុំគ្នា

agrouper *v.t.* ប្រមូលឲ្យជុំគ្នា ។ s'agrouper *v.pr.* ប្រជុំគ្នា

agrumes *n.m.pl.* ក្រូច

aguerrir *v.t.* ការបង្ហឹកខាងផ្លូវសឹក ឬ ខាងការពិបាក ។ s'aguerrir *v.pr.* បង្ហឹកខ្លួនខាងផ្លូវសឹក ឬ ខាងការពិបាក

aguerrissement *n.m.* ការបង្ហឹកខាងផ្លូវសឹក ឬ ខាងការពិបាក; ភាពធ្លាក់នឹងសឹក ឬ នឹងការពិបាក

aguets *n.m. pl.* ការឈ្លប ។ être, se tenir aux aguets ល្បប

aguichant,e *a.* ម៉ិកម៉ក់

aguicher *v.t. Fam.* ធ្វើឫកម៉ិកម៉ក់

aguicheur,euse *a.* ដែលធ្វើឫកម៉ិកម៉ក់

ah ! *int.* ឃើ ! អៃយ៉ា !

aheurté,e *a.* ដែលជំពប់ ។ *Fig.* ដែលប៉ះទង្គិច

aheurtement *n.m.* ការបះបោស ។ *Fig.* ការជំពាក់ចិត្តខ្លាំង

aheurter (s') *v.pr.* បះបោស; ទង្គិច; ជាក់បែក

ahi! *int.* ម.ព. aïe !

ahuri,e *a.* ឡើងឡាំង, ស្រឡាំងកាំង

ahurir *v.t.* ធ្វើឲ្យទៅជាឡើងឡាំង

ahurissant, e *a.* គួរឲ្យឆ្ងល់

ahurissement *n.m.* ភាពស្រឡាំងកាំង, ភាពមិនងមាំង; ការឆ្ងល់ខ្លាំង

aiche, èche ឬ **esche** *n.f.* នុយ

aide *n.f.* ការជួយ, ជំនួយ, ការទំនុកបំរុង,ឧបត្ថម្ភ។ *n.m.&f.* អ្នកជួយ,អ្នកទំនុកបំរុង, អ្នកឧបត្ថម្ភ ។ aide de camp អង្គរក្ស ។ aide-opérateur អនុការី ។ aide-vaccinateur អនុបសុព្យាបាល [–ប៉ះ-សុ–] (អ្នកជំនួយបណ្ដុះមេរោគខាងបសុពេទ្យ) *n.f.pl.* ពន្ធមិនចំពោះ

aide-mémoire *n.m.inv.* ជំនួយស្មារតី, សៀវភៅបំព្រួញ

aider *v.t.* ឧបត្ថម្ភ, ជួយ,គាំទ្រ ។ *v.i.* ជួយរំលែកការ ។ s'aider *v.pr.* ប្រើប្រាស់ ។ s'aider des deux mains ប្រើដៃទាំងពីរ (ដើម្បីធ្វើការ)។ aide-toi, le ciel t'aidera បេះពីរៀនមានពីរក (ខំខ្លួនឯងមុនសិនទើបទេវតាជួយជាក្រោយ)

aïé ឬ **ahi !** *int.* យ៉ូយ(សំរែកបញ្ចេញការឈឺចាប់)

aïeul,e *n.* ជីតា,ជីដូន ។ aïeux *n.m.pl.* បុព្វបុរស

aigle *n.m.* ឥន្ទ្រី ។ *Fig.* អ្នកប្រាជ្ញ ។ yeux, regards d'aigle ភ្នែកមុត ។ *n.f.* ឥន្ទ្រីញី; ទង់ជាតិ

aiglon,onne *n.* កូនឥន្ទ្រី

aigre *a* ជូរ (រស) ។ *Fig.* ញើរ; ទ្រគោះ (សំឡេង) ; ឆ្នាស (ស្រី)

aigre-doux,ce *a.* ជូរអែម

aigrefin *n.m.* មនុស្សមានឧបាយទុច្ចរិត

aigrelet,ette *a.* ជូរបន្តិចៗ

aigrement *adv.* យ៉ាងជូរ

aigret,ette *a.* ជូរបន្តិចៗ

aigrette *n.f.* សយ (កំពោយបក្សី), សំណុំរោម

aigretté,e *a.* ដែលមានសយ

aigreur *n.f.* ភាពជូរ ។ *Fig.* សេចក្ដីអួមៅ

aigrir *v.t.* ធ្វើឲ្យជូរ ឬ ឲ្យផ្អូម។ *Fig.* ធ្វើឲ្យអួមៅ ។ *v.i.* ឡើងជូរ ។ s'aigrir *v.pr.* ឡើងជូរ ។ *Fig.* អួមៅ

aigrissement *n.m.* ការធ្វើឲ្យជូរ,

ភាពឡើងជូរ

aigu,ë *a.* ស្រួច ។ *Fig.* គ្រលួច ។ angle aigu មុមស្រួច ។ douleur aiguë ការឈឺចាប់ខ្លាំង ។ Maladie aiguë រោគខ្លាំងក្លា ។ *Mus.* ឯក

aiguade *n.f.* ស្បៀងទឹកសាបសំរាប់នាវា

aiguail ឬ **aigail** *n.m.* សន្សើមជាប់លើស្លឹកឈើ

aiguayer *v.t.* បោក, លាង

aigue - marine *n.f.* ត្បូងមរកត (យកពីក្នុងសមុទ្រ)

aiguière *n.f.* ទីកោទឹក (ថូទឹកម្យ៉ាង)

aiguillage *n.m.* ការប្តូរផ្លូវរទេះភ្លើង

aiguille *n.f.* ម្ជុល, ទ្រនិច (នាឡិកា); កំពូលស្រួច ។ *Prov.* de fil en aiguille ពីរឿងមួយទៅរឿងមួយ ។ chercher une aiguille dans une botte de foin រាវរកម្ជុលក្នុងទន្លេ (រកវត្ថុដែលពុំអាចរកឃើញ)

aiguiller *v.t.* ប្តូរផ្លូវរទេះភ្លើង ។ *Fig.* ដឹកនាំឆ្ពោះទៅ

aiguillerie *n.f.* រោងចក្រ ឬ ជំនួញម្ជុល

aiguilleur *n.m.* អ្នកប្តូរផ្លូវរទេះភ្លើង

aiguillier *n.m.* ក្លាក់ម្ជុល

aiguillon *n.m.* ជន្លួញ; ទ្រនិច (សត្វល្អិត); បន្លា ។ *Fig.* អ្វីៗជាគ្រឿងដាក់ឲ្យស្ទុះ

aiguillonnement *n.m.* ការចាក់នឹងជន្លួញ; ការទិច

aiguillonner *v.t.* ចាក់នឹងជន្លួញ; ទិច ។ *Fig.* ដាស់សតិ, លើកទឹកចិត្ត

aiguiser *v.t.* សំលៀង,សំរួច ។ *Fig.* aiguiser l'appétit ធ្វើឲ្យឃ្លាន

aiguiseur,euse *n.* អ្នកសំលៀង-សំរួច

aiguisoir *n.m.* ប្រដាប់សំលៀង-សំរួច

ail *n.m.* ខ្ទឹមស (*pl.* des aulx, des ails)

aile *n.f.* ស្លាប ។ *Fig.* ការឧបត្ថម្ភ ។ *loc. adv.* voler de ses propres ailes ជិះស្លាបហើយ(អាចធ្វើអ្វីដោយខ្លួនឯងបាន) ។ battre de l'aile មានកង្វល់ ។ ne battre que d'une aile ប្រទះឧបសគ្គ, ប្រទះការលំបាក ។ rogner **les** ailes à quelqu'un បន្ថយអំណាច, បន្ថយកំរៃ ។ à tire-d'aile ម.ព. tire-d'aile

ailé,e *a.* ដែលមានស្លាប

aileron *n.m.* ចុងស្លាប; ព្រុយត្រីខ្លះ

ailette *n.f.* ស្លាបតូច

ailleurs *adv.* នៅទីដទៃ ។ d'ailleurs *loc.adv.* ម្យ៉ាងទៀត

aimable *a.* គួរស្រឡាញ់

aimablement *adv.* ដោយគួរស្រឡាញ់

aimant *n.m.* លោហកាន្ត, មេដែក ។ *Fig.* គ្រឿងទាក់ចិត្ត

aimant,e *a.* ប្រកបដោយស្នេហា

aimantation *n.f.* ការបញ្ចុះមេដែក

aimanter *v.t.* បញ្ចុះមេដែក

aimer *v.t.* ស្រឡាញ់, ចូលចិត្ត

aine *n.f.* ចង្កាក់ត្រីឆ្អើរ

aine *n.f.* ក្រលៀន

ainé,e *a.&n.* ច្បង, បង

ainesse *n.f.* ភាពជាបង

ainsi *adv.* ដូច្នេះ ។ ainsi que *loc. conj.* ដូច...ដែរ, ព្រមទាំង

air *n.m.* ខ្យល់, អាកាស ។ prendre l'air ដើរយកខ្យល់អាកាស; ហោះឡើង (អាកាសយាន) ។ en l'air មិនប្រាកដ (ឧ. parole en l'air សំដីឥតសព្វឥតសារ) ; រំជើបរំជួល (ឧ. toute la ville en l'air); គ្មានទីពឹង, គ្មានមូលហេតុ, ច្របូកច្របល់ (ឧ. mettre tout en l'air) ; ឡើងលើ (ឧ. lancer en l'air)។ *pl.* អាកាស

air *n.m.* អាការៈ, ទំនង, ឫកពា។ avoir l'air មានទំនងជា ។ prendre des airs ប្រកាន់ឫកភ្លេសហិនៈខ្លួន

air *n.m.* បទភ្លេង ។ l'air et la chanson ភេទក្រៅនឹងការពិត

airain *n.m.* លង្ហិន ។ *Fig.* កាំភ្លើងធំ។ cœur d'airain ចិត្តឥតមេត្តា, ចិត្តអាក្រក់ ។ âge d'airain ម.ព. âge ។ loi d'airain ទ្រឹស្តីសេដ្ឋកិច្ចដែលកប្រិតប្រាក់ឈ្នួលកម្មករឲ្យតិចបំផុតល្មមតែរស់ ។ *Prov.* les injures s'inscrivent sur l'airain, et les bienfaits sur le sable គុណរយសំពៅ ទោសមួយចូលទៅ រលាយបាត់អស់

aire *n.f.* លានបោក ឬ បញ្ជាន់ស្រូវ ; ក្រឡាផ្ទៃ; សំបុកបក្សីរំពា

aisance *n.f.* អាការងាយ; ទ្រព្យសម្បត្តិគ្រប់គ្រាន់ ។ lieux, cabinets d'aisances បង្គន់

aise *n.f.* ភាពរីករាយ ។ à l'aise, à son aise *loc.adv.* ដោយងាយ, ដោយគ្មានប្រឹង; ដោយមិនរអែងខ្លួន ។ *pl.* សេចក្តីស្រណុក(មិនទៀយ)

aise *a.* រីករាយ

aisé,e *a.* ងាយ;ដែលមានសម្បត្តិគ្រប់គ្រាន់

aisément *adv.* ដោយងាយ; ដោយគ្មានខ្វះអ្វី

aisselle *n.f.* ក្លៀក

ajointer *v.t.* តភ្ជាប់គ្នា,តកុងនឹងកុង

ajour *n.m.* ក្បាច់ចោះ

ajouré,e *a.* ដែលចោះ

ajourer *v.t.* ចោះ

ajourné *a.&n.m.* ដែលប្រឡងធ្លាក់; ដែលផ្អាក

ajournement *n.m.* ការលើកពេលវេលា ឬ ផ្អាក; ការកោះឲ្យចូលខ្លួនតាមកំណត់ថ្ងៃ

ajourner *v.t.* លើកពេលវេលា,បង្អង់,ផ្អាក

ajoutable *a.* អាចបន្ថែមបាន

ajouté, ajout ឬ **ajoutis** *n.m.*, **ajouture** *n.f.* អ្វីៗដែលគេបន្ថែម

ajouter *v.t.* បន្ថែម។ ajouter foi ជឿ

ajustage *n.m.* ការធ្វើឲ្យត្រូវ ឬ ឲ្យល្មម; ការភ្ជិត

ajustement *n.m.* ការផ្ទៀងប្រៀង; ការរៀបចំ; សំលៀកបំពាក់

ajuster *v.t.* ធ្វើឲ្យត្រូវ; ផ្សំឲ្យល្មម; រៀបចំ; ផ្ទៀងប្រៀង; ភ្ជិត; ស្លៀកពាក់

ajusteur *n.m.* ជាងភ្ជិត

alaire *a.* នៃស្លាប

alambic *n.m.* ឆ្នាំងបិតស្រា (សំរាប់ចំហុយយកញើស)។ *Fig.* passer à l'alambic ពិនិត្យយ៉ាងហ្មត់ចត់

alambiquer *v.t.* បិតស្រា

alanguir *v.t.* ធ្វើឲ្យអស់កម្លាំង ។ s'alanguir *v.pr.* អស់កម្លាំង

alanguissement *n.m.* ភាពអស់កម្លាំង

alarguer *v.i. Mar.* ចេញកណ្ដាលសមុទ្រ

alarmant,e *a.* ដែលនាំឲ្យផ្អើលឬឲ្យភ័យ

alarme *n.f.* ភ័យអាសន្ន, ភេរីសញ្ញា។ *pl.* បារម្ភ

alarmer *v.t.* បន្ផើល, បំភ័យ ។ s'alarmer *v.pr.* ភ័យ, បារម្ភ

alarmiste *a.&n.* អ្នកផ្សាយដំណឹងបន្ផើល ឬ បំភ័យ

albanais,e *a.* នៃប្រទេសអាល់បានី ។ *n.* ជនជាតិអាល់បានី

albâtre *n.m.* ថ្មកែវសាច់ ស-ភ្លឺ-ទន់ ។ *Fig.* ភាព ស ភ្លឺង

albinisme *n.m.* ភាពស្វៀក ឬ ឃ្លោច

albinos *n.&a.* ស្វៀក, ឃ្លោច

albugineux,euse *a.* ស ភាវ

album *n.m.* សៀវភៅសម្រាំយរូប

albumen *n.m.* ជាតិ ស នៃស៊ុត

albumine *n.f.* អណ្ដាសេត

albuminé,e *a.* ដែលមានអណ្ដាសេត

albumineux, euse *a.* ដែលមានអណ្ដាសេត

albuminoïde *a.&n.m.* អណ្ដាសេត-ជាតិ

alcali *n.m.* ជាតិក្បុង

alcalimètre *n.m.* បាសអាត្រ

alcalimétrie *n.f.* បាសមាត្រវិធី

alcalin,e *a.* នៃក្បុង

alcalinité *n.f.* លោហណភាព, ភាពប្រៃ

alcool *n.m.* សុរា, ស្រា

alcoolé *n.m.* ស្រាថ្នាំ

alcoolique *a.* ដែលមានជាតិស្រា; នៃស្រា ។ *n.* អ្នកប្រមឹក

alcoolisable *a.* អាចធ្វើទៅជាស្រាបាន

alcoolisation *n.f.* ការធ្វើ ឬ លាយស្រា (ជាមួយនឹងកេសជ្ជៈឯទៀត)

alcooliser *v.t.* ធ្វើស្រា, លាយស្រា (នឹងកេសជ្ជៈឯទៀត); ធ្វើឲ្យញៀនស្រា

alcoolisme *m.n.* សុរាសោណ្ឌរោគ, រោគញៀនស្រា ឬ រោគបណ្ដាលពីស្រា

alcoomètre ឬ **alcoolomètre** *n.m.* សុរាមាត្រ, សំទង់ស្រា

alcoométrie ឬ **alcoolométrie** *n.f.* សុរាមាត្រវិធី

aléa *n.m.* សំណាង, រឿងមិនទៀង

aléatoire *a.* មិនទៀង

aléatoirement *adv.* ដោយមិនទៀង

aléne *n.f.* ម្ជុលដេរស្បែក

alentour *adv.*ជុំវិញ, ជិតខាង

alentours *n.m. pl.* ទីបរិវេណ

alerte *a.* រហ័សរហួន ។ *n.f.* ការភ្ញើល, ភេរវសញ្ញា

alerter *v.t.* បង្អើល, ឲ្យភេរវសញ្ញា

alester *v.t.* សម្រាល

alevin *n.m.* កូនត្រី

aleviner *v.t.* លែងកូនត្រី (ចិញ្ចឹម)

alevinier *n.m.* ឬ **alevinière** *n.f.* កន្លែងដាក់កូនត្រី (ចិញ្ចឹម)

alexandrin,e *a.&n.m.* កាព្យ ១២ ព្យាង្គ

alezan,e *a.&n.* សេះសម្បុរក្រាក

algarade *n.f.* ការស្រែកជេរ

algèbre *n.m.* ពីជគណិត

algébrique *a.* នៃពីជគណិត

algébriquement *adv.* ដោយពីជគណិត

algébriste *n.* អ្នកពីជគណិត

algérien,enne *a.* នៃប្រទេសអ័លហ្សេរី ។ *n.* ជនជាតិអ័លហ្សេរី

algue *n.f.* សារាយ

alibi *n.m.* សំអាងដាក់ស្ដែង

aliboron *n.m.* លា ។ *Fig.* មនុស្សកញ្ជោត

aliénabilité *n.f.* ភាពអាចលក់ ឬ ផ្ទេរសិទ្ធិបាន

aliénable *a.* ដែលអាចលក់ឬផ្ទេរសិទ្ធិបាន

aliénataire *n.* អ្នកដែលគេលក់ ឬ ផ្ទេរសិទ្ធិឲ្យ

aliénateur, trice *n.* អ្នកលក់ ឬ ផ្ទេរសិទ្ធិឲ្យគេ

aliénation *n.f.* ការលក់ឬផ្ទេរសិទ្ធិ ។ *Fig.* វិកលចរិត, ដំណើរឆ្កួត ។ aliénation mentale ពុទ្ធិវិបល្លាស [–ប៉ុល.ល៉ាស–] (ភាវៈនៃបញ្ញាដែលប្រែប្រួលពីល្អទៅអាក្រក់)

aliéné, e *a.&n.* វិបល្លាស, ឆ្កួត

aliéner *v.t.* លក់; ផ្ទេរសិទ្ធិ; ធ្វើឲ្យឡប់

aliénisme *n.m.* ពុទ្ធិវិបល្លាសវិទ្យា

aliéniste *n.&a.m.* ពុទ្ធិវិបល្លាសវិទូ, ពេទ្យព្យាបាលរោគឆ្កួត

aliforme *a.* ដែលមានរាងដូចស្លាប

alignée *n.f.* ភាពត្រង់ជួរ

alignement *n.m.* ជួរ, ការរៀបជាជួរ ។ *Fig.* ការសម្របតាម

aligner *v.t.* រៀបជាជួរ ។ s'aligner *v.pr.* ឈរក្នុងជួរ ។ *Fig.* សម្របតាម ។ *Fam.* ប្រឈមមុខប្រយុទ្ធ

aliment *n.m.* អាហារ

alimentaire *a.* អាហារណីយ, នៃអាហារ ។ pension alimentaire ម.ព. pension

alimentateur,trice *a.* ជាអាហារ; ដែលផ្គង់អាហារ

alimentation *n.f.* អាហារូបត្ថម្ភ, ការចិញ្ចឹមជីវិត, ការឲ្យស្បៀង, ការបំរុងអាហារ

alimenter *v.t.* ចិញ្ចឹម, ផ្គង់អាហារ; បំរុងអាហារ

alinéa *n.m.* វាក្យខណ្ឌ, វគ្គ, ចន្លោះដើមបន្ទាត់ដែលលូកចូល

alinéaire *a.* ដែលសំគាល់វាក្យខណ្ឌ, ដែលសំគាល់វគ្គ

alitement *n.m.* ការដេកដាប់ (ដោយមានជម្ងឺ), ការដាក់ឲ្យដេកលើគ្រែ

aliter *v.t.* បង្ខំឲ្យដេក (ដោយមានជម្ងឺ) ។ s'aliter *v.pr.* ដេកដាប់ (ដោយមានជម្ងឺ)

alizé *a.&n.m.* ខ្យល់ប្យ៉ាង

allaitement *n.m.* ការបំបៅ

allaiter *v.t.* បំបៅ

allant,e *a.* ដែលចូលចិត្តដើរទៅមក ។ *n.m. pl.* អ្នកទៅ(ផ្ទុយនឹង venant អ្នកមក) ។ *sing.* ភាពរហ័សរហួន

alléchant,e *a.* គួរឲ្យចូលចិត្ត

allèchement *n.m.* សេចក្ដីចូលចិត្ត

allécher *v.t.* ទាក់, ល្បួង (ដោយបង្ហាញនុយ)

allée *n.f.* ផ្លូវសួន ។ allées

venues ការទៅមករឿយ ៗ

allégation *n.f.* ទឡ្ហីករណ៍, ការពោលរេក

allégeage *n.m.* ការសំរាល

allégeance *n.f.* ការបន្ធូរបន្ថយ; ការនៅក្នុងឱ្យឱវាទ (ខាងនយោបាយ)

allégement *n.m.* ការសំរាល ។ *Fig.* ការបន្ធូរបន្ថយ

alléger *v.t.* សំរាល ។ *Fig.*បន្ធូរបន្ថយ

allègre *a.* រីករាយ, រហ័សរហួន

allégrement *adv.* យ៉ាងរីករាយ,យ៉ាងរហ័សរហួន

allégresse *n.f.* សេចក្ដីរីករាយ

alléguer *v.t.* ពោលអាង,និយាយដោះសា

allemand,e *a.* នៃប្រទេសអល្លឺម៉ង់ ។ *n.* ជនជាតិអល្លឺម៉ង់ ។ *n.m.* ភាសាអល្លឺម៉ង់

aller *v.i.* ទៅ; ហៀបនឹង; ដើរ; ឿន, កើន (ឧ. ce travail ne va pas) ; មានសុខភាព (ឧ. je vais bien ឬ mal) ; ល្មម, សម (ឧ. cet habit vous va bien) ; ចំរុងចំរើន (ឧ. ce commerce va) ។ aller aux voix ទៅបោះឆ្នោត ។ se laisser aller បណ្ដោយបណ្ដោយ ។ il y va de ជីវិត ។ s'en aller *v.pr.* ចេញ; ស្លាប់

aller *n.m.* ដំណើរទៅ, ការដើរ

alliacé, e *a.* ដូចខ្ទឹមស

alliage *n.m.* ធាតុលាយលោហធាតុ,លោហធាតុផ្សំ ។ *Fig.* ការផ្សំរបស់មិនសុទ្ធ

alliance *n.f.* អាពាហ៍ពិពាហ៍; សម្ពន្ធភាព,ការចងពន្ធប្រឹងស្ពានមេត្រី។*Fig.* ការរួបរួមនៃមនុស្សពីរនាក់ឬរបស់ពីរមុខ

allié, e *a.*&*n.* ញាតិពន្ធ, សម្ពន្ធមិត្រ

allier *v.t.* លាយ, បញ្ចុះលោហធាតុ ។ *Fig.* ផ្សំ ។ s'allier *v.pr.* ចងស្ពានមេត្រី, រួបរួម

allégator *n.m.* ក្រពើ

allô ! *int.* អាឡូ ! (ពាក្យសំរាប់បន្លឺក្នុងការឡើងដំណឹង ឬ សួរឈ្មោះជាមុនទៅវេលាផ្ដើមនិយាយដោយទូរសព្ទ)

allocataire *n.* វិភាជនលាភី (អ្នកបានវិភាជន៍)

allocation *n.f.* វិភាជន៍ ។ allocation familiale វិភាជន៍គ្រួសារ

allocution *n.f.* សង្កថា [ស័ង-កៈ–] (សុន្ទរកថាសង្ខេប)

allogène *a.*&*n.* ជាពូជដទៃ

allonge *n.f.* អនុប័ត្រ; ទំពក់ព្យួរ; អ្វី ៗ សំរាប់បន្ថែម

allongement *n.m.* ការបន្លាយ

allonger *v.t.* បន្លាយ; សន្ធឹង; លាយទឹក ។ *v.i.* រឹតតែវែងឡើង

allouer *v.t.* ឲ្យ (ឧ. allouer un crédit, une indemnité)

allumage *n.m.* ការអុជ, ការឆេះ

allume-feu *n.m.inv.* រំកាច់ ឬ អ៊ីវ សំរាប់បង្កាត់ភ្លើង

allumer *v.t.* អុជ, ដុត ។ *Fig.* បង្ក

allumette *n.f.* ឈើគូស

allumettier,ère *n.* អ្នកធ្វើឈើគូស

allumeur,euse *n.* អ្នកអុជចង្កៀង; ប្រដាប់អុជ ឬ ដុត

allumoir *n.m.* ប្រដាប់អុជ ឬ ដុត

allure *n.f.* ដំណើរ (របៀបដើរ) ។ *Fig.* ទំនង

allusion *n.f.* ពាក្យបញ្ឆៀង ឬ ជៀមជាម

alluvial,e, aux; alluvien, enne; alluvionnaire *a.* នៃល្បប់

alluvion *n.f.* ល្បប់

alluvionnement *n.m.* ដំណើរដុះល្បប់

alluvionner *v.i.* នាំមកនូវល្បប់

almanach *n.m.* មហាសង្ក្រាន្ត

aloi *n.m.* ទឹក (មាស ឬ ប្រាក់) ។ *Fig.* គុណភាព (ល្អ ឬ អាក្រក់) ។ marchandises de bon aloi ទំនិញដែលមានគុណភាពល្អ

alors *adv.* កាលនោះ, ដូច្នោះ ។ jusqu'alors *loc.adv.* រហូតដល់ពេលនោះ ។ alors que *loc. conj.* ទុកណាជា, ក្នុងពេលដែល

alouette *n.f.* ព្រួចអ៊ុត (អ៊ុត : grisoller) ។ *Prov.* attendre que les alouettes tombent toutes roties ការប៉ុនប៉ងរង់ចាំទឹកភ្លៀង (ដេកចាំដោយមិនប្រឹងប្រែង)

alourdir *v.t.* ធ្វើឲ្យធ្ងន់

alourdissement *n.m.* ភាពធ្ងន់

alpage *n.m.* វាលស្មៅសត្វលើភ្នំ

alpestre *a.* នៃភ្នំអ័ល្ប, ដូចភ្នំអ័ល្ប

alphabet *n.m.* អក្ខរក្រម

alphabétique *a.* តាមលំដាប់អក្ខរក្រម

alphabétiquement *adv.* ដោយតាមលំដាប់អក្ខរក្រម

alphabétiser *v.t.* រៀបតាមលំដាប់អក្ខរក្រម

alpin, e *a.* ដែលរស់នៅ ឬ ដែលដុះលើភ្នំអ័ល្ប ឬ លើភ្នំខ្ពស់ ៗ

alpinisme *n.m.* ការហាត់ឡើងភ្នំខ្ពស់ៗ

alpiniste *n.* អ្នកឡើងភ្នំខ្ពស់ ៗ

alsacien,enne *a.* នៃស្រុកអ័លស៉ាស ។ *n.* ជនជាតិអ័លស៉ាស

altérabilité *n.f.* ភាពអាចខូច ឬក្លែងបាន

altérable *a.* ដែលអាចខូច ឬ ក្លែងបាន

altérant,e *a.* ដែលធ្វើឲ្យខូច; ដែលនាំឲ្យស្រេក

altérateur, trice *n.* អ្នកធ្វើឲ្យខូច

altératif,ive *a.* ដែលធ្វើឲ្យខូច

altération *n.f.* ការខូច;ការក្លែង;ការប្រែទឹកមុខ ឬប្រែសំឡេងដោយរំជួលចិត្ត

altercation *n.f.* ការជជែកគ្នា, ការទាស់ទែងគ្នា

altérer *v.t.* ធ្វើឲ្យខូច; ក្លែង; នាំឲ្យស្រេក ។ s'altérer *v.pr.* ខូច

alternance *n.f.* ការផ្លាស់គ្នា

alternant,e *a.* ដែលផ្លាស់

alternatif,ive *a.*ដែលផ្លាស់គ្នា,ម្តងម្នាក់

alternative *n.f.* វេនបជី,ការផ្លាស់គ្នា។ *Fig.*ការរើសយក(ឧ. vous avez l'alternative du silence ou de la mort ចូរអ្នករើសយក តើសុខចិត្តនៅស្ងៀម ឬ សុខចិត្តស្លាប់)

alternativement *adv.*ដោយផ្លាស់គ្នា

alterner *v.i.* ផ្លាស់គ្នា ។ *v.t.* ផ្លាស់គ្នា

Altesse *n.f.* ទ្រង់, អ្នកអង្គម្ចាស់

altier, ère *a.* កោង, ឆ្មើងឆ្មៃ

altièrement *adv.* ដោយកោងឬឆ្មើងឆ្មៃ

altimètre *n.m.* ប្រដាប់វាស់កំពស់

altimétrie *n.f.* វិធីវាស់កំពស់

altissime *a.* ខ្ពស់ណាស់; ថ្កែកណាស់

altitude *n.f.* កំពស់

alto *n.m.* ជាប៉ុអ័លតូ

altruisme *n.m.* បរទត្ថភាព [ប៉ៈ-រ៉ៈ-ទ័ត-ថៈ-] (ភាពនៃអ្នកដែលឃើញប្រយោជន៍អ្នកដទៃ)

altruiste *a.*នៃបរទត្ថភាព។ *n.*បរទត្ថជន

aluminium *n.m.* អាលុយមីនីយ៉ូម (លោហធាតុ ស ស្រាល)

alvéole *n.m.* រន្ធសំបុកឃ្មុំ; រន្ធធ្មេញ

amabilité *n.f.* ប្រិយភាព,ភាពរួសរាយ

amadou *n.m.* ប៉ុយ

amadouement *n.m.* ការលួងលោម; ការបញ្ជោរ; ការបញ្ឆោតអង្អែល

amadouer *v.t.* បន្ទន់ចិត្តដោយលួង-លោម ឬ ដោយបញ្ជោរ

amaigrir *v.t.* ធ្វើឲ្យស្គម ។ *v.i.*ចុះស្គម

amaigrissant, e *a.* ដែលធ្វើឲ្យស្គម

amaigrissement *n.m.* ការចុះស្គម

amalgame *n.m.* ការបញ្ចុះបារតក្នុងលោហធាតុដទៃទៀត ។ *Fig.* ការបញ្ចុះជ្រំ; ការច្របូកច្របល់

amalgamer *v.t.* បញ្ចុះបារតក្នុងលោហធាតុ ។ s'amalgamer *v.pr.* ច្របល់ចូលគ្នា

amande *n.f.* អាម៉ង់ដ៍ (ផ្លែឈើម្យ៉ាង); សាច់គ្រាប់ (ដូចជាគ្រាប់ចំបក់ជាដើម) ។ *Prov.* pour avoir l'amande il faut casser le noyau ចេះពីរៀនមានពីរក, ដើម្បីបានផលល្អត្រូវខំប្រឹង

amant, e *n.* គូសង្សារ, សហាយ

amarante *n.f.* ដើមផ្កាស៊ីរម៉ាន់, ផ្ទី ។ amarante épineuse ផ្ទីបន្លា

amarrage *n.m.* ការចងនាវា; ចំណង

amarre *n.f.* ព្រួរចងនាវា

amarrer *v.t.* ចងនាវា, ចត

amas *n.m.* គំនរ, ពំនូក

amassement *n.m.* ការគរ, ការពូន

amasser *v.t.* គរ, ពូន, ប្រមូល

amasseur, euse *n.* អ្នកគរ, អ្នកពូន

amateur *n.&a.* អ្នកចូលចិត្តធ្វើអ្វីមួយ

ambages *n.f.pl.* សំដីពង្វាងមិនច្បាស់លាស់ ។ parler sans ambages និយាយត្រង់ៗ គ្មានបញ្ចេញបញ្ចូល

ambassade *n.f.* ស្ថានឯកអគ្គរដ្ឋទូត ឬ រាជទូត, តំណែងឯកអគ្គរដ្ឋទូត ឬ រាជទូត; ភ្នាក់ងារទាំងឡាយក្នុងស្ថានឯកអគ្គរដ្ឋទូតឬរាជទូត ។ *Fig.&Fam.* សារ

ambassadeur *n.m.* ឯកអគ្គរដ្ឋទូត ឬ រាជទូត ។ *Fig.&Fam.* អ្នកទទួលសារ

ambassadrice *n.f.* ភរិយាឯកអគ្គរដ្ឋទូត ឬ រាជទូត; ទូតី (ទូតស្រី)

ambiance *n.f* បរិយាកាស (ការណ៍ដែលនៅជុំវិញ, មជ្ឈដ្ឋានប្រកបដោយសម្ភារ បញ្ញា និងផ្លូវចិត្ត)

ambiant ,e *a.* ដែលនៅព័ទ្ធជុំវិញ

ambigu, ë *a.* ដែលមានន័យមិនច្បាស់

ambiguïté *n.f.* ភាពមានន័យមិនច្បាស់

ambitieusement *adv.* ដោយមហិច្ឆតា, ដោយប្រាថ្នាធំ

ambitieux, euse *n.&a.* មហិច្ឆតា, ដែលប្រាថ្នាច្រើន

ambition *n.f.* មហិច្ឆតា, ការប្រាថ្នាច្រើន

ambitionner *v.t.* ប្រាថ្នាហំ

ambre *n.m.* ជ័រអៀម ។ fin comme l'ambre ប៉ិនប្រសប់

ambré, e *a.* ប្រឡាក់ក្លិនល្អសទេស; ដែលមានពណ៌លឿងៗដូចជ័រអៀម

ambroisie *n.f.* អម្រឹតជាតិ ។ *Fig.* ម្ហូបឆ្ងាញ់

ambulance *n.f.* បរិចរភាព, ភាពនៅមិនទឹងកន្លែង; រថគិលានសង្គ្រោះ

ambulancier, ère *n.* អ្នកតាមរថគិលានសង្គ្រោះ

ambulant,e *a.* បរិចរ, ដែលនៅមិនទឹងកន្លែង

ambulation *n.f.* ការដើរ

ambulatoire *a.* ដែលគ្មានទីសំណាក់ការនឹងកន្លែង

âme *n.f.* ព្រលឹង; អាត្មន; បណ្ដាជន; រន្ធ (កាំភ្លើង) ។ rendre l'âme ដាច់ខ្យល់ (ស្លាប់) ។

améliorable *a.* អាចធ្វើឲ្យប្រសើរបាន

améliorant,e *a.* ដែលធ្វើឲ្យប្រសើរ

améliorateur, trice *a.* ស័ក្ដិធ្វើឲ្យប្រសើរ

amélioration *n.f.* សុវឌ្ឍិកម្ម,សុវឌ្ឍិការ, ការចំរើនខាងល្អ, ការធ្វើឲ្យបានប្រសើរ

améliorer *v.t.* ធ្វើឲ្យបានប្រសើរ

aménagement *n.m.* ការរៀបចំ

aménager *v.t.* តុបតែង, រៀបចំ

amendable *a.* អាចកែឲ្យល្អបាន

amende *n f.* ពិន័យ ។ *Fam.* faire amende honorable ទទួលខុស, សុំទោស

amendement *n.m.* វិសោធនកម្ម(ការធ្វើឲ្យប្រពៃឡើង, សេចក្ដីស្នើកែញត្តិ) ; ការកែឲ្យល្អ: ការកែប្រែ; ដីជាតិ

amender *v.t.* វិសោធ,ធ្វើវិសោធនកម្ម; កែឲ្យល្អ. កែប្រែ; ដាក់ដីជាតិ

amener *v.t.* នាំមក ។ *Fig.* បញ្ចូល; បណ្ដាល ។ *Mar.* amener les voiles ទម្លាក់ក្ដោង។amener son pavillon, sescouleurs ចុះចាញ់។s'amener *v.pr.Pop.* មក

aménité *n.f.* ភាពជាទីគាប់ចិត្ត

amenuiser *v.t.* ធ្វើឲ្យស្ដួច-ឲ្យតូច ឬ ឲ្យល្អិត

amer, ère *a.* ល្វីង, ចត់ (មានរសជាតិមិនប្រសើរ)។ l'onde amère ទឹកសមុទ្រ។ *Fig.* ក្រៀមក្រំខ្លាំង ។ *n.m.* ថ្នាំល្វីង; ប្រមាត់សត្វ

amèrement *adv.* ដោយក្រៀមក្រំ

américain, e *a.&n.* នៃសហរដ្ឋអាមេរិក; ជនជាតិអាមេរិកាំង

américaniser *v.t.* ឲ្យមានលំនាំដូចជាតិអាមេរិកាំង ។ s'américaniser យកទំនៀមទម្លាប់ជនជាតិអាមេរិកាំង

américanisme *n.m.* អាមេរិកាំងនិយម, របៀបរស់នៅនៃជនជាតិអាមេរិកាំង, ការស្ញើចជនជាតិអាមេរិកាំងជ្រុលពេក

amerrir *vi.* ចុះលើទឹក (យន្តហោះ)

amerrissage *n.m.* ការចុះលើទឹក

amertume *n.f.* រសល្វីង ។ *Fig.* បដិឃចិត្ត, សេចក្ដីក្រៀមក្រំ

améthyste *n.f.* ដម្ពូរត្ន,ត្បូងស្វាយ

ameublement *n.m.* សេនាសនភណ្ឌ,

គ្រឿងគុគាំង

ameublir *v.t.* ជ្រួយដី

ameublissement *n.m.* ការជ្រួយដី

ameutement. *n.m.* ការប្រមូលឆ្កែដើម្បីប្រដេញសត្វ។ *Par ext.* ការបំបះបំបោរ

ameuter *v.t.* ប្រមូលឆ្កែដើម្បីប្រដេញសត្វ ។ *Par ext.* បំបះបំបោរ

ami, e *n.* មិត្ត ។ *Fig.* បក្សពន្ធ ។ *a.* អនុគ្រោះ

amiable *a.* រីករាយ, ដែលធ្វើដោយស្រុះស្រួលគ្នា ។ à l'amiable *loc. adv.* ដោយស្រុះស្រួលគ្នា

amibe *n.m.* អាមីប (អតិសុខុមប្រាណ គឺសត្វតូចក្រៃលែង រស់នៅក្នុងទឹក)

amical,e,aux *a.* ធន្មមិត្រ, ជាមិត្រ

amicale *n.f.* សមាគមមិត្រ

amicalement *adv.* ដោយមិត្តភាព

amidon *n.m.* បិដ្ឋជាតិ [ប៉ិត-ឋៈ–] (ម្សៅគ្រាប់ ឬ ម្សៅមើមផ្សេងៗ)

amidonnage *n.m.* ការជ្រលក់ម្សៅ

amidonner *v.t.* ជ្រលក់ម្សៅ

amincir *v.t.* ធ្វើឲ្យស្តើង

amincissement *n.m.* ការធ្វើឲ្យស្តើង

amiral *n.m.* ឧត្តមនាវី ។ amiral d'escadre ឧត្តមនាវីនាយក។ amiral de la flotte ឧត្តមនាវីឯក ។ vice-amiral ឧត្តមនាវីទោ ។ contre-amiral ឧត្តមនាវីត្រី

amiralat *n.m.* ឋានៈឧត្តមនាវី

amirale *n.f.* ភរិយាឧត្តមនាវី

amirauté *n.f.* មន្ទីរឧត្តមនាវី

amitié *n.f.* មិត្តភាព, មេត្រីភាព

ammoniaque .*n.f.* អាម៉ូនីយ៉ាក់ (ខ្មែរយើងច្រើនហៅទឹកនោមអួត)

amnésie *n.f.* សតិវិប្បលាស, ការខូចស្មារតី

amnésique *a.* ដែលខូចស្មារតី

amnistiable *a.* ដែលអាចលើកលែងទោសបាន, គួរលើកលែងទោស

amnistiant,e *a.* ដែលលើកលែងទោស

amnistie *n.f.* ការលើកលែងទោស

amnistier *v.t.* លើកលែងទោស

amodiataire *n.* អ្នកទទួលប្រវាស់ដី ឬ ទទួលជួលដី

amodiateur,trice *n.* អ្នកឲ្យប្រវាស់ដី ឬ ឲ្យជួលដី

amodiation *n.f.* ការប្រវាស់ ឬ ជួលដី

amodier *v.t.* ប្រវាស់ដី ជួលដី

amoindrir *v.t.* ធ្វើឲ្យអន់ថយ ។ s'amoindrir *v.pr.* ចុះអន់ថយ

amoindrissement *n.m.* ការចុះអន់ថយ

amollir *v.t.* បន្ទន់ ។ *Fig.* ធ្វើឲ្យខ្សោយ

amollissant,e *a.* ដែលបន្ទន់

amollissement *n.m.* ការបន្ទន់ ។ *Fig.* ការធ្វើឱ្យខ្សោយ

amonceler *v.t.* ពូន, គរ

amoncellement *n.m.* ការពូន, ការគរ

amont *n.m.* ខាងលើទឹក ។ en amont de *loc. pré.* ខាងលើ

amoral, e, aux *a.* គ្មានសីលធម៌, មិនចេះសីលធម៌ (កុំច្រឡំនឹង immoral)

amorçage *n.m.* ការដាក់ឆ្នុក, ការចាក់ទឹកក្នុងបំពង់ម៉ាស៊ីនបូម

amorce *n.f.* នុយ; ឆ្នុក

amorcer *v.t.* បំពុនុយ; ដាក់ឆ្នុក; ចាក់ទឹកក្នុងបំពង់ម៉ាស៊ីនបូម ។ *Fig.* ល្បួង; ចាប់ផ្ដើម

amorphe *a.* គ្មានសណ្ឋានប្រាកដ

amorphie *n.f.* ភាពគ្មានសណ្ឋានប្រាកដ

amorti, e *a.* ដែលត្រូវទប់; ខ្សោយ

amortir *v.t.* ទប់, រំលស់

amortissable *a.* ដែលអាចរំលស់បាន

amortissement *n.m.* ការរំលស់ (ឧ. ១-ធិះរទេះគោបើខ្លាចរលាក់ឈើខ្នួនគេយកចំបើងមកទ្រាប់; ២-ក្នុងភាសាហិរញ្ញវត្ថុ គឺការសងដំណាក់គេម្ដងបន្តិចៗដើម្បីឱ្យរលស់)

amortisseur *n.m.* គ្រឿងរំលស់ (មើលឧទាហរណ៍ទី១នៃពាក្យ amortissement)

amour *n.m.* ស្នេហ៍, ស្នេហា, ការចូលចិត្ត ។ *Myth.* កាមទេព

amouracher *v.t.* បង្កស្នេហាមិនជាប់ថេរ ។ s'amouracher *v.pr.* ស្រឡាញ់មិនថិតថេរ, ស្រឡាញ់មិនជាប់

amourette *n.f.* ស្នេហាមិនថិតថេរ

amoureusement *adv.* ដោយស្នេហា

amoureux, euse *a.* ដែលស្រឡាញ់ពិត ។ *n.* សហាយកំណាន់

amour-propre *n.m.* អស្មិមានះ

amovibilité *n.f.* ភាពអ្នករាជការដែលគេអាចផ្លាស់ ឬ ហូតងារបាន

amovible *a.* ដែលគេអាចផ្លាស់ឬហូតងារបាន (អ្នករាជការ); អាចដោះចេញបាន

ampélidacées *n.f.pl.* ដំណូកូល (ត្រកូលទំពាំងបាយជូរ)

amphibie *a.&n.m.* ថលជលិក [ថ:-ល:-ជ:—] (ដែលប្រព្រឹត្តទៅបានទាំងលើគោកទាំងក្នុងទឹក)

amphibiens *n.m.pl.* ម.ព. batraciens

amphibole *n.f.* អំភីបូល

amphithéâtre *n.m.* រង្គមណ្ឌល, រង្គដ្ឋាន

ample *a.* ទូលាយ ។ *Fig.* ហួសធម្មតា

amplement *adv.* យ៉ាងទូលាយ; ដោយ

បរិបូណ៌

ampleur *n.f.* ភាពទូលាយ ។ *Fig.* ភាពបរិបូណ៌

ampliateur *n.m.* អ្នកចម្លងចែក

ampliatif, ive *a.* នៃការចម្លងចែក

ampliation *n.f.* ការចម្លងចែក ។ pour ampliation ដើម្បីចម្លងចែក

amplifiant,e *a.* ដែលពង្រីក

amplificateur, trice *n.&a.* ដែលពង្រីក, ដែលបំផ្លើស ។ *n.m.* ប្រដាប់ពង្រីក

amplificatif, ive *a.* ដែលសំរាប់ពង្រីក

amplification *n.f.* ការរ៉ាយរ៉ាប់; ភាពរីក ។ *Fig.* ការបំផ្លើស

amplifier *v.t.* ពង្រីក; អធិប្បាយ ។ *Fig.* បំផ្លើស

amplissime *a.* សំបើម ឬ សន្ធឹកណាស់

amplitude *n.f.* ទោលនា

ampoule *n.f.* ពង (លើស្បែក); កូនដប; អំពូល (ចង្កៀងអគ្គិសនី)

amputation *n.f.* ការកាត់ដៃជើង ឬ អវយវៈណាមួយ

amputé, e *a.&n.* ដែលត្រូវកាត់ដៃជើង ឬ អវយវៈណាមួយ

amputer *v.t.* កាត់ដៃជើង ឬ អវយវៈណាមួយ

amulette *n.f.* ខ្សែកថា

amunitionner *v.t.* ផ្តល់ស្បៀង

amusant,e *a.* ដែលឲ្យសប្បាយ

amusement *n.m.* ការលេងសប្បាយ, ល្បែង (សប្បាយ)

amuser *v.t.* បទ្វែង, នាំលេង, ធ្វើឲ្យសប្បាយ ។ *Fig.* បញ្ឆោត ។ s'amuser *v.pr.* លេងសប្បាយ

amusette *n.f.* ល្បែងបន្តិចបន្តួច; សប្បាយភ័ណ្ឌ, ប្រដាប់លេង

amuseur,euse *n.* អ្នកបទ្វែង

an *n.m.* ឆ្នាំ

anachorète *n.m.* ឥសី, តាបស

anachronique *a.* ខុសកាលសម័យ

anachronisme *n.m.* កំហុសក្នុងកាលប្រវត្តិវិជ្ជា, អំពើខុសកាលសម័យ

anaérobie *a.* ដែលរស់ដោយមិនត្រូវការខ្យល់អាកាស

anal,e,aux *a.* នៃវច្ចមគ្គ (នៃរន្ធគូថ)

analgésie ឬ **analgie** *n.f.* ភាពស្ពឹក (មិនដឹងឈឺ)

analgésique ឬ **analgique** *a.&n.* ដែលធ្វើឲ្យស្ពឹក ។ *n.* មនុស្សស្ពឹក(មិនដឹងឈឺ)

analogie *n.f.* សទិសភាព, ភាពស្រដៀង

analogue *a.* សទិស, ស្រដៀង

analphabète *a.* ដែលមិនចេះអក្សរ

analphabétisme *n.m.* ភាពមិនចេះអក្សរ

analysable *a.* ដែលអាចធ្វើវិធីសម្ពន្ធ ឬ ធ្វើវិភាគបាន

analyse *n.f.Gram.* វិធីសម្ពន្ធ(ការទាក់ទងរបស់សព្ទក្នុងប្រយោគ)។analyse grammaticale សម្ពន្ធវេយ្យាករណ៍។ analyse logique សម្ពន្ធប្រយោគ ។ *Sc.* វិភាគ (វិទ្យាសាស្ត្រ=ការញែកធាតុ។គណិតសាស្ត្រ=ការយកពីជគណិតទៅប្រើក្នុងរេខាគណិត) ។ analyse mathématique វិភាគគណិតសាស្ត្រ ។ *Litt.* វិភាគបទ (ការបំប្រួញអត្ថបទយកសារៈសំខាន់)

analyser *v.t. Gram.* ធ្វើវិធីសម្ពន្ធ ។ *Math.* ធ្វើវិភាគ ។ *Sc.* ញែកធាតុ

analyseur *n.m.* អ្នកវិភាគជ្រុល;វិភាគភណ្ឌ (ប្រដាប់ធ្វើវិភាគ)

analyste *n.m.* អ្នកវិភាគ

analytique *a.* វិភាគី (ដែលធ្វើដោយប្រើវិធីវិភាគ)

analytiquement *adv.* ដោយវិធីវិភាគ

ananas *n.m.* ម្នាស់

anarchie *n.f.* អនាធិបតេយ្យ (ភាពនៃប្រជារាស្ត្រគ្មានរដ្ឋាភិបាល ឬ មានរដ្ឋាភិបាលដែរ ប៉ុន្តែគ្មានរបៀបរៀបរយ)

anarchique *a.* នៃអនាធិបតេយ្យ

anarchiquement *adv.* ដោយអនាធិបតេយ្យ

anarchiser *v.t.* បង្កអនាធិបតេយ្យ

anarchisme *n.m.* អនាធិបតេយ្យនិយម

anarchiste *n.* អ្នកអនាធិបតេយ្យនិយម។ *a.* នៃអនាធិបតេយ្យនិយម

anathématisation *n.f.* ការដាក់បណ្ដាសា; ការដេញចេញពីសាសនា

anathématiser *v.t.* ដាក់បណ្ដាសា; ដេញចេញពីសាសនា(សាសនាគ្រិស្ត)។ *Par ext.* បន្ទោសយ៉ាងខ្លាំង

anathème *n.m.* បណ្ដាសា, និក្ខន្ទកម្ម ។ *n.* អ្នកត្រូវបណ្ដាសា

anatomie *n.f.* កាយវិភាគសាស្ត្រ ; ការធ្វើកាយវិភាគ ។ *Fig.* ការធ្វើវិភាគដោយហ្មត់ចត់

anatomique *a.* នៃកាយវិភាគសាស្ត្រ

anatomiquement *adv.* ដោយកាយវិភាគសាស្ត្រ; ជាអ្នកកាយវិភាគសាស្ត្រ

anatomiser *v.t.* ធ្វើកាយវិភាគ;វះកាត់ដើម្បីរៀនសង្កេតចំណាំអាការក្នុងខ្លួន

anatomiste *n.m.* អ្នកកាយវិភាគសាស្ត្រ

ancestral, e, aux *a.* នៃបុព្វបុរស; នៃអតីតកាល

ancêtres *n.m.pl.* បុព្វបុរស, ដូនតា

anche *n.f. Mus.* អណ្ដាត (គ្រឿងផ្លុំ)

ancien,enne *a.* ចាស់, បុរាណ ។ *Pl.* មនុស្សចាស់

anciennement *adv.* ពីដើម, ពីអតីត

ancienneté *n.f.* អតីតភាព

ancrage *n.m. Mar.* កន្លែងបោះយុថ្កា

ancre *n.f.* យុថ្កា

ancrer *v.i.* បោះយុថ្កា ។ *Fig.* ពង្រឹង

androphobie *n.f.* ការស្អប់មនុស្ស

âne *n.m.* លាឈ្មោល ។ *Fig.* មនុស្សល្ងង់ហើយមុខរឹង ។ âne bâté មនុស្សល្ងង់សព្វជាតិ ។ *Prov.* faire l'âne pour avoir du son ធ្វើជាល្ងង់ដើម្បីស្រួលបញ្ឆោត

anéantir *v.t.* បំផ្លាញឲ្យសាបសូន្យ ។ *Par ext.* ធ្វើឲ្យស្រឡាំងកាំង; ធ្វើឲ្យហត់ខ្លាំង; ធ្វើឲ្យព្រួយខ្លាំង

anéantissement *n.m.* អភិសូន្យ, ការបំផ្លាញឲ្យសាបសូន្យ ។ *Par ext.* សេចក្ដីហត់ខ្លាំង; សេចក្ដីព្រួយខ្លាំង

anecdote *n.f.* និទានខ្លី ៗ

anecdotique *a.* នៃនិទានខ្លីៗ

anémie *n.f.* អប្បលោហិត [អ័ប-ប៉ះ–], ភាពមានឈាមតិច

anémier *v.t.* បណ្ដាលអប្បលោហិត, បណ្ដាលឲ្យមានឈាមតិច

anémique *a.* ដែលបណ្ដាលមកពី អប្បលោហិត, ដែលមានឈាមតិច

ânerie *n.f.* សេចក្ដីល្ងង់ ។ *Fam.* កំហុសធំ

anesse *n.f.* លាញី

anesthésiant,e *a.&n.* ម.ព. anesthésique

anesthésie *n.f.* ការដាក់ថ្នាំស្ពឹក

anesthésier *v.t* ដាក់ថ្នាំស្ពឹក

anesthésique *a.* ដែលធ្វើឲ្យស្ពឹក (មិនដឹងឈឺ) ។ *n.m.* ថ្នាំស្ពឹក

anfractueux, euse *a.* ក្រងិកក្រងក់ ក្រហេងក្រហូង

anfractuosité *n.f.* ភាពក្រងិកក្រងក់ ភាពក្រហេងក្រហូង; ក្រហែង

ange *n.m.* ទេវតា, ទេព្ធបុត្រ ។ *Fig.* មនុស្សស្លូត ។ comme un ange ល្អណាស់ ។ être aux anges សប្បាយអណ្ដែតអណ្ដូង

angélical, e, aux ឬ **angélique** នៃទេវតា

angéliquement *adv.* ដូចទេវតា

angéliser *v.t.* ប្រដូចនឹងទេវតា

angine *n.f.* រោគបំពង់ក

angiospermes *n.f.pl.* ឆន្នបុប្ផាល្អា

anglais,e *a.* នៃប្រទេសអង់គ្លេស។ *n.* ជនជាតិអង់គ្លេស។ *n.m.* ភាសាអង់គ្លេស

angle *n.m.* មុម,កោណ,ជ្រុង។ angles adjacents មុមជាប់គ្នា ។ angle aigu មុមស្រួច។ angles alternes internes មុមឆ្លាស់ក្នុង។ angle au centre មុមកណ្ដាល ។ angles complémentaires មុមបំពេញ។ angles correspondants មុមអនុលោម។ angle droit មុមកែង។ angle inscrit មុមចារឹកក្នុង ។ angles intérieurs du même côté មុមក្នុងនាទិសជាមួយ ។ angle obtus មុមញាយ។ angle opposé មុមឈម។ angles opposés par le sommet មុមឈមត្រង់កោណន្ត។ angle orienté មុមបែរ ។ angle plat មុមលាត ។ angle rentrant មុមផត ។ angle saillant មុមលៀន ។ angles supplémentaires មុមបន្ថែម

anglicanisme *n.m.* សាសនាអង់-គ្លីកង់ (សំរាប់រដ្ឋអង់គ្លេស)

angliciser *v.t.* ឲ្យមានលំនាំដូចអង់គ្លេស ។ s'angliciser *v.pr.* យកលំនាំតាមអង់គ្លេស

anglicisme *n.m.* និយាតសព្ទនៃភាសាអង់គ្លេស; ពាក្យអង់គ្លេសដែលប្រើក្នុងភាសាដទៃ

anglomane *n.&a.* អ្នកត្រាប់ទម្លាប់អង់គ្លេសហួសប្រមាណ

anglomanie *n.f.* ការត្រាប់ទម្លាប់អង់គ្លេសហួសប្រមាណ

anglophile *n.&a.* អ្នកស្រឡាញ់ជនជាតិអង់គ្លេស

anglophilie *n.f.* ការស្រឡាញ់ជនជាតិអង់គ្លេស

anglophobe *n.&a.* អ្នកស្អប់ជនជាតិអង់គ្លេស

anglophobie *n.f.* ការស្អប់ជនជាតិអង់គ្លេស

angoissant,e *a.* ដែលឲ្យទន្ទឹះចិត្ត,ដែលឲ្យមានឧបាយាស

angoisse *n.f.* ការទន្ទឹះចិត្ត,សេចក្ដីតានតឹង (ក្នុងខ្លួន,ក្នុងចិត្ត),ឧបាយាស(ឧ.អសន្តិ-សុខក្នុងនិគមជនបទរមែងធ្វើឲ្យអ្នកស្រុករកទទួលទានដោយមានឧបាយាសជានិច្ច)

angoisser *v.t.* ធ្វើឲ្យទន្ទឹះចិត្ត,ធ្វើឲ្យមានឧបាយាស

angon *n.m.* លំពែងស្នែងក្របី

angrois *n.m.* ស្នៀតដែក (សំរាប់បោះពង្រឹងដងញញួរ-ពូថៅ ។ល។)

anguiforme *a.* ទំយសណ្ឋាន, ដែលមានសណ្ឋានដូចពស់

anguille *n.f.* អន្ទង់ ។ *Prov.* il y a anguille sous roche មានការលួចគិតអ្វីជាសម្ងាត់

anguillère *n.f.* កន្លែងគ្រោះអន្ទង់

anguillule *n.f.* ព្រូយ,ដង្កូវឈើ·មនុស្ស ឬ សត្វ

angulaire *a.* ដែលមានមុម,ដែលមានជ្រុង, ដែលនៅត្រង់ជ្រុង ។ pierre angulaire ថ្មជ្រុងគ្រឹះស្ថាន។ *Fig.* គ្រឹះ, មូលដ្ឋាន, គោលសំខាន់

angulairement *adv.* ជាមុម

angulé,e *a.* ដែលមានមុម

anguleux,euse*a.*ដែលមានជ្រុង។*Par ext.*visage anguleux មុខជ្រុង

anhélation *n.f.* ការដង្ហក់

anhéler *v.i.* ដង្ហក់;ថែភ្លើង(កន្លែងធ្វើកែវ)

anhydre *a.* អនោទកៈ, ដែលគ្មានទឹក

anhydride *n.m.* អនោទកៈ

anicroche *n.f. Fam.* ការរអាក់-រអួល, កង្វល់ ។ sans anicroche គ្មានរអាក់រអួល

anil *n.m.* ដើមត្រុំ

anille *n.f. Bot.* ដៃ (នៃវល្លិ)

animal, aux *n.m.* សត្វ ។ *Fig.* មនុស្សថ្លើដង ។ animaux inférieurs សត្វហីនជាតិ, ហីនជាតសត្វ

animal, e, aux *a.* នៃសត្វ

animalcule *n.m.* អតិសុខុមសត្វ

animalesque *a.* នៃសត្វ

animalier *n.m.* អ្នកគូរ ឬ ឆ្លាក់រូបសត្វ

animalisation *n.f.* ដំណើរនៃអាហារដែលប្រែក្លាយទៅជាសាច់ឈាមសត្វ

animaliser *v.t.* ធ្វើឲ្យប្រែក្លាយទៅជាសាច់ឈាមសត្វ ។ *Fig.* បន្ថោកជាសភាពសត្វ។s'animaliser *v.pr.* ប្រែក្លាយទៅសាច់ឈាមសត្វ ; ចុះជាសភាពសត្វ

animalité *n.f.* សត្តភាព

animateur, trice *a.&n.*អ្នកបាត់ចែង

animation *n.f.*ការកំរើករើកៈភាពអ៊ូអរ

animé,e *a.* ដែលមានជីវិត;ដែលកំរើករើក; អ៊ូអរ

animer *v.t.* ឲ្យមានជីវិត, ធ្វើឲ្យកំរើក ។ *Fig.*ពន្យុះ, លើកទឹកចិត្ត, លើកកម្លាំង

animosité *n.f.* វិទ្វេស,កំហឹង,សំអប់

ankylose *n.f.* ការរឹងសន្លាក់

ankylosé, e *a.* ដែលរឹងសន្លាក់

ankyloser *v.t.* ធ្វើឲ្យរឹងសន្លាក់

annales *n.f.pl.*វស្សប្បវត្តិ. ពង្សាវតារ

annaliste *n.m.* អ្នកវស្សប្បវត្តិ, អ្នក

ពង្សាវតារ

annamite *a.&n.* នៃប្រទេសអណ្ណាម

anneau *n.m.* កង,ក្រវិល,ចិញ្ចៀន,វង់

année *n.f.* ឆ្នាំ, វស្សា, វត្សរ

annelé,e *a.* ក្រវង់, ដែលមានសណ្ឋានជាកង់ ៗ

anneler *v.t.* ពត់សក់ឲ្យមូលក្រវង់ៗ

annexe *a.* រង ។ *n.f.* ឧបសម្ពន្ធ

annexer *v.t.* ភ្ជាប់, បញ្ចូលជាឧបសម្ពន្ធ

annexion *n.f.* ការបញ្ចូលជាឧបសម្ពន្ធ

annihilable *a.* អាចធ្វើឲ្យសាបសូន្យបាន

annihilation *n.f.* បរិសូន្យ, ការធ្វើឲ្យសាបសូន្យ

annihiler *v.t.* ធ្វើបរិសូន្យ, ធ្វើឲ្យសាបសូន្យ; លំអិត; បំផ្លាញ

anniversaire *n.m.* ថ្ងៃគំរប់មួយខួបឆ្នាំ; បុណ្យខួប ។ anniversaire de la naissance បុណ្យចំរើនអាយុ

annonce *n.f.* លិខិតផ្សាយ

annoncer *v.t.* ផ្សាយ,ប្រាប់ដំណឹង;ទាយ

annonciateur,trice *a.* ដែលផ្សាយ, ដែលប្រាប់

annotateur *n.&a.m.* អ្នកចារសេចក្ដីពន្យល់

annotation *n.f.* ចំណារ

annoter *v.t.* ចារសេចក្ដីពន្យល់

annuaire *n.m.* សៀវភៅកំណត់ប្រចាំឆ្នាំ

annualité *n.f.* អនុសំវច្ឆរភាព

annuel,elle *a.* អនុសំវច្ឆរៈ, រាល់ឆ្នាំ, ប្រចាំឆ្នាំ, ផ្ដាច់ឆ្នាំ

annuellement *adv.* ជារាល់ឆ្នាំ, ជារៀងរាល់ឆ្នាំ

annuité *n.f.* អនុសំវច្ឆរ័ត្ត (ចំនួនប្រាក់ដែលត្រូវសងរាប់ឆ្នាំទាំងកុងទាំងដើម (ឧ. ជនម្នាក់ជំពាក់ប្រាក់គេប្រាំម៉ឺនរៀល ហើយត្រូវសងទាំងប្រាក់ការទាំងប្រាក់ដើមប្រាំឆ្នាំឲ្យអស់ ដូច្នេះគេថាជននោះត្រូវសងប្រាក់គេ ប្រាំ អនុសំវច្ឆរ័ត្ត)

annulabilité *n.f.* ភាពអាចទុកជាមោឃៈបាន

annulable *a.* អាចទុកជាមោឃៈបាន

annulaire *a.* ដែលមានរាងដូចកង់ ។ *n.m.* នាងដៃ (សំរាប់ពាក់ចិញ្ចៀន)

annulatif, ive *a.* ដែលទុកជាមោឃៈ

annulation *n.f.* មោឃកម្ម

annuler *v.t.* ទុកជាមោឃៈ

anoblir *v.t.* លើកជាអភិជន

anoblissement *n.m.* ការលើកជាអភិជន

anode *n.f.* ឧទ្វារ

anodin,e *a.* បន្តិចបន្តួច;ស្លូត,គ្មានពិស។ *Méd.* ដែលឲ្យអន់ឈឺចាប់

anodontie *n.f.* ភាពគ្មានធ្មេញ

anomal, e, aux *a.* ប្លែក, ពិសេស

anomalie *n.f.* ការប្លែក, ភាពមិនសមហេតុផល

ânon *n.m.* កូនលា

ânonnement *n.m.* ការនិយាយឬអានដោយរដាក់រដឹន

ânonner *v.i.* និយាយ ឬ អានរដាក់រដឹន

anonymat *n.m.* អនាមិកភាព

anonyme *a.* អនាមិក [អៈ-ណា-មិក] (គ្មានឈ្មោះ, មិនចេញឈ្មោះ)

anonymement *adv.* ដោយអនាមិក

anophèle *n.m.* មូសដែកគោល

anormal,e,aux *a.&n.* ប្លែកពីធម្មតា, មិនប្រក្រតី

anormalement *adv.* ដោយប្លែកពីធម្មតា, ដោយមិនប្រក្រតី

anoure *a.* អនង្គុដ្ឋ (ដែលគ្មានកន្ទុយ)។ *n.m. pl.* អនង្គុដ្ឋសត្វ (សត្វានកង្កែប, គីង្គក់)

anse *n.f.* ដៃ, ត្រចៀក (ថាំង, ពែង)

anser *n.m.* ក្ងានព្រៃ

ansette *n.f.* ចិញ្ចៀនខ្សែ; ជើងក្រានមានដៃយួរ

antagonique *a.* ផ្ទុយ, ប្រឆាំង

antagonisme *n.m.* បដិបក្ខភាព

antagoniste *a.&n.* បដិបក្ខ, សត្រូវ

antalgique *a.* សំរាប់ធ្វើឲ្យអន់ឈឺចាប់

antan *n.m.* ឆ្នាំទៅ, អតីតកាល

antarctique *a.* ខាងត្បូង

antécédemment *adv.* ពីមុន, ពីដើម

antécédence *n.f.* ភាពមានពីមុន

antécédent, e *a.* បុព្វគាមី, ដែលមានពីមុន។ *n.m.pl.* អំពើ ឬ កិរិយាពីដើម

antédiluvien, enne *a.* *Fig.* & *iron.* ផុតសម័យ

ante méridiem *loc. lat.* ព្រឹក (មុនថ្ងៃត្រង់) (សរសេរកាត់ជាៈ *A.M.*)

antenne *n.f.* *Mar.* ផងក្ដោង ។ ពុកធំ (អាការៈសត្វខ្លះដែលដុះចេញជាសរសៃវែងៗមានសណ្ឋានស្រដៀងនឹងពុកមាត់ៈ ពុកបង្កង-កំពឹស) ; ខ្សែអាកាសវិទ្យុ

antennule *n.f.* ពុកតូច

anténuptial,e, aux *a.* មុនអាពាហ៍-ពិពាហ៍

antérieur,e *a.* បុរេគត, ដែលកើតមុន ឬ មានពីមុន

antérieurement *adv.* ដោយបុរេគត, ពីមុន

antériorité *n.f.* បុរេភាព, ភាពកើតមុន, ភាពមានមុន

anthologie *n.f.* មាលីបទ, រត្នបទ

សម្រាំងរបស់កវីនិពន្ធ

anthracite *n.m.* សិលាង្គារ [សិ-ល៉ាង-គារ] (ត្បូងថ្មរឹងខ្មៅភ្លឺ ពិបាកឆុត ប៉ុន្តែគ្មានក្លិនគ្មានផ្សែងហើយឲ្យកំដៅច្រើន)

anthropologie *n.f.* នរវិទ្យា (វិទ្យាលើមនុស្ស)

anthropologique *a.* នៃនរវិទ្យា

anthropologiste ឬ **anthropologue** *n.m.* នរវិទូ (បណ្ឌិតខាងវិទ្យាលើមនុស្ស)

anthropophage *a.&n.* ដែលបរិភោគសាច់មនុស្ស

anthropophagie *n.f.* ទម្លាប់បរិភោគសាច់មនុស្ស

anti *préfixe* បដិបក្ខ [ប៉ៈ-ដិប័ក] (បុព្វបទសម្រាប់បង្ហាញការប្រឆាំង ឬ ផ្ទុយ)

antiaérien,enne *a.* ប្រឆាំងយន្តហោះ

antialcoolique *a.* ប្រឆាំងការសេពសុរា

antiartistique *a.* ផ្ទុយនឹងសិល្បៈ

antibiotique *n.m.* បដិបក្ខប្រាណ (ឈ្មោះថ្នាំសម្រាប់សម្លាប់សត្វល្អិតៗដែលបណ្ដាលឲ្យកើតរោគដូចជាមីក្រុប)

antichambre *n.f.* ល្វែងក្បែរមាត់ទ្វារ (សំរាប់រង់ចាំ) ។ *Par ext.* ទាសៈទាសី ក្នុងផ្ទះ ។ faire antichambre រង់ចាំឲ្យគេទទួល

antichar *a.* ប្រឆាំងរថក្រោះ

anticholérique *a.* សំរាប់ព្យាបាលអាសន្នរោគ

antichrèse *n.f.* ឧបនិធាន (កិច្ចសន្យាដែលអ្នកខ្ចីប្រាក់ ប្រគល់អសង្ហារិមភណ្ឌឲ្យម្ចាស់បំណុលប្រើប្រាស់ ដើម្បីកាត់ការប្រាក់នឹងរំលស់ដើមប្រាក់ខ្លះ)

antichrétien, enne *a.&n.* ប្រឆាំងសាសនាគ្រិស្ត

anticipation *n.f.* ការធ្វើមុនពេលវេលា, ការគិតដល់អនាគត ។ par anticipation *loc.adv.* ជាមុន

anticipé,e *a.* ជាមុន, ដែលធ្វើទុកជាមុន

anticiper *v.t.* ធ្វើមុន, គិតមុន, ធ្វើមុនពេលវេលា

anticlinal *n.m.* ឧទ្ធាលី

anticonstitutionnel,elle *a.* ផ្ទុយនឹងរដ្ឋធម្មនុញ្ញ

anticonstitutionnellement *adv.* ដោយផ្ទុយនឹងរដ្ឋធម្មនុញ្ញ

antidate *n.f.* បុព្វកាលបរិច្ឆេទ

antidater *v.t.* ចុះបុព្វកាលបរិច្ឆេទ

antidémocratique *a.* ប្រឆាំងលទ្ធិប្រជាធិបតេយ្យ

antidiphtérique *a.* សំរាប់ព្យាបាលរោគខាន់ស្លាក់

antidote *n.m.* ថ្នាំបន្សាប ។ *Fig.* ថ្នាំសំរាប់ការពារ

antigouvernemental, e, aux *a.* ប្រឆាំងរដ្ឋាភិបាល

antihumain, e *a.* ផ្ទុយនឹងមនុស្សធម៌

antihygiénique *a.* ផ្ទុយនឹងអនាម័យ

antimigraineux,euse *a.* សំរាប់ព្យាបាលរោគឈឺក្បាល

antimilitarisme *n.m.* បដិបក្ខរណនិយម

antimilitariste *a.&n.* អ្នកបដិបក្ខរណនិយម

antimoine *n.m.* គិបុក, សំណពាំហាំង

antimonarchique ឬ **antimonarchiste** *a.* បដិបក្ខរាជាធិបតេយ្យ

antiparlementaire *a.* ផ្ទុយនឹងទម្លាប់សភា ។ *n.&a.* អ្នកបដិបក្ខសភា

antiparlementarisme *n.m.* បដិបក្ខសភានិយម

antipathie *n.f.* វិសមានចិត្ត, ការមិនចូលចិត្ត

antipathique *a.* ដែលគួរស្អប់

antipesteux, euse *a.* សំរាប់ព្យាបាលរោគប៉េស្ត

antipode *n.m.* *Par ext.* ទីឆ្ងាយដាច់ស្រយាល ។ *Fig.* អ្វីៗ ដែលផ្ទុយ

antipyrine *n.f.* អង់ទីពីរីន (ថ្នាំគ្រុន)

antiquaille *n.f.* បុរាណវត្ថុ, របស់ផុតសម័យ

antiquaire *n.m.* អ្នកសិក្សា ឬ លក់បុរាណវត្ថុ

antique *a.* បោរាណិក (ដែលមានតាំងពីព្រេងនាយមក) ; ផុតសម័យ (ឧ.habit antique) ។ *n.m.* សិល្បវត្ថុបុរាណទាំងឡាយដែលនៅសល់។ *n.f.* ស្ថានបុរាណ

antiquité *n.f.* បុរាណកាល; បុរាណជនតា (ឧ.l'antiquité ne connaissait pas la vapeur) ; បុរាណវត្ថុ (ឧ.les antiquités de Rome sont célèbres)

antirabique *a.* បដិបក្ខឧម្មត្តករោគ, សំរាប់ព្យាបាលរោគឆ្កែឆ្កួតខាំ

antiréglementaire *a.* ផ្ទុយនឹងបទបញ្ញា

antireligieux,euse *a.* ប្រឆាំងសាសនា

antirépublicain,e *a.&n.* ប្រឆាំងសាធារណរដ្ឋ

antirévolutionnaire *a.&n.* បដិបក្ខបដិវត្តន៍

antiseptie *n.f.* ឬតិប្រតិបក្សវិធី, វិធីកំចាត់មេរោគ

antiseptique *a.* ឬតិប្រតិបក្ស

antisociable *a.* មិនចេះរស់នៅក្នុងសង្គម

antisocial, e, aux *a.* ប្រឆាំងសង្គម

anti-sous-marin *a.* ប្រឆាំងនាវាមុជទឹក

antitank *a.* ម.ព. **antichar**

antitoxine *n f.* បដិបក្ខវិសករស (ជាតិដែលបន្សាបជាតិពុលនៃអតិសុខុមប្រាណ)

antituberculeux, euse *a.* សំរាប់ព្យាបាលរោគរបេង; ដែលប្រយុទ្ធនឹងរោគរបេង

antivénéneux,euse *a.* សំរាប់បន្សាបជាតិពុល

antivenimeux,euse *a.* សំរាប់បន្សាបពិសពស់

antonyme *n.m.* របស់ផ្ទុយ; ពាក្យផ្ទុយ

antre *n.m.* រូង; ទីអាស្រ័យនៃសត្វសាហាវ ។ កន្លែងមានគ្រោះថ្នាក់ ។ *loc. prov.* l'antre du lion រូងយក្ស (ក្នុងភាសិតថាស៊ីរូងយក្ស គឺទៅមិនបានមកវិញ)

anus *n.m.* រន្ធគូថ, ទ្វារធំ (ទ្វារលាមក)

anxiété *n.f.* កង្វល់; ការថប់បារម្ភ

anxieusement *adv.* ដោយកង្វល់; ដោយថប់បារម្ភ

anxieux,euse *a.* ដែលខ្វល់ចិត្ត ឬ គំនិត

août *n.m.* សីហា (ខែ)

aoûtage *n.m.* ការងារអ្នកស្រែចំការក្នុងខែសីហា; ចំរូត

aoûté,e *a.* ទុំដោយកំដៅ (ឧ.fruits aoûtés)

aoûter *v.t.* បន្ទុំ, ធ្វើឲ្យទុំ ។ s'aoûter *v.pr.* ទុំ (ឧ.fruits qui s'aoûtent)

apaisement *n.m.* ការរសាយ, ការស្រាក

apaiser *v.t.* ធ្វើឲ្យស្ងប់ ឬ ឲ្យស្រាក (ឧ. apaiser la colère) ។ s'apaiser *v.pr.* រសាយ

apanage *n.m. Fig.* ចំណែក, អ្វីៗដែលត្រូវបានជាចំណុចដល់មនុស្សម្នាក់ ឬ រដ្ឋមួយ

apathie *n.f.* ភាពស្ពឹក-ប្រអូស ឬ កន្តើយ

apathique *a.* ស្ពឹក, ប្រអូស

apathiquement *adv.* ដោយស្ពឹក ឬ ប្រអូស

apepsie *n.f.* ដំណើររំលាយអាហារមិនស្រួល

apercevoir *v.t.* ក្រឡេកឃើញ, ឃើញពីចម្ងាយ ។ s'apercevoir ដឹងខ្លួន, សំគាល់ឃើញ

aperçu *n.m.* ខណិកទស្សន៍, ការក្រឡេកមើល; សង្ខិតភាព (ការដំណាលខ្លីៗ)

apéritif,ive *a.* ដែលនាំឆ្ងាញ់បាយ ។ *n.m.* ស្រាឆ្ងាញ់បាយ

apétale *a.* អទលី (ផ្កាគ្មានត្របក)

apetisser *v.t.* បន្តួច ។ s'apetisser *v.pr.* រុះតូច

à-peu-près *n.m.* ការប្រហែល;ល្បើង សង្ដី ។ à peu près *loc.adv.* ម.ព. peu

apeuré, e *a.* ដែលកំពុងខ្លាច

apeurer *v.t.* បន្លាច

aphasie *n.f.* ការនិយាយមិនរួច

aphasique *a.* ដែលនិយាយមិនរួច

aphone *a.* ឥតសំឡេង

aphonie *n.f.* ដំណើរឥតសំឡេង

apicole *a.* នៃមធុវប្បកម្ម

apiculteur *n.m.* មធុវប្បករ, អ្នកចិញ្ចឹមឃ្មុំ

apiculture *n.f.* មធុវប្បកម្ម, ការចិញ្ចឹមឃ្មុំ

apitoiement *n.m.* សេចក្ដីអាណិត

apitoyer *v.t.* ធ្វើឲ្យអាណិត ។ s'apitoyer *v.pr.* អាណិត

aplanir *v.t.* ពង្រាប (ឧ. aplanir un chemin) ។ *Fig.* បំបាត់, ដំនះ (ឧ. aplanir les difficultés ដំនះឧបសគ្គ)

aplanissement *n.m.* ការពង្រាប

aplanisseur, euse *n.* អ្នកពង្រាប

aplatir *v.t.* ផែ;វាយជាត, ធ្វើឲ្យសំប៉ាត។ s'aplatir *v.pr.* ឡើងសំប៉ាត ។ *Fig.* បន្ទាបខ្លួន

aplatissement *n.m.* ការផែ, ការធ្វើឲ្យសំប៉ាត;ភាពសំប៉ាត។ *Fig.* ការបន្ទាបខ្លួន

aplatissoir *n.m.* ឬ **aplatissoire** *n.f.* ប្រដាប់ផែ ឬ ញញួរដំឲ្យសំប៉ាត

aplomb *n.m.* ដំហរត្រង់; តុល្យភាព; សេចក្ដីអង់អាច (ឧ. avoir de l'aplomb) ។ d'aplomb *loc. adv.* ត្រង់តាមកូនប្រយោល, ដោយមានតុល្យភាព, ដោយរឹងប៉ឹង (មិនដួល)

apogée *n.m.* *Fig.* ឧត្តុង្គ, កំពូល (ឧ. être à l'apogée de sa fortune, de sa gloire)

apolitique *a.* ក្រៅនយោបាយ

apologie *n.f.* ការកាន់ជើង (ឧ. faire l'apologie de quelqu'un)

apologue *n.m.* រឿងគតិលោក

Apollon *Myt.* អាភាករ (អាទិទេពនៃពន្លឺ)

apophtegme *n.m.* បណ្ឌិតភាសិត

apophyse *n.f.* ពកឆ្អឹង

apostagie *n.f.* ការបោះបង់សាសនា ។ *Fig.* ការបោះបង់បក្សពួក

apostasier *v.i.* បោះបង់សាសនា ឬ បក្សពួក

aposter *v.t.* ដាក់ឲ្យឈ្លប (ដោយបំណង

អាក្រក់)

a posteriori *loc.adv.* ក្នុងបច្ឆាកាល (សំរាប់ប្រើក្នុងវិចារណកិច្ច : ក្រោយពីសោធន៍ ឧ. ក្នុងបច្ឆាកាលខ្ញុំឃើញលោកយល់ត្រូវ)

apostolat *n.m.* ការផ្សាយគំនិតថ្មី

apostrophe *n.f.* សន្ទាន; សញ្ញា ('); ការនិយាយទៅកាន់ភ្លាមៗ

apostropher *v.t.* ពោលពាក្យមិនពីរោះទៅកាន់

apothème *n.m.* កាជើងតក

apothéose *n.f.* ការលើកឋានៈជាអាទិទេព; កិត្តិយសឧត្តុង្គឧត្តម

apôtre *n.m.* សាវ័ក។*Fig.* faire le bon apôtre ធ្វើជាត្រឹមត្រូវ

apparaître *v.i.* លេចឡើង, ចេញស្តែងឡើង

apparat *n.m.* ក្បួនអឹកធឹក, អធិកភាព (ភាពអឹកធឹក ឬ រុងរឿង)។ costume d'apparat សំលៀកបំពាក់ជាអធិកភាព ។ jour d'apparat ថ្ងៃជាអធិកភាព ។ dîner d'apparat សាយភោជន៍ជាអធិកភាព

apparaux *n.m.pl.* ឧបករណ៍នាវា

appareil *n.m.* បរិធាន (ប្រដាប់ផ្សេងៗមានប្រដាប់សម្រាប់ថតរូបជាដើម);គ្រឿងយន្ត។ appareil digestif បរិធានជីរណិក(គ្រឿងរំលាយអាហារ)។appareil moteur បរិធានចលនា។appareil de nutrition បរិធាននៃបោសនា [ប៉ោ-ស:-នា] ។ appareil respiratoire គ្រឿងដកដង្ហើម

appareillage *n.m.* *Mar.* ការចេញនាវ; គ្រឿងបន្ទាប់បន្សំ

appareiller *v.t.* ផ្គុំឬផ្ទឹមរបស់ដូចគ្នា, ទឹមសត្វសម្បុរដូចគ្នា ហើយស្មើកម្លាំងគ្នា; បង្កាត់កូន ។ *Mar.* រៀបចំឧបករណ៍នាវា ។ appareiller une voile បើកក្ដោង។ *v.i.* រៀបចំចេញដំណើរ, ចេញនាវា ។ s'appareiller *v.pr.* ត់រកគ្នា (មនុស្សដូចគ្នាសេពគប់គ្នា) ; ជាន់គ្នា (បក្សី)

apparemment *adv.* តាមពហិលក្ខណៈ, តាមអាការៈក្រៅ, ប្រហែល

apparence *n.f.* ពហិលក្ខណៈ,អាការៈក្រៅ, ទំនង ។ sauver les apparences បំបិទការអាក្រក់ ។ en apparence *loc.adv.* តាមអាការៈក្រៅ; ហាក់ដូចជា

apparent, e *a.* ពហិលក្ខណ៍, ស្តែង; ដែលអាចមើលឃើញ; សំបើម; សំខាន់

apparenter *v.t.* ភ្ជាប់ជាសម្ពន្ធញាតិ។

s'apparenter *v.pr.* ចងសម្ពន្ធ

appariement *n.m.* ការផ្គូ, ការផ្ទឹម

apparier *v.t.* ផ្គូ, ផ្ទឹម

apparition *n.f.* ការផុះឡើង, ការលេចធ្លោឡើង; ខ្មោច (លង)

apparoir *v.impers.* លេចស្តែង, ជាហេតុ

appartement *n.m.* លំនៅបន្ទប់ច្រើន

appartenance *n.f.* ភាពនៅរួម; ដំណើរចូលរួមក្នុងបក្សណាមួយ (ឧ. appartenance à un parti politique ដំណើរចូលរួមក្នុងគណៈបក្សនយោបាយ)

appartenant,e *a.* ជារបស់ (ឧ. maison à lui appartenante ផ្ទះជារបស់គាត់)

appartenir *v.i.* ជារបស់, ជាកម្មសិទ្ធិរបស់; រាប់ចូលក្នុង (ឧ. le pin appartient à la famille des conifères ស្រល់រាប់ចូលក្នុងសរលកុល ។ s'appartenir *v.pr.* មិនជាប់ជំពាក់អ្វី (មានសេរីភាព)

appas *n.m. pl.* (ពហុវចនៈនៃពាក្យ appât); អាមិស, នុយ (ឧ. les appas de la gloire)

appât *n.m.* អាមិស, នុយ ។ *Fig.* សម្រស់; គ្រឿងទាក់ចិត្ត ឬ គ្រឿងជន្លេញចិត្ត

appâter *v.t.* បំពនុយ; បំប៉នបក្សី ។ *Fig.* ធ្វើឲ្យទាក់ចិត្ត (ឧ.l'appât du gain)

appauvrir *v.t.* ធ្វើឲ្យចុះក្រ (ឧ. la guerre appauvrit un pays) ។ *Fig.* ធ្វើឲ្យអស់ជីជាតិ (ឧ.appauvrir un terrain); ធ្វើឲ្យអន់ថយ (ឧ. appauvrir une langue) ។ s'appauvrir *v.pr.* ចុះក្រ ។ *Fig.* អស់ជីជាតិ (ដី)

appauvrissement *n.m.* ភាពចុះក្រ ។ *Fig.* ភាពចុះអន់ថយ ឬ ចុះកម្លាំង (ឧ. appauvrissement du sang, d'une langue)

appel *n.m.* ការហៅ (ឧ. cri d'appel) ; ការអំពាវនាវ (ឧ.appel à l'insurrection); ការរើសទាហាន; ឧទ្ធរណ៍ [អ៊ុត-ធ ឬ អ៊ុត-ទ] ។ cour d'appel ម.ព.cour ។ appel de fonds ការអំពាវនាវមូលនិធិ ។ appel d'offres ការដេញថ្លៃចុះ ។ faire appel à អំពាវនាវចំពោះ ។ appel d'air ការស្រូបខ្យល់

appelant,e *a.&n.* អ្នកឧទ្ធរណ៍ ។ *n.m.* ធ្នាក់ (បក្សី)

appeler *v.t.* ហៅ(appeler la garde); កោះ (ឧ. appeler en témoignage); ហៅឲ្យធ្វើទាហាន(ឧ. appeler la réserve sous les drapeaux); ឲ្យឈ្មោះ (ឧ.appeler un enfant Chhum)។ *v.i.* ឧទ្ធរណ៍ (រើប្ដឹងជាថ្មីទៀត)។ s'appeler *v.pr.* មានឈ្មោះថា, ឈ្មោះថា (ឧ.s'appeler Phan)

appellation *n.f.* សមញ្ញា [សៈ-ម៉ាញ់-ញ៉ា]; ការហៅ

appendice *n.m.* បរិសិដ្ឋ;សេចក្ដីបន្ថែម

appendicite *n.f.* បរិសិដ្ឋរោគ

appentis *n.m.* ញ៉ាប

appert (il) (*v. apparoir*) គេឃើញស្ដែង; ជាហេតុ

appesantir *v.t.* នាំឲ្យធ្ងន់ (ឧ. l'eau appesantit les vêtements); សង្កត់។ *Fig.* appesantir son pouvoir ប្រើអំណាចសង្កត់សង្កិនថែម។ s'appesantir *v.pr.* ឡើងធ្ងន់; ទទូច (ឧ.s'appesantir sur un sujet)

appesantissement *n.m.* ភាពឡើងធ្ងន់; ភាពធ្ងន់

appétence *n.f.* អភិជ្ឈា; បំណង

appéter *v.t.* ចង់ខ្លាំង (ឧ.l'estomac appète les aliments)

appétisant,e *a.* ដែលធ្វើឲ្យឃ្លាន, ដែលធ្វើឲ្យចង់បាន

appétit *n.m.* ជិឃច្ឆា,ការឃ្លាន;បំណង; ការស្រេកឃ្លាន ។ *Prov.* l'appétit vient en mangeant អ្នកមានរឹតតែចង់មានថែមទៀត

appétitif,ive *a.* ដែលឲ្យស្រេកឃ្លាន, ដែលឲ្យចង់

appétition *n.f.* បំណងខ្លាំង

applaudir *v.t.* ទះដៃសាទរ (ឧ. applaudir un acteur); សរសើរ។ *v.i.* applaudir à យល់ព្រម (ឧ. j'applaudis à tout ce que vous dites) ។ s'applaudir *v.pr.* សរសើរខ្លួនឯង, សប្បាយចិត្ត (s'applaudir d'avoir pris une résolution)

applaudissement *n.m.* ការទះដៃសាទរ

applaudisseur, euse *n.* អ្នកទះដៃសាទរច្រើន

applicabilité *n.f.* ភាពអាចអនុវត្តបាន

applicable *a.* ដែលត្រូវអនុវត្ត, អាចអនុវត្តបាន

applicage *n.m.* ការបិទត្រួតលើ; ការលាបត្រួតលើ

application *n.f.* ការអនុវត្តន៍ (ឧ.application d'un principe) កិច្ចអនុវត្តន៍; ការសំភីផ្ចិតផ្ចង់ (ឧ.application à l'étude)

appliquer *v.t.* បិទ ឬ លាបត្រួតលើ (ឧ.appliquer des couleurs)។ appliquer un soufflet ទះកំភ្លៀងមួយដៃ ។ *Fig.* appliquer son esprit à ផ្ចង់ស្មារតីលើ ។ ប្រើ (ឧ. appliquer un remède ប្រើឱសថ) ។ អនុវត្ត (ឧ.appliquer l'algèbre à la géométrie អនុវត្តពីពីជគណិតមករេខាគណិត) ។ s'appliquer *v.pr.* សំភី, ផ្ចិតផ្ចង់ (ឧ.s'appliquer à bien faire); រើសដាក់ខ្លួន(ឧ. s'appliquer les louanges)

austèrement *adv.* យ៉ាងតឹងរ៉ឹង,ដោយម៉ឹងម៉ាត់

austérité *n.f.* តបកម្ម [ត:-ប៉:-], ការកាន់វត្តប្រតិបត្តិតឹង ។ *Fig.* សេចក្តីតឹងរ៉ឹង

austral,e,als ឬ **aux** *a.* ខាងត្បូង

australien, enne *a.* នៃប្រទេសអូស្ត្រាលី ។ *n.* ជនជាតិអូស្ត្រាលី

autant *adv.* ដូច្នេះដែរ, ប៉ុណ្ណឹងដែរ, មិនតិចជាង, មិនតូចជាង, មិនអន់ជាង ។ autant que *loc.conj.* ស្មើគ្នា, ដូចគ្នា ។ d'autant que *loc. conj.* ព្រោះថា, ដោយហេតុថា ។ autant de សុទ្ធតែជា (ឧ. les étoiles sont autant de soleils immenses); ប៉ុន្មាន . . . ប៉ុណ្ណោះដែរ (ឧ. autant d'hommes, autant d'avis différents) ។ autant de ... que ដូចគ្នានឹង ... ដែរ (ឧ. les victoires traînent toujours après elles autant de calamités pour l'Etat que les plus sanglantes défaites) ។ c'est autant de តិចបាន ... ប៉ុណ្ណោះដែរ (ឧ. c'est autant d'épargné បានសំចៃប៉ុណ្ណោះដែរ) ។ d'autant *loc. adv.* ប៉ុណ្ណឹងដែរ (ឧ. payez un acompte, vous diminuerez vos dettes d'autant); ច្រើនដូចគ្នា (ឧ. manger comme quatre, et boire d'autant); boire d'autant ផឹកច្រើន ។ tout autant *loc.adv.* ស្មើគ្នា, ដូចគ្នា ។ d'autant plus *loc.adv.* រឹតតែច្រើនណាស់ ។ d'autant moins *loc adv.* រឹតតែតិចណាស់ ។ autant . . . autant . . . ប៉ុណ្ណា . . . ប៉ុណ្ណឹងដែរ (ឧ. autant la concentration politique est nécessaire, autant la concentration administrative est haïssable) ។ autant vaut ទុកដូចជា (ឧ. c'est un homme mort, ou autant vaut) ; ជាជាង, គ្រាន់បើជាង (ឧ.autant vaut faire cela que de différer)

autarchie *n.f.* ស្វ័យាធិបតេយ្យ, ការគ្រប់គ្រងនៃពលរដ្ឋដោយខ្លួនឯង

autarchique *a.* នៃស្វ័យាធិបតេយ្យ

autarcie *n.f.* ភាពនៃរដ្ឋមានធនធានគ្រប់គ្រាន់ដោយខ្លួនឯង

autarcique *a.* ដែលផ្អែកលើភាពមានធនធានគ្រប់គ្រាន់ដោយខ្លួនឯង

autel *n.m* អាសនៈ, គ្រែព្រះធម៌, ហ៊ុង, អាសនៈ, បុស្បុក [បុស-ស្បុក] ។ autel de la patrie អាសនៈមាតុភូមិ ។

Fig. le trône et l'autel រាជបល្ល័ង្កនិងសាសនា

auteur *n.m.* អ្នកបង្កើត;ម្ចាស់;អ្នកនិពន្ធ; អ្នកប្រឌិត, អ្នកបង្ក (ឧ. l'auteur d'un accident en est responsable) ។ droit d'auteur សិទ្ធិអ្នកនិពន្ធ (កម្មសិទ្ធិរបស់អ្នកនិពន្ធ) ។ auteur classique អ្នកនិពន្ធគន្ថី (តាមតម្រាបុរាណ) ។ l'auteur de l'univers អាទិទេព, ព្រះព្រហ្ម

authenticité *n f.* យថាភាព, សភាវៈនៃការពិត ឬ នៃការត្រឹមត្រូវតាមច្បាប់

authentifier *v.t.* ម.ព. authentiquer

authentique *a.* យថាភូត, ពិតប្រាកដ (ឧ. histoire authentique); ត្រឹមត្រូវតាមច្បាប់(ឧ.acte authentique)

authentiquement *adv.* ដោយយថាភូត,ដោយពិតប្រាកដឬត្រឹមត្រូវតាមច្បាប់

authentiquer *v.t.* បញ្ជាក់តាមយថាភូត; បញ្ជាក់ថាពិតប្រាកដ ឬ ថាត្រឹមត្រូវតាមច្បាប់ (ឧ. authentiquer un acte)

auto *préf.* ស្វ័យ(បុព្វបទមានន័យថាខ្លួនឯង, ដោយខ្លួនឯង, ពីខ្លួនឯង)

auto *n.f.* ពាក្យបំប្រួញនៃពាក្យ automobile

autobiographie *n.f.* ស្វ័យជីវប្រវត្តិ

autobus *n.m.* រថយន្តក្រុង

autocamion *n.m.* រថយន្តកាម៉ុង

autocar *n.m.* អូតូការ, រថយន្តដឹកនាំសាធារណ៍

autochtone *a.*&*n.* ផ្ទៃរាស៊ី-ស៊ីនី(មនុស្សដែលមានដើមកំណើតក្នុងរដ្ឋស្រាប់)

autoclave *a.* សំរាប់ចំហុយ ។ *n.m.* ឆ្នាំងចំហុយ

autocrate *n.m.* សម្បូណ៌ាញាសិទ្ធិរាជ

autocratie *n.f.* សម្បូណ៌ាញាសិទ្ធិរាជាធិបតេយ្យ

autocratique *a.* នៃសម្បូណ៌ាញាសិទ្ធិរាជាធិបតេយ្យ

autocritique *n.f.* ស្វ័យវិក្រិត, ការរិះគន់ខ្លួនឯង

autodéfense *n.f.* ស្វ័យត្រាណ

autodétermination *n.f.* ស្វ័យប្រណិធាន

autodidacte *a.*&*n.* ស្វ័យប្បទេស (អ្នករៀនខ្លួនឯង)

autofécondation *n.f.* ស្វ័យផលការ

autofinancement *n.m.* ស្វ័យហិរញ្ញទាន

autogène *a.* ស្វ័យុប្បត្ត, ដែលកឡើង ឬមានឡើងខ្លួនឯង ។ soudure autogène បន្សាស្វ័យុប្បត្តិ(ការផ្សារដោយរំលាយមុខបន្សាភ្ជាប់គ្នា)

autographe *a.* & *n.m.* ស្វ័យលេខនា (ដែលអ្នកនិពន្ធសរសេរដោយដៃឯង)

autographie *n.f.* ស្វ័យលេខនាវិធី

autographier *v.t.* បោះពុម្ពដោយស្វ័យលេខនាវិធី

automate *n.m.* ស្វ័យប្រវត្តក (ដែលប្រព្រឹត្តទៅខ្លួនឯង) ; រូបយន្ត ។ *Fig.* អនុស្សទីងមោង

automaticité *n.f.* ស្វ័យប្រវត្តភាព

automation *n.f.* ស្វ័យប្រវត្តិកម្ម

automatique *a.* ស្វ័យប្រវត្ត ។ *Fig.* ដែលធ្វើដោយមិនបាច់គិត

automatiquement *adv.* ដោយស្វ័យប្រវត្ត; ដោយមិនបាច់គិត

automatiser *v.t.* ធ្វើឲ្យទៅជាស្វ័យប្រវត្ត

automatisme *n.m.* លក្ខណៈស្វ័យ-ប្រវត្ត; លក្ខណៈដូចម៉ាស៊ីន (ធ្វើដោយមិនបាច់គិត)

automitrailleuse *n.f.* រថកាំភ្លើងយន្ត

automnal,e,aux *a.* នៃសរទរដូវ

automne *n.m.* សរទរដូវ [សៈ រ:-ទ:-] (រដូវសំហើយៈ ពីថ្ងៃទី ២២ កញ្ញាទៅថ្ងៃទី ២១ ធ្នូ)

automobile *a.* ស្វ័យចល័ត; យន្ត ។ *n.f.* រថយន្ត

automobilisme *n.m.* ការសង់រថ-យន្ត; កីឡារថយន្ត

automobiliste *n.* អ្នកបើករថយន្ត; អ្នកកីឡារថយន្ត

automoteur,trice *a.* ស្វ័យយន្ត ។ *n.f.* អូតូរ៉ៃ ។ *n.m.* កប៉ាល់ដឹកទំនិញម្យ៉ាង

autonome *a.* ស្វយ័ត (ស្វ:-យ័ត)

autonomie *n.f.* ស្វ័យភាព្យ;ស្វ័យភាព។ autonomie financière ស្វ័យ-ភាពហិរញ្ញ

autonomiste *n.m.*អ្នកស្វ័យភាពនិយម

autopsie *n.f.* ការវះពិនិត្យសព

autopsier *v.t.* វះពិនិត្យសព

autorail *n.m.* អូតូរ៉ៃ ឬ អ័យរថ

autorisation *n.f.* អនុញ្ញាត; សំបុត្រ-អនុញ្ញាត

autoriser *v.t.* អនុញ្ញាត,បើកអំណាច។ personne autorisée អ្នកមានអំណាច (ធ្វើអ្វីមួយ)។ s'autoriser *v.pr.* សំអាងលើ

autoritaire *n.&a.* ដែលប្រើអំណាច; ដែលមិនព្រមទទួលការជំទាស់

autoritarisme *n.m.* អំណាចនិយម

autorité *n.f.* អាជ្ញា,អំណាច;អនុញ្ញាត (ឧ.une femme ne peut agir sans l'autorité de son mari) ។ *pl.* អាជ្ញាធរ, អ្នកកាន់អំណាច; មន្ត្រីជាន់ខ្ពស់ ។ d'autorité ដោយអំណាច (ដោយគ្មានពិគ្រោះអ្នកណា) ។ de pleine autorité ដោយពេញអំណាច ។ de son autorité, de sa propre autorité, de son autorité privée ដោយគ្មានសិទ្ធិ ។ autorité de justice អាជ្ញាតុលាការ (ឧ.vente par autorité de justice លក់តាមអាជ្ញាតុលាការ) ។ autorité de la chose jugée ម.ព. chose ។ coup d'autorité សេចក្ដីសម្រេចទាំងអំណាច

autoroute *n.f.* យន្តបថ

auto-stop *n.m.* ការសុំដោយសាររថយន្ត

autosuggestion *n.f.* អត្តន័យ; ការបង្គាប់ខ្លួនឯង

autour *adv.* ជិតខាង (ឧ. ceux qui vivent autour de nous);ជុំវិញ (ឧ.la terre tourne autour du soleil); ប្រហែល (ឧ.posséder autour d'un million)។ tout autour *loc.adv.* ជុំវិញ, ពីគ្រប់ទិស។autour de *loc. pré.* ជុំវិញ ។ ici autour នៅជិតនេះ (ឧ. il demeure ici autour) ។ tourner autour du pot *loc. prov.* និយាយមិនចំចំណុចរឿង ។ il ne faut pas confondre «autour» et «alentour» *loc. prov.* កុំច្រឡំគ្នា

autre *a.ind.* ផ្សេង,ឯទៀត,ម្នាក់ទៀត; ដទៃ;ភាពស្មើគ្នា,ភាពដូចគ្នា (ឧ. c'est un autre moi-même) ។ *pr. ind.* អ្នកឯទៀត, អ្នកផង ។ l'un l'autre ឬ les uns les autres ទៅវិញទៅមក ។ nous autres ចំណែកខាងយើង (ឧ. nous autres cambodgiens, nous ne sommes pas de cet avis) ។ vous autres ចំណែកខាងលោក។ l'autre jour ថ្ងៃមុន ។ autre part កន្លែងឯទៀត ។ d'autre part ម្យ៉ាងទៀត ។ de temps à autre ម្ដងៗ, ជួនកាល។ un autre jour, une autre fois ចាំថ្ងៃក្រោយ ។ un jour ou l'autre

ថ្ងៃណាមួយ ។ l'autre vie ជាតិក្រោយ (ក្រោយស្លាប់) ។ sans autre គ្មានអ្វីទៀត, តែប៉ុណ្ណោះ ។ prendre l'un pour l'autre ច្រឡំគ្នា ។ prendre quelqu'un pour un autre យល់ខុស,មើលមិនយល់ (ចំពោះកិរិយាមារយាទ) ។ voir ឬ regarder une chose d'un autre œil មានយោបល់ផ្សេង, យល់ផ្សេង ។ l'un vaut l'autre ដូចគ្នា, មិនជាងគ្នា ។ c'est tout un ou tout autre ដូចគ្នា, មិនបាច់រើស ។ il y en a d'uns et d'autres មានល្អមានអាក្រក់ ។ à d'autres ! *loc. int.* ចូរទៅរកអ្នកផ្សេងទៀតចុះ !

autrefois *adv.* ពីដើម, ពីមុន

autrement *adv.*ផ្សេងពី (ឧ.il parle autrement qu'il ne pense); បើមិនដូច្នោះ (ឧ. obéissez ! autrement vous serez puni); តាមបែបផ្សេង (ឧ. faire autrement)

autrichien,enne *a.*នៃប្រទេសអូទ្រីស។ *n.* ជនជាតិអូទ្រីស

autruche *n.f.* អូទ្រុស (បក្សីម្យ៉ាងរត់លឿន មានកំពស់ដល់២ម,៥០)

autrucherie *n.f.* កន្លែងចិញ្ចឹមអូទ្រុស

autrui *pr.ind.* អ្នកដទៃ, អ្នកឯទៀត

auvent *n.m.* ជាំងសាច, ដើយគម្របវេយន្ត ឬ យន្តហោះ

auvergne *n.f.* សំបកឈើត្រាំសម្រាប់សម្លាប់ស្បែក

auxiliaire *a.&n.* ជំនួយ

auxiliateur, trice *n.&a.* អ្នកជួយ

avachi,e *a.*រេចរឹល; ស្រពោន; ខូចទ្រង់ទ្រាយ ។ *Pop.* ទន់ (មិនស្វាហាប់)

avachir (s') *v.pr.Fam.* រេចរឹល; ពុះទន់ខ្សោយ;ខូចទ្រង់ទ្រាយ

avachissement *n.m.* ភាពរេចរឹល; ភាពចាស់

aval *n.m.* របិយបដិភោគ (ការធានាលើភាណិជ្ជប័ត្រ) (*pl.* des avals)

aval *n.m.* ទីក្រោមទឹក។ en aval de *loc.pré.* ខាងក្រោម(ក្រោមទឹក) (ឧ. Phnom Penh est en aval de Kompong Cham)

avalanche *n.f.* ផ្ទាំងទឹកកកធំសម្បើមដែលរអិលធ្លាក់ពីលើភ្នំ

avalement *n.m.* ការលេប,ការចុះតាមទឹក

avaler *v.t.* លេប ។ *Fig.* & *Fam.*

ជឿ (ឧ. avaler des mensonges); ទ្រាំ(ឧ.avaler l'humiliation)។ អានដោយរហ័ស(ឧ.avaler des romans) ។ avaler des yeux សម្លឹងមិនដាក់ភ្នែក (ដូចគេចង់លេប) ។ l'avaler សំឡក់ (ដោយខឹង)។ *Arg.* avoir avalé le pépin មានគភ៌ ។ avaler sa langue អផ្សុក, ស្ងាបខ្លាំង; មិនចេញស្តី; ស្លាប់ ។ avaler des couleuvres លេបថ្មលេបក្រួស (ទ្រាំទទួលអំពើមិនគាប់ចិត្ត) ។ en faire avaler ធ្វើឲ្យជឿការមិនសមហេតុផល ។ *Prov.* morceau avalé n'a plus de goût ម្ហូបដែលលេបផុតហើយលែងមានរសជាតិ, ការសប្បាយដែលកន្លងទៅជាអសារបង់ ។ il avalerait la mer et ses poissons ស្រេកខ្លាំង, ល្មោភខ្លាំង ។ *v.i.* ចុះតាមទឹក

avaleresse *n.f.* អណ្តូងកំពុងជីក

avaleur,euse *n.Fam.* អ្នកល្មោភស៊ី

avaliser *v.t.* ចុះរូបិយបដិភោគ (ចុះកិច្ចធានាលើភណ្ឌិដ្ឋប័ត្រ)

avaliseur ឬ **avaliste** *n.&a.* រូបិយបដិភោគី (អ្នកចុះកិច្ចធានាលើភណ្ឌិដ្ឋប័ត្រ)

avaloire *n.f.* ឬ **avaloir** *n m.* ខ្សែព្រយុងភ្លៅ(សេះ)។ *Pop.* បំពង់ក;មាត់

avance *n.f.* យ៉ផ្លូវ; ការលឿនជាង (ឧ. avoir une avance d'un kilomètre);ប្រាក់បុរេប្រទាន, ប្រាក់បើកមុន (ឧ. faire une avance à un ouvrier);ប្រាក់កក់។*Fig.* ការផ្តើមទាក់ទង (ឧ. faire les avances) ។ *loc.adv.* à l'avance, d'avance, par avance ជាមុន (ឧ.se réjouir d'avance)។ en avance មុនម៉ោង

avancé,e *a.*ដែលលូក (ឧ.retirer la main avancée) ; ដែលលឿនឬត្រីលទៅមុខ ;ដែលនៅមុខ (ឧ.poste avancé បុស្តិ៍មុខ) ; ដែលបានថ្លែងហើយ (ឧ. prouver les faits avancés);ដែលចេញមុន(ឧ. somme avancée) ; ជឿនទៅមុខ (ឧ. travail avancé); វិសេសវិសាល (ឧ.civilisation avancée);ដែលបានចម្រើនជាងគេ (ឧ. avoir les idées avancées ; l'écolier avancé) ។ *n.f.* អ្វីៗដែលលូតទៅមុខគេ (ឧ. les avancés d'un

fort); ប្រចីសន្ទូច (ហៅ avançon ក៏បានដែរ)

avancement *n.m.* ការទិត;ការឡើងឋានន្តរស័ក្តិ;សេចក្តីចម្រើន;ភាពលយ;ការលឿនទៅមុខ ។ avancement d'hoirie មត៌កទទួលមុន

avancer *v.t.* លូក;រុញ;លូក; ជ្រួលទៅមុខ; ថ្លែង; បង់ប្រាក់មុន;ឡូវី;បង់ប្រាក់កក់ ។ *Fig.* ស្រួក,ប្រញាប់(ឧ.avancer son départ);avancer une proposition ស្នើ ។ *v.i.* ដើរទៅមុន; បានចម្រើន;លឿន (ឧ. les travaux avancent rapidement); ដើរលឿនពេក (ឧ. ma montre avance); លយទៅមុខ (ឧ. ce mur avance); ជិតបានសម្រេច (ឧ. l'ouvrage avance)។s'avancer *v.pr.*ដើរទៅមុខ

avanie *n.f.* ការប្រមាថកណ្តាលចំណោម, ការបំបាក់មុខ

avant *pré.* មុន ។ bien avant dans la nuit យប់ជ្រៅ ។ avant tout, avant toutes choses ជាដើម, មុនបង្អស់ ។ avant peu មិនយូរ ។ *adv.* មុខ, ខាងមុខ។ ជ្រៅ, ឆ្ងាយ(ឧ. entrer avant dans la forêt) ។ en avant *loc.adv.* ឯមុខ,ទៅមុខ, ទៅខាងមុខ ។ aller en avant ទៅមុខ(ដោយក្លាហាន ឬដោយមិនរវល់នឹងឧបសគ្គ) ។mettre une chose en avant សំអាងលើរបស់អ្វីមួយ។ avant que *loc, conj.* មុន (ឧ. la vérité est avant que l'homme la connaisse) ។ en avant de *loc. pré.* ពីមុខ ។

avant *n.m.* ផ្នែកខាងមុខ;ក្បាល(នាវា)។ à l'avant, sur l'avant ខាងក្បាល,ខាងមុខ ។ aller de l'avant, marcher de l'avant ទៅមុខជានិច្ច; បន្ទាន់ការ ។ être de l'avant à quelqu'un ឬ quelque chose បានចម្រើនជាង; លឿនជាង ។ engagé par l'avant ចូលក្បាល ។ le vent hale l'avant, se rapproche de l'avant ខ្យល់មកពីមុខ ។ avant partout អុំទៅមុខព្រមគ្នា

avantage *n.m.* អត្ថប្រយោជន៍ ។ avantage matériel អត្ថប្រយោជន៍ខាងសម្ភារៈ។avantages en nature អត្ថប្រយោជន៍ជាវត្ថុ ។

ប្រៀប (ឧ. profiter de son avantage) ; ជ័យជំនះ (ឧ.remporter quelques avantages)

avantager *v.t.* ឲ្យអត្ថប្រយោជន៍; អនុគ្រោះ

avantageusement *adv.* ដោយមានអត្ថប្រយោជន៍, ដោយមានកិត្តិសព្ទ

avantageux,euse *a.* ដែលមានអត្ថប្រយោជន៍;ដែលជួយអួត;ដែលជួយគាំពារ(ឧ. parler d'une personne en termes avantageux)។ *n.m. Fam.* មនុស្សក្អេងក្អាង (ឧ. c'est un avantageux)

avant-bras *n.m.* កំភួនដៃ

avant-clou *n.m.* ដែកកណ្ដារ(សម្រាប់ខួងរន្ធបោះដែកគោល)

avant-corps *n.m* ញកមុខ

avant-cour *n.f.* ធ្លាមុខ

avant-coureur *a.&n.m.* អ្នកនាំមុខ។ *Fig.* បុព្វនិមិត្ត, ហេតុភេទដែលឲ្យឃើញជាមុន (ឧ. signes avant-coureurs de la tempête)

avant-dernier,ère *a.&n.* បន្ទាប់ចុងបំផុត(*pl.* des avant-derniers)

avant-garde *n.f.Mil.* ទ័ពស្រួច, ទ័ពឈានមុខ ។ *Par ext.* បុព្វនិមិត្ត; ដែលទៅមុន ; ដែលឲ្យសញ្ញាមុន (ឧ. être à l'avant-garde du progrès)

avant-goût *n.m.* បុព្វរស,រសដឹងជាមុន

avant-guerre *n.m.* ឬ *f.* ពេលមុនសង្គ្រាម

avant-hier *loc.adv.* ម្សិលម្ង៉ៃ

avant-main *n.m* ជាតដៃ;ប៉ែកខាងមុខនៃសេះ(គឺក្បាល,កនឹងជើងមុខ)

avant-port *n.m.* កំពង់មុខ (កំពង់តូចតាំងខាងមុខកំពង់ធំ)

avant-poste *n.m.* ប៉ុស្តិ៍មុខ

avant-projet *n.m.* សំណៅព្រាង

avant-propos *n.m.* កថាមុខ, បុព្វកថា

avant-scène *n.f.* មុខឆាក, វិកសនៈ (ឡូសល្ខោន)

avant-toit *n.m.* ជំបូលលយទៅមុខ

avant-train *n.m.* ប៉ែកខាងមុខនៃរថ

avant-veille *n.f.* ម្សិលម្ង៉ៃ

avare *a.&n.* មច្ឆរី-រិនី,កំណាញ់។*Fig.* សំចៃខ្លាំង (ឧ.être avare de son temps)

avarice *n.f.* មច្ឆរិយៈ, សេចក្ដីកំណាញ់

avaricieusement *adv.* ដោយស្វារធន

avaricieux,euse *a.&n.* ស្វារ,ស្វារធន

avarie *n.f.* ការខូចខាត; របស់ខូចខាត

avarié,e *a.* ខូចខាត ។ *a.&n.* ដែលកើតរោគស្វាយ

avarier *v.t.* ធ្វើឲ្យខូចខាត

avatar *n.m.* អវតារ(ចុតិនៃទេវតា,ដំណើរធ្លងចុះពីមួយ ទៅមួយ ជាលំដាប់គ្នា)

à vau-l'eau *loc.adv.* ម.ព. vau-l'eau (à)

avé ឬ **avé-maria** *n.m.* ក្ងនផ្កាំ

avec *pré.* ព្រមនឹង, ជាមួយនឹង ដោយ (ឧ. ouvrir avec une clef) ; ប្រកបដោយ;ចំពោះ(ឧ. être docile avec ses maîtres) ។ ដោយមាន... នឹង; (ឧ. avec tout le respect que je vous dois ដោយគោរព) លើកលែងតែ

aven *n.m.* ជ្រោះ

avenant *n m.* កិច្ចសន្យាបន្ថែម

avenant,e *a.* ស្រស់ស្រាយ, រួសរាយ។ à l'avenant *loc.adv.* ស្មើគ្នា; ក៏...ដែរ (ឧ.jolis yeux, teint à l'avenant ភ្នែកល្អ សម្បុរក៏ល្អដែរ)។ à l'avenant de *loc.pré.* សមនឹង (ឧ. dessert à l'avenant du repas)

avènement *n m* ព្រឹត្តិការណ៍;ដំនាន់; ការបានឡើងឋានន្តរសក្តិខ្ពស់បំផុត

avenir *n.m.* អនាគត (ឧ.l'avenir est incertain); អនាគតកាល, កាលខាងមុខ ។ *Fig.* អនាគតល្អ (ឧ. assurer l'avenir de son enfant) ; ជំនាន់ក្រោយ (l'avenir nous jugera) ។ à l'avenir *loc. adv.* តទៅអនាគត,អំណើះតទៅ

aventure *n f.* យថាការណ៍, ការផ្សងព្រេង;ព្រឹត្តិការណ៍ចំឡែក ។ la bonne aventure ការទាយអនាគត ។ *loc.adv.* à l'aventure សាត់អណ្តែត, តាមតែប្រទះ។ par aventure, d'aventure ដោយចៃដន្យ, ដោយដួន

aventurer *v.t.* ប្រថុយ (ឧ. aventurer une somme); ផ្សងព្រេង។ s'aventurer *v.pr.* ប្រថុយខ្លួន ; ដើរទេស; ដើរសាត់អណ្តែត

aventureusement *adv.* តាមយថាការណ៍,ដោយប្រថុយ, ដោយផ្សងព្រេង

aventureux,euse *a.* ដែលប្រថុយ, ដែលផ្សងព្រេង; សាត់អណ្តែត (ឧ. homme aventureux)

aventurier,ère *n.* អ្នកផ្សងព្រេង, ធ្វើរទេស; មនុស្សសាត់អណ្តែត

avenu,e *a.* non avenu *loc. adv.*

មិនបានការ, មោឃៈ

avenue *n.f.* វិថី (ផ្លូវមានដើមឈើអម); ផ្លូវទៅកាន់ទីណាមួយ

avéré,e *a.* ដែលគេពិនិត្យឃើញថាពិត (ឧ. fait avéré)

avérer *v.t.* ពិនិត្យឃើញថាពិត (ឧ. avérer une nouvelle) (កុំថា: cela s'est avéré faux; il s'avère que)

avers *n.m.* មុខ (រូបិយវត្ថុ, មេដាយ)

averse *n.f.* ភ្លៀងអុរ ។ à verse *loc. adv.* ម.ព. verse(à)

aversion *n.f.* ការស្អប់ខ្ពើម

averti,e *a.* ដែលបានទទួលការព្រមានឬការដាស់តឿន (ឧ. se tenir pour averti); ចេះ, ឆ្លាត (ឧ. un critique averti)។ *Prov.* un homme averti en vaut deux អ្នកដឹងខ្លួនមុន មានអានុភាពស្មើមនុស្សពីរនាក់(សុភាសិតខ្មែរមានន័យស្រដៀងថា «អ្នកចេះដប់មិនស្មើអ្នកប្រសប់មួយ»)

avertir *v.t.* ព្រមាន,ដាស់តឿន,រំឭក

avertissement *n.m.* ការព្រមាន, ការដាស់តឿន,ការរំឭក,ដំណឹង; អារម្ភកថា (ឧ. avertissement au lecteur)

avertisseur *a.& n.m.* ដែលព្រមាន; ដែលឲ្យសញ្ញា (ឧ. signal avertisseur)

aveu *n.m.* ការទទួលសារភាព (ឧ. faire l'aveu de ses fautes); ការយល់ព្រម (ឧ. sans votre aveu);ចម្លើយកសិណ(ឧ.de l'aveu de tout le monde)។ homme sans aveu មនុស្សអនាថា

aveuglant,e *a.* ដែលបាំងភ្នែក;ដែលឲ្យស្រវាំងភ្នែក

aveugle *a.&n.* ខ្វាក់, មនុស្សខ្វាក់។ *Fig.* ដែលគ្មានពិចារណា;ដែលមោហ៍បាំង (ឧ. la colère rend aveugle, faire l'aveugle)។ soumission aveugle ការស្ដាប់បង្គាប់ដោយឥតប្រកែក ។ à l'aveugle, en aveugle, aveuglément ដោយឥតពិចារណា ។ *Prov. &loc. prov.* changer, troquer son cheval borgne contre un cheval aveugle ចាក់អង្ករយកអង្កាម ។ crier comme un aveugle ស្រែកចណ្ឌាល(ដូចមនុស្សខ្វាក់បាត់ឈើច្រត់) ។ c'est un aveugle qui en conduit un

autre និរីខ្វាក់ទ្រមាក់ឆ្គត ។ au royaume des aveugles, les borgnes sont rois អ្នកបេះតិចធ្វើងក្នុងចំណោមអ្នកល្ងង់ ។ il n'est pire aveugle que celui qui ne veut pas voir ខ្វាក់ព្រមិនស្មើអ្នកមិនចង់ឃើញ ។

aveuglement *n.m.* ភាពខ្វាក់ ។ *Fig.* ភាពមោហ៍ជាំង, ភាពវង្វេងស្មារតី; ភាពងងឹតមុខ

aveuglément *adv.* ដោយឥតពិចារណា

aveugle-né,e *n.&a.* ខ្វាក់ពីកំណើត

aveugler *v.t.* ធ្វើឲ្យខ្វាក់ ។ *Fig.* ធ្វើឲ្យព្រិលភ្នែក (ឧ. le ciel m'aveugle); ធ្វើឲ្យវង្វេងស្មារតី (ឧ. la passion aveugle); មោហ៍ជាំង; ពុករន្ធ ។ s'aveugler *v.pr.* មិនដឹងខុសត្រូវ, កំភេលពូល

aveuglette (à l') *loc.adv.* ដោយស្ទាប, ដោយភរ ។ *Fig.* ដោយប្រថុយ, ទាំងងងឹតងងល់ (ឧ. agir à l'aveuglette)

aveulir *v.t.* ធ្វើឲ្យទន់, ធ្វើឲ្យខ្សោយ ឬ ឲ្យមិនស្វាហាប់ (ឧ. l'oisiveté aveulit l'homme)

aveulissement *n.m.* ការធ្វើឲ្យទន់ ឬ ឲ្យមិនស្វាហាប់; ភាពទន់ឬមិនស្វាហាប់

aviateur,trice *a.* នៃអាកាសយាន (ឧ. machine aviatrice) ។ *n.* អាកាសយានិក-និកា (អ្នកបើកយន្តហោះ)

aviation *n.f.* អាកាសចរណ៍ ។ Aviation Royale Khmère អាកាសចរណ៍ខេមរភូមិន្ទ

aviculteur *n.m.* បក្សីវប្បករ (អ្នកចិញ្ចឹមបក្សី)

aviculture *n.f.* បក្សីវប្បកម្ម (ការចិញ្ចឹមបក្សី)

avide *a.* ដែលឃ្លានខ្លាំង, ដែលចង់បានខ្លាំង (ឧ. avide de gloire); លោភ

avidement *adv.* ដោយល្មោភ

avidité *n.f.* សេចក្ដីឃ្លានខ្លាំង, សេចក្ដីលោភខ្លាំង

avilir *v.t.* បន្ថោក (ឧ. avilir une marchandise); ធ្វើឲ្យរាបកិត្តិយស (ឧ. l'alcoolisme avilit l'homme) ។ s'avilir *v.pr.* ធ្វើឲ្យថោកខ្លួន; ចុះថោកទាប

avilissant,e *a.* ដែលធ្វើឲ្យថោក ឬ ឲ្យថយកិត្តិយស

avilissement *n.m.* ការចុះថោកទាប; ភាពគេមិនរាប់អាន

avilisseur,euse *n.&a.* ដែលបន្ថោក-

បន្ទាបគេ

aviner *v.t.* ត្រាំស្រា ។ s'aviner *v.pr.* សេពសុរាហួសកំណត់;ស្រវឹង

avion *n.m.* អាកាសយាន, យន្តហោះ

avionnette ឬ **aviette** *n.f.* អាកាសយានតូច, យន្តហោះតូច

aviron *n.m.* ច្រវាទូក; ការលេងទូក

avis *n.m.* ប្រកាស (ឧ. avis au public) ។ avis de crédit ប្រកាសឥណទាន ។ avis de débit ប្រកាសឥណទេយ្យ ។ avis de virement ប្រកាសបង្វែរ។ យោបល់ (ឧ. partager l'avis de quelqu'un មានយោបល់ស្របនឹង) ។ pour avis ដើម្បីយោបល់ ។avis favorable យោបល់អនុគ្រោះ ។ avis défavorable យោបល់ឥតអនុគ្រោះ ។ ការពិគ្រោះ;ការរំឭក ។ *Prov.* deux avis valent mieux qu'un គួរតែពិគ្រោះគ្នាច្រើន (មុននឹងធ្វើអ្វីមួយ) ។ autant de têtes, autant d'avis គ្នាច្រើនមានយោបល់ច្រើន (សុភាសិតខ្មែរមានន័យថា «បួសដោយវត្តចិត្តដោយខ្លួន»)

avisé,e *a.* វៃ, ឆ្លាត, គិតត្រូវ

aviser *v.t.* ឃើញ;ហាម;ប្រាប់;ប្រកាស។ *v.i.* គិតរកមធ្យោបាយ (ឧ.avisons à sortir d'ici យើងគិតរកមធ្យោបាយនឹងចេញពីទីនេះ)។ s'aviser *v.pr.* រកឃើញ(ឧ.il s'avisa d'un bon expédient); នឹកឃើញប្លែក

aviso *n.m.* នាវានាំសារ

avitaillement *n.m.* យានូបភោគ

avitailler *v.t.* ផ្តល់ស្បៀង

avitaminose *n.f.* អប្បជីវជាតិ (កើតបណ្តាលពីការខ្វះជីវជាតិ)

avivage *n.m.* ការធ្វើឲ្យស្រស់-ឲ្យក្លៀវក្លា ឬឲ្យភ្លឺ ។ *Techn.* ការជ្រលក់សំពត់ឲ្យឡើងពណ៌ស្រស់

aviver *v.t.* បើឲ្យឆេះ (ឧ. aviver le feu); ធ្វើឲ្យស្រស់ (ឧ.aviver une couleur); ធ្វើឲ្យក្លៀវក្លា ឬឲ្យភ្លឺ;ចាក់ឆ្កៀល ឬ ធ្វើឲ្យក្លាយ(ឧ.aviver une blessure) ។ ធ្វើឲ្យរឹតតែខ្លាំង (ឧ. aviver le chagrin) ។ កោសសាច់ដំបៅ (ឧ.aviver les bords d'une cicatrice) ។ *Techn.* ជ្រលក់សំពត់ឲ្យឡើងពណ៌ស្រស់;កោសសំណាគ្រឿងកន្លែងដែលគេត្រូវការផ្សារ ។ aviver l'or, l'argent ខាត់មាស,ប្រាក់ឲ្យរលើងយង់ ។ *Menuis.* aviver une poutre ប្រមុំ,ធ្វើឲ្យ

មានជ្រុង

avocaillon *n.m.* មេធាវីឥតកិត្តិសព្ទ

avocasser *v.i.* ធ្វើជាមេធាវីឥតកិត្តិសព្ទ

avocasserie *n.f.* របរមេធាវីឥតកិត្តិសព្ទ; ការមិនចេះកាន់ក្ដី

avocassier,ère *a.* នៃមេធាវីឥតកិត្តិសព្ទ ។ *n.m.* មេធាវីមិនជំនាញ

avocat *n.m.* មេធាវី ។ avocat général អគ្គមេធាវី, អគ្គនីតិមេធី ។ barreau des avocats វិជ្ជាជីវៈនីតិបណ្ឌិត ឬ មេធាវី ។ bâtonnier de l'ordre des avocats នាយកគណៈមេធាវី

avocatoire *a.* ដែលរំឭក (ឧ.lettre avocatoire សំបុត្ររំឭក)

avoine *n.m.* អាវ៉ែន (ស្រូវម្យ៉ាងប្រើជាចំណីសេះ)។folle avoine អាវ៉ែនព្រៃ

avoir *v.t.* មាន(ឧ.avoir du bien មានទ្រព្យ); បាន(ឧ.avoir le prix បានរង្វាន់) ។ avoir faim ឃ្លាន ។ avoir soif ស្រេក ។ avoir à ត្រូវ (ឧ. avoir à payer ត្រូវបង់ប្រាក់) ។ avoir pour មានជា (ឧ. avoir pour parent មានជាបងប្អូន);ទុកជា(ឧ.avoir quelqu'un pour insolvable)។en avoir អន់ចិត្ត (ឧ. en avoir contre quelqu'un) ។ il y a មាន ។en avoir pour son argent ថ្លៃសមនឹងតម្លៃវា។ avoir de quoi មានគ្រប់គ្រាន់។avoir dans la main ឬ en main មានក្នុងកណ្ដាប់ដៃ,ក្ដាប់ក្នុងដៃ, មានអំណាចលើ (ឧ.un bon capitaine a tous ses hommes dans la main)។ avoir sous la main មានស្រាប់,មាននៅជិតដៃ (គឺអាចប្រើបានភ្លាម នៅពេលត្រូវការ) (ឧ. je n'ai pas ce livre sous la main) ។ avoir en tête មានគំនិត (ចង់ធ្វើអ្វីមួយ) ។ avoir beau faire ខំឥតអំពើ ។ avoir l'air ដូចជា,មានទំនងជា ។ avoir raison de ឈ្នះ។en avoir par dessus la tête ធុញទ្រាន់ ។ en avoir assez លែងទ្រាំបាន។ avoir son soûl, tout son soûl d'une chose ឆ្អែត,ទ្រាន់ ។ tant y a que ឬtant il y a que ទុកជាដូចម្ដេចក៏ដោយ;ទាល់តែ(ឧ. ils se querellèrent, se dirent des injures, tant il y a qu'ils finirent par se battre)

avoir *n.m.* ធនធាន ។ *Com.* ប្រាក់ត្រូវបាន(បញ្ជី) ។ avoir en nature ធនធានជាវត្ថុធាតុ

avoisinant,e *a.* ក្បែរ, ជិត

avoisiner *v.t.* នៅក្បែរ,នៅជិត

avortement *n.m.* ដំណើររលូតកូន ។ *Fig.* ការមិនបានសម្រេច

avorter *v.i.* រលូតកូន ។ *Fig.* មិនបានសម្រេច

avorton *n.m.* កូនរលូត ។ *Par plais.* មនុស្សក្រញេញ

avouable *a.* គួរឆ្លើយទទួលសារភាព

avoué *n.m.* ចៅក្រមយក្តី, ស្មាក្តី

avouer *v.t.* ឆ្លើយទទួលសារភាព,ទទួលខ្លួន

avoyer *v.t.* បើកមុខរណារ

avril *n.m.* ខែមេសា ។ *Fig.* poisson d'avril ការបញ្ឆោតលេង(ប្រវត្តិនៃសំនួនពាក្យនេះសឹងមានដូចតទៅៈព្រះបាទសាល់ទី ៩ (មហាក្សត្រប្រទេសបារាំង)បានទ្រង់ព្រះរាជបញ្ញត្តឲ្យចូលឆ្នាំនៅថ្ងៃទី ១ មករាវិញ មិនមែននៅថ្ងៃទី ១ មេសាដូចកាលពីដើមទេ ។ ដូច្នេះបានជាគេរមែងជូនជំនូនគ្នាទៅវិញទៅមក នៅថ្ងៃទី ១ មករា លុះដល់ថ្ងៃទី ១ មេសាគេជូនពរដោយចំអក ចំពោះអ្នកដែលមិនចូលចិត្តរបៀបនេះ ។ មិនតែប៉ុណ្ណោះគេថែមទាំងកំប្លែងដោយជូនដល់ជនខាងលើនេះ នូវជំនូន ឬសំបុត្រកំប្លែងផ្សេងៗ ។ ម្យ៉ាងទៀតក្នុងខែមេសានេះ ព្រះអាទិត្យចេញផុតពីមីនរាសីផង)

avrillé,e *a.* សាប ឬ ដាំក្នុងខែមេសា

avrillet *n.m.* ស្រូវសាលីសាបក្នុងខែមេសា

Av.R.K.(Aviation Royale Kmère) អ.ខ.ភ.(ម.ព. **aviation**)

avulsion *n.f.* ការដក (ឧ. avulsion d'une dent)

avunculaire *a.* នៃមា ឬ មីង (ឧ. puissance avunculaire)

axe *n.m.* អ័ក្ស, អ័ក្ស; ភ្លៅរទេះ; ស្នូល ។ *Fig.* អ័ក្ស(បន្ទាត់នយោបាយ) ។ **axe terrestre** អ័ក្សភូគោល ។

axer *v.t.* បំបែរតាមអ័ក្ស

axial,e *a.* នៃអ័ក្ស, តាមអ័ក្ស

axile *a.* ដែលបង្កើតជាអ័ក្ស

axillaire *a.* នៃក្លៀក (ឧ. nerf axillaire)

axioinc *n.m.* ស្វ័យសច្ច

axonge *n.f.* ខ្លាញ់ជ្រូកការ (ម.ព. saindoux ផង)

ayant cause *n.m.* ប្រតិសិទ្ធិ(អ្នកដែល

ទទួលសិទ្ធិបន្តពីគេ ដើម្បីប្រកបការរបស់ខ្លួនផង ជំនួសគេផង) (*pl.* des ayants cause)

ayant droit *n.m.* សិទ្ធិវន្ត (អ្នកមានសិទ្ធិលើវត្ថុអ្វីមួយ)(*pl.* des ayants droit)

azotate *n.m.* អាហ្សូតាត

azote *n.m.* និដ្ឋីព,អាហ្សូត

azoté,e *a.* ដែលមានអាហ្សូត

azoteux *a.* នៃអាហ្សូត(ម.ព. nitreux ផង)

azotique *a.*នៃអាហ្សូត(ម.ព.nitrique ផង)

azotite *n.m.* អាហ្សូទីត(ម.ព. nitrite ផង)

azotobacter *n.m.* អាហ្សូតូបាក់ទែរ (មេ-ក្រាណូដែលរស់នៅក្នុងឫសឈើ ហើយដែលបេះស្រូបជាតិអាហ្សូតពីអាកាស)

azur *n.m.* ពណ៌ខៀវម្យ៉ាង (កើតអំពីអុកស៊ីដឹកូបាល់),ពណ៌ខៀវនៃមេឃ-នៃអាកាស ឬសមុទ្ទ; អាកាស, មេឃ (ឧ. s'envoler dans l'azur) ។ *Fig.* សេចក្ដីស្ងប់ (ព្រោះមេឃស្ងប់មានពណ៌ខៀវ)

azuré,e *a.* ខៀវ។ la voute **azurée** មេឃ ។ plaine azurée សមុទ្ទ

azurer *v.t.* ជ្រលក់ពណ៌ខៀវ

azyme *a.* គ្មានដំបែ, គ្មានមេ



b *n.m.* អក្សរទី២នៃអក្ខរក្រមឡាតាំង

baba *a. Pop.* ធ្ងល់ស្រឡាំងកាំង (ឧ. rester baba)

babil *n.m.* ពាក្យប៉ប៉ាច់ប៉ប៉ោច; ពាក្យកកែកករនៃក្មេងតូច; សម្រែកចេចចាចនៃបក្សីខ្លះ

babillage ឬ **babillement** *n.m.* ការនិយាយប៉ប៉ាច់ប៉ប៉ោច ឬ កកែកករ

babillard,e *a.* ប៉ប៉ាច់ប៉ប៉ោច, កកែកករ (ក្មេង); ចេចចាច (បក្សី) ។ *n.* អ្នកនិយាយប៉ប៉ាច់ប៉ប៉ោច ។ *n.m. Fam.* សំបុត្រ

babiller *v.i.* និយាយប៉ប៉ាច់ប៉ប៉ោច; កកែកករ (ក្មេង); ស្រែកចេចចាច(បក្សី)

babine ឬ **babouine** *n.f.* បបូរមាត់ធ្លាក់ (ចំពោះឆ្កែ,ស្វា ។ ល ។)

babiole *n.f.* កឡូនភណ្ឌក្មេង។ *Fig.* វត្ថុបន្ទាប់បន្សំ ឬ គ្មានតម្លៃ

bâbord *n.m.* គែមឆ្វេងនៃនាវា (ព.ផ. tribord)

babouche *n.f.* ស្បែកជើងផ្ទាត់

baby *n.m.* (ពាក្យអង់គ្លេស) កូនង៉ែត

bac *n.m.* ស្រឡាង,ទូកចម្លង;ថាំងធំ,ធុង

baccalauréat *n.m.* ស្នាតកប័ត្រ [-ត:ក:-]។ baccalauréat, 1ère partie ស្នាតកប័ត្រភាគទី ១; baccalauréat, 2e partie ស្នាតកប័ត្រភាគទី ២ ។ baccalauréat de l'enseignement secondaire série classique ស្នាតកប័ត្រ

មធ្យមសិក្សាផ្នែកគន្លឹ ។ baccalauréat série mathématiques ស្នាតកប័ត្រផ្នែកគណិតសាស្ត្រ ។ baccalauréat série moderne ស្នាតកប័ត្រផ្នែកទំនើប ។ baccalauréat série philosophie ស្នាតកប័ត្រផ្នែកទស្សនវិជ្ជា ។ baccalauréat série sciences expérimentales ស្នាតកប័ត្រផ្នែកវិទ្យាសាស្ត្រពិសោធ

baccara *n.m.* បៀភ្នាក

bacchanal *n.m.* សូរសន្ធឹក

bacchanale *n.f.* ពិធីថ្វាយចំពោះសុភទេព ។ *Fig.* ការរាំលេកក្រៀវ

bacchante *n.f.* ស្ត្រីសុភទេព ។ *Fig.* ស្ត្រីប្រមឹក, ស្ត្រីចណ្ឌាល

Bacchus *n. prop.* សុភទេព

bâchage *n.m.* ការគ្របដោយសំពត់ ឬស្បែកក្រាស់

bâche *n.f.* សំពត់ឬស្បែកក្រាស់(សម្រាប់គ្របដំបូលរថយន្តឬនាវា); ឡាំងកញ្ចក់គ្របកូនរុក្ខជាតិ; ឡាំង; ថ្នូងម៉្យាង

bachelier, lière *n.* ស្នាតកៈ-តកា [-តៈ-កៈ, តៈ-កា]

bâcher *v.t.* គ្របដោយសំពត់ ឬ ស្បែកក្រាស់ (ឧ bâcher une voiture)

bachot *n.m.* នាវាតូច ។ *Arg.* ស្នាតកប័ត្រ

bachotage *n.m.* *Fam.* ការសិក្សាប្រូសៗដើម្បីប្រឡងស្នាតកប័ត្រ ។ *Par ext.* ការសិក្សាប្រូសៗ ដើម្បីប្រឡង

bachoteur *n.m.* អ្នកបើកនាវាតូច

bachotte *n.f.* ធុងដឹកនាំត្រីរស់

bacillaire *a.* *Minér.* ដែលមានរាងអាក់ ។ *Méd.* ដែលបង្កើតដោយទណ្ឌាណូ ។ *n.f.* សារាយម៉្យាង

bacille *n.m.* ទណ្ឌាណូ (អតិសុខុមប្រាណរាងដូចចង្កឹះត្រង់ឬកោង)

bacilliforme *a.* ទណ្ឌាណូសណ្ឋាន

bacillose *n.f.* រោគរបេង (ម.ព. tuberculose ផង)

bâclage *n.m.* ការខ្ទាស់រនុកទ្វារ ឬ បង្ហូច ; ការចងខ្សែសន្ទឹងបិទស្ទឹង ; ការធ្វើប្រហែលៗ

bâcle *n.f.* រនុកទ្វារ

bâcler *v.t.* ខ្ទាស់រនុកទ្វារ ឬ បង្ហូច; ធ្វើប្រហែលៗ (ឧ.bâcler un travail)

bâcleur *n.m.* អ្នកខ្ទាស់រនុកទ្វារ ឬ បង្ហូច; អ្នកធ្វើប្រហែលៗ

bacon *n.m.* (ពាក្យអង់គ្លេស) ខ្លាញ់ជ្រូក; ភ្លៅជ្រូកឆ្អើរ

bactéricide *a.* បេក្រាណូឃាត(ថ្នាំសម្លាប់បេក្រាណូ ឬ មីក្រុប)

bactérie *n.f.* បាក់តេរី (រ.វ. microbe)

bactérien, rienne *a.* នៃបាក់តេរី

bactériologie *n.f.* បាក់តេរីវិទ្យា

bactériologiste ឬ **bactériologue** *n.m.* បាក់តេរីវិទូ

bactrioles *n.f. pl.* កំទេចមាស

badaud, aude *n.&a.* អ្នកឈប់ឈរមើល ឬឈប់ឈរស្ដាប់; កញ្ជ្រោត

badaudage *n.m.* ការឈប់ឈរមើល ឬ ឈប់ឈរស្ដាប់

badauder *v.i.* ឈប់ឈរមើល; ឈប់ឈរស្ដាប់ ; បង្ខាតពេល

baderne *n.f. Mar.* ព្រួរចងកុំឲ្យនាវាកកិត ។ *Fig.* វត្ថុចាស់ប្រើមិនកើត ; មនុស្សកំព្រយ

badigeon *n.m.* ថ្នាំទឹកកំបោរ

badigeonnage *n.m.* ការលាបថ្នាំទឹកកំបោរ; ការលាបឱសថ

badigeonner *v.t.* លាបថ្នាំទឹកកំបោរ; លាបឱសថ (ឧ. badigeonner de teinture d'iode)

badigeonneur *n.m.* ជាងលាបថ្នាំ ; ជាងគំនូរមិនជំនាញ

badin, e *a.&n.* អ្នកចូលចិត្តលេងសើច (ឧ. esprit badin)

badin *n.m. Aviat.* នាឡិកាល្បឿន (អាកាសយាន)

badinage *n.m.* ការនិយាយលេងសើច; សំដីកំប្លែង

badine *n.f.* រំពាត់ទន់

badiner *v.i.* និយាយលេងសើច, និយាយកំប្លែង

badinerie *n.f.* អំពើលេងសើច; ការកំប្លែង; ល្បែងក្មេង

badminton *n.m.* បាតមិនតោន(ល្បែងសីម្យ៉ាងដើមកំណើតពីប្រទេសអង់គ្លេស)

bafouer *v.t.* ឡកឡឺយ; ប្រមាថ; ញាំញី

bafouillage *n.m.Fam.* សំដីឡប់ឡប; វាចាគ្មានឱតគ្មានភ័ន្ត

bafouiller *v.t.Fam.* និយាយឡប់ឡប

bafouilleur, euse *n. Fam.* អ្នកនិយាយឡប់ឡប

bâfre ឬ **bâfrée** *n.f.Pop.* ការស៊ីផឹក (ពាក្យសាមញ្ញ)

bâfrer *v.t. &i. Pop.* ស៊ីឡើបឡប់ (ពាក្យសាមញ្ញ)

bâfreur, euse *n. Pop.* អ្នកស៊ីឡើបឡប់; អ្នកល្មោភស៊ី (ពាក្យសាមញ្ញ)

bagage *n.m.* ភារវត្ថុ,ប្រដាប់អ្នកដំណើរ, អីវ៉ាន់ ។ *Fig.* plier bagage រត់

(ភៀសខ្លួន); ស្លាប់

bagarre *n.f. Fam.* ដំណើរពពាក់-ពពូន; ជំលោះតឹកកង

bagasse *n.f.* កាកអំពៅ

bagatelle *n.f.* អប្បគ្ឃវត្ថុ [អ័ប-ប៉ុក-យៈ-],របស់ឥតតម្លៃ;វត្ថុតម្លៃស្តួចស្តើង; វត្ថុភយរង ។ *Fig.* ការកំប៉ុកកំប៉ុក

bagnard *n.m.* អ្នកទោសឧក្រិដ្ឋ

bagne *n.f.* គុកអ្នកទោសឧក្រិដ្ឋ (នៅកំពង់ផែ)

bagnole *n.f. Fam.* ឡានមិនល្អ (ពាក្យសាមញ្ញ)

bagout ឬ **bagou** *n.m.* សំដីប៉ប៉ាច់-ប៉ប៉ោចឥតញញើត

baguage *n.m.* ការលាក់សំបកឈើ

bague *n.f.* ចិញ្ចៀន,ក្រវិល; ស្លាប់ផ្សិត; ស្រង

baguenauder *v.i.* លេងឥតការ

baguenauderie *n.f.* សំដីសារ៉ា

baguer *v.t.* បំពាក់ចិញ្ចៀន, ដាក់ក្រវិល ។ *Cout.* ដាន (ម.ព. faufiler ផង) ។ *Hort.* លាក់សំបកឈើ

baguette *n.f.* ចង្កឹះ

bagueur *n.m.* កាំបិតលាក់សំបកឈើ

baguier *n.m.* ប្រអប់ដាក់ចិញ្ចៀននឹងគ្រឿងអលង្ការផ្សេងៗ

bah! *int.* យីអើ! ។ ah bah! ល្មើយ!

bahut *n.m.* ហិបឈើ; ទូឈើ ។ *Arg.* សាលា

bahutier *n.m.* ជាងធ្វើហិប ឬ ទូឈើ

bai,e *a.* សម្បុរត្នោត (សេះ)

baie *n.f.* ឆកសមុទ្ទ ; ច្រក ឬ រង្វះទ្វារ បង្អួច

baie *n.f.* ផ្លែឈើសាច់ច្រើន

baignade *n.f.* ស្ពាន,ការងូតទឹក; ស្ពានផ្លាន, កំពង់ងូតទឹក

baignage *n.m.* ការផ្ងូតទឹក

baigner *v.t.* ផ្ងូតទឹក ។ *Fig.* ស្រោច, បញ្ជោក (ឧ. visage baigné de larmes មុខប្រឡាក់ទឹកភ្នែកជោក); ហូរកាត់ឬព័ទ្ធ (ឧ. la mer baigne la ville) ។ *v.i.* ត្រាំ (ឧ. ces fruits baignent dans l'eau de vie) ។ baigner dans le sang ប្រឡាក់ឈាមពេញខ្លួន ។ se baigner *v.pr.* ងូតទឹក, ស្រង់ទឹក (ឧ. il ne faut pas se baigner quand on vient de manger)

baigneur ,euse *n.* ស្នានិក-និកា, អ្នកងូតទឹក; អ្នកផ្ងូតទឹក ; នាយស្នានគ្រឹះ

baigneuse *n.f.* ស្នានពស្ត្រ (សំលៀកបំពាក់ងូតទឹក)

baignoire *n.f.* ស្ថានភាជន៍, អាងងូតទឹក; បន្ទប់មើលល្ខោនជាន់ក្រោម

bail *n.m.* ភតិសន្យា, កិច្ចសន្យាជួល (*pl.* des baux)

baille *n.f.* ធុង ។ *Arg.* សមុទ្រ; កប៉ាល់កញ្ចាស់

bâillement *n.m.* ការស្ងាប

bailler *v.t.* ប្រគល់ឲ្យ; បង្ខំឲ្យជឿ

bâiller *v.i.* ស្ងាប ។ *Par ext.* ហើប (ឧ. la porte bâille) (កុំថា: bâiller aux corneilles, ត្រូវថា: bayer aux corneilles)

bailleur, eresse *n.* ភតិសន្យាបតី-តានី (អ្នកជួលឲ្យ) ។ bailleur de fonds ភតិសន្យាបតីមូលធន, អ្នកជំហរចេញប្រាក់

bâilleur, euse *n.* អ្នកហៃស្ងាប

bâillon *n.m.* ឆ្នុកមាត់

bâillonnement *n.m.* ការចុកមាត់

bâillonner *v.t.* ចុកមាត់ (កុំឲ្យស្រែករួច) ។ *Fig.* បំបិទមាត់ (មិនឲ្យនិយាយ)

bain *n.m.* ទឹកងូត; ការងូតទឹក ។ bain de soleil ការប្រព្រឹត្តហាលថ្ងៃ ។ bain de vapeur ការផ្សង ។ *pl.* ស្ថានគ្រឹះ (គ្រឹះស្ថានងូតទឹក) ។ *Fig. & Fam.* être dans le bain ជាប់កុនក្នុងរឿងអ្វីមួយ ។ bain-marie ការចំហុយ; ឆ្នាំងរបួល (*pl.* des bains-marie)

baïonnette *n.f.* បៃយ៉ូណែត, លំពែងចំពុះទុង (សំរាប់ភ្ជាប់នៅចុងកាំភ្លើង)

baiser *v.t.* ថើប

baiser *n.m.* ការថើប ។ baiser de Judas ការថើបនៃមនុស្សក្បត់

baiseur, euse *n.* អ្នកហៃថើប

baisoter *v.t.* ថើបញយៗ

baisse *n.f.* ការស្រក (ឧ. la baisse des eaux); ការចុះថ្លៃ ។ jouer à la baisse លេងកំរៃពីការចុះដំឡៃនៃប្រាក់សាធារណៈ

baissement *n.m.* ការទម្លាក់ចុះ, ការបន្ទាប

baisser *v.t.* ទម្លាក់ចុះ (ឧ. baisser un store); ដាក់ចុះ, បន្ទាប (ឧ. baisser un toit) ។ *Fig.* baisser l'oreille អៀនខ្មាស ។ baisser pavillon ញ៉ម, ចុះចាញ់ ។ *v.i.* ស្រក (ឧ. les rivières baissent en été); ថយចុះ, អន់ថយ (ឧ. la vue baisse avec l'âge) ។ se baisser *v.pr.* ឱន, បន្ទាបខ្លួន

bajoue *n.f.* ថ្ពាល់កូនសត្វ ; ថ្ពាល់យារ (មនុស្ស)

bajoyer *n.m.* ជញ្ជាំងទប់ច្រាំងស្ទឹង

bal *n.m.* នាដសាល, រោងរាំ; ក្រុមរាំកំសាន្ត

balade *n.f. Pop.* ការដើរលេង

balader (se) *v.pr. Pop.* ដើរលេង

baladeur *a.* train baladeur គ្រឿងប្ដូរល្បឿន (រថយន្ត)

baladin, e *n.* ត្លុក , មនុស្សក្រមាច់

baladinage *n.m.* ពាក្យកំប្លែង; របរត្លុក ; ការកំប្លែងមិនស្រួល

baladiner *v.t.* ធ្វើត្លុក , កំប្លែង

balafre *n.f.* សម្លាកមុខ

balafré,e *a.* ដែលមានសម្លាកមុខ ។ *n.* អ្នកមានសម្លាកមុខ

balafrer *v.t.* ធ្វើឲ្យមានសម្លាកមុខ

balai *n.m.* អំបោស; កន្ទុយបក្សី; ពុងកន្ទុយផ្កៃ;រថយន្តក្រោយបង្អស់(ក្នុងក្បួនមួយ)។balai mécanique អំបោសយន្ត ។ manche à balai ដងអំបោស;ដៃចង្កូតយន្តហោះ ។ *Fig.* donner un coup de balai បណ្ដេញ (ភ្នាក់ងាររាជការ ឬ អ្នកបំរើ); ចាត់ការ ។ rôtir le balai រស់នៅដោយកយមាយ

balaiement *n.m.* ការបោស

balais *a.m.* ។ rubis balais ត្បូងទទឹមពណ៌ផ្កាឈូក

balan *n.m.* ម.ព. **ballant**

balance *n f* ជញ្ជីង ។ balance ordinaire ជញ្ជីងត្រាជូ។balance Roberval ជញ្ជីងថាស ។ balance romaine ជញ្ជីងដង ។ បដិមរូបតុលាការ;យុត្តិធម៌;តុល្យភាព ។ balance des comptes តុល្យភាពគណនី។balance d'inventaire តុល្យភាពបញ្ជីសារពើភណ្ឌ ។ balance de vérification តុល្យភាពនៃការមើលបញ្ជី ។ être en balance រារែក,ស្ទាក់ស្ទើរ ។ faire pencher la balanceឲ្យឈ្នះ។ mettre en balance ថ្លឹងមើល (រកល្អអាក្រក់) ។ mettre dans la balance ដាក់ផ្ទឹមគ្នា, គិតធៀបគ្នា ។ *Astr.* តុលារាសី (រាសីជញ្ជីង)

balancement *n.m.* ការយោល ។ *Fig.* ការរារែក

balancer *v.t.* យោល,យោគ(ឧ.le vent balance les arbres) ។ *Fig.* ត្រិះរិះ,ថ្លឹង (ឧ.balancer le pour et le contre); ធ្វើឲ្យមានតុល្យភាព

(ឧ. période bien balancée); ទូទាត់ (ឧ. balancer un compte); លុបលាង (ឧ. ses vertus balancent ses vices) ។ *Fam.* បណ្ដេញចោល, ទាត់ចោល ។ *v.i.* រារែក, ស្ទាក់ស្ទើរ (ឧ. il n'y a pas à balancer); មិនទាន់ប្រាកដ (ឧ. la victoire balança longtemps) ។ se balancer *v.pr.* យោល; យោលខ្លួន; ដើរយោលខ្លួន (ឧ. l'ours se balance en marchant) ។ *Pop.* s'en balancer ចំអកឡ

balancier *n.m.* ប៉ោល

balancier *n.m.* ដាងជញ្ជីង

balancine *n.f.* ខ្សែសារក្ដោង ។ *pl.* *Arg.* ខ្សែព្រយុង

balançoire *n.f.* ទោង ។ *Fig.* សំដីឥតខ្លឹមសារ

balant *n.m.* ម.ព. **ballant**

balayage *n.m.* ការបោស

balayer *v.t.* បោស; បោកលើ (ឧ. les vagues balaient le pont) ។ *Fig.* ដេញ

balayette *n.f.* អំបោសតូច

balayeur, euse *n.* អ្នកបោស

balayeuse *n.f.* អំបោសយន្ត; រំយោលជាយសំពត់

balayures *n.f. pl.* សំរាមដែលបោសប្រមូល

balbutie *n.f.* ភាពអ្នកនិយាយប្រប៉ិបប្រប៉ុប (ឧ. la balbutie de l'enfance, de la vieillesse)

balbutiement *n.m.* សំដីប្រប៉ិបប្រប៉ុប

balbutier *v.i.* និយាយប្រប៉ិបប្រប៉ុប ។ *v.t.* ថ្លែងដោយប្រប៉ិបប្រប៉ុប (ឧ. balbutier un compliment)

balbutieur, euse *n.* អ្នកនិយាយប្រប៉ិបប្រប៉ុប

balcon *n.m.* ហើយ, ញក

bale *n.f.* ម.ព. **balle**

baleine *n.f.* ពិទូង (ត្រីសមុទ្រធំសម្បើម); ឆ្អឹង (ឧ. baleines de parapluie ឆ្អឹងឆ័ត្រ; baleine de corset ឆ្អឹងអាវទ្រនាប់ (សម្រាប់សឹកឡើង)

baleiné, e *a.* ដែលមានឆ្អឹង (ឧ. corsage baleiné)

baleineau *n.m.* កូនពិទូង

baleinier *n.m.* នាវានេសាទពិទូង; អ្នកនេសាទពិទូង

baleinière *n.f.* *Mar.* ទូកនេសាទពិទូង

balèvre *n.f.* បបូរមាត់ក្រោម ។ *pl.*

បបួរមោតទាំងពីរ ។ *Constr.* ថ្មឬឥដ្ឋដែលលៀនចេញ

balisage *n.m.* ការបោះពោង; ពោងសម្គុទ្ទ

balise *n.f.* ពោង, សញ្ញានាំផ្លូវនាវា ឬអាកាសយាន

balisement *n.m.* ការបោះពោង

baliser *v.t.* បោះពោង

baliseur *n.m.Mar.* អ្នកបោះ ឬថែពោង; នាវាបោះពោង

baliste *n.f.* ស្នាយន្ត(ដែលពួករ៉ូម៉ាំងប្រើក្នុងសង្គ្រាម)

balistique *a.* នៃការបាញ់ (ឧ.théorie balistique)

balivage *n.m.* ការជ្រើសដើមឈើដែលត្រូវទុក (ក្នុងព្រៃគុប)

baliveau *n.m.* ដើមឈើបម្រុងទុក (ក្នុងព្រៃគុប) .

baliverne *n.f.* សំដីឥតសព្វឥតសារ

baliverner *v.i.* និយាយការឥតប្រយោជន៍

balkanique *a.* នៃប្រទេសប័លកង់

ballade *n.f.* កាព្យនិទានម្យ៉ាង

ballant,e *a.* ដែលយោល ។ aller les bras ballants ដើរដៃទទេ ។ *n.m.* ចលនាយោល (ឧ.véhicule qui a du ballant)

ballast *n.m.* ថ្មីធារ

ballastage *n.m.* ការក្រាលថ្មធារ

balaster *v.t.* ក្រាលថ្មធារ (ឧ. ballaster la voie); ដឹកថ្មធារ

ballastière *n.f.* កន្លែងយកថ្មធារ

balle *n.f.* ឃ្លី, កូនបាល់; គ្រាប់កាំភ្លើង ។ balle traçante គ្រាប់កាំភ្លើងភ្លឺ ។ កញ្ចប់ទំនិញធំៗ; ហុង ។ *Fig.* renvoyer la balle សងសំដីភ្លាមៗ ។ à vous la balle ដល់វេនអ្នកម្ដង ។ prendre la balle au bond ឆ្លៀតយកឱកាសល្អ

balle *n.f.* អង្កាម

baller *v.i.* រាំ, លោត

ballerine *n.f.* នាដិកា

ballet *n.m.* របាំ ។ corps de ballet ក្រុមល្ខោន (អ្នករាំ) ។ le corps du ballet royal ក្រុមល្ខោនព្រះរាជទ្រព្យ

ballon *n.m.* បាល់ធំ ; គោមហោះ ; ដបកំប៉ោងធំ; កំពូលភ្នំមូល (ឧ.ballon d'Alsace) ។ pneu ballon កង់រថយន្តឬទោចក្រយាន ។ ballon d'essai, ballon-pilote គោមល្បង (កូនគោមបង្ហោះស្ទង់ខ្យល់) ។ *Fig.* ballon d'essai ការស្ទង់យោបល់

ballonné,e *a.* ប៉ោង, តឹង

ballonnement *n.m.* ការហើមពោះ

ballonner *v.t.* បំប៉ោង

ballonnet *n.m.* កូនគោមហោះ

ballonnier *n.m.* អ្នកធ្វើបាល់

ballon-sonde *n.m.* គោមស្ទង់ (*pl.* des ballons-sondes)

ballot *n.m.* កញ្ចប់, បង្វិច ។ *Pop.* មនុស្សឆ្កួង

ballottage *n.m.* ការយោល, ការញ្ញួយ ។ *Pol.* ការបោះឆ្នោតមិនបានលទ្ធផល (ដោយបេក្ខជនមិនបានសន្លឹកឆ្នោតគ្រប់ចំនួន) (ឧ. scrutin de ballottage)

ballottement *n.m.* ការយោល

ballotter *v.t.* ធ្វើឲ្យរញ្ជួយ (ឧ. la mer ballotte les gros navires) ។ *Fig.* ballotter quelqu'un បញ្ជូនពីម្នាក់ទៅម្នាក់ ។ ballotter des candidats បោះឆ្នោតឲ្យដោយចំនួនមិនគ្រប់ (បេក្ខជនត្រូវឈរឈ្មោះឲ្យបោះឆ្នោតឡើងវិញ) ។ *v.i.* យោល, រញ្ជួយ (ឧ. cette porte ballotte)

ballotin *n.m.* កូនកញ្ចប់, កូនបង្វិច

balluchon ឬ **baluchon** *n.m.* *Fam.* បង្វិចខោអាវ (ពាក្យសាមញ្ញ)

balnéaire *a.* ស្ថានីយ,នៃការងូតទឹក ។ une station balnéaire ស្ថានីយងូតទឹក

balnéation *n.f.* ការព្យាបាលរោគដោយងូតទឹក

balnéatoire *a.* ដែលផ្អែកលើការងូតទឹក (ឧ. thérapeutique balnéatoire)

balnéothérapie *n.f.* ស្ពានតិកិច្ចា, ការព្យាបាលរោគដោយងូតទឹក

balourd,e *a.&n.* សំពឹក, ភ្លើ, កំភោល (ឧ.se conduire en balourd)

balourdise *n.f.* ការធ្វើឬការនិយាយដោយគ្មានគិត

balsamier ឬ **baumier** *n.m.* ដើមឈើជ័រក្រអូប

balsamifère *a.* ដែលមានជ័រក្រអូប

balsamique *a.* ដែលមានលក្ខណៈដូចជ័រក្រអូប; ក្រអូប (ឧ. odeur balsamique) ។ ដែលធ្វើឲ្យស្រាក (ឧ.vertu balsamique) ។ *n.m.* ថ្នាំរែត

baluchon *n.m.* ម.ព. balluchon

balustrade *n.f.* ជើងទៀន ។ *Par ext.* បង្កាន់ដៃ

balustre *n.m.* បង្កាលបង្កាន់ដៃ

balustrer *v.t.* ដាក់បង្កាន់ដៃ

balzane *n.f.* ផ្កាយជើងសេះ

bamboche *n.f.* អាយ៉ង; ឫស្សីពន្លុង ។ *Fam.* អនាចារ; មនុស្សរូបអាក្រក់

bambocher *v.i.Pop.* ប្រព្រឹត្តអនាចារ

bambocheur,euse ឬ **bambochard,e** *a.&n. Fam.* មនុស្សអនាចារ

bambin,e *n. Fam.* ក្មេងតូច

bambou *n.m.* ឫស្សី

ban *n.m.* បទបញ្ជាប្រកាសជាសាធារណ៍។ *Par dériv.* ទណ្ឌកម្ម (គឺការពិន័យ ឬ ការនិរទេស ព្រោះរំលងបទបញ្ជា) ។ *Par ext.* ការលាក់ឡាយឡង; ការប្រកាសអាពាហ៍ពិពាហ៍; ការកេណ្ឌធ្វើទាហាន ។ mettre quelqu'un au ban de l'Empire ប្រកាសថា អ្នកឯណាមួយប្រាសចាកសិទ្ធិ (ទំនៀមទម្លាប់ប្រទេសអាល្លឺម៉ាញ); បណ្ដេញចេញពីស្រុក, និរទេស។ *Mil.* ការកេទស្គរ ឬ ផ្លុំត្រែ (ក្នុងពិធីបំពាក់គ្រឿងឥស្សរិយយស ឬ ប្រកាសសាលក្រម ។ល។)(ឧ. ouvrir le ban; fermer le ban) ។ *Par ext. & Fam.* ការទះដៃបន្ទរដោយត្រូវចង្វាក់ (ឧ. un ban pour l'orateur) ។ rupture de ban ការលបចូលមកនៅស្រុកវិញ (អ្នកត្រូវនិរទេស) ។ convoquer le ban et l'arrière-ban កេណ្ឌធ្វើទាហានទាំងអស់គ្នា ។ le ban et l'arrière ម.ព. arrière-ban

banal,e,aux *a.* ធម្មតា; សាមញ្ញ; ទាបថោក

banalement *adv.* ជាធម្មតា; ជាសាមញ្ញ

banaliser *v.t.* ធ្វើឲ្យទៅជាសាមញ្ញ

banalité *n.f.Fig.* ភាពធម្មតាឬសាមញ្ញ; វត្ថុធម្មតា ឬ សាមញ្ញ

banane *n.f.* ផ្លែចេក ។ *Fam.* ការតែងលំអ

bananeraie *n.f.* ចំការចេក

bananier *n.m.* ដើមចេក

banban *a.&n. Pop.* ខ្ញើច

banc *n.m.* ជើងម៉ា, កៅអី, តាំង; តុជាង (ឧ.banc de tourneur)។ *Mar.* កន្លែងទឹករាក់ ។ petit banc កូនកៅអី, កូនតាំង ។ banc de coraux ថ្មផ្កាថ្ម ។ banc de sable ដីកខ្សាច់។ banc de poissons ហ្វូងត្រី ។ *Pl.&Fig.* être sur les bancs នៅរៀនសាលា ។ banc d'essai តុល្បងម៉ាស៊ីន

bancaire *a.* នៃធនាគារ

bancal,e,als *a.&n.* ដែលមានជើងវៀច (ឧ. mendiant bancal ; une chaise bancale) ។ *n.m.* ដាវ ង

bancelle *n.f.* កូនកៅអី

bancroche *a.&n.* វៀច, រមួល

bandage *n.m.* ការរុំ; វណ្ឌកង់ ។ *Chir.* ស្នាប់

bandagiste *n.&a.* អ្នកធ្វើឬលក់សំពត់រុំ ឬ ស្នាប់

bande *n.f.* បន្ទះសំពត់សំរាប់រុំ; ចំរៀក; ឆ្នូត (ឧ. une bande colorée); ខ្សែ, បន្ទះ ។ *Par ext.* អ្វីៗតូចវែង (ឧ. une bande de terre, de gazon) ។ ខ្សែភាពយន្ត ។ *Radio* ផ្លូវ(រលកធាតុអាកាស) ។ *Mar.* ការផ្អៀង (ឧ. donner de la bande ផ្អៀង) ។ *Art mil.* ខ្សែប្រហោកគ្រាប់កាំភ្លើង (ឧ. bande de mitrailleuse) ។ bande molletière ម.ព. molletière

bande *n.f.* ហ្វូង, បន, ក្រុម (ឧ. une bande de voleurs) ។ faire bande à part នៅបែកពីគេ, នៅក្រុមដោយឡែក

bandeau *n.m.* ឈ្នួត,សំពត់ចងបិទមុខ។ *Fig.* ការវង្វេងស្មារតី (ឧ. le bandeau de l'erreur)។bandeau royal ក្បាំងណា ។ *Arch.* ខ្សែ (ក្បាច់ខ្ពស់វែងដូចខ្សែ)

bandelette *n.f.* បន្ទះតូច, ចំរៀកតូច

bander *v.t.* វណ្ឌា, រុំ (ឧ. bander une blessure) ។ bander les yeux បិទមុខ ។ យឹត (ឧ. bander un arc យឹតធ្នូ)

bandereau *n.m.* ខ្សែស្ពាយត្រែ

banderole *n.f.* បដា; ខ្សែស្ពាយកាំភ្លើង

bandit *n.m.* ចោរប្លន់; មនុស្សខូច

banditisme *n.m* ភាពស្រុកកើតចោរប្លន់; ភាព-លក្ខណៈ ឬ របរនៃចោរប្លន់

bandoulière *n.f.* ខ្សែស្ពាយកាំភ្លើង។ en bandoulière ស្ពាយឆៀង

banian ឬ **figuier,arbres des banians** *n.m.* ដើមពោធិ៍

banjo *n.m.* បង់ហ្សូ (ចាប៉ីម្យ៉ាង)

bank-note *n.f.* ធនប័ត្រអង់គ្លេស(*pl.* des bank-notes)

banlieue *n.f.* ជាយក្រុង

banlieusard *n.m.* *Fam.* ជនជាយក្រុង

banne *n.f.* រទេះដឹកធ្យូង;កញ្ជេ ឬ ដាល;

សំពត់គ្របទំនិញ

banner *v.t.* គ្របដោយសំពត់

banneton *n.m.* ទ្រុងត្រោះត្រី;កញ្ជ្រែង ដាក់ម្សៅនំប៉័ងឲ្យឡើង

bannette *n.f.* កញ្ជេ ឬ ដាលតូច

banni,e *a.&n.* ដែលត្រូវបំបរបង់ ។ *Fig.* ដែលគេប្រានចោល

bannière *n.f.* ទង់នាវា, ទង់ ។ *Fig.* បក្សពួក (ឧ. se ranger sous la bannière de...) ។ la croix et la bannière ទម្រង់ការគ្រប់យ៉ាង; *au fig.&iron.* ការទទួចខ្លាំងណាស់ (ឧ.pour le décider à agir, il a fallu la croix et la bannière)។*Pop.* អាវស៊ីមីស,អាវទ្រនាប់ (ឧ. se promener en bannière)

bannir *v.t.* បំបរបង់,បណ្ដេញ ។ *Fig.* ប្រានចោល (ឧ. bannir toute crainte)

bannissement *n.m.* ការបំបរបង់,ការបណ្ដេញ; ភាពអ្នកត្រូវបំបរបង់; ទោសបំបរបង់

bannisseur *n.m.* អ្នកបំបរបង់

banque *n.f.* ធនាគារ, ជំនួញប្រាក់ ។ banque d'affaires ធនាគារភារកិច្ច ។ banque de dépòt ធនាគារទិក្ខិត្តភណ្ឌ

banquer *v.t.* ដាក់ជើងម៉ាឬកៅអី (ដលយាន)

banqueroute *n.f.* ទិទ្ធិនភាព ។ *Fig.* ការមិនកាន់ពាក្យសន្យា

banqueroutier,ère *n.* ទិទ្ធិន

banquet *n.m.* ការជប់លៀង

banqueter *v.t.* ជប់លៀង

banquette *n.f.* ជើងម៉ាមានពូក

banquier,ère *n.* ធនាគារិក-រិកា (អ្នកកាន់កាប់ធនាគារ)

banquise *n.f.* គំនរទឹកកក (តាមឆ្នេរ ឬ ក្នុងសមុទ្រ)

banquiste *n.m.* ជាំហ៊ុ; គ្រូបោកប្រាស។ *Fig.* អ្នកសន្យាមិនបានការ

baobab *n.m.* ដើមឈើម្យាំងធំសំបើម (ឧ. le baobab dépasse 20 mètres de circonférence)

baptême *n.m.* ការលាងអាទិបាប(បាបដើម,បាបពីកំណើត តាមសាសនាកាតូលិក) ។ baptême d'un navire ការប្រសិទ្ធនាវា ។ baptême de l'air ការជិះយន្តហោះដំបូង ។ recevoir le baptême de feu ចូលច្បាំងដំបូង ។ nom de baptème

ប្រសិទ្ធនាម, (នាមដែលដាក់ក្នុងពិធីប្រសិទ្ធ)

baptiser *v.t.* លាងអាទិបាប; ប្រសិទ្ធ; ដាក់នាម ។ *Fam.* baptiser du vin លាយទឹកស្រា

baptismal,e, aux *a.* នៃការលាងអាទិបាប; នៃការប្រសិទ្ធ; សម្រាប់លាងអាទិបាប; សម្រាប់ប្រសិទ្ធ ។ fonts baptismaux អាងលាងអាទិបាប

baptistaire *a.* ដែលបញ្ជាក់ការប្រសិទ្ធ

baptistère *n.m.* អគារសម្រាប់ប្រសិទ្ធ ឬ សម្រាប់លាងអាទិបាប

baquet *n.m.* ផាំងឈើតូច

baqueter *v.t.* ដួសទឹកក្នុងផាំងឈើ (ឧ. baqueter de l'eau)

bar *n.m.* បានីយដ្ឋាន ។ bar-restaurant បានីយភោជនីយដ្ឋាន

baragouin *n.m.* ភាសាមិនត្រឹមត្រូវ ហើយស្ដាប់មិនបាន

baragouinage *n.m.* *Fam.* ការនិយាយភាសាមិនត្រឹមត្រូវ ហើយស្ដាប់មិនបាន

baragouiner *v.t.* &*i.* និយាយភាសាមិនត្រឹមត្រូវ (ឧ. baragouiner l'anglais)

baragouineur,euse *n.* អ្នកនិយាយភាសាមិនត្រឹមត្រូវ

baraque *n.f.* ខ្ទម, ផ្ទះឈើតូច ។ *Fig.* ផ្ទះមិនស្អាត

baraquement *n.m.* ផ្ទះឈើតូច (សម្រាប់ទាហាន - អ្នកភៀសខ្លួន ឬ អ្នកជម្ងឺ)

baraquer *v.t.* ឲ្យនៅផ្ទះឈើ (ឧ. baraquer un régiment) ។ *v.i.* នៅក្នុងផ្ទះឈើ (ឧ. troupes qui baraquent); អង្គុយ (អូដ្ឋ)

barattage *n.f.* ឬ **barattement** *n.m.* ការវីកទឹកដោះធ្វើប៊ឺរ ។ barattage de l'Océan ការកូរទឹកអម្រឹត

baratte *n.f.* ធុងកូរទឹកដោះធ្វើប៊ឺរ

baratter *v.t.* វីកទឹកដោះធ្វើប៊ឺរ

baratteur,euse *n.* អ្នកវីកទឹកដោះធ្វើប៊ឺរ, ម៉ាស៊ីនវីកទឹកដោះធ្វើប៊ឺរ

barattin ឬ **baratin** *n.m.* *Arg.* អំនួត

barattiner ឬ **baratiner** *v.i.* *Arg.* អួត

baratton ឬ **baraton** *n.m.* ឈើវីកទឹកដោះ

barbant,e *a.* *Pop.* ដែលឲ្យធុញទ្រាន់

barbare *a.*&*n.* អនារ្យ ។ *Fig.* ឃោរឃៅ; ឥតមនុស្សធម៌; ខុស (ឧ. terme barbare ។ *n.m. pl.*

អនារ្យប្រជាគម

barbarement *adv.* ដោយឃោរឃៅ

barbaresque *a.* ជារបស់អនារ្យប្រជា-គម (ឧ. les Etats barbaresques) ។ *n.* អនារ្យប្រជាគម

barbarie *n.f.* អនារ្យធម៌ ។ *Fig.* អំពើឃោរឃៅ; អមនុស្សធម៌

barbariser *v.t.* ធ្វើឲ្យអស់អារ្យធម៌; ធ្វើឲ្យកាន់អនាចារ

barbarisme *n.m.* ពាក្យគ្មានក្នុងភាសា; ពាក្យប្រើខុសន័យ

barbe *n.f.* ពុកចង្កា,អមគាង ។ *Fig.* ផ្សិត; ស្នាមហៀរពុម្ព (ឧ. barbe d'un pièce de métal); កេម (ឧ. barbe d'un épi) ។ barbe d'une plume ពុកស្លាប ។ *n.f.* *Pop.* សេចក្ដីអផ្សុក ។ barbe grise មនុស្សចាស់ (ពុកចង្កាស្កូវ) ។ *Fig.* rire dans sa barbe សើចក្នុងពោះ ។ agir à la barbe de quelqu'un ស៊ីក្រោមភ្នែក ។ faire la barbe à quelqu'un ឈ្នះ, ខ្លាំងជាង

barbelé,e *a.* ដែលមានទំពក់ - ផ្លៀង ឬ បន្លា ។ fil de fer barbelé លួសបន្លា

barbelure *n.f.* ភាពមានទំពក់-ផ្លៀង ឬ បន្លា

barber *v.t. Pop.* ធ្វើឲ្យអផ្សុក ។ se barber *v.pr.* អផ្សុក

barbet,ette *n.&a.* ឆ្កែម្យ៉ាងរោមស្រមូវ

barbiche *n.f.* ពុកចង្កា

barbichon,barbichet ឬ **barbiche** *n.m.* កូនឆ្កែរោមស្រមូវ

barbier *n.m.* ជាងកោរពុកមាត់ពុកចង្កា

barbifier *v.t. Fam.* កោរពុកមាត់ពុកចង្កា; កោរ

barbille *n.f.* ស្នាមហៀរពុម្ព

barbillon *n.m.* ផ្លៀង; ពុកមាត់ត្រី

barbon *n.m.* មនុស្សចាស់

barbotage,barbotement *n.m.* ការកញ្ជ្រោកទឹក,ការលេងទឹក (ឧ. le barbotage est naturel aux canards) ។ *Arg.* ការលួច

barboter *v.i.* កញ្ជ្រោកទឹក;លេងទឹក (ឧ. les canards aiment à barboter) ។ *Par ext.* លុយភក់ ។ *Chim.* ផុស (ឧ. faire barboter un gaz dans l'eau) ។ *Fam. & fig.* និយាយទទាក់ទទាម; រស់នៅដោយរហេមរហាម ។ *v.t. Arg.* លួច

barboteur *n.m.* ទាស្រុក ។ *n.f.*

សំលៀកបំពាក់ស្រុយទឹក; ម៉ាស៊ីនបោកខោអាវ

barbotière *n.f.* គ្រាំងសម្រាប់ទាលេងទឹក; ថាំងដាក់ទឹកឲ្យសត្វផឹក

barbouillage ឬ **barbouillis** *n.m.* ការព្រលាំងពណ៌; រូបវិចិត្ររាក្រក់; អក្សរអាក្រក់ ។ *Fig.* សំដីរដាក់រដុប

barbouillé,e *a.* ព្រលូស, ប្រឡេកប្រឡាក, ក្រវេមក្រវាម; ជ្រមូស

barbouiller *v.t.* ធ្វើឲ្យប្រឡាក់, ធ្វើឲ្យខូច, ព្រលាំងពណ៌, ផាត់ពណ៌ខ្ជីខ្ជា; ធ្វើឲ្យល្អក់ (ចិត្ត) (ឧ. barbouiller le cœur) ។ *Fig.* barbouiller du papier សរសេរអក្សរអាក្រក់; ដាក់សេចក្ដីមិនល្អ ។ *v.i.* ថាមិនច្បាស់

barbouilleur,euse *n.* អ្នកធ្វើឲ្យប្រឡាក់ ។ *Fig.* ជាងគំនូរមិនប៉ិនប្រសប់; អ្នកនិពន្ធមិនជំនាញ; អ្នកនិយាយច្រើនស្ដាប់មិនបាន

barbu,e *a.* ដែលមានពុកមាត់ពុកចង្កា

barbule *n.f.* រោមស្លាប

barcarolle *n.f.* ចម្រៀងអ្នកទូកប្រទេសវេនីស

barcelonnette *n.f.* ម.ព. bercelonnette

bard ឬ **bar** *n.m.* ឈើស្នែងម្យ៉ាង (ហៅ bayart ឬ boyart ក៏បានដែរ)

barda *n.m.* *Pop.* បរិក្ខារទាហាន

bardage *n.m.* ការសែងដោយឈើស្នែង

barde *n.f.* គ្រោះពាសទ្រូងសេះចម្បាំង; បន្ទះខ្លាញ់ស្រោបសាច់ខ្វៃ

bardé,e *a.* ដែលពាសគ្រោះ; ដែលស្រោបខ្លាញ់ (ឧ. caille bardée)

bardelle *n.f.* អានសេះធ្វើពីសំពត់ញាត់គ

barder *v.t.* ពាសដែក, ស្រោបគ្រោះ (ឧ. barder de fer un chevalier); ស្រោបខ្លាញ់ (ឧ. barder une volaille)

barder *v.t.* សែងដោយឈើស្នែង

barder *v.imp.* *Arg.* ប្រឹងអស់ទំហឹង

bardeur *n.m.* អ្នកសែងដោយឈើស្នែង

bardot ឬ **bardeau** *n.m.* សេះទេសកាត់ពីសេះឈ្មោលនឹងលាញី

barème ឬ **barrème** *n.m.* តារាងអត្រា

baréter *v.i.* ម.ព. barrir

barguignage *n.m.* ការរារែក

barguigner *v.i.* រារែក

barguigneur,euse *a.* អ្នករារែក

baricaut *n.m.* កូនធុងឈើ

baril *n.m.* ធុងឈើតូច

barillage *n.m.* ការដាក់ធុង

barillet *n.m.* កូនធុងឈើ

barilleur ឬ **barilier** *n.m.* ជាងធុងឈើ

bariolage *n.m.* ការចម្រុះពណ៌មិនស៊ីគ្នា

bariolé,e *a.* ចម្រុះពណ៌មិនស៊ីគ្នា

barioler *v.t.* លាបចម្រុះពណ៌មិនស៊ីគ្នា

bariolure *n.f.* ភាពចម្រុះពណ៌មិនស៊ីគ្នា

barlong,gue *a.* ញយ (វែងម្ខាង) (ឧ. un châle barlong)

barman *n.m.* អ្នកកាន់កាប់ជានីយដ្ឋាន; អ្នកបម្រើក្នុងជានីយដ្ឋាន (*f.* barmaid)

barne *n.f.* ស្រែអំបិល

barographe *n.m.* នាឡិកាស្ទង់កំពស់យន្តហោះ

baromètre *n.m.* ប្រដាប់ស្ទង់ធាតុអាកាស

barométrique *a.* នៃប្រដាប់ស្ទង់ធាតុអាកាស (ឧ. observations barométriques)

baron *n.m.* បារ៉ុង (អភិជន)

baronnage *n.m.* ឋានន្តរបារ៉ុង; អង្គបារ៉ុង

baronne *n.f.* ភរិយាបារ៉ុង

baronnie *n.f.* ដែនដីបារ៉ុង

baroque *a.* មិនត្រឹមត្រូវ; ប្លែក (ឧ. idée baroque)

barouf ឬ **baroufle** *n.m.Pop.* ស្ងូរអ៊ូអែ

barque *n.f* ទូក ។ *Fig.* ចរិយា;ផលប្រយោជន៍ (ឧ. bien mener sa barque)

barquette *n f.* កូនទូក; នំរាងដូចទូក

barrage *n.m.* ការរាំង; របាំង; ទំនប់ទឹក; ធ្នស់ ។ *Mil.* tir de barrage ការបាញ់រាំង

barre *n.f.* ដុំវែង (ឧ. une barre de fer); បន្ទាត់គូសដោយទឹកខ្មៅ; រនុក; របាំង ។ paraître à la barre បង្ហាញខ្លួនចំពោះមុខចៅក្រម ។ *Mar.* នៃចង្កូតនាវា; ផ្លូកខ្សាច់ខាំងមាត់ទន្លេ;រលកខ្ទប់ច្រាំង។ barre de justice ខ្នោះជើង ។ *pl.* ល្បែងក្មេងរត់ប្រណាំង ។ avoir barre sur quelqu'un មានអំណាចគ្របសង្កត់លើ ។ *Mus.* ឃ្នង ។ double barre ឃ្នងពីរ ។ barre de mesure របាំង

barreau *n.m.* រនុកតូច ។ *Fig.* កៅអីសម្រាប់ស្មាក្ដី; វិជ្ជាជីវៈស្មាក្ដី (ឧ. entrer dans le barreau ធ្វើស្មាក្ដី)

barrême *n.m.* ម.ព. barème

barrement *n.m.* ការឆូតបន្ទាត់ទឹកខ្មៅ

barrer *v.t.* ញៀរនុក; ទស់; រាំង,ករាំង; ឆូតបន្ទាត់ (ឧ.barrer un chèque);

លុប ។ *v.i.* កាន់ចង្កូតនាវា

barrette *n.f.* កាតឹប។ *Fig.* parler à la barrette de quelqu'un ទះកំផ្លៀង(ឲ្យធ្លាក់កាតឹបពីលើក្បាល) ។ កាតឹបក្រហមរបស់ការឌីណាល ។ recevoir la barrette ត្រូវតែងតាំងជាការឌីណាល

barrette *n.f.* ខ្ទុកក្តួច, កន្ទាស់ (គ្រឿងអលង្ការ)

barreur *n.m.* អ្នកកាន់ចង្កូតនាវា

barricade *n.f.* គ្រឿងទស់ទាត

barricader *v.t.* សង់គ្រឿងទស់ទាត ។ barricader une porte ទាស់ទ្វារយ៉ាងមាំ ។ se barricader *v.pr.* ការពារខ្លួនដោយសង់គ្រឿងទស់ទាត; មិនព្រមឲ្យគេជួប

barrière *n.f.* របង,រនាំង។*Fig.* ឧបសគ្គ, ទំនាស់ (ឧ. les lois sont des barrières contre le crime)។ barrière douanière រនាំងគយ

barrique *n f* ធុងឈើ (ចំណុះពី២០០ ល.ទៅ២៥០ល.); វត្ថុដាក់ក្នុងធុង

barrir *v.i.* កង្កួច (ដំរីស្រែក)

barrit ឬ **barrissement** *n.m.* កង្កួចដំរី (សំរែកដំរី)

barycentre *n.m.* ចំណុចនៃភារពល (ម.ព.centre de gravité ផង)

barymétrie *n.f.* ការមាត្រវិធី

bas,basse *a.* ទាប; ក្រោម (bas officier; bas peuple); ថោកទាប (âme basse); សាមញ្ញ(ឧ. style bas);ថោក(ឧ.à bas prix);អាប់ឱន (ឧ.bas-Empire); តិច,ស្រួល (ឧ.voix basse) ។ temps bas មេឃទ្ងំម ។ avoir la vue basse មើលមិនឃើញឆ្ងាយ ។avoir l'oreille basse, la tête basse ខ្មាសអៀន, ដាក់មុខ ។ bas âge វ័យក្មេង ។ mer basse សមុទ្ទទឹកនាច។ ce bas monde ពិភពលោក, លោកនេះ ។ faire main basse លួច, ប្លន់; សម្លាប់ ។ *adv.* parler bas និយាយតិចៗ ។ mettre bas les armes ទម្លាក់អាវុធ។mettre bas កើតកូន (សត្វ) ។ traiter de haut en bas ប្រព្រឹត្តទៅលើដោយក្រអឺតក្រអោង ។ ce malade est bien bas ជម្ងឺនេះជាបណាស់ហើយ (ជិតស្លាប់ហើយ)។ à bas! បរាជ័យ! (សំរែកសំដែងសេចក្តីមិនយល់ព្រម) ។ être à bas ហិនហោច, ធ្លាក់ក្រ ។ *loc.adv.* en bas, par en bas

ខាងទាប, ខាងក្រោម

bas *n.m.* ចំណែកខាងទាប ឬ ខាងក្រោម (ឧ.le bas du visage) ។ bas de l'eau ទឹកនាច

bas *n.m.* ស្រោមជើងវែង (ឧ.bas de laine, de fil, de coton, de soie)។ bas de laine ប្រាក់សំចៃ

basal,e,aux *a.* ពីមូលដ្ឋាន,ពីខាងក្រោម (ឧ. le polypier s'accroit par gemmation basale irrégulière)

basalte *n.m.* ថ្មពពុះ

basaltique *a.* នៃថ្មពពុះ

basane *n.f.* ស្បែកចៀមសម្លាប់

basané,e *a.* ខ្មៅស្រអែម, ដាំនែង

basaner *v.t.* ធ្វើឲ្យមានសម្បុរខ្មៅស្រអែម ឬ ដាំនែង

bas-bleu *n.m.* ស្ត្រីអ្នកនិពន្ធអួតចំណេះ (*pl.* des bas-bleus)

basculaire *a.* នៃជញ្ជីងប៉ុង;ជាក់ប៉ើក(ឧ. mouvement basculaire) ។ pont bascule ជញ្ជីងស្ពាន

bascule *n.f.* ជញ្ជីងប៉ុង

basculement *n.m.* ការបំបះ; ការធ្វើជាក់ប៉ើក

basculer *v.i.* ធ្វើជាក់ប៉ើក; បំបះ; ធ្លាក់

basculeur *n.m.* គ្រឿងបំបះ (រទេះជាដើម) (ហៅ culbuteur ក៏បានដែរ)

base *n.f.* ជាត ។ *Fig.* មូលដ្ឋាន (ឧ. la justice est la base d'un Etat) ។ éducation de base ការអប់រំមូលដ្ឋាន ។ *Gram.* ធាតុគុណ ។ *Chim.* ជាស។ *Mil.* base militaire ស្ថានទ័ព ។ base de feux មូលដ្ឋានបាញ់ (ការបាញ់បម្រុះដើម្បីគាំពារការវាយលុក) ។ base décimale មូលដ្ឋានទសភាគ

baser *v.t.* ផ្អែកលើ ។ se baser *v.pr.* អាងលើ

bas-fond *n.m.* ទំនាប,អន្លង់ ។ *Fig.* & *pl.* ប្រជាជនជាន់ទាប (*pl.* des bas-fonds)

basket-ball *n.m.* កីឡាបាល់បោះ

basoche *n.f.* *Fam.* ប្រជុំអ្នកច្បាប់

basochien,enne *a.&n.* នៃប្រជុំអ្នកច្បាប់

basquet *n.m.* ជាលភ្លែកក្រូច (ប្រកផ្លែឈើ)

bas-relief *n.m.* ចម្លាក់ក្រឡោត (*pl.* des bas-reliefs)

basse *n.f.* កន្លែងទឹករាក់មានខ្សាច់ឬថ្មពីក្រោម

basse-cour *n.f.* ធ្លាចិញ្ចឹមបសុបក្សី;បសុ-សត្វ (*pl.* des basses-cours)

basse-courier,ère *n.* អ្នកថែបសុសត្វ

basse-fosse *n.f.* គុកងងឹត (ក្នុងរូងដី) (ហៅ cul-de-basse-fosse ក៏បាន ដែរ) (*pl.* des basses-fosses)

bassement *adv.* ដោយថោកទាប

bassesse *n.f.* ហីនភាព,អាការថោកទាប (ឧ. bassesse de cœur)

basset *n.m.* ឆ្កែតឿម្យ៉ាង

bassin *n.m.* អាងទឹក;ទឹកក្នុងអាង;ថាសជញ្ជីង; ភាជន៍ដែក; ស្រទាប់ត្បូងថ្ម ឬ ដែកក្នុងដី ។ *Anat.* ត្រគាក ។ *Géogr.* ដលសីមា ។ bassin d'un fleuve ដលសីមានៃទន្លេ

bassinage *n.m.* ការកំដៅ; ការផ្សើម (ឧ.bassinage d'une plaie)

bassine *n.f.* ចាំងដែក

bassinée *n.f.* ចំណុះចាំងដែក

bassinement *n.m.* ការកំដៅ;ការផ្សើម

bassiner *v.t.* កំដៅ (ឧ bassiner un lit);ផ្សើម, ស្រប់ទឹក។*Pop.*ធ្វើឲ្យធុញ

bassinet *n.m.* អាងតូច ។ *Fam.* cracher au bassinet ឲ្យប្រាក់ ដោយទើសទាល់

bassinoire *n.f.* ផើងក្រានកំដៅគ្រែ ។ *Pop.* នាឡិកាដក់ធំ; អ្នកធ្វើឲ្យគេធុញ

bastille *n.f.* ប្រាសាទបន្ទាយ;ពន្ធនាគារ ធំនៅក្រុងប៉ារីស (ជាន់ដើម)

bastingage *n.m.* បង្កាន់ដៃដំបូលនាវា

bastingue *n.f.* សំពត់គ្របដំបូលនាវា

bastinguer *v.t.* គ្របសំពត់ដំបូលនាវា

bastion *n.m.* កំពែងសារពើសូត្រ (សម្រាប់ការពារ)

bastionner *v.t.* ការពារដោយកំពែង សារពើសូត្រ(ឧ.fort bastionné)

bastonnade *n.f.* ការវាយច្រើនដំបង(ឧ. recevoir une bastonnade)

bas-ventre *n.m.* ក្បាលពោះ,ភាគក្រោម នៃពោះ (*pl.* des bas-ventres)

bat *n.m.* ដងវាយកូនគោល

bât *n.m.* អានឬកែប(សេះ) ។ *Prov.* savoir, sentir où le bât blesse ស្គាល់ហេតុនៃទុក្ខ

bataclan *n.m.* គ្រឿងរយីងរយ៉ាង

bataille *n.f.* សម្បហារ,សង្គ្រាម,ចំបាំង។ *Fig.* ជំលោះ ។ en bataille ជាជួរ លាត (ចំពោះមុខសត្រូវ) ។ cheval de bataille សេះសង្គ្រាម ។ ល្បែង បៀលេងតែពីរនាក់

batailler *v.t.* ច្បាំងគ្នា;ឈ្លោះគ្នា;ប្រកែក គ្នា(ឧ.batailler sur des riens)

batailleur, euse *a.&n.* ហៃឈ្លោះ

bombarde *n.f.* គ្រឿងបាញ់ដុំថ្មធំៗ (ប្រើក្នុងយុគកណ្ដាល)

bombardement *n.m.* ការទម្លាក់ឬបាញ់គ្រាប់បែក

bombarder *v.t.* ទម្លាក់ឬបាញ់គ្រាប់បែក (ឧ. bombarder une ville) ។ *Fam.* រំអុក (ឧ.bombarder quelqu'un de demandes); តែងតាំងភ្លាមៗ (ឧ. bombarder un journaliste trésorier général)

bombardier *n.m.* ទាហានបាញ់គ្រាប់បែក; អាកាសយានទម្លាក់គ្រាប់បែក

bombe *n.f.* គ្រាប់បែក ។ arriver comme une bombe មកដល់មិនដឹងខ្លួន,មកដល់ដោយឥតដំណឹងជាមុន។ bombe atomique គ្រាប់បែកបរមាណូ។ bombe à hydrogène ឬ bombe H គ្រាប់បែកហ៊ីដ្រូហ្សែន ។ bombe incendiaire គ្រាប់បែកឆេះ ។ bombe volante គ្រាប់បែកហោះ ។ bombe volcanique ថ្មលោយដែលផ្ទុះចេញពីភ្នំភ្លើង។ bombe glacée ទឹកកកកូត ។ *Pop.* ការស៊ីផឹក (ឧ. faire la bombe)

bombé,e *a.* កំពុង, ប៉ោង

bombement *n.m.* កន្លែងកំពុង

bomber *v.t.* បំប៉ោង, បំប៉ោង (ឧ. bomber la poitrine) ។ *v.i.* ប៉ោង,ប៉ោង (ឧ. ce mur bombe)

bombyx ឬ **bombyce** *n.m.* មេអំបៅនាងនាង

bon,bonne *a.* ល្អ (ឧ. bon père ឪពុកល្អ; bonne conduite ចរិយាល្អ; bon mot ពាក្យប្រសើរ(បង្ហាញការឆ្លាត)។ bonne famille ត្រកូលល្អ, ត្រកូលខ្ពស់។ bonne maison ពូជល្អ,ពូជខ្ពស់។ច្រើន(ឧ.bon nombre) ។ ត្រឹមត្រូវ (ឧ. bon compte) ។ ល្មម, ដល់ពេល (ឧ. moisson bonne à couper) ។ សម្រាប់ (ឧ. onguent bon pour la brûlure ថ្នាំរលាកភ្លើង; billet d'entrée bon pour deux personnes បណ្ណចូលសម្រាប់ពីរនាក់) ។ *Par ext.* bonne année ឆ្នាំសប្បុរសប្បាយ។ bon augure

ប្រផ្នូលល្អ ។ bon vent ខ្យល់ល្អ ។ bonne occasion ឱកាសល្អ ។ bon cœur ចិត្តល្អ ។ bon ange, bon génie អ្នកមានព្រហ្មវិហារ (ឧ. notre mère est notre bon ange) ។ bon ami, bonne amie កល្យាណមិត្ត ។ une bonne fois តែម្តងឲ្យស្រេច ។ à la bonne heure! ល្អហើយ ! ។ de bonne heure ឆាប់ ។ de bon matin ពីព្រលឹម ។ la donner bonne និយាយសំដីមិនគួរជឿ ។ la garder bonne គុំ,ចងគំនុំ ។ à quoi bon? ប្រយោជន៍អ្វី ? (គ្មានប្រយោជន៍អ្វីសោះ) ។ trouver bon ចូលចិត្ត ។ trouver tout bon ត្រូវចិត្តទាំងអស់ ។ comme bon me semble តាមចិត្តខ្ញុំ ។ *loc. fam.* bon! យើះ ! (សូរលាន់មាត់ ដោយឆ្ងល់ ឬ ដោយមិនជឿ) ។ c'est bon បានហើយ, ល្មមហើយ

bon, bonne *n.* អ្វីៗដែលល្អ (ឧ.boire du bon; acheter du bon; que le bon soit toujours camarade du beau);មនុស្សល្អ (ឧ. les bons et les méchants)។*Fam.* c'est un bon មនុស្សល្អ (យកជាការបាន) ។ ផ្នែកល្អ (ឧ. il y a du bon dans la vie)។ *Pop.* il y a du bon បានស្រួលហើយ, មុខជាបានការហើយ ។ en voilà une bonne!នេះបានចំជាចំឡែក !។ en dire, en conter de bonnes និយាយអំពីរបស់មិនគួរជឿ; និយាយចំៗ ឬ ហ៊ាឡូដល់ៗ ។ à la bonne franquette ដោយមិនគួរសមពេក ។ *Pop.* à la bonne ដោយមិនបាច់គួរសម; ដោយគ្មានញាប់ញ័រ (ឧ.prendre quelque chose à la bonne) ។ être dans ses bonnes កំពុងតែស្រួលចិត្ត ។ *loc. prov.* aux derniers les bons អ្នកមុនកំសោយ អ្នកក្រោយមានលាភ (របស់ដែលសល់ពីគេរើសច្រើនតែល្អ)

bon *n.m.* ប័ណ្ណ ។ bon d'achat ប័ណ្ណទិញ ។ bon de commande ប័ណ្ណបញ្ជាទិញ ។ bon pour délivrer ប័ណ្ណប្រគល់ឲ្យ ។ bon pour ប័ណ្ណទិញជឿ ។ *Chem. de f.* bon de transport ប័ណ្ណដឹកនាំ ។ *Fig.* bon du trésor ប័ណ្ណ

ភេសាគារ ។ bon de poste ប័ណ្ណប្រៃសណីយ ។ *Typogr.* bon à tirer អនុញ្ញាតឲ្យបោះពុម្ព

bon *adv.* ល្អ ។ il fait bon អាកាសល្អ(មិនត្រជាក់ពេកមិនក្ដៅពេក) ។ ស្រួល (ឧ. il fait bon dormir quand on est fatigué)។*Fig.* il ne fait pas bon s'y aventurer មិនគួរប្រថុយទេ (ក្រែងមានគ្រោះថ្នាក់)។ il y fait bon កន្លែងនេះស្រួល (ធ្វើឲ្យស្រួលខ្លួន) ។sentir bon ធុំក្រអូប, ធុំក្លិនល្អ ។ tenir bon តស៊ូ,មិនបោះបង់(មិនព្រមចុះចាញ់) ។ coûter bon ថ្លៃ, អស់សោហ៊ុយច្រើន; *au fig.* អស់កម្លាំងច្រើន ។ *loc. adv.* tout de bonឬ pour tout de bonមែនទែន(មិនលេងសើច) ។ *Prov.* il fait bon vivre et ne rien savoir ស្រួលតែពុំដឹងរឿងមិនគប្បី

bonace *n f.*ភាពសមុទ្រស្ងប់ (ឧ.temps de bonace) ។ *Fig.* ភាពស្ងប់

bonasse *a.* ដែលមានចិត្តល្អហួសពេក; ស្លូតហួសពេកហើយមិនប្រកាន់ខ្លួន

bonassement *adv.* ដោយល្អឬស្លូតហួសពេក

bonasserie *n.f.* ភាពចិត្តល្អ ឬ ស្លូតហួសពេក

bon-bec *n.m.* មនុស្សមាត់រឹង (អ្នកនិយាយច្រើនហើយចេះការពារខ្លួន)(*pl.* des bons-becs)

bonbon *n.m.* ស្ករគ្រាប់

bonbonneឬ**bombonne** *n.f.* ទីទន, ក្រឡ, ដបកំពីងម្យ៉ាង

bonbonnerie *n.f.* ឧស្សាហកម្មឬជំនួញស្ករគ្រាប់

bonbonnière *n.f.* ប្រអប់ស្ករគ្រាប់ ។ *Fig.* ផ្ទះតូច, បន្ទប់តូចរៀបចំសមសួន

bond *n.m.* ការផ្លោះ, ការលោត (ឧ. faire un bond)។ *Fig* ការបានដល់យ៉ាងរហ័ស (ឧ. arriver d'un bond à une haute position)។ du premier bondភ្លាម១។faire faux bon មិនធ្វើតាមកិច្ចសន្យា ។ prendre la balle au bond ម.ព. balle ។ entre bond et volée ក្នុងឱកាសដ៏ល្អិត (ឱកាសដ៏ខ្លីដែលត្រូវចាប់យកដោយប្រុងប្រយ័ត្ន) ។ de bond ou de volée តាមរបៀបណាក៏បាន

bonde *n.f.* សន្ទះទឹក; ប្រហោងមូលសម្រាប់ច្រកទឹក; ឆ្នុក

bonder *v.t.* ញាត់ណែនតាន់ (ឧ. bonder une valise)។ *Fig.* salle bondée de spectateurs សាលដែលមានអ្នកមើលខ្នាន់ខ្នាប់

bondérisation *n.f.* ការការពារដែកកុំឲ្យច្រែះចាប់

bondir *v.i.* លោត, ផ្លោះ, ស្ទុះ ។ *Fig.* cela fait bondir ឬ cela fait bondir le cœur របស់នោះធ្វើឲ្យអន់ចិត្តឬឲ្យខ្ពើម។bondir de joie សប្បាយដោយរំភើបចិត្ត

bondissant,e *a.* ដែលលោត

bondissement *n.m.* ការលោត, ការផ្លោះ

bondon *n.m.* ឆ្នុកធុងឈើ

bonheur *n.m.* សុភមង្គល (ឧ. le bonheur parfait n'existe pas);សំណាង(ឧ. c'est un bonheur qu'on ait entendu ses cris) ។ par bonheur *loc. adv.* ដោយសំណាងល្អ, ព្រោះជា

bonhomie *n.f.* ចិត្តល្អ; ភាពស្លូតហួសហេតុ; ភាពមិនប្រកាន់ខ្លួន; ភាពងាយជឿ

bonhomme *n.m.* មនុស្សសុភាព-ស្លូត ឬ មិនប្រកាន់ខ្លួន ; មនុស្សកញ្ជោត ។ faux bonhomme មនុស្សលាក់ពុត(ធ្វើជាល្អ, ធ្វើជាស្លូត) ។ មនុស្សចាស់ ។ un petit bonhomme ក្មេងតូច។ រូបមនុស្សអាក្រក់(ឧ.dessiner des bonshommes)

boni *n.m.* សំណល់ចំណាយ ។ *Par ext.* ចំណេញ (*pl.* des bonis)

boniface *n.&a. Pop.*មនុស្សកញ្ជោត

bonification *n.f.* បសន្តិកម្ម(ការធ្វើឲ្យល្អឡើងឬឲ្យចម្រើនឡើង);ការបញ្ចុះថ្លៃ

bonifier *v.t.* ធ្វើបសន្តិកម្ម (ធ្វើឲ្យល្អឡើង- ឲ្យចម្រើនឡើង ឬ ឲ្យចំណេញ) (ឧ. bonifier des terres; bonifier des intérêts)

boniment *n.m.* ការបួត

bonjour *n.m.* អរុណសួស្តី (វន្ទនកិច្ចពេលព្រឹក)

bonne *n.f.* ស្រីបំរើ, ជាវស្រី ។ bonne à tout faire ស្រីបំរើគ្រប់មុខក្នុងផ្ទះ

bonne-maman *n.f.*ជីដូន,ម៉ាក់យាយ (ពាក្យទំយើ)

bonnement *adv.* ដោយស្មោះត្រង់; តាមត្រង់; ដោយឆោត (ឧ. convenir bonnement d'une chose)

bonnet *n.m.* កាតិបក្រពះជក ។ bon-

net de nuit កាតិបពាក់ដេក ។ bonnet d'âne មួកក្រដាសសម្រាប់បំពាក់សិស្សអាក្រក់ ។ *Fig.* gros bonnet អ្នកធំ(អ្នកមានបណ្ដាសក្តិ) ។ *loc. prov.* prendre sous son bonnet ប្រឌិត; ទទួលខុសត្រូវលើខ្លួន ។ avoir la tête près du bonnet ចិត្តនៅចុងប្រមុះ(ឆាប់ខឹង)។ deux têtes dans un bonnet មនុស្សពីរនាក់ដែលមានយោបល់ស្របគ្នាជិតប ។ triste comme un bonnet de nuit (ឬ comme un bonnet de coton)ព្រួយខ្លាំង ។ jeter son bonnet par dessus les moulins ប្រព្រឹត្តមិនល្អ, ប្រព្រឹត្តដោយឥតខ្លាចដំនៀល

bonneteau *n.m.* ល្បែងបោះបៀបីសន្លឹក

bonneterie *n.f.* ជំនួញកាតិបព្រពះចក, ទំនិញលក់ក្នុងហាងកាតិបព្រពះចក(មានស្រោមជើង អាវយឺតជាដើម) (ឧ. acheter de la bonneterie)

bonneteur *n.m.* អ្នកបោះបៀបីសន្លឹក

bonnetier,ère *n.* អ្នកធ្វើ ឬ លក់កាតិបព្រពះចក-ស្រោមជើង-អាវយឺត ។ល។

bonnette *n.f.* ព្រពះចកកូនក្មេង ។ *Mar.* ក្ដោងតូច (សម្រាប់បន្ថែមកម្លាំងក្ដោងធំ)

bonniche *n.m. Fam.* ស្ដ្រីបម្រើតូច

bonnichon *n.m. Fam.* កូនមួក

bon-papa *n.m.* ជីតា (ពាក្យទំយើ) (*pl.* des bons-papas)

bonsoir *n.m.* សាយ័ណ្ហសួស្ដី (វន្ទនកិច្ចពេលល្ងាច)

bonté *n.f.* ភាពល្អ (ឧ.bonté d'un terrain); ការចូលចិត្តធ្វើល្អ, សេចក្ដីល្អ; ចិត្តល្អ, ចិត្តមេត្តា, ចិត្តប្រណី; ភាពស្លូត; មនុស្សធម៌ (ឧ. la bonté gagne les cœurs)។ *pl.* អំពើល្អ (ឧ. avoir pour quelqu'un mille bontés)

bonze *n.m.* ភិក្ខុសង្ឃ (*f.* bonzesse ភិក្ខុនីសង្ឃ)

bonzerie *n.f.* កុដិ

bookmaker [bouk-mé-keur] *n.m.* អ្នកកាន់បញ្ជីដំណាំងក្នុងភលវង់

boom *n.m.* ដំណើរឆាប់នៃទំនិញ; ការឡើងថ្លៃភ្លាមៗ (ដោយគ្មានហេតុ); ការចម្រើនភ្លាមៗ (ដោយមិនបីតថេរ)

boomerang *n.m.* ម.ព. boumerang

bootlegger [bout-lé-gheur] *n.m.* អ្នកគេតយស្រា (នៅប្រទេសអាមេរិក)

boqueteau *n.m.* ព្រៃតូច

borasse *n.m.* តាលជាតិ (ពួកដើមត្នោត) ។ borasse éventail ដើមត្នោត

borborygme *n.m.* សូរពួរពោះ

bord *n.m.* គែម, ហាម (ឧ. bord d'une table; les bords d'un vase); ឆ្នេរ; ច្រាំង (ឧ. les bords d'un fleuve); មាត់ (ឧ. les bords d'un précipice); សំពត់បំ (ឧ. mettre un bord de soie à un corsage); នាវា (ឧ. monter à bord ជិះនាវា ។ à bord នៅលើនាវា ។ être du bord de quelqu'un យល់ស្របតាម, កួលដៃខាង ។ *Fig.* les sombres bords ឋាននរក ។ bord à bord *loc adv.* អែបគ្នា (នាវា)

bordage *n.m.* ការបំ (សំលៀកបំពាក់) (ឧ. le bordage d'un habit); ការដាក់គែម (នាវា)

bordeaux *n.m.* ស្រាទំពាំងបាយជូរប៊័រដូ ។ *a.* ក្រហមស្វាយ (ឧ. une robe bordeaux)

bordée *n.f.* ពួកកម្មករដែលត្រូវបំពេញកិច្ចម្ខាងៗនាវា; កាំភ្លើងធំម្ខាងៗនាវា; ការបាញ់ព្រុះនៃកាំភ្លើងធំម្ខាងៗនាវា ។ *Fig.* une bordée d'injures ការជេរ (ក្នុងមួយលើក) ។ *Mar.* ចម្ងាយនាវាបើកក្ដោងបត់ (ឧ. courir une bordée) ។ *Fig.* courir, tirer une bordée លួចឡើងគោក (កម្មករនាវា)

bordelaise *n.f.* ធុងស្រាទំពាំងបាយជូរប៊័រដូ (ចំណុះពី ២២៥ ដល់ ២៣០ល.); ដបម្យ៉ាង (ចំណុះពី ៦៨ ដល់ ៧៥ល.)

border *v.t.* បំ(សំលៀកបំពាក់); ដាក់គែម (នាវា) ។ *Mar.* បើកស្បៀរមាត់ច្រាំង (ឧ. navire qui borde la côte) ។ border un lit គ្រសាប់កម្រាលពូក (ញាត់ជាយកម្រាលទៅក្រោមពូក) ។ *Fam.* être mal bordé មិនសប្បាយចិត្ត(មានអារម្មណ៍មិនល្អ) ។ *Mil.* ឃាមពីក្រៅ(ឧ. border un retranchement, un parapet); border la haie ឈរអមផ្លូវ (ដាក់កិត្តិយស) (ជា faire la haie ក៏បាន) ។ *Hort.* border une planche លើកដីជាយរង ។ se border *v.pr.* មានបំ (សំលៀកបំពាក់); មានដាក់គែម (នាវា)

bordereau *n.m.* ដីកាអម ។ bordereau d'envoi ដីកាអមផ្ញើ ។ bor-

dereau d'expédition ឌីការអម បេសនកម្ម ។ bordereau de virement ឌីការអមបង្វែរ ។ bordereau d'escompte ឌីការអមអបហារ [អ:-ប៉:-]

borderie *n.f.* ដីអំពក

bordier, ère *n.&a.* អ្នកទទួលប្រវាស់ដីអំពក

bordure *n.f.* ហាម,ក្រប,គែម(ឧ.bordure d'un tableau; bordure de gazon, de fleurs); ទៀន ដីកញ្ចៀមថ្នល់ ។ bordure d'un bois ជាយព្រៃ

boréal,e,aux *a.* ខាងជើង(ឧ. hémisphère boréal)

borée *n.m.* ខ្យល់ពីទិសខាងជើង ។ *Myth.* ព្រះវាយុទេព ឬ ព្រះវាលាហក

borgne *a.&n.* ខ្វាក់ម្ខាង ។ *Fig.* គ្មានសណ្ដាប់; មិនល្អ (ឧ.maison borgne; cabaret borgne)។*Prov.* troquer son cheval borgne contre un aveugle; au royaume des aveugles le borgne est roi ម.ត. aveugle

borin,e *n.&a.* កម្មករអណ្ដូងត្បូងថ្ម

borinage *n.m.* ការដឹកយកត្បូងថ្ម; ពួកកម្មករអណ្ដូងត្បូងថ្ម

bornage *n.m.* ការបោះគោលព្រំដែន; តាវិចារណ៍ផិតៗ

borne *n.f.* គោល, ក៏ល ។ borne-fontaine ម.ត. នេះ ។ borne kilométrique គោលគីឡូម៉ែត្រ។ *Pop.* គីឡូម៉ែត្រ ។ *pl.* ព្រំដែន (ឧ. bornes d'un empire; bornes de l'univers; bornes de l'esprit humain)។passer, dépasser, franchir les bornes, ឬ sortir des bornes ប្រព្រឹត្តហួសហេតុ(ហួសយុត្តិធម៌ ឬ ការសមរម្យ)

borné,e *a.* មិនទូលាយ, ដែលមានព្រំដែន ។ *Fig.* esprit borné ប្រាជ្ញាអាប់

borne-fontaine *n.f.* គោលម៉ាស៊ីនទឹក

borner *v.t.* បោះគោល; ដាក់ព្រំដែន ។ *Fig.* ទប់(ឧ.borner les désirs)

bornoyer *v.t.* ស្រងៀវភ្នែក

borraginacées *n.f. pl.* សោណ្ឌកុល

boscot,otte *a.&n. Pop.* មនុស្សទាប និងគមនង

bosquet *n.m.* ព្រៃតូច, ដង្ហំព្រៃ

bosse *n.f.* ពក, ប្លក; ភាពហើម;

ក្បាច់ក្រឡេត; សប្បទា (ឧ. avoir la bosse du commerce) ។ *Mar.* ពួរមានក្រវិល

bosselage *n.m.* ក្បាច់ដំរលេចលើគ្រឿងបាន (ឧ. travailler en bosselage)

bosseler *v.t.* ឌុន, ដំក្បាច់រលេច; ធ្វើឲ្យពក ។ se bosseler *v.pr.* ពក

bossellement *n.m.* ការដំក្បាច់រលេច, ការធ្វើឲ្យពក

bosselure *n.f.* ក្បាច់ដំរលេច; ភាព ឬ ផ្ទៃរដិបរដុប

bosser *v.t. Mar.* ទាក់ដោយខ្សែពួរ ។ *Arg.* ធ្វើការ

bossu,e *a.* គម ។ *n.* មនុស្សគម ។ rire comme un bossu សើចក្អាកក្អាយ

bossuer *v.t.* ធ្វើឲ្យពក (ជា bosseler ក៏បានដែរ)

boston *n.m.* ល្បែងបៀយ៉ាងលេងគ្នា ៤ នាក់

bot,e *a.* ក្ញង (ឧ. main bote); កែក (ឧ. pied bot)

botanique *n.f.* ភូតគាមសាស្ត្រ ។ *a.* នៃភូតគាមសាស្ត្រ ។ jardin botanique អាបអោទ្យាន

botaniste *n.* អ្នកភូតគាមសាស្ត្រ

botte *n.f.* កណ្ដាប់, ជាប់ (ឧ. botte d'asperge)

botte *n.f.* ការចាក់ដោយដាវ ។ *Fig.* porter, pousser une botte à quelqu'un ស្ដីដ្ដុញ

botte *n.f.* ធុងយ៉ាង; ថ្លោកស្បែកក្រកទឹក; ស្បែកជើងកវែង(ឧ. botte de chasse) ។ à propos de bottes ដោយកាលមិនគួរ, ដោយឥតសមហេតុផល

bottelage *n.m.* ការចងជាកណ្ដាប់, ការចងជាជាប់ (ឧ. le bottelage du foin, de la paille)

botteler *v.t.* ចងជាកណ្ដាប់; ចងជាជាប់ (ឧ. botteler du foin)

bottelette *n.f.* កូនកណ្ដាប់, កូនជាប់ (ឧ. bottelettes d'oignons, de carottes)

botteleur,euse *n.* អ្នកចងជាកណ្ដាប់ ឬ ជាជាប់

botteloir *n.m.* ឬ **botteleuse** *n.f.* ម៉ាស៊ីនចងកណ្ដាប់

botter *v.t.* ផ្ដល់ស្បែកជើងកវែង (ឧ. botter un régiment de cavalerie); បំពាក់ស្បែកជើងកវែង(ឧ. botter un chasseur); ធាក់,

ទាត់ ។ singe botté មនុស្សកន្ទ្រញ-កន្ទ្រញ ។ se botter *v. pr.* ពាក់ស្បែកជើងកវែង

bottier *n.m.* ជាងស្បែកជើង; ឈ្មួញស្បែកជើង

bottillon *n.m.* កូនបាច់ស្មៅ ឬ បន្លែ; ស្បែកជើងកវែងស្ត្រី

bottine *n.f.* ស្បែកជើងកវែង (មានខ្សែរ ឬ ចងខ្សែ); ស្បែកជើងវែងតូច

botulisme *n.m.* ការពុលដោយសាច់ស្អុយ

boubouler *v.i.* យំ (ទីទុយ)

bouc *n.m.* ពពែឈ្មោល; ពុកចង្កា ។ bouc émissaire អ្នករងកំហុស

boucan *n.m.* ចង្អើរសាច់

boucan *n.m.* *Fam.* សូរសន្ធឹក (ឧ. c'est un boucan à ne pas s'entendre)

boucanage *n.m.* ការឆ្អើរសាច់ ឬ ត្រី

boucaner *v.t.* ឆ្អើរសាច់ ឬ ត្រី; បរបាញ់គោព្រៃ

boucau *n.m.* ច្រកចូលផែ

boucaut *n.m.* ធុងដាក់ទំនិញស្ងួត (ឧ. morue en boucaut)

bouchage *n.m.* ការចុក (ឧ. le bouchage des bouteilles); ឆ្នុក (ឧ. bouchage solide)

bouche *n. f.* មាត់ ។ prendre sur sa bouche សន្សំលើអាហារ (មិនហ៊ានបរិភោគ) ។ s'ôter le morceau de sa bouche ផ្តាច់ពីមាត់ (មិនហ៊ានបរិភោគ, សុខចិត្តអត់ទ្រាំឲ្យខ្វះ)។ ouvrir la bouche ហាមាត់និយាយ ។ ouvrir la bouche à quelqu'un ប្រើឲ្យនិយាយ ។ fermer la bouche à quelqu'un បំបិទមាត់(មិនឲ្យនិយាយ) ។ avoir un mot à la bouche ទន្ទេញតែពាក្យមួយម៉ាត់ ។ avoir la bouche pleine d'une chose និយាយតែអំពីរឿងមួយ។ aller, passer ឬ voler de bouche en bouche ល្បីពីមាត់មួយទៅមាត់មួយ; មានល្បី ។ être dans la bouche de tout le monde ឬ être dans toutes les bouches ឲ្យគេនិយាយគ្រប់មាត់ ។ la déesse aux cent bouches កិត្តិសព្ទ ។ ne pouvoir tirer un mot de la bouche de quelqu'un សុំឲ្យនិយាយតែមួយម៉ាត់ក៏មិនបាន ។ arra-cher quelque chose de la

bouche de quelqu'un បង្ខំឲ្យនិយាយ ។ dire tout ce qui vient à la bouche និយាយតាមតែនឹកឃើញ (ដោយគ្មានរំរែង ឬ ដោយគ្មានគិត) ។ dans la bouche de តាមសំដីនៃ... ។ être fort en bouche មាត់ឆៅ (និយាយឥតកោតក្រែង) ។ bouche close ឬ bouche cousue មិនហើបមាត់ ។ provisions de bouche ស្បៀងអាហារ ។ faire venir l'eau à la bouche ធ្វើឲ្យស្រក់ទឹកមាត់ (ធ្វើឲ្យមានចំណង់) ។ faire la petite bouche បរិភោគល្បិចល្បៀម; រើសម្ហូប; ធ្វើជាខ្ពើម ។ faire la bouche en cœur ធ្វើប៊ិកម៉ិក ។ dépenses de bouche ចំណាយទិញអាហារ ។ flux de bouche កេតស្រៀវទឹកមាត់ ។

Par ext. បបូរមាត់ (ឧ. bouche vermeille et bien dessinée) ។ *Fig.* មាត់ (មនុស្សដែលត្រូវបរិភោគអាហារ) (ឧ. faire sortir de la ville assiégée les bouches inutiles) ។ bouche fendue jusqu'aux oreilles រង្វះមាត់ធំ ។ être, demeurer ឬ rester bouche béante ឬ bouche bée ធ្វើមាត់ព្រហ (ដោយឆ្ងល់, ដោយប្រុងស្តាប់) ។ bonne bouche រសឆ្ងាញ់ជាប់ក្នុងមាត់ ។ rester ឬ demeurer sur la bonne bouche ពេញរសឆ្ងាញ់ (បរិភោគម្ហូបឆ្ងាញ់ហើយលែងបរិភោគអ្វីទៀត) ; *au fig.* បានសម្រេចផលអ្វីម្យ៉ាងហើយលែងធ្វើអ្វីតទៅទៀតដោយខ្លាចមិនបានសម្រេចទៀត ។ garder pour la bonne bouche ទុកម្ហូបឆ្ងាញ់សម្រាប់បរិភោគក្រោយ ។ mauvaise bouche រសប្រហាតជាប់មាត់ (ឧ. l'excès de la boisson donne mauvaise bouche) ។ bouche mauvaise មាត់ប្រហាត ឬ ធុំក្លិនអាក្រក់ ។ *Fig.* demeurer sur la mauvaise bouche កំពុងតែមានអារម្មណ៍មិនល្អ ។

Géogr. ពាម (ឧ. les bouches du Mékong ពាមទន្លេមេគុង); មាត់ព្រែកចូល (នៃដែនសមុទ្រ); មាត់រន្ធ (ឧ. la bouche d'un four មាត់ឡ ; la bouche d'un puits មាត់អណ្តូង; la bouche d'un volcan មាត់រន្ធភ្នំភ្លើង) ។ bouche

d'incendie ក្បាលម៉ាស៊ីនទឹកលត់អគ្គិភ័យ ។

Artill. មាត់ត្រែ។ bouche à feu កាំភ្លើងធំ ។

Loc. adv. de bouche ផ្ទាល់មាត់ ។ manger à pleine bouche បរិភោគទ្វេញមាត់ ។ bouche à bouche ទល់មាត់គ្នា(មាត់នឹងមាត់ប៉ះគ្នា) ។

Prov. il dit cela de bouche, mais le cœur n'y touche អ្នកនេះថាតែមាត់ទេ ប៉ុន្តែគំនិតផ្សេង ។ gouverne ta bouche selon ta bourse ដាំដើងក្រានឲ្យប្រមាណខ្លាំង (យើងត្រូវប្រមាណការបរិភោគ តាមធនធានរបស់យើង)។qui garde sa bouche garde son âme អណ្ដាតជាអាទឹកន្លង បានសុខទុក្ខផង ពីព្រោះអណ្ដាត (គួរតែប្រយ័តមាត់កុំនិយាយឲ្យភ្លាត់ខុស)

bouché,e *a.* ស្ទះ, ចុក, បិទ (ឧ.trou bouché)។ *Fig.* គគ្រាញ(ឧ.enfant bouché);ស្រាងិប(មានឆ្នុកបិទជិត)។temps bouché មេឃស្រអាប់

bouchée *n.f.* ម៉ាត់(ចំនួនល្មមនឹងមាត់)។ manger une bouchée បរិភោគបួយម៉ាត់បួយក (ប្រញាប់ប្រញាល់) ។ *Fig.* ne faire qu'une bouchée de គ្រលាក់តែមួយម៉ាត់ (ធ្វើឬយកជ័យជំនះបានដោយងាយ)

boucher *v.t.* បិទ, ចុក,ញាត់(ឧ.boucher une fenêtre, une bouteille)

boucher *n.m.* ឈ្មួញសាច់ស្រស់ ។ *Fig.* មនុស្សកំណាចយង់ឃ្នង ។ *Fam.* សល្យពេទ្យមិនប៉ុនប្រសប់

bouchère *n.f.* ប្រពន្ធឈ្មួញសាច់ស្រស់

boucherie *n.f.* ទីលក់សាច់ស្រស់, ជំនួញសាច់ស្រស់ ។*Fig.* ការសម្លាប់រពោយ(ឧ.mener des troupes à la boucherie) ។ bœuf de boucherie ម.ព. bœuf

boucheton(à) *loc.adv.* ផ្កាប់ត្រួតគ្នា

bouche-trou *n.m.* មនុស្សឬវត្ថុដែលគ្រាន់តែបំពេញកន្លែងទំនេរ (ឧ. *pl.* des bouche-trous)

bouchon *n.m.* ឆ្នុក; កំស្ទួល (សន្ទូច); សំណុំចំបើងក្រញួញ

bouchonner *v.t.* ជុសសំរោគដោយសំណុំចំបើង(ឧ. bouchonner un cheval)

bouchonnier *n.m.* អ្នកធ្វើ ឬ លក់

ភ្នកឆប

bouchure *n.f.* របងរុក្ខជាតិរស់

boucle *n.f.* ក្រវិល;កន្លាស់(ឧ.boucle de ceinturon) ; ផ្នត់សក់ (ឧ. boucles ondoyantes); របត់ (ផ្លូវទឹក);ផ្លូវបត់មួយជុំ(អយស្ម័យយាន); ការហោះក្រឡប់មួយជុំ (អាកាសយាន)(ឧ.boucler la boucle)។ boucle de ceinture ក្បាលខ្សែក្រវាត់ ។ boucle d'oreille ការ, ទំហូ ។ se serrer la boucle *loc. fam.* រឹតខ្សែក្រវាត់ (ទ្រាំអត់ទ្រាំឃ្លាន)

bouclé,e *a.* ដែលមានក្រវិល ឬ ផ្នត់

bouclement *n.m.* ការខ្ទះសត្វ

boucler *v.t.* ចងរឹត (ដោយក្រវិល) (ឧ.boucler des guêtres, une valise); ធ្វើឲ្យមានផ្នត់ (សក់) (ឧ. boucler des cheveux);ខ្ទះសត្វ; ដើរមួយជុំ (សំដៅត្រង់ទីបញ្ចប់នៃដំណើរ) ។ *v.i.* រួញជាផ្នត់ (ឧ. ses cheveux bouclent)

bouclette *n.f.* ក្រវិលតូច

bouclier *n.m.* ខែល (ឧ. certaines peuplades sauvages se servent encore de boucliers) ។ levée de boucliers ការបះបោរ។ *Fig.* អ្នកការពារ;គ្រឿងការពារ;ពំនឹង (ឧ. le bouclier des lois)

Bouddha *n.m.* ព្រះពុទ្ធ

bouddhique *a.* ពុទ្ធិកៈ-កា, នៃពុទ្ធសាសនា

bouddhisme *n.m.* ពុទ្ធសាសនា

bouddhiste *n.* ពុទ្ធមាមកៈ (អ្នកកាន់ពុទ្ធសាសនា)

bouder *v.i.* ងឿកងរ, កកពុក,ក្អុកក្អក់ ។ *v.t.* bouder quelqu'un បង្ហាញអាការមិនស្រួលចិត្តដល់អ្នកណាម្នាក់

bouderie *n.f.* ការងឿកងរ

boudeur,euse *a.&n.* ពោរងឿកងរ; ដែលបង្ហាញអាការងឿកងរ (ឧ. mine boudeuse)

boudin *n.m.* ប៊ូដាំង (សាច់ក្រកត្រូកលាយឈាមនឹងខ្លាញ់)។ s'en aller en eau de boudin រលាយខ្ចប អំបិលត្រូវទឹក(អន្តរធាន)។ ressort à boudin រ៉ឺស័រតូចខ្លៅ

boudiné,e *a.* ចង្អៀតណែន (ឧ. boudiné dans un corset)

boudiner *v.t.* គ្រួញ (មុនបញ្ចូលហ្វុង)

boudoir *n.m.* កន្លែងទទួលភ្ញៀវស្ត្រី

boue *n.f.* ភក់, ជ្រាំ ។ *Fig.* អំពើ

ឈាមក (អំពើថោកទាប) (ឧ. âme de boue) ។ traîner dans la boue ធ្វើថោកទាប ។ tirer quelqu'un de la boue ទាញចេញពីភាពថោកទាប; ជាយរគោម៍យ ។ *n.m pl.* កករ

bouée *n.f.* ពោង ។ bouée lumineuse ពោងបំភ្លឺ ។ bouée sonore ពោងកញ្ចែ ឬ កណ្ដឹង ។ bouée de sauvetage ពោងសង្គ្រោះ(សម្រាប់សង្គ្រោះមនុស្សលង់ទឹក)

boueur *n.m.* អ្នកយកសម្រាម(ក្នុងក្រុង)

boueux,euse *a.* ដែលមានភក់ (ឧ. chemin boueux); ប្រឡាក់ភក់ (ឧ. souliers boueux) ។ *n.m. Pop.* អ្នកយកសម្រាម

bouffant,e *a.* ប៉ោង (ឧ. manche bouffante); កន្ទ្រើង (ឧ. cheveux bouffants)

bouffarde *n.f. Pop.* ខ្សៀរ

bouffe *a.* កំប្លែង (ឧ. opéra bouffe) ។ *n.m.* អ្នកច្រៀងកំប្លែង

bouffée *n.f.* ការបក់មកលើ(ឧ. bouffée de vent, de fumée); កំសួល(ឧ. bouffée de chaleur); ក្លិនហត់ (ឧ. bouffée de vin ក្លិនស្រាចេញពីមាត់) ។ *Fig.* សំទុះ (ឧ. bouffée d'orgueil, de générosité)

bouffer *v.i.* ធ្វើក្របូរ(សំដែងអាការអន់ចិត្តដោយប៉ោងថ្ពាល់); ឡើងប៉ោង(ឧ. cette étoffe bouffe) ។ *Pop.* ស៊ីឃ្លាមៗ

bouffette *n.f.* សំណុំសូត្រ ឬ រោមចៀម; ផ្កាសំពត់បូ

bouffi,e *a.* ក្រមប់, ហើម (ឧ. visage bouffi); ដែលឡើងឫក (ឧ. bouffi d'orgueil)

bouffir *v.t.* បំប៉ោង; ធ្វើឲ្យហើម (ឧ. l'hydropisie bouffit le corps) ។ *v.i.* ឡើងក្រមប់, ហើម (ឧ.visage qui bouffit)

bouffissure *n.f.* ការហើម ។ *Fig.* ការឡើងឫកក្រអឺត

bouffon *n.m.* តុ្លក

bouffon,onne *a.* កំប្លែង, ក្រមាច់(ឧ. esprit, discours bouffon)

bouffonner *v.i.* កំប្លែងជាកតុ្លក; ពោលពាក្យកំប្លែង

bouffonnerie *n.f.* ការកំប្លែង, អំពើក្រមាច់

bouge *n.m.* ផ្ទះតព្រក់; ផ្ទះឧបទ្រព (ផ្ទះ

ជាផ្ទះបទ ផ្ទះបើកក្បាលបៀ ជាដើម) ; ក្អួង(ភាគដែលប៉ោង)

bougeoir *n.m.* ជើងទៀន (ប្រដាប់ដោតទៀនមានសណ្ឋានដូចចានទៀប)

bougeotte *n.f. Fam.* ការរពឹស (នៅមិនស្ងៀប)

bouger *v.i.* កម្រើក ។ *v.t.* ផ្លាស់កន្លែង (ឧ.bouger des livres, des meubles)

bougie *n.f.* ទៀន; តម្រងទឹកម្យ៉ាង

bougier *v.t.* កោលជាយសំពត់កុំឲ្យរសាត់

bougnat *n.m.Pop.* អ្នកលក់ធ្យូង

bougon,onne *n.* ហៃរអ៊ូទាំ

bougonnement *n.m.* ការរអ៊ូទាំ

bougonner *v.i.Fam.* រអ៊ូទាំ

bougonneur,euse *a.* ដែលរអ៊ូទាំ

bougran *n.m.* សំពត់ក្រាស់លាបជ័រ

bougre,esse *n.Pop.* មនុស្ស (ពាក្យប្រមាថ)។ bon bougre ក្មេងល្អ ។ *a.* bougre d'idiot ភ្លើពេញទី

bougrement *adv.Pop.* ច្រើន,ណាស់

boui-boui *n.m.Pop.* ល្ខោនឬរោងភ្លេងថោកអន់ (*pl.* des bouis-bouis)

bouif *n.m.Pop.* អ្នកជួសជុលស្បែកជើង

bouillabaisse *n.f.* ប៊ូយ៉ាបែស, សម្លម្យ៉ាងគេនិយមក្នុងខេត្តប្រូវង្ស

bouillant,e *a.* ដែលពុះ (ឧ. huile bouillante) ។ *Fig.* ឈាមក្តៅ(ឧ. jeunesse bouillante)

bouille *n.m.* ភាជន៍ទឹកដោះម្យ៉ាង ។ *n.f.* ឈើកូរទឹកឡល្អក់ (ម.ព. bouloir ផង)។ *Fig.* មុខមាត់(ឧ. avoir une bonne bouille)

bouiller *v.t.* កូរទឹកឡល្អក់

bouilleur *n.m.* ឆ្នាំងបិតស្រាអូដឺវី

bouilli *n.m.* សាច់ស្ងោរ (ឧ. bouilli de bœuf, de mouton)

bouillie *n.f.* បបរម្សៅលាយទឹកដោះគោ; ម្សៅស្ងួតធ្វើក្រដាស ។ *Fig.&Fam.* bouillie pour les chats ការហត់នឿយឥតផល; ការណ៍ពិបាកយល់

bouillir *v.i.* ពុះ ។ *Fig.* bouillir de colère ខឹងប្រឡូក, ពុះពោរ ។ la tête bout កំពុងតែស្រើប

bouilloire *n.f.* កំសៀវ

bouillon *n.m.* ទឹករម្ងាស់(គេស្ងោរសាច់នឹងបន្លែឲ្យស្ងួយ)។ bouillon fort ទឹករម្ងាស់ខាប់ ។ bouillon faible ទឹករម្ងាស់រាវ ។ ពពុះ (ព្លូចទឹកពុះ); ទឹកដែលខ្លោល (ឧ.l'eau sort à gros bouillons ទឹកចេញខ្លោលៗធំៗ) ។ *pl.* សំពត់ដែលយ៉ោង;ផ្នែសាច់(ដំបៅ);

ស្រៀវភៅ ឬ កាសែតលក់មិនដាច់ ។ bouillon de culture ទឹករម្ងាស់បំពងមេរោគ ។ *Fam.* boire un bouillon ខាតបង់ ។ bouillon d'onze heures ទឹកបំពុល ។ bouillon pointu ការបូមទឹកលាងពោះវៀន

bouillonnement *n.m.* ភាពទឹកពុះខ្ជោល ។ *Fig.* ការរំជើបរំជួល

bouillonner *v.i.* ពុះខ្ជោល ។ *Fig.* រំជើបរំជួល; លក់មិនអស់(កាសែត) ។ *v.t.*ធ្វើឲ្យឡើងប៉ោង (ឧ.bouillonner une robe)

bouillotte *n.f.* ដបបំពង់ទឹកក្ដៅ(សម្រាប់កំដៅ); កំសៀវតូច; បៀមួយយ៉ាង

bouillotter *v.i.* ពុះប្រិចៗ (ពុះតិចៗ)

boulange *n m.* របរ ឬ ជំនួញនំបុ័ង ។ bois de boulange អុសដុតឡ

boulanger, ère *n.* អ្នកធ្វើ និង លក់នំបុ័ង ។ *n.f.* រទេះសៀង; រថយន្តចែកនំបុ័ង

boulanger *v.t.* boulanger de la farine លាយម្សៅធ្វើនំបុ័ង។ *Absol.* ធ្វើនំបុ័ង

boulangerie *n.f.* ការធ្វើនំបុ័ង; ជំនួញនំបុ័ង; កន្លែងធ្វើ ឬ លក់នំបុ័ង

boulant,e *a.* ដែលរាប ឬ ហូរដូចទឹក (ឧ. sables boulants)

boulbène *n.f.* ដីល្បាយខ្សាច់, ដីឥដ្ឋលាយខ្សាច់

boule *n.f.* ដុំមូល (ឧ. boule de bois; boule de neige) ។ សញ្ញា (ក្នុងការបោះឆ្នោត ឬ ការប្រឡង) (ឧ. déposer sa boule dans l'urne) ។ boule blanche សញ្ញាយល់ព្រម (ក្នុងការបោះឆ្នោត); សញ្ញាថាល្អណាស់ (ក្នុងការប្រឡង) ។ boule noire សញ្ញាមិនយល់ព្រម ។ la boule noire lui tombe toujours អ្នកនេះស៊យណាស់ (ធ្វើអ្វីក៏មិនបានសម្រេច)។ boule rouge សញ្ញាថាល្អ (ក្នុងការប្រឡង) ។

Loc. fam. la boule, notre boule ផែនដី ។ boule de neige អ្វីៗ ដែលចេះតែរីកធំឡើងជាប់ (ឧ. la dette, en faisant la boule de neige, finit par écraser l'emprunteur)។être rond, s'arrondir comme une boule ឡើងកន្ទុល, ធាត់ដុះពោះ ។ se rouler en boule ដេកក្រវៀន ។

Pop. ក្បាលមនុស្ស, មុខមាត់(ឧ. avoir une bonne boule) ។ boule de son មុខមានអាចម៍រុយច្រើន ។ boule de neige ជនជាតិស្បែកខ្មៅ (ដោយចំអក) ។ ខួរក្បាល (ឧ. avoir des idées dans la boule) ។ perdre la boule ឆ្កួត; ស្វន់ ។ avoir les yeux en boules de loto ភ្នែកលៀនក្រឡោត ។

Arg.mil. boule de son នំប៉័ងស្បៀង ។

Jeux បូលបោះ, ដុំបោះ ។ avoir la boule មានសិទ្ធិបោះមុនគេ ។ à boule vue ដោយប្រញាប់ប្រញាល់, ដោយគ្មានគិត ។ pied à boule ឬ tenir pied à boule ឈរត្រង់កន្លែងដុំបោះរបស់ខ្លួន; *au fig.* ទប់, មិនថយ ។

Mar. boule de signaux ពោងសញ្ញា (ក្នុងផែ)

bouledogue *n.m.* ឆ្កែប៉្លាំងថ្គាមមាំ

bouler *v.i.* រមៀល (ដូចដុំមូល) ។ *Pop.* envoyer bouler បណ្ដេញចេញ; ច្រានចោល ។ *v.t.* បំពុលជាយអ ។ bouler les cornes d'un taureau រុំចុងស្នែងគោឈ្មោល

boulet *n.m.* គ្រាប់កាំភ្លើងធំ ។ *Fig.* & *Fam.* មនុស្សក្នុងបន្ទុក; រឿងដែលឲ្យធុញទ្រាន់ ។ traîner son boulet រស់នៅដោយចង្អៀតចង្អល់ (មកអំពីមានកាតព្វកិច្ចធ្ងន់ដែលត្រូវបំពេញ)

boulette *n.f.* ដុំមូលតូច; ពំនូតម្សៅ ឬ សាច់ចិញ្ច្រាំ ។ *Fig.* & *fam.* ការកាន់ច្រឡំ

bouleux,euse *n.* សេះទាបក្រអាញ (សម្រាប់ប្រើការធ្ងន់)

boulevard *n.m.* មហាវិថី ។ *Fig.* ជាការដ្ឋាន(ក្រុងមានគ្រឿងការពារ)(ឧ. cette ville est le boulevard de l'Italie) ; ការឧបត្ថម្ភ

boulevarder *v.i.* ដើរកំសាន្តតាមមហាវិថី (នៅទីក្រុងប៉ារីស)

boulevardier,ère *n.* អ្នកដើរកំសាន្តតាមមហាវិថី ។ *a.* នៃអ្នកដើរកំសាន្តតាមមហាវិថី

bouleversant,e *a.* ដែលធ្វើឲ្យរំភើបញាប់ញ័រ ឬ ឲ្យរំជើបរំជួល (ឧ. nouvelles bouleversantes)

bouleversement *n.m.* ការរំភើបញាប់ញ័រ; ការរំជើបរំជួល; ការកាន់ប្រែ

bouleverser *v.t.* ធ្វើឲ្យរាត់រាយ (ឧ.

bouleverser une bibliothèque)។ ធ្វើឲ្យរំដើបរំពួល-ឲ្យហិនហោច ឬ ឲ្យកាន់ប្រែ (ឧ.bouleverser un Etat)។*Fig.* ធ្វើឲ្យរំភើបញាប់ញ័រខ្លាំង

boulevue (à la ឬ à)*loc.adv.* ម.ព. boule

boulier *n.m.* ក្តាចំម្យ៉ាងសម្រាប់បង្រៀនក្មេងរាប់

boulimie *n.f.* រោគឃ្លាន (មិនចេះស្រន់)

boulimique *a.* នៃរោគឃ្លាន(មិនចេះស្រន់)(ឧ.gastrite boulimique)។ *n.* អ្នកកើតរោគឃ្លាន (មិនចេះស្រន់)

boulin *n.m.* រន្ធផ្ទះព្រាប; ប្រឡោះប្រហោងនៅនាជញ្ជាំង; រន្ធគន្ធា

bouline *n.f.* ខ្សែក្តោង

bouliner *v.t.* ទាញខ្សែក្តោង ។ *v.i.* បើកក្តោង។ *Fam.* ដើរច្រំដែង

boulingrin *n.m.* សួនស្មៅ

bouliste *n.* អ្នកលេងប៊ូលបោះ

bouloir *n.m.* ប្រដាប់លាយបាយអ

boulon *n.m.* ដែកឡោស៊ី;ដែកប៊ូឡុង

boulonner *v.t.* ចាប់ឡោស៊ី ។ *Arg.* ធ្វើការ

boulonnerie *n.f.* រោងធ្វើដែកឡោស៊ី; ការធ្វើដែកឡោស៊ី

boulot,otte *a.&n.Fam.* កន្តុល (ធំ, ធាត់គ្រមុល) ។ *n.m.Pop.* ការងារ; នំប៉័ងមូលវែង

boulotter *v.i.Pop.* រស់នៅដោយមិនស្រវាស្រទេញ,រស់នៅដោយគ្មានព្រាជ្ញាច្រើន; ចំរើនឡើងបន្តិចៗម្តង (ឧ. ça boulotte) ។ *v.t.Arg.* ស៊ី (ឧ. boulotter son pain)

boum! *int.* ផ្ទង (សូរឮដោយទះ-គោះ-បែក ឬ ផ្ទុះជាដើម)

boumerang ឬ boomerang *n.m.* ដំបងប៊ូម៉ឺរ៉ង់ (ដំបងដែលជនជាតិអូស្ត្រាលីប្រើជាអាវុធសំខាន់)

bouquet *n.m.* ភួង,បាច់ ។ bouquet d'arbres ព្រៃតូច។ *Fig.* ក្លិនក្រអូបនៃស្រាទំពាំងបាយជូរ; សេចក្តីសម្រេច; ជំនូនពេលបុណ្យ ។ *Fam.* c'est le bouquet គឺវិសេសជាងគេហើយ ។ bouquet de la mariée កុលាបម្យ៉ាងផ្កាតូចៗតែច្រើន

bouquet *n.m.* ទន្សាយឈ្មោល

bouquet *n.m.* កមរមាស់ចៀម

bouquetière *n.f.* ស្ត្រីអ្នកលក់ផ្កា

bouquetin *n.m.* ពពែភ្នំ

bouquin *n.m.* ពពែឈ្មោលចាស់ ; ទន្សាយឈ្មោល

bouquin *n.m.* សៀវភៅចាស់

bouquiner *v.i.* រកសៀវភៅចាស់; អានសៀវភៅចាស់ ។ *Fam.* អាន

bouquinerie *n.f.* ជំនួញសៀវភៅចាស់; គំនរសៀវភៅចាស់; ការចូលចិត្តអានសៀវភៅចាស់

bouquineur,euse *n.&a.* ដែលចូលចិត្តអានសៀវភៅចាស់; អ្នកស្រឡាញ់សៀវភៅចាស់

bouquiniste *n.m.* ឈ្មួញសៀវភៅចាស់

bourbe *n.f.* ភក់ល្បាប់(នៅបាតបឹងត្រពាំង)

bourbeux,euse *a.* ពាសពេញដោយភក់ល្បាប់, លាយភក់ល្បាប់

bourbier *n.m.* ថ្លុក (រណ្ដៅភក់)។ *Fig.* ស្ថានការណ៍ពិបាក (ឧ. il s'est mis dans un bourbier); អំពើទុយ៌ស (ឧ. bourbier du vice)

bourbillon *n.m.* កំពូកភក់ ។ *Pathol.* គ្រាប់បូស

bourcer *v.t.* មូរក្ដោងមួយភាគ

bourcet *n.m.* ក្ដោងបួនជ្រុងធ្នាយ

bourbouil *n.m.* ឬ **bourbouille** *n.f.* ចែងថ្ងៃ (រោគសើស្បែក)

bourde *n.f.* *Fam.* ពាក្យភូត (ឧ. conter des bourdes និយាយរឿងភូត)

bourder *v.i.* ភូត

bourdon *n.m.* ឪម៉ាល់; ជួងធំ។ faux bourdon ឃ្មុំឈ្មោល

bourdonnant,e *a.* ដែលបន្លឺសូររង្វូងៗ

bourdonnement *n.m.* សូរសត្វល្អិតហើរ (ឧ. le bourdonnement des abeilles)។ *Fig.* សូរទ្រហឹង (ឧ. bourdonnement de la foule); ការហ៊ឹងត្រចៀក

bourdonner *v.i.* បន្លឺសូររង្វូងៗ ឬសូរទ្រហឹង; និយាយរទូ ។ *v.t.* ច្រៀង ឬ និយាយហ៊ឹមៗ (ឧ. bourdonner un air)

bourgeois,e *n.* គហបតី-គានី; ចៅកែ (ក្នុងភាសាកម្មករ)។ *Pop &f.* ប្រពន្ធ។ *a.* ជារបស់គហបតី (ឧ. maison bourgeoise); សាមញ្ញ (ឧ. manière bourgeoise); ផាសុខ (ឧ. ordinaire bourgeois)

bourgeoisement *adv.* តាមរបៀបគហបតី; យ៉ាងផាសុខ; យ៉ាងសាមញ្ញ

bourdonneur,euse *n. &a.* ដែលបន្លឺសូររង្វូងៗ (ឧ. insecte bourdonneur)

bourg *n.m.* ភូមិធំ

bourgade *n.f.* ភូមិធំផ្ទះរង្វើលៗ

bourgeoisie *n.f.* គហបតីភាព; វណ្ណៈគហបតី

bourgeon *n.m.* ពន្លក,ខ្នែង ។ *Fig.* មុន (កេតសើស្បែកកើតត្រង់មុខ)

bourgeonnement *n.m.* ការផុះពន្លក, ការបែកខ្នែង (ឧ. le bourgeonnement s'opère au printemps)

bourgeonner *v.i.* ផុះពន្លក, បែកខ្នែង (ឧ. les arbres bourgeonnent)។ *Fig.* កើតមុន (ឧ. son nez bourgeonne)

bourgmestre *n.m.* ចៅហ្វាយក្រុង (ប្រទេសអ័ល្លឺម៉ាញ–ស្វីស ។ល។)

bourgogne *n.m.* ស្រាទំពាំងបាយជូរ ប៊ួរហ្គោញ (ឧ. boire un verre de bourgogne)

bourlinguer *v.i.Mar.* បើកនាវាក្នុងពេលមានរលកធំៗ ។ *Pop. & fig.* ធ្វើការលំបាក

bourrache *n.f.* ដើមផកព [ផក-ព]

bourrade *n.f.* ការត្របាក់ដោចរោម (ឆ្កែត្របាក់សត្វព្រៃ)។ *Fig.* ការច្រាន; ការគប់; ការត្បក; ការឆ្លើយសឹក

bourrage *n.m.* ការញាត់គរ; ការបង្អក ចំណី; ការត្របាក់ដោចរោម (ឆ្កែ)

bourrasque *n.f.* ពលាភត [ពលះ–] (ខ្យល់ព្យុះឆាប់ស្ងប់) ។ *Fig.* កំហឹងមួយឆាប

bourre *n.f.* រោមសត្វដែលឆ្កែត្របាក់ដោច; រោម ឬ សំឡីញាត់ពូក; អាចម៍ស្ប្រត ឬ អំបោះ ។ *Bot.* ពន្លក ។ *Fig.* វត្ថុគ្មានតម្លៃ

bourreau *n.m.* ពេជ្ឈឃាត ។ *Fig.* មនុស្សសាហាវ ។ bourreau d'argent អ្នកកញ្ជះកញ្ជាយ, អ្នកចាយវាយខ្ជះខ្ជាយ

bourrée *n.f.* ចង់កាច់អុស

bourrèlement *n.m.* ការឈឺចាប់ខ្លាំង។ *Fig.* ការក្តៅក្រហាយចិត្ត (ឧ. le bourrèlement du remords)

bourreler *v.t.* ធ្វើឲ្យឈឺចាប់ខ្លាំង (ដូចជាពេជ្ឈឃាតធ្វើទុក្ខអ្នកមានទោស) ។ *Fig.* ធ្វើឲ្យក្តៅក្រហាយចិត្ត (ឧ. la conscience bourrelle les méchants)

bourrelet *n.m.* រង្វេល; ទ្រនាប់

bourrelier *n.m.* អ្នកធ្វើ ឬ លក់គ្រឿងបង្ហៀរសេះ

bourrellerie *n.f.* ជំនួញគ្រឿងបង្ហៀរសេះ; ហាងលក់គ្រឿងបង្ហៀរសេះ

bourrer *v.t.* ត្របាក់ដោចរោមសត្វ(ឆ្កែ) (ឧ. chien qui bourre un lièvre); ញាត់គរឬរោមសត្វ,ទ្រាប់ពូក (ឧ. bourrer un fauteuil);

បង្អកចំណី(ឧ.bourrer un enfant de gâteaux) ។ *Fig.* bourrer un élève de grec បង្ខំសិស្សឲ្យរៀនភាសាក្រិក(ដូចគេញាត់គរក្នុងពូក); វាយ(ឧ.bourrer quelqu'un de coups) ។ *loc. fam.* bourrer le crâne បញ្ចុះបញ្ចូល (ដោយឃោសនាអកុសល)។ *Techn.* ស្នុះ(អាចម៍ដែកឈូសជាប់ក្នុងដំណាប់ស្នូក) ។ se bourrer *v.pr.* se bourrer l'estomac ឬ se bourrer បរិភោគច្រើនហួស

bourret *n.m.* ទាដំទង់; គោឈ្មោលដំទង់ (អាយុមួយឆ្នាំ)

bourrette *n.f.* *Com.* សូត្រក្បាល (សូត្រគគ្រើម) ។ *Mam.* កូនគោញីអាយុមួយឆ្នាំ

bourriche *n.f.* កញ្ច្រែងត្រី, ចំណុះកញ្ច្រែង

bourricot *n.m.* កូនលា

bourrin *n.m.* *Fam.* លា, សេះ

bourrique *n.f.* លាញី ។ *Fig.* ល្ងង់សព្វជាតិ (ឧ. tel fait le savant qui n'est qu'une bourrique) ។ *Arg.* ភ្នាក់ងារប៉ូលិស

bourriquet *n.m.* កូនលា, លាតូច; កង្ហារស្ទូចក្នុងអណ្ដូងរ៉ែ

bourru,e *a.&n.* គគ្រាត, គគ្រើប(ឧ. fil bourru) ។ *Fig.* រម៉ាំងរម៉ោក ។ vin bourru ស្រាថ្មី(មិនទាន់ជូរនៅល់កម្រិត)

bourse *n.f.* ថង់ប្រាក់ ។ *Fig.* ប្រាក់ក្នុងថង់(ឧ. aider quelqu'un de sa bourse) ។ sans bourse délier ដោយគិតចេញប្រាក់។ *Com.* ផ្សារតម្លៃ ។ *Ens.* អាហារូបករណ៍ ។ bourse d'enseignement ឬ bourse scolaire អាហារូបករណ៍សិក្សា

boursicot ឬ **boursicaut** *n.m.* ថង់តូច; ប្រាក់សន្សំបានបន្តិចបន្តួច

boursicoter *v.i.* សន្សំប្រាក់បន្តិចបន្តួច

boursier,ère *n.* អ្នកធ្វើថង់ប្រាក់ ។ *Ens.* អាហារូបករណិក-ណិកា (អ្នកទទួលអាហារូបករណ៍)

boursouflé,e *a.* ប៉ោង,ហើម។ *Fig.* គ្មានខ្លឹមសារ (ឧ. discours boursouflé)

boursouflement *n.m.* ភាពប៉ោង; ការកើនទំហំ

boursoufler *v.t.* បំប៉ោង;ធ្វើឲ្យហើម។ *Fig.* ធ្វើឲ្យឡើងឫកឡឹត (ឧ. l'or-

gueil boursoufle les sots)។ se boursoufler *v pr.* ឡើងប៉ោង, ឡើងហើម

boursouflure *n.f.* ភាពប៉ោង, ភាពហើម (ឧ. la boursouflure du visage) ។ *Fig.* ភាពឥតខ្លឹមសារ (ឧ. boursouflure du style)

bousculade *n.f.* ការច្រានគ្នា,ការដោលគ្នា(ហៅ bousculement ក៏បានដែរ)

bousculer *v.t.* ធ្វើឲ្យច្របូកច្របល់; ច្រានទទឹងទទែង ។ *Fig.* ស្ដីបន្ទោស; ញុះ; បង្ខំ ។ se bousculer *v.pr.* ច្រានគ្នា, ដោលគ្នា, ប្រញាប់

bouse *n.f.* អាចម៍គោ

bouser *v.i.* ជុះអាចម៍ (គោ) ។ *v.t.* ព្រលាំងបាតក្រង់ដោយដីលាយអាចម៍គោ

bousillage *n.m.* មត្តិកា (បាយអគោម៍យដីលាយនឹងចំបើង)។ *Fig.&Fam.* កិច្ចការខ្ជីខ្ជា

bousiller *v.i.* បូកមត្តិកា ។ *v.t.Fam.* ធ្វើខ្ជីខ្ជា; បំបែក,បំបាក់,បង្ខូច

bousilleur,euse *n.* អ្នកបូកមត្តិកា ។ *n.m.Fam.* ជាងខ្ជីខ្ជា

bousin *n.m.* សម្រាមគ្រួបថ្ម ។ *Pop.* សូរក្ដុងក្ដាំង

boussole *n.f.* ត្រីវិស័យ ។ *Fig.* vos conseils seront ma boussole ឱវាទរបស់លោកជាត្រីវិស័យរបស់ខ្ញុំ (ខ្ញុំនឹងប្រព្រឹត្តតាមឱវាទរបស់លោក) ។ *Très fam.* perdre la boussole ស្ទន់

boustifaille *n.f.Pop.* ការស៊ីផឹក ។ *Par ext.* ម្ហូបអាហារ

bout *n.m.* ចុង(ឧ.le bout d'une gaule); ដំណាច់ (ឧ.le bout de l'année); ទីបំផុត;កន្ទុយ (ឧ.bout de chandelle);ចំនួនបន្តិចបន្តួច(ឧ. faire un bout de promenade) ។ *Fam.* bout de femme, bout d'homme មនុស្សមាឌតូច ។ bout d'aile ស្លាបកែវ (ស្លាបដុះនៅខាងចុងចំអែងស្លាបបក្សី)។ bout de l'an បុណ្យខួបមួយឆ្នាំ (បុណ្យឧទ្ទិសផលចំពោះបុគ្គលធ្វើមរណកាលទៅបានគំរប់មួយឆ្នាំ) ។ *Fig.* du bout des levres ឬ du bout des dents ចុងមាត់ចុងក; ដោយមិនស្មោះ ។ rire du bout des dents ខំប្រឹងសើច (ដោយមិនស្មោះ, ដោយគ្មានចំណង់) ។ savoir sur le bout des doigts ចេះស្ទាត់,ដឹង ឬ ស្គាល់ច្បាស់ ។ avoir...

au bout de la langue នៅចុង មាត់ (នឹកហៀបរតែនឹងឃើញ) ។ pousser à bout ធ្វើឲ្យទ្រាំមិនបាន ។ mettre à bout ផ្ចាញ់ឲ្យ (បន្ទុចបង្អាក់ឲ្យទាល់ពាក្យសំដី) ។être à bout ទាល់គំនិត;អស់មធ្យោបាយ; អស់(ឧ. ma patience et mes forces sont à bout) ។ venir à bout de ឈ្នះ,បានសម្រេច ។ à tout bout de champ គ្រប់ពេល ។ au bout du monde នៅជើងមេឃ,ឆ្ងាយណាស់។ à bout de *loc. pré.* អស់,ទាល់(ឧ. être à bout de force អស់កម្លាំង, លែងធ្វើអ្វីកើត; être à bout de ressources ទាល់ច្រកថ្លី,ទាល់គំនិត; être à bout de patience លែងទ្រាំបាន) ។

Loc. adv. bout à bout បន្តគ្នា ។ de bout en bout ឬ d'un bout à l'autre ពីដើមដល់ចុង, រហូត ។ tirer à bout portant បាញ់ផ្ទប់ (បាញ់ជិតណាស់) ។ au bout du compte ដោយសម្រេចទៅ, ដោយគិតមែនទែនទៅ ។ au bout de deux heures ក្រោយរយៈពេលពីរម៉ោង

boutade *n.f.* ចិត្តសាវ៉ា (ឧ.agir par boutades); ពាក្យប្រមាថ (ឧ. il nous a amusés de ses boutades) ។ *Particul.*សំដីគ្រៀមក្រំ (ឧ. les boutades d'Alceste)

boute-en-train *n.m.inv.* អ្នកនាំឲ្យសប្បាយ, អ្នកនាំឲ្យក្លៀវក្លា

boutefeu *n.&a.m.* ប្រឆេះអុជកាំភ្លើងធំ ។ *Fig.* អ្នកបង្កជម្លោះ ឬ ចលាចល

bouteille *n.f.* ដប, ចំណុះដប ។ aimer la bouteille ស្រឡាញ់ដប (ស្រា), ចូលចិត្តផឹក ។ c'est la bouteille à l'encre គឺជារឿងស្មុគស្មាញមិនអាចយល់បាន ។ *Mar.* បង្គន់ក្នុងនាវា

bouteiller ឬ **boutillier** *n.m.* ចាងហ្វាងដបស្រា (ក្នុងព្រះរាជវាំង)

bouteillon *n.m.* *Mil.* ឆ្នាំងដប្រៃ

bouter *v.t.* ដាក់, ច្រាន ។ *Techn.* ដុះលាងស្បែក

boutique *n.f.* ហាងលក់ទំនិញ; ទំនិញតាំងលក់ក្នុងហាង; រោងជាង; ប្រដាប់ប្រដារបស់ជាងម្នាក់ ។ *Fam.* ការកិច្ច (ឧ. faire marcher sa boutique) ។ *Par dénigr.* ផ្ទះគ្មាន

សណ្ដាប់ធ្នាប់(ឧ. quelle boutique)

boutiquier,ère *n.* អ្នកកាន់ការហាង លក់ទំនិញ

boutis *n.m.* កន្លែងជ្រូកព្រៃឈ្លុះ

boutoir *n.m.* *Véner.* ច្រមុះជ្រូកព្រៃ។ *Fig.* coups de boutoir សំដីធ្ងន់ធ្ងាស់ ។ *Techn.* ដែកកោស,ដែកលុង

bouton *n.m.* ខ្ទង (ឧ. bouton de rose); ពក, ផ្គត (ឧ.bouton de fièvre); ឡេវ; អ្វីៗដែលមានរាងស្រ-ដៀងនឹងឡេវ(ឧ. bouton de fleuret ចុងគ្រមោងនៃដាវ); កិបចុច (គ្រឿងអគ្គិសនី-កណ្ដឹង ។ល។)(ឧ. bouton de sonnette)

boutonnage *n.m.* ការបិទឡេវ

boutonnant, e *a.* ដែលមានឡេវ សម្រាប់បិទ (ឧ.robe, redingote boutonnante)

boutonner *v.i.* ដុះខ្ទង (ឧ. rosiers qui commencent à boutonner) ។ *Fam.* មានពក,មានផ្គត(ឧ. nez qui boutonne); មានឡេវ (ឧ. corsage qui boutonne par derrière)។ *v.t.* បិទឡេវ(ឧ. boutonner son vêtement)។ *Escr.* ចាក់ដោយដាវចុងគ្រមោង (ឧ. boutonner son adversaire)។ se boutonner *v.pr.* កេនឡេវ បិទ (ឧ. pantalon qui se boutonne sur les côtés); បិទឡេវ ទោ (ឧ.enfant qui ne sait pas encore se boutonner)

boutonnerie *n.f.* រោងធ្វើឡេវ; ជំនួញ ឡេវ (ឧ. ouvrir une boutonnerie)

boutonneux,euse *a.* ដែលមានផ្គត លើស្បែក (ឧ. visage boutonneux); ដែលឲ្យចេញផ្គត (ឧ. rougeole boutonneuse)

boutonnier,ère *n.* អ្នកធ្វើ ឬ លក់ឡេវ

boutonnière *n.f.* ប្រហោងឡេវ; ផ្កា ដែលគេពាក់ត្រង់ករអាវ

bouton-pression *n.m.* ឡេវកិប (*pl.* des boutons-pression)

bouts-rimés *n.m. pl.* ពាក្យកាព្យ តែងតាមចុងធួនដែលគេដាក់ឲ្យស្រាប់។ *Sing.* កំណាព្យតែងតាមចុងធួនដែល គេដាក់ឲ្យស្រាប់ (ឧ. un mauvais bout-rimé)

bouturage *n.m.* ការផ្សាំ

bouture *n.f.* កូនផ្សាំ

bouturer *v.i.* ដុះលំពង់តាមឫសឬមែក។

v.t. ផ្គុំ

bouverie *n.f.* ក្រោលគោ

bouvet *n.m.* ដែកលក

bouvier,ère *n.* គោបាល, គង្វាលគោ។ *Fig.* មនុស្សឥតគួរសម ។ bouvier des Flandres ឆ្កែគង្វាលម្យ៉ាង

bouvillon *n m.* គោស្ទាវ (ហៅ bouveau ឬ bouvelet ក៏បានដែរ)

bouvril *n.m.* រោងគោក្នុងទីសត្តឃាដ

bovidés *n.m. pl.* គោសាទិសសត្វ [សា-ទិ-សះ-] (ពួកសត្វសណ្ឋានគោ)

bovin,e *a.* គោសាទិស [-ទិ-សះ](ឧ. race bovine)

bovinés ឬ **bovins** *n.m.pl.* ពួកគោ

box *n.m.* បន្ទប់សេះក្នុងក្រោល (សម្រាប់សេះមួយ); បន្ទប់រោងរថយន្ត

boxe *n.f.* កីឡាប្រដាល់,ការប្រដាល់។ boxe anglaise ការប្រដាល់របៀបអង់គ្លេស

boxer *v.t.* ប្រដាល់

boxeur,euse *n.&a.* អ្នកប្រដាល់

boy *n.m.* បោយ,អ្នកបម្រើ(ក្នុងប្រទេសអាណានិគម)

boyau *n.m.* ពោះវៀន; បំពង់កៅស៊ូបន្តពីម៉ាស៊ីនបូមទឹក ។ *Fig.* ផ្លូវច្រកវែងហើយចង្អៀត; លេណដ្ឋានចង្អៀតភ្ជាប់ទីប្រយុទ្ធ ។ corde à boyau ខ្សែទ្រ, ខ្សែពិណ (ធ្វើអំពីពោះវៀនសត្វ)

boyauderie *n.f.* កន្លែងធ្វើពោះវៀនសត្វ

boyaudier,ère *n.* ជាងធ្វើពោះវៀនសត្វ

boycottage *n.m.* ពហិការ (ការមិនអើពើ ឬ មិនរាប់រក ដោយផ្ទាល់)

boycotter *v.t.* ធ្វើពហិការ, មិនអើពើ ឬ ឬមិនរាប់រក (ដោយផ្ទាល់)

boycotteur,euse *n.* ពហិការី

boy-scout *n.m.* កាយរឹទ្ធ (*pl.* des boy - scouts)

brabant *n.m.* នង្គ័លដែកម្យ៉ាង

bracelet *n.m.* កងដៃ, ខ្សែដៃ; រឹង មានរាងស្រដៀងកងដៃ

bracelet-montre *n.m.* នាឡិកាដៃ (*pl.* des bracelets-montres)

brachial,e,aux *a.* នៃដៃ (ឧ. artère brachiale)

braconnage *n.m.* ការបរបាញ់ ឬ នេសាទដោយលួចលាក់

braconner *v.i.* បរបាញ់ ឬ នេសាទដោយលួចលាក់(គឺ:១-ក្នុងសម័យហាមឃាត់;២-ដោយប្រើគ្រឿងប្រដាប់ហាមឃាត់; ៣- ដោយគ្មានអនុញ្ញាត;៤-ត្រង់កន្លែងហាមឃាត់)

braconnier,ère *n.* អ្នកបរបាញ់ ឬ

នៃសាទរដោយល្អចលាក់

bractéal,e,aux *a.* នៃស្លឹកទ្រនាប់ផ្កា

bractée *n.f.* ស្លឹកទ្រនាប់ផ្កា

brader *v.t.* លក់ឡូយឡុងរបស់ចាស់

braderie *n.f.* ការលក់ឡូយឡុងរបស់ចាស់

bradypepsie *n.f.* ការរំលាយអាហារដោយពិបាក

brahmane, brahme, bramé, bramine *n.m.* ព្រាហ្មណ៍

brahmanique *a.* ព្រហ្មញ្ញ.ព្រាហ្មណិក

brahmanisme *n.m.* ព្រហ្មញ្ញសាសនា

brahme *n.m.* ម.ព. brahmane

braie *n.f.* សំពត់រុំកូនក្មេង

braillard,e ឬ **brailleur, euse** *a.&n.* ដែលឡូឡា

braille *n.m.* អក្សរសម្រាប់មនុស្សខ្វាក់

braillement *n.m.* ការស្រែកឡូឡា

brailler *v.i.* ស្រែកឡូឡា; យំ (ក្មេង) ។ *Fig.* ស្រែក; ច្រៀងខ្លាំងហើយមិនពិរោះ

braiment *n.m.* សម្រែកលា

braire *v.i.* កញ្ជ្រៀវ (លា)

braise *n.f.* ធ្យូង, រងើក

braiser *v.t.* រំងំ (ពិសិនលើរងើក) (ឧ. braiser une gigot de mouton)

braisette *n f.* រងើកតូច

braisier *n.m.* ឡាំងធ្យូង

braisière *n.f.* ប្រដាប់សត់រងើកធ្យូង; ឆ្នាំងភ្លើង

braisiller *v.i.* ព្រាយពន្លឺ

brame *n.m.* ម.ព. brahmane

bramement *n.m.* សម្រែករមាំងឬក្តាន់

bramer *v.i.* ថ្ងូច (រមាំង ឬ ក្តាន់)

bramine *n.m.* ម.ព. brahmane

bran *n.m.* ដើមកន្ទក់ (កន្ទក់គ្រាប់ធំ) ។ *Pop.* អាចម៍ (ពាក្យសាមញ្ញ) ។ bran de scie អាចម៍រណារ

branc ឬ **brand** *n.m.* ដាវមុខធំ (ប្រើក្នុងយុគកណ្តាល)

brancard *n.m.* ស្នែងរបួស។ *Techn.* ទូករទេះ

brancardage *n.m.* ការសែងជម្ងឺដោយស្នែងរបួស

brancardier *n.m.* អ្នកសែងជម្ងឺដោយស្នែងរបួស

branchage *n.m.* មែក (នៃឈើមួយដើម)(ឧ. élaguer le branchage d'un arbre trop touffu); ពំនរមែក (ឧ. faire des huttes de branchages) ។ *Par ext.* &*Poésie* ស្នែងក្តាន់

branche *n.f.* សាខា មែកឈើ:ដៃស្ទឹង ឬ ទន្លេ (ឧ. les branches du Mékong) ។ *Fig.* សាខា (ឧ. les branches de l'enseignement)

branchement *n.m.* ការទំលើមែកឈើ; ការព្យួរ; ការតបំបែក; ខ្សែ ឬ បំពង់រង

brancher *v.i.* ទំលើមែកឈើ (ឧ. l'alouette ne branche pas) ។ *v.t.* ព្យួរនៅមែកឈើ (ឧ. brancher un voleur); តបំបែក (ឧ. brancher un tuyau)

branchial,e,aux *a.* នៃស្រកីត្រី (ឧ. veines branchiales)

branchies *n.f. pl.* ស្រកី (ត្រី)

branchu,e *a.* ដែលមែកមែកច្រើន

brand *n.m.* ម.ព. branc

brandi *a.* tout brandi ទាំងមូល, ទាំងស្រុង (ឧ. le faire passer tout brandi par la fenêtre)

brandiller *v.t.* យោល, ទោង (ឧ. brandiller les jambes) ។ *v.i.* បក់, អណ្ដែត

brandir *v.t.* យារ,ងារ, គ្រវី (ឧ. brandir un sabre, un javelot)

brandon *n.m.* តប់ចង្កៀង; ដំរុយចំបើង (ដោតក្នុងស្រែ ឬ បំការជាសញ្ញាថាស្រូវ ឬ ផលស្រែចំការនោះត្រូវរឹបអូស); ផ្កាភ្លើង ។ *Fig.* allumer le brandon de la discorde បង្កជម្លោះ

brandy *n.m.* ស្រាប្រាន់ឌី

branlant,e *a.* រង្គើ,រញ្ជួយ,ដែលយោល (ឧ. tête branlante)

branle *n.m.* ការយោល, ការរញ្ជួយ (ឧ. le branle d'une cloche) ។ *Fig.* ការធ្វើឲ្យកម្រើក (ឧ. mettre en branle) ។ *Mar.* អង្រឹងកម្មករនាវា ។ ការកំដាវង់មូល ។ *Fig.* donner le branle ដឹកនាំឲ្យសប្បាយ ឬ ឲ្យធ្វើការ

branle-bas *n.m.inv.* ការរៀបចំប្រយុទ្ធលើនាវា (ឧ.sonner le branle-bas) ។ *Fig.* ការច្របូកច្របល់; សួរអ្វីអែរ

branlement *n.m.* ដំណើរយោល, ដំណើររញ្ជួយ ឬ រង្គើ

branler *v.t.* យោល, អង្រួន, គ្រវី (ឧ. branler la tête) ។ *v.i.* រញ្ជួយ, រង្គើ (ឧ. le plancher branle) ។ *Fig. & Fam.* branler dans le manche មានគ្រោះថ្នាក់ដោយបាត់កន្លែងធ្វើការ ឬ ដោយខ្វះចក្ខុគាប់

branloire *n.f.* ក្តារទោង

braquage *n.m.* ម.ព. braquement

braque *n.m.* ឆ្កែប្រមាញ់កេមខ្វង ។ *n.&a. Fig.&Fam.* ពាយងាយ, ល្ងេល្ងើ

braquemart *n.m.* ដាវម្យ៉ាងផ្លែខ្លី

braquement *n.m.* ការដម្រង់, ការភ្ជង់ (ឧ. le braquement d'un canon)

braquer *v.t.* ដម្រង់, ភ្ជង់ (ឧ. braquer un canon)។ *Par ext.* braquer les yeux sur quelqu'un សម្លឹងសម្លក់ ។ *Autom.* បត់ (រថយន្ត)

bras *n.m.* ដៃ។ bras ឬ le haut du bras ដើមដៃ ។ avant-bras ម.ព. នេះ។ *Par ext.* ដៃ (ការងារធ្វើដោយដៃ) (ឧ. n'avoir que le bras pour se nourrir) ; ដៃ(អ្នកធ្វើការដោយដៃ) (ឧ. l'agriculture manque de bras)។ *Fig.* ការជួយ, ឧបត្ថម្ភ (ឧ. prêter, refuser son bras à une cause); តេជានុភាព (ឧ. le bras de Dieu); ដៃ(សេចក្ដីអង់អាច) (ឧ. tout cède à son bras អ្វីក៏ចាញ់ដៃគាត់ទាំងអស់); កណ្ដាប់ដៃ (ឧ. arracher une victime des bras de la mort)។ bras de fer ឬ d'airain កម្លាំងកាយ; *au fig.* ឆន្ទៈមុះមុត (ឧ. il faut un bras de fer pour gouverner certaines maisons) ។ avoir le bras long មានអំណាច ។ être le bras droit de quelqu'un ជាដៃស្ដាំរបស់ (ជាអ្នកជំនួយសំខាន់) ។ avoir quelque chose sur les bras រងបន្ទុក; កំពុងតែខ្វល់នឹងអ្វីមួយ (ឧ. il a une vilaine affaire sur le bras) ។ avoir quelqu'un sur les bras រងបន្ទុក, ចិញ្ចឹម (ឧ. avoir quatre enfants sur les bras)។ avoir, se mettre quelqu'un sur les bras ត្រូវទប់ទល់នឹង, ធ្វើឲ្យគេប្រទូសរ៉ាយ (ឧ. avoir l'armée tout entière sur les bras)។ rester les bras croisés ឈរឱបដៃ (នៅស្ងៀមមិនធ្វើអ្វី) ។ donner, offrir le bras à quelqu'un លូកដៃជួយគ្រាហ៍ ។ avoir quelqu'un sous le bras ជួយគ្រាហ៍ ។ prendre le bras de quelqu'un ទប់ខ្លួនលើដៃអ្នកណាមួយ ។ bras dessus bras dessous ដោយប្រកៀកដៃគ្នា ។ ouvrir ឬ tendre ses bras à quel-

qu'un ហុចដៃឲ្យ; *au fig.* ជួយ; ឱបអរ (រាប់អានឬទទួលបដិសណ្ឋារ ដោយមានអំណរក្រៃពេក ហាក់ដូចជានឹងស្ទុះទៅឱប); លើកទោស; ចង់ឲ្យមក ។ tendre les bras vers quelqu'un ឬ à quelqu'un សុំឲ្យគេជួយ ។ tendre les bras vers quelque chose ចង់បានរបស់អ្វីមួយខ្លាំងណាស់ ។ se jeter dans les bras ឬ entre les bras de quelqu'un ឱបរឹត; *au fig.* បណ្ដោយខ្លួនឲ្យ; ឱបដៃឱបជើង (សុំពឹងផ្អែក ឬ ជ្រកកោន) ។ être dans les bras de Morphée ដេកលក់ ។ s'endormir dans les bras du Seigneur ទទួលអនិច្ចកម្ម (ដោយស្រួល) ។ avoir les bras rompus ចង់រលេះដៃ (ហត់) ។ les bras me tombent រកក់រលេះដៃ (ហត់); ខ្ញុំធ្លល់ស្រឡាំងកាំង ។ couper bras et jambes à quelqu'un ធ្វើឲ្យស្រឡាំងកាំង; កាត់ដៃកាត់ជើង (លែងឲ្យធ្វើអ្វីកើត) ។ arrêter le bras de quelqu'un ចាប់ដៃ (ឃាត់មិនឲ្យសងសឹក-មិនឲ្យធ្វើទោស ឬ មិនឲ្យធ្វើអំពើអាក្រក់) ។ faire de gros bras ក្អាដៃ ។

Loc. adv. à bras ដែលគេធ្វើឲ្យដើរដោយដៃ (ឧ. un moulin à bras; une presse à bras) ។ à force de bras ដោយកម្លាំងដៃ ។ à tour de bras អស់ទំហឹងដៃ; គ្មានប្រណី ។ à bras raccourci គ្មានរាពណិត; អស់ទំហឹង ។ à bras ouverts ឬ les bras ouverts ដោយរាក់ទាក់ ។ à pleins bras ពេញដៃ ។ à bras-le-corps (saisir quelqu'un à bras-le-corps ចាប់ឱបពាក់កណ្ដាលខ្លួន) ។ l'arme au bras អាវុធនៅដៃ; *au fig.* ដោយប្រុងប្រយ័ត, គ្មានធ្វេស ។ gros comme le bras ពេញមាត់, គ្មានញញើត, គ្មានសំចៃមាត់ (ឧ. appeler quelqu'un « monseigneur » gros comme le bras) ។

Prov. les bons bras font les bonnes lames (ជាងចំណានដំកាំបិតបានល្អ) ជាងមិនកើតកុំបន្ទោសដែក ។

Ameubl. ភ្នាក់ដៃ (ឧ. bras de fauteuil) ។ *Arbor.* **bras**

de vigne មែកទំពាំងបាយជូរ (មែកធំដែលបែកពីដើម៖ ហៅថា corne ឬ mère branche ក៏បានដែរ) ។ *Géogr.* ដៃ (ឧ.un bras du Mékong; un bras de mer)។ *Hippol.* ភ្លៅមុខៗនៃសេះ

brasage *n.m.* ម.ព. brasure

braser *v.t.* ផ្សារតភ្ជាប់លោហធាតុ(ដោយយកលោហធាតុផ្សេងធ្វើជាទឹកបន្សារ)

brasero *n.m.* ជើងក្រានរងើក (*pl.* des braseros)

brasier *n.m.* រងើកភ្លើង

brasiller *v.t.* អាំង(ដោយរងើកភ្លើង)(ឧ. brasiller des côtelettes) ។ *v.i.* ចាំងពន្លឺ (ទឹកសមុទ្រ)

brasque *n.f.* ដីបាក់ពុម្ពឬដីធំបូក(ដីឥដ្ឋលាយនឹងកំទេចធ្យូង); ការពាសលោហធាតុរឹង (មិនរលាយ)

brassage *n.m.* ការលាយច្របល់ឬកូររើក

brassard *n.m.* ក្រោះពាសដៃ; ប៉ានដៃ

brasse *n.f.* ព្យាម (១ម៉៦២); របៀបហែលម្យ៉ាង

brassée *n.f.* ឱប(អ្វីៗដែលក្រសោបបាន) (ឧ. une brassée de paille ចម្បើងមួយឱប); ចលនាដៃវាសព្រមគ្នានៃអ្នកហែលទឹក;សំទុះហែលមួយវាសដៃ

brasser *v.t.* ច្របាច់ច្របល់; កូររើក; ធ្វើបៀរ ។ *Fig.* ធ្វើដោយប្រញាប់ប្រញាល់ (ឧ.brasser des affaires); ល្បួចធ្វើ (ឧ.brasser une intrigue)

brasserie *n.f.* កន្លែងធ្វើបៀរ; ការធ្វើបៀរ ; ផ្ទះលក់បៀរ នឹង គ្រឿងស្រស់ស្រូប

brasseur,euse *n.* អ្នកធ្វើ ឬ លក់បៀរដុំ ។ *Fig.* brasseur d'affaires អ្នកកាន់ការច្រើនមុខ

brassicourt *a* &*n.m.* សេះជើងកោងត្រង់ជង្គង់

brassière *n.f.* អាវកូនងែត ។ *loc. fam.* être, mettre ឬ tenir quelqu'un en brassière ឬ en brassières គ្មានសេរីភាព;បង្ខាំងមិនឲ្យធ្វើអ្វីតាមចិត្ត; ដឹកនាំដូចកូនក្មេង។ *pl.* ខ្សែស្ពាយចងបរិក្ខារ ឬ ជាល; ខ្សែប្រហកដៃ (ក្នុងរថយន្ត)

brassin *n.m.* ធុងបៀរ

brasure *n.f.* មុខបន្សារ; ការផ្សារតភ្ជាប់លោហធាតុ; ទឹកបន្សារ

bravache *n.m.* អ្នកធ្វើឫកក្លាហាន។*a.* air bravache ឫកក្លែងជាក្លាហាន

bravade *n.f.* ឫកគយេរ (ឧ.se laisser

intimider par les bravades d'un fanfaron);ការធ្វើឫកក្លាហាន (ឧ.s'exposer au danger par bravade ធ្វើឫកដំបិនខ្លាចគ្រោះថ្នាក់)

bravader *v.i.* ធ្វើឫកគយរ;ធ្វើឫកក្លាហាន

brave *a.* ក្លាហាន(ឧ.homme brave); ទៀងត្រង់,ល្អ(ឧ.brave homme)។ *n.m.* អ្នកក្លាហាន

bravement *adv.* ដោយក្លាហាន

braver *v.t.* តស៊ូ; ជំទាស់ (ឧ.braver quelqu'un); ពុះពារ (ឧ.braver la mort)

bravissimo *int.* ជយោ! (អតិវិសេសសព្ទនៃ bravo)

bravo ! *int.* ជយោ! ។ *n m.* ការយល់ស្រប, ការទះដៃសរសើរ (ឧ. redoubler les bravos)

bravoure *n.f.* សុរភាព, សេចក្តីក្លាហាន

break [brék] *n.m.* រទេះម៉្យាងមានកង់បួន

brebis *n.f.* ចៀមញី (cri: la brebis bêle); បរិស័ទគ្រិស្តសាសនាក្រោមឱវាទនៃបព្វជិតមួយរូប ។ *Fig.* brebis galeuse មនុស្សឧក្បាត ។ *Prov.* brebis qui bêle perd sa goulée ពោកៗសឹកតែមាត់ត្រដោក ឆ្អែតឯពោះក្រពើ ។ qui se fait brebis, le loup le mange ស្លូតស្លាប់ ឿងរឿរមានភព្វអាយុយឺនយូរ (អ្នកដែលស្លូតពេក រមែងមានជនពាលបៀតបៀន)

brèche *n.f.* ប្រហោងជញ្ជាំង - កំពែង ឬ របង; មុខដែប(កាំបិត) ។ *Fig.* ការសៅហ្មង (ឧ.c'est une brèche à l'honneur) ។ être toujours sur la brèche មានការប្រយុទ្ធ ឬ មានកិច្ចរវល់ជាប់ជានិច្ច ។ mourir sur la brèche ស្លាប់ក្នុងពេលកំពុងប្រយុទ្ធ ។ battre en brèche បាញ់ដោយកាំភ្លើងធំ; *au fig.* ចោទប្រកាន់ ឬ បដិសេធដោយម៉ឺងម៉ាត់ (ឧ. battre en brèche un principe)

brèche-dent *a.&n.* ដែលបាក់ធ្មេញមុខ (*pl.* des brèche-dents)

bréchet *n.m.* ឆ្អឹងទ្រូងបក្សី

bredouillage ឬ **bredouillement** *n.m.* ដំណើរនិយាយឡប់ៗ;សំដីឡប់ៗ

bredouille *n.f.* ការមិនបានសម្រេច ។ *a.* ឥតបាន,គ្រាំស្អេក(ឧ.revenir bredouille)

bredouiller *v.i.* និយាយឡប់ៗ

bredouilleur,euse *a.&n.* ដែល

និយាយឡប់ៗ

bref,ève *a.* ស្បែះ, ខ្លី (ឧ. discours bref); បំព្រួញ; ឆាប់; កំបុត (សំដី) (ឧ. ton bref; parole brève)។ *n.f.* ព្យាង្គខ្លី ។ bref *adv.* នៅទីបំផុតនេះ, ពោលដោយខ្លីទៅ (ឧ. bref, je ne veux pas)

bréhaigne *a.f.* អា (បសុសត្វញី)

brelan *n.m.* ល្បែងបៀបីសន្លឹក; ផ្ទះបើកក្បាលបៀ (ឧ. tenir brelan chez soi)

breloque *n.f.* អលង្ការរបោកៗ; បន្តោកខ្សែនាឡិកា។battre la breloque ដើរម៉ិនទៀង(ឧ. une montre qui bat la breloque); និយាយផ្តេសផ្តាស, និយាយរវើរវាយ

brésil *n.m.* ស្បែង (ឈើមានខ្លឹមក្រហមសម្រាប់ជ្រលក់ពណ៌) (ហៅ bois de brésil ក៏បានដែរ)

brésilien,enne *a.* នៃប្រទេសប្រេស៊ីល។ *n.* ជនជាតិប្រេស៊ីល

brésiller *v.t.* ជ្រលក់ស្បែង

brésiller *v.t.* កំទេច(ដូចគេកិនបំបែក)។ se brésiller *v.pr.* ឬ *v.i.* បែកជាផង់ (ដោយស្ងួត)

bretailler *v.i.* វាយហួតដាវ

bretailleur *n.m.* អ្នកវាយហួតដាវ

bretauder *v.t.* កាត់រំញរខុញ (រោមសត្វ); កាត់ត្រចៀកសត្វ; ក្រៀវសត្វ

bretelle *n.f.* ខ្សែស្ពាយ ។ *pl.* ខ្សែព្រយុងខោ

breton,onne *a.* នៃខេត្តប្រឺតាញ។ *n.* ជនខេត្តប្រឺតាញ ។ *n.m.* ភាសាខេត្តប្រឺតាញ

bretonnant,e *a.* ដែលរក្សាទំនៀមទម្លាប់ចាស់នៃខេត្តប្រឺតាញ

brette *n.f.* ដាវវែង

bretteler *v.t.* កាត់ដោយប្រដាប់មានធ្មេញ (ដើម្បីឲ្យមានស្នាមរំញរខុញ)

bretteur *n.m.* អ្នកចូលចិត្តប្រយុទ្ធគ្នាដោយដាវ

breuil *n.m.* ព្រៃល្បាស់មានរបងសម្រាប់សត្វជ្រកពួន

brevage *n.m.* ភេសជ្ជៈ; ឱសថទឹកសម្រាប់សត្វ

brevet *n.m.* ប្រកាសនីយប័ត្រ ។ brevet élémentaire ប្រកាសនីយប័ត្រជាន់ដំបូង។brevet supérieur ប្រកាសនីយប័ត្រជាន់ខ្ពស់ ។ brevet d'études du 1er cycle du second degré ប្រកាសនីយប័ត្រសិក្សាបឋមភូមិថ្នាក់ទី ២ ។ brevet

d'aptitude pédagogique ប្រកាសនីយប័ត្រគរុកោសល្យសម្បទា ។ brevet de capacité ប្រកាសនីយប័ត្រសមត្ថភាព ។ brevet d'enseignement industriel ប្រកាសនីយប័ត្រវិជ្ជាឧស្សាហកម្ម ។ acte en brevet លិខិតសារការីឥតដើម ។ brevet d'invention ប្រកាសនីយប័ត្រតក្កកម្ម

brevetable *a.* អាចទទួលប្រកាសនីយប័ត្របាន; អាចការពារដោយប្រកាសនីយប័ត្របាន

breveté,e *n.m.* អ្នកមានប្រកាសនីយប័ត្រ ។ *a.* ដែលមានប្រកាសនីយប័ត្រ (មានវិជ្ជាឯកទេស) (ឧ. un canonnier breveté)

breveter *v.t.* ឲ្យប្រកាសនីយប័ត្រ; ការពារដោយប្រកាសនីយប័ត្រ (ឧ. breveter une invention)

bréviaire *n.m.* សៀវភៅធម៌ប្រចាំថ្ងៃ (ក្នុងគ្រិស្តសាសនា); ធម៌សូត្រប្រចាំថ្ងៃ ។ *Fig.* សៀវភៅសំណប់ (ដែលអានរាល់ថ្ងៃ) (ឧ. Horace est le bréviaire des gens de lettres)

brévité *n.f.* រស្សភាព, ភាពខ្លី (ឧ. brévité d'une syllabe)

briard *n.m.* ឆ្កែគង្វាលបារាំង

bribe *n.f.* សំណល់អាហារ ។ *Par ext.* ផ្នែកតូចៗ; ឃ្លាដាច់ៗ

bric-à-brac *n.m.inv.* ទំនិញចាស់ៗ; ហាងលក់ទំនិញចាស់ៗ

bric et de broc (de) *loc. adv.* ដោយផ្សេងៗ (ឧ. il a ramassé ça de bric et de broc); ដោយមធ្យោបាយផ្សេងៗ

brick *n.m.* នាវាក្តោងម្យ៉ាង

bricolage *n.m.* ការធ្វើការកំប៉ុកកំប៉ុកក្នុងផ្ទះ

bricole *n.f.* ស្នាម្យ៉ាង (ប្រើក្នុងយុគកណ្តាល); ការផ្លាត (គ្រាប់) (ឧ. toucher un but par bricole); ការខ្ទាតមកវិញ (បាល់ដែលគប់ទៅប៉ះនឹងជញ្ជាំង) ។ *Fig.* ផ្លូវវៀច, ឧបាយកល (ឧ. la politique n'est qu'un jeu de bricole) ។ *Fam.* កិច្ចបន្តិចបន្តួច (ឧ. s'occuper à des bricoles); របស់គ្មានតម្លៃ (ឧ. ça, c'est de la bricole) ។ *Artill.* bricole de manœuvre ខ្សែអូសកាំភ្លើងធំ ។ *Harnach.* គ្រឿងទំបំពាក់ត្រង់ទ្រូង ។ *Techn.* ខ្សែអូស

bricoler *v.i.* ផ្លាត (ឧ. balle qui

bricole); ខ្ទាតមកវិញ (ឧ. bille qui bricole)។ *Fig* ប្រើឧបាយកល ។ *Fam.* ជាប់របរនេះបន្តិចនោះបន្តិច (ឧ. que fait-il? il bricole); ធ្វើការកំប៉ិកកំប៉ុកក្នុងផ្ទះ ។ *v.t.* bricoler un cheval បំពាក់ខ្សែអួស ។ *Fam.* bricoler le chemin ដើរបត់បែន(ដូចមនុស្សស្រវឹង) ។ se bricoler *v.pr.* ត្រូវគិតគូរ,ត្រូវបានសម្រេច (ឧ. que d'affaires se bricolent au café!)

bricoleur,euse *n.* អ្នកធ្វើការកំប៉ិកកំប៉ុកក្នុងផ្ទះ

bride *n.f.* បង្ហៀរសេះ ។ main de bride ដៃឆ្វេង (ដៃដែលកាន់បង្ហៀរ) ។ *Fig.* គ្រឿងទប់ (ឧ.la méchanceté est l'éperon de l'esprit, la bonté est la bride)។

Loc. fam. bride abattue, à bride abattue, à toute bride ដោយបំបោល ឬ លែងបង្ហៀរ ; យ៉ាងលឿន (ឧ. enfant qui court à bride abattue)។ la bride sur le cou ដោយគ្មានទប់, តាមចិត្ត ។ aller bride en main ធ្វើដោយប្រុងប្រយ័ត្ន (ដូចគេកាន់បង្ហៀរជាប់នៅដៃ) ។ tourner bride ត្រឡប់មកវិញ ។ tenir bride ទប់ដោយបង្ហៀរ; *au fig.* ទប់ (ឧ. tiens en bride tes mouvements naturels) ។ tenir la bride, la bride haute, la bride courte, serrer la bride ទាញបង្ហៀរទប់យ៉ាងមាំ ; *au fig.* រឹតត្បិត, ធ្វើតឹងរ៉ឹង (មិនបណ្តែតបណ្តោយ) (ឧ. les enfants ont souvent besoin qu'on leur tienne la bride courte)។ lâcher la bride បណ្តោយតាមចិត្ត ។ *Cout.* ខ្សែចង្កា (ខ្សែពាក់ក្រោមចង្កាកុំឲ្យប្លូកប៉ើង); ថ្នេរស្រេះប្រហោងឡេវ។

Prov. à cheval donné, on ne regarde pas à la bride (ឬ aux dents) ម.ព. cheval ។ il a plus besoin de bride que d'éperon មនុស្សនេះមិនបាច់ជម្រុញទេ មានតែត្រូវឃាត់វិញ ។

brider *v.t.* បំពាក់បង្ហៀរ (ឧ. brider un cheval) ។ *Par ext.* រឹតពេក, ចង្អៀត (ឧ. habit qui bride aux emmanchures) ។

Arg. បិទ(ឧ. brider la lourde បិទទ្វារ) ។ *Art cul.* brider une volaille ចងជើង ចងស្លាបក្រៀបគ្នា (មាន់ទា) ។ *Fig.* ទប់, រៀប ។ *loc.fam.* brider quelqu'un, brider la bécasse កៀងបញ្ចូលសឹង (ដឹកនាំឲ្យជាប់កុន) ។ brider son cheval (ឬ son âne) par la queue ទឹមគោពីកន្ទុយ, ធ្វើការច្រាស ។ *Prov.* chacun bride sa bête គោអ្នកណា អ្នកនោះទឹម; ម្នាក់ៗអាចប្រព្រឹត្តតាមទំនើងចិត្តខ្លួន

bridge *n.m.* ល្បែងបៀម៉្យាង ។ *Art dent.* ធ្មេញមាស

bridger *v.i.* លេងបៀ

bridgeur,euse *n.* អ្នកលេងបៀ

bridon *n.m.* បង្ហៀរតូច

brièvement *adv.* ដោយយ៉ាងខ្លី,យ៉ាងខ្លី

brièveté *n.f.* ពេលខ្លី, ភាពខ្លី (brièveté de la vie); ភាពសង្ខេប (ឧ.trop de brièveté rend le style obscur)

brigade *n.f.* *Armée* កងពលតូច ។ général de brigade ឧ.ព. général ។ *Police* កងឥស្សរៈ brigade centrale កងឥស្សរកណ្តាល ។ brigade de police spéciale កងប៉ូលិសពិសេស

brigadier *n.m.* អ្នកត្រួត ។ brigadier de la P.M.K. អ្នកត្រួត ក.ត.ទ.ខ. (កងតម្រួតទាហានខ្មែរ) ។ *Par abrév.* ឧត្តមសេនីយត្រី

brigand *n.m.* ចោរប្លន់ ។ *Par ext.* មនុស្សកំណាច; អ្នកស៊ីសំណូក

brigandage *n.m.* ការប្លន់; ការប្លន់ដោយបងិងផ្លូវ ។ *Fig.* ការឆក់ឧណ្តើម; ការស៊ីសំណូក

brigander *v.i.* រកស៊ីធ្វើចោរប្លន់; ប្លន់

brigandine *n.f.* អាវក្រោះតូច

brigantin *n.m.* នាវាធំបួលមួយ

brigue *n.f.* ការរួមគំនិតគ្នាគំ,ឧបាយទុច្ចរិត

briguer *v.t.* ព្យាយាមសម្រេចការដោយឧបាយទុច្ចរិត; ស្វែងរកដោយព្យាយាម (ឧ.briguer un poste)

brillamment *adv.* យ៉ាងរលើប, យ៉ាងរុងរឿង

brillance *n.f.* ពន្លឺរលើបរលង់

brillant,e *a.* រលើប, រលោង ។ *Fig.* ល្បីឈ្មោះ, ចំណាន, រុងរឿង (ឧ. réputation brillante); ។ *n.m.* ពន្លឺឆ្លេក(ឧ.le brillant de l'or); ពេជ្រជ្ញៃ

brillanté,e *a.* ដែលភ្លឺកាឡៃ ។ *n.m.* សំពត់អំបោះផ្កា

brillanter *v.t.* តែងលំអដោយរបស់ភ្លឺ (ឧ.brillanter un corsage)។ *Techn.* ឆ្នៃ (ឧ. brillanter un diamant); ប្រមោកឲ្យរលើប ។ se brillanter *v.pr.* ឡើងភ្លឺរលើប (ឧ. les flots se brillantent aux premiers feux du jour)

brillantine *n.f.* ព្រីយ៉ង់ទីន, ប្រេង ឬ ក្រមួនក្រអូបលាបសក់

briller *v.i.* ព្រាយពន្លឺ,មានរស្មី,ភ្លឺ។ *Fig.* រុងរឿង,បញ្ចេញសមត្ថភាពឲ្យគេស្គាល់ខ្លួន(ឧ. briller au barreau) ។ បញ្ចេញពន្លឺឲ្យឃើញ (ឧ. la joie brille dans ses regards)។ *Prov.* tout ce qui brille (ឬ tout ce qui reluit) n'est pas or ភ្លឺៗមិនមែនសុទ្ធតែមាស(កុំជឿភេទក្រៅៈ ត្រូយ៉ាងដូចផ្លែល្វានិងផ្លែខ្នុរៈ សមតាមបុរាណភាសិតថា ឧទុម្ពរទុំ សំបកក្រៅរុំ ក្រហមរលង់ ខាងក្នុងពេញទៅដង្កូវរមង់ ដូចមនុស្សទ្រង់ ចិត្តឆ្ងាយឫស្យា ។ផ្លែខ្នុរណាំងទុំ សំបកក្រៅរុំ ព្រួងក្រាងបន្លា ខាងក្នុងសឹងក្លែប ក្រអែបពិសា ដូចអ្នកសទ្ធា ចិត្តជាសប្បុរស)

brimade *n.f.* ការបំបាក់បំបបអ្នកចូលថ្មី (ទាហាន,សិស្សសាលា)។ *Par ext.* អំពើបំបាក់មុខពិតប្រយោជន៍

brimbalement *n.m.* ការអង្រួនរន្ទាន (ឧ. le brimba'ement des cloches)

brimbaler *v.t.* អង្រួនរន្ទាន(ឧ.brimbaler les cloches) ។ *v.t.* យោល (ឧ. breloques qui brimbalent)

brimborion *n.m.* របស់ឥតតម្លៃ

brimer *v.t.* ឈោកបញ្ឆោត; បំបាក់បំបប; ធ្វើបាប

brin *n.m.* ពន្លក (ឧ.brin d'herbe); សរសៃ (សរសៃខ្សែ ឬ ព្រួ) (ឧ.brin de paille); ភាគតូច, ដុំតូច (ឧ. un brin de pain)។ *Fig.* un beau brin de fille ស្រីល្អហើយមាំមួន

brinde *n.f.* ការលើកកែវផឹកឲ្យពរ ។ être dans les brindes ស្រវឹង

brindille *n.f.* មែកឆ្មារ

bringue *n.f.* បំណែក,កំទេច(ឧ.mettre en bringues) ។ *Fam.* ស្រីខ្ពស់ចង្រ្កាង; អាយមុខ ។ *loc.adv.* en bringues (ឧ. mettre en bringues កំទេច)

bringuebaler *v.t.* ម.ព.brimbaler

brio *n.m.* ភាពរៀវរា; ភាពរហ័សរហួន

brioche *n.f.* នំបុ័ង ។ *Fig.&Fam.* ការភាន់ច្រឡំ (ឧ.faire des brioches)

brique *n.f.* ឥដ្ឋ; ដុំវត្ថុរាងដូចឥដ្ឋ (ឧ. une brique de savon) ។ ton de brique ពណ៌ឥដ្ឋ (ក្រហមការ)

briquer *v.t.Fam.* រូសដោយឥដ្ឋ: ដុសលាងយ៉ាងខ្លាំង

briquet *n.m.* ដែកភ្លើង; ឆ្កែប្រមាញ់មាឌតូច; ដាវវែខ្លីហើយ ង

briquetage *n.m.* គ្រឿងជញ្ជាំងឥដ្ឋ; ថ្នាំលាបពណ៌ឥដ្ឋ

briqueter *v.t.* ក្រាល ឬ រៀបឥដ្ឋ; ធ្វើឲ្យដូចឥដ្ឋ

briqueterie *n.f.* ឡឥដ្ឋ(កន្លែងធ្វើឥដ្ឋ)

briqueteur *n.m.* ជាងរៀបឥដ្ឋ

briquetier *n.m.* អ្នកធ្វើ ឬ លក់ឥដ្ឋ

briquette *n.f.* ដុំឥដ្ឋតូច; ដុំធ្យូងថ្ម (កំទេចធ្យូងសូនជាដុំដូចឥដ្ឋ)

bris *n.m.* ការបំបាក់ ឬ បំបែក (ឧ.bris de scellés, de glace) ; ការបាក់ ឬ បែក

brisant,e *a.* ដែលបំបាក់ ឬ បំបែក (ឧ. abus brisant) ។ *n.m. Mar.* ថ្មប៉ប្រះទឹក

brise *n.f.* ខ្យល់រំភើយ

brisé,e *a.* កាច់, បត់ ។ ligne brisée បន្ទាត់កាច់ (ម.ព.ligne ផង)

brise-bise *n.m.inv.* សំពត់វាំងបង្អួច

brisées *n.f. pl.* កំណាច់ឈើ(សម្រាប់ចំណាំ) ។ *Fig.* suivre les brisées de quelqu'un ដើរតាមគន្លង, យកតម្រាប់ ។ aller, marcher sur les brisées de quelqu'un កាត់មុខ,ប្រកួតប្រជែង។ revenir sur ses brisées សាធ្វើជាថ្មី

brise-fer *n. inv.* ម.ព. brise-tout

brise-glace *n.m.inv.* ប្រដាប់បំបែកទឹកកក; នាវាមានប្រដាប់បំបែកទឹកកក

brise-lames *n.m.inv.* ជាំងរលក (ទំនប់លើកមុខផែសម្រាប់ទប់រលក)

brisement *n.m.* ការបំបាក់,ការបាក់។ *Fig.* brisement de cœur សេចក្ដីខ្លោចផ្សារ

brise-mottes *n.m.* ប្រដាប់បំបែកដុំដី

briser *v.t.* បំបាក់, បំបែក, កាច់, កំទេច (ឧ. briser une glace)។ *Fig.* ធ្វើឲ្យអស់កម្លាំង (ឧ. la voiture m'a brisé); បំផ្លាញ, បំបាត់

(ឧ. briser une institution); កាច់, ធ្វើឲ្យបាក់ទឹកចិត្ត (ឧ. briser les courages) ។ briser ses fers រួចខ្លួន ។ *v.i.* បោកទៅលើ (បំពោះលោកទឹក) (ឧ. vagues qui brisent à la côte) ។ briser avec quelqu'un លែងរាប់រក ។ brisons là ឈប់និយាយគ្នាត្រឹមនេះ ។ se briser *v.pr.* បែកខ្ទាយ

brise-tout *n. inv.* មនុស្សដៃភ្លើងជើងមាន់ (មនុស្សឆ្គងកាន់ការអ្វីខូចការនោះ)

briseur, euse *n.* អ្នកបំបាក់ឬបំបែក; អ្នកចូលចិត្តបំបាក់ឬបំបែក

briska *n.m.* រទេះម៉្យាង (នៅប្រទេសរុស្ស៊ី)

briske *n.f.* សក្តិពាក់នៅដៃ

brisure *n.f.* ស្នាមប្រេះ; ផ្នត់; កំទេច; អំបែង ។ brisure de riz ចុងអង្ករ

britannique *a.* នៃប្រទេសអង់គ្លេស

broc *n.m.* គយទឹក

brocantage *n.m.* ជំនួញពាណិជ្ជកិច្ច (ការទិញ-លក់ឬដូររបស់ចាស់)

brocante *n.f.* ជំនួញពាណិជ្ជ, ជំនួញរបស់ចាស់; របស់គ្មានតម្លៃ

brocanter *v.i.* ដូរញរបស់ចាស់

brocanteur,euse *n.* ជំនួញពាណិជ្ជករ, ឈ្មួញរបស់ចាស់

brocard *n.m. Fam.* ពាក្យឌឺដង (ឧ. lancer des brocards)

brocard ឬ **brocart** *n.m.* ប្រើសឈ្លោកលដំទង់

brocard *n.m.* ញ្ញាប់

brocarder *v.t.* ពោលពាក្យឌឺដងឲ្យ (ឧ. l'ancien monde brocarda le nouveau)

brocardeur,euse *n.* អ្នកពោលពាក្យឌឺដង

brocart *n.m.* ចរបាប់ (សំពត់)

brocatelle *n.f.* ចរបាប់ម៉្យាង; ថ្មកែវច្រើនពណ៌

brochage *n.m.* ការដេរសៀវភៅ

broche *n.f.* តំបុត,ដែកព្រនួច(ឧ.mettre un poulet à la broche) ។ *Fig.&Fam.* faire un tour de broche អាំងភ្លើង ។ *Chir.* ដែកស្ទបឆ្អឹងបាក់ ។ *Cost.* កន្ទាស់ក (អលង្ការ)។ *Techn.* ខ្នារ; ម្ជុលជាក់ ។ *Véner.* ស្នែងខ្ទី; ខ្នាយជ្រូកព្រៃ ។ *Prov.* il ne faut pas mettre tout son rôt à une même broche កុំរកស៊ីគ្រាប់ស្ទូ ត្រូវរកស៊ីគ្រាប់ល្ហុក; ធ្វើស្រែទិសប្រាំបី; ធ្វើស្រែកុំបោលចំការ (កុំរកស៊ីតែមួយផ្លូវ)

broché *n.m.* ការប៉ាក់ខ្សែសយ; សំពត់ប៉ាក់ខ្សែសយ

brochée *n.f.* សាច់ក្រឡុច

brocher *v.t.* ប៉ាក់ខ្សែសយ; ដេរសៀវភៅ ។ *Fig.&Fam.* ធ្វើប្រញាប់ប្រញាល់ (ឧ.cet écolier broche ses devoirs)

brochet *n.m.* ត្រីទឹកសាបម្យ៉ាង

brocheter *v.t.* ដេរដោយម្ជុលម្យ៉ាង ។ *Art cul.* ដោតចង្កាក់ ឬ ត្រណោត (ឧ.brocheter une volaille)

brochette *n.f.* ប្រឡុចតូច, ចង្កាក់, ត្រណោត ។ *Par ext.* គ្រឿងឥស្សរិយយសតូច; ប្រដាប់បញ្ចុកចំណីកូនបក្សី ។ *Fig.* élever à la brochette ចិញ្ចឹមដោយថ្នាក់ថ្នម

brocheur,euse *n.* អ្នកដេរសៀវភៅ ។ brocheuse mécanique ម៉ាស៊ីនដេរសៀវភៅ ។ *n.m.* ម៉ាស៊ីនប៉ាក់ខ្សែសយ

brochoir *n.m.* ញញួរដោះក្រចកសេះ

brochure *n.f.* ការដេរសៀវភៅ; សៀវភៅស្តើង

brodequin *n.m.* ប្រដឹកង, ស្បែកជើងឃ្មុប; ស្បែកជើងពួកតួកដាន់ដើម ។ *Fig.* chausser le brodequin និពន្ធរឿងល្ខោន; លេងល្ខោន ។ *Dr.* brodequins ប្រដាប់គាបជើង (ធ្វើទារុណកម្ម)

broder *v.t.* ប៉ាក់ ។ *Fig.* លំអ,បញ្ចេញបញ្ចូល (រឿងនិទាន) (ឧ. broder n'est pas mentir, mais farder la vérité)

broderie *n.f.* គ្រឿងប៉ាក់ ។ *Fig.* ការបញ្ចេញបញ្ចូល

brodeur,euse *a.* សម្រាប់ប៉ាក់ ។ *n.* អ្នកប៉ាក់

broie *n.f.* ប្រដាប់កិនដើមធ្មៃ ឬ ក្រចៅ

broiement *n.m.* ម.ព. broyage

broker (ពាក្យអង់គ្លេស) *n.m.* ជើងសារដំនួញ

brome *n.m.* ប្រូម

bronche *n.f.* ទងសួតធំ

bronchement *n.m.* ការជំពប់ជើង; ការកម្រើក

broncher *v.i.* ភ្លាត់ជើង(ឧ.un cheval qui bronche), ជំពប់ជើង (ឧ. broncher contre une pierre)។*Fig.* ne pas broncher គ្មានកម្រើក (ឧ. que personne ne bronche)។sans broncher គ្មានព្រឺម(ឧ.il a reçu cette insulte

sans broncher) ។ *Prov.* Il n'y a si bon cheval qui ne bronche សេះជើងបួនគង់មានភ្លាត់ អ្នកប្រាជ្ញចេះស្ទាត់គង់មានភ្លេច

bronchial,e,aux *a.* នៃទងសួត

bronchiole *n.f.* ទងសួតតូច

bronchique *a.* នៃទងសួត

bronchite *n.f.* រោគរលាកទងសួត

bronchitique *a.* នៃរោគរលាកទងសួត ។ *n.* អ្នកឈឺទងសួត

broncho-pneumonie *n.f.* គ្រុនរលាកទងសួតនឹងថង់សួត

bronchorrée *n.f.* ការធ្លាក់កំហាកថ្លាច្រើន

bronchotomie *n.f.* ការកាត់ទងសួត

brondir *v.i.* ឮសូរវ្ហូ(ដូចសំឡេងរ្វៃដែលវិលដក់)

brondissement *n.m.* សូរវ្ហូ (ដូចសំឡេងរ្វៃដែលវិលដក់)

bronzage *n.m.* ការធ្វើឲ្យឡើងពណ៌ស្ពាន់ដែង

bronze *n.m.* ទង់ដែង; រូបគំនូរឬគ្រឿងឥស្សរិយយសធ្វើពីទង់ដែង (ឧ. voilà un beau bronze) ។ *Fig.* cœur de bronze ចិត្តរឹង (មិនចេះអាណិតគេ)

bronzé,e *a.* ស្ពាន់ដែង (ឧ. visage, teint bronzé)

bronzer *v.t.* ធ្វើឲ្យមានសភាពដូចទង់-ដែង; ធ្វើឲ្យឡើងពណ៌ស្ពាន់ដែង

bronzerie *n.f.* សិប្បៈជាងទង់ដែង

bronzeur *n.m.* ជាងទង់ដែង

broquart *n.m.* ម.ព. brocard

broquette *n.f.* ក្តនដែកគោលក្បាលសំប៉ែត

brossage *n.m.* ការដុសដោយច្រាស; ការលាបឡេលាប

brosse *n.f.* ច្រាស; ដក់ ។ brosse à dents ច្រាសដុសធ្មេញ ។ cheveux en brosse សក់ផ្លង (សក់កាត់ខ្លី)

brossée *n.f.* ការដុសដោយច្រាស; ការវាយច្រើន; បរាជ័យ (ឧ. recevoir une brossée)

brosser *v.t.* ច្រាស, ដុសដោយច្រាស; លាបឡេលាប ។ *Fam.* វាយដំណប់ ។ se brosser *v. pr.* ដុសសំលៀកបំពាក់ខ្លួនឯងដោយច្រាស ។ *loc. fam.* se brosser le ventre, se brosser ទំទ្រាំអត់ទ្រាំឃ្លាន; ទ្រាំរត់ (ឧ. tu comptais sur une gratification?...tu peux te brosser!)

brosserie *n.f.* រោងចក្រធ្វើច្រាស; ជំនួញ

ព្រាស

brossier *n.m.* អ្នកធ្វើព្រាស; អ្នកលក់ព្រាស

brou *n.m.* សំបកខៀវនៃផ្លែឈើមានលលាដ៍

brouet *n.m.* អាហាររាវ

brouettage *n.m.* ការដឹកដោយរទេះរុញ

brouette *n.f.* រទេះរុញ

brouettée *n.f.* ចំណុះរទេះរុញ

brouetter *v.t.* ដឹកដោយរទេះរុញ

brouetteur ឬ **brouettier** *n.m.* អ្នកដឹកដោយរទេះរុញ

brouhaha *n.m.Fam.* សូរអ៊ូអែ

brouillage *n.m.* ការស្រូយបំភាន់(វិទ្យុ)

brouillamini *n.m. Fig.* ការច្របូកច្របល់;ការកកាយ(កុំថា:embrouillamini)

brouillard *n.m.* អ័ព្ទ ។ *Com.* សៀវភៅកំណត់ដៃ (ហៅ brouillon ឬ main courante ក៏បាននែរ) ។ *loc.fam.* voir à travers un brouillard មើលឃើញស្រពេចស្រពិល ។ n'y voir que du brouillard មិនយល់ ។ être dans les brouillards ស្រវឹងស្រៀងៗ ។ *a.* papier brouillard ក្រដាសជ្លក់

brouillasse *n.f.* អ័ព្ទស្តើង

brouillasser *v.i.* ចុះអ័ព្ទ

brouille *n.f.Fam.* ការទាស់ទែងគ្នា, ការបាក់បែកគ្នា(ឧ.être en brouille avec quelqu'un)

brouillement *n.m.* ការលាយឡំគ្នា; ភាពច្របូកច្របល់ (ម.ព. brouillamini និង embrouillement ផង)

brouiller *v.t.* លាយ (ឧ. brouiller du vin); កូរវែក (ឧ. brouiller des œufs); លាយឡំ, ច្របល់ (ឧ. brouiller des papiers); ធ្វើឲ្យស្មុគស្មាញ ឬ ឲ្យជំពាក់ (ឧ. brouiller du fil) ។ *Par ext.* ធ្វើឲ្យខូច (ឧ.brouiller une serrure) ។ *Fig.* ធ្វើឲ្យច្របូកច្របល់ (ឧ. les hommes brouillaient les idées qu'ils avaient reçues); ធ្វើឲ្យវង្វេង (ឧ. la métaphysique a brouillé bien des cerveaux);ធ្វើឲ្យទាស់ទែងគ្នា (ឧ. il suffit d'un cancanier pour brouiller toute une ville) ។ brouiller les cartes រំលៀ; *au fig.* ធ្វើឲ្យរឹករវរ,ធ្វើឲ្យបែកបាក់គ្នា ។ brouiller du

papier គូរក្រវែមក្រោមលើក្រដាស។

Loc. fam. être brouillé avec ឆាប់ភ្លេច, ពិបាកចាំ (ឧ.être brouillé avec les chiffres, avec les noms propres) ។ être brouillé avec la Monnaie ឬ avec l'Hôtel des monnaies គ្មានប្រាក់ ។

se brouiller *v.pr.* ឈាយគ្នា, ច្របូល់គ្នា; ជំពាក់គ្នា (ឧ. cordes qui se sont brouillées)។ le ciel se brouille មេឃស្រអាប់ ។ *Fig.* les idées se brouillent គំនិតច្របូកច្របល់គ្នា ។ affaires qui se brouillent រឿងដែលទៅជាស្មុគស្មាញ ។ ទាស់ទែងគ្នា (ឧ. se brouiller avec un ami) ។ *Fam.* se brouiller avec la justice មានរឿង (ឲ្យតុលាការហៅទប្រកាន់)។ se brouiller la cervelle ឆ្កួត ។ les cartes se brouillent មានការទាស់ទែងគ្នា

brouillerie *n.f.* ការទាស់ទែង ឬ បាក់បែកគ្នា

brouillon,onne *a.&n.* ដែលធ្វើឲ្យច្របូកច្របល់ (ឧ.esprit brouillon);ដែលធ្វើឲ្យទាស់ទែងគ្នា។ *n.m.* សេចក្តីព្រាង(ឧ.brouillon de lettre) ។ *Com.* ប.ព. brouillard

brouillonner *v.t.* សរសេរសេចក្តីព្រាង

brouir *v.t.* រោល,ធ្វើឲ្យស្វោក (ចំពោះតែរុក្ខជាតិដែលត្រូវត្រជាក់ហើយទៅត្រូវកំដៅព្រះអាទិត្យ)

brouissure *n.f.* ភាពស្វោក (រុក្ខជាតិត្រូវកំដៅព្រះអាទិត្យ)

broussaille *n.f.* គុម្ពបន្លា ។ sourcil, barbe en broussaille ចិញ្ចើម, ពុកចង្ការក្រាស់កន្ទ្រាញ

broussailleux,euse *a.* ដែលមានគុម្ពបន្លា

broussard *n.m.* អ្នកនៅក្នុងព្រៃ; អ្នកនៅក្នុងអាណានិគម

brousse *n.f.* ព្រៃគុម្ពោត ។ école de brousse ប.ព. école

broussin *n.m.* ពក (ឈើ)

brout *n.m.* ពន្លកឈើដុះក្នុងនិទាឃរដូវ។ mal de brout ការរាក (ចំពោះសត្វដែលស៊ីស្មៅខ្ចី)

brouter *v.t.* ស៊ីស្មៅ; ស៊ីមិនស្មើ (គ្រឿងចក្រ, គ្រឿងទប់) ។ où la chèvre est attachée, il faut qu'elle broute យើងត្រូវចេះរស់នៅតាមធន-

ធានរបស់យើង ។ l'herbe sera bien courte, s'il ne trouve pas à brouter មនុស្សនេះមិនអត់បាយស្លាប់ទេ (កន្លែងណាគេរកមិនបានគាត់ចេះតែរកបាន)

broutille *n.f.* មែកឈើតូច, រំកាច់ ។ *Fig.* របស់រំកាប់រំកោច

brouture *n.f.* ពន្លកដែលសត្វស៊ីកំបុត

browning *n.m.* កាំភ្លើងដៃយន្តព្រូនីញ

broyage *n.m.* ការកិន, ការកំទេច (ជា: broiement ក៏បានដែរ)

broyer *v.t.* កិន(ឧ. broyer du poivre);កិនជាម្សៅ;កំទេច,បំបែក។*Fig.* broyer du noir ខូចចិត្ត,កើតទុក្ខ

broyeur,euse *n.* អ្នកកិនកំទេច ។ *a.* machine broyeuse ឬ broyeuse ម៉ាស៊ីនកិនកំទេច

bru *n.f.* កូនប្រសាស្រី

brucelles *n.f.* តំបៀតដែក

bruine *n.f.* រលឹមត្រដាក់

bruiner *v.imp.* រលឹមត្រដាក់ (ធ្លាក់រលឹមត្រដាក់) (ឧ.il bruine)

bruineux,euse *a.* ដែលមានរលឹម (ឧ. temps bruineux)

bruir *v.t.* ចំហុយសំពត់-សរសៃសូត្រឬអំបោះឲ្យទន់ (ឧ. bruir du drap)

bruire *v.i.* បន្លឺសូរខ្សៀកៗ

bruissage *n.m.* ការចំហុយសំពត់-សរសៃសូត្រឬអំបោះឲ្យទន់

bruissant,e *a.* ដែលបន្លឺសូរខ្សៀកៗ

bruissement *n.m.* សូរខ្សៀកៗ(ឧ. le bruissement des feuilles)

bruit *n.m.* សូរ, សំឡេង ។ *Fig.* សូរ (ដំណឹង) (ឧ. le bruit court ឮសូរថា); ការឮខ្ចរខ្ចាយ (ឧ. cette affaire fait grand bruit); ចលាចល (ឧ. il y a du bruit dans la ville); កិត្តិសព្ទ (ឧ. il fait du bruit dans le monde)

bruitage *n.m.* ការបន្លឺសូរត្រាប់

bruiter *v.t.* បន្លឺសូរត្រាប់(របាំ,ភាពយន្ត,វិទ្យុ)

bruiteur *n.m.* អ្នកបន្លឺសូរត្រាប់

brûlage *n.m.* ការដុត, ការឆេះ

brûlant,e *a.* ដែលឆេះ, ក្ដៅចែស ។ *Fig.* រហ័សរហួន

brûlé *n.m.* ក្លិនឈ្ងៀម

brûlée *n.f.* *Pop.* donner une brûlée វាយដំយ៉ាងខ្លាំង

brûle-gueule *n.m.inv.Pop.* ខ្សៀខ្លី

brûlement *n.m.* ការឆេះ,ការដុត, ការរោល; អគ្គិភ័យ; ការក្រហាយ;មុខរបួស

រលាកភ្លើង

brûle-parfum *n.m. inv.* សុគន្ធ-ភាជន៍ (ភាជន៍ដុតគ្រឿងក្រអូប)

brûle-pourpoint (à) *loc. adv.* ប្រកិត, ភ្លាមៗ

brûler *v.t.* ដុត (ឧ.brûler des papiers; brûler quelqu'un sur le bûcher; brûler du bois, du coke); ធ្វើឲ្យរលាក (ឧ. brûler ses doigts); ធ្វើឲ្យខ្លោច(ឧ.brûler le rôti); ធ្វើឲ្យឆេះ (ឧ. brûler sa moustache en la frisant); ធ្វើឲ្យខូចដោយកំដៅ (ឧ. le soleil a brûlé la récolte) ។ *Par ext.* le grand soleil brûle le visage ចំហាយក្តៅខ្លាំងនៃព្រះអាទិត្យធ្វើឲ្យមុខឡើងសម្បុរដាំដែង ។ ដាំកំដៅ (ឧ. brûler du café); ស៊ី,ធ្វើឲ្យរលាក(ឧ.les acides brûlent la peau; les liqueurs alcooliques brûlent l'estomac) ។ *Fig.* ធ្វើឲ្យក្តៅក្រហាយ (ឧ. les convoitises nous brûlent)

Loc.fam. brûler un cochon ភេលជ្រូក (ភេលជ្រូកដែលគេសម្លាប់ហើយឲ្យឆេះរោមអស់) ។ brûler une amorce ដុតឈ្នួន(បណ្តាលឲ្យផ្ទុះ)។sans brûler une amorce គ្មានបាញ់មួយគ្រាប់។brûler le pavé, le chemin, etc ... ដើរយ៉ាងលឿន។brûler une étape, un gîte, un endroit ទៅបង្ហួស (មិនឈប់ត្រង់ទីសំចត-ត្រង់សំនៅឬត្រង់កន្លែងណាមួយ)។brûler ses vaisseaux ប្តេជ្ញាថាមិនថយក្រោយ (មាននិទានថា មេទ័ពធំៗខ្លះ កាលដែលឡើងវាយលុកប្រទេសសត្រូវ ដុតនាវារបស់ខ្លួនចោលដើម្បីកុំឲ្យមានរំពឹងថានឹងថយក្រោយវិញបាន)។ brûler la politesse à quelqu'un ចាកចេញគ្មានលា ។ brûler la cervelle បាញ់បំបែកក្បាល (បាញ់ពីទីជិត) ។ brûler une voiture ដេញរថមួយ ។ brûler un coureur រត់ដេញ(រត់លឿនជាង)។ brûler un espion ប្តឹងបរិហារអំពីចារបុរសម្នាក់។brûler du sucre ដុតស្ករ(ដើម្បីកំចាត់ក្លិនអាក្រក់); *au fig.* រៀបចំបរិយាកាសឲ្យស្រួលឡើងវិញ (នៅពេលដែលមនុស្សពាលចាកចេញ) ។

Prov. & loc. prov. brûler de l'encens devant quel-

qu'un(ឬ sous les narines de quelqu'un)បញ្ឆោរហើយតោរពខ្លាំងពេក ។ brûler la chandelle par les deux bouts ខ្ជះខ្ជាយខ្លាំងពេក (ចំពោះទ្រព្យសម្បត្តិឬសុខភាព) ។

V.i. ឆេះ (ឧ.bois qui brûle trop vite) ។ *Par ext.* feu qui brûle dans la cheminée ភ្លើងដែលឆេះក្នុងឧសុមតោឆ្នក ។ *Fig.* fièvre qui brûle dans les veines គ្រុនដែលឆេះក្នុងសរសៃឈាម។ខ្លោច(ឧ. rôti qui brûle)។ក្តៅណាស់(ឧ. tête, front, main qui brûle)។ក្តៅដូចគេដុត (ឧ.on brûle dans le Sahara)។*Fig.* ភេលភល ឬក្តៅក្រហាយ (ដោយភ្លើងកាម)(ឧ. brûler d'amour ភេលភលដោយភ្លើងស្នេហា); brûler de zèleដុតដៃដុតជើង(រៀសរវៃណាស់); brûler d'impatienceអន្ទះអន្ទែងខ្លាំង (ដោយប្រញាប់); ចង់ខ្លាំងណាស់ (ឧ. brûler de combattre, de parler) ។

Jeux ហៀបនឹងរកឃើញ(របស់ដែលគេលាក់) (ដូចពាក្យយើងថា ប៉ើពស់ចិកហើយ) ។

Loc. fam. ឬ *prov.* brûler à petit-feu វិនាសបន្តិចម្តងៗ ។ brûler de soif ស្រេកខ្លាំងណាស់ (ដូចឆេះបំពង់ក) ។ les pieds lui brûlent រមាស់ជើងឈរមិននឹង(អន្ទះអន្ទែងចង់ចេញដំណើរណាស់) ។ les mains lui brûlent រមាស់ដៃ (អន្ទះអន្ទែងចង់ធ្វើណាស់)។ le torchon brûle មិនចេះរក្សាភ្លើងបី (ចំពោះគ្រួសារដែលចេះតែទាស់ទែងគ្នា) ។

Se brûler *v.pr.* រលាក (ឧ. qui touche le feu se brûle) ។ *Fig.* ក្តៅភេលភល (ដោយភ្លើងកាម) (ឧ. se brûler aux yeux d'une jolie fille) ។ se brûler à la chandelle ផុងខ្លួន (ដូចមមាចហើរចូលភ្លើង)(ថា se brûler les ailes, brûler ses ailes ឬ se brûler les doigts ក៏បានដែរ) ។ sang qui se brûle ឈាមភរ

brûlerie *n.f.* រោងរំគស្រា; រោងលីងកាហ្វេ

brûle-tout *n.m. inv.* ជើងអុជកន្ទុយទៀន (ថា: brûle-bout ក៏បានដែរ)

brûleur *n.m.* អ្នកដុត (ឧ. un brûleur de livres) ។ *loc. fam.*

être fait comme un brûleur de maisons មុខមាត់អាក្រក់ណាស់; ស្មៀកពាក់អាក្រក់ណាស់ ។ brûleur de vin អ្នកបិតស្រា

brûlis *n.m.* ព្រៃដុតធ្វើចំការ

brûloir *n.m.* ប្រដាប់លីងកាហ្វេ

brûlure *n.f.* ដំបៅរលាក(ឧ. se faire une brûlure à la main)

brumaire *n.m.* ខែទី២ក្នុងប្រក្រតិទិននៃសាធារណរដ្ឋបារាំង (ពីថ្ងៃទី ២២ ឬ ២៣ តុលា ទៅថ្ងៃទី ២០ ឬ២១វិច្ឆិកា)

brumasse *n.f.* អ័ព្ទស្តើង

brumasser *v.imp.* ចុះអ័ព្ទស្តើងៗ (ឧ. il brumasse)

brume *n.f.* អ័ព្ទក្រាស់ ។ *Fig.* ភាពងងឹត ; ភាពមិនច្បាស់ ឬ មិនប្រាកដ; សេចក្តីព្រួយ

brumer *v.imp.* ចុះអ័ព្ទ(ឧ.il brume)

brumeux,euse *a.* ដែលមានអ័ព្ទក្រាស់

brun,e *a.&n.* ដាំដែង,សម្បុរស្គាត; អ្នកមានសក់សម្បុរដាំដែង។ *n.m.* សម្បុរដាំដែង,សម្បុរស្គាត

brunâtre *a.* ស្គាតគរ, ដាំដែងគរ (ពណ៌,សម្បុរ)

brune *n.f.* សាយណ្ហកាល, ពេលល្ងាច (ឧ. sur la brune នៅពេលល្ងាច)

brunet,ette *a.&n.* ក្មេងដំទង់សម្បុរដាំដែង

bruni *n.m.* ភាពរលោងនៃលោហធាតុ (ផ្ទុយនឹងភាពស្រអាប់)

brunir *n.m.* ធ្វើឲ្យឡើងសម្បុរស្គាត; ខាត់ (ឧ.brunir l'or)។ *v.i.*ឡើងសម្បុរដាំដែង(ឧ.son teint brunit)

brunissage *n.m.* ការខាត់(លោហធាតុ); ការបន្ទៀក (គ្រឿងយន្ត)

brunissement *n.m.* ដំណើរឡើងសម្បុរស្គាត ឬដាំដែង(ឧ. le brunissement des cheveux)

brunisseur,euse *n.* ជាងខាត់លោហធាតុ

brunissoir *n.m.* ប្រដាប់ខាត់គ្រឿងមាសប្រាក់

brunissure *n.f.* ភាពរលោង (ដោយការខាត់)

brusque *a.* ភ្លាមៗ(ឧ.attaque brusque); រហ័ស(ឧ.manières brusques);ឆោះឆោក(ឧ.ton brusque)

brusquement *adv.* យ៉ាងរហ័ស; ភ្លាមៗ; ព្រួស; ង៉ក់

brusquer *v.t.* គំហុក; បង្ខំ; ធ្វើដោយប្រញាប់ ។ *Fig.* brusquer une affaire គំហុកការ ។ attaque

brusquée ការវាយរុកភ្លាមៗ

brusquerie *n.f.* ការធ្វើដោយពំរុក; សំដី ឬ អំពើគោះគោក

brut,e *a.* គ្មានទទួលការអប់រំ, ដំបូងមូល, ព្រៃ (ឧ. certaines tribus sont plus près de la bète brute que de l'homme); មិនទាន់រចនា (ឧ. matière brute); មិនទាន់ឆ្នៃ (ឧ. un diamant brut n'est pas transparent) ។ *Com.* poids brut ទម្ងន់សរុប (មិនទាន់ផាត់សំបក) (ប.ព. poids ផង) ។ *Métall.* métal brut លោហធាតុមិនទាន់ស្ល ។ *n.m.* អ្វីៗដែលមិនទាន់រចនា ឬ មិនទាន់ផាត់ទាត់ (ឧ. le net et le brut) ។ *adv.* មិនទាន់ផាត់ទាត់ (ឧ. affaire qui produit brut un demi million; ballot qui pèse brut deux cents kilogrammes)

brutal,e,aux *a.* តិរច្ឆាន, ព្រៃ (ឧ. instinct brutal; si la force morale disparaît tout à fait, la force brutale régnera tout à fait); កម្រោល (ឧ. charretier brutal); ខ្លាំង (ឧ. un coup brutal); គ្មានសំចៃ,បំ (ឧ. un réalisme brutal) ។ *n.* មនុស្សកម្រោល (ឧ. la valeur seule ne fait que des brutaux, la raison fait les braves) ។ *Arg.* កាំភ្លើងធំ (ឧ. rire à la gueule du brutal)

brutalement *adv.* ទាំងកម្រោល; ទាំងអំណាច; ដោយគម្រោះគម្រើយ

brutaliser *v.t.* ប្រព្រឹត្តគម្រោះគម្រើយដាក់ (ឧ. il ne faut jamais brutaliser les enfants); ធ្វើឲ្យទៅជាដូចសត្វតិរច្ឆាន

brutalité *n.f.* អំពើតិរច្ឆាន ឬ ព្រៃ; អំពើគម្រោះគម្រើយ (ឧ. essuyer les brutalités de quelqu'un)

brute *n.f.* សត្វតិរច្ឆាន, សត្វឥតវិចារណញ្ញាណ (ឧ. l'instinct tient lieu de raison aux brutes) ។ *Par anal.* អនរិយជន (ឧ. l'ignorant est une brute à face d'homme); មនុស្សកម្រោល (ឧ. c'est une brute qui martyrisait un pauvre cheval)

bruyamment *adv.* ដោយសន្ធឹកគឹកកង

bruyant,e *a.* គឹកកង, ខ្សៀវខ្សារ, អ៊ូអែ

bryologie *n.f.* វិទ្យាសាស្ត្រខាងស្លែ

bryon ឬ **brion** *n.m.* ស្លែដុះលើសំបកឈើ

buanderie *n.f.* កន្លែងបោកខោអាវ

buandier,ère *n.* អ្នកដ្រលក់សំពត់ឲ្យស ។ *n.f.* ស្រីអ្នកបោកខោអាវ

bube *n.f.* រលកកៃ (កើតលើស្បែក)

bubon *n.m.* កូនកណ្ដុរហើម

bucaille *n.f.* ស្រូវសាលីខ្មៅ

buccal,e,aux *a.* នៃមាត់

buccin *n.m.* ខ្យងសមុទ្រម្យ៉ាង

buccinateur *a.&n.m.* សាច់ថ្ពាល់

bucéphale *n.m.* សេះចម្បាំង; សេះសម្រាប់ពិធីគ្រូគពល

bucéros *n.m.* ម.ព. cala

bûche *n.f.* អង្កត់អុស ។ *Fig.* មនុស្សស្ពឹក(ដូចអង្កត់អុស)។ *Fam.* prendre (ឬ ramasser) une bûche ដួល

bûcher *n.m.* កន្លែងគរអុស; គំនរអុសបូជាសព ឬ ដុតមនុស្សទោស (ឧ. Jeanne d'Arc mourut sur le bûcher)

bûcher *v.t.* ចាំងឈើ, ស៊ែង ។ *v.i.* *Pop.* វាយ; ធ្វើការគ្មានឈប់ឈរ ។ se bûcher *v.pr. fam.* វាយគ្នា

bûcheron,onne *n.* អ្នកកាប់ឈើក្នុងព្រៃ

bûchette *n.f.* កំណាត់ឈើ, កំណាត់អុស ។ tirer à la bûchette ចាប់ឆ្នោត (ដោយហូតកំណាត់ឈើ)

bûcheur, euse *n.Fam.* អ្នកធ្វើការច្រើន

bucolique *a.* នៃជីវភាពគង្វាលចៀម(ឧ. existence bucolique)

bucrane *n.m.* ក្បាលគោ (ប្រើជាលំអគេហដ្ឋាន)

budget *n.m.* ថវិកា; ថង់ ។ budget national ថវិកាជាតិ ។ budget municipal ថវិកាក្រុង ។ budget provincial ថវិកាខេត្ត ។ budget communal ថវិកាឃុំ

budgétaire *a.* នៃថវិកា (ឧ.loi budgétaire)

budgétivore *a.&n.* *Par plaisant.* ពួកភ្នាក់ងាររាជការ (ដែលរស់នៅដោយសារថវិកា)

buée *n.f.* ចំហាយទឹកពុះ; ដំណក់ចំហាយទឹក(ដែលជាប់លើគ្រប់ឆ្នាំងជាដើម)(ឧ. vitre couverte de buée)

buen-retiro *n.m.* លំនៅឯកជន; ភូមិគ្រឹះដាច់ស្រយាល ។ *Iron.* បង្គន់

buffet *n.m.* ទូល្អោ; ទូបាន; ភោជនីយដ្ឋាន

buffetier,ère *n.* អ្នកកាន់កាប់ភោជនីយដ្ឋាន (ក្នុងស្ថានីយ៍រថយន្តយាន)

buffle *n.m.* ក្របី:ស្បែកក្របី។ buffle sauvage ក្របីព្រៃ

buffleterie *n.f.* ខ្សែស្ពាយអាវុធ (ធ្វើដោយស្បែកក្របី)

buffletin ឬ **bufflon** *n.m.* កូនក្របី

bufflonne, bufflette ឬ **bufflesse** *n.f.* ក្របីញី

buggy [begh-ghé] *n.m.* រទេះកង់ពីរម៉្យាង (ហៅ beghei ក៏បានដែរ)

building *n.m.* ប៊ុលឌិញ, មហាគ្រឹះ

buire *n.f.* ថូម្យ៉ាងមានដៃមានចំពួយ(ឧ. buire d'argent)

buisson *n.m.* គុម្ពោត, ព្រៃគោះ។ battre les buissons លើកគោត្ត; *au fig.* ស្រាវជ្រាវរក

buissonneur,euse *a.* ពាសពេញដោយគុម្ពោត

buissonnier,ère *a.*ដែលនៅក្នុងគុម្ពោត (ឧ.lapin buissonnier)។*Fig.* faire l'école buissonnière វេះមិនទៅសាលា

bulbaire *a.* នៃមើម

bulbe *n.m.* ឬ *f.*មើម;ដុំមានសណ្ឋានដូចមើមខ្ទឹម ។ bulbe rachidien ខួរកញ្ចឹងក

bulbeux,euse *a.* ដែលជាមើម; ដែលមានមើម

bulbille *n.f.* ពន្លកគ្រាប់ពលស្លឹក

bulgare *a.* នៃប្រទេសប៊ុលហ្គារី ។ *n.* ជនជាតិប៊ុលហ្គារី

bulldozer *n.m.* ប៊ុលដូហ្សែរ, ម៉ាស៊ីនឈូសឬពង្រាបដី .

bulle *n.f.* ពពុះទឹក (ឧ. faire des bulles); ដែកគោលសំរ; ពងស្បែក; ស្នាមត្រាបោះលើលិខិត; លិខិតបោះត្រា ។ *n.&a.m.* papier bulle ក្រដាសគគ្រើមពណ៌លឿងការ

bulletin *n.m.* ព្រឹត្តិប័ត្រ ។ bulletin d'un écolier ព្រឹត្តិប័ត្រសិស្ស ។ bulletin de notes ព្រឹត្តិប័ត្រកំណត់ ។ bulletin individuel de notes ព្រឹត្តិប័ត្រកំណត់បច្ចេកជន ។bulletin de soit communiqué (B.S.C.) ព្រឹត្តិប័ត្រដែលត្រូវតាម ។ bulletin de traction ព្រឹត្តិប័ត្រអាពាហ៍ ។ bulletin de versement ព្រឹត្តិប័ត្រឲ្យបង់ប្រាក់ ។ bulletin officiel រាជកិច្ច ។

សន្លឹកឆ្នោត (ឧ. mettre son bulletin dansl'urne);បង្កាន់ដៃ

ទទួល(ឧ. bulletin de bagage)

bulleux,euse *a.* ដែលដាំពពុះ (ឧ. éruption bulleuse)

bull-terrier *n.m.* ឆ្កែអង់គ្លេស សម្រាប់ចាប់កណ្ដុរ) *pl.* des bull-terriers)

bulteau *n.m.* ដើមឈើកាត់ផាកងមូល

buna *n.m.* កៅស៊ូស្ង

bungalow *n.m.* កេហដ្ឋាគារ

bungare *n.m.* ពស់វែកម្យ៉ាងមាននៅប្រទេសក្លិង្គនិងម៉ាឡាយូ

bupreste *n.m.* កំភេម

buraliste *n.m.* អ្នកកាន់កាប់ការិយាល័យចំណូល-ចំណាយ។ល។; អ្នកកាន់កាប់តៀមលក់ថ្នាំ-ជារី; អ្នកជំនួយក្រុមវណ្ណការ

bureau *n.m.* តុសរសេរ; កន្លែងដាក់តុសរសេរ; ការិយាល័យ (ឧ. bureau d'un ministère)។ bureau d'ordre ការិយាល័យរបៀប ។ bureau du personnel ការិយាល័យបុគ្គលិក ។ bureau de la comptabilité ការិយាល័យគណនេយ្យ។ bureau administratif ការិយាល័យរដ្ឋបាល, ការិយាល័យអភិបាល។ bureau du contentieux ការិយាល័យក្រុមវិវាទ។ **bureau de** la législation ការិយាល័យនីតិការ។ bureau fiscal ការិយាល័យពន្ធដារ ។ bureau foncier ការិយាល័យភូមិបាល ។ **bureau de** postes ការិយាល័យប្រៃសណីយ ។ bureau de placement ការិយាល័យរកការធ្វើ ។ **bureau de** bienfaisance ម.ព. bienfaisance ។ **bureau des longi**tudes ការិយាល័យរយៈបណ្ដោយ(ក្រុមហ៊ុនដាផ្លូវការនៃអ្នកប្រាជ្ញខាងគណិតសាស្ត្រ និងហោរាសាស្ត្រ) ។ bureau de tabac តៀមលក់ជារី ។

bureaucrate *n.m.* ការិយលេខានុការ

bureaucratie *n.f.* ការិយាធិបតេយ្យ (អំណាច, ទម្លាប់, របៀបចាត់ការរដ្ឋ)

bureaucratique *a.* នៃការិយាធិបតេយ្យ

bureaucratisme *n.m.* ការិយាល័យនិយម

bureaucratiser *v.t.* ឲ្យមានរបបការិយាធិបតេយ្យ

burette *n.f.* ដប កវែង; បំពង់បន្តក់ប្រេងម៉ាស៊ីន

burgau *n.m.* ខ្យងដាំ (សំបកខ្យងដែលគេយកមកដាំលើគ្រឿងឈើ)

burgrave *n.m.* មេបញ្ជាការក្រុង ឬ បន្ទាយ (នៅប្រទេសអាល្លឺម៉ង់ ក្នុងយុគកណ្ដាល) ។ *Fam.* មនុស្សចាស់កាន់គំនិតហួសសម័យ

burgraviat *n.m.*ឋានន្តរជាមេបញ្ជាការក្រុង ឬ បន្ទាយ

burin *n.m.* ដែកដាប់ (ពន្លាកកាត់ដែក); ខ្ទិត (ពន្លាកឆ្លាក់លោហធាតុ)

buriner *v.t.* ដាប់ដែក; ឆ្លាក់លោហធាតុ (ឧ. buriner une planche de cuivre) ។ *Absol. Pop.* ធ្វើការឥតឈប់ឈរ

burineur *n.m.* ជាងដាប់ដែក; ជាងឆ្លាក់លោហធាតុ។*Pop.*អ្នកធ្វើការច្រើន

burlesque *a.* ព្រមាប់ (ឧ. poème burlesque) ។ *n.m.* រឿងព្រមាប់

burnous *n.m.* អាវឈ្នួតអារ៉ាប់

buron *n.m.* ខ្ទមគង្វាលចៀម; កន្លែងធ្វើប្រហុកម៉ាស

buronnier *n.m.* អ្នកធ្វើប្រហុកម៉ាសក្នុងផ្ទះ

bursal,e, aux *a.* នៃពន្ធពិសេស (ឧ. édit bursal)

busc *n.m.* ឆ្អឹង (សម្រាប់ទល់ឲ្យរឹង)

buse *n.f.* មិសកក្សបក្សីមួយយ៉ាង។ *Fig.* មនុស្សកញ្ជោត

buse *n.f.* ផ្លូវទឹក;លូ,បំពង់ទឹក (ឧ. buse d'échappement); បំពង់ខ្យល់

business *n.m.* [biz-nès] (ពាក្យអង់គ្លេស) *Pop.* កិច្ចការ; រឿងស្មុគស្មាញ

busqué,e *a.* កោង (ច្រមុះ) (ឧ. nez busqué)

busquer *v.t.* ដាក់ឆ្អឹង (ឲ្យរឹង) (ឧ. busquer un corset); បង្កោង

buste *n.m.* ឧទ្ធកាយ (ដងខ្លួន; គំនូរ-ចំឡាក់ឬស្ថិតរូបយកំណាក់ខ្លួនឡើងលើ)

but *n.m.* ទី, គោលដៅ (ឧ. bien viser au but; toucher le but) ។ *Fig.* វត្ថុបំណង (ឧ. le travail n'est pas un but, mais un moyen)។ *Par ext.* គោលបំណង (ឧ. un but louable) ។ aller au but, aller droit au but ចំពោះឲ្យចំ(ឥតពង្វាង)។ toucher ឬ frapper au but បានសម្រេច; ស្រាយបញ្ហារួច។ atteindre son but ឬ à son but បានសម្រេចដូចបំណង ។ passer ឬ dépasser le but, aller au-delà du but បានសម្រេចលើសគោលបំណង។ *loc. pré.* dans le but de ដើម្បីនឹង។ *loc.adv.* but à but ស្មើគ្នា,គ្មានប្រៀបលើគ្នា ។ de but en blanc

ភ្លាមៗ, គ្មានប្រុងប្រៀប ឬ រៀបចំមុន (ឧ. en venir de but en blanc à l'union conjugale) ។ *Jeux* ទី; ពិន្ទុល្អ

bute *n.f.* ប្រដាប់កាត់ក្រចកសេះ

buter *v.i.* ព្រាត់ ឬ ផ្អែកលើ; ជំពប់; មានបំណាង ។ *v.t.* ទល់ (ឧ. buter un mur) ។ se buter *v.pr.* ជំពប់, ទង្គិច ។ *Fig.* ចចេស, ទទូច

butin *n.m.* របស់ដែលយកបានពីសត្រូវ; វត្ថុដែលអង្គាស ឬ ប្រមូលសន្សំបាន (ឧ. le butin d'une abeille); អ្វីៗដែលបានដោយខំរក ឬ ដោយខំរៀន ។ *Pop.* ធនធានដែលសន្សំបាន

butiner *v.t. & i.* យកបានពីសត្រូវ; អង្គាស; ប្រមូលសន្សំ, ខំរក ។ les abeilles butinent les fleurs ឃ្មុំត្រឹបផ្កា

butineur,euse *a.* ដែលប្រមូលសន្សំ, ដែលត្រឹប(ឧ. insecte butineur)

butoir *n.m.* កំណល់

butor *n.m.* ខ្វែក។ *Fig.* មនុស្សសំពីក, មនុស្សភ្លើ ។ *n.f. Pop.* ស្ត្រីសំពីក

buttage *n.m.* ការពូនគល់

butte *n.f.* ទួលខ្ពស់; ទួលបាញ់វែង; ពំនូក។ butte-témoin ពំនូកកសិណ។ *Fig.* être en butte à ត្រូវផង, ត្រូវទទួល

butter ពូនគល់(ឧ.butter un arbre, une plante)

buttoir ឬ **butteur** *n.m.* ឧបករណ៍សម្រាប់ពូនគល់ដំណាំ ។ *Techn.* ប្រដាប់ឆ្នាក់ឈើ ។ *Chem. de fer* ទំនប់ចុងផ្លូវរថភ្លើង

butyreux,euse *a.* ជាជាតិប៊ឺរ (ឧ. le cacao contient une matière butyreuse)

butyrine *n.m.* ប៊ុយទីរីន,ជាតិខ្លាញ់នៃប៊ឺរ

buvable *a.* អាចផឹកបាន (ឧ. vin qui n'est pas buvable)

buvard *a.&n.* ក្រដាសផ្ចិត

buvée *n.f.* ទឹកលាយកន្ទក់សម្រាប់សត្វផឹក

buvetier,ère *n.* សុរាការិក - រិកា, អ្នកកាន់កាប់តៀមស្រា

buvette *n.f.* តៀមស្រា

buveur,euse *n.* អ្នកផឹក (ឧ. un buveur d'eau); អ្នកប្រមឹក

buvoter *v.i.* ផឹកតិចៗ, ក្រេប

byzantin,e *a.* នៃប្រទេសប៊ីសង់



c *n.m.* អក្សរទីបីនៃអក្ខរក្រមឡាតាំង

C (លេខរ៉ូម៉ាំង) ១០០

ça *pr. dém.* (ពាក្យបំប្រួញនៃ cela) របស់នោះ (ឧ. dis-moi ça)

çà *adv. de lieu* ឯនេះ ។ çà et là *loc. adv.* ខាងនេះបន្តិចខាងនោះបន្តិច (ឧ. courir çà et là)

cab *n.m.* (ពាក្យអង់គ្លេស) រថម្យ៉ាងកង់ពីរ

cabale *n.f.* ការទាក់ទងនឹងបិសាច; ពួកអ្នកកាន់លទ្ធិអ្វីមួយ; ការសម្ងាត់ (ឧ. former des cabales)

cabaler *v.i.* គិតក្បត់

cabaleur,euse *n.* អ្នកគិតក្បត់

cabaliste *n.* អ្នកជំនាញខាងការគិតក្បត់

cabalistique *a.* នៃការសម្ងាត់, ដែលគេមើលមិនយល់ (ឧ.signes cabalistiques)

caban *n.m.* អាវភ្លៀងម្យ៉ាង

cabanage *n.m.* កន្លែងសង់ខ្ទម; ការនៅក្នុងខ្ទម

cabane *n.f.* ខ្ទម; ទ្រុងសត្វ (ឧ. cabane à lapins)

cabaner *v.i.* នៅក្នុងខ្ទម; រៀបចំបែកមនឲ្យទាងធ្វើសំបុក

cabanon *n.m.* កូនខ្ទម; បន្ទប់សម្រាប់មនុស្សឆ្កួត ឬ អ្នកទោសឧក្រិដ្ឋ

cabaret *n.m.* មជ្ជាគារ, សុរាបានដ្ឋាន, តៀមស្រា ។ pilier de cabaret មនុស្សដែលនៅតែក្នុងតៀមស្រា;មនុស្សប្រមឹក ។ cabaret borgne តៀមស្រាកេរ្តិ៍ឈ្មោះអាក្រក់ ។ កូនតុ ឬ ថាសទ្រកែវ

cabaretier,ère *n.* នាយមង្គាគារ

cabas *n.m.* កញ្ជ្រែងម្យ៉ាង

cabestan *n.m.* កង្ហារ (គ្រឿងចក្រទាញរបស់ធ្ងន់) ឧ. on lève l'ancre des navires au moyen du cabestan)

cabillot *n.m.* បង្គោលចងខ្សែ

cabine *n.f.* បន្ទប់កប៉ាល់;បន្ទប់យន្តហោះ (សម្រាប់យានិកនឹងយានបរ);បន្ទប់ផ្លាស់សម្លៀកបំពាក់ (សម្រាប់អ្នកងូតទឹក); បន្ទប់ពិសេស (ឧ. cabine téléphonique បន្ទប់ទូរសព្ទ)

cabinet *n.m.* បន្ទប់តូច (ឧ. cabinet de toilette); ការិយាល័យ (ឧ. cabinet du Directeur, d'un homme d'affaires); ខុទ្ទកាល័យ, កាប៊ីណេត៍; រដ្ឋមន្ត្រីមណ្ឌល; គណរដ្ឋមន្ត្រី ។ chef de cabinet នាយខុទ្ទកាល័យ ឬ នាយកាប៊ីណេត៍ ។ chef de cabinet du Palais Royal នាយមន្ទីរក្រុមព្រះរាជាយុត្តកៈ ។ cabinet de toilette ម.ព. toilette ។ cabinet de lecture បន្ទប់អាន (កាសែត, សៀវភៅ) ។ homme de cabinet អ្នកចូលចិត្តខាងសិក្សា ។ *Hist. nat.* សមុច្ចយវិទ្យាសាស្ត្រ (ឧ. cabinet d'histoire naturelle) ។ *Pl.* បង្គន់

câblage *n.m.* ការផ្ញើសារទូរលេខ

câble *n.m.* ខ្សែពួរ, ពួរល្ហួស;ខ្សែស្រោបគ្រឿងទូរលេខ-ទូរសព្ទ ។ល។; សារទូរលេខ

cablé *n.m.* ខ្សែធំ(សម្រាប់ពួរផ្ទាំងគំនូរជាដើម)

câblé,e *a.* វេញ (ឧ. fil câblé); ដែលមានសណ្ឋានដូចខ្សែពួរ (ឧ. moulure cablée)

câbleau ឬ **câblot** *n.m.* ខ្សែពួរតូច

câbler *v.i.* វេញពួរ ។ *v.t.* ផ្ញើសារទូរលេខ (ឧ. câbler une victoire)

câblerie *n.f.* ការធ្វើពួរ

câblogramme *n.m.* សារទូរលេខ (បញ្ជូនតាមខ្សែកាត់សមុទ្រ) (ឧ. envoyer un cablogramme)

cabochard,e *a* &*n.* ចចេស,ក្បាលរឹង

caboche *n.f.* *Fam.* ក្បាលធំ; ដែកគោលក្បាលធំមូល

cabochon *n.m.* ពេជ្រខាត់រលីងប៉ុន្តែមិនឆ្នៃ; ដែកគោលក្បាលធំ

cabosse *n.f.* ស្នាមឆាំ; ពក; ផ្លែកាកាវ

cabosser *v.t.* ធ្វើឲ្យកំពឹកកំពក (ឧ. cabosser de l'argenterie

pour la faire paraître plus ancienne)

cabot *n.m.* ត្រីម្យ៉ាង ។ *Pop.* តួល្ខោនថោកទាបឥតឈ្មោះ ។ *Arg.* ឆ្កែ ។ *Arg. mil.* នាយទោ ។ ពាក្យបំព្រួញនៃ cabotin

cabotage *n.m.* គីរនាវាចរណ៍ (នាវាចរណ៍ក្បែរឆ្នេរសមុទ្រ) (ព.ផ. navigation à long cours)

caboter *v.i.* ធ្វើគីរនាវាចរណ៍, ធ្វើនាវាចរណ៍ក្បែរឆ្នេរសមុទ្រ

caboteur ឬ **cabotier** *a.&n.m.* គីរនាវាចរ

cabotin,e *a.* តួល្ខោនថោកទាបឥតឈ្មោះ ។ *Fam.&Fig.* អ្នកធ្វើឫកធំ (ឲ្យគេស្គាល់ខ្លួន)(ឧ.les cabotins de la politique) (ពាក្យបំព្រួញៈ cabot)

cabotinage *n.m.* មុខរបរតួល្ខោនថោកទាបឥតឈ្មោះ; ការធ្វើឫកធំឲ្យគេស្គាល់ខ្លួន

cabotiner *v.i.* ធ្វើជាតួល្ខោនថោកទាបឥតឈ្មោះ; ធ្វើឫកធំឲ្យគេស្គាល់ខ្លួន

cabrer(se) *v.pr.* បំព្រារ(សេះ)។ *Fig.* ប្រឆាំង; ក្រឡេក (ឧ. l'amour-propre se cabre devant les railleries)។ *v.t.* នាំរង់ឡើងលើ

cabri *n.m.* កូនពពែ ។ sauter comme un cabri លោតកញ្ឆេង

cabriole *n.f.* ការលោតជាំទីង ។ *Fig.* faire la cabriole បញ្ចេញភាពទន់ភ្លន់, បះបង្កោនខ្លួនតាមទេសកាល

cabrioler *v.i.* លោតជាំទីង

cabriolet *n.m.* រទេះសេះម្យ៉ាងមានដំបូល (ដំបូល)

cabrioleur, euse *a.&n.* អ្នកលោតជាំទីង

caca *n.m.* អាចម៍ (ពាក្យក្មេង)

cacaber *v.i.* រងាវ (ទទា)

cacahuète *n.f.* ផ្លែសណ្តែកដី (ហៅ cacahouète ក៏បានដែរ)

cacao *n.m.* កាកាវ ។ beurre de cacao ជាតិប្រេងកាកាវ

cacaoté,e *a.* ដែលមានលាយកាកាវ

cacaoyer ឬ **cacaotier** *n.m.* ដើមកាកាវ

cacaoyère ឬ **cacaotière** *n.f.* ចំការកាកាវ

cacarder *v.i.* ស្រែក (ក្ងាន)

cacatoès *n.m.* សេកម្យ៉ាងសម្បុរស្រស់ (ហៅ cacatois ក៏បានដែរ)

cachalot *n.m.* ពិន្ទុងម្យ៉ាង

cache *n.f.* កន្លែងលាក់ ។ *n.m.* ក្រដាសរំហោក

cache-cache *n.m.* បិទពួន (ល្បែង)

cache-col *n.m.* ក្រមារុំក

cachectique *a.&n.* នៃភាពរីងរៃ;ដែលរីងរៃ

cache-entrée *n.m. inv.* គំរបប្រហោងសោ

cache-misère *n.m. inv. Pop.* អាវពាក់បិទបាំងសំលៀកបំពាក់ចាស់

cache-mouchoir *n.m. inv.* លាក់កន្សែង (ល្បែង)

cache-nez *n.m.* សំពត់រុំកឲ្យកក់ក្ដៅ

cache-pot *n.m. inv.* របាំងផើង (គ្រឿងលំអសម្រាប់បាំងកុំឲ្យគេឃើញផើងផ្កា)

cache-poussière *n.m.* អាវពាក់ការពារធូលី

cacher *v.t.* បិទ,បាំង (ឧ. les femmes arabes cachent leur visage sous un voile); លាក់ (ឧ. cacher sa joie); បំពួន។ se cacher *v.pr.* ពួន។ se cacher d'une chose លាក់របស់អ្វីមួយ (មិនចង់ឲ្យគេដឹង) (ឧ. pourquoi se cacher d'un scrupule honorable?) ។ se cacher de quelqu'un លួចធ្វើ (មិនឲ្យគេដឹង)

cache-sexe *n.m. inv.* សំពត់ប៉ឹង

cachet *n.m.* ត្រា; ស្នាមត្រា (ឧ. les lettres chargées doivent être scellées de cinq cachets) ។ payer au cachet un maître ឲ្យរង្វាន់គ្រូតាមចំនួនមេរៀនដែលបានធ្វើ ។ courir le cachet បង្រៀនសិស្សដល់ផ្ទះ (ដើម្បីចិញ្ចឹមជីវិត) ។ សំបុកពីងពាង (ស្រោមដាក់ថ្នាំសណ្ឋានសំបុកពីងពាង)។ *Fig.* លក្ខណសញ្ញា (ឧ. le cachet du génie) ។ *Par ext.* លក្ខណៈប្លែក(ឧ. œuvre qui n'a point de cachet)

cachetage *n.m.* ការបោះត្រា; ការបិទបោះត្រា

cache-tampon *n.m.* ម.ព. cache-mouchoir

cacheter *v.t.* បោះត្រា;បិទកាកល័ខ(បិទបោះត្រា);បិទស្រោមសំបុត្រ។ cire à cacheter អាចម៍ល័ខសម្រាប់បោះត្រា

cachette *n.f.* ទីបំពួន ។ en cachette *loc. adv.* ដោយស្ងាត់កំបាំង (ឧ. rire en cachette)

cachexie *n.f.* ភាពរីងរៃ (ឧ. la cachexie est souvent la forme suprême des maladies de

la nutrition)

cachot *n.m.* គុកងងឹត (ឧ. les cachots de la Bastille)

cachotterie *n.f.* *Fam.* ការលាក់រឿងតូចតាច (ឧ. faire des cachoteries)

cachottier,ère *a.&n.* អ្នកចូលចិត្តលាក់រឿងតូចតាច

cacochyme *a.&n.* កំព្រឹង (ឧ. vieillard cacochyme)។*Fig.*ឆាប់ខឹង

cacochymie *n.f.* ភាពកំព្រឹង។ *Fig.* ភាពឆាប់ខឹង

cacodylate *n.m.* កាកូឌីឡាត (ឈ្មោះឱសថមួយយ៉ាង)

cacographie *n.f.* អក្សរអាក្រក់

cacophonie *n.f.* សូរសៀងគ្រោតគ្រៀក (ព.ផ. euphonie)

cacophonique *a.* ដែលឮសៀងគ្រោតគ្រៀក

cactus ឬ **cactier** *n.m.* ដំបងយក្ស

c-à-d. (ពាក្យបំព្រួញនៃ c'est-à-dire) ម.ព. dire

cadastrage *n.m.* ឬ **cadastration** *n.f.* ការវាស់ចុះបញ្ជីសុរិយោដី

cadastral,e, aux *a.*នៃសុរិយោដី (ឧ. registre cadastral; plan cadastral)

cadastre *n.m.* សុរិយោដី

cadastrer *v.t.* វាស់ចុះបញ្ជីសុរិយោដី (ឧ. cadastrer le territoire d'une commune)

cadavéreux,euse *a.* ដូចខ្មោច (ឧ. teint cadavéreux)

cadavérique *a.* នៃខ្មោច, ដូចខ្មោច (ឧ. rigidité cadavérique)

cadavre *n.m.* ខ្មោច, បុគ្គល, សព, សាកសព,អស្សុភ។*Par ext.* មនុស្សជិតស្លាប់ (ឧ. c'est un cadavre ambulant)

cadeau *n.m.* ជំនូន,ជំងាយ,បណ្ណាការ, អំណោយ(ឧ.faire cadeau d'une montre)

cadenas *n.m.* សោត្រដោក

cadenasser *v.t.* ដាក់សោត្រដោក (ឧ. cadenasser une porte)

cadence *n.f.* ចង្វាក់ (ឧ. marcher en cadence)

cadencer *v.t.* ធ្វើឲ្យត្រូវចង្វាក់ (ឧ. cadencer le pas)

cadet,ette *a.&n.* ប្អូន ។ (ឧ. sous l'Ancien Régime, les aînés étaient avantagés au détri-

ment des cadets); ញាតិខ្សែខាងប្អូន(ឧ. la branche cadette des Bourbons descend de Philippe d'Orléans, frère de Louis XIV)។ *n.m.* ពៅ (ឧ. le cadet de toute la famille)។ *Fig.* ប្អូន (អាយុតិចជាង) (ឧ. il est mon cadet); សិស្សនាយទាហាន។ c'est un fier cadet ក្មេងនេះក្លាហានណាស់ ។ ក្មេងពើសជាល់ (ក្នុងល្បែងកូលហ្វ)។ *loc. adv.* c'est le cadet de mes soucis ខ្ញុំគ្មានជាអង្គរំពីរឿងនេះបន្តិចសោះ

cadogan *n.m.* បួងសក់ (ហៅ catogan ក៏បាន)

cadole *n.f.* គន្លឹះទ្វារម្យ៉ាង

cadrage *n.m.* *Photogr.* ការលៃរូបដែលប្រុងនឹងថតឲ្យត្រូវកន្លែង ។ *Cinéma* ការលៃបញ្ចូលរូបភាពយន្តក្នុងផ្ទាំងសំពត់ស

cadran *n.m.* មុខនាឡិកា, ផ្ទាំងលេខ

cadre *n.m.* ក្រប (រូបថតឬរូបគំនូរ); តួ (ទោចក្រយាន); ក្របខ័ណ្ឌ (ផ្នែកកិច្ចការ ថ្នាក់អ្នករាជការ ជាន់ខ្ពស់ ជាន់បន្ទាប់នឹងជាន់ទាប) ។ cadre latéral ក្របខ័ណ្ឌពេញ ។ cadre supérieur ក្របខ័ណ្ឌជាន់ខ្ពស់។ cadre secondaire ក្របខ័ណ្ឌជាន់បន្ទាប់។ cadre subalterne ក្របខ័ណ្ឌជាន់ទាប

cadrer *v.i.* ទាក់ទងនឹងគ្នា, ត្រូវគ្នា

caduc,caduque *a.* ជីណ្ណ, ចាស់, ទ្រុឌទ្រោម (ឧ. l'intempérance rend l'homme caduc avant l'âge); ប្រុងនឹងជ្រុះ,ដែលជ្រុះហើយលាស់វិញរាល់ឆ្នាំ (ឧ. feuilles caduques) ។ *Fig.* មោឃៈ (ឧ. un legs devient caduc en cas d'aliénation par le testateur de la chose léguée)

caducité *n.f.* ជីណ្ណភាព [ជិន-ណៈ-] (ភាពចាស់-ទ្រុឌទ្រោម - ប្រុងនឹងជ្រុះ); វ័យចាស់ (ពីអាយុ៨០ដល់៩០ឆ្នាំ)

cæcal,e *a.* នៃពោះវៀនទាល់

cæcum *n.m.* ពោះវៀនទាល់

C.A.F. (ពាក្យបំព្រួញនៃ Coût Assurance Fret(បរិយាយនក៏ប៉ុនេះ នាវាថែត)ថ្លៃទំនិញដឹកនាំដល់ដែនប្រទេសអ្នកទិញដោយគិតរួមតម្លៃបំរុខខាងលើនេះ) គួរដាក់បំព្រួញជាខ្មែរថា= ប.វ.ន. (ឧ. 2,000 francs C.A.F. Phnom-Penh ២.០០០ ក្រវណាត ប.វ.ន.

ភ្នំពេញ គឺៈ ទំនិញដឹកជល់ផែភ្នំពេញ ថ្លៃ ២.០០០ ក្រណោត)

cafard,e *a. Fam.* ដែលលាក់ពុត ។ air cafard ទំនងជាលាក់ពុត

cafard *n.m.* កន្លាត ។ *Fam.* សេចក្ដីអផ្សុក (ឧ. avoir le cafard)

cafardage *n.m.* ការលាក់ពុត; ការលួចប្ដឹង

cafarder *v.i.* លាក់ពុត។ *v.i.Fam.* លួចប្ដឹង

cafardeux,euse *a.* ដែលធ្វើឲ្យអផ្សុក; ដែលបញ្ចេញសេចក្ដីអផ្សុក (ឧ. mine cafardeuse)

café *n.m.* កាហ្វេ (ឧ.prendre du café); គៀមកាហ្វេ (ផ្ទះលក់កាហ្វេនឹងភេសជ្ជៈ); café au lait (ឬ café blanc) កាហ្វេទឹកដោះគោ។ café noir កាហ្វេខ្មៅ (កាហ្វេទទេ) ។ *a.inv.* ពណ៌កាហ្វេ, ត្រូវមៅ(ឧ. une robe café អាវត្រូវមៅ)

café-concert *n.m.* គៀមកាហ្វេមានភ្លេង (*pl.* des cafés-concerts)

caféier *n.m.* ដើមកាហ្វេ

caféière *n.f.* ចំការកាហ្វេ

caféine *n.f.* កាហ្វេអ៊ីន, កាហ្វេរស

caféisme *n.f.* រោគញៀនកាហ្វេ

cafetier *n.m.* អ្នកលក់កាហ្វេ

cafetière *n.f.* ជាន់ឆុងកាហ្វេ (ឧ. cafetière d'argent)

caffut *n.m.* អំបែងគ្រាប់បែក

cafouiller *v.i. Arg.* និយាយឡប់ឡប; ធ្វើការ ។ *Techn.* ដើរមិនស្រួល (ឧ. moteur qui cafouille)

cage *n.f.* ទ្រុង(ឧ. cage d'oiseau; cage de fer) ។ *Fig.& Fam.* គុក (ឧ. mettre un voleur en cage) ។ cage d'une maison ជញ្ជាំងធំៗនៃផ្ទះ ។ cage thoracique ម.ព. thoracique

cageot *n.m.* ទ្រុងតូច

cagette *n.f.* កូនទ្រុង

cagibi *n.m.* *Pop.* ជម្រក

cagna *n.f. Arg. mil.* ផ្ទះ

cagnard,e *a.&n. Fam.* កម្ជិល (ឧ. vie cagnarde; c'est un cagnard);ជានដីដើងបួន;កន្លែងជ្រកខ្យល់

cagnarder *v.i.Fam.* រស់នៅដោយខ្ជិល

cagnardise *n.f. Fam.* ភាពខ្ជិល

cagne *n.f.* ឆ្កែមិនល្អ។*Fig.*មនុស្សកម្ជិល

cagneux,euse *a.&n.* ជង្គង់សេក(ជើង) (ឧ. jambes cagneuses)

cagnotte *n.f.* ហិបទទួលវិភាគទាន;

ចំនួនប្រាក់ក្នុងហិបនោះ

cagot,e *a.&n.* ដែលក្លែងគោរព (ឧ. évitez les cagots autant que les dissipés)

cagoterie *n.f.* ការក្លែងគោរព

cagotisme *n.m.* ចរិតក្លែងគោរព

cahier *n m.* សៀវភៅសរសេរ (ឧ. tenez vos cahiers propres)។ cahier des charges សៀវភៅបន្ទុក ។ cahier de notes សៀវភៅកំណត់

cahin-caha *loc. adv. Fam.* គេះគះ, គគិបគគុប (ឧ. aller cahin-caha)

cahot *n.m.* សំទុះរលាក់ ។ *Fig.* ឧបសគ្គ (ឧ. cahot de la vie)

cahotage *n.m.* ការរលាក់ញយៗ

cahotant,e *a.* រលាក់ (ឧ. voiture cahotante; chemin cahotant)

cahotement *n.m.* ដំណើររលាក់

cahoter *v.i.* ត្រូវរលាក់។ *v.t.* រលាក់។ *Fig.& Fam.* ធ្វើបាប

cahoteux,euse *a.* ដែលធ្វើឲ្យរលាក់ (ឧ. roue cahoteuse)

cahute *n.f.* កូនខ្ទម (ឧ. les cahutes des Arabes sont faites de boue et de paille)

caillage *n.m.* ការខន់ឬកក (ឧ. on évite le caillage prématuré du lait en le faisant bouillir)

caille *n.f.* ក្រួច (សត្វ)

caillé *n.m.* ទឹរដោត; ទឹកដោះកក

caillebotte *n.f.* ដុំទឹកដោះកក

caille-botter *v.t.* ធ្វើឲ្យកកជាដុំៗ។ se caille-botter *v.pr.* កកជាដុំៗ

caillement *n.m.* ការកក ឬ ខន់; ភាពកក ឬ ខន់

cailler *v.t.* ធ្វើឲ្យខន់ ឬ ឲ្យកក (ឧ. la présure caille le lait)

cailletage *n.m.* ការនិយាយច្រើន

cailleter *v.i.* និយាយច្រើន

caillette *n.f.* អ្នកនិយាយច្រើន; មនុស្សសាវ៉ា

caillette *n.f.* ក្រពះកំឡៀង (សត្វទំពាអៀង)

caillot *n.m.* យនលោហិត (ដុំឈាមកក); យនក្សីរ (ដុំទឹកដោះកក)

caillou *n.m.* ក្រួស ។ *Fig.* ឧបសគ្គ

cailloutage *n.m.* ការក្រាលក្រួស

caillouter *v.t.* ក្រាលក្រួស (ឧ. caillouter une route)

caillouteux,euse *a.* ដែលមានក្រួសពាសពេញ (ឧ. chemin caillouteux)

cailloutis *n.m.* គំនរដុំថ្ម (ដែលគេ

បំបែកសម្រាប់ក្រាលផ្លូវ)

caïman *n.m.* ក្រពើ

caisse *n.f.* បេឡា [ប៉េ-], ហិប, ហិបប្រាក់; ប្រអប់; ស្គរ ។ caisse générale បេឡាឧភាស ។ caisse des pensions civiles du Kampuchea (C.P.C.K) បេឡាសោធនស៊ីវិលកម្ពុជរដ្ឋ(ប.ស.ស.ក.)។ caisse provinciale de crédit populaire បេឡាប្រចាំខែត្រសម្រាប់ចងការឲ្យប្រជាជន ។ caisse sociale ហិបប្រាក់ក្រុមហ៊ុន

caisserie *n.f.* កន្លែងធ្វើហិប ឬ ប្រអប់

caissette *n.f.* ហិបតូច, ប្រអប់តូច

caissier,ère *a.* បេឡាធិការ - ការិនី, អ្នករក្សាហិប ។ caissier général បេឡាធិការឧភាស ។ caissier particulier បេឡាធិការពិសេស

caisson *n.m.* រទេះដឹកស្បៀង ឬ យុទ្ធភណ្ឌ (ឧ. chaque pièce d'artillerie est accompagnée de son caisson); ក្រង់រទេះ

cajeput *n.m.* អង្គញ់ (ឈើ)

cajoler *v.t.* ប្រលោម (ឧ. cajoler un vieillard pour se faire nommer sur son testament) ។ *Navig.* រសាត់បន្តិចម្តងៗ

cajoleur,euse *a.&n.* អ្នកប្រលោម

cake *n.m.* [Kèk'] (ពាក្យអង់គ្លេស) នំ

cal *n.m.* ផ្ទៃនៃសាច់ ឬ ឆ្អឹង

calage *n.m.* ការកល់

calaison *n.f.* ជម្រៅស៊ីទឹក(នាវា) (ម.ព. tirant d'eau ផង)

calambar,calambac ឬ calambour *n.m.* ក្លំពាក់

calamité *n.f.* វិបត្តិភ័យ (ឧ. la famine, la guerre sont des calamités)

calamiteux,euse *a.* មានវិបត្តិភ័យ (ឧ. la guerre calamiteuse)

calamus *n.m.* ផ្តៅ

calandre *n.f.* ម៉ាស៊ីនកិនសំពត់ឲ្យរាបស្មើ ឬ ឲ្យរលោង; ខ្ទូតម្យ៉ាង

calandrer *v.t.* កិនឲ្យរាបស្មើ ឬ ឲ្យរលោង

calandreur,euse *n.* អ្នកកិនសំពត់ឲ្យរាបស្មើ ឬ ឲ្យរលោង

calao *n.m.* កេងកង (ហៅ bucéros ក៏បាន)

calcaire *a.&n.m.* បុណ្ណីយ (ដែលមានជាតិកំបោរ)

calcanéum *n.m.* ឆ្អឹងកែងជើង

calcification *n.f.* បុណ្ណីយកម្ម

calcin *n.m.* ផង់កែវ

calcination *n.m.* ការដុត (ឧ. la calcination du gypse fournit le plâtre)

calciner *v.t.* ដុតកំបោរ; ដុត

calcique *a.* នៃកាល់ស្យូម; នៃកំបោរ

calcium *n.m.* កាល់ស្យូម (លោហធាតុម្យ៉ាង)

calcul *n.m.* គណនា, ការគិតលេខ; ការត្រិះរិះ; ក្បួនធ្វើចំណោទ ។ calcul écrit លេខគណនា។ calcul mental មុឆាគណនា ។ calcul oral មុខគណនា ។ calcul pratique គណនាតាមប្រតិបត្តិ ។ calcul du capital គណនារកប្រាក់ដើម ។ calcul de l'intérêt គណនារកការប្រាក់ ។ calcul du taux គណនារកអត្រា ។ calcul du temps គណនារកពេល ។ calcul infinitésimal គណនាអត្យាណូ ។ calcul intégral គណនាអនុកល។ calcul différentiel គណនាអវកល ។ *Méd.* គ្រាប់ប្រមេះ

calculable *a.* អាចគណនាបាន

calculateur,trice *a.&n.* អ្នកគិតលេខ; អ្នកត្រិះរិះ (ឧ. esprit calculateur) ។ *n.f.* ម៉ាស៊ីនគិតលេខ (ឧ. calculatrice électronique)

calculer *v.t.* គណនា ។ *Fig.* គិត, លៃ, ត្រិះរិះ (ឧ. il faut calculer ses dépenses d'après ses revenus) ។ machine à calculer ម៉ាស៊ីនគិតលេខ

calculeux,euse *a. Méd.* ដែលមានគ្រាប់ប្រមេះ; នៃគ្រាប់ប្រមេះ

cale *n.f.* កំណល់

cale *n.f.* បាតនាវា (ឧ. on arrime les marchandises dans le cale); អ៊ូ (កន្លែងធ្វើ ឬ ជួសជុលនាវា)។ *Fig.&Fam.* à fond de cale នាបាតនាវា; *au fig.* ទាល់ (គ្មានធនធាន)

calé,e *a.* ដែលមានកំណល់ ។ *Fig.&Pop.* មាន, ចេះ, ប្រាជ្ញ, ជំនាញ, ពូកែ (ឧ. calé en histoire)

calebasse *n.f.* ផ្លែឃ្លោក; បំពង់ធ្វើដោយផ្លែឃ្លោក

calebassier *n.m.* ដើមឃ្លោក

calèche *n.f.* រទេះកង់បួនម្យ៉ាង

caleçon *n.m.* ខោទ្រនាប់, ខោស្នាប់ភ្លៅ, ខោខ្លី ។ caleçon de bain ខោខ្លីងូតទឹក ។ jeter le caleçon

à quelqu'un បបួលប្រយុទ្ធ

caléfaction *n.f.* អំពើនៃភ្លើង(ធ្វើឲ្យក្ដៅ)

calembour *n.m.* ការលេងពាក្យ(ដោយប្រើពាក្យមានសម្លេងប្រហែលគ្នា)

calembredaine *n.f.* សំដីឥតប្រយោជន៍; ការនិយាយចំអន់លេង (ឧ. débiter des calembredaines)

calendrier *n.m.* ប្រតិទិន ។ *Fig. &fam.* ce n'est pas un saint de votre calendrier មនុស្សនេះមិនមែនមិត្តភក្តិអ្នកទេ

calepin *n.m.* កូនសៀវភៅកំណត់ ។ *Fig.* mettez ceci sur votre calepin ចូរអ្នកចាំឲ្យច្បាស់

caler *v.t.* កល់;ដាក់ឲ្យត្រូវកន្លែង។caler la voile ទម្លាក់ក្ដោង។*v.i.* ស៊ីជម្រៅ (នាវា) ។ *Pop.* បោះបង់, ថយ ។ *Fig.* តាំង(គ្រឿងចក្រ) ។ *Pop.* se caler les joues បរិភោគច្រើន

calfat *n.&a.m.* ជាងបិទទៀវទូក ឬ កប៉ាល់

calfatage *n.m.* ការបិទទៀវទូកឬកប៉ាល់

calfater *v.t.* បិទទៀវទូក ឬ កប៉ាល់

calfeutrage *n.m.* ការបិទប្រហោងទ្វារ ឬ បង្អួច

calfeutrer *v.t.* បិទប្រហោងទ្វារ ឬបង្អួច។ se calfeutrer *v.pr.* សំងំក្នុងផ្ទះ (ឧ. se calfeutrer chez soi)

caliborgne *a. Pop.* ខ្វាក់ម្ខាង

calibrage ឬ **calibrement** *n.m.* ព្យាសកម្ម (ការធ្វើឲ្យគ្រាប់កាំភ្លើងមានព្យាស(ទំហំ)តាមត្រូវការ,ការវាស់ព្យាស)

calibre *n.m.* ព្យាស(ទំហំគ្រាប់កាំភ្លើង) (ឧ. un fusil de calibre 7,5 mm.) ។ calibre de l'artère ព្យាសនៃលោហិតណី

calibrer *v t.* ធ្វើព្យាសកម្ម (ឧ. calibrer des balles)

calice *n.m.* កន្ទ្រាមផ្កា,ត្របកផ្កា;ភាជន៍ម្យ៉ាង ។ *Fig.* boire le calice jusqu'à la lie រងទុក្ខវេទនាពេញបន្ទុក (ម.ព. boire ផង)

calicot *n.m.* ទេសឯក, ផាឌិប

calife *n.m.* ព្រះចៅកាលីហ្វ (តំណាងម៉ាហូម៉េត)

californien,enne *a.&n.* នៃប្រទេសកាលីហ្វ័រនី

califourchon (à) *loc. adv.* ក្រោកគាវ (ឧ. le cornac se place à califourchon sur le cou de l'éléphant) ។ califourchon *n.m. Fig.& fam.* ការចូលចិត្ត(ឧ.

c'est son califourchon)

câlin,e *a.&n.* ទងវែង,ទន់ភ្លន់ (ឧ. des manières câlines)

câlinement *adv.* ដោយទងវែងឬទន់ភ្លន់

câliner *v.t.* បញ្ជោសអង្អែល ។ se câliner *v.pr.* រស់នៅដោយខ្ជិល; បញ្ជោសអង្អែលគ្នាទៅវិញទៅមក

câlinerie *n.f.* ការបញ្ជោសអង្អែល; របៀបទងវែង ឬ ទន់ភ្លន់

calleux,euse *a.* ដែលក្រិន ឬ ផ្លែ(ឡើងរឹងសាច់) ។ *Anat.* corps calleux កិណាគ្គ, អង្គក្រិន

calligraphe *n.&a.* អ្នកអក្ខរវិចិត្រសាស្ត្រ, អ្នកសរសេរអក្សរល្អ

calligraphie *n.f.* អក្ខរវិចិត្រសាស្ត្រ (វិជ្ជាខាងសរសេរអក្សរល្អ)

calligraphier *v.t.* សរសេរអក្សរល្អ (ឧ.calligraphier une lettre)

calligraphique *a.* នៃអក្ខរវិចិត្រសាស្ត្រ

callinecty *n.f.* ក្តាមសេះ

callosité *n.f.* សាច់ក្រិន,ផ្លែ(សាច់កន្ទួល)

calmant,e *a.* ដែលធ្វើឲ្យអន់ ឬ ឲ្យធូរ; ដែលរម្ងាប់ ។ *Fig.* ដែលធ្វើឲ្យស្រាក (ឧ. l'espérance est un précieux calmant)

calme *a.* ស្ងប់,នឹង(ឧ.mer calme)។ *n.m.* ភាពស្ងប់ឬនឹង (ឧ.le calme de la mer) ។ *Fig.* សេចក្តីស្ងប់

calmement *adv.* ដោយស្ងប់ ឬ មិនក្រឡេត

calmer *v.t.* ល្ងង, ធ្វើឲ្យស្ងប់, បន្ធូរ, រម្ងាប់ (ឧ. calmer la colère) ។ se calmer *v.pr.* ស្ងប់

calmir *v.i.* *Mar.* ស្ងប់, ស្រាក (ឧ. le vent calmit)

caloge *n.f.* ផ្ទះថ្ពែ; រូងទន្សាយ; នាវាឆ្លាប់សម្រាប់ត្រីក

calomniateur,trice *n.&a.* ដែលបង្កាច់ (ឧ. un lâche calomniateur)

calomnie *n.f.* ពាក្យបង្កាច់ (ឧ. la calomnie est l'arme des lâches)

calomnier *v.t.* និយាយបង្កាច់ (ឧ. le moyen sûr de ne jamais calomnier, c'est de ne jamais médire)

calomnieusement *adv.* ដោយបង្កាច់

calomnieux,euse *a.* ប្រកបដោយពាក្យបង្កាច់ (ឧ. imputation calomnieuse)

caloricité *n.f.* ភាពបញ្ចេញកាឡូរី

calorie *n.f.* កាឡូរី (មាត្រាកំរិតកំដៅ)

calorifère *a.* ដែលមាន ឬ ដែលបញ្ចេញកាឡូរី ។ *n.m.* ម៉ាស៊ីនកំដៅ (ឧ. calorifère à air chaud, à eau chaude, à vapeur)

calorifiant,e *a.* ដែលកំដៅ

calorification *n.f.* ការបញ្ចេញកំដៅ

calorifique *a.* ដែលឲ្យកំដៅ

calorifuge *a.* & *n.m.* ដែលមិនឲ្យជាត់កំដៅ (ឧ. l'amiante est calorifuge)

calorimètre *n.m.* កាឡូរីមាត្រ (ប្រដាប់ស្ទង់កាឡូរី)

calorimétrie *n.f.* កាឡូរីមាត្រវិធី (វិធីស្ទង់កាឡូរី)

calorimétrique *a.* នៃកាឡូរីមាត្រវិធី

calorique *n.m.* កំដៅ

calot *n.m.* ឈើកំណល់

calot *n.m.* កាតិបស៊ឹង ។ *Pop.* ភ្នែក

calotin ឬ **calottin** *n.m.* *Par dénigr.* បព្វជិត (គ្រិស្តសាសនា); អ្នកកាន់ជើងបព្វជិតគ្រិស្តសាសនា

calotte *n.f.* កាតិបមូលកក់ (ឧ. les cardinaux portent la calotte rouge)។ *Par dénigr.* & *fam.* ពួកបព្វជិតគ្រិស្តសាសនា; ដោមតូច ។ calotte du crâne បន្ទូលក្បាល។ calotte sphérique ចំណិតជុំមណ្ឌល ។ calotte des cieux មេឃ ។ *Fam.* ការទះក្បាល

calotter *v.t.* ទះក្បាល

calquage *n.m.* ការផ្តាប់ចម្លង,ការសាក

calque *n.m.* រូបផ្តាប់ចម្លង ។ *Fig.* ការត្រាប់ទាំងងងឹតងងល់

calquer *v.t.* ផ្តាប់ចម្លង, សាក (ឧ. calquer une carte) ។ *Fig.* ត្រាប់ទាំងងងឹតងងល់

calquoir *n.m.* ដែកសម្រាប់ផ្តាប់ចម្លង

calter ឬ **caleter** *v.i.* *Pop.* រត់ (គេចខ្លួន)

calumet *n.m.* ខ្សៀបំពង់វែង

calus *n.m.* ម.ព. cal

calvaire *n.m.* ឈ្មោះភ្នំដែលគេឆ្កាងព្រះយេស៊ូ; ទួលមានឈោគឈើឆ្កាង។*Fig.* ទុក្ខវេទនាខ្លាំង (ឧ. gravir son calvaire)

calvinisme *n.m.* លទ្ធិកាល់វ៉ាំង

calviniste *a.* នៃលទ្ធិកាល់វ៉ាំង ។ *n.* សាវ័កបេស់កាល់វ៉ាំង

calvitie *n.f.* ភាពទំពែក(ឧ. la calvitie est difficilement curable)

camail *n.m.* ព្រោះការពារកនឹងស្មា; ផ្លិតកមាន់ (រោមស្លាបត្រង់កមាន់)

camarade *n.* គូកន,ក្មើ,ពួកម៉ាក (ឧ. deux camarades de pension)។ *Fam.* faire camarade លើកដៃសុំចាញ់

camaraderie *n.f.* ភាពជាគូកន-ជាក្មើ ឬ ជាពួកម៉ាក; ការរាប់អានគ្នា; ការរួមគំនិត (ឧ. la camaraderie littéraire)

camard,e *a.&n.* ច្រមុះរៀច។ *Pop.* la camarde សេចក្ដីស្លាប់

cambial,e,aux *a.* ខាងការប្ដូររូបិយវត្ថុ (ឧ. droit cambial)

cambiste *n.m.* អ្នកកាន់កាប់ការប្ដូររូបិយវត្ថុ

cambium *n.m.* ឯតា (រំអិលឈើ) ។ assise du cambium ឯតាស័យ

cambodgien,enne *a.&n.* កម្ពុជិក-ជិកា, ខេមរៈ, ខ្មែរ

cambrage *n.m.* ការបង្កោងឬការបង្អើន

cambré,e *a.* កោង, អែន

cambrement *n.m.* ការបង្កោង; ការបំកោង

cambrer *v.t.* បង្កោង, បង្អើន, បំកោង (ឧ. cambrer sa taille; cambrer un longeron)

cambriolage *n.m.* ការលួចដោយក្លាហាន(មានឡើងទំងគាស់ទ្វារផ្ទះជាដើម)

cambrioler *v.t.* លួចដោយក្លាហាន

cambrioleur,euse *n.* ចោរលួចដោយក្លាហាន

cambrouse *n.f. Pop.* ស្រុកស្រែ

cambrure *n.f.* ភាពកោង (ដូចជងធ្នូ) (ឧ. la cambrure d'une pièce de bois)

cambuse *n.f.* ឃ្លាំងស្បៀង (ក្នុងនាវា); អាហារដ្ឋាន (ក្នុងការដ្ឋាន) ។ *Pop.* ភោជនាល័យ; ផ្ទះគ្មានរបៀបរៀបរយ

cambusier *n.m.* អ្នកចែកស្បៀងក្នុងនាវា

came *n.f.* កង់មានស្ពឺ (សម្រាប់ធ្វើឲ្យគ្រឿងចក្រដើរ)

caméléon *n.m.* សត្វប្រឡាំងសត្វានបង្គួយ។ étoffe caméléon សំពត់ភ្លឺផ្លេកៗ។ *Fig.* អ្នកប្រែគំនិតភ្លាមៗ (តាមប្រយោជន៍ខ្លួន)

camelot *n.m.* សំពត់ចោក; អ្នកលក់ទំនិញរាយរង; អ្នកលក់កាសែត

camelote *n.f.* ទំនិញរាយរង (ឧ. vendre, acheter de la camelote); ការធ្វើដោយខ្ជីខ្ជា

cameloter *v.t.* ត្បាញសំពត់ចោក; ធ្វើរបស់រាយរង ។ *v.i.* លក់ទំនិញរាយរង

caméra ឬ **camera** *n.f.* ម៉ាស៊ីនថតភាពយន្ត

camion *n.m.* កាម៉ុង (រថយន្តបន្ទុក) ។ camion-citerne ម.ព. citerne

camionnage *n.m.* ការដឹកដោយកាម៉ុង

camionner *v.t.* ដឹកដោយកាម៉ុង(ឧ.camionner des marchandises)

camionnette *n.f.* កាម៉ុងតូច

camionneur *n.m.* អ្នកបើកកាម៉ុង

camisole *n.f.* អាវស្រីម្យ៉ាង

camouflage *n.m.* ការក្លែង ។ *Spéc.* ការលាក់ ឬ បំបាំងដោយបន្លំ

camoufler *v.t.* ក្លែង;បំបាំងឬ បន្លំលាក់

camouflet *n.m.* ផ្សែងផ្លុំដាក់មុខគេ ។ *Fig.* ការប្រមាថ(ឧ. recevoir un camouflet)

camoufleur *n.m.* អ្នកក្លែង - បំបាំង ឬ បន្លំលាក់

camp *n.m.* បន្ទាយ, ជំរំ, ពួក ។ camp de concentration បន្ទាយសមាធ, បន្ទាយផ្ដុំជន ។ camp volant កងអ្នកនាំផ្លូវ ។ *Par ext.* ការសំចតនៃជនអនាថា ។ *Fig.* en camp volant ដោយបណ្ដោះអាសន្ន ។ aide de camp អង្គរក្ស, អ្នករក្សាអង្គ ។ lever le camp, ficher le camp ថយចេញ

campagnard,e *n.* អ្នកជនបទ, អ្នកស្រែចំការ ។ *a.* នៃជនបទ (ឧ. manières campagnardes)

campagne *n.f.* ជនបទ; ស្រុកស្រែចំការ (ឧ. les travaux de la campagne) ។ rase campagne ដីរាបស្មើ (ឧ. il est déshonorant pour un général de capturer en rase campagne) ។ *Fig.* យុទ្ធការ [យុត-ធៈ-] (ការតយុទ្ធ, ចម្បាំង) (ឧ. campagne de Srê Ches) ។ mettre en campagne ប្រើ (ផ្អែកលើ) (ឧ. solliciteur qui met toutes ses relations en campagne)។ se mettre en campagne ចេញនាំផ្លូវ(នាំទ័ព); *au fig.* ចេញគិតការ។ être en campagne ប្រឹងប្រែងគិតការ,កំពុងធ្វើ(ឧ. je crois qu'il y a quelque amour en campagne)។ son imagination est en campagne គំនិតគាត់កំពុងស្ទុះស្ទា (គាត់កំពុងគិតខ្លាំង)។ faire une belle campagne គិតគួរមិនបានការ ។ tenir la

campagne ទប់ទល់នឹងសត្រូវ ។ aller à la campagne ទៅជនបទ ឬ ស្រុកស្រែ,ចេញពីក្រុង ។ aller en campagne ដើរមានការ ។ battre la campagne ដើររុករើ; *au fig.* និយាយមិនសមហេតុផល;និយាយសាវ៉ា ។ entrer en campagne ចូលតយុទ្ធ; *au fig.*ចាប់ផ្ដើម (ធ្វើកិច្ចការអ្វីមួយ) ។ faire ses premières campagnes ចូលច្បាំងដំបូង; *au fig.* ផ្ដើមគិតអ្វីមួយៗ រដូវ(ឧ. maison bâtie en deux campagnes); សម័យ(ឧ. campagne électorale សម័យបោះឆ្នោត; campagne de pêche សម័យនេសាទ)

campagnol *n.m.* កណ្ដុរល្មេះ (ឧ. les campagnols se multiplient avec une rapidité dangereuse pour l'agriculture)

campane *n.f.* ផ្ទឹង;គ្រឿងលំអរជារាងផ្ទឹង

campanile *n.f.* រោងផ្ទឹងគ្មានជញ្ជាំង

campé,e *a.* ដែលបោះជំរំ; ដែលដាក់ ។ *Fig.&fam.* un gaillard bien campé មនុស្សមាឌធំ

campement *n.m.* ការបោះជំរំ; ទីបោះជំរំ; ទ័ពបោះជំរំ; ក្រុមអ្នករៀបចំទីជំរំ ។ matériel de campement សម្ភារៈបោះជំរំ

camper *v.i.* បោះជំរំ,នៅជាបណ្ដោះអាសន្ន ។ *v.t.* បោះទ័ព (ឧ. camper son armée sur une colline) ។ *Fam.* រៀបចំ, ដាក់, ពាក់ (ឧ. camper son chapeau sur l'oreille);ចាកចេញភ្លាម(មិននៅជិត) (ឧ. camper là quelqu'un) ។ se camper *v.pr. Fam.* ឈរបំពាំង (ឧ. il se campa au milieu du salon)

campeur,euse *n.* អ្នកបោះជំរំ

camphre *n.m.* ទេព្វិរូ (ឈ្មោះឈើមួយយ៉ាងសម្បកមានក្លិនក្រអូប ប្រើនប្រើជាថ្នាំខ្យល់)

camphré,e *a.* ដែលមានដាក់ទេព្វិរូ

camphrer *v.t.* ដាក់ទេព្វិរូ (ឧ. on camphre les fourrures et les lainages pour les préserver des insectes)

camphrier *n.m.* ដើមទេព្វិរូ

camping *n.m.* ខ្ទាសិរកិច្ច, ការបោះជំរំកំសាន្ត (ឧ. faire du camping)

campos *n.m. Fam.* ការឈប់ហែ, ការសម្រាក (ឧ. donner campos

à des écoliers)

camus,e *a.* ញៀច ឬ ខ្ទេច (ច្រមុះ) (ឧ. les nègres ont généralement le nez camus); ដែលមានច្រមុះញៀច (ឧ. homme camus) ។ *Fig.&Fam.* ស្រឡាំងកាំង (ឧ. rester tout camus)

canadien,enne *a.* នៃប្រទេសកាណាដា ។ *n.* ជនជាតិកាណាដា

canaille *n.f.* ជនថោកទាប; ភាគតិចបំផុត (ឧ. la canaille écrivante; la canaille cabalante) ។ *Spécial.* une canaille ជនទុច្ចរិត ។ franche canaille ជនទុច្ចរិតពេញទី

canaillerie *n.f.* អំពើថោកទាបឬទុច្ចរិត

canal *n.m.* ព្រែកជីក, ប្រឡាយ (ឧ. les canaux sont une ressource précieuse pour l'industrie d'un pays) ។ canal maritime ព្រែកជីកភ្ជាប់សមុទ្រពីរ ។ canal latéral ព្រែកជីកអមទន្លេ (ដែលពិបាកបើកកប៉ាល់) ។ ប្រឡាយ; បំពង់ (ឧ. canal pour la vapeur) ។ canal d'irrigation ព្រែកបញ្ចូលទឹក ។ *Fig.* មធ្យោបាយ (ឧ. réussir par le canal de quelqu'un) ។ *Anat.* ប្រណាលី ។ canal cholédoque ប្រណាលីប្រមាត់ ។ canal pancréatique ប្រណាលីលំពែង ។ canal excréteur ប្រណាលីមលមោចនីក [មៈ-លៈ-មោ-ចៈ-នីក] ។ canal thoracique ប្រណាលីឱរិក

canalicule *n.m.* បំពង់តូច,ប្រឡាយតូច

canalisable *a.* អាចជីកជាព្រែកបាន(ឧ. cours d'eau canalisable)

canalisateur,trice *a.* ដែលជីកព្រែក

canalisation *n.f.* ការជីកព្រែក; បណ្ដាញព្រែកជីក-ប្រឡាយឬខ្សែអគ្គិសនី

canaliser *v.t.* ជីកព្រែក; រៀបចំផ្លូវនាវា ។ *Fig.* ប្រមូល, ផ្ដុំ

canamelle ឬ **cannamelle** *n.f.* ដើមអំពៅ

canapé *n.m.* កៅអីវែង; ចំណិតនំប៉័ងអាំងផ្ទាប់សាច់

canard *n.m* ទាឈ្មោល; ដំណឹងមិនពិត(ឧ. les canards des journaux); កាសែត; សម្លេងផើរ ។ *Pop.* សេះ ។ *Mar.* ភាពជ្រុំឬពៀបក្បាល (នាវា)

canardeau *n.m.* ទាជំទង់

canarder *v.t.* ពួនបាញ់, លបបាញ់ ។

v.i. Fam. ច្រៀង ឬ លេងភ្លេងឈ្លើយ; ផ្សាយដំណឹងមិនពិត ។ *Arg.* បរបាញ់; បរបាញ់ដោយគ្មានអនុញ្ញាត។ *Mar.* ផ្ងោង, ងោកលោក (ឧ. frégate qui canarde à démâter)។ se canarder *v.pr.* បាញ់គ្នា

canardière *n.f.* ត្រពាំងសម្រាប់ទា ; កន្លែងទាក់ទាព្រៃ; កាំភ្លើងម្យ៉ាងសម្រាប់បាញ់ទាព្រៃ

canasson *n.m. Pop.* សេះមិនល្អ

cancan *n.m.* ការនិយាយអាក្រក់ពីគេ (ឧ.faire des cancans); កង់កង់ (របាំម្យ៉ាង)

cancaner *v.i.* ស្រែកកាបៗ (ទា) ។ *Fam.* និយាយអាក្រក់ពីគេ; រាំកង់កង់

cancanier,ère *a.&n.* អ្នកហៃនិយាយអាក្រក់ពីគេ

cancellariat *n.m.* ឋានន្តរអធិការបតី

canceller *v.t.* ឆូតចោល

cancer *n.m.* ដំបៅមហារីក។ *Astron.* កក្កដរាសី (រាសីក្ដាម)

cancéreux,euse *a.* នៃដំបៅមហារីក។ *n.* អ្នកកើតដំបៅមហារីក

cancérisation *n.f.* ការក្លាយជាដំបៅមហារីក

cancre *n.m.* ក្ដាម, កណ្ដូសសមុទ្រ ។ *Fam.* សិស្សខ្ជិល

cancrelat *n.m.* កន្លាត(ម.ព. cafard នឹង blatte ផង)

cancroïde *n.m.* ដំបៅមហារីកស៊ីស្បែក

candélabre *n.m.* ជើងទៀនផ្កា; បង្គោលចង្កៀង; ដំបងយក្សម្យ៉ាង(រុក្ខជាតិ)

candeur *n.f.* បរិសុទ្ធចិត្ត;ភាពឆោត(ឧ. un aveu plein de candeur)

candi *a.&n.m.* ស្ករក្រាមធំ, ស្ករតាំងស៊ុន

candidat,e *n.* បេក្ខជន [ប៉េក-ខ:-] (ជន អ្នកសំឡឹងឬអ្នកប៉ងប្រយោជន៍អ្វីមួយ ។ ក្នុងទីនេះសំដៅយកអ្នកឈរឈ្មោះឲ្យគេបោះឆ្នោត, អ្នកដែលចុះឈ្មោះប្រឡង ឬ អ្នកសុំចូលកាន់តំណែងណាមួយ) ។ bonze candidat បេក្ខសមណៈ។ candidat libre បេក្ខជនសេរី

candidature *n.f.* បេក្ខភាព [ប៉េក-ខ:-] (ភាពបេក្ខជន) (ឧ. poser sa candidature; soutenir la candidature de quelqu'un)

candide *a.&n.* ឆោត (ឧ. les candides sont souvent les dupes des trompeurs; air candide); ប្រកបដោយបរិសុទ្ធចិត្ត

candidement *adv.* ដោយបរិសុទ្ធចិត្ត; ដោយឆោត

candir (se) *v.pr.* ឡើងក្រាម(ស្ករ) (ឃា faire candir le sucre ក៏បាន)

candisation *n.f.* ការធ្វើឲ្យឡើងក្រាម

cane *n.f.* ទាញី

canepin *n.m.* ស្បែកកូនចៀម

caner *v.i Pop.* ដើរតេបតាប (ដូចទា); ខ្លាច, ថយ

caneton *n.m.* ទាឈ្មោលជំទង់, កូនទា

canette *n.f.* ទាញីជំទង់

canette *n.f. Techn.* ខ្នារអម្បោះ

canevas *n.m.* សំពត់កម្រាល; សំពត់ក្តោង ។ *Fig.* គ្រោងការសៀវភៅ ។ *Mus.* ទំនុកច្រៀង

cange *n.f.* ទូកតូចម្យ៉ាងប្រើក្នុងទន្លេនិល (ប្រទេសអេហ្ស៊ីប)

cangue *n.f.* ឃ្នោង, ត្រោក (ឧ. le poids de la cangue varie avec la gravité de la faute commise); ទោសដាប់ឃ្នោង

caniche *n.m.* ឆ្កែម្យ៉ាងរោមរួញ

caniculaire *a.* នៃសីហភសី

canicule *n.f.* ផ្កាយសីហៈ; សីហភសី (រដូវដែលផ្កាយព្រឹករះហើយលិចជំ-ណាលនឹងព្រះអាទិត្យគឺពី ២២ កក្កដា ដល់ ២៣ សីហា)

canidés *n.m. pl.* សុនខសាទិស [សុ-ណក់-សា-ទិស] (ពួកសត្វស្មានឆ្កែ)

canif *n.m.* កាំបិតបត់

canin,e *a.* នៃសុនខ, នៃឆ្កែ ។ faim canine គម្លានខ្លាំង ។ l'espèce canine សុនខ, ឆ្កែទាំងឡាយ

canine *n.f.* ចង្កូម (ឧ. les canines sont la marque distinctive des mammifères carnassiers) ។ *a.* នៃចង្កូម

canitie *n.f.* ភាពស្កូវ (សក់) (ឧ. la canitie est un signe habituel de la vieillesse)

caniveau *n.m.* ចង្អូរទឹក, ប្រឡាយទឹក

cannaie *n.f.* ចំការអំពៅ

canne *n.f.* ដំណាំពួកអំពៅ ត្រែង។ល។; ឈើច្រត់ (ឧ. les grands seigneurs des XVIIe et XVIIIe siècles portaient des cannes magnifiquement ouvragées); ដំបង ។ canne à pêche ដងសន្ទូច ។ canne à épée ដំបងដាវ (ដំបងបង្កប់ដាវពីក្នុង) ។ canne à sucre អំពៅ

cannelé,e *a.* ដែលមានក្បាច់ចង្អូរ (សសរ) ។ *n.m.* សំពត់ព្រែ

canneler *v.t.* លំអដោយក្បាច់ចង្អូរ

cannelier *n.m.* ដើមសម្បុរល្វែង

cannelle *n.f.* សំបកសម្បុរល្វែង ។ pomme cannelle ផ្លែទៀប

cannelle ឬ **cannette** *n.f.* បំពួយ

cannelure *n.f.* ក្បាច់ចង្អូរ (សសរ); ឆ្នូតដើមឈើ

cannetille *n.f.* ខ្សែសយ

cannibale *a.&n.* ដែលស៊ីសាច់មនុស្ស (ឧ. il existe encore, en Afrique centrale, des cannibales) ។ *Fig.* មនុស្សឃោរឃៅ

cannibalisme *n.m.* ការនិយមស៊ីសាច់មនុស្ស ។ *Fig.* អំពើឃោរឃៅ

canoë *n.m.* កាណូអេ (ទូកស្រាលម្យ៉ាងអាចលើកបាន)

canoéiste *n.* អ្នកលេងកាណូអេ

canon *n.m.* កាណុង, កាំភ្លើងធំ; បំពង់កាំភ្លើង(ឧ. le canon rayé augmente la portée du fusil)

canon *n.m.* សាសនបញ្ញត្តិ, គម្ពីរ; គំរូ (ឧ. l'Apollon du Belvédère est comme le canon de la beauté antique) ។ droit canon ឬ droit canonique ច្បាប់សម្រាប់សាសនា ឬ សម្រាប់បព្វជិត

cañon ឬ **canyon** *n.m.* ជ្រោះជ្រៅជាស្នាមផ្លូវទឹក

canonial,e,aux *a.* ដែលមានចែងក្នុងសាសនបញ្ញត្តិ (ឧ. défenses canoniales); ត្រូវតាមសាសនបញ្ញត្តិ

canonicat *n.m. Fig.&fam.* មុខរបរស្រួល

canonicité *n.f.* លក្ខណៈត្រូវតាមសាសនបញ្ញត្តិ

canonique *a.* ត្រូវតាមសាសនបញ្ញត្តិ (ឧ. peines canoniques) ។ droit canonique ម.ព. canon

canoniquement *adv.* តាមសាសនបញ្ញត្តិ

canonisable *a.* អាចលើកជាសន្តជនបាន

canonisation *n.f.* ការលើកជាសន្តជន

canoniser *v.t.* លើកជាសន្តជន ។ *Fig.&fam.* សរសើរហួសហេតុ

canoniste *n.m.* អ្នកប្រាជ្ញខាងច្បាប់សម្រាប់សាសនា

canonnade *n.m.* សូរកាំភ្លើងធំ; ការបាញ់កាំភ្លើងធំតគ្នា

canonnage *n.m.* វិជ្ជាប្រើកាំភ្លើងធំ

canonner *v.t.* បាញ់ដោយកាំភ្លើងធំ (ឧ. canonner une place)

canonnier *n.m.* ខ្មាន់កាំភ្លើងធំ

canonnière *n.f.* រន្ធសម្រាប់បាញ់;

កាំភ្លោះ (គ្រឿងក្មេងលេងធ្វើដោយដាង ក្នុងនាដើម); កាំភ្លើងរ៉ៃ

canot *n.m.* ទូកបុក, កណូត ។ canot de sauvetage កណូតសង្គ្រោះ

canotage *n.m.* ការកំសាន្តដោយកណូត (ឧ. le canotage est devenu un véritable sport)

canoter *v.i.* កំសាន្តដោយកណូត, អុំ

canotier *n.m.* អ្នកអុំកណូត, អ្នកលេងកណូត

cantatrice *n.f.* គីតិកា (ស្ត្រីច្រៀងល្បីល្បាញ)

canter [–teur] *n.m.* (ពាក្យអង់គ្លេស) ការផាយល្បឿង (សេះ) (ឧ. prendre un canter)

cantine *n.f.* ភោជនាដ្ឋាន

cantinier,ère *n.* អ្នកលក់ម្ហូប-ទឹក, អ្នកកាន់កាប់ភោជនាដ្ឋាន

cantique *n.m.* ចម្រៀងសម្រាប់សាសនាកាតូលិក

canton *n.m.* ឃុំ, ក្រុម

cantonnement *n.m.* ការបោះទ័ពបណ្ដោះអាសន្ន (ឧ. le cantonnement vaut mieux pour la santé du soldat que le bivouac); ទីបោះទ័ពបណ្ដោះអាសន្ន; ការចែកកន្លែង; ការដាក់ព្រំដែនច្បាប់ (ឧ. cantonnement d'une saisie arrêt); ខណ្ឌ ។ cantonnement des pêches ខណ្ឌនេសាទ

cantonner *v.t.* បោះទ័ព; ដាក់ឲ្យនៅដាច់ពីគ្នា ។ *v.i.* បោះទ័ព ។ se cantonner *v.pr.* សម្ងំ (ឧ. se cantonner dans une prudente réserve)

cantonnier *n.m.* អ្នករក្សាផ្លូវថ្នល់

canule *n.f.* បំពង់សុល

canulant,e *a. Pop.* ដែលឲ្យអផ្សុក

canuler *v.t. Pop.* ធ្វើឲ្យអផ្សុក

caolin *n.m.* ម.ព. Kaolin

caoutchouc *n.m.* កៅស៊ូ ។ caoutchouc synthétique កៅស៊ូស្ង

caoutchoutage *n.m.* ការលាប ឬ ពាសកៅស៊ូ

caoutchouter *v.t.* លាបឬពាសកៅស៊ូ (ឧ. on caoutchoute les tissus pour les rendre imperméables)

caoutchoutier,ère *a.* នៃកៅស៊ូ

cap *n.m.* ក្បាល ។ armé de pied en cap មានគ្រឿងពីក្បាលដល់ចុងជើង (មានគ្រឿងគ្រប់មុខ) ។ cap à

cap គ្ន, ប្រទល់មុខគ្នា, តែពីរនាក់ ។ ក្បាល (នាវ); ជ្រោយ (ឧ. Barthélemy Diaz découvrit le cap de Bonne-Espérance)។ doubler un cap សៀវតាមជ្រោយ ។ mettre le cap sur បើកតម្រង់ចំ

capable *a.* សមត្ថ, ដែលអាច, ដែលចេះ; ប្រសប់; ឆ្លាត ។ capable de tout គ្មានញញើតឬគ្មានរួញរាអ្វីសោះ ។ *Dr.* សមត្ថ (ឧ. le mineur n'est pas capable)។ faire le capable ធ្វើឫកជាប្រសប់

capacité *n.f.* ចំណុះ (ឧ. capacité d'un vase) ។ mesures de capacité ខ្នាតចំណុះ (ម.ព. mesure ផង)។ សមត្ថភាព, ប្រាជ្ញា, ចំណេះ (ឧ. personne d'une haute capacité); អ្នកមានប្រាជ្ញា, អ្នកមានចំណេះឬវិជ្ជា (ឧ. consulter des capacités médicales) ។ *Dr.* សមត្ថភាព (ឧ. la capacité de la femme mariée)

caparaçon *n.m.* គ្រឿងលំអសេះក្នុងពិធីផ្សេងៗ

caparaçonner *v.t.* បំពាក់គ្រឿងលំអឲ្យសេះ

cape *n.f.* អាវដណ្ដប់គ្មានដៃ; មួកម្យ៉ាង; ក្រោមសុំប្ដូរ (ជារី)។ rire sous cape លួចសើចក្នុងពោះ ។ n'avoir que la cape et l'épée មានតែខោមួយចង្កេះ (គ្មានសម្បត្តិទ្រព្យ)

capillaire *a.* កេសធា (នៃសក់, ឆ្មារដូចសក់) (ឧ. sève capillaire) ។ vaisseaux capillaires ឬ capillaires *subst.* ធមនីកេសធា (សរសៃតូចបំផុតសម្រាប់ឈាមរត់)

capillarité *n.f.* កេសនភាព (ភាពឆ្មារដូចសក់)

capilotade *n.f.* *Fig.* mettre en capilotade បំបែកឲ្យខ្ទេច

capitaine *n.m.* នាយក្រុម, មេ, មេទ័ព។ *Mil.* អនុសេនីយឯក ។ capitaine de corvette វរនាវីត្រី [វ-រៈ-] ។ capitaine de frégate វរនាវីទោ ។ capitaine de vaisseau វរនាវីឯក ។ capitaine des navires នាវាប្រមុខ

capital,e,aux *a.* សំខាន់ (ឧ. point capital); ធំ; ផលដល់ជីវិត (ឧ. sentence capitale) ។ peine capitale ទោសដល់ជីវិត ។ lettre ca-

pitale អក្សរធំ

capital *n.m.* ការសំខាន់ (ឧ.se bien conduire, voilà le capital); ដើមទុន (ឧ. manger son capital); មូលធន [មូ-លៈ-ធន់] (ឧ. l'industrie vit de l'union du capital et du travail) ។ capital disponible មូលធនទំនេរ (ដើមទុនសល់ពីការប្រើប្រាស់)។ capital engagé មូលធនជាប់ប្រើ (ដើមទុនដែលកំពុងប្រើប្រាស់) ។ capital immobilisé មូលធនកប់ (ដែលដំកល់ទុកឥតប្រើប្រាស់) ។ capital investi មូលធនប្រកបការ (សម្រាប់ប្រើប្រាស់ចេញចូល) ។ capital mobilier មូលធនសង្ហារិម (សង្ហារិមវត្ថុដែលទុកជាដើមទុន) ។ capital social ដើមទុនក្រុមហ៊ុន

capitale *n.f.* រាជធានី, រដ្ឋធានី (ឧ.ក្រុងភ្នំពេញ ជារាជធានីកម្ពុជរដ្ឋ); អក្សរធំ

capitalisable *a.* អាចដាក់ជាដើមទុនបាន (ឧ. intérêts capitalisables)

capitalisation *n.f.* ការដាក់ជាដើមទុន។ *Fig.* ការប្រមូល

capitaliser *v.t.* ដាក់ជាដើមទុន ។ *v.i.* ប្រមូលប្រាក់ទុក

capitalisme *n.m.* មូលធននិយម

capitaliste *n.&a.* មូលធនិក [មូ-លៈ-ធៈ-និក] (អ្នកមានមូលធនច្រើន) ។ អ្នកមូលធននិយម ។ régime capitaliste របបមូលធននិយម

capitation *n.f.* ពន្ធខ្លួន (ឧ.les prestations sont une forme de capitation)

capiteux,euse *a.* ដែលសាយដល់ក្បាល (ស្រា) (ឧ.vin capiteux)

capitole *n.m.* ឈ្មោះភ្នំមួយនៃក្រុងរ៉ូម។ *Par ext.* មហាគ្រឹះ ។ monter au capitole, être conduit au capitole មានជ័យជំនះ

capiton *n.m.* អាចម៍សូត្រ

capitonnage *n.m.* ការញាត់គរឬរោមសត្វ; របស់ញាត់គរ ឬរោមសត្វ

capitonner *v.t.* ញាត់គរ ឬ រោមសត្វ

capitulard *n.m.Fam.* កម្សាច

capitulation *n.f.* ការចុះចាញ់ (ឧ. la capitulation de l'Allemagne en 1945) ។ *Par ext.* ការសម្រុះសម្រួល ។ *Fig.* ពលិកម្ម

capituler *v.i.* ចុះចាញ់ ។ *Fig.* សម្រុះសម្រួល

capon,onne *a.&n.* កំសាកញី

caponner *v.i. Pop.* ធ្វើឫកកំសាកញី

caporal *n.m.* នាយទោ, កាប៉ូរ៉ាល់ ។ caporal-chef នាយឯក ។ petit caporal សម្ញានាមរបស់ណាប៉ូឡេអុងទី ១

capot *n.m.* អាវភ្លៀង;គម្របក្បាលរថយន្ត

capot *a. inv.* (ក្នុងល្បែងបៀ) ទីរ (ឧ. elle est restée capot)។ faire capot កាត់គ្រប់សន្ទឹកបៀ ។ *Fig.* ស្រមេះ (ឧ. rester capot devant une réprimande) ។ *n.m.* ការបន្ទីរ (ឧ. craindre le capot)

capotage *n.m.* ការដាក់គម្របក្បាលរថយន្ត; ការក្រឡាប់ (រថយន្ត)

capote *n.f.* អាវភ្លៀង; ប្លុកស្រី; គម្របក្បាលរថយន្ត

capoter *v.i. Autom.& Aviat.* ក្រឡាប់ផ្កាប់ផ្ងារ; ដាក់គម្របក្បាលរថយន្ត

capricant,e *a.* មិនស្មើ, លោតៗ (ឧ. allure capricante)

caprice *n.m.* កប៉ចិត្ត[ក:–ប៉ុ:–] (ចិត្តសាវ៉ា-រប៉ិលរប៉ូច); ការផ្លាស់ប្តូរ (ឧ. les caprices de la mode)

capricieusement *adv.* ដោយកប៉ចិត្ត

capricieux,euse *a.* ដែលមានកប៉ចិត្ត, សាវ៉ា, រប៉ិលរប៉ូច ។ *n.* មនុស្សសាវ៉ា ឬ រប៉ិលរប៉ូច

capricorne *n.m. Astron.* មករាសី (ពីថ្ងៃទី ២២ ធ្នូ ដល់ថ្ងៃទី២០ មករា)

caprin,e *a.* រជពសាទិស, នៃពពែ (ឧ. race caprine)

capsulage *n.m.* ការដាក់គម្របក្បាលដប (គម្របលោហធាតុ)

capsulaire *a.* ដែលបែកជារាងបំពង់ (ឧ. fruit capsulaire)

capsule *n.f.* គម្របក្បាលដប (ធ្វើពីលោហធាតុ); ឡុត (ប្រអប់តូច) ។ *Pop.* ប្លុករាងជាបំពង់ ។ *Anat.* អវយវៈដែលមានសណ្ឋានជាបំពង់ ។ *Bot.* សំបកស្ងួតមានគ្រាប់ (ឧ. le fruit du pavot est une capsule)

capsuler *v.t.* ដាក់ក្នុងឡុត; ដាក់គម្របក្បាលដប

capsulerie *n.f.* កន្លែងធ្វើឡុត ឬ ធ្វើគម្របក្បាលដប

captage *n.m.* ការបង្ហូរទឹកពីប្រភព (ឧ. le captage des eaux de la Vanne a donné à Paris des eaux très pures)

captateur,trice *n.* អ្នកល្បួង

captation *n.f.* ការល្បួង(ឧ. la captation, si elle est prouvée,

entraine la nullité du testament)

captatoire *a.* ដែលបប្រុងនឹងល្បួង(ឧ. manœuvre captatoires); សៅហ្មងដោយការល្បួង

capter *v.t.* ល្បួង (ឧ. capter la confiance de quelqu'un) ; បង្ហូរទឹកពីប្រភព។ *Radio* បើកស្តាប់, ចាប់សម្លេងផ្សាយ

captieusement *adv.* ដោយចង់បំភាន់ (ឧ. interroger captieusement un accusé)

captieux,euse *a.* ដែលចង់បំភាន់ (ឧ. argument captieux)

captif,ive *a.* &*n.* ដែលជាប់ឃុំ,ឈ្លើយ (ឧ. les Romains, au lendemain du triomphe massacraient leurs captifs) ។ ballon captif បាល់ហោះចងខ្សែ

captivant,e *a.* ដែលឲ្យចាប់ចិត្ត (ឧ. les romans de Dumas père sont en général captivants)

captiver *v.t.* ចាប់ជាឈ្លើយ, ចាប់ឃុំ; ធ្វើឲ្យចាប់ចិត្ត ។ captiver l'attention ទាញស្រូបសតិសម្បជញ្ញៈ,

captivité *n.f.* ភាពជាប់ឃុំ ឬ ជាប់ទ្រុង (ឧ. beaucoup d'oiseaux ne peuvent vivre en captivité) ។ *Fig.* ការនៅក្រោមអនុភាព, ភាពចង្អៀតចង្អល់

capture *n.f.* ការចាប់, ការចាប់ចង, ការទាក់; អ្វីៗដែលចាប់បាន

capturer *v.t.* ចាប់បាន

capuchon *n.m.* គម្របក្បាល; គ្រប;ឆ្នុក

capuchonner *v.t.* បិទគ្របបំពង់ភ្លើង

caque *n.f.* ធុងបញ្ជូនត្រីហារ៉ង់ (ឧ. se serrer comme des harengs en caque) ។ *Prov.* la caque sent toujours le hareng ពាងព្រហុកមិនចោលក្លិនព្រហុក (ជនមានដើមកំណើតថោកទាប ឬ ពាលមិនអាចបំបិទបំបាំងដើមកំណើតរបស់ខ្លួនបានឡើយ)

caquer *v.t.* ដាក់ត្រីហារ៉ង់ក្នុងធុង (ថា encaquer ក៏បាន)

caquet *n.m.* សំឡេងខ្ទត(មាន់ញី)។ *Fig.* ពាក្យប៉ប៉ាច់ប៉ប៉ោច ។ rabattre le caquet de quelqu'un បញ្ឈប់ឲ្យលែងនិយាយ ។ *pl.* សំដីចាក់ដោត

caquetage *n.m.* ការខ្ទត (មាន់ញី)

caqueter *v.i.* ខ្ទត (មាន់ញី) ។ *Fig.* និយាយប៉ប៉ាច់ប៉ប៉ោច

caqueteur,euse *a.&n.* អ្នកនិយាយប៉ឆ៉ាច់ប៉ឆ៉ោច

car *conj.* ព្រោះ,ដ្បិត (ឧ. travaillez, car le temps presse)។ *n.m. inv.* les car ពាក្យតឡស់, ពាក្យដោះសា (ឧ. avec ces gens retors, il y a toujours des si, des mais et des car)

car *n.m.* (ពាក្យបំព្រួញនៃ autocar) រថយន្តដឹកមនុស្ស

carabine *n.f.* កាំភ្លើងកាប៊ីន

carabiné,e *a. Fam.* ខ្លាំង,ហួសហេតុ (ឧ. recevoir une réprimande carabinée)

carabiner *n.m.* ទាហានកាន់កាប៊ីន

caracole *n.f.* កាពខ្វង់ (មានសណ្ឋានដូចពួចខ្យងខ្ចៅ) (ឧ. escalier en caracole); ការឲ្យសេះដើរជាវង់មូល

caracoler *v.i.* ឲ្យសេះដើរជាវង់មូល (ឧ.charles VIII aimait à voir Bayard caracoler); ដើរវេស; លោតកញ្ចែង

caractère *n.m.* អក្សរ(ឧ.caractères arabes, caractères d'imprimerie); ចរិត(ឧ.ce n'est pas notre situation, c'est notre caractère qui nous rend heureux ou malheureux); សេចក្តីអង់អាច (ឧ. montrer du caractère); សញ្ញា(ឧ. à la cour de Louis XIV, on voyait tous les caractères de la grandeur); លក្ខណៈ(ឧ. la raison est le caractère distinctif de l'homme)

caractériel,elle *a.* នៃចរិត (ឧ.anomalies caractérielles)

caractériser *v.t.* បង្អុលចរិតលក្ខណៈ (ឧ. caractériser un personnage, un siècle)

caractéristique *a.* ដែលមានចរិតលក្ខណៈ (ឧ. signe caractéristique)។ *n.f.* ចរិតលក្ខណៈ

caractérologie *n.f.* ចរិតវិទ្យា, វិជ្ជាសំគាល់ចរិត

carafe *n.f.* ថូ

carafon *n.m.* ថូតូច

carambole *n.f.* ផ្លែស្ពឺ

carambolier *n.m.* ដើមស្ពឺ

carambouillage *n.m.* ការលក់របស់ដែលខ្លួនបោកបានពីគេ

carambouilleur *n.m. Arg.* អ្នកលក់

របស់ដែលខ្លួនបោកបានពីគេ

caramel *n.m.* ស្ករតាំងម៉ែ (ឧ.le caramel possède une odeur aromatique et caractéristique)

caramélisation *n.f.* ការធ្វើស្ករតាំងម៉ែ

caraméliser *v.t.* ធ្វើស្ករតាំងម៉ែ; លាយស្ករតាំងម៉ែ

carapace *n.f.* ស្នូក(ក្ដាម ឬ អណ្ដើក)

carat [—ra] *n.m.* ការ៉ាត (ឈ្មោះដំឡឹងត្បូងមានទម្ងន់ ២០៥ មិល្លីក្រាម)។ du carat ពេជ្រដែលគេលក់តាមការ៉ាត។ *Fig.* sot à vingt quatre carats ភ្លើគ្មានលេខដាក់

caravane *n.f.* ពួកទូរបារ, ពួកទូរគម, សត្ថបារ (ពួកអ្នកធ្វើដំណើរទៅកាន់ទីឆ្ងាយដោយរួមគ្នា) (ឧ.le chameau est la bête de somme des caravanes); គេហបារ [—ហះ—] (ផ្ទះមានកង់ សម្រាប់ធ្វើដំណើរទៅសំដែងទស្សនីយភាពក្នុងទីផ្សេងៗ)

caravanier *n.m.* អ្នកបរសត្វ (ក្នុងពួកទូរបារ)

caravansérail *n.m.* ជម្រកនៃពួកទូរបារ; សាលាសំណាក់ ។ *Fig.* កន្លែងដែលជនបរទេសទៅកាន់ច្រើន

caravelle *n.f.* សំពៅម្យ៉ាង(ក្នុងសតវត្សទី ១៥ និង ១៦) (ឧ. c'est avec deux frêles caravelles que Colomb découvrit l'Amérique)

carbonado *n.m.* ពេជ្រខ្មៅប្រើធ្វើជាប្រដាប់ចោះ

carbone *n.m.* *Chim.* ការបោន ។ papier carbone ក្រដាសការបោន (សម្រាប់ផ្លាប់ចម្លង)

carboné,e *a.* ដែលមានការបោន

carboneux,euse *a.* ដែលមានការបោន; នៃការបោន

carbonifère *a.* ដែលមានធ្យូង (ឧ. terrain carbonifère)

carbonisation *n.f.* ការដុតឲ្យទៅជាធ្យូង (ឧ.la carbonisation des os fournit le noir animal)

carboniser *v.t.* ដុតឲ្យទៅជាធ្យូង ។ *Par anal.& fam.* កម្លោច

carbonnade *n.f.* សាច់អាំងដោយធ្យូង

carburant *a.&n.m.* ប្រេងឥន្ធនៈ

carburateur *n.m.* ការប៊ុយរ៉ាទ័រ

carburation *n.f.* ការបញ្ចូលការបោន (ឧ. la carburation du fer a pour objet de le transfor-

mer en acier); ការលាយប្រេង ឥន្ធនៈនឹងខ្យល់

carburer *v.t.* បញ្ចូលការបោន។ *Arg.* ដើរស្រួល

carcailler *v.i.* អ៊ុត (ក្រួច)

carcan *n.m.* ខ្នោះក។*Pop.* សេះមិនល្អ

carcasse *n.f.* គ្រោងឆ្អឹង (ឧ. la carcasse humaine s'appelle squelette) ។ *Fam.* សំបកខ្លួន, ឆ្អឹង (គ្រឿងទ្រ) (ឧ. promener sa carcasse)។ *Techn.* គ្រឿងទ្រ(ឧ. carcasse d'abat-jour); គ្រោង (ឧ. carcasse d'un navire)

carcimone *n.m.* ម.ព. cancer

cardage *n.m.* ការសិត (អំបោះ, សូត្រ)

cardamome *n.m.* ក្រវាញ

carde *n.f.* ប្រែង (ស្និតសិតអំបោះ ឬ សូត្រ); ដំពេច

carder *v.t.* សិត (អំបោះ, សូត្រ); ផ្ចិត

cardeur,euse *n.* អ្នកសិត ។ *n.f.* ម៉ាស៊ីនសិត(អំបោះ-សូត្រ)

cardia *n.m.* មាត់ក្រពះ

cardialgie *n.m.* ការឈឺបេះដូង ឬ មាត់ក្រពះ

cardiaque *a.* នៃហឫទ័យ, នៃបេះដូង; នៃថ្នាំបេះដូង ។ *n.* អ្នកឈឺបេះដូង

cardinal,e,aux *a.* សំខាន់ ។ points cardinaux ទិសធំ (កើត, ត្បូង, លិច, ជើង)។ nombre cardinal បកតិសំខ្យា

cardinal *n.m.* ការឌីណាល់ (សមណសក្តិក្នុងគ្រិស្តសាសនា); បក្សីម្យ៉ាង

cardinalat *n.m.* ឋានន្តរការឌីណាល់

cardiogramme *n.m.* ហទយលេខ

cardiographe *n.m.* ហទយបរិការ

cardiographie *n.f.* ហទយសាស្ត្រ

cardiologie *n.f.* ហទយវិទ្យា

cardite *n.f.* ហទយរោគ, រោគរលាកបេះដូង

carême *n.m.* ពេលតមសាច់(ក្នុងសាសនាកាតូលិក) ។ *Fig.* visage de carême មុខស្លេកស្លាំង ។ *Prov.* arriver comme marée en carême មកដល់ត្រូវពេល (ដូចបានត្រីក្នុងពេលតមសាច់) (ប្រហែលនឹងពាក្យខ្មែរថា គេអុសកានទៅកើឈើងាប់)

carême-prenant *n.m.* ថ្ងៃទាំងបីមុនពេលតមសាច់ (ក្នុងបីថ្ងៃនេះគេអនុញ្ញាតឲ្យបរិភោគសាច់តាមចិត្ត) ។ *Fig.* អ្នកក្លែងខ្លួន ឬ ស្លៀកពាក់យ៉ាងចម្លែក (*pl.* des carêmes - prenants)

carénage *n.m.* ការពេនាវាយាន(ឲ្យ

កេនល្បឿន); កន្លែងដូសផុលនាវា

carence *n.f.* ការខ្វះ, បលិពោធ [ប៉ៈ-លិ-ពោគ]

carène *n.f.* ភាគលិចទឹកនៃនាវា

caréner *v.t.* លាង ឬ ដូសផុលភាគលិចទឹកនៃនាវា; រចនាតួយាន(ឲ្យមានល្បឿន)

caressant,e *a.* ដែលបបោសអង្អែល; ត្រសៀក

caresse *n.f.* ការបបោសអង្អែល (ឧ. faire des caresses à un enfant) ។ *Poét.* ការបក់ត្រសៀក (ឧ.les caresses de la brise)

caresser *v.t.* បបោសអង្អែល

caret *n.m.* ក្រាស (អណ្ដើកសមុទ្រ)

caret *n.m.* រហាត់វេញខ្សែ ។ fil de caret សរសៃវេញពួរ

cargaison *n.f.* នាវាភណ្ឌ, បន្ទុកនាវា (ទំនិញ) (ឧ. le capitaine du navire est responsable de la cargaison)

cargo-boat ឬ **cargo** *n.m.* កប៉ាល់បន្ទុក ។ (*pl.* des cargo-boats, des cargos)

cargue *n.f.* ខ្សែលុត (ខ្សែរូតក្ដោង)

carguer *v.t.* រូតក្ដោង

cari,cary,carry ឬ **curry** *n.m.* ការី (គ្រឿងសម្ល)

cariatide *n.f.* សែរ៉ា (ទេវទេយ្យត្រីហាមានរាងសណ្ឋានស្ដ្រីជារូបគ្រុឌសម្រាប់ដាក់ទ្រទ្រង់ស្បូវ គ្រប់សសរប្រាសាទ, វិហារ ឬ សាលាជាដើម ប្រើជាគ្រឿងរចនាឲ្យលេចលំអ)

caricatural,e,aux *a.* នៃរូបកាក ឬ រូបតុក្ក(ឧ.portrait caricatural)

caricature *n.f.* រូបកាក,រូបតុក្ក (ឧ. la caricature exige une réelle science du dessin) ។ *Fig.& fam.* មនុស្សគួរឲ្យអស់សំណើច

caricaturer *v.t.* គូររូបកាក ឬ រូបតុក្ក

caricaturiste *n.m.* អ្នកគូររូបកាក ឬ រូបតុក្ក

carie *n.f.* ដម្បូធ្មេញ, ដង្កូវស៊ីធ្មេញ

carien,enne *a.&n.* នៃដម្បូឆ្អឹង ឬ ធ្មេញ

carier *v.t.* នាំឲ្យមានដម្បូធ្មេញឬឆ្អឹង (ឧ. une dent malade suffit pour carier toutes les autres) ។ se carier *v.pr.* មានដម្បូ (ដង្កូវស៊ីជាដើម) (ឧ. os qui se carie)

carillon *n.m.* ជួងទាំងឡាយនៃវត្តមួយសម្រាប់វាយព្រមគ្នា; នាឡិកាភ្លេង ។ *Par ext.* សូរគ្នាន់នៃជួង ។ *Fig.* សូរសន្ធឹកខ្លាំង (ឧ. faire du ca-

rillon)

carillonnement *n.m.* ការវាយជួង ច្រើនព្រមគ្នា

carillonner *v.i.* វាយជួងច្រើនព្រមគ្នា; វាយជួងរន្ទាន់ ។ *v.t.* វាយជួងជាបទ (ឧ. carillonner un air)

carillonneur *n.m.* អ្នកវាយជួង

carlin *n.m.* ឆ្កែម្យ៉ាងមាឌតូច

carlingue *n.f.* បន្ទប់អ្នកជិះ(ក្នុងអាកាសយាន)

carmin *n.m.* ពណ៌ល័ខ (ក្រហម) ។ *Fig.* des lèvres de carmin បបូរមាត់ក្រហមប៉ប្រែ

carminatif, ive *a.* ដែលធ្វើឲ្យបាត់ហើមពោះ ។ *n.m.* ថ្នាំហើមពោះ

carminé,e *a.* ដែលមានលាយល័ខ (ក្រហម)(ឧ. laque carminée)

carminer *v.t.* ជ្រលក់ក្រហម

carnage *n.m.* ការសម្លាប់រង្គាល; រំពា, សាច់ជាអាហារសត្វសាហាវ

carnaire *a.* បំសាហារ

carnassier,ère *a.* មំសភក្ស [ម៉ាំង-សៈ-ភាក់], ដែលចូលចិត្តសាច់ឆៅ ។ *n.m. pl.* មំសភក្សសត្វ, សត្វស៊ីសាច់ឆៅ (មានសិង្ហ, ខ្លា, ឆ្មា, ឆ្កែជាដើម) (ហៅ carnivores ក៏បាន)

carnassière *n.f.* ថង់ដាក់សត្វ(សម្រាប់អ្នកប្រមាញ់) (ហៅ carnier ក៏បាន)

carnation *n.f.* សម្បុរសាច់មនុស្ស

carnaval *n.m.* រដូវល្បែង (សម្រាប់សាសនាកាតូលិក); ល្បែង ។ *Par ext.* មនុស្សស្លៀកពាក់ចម្លែក (*pl.* des carnavals)

carne *n.f.* មុមជ្រុង (តុ, ថ្មី)

carne *n.f.* *Pop.* សាច់ធុនអន់

carné,e *a.* ពណ៌សាច់ (ឧ. œillet carné); ដែលមានសាច់ (ឧ. alimentation carnée)

carnet *n.m.* បុស្តិ៍ក [ប៉ុស-តាក់], កូនសៀវភៅកំណត់ ។ carnet à souche សៀវភៅបង្កាន់ដៃមានគល់ ។ carnet portatif de minutie បុស្តិ៍កហោប៉ៅវត្ថុស្ទួចស្ទើង ។ carnet de warant et de nantissement បុស្តិ៍កទែអធិបត្រនឹងសច្ចការ

carnier *n.m.* ម.ព. carnassière

carnivore *a.&n.* មំសាសី (ដែលមានសាច់ជាអាហារ)

carogne *n.f.* ម.ព. charogne

carotte *n.f.* ការ៉ុត (បន្លែម្យ៉ាង)។ tirer une carotte à quelqu'un បោកប្រាស់យករបស់អ្វីមួយ

carotter *v.t. Fam.* បោកប្រាស់

carotteur,euse *n. Fam.* អ្នកបោកប្រាស់(ហៅ carottier,ère ក៏បាន)

carpe *n.f.* ត្រីប៉្រាំងសន្ទានត្រីក្អែក ។ *Fig.* មនុស្សល្ងីល្ងើ ។ saut de carpe ការលោតត្រឡប់ខ្លួន ។ *loc. fam.* bailler comme une carpe ស្ងាបព្រហមាត់ ។ s'ennuyer comme une carpe អផ្សុកខ្លាំង ។ être muet comme une carpe ស្ងាត់មាត់ដូចត្រីកន្ទប់ (មិនហើបមាត់និយាយ) ។ faire la carpe pamée ពុតធ្វើដាឈឺ ។

carpe *n.m.* ឆ្អឹងកដៃ

carpette *n.f.* ព្រំ (កម្រាលម៉្យាង)

carpien,enne *a.* នៃឆ្អឹងកដៃ

carpologie *n.f. Bot.* ផលវិទ្យា (វិជ្ជាខាងផ្លែឈើ)

carquois *n.m.* បំពង់ព្រួញ ។ *loc.* avoir vidé son carquois ទាល់សំដីអាក្រក់ (រកសំដីអាក្រក់មកនិយាយទៀតមិនបាន)

carré,e *a.* ការ៉េ,ដែលមានបួនជ្រុងស្មើ។ mètre carré ម៉ែត្រការ៉េ ។ *Fig.* épaules carrées ស្មាគាង ។ *Fig.* ត្រង់ ។ racine carrée (ម.ព. racine)

carré *n.m.* ចតុរង្សមុមស្មើ (ផ្ទៃបួនជ្រុងស្មើ) ។ carré d'un nombre ការ៉េនៃចំនួនមួយ (ឧ. ២៥ ជាការ៉េនៃ ៥) ។ ថ្នាក់ជណ្តើរ (ឧ. deux locataires habitant sur le même carré) ។ បន្ទប់បាយ; រងដំណាំ; ទំព័រក្រឡាចតុរង្ស

carreau *n.m.* ចតុរង្សស្មើតូច; ឥដ្ឋក្រាល; កញ្ចក់បង្អួច; ខ្នើយបួនជ្រុង; ការ៉ូ (បៀរូបបួនជ្រុងស្មើពណ៌ក្រហម); ដែកអង្រួសធំបួនជ្រុង ។ demeurer, rester sur le carreau ស្លាប់នៅកន្លែង ។ carreau de mine កន្លែងដាក់រ៉ែដែលទើបយកចេញពីអណ្តូង ។ *Fam.* se garder à carreau ប្រយ័ត្នមិនឲ្យមានគ្រោះថ្នាក់ ។ *Pl.* ផ្គរ(ឧ. les carreaux de Jupiter)

carrée *n.f.* ដំបូលគ្រែ។*Arg.* បន្ទប់; ផ្ទះ

carrefour *n.m.* ផ្លូវត្រឡែងកែង ។ manières, langage de carrefour ឫក, ភាសាជាតផ្សារ

carrelage *n.m.* ការក្រាលឥដ្ឋ;កម្រាលឥដ្ឋ

carreler *v.t.* ក្រាលឥដ្ឋ;ដេរសង្គុលស្បែក

ជើងចាស់

carrelet *n.m.* ម្ជុលដេររូក; បន្ទាត់ (ដែលសិស្សប្រើក្នុងសាលា); ល្អក់ (នេសាទុបករណ៍មួយយ៉ាងមានសណ្ឋានដូចថ្នង មានចំពាស់៤មានដង១)

carreleur *n.m.* ជាងក្រាលឥដ្ឋ; អ្នកដើរជួសជុលស្បែកជើង

carrelure *n.f.* ការផ្លាស់បាតស្បែកជើង

carrément *adv.* ជាបួនជ្រុងស្មើ, ជាមុមកែង (ឧ. disposer carrément deux madriers)។ *Fig.* ដោយត្រង់(ឧ. répondez carrément)

carrer *v.t.* ធ្វើឲ្យទៅជាបួនជ្រុងស្មើ (ឧ. carrer une pierre); គុណនឹងខ្លួនឯង (ឧ. carrer un nombre)។ se carrer *v.pr.* ឈរតម្រៀបជាក្រឡូចតុរង្ស:ប្រកាន់ឥរិយាបថយ៉ាងខែង (ឧ. se carrer dans un fauteuil); ធ្វើឫកខែង

carrier *n.m.* អ្នកយកថ្ម

carrière *n.f.* ភិលវង់; ការប្រណាំង ។ *Fig.* ជីវភាព (ឧ. bien remplir sa carrière); អាជីព, របរ (ឧ. embrasser la carrière des armes ធ្វើទាហាន)។ *Abs.* អាជីពក្នុងអង្គទូត។ carrière administrative អាជីពក្នុងរាជការ។ entrer dans la carrière ចាប់ធ្វើការពិបាក ។ donner carrière បណ្ដោយតាមចិត្ត

carrière *n.f.* កន្លែងយកថ្ម

carriole *n.f.* រទេះតូច ។ *Par dénigr.* រទេះគម្រក់

carrossable *a.* ដែលរថយន្តបើកបាន(ផ្លូវ)

carrossage *n.m.* ការដឹកនាំដោយរទេះ

carrosse *n.m.* ព្រះរាជរថ,រទេះមុនជា (រទេះរាងជាព្រែមានដំបូលមានកង់បួន)។ rouler carrosse មានទ្រព្យច្រើន

carrossée *n.f.* បន្ទុករទេះ (ចំនួនមនុស្សដែលជិះរទេះ)

carrosser *v.t.* ដឹកនាំដោយរទេះ; ដាក់តួ (រថ)

carrosserie *n.f.* រថវិជ្ជា (វិជ្ជាធ្វើរថ); រថពាណិជ្ជ(ជំនួញរថ); រថបញ្ជរ (តួរថ)

carrossier *n.m.* រថការី (អ្នកធ្វើរថ)

carrure *n.f.* កម្រាស់ខ្នង; មាឌមាំ (ឧ. les mariniers sont en général d'une belle carrure)

carry *n.m.* ប.ព. cari

cartable *n.m.* កស្ត្រា, ការពាប,សំពៀតដាក់សៀវភៅ; ក្រដាសផ្តិត

carte *n.f.* ផែនទី(ភូមិសាស្ត្រ)។ carte

physique ផែនទីរូបនិយម ។ carte politique ផែនទីប្រតិភាគណាន់ [-ប្រតិ-គន់] ។ carte économique ផែនទីសេដ្ឋកិច្ច ។ carte routière ផែនទីគមនាគមន៍ ។ បញ្ជីភោជនីយប្បូ (ភោជនាគារ) ។ ប័ណ្ណ ។ carte d'alimentation ភោជនីយប័ណ្ណ ។ carte de circulation ប័ណ្ណចរាចរណ៍ ។ carte diplomatique ទូតប័ណ្ណ ។ carte grise ប័ណ្ណប្រផេះ (ប័ណ្ណកម្មសិទ្ធិនៃយានដើរដោយម៉ាស៊ីន) ។ carte rose ប័ណ្ណកុលាប (ប័ណ្ណបើករថយន្ត) ។ carte d'identité អត្តសញ្ញាណ-ប័ណ្ណ ឬ ប័ណ្ណសំគាល់ខ្លួន ។ carte postale ប័ណ្ណប្រៃសណីយ ។ carte de rationnement បរិភោគប័ណ្ណ [បរិភោគៈ—] ។ carte de service ប័ណ្ណបុគ្គការ ។ carte de visite នាមប័ណ្ណ [នា·មៈ—] ។ បៀ ។ tirer les cartes ប្ញូលបៀ (ទាយដោយសន្លឹកបៀ) ។ *Fig.* le dessous des cartes រឿងលាក់បំបាំង ។ donner carte blanche ឲ្យអំណាចធ្វើតាមចិត្ត ។ perdre la carte ឡប់ ។ jouer cartes sur table លេងចេញមុខ (គ្មានលាក់លៀមអ្វី) ។ jouer sa dernière carte ល្បងលើកក្រោយបំផុត

cartel *n.m.* ការបបួលប្រយុទ្ធតទល់; អនុសញ្ញាបណ្ដោះអាសន្ន ។ *Econ. pol.* ការតែល (ការព្រមព្រៀងរវាងផលិតករក្នុងមុខរបរជាមួយគ្នា ដើម្បីចៀសវាងការលក់ប្រជែងគ្នា ហើយកម្រិតតម្លៃទំនិញឲ្យនៅខ្ពស់)

cartel *n.m.* ក្បាច់សំអនាឡិកា; នាឡិកាសំអដោយក្បាច់

carte-lettre *n.f.* ប័ណ្ណលិខិត (ប័ណ្ណប្រៃសណីយបិទជិតហើយមានតាំងតម្លៃនិងសំបុត្រ)(*pl.* des cartes-lettres)

carter *n.m.* ស្រោប (គ្រឿងយន្ត)

carterie *n.f.* ឧស្សាហកម្មបៀ

cartésianisme *n.m.* លទ្ធិទស្សនវិជ្ជារបស់ដេការត៍ (Descartes)

cartésien,enne *a.* នៃលទ្ធិទស្សន-វិជ្ជារបស់ដេការត៍ (ឧ. la philosophie cartésienne)

cartier *n.m.* អ្នកធ្វើបៀ

cartilage *n.m.* ឆ្អឹងខ្ចី (ឧ. les cartilages constituent entièrement le squelette des vertébrés inférieurs)

cartilagineux,euse *a.* នៃឆ្អឹងខ្ចី (ឧ.

tissu cartilagineux)

cartographe *n.m.* អ្នកគូរផែនទី

cartographie *n.f.* សិល្បៈខាងគូរផែនទី (ឧ. Mercator a créé la cartographie scientifique moderne)

cartographique *a.* នៃសិល្បៈខាងគូរផែនទី (ឧ. la science cartographique)

cartomancie *n.f.* ហួនបូលបៀ (ហួនទាយដោយសន្លឹកបៀ) (ឧ. la cartomancie fait encore de trop nombreuses victimes)

cartomancien,enne *n.* គ្រូបូលបៀ

carton *n.m.* ការតុង, ក្រដាសរឹង (ឧ. le carton durci remplace le bois ou même le fer pour certains usages); ប្រអប់ធ្វើដោយក្រដាសរឹង (ឧ. carton à chapeau); តំនូរព្រាង; ផែនទីតូច

cartonnage *n.m.* ការធ្វើរបស់ដោយក្រដាសរឹង; របស់ធ្វើដោយក្រដាសរឹង; ក្របសៀវភៅធ្វើដោយក្រដាសរឹង

cartonner *v.t.* ពាសការតុង, ពាសក្រដាសរឹង; ចងសៀវភៅដោយក្រដាសរឹង ។ *v.i. Fam.* លេងបៀ

cartonnerie *n.f.* ការធ្វើរបស់ដោយក្រដាសរឹង; រោងធ្វើក្រដាសរឹង

cartonneur,euse *n.* ជាងចងសៀវភៅដោយក្រដាសរឹង

cartonneux,euse *a.* ដូចក្រដាសរឹង

cartonnier,ère *n.* អ្នកធ្វើឬលក់ក្រដាសរឹង; អ្នកធ្វើ ឬលក់របស់ធ្វើដោយក្រដាសរឹង ។ *n.m.* ទូខណ្ឌដោយក្រដាសរឹង

carton-paille *n.m.* ក្រដាសរឹងធ្វើដោយចំបើង

carton-pierre *n.m.* ក្រដាសថ្ម (ក្រដាសរឹងសម្រាប់ធ្វើជាគ្រឿងលំអលើគ្រឿងឈើជាដើម)

cartouche *n f.* គ្រាប់កាំភ្លើង; ផោក (ហោជារី); ក្រឡាន

cartoucherie *n.f.* កន្លែងធ្វើគ្រាប់កាំភ្លើង

cartouchière *n.f.* ការទូស្បៀរ, ថ្លោក គ្រាប់កាំភ្លើង

caryatide *n.f.* ម.ព. cariatide

cas *n.m.* ករណី [ក:-រ:-ណី] (ឧ. agir selon le cas; cas imprévu; cas particulier) ។ *Par ext.* ហេតុ; រឿង (ឧ. un cas est arrivé; ce n'est pas grand cas) ។ faire cas, faire grand cas de quelqu'un

ឬ de quelque chose គប់អាន, ចូលចិត្ត, យកជាការសំខាន់(ឧ. nous faisons cas du beau)។ ឧកាស។ être ឬ n'être pas dans le cas de faire quelque chose ត្រូវធ្វើឬមិនត្រូវធ្វើអ្វីមួយ។ *Dr.* cas fortuit ឬ cas de force majeure ករណីប្រធានសក្តិ។ dans le cas où ប្រសិនបើ ។ en ce cas *loc.adv.* បើដូចនេះ ។ en tout cas ឬ dans tous les cas *loc.adv.* ទោះយ៉ាងណាក៏ដោយ។ en cas de, en cas que ឬ au cas que *loc. pré.* ក្នុងករណី ។ en-cas *n.m.* ប.ព. en-cas

casanier,ère *n.* អ្នកចូលចិត្តនៅផ្ទះ(មិនសូវចេញដើរ) ។ *a.* ដែលមិនសូវចេញពីផ្ទះ(ឧ.habitudes casanières)

casaque *n.f.* អាវក្រៅម្យ៉ាង ។ *Fig.* tourner casaque ផ្លាស់បក្ស, ផ្លាស់មតិ

cascade *n.f.* ទឹកឈ្លូ, ទឹកធ្លាក់។ *Fig.* ការធ្លាក់តាមថ្នាក់; ចរិយាពាយងាយ ។ en cascade ហូរហែ

cascader *v.i.* ធ្លាក់(ពីថ្នាក់លើមកថ្នាក់ក្រោម)។ *Pop.&fig.* មានចរិយាពាយងាយ

cascadeur,euse *n.Fam.* ពាយងាយ

cascatelle *n.f.* ទឹកឈ្លូតូច

case *n.f.* ខ្ទម (ឧ. une case de bambou); ខណ្ឌ (នៃហិប, ប្រអប់ ។ល។) ។ *Fig.* ក្រឡាចត្រង្គ - រែក ។ល។; ក្រឡាបន្ទាត់

caséeux,euse *a.* នៃខីរជាតិ,ដូចខីរជាតិ (ឧ. la partie caséeuse du lait)

caséification ឬ **caséation** *n.f.* ខីរកម្ម (ការបង្កើតខីរជាតិក្នុងទឹកដោះ)

caséifier *v.i.* ធ្វើខីរកម្ម (បង្កើតខីរជាតិក្នុងទឹកដោះ)

caséine *n.f.* ខីរជាតិ

caséinerie *n.f.* កន្លែងធ្វើខីរជាតិ

casemate *n.f.* រូងនៃបន្ទាយ ។ *Par ext.* អ្វីៗសម្រាប់ការពារ

casemater *v.t.* ដាក់រូងក្នុងបន្ទាយ

caser *v.t.* រៀបចំ (ឧ. caser des marchandises) ។ *Fig.* រកការឱ្យធ្វើ (ឧ. on ne peut pas réussir à le caser)

caserne *n.f.* បន្ទាយទាហាន; ទាហានក្នុងបន្ទាយ ។ *Fig.* ផ្ទះល្អស្មោះ

casernement *n.m.* ការតាំងជាបន្ទាយទាហាន; ការនៅក្នុងបន្ទាយទាហាន;

អគារទាំងឡាយក្នុងបន្ទាយទាហាន

caserner *v.t.* តាំងជាបន្ទាយទាហាន ។ *v.i.* នៅក្នុងបន្ទាយទាហាន

cash *adv.* ដល់ដៃ (មិនបណ្តាក់) (ឧ. un paiement cash)

casher *a.* ម.ព. cawcher

casier *n.m.* ទូមានខណ្ឌ(ដូចជាទូបណ្ណាល័យជាដើម(ឧ.les casiers d'une bibliothèque); និល័យ; ឋត ។ casier judiciaire បញ្ជីហ្គោលទោស (ឧ. avoir un casier judiciaire vierge)។ ខ្នង់ ។ casier de colmatage ខ្នង់ចម្រើនល្បប់ ។ casier d'irrigation ខ្នង់បញ្ចូលទឹក ។ casier de protection ខ្នង់គាំពារ។ *Pêch.* ទ្រូជាក់បង្គង

casino *n.m.* គ្រឹះស្ថានល្បែង

casoar *n.m.* កាសូអារ (បក្សីម្យ៉ាងនៅអូស្ត្រាលី ជាសត្វរត់លឿន)

casque *n.m.* គ្រោះការពារក្បាល; មួករឹង; ប្រដាប់ស្តាប់ (សម្រាប់ពាក់នឹងក្បាល)

casqué,e *a.* ដែលមានគ្រឿងការពារក្បាល

casquette *n.f.* កាស្កែត (មួកមានក្បាំងមុខ)

casquettier,ère *n.* អ្នកធ្វើ ឬ លក់កាស្កែត

cassable *a.* អាចកាច់ ឬ បំបែកបាន

cassage *n.m.* ការកាច់ ឬ បំបែក(ឧ. le cassage des minerais s'opère mécaniquement)

cassant,e *a.* ស្រួយ,ឆាប់បាក់ ។ *Fig.* ton cassant សំដីម៉ាត់ៗ

cassation *n.f.* បដិសេធន៍ ។ cour de cassation សាលាវិនិច្ឆ័យ ។ *Mil.* ការបកស័ក្តិ (ទណ្ឌកម្មសឹក)

cassave *n.f.* ម្សៅក្តួច

casse *n.f.* ការបាក់ ឬ បែក; របស់បាក់ ឬ បែក (ឧ.payer la casse); របួស

casse *n.f.* ផ្លែឈើម្យ៉ាង ។ *Prov.* passez-moi la casse, je vous passerai le séné ត្រូវយើងបន្ទូរបន្ថយគ្នាទៅវិញទៅមក

casse *n.f.* ប្រអប់មានខណ្ឌសម្រាប់ដាក់អក្សរពុម្ព; ផ្ទាំងខ្នះស្តាន់

cassé,e *a.* ចាស់; ពិការ (ឧ. vieillard tout cassé); ញ័រ(ឧ.voix cassée)

casse-cou *n.m.inv.* កន្លែងងាយនឹងធ្លាក់; មនុស្សធ្វេសប្រហែស

casse-croûte *n.m.inv.* ការស្រស់ស្រូប

cassement *n.m.* ការបាក់ ឬ បែក ។ cassement de tête ដំណើរឈឺក្បាល(ដោយធ្វើការច្រើនឬឮសូរខ្លាំង)។

ដំណើរអស់កម្លាំង

casse-noix *n.m.inv.* ប្រណាក

casse-pieds *n.m.inv.Fam.* អ្នករំខាន

casse-pierres *n.m.inv.* ញញួរវាយថ្ម

casse-pipes *n.m.inv.* ការហោតបាញ់ ។ *Pop.* ចម្បាំង (ឧ. aller au casse-pipes)

casser *v.t.* កាច់,បំបាក់,បំបែក ។ *Fig.* ធ្វើឲ្យវង្វេងវង្វាង (ឧ. ce vin casse la tête); បដិសេធ (ឧ. la cour d'appel casse les jugements de première instance) ។ casser un officier បកសក្តិនាយទាហាន ។ casser les vitres ធ្វើឲ្យអស់ដៃ (ធ្វើឥតសំចៃ) ។ casser bras et jambes កាត់ដៃកាត់ជើង (មិនឲ្យមានកម្លាំង, មិនឲ្យមានមធ្យោបាយធ្វើអ្វី) ។ se casser *v.pr.* បាក់,បែក ។ *Fam.* se casser la tête ប្រឹងគិតខ្លាំងពេក (ស្ទើរបែកក្បាល) ។ se casser le nez មិនបានសម្រេច ។ *Pop.* ne rien casser មិនសំខាន់ ។ à tout casser គ្មានសំចៃ ។ *Prov.* qui casse les verres les paie អ្នកណាធ្វើឲ្យខូចអ្នកនោះត្រូវសង

casserole *n.f.* ឆ្នាំងដែកមានដៃ។*Arg.* អ្នកចាក់រុក

casserolée *n.f.* បំណុះឆ្នាំងដែក

casse-sucre *n.m. inv.* ប្រដាប់កាត់ស្ករជាដុំៗ

casse-tête *n.m.* មោង (ដំបងមានគល់ទ្រមឹង) (ឧ. la casse-tête fut sans doute la première arme de l'homme)។*Fig.* ការងារឲ្យគិតច្រើន (ឧ. l'algèbre apparait aux débutants comme un vrai casse-tête); សូរសន្ធឹកដែលនាំឲ្យអស់កម្លាំង

cassette *n.f.* ហិបប្រាក់; ព្រះកងទ្រព្យ (ឧ.Louis XIV pensionna les écrivains sur sa cassette particulière)

casseur,euse *n.* អ្នកបំបែក ។ casseur de pierres អ្នកវាយថ្ម ។ *a.* ហែឲ្យបែក

cassis *n.m.* ល្បាក់ ឬ រលាក់ (ទីដែលបាក់ស្រុតខ្ពស់ទាបត្រង់ទ្រូងថ្នល់)

cassure *n.f.* មុខបែកឬបាក់(ឧ.examiner la cassure d'un minéral)

castagnettes *n.f.pl.* ក្រាប់(សម្រាប់

បន្ទរចង្វាក់ភ្លេង) (ឧ. les danses espagnoles se jouent avec accompagnement de castagnettes)

caste *n.f.* វណ្ណៈ (ថ្នាក់ពូជអម្បូរមនុស្ស ក្នុងសម័យបុរាណ) (ឧ. caste des brahmanes វណ្ណៈព្រាហ្មណ៍)

castel *n.m.* ប្រាសាទ

castillan,e *a.* នៃក្រុងកាស្ទីយ ។ *n.* ជនក្រុងកាស្ទីយ

castor *n.m.* កាស្ទ័រ(សត្វចតុប្បាទម្យ៉ាង)

castrat *n.m.* មនុស្សកម្រៀវ

castration *n.f.* ការក្រៀវ

castrer *v.t.* ក្រៀវ

casualité *n.f.* ភាពមានដោយដួន

casuel,elle *a.* ដែលមានដោយដួន ។ *n.m.* ប្រាក់ដែលរកបានក្រៅអំពីបៀវត្ស

casus belli (cas de guerre) *loc. lat.* យុទ្ធហេតុ (ឧ. une insulte faite à un ambassadeur peut être un casus belli)

cataclysme *n.m.* ដំណើរប្រែឡប់ផែនដី; មហាវិនាស

catacombes *n.f. pl.* ឧមង្គសព

catafalque *n.m.* គ្រឿងលំអដាក់លើមឈូស

catalogue *n.m.* នាមវលី,វគ្គវលី (បញ្ជីរាយឈ្មោះរបស់) (ឧ. catalogue de plantes, de livres)

cataloguer *v.t.* ចុះក្នុងនាមវលីឬវគ្គវលី (ចុះឈ្មោះរៀងក្នុងបញ្ជី)

cataplasme *n.m.* ថ្នាំបិទពោក

catapulte *n.f.* ដង្ហក់ (ឧ. la catapulte était en usage chez les Romains)

catapulter *v.t.* ចោលដង្ហក់

cataracte *n.f.* ទឹកធ្លាក់ (ឧ. la cataracte du Niagara) ។ *Pathol.* ណាយភ្នែក (ឧ. la cataracte se guérit par l'ablation du cristallin)

catastrophe *n.f.* មហន្តរាយ, សេចក្ដីវិនាសធំ

catastrophé,e *a. Fam.* ធ្លល់ខ្លាំង (ឧ. avoir un air catastrophé)

catastrophique *a.* ដែលជាមហន្តរាយ

catch *n.m.* ចម្បាប់អង់គ្លេស

catcheur,euse *n.* អ្នកចម្បាប់អង់គ្លេស

catéchisation *n.f.* ការបង្រៀនគោលសំខាន់នៃគ្រិស្តសាសនា

catéchiser *v.t.* បង្រៀនគោលសំខាន់នៃគ្រិស្តសាសនា។ *Fig.* បញ្ចុះបញ្ចូល

catéchisme *n.m.* សាសនសន្ទនា (ការ ឬ សៀវភៅសន្ទនាពីសាសនា)

catéchiste *n.* អ្នកបង្រៀនសាសនា

catégorie *n.f.* ប្រភេទ ។ *Fig.* ថ្នាក់

catégorique *a.* ដាច់ខាត, ប្រាកដប្រជា (ឧ. mise en demeure catégorique)

catégoriquement *adv.* ដោយដាច់ខាត, ជាដាច់អហង្ការ (ឧ. répondre catégoriquement)

catgut *n.m.* ក័តគុត (របស់ប្រើក្នុងសល្យពេទ្យធ្វើអំពីពោះវៀនពពែ ឬ ឆ្មា)

cathédrale *n.f.* វិសាលវិហារ (ឈ្មោះវិហារខាងគ្រិស្តសាសនា)

cathode *n.f.* និទ្វារ

cathodique *a.* នៃនិទ្វារ ។ rayons cathodiques កម្មនិទ្វារ

catholicisme *n.m.* កាតូលិកសាសនា

catholicité *n.f.* ពាក្យប្រៀននៃកាតូលិកសាសនា; កាតូលិកមាបិកជនទាំងឡាយ (ឧ. le pape est le chef de la catholicité)

catholique *a.* នៃកាតូលិកសាសនា ។ Sa Majesté Catholique មហាក្សត្រប្រទេសអេស្ប៉ាញ ។ *n.* កាតូលិកសាសនិក (អ្នកកាន់កាតូលិកសាសនា)

catimini (en) *loc. adv. Fam.* ដោយលួចលាក់

catogan *n.m.* ម.ព. cadogan

caucasien, enne *a.&n.* ឬ **caucasique** *a.* នៃប្រទេសកូកាស

cauchemar *n.m.* ទុស្សុបិន, សប្តិអាក្រក់ (ឧ. avoir le cauchemar) ។ *Fig.&Fam.* អ្នកធ្វើឲ្យគេធុញទ្រាន់ (ឧ. cet homme est mon cauchemar)

caudal,e,aux *a.* នៃកន្ទុយ (ឧ. nageoire caudale)

caudataire *n.m.* អ្នកកាន់ជាយអាវ ។ *Fig.* អ្នកបញ្ចើចបញ្ចើ

caudillo *n.m.* ប្រមុខទ័ព (នៅប្រទេសអេស្ប៉ាញ) (ឧ. le caudillo Franco)

caulescent,e *a.* ដែលមានដើម (ឧ. plante caulescente)

causal,e *a.* សហេតុ, ដែលប្រាប់ការទាក់ទងហេតុនិងផល

causalité *n.f.* សហេតុធម៌, ការទាក់ទងហេតុនិងផល

causalisme *n.m.* សហេតុនិយម

causant,e *a.* ដែលចូលចិត្តនិយាយ

causatif,ive *a.Gram.* ការិត, ហេតុកត្តុ

cause *n.f.* ហេតុ, មូលហេតុ, បុព្វហេតុ (ឧ. agir sans cause); រឿងក្ដី (ឧ.les causes célèbres passionnent l'opinion publique) ។ cause première មូលហេតុដំបូង ។ causes secondes មូលហេតុបន្ទាប់ ។ cause finale មូលហេតុសម្រេច (មូលហេតុដែលនាំឲ្យធ្វើរបស់អ្វីមួយ) ។ défendre la cause de la paix ការពារមូលហេតុសន្តិភាព។ à cause de *loc. pré.* ព្រោះតែ, ដោយហេតុតែ ។ *Prov.* il n'y a pas d'effet sans cause មានប្រឡាយទឹកទើបហូរ; ទំពក់ភាទៅទើបភ្លៀភមក (ទាល់តែមានហេតុទើបមានផល)

causer *v.t.* បង្កហេតុ, បណ្ដាល, ញុំាង

causer *v.i.* សន្ទនា (ត្រូវថា causer avec quelqu'un ពុំថា causer à quelqu'un); និយាយច្រើន (ឧ. il ne fait que causer)

causerie *n.f.* ជំពូកថា, សន្ទនា ឬ សំសន្ទនា (ឧ. le ton de la causerie n'est pas celui de la conférence)

causette *n.f. Fam.* សន្ទនាបន្តិចបន្តួច (ឧ. faire la causette)

causeur *a.&n.* ដែលចូលចិត្តសន្ទនា

causeuse *n.f.* កៅអីអង្គុយពីរនាក់ (សម្រាប់សន្ទនាគ្នា)

causticité *n.f.* លក្ខណៈនៃវត្ថុដែលកាត់ (ដូចជាអាស៊ីដ) ។ *Fig.* ការចូលចិត្តនិយាយរិះគន់

caustique *a.&n.m.* ដែលកាត់ (ដូចជាអាស៊ីដ) (ឧ. remède caustique) ។ *Fig.* ដែលរិះគន់

cautèle *n.f.* ការប្រយ័ត្នជាកលល្បិច

cauteleusement *adv.* ដោយប្រយ័ត្នជាកលល្បិច

cauteleux,euse *a.* ល្បាស, ប្រកបដោយកលល្បិច (ឧ. esprit cauteleux)

cautère *n.m.* ប្រដាប់រោល; ដំបៅរោល ។ *Prov.* c'est un cautère sur une jambe de bois ដូចដាក់ទឹកលើក្បាលទា (គឺថ្នាំឬមធ្យោបាយដែលប្រើឥតបានផលសោះ)

cautérisation *n.f.* ការរោល (ដាក់ដែកក្ដៅប្រឡៀលស្រាលៗពីលើ); ការបង្កាត់ដោយថ្នាំ

cautériser *v.t.* រោល (ដាក់ដែកក្ដៅប្រឡៀលស្រាលៗពីលើ); បង្កាត់ដោយថ្នាំ

caution *n.f.* ការធានា; អ្នកធានា; សំអាង ។ caution-consignation ប្រាក់ធានាទុក ។ caution personnelle អ្នកធានាអាងខ្លួន។ caution réelle អ្នកធានាអាងទ្រព្យ ។ *Fig.* sujet, sujette à caution ដែលមិនអាចទុកចិត្តលើបាន

cautionnement *n.m.* កិច្ចធានា; ប្រាក់ធានា

cautionner *v.t.* ធានាឲ្យគេ

cavalcade *n.f.* ពិធីជិះសេះ; ទ័ពសេះ

cavalcader *v.i.* ធ្វើពិធីជិះសេះ

cavalcadour *a.m.* នៃអស្សបតិ ។ *n.m.* អស្សបតី (អ្នកត្រួតត្រាខាងការរក្សាសេះនៃព្រះរាជាដើម)

cavale *n.f.* *Poét.* សេះញី

cavaler *v.i.* *Pop.* រត់ ។ *v.t.* រំខាន។ se cavaler *v.pr.* រត់ (គេចខ្លួន)

cavalerie *n.f.* ក្រុមទាហានពាជី, អស្សានីក, ទ័ពសេះ

cavalier *n.m.* អស្សសាទិន, អ្នកជិះសេះ; ទាហានទ័ពសេះ; អ្នករាំ (ប្រុស)។ *Echec* សេះ (កូនចត្រង្គ)

cavalier,ère *a.* ក្រអឺត (ឧ. air cavalier); ព្រឡោះបោះ (ឧ. réponse cavalière) ; សម្រាប់ជិះសេះ (ឧ. piste cavalière)

cavalière *n.f.* អស្សសាទិនី, ស្រីអ្នកជិះសេះ (ច្រើនហៅថា amazone ផង); អ្នករាំ (ស្រី)

cavalièrement *adv.* យ៉ាងក្រអឺត, យ៉ាងព្រឡោះបោះ (ឧ. répondre cavalièrement à une observation)

cave *a.* ផត, ខួង (ឧ. joues caves)។ veines caves ធមនីហទយក័ណ្ណ។ veine cave supérieure ធមនីហទយក័ណ្ណលើ ។ veine cave inférieure ធមនីហទយក័ណ្ណក្រោម

cave *n.f.* ភូមិគ្រឹះ (បន្ទប់នៅក្នុងដីសម្រាប់ទុកវត្ថុផ្សេងៗ) (ឧ. la température d'une bonne cave doit rester la même toute l'année); ស្រាក្នុងភូមិគ្រឹះ (ឧ. boire toute sa cave); ប្រយោគតំណាំង (ក្នុងល្បែង)

caveau *n.m.* ភូមិគ្រឹះតូច; ឧបុង្គ

cave ne cada (prends garde de tomber) *loc. lat.* ប្រយ័ត្នធ្លាក់

caver *v.t.* ជីករូង, បង្ហូង (ឧ. l'eau cave lentement la pierre)

caver *v.t.* ដាក់ប្រយោគតំណាំង ។ se caver *v. pr.* ដាក់ (ភ្នាល់)

caverne *n.f.* រូងភ្នំ, គុហា, ជម្រកមនុស្សទុច្ចរិត

caverneux,euse *a.* ដែរដាសដោយរូង (ឧ. montagnes caverneuses) ។ *Fig.* ខ្សោយ (សម្លេង) (ឧ. voix caverneuse)

cavernicole *a.*&*n.* ដែលចូលចិត្តនៅក្នុងរូង (សត្វ)

cavet *n.m.* ក្បាច់ល្អក

cavité *n.f.* ដិទ្ធរ្ហាន, ក្រហូង, ក្រហែង (ឧ. les cavités de la terre, du cœur)

cawcher,ère *a.* ដែលគេបានឲ្យពរមុនសម្លាប់(សាច់សត្វ)(សរសេរជាcachère, casher ឬ kasher ក៏បាន)

ce *pr. dém. m. sing.* របស់ដែល, អ្វីដែល, គឺជា

ce, cet. *a. dém. m.sing.* ; **cette***f. sing.* ; **ces** *pl.* នេះ

céans *adv.* ទីនេះ (ឧ. sortez de céans)

ceci *pr. dém.* របស់នេះ(ម.ព. cela)

cécité *n.f.* អន្ធការ, ភាពខ្វាក់

cédant,e *n.* អនុប្បទាយី(អ្នកបង្ហានសិទ្ធិរបស់ខ្លួនឲ្យទៅអ្នកដទៃដោយកិច្ចសន្យាអនុប្បទានតំណទេយ្យ)

cédé,e *n.* អនុប្បទិន្ន(អ្នកទទួលសិទ្ធិពីអ្នកដទៃដោយកិច្ចសន្យាអនុប្បទានតំណទេយ្យ)

céder *v.t.* ធ្វើអនុប្បទាន, បង្ហានសិទ្ធិឲ្យទៅអ្នកដទៃ;ផ្ទេរ;ប្រគល់ឲ្យ;លក់ឲ្យ (ឧ. céder un fonds de commerce); ចែកឲ្យ ។ *v.i.* ញ៉ម,ចុះចាញ់ (ឧ. céder à la force) ; ទប់ទល់មិនបាន(ឧ. céder à la douleur); ទន់ទោរ(ឧ.céder sous le poids)

cégésimal,e *a.* នៃប្រព័ន្ធ ស.ក.វ. (ម.ព. C.G.S. ផង)

ceindre *v.t.* ព័ទ្ធ, ឡោម; រ័ណ្ឌ, ក្រវាត់; ពាក់, ដូត។ ceindre le diadème ឡើងសោយរាជ្យ។ceindre la tiare ត្រូវជ្រើសតាំងជាប៉ាប

ceinturage *n.m.* ការរ័ណ្ឌ (កង់ជាដើម)

ceinture *n.f.* ខ្សែក្រវាត់ (ឧ. passer un poignard à sa ceinture); ចង្កេះ (ឧ.être nu jusqu'à la ceinture); រ័ណ្ឌ; អ្វីៗដែលព័ទ្ធជុំវិញឬដែលការពារ (ឧ. ceinture de muraille) ។ ceinture de sauvetage ក្រវាត់សង្គ្រោះ (ពោងពាក់នៅចង្កេះសម្រាប់ជួយយោងមនុស្សលង់ទឹក) ។ *Pop.* se mettre ឬ se

serrer la ceinture ទ្រាំអត់ឃ្លាន (រឹតខ្សែក្រវាត់) ។ *Prov.* bonne renommée vaut mieux que ceinture dorée កេរ្តិ៍ឈ្មោះល្អប្រសើរជាងទ្រព្យសម្បត្តិច្រើន

ceinturer *v.t.* ក្រវាត់; រ័ណ្ឋ; ឱបចង្កេះ

ceinturon *n.m.* ស័ងទុយរ៉ុង,ខ្សែក្រវាត់ព្យួរ(សម្រាប់ព្យួរដាវ,ប្រអប់គ្រាប់។ល។)

cela *pr.dém.* របស់នោះ(ឧ.secourez votre prochain : n'oubliez pas cela) (ម.ព. ceci ផង)

célébration *n.f.* ការធ្វើពិធី (ឧ. la célébration d'un mariage, des funérailles, etc...)

célèbre *a.* វិស្សុត, ល្បីល្បាញ (ឧ. mieux vaut chercher à être utile qu' à être célèbre)

célébrer *v.t.* សរសើរយ៉ាងអធិកអធម; (ឧ.célébrer un héros); ធ្វើពិធី (ឧ.célébrer un mariage)

célébrité *n.f.* វិស្សុតភាព,ភាពល្បីល្បាញ (ឧ. l'estime vaut mieux que la célébrité); ជនល្បីល្បាញ (ឧ. c'est une de nos célébrités)

celer *v.t.* លាក់ (លាក់របស់, លាក់មិននិយាយប្រាប់គេ)

célérité *n.f.* ភាពរហ័សរហួន (ឧ. la célérité des manœuvres de Napoléon 1er)

céleste *a.* នភាកាស,នៃមេឃ (ឧ. les planètes sont des corps célestes) ។ sphère céleste គោលនភាកាស(ម.ព.sphère ផង)។ ដែលមកពីលើមេឃ; ទិព្វ; នៃអាទិទេព (ឧ. bonté céleste) ។ Le Père céleste អាទិទេព ។ esprits célestes នភាកាសភូត(ភូតដែលបិតលើមេឃ) ។ *n.Fam.* ចិន (ព្រោះធំណាលជាព្រះរាជាដើមនៃប្រទេសចិនជាអាទិទេព)

célibat *n.m.* ភាពលីវ (គ្មានប្រពន្ធ ឬ គ្មានប្ដី)

célibataire *a.* លីវ (គ្មានប្រពន្ធឬគ្មានប្ដី)។ *n.* មនុស្សលីវ

celle,celles *pr.dém.f.* ម.ព. celui

cellulaire *a.* ផ្សំដោយកោសិកា (ឧ.tissu cellulaire); នៃកោសិកា (ឧ. théorie cellulaire) ។ voiture cellulaire រទេះដឹកមនុស្សទោស

cellule *n.f.* កោសិកា (ជីវសាស្ត្រ) ។ cellule glandulaire កោសិកាគ្រន្ថិ។ តូបសង្ឃ; គុកឬ បន្ទប់ឃុំ សម្រាប់

ដាក់តែមនុស្សម្នាក់ៗ។*Néol.* កោសិកា (ផ្នែកនៃបក្សកុម្មុយនិស្ត)

celluleux,euse *a.* ដែលចែកជាកោសិកា

celui,celle *pr. dém. sing.*; **ceux, celles** *pl.* អ្នក, របស់ ។ celui-ci celle-ci អ្នកនេះ, របស់នេះ ។ celui-là, celle-là អ្នកនោះ, របស់នោះ

cément *n.m.* ម្រ្សាមឫសធ្មេញ

cendre *n.f.* ផេះ ។ réduire en cendres ដុតកំទេចជាផេះ ។ renaître de ses cendres រស់ឡើងវិញ ។ *pl.* អដ្ឋិធាតុ (ឧ. les cendres de Napoléon 1er furent ramenées en France en 1840)

cendré,e *a.* ប្រផេះ (ឧ. cheveux blond cendré)

cendrer *v.t.* លាបពណ៌ប្រផេះ (ឧ. cendrer un mur); ឲ្យមានពណ៌ប្រផេះ; លាយនឹងផេះ

cendreux,euse *a.* ពោរពេញដោយផេះ

cendrier *n.m.* ផ្នែកជើងក្រានដែលទទួលផេះ; ប្រដាប់គោះកំទេចបារី

cendrillon *n.f.* ស្ត្រីដែលអង្គុយជិតជើងក្រានជានិច្ច ។ *Fam.* ស្ត្រីបំរើកខ្វក់

cénotaphe *n.m.* ផ្នូរឧទ្ទិស (ផ្នូរដែលគេសាងរំឭក ចំពោះបុគ្គលម្នាក់ដែលគេមិនបានសាកសព)

cens *n.m.* ការជំរឿនពលរដ្ឋប្រាំឆ្នាំម្តង (ទម្លាប់នៃជនជាតិរ៉ូម៉ាំង); សួយ

censé,e *a.* ដែលសន្មតថា (ឧ. nul n'est censé ignorer la loi គេសន្មតថាគ្មានអ្នកណាមិនចេះច្បាប់)

censément *adv.Pop.* ដោយសន្មតិ (ឧ. être censément le maître)

censeur *n.m.* អ្នករិះគន់; ពិរុទ្ធាបេក្ខ, អ្នកចាប់ពិរុទ្ធ; ។ *Ens.* សិក្សាភិរក្ស

censurable *a.* គួរចាប់ពិរុទ្ធ, គួរបន្ទោស

censure *n.f.* ការរិះគន់; ពិរុទ្ធការ, ការចាប់ពិរុទ្ធ-ចាប់កំហុស ឬ ចាប់ភ្លាក់; ការបន្ទោស (ឧ. s'exposer à la censure du public) ។ censure simple ការបន្ទោសស្រាល, ការចាប់ភ្លាក់ ឬ ចាប់កំហុសស្រាល

censurer *v.t.* រិះគន់; បន្ទោស; ចាប់ពិរុទ្ធ, ចាប់កំហុស, ចាប់ភ្លាក់

cent *a. num.* សតៈ [សៈ-តៈ], រយ (ឧ. trois cents hommes; quatre cent huit hommes); ទីមួយរយ (ឧ. l'an neuf cent; page cinq cent); ចំនួនច្រើន ។ pour cent ក្នុងរយ (ក្នុងមួយរយ) (ឧ. prêter à deux pour cent (2%) ឲ្យខ្ចី

យកការពីរក្នុងរយ (២%) ។ cent pour cent ពេញទី, ទាំងអស់ (ឧ. cent pour cent cambodgien)

cent *n.m.* សង់ (ភាគរយនៃដុល្លារ)

centaine *n.f.* សតកៈ [សៈ-តៈ-កៈ] ។ une centaine ប្រមាណជាមួយរយ។ plusieurs centaines ច្រើនរយ

centaure,esse *n.* សត្វប្រាំងក្នុងរឿងព្រេង មានក្បាលជាមនុស្ស ខ្លួនជាសេះ

centenaire *a.&n.* ដែលមានអាយុ ១០០ឆ្នាំ។ *n.m.* បុណ្យខួប ១០០ ឆ្នាំ

centennal,e,aux *a.* ដែលមាន ១០០ ឆ្នាំម្ដង

centésimal,e,aux *a.* សតភាគ, ដែលចែកជា ១០០ ភាគ (ឧ. l'échelle normale du thermomètre est centésimale)

centiare (ca) *n.m.* សង់ធារ (១សង់ធារ គឺ ១ ម៉ែត្រការ៉េ)

centième *a. ord.* សតមៈ,ជាទី១០០។ *n.m.* ភាគរយ ។ deux centièmes (2/100) ពីរភាគរយ(២/១០០)

centigrade *a.* សង់ទីក្រាដ ។ *n.m.* centigrade (*cgr.*) សង់ទីក្រាដ (ស.ក្រ) (ភាគរយនៃក្រាដ)

centigramme (cg.) *n.m.* សង់ទីក្រាម (ស.ក)

centilitre (cl.) *n.m.* សង់ទីលីត្រ (ស.ល)

centime *n.m.* សង់ទីម (ភាគរយនៃហ្វ្រង់) ។ centimes additionnels ឬ centimes le franc ម.ព. additionnel

centimètre (cm.) *n.m.* សង់ទីម៉ែត្រ (ស.ម), ហ៊ុន, ធឹង

centrage *n.m.* ការកំណត់រកមជ្ឈមណ្ឌល ឬ អ័ក្ស

central,e,aux *a.* កណ្ដាល, ធំ ។ *n.m.* អង្គការកណ្ដាល, ការិយាល័យកណ្ដាល (ឧ. central téléphonique) ។ *n.f.* រោងចក្រធំ (ឧ. centrale électrique)

centralisateur,trice *a.&n.* ដែលធ្វើមជ្ឈការ, ដែលប្រមូល

centralisation *n.f.* មជ្ឈការ [ម័ច-ឈៈ--], ការប្រមូល (ឧ. centralisation administrative)

centraliser *v.t.* ធ្វើមជ្ឈការ, ប្រមូល (ឧ. centraliser des renseignements)

centre *n.m.* នាភី, មជ្ឈមណ្ឌល [ម័ច ឈៈ--]; មន្ទីរ; ទីប្រជុំជន, ទីក្រុង ។

centre d'essai មជ្ឈមណ្ឌលល្បង។ centre équestre មជ្ឈមណ្ឌលអស្សារោហ៍។ centre mondial មជ្ឈមណ្ឌលពិភពលោក។ centre régional មជ្ឈមណ្ឌលភូមិភាគ។ centre de recherches scientifiques et techniques មជ្ឈមណ្ឌលស្វែងរកខាងវិទ្យាសាស្ត្រនិងតិកនិក។ centre de pédiatrie មន្ទីរពេទ្យកុមារ។ centre de traitement antisiphilitique មន្ទីរព្យាបាលរោគស្វាយ។ centre d'hébergement des miséreux ទីអភិបាលជនទុគ៌ត។ centre rural ទីជនបទ។ centre urbain ទីក្រុង។ centre de gravité ម.ព. gravité។ centre d'intérêt ប្រធានសព្ទ(ប្រើតែក្នុងការសិក្សា)

centrer *v.t.* ដាក់ ឬ រកមជ្ឈមណ្ឌល; ទាញមកកណ្ដាល។ *Fig.* បំបែរក

centrifuge *a.* ដែលឃ្លាតចាកមជ្ឈមណ្ឌល (ឧ. force centrifuge)

centrifuger *v.t.* ធ្វើឲ្យឃ្លាតចាកមជ្ឈមណ្ឌល

centripète *a* ដែលចូលរកមជ្ឈមណ្ឌល (ឧ. force centripète)

centuple *a.&n.m.* សតគុណ (១០០ គុណ)។ au centuple *loc.adv* សតគុណ, ១០០គុណ; លើសច្រើន(ឧ. être payé au centuple)

centupler *v.t.* បង្កើន ១០០ ដង

centurie *n.f.* ក្រុម១០០នាក់ (ទម្លាប់ជនជាតិរ៉ូម៉ាំងកប្រិតយកមនុស្សមួយរយនាក់ធ្វើជាក្រុមមួយទោះក្នុងទាហានក្ដីក្នុងរាជការស៊ីវិលក្ដី); សៀវភៅប្រវត្តិសាស្ត្រចែកជាសតវត្ស

centurion *n.m.* អ្នកត្រួតពលមួយរយនាក់ (ទំនៀមជនជាតិរ៉ូម៉ាំង)

cep *n.m.* ច្រវាក់ដាក់មនុស្សទោស; គល់ទំពាំងបាយជូរ

cépage *n.m.* ដើមទំពាំងបាយជូរ (ឧ. les cépages américains ont servi à reconstituer le vignoble français)

cependant *adv.* ក្នុងខណៈនោះ, ក្នុងពេលនោះ(ឧ.nous bavardons, et cependant le temps fuit)។ *Conj.* ប៉ុន្តែ, តែ (ឧ. les moineaux sont pillards, et cependant ils sont utiles)

céphalogie *n.f.* រោគឈឺក្បាល

céphalique *a.* នៃក្បាល

céphalopodes *n.m.pl.* សិរបាទ (សត្វទន់មានជើងនៅលើក្បាលដូចជាមឹកហ៊ឹតជាដើម)

céphalo-rachidien *a.* នៃខួរក្បាលនឹងខួរឆ្អឹងខ្នង (ឧ. liquide céphalo-rachidien)

céphalothorax *n.m.* ក្បាល (ចំពោះពួកសត្វទន់ខ្លះដែលមានក្បាលនឹងទ្រូងនៅជាមួយគ្នា)

cérame *n.m.* កុលាលភាជន៍, ភាជន៍ដី

céramique *a.* នៃកុលាលភាជន៍។ *n.f.* កុលាលភាជន៍ [កុ-ឡា-ល:-ភាជ] (ភាជន៍ដី, សិល្ប:ខាងធ្វើភាជន៍ដី)

céramiste *a.&n.* អ្នកធ្វើភាជន៍ដី

cerbère *n.m.* ទ្វារបាលគំរោះគំរើយ

cerceau *n.m.* វង់មូល, កង់ក្មេងវាយលេង (ឧ. jouer au cerceau)

cerclage *n.m.* ការវ័ណ្ឌ;ការដាក់បង្កំ; ការក្តាប់ ឬ ការគ្រៀមកណ្តាប់

cercle *n.m.* មណ្ឌល (វង់មូល, ផ្ទៃមូល); វ័ណ្ឌ(ឧ.cercle d'un tonneau); បង្កំ; កណ្តាប់; ធុង (ឧ.vin en cercles); ការប្រជុំ,សមាគម (ឧ.cercle nombreux),កន្លែងប្រជុំ (ឧ.aller au cercle)។ cercle nautique មណ្ឌលកីឡាទូក។ cercle sportif កីឡាមណ្ឌល។ *Fig.* វិសាលភាព, ព្រំដែន (ឧ.cercle des connaissances humaines)

cercler *v.t.* វ័ណ្ឌដោយវង់មូល; ដាក់វ័ណ្ឌ ឬ បង្កំ; ក្តាប់ ឬ គ្រៀមកណ្តាប់ (ឧ. cercler un tonneau)

cercueil *n.m.* មឈូស ។ *Fig.* សេចក្តីស្លាប់ (ឧ. du berceau au cercueil, l'homme est sujet à mille maux)។ descendre au cercueil ចូលមឈូស (ស្លាប់)

céréale *a.& n.f.* ធញ្ញជាតិ

cérébelleux,euse *a.* នៃខួរតូច (ឧ. artères cérébelleuses)

cérébral,e,aux *a.* នៃខួរក្បាល (ឧ. artères cérébrales; fièvre cérébrale)។ *n.f.* *Gram.* មុទ្ធជ: [មុត-ធ:-ជ:] (សម្លេងកើតក្នុងក្បាល) (ម.ព. linguale ផង)

cérémonial,e,aux *a.* ដែលកេនពិធី។ *n.m.* ពិធី; សៀវភៅពិធី

cérémonie *n.f.* ពិធីបុណ្យ (ឧ. les cérémonies du culte romain sont pompeuses); ក្បួនអធិកអធម (ឧ. grande cérémonie); ការគួរសម (ឧ. visite de

cérémonie); សេចក្ដីគួរសមខ្លាំងពេក។ sans cérémonie គ្មានគួរសមច្រើន (មិនជាប់គួរសម)

cérémoniel,elle *a.* ដែលធ្វើដោយពិធី

cérémonieusement *adv.* ដោយមានការគួរសមខ្លាំង;ដោយរាក់ទាក់ខ្លាំង

cérémonieux,euse *a.* ដែលមានការគួរសមខ្លាំង (ឧ. saluts cérémonieux);ដែលមានការរៀបចំប្រិតប្រៀប (ឧ.parure cérémonieuse)

Cérès *Myth.* ព្រះពៃស្រពណ៍ (ទេវតាខាងកសិកម្ម) ។ dons, présents, trésors de Cérès ស្រូវ, ធញ្ញជាតិ, ចម្រូត

cérès *n.f.* គួរស្រូវទុំ; ស្រូវផិតព្រួត; ស្រូវនឹងធញ្ញជាតិឯទៀត; នំបុ័ង, បាយ ។ល។; រដូវចម្រូត; វស្សានរដូវ

cerf *n.m.* ពួកសត្វរមាំង ប្រើសក្ដាន់។ល។ cerf d'Eld រមាំង ។ cerf des marais ក្ដាន់។ cerf d'Aristote ប្រើស។cerf de muntjac ឈ្លូស។ (cri: le cerf brame) ។ *Fig.* &*fam.* មនុស្សរត់លឿន;មនុស្សកំសាក

cerf-volant *n.m.* សត្វកញ្ចែ;ខ្លែងបង្ហើរ (*pl.* des cerfs-volants)

cérifère *a.* ដែលឲ្យក្រមួន(ឧ.plante, insecte cérifère)

cerisaie *n.f.* ចំការសិរីស

cerise *n.f.* ផ្លែសិរីស ។ *a.* ពណ៌សិរីស (ក្រហម) (ឧ. des rubans cerise) ។ rouge cerise ក្រហមឆ្អៅ។ *Pop.* សំណាង (អកុសល) (ឧ. avoir la cerise)

cerisette *n.f.* ផ្លែសិរីសហាល; ភេសជ្ជៈធ្វើអំពីផ្លែសិរីស

cerisier *n.m.* ដើមសិរីស

cerne *n.m.* វង់មូល;វង់(វង់ស្រទាប់សាច់ឈើដែលគេកាត់ទទឹងដើម) (ឧ. le nombre des cernes sert à reconnaître l'âge d'un arbre); កណ្ដាប់ (ដំបៅ); រង្វង់ខ្មៅជុំវិញភ្នែក (ដែលត្រូវគេវាយ)(ថា cernure ក៏បាន); វង់មុខ

cerné,e *a.* ដែលត្រូវឡោម ។ yeux cernés ភ្នែកខ្មៅ (មានរង្វង់ខ្មៅជុំវិញ)

cerner *v.t.* លាក់ជុំវិញ (ឧ. cerner un arbre); ឡោម (ឧ. César cerna Vercingétorix dans Alésia); គូសវង់ជុំវិញ (ឧ. cerner une silhouette) ។ *Fig.* បំភាន់ (ឧ. cerner quelqu'un)

cernoplastique *n.f.* សិល្បៈខាងសូន

រូបក្រមួន

certain,e *a.* ជាក់, ប្រាកដ, ទៀង (ឧ. fait certain; gage certain); ដែលមានកំណត់ (ឧ. se réunir à certaines heures); ខ្លះ, អ្នកខ្លះ (ឧ. certain auteur; vin d'une certaine renommée)។ *n.m.* របស់ជាក់-ប្រាកដ ឬ ទៀង (ឧ. préférer le certain à l'incertain)

certainement *adv.* ប្រាកដហើយ, ទៀងហើយ; បាទ (ចម្លើយទទួល) (ឧ. viendrez-vous demain? —certainement)

certes *adv.* ប្រាកដណាស់ហើយ (ឧ. oui, certes; certes pour un amant la fleurette est mignonne)

certificat *n.m.* វិញ្ញាបនប័ត្រ [វិញ-ញា-ប៉ះ-នៈ-បាត់], លិខិតបញ្ជាក់ ។ certificat d'aptitude à ... វិញ្ញាបនប័ត្រសម្បទាខាង... ។ certificat d'aptitude pédagogique វិញ្ញាបនប័ត្រគរុកោសល្យសម្បទា។ certificat d'aptitude physique វិញ្ញាបនប័ត្រកាយសម្បទា។ certificat d'aptitude professionnelle វិញ្ញាបនប័ត្រវិជ្ជាជីវសម្បទា។ certificat d'assiduité វិញ្ញាបនប័ត្រនិច្ចសិក្សា ។ certificat circonstancié វិញ្ញាបនប័ត្របរិបូណ៌ ។ certificat d'études primaires វិញ្ញាបនប័ត្របឋមសិក្សា។ certificat de fin d'études វិញ្ញាបនប័ត្រចប់ការសិក្សា។ certificat d'inscription វិញ្ញាបនប័ត្រចុះនាម។ certificat de jaugeage វិញ្ញាបនប័ត្រចំណុះនាវា ។ certificat médical d'aptitude physique វិញ្ញាបនប័ត្រពេទ្យខាងកាយសម្បទា ។ certificat de scolarité វិញ្ញាបនប័ត្រសាលារៀន។ certificat de viduité វិញ្ញាបនប័ត្រវិធវកាល [—វិ-ធៈ-វៈ-កាល]

certificateur *a.&n.m.* វិញ្ញាបនករ, អ្នកបញ្ជាក់; អ្នកធានារង (អ្នកធានាលើអ្នកធានាទី ១)

certificatif,ive *a.* សម្រាប់បញ្ជាក់

certification *n.f.* វិញ្ញាបនកម្ម, ការបញ្ជាក់ដោយលិខិត ។ pour certification ដើម្បីវិញ្ញាបនកម្ម

certifié,e *a.&n.* ដែលមានវិញ្ញាបនប័ត្រ

certifier *v.t.* ធ្វើវិញ្ញាបនកម្ម, បញ្ជាក់

(ឧ. Galilée certifia que la terre tourne); អះអាង ។ certifier une caution ធានាលើអ្នកធានាទី ១

certitude *n.f.* និស្ស័យ, ការជាក់ច្បាស់; (ឧ. la certitude d'un évènement historique est souvent difficile à contrôler) ; ការជឿជាក់ជា (ឧ. Jeanne d'Arc avait la certitude de sauver la France)

cérulien,enne *a.* ខៀវការ

cérumen *n.m.* អាចម៍ត្រចៀក

cérumineux,euse *a.* ដែលបង្កើតអាចម៍ត្រចៀក; ដូចក្រមួន (ឧ. matière cérumineuse)

cerveau *n.m.* ខួរក្បាល។ *Fig.* គំនិត, ប្រាជ្ញា (ឧ. Napoléon 1er fut le cerveau le plus puissant de son temps) ។ cerveau brûlé មនុស្សបំភ្លេក

cervelet *n.m.* ខួរតូច

cervelle *n.f.* សាច់ខួរក្បាល (ឧ. retiré de la tête, le cerveau n'est plus qu'une cervelle)។ *Fig.* គំនិត ។ homme, tête sans cervelle មនុស្សឆ្កួត ឬ រវើករវាក់។ *Fam.* brûler la cervelle (ម.ព. brûler) ។ rompre la cervelle ខ្ទេន

cervical,e,aux *a.* នៃក

cervidés *n.m.pl.* សត្វសន្តានក្តាន់

cervier *a.m.* ម.ព. loup-cervier

ces *a.dém.* ម.ព. ce

cessant,e *a.* ដែលឈប់ (ឧ. toute affaire cessante)

cessation *n.f.* ការឈប់ (ឧ. la cessation des paiements est le premier acte de faillite)

cesse *n.f.* ការសម្រាក,ការឈប់,ការផ្អាក (ឧ. il n'avait point de cesse qu'il n'eut réussi) ។ sans cesse *loc.adv.* គ្មានឈប់ឈរ

cesser *v.t.* ឈប់, ផ្អាក (ឧ cesser une poursuite)។ *v.i.* អស់,ចប់, ផុត (ឧ. l'orage a cessé)

cessez-le-feu *n.m.* ការឈប់បាញ់គ្នា

cessibilité *n.f.* អនុប្បទានីយភាព, ភាពអាចប្រគល់ ឬ ផ្ទេរបាន

cessible *a.* អនុប្បទានីយ, គួរប្រគល់ឲ្យ

cession *n.f.* អនុប្បទាន, ការប្រគល់ឲ្យ; ការលក់ ។ cessation de biens

អនុប្បទានទ្រព្យ (ការដែលកូនបំណុលប្រគល់ទ្រព្យរបស់ខ្លួនឲ្យម្ចាស់បំណុល)។ cession de créance អនុប្បទានប្រាក់ជំពាក់

cessionnaire *n.* អនុប្បទានិក,អ្នកទទួលយក ឬ ទទួលទិញ

c'est-à-dire *loc. conj.* គឺជា,ពោលគឺ

ceste *n.m.* ស្នាប់ដៃបញ្ចុះដែក ឬ សំណ

cet, cette *pr. dém. sing.* នេះ

cétacé,e *a.* នៃថនិកមច្ឆា ។ *n.m.pl.* ថនិកមច្ឆា (ឧ. les cétacés contiennent les géants des mammifères)

ceux, celles *pr.dém.pl.* ម.ព.celui

C.G.S. (Centimètre, Gramme, Seconde) ស.ក.ន.(របៀបនិយមប្រើសង់ទីម៉ែត្រ,ក្រាម,នាទី ជាទីមានទណ្ឌ)

chabler *v.t.* វាយដោយដំពក់ (ឧ.chabler des noix); វេញបញ្ចូលគ្នា

chabraque ឬ **schabraque** *n.f.* កែបសេះ

chacal *n.m.* ចចក (cri: le chacal jappe) (*pl.* des chacals)

chacun,e *pr. ind.* ម្នាក់ៗ; និមួយៗ; គ្រប់គ្នា(ឧ. chacun le dit)។*Prov.* chacun pour soi et Dieu pour tous ម្នាក់ៗត្រូវគិតតែខ្លួនឯង រកទិទេពទើបគិតដល់គ្រប់គ្នា

chacunière *n.f.Fam.* ផ្ទះរបស់ម្នាក់ៗ

chadouf *n.m.* ជិងយោង(ប្រដាប់យោងទឹកអណ្ដូង)

chagrin,e *a.* ដែលព្រួយ, ម្លូរម៉ៅ

chagrin *n.m.* ទុក្ខព្រួយ, ជារម្ភ (ឧ. avoir du chagrin)

chagrinant,e *a.* ដែលធ្វើឲ្យព្រួយ ឬ ឲ្យតូចចិត្ត

chagriné,e *a.* ធ្វើចជាព្រួយ

chagriner *v.t.* ធ្វើឲ្យព្រួយ ឬ ឲ្យតូចចិត្ត

chah *n.m.* ព្រះចៅសាហ៍ (មហាក្សត្រប្រទេសអៀរ៉ង់)

chahut *n.m.Fam.* ស្រែករំពង (ឧ. faire du chahut)

chahuter *v.t.Fam.* បន្លឺស្រែករំពង។ *v.i. Arg.* ធ្វើឲ្យច្របូកច្របល់

chainage *n.m.* ការវាស់ដោយខ្សែម៉ែត្រ; ខ្សែត្របែងដញ្ញាំង(កុំឲ្យញែកចេញពីគ្នា)

chaine *n.f.* ច្រវាក់(ឧ.chaine d'or); ខ្សែអន្ទង;ខ្សែម៉ែត្រ។ chaine d'arpenteur ខ្សែឌប់ម៉ែត្រ ។ chaine de froid សារព័ន្ធសីតកម្ម។chaine de montagnes ជួរភ្នំ ។ chaine des osselets កម្រងឆ្អឹងតូច ។ ré-

action en chaine ប្រតិកម្មបន្តគ្នា ។ *Fig.* ភាពជាប់ឃុំឃាំង ឬ នៅក្នុងចំណុះគេ។ briser les chaînes បំបែកចំណង (រកសេរីភាព) ។ ការហុចរបស់បន្តគ្នា (ឧ. faire la chaîne dans un incendie); ការជាប់ទាក់ទងគ្នា (ឧ. la chaîne des idées)

chaîner *v.t.* វាស់ដោយខ្សែម៉ែត្រ; ចងត្រឡែងជញ្ជាំង (កុំឲ្យញែកចេញពីគ្នា)

chaînette *n.f.* ច្រវាក់តូច ។ *Cout.* point de chaînette ថ្នេរផ្កាខ្លូង

chaîneur *n.m.* អ្នកទាញខ្សែម៉ែត្រ

chaînier ឬ **chaîniste** *n.m.* ជាងធ្វើច្រវាក់

chaînon *n.m.* កងច្រវាក់, ក្រវិលច្រវាក់; ភាគមួយៗ ក្នុងជួរ

chair *n.f.* សាច់ ។ *Fig.* ធម្មជាតិមនុស្ស (ប្រកបដោយភគៈ); ខ្លួន; សាច់ផ្លែឈើ។ chair de poule សម្បុរគីង្គក់ ។ avoir la chair de poule ខ្លាចព្រឺខ្លួន ។ *Prov.* il n'est ni chair ni poisson នៅអន្លឹអន្លែ, មិនជាប់ស្រេច

chaire *n.f.* អាសនៈ, កៅអី ។ *Fig.* អាសនៈ (ដំណែងសាស្ត្រាចារ្យ) (ឧ. chaire de philosophie) ។ indemnité de chaire ម.ព. indemnité

chaise *n.f.* កៅអី ។ chaise à porteurs គ្រែស្នែង; ស្នែងកាប់សង្រែក។ chaise longue កៅអីទម្រេត

chaisier, ère *n.* អ្នកធ្វើកៅអី

chaland *n.m.* កណ៉ាល់ដឹកទំនិញ

chaland, e *n.* អ្នកទិញ (ឧ. dans le commerce il faut savoir attirer les chalands)

chalcographe *n.m.* ជាងឆ្លាក់លោហធាតុ

chalcographie *n.f.* សិល្បៈ ឬ កន្លែងឆ្លាក់លោហធាតុ

châle *n.f.* ក្រមាបង់ក

chaleil *n.m.* ចង្កៀងប្រេង

chalet *n.m.* ផ្ទះឈើប្រក់ក្តារ; ផ្ទះនៅជនបទ ។ chalet de nécessité បង្គន់សាធារណ៍

chaleur *n.f.* ចំហាយ, កំដៅ ។ *Fig.* សេចក្តីក្លៀវក្លា (ឧ. la chaleur du combat); សេចក្តីឈឺឆ្អាល

chaleureusement *adv.* ដោយរាក់ទាក់, ដោយកក់ក្តៅ

chaleureux, euse *a.* រាក់ទាក់; ដាទីកក់ក្តៅ; ដែលឈឺឆ្អាល (ឧ. recom-

mandation chaleureuse)

chaloupe *n.f.* កញ៉ាល់

chalouper *v.i.* ដើរយេួងយោង

chalumeau *n.m.* បំពង់ចំបើងឬប្របុះ; ប៉ី; បំពង់ផ្លុំភ្លើង

chalut *n.m.* ថៃភ៉ (នេសាទុបករណ៍);ថ្នង

chalutier *n.m.* អ្នកនេសាទត្រីដោយថៃភ៉; ទូកថ្នង

chamailler *v.i.* & *t.* ឈ្លោះ ។ *Fig.* se chamailler *v.pr.* ភាយគ្នា, ឈ្លោះគ្នា (ដោយមានសូរសន្ធឹក)

chamaillerie *n.f.* ការឈ្លោះគ្នា

chamarrer *v.t.* ពាក់សក្តិនឹងគ្រឿងលំអផ្សេងៗ(ឧ. un général chamarré de décorations)(ច្រើនតែនិយាយដោយចំអក)

chamarrure *n.f.* របៀបពាក់សក្តិនឹងគ្រឿងលំអ; របៀបតុបតែងមិនសម

chambard *n.m.Pop.* សូរសន្ធឹក;ការរំដើបរំជួល

chambardement *n.m.Pop.* ការធ្វើឲ្យច្របូកច្របល់ ឬ រំដើបរំជួល; ការធ្វើឲ្យឮសូរសន្ធឹក

chambarder *v.t. Pop.* ធ្វើឲ្យច្របូកច្របល់, ធ្វើឲ្យរំដើបរំជួល; ធ្វើឲ្យឮសូរសន្ធឹក

chambellan *n.m.* អ្នកថែទាំក្រឡាបន្ទំ

chambouler *v.t. Arg.* ធ្វើឲ្យច្របូកច្របល់

chambranle *n.m.* ក្របទ្វារ ឬ បង្អួច

chambre *n.f.* បន្ទប់ ។ garder la chambre នៅផ្ទះ (មិនចេញក្រៅផ្ទះដោយមានជម្ងឺ) ។ travailler en chambre ធ្វើការដោយគ្មានបើកហាង ។ មន្ទីរប្រជុំ ។ chambre mixte de commerce et d'industrie មន្ទីរចម្រុះពាណិជ្ជកម្មនឹងឧស្សាហកម្ម ។ chambre de compensation អគារទូទាត់(កន្លែងសម្រាប់ភ្នាក់ងារធនាគារប្តូរមូលប្បទានប័ត្រនឹងផលប័ត្រដែលជំពាក់គ្នាទៅវិញទៅមកហើយជំរះគណនីរបស់ខ្លួនដោយកុំឲ្យខាតខាយរូបិយវត្ថុច្រើនពេក) ។ chambre de mise en accusation សាលាក្រុមចោទ ។ សភា; ក្រុមសមាជិកសភា; ប្រហោង, រន្ធ ។ - chambre à air ពោះវៀនកង់

chambrée *n.f.* មនុស្សដែលអាស្រ័យនៅក្នុងបន្ទប់ជាមួយ(ឧ. il faut supporter avec bonne humeur les plaisanteries de la chambrée)

chambrer *v.i.* អាស្រ័យនៅក្នុងបន្ទប់ជាមួយ។ *v.t.* បង្ខាំងក្នុងបន្ទប់(ទណ្ឌកម្ម)

chambrette *n.f.* បន្ទប់តូច

chameau *n.m.* អូដ្ឋឈ្មោល (cri: le chameau blatère) ។ *Pop.* មនុស្សកំណាច

chamelier *n.f.* អ្នកថែទាំនិងបរអូដ្ឋ

chamelle *n.f.* អូដ្ឋញី

chamois *n.m.* សត្វចតុប្បាទម្យ៉ាងនៅលើភ្នំទ្វីបអឺរុប; ស្បែកសត្វនោះ ។ *a.&n.* លឿងខ្ចី (ឧ.robe chamois)

chamoisage *n.m.* ការធ្វើស្បែកឲ្យទន់

chamoiser *v.t.* ធ្វើស្បែកឲ្យទន់ល្មៃ

chamoiserie *n.f.* កន្លែងធ្វើស្បែកឲ្យទន់ល្មៃ; ស្បែកទន់ល្មៃ

chamoiseur *n.m.* អ្នកសម្លាប់និងលក់ស្បែក

champ *n.m.* ស្រែ,ចំការ ។ *pl.* ជនបទ។ ទី។ champ d'action ទីគោចរ។ ស្នាម។ champ de bataille ស្នាមចំបាំង,រណក្សេត្រ [រៈ-ណៈ-]។ សមរភូមិ។ champ de courses ស្នាមប្រណាំងសេះ, ភិលវង់ ។ champ d'honneur រណរង្គ ។ champ de tir កន្លែងបាញ់វង់ ។ champ magnétique ស្នាមកុម្ពិត ។ champ de Mars ស្នាមសមយុទ្ធ។ champ de mines ទីកប់គ្រាប់បែក។ champ d'aviation ភិលយន្ត-ហោះ។ champ de repos កន្លែងកប់ខ្មោច។ដែន។champ d'application ដែនអនុវត្តន៍ ។ champ de vision ដែនចក្ខុវិស័យ ។ se battre en champ clos ប្រ-យុទ្ធគូ ។ prendre la clef des champs រត់(គៀសខ្លួន)។sur-le-champ *loc. adv.* ភ្លាម១, ឥតបង្អង់ ។ à tout bout de champ *loc. adv.* គ្រប់ពេល

champêtre *a.* នៃស្រែចំការឬជនបទ។ agent champêtre ភ្នាក់ងារជនបទ

champi,isse *a.&n.* ក្មេងដែលគេរើសបាននៅជនបទ

champignon *n.m.* កព៌ក [កៈ-ពក់], ផ្សិត ។ pousser comme des champignons ដុះដាលយ៉ាងរហ័ស

champignonnière *n.f.* កន្លែងបណ្ដុះផ្សិត

champignonniste *n.m.* អ្នកបណ្ដុះផ្សិត

champion *n.m.* អ្នកមានជ័យក្នុងកីឡា, អ្នកជើងឯក(ឧ. champion de la

course) ។ *Fig.* អ្នកការពារ (ឧ. Voltaire fut en son temps le champion de la tolérance)

championnat *n.m.* ការប្រជែងជើងឯក

chançard,e *n.&a. Pop.* ហេង(ដែលមានភ័ព្វ)

chance *n.f.* លាភ, សំណាង, ភ័ព្វ, ជោគ

chancelant,e *a.* ទ្រេតទ្រោត(ឧ. vieillard chancelant)។ *Fig.* មិនរឹងប៉ឹង (ឧ. santé chancelante)

chanceler *v.i.* មានដំណើរទ្រេតទ្រោត (ឧ. cet homme chancelle)។ *Fig.* សាញ

chancelier *n.m.* អធិការបតី; រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ chancelier de l'Echiquier រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ (ប្រទេសអង់គ្លេស)

chancelière *n.f.* ភរិយាអធិការបតី; ថង់រុំជើងឲ្យក្ដៅ

chancellerie *n.f.* ស្ថានអធិការបតី; ការិយាល័យឥស្សរិយយស; មន្ទីររដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ commis de chancellerie ម.ព. commis

chanceux,euse *a.* ដែលមានលាភឬហានភ័ព្វ, ហេង(ឧ. homme chanceux); មិនទៀង (ឧ. cette affaire est chanceuse)

chanci,e *a.* ដែលដុះផ្សិត។ *n.m.* ផ្សិត

chancir *v.i.* ដុះផ្សិត

chancissure *n.f.* ផ្សិត(ស្លាបកើតនៅវត្ថុផ្អូមផ្អូរ)

chancre *n.m.* ទាមឡា, ដំបៅល្អួយ។ *Fig.* ហេតុនៃការវិនាស (ឧ. les vices sont des chancres qui rongent l'âme)។ *Pop.* manger comme un chancre ស៊ីច្រើន ។ *Arb.* រោគដើមឈើ

chancreux,euse *a.* នៃទាមឡា; ដែលកើតទាមឡា

chandail *n.m.* អាវយឺតបត់ក

chandelier *n.m.* ជើងទៀន

chandelier,ère *n.* អ្នកធ្វើឬលក់ទៀន

chandelle *n.f.* ប្រទីប, ទៀន។ économie de bouts de chandelle ការសន្សំបន្តិចបន្តួច ។ brûler la chandelle par les deux bouts ខ្ជះខ្ជាយទ្រព្យសម្បត្តិ, ធ្វើឲ្យខូចសុខភាព ។ devoir une belle, une fière chandelle à quelqu'un ជំពាក់ឧបការគុណ។ faire voir à quelqu'un trente-six chandelles វាយក្បាល

យ៉ាងខ្លាំង (ឲ្យបែកអំពិលអំពែក) ។ monter en chandelle ឡើងត្រង់ទៅលើ ។ *Pop.* សម្បោរ

change *n.m.* ការដូរ; ការដូររូបិយវត្ថុ; តម្លៃដូរ (ឧ. les fluctuations du change); កន្លែងដូរ; ការិយាល័យដូររូបិយវត្ថុ ។ prendre le change ចាញ់បោក, ចាញ់បញ្ឆោត ។ donner le change បោក, បញ្ឆោត ។ lettre de change ម.ព. lettre ។ contrôle des changes ម.ព. contrôle

changeable *a.* អាចដូរបាន;ដែលត្រូវដូរ

changeant,e *a.* ដែលប្រែប្រួល (ឧ. caractère changeant)

changement *n.m.* ការផ្លាស់ប្ដូរ; ការប្រែប្រួល (ឧ. changement de temps) ។ changement de vitesse លេខរថយន្ត (ប្រដាប់ផ្លាស់ល្បឿន)

changer *v.t.* ផ្លាស់(ឧ. changer un rouage de montre) ។ changer un enfant ផ្លាស់សំលៀកបំពាក់ឲ្យក្មេង ។ ដូរ(ឧ. changer les métaux en or) ។ *v.i.* ប្រែប្រួល (ឧ. le temps va changer)។ changer de visage ផ្លាស់ទឹកមុខ

changeur *n.m.* អ្នកដូររូបិយវត្ថុ

chanoine *n.m.* ឋានន្តរសក្តិនៃបព្វជិតគ្រិស្តសាសនា

chanson *n.f.* ចម្រៀង ។ *pl. Fig.* ពាក្យឥតខ្លឹមសារ ។ *loc. prov.* l'air ne fait pas la chanson អាការៈក្រៅមិនមែនជាការពិតទេ ។ il en a l'air et la chanson អ្នកនេះឃើញខាងក្រៅដូចម្ដេចខាងក្នុងក៏ដូច្នោះដែរ ។ le ton fait la chanson ស្ដាប់តែសំដី គេអាចដឹងការពិតបាន

chansonner *v.t.* តែងចម្រៀងដៀលត្មះ

chansonnette *n.f.* ចម្រៀងខ្លីៗ

chansonnier,ère *n.* អ្នកតែងចម្រៀងហើយច្រៀងខ្លួនឯង ។ *n.m.* កម្រងចម្រៀង

chant *n.m.* ទំនុកច្រៀង,ចម្រៀង;សម្រែកបក្សី។ chant du coq សម្លេងមាន់រងាវ

chant *n.m.* ទោល (ផ្ទុយនឹងបន្ទារ) ។ de chant *loc. adv.* ខាងទោល

chantage *n.m.* ការគំរាមហែកកេរ(ឧ. pratiquer un chantage)

chantant,e *a.* ដែលច្រៀង; ដែលមានចម្រៀង (ឧ. café chantant);

ស្រួលច្រៀង (ឧ. une mélodie très chantante)

chanter *v.i.* ច្រៀង; រងាវ, យំ, ស្រែក (បក្សី)(ឧ.le coq chante);សរសើរ (ឧ. chanter la gloire, les vertus); ប៉ះអក។ faire chanter quelqu'un គំរាមបំភិតបំភ័យ។ se chanter *v.pr.* មានគេច្រៀង (ឧ. cet air se chante partout)

chanteur,euse *n.* អ្នកចំរៀង។ *a.* ដែលមានសំប្រែកពីរោះ (ឧ.oiseaux chanteurs)។ maître chanteur អ្នកគំរាមបំភិតបំភ័យគេ

chantier *n.m.* ការដ្ឋាន;កន្លែងគរឈើឬធ្យូងលក់; កន្លែងសង់នាវា ។ *Fig.* avoir un ouvrage sur le chantier កំពុងធ្វើការអ្វីមួយ

chantonnement *n.m.* ការច្រៀងតិចៗ

chantonner *v.t.& i.* ច្រៀងតិចៗ (ឧ. chantonner une mélodie)

chantoung *n.m.* ព្រែសង់ទុង

chantourner *v.t.* វៀល (ឧ. chantourner une bordure)

chantre *n.m.* អ្នកច្រៀងក្នុងវិហារកាតូលិក ។ *Fig.* កវី ។ les chantres des bois បក្សា, បក្សី

chanvre *n.m.* ធ្មៃ, សរសៃធ្មៃ។chanvre indien កញ្ឆា

chanvrier,ère *n.* អ្នកធ្វើធ្មៃ។*a.* នៃធ្មៃ

chaos *n.m.* ភាពច្របូកច្របល់នៅពេលមុន ក ផែនដី ។ *Fig.* ការវឹកវរ, ការច្របូកច្របល់(ឧ.un chaos d'arguments)

chaotique *a.* ច្របូកច្របល់

chapardage *n.m.Pop.* ការលួចបន្តិចបន្តួច

chaparder *v.t.* លួចបន្តិចបន្តួច

chapardeur, euse *a.* ដែលលួចបន្តិចបន្តួច

chape *n.f.* អាវផាយម្យ៉ាង (នៃបព្វជិតគ្រិស្តសាសនា)(ឧ. la chape ne se porte que pendant la cérémonie); សំបក; គម្រប

chapé,e *a.* ដែលមានសំបក ឬ គម្រប

chapeau *n.m.* មួក។ coup de chapeau ការបើកមួកគំនាប់។ recevoir le chapeau បានឋានន្តរជាការឌីណាល់។ ក្បាលផ្សិត; ក្បាលគ្រឿងយន្ត (ឧ.le chapeau d'un marteau pilon; chapeau de roue)

chapeauter *v.t.Fam.* បំពាក់មួក

chapechute *n.f.* លាភបានដោយការ

ធ្វេសនៃអ្នកដទៃ ឬ ដោយគ្រោះថ្នាក់

chapelet *n.m.* ផ្គាំ (ឧ. un chapelet de corail)។ធម៌ដែលគេសូត្រប្រឡះផ្គាំ(ឧ. dire un chapelet);ចង្កោម (របស់អ្វីដែលផ្គុំគ្នាដូចគ្រាប់ផ្គាំ)(ឧ.certaines rivières russes sont de véritables chapelets de lacs)។ *Fig.* ឈុត,ជប់(ឧ.défiler un chapelet d'injures) ។ របាក់ទឹក។ défiler son chapelet និយាយឲ្យអស់ពីពោះ

chapelier *n.m.* អ្នកធ្វើ ឬ លក់មួក

chapelle *n.f.* វិហារតូច

chapellerie *n.f.* ការធ្វើ ឬ លក់មួក; ហាងមួក

chaperon *n.m.* មួកម្យ៉ាងគ្របដល់ស្មា។ *Fig.* ស្រីអ្នកជូន (ស្រីចាស់ដែលតាមជូនស្រីក្មេង)

chaperonner *v.t.* បពាក់គំរប។ *Fig.* តាមជូន (ដើម្បីចាំការពារស្រីក្មេង)

chapiteau *n.m.* ក្បាច់ក្បាលសសរ

chapitre *n.m.* ជំពូក;បរិច្ឆេទ;កថាភាគ; វគ្គ; ក្រុមប្រឹក្សានៃបព្វជិត ; សន្និបាត។ avoir voix au chapitre មានសិទ្ធិឲ្យយោបល់ ។ chapitre du budget ជំពូកនៃថវិកា ។ *Fig.* រឿងដែលគេកំពុងនិយាយ (ឧ. causons sur ce chapitre)

chapitrer *v.t.* ស្តីបន្ទោស; ផ្តាំ

chapon *n.m.* មាន់ក្រៀវ

chaponner *v.t.* ក្រៀវមាន់

chaque *a.ind.* រាល់,និមួយៗ,គ្រប់ (ឧ. il faut une place pour chaque chose et chaque chose à sa place) ។ chaque fois que កាលណាបើ(ម.ព. chacun ផង)

char *n.m.* រថ,រទេះ ។ char funèbre ឆររថ(រថដាក់សព) ។ char de combat, char d'assaut រថក្រោះ

charabia *n.m.* ភាសាស្តាប់មិនបាន

charançon *n.m.* ខ្មូត

charançonné e *a.* ដែលខ្មូតស៊ី (ឧ. maïs charançonné)

charasse *n.f.* ហិបប្រដិស

charbon *n.m.* ធ្យូង ។ charbon ardent រងើកភ្លើង ។ *Méd.* អង្គាររោគ (រោគពិសម្យ៉ាង) ។ *Fig.* être sur les charbons មានការលំបាក។ charbon de terre ធ្យូងថ្ម

charbonnage *n.m.* ការយកធ្យូងថ្ម

charbonner *v.t.* កំឡោច (ឧ. charbonner un roti);គូរក្រវេបក្រវាប

ដោយធ្យូង (ឧ. charbonner les murs)។ *v.i.* ទៅជាធ្យូង

charbonnerie *n.f.* ឃ្លាំងធ្យូង។ *Pol.* សមាគមនយោបាយនៅប្រទេសអ៊ីតាលី

charbonnette *n.f.* កំណាត់ឈើសម្រាប់ដុតធ្យូង

charbonneux,euse *a.* ដូចធ្យូង; ប្រឡាក់ធ្យូង

charbonnier,ère *n.* អ្នកដុត ឬ លក់ធ្យូង ។ *a.* នៃធ្យូង (ឧ. les centres charbonniers)។ *n.m.* នាវាដឹកធ្យូង ។ *Prov.* charbonnier est maître chez soi (ឬ chez lui) អ្នកក្រជាចៅហ្វាយក្នុងផ្ទះខ្លួន (អាចធ្វើតាមទំនើងចិត្តបានក្នុងផ្ទះខ្លួន)

charbonnière *n.f.* ឡដុតធ្យូង

charcuter *v.t.* កាប់សាច់ដោយមិនស្អាត (ឧ.charcuter une volaille)។ *Chir.* វះដោយឆ្គង

charcuterie *n.f.* របរឬទីលក់សាច់ក្ដិន

charcutier,ère *n.* អ្នកលក់សាច់ក្ដិន, អ្នកលក់សាច់ជ្រូក

charge *n.f.* បន្ទុក ។ charges sociales បន្ទុកខាងសង្គមកិច្ច។ être à charge de quelqu'un នៅក្នុងបន្ទុកអ្នកឯណាមួយ; *au fig.* ឡើពាកក្រាំក្រ។ មុខងារក្នុងរាជការ(ឧ. occuper de hautes charges); ភារៈ (ឧ. avoir charge de vendre un bien); ពិរុទ្ធ (ឧ. relever de lourdes charges contre un inculpé); ពន្ធ; ការចូលវាយលុក; ការព្រេច (ដំរី); ការទូងស្គរផ្លុំត្រែចូលលុក (ឧ. battre, sonner la charge); រំសេវ (ក្នុងគ្រាប់កាំភ្លើង)។ revenir à la charge វាយលុកឡើងវិញ,សុំឡើងវិញ។ល។ femme de charge ស្រីអ្នកថែទាំសម្លៀកបំពាក់-បាន ។ល។ témoin à charge កសិណខាងចោទក៏។ *Fig.* រូបកាក, ការគ្រាប់កំប្លែង។ *Par ext.* ការលេងកំប្លែង, ការបញ្ឆោតលេង ។ à charge de *loc.adv.* លុះត្រាតែ

chargé,e *a.* &*n.* ដែលទទួលបន្ទុក ឬ ទទួលភារៈ; ដែលមានច្រើនពេក;ដែលត្រូវវាយសម្រុក ។ *Fig.* ដែលបានទទួលច្រើន (ឧ. chargé d'honneurs) ។ temps chargé មេឃមានពពកដិតស ។ lettre chargée សំបុត្រមានតម្លៃ។*n.*ឆារ៍-វ៉ិណ៍។chargé d'affaires ភារធារី [ភា-រៈ-] (អ្នកទទួលបន្ទុកការកិច្ចការជំនួសទូត)។

chargé extraordinaire ធារីវិសាមញ្ញ ។ chargé de cours សិក្ខាបនធារី [—ប៉ះ-នះ—] ។ chargé de l'enseignement សិក្សាធារី។ chargé de recettes ធារីចំណូល ។ chargé auxiliaire ធារីជំនួយ ។

chargement *n.m.* ការផ្ទុក (ឧ. le chargement des navires); បន្ទុកនាវាឬរទេះ; ការផ្ញើសំបុត្រមានតម្លៃ

charger *v.t.* ផ្ទុក (ឧ. charger un portefaix); ដាក់ពេញពោរ (ឧ. charger une table de mets) ។ *Pop.* ផ្ទុក, ដឹក (ឧ. cocher qui a chargé un client) ។ *Fig.* ឲ្យរងបន្ទុក (ឧ. charger d'impôts); តាំង (ឧ. charger un avoué d'une affaire)។វាយសម្រុក (ឧ. charger l'ennemi); សម្រុកចូល; ប្រកគ្រាប់; ចោទប្រកាន់ (ឧ. charger un accusé); បំផ្លើស (ឧ. charger un récit)។ se charger *v.pr.* ទទួលភារៈ; ទទួលរ៉ាប់រង; វាយសម្រុកគ្នាទៅវិញទៅមក; ប្រកគ្រាប់ (ឧ. arme qui se charge par la culasse); ទទួលភារៈ (ឧ. je me charge de tout) ។ se charger de quelqu'un ទទួលរ៉ាប់រងលើខ្លួន ។ le temps se charge មេឃឡើងបារស្រទំ (មានពពកដាស)

chargeur *n.m.* អ្នកផ្ទុក; ឡុតគ្រាប់កាំភ្លើង

chariot *n.m.* រទេះបន្ទុកកង់ ៤; ក្រង់មានកង់ (សម្រាប់កូនក្មេងរៀនដើរ) ។ chariot de David ភាគខ្លួននៃផ្កាយក្រពើ

charitable *a.* សប្បុរស

charitablement *adv.* ដោយសប្បុរស

charité *n.f.* សេចក្ដីសប្បុរស; ទាន ។ *Prov.* charité bien ordonnée commence par soi-même មុននឹងគិតដល់គេ ត្រូវគិតខ្លួនឯងសិន (ជាភាសិតអសប្បុរស)

charivari *n.m.* សូរគគ្រាំគគ្រេង (ឧ. donner un charivari)។*Fig.* ភ្លេងធូងធាង, សូរគគ្រឹកគគ្រេង

charlatan *n.m.* អ្នកលក់ថ្នាំសង្កូវ ឬអ្នកដកធ្មេញ (តាមផ្លូវសាធារណៈ)។ *Fig.* គ្រូបោកប្រាស់

charlatannerie *n.f.* របរគ្រូបោកប្រាស់; អំនួតដើម្បីបោកប្រាស់

charlatanesque *a.* ដែលប្រុងនឹងបោកប្រាស់

charlatanisme *n.m.* ក្បួនគ្រូឆោកប្រាស់; អំនួត

charlemagne (faire) លេងល្បះរត់ (ល្បះល្បែងហើយឈប់លេងតទៅទៀត)

charmant,e *a.* ល្អ, ស្រស់, គួរគាប់ចិត្ត។ Prince charmant តួប្រុសក្នុងរឿងព្រេង; ប្រុសរូបល្អ

charme *n.m.* ស្នេហ៍ (ឧ. rompre le charme ដោះស្នេហ៍) ។ *Fig.* ស្នេហ៍មុខ, សម្រស់ ។ se porter comme un charme *loc.fam.* មានសុខភាពបរិបូណ៌ ។ *pl.* លំអ

charmer *v.t.* ដាក់ស្នេហ៍; សណ្ដំ (ឧ. le serpent, dit-on, charme l'oiseau) ។ *Fig.* មានស្នេហ៍មុខ, ធ្វើឲ្យគេស្រឡាញ់ឬឲ្យគេកោតសរសើរ (ឧ. charmer l'esprit) ; ធ្វើឲ្យស្រាក (ឧ.charmer la douleur, les peines)

charmeur,euse *n.* គ្រូស្នេហ៍។ charmeur de serpents អាលម្ពាយ (អ្នកចេះសិល្បវិទ្យាចាប់ពស់) ។ *a.&n. Fig.* អ្នកមានស្នេហ៍មុខ(ដែលធ្វើឲ្យគេស្រឡាញ់ ឬ ឲ្យគេចូលចិត្ត) ។ *n.f.* សំពត់ព្រែម្យ៉ាង

charnel,elle *a.* ដែលត្រេកត្រអាល(ឧ. homme charnel); ប្រកបដោយកាមគុណ(ឧ.plaisirs charnels)

charnellement *adv.* ដោយត្រេកត្រអាល

charnier *n.m.* ទីទុកសាច់ងៀត។ *Par anal.* ទីស្មសាន ; កន្លែងគរខ្មោច-គរឆ្អឹងមនុស្ស ឬ សត្វ

charnière *n.f.* ត្រចៀកទ្វារ ឬ បង្អួច

charnu,e *a.* ដែលជាសាច់ (ឧ.masse charnue); ដែលមានសាច់ច្រើន (ឧ. bras charnus)។ *Fig.* ដែលមានសាច់ក្រាស់ហើយផ្អែម (ផ្លែឈើ)

charogne *n.f.* គម្រង់សត្វ

charpentage *n.m.* ការធ្វើគ្រឿងដំបូល

charpente *n.f.* គ្រឿងដំបូលផ្ទះ ។ bois de charpente ឈើសម្រាប់គ្រឿងដំបូល ។ *Fig.* គ្រោងឆ្អឹង (ឧ. la charpente humaine)

charpenter *v.t.* កាត់; អារ ។ *Fig.* គិតគ្រោង (ឧ. charpenter un drame)

charpenterie *n.f.* សិល្បៈធ្វើគ្រឿងដំបូល

charpentier *n.m.* ជាងគ្រឿងដំបូល

charpie *n.f.* ចម្រៀកសំពត់ចាស់ៗ សម្រាប់រុំដំបៅ។ viande en char-

pie សាច់ដាត់ ។ mettre en charpie បំផ្លាញ

charrée *n.f.* កាកក្បុង

charretée *n.f.* ចំណុះរទេះ (ឧ. une charretée de bois)

charreterie ឬ **charretterie** *n.f.* ម.ព. chartil

charretier,ère *a.* ដែលរទេះអាចបរបាន ។ *n.m.* អ្នកបររទេះ ។ jurer comme un charretier ពោលពាក្យលាមកគ្រប់ពេល

charreton *n.m.* រទេះលាតតូច

charrette *n.f.* រទេះ ។ charrette à bœufs រទេះគោ

charriage *n.m.* ការដឹកនាំ (ដោយរទេះ ឬ ដោយបណ្ដែតតាមទឹក ។ល។)

charrier *v.t.* ដឹកដោយរទេះ(ឧ.charrier des pierres); នាំ (ដោយកំឡាំងទឹកហូរ) (ឧ. le fleuve charrie du sable) ។ *Pop.* បំភ្លើស; បំអក

charroi *n.m.* ការដឹកដោយរទេះ (ឧ. l'extention des chemins de fer a porté un coup mortel au charroi); ក្បួនជូនទ័ព

charron *n.m.* ជាងរទេះ-នង្គ័ល

charronnage *n.m.* ការធ្វើរទេះ-នង្គ័ល

charronnerie *n.f.* របរធ្វើរទេះ-នង្គ័ល

charroyer *v.t.* ដឹកដោយរទេះ-រថ ។ល។

charroyeur *n.m.* អ្នកដឹកដោយរទេះ-រថ ។ល។

charrue *n.f.* នង្គ័ល ។ *Fig.* cheval de charrue មនុស្សខ្លាំងតែល្ងង់ ។ tirer la charrue ធ្វើការធ្ងន់ ។ *Prov.* mettre la charrue avant (ឬ devant) les bœufs ទឹមនង្គ័លពីមុខគោ (ធ្វើការប្រាសចុង)។ c'est une charrue mal attelée និយាយចំពោះសមាគមដែលមានសមាជិកមិនស្រុះស្រួលគ្នា

charte *n.f.* កតិកាសញ្ញា, ធម្មនុញ្ញ ។ charte des nations unies ធម្មនុញ្ញសហប្រជាជាតិ ។ charte-partie ធម្មនុញ្ញភាគី (លិខិតជួលផ្ទុកនាវា)

chartil *n.m.* រទេះដឹកកណ្ដាប់; រោងរថ

chartre *n.f.* គុក ។ tenir quelqu'un en chartre privée ឃុំឃាំងអ្នកណាមួយដោយចិត្តឯង (តុលាការមិនបានអនុញ្ញាត)

chas *n.m.* គូថម្ជុល

chasse *n.f.* ការបរបាញ់, ប្រមាញ់;

កន្លែងបរបាញ់; សត្វដែលបាញ់បាន ។ donner la chasse à ដេញតាម។ *Prov.* qui va à la chasse perd sa place អ្នកដើរស្វែងរមែងបាត់កន្លែង (អ្នកដែលបានកន្លែងហើយដើរស្វែងរកកន្លែងថ្មីទៀត ច្រើនតែបាត់កន្លែងចាស់)

chasse *n.f.* ប្រអប់ដាក់សារីរិកធាតុ; ជិង (ឧ. la chasse d'un verre de lunettes); ញញួរម្យ៉ាង ។ *n.m. pl. Arg.* ភ្នែក

chasse-clous *n.m. inv.* ដែកបញ្ចូន (ដែកស្រួចសម្រាប់វាយដែកគោលឲ្យកប់)

chasse-mouches *n.m. inv.* ស៊ើ

chasse-neige *n.m.* ខ្វៀសទឹកកក (ប្រដាប់កៀសទឹកកកចេញពីផ្លូវ)

chasse-pierres *n.m.* ខ្វៀសថ្ម (ប្រដាប់កៀសថ្ម ឬ វត្ថុឯទៀតចេញពីផ្លូវរថភ្លើង)

chassepot *n.m.* កាំភ្លើងចម្បាំងម្យ៉ាង

chasser *v.t.* បរបាញ់; ប្រដេញ (ឧ. chasser le cerf, la perdrix) ។ *Par ext.* ដេញ (ឧ. chasser les mouches, chasser les vaches); ច្រាន (ឧ. le vent chasse un navire vers la côte); បញ្ចូន (ឧ. chasser un clou à coups de marteau); បណ្ដេញ (ឧ. chasser l'ennemi hors de ses positions; chasser un domestique); បំបាត់, កំចាត់ (ឧ. chasser la contagion; le jour chasse la nuit, et la nuit le jour) ។

Fig. chasser de tristes pensées កំចាត់គំនិតដែលឲ្យកើតទុក្ខ។ *Pop.* chasser le brouillard ផឹកអុរ (ផឹកស្រាពីព្រហាម) ។ *Mar.* chasser un navire ដេញតាមនាវាមួយ។ chasser la terre ស្វែងរកដី (បំពោះនាវាស្វែងរកត្រើយ) ។

Prov. un clou chasse l'autre បានថ្មីចោលចាស់ ឬ បានស្វាយណាយក្រូច។ la faim chasse le loup du bois ពោះឃ្លានចិត្តហ៊ាន (សេចក្ដីត្រូវការបង្ខំឲ្យយើងហ៊ានប្រព្រឹត្តអំពើដែលយើងមិនធ្លាប់ធ្វើពីដើមមក) ។

v.i. បរបាញ់ (ឧ. passer son temps à chasser); ដេញសត្វ (ឧ. les bons chiens chassent d'eux-mêmes)។ chasser à ចាប់ (ឧ. les chattes chas-

sent aux souris comme aux oiseaux); ប្រដេញដោយ (ឧ. chasser aux chiens courants) ។ chasser au poil, à la plume ប្រដេញសត្វរោម, សត្វស្លាប ។ chasser de race កាត់ពូជល្អ (ឆ្កែប្រមាញ់); មានគុណសម្បត្តិដូចជីដូនជីតា (មនុស្ស) ។ chasser sur les terres de quelqu'un បានការលើសិទ្ធិ ឬ មុខការអ្នកដទៃ ។ chasser aux écus ស្វែងរកប្រាក់ chasser aux maris ស្វែងរកប្តី។ chasser de loin ជាប់ត្រកូលខ្ពស់ ដែលមានយូរយារមកហើយ ។

〃 (រថយន្តដែលទប់ហ្វ្រាំងហើយរអិល) ។ *Mar.* chasser sur ses ancres មិនជាប់យុថ្កា (ចំពោះនាវាដែលយុថ្កាមិនថ្កក់ដី); *au fig.* សាត់អណ្តែត (គ្មានមធ្យោបាយស្រោចស្រង់) (ឧ. toutes les boussoles sont perdues, la société chasse sur ses ancres)។ un bateau ឬ une bouée a chassé នាវា ឬ ពោងរសាត់ ។

Prov. bon chien chasse de race ឆ្កែពូជល្អ ច្រើនតែល្អ; ផ្លែឈើជ្រុះមិនឆ្ងាយពីគល់ ។ leurs chiens ne chassent pas ensemble មនុស្សពីរនាក់នោះមិនត្រូវគ្នាទេ ។ chassez le naturel, il revient au galop ម.ព. naturel ។

se chasser *v.pr.* ប្រដេញគ្នា (ឧ. dynasties qui se chassent au trône); ត្រូវគេបរបាញ់ (ឧ. les alouettes se chassent au miroir)

chasseresse *n.f. Poét.* ស្ត្រីប្រមាញ់ (ប្រើក្នុងកាព្យឃ្លោង)

chasseur,euse *n.* ព្រាន, ប្រមាញ់; ទាហានប្រដេញ; នាវា ឬ យន្តហោះប្រដេញ

chassie *n.f.* ពពកភ្នែក, អាចម៍ភ្នែក

chassieux,euse *a.* ដែលកេនពពកភ្នែក ឬ អាចម៍ភ្នែក

châssis *n.m.* ប្រអប់; ក្រប; តួរថយន្ត; តួបង្អួច; ទូក (រទេះ)

chaste *a.* ព្រហ្មចារី-រិនី, បរិសុទ្ធដោយចិត្តនិងកាយ

chastement *adv.* ដោយបរិសុទ្ធិ

chasteté *n.f.* ព្រហ្មចរិយភាព, សេចក្តីបរិសុទ្ធដោយចិត្តនិងកាយ

chat,chatte *n.* ឆ្មា (cri: le chat

miaule) ។ chat sauvage ឆ្មាព្រៃ ។ chat musqué ឬ civette សំពោច ។ *Fam.* ពាក្យស៊ីទូស្ពាល សម្រាប់ហៅអ្នកដែលគេស្រឡាញ់ ។ *Par ext.* chat fourré ចៅក្រម ឬមន្ត្រីខ្លះ(ដែលពាក់អាវមានរោមសត្វ)។ chat grillé ភ្លេងសំពម ។ musique de chat ភ្លេងធ្លុងធាង ។

Loc. fam. chien et chat ជាសត្រូវនឹងគ្នា។ écrire, griffonner comme un chat សរសេរអក្សរអានមិនដាច់ ។ avoir joué avec un chat មានរលាត់មុខ (ដូចឆ្មាក្រចៅ) ។ c'est le chat ពាក្យឆ្លើយចំអកឲ្យអ្នកដែលធ្វើរក្រក់ហើយប្រកែកថាមិនធ្វើ, ពាក្យនេះមានន័យថា បើអ្នកឯងមិនធ្វើទេ មានតែឆ្មាធ្វើ ។ pas un chat គ្មានម្នាក់ (ឧ. on ne rencontre pas un chat dans la rue) ។ il n'y a pas là de quoi fouetter un chat របស់នោះមិនសំខាន់ទេ ។ courir comme un chat maigre រត់គ្រហេបគ្រហប; ដើរចង់ស្រី ។ être comme le chat, qui retombe toujours sur ses pattes ចេះតែជោះកុនជានិច្ច; មិនចេះភ្លាត់ចំណាប់គេណ: ។ jeter sa langue aux chat (ឬ aux chiens) ទទួលសារភាពថារកមិនឃើញ ឬ ចាញ់ចំណោទ ។ jeter le chat aux jambes ទម្លាក់ទោសលើ ។ avoir un chat dans la gorge ស្អួលដើមកភ្លាម ។ bailler le chat par les pattes ចាប់និយាយពីខាងពិបាកមុន។ se servir de la patte du chat pour tirer les marrons du feu ខ្ចីដៃគេលូកយករបស់ពីក្នុងភ្លើង (ឲ្យគេរងគ្រោះភ្លាក់ ខ្លួនឯងចាំទទួលផល) ។ avoir une mine de chat fâché មុខដូចជាខឹងខ្លាំង ។ acheter ឬ vendre chat en poche ទិញ ឬ លក់ឆ្គួចភ្នែក (ដោយមិនមើល ឬ មិនសុំមើលទំនិញមុនសិន) ។ réveiller le chat qui dort កេះគយឲ្យអង្គរ (ឬ អាការ?); ដំចៅមិនឈឺយកឈើចាក់ (រឿងជាត់ស្ងាត់ហើយទៅបង្កើបឡើងវិញ) ។ il n'y avait que le chat គ្មានកសិណម្នាក់ ។ payer en chats et en rats សងជារបស់តូចតាច ។ emporter le chat លួចចេញ, ចេញដោយគ្មានលាម្ចាស់ផ្ទះ ។

Jeux ល្បែងក្មេងដេញចាប់គ្នា។ *Prov.* on ne peut prendre de tels chats sans mitaines ការស្ទុះស្ទាញចម្បងចម្រាសដែលត្រូវប្រយ័តមែនទែន ។ le chat parti, les souris dansent ឆ្មាមិននៅ កណ្ដុរឡើងកឆ្ង។ la nuit tous les chats sont gris ក្នុងទីងងឹតមើលគ្នាមិនស្គាល់(របស់ឬមនុស្សច្រឡំគ្នាអស់)។ le mou est pour le chat របស់នេះជាកម្មសិទ្ធិនៃអ្នកណាមួយ។ à bon chat bon rat ឆ្មាប្រសប់ កណ្ដុរក៏ប្រសប់ (គូប្រឆាំងមានសមត្ថភាពដូចគ្នា) ។ chat échaudé craint l'eau froide ឆ្មាធ្លាប់រលាកទឹកក្ដៅខ្លាចទឹកត្រជាក់ ឬ អ្នកធ្លាប់ស៊ីសំបកដូងខ្លាចសំបកឪឡឹក (អ្នកដែលរងរោទ៏នឹងរបស់អ្វីមួយសូម្បីតែស្រមោលរបស់នោះក៏ខ្លាចដែរ)

châtain,e *a.* សម្បុរត្នោត(ឧ. cheveux châtains; couleur châtaine)

château *n.m.* ប្រាសាទ; ផ្ទះថ្មធំ ។ château d'eau ភិរធារី(ឃ្លាំងទឹក, ធុងទឹក), ប៉មទឹក ។ *Fig.* château de cartes អ្វីៗដែលងាយបំផ្លាញ។ bâtir des châteaux en Espagne សង្ឃឹមឆ្ងាយលើមេឃ

châtelain *n.m.* ម្ចាស់ប្រាសាទឬផ្ទះថ្មធំ

chatelaine *n.f.* ភរិយាម្ចាស់ប្រាសាទ ឬ ផ្ទះថ្មធំ; ស្ត្រីម្ចាស់ប្រាសាទ ឬ ផ្ទះថ្មធំ

chatelet *n.m.* ប្រាសាទតូច

chat-huant *n.m.* ខ្លែងស្រាក (*pl.* des chats-huants)

châtier *v.t.* ធ្វើទោស (ឧ. chatier des rebelles); ស្ដីបន្ទោស, វាយ។ *Fig.* ធ្វើឲ្យបរិសុទ្ធ ។ *Prov.* qui aime bien chàtie bien បើស្រឡាញ់ណាស់ត្រូវស្ដីប្រដៅណាស់

châtiment *n.m.* ទណ្ឌកិច្ច, ការធ្វើទោស

chatoiement *n.m.* ពន្លឺផ្លេកៗ (ចំពោះថ្ម, សំពត់)

chaton *n.m.* កូនឆ្មា

chaton *n.m.* ក្រចាប់ចិញ្ចៀន; ត្បូងចិញ្ចៀន ។ *pl.* ផ្កាជាចង្កោម

chatonner *v.t.* ដាំ (បង្កប់ក្នុងក្រចាប់ចិញ្ចៀន)

chatouille *n.f. Fam.* ការចាក់ក្រឡេក(ឧ. faire des chatouilles)

chatouillement *n.m.* ការចាក់ក្រឡេក; ការរសើប។ *Fig.* ការឡើងទឹកចិត្ត(ឧ. les chatouillements de l'amour-propre)

chatouiller *v.t.* ចាក់ក្រឡេក; ស្ទាប ។ *Fig.* ធ្វើឲ្យរីករាយ (ឧ. les louanges chatouillent l'oreille)

chatouilleur, euse *a.* ដែលចាក់ក្រឡេក; ដែលឲ្យរីករាយ

chatouilleux,euse *a.* រសើប ។ *Fig.* ឆាប់ខឹង (ឧ. esprit chatouilleux)

chatoyant,e *a.* ភ្លឺរលើក, ភ្លឺផ្លេកៗ

chatoyer *v.i.* មានពន្លឺរលើកផ្លេកៗ

châtrer *v.t.* ក្រៀវ, កាត់

chatte *n.f.* ឆ្មាញី

chattemite *n.f. Fam.* មនុស្សពុតធ្វើជាស្លូត(ដូចឆ្មាលាក់ក្រចក) (ឧ. faire la chattemite)

chatterie *n.f.* ពុតឆ្មាលាក់ក្រចក, ការលាក់ពុត; បង្អែម

chat-tigre *n.m.* ខ្លាត្រី (*pl.* des chats-tigres)

chaud,e *a.* ក្ដៅ(ឧ. climat chaud); កក់ក្ដៅ (ឧ. vêtement chaud)។ *Fig.* ខ្លាំង (ឧ. une chaude dispute); រហ័សរហួន; ថ្មី (ឧ. nouvelle toute chaude)។ pleurer à chaudes larmes យំសស្រាក់ (យំខ្លាំង) ។ *n.m.* កំដៅ។ à chaud កំពុងគ្រុន; កំពុងក្ដៅ

chaude *n.f.* ភ្លើងក្ដៅល្អ (ឧ. faire une chaude); ការដុតដែក

chaudement *adv.* យ៉ាងកក់ក្ដៅ (ឧ. se vêtir chaudement); យ៉ាងក្លៀវក្លា (ឧ. poursuivre chaudement une affaire)

chaudière *n.f.* ឆ្នាំងខ្ទះ ។ chaudière à vapeur ខ្ទះដុតយកចំហាយ

chaudron *n.m.* ឆ្នាំងខ្ទះតូច។ *Fam.* ប៉្យាណូមិនល្អ (គ្រឿងភ្លេង)

chaudronnée *n.f.* ចំណុះឆ្នាំងខ្ទះ

chaudronnier, ère *n.* អ្នកធ្វើ ឬ លក់ឆ្នាំងខ្ទះ

chauffage *n.m.* ការដុត (ឧ. chauffage au bois, au charbon); របៀបកំដៅ ។ bois de chauffage អុស (ឧ. le stère est l'unité de mesure pour le bois de chauffage)

chauffant,e *a.* ដែលកំដៅ

chauffard *n.m.* អ្នកបើករថយន្តមិនប្រសប់ ឬ ធ្វេសប្រហែស

chauffe *n.f.* ការកំដៅ; ការបិត (យកញើស) ។ surface de chauffe ផ្ទៃត្រូវភ្លើង

chauffe-eau *n.m.inv.* ប្រដាប់កំដៅទឹក

chauffe-pieds *n.m. inv.* ម.ព. chaufferette

chauffe-plats *n.m.* ជើងក្រានកំដៅម្ហូប

chauffer *v.t.* កំដៅ;ដុតបង្កំ ។ *Fig.* & *fam.* បង្កំឲ្យលឿន (ឧ. chauffer une affaire) *v.i.* ឡើងក្តៅ (ឧ. le bain chauffe); ស្រើប ។ *Fam.* បង្កំ (chauffer des candidats)

chaufferette *n.f.* ប្រដាប់កំដៅជើង; ប្រដាប់កំដៅ

chaufferie *n.f.* កន្លែងដុត (រោងច័ក្រ); បន្ទប់ដុតភ្លើង (នាវា)

chauffeur *n.m.* អ្នកថែភ្លើង (នាវា); អ្នកបើករថយន្ត

chauffeuse *n.f.* កៅអីអង្គុយអាំងភ្លើង; ស្រីអ្នកបើករថយន្ត

chauffoir *n.m.* សាលកំដៅឬអាំងភ្លើង

chaufournier *n.m.* អ្នកដុតកំបោរ

chaulage *n.m.* ការដាក់កំបោរក្នុងដី

chauler *v.t.* លាបទឹកកំបោរ;ដាក់កំបោរក្នុងដី (ដើម្បីធ្វើជាជី)

chaumage *n.m.* ការបោចជញ្ជ្រាំង;រដូវបោចជញ្ជ្រាំង

chaume *n.m.* ចំបើង;ស្បូវ;ជញ្ជ្រាំង ។ *Fam.* ផ្ទះស្បូវ

chaumer *v.t.* & *i.* បោចជញ្ជ្រាំង

chaumière *n.f.* ផ្ទះស្បូវ

chaumine *n.f.* ផ្ទះស្បូវតូច (ឧ. une chaumine de bûcheron)

chaussant,e *a.* ដែលពាក់ស្រួល(ស្រោមជើង ឬ ស្បែកជើង)

chausse *n.f. pl.* ខោម្យ៉ាង ។ n'avoir pas de chausses រកខោស្លៀកគ្មាន (ក្រណាស់)។ tirer ses chausses ណាត់ជើងខោរត់ (រត់យ៉ាងលឿន) ។ porter les chausses មានអំណាចលើគ្រួសារ ។ avoir la clef de ses chausses ចិត្តសមល្មមលែងត្រូវកែតហើយ ។ être après les chausses de quelqu'un តាមយាយីមិនឈប់ឈរ ។ tenir quelqu'un au cul et aux chausses តាមឃ្លាំមើលអ្នកណាមួយមិនឲ្យដាច់ ។ faire dans ses chausses ខ្លាច ឬ ភ័យណាស់ ។ prendre son cul pour ses chausses ច្រឡំយ៉ាងខ្លាំង ។ y laisser ses chausses ស្លាប់(បោលភ្លឹង) នៅកន្លែងនោះ

chaussée *n.f.* ទំនប់ទឹក; ថ្នល់លើក; ទ្រូងផ្លូវ

chausse-pied *n.m.* ស្លាបព្រាពាក់

ស្បែកជើង (*pl.* des chausse-pieds)

chausser *v.t.* បំពាក់ស្រោមជើងឬស្បែកជើង;ធ្វើ ឬ ផ្គត់ផ្គង់ស្បែកជើង។ chausser ses lunettes ពាក់វ៉ែនតាឲ្យល្មមច្រមុះ ។ chausser une plante លើកដីទប់ជុំវិញដើមឈើ ។ *v.t.& i.* ត្រូវជើងល្មម(ឧ. ce soulier vous chausse parfaitement)

chaussette *n.f.* ស្រោមជើងខ្លី

chausseur *n.m.* អ្នកធ្វើ·លក់ឬដូសជុលស្បែកជើង

chausson *n.m.* ស្បែកជើងសំពត់; ការទាត់ធាក់គ្នា

chaussure *n.f.* ស្បែកជើង,ស្រោមជើង។ *loc. fam. fig.* chaussure à tout pied របស់រយ ។ trouver une chaussure à son pied រកស្រុសបានលើឈើងាប់(ប្រទះលើរបស់ដែលគេត្រូវការ) ។ avoir un pied dans deux chaussures ចង់ទៅខាងណាក៏បាន (បានផលទ្វិចគ្នា) ។ *Prov.* cordonnier, pas plus haut que la chaussure កុំនិយាយឲ្យហួសសមត្ថកិច្ចខ្លួន

chauve *a.* ទំពែក (ឧ. crâne chauve)។ *Par ext.* ត្រងិល(ឧ.mont chauve) ។ *Prov.* l'occasion est chauve ឱកាសចង្អៀតចង្អល់ពិបាកចាប់យកណាស់

chauve-souris *n.f.* ជ្រឹង, ប្រចៀវ

chauvin,e *n.* អ្នកស្នេហាជាតិហួសពេក

chauvinisme *n.m.* ការស្នេហាជាតិហួសពេក

chaux *n.f.* កំបោរ ។ chaux vive កំបោររស់ ។ chaux éteinte កំបោរងាប់ ។ lait de chaux ម.ព. lait។ chaux grasse កំបោរហើម (កើនទំហំដោយស្រូបទឹក)។ chaux maigre កំបោរមិនហើម ។ eau de chaux ទឹកជាតិកំបោរ

chavirement *n.m.* ការក្អូក ឬ ក្រឡាប់

chavirer *v.i.* ក្អូក,ក្រឡាប់,លិច(នាវា) ។ *Fig.* បង្កើតវិបរិត

cheddite *n.f.* គ្រឿងផ្ទុះម្យ៉ាង

chef *n.m.* ក្បាល, ប្រមុខ, ប្រធាន, មេ, នាយ ។ chef de l'armée នាយកងទ័ព។ chef de bataillon នាយកងវរសេនាតូច។ chef de brigade នាយកងពលតូច (កងទ័ព); នាយត្រួត (នគរបាល) ។ chef de bureau នាយការិយាល័យ។ chef de chau-

tier នាយការផ្សាន ។ chef de clinique នាយមន្ទីរពេទ្យបាល។ chef de compagnie នាយកងអនុសេនាធំ ។ chef de contrôle នាយត្រួតត្រា។ chef de division នាយកងពលធំ ។ chef de dragueur នាយនាវាខ្ទាំ ។ chef d'équipe នាយយុគន្ធ។ chef de gare នាយស្ថានីយ៍ ។ chef de groupe នាយកង។ chef de quart នាយវេន ។ chef de régiment នាយកងវរសេនាធំ ។ chef de section នាយកងអនុសេនាតូច(កងទ័ព); នាយផ្នែក។ chef de service នាយក្រុម ។ chef de service administratif នាយក្រុមរដ្ឋបាល ។

Loc.adv. en chef ក្នុងឋានៈជាមេ ឬ ជានាយ ។de son chef ដោយចិត្តឯង, ដោយអំណាចឯង

chef-d'œuvre *n.m.* ស្នាដៃឯក (*pl.* des chefs-d'œuvre)

chefferie *n.f.* នាយដ្ឋាន[នា-យ៉ក់-ឋាន]

cheffesse *n.f.Fam.* នាយស្រី (ឧ. cheffesse de rayon)

chef-lieu *n.m.* ទីប្រជុំ(នៃខេត្តឬស្រុក) (*pl.* des chefs-lieux)

cheftaine *n.f.* នាយិកា(ស្រីនាយបុគ្គការយុវជន)

chéiroptères [Ké-i] *n.m.pl.* ម.ព. chiroptères

chéloniens [Ké-lo-nyin] *n.m.pl.* កច្ឆបសត្វ [ក័ច-ឆៈ-ប៉ៈ–], សត្វពួកអណ្តើក

chemin *n.m.* ផ្លូវ,ផ្លូវដើរ។ *Par ext.* ចម្ងាយ ។ *Fig.* ចរិយាបថ ។

Loc. div. chemin de velours, chemin de fleurs, chemin sur une pelouse *Fig.* ផ្លូវងាយ, ផ្លូវស្រួល ។ chemin des écoliers *Fig.* ផ្លូវវៀង ។ chemin du paradis ផ្លូវឡើងឋានសួគ៌ (ផ្លូវពិបាក) ។ passer son chemin មិនឈប់; *au fig.* មិនចូលដៃនឹងគេ ។ aller son chemin, son droit chemin ធ្វើតាមគ្រោងការរបស់ខ្លួន (មិនងាកបែរតាមអ្នកណា)។ aller son chemin, son bonhomme de chemin ទៅមុខសន្សឹមៗធិរាប។ ne pas aller, ne pas y aller par quatre chemins ធ្វើត្រង់ៗ (គ្មានពង្វាង ឬគ្មានឧបាយកល)។ suivre le bon

chemin, être dans le bon chemin ដើរផ្លូវត្រូវ។ être en bon chemin ជិតបានសម្រេចហើយ ។ s'arrêter, demeurer en bon chemin, dans son chemin, à mi-chemin បោះបង់កិច្ចការកណ្ដាលផ្លូវ ។ faire du chemin ជឿនទៅមុខ; *au fig.* បានចម្រើន។ faire son chemin បានសម្រេច, បានស្ថានភាពល្អ។ montrer le chemin បង្ហាញផ្លូវ, ឲ្យតម្រាប់ ។ trouver quelqu'un sur son chemin មានអ្នកឯណាមួយមកប្រឆាំង ។ trouver des pierres en son chemin ប្រទះឧបសគ្គ។ mener quelqu'un par un chemin où il n'y a pas de pierres តាមធ្វើបាបអ្នកឯណាមួយ ។

chemin battu ផ្លូវគេធ្លាប់ដើរ; *au fig.* អ្វីៗ ដែលគេធ្លាប់ធ្វើ ឬ ធ្លាប់ដឹងហើយ ។ grand chemin ផ្លូវធំតាមជើងគោក; *au fig* ផ្លូវត្រូវ (l'instruction est le grand chemin de la civilisation)។ voleur de grand chemin ចោរប្លន់ផ្លូវ ។ chemin de traverse ផ្លូវកាត់ ។ chemin de fer អយស្ម័យយាន [អៈ-យៈ-ស្ម័យ-]។

Astr. chemin de Saint Jacques គន្លងដំរីស (ម.ព. voie lactée ក្នុងពាក្យ lacté ផង)។

chemin faisant, en chemin *loc.adv.* កណ្ដាលផ្លូវ; តាមផ្លូវ។ en chemin de *loc.pré.* កំពុងតែ

Prov. bonnes terres, mauvais chemins ដីល្អផ្លូវអាក្រក់ (ដីមានជីជាតិធ្វើជាផ្លូវមិនល្អទេ) ។ à chemin battu il ne croit point d'herbes ផ្លូវដើរច្រើន ស្មៅរេច; ជំនួញណាមានគេធ្វើច្រើនគ្មានផលទេ ។ tout chemin mène à Rome មានមធ្យោបាយច្រើនដើម្បីសម្រេចគោលបំណងមួយ។ qui trop se hâte reste en chemin តូងតាំងដេកផ្លូវ ស្លូវៗដល់ផ្ទះ

chemineau *n.m.* កម្មករស្វែងរកការតាមផ្លូវ; យាចក (អ្នកដើរសូមទាន)

cheminée *n.f.* ឧសុមកោដ្ឋក [អ៊ុ-សុ-ម៉ៈ-កោត] (បន្ទប់មានជើងក្រានដុតភ្លើងបង្ហុយឲ្យមានចំហាយក្ដៅសម្រាប់ការពាររងាជាដើម); បំពង់ភ្លើង; លំផ្លង ។ agir sous la cheminée ធ្វើដោយ

សម្គាត់

cheminement *n.m.* ការដើរ;ការចូលជិតសត្រូវ

cheminer *v.i.* ដើរ,ធ្វើរ; ពានទៅប្រយ័ត្ន; ចូលជិតសត្រូវ

cheminot *n.m.* ភ្នាក់ងាររថយន្តយាន

chemise *n.f.* អាវស៊ីមីស, អាវទ្រនាប់; ស្រោម

chemiser *v.t.* បំពាក់ស្រោម

chemiserie *n.f.* កន្លែងធ្វើ ឬ លក់អាវទ្រនាប់

chemisette *n.f.* អាវស្រីឃ្យ៉ុង

chemisier,ère *n.* អ្នកធ្វើ ឬ លក់អាវទ្រនាប់ ។ *n.m.* អាវស្រីឃ្យ៉ុង

chenal *n.m.* ប្រឡាយ, ព្រែង, ព្រែក

chenapan *n.m.* មនុស្សពាលព្យៀត, មនុស្សខូច

chéneau *n.m.* រាងស្បូវ

chenevière *n.f.* ចំការខ្ញុំ

chènevis *n.m.* គ្រាប់ខ្ញុំ

chenil *n.m.* សុនខាគារ [សុ-ណាក់-ខា-] (កន្លែងបង្ខាំងឆ្កែប្រមាញ់) ។ chenil militaire សុនខាគារទាហាន ។ *Fig.* ផ្ទះកខ្វក់ឬគ្មានសណ្ដាប់ធ្នាប់

chenille *n.f.* ដង្កូវមេអំបៅ(ពួកនេះច្រើនមានរោម); ប្រភេទក្រណាត់ទ្រនាប់កន្សែងក្រាស់

chenillette *n.f.* រថក្រោះតូច

chenu,e *a.* ស្កូវ (ឧ. tête chenue)។ *Fig.* ដែលមានទឹកកក (ឧ. la cime chenue du mont Blanc)។ arbre chenu ឈើគ្រាំល (ដើមឈើគ្មានមែក) ។ *Pop.* ល្អ (ឧ. du vin chenu)

cheptel *n.m.* កិច្ចសន្យាប្រវាស់សត្វ; បសុគណន៍ ។ cheptel mort គ្រឿងកសិកម្មផ្ទាល់

chèque *n.m.* មូលប្បទានប័ត្រ។chèque au porteur មូលប្បទានប័ត្រចំពោះគាហក [-ហ៊ក់]។chèque à ordre មូលប្បទានប័ត្របញ្ជា ។ cheque barré មូលប្បទានប័ត្រឆូត ។ chèque certifié មូលប្បទានប័ត្របញ្ជាក់។ chèque sans provision មូលប្បទានប័ត្រគ្មានសំវិធានធន ។ chèque de virement មូលប្បទានប័ត្របង្វែរ

chéquier *n.m.* កូនសៀវភៅមូលប្បទានប័ត្រ

cher,ère *a.* ជាទីស្រឡាញ់ (ឧ. cher à sa famille); ថ្លៃ (ឧ. étoffe chère);ដែលមានតម្លៃ(ឧ.les moments sont chers)

chercher *v.t.* រក, ស្វែងរក, ខំប្រឹង (ឧ.

chercher à plaire)។ *Pop.* ទៅដល់(ឧ. cela va chercher dans les 100 riels) ។ chercher la petite bête ល្អិតល្អន់ហួសហេតុ ។ se chercher *v.pr.* ខំប្រឹងឲ្យស្គាល់ខ្លួនឯង ។ *Prov.* qui cherche trouve អ្នកណារក មុខតែឃើញ

chercheur *n.* អ្នករក (ឧ. les chercheurs d'or)

chère *n.f* មុខ (ឧ. faire bonne chère à quelqu'un ធ្វើមុខល្អដាក់); របៀបទទួលភ្ញៀវក្នុងពេលបាយ; ម្ហូប (ឧ. faire bonne, mauvaise chère)

chèrement *adv.* ដោយស្នេហា; យ៉ាងថ្លៃ។ vendre chèrement sa vie សម្លាប់សត្រូវបានច្រើនមុននឹងស្លាប់ខ្លួនឯង

chéri,e *a.* ជាទីស្រឡាញ់ក្រៃលែង

chérif *n.m.* សេរីហ្វ, ខត្តិយវង្សអារ៉ាប

chérir *v.t.* ស្រឡាញ់ជាទីបំផុត (ឧ. chérir sa patrie)

cherté *n.f.* តម្លៃខ្ពស់ (ម្ហូប)

chétif,ive *a.* ខ្សោយ (ឧ. les exercices physiques conviennent aux enfants chétifs); តិចតួច (ឧ. chétive récolte); គ្មានតម្លៃ

chétivement *adv.* យ៉ាងខ្សោយ, យ៉ាងតិចតួច

cheval *n.m.* សេះឈ្មោល, សេះ (cri: le cheval hennit); សាច់សេះ ។ cheval pur sang សេះពូជសុទ្ធ ។ cheval de bataille សេះសង្គ្រាម; *au fig.* ស្នៀតជជែក ដែលគេបញ្ចេញគ្រប់ពេល ។ cheval de course សេះប្រណាំង ។ cheval de relais សេះបន្លាស់ (តាមផ្លូវឆ្ងាយ) ។ cheval de carosse សេះអូសរទេះ; *au fig. & fam.* មនុស្សល្ងង់ហើយសំដីគគ្រោះគគ្រើម ។ cheval de bât សេះបន្ទុក; *au fig.* អ្នកទទួលធ្វើការធ្ងន់;មនុស្សសំដីគគ្រោះគគ្រើម។

à cheval ដោយជិះសេះ(ឧ. se promener à cheval);ដោយប្រើសេះនាំយកមក(ឧ.écrire à quelqu'un une lettre à cheval) ។ monter à cheval ជិះសេះ ។ à cheval sur ដោយជិះស្រកតរពីលើ (ឧ. se mettre à cheval sur un mur); ទាំងពីរខាង (ឧ. mettre sa troupe à cheval sur une route, sur un fleuve) ។

Fig. à cheval sur ដោយយល់ច្បាស់; ដោយអាងមាំលើ (ឧ. être à cheval sur son droit អាងយ៉ាងមាំលើសិទ្ធិរបស់ខ្លួន)

Loc. div. homme de cheval, gens de cheval អ្នកចូលចិត្តជិះសេះ ។ fièvre, médecine, remède de cheval គ្រុន, ឱសថខ្លាំង ។ être mal à cheval មានជំហរមិនរឹង ។ mettre quelqu'un à cheval បង្ហាត់ជិះសេះ; *au fig.* ជួយផ្គុំផ្ដើម ។ *Fig.* n'avoir ni cheval ni mule ខ្លួនទទេ; គ្មានធនធានសោះ ។ tirer quelqu'un à quatre chevaux ចងនឹងសេះបួនឲ្យហែក (មនុស្សទោស) ។ monter sur de grands chevaux ខឹងច្រឡោត ។ brider son cheval par la queue ទឹមសេះពីកន្ទុយ (ធ្វើការច្រាស) ។ fermer l'écurie quand les chevaux sont dehors ប្រយ័ត្នខុសពេល ។ c'est un cheval à l'écurie ចំណាយនេះមានរាល់ថ្ងៃ ។ c'est un cheval pour le travail, c'est un vrai cheval à la besogne មនុស្សនេះធ្វើការប្រដិតប្រដី ។ travailler comme un cheval ធ្វើការដូចគោ (ធ្វើការច្រើន) ។ cela ne se trouve point dans le pas d'un cheval របស់នោះពិបាករកណាស់ ។

Arg. cheval de retour អ្នកប្រព្រឹត្តខុសក្នុងបទដដែលទៀត ។ *Gymn.* cheval de bois សេះឈើ (សម្រាប់ហាត់លោត) ។ cheval-arçons សេះឈើមានដៃកាន់ ។ *Ichtyol.* cheval marin ត្រីសេះ(ត្រីសមុទ្រម្យ៉ាងតូចរូបរាងដូចសេះ) ។

Prov. quand le foin manque au râtelier, les chevaux se battent ការខ្វះប្រាក់ធ្វើឲ្យប្ដីប្រពន្ធឈ្លោះគ្នា ។ il n'est si bon cheval qui ne bronche ម.ព. broncher ។ à jeune cheval vieux cavalier សេះស្លាវត្រូវការអ្នកជិះប្រសប់ ។ à méchant cheval bon éperon ក្នុងកាលៈទេសៈពិបាកត្រូវប្រិតប្រៀនឲ្យប៉ុងម៉ាត់ ។ à cheval hargneux il faut une écurie à part មនុស្សកំណាចត្រូវឲ្យនៅឆ្ងាយពីគេ ។ il fait tou-

jours bon tenir son cheval par la bride យើងត្រូវត្រួតមើលកិច្ចការរបស់យើងជានិច្ច (ត្រូវនឹងសុភាសិតខ្មែរថា ប្រហែសធ្លាក់ ប្រយ័ត្នគង់)។ l'œil du maître engraisse son cheval កិច្ចការរបស់ឯង ត្រូវមើលខ្លួនឯង (មានក្នុងសាស្ត្រាច្បាប់ ថា ទុកចិត្តខ្ញុំឲ្យដាក់ ស្មើភ្នែកខ្វាក់ទាំងសងខាង ឲ្យកូនគន់មើលគាង ស្មើភ្នែកម្ខាង ពុំពេញពីរ) ។ à cheval donné on ne regarde pas à la bouche (à la dent, à la bride, etc...) យើងមិនត្រូវរិះគន់របស់ដែលគេឲ្យទេ ។ changer ឬ troquer son cheval borgne contre un cheval aveugle ម.ព. aveugle

chevaler *v.t.* ទល់ (ឧ. chevaler un mur)

chevaleresque *a.* ដែលមានចិត្តទូលាយ

chevaleresquement *adv.* ដោយចិត្តទូលាយ

chevalet *n.m.* ជ្រោង; ជើងក្ដារខៀនបញ្ឈរ; យ៉ងទ្រ

chevalier *n.m.* សឺវ៉ាលីយេរ, អស្សឫទ្ធិ (គ្រឿងឥស្សរិយយស)។ chevalier d'industrie អ្នករកស៊ីកញ្ឆក់កញ្ឆៀត

chevalière *n.f.* ចិញ្ចៀនក្រា

chevaline *a.* នៃសេះ (ឧ. bête, race chevaline)

cheval-vapeur *n.m.* ហយពល [ហៈ-យៈ-ពល់] (កម្លាំងសេះ)

chevauchée *n.f.* ទស្សនាការដោយសេះ; ល្បើក (ចម្ងាយដែលសេះឬសត្វឯទៀតរត់បានគ្មានឈប់)

chevauchement *n.m.* ការជិះសេះ; ការជិះប្រកតាវ

chevaucher *v.i.* ជិះសេះ; ជិះប្រកតាវ; គងលើគ្នា(ដូចក្បឿង)(ឧ. ces tuiles ne chevauchent pas bien)

chevau-léger *n.m.* ទាហានទ័ពសេះជាក់ក្នុងសតវត្សទី ១៦ (*pl.* des chevau-légers)

chevelu,e *a.* ដែលមានសក់ពេញ; ដែលមានសក់វែង

chevelure *n.f.* សក់ (ទាំងក្បាល); កន្ទុយផ្កាយ

chevet *n.m.* ក្បាលគ្រែ; ខ្នើយខប ។ livre de chevet សៀវភៅដែលអានញយៗ(សៀវភៅបែបនេះគេដាក់ខាងក្បាលដំណេកជានិច្ច)។ épée de chevet ដាវដែលដាក់ជិតដៃជានិច្ច ។

Fig. ពំនាក់

chevêtre *n.m.* រោគ;សំពត់រណ្ដា;ប្រឡៀក

cheveu *n.m.* សក់។ *Fig.* se prendre aux cheveux ប្រកែកគ្នា ។ faire dresser les cheveux ធ្វើឲ្យព្រឺក្បាល ។ ne tenir qu'à un cheveu ជិត (នៅតែប៉ុនសរសៃសក់ទៀត)។raisonnement tiré par les cheveux វិចារណកិច្ចមិនសមហេតុផល ។ saisir l'occasion aux cheveux ឆ្លៀតឱកាសយ៉ាងប្រញាប់ ។ fendre, couper un cheveu en quatre សក់មួយសរសៃ ញៀកជាជំប់ ។ *Pop.* se faire des cheveux កើតទុក្ខ, ខ្វល់ខ្វាយ។ avoir mal aux cheveux ឈឺក្បាល

chevillard *n.m.* អ្នកលក់សាច់ស្រស់

cheville *n.f.* សន្លង់; ទំពក់ក្បួរ, ភ្លោកជើង ។ ne pas arriver à la cheville de quelqu'un មិនដល់កែងជើងគេទេ(តាញ់គេឆ្ងាយណាស់) ។ cheville ouvrière ទំពក់សណ្ដោង; *au fig.* ដើមហេតុ; មេដំណើរ (ឧ. il est la cheville ouvrière de cette entreprise)

cheviller *v.t.* ស្នង់ភ្ជាប់គ្នា;បំពេញដោយពាក្យឥតប្រយោជន៍ ។ avoir l'âme chevillée au corps អាយុវែង, អាយុវែង

chevillette *n.f.* សន្លង់តូច

chevir *v.i.* បានឈ្នះ (ឧ. nous n'en saurions chevir)

chèvre *n.f.* ពពែញី (cri: la chèvre bêle ; ពពែឈ្មោលហៅថា: le bouc); ម៉ាស៊ីនលើកវត្ថុធ្ងន់ ។ ménager la chèvre et le chou ធ្វើឲ្យបានស្រួលទាំងពីរខាង

chevreau *n.m.* កូនពពែ;ស្បែកកូនពពែ

chevreter ឬ **chevretter** *v.i.* កើតកូន (ពពែ)

chevrette *n.f.* ពពែញីជំទង់; ប្រើសញី

chevreuil *n.m.* ប្រើស (ប្រើសជំទង់ហៅថា: le faon)

chevrier,ère *n.* គង្វាលពពែ

chevrillard *n m.* កូនប្រើស

chevron *n.m.* ផ្ទាន; បានសក្តិពាក់នៅដៃអាវ

chevronner *v.t.* វាយផ្ទាន

chevrotain,chevrotin *n.m.* ឈ្លូស

chevrotant,e *a.* ដែលញ័រ (សំឡេង)

chevrotement *n.m.* ការច្រៀង ឬ និយាយ:ដោយសម្លេងញ័រ; សម្លេងញ័រ

chevroter *v.i.* ច្រៀងឬ និយាយដោយសម្លេងញ័រ; ស្រែក (កូនពពែ)

chevrotin *n.m.* ស្បែកកូនពពែ

chevrotine *n.f.* គ្រាប់ព្រាយ

chewing-gum [chouign-gœm] *n.m.* (ពាក្យអង់គ្លេស) ស្ករកៅស៊ូ (សម្រាប់ទំពា)

chez *pré.* នៅផ្ទះ(ឧ. chez moi);នៅស្រុក (ឧ. chez les Turcs); ក្នុងសម័យ (ឧ. chez les Anciens); ក្នុងវង្សត្រកូល (ឧ. servir chez un prince)។

Par ext. ស្រុកខ្ញុំ(ស្រុកកំណើតរបស់ខ្ញុំ)។ *Fig.* chez lui tout plait តាមគាត់អ្វីក៏ល្អដែរ ។ c'est chez lui une habitude គឺជាទម្លាប់របស់គាត់ ។ pour un fourbe chez vous la pitié trouve place លោកនេះតែមានមេត្តាលើមនុស្សពុតអាក្រក់ ។

Subst. un chez moi ផ្ទះខ្ញុំ

chez-soi *n.m. inv.* ទីលំនៅ, ផ្ទះ។ avoir un chez-soi មានលំនៅខ្លួនឯង

chialer *v.i. Pop.* យំ

chiasma *n.m. Anat.* ភាពខ្វែង(ឧ. le chiasma des nerfs optiques)

chiasse *n.f.* ពពុះលោហធាតុ; អាចម៍រុយ, អាចម៍ដង្កូវ

chibouque *n.f.* ឬ **chibouk** *n.m.* ខ្សៀវវែង (ប្រើក្នុងប្រទេសទួរគី)

chic *n.m. Fam.* ឫកខ្វែង (ឧ. avoir du chic)។ *a.* សង្ហា(ឧ. femme chic; robes chics)។*Fam.*ស្មៀង, ចិត្តទូលាយ (ឧ. se montrer chic envers quelqu'un)។de chic ដោយប្រឌិត, គ្មានគំរូ

chicane *n.f.* ក្ដី (ឧ. aimer la chicane); ជម្លោះ (ឧ. chercher chicane)

chicaneau *n.m. Fam.* អ្នកដូញក្ដី, អ្នកសន្សំរឿង

chicaner *v.t.* តវ៉ាដោយគ្មានហេតុផល; ស្ដីបន្ទោសដោយការបួលបង្កាច់; ដូញក្ដី, សន្សំរឿង

chicanerie *n.f.* ជម្លោះ

chicaneur,euse *a.&n.* អ្នកដូញក្ដី, អ្នកសន្សំរឿង

chiche *a.* ត្បិតត្បៀត; កំណាញ់; ស្វិតស្វាញ; ហោកទាប(ឧ. un homme, un dîner chiche, être chiche de compliments)

chichement *adv.* ដោយត្បិតត្បៀត; ដោយកំណាញ់

chichi *n.m.* សក់ក្លែង ។ *Pop.* faire du chichi គរ៉ា; លួងលោម ។ *pl. Fam.* ការធ្វើឫកពា ។ faire des chichis ធ្វើឫកពា

chichiteux,euse *a.Fam.* ដែលធ្វើឫកពា

chicorée *n.f.* សាឡាត់ក្រញាញ់

chicot *n.m.* ជើងជង់(គល់ឈើដែលគេកាប់ទុកឲ្យសល់នៅដី); ឫសធ្មេញបាក់

chien,enne *n.* សុនខ-ខី,ឆ្កែ;អ្នកចូលចិត្តជម្លោះ; ឆ្កែ(មនុស្សទាបថោក ឬ ខ្ញុំកញ្ជះគេ(ឧ. être le chien de la maison); មនុស្សកំណាញ់(ឧ. patron qui est trés chien) ។ chien de chasse ឆ្កែប្រមាញ់ ។ chien de berger ឆ្កែគង្វាល ។ chien courant ឆ្កែប្រដេញសត្វ ។ chien allant ឆ្កែកៀងសត្វ ។ chien couchant ឬ chien d'arrêt ឆ្កែស្រង់ក្លិនសត្វ ។ chien babillard ឬ clabaud ឆ្កែដែលព្រុសឥតហេតុ ។ chien secret ឬ furet ឆ្កែតាមក្លិនឥតព្រុស ។ chien fou ឆ្កែកញ្ជ្រោលតាមសត្វ(ដូចខឹង) ។ chien étruffé ឆ្កែខ្វក ។ chien coiffé ឆ្កែត្រចៀករួបគ្របច្រមុះ ។ chien d'aiguail ឆ្កែប្រមាញ់ពេលព្រឹក (ប្រដេញសត្វបានស្រួលតែពេលព្រឹក) ។ chien de haut jour ឆ្កែប្រមាញ់ថ្ងៃត្រង់ ។ chien de haut nez ឆ្កែប្រមាញ់ថ្ងៃរសៀល ។ chien de nez fin ឆ្កែប្រមាញ់ថ្ងៃក្ដៅ ។ chien de nez dur ឆ្កែច្រមុះមិនវៃ (តែបាត់ដានសត្វហើយរកវិញក្រឃើញ) ។ chien de tête ឬ de bonne affaire ឆ្កែក្លាហានហើយខ្លាំង ។ *Fig.* chien de chasse អ្នកលួចឃ្លាំឬលួចយកការណ៍ឲ្យអ្នកឯទៀត ។ chien couchant ជនអ្នករាប់អានឬគួរសមហួសពេក ។

Fam. chien de cours អនុរក្សក្នុងវិទ្យាល័យ ។ chien de caserne ឬ chien du quartier ព្រឹទ្ធបាល ។ chien de bord អនុបញ្ជា(ដែលនៅលើនាវាពាណិជ្ជ)។ chien du commissaire លេខាធិការនៃស្នងការ។

Arg. avoir du chien ស្រាប់តែទឹកភ្នែកចង់ធ្វើសិល្បករ (ក្នុងរបាំ); មានឫកពាឬរាងរៀលល្អគួរឲ្យស្រឡាញ់ (ចំពោះស្ត្រី) ។ piquer un

chien(ឬson chien)ដើក។chien perdu អត្ថបទឬឃ្លាសម្រាប់បំពេញចន្លោះក្រដាស(ក្នុងការរៀបពុម្ពអក្សរ)។ sacré chien រូជីវ៍ (សុក) ខ្លាំង ។

Techn. ច្រាសរឹងសម្រាប់ដុសលាងសម្លៀកបំពាក់; ក្បាលឆ្កែ(កាំភ្លើង); កូនឆ្កែ (ទប់ធ្មេញកង់គ្រឿងច័ក្រ) ។

Loc. div. être maigre comme un chien fou ស្គមកំព្រឹង (ស្គមណាស់) ។ vivre comme un chien ឬ vivre en chien រស់នៅដោយខ្ជីខ្ជា ឬ រស់នៅដោយវេទនា ។ mourir comme un chien ស្លាប់ដូចខ្មោចឆ្កែ(ស្លាប់តែម្នាក់ឯងឥតអ្នកណាជួយថែរក្សា ឬ ឥតបានទទួលធម៌)។ rompre les chiens បំបែរការសន្ទនាចេញពីរឿងដែលអាចឲ្យមានគ្រោះថ្នាក់។ avoir du crédit quelque part comme un chien à la boucherie គ្មានគេរាប់អាន។ jeter un os à la geule d'un chien pour le faire taire សូកកុំឲ្យនិយាយ(ដោយខ្លាចបែកការណ៍) ។ jeter quelque chose au chien ប្រើខ្ជះខ្ជាយ ។ ne pas donner sa part au chien មិនបោះបង់ចំណែកខ្លួន, មិនលះបង់ទាមទារ ។ ne pas attacher ses chiens avec des saucisses គិតណាស់ (មិនខ្ជះខ្ជាយ, មិនហ៊ានឲ្យខាតបន្តិចបន្តួចសោះ) ។ écorcher son chien pour en avoir la peau សម្លាប់ឆ្កែយកស្បែក (បោះបង់របស់ល្អទៅយករបស់ឥតតម្លៃព្រោះឆ្កែរស់មានប្រយោជន៍ ឯស្បែកឆ្កែគ្មានប្រើការទេ) ។ fréquenter le chien et le chat ទៅមករាប់រកជនគ្រប់ប្រភេទ ។ promettre (ឬ garder) à quelqu'un un chien de sa chienne ប្រកាសថានឹងសងសឹកវិញដោយពេញទី ។ ne valoir pas les quatre fers d'un chien គ្មានតម្លៃអ្វីសោះ ។ avoir été mordu par un chien enragé ខឹងច្រើន, ឆាប់ខឹង ។ ce sont deux chiens après l'os គឺជាមនុស្សពីរនាក់ដែលដណ្ដើមដំណែងឬវត្ថុតែមួយ។ il y a trop de chiens après l'os មានអ្នកត្រូវការច្រើនក្នុងរឿងនេះ។ c'est une charrue à chiens គឺជាសមាគមដែលឥតបានធ្វើអ្វីជាប្រយោជន៍។c'est

un chien au grand collier ជាអ្នកធំ, ជាអ្នកមានអំណាច ។ c'est beau chien s'il voulait mordre ជាមនុស្សឈាក់ពុត (ដែលសំដែងតែអាការៈក្រៅ)។ c'est un chien qui aboie à la lune ជាអ្នកយកពងមាន់ទៅជាន់នឹងថ្ម (ជាអ្នកប្រឆាំងដោយឥតផលនឹងអ្នកខ្លាំងជាងខ្លួន) ។ leurs chiens ne chassent pas ensemble ម.ព.chasser ។ entrez, nos chiens sont liés អញ្ជើញចូលមកដោយកុំកោតញញើតអ្វី (ឥតមានគ្រោះថ្នាក់អ្វីទេ) ។ il a été à Saint-Malo, les chiens lui ont mangé l'os មនុស្សនេះស្អុយណាស់។ un chien regarde bien un évêque ជាមនុស្សដែលខឹងនឹងគេមើលមកខ្លួន។ c'est saint Roch et son chien គឺជារូបនឹងស្រមោល (មិនបែកគ្នាសោះ) ។

être chien avec quelqu'un ស្វិតស្វាញជាមួយនឹងអ្នកឯណាមួយ ។ n'être pas bon à jeter aux chiens គ្មានបានការអ្វីសោះ។ recevoir quelqu'un comme un chien dans un jeu de quille ទទួលដោយគំរោះគំរើយ ។ de chien អាក្រក់(métier de chien; mine de chien; chien de temps)។ entre chien et loup ពេលព្រលប់។ se regarder en chiens de faïence សម្លឹតសម្លក់គ្នា ។ vivre comme chien et chat មិនចេះត្រូវគ្នាសោះ (ដូចក្របីនឹងចេក) (ម.ព. chat ផង) ។ jeter, donner sa langue aux chiens (ឬ au chat) ស្បថលែងចង់យល់, លែងចង់ដឹង(ម.ព.chat ផង)។ chien de, chienne de សម្រាប់សំដែងសេចក្ដីស្អប់ខ្ពើម (ឧ. chienne de vie)។ couché en chien de fusil ដេកក្រៀន, ដេកអង្គុញជើង ។

Prov. chien hargneux a toujours l'oreille déchirée អ្នកហ៊ានស្បែកជាប អ្នកខ្លាចស្បែកជា (អ្នកហៃហ្ពោះតែងតែមានរបួសខ្លះជានិច្ច) tous les chiens qui aboient ne mordent pas ឆ្កែព្រុសមិនដែលខាំ។ qui veut noyer son chien l'accuse de la rage គេតែងតែបន្ទោសរបស់ដែលគេលែងត្រូវការ។ le chien en vie vaut mieux

que le lion mort ឆ្កែរស់ក្រាន់បើជាងសិង្ហស្លាប់, មនុស្សដែលស្លាប់លែងមានតម្លៃអ្វីសោះ។ bon chien chasse de race ឧ.ព. chasser។ un bon chien n'aboie pas à faux មនុស្សឆ្លាតមិនប្រើស្មៀតល្អឲ្យសាបឥតអំពើទេ ។ l'hôpital n'est pas fait pour les chiens មិនត្រូវញកទឹងតវ៉ាយករបស់សម្រាប់សាធារណៈមកប្រើទេ ។ il n'est chasse que de vieux chiens គ្មានអ្វីមកផ្ទឹមនឹងការពិសោធន៍របស់មនុស្សចាស់បានឡើយ ។ on ne peut empêcher le chien d'aboyer ni le menteur de mentir គេមិនអាចនឹងបង្ខំអ្នកណាមួយឲ្យចោលឬកពាក់កំណើតរបស់ខ្លួនបានឡើយ។ pendant que le chien pisse le lièvre s'en va ការភរែកបន្តិចបន្តួចអាចឲ្យខូចឱកាសល្អបាន ។ autant vaut être mordu d'un chien que d'une chienne ចំពោះការណ៍អាក្រក់ដូចគ្នា គ្មានប្រយោជន៍អ្វីនឹងរើសឡើយ ។

chiendent *n m.* ឃាសកូលចង្រៃយ៉ាង។ *Fig. & Fam.* សេចក្ដីលំបាក

chien-loup *n.m.* ឆ្កែប៉ូលិសរូបរាងដូចឆ្កែព្រៃ

chienner *v.i.* កើតកូន (ឆ្កែ)

chiennerie *n.f.* ឆ្កែទាំងឡាយ។ *Fam.* សេចក្ដីកំណាញ់ស្វិត

chiffon *n.m.* កន្ទប; វត្ថុគ្មានតម្លៃ ។ un chiffon de papier ក្រដាសដែលគេឈ្លីចោល ។ *Par ext.* អលង្ការស្រី(ឧ. parler chiffons)។ *Par anal.* ក្រដាសតូច។ *Arg.* chiffon rouge អណ្ដាត ។ balancer le chiffon rouge និយាយ

chiffonnable *a.* អាចឈ្លីចោលបាន

chiffonnage *n.m.* ការឈ្លី; សំពត់ទក់

chiffonné,e *a.* ទក់, ដែលគេឈ្លី (ឧ. étoffe chiffonnée)

chiffonnement *n.m.* ការឈ្លី; ផ្នត់អង្កាញ់

chiffonner *v.t.* ឈ្លី; បត់សំពត់យ៉ាងប្រួសប៉ា។ *Fig.* ធ្វើឲ្យស្រពន់ចិត្ត(ឧ.cette nouvelle me chiffonne)។ *v.i.* ដើររើសកន្ទបឬរបស់អ្វីតាមផ្លូវ

chiffonnier,ère *n.* អ្នកដើររើសកន្ទបឬរបស់ផ្សេងៗទៀតតាមផ្លូវ ។ *n.m.* តុដាក់របស់តូចតាច

chiffrage *n.m.* ការសរសេរជាលេខ;

ការដាក់តម្លៃ

chiffre *n.m.* លេខ; ចំនួនប្រាក់ឬតម្លៃ។ chiffre d'affaires ទឹកប្រាក់ជំនួញ (ចំនួនទឹកប្រាក់ចេញចូល) ។ អក្សរសម្ងាត់, លេខសោ។ chiffres arabes លេខបែប: 1,2,3,4,5,6,7,8,9,0 ។ chiffres romains លេខបែប: I=១, V=៥, X=១០, L=៥០, C=១០០, D=៥០០, M=១.០០០

chiffrer *v.i.* គិតលេខ ។ *v.t.* បង់លេខ (ឧ.chiffrer des pages); សរសេរជាអក្សរសម្ងាត់ (ឧ. télégramme chiffré) ។ *Fig.* មានចំនួនច្រើន

chiffreur *n.m.* អ្នកប៉ិនគិតលេខ; អ្នកប្រើអក្សរសម្ងាត់

chignon *n.m.* ផ្នួងសក់, សក់បួង

chilien,enne *a.&n.* នៃប្រទេសស៊ីលី

chi lo sa? [ki-] (qui le sait?) *loc. ital.* អ្នកណាដឹង?

chimère *n.f.* គំនិតរវើរវាយ (ឧ.se repaître de chimères)

chimérique *a.* រវើរវាយ (ឧ. esprit chimérique); មិនសមហេតុផល (ឧ. projet chimérique)

chimie *n.f.* គីមី(វិទ្យាសាស្ត្រខាងផ្សំធាតុ)។ chimie organique គីមីសរីរាង្គ ។ chimie minérale គីមីខនិជ ។ chimie structurale គីមីរចនាសម្ព័ន្ធ ។ chimie atomique គីមីបរមាណូ

chimique *a.* នៃគីមី ។ guerre chimique សង្គ្រាមខាងគីមី (ដោយប្រើឧស្ម័ន)

chimiquement *adv.* តាមរបៀបគីមី

chimisme *n.m.* ប្រតិកម្មទាំងឡាយខាងគីមី (ឧ. chimisme stomacal)

chimiste *n.m.* អ្នកគីមី

chimpanzé *n.m.* ទោចម្យ៉ាង (ឧ. le chimpanzé est un des singes le plus voisin de l'homme)

chinage *n.m.* ការជ្រលក់គាត (ឬតាធ)

chiné,e *a.* ដែលមានពណ៌ច្រើនចម្រុះគ្នា (ឧ. bas chiné)

chiner *v.t.* ជ្រលក់គាត ។ *Arg.* រិះគន់

chineur,euse *n.Pop.* ឈ្មួញរបស់ចាស់; អ្នកចំអក

chinois,e *a.&n.* ចិន, ដូចចិន។ ombre chinoise ម.ព. ombre ។ *n.m.* ភាសាចិន

chinoiserie *n.f.* គ្រឿងតាំងមកពីប្រទេសចិន; វិធានការសាំញ៉ាំ (ឧ. les chinoiseries administrati-

ves)

chinure *n.f.* ភាពសំគាល់ពណ៌ច្រើនចម្រុះគ្នា

chiot *n.m.* កូនឆ្កែ

chiourme *n.f.* អ្នកជាប់ទោសឧក្រិដ្ឋទាំងឡាយមួយគុក

chiper *v.t.Fam.* លួច, ឡឹប (ឧ.chiper sa place à quelqu'un)

chipeur,euse *n. Pop.* អ្នកលួច, អ្នកឡឹប

chipotage *n.m.* ការទំពាញ៉ំៗ (ទំពាបន្តើរៗ)

chipoter *v.i.Fam.* ទំពាញ៉ំៗ; ធ្វើការចំរៀក; ធ្វើឲ្យពិបាក

chipoteur, euse ឬ **chipotier, ère** *n.&a.* អ្នកទំពាញ៉ំៗ;អ្នកធ្វើការចំរៀក

chique *n.f.* ដុំ(ឧ. une chique de pain); កូនពែង; កញ្ចុកថ្នាំ; មួមួយម៉ាត់ ។ *Pop. & fig.* ភាពស្រវឹងស្រៀងៗ;ភាពមិនសប្បាយចិត្ត។couper la chique à quelqu'un និយាយកាត់ផាង ។ avaler sa chique ស្លាប់។ ça ne vaut pas une chique របស់នោះឥតបានការអ្វីសោះ

chiqué *n.m.Fam.* ការក្លែង; ការកំឡា

chiquenaude *n.f.* ការផ្ទាត់ម្រាមដៃ

chiquer *v.i.* ទំពាម្លូ-ស្លាឬថ្នាំ។*Fig.*ស៊ី។ *v.t.* chiquer du tabac ពុកថ្នាំ

chiquet *n.m.* ភាគតូច

chiqueur *n.m.* អ្នកទំពាម្លូ-ស្លា ឬ ថ្នាំ

chiromancie *n.f.* ហស្តលេខាវិជ្ជា (វិជ្ជាទាយបាតដៃ)

chiromancien,enne *n.* ហស្តលេខាវិទូ (គ្រូទាយបាតដៃ)

chiroptères ឬ **chéiroptères** *n.m. pl.* ចម្មបក្សី (សត្វដែលមានស្បែកភ្ជាស្លាបនឹងចប្រជៀវ - ជ្រឹង ជាដើម)

chirurgical,e,aux ឬ **chirurgique** *a.* នៃសល្យសាស្ត្រ

chirurgie *n.f.* សល្យសាស្ត្រ,សល្យកម្ម (ការវះកាត់)។chirurgie dentaire សល្យសាស្ត្រទន្តិក

chirurgien *n.m.* សល្យពេទ្យ(ពេទ្យខាងវះកាត់) ។ chirurgien dentiste សល្យពេទ្យទន្តិក

chitine [ki-] *n.f.* គីទីន (សារជាតិនៃសំបកក្តាម ឬ ស្នូកអណ្តើក)

chitineux,euse *a.* នៃគីទីន (ឧ. enveloppe chitineuse)

chiure *n.f.* អាចម៍រុយ (ឬជាណកសត្វ)

chi [ki] **va piano, va sano** (qui va doucement, va sûrement) *Prov. ital.* សន្សឹមៗ

បំបោល ក្រែងពុំដល់ដូចប្រាថ្នា

chlore *n.m.* ក្លរ

chlorophylle *n.f.* ហរិតជាតិ [ហៈ-រិ-តៈ—] (ធាតុខៀវក្នុងស្លឹកឈើ)

chlorure *n.m.* ក្លរួ ។ chlorure de sodium ក្លរួដឺសូឌីយ៉ូម (អំបិល)

choc *n.m.* ការប៉ះទង្គិចឬរណ្ដំគ្នា (ឧ. le choc des verres); ការប្រឡូក (ឧ.soutenir le choc de l'ennemi); វិបល្លាស;ការប្រឆាំង (ឧ. le choc des idées)

chocolat *n.m.* សូកូឡា (ម្សៅកាកាវនឹងស្ករ) ។ *Pop.* être chocolat ត្រូវគេចាប់បាន

chocolaterie *n.f.* កន្លែងធ្វើសូកូឡា

chocolatier,ère *n.&a.* អ្នកធ្វើ ឬ លក់សូកូឡា

chocolatière *n.f.* កំសៀវឆុងសូកូឡា

chœur *n.m.* វង់ភ្លេង,ភ្លេងនិងចម្រៀង។ en chœur *lcc. adv.* ស្រុះគ្នា

choir *v.i.* ជ្រុះ, ធ្លាក់; ធន់មិនបាន

choisi,e *a.* ជម្រើស

choisir *v.t.* ជ្រើស, ស្រាល់ជ្រើស;រើស

choix *n.m.* ការជ្រើសរើស; អំណាចជ្រើសរើស;ការបោះឆ្នោតរើស ។ n'avoir pas le choix មានតែមួយផ្លូវទេ ។ de choix សំរាំង ។ sans choix ដោយគ្មានពិចារណា ។ au choix de តាមចំណង់នៃ

cholédoque [ko-] *a.m.* canal cholédoque ប្រណាលប្រមាត់

choléra [ko-] *n.m.* អហិវាតរោគ, អាសន្នរោគ

cholériforme [ko-] *a.* ដូចអាសន្នរោគ (ឧ.diarrhée cholériforme)

cholérine [ko-] *n.f.* អាសន្នរោគស្រាល

cholérique [ko-] *a.* នៃអាសន្នរោគ ។ *n.* អ្នកកើតអាសន្នរោគ

chômable *a.* អាចឈប់សម្រាកបាន (ឧ. jour chômable)

chômage *n.m.* ពេលខ្វះការធ្វើ (ឧ. le chômage du textile); ពេលឈប់សម្រាក (ឧ.le chômage du dimanche)

chômer *v.i.* ឈប់សម្រាក; ខ្វះការធ្វើ (ឧ. cet ouvrier chôme) ។ *v.t.* ឈប់បុណ្យ (ធ្វើបុណ្យដោយឈប់សម្រាក)(ឧ. chômer un saint)

chômeur,euse *n.* អ្នកគ្មានការធ្វើ

chop *n.m.* (ពាក្យអង់គ្លេស) ឆ្អឹងជំនីរ

chope *n.f.* កែវមានដៃសម្រាប់ផឹកប៊ីយែរ (ឧ. la chope tient environ

un tiers de litre)

choper *v.t. Pop.* ម.ព. chiper ។ *Pop.* ចាប់បាន

chopin *n.m. Pop.* កំរៃ, លាភ

chopper *v.i.* ភ្លាត់ជើង, ជំពប់ជើង

choquant,e *a.* ដែលទាស់ចិត្ត ឬ ទាស់ភ្នែក; គ្រោតគ្រាត (ឧ. paroles choquantes)

choquer *v.t.* ជល់, ទង្គិច ។ *Fig.* ធ្វើឲ្យទាស់ចិត្ត ឬ ទាស់ភ្នែក; ធ្វើឲ្យអន់ចិត្ត។ choquer les verres លើកកែវទង្គិចគ្នា

choral,e [ko-] *a.* នៃភ្លេងនឹងចម្រៀង។ *n.m.* ចម្រៀងសាសនា (*pl.* des chorals)

chorégraphie [ko-] *n.f.* នាដសាស្ត្រ [នា-ដ:-], វិជ្ជារបាំ

chorégraphique [ko-] *a.* នៃរបាំ (ឧ. art chorégraphique)

choriste *n.* អ្នកចម្រៀងក្នុងវង់ភ្លេង

chorégraphie *n.f.* ទេសពិពណ៌នា (ពិពណ៌នាអំពីប្រទេសមួយ)

choroïde [ko-] *n.f. Anat.* កាឡកោស (ស្រោមខ្មៅនៃភ្នែក)

chorus [ko-rus] *n.m.* faire chorus ជាព្រមគ្នា ។ *Fig.* បន្ទរ, ជាតាម

chose *n.f.* របស់ (វត្ថុ, អ្វីៗដែលមានរូប ផ្ទុយនឹងអ្វីៗដែលគ្មានរូប) (ឧ. le mot et la chose); របស់ (មានម្ចាស់) (ឧ. c'est sa chose; être la chose de quelqu'un)។ *Fam.* អាណោះ (អ្នកអាណោះ : ចង្អុលមនុស្សដែលមិនស្គាល់ឈ្មោះ) ។

Loc. div. l'auteur des choses អាទិទេព (អ្នកបង្កើតវត្ថុគ្រប់យ៉ាង) ។ les choses humaines របស់មនុស្សលោក (អ្វីៗទាំងអស់ដែលធ្វើក្នុងបណ្ដាមនុស្ស) ។ être un peu chose កញ្ជៀតបន្តិចៗ។ être tout chose, rester tout chose ស្រឡាំងកាំង; រហ៊ឹតរហៃ។ quelque chose អ្វីខ្លះ (ឧ. il y a quelque chose de bon dans une révolution); អាហារឬភេសជ្ជៈបន្តិច (ឧ. prendre quelque chose បរិភោគអ្វីបន្តិចបន្តួច; *fam.* ត្រូវដំបង); មនុស្ស ឬ វត្ថុធំដុំគ្រាន់បើ (ឧ. c'est quelque chose que cela)។ faire quelque chose មានមុខងារ ឬ មុខរបរ; បានសម្រេច (ឧ. je pense que nous ferons quelque chose) ។ être pour

quelque chose dans ជាន់ម្ដួយខ្លះក្នុង ។ être de quelque chose à quelqu'un ជាប់សាច់ញាតិខ្លះជាមួយ ឬ មានការរាប់រកខ្លះ ។ devenir quelque chose បានធំដុំគ្រាន់បើ ។ quelque chose que អ្វីក៏ដោយដែល(ឧ.quelque chose que vous ayez promise, donnez-la)។ avoir quelque chose avec quelqu'un មានការទាស់ទែងគ្នា ។ il y a quelque chose comme មានប្រមាណជា, មានប្រហែលជា ។ sur toute chose ធំបង្អស់ (ត្រូវគិតមុនគេបង្អស់) (ឧ. sur toute chose, soyez honnête)។ toute chose cessante ភ្លាមៗ, គ្មានបង្អង់ ។ grand-chose របស់ធំដុំ (មានតម្លៃ) (ឧ. l'argent, ce n'est pas grand-chose) ។ homme ឬ femme de peu de chose ជនត្រកូលទាប(គ្មានល្បីល្បោះ)។dire le mot et la chose និយាយចំៗ, មិនកែសម្រួលពាក្យ ។ dire bien des choses à quelqu'un និយាយសរសើរ ។ faire bien les choses ធ្វើដោយកែភាយ; មិនតឿតតៀតក្នុងចំណាយ ។ la chose parle d'elle-même឴ឃើញច្បាស់ក្រឡែតដោយឯងៗ (មិនបាច់បង្ហាញ ឬ បញ្ជាក់)។

la chose publique រដ្ឋ, ប្រទេសជាតិ ។ *Dr.* chose jugée សាលក្រមអស់ជំនុំ ។ autorité de la chose jugée អាជ្ញាអស់ជំនុំ (ត្រូវមានអង្គ ៣ គឺ: ១- ដើមចោទក៏ដូចគ្នាប្ដឹងក្នុងឋានៈដូចគ្នា; ២- ដំណើររឿងដូចគ្នា; ៣- រឿងដូចគ្នា)។ en force de la chose jugée ជាអាជ្ញាអស់ជំនុំ

chou *n.m.* ស្ពៃ ។ chou pommé ស្ពៃក្ដោប ។ chou vert ស្ពៃខៀវ។ chou de Milan ស្ពៃក្រញាញ់ ។ chou-fleur ផ្កាស្ពៃ ។ chou-navet ស្ពៃមើម។ *Fig.&fam.* chou blanc លទ្ធផលសូន្យ ។ aller planter ses choux ទៅនៅស្រុកស្រែ ។ faire ses choux gras d'une chose ឆ្លៀតយកកំរៃពី

chouchou,oute *n. Fam* សំឡាញ់, សំណប់

chouchouter *v.t. Fam.* ថ្នម, ទំរើស

choucroute *n.f.* ស្ពៃជ្រក់

chouette *n.f.* មៀម

chou-fleur *n.m.* ម.ព. chou

chou-navet *n.m.* ម.ព. chou

chou-palmiste *n.m.* តម (បណ្ដូលកឈើក្នុងពួកត្នោត-ដូង-ស្លា)

chouriner *v.t. Arg.* ចាក់សម្លាប់ដោយកាំបិត

chourineur *n.m. Arg.* អ្នកចាក់សម្លាប់ដោយកាំបិត

choyer *v.t.* ថ្នាក់ថ្នម

chrestomathie [kré-sto-ma-si ឬ ti] *n.f.* ជាហ៊ាវសី [ជ៉-ហ៊-វៈ-សី], សង្គហបទ (សៀវភៅអត្ថបទសម្រាំងស្រង់យកពីការនិពន្ធផ្សេងៗដែលទុកជាបែបយ៉ាង)

chrétien,enne *n.* គ្រិស្តសាសនិក,អ្នកកាន់សាសនាគ្រិស្ត ។ *a.* នៃគ្រិស្តសាសនា ។ le roi Très Chrétien ឬ Sa Majesté Très Chrétienne មហាក្សត្រប្រទេសបារាំង

chrétiennement *adv.* តាមគ្រិស្តសាសនា

chrétienté *n.f.* បណ្ដាប្រទេស ឬ ជនកាន់គ្រិស្តសាសនា

christ *n.m.* ព្រះយេស៊ូគ្រិស្ត

christianiser *v.t.* ញុំាងឲ្យកាន់គ្រិស្តសាសនា

christianisme *n.m.* គ្រិស្តសាសនា

christmas *n.m.* (ពាក្យអង់គ្លេស)គ្រិស្តម៉ាស ឬ បុណ្យណូអែល (ម.ព. noël ផង)

chromage *n.m.* ការលាបក្រូម(លោហធាតុភ្លឺ)

chromatique *a.* នៃពណ៌

chromatisme *n.m.* ការលាបពណ៌

chrome *n.m.* ក្រូម (លោហធាតុភ្លឺ)

chromer *v.t.* លាបក្រូម (ឲ្យភ្លឺ)

chronicité *n.f.* ភាពរ៉ាំរ៉ៃ ឬតគ្រឹតគ្រើយ (រោគ) (ឧ. la chronicité d'une maladie)

chronique *n.f.* កាលប្បវត្តិ (ប្រវត្តិសាស្ត្ររៀបរៀងតាមលំដាប់កាល) (ឧ. les chroniques de Saint-Denis); ទិដ្ឋព្រឹត្តិ (ឧ. chronique politique, théâtrale, artistique, financière); មាត់ជាបមាត់ព្រាប (សំដីដែលនិយាយតៗគ្នា)

chronique *a.* រ៉ាំរ៉ៃ, ទាំ, តគ្រឹតគ្រើយ, គ្រាំគ្រែង

chroniquement *adv.* រ៉ាំរ៉ៃ, តគ្រឹតគ្រើយ, គ្រាំគ្រែង

chroniqueur,euse *n.* អ្នកកាលប្បវត្តិ; អ្នកទិភាគព្រឹត្តិ, អ្នកនិពន្ធសារព័ត៌មាន

chronologie *n.f.* កាលប្បវត្តិវិជ្ជា (ក. ឡ:-), វិទ្យាសាស្ត្រខាងកាលបរិច្ឆេទ (ឧ. la chronologie des dynasties égyptiennes)

chronologique *a.* នៃកាលប្បវត្តិវិជ្ជា; ដែលរៀងតាមកាល

chronologiquement *adv.* ដោយរៀងតាមកាល

chronométrage *n.m.* ការផ្ទៀងពេល

chronomètre *n.m.* នាឡិកាផ្ទៀងពេល

chronométrer *v.t.* ផ្ទៀងពេល (ឧ. chronométrer une course)

chronométreur *n.m.* អ្នកផ្ទៀងពេល

chronométrie *n.f.* វិធីផ្ទៀងពេល

chrysalide *n.f.* ដង្កូវក្នុងសំបុកដែលនឹងក្លាយជាមេអំបៅ

chrysocale ឬ **chrysocalque** *n.m.* ទង់ហ៊ា

chuchotement *n.m.* ការខ្សឹប

chuchoter *v.i.* ខ្សឹប។ *v.t.* និយាយខ្សឹប (ឧ. chuchoter quelques mots)

chuchoterie *n.f.* ការនិយាយខ្សឹប

chuchoteur,euse *a.&n.* អ្នកខ្សឹប; អ្នកចូលចិត្តខ្សឹប (ឧ. vieillard chuchoteur)

chuchotis *n.m.* ការខ្សឹប

chuintement *n.m.* សម្រែករៀម

chuinter *v.i.* ស្រែក (រៀម)

chut! *int.* ស្ងៀម!

chute *n.f.* ការជ្រុះ, ការធ្លាក់ (ឧ. la chute d'une pomme a révélé à Newton le système de l'univers)។ *Fig.* ការរលំ; ការវិនាស(ឧ. la chute de l'Empire); ការមិនបានសម្រេច; ចុតិ; ការខូចឈ្មោះ (ឧ. la chute d'une jeune fille)។ *Techn.* ចំនៀរ (ក្រដាស, សំពត់ ។ល។)។ *Poét.* chute de feuilles សារទរដូវ (រដូវស្លឹកឈើជ្រុះ)។ *Théât.* chute du rideau ការទម្លាក់វាំងនន (ឧ. sortir sans attendre la chute du rideau)។ chute d'eau ទឹកធ្លាក់។ chute du jour យប់។

chuter *v.i.Fam.* ជ្រុះ, ធ្លាក់

chuter *v.t.* ស្រែកឲ្យស្ងៀម (មកពីពាក្យ chut! ស្ងៀម!)

chyle *n.m.* អន្តលស:[អន់-ត:-ល:-ស:] (វត្ថុរាវពណ៌ ស ដែលជ្រាបចូលក្នុងពោះវៀន: គឺ អាហារដែលរលាយ)

chylifère *a.* ដែលនាំអន្តួលសៈ (ឧ. vaisseaux chylifères)

chylification *n.f.* អន្តួលសកម្ម [អន់-តៈ-លៈ-សៈ-ក័ម], ការបង្កើតអន្តួលសៈ

ci *adv.* នេះ ។ *loc.adv.* par-ci par-là ឯនេះខ្លះឯនោះខ្លះ។ ci-après បន្ទាប់នេះ ។ ci-contre អភិមុខ, ទល់ភ្លាមនេះ។ ci-dessous ខាងក្រោមនេះ។ ci-dessus ខាងលើនេះ។ ci-devant អតីត (ឧ. le ci-devant roi); *Subst.* អភិជនដែលត្រូវរឹប(ក្នុងសម័យបដិវត្តន៍បារាំង)។ ci-entour នៅជុំវិញនេះ ។ de-ci de-là ខាងនេះផងខាងនោះផង

cible *n.f.* រង្វង់ (ឧ. tirer à la cible) ។ *Fig.* គោល

ciboule *n.f.* ខ្ទឹមសន្លឹក

ciboulot *n.m.Fam.* ក្បាល

cicatrice *n.f.* ស្នាម(ឧ. visage balafré de cicatrices) ។ *Par ext.* ការខូចខាត ។ *Fig.* លទ្ធផលអាក្រក់

cicatriciel,elle *a.* នៃស្នាម (ឧ. tissu cicatriciel)

cicatricule *n.f.* ស្នាមតូច

cicatrisable *a.* អាចសះបាន

cicatrisant,e *a.&n.m.* ដែលផ្សះ

cicatrisation *n.f* ដំណើរសះ (ដា)

cicatriser *v.t.* សះ (ដា)។ *Fig.* ធ្វើឲ្យស្រាក (ឧ. le temps cicatrise les plus grandes douleurs)

cicérone ឬ **cicerone** *n.m.* អ្នកនាំផ្លូវ (ក្នុងក្រុង)

cidre *n.m.* ស្រាផ្លែប៉ោម

cidrerie *n.f.* កន្លែងធ្វើស្រាផ្លែប៉ោម

cidrier,ère *a.* នៃស្រាផ្លែប៉ោម(ឧ.l'industrie cidrière)

Cie (ពាក្យបំព្រួញនៃ compagnie)

ciel *n.m.* មេឃ, អាកាស (ឧ. un ciel serein); ឋានសួគ៌។ *Fig.* អាទិទេព, ព្រះ ។ élever jusqu'au ciel លើកកំពស់មេឃ (សរសើរខ្លាំង) ។ remuer ciel et terre ខំប្រឹងករក្រើកមេឃករក្រើកដី (ខំប្រឹងខ្លាំង) ។ les plaines du ciel អាកាស ។ le feu du ciel រន្ទះ។ à ciel ouvert ចំហថ្ងៃ; កណ្ដាលវាល ។ être ravi au troisième, au septième ciel សប្បាយអណ្ដែតអណ្ដូង (ឃើញឋានសួគ៌)។tomber du ciel មកដល់ភ្លាមនៅពេលត្រូវការ ។ voir les cieux ouverts សប្បាយ

ណាស់ (ដូចឡើងឋានសួគ៌ទាំងរស់)។ entre ciel et terre នៅឯអាកាស (លើមេឃ)។ *a.* bleu ciel ពណ៌ផ្ទៃមេឃ (ខៀវ)

cierge *n.f.* ទៀនគោល។ droit comme cierge ត្រង់ភ្លឹង (ត្រង់ហើយរឹង)។ devoir un beau cierge à quelqu'un ជំពាក់គុណច្រើន

C.I.F. ពាក្យបំព្រួញនៃពាក្យអង់គ្លេស Cost=coût, Insurance= assurance, Freight=fret ម.ព. C.A.F.

cigale *n.f.* រៃ (សត្វ)

cigalière *n.f.* កន្លែងមានរៃច្រើន

cigare *n.m.* ស៊ីហ្គារ (បារី)

cigarette *n.f.* បារី

cigarière *n.f.* កម្មករស្រីមូរស៊ីហ្គារ (បារី)

cigogne *n.f.* សត្វប្រវ៉ាងដូចត្រដក់

cil *n.m.* រោមភ្នែក

ciliaire *a.* នៃរោមភ្នែក (ឧ. muscles ciliaires)

cilié,e *a.* ដែលមានរោម (ឧ. graine ciliée)

cillement *n.m.* ការប៉ប្រិចភ្នែក

ciller *vt.&i* ប៉ប្រិចភ្នែក ។ personne n'ose ciller គ្មានអ្នកណាហ៊ានកម្រើកខ្លួន (មិនហ៊ានប៉ប្រិចភ្នែក)

cime *n.f.* កំពូល, ចុង

ciment *n.m.* ស៊ីម៉ង់ ។ *Fig.* fait à chaux et à ciment ដែលធ្វើដោយហ្មត់ចត់ណាស់ ។ អ្វីៗសម្រាប់បង្រួបបង្រួម (ឧ. le ciment des nations)

cimenter *v.t.* ភ្ជាប់ដោយស៊ីម៉ង់។ *Fig.* ពង្រឹង (ឧ. cimenter la paix)

cimentier *n.m.* អ្នកធ្វើស៊ីម៉ង់

cimeterre *n.m.* ដាវវែង

cimetière *n.m.* ស្មសាន, ប៉ាឆា, កន្លែងបញ្ចុះសព

cinéaste *n.m.* អ្នកលេងភាពយន្ត

ciné-club *n.m.* សមាគមភាពយន្ត (*pl.* des ciné-clubs)

cinégraphique *a.* នៃការរៀបចំខ្សែភាពយន្ត

cinéma *n.m.* (ពាក្យបំព្រួញនៃ cinématographe) ភាពយន្ត ឬ កុន ។ cinéma sonore ឬ parlant ភាពយន្តឬកុននិយាយ ។ cinéma muet ភាពយន្ត ឬ កុន គ

cinémascope *n.m.* ភាពយន្តសព្វទស្សន៍ (ភាពយន្តប្រើផ្ទាំងសំពត់ស ធំ)

cinémathèque *n.f.* កន្លែងទុកខ្សែ

ភាពយន្ត

cinématique *n.f. Méc.* ជវកបរិញ្ញា [ស៊ី-ណេ-ម៉ា-ទិច]

cinématographe *n.m.* ភាពយន្ត,កុន (ប.ព. cinéma ផង)

cinématographie *n.f.* ការបញ្ចាំងភាពយន្ត

cinématographier *v.t.* ថតភាពយន្ត

cinématographique *a.* នៃភាពយន្ត

cinéraire *a.* urne cinéraire កោដ្ឋដាក់ធាតុ

cinérama *n.m.* ភាពយន្តវិសាល

ciné-roman *n.m.* ភាពយន្តប្រលោមលោក (ប្រលោមលោកស្រង់ចេញពីខ្សែភាពយន្ត)

cinétique *a.* នៃចលនា (ឧ. énergie cinétique)

cingalais,e *a.&n.* នៃប្រទេសលង្កា

cinglage *n.m.* ចម្ងាយនាវាបើកបានក្នុង ២៤ ម៉ោង

cinglant,e *a.* ខ្លាំង ។ *Fig.* តឹងរ៉ឹង (ឧ. une cinglante leçon)

cinglé,e *a. Pop.* ដែលស្រពន់បិន្ត

cingler *v.i.* បើកតម្រង់ទៅ (នាវា) (ឧ. cingler vers le port)

cingler *v.t.* វាយរំពាត់ (ឧ. cingler un cheval d'un coup de fouet); ប៉ះយ៉ាងខ្លាំង (ឧ.la neige cingle le visage); និនែក;ឆ្ងាស់និងដែកញ្ចាប់ភ្លា; វាយខ្សែបន្ទាត់

cinglon *n.m.* ការវាយរំពាត់

cinq *a. num.* ប្រាំ, ទី ៥ ។ *n.m.* លេខ ៥

cinquantaine *n.f.* ចំនួនប្រហែលជាហាសិប ។ avoir la cinquantaine មានអាយុ ៥០ ឆ្នាំ

cinquante *a. num.* ហាសិប

cinquantenaire *a.&n.* អ្នកមានអាយុ ៥០ ឆ្នាំ ។ *n.m.* បុណ្យខួប ៥០ ឆ្នាំ

cinquantième *a. ord.* ទីហាសិប ។ *n.m.* ភាគ ៥០

cinquième *a. ord.* ទី ៥ ។ *n.* អ្នកទី ៥ ។ *n.m.* ភាគ៥ ។ *Ens.n.f.* ថ្នាក់ទី ៥

cinquièmement *adv.* ទី ៥

cintrage *n.m.* ការធ្វើឲ្យកោង

cintre *n.m.* រង្វង់ក្នុងនៃបង្អួរ; សណ្ឋានកោងនៃធ្នូ

cintrer *v.t.* ធ្វើឲ្យមានសណ្ឋានកោង

cirage *n.m.* ការខាត់ដោយក្រមួន;ក្រមួនខាត់ស្បែកជើង

circoncire *v.t.* កាត់ស្បែក (ស្បែកអង្គ-

ជាតិតាមសាសនាអ៊ីស្លាម)

circoncis,e *a.* ដែលកាត់ស្បែក

circoncision *n.f.* ការកាត់ស្បែក(កាត់ស្បែកអង្គជាតិតាមសាសនាអ៊ីស្លាម)

circonférence *n.f.* វណ្ឌមណ្ឌល (គំនូរ ឬ ប្រវែង វង់មូល)

circonflexe *a.* ក្រវិកក្រវក់ ។ accent circonflexe សញ្ញា (^)

circonlocution *n.f.* បរិវទៈ, ពាក្យពង្វាង (ឧ. prendre une circonlocution pour annoncer une nouvelle désagréable)

circonscription *n.f.* មណ្ឌល (ឧ. circonscription électorale មណ្ឌលបោះឆ្នោត) ។ *Géom.* ការចារឹកជុំវិញ

circonscrire *v.t.* កម្រិតមណ្ឌល;ចារឹកជុំវិញ

circonscrit,e *a.* *Math.* ចារឹកជុំវិញ

circonspect,e *a.* ប្រយ័ត; ស្ងប់ស្ងៀម (ឧ. tenir un langage circonspect)

circonspection *n.f.* សង្វរក្ស;ប្រយ័ត្ន; ភាពស្ងប់ស្ងៀម(ឧ. la circonspection mesure les paroles du sage)

circonstance *n.f.* កាលៈទេសៈ ។ circonstance aggravante ម.ព. aggravant ។ circonstance atténuante ម.ព. atténuant

circonstancié,e *a.* បរិបូណ៌, ពិស្តារ (ឧ. faire un rapport circonstancié) ។ certificat circonstancié ម.ព. certificat

circonstanciel,elle *a.* តាមដំណើរហេតុ, តាមទេសៈកាលៈ

circonstancier *v.t.* ថ្លែងដោយបញ្ជាក់ទេសៈកាលៈ (ឧ. circonstancier un fait)

circonvenir *v.t.* កេបកាន់ (ឧ. circonvenir un juge)

circonvoisin,e *a.* ជិត,ខាង(ឧ.lieux circonvoisins)

circonvolution *n.f.* ចង្វាយ (ពោះវៀន); ផ្នត់ (ខួរក្បាល)

circuit *n.m.* បរិបថ, វង់ជុំវិញ, ព្រំក្រៅ (ឧ. cette ville a une lieue de circuit); វង់ប្រណាំង ។ *Fig.* ការពង្វាង (ឧ. un long circuit de paroles)

circulaire *a.* ជាវង់មូល (ឧ. surface circulaire; mouvement cir-

culaire) ។ *n.f.* សារាចរ (ឧ.circulaire ministérielle)

circulairement *adv.* ជារង្វង់មូល

circulant,e *a.* ដែលកំពុងចរាចរ ឬ ចរត្រេច; ដែលគេចាយ (ឧ. la monnaie circulante)

circulation *n.f.* ចរាចរណ៍, ការចរត្រេច (ឧ. la circulation est devenue de plus en plus difficile à Phnom-Penh); ការផ្សាយ (ឧ. la circulation des idées) ។ circulation du sang ដំណើរឈាមរត់ ។ circulation monétaire ការចាយប្រាក់

circulatoire *a.* នៃការឈាមរត់ (ឧ. troubles circulatoires) ។ appareil circulatoire បរិធានឈាមរត់ (មានបេះដូង, សរសៃឈាម ។ល។)

circuler *v.i.* ត្រេចរៀន, ចរាចរ, ទៅមក (ឧ. les voitures circulent); រត់(ឈាម)(ឧ.le sang circulent dans les veines); ទៅពីម្នាក់ទៅម្នាក់ (ឧ. l'argent circule) ។ *Fig.* ផ្សាយ, ឮសុសសាយ (ឧ. un bruit circule)

circumnavigation *n.f.* បរិនាវាចរណ៍' នាវាចរណ៍ជុំវិញទ្វីប (ឧ. les Phéniciens firent la circumnavigation de l'Afrique)

circumpolaire *a.* ជុំវិញអក្សាសាន ឬ ប៉ូល (ឧ. région, navigation circumpolaire)

cire *n.f.* ក្រមួន,ទៀនក្រមួន;អាចម៍ល័វ; អាចម៍ត្រចៀក ។ cire molle ឬ cire បរិគងាយដឹកនាំ ។ jaune comme cire សម្បុរលឿងដូចក្រមួន ។ cire végétale ក្រមួនសុទ្ធ ។ être égaux comme de cire ដូចគ្នាបេះបិទ (ដូចជាចេញពីពុម្ពជាមួយគ្នា) ។ fondre comme la cire au soleil រលាយដូចក្រមួនត្រូវថ្ងៃ

ciré,e *a.* ដែលមានលាបក្រមួន ឬ ជ័រ ។ *n.m.* សំលៀកបំពាក់មិនជ្រាបទឹក

cirer *v.t.* ជ្រលក់ក្រមួន ឬ ជ័រ; ខាត់ស្បែកជើង

cireur,euse *n.* អ្នកខាត់ (ឧ. cireur de bottes, de parquets) ។ *n.f.* ម៉ាស៊ីនខាត់

cireux,euse *a.* ដូចក្រមួន (ឧ. une pâleur cireuse)

cirier,ère *a.* ដែលចេះធ្វើក្រមួន (ឧ.

abeille cirière)

cirque *n.m.* កន្លែងលេងសៀក, សៀក

cirre ឬ **cirrhe** *n.m.* នៃ (ទំពក់វល្លិ)

cirrhose *n.f.* រោគថ្លើម

cirus *n.m.* ពពកស្រកានាគ

cisailles *n.f.pl.* កន្ត្រៃធំកាត់លោហធាតុ ឬមែកឈើ

cisaillement *n.m.* ការកាត់ដោយកន្ត្រៃធំ; ភាពឡេកនៃមុខដំណ

cisailler *v.t.* កាត់ដោយកន្ត្រៃធំ

ciseau *n.m.* ពន្លាក។ *n.m.pl.* កន្ត្រៃ។ *Fig.* ការឆ្លាក់

cisèlement *n.m.* ការកាត់ផ្លែអាក្រក់ចោល (ទំពាំងបាយជូរ)

ciseler *v.t.* ឆ្លាក់លោហធាតុ; កាត់ជារូប

ciselet *n.m.* ខ្ទិត (ពន្លាកជាងទងឬជាងឆ្លាក់)

ciseleur *n.m.* ជាងឆ្លាក់ (ដោយខ្ទិត)

ciselure *n.f.* ចំឡាក់លោហធាតុ

cistude *n.f.* អណ្តើកទឹកសាប

citadelle *n.f.* បន្ទាយប្រាការ

citadin,e *n.* នាគរិក-រិកា ឬ នាគរី, អ្នកក្រុង។ *n.f.* រទេះម្យ៉ាង

citation *n.f.Mil.* គុណកថា (ការពោលសរសើរអំពីគុណ)។ *Litt.* អាគតដ្ឋាន (សេចក្តីស្រង់ពីទីដទៃដោយពិតមានល្បៀកពីមទដើម)។ *Just.* ដីកាកោះ

cité *n.f.* ក្រុង. នគរ, បុរី, ធានី, ស្ថានីយ។ la cité sainte ក្រុងយេរូសាឡឹម (Zérusalem)។ droit de cité សិទ្ធិពលរដ្ឋ។

citer *v.t.* ទាញអាគតដ្ឋាន(ឧ. citer la Bible); ទាញហេតុសំអាង (ឧ. citer des faits); ធ្វើឲ្យគេសំគាល់ (ឧ. il est cité pour sa bravoure); រាប់ឈ្មោះ (ឧ. citer quelques noms)។ *Just.* កោះឲ្យចូលខ្លួន។ *Mil.* ប្រកាសគុណកថា

citérieur,e *a.* ខាងនាយ

citerne *n.f.* អាងទឹក។ camion-citerne កាម៉ុងដឹករាវ។ wagon-citerne ម.ព. wagon

cithare *n.f.* ពិណម្យ៉ាង

citharède *n.* អ្នកច្រៀងពិណ

cithariste *a.&n.* អ្នកលេងពិណ។

citoyen,enne *n.* ពលរដ្ឋ។ *Fam.* un drôle de citoyen មនុស្សចំឡែក

citoyenneté *n.f.* លក្ខណៈជាពលរដ្ឋ

citrique *a.* ដែលយកចេញពីក្រូចឆ្មារ

citron *n.m.* ផ្លែក្រូចឆ្មារ។ *a. inv.* លឿងភាវ

citronnade *n.f.* ទឹកក្រូច (ដាក់ដប)

citronné,e *a.* ដែលមានក្លិនក្រូចឆ្មារ; ដែលមានដាក់ក្រូចឆ្មារ

citronnelle *n.f.* ស្លឹកគ្រៃ; រុក្ខជាតិដែលមានក្លិនដូចក្រូចឆ្មារ; ភេសជ្ជៈផ្សំដោយសំបកក្រូចឆ្មារ

citronner *v.t.* ប្រជាប់ក្រូចឆ្មារ (ឧ. citronner un poisson)

citronnier *n.m.* ដើមក្រូចឆ្មារ

citrouille *n.f.* ល្ពៅ

Civa *n.m.* ព្រះសិវៈ ឬ ព្រះឥស្សូរ (ទេវតា ឬ ព្រះស័ក្តិសិទ្ធិវិសេសមួយអង្គរបស់ពួកព្រាហ្មណិក)

civette *n.f.* សំពោច; ក្លិនប្រហើរនៃសំពោច

civière *n.f.* គ្រែស្នែងអ្នកជម្ងឺ

civil,e *a.* នៃពលរដ្ឋ, គួរសម, ត្រង់ ។ *n.m.* អសេនិក, ជនស៊ីវិល (មិនមែនទាហានឬមិនមែនអ្នកបួស) ។ guerre civile ចំបាំងគ្នាឯង។ droit civil ច្បាប់រដ្ឋប្បវេណី ។ action civile ម.ព. action។ mort civile ការប្រាសចាកសិទ្ធិពលរដ្ឋ

civilement *adv.* ជារឿងរដ្ឋប្បវេណី (ឧ.juger civilement); ដោយគួរសម (ឧ. parler civilement)

civilisable *a.* អាចឲ្យមានអារ្យធម៌បាន

civilisateur,trice *a.* ដែលនាំឲ្យមានអារ្យធម៌

civilisation *n.f.* អារ្យធម៌ [អា-រ្យៈ]; ការនាំឲ្យមានអារ្យធម៌

civiliser *v.t.* ធ្វើឲ្យមានអារ្យធម៌; នាំឲ្យបេះនៅក្នុងសង្គម ឬ ឲ្យបេះគួរសម

civilité *n.f.* សេចក្តីគួរសម។ *pl.* សំដីគួរសម (ឧ. faire des civilités)

civique *a.* នៃពលរដ្ឋ (ឧ. devoirs civiques)

civisme *n.m.* រដ្ឋនិយម (ការបម្រើរដ្ឋ ឬ ប្រយោជន៍សាធារណៈ)

claie *n.f.* ប្រទាស, ប្រដឹស, របង

clair,e *a.* ថ្លា (ឧ. vitre claire; eau claire); ភ្លឺ(ឧ.feu claire;chambre très claire); ច្បាស់(ឧ. voix claire); ខ្ចី (ពណ៌); មិនសូវខាប់ (ឧ. sirop clair) ។ *Fig.* ងាយយល់, ឆាប់យល់ ។ *n.m.* ពន្លឺ(ឧ. le clair de lune); ផ្នែកភ្លឺ; អក្សរមិនសម្ងាត់។ tirer quelque chose au clair បញ្ជាក់ឲ្យច្បាស់។ voir clair ឃើញច្បាស់, យល់ច្បាស់

clairement *adv.* ដោយច្បាស់លាស់, យ៉ាងងាយយល់(ឧ. écrire claire-

ment, c'est déjà bien écrire)

claire-voie *n.f.* ប្រដឹស។ à claire-voie *loc. adv.* រង្វើល (*pl.* des claires-voies)

clairière *n.f.* ព្រៃរោះ (ឬល្ហោះ)

clair-obscur *n.m.* ពន្លឺស្រពិល (ស្មើរភ្លឺស្មើរងងឹត)

clairon *n.m.* ត្រែ; អ្នកផ្លុំត្រែ

claironnant,e *a.* ដែលមានសូរដូចត្រែ (ឧ. voix claironnante)

claironner *v.i.* ផ្លុំត្រែ ។ *Fig.* បញ្ចេញសូរ ឬ សំឡេងដូចត្រែ (ឧ. voix qui claironne) ។ *v.t.* ប្រកាសដោយផ្លុំត្រែ ឬ ទូងស្គរ (ឧ. claironner une victoire)

clairsemé,e *a.* រង្វើល, រោះ ឬ ល្ហោះ

clairvoyance *n.f.* ការឈ្វេងយល់

clairvoyant,e *a.* ដែលឈ្វេងយល់

clamer *v.t.* ស្រែក (ឧ. clamer sa douleur)

clameur *n.f.* សម្រែកគឹកកង; សូរគគ្រាំគគ្រេង

clampin *n.m. Fam.* មនុស្សបំរៀក

clan *n.m.* បក្ខសម្ព័ន្ធ [ប៉ាក់-សំ-ពាន់] ។ *Fig.* បក្សពួក

clandestin,e *a.* ដែលលួចលាក់នឹងច្បាប់

clandestinement *adv.* ដោយលួចលាក់

clandestinité *n.f.* ភាពលួចលាក់; បណ្ដាអ្នកលាក់ខ្លួនពួនរកត្បា

clapet *n.m. Méc.* សន្ទះមានត្រចៀក

clapier *n.m.* រូងទន្សាយ; ទ្រុងទន្សាយ

clapir *v.i.* យំ (ទន្សាយ)

clapir (se) *v.pr.* ពួនក្នុងរូង (ទន្សាយ)

clapotage,clapotement ឬ **clapotis** *n.m.* សូររលកប៉ះគ្នាតិចៗ

clapoter *v.i.* លាន់សូរតិចៗ ដោយរលកប៉ះគ្នា (ឧ. les eaux clapotent doucement le long des côtes)

clapoteux,euse ឬ **clapotant,e** *a.* ដែលលាន់សូរតិចៗ ដោយរលកប៉ះគ្នា

clappement *n.m.* សូរក្ដក់

clapper *v.i.* ក្ដក់

claquant,e *a.* ដែលលាន់សូរខ្ទាប់ ។ *Pop.* ដែលឲ្យអស់កម្លាំង

claque *n.f.* ការទះ (ឧ. recevoir une claque)

claqué,e *a.* ដែលត្រូវទះ។ *Fig.* ដែលហត់

claquedent ឬ **claquefaim** *n.m.* មនុស្សអត់ឃ្លាន

claquement *n.m.* សូរខ្ទាប់ (ដោយ

រំពាត់, ដោយទះដៃ)

claquemurer *v.t.* បង្ខាំងក្នុងបន្ទប់។ se claquemurer *v. pr.* សម្ងំក្នុងផ្ទះ

claquer *v.t.* លាន់សូរ (ដោយអណ្ដាតផ្ទប); លាន់សូរខ្ទាប់ (ដោយរំពាត់)។ *Fig.& fam.* faire claquer son fouet គោះរំពាត់ ឬវាត់ខ្សែតី(ដើម្បីកំញើញ)។ *Pop.* ស្លាប់។ *Pop.* ធ្វើឲ្យរលស់កម្លាំង។ *Pop.* មិនបានសម្រេច (ឧ. cette affaire a claqué)។ *Pop.* claquer du bec ឃ្លាន។ *v.t.* ទះ (ប្រហារ); ទះដៃ (អបអរសាទរ)

claquet *n.m.* បន្ទះផ្ទាត់ (បន្ទះស្តើងចងភ្ជាប់នឹងរបស់អ្វីដែលវិលឲ្យផ្ទាត់ឮសូរប៉ុកៗ)។ *Fig.* sa langue va comme un claquet និយាយមិនឈប់ (ហូរដូចទឹក)

claqueter *v.i.* ខ្វាក ឬ ខ្វត (មាន់)

claquette *n.f.* ឬ **claquoir** *n.m.* ក្រាប់។ danse à claquettes របាំក្រាប់

claquoir *n.m.* ម.ព. claquette

clarifiant,e *a.* ដែលធ្វើឲ្យថ្លា ឬ ឲ្យរង។ *n.m.* អ្វីៗ ដែលធ្វើឲ្យថ្លា ឬ ឲ្យរង

clarification *n.f.* ការធ្វើឲ្យថ្លា-ឲ្យរង ឬ ឲ្យបរិសុទ្ធ

clarifier *v.t.* ធ្វើឲ្យថ្លា-ឲ្យរង ឬឲ្យបរិសុទ្ធ

clarine *n.f.* ត្រដោក ឬ ក្ដោក

clarinette *n.f.* ក្លារីណែត (ខ្លុយភ្លេង); អ្នកផ្លុំក្លារីណែត

clarinettiste *n.m.* អ្នកផ្លុំក្លារីណែត

clarté *n.f.* ប្រភា, ពន្លឺ (ឧ. la clarté du jour); សភាពថ្លា (ឧ. la clarté du verre)។ *Fig.* សេចក្ដីច្បាស់លាស់។ *pl.* បញ្ញា, ចំណេះវិជ្ជា

classe *n.f.* ថ្នាក់; ជាន់; ថ្នាក់រៀន; សិស្សមួយថ្នាក់; មេរៀន។ classe maternelle មត្តេយ្យស្ថាន។ classe de 2e (seconde) ថ្នាក់ទី ២។ classe de 1ère (première) ថ្នាក់ទី ១។ classe de mathématiques élémentaires ថ្នាក់គណិតសាស្ត្រជាន់ដំបូង។ classe de philosophie ថ្នាក់ទស្សនវិជ្ជា។ classe de sciences expérimentales ថ្នាក់វិទ្យាសាស្ត្រពិសោធ។ *Hist. nat.* ក្រុម។ វណ្ណៈ (ឧ. lutte des classes)។ *Fam.* ភាពសមសួន

classement *n.m.* ការដាក់ថ្នាក់, លេខដាក់ថ្នាក់។ classement annuel ការដាក់ថ្នាក់ប្រចាំឆ្នាំ។ classe-

ment hebdomadaire ការចាត់ថ្នាក់ប្រចាំសប្ដាហ៍ ។ classement mensuel ការចាត់ថ្នាក់ប្រចាំខែ ។ *Hist. nat.* ការបញ្ចូលក្នុងក្រុម(ឧ. classement des animaux); ការរៀបចំទុក (ឧ. classement des dossiers) ។ *Dr.* ការផ្អាប់ទុក ។ classement sans suite ការផ្អាប់ទុកចោល

classer *v.t.* ចាត់ថ្នាក់; ចាត់ជាក្រុម (ឧ. classer des plantes); រៀបចំទុក (ឧ. classer des papiers)។ *Dr.* ផ្អាប់ទុក ។ classer sans suite ផ្អាប់ទុកចោល

classeur *n.m.* អ្នករៀប; ទូរៀបបញ្ជី

classicisme *n.m.* គន្ថីនិយម

classificateur *n.m.* អ្នកចាត់ជាពួក ឬ ជាក្រុម (វិទ្យាសាស្ត្រ)

classification *n.f.* វគ្គីករណ៍, ការចាត់ជាថ្នាក់-ជាពួក ឬ ជាក្រុម

classifier *v.t.* ធ្វើវគ្គីករណ៍, ចាត់ជាថ្នាក់-ជាពួក ឬ ជាក្រុម

classique *a.* គន្ថ, សម្រាប់ថ្នាក់រៀន, សម្រាប់រៀន, ត្រូវតម្រាប្ញភណា ។ langue classique ភាសាគន្ថី។ *n.m.* គន្ថ (អ្នកនិពន្ធ ឬ សៀវភៅដែលអាចទុកជាគំរូបាន) ។ livre classique សៀវភៅរៀន

claudicant,e *a.* ខ្វក, ខ្ញើច

claudication *n.f.* ដំណើរខ្វក

clause *n.f.* ខសំខាន់

claustral,e,aux *a.* នៃរាភម (ឧ.discipline claustrale)

claustration *n.f.* ការបង្ខាំងក្នុងកំពែង

claustrer *v.t.* បង្ខាំងក្នុងកំពែង

clavicule *n.f.* ឆ្អឹងដងកាំបិត

clavier *n.m.* ភនផ្លែចុច(ខ្ទង់សម្រាប់ចុច)

claymore [Klé–] *n.f.* ដាវសម្រាប់កាន់ដៃពីរ

clayon *n.m.* ប្រទាស;របងក្រោលចៀម

clayonnage *n.m.* ចម្រឹងច្រុះដីឬទប់ទឹក

clayonner *v.t.* ទប់ដោយចម្រឹងត្បាញ

clef,clé *n f.* កូនសោ ។ *Par ext.* ចំណុចសោ (ក្នុងយុទ្ធសាស្ត្រ)(ឧ. Gibraltar est la clef de la Méditerranée); ប្រធាន(ឧ.problème, industrie clef)។ *Fig.* clef des champs សេរីភាពទៅណាបានតាមចិត្ត។ sous clef ដោយចាក់សោ; ជាប់គុក ។ mettre la clef sous sa porte ភៀសខ្លួនបាត់ (ដោយបង្កប់សោក្រោមទ្វារ) ។ les

clefs de saint Pierre កូនសោហានស្វត៌; រឿងដែលនាំឲ្យយល់បញ្ហា ឬរឿងមួយ។ trouver la clef d'un mystère ដោះស្រាយបញ្ហាបាន ។ clef de voûte *Fig.* មូលដ្ឋាន ។ *Mécan.* សោ (សម្រាប់មួលឡោស៊ី)។ clef anglaise សោក្បាលមួលបង្កើបបាន ។ clef universelle សោសាកល (មួលឡោស៊ីគ្រប់ធុនបាន) ។ *Mus.* clef de sol កូនសោសុល

clémence *n.f.* សេចក្ដីអត់ឱន

clément,e *a.* ដែលអត់ឱន ។ ciel clément អាកាសធាតុត្រជាក់ល្អ ។ *Fig.* ភិសនាល្អ

clenche *n.m.* គន្លឹះទ្រនុកទ្វារ

cleptomane ឬ **kleptomane** *n.* ចោរមត្ត (ដែលវក់ខាងលួច)

cleptomanie ឬ **kleptomanie** *n.f.* ចោរម័ទ (ការវក់ខាងលួច)

clerc *a.&n.* អ្នកប្រាជ្ញជាសហធម្មិក ។ *Fig.* អ្នកប្រាជ្ញ; ស្មៀននៃសារការី ។ pas de clerc ការគិតអ្វីមិនបានសម្រេច

clergé *n.m.* សហធម្មិក (បព្វជិតដែលប្រព្រឹត្តធម៌ត្រូវគ្នា)

clérical,e,aux *a.&n.* នៃសហធម្មិក

clic *int.* ប៉ុក! (គ្រាប់ស្វរ)

cliché *n.m.* ក្លីសេ (បន្ទះលោហធាតុឆ្លាក់ជាអក្សរ ឬរូបសម្រាប់បោះពុម្ព); រូបថតមិនទាន់ផ្តិតចេញ ។ *Fig.& fam.* គំនិតសាមញ្ញ

client,e *n.* អតិថិជន [អៈ-តិ-ថិ—]

clientèle *n.f.* អតិថិតា [អៈ-តិ-ថិ—], អតិថិជនទាំងឡាយ

clignement *n.m.* ការបិចភ្នែក

cligne-musette *n.f.* ប.ព. cache-cache

cligner *v.t.* មិចភ្នែក ។ *v.i.* cligner de l'œil មិចភ្នែកឲ្យជាសញ្ញា

clignotant,e *a.* ភ្លឹបភ្លែត

clignotement *n.m.* ការប៉ប្រិចភ្នែក; ការធ្វើភ្លឹបភ្លែត

clignoter *v.t.&i.* ប៉ប្រិចភ្នែក (ឧ. la lumière trop vive fait cligner les yeux); ញ័រ, ធ្វើភ្លឹបភ្លែត (ឧ. feu qui clignote)

climat *n.m.* អាកាសធាតុ; ប្រទេស (ឧ. changer de climat)។ climat équatorial អាកាសធាតុភូមធ្យមខា។ climat frais អាកាសធាតុត្រជាក់។ climat froid អាកាសធាតុរងា ។ climat polaire អាកាសធាតុ

អក្សោភាន។ climat subtropical អាកាសធាតុឧបនិវត្ត។ climat tempéré អាកាសធាតុបមាណយុត្ត ។ climat tropical អាកាសធាតុនិវត្ត ។ *Fig.* ទឹកចិត្ត

climatérique *a.* année climatérique ឆ្នាំដែលមានគ្រោះ (គឺក្នុងអាយុ ៧, ៩, ៦៣ ឆ្នាំ ជាដើម)

climatique *a.* នៃអាកាសធាតុ (ឧ. influence climatique)

climatisation *n.f.* ការធ្វើឲ្យមានអាកាសធាតុល្អក្នុងបន្ទប់

climatisé,e *a.* ដែលគេធ្វើឲ្យមានអាកាសធាតុល្អជាប់ (បន្ទប់) (ឧ. salle climatisée)

climatiser *v.t.* ធ្វើឲ្យមានអាកាសធាតុល្អក្នុងបន្ទប់; ធ្វើឲ្យធន់នឹងអាកាសធាតុហួសកំណត់បាន (ម៉ាស៊ីនឬយន្ត)

climatologie *n.f.* អាកាសធាតុសាស្ត្រ

climatologique *a.* នៃអាកាសធាតុសាស្ត្រ

climatologue *n.* អាកាសធាតុវិទូ

clin *n.m.* clin d'œil ការប៉ប្រិចភ្នែក។ en un clin d'œil *loc. adv.* មួយប៉ប្រិចភ្នែក (មួយភ្លែត) (*pl.* des clins d'œil ឬ clins d'yeux)

clinicien *n.m.* & *a.* គ្រូពេទ្យពិនិត្យអ្នកជំងឺផ្ទាល់

clinique *a.* ដែលធ្វើពិនិត្យលើអ្នកជំងឺ (ឧ. leçons cliniques)។signes cliniques អាការក្រៅនៃរោគ (ដែលអាចដឹងបានដោយគ្រាន់តែមើល-ស្ទាប-ស្តាប់ ។ល។)។ *n.f.* ការសិក្សាខាងព្យាបាលរោគ (ឧ. professeur de clinique); មន្ទីរព្យាបាលរោគ ។ clinique ophtalmologique et oto-rhino-laryngologique មន្ទីរព្យាបាលចក្ខុ-សោតៈ-ឃានៈ-កណ្ឋរោគ (ភ្នែក-ត្រចៀក-ច្រមុះនិងក)

clinomètre *n.m.* កែវស្ទង់ល្អៀង

clinquant *n.m.* បន្ទះលោហធាតុភ្លឺប្រើក្នុងការប៉ាក់ ។ *Par anal.* ត្បូងសូ (ឧ. bijoux de clinquant) ។ *Fig.* ពន្លឺបំភាន់ (ឧ. mobilier qui n'est que du clinquant)

clip *n.m.* ដង្កៀប (មានរ៉ឺស្ស័រ)

clipper *n.m.* សំពៅ; យន្តហោះធំឆ្ងាយ

clique *n.f.* *Fam.* បក្សពួកល្ងង់ខ្លៅ ។ *Mil.* ពត្តពួក (ក្រុមភ្លេងទាំងស្គរសម្រាប់កងវរសេនាធំ)។ *Pl.* ស្បែកជើងឈើ។ prendre ses cliques et ses claques ជញ្ជូនអីវ៉ាន់ចេញ; ចាកចេញ

cliquet *n.m.* ក្បាលឆ្កែ (គ្រឿងស៊ី)

cliqueter *v.i.* ធ្វើឲ្យឮសូរដោយទង្គិច

cliquetis *n.m.* សូរទង្គិចគ្នា (ឧ. le cliquetis des armes, des verres) ។ cliquetis de mots ពាក្យឧត្តុង្គឧត្តមសូរ១ប្លែកឥតប្រយោជន៍

cliquette *n.f.* ក្រាប់ ។ *Pêch.* សំណជើងមង

clissage *n. m.* ការដាក់ប្រទាស

clisse *n.m.* ប្រទាស (សម្រាប់ដាក់ហ្វ្រូម៉ាសឲ្យស្រក់ទឹក); ស្រោបដប ។ *Chir.* ម.ព. éclisse

clisser *v.t.* ដាក់ប្រទាស (ឲ្យស្រក់ទឹក); ដាក់ស្រោបដប (ឧ. clisser une bouteille)

clivable *a.* អាចពុះឬសកជាស្រទាប់បាន

clivage *n.m.* ការពុះឬសកជាស្រទាប់តាមបណ្ដោយសាច់ (ខនិជ). ស្នាមប្រេះ (ពេជ្រ)

cliver *v.t.* ពុះ ឬ សកជាស្រទាប់តាមបណ្ដោយសាច់ (ខនិជធាតុ)

cloaque *n.m.* ថ្លុកលាមក, បំពង់បង្ហូរទឹកស្អុយ; កន្លែងទទួលទុកសំអុយឬរបស់ស្មោកគ្រោកៈគ្រាំ (ឧ. tomber dans un cloaque); កន្លែងស្មោកគ្រោក ។ *Fig.* អ្វីៗដែលមិនស្អាត - ដែលមានមេរោគ ។ *Zool.* ថ្លុកគូថបក្សី

clochard,e *n.Pop.* ជនរកាំរែ

cloche *n.f.* រគាំង, ជួង; សាជី ឬ សជី (ប្រដាប់សម្រាប់គ្រប) ។ chapeau cloche ឬ cloche មួកមានខួប ។ ពង (ស្បែក ឬ សាច់ដែលប៉ោងស្គុលឡើង) ។ *Fig.&fam.* déménager à la cloche de bois រើផ្ទះឬផ្លាស់លំនៅដោយស្ងាត់ ។ sonner la cloche à quelqu'un ស្ដីបន្ទោសខ្លាំង ។ *Pop.* la cloche ក្រុមសូមយាចក ។ *Prov.* qui n'entend qu'une cloche n'entend qu'un son អ្នកស្ដាប់តែភាគីម្ខាងមិនអាចដឹងរឿងពិតបានទេ

clochement *n.m.* ដំណើរខ្ចក; ភាពមានខ្ចោះ

cloche-pied(à) *loc.adv.* ចាក់កន្ត្រង់ ឬលោតកន្ត្រង់ (លោតដោយជើងតែម្ខាង) (ឧ. sauter à cloche-pied)

clocher *n.m.* រោងជួង; ស្រុកកំណើត (ឧ. aller revoir son clocher) ។ *Fig.* rivalité de clocher ជម្លោះរវាងអ្នកភូមិជាមួយ ឬ អ្នកភូមិជិតខាងគ្នាដោយប្រណែន ។ *Prov.* il faut placer le clocher au milieu de la paroisse ត្រូវដាក់រោងជួង (រឿ

ដែលគេត្រូវការគ្រប់គ្នា) ចំកណ្ដាលភូមិ

clocher *v.i.* ដើរខ្វក ។ *Fig.* មានខ្វះ (មិនបានល្អ) (ឧ. cette comparaison cloche)

clocheter *v.i.* ភាយជួង, អង្រួនកណ្ដឹង

clocheton *n.m.* រោងជួងតូច; ដោម

clochette *n.f.* កណ្ដឹង, ចង្រ្កង់, ត្រដោក; ផ្ការាងកណ្ដឹង (ដូចផ្កាត្រកួនជាដើម)

cloison *n.f.* ជញ្ជាំងខណ្ឌ។ *Anat.* សន្ទះ (ស្បែកខណ្ឌ)(ឧ.cloison du nez)។ *Bot.* សន្ទះក្លែបឈើ។ *Fig.* ការបែកដាច់ស្រឡះពីគ្នា

cloisonnage ឬ **cloisonnement** *n.m.* ការបាំងឬខណ្ឌ; គ្រឿងខណ្ឌ

cloisonné,e *a.* ដែលខណ្ឌជាបន្ទប់

cloisonner *v.t.* ខណ្ឌដោយជញ្ជាំង

cloître *n.m.* រោងក្នុងអារាមមានសួនព័ទ្ធជុំវិញ។ *Par ext.* អារាម (ឧ.finir ses jours dans un cloitre)។ *Fig.* ជីវភាពក្នុងអារាម (ការរស់នៅដោយបង្ខាំង)

cloitré,e *a.* ដែលគេបង្ខាំង

cloitrer *v.t.* ឃុំឃាំង, បង្ខាំង (ឧ. cloitrer quelqu'un dans une chambre) ។ se cloitrer *v.pr.* ចូលនៅក្នុងអារាម។ *Fig.* រស់នៅម្នាក់ឯង (គ្មានឲ្យជួបមុខអ្នកណា)

clone *n.m. Bot.* កូនឈើ(ដែលដុះដាលឡើង)

clopin-clopant *loc. adv. Fam.* ដោយខ្ចើច

clopiner *v.t.* ដើរខ្ចើច

cloporte *n.m.* ខ្វតដី

cloque *n.f.* ពងស្បែក(ដោយរលាកភ្លើង ឬ កកិត)

cloquer *v.i.* ឡើងពង, ឡើងកន្ទួល (ឧ. peinture qui cloque) ។ *v.t.* បោះពុម្ពកន្ទួល (ឧ. étoffe cloquée)

clore *v.t.* បិទ, ចុក (ឧ. clore un passage); ធ្វើរបងព័ទ្ធ (ឧ. clore un champ de fossés)។*Fig.* បញ្ចប់(ឧ.clore un compte, une discussion); ប្រកាសបិទ (ប្រកាសថាចប់) (ឧ. clore une séance); ចុះរាបណាសញ្ញាជាស្ថាពរ (ឧ. clore un marché)។clore les yeux, la paupière ធ្មេចភ្នែក(ដេក)។ *v.i.* បិទ (ឧ. fenêtre qui clôt mal)

clos,e *a.* ដែលបិទ, ដែលចប់ហើយ (ឧ. la séance est close); ធ្លាព័ទ្ធរបង(សម្រាប់ប្រយុទ្ធគ្នា)។bouche

close គ្មានហើបមាត់(គិតនិយាយមួយម៉ាត់)។ les yeux clos ដោយផ្ទេចភ្នែក; *au fig.* ដោយប្រថុយ។ à la nuit close ដល់ពេលយប់

clos *n.m.* ចំការមានរបង ។ *Partic.* ចំការទំពាំងបាយជូរ

closeau *n.m.* ឬ **closerie** *n.f.* ចំការតូចមានរបង; ដីប្រភស់

closier *n.m.* ម.ព. métayer

clôture *n.f.* របង ។ *Fig.* ការបញ្ចប់, ការបិទ (ឧ.clôture d'un inventaire, d'une session)។séance de clôture សម័យប្រជុំចុងក្រោយបង្អស់

clôturer *v.t.* ព័ទ្ធរបង (ឧ. clôturer un jardin)។ *Fig.* បញ្ឈប់,បញ្ចប់ (ឧ. clôturer un compte, une discussion)

clou *n.m.* ដែកគោល ។ ne tenir ni à fer ni à clou មិនមាំទេ;ជីវិតផុយណាស់។ suspendre un objet au clou ព្យួរប្រើរបស់អ្វីមួយ (ព្យួរគោល)។ river un clou ភាយបបត់មុខដែកគោល ។ *Fig.* river son clou à quelqu'un ផ្ចាញ់បិទឲ្យឆ្លើយរួច ។ *Fam.* អ៊ូចដំណើត; បូសទ្រនិច ។ clou de girofle ម.ព. girofle ។ ម៉ាស៊ីនចាស់ (ឧ. sa bicyclette est un clou); ល្បែងកំសាន្តធំ (ឧ. clou de la fête) ។ *Pop.* ក្រុងស៊ីបញ្ចាំ (ឧ. mettre sa montre au clou)។ *Prov.* un clou chasse l'autre ម.ព. chasser

clouage ឬ **clouement** *n.m.* ការឬរបៀបបោះដែកគោល

clouer *v.t.* បោះដែកគោល ។ *Par ext.* ភ្ជាប់ដោយរឿងមានមុខស្រួច ។ *Fig.* បង្ខំឲ្យនៅស្ងៀម; ធ្វើឲ្យនៅជាប់មួយកន្លែង(ឧ. la maladie nous cloue à la chambre)។ *Fam.* ផ្ចាញ់ឲ្យ (ឧ. clouer un contradicteur); clouer le bec à quelqu'un ធ្វើឲ្យហើបមាត់មិនរួច

cloutage *n.m.* ការវាយដែកគោល(ដួល)

clouter *v.t.* វាយដែកគោល (ឧ. passage clouté)

clouterie *n.f.* ជំនួញឬការធ្វើដែកគោល

cloutier *n.m.* ជាងធ្វើដែកគោល;ឈ្មួញលក់ដែកគោល

cloutière ឬ **clouière** *n.f.* ប្រដាប់ធ្វើក្បាលដែកគោល; ប្រអប់ដែកគោល

clown [kloun] *n.m.* ត្លុក

clownerie [klou-ne-ri] *n.f.* ល្បែងត្លុក; ក្បាច់ត្លុក

clownesque [klou-nès-ke] *a.* នៃត្លុក

cloyère *n.f.* កញ្ច្រែងដាក់ត្រី

club [klub' ឬ kleub'] *n.m.* ក្លឹប, សមោសរនយោបាយ [ស-ម៉ោ-ស-]; កីឡាមណ្ឌល; មិត្តសមាគម

clubiste *n.m.* សមាជិកក្លឹប(ខាងនយោបាយ)

clubman *n.m.* សមាជិកក្លឹប(ខាងកីឡាមណ្ឌល ឬ មិត្តសមាគម)

coaccusé,e *n.* អ្នកត្រូវចោទរួមគ្នា

coach *n.m.* ទូកេត(រថយន្តទ្វារពីរកញ្ចក់បួន)

coacquéreur *n.m.* អ្នកទិញ ឬ អ្នកជាវរួមគ្នា

coaction *n.f.* ការបង្ខិតបង្ខំ, ការបំពា-បំពាន

coagulable *a.* អាចកក ឬ ខាប់បាន

coagulant,e *a.* ដែលកក ឬ ខាប់

coagulateur,trice *a.* ដែលធ្វើឲ្យកក

coagulation *n.m.* ការកក; ការខាប់

coaguler *v.t.* ធ្វើឲ្យកក ឬ ឲ្យខាប់ (ឧ. coaguler le sang) ។ se coaguler *v.pr.* កក, ខាប់ (ឧ. le lait se coagule)

coagulum *n.m.* ដុំវត្ថុកក; រឿងដែលកក ឬ ដែលធ្វើឲ្យកក

coalisé,e *a.* សហពលករ, ដែលរួមកម្លាំងគ្នា ។ *n.m. pl.* សហពលករ

coaliser *v.t.* ប្រជុំ, ប្រមូល(ឧ.coaliser tout le monde contre soi)។ se coaliser *v.pr.* ធ្វើសហពលកម្ម, រួមគ្នាជាបក្ស; ពួកដៃគ្នា

coalition *n.f.* សហពលកម្ម, ការរួមគ្នាជាបក្ស; ការពួកដៃគ្នា

coassement *n.m.* សម្រែកកង្កែប

coasser *v.i.* យំ (កង្កែប)(កុំច្រឡំនឹងពាក្យ croasser) ។ *Fig.* ស្រែកឡូឡា

coassocié,e *n.* អ្នកចូលហ៊ុនជាមួយ

coassurance *n.f.* ការធានារួមគ្នា

coauteur *n.m.* អ្នកនិពន្ធរួម[redacted]; អ្នកប្រព្រឹត្ត[illegible]រួម[redacted]

coaxial,e,aux *a.* ដែលមានអ័ក្សរួមគ្នា

cobalt *n.m.* កូបាល់ (លោហធាតុម្យ៉ាងរឹងហើយស្រួយ ពណ៌ខៀវ)

cobaye *n.m.* កណ្ដុរម្យ៉ាង ។ *Fig. Fam.* អ្នកឲ្យគេពិសោធលើខ្លួន

cobelligérant *n.m.&a.* សហយុទ្ធករ (ដែលកំពុងប្រយុទ្ធច្បាំងនឹងសត្រូវតែមួយ)

cobra,cobra capello *n.m.* ពស់វែក

cocagne *n.f.* ភាពសម្បូណ៌។ pays de cocagne ស្រុកសម្បូណ៌សប្បាយ ។ mât de cocagne សសរខ្លាញ់

cocarde *n.f.* សញ្ញាពាក់នៅមួក; សញ្ញាពណ៌ទង់ជាតិ; បូសំពត់

cocardier,ère *a.&n.* អ្នកចូលចិត្តកងទ័ព ឬ ឯកសណ្ឋាន

cocasse *a. Fam.* ព្រមាច

cocasserie *n.f.* ភាពព្រមាច; របស់ធ្វើឲ្យគេសើច

coccinelle *n.f.* អណ្តើកមាស(គេច្រើនហៅថា bête à bon Dieu ដែរ)

coche *n.m.* រទេះសេះ(សម័យបូរាណ)។ *Fig.* manquer le coche ខូចឱកាស ។ mouche du coche មនុស្សឡេមឡឹម

coche *n.m.* ទូកបន្ទុកអូសដោយសេះ

coche *n.f.* ស្នាមឆ្លាក់,ស្នាមគ្រីត;គំនូសចំណាំ; ក្បៀស

coche *n.f.* ជ្រូកញី

cochelet *n.m.* មាន់ស្ទាវ; មាន់តូច

cochenille *n.f.* មេល័ខ(សត្វល្អិតដែលបង្កើតល័ខក្រហម)

cocher,ère *n.* សារថី, អ្នកបររទេះសេះ

cocher *v.t.* ក្បៀស, គ្រីត, ណាក់ចំណាំ

côcher *v.t.* ជាន់ញី (បក្សី)

cochère *n.f.* porte cochère ទ្វារសម្រាប់រទេះ ឬ រថយន្តចូល

cochet *n.m.* មាន់ស្ទាវ

cochon *n.m.* ជ្រូកឈ្មោល (cri: le cochon grogne); សាច់ជ្រូក; ម្ហូបធ្វើដោយសាច់ជ្រូក ។ *Fig.* មនុស្សស្មោកគ្រោក ឬ ធ្វើការអាក្រក់អ្វីមួយ(ក្នុងន័យនេះបើស្រីគេថា cochonne) ។ cochon de lait កូនជ្រូកនៅបៅ ។ cochon d'Inde ម.ព. cobaye

cochonnaille *n.f. Pop.* សាច់ជ្រូក

cochonner *v.i.* កើតកូន(ជ្រូក)។ *v.t. Pop.* ធ្វើការមិនស្អាត

cochonnerie *n.f. Pop.* ភាពស្មោកគ្រោក; របស់ធ្វើដោយខ្ជីខ្ជា ។ *Fig. Pop.* អំពើ ឬ សំដីអាសអាភាស

cochonnet *n.m.* ជ្រូកជំទង់

cocker *n.m.* ឆ្កែប្រមាញ់ម៉្យាងរោមវែង

cockpit *n.m. Mar.* បន្ទប់អ្នកកាន់ចង្កូត (នាវា) ។ *Av.* បន្ទប់អ្នកបើកយន្តហោះ

coktail *n.m.* កុកតៃ (ស្រាលាយស៊ីរ៉ូនឹងទឹកកក; ការលៀងស្រា)

coco *n.m.* ផ្លែដូង ។ lait de coco ទឹកដូង ។ *Fam.* ជន (ឧ. un joli coco) (សាច់ដូងហៅ coprah)

cocon *n.m.* សំបុកនាង

cocontractant *n.m.*ភាគីនៃកិច្ចសន្យា

cocorico *n.m.* ពាក្យត្រាប់មាន់រងាវ

cocose *n.f.* ប៊ឺខ្ទិះដូង

cocotier *n.m.* ដើមដូង

cocotte *n.f.* ឆ្នាំងខ្ទះដែក; ភេគរលាក ត្របកភ្នែក; គ្រុនគោ ឬ ចៀម

cocotte *n.f.* មេមាន់ (ពាក្យក្មេង); ក្រដាសបត់ជារូបមាន់;ស្រីពាយងាយ។ *Fam.* សម្លាញ់

coction *n.f.* ការចំអិន; ការរំលាយអាហារក្នុងក្រពះ

cocu *n.m.* *Pop.* វែក(ប្រុសប្រពន្ធផិត)

cocuage *n.m.* *Pop.*ភាពប្រុសប្រពន្ធផិត

code *n.m.* ក្រម, ~~ច្បាប់~~, ប្រជុំច្បាប់ក្បួន, ~~បញ្ញត្តិ~~។ code civil ក្រមរដ្ឋប្បវេណី [–រ៉ត-ប៉ប-ប៉ៈ-វេនី] ។ code des douanes ក្រមគយ។code pénal ក្រមព្រហ្មទណ្ឌ ។ code de la route ហត្ថបញ្ញត្តិ (បញ្ញត្តិរឿងផ្លូវ)។ code noir លក្ខន្តិកៈទាសករអ្នករ ។ *Fig.* code de la politesse ច្បាប់គួរសម

codébiteur,trice *n.* សហកូនបំណុល-រ័ត្តិ (អ្នកជំពាក់បំណុលរួមគ្នា)

codemandeur,cresse *n.* អ្នកប្ដឹងរួមគ្នា

codétenteur,trice *n.* អ្នករក្សារបស់អ្វីមួយរួមគ្នា

codétenu,e *n.* អ្នកជាប់ឃុំជាមួយគ្នា

codex *n.m.* ក្បួនឱសថ

codicillaire *a.*ដែលចុះក្នុងលិខិតកែបតកសាសន៍

codicille *n.m.* លិខិតកែមតកសាសន៍

codificateur,trice *a.&n.* អ្នកប្រមូលជាក្រម ឬ ជាច្បាប់តែមួយ

codification *n.f.* ការប្រមូលជាក្រម ឬ ជាច្បាប់តែមួយ

codifier *v.t.*ប្រមូលជាក្រម ឬ ជាច្បាប់តែមួយ; ធ្វើឲ្យមានរបៀបរៀបរយ (ឧ. codifier la langue)

codirecteur,trice *a.&n.* សហនាយក-យិកា, អ្នកចាត់ការរួម

coéchangiste *n.* គូប្ដូរ, អ្នកប្ដូរជាមួយ

coéducation *n.f.* ការធ្វើ ឬ ទទួលការអប់រំជាមួយគ្នា

coefficient *n.m.*មេគុណ,ចំនួនបង្កើន។ *Fig.* វត្ថុធាតុ (ឧ. coefficient d'erreur)

cœlentérés [sé-lan-] *n.m. pl.*ប្រហោងទ័យ (សាខាបតិសត្វដែលពោះនៅពេញខ្លួន)

cœliaque [sé-] *a.* នៃពោះវៀន

cœnure [sé-] ឬ **cénure** *n.m.*ព្រូនឆ្កែ

coéquipier,ère *n.* សហយោធិន (អ្នកនៅក្នុងកង ឬ ក្រុមជាមួយ)

coercibilité *n.f.* ភាពកៀបបង្ហាប់បាន

coercible *a.* កៀបបង្ហាប់បាន (ឧ. la vapeur est coercible)

coercitif,ive *a.* ដែលមានអំណាចធ្វើពលការ, ដែលមានអំណាចបង្ខំ (ឧ. force coercitive)

coercition *n.f.* ពលការ, អំណាច, ការបង្ខំ (ឧ. pouvoir de coercition)

coéternel,elle *a.* ដែលនៅរួមគ្នាជាអនន្តកាល

cœur *n.m.* បេះដូង; ក៏ (បៀរូបបេះដូង)។ *Fig.* ហទយវត្ថុ, បេះដូង (ភាគសំខាន់) (ឧ. le cœur du problème); ភាគកណ្ដាល (ឧ. le cœur d'une ville)។ *Bot.* បណ្ដូល, ខ្លឹមឈើ។ au cœur de l'été កំពុងពេញវស្សានរដូវ ។ ចិត្ត (ឧ. avoir le cœur à l'ouvrage)។ un cœur de pierre ចិត្តរឹង ។ សេចក្ដីក្លាហាន (ឧ. homme de cœur មនុស្សក្លាហាន ឬ មនុស្សមានចិត្ត) ។ avoir mal au cœur ពិបាកចិត្ត ។ prendre une chose à cœur យកចិត្តទុកដាក់ ។ ouvrir son cœur ប្រាប់អស់ (គ្មានលាក់)។ avoir le cœur gros ព្រួយចិត្ត, កើតទុក្ខ ។ peser sur le cœur ធ្វើឲ្យពិបាកចិត្ត ។ aller au cœur ធ្វើឲ្យរំជួលចិត្ត។ en avoir le cœur net អស់ចិត្ត។ travailler avec cœur ធ្វើការយ៉ាងរហ័សរហួន ។ redonner du cœur ធ្វើឲ្យមានកម្លាំងឬឲ្យមានសេចក្ដីក្លាហានឡើងវិញ។ par cœur *loc. adv.* ចាំរត់មាត់ ឬ ចាំស្ទាត់។ à cœur ouvert ឬ cœur à cœur *loc. adv.* ដោយស្មោះ ឬ ដោយត្រង់អស់ពីពោះ។ à contre cœur *loc.adv.* ដោយមិនចង់, ដោយបង្ខំ, ដោយស្ដាយ។ de bon cœur *loc.adv.* ដោយរីករាយ ។ de tout cœur ឬ avec cœur *loc.adv.* ដោយអស់ពីចិត្ត, ដោយខិតខំ ។ *Prov.* loin des yeux, loin du cœur ឃ្លាតកាយណាយចិត្ត

coexistant,e *a.* ដែលមានសហត្ថិភាព, ដែលរួមរស់; ដែលមានដំណាលគ្នា

coexistence *n.f.* សហត្ថិភាព, ការរួមរស់ (ឧ. coexistence pacifique)

coexister *v.i.* រួមរស់, មាន ឬ រស់នៅ

ជាមួយគ្នា

coffrage *n.m.* ល្វ ឬ ក្ដារដែលប្រុះគាំ អណ្ដូង ឬ រោណធ្លាន; ពុម្ពស៊ីម៉ង់

coffre *n.m.* ហិប, ទូប្រាក់; បន្ទប់ដាក់អីវ៉ាន់នៃរថយន្ត។ les coffres de l'Etat រតនាគារសាធារណៈ ។ *Fam.* ទ្រូង (ឧ. avoir le coffre solide)

coffre-fort *n.m.* ទូដែក (*pl.* des coffres-forts)

coffrer *v.t.* ដាក់ល្វ ឬ ប្រុះក្ដារគាំ ។ *Fam.* ដាក់គុក

coffret *n.m.* ហិបតូច

coffretier *n.m.* អ្នកធ្វើហិប

cofidéjusseur *n.m.* អ្នកធានារួមក្នុងបំណុលតែមួយ

cogérance *n.m.* ការកាន់កាប់រួម

cogérant,e *n.m.* អ្នកកាន់កាប់រួម

cogestion *n.f.* អភិបាលឬការកាន់កាប់រួម

cogitation *n.f.* ការគិត

cogiter *v.i. Fam.* គិត

cognac *n.m.* ស្រាកូញ៉ាក់

cognat *n.m.* ញាតិសាលោហិត(ផ្ទុយនឹងញាតិពន្ធ)

cognation *n.f.* ភាពជាញាតិសាលោហិត (ផ្ទុយនឹងញាតិពន្ធ)

cogne *n.m. Arg.* ភ្នាក់ងារក្រុមនគរបាល

cognée *n.f.* ដឹង, ពូថៅ ។ *Fig.* jeter le manche après la cognée បោះបង់ចោលទាំងអស់ (ដោយនឿយណាយ)

cognement *n.m.* ការដំបញ្ចូល, ការវាយ

cogner *v.t.* ដំបញ្ចូល, វាយ។ *v.i.* ទង្គិច, គោះ(ឧ.cogner à une porte)។ *Pop.* se cogner *v.pr.* វាយគ្នា, ទង្គិចគ្នា

cognitif,ive *a.* អាចស្គាល់ ឬ ដឹង

cognition *n.f.* ការស្គាល់ ឬ ដឹង

cohabitation *n.f.* ការរស់នៅរួមគ្នា ។ *Part.* ការរួមសង្វាស

cohabiter *v.t.* រស់នៅរួមគ្នា;រួមសង្វាស

cohérence *n.f.* ភាពជិតស្និទ្ធ ។ *Fig.* សេចក្ដីទាក់ទងគ្នាដំកហូរហែ

cohérent,e *a.* ជាប់ស្និទ្ធ (ឧ. molicule cohérent) ។ *Fig.* ដែលទាក់ទងគ្នារើកហូរហែ (ឧ. raisonnement cohérent)

cohériter *v.i.* ទទួលមត៌ករួមគ្នា

cohéritier,ère *n.* សហទាយាទ, អ្នកទទួលមត៌ករួមគ្នា

cohésif,ive *a.* ដែលភ្ជាប់ស្និទ្ធ

cohésion *n.f.* សំនិទ្ធភាព, កម្លាំងស្អិតជាប់។ *Phys.* force de cohésion

សំនិទ្ធពល (ម.ព. attraction ផង)។ *Fig.* ការរួបរួម (ឧ. la cohésion de différentes parties d'un Etat); ភាពតំណទាក់ទងគ្នាល្អហៃ(ឧ. la cohésion d'un exposé)

cohorte *n.f.* កងទ័ព ។ *Fam.* ហ្វូងមនុស្ស

cohue *n.f.* ប្រជុំធំ (មនុស្ស); ការប្រជុំអ៊ូអរ (ឧ. fuir la cohue); ការច្របូកច្របល់ (ឧ. la cohue d'un grand magasin)

coi,coite *a.* ស្ងៀមស្ងាត់ ។ se tenir coi នៅស្ងៀម (គិតហើយមាត់)

coiffant,e *a.* ដែលពាក់ត្រូវល្មម (ឧ. un chapeau très coiffant)

coiffe *n.f.* មួកស្រី;ស្រោបទារក។ *Bot.* ក្បាលឬសកែវ ។ coiffe de chapeau ទ្រនាប់មួកខាងក្នុង

coiffé,e *a.* ដែលបានរៀបចំសក់; ដែលពាក់មួក ។ *Fig.* ដែលជាប់នឹង (ឧ. être coiffé d'une personne)។ être né coiffé មានសំណាង

coiffer *v.t.* បំពាក់ (លើក្បាល) (ឧ. coiffer d'un chapeau); រៀបចំសក់។ *Mil.* coiffer un objectif បាញ់ត្រូវ, វាយយកបាន ។ coiffer sainte Catherine ដល់អាយុ២៥ឆ្នាំ ហើយនៅក្រៅនៅឡើយ (ចំពោះតែស្រី) ។ *Fam. & Fig.* se faire coiffer sur le poteau បណ្តោយឲ្យគេឈ្នះបាននៅពេលដែលទៅដល់ទី។ se coiffer de *v.pr.* ពាក់មួក ឬ ទទួរ; រៀបចំសក់ខ្លួនឯង ។ *Fam.* ស្រឡាញ់ងប់

coiffeur,euse *n.* ជាងកាត់ ឬ អ៊ុតសក់

coiffeuse *n.f.* តុសំអាង

coiffure *n.f.* ប្រដាប់ពាក់ក្បាល; ការរៀបចំសក់(ឧ. salon de coiffure)

coin *n.m.* ត្រាបោះប្រាក់ ឬ គ្រឿងមាស; ជ្រុង (ឧ. coin d'une rue);កៀន, មុម(ឧ. les coins d'une chambre); ទីដីតូច (ពាក្យប្រើជាសាមញ្ញច្រើនថាដីមួយក្រូក) (ឧ. un coin de terre); មួស (ស្នៀត) ; ស្រុកចុងកាត់មាត់ញក (ឧ. vivre dans un petit coin de campagne) ។ du coin de l'œil ចុងភ្នែក ។ les quatre coins ល្បែងស្វាដិតណ្ដើមទី។ *Fig.* លក្ខណៈ (ឧ. œuvre marquée au coin du génie)

coinçage *n.m.* ការវាយមួសឬស្នៀត

coincement *n.m.* ភាពគាំង (ម៉ាស៊ីន)

coincer *v.t.* វាយមូស, វាយស្នៀត ។ *Fam.* ផ្ទប់ (ឧ. coincer quelqu'un derrière une porte)។ se coincer *v.pr.* គាំង

coïncidence *n.f.* *Math.* ភាពផ្គាប់គ្នាបាន។ *Fig.* ភាពកើតឡើងព្រមគ្នា, ការគាប់ជួន (ឧ. heureuse coïncidence)

coïncident,e *a.* *Math.* ដែលផ្គាប់គ្នាបាន(ឧ. lignes, figures coïncidentes); ដែលកើតឡើងព្រមគ្នា

coïncider *v.t.* ជាប់គ្នា - ត្រូវគ្នា ឬ ដូចគ្នា ដោយជិតស្និទ្ធ (ឧ. ces deux surfaces coïncident)។ *Fig.* កើតឡើងព្រមគ្នា (ឧ. la découverte de la boussole coïncide avec celle de la poudre)

coin-coin *n.m.* *inv.* កាបៗ(ពាក្យត្រាប់សំប្រែកទា)

coïnculpé,e *n.* អ្នកជាប់ចោទរឿងដូចគ្នា

coïntéressé,e *a.* ដែលមានប្រយោជន៍រួម

coir *n.m.* ស្រកីដូង (f. kaïr)

coït *n.m.* ការសេពមេថុនធម្ម

coke *n.m.* កាកធ្យូងថ្ម (ធ្យូងថ្មចំហុយ)

cokéfaction *n.f.* ការចំហុយធ្វើកាកធ្យូងថ្ម

cokéfiable *a.* ដែលអាចចំហុយធ្វើកាកធ្យូងថ្មបាន

cokéfier *v.t.* ចំហុយធ្វើកាកធ្យូងថ្ម

cokerie *n.f.* រោងចក្រធ្វើកាកធ្យូងថ្ម

col *n.m.* ក (ឧ. col d'une bouteille); ករាវ, ស្រងក ។ *Géogr.* ច្រកភ្នំ, ទ្វារភ្នំ

colback *n.m.* កាតិបម្យ៉ាងរាងសាជីកំពុត

col-bleu *n.m.* *Fam.* ទាហានជើងទឹក

cold-cream *n.m.* ក្រែមរងា (ថ្នាំក្រមួនសម្រាប់លាបនៅរដូវរងាកុំឲ្យបែកស្រកា)

colégataire *n.* អ្នកទទួលអច្ច័យទានរួម

coléoptères *n.m.* *pl.* កញ្ចុកបត្ត(សត្វដែលមានស្លាបរឹងគ្របលើស្លាបស្តើង)

colère *n.f.* កំហឹង(ឧ. la colère est mauvaise conseillère)។ *Fam.* កំហឹងឆួល ។ *Fig.* ការបោកបក់ខ្លាំង (ឧ. la colère des vents, des flots)។ *a.* ដែលខឹង(ឧ. personne colère)

coléreux,euse ឬ **colérique** *a.* ដែលឆាប់ខឹង, ដែលមានចិត្តស្រាល

colibri *n.m.* ចាបចង្រ្កង់

colifichet *n.m.* របស់ឥតតម្លៃ; នំសម្រាប់បក្សី

colimaçon *n.m.* ខ្យងហៀន ។ es-

calier en colimaçon ជណ្តើរវៀនគួចខ្យង (ម.ព. escalier ផង)

colin-maillard *n.m.* ល្បែងរាវបង្គង (គេបិទមុខអ្នកលេងម្នាក់ ឲ្យស្ទាបរកអ្នកឯទៀត ហើយទាយឈ្មោះ)

colique *n.f.* រោគចុកពោះ (ឧ. les fruits verts, les boissons glacées peuvent causer des coliques)។colique de plomb រោគចុកពោះបណ្តាលអំពីពុលសំណ។ colique hépatique រោគចុកថ្លើម ។ colique néphrétique រោគចុកផ្លូវនោម ។ *Fig. & fam.* donner la colique ធ្វើឲ្យកើតទុក្ខ ។ avoir la colique ខ្លាច

colis *n.m.* ភណ្ឌិកា, ហិបឬកញ្ចប់ទំនិញ។ colis postal ភណ្ឌិកាប្រៃសណីយ

colite *n.f.* រោគរលាកពោះវៀនធំ

colitigant,e *a.* ដែលប្តឹងគ្នាទៅវិញទៅមក

collaborateur,trice *n.* សហការី-រិនី [សះ-ហះ-កា-រ៉ី-រិនី]។ *Spécialem.* អ្នកចូលដៃនឹងសត្រូវ

collaboration *n.f.* សហការ [សះ-ហះ-]; ក្រុមសហការី។ *Spécialem.* ការចូលដៃនឹងសត្រូវ

collaborationniste *a* អ្នកសហការនិយម(អ្នកនិយមខាងចូលដៃនឹងសត្រូវ)

collaborer *v.i.* ធ្វើសហការ

collage *n.m.* ការបិទក្រដាសជញ្ជាំង;ការបិទកាវ;ភាពវត្ថុបិទជាប់; ការធ្វើស្រាឲ្យថ្លា។ *Fig. & Fam.* ភាពប្តីប្រពន្ធគតខាន់ស្លា

collant,e *a.* ស្អិត (ឧ. la glu est une matière collante); ដែលក្តាប, ដែលបញ្ចេញរាង (ឧ. pantalon collant)។*Fam.* ដែលរំខាន។ *n.m.* សំលៀកបំពាក់ក្តាបនឹងសាច់

collatéral,e,aux *a.* ដែលជាប់ ឬ ទាក់ទងដោយជ្រុងមួយ ។ ligne collaterale ម.ព. ligne ។ points collatéraux អនុទិស ។ *a.&n.* សាខាញាតិ(អ្នកដែលកើតចេញពីគោត្រជាមួយគ្នាដែរ តែបែកទៅជាមែកដទៃ ដូចយ៉ាងបងប្អូនបង្កើត, មាមីងនឹងក្មួយ បងប្អូនជីដូនមួយ ជីទួតមួយ ចុះរៀងទៅ)

collation *n.f.* ការឲ្យសញ្ញាបត្រ; ការផ្ទៀងផ្ទាត់អត្ថបទ;ការស្រស់ស្រូប(ពេលរសៀល)

collationnement *n.m.* ការផ្ទៀងផ្ទាត់

collationner *v.t.* ផ្ទៀងផ្ទាត់អត្ថបទ ។ *v.i.* ស្រស់ស្រូប (ពេលរសៀល)

colle *n.f.* កាវបិទ (ឧ. colle de pâ-

te)។ colle forte កាវស្បែកក្របី ។ colle blanche ជាបរម៉ាន ។ *Fig.* ឧបសគ្គ; បញ្ហាពិបាក, សំនួរពិបាកឆ្លើយ (ឧ. poser une colle) ។ *Arg. scol.* ពេលសួរមេរៀន; ទណ្ឌកម្មបង្ខំឲ្យទៅសាលាក្រៅពេលម៉ោងរៀន

collecte *n.f.* ការអង្គាស

collecter *v.t.* ប្រមូល, អង្គាស; ទារពន្ធ (និយាយចំពោះតែប្រាក់)

collecteur *n.m.* អ្នកទារពន្ធ; អ្នកអង្គាស, អ្នកប្រមូល (ចំពោះតែប្រាក់)

collectif,ive *a.* រួមគ្នា (ឧ. représentation collective)។ *Fin. n.m.* ថវិកាប្រតួន

collection *n.f.* សមុច្ច័យ, សមូហកម្ម; ការសម្រាំង; ការប្រមូលរូបរួមវត្ថុមួយពួក

collectionner *v.t.* ធ្វើសមូហកម្ម; សម្រាំងប្រមូលរូបរួមវត្ថុមួយពួក

collectionneur,euse *n.* អ្នកសម្រាំង; អ្នកធ្វើសមូហកម្ម

collectivement *adv.* ដោយរួមគ្នា

collectivisation *n.f.* ការអនុវត្តតាមសមូហការនិយម

collectiviser *v.t.* អនុវត្តតាមសមូហការនិយម

collectivisme *n.m.* សមូហការនិយម

collectiviste *a.* នៃសមូហការនិយម ។ *n.* អ្នកសមូហការនិយម

collectivité *n.f.* ពួកមួយក្រុម; សមូហភាព ។ collectivité privée សមូហភាពឯកជន ។ collectivité publique សមូហភាពសាធារណៈ

collège *n.m.* សហសេវិកា, ក្រុមអ្នកមានឋានៈស្មើគ្នា (ឧ. collège de cardinaux)។ collège électoral គណៈអ្នកបោះឆ្នោត ។ *Ens.* អនុវិទ្យាល័យ; ក្រុមសិស្សអនុវិទ្យាល័យ

collégial,e,aux *a.* នៃសហសេវិកា

collégien,enne *a.* នៃអនុវិទ្យាល័យ, នៃសិស្សអនុវិទ្យាល័យ ។ *n.* សិស្សអនុវិទ្យាល័យ

collègue *n.* សហសេវិក-វិកា (អ្នកមានមុខការដូចគ្នា)

collement *n.m.* ភាពជាប់គ្នា

coller *v.t.* ឲ្យជាយ (សំពត់); បិទ (ដោយកាវ ឬ អ្វីដែលស្អិត); ដាក់ផ្ទាប់; ផ្អោប។ coller du vin ធ្វើឲ្យស្រាឡើងថ្លា។ *Fam.* ផ្ចាញ់ (ធ្វើកុំឲ្យហើបមាត់រួច)(ឧ. il m'a collé d'un seul mot)។ *Fig.* ដាក់ទោសសិស្ស (ឧ. coller un élève); ធ្លាក់ (មិនឲ្យជាប់ក្នុងការប្រឡង)។ *Fam.* coller une

gifle ទះមួយកំផ្លៀង។ *v.i.* ស្អិតជាប់ (ឧ. ce papier colle mal); ត្រូវល្មម (ក្លំ) (ឧ. cet habit colle bien)។ *Fam.* ត្រូវ (មិនទាស់ភ្នែក, មិនឆ្គង)

collerette *n.f.* ស្រងក; វណ្ណាបំពង់

collet *n.m.* កអាវ; អាវវែងឃ្លានដៃ។ prendre au collet ក្របួចក, ចាប់។ *Chass.* ផង់, បន្ទង់។ *Anat.* collet d'une dent គល់ធ្មេញ ។ *Fig.* collet monté ដែលធ្វើឫកជាខ្ពស់ហួសហេតុ (ឧ. cette femme est bien collet monté)

colleter *v.t.* ក្របួចក។ *v.i.* ដាក់ផង់ ឬ បន្ទង់។ se colleter *v.pr.* ប្រវាយគ្នា

colleteur *n.m.* អ្នកដាក់ផង់ ឬ បន្ទង់

colletin *n.m.* គ្រោះការពារកនិងស្មា

colleur *n.m.* អ្នកបិទ (ឧ. colleur d'affiche)។ *Arg. scol.* អ្នកសួរពិសេស

colleuse *n.f.* ម៉ាស៊ីនឲ្យជាយសំពត់

colley *n.m.* ឆ្កែគង្វាលម៉្យាង

collier *n.m.* កងក, ខ្សែក (ឧ. collier de perle); កណ្ឋាភរណ [កន់-ថា-ភ័ន]។ collier de l'Ordre de la R.A.U. កណ្ឋាភរណឥស្សរិយយសនៃ ស.អ.រ. (សាធារណរដ្ឋអារ៉ាបរួម)។ ប្រឡោក (ឆ្កែ); ស្រងក (ប្រដាប់ទឹមសេះ); ភ្លូតក (មាន់) ។ cheval franc du collier សេះដែលប្រឹងអូសរទេះ ។ *Fig.* homme franc du collier មនុស្សត្រង់ហើយក្លាហាន។ coup de collier ការប្រឹងប្រែង។ collier de misère ទុក្ខវេទនាធម្មតា។ កិច្ចការដែលឲ្យធុញទ្រាន់ (ឧ. reprendre le collier)

colliger *v.t.* ស្រង់អត្ថបទសៀវភៅ; ប្រមូលជាក្រុម

colline *n.f.* ភ្នំតូច

collision *n.f.* ការប៉ះទង្គិចគ្នា ។ *Fig.* ការប្រយុទ្ធ (ឧ. une collision entre le peuple et l'armée)

collocation *n.f.* ការចុះឈ្មោះម្ចាស់បំណុលរៀងតាមលំដាប់ដែលត្រូវសងប្រាក់ ; ការចាត់ថ្នាក់

colloïdal,e,aux *a.* អន្ទិល

colloïde *n.m.* ជាតិអន្ទិល

colloque *n.m.* ការសន្ទនា; សន្និសីទខាងនយោបាយ ឬ ខាងសាសនា

colloquer *v.t.* យកចេញឲ្យបាត់ពីមុខ (ដោយដាក់ទៅកន្លែងណាមួយ - លក់ចោល ឬ ឲ្យទៅគេ ដើម្បីឲ្យផុតស្រឡះ

ពីខ្លួន) (ឧ. colloquer un invité au bout de la table; colloquer un paquet à quelqu'un)។ *Pop.* colloquer deux claques ទះពីរផែ ។ *Dr.* colloquer des créanciers ចុះឈ្មោះម្ចាស់បំណុលរៀងតាមលំដាប់ដែលត្រូវសងប្រាក់ ។ se colloquer *v.pr.* *Fam.* រកកន្លែងធ្វើការ

collotypie *n.f.* ការបោះពុម្ពជាហ្វូយ

collusion *n.f.* ការគប់គិត

collusoire *a.* ដែលធ្វើដោយគប់គិត

collyre *n.m.* ថ្នាំភ្នែក

colmatage *n.m.* ការបម្រើនដីល្បប់ (ឧ. le colmatage d'un sol stérile)

colmater *v.t.* បម្រើនដីល្បប់។ *Abusiv.* បិទប្រហោង

colocataire *n.* អ្នកជួលផ្ទះជាមួយគ្នា

colombe *n.f.* ព្រាប

colombier *n.m.* ផ្ទះព្រាប (ពាក្យកាព្យ) (ម.ព. pigeonnier ផង)

colombin,e *a.* ស្មើរក្រហមស្មើរស្វាយ (ឧ. soie colombine) ។ *n.f.* អាចម៍ព្រាប នឹង បសុបក្សី (ប្រើជាដី) ។ *n.m.pl.* កបោតបក្សី [ក:-ប៉ោ-ត:-] (ពួកបក្សីសត្វព្រាប, លលក)

colombophile *a.&n.* ដែលស្រឡាញ់ព្រាប,ដែលចូលចិត្តចិញ្ចឹមព្រាប។ *Mil.* ទាហានថែព្រាប

colombophilie *n.f.* សិល្បៈចិញ្ចឹមព្រាប

colon *n.m.* អាណានិគមជន; អ្នកជួល ឬ ប្រវាស់ដី ។ colon partiaire អ្នកទទួលប្រវាស់ដី

côlon *n.m.* ពោះវៀនធំ

colonage *n.m.* ការប្រវាស់ដី

colonat *n.m.* ភាពអាណានិគមជន; របៀបប្រវាស់ដី

colonel *n.m.* វរសេនីយឯក(ឧ. le colonel commande normalement un régiment)

colonelle *a.&n.f.* កងវរសេនាធំ(ដែលមានវរសេនីយឯកជាមេបញ្ជាការ); ភរិយាវរសេនីយឯក

colonial,e,aux *a.* នៃអាណានិគម (ឧ. régime colonial); ដែលមកពីអាណានិគម (ឧ. denrées coloniales) ។ *n.f.* ទ័ពនៅអាណានិគម ។ *n.m.* ប្រជាជននៅអាណានិគម

colonialisme *n.m.* អាណានិគមនិយម

colonialiste *n.m.* អ្នកអាណានិគមនិយម

colonie *n.f.* អាណានិគម, ស្រុកចំណុះ

(ឧ. colonies d'Afrique); ឧបនិវេសន៍ (ក្រុមអ្នកចេញទៅនៅប្រទេសក្រៅ) (ឧ. colonie française de New York)។ colonie de vacances ឧបនិវេសន៍វិស្សមកាល ។ ក្រុម (ឧ. colonie de peintres, d'abeilles)។ colonie pénitentiaire ពន្ធនាគារក្មេង

colonisable *a.* អាចដាក់ជាអាណានិគមបាន

colonisateur,trice *n.&a.* ឧបនិវេសិក

colonisation *n.m.* ឧបនិវេសនកម្ម; អាណានិគមកិច្ច

coloniser *v.t.* ធ្វើឧបនិវេសនកម្ម (ឧ. les Anglais ont colonisé l'Australie); តាំងអាណានិគម

colonnade *n.f.* ជួរសសរ

colonne *n.f.* ស្តម្ភ, សសរ ។ *Fig.* ពំនឹង (ឧ. Bossuet fut une des colonnes de l'église); បូជនីយស្តម្ភ(បូ-ជៈ-នីយៈ-)(ឧ. la colonne Vendôme rappelle les exploits de la Grande Armée); ជួរ; ខ្នង់ទំព័រ(ឧ les colonnes d'un journal); កងពលដើរជាជួរ ។ *Par ext.* កងពលបំពេញបេសកកម្មពិសេស (ឧ. colonne de secours)។ cinquième colonne កងទីប្រាំ (បណ្តាអ្នកក្លែងខ្លួនចូលក្នុងកងទ័ពបច្ចាមិត្ត)។ colonne vertébrale ឆ្អឹងខ្នង។ colonne d'un lit បង្គោលគ្រែ

colonnette *n.f.* សសរតូច

colophane *n.f.* ជ័រទ្រ (ជ័ររូតខ្សែឆាកទ្រ) (គេហៅថា arcanson ដែរ)

coloquinte *n.f.Pop.* ក្បាល

colorant,e *a.* ដែលសម្រាប់ជ្រលក់ពណ៌ (ឧ. substances colorantes)

coloration *n.f.* ការដាក់ពណ៌ ឬជ្រលក់ពណ៌; ភាពមានពណ៌(ឧ.coloration de la peau)

coloré,e *a.* ដែលមានពណ៌ (ឧ. verre coloré en bleu); ដែលមានពណ៌ឆើត (ឧ. teint coloré) ។ *Fig.* ឆើត, ស៊ើរើក (ឧ. style coloré)

colorer *v.t.* ជ្រលក់ពណ៌, ធ្វើឲ្យមានពណ៌ (ឧ. le soleil colore les fruits)។ *Fig.* se colorer *v.pr.* ឡើងពណ៌

coloriage *n.m.* ការដាត់ពណ៌

colorier *v.t.* ដាត់ពណ៌, ដាក់ពណ៌ (គំនូរ) (ឧ. colorier un dessin)

colorimètre *n.m.* វណ្ណមាត្រ (ប្រដាប់ស្ទង់កំរិតពណ៌ទឹក)

coloris *n.m.* សិល្បៈខាងផាត់ពណ៌; លំអនៃពណ៌បំរុះ; សម្រស់ពណ៌មុខ-ផ្កា-ផ្លែ ។ ល ។ (ឧ. pêche d'un beau coloris)

coloriste *n.* វិចិត្រករខាងផាត់ពណ៌

colossal,e,aux *a.* ដែលមានទំហំហួសខ្នាត (ឧ. statue colossale) ។ *Fig.* ធំសំបើម (ឧ. entreprise colossale)

colossalement *adv.* យ៉ាងសំបើម

colosse *n.m.* បដិមាករធំមហិមា (ឧ. le colosse de Rhodes); មនុស្ស ឬសត្វធំមហិមា (ឧ. Pierre le grand était un colosse)

colostrum [–trom'] *n.m.* ទឹកដោះដំបូង (ឧ. le colostrum a des propriétés purgatives)

colportage *n.m.* ការរែកលក់; ការផ្សាយ

colporter *v.t.* រែកលក់ ។ *Fig.* ផ្សាយ (ឧ. colporter une nouvelle)

colporteur,euse *n.* អ្នករែកលក់ ។ *Fig.* អ្នកផ្សាយដំណឹង (ឧ. colporteur de mauvaises nouvelles)

colt *n.m.* កាំភ្លើងដៃកុល

coltinage *n.m.* របរអ្នកលីសែងវត្ថុធ្ងន់

coltiner *v.t.* លីសែងវត្ថុធ្ងន់

coltineur *n.m.* អ្នកលីសែងវត្ថុធ្ងន់

coma *n.m.* ដំណើរភ្លឹក (រលត់ស្មារតី)

comandant *n.m.* សហាណត្តិទាយក (អ្នកប្រគល់អាណត្តិរួមគ្នា)

comateux,euse *a.* ដែលឲ្យភ្លឹក (ឧ. fièvre comateuse) ។ *a.* & *n.* ដែលភ្លឹក

combat *n.m.* ការប្រយុទ្ធ (ឧ. livrer un combat ចូលប្រយុទ្ធ ។ soutenir un combat ទប់ទល់ការប្រយុទ្ធ) ។ *Fig.* ការប្រយុទ្ធ (នឹងឧបសគ្គ) (ឧ. la vie est un combat perpétuel); ការភរែក, ភាពកើតទុក្ខ ។ combat singulier ការប្រយុទ្ធតត្ថ ។ combat naval ការប្រយុទ្ធក្នុងសមុទ្ទ ។ coq de combat មាន់ប្រជល់ ។ poisson de combat ត្រីក្រឹម (ម.ព. combattant ផង) ។ hors de combat លែងប្រយុទ្ធបាន (ដោយខូចខាតច្រើន ឬរបួសធ្ងន់)

combatif,ive *a.* ដែលចូលចិត្តប្រយុទ្ធ; កាច (ដែលចង់ឈ្នះគេ) (ឧ. humeur combative)

combativité *n.f.* ការចូលចិត្តប្រយុទ្ធ

combattant,e *a.* ដែលប្រយុទ្ធ (ឧ. unité combattante) ។ *n.m.* អ្នកចំបាំង, អ្នកប្រយុទ្ធ, យោធិន ។ *Zool.* ត្រីក្រិម

combattre *v.t.* ប្រយុទ្ធ, តយុទ្ធ (ឧ. combattre l'ennemi); ទប់ទល់កុំឲ្យរាលដាល (ឧ. combattre un incendie) ។ *Fig.* combattre ses passions រម្ងាប់ឬរំលត់តណ្ហា ។ *v.i.* ប្រយុទ្ធ, វាយគ្នា

combien *adv.* ប៉ុន្មាន (ប្រាប់ចំនួន = ឧ. combien d'étoffe? combien sont-ils?; ប្រាប់ទំហំ = ឧ. combien mesure-t-il?; ប្រាប់តម្លៃ= ឧ. combien a-t-on payé?); យ៉ាងណា (ឧ. combien il était brave) ។ *n.m. inv. Fam.* ទីប៉ុន្មាន (ឧ. le combien êtes-vous?); ថ្ងៃណា ឬ ថ្ងៃប៉ុន្មាន (ឧ. le combien sommes-nous?); ក្នុងប៉ុន្មានពេលមានម្តង (ឧ. l'autobus passe tous les combiens?)

combinaison *n.f.* សមាយោគ, ការរៀបចំ, ការផ្សំគ្នា (ឧ. combinaison de chiffres, de couleurs); សំលៀកបំពាក់ក្នុងនៃស្ត្រី; សំលៀកបំពាក់ធ្វើការ ។ *Fig.* ការគិតគូរ (ដើម្បីឲ្យបានសម្រេចគោលបំណង) (ឧ. les combinaisons d'un homme politique)

combinat *n.m.* សង្គហុស្សាហកម្ម

combine *n.f.* ការគិតគូរ (ដើម្បីឲ្យបានសម្រេចគោលបំណង

combiné,e *a. Mil.* ដែលជាភារៈនៃទ័ពច្រើនពួក (ឧ. opération combinée)

combiner *v.t.* រៀបចំ, ផ្សំគ្នា (ឧ. combiner les couleurs) ។ *Fig.* គិតគូរ, រៀបចំ (ឧ. combiner un plan)

comble *n m.* អ្វីៗដែលពេញកំពុង (ឧ. le comble d'un boisseau d'avoine) ។ *Constr.* ដំបូល (ឧ. être logé sous les combles) ។ *Fig.* កំពូល, កម្រិតខ្ពស់បំផុត (ឧ. le comble de la joie) ។ pour comble de *loc.adv.* ដោយថែមត្រួតលើ ។ de fond en comble ពីក្រោមដល់លើ, គ្មានសល់ (ពីជាតដល់ដំបូល) (ឧ. remuer une maison de fond en comble)

comble *a.* ពេញកំពុង, ពេញហូរហៀរ (ឧ.

la salle est comble) ។ *Fig.* ហួសពេកហើយ, ទ្រាំលែងបានហើយ (ឧ. la mesure est comble)

comblement *n.m.* ការបំពេញ; ការលុប; ការបំពេញបំណង

combler *v.t.* បំពេញ (ឧ. combler une mesure); លុប (ឧ. combler un fossé)។ *Fig.* បំពេញបំណង(ឧ. combler les désirs de quelqu'un) ។ ឲ្យច្រើន (ឧ. combler de bienfaits)។ combler la mesure ធ្វើហួសហេតុ ។ se combler *v. pr.* ឡើងពេញ ។ *Fig.* បំពេញគ្នាទៅវិញទៅមក

combustibilité *n.f.* ឥន្ធនីយភាព,ភាពដុតឆេះ

combustible *a.* ឥន្ធនីយ, ដែលដុតឆេះ ។ *n.m.* ឥន្ធនៈ, ទហនវត្ថុ, វត្ថុសម្រាប់ដុត (ឧ. la tourbe est un combustible de qualité inférieure) ។ combustibles fossiles ឥន្ធនៈជាសាណ៌ភូត (ធ្យូងថ្ម នឹងប្រេងកាត)

combustion *n.f.* ឥន្ធនកម្ម,ទហនកម្ម, ការឆេះ (ឧ. l'air est nécessaire à la combustion)

comédie *n.f.* ហាស្យនាដកម្ម,រឿងកំប្លែង (ឧ. comédie de Molière); ល្ខោន;ការសម្ដែងរឿង(ឧ.donner la comédie) ។ *Fig.* រឿងឲ្យសើច; អាការពើ(ឧ.jouer la comédie); ការញាក់មុខ ។ personnage de comédie ជនដែលគេមិនយកជាការ

comédien,enne *n.* ហាស្យនាដករ,អ្នកលេងរឿងកំប្លែង។*Fig.*មនុស្សលាក់ពុត

comestible *a.* ដែលបរិភោគបាន ។ *n.m.pl.* អាហារ

cométaire *a.* នៃធូមកេតុ

comète *n.f.* ធូមកេតុ (ផ្កាយដុះកន្ទុយ)

comices *n.m.* សន្និបាតប្រជារាស្ត្ររ៉ូម៉ាំង។ comice agricole សន្និបាតកសិករ

comique *a.* ខាងរឿងកំប្លែង (ឧ.poète comique); គ្រមាច់, កំប្លែង, គួរសើច (ឧ.aventure comique)។*n.m.* រឿងកំប្លែង (ឧ. le comique de la situation); អ្នកនិពន្ធ ឬ អ្នកលេងរឿងកំប្លែង

comiquement *adv.* យ៉ាងកំប្លែង

comité *n.m.* គណៈកម្មាធិការ ។ comité directeur គណៈកម្មាធិការនាយក ។ comité de solidari-

té គណៈកម្មាធិការសាមគ្គីធំ ។ comité d'urbanisme et d'habitat គណៈកម្មាធិការក្បួនតែងទីក្រុងនិងលំនៅ ។ petit comité ការជួបជុំស្និទ្ធស្នាល (រវាងមិត្តភក្តិ)

command *n.m.* អ្នកឈរឈ្មោះទិញ ឬ ដេញថ្លៃឲ្យគេ(ម.ព.déclarationផង)

commandant *n.m.* វរសេនីយត្រី (ឋានន្តរសក្តិ); អ្នកបញ្ជាការ (មុខងារសម្រាប់ឧត្តមសេនីយ); អ្នកបង្គាប់ការ (មុខងារសម្រាប់វរសេនីយ);អ្នកកាន់ការ (មុខងារសម្រាប់អនុសេនីយ) ។ commandant en chef អគ្គបញ្ជា ។ commandant en second អនុបញ្ជា ។ commandant du quartier អ្នកបង្គាប់ការសង្កាត់ ។ commandant du sous-quartier អ្នកបង្គាប់ការសង្កាត់រង។ commandant de secteur អ្នកបង្គាប់ការប៉ែក ។ commandant d'armes អាវុធបតី

commande *n.f.* បញ្ជាទិញ; បញ្ជា (ប្រដាប់ធ្វើឲ្យម៉ាស៊ីនដើរ) ។ *Fig.* de commande *loc.adv.* ដោយបង្ខំ ឬ ក្លែង (ឧ. pleurs de commande) ។ tenir les commandes កាត់ការ, ដឹកនាំ

commandement *n.m.* សេចក្តីបង្គាប់ ឬ បញ្ជា (ឧ. commandement verbal); អំណាចបញ្ជា (ឧ. avoir le commandement d'un bateau); សិក្ខាបទ(ឧ.commandement de Dieu); ដីកាបញ្ជា (គេតាគារជាតិ); កងបញ្ជាការ; អំណាចបញ្ជាការ។ commandement en chef អគ្គបញ្ជាការ។ commandement des forces nationales បញ្ជាការសេនានុភាពជាតិ ។ *Dr.* ដីកាបង្ខំ

commander *v.t.*បង្គាប់, បញ្ជា (ឧ. je lui ai commandé de partir)។service commandéសេវាបញ្ជា។បញ្ជា(មានអំណាចលើ)(commander une armée); បង្ខំឲ្យមាន (ឧ. commander le respect);បញ្ជាទិញ(ឧ.commander un repas) ។ *Méc.* បញ្ជា (ធ្វើឲ្យមានចលនា) ។ *v.i.* ត្រួតត្រា, មានអំណាចលើ (ឧ. le père commande à ses enfants); គ្រប់សង្កត់ (ឧ. commander à ses passions)។ se commander

v.pr. ត្រូវបង្ខំ; ជាប់គ្នា(ទាក់ទងគ្នា)(ឧ. ces salles se commandent)

commandeur *n.m.* ក្រុមសេនា(គ្រឿងឥស្សរិយយស) (ឧ.commandeur de la Légion d'honneur)

commanditaire *n.m.* សហេតិកធន-ការី, អ្នកចេញដើមទុន

commandite *n.f.* ឬ **société en commandite** សមាគមអនុប្បទាន (សមាគមពាណិជ្ជកម្មដែលមានសមាជិកខ្លះគ្រាន់តែផ្តល់ទុន មិនចូលកាន់កាប់)

commanditer *v.t.* ធ្វើអនុប្បទាន, ចេញដើមទុន

commando *n.m.* ក្រុមស្ម័គ្រ (ឧ. commando de prisonniers); កងកុម្ម៉ង់ដូ, កងពិសេស (ឧ. commando de marine)។ commando cynophyle កងពិសេសសុនខភក្តិ។ commando de contre guérilla កងពិសេសទល់ទ័ពព្រៃ

comme *conj.* ដូច(ឧ.hardi comme un lion; ceci est arrivé comme je l'espérais); បែប (ឧ. un homme comme lui); ក្នុងឋានៈជា ។ *Conj.* ដោយ, ពីព្រោះ (ឧ. comme je m'ennuyais, je suis sorti); ក្នុងពេលដែល (ឧ. comme je dînais, il arriva)។ *adv.* ណាស់ហ្ន៎! (ឧ. comme il fait noir dans cette salle!); យ៉ាងណាទៅ; បែបណា, ហាក់ដូចជា (ឧ. il était comme muet)។ comme ci, comme çà មិនល្អមិនអាក្រក់ ។

Loc. div. comme tout ណាស់ (ឧ. aimable comme tout)។ tout comme, tout à fait comme ដូច (ឧ. flamber tout comme une allumette)។ ដូចគ្នា, មិនខុសគ្នា (ឧ. je n'ai pas encore donné ma parole, mais c'est tout comme) ។ comme de raison តាមយុត្តិធម៌ (ឧ. payer son écot comme de raison) ។ comme il faut ត្រឹមត្រូវ(ឧ. préparer un dîner comme il faut); ចំណាន ។

Pop. comme s'il en pleuvait ច្រើនណាស់ (ដូចគ្រាប់ភ្លៀង)។ *Prov.* comme on fait son lit on se couche ម្នាក់ៗសាងអនាគតរបស់ខ្លួន (ទទួលផលកម្មរបស់ខ្លួន)

comméмoratif,ive *a.* ដែលរំឭក

commémoration *n.f.* បុណ្យរំឭក;ការរំឭក

commémorer *v.t.* រំឭក

commençant,e *n.* អ្នករៀនថ្មី

commencement *n.m.* ដើមកំណើត; ដើមដំបូង

commencer *v.t.* ចាប់ផ្ដើម(ឧ. commencer un ouvrage)។ *v.i.* ចាប់ពី, មានដំបូង (ឧ. l'été commence le 21 Juin)

commensal,e,aux *n.* អ្នកបរិភោគជាមួយ, អ្នកនៅជាមួយ ឬ នៅជិត

commensurabilité *n.f.* ភាពមានខ្នាតរួម

commensurable *a.* ដែលមានខ្នាតរួម (ឧ.la longueur de la circonférence et son diamètre ne sont pas commensurables)

comment *adv.* ដូចម្ដេច, យ៉ាងណា, បែបណា(ឧ.comment a t- il pu réussir?); ហេតុអ្វី(ឧ. comment s'est-il adressé à moi?)។ *Int.* អុញ៎ះ (សំដែងសេចក្ដីភ្ញាក់ ឬ សេចក្ដីខឹង)(ឧ. comment! vous voilà?)

commentaire *n.m.* បរមាធិប្បាយ, អត្ថាធិប្បាយ (ឧ. commentaire littéraire)។ *Fig.* ការនិយាយដើម (ឧ.faire des commentaires sur autrui) ។ *Fam.* pas de commentaire លែងនិយាយ,នៅស្ងៀម។ *pl.* សារណា

commentateur,trice *n.* អ្នកធ្វើបរមាធិប្បាយ ឬ អត្ថាធិប្បាយ

commenter *v.t.* ធ្វើបរមាធិប្បាយ, ធ្វើអត្ថាធិប្បាយ (ឧ. commenter Virgile); ឲ្យយោបល់លើ, និយាយដើម (ឧ.commenter les actes de quelqu'un)

commérage *n.m.* សំដីអេចរូច

commerçable *a.* អាចធ្វើសេដ្ឋពាណិជ្ជបាន, អាចលក់ដូរបាន

commerçant,e *a.&n.* ពាណិជ្ជករ, អ្នកជំនួញ

commerce *n.m.* ពាណិជ្ជកម្ម, ជំនួញ; (ឧ. commerce de gros); ក្រុមអ្នកជំនួញ (ឧ. le commerce de Phnom- Penh); ហាង (ឧ. quitter son commerce)។ code de commerce ក្រមពាណិជ្ជកម្ម ។ tribunal de commerce តុលា-

ការពាណិជ្ជកម្ម ។ chambre de commerce មន្ទីរពាណិជ្ជកម្ម(ម.ព. chambre ផង)។ livre de commerce សៀវភៅពាណិជ្ជកម្ម (បញ្ជីគណនេយ្យពាណិជ្ជកម្ម) ។ effet de commerce ម.ព. effet។ commerce de gros ពាណិជ្ជធំ។ commerce de demi-gros ពាណិជ្ជធំមធ្យម ។ commerce de détail ពាណិជ្ជរាយ ។ commerce intérieur អន្តោពាណិជ្ជ (ក្នុងប្រទេស) ។ commerce extérieur ពហិពាណិជ្ជ(ក្រៅប្រទេស)។ ការសេពគប់(ឧ. le commerce des honnêtes gens); ឫកពា (ឧ. un homme d'un commerce agréable)។ avoir commerce avec quelqu'un ទៅមក, រាប់រកដោយជិតស្និទ្ធ

commercer *v.i.* ធ្វើពាណិជ្ជកម្ម,ធ្វើជំនួញ, ជួញ

commercial,e,aux *a.* នៃពាណិជ្ជកម្ម (ឧ. entreprise commerciale) ។ *n.f.* រថយន្តពាណិជ្ជ (រថដឹកទំនិញបាន)

commercialement *adv.* តាមផ្លូវជំនួញ

commercialiser *v.t.* ដាក់ជាជំនួញ

commercialité *n.f.* ភាពដាក់ជាជំនួញបាន(ឧ. commercialité d'une dette)

commère *n.f. Fam.* ម្ដាយធម៌(ពាក្យសម្រាប់ឪពុកធម៌ហៅម្ដាយធម៌ដែលមិនមែនជាប្រពន្ធរបស់គាត់); ព្រាក់ (ឧ. ma commère); ស្ត្រីរអេចរអូច (ឧ.une insupportable commère)

commérer *v.i. Fam.* និយាយរអេចរអូច

commettage *n.m.* ការវេញបញ្ចូលធ្លុង

commettant *n.m.* ការយ្យទាយី (អ្នកប្រគល់ឲ្យអ្នកដទៃកាន់កាប់ប្រយោជន៍របស់ខ្លួន)

commettre *v.t.* ប្រព្រឹត្ត,ធ្វើ(ប្រើចំពោះតែអំពើមិនគប្បី) (ឧ. commettre une erreur); តាំង;វេញបញ្ចូលធ្លុង; ធ្វើឲ្យខូច (ឧ.commettre sa réputation)។se commettre *v. pr.*សេពគប់មនុស្សពាល(ជាហេតុនាំឲ្យខូចកិត្តិយសឬកិត្តិនាម) (ឧ. se commettre avec des fripons)

comminatoire *a. Dr.* ដែលគ្រាន់តែជាការកំហែង (ឧ. arrêt comminatoire) ។ *Par ext.* សម្រាប់

កំហែងឬគម្រាម(ឧ.parler à quelqu'un sur un ton comminatoire)

commis *n.m.* ពេមី(និយោជិកផ្ទះជំនួញឬការិយាល័យ);អ្នកទទួលធ្វើការដោយទៀត។commis voyageur ម.ព. voyageur (de commerce) ។ commis de chancellerie អធិការបតីរង ។ grand commis de l'Etat មន្ត្រីជាន់ខ្ពស់

commisération *n.f.* សេចក្ដីអាណិត

commissaire *n.m.* ស្នងការ ។ haut-commissaire ឧត្ដមស្នងការ ។ commissaire général អគ្គស្នងការ ។ commissaire du gouvernement ស្នងការរដ្ឋាភិបាល ។ commissaire de police ស្នងការប៉ូលិស

commissaire-priseur *n.m.* ស្នងការលក់ដេញថ្លៃ (*pl.* des commissaires-priseurs)

commissariat *n.m.* មុខងារស្នងការ; ស្នងការដ្ឋាន។commissariat général អគ្គស្នងការដ្ឋាន។commissariat de police ស្នងការដ្ឋានប៉ូលិស។commissariat central de police ឧត្ដមស្នងការដ្ឋានប៉ូលិស

commission *n.f.* ការទិញ ឬ បំពេញមុខការឱ្យគេ (ដោយយកកម្រៃ) (ឧ. acheter à la commission); កម្រៃជើងសារ (ឧ. toucher une commission); ទំនិញដែលទិញឱ្យអ្នកដទៃ,កិច្ចការដែលបំពេញឱ្យអ្នកដទៃ (ឧ.faire les commissions de quelqu'un); ការស្ដី ឬ ពិងរក ។ គណៈកម្មការ ។ commission d'administration គណៈកម្មការរដ្ឋបាលឬអភិបាល។ commission de bornage គណៈកម្មការបោះព្រំដី។ commission culturelle គណៈកម្មការវប្បធម៌។commission permanente គណៈកម្មការអចិន្ត្រៃយ។ commission de prix គណៈកម្មការដាក់ថ្លៃ ។ *Méd.* commission de réforme គណៈកម្មការពិនិត្យរឹការរូប ។ *Douanes* commission d'emploi ប័ណ្ណនិយោជន៍

commissionnaire *n.m.* ជើងសារ, អ្នកទិញនឹងលក់ជួសគេយកកម្រៃ ។ commissionnaire en douane ជើងសារគយ

commissionner *v.t.* ប្រគល់អំណាច;

ប្រគល់មុខការ; ឲ្យគេលក់ ឬ ទិញជួស

commissoire *a. Dr.* ដែលលុបលាង

commissure *n.f. Anat.* ថ្នើរ (នៃសរីរកាយ) (ឧ. commissure des lèvres)

commodat *n.m.* ការឲ្យខ្ចីប្រើ (ដោយឥតយកថ្លៃ)

commode *a.* ស្រួលប្រើ (ឧ. un outil commode); ស្រណុក, ងាយ (ឧ. un homme commode à vivre); ដែលអត់ឱន (ឧ. homme qui n'est pas commode); ដែលធូរ (មិនតឹងរ៉ឹង) (ឧ. morale commode)

commode *n.f.* មញ្ជូសា, ទូសំរាង, ទូតូចមានថត (ដាក់សំលៀកបំពាក់)

commodément *adv.* យ៉ាងស្រួល

commodité *n.f.* របស់ ឬ ស្ថានការណ៍ស្រួល (ឧ. commodité d'une maison); ឱកាសល្អ (ឧ. à votre commodité) ។ *pl.* សុខ (ឧ. commodités de la vie); បង្គន់

commodo et incommodo ប.ក. de commodo et incommodo

commonwealth *n.m.* សហធន

commotion *n.f.* ការរញ្ជួយ (ឧ. commotion d'un tremblement de terre) ។ *Fig.* ការរំភើបខ្លាំង

commotionner *v.t.* ធ្វើឲ្យរញ្ជួយ ។ *Fig.* ធ្វើឲ្យរំភើបខ្លាំង

commuable *a.* អាចបន្ធូរឬសម្រាលបាន (ទោស)(ឧ.peine commuable)

commuer *v.t.* បន្ធូរ ឬ សម្រាល (ទណ្ឌកម្ម) ។ commuer une peine បន្ធូរទោស (ឧ. commuer la peine de mort en travaux forcés à perpétuité)

commun,e *a.* សាធារណ៍ (ឧ. cour commune); សាទិស; រួមគ្នា (ឧ. œuvre commune, repas commun); ទូទៅ (ឧ. intérêt commun); ធម្មតា, សាមញ្ញ (ឧ. expression peu commune); មិនថ្លៃថ្នូរ (ឧ.manière commune); ធុនរន់, ធុនថោក (ឧ. marchandise commune) ។ faire cause commune រួមប្រយោជន៍គ្នា ។ sens commun សុភវិនិច្ឆ័យ ។ *Gram.* nom commun សាធារណនាម ។ en commun *loc.adv.* រួមគ្នា, ជាមួយគ្នា ។ *n.m.* ភាគច្រើន (ឧ. le commun des hommes); ជន

ធោកទាប (ឧ. homme du commun) ។ *Pl.* បង្គន់

communal,e,aux *a.* ជារបស់ឃុំ, នៃឃុំ ។ *n.m. pl.* សម្បត្តិឃុំ

communaliser *v.t.* ដាក់ក្នុងអំណាចឃុំ

communautaire *a.* សហគត [-គត់]

communauté *n.f.* ភាពដូចគ្នា ឬ ត្រូវគ្នា (ឧ. communauté de sentiments); សហគមន៍ (ឧ. communauté nationale); សហពន្ធ; សហនិកាយ; ជំនុំសង្ឃ ។ *Dr.* ទ្រព្យសម្បាច់

commune *n.f.* ឃុំ; មនុស្សក្នុងឃុំ ។ chambre des communes រដ្ឋសភា (នៅប្រទេសអង់គ្លេស)

communément *adv.* តាមធម្មតា; ដោយទូទៅ

communiant,e *n.* អ្នកទទួលព្រះព្រយា (ម.ព. communier ផង)

communicable *a.* អាចបញ្ជូន - ឲ្យដំណឹង ឬ ទាក់ទងបាន

communicant,e *a.* ដែលជាប់ឬតគ្នា

communicateur,trice *n.* ដែលតភ្ជាប់ (ឲ្យមានទាក់ទងគ្នា) (ឧ. fil communicateur)

communicatif,ive *a.* ដែលបញ្ជូនឲ្យគ្នា; ដែលឆ្លងគ្នា (ឧ. rire communicatif); ដែលចូលចិត្តថ្លែងយោបល់

communication *n.f.* គមនាគមន៍ (ឧ. voie de communication); ការទាក់ទងគ្នា (ឧ. être en communication avec quelqu'un); ការនិយាយទូរសព្ទ (ឧ. prendre, recevoir une communication); ពត៌មាន, ដំណឹង (ឧ. communication d'une nouvelle) ។ en communication à ដើម្បីជាដំណឹងដល់

communier *v.i.* ទទួលព្រះព្រយា (នំប៉ុងនឹងស្រាទំពាំងបាយជូរ ដែលជាដំណាងសាច់នឹងឈាមព្រះយេស៊ូ) ។ មានសមសន្តា, ត្រូវគ្នា (ឧ. tous les êtres communient dans la douleur)

communion *n.f.* សមសន្តា (ឧ. communion des fidèles); ទទួលព្រះព្រយា (ម.ព. communier ផង); ត្រូវគំនិតគ្នា (ឧ. être en communion d'idée avec quelqu'un)

communiqué *n.m.* សេចក្ដីថ្លែងការណ៍; ការជូនដំណឹង

communiquer *v.t.* បញ្ជូន (ឧ. le soleil communique la chaleur); ឲ្យដំណឹង (ឧ. communiquer un avis)។ *Fig.* ឲ្យទទួលផង (ឧ. communiquer sa joie)។ *v.i.* មានផ្លូវកាន់គ្នាទៅវិញទៅមក; មានការទាក់ទងគ្នា (ឧ. communiquer avec un savant); មានផ្លូវ ឬមានទ្វាររួមគ្នា (ឧ. chambres qui communiquent)

communisme *n.m.* លទ្ធិកុម្មុយនិស្ត, លទ្ធិរួមសម្បាច់និយម

communiste *a. &n.* អ្នកកាន់លទ្ធិកុម្មុយនិស្ត

commutatif,ive *a.* នៃការប្តូរ។ contrat commutatif កិច្ចសន្យាប្តូរ

commutation *n.f.* ការប្តូរ ឬ ផ្លាស់; ការបន្ថយ ឬ សម្រាលទោស

compacité *n.f.* ភាពណែន-កាន់ឬខាប់

compact,e *a.* ណែន, កាន់, ខាប់; ខ្នាន់ខ្នាប់ (ឧ. foule compacte)

compactage *n.m.* ការបុកដីបង្ហាប់

compagne *n.f.* សហជីវិនី, គូ (ឧ. compagne de jeux); ប្រពន្ធ (ឧ. choisir une compagne)

compagnie *n.f.* ជំនុំ, ក្រុមហ៊ុន, សមាគម ។ compagnie d'assurance générale ក្រុមហ៊ុនរ៉ាប់រងទូទៅ។ ក្រុម, ពួក, កង (ឧ. être en joyeuse compagnie)។ compagnie administrative du service du matériel de la F.A.R.K. កងអភិបាលក្រុមសម្ភារៈរបស់ស.ខ.ភ.។ *Mil.* កងអនុសេនាធំ ។ compagnie de parachutistes កងអនុសេនាធំនៃទាហានឆ័ត្រយោង។ compagnie des parcs et ateliers de génie កងអនុសេនាធំខាងដំណាក់រថឹងរោងជាងនៃទាហាន ។ compagnie de quartier général កងអនុសេនាធំនៃទីបញ្ជាការ ។ tenir compagnie à quelqu'un កំដរ។ fausser compagnie រត់ចោល (លែងកំដរ)។ la bonne compagnie សង្គម (ការប្រជុំ) អ្នកចេះដឹង ។ de compagnie ឬ en compagnie *loc. adv.* ជាមួយគ្នា

compagnon *n.m.* សហជីវិន, គូកន (ឧ. compagnon d'étude); កម្មករ ។ bon compagnon អ្នកចូលចិត្តសប្បាយ

compagnonnage *n.m.* សមាគម

កម្មករនៃវិជ្ជាជីវៈមួយ

comparable *a.* អាចប្រៀបធៀបបាន

comparaison *n.f.* ការប្រៀបធៀប, ការផ្ទឹម (ឧ. établir une comparaison entre deux personnes, deux choses)។ en comparaison de ឬ par comparaison *loc. adv.* ដោយប្រៀបធៀបនឹង

comparaître *v.i.* ចូលខ្លួន

comparant,e *a.&n.* អ្នកចូលខ្លួន (ចំពោះមុខតុលាការ ឬ សារការី)

comparatif,ive *a.* ដែលប្រៀបធៀប, ដែលប្តូរ (ឧ. tableau comparatif)។ comparatif *n.m.* ឬ adjectif comparatif ម.ព. adjectif

comparativement *adv.* ដោយប្រៀបធៀប

comparer *v.t.* ប្រៀបធៀប, ប្រៀបផ្ទឹម

comparoir *v.i.* ចូលខ្លួនចំពោះមុខតុលាការ (ឧ assigner à comparoir) (ពាក្យនេះប្រើតែជា infinitif នឹង participe présent: «comparant» ប៉ុណ្ណោះទេ)

comparse *n. Théât.* តួរាយរង។ *Par ext.* តើងរាយរង(អ្នកកាន់មុខការរាយរង)

compartiment *n.m.* ទ័ល្ហា, បន្ទប់, ផ្ទះល្វែង

compartimentage *n.m.* ការចែកជាបន្ទប់

compartimenter *v.t.* ជាំងជាបន្ទប់ឬជាល្វែង ។ *Fig.* ចែកជាក្រុម ឬ ជាពួក

comparution *n.f.* ការចូលខ្លួន (ចំពោះមុខតុលាការ)

compas *n.m.* ប្រពាយឬដែកឈាន;ត្រីវិស័យសមុទ្ទ ។ compas d'épaisseur ប្រពាយវាស់កម្រាស់។ *Pop.* ជើង ។ *Fig. &Fam.* avoir le compas dans l'œil ស្មាននឹងភ្នែកមិនខុស

compassé,e *a.* ដែលធ្វើឫកពា (ឧ. démarche compassée)

compassement *n.m.* ការវាស់ដោយប្រពាយ

compasser *v.t.* វាស់ដោយប្រពាយ;ដាក់ឲ្យមានសមប្បមាណ; គូសដោយត្រឹមត្រូវ (ឧ. compasser les allées d'un jardin) ។ *Fig.* រៀបចំដោយប្រិតប្រៀប (ឧ. compasser son attitude, son style)

compassion *n.f.* សេចក្ដីអាសូរ

compatibilité *n.f.* សមិតភាព, ភាព

ត្រូវគ្នា ឬ ចូលគ្នាចុះ (ឧ. compatibilité d'humeur)

compatible *a.* សមិត, ត្រូវគ្នា ឬ ចូលគ្នាចុះ(ឧ. des caractères compatibles)

compatir *v.t.* អាណិតអាសូរ (ឧ. compatir à un deuil)

compatissant,e *a.* ដែលបង្ហាញសេចក្ដីអាណិតអាសូរ (ឧ. regard compatissant); ដែលធ្វើដោយមកពីអាណិតអាសូរ (ឧ. soins compatissants)

compatriote *n.* ជនរួមជាតិ

compendieusement *adv.* ដោយបំប្រួញ

compendieux,euse *a.* ដែលបង្រួញ ឬ បំប្រួញ

compendium [kon-pin-dyom'] *n.m.* ការបំប្រួញ, សេចក្ដីបំប្រួញ ។ (*Pl.* des compendiums)

compensateur,trice *a.* ដែលដាត់ទាត់ ឬ ទូទាត់

compensation *n.f* ការដាត់ទាត់ឬទូទាត់ (ឧ. compensation entre les avantages et les inconvénients); សំណង (ឧ. donner quelque chose en compensation); ការទូទាត់បំណុល (ឧ. chambre de compensation ឬ clearing house)

compensatoire *a.* សម្រាប់ទូទាត់ (ឲ្យលែងទាក់ទិននឹងគ្នា)

compenser *v.t.* ដាត់ទាត់,ទូទាត់ (ឧ. compenser des défauts par des qualités) ។ *Dr.* សង

compérage *n.m.* ភាពជាឪពុកធម៌ ។ ការសមគំនិតគ្នាពីរនាក់ដើម្បីឆបោកសាធារណជន

compère *n.m.* ឪពុកធម៌ (ជាគូនឹងពាក្យ commère ម.ព. នេះផង) ។ *Fig.* អ្នកចូលដៃក្នុងការឆបោក ។ bon compère មនុស្សសប្បាយ ។ fin, rusé compère មនុស្សប្រសប់ហើយមានកលល្បិច

compétence *n.f.* សមត្ថកិច្ច; សមត្ថកម្ម (ឧ. compétence d'un tribunal); សមត្ថភាព (ឧ faire appel à la compétence d'un spécialiste)

compétent,e *a.* ដែលមានសមត្ថកិច្ច ឬ សមត្ថកម្ម (ឧ juge compétent); ដែលមានសមត្ថភាព (ឧ. un criti-

que compétent)

compéter *v.i.* មានសមត្ថកិច្ច ឬ សមត្ថកម្ម; មានសមត្ថភាព

compétiteur,trice *n.* អ្នកប្រកួត

compétitif,ive *a.* អាចប្រកួតបាន (ឧ. prix compétitif); ដែលមានការប្រកួត(ឧ. marché compétitif)

compétition *n.f.* ការប្រកួត ។ compétition pacifique ការប្រកួតដោយសន្តិភាព

compilateur,trice *n.* គន្ថរចនាចារ្យ (អ្នកប្រមូលអត្ថបទផ្សេងៗធ្វើជាសៀវភៅ)

compilation *n.f.* គន្ថរចនា (ការប្រមូលអត្ថបទផ្សេងៗ ធ្វើជាសៀវភៅ)

compiler *v.t.* ធ្វើគន្ថរចនា (ប្រមូលអត្ថបទផ្សេងៗ ធ្វើជាសៀវភៅ)

complainte *n.f.* ចំរៀងរឿងទុក្ខ ឬ រឿងសាសនា ។ *Dr.* ការប្តឹងតុលាការ

complaire (à) *v.t.* ផ្គាប់ចិត្ត, តម្រូវចិត្ត (ឧ. il ne cherche qu'à vous complaire) ។ se complaire *v.pr.* គាប់ចិត្តនឹង, ចូលចិត្តនឹង (ឧ. se complaire à contredire)

complaisamment *adv.* ដោយបំពេញចិត្ត; ដោយការគួរសម

complaisance *n.f.* ការផ្គាប់ចិត្ត;សេចក្តីពេញចិត្ត; ការតម្រូវចិត្ត (ឧ. la complaisance doit être réciproque);ការគួរសម(ឧ.ayez la complaisance de . . .)។ de complaisance *loc.adv.* ជាការបំពេញចិត្ត(ឧ certificat de complaisance) ។ effets de complaisance ផលប័ត្របំណុលក្លែង

complaisant,e *a.* ដែលផ្គាប់ចិត្ត; ចិត្តបាន

complanter *v.t.* ដាំដើមឈើ (ឧ. complanter une terre d'orangers)

complément *n.m.* របស់បន្ថែមបំពេញ ឬ បង្គ្រប់ (ឧ.complément d'une somme) ។ *Gram.* កម្ម (វេយ្យាករណ៍)។ officier de complément នាយទាហានបម្រុង

complémentaire *a.* ដែលបន្ថែម-បំពេញ ឬ បង្គ្រប់(ឧ. somme complémentaire)

complet,ète *a.* គ្រប់(ឧ. trousseau complet); គត់,បរិបូណ៌ (ឧ. faire un tour complet); ពេញ, គ្រប់ចំណុះ(ឧ.un autobus complet); ពេញលេញ(ឧ un athlète com-

plet; une étude complète)។ *n.m.* មួយប្រដាប់ (សំលៀកបំពាក់)។ au complet, au grand complet *loc.adv.* ដោយពេញលេញ, គ្រប់ចំនួន

complètement *adv.* យ៉ាងពេញលេញ; យ៉ាងបរិបូណ៌; ស៊ប់; ពេញទី

complètement *n.m.* ការបំពេញ ឬបង្គ្រប់(ឧ.complètement d'une collection)

compléter *v.t.* បន្ថែម, បំពេញ, បង្គ្រប់ (ឧ. compléter son mobilier) ។ se compléter *v.pr.* បង្គ្រប់គ្នា (ឧ. caractère qui se complète);មានគ្រប់(ឧ. dossier qui se complète peu à peu)

complexe *a.* ដែលរួមបញ្ចូលរបស់ច្រើន; ស្មុគស្មាញ (ឧ. idée complexe) ។ *Math.* មិស្សភាគ (ម.ព. nombre ផង) ។ មាន: ។ complexe d'infériorité ហីនមាន: ។ complexe de supériorité សេយ្យមាន:

complexion *n.f.* រូបកាយ (ឧ. complexion robuste);ចរិត(ឧ.être de complexion triste)

complexité *n.f.* មិស្សភាព, ភាពស្មុគស្មាញ ឬ ពិបាក (ឧ. la complexité d'un problème)

complication *n.f.* ការស្មុគស្មាញ,ការសាំទ៉ុណ្ណ; ការពិបាក (ឧ. complication diplomatique)

complice *a.* &*n.* អ្នកចូលដៃ (ក្នុងបទល្មើសផ្សេងៗ) ។ *Fig.* អ្នកសមគំនិត, អ្នកជួយ, អ្នកឧបត្ថម្ភ

complicité *n.f.* ការចូលដៃ (ឧ.faire un acte de complicité) ។ *Fig.* ការសមគំនិត

compliment *n.m.* អភិនន្ទការ (ឧ. réciter un compliment) ។ *Pl.* ពាក្យគួរសម, ពាក្យសរសើរ (ឧ. présenter ses compliments)

complimenter *v.t.* សរសើរ(ឧ.complimenter un élève)។*Absol.* ថ្លែងពាក្យគួរសម

complimenteur,euse *a.* &*n.* អ្នកសរសើរច្រើនពេក

compliqué,e *a.* ស្មុគស្មាញ (ឧ. machine compliquée) ។ *Fig.* ស្មុគស្មាញ,ពិបាកយល់(ឧ. problème compliqué); ដែលស្វែងរកតែការពិបាក (ឧ. esprit compliqué)

compliquer *v.t.* ធ្វើឲ្យស្មុគស្មាញ ឬ

ឲ្យពិបាក(ឧ.compliquer à plaisir une affaire toute simple)

complot *n.m.* ការរួបគំនិតក្បត់

comploter *v.t.* រួមគំនិតក្បត់(ឧ.comploter de renverser l'Etat); ល្បួចគិតជាមួយគ្នា (ឧ. ils complotent notre ruine)

comploteur *n.m.* អ្នករួមគំនិតក្បត់

componction *n.f.* ការស្ដាយដោយប្រព្រឹត្តខុសចំពោះអាទិទេព; ឫករម្យទម (ឧ. air de componction)

comportement *n.m.* អាចារៈ, មារយាទ, ការប្រព្រឹត្ត

comporter *v.t.* មាន (ឧ. cette règle comporte des exceptions); គប្បី,បើកឲ្យ (ឧ. votre conduite ne comporte aucune excuse)។ se comporter *v.pr.* កាន់មារយាទ,ប្រព្រឹត្ត (ឧ. se comporter en honnête homme)

composant,e *a.* ជាសមាសភាគ ។ *n.m.* សមាសភាគ (ឧ. composant de l'eau)។ composante *n.f. Méc.* សមាសពល

composé,e *a.* ដែលមានសមាសភាព; ជាសមាសធាតុ ។ *Gram.* nom composé សមាសនាម ។ *n.m.* សមាសធាតុ,ធាតុផ្សំ ។ *Fig.* ដែលមិនមែនជាធម្មតា(ឧ. allure, attitude composée)

composées *n.f. pl. Bot.* សមាសកូល ឬ និម្ពកូល

composer *v.t.* បង្កើត; រៀបរៀង, ចងក្រង,តែង (ឧ. composer un ouvrage);រៀបចំ,ធ្វើ (ឧ. composer un visage); រួបរួម; ផ្សំ (ឧ. composer un remède)។ *v.i.* ធ្វើកិច្ចការក្លុងភ្នាក់;សម្រុបសម្រួល (ឧ.composer avec ses créanciers)

composite *a. Fig.* ដែលមានឈាយវត្ថុផ្សេងៗ, ចម្រុះ (ឧ. mobilier, assemblée composite)

compositeur,trice *n.* អ្នកតែងបទភ្លេង;អ្នករៀបអក្សរពុម្ព; រាជ្ញាកណ្ដាល; អ្នកផ្គុំ ។ compositeur et héliographe des travaux publics អ្នកផ្គុំនិងសុរិយលេខនៃសាធារណការ

composition *n.f.* ការតែងឬរៀបរៀង; ការផ្សំ (ឧ. composition d'un mot); ការរួបរួម; ការរៀបអក្សរពុម្ព; ការតែងបទភ្លេង;សមាសភាព(ឧ.composition d'une commis-

sion);វិញ្ញាសាប្រឡង។*Fig.*ការស្រុះស្រួលគ្នា(ឧ. entrer en composition)។ *Gram.* សមាសកម្ម

compost *n.m.* អំពុក (ដីផ្សំដោយកាកវត្ថុផ្សេងៗ នឹងកំបោរ)

compostage *n.m.* ការដាក់អំពុក

composter *v.t.* ដាក់អំពុក

composteur *n.m.* ត្រាបោះកាលបរិច្ឆេទ

compote *n.f.* ផ្លែឈើដិងស្ករ ។ *Fig.* & *fam.* en compote ដាំ(ឧ. visage en compote)

compotier *n.m.* ភាជន៍ដាក់ផ្លែឈើដិងស្ករនឹងផ្លែឈើ

comprador *n.m.* កុំប្រាឌ័រ (ជើងសារជំនួញ)

compréhensibilité *n.f.* ភាពអាចយល់បាន

compréhensible *a.* អាចយល់បាន

compréhensif,ive *a.* ដែលយោគយល់

compréhension *n.f.* ញាណ, ការយល់, ប្រាជ្ញា (ឧ. avoir la compréhension lente);ការស្តាប់បាន (ឧ. note nécessaire à la compréhension d'un texte); ការយោគយល់ (ឧ. manquer de compréhension)

comprendre *v.t.* មាន(រួមបញ្ចូល)(ឧ. Phnom-Penh comprend sept quartiers)។ *Fig.* យល់, យល់ច្បាស់ (ឧ. comprendre la pensée de quelqu'un)

compresse *n.f.* សំពត់បិទដំបៅ

compresseur *a.m.* ដែលសម្រាប់សង្កត់ ។ *n.m.* ប្រដាប់សង្កត់,គ្រឿងបង្ហាប់

compressibilité *n.f.* ភាពអាចសង្កត់ឲ្យណែនបាន

compressible *a.* អាចសង្កត់ឲ្យណែនបាន

compressif,ive *a.* ដែលសម្រាប់សង្កត់ឲ្យណែន(ឧ. appareil compressif) ។ *Fig.* ដែលសង្កត់សង្កិន (ឧ. régime compressif)

compression *n.f.* ការសង្កត់ឲ្យណែន, ការកិនបង្ហាប់, ការញាត់; ការបន្ថយចំនួន ។ *Fig.* ការត្បិតត្បៀត;ការបង្ខំ; ការសង្កត់សង្កិន (ឧ. mesure de compression)

comprimé,e *a.* ណែនដោយសង្កត់ ឬដោយញាត់ (ឧ. air comprimé); សំប៉ែត ។ *n.m.* គ្រាប់ (ថ្នាំ)

comprimer *v.t.* សង្កត់ឲ្យណែន, កិនបង្ហាប់, ញាត់; បង្រួម ។ *Fig.* ទប់(ឧ.

comprimer ses larmes); បង្ក្រាប (ឧ comprimer les factions); ត្បិតត្បៀត

compris,e *a.* ដែលរាប់បញ្ចូល; ដែលគេយល់ (ម.ព. comprendre ផង)

compromettant,e *a.* អាចនាំឲ្យមានគ្រោះថ្នាក់ឬឲ្យខូច(ឧ. parole compromettante)

compromettre *v.t.* ធ្វើឲ្យមានគ្រោះថ្នាក់ឬឲ្យខាន(ឧ.compromettre sa santé); ធ្វើឲ្យខូចកិត្តិយស (ឧ. compromettre une femme)។ *v.i.* សម្រុះ

compromis *n.m.* ការសម្រុះ (ម.ព. arbitrage ផង); ការសម្រុះសម្រួល (ឧ. préférer un compromis à un procès)

compromission *n.f.* ការធ្វើឲ្យមានគ្រោះថ្នាក់ ឬ ឲ្យខូចកិត្តិយស

compromissoire *a.* សម្រាប់សម្រុះសម្រួល(ឧ.clause compromissoire)

comptabilisation *n.f.* គណនេយ្យកម្ម, ការបញ្ចូលក្នុងគណនេយ្យ (ឧ. comptabilisation des recettes et des dépenses)

comptabiliser *v.t.* ធ្វើគណនេយ្យកម្ម, បញ្ចូលក្នុងគណនេយ្យ

comptabilité *n.f.* គណនេយ្យ ។ comptabilité publique គណនេយ្យសាធារណៈ (សម្រាប់កាន់កាប់ផលទុនរដ្ឋ)។ comptabilité économique ឬ nationale គណនេយ្យសេដ្ឋកិច្ច ឬ ជាតិ ។ comptabilité industrielle គណនេយ្យឧស្សាហកម្ម។ comptabilité centrale គណនេយ្យកណ្ដាល។ comptabilité générale គណនេយ្យទិកាស។ comptabilité matière គណនេយ្យរូបធាតុ ។ comptabilité en partie double គណនេយ្យទ្វេភាគ។ comptabilité en partie simple គណនេយ្យសរលភាគ [-សៈរ៉ល់-]។ comptabilité de l'ordonnateur គណនេយ្យអាណាប៉ក [ប៉ាក់]

comptable *a.* គណនេយ្យករ (ឧ.officier comptable); ដែលទទួលខុសត្រូវ (ឧ. être comptable de ses actions envers quelqu'un)។ *n.m* គណនេយ្យករ

comptage *n.m.* ការរាប់

comptant *a.m.* ដល់ដៃ (ឧ.argent comptant) ។ vendre au comptant លក់ដល់ដៃ ។ *Fig.* prendre pour argent comptant ទុកចិត្ត, យកជាការបាន (ទុកដូចជាបានឲ្យប្រាក់ដល់ដៃ); ជឿតាមពាក្យសន្យា (ដោយឆោតពេក) ។ *adv.* payer comptant បង់ប្រាក់ដល់ដៃ ។ *Fig.* ភ្លាម (ឧ. le plaisir de faire du bien nous paye comptant de notre bienfait)

compte *n.m.* គណនី, ការរាប់ (ឧ. faire le compte de sa fortune); បញ្ជីចំណូលចំណាយ (ឧ. vérifier son compte); ការគិតលេខ, ចំនួន ។ *Fig.* ផលប្រយោជន៍ (ឧ. trouver son compte) ។ donner son compte à un domestique ដេញជាក្រៅចោល (ដោយបើកប្រាក់ឲ្យរួច) ។ rendre compte de រាយការណ៍, ពន្យល់, បរិការណ៍ ។ se rendre compte de យល់,ដឹងខ្លួន ។ tenir compte de ទទួលយកជាការ ឬ យកមកគិត ។ compte administratif គណនីអភិបាល ។ compte courant គណនីចរន្ត ។ compte de gestion គណនីគ្រប់គ្រង, គណនីខាងការចាត់ចែងឬការចាយវាយ ។ compte ouvert គណនីចំហ ។ compte d'exploitation គណនីទោហកម្ម។ compte de résultat ឬ compte de profit et de perte គណនីលទ្ធផល ឬ គណនីគុណប្រយោជន៍ និងការខាតបង់ ។ compte d'actif គណនីសកម្ម ។ compte de passif គណនីអកម្ម។ compte général គណនីទូទៅ ។ compte particulier គណនីដោយឡែក។compte collectif គណនីរួម ។ compte étranger គណនីបរទេស ។ compte loro បរគណនី [ប៉ៈ-រៈ-] ។ compte nostro នោគណនី ។ compte divisionnaire វិភត្តគណនី ។ compte E.F.Ac. ម.ព.E.F.Ac. ។ compte rendu គណនាការណ៍, សេចក្ដីរាយហេតុ ។ à bon compte *loc.adv.* ដោយថោក ។ au bout du compte ឬ en fin de compte ឬ tout compte fait *loc. adv.* បើគិតឲ្យសព្វទៅ ។ de compte à demi

loc. adv. ដោយចែកចំណេញគ្នា ។ *Prov.* les bons comptes font les bons amis បើចង់រាប់អានគ្នាជាមិត្ត ត្រូវកុំបំបាត់ធ្លាក់គ្នា

compte-gouttes *n.m.* បំពង់ដំណក់ ។ au compte-gouttes *loc. adv. Fig.&Fam.* ដោយត្បិតត្បៀត

compter *v.t.* គណនា,រាប់ (ឧ.compter des livres); រាប់បញ្ចូល (ឧ. compter quelqu'un parmi ses amis); វាយតម្លៃ (ឧ.compter quelque chose pour rien); មាន (ឧ. Phnom-Penh compte cinquante mille habitants)។ compter ses pas ដើរមួយៗ(ដើរយឺត)។ *v.i.* រាប់បញ្ចូល (ឧ. syllabe qui ne compte pas); គិតលេខ (គិតរកចំនួន) (ឧ. compter sur ses doigts); បញ្ឈប់គណនី; គិតបម្រុងនឹង (ឧ. je compte partir demain) ។ compter avec គិតដល់ ។ មានសារសំខាន់ (ឧ. cela compte beaucoup) ។ compter sur អាងលើ, ទុកចិត្តលើ ។ à compter de តាំងពី (កាលបរិច្ឆេទ)

compteur,euse *n.* អ្នករាប់ ។ *n.m.* នាឡិកាស្ទង់កម្លាំង

comptoir *n.m.* តុវែងសម្រាប់ដាក់ទំនិញលក់ក្នុងហាង; គណនីយដ្ឋាន; សាខាគ្រឹះស្ថានជំនួញ ឬ ធនាគារ; គ្រឹះ-ស្ថានចងការប្រាក់ឲ្យមហាជន

compulsion *n.f.* ការបើកក្នុងបញ្ជី

compulser *v.t.* ទទួលដឹងតាមផ្លូវការ; បើកក្នុងបញ្ជី

compulsoire *n.m.* សាលក្រមទទួលដឹងតាមផ្លូវការ

computer *v.t.* រាប់

comte,comtesse *n.* កុងត៍ (អភិជន)

comté *n.m.* ដីរបស់កុងត៍

concassage *n.m.* ការកិន; ការវាយបំបែក

concasser *v.t.* កិន; វាយបំបែក (វត្ថុរឹង)

concasseur *n.m.* ប្រដាប់វាយបំបែក

concave *a.* ខ្វង,ផត(ព.ផ. convexe)

concavité *n.f.* សភាពផត, ភាពខ្វង; ប៉ែកខាងផត; ក្រហូង (ឧ. les concavités d'un rocher)

concéder *v.t.* ព្រមឲ្យ (ឧ.concéder l'exploitation d'un service public); សុខចិត្ត, យល់ព្រម (ឧ. vous concéderez que j'ai

raison)

concedo (j'accorde) *loc.lat.* ពិតហើយ (ខ្ញុំយល់ស្របហើយ) (ឧ. la guerre est parfois un mal nécessaire, concedo; mais on doit tout faire pour l'éviter)

concentration *n.f.* ការប្រមូលផ្តុំ (ឧ. concentration de troupe); សមាធិ; ភាពខាប់ ។ camp de concentration ម.ព. camp

concentrationnaire *a.* នៃបន្ទាយផ្តុំជន

concentré,e *a.* ខាប់ (ឧ. acide concentré; lait concentré); ទឹកដោះគោខាប់ ។ *Fig.* មិនសូវស្តីនិយាយ

concentrer *v.t.* ប្រមូលផ្តុំ, ប្រមូល(ឲ្យនៅកន្លែងមួយ)(ឧ.concentrer des troupes) ។ *Phys.* រម្ងាស់ឲ្យខាប់ (ឧ.concentrer une solution)។ *Fig.*ប្រមូល (ឧ.concentrer son énergie ប្រមូលថាមពល (កម្លាំង)។ concentrer ses affections ស្រឡាញ់តែរបស់អ្វីមួយ(ប្រមូលសេចក្តីស្នេហាមកលើតែរបស់មួយនោះ) ។ ទប់ (ឧ. concentrer sa colère, sa douleur) ។ se concentrer *v.pr.* ផ្ចង់គំនិត (គិតខ្លាំង)

concentrique *a. Math.* សហនាភី, ដែលមានសហមណ្ឌល; ដែលសំដៅទៅមជ្ឈមណ្ឌល (ឧ. mouvement concentrique)

concentriquement *adv.* ជាសហនាភី

concept *n.m.* គំនិត, វត្ថុដែលគិតឃើញ (ឧ. concept du temps)

conceptible *a.* អាចយល់បាន

conception *n.f.* ការចាប់បដិសន្ធិ ។ *Fig.* ការយល់ (ឧ.avoir la conception facile) ; ទស្សនាទាន; គំនិត,យោបល់ (ឧ. une conception originale de la vie)

conceptuel,elle *a.* នៃទស្សនាទាន, នៃគំនិត, នៃយោបល់

concerner *v.t.* ទាក់ទងនឹង (ឧ. cela concerne votre intérêt)

concert *n.m.* សមង្គីភាព,តន្ត្រី,ចម្រៀង, ការប្រគំ ។ *Fig.* ការព្រមព្រៀង ។ concert des nations សមង្គីភាពនៃប្រជាជាតិ ។ de concert *loc. adv.* ដោយព្រមព្រៀងគ្នា (ឧ. agir de concert)

concertant,e *n.&a.* ដែលលេង ឬ

ច្រៀងក្នុងការប្រគំតន្ត្រី

concerter *v.t.* រៀបចំដោយព្រមព្រៀងគ្នា (ឧ. plan bien concerté) ។ se concerter *v.pr.* ពិគ្រោះគ្នា, ព្រមព្រៀងគ្នា

concertiste *n.m.* អ្នកលេងក្នុងការប្រគំ

concesseur *n.m.* សម្បទាយី, អ្នកធ្វើសម្បទាន

concessible *a.* សម្បទានីយ, អាចធ្វើសម្បទានបាន

concession *n.f.* សម្បទាន (ការប្រគល់ឲ្យ,ការឲ្យដាច់)(ឧ.la concession d'une mine); ដីសម្បទាន (ឧ. concession à perpétuité)។ concession minière សម្បទានរណ្ដៅរ៉ែ ។ *Fig.* ការរំលែកឲ្យ, ការព្រមរំលែកឲ្យ;ការបោះបង់(ដើម្បីសម្របសម្រួលគ្នា) (ឧ. faire des concessions)

concessionnaire *n.* សម្បទានិក, អ្នកទទួលសម្បទាន;អ្នកទទួលលក់ដាច់មុខ (ក្នុងជំនួញ)

concevable *a.* អាចគិត ឬ យល់បាន

concevoir *v.t.* មានគភ៌,ដើម ។ *Fig.* យល់, គិត, នឹក(ឧ. je ne conçois pas comment vous avez pu vous tromper);បង្កើត,ផ្ដើម, ប្រឌិត(ឧ. concevoir un projet); ចាប់មានឡើង,កើតមាន (ផ្ដួចក្នុងចិត្ត) (ឧ. concevoir de l'amitié pour quelqu'un); សរសេរថា, ដាក់ថា (ឧ. la dépêche était ainsi conçue)

conchoïdal,e,aux [—ko-i—] *a.* ដូចសំបកខ្យងខ្ចៅ

conchylien,enne [—ki—] *a.* ដែលមានសំបកខ្យងខ្ចៅ (ឧ. calcaire conchylien)

conchyliogie [—ki—] *n.f.* វិទ្យាសាស្ត្រខាងខ្យងខ្ចៅឬខាងសំបកខ្យងខ្ចៅ

concierge *n.* គេហបាល

conciergerie *n.f.* គេហបាលដ្ឋាន; មុខងារគេហបាល ។ *Spécial.* គុក (នៅប្រទេសបារាំង)

concile *n.m.* សង្គាយនា(ការប្រជុំសង្ឃផ្ទៀងធម៌ ឬ ច្បាប់សាសនា)

conciliable *a.* អាចផ្សះផ្សាបាន

conciliabule *n.m.* រហស្សសន្និបាត, ការប្រជុំសម្ងាត់ (ដើម្បីរួមគំនិតក្បត់); ការសន្ទនាខ្សឹបៗ

conciliaire *a.* នៃសង្គាយនា

conciliant,e *a.* សម្រាប់សម្រុះសម្រួល

(ឧ. paroles conciliantes); ឆាប់ស្រុះស្រួល (ឧ. caractère conciliant)

conciliateur,trice *n.&a.* អ្នកផ្សះផ្សា

conciliation *n.f.* ការផ្សះផ្សា, ការសម្រុះសម្រួល; ការស្រុះស្រួលគ្នាវិញ

conciliatoire *a.* សម្រាប់សម្រុះសម្រួល (ឧ.mesure conciliatoire)

concilier *v.t.* ផ្សះផ្សា,សម្រុះសម្រួល (ឧ. concilier des adversaires) ។ se concilier *v.pr.* ជានឹងគ្នា;បាន, ទទួល(ឧ. se concilier l'estime d'autrui)

concis,e *a.* ខ្លី, សង្ខេប

concision *n.f.* សភាពខ្លី ឬ សង្ខេប

concitoyen,enne *n.* សហពលរដ្ឋ [សៈ-] (ពលរដ្ឋនៃប្រទេសឬក្រុងជាមួយគ្នា)

concluant,e *a.* ដែលបញ្ជាក់សម្រេច(ឧ. argument concluant)

conclure *v.t.* សម្រេច, បង្ហើយ, បញ្ចប់ (ឧ. conclure une affaire); សន្និដ្ឋាន(ឧ.conclure une chose d'une autre) ។ *v.i.* ឲ្យយោបល់; សម្រេចសេចក្ដី (ឧ. on vous demande de conclure); មានជាក់ស្ដែង (ឧ. les témoignages concluent contre lui)

conclusif,ive *a.* ដែលសម្រេចសេចក្ដី

conclusion *n.f.* សេចក្ដីសន្និដ្ឋាន,សេចក្ដីសម្រេច (ឧ. conclusion d'un traité); ការបញ្ចប់, ទីបំ (ឧ.conclusion d'un discours)។ *pl.* សេចក្ដីសុំរបស់អ្នកប្ដឹង ។ en conclusion *loc.adv.* ដោយសម្រេចទៅ

concombre *n.m.* ត្រសក់; ផ្លែត្រសក់

concomitamment *adv.* ដោយសហវត្ត (ជាមួយគ្នា)

concomitance *n.f.* សហវត្តភាព, ភាពរួបរួម-ទៅជាមួយ ឬ មានឡើងព្រមគ្នា

concomitant,e *a.* សហវត្ត, ដែលមានជាមួយឬព្រមគ្នា(ឧ. des faits concomitants)

concordance *n.f.* ភាពត្រូវគ្នាឬស្របគ្នា (ឧ. concordance de témoignages)

concordant,e *a.* ត្រូវគ្នា, ស្របគ្នា (ឧ. témoignages concordants)

concordat *n.m.* *Dr.* អនុរូបសញ្ញា (សន្ធិសញ្ញាតាមបទតុលាការ រវាងអ្នកធនក្ស័យ និងពួកម្ចាស់បំណុល តាមល័ក្ខខ័ណ្ឌខ្លះ)

concorde *n.f.* ការស្រុះស្រួលគ្នា (ឧ.

rétablir la concorde entre les citoyens);

concorder *v.i.* ស្របគ្នា (ឧ. dates qui concordent); ស្រុះស្រួលគ្នា

concourant,e *a.* ដែលសំដៅគោលតែមួយ

concourir *v.t.* សំដៅគោលតែមួយ;ជួយ (ឧ.concourir au succès d'une affaire)។ *v.i.* ប្រឡងប្រជែង (ឧ. concourir pour un prix)

concours *n.m.* ភាពគាប់ជួន (ឧ. un concours de circonstances); ជំនួយ, ការជួយ (ឧ. offrir son concours); ការប្រឡងប្រជែង (ឧ. se présenter à un concours)។ concours d'infraction ប្រជុំបទល្មើស

concret,ète *a.* រូបី (ដែលមានរូប); ច្បាស់លាស់, ពិត (ឧ. obtenir des avantages concrets); ខាប់(ឧ. huile concrète) ។ *n.m.* រូបី (វត្ថុមានរូប)

concréter *v.t.* ធ្វើឲ្យខាប់-ឲ្យខះឬឲ្យកក

concrétion *n.f.Phys.* ការឡើងខាប់-ខះឬកក(ឧ.concrétion du sang)

concrétionner(se) *v.pr.* ឡើងខាប់, ខះ, កក

concrétiser *v.t.* ធ្វើឲ្យជារូបី ឬ ឲ្យច្បាស់លាស់(ឧ.concrétiser une idée)

concubin,e *a.&n.* អនីតិសង្វាសនី, សហាយ

concubinage *n.m.* អនីតិសង្វាស, ភាពជាសហាយ

concubinaire *n.m.* អនីតិសង្វាសី, សហាយប្រុស

conculquer *v.t.* ជាន់នឹងជើង

concupiscence *n.f.* រាគតណ្ហា

concupiscent,e *a.* ដែលបង្ហាញរាគតណ្ហា (ឧ. regards concupiscents); ដែលជាប់ជំពាក់នឹងរាគតណ្ហា

concupiscible *a.* ដែលមានរាគតណ្ហា

concurremment *adv.* ដោយប្រជែងគ្នា; ជាមួយគ្នា (ឧ. agir concurremment avec quelqu'un)

concurrence *n.f.* ការប្រដេញដើងគ្នា, ការប្រជែង (ឧ. entrer en concurrence avec quelqu'un); ក្រុមអ្នកប្រដេញដើងគ្នា (ក្នុងជំនួញ) ។ jusqu'à concurrence de *loc. pré.* រហូតដល់ចំនួន

concurrencer *v.t.* ប្រដេញថ្លៃឬប្រជែង

concurrent,e *a.* ដែលប្រដេញ ឬ

ប្រជែង ។ *n.* គូប្រជែង ឬ ប្រជែង

concussion *n.f.* ការស៊ីសំណូក

concussionnaire *a.&n.* អ្នកស៊ីសំណូក

condamnable *a.* ទណ្ឌ្យ, គួរផ្ដន្ទាទោស (ឧ. acte condamnable)

condamnation *n.f.* ទណ្ឌកិច្ច, ការផ្ដន្ទាទោស, ទណ្ឌកម្ម ។ *Fig.* ការបន្ទោស, ការមិនយល់ព្រម (ឧ. condamnation des abus)

condamnatoire *a.* ដែលដាក់ទណ្ឌកិច្ច

condamné,e *n.* ទណ្ឌិត, អ្នកត្រូវទោស

condamner *v.t.* ផ្ដន្ទាទោស, កាត់ទោស (ឧ. condamner un criminel); បន្ទោស, មិនយល់ព្រម (ឧ. condamner une opinion, un usage)។ *Par ext.* ហាមឃាត់ (ឧ. condamner la vente de certains journaux); ថ្លែងថាលែងកែបាន ឬ ថាមើលលែងជា (រោគ) (ឧ. les médecins l'ont condamné); បិទចោល(ឧ. condamner une porte); បង្ខំ (ឧ. condamner au repos)

condensable *a.* អាចធ្វើឲ្យមានឃនភាពបាន, អាចបង្រួមបាន

condensateur *n m.* ប្រដាប់រក្សាទុកនូវកម្លាំងអគ្គិសនី

condensation *n.f.* ការធ្វើឲ្យមានឃនភាព; ការធ្វើឲ្យឧស្ម័នកកជាទឹក (ព.ផ. dilatation)

condensé *n.m.* សៀវភៅបំព្រួញ

condenser *v.t.* ធ្វើឲ្យមានឃនភាព; ធ្វើឲ្យរួម(តូច); ធ្វើឧស្ម័នឲ្យកកជាទឹក(ដោយត្រជាក់) (ឧ. le froid condense la vapeur d'eau)។ *Fig.* និយាយខ្លី(ឧ. condenser sa pensée)។ se condenser *v.pr. Fig.* ប្រជុំគ្នា, ប្រមូល; ក្លាយទៅជាទឹក

condescendance *n.f.* និភតភាព, ការធ្វើត្រូវចិត្តគេ ។ *Péjor.* ឫកធំ

condescendant,e *a.* ប្រកបដោយនិភតភាព, ដែលធ្វើត្រូវចិត្តគេ; ដែលធ្វើឫកធំ(ឧ. air condescendant)

condescendre *v.t.* ធ្វើត្រូវចិត្ត (ឧ. condescendre aux désirs de quelqu'un)

condiment *n.m.* គ្រឿងសម្ល (ម្រេច, អំបិល ។ល។)

condisciple *n.m.* សមានាចារ្យ, អ្នកមានគ្រូជាមួយគ្នា

condition *n.f.* ឋានៈ (ក្នុងសង្គម) (ឧ.

inégalité des conditions); ស្ថានភាព (ឧ. améliorer les conditions matérielles de l'existence); មូលហេតុ (ឧ. le travail est la condition du succès); ភាព (ឧ. condition humaine); លក្ខណសម្បត្តិ; ល័ក្ខខ័ណ្ឌ (ឧ. les conditions d'un armistice); កំហិត ។ dans ces conditions ក្នុងស្ថានភាពនេះ; ក្នុងកាលៈទេសៈនេះ ។ sous condition ដោយមានល័ក្ខខ័ណ្ឌ ។ personne de condition មនុស្សពូជខ្ពស់ ។ être en condition ធ្វើជាបាវគេ ។ acheter à condition ទិញដោយមានល័ក្ខខ័ណ្ឌ (អាចសងរបស់វិញបាន) ។ condition d'éligibilité លក្ខណសម្បត្តិនៃបេក្ខជន ។ condition générale ល័ក្ខខ័ណ្ឌទូទៅ ។ à condition que *loc.conj.* លុះណាតែ

conditionnel,elle *a.* ដែលប្រព្រឹត្តទៅដោយមានល័ក្ខខ័ណ្ឌ (ឧ. promesse conditionnelle)

conditionnellement *adv.* ដោយមានល័ក្ខខ័ណ្ឌ, ដោយមានកំហិត

conditionnement *n.m.* ការពិនិត្យគុណភាព; ការធ្វើឲ្យអស់សម្ងួត (ព្រៃ, រោមចៀម ។ល។); ការធ្វើឲ្យបន្ទប់មានអាកាសធាតុស្រួល; ការខ្ចប់ទំនិញឲ្យល្អមើល (ដើម្បីដាក់លក់)

conditionner *v.t.* ដាក់ឲ្យមានល័ក្ខខ័ណ្ឌ; ធ្វើឲ្យអស់សម្ងួត; ធ្វើឲ្យមានអាកាសធាតុស្រួលក្នុងបន្ទប់; ខ្ចប់ទំនិញឲ្យល្អមើល

conditionneur,euse *n.* & *a.* អ្នកខ្ចប់ទំនិញ

condoléances *n.f.pl.* សមានទុក្ខ, ការជួយរួមទុក្ខ, ការចូលកាន់មរណទុក្ខជាមួយ

condominium *n.m.* សហវិជិតរាជ្យ

condor *n.m.* ត្មាតធំម្យ៉ាងនៅអាមេរិកខាងត្បូង

conducteur,trice *a.* & *n.* ដែលនាំ ។ *n.m.* អ្នកដឹកនាំ; អ្នកបរ (ឧ. conducteur d'autobus); នាយការ ។ conducteur des Travaux Publics នាយការសាធារណការ ។ *Phys.* វត្ថុដែលចម្លងចំហាយក្តៅ ឬ អគ្គិសនី (ឧ. les métaux sont bons conducteurs de l'électricité)

conductibilité *n.f.* លក្ខណៈនាំកំដៅ ឬ អគ្គិសនី

conductible *a.* ដែលមានលក្ខណៈនាំកំដៅ ឬ អគ្គិសនី

conduction *n.f. Dr.* ការជួល

conduction *n.f. Phys.* ការនាំកំដៅ ឬ អគ្គិសនី

conduire *v.t.* នាំ;ដឹកនាំ(ឧ.conduire au désespoir); ជូន (ឧ. conduire un enfant à l'école); បរ(ឧ. conduire une voiture, un cheval); បង្គាប់; អភិបាល ។ *Fig.* នាំទៅដល់ (ឧ. ce chemin conduit à la ville); នាំមកនូវ (ឧ. la vertu conduit au bonheur) ។ conduire bien sa barque កាន់កាប់មុខរបរបានល្អ ។ *v.i.* បើកបរ(ឧ. apprendre à conduire) ។ se conduire *v.pr.* ប្រព្រឹត្ត, កាន់មារយាទ

conduit *n.m.* ប្រឡាយ, បំពង់ ។ conduit auditif រន្ធត្រចៀក

conduite *n.f.* ការនាំ; ការដឹកនាំ; ការបរ, ការបើក (ឧ. conduite d'un troupeau, d'un avion);ការជូន (ឧ.faire la conduite) ។ *Fig.* អភិបាល(ឧ.conduite de l'Etat); ការប្រព្រឹត្ត; ចរិយា (ឧ. conduite versatile);លំនាំការ។ conduite générale លំនាំការទូទៅ ។ បំពង់ ។ conduite intérieure រថយន្តដំបូលជិត (ផ្ទុយនឹងរថយន្តដំបូលចំហ) ។ *Fam.* faire une conduite de Grenoble à quelqu'un បណ្ដេញចេញ

cône *n.m.* សាជីមូល

cône *n.m.* ផ្លែសរលក្ខូល (ស្រល់)

confection *n.f.* ការធ្វើ; ភាពរួចរាល់ (ឧ. la confection d'une machine);ការកាត់ដេរសំលៀកបំពាក់រយ (ឧ.un complet de confection)

confectionner *v.t.* ធ្វើ(ឧ.confectionner un plat); កាត់ដេរសំលៀកបំពាក់រយ

confectionneur,euse *n.* អ្នកកាត់ដេរសំលៀកបំពាក់

confédéral,e,aux *a.* នៃសហព័ន្ធ, នៃសម្ព័ន្ធ

confédératif,ive *a.*ម.ព. fédératif

confédération *n.f.* សហព័ន្ធ(ឧ.confédération helvétique);សម្ព័ន្ធ (ឧ. la confédération générale du travail)

confédéré,e *a.&n.* ដែលចូលជាសហ-

រដ្ឋ ឬ សម្ព័ន្ធ (ឧ. puissances confédérées)

confédérer *v.t.* រួបរួមជាសហរដ្ឋ ឬ ជាសម្ព័ន្ធ

confer [-fèr] (*mot lat.*) យោងទៅ (សុំមើល...); ប្រៀបធៀបនឹង (សរសេរកាត់ជា: conf. ឬ cf.)

conférence *n.f.* ការប្រជុំ, សន្និសីទ (ឧ. la conférence du désarmement)

conférencier,ère *n.* អ្នកធ្វើសន្និសីទ

conférer (avec) *v.i.* សន្ទនាការ (ឧ. conférer avec son avocat) ។ *v.t.* ឲ្យ, អនុញ្ញាត (ឧ. conférer le baptême); ប្រៀបធៀប (ក្នុងន័យនេះគេសរសេរបំព្រួញជា (cf.))

confesse *n.f.* ការសំដែងទោស(ឧ. aller à confesse; revenir de confesse)

confesser *v.t.* ឆ្លើយសារភាព, សារទោស, ទទួលខ្លួន (ឧ. confesser son ignorance); ប្រកាស (ឧ. confesser sa foi); ទទួលស្ដាប់ការសំដែងទោស (ឧ. confesser un pénitent) ។ *Fig.* សួង ។ confesser quelqu'un ធ្វើឲ្យឆ្លើយសារភាព ។ se confesser *v.pr.* សំដែងទោសខ្លួន, សារទោសខ្លួន

confession *n.f.* ការសំដែងទោស, ការឆ្លើយសារភាព, ការទទួលខ្លួន; ជំនឿ, សាសនា (ឧ. les diverses confessions)

confessionnal *n.m.* បន្ទប់សម្រាប់បព្វជិតកាតូលិក អ្នកស្ដាប់ការសំដែងទោស

confessionnel,elle *a.* នៃជំនឿខាងសាសនា (ឧ. querelles confessionnelles)

confetti *n.m. pl.* ផ្កាក្រដាស (សំរាប់បាចក្នុងពេលបុណ្យ)

confiance *n.f.* សេចក្ដីសង្ឃឹមលើ (ឧ. avoir confiance dans l'avenir); សេចក្ដីទុកចិត្ត (ឧ. perdre la confiance de quelqu'un); សេចក្ដីអង់អាច(ឥតញញើត)(ឧ. manquer de confiance en soi) ។ faire confiance ទុកចិត្តលើ ។ homme de confiance ព្រនាក់បំពង់ (អ្នកទំនុកទុកចិត្ត) ។ poste de confiance កន្លែងដែលត្រូវដាក់អ្នកជាទំនុកទុកចិត្តរបស់ខ្លួន ។ de confiance, en confiance *loc. adv.* ដោយឥតញញើត, ដោយឥតក-

ថែក(ឧ. acheter de confiance)

confiant,e *a.* ដែលទុកចិត្ត ឬ សង្ឃឹម

confidemment *adv.* ដោយអាថ៌កំបាំង

confidence *n.f.* ការប្រាប់រឿងអាថ៌កំបាំង (ឧ. faire des confidences à quelqu'un); រឿងអាថ៌កំបាំង (ឧ. être dans la confidence d'un projet) ។ en confidence *loc. adv.* យ៉ាងអាថ៌កំបាំង, ដោយស្ងាត់

confident,e *n.* អ្នកដែលគេប្រាប់រឿងអាថ៌កំបាំង; មនុស្សជំនិត

confidentiel,elle *a.* អាថ៌កំបាំង (ឧ. avis confidentiel)

confidentiellement *adv.* ដោយអាថ៌កំបាំង

confier *v.t.* ប្រគល់លើ (ឧ. confier un enfant); ប្រាប់រឿងអាថ៌កំបាំង (ឧ. confier ses peines) ។ *Fig.* ដាក់ជើ (ឧ. confier la semence à la terre) ។ se confier *v.pr.* ទុកចិត្តលើ (ឧ. se confier en quelqu'un); ប្រាប់រឿងអាថ៌កំបាំង (ឧ. se confier à ses amis)

configuration *n.f.* រូបសណ្ឋាន, រូបរាងខាងក្រៅ (ឧ. configuration d'un pays)

configurer *v.i.* ឲ្យមានរូបសណ្ឋាន

confinement *n.m.* ការដាក់ឲ្យនៅទីកៀនកោះ ឬ ទីឆ្ងាយ; ការដាក់មនុស្សទោសឲ្យនៅដាច់ពីគ្នា

confiner(à) *v.i.* មានព្រំដែនរួម (ឧ. le Laos confine au Cambodge) ។ *Fig.* ប្បែនឹង,ជិតនឹង (ឧ. cet acte confine à la folie) ។ *v.t.* ដាក់ឲ្យនៅទីកៀនកោះ ឬ ឲ្យនៅទីឆ្ងាយ (ឧ. confiner quelqu'un dans un monastère) ។ air confiné អាកាសរួមអាប់ ។ se confiner *v.pr.* ទៅនៅឆ្ងាយពីគេ (ឧ. se confiner chez soi); សម្ងំនៅ (ឧ. se confiner dans un rôle)

confins *n.m.pl.* ព្រំដែនរួមគ្នា ។ aux confins de la terre នៅចុងកាត់មាត់ញក

confire *v.t.* ធ្វើជំណាប់ ឬ ត្រាំ (ដាក់ក្នុងទឹកខ្មេះ ឬ ស្ករដើម្បីទុកបានយូរ) (ឧ. confire les mangues) ។ *Techn.* confire les peaux ត្រាំស្បែក ។ *Fam. & fig.* ទុកចោលមិនប្រើ; ងប់ (ឧ. se confire en

dévotion)

confirmatif,ive *a.* ដែលបញ្ជាក់

confirmation *n.f.* ការអះអាងបន្ថែម, ការបញ្ជាក់ (ឧ. confirmation d'une dépêche)

confirmatoire *a.* សម្រាប់បញ្ជាក់

confirmer *v.t.* គាំទ្រ (ឧ.confirmer quelqu'un dans son opinion); អះអាងបន្ថែម,បញ្ជាក់(ឧ.confirmer une nouvelle,un témoignage); យល់ព្រម (ឧ. confirmer une dotation)។*Fam.* ទះកំផ្លៀង

confiscable *a.* អាចរឹបអូសបាន

confiscation *n.f.* រឹប, ការរឹបអូស; ទ្រព្យរឹបអូស

confiserie *n.f.* សិល្បៈឬជំនាញដំណាប់ (បង្អែម); ហាងលក់ដំណាប់; ដំណាប់ (ឧ. manger des confiseries); កន្លែងធ្វើគ្រឿងប្រអប់

confiseur,euse *n.* អ្នកធ្វើ ឬ លក់បង្អែម

confisquer *v.t.* រឹបអូស (ដើម្បីយកជារបស់រដ្ឋ) (ឧ. confisquer des marchandises) ។ *Fam.* យក, យកចេញ (ឧ. confisquer à un écolier un livre défendu)

confit,e *a.* ដំណាប់ ឬ ត្រាំ (ឧ.fruits confits) ។ *Fig.* ដែលត្រាំត្រែងក្នុង (ឬងប់ក្នុង) (ឧ. confit en dévotion)។ *n.m.* សាច់ត្រាំក្នុងខ្លាញ់ (ឧ. confit d'oie)

confiture *n.f.* ដំណាប់ផ្លែឈើ, បង្អែមកំប៉ុង

confiturerie *n.f.* សិល្បៈ ឬ ជំនាញដំណាប់ ឬ បង្អែម; កន្លែងធ្វើដំណាប់ ឬ បង្អែមកំប៉ុង

confiturier,ère *n.* អ្នកលក់ដំណាប់ ឬ បង្អែមកំប៉ុង ។ *n.m.* កំប៉ុងដំណាប់ ឬ បង្អែម

conflagration *n.f.* មហាអគ្គិភ័យ; ការរំដើបរំជួលឬភាន់ប្រែខ្លាំង(ឧ.conflagration européenne)

conflit *n.m.* សង្គ្រាម ការប៉ះទង្គិច; ការប្រយុទ្ធ; ជម្លោះ; ការប្រឆាំង។ conflit armé អាវុធសង្គ្រាម

confluence *n.f.* ការប្រសព្វគ្នា, ការហូរចាក់ (ទន្លេ)

confluent *n.m.* ប្រសព្វមុខ (ទន្លេ)

confluer *v.i.* ប្រសព្វគ្នា, ហូរចាក់ទៅ (ទន្លេ)

confondre *v.t.* លាយឡំគ្នា, បញ្ចូលគ្នា (ឧ. ces deux fleuves confondent leurs eaux);ច្រឡំ (ឧ.

confondre le vrai avec le faux; confondre deux jumeaux)។ *Fig.* ផ្ចាញ់ផ្ចាល (ឧ. confondre un calomniateur); ធ្វើឲ្យឆ្ងល់ ឬ ឲ្យអៀនខ្មាស (ឧ. voilà qui me confond); ធ្វើឲ្យមានអំណរគុណ (ឧ. vos bontés me confondent)។ se confondre *v.pr.* ច្រូលឈាយឡំ; ឡប់ស្មារតី (ឧ. ma raison se confond)។ se confondre en politesses ខំប្រឹងសំដែងសេចក្ដីគួរសម

conformateur *n.m.* ខ្នាតក្បាលឬខ្នាតជើង (ប្រដាប់ដាងធ្វើមួកឬធ្វើស្បែកជើងសម្រាប់ភ្ជាប់វង់ក្បាល ឬ ជើង); ប្រដាប់ពង្រីកស្បែកជើង

conformation *n.f.* រូបសម្ព័ន្ធ។ vice de conformation វិការូបសម្ព័ន្ធ

conforme *a.* អនុលោម, ស្រប

conformément *adv.* ដោយអនុលោម

conformer *v.t.* ឲ្យមានរូបរាង; សម្រប, អនុលោម (ឧ. conformer sa conduite à ses paroles)។ se conformer *v.pr.* ប្រតិបត្តិតាម (ឧ. se conformer aux circonstances)

conformisme *n.m.* អនុលោមនិយម, ការនិយមតាមទម្លាប់

conformiste *n.* អ្នកអនុលោមនិយម

conformité *n.f.* សភាពដូចគ្នា (ឧ. la conformité de deux objets)។ *Fig.* ការស្របគ្នា ឬ ត្រូវគ្នា (ឧ. conformité de goût)។ en conformité *loc.pré.* ដោយអនុលោមតាម

confort *n.m.* ផាសុកភាព (ឧ. aimer le confort)

confortable *a.&n.m.* ផាសុក។ *n.m.* កៅអីម្យ៉ាង។ *n.m.pl.* ស្បែកជើងម្យ៉ាង

confortablement *adv.* យ៉ាងផាសុក, យ៉ាងស្រួល (ឧ. vivre confortablement)

confraternel,elle *a.* នៃសហភាតា

confraternité *n.f.* សហភាតរភាព

confrère *n.m.* សហភាតា, អ្នកមានវិជ្ជាជីវៈដូចគ្នា

confrérie *n.f.* សហភាតសង្គ្រោះ; សាសនិកសមាគម

confrontation *n.f.* សម្មុខីកម្ម, ការប្រទល់មុខ; ការទូរគ្នា

confronter *v.t.* ធ្វើសម្មុខីកម្ម, ប្រទល់

មុខ (ឧ. confronter les accusés); ទូរក្លា (ឧ. confronter des écritures) ។ *v.i.* នៅជាប់ (ឧ. champ qui confronte à la route)

confucéen,enne ឬ **confucien, enne** *a.&n.* នៃលទ្ធិខុងជឺ

confucianisme *n.m.* លទ្ធិខុងជឺ

confucianiste *n.* អ្នកកាន់លទ្ធិខុងជឺ

confus,e *a.* ច្របូកច្របល់ (ឧ. un amas confus)។ *Fig.* អៀនខ្មាស (ឧ. être confus de son erreur); ពិបាកយល់ (ឧ. discours confus); មិនច្បាស់, ស្រពេចស្រពិល (ឧ. un souvenir confus)

confusément *adv.* ដោយស្រពេចស្រពិល; ដោយច្របូកច្របល់

confusion *n.f.* ច្របូកច្របល់ភាព, ការច្របូកច្របល់ (ឧ. jeter la confusion dans les rangs); ភាពមិនច្បាស់; ការច្រឡំ (ឧ. confusion de noms, de dates); ការភត់ភាយ ។ *Fig.* ការអៀនខ្មាស; ភាពកុះករ។ en confusion *loc. adv.* ដោយកុះករ

confusionisme *n.m.* ច្របូកច្របល់និយម (លទ្ធិនិយមធ្វើឲ្យមានការច្របូកច្របល់)

congé *n.m.* ការឈប់សម្រាក, ការលំហែ (ឧ. congé de convalescence); ការបណ្ដេញអ្នកបំរើ (ឧ. donner son congé); លិខិតអនុញ្ញាតដឹកនាំទំនិញ; ការលែងលួល; លិខិតកំណត់ពេលលែងលួល; ការលា (ឧ. prendre congé លា)

congéable *a.* អាចលែងលួលបាន

congédiable *a.* អាចបណ្ដេញឬបញ្ឈប់បាន

congédiement *n.m.* ការបណ្ដេញ ឬ បញ្ឈប់ ។ *Adm.* ការឲ្យឈប់សម្រាក ឬ ការបានឈប់សម្រាក

congédier *v.t.* បណ្ដេញ (ឧ. congédier un importun); បញ្ឈប់ (ឧ. congédier un domestique)

congelable *a.* អាចបង្កកបាន

congélation *n.f.* យនកម្ម, ការបង្កក; ការកក; ភាពកក

congeler *v.t.* បង្កក, ធ្វើឲ្យកក (ឧ. une température de-130°C congèle l'alcool); ត្រាំទឹកកក (ទុកឲ្យបានយូរ) (ឧ. congeler de la viande); ធ្វើឲ្យស្ពឹក (ដោយត្រជាក់) (ឧ. congeler les mains, les pieds)។ se congeler *v.pr.* កក

congénère *a.* សជាតិ [សៈ-ជាតិ], ដែលមានជាតិដូចគ្នា (ឧ. plantes, animaux congénères)

congénital,e,aux *a.* ដែលមានពីកំណើត(ឧ. une malformation congénitale)

congestif,ive *a.* នៃរោគស្លាក់ឈាម ។ *Bot.* ក្រៀកគ្នា, ជិតគ្នា, ហាប់

congestion *n.f.* រោគស្លាក់ឈាម

congestionner *v.t.* ធ្វើឲ្យស្លាក់ឈាម (ឧ. la chaleur congestionne le cerveau)។ *Fig.* ធ្វើឲ្យទទើសទទែង (ឧ. congestionner une route)

conglomérat *n.m.* បិណ្ឌសិលា

conglomération *n.f.* បិណ្ឌីករណ៍, ការប្រមូលផ្តុំ

conglomérer *v.t.* ប្រមូលផ្តុំ,ធ្វើឲ្យក្តាំង (ឧ. conglomérer les particules de matières)

conglutinant,e ឬ **conglutinatif, ive** *a.* ដែលសម្រាប់ធ្វើឲ្យស្អិតឬអន្ទិល

conglutination *n.f.* ការធ្វើឲ្យស្អិត ឬ អន្ទិល; ភាពស្អិត ឬ អន្ទិល

conglutiner *v.t.* ធ្វើឲ្យស្អិត ឬ អន្ទិល

congolais,e *a.&n.* នៃប្រទេសកុងហ្គោ, នៃជនជាតិកុងហ្គោ

congratulateur,trice *a.&n.* អ្នកសរសើរ

congratulation *n.f.* អភិនន្ទន៍, ការសរសើរ

congratulatoire *a.* ដែលសរសើរ

congratuler *v.t.* សរសើរ ។ se congratuler *v.pr.* សរសើរខ្លួនឯង; សរសើរគ្នាទៅវិញទៅមក

congréganiste *a.&n.* នៃសហធម្មចារី

congrégation *n.f.* សហធម្មចារី, ក្រុមអ្នកប្រព្រឹត្តធម៌ត្រូវគ្នា

congrès *n.m.* សមាជ (ការប្រជុំដើម្បីពិភាក្សាអំពីរឿងអ្វីមួយ (ឧ. congrès national) (នៅប្រទេសបារាំង គឺការប្រជុំរួមគ្នានៃរដ្ឋសភានឹងក្រុមប្រឹក្សាសាធារណរដ្ឋ ដើម្បីជ្រើសតាំងប្រធានាធិបតីសាធារណរដ្ឋ។ នៅសហរដ្ឋអាមេរិក គឺ សភាទាំងពីរ=ព្រឹទ្ធសភានឹងសភាអ្នកតំណាង)

congressiste *n.* សមាជិកសមាជ

congru,e *a.* ត្រូវចំ, ត្រូវត្រង់, មិនល្អៀង (ឧ. réponse congrue)។ portion congrue ធនធានរស់មាត់ ឬ ប្រដុតប្រដើយសម្រាប់ចិញ្ចឹមជីវិត

congruence *n.f.* ការព្រមព្រៀង, ការ

ត្រូវគ្នា

congruent,e *a.* ត្រូវ(ឧ.expressions congruentes)

congruité *n.f.* ភាពត្រូវគ្នា

congrûment *adv.* ដោយត្រូវចំ;ដោយសមរម្យ

conicité *n.f.* រាងសាជី

conifères *n.m. pl.* សរល្លឹល[សៈ-រៈ-]

conique *a.* ដែលមានរាងសាជីមូល (ឧ. engrenage conique)

conjectural,e,aux *a.* ដែលរាងលើការប្រមាណ(ឧ. science conjecturale)

conjecturalement *adv.* ដោយប្រមាណ

conjecture *n.f.* ប្រមាណ, ស្មាន

conjecturer *v.t.* ស្មាន(ឧ. conjecturer la perte de quelqu'un)

conjoindre *v.t.* ដាក់ភ្ជាប់ស្និទ្ធនឹងគ្នា; ផ្សំផ្គុំគ្នា (ជាប្ដីប្រពន្ធ)

conjoint,e *a.* ដែលជាប់ស្និទ្ធជាមួយគ្នា។ *Dr.* ដែលជាប់កាតព្វកិច្ចរួមគ្នា ។ *n.m.* សហព័ន្ធ (ស្វាមី ឬ ភរិយា)

conjointement *adv.* ព្រមគ្នា,ជាមួយគ្នា (ឧ. agir conjointement avec quelqu'un)

conjonctif,ive *a.* សន្ធាន,ដែលសម្រាប់ភ្ជាប់ ។ locution conjonctive កេិយាសន្ធាន ។ tissu conjonctif ជាលិកាសន្ធាន (ឧ. le derme, les tendons des muscles, la sclérotique sont formés de tissus conjonctifs)

conjonction *n.f.* សន្ធានកម្ម, ការជួបគ្នា (ឧ. une extraordinaire conjonction de talents) ។ *Gram.* សន្ធានសព្ទ

conjonctive *n.f.* យុជា (ស្បែកនៃគ្របភ្នែកក្នុងនឹងប្រស្រីភ្នែក)

conjonctivite *n.f.* យុជារោគ,ជម្ងឺភ្នែកក្រហម

conjoncture *n.f.* មហោកាស (ឧ. se trouver dans des conjonctures difficiles); ទេសកាល:

conjugable *a.* អាចធ្វើកិរិយាវិភាគបាន

conjugaison *n.f.* ធាតុវិភាគ ឬ កិរិយាវិភាគ (ការបំបែកកិរិយាសព្ទ)

conjugal,e,aux *a.* នៃសហព័ន្ធ ឬ ប្ដីប្រពន្ធ(ឧ.la fidélité conjugale)

conjugalement *adv.* ជាប្ដីប្រពន្ធ(ឧ. vivre conjugalement)

conjugué,e *a.* សន្ធាន (ឧ. feuilles

conjuguées ស្លឹកសន្ទាន(ស្លឹកដែលមានស្លឹកតូចច្រើនតួសើទងតែមួយ) ។ *Anat.* nerfs conjugués ប្រសាទសន្ទាន

conjuguer *v.t.* បញ្ចូលគ្នា,រួមគ្នា(ឧ. ils conjuguèrent leurs efforts)។ *Gram.* conjuguer un verbe ធ្វើកិរិយាវិភាគ, បំបែកកិរិយាសព្ទ

conjungo *n.m.* *Fam.* ការបានប្ដីឬប្រពន្ធ (ឧ. aspirer au conjungo)

conjurateur *n.m.* គ្រូបណ្ដេញខ្មោច (ឧ.conjurateur de démons); មេបដិញ្ញាក្បត់

conjuration *n.f.* ការបដិញ្ញាក្បត់; ការសោកមន្តអាគមដេញខ្មោចបិសាច។ *pl.* ការទទូចអង្វរ

conjuré,e *a.&n.* អ្នកចូលរួមបដិញ្ញាក្បត់; ចៀសផុតហើយ

conjurer *v.t.* ទទូចអង្វរ (ឧ. je vous conjure de faire cela);បណ្ដេញខ្មោច ។ *Fig.* បញ្ចៀស (ឧ. conjurer le mauvais sort; le danger est conjuré); ប្ដេជ្ញាចិត្ត (ឧ. conjurer la perte de l'ennemi) ។ *v.i.* បដិញ្ញាក្បត់ ។ se conjurer *v.pr.* រួមគ្នា;បដិញ្ញាក្បត់

connaissable *a.* អាចស្គាល់បាន

connaissance *n.f.* អភិញ្ញាណ, ការចេះ (ឧ. la connaissance des lois); ការដឹង (ឧ.prendre connaissance d'un texte); ការស្គាល់រាប់អាន,ការស្គាល់គ្នា (ឧ.faire la connaissance de quelqu'un); អ្នកដែលស្គាល់រាប់អាន ។ vieille connaissance អ្នកដែលរាប់អាន ឬស្គាល់គ្នាយូរហើយ។ ការនៅដឹងខ្លួន (មិនសន្លប់) (ឧ. tomber sans connaissance ដួលសន្លប់ (មិនដឹងខ្លួន)។ connaissance discursive វិជាភិញ្ញាណ ។ connaissance immédiate ទិប្បាភិញ្ញាណ ។ *pl.* វិជ្ជា(ឧ. avoir des connaissances étendues)

connaissant,e *a.* ដែលស្គាល់

connaissement *n.m.* អញ្ញាតប័ណ្ណ [អាញ់-ញ៉ាតៈ-](សម្ពុទ្ធពាណិជ្ជ=លិខិតទទួលទំនិញដាក់ក្នុងកប៉ាល់) (ឧ. les clauses du contrat figurent fréquemment sur le connaissement)

connaisseur,euse *a.* អ្នកស្គាល់-ចេះ ឬ មានសមត្ថភាពនឹងវិនិច្ឆ័យ (ឧ.con-

naisseur en musique)

connaitre *v.t.* ដឹង, ស្គាល់ (ឧ. connaitre le nom, l'adresse de quelqu'un; connaitre le monde; connaitre la misère); រាប់អាន (ឧ. connaitre un ministre, un ambassadeur); ចេះ (ឧ. connaitre le grec); ធ្លាប់ ។ à l'œuvre on connait l'artisan ឃើញការគេស្គាល់ជាង ។ ne connaitre ni Dieu ni diable មិនជឿសាសនា ឬ គ្មានស្គាល់-គ្មានយល់អ្នកឯណាសោះ។ *Fig.* se faire connaitre បញ្ចេញសមត្ថភាពឲ្យគេស្គាល់; ប្រាប់ឈ្មោះ ឬ ប្រាប់ឋានន្តរឲ្យគេដឹង ។ ne connaitre ni d'Eve ni d'Adam មិនដែលស្គាល់សោះ ។ *Pop.* la connaitre មានការពិសោធ ។ *v.i. Dr.* មានសមត្ថកិច្ចជំនុំជំរះ (ឧ. le tribunal de commerce ne connait pas des causes civiles) ។ se connaitre *v.pr.* ស្គាល់ខ្លួនឯង ។ ne plus se connaitre ខឹងប្រឡេត ។ se connaitre, s'y connaitre en (ឬ à) quelque chose ប្រសប់, ចេះច្បាស់ (ឧ. se connaitre en tableaux)

connétable *n.m.* បេទ័ព

connétablie *n.f.* ការៈបេទ័ព

connexe *a.* ប្រទាក់គ្នា (ឧ. sciences connexes)

connexion *n.f.* ការប្រទាក់គ្នា (ឧ. connexion des idées)

connexité *n.f.* ភាពប្រទាក់គ្នា

connivence *n.f.* ការសមគំនិត

connivent,e *a.* ដែលចេះតែបែរកដិតគ្នា (ឧ. feuilles conniventes)

connu,e *a.* ដែលគេស្គាល់ (ឧ. c'est une chose bien connue; le monde connu); ល្បីល្បាញ (ឧ. auteur connu)។ *n.m.* អ្វីៗដែលគេស្គាល់ ឬ ដែលគេដឹង (ឧ. aller du connu à l'inconnu)

conoïdal,e *a.* ជារាងសាជី

conoïde *a.* ដែលមានរាងសាជី (ឧ. coquille conoïde)

conque *n.f.* ស័ង្ខ។ *Anat.* ទ្វេត្រចៀក

conquérant,e *a.&n.* អ្នកច្បាំងដណ្ដើម ។ *a. Fig.* ក្រអឺត (ឧ. un air conquérant)

conquérir *v.t.* ធ្វើសញ្ជ័យ, ច្បាំងដណ្ដើម

(ឧ. César mit huit ans pour conquérir la Gaule) ។ *Fig.* លួង, ធ្វើឲ្យជាប់ចិត្ត ។ conquérir les cœurs ធ្វើឲ្យគេស្រឡាញ់

conquêt *n.m.* លទ្ធទ្រព្យ, ទ្រព្យដែលរកបាន

conquête *n.f.* សញ្ជ័យ, ការច្បាំងដណ្ដើម (ឧ. la conquête d'un royaume); របស់ដែលច្បាំងបាន (ឧ. les conquêtes de Napoléon 1er)

conquis,e *a.* ដែលដណ្ដើមបាន; ដែលចាញ់ ។ *Fig.* se conduire comme en pays conquis ធ្វើឥតសំចៃដៃ ឬ ឥតប្រណី

conquistador *n.m.* អ្នកចម្បាំងព្រេងជាតិអេស្ប៉ាញ៉ុល ដែលដណ្ដើមយកទ្វីបអាមេរិក (*pl.* des conquistadores)

consacré,e *a.* ដែលឧទ្ទិសរួចហើយ (ឧ. lieu consacré); ប្រសិទ្ធ, ដែលគេទទួលស្គាល់ (ឧ. expression consacrée)

consacrer *v.t.* ឧទ្ទិស (ឧ. វិហារនេះគេសាងឧទ្ទិសចំពោះព្រះពិស្ណុ); ប្រសិទ្ធ (ឧ. mot que l'usage a consacré); ទុកសម្រាប់, ប្រើ(ប្រើពេល) (ឧ. consacrer son temps à l'étude); ធ្វើឲ្យឋិតថេរ (ឧ. consacrer le souvenir d'une victoire) ។ se consacrer *v.pr.* ឧទ្ទិសខ្លួនក្នុង (ឧ. se consacrer à une œuvre)

consanguin,e *a.&n.* ជាញាតិខាងឪពុក (រួមឈាម) ។ frère consanguin បងប្អូនឪពុកជាមួយ (ត.ផ. utérin) ។ *Par ext.* ដែលមានបុព្វបុរសរួមគ្នា

consanguinité *n.f.* ភាពជាញាតិខាងឪពុក ។ *Par ext.* ភាពមានបុព្វបុរសរួមគ្នា

consciemment *adv.* ដោយដឹងខ្លួន

conscience *n.f.* conscience psychologique ឬ conscience សម្បជញ្ញៈ, សេចក្ដីដឹងខ្លួន ។ conscience morale ឬ conscience មនសិការៈ; ដំណើរយកចិត្តទុកដាក់ ។ conscience professionnelle មនសិការៈក្នុងវិជ្ជាជីវៈ ។ *Fig.* ជំនឿខាងសាសនា (ឧ. la liberté de conscience est le fondement de toutes les autres libertés) ។ liberté de conscience សេរីភាពខាងជំនឿ(ក្នុងសាសនា) ។ *Pop.* ក្រពះ (ឧ. se mettre

une aune de boudin sur la conscience) ។

Loc.div. conscience large មនសិការៈទូលាយ(ព្រមឲ្យធ្វើអំពើអាក្រក់ដោយងាយ) ។ mauvaise conscience មនសិការៈមិនល្អ (ចំពោះអ្នកប្រព្រឹត្តអាក្រក់)។ dans ma conscience ឬ en mon âme et conscience តាមជំនឿរបស់ខ្ញុំ ។ mettre la main sur la conscience និយាយដោយត្រង់ ។ avoir sur la conscience មានអ្វីដែលត្រូវការនិយាយឲ្យគេស្ដាប់ (ឧ. dire tout ce qu'on a sur la conscience និយាយឲ្យអស់ពីពោះ) ។ avoir quelque chose sur la conscience មានកំហុសក្នុងខ្លួន ។ mettre sur la conscience ឲ្យទទួលខុសត្រូវអំពើ ។ avoir la conscience nette ស្អាតខ្លួន(គ្មានកំហុសអ្វីគួរឲ្យបន្ទោស) ។ se faire ឬ faire conscience de... ឬ une conscience de... ខ្វល់ចិត្តអំពើ ។ vendre sa conscience គិតប្រយោជន៍ខ្លួនជាងករណីយកិច្ច(សុខចិត្តធ្វើអំពើអាក្រក់ឲ្យបានប្រយោជន៍ផ្ទាល់ខ្លួន)។acheter les consciences សូកឲ្យធ្វើអាក្រក់ ។ opprimer les consciences បំបិទសេរីភាពខាងមនោសញ្ចេតនា-ខាងមតិនឹងខាងជំនឿ។ par acquit de conscience ម.ព. acquit។avoir conscience ដឹងខ្លួន ។ en conscience *loc. adv.* តាមការពិត; តាមត្រង់

consciencieusement *adv.* ដោយយកចិត្តទុកដាក់

consciencieux,euse *a.* ដែលមានមនសិការៈ, ដែលយកចិត្តទុកដាក់ (ឧ. travail conciencieux)

conscient,e *a.* ដែលមានសម្បជញ្ញៈ, ដែលដឹងខ្លួន

conscription *n.f.* ការកេណ្ឌអ្នកមានអាយុត្រូវធ្វើទាហាន

conscrit *n.m.* អ្នកបានអាយុត្រូវធ្វើទាហាន;ទាហានថ្មី ។ pères conscrits សមាជិកព្រឹទ្ធសភារ៉ូម៉ាំង ។ *Fig.* មនុស្សគ្មានពិសោធន៍

consécration *n.f.* ការឧទ្ទិស (ឧ. la consécration d'une église); ការប្រសិទ្ធ (ឧ. la consécration de l'usage) ។ *Rel.cath.* ពិធីប្រសិទ្ធនំបុ័ងនឹងស្រាទំពាំងបាយជូរជា

សាប់ទឹងឈាមព្រះយេស៊ូគ្រិស្ត

consécutif,ive *a.* ជាប់គ្នា ឬ តគ្នា (ឧ. avoir la fièvre trois jours consécutifs);ដែលជាផលនៃ,បន្ទាប់អំពី (ឧ. fatigue consécutive à une longue marche)

consécution *n.f.* ការតភ្ជាប់

consécutivement *adv.* តគ្នា,មិនដាច់

conseil *n.m.* ឱវាទ; យោបល់; គណៈ; ក្រុមប្រឹក្សា; សន្និបាត ។ conseil d'administration ក្រុមប្រឹក្សាភិបាល។ conseil de cabinet សន្និបាតរដ្ឋមន្ត្រី ។ conseil de la Couronne ក្រុមប្រឹក្សារាជសម្បត្តិ ។ conseil de discipline ក្រុមប្រឹក្សាវិន័យ ។ conseil de guerre ក្រុមជំនុំសឹក ។ conseil d'Etat ក្រុមប្រឹក្សារដ្ឋ ។ conseil de la famille royale ក្រុមសង្គហៈព្រះរាជវង្សានុវង្ស ។ conseil de la magistrature ក្រុមប្រឹក្សាតុលាការ។ conseil de perfectionnement ក្រុមប្រឹក្សាសម្រិតការ ។ conseil des ministres គណៈរដ្ឋមន្ត្រី។ conseil le l'ordre គណៈនេតិបណ្ឌិត ឬ វេជ្ជ ។ conseil de régence ក្រុមព្រះរាជានុសិទ្ធិ ។ conseil du Roi ក្រុមប្រឹក្សាព្រះរាជា ។ conseil du royaume ក្រុមប្រឹក្សាព្រះរាជាណាចក្រ ។ conseil du Trône ក្រុមប្រឹក្សារាជបល្ល័ង្ក

conseiller *v.t.* ទូន្មាន, ឲ្យឱវាទ; បញ្ឆេះ; ប្រដៅ(ឧ.conseiller un enfant; conseiller la prudence)

conseiller,ère *n.* អ្នកឲ្យឱវាទ (ឧ. un sage conseiller);ទីប្រឹក្សា,សមាជិកក្រុមប្រឹក្សា ។ *n.f.* ភរិយាទីប្រឹក្សា ។ conseiller d'ambassade ទីប្រឹក្សាស្ថានឯកអគ្គរដ្ឋទូត (ឬ រាជទូត) ។ conseiller de légation ទីប្រឹក្សាស្ថានអគ្គរដ្ឋទូត (ឬ រាជទូត)

conseilleur,euse *n.* អ្នកបញ្ឆេះ

consensuel,elle *a.Dr.* ដែលគ្រាន់តែព្រមព្រៀងគ្នា (កិច្ចសន្យា)

consensus *n.m* ការព្រមព្រៀងរវាងគ្នាច្រើន ឬ រវាងអង្គការច្រើន

consentant,e *a.* ដែលយល់ព្រម

consentement *n.m.* ការយល់ព្រម(ឧ. le consentement universel est un indice, mais non une preuve de vérité) ។ du consentement de tous *loc.*

adv. ដោយយល់ព្រមទាំងអស់គ្នា

consentir *v.i.* យល់ព្រម (ឧ. consentir à un arrangement)។ *v.t.Dr.* ព្រម, អនុញ្ញាត (ឧ. consentir une vente) ។ *Prov.* qui ne dit rien consent អ្នកមិនស្ដីទុកជាយល់ព្រម (អ្នកដែលមិនប្រកែកគេសន្មតថាយល់ព្រម)

conséquemment *adv.* តាមដំណើរហេតុ; ដោយហេតុនេះ

conséquence *n.f.* វិបាក (ផលកម្មអាក្រក់ ឬ ល្អដែលផ្ដល់ឲ្យតាមហេតុ) (ឧ.prévoir les conséquences d'une action); ផល ។ *Fig.* សារៈសំខាន់(ឧ. affaire de conséquence) ។ tirer à conséquence មានសារៈសំខាន់ ។ sans conséquence គ្មានសារៈសំខាន់ ។ en conséquence *loc. adv.* ដោយហេតុនេះ, តាមដំណើរហេតុ (ឧ. j'ai reçu votre lettre et j'agirai en conséquence)

conséquent,e *a.* ដែលពិចារណា (ឧ. homme conséquent dans sa conduite) ។ *Pop.* សំខាន់, ធំ (ឧ. affaire, ville conséquente)។ par conséquent *loc. conj.* ដូច្នេះ, ដោយហេតុនេះ

conservateur,trice *a.&n.* អភិរក្ស (ដែលរក្សាទុក) ។ conservateur des hypothèques អភិរក្សនិក្ខេប។ parti conservateur គណបក្សអភិរក្ស

conservation *n.f.* ការអភិរក្ស (ការរក្សាទុក); អភិរក្ខភាព (ភាពនៃវត្ថុដែលរក្សាទុក) (ឧ. ouvrage dans un état de bonne conservation) ។ មុខងារអភិរក្ស;មន្ទីរអភិរក្ស។ conservation d'Angkor មន្ទីរអភិរក្សអង្គរ ។conservation cadastrale មន្ទីរអភិរក្សសុរិយោដី ។ conservation du domaine ការអភិរក្សនៃទ្រព្យរាជការ។ conservation des hypothèques មន្ទីរអភិរក្សនិក្ខេប

conservatisme *n.m.* អភិរក្សនិយម

conservatoire *a.* ដែលសម្រាប់រក្សាទុក(ឧ. l'apposition des scellés est une mesure conservatoire) ។ *n.m.* វិជ្ជាឋានអភិរក្ស

conserve *n.f.* *Mar.* naviguer de conserve ធ្វើនាវាចរណ៍ជាមួយគ្នា

(ដើម្បីជួយគ្នា)។ *Par ext.* ជាមួយគ្នា

conserve *n.f.* ដំណាប់ក្រៀម, អាហារប្រអប់ (ឧ. conserve de légumes)

conserver *v.t.* អភិរក្ស, រក្សាទុក (ឧ. conserver sa santé; conserver un secret; conserver son calme)។ personne bien conservée មនុស្សសាច់ថាំ (អាយុច្រើនប៉ុន្តែសាច់នៅដូចក្មេង)។ se conserver *v.pr.* រក្សាខ្លួន (រក្សាសុខភាព); ឋិតថេរ; នៅល្អ

conserverie *n.f.* ឧស្សាហកម្មដំណាប់ក្រៀម ឬ អាហារប្រអប់; កន្លែងធ្វើដំណាប់ក្រៀម ឬ អាហារប្រអប់

considérable *a.* សំខាន់, ធំដុំ (ឧ. situation considérable); ច្រើន, សន្ធឹក (ឧ. dépense considérable; armée considérable; travail considérable)

considérablement *adv.* យ៉ាងសន្ធឹក

considérant *n.m.* មូលបទ (ខាងតុលាការ ឬ ខាងរដ្ឋបាល)។ considérant que *loc.conj.* ដោយយល់ថា

considération *n.f.* ការពិនិត្យពិច័យ, ការពិចារណា (ឧ. cela mérite considération)។ *Fig.* ហេតុ (ឧ. cette considération m'a décidé); សម្មានការ, សេចក្ដីរាប់អាន (ឧ. mériter la considération de tous)។ *pl.* ការគ្រាន់តែនិយាយ (ផ្ទុយនឹងការធ្វើ) (ឧ. se perdre en considération)។ en considération de ដោយយល់ដល់ (ឧ. en considération des services rendus)។ prendre en considération ទទួលយកជាការ, ទទួលយកមកពិចារណា

considérément *adv.* ដោយប្រយ័ត្ន

considérer *v.t.* ពិនិត្យ (ឧ. considérer quelqu'un de la tête aux pieds)។ *Fig.* ពិចារណា, ពិតប្អឹង (ឧ. considérer les avantages); រាប់អាន (ឧ. on le considère beaucoup); ចាត់, រាប់ (ឧ. considérer comme រាប់ជាជា)

consignataire *n.m.* អ្នកទទួលបញ្ញើទុក

consignateur,trice *n.* អ្នកផ្ញើ

consignation *n.f.* ការផ្ញើទុក, បញ្ញើ (ឧ. retirer sa consignation)

consigne *n.f.* អាជ្ញា, សេចក្ដីបង្គាប់ជាដាច់ខាត; ទណ្ឌកម្មហាមមិនឲ្យចេញ (ចំពោះ

សិស្សនឹងទាហាន); ទីទុកអីវ៉ាន់បណ្ដោះអាសន្ន (ក្នុងស្ថានីយ៍អយស្ម័យយាន)

consigner *v.t.* ដាក់ផ្ញើទុក (ឧ. consigner une somme, des marchandises)។ *Fig.* កត់ត្រាទុក(ឧ. consigner un fait); ដាក់ទោសមិនឲ្យចេញ (ឧ. consigner la troupe) ។ consigner quelqu'un à sa porte ឬ consigner sa porte à quelqu'un ហាមមិនឲ្យចូល

consistance *n.f.* សង្កតភាព [សង់-កត់-] ភាពកក; ភាពជាប់ (ឧ. ce bois manque de consistance) ។ *Fig.* សោចក្ដីប៉ុងម៉ាត់ (ឧ. esprit sans consistance); ភាពប្រាកដ (ឧ. bruit sans consistance); ស្ថិរភាព

consistant,e *a.* សង្កត, ដែលកក; ជាប់; ហាប់

consister (dans,en) *v.i.* មានជា (ឧ. son revenu consiste en rentes); ឋិតនៅលើ (ឧ. le bonheur consiste dans la vertu)

consœur *n.f.* *Par plaisant.* សហភគិនី [សះ-ហៈ-ភៈ-]

consolable *a.* អាចលួងចិត្តបាន

consolant,e *a.* ដែលលួងចិត្ត

consolateur,trice *a.&n.* ដែលធ្វើឲ្យស្រាកទុក្ខ, ដែលលួងចិត្ត (ឧ. espoir consolateur)

consolation *n.f.* ការស្រាកទុក្ខ, ការលួងចិត្ត (ឧ. être privé de consolation ; consolations affectueuses); អ្វីៗដែលលួងចិត្ត(ឧ. la lecture est sa seule consolation)

console *n.f.* ធ្នឹមកើយ (ធ្វើអំពីថ្ម ឬលោហធាតុ) (ឧ. les consoles d'un balcon); តុរចនា (ឧ. console Empire តុរចនាជំនាន់រាជាធិរាជណាបព្រ)

consoler *v.t.* លួងចិត្ត (ឧ.consoler les malheureux); ធ្វើឲ្យស្រាកទុក្ខ (ឧ. il consolait leur captivité) ។ se consoler *v.pr.* ស្រាកទុក្ខ

consolidation *n.f.* ឬ **consolidement** *n.m.* ការពង្រឹង; ការធ្វើឲ្យជាប់ ឬ ឲ្យរឹងមាំឡើង (ឧ. consolidation d'un édifice, d'une fortune)

consolider *v.t.* ពង្រឹង, ធ្វើឲ្យរឹង (ឧ. consolider un mur) ។ *Fig.* ពង្រឹង (ធ្វើឲ្យមាំ ឬ ឲ្យពូកែឡើង (ឧ. consolider le pouvoir)

consommable *a.* អាចបរិភោគ ឬ ប្រើប្រាស់បាន

consommateur,trice *n* អ្នកបរិភោគ, អ្នកប្រើប្រាស់ (ឧ. les consommateurs supportent les augmentations des droits de douane et des impôts indirects);អ្នកបរិភោគ(ក្នុងភោជនីយដ្ឋាន)

consommation *n.f.* ការបរិភោគ;ការប្រើប្រាស់ (ឧ. consommation d'électricité); ឧបភោគបរិភោគ (ឧ.si la consommation s'accroît en raison de la production, cette dernière est également stimulée par la consommation) ; ការសម្រេចកិច្ច, ការប្រព្រឹត្ត (ឧ. la consommation d'un crime) ។ consommation des siècles ទីអវសាននៃកាល ។ ភេសជ្ជៈ (ដែលគេផឹកក្នុងភោជនីយដ្ឋាន) (ឧ. payer sa consommation)

consommé,e *a.* ឥតខ្ចោះ(ឧ. sagesse consommée); ប្រសប់ (ឧ. technicien consommé) ។ *n.m.* ស៊ុបសាច់

consommer *v.t.* សម្រេចកិច្ច, ប្រព្រឹត្ត (ឧ. consommer un forfait); បរិភោគ (ឧ. consommer des aliments); ប្រើប្រាស់; ស៊ី (ឧ. ce poêle consomme trop de charbon) ; ផឹកភេសជ្ជៈ (ក្នុងភោជនីយដ្ឋាន)

consomptible *a.Dr.* ខយគម [ខៈ-យៈ-គំ](ដែលអស់ដោយការប្រើប្រាស់) (ឧ. ម្ហូបអាហារ, ប្រេងសាំង។ ល ។)

consomptif,ive *a.* ដែលឲ្យរីង (ពុះស្គមជាលំដាប់) (ឧ. diabète consomptif)

consomption *n.f.* ភាពរីង (ពុះស្គមបន្តិចម្តងៗ)

consonance *n.f. Mus.* ភាពពីរោះរងំ; ភាពរៀលរណ្តំ។*Par ext.*សំឡេងដូច (ឧ.un mot aux consonances harmonieuses, agréables)

consonne *n.f.* ព្យញ្ជនៈ (ឧ. l'alphabet cambodgien comprend trente trois consonnes)។ *a.*

lettre consonne ព្យញ្ជនៈ

consonner ឬ **consoner** *v.i.* ត្រូវគ្នា; ផ្សំសំឡេងពីរោះ

consort *a.m.* prince consort សម្តេចព្រះភស្តានៃព្រះមហាក្សត្រិយានី។ *n.m.pl.* សហគត, អ្នកមានប្រយោជន៍រួមគ្នាក្នុងរឿងមួយ

consortium *n.m.* សហគម ។ consortium banquaire សហគមធនាគារិក

conspirant,e *a.* ដែលនាំឲ្យផលផ្ទួបគ្នា

conspirateur,trice *n.* អ្នករួមគំនិតក្បត់ ។ *a.f.* menées conspiratrices កលល្បិចរួមគំនិតក្បត់

conspiration *n.f.* សហក្បដ, ការគិតក្បត់; ការរួមកម្លាំងគ្នា

conspirer *v.t.* រួមគំនិតធ្វើអំពើអាក្រក់ (ឧ. conspirer la ruine de quelqu'un)។ *v.t.ind.* conspirer à ជួយ (ផ្តល់ឲ្យព្រម) (ឧ. tout conspire à son bonheur) ។ *v.i.* ធ្វើសហក្បដ, រួមគំនិត

conspuer *v.t.* សំដែងសំអប់ក្នុងទីសាធារណ៍(ឧ.conspuer un acteur, une pièce)

constamment *adv.* និរន្តរ, ជានិច្ច, ឥតឈប់, រឿយៗ(ឧ. bavarder constamment)

constance *n.f.* ចិត្តនឹង, សេចក្តីខ្ជាប់ខ្ជួន (ឧ. souffrir avec constance; poursuivre un dessein avec constance; amitié d'une rare constance); ភាពខ្ជាប់ខ្ជួន (ឧ. la constance d'un phénomène)

constant,e *a.* ដែលមានចិត្តនឹង, ខ្ជាប់ខ្ជួន, ដែលមិនប្រែប្រួល(ឧ.être constant dans l'adversité; bonheur constant)

constat *n.m.* ការពិនិត្យកត់ត្រា

constatation *n.f.* ការសំគាល់ឃើញ; ការពិនិត្យកត់ត្រា; តឹកតាង

constater *v.t.* សំគាល់ឃើញ(ឧ.constater une absence); កត់ត្រាទុក (ឧ. constater un décès);ពិនិត្យកត់ត្រា (ឧ. constater l'état de lieux) ។ constater un droit ត្រាពន្ធទុក

constellation *n.f.* តារានិករ, ក្រុមផ្កាយ

constellé,e *a.* ដែលភាយផ្កាយឬលេចដោយវត្ថុមានពន្លឺផ្លេកៗ

consteller *v.t.* ភាយផ្កាយ។*Fig.* លេចដោយវត្ថុមានពន្លឺផ្លេកៗ (ឧ. les dé-

corations qui constellent un uniforme)

consternation *n.f.* ដំណើរភាំង ឬ ស្រឡាំងកាំង; ការកើតទុក្ខខ្លាំង

consterné,e *a.* ស្រឡាំងកាំង

consterner *v.t.* បំភាំងឬធ្វើឲ្យស្រឡាំងកាំង (ឧ. nouvelle qui consterne le pays)

constipant,e *a.* ដែលឲ្យទល់លាមក

constipation *n.f.* ប្រដិត, រោគទល់លាមក

constiper *v.t.* ឲ្យទល់លាមក

constituant,e *a.* បតិដ្ឋាភាគ (ឧ. les parties constituantes d'un corps) ។ *n.m.* បតិដ្ឋាជន ។ l'assemblée constituante ឬ la constituante *n.f.* សភាបញ្ញត្តច្បាប់

constitué,e *a.* homme bien constitué មនុស្សរឹងប៉ឹង (មានកម្លាំងហើយមិនសូវឈឺ) ។ autorités constituées អាជ្ញាធរតែងតាំងតាមច្បាប់

constituer *v.t.* ធ្វើបតិដ្ឋាកម្ម ឬធ្វើបតិដ្ឋាប័ន, ផ្សំជា, រួមជា (ឧ. ces divers projets constituent un système cohérent); បង្កបង្កើត (ឧ. constituer une société); តែងតាំង (ឧ. constituer un gouvernement); ជាមូលដ្ឋាន (ឧ. l'intention constitue le crime); ទុកសម្រាប់ (ឧ. constituer une dot, une rente) ។ se constituer *v.pr.* se constituer prisonnier ចូលខ្លួនឲ្យគេចាប់ (ចូលខ្លួនឲ្យតុលាការជំនុំជំរះដោយខ្លួនឯង; ចូលខ្លួនឲ្យសត្រូវចាប់)

constitutif,ive *a.* នៃបតិដ្ឋាភាគ; ជាបតិដ្ឋាប័ន; ជាភាគផ្សំ (ឧ. les éléments constitutifs d'un corps) ។ acte constitutif សាលិខិតជាបតិដ្ឋាប័ន

constitution *n.f.* បតិដ្ឋាកម្ម, បតិដ្ឋាប័ន, ការតែងតាំង (ឧ. procéder à la constitution d'un gouvernement); ភាគធាតុរួម (ឧ. la constitution de l'air); អត្តភាព, រូបកាយ ។ bonne constitution រូបកាយរឹងប៉ឹង (មិនសូវឈឺ); mauvaise constitution រូបកាយទន់ខ្សោយ (ឈឺច្រើន) ។ ការដកល់ទុកសម្រាប់ (ឧ. constitution d'une rente); ការចាត់តាំង (ឧ. consti-

tution d'un avoué) ។ constitution de partie civile ការប្ដឹងទារជម្ងឺចិត្តពីបទអាជ្ញា ។ រដ្ឋធម្មនុញ្ញ (ឧ. la constitution cambodgienne)

constitutionnaliser *v.t.* ឲ្យមានលក្ខណៈជារដ្ឋធម្មនុញ្ញ

constitutionnalité *n.f.* ភាពត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ (ឧ. la constitutionnalité des lois)

constitutionnel,elle *a.* ត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ; ដែលអាស្រ័យរដ្ឋធម្មនុញ្ញ (ឧ.l'Angleterre est une monarchie constitutionnelle)

constitutionnellement *adv.* ដោយត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ

constricteur *a.& n.m.* សាច់ដុំខ្ទឹប

constrictif,ive *a* សម្រាប់ខ្ទឹប

constriction *n.f.* ការខ្ទឹប,ការបង្រួមវង់ឲ្យតូច

constringent,e *a.* ដែលរឹតរួត

constructeur *n.m.* ស្ថាបនិក,អ្នកសង់, អ្នកសាង

constructif,ive *a.* ស្ថាប័ន, ស្ថាបនា (ឧ. esprit constructif)

construction *n.f.* សំណង់,ការស្ថាបនា; អគារដែលគេសង់។ *Fig.* ការតែង(ឧ: construction d'un poème)។ *Gram.* ការចងក្រង, ការរៀបពាក្យក្នុងប្រយោគ

construire *v.t.* ស្ថាបនា,សង់(ឧ.construire une maison); សាង, ធ្វើ (ឧ. construire un avion); គូរ(ឧ.construire un triangle)។ *Fig.* ស្ថាបនា,តែង(ឧ.construire une théorie) ។ *Gram.* ចងក្រង, តែង, រៀបពាក្យ (ឧ. construire une phrase)

consul *n.m.* កុងស៊ុល ។ consul de carrière កុងស៊ុលអាជីព (កុងស៊ុលកាន់ការក្នុងតំណែង ជាកុងស៊ុលជានិច្ចកាល)។ consul général អគ្គកុងស៊ុល ។ consul marchant កុងស៊ុលគោចរ

consulaire *a.* នៃកុងស៊ុល (ឧ.dignité consulaire); នៃតុលាការពាណិជ្ជកម្ម(ឧ.tribunaux consulaires)

consulat *n.m.* បន្ទុកកុងស៊ុល; ស្ថានកុងស៊ុល

consultant,e *a.&n.* អ្នកឲ្យយោបល់ ។ médecin consultant ពេទ្យពិនិត្យជំងឺ ។ អ្នកពិគ្រោះ ; អ្នកឲ្យពេទ្យ

ពិនិត្យជម្ងឺ; អ្នកពឹងមេធាវី

consultatif,ive *a.* ដែលសម្រាប់ពិគ្រោះ ឬ ឲ្យយោបល់ (ឧ. comité consultatif)។ avoir voix consultative មានសិទ្ធិឲ្យយោបល់ (ប៉ុន្តែគ្មានសិទ្ធិបោះឆ្នោត)

consultation *n.f.* ការពិគ្រោះ; ការសុំយោបល់; យោបល់ពេទ្យឬមេធាវី; ការពិនិត្យជម្ងឺ (ឧ. la consultation du médecin)

consulte *n.f.* គុណការនៃប្រទេសស៊ូស

consulter *v.t.* ពិគ្រោះ, សុំយោបល់ (ឧ. consulter un médecin); រកពត៌មាន, រកសេចក្ដីពន្យល់ (ឧ. consulter un dictionnaire)។ តាម (ឧ. consulter sa raison)។ *v.i.* ពិនិត្យជម្ងឺ (ឧ. médecin qui consulte tous les jours)

consulteur *a.&n.* អ្នកឲ្យគេពិគ្រោះ (សម្រាប់គេសួរពត៌មាន)

consumable *a.* អាចធ្វើឲ្យវិនាសបាន

consumer *v.t.* ធ្វើឲ្យវិនាស (ឧ. le feu a tout consumé)។ *Fig.* ធ្វើឲ្យរីងខ្លួន, ធ្វើឲ្យឈឺចាប់ (ឧ. les soucis nous consument)។ se consumer *v.pr.Fig.* សង្រេងសង្រៃ, រីងខ្លួន

consumptible *a.* អាចវិនាសបាន

contact *n.m.* ផុសនា [ផុ-សៈ-ណា], ការពាល់ត្រូវ (ឧ. maladies qui se propagent par le contact); កុងតាក់ (ប្រដាប់បើកឬបិទចរន្តអគ្គិសនី)។ *Fig.* ការសេពគប់ (ឧ. être en contact avec quelqu'un)។ *Math.* point de contact ចំណុចផុសនា។ *Mil.* prise de contact ការស្ទង់កម្លាំង។ rompre contact ដោះដៃ (រ. décrocher)។ perdre contact ឲ្យសត្រូវដោះដៃរួច ។ verres, lentilles de contact កែវវ៉ែនតាពាក់ផ្ទាល់ភ្នែក

contacter *v.t.* ចូលទាក់ទង

contadin,e *a.&n.* ដែលរស់នៅក្នុងជនបទ, អ្នកស្រែ (នៅប្រទេសអ៊ីតាលី)

contage *n.m.* អ្វីៗដែលនាំគ្រឿងចម្លង (រោគ)

contagieux,euse *a.* ឆ្លង (រោគ)។ *Fig.* ឆ្លង (ឧ. une erreur contagieuse)។ *n.* អ្នកកើតរោគឆ្លង

contagion *n.f.* ការឆ្លង(រោគ)។ *Fig.* ការគ្រាប់គំនិតពាលដោយសេពគប់; ការឆ្លង (ឧ. la contagion du fou rire)

contagionner *v.t.* ឆ្លង (រោគ) ។ se contagionner *v.pr.* មានរោគដោយឆ្លង

contagiosité *n.f.* សង្កមភាព,ភាពឆ្លង

container *n.m.* (ពាក្យ អង់គ្លេស-អាមេរិកាំង)ហិបដឹកទំនិញ; ហិបដាក់អីវ៉ាន់ៗម្នាក់តាមដ័ត្រយោង

contaminable *a.* អាចចម្លងរោគ ឬ ឆ្លងរោគបាន

contamination *n.f.* ការចម្លងមេរោគ (ឧ. le pou est l'agent de contamination du typhus)។ *Fig.* ភាពសៅហ្មង

contaminer *v.t.* ចម្លងមេរោគ ។ *Fig.* មានសៅហ្មងដោយការសេពគប់ ។ se contaminer *v.pr.* មានរោគឆ្លង

conte *n.m.* រឿងប្រឌិត (ឧ. les contes de Perrault); រឿងកុហក(ឧ. c'est un conte)

contemplateur,trice *n.* អ្នកសម្លឹងពិនិត្យ, អ្នកសង្កេតដោយហ្មត់ចត់; អ្នកកំពុងភាវនា ឬ កំពុងសញ្ជឹងគិត

contemplatif,ve *a.* អ្នកចូលចិត្តសញ្ជឹងគិត (ឧ.esprit contemplatif)។ vie contemplative ការចម្រើនភាវនា

contemplation *n.f.* ការសម្លឹង(ដោយមំសចក្ខុ ឬ ដោយបញ្ញាចក្ខុ)(ឧ. contemplation des astres); ការចម្រើនភាវនា។ *Par ext.* ការសញ្ជឹងគិត (ឧ.vivre dans la contemplation)

contemplativement *adv.* ដោយសញ្ជឹងគិត; ដោយចំរើនភាវនា

contempler *v.t.* សម្លឹង (ដោយមំសចក្ខុ ឬ ដោយបញ្ញាចក្ខុ); សង្កេតដោយយកចិត្តទុកដាក់; ចំរើនភាវនា

contemporain,e *a.&n.* សហកាលិក, សហកាល, ស្រករ

contempteur,trice *n.* អ្នកបន្តុះបង្អាប់, អ្នកនិយាយបង្អាប់(ឧ.les contempteurs de la religion)

contenance *n.f.* ចំណុះ (ឧ contenance d'un vase)។ *Par ext.* ទំហំ (ឧ. contenance d'un champ) ។ *Fig.* អាកប្បកិរិយា (ឧ. contenance embarrassée)។ *Fig.* faire bonne contenance មិនតក់ស្លុត (ក្នុងពេលអាសន្ន) ។ perdre contenance តក់ស្លុត, ឡប់ស្មារតី

contenant,e *a.* ដែលមានចំណុះឬទំហំ។

n.m. របស់សម្រាប់ដាក់ (ឧ. le contenant est plus grand que le contenu)

contendant,e *a.&n.* ដែលប្រកួតប្រជែងគ្នា។ *Dr.* parties contendantes គូវិវាទ

contenir *v.t.* មានចំណុះ (ឧ. le décalitre contient dix litres)។ *Fig.* មាន (ឧ. ce livre contient de grandes vérités); ទប់ (ឧ. contenir la foule; contenir la colère); បង្ក្រាប (ឧ.contenir le peuple)។ se contenir *v.pr.* ទប់ (ឈ្នះខ្លួនឯង); ទប់គ្នាទៅវិញទៅមក

content,e *a.* សប្បាយចិត្ត (ឧ. peu de gens sont contents de leur sort; un maître content de ses élèves; un air content)។ être content de soi សប្បាយចិត្តនឹងខ្លួនឯង ។ *n.m.* avoir son content d'une chose មានបរិបូណ៌

contentement *n.m.* ការបំពេញ(ចិត្ត) (ឧ. le contentement des désirs); ការសប្បាយចិត្ត ។ contentement passe richesse ការសប្បាយចិត្ត ប្រសើរជាងការមានទ្រព្យសម្បត្តិ

contenter *v.i.* ធ្វើឲ្យសប្បាយចិត្ត (ឧ. contenter ses maîtres); សងប្រាក់ (ឧ.contenter des créanciers)។ se contenter de *v.pr.* ពេញចិត្តនឹង (ឧ.se contenter de peu)។ *Abs.* បំពេញបំណង, គ្រាន់តែ

contentieux,euse *a.* ដែលមានវិវាទ (ឧ. affaire contentieuse) ។ *n.m.* រឿងវិវាទ, ក្រុមវិវាទ ។ contentieux administratif ក្រុមវិវាទខាងរដ្ឋបាល

contentif,ive *a.Chir.* ដែលទប់ (ឧ. appareil contentif)

contention *n.f.* ការប្រឹងគិត

contention *n.f.* moyens de contention វិធី ឬ ប្រដាប់ក្រៀក

contenu,e *a.* ដែលមានក្នុង ។ *Fig.* ដែលទប់ឈ្នះ (ឧ. colère contenue) ។ *n.m.* អន្តរវត្ថុ, បន្ទុក, ចម្រុក (ឧ.le contenu d'un flacon)។ *Fig.* សេចក្តីខាងក្នុង, ន័យ (ឧ. le contenu d'une lettre)

conter *v.t.* និយាយរឿង, និយាយរ៉ាយរ៉ាប់ (ឧ. conter un fait) ។ en

conter de belles និយាយរឿងមិនគួរជឿ។ s'en laisser conter ឲ្យគេកុហកបាន

contestable *a.* អាចប្រកែកបាន

contestation *n.f.* វិវាទកម្ម,ការប្រកែក ឬ ជំទាស់(ឧ.contrat qui donne lieu à des contestations; accepter sans contestation); ការទាស់ទែង (ឧ. entrer en contestation avec quelqu'un)។ sans contestation *loc. adv.* ឥតជំទាស់, ឥតប្រកែក

conteste *n.f.* sans conteste *loc. adv.* ដោយឥតប្រកែកបាន

contester *v.t.* ប្រកែក; ជំទាស់ (ឧ. contester une succession; je conteste sa sincérité)។ *v.t.ind.* contester sur ឈ្លោះប្រកែកអំពី (ឧ.contester sur des choses insignifiantes)

conteur,euse *n.* អ្នកនិយាយរឿង (ឧ. un conteur agréable);អ្នកនិពន្ធរឿងប្រឌិត

contexte *n.m.* បរិបទ (អត្ថបទទាំងមូលដែលនៅពីមុខ ឬ ពីក្រោយប្រយោគ ឬ សំនួនសេចក្ដីមួយ) (ឧ. éclairer par le contexte un passage difficile); បរិការណ៍ (ការណ៍ទាំងឡាយដែលកើតក្រោយព្រឹត្តិការណ៍មួយ) (ឧ. replacer un fait dans son contexte historique)

contexture *n.f.* បទសម្ពន្ធ (ការទាក់ទងភាគផ្សេងនៃរបស់ទាំងមូល) (ឧ. la contexture des muscles)។ *Fig.* contexture d'un discours បទសម្ពន្ធនៃសុន្ទរកថា

contigu,ë *a* ជាប់គ្នា (ប៉ះគ្នា); បន្ទាប់គ្នា (ឧ.chambre contiguë à une autre)

contiguïté *n.f.* ភាពនៅជិតគ្នា (ប៉ះគ្នា)

continence *n.f.* មេថុនវិរតិ; ការវៀរចាកមេថុន

continent,e *a.* មេថុនវិរត,ដែលវៀរចាកមេថុន

continent *n.m.* ទ្វីប។ *Abs.* អឺរ៉ុបគោក (ផ្ទុយនឹងប្រទេសអង់គ្លេសដែលជាកោះ)។ Ancien Continent ទ្វីបចាស់ (អឺរ៉ុប,អាស៊ីនិងអាហ្វ្រិក)។ Nouveau Continent ទ្វីបថ្មី (អាមេរិក)

continental,e,aux *a.* នៃទ្វីប ។ climat continental អាកាសធាតុនៃទ្វីប (អាកាសធាតុដែលខុសគ្នា

ខ្ទាំងរវាងរដូវក្តៅនឹងរដូវរងា)

contingence *n.f.* អនិមិត្តភាព (ដំណើរដែលកើតហេតុជាគ្រឿងកំណត់ផ្លាន) ។ *pl.* ព្រឹត្តិការណ៍អនិមិត្ត (ឧ. tenir compte des contingences)

contingent,e *a.* អនិមិត្ត,ដែលអាចមាន ឬ មិនមាន ។ *n.m.* សមាយាគ, (ចំណែកដែលត្រូវបង់ ឬ ត្រូវទទួល ឧ. réclamer son contingent។ អតិបរិមាណទំនិញដែលត្រូវនាំចេញ ឬ នាំចូលក្នុងកំណត់កាលមួយ ។ យុវជនទាំងឡាយដែលត្រូវចូលធ្វើទាហាននៅថ្ងៃជាមួយគ្នា)

contingentement *n.m.* សមាយាគវិភាគ; ការកំណត់ព្រំដែន; ការចែក

contingenter *v.i.* កំណត់សមាយាគ; ចែក (ទំនិញ ឬ ផលិតផលអ្វីមួយ)

continu,e *a.* និរន្តរ,ឥតមានចន្លោះ, ឥតដាច់ (ឧ. ligne continue); ឥតឈប់ (ឧ. travail continu) ។ *n.m.* អ្វីៗដែលមានមិនដាច់

continuateur,trice *n.* អ្នកបន្ត

continuation *n.f.* ការបន្ត (ឧ.entreprendre la continuation d'un édifice); អ្វីៗដែលគេធ្វើបន្ត (ឧ. ceci est la continuation de cela; la continuation d'une route)

continuel,elle *a.* ជានិច្ច,មិនដែលដាច់ (ឧ. effort continuel)

continuellement *adv.* ជានិច្ចកាល

continuer *v.t.* បន្ត,ធ្វើបន្ត (ឧ continuer un voyage); ត (ឧ.continuer un mur) ។ *v.t. ind.* continuer à ទទូច, មិនឈប់ (ឧ. continuer à fumer) ។ *v.i.* មិនទាន់ចប់ (ឧ. la séance continue)

continuité *n.f.* និរន្តរភាព, ភាពតគ្នាមិនដាច់, ការបន្ត ។ solution de continuité ភាពដាច់

continûment *adv.* គ្មានដាច់,គ្មានឈប់

contondant,e *a.* ដែលមានមុខទាល (ដូចជាដំបង, ញញួរ ។ល។)

contorsion *n.f.* ការមួល (ឧ.la contorsion d'une lampe métallique);ការរមួល (ឧ. contorsion des bras)។*Par ext.* ការគ្នាដៃ-ជើង ឬ ការញញាក់មុខ (ដែលគួរឲ្យអស់សំណើច); អាកប្បកិរិយាធ្វើដោយបង្ខំ។ *Fig.*donner une contorsion à la vérité មួល ឬ ក្លែងសេចក្តីពិត

contorsionner *v.t.* មួល (ឧ. contorsionner ses membres)។ se contorsionner *v.pr.* មួលខ្លួន; ញាក់មុខ

contour *n.m.* វង់ជុំវិញ (ឧ. des contours arrondis); ព្រំព្រៃ (ឧ. le contour d'une forêt); គន្លងបត់បែន (ឧ. les contours d'une rivière)

contourné,e *a.* ខូចរាង (ឧ. taille contournée); ដែលក្លែង, ដែលធ្វើឫក (ឧ. style contourné)

contourner *v.t.* គូសវង់ជុំវិញ (ឧ. contourner un vase); ដើរព័ទ្ធ (ឧ. contourner une montagne); ធ្វើឲ្យខូចរាង

contractant,e *a.&n.* គូសញ្ញា, ដែលចុះកិច្ចសន្យា។ les parties contractantes ភាគីគូសញ្ញា។ hautes parties contractantes ឧត្តមភាគីគូសញ្ញា។ *n.* គូសញ្ញា

contracter *v.t.* បង្រួម, បង្រួញ (ឧ. le froid contracte les corps)។ se contracter *v.pr.* រួម; រួញ

contracter *v.t.* ចុះកិច្ចសន្យា (ឧ. contracter une alliance)។ *Fig.* contracter des obligations ទទួលរបស់ដែលនាំឲ្យជំពាក់គុណ។ contracter une habitude មានទម្លាប់។ contracter une maladie កើតរោគ។ contracter des dettes ជំពាក់បំណុល។ se contracter *v.pr.* ជាប់កិច្ចសន្យា

contractif,ive *a.* ដែលបង្រួម ឬ បង្រួញ,

contractile *a.* អាចរួញបាន

contractilité *n.f.* ភាពអាចរួញបាន

contraction *n.f.* សញ្ជូរ, ដំណើរខ្ទប, ដំណើររួម ឬ រួញ។ contraction du cœur សញ្ជូរនៃបេះដូង

contractuel,elle *a.* ដែលបញ្ញត្តដោយកិច្ចសន្យា។ *n.* ភ្នាក់ងារជាប់កិច្ចសន្យា

contradicteur *n.m.* បដិវាទករ, អ្នកជំទាស់

contradiction *n.f.* បដិវាទកម្ម, ការជំទាស់ (ឧ. ne pas aimer la contradiction); អំពើ ឬ សំដីផ្ទុយ (ឧ. les contradictions d'un accusé); ភាពផ្ទុយគ្នា (ឧ. être en contradiction avec ses paroles)។ esprit de contradiction គំនិតបដិវាទ (ចូលចិត្តជំទាស់)។ *Philos.* principe de con-

tradiction គោលការណ៍បដិវាទកម្ម

contradictoire *a.* ផ្ទុយគ្នា,ដែលជំទាស់ (ឧ.opinions contradictoires); ដែលធ្វើចំពោះមុខសាមីខ្លួន (ឧ. jugement contradictoire)។ *n.m. pl.* របស់ដែលជាទំនាស់គ្នា

contradictoirement *adv.* ដោយផ្ទុយគ្នា; ដោយចំពោះមុខ (ឧ. juger contradictoirement)

contraignable *a.* អាចបង្ខិតបង្ខំបាន

contraignant,e *a.* ដែលបង្ខិតបង្ខំ

contraindre *v.t.* បង្ខិតបង្ខំ (ឧ.on le contraignit à partir) ។ *Jurispr.* បង្ខំ (ដោយផ្លូវច្បាប់) (ឧ. contraindre par corps បង្ខំលើរូបកាយ) ។ se contraindre *v.pr.* ទប់ (ចិត្ត, គំនិត)

contraint,e *a.* ដែលត្រូវគេបង្ខិតបង្ខំ; ដែលធ្វើដោយទើសទាល់ (ឧ.air contraint)

contrainte *n.f.* ការបង្ខិតបង្ខំ (ឧ. régime de contrainte); ការរអែង(ឧ.agir sans contrainte); កំហិត (ឧ. vivre sous la contrainte) ។ contrainte extérieure កំហិតខាងក្រៅ ។ contrainte par corps ការបង្ខំលើរូបកាយ(ដោយចាប់ខ្លួនបំណុលដាក់គុក ដើម្បីឲ្យសងប្រាក់គេ)

contraire *a.* ផ្ទុយ (ឧ. courir en sens contraire; contraire à la vérité)។ *Fig.* ដែលឲ្យទោស, អាក្រក់ (ឧ. le vin vous est contraire) ។ *n.m.* ការផ្ទុយ (ឧ. prouver le contraire) ។ *Gram.* វិសទិសសព្ទ, ពាក្យផ្ទុយ ។ au contraire *loc.adv.* ដោយផ្ទុយទៅវិញ

contrairement *adv.* ដោយផ្ទុយ

contrariant,e *a.* ដែលចូលចិត្តជំទាស់ (ឧ. esprit contrariant); ដែលរាំង (ឧ. pluie contrariante)

contrarié,e *a.* ដែលទើសចិត្ត (ឧ. un air contrarié)

contrarier *v.t.* ជំទាស់ (ឧ. contrarier un dessein); ធ្វើឲ្យទាស់ចិត្ត (ឧ. voilà qui me contrarie); រាំងរា, រំខាន (ឧ. les vents contrarient la marche du navire)

contrariété *n.f.* ដំណើរឃ្លើសចិត្ត; ឧបសគ្គ

contrastant,e *a.* ដែលមានភាពផ្ទុយ

contraste *n.m.* ព្យតិរេក, ភាពផ្ទុយគ្នា (ឧ.contraste d'ombre et de lumière)

contraster *v.i.* មានភាពផ្ទុយ(ឧ.couleurs qui contrastent) ។ *v.t.* ធ្វើឲ្យឃើញខុសគ្នា (ឧ. dans son tableau il a su contraster les figures)

contrat *n.m.* កិច្ចសន្យា(ឧ.un contrat est nul s'il a été obtenu d'une personne par dol, fraude ou violence)។contrat d'adhésion កិច្ចសន្យាសដ្ឋកម្ម (កិច្ចសន្យាដែលភាគីម្ខាងចាំតែយល់ព្រម ដូចជាក្នុងការដាក់ប្រចាំទូរសព្ទ, អគ្គិសនី ។ល។)។contrat administratif កិច្ចសន្យារដ្ឋបាល ។ contrat de travail កិច្ចសន្យាការងារ (កិច្ចសន្យារវាងចៅហ្វាយនឹងកូនឈ្នួល)

contravention *n.f.*ការល្មើស;សេចក្ដីកត់ហេតុអំពីបទល្មើស (ឧ. dresser une contravention à quelqu'un) ។ *Spécial.* បទលហុ

contravis *n.m.* ការប្រកាសតប, ប្រកាសផ្ទុយនឹងប្រកាសមុន

contre *pré.*ផ្ទាល់នឹង,ជាប់នឹង (ឧ. serrer contre sa poitrine); ផ្ទុយនឹង (ឧ. agir contre son gré); ទល់នឹង, ប្រឆាំងនឹង (ឧ. marcher contre l'ennemi); សម្រាប់ការពារ, សម្រាប់ព្យាបាល (ឧ. remède contre la toux); ដោយ (មានការប្តូរ) (ឧ. acheter contre argent comptant) ។ *adv.* ផ្ទាល់នឹង; ប្រឆាំងនឹង (ឧ. voter contre)។*n.m.* របស់ផ្ទុយ; អ្វីៗដែលប្រឆាំង (ឧ. soutenir le pour et le contre) ។ *loc. adv.* ci-contre អភិមុខ, ចំពោះមុខ ។ par contre តែថា ។ tout-contre ជិតបង្កើយ ។ là-contre ស៊ើរប៉ះគ្នា ។ *Mar.* à contre *loc.adv.* ច្រាសវិញ (ពីខាងផ្ទុយ) ។ contre à contre *loc.adv.* អែបគ្នា (មិនប៉ះគ្នា)

contre-allée *n.f.* ផ្លូវសួនតូច (ស្របនឹងផ្លូវសួនធំ) (*pl.* des contre-allées)

contre-amiral *n.m.* ឧត្ដមនាវីត្រី (ម.ព. amiral ផង)

contre-appel *n.m.* ការហៅឈ្មោះត្រួតមើល (*pl.* des contre-appels)

contre-assurance *n.f.* ធានាការត្រួត (ការធានាលើធានាការមួយទៀត ឬ កំណត់ការខាតបង់នៃធានាការនេះ) (*pl.* des contre-assurances)

contre-attaque *n.f.* ការវាយតប ។ *pl.* des contre attaques គ្រឿងទប់ប្រឆាំងនឹងអ្នកឡោមព័ទ្ធ

contre-attaquer *v.t.* វាយតប

contre-avis *n.m.* ម.ព. contravis

contrebalancer *v.t.* មានទម្ងន់ស្មើ (ឧ. poids qui en contrebalance un autre) ។ *Fig.* ទប់ទល់គ្នាបាន,មានកម្លាំងឬ មានតម្លៃស្មើ; ទូទាត់គ្នាបាន (ឧ. les avantages contrebalancent les inconvénients)

contrebande *n.f.* ការរត់គយ (ឧ. faire la contrebande); របស់រត់គយ (ឧ. acheter de la contrebande) ។ *Fig. & fam.* de contrebande ខុសច្បាប់, ដែលគេហាម

contrebandier,ère *a.&n.* ដែលរត់គយ

contrebas *adv.* ខាងក្រោម, ឆ្ពោះទៅទំនាប ។ *n.m.* ដីក្រោល។ en contrebas *loc.adv.* ទៅក្រោម, ទៅទំនាប (ឧ. regarder en contrebas)

contrebasse *n.f.* គ្រឿងភ្លេងស្សូរធ្ងន់រណ្ដំ (ដូចជារនាតធុង)

contrebassiste ឬ **contrebassier** *n.m.* អ្នកកាន់គ្រឿងភ្លេងស្សូរធ្ងន់

contrebatterie *n.f.* ការបាញ់តប (បាញ់ កាំភ្លើងធំប្រឆាំងនឹងកងកាំភ្លើងធំសត្រូវ)។ tir de batterie ការបាញ់លើកងកាំភ្លើងធំសត្រូវ ។ *Fig.* ល្បិចដោះកលឧបាយសម្ងាត់

contrebattre *v.t.* បាញ់តប

contre-biais (à) *loc.adv.* ច្រាស

contre-bord (à) *loc.adv.* ច្រាសគ្នា (នាវាពីរដែលបើកផ្ទុយគ្នា)

contre-boutant *n.m.* បង្កាញ់ (*pl.* des contre-boutants)

contre-bouter ឬ **contre-duter** *v.t.* ទល់ទ្រើងដោយបង្កាញ់

contre-calquer *v.t.* ផ្ដាប់ចម្លងច្ទេង (បានរូបផ្ទុយពីរូបដើម)

contrecarrer *v.t.* ប្រឆាំង (ឧ. contrecarrer des projets)

contre-cœur (à) *loc.adv.* ដោយបង្ខំ,ដោយមិនចូលចិត្ត,ដោយទើសទាល់

contrecoup *n.m.* ការទង្គិចបន្ត។ *Fig.* ប្រតិការណ៍ (ព្រឹត្តិការណ៍ជាផលបិនប៉ះពោះនៃព្រឹត្តិការណ៍ដទៃ) (ឧ. la Révolution française eut des contrecoups en Europe)

contre-courant *n.m.* ទឹកសង ។ *Fig.* ទិសផ្ទុយ, ដំណើរច្រាស (*pl.* des contre-courants)

contre-déclaration *n.f.* ប្រតិនិវេទន៍ (សេចក្ដីថ្លែងការណ៍ផ្ទុយពីគ្នា) (*pl.* des contre-déclarations)

contre-digue *n.f.* ថ្នល់ទំនប់រង (សម្រាប់ថែមកម្លាំងលើទំនប់ឯទៀត) (*pl.* des contre-digues)

contredire *v.t.* និយាយផ្ទុយ, និយាយប្រឆាំង (ឧ. contredire un témoin); មានសភាពផ្ទុយ (ឧ. ses actes contredisent ses paroles) ។ se contredire *v.pr.* និយាយជាន់កែងឯង

contredisant,e *a.* ដែលចូលចិត្តនិយាយប្រឆាំង (ឧ. esprit contredisant)

contredit *n.m.* ការឆ្លើយតបដោយលាយលក្ខណ៍អក្សរ ។ sans contredit *loc.adv.* ដោយឥតប្រកែកកើត (ឧ. il est sans contredit le plus fort)

contrée *n.f.* ទេសភូមិ (ឧ. une contrée fertrle)

contre-empreinte *n.f.* ស្នាមផ្តិតចម្លង (*pl.* des contre-empreintes)

contre-enquête *n.f.* ការអង្កេតតប (*pl.* des contre-enquêtes)

contre-épreuve *n.f.* បដិវិញ្ញាសា

contre-espionnage *n.m.* ប្រតិចារកិច្ច (*pl.* des contre-espionnages)

contre-essai *n.m.* ការសាកគ្រួត (*pl.* des contre-essais)

contre-expertise *n.f.* ប្រតិកោសល្យវិច័យ (*pl.* des contre-expertises)

contrefaçon *n.f.* ការក្លែងក្លាយ;របស់ក្លែងក្លាយ (ឧ. une grossière contrefaçon) ។ contrefaçon de librairie សៀវភៅប្លម

contrefacteur *n.m.* អ្នកក្លែងក្លាយ

contrefaction *n.f.* ការក្លែងបោះប្រាក់ ឬ ផលប័ត្រសាធារណៈ

contrefaire *v.t.* ក្លែង (ឧ. contrefaire l'écriture de quel-

qu'un) ; ត្រាប់ (ដើម្បីសើចលេង) ; ក្លែងក្លាយ (ឧ. contrefaire un billet de banque)

contrefaiseur,euse *n. Fam.* អ្នកត្រាប់សំដី ឬ កាយវិការ

contrefait,e *a.* ក្លែងក្លាយ (ឧ. sceau contrefait) ; ដែលមានរូបរាងក្រក់ (ឧ. taille contrefaite)

contre-fiche *n.f. Constr.* បង់ពាញ់ (*pl.* des contre-fiches)

contreficher (se) *v.pr. Fam.* ចំអកឲ្យ

contre-fil *n.m.* ទិសច្រាស (ឧ. le contre-fil de l'eau, du bois) (*pl.* des contre-fils)។ à contre-fil *loc.adv.* ច្រាស

contrefort *n.m. Arch.* ទន្ទល់(ទប់សសរឲ្យមាំ) ។ *Géogr.* ជួរភ្នំរង

contre-haut (en) *loc.adv.* ឡើងលើ, ឆ្ពោះទៅទីខ្ពស់

contre-indication *n.f.* ការហាមមិនឲ្យប្រើឱសថខ្លះ (*pl.* des contre-indications)

contre-indiquer *v.t.* បង្ហុល ឬ ប្រាប់ខុសពីលើកមុន ។ *Méd.* នាំឲ្យប្រើរបៀបព្យាបាលខ្លះមិនបាន (ឧ. l'urémie contre-indique l'intervention chirurgicale)

contre-jour *n.m. inv.* បញ្ច្រាក, ពន្លឺច្រាស។ à contre-jour *loc.adv.* ដោយបញ្ច្រាក, ច្រាសពន្លឺ

contre-lettre *n.f.* ប្រតិលិខិត (លិខិតសម្ងាត់ដែលធ្វើឡើងសម្រាប់បំបែរលិខិតចេញមុខ) (*pl.* des contre-lettres)

contremaître,esse *n.* ឆាយរង

contre-mandat *n.m.* ប្រតិអាណត្តិ, អាណត្តិលុបអាណត្តិមុនចោល (*pl.* des contre-mandats)

contremandatement *n.m.* ការធ្វើប្រតិអាណត្តិ, ការលុបអាណត្តិមុនចោល

contremandater *v.t.* ធ្វើប្រតិអាណត្តិលុបអាណត្តិមុនចោល

contremander *n.f.* ចេញប្រតិអាណត្តិ, បដិសេធបង្គាប់មុនចោល (ឧ. contremander un repas)

contre-manifestant,e *n.* ប្រតិបាតុករ (*pl.* des contre-manifestants)

contre-manifestation *n.f.* ប្រតិបាតុកម្ម, បាតុកម្មតប (*pl.* des contre-manifestations)

contre-manifester *v.t.* ធ្វើប្រតិបាតុកម្ម, ធ្វើបាតុកម្មតប

contremarche *n.f.* ដំណើរក្រោយ(កងទ័ព); រយាំងកាំជណ្ដើរ

contremarque *n.f.* ត្រាសញ្ញារង; សំបុត្រឲ្យអ្នកមើលកាន់ចេញមួយភ្លែត

contremarquer *v.t.* បោះត្រាសញ្ញារង

contre-mesure *n.f.* ប្រតិវិធានការ (វិធានការផ្ទុយនឹងវិធានការមុន) (*pl.* des contre-mesures)។ à contre-mesure *loc.adv.* ដោយខុសពេល

contre-mine *n.f.* រយាំងគ្រាប់បែកកប់ (រូងដីជីកជុំវិញសំណង់អ្វីមួយដើម្បីការពារសំណង់នោះចំពោះគ្រាប់បែកកប់) *Fig.* ឧបាយតប

contre-miner *v.t.* ធ្វើរយាំងគ្រាប់បែកកប់ ។ *Fig.* ធ្វើឧបាយតប

contre-mot *n.m.* ប្រតិសព្ទ (សព្ទសម្រាប់ឆ្លើយតបនឹងសព្ទសញ្ញាដើម្បីឲ្យស្គាល់គ្នា) ។ ម.ព. mot d'ordre ក្នុងពាក្យ mot ផង

contre-mur *n.m.* ជញ្ជាំងរង (ដែលសង់អែបដើម្បីទប់ជញ្ជាំងមួយទៀតឲ្យមាំ) (*pl.* des contre-murs)

contre-offensive *n.f.* ការលុកចូលតប (*pl.* des contre-offensives)

contre-opération *n.f.* ប្រតិបត្តិការតប

contre-ordre ឬ **contrordre** *n.m.* បង្គាប់ផ្ទុយ (បដិសេធបង្គាប់មុន)

contre-ouverture *n.f.* ប្រតិរន្ធ (ប្រហោងចំគ្នា) (*pl.* des contre-ouvertures)

contrepartie *n.f.* បដិភាគ, ទៀភាគនៃបញ្ជី; ជួរ; ចំណូលចំណាយ; ផ្នែកផ្ទុយ។ *Fig.* យោបល់ផ្ទុយ ។ fonds de contrepartie មូលនិធិបដិភាគ

contre-pas *n.m.* ការផ្លាស់ជើង (ដើម្បីដើរឲ្យត្រូវជើងក្នុងក្បួន)

contre-passation *n.f.* ការបង្វិលរូបិយាណត្តិឲ្យម្ចាស់វិញ; ប្រតិក្រាន្ត (ការលុបឥណទានចោល)

contre-passer *v.t.* បង្វិលរូបិយាណត្តិឲ្យម្ចាស់វិញ; ធ្វើប្រតិក្រាន្ត

contre-pente *n.f.* ជំរាលខាងនាយ (*pl.* des contre-pentes)

contre-peser *v.t.* មានទម្ងន់ស្មើ; ទប់

contre-pied *n.m.* ការតាមដានច្រាស (ឆ្កែប្រដេញសត្វ) ។ *Fig.* អ្វីៗដែលផ្ទុយ (ឧ. prendre le contre-pied d'une opinion ប្រកាន់មតិផ្ទុយ) ។ à contre-pied *loc.*

adv. ច្រាស ។ *Sports* ការខ្ទួល ដោយចាញ់បញ្ឆោតគេ (ក្នុងកីឡា)

contre-placage *n.m.* ការបិទក្ដារបន្ទះ (*pl.* des contre-placages)

contre-plaqué *n.m.* ក្ដារបន្ទះ (*pl.* des contre-plaqués)

contre-plaquer *v.t.* បិទក្ដារបន្ទះ

contrepoids *n.m.* ទម្ងន់សម្រាប់ទប់ទម្ងន់មួយទៀត (ឧ. le contrepoids d'une horloge)។ *Fig.* កម្លាំងទប់ (ឧ. apporter un contrepoids nécessaire)

contre-poil *n.m.* à contre-poil *loc.adv.* ច្រាស

contre-pointe *n.f.* ចុងស្រួចនៃខ្នងដាវ

contrepoison *n.m.* ថ្នាំបន្សាបពិស

contre-police *n.f.* ប៉ូលិសសម្ងាត់ដែលត្រួតមើលប៉ូលិសដទៃ

contreprojet *n.m.* សេចក្ដីព្រាងតប

contreproposition *n.f.* សេចក្ដីស្នើតប

contrer *v.t.* &*v.i.* *Fig.*&*fam.* ប្រឆាំង (ឧ. contrer un rival)

contre-rail *n.m.* *Ch. de f.* ផ្លូវដែកខាងក្នុង (ដែលដាក់ស្របនឹងផ្លូវដែកធម្មតា ត្រង់កន្លែងផ្លូវខ្វែង ផ្លូវបត់ នឹងផ្លូវឆ្លងថ្នល់)(*pl.* des contre-rails)

contre-révolution *n.f.* ប្រតិបដិវត្តន៍ (*pl.* des contre-révolutions)

contre-saison *n.f.* ផ្កាខុសរដូវ ។ à contre-saison *loc.adv.* ខុសរដូវ

contre-révolutionnaire *a.* បក្សខាងប្រតិបដិវត្តន៍ ។ *n.* អ្នកប្រតិបដិវត្តន៍ (*pl.* des contre-révolutionnaires)

contrescarpe *n.f.* ភ្លឺជុំវិញស្រះព័ទ្ធបន្ទាយ

contre-sceau ឬ **contre-scel** *n.m.* សញ្ញាលើខ្នងត្រា (*pl.* des contre-sceaux ឬ des contre-scels)

contre-sceller *v.t.* ឆ្លាក់សញ្ញាលើខ្នងត្រា

contreseing *n.m.* ហត្ថលេខាអម

contresens *n.m.* ខាងខុស (ឧ. le contresens d'une étoffe); វិសទិសន័យ, ន័យផ្ទុយ, ការយល់ខុស (ឧ. version remplie de contresens); អំពើមិនសមហេតុផល (ឧ. sa conduite est un contresens) ។ à contresens ដោយបញ្ច្រាស

contresignataire *a.*&*n.* អ្នកចុះហត្ថលេខាអម

contresigner *v.t.* ចុះហត្ថលេខាអម

contretemps *n.m.* ហេតុអាក្រក់ដែលនាំឲ្យស្ទះការ ។ à contretemps *loc.adv.* ដោយខុសពេលវេលា (ឧ. agir à contretemps)

contre-torpilleur *n.m.* នាវាប្រឆាំងនឹងនាវាបាញ់គ្រាប់បែក (*pl.* des contre-torpilleurs)

contre-valeur *n.f.* តម្លៃថ្នូរ (*pl.* des contre-valeurs)

contrevenant,e *n.* អ្នកប្រព្រឹត្តល្មើស

contrevenir (à) *v.t. ind.* ប្រព្រឹត្តល្មើស

contrevérité *n.f.* បដិសច្ច, អ្វីៗផ្ទុយនឹងសេចក្ដីពិត (ឧ. dire une contre-vérité); សំដីនិយាយដើម្បីឲ្យគេយល់ផ្ទុយទៅវិញ (ឧ. son blâme était une contrevérité et une ingénieuse flatterie)

contre-visite *n.f.* ប្រតិពិនិត្យ (ការពិនិត្យត្រួតអាការរោគ)(*pl.* des contre-visites)

contre-voie *n.f.* ផ្លូវស្របនឹងផ្លូវរយស្ម័យយាន (*pl.* des contre-voies)

contribuable *a.&n.* អ្នកជាប់ពន្ធ

contribuant *n.m.* អ្នកចេញវិភាគទាន; អ្នកជួយឲ្យបានសម្រេចការ

contribuer *v.t.* ចេញវិភាគទាន (ឧ. contribuer à l'entretien d'une maison); នាំឲ្យ, ជួយឲ្យបាន .. ឬ ឲ្យមាន ... (ឧ. l'argent contribue au bonheur)

contributif,ive *a.* នៃពន្ធជំនួយ (ឧ. rôles contributifs); ដែលជួយឲ្យបានសម្រេច (ឧ. part contributive)

contribution *n.f.* បរិវិសទាន [ប៉ៈ-រិ-វិ-សៈ--]; វិភាគទាន (អំណោយមិនកំណត់ចំនួន); ពន្ធជំនួយ,ពន្ធ ។ contributions directes ពន្ធចំពោះ។ contributions indirectes ពន្ធមិនចំពោះ ។ mettre à contribution យកមកជួយឲ្យបានសម្រេច។ ការជួយរួមកម្លាំង

contristant,e *a.* ដែលធ្វើឲ្យកើតទុក្ខ

contrister *v.t.* ធ្វើឲ្យកើតទុក្ខ (ឧ.contrister ses parents)

contrit,e *a.* ដែលមានបច្ឆាទុក្ខ ។ *Par ext.* ដែលស្ដាយក្រោយខ្លាំងដោយបានធ្វើខុស; ដែលកើតទុក្ខ

contrition *n.f.* បច្ឆាទុក្ខ; ទុក្ខស្ដាយ

ក្រោយដោយបានធ្វើខុស

contrôlable *a.* អាចត្រួតត្រាបាន

contrôle *n.m.* បញ្ជីបុគ្គលិក (ឧ. officier rayé des contrôles de l'armée);អភិបាលដ្ឋាន,កន្លែងពិនិត្យត្រួត;អភិបាល,ការត្រួត (ឧ. le contrôle d'une caisse); ត្រាសញ្ញានៃការត្រួតត្រារបស់រដ្ឋលើគ្រឿងមាសប្រាក់ឬប៉្លាទីន ។ contrôle des échanges ពិនិត្យប្តូរប្រាក់ ។ contrôle général អគ្គាភិបាល ។ ក្រុមអភិបាល ។ contrôle des dépenses engagées ក្រុមអភិបាលចំណាយវលញ្ជិត ។ *Fig.* ការត្រួត, ការរិះគន់ (ឧ. être chargé du contrôle de quelqu'un)

contrôler *v.t.* អភិបាល, ពិនិត្យត្រួត (ឧ. contrôler les dépenses; contrôler les bijoux; les Etats-Unis contrôlent le canal de Panama)។ រិះគន់ (ឧ.contrôler la conduite de quelqu'un)

contrôleur,euse *n.* អភិបាល,អ្នកពិនិត្យត្រួត;ប្រដាប់សម្រាប់ពិនិត្យត្រួត។ contrôleur général អគ្គាភិបាល ។ contrôleur des dépenses engagées អភិបាលចំណាយវលញ្ជិត ។ *Fig.* អ្នករិះគន់។ *n.m.* ប្រដាប់ពិនិត្យត្រួត

contrordre *n.m.* ម.ព. contre-ordre

controuver *v.t.* ភូត (ប្រើតែក្នុង part. passé: fait controuvé រឿងភូត)

controversable *a.* អាចឲ្យមានវាទប្បដិវាទបាន (ឧ.fait controversable)

controverse *n.f.* វាទប្បដិវាទ,ការជជែករកខុសត្រូវ

controverser *v.t.* ឲ្យមានវាទប្បដិវាទ (ឧ.question controversées)។ *Abs.* ជជែករកខុសត្រូវ (ឧ. controverser avec passion)

controversiste *n.m.* អ្នកវាទប្បដិវាទ (ខាងផ្លូវសាសនា)

contumace *n.f.* ទុដ្ឋភាព, ការមិនព្រមចូលខ្លួនទៅតុលាការ (ឧ. la contumace est considérée comme un aveu du crime)។ purger sa contumace ទទួលទុដ្ឋភាព (ចូលខ្លួនទៅតុលាការក្រោយការកាត់ទោសដោយពុំបានចូលខ្លួន)។ *a.&n.* អ្នកបាត់ខ្លួន(គេថាcontumax ក៏បាន)

contumax *n.* ម.ព. contumace

contus,e *a.* ជាំ(ដោយត្រូវនឹងអាវុធទាល)

contusion *n.f.* ភាពជាំ (ដោយត្រូវនឹងអាវុធទាល)

contusionner *v.t.* ធ្វើឲ្យជាំ

convaincant,e *a.* ដែលធ្វើឲ្យជឿ ឬ ឲ្យចូលចិត្ត(ឧ.raisonnement convaincant)

convaincre *v.t.* ធ្វើឲ្យជឿ ឬ ឲ្យចូលចិត្ត; បញ្ចុះបញ្ចូល (ឧ. convaincre un crédule)។ convaincre quelqu'un de ជូនភស្តុតាងជាក់ច្បាស់អំពី (ឧ. convaincre quelqu'un de mensonge)

convaincu,e *a.* ដែលជឿជាក់

convalescence *n.f.* អាពាធវុដ្ឋាន,ភាពងើបពីឈឺ; ការឈប់សម្រាកដោយងើបពីឈឺ

convalescent,e *a.&n.* អាពាធវុដ្ឋានិក, អ្នកងើបពីឈឺ

convenable *a.* សមរម្យ(ឧ.mariage convenable; salaire convenable; tenue convenable)

convenablement *adv.* ដោយសមគួរ; ដោយសមរម្យ

convenance *n.f.* លោកានុកូល, ភាពត្រូវគ្នា (ឧ. convenance de fortune, de caractère); ភាពស្រួល, ភាពត្រូវចិត្ត (ឧ. congé de convenance personnelle)។ mariage de convenance អាពាហ៍ពិពាហ៍តាមភាពសមរម្យ (គេសម្លឹងតួជាពង្សនឹងធនធានជាងចិត្តថ្លើម)។ *pl.* ការគួរសម(ឧ. respecter les convenances)

convenant,e *a.* សមគួរ; សមរម្យ

convenir *v.t.ind.* **(de ឬ à)** ព្រមព្រៀងគ្នា(ឧ. ils conviennent de se réunir); ទទួលខុស (ឧ. il convient de sa méprise); ត្រូវចិត្ត,សមនឹងចិត្ត(ឧ.cet emploi lui aurait bien convenu)។ *v.impers.* il convient de... ត្រូវតែ... ។ se convenir *v.pr.* ចូលចិត្តគ្នាទៅវិញទៅមក, ត្រូវគ្នា (ឧ. se ressembler n'est pas toujours une raison pour se convenir)

conventicule *n.m.* ឧបសន្និបាត(ការប្រជុំសម្ងាត់)

convention *n.f.* អនុសញ្ញា;ការសន្មត។ *Par ext.pl.* les conventions

socіales ច្បាប់សង្គម (ការប្រព្រឹត្តតាមសុភាវធម៌)។ de convention *loc.adv.* ដែលសន្មត(ឧ.langage de convention)

conventisme ឬ **conventionalisme** *n.m.* អនុសញ្ញានិយម

conventionnel,elle *a.* អនុសញ្ញិក, ដែលសន្មត (ឧ. signe conventionnel); សាមញ្ញ (ឧ. formule conventionnelle)

conventionnellement *adv.* ដោយអនុសញ្ញិក,ដោយសន្មត

convenu,e *a.* ដែលសន្មត(ឧ.langage convenu)

convergence *n.f.* ការសំដៅទៅរកកន្លែងតែមួយ(ឧ.convergence de rayons lumineux)។ *Fig.* ការរួមគ្នា(សំដៅគោលបំណងតែមួយ) (ឧ. convergence des efforts)

convergent,e *a.* ដែលសំដៅទៅរកកន្លែងតែមួយ,រួមគ្នា(ឧ.des efforts convergents; des opinions convergentes)

converger *v.i.* សំដៅទៅរកកន្លែងតែមួយ (ឧ.les voies ferrées convergent sur Paris)

conversation *n.f.* ការសន្ទនាដោយស្និទ្ធស្នាល, ការសំណេះសំណាល (ឧ. lier conversation avec quelqu'un);សិល្បៈឬរបៀបសន្ទនា(ឧ.sa conversation est agréable)

converser *v.i.* សន្ទនាដោយស្និទ្ធស្នាល, សំណេះសំណាល

conversible *a.* ម.ព. convertible

conversion *n.f.* បរិវត្តន៍, ការញុំាងឲ្យជឿសាសនា (ឧ. conversion d'un athée); ការផ្លាស់សាសនា (ឧ.conversion d'un païen)។ *Par ext.* ការផ្លាស់មតិ,ការផ្លាស់ចរិយា (ឧ.conversion aux idées modernes); ការផ្ទេរ (ផ្ទេររង្វាស់រង្វាល់មយ៉ាងទៅជារង្វាស់រង្វាល់មយ៉ាងទៀត) ។ *Dr.* ការផ្លាស់សារលិខិតជាថ្មី

convertible *a.* ដែលអាចប្តូរ ឬ ដូរបាន

convertir *v.t.* បរិវត្ត, ញុំាងឲ្យជឿ ឬឲ្យផ្លាស់សាសនា (ឧ. convertir des infidèles); ញុំាងឲ្យប្រតិបត្តិសាសនាឡើងវិញ; ញុំាងឲ្យផ្លាស់គំនិតឬផ្លាស់មតិ;ប្តូរ,ដូរ;ផ្ទេរ(រង្វាស់រង្វាល់)។ se convertir *v.pr.* ផ្លាស់មតិ; ផ្លាស់បក្ស; ផ្លាស់សាសនា

convertissable *a.* អាចញុំាងឲ្យផ្លាស់

គំនិត ឬ ឆ្លាស់សាសនាបាន

convertissement *n.m.* ការប្តូរ (ឧ. le convertissement des monnaies ការប្តូររូបិយវត្ថុ)

convertisseur *n.m.* អ្នកបញ្ចុះបញ្ចូលឲ្យកាន់សាសនា; ឡស្លដែកស្វិតឲ្យទៅជាដែកថែប; ត្បាល់កិនម្សៅ

convexe *a.* ប៉ោង (ផ្ទុយនឹងផត), កំពុង (ឧ. miroir convexe)

convexité *n.f.* ភាពកំពុង; ភាពប៉ោង; ភាពមូល (ឧ. la convexité de la terre)

convict *n.m.*(ព.អ.)មនុស្សទោសឧក្រិដ្ឋ (ដែលត្រូវជាប់គុក ឬ ត្រូវនិរទេស)

conviction *n.f.* ជំនឿស៊ប់ (ឧ. agir par conviction)

convié,e *n.* ភ្ញៀវ

convier *v.t.* អញ្ជើញភ្ញៀវ។*Fig.*បបួល, ធ្វើឲ្យមានបំណង(ឧ.le beau temps convie à la promenade)

convive *n.* ភ្ញៀវបាយ

convocable *a.* អាចកោះបាន

convocation *n.f.*ការកោះ,ការហៅប្រជុំ (ឧ.convocation d'une assemblée); ដីកាកោះ, លិខិតហៅប្រជុំ (ឧ.lancer une convocation)

convoi *n.m.* អនុគមណ៍, ក្បួនដូន; ខ្សែអយស្ម័យរថ

convoiement ឬ **convoyage** *n.m.* ការដូនក្បួនដើម្បីការពារ

convoitable *a.* គួរប៉ងចង់បាន

convoiter *v.t.* លោភ, ប៉ងចង់បាន (ឧ. convoiter le bien d'autrui)

convoiteur,euse *a.* ដែលប៉ងចង់បាន

convoitise *n.f.* អភិជ្ឈា, វិសមលោភ, លោភលន់, បំណងខ្លាំង

convol *n.m.* ការមានគូស្រករជាថ្មី

convoler*v.i.Ironiq.*មានគូស្រករជាថ្មី

convolvulacées *n.f.pl.* សំវេលកុល [ស័ង-វេលៈ] (វល្លិជាតិត្រកូលត្រកួន)

convolvulus *n.m.Bot.*សំវេល,ត្រកួន

convoquer *v.t.* កោះ; ហៅប្រជុំ (ឧ. convoquer les chambres)

convoyage *n.m.* ម.ព. convoiement

convoyer *v.t.* ជូនក្បួនដើម្បីការពារ(ឧ. convoyer des navires)

convoyeur *n.m.* អ្នកអនុគម, អ្នកជូនក្បួន; នាវាជូន ។ courrier convoyeur អនុគមហារីយ

convulser*v.t.*ញាក់,កន្ត្រាក់(ឧ.visage convulsé par la terreur)

convulsif,ive *a.* ដែលមានលក្ខណៈញាក់កន្ត្រាក់ឬប្រកាច់; ដែលញ័រ,ឆាប់ៗ (ឧ. rire convulsif)

convulsion *n.f.* ការញាក់កន្ត្រាក់, ការប្រកាច់។ *Fig.* វិបល្លាស;ការប្រែប្រួលខ្លាំង(ឧ.convulsion politique)

convulsionnaire *a.&n.* ដែលញាក់កន្ត្រាក់ ឬ ប្រកាច់

convulsionner *v.t.* ធ្វើឲ្យញាក់ ឬ ឲ្យកន្ត្រាក់

convulsivement *adv.* ដោយញាក់ឬកន្ត្រាក់ (ឧ. s'agiter convulsivement)

coobligé,e *n.* អ្នកជំពាក់បំណុលរួមគ្នា

cooccupant,e *n.* អ្នកកាន់កាប់រួម

coolie *n.m.* គូលី, កូនឈ្នួល

coopérateur,trice *n.* សហប្រតិបត្តិការី-ការិនី; សមាជិកសហករណ៍

coopératif,ive *a.* ដែលជាសហប្រតិបត្តិការ(ឧ.société coopérative)។ *n.f.* សហករណ៍ ។ coopérative de consommation សហករណ៍ឧបភោគបរិភោគ ។ coopérative de crédit សហករណ៍ចងការ ។coopérative d'écoulement សហករណ៍លក់ចេញ ។ coopérative de culture សហករណ៍វប្បកម្ម ។ coopérative rurale de colonisation ជនបទសហករណ៍ភនទីកសិកម្ម ។ coopérative rurale d'épargne ជនបទសហករណ៍សន្សំ។ coopérative de transformation សហករណ៍ប្លែងភាព ។ coopérative d'investissement សហករណ៍ផ្តុំទុនប្រកបការ ។ coopérative de production សហករណ៍ផលិតកម្ម។coopérative à fonctions multiples សហករណ៍មុខងារពហុគុណ

coopération *n.f.* សហប្រតិបត្តិការ

coopératisme *n.m.* សហប្រតិបត្តិការនិយម

coopérer (à) *v.i.* ធ្វើសហប្រតិបត្តិការ

cooptation *n.f.* ការជ្រើសតាំងសមាជិកដោយខ្លួនឯង (សភា)

coopter *v.t.* ជ្រើសតាំងសមាជិកដោយខ្លួនឯង (សភា)

coordination *n.f.* ការសម្របសម្រួល

coordonnateur,trice *a.* ដែលសម្របសម្រួល

coordonné,e *a.* ដែលរៀបចំល្អ

coordonnées *n.f.pl.Géom.* និយា-

បក [–ម:–ក] ។ coordonnées célestes នភាកាសនិយាមក ។ coordonnées géographiques និយាមកាភូមិសាស្ត្រ

coordonner *v.t.* សម្របសម្រួល

copain *n.m.* ម.ព. copin

copartage *n.m.* ការចែកឲ្យគ្នាច្រើន

copartageant,e *a.&n.* អ្នកចែករួមគ្នាច្រើន (ឧ. héritiers copartageants)

copartager *v.t.* ចែកគ្នាច្រើន

coparticipant *n.m.* សហភាគិន-គិនី, អ្នកចូលរួបរួម

coparticipation *n.f.* សហភាគកម្ម, ការចូលរួបរួម

copeau *n.m.* អាចម៍ដែកឈូស, រំកាប់, ចំណាំង

copeck *n.m.* ម.ព. kopeck

coperuneter *v.t.* ប្តូរ (ច្រើនប្រើតែ coperuneter des bénéfices)

copie *n.f.* សេចក្តីឬរបស់ចំឡង; សំណៅ; កិច្ចការសិស្ស (ឧ. corriger des copies); ការត្រាប់ទាំងងងឹតងងល់; ជនដែលដូច (ឧ. c'est la copie de sa mère កូននេះដូចម្តាយវាបេះបិទ) ។ pour copie conforme ថានចម្លងត្រឹមត្រូវតាមច្បាប់ដើមហើយ

copier *v.t.* ចម្លង (ឧ. copier un tableau; copier le devoir d'un camarade) ។ *Fig.* យកតម្រាប់ (ឧ. copier les gestes de quelqu'un)

copieusement *adv.* ដោយពោរពាស

copieux,euse *a.* ពោរពាស (ឧ. un repas copieux)

copilote *n.m. Aéron.* តៃកុងជំនួយ

copin,e *n.Fam.* ពួកម៉ាក, ភ្នើ, ប្រាក់

copiste *n.m.* ស្មៀន, អ្នកចំឡង

coposséder *v.t.* មានរួមគ្នា

copossesseur *n.m.* អ្នកមានរួមគ្នា, ម្ចាស់រួមគ្នា

copossession *n.m.* ការមានរួមគ្នា

coprah ឬ **copra** *n.m.* សាច់ដូងស្ងួត

coproduction *n.f.* សហផលិតកម្ម, ការបង្កើតផលរួម (ឧ. film en coproduction)

coprophage *a.* ដែលស៊ីលាមក (ឧ. insecte coprophage)

copropriétaire *n.* សហកម្មសិទ្ធិករ, អ្នកមានសហកម្មសិទ្ធិ

copropriété *n.f.* សហកម្មសិទ្ធិ, កម្មសិទ្ធិរួមគ្នា (ឧ. un immeuble en

copropriété)

copter *v t.* វាយជួងតែមួយម៉ឺង

copulation *n.f.* ការដោយញីឈ្មោល, ការពាក់ផ្កា(ចំពោះសត្វចតុប្បាទ)

copyright [pérait] *n.m.* សិទ្ធិបោះពុម្ពផ្សាយព្រមទាំងលក់

coq *n.m.* មាន់ឈ្មោល ។ coq de combat ម.ព. combat ។ *Par ext.* coq faisan មាន់ទោឈ្មោល ។ coq héron ក្រសាឈ្មោល ។ coq d'Inde ឬ dindon មាន់បារាំង ។ រូបមាន់ដាក់លើដំបូលផ្ទះ (ឧ. revoir le coq de son clocher) ។ *Fam.* ជនក្មៀវក្លាខាងស្នេហា ។ *Art cul.* coq vierge មាន់ក្រៀវ។ *Chir.* crête de coq ឫស(ភេគជុះចេញពីសាច់មានសណ្ឋានជាពកមួល)។ *Hist.* coq gaulois ឬ coq រូបមាន់(ដែលជាបដិមរូបប្រទេសបារាំង) (ឧ. le coq gaulois a décoré les drapeaux français pendant la Révolution) ។

Loc. fam. coq du village មនុស្សដែលគេរាប់អានជាងគេ (ជាពិសេសគឺមនុស្សដែលស្រី ៗ ស្រឡាញ់ជាងគេ) ។ coq d'Inde មនុស្សឫកពង់ (កោងហើយកញ្ជ្រោតដូចមាន់បារាំង ឬ ក្អោកដែលតែងតែពង់) ។ fier comme un coq ខ្ជួតដូចមាន់, ខេងណាស់ ។ rouge comme un coq ក្រហមមុខដូចមាន់គក(ដោយខឹង ឬ ដោយក្ដៅ) ។ jambes de coq ជើងឆ្នារណាស់ ។ au chant du coq ពេលមាន់រងាវ (ពីព្រលឹម)។ à nous le coq យើងប្រសើរជាងគេ ។

Prov.&loc. prov. être comme le coq en pâte (ឬ le coq en panier) មានគេថ្នាក់ថ្នម ។ la poule ne doit pas chanter avant(ឬ devant) le coq ប្រពន្ធត្រូវតែខ្លាចប្ដី ។ chétive est la maison où le coq se tait et la poule chante គ្រួសារដែលប្ដីខ្លាចប្រពន្ធមិនរុងរឿងទេ ។

Allus.hist. renier au premier chant du coq បោះបង់សាសនា ឬ លទ្ធិរបស់ខ្លួននៅពេលមានគ្រោះថ្នាក់។ sacrifier un coq à Esculape គួរតែធ្វើពលិកម្មខ្លះចំពោះជំនឿ ឬ មតិខ្លះៗ ទុកជាយើងមិនជឿក៏ដោយ (ឧ. គួរតែយើងសែនព្រេនខ្លះ

ប្រសិនជាត្រូវការ ទុកជាយើងមិនធ្វើរបៀបនេះក៏ដោយ)

coq *n.m.* អ្នកធ្វើម្ហូបក្នុងនាវាធំ១

coq-à-l'âne *n.m. inv.* ការនិយាយពីនេះពីនោះ; ការស្ដាប់ច្រឡំ

coquard *n.m.* មាន់ឈ្មោលចាស់; មនុស្សចាស់ក្រអឺតក្រទម ។ *Pop.* ស្នាមភ្នែក

coquassier *n.m.* ម.ព. coquetier

coque *n.f.* សំបកស៊ុត (ឧ. le poussin brise la coque de l'œuf avec son bec) ។ œuf à la coque ពងមាន់ស្រុសទឹកក្ដៅ ។ *Par anal.* សំបុក (សំបុកនាងដំណើម) (ឧ. le ver à soie, la chenille se filent une coque) ។ *Par ext.* សំណាំផ្លែឈើ (ឧ. une coque d'amende, de noisette) ។ សំបកតួនាវាឬយន្តហោះ; ខ្យងខ្ចៅដែលបរិភោគបាន ។ *Fig.* ភាពជាក្មេងតូច (ឧ. ne faire que sortir de la coque ទើបនឹងញាស់); កំណើតះថោកទាប (ឧ. le cardinal Dubois sentait encore la vile coque d'où il était sorti); ភាពនៅម្នាក់ឯង (ឧ. se renfermer dans sa coque) ។ *Loc.fam.* coque de noix ឬ coque ទូកតូច ។ je n'en donnerais pas une coque de noix ខ្ញុំមិនរវល់ទេ, ខ្ញុំមិនយកចិត្តទុកដាក់ទេ

coquebin *n.m.* កញ្ចាត

coqueleux,euse *n.* អ្នកចិញ្ចឹមមាន់ប្រជល់

coqueluche *n.f.* ក្អកមាន់ ។ *Fig. & fam.* អ្នកគេនិយមរាប់អាន (ឧ. être la coqueluche de la ville)

coquelucheux,euse *a.* នៃរោគក្អកមាន់ ។ *a.&n.* អ្នកកើតរោគក្អកមាន់

coquemar *n.m.* កំសៀវមានដៃ

coquerico ម.ព. cocorico

coquerie *n.f.* ចង្ក្រានធ្វើម្ហូបសម្រាប់កងនាវិក; ផ្ទះបាយសម្រាប់កម្មករនាវា

coqueriquer *v.i.* រងាវ (មាន់)

coquet,ette *a.&n.* ដែលចង់ឲ្យគេស្រឡាញ់ (ឧ. fille coquette); ដែលចូលចិត្តតែងខ្លួន (ឧ. homme trop coquet); ល្អ, ច្រឡឹង (ឧ. appartement coquet); សមល្មមគួរសម (ឧ. somme coquette)

coqueter *v.i.Fam.* ចូលចិត្តធ្វើឲ្យគេស្រឡាញ់ (ឧ. au fond peu vicieuse, elle aime à co-

queter); ចែចង់

coquetier *n.m.* ឈ្មួញស៊ុតមាន់ នឹង បសុបក្សី; ពែរទ្រស៊ុតមាន់ស្រុស

coquetière *n.f.* ឆ្នាំងស្រុសស៊ុតមាន់

coquettement *adv.* យ៉ាងល្អ, យ៉ាងព្រឡឹង

coquetterie *n.f.* ការចូលចិត្តឲ្យគេស្រឡាញ់; ការចូលចិត្តតុបតែង (ឧ. maison meublée avec coquetterie)

coquillage *n.m.* សត្វខ្យងខ្ចៅ; សំបកខ្យងខ្ចៅ

coquille *n.f.* សំបកខ្យងខ្ចៅ ។ *Fig.* rentrer dans sa coquille រួញខ្លួន (លែងហ៊ាននិយាយ, លែងហ៊ានឲ្យគេឃើញមុខ)។សំបកស៊ុតឬផ្លែឈើ។ *Fig.* coquille de noix កប៉ាល់តូច; ពាក្យខុសដោយរៀបពុម្ពច្រឡំ

coquiller *v.i.* ឡើងពងៗ (ឧ. ce pain est coquillé)

coquilleux,euse *a.* ដេរដាសដោយសំបកខ្យងខ្ចៅ

coquiller,ère *a.* ដែលមានសំបកខ្យងខ្ចៅ

coquillier,ère *a.* ដែលមានលាយសំបកខ្យងច្រើន (ឧ. calcaire coquillier) ។ *n.m.* សំបកខ្យងដែលគេប្រមូល

coquin,e *n.* ជនខិលខូច,ជនបោកបាប។ *Par plais.* ក្មេងប៉ិលប៉ូច

coquinerie *n.f.* អំពើខិលខូច-បោកបាប ឬ ប៉ិលប៉ូច

cor *n.m.* ស្នែងផ្លុំ; ត្រែ; អ្នកផ្លុំត្រែ ។ à cor et à cri *loc.adv.* ដោយសន្ធឹកសន្ធាប់

cor *n.m.* ផ្ទៃប្រមាបជើង (សាច់កន្ទួលរឹងដោយពាក់ស្បែកជើង)

cor *n.m.* ខ្នែងនៃស្នែងក្តាន់ ។ cerf dix cor ក្តាន់អាយុប្រាំពីរឆ្នាំ

corail *n.m.* ផ្កាថ្ម (*pl.* des coraux)

corailleur *a.&n.m.* អ្នកយកផ្កាថ្ម

coran *n.m.* គូរអាន (គម្ពីរសាសនាអ៊ិស្លាម)

coranique *a.* នៃគូរអាន

corbeau *n.m.* ក្អែក ។ *Fig.* មនុស្សទុច្ចរិត ។ noir comme le corbeau ខ្មៅដូចក្អែក

corbeille *n.f.* កញ្ជើ, កញ្ច្រែង, កញ្ជេ; ចំនួនមួយកញ្ជើ-មួយកញ្ច្រែងឬមួយកញ្ជេ (ឧ. offrir une corbeille de fruits); ជូនផ្កាកងមូលឬមូលទ្រវែង។ *Fig.* corbeille de mariage ជំនូនកូនក្រមុំ

corbeillée *n.f.* ចំនួនមួយកញ្ច្រែង-មួយកញ្ចើ ឬ មួយកញ្ចេ

corbillard *n.m.* សវរថ, រថដឹកសព

corbillat *n.m.* កូនក្អែក

corbillon *n.m.* កូនកញ្ច្រែង

corbin *n.m.* ក្អែក ។ en bec de corbin កោងហើយស្រួច (ម.ព. bec-de-corbinផង)

cordage *n.m.* ខ្សែពួរប្រើក្នុងនាវា

corde *n.f.* ខ្សែ (ឧ. échelle de corde); ខ្សែគ្រឿងភ្លេង (ឧ. corde de violon)។ *Sports* ខ្សែបន្ទាត់។ tenir la corde នៅជិតខ្សែបន្ទាត់ (ក្នុងការរត់ប្រណាំង) ; *au fig.* មានប្រៀបលើគេ។ខ្នាតឧសចំណុះបួនស្ទែរ។ cordes vocales ផ្ចិតសម្លេង (ក្នុងបំពង់ក) (ឧ. les vibrations des cordes vocales sont à l'origine de la voix) ។ បន្ទោះ (ខ្សែស្ពា ឬ ធ្នូ) ។ mettre la corde au cou យកកទៅលអន្ទាក់ ; *par plaisant.* មានគូស្រករ(ជាប់ចំណង)។ *Fig.* toucher la corde sensible និយាយត្រូវចំណុច ។ *Fig.* avoir plusieurs cordes à son arc មានកលល្បិចច្រើន,មិនចេះទាល់។ *Fig.* ទោសគ្នោក(ចងព្យួរបគ្នោក) (ឧ.mériter la corde)។se rendre la corde au cou ឬ venir la corde au cou ចូលខ្លួនឲ្យគេធ្វើម្ដេចតាមចិត្ត ។ *Fig.* montrer la corde, être usé jusqu'à la corde របរស់(សំលៀកបំពាក់); *au fig.* អស់ផ្លូវហើយ (គេលែងទុកចិត្ត; អស់មធ្យោបាយ) ។ sentir la corde គួរសង្ស័យណាស់, ដូចជាមិនស្រួលសោះ ។ friser la corde គួរគ្នោក។ filer sa corde វេញខ្សែសម្រាប់គ្នោកខ្លួនឯង; ប្រព្រឹត្តអំពើដែលនាំឲ្យគេគ្នោក។ mettre la corde au cou de quelqu'un បំផ្លាញ, ធ្វើឲ្យហិនហោច ។ homme de sac et de corde ចោរហៅនយៀ [ហៈ-នៃ-យុង] (គប្បីសម្លាប់)។ tirer sur la même corde ចូលថ្លុងមួយ (ស្រុះគ្នា) ។ trop tirer sur la corde ប្រើតែមធ្យោបាយដដែលៗពេក ។ *Géom.* បន្ទោះ ។ *pl.* គ្រឿងខ្សែ (គ្រឿងភ្លេង) ។

Prov. il ne vaut pas la corde pour le pendre កុំធ្វើវានាំឲ្យហោកដៃ (មនុស្សនេះហោកទាប

ណាស់ យើងមិនសមនឹងទៅធ្វើអ្វីភាទេ ព្រោះនាំឲ្យហោកទាបដល់យើងទៀត)។ il a toujours la corde de pendu dans sa poche មនុស្សនោះស្ទាក់លាភណាស់ (លេងល្បែងបេះតែឈ្នះ, ធ្វើអ្វីក៏បានប្រកប)។ il ne faut pas parler de corde dans la maison d'un pendu កុំនិយាយពីរឿងគ្មានសក់ចំពោះមុខមនុស្សក្បាលទំពែក

cordé,e *a.* ដែលមានរាងដូចបេះដូង(ឬដូចរូបបេះដូងក្នុងសន្លឹកបៀ)

cordeau *n.m.* ខ្សែបន្ទាត់ (ឧ. allée tirée au cordeau)។*Art mil.* ឆ្នូន ។ *Péch.* សន្ទូចរនង

cordée *n.f.* ជាប់ (ឧ. une cordée de bois); អ្វីៗដែលគេចងព័ទ្ធនឹងខ្សែបាន ។ *Fig.* អ្វីៗដែលមានបន្តគ្នា ។ *Péch.* រនងសន្ទូច ។ *Alp.* ពួកអ្នកឡើងភ្នំដែលចងខ្សែភ្ជាប់គ្នា

cordeler *v.t.* វេញជារាងខ្សែ

cordelette *n.f.* កន្សួយខ្សែ; ខ្សែតូចខ្លី

cordelière *n.f.* ខ្សែក្រវាត់ចង្កេះ (ឧ. la cordelière d'une robe de chambre)

cordelle *n.f.* ខ្សែសម្រាប់អូសនាវា

corder *v.t.* វេញខ្សែ; ចងនឹងខ្សែ (ឧ. corder une malle)។corder du bois វាស់ឈើដោយខ្សែ

corderie *n.f.* របរវេញខ្សែ; ជំនួញខ្សែ; កន្លែងធ្វើខ្សែ

cordialement *adv.* ដោយសុប្រាំទ ឬស្មោះស្ម័គ្រ

cordialité *n.f.* សុប្រាំទភាព, ភាពជិតស្និទ្ធ(ឧ.parler avec cordialité)

cordier *n.m.* អ្នកធ្វើខ្សែ; ឈ្មួញខ្សែ

cordiforme *a.* ដែលមានទ្រង់ទ្រាយដូចបេះដូង

cordillère *n.f.* ជួរភ្នំ

cordon *n.m.* សរសៃព្ធរ; ខ្សែតូច (ឧ. cordon de sonnette);ខ្សែឥស្សរិយយស (ឧ. le grand cordon de la Légion d'honneur); ជួរ (មនុស្ស, របស់ ឬ ប៉ុស្តិ៍ទាហាន) (ឧ. cordon de troupes, de police); ហាមរូបិយវត្ថុ (ហាមប្រាក់កាក់ជាដើម) ។ cordon ombilical ទងសុក (ជាប់ពីសុកម្ដាយទៅផ្ចិតកូន)

cordon-bleu *n.m.*ចុងភៅចំណាន(*pl.* des cordons-bleus)

cordonner *v.t.* វេញព្ធរឬខ្សែឆ្មារ

cordonnerie *n.f.* របរឬជំនួញធ្វើស្បែក

ជើង; កន្លែងធ្វើ-លក់ ឬ ជួសជុលស្បែកជើង

cordonnier,ère *n.* អ្នកធ្វើ-លក់ឬជួសជុលស្បែកជើង ។ *Prov.* les cordonniers sont les plus mal chaussés ជាងទងស៊ីរងកំបែក ជាងដែកស៊ីហែកនឹងដៃ ។ cordonnier, pas plus haut que la chaussure ម.ព. chaussure

coréen,enne *a.&n.* នៃប្រទេសកូរ៉េ ។ *n.m.* ភាសាកូរ៉េ

coreligionnaire *n.* សហសាសនិក (អ្នកដែលកាន់សាសនាដូចគ្នា)

coriace *a.* ស្វិត ។ *Fig.* ស្វិតស្វាញ, កំណាញ់, ចចេស

coriacé,e *a.* រឹងដូចស្បែក

coriandre *n.f.* ជីរវ៉ាន់ស៊ុយ

cormoran *n.m.* ក្អែកទឹក

cornac *n.m.* ហ្មូ ឬ ទ្រមាក់ដំរី ។ *Fig.* អ្នកណែនាំ, អ្នកនាំផ្លូវ

cornard *a.&n.m.* ដែលមានស្នែង (ឧ. diable cornard) ។ *Pop.* វ៉ក (ប្រុសប្រពន្ធផិត)

corne *n.f.* ស្នែង (ឧ. les bovidés ont les cornes creuses); ជាតិស្នែង (ឧ. peigne de corne); ក្របកជើងសត្វខ្លះ ; ស្នែង (សាច់ដុះពកចេញពីក្បាលខ្យងសោក ឬ សត្វល្អិតខ្លះ សណ្ឋានដូចស្នែង); ស្នែងផ្លុំ; ផ្នត់ជ្រុងក្រដាស (ឧ. faire des cornes à un livre); មួកស្រួច (ឧ. chapeau à trois cornes); មុម ឬ ជ្រុងដែលលយចេញ (ឧ. la corne d'un bois) ។ corne d'abondance ម.ព. abondance ។ *loc. adv.* les cornes lui en sont venues à la tête ឆ្ងល់ខ្លាំង ។ on prend les hommes par les paroles, et les bêtes par les cornes គេទាក់មនុស្សនឹងសំដី គេទាក់ដំរីនឹងខ្សែ ។ *Fig. & fam.* prendre les taureaux par les cornes មិនញញើតនឹងចាប់ការពិបាក (ចាប់ការពិបាកដោយក្លាហាន)

corné,e *a.* ជាជាតិស្នែង; ដែលដូចស្នែង

corneau ឬ **corniaud** *n.m.* ឆ្កែកូនកាត់ (ពូជមិនសុទ្ធ)

corned-beef *n.m.* សាច់គោប្រអប់

cornée *n.f.* កញ្ចក់ភ្នែក

corneille *n.f.* បក្សីម្យ៉ាងដូចក្អែក (cri: la corneille craille) ។ *loc.*

fam. bayer aux corneilles ម.ព. bayer ។ comme une corneille qui abat des noix ប៊ិនមើលមុខមើលក្រោយ

cornéen,enne *a.* នៃកញ្ចក់ភ្នែក

cornélien,enne *a.* តាមរបៀបគ័រណី (អ្នកនិពន្ធរឿងល្ខោនក្នុងសតវត្សទី ១៧)

cornement *n.m.* ការហ៊ឹងត្រចៀក

cornemuse *n.f.* គ្រឿងភ្លេងសម្រាប់ផ្លុំមួយយ៉ាង

corner *v.i.* ផ្លុំស្នែង ។ corner aux oreilles de quelqu'un ស្រែកដាក់ត្រចៀក, និយាយខ្លាំងៗទៅកាន់អ្នកណាមួយ; ហ៊ឹងត្រចៀក ។ *v.t.* បត់ជ្រុង (ឧ. corner une carte de visite) ។ *Fig. & fam.* ដើរនិយាយគ្រប់ទិសដំបន់ឥតឈប់ឈរ (ឧ. corner une nouvelle)

corner *n.m.* គ័រនែរ (កំហុសមួយយ៉ាងក្នុងកីឡាបាល់ទាត់)

cornet *n.m.* ត្រែម្យ៉ាង ។ *Anat.* ឆ្អឹងខ្ចង់ច្រមុះ ។ ក្រដាសមូរជារាងសាជី ។ cornet acoustique ម.ព. acoustique

cornette *n.f.* មួកដូនជី; មេលើមកន្ទុយពីរ (ទង់នាវា) ។ *Fig. & fam.* ស្រីប្ដីក្បត់ចិត្ត

corniaud ឬ **corniot** *n.m.* ម.ព. corneau

corniche *n.f.* *Archit.* ក្បាំងក្បាលជញ្ជាំង ។ *Géogr.* បំណេកត (ដីចោត)

cornichon *n.f.* ត្រសក់ជ្រក់ ។ *Fam.* មនុស្សកញ្ចោត, មនុស្សភ្លើ

cornier,ère *a.* ដែលនៅត្រង់ជ្រុងឬត្រង់មុម; ទជ្រុងដំបូល ។ *Constr.* ដែកកន្ទុយត្រី

cornillon *n.m.* ឆ្អឹងគល់ស្នែង

corniste *n.m.* អ្នកផ្លុំត្រែឬស្នែង

corn-picker *n.m.*(ព.អ.) ម៉ាស៊ីនកាច់ពោត(បេះពោត) (*pl.* des corn-picker)

cornu,e *a.* ដែលមានស្នែង(ឧ. animal cornu) ។ *Fig.* raisons, visions cornues គំនិតវង្វេងស្មារតី

cornue *n.f.* ឆ្នាំងចំហុយ, ឡចំហុយ

corollaire *n.m.* អនុលោម

corolle *n.f.* *Bot.* កន្សោមផ្កា

coronal,e,aux *a.* ដូចកម្រង (ជារាងមូលគ្របពីលើ) ។ *Anat.* នៃឆ្អឹងថ្ងាស (ឧ. os coronal) (ដូនកាលគេថា os frontal)

coroner [-neur] *n.m.* (ព.អ.) នាយក្រុម

នគរបាលតុលាការអង់គ្លេស

corossol *n.m.* ផ្លែទៀបបន្លា

corporatif,ive *a.* នៃសាជីវកម្ម (ឧ. groupement corporatif)

corporation *n.f.* សាជីវកម្ម

corporatisme *n.m.* សាជីវកម្មនិយម

corporel,elle *a.* ដែលមានរាងកាយ; ដែលមានរូប;ចំពោះរាងកាយ(ឧ.peine corporelle) ។ *Dr.* bien corporel រូបទ្រព្យ (ព.ផ. bien incorporel)

corporellement *adv.* ចំពោះរាងកាយ

corps *n.m.* ខ្លួន,ប្រាណ;ភាព;រាងកាយ; កង ។ corps franc កងឯកទេស ។ corps d'armée កងអង្គទ័ព ។ អង្គ ។ corps consulaire អង្គកុងស៊ុល ។ corps diplomatique អង្គទូត ។ corps simple អង្គសរល [ស:-រ:-ល:] ។ corps composé អង្គសមាស ។ corps gras អង្គខ្លាញ់ ឬ ប្រេង ។ corps volatil អង្គភសិត (ដែលហើរ) ។ les trois états du corps ត្រៃភាពនៃអង្គ ។ corps solide អង្គរឹង ឬ អង្គធុំ ។ corps liquide អង្គរលីនឬអង្គរាវ ។ corps gazeux អង្គឧស្ម័ន ។ corps calleux កំណាង្គ ។ *Fig.* ភាពជាប់ (ឧ.cette étoffe a du corps)។ *Impr.* អង្គអក្សរពុម្ព ។

Loc.div. corps sans âme, corps privé de vie រូបឥតព្រលឹង ឬ ឥតវិញ្ញាណ (មនុស្ស-សត្វ ឬ វត្ថុ ដែលខ្វះគ្រឿងសំខាន់អ្វីមួយ) (ឧ. une armée sans général est un corps sans âme); មនុស្សដែលវិលវល់ចិត្ត ឬ ដែលរារែក ។ corps et biens ទាំងខ្លួនទាំងទ្រព្យ (ឧ. s'obliger corps et biens; périr corps et biens)។ corps et âme ពេញទី, ទាំងស្រុង, គ្មានលាក់លៀម ។ c'est l'ombre et le corps គឺជាស្រមោលនឹងប្រាណ (មនុស្សដែលជាប់គ្នាជានិច្ច) ។ prendre l'ombre pour le corps យកភេទក្រៅ (ឬ អាការៈក្រៅ) ជាការពិត ។ faire de son corps une boutique d'apothicaire ប្រើថ្នាំច្រើន ។ faire folie (ឬ être folle) de son corps ប្រព្រឹត្តខុសសីលធម៌ (ចំពោះតែស្ត្រី) ។ faire corps neuf ធ្វើឲ្យមានសុខភាព-ឲ្យមានកម្លាំងឡើងវិញ (ច្រើនតែប្រើចំពោះ

សេះដែលគេយកទៅបំប៉ននៅស្រុកស្រែ) ។ n'être qu'un en deux corps មនុស្សពីរនាក់ ប៉ុន្តែចិត្តតែមួយ (ស្រឡាញ់គ្នាដោយស្និទ្ធស្នាលខ្លាំង) ។ avoir dans le corps មានពំកំណើត ។ faire rentrer dans le corps បង្ខំឲ្យនៅស្ងៀម-ឲ្យបំបិទ ចោល (កុំឲ្យនិយាយ ឬ ទឹកនាដិល់) ។ avoir le diable au corps ប្រឡេតខ្លាំង,ខឹងខ្លាំង(ដូចខ្មោចចូល)។ avoir sur le corps ត្រូវរង, មានទាក់ទាមក្នុង(ឧ.avoir une accusation criminelle sur le corps)។ passer sur le corps de ប៉ះទង្គិចហើយដើរជាន់(ឧ. passer sur le corps d'un regiment ennemi ។ tomber sur le corps à quelqu'un ធ្វើបាប, និយាយអាក្រក់ពីអ្នកណាមួយ ។

Loc. adv. corps à corps ដោយប្រកៀកគ្នា, ដោយចំពីមុខ ។ à corps perdu ដោយខ្លាំងក្លា,ដោយឥតគិត ឬ ឥតសង្ឃឹមនឹងវិលវិញ ។ en corps ទាំងក្រុម, ទាំងអស់គ្នា (ឧ. assister en corps à une cérémonie) ។ à mi-corps ពាក់កណ្តាលខ្លួន.ត្រឹមចង្កេះ។ à bras-le-corps ឱប (ព.ម. bras ផង) ។ à son corps défendant ដើម្បីការពារខ្លួន (ឧ. s'il l'a tué, c'est à son corps défendant); *au fig.* ដោយទើសទាល់,ដោយបង្ខំ (ឧ.il faut parler sobrement de soi, et presque à corps défendant) ។ prendre du corps ធុះពោះ ។ corps du délit ភស្តុតាងបទល្មើស។corps céleste ពាភ ។ corps de garde ប៉ុស្តិ៍ទាហាន ។ corps et âme ទាំងស្រុង,គ្មានសំចៃ ។

corpulence *n.f.* ទំហំទំហាត់(ឧ.forte corpulence); ភាពធំធាត់(ឧ.être gêné par sa corpulence)

corpulent,e *a.* ធំធាត់

corpus *n.m.* ក្រម, កម្រង (បំពោះរឿងជាមួយគ្នា)

corpusculaire *a.* នៃទេហាណូ

corpuscule *n.m.* ទេហាណូ (អង្គល្អិតឆ្មារ) ។ corpuscule du tact ទេហាណូនៃផស្ស:

correct,e *a.* ត្រឹមត្រូវ (ឧ. style correct);រៀបរយ,សមសួន (ឧ. tenue

correcte)

correctement *adv.* ដោយត្រឹមត្រូវ, ដោយរៀបរយ; ដោយសមគួរ

correcteur,trice *a.* ដែលកែតម្រូវ(ឧ. des verres correcteurs)។*n.* អ្នកកែ (វិញ្ញាសាពុម្ព); មេប្រយោគ

correctif *a.* ដែលសម្រាប់កែ ឬ សម្រាប់តម្រង់ (ឧ. gymnastique corrective) ។ *n.m.* អ្វីៗសម្រាប់កែ ឬ សម្រួល (ឧ. le sucre est le correctif des acides) ។ *Fig.* ពាក្យសម្រួល

correction *n.f.* ការកែ (ការកែកិច្ចការសិស្ស, វិញ្ញាសាប្រឡង, វិញ្ញាសាបោះពុម្ព); ការកែតម្រូវ (ឧ. apporter une correction à sa copie); ការស្ដីប្រដៅ; ទណ្ឌកម្ម (ឧ.recevoir une correction); ភាពត្រឹមត្រូវ (ឧ. conduite d'une parfaite correction)។ *Loc. adv.* sauf correction លើកលែងតែមានការភាន់ច្រឡំ

correctionnalisation *n.f.* ការកែរឿងបទឧក្រិដ្ឋជារឿងបទមជ្ឈិម

correctionnaliser *v.t.* កែរឿងបទឧក្រិដ្ឋជារឿងបទមជ្ឈិម

correctionel,elle *a.* នៃបទមជ្ឈិម(ឧ. peine, police correctionnelle; tribunal correctionnel) ។ *n.f. Pop.* សាលាលហុ

correctionnellement *adv.* ជាបទមជ្ឈិម

corrélatif,ive *a.* សហសម្ពន្ធ័ ។ *n.m.* សហសម្ពន្ធ័សព្ទ(ឧ.les mots souverain et sujet sont des corrélatifs)

corrélation *n.f.* សហសម្ពន្ធ; ការទាក់ទងគ្នាទៅវិញទៅមក

correspondance *n.f.*ភាពស្របគ្នា(ឧ. correspondance d'idées);ការឆ្លើយឆ្លង (ឧ. entretenir une correspondance avec quelqu'un); សំបុត្រ (ឬលិខិត) ឆ្លើយឆ្លង (ឧ. lire sa correspondance); ការទាក់ទងគ្នា (រវាងដំបន់ឬយានពីរ); យានដឹកនាំ(សម្រាប់ការទាក់ទងពីដំបន់មួយទៅដំបន់មួយ)(ឧ attendre la correspondance)

correspondancier,ère *n.* ភ្នាក់ងារអ្នកទាក់ទងនឹងអតិថិជន (អ្នកទិញ)

correspondant,e *a.* តជានរូប, ស្របគ្នា, ត្រូវគ្នា(ឧ.idées correspon-

dantes) ។ *n.m.* អ្នកឆ្លើយឆ្លង

correspondre *v.i.* ទាក់ទង (ឧ. ces pièces correspondent entre elles);ឆ្លើយឆ្លង(ឧ.correspondre avec ses amis); មានភាពដាគជា-ន្សូប (ស្របគ្នា); ធ្វើការទាក់ទង(មធ្យោ-បាយដឹកនាំ) (ឧ. ce car correspond avec le train de Battambang)

corrida *n.m.* ការប្រណាំងគោ (នៅប្រទេសអេស្ប៉ាញ)

corridor *n.m.* គេហបថ, ច្រកក្នុងគេហស្ថាន ។ *Fig.* ទ្វារ (ច្រកចង្អៀត)

corrigé *n.m.* កិច្ចការគំរូ(សម្រាប់សិស្ស)

corriger *v.t.* កែ(ធ្វើឲ្យល្អឡើង)(ឧ.corriger les mœurs); កែ(ធ្វើឲ្យអស់កំហុស)(ឧ.corriger une épreuve);ស្តីប្រដៅ,ធ្វើទោស(ឧ. corriger un enfant); បន្សាប, បង្អន់ (ឧ. corriger l'acidité d'une boisson); បន្ធូរ, សម្រាល (ឧ.corriger l'injustice du sort) ។ se corriger(de) *v.pr.* កែខ្លួន, បំបាត់ចោល(ឧ.se corriger d'un défaut)

corrigeur *n.m.* អ្នកកែអក្សរពុម្ព

corrigible *a.* អាចកែបាន

corroborant,e *a.* ដែលឲ្យមានកម្លាំង (ឧ. remède corroborant; preuve corroborante)

corroboratif,ive *a.* ដែលបន្ថែមកម្លាំង

corroboration *n.f.* បមាណីករណ៍; ការបន្ថែមកម្លាំង; ការបញ្ជាក់

corroborer *v.t.* ធ្វើបមាណីករណ៍,បន្ថែមកម្លាំង; បញ្ជាក់ (ឧ. l'aveu d'un accusé corrobore l'accusation)

corrodant,e *a.* ដែលស៊ី(ដូចជាទឹកក្រូតស៊ីដែក)

corroder *v.t.* ស៊ី(ទឹកក្រូតស៊ីដែក),កាត់; ធ្វើឲ្យវិនាស

corrompre *v.t.* ធ្វើឲ្យខូច,ធ្វើឲ្យរលួយ (ឧ. la chaleur corrompt la viande) ។ *Fig.* ញៀវក្លួម, នាំខូច (ឧ. corrompre les mœurs); បង្ខូច (បំបែរចេញពីករណីយកិច្ចខ្លួន) (ឧ. corrompre un juge)

corrosif,ive *a.* & *n.m.* ដែលស៊ី,ដែលកាត់ (ឧ. le nitrate d'argent est un corrosif) ។ *a. Fig.* កាច, ខ្លាំង, ឃោរឃៅ (ឧ. ironie corrosive)

corrosion *n.f.* ការកាត់, ការស៊ី (ដូច ទឹកក្រូត)

corroyage *n.m.* ការធ្វើស្បែកឲ្យទន់ ។ *Métall.* ការផ្សារដែកភ្ជាប់គ្នា

corroyer *v.t.* ធ្វើស្បែកឲ្យទន់; ផ្សារដុំដែកភ្ជាប់គ្នា; ឈូសរំលីងឈើ

corroyeur *n.m.* អ្នកធ្វើស្បែកឲ្យទន់

corrupteur,trice *a.&n.* អ្នកនាំខូច, អ្នកញៀវក្លួម, អ្នកបង្ខូច

corruptibilité *n.f.* ភាពអាចនាំខូច ឬ ញៀវក្លួមបាន

corruptible *a.* អាចនាំខូចបាន

corruption *n.f.* ការស្អុយ;ការខូច(ឧ. la corruption du sang)។ *Fig.*ការខូច(ឧ.corruption d'un texte, du goût);ការញៀវក្លួម,ការនាំឲ្យខូច,ការបង្ខូច(ឧ. corruption des mœurs);ការពុករលួយ(ចំពោះនាម៉ឺនដែលស៊ីសំណូក)

corsage *n.m.* ដងខ្លួនមនុស្ស; អាវស្រីខ្លី

corsaire *n.m.* ចោរជើងទឹក; កប៉ាល់ប្រដាប់ដោយអាវុធ ។ *Fig.* មនុស្សលោភហើយឥតមេត្តា ។ *a.* pantalon corsaire ខោរបស់ព្រាបជង្គង់

corsé,e *a.* ជាប់ (ឧ. drap corsé); ដែលមានក្លិនឆ្ងុល (ឧ. vin corsé)។ *Fig.* histoire corsée រឿងកុបតិន; រឿងស្មុគ្រស្មាញ

corser *v.t.* លើករស (ធ្វើឲ្យកេនឌជារស) (ឧ.corser un vin, un récit)។ se corser *v.pr.* ឡើងស្មុគ្រស្មាញ, ទៅជាធំ (ចំពោះរឿងហេតុ)

corset *n.m.* អាវទ្រទាប់ដាក់ឆ្អឹង

cortège *n.m.* ក្បួនហែ ។ *Fig.* អ្នកហែហម

cortical,e,aux *a.* នៃសំបក

coruscant,e *a. Poét.* រលោង,ចិញ្ចាច

corvéable *a.* អាចកេណ្ឌឲ្យធ្វើការយកម្មបាន

corvée *n.f.* ការយកម្ម ។ *Fig.* ការលំបាកហើយគ្មានផល

corvette *n.f.* នាវាចម្បាំងជាន់ចាស់ ។ capitaine de corvette ម.ត. capitaine

corvidés *n.m. pl.* កាកសកុណ [កា-កៈ-] (ពួកសត្វសត្វានក្អែក)

cosaque *n.m.* ទាហានទ័ពសេះជាតិរុស្ស៊ី ។ *Fig.* មនុស្សកំណាច ។ *n.f.* របាំមួយយ៉ាង

cosignataire *n.&a.* អ្នកចុះហត្ថលេខារួម

cosinus *n.m.* កូស៊ីនុស

cosmétique *n.m.* &*a.* ថ្នាំថែមុខ-ខ្លួននិងសក់: ថ្នាំជ្រុះសក់(លាបកុំឲ្យជ្រុះសក់)

cosmétiquer *v.t.* លាបថ្នាំសក់

cosmétologie *n.f.* វិទ្យាសាស្ត្រខាងថែមុខ-ខ្លួននិងសក់

cosmique *a.* នៃលោកធាតុ(ឧ. espace cosmique) ។ rayons cosmiques កាំរស្មីលោកធាតុ

cosmographe *n.m.* អ្នកលោកធាតុសាស្ត្រ

cosmographie *n.f.* លោកធាតុសាស្ត្រ

cosmographique *a.* នៃលោកធាតុសាស្ត្រ

cosmologie *n.f.* លោកធាតុវិទ្យា

cosmologique *a.* នៃលោកធាតុវិទ្យា

cosmopolite *n.* លោកសម្ពន្ធ, ពលរដ្ឋនៃសាកលលោក ។ *Fig.* អ្នកចូលចិត្តធ្វើដំណើរក្នុងសាកលលោក។ *a.* ដែលមានលំនាំតាមបរទេស (ឧ. mœurs cosmopolites)។ quartier cosmopolite សង្កាត់មានជនបរទេសច្រើនសញ្ជាតិនៅច្រុះគ្នា

cosmopolitisme *n.m.* លោកសម្ពន្ធនិយម

cosmorama *n.m.* លោកចិត្រកម្ម

cosmos *n.m.* លោកធាតុ

cosse *n.f.* សំបក (សណ្ដែកជាដើម)

cosser *v.i.* ជល់គ្នា (ចៀម) ។ *Fig.* ប្រយុទ្ធ

cossu,e *a.* ដែលមានសំបក ។ *Fig.* ដែលមានភោគទ្រព្យ (ឧ. homme cossu); ដែលបង្ហាញឲ្យឃើញថាមានភោគទ្រព្យ (ឧ. mobilier cossu; maison cossue)

costal,e,aux *a.* នៃឆ្អឹងជំនីរ

costaud ឬ **costeau** *a.*&*n.* *Arg.* ខ្លាំង, ក្រទា

costume *n.m.* របៀបស្លៀកពាក់; សំលៀកបំពាក់ (ឧ. costume sur mesure); សំលៀកបំពាក់របាំ, សំលៀកបំពាក់ក្លែង

costumé,e *a.* ដែលស្លៀកពាក់ ។ bal costumé ការរាំដោយស្លៀកពាក់ក្លែង

costumer *v.t.* ស្លៀកពាក់ក្លែង

costumier,ère *n.* អ្នកធ្វើសំលៀកបំពាក់; ឈ្មួញសំលៀកបំពាក់។ *Théât.* អ្នកតុបតែងសំលៀកបំពាក់

cosy-corner [-neur] ឬ **cosy** *n.m.* (ព.អ.) ជ្រុងជញ្ជាំងដាក់ទូមានថ្នាក់។ *Par ext.* ទូដាក់ជ្រុងជញ្ជាំង

cotation *n.f.* ការបង់លេខ; ការដាក់ថ្លៃ

cote *n.f.* កម្រិត; ចំណែកដែលម្នាក់ៗត្រូវ

បង់ (ក្នុងចំណាយរួម ឬ ក្នុងពន្ធអាករ) (ឧ. cote mobilière); សញ្ញាចំណាំ; លេខទំហំ (គំនូរ); តម្លៃ (ឧ. cote de la Bourse); កំពស់ (ដែលគ្រាទុកលើផែនទី) ។ cote d'alerte កម្រិតភេរវសញ្ញា (កម្រិតកំពស់ទឹកស្ទឹងទន្លេដែលអាចនឹងបណ្ដាលឲ្យមានជំនន់លិចបើឡើងហួសពីកម្រិតនេះ); *au fig.* ការគួរឲ្យភ័យ ។ *Fig. & fam.* កម្រិតការរាប់អាន (ឧ. avoir une bonne cote)

coté,e *a.* ដែលមានកម្រិត (ឧ. croquis coté)

côte *n.f.* ឆ្អឹងជំនីរ (ឧ. l'homme possède douze paires de côtes); ច្រនុង, ជំនីរភ្នំ; ផ្លូវឡើងជំនីរភ្នំ; ឆ្នេរសមុទ្រ; ភាគដែលលយចេញ (ឧ. les côtes d'un melon; étoffe à côtes) ។ faire côte, aller à la côte កៀងជិតឆ្នេរ ។ être à la côte, être au pied de la côte មានដំណើរមិនសូវស្រួល (ការជំនួញ); គ្មានធនធាន ។ frère de la côte ពួកម៉ាកកំសត់កម្រ ។ se tenir les côtes សើចរឹងពោះ ។ côte à côte *loc.adv.* ទន្ទឹមគ្នា

côté *n.m.* ជំនីរ; ខាង (ឧ. suivre le côté droit de la route); ទិស, ដំបន់ (ឧ. de tous côtés) ។ *Géom.* បស្សរេខា ។ *Fig.* ប៉ែកខាង (ឧ. les bons côtés d'une affaire) ។ ញាតិខាង (ឧ. côté paternel); យោបល់, ប៉ែកខាង (ឧ. je me range de votre côté) ។ côté faible d'une chose ប៉ែកខាងមិនល្អ ។ côté faible d'une personne កំហុសធម្មតានៃមនុស្សម្នាក់ ។ à côté *loc. adv.* ជិត; *au fig.* donner à côté ខុស, មិនត្រូវតាមគោលបំណង ។ de côté *loc.adv.* ពីចំហៀង, បញ្ឆៀង (ឧ. marcher de côté); *au fig.* regarder de côté មើលមិនចំ (ដោយគ្រាន់តែចោលភ្នែក, ដោយស្ទាក់ស្ទើរ) ។ laisser de côté ទុកដោយឡែក; មិនរវល់ផល់, បោះបង់ចោល ។ du côté de *loc. pré.* ប៉ែកខាង ។ à côté de *loc. pré.* ជិត

coteau *n.m.* ជម្រាលភ្នំ; ភ្នំតូច ។ *Par ext.* ចំការទំពាំងបាយជូរ

côtelé,e *a.* ដែលមានឆាយ (សំពត់) (ឧ.

velours côtelé)

côtelette *n.f.* ឆ្អឹងជំនីរជៀម-កូនគោឬជ្រូក

coter *v.t.* បង់លេខ; ដាក់ថ្លៃ (ឧ. coter les marchandises); ដាក់ពិន្ទុ (ឧ. coter un devoir d'élève)។ *Fig.* ចូលចិត្ត,រាប់អាន(ឧ. être bien coté par ses supérieurs); យកជាការ

coterie *n.f.* ប្រជុំជនអ្នកស្និទ្ធស្នាល ឬអ្នករួមគំនិតគ្នាត់

côtier,ère *a.* តាមឆ្នេរសមុទ្រ (ឧ. navigation côtière)។ ដែលស្គាល់ឆ្នេរ (ឧ. pilote côtier)។ fleuve côtier ទន្លេដែលមានប្រភពជិតឆ្នេរ។ *n.m.* នាវាដើរតាមឆ្នេរ

cotier *n.m.* សេះសម្រាប់ឡើងទីចោត

cotillon *n.m.* សំពត់ក្នុង ។ courir le cotillon រកទាក់ទងនឹងស្រីៗ

cotir *v.t.* ធ្វើឲ្យជាំ (ផ្លែឈើ) (ឧ. la grêle a coti ces pommes)

cotisant,e *a.* ដែលចេញភាគទាន ។ *n.m.* អ្នកចេញភាគទាន

cotisation *n.f.* ការចេញភាគទាន (អំណោយមានកំណត់ចំនួនស្មើគ្នា); ការប្រាក់, ការរៃ; ការប្រមូលភាគទាន; ភាគទាន

cotiser *v.i.* ចេញភាគទាន ។ se cotiser *v.pr.* ប្រមូលភាគទាន; ប្រាក់; រៃ

cotissure *n.f.* ស្នាមជាំលើផ្លែឈើ

coton *n.m.* សំឡីកប្បាស, អំបោះ ឬ សំពត់កប្បាស ។ *Fig. & fam.* filer un mauvais coton ខូចការ, ខូចសុខភាព ។ល។ élever un enfant dans le coton ទំរើសកូន (ចិញ្ចឹមកូនដោយថ្នមជំនួយ)

cotonnade *n.f.* កប្បាសប៉័យ[ក្រប់-ជាស-មុំយ], សំពត់អំបោះ,សំពត់ទេសឯក

cotonné,e *a.* គ្របឬទ្រាប់ដោយសំឡីកប្បាស ។ cheveux cotonnés សក់រួញអង្កាជី

cotonner(se) *v.pr.* មានរោម(សំពត់, ផ្លែឈើ)

cotonnerie *n.f.* កន្លែងធ្វើអំបោះ; ចំការកប្បាស; ដំណាំកប្បាស

cotonneux,euse *a.* ដែលមានរោមទន់ (ឧ. fruit cotonneux)។ *Fig.* ដូចសំឡី (ឧ. ciel cotonneux)

cotonnier,ère *a.* នៃកប្បាស។ *n.* កម្មការី-ការិនី នៃកម្មន្តសាលកប្បាស

cotonnier *n.m.* ដើមកប្បាស

coton-poudre ឬ **fulmicoton** *n.m.* រំសេវធ្វើដោយកប្បាស(*pl.* des cotons-poudre)

côtoyer *v.t.* សៀរ (ឧ. côtoyer une rivière) ។ *Fig.* ស្ទើរតែ (ឧ. côtoyer le ridicule)

cotret *n.m.* ជាប់ឧសខ្ចីហើយធំល្មម

cottage *n.m.* ផ្ទះតូចនៅស្រុកស្រែ

cotte *n.f.* សំពត់ខិងសម្រាប់ស្រីស្រុកស្រែ (សំពត់ស្ទ្រុប); សំលៀកបំពាក់ធ្វើការ ។ cotte de maille ម.ព. haubert

cotutelle *n.f.* សហាធ្យាបកភាព (ដំណែងរបស់ប្ដីអធ្យាបិកា)

cotuteur, trice *n.* សហាធ្យាបក-បិកា, អធ្យាបក-បិការួម

cotyle *n.f.* រន្ធឆ្អឹងត្រគាកសន្លាក់

cotylédon *n.m.* ពីជបត្ត

cotylédonné,e *a.* ដែលមានពីជបត្ត

cou ឬ **col** *n.m.*ក (ឧ. la girafe a un long cou) ។ *Par ext.* ក (កាជិនចុនខ្វះ) (ឧ. le cou ឬ col d'une bouteille) ។ *Fam.* cou de cigogne, de grue កវែង ។

Loc. fam. jusqu'au cou ត្រឹមក, ដល់ក (ឧ. se mettre dans l'eau jusqu'au cou); *au fig.* être dans la misère jusqu'au cou ក្រលំបាកក្រៃពេក ។ la corde au cou ដាប់ខ្សែនៅក (ជាសញ្ញានៃការចុះចាញ់); *au fig.* វ័ណ្ឌក (អស់សង្ឃឹម) ។ mettre la corde au cou de quelqu'un ម.ព. corde ។ la bride sur le cou លែងបង្ហៀរ ។ prendre quelqu'un par le cou ឆ្កាក ។ tendre le cou ហុចក្បាល (ឲ្យគេវាយសម្លាប់); *au fig.* ចូលខ្លួនទទួលទោស ។ couper le cou កាត់ក ។ tordre le cou កាច់កឲ្យវៀច; មួលក; សម្លាប់ ។ se rompre, se casser le cou បាក់ក (ធ្លោស ឬ ធ្លាក់ស្លាប់) ។ rompre ឬ casser le cou à quelqu'un កាច់ក, សម្លាប់; *au fig.* ធ្វើមិនឲ្យបានសម្រេច; បំផ្លាញ ។ prendre ses jambes à son cou ដាក់រមដាយ (រត់) ។ se jeter ឬ sauter au cou de quelqu'un ស្ទុះទៅឱបក ។ être toujours pendu au cou de quelqu'un ចេះតែឱបតែញយៗ ។

Par anal. le cou d'une bouteille កដប ។ cou d'une cruche កក្អម ។

Poét. cou d'ivoire, de lis, d'albâtre ឬ de neige កស

ខ្ទិចខាន

couac *n.m.* សម្លេងឈ្លើយ

couaille *n.f.* រោមចៀមធុនអន់កាត់ពីកន្ទុយ

couard,e *a.&n.* កំសាក, កម្សាច

couardise *n.f.* សេចក្ដីកំសាក ឬ កម្សាច

couchage *n.m.* ការផ្ដេក; ប្រដាប់ដេក; សយនដ្ឋាន

couchant,e *a.* ដែលដេក ។ chien couchant *Fig.* មនុស្សលុតក្រាប (ម.ព. chien ផង) ។ soleil couchant ព្រះអាទិត្យជិតលិច ។ *n.m.* បច្ឆិមទិស, ទិសខាងលិច ។ *Fig.* ជរាភាព; ភាពចមចយ

couche *n.f. Poét.* គ្រែ (ឧ.être étendu sur sa couche); សំពត់រុំកូនក្មេង; កន្លែងដេក; ជាន់ (ឧ.couche de fruits); ឋានៈ ។ *Géol.* ស្រទាប់ (ឧ. couche d'argile) ។ *Fig.* ប្រភេទ, វណ្ណៈ (ឧ. les couches sociales) ។ *Pop.* en avoir une couche ឆោត, ល្ងង់ ។ *Pl.* ប្រសូតិកម្ម (ការសម្រាលកូន) (ឧ. une femme en couches)

couché,e *a.* ដេក, ទ្រេត (ឧ. écriture couchée) ។ papier couché ក្រដាសរលោង

couchée *n.f.* កន្លែងដេក ឬ សំណាក់

coucher *v.t.* ផ្ដេក (ឧ.coucher un enfant); បន្ទ្រាម (ឧ.les pluies ont couché le riz) ។ *Fig.* coucher sur le carreau សម្លាប់។ កត់(ឧ.coucher sur une liste) ។ coucher en joue តម្រង់ដាក់ ។ បន្ទ្រេត (ឧ. coucher son écriture)។ *v.i.* ដេកយប់ (ឧ.coucher dans une auberge); *au fig.* ប្រថុយខាត(ឧ.il a couché de son reste)។ *Mar.* ផ្អៀង(ឧ. navire qui couche)។ se coucher *v.pr.* ដេក, ក្រាប, ទ្រោម ។ *Fig.* លិច (ឧ. le soleil se couche) ។ *Pop.* envoyer coucher បណ្ដេញ ។ *loc. prov.* coucher dans son fourreau comme l'épée du roi ឬ coucher dans son fourreau ដេកទាំងសំលៀកបំពាក់

coucher *n.m.* ការដេក (ឧ. l'heure du coucher); ដំណេក (ឧ. le coucher sur le côté; un bon coucher) ។ le coucher du

soleil ពេលព្រះអាទិត្យអស្តង្គត

couchette *n.f.* កូនគ្រែ, គ្រែក្នុងនាវា ឬ ក្នុងអយស្ម័យយាន

coucheur,euse *n.* អ្នករួមដំណេក ។ mauvais coucheur មនុស្សដែលគេពិបាកនឹងរួមរស់ជាមួយ

couchis *n.m.* ស្រទាប់ខ្សាច់ដែលគេក្រាលឥដ្ឋពីលើ

couci-couça ឬ **couci-couci** *loc. adv. Fam.* សុខទុក្ខជាធម្មតា (ឧ. comment vous portez-vous ? លោកសុខសប្បាយឬទេ? – couci-couça សុខទុក្ខជាធម្មតា)

coucou *n.m.* ប៉ោលគោក; នាឡិកាឈើ

coude *n.m.* កែងដៃ; មុមជញ្ជាំង; ផ្លូវកែង ។ jouer des coudes កែផ្លូវដោយគះនឹងកែងដៃ ។ lever ឬ hausser le coude ផឹកច្រើន

coudé,e *a.* ដែលបង្កោង (បត់ដូចកែងដៃ)

coudée *n.f.* ហត្ថ (ខ្នាតវាស់ប្រវែងប្រមាណជា ០,៥០ម) ។ *Fig.* avoir ses coudées franches មានសេរីភាពប្រព្រឹត្តតាមចិត្ត

cou-de-pied *n.m.* កជើង (*pl.* des cous de pied)

couder *v.t.* បង្កោង (បត់ដូចកែងដៃ) (ឧ. couder une barre de fer)

coudoiement *n.m.* ការថង, ការបុះ ឬ គប់នឹងកែងដៃ; ការដើរបៀត

coudoyer *v.t.* ថង-បុះ ឬគប់នឹងកែងដៃ; ដើរបៀត (ឧ. on est exposé à coudoyer sans cesse de malhonnêtes gens)

coudre *v.t.* ដេរ ។ machine à coudre ម៉ាស៊ីនដេរ

couenne *n.f.* ស្បែកជ្រូកកោស; ស្បែកក្រាស់ (ដូចស្បែកជ្រូក) ។ *Pop. & fig.* មនុស្សកញ្ចោត; មនុស្សឆ្កួង ។ *Arg.* ស្បែក; សាច់មនុស្ស; ថ្ពាល់ធ្លាក់

couenneux,euse *a.* ដូចស្បែកជ្រូក

couette *n.f.* កន្ទុយតូច (ឧ. la couette d'un lapin)

couic *! int.* សម្លេងព្រាប់សម្រែកសត្វតូចមួយ ។ faire couic ស្លាប់

couiner *v.i. Fam.* ស្រែកតិចៗ

coulage *n.m.* ការហូរ; ការសិតលោហធាតុ; ការកំពប់ ។ *Fig.* ការខ្ជះខ្ជាយ

coulant,e *a.* ដែលហូរ; រអិល (ឧ. style coulant) ។ *Fig.* ស្រួល (ឧ. caractère coulant) ។ nœud coulant អន្ទាក់រូត

coulant *n.m.* រង្វង់អន្ទាក់រូត; ខ្សែរូត

coule *n.f.Pop.* ការខ្ជះខ្ជាយ។ *Fam.* être à la coule មានល្បិចគ្រប់យ៉ាងដើម្បីរកប្រែ

coulée *n.f.* អក្សរជ្រៀង; ការចាក់ពុម្ព; រូបធាតុដែលកំពុងរលាយ; ផ្លូវម្រឹគ

couler *v.i.* ហូរ (ឧ. le Mékong coule vers le sud); ហៀរ,លេច (ឧ.ce tonneau coule); លិច(ឧ. ce vaisseau a coulé à pic); សម្រូត(ឧ. se laisser couler le long d'une corde) ។ *Fig.* កន្លងទៅ (ឧ. les années coulent) ។ couler de source ហូរចេញពីមេះធ្លូង; មានឡើងដោយគប្បីតា (ដោយបណ្ដាលមកពីហេតុដែលមានពីមុនមកហើយ); មានជាក់ស្ដែង ។ *v.t.* ចាក់បង្ហូរ;សិតពុម្ព (ឧ. couler une statue); ពន្លិច (ឧ. couler un bateau); បង្ខូចគ្រឿងប៉ប្រា (ដោយមិនដាក់ខ្លាញ់ ឬ ប្រេង) (ឧ. couler une bielle) ។ *Fig. & fam.* ធ្វើឲ្យវិនាស(ឧ.couler une affaire); បង្ខូចកេរ្តិ៍ឈ្មោះ (ឧ. couler quelqu'un); ហុចឲ្យដោយសម្ងាត់ (ឧ. couler un billet) ។ se couler *v.pr.* បន្ទូល

couleur *n.f.* ពណ៌,សម្បុរ (ឧ. avoir de belles couleurs); ថ្នាំពណ៌ (វត្ថុធាតុមានពណ៌) (ឧ. broyer des couleurs) ។ linge de couleur សម្លៀកបំពាក់ពណ៌ ។ *Fig.* អាការៈល្អ(ឧ.peindre l'avenir sous de belles couleurs); ពន្លឺ (ឧ.description pleine de couleur)។ *Fam.* សំដីភូតភរ (ឧ. conter des couleurs) ។ la couleur d'un journal ពណ៌នៃកាសែត (លក្ខណៈនៃមតិ) ។ couleur politique ពណ៌នយោបាយ។ changer de couleur ផ្លាស់ទឹកមុខ (ឡើងស្លាំង ឬ ឡើងមុខក្រហម) ។ homme de couleur ជនស្បែកខ្មៅ (ក្រៅពីពួកជាតិស្បែកស)។ *Fam.* en faire voir à quelqu'un de toutes les couleurs ធ្វើទុក្ខបុកម្នេញ ។ couleur locale ម.ព. local។ *Pl.* ពណ៌ទង់ជាតិ (ឧ. les couleurs nationales); ទង់ជាតិ (ឧ. hisser les couleurs) ។ sous couleur de *loc. pré.* ដោយអាងលេសថា (ឧ. sous couleur de se défendre)

couleuvre *n.f.* ពស់សម្លាប់កង្កែប ។ *Fig.* avaler des couleuvres លេបថ្មលេបក្រួស

couleuvreau *n.m.* កូនពស់សម្លាប់កង្កែប

couleuvrine *n.f.* កាំភ្លើងធំជាន់ដើម

coulis *n.m.* ទឹកជម្រង់សាច់-ត្រី ឬ បន្លែ (ឧ.coulis d'écrevisse); ជាយអស៊ីម៉ង់ ឬ កំបោរ ។ *a.* vent coulis ខ្យល់ដែលចូលតាមប្រហោង

coulissant,e *a.* ដែលរអិលតាមចង្អូររអិល (ឧ. porte coulissante)

coulisse *n.f.* ចង្អូររអិល (ឧ. porte à coulisse); ឆាកល្ខោន ។ *Fig.* ឆាក (រឿងសម្ងាត់) (ឧ. les coulisses de la politique) ។ se tenir dans la coulisse មិនចេញមុខ ។ *Fam.* yeux en coulisse, regards en coulisse ការមើលដោយកន្ទុយភ្នែក; ការមត់គ្នាដោយមិចភ្នែក; ការសម្លឹងដោយស្នេហា

coulissé,e *a.* ដែលមានចង្អូររអិល

coulisseau *n.m.* ចង្អូររអិលតូច;អណ្តាតរអិលក្នុងចង្អូរ

coulissement *n.m.* ការរអិលក្នុងចង្អូរ

coulisser *v.t.* ដាក់ចង្អូររអិល (ឧ.coulisser un tiroir) ។ *v.i.* រអិល (ឧ. porte qui coulisse facilement)

couloir *n.m.* របៀង; ខ្សែបន្ទាត់ (ក្នុងកីឡដ្ឋាន)

couloire *n.f.* ឆ្នាំងចម្រោះ(ធ្វើឲ្យស្រក់ទឹក)

coulpe *n.f.* កំហុស,បាប។ battre sa coulpe សំដែងសេចក្តីស្តាយក្រោយ

coulure *n.f.* លោហធាតុដែលហៀរពីមាត់ពុម្ព

coup *n.m.* ការប៉ះទង្គិច, ការវាយ, ការកាប់ ឬ ចាក់ ។ coup de pied ការទាត់ ឬ ធាក់ ។ coup de poing ការដាល់ ។ coup d'épée ការកាប់ ឬ ចាក់ដោយដាវ ។ coup de bâton ការវាយដោយដំបង ។ porter, asséner un coup វាយ, កាប់ ឬ ចាក់ ។ recevoir un coup ត្រូវគេវាយ-កាប់ ឬ ចាក់ ។ parer un coup កាត់ ឬ រង (ដាវ ឬ ដំបង) ។ se donner un coup contre un arbre ជល់នឹងដើមឈើ ។ frapper à coups redoublés វាយច្រើន, វាយហើយវាយទៀត ។ *Fig.* coup du ciel ភ័ព្វល្អ ។ coup dur កិច្ចពិបាក; គ្រោះកាច ។ les coups du

sort ភ័ព្វអាក្រក់ ។ porter un coup terrible à ... ធ្វើឲ្យមានការលំបាកខ្លាំងណាស់... ។ *Par ext.* ស្នាមរបួស (ឧ. avoir des coups bleux sur tout le corps; tomber percé de coups) ។ *Part.* ណាត់ (ការបាញ់កាំភ្លើង) ។ ស្នូររបស់អ្វី ៗ ដែលគេវាយ (ឧ. coup de cloche, de tambour) ។ ម៉ោង(ម៉ោងដែលនាឡិកាកំពុងវាយ)(ឧ. au coup de midi); ស្នូរ (ឧ. coup de tonnerre; coup de fouet)។ jeter un coup d'œil sur quelqu'un ក្រឡេកមើលមួយភ្លែត។

Fig. ការវាយប្រហារយ៉ាងខ្លាំង (ឧ. frapper un coup décisif) ។ manquer son coup ការខកមិនបានសម្រេច ។ ឱកាស(ឧ.c'est ce coup qu'il est bon de partir, mes enfants) ។

Arg. &Pop. coup de casserole ការបរិហារ ។ coup de fourchette ការលួចឆក់ដោយម្រាមដៃពីរ (ម.ព. fourchette ផង) ។ coup de vague ការលួចតាមតែប្រទះ ។ coup de Raguse ការក្បត់។ coup de torchon ការប្រជាល់គ្នា។ coup de lapin ការប្រើស្នៀតខូចក្នុងពេលប្រឡូក; *fig.* donner à quelqu'un le coup de lapin បង្អើយក្នុងការបំផ្លាញ ។ *Constr.* faire coup ឬ prendre coup ប្រេត(ផញ្ចាំង)។ *Jeux* ក្ដារឬដៃ(លេងមួយក្ដារ ឬ លេងមួយដៃ)

Loc. div. coup d'air រោគត្រូវខ្យល់ ។ coup de butoir សំដីសំកសៀត ។ coup de chapeau ការបើកមួកគំនាប់។coup de chien ការលួចប្រព្រឹត្តអំពើអាក្រក់; ចលាចល (ឧ. je ne serais pas étonné qu'il y eût un coup de chien l'année prochaine) ។ coup de dent ការស៊ី។ coup double លទ្ធផលទ្វេ (ដូចជាបាញ់មួយកាំភ្លើងបានសត្វពីរ)។ faire d'une pierre deux coups ធ្វើតែម្ដងបានលទ្ធផលទ្វេ (សភាសិតអង់គ្លេសថា: បាញ់មួយកាំភ្លើងបានសត្វពីរ) ។ coup dans l'eau ឬ coup d'épée dans l'eau ការធ្វើឥតបានផល (ម.ព. eau ផង) ។ coup

d'épingle ការចាក់ដោយម្ជុល; *au fig.* ការអន់ចិត្តបន្តិចបន្តួច ។ coup d'essai ការល្បង។coup de sang ជម្ងឺឈាមហូរចាល់ក្នុងខួរ ។coup de soleil សុរិយរោគ (រោគត្រូវកំដៅព្រះអាទិត្យ) ។

*Par ext.*coup de l'étrier ការផឹកមុនឡើងជិះសេះ ។ coup de feu ការបាញ់កាំភ្លើង។*Cuis.* ដំណើរភ្លើងពេលខ្លាច ។ *Pop.* ភាពស្រវឹង។ coup de filet ការបង់សំណាញ់; ត្រីបានក្នុងមួយសំណាញ់ (ឧ. acheter un coup de filet);*au fig.* & *fam.* វិធានការប៉ូលិសដែលចាប់មនុស្សច្រើនក្នុងមួយលើក(ឧ. bande prise d'un coup de filet)។ *Fig.* coup de fouet ការជួយចូកចែវ (ឧ. entreprise qui a besoin d'un coup de fouet)។ coup de fusil ម្ហូបមិនឆ្ងាញ់ហើយថ្លៃ ។ coup de grâce ការបង្ហើយ (វាយ ឬ កាប់ថែមឲ្យស្លាប់) ។ coup de main ការវាយប្រហារដោយឆ្មក់ ហើយគ្មានប្រដាប់គ្រប់គ្រាន់; ប្រតិបត្តិការដោយក្លាហានហើយដោយរហ័ស; ការជួយ (ជួយដៃមួយជើង) (ថា coup d'épaule ក៏បាន) ។ coup de maître អ្វីៗដែលធ្វើបានសម្រេចផលល្អ ។ avoir un coup de marteau ឬ un coup de hache ឆ្កួត ។ coup monté ព្រឹត្តិការណ៍រៀបចំទុកមុន ។ monter le coup បំភាន់ ។ *Fam.* se monter le coup បំភាន់ខ្លួនឯង ។ tenir le coup ទប់ទល់, អត់ធន់ ។ coup de la mort របួស ឬ ហេតុនាំឲ្យស្លាប់; *au fig.* ហេតុនៃបរាជ័យ ឬ នៃការវិនាស (ដែលមិនអាចកែបាន)។ coup d'œil ការក្រឡេកមើល;ការពិនិត្យយ៉ាងរហ័ស; ការគ្រួតមើលតែមួយភ្លែត (ឧ. donner un coup d'œil à un travail); បញ្ញាឆាប់យល់ ឬ ឆាប់វិនិច្ឆ័យបាន (ឧ. avoir le coup d'œil juste, sùr; avoir du coup d'œil) ។

Pop. ការប្រវាយបោចសក់គ្នា។ coup de pied ការដើរ (ឧ.donner un coup de pied jusqu'à . . .); *au fig.* ការមិនបានសម្រេច; គ្រោះថ្នាក់ ។ faire le coup de poing ប្រដាល់គ្នា; *au fig.* coup de poing de la fin អ្វីៗដែលគេ

រៀបចំឲ្យបានសម្រេចនៅពេលបញ្ចប់ ។ coup de tête ការធ្វើដោយគ្មានគិត។ *Fig.* coup de tonnerre ឬ coup de foudre ព្រឹត្តិការណ៍កេក្រក់ដែលមានឡើងភ្លាមៗ (ហាក់ដូចជាផ្ទះបាញ់) (ឬ coup de massue ក៏បាន); ការជាប់ចិត្តស្នេហាភ្លាមៗ ។ porter coup វាយ,កាប់ឬចាក់;បានដូចបំណង ។ faire les cent coups, les quatre ឬ les cinq cents coups ធ្វើគ្រងគាង; ប្រព្រឹត្តអនាចារ ។ être aux cent coups នៅមិនមាំង ។ mettre aux cent coups ធ្វើឲ្យមិនមាំង ។ n'être pas sujet au coup de cloche ឬ au coup de marteau មានពេលច្រើន,មិនបាច់ប្រញាប់ (មិនបាច់ស្ដាប់សូរខ្លួងឡើយ)។ sans coup férir ដោយមិនបាច់បាញ់មួយគ្រាប់, ដោយមិនបាច់វាយគ្នា; ដោយស្រួល ។ rabattre les coups សម្រុះសម្រួល (អ្នកដែលអាក់អន់ចិត្តនឹងគ្នា) ។ tout coup veille ទុកជាមានហេតុអ្វីក៏ដោយ ។ le donner à quelqu'un en trois coups ឬ en six coups ភ្នាល់ឲ្យគេធ្វើបីនឹងឬប្រាំមួយដង ។ boire un coup លង់ទឹក,រឺះលង់ទឹក។ coup d'Etat រដ្ឋប្រហារ ។ coup de force ពលប្រហារ។coup de théâtre ប្រវត្តិប្រហារ, ការប្រែប្រួលភ្លាមៗក្នុងស្ថានការណ៍ ។ coup de pouce ម.ព. pouce ។

N.m. pl. ការវាយគ្នា (ឧ. en venir aux coups); ការប្រយុទ្ធគ្នា (ឧ. la diplomatie ne se tait que lorsque les coups empèchent qu'on l'entendent)។

Loc.div être secret comme un coup de canon ឬ comme un coup de tonnerre ស្ងាត់ដូចផ្ទះទាំងប្រាំពីរ; មាត់ជាចណាស់ (មិនចេះលាក់អាថ៌កំបាំងសោះ) ។

Loc. adv. tout à coup មួយរំពេច.ស្រាប់តែ។tout d'un coup តែម្ដង, ភ្លាមៗ (ឧ. personne ne devient scélérat tout d'un coup)។ à tout coup រាល់ពេល។ à coup sûr ប្រាកដ។ coup sur coup បន្តគ្នា។après coup ក្រោយមកហើយ (ហួសពេលទៅហើយ) (ឧ.

s'aviser après coup de ce qu'il aurait fallu faire) ។ pour le coup ឬ à ce coup ម្ដងនេះ (ឧ. pour le coup ឬ à ce coup, vous ne m'échapperez pas!) ។ encore un coup ម្ដងទៀត (ឧ. essayez encore un coup!) ។ sous le coup ស្រឡាំងកាំង (ឧ. il était resté sous le coup, ne pouvant dire ni oui ni non) ។

Loc. pré. sous le coup de ក្រោមអំណាចនៃ,ក្រោមការគំរាមនៃ(ឧ.être sous le coup d'une saisie, d'une saisie mobilière) ។ à coups de (ភាយ ឬ ប្រហារ) ដោយ (ឧ. à coups de canon; à coups de fusil); ដោយប្រើ(ឧ. traduire un texte à coups de dictionnaire) ។ casser le nez à quelqu'un à coups d'encensoir សរសើរខ្លាំងពេកនៅចំពោះមុខ ។

Allus. hist. coup de Jarnac ឬ coup du commandant ការប្រហារដោយកលល្បិច(ឧ. គេស្រែកថា «ប៉ូលិស!»ហើយនៅពេលដែលគូសត្រូវងាកមុខចេញ គេលួចចាក់ពីក្រោយ) ។ le coup de pied de l'âne ការប្រមាថអ្នកដែលគេលែងគោរព(ដូចលាធាក់សិង្ហកញ្ចាស់ក្នុងរឿងល្បើករបស់ ឡាហ្វុងតែន) ។

Dr. pén. coups et blessures អំពើឈ្លានពាន

coupable *a.* ពិរុទ្ធិក, ដែលមានទោស; ដែលធ្វើខុស,គួរបន្ទោស,គួរដាក់ទណ្ឌកម្ម (ឧ. faiblesse coupable)។ *n.* ពិរុទ្ធិកជន (អ្នកមានពិរុទ្ធ)

coupage *n.m.* ការកាត់;ការលាយស្រាច្រើនមុខ ; ការលាយទឹក (ដើម្បីឲ្យខ្សោយ)

coupailler *v.t.* កាត់រខិញរខុញ

coupant,e *a.* មុត ។ *Fig.*កម្បុត(សំដី) (ឧ. un ton coupant) ។ *n.m.* មុខ(កាំបិត)(ឧ.le coupant d'une lame)

coup-de-poing *n.m.* កាំភ្លើងដៃតូច; ផ្លែស្វានដែកមួយបែប; ស្នាប់ដៃ (*pl.* des coups-de-poing)

coupe *n.f.* កែវផឹក(កែវបែបនេះមានមាត់ធំហើយរាក់); អ្វីៗដែលដាក់ក្នុងកែវផឹក (ឧ. coupe de champagne);

ពានរង្វាន់(រង្វាន់នៃការប្រជែងក្នុងកីឡា); ការប្រជែងយកពានរង្វាន់ (ក្នុងកីឡា) ។ *Fig.* ប្រភព ។ *Prov.* il y a loin de la coupe aux lèvres ពីសេចក្ដីសង្ឃឹមទៅសេចក្ដីសម្រេចនៅមានការលំបាកច្រើន

coupe *n.f.* ការកាត់ ឬ កាប់ (ឧ. la coupe des cheveux); ព្រៃគុប (ព្រៃដែលបើកឲ្យកាប់ឈើ) ។ coupe claire ការកាប់រំលស់ (កាប់ឈើអស់ច្រើន) ។ coupe sombre ការកាប់ឡោលៗ (កាប់ទុកឲ្យនៅសល់ឈើច្រើន); *au fig.* រំលស់ច្រើន, បំបាត់ច្រើន ។ ការ ឬ របៀបកាត់សំលៀកបំពាក់(ឧ. coupe élégante d'un habit); កំណាត់ (របស់ដែលគេកាត់) (ឧ. une coupe d'étoffe); សិល្បៈកាត់ថ្ម ។ *Jeux* ការកាប់(បៀ) ។ être sous la coupe de quelqu'un នៅក្រោមចំណុះ ។ mettre en coupe réglée ដកហូតយកច្រើនអំពីជន ឬ ក្រុមណាមួយ

coupé *n.m.* គូប៉េ, រថកង់បួនសម្រាប់ជិះពីរនាក់; ថ្នាក់មុខនៃរទេះសេះ; ចង្វាក់រាំ

coupe-cigares *n.m.inv.* ប្រដាប់កាត់កន្ទុយសីហ្គារ

coupe-circuit *n.m.inv.* ខ្សែសំណប្រើក្នុងគ្រឿងអគ្គិសនី

coupe-coupe *n.m. inv.* កាំបិតផ្គាក់ (សម្រាប់ឆ្ការព្រៃ)

coupée *n.f. Mar.* ច្រកលើស្នូកនាវា (សម្រាប់ចូល ឬ ចេញដោយឡើង ឬ ចុះតាមខ្សែ)

coupe-feu *n.m. inv.* របាំងភ្លើង (គ្រឿងធ្វើជាជញ្ជាំង ឬ ច្រលងការពារកុំឲ្យភ្លើងរាលឆេះព្រៃ)

coupe-file *n.m. inv.* ប័ណ្ណកាត់ផ្លូវ (ប័ណ្ណប្រគល់អំណាចឲ្យរថយន្តណាមួយទៅមុនគេ)

coupe-gorge *n.m.* ចោរកន្តារ (កន្លែងមានពួកចោរស្កាត់)

coupe-jarret *n.m.* ចោរប្លន់ ។ *Fig.* មនុស្សកំណាច (*pl.* des coupe-jarrets)

coupe-légumes *n.m. inv.* កាំបិតឆ្លាក់បន្លែ

coupelle *n.f.* កែវដឹកតូច

coupement *n.m.* ការកាត់; ផ្លូវកាត់គ្នា (អយស្ម័យយាន)

coupe-ongles *n.m. inv.* កាំបិតកាត់ក្រចក

coupe-papier *n.m. inv.* កាំបិតកាត់

ក្រដាស (ធ្វើអំពីឈើ, ឆ្អឹង, ស្នែង។ល។)

coupe-pâte *n.m.inv.* កាំបិតកាត់ម្សៅ (ធ្វើនំបុ័ង)

couper *v.t.* កាត់ (ឧ. couper du pain); កាប់; ក្រៀក; ច្រិប; កាត់សំលៀកបំពាក់ (ឧ. couper une robe); លាយទឹក (ស្រា) (ឧ. couper du vin); ផ្ដាច់ (ឧ. couper un pont, une communication téléphonique); កាត់ (ទៅបណ្ដោយ ឬ ទទឹង) (ឧ. la route qui coupe une autre); កាត់ចោល (ដកចោល, បំបាត់ចោល) (ឧ. couper les passages d'un manuscrit); ស្កាត់, ស្ទាក់ (ឧ. couper la retraite)។ couper les vivres ផ្ដាច់ស្បៀង; *au fig.* លែងជួយ ។ *v.i.* មុត (ឧ. ce couteau coupe bien); កាប់បៀ (ឧ. couper les cartes); ដើរកាត់ (ឧ. couper à travers champs)។ *Fam.* គេច (ឧ. couper à une corvée) ។ couper court à បញ្ឈប់ (ម.ព. court ផង)។ se couper *v.pr.* មុត (ធ្វើឲ្យមានរបួសខ្លួនឯង) (ឧ. il s'est coupé le doigt) ។ *Fig. & fam.* និយាយផ្ទាន់កែងឯង (ឧ. le menteur se coupe sans cesse)

coupe-racines *n.m. inv.* កាំបិតហាន់ឫស (ដើម្បីឲ្យជាចំណីសត្វ)

couperose *n.f.* ក្រហមមុខ

couperosé,e *a.* ដែលឡើងក្រហម(មុខ) (ឧ. visage couperosé)

couperet *n.m.* កាំបិតផាង; កាំបិតម៉ាស៊ីនកាត់ក

coupeur,euse *n.* ជាងកន្ត្រៃ (កាត់សំលៀកបំពាក់ ឬ ស្បែកជើង) ។ *Fam.* coupeur de bourses ចោរប៉ិនប្រសប់

couplage *n.m.* ការផ្គុំគ្រឿងម៉ាស៊ីន; ការដាក់ឲ្យគ្រឿងម៉ាស៊ីនដើរស្មើគ្នា

couple *n.f.* គូ (របស់ពីរដូចគ្នា) (ឧ. une couple d'œufs); ខ្សែចងភ្ជាប់គ្នា (ឧ. la couple des chiens de chasse)

couple *n.m.* គូ, ជនពីរនាក់ដែលស្រឡាញ់រាប់អានគ្នា (ឧ. un couple d'amis, de fripons); គូ (ឈ្មោលញី) (ឧ. un couple de pigeons)។ *Méc.* មិថុនា

couplement *n.m.* ការភ្ជាប់; ការផ្គុំ; ភាពជាប់គ្នា, ភាពផ្គុំហើយ

coupleur *n.m.* ប្រដាប់ភ្ជាក់ភ្ជួរ (ឧ. un coupleur hydrolique)

coupler *v.t.* ភ្ជាក់ភ្ជួ ។ coupler un train de bois ចង (ភ្ជុំ) ក្បូនឈើ

couplet *n.m.* ឃ្លាចម្រៀង(ឧ. chanson de dix couplets); ចម្រៀង

coupoir *n.m.* ប្រដាប់កាត់វត្ថុរឹង

coupole *n.f.* ដោម,ដំបូលមូល។*Fam.* បណ្ឌិតសភាបារាំង (ឧ. être reçu sous la coupole)

coupon *n.m.* កំណាត់សំពត់(សល់ពីដាប់ ឬ កី) (ឧ. coupon de soie); ខណ្ឌប័ណ្ណ ។ *Théât.* ប័ណ្ណចូល ។ coupon-réponse postal ប័ណ្ណឆ្លើយនៃប្រៃសណីយ

coupure *n.f.* ស្នាមមុត ។ *Fig.* ការកាត់ភាគខ្លះចោល (ក្នុងសៀវភៅ, ភាពយន្ត); សេចក្ដីស្រង់នៃអត្ថបទកាសែត; ការផ្ដាច់ (ឧ. coupure entre le présent et le passé; coupure de courant électrique); ធនប័ត្រ (តិចជាង ១.០០០ ក្រណោត)

cour *n.f.* លាន,ធ្លា(ឧ. la cour d'un hôtel, d'une ferme)។ basse-cour ម.ព.នេះ ។ cour d'honneur ធ្លាកិត្តិយស (ធ្លាល្អបំផុតនៅមុខប្រាសាទ)(ឧ. la cour d'honneur du palais de Fontainebleau)។ ព្រះរាជវាំង; ក្រុមព្រះរាជបរិពារជាន់ខ្ពស់ (ឧ. la cour de François 1er fut très brillante; avoir une charge à la cour); រាជវន្ទាភិបាល (ចំពោះនយោបាយក្រៅប្រទេស) (ឧ. la cour de Londres, de Vienne) ។

Par anal. ក្រុមបរិវារ (ឧ. tout homme riche est sûr d'avoir une cour; cette femme a toute une cour auprès d'elle); ការផ្គាប់ផ្គុន (ឧ. faire sa cour au prince, à son patron); របៀបក្នុងព្រះរាជវាំង(ឧ. vous êtes peu du monde et savez mal la cour) ។

Dr. សាលាតុលាការជាន់ខ្ពស់ ។ cour d'appel សាលាឧទ្ធរណ៍ [អ៊ុត-ទ] ។ cour d'assises សាលាឧក្រិដ្ឋ ។ cour de cassation សាលាវិនិច្ឆ័យ ។ cour martiale សាលាយុទ្ធតុលាការ, សាលាតុលាការអាជ្ញាសឹក ។ cour des comptes តុលាការគណនី។ បៅក្រុម

(តុលាការជាន់ខ្ពស់) (ឧ. la cour se retire pour délibérer) ។

Hist. cour plénière ការជំនុំអ៊ុកធឹក (ទំនៀមទម្លាប់មហាក្សត្រជាន់ដើម) ។ *Fam.* avoir ឬ tenir cour plénière ប្រជុំគ្នាច្រើន ។

Loc.div. homme, femme de la cour ឬ gens de la cour ព្រះរាជបរិពារ ។ homme, femme ឬ gens de cour អ្នកចេះរបៀបក្នុងព្រះរាជវាំង ។ amitié de cour មិត្តភាពក្លែង ។ ami de cour មិត្តក្លែង (សំដែងមិត្តភាពតែខាងក្រៅ) ។ être bien en cour កំពុងតែគាប់ ។ être mal en cour កំពុងតែមិនគាប់ ឬ កំពុងតែទាស់ ។ faire sa cour ឬ faire la cour à ឬ auprès de ផ្គាប់ផ្គុន (ឧ. tout le monde en France fait sa cour) ។

Cour céleste ឋានសួគ៌, អាទិទេពនឹងទេវតាទាំងឡាយ ។

Allus.hist. la cour du roi Pétaud ផ្ទះដែលគ្មានអ្នកណាស្ដាប់បង្គាប់អ្នកណា

courage *n.m.* សេចក្ដីក្លាហាន, ចិត្តមុត; សេចក្ដីក្លៀវក្លា (ឧ. travailler avec courage) ។ *Fig.* ចិត្តរឹង, ចិត្តដាច់មេត្តា (ឧ. avez-vous le courage de refuser l'aumone?) ។ prendre son courage à deux mains ខំប្រឹង (កាត់ចិត្ត) ។ *int.* courage ! ខំប្រឹងឡើង!

courageusement *adv.* យ៉ាងក្លាហាន

courageux,euse *a.&n.* ក្លាហាន (ឧ. réponse courageuse)

courailler *v.i.* ដើរទៅខាងនេះបន្តិចខាងនោះបន្តិច

couramment *adv.* យ៉ាងថ្នឹក, យ៉ាងរហ័ស, ស្រួល (ឧ. lire, écrire couramment); ជាធម្មតា, ជាហូរហែបក (ឧ. on dit couramment que...)

courant,e *a.* ចរន្ត; ដែលប្រដេញ (ឧ. une chienne courante); ដែលហូរ (ឧ. eau courante); រហ័ស ។ écriture courante អក្សរធម្មតា (ដែលសរសេរបានរហ័ស) ។ lecture courante ការអានរត់មាត់ ។ mois courant ខែនេះ (ដែលកំពុងតែប្រព្រឹត្តទៅ) ។ *Par ext.* ធម្មតា (ឧ. dépenses courantes; langage

courant) ។ *Fig.* affaires courantesការកិច្ចធម្មតា។ compte courant គ.ម. compte ។ prix courant តម្លៃធម្មតា ។ monnaie courante រូបិយវត្ថុ ឬ ប្រាក់ដែលគេចាយជាធម្មតា; *au fig.* របស់ធម្មតា (ដែលធ្លាប់តែមានមកហូរហែ) ។ main courante សៀវភៅកំណត់ដៃ (ម.ព. brouillard ផង); បង្កាន់ដៃជណ្ដើរ

courant *n.m.* ចរន្ត [ច:-រ៉ន់] (ខ្សែទឹកដែលហូរ ឧ. suivre le courant d'un fleuve; ខ្សែខ្សាច់ដែលបក់) ។ courant marin ចរន្តសមុទ្រ (ឧ. le Gulf Stream est un courant marin) ។ courant de marées ចរន្តទឹកជោរនាច ។ courant électrique ចរន្តអគ្គិសនី ។ courant continu តរន្តសន្តតិ ។ courant alternatif ចរន្តអសន្តតិ ។ courant polyphasé ចរន្តពហុវិស្សមាន ។ *Fig.* courant d'idées ចរន្តនៃគំនិត ។ les courants de la population ចរន្តនៃប្រជាជន(ដំណើរពីកន្លែងមួយទៅកន្លែងមួយ) ។ le courant de l'histoire ចរន្តនៃប្រវត្តិសាស្ត្រ។ dans le courant du mois ក្នុងខែ ។ au courant *loc.adv.* ហើយត្រឹមត្រូវ (ឧ.un bon teneur de livres doit toujours être au courant) ។ être au courant de ដឹង ។ être au courant ថ្មីក ។ tenir ឬ mettre au courant ប្រាប់ឲ្យដឹង

courante *n.f.* អក្សរច្រៀង (អក្សរធម្មតា) ។ *Fam.* រាគចុះរាក

courbache *n.f.* រំពាត់

courbatu,e *a.* ដែលឈឺចុកដៃជើង;ហត់ណាស់ (ឧ. il est rentré tout courbattu)

courbature *n.f.* ជម្ងឺចុកដៃជើង

courbaturé,e *a.* ហត់ណាស់

courbaturer *v.t.* ធ្វើឲ្យឈឺចុកដៃជើង។ *Par ext.* ធ្វើឲ្យហត់ខ្លាំង (ឧ. une marche trop longue courbature le corps)

courbe *a.* កោង ។ ligne courbe បន្ទាត់កោង

courbement *n.m.* ការពត់ឲ្យកោង;ការបង្អោន (ឧ. le courbement du bois)

courber *v.t.* ពត់ឲ្យកោង,ធ្វើឲ្យទោរទន់ (ឧ. l'âge courbe la taille); បង្អោន (ឧ. courber la tête)។ *v.i.* ឡើងកោង; ទោរទន់ (ឧ. il courbe sous le fardeau)។ se courber *v.pr.* ឡើងកោង, ទោរទន់ (ឧ. les arbres se courbent sous le poids des fruits); ឱន (ឧ. il se courba pour le saluer)។ *Fig.* បន្ទាបខ្លួន; ចុះចាញ់

courbette *n.f.* ដំណើរសេះចំប្រាវតិចៗ។ *Fig.n.f.pl.* ការលុតក្រាប (ឧ. faire des courbettes)

courbure *n.f.* ភាពកោង។ double courbure ភាពកោងចុងទាំងពីរដូចអក្សរ "S"

courcailler *v.i.* ម.ព. carcailler

courcaillet *n.m.* សំឡេងរ៉ុត (ក្រួច)

courette *n.f.* ធ្លាតូច

coureur,euse *n.* អ្នករត់ (ឧ. bon coureur); អ្នកប្រណាំង (ឧ. coureur cycliste); សេះប្រណាំង; អ្នករត់សំបុត្រ។ coureur de អ្នកទៅកាន់កន្លែងណាមួយរឿយៗ (ឧ. coureur de bals)។ coureur de cafés អ្នកចូលចិត្តចូលតៀមកាហ្វេ។ អ្នកស្វែង (ឧ. coureur de places អ្នកស្វែងរកកន្លែងធ្វើការ)។ មនុស្សខិល (ឧ. un coureur de filles)។ *n.m.pl.* ធាវកៈ [ធា-វ:-ក:] (ដែលរត់លឿន)។ *a.* oiseau coureur ធាវកបក្សី (បក្សីដែលរត់លឿន)

courge *n.f.* ល្ពៅ។ courge blanche ឬ cireuse ត្រឡាច

courir *v.i.* រត់ (ឧ. l'autruche court très vite); រត់ប្រណាំង (ឧ. ce cheval ne court pas aujourd'hui)។ courir à រត់ចូល (ឧ. courir au secours de quelqu'un)។ *Fig.* កន្លងទៅ (ឧ. le temps court); ឮសុសសាយ (ឧ. un bruit court); កំពុងប្រព្រឹត្តទៅ (ឧ. le mois qui court)។ le temps qui court ពេលបច្ចុប្បន្ននេះ; លាតសន្ធឹងតាមបណ្ដោយ ឬ ក្នុងបន្លោះ (ឧ. route qui court parmi les vignes)។ courir après ដេញតាម (ឧ. courir après un voleur); *au fig.* ស្វែងរក, ប្រាថ្នា (ឧ. courir après la

fortune, les honneurs) ។ *v.t.*ដេញ (ឧ. courir le cerf); រត់ប្រណាំង (ឧ. courir un cent mètres); ដើរស្វែង (ឧ. courir les places); ដើរកាត់ (ឧ. courir les champs) ។ ទៅរឿយៗ (ឧ. courir les salons) ។ courir un danger មានគ្រោះថ្នាក់ ។ ចចើងចង់បាន (ឧ. courir les honneurs) ។ *Fig.* courir les rues មានគេនឹងឮសុសសាយ; ជារបស់សាមញ្ញ ។ courir deux lièvres à la fois ជាប់ធ្វើការពីរមុខតែម្តង

couronne *n.f.* កម្រងផ្កា ឬ ស្លឹក (ឧ. couronne de laurier); មកុដ (ឧ. la couronne de fer était celle des rois lombards); ក្រជ (ឧ. couronne mortuaire ក្រជមរណៈ); វណ្ណផែក (ឧ. la couronne d'un cabestan); ឆ្លាក់ (រូបយន្ត) ។ *Fig.* រង្វាន់ (ឧ. couronne académique); រាជសម្បត្តិ (ឧ. abdiquer la couronne); កិត្តិស័ព្ទ (ឧ. la couronne du martyre) ។ couronne d'épines ទុក្ខវេទនាខ្លាំង ។ *Math.* couronne circulaire ហោមមណ្ឌល ។ couronne d'une dent តួធ្មេញ ។ ធ្មេញមាស

couronné,e *a.* ដែលទទួលមកុដឬកម្រងផ្កា; ដែលទទួលរង្វាន់; ព័ទ្ធជុំវិញ (ឧ. tour couronnée de feu) ។ tête couronnée មហាក្សត្រសោយរាជ្យ ។ cheval couronné សេះដែលធ្លាក់រលាត់ក្បាលជង្គង់

couronnement *n.m.* ពិធីអភិសេក; ផ្នែកខាងលើ (នៃផ្ទះ, តុ, ទូ ។ល។) ។ *Fig.* ការបញ្ចប់ (ឧ. le couronnement d'une carrière)

couronner *v.t.* បំពាក់កម្រងលើក្បាល (ឧ. couronner de fleurs); បំពាក់មកុដ, អភិសេក (ឧ. couronner un empereur); ពទ្ធជុំវិញ (ហើយឋិតនៅទីខ្ពស់) (ឧ. les montagnes couronnent la ville); ជាផ្នែកខាងលើនៃគ្រឹះស្ថាន ។ *Fig.* លើកដំកើង (ឧ. couronner la vertu); ឲ្យរង្វាន់ (ឧ. couronner un ouvrage); ជារង្វាន់នៃ (ឧ. le succès a couronné son entreprise) ។ se couronner *v.pr.* ពាក់មកុដ; ឡើងសោយរាជ្យ ។

les arbres se couronnent de fleurs ដើមឈើមានផ្កាពាសពេញ(ដូចពាក់មកុដលើក្បាល) ។ *Art vétér.* របួសក្បាលជង្គង់ (សេះ)

courre *v.t.* ដេញ (ឧ. courre un cerf) ។ chasse à courre ការប្រដេញសត្វ ។ *v.i.* ប្រដេញ

courrier *n.m.* ហារ័យ, គូរីយេរ (មនុស្ស ឬយានដឹកនាំសំបុត្រ;ការដឹកនាំសំបុត្រ; សំបុត្រផ្ញើយផ្លូង) ។ courrier convoyeur អនុគមន៍ហារ័យ

courriériste *n.m.* អ្នកនិពន្ធហារ័យ (កាសែត)

courroie *n.f.* ព្រ័ត្រ; ខ្សែពាន

courroucer *v.t.* ធ្វើឲ្យក្រោធ ។ se courroucer *v.pr.* ក្រោធ (ប្រើតែក្នុងពាក្យកាព្យ)

courroux *n.m.* ក្រោធ (ឧ. apaiser le courroux d'un père) ។ *Fig.* le courroux de la mer សមុទ្រដែលមានរលកខ្លាំង

cours *n.m.* ខ្សែទឹក (ឧ. le cours du Mékong) ។ *Ens.* សិក្ខាប័ន ។ chargé de cours សិក្ខាប័នធារី (ម.ព. chargé ផង) ។ វិជ្ជាសិក្សា, វិជ្ជាបង្រៀន ។ cours du soir វិជ្ជាបង្រៀនពេលល្ងាច ។ ថ្នាក់វិជ្ជា ។ cours enfantin កុមារដ្ឋាន ។ cours préparatoire បរិវ្ឌនដ្ឋាន ។ cours élémentaire អាទិកដ្ឋាន ។ cours moyen 1ère année មធ្យមដ្ឋានឆ្នាំទី១ ។ cours moyen 2e année មធ្យមដ្ឋានឆ្នាំទី ២ ។ cours supérieur ឧត្តមដ្ឋាន ។

Com. តម្លៃហាងឆេង (ឧ. acheter cinq cents balles de café au cours du jour); តម្លៃ (ឧ. signature qui n'a pas cours sur la place de Phnom-Penh) ។

Géogr. cours d'eau ជលមាគ៌ា,ភរិបថ,ផ្លូវទឹក ។ cours inférieur ដងក្រោម។ cours moyen ដងកណ្ដាល ។ cours supérieur ដងលើ ។

Astr. ដំណើរ (ឧ. cours de la lune, du soleil) ។

ឧទ្យាន (សួនមានដាំដើមឈើសម្រាប់សាធារណជនដើរលេងកំសាន្ត)។ voyage au long cours ដំណើរទៅប្រទេសឆ្ងាយ ។

Fig. ដំណើរ(ឧ.le cours des saisons);កំឡុងពេល (ឧ.le cours de la vie) ។ donner cours à son ambition បណ្ដោយតាមមហិច្ឆតា ។ en cours កំពុងតែប្រព្រឹត្តទៅ

course *n.f.* ការរត់; ល្បឿនរត់; រយៈផ្លូវរត់ ។ *Sports* ការប្រណាំង (ឧ. course de chevaux)។course plate ការរត់លាត ។ course au clocher ការប្រណាំងសេះដោយមានឧបសគ្គ ។ ការដើរកាត់ (ឧ. faire une longue course en montagne); ការដើរតិតតូរ (ឧ. faire plusieurs courses pour une affaire); ការដើររកទិញ (ឧ. faire des courses dans les magasins); ដំណើរនៃពេល, ដំណើរនៃតារា (ឧ. la course du soleil)

coursier *n.m.*សេះចំបាំង។*Poét.* សេះ

coursier, ère *n.* អ្នកនាំសារ

coursive *n.f.* ច្រកបណ្ដោយក្នុងនាវា

court,e *a.* ខ្លី (ឧ. taille courte); ខ្លីឬរហ័ស (ឧ. trouver le temps court) ។ courte paille ការបូលហូត (ក្នុងល្បែងនេះមានម្នាក់កាន់ក្ដាប់ដើងធូបឬគ្រាប់ឈើតូចជាដើម ហើយបន្ទិចតែចុងម្ខាងឲ្យអ្នកឯទៀតហូត អ្នកដែលហូតបានខ្លីជាងគេ ត្រូវចាញ់ឬឈ្នះតាមតែសន្យាគ្នា)។ vue courte ការមិនឃើញឆ្ងាយ ; *au fig.* បញ្ញាខ្លី ។ avoir la mémoire courte ភ្លេចស្មារតី, ឆាប់ភ្លេច ។ haleine courte ដំណើរដង្ហក់ ។ être court d'argent ឬ à court d'argent ខ្វះប្រាក់។*Fig.*courte honte សេចក្ដីអាម៉ាស់មុខ ។

Prov. le chemin le plus long est quelquefois le plus court ផ្លូវវាងអាចទៅជាផ្លូវកាត់បាន (ព្រោះផ្លូវវាងគេមិនប្រទះឧបសគ្គផ្សេងៗដែលនាំឲ្យយឺត) ។ à vaillant homme courte épée មនុស្សក្លាហានមិនបាច់មានអាវុធទេ;*au fig.* មនុស្សប្រសប់ មិនបាច់មានប្រដាប់ទេ (ម.ព. épée ផង)

court *adv.* យ៉ាងខ្លី (ឧ. des cheveux coupés court) ។ couper court ឬ trancher court កាត់យ៉ាងខ្លី (បញ្ចប់ដោយនិយាយតែពីរបីម៉ាត់);couper court à ឬ trancher ឬ arrêter court កាត់, បញ្ឈប់។ couper court à quel-

qu'un ជាកចេញភ្លាម ។ tourner court បត់ភ្លាម ; *au fig.* ផ្លាស់ចរិយា ឬ ផ្លាស់សំដីភ្លាម (ប្រហែលនឹងពាក្យខ្មែរថា «ទូកខ្លី» គឺអាចបត់បែរបានភ្លាមៗ)

Loc. adv. de court ដោយមិនឲ្យដឹងខ្លួនមុន ។ prendre de court ប្រថុចប្រថំ ។ tenir de court កាន់ជិត ; *au fig.* មិនបណ្ដោយឲ្យមានសេរីភាពច្រើន។ tout court យ៉ាងខ្លី, តែប៉ុណ្ណឹង។ à court de *loc. pré.* ខ្វះ (ឧ. à court d'argent)

court *n.m.* ធ្លាលេងបាល់តិន្នីស

courtage *n.m.* របរ ឬ កម្រៃជើងសារជំនួញ

courtaud,e *a.* ក្រអាញ ។ *n.* សត្វដែលគេកាត់ត្រចៀកនឹងកន្ទុយ

courtauder *v.t.* កាត់ត្រចៀកនឹងកន្ទុយ (ឧ. courtauder un chien)

courtier,ère *n.* ជើងសារជំនួញ

courtil *n.m.* សួនតូចក្បែរផ្ទះ

courtilière *n.f.* ខ្ទុល

courtine *n.f.* វាំងននគ្រែ

courtisan *n.m.* អ្នកក្នុងវាំង;អ្នកបញ្ជោរយកប្រយោជន៍

courtisane *n.f.* ស្រីខូច

courtisanerie *n.f.* ការបញ្ជោរយកប្រយោជន៍

courtiser *v.t.* ចែចង់; បញ្ជោរយកប្រយោជន៍ ។ *Fig.* ស្វែងរក (ឧ. courtiser la fortune) ។ courtiser les Muses តែងកាព្យ

courtois,e *a.* ហៅរី, គួរសម (ឧ. courtois envers tout le monde; manières courtoises)

courtoisement *adv.* ដោយគួរសម

courtoisie *n.f.* ហៅរីភាព,សេចក្ដីគួរសម

court-vêtu,e *a.* ដែលមានសំលៀកបំពាក់ខ្លី (ឧ. jeune fille court-vêtue) (pl. court-vêtus,es)

couru,e *a.* ដែលគេចូលចិត្ត (ឧ. spectacle très couru) ។ *Fig.& fam.* c'est couru ប្រាកដហើយ

cousette *n.f. Fam.* ក្មេងស្រីអ្នកដេរ

couseuse *n.f.* ស្ត្រីអ្នកដេរ; ម៉ាស៊ីនដេរសៀវភៅ; ម៉ាស៊ីនដេរក្នុងឧស្សាហកម្ម

cousin,e *n.* បងប្អូនជីដូនមួយ, ជីទួតមួយ ។ល។ cousin germain បងប្អូនជីដូនមួយ ។ cousins issus de germains បងប្អូនជីទួតមួយ (ម.ព. germain ផង)

cousin *n.m.* មូស

cousinage *n.m. fam.* ភាពជាបងប្អូនជីដូនមួយឬជីទួតមួយ; បងប្អូនជីដូនមួយ ឬ ជីទួតមួយទាំងឡាយ

cousiner *v.i.* រស់នៅដោយស្រុះស្រួលគ្នា

coussin *n.m.* ខ្នើយ, ទ្រនាប់

coussinet *n.m.* កូនខ្នើយ

cousu,e *a.* cousu d'or មានណាស់ (ប្រហែលនឹងពាក្យខ្មែរថា ស្រោបមាស)

coût *n.m.* បរិយាទាន, តម្លៃ (ឧ. coût d'une marchandise) ។ coût de production បរិយាទាននៃផលិតកម្ម ។ coût de distribution បរិយាទាននៃការចែក(សោហ៊ុយផ្សេងៗ តាំងពីពីទំនិញចេញពីឧស្សាហកម្ម រហូតដល់អ្នកបរិភោគ) ។ coût de la vie បរិយាទាននៃជីវភាព

coûtant (à prix) តាមតម្លៃមែនទែន (តម្លៃដើមគ្មានគិតចំណេញ)

couteau *n.m.* កាំបិត ។ couteau à papier កាំបិតកាត់ក្រដាស។ avoir le pain et le couteau មានគ្រប់ទាំងអស់ (គឺមានទាំងនំបុ័ងទាំងកាំបិតកាត់នំបុ័ង) ។ jouer du couteau ឬ des couteaux ប្រយុទ្ធគ្នាដោយកាំបិតឬដោយដាវ ។ être à couteaux tirés ជាសត្រូវចេញមុខ ។ porter le couteau à ឬ sur កាត់ចេញ ឬ ដកចេញដោយគ្មានមេត្តា ។ enfoncer le couteau dans le sein de quelqu'un ធ្វើឲ្យកើតទុក្ខខ្លាំង ។ le couteau sur la gorge កាំបិតផ្តាប់ក(កំហែង, បង្ខំ) (ម.ព. épée ផង) ។

Prov. aller en Flandre sans couteau ចាប់ធ្វើការអ្វីដោយគ្មានបច្ច័យសោះ ។ c'est comme le couteau de Janot គឺជារបស់ផ្សេង តែឈ្មោះនៅដដែល (ឧ. ដងកាំបិត ឬ ផ្លែកាំបិតទទេ ក៏គេហៅថាកាំបិតដែរ) ។ les mauvais couteaux coupent les doigts et laissent le bois កាំបិតមិនល្អមុតដៃ មិនមុតឈើ (មធ្យោបាយខុសនាំមកនូវលទ្ធផលផ្ទុយដូចជាអ្នកចង់កាប់ឈើ មិនមុតឈើ ទៅមុតឯដៃអ្នកកាប់ទៅវិញ) ។ tel couteau, tel fourreau ស្រោមត្រូវឲ្យល្មមកាំបិត

coutelas *n.m.* ប៉ុងតោ, កាំបិតធំ (ឧ. coutelas de boucher); ដាវផ្លែធំមុខតែម្ខាង

coutelier *n.m.* អ្នកធ្វើ ឬ លក់កាំបិត

នឹងប្រដាប់សម្រាប់ប្រើកាប់កាត់ផ្សេងៗ)

coutellerie *n.f.* សិល្បៈ ឬ កន្លែងធ្វើកាំបិត; ជំនួញកាំបិត

coûter *v.i.* មានតម្លៃ (ឧ. combien coûtent ces livres?) ។ *Fig.* នាំឲ្យខាតបង់ (ឧ. cet accident lui a coûté cher) ។ *Absol.& impers. Fig.* ឲ្យពិបាកធ្វើ (ឧ. aveu qui coûte; il lui en coûte de refuser)។

Loc. adv. coûter cher ឲ្យខាតបង់ច្រើន ។ coûter bon មានតម្លៃច្រើន។ coûter la vie ធ្វើឲ្យបង់ជីវិត ។ rien ne lui coûte គាត់ធ្វើដោយគ្មានរួញរា;គាត់គ្មានប្រណីអ្វីសោះ។ tout lui coûte គាត់ឃើញតែខាងពិបាក ។ coûte que coûte ទោះជាយ៉ាងណាក៏ដោយ ។ *Fam.* coûter les yeux de la tête នាំឲ្យខាតបង់ច្រើនណាស់។

Prov. il n'y a que le premier pas qui coûte ពិបាកតែពេលដំបូងទេ

coûteusement *adv.* យ៉ាងថ្លៃ

coûteux,euse *a.* ថ្លៃ (ឧ. voyage coûteux) ។ *Fig.* ដែលនាំឲ្យមានការពិបាកច្រើន (ឧ. coûteuse erreur)

coutume *n.f.* ទំនៀម (ឧ. chaque pays a ses coutumes) ; ទម្លាប់ (ឧ. c'est sa coutume d'arriver à l'heure) ។ *Par ext.* បវេណី(ខាងច្បាប់) ។ de coutume *loc. adv.* តាមទម្លាប់ ។ mœurs et coutumes ទំនៀមទម្លាប់

coutumier,ère *a.* ដែលមានទម្លាប់, ដែលធ្លាប់ធ្វើ (ឧ. être coutumier d'un fait; nos travaux coutumiers) ។ droit coutumier ច្បាប់ប្រពៃណី

couture *n.f.* ការដេរ (ឧ. apprendre la couture); ថ្នេរ (ឧ. couture faite à la main); វិជ្ជាជីវៈនៃជាងដេរ (ឧ. la haute couture) ។ maison de couture ផ្ទះកាត់ដេរសំលៀកបំពាក់ស្ត្រី ។ សម្លាក (ឧ. visage plein de coutures) ។ *Fam.* sur toutes les coutures គ្រប់សព្វ (គ្មានសល់ចន្លោះកន្លែងណា)។ battre à plate couture *loc. adv.* ឈ្នះយ៉ាងសម្បើម

couturer *v.t.* ធ្វើឲ្យមានសម្លាក (ឧ.

avoir le visage tout couturé); ធ្វើឲ្យមានស្នាម (ឧ. manuscrit couturé de ratures)

couturier *n.&a.m.* ជាងដេរ; ជាងកាត់សំលៀកបំពាក់ស្ត្រី

couturière *n.f.* ស្ត្រីអ្នកដេរ; ជាងស្ត្រីកាត់សំលៀកបំពាក់ស្ត្រី

couvain *n.m.* ពងនឹងដង្កូវក្នុងសំបុក(នៃជាណាកជាតិរស់នៅជាក្រុមដូចជាឃ្មុំ, ស្រមោចជាដើម)

couvaison *n.f.* ពេលក្រាបពង

couvée *n.f.* ពងឬកូនមួយសំបុក។ *Fig. & fam.* គ្រួសារទាំងមូល

couvent *n.m.* អាវាសដូនជី; អគារអប់រំរបស់ដូនជី។ entrer au couvent ចូលបួស

couventine *n.f.* អ្នកបួសក្នុងអាវាសដូនជី; កុមារីដែលគេចិញ្ចឹមក្នុងអាវាសដូនជី

couver *v.t.* ក្រាបពង ។ *Fig.* គាំទ្រ, ប្រុងប្រៀប (ឧ. couver une trahison)។ couver une maladie មានរោគក្រប (មានរោគហើយប៉ុន្តែរោគនោះមិនទាន់ចេញឲ្យឃើញ)។ couver des yeux សម្លឹងដោយស្រឡាញ់ ឬ ដោយចង់បាន។ *v.i.* នៅដំ (ឧ. feu qui couve); ប្រុងប្រៀប (ឧ. c'est un complot qui couve)

couvercle *n.m.* គ្រប, គម្រប

couvert *n.m.* អ្វីៗ ដែលគ្រប ឬ ដែលឧបត្ថម្ភ; ដំបូល (សម្រាប់ជ្រកគឺលំនៅ) (ឧ. s'assurer le vivre et le couvert); ម្លប់ (ឧ. un beau couvert d'arbres); ស្រោម (នៃកញ្ចប់ ឬ លិខិត); រយៈ(អាសយដ្ឋានដែលកានៅស្រោមសំបុត្រ) (ឧ. recevoir une lettre sous le couvert d'un parent ទទួលសំបុត្រតាមរយៈបងប្អូនម្នាក់); *au fig.* ដោយពួនមុខពីក្រោយ... (ឧ. trahir sous le couvert de l'amitié)។

ឧបភោគភ័ណ្ឌដាក់លើតុអាហារ (កម្រាល, សម, ស្លាបព្រា, ចាន, កែវ) (ឧ. mettre, ôter le couvert); តុអាហារ (ឧ. se retrouver au même couvert); ឧបភោគភ័ណ្ឌសម្រាប់ភ្ញៀវជាយម្នាក់ៗ(ឧ. une table de trente couverts)។ avoir son couvert mis chez quelqu'un អាចទៅបរិភោគបាយបានតាមត្រូវការនៅផ្ទះណាមួយ។ ស្លាបព្រាសមទាំងសម្រាប់ (ឧ. acheter

un couvert d'argent); ប្រអប់ដាក់ស្លាបព្រាសមនឹងកាំបិតមួយសម្រាប់ (ឧ. couvert de voyage) ។ grand couvert ភត្តកាល អ៊ុកធឹក (ពេលជាយហ៊ុកហក់) ។ petit couvert ភត្តកាល មិនរ៉ុកធឹក ។

Art mil. ជម្រក(កន្លែងពួនមិនឲ្យសត្រូវមើលឃើញ ឬ បាញ់ត្រូវ)។ couverts naturels ជម្រកធម្មជាតិ (របង, ដើមឈើ, ផ្ទះ ។ល។) ។ couverts artificiels ជម្រកសិប្បនិម្មិត (លេណដ្ឋាន, ការបំបាំងដោយបន្ទំ ។ល។) ។

à couvert *loc.adv.* ដោយជ្រក (ឧ. se mettre à couvert sous un arbre ចូលជ្រកក្រោមដើមឈើ); ផុតភ័យ, ផុតអន្តរាយ (ឧ. mettre sa fortune, son honneur, sa réputation à couvert) ។ servir à couvert ប្រើបានគ្រប់ដាក់ម្ហូប (ដាក់តុឲ្យយស ពិសេស)។

Loc.pré. à couvert de ដោយជ្រក (ឧ. se mettre à couvert de la pluie ជ្រកភ្លៀង); ផុតពីពី (ឧ. je ne me vante pas d'être à couvert des surprises de la vanité); ដោយអាងលើ (ឧ. à couvert de sa mauvaise mine)

couvert,e *a.* ដែលបិទ;ដែលគ្រប,ដែលមានគំរូល,ដែលប្រក់ដោយ; ដែលមានពាសពេញ ។ *Fig.* ត្រូវរួចទោស (ឧ. un inférieur est couvert par les ordres reçus); ដែលមានច្រើន (ឧ. arbre couvert de fruits); *au fig.* couvert de honte ដែលអៀនខ្លាំង ។ ដែលស្លៀកពាក់ (ឧ. en hiver, il faut être bien couvert); ដែលមិនដោះមួក (ឧ. rester couvert); ដែលមានព្រៃ (ឧ. pays couvert) ។ mots couverts សំដីបិទមុខ (ឧ. parler à mots couverts) ។ temps couvert មេឃស្រទំ

couverture *n.f.* ភួយ។ *Fig.&fam.* tirer la couverture à soi ទាញយកភួយតែម្នាក់ឯង; ឧស្សាហ៍យកចំណែកធំតែម្នាក់ឯង ។ mettre un homme dans la couverture ឲ្យលោតទៅក្នុងភួយដែលគេកាន់មុំទាំងបួន; *au fig.* បោក (បញ្ឆោត) ។

Constr. ដំបូល (ឧ. la couverture d'une maison)។ ស្រោម (ឧ. une couverture de fauteuil); ក្រប (ឧ. une couverture de livre)។

Fig. ការលាក់បំបាំង,លេស(ឧ. il fallait trouver quelque couverture à un défaut si visible; sous couverture d'amitié)។

Agr. សម្រាមគ្របគល់ឈើ (ឧ. les couvertures sont réservées pour les terrains légers)។

Bours. ធានាប្រាក់(របស់ដាក់ធានា)។

couvet *n.m.* ជើងក្រានកំដៅជើង

couveuse *n.f.* មេមាន់ក្រាប;ប្រដាប់ញាស់ពង; ប្រដាប់ក្រុងទារកកើតមិនគ្រប់ខែ

couvi *a.m.* des œufs couvis ពងជាស់ប្រុក (ដែលមិនញាស់)

couvoir *n.m.* សំបុកក្រាបពង; កន្លែងដាក់សំបុក ឬ ដាក់ម៉ាស៊ីនញាស់ពង

couvre-nuque *n.m.* រនាំងកញ្ចឹងក (*pl.* des couvre-nuques)

couvre-chef *n.m.Fam.* សិរោរាណ [សិ - រៈ - តាណ] (មួក) (*pl.* des couvre-chefs)

couvre-feu *n.m.* បម្រាមគោចរ(បម្រាមមានកម្រិតពេលមិនឲ្យដើរទៅមកក្នុងទីដែលត្រូវប្រយ័ត្ន)។ *n.m.inv.* ប្រដាប់គ្របភ្លើង ; ម៉ោងបម្រាមគោចរ (*pl.* des couvre-feux)

couvre-joint *n.m.Constr.* ជាយអរបិទប្រហោងជញ្ជាំង ។ *Techn.* នីវ (*pl.* des couvre-joints)

couvre-pieds ឬ **couvre-pied** *n.m.* ភួយគ្របជើង (*pl.* des couvre-pieds)

couvre-plat *n.m.* គម្របចាន(*pl.* des couvre-plats)

couvreur *n.m.* ជាងប្រក់ផ្ទះ

couvrir *v.t.* គ្រប (ឧ. couvrir la marmite); ខ្ទប់ (ឧ. couvrir le visage de ses mains); បិទ (ឧ. couvrir ses yeux d'un bandeau)។ couvrir une maison ឬ *absol.* couvrir ប្រក់ផ្ទះ។ ដាក់គរលើ(ឧ. couvrir une table de fleurs)។ *Fig.* ផ្តល់ ឬ ឲ្យយ៉ាងច្រើន(ឧ. couvrir d'applaudissements, d'infamie, de honte, d'éloges); និញ្ញប់ (ឧ. cou-

vrir un nouveau-né de linge); ឲ្យស្លៀកពាក់(ឧ.couvrir les pauvres); ការពារ (ឧ.l'armée qui nous couvrait des ennemis était invincible)។*Fig.* លើកទោស (ឧ. couvrir ses fautes)។ *Par ext.* ទទួលខុសត្រូវលើខ្លួន (ឧ. couvrir un subordonné)។ បាំង (ឧ. nuage qui couvre le soleil)។ *Fig.* លាក់, បំបិទបំបាំង (ឧ.couvrir quelque chose d'un mensonge; couvrir l'injustice d'un voile d'équité); ធ្វើមិនឲ្យស្ដាប់ឮ (ឧ. cascade dont le bruit couvre la voix)។

Partic. ឡើងពាក់ (ចំពោះសត្វឈ្មោល)។

Bours. ឲ្យជារូបន៍។ *Courses* ដើរ, បើកបរ (ឧ. couvrir cinquante kilomètres en une heure)។

Dr. couvrir une enchère ដេញថ្លៃឡើង។ le pavillon couvre la marchandise មេឈើម ការពារទំនិញ (តាមច្បាប់អន្តរជាតិ នាវាដែលមានទង់ជាតិអព្យាក្រឹត មិនត្រូវឲ្យយុទ្ធការីឆែកឆេរ ដោយអាងលេសជារត់គយ ឬ ចម្បាំងឡើយ) ; *au fig.* យីហោការពារទំនិញ (គេទទួលស្គាល់ដោយងាយនូវរបស់ដែលមានយីហោល្បីល្បាញ)(ឧ.tel mauvais livre de tel illustre auteur a bien réussi; le pavillon a couvert la marchandise)។

Jeux couvrir un enjeu ចាប់(ក្នុងការភ្នាល់)។ couvrir l'échec ចងក្រឡា (ក្នុងល្បែងចត្រង្គ)។ couvrir son jeu លាក់ស្នៀត។

Loc. div. Fig. couvrir les jeux បំបិទភ្នែក (មិនឲ្យឃើញសេចក្ដីពិត)។ couvrir de ténèbres ធ្វើឲ្យងងឹត, ធ្វើឲ្យកើតទុក្ខ។ couvrir d'or ទិញយ៉ាងថ្លៃ។ couvrir de boue, de fange ធ្វើឲ្យសៅហ្មងកេរ្តិ៍ឈ្មោះ។ couvrir de ses ailes ការពារ (ដូចមេមាន់ក្រុងកូន)។

se couvrir *v.pr.* ពាក់(ពាក់មួក, ពាក់អាវ,ពាក់គ្រឿងអលង្ការណ៍)។ *Fig.* se couvrir du manteau de la vertu លាក់ពុត,ធ្វើឫកជាល្អ។

se couvrir de laurier មានកិត្តិស័ព្ទ ។ se couvrir de sang ប្រព្រឹត្តឃាតកម្មច្រើន (ខ្លួនប្រឡាក់សុទ្ធតែឈាម) ។ មានស្លឹកស្កុះ (ឧ. les arbres se couvrent de fleurs)។

Escr. & Boxe ចង, កាត់

covenant *n.m.* (ព.អ.) កតិកាសញ្ញា, អនុសញ្ញា

covenantaire *n.m.* ភាគីកតិកាសញ្ញា ឬ អនុសញ្ញា

covendeur,euse *n.* អ្នកលក់រួម

cow-boy *n.m.* កូវបោយ (គង្វាលសត្វនៅប្រទេសអាមេរិកខាងជើង) (*pl.* des cow-boys)

cowpox *n.m.* កូវប៉ុក(ម.ព.vaccine)

coxal,e,aux *a.* នៃចង្កេះ

coxalgie *n.f.* រោគរបេងចង្កេះ

coxalgique *a.* នៃរោគរបេងចង្កេះ ។ *a. &n.* ដែលកើតរោគរបេងចង្កេះ

C.Q.F.D. (ពាក្យបំព្រួញនៃ Ce Qu'il Fallait Démontrer)

crabe *n.m.* ក្ដាម

crabier *a.&n.m.* បក្សីម្យ៉ាងស៊ីក្ដាមជាអាហារ

crachat *n.m.* កំហាក។*Fig.&fam.* ផ្លាកគ្រឿងឥស្សរិយយសជាន់ខ្ពស់

crachement *n.m.* ការស្ដោះ,ការខាក; ការព្រួស, ការខ្ជាក់

cracher *v.t.* ខ្ជាក់;ខ្ជាក់តាមមាត់(ឧ.cracher du sang); ខ្ពុរ, ព្រួស (ឧ. volcan qui crache des larves)។ *v.t.* ខាក, ស្ដោះ (ឧ. il ne cesse de cracher); ករ (ស្លាបប៉ាកកា)(ឧ.plume qui crache)។

Fig.&pop. ចេញប្រាក់ (ឧ. cracher mille riels); និយាយច្រើនឥតបានការ (ឧ. cracher des proverbes); ថាឲ្យចំៗ (មាត់ទៅ) (ឧ.cracher son fait à quelqu'un); និយាយសំដីអាក្រក់ដោយកំហឹង (ឧ.cracher des injures; cracher sa malédiction) ។ cracher ses poumons ខ្ជាក់កំហាកច្រើន ។ cracher du coton ឬ cracher des pièces de dix sous ឬ cracher blanc ស្រេកទឹកខះក(ទឹកមាត់ឡើងពណ៌ស)។

Loc.div. cracher sur មាក់ងាយ។ ne pas cracher sur ស្រឡាញ់, ចូលចិត្ត (ឧ. ne pas cracher sur les bons mor-

ceaux) ។ cracher sur quelqu'un ឬ au visage ឬ au nez de quelqu'un ជេរប្រមាថ ។ cracher contre le ciel ផ្ដាសា, ពោលផរុសវាចា ។ cracher au bassin ឬ au bassinet ឲ្យប្រាក់ដោយទើសទាល់ (អ្នកដែលគេទើបនឹងដកធ្មេញរួចដូចជាក្អួយមិនចង់ស្ដោះទឹកមាត់ដាក់កន្ថោរ) ។ cela est à cracher dessus របស់នោះថោកទាបណាស់ ។

Loc. prov. il a craché en l'air et son crachat lui est retombé sur le nez ឬ il a craché en l'air ស្ដោះទឹកមាត់ដាក់ទ្រូងឯង ឬ ស្រោចគល់ ។

être le portrait tout craché (ឬ tout craché) ដូចបេះបិទ (ឧ. cet enfant est son père tout craché)

cracheur,euse *n.* អ្នកចូលចិត្តខាកស្ដោះ; ដែលភក (ស្វាបឆ្អកកា)

crachin *n.m.* រលឹមភោយស្បៃ

crachoir *n.m.* កន្ថោរ ។ *Pop.* tenir le crachoir និយាយ

crachotement *n.m.* ការខាកស្ដោះបន្តិចៗញយៗ

crachoter *v.i.* ខាកស្ដោះបន្តិចៗញយៗ

crack *n.m.* កូនសេះប្រណាំងដែលគេស្រឡាញ់ជាងគេ ។ *Fam.* ជើងឯក

craie *n.f.* ដីស

craindre *v.t.* ខ្លាច, ញញើត(ឧ. je crains qu'il ne vienne ខ្ញុំខ្លាចក្រែងគាត់មក ។ je ne crains pas qu'il vienne ខ្ញុំមិនខ្លាចគាត់មកទេ ។ ញញើត; គោរព; ស្ដាប់បង្គាប់ (ឧ. craindre son père)

crainte *n.f.* សេចក្ដីខ្លាច, ញញើត (ឧ. la crainte est mauvaise conseillère); ការគោរព (ឧ. la crainte de Dieu) ។ dans la crainte que ឬ de crainte que *loc.conj.* ខ្លាចក្រែង (ឧ. fuyez, de crainte qu'on ne vous voie)

craintif,ive *a.* ខ្លាចច្រើន, ដែលញញើតញញើម (ឧ. un enfant craintif); ដែលសំដែងសេចក្ដីខ្លាច (ឧ. regard craintif)

craintivement *adv.* ដោយញញើតញញើម

cramoisi,e *a.* ក្រហមឆ្អៅ ។ *n.m.* ពណ៌

ក្រហមឆាំ

crampe *n.f.* ដំណើរក្តាមកាច់ជើង ឬ រមួលក្រពើ ។ crampes d'estomac ដំណើររមួលពោះ

crampillon *n.m.* ដែកគោលបត់មុខពីរ

crampon *n.m.* ដែកក្រចាប់ ។ *Bot.* ឫសតោង ។ *Fig.&fam.* អ្នករំខាន

cramponnement *n.m.* ការភ្ជាប់ដោយដែកក្រចាប់; ការតោង

cramponner *v.t.* ភ្ជាប់ដោយដែកក្រចាប់ ។ *Fig.&fam.* រំខាន ។ se cramponner *v.pr.* តោង (ឧ. le lierre se cramponne au tronc des arbres) ។ *Fig.* ប្រតោង, ក្រាញ; ប្រកាន់យ៉ាងមាំ (ឧ. se cramponner à une opinion)

cramponnet *n.m.* ដែកក្រចាប់តូច; ប្រអប់សោ

cran *n.m.* គន្លាក់; កង្កាញ់, ភាពខ្ពស់ទាប ។ *Fig.* ថ្នាក់ (ឧ. monter, baisser d'un cran) ។ *Fig. & fam.* សេចក្ដីអង់អាច (ឧ. avoir du cran) ។ être à cran ក្ដៅក្រហាយ

crâne *n.m.* លលាដ៍ក្បាល

crâne *a.&n.* ហ៊ឺហា, ក្អេង (ឧ. air crâne)

crânement *adv.* យ៉ាងហ៊ឺហា, យ៉ាងក្អេង

crâner *v.i.* ធ្វើឫកក្អេង

crânerie *n.f.* ការធ្វើឫកក្អេង

crâneur,euse *n.Fam.* អ្នកធ្វើឫកក្អេង

crânien,enne *a.* នៃលលាដ៍ក្បាល (ឧ. nerf cranien)

crâniologie *n.f.* លលាដវិទ្យា [លៈ-លា-ដិៈ-]

cranioscopie *n.f.* លលាដទស្សន៍ [លៈ- លា-ដិៈ ទស់ -]

cranter *v.t.* លាក់, ធ្វើឲ្យមានគន្លាក់

crapaud *n.m.* គីង្គក់ ។ *Fam.* កូនតូច (ឧ. bonjour, petit crapaud) ។ *loc.fam.* avaler un crapaud ធ្វើការពិបាក (ដែលគេមិនចង់ធ្វើ ដូចជាត្រូវបង្ខំឲ្យលេបគីង្គក់) ។ sauter comme un crapaud លោតយ៉ាងធ្លង; *au fig.* ធ្វើអ្វីដោយមិនចង់

crapaud,e *a.* អាក្រក់ណាស់ (ដូចគីង្គក់)

crapaud-buffle *n.m.* ហ៊ឹង

crapaudière *n.f.* សំបុកគីង្គក់; ទីសើមកខ្វក់

crapaussin,e *n.Pop.* មនុស្សមាឌតូចរូបអាក្រក់ ។ *Fam.* ក្មេងតូច

crapule *n.f.* អំពើថោកទាប (ឧ. vivre

dans la crapule); ជនថោកទាប (ឧ. fréquenter la crapule)

crapulerie *n.f.* អំពើថោកទាប ឬ ទុច្ចរិត

crapuleusement *adv.* យ៉ាងថោកទាប

crapuleux,euse *a.* ថោកទាប (ឧ. gens crapuleux)។ crime crapuleux បទឧក្រិដ្ឋដើម្បីលួច

craque *n.f.Fam.* សំដីភរ; អំនួត

craqueler *v.t.* ធ្វើឲ្យប្រេះស្នាំ (ឧ. craqueler de la porcelaine)

craquelin *n.m.* នំស្រួយ ។ *Fig.* & *Fam.* មនុស្សស្គម, មនុស្សខ្សោយ

craquelure *n.f.* ស្នាមប្រេះនៃវែរទី ឬ ថ្នាំលាប

craquement *n.m.* សូរលាន់ប្រឹបៗ (ដោយធាក់ជាដើម)

craquer *v.i.* លាន់ប្រឹបៗ(អ្វីៗដែលធាក់); ប្រេះ, បែក(ឧ. les poches pleines à craquer) ។ *Fig.&fam.* កក្រើក (ឧ. les vieux systèmes craquent); ស្អុន, មិនបានសម្រេច (ឧ. projet qui craque)

craquètement *n.m.* សូរលាន់ប្រឹបៗ តិចៗ; សូរសណ្តំថ្គាម; សម្រែកបក្សីខ្លះ

craqueter *v.i.* សណ្តំធ្មេញសូរតិចៗ; ស្រែក (ចំពោះបក្សីខ្លះ) (ឧ. la cigogne craquette)

craqueur *n.Pop.* មេភរ; មេអំនួត

crasse *n.f.* ក្អែល ។ *Techn.* អាចម៍លោហធាតុដែលរលាយ។ *Fig.* ហីនៈ ថោកទាប; សេចក្ដីតោកយ៉ាក; សេចក្ដីកំណាញ់ក្រៀតក្រ ។ *Pop.* ល្បែងថោកទាប (ឧ. faire une crasse à quelqu'un)

crasse *a.f.* កម្រោល, គួរឲ្យខ្ពើម (ឧ. ignorance crasse)

crasser *v.t.* ឲ្យប្រឡាក់ក្អែល។ se crasser *v.pr.* ប្រឡាក់ក្អែល

crasseux,euse *a.* កខ្វក់ដោយក្អែល (ឧ. chapeau crasseux)។ *Fig.& fam.* កំណាញ់ក្រៀតក្រ(ឧ.homme crasseux)

crassier *n.m.* គំនរកាករ៉ែ ឬ អាចម៍លោហធាតុ

cratère *n.m.* មាត់ភ្នំភ្លើង ។ lac de cratère បឹងមាត់ភ្នំភ្លើង (ទឹកដែលដក់ក្នុងមាត់ភ្នំភ្លើងរលត់) ។ មាត់ឡដុតកែវ

cravache *n.f.* រំពាត់ខ្សែតី

cravacher *v.t.* វាយដោយរំពាត់ខ្សែតី

cravate *n.f.* ក្រវ៉ាត់, បូ ។ *Fam.* cravate de chanvre ខ្សែផ្លាក

cravater *v.t.* ចងក្រវ៉ាត់ឲ្យ (ឧ. cra-

vater un enfant)។ *v.i.* បំផ្លើស, និយាយបញ្ចេញ

crawl [krôl] *n.m.* របៀបហែលបង្វិលខ្លួន

crayeux,euse *a.* នៃជាតិដីស (ឧ. terrain crayeux)

crayon *n.m.* ដីខ្មៅ ឬ ខ្មៅដៃ; ជុំ (ឧ. crayon de rouge à lèvres)។ *Fig.* របៀបគូរ (ឧ. avoir le crayon ferme, facile): គំនូរខ្មៅដៃ

crayonnage *n.m.* គំនូរខ្មៅដៃ

crayonner *v.t.* គូរដោយខ្មៅដៃ (ឧ. crayonner un portrait); គូរហ័ស (ឧ. crayonner à la hâte un croquis)

crayonneur *n.m.* ជាងគំនូរមិនប្រសប់

créance *n.f.* ជំនឿ ។ donner créance ធ្វើឲ្យគួរជឿ ។ hors de créance មិនគួរជឿ ។ *Fig.* ការទុកចិត្ត (ឧ. perdre toute créance)។ *Dr.* ឥណទេយ្យ ។ lettres de créance *Com.* លិខិតឥណទេយ្យ ; *Dipl.* សារតាំង

créancier,ère *n.* ឥណទាយក-យិកា, ម្ចាស់បំណុល

créateur,trice *n.* មាបកៈ-បិកា [មា-ប៉ៈ-កៈ]. អ្នកបង្កើត(ឧ. le créateur de l'univers) ។ *Absol.* le Créateur អាទិទេព

création *n.f.* មាបនកម្ម [មា-ប៉ៈ-នៈ-], ការបង្កើត (ឧ. la création de l'homme); ពិភពលោក; សត្វលោកទាំងឡាយ ។ *Fig.* ការប្រឌិត, ការបង្កើតដំបូង; មាបនវត្ថុ (វត្ថុដែលបង្កើតឡើង)

créature *n.f.* សត្វលោក; មនុស្ស (ទីទៃពីអាទិទេពអ្នកបង្កើតមនុស្ស) (ឧ. créature raisonnable); ជនថោកទាប។ *Fig.* les créatures du ministre មនុស្សរបស់រដ្ឋមន្ត្រី (មនុស្សដែលរដ្ឋមន្ត្រីឧបត្ថម្ភ)

crécelle *n.f.* ក្រាប់ ។ *Fig.* មនុស្សនិយាយច្រើន។ voix de crécelle សំឡេងឆ្អក

crèche *n.f.* កន្លែងដាក់ចំណីសត្វ; ទារកដ្ឋាន (កន្លែងទទួលរក្សាក្មេងអាយុតិចជាង ៣ ឆ្នាំ ក្នុងពេលថ្ងៃ)

crédibilité *n.f.* ហេតុដែលនាំឲ្យជឿ

crédirentier *n.m.* ឥណទានលាភី

crédit *n.m.* ភាពមានប្រាក់សង; ការជឿ (ឧ. avoir deux mois de crédit ជឿបានពីរខែ)។ acheter à

crédit ទិញជឿ ។ មន្ទីរចងការ ។ crédit agricole មន្ទីរចងការកសិកម្ម ។ crédit foncier មន្ទីរចងការភូមិបាល ។ crédit municipal មន្ទីរចងការក្រុង ឬ ក្រុមមឿង។

Com.&Fin. ឥណទាន ។ ouvrir un crédit à quelqu'un បើកឥណទានឲ្យ(អនុញ្ញាតឲ្យយកប្រាក់ជាយ) ។ crédit budgétaire ឥណទានថវិកា ។ crédit documentaire ឥណទានឯកសារ ។ crédit d'enlèvement ឥណទាននៃការលើកចេញ ។ crédit de droit ឥណទានសិទ្ធិ ។ crédit par caisse ឥណទានបេឡា ។ crédit personnel ឥណទានជាតិបុគ្គល [—ជា - តិ—] ។ crédit réel ឥណទានភណ្ឌិក ។ crédit de campagne ឥណទានផលសម័យ។ crédit de courrier ឥណទានហារើយ ។ *Fig.* អំណាច, សេចក្តីរាប់អាន (ឧ.avoir du crédit) ។ à crédit *loc.adv.* ជឿ,ដោយបណ្ដាក់

créditer *v.t. Com.* ចុះក្នុងឥណទាន; អនុញ្ញាតឲ្យបើក

créditeur,trice *n.* ឥណទាយី-យិនី ។ *a.* compte créditeur គណនីឥណទាយី ។ solde créditeur សមតុល្យឥណទាយី

crédo *n.m.inv.Fig.* គោលជំនឿ

crédule *a.* សទ្ធាលុ, ឆាប់ជឿ (ឧ. esprit crédule)

crédulement *adv.* ដោយឆាប់ជឿ

crédulité *n.f.* សទ្ធាលុភាព,ភាពងាយជឿ

créer *v.t.* បង្កើត (ឧ. Dieu, dit la Bible, a créé le ciel **et la** terre; créer un mot) ។ *Fig.* ជាហេតុនៃ,បណ្ដាល (ឧ. créer des embarras à quelqu'un); តាំង, បើក(ឧ. créer une maison de commerce) ។ créer un produit nouveau បង្កើតផលិតផលមួយថ្មី

crémaillère *n.f.* ទំពក់ព្យួរឆ្នាំង។*Fig. & fam.* pendre la crémaillère ឡើងផ្ទះថ្មី ។ *Méc.* គ្រឿងមានធ្មេញ (គ្រឿងចក្រ)

crémation *n.f.* ឈាបនកិច្ច,ការរំលាយសព

crématoire *a.* នៃឈាបនកិច្ច ។ four crématoire ឈាបនដ្ឋាន

crême *n.f.* ខ្លាញ់ទឹកដោះ; បង្អែម

ធ្វើដោយទឹកដោះ ស៊ុតនិងស្ករ។ ក្រែម។ crème de beauté ក្រែមស៊ិតស្អាងខ្លួន។ crème glacé ក្រែមកក ។ ខ្ទិះ (ឧ. crème de cacao) ។ *Fig. & fam.* ខ្ទិះ,អ្វីៗដែលវិសេសបំផុត (ឧ. la crème des honnêtes gens មនុស្សត្រង់បំផុតក្នុងចំណោមមនុស្សត្រង់នានា ។ *a.inv.* ពណ៌ពងមាន់ (សហើយលឿងបន្តិចៗ)

crémer *v.i.* ចេញខ្លាញ់ទឹកដោះ; ឲ្យមានពណ៌ខ្លាញ់ទឹកដោះឬពណ៌ពងមាន់

crémer *v.t.* ធ្វើឈាបនកិច្ច

crémerie *n.f.* កន្លែងលក់ទឹកដោះ ស៊ុត ។ល។; ភោជនីយដ្ឋានតូច

crémeux,euse *a.* ដែលមានខ្លាញ់ទឹកដោះច្រើន (ឧ. lait crémeux)

crémier,ère *n.* អ្នកលក់ទឹកដោះ ស៊ុត ។ល។

crémone *n.f.* ដែមួលគន្លឹះបង្អួច-ទ្វារ

crénage *n.m.* ការលោក់(ឲ្យមានគន្លាក់)

créneau *n.m.* ក្បាច់ត្របកឈូក; រន្ធនៅជញ្ជាំងសម្រាប់បាញ់

crénelé,e *a.*ដែលមានក្បាច់ត្របកឈូក (ឧ. tour crénelée) ។ *Bot.& zool.* ដែលមានហាមរធេងរធ្លង

créneler *v.t.* ធ្វើក្បាច់ត្របកឈូក ឬក្បាច់ធ្មេញរណារ (ឧ. créneler un mur)

crénelure *n.f.* ស្នាមដែកជាក្បាច់ត្របកឈូក ឬ ក្បាច់ធ្មេញរណារ

créner *v.t.* លាក់ (ទងអក្សរពុម្ព)

créole *a.&n.* ក្រេអូល (ជនជាតិស្បែកសដែលកើតក្នុងអាណានិគម)

créophage *n.&a.* ដែលបរិភោគសាច់

crêpe *n.m.* សំពត់ក្រែប ឬ សំពត់កំពឹង-ខ្លីង; មរណសញ្ញា; កៅស៊ូសន្លឹក ។ *n.f.* នំក្រៀប

crépé *n.m.* បំណាំងសក់ (សម្រាប់បន្ថែមលើសក់មែនទែន)

crépelé,e ឬ **crépelu,e** *a.* រួញបន្តិចៗ (ឧ. cheveux crépelés)

crépelure *n.f.* ភាពរួញបន្តិចៗ (សក់)

crêper *v.t.* ធ្វើឲ្យជ្រួញខ្លួចសំពត់ក្រែប (ឧ. crêper une étoffe) ។ se crêper *v.t.* ឡើងជ្រួញៗ ។ *Pop.* se crêper le chignon ប្រចាបសក់គ្នា (ស្រីៗដែលប្រឈ្លោះគ្នា)

crépi *n.m.* បាយអរបូកគ្រោតគ្រាត

crépière *n.f.* ស្ត្រីអ្នកលក់សំពត់ក្រែប

crépir *v.t.* បូកបាយអរគ្រោតគ្រាត

crépissage *n.m.* ការបូកបាយអរគ្រោតគ្រាត

crépitant,e *a.* ដែលផ្ទុះ(ដូចអំបិលលីង)

crépitation *n.f.* សូរផ្ទុះ (ដូចអំបិលលីង) ។ *Méd.* សូរខ្យល់ក្នុងដើមទ្រូង

crépitement *n.m.* ការផ្ទុះ (ដូចអំបិលលីង)

crépiter *v.i.* ផ្ទុះឮប្រស់ៗ (ដូចអំបិលលីង) (ឧ. le feu crépite; la fusillade crépite)

crépon *n.m.* សំពត់ក្រេប៉ុង (សំពត់ក្រេបមួយយ៉ាង)

crépu,e *a* ព្រញាញ់ឫសឫស្សី(ឧ. cheveux crépus);ដែលមានឫកាមអង្កាញ់

crépure *n.f.* ការធ្វើឲ្យជ្រួញដូចសំពត់ក្រេប

crépusculaire *a.* នៃសន្ធ្យាប្រកាស (ឧ. lumière crépusculaire)។ animaux crépusculaires សត្វដែលចេញរកស៊ីក្នុងសន្ធ្យាប្រកាស (មើល. crépuscule ផង)

crépuscule *n.m.* សន្ធ្យាប្រកាស (ពន្លឺមុនព្រះអាទិត្យរះ និងក្រោយព្រះអាទិត្យអស្តង្គត) ។ *Fig.* បច្ឆិមវ័យ, ភាពខូចបរ (ឧ. le crépuscule d'un empire)

crescendo *n.m. inv.* ការបង្កើនជាលំដាប់នៃសំឡេង ។ *Mus.* សោយ ។ *adv.* កាន់តែខ្លាំងឡើង(ឧ. son mal va crescendo)

cresson *n.m.* ច្រាំស្លុង (បន្លែបារាំង) ។ cresson d'eau ច្រាច់

crésus *n.m.* អ្នកមានទ្រព្យច្រើន

crésyl *n.m.* ទឹកក្រេស៊ីល

crête *n.f.* សិរ (ឧ. la crête des gallinacés (coq) est charnue, rouge et dentelée); ផ្លូវកំពូលភ្នំ; ទ្រនុង; ដំបូល; កំពូល; កំពូលរលក

crêté,e *a.* ដែលមានសិរ ឬ មានកំពូល

crête-de-coq *n.f. Bot.* ដើមផ្កាសិរមាន់ (*pl.* des crêtes-de-coq)

crêteler *v.i.* ខ្ពត(មេមាន់ទើបនឹងពងរួច)

crêter *v.t.* ដាក់កំពូល ។ se crêter *v.pr.* បំប៉ោងយ៉ាងក្រអឺត

crétin,e *n.* មនុស្សស្គមហើយភ្លីភ្លើ ។ *Fig.* មនុស្សល្ងង់ល្ងើ

crétons *n.m. pl.* កាកខ្លាញ់ (ដែលពួតជាដុំៗឲ្យជាចំណីឆ្កែ)

creusage ឬ **creusement** *n.m.* ការជីក (ឧ. creusage d'un puits)

creuser *v.t.* ល្មុង (ឧ. creuser une pierre); ជីក (ឧ. creuser un puits) ។ *Fig.* ជជីក; ពិនិត្យដោយជ្រៅជ្រះ(ឧ. creuser un sujet);

ធ្វើឲ្យឃ្លាន(ឧ. la chasse creuse l'estomac)។se creuser *v.pr.* ទៅជាប្រហោង,ទៅជាជ្រៅ។ se creuser le cerveau ឬ l'esprit ឬ la tête ខំប្រឹងគិត

creuset *n.m.* ឡរំលាយ ។ *Fig.* ការបង្វឹក (ឧ. le creuset de l'expérience) ; កន្លែងដែលរបស់ច្រើនត្រូវលាយឡំគ្នា

creux,euse *a.* ប្រហោងក្នុង(ឧ.arbre creux); ទទេ (គ្មានអ្វីនៅក្នុង) (ឧ. ventre creux); ខូង (ឧ. joues creuses; des yeux creux); ជ្រៅ (ឧ. puits creux) ។ chemin creux ផ្លូវទំនាប ។ projectile creux គ្រាប់បែក ។ *Fig.* esprit creux មនុស្សគ្មានបញ្ញា។ tête creuse មនុស្សគ្មានពិចារណា ។ raisonnement creux វិចារណកិច្ចមិនសមហេតុផល ។ avoir le ventre creux ឬ avoir un creux dans l'estomac ឃ្លាន។ avoir le nez creux ប្រាជ្ញាវៃ (ចាប់បាន់ដឹងការ)។heure creuse ពេលទំនេរ(មិនសូវមានការធ្វើ)។ប្រហោង (ឧ. le creux d'un rocher)។ creux de la main កម្បង់ដៃ ។ ពុម្ពប្រហោង (សម្រាប់ធ្វើក្បាច់កន្ទួល) ។

crevaison *n.f. Fam.* ការបែក ឬ ផ្ទុះ (ឧ. la crevaison d'un pneumatique)

creuvant,e *a. Pop.* ហត់ (ឧ. un travail crevant)។ *Pop.* ដែលឲ្យសើចរឹងពោះ (ឧ. spectacle crevant)

crevasse *n.f.* ក្រហែង; ស្នាមប្រេះ

crevasser *v.t.* ធ្វើឲ្យប្រេះ(ឧ.le froid crevasse les mains);ធ្វើឲ្យបែកក្រហែង ។ *v.i.*& se crevasser *v.pr.* ប្រេះ,បែកក្រហែង(ឧ.ce mur crevasse ឬ se crevasse)

creuvé *n.m. Pop.* មនុស្សគ្មានកម្លាំង

crève-cœur *n.m. inv.* ការឈឺចាប់ក្នុងចិត្ត

crever *v.t.* បំបែក, ទម្លាយ(ឧ. le torrent a crevé la digue); ចាក់ទម្លុះ (ឧ. on lui a crevé les yeux)។ *Fig.* cela crève les yeux ពិតស្ដែងណាស់ ។ crever le cœur ធ្វើឲ្យខ្លោចចិត្ត ។ crever un cheval ធ្វើឲ្យសេះហត់ទាល់តែដួល ។ crever de dépit តូចចិត្តណាស់។

crever de faim ឃ្លានពេកស្ទើរដាច់ពោះវៀន។ crever de soif ស្រេកខ្លាំង។ crever de rire សើចខ្លាំងពេក

crevette *n.f.* បង្កង, បង្គា, ក្រោន

crevettier *n.m.* មងដឹកបង្កង

cri *n.m.* សម្រែក។ jeter des cris ស្រែក។ cri de douleur សម្រែកនៃការឈឺចាប់។ imiter le cri d'un oiseau ត្រាប់សម្រែកបក្សី។ cris séditieux សម្រែកបះបោរ។ cri de guerre សម្រែកសង្គ្រាម។ cri de détresse សម្រែកនៃទុក្ខភ័យ (ហៅឲ្យគេជួយ)។ ស្នូរមិនពីរោះ (ឧ. le cri de la scie)។ *Fam.* dernier cri ថ្មីបំផុត, ទំនើបបំផុត (ឧ. cette robe est le dernier cri)។ *Fig.* le cri de la conscience សម្រែកនៃមនសិការ (ការប្រកែកនៃមនសិការដែលមិនចង់ឲ្យយើងប្រព្រឹត្តអាក្រក់)។ *Fig.&fam.* pousser les hauts cris តវ៉ាដោយកំហឹង។ à cor et à cri *loc. adv.* ម.ព. cor

criaillement *n.m.* សម្រែក ឬ ស្នូរមិនពីរោះ; ការដេញកញ្ជា

criailler *v.i.* ស្រែក (ក្ងាន, ក្អែក។ល។)។ *Fig.* ស្រែកឡូឡា

criaillerie *n.f.* *Fam.* សម្រែកតម្អូញ; ជម្លោះ; បណ្ដឹងដែលនាំឲ្យរំខាន

criailleur,euse *n.&.a.* *Fam.* អ្នកឡូឡា

criant,e *a.* ដែលឲ្យទ្រាំទានតវ៉ាមិនបាន, គួរឲ្យក្ដៅក្រហាយ (ឧ. injustice criante; abus criants)

criard,e *a.* ដែលចូលចិត្តស្រែកឡូឡា (ឧ. les criards font généralement peu de besogne)។ *a.* ដែលស្រែកឡូឡាគ្មានហេតុផល; ដែលស្រែកឡូឡាមិនឈប់ឈរ (ឧ. une femme criarde)។ voix criarde សំឡេងសង្កៀរត្រចៀក។ couleurs criardes ពណ៌ភ្លៅឬព្រាល (ពណ៌ឆើតពេក)។ dettes criardes បំណុលដែលគេទារញយៗ

criblage *n.m.* ការរែង (ឧ. le criblage des grains)

crible *n.m.* កញ្ច្រែងរែង, កាតៅ។ *Fig.* មធ្យោបាយជ្រើសរើស ឬ វែកញែក។ passer au crible ពិនិត្យដោយហ្មត់ចត់

cribler *v.t.* រែង។ *Fig.* être criblé de blessures មានរបួសពាស

ពេញទាំងខ្លួន ។ être criblé de dettes ជំពាក់បំណុលរុំពោះ

cribleur,euse *n.* អ្នករែង; ម៉ាស៊ីនរែង

criblure *n.f.* សំណល់ពីរែង

cric *n.m.* គ្រីប

cric *int.* ប្រិប! (គ្រាប់ស្នូរដាក់ ឬ រហែក)

cricket [kri-kèt] *n.m.* គ្រីកកែត (ល្បែងកូនគោលអង់គ្លេស)

cricri *n.m.* ចង្រិតនៃក

crid *n.m.* ម.ព. criss

criée *n.f.* ការលក់ឡាយឡុង(ឧ. acheter à la criée)

crier *v.i.* ស្រែក (ឧ. crier de douleur); ស្រែកឡូឡា, ឥតឈ្លោះខ្លាំង(ឧ. discuter sans crier); ស្រែកប្រកាស (ឧ. crier à l'injustice); ឮស្នូរសង្កៀរគ្រាញ៉ៀក (ឧ. l'essieu crie) ។ *Fam.* ឡូឡាដាក់ (ស្តីឲ្យ) (ឧ. crier après quelqu'un) ។

Loc. div. crier à ស្រែកអំពាវនាវ, ស្រែកឲ្យគេដឹង (ឧ. crier à l'oppression, au scandale, à la trahison) ។ crier à tue-tête, crier comme un aveugle, comme un sourd, comme un paon, comme un veau ឬ crier comme un perdu ស្រែកចង្កាល (ម.ព. aveugle ផង) ។ crier comme un fou, comme un furieux, comme un enragé, comme un aigle ឬ comme un beau diable ស្រែកឡូឡាដោយកំហឹង ។

Arg. crier au vinaigre ស្រែកជាចោរ ។ crier aux petits pâtés ស្រែក (ចំពោះស្ត្រីឈឺពោះឆ្លងទន្លេ) ។

v.t. crier gare ស្រែកឲ្យប្រយ័ត្ន ។ crier une chose sur les toits ស្រែកប្រកាសឲ្យគេដឹងគ្រប់គ្នា ។ ប្រកាសជាសាធារណៈ(ឧ. crier un ordre à son de trompe); ស្រែកតវ៉ា(ឧ. l'iniquité de l'impôt a de tout temps fait crier les populations) ។

Fig. crier famine ឬ crier misère ត្អូញត្អែរថាអត់បាយ ឬ ពិបាកលំបាក ។

Com. ការលក់ឡាយឡុង(ឧ. crier des meubles, des propriétés immobilières); ស្រែកពណ៌នាយ (ឧ. crier de la sa-

lade, de vieux habits, des journaux) ។

Dr.anc. កោះ (ឧ. crier un prévenu) ។ crier haro sur បង្គាប់ឲ្យចាប់ខ្លួន ។ *Fam.* crier haro sur quelqu'un ញុះញង់ឲ្យគេស្អប់អ្នកណាមួយ ។

Prov. & loc. prov. on a tant crié Noël, qu'à la fin il est venu របស់ដែលគេទន្ទឹងណាស់ ឥឡូវមកដល់ហើយ ។ plumer la poule sans la faire crier ដោចរោមមាន់មិនឲ្យឮខ្ទក (យកអីវ៉ាន់អស់ពីខ្លួនហើយ មិនឲ្យឮមាត់បន្តិច ។ សុភាសិតបុរាណថា: «អូសទូកពុំឲ្យល្អូន ចាប់ត្រីបានពុំឲ្យល្អក់ទឹក») ។ crier famine sur un tas de blé ម.ព. blé ។ il crie avant qu'on l'écorche ខ្លាចមិនសមហេតុផល (ដូចជាគេមិនទាន់ពន្លះស្បែកផងខំស្រែកមុន) ។

Fig. ធ្វើឲ្យក្ដៅក្រហាយ ។ *v.t.* ផ្សាយ (ឧ. crier une annonce) ។ crier une vente ស្រែកប្រកាសលក់ឡាយឡុង

crierie *n.f.* សម្រែករំខាន

crieur,euse *n.* អ្នកស្រែក, អ្នកស្រែកប្រកាស ។ crieur public អ្នកប្រកាសជាសាធារណៈ ។ អ្នកពពាយឆាយ

crime *n.m.* បទឧក្រិដ្ឋ (ឧ. perpétrer un crime); ឧក្រិដ្ឋជន (ឧ. poursuivre le crime)

criminaliser *v.t.* ផ្លាស់ជារឿងឧក្រិដ្ឋ

criminaliste *n.m.* នេតិបណ្ឌិតខាងបទឧក្រិដ្ឋ

criminalité *n.f.* ឧក្រិដ្ឋភាព; បទឧក្រិដ្ឋទាំងឡាយ (ឧ. la criminalité a progressé avec l'alcoolisme)

criminel,elle *a.* នៃបទឧក្រិដ្ឋ (ឧ. procédure criminelle); ដែលប្រព្រឹត្តបទឧក្រិដ្ឋ (ឧ. homme criminel) ។ *n.* ឧក្រិដ្ឋជន (ឧ. punir un criminel)

criminellement *adv.* ដោយបទឧក្រិដ្ឋ; ចំពោះសាលាឧក្រិដ្ឋ

criminologie *n.f.* ឧក្រិដ្ឋវិទ្យា (វិទ្យាសាស្ត្រខាងបទឧក្រិដ្ឋ)

criminologiste *n.* ឧក្រិដ្ឋវិទូ

crin *n.m.* ប្រែង, រោមកន្ទុយ ។ crin végétal ឆក់ត្នោត(ឬរុក្ខជាតិឯទៀត) ។ à tous crins ដែលមានរោមគ្រប់;

au fig. ខ្លាំង, ធន់ ។ être comme un crin ឆាប់ខឹង

crincrin *n.m.* ទ្រមិនល្អ(ឮឮសូរព្រាំងៗ)

crinière *n.f.* កេសរ (សំណុំរោមកសត្វចតុប្បាទមានសិង្ហជាដើម); សក់ក (សេះ) ។ *Fam.* សក់វែង

crique *n.f.* កៀន (ឈូងតូច)

criquet *n.m.* កណ្ដូប; សេះកំសោយ ។ *Fig.* មនុស្សស្គម

crise *n.f.* វិបត្តិ ។ crise économique វិបត្តិសេដ្ឋកិច្ច ។ crise financière វិបត្តិហិរញ្ញវត្ថុ ឬ ហិរញ្ញវិបត្តិ ។ crise ministérielle វិបត្តិគណរដ្ឋមន្ត្រី ។ crise politique វិបត្តិនយោបាយ

crispant,e *a.* ដែលធ្វើឲ្យក្ដាញ់

crispation *n.f.* ការរួញ (ឧ. crispation du cuir sous l'action du feu); ការរមួលសាច់ដុំ, ការញាក់សរសៃ ។ *Fam.* ការក្ដាញ់

crisper *v.t.* ធ្វើឲ្យរួញ-ឲ្យរមួល ឬ ឲ្យញាក់ (ឧ. liqueur qui crispe l'estomac; douleur qui crispe le visage) ។ crisper les nerfs ឬ crisper ធ្វើឲ្យញាក់សរសៃវិញ្ញាណ (ធ្វើឲ្យអន្ទះអន្ទែង) ។ crisper les poings ក្ដាប់ដៃយ៉ាងខ្លាំង។ *Fig.* ធ្វើឲ្យក្ដាញ់ ។ musique qui crispe les nerfs ភ្លេងដែលធ្វើឲ្យរសាប់រសល់ ឬ អន្ទះអន្ទែង

criss *n.m.* កាំបិតស្នៀតផ្លែរមួល

crissement *n.m.* សូរសង្កៀត, សូរលាន់; ការសង្កៀត, ការលាន់

crisser *v.i.* សង្កៀត, លាន់សូរ (ឧ.gravier qui crisse sous le pas)

cristal *n.m.* ក្រាម (គ្រាប់ល្អិតនៃស្ករ អំបិល ។ល។ ដែលកក); ផលិក (ឈ្មោះថ្មកែវវិសេសមួយយ៉ាងមានពណ៌ស) ។ *pl.* ផលិកភណ្ឌ ។ *Fig.* ភាពថ្លាធ្លង់

cristallerie *n.f.* ការធ្វើផលិក; កន្លែងធ្វើផលិក; ផលិកភណ្ឌ

cristallier *n.&a.* អ្នកឆ្លាក់ផលិក

cristallin,e *a.* ផលិក(ឧ.corps cristallin); ដូចផលិក (ឧ.eaux cristallines; voix cristalline) ។ roche cristalline ម.ព. roche ។ *n.m.* កែវភ្នែក

cristallisable *a.* អាចធ្វើឲ្យឡើងក្រាមបាន (ឧ.solution cristallisable)

cristallisant,e *a.* ដែលឡើងក្រាម (ឧ. corps cristallisant); ដែលធ្វើឲ្យឡើងក្រាម (ឧ. propriétés cris-

tallisantes)

cristallisation *n.f.* ដំណើរឡើងក្រាម, ការធ្វើឲ្យឡើងក្រាម

cristallisé,e *a.* ក្រាម (ឧ. sucre cristallisé)

cristalliser *v.t.* ធ្វើឲ្យឡើងក្រាម (ឧ. cristalliser du sucre)។ *Fig.* ធ្វើឲ្យជាក់ច្បាស់ (ឧ. cristalliser des impressions confuses)។ *v.i.* ឡើងក្រាម។ *v.i.* se cristalliser *v.pr.* ឡើងក្រាម ។ *Fig.* ឡើងជាក់ច្បាស់(ឧ.souvenirs qui se cristallisent)

cristallisoir *n.m.* ជើងសម្រាប់ធ្វើឲ្យឡើងក្រាម

cristalloïde *a.* ដូចក្រាម(ឧ. pierre cristalloïde)

critérium ឬ **critère** *n.m.* លក្ខណវិនិច្ឆ័យ(ឧ.l'évidence est le critère de la vérité ភាពជាក់ស្តែងជាលក្ខណវិនិច្ឆ័យនៃការពិត)

criticisme *n.m.* វិវេចនានិយម (លទ្ធិទស្សនវិជ្ជារបស់កង្ត ទស្សនវិទូជាតិអាល្លឺម៉ង់ដែលកំណត់រកព្រំដែននៃបញ្ញាមនុស្ស)

critiquable *a.* អាចធ្វើវិវេចនាបាន (អាចនិន្ទា-បន្ទោស ឬ រិះគន់បាន) (ឧ. attitude critiquable)

critique *a.* ដែលសម្រេចការស្លាប់រស់ (ឧ.phase, période critique)។ *Par ext.*ដែលសម្រេចវិសនា,ប្រកបដោយគ្រោះថ្នាក់ (ឧ. position critique); នៃវិវេចនា (ឧ. observations critiques) ។ esprit critique គតិវិវេចនា; *par ext.* គំនិតចូលចិត្តរិះគន់ ឬ និន្ទា ។ *n.m.* អ្នកធ្វើវិវេចនា(ឧ. un critique dramatique); អ្នករិះគន់, អ្នកនិន្ទា (ឧ.critique impitoyable) ។ *n.f.* វិវេចនា, វិគ្រោះ (ឧ. critique dramatique, musicale; faire la critique d'un roman); អ្នកធ្វើវិវេចនាទាំងឡាយ (ឧ. faire taire la critique); ការរិះគន់, ការនិន្ទា (ឧ. ne pas supporter les critiques)

critiquer *v.t.* ធ្វើវិវេចនា, ធ្វើវិគ្រោះ, រិះគន់, និន្ទា

critiqueur *n.m.* អ្នកតែងរិះគន់

croassant,e *a.* ដែលស្រែក (ក្អែក)

croassement *n.m.* សម្រែកក្អែក

croasser *v.i.* ស្រែក(ក្អែក) (កុំប្រឡូកនឹង

ពាក្យ coasser)

croc *n.m.* កង្វារ; ទំពក់ ។ *Mar.* យ្លោល មានទំពក់ ។ moustaches en croc ពុកមាត់ងពុង (ដូចទំពក់) ។ *pl.* ចង្កូម ។ *Fam.* donner un coup de croc ខាំ ។ *Pop.* faire un croc ខ្ចីប្រាក់គេមិនសង ។ croc à éléphant កង្វេរ (សម្រាប់ការដំរី)

croc-en-jambe *n.m.* ការខ្ទាស់ជើង ផ្ដួល (*pl.* des crocs-en-jambe)

croche *a.* ខុប, គាំ, រមួល (ឧ. jambe croche) ។ *Mus.* ទំពក់ ។ *n.f. pl.* ដង្កាប់ដាងដែក

croche-pied *n.m.* ម.ព. croc-en-jambe (*pl.* des croche-pieds)

crocher *v.t.* ឆ្កឹក; ខាំនឹងចង្កូម

crochet *n.m.* ទំពក់តូច; កង្វារ; ងៀង; ស្រឡូវ; ម្ជុលចាក់មានងៀង (ឧ. broder au crochet) ។ សក់ខ្វង់ត្រង់ស្មៀគន្ធ *Gram.* វង់ដង្កៀប [ ] ។ *Boxe* ការដាល់ខារ ។ *Fig.* ផ្លូវកោង ។ faire un crochet ដើរគេច; ដើរកោង ។ clou à crochet ដែកគោលទំពក់ ។ *pl* ចង្កូម (ពស់មានពិស) (ឧ. les crochets de la vipères ont creux); ទំពក់ (សម្រាប់អ្នកលីសែង) ។ être aux crochets de quelqu'un ស៊ីដឹងគេ (ស៊ីដោយសារគេ) ។ *Mus.* ងៀង

crochetable *a.* អាចផ្ដើះដោយទំពក់បាន (បើកសោដោយទំពក់)

crochetage *n.m.* ការផ្ដើះដោយទំពក់

crocheter *v.t.* ផ្ដើះសោដោយទំពក់; ចាក់ (ធ្វើជាសំលៀកបំពាក់)

crocheteur *n.m.* អ្នកលីសែង ។ *Par ext.* មនុស្សកម្រោល ។ crocheteur de serrures អ្នកផ្ដើះសោដោយទំពក់

crochu,e *a.* ខុប ។ avoir les mains crochues មានដៃមានជើង (ពូលចិត្តលួច)

crocodile *n.m.* ក្រពើ (cri: le crocodile vagit ក្រពើកេវ) ។ *Fig.* larmes de crocodile ការធ្វើពុតដាយំ

crocodiliens *n.m.pl.* សត្វសន្ដានក្រពើ

croire *v.t.* ជឿ (ឧ. nous sommes prompts à croire tout ce qui nous flatte; croire quelqu'un; croire son médecin) ។ *Relig.* ជឿ, មានសទ្ធា (ឧ.

ceux qui souffrent éprouvent un plus grand besoin de croire; il croit pleinement); ស្មាន (ឧ.j'ai cru bien faire; croire habile)។

v.i. ជឿ (ឧ. croire à la parole de quelqu'un; croire en Dieu; croire en la médecine, aux médecins)។

Loc. adv. c'est à n'y pas croire គិតពិបាកនឹងជឿ។ croire en soi ទុកចិត្តលើខ្លួនឯងពេញទី។ faire croire ធ្វើឲ្យជឿ (ឧ. personne à qui l'on fait croire tout ce qu'on veut)។ se faire croire ធ្វើឲ្យគេជឿខ្លួន (ឧ. les menteurs réussissent rarement à se faire croire); ជឿខ្លួនឯង (ឧ. à force de se dire qu'on est un sot, on se le fait croire)។ à ce que je crois ឬ comme je crois ឬ que je crois ឬ je crois តាមយោបល់ខ្ញុំ។ comme vous pouvez croire ដូចលោកប្រាប់ស្រាប់។ je crois bien ខ្ញុំជឿដាក់។ *Pop.* j'te crois... ! ពិតហើយ, ប្រាកដហើយ។

Loc. prov. croire comme parole d'Evangile ឬ comme l'Evangile ឬ comme article de foi ជឿដាក់ណាស់។ si vous ne le croyez pas, allez y voir បើលោកមិនជឿសុំទៅពិនិត្យខ្លួនឯង។ j'aime mieux le croire que d'y aller voir ខ្ញុំសុំមិនបាច់រកខុសត្រូវទេ (ខ្ញុំមិនជឿទេ ប៉ុន្តែខ្ញុំមិនចង់ឈ្លោះហាញទេ)។ croyez cela et buvez de l'eau ឬ croyez cela et tenez-vous les pieds chauds ម.ព. boire។

se croire *v.pr.* នឹកស្មានខ្លួនឯង (ឧ.se croire un grand homme; il se croit heureux)។ s'en croire ធ្វើតាមអំពើចិត្តខ្លួន។ s'en croire beaucoup នឹកស្មានថាខ្លួនឯងគ្រាន់បើណាស់។ មានគេជឿ (ឧ.il est des choses qui se répandent et se croient à la légère)

croisade *n.f.* បូជនីយកិច្ច (ឧ. partir pour la croisade)។ *Fig.*

croisade antialcoolique បូជនីយកិច្ចប្រឆាំងនឹងការសេពសុរា។ croisade de l'indépendance បូជនីយកិច្ចដើម្បីឯករាជ្យ

croisé *n.m.* បូជនីយជន (អ្នកធ្វើបូជនីយកិច្ច)

croisé,e *a.* ដែលខ្វែងគ្នា។ feux croisés ការបាញ់ឆ្លាស់។ mots croisés ម.ព. mots ។ sangs croisés ឈាមកាត់

croisée *n.f.* បង្អួច; ខ្វែង (ទីដែលមានវត្ថុពីរខ្វែងគ្នា) ។ la croisée de deux chemins ផ្លូវខ្វែង, ផ្លូវក្រឡែងកែង

croisement *n.m.* ការដាក់ខ្វែង ។ croisement des bras ការឱបដៃ ។ ការជួបគ្នា (ឧ. croisement de deux voitures); ផ្លូវខ្វែង, ផ្លូវក្រឡែងកែង (ឧ. s'arrêter à un croisement) ។ *Biol.* ការបង្កាត់ពូជ (ឧ. le croisement de l'âne et de la jument donne le mulet)

croiser *v.t.* ដាក់ខ្វែង; ដាក់ប្រជ្រួសមុខគ្នា (ឧ. croiser un veston); ខ្វែង, កាត់ទទឹង (ឧ. sentier qui croise une route); ជួប (ឧ. croiser quelqu'un dans la rue) ។ *Biol.* បង្កាត់ (សត្វ); ខ្វែងពោល (ឧ. croiser un alinéa)។ croiser la baïonnette ភ្ជង់លំពែងបំពុះទុង។ *Fig.* croiser (ឬ se croiser) les bras ឱបដៃ, នៅស្ងៀម។ *v.i.* *Mar.* ល្បាតផ្លូវ ។ se croiser *v.pr.* ជួបគ្នា (ដោយមកពីទិសផ្ទុយគ្នា); ចូលរួមក្នុងបូជនីយកិច្ច

croisette *n.f.* កាកបាទឬឈើឆ្កាងតូច

croiseur *n.m.* នាវាល្បាត

croisière *n.f.* បរិគមន៍, ដំណើរទេសចរតាមផ្លូវទឹកឬតាមអាកាស។ *Mar.* ការយាមល្បាតដោយនាវា; នាវាល្បាត

croisillon *n.m.* មេទទឹងនៃឈើខ្វែង, មេនីមួយៗនៃឈើខ្វែង

croissance *n.m.* ការលូតលាស់, ការចម្រើន

croissant *n.m.* អឌ្ឍចន្ទ; នំប៉័ងរាងអឌ្ឍចន្ទ ។ *Par ext.* សាសនាអ៊ីស្លាម; អាណាចក្រទួរគី

croissant,e *a.* ដែលលូតលាស់, ដែលចម្រើន។ lune croissante ខ្នើត

croit *n.m.* ការចម្រើននៃហ្វូងសត្វ (ដោយសារយកូន)

croitre *v.i.* ចម្រើន, កើនឡើង, លូត-

ឈាស់(ឧ. arbre qui croît); ជន់, ឡើង (ឧ. la rivière a crû; la marée croît); ធំឡើង(ឧ. enfant qui croît)។ *Fig.* ចម្រើន, មានកាន់តែច្រើន (ឧ. les préjugés n'ont fait longtemps que croître en France; son courage croissait avec le péril); រឹតតែខ្លាំងឡើង (ឧ. le bruit croît; le vent croît); ចម្រើន, ដុះដាល (ឧ. les facultés de l'intelligence croissent par le travail); រឹតតែយូរ, រឹតតែវែង (ឧ. les jours croissent en hiver et au printemps); ដុះ, លូតលាស់ (ឧ. le bouleau ne croît que dans les pays froids; le blé croît presque partout)។

Impers. មានដុះ (ឧ. il croît en France des plantes de tous les climats)។

Loc. div. croître en ឬ dans រីកខាង (ឧ. croître en larger, en volume); ចម្រើនខាង(ឧ. croître en sagesse, en vertu)។ *Fam.* ne faire que croître et embellir រឹតតែធំហើយរឹតតែល្អឡើង។ *Fig. & iron.* la sottise tous les jours ne fait que croître et embellir រឹតតែភ្លីភ្លើឡើងមួយថ្ងៃបន្តិចៗ។ l'herbe y croît មានតែស្មៅដុះ (កន្លែងគ្មានមនុស្សនៅ); *au fig.* គឺជារបស់គេទុកចោល (ដែលគេមិនត្រូវការ)។

Prov. à chemin battu il ne croît point d'herbes ម.ព. chemin។ mauvaise herbe croît toujours *Par plais.* ក្មេងខិលឆាប់ធំណាស់; *par ext.* កូនក្មេងឆាប់ធំណាស់។

v.i. ធ្វើឲ្យចម្រើន, ធ្វើឲ្យលូតលាស់, ធ្វើឲ្យរឹតតែខ្លាំងឡើង (ឧ. m'ordonner du repos c'est croître mes malheurs; que ce nouvel honneur va croître son audace!)

croix *n.f.* កាកបាទ, ឈើឆ្កាង (ឧ. élever, planter une croix)។ *Par ext.* សាសនាគ្រិស្ត (ដោយរឮកដល់ព្រះយេស៊ូគ្រិស្តដែលត្រូវឆ្កាង)។ បាងណាង (គ្រឿងអលង្ការ, គ្រឿងឥស្សរិយយស); ខាងមុខ ឬ ខាងផ្កា

(រូបិយវត្ថុ)(ឧ. jouer à croix ou pile លេងផ្កាប់ផ្ងារ) ។ signe de croix សញ្ញាកាកបាទ ។ ទុក្ខវេទនា (ឧ. chacun porte sa croix dans ce monde) ។ croix gammée សួស្តិកៈ 卐 ។ croix rouge ឬ de Genève កាកបាទក្រហម ។ en croix *loc. adv.* ជាកាកបាទ, ជាឈើឆ្កាង, ខ្វែង (ឧ. bras en croix)

crône *n.m.* ម៉ាស៊ីនស្ទូចសម្រាប់ផ្ទុក ឬរើបន្ទុកនាវា

croquant *n.m.* មនុស្សតូចតាចឬពោកយ៉ាក

croquant,e *a.* ស្រួយខ្ទោក(ឧ. biscuit croquant) ។ *n.m.* ម.ព. croquante

croquante *n.f.* រលីង (គ្រាប់ផ្លែឈើលីងមានលើងឈូកជាដើម)

croque au sel (à la) *loc. adv.* នៅជ្រលក់អំបិល (ដែលគេជ្រលក់អំបិលអាស្រ័យនៅ)

croquembouche *n.f.* នំស្រួយ, នំក្រុក

croque-mitaine *n.m.* ទីងមោង(ពាក្យសម្រាប់បន្លាចក្មេង) (*pl.* des croque-mitaines)

croque-mort *n.m.* អ្នកភ្លុក (អ្នកដឹកខ្មោច) (*pl.* des croque-morts)

croquenot *n.m. Pop.* ស្បែកជើង

croque-note *n.m. Fam.* អ្នកភ្លេងមិនប្រសប់(*pl.* des croque-notes)

croquer *v.i.* ទំពាឮក្រួបៗ ។ *v.t.* ទំពារបស់ស្រួយ (ឧ. croquer des noisettes) ។ *Par ext.* ទំពាស៊ី (ឧ. croquer une souris) ។ *Fig.* បង្ហិន (ឧ. croquer un héritage) ។ *Fam.* croquer le marmot ចាំយូរ ។ គូរភស (ឧ. croquer un paysage) ។ **joli** à croquer ល្អដូចគំនូរ (ល្អណាស់គួរឲ្យចង់គូររូបទុក)

croquette *n.f.* ចាយ៉ (ម្ហូបចៀនធ្វើដោយសាច់នឹងបន្លែ)

croqueur,euse *n.* អ្នកទំពាស៊ី (ឧ. le renard, croqueur de poules)

croquignole *n.f.* នំស្រួយមួយយ៉ាង; ការបូតច្រមុះ

croquignolet,ette *a. Fam.* តូចច្រឡឹង

croquis *n.m.* គំនូរភស ។ *Fig.* សេចក្ដីព្រាង

croskill *n.m.* រនាស់បំបែកដុំដី

croquisseur *n.m.* អ្នកគូរភស

cross-country *n.m.* ការរត់ប្រណាំងកាត់ឧបសគ្គ

crosse *n.f.* ដំបងវាយបាល់ឬកូនគោល; ល្បែងកូនគោល; ស្លាកកាំភ្លើង។ *Pop.* chercher des crosses à quelqu'un រករឿង។ crosser *v.t.* វាយបាល់ឬកូនគោល ។ *Fig. & fam.* មើលងាយហើយធ្វើបាប ។ *v.i.* លេងល្បែងកូនគោល

crosseur *n.m.* អ្នកលេងកូនគោល ។ *Fig.* អ្នកមើលងាយហើយធ្វើបាប

crotale *n.m.* ពស់វែកមួយយ៉ាងមានកណ្ដឹងនៅកន្ទុយ (ហៅថា serpents à sonnettes ដែរ)

croton *n.m.* ដើមតាក្រៅ

crotte *n.f.* អាចម៍សត្វចំពួកខ្លះ (ដូចជាឆ្កែ, កណ្ដុរ, ពពែ, ទន្សាយ); ភក់; ក្រមរដំបៅ ។ *Fig.* សេចក្ដីគោកយ៉ាក, សេចក្ដីថោកទាប។ crotte de chocolat ស្ករគ្រាប់សូកូឡា

crotter *v.t.* ធ្វើឲ្យប្រឡាក់ភក់ ។ se crotter *v.pr.* ប្រឡាក់ភក់ខ្លួនឯង

crottin *n.m.* អាចម៍សេះ

croulant,e *a.* ដែលរលំ (ឧ. murs croulants)។ *Fig.* ដែលហៀបនឹងរលំ (ឧ. empire croulant) ។ *n. Pop.* កញ្ចាស់, ខេកខាក

croulement *n.m.* ការរលំ

crouler *v.i.* រលំ (ឧ. cette maison croule)។ *Par ext.* ញ័រ (ឧ. la salle croulait sous les applaudissements) ។ *Fig.* ធ្វើឲ្យអន្តរាយ(ឧ. cette objection fait crouler votre système); ស្រែក (ប្រទៀប) ។ *v.t.* រលំ

croupe *n.f.* ត្រគាកសត្វចំពួកខ្លះ (មានសេះជាដើម) ។ *Géogr.* កូនភ្នំ ។ en croupe *loc. adv.* ជិះសេះត្រងរ

croupetons(à) *loc.adv.* ច្រហោង

croupi,e *a.* ដែលដក់ត្រាំក្រែង (ឧ. les eaux croupies sont très dangereuses à boire)

croupier *n.m.* សមាជិកូបត្ថម្ភ [–ជាត់-ចឺម] (អ្នកអបស្ទបការខាតចំណេញរបស់សមាជិកម្នាក់ៗ)

croupière *n.f.* ខ្សែហាង(សម្រាប់សេះ); ខ្សែក្រពាត់(សំរាប់ដំរី)។ tailler des croupières à quelqu'un ដេញពីក្រោយ; *au fig.* ធ្វើឲ្យអំពល់

croupion *n.m.Fam.* ពន្ធញគូថ,កន្ទុកអ្វែងបក្សី

croupir *v.i.* មានក្លិនស្អុយ (ចំពោះទឹក

ដែលមានវត្ថុផ្សេងៗរលួយ); រលួយក្នុងទឹក។ *Fig.* រស់នៅដោយហោកទាប (ឧ. croupir dans l'ignorance)

croupissant.e *a.* ស្អុយរលួយ

croupissement *n.m.* ការស្អុយរលួយ

croustillant,e *a.* ស្រួយស្រើប

croustille *n.f.* ក្តាំងតូច ។ *Fam.* & *par ext.* ការស្រស់ស្រួប;ដំឡូងឆាប

croûte *n.f.* ក្តាំង, ក្រមរ ។ casser la croûte ឬ une croûte ស្រស់ស្រួប ។ *Fig.* រូបគំនូរមិនល្អ (ឧ. peintre qui ne fait que des croûtes) ។ croûte terrestre សំបកផែនដី (ភាគមុខលើនៃផែនដី)

croûteux,euse *a.* ដែលមានក្តាំង,ដែលមានក្រមរ (ឧ. dermatose croûteuse)

croûton *n.m.* ចុងនំប៉័ង; បំណិតនំប៉័ងជៀន ។ *Fig.& fam.* មនុស្សមិនដឹងខ្យល់ (ល្ងង់)

croyable *a.* គួរជឿ

croyance *n.f.* ជំនឿ, សទ្ធា (ឧ. cela passe toute croyance; croyances politiques)

croyant,e *a.&n.* អ្នកជឿសាសនា

cru *n.m.* ផលិតកម្មស្រាទំពាំងបាយជូរ (ឧ. les crus de Bourgogne sont universellement estimés); កន្លែងដាំដំណាំពិសេស។ *Fig.* dire une chose de son cru និយាយបញ្ចេញពីមាត់ឯង

cru,e *a.* ឆៅ (ឧ. viande crue)។ soie crue សូត្រឆៅ ។ ដែលឲ្យទាស់ចិត្ត ឬ ទាស់ត្រចៀក (ឧ. anecdote un peu crue); ខ្លាំងពេក (ឧ. une lumière crue); ឆើតពេក(ឧ. une couleur crue)។ à cru *loc.adv.* ចំ (ឧ. lumière qui tombe à cru) ។ monter à cru ជិះផ្ទាល់ (គ្មានកែប)

cruauté *n.f.* បណ្តាភាព, ភាពឃោរឃៅ ; ភាពសាហាវ (ឧ. cruauté du tigre) ។ la cruauté du destin ភាពវិសនាអាក្រក់ ។ អំពើឃោរឃៅ (ឧ. la cruauté d'un acte ; réprimer les cruautés)

cruche *n.f.* ក្អម ។ *Fig.* & *Pop.* មនុស្សកម្លៅ ។ *Prov.* tant va la cruche à l'eau qu'à la fin elle se brise ក្អមដែលយើងប្រើគង់តែបែកថ្ងៃណាមួយ; កំហុសដែលយើងប្រព្រឹត្តញយ ៗ គង់នឹងឲ្យទោសថ្ងៃ

ណាមួយ

cruchée *n.f.* ចំនួនមួយក្អម

cruchette *n.f.* ឬ **cruchon** *n.m.* កូនក្អម

crucial,e,aux *a.* ដែលខ្វែងជាជើងក្អែក (ឧ. incision cruciale)។ *Phil.* សំខាន់(ឧ. expérience cruciale; question cruciale)

cruciféracées *n f.pl.* គោត្តកកូល

crucifère *a.* ដែលទ្រឈើឆ្កាង (ឧ. colonne crucifère)។ *n.m. pl.* ម.ព. cruciféracées

crucifié, *a.* ដែលត្រូវឆ្កាង។ *Fig.* ដែលរងទារុណកម្ម។ *n.m.* Le crucifié ព្រះយេស៊ូ

crucifiement *n.m.* ឬ **crucifixion** *n.f.* ការឆ្កាង; រូបគំនូរព្រះយេស៊ូគ្រិស្តត្រូវឆ្កាង ។ *Fig.* ការធ្វើទារុណកម្ម

crucifier *v.t.* ឆ្កាង។ *Fig.* ធ្វើទារុណកម្ម

crucifix *n.m.* រូបចម្លាក់ព្រះយេស៊ូជាប់ឆ្កាង (ឧ. crucifix de bois)

crucifixion *n.f.* ព.ម. crucifiement

cruciforme *a.* ជារាងកាកបាទ ឬ ជារាងឈើឆ្កាង

cruciverbiste *n.* អ្នកចូលចិត្តលេងពាក្យខ្វែង

crudité *n.f.* ភាពឆៅ(ឧ. crudité des fruits); ភាពពិបាករំលាយ(នៃអាហារឆៅ) (ឧ. crudité des fruits verts)។ *Fig.* ភាពខ្លាំងពេក ឬ ឆើតពេក(ឧ. crudité de la lumière); ភាពច្រឡោះបោះ (ឧ. crudité du langage)។ *pl.* ផ្លែឈើឬបន្លែស្រស់ (ឧ. manger des crudités)។ *Fig.* សំដីអាសគ្រាម(ឧ. dire des crudités)

crue *n.f.* ជំនន់ទឹក

cruel,elle *a.* ឃោរឃៅ(ឧ. un cruel tyran); ដែលសំដែងអំពើឃោរឃៅ (ឧ. sourire cruel); អាក្រក់ណាស់, គ្មានមេត្តា(ឧ. destin cruel); ដែលឲ្យកើតទុក្ខខ្លាំង(ឧ. perte cruelle)

cruellement *adv.* យ៉ាងឃោរឃៅ; ដោយគ្មានមេត្តា

crûment *adv.* ដោយទ្រគោះ; ដោយឥតញញើត (មាត់ឆៅ) (ឧ. dire crûment les choses ជាចំៗ)

crural,e,aux *a.* នៃជើង (ឧ. nerf crural)

crustacés *n.m.pl.* សត្វវង្គជាតិ[ស័គ-គៈ-វ័ង-កៈ-](*sing.* un crustacé)

cryogène *a.* សីតុប្បត្តិ,ដែលធ្វើឲ្យត្រជាក់

cryogénie *n.f.* សីតកម្ម,ការធ្វើឲ្យត្រជាក់

cryothérapie *n.f.* សីតតិកិច្ចា

cryptogame *a.&n.f.* បដិប្ពន្ធជាតិ

cryptogamique *a.* បដិប្ពន្ធជាត, ដែលបង្កដោយផ្សិត (ឧ. le midiou est une maladie cryptogamique)

cryptogénétique *a.* ដែលគេមិនដឹងដើមហេតុ(ឧ. une anémie cryptogénétique)

cryptogramme *n.m.* រហស្សលេខ (លិខិតសរសេរជាអក្សរសម្ងាត់)

cryptographe *n.* អ្នករហស្សលិខសាស្ត្រ

cryptographie *n.f.* រហស្សលិខសាស្ត្រ

cryptographique *a.* នៃរហស្សលិខសាស្ត្រ

cubage *n.m.* ការវាស់ជាគីប (ឧ. le cubage des bois)

cubain,e *a.&.n.* នៃប្រទេសគុយបា

cubature *n.f.* ការផ្ទេរជាគីប

cube *n.m.* គីប, ធម្យ័ង្ស(ដុំមានបាទប្រាំមួយជាបួនជ្រុងស្មើ) (ឧ. le volume d'un cube s'obtient en multipliant trois fois par elle-même la longueur de son côté) ។ *Math.* cube d'un nombre គីបនៃចំនួន (ឧ. 27 est le cube de 3) ។ *a.* mètre cube ម៉ែត្រគីប

cuber *v.t.* គុណគីប; រកទំហំជាគីប (ឧ. cuber des pierres); មានចំណុះ (ឧ. ce tonneau cube 300 litres)

cubique *a.* នៃគីប ។ racine cubique ម.ព. racine ។ ធម្យ័ង្ស (ដែលជាដុំមានបាទប្រាំមួយជាបួនជ្រុងស្មើ)

cubisme *n.m.* ធម្យ័ង្គនិយម

cubiste *a.&.n.* អ្នកធម្យ័ង្គនិយម

cubital,e,aux *a.* នៃកែងដៃ

cubitière *n.f.* គ្រោះកែងដៃ

cubitus *n.m.* ឆ្អឹងធំនៃដើមដៃ

cucumis *n.m.* ត្រសក់ផ្អែ

cucurbitacées *n.f. pl.* សន្តានត្រឡាចល្ពៅ (*Sing.* une cucurbitacée)

cueillage *n.m.* ឬ **cueillaison** ឬ **cueille** *n.f.* ការបេះ; រដូវបេះផ្លែ

cueille-fruits *n.m. inv.* ម.ព. cueilloir

cueillette *n.f.* ការបេះ

cueilleur,euse *n.* អ្នកបេះ

cueillir *v.t.* បេះ ។ *Fig.* cueillir un baiser ថើប ។ cueillir des

lauriers បានកិត្តិគុណ ។ *Fam.* ចាប់ (ឧ. cueillir un voleur)

cueilloir *n.m.* កញ្ច្រែងដាក់ផ្លែឈើដែលបេះ; ទំពក់បេះផ្លែឈើ

cuiller ឬ **cuillère** *n.f.* ស្លាបព្រា ។ cuiller à pot វែកសម្ល; វែង

cuillerée *n.f.* ចំណុះស្លាបព្រា ឬ វែក

cuilleron *n.m.* ផ្លែស្លាបព្រា

cuir *n.m.* ស្បែក; ស្បែកសម្លាប់ ។ cuir chevelu ស្បែកក្បាល

cuirasse *n.f.* ក្រោះ(សម្រាប់ការពារដងខ្លួនមនុស្ស, នាវា, រថ); ស្រោមរឹងរបស់សត្វបំពួកខ្លះ ។ défaut de la cuirasse ចន្លោះក្រោះ; *au fig.* ចន្លោះចាប់ភ្លាក់បាន

cuirassé,e *a.* ដែលពាសដោយក្រោះ(ឧ. navire cuirassé) ។ *Fig.* អាចទប់ ឬ ការពារបាន (ឧ. être cuirassé contre les passions, le remords)

cuirassé *n.m.* នាវាក្រោះ

cuirassement *n.m.* ការពាសក្រោះ; ក្រោះ

cuirasser *v.t.* ពាសក្រោះ។ *Fig.* បង្អឹកឲ្យរឹង (ឧ. cuirasser son cœur contre l'émotion)។ se cuirasser *v.pr.* បង្អឹកខ្លួន (ឧ. se cuirasser contre l'adversité)

cuirassier *n.m.* រ៉ឺម៉ឹត [រ៉ឺម-មិត], ទាហានពាក់ក្រោះ

cuire *v.t.* ចំអិន; ដណ្តាំ; ដុត; បន្ទុំ។ *v.i.* ឆ្អិន (ឧ. le dîner cuit)។ *Fig.* ក្រហាយ, ឈឺចាប់ ឬ ផ្សា (ឧ. les yeux me cuisent)។ *Impers.* il vous en cuira អ្នកនឹងស្តាយក្រោយ ។ *Prov.* trop gratter cuit,trop parler nuit អេះច្រើនក្រហាយ និយាយច្រើនអន្តរាយ

cuisage *n.m.* ការដុតឈើធ្វើធ្យូង

cuisant,e *a.* ឆាប់ឆ្អិន (ឧ. haricots cuisants); ខ្លាំង (ឧ. douleur cuisante)។ *Fig.* ដែលឲ្យឈឺចាប់ (ឧ. remarque cuisante)

cuiseur *n.m.* ឆ្នាំង ឬ ខ្ទះធំ

cuisine *n.f.* ផ្ទះបាយ; សូទវិទ្យា, សិល្បៈខាងធ្វើម្ហូប; ម្ហូប(ឧ.manger de la bonne cuisine បរិភោគម្ហូបឆ្ងាញ់)។ *Fig.* &*fam.* កលល្បិច (ឧ. la cuisine politique, électorale)។ *Prov.* petite cuisine agrandit la maison ស៊ីតិចឆាក់ប្រាក់ឲ្យចម្រើនធន

cuisiner *v.i.* ធ្វើម្ហូប។ *v.t.* ស្ល, ឆ្អិនគ្រឿង (ឧ. cuisiner un ragoût) ។ *Fig.* រៀបចំ (ឧ. cuisiner une élection) ។ *Fig. & fam.* សួរ, ឈ្លបសួរ

cuisinier,ère *n.* ចុងភៅ ។ *n.f.* ជើងចង្ក្រាន

cuissard *n.m.* ក្រោះភ្លៅ; ផ្នែកស្រោមជើងគ្របភ្លៅ

cuisse *n.f.* ភ្លៅ ។ *Fam.* se croire sortir de la cuisse de Jupiter ឡូតណាស់

cuisson *n.f.* ការដណ្ដាំ, ការចំអិន (ឧ. la cuisson du pain); ភាពឆ្អិន។ *Par anal.* ភាពផ្សា ឬ ក្រហាយ

cuissot *n.m.* ភ្លៅ (ជ្រូក-ក្ដាន់)

cuistot *n.m. Arg. mil. & pop.* ចុងភៅ

cuistre *n.m. Fam.* មនុស្សសំដីខ្ពស់ គួរឲ្យអស់សំណើច

cuistrerie *n.f.* សំដីខ្ពស់; ការធ្វើឫកគួរឲ្យអស់សំណើច

cuit,e *a.* ឆ្អិន

cuite *n.f.* ការដុតឥដ្ឋឬដុតចាន; រ៉ូវដែលគេចំអិនតែម្ដង។ *Pop.* ការស្រវឹង (ឧ. prendre une cuite ផឹកមួយស្រវឹង)

cuiter (se) *v.pr. pop.* ស្រវឹង

cuivrage *n.m.* ការពាសឬស្រោបស្ពាន់

cuivre *n.m.* អាគ្រូដ, ស្ពាន់

cuivré,e *a.* ដូចស្ពាន់ (ឧ. teint cuivré ; voix cuivrée)

cuivrer *v.t.* ពាស ឬ ស្រោបស្ពាន់; ធ្វើឲ្យឡើងពណ៌ស្ពាន់

cuivrerie *n.f.* អាគ្រូដម័យ, វត្ថុ ឬ គ្រឿងលំអធ្វើដោយស្ពាន់

cuivreux,euse *a.* ដែលមានជាតិស្ពាន់; ជាជាតិស្ពាន់; ដូចស្ពាន់ (ឧ. couleur cuivreuse)

cul *n.m.* គូថ; បាត (ឧ. un cul de bouteille)

culasse *n.f.* បំពង់កាំភ្លើង (ខាងប្រកគ្រាប់) ។ fusil se chargeant par la culasse កាំភ្លើងកាប់ប្រក។ *Pop.* ខ្នង ។ être renforcé par la culasse មានគូថ ង

culbute *n.f.* ការដាំទីង (ឬដាំដូង); ការដួលដំណាំ (ឧ. faire une culbute dans l'escalier) ។ faire la culbute លក់ទូតម្លៃទិញ ។ *Fig. & fam.* ការវិនាស, ការរលំ (ឧ. la culbute d'un ministère)

culbutement *n.m.* កាផ្ដួល; ការដាំទីង។

Fig. ការផ្ចាញ់

culbuter *v.t.* ផ្តួល។ *Fig.* ផ្ចាញ់ (ឧ. culbuter l'ennemi)។ *v.i.* ផាំទឹង

culbuteur *n.m.* គ្រឿងប៉ប៉ះ

culbutis *n.m.* គំនររបស់រលំ

cul-de-basse-fosse *n.m.* គុកងងឹតក្នុងដី (*pl.* des culs-de-basse-fosse)

cul-de-jatte *n.m.* មនុស្សខ្វិន ឬ កំបុតដៃជើង (*pl.* des culs-de-jattes)

cul-de-sac *n.m.* ផ្លូវទាល់ ។ *Fig.* អាជីពគ្មានអនាគត (*pl.* des culs-de-sac)

culer *v.i.* ថយ (ឧ. navire qui cule)

culex *n.m.* មូស(គេហៅcousinក៏បាន)

culière *n.f.* ខ្សែក្រពាត់(សម្រាប់ចងកូបពាក់តាមកន្ទុយដំរី)

culinaire *a.* នៃម្ហូបអាហារ។ art culinaire សូទវិជ្ជា, វិជ្ជាធ្វើម្ហូប

culmen *n.m.* កំពូលខ្ពស់បំផុត

culminant,e *a.* នៃកំពូល ។ point culminant កំពូលខ្ពស់បំផុត(ឧ.le mont Blanc est le point culminant des Alpes); *au fig.* កម្រិតខ្ពស់បំផុត (ឧ. le point culminant de la fortune)

culminer *v.t.* *Géogr.* មានកំពស់ (ខ្ពស់បំផុត)

culo *n.m.* *Fam.* កូនពៅ; អ្នកប្រឡងជាប់លេខចុងគេ; អាចម៍ខ្សៀ ។ *Pop.* ឫកគល្ងើន

culottage *n.m.* ការឡើងខ្មៅ (ខ្សៀដែលប្រើ)

culotte *n.f.* ខោខ្លី ។ *Abus.* ខោ, ខោស្អាប់ភ្លៅ, ខោទ្រនាប់ ។ *Pop.* prendre une culotte ស្រវឹង; ចាញ់ក្នុងល្បែង ។ culotte de peau ទាហានចាស់

culotter *v.t.* ឲ្យស្លៀកខោ

culottier,ère *n.* អ្នកដេរខោ

culpabilité *n.f.* ពិរុទ្ធភាព, ភាពមានទោស (ឧ. avouer sa culpabilité)

culte *n.m.* ការបូជា, ពិធីក្នុងសាសនា; សាសនា(ឧ. changer de culte)។ Ministère des cultes មន្ទីររដ្ឋមន្ត្រីក្រសួងធម្មការ ។ *Fig.* ការគោរព (ឧ. avoir un culte pour ses parents)

cul-terreux *n.m.* *Fam.* អ្នកស្រែ (*pl.* des culs-terreux)

cultivable *a.* អាចដាំឬបណ្ដុះបាន (ឧ.

terre cultivable)

cultivateur,trice *a.&n.* អ្នកស្រែ, កសិករ ។ *n.m.* ឧបករណ៍ភ្ជួររាស់ដី

cultivé,e *a.* ដែលមានដំណាំ ។ *Fig.* ដែលមានវប្បធម៌ឬមានវិជ្ជា (ឧ. esprit cultivé)

cultiver *v.t.* ធ្វើកសិកម្ម, ធ្វើស្រែចំការ, ដាំ (ឧ. cultiver un champ; cultiver des céréales)។ *Fig.* សិក្សា, រៀន (ឧ. cultiver les sciences); ហាត់ (ឧ. cultiver sa mémoire); សេពគប់; រក្សា (ឧ. cultiver l'amitié de quelqu'un)

cultuel,elle *a.* នៃការបូជា,នៃសាសនា (ឧ. association cultuelle)

cultural,e,aux *a.* នៃការដាំដំណាំ (ឧ. étude culturale)

culture *n.f.* វប្បកិច្ច,វប្បកម្ម,ការសាបព្រោះ, ការដាំ (ឧ. la culture des fleurs); ដីដាំដំណាំ (ឧ. l'étendue des cultures); ការបណ្ដុះ។ *Fig.* វប្បធម៌, វិជ្ជា (ឧ. une forte culture; la culture gréco-latine)។ culture générale សារពើវប្បធម៌, វិជ្ជាទូទៅ ។ culture intellectuelle បញ្ញាវប្បធម៌ ។ culture physique កាយវប្បកម្ម

culturel,elle *a.* នៃវប្បធម៌ (ឧ. relations culturelles)

cumul *n.m.* ការបំពេញមុខងារត្រួត ។ cumul de peines ការត្រួតទោស (ការដាក់ទោសថែមលើទោសមុន)

cumulard *n.m.* អ្នកបំពេញមុខងារត្រួត

cumulatif,ive *a.* ដែលត្រួតលើគ្នា

cumulativement *adv.* ដោយត្រួតគ្នា

cumuler *v.t.* កាន់មុខងារត្រួត

cumulus *n.m.* ភ្នំទឹក (ពពក)

cunéiforme *a.* ដែលមានសណ្ឋានជាស្នៀត ឬ ម្ជុស

cunette *n.f.* ស្នាមភ្លោះ

cuniculiculture *n.f.* ការចិញ្ចឹមទន្សាយ

cupide *a.* អភិជ្ឈាភិភូត-ភូតា, លោភលន់

cupidement *adv.* ដោយអភិជ្ឈា, យ៉ាងលោភលន់

cupidité *n.f.* អភិជ្ឈា, លោភលន់

cuprifère *a.* តម្រកូតវត្ថុ,ដែលមានស្ពាន់ (ឧ. roche cuprifère)

cuprique *a.* *Chim.* នៃស្ពាន់

cupuliféracées ឬ **cupilifères** *n.f.pl.* ចសកក្ខល [ចៈ-សៈ-កៈ--]

curabilité *n.f.* ភាពអាចមើលជា(រោគ)

(ឧ. curabilité incertaine)

curable *a.* អាចមើលជា-(រោគ)

curage ឬ **curement** *n.m.* ការឆ្កៀល ឬគ្រូរ (ឧ. le curage d'un égoût)

curare *n.m.* ជ័រឆ្វេះ, ជ័រធក់

curatelle *n.f.* មុខងារអ្នកអាណាព្យាបាល

curateur,trice *n.* អ្នកអាណាព្យាបាល

curatif,ive *a.* សម្រាប់កែរោគ

curculionidés *n.m. pl.* សន្តានសត្វខ្វត

curcuma *n.m.* រមៀត

cure *n.f.* (ប្រើតែក្នុងសេចក្ដីថា n'en avoir cure មិនរវល់សោះ; n'avoir cure de rien មិនរវល់នឹងអ្វីសោះ) ។ *Méd.* អារោគ្យកម្ម, ការព្យាបាលរោគ (ឧ. cure de sommeil) ។ centre de cure មជ្ឈមណ្ឌលអារោគ្យកម្ម ។ កើយក្នុងអនាមយដ្ឋានសម្រាប់អ្នកជម្ងឺសម្រាក ។ ការសេះស្បើយ ។ មុខងារឬលំនៅគុយរ៉េ

curé *n.m.* គុយរ៉េ (អ្នកបួសក្នុងសាសនាកាតូលិក) ។ *Prov.* c'est gros Jean qui en remontre à son curé ខ្លៅចង់ប្រដៅប្រាជ្ញ

cure-dents ឬ **cure-dent** *n.m.* ឈើចាក់ធ្មេញ

curée *n.f.*ពោះសត្វចោលឲ្យឆ្កែ; ការស៊ីពោះសត្វ (ឆ្កែ) ។ *Fig.* sonner la curée ផ្ដើមកំរៃ ឬ មុខដំណែង

cure-ongle *n.m. inv.* ប្រដាប់ឆ្កឹះក្រចក

cure-oreille *n.m.* កន្ធាររត្រចៀក (*pl.* des cures-oreilles)

curer *v.t.* សំអាត, ជារ, ខ្វារ, គ្រូរ

curetage *n.m.* *Chir.* ការខ្វារសំអាត

cureter *v.t.* ខ្វារសំអាត

curette *n.f.* ប្រដាប់ដុសសំអាត; កន្ធារ (ប្រដាប់ពេទ្យ)

cureur *n.m.* អ្នកស្តារអណ្ដូង, អ្នកកកាយប្រឡាយទឹក

curial,e,aux *a.* នៃអារោគ្យកម្ម, នៃការព្យាបាលរោគ ។ maison curiale លំនៅគុយរ៉េ

curieusement *adv.* ដោយគួរឲ្យចង់ដឹង

curieux,euse *a.* ដែលចង់ដឹង ឬ ចង់ឃើញ (ឧ. un esprit curieux); ដែលចង់ដឹងការគេ(ឧ.enfant trop curieux); ប្លែក, គួរឲ្យឆ្ងល់(ឧ.une curieuse nouvelle) ។ *n.* អ្នកចង់ដឹង, អ្នកឈរមើលឬឈរស្ដាប់ (ឧ.

un attroupement de curieux)។ *n.m.* កន្លែងឬចំណុចប្លែក (ឧ. le curieux de l'affaire)

curiosité *n.f.* ញាណិច្ឆតា, ការចង់ដឹងឬចង់ឃើញ(ឧ. satisfaire sa curiosité); ការចង់ដឹងរឿងគេ (ឧ. sa curiosité a été punie)។ *pl.* របស់កម្រ (ឧ. amateur de curiosités)

curiste *n.* អ្នកទៅព្យាបាលរោគនៅមាត់ស្រោះទឹកក្តៅ

curriculum vitæ *n.m.* (carrière de la vie) អាជីវប្រវត្តិ

cursif,ive *a.* នៃអក្សរជ្រៀង ។ *n.f.* អក្សរជ្រៀង។ *a. fig.* រហ័ស, ញាប់ (ឧ. lecture cursive)

curvatif,ive *a.* វង្កទិន្ន, ដែលឡើងកោង

curviligne *a. Géom.* វង្ករេខា, ដែលផ្សំដោយបន្ទាត់កោង

cuscute *n.f.* វល្លិមាស [វ័ល-]

cuspide *n.f. Bot.* ចុងវែងស្រួច

cuspidé,e *a. Bot.* ដែលមានចុងស្រួច

cutané,e *a. Méd.* នៃស្បែក (ឧ. maladie cutanée ជម្ងឺស្បែក)

cut-back *n.m.* (ព.អ.)កៅស៊ូស្ងួតក្រាលថ្នល់

cuti-réaction *n.f.* តចប្រតិកម្ម [តៈ-ចៈ-], ការពិសោធរោគលើស្បែក (មានរោគរបេងជាដើម) (*pl.* des cuti-réactions)

cuvage *n.m.* ឬ **cuvaison** *n.f.* ការដាក់ធុង (ទំពាំងបាយជូរ)

cuve *n.f.* ធុងឈើ

cuveau *n.m.* កូនធុងឈើ

cuvée *n.f.* ចំណុះធុង

cuvelage *n.m.* ឈើប្រុះអណ្តូងរ៉ែ; ការដាក់បំពង់តាមទន្ទ្រូងអណ្តូង

cuveler *v.t.* ប្រុះអណ្តូងរ៉ែ, ដាក់បំពង់តាមទន្ទ្រូងអណ្តូងធុស

cuver *v.i.* រលួយទៅជាស្រាក្នុងធុងឈើ។ *v.t. Fig.* cuver son vin ផឹករួចដេក

cuvette *n.f.* ផើង, ក្លាំ។ *Géogr.* រលោង (ដីទំនាប)។ *Mécan.* ប្រអប់ស្ពឺ

cuvier *n.m.* ធុងបោកខោអាវ

cyanox *n.f.* រោគខៀវសាច់

cycadées *n.f. pl.* កង្គុតាលកូល [ក័ង-គុ-តា-ល:-]

cyclable *a.* ដែលទោចក្រយានរាចបរបាន, ដែលទុកសម្រាប់ទោចក្រយាន (ឧ. piste cyclable)

cycle *n.m.* ចក្រ, កង់; ការវិល (ឧ. le

cycle des saisons) ។ *Astr.* cycle lunaire ចក្រព្រះចន្ទ ។ cycle solaire ចក្រព្រះអាទិត្យ ។ *Econ.* cycle économique ចក្រសេដ្ឋកិច្ច ។ cycle d'érosion ចក្រចម្រោះ ។ *Phisiol.* cycle menstruel ចក្ររដូវ (រដូវស្ត្រី) ។ *Ens.* ភូមិ (សិក្សា) ។ cycle primaire élémentaire បឋមភូមិជាន់ដំបូង ។ cycle primaire complémentaire បឋមភូមិបំពេញវិជ្ជា ។ cycle primaire supérieur បឋមភូមិជាន់ខ្ពស់ ។ cycle secondaire ទុតិយភូមិ ។ cycle secondaire du 1er degré ទុតិយភូមិថ្នាក់ទី ១

cyclecar *n m.* ស៊ីក្លីការ, រថយន្តតូចកង់បី ឬ បួន

cyclique *a.* នៃចក្រភសី (ឧ. année cyclique) ។ *Econ. pol.* crise cyclique ចក្រវិបត្តិ

cyclisme *n.m.* ចក្រកីឡា (កីឡាប្រណាំងកង់)

cycliste *a.* នៃចក្រកីឡា ។ *n.* ចក្រយានិក, អ្នកជិះទោចក្រយាន

cyclomoteur *n.m.* ស៊ីក្លូម៉ូទ័រ, ទោចក្រយានយន្ត

cyclonal,e,aux ឬ **cyclonique** *a.* នៃចក្រវាត (ឧ. aire cyclonale; pluies cycloniques)

cyclone *n.m.* ចក្រវាត (ខ្យល់ព្យុះកំបុត្រត្បូង)

cyclope *n.m.* យក្សឯកនេត្រ

cyclopéen,enne *a.* នៃមហាប្រាសាទបុរាណ ។ *Fig.* សម្បើម (ឧ. un travail cyclopéen)

cyclotourisme *n.m.* ទេសចរណ៍ដោយទោចក្រយាន

cygne *n.m.* ហង្ស ។ blanc comme un cygne សក្បុស ។ cou de cygne កវែង ។ en col de cygne ដែលមានរាងដូចកហង្ស

cylindrage *n.m.* ការកិនដោយវត្ថុមូល ។ *Trav. publ.* ការកិនថ្នល់ (ឧ. le cylindrage du macadam); ការលញ់សសរ

cylindre *n.m.* រម្ភការ, បំពង់, បំពង់ចក្រ, ក្ញា

cylindrée *n.f.* ចំណុះបំពង់ចក្រ

cylindrer *v.t.* លញ់, ធ្វើឲ្យមានរាងជាបំពង់; កិន (ដោយវត្ថុមូល); មូរ (ឧ. cylindrer du papier)

cylindreur,euse *n.* កម្មករកិន ឬ មូរ

cylindricité *n.f.* ស្តុកភាព, ភាពជារាងបំពង់

cylindrique *a.* ស្តុក, ជារាងបំពង់ (ឧ. rouleau cylindrique); នៃបំពង់

cylindroïde *a.* ដែលមានរាងជាបំពង់

cylindrophis *n.m.* ពស់ដែកឈារ

cymbale *n.f.* ឆាប (គ្រឿងភ្លេង), ឃ្មោះ

cymbalier *n.m.* អ្នកវាយឃ្មោះ,អ្នកគោះឆាប (ហៅ cymbaliste ក៏បាន)

cynégétique *a.* នៃប្រមាញ់ (ឧ. plaisirs cynégétiques), សម្រាប់ប្រមាញ់ ។ *n.f.* សិប្បៈខាងប្រមាញ់

cynique *a.* ដែលមិនរវល់នឹងការគួរសម; គិតអៀនខ្មាស, មិនគប្បី (ឧ. langage cynique)

cyniquement *adv.* ដោយគិតអៀនខ្មាស, ដោយមិនគប្បី

cynisme *n.m.* ការគិតអៀនខ្មាស (ឧ. un cynisme révoltant)

cynodrome *n.m.* វាលរង់ប្រណាំងឆ្កែ

cyon *n.m.* ឆ្កែព្រៃ នៅទ្វីបអាស៊ី (ឧ. le cyon n'aboie pas)

cyprin *n.m.* ត្រីព្រួល

cyprinidés *n.m.* សន្តានត្រីព្រួល

cystique *a.* នៃផ្លោកនោម ឬ ប្រមាត់ (ឧ. le canal cystique relie la vésicule au canal hépatique)

cystite *n.f.Méd.*រោគរលាកផ្លោកនោម

cytologie *n.f.* កោសិកាសាស្ត្រ

czar, czarine ឬ **tsar, tsarine** *n.* អធិរាជប្រទេសរុស្ស៊ី



d អក្សរទីបួននៃអក្ខរក្រមឡាតាំង ។ D (*chiffre romain*) ៥០០។*Pop.* Système D របៀបដោះកុន, ការប្រើប្រាស់ដោះកុន

da capo *loc. adv.* (à partir de la tête) *Mus.* ចាប់ពីដើមឡើងវិញ

dacryocystite *n.f.* រោគរលាកថង់ទឹកភ្នែក

dactylé,e *a.* ដែលមានរាងដូចម្រាមដៃ

dactylo ឬ **dactylographe** *n.&a.* អ្នកអង្គុលីលេខ

dactylographie *n.f.* អង្គុលីលេខ

dactylographier *v.t.* វាយអង្គុលីលេខ (ឧ. dactylographier une lettre)

dactylographique *a.* នៃអង្គុលីលេខ

dactylologie *n.f.* របៀបនិយាយដោយធ្វើដៃ (សម្រាប់មនុស្ស គ)

dactyloscopie *n.f.* ការរកអត្តសញ្ញាណដោយមើលស្នាមម្រាមដៃ

dactylotype *n.f.* ម៉ាស៊ីនអង្គុលីលេខ

dada *n.m.* សេះ (ពាក្យក្មេង)។ *Fig.& Fam.* ការចូលចិត្ត, គំនិតប្រកាន់ជាប់

dadi *n.m.* មនុស្សភ្លើ, មនុស្សឆ្កួង

dague *n.f.* សំសៃ (ដាវម្យ៉ាងផ្លែស្រដៀងនឹងលំពែង); ស្នែងក្តាន់ទើបនឹងពក (ក្តាន់អាយុជាងមួយឆ្នាំ); ខ្នាយជ្រូកព្រៃ

daguet *n.m.* ក្តាន់ជំទង់ទើបនឹងពកស្នែង (ក្តាន់អាយុពី១ឆ្នាំទៅពីរឆ្នាំ)

daigner *v.t.* ព្រម, សុខចិត្ត (ឧ. il n'a

pas daigné me répondre)

daim *n.m.* រមាំង (bramer ថ្ងូច; daine រមាំងញី); ស្បែករមាំងសម្លាប់ (ឧ. chaussure de daim)

daïmio *n.m.* (ពាក្យជប៉ុន) អធិភជប្រ-ទេសជប៉ុនក្នុងសម័យបុរាណ

daine *n.f.* រមាំងញី

dais *n.m.* បុស្បុក [បុស–ស្បុក]។ *Poét.* ជម្រក (ឧ. dais de feuillage)

dallage *n.m.* ការក្រាលឥដ្ឋ: កម្រាលឥដ្ឋ

dalle *n.f.* ឥដ្ឋក្រាល

daller *v.t.* ក្រាលឥដ្ឋ

dalleur *n.m.* ជាងក្រាលឥដ្ឋ

dalot *n.m.* រន្ធបង្ហូរទឹកពីនាវា; លូទឹកក្រោមថ្នល់

daltonien,ienne *a.&n.* អ្នកកើតរោគភ្នែកបណ្ដាលឲ្យមើលពណ៌មិនស្គាល់

daltonisme *n.m.* រោគភ្នែកបណ្ដាលឲ្យមើលពណ៌មិនស្គាល់

dam *n.m.* ការខូចខាត (ប្រើតែក្នុងសំនួនសេចក្ដីថា: au grand dam និង au dam de); បណ្ដាសា (ឧ. peine du dam)

damage *n.m.* ការបុកបង្ហាប់ដី

damas *n.m.* សំពត់ព្រែមកពីប្រទេសដាម៉ាស, សំពត់ផ្កា; ដាវធ្វើដោយដែកថែបល្អ

damasquinage *n.m.* ការបញ្ចុះមាស ឬប្រាក់

damasquiner *v.t.* បញ្ចុះមាសឬប្រាក់

damasquineur *n.&a.* ជាងបញ្ចុះមាស ឬប្រាក់

damassé,e *a.* នៃសំពត់ផ្កា; នៃដែកថែបលត់ល្អ។ *n.m.* សំពត់ល្បើក

damasser *v.t.* ត្បាញសំពត់ល្បើក; វេញដែកផ្សារបញ្ចូលគ្នា

damassure *n.f.* ការត្បាញសំពត់ល្បើក

dame *n.f.* អ្នកស្រី, លោកស្រី ។ *Par ext.* ស្ត្រី (ឧ. coiffeur pour dame); កូនក្រមុំ (រូបសន្លឹកបៀ)។ *Echec* នាង (កូនចត្រង្គ) ។ ដើងជំរី (ប្រដាប់សម្រាប់ប្រើបុកបង្ហាប់ដី); ដើងចែវ (បង្គោលពាក់ចែវ)

dame! *int.* យី !

dame-d'onze-heures *n.f.* ផ្កាម៉ោងមួយជណ្ដាប់

dame-jeanne *n.f.* ដបពីង (*pl.* des dames-jeannes)

damer *v.t.* បុកបង្ហាប់ដោយដើងជំរី

dameret *n.m.* ប្រុសធ្វើឫកដូចស្រី

damun *a.* & *n.m.* ម៉ាស៊ីនកិនបង្ហាប់ (សាធារណការ)

damier *n.m.* ក្តារចត្រង្គអុក្យ៉ង; ក្បាច់ក្រឡាចតុរង្ស

damnable *a.* គួរដាក់បណ្តាសា; គួរធ្លាក់នរក (ឧ. action damnable) ។ *Par ext.* គួរធ្វើទារុណកម្ម, គួរស្តីបន្ទោស (ឧ. une entreprise damnable)

damnation *n.f.* ដំណើរធ្លាក់នរក; បណ្តាសា

damné,e *a.&n.* ដែលធ្លាក់នរក។ âme damnée អ្នកស៊ូស្លាប់រស់នឹងជនឯទៀត ។ *Fam.* ដែលនាំឲ្យអំពល់ (ឧ. cette damnée voiture) ។ souffrir comme un damné រងទុក្ខយ៉ាងខ្លាំង

damner *v.t.* ទម្លាក់នរក, នាំចុះនរក (ឧ. damner son âme)។ *Fig. & fam.* faire damner quelqu'un ធ្វើទារុណកម្មយ៉ាងខ្លាំង, ធ្វើទុក្ខបុកម្នេញខ្លាំង ។ se damner *v.pr.* នាំខ្លួនទៅនរក

damoiseau ឬ **damoisel** *n.m.* កម្លោះអ្នករួសរាយនឹងស្ត្រី

damoiselle *n.f.* នារីត្រកូលខ្ពស់

damper [dam'-peur] (ព.អ.) ដាំព័រ (រ៉ែសស៊័រដែកស្វាន)

dancing *n.m.* នាដិសាល, រង្គសាល, សាលរាំ

dandin *n.m. Fam.* បុរសល្ងង់

dandinement *n.m.* ដំណើរតេបតាប ឬអ៊ុកអ៊ាក

dandiner *v.i.* ដើរតេបតាប ឬ អ៊ុកអ៊ិក (ដើរយោលខ្លួន) ។ se dandiner *v.pr.* ដើរតេបតាបឬអ៊ុកអ៊ិក

dandy *n.m.* អ្នកលេងខ្លួន (*pl.* des dandys ឬ dandies)

dandysme *n.m.* លេងខ្លួននិយម

danger *n.m.* ភេរព, គ្រោះថ្នាក់ (ឧ. affronter les dangers); ភយន្តរាយ, ផលអាក្រក់ (ឧ. le danger des mauvaises fréquentations)

dangereusement *adv.* ដោយមានគ្រោះថ្នាក់

dangereux,euse *a.* ភេរព, ប្រកបដោយគ្រោះថ្នាក់, ដែលអាចមានគ្រោះថ្នាក់; ដែលឲ្យទុក្ខទោស, ចង្រៃ (ឧ. aventure dangereuse; lecture dangereuse)

danois,e *a.* នៃប្រទេសដាណឺម៉ាក ។ *n.* ជនជាតិដាណឺម៉ាក។ *n.m.* ភាសាដាណឺម៉ាក; ឆ្កែមាឌធំ (ពូជមកពីប្រទេស

ដាណឺម៉ាក)

dans *pré.* ក្នុង (ប្រាប់កន្លែងដែលគេនៅ ឬដែលគេទៅ ឧ. être dans sa chambre; entrer dans sa maison; ប្រាប់កាល ឬ ពេល ឧ. dans l'année; vivre dans le passé; ប្រាប់អនាគតកាល ឧ. il viendra dans trois jours; ប្រាប់ស្ថានភាព ឧ. être dans la joie, dans l'embarras)។ *Fam.* ប្រមាណជា (ឧ. coûter dans les mille riels)

dansant,e *a.* ដែលមានរបាំ(ឧ. soirée dansante); ដែលនាំឲ្យចង់រាំ (ឧ. musique dansante)

danse *n.f.* នាដកម្ម, របាំ; បទភ្លេងរបាំ; របៀបនៃរបាំ។ *Fig.* & *Fam.* កិច្ច, ចលនា, សកម្មភាព (ឧ. entrer en danse)។ *Pop.* ការស្តីបន្ទោស (ឧ. recevoir une danse)

danser *v.i.* រាំ; ញ័រ (ឧ. les flammes dansaient) ។ *Fig.* ne savoir sur quel pied danser មិនដឹងធ្វើដូចម្តេច, មិនដឹងគិតយ៉ាងណា, រារែក។ *v.t.* រាំតាមចង្វាក់(ឧ.danser une valse)។ *Fig.* faire danser quelqu'un ធ្វើបាប ។ faire danser les écus ចាយខ្ជះខ្ជាយ។ faire danser l'anse du panier ពន្លើសថ្លៃវត្ថុដែលទិញឲ្យអ្នកដទៃ

danseur,euse *n.* នាដកៈ, នាដិកា, អ្នករាំ (ឧ. couple de danseurs); អ្នករកស៊ីរាំ ។ en danseuse ដោយមិនអង្គុយលើកែប ឬ ដោយគូថមិនជាប់នឹងកែប (អ្នកជិះទោចក្រយាន)

dansotter *v i. Fam.* រាំផ្តេសផ្តាស (រាំឥតក្បួនខ្នាត)

dantesque *a.* សម្បើម (ឧ. spectacle dantesque)

daraise *n.f.* ដៃបឹង (កន្លែងដែលមានទឹកហូរចេញពីបឹង)

dard *n.m.* ស្នា, លំពែង ។ *Fig.* សំដីមុត; អណ្តាតពស់; ទ្រនិចសត្វ

dardement *n.m.* ការចាក់ដោយស្នា ឬ លំពែង; ការទិច

darder *v.t.* ចាក់ដោយស្នា ឬ លំពែង; ទិច ។ *Fig.* ចោល (កម្មរស្មី)(ឧ. le soleil darde ses rayons); សម្លក់ (ឧ. darder un regard furieux)

dardillon *n.m.* ទ្រនិចតូច, ស្នា ឬ លំពែងតូច

dare-dare *loc. adv. Fam.* យ៉ាងឆាប់, យ៉ាងរហ័ស

darne *n.f.* កង់ត្រី (ឧ. une darne de saumon)

darse *n.f. Mar.* ផលសីមក្នុងកំពង់ផែ (ច្រើននិយាយចំពោះតែកំពង់ផែក្នុងសមុទ្រមេឌីទែរ៉ាណេ)

dartre *n.f.* រោគស្រែង, រោគភ្លឺ; ក្រមរស្រែង

dartreux,euse *a.* សស្រែង, ជារោគស្រែង ឬ ភ្លឺ (ឧ. affection dartreuse)

dartrier *n.m.* ដើមដង្កិត

datation *n.f.* ការចុះកាលបរិច្ឆេទ

date *n.f.* កាលបរិច្ឆេទ, ថ្ងៃខែ (ឧ. mettre la date sur une lettre); លេខដែលប្រាប់ថ្ងៃខែ; ពេល, សម័យ, កាល (ឧ. amitié de vieille date) ។ prendre date ណាត់ថ្ងៃជួបគ្នា ។ faire date កំណត់ ឬ ទៅជាពេលសំខាន់ក្នុងប្រវត្តិសាស្ត្រ ។ être le premier en date មានឬដល់មុនគេ ។ *Dr.* date certaine កាលបរិច្ឆេទប្រាកដប្រជា (ដែលពុំអាចប្រកែកបាន)

dater *v.t.* ចុះកាលបរិច្ឆេទ, ចុះថ្ងៃខែ (ឧ. dater une lettre, un testament) ។ *v.i.* មានតាំងពី (ឧ. ceci date du siècle dernier); មានជាប់ទុកមក (ឧ. événement qui date dans l'histoire) ។ *Fig.* មានមកតាំងពី (ឧ. sa haine date de loin); មានចំណាស់, ហួសសម័យ (ឧ. robe qui date) ។ à dater de *loc. pré.* តាំងពី (ឧ. à dater de ce jour)

dateur *a.* សម្រាប់ចុះកាលបរិច្ឆេទ (ឧ. timbre dateur)

datif,ive *a.* ដែលឲ្យ ឬ អនុញ្ញាតតាមផ្លូវតុលាការ ឬ តាមមតកសាសន៍ (ឧ. tuteur datif) ។ *Gram.* ជាចតុត្ថីវិភត្តិ ។ *n.m.* ចតុត្ថីវិភត្តិ, វិភត្តិទី ៤

dation *n.f. Dr.* ការប្រគល់ឲ្យ (តាមផ្លូវតុលាការ) (ឧ. dation du conseil judiciaire) ។ dation en paiement ការសង (ជាវត្ថុផ្សេងពីវត្ថុដែលបានសន្យា)

datte *n.f.* ផ្លែលម៉ើ

dattier *n.m.* ដើមលម៉ើ

datura *n.m.* ដើមស្លាក់

daube *n.f.* ការខ្វៃសាច់; សាច់ខ្វៃ

dauber *v.t. Fam.* ជល់, ខោក ។

Fig. v.t. & v.i. និយាយអាក្រក់ពីគេ, និយាយដើមគេ, និយាយចំអក (ឧ. dauber quelqu'un, sur quelqu'un)

dauber *v.t.* ខ្វៃសាច់

daubeur,euse *n.&a.* អ្នកចូលចិត្តនិយាយអាក្រក់ពីគេឬចូលចិត្តចំអកឲ្យគេ

daubière *n.f.* ឆ្នាំងសម្រាប់ខ្វៃសាច់

dauphin *n.m.* រាជបុត្រច្បងនៃមហាក្សត្រប្រទេសបារាំង ។ le grand dauphin រាជបុត្រព្រះបាទល្វីទី ១៤

dauphine *n.f.* មហេសីនៃរាជបុត្រមហាក្សត្រប្រទេសបារាំង

davantage *adv.* តទៅទៀត, ច្រើនទៅទៀត (ឧ. je n'en sais pas davantage); ជាង (ឧ. je l'aime davantage que son frère); យូរទៅទៀត (ឧ. ne restez pas davantage)

davier *n.m.* ដង្កាប់ដកធ្មេញ; ដង្កាប់ដាងឈើ ឬ ដាងដែក

D.C.A. ដេ.សេ.អា. (ពាក្យបំព្រួញនៃ Défense Contre Aéronef ការតទប់នឹងអាកាសយាន

D.D.T. *n.m.* ដេ.ដេ.តេ. (ពាក្យបំព្រួញនៃ dichlorodiphényltrichloréthane ថ្នាំបំពុលជាណកសត្វ)

de *pré.* ពី (ប្រាប់ទីដើម ឧ. venir de Phnom-Penh; ប្រាប់ពេល ឧ. de cinq heures à midi); នៃ,របស់ (ប្រាប់កម្មសិទ្ធិ ឧ. le livre de Chuon); នូវ, ដោយ (ប្រាប់រូបធាតុ ឧ. se nourrir de viande); ដោយ, ព្រោះ (ប្រាប់ហេតុ ឧ. mourir de faim; ប្រាប់របៀប ឧ. citer de mémoire; ប្រាប់មធ្យោបាយ ឧ. prendre de force); ដោយ,នឹង (ឧ. montrer du doigt); សម្រាប់ (ឧ. salle de spectacle); អំពី, ដោយ (ប្រាប់វត្ថុធាតុ ឧ. table de béng); ក្នុងពេល (ឧ. partir de nuit); អំពី (ឧ. parler de cette affaire); ជា (ឧ. traiter de lâche)

Loc.div. de par ក្នុងនាមនៃ (ឧ. de par la loi) ។ de plus ថែមទៀត ។ de rien គិតមានការទាក់ទង (ឧ. fille perdue, qui n'est plus de rien pour sa famille)

dé *n.m.* ស្នាប់ដេរ ឬ ស្នាប់ម្រាមនៃ

dé *n.m.* កូនឡុកឡាក់

déalbation *n.f.* ការឡើងស

déambulation *n.f.* ការដើរលេង; ដំណើរ

déambuler *v.i.* ដើរលេង (ឧ.déambuler à traver les rues); ដើរ

de auditu (par ouï-dire) *loc.lat.* ដោយឮតៗមក(ឧ. ne savoir une chose que de auditu)

débâclage ឬ **débâclement** *n.m.* ការបើក; ការបើចេញឲ្យស្រឡះ

débâcle *n.f.* ការបាក់បែកផ្ទាំងទឹកកក ។ *Fig.* ការចុះរាសី; ការប្រែប្រួលនៃវាសនា (ជាហេតុឲ្យចុះដុនដាប); ការបាក់ទ័ព (ឧ. la retraite s'acheva en débâcle)

débâcler *v.t.* បើក, បើចេញឲ្យស្រឡះ ។ *v.t.* ជន់ (ទន្លេ, ស្ទឹង)

débagauler *v.i.* ក្អួត

déballage *n.m.* ការរុះបើកញ្ចប់ឬហិប; ទំនិញថោកៗលក់តាមតូប; តូបលក់ទំនិញ

déballer *v.t.* រុះបើកញ្ចប់ឬហិប; តាំងទំនិញលក់

déballeur *n.m.* បរិចារពាណិជ, អ្នកដើរលក់

débandade *n.f.* ការបែកខ្ញែក; ការបាក់ទ័ព (ឧ. la débandade d'une armée) ។ à la débandade *loc. adv.* រាត់រាយ

débander *v.t.* ណាក់ណាត់រុំ (ឧ. débander les yeux); បន្ធូរ, គម្លាះ (ធ្នូ) (ឧ. débander un arc)

débander *v.t.* ធ្វើឲ្យបែកខ្ញែក, បំបាក់ទ័ព (ឧ. débander un régiment ennemi) ។ se débander *v.pr.* បែកខ្ញែកគ្នា, រត់ប្រូកប្រាស (ឧ. les troupes se débandèrent)

débaptiser *v.t.* ផ្លាស់ឈ្មោះ (ឧ. débaptiser une rue)

débarbouillage *n.m.* ការលុបមុខឲ្យ

débarbouiller *v.t.* លុបមុខឲ្យ (ឧ. débarbouiller un enfant) ។ se débarbouiller *v.pr.* លុបមុខ ។ *Fig. & fam.* ដោះកុនខ្លួន

débarcadère *n.m.* ផែរើទំនិញ

débardage *n.m.* ការរើទំនិញពីនាវា, ការរើចេញ; ការជញ្ជូនចេញ; ការដឹកឈើចេញពីព្រៃ

débarder *v.t.* រើទំនិញពីនាវា; រើចេញ, ជញ្ជូនចេញ; ដឹកឈើចេញពីព្រៃ; ដឹកថ្មចេញពីអណ្ដូងរ៉ែ

débardeur *n.m.* & *a.* អ្នកដឹកញ្ជូនចេញ; កម្មកររើទំនិញពីនាវាឬពីរថយន្ត

débarqué,e *a.* & *n.* ដែលដាក់ពីនាវា ឬរថ; ដែលចុះពីនាវា ឬ រថ ។ un nouveau débarqué អ្នកទើបនឹងមកដល់ពីស្រុកខ្លួន

débarquement *n.m.* ការរំសៀង (ការរើពីនាវា; ការចុះពីនាវា ឬរថ) (ឧ. quai de débarquement); ការឡើងគោក ។ taxe de débarquement អាកររំសៀង

débarquer *v.t.* រំសៀង,រើពីនាវាឬរថ(ឧ. débarquer des marchandises)។*Fig.*&*Fam.* រលាស់ចោល, បណ្ដេញចេញ ។ *v.i.* ចុះចេញពីរថឬនាវា(ឧ. il débarqua le matin); ឡើងគោក។ *n.m.* au débarquer de quelqu'un នៅពេលដែលចុះពីនាវា ឬរថ

débarras *n.m.* *Fam.* ការស្រឡះមុខមាត់ (ផុតពីការទទើសទទែង) (ឧ. il est parti, bon débarras); ភាពគ្មានឧបសគ្គ ឬ គ្មានទទើសទទែង (ផ្ទុយពី embarras); ជង្រុកដាក់របស់មិនត្រូវការ

débarrasser *v.t.* ដកចេញឲ្យស្រឡះ (ឧ. débarrasser quelqu'un d'un fardeau)។*Fig.* ដោះធុរៈ, សម្រាលទុក្ខ (ឧ. débarrasser quelqu'un de ses soucis)។ se débarrasser *v.pr.* រលាស់ចោល,យកចេញពីខ្លួន,បំបាត់ចោល(ឧ. se débarrasser d'une idée)

débarrer *v.t.* ដករនុក

débat *n.m.* ការពិភាក្សាតទល់(ឧ. soulever, trancher un débat passionné)។ *Pl.* ការពិភាក្សាខាងនយោបាយ (ឧ. les débats des assemblées parlementaires); ការជំនុំជំរះជាសាធារណៈ (ឧ. suivre les débats)

débâter *v.t.* ដោះកែបឬកូបចេញ (ឧ. débâter un cheval)

débâtir *v.t.* រុះ, រើ; រុះថ្នេរដានចេញ

débattement *n.m.* ចន្លោះទំនេរពីភ្លៅទៅតួរថ (សម្រាប់ឲ្យរថលោកចុះឡើងបានតិចទើស)

débattre *v.t.* ពិភាក្សា, ពិភាក្សាតទល់ (ឧ. débattre une question)។ se débattre *v.pr.* ត្រូវដាក់ឲ្យពិភាក្សា; បម្រះ, ការពារខ្លួន (ឧ. se débattre contre le courant,

la misère)

débauchage *n.m.* ការនាំឲ្យបោះបង់ការងារ (ចំពោះអ្នកទទួលប្រាក់ឈ្នួល)

débauche *n.f.* អនាចារ, អបាយមុខ; ការស៊ីផឹកហួសកម្រិត; ការប្រព្រឹត្តហួសកម្រិត(ឧ. faire une débauche de gestes)

débauché,e *n.&a.* មនុស្សអនាចារ, អ្នកប្រព្រឹត្តអបាយមុខ

débaucher *v.t.* នាំឲ្យបោះបង់ការងារ; បញ្ឈប់កម្មករ (ដោយគ្មានការឲ្យធ្វើ)។ *Par ext.* ញៀវក្លូម (បញ្ចុះបញ្ចូលផ្លូវអាក្រក់); នាំខូច

débaucheur,euse *n.* អ្នកនាំឲ្យបោះបង់ការងារ; អ្នកញៀវក្លូម; អ្នកនាំខូច

débet *n.m.* ហិរញ្ញវេកល្យ (ប្រាក់ខ្វះពីចំនួនក្នុងបញ្ជី)។ arrêté de débet ប្រកាសហិរញ្ញវេកល្យ

débile *a.* ខ្សោយ, ឥតកម្លាំង(ឧ. enfant débile); អន់ថយ (ឧ. santé débile)។ débile mental ឬ débile អ្នកមានបញ្ញាអន់ថយ, ជនវិបល្លាស(ឆ្កួត)

débilement *adv.* យ៉ាងខ្សោយ, ដោយឥតកម្លាំង

débilitant,e *a.* ដែលធ្វើឲ្យខ្សោយ, ដែលធ្វើឲ្យអស់កម្លាំង ។ *n.m.* ថ្នាំសម្រាប់ធ្វើឲ្យខ្សោយ

débilité *n.f.* ភាពខ្សោយ, ភាពល្ហើយ, ភាពអស់កម្លាំង។ débilité mentale បញ្ញាយឺត (បញ្ញាចំរើនយឺតជាងអាយុ)

débiliter *v.t.* ធ្វើឲ្យខ្សោយ (ឧ. régime qui débilite l'estomac); ធ្វើឲ្យអស់កម្លាំង ។ se débiliter *v.pr.* ចុះខ្សោយ

débillarder *v.t.* ចាំងលុបជ្រុងឈើ

débinage *n.m.Pop.* ការនិយាយបង្កាច់

débine *n.f.Pop.* ភាពក្រជុនជាប

débiner *v.t.Pop.* និយាយបង្កាច់។ ដឹង, ឮ (ឧ. débiner un truc); បង្ហាញ។ se débiner *v.pr. Pop.* ចាកចេញ, គេចខ្លួន

débineur,euse *n.Pop.* អ្នកនិយាយបង្កាច់

débirentier,ère *n.* ឥណពន្ធលាភី, អ្នកជំពាក់ធនលាភ

débit *n.f.* ការបំបែកឬច្រៀកឈើ (ក្នុងន័យនេះគេអាចថា débitage ក៏បានដែរ); ការលក់, ការលក់រួស(ឧ. marchandise d'un débit facile); ការលក់រាយ (ឧ. débit de tabac); ទៀមលក់រាយ (ឧ. entrer dans un débit de boissons);

ការបញ្ចេញ។ *Géogr.* débit d'un cours d'eau ធារទឹក ។ débit d'une arme ចំនួនគ្រាប់ដែលគេបាញ់បានក្នុងមួយនាទី ។ *Fig.* របៀបនិយាយឬអាន (ឧ. avoir le débit rapide)

débit *n.m. Com.* ឥណពន្ធ (ប៉ែកចំណាយនៃបញ្ជី; គណនីប្រាក់ជំពាក់)

débitable *a.* អាចលក់បាន; អាចបំបែកបាន

débitage *a.* ការបំបែកឬច្រៀកឈើ (ឧ. débitage d'un néang nuon) (ម.ព. débit ផង)

débitant,e *n.* អ្នកលក់រាយ

débiter *v.t.* លក់,លក់ដូរ,លក់រាយ (ឧ. débiter du vin); បំបែកឬច្រៀកឈើ (ឧ. débiter un chhoeuteal); កាត់ (ជាដុំ) (ឧ. débiter un bœuf); បញ្ចេញ។ *Fig.* សូត្រ (ក្នុងទីសាធារណៈ)(ឧ.débiter son rôle); និទាន, និយាយ (ដោយឥតពិត) (ឧ. débiter des mensonges)

débiter *v.t.* ចុះឥណពន្ធ (ចុះខាងប៉ែកចំណាយនៃបញ្ជី)

débiteur,euse *n.* អ្នកនិយាយ ឬ និទាន (ឧ. débiteur de nouvelles); អ្នកលក់រាយ

débiteur,trice *n.* ឥណាយិក-យិកា(កូនបំណុល) (ព.ផ. créancier) ។ *a.* solde débiteur សមតុល្យឥណាយិក ។ compte débiteur គណនីឥណាយិក

débitmètre *n.m.* រង្វាស់ធារទឹក

déblai *n.m.* ការឆាយពង្រាបដី (ឧ. le déblai d'une voie ferrée) ។ *Pl.* អាចម៍ដី (ព.ផ. remblai)

déblaiement *n.m.* ការរើសំអាត

déblayer *v.t.* រើសំអាត(ឧ.déblayer une cour) ។ *Fig.* déblayer le terrain រៀបចំកិច្ចការ (ដោយបំបាត់ឧបសគ្គជាមុន)

déblocage *n.f.* ការធ្វើឲ្យលែងឡោមព័ទ្ធ; ការដោះ;ការបើកឲ្យដឹកនាំ ឬ លក់ទំនិញវិញ

débloquement *n.m.* ការបើកឲ្យចេញចូលវិញ

débloquer *v.t.* ធ្វើឲ្យសត្រូវលែងឡោមព័ទ្ធ; ដោះ (ធ្វើឲ្យបាត់គាំង); បើកឲ្យដឹកឬលក់ទំនិញវិញ; បើកឲ្យប្រើវិញនូវឥណទាន ឬ គណនីដែលមានក្នុងធនាគារ

déboire *n.m.* ទុក្ខព្រួយ; ការខកចិត្ត

déboisement *n.m.* វិនការ,

ការបង្អួនព្រៃ; សភាពគ្មានព្រៃ

déboiser *v.t.* ធ្វើវែនការ, បង្អួនព្រៃ ។ se déboiser *v.pr.* វិនាសព្រៃអស់ (ឧ. pays qui se déboise)

déboîtement *n.m.* ការភ្លាត់ឆ្អឹង, ការគ្រេច

déboîter *v.t.* ដោះវត្ថុដែលស៊កចូលគ្នាចេញ(ឧ.déboîter des tuyaux); ធ្វើឲ្យភ្លាត់,ធ្វើឲ្យគ្រេច (ឧ. sa chute lui a déboîté l'épaule)។ *v.i.* ចេញពីជួរ (រថយន្ត ឬ ក្បួនហែ)

débonder *v.t.* ដកឆ្នុក។ *v.t.* ហៀរហូរ (ឧ. lac qui a débondé)

débondonner *v.t.* ដកឆ្នុកធុង

débonnaire *a.* ស្លូតហួស, ល្អហួស

débonnairement *adv.* ដោយល្អហួស

débonnaireté *n.f.* ភាពល្អហួស

débord *n.m.* ការហូរចេញខ្លាំង; ជាយ, ហាម; ដំណើរជន់ហៀរ (ទឹក)

débordant,e *a.* ដែលហៀរ ។ *Fig.* ដែលទប់មិនបាន, ពោរពេញ

débordé,e *a.* ពុះពោរ ; ដែលប្រព្រឹត្តអនាចារ; ដែលមានការច្រើនហួសបន្ទុក (ឧ. débordé de travail)

débordement *n.m.* ការហៀរ (ឧ. le débordement du Mékong) ។ *Fig.* អនាចារ, ការវិលវល់; ភាពហូរហៀរ, ភាពច្រើនជាអនេក (ឧ. débordement d'injures)

déborder *v.i.* ហៀរ (ឧ. la rivière a débordé ឬ est débordée); ចូលពាសពេញ (ឧ. la foule débordait sur la chaussée); ហូរចេញខ្លាំង។ *v.t.* យកហាមឬជាយចេញ (ឧ. déborder un chapeau)។ déborder un lit គ្រាស់ជាយកម្រាលពូក។ចេញហួស (ឧ. ville qui déborde son enceinte); លយចេញ(ឧ. la terrasse du café déborde la maison); ដើរហួស,ដើររំលង (ឧ.déborder l'aile ennemie) ។ *Fig.* ទៅហួស, កន្លងហួស (ឧ. les évènements l'ont débordé) ។ *Mar.* ច្រានចេញទៅឆ្ងាយ(បំពោះនាវាដែលចតនៅផែឬដែលអែបនឹងគេ)

débosseler *v.t.* ពង្រាប(មិនឲ្យពក)

débotté ឬ **débotter** *n.m.* ពេលមកដល់ (ពេលកំពុងដោះស្បែកជើង) (ឧ. se trouver au débotter (ឬ au débotté) d'un ami)។ *Fig.* au débotter ដោយមិនបាននឹង

ខ្លួនមុន

débotter *v.t.* ដោះស្បែកជើងឡ

débouché *n.m.* ច្រកចំហ, ចុងច្រក ឬ ចុងផ្លូវចង្អៀត (ឧ. le débouché d'une rue); ការបញ្ចេញក្បាលទ័ព ដើម្បីប្រយុទ្ធ (ឧ. le débouché des chars); ពេលបញ្ចេញទ័ព (ឧ. au débouché de l'attaque)។ *Com.* វិរដ្ឋាន [វិ-រៈ-រ័ត-], កន្លែងនាំទំនិញចេញទៅលក់ (ឧ. l'expansion économique implique la création de débouchés nouveaux)។ *Fig.* ករណីដែលអាចប្រកបបាន

débouchement ឬ **débouchage** *n.m.* ការដកឬបើកឆ្នុក; ការចេញផុតច្រកចង្អៀត

déboucher *v.t.* យកវត្ថុដែលស្ទះចេញ (ឧ. déboucher un tuyau); បើកច្រក (ឧ. déboucher un passage); ដកឬបើកឆ្នុក (ឧ. déboucher une bouteille); កាច់ក្បាលគ្រាប់បែក (ដើម្បីបោលទៅឲ្យផ្ទុះ)។ *v.i.* ចេញពីច្រកចង្អៀត (ឧ. déboucher d'un sentier sur la route); ធ្លាយទៅលើ (ទៅជាប់នឹងទីទូលាយ) (ឧ. la ruelle qui débouche sur le boulevard); ហូរធ្លាក់ទៅ (ទន្លេ)

débouchoir *n.m.* ប្រដាប់ដកឬបើកឆ្នុក; ប្រដាប់ដាងឆ្នៃត្បូង

déboucler *v.t.* ដោះក្រវិល, ដោះកន្ទាស់ក្បាលខ្សែក្រវាត់

débouilli ឬ **débouillissage** *n.m.* ការជ្រលក់សំពត់ក្នុងទឹកក្ដៅសាកពណ៌ (តើចេញឬមិនចេញ)

débouillir *v.t.* ជ្រលក់សំពត់ក្នុងទឹកក្ដៅសាកពណ៌ (តើចេញឬមិនចេញ)

déboulé ឬ **débouler** *n.m.* ការរត់ចេញប្រូចពីមុខព្រាន (ទន្សាយ)។ au déboulé នៅពេលសត្វចេញពីរូង

débouler *v.i.* រត់ចេញប្រូចពីមុខព្រាន (ទន្សាយ); ធ្លាក់ ឬ រមៀលចុះ (ឧ. débouler dans un escalier); ចុះប្រញាប់ប្រញាល់ (ឧ. il a déboulé l'escalier)

déboulonnement ឬ **déboulonnage** *n.m.* ការដោះឡេស៊ី

déboulonner *v.t.* ដោះឡេស៊ី (ឧ. déboulonner un rail)។ *Fig.* & *Fam.* ដេញចេញពីកន្លែង; បង្ខូចកិត្តិសព្ទ

débouquement *n.m.* ការចេញពីពាម; ច្រកព្រែក, ច្រកស្រឡង

débouquer *v.i.* ចេញពីពាមទៅសមុទ្រ

débourbage *n.m.* ការជម្រះភក់ (រ៉ែ)

débourber *v.t.* ជម្រះភក់ (រ៉ែ); យកចេញពីភក់ (ឧ. débourber une voiture); ស្តារភក់ចេញ (ឧ. débourber un marais); ជម្រះក្លិនភក់(ត្រី) ។ *Fig.* ដោះក្ដួន (ជួយឲ្យផុតពីការពិបាក)

débourbeur *n.m.* ប្រដាប់ជម្រះភក់រ៉ែ

débourrage *n.m.* ការសំរេចប្រេងប្រាស; ការរើសកំទេចរោមចៀមចេញ; ការជម្រះរោមស្បែកដែលគេយកទៅសម្លាប់

débourrement *n.m.* ការប៉ិចពន្លក

débourrer *v.t.* ជារតេចេញ; ជារថ្នាំចេញពីខ្សៀ

débours *n.m.* ប្រាក់ចេញមុន (ឧ. rentrer dans ses débours)

déboursement *n.m.* ការចេញប្រាក់ (ព.ផ. remboursement)

débourser *v.i.* ចេញប្រាក់ (ព.ផ. encaisser)

debout *adv.* ឈរ, ដែលក្រោក, ដែលជាប់ត្រ (ឧ. il est toujours debout de bonne heure); នៅរស់, នៅមាន, មិនទាន់ខូច (ឧ. le temple est encore debout)។ *Mar.* vent debout ខ្យល់ប្រាស (ខ្យល់បក់មកពីមុខនាវ) ។ debout! *int.* ក្រោកឡើង !

débouté *n.m.* សាលក្រមបដិសេធបណ្ដឹង; អ្នកដែលត្រូវគេបដិសេធបណ្ដឹង

déboutement *n.m.* ការបដិសេធបណ្ដឹង

débouter *v.t.* បដិសេធបណ្ដឹង

déboutonner *v.t.* ដោះឡេវ ។ *Fam.* rire à ventre déboutonné សើចកាច់កកាច់ស្រង ។ manger à ventre déboutonné ស៊ីផ្ចិបគេប្រកខុស(ស៊ីច្រើនពេក)។ se déboutonner *v.pr.* របូតឡេវ ។ *Fig.* ដកដង្ហើមស្រួល ។ *Fig.* & *Fam.* និយាយឥតសំចៃ (ដឹងអ្វីជាទាំងអស់)

débraillé,e *a.* កន្ត្រុកកន្ត្រាក ។ *Fig.* មិនដឹងខ្លួន, មិនសុភាព (ឧ. des manières débraillées) ។ *n.m.* សំលៀកបំពាក់កន្ត្រុកកន្ត្រាក

débrailler(se) *v.pr.* លែងខ្លួនដោយឥតសមរម្យ

débranchement *n.m.* ការកាត់ខ្សែ

ភ្លើង, ការផ្ដាច់ចរន្តអគ្គិសនី

débrancher *v.t.* កាត់ទូរយស្ម័យយាន ចេញពីក្បួន; កាត់ខ្សែភ្លើង, ផ្ដាច់ចរន្តអគ្គិសនី

débrayage ឬ **désembrayage** *n.m.* ការដោះលេខម៉ាស៊ីន

débrayer ឬ **désembrayer** *v.t.* ដោះលេខម៉ាស៊ីន ។ *v.i.* *Pop.* បញ្ឈប់ការក្នុងរោងចក្រ

débridé,e *a.* ដែលគ្មានបង្ហៀរ (គ្មានគ្រឿងទប់)

débridement *n.m.* ការដោះបង្ហៀរ; ការបើកមុខដំបៅ

débrider *v.t.* ដោះបង្ហៀរ ។ débrider une plaie បើកមុខដំបៅឲ្យហូរខ្ទុះ (ដោយកាត់កណ្ដាប់ចេញ) ។ *Fig.* sans débrider ឥតឈប់, ឥតផ្អាក

débris *n.m.* កាក, កំទេច, កំទេច, អំបែង ។ *Pl. Fig.* សំណល់ (ឧ. débris d'une fortune); សំណល់អាហារ (ឧ. manger les débris d'un pâté)

débrocher *v.t.* ហូតចង្កាក់ឬឈើច្រនួច; រុះសៀវភៅ

débrouillage ឬ **débrouillement** *n.m.* ការដោះជំពាក់; ការធ្វើឲ្យរៀបរយឡើងវិញ

débrouillard,e *a.&n. Fam.* ឆ្លាត, ប្រសប់ដោះកុន, ល្ងុសល្ងុល

débrouillardise *n.f.Fam.* ការឆ្លាត, ការប៉ិនប្រសប់ដោះកុន

débrouiller *v.t.* ដោះជំពាក់ (ឧ. débrouiller les fils d'un écheveau); ធ្វើឲ្យរៀបរយឡើងវិញ ។ *Fig.* បំភ្លឺការណ៍ (ឧ. débrouiller une affaire) ។ *Fam.* débrouiller quelqu'un បង្ហាត់ឲ្យដោះកុន ។ se débrouiller *v.pr.Fam.* ដោះកុនខ្លួន

débroussaillement *n.m.* ការកាប់ឆ្ការ, ការកាប់គាស់ព្រៃគុម្ពោត

débroussailler *v.t.* កាប់ឆ្ការ, កាប់គាស់ព្រៃគុម្ពោត

débrutir *v.t.* ឆ្នៃ (ត្បូង); ខាត់ (ថ្មកែវ)

débrutissement *n.m.* ការឆ្នៃ, ការខាត់

débûcher,débucher *v.i.* ចេញពីព្រៃ (សត្វសាហាវ) ។ *v.i.* ដេញចេញពីព្រៃ (ឧ.débucher un cerf) ។ *n.m.* ពេលសត្វសាហាវចេញពីព្រៃ; ការបន្លឺសូរ (ត្រែ ឬ អ្វីផ្សេងៗទៀត) ជាសញ្ញាឲ្យដឹងថាសត្វចេញពីព្រៃ (ក្នុងការបរបាញ់) (ក្នុងន័យនេះគេអាចសរសេរជា

débuché ក៏បាន)

débusquement *n.m.* ការដេញចេញពីព្រៃ-ពីជម្រកឬពីរូង(សត្វ); ការបណ្ដេញចេញពីកន្លែង

débusquer *v.t.* ដេញចេញពីព្រៃ-ពីជម្រក ឬ ពីរូង (សត្វ) (ឧ. débusquer un cerf, un lièvre); បណ្ដេញពីកន្លែងដែលមានអត្ថប្រយោជន៍ (ឧ. débusquer un ennemi)

début *n.m.* ក្បាលដំបូង(ល្បែង)(ឧ. faire un beau début) ។ *Fig.* ការចូលកាន់មុខដំណែង-មុខការឬមុខរបរជាដំបូង(ឧ. faire ses débuts dans la diplomatie ចូលកាន់ដំណែងក្នុងការទូតជាដំបូង); ដើម, ផ្នែកដើម (ឧ. le début du jour, d'un discours)

débutant,e *n.&a.* អ្នកធ្វើការថ្មី

débuter *v.i.* ចាប់ផ្ដើម, ចូលធ្វើការថ្មី; ផ្ដើមលេង

deçà *pré.* ខាងអាយ ។ deçà et delà *loc. adv.* ទាំងខាងនេះទាំងខាងនោះ, ឯនេះឯនោះ, ពីនេះទៅនោះ, តែកាស ។ jambe deçà, jambe delà ជើងសងខាង; ប្រកតាវ (ផ្ទុយពីពាក់ឈៀង)។ par deçà, en deçà ឬ au-deçà *loc. adv.& pré.* ខាងនេះ, ខាងអាយ; *au fig.* ខាងក្រោម, តិចជាង (ឧ. en deçà de la vérité)

décachetage *n.m.* ការបើកស្រោម(សំបុត្រ); ការបើកកាកស័ខ

décacheter *v.t.* បើកស្រោម(សំបុត្រ); បើកកាកស័ខ

décadaire *a.* ដែលមានដប់ថ្ងៃម្ដង

décade *n.f.* ភាគនៃសៀវភៅមានបរិច្ឆេទដប់ (ឧ. les décades de Tite-Live); ទសទិន,ដប់ថ្ងៃ ។ *Par ext.* ទសវត្សរ៍ (១០ ឆ្នាំ) (ឧ. la dernière décade du XIXe siècle)

décadence *n.f.* អត្ថង្គត, ភាពជុនជាប, ភាពអាប់ពុន, ភាពអាប់ឱន (ឧ. décadence d'un empire)

décadent,e *a.* ជុនជាប, អាប់ឱន, អាប់ពុន

décadi *n.m.* ថ្ងៃទីដប់នៃទសទិន

décaèdre *n.m.* ប្រសព្វជ្រុង ១០

décaféiner *v.t.* យកកាហ្វេអ៊ីនចេញ

décagonal,e,aux *a.* នៃទសកោណ; ដែលមានរាងជាទសកោណ; ដែលមានមុំដប់

décagone *n.m.* ទសកោណ

décagramme (dag.) *n.m.* ដេកាក្រាម (ដា.ក)

décaissement ឬ **décaissage** *n.m.* ការយកចេញពីហិប; ការចេញប្រាក់

décaisser *v.t.* យកចេញពីហិប (ឧ. décaisser un oranger); ចេញប្រាក់ (ឧ. décaisser une somme)

décalage *n.m.* ការដោះកំណល់; ការបង្វិត ។ *Fig.* ការឃ្លាតពីគ្នា (ឧ. décalage entre la pensée et son expression); ចន្លោះពេល

décalcification *n.f.* និចុណ្ណីយាការ, ដំណើរអស់ជាតិកំបោរក្នុងខ្លួន

décalcifier *v.t.* ធ្វើឲ្យអស់ជាតិកំបោរ។ se décalcifier *v.pr.* អស់ជាតិកំបោរក្នុងខ្លួន

décalcomanie *n.f.* របៀបផ្តិតរូបពណ៌លើថាន លើកែវ ឬលើប្រដាស

décaler *v.t.* ដោះកំណល់; បង្វិត (ឧ. décaler un horaire)

décalitre (dal.) *n.m.* ដេកាលីត្រ (ដា.ល)

décalogue *n.m.* សិក្ខាបទដប់យ៉ាងនៃអាទិទេព (សិក្ខាបទដែលអាទិទេពញ៉ាំងម៉ូអ៊ីសឲ្យសមាទាននាភ្នំស៊ីណៃរ៉ា)

décalotter *v.t.* បើកគាតឹប; យកកំពូលចេញ (ឧ. décalotter un pot)

décalquage ឬ **décalque** *n.m.* ការផ្តិតគំនូរ, ការផ្តាប់ចម្លងរូប

décalquer *v.t.* ផ្តិតគំនូរ, ផ្តាប់ចម្លង

décalvant,e *a.* ដែលធ្វើឲ្យទំពែក

décamètre (dam.) *n.m.* ដេកាម៉ែត្រ (ដា.ម); ម៉ែត្រខ្សែដែក

décampement *n.m.* ការលើកជម្រំ

décamper *v.i.* លើកជម្រំ (ឧ. l'ennemi décampa pendant la nuit) ។ *Fam.* ថយចេញដោយប្រញាប់, រត់ចេញ

décanal,e,aux *a.* នៃមុខងារព្រឹទ្ធបុរស

décanat *n.m.* ស័ក្តិយសឬមុខងារនៃព្រឹទ្ធបុរស

décaniller *v.i.* *Pop.* រត់, ចាកចេញ

décantation *n.f.* ឬ **décantage** *n.m.* ការច្រោះ, ការសំរិត (ឧ. décanter un sirop) ។ *Fig.* បំភ្លឺ, បញ្ជាក់ (ឧ. décanter ses idées)

décanter *v.t.* ច្រោះ, សំរិត

décanteur *n.m.* ប្រដាប់ច្រោះ

décapage ឬ **décapement** *n.m.* ការខាត់, ការសំអាតលោហជាតិជញ្ជាំងឬថ្ម

décapan *n.m.* វត្ថុប្រើសម្រាប់ខាត់ ឬដុសសំអាត

décaper *v.t.* ខាត់,កុសសំអាតលោហធាតុជញ្ជាំង ឬ ថ្ម

décaper *v.i.* ចេញផុតគ្រោះ (នាវា)

décapeuse *n.f.* ប្រដាប់លើកឬជីកដី

décapitation *n.f.* ការកាត់ក្បាល

décapité,e *n.* អ្នកត្រូវទោសកាត់ក្បាល

décapiter *v.t.* កាត់ក្បាល(ឧ.décapiter un criminel)។ *Par ext.* កាត់កំពូលឬចុងចេញ(ឧ. décapiter un arbre); ផ្តាច់ពំនឹង (ឧ. décapiter un parti de ses dirigeants)

décapotable *a.* អាចបើកដំបូលបាន (រថយន្ត)

décapoter *v.t.* បើកដំបូល (រថយន្ត)

décarburant,e *a.* អាចបំបាត់ជាតិធ្យូងបាន

décarburer *v.t.* បំបាត់ជាតិធ្យូង

décarcasser *v.t.* យកគ្រោងឆ្អឹងចេញ; បកស្បែក។ se décarcasser *v.pr.* *Pop.* ដើរធ្វេឆ្វា,ត្រដរ,ខំប្រឹងខ្លាំង

décarêmer (se) *v.pr.* បំពេញការខ្វះខាត ឬ ការអត់ឃ្លានពីមុនមក

décarrelage *n.m.* ការគាស់ឥដ្ឋក្រាលចេញ

décarreler *v.t.* គាស់ឥដ្ឋក្រាលចេញ

décartellisation *n.f.* ការលុបកាតែលចេញ (ម.ព. cartel ផង)

décastère (*dast.*) *n.m.* ដេកាស្តែរ (ដា.ស្ត)

décasyllabe ឬ**décasyllabique** *a.* ជាទសព្យាង្គ, ដែលមានដប់ព្យាង្គ (ពាក្យកាព្យ)

décati,e *a.* *Fig.* & *Fam.* ស្រអាប់, គ្មានសម្រស់ឬបាត់សម្រស់ (ឧ. une femme décatie)

décatir *v.t.* បំហុយសំពត់ឲ្យបាត់រលោង ។ *Fig.* ធ្វើឲ្យស្រអាប់; ធ្វើឲ្យបាត់សម្រស់

décatissage *n.m.* ការធ្វើឲ្យស្រអាប់; ការបំហុយសំពត់ឲ្យបាត់រលោង(គេថា: délustrage ក៏បាន)

décatisseur *n.* & *a.m.* សម្រាប់ធ្វើឲ្យស្រអាប់

décavé,e *a.*&*n.* ដែលចាញ់អស់ពីខ្លួន (ក្នុងល្បែងស៊ីសង)។ *Fam.* ដែលបាត់បង់ធនធានអស់

décaver *v.t.* ឈ្នះយកអស់ពីគូល្បែង; ឈ្នះក្នុងល្បែង

décéder *v.i.* ស្លាប់ (និយាយចំពោះតែមនុស្ស)

déceindre *v.t.* ដោះខ្សែក្រវាត់ឲ្យ (ឧ.

déceindre un enfant)

décèlement *n.m.* ការបញ្ចេញឲ្យឃើញ, ការបង្ហាញ (រឿងលាក់កំបាំង)

déceler *v.t.* រកឃើញ(រឿងលាក់កំបាំង) (ឧ. déceler un complot); បញ្ចេញឲ្យឃើញ, បង្ហាញ (ឧ. son embarras décèle sa faute)

décembre *n.m.* ខែធ្នូ (ឧ. décembre a 31 jours)

décemment *adv.* ដោយសមរម្យ(ឧ. décemment, il ne pouvait refuser); ដោយត្រឹមត្រូវ

décence *n.f.* ភាពសមរម្យ (ឧ. un maintien plein de décence)

décennaire *a.* ដែលគិតដប់ៗ (ឧ. numération décennaire ការរាប់ដប់ៗ)

décennal,e,aux *a.* ទសវត្ស, ដែលមានរយៈពេលដប់ឆ្នាំ(ឧ. magistrature décennale); ដែលមានក្នុងដប់ឆ្នាំម្ដង (ឧ. fête décennale)

décennie *n.f.* រយៈពេលដប់ឆ្នាំ

décent,e *a.* សមរម្យ, ត្រឹមត្រូវ (ឧ. conduite décente; habit décent)

décentrage *n.m.* ការធ្វើវិមជ្ឈមណ្ឌល

décentralisateur,trice *a.* នៃវិមជ្ឈការ ។ *n.m.* វិមជ្ឈករ, បក្សពួកខាងវិមជ្ឈការ

décentralisation *n.f.* វិមជ្ឈការ, ការរំលែក (ឧ. la décentralisation administrative)

décentraliser *v.t.* ធ្វើវិមជ្ឈការ, រំលែក

décentration *n.f.* ឬ **décentrement** *n.m.* *Optiq.* វិមជ្ឈមណ្ឌល

décentrer *v.t.* ធ្វើវិមជ្ឈមណ្ឌល

déception *n.f.* ការខកចិត្ត; ភាពស្រងាកចិត្ត

décercler *v.t.* ដោះវណ្ឌាចេញ

décerner *v.t.* បង្គាប់តាមផ្លូវច្បាប់ (ឧ. décerner un mandat d'arrêt); ឲ្យ (ឧ. décerner un prix)

décès *n.m.* មរណភាព(ចំពោះតែមនុស្ស) acte de décès លិខិតមរណភាព

décevant,e *a.* ដែលបញ្ឆោត; ដែលធ្វើឲ្យខកចិត្ត ឬ ឲ្យស្រងាកចិត្ត

décevoir *v.t.* បញ្ឆោត; ធ្វើឲ្យខកចិត្ត

déchaîné,e *a. Fig.* ហួសហេតុ; ខឹងច្រឡោត (ឧ. un enfant déchaîné; les flots déchaînés)

déchaînement *n.m.* ការច្រឡោត; ការកញ្ច្រាល; ដំណើរក្លៀវក្លា (ឧ. le

déchainement des passions)

déchainer *v.t.* ដោះច្រវាក់(ឧ.déchainer un chien) ។ *Fig.* ធ្វើឲ្យច្រឡោត; ធ្វើឲ្យញៀវក្លា; បណ្ដាលឲ្យ (ឧ. déchainer l'hilarité) ។ se déchainer *v.pr.* ខឹងខ្លាំង, បោកបក់ខ្លាំង (ខ្យល់)

déchaler *v.i.* នាច (ទឹក); ស្រឡះ, នៅកណ្ដាលភល (ឧ. la plage déchale)

déchanter *v.i.Fam.* លែងក្អេងក្អាង; អស់សង្ឃឹម

décharge *n.f.* ការបាញ់កាំភ្លើង, ការបាញ់បម្រុះ (ឧ. décharge d'artillerie); គ្រាប់ដែលបាញ់(ឧ.recevoir une décharge); ការដោះបន្ទុក, ការផ្ទេរបន្ទុក (ឧ. décharge de mandat); ការឲ្យរួចខ្លួន (ឧ. donner décharge); បន្ទប់ដាក់អីវ៉ាន់ដែលមិនសូវប្រើប្រាស់; ប្រដាប់បញ្ចេញទឹកចោល(ឧ.tuyau de décharge)។ témoin à décharge កសិណខាងចម្លើយ ។ décharge électrique ការអស់កម្លាំងអគ្គិសនី

déchargement *n.m.* ការបើបន្ទុកនាវា ឬរថផ្សេងៗ; ការដកគ្រាប់; ការបាញ់កាំភ្លើង

déchargeoir *n.m.* ផ្លូវបង្ហៀរទឹក; ដុំ (ឈើសម្រាប់មូរសាច់សំពត់ដែលត្បាញបាន); បំពង់ផ្សែង (ម៉ាស៊ីនប្រើចំហាយ)

décharger *v.t.* បើបន្ទុក (ឧ. décharger un navire)។ *Fig.* សម្រាល (ឧ. décharger sa conscience); បន្ធូរពន្ធ, ដោះបន្ទុក(ឲ្យរួចខ្លួនពីកាតព្វកិច្ច) (ឧ. décharger un ami d'un devoir); បង្អស់កម្លាំងអគ្គិសនី (ឧ. décharger un condensateur); បញ្ចេញ (ឧ. décharger sa bile បញ្ចេញកំហឹង); ឆ្លើយដោះសាឲ្យគេ (ឧ. décharger un accusé)។ décharger une arme ដកគ្រាប់ចេញ; បាញ់កាំភ្លើង ។ décharger sa conscience ទទួលខុស ។ *v.i.* បើទំនិញចេញ (ឧ. le navire déchargea); ហើរឬចេញពណ៌ (ឧ. étoffe qui décharge) ។ se décharger *v.pr.* ហូរចេញ ។ se décharger une affaire sur quelqu'un ទម្លាក់បន្ទុកលើអ្នកណាមួយ

déchargeur *n.m.* អ្នកបើទំនិញ (ឧ. les déchargeurs de la halle)

décharné,e *a.* គ្មានសាច់, ស្គមកំព្រឹង

décharner *v.t.* ពន្លះសាច់ចេញ (ឧ. décharner un cadavre); ធ្វើឲ្យស្គម (ឧ. sa maladie l'a décharné)

déchaumage *n.m.* ការភ្ជួរដាស់ដី(ការភ្ជួរបង្កប់ស្មៅឬជញ្រ្ជាំង; ការភ្ជួរដីសើរ)

déchaumer *v.t.* ភ្ជួរដាស់ដី (ភ្ជួរបង្កប់ស្មៅ ឬ ជញ្រ្ជាំង; ភ្ជួរដីសើរ)

déchaumeuse *n.f.* ម៉ាស៊ីនភ្ជួរដាស់ដី (ម៉ាស៊ីនភ្ជួរបង្កប់ស្មៅ ឬ ជញ្រ្ជាំង)

déchaussage ឬ **déchaussement** *n.m.* ការដោះស្បែកជើងឲ្យ; ការកាយដីគល់

déchausser *v.t.* ដោះស្បែកជើងឲ្យ; កាយដីគល់ (ឧ. déchausser un arbre)។ se déchausser *v.pr.* ដោះស្បែកជើង, ចេញគល់នៅកណ្ដាលភ្លក (ឧ. les dents qui se déchaussent)

déchaussoir *n.m.* ប្រដាប់គាស់ឫសធ្មេញ; ប្រដាប់កាយដីចេញពីគល់ឈើ

déchaussure *n.f.* ស្នាមផ្ដៃព្រៃកាយដី

dèche *n.f. Pop.* ការទាល់ក្រខ្លាំង; ទុគ៌តភាព

déchéance *n.f.* ការព្រាត់បាត់សិទ្ធិ (ការបាត់បង់សទ្ធិ ដោយហេតុមិនបានបំពេញល័ក្ខខណ្ឌដែលច្បាប់ឬកិច្ចសន្យាតម្រូវឲ្យក្នុងរយៈពេលមានកំណត់) (ឧ. la déchéance paternelle); ការព្រាត់បាត់អំណាច, ការធ្លាក់បុណ្យ; ការធ្លាក់(ពុះខ្ទិនជាប) (ឧ. déchéance physique, morale)

déchet *n.m.* សំណល់,កាក (ឧ.déchet de laine);សម្រក(ទំនិញ)។ déchet gazeux ឧច្ចិដ្ឋឧស្ម័ន ។ déchet de route ឬ freinte សម្រកតាមផ្លូវ (ចំនួនទំនិញដែលស្រកបាត់តាមការដឹកនាំ) ។ *Fig.* ការខូច; ការខូចតម្លៃ; ការស្រក

décheveler *v.t.* ធ្វើសក់គេឲ្យរាត់រាយ

déchevêtrer *v.t.* ដោះប្រឡៅក

déchiffrable *a.* អាចអានបាន (ឧ. écriture déchiffrable)

déchiffrage ឬ **déchiffrement** *n.m.* ការអាន

déchiffrer *v.t.* បកស្រាយសារសម្ងាត់ (ឧ. déchiffrer un message); អានសេចក្ដីដែលសរសេរមិនច្បាស់ (ឧ. déchiffrer une inscription, un manuscrit) ។ *Fig.* ស្រាយបញ្ហា(ឧ.déchiffrer une énigne)

déchiffreur,euse *n.* អ្នកពូកែអាន, អ្នកពូកែស្រាយបញ្ហា

déchiquetage *n.m.* ការច្រៀក, ការចិញ្ច្រាំ

déchiqueté,e *a.* ដែក, រដេងរដូង(ស្លឹកឈើ) ។ *Fig.* រដាច់រដោច

déchiqueter *v.t.* ច្រៀក (ឧ. déchiqueter la peau); ចិញ្ច្រាំ

déchiqueteuse *n.f.* ប្រដាប់កាត់សន្លឹករូបថត

déchiqueture *n.f.* ស្នាមកាត់ឬរហែកនៅសំពត់

déchirage *n.m.* ការស្រាយបំបែកក្បូនឈើ; ការបំបែកទូកចាស់; ឈើដែលស្រាយចេញពីក្បូន; ក្ដារបំបែកទូក

déchirant,e *a.* ដែលឲ្យខ្លោចចិត្ត (ឧ. pousser des cris déchirants)

déchirement *n.m.* ការរហែក។ *Fig.* ការឈឺចាប់ (ឧ. déchirement d'entrailles រោគចុកពោះខ្លាំង)(ដូចជាដាច់ពោះវៀន) ។ déchirement de cœur ឬ déchirement ទុក្ខព្រួយ (ឧ. le départ d'un être cher cause un grand déchirement) ។ ការបាក់បែក (ឧ. nation en proie à des déchirements)

déchirer *v.t.* រហែក (ឧ. déchirer une étoffe); បក ។ *Fig.* ធ្វើឲ្យបាក់បែក (ឧ. la guerre civile déchira le Cambodge); ធ្វើឲ្យឈឺចាប់; ធ្វើឲ្យកើតទុក្ខ; ធ្វើឲ្យសង្កៀរត្រចៀក(ឧ. déchirer l'oreille); និយាយអាក្រក់, រហែកកេរ្ដិ៍ (ឧ. déchirer son prochain)

déchirure *n.f.* រំហែក; ដំណើររហែក (ឧ. déchirure d'un muscle); ភាពរហែក

déchloruré,e *a.* សាប(គ្មានអំបិល)(ឧ. régime déchloruré)

déchlorurer *v.t.* យកក្លរ(អំបិល)ចេញ

déchoir *v.i.* ធ្លាក់ចុះ (ឧ. déchoir de son rang); ថយ (ឧ. son influence a déchu de jour en jour); ប្រាសចាក (ឧ. déchoir des droits)

déchristianisation *n.f.* ការធ្វើឲ្យលែងកាន់ ឬ លែងជឿសាសនាគ្រិស្ត; ការលែងកាន់ឬលែងជឿសាសនាគ្រិស្ត

déchristianiser *v.t.* ធ្វើឲ្យលែងកាន់សាសនាគ្រិស្ត (ឧ. déchristianiser un pays)

déchu,e *a.* ដែលច្យុត; ដែលប្រាសចាក (ឧ. déchu de ses droits)

déciare (da.) *n.m.* ដេស៊ីអារ (ដ.អ) (១០ម៉ែត្រការ៉េ)

décibel (db.) *n.m.* ដេស៊ីបែល(មាត្រាទណ្ឌនៃសូរ) (ឧ. la voix moyenne a pour intensité 10 décibels, le bruit du tonnerre 70, etc...)

décidé,e *a.* ដែលសម្រេចហើយ (ឧ. c'est une affaire décidée); ចិត្តស្លួយ, មិនសាញ (ឧ. caractère décidé)

décidément *adv.* ដោយដាច់ (ឧ. décidément il est fou)

décider *v.t.Dr.* វិនិច្ឆ័យ, សម្រេចសេចក្ដី (ឧ. décider un différend, une question)។ សម្រេច (ឧ. décider un programme de travail); សម្រេចចិត្ត (ឧ. il a décidé de rester)។ ដឹកនាំ (ឲ្យធ្វើអ្វីមួយ) (ឧ. il le décide à partir); បញ្ចូលចិត្ត (ឧ. il l'a enfin décidé)។ *v.i.* សម្រេច (ឧ. il décide à tort et à travers; décider de la paix)។ se décider *v.pr.* សម្រេចចិត្ត (ឧ. il s'est décidé à travailler)

décigrade (dgr.) *n.m.* ដេស៊ីក្រាត (ដ.ក្រ)

décigramme (dg.) *n.m.* ដេស៊ីក្រាម (ដ.ក)

décilitre (dl.) *n.m.* ដេស៊ីលីត្រ(ដ.ល)

décimable *a.* ដែលជាប់អាករទសភាគ (ឧ. terre décimable)

décimal,e,aux *a.* ទសភាគ, ដែលយកដប់ជាគោល (ឧ. nombre décimal; fraction décimale)។ système décimal ប្រព័ន្ធទសភាគ។ *n.f.* លេខទសភាគ

décimalité *n.f.* ទសភាគភាព

décimateur *n.m.* អ្នកមានអំណាចហូតអាករទសភាគ

décimation *n.f.* ការសម្លាប់ម្នាក់ក្នុងដប់នាក់

décime *n.m.* ដេស៊ីម (ទសភាគនៃហ្វ្រង់); ការតម្លើងមួយភាគដប់

décimer *v.t.* សម្លាប់ម្នាក់ក្នុងដប់នាក់(ឧ. décimer les habitants d'une ville)។ *Par ext.* សម្លាប់រំគាល (ឧ. la peste décima l'armée de Saint Louis)

décimètre (dm.) *n.m.* ដេស៊ីម៉ែត្រ (ដ.ម), តឹក

décimétrique *a.* ដែលមានប្រវែងជាដេស៊ីម៉ែត្រ (ឧ. ondes décimétriques)

décimo *adv.* ទដប់, ជាគម្រប់ដប់

décisif,ive *a.* ដែលសម្រេច (ឧ. argument décisif; combat décisif); ដាច់ខាត, ម៉ឺងម៉ាត់ (ឧ. ton décisif)

décision *n.f.* ការសម្រេច (ឧ. prendre une décision សម្រេច); ការវិនិច្ឆ័យ (ឧ.décision de justice); ដីកា (សេចក្ដីសម្រេចរបស់ចៅហ្វាយខេត្រ); សម្រេច (សេចក្ដីសម្រេចរបស់រដ្ឋមន្ត្រី); décision motivée ដីកា ឬ សម្រេចចង្អុលហេតុផល ។ ភាពចិត្តស្លុយ (មិនរួញរា) (ឧ.montrer de la décision)

décisivement *adv.* ដោយដាច់ខាត

décisoire ឬ litis-décisoire *a. Dr.* ដែលសម្រាប់សម្រេច (ឧ. serment décisoire ឬ litis - décisoire សម្បថសម្រេច(ដោយគ្មានភស្តុតាងគ្រប់គ្រាន់គូក្ដីម្ខាងអាចសុំឲ្យគូក្ដីម្ខាងទៀតស្បថដើម្បីសម្រេចរឿងវិវាទ) (ម.ព. serment ផង)

décistère(dst.) *n.m.* ដេស៊ីស្ទែរ (ដ.ស្ទ)

déclamateur *n.m.* អត្ថវិការី, អ្នកថ្លែងក្នុងទីប្រជុំជន ។ *Fig.* ដែលបំភ្លៃវោហារ (ឧ. ton déclamateur)

déclamation *n.f.* អត្ថវិការ, សេចក្ដី ឬ របៀបថ្លែងតាមវគ្គស្មើ ។ *Fig.* ការបំភ្លៃវោហារ

déclamatoire *a.* ដែលបំភ្លៃវោហារ (ឧ. style déclamatoire)

déclamer *v.t.* ធ្វើអត្ថវិការ, ថ្លែងតាមវគ្គស្មើ (ឧ. déclamer des vers)។ *v.i.* ថ្លែងជំទាស់ដោយម៉ឺងម៉ាត់ (ឧ. déclamer contre les vices du temps); ថ្លែងដោយបំភ្លៃវោហារ

déclarant,e *a.&n.* អ្នកប្ដឹង(ចំពោះមន្ត្រីអត្រានុកូលដ្ឋាន)

déclaratif,ive *a.Dr.* ដែលមានការប្រកាស (ឧ. partage déclaratif d'une propriété)

déclaration *n.f.* ការថ្លែង; សេចក្ដីថ្លែងការណ៍ ។ *Dr.* បណ្ដឹង ។ déclaration de naissance បណ្ដឹងកំណើត ។ déclaration de mariage បណ្ដឹងអាពាហ៍ពិពាហ៍ ។ déclaration de décès បណ្ដឹង

មរណភាព ។ déclaration de revenus បណ្ដឹងផលទុន ។ déclaration de valeurs contenues dans les correspondances បណ្ដឹងតម្លៃផ្ញើតាមលិខិតឆ្លើយឆ្លង ។ ប្រកាស ។ déclaration d'absence ប្រកាសអវត្តមាន (សាលក្រមប្រកាសថាជនណាម្នាក់បាត់ខ្លួនពីលំនៅ) ។ déclaration d'hypothèque ប្រកាសនិក្ខេប (ដាក់បញ្ចាំ) ។ déclaration de command ប្រកាសប្រាប់ឈ្មោះអ្នកទិញ (ម.ព. command ផង) ។ déclaration d'émission de mandat de trésorerie ប្រកាសបេញអាណត្តិរតនាគារ ។ déclaration de faillite ប្រកាសធនក្ស័យ ។ déclaration d'utilité publique ប្រកាសថាជាប្រយោជន៍សាធារណៈ ។ déclaration affirmative ប្រកាសទទួលជំពាក់ ។ déclaration de naturalité ប្រកាសឲ្យចូលសញ្ជាតិ ។ ប្រតិវេទន៍ ។ déclaration de (ឬ en) douane ប្រតិវេទន៍គយ ។ déclaration de marchandises en douane ប្រតិវេទន៍ទំនិញផ្ទុកក្នុងឃ្លាំងគយ (ទំនិញមិនទាន់បង់ពន្ធ) ។ déclaration d'entrée ប្រតិវេទន៍នាំចូល (លិខិតបើបេញពីនាវានូវទំនិញនាំចូល) ។ déclaration de sortie ប្រតិវេទន៍នាំចេញ (លិខិតផ្ទុកទំនិញនាំចេញ) ។ déclaration de cargaison ប្រតិវេទន៍នាវាភណ្ឌ (ការចុះហត្ថលេខាលើបញ្ជីរាយមុខទំនិញផ្ទុកក្នុងនាវា) ។ déclaration d'élection de domicile ប្រតិវេទន៍អំពីការជ្រើសលំនៅ ។ déclaration de non cumul ប្រតិវេទន៍អំពីគ្មានការតម្រួត ។

Pol. déclaration d'un ministre សេចក្ដីថ្លែងការណ៍នៃរដ្ឋមន្ត្រី ។ déclaration de droits de l'homme ប្រកាសសិទ្ធិមនុស្ស ។ déclaration de guerre ប្រកាសសង្គ្រាម ។ déclaration de neutralité ប្រកាសអព្យាក្រឹតភាព (ប្រកាសអព្យាក្រឹតភាពមានពីរបែបៈ ១- ប្រកាសរបស់ប្រទេសដែលធ្វើសង្គ្រាមទទួលស្គាល់ ឬ ដាក់លក្ខខណ្ឌឲ្យប្រទេសណាមួយនៅជាអព្យាក្រឹត ។ ២- ប្រកាសរបស់ប្រទេសអព្យាក្រឹតថា មិនចូលដៃខាងប្រទេសណាមួយដែលជាគូ-

វិភេទ)

déclaratoire *a.Dr.* ដែលប្ដឹងតាមផ្លូវច្បាប់ (ឧ. acte déclaratoire)

déclarer *v.t.* ប្រតិវេទ, ប្រកាស (ឧ. déclarer le guerre); ថ្លែង (ឧ. déclarer ses intentions); ប្ដឹង (ឧ. déclarer ses revenus); ថ្លែងការណ៍។ se déclarer *v.pr.* ចេញឲ្យឃើញ (ឧ. maladie qui se déclare); សំដែង (ជាកូលចិត្តខាងណា) (ឧ. se déclarer pour un candidat); ថ្លែង

déclassé,e *a.&n.* ដែលធ្លាក់ពីឋានៈខ្លួន

déclassement *n.m.* ការរុះរើ; ការបញ្ចុះឋានៈ

déclasser *v.t.* រុះរើ (ឧ. déclasser les livres d'une bibliothèque); បញ្ចុះឋានៈ, ធ្វើឲ្យថោកទាប (ឧ. ses fréquentations l'ont déclassé)។ déclasser un voyageur ផ្លាស់ថ្នាក់អ្នកដំណើរ (ក្នុងអយស្ម័យយាន)។ ដាក់ក្នុងប្រភេទអន់ (ឧ. déclasser du matériel)

déclenchement *n.m.* ការធ្វើឲ្យគ្រឿងចក្រដើរ។ *Fig.* ការធ្វើឲ្យដើរ ។ déclenchement d'une attaque ការផ្ដើមវាយប្រហារ

déclencher *v.t.* ធ្វើឲ្យគ្រឿងចក្រដើរ; ធ្វើឲ្យដើរ។ déclencher la sonnerie ចុចកណ្ដឹង។ *Fig.* déclencher une guerre ផ្ដើមសង្គ្រាម

déclencheur *n.m.* *Techn.* ប្រដាប់ធ្វើឲ្យគ្រឿងចក្រដើរ

déclic *n.m.* គន្លឹះ; សូរគន្លឹះផ្ទាត់

déclin *n.m.* ឱនភាព (ការចុះអន់ថយ) (ឧ. déclin d'une puissance); ដំរេប្រ (កាលទ្រេតទ្រេ) (ឧ. déclin du jour, de la vie)។ *Fig.* ការឱនថយកិត្តិសព្ទ (ឧ. le déclin de Corneille)

déclinable *a.* អាចផ្លៀងបាន

déclinaison *n.f.* *Astr.* ចម្ងាយពីតារាទៅចក្រវាឡ ។ *Gram.* ការបំបែកនាមសព្ទ

déclinant,e *a.* ដែលអន់; ដែលចុះខ្សោយ (ឧ. puissance déclinante); ដែលងាក

déclination *n.f.* ឬ **déclinement** *n.m.* ដម្រាល; ការផ្លៀង; ការងាក

déclinatoire *n.m.* *Dr.* ការមិនទទួលស្គាល់សមត្ថកិច្ចតុលាការណាមួយ។ *a.* សម្រាប់មិនទទួលស្គាល់នីតិកម្ម(ឧ.ex-

ceptions déclinatoires)

décliner *v.i* ចុះថយ (ឧ. les forces déclinent avec l'âge); ទេរ, ទ្រេតទ្រោត (ឧ. le jour décline); ផ្អៀង, បែរចេញពីទិសខាងជើង (ទ្រនិចត្រីវិស័យ) ; ចរចេញពីចក្រវាឡ (តារា) ។ *v.t.* *Dr.* មិនទទួលស្គាល់ (ឧ. décliner la compétence d'un tribunal); មិនព្រមទទួល (ឧ. décliner un honneur, toute responsabilité) ។ *Gram.* បំបែកតាមសព្ទ ។ *Fig.* décliner son nom ប្រាប់ឈ្មោះខ្លួន

déclinquer *v.t.* ពំទេច

décliquer *v.t.* សង្កត់ ឬ គ្នឹះគន្លឹះ

décliquetage *n.m.* ការដោះស្ដីក្បាលឆ្កែ

décliqueter *v.t.* ដោះស្ដីក្បាលឆ្កែ

déclive *a.* ទ្រាល (ឧ. terrain déclive) ។ *n.m.* ជម្រាល (ឧ. chaussée en déclive)

décliver *v.i.* ទ្រាល, ទេរ

déclivité *n.f.* ភាពទ្រាល

déclore *v.t.* បើករបង

déclouer *v.t.* ដកដែកគោល

décochement *n.m.* ការបាញ់នឹងធ្នូ ឬ ស្នា ។ *Fig.* សំដីដាក់ផ្លែ

décocher *v.t.* បាញ់នឹងធ្នូ ឬ ស្នា (ឧ. décocher une flèche) ។ *Par ext.* décocher une ruade ព្រាយ (ធាក់ដោយជើងទាំងពីរទៅក្រោយ) ។ *Fig.* ដាក់មួយផ្លែ (ឧ. décocher une épigramme)

décocté *n.m.* ទឹកស្ងោរ

décoction *n.f.* ការស្ងោរ; ទឹកដាំឬស្ងោរ

décoder *v.t.* បកស្រាយអក្សរសម្ងាត់

décoffrage *n.m.* ការបកពុម្ពស៊ីម៉ង់

décoffrer *v.t.* បកពុម្ពស៊ីម៉ង់

décoiffement *n.m.* ការបើកមួក; ការរំសាយសក់

décoiffer *v.t.* បើកមួក (ឧ. décoiffer un enfant); រំសាយសក់, រុះរើសក់ (ដែលសិត ឬ បួងស្អាត) (ឧ. le vent l'a toute décoiffée) ។ décoiffer une bouteille បកស្រោបឆ្នុកដប

décoincement *n.m.* ការដោះស្នៀតចេញ

décoincer *v.t.* ដោះស្នៀតចេញ

décolérer *v.i.* លែងខឹង, រសាយកំហឹង

décollage *n.m* ការបក; ការហោះឡើង (ឧ. le décollage d'un avion)

décollation *n.f.* ការកាត់ក (ឧ. décollation d'un criminel)

décollement *n.m.* ការបក; ការរបើក (ឧ.décollement de la rétine)

décoller *v.t.* បក (ឧ. décoller un timbre)។ *v.i.* ហោះឡើង(អាកាសយាន) ។ *Pop.* ថយចេញ (ឧ. on ne peut pas le faire décoller)

décoller *v.t.* កាត់ក

décolletage *n.m.* ការបើកចំហគល់កនឹងស្មា;ការកាត់ឬពន្លាត់ករអាវ; ការកាត់ពុង (រុក្ខជាតិ); ការធ្វើដែកឡេស៊ី

décolleté,e *a.* ដែលចំហគល់កនឹងស្មា; (ឧ.femme décolletée)។ *n.m.* ភាគករអាវដែលពន្លាត់ចុះ ឬ កាត់ចេញ (ឧ. en grand décolleté); ភាគកដែលបើកចំហ

décolletter *v.t.* បើកចំហគល់កនឹងស្មា, កាត់ឬបត់ចំហគល់កនឹងស្មា (ឧ. décolleter une robe) ។ *Arg.* កាត់ពុង (រុក្ខជាតិ) ។ tour à décolleter ម៉ាស៊ីនធ្វើដែកឡេស៊ី

décolleteur,euse *n.* ជាងកាត់អាវពន្លាត់ក។ *n.f.* ម៉ាស៊ីនកាត់ពុងរុក្ខជាតិ; ម៉ាស៊ីនធ្វើដែកឡេស៊ី

décolorant,e *a.*ដែលធ្វើឲ្យហើរពណ៌ ។ *n.m.* ថ្នាំបង្ហើរពណ៌

décoloration *n.f.* ការហើរឬបាត់ពណ៌

décoloré,e *a.* ដែលបាត់ពណ៌

décolorer *v.t.* បង្ខូចពណ៌, បំបាត់ពណ៌ (ឧ. le soleil décolore les nuances vives)។ se décolorer *v.pr.* ហើរពណ៌

décombler *v.t.* ស្តារ (ឧ. décombler un puits)

décombrement *n.m.* ការរើយកកំទេចចេញ

décombrer *v.t.* រើយកកំទេចចេញ ។ *Fig.* បំបាត់ឧបសគ្គ (ឧ. décombrer la route du progrès)

décombres *n.m. pl.* កំទេចគេហស្ថាន; កំទេច

décommander *v.t.* បដិសេធ (ការបង្គាប់ឬការណាត់ជួបគ្នា) (ឧ.décommander des invités)

décommettre *v.t. Mar.* លាខ្សែពួរនាវា

de commodo et incommodo (de l'avantage et inconvénient) *loc.lat.* សុវិធាននឹងអសុវិធាន (ម.ព. enquête នឹង)

décompléter *v.t.* ធ្វើឲ្យខ្វះ

décomposable *a.* អាចបំបែកធាតុបាន (ឧ. mot décomposable)

décomposé,e *a.* រលួយ (ឧ. corps décomposé)។ *Fig.* ខូច, សៅហ្មង (ឧ. visage décomposé par la douleur)

décomposer *v.t.* បំបែកធាតុ (ឧ. décomposer l'eau)។ *Fig.* décomposer une phrase បំបែកប្រយោគ។ ធ្វើឲ្យរលួយ (ឧ. la chaleur décompose les viandes)។ *Fig.* ធ្វើឲ្យខូច, ធ្វើឲ្យសៅហ្មង (ឧ. la peur décompose ses traits)។ se décomposer *v.pr.* រលួយ

décomposition *n.f.* វិសមាសកម្ម; ការបំបែកធាតុ; ការខូចទ្រង់ទ្រាយ; ភាពរលួយ

décompresseur *n.m.* ប្រដាប់បន្ធូរខ្យល់ ឬ ចំហាយ

décompression *n.f.* ការបន្ធូរ

décomprimer *v.t.* បន្ធូរ (ឲ្យលែងហាប់ឬណែន)

décompte *n.m.* វិគណនី (ការរាយមុខបរិមាណប្រាក់, ការរាប់ប្រាក់; ការគិតទូទាត់; ការកាត់ប្រាក់)។ *Fig.* ការខកចិត្ត (ឧ. éprouver du décompte)

décompter *v.t.* កាត់ប្រាក់, រាប់ប្រាក់។ *v.i.* បង្អន់សេចក្ដីទុកចិត្តលើខ្លួន ឬ សេចក្ដីសង្ឃឹម; វាយម៉ោងខុស(នាឡិកា)

déconcentration *n.f.* ការរំលែកអំណាច

déconcertant,e *a.* ដែលឲ្យទាល់គំនិត ឬឲ្យទាល់ប្រាជ្ញ (ឧ. d'une impassibilité déconcertante)

déconcerter *v.t.* យាយី (ឧ. déconcerter une ligue); ធ្វើឲ្យទាល់គំនិត ឬ ឲ្យទាល់ប្រាជ្ញ (ឧ. cette réponse nous a déconcertés)

déconfit,e *a.* ម៉ងម៉ាំង (ឧ. mine déconfite)

déconfiture *n.m.* ការៈលាញ (ភាពអ្នកបំពេញកិច្ចសន្យាមិនបាន, ភាពហិនហោច; ការធ្លាក់ទ័ព, ការចាញ់)

décongeler *v.t.* រំលាយវត្ថុដែលកកឬខះ

décongestionner *v.t.* ធ្វើឲ្យបាត់ស្លាក់ឈាម (ឧ. décongestionner les poumons)។ *Fig.* ធ្វើឲ្យស្រឡះឬឲ្យទូលាយ (ឧ. décongestionner une rue)

déconseiller *v.t.* ឲ្យឱវាទឬឲ្យយោបល់ឃាត់

déconsidération *n.f.* ការខូចសេចក្ដីរាប់អាន

déconsidérer *v.t.* ធ្វើឲ្យថយថោក; ធ្វើឲ្យខូចសេចក្ដីរាប់អាន។ se déconsidérer *v.pr.* ចុះថយថោក; បាត់សេចក្ដីរាប់អាន

décontenancer *v.t.* ធ្វើឲ្យស្លន់, បន្ទប់ (ឧ. décontenancer des candidats)។ se décontenancer *v.pr.* ស្លន់, ឡប់

décontracté,e *a.* ដែលសម្រាកស្រួល

décontracter *v.t.* លាវិញ (ឧ. décontracter ses muscles)។ se décontracter *v.pr.* លាសាច់ដុំ។ *Fig.* សម្រាក

décontraction *n.f.* ការលាសាច់ដុំវិញ

déconvenue *n.f.* ការស្រងាកចិត្ត

décor *n.m.* អលង្កត [អៈ-ឡុង-ក័ត] (គ្រឿងតែងលំអ)។ *Par ext.* អាការៈក្រៅ។ *Pl.* អលង្កត, លំអនៃកន្លែងលេងល្ខោន; ទេសភាពល្អ។ décors et meubles គ្រឿងតែងលំអនឹងសង្ហារិម

décorateur,trice *n.* អលង្ការី-រិនី, អ្នកតែងលំអ

décoratif,ive *a.* នៃការតែងលំអ (ឧ. art décoratif); សម្រាប់តែងលំអ (ឧ. tableau décoratif); ជាលំអ។ *Fig.&Fam.* ដែលមានស្វាហាប់ល្អ (ឧ. personnage décoratif)

décoration *n.f.* អលង្ករណ៍, ការតែងលំអ (ឧ. la décoration d'un appartement); គ្រឿងលំអទាំងឡាយ (ឧ. la décoration de l'autel); សិល្បៈខាងតែងលំអ; របៀបតែងលំអ (ឧ. entendre la décoration យល់របៀបតែងលំអ); គ្រឿងឥស្សរិយយស

décorder *v.t.* លាធ្លុងខ្សែ ឬ ពួរ (ឧ. décorder un câble); ស្រាយលែង (ឧ. décorder des bœufs)

décoré,e *a.* អលង្កត, ដែលមានលំអ; ដែលពាក់គ្រឿងឥស្សរិយយស (ឧ. soldat décoré)។ *n.* អ្នកទទួលគ្រឿងឥស្សរិយយស

décorer *v.t.* តែងលំអ (ឧ. décorer un appartement); បំពាក់គ្រឿងឥស្សរិយយស

décorner *v.t.* កាត់ស្នែងចេញ (ឧ. décorner un bœuf)។ vent ឬ

bise à décorner un bœuf ខ្យល់ខ្លាំងណាស់(ស្ទើរសណ្ដកស្នែងគោ)

décortication *n.f.* ឬ **décorticage** *n.m.* ការយកសំបកចេញ; ការកិន ឬ បុក (ស្រូវ); ការជ្រុះសំបក

décortiquer *v.t.* យកសំបកចេញ; កិន ឬ បុក (ស្រូវ)

décorum *n.m.* ច្បាប់គួរសម (ឧ. être soucieux du décorum); ពិធីផ្លូវការ (ឧ. décorum royal)

décote *n.f.* ការលស់ពន្ធ

découcher *v.t.* ចោលដំណេក (ដេកក្រៅពីផ្ទះខ្លួន)

découdre *v.t.* រុះថ្នេរ; ខ្វេះ, ធ្វើឲ្យរបួស (ឧ. le sanglier découd un chien ជ្រូកព្រៃខ្វេះឆ្កែ) ។ *v.i.Fig.* en découdre វាយគ្នា (ឧ. l'ennemi s'avance, nous allons en découdre)

découler *v.i.* ហូរព្រិញៗ។*Fig.*មកអំពី (ឧ. découler d'un principe)

découpage *n.m.* ការកាត់ ។ *Cin.* ការបែកជាឈុត។ អត្ថបទដែលបែងចែកជាឈុត។ découpage électoral ការតាំងមណ្ឌលបោះឆ្នោត

découpe *n.f.* ក្រួមកាត់វិចិត្រនៅសំពត់

découpé,e *a.*ដែលមានជាយដែកៗ(ស្លឹក)

découper *v.t.* កាត់ជាដុំស្មើគ្នា (ឧ. découper une volaille); កាត់តាមវង់គំនូស (ឧ. découper des images)។ se découper *v.pr.* លេចធ្លោឡើង (ឧ. montagne se découpant sur le ciel)

découpeur,euse *n.* អ្នកកាត់ ។ *n.f.* ម៉ាស៊ីនកាត់

découple ឬ **découpler** *n.m.* ការស្រាយលែងឆ្កែប្រដេញ

découplé,e *a.* ដែលមានរូបរាងសម (ឧ. sportif bien découplé)

découpler *v.t.* ស្រាយលែង (ឆ្កែដែលចងភ្ជាប់គ្នាពីរៗ) ។ *Fig. &Fam.* ពន្ធ្វងឲ្យដេញតាម (ឧ. découpler des agents après un voleur)

découpoir *n.m.* ប្រដាប់កាត់; ម៉ាស៊ីនកាត់

découpure *n.f.* ការកាត់;មុខកាត់ផ្ដាច់; វត្ថុដែលកាត់ច្រៀក;ជាយដែកៗនៃស្លឹក។ *Géogr.* ច្រាំងឆកដែប

décourageant,e *a.* ដែលឲ្យនឿយណាយ ឬ ឲ្យខូចទឹកចិត្ត (ឧ. nouvelle décourageante)

découragement *n.m.* ការនឿយ-

ណាយ; ការខូចទឹកចិត្ត

décourager *v.t.* ធ្វើឲ្យខូចទឹកចិត្ត, ធ្វើឲ្យអស់កម្លាំង(ឧ.l'injustice nous décourage); ធ្វើឲ្យនឿយណាយ (ឧ. décourager quelqu'un d'écrire) ។ se décourager *v.pr.* ខូចទឹកចិត្ត, នឿយណាយ

découronnement *n.m.* ការទម្លាក់រាជ្យ; ការកាត់ចុង; ភាពកំបុតចុង(ឈើ)

découronner *v.t.* ទម្លាក់រាជ្យ (ឧ. découronner un roi);កាត់ចុងឈើ

décours *n.m.* រនោច; ការស្រកនៃជម្ងឺ

décousu,e *a.* ដែលដាច់ថ្នេរ ។ *Fig.* រដាក់រដុប, មិនហូរហែ (ឧ. style décousu)

décousure *n.f.* កន្លែងដាច់ថ្នេរ; របួសឆ្កែដោយសត្វព្រៃវែធ ឬ ខ្វែះ

découvert,e *a.* ចំហ, គ្មានគ្រប; ដែលនៅកណ្តាលវាល; មិនពាក់មួក (ឧ. tête découverte)។ pays découvert ស្រុកវាល (គ្មានព្រៃឈើ)។ à découvert *loc.adv.* កណ្តាលវាល; ឥតមានអ្វីការពារ(ឧ. combattre à découvert)។ être à découvert គ្មានធានា(ចំពោះវត្ថុឬប្រាក់ខ្ចី), ឲ្យខ្ចីប្រាក់ដោយគ្មានរបស់បញ្ចាំ ។ *Fig.* parler à découvert និយាយដោយស្មោះ (ឥតវៀចវេរ) ។ ទីកណ្តាលវាល ។ *n.m. Fin.* វិជារូបន៍ [វិ-ជ៉ា-រូប] (ឥណទានដែលធនាគារីកព្រមបើកឲ្យអ្នកជំនួញតាមគណនីចរន្តក្នុងលក្ខខណ្ឌដូចមានចែងក្នុងកិច្ចសន្យាដែលភាគីបានធ្វើ)។ប្រាក់ខ្វះ (ឧ. combler un découvert)។ découvert du Trésor ប្រាក់ខ្ចីពីរតនាគារដើម្បីបំពេញការខ្វះក្នុងថវិការដ្ឋ

découverte *n.f.* ការរកឃើញ (ឧ. la découverte de la pénicelline) របស់រកឃើញ។ à la découverte *loc. adv.* ដើម្បីរក, ដើម្បីស្គាល់

découvreur,euse *n.* អ្នករកឃើញ

découvrir *v.t.* បើកគ្រប,បើកចំហ,បើករបស់អ្វីដែលគ្រប ឬ ដែលការពារ (ឧ. découvrir une statue; découvrir son flanc à l'attaque); រកឃើញ (របស់ដែលគេលាក់ឬដែលគេមិនស្គាល់) (ឧ. découvrir un trésor; découvrir un vaccin); ឃើញពីចម្ងាយ (ឧ. découvrir le mont Blanc); ប្រាប់, បង្ហាញ (ឧ. découvrir un secret) ។ *v.i.* លេចឡើង (ឧ. ro-

cher qui découvre) ។ se découvrir *v.pr.* បើកមួក; ឡើងស្រឡះ (មេឃ); នៅកណ្ដាលវាល; ឲ្យឃើញ; គ្មានអ្វីការពារ ។ *Fig.* បង្ហាញគំនិតខ្លួន

décrassement ឬ **décrassage** *n.m.* ការដុសក្អែល

décrasser *v.t.* ដុសក្អែល។ *Fig.* ជួយឲ្យរួចពីទុក្ខវេទនា; បំបាត់អំពើគ្នាំគ្នង, អប់រំ (កុំឲ្យល្ងង់ខ្លៅពេក)។ se décrasser *v.pr.* ចាកភាពថោកទាប

décrassoir *n.m.* ច្រាសជម្រះក្បាល ឬ ជម្រះក្អែលច្រាស

décréditer *v.t.* បង្ខូចកេរ្តិ៍ឈ្មោះ

décrépir *v.t.* កោសបាយអបូក ។ se décrépir *v.pr.* របើកបាយអបូក

décrépissage *n.m.* ការកោសបាយអបូក

décrépit,e *a.Fig.* ជរាទុព្វល, ចាស់រយាក (ឧ. vieillard décrépit)

décrépitation *n.f.* ការផ្ទុះ (អំបិល)

décrépiter *v.i.* ផ្ទុះ (អំបិល) ។ *v.t.* décrépiter le sel លីងអំបិល

décrépitude *n.f.* ជរាទុព្វលភាព ។ *Fig.* ភាពចាស់រយាក

décrescendo *adv.* ដោយថយចុះជាលំដាប់; កាន់តែតិចទៅៗ

décret *n.m.* ក្រឹត្យ ។ décret royal ព្រះរាជក្រឹត្យ

décréter *v.t.* បញ្ញត្ត(ដោយក្រឹត្យ)។ décret-loi *n.m.* ក្រឹត្យក្រម (*pl.* des décret-lois)

décri *n.m.* ការចុះតម្លៃនៃរូបិយវត្ថុ ឬ ទំនិញ ។ *Fig.* ការខូចកិត្តិសព្ទ, ការអស់សេចក្ដីរាប់អាន (ឧ. tomber dans le décri public)

décrier *v.t.* បង្ខូចកិត្តិសព្ទ; បង្ខូចតម្លៃ; បន្ថាប់; និយាយបន្ថាប់ (ឧ. décrier l'œuvre de quelqu'un)

décrire *v.t.* ពិពណ៌នា (ឧ. décrire un pays); រៀបរាប់; គូស (ឧ. décrire une ellipse)

décrochage ឬ **décrochement** *n.m.* ការដោះដៃពីសត្រូវ; ការដោះវត្ថុដែលថ្ពក់

décrocher *v.t.* ដោះវត្ថុដែលថ្ពក់ ។ *Fig.&Fam.* បាន (ឧ. décrocher une commande)។ *Pop.* លោះវត្ថុបញ្ចាំ។ décrocher un enfant រលូតកូន; រំលូតកូន។ *v.i. Mil.* ដោះដៃពីសត្រូវ

décrochez-moi-ça *n.m. inv.* *Pop.* សំលៀកបំពាក់ចាស់; ហាងលក់

សំលៀកបំពាក់ចាស់

décrochoir *n.m.* ប្រដាប់ដោះវត្ថុដែលជាប់

décroisement *n.m.* ការលា ឬ ដោះ (អ្វីៗដែលព័ន្ធគ្នា)

décroiser *v.t.* លាឬដោះអ្វីៗដែលព័ន្ធគ្នា (ឧ. décroiser les jambes)

décroissance *n.f.* ម.ព. décroissement

décroissant,e *a.* ដែលអន់ថយ, ដែលថយចុះ (ឧ. vitesse décroissante) ។ lune décroissante រនោច

décroissement *n.m.* ឬ **décroissance** *n.f.* ការលស់; ការថយចុះ; ការស្រក

décroît *n.m.* រនោច (ឧ. la lune est dans son décroît)

décroître *v.t.* ថយចុះ (ឧ. les jours décroissent); ស្រក (ឧ. les eaux décroissent)

décrottage *n.m.* ការជម្រះរេចម៍សត្វ ពាហណៈ ឬ ភក់

décrotter *v.t.* ជម្រះភក់ (ឧ. décrotter des chaussures) ។ *Fig.&fam.* décrotter quelqu'un បង្រៀន, អប់រំ

décrotteur *n.m.* អ្នកដុសសំអែត; អ្នកខាត់ស្បែកជើង; ម៉ាស៊ីនលាងមើម

décrotteuse ឬ **décrottoire** *n.f.* ច្រាសជម្រះភក់ ឬ រេចម៍សត្វ

décrottoir *n.m.* ប្រទាសជូតភក់ជើង

décrue *n.f.* ដំណើរស្រក (ទឹក); ទឹកសំរក (ឧ. une décrue d'un mètre)

décruer, décruser ឬ **décreuser** *v.t.* ប្រមោក (សូត្រ អម្បោះ)

décrûment, décrusage, décreusage ឬ **décreusement** *n.m.* ការប្រមោក (សូត្រ អម្បោះ)

décrypter *v.i.* អានរហស្សលេខ, អានអក្សរសម្ងាត់ដែលគេមិនបេះ

déçu,e *a.* ខកចិត្ត; ដែលចាញ់បញ្ឆោតគេ; ដែលមិនសម្រេច (ឧ. espoir déçu)

décuirasser *v.t.* ដោះគ្រោះ

déculotter *v.t.Fam.* សម្រាតខោ

décuple *n.m.&a.* ទសគុណ (១០ គុណ)

décuplement *n.m.* ការគុណនឹង១០

décupler *v.t.* គុណនឹង១០ ។ *Fig.* បង្កើនយ៉ាងច្រើន (ឧ. la colère décuple les forces) ។ *v.i.* ឡើងធំជាង១០ដង (ឧ. fortune qui décuple)

décuvage *n.m.* ឬ **décuvaison** *n.f.*

ការផ្ទេរធុងស្រា

décuver *v.t.* ផ្ទេរធុងស្រា

dédaignable *a.* គួរមើលងាយ

dédaigner *v.t.* មាក់ងាយ (ឧ.dédaigner les sots); មិនទទួល (ដោយយល់ថាមិនសមនឹងឋានៈខ្លួន) (ឧ. dédaigner une offre) ។ dédaigner de មិនរវល់នឹង, មិនខ្វី (ឧ. il dédaigne de répondre)

dédaigneusement *adv.* ដោយមើលងាយ

dédaigneux,euse *a.* ដែលមើលងាយ, ឆ្មើងឆ្មៃ (ឧ.regard dédaigneux)

dédain *n.m.* សេចក្ដីមើលងាយ, ការឆ្មើងឆ្មៃ

dédale *n.m.* ទីខ្វាត់ខ្វែងនាំឲ្យវង្វេង ។ *Fig.* ការសាំញ៉ាំ (ឧ.le dédale des lois)

dédaléen,enne *a.* សាំញ៉ាំ, រើមរភម

dedans *adv.* ក្នុង, ខាងក្នុង ។ *Loc. adv.* là-dedans ក្នុងទីនេះ; *au fig.* ក្នុងរឿងនេះ (ឧ. il y a là-dedans quelque chose que je ne comprends pas) ។ en dedans, au-dedans ឬ par dedans ខាងក្នុង ។ par dedans តាមខាងក្នុង ។ mettre dedans ដាក់គុក; *au fig.* បញ្ឆោត, យកជ័យជំនះក្នុងការជំដែក ។ donner dedans ចាញ់បញ្ឆោត ។ être dedans ស្រវឹងស្រា ។ ne savoir si l'on est dedans ou dehors មិនស្រេចថាយកខាងណា ។ n'être ni dedans ni dehors មិនច្បាស់ថានៅខាងណា ។ être en dedans សញ្ជប់សញ្ជឹង (ជ្រប់ធ្មឹង); មិនរួសរាយ ។ esprit ឬ caractère en dedans មូរមុខ, លាក់ពុត ។ *Loc. pré.* au dedans de ឬ par dedans de ខាងក្នុងនៃ

dedans *n.m.* ផ្នែកខាងក្នុង (ឧ. le dedans d'un édifice)

dédicace *n.f.* ការឧទ្ទិស; ពិធីឧទ្ទិស; សេចក្ដីឧទ្ទិស (របស់អ្នកនិពន្ធ)

dédicacer *v.t.* ឧទ្ទិស (ឧ. dédicacer un livre)

dédicatoire *a.* ដែលមានសេចក្ដីឧទ្ទិស (ឧ. épître dédicatoire)

dédier *v.t.* ឧទ្ទិស (ចំពោះសាសនា) (ឧ. dédier un autel à la Vierge); ឧទ្ទិសសៀវភៅ; ថ្វាយ, ជូន

dédire *v.t.* បដិសេធសំដី ឬ កិច្ចដែលគេ

ធ្វើជំនួសខ្លួន (ឧ. dédire un supérieur) ។ se dédire *v.pr.* ប្រែប្រួលសំដី (ឧ. le témoin s'est dédit); មិនកាន់សំដី (ឧ. se dédire de son engagement); និកពាក្យសំដី

dédit *n.m.* ការប្រែប្រួលសំដី, ការមិនកាន់សំដី; ការដកពាក្យ; ប្រាក់ត្រូវបង់កាលណាគេមិនកាន់តាមកិច្ចសន្យា

dédommagement *n.m.* ការជួសជុលសោហ៊ុយ (ឧ. recevoir une somme en dédommagement d'un accident); សំណង

dédommager *v.t.* ជួសជុលសោហ៊ុយ, ប៉ូវ (ឧ. dédommager quelqu'un d'une perte); សង ។ *Fig.* ជារង្វាន់ (ឧ. la réussite l'a dédommagé de ses efforts)

dédorage *n.m.* ឬ **dédorure** *n.f.* ការកោសមាសដែលទឹប; ដំណើរបកមាសដែលទឹប

dédouanement *n.m.* ការបើចេញពីគយ (ដោយបង់ពន្ធ)

dédouaner *v.t.* បើចេញពីគយ (ដោយបង់ពន្ធ) ។ *Fig.* ហៅមកឲ្យកាន់គំណែងនយោបាយវិញ (ចំពោះមនុស្សដែលគេបនិសេធពីអតីត)

dédoublage *n.m.* ការបកទ្រនាប់ចេញ ។ dédoublage de l'alcool ការលាយស្រានឹងទឹក

dédoublement *n.m.* ទ្វេយការ [ទ្វៈ-យៈ-], អកការ ឬ ដំណើរចែកជាពីរ ។ dédoublement de la personnalité ទ្វេយការនៃបុគ្គលិកលក្ខណៈ (រោគវិកលចរិតដែលបណ្ដាលឲ្យអ្នកជម្ងឺបញ្ចេញនូវបុគ្គលិកលក្ខណៈពីរខុសគ្នាគឺ ម្ដងជាមនុស្សធម្មតា ម្ដងទៀតជាមនុស្សវិកល)

dédoubler *v.t.* បកទ្រនាប់ចេញ (ឧ. dédoubler un manteau); លាតក្ដារឿងដែលបត់ជាពីរ (ឧ. dédoubler une feuille de papier) ។ *Par ext.* ចែកជាពីរ (ឧ. dédouler une classe) ។ dédoubler un train ឲ្យមានអយស្ម័យរថពីររត់នូវមួយ

déductif,ive *a.* អនុមាន, ដែលទាញផល (ឧ. le syllogisme est un raisonnement déductif)

déduction *n.f.* ការហូតចេញ; ការបន្ថយ (ឧ. déduction des sommes déjà payées) ។ *Phil.*

អនុមាន, ផលដែលទាញចេញអំពីវិចារណកិច្ច (ឧ. une suite de déductions)។សេចក្ដីរាយការណ៍ដ៏ល្អិត

déduire *v.t.* ហូតចេញ,បន្ថយ (ឧ. déduire ses frais); ធ្វើអនុមាន, ទាញផលអំពីវិចារណកិច្ច, សន្និដ្ឋាន (ឧ. je déduis de là que...); រាយការណ៍

déesse *n.f.* ទេពធីតា។ *Par ext.* ស្ត្រីមានឫកពាថ្លៃថ្នូរ

de facto *loc. adv.* តាមព្រឹត្តន័យ(តាមដំណើរការណ៍ដែលមានមកស្រេចហើយ) (ឧ. gouvernement reconnu de facto) (ព.ផ. de jure។ ម.ព. reconnaissance ផង)

défâcher (se) *v.pr. Fam.* បាត់ខឹង

défaillance *n.f.* គុណវិបត្តិ (ឧ. défaillance d'une race)។ *Par ext.* ទុព្វលភាព, ភាពខ្សោយ (ឧ. la vieillesse cherche des appuis pour soutenir sa défaillance); ការសន្លប់ (ឧ. selon Saint-Foix, le chevalier Bacon tombait en défaillance toutes les fois qu'il y avait une éclipse de lune)។ *Fig.* ការភ្លាំងភ្លាត់ (ឧ. chacun a ses moments de défaillance)។ *Dr.* ការមិនប្រតិបត្តិតាមកិច្ចសន្យា; ការមិនធ្វើតាមបង្គាប់; ការមិនចូលខ្លួន

défaillant,e *a.* ដែលខ្វះ។ *Par ext.* ទន់ខ្សោយ (ឧ. vieillard défaillant; main défaillante; mémoire défaillante)។*Fig.* មានសមត្ថភាពពុំគ្រប់គ្រាន់ (ឧ. chef défaillant); ដែលភ្លាំងភ្លាត់ ។ *Dr.* ដែលមិនប្រតិបត្តិតាមកិច្ចសន្យា ឬ តាមបង្គាប់;ដែលមិនចូលខ្លួន (ឧ. partie défaillante) ។ *n.* អ្នកមិនបានចូលខ្លួន

défaillement *n.m.* ការខ្វះ; ការឈប់

défaillible *a.* អាចភ្លាំងភ្លាត់បាន

défaillir *v.i.* ខ្វះ; មិនប្រតិបត្តិតាម, មិនបំពេញ (ឧ. défaillir à son devoir); អស់, ពាយ (ឧ. certaines espèces de poissons ont défailli pour toujours)។ *Par ext.* អស់កម្លាំង, ចុះទន់ខ្សោយ (ឧ. je m'aperçois que ta vie mortelle défaut); បែកធ្លាយ (ស្លាប់) (ឧ. mon corps défaut avant mon esprit)។ *Fig.* ប្រព្រឹត្តភ្លាំងភ្លាត់ (ឧ. errez,

défaillez, péchez, mais soyez des justes) ។ se défaillir *v.pr.* ប្រតិបត្តិខុសចំពោះខ្លួនឯង (ឧ. je ne veux pas me défaillir à moi-même)

défaire *v.t.* រុះ; បំផ្លាញវិញ (ឧ. défaire un ouvrage); រុះរើ (ឧ. défaire un lit, sa coiffure); ស្រាយ (ឧ. défaire sa cravate) ។ *Fig.* ធ្វើឲ្យទន់ខ្សោយ ឬ ឲ្យស្គម (ឧ. la maladie l'a défait); វាយបំបាក់ទ័ព (ឧ. défaire l'ennemi); យកចេញ (ឧ. défaites-moi de cet importun) ។ se défaire *v.pr.* លក់ ឬ ឲ្យ (ព្រោះមិនចង់ទុក) (ឧ. se défaire d'un cheval); គេចចេញពី, ដោះដៃចេញពី (ឧ. se défaire d'un raseur) ។ *Fig.* កែខ្លួន (ឧ. se défaire d'un défaut); សម្លាប់ខ្លួន (ឧ. il s'est défait); ស្រាត (ឧ. se défaire pour prendre le bain); រលាស់ចោល, បដិសេធ (ឧ. se défaire de ses préjugés); ខូច, របូត (ឧ. un nœud qui se défait); ស្រពោន

défait,e *a.* ស្លេកស្លាំង, ស្គមស្គាំង; ស្រមើស (ឧ. visage défait)

défaite *n.f.* រណបរាជ័យ; បរាជ័យ; ការចាញ់ (ឧ. défaite électorale)

défaitisme *n.m.* បរាជ័យនិយម

défaitiste *a.* នៃបរាជ័យនិយម ។ *n.* អ្នកបរាជ័យនិយម

défalcation *n.f.* ការដកចេញ, ការហូតចេញ, ការផាត់ចេញ

défalquer *v.t.* ដកចេញ, ហូតចេញ, កាត់ចេញ, បន្ថយ, ផាត់ចេញ

défaufiler *v.t.* រុះថ្នេរជាន

défausser *v.t.* កែតម្រូវ ។ se défausser *v.pr.* ធីបបៀចោល (ទម្លាក់ចោល)

défaut *n.m.* សេចក្ដីខ្វះ (ឧ. défaut de courage); កំហុស, ទោស (ឧ. on est aveugle sur ses défauts, clairvoyant sur ceux des autres ទោសខ្លួនឯងមើលមិនយល់ ទោសគេតូចសោតសល់ មើលយល់ប៉ុនទាំងភ្នំ) ។ គុណវិបត្តិ (ឧ. drap qui a un léger défaut; critiquer les défauts d'un poème) ។

Par ext. ចុង (ទីផុត) (ឧ. être frappé au défaut des

côtes វាយត្រូវត្រង់ចុងឆ្អឹងជំនីរ) ។ *Fig.* ចំណុចខ្សោយ (ឧ. fuyez un ennemi qui sait votre défaut) ។ défaut de la cuirasse មុខតំណក្រោះ; *au fig.* ទោស (ឧ. toute passion est un défaut de la cuirasse) (ម.ព. cuirasse ផង)។ jugement par défaut សាលក្រមដាច់ណាត់ ។

Loc. pré. à défaut de បើគ្មាន។ au défaut de ជាជំនួយ។ faire défaut ខ្វះ (ឧ. triste situation quand le travail fait défaut); មិនចូលខ្លួនទៅតុលាការ; មិនបានបំពេញករណីយកិច្ច (ឧ. faire défaut à ses engagements មិនកាន់ពាក្យសន្យា)។ mettre en défaut ធ្វើឲ្យច្រឡំ, ធ្វើឲ្យភ័ន្ត (ឧ. les fautes des sots sont quelquefois si difficiles à prévoir qu'elles mettent les sages en défaut)។

Loc. prov. c'est là son moindre défaut នេះជាកំហុសតូចបំផុតរបស់គាត់ (បើផ្ទឹមទៅនឹងកំហុសធំៗឯទៀតដែលអ្នកនោះមាន)

défaveur *n.f.* ការខូចសេចក្ដីរាប់អានឬសេចក្ដីអនុគ្រោះ (ឧ. être en défaveur auprès de quelqu'un)

défavorable *a.* ឥតអនុគ្រោះ; ដែលមិនយល់ព្រម, ដែលប្រឆាំង (ឧ. opinion défavorable)

défavorablement *adv.* ដោយឥតអនុគ្រោះ; ដោយមិនយល់ព្រម

défavoriser *v.t.* ធ្វើឲ្យចាញ់ប្រៀប; ចាញ់ប្រៀប (ឧ. être défavorisé par rapport à d'autres)

défécateur *n.m. Chim.* ប្រដាប់ពង្រងទឹក; ប្រដាប់បញ្ចេញលាមក

défécation *n.f. Chim.* ការពង្រងទឹក; ការបញ្ចេញលាមក

défectibilité *n.f.* អនិបុណភាព; ភាពមានខ្វះ; ភាពមានសៅហ្មង

défectible *a.* អនិបុណ៌យ, ខ្វះ, សៅហ្មង, មិនពេញលេញ (ឧ. tout homme est défectible)

défection *n.f.* ការបោះបង់រឿងអ្វីមួយ, ការបោះបង់ (ឧ. la défection des alliés) ។ faire défection បាត់មុខ (មិនទៅកាន់កន្លែងដែលគេរង់ចាំ)

défectueusement *adv.* ដោយខ្វះគោលសំខាន់, ដោយមិនពេញលក្ខណៈ

défectueux,euse *a.* ដែលខ្វះគោលសំខាន់, មិនពេញលក្ខណៈ (ឧ. jugement ឬ acte défectueux); ដែលមានខ្ចោះ (ឧ.produit défectueux)

défectuosité *n.f.* វិកលភាព, ភាពមិនពេញលក្ខណៈ, ភាពមានខ្ចោះ

défendable *a.* អាចការពារបាន

défendeur,eresse *n.* ចុងចោទក៏, ចម្លើយ (ក្នុងរឿងក្ដី)

défendre *v.t.* ការពារ (ឧ. défendre sa vie; défendre sa patrie); ហាមឃាត់ (ឧ. défendre l'alcool à un malade ហាមឃាត់មិនឲ្យអ្នកជំងឺផឹកស្រា); ការពារ (ជួយដោះសា) (ឧ. défendre un accusé)។ *Mar.* រាំងច្រកចូល (ឧ. le vent défend le canal)។ défendre de ឬ que ហាមមិនឲ្យ (ឧ.défendre de parler ហាមមិនឲ្យនិយាយ)។ défendre de ការពារចំពោះ (ឧ. cette montagne défend ma maison du vent du Nord)។ à son corps défendant *loc. adv.* ដោយការពារខ្លួន (ចំពោះការបៀតបៀនដោយអាវុធ) (ឧ. tuer son antagoniste à son corps défendant); *au fig.* ដោយបង្ខំ, ដោយទើសទាល់, ដោយមិនចូលចិត្ត (ឧ. le peuple le plus spirituel du monde ne progresse qu'à son corps défendant) (ម.ព. corps ផង)។ se défendre *v.pr.* ការពារខ្លួន; និយាយដោះសា; ប្រកែក (ឧ. se défendre d'avoir fait quelque chose)។ *Fam.* ធន់នឹងរោគ (ឧ. vieillard qui se défend); បញ្ចេញការប៉ិនប្រសប់ (ឧ.se défendre au jeu, dans les affaires); ទប់ (ឧ. il ne put se défendre de sourire)

défenestration *n.f.* ការបោះមនុស្សតាមបង្អួច

défens,défend ឬ **défends** *n.m.* ការហាមឃាត់មិនឲ្យកាប់ឈើ; ការហាមឃាត់មិនឲ្យសត្វចូលស៊ីក្នុងព្រៃ

défense *n.f.* ការការពារ (ឧ. prendre la défense d'un faible; la défense est difficile pour un avocat si jeune; ouvrage pour la défense d'une

ville); *par ext.* មធ្យោបាយការ-ពារ; គ្រឿងការពារ (ឧ. ville sans défense); ការហាមឃាត់ (ឧ. faire défense de fumer à un enfant) ។ *Mil.* ការទប់ទល់ (ឧ. place de défense កន្លែងទប់ទល់ ។ ligne de défense តំបន់ទប់ទល់។ mettre en défense ឬ en état de défense រៀបចំការ-ការពារខ្លួន, ប្រុងប្រៀបនឹងភ័យប្រឆាំង ។ prendre la défense de ឬ embrasser la défense de ការពារ, ជួយកាន់ខាង . . . ។ *Zool.* ភ្លុក,ចែ, ខ្នាយ,កុយ, កាំ (ប្រម៉ា) ។ *Bot.* បន្លា។ *Dr.* la défense ចម្លើយ (ក្នុងទោទក៌); ការដោះសា

défenseur *n.m.* អ្នកការពារ,អ្នកឧបត្ថម្ភ (ឧ. défenseur du peuple, d'une idée); អ្នកគាំទ្រ, មេធាវី

défensif,ive *a.* សម្រាប់ការពារ (ឧ. organisation défensive)

défensive *n.f.* ការទប់ (ឧ. être ឬ se tenir sur la défensive ប្រុងតែការពារខ្លួន)

défensivement *adv.* ដើម្បីការពារ (ឧ. un village organisé défensivement)

déféquer *v.t.* ច្រោះ, ត្រង, ពង្រង

déférence *n.f.* សេចក្តីគោរព (ឧ. avoir de la déférence pour les vieillards)

déférent,e ឬ **déférant,e** *a.* ដែលមានសេចក្តីគោរព (ឧ. humeur douce et déférante); ដែលនាំចេញ (ឧ. canal déférent)

déférer *v.t.* ចេញឲ្យ (ឧ. déférer des honneurs); ដាក់ឲ្យតុលាការជំនុំជំរះ (ឧ. déférer une cause à une cour); ប្តឹង (ឧ. déférer en justice) ។ *v.t. ind.* ព្រមតាម (ឧ. déférer à l'avis de quelqu'un)។ déférer le serment à quelqu'un បង្ខំឲ្យអ្នកណាមួយកាន់តាមសម្បថខ្លួន

déferlage ឬ **déferlement** *n.m.* ការរំដំរំដែង, ការហៀរហូរជាបសាប (ឧ. le déferlement des vagues)

déferlant,e *a.* ដែលរំដំរំដែង, ដែលហៀរហូរជាបសាប

déferler *v.t. Mar.* លាតក្តោង ។ *v.i.* រំដំរំដែង(លោក)។ *Fig.* ហៀរហូរជាប-សាប (ឧ. la foule déferlait)

déferrage ឬ **déferrement** *n.m.* ការដោះដែកចេញ; ការដោះដែកក្រចកជើងសត្វចេញ

déferrer *v.t.* ដោះដែកចេញ; ដោះដែកក្រចកជើងសត្វចេញ (ឧ. déferrer un cheval)។ *Fig. & Fam.* ធ្វើឲ្យទាល់គំនិត ឬ ទាល់ប្រាជ្ញ; ដោះខ្លោះ។ se déferrer *v.pr.* រដោះ ឬ រង្គោះដែក

déferrure *n.f.* ការដោះដែកចេញ; ការរដោះ ឬ រង្គោះដែក

défervescence *n.f. Chim.* ភាពមិនពុះ ឬ អន់ពុះ។ *Méd.* ដំណើរស្រាកគ្រុន

défets *n.m. pl.* សន្លឹកសៀវភៅសល់

défeuillaison *n.f.* ម.ព. défoliation

défeuiller *v.t.* បេះស្លឹកឈើ (ឧ. défeuiller des mûriers)

défi *n.m.* ការបង្កហេតុ(ដោយមើលងាយថាគូប្រឆាំងគ្មានសមត្ថភាពនឹងធ្វើអ្វីមួយកើត) (ឧ. accepter ឬ relever un défi); ការបបួលប្រកួត។ mettre quelqu'un au défi de ភ្នាល់ថាគ្មានសមត្ថភាព ថាធ្វើមិនកើត (ឧ. je vous mets au défi de soulever ce poids)

défiance *n.f.* ការមិនទុកចិត្ត, ការដកសេចក្ដីទុកចិត្ត (ឧ. voter la défiance au gouvernement)

défiant,e *a.* ដែលមិនទុកចិត្ត(ឧ. avoir un caractère défiant); ដែលសំដែងសេចក្ដីមិនទុកចិត្ត (ឧ. air défiant)

défibrage *n.m.* ការហូតសរសៃចេញ; ការសក

défibrer *v.t.* ហូតសរសៃចេញ; សក (ឧ. défibrer la canne à sucre)

défibreuse *n.f.* ម៉ាស៊ីនហូតសរសៃ, ម៉ាស៊ីនសក

déficeler *v.t.* ស្រាយខ្សែចំណង

déficience *n.f.* ការអួនថយ, ភាពទន់ខ្សោយ (ខាងកម្លាំងកាយ ឬ ខាងសតិ)

déficient,e *a.* ដែលខ្វះ, ទន់ខ្សោយ (ខាងកម្លាំងកាយ ឬ ខាងសតិ) (ឧ. enfant déficient)

déficit *n.m.* ឱនភាព, ការខ្វះ; ចំនួនខ្វះ (ឧ. budget en déficit)

déficitaire *a.* ឱនគត, ដែលខ្វះ (ឧ. récolte déficitaire)

défier *v.t.* បង្កហេតុ, បបួលប្រកួត (ឧ. défier quelqu'un à la course);

មិនជឿថាមានសមត្ថភាព (ឧ. défier quelqu'un de parler)។ *Fig.* ជំនះ, ប៉ះពាន, ពុះពារ (ឧ. défier la mort)។ se défier *v.pr.* មិនទុកចិត្ត, សង្ស័យ (ឧ. je me défiais de cela); ប្រកួតគ្នា

défiger *v.t.* រំលាយ (វត្ថុដែលកក)

défigurer *v.t.* ធ្វើឲ្យមើលមិនស្គាល់ (ឧ. visage défiguré par un accident); ធ្វើឲ្យខូចរូបរាង។ *Fig.* ធ្វើឲ្យខូច ឬ ឲ្យក្លាយ (ឧ. défigurer l'histoire)

défilade *n.f.* ការហែជាក្បួន (ឧ. la défilade de la flotte)។ *Fam.* ការស្លាប់បន្តគ្នា (ឧ. chaque hiver amène une défilade)

défilage *n.m.* ការហូតចេស; ការចិញ្ច្រាំកន្ទបធ្វើក្រដាស (ថា effilochage ក៏បាន)

défilé *n.m.* ថ្នារ, ច្រក (ឧ. les défilés de l'Argonne); ព្យុហយាត្រា, ការហែក្បួន, ក្បួនហែ។ *Par ext.* ការទៅជាជួរ, ការទៅបន្តៗគ្នា (ឧ. défilé de manifestants, de visiteurs)។ *a. Art mil.* zone défilée ទីកំបាំង (ទីដែលបាញ់មិនត្រូវឬមើលមិនឃើញដោយមានអ្វីបាំង)

défilement *n.m. Mil.* របៀបបំបាំង (ទ័ព យុទ្ធភណ្ឌ ។ល។) (ឧ. faire avancer une troupe à défilement d'une crête)

défiler *v.t.* ហូតចេសចេញ (ឧ. défiler un collier); ចិញ្ច្រាំកន្ទបធ្វើក្រដាស។ *Mil.* បំបាំងទ័ព (ឧ. défiler des chars)។ se défiler *v.pr.* ពួន។ *Pop.* រត់គេច

défiler *v.t.* បន្តគ្នា (ឧ. témoins qui défilent); ដើរជាជួរ, ដើរដង្ហែគ្នា (ឧ. troupe qui défile)

défileuse *n.f.* ម៉ាស៊ីនចិញ្ច្រាំកន្ទបធ្វើក្រដាស

défilocher *v.t.* ម.ព. effilocher

défini,e *a.* ច្បាស់លាស់, ដែលមានអត្ថន័យ (ឧ. mot défini)

définir *v.t.* ឲ្យអត្ថន័យ (ឧ. définir le triangle); កំណត់ដោយច្បាស់-លាស់ (ឧ. définir un plan); ចង្អុលលក្ខណៈ ឬ ចរិត (ឧ. définir quelqu'un)

définissable *a.* អាចកំណត់ឬប្រាប់បាន

définitif,ive *a.* ស្ថាពរ, ដាច់ស្រេច (ឧ. règlement définitif)។ en

définitive *loc.adv.* ក្នុងទីបំផុត, ដោយគិតឲ្យហ្មត់ចត់ទៅ

définition *n.f.* អត្ថន័យ, ន័យរបស់សេចក្ដី (ឧ. une bonne définition ne s'applique qu'à l'objet défini)

définitivement *adv.* ជាស្ថាពរ

déflagrant,e *a.* ដែលឆេះផ្ទុះ (ឧ. matières déflagrantes)

déflagrateur *n.m.* ប្រដាប់ធ្វើឲ្យផ្ទុះ

déflagration *n.f.* ការឆេះហ្មត់ក្នុងមួយឆាប (ឧ. la déflagration du coton-poudre est instantanée) ។ *Fig.* ការរោលរាល (ឧ. déflagration de la passion)

déflagrer *v.i.* ឆេះផ្ទុះ

déflation *n.f.* ការស្រូបខ្យល់ ។ *Fin.* បរិត្តផរណា, ការបន្ថយចំនួនក្រដាសប្រាក់ (ព.ផ. inflation)

défleurir *v.i.* ជ្រុះផ្កា ។ *v.t.* ជម្រុះផ្កា។ *Fig.* ធ្វើឲ្យស្រពោន; បំបាត់សម្រស់

déflexion *n.f.* ការពារង (ចំពោះអវយវៈណាមួយដែលបត់លែងបាន) (ឧ. la déflexion de la tête du fœtus gène l'accouchement)

défloraison ឬ **défleuraison** *n.f.* ការរោយ ឬ ស្រពោន (ផ្កា)

déflorer *v.t.* បង្ខូចព្រហ្មចារ្យ (ឧ. déflorer une fille); បំបាត់សម្រស់ (ឧ. déflorer un sujet de roman) ។ se déflorer *v.pr.* ជម្រុះផ្កា ។ *Fig.* បាត់សម្រស់

défoliation *n.f.* ការជម្រុះស្លឹក

défonçage ឬ **défoncement** *n.m.* ការទម្លុះបាត; ការទម្លុះ; ការភ្ជួរប្រែ

défoncer *v.t.* ទម្លុះបាត (ឧ. défoncer un tonneau); ទម្លុះ, ទម្លាយ (ឧ. défoncer une porte, une route); ភ្ជួរប្រែ (ឧ. défoncer un terrain) ។ *Par ext.* ទម្លាយទ័ព

défonceuse *n.f.* នង្គ័លភ្ជួរប្រែ

déformation *n.f.* វិរូបកម្ម, ការបង្ខូចទ្រង់ទ្រាយ ។ déformation professionnelle វិរូបកម្មតាមវិជ្ជាជីវៈ (ការលំអៀងតាមទម្លាប់នៃវិជ្ជាជីវៈរបស់ខ្លួន)

déformer *v.t.* ធ្វើវិរូបកម្ម, បង្ខូចទ្រង់ទ្រាយ (ឧ. les miroirs concaves déforment les images) ។ *Fig.* ធ្វើឲ្យខូច, ធ្វើឲ្យក្លាយ (ឧ. déformer la vérité) ។ se déformer *v. pr.* ខូចរូបរាង

défoulement *n.m.* ការបំបាត់មានះចេញ

défournage ឬ **défournement** *n.m.* ការយកចេញពីឡ

défourner *v.t.* យកចេញពីឡ

défraichir *v.t.* ធ្វើឲ្យស្រពោន; ធ្វើឲ្យស្រអាប់, ធ្វើឲ្យស្លេកពណ៌ (ឧ. le soleil défraichit les étoffes claires) ។ se défraichir *v. pr.* ស្រពោន, អាប់ស្មើ

défranciser *v.t.* បំបាត់លក្ខណៈជាបារាំង (ឧ. défranciser un bateau de commerce); បំបាត់សន្តានចិត្តជាបារាំង

défrayer *v.t.* ចេញប្រាក់ចំណាយជូនគេ។ défrayer la conversation ចូលសន្ទនាជាមួយ;ធ្វើឲ្យគេនិយាយពីខ្លួន

défrichable *a.* អាចរានជាស្រែចំការបាន

défrichement ឬ **défrichage** *n.m.* ការកាប់រាន,ការរានស្រែចំការ; ដីដែលកាប់រាន

défricher *v.t.* កាប់រាន, រានស្រែចំការ។ *Fig.* បំភ្លឺសេចក្ដី (ឧ. défricher un sujet)

défricheur *n.m.* អ្នកកាប់រាន,អ្នករានស្រែចំការ

défriper *v.t.* ធ្វើឲ្យបាត់ទក់

défrisement *n.m.* ការសម្រួតសក់, ការធ្វើឲ្យស្លូតឬឲ្យលោសក់

défriser *v.t.* ធ្វើឲ្យបាត់ក្រញាញ់, ធ្វើឲ្យលោសក់, ធ្វើឲ្យស្លូតសក់ ។ *Fig.* ធ្វើឲ្យស្រងាកចិត្ត (ឧ.voilà qui me défrise)

défroisser *v.t.* ធ្វើឲ្យបាត់ទក់

défroncement *n.m.* ការធ្វើឲ្យបាត់ជ្រួញ; ភាពបាត់ជ្រួញ ។ *Fig.* ការស្រាយចិញ្ចើម

défroncer *v.t.* បាត់ជ្រួញ ។ défroncer les sourcils ស្រាយចិញ្ចើម (លែងខឹង)

défroque *n.f.* មតកភណ្ឌ;ចីវរបព្វជិតដែលទទួលអនិច្ចកម្ម; សំលៀកបំពាក់ចាស់ដែលគេលែងប្រើ

défroqué,e *a.* ដែលសឹក (ដាក់ផ្នួស)

défroquer *v.i.* បាកសិក្ខា, ដាក់ផ្នួស

défruiter *v.t.* បេះផ្លែចេញអស់; បំបាត់រសជាតិផ្លែ (ឧ. défruiter de l'huile d'olive)

défunt,e *a.&n.* ដែលស្លាប់ទៅហើយ; មតក;ខ្មោច ។ (រ.ស.) ព្រះសព

dégagé,e *a.* ០ះ; ស្រឡះ, គ្មានទាក់ទាម (ឧ.air dégagé) ។ *Fin.*

អវលញ្ជិត

dégagement *n.m.* ការដោះសន្យា;ការលោះ;ការដោះ;ការឲ្យរួចពីកាតព្វកិច្ច(ឧ. dégagement d'une promesse);ការភាយឬផ្សាយចេញ(ឧ.dégagement de chaleur); ការធ្វើឲ្យស្រឡះ (ឧ. dégagement de la voie publique); ទីទំនេរឬស្រឡះ (ឧ. le dégagement devant la maison); របៀងពីបន្ទប់មួយទៅបន្ទប់មួយ ។ *Fin.* អវលញ្ជនកិច្ច

dégager *v.t.* លោះ (ឧ. dégager ses bijoux); ដោះ(ឧ. dégager sa main prise dans un engrenage); ដោះសន្យា; ធ្វើឲ្យស្រឡះ (ឧ. dégager un passage) ។ *Escr.* ដោះអាវុធ ។ *Fig.* ភាយក្លិន (ឧ. le phosphore dégage une odeur d'ail);ឲ្យរួចពីកាតព្វកិច្ច (ឧ. dégager quelqu'un de sa promesse); បញ្ចេញឲ្យឃើញ (ឧ. dégager l'idée essentielle)។ dégager sa parole ដកពាក្យ ។ se dégager *v.pr.* ដោះខ្លួន

dégaine *n.f. Fam.* ឫកពាឬដំណើរគួរឲ្យអស់សំណើច (ឧ. quelle dégaine!)

dégainer *v.t.* ហូតចេញពីស្រោម។ *vi.* ហូតដាវ (ដើម្បីប្រយុទ្ធ)

dégalonner *v.t.* ដោះប៉ាននចេញ; ដោះប៉ានស័ក្តិចេញ

déganter *v.t.* ដោះស្រោមដៃចេញ

dégarnir *v.t.* រើចេញ (ឧ. dégarnir une table)។ dégarnir un arbre កាត់មែកឈើចេញ ។ se dégarnir *v.pr* ជាត់ស៊ុមទ្រុម(ឈើ)។ sa tête se dégarnit ក្បាលគាត់ឡើងត្រងោល (សក់ជ្រុះ)។ នៅទទេ (ឧ. la table se dégarnit)

dégât *n.m.* អន្តរាយ,ការខូចខាត; របស់ខូចខាត

dégauchir *v.t.* រំលើង ។ *Fig.* អប់រំឲ្យបាត់ខ្មាស (ឧ.dégauchir un jeune homme timide)

dégauchissage *n.m.* ការរំលើង

dégauchisseuse *n.f.* ដែកឈូសយន្ត

dégazonnement *n.m.* ការជម្រះស្មៅ (ឧ.dégazonnement d'un pré)

dégazonner *v.t.* ជម្រះស្មៅ

dégel *n.m.* ការរលាយនៃទឹកកក

dégelée *n.f. Pop.* ការវាយច្រើន

dégèlement *n.m.* ការរំលាយ; ការរលាយ (ទឹកកក)

dégeler *v.t.* រំលាយ (ឧ. dégeler de l'huile)។ *Par ext.* កំដៅ(ឧ. dégeler les pieds)។*Econ.pol.* ដាក់ប្រើប្រាស់ (ឧ. dégeler des créances, des crédits)។ *Fig.* ធ្វើឲ្យរីករាយក្នុងចិត្ត(ឧ.un peu d'amour suffit pour dégeler un cœur)។ *v.i.* រលាយទឹកកក(ឧ. la rivière qui dégèle) ។ *Fig.* រីករាយក្នុងចិត្ត (ឧ.il dégèle enfin grâce à vos bonnes paroles)។ se dégeler *v.pr.* រលាយ (ឧ.rivière qui se dégèle);*au fig.* រីករាយក្នុងចិត្ត (ឧ. cet homme commence à se dégeler)

dégénération *n.f.* ភាពអន់ថយ; ការក្លាយ (ឧ. la dégénération d'une famille)

dégénéré,e *a.&n.* ដែលមានភាពអន់ថយ; ដែលក្លាយ

dégénérer *v.i.* មានភាពអន់ថយ;ក្លាយ (ឧ. personnes, animaux qui dégénèrent); ប្រែក្លាយ (ពីល្អទៅអាក្រក់) (ឧ. la dispute dégénéra en rixe)

dégénérescence *n.f.* ភាពអន់ថយ; ភាពក្លាយ

dégénérescent,e *a.* ដែលចុះអន់ថយ (ឧ. tissu dégénérescent); ដែលក្លាយ

dégermer *v.t.* កាត់ពន្លកចេញ (ឧ. dégermer des pommes de terre)

dégingandé,e *a. Fam.* រយើករយោក (ដំណើរ)

dégingandement *n.m.* ដំណើររយើករយោក

dégingander *v.t.* ធ្វើភាំង ឬ ធ្វើដំណើររយើករយោក

dégivrage *n.m.* ការជម្រុះទឹកកក(ជាប់លើកញ្ចក់រថយន្ត ឬ លើស្លាបយន្តហោះចេញ)

dégivrer *v.t.* ជម្រុះទឹកកក (ជាប់លើកញ្ចក់រថយន្តឬលើស្លាបយន្តហោះចេញ)

dégivreur *n.m.* ប្រដាប់ជម្រុះទឹកកក (ជាប់លើកញ្ចក់រថយន្តឬស្លាបយន្តហោះ)

déglaçage ឬ **déglacement** *n.m.* ការកាយទឹកកកចេញពីផ្លូវសាធារណៈ; ការបំបាត់ភាពរលោងនៃក្រដាស

déglacer *v.t.* រំលាយទឹកកកក្នុង (ឧ. déglacer un bass'n); កំដៅ (ឲ្យជាត់រងា) (ឧ. déglacer un voyageur); បំបាត់ភាពរលោង (ឧ. déglacer un papier)

déglinguer *v.t. Fam.* បំបាក់បំបែក (ឬ déclinquer ក៏បាន)

dégluer *v.t.* ដោះពីជ័រជាម

déglutiner *v.t.* ដកប្រះជ័រធ្លាមដែលជាប់នៅស្លាបបក្សី

déglutir *v.t.* លេប; ត្រូវលៀវលេប (ឧ. déglutir le bol de riz)

déglutition *n.f.* ការលេប

dégobillage *n.m. Pop.* ការក្អួត

dégobiller *v.t.&i. Pop.* ក្អួត

dégoiser *v.t.&i. Triv.* និយាយរឡាញ

dégommage *n.m.* ការលាងជ័រកាវចេញ (ឧ. le dégommage de la soie)

dégommer *v.t.* យកជ័រកាវចេញ។ *Fam.* បញ្ឈប់លែងឲ្យធ្វើការ

dégonflement *n.m.* ការបន្ធូរ; ការធ្លូរ; ការស្រក (ជាត់ហើម)

dégonfler *v.t.* បន្ធូរ; ធ្វើឲ្យស្រក(ជាត់ហើម)។ *Fig.* បន្ធូរចិត្ត(ឧ. les larmes dégonflent le cœur)។ se dégonfler *v.pr. Fam.* ញ៉ម, ខ្លាច

dégorgeage ឬ **dégorgement** *n.m.* ការហូរ (ទឹកធម្មតាឬទឹកសំអុយដែលដក់) ការហៀរ; ការហូរ (ឧ. dégorgement de la bile); ការសំអាតសូត្រ

dégorgeoir *n.m.* ប្រដាប់កាត់ដែកក្ដៅ; ប្រដាប់ដោះផ្លែសន្ទូចពីត្រី; កន្លែងដែលទឹកហូរធ្លាក់ទៅ

dégorger *v.t.* ក្អួត,ក្អែ (ឧ.dégorger la nourriture); ធ្វើឲ្យក្អួតឬឲ្យក្អែ (ឧ.dégorger des sangsues)។ *Par ext.* បង្ហូរទៅ (ឧ. gouttière qui dégorge l'eau fangeuse); លាងជម្រះ (ឧ. dégorger une bouteille)។ *v.i.* ហៀរហូរ, ហូរធ្លាក់ទៅ (ឧ. égout qui dégorge dans une rivière)

dégoter ឬ **dégotter** *v.t. Fam.* ជាញ់ឬហោល។ *Pop.* ឈ្នះ; រកឃើញ

dégoudronner *v.t.* យកជ័រប្រេងក្យៅចេញ

dégouliner *v.i. Fam.* ស្រក់តក់ៗ(ឧ. la sueur lui dégoulinait du visage)

dégourdi,e *a.&n.* ប្រសប់; វៃ; ឆ្លាត

dégourdir *v.t.* ធ្វើឲ្យបាត់ស្រពន់ (ឧ. dégourdir ses membres); កំដៅ(ឧ.dégourdir de l'eau)។ *Fig.* ធ្វើឲ្យបាត់ឆោត, ធ្វើឲ្យបាត់ម្ងរ-ម្ងុះ(ឧ. dégourdir un enfant)

dégourdissement *n.m.* ការបាត់ស្រពន់

dégoût *n.m.* ការមិនឃ្លាន; ការខ្ពើម; ការធុញ(ឧ. avoir du dégoût pour le vin) ។ *Fig.* ការស្អប់ (ឧ. dégoût du monde); ទុក្ខព្រួយ,ការមិនសប្បាយចិត្ត (ឧ. essuyer des dégoûts)

dégoûtamment *adv. Fam.* ដោយគួរឲ្យខ្ពើមរអើម

dégoûtant,e *a.&n.* គួរឲ្យខ្ពើម (ឧ. logement dégoûtant)។ *Fig.* គួរខ្ពើមរអើម (ឧ. action dégoûtante) ។ *Fam.* គួរឲ្យធុញទ្រាន់ ឬ ឲ្យរអា

dégouté,e *a. &n.* ដែលរើសត្អើស

dégoûter *v.t.* ធ្វើឲ្យបាត់ឃ្លាន ឬឲ្យធុញ (ឧ. ce mets nous dégoûte); ធ្វើឲ្យធុំ ឬ ឲ្យលែងមានរសជាតិ (ឧ. l'usage habituel du riz ne nous en dégoûte pas); ធ្វើឲ្យលែងមានបំណង (ឧ. cela les dégoûte de travailler)។ *Fig.* ធ្វើឲ្យខ្ពើម (ឧ. cela me dégoûte); ធ្វើឲ្យស្អប់ (ឧ. cette personne me dégoûte); ធ្វើឲ្យធុញទ្រាន់ (ឧ. dégoûter de la vie, ce n'est pas fortifier le courage; la prolixité dégoûte le lecteur)។ se dégouter de *v.pr.* ធុញទ្រាន់នឹង(លែងមានបំណង) (ឧ. se dégoûter du vin, de l'étude)

dégouttant,e *a.* ដែលស្រក់; ដែលសម្រក់ (ឧ. des feuilles dégouttantes de pluie, de rosée)

dégouttement *n.m.* ការស្រក់; ការសម្រក់

dégoutter *v.t.* ស្រក់ (ឧ. la sueur qui dégoutte du front); សម្រក់ (ឧ. le couteau du charcutier dégoutte de la graisse)។ *Prov.* à la cour, s'il n'y pleut, il y dégoutte អ្នកនៅជិតព្រះអាទិត្យរមែងតែបានទទួលពន្លឺព្រះអាទិត្យខ្លះមិនខាន(បាំងថា នៅក្នុង

ភាំង បើមិនផ្សៀងក៏មានស្រក់ទឹកខ្លះមិនខាន គឺថា អ្នកនៅជិតអ្នកធំរមែងតែបានទទួលលាភមិនខានបើមិនច្រើនក៏តិច)។ quand il pleut sur le curé, il dégoutte sur la vicaire ទៅហ្វាយមានបុណ្យ ខុនមានសក្តិ ទៅហ្វាយអប្បល័ក្ខណ៍ ខុនធ្លាក់អណ្តូង

dégradant,e *a.* ដែលធ្វើឲ្យទាបថោក (ឧ. conduite dégradante)

dégradation *n.f.* ការគម្លោះយសស័ក្តិ (ឧ. la dégradation militaire entraîne l'exclusion de l'armée); វិការភាព, ទុព្វលភាព; ការខូចខាត(ឧ. dégradation des couleurs) ។ dégradation civique ការប្រាសចាកសិទ្ធិជាពលរដ្ឋ ។ *Fig.* ការអប្បយស, ការចុះថោកទាប (ឧ. tomber dans la dégradation)

dégrader *v.t.* គម្លោះយសស័ក្តិ; ធ្វើឲ្យខូចខាត (ឧ. dégrader une façade) ។ *Fig.* ធ្វើឲ្យអប្បយស, ធ្វើឲ្យថោកទាប (ឧ. sa conduite le dégrade)

dégrader *v.t.* ធ្វើឲ្យអន់ថយ (ឧ. dégrader les teintes, la lumière)

dégrafer *v.t.* ដោះកន្ទាស់ (ឧ. dégrafer une robe)។ se dégrafer *v.pr.* របូតកន្ទាស់;ដោះកន្ទាស់ខ្លួនឯង

dégraissage ឬ **dégraissement** *n.m.* ការយកខ្លាញ់ចេញ; ការជម្រះស្នាមប្រឡាក់ខ្លាញ់

dégraisser *v.t.* យកខ្លាញ់ចេញ (ឧ. dégraisser un bouillon); ជម្រះស្នាមប្រឡាក់ខ្លាញ់(ឧ. dégraisser un habit); ធ្វើឲ្យស្រកខ្លាញ់ (ឧ. l'exercice dégraisse l'obèse)។ dégraisser les terres ផ្សោះដី(បំពោះទឹកដែលប្រោះដីឲ្យសោះអស់ជីជាតិ)។ se dégraisser *v. pr.* អស់ជាតិខ្លាញ់ (ឧ. les viandes se dégraissent par la cuisson) ។ *Fam.* ស្រកខ្លាញ់, ស្រកសាច់ ។ *Fig.* ចុះក្របន្តិច

dégraisseur,euse *n.* អ្នកលាងសំអាតសំពត់ (លាងជម្រះខ្លាញ់ដែលប្រឡាក់)

dégras *n.m.* ថ្នាំបន្ទន់ស្បែក

dégraveler ឬ **dégraver** *v.t.* យកក្រួសល្អិតចេញ(ឧ.dégraveler un tuyau)

dégravoiement ឬ **dégravoiment**

n.m. ដំណើរហូរច្រោះជើងជញ្ជាំង; ដំណើរហូរនាំក្រួសល្អិតចេញពីបាតស្ទឹង

dégravoyer *v.t.* ច្រោះជើងជញ្ជាំង ជើងសសរ (ឧ. l'eau a dégravoyé ce mur, ces pilotis); ហូរនាំក្រួសល្អិតចេញពីបាតស្ទឹង (ឧ. dégravoyer un bras de rivière)

degré *n.m.* កាំជណ្តើរ (ឧ. descendre les degrés) ។ *Fig.* ឋានៈក្នុងសង្គម (ឧ. monter ឬ descendre les degrés de l'échelle sociale); ថ្នាក់, ជាន់ (ឧ. il y a bien des degrés dans la vertu); មធ្យោបាយ (ឧ. Toutes ces cruautés sont des degrés sanglants dont Auguste a fait choir, Pour monter sur le trône et nous donner des lois (Corneille) ; ជណ្តើរ (ឧ. les premières connaissances ont servi de degrés aux autres) ។ *Dr.* degré de juridiction លំដាប់តុលាការ ។ *Phys.* កម្រិត (ឧ. les degrés du thermomètre; alcool 90°) ។ *Ens.* ថ្នាក់(ក្នុងការសិក្សា)។ *Génér.* ជួរដើសន្តាន (ឧ. cousin au cinquième degré) ។ *Géogr.* អង្សា។ degré de latitude អង្សារិក្លាន្តរ(ម.ព.latitude ផង)។ degré de longitude អង្សាយាមន្តរ(ម.ព. longitude ផង)។ *loc.adv.* par degré ជាលំដាប់ (ឧ. le son s'affaiblit par degré)

dégréer *v.t.* រើនាវាភ័ណ្ឌចេញ (ដើម្បីដួសដុលនាវា)

dégressif,ive *a.* ដែលថយចុះជាលំដាប់ (ឧ. mouvement dégressif) ។ *Fin.* impôt dégressif ពន្ធលស់ (ពន្ធដែលមានអត្រាថយចុះតាមធនធានអ្នកជាប់ពន្ធ)

dégrèvement *n.m.* ការលស់លា,ការបន្ធូរបន្ថយ (ពន្ធ, អាករ)

dégrever *v.t.* លស់លាឬបន្ធូរបន្ថយពន្ធ

dégringolade *n.f.* *Fam.* ការចុះប្រញាប់ប្រញាល់ ។ *Fig. & Fam.* ការចុះដុនដាប(ឧ. la dégringolade d'une entreprise)

dégringoler *v.t.* *Fam.* ចុះប្រញាប់ប្រញាល់ (ឧ. dégringoler un escalier)។ *v.i.* រមៀលចុះ (ឧ. dégringoler du haut de l'es-

calier)។ *Fig.* ធ្លាក់ហិនហោច (ឧ. une maison de commerce qui dégringole)

dégrisement *n.m.* ការធ្វើឲ្យស្វាងស្រវឹង

dégriser *v.t.* ធ្វើឲ្យស្វាងស្រវឹង ។ *Fig.* ធ្វើឲ្យដឹងខ្លួន (ឲ្យបាត់ការគំនិត) (ឧ. cet échec l'a dégrisé) ។ se dégriser *v.pr.* បាត់ស្រវឹង

dégrosser *v.t.* ផែ (ដើម្បីឲ្យគជាល្អស)

dégrossir *v.t.* ធ្វើឲ្យនៅតូច; ធ្វើឲ្យមានរាង(ជាងលំៗ) (ឧ. dégrossir un bloc de marbre) ។ *Fig.* ព្រាង (ឧ. dégrossir un discours; dégrossir un travail)។ ហ្វឹកហ្វឺនប្រដៅ, បង្រៀន (ឧ. dégrossir un écolier); បំភ្លឺការណ៍(ឧ. dégrossir une affaire) ។ se dégrossir *v.pr.* មានរាងខ្លះ (បាត់សភាពគគ្រោស) ។ *Fig.* សែងឆ្លង, ចេះដឹង

dégrossissage ឬ **dégrossissement** *n.m.* ការធ្វើឲ្យមានរាង; ការព្រាង

déguenillé,e *a.&n.* ដែលរហែកខ្ទប

déguerpir *v.i.* ចាកចេញ (ដោយបង្ខំ ឬ ដោយខ្លាច) (ឧ. Jeanne d'Arc fit déguerpir les Anglais d'Orléans)។ *v.t. Dr.* បោះបង់ (ឧ. déguerpir un héritage, une maison, une rente)

déguerpissement *n.m.* ការចាកចេញ (ដោយបង្ខំ ឬ ដោយខ្លាច); ការបោះបង់

dégueuler *v.t.&i.Pop.* ក្អួត (ឧ. dégueuler son dîner) ។ *Fig.* dégueuler des injures ជេរប្រទេច

déguignonner ឬ **désenguignonner** *v.t.* ធ្វើឲ្យបាត់ស៊យ(ឧ. il suffit d'une circonstance pour déguignonner un théâtre)។ se déguignonner *v.pr.* អស់ស៊យ (ឧ. il a changé de partenaire pour se déguignonner)

déguisé,e *a.* ដែលក្លែងខ្លួន។ *n.* អ្នកក្លែងខ្លួន

déguisement *n.m.* ភាពអ្នកក្លែងខ្លួន; ការក្លែងខ្លួន; ប្រដាប់សម្រាប់ក្លែងខ្លួន (ឧ. un déguisement de carnaval)។ *Fig.* ការលាក់លៀម (ឧ. parler sans déguisement)

déguiser *v.t.* ក្លែង ។ *Par ext.* déguiser sa voix ក្លែងសម្លេងខ្លួន ។

Fig. លាក់លៀម (ឧ. déguiser ses sentiments); ក្លែង (ឧ. déguiser son écriture)។ se déguiser *v.pr.* ក្លែងខ្លួន

dégustateur,trice *a.&n.* អ្នកភ្លក់សុរា

dégustation *n.f.* ការភ្លក់សុរា

déguster *v.t.* ភ្លក់សុរា (ឧ. déguster du vin, une liqueur); ក្រេបរសជាតិ (ឧ. déguster des friandises)

déhaler *v.t. Mar.* អូសចេញពីផែ (នាវា) ។ *v.i.* ចេញពីផែ

déhâler *v.t.* បំបាត់សម្បុរខ្មៅថ្ងៃ (ឧ. pommade qui déhâle)

déhanché,e *a.&n.* ដែលភ្លាត់ចង្កេះ; ដែលដើរគ្រវីចង្កេះ;ដែលដើរវៀចឈោង (ច្រត់តែលើជើងម្ខាង) ។ *Fig.* ដែលមានដំណើរការណ៍មិនល្អ (រឿងមិនស្រួល ដោយអាក់អួលជាដើម)

déhanchement *n.m.* ការដើរគ្រវីចង្កេះ; ដំណើរល្ហោសល្ហៃ

déhancher *v.t.* ធ្វើឲ្យភ្លាត់ចង្កេះ។*Fig.* បំបែកបំបាក់ ។ se déhancher *v.pr.* គ្រវីចង្កេះ (ឧ. danseuse habile à se déhancher); ដើរវៀចឈោង; ធ្វើជាខំប្រឹង ។ *Fig.* il n'y a pas là de quoi se déhancher ការនេះមិនបាច់ខំប្រឹងពេកទេ

déharnachement *n.m.* ការដោះបង្ហៀរសេះ

déharnacher *v.t.* ដោះបង្ហៀរសេះ ។ *Fig. & Fam.* ដោះសំលៀកបំពាក់យើងរយោងចេញ

déhiscence *n.f. Bot.* ការប្រេះ,ការហា (ផ្លែឈើសំបករឹង) (ឧ. déhiscence longitudinale ការប្រេះតាមបណ្តោយ។ déhiscence poricide ការប្រេះតាមរន្ធរុង

déhiscent,e *a.Bot.* ដែលប្រេះ, ដែលហា (ផ្លែឈើ)

déhors *adv.* ខាងក្រៅ (ឧ. mettre ឬ jeter quelqu'un dehors បណ្តេញចេញក្រៅ)។ *Fam. & fig.* ne savoir si l'on est dedans ou dehors ឬ ne pas savoir si quelqu'un est dedans ou dehors ឬ n'être ni dedans ni dehors មិនដឹងច្បាស់ថា តើការរបស់ខ្លួន មានដំណើរដល់ណាហើយ ; មិនដឹងគិតដូចម្តេច; មិនដឹងជាគេត្រូវនឹងខ្លួនឬមិនត្រូវ; មិនដឹងយោបល់អ្នកណា

ម្នាក់ (ម.ព. dedans ផង)។

Mar. កណ្ដាលសមុទ្រ (ក្រៅ ដី)។ toutes les voiles ឬ toutes voiles dehors បើកក្ដោង ទាំងអស់ ។ *Fig.* toutes voiles dehors ទៅយ៉ាងលឿន។ mettre toutes voiles dehors មិនមានអាសង្កា, មិនសំចៃ; មិនសន្ដោស

dehors *n.m.* ម៉ែកខាងក្រៅ(ឧ. le dehors d'une maison); ខាងក្រៅ (ឧ. les bruits du dehors ស្នូរពីក្រៅ); បរទេស (ឧ. travailleurs venus du dehors); ផ្ទៃឬផ្លាក្រៅផ្ទះ(ឧ.la maison qui a de beaux dehors); ខាងក្រៅផ្ទះ (ឧ.l'homme prend soin des affaires du dehors,et la femme de celles du dedans)។ *Fig.* ភេទក្រៅ, អាការៈក្រៅ (ឧ. apprenons à nous défier des faux dehors d'amitié)។ garder les dehors សង្រួមអាការៈក្រៅ ឲ្យសមសួន ; បំប្លែងអាការៈ ។

Loc.adv. au dehors នាខាងក្រៅ ។ de dehors ពីខាងក្រៅ (ឧ. venir de dehors)។en dehors តាមខាងក្រៅ; ពីខាងក្រៅ (ឧ. porte qui s'ouvre en dehors ទ្វារបើកពីក្រៅ) ។ mettre en dehors សម្ដែងចេញ (ឧ. mettre l'âme en dehors par l'écrit)។ être en dehors នៅឯឆាយ,នៅខាងក្រៅ (ឧ.être en dehors des jetées); *au fig.* être en dehors ឬ être tout en dehors ស្មោះត្រង់បំផុត ឬស្រាយណាស់ ។ par dehors ដោយសារខាងក្រៅ (ឧ. maison belle par dehors ផ្ទះល្អដោយសារខាងក្រៅ) ។

Loc. pré. au dehors de នាខាងក្រៅ (ឧ. au dehors de la ville) ។ en dehors de ក្រៅ (ឧ. en dehors d'une ligne); *au fig.* ក្រៅពី (ឧ. en dehors du bien, tout est mal) ។ par dehors តាមខាងក្រៅ (ឧ. passer par dehors)

déhouiller *v.t. Min.* កាយយកធ្យូងថ្មអស់

déicide *a.* ដែលពិឃាតអាទិទេព (ឧ. les Juifs déicides) ។ *n.m.* អ្នកពិឃាតអាទិទេព (ពិឃាតព្រះយេស៊ូគ្រិស្ដ)

déicole *a.&n.* ដែលធ្វើសក្ការៈចំពោះអាទិទេព

déification *n.f.* ការលើកជាអាទិទេព

déifier *v.t.* លើកជាអាទិទេព (ឧ. les Romains déifièrent la plupart de leurs empereurs); ធ្វើសក្ការៈ; រាប់អាន, គោរព (ឧ. la Convention déifia la Raison)

déisme *n.m.* អាទិទេពនិយម (ម.ព. théisme ផង)

déiste *n.&a.* អ្នកអាទិទេពនិយម (ព.ផ. athée)

déité *n.f.* ភាពជាអាទិទេព

déjà *adv.* ទៅហើយ (តាំងពីពេលនេះទៅហើយ) (ឧ. le moment où je parle est déjà loin de moi); (តាំងពីពេលនោះម៉្លេះ) (ឧ. je serrais les bras...., mais j'avais déjà perdu ce que je tenais)។ រួចហើយ (ឧ. je vous ai déjà dit ce que je pensais) ។ ហើយ (ឧ. il revient déjà; il finit déjà)

déjanter *v.t.* ដោះកៅស៊ូចេញពីខ្នងកង់

déjauger *v.i.* អណ្ដែតហួសបន្ទាត់ផ្ទៃទឹក (នាវា)

déjection *n.f.* ការបន្ទោបង់លាមក ។ *pl.* លាមក; វត្ថុដែលព្រួសចេញពីភ្នំភ្លើង

déjeté,e *a.* កោង, វៀច (ឧ. taille déjetée) ។ *Pop.* អាក្រក់; ចាស់

déjeter *v.t.* ពត់ឲ្យវៀច, ធ្វើឲ្យកោង (ជើង); ធ្វើឲ្យពោរ (ឧ. l'humidité déjette les bois)។ se déjeter *v.pr.* ឡើងកោង, ឡើងវៀច, ឡើងពោរ

déjettement *n.m.* ការវៀច, ការពោរ

déjeuner ឬ **déjeuné** *n.m.* អាហារព្រឹក ឬ ថ្ងៃត្រង់; ការបរិភោគព្រឹក ឬ ថ្ងៃត្រង់។ petit déjeuner ការស្រស់ស្រូបព្រឹក; អាហារស្រស់ស្រូបព្រឹក ។ *Fam. & Fig.* déjeuner de soleil ចំណីថ្ងៃ(ចំពោះពណ៌ដែលឆាប់ហើរដោយត្រូវកំដៅព្រះអាទិត្យ); វត្ថុឆាប់ខូច ។ il n'y a pas pour un déjeuner ទ្រព្យសម្បត្តិដែលឆាប់វិនាស, របស់ដែលឆាប់ខូច ។ *Mobil.* ពូនថាសដាក់ពែង (ឧ. un déjeuner de vermeil); ពែងមានចានទ្រនាប់ (ឧ. un déjeuner en porcelaine)

déjeuner *v.t.* បរិភោគព្រឹក ឬ ថ្ងៃត្រង់

déjeuneur,euse *n.* អ្នកបរិភោគព្រឹក

déjoindre *v.t.* ម.ព. disjoindre

déjouer *v.t.* ដោះកលឧបាយ; ធ្វើឲ្យខកខាន (ឧ. déjouer les complots)

déjucher *v.i.* ចុះពីទ្រនំ ។ *v.t.* ដាក់ឬបញ្ចុះពីទ្រនំ (ឧ. déjucher les volailles)

déjuger *v.t.* បដិសេធសាលក្រមមុនចោល (ឧ. déjuger son propre arrêt) ។ se déjuger *v.pr.* សម្រេចផ្ទុយពីសេចក្ដីសម្រេចមុន

de jure (selon le droit) *loc. adv.* ជានីតិន័យ, តាមផ្លូវច្បាប់ (ឧ. reconnaître un gouvernement de jure)(ម.ព. reconnaissance ផង)

delà *pré.* ខាងណាយ, ខាងម្ខាងនោះ (ឧ. delà la rivière) ។ *adv.* ឯនោះ (ឧ. écrivez-moi de delà) ។ *loc.adv.* au delà, par delà ឬ en delà ហួសអំពីនោះ (ឧ. l'homme atteint quelquefois cent ans, mais ne va guère au delà); លើសពីនោះទៅទៀត (ឧ. cela vaut cent riels et au delà) ។ deçà et delà ឬ deçà delà ម.ព. deçà ។ jambe deçà, jambe delà ព.ម. deçà ។ *loc. pré.* par delà, de delà ឬ au delà de ខាងណាយ (ឧ. habiter par delà les monts; venir de delà les monts; aller au delà des monts); *au fig.* ហួសអំពី; លើសអំពី (ឧ. au delà des intentions ឬ des espérances) ។ l'au-delà *n.m.* បរលោក, ជាតិក្រោយ (ឧ. la crainte de l'au-delà)

délabré,e *a.* រេចករខាក, ទ្រុឌទ្រោម (ឧ. maison ឬ santé délabrée)

délabrement *n.m.* ការទ្រុឌទ្រោម, ការរេចករខាក (ឧ. le délabrement d'une maison) ។ *Fig.* ការដុនដាប (ឧ. le délabrement de la santé)

délabrer *v.t.* ធ្វើឲ្យបាក់បែក, ធ្វើឲ្យទ្រុឌទ្រោម (ឧ. délabrer une machine) ។ *Fig.* ធ្វើឲ្យខូច (ឧ. l'intempérance délabre l'estomac) ។ se délabrer *v.pr.* ខូច; ចុះទ្រុឌទ្រោម

délacer *v.t.* បន្ធូរឬស្រាយខ្សែស្បែកជើង (ឧ. délacer un soulier) ។ *Par*

ext. ស្រាយខ្សែសៀកបំពាក់ឲ្យ (ឧ. délacer une femme) ។ se délacer *v.pr.* ស្រាយខ្សែសៀកបំពាក់ខ្លួន (ឧ. petite fille qui se délace seule); ត្រូវគេស្រាយខ្សែ (ឧ. ces souliers ne se délacent pas aisément គេមិនអាចនឹងស្រាយខ្សែស្បែកជើងនេះបានដោយងាយទេ)

délai *n.m.* រយៈពេល, កំឡុងពេល(ដែលគេទុកឲ្យ)(ឧ. obtenir un délai); ការពន្យារពេល, ការផ្អាក។ délai de grâce រយៈពេលអនុគ្រោះ(រយៈពេលដែលតុលាការបន្តឲ្យកូនបំណុល ដើម្បីទៅរកប្រាក់សងគេ) ។ délai de route រយៈពេលដើរផ្លូវ។ *Dr.* délai franc រយៈពេលគត់ (មិនគិតថ្ងៃដើមនឹងថ្ងៃចុង) ។ sans délai ភ្លាមៗ, គ្មានបង្អង់

délai-congé *n.m.* រយៈពេលព្រមាន (រយៈពេលដែលច្បាប់បញ្ញត្តឲ្យព្រមានជាមុនកាលបើត្រូវបញ្ឈប់កិច្ចសន្យាដូចអ្វីមួយ)(*pl.* des délais-congés)

délainage *n.m.* ការបោចរោមចៀម

délaissé,e *a&n.* ដែលគេបោះបង់, ដែលគ្មានពំនឹង

délaissement *n.m.* ការបោះបង់; ការគ្មានពំនឹង ឬ គ្មានឧបត្ថម្ភ (ឧ. être dans un grand délaissement)។ *Prat.* ការបោះបង់សម្បត្តិឬសិទ្ធិ

délaisser *v.t.* បោះបង់(ឧ. délaisser un travail trop pénible); បោះបង់សម្បត្តិឬសិទ្ធិ(ឧ. délaisser un héritage)

délaitement ឬ **délaitage** *n.m.* ការសម្រិតទឹកដោះរងចេញ

délaiter *v.t.* សម្រិតទឹកដោះរងចេញ (ឧ. délaiter le beurre)

délaiteuse *n.f.* ម៉ាស៊ីនសម្រិតទឹកដោះរងចេញ (ក្នុងការធ្វើប៊ឺរ)

délardement *n.m.* ការពន្លះយកខ្លាញ់ចេញ (ពីសាច់ជ្រូក) ។ *Par ext.* ការលុបជ្រុងឈើ

délarder *v.t.* ពន្លះខ្លាញ់ចេញ (សាច់ជ្រូក); លុបជ្រុងឈើ

délassant,e *a.* ដែលឲ្យលំហែ; ដែលឲ្យសម្រាក

délassement *n.m.* ការលំហែ; ការសម្រាក (ឧ. la lecture est un délassement pour l'esprit)

délasser *v.t.* លំហែ; សម្រាក, ឲ្យបាត់

ហត់ (ឧ. les bains tièdes délassent le corps) ។ se délasser *v.pr.* ឈប់សម្រាក

délateur,trice *n.* អ្នកលួចប្ដឹង (ឧ. les délateurs sont méprisables)

délation *n.f.* ការលួចប្ដឹង (ដើម្បីយករង្វាន់) ។ *Dr.* ការបង្ខំឲ្យអ្នកណាម្នាក់កាន់តាមសម្បថខ្លួន (ឧ. la délation du serment)

délavage *n.m.* ការលាងឲ្យចេញពណ៌; ការជ្រលក់ទឹក

délaver *v.t.* លាងឲ្យចេញពណ៌; ជ្រលក់ទឹក

délayage ឬ **délayement** *n.m.* ការរំលាយ; វត្ថុរំលាយ; ការលាយនឹងទឹក; វត្ថុលាយនឹងទឹក ។ *Fig.* ភាពវែងពេក (បែបនិពន្ធ)

délayer *v.t.* លាយនឹងទឹក ។ *Fig.* délayer une pensée បញ្ចេញយោបល់វែងពេក

delco *n.m.* ដិលកូ (គ្រឿងយន្ត)

déléatur *n.m.inv.* (latin) សញ្ញាប្រើក្នុងការបោះពុម្ពមានន័យថា «ត្រូវលុបចោល» (₰)

délébile *a.* អាចលុបឬលាងបាន (ឧ. encre délébile)

délectable *a.* ប្រណីត, ជាទីគាប់ចិត្ត, ឆ្ងាញ់ (ឧ. un entremets délectable)

délectation *n.f.* អស្សាទកម្ម, សេចក្ដីរីករាយ (ឧ. lire avec délectation)

délecter *v.t.* ធ្វើឲ្យសប្បាយ; ធ្វើឲ្យមានដំរេក ។ se délecter *v.pr.* ស្រើបស្រាល (ឧ. se délecter à l'étude ស្រើបស្រាលក្នុងការសិក្សា)

délégataire *n.* អ្នកទទួលសិទ្ធិ, អ្នកទទួលអំណាច (ដើម្បីធ្វើជំនួស)

délégateur,trice *n.* អ្នកបែងសិទ្ធិ, អ្នកបែងអំណាច (ឲ្យគេធ្វើជំនួស)

délégation *n.f.* កិច្ចបែងសិទ្ធិឬអំណាច។ p. (pour) le ministre et par délégation ជ. (ជួស) រដ្ឋមន្ត្រីដែលបានបែងអំណាចឲ្យ ។ សិទ្ធិ ឬ អំណាចដែលបែងឲ្យ; គណៈប្រតិភូ (ឧ. envoyer une délégation) ។ délégation de solde ការកាត់ប្រាក់ខែឲ្យអ្នកណាម្នាក់ ឬ សងបំណុល

délégatoire *a.* នៃការបែងសិទ្ធិឬអំណាច

délégué,e *n.* ប្រតិភូ, អ្នកតំណាង (ឧ. les délégués du peuple) ។

délégué de Sa Majesté ភតិ-ប្រតិភូ

déléguer *v.t.* ឲ្យធុរៈ; ឲ្យអំណាច ឬ សេចក្ដីយល់ព្រម; ចាត់ប្រតិភូ ។ déléguer ses pouvoirs បែងអំណាចឲ្យ

délestage *n.m.* ការសម្រាល;ការផ្ដាច់ចរន្តអគ្គិសនីមួយដងមួយកាល

délester *v.t.* សម្រាល;ផ្ដាច់ចរន្តអគ្គិសនីមួយដងមួយកាល

délesteur *n.m.* អ្នកបើសម្រាលនាវ(ក្នុងកំពង់ផែ)

délétère *a.* ដែលយាយីសុខភាព ឬ ជីវិត (ឧ. l'oxyde de carbone est un gaz délétère) ។ *Fig.* ដែលបង្ខូចគំនិតមារយាទ (ឧ. doctrine délétère)

déliaison *n.f.* ដំណើរធូរខ្ចៅ (ក្នុងគ្រឿងនាវ)

délibérant,e *a.* ដែលពិគ្រោះ, ដែលពិភាក្សា (ឧ.assemblée délibérante)

délibératif,ive *a.* ដែលមានសិទ្ធិពិភាក្សា (ឧ.avoir voix délibérative មានសិទ្ធិបោះឆ្នោត ឬ ពិភាក្សា) (ប.ព. consultatif ផង)

délibération *n.f.* ការពិភាក្សា(ឧ.les délibérations de l'Assemblée Nationale sont publiques) ។ សេចក្ដីសម្រេច (ក្រោយពីការពិភាក្សា) (ឧ.par délibération du Conseil); ការជញ្ជឹង, ការគិត(មុននឹងសម្រេច) (ឧ. la délibération n'a de sens que si l'homme est libre)

délibératoire *a.* នៃការពិភាក្សា (ឧ. forme délibératoire)

délibéré,e *a.* លះ,មិនស្ញូញសាញ (ឧ. avoir un air délibéré); ដែលបានគិតទុកជាមុន;ដែលដឹងខ្លួន(ឧ.volonté délibérée) ។ de propos délibéré ដោយមានបំណង, ដោយចេតនា(ឧ.rendre un mauvais service de propos délibéré) ។ *n.m.* *Procéd.* ការពិភាក្សា(របស់ចៅក្រមមុនវិនិច្ឆ័យសេចក្ដី) (ឧ. ordonner un délibéré; affaire en délibéré) ។ vider un délibéré វិនិច្ឆ័យរឿងដែលបានពិភាក្សាហើយ

délibérément *adv.* យ៉ាងលះ,ដោយមិនរួញរា (ឧ. marcher délibé-

rément)

délibérer *v.i.* ពិគ្រោះ,ពិភាក្សា (ឧ. les juges délibèrent à huis clos); ផ្ចិងគិត (ឧ. l'animal, en bien des occasions, pense, raisonne et délibère avec lui-même) ។ délibérer de សម្រេចចិត្តជានឹង (ឧ. quand saint Pierre et les Apôtres délibèrent d'abolir la circoncision...); សម្រេច (ឧ. les chambres délibèrent librement les lois, la magistrature les applique) ។ se délibérer *v.pr.* ត្រូវដាក់ពិភាក្សា

délicat,e *a.* ប្រណិត (ថ្លៃថ្លា, ផ្ចិតផ្ចង់, ឆ្ងាញ់ពិសា) (ឧ. viande délicate; ouvrage délicat; goût délicat); ដែលពោលពង្វាងដោយឆ្លៀវឆ្លាស (ឧ. louange délicate); ម៉ុនប្រសប់, ថ្នមៗ, ស្រាលៗ (ឧ. d'une main délicate; un toucher délicat) ។ ប្រណិត, ឆ្មារ (ឧ. une dentelle délicate) ។ *Par ext.* ទន់ (ឧ. duvet délicat) ។ ល្អិតល្អន់(ពិបាកយល់) (ឧ. la différence est si délicate qu'elle échappe à beaucoup de personnes); ពិបាក(ឧ. question ឬ matière délicate; se tirer d'un pas bien délicat); ឆាប់ឈឺ, ឆាប់ខូច (ឧ. estomac délicat; teint délicat); ពិបាកដោះស្រាយ (ឧ. situation délicate) ។ ដែលមានអាសង្កា (ឧ. conscience délicate) ។ ទន់ខ្សោយ (ឧ. membres délicats; santé délicate) ។ sommeil délicat ដំណេករហ័ស (ឆាប់ភ្ញាក់) ។ oreille délicate ត្រចៀកវៃ (ឆាប់ឮ) ។ esprits délicats ប្រាជ្ញាវៃ (ឆាប់យល់) ។ ចិត្តស្រាល (ឆាប់ខឹង) (ឧ. ils deviennent si délicats que tout ce qui n'est point flatteur les blesse et les irrite) ។ *n.* អ្នករើសគ្លើស (ឧ. Les délicats sont malheureux, Rien ne saurait les satisfaire (La Fontaine)

délicatement *adv.* យ៉ាងប្រណិត; ដោយថ្នាក់ថ្នម (ឧ. enfant élevé trop délicatement)

délicatesse *n.f.* ប្រណីតភាព (ឧ. délicatesse des traits); ការប៉ុនប្រសប់ (ឧ. délicatesse de pinceau); ភាពខ្សោយ (ឧ. délicatesse d'estomac); អាសង្កា, ការនឹករអែង (ឧ. délicatesse de conscience)

délices *n.f.pl.* អស្សាទ, សេចក្ដីរីករាយខ្លាំង, សុភមង្គល (ឧ. cet enfant fait les délices de sa mère)។ *n.m.sing.* សេចក្ដីរីករាយ (ឧ. quel délice cause une bonne action !)

délicieusement *adv.* ដោយអស្សាទ, ដោយរីករាយក្រៃលែង

délicieux,euse *a.* អស្សាទនីយ, ដែលនាំឲ្យរីករាយយ៉ាងក្រៃលែង, ឆ្ងាញ់ ឬ ក្រអូបក្រៃលែង (ឧ. parfum délicieux)

délictueux,euse *a.* ដែលជាបទបញ្ញៀប (ឧ. fait délictueux)

délié,e *a.* ឆ្មារ (ឧ. trait de plume fort délié; fil délié); ល្អិត (ឧ. taille déliée); ស្ដើង (ឧ. il porte une chemise très déliée; cette étoffe est un peu déliée); ច្បាស់, ឆ្មារ(សម្លេង) (ឧ. une voix déliée); ឆាប់ជ្រាប(វត្ថុរាវ) (ឧ. des humeurs déliées)។ *Fig.* ឈ្លាសវៃ (ឧ. argumentation déliée); ច្បាស់ (ឧ. langage délié); ប៉ិន, ប្រសប់ (ឧ. c'est un courtisan délié)។ *n.m.* គំនូសឆ្មារនៃតួអក្សរ (ឧ. la lettre O a deux pleins et deux déliés)

déliement *n.m.* ការស្រាយ

délier *v.t.* ស្រាយចំណង។ *Fig.* ដក (កិច្ចសន្យា, សំដី) (ឧ. délier un serment)

délimitation *n.f.* ការកំណត់ព្រំដែន

délimiter *v.t.* កំណត់ព្រំដែន

délinéament *n.m.* រាង, ទ្រង់ទ្រាយ

délinéer *v.t.* គូសរាង, គូសទ្រង់ទ្រាយ (ឧ. délinéer un plan)

délinquance *n.f.* បទល្មើស (ដែលកើតមានក្នុងដំបន់ ឬ ក្នុងក្រុមនីមួយៗ) (ឧ. délinquance juvénile)

délinquant,e *n.* អ្នកប្រព្រឹត្តបទល្មើស (ឧ. punir un délinquant)។ délinquant primaire អ្នកប្រព្រឹត្តបទល្មើសជាដំបូង

déliquescence *n.f.* លក្ខណៈនៃវត្ថុខ្លះ ដែលស្រូបធាតុទឹកក្នុងខ្យល់ (ដូចជា អំ-

អំបិល ឬ ស្ករដែលយើងថា ដោរ ឬ យំ)។ *Fig.* ការចុះអាប់ឱន (ឧ. un art en déliquescence)

déliquescent,e *a.* ដែលស្រូបធាតុទឹកក្នុងខ្យល់(ពាក្យសាមញ្ញថា ដោរឬយំ)។ *Fig.* ដែលអូនថយ

déliquium *n.m.* ភាពរលាយដោយធាតុទឹកដែលស្រូបពីខ្យល់ (ឧ. អំបិល,ស្ករ ។ល។)

délirant,e *a.* ដែលរវើរវាយ (ឧ. malade délirant); ដែលឲ្យរវើរវាយ (ឧ. fièvre délirante) ។ *Fig.* ហួសប្រមាណ(ឧ. joie délirante); ភយមាយ (ឧ. imagination délirante)។ *Fam.* ដែលនាំឲ្យរីករាយក្រៃលែង (ឧ. partie de plaisir délirante)។ *n.* អ្នករវើរវាយ(ឧ. les délirants doivent être surveillés avec le plus grand soin) ។ *n.m.* ឱសថដែលបណ្ដាលឲ្យរវើរវាយ(ឧ. tous les délirants sont des narcotiques)

délire *n.m.* ការរវើរវាយ ។ *Fig.* ការរំជួលចិត្តខ្លាំង(ឧ. foule en délire) ។ *Poét.* ការរំភើបចិត្ត (ឧ. le délire sacré du poète)

délirer *v.i.* រវើរវាយ

delirium tremens [déliryom'trémiuss] *n.m.* ការរវើរវាយញ័រដៃជើង (ចំពោះតែអ្នកប្រមឹក)

délissage *n.m.* ការចិញ្រ្ចាំកន្ទប (ធ្វើក្រដាស); ការស្រោស់ក្រដាស

délisser *v.t.* ធ្វើឲ្យបាត់រលីងឬរលោង; ចិញ្រ្ចាំកន្ទប(ធ្វើក្រដាស);ស្រោស់ក្រដាស

délit *n.m.* បទល្មើសជាមជ្ឈិម ។ le corps du délit អង្គបទល្មើស (វត្ថុជាភស្តុតាងនៃបទល្មើស)។ quasi-délit ម.ព. នេះ ។ prendre en flagrant délit ចាប់ជាក់ស្ដែង (កំពុងប្រព្រឹត្តបទល្មើស)

délit *n.m.* ស្នាមស្រទាប់បណ្ដោយសាច់ (នៃសិលា) ។ *Constr.* en délit ទទឹងសាច់

délitage ឬ **délitement** *n.m.* ការរើអាចម៍ជង្កួវនាង, ការផ្លាស់ទ្រនំជង្កួវនាង

délitation *n.f.* **délitage** ឬ **délitement** *n.m.* ការបំបែកថ្មតាមបណ្ដោយសាច់

déliter *v.t.* ដាក់បញ្ឈរទទឹងសាច់ (ឧ. déliter une pierre); បំបែកថ្មតាមបណ្ដោយសាច់; ផ្លាស់ទ្រនំជង្កួវនាង, រើអាចម៍ជង្កួវនាង។ se déliter

v.pr. ផុស (បែកធំដោយត្រូវធាតុអាកាសឬទឹក) (ឧ. la chaux vive se délite); បែក

délitescence *n.f.* *Chim.* ការផុស (បែកធំដោយត្រូវទឹក)

délitescent,e *a.* ផុស

délivrance *n.f.* ការដោះលែង (ឧ. la délivrance d'un prisonnier)។ *Fig.* ការដោះឲ្យផុត (អំពីទុក្ខទោស) (ឧ. qui nous apportera la délivrance de toutes nos peines); ការប្រគល់ ឬ ការចេញឲ្យ (ឧ. délivrance d'un certificat)។ *Chir.* ការទម្លាក់សុក ឬស្រោមទារក (ក្រោយឆ្លងទន្លេ) (ឧ. la délivrance s'opère par le même mécanisme que la sortie du fœtus); ការសម្រាលកូន (ឧ. une délivrance douloureuse)

délivre *n.m.* សុក, ស្រោមទារក (ឃើ. placenta)

délivrer *v.t.* ដោះលែង (ឧ. délivrer un prisonnier); ប្រគល់ឲ្យ (ឧ. délivrer de la marchandise, un médicament)។ *Fam.* délivrer des coups de bâton វាយ (ដោយដំបង)។ *Fig.* ដោះឲ្យផុត (ឧ. délivrer sa patrie des guerres intestines; délivrer d'un danger)។ *Chir.* សម្រាលកូន (ឧ. médecin qui délivre une femme); ទម្លាក់សុក (ឧ. femme que l'on a accouchée, mais non encore délivrée)

déloger *v.i.* ចាកចេញពីលំនៅ; ចាកចោលកន្លែង។ *Fig.* ស្លាប់ (ឧ. tôt ou tard, il faut déloger); កំចាត់ (ឧ. faire déloger la fièvre)។ *Art mil.* លើកជំរំ; ថយចេញដោយប្រញាប់ (ឧ. déloger sans tambour ni trompette ចាកចេញដោយស្ងាត់)។ *v.t. Fam.* បណ្ដេញចេញពីលំនៅ (ឧ. déloger un locataire); បណ្ដេញចេញពីកន្លែង (ឧ. déloger un fonctionnaire)

déloyal,e,aux *a.* មិនស្មោះត្រង់ (ឧ. ami déloyal); វៀចវេរ (ឧ. procédé déloyal)

déloyalement *adv.* ដោយមិនស្មោះ-

ត្រង់, ដោយវៀចវេរ (ឧ. rompre déloyalement une trêve)

déloyauté *n.f.* សេចក្ដីមិនស្មោះត្រង់ (ឧ. la déloyauté d'un ennemi); សេចក្ដីវៀចវេរ (ឧ. commettre une déloyauté)

déloyalement *adv.* ដោយមិនស្មោះត្រង់, ដោយវៀចវេរ

delta *n.m.* ដិលតា, អក្សរទី៤នៃអក្សរក្រមក្រិក (រាងត្រីកោណ); វត្ថុរាងត្រីកោណ; ដែនដីសណ្ដរ ។ aile en delta ស្លាបរាងត្រីកោណស្មើជ្រុងពីរ (អាកាសយាន)

deltaïque *a.* នៃដែនដីសណ្ដរ (ឧ. les formations deltaïques)

deltoïde *a.* ដែលមានរាងដូចអក្សរក្រិកដិលតា ។ *n.m. Anat.* សាច់ដុំសន្ទាក់ស្មា

déluge *n.m.* ទឹកដែលជោរជន់នៅពេលកដែនដី(មានចែងក្នុងគម្ពីរពុទ្ធសាសនា និងគម្ពីរគ្រិស្ដសាសនា) ។ *Par anal.* ជំនន់លោ (ជំនន់ធំលិចសាយពេញពាស) ។ *Par ext.* ភ្លៀងរលោ (ឧ. fleuves gonflés des déluges de l'hiver) ។ ចំនួនច្រើននៃវត្ថុដែលហៀរហូរ (ឧ. un déluge de pleurs) ។ *Fig.* ចំនួនច្រើនជាអនេក (ឧ. un déluge de pierres, de paroles, de mauvais livres) ។ *Fam.* សម័យយូរយារណាស់មកហើយ (ឧ. cela date du déluge); remonter au déluge មានយូរយារណាស់មកហើយ; *au fig.* និយាយឬរាប់តាំងពីដើមរៀងមក

déluré,e *a.&n.* រាងវៃ (ឧ. un garçon déluré) ។ *Péjor.* ដែលហ៊ានពេក, គិតរឿនខ្លាស (ឧ. une fille bien délurée)

délurer *v.t.* ធ្វើឲ្យរាងវៃ

délusoire *a.* សម្រាប់បញ្ឆោត (ឧ. argument délusoire)

délustrage *n.m.*ម.ព.décatissage

délustrer *v.t.* បំបាត់កាពរលោង,ធ្វើឲ្យស្រអាប់

démagnétisation *n.f.* ការដកមេដែកចេញ

démagnétiser *v.t.* ដកមេដែកចេញ

démagogie *n.f.* ប្រជាភិថុតិ,ការបញ្ចើចរាស្ត្រ

démagogique *a.* នៃប្រជាភិថុតិ, នៃការបញ្ចើចរាស្ត្រ (ឧ. discours dé-

magogique)

démagogue *n.m.* ប្រជាភិថុតិកៈ,អ្នកបញ្ជោចរាស្ត្រ

démaigrir *v.i.* អន់ស្គម (ឧ.il n'est pas engraissé, mais il a démaigri)។ *v.t.* ធ្វើឲ្យអន់ស្គម

démaigrir *v.t. Techn.* ធ្វើឲ្យស្តើងបន្តិច (ឧ.démaigrir une pierre, une poutre)

démaigrissement *n.m. Techn.* ការធ្វើឲ្យស្តើងបន្តិច(ឧ. le démaigrissement d'une pierre); ភាគនៃថ្មឬឈើដែលចាំងចេញឲ្យស្តើង

démaillage *n.m.* ការកាត់ថ្លើលប្រវ៉ាក់ចេញ; ការរុះក្រឡា (សំពត់ចាក់)

démailler *v.t.* កាត់ថ្លើលប្រវ៉ាក់; រុះក្រឡា (សំពត់ចាក់)

démailloter *v.t.* ដោះអាវយឺតឲ្យ (ឧ. démailloter un enfant)

demain *adv.* ស្អែក (ឧ. c'est demain qu'il faut tout de bon écouter)។ *Par ext.* បន្តិចទៀត, ថ្ងៃក្រោយ(ក្នុងពេលដ៏ខ្លី)(ឧ.aujourd'hui dans le trône, et demain dans la boue)។ *n.m.* អនាគត (ឧ. non, demain n'est à personne)។ à demain ពាក្យលាគ្នាមានន័យថាចាំជួបគ្នាវិញថ្ងៃស្អែក; ចាំស្អែក, ទុកស្អែក (ឧ. remettons cela à demain)។ jusqu'à demain យូរ (ឧ. il bavarderait jusqu'à demain)។ *Fam.* aujourd'hui pour demain តាំងពីឥឡូវនេះទៅ ឬ ក្នុងពេលណាមួយ

démanché,e *n.* អ្នកមានដំណើរយើកយោក។ *n.m.* ម.ព. démanchement

démanchement *n.m.* ការដោះដងចេញ; ភាពរង្គោះដង។ *Fig.* ការបាក់បែក

démancher *v.t.* ដោះដងចេញ (ឧ. démancher une cognée)។ *Fig.* កំចាត់កំចាយ (ឧ. démancher un complot)។ se démancher *v.pr.* រង្គោះដង (ឧ. couteau qui se démanche)។ *Fig.* ខ្ចាត់ខ្ចាយ (ឧ. le complot qui se démanche)។ *Pop.* ធ្វេធ្លា,ប្រាស់ប្រាល់ (ឧ. qu'avez-vous besoin de tant vous démancher ?)

démancher *v.t.* កាត់ដៃអាវចោល (ឧ. démancher une chemise)។

Mar. ចេញពីផែសមុទ្រ (ឧ. notre vaisseau a démanché- ce matin et est entré dans l'océan)

demandable *a.* អាចសុំបាន (ឧ. faveur qui n'est pas demandable)

demandant,e *a.* ដែលសុំ (ឧ. compagnie demandante)

demande *n.f.* ការសុំ (ឧ. faire une demande); ក្តីសុំ (ឧ. accorder une demande); ពាក្យសុំ (លិខិតសុំ) (ឧ. mettre une demande à la poste); ការចូលដណ្តឹងកូនក្រមុំ (ឧ. faire sa demande); សំនួរ (ឧ. demande indiscrète) ។ *Dr.* ការប្តឹងទាមទារ (ឧ. la demande s'introduit ordinairement par exploit d'huissier) ។ demande principale បណ្តឹងប្រធាន (ពាក្យប្តឹងលើកដំបូង ហើយដែលជាគោលនៃការស៊ើបអង្កេត) ។ demande accessoire បណ្តឹងបរិភារ (ពាក្យប្តឹងថែមលើបណ្តឹងប្រធាន) ។ demande nouvelle បណ្តឹងថ្មី (ពាក្យប្តឹងដែលដាក់នៅពេលឧទ្ធរណ៍) ។ demande préjudicielle បណ្តឹងដែលត្រូវជម្រះមុនបណ្តឹងប្រធាន ។ demande reconventionnelle បណ្តឹងតប (បណ្តឹងចុងចោទក៏តបនឹងបណ្តឹងដើមចោទ) ។ demande subsidiaire បណ្តឹងជំនួយ (បណ្តឹងដាក់ការពារក្រែងបណ្តឹងប្រធានមិនបានសម្រេច) ។ demande provisoire បណ្តឹងសុំឲ្យវិនិច្ឆ័យសេចក្តីជាបណ្តោះអាសន្ន ។ *Econ. pol.* សេចក្តីត្រូវការ (សរុបផលិតផលឬការងារដែលគេត្រូវការរកទិញឬជួល) (ឧ. l'offre et la demande) (ម.ព. offre ផង) ។ loi de l'offre et de la demande ម.ព. loi ។ *Mar.* filer un càble ឬ une chaîne à la demande បន្ធាយពួរ ឬច្រវាក់តាមទំហឹងទាញតឹង ។ *Techn.* pièce de bois à la demande ឬ allant à la demande ឈើដែលអារឬចាំងឲ្យល្មមនឹងរណ្តៅ ឬ ដំណាប់ដែលត្រូវបញ្ចុះ(ពន្លួញ) ។ voilà une belle demande! ឬ belle demande! នេះជាការធម្មតាទេ ។ à la demande générale តាមបំណង

ខ្សែទៅ, តាមបំណងមហោជន ។

Prov. à folle (ឬ à sotte) demande point de réponse មិនត្រូវឆ្លើយតបនឹងពាក្យសុំមិនសមហេតុផលឡើយ

demander *v.t.* សុំ (ឧ. demander de l'argent, un renseignement, etc.); សុំ(ប្រាប់បំណង)(ឧ. il demande à parler, à manger; il demande de ne pas vous accompagner à Pochentong; il demande qu'il vienne plus tard; ស្នើរក (ឧ. demander son auto, son habit; demander un livre d'histoire à un libraire; demander un employé); ពឹង, ស្តី (ឧ. demander quelqu'un à garder la maison); ត្រូវប្រើ (ឧ. c'est au travail qu'il faut demander un remède contre la douleur ការងារជាឱសថ ដែលត្រូវប្រើដើម្បីកំចាត់ទុក្ខ); សួរ (ឧ. demander son chemin); សុំ, ត្រូវការ (ឧ. demander secours à ses alliés; enfant qui demande sa mère); *au fig.* ត្រូវការ (ឧ. la terre demande de la chaleur et de l'eau, le travail demande le silence); ចង់បាន (ឧ. quel prix demandez-vous pour ce tableau?); ទាមទារ(ឧ. demander des dommages et intérêts); *au fig.* ត្រូវការ (ឧ. la santé demande de grands ménagements; ne pensons qu'aux devoirs que notre pays demande); ទាររក (ឲ្យមកចំពោះមុខ) (ឧ. demander un témoin); ប្ដឹងទាមទារ (ឧ. demander un jugement); ប្រាម (ឧ. le maître demande à ses élèves un complet silence) ។ ne pas demander mieux យល់ព្រមបាន (មិនសុំអ្វីលើសពីនេះ)។ ne demander que សុំតែប៉ុណ្ណោះ (គ្មានបំណងអ្វីក្រៅទៀតទេ)(ឧ. il ne demande qu'à travailler)។ demander son pain; demander l'aumône, la charité ឬ de-

mander សុំទាន (ឬ demander sa vie ក៏បាន) ។ demander en mariage ឬ demander ដណ្ដឹងប្រពន្ធ។ demander merci សុំទាញ។ demander raison à quelqu'un ហៅមកសងសឹកគ្នា; *au fig.* ហៅមករកខុសត្រូវ, ហៅឲ្យដោះសា ។ *Fam.* ne pas demander son reste គេចយករួចខ្លួន (ឲ្យផុតអំពីការស្ដីបន្ទោស ឬ ការវាយដំ) ។ demandez-moi pourquoi សួរខ្ញុំធ្វើអ្វី (សួរអំពីរឿងដែលពន្យល់មិនបាន) ។ je vous demande un peu ខ្ញុំសុំសួរបន្តិចមើល! (សួរឲ្យពន្យល់ ឬ ធ្វើឲ្យដឹងថាការណ៍នោះមិនសមហេតុផល)។*Hipp.* demander à un cheval បង្ខំសេះ (ក្នុងការប្រណាំង)។ *Mar.* demander du câble បន្ធូរពួរ (បំពោះនាវដែលបោះតែថយ) ។

se demander *v.pr.* គិតក្នុងខ្លួន (ឧ. je me demande si j'irai);ពិគ្រោះគ្នា (ឧ. ils se demandent ce qu'ils doivent faire); ត្រូវសុំ (ឧ. une telle faveur ne se demande pas); ត្រូវសួរ (ឧ. cela ne se damande pas រឿងនេះមិនត្រូវសួរទេ ឬ រឿងនេះទៅឯង ៗ ទេ (មិនបាច់គិតគូរដល់ទេ)

demandeur, eresse *n. Procéd.* អ្នកប្ដឹងទាមទារ, ដើមចោទក៍

démangeaison *n.f.* ស្លៀប, រមាស់។ *Fig.* បំណងខ្លាំង (ឧ.démangeaison de parler)

démanger *v.t.* ធ្វើឲ្យរមាស់ឬឲ្យស្លៀប។ *Fig.* la langue lui démange គាត់រមាស់មាត់ (ចង់និយាយ)

démantèlement *n.m.* ការរំលំកំពែង (ឧ. le déclassement d'une place forte n'entraîne pas toujours son démentèlement)

démanteler *v.t.* រំលំកំពែង; ទំលាយគ្រឿងការពារ

démantibuler *v.t.* គម្លោះឲ្យខូច; ធ្វើឲ្យខូច (ឧ. démantibuler une machine, un meuble) ។ se démantibuler la mâchoire ភ្លាត់ថ្គាម

démaquiller *v.t.* ជូតម្សៅដែលលាបមុខចេញ

démarcatif,ive *a.* សីមាពទ្ធ, ដែលកម្រិតព្រំដែន (ឧ. ligne démarcative)

démarcation *n.f.* សីមាពន្ធន៍, ការកម្រិតព្រំដែន។ ligne de démarcation ខ្សែសីមាពន្ធន៍, ខ្សែកំណត់ព្រំដែន។ *Fig.* អ្វីៗដែលកម្រិតព្រំដែនសិទ្ធិ ឬ មុខងារអំណាចពីរ; អ្វីៗដែលវែកញែក

démarche *n.f.* ដំណើរ (ឧ. démarche lourde)។*Fig.*សេចក្តីស្នើការ (គិតគូរ) (ឧ. démarche inutile)

démarcheur *n.m.* អ្នកដើរគិតគូរ (អ្នកដើរហៅអ្នកទិញ)

démariage *n.m.* ការបំបែកប្តីប្រពន្ធតាមផ្លូវច្បាប់;ការរើក (ការដកកូនដំណាំចេញខ្លះឲ្យរង្វើល ដើម្បីដុះបានល្អ)

démarier *v.t.* បំបែកប្តីប្រពន្ធតាមផ្លូវច្បាប់; រើក (ដកកូនដំណាំចេញខ្លះឲ្យរង្វើល) (ឧ. démarier des betteraves)

démarquage *n.m.* ការលុបយីហោ; ការចម្លងបន្ទំសៀវភៅ គំនូរ ។ល។

démarque *n.f.* ការលក់ចុះថ្លៃ

démarquer *v.t.* លុបយីហោ, បកយីហោចេញ (ឧ. démarquer du linge); លក់ចុះថ្លៃ; ចម្លងបន្ទំ (សៀវភៅ គំនូរ ។ល។)

démarrage *n.m.* *Mar.* ការស្រាយពួរ (កប៉ាល់)។ ការចេញដំណើរ

démarrer *v.t.* *Mar.* ស្រាយពួរ(កប៉ាល់)។ *v.i.* ចេញដំណើរ (ឧ. voiture qui démarre); ចាប់ដើរ (គ្រឿងម៉ាស៊ីន) (ឧ. moteur qui démarre)។ *Fig.* បានដុះដាល(ឧ. l'économie khmère a démarré) ។ *Fam.* ចាកចេញ (ឧ. ne démarrez pas de là)

démarreur *n.m.* ដេម៉ារ៉ឺ (ប្រដាប់បញ្ឆេះម៉ាស៊ីន)

démasquer *v.t.* ដោះរបាំងមុខ (ឧ. démasquer une femme au bal) ។ *Fig.* បើកមុខ (បង្ហាញឲ្យឃើញការពិត)(ឧ.démasquer un traître); បើក, បង្ហាញ (ឧ. démasquer une porte secrète)។ *Fig.* បង្ហាញ (démasquer une fourberie)។

Art mil. démasquer une batterie បញ្ចេញឲ្យឃើញគ្រឿងកាំភ្លើង; *au fig.* démasquer ses batteries បញ្ចេញ

ក្រោងការ ឬ គំនិតខ្លួន(ឲ្យគេដឹង) ។ se démasquer *v.pr.Fig.* សំដែង បំណងរបស់ខ្លួន

démasticage *n.m.* ការបកជ័រប៊ិទ

démastiquer *v.t.* បកជ័រប៊ិទ

dématage ឬ **dématement** *n.m.* *Mar.* ការទម្លាក់ក្ដោង; ការបំបាក់ក្ដោង; ដំណើរបាក់ក្ដោង

démâter *v.t.* *Mar.* ទម្លាក់ក្ដោង; បំបាក់ក្ដោង ។ *v.i.* បាក់ក្ដោង (ឧ. le vaisseau démâta)

démélage *n.m.* ការសេសោះ(សូត្រ, អំបោះ ។ល។)

démêlé *n.m.* ជម្លោះ, រឿង (ឧ. avoir des démêles avec quelqu'un)

démêler *v.t.* សសោះ (ឧ. démêler un écheveau de fil) ។ *Fig.* បំភ្លឺការណ៍ (ឧ. démêler une intrigue); ស្គាល់ (ដោយមិនច្រឡំគ្នា) (ឧ.démêler le vrai du faux); ប្រកែកគ្នា (ឧ. qu'ont-ils à démêler ensemble?) ។ se démêler *v.pr.* ដោះខ្លួន (ឧ. se démêler d'une affaire)

démêleur,euse *n.* អ្នកសសោះ (សូត្រ អំបោះ ។ល។)

démêloir *n.m.* ក្រាសសសោះសក់ (ក្រាសធ្មេញឈើសម្រាប់សិតសក់កុំឲ្យកណ្ដាញ់); ប្រដាប់សសោះ

démêlures *n.f.pl.* សក់សិតជ្រុះ

démembrement *n.m* ការបែងចែក (ឧ. le démembrement de l'empire de Charlemagne)

démembrer *v.t.* ផ្ដាច់អវយវៈចេញពីខ្លួន ។ *Fig.* បែងចែក (ឧ. démembrer un Etat, une domaine)

déménagement *n.m.* ការរើផ្ទះ

déménager *v.t.* រើផ្ទះ ។ *v.i.* ផ្លាស់លំនៅ (ឧ. nous avons déménagé ឬ nous sommes déménagés) ។ *Fig. & fam.* sa tête déménage វិលខួរ (និយាយមិនសមហេតុផល)

déménageur *n.m.* អ្នកស៊ីឈ្នួលរើផ្ទះ

démence *n.f.* ភាពឆ្កួតវង្វេង ។ *Par ext.* ការប្រព្រឹត្តមិនសមហេតុ (ឧ. c'est de la démence d'agir ainsi)

démener (se) *v.pr.* បម្រះ, ឆ្វេឆ្វា (ឧ. se démener comme un diable dans un bénitier ឆ្វេ-

ឆ្អឹងចមាន់រកពង)។ *Fig.* ខំប្រឹងខ្លាំង

dément,e *a.* ឆ្កួតវង្វេង។ *n.m.* មនុស្សឆ្កួតវង្វេង

démenti *n.m.* បដិសេធកិច្ច,ការប្រកែក (ឧ. donner, recevoir un démenti)។ *Fig. & Fam.* ការអៀនខ្មាស ដោយពុំបានសម្រេចតាមបំណង (ឧ. il a eu le démenti)

démentiel,elle *a.* នៃការឆ្កួតវង្វេង (ឧ. accès démentiel)

démentir *v.t.* បដិសេធ, ប្រកែក (ឧ. démentir un témoin; démentir une nouvelle); ដំទាស់, មិនស្របតាម (ឧ. prédiction que l'évènement a démenti)។ **se démentir** *v.pr.* លែងមាំ, ទ្រុឌទ្រោម (ឧ. cette maison se dément)។ *Par ext.* ចុះអន់ថយ (ឧ. sa fermeté ne s'est pas démentie un seul instant); ប្រព្រឹត្តខុស

démérite *n.m.* អ្វីៗដែលគួរបន្ទោស

démériter *v.i.* ធ្វើឲ្យខូចសេចក្ដីរាប់អាន ឬ ការចូលចិត្ត (ឧ. en quoi a-t-il démérité ?)

démesure *n.m.* ការខ្វះប្រមាណ

démesuré,e *a.* ធំខុសខ្នាត (ឧ. taille démesurée)។ *Fig.* ហួសហេតុ (ឧ. ambition démesurée)

démesurément *adv.* ដោយហួសហេតុ

démettre *v.t.* ធ្វើឲ្យភ្លាត់ឬឲ្យគ្រេច (ឧ. démettre un bras)។ *Procéd.* បដិសេធបណ្ដឹង។ *Fig.* បញ្ឈប់ (ឧ. démettre quelqu'un d'un emploi)។ **se démettre** *v.pr.* លាឈប់ពីដំណែង

démeublé,e *a.* ដែលលែងមានគ្រឿង។ *Fam.* bouche démeublée មាត់គ្រហុប (មាត់គិតធ្មេញ)

démeublement *n.m.* ការយកគ្រឿងចេញ; ដំណើរគ្មានគ្រឿង

démeubler *v.t.* យកគ្រឿងចេញ

demeurant,e *a.* ដែលឋិតនៅ។ *n m.* អ្នកនៅ; អ្នកនៅរស់; របស់ដែលនៅសល់។ **au demeurant** *loc. adv.* ដោយសរុបសេចក្ដីទៅ (ឧ. au demeurant, c'est un bon garçon)

demeure *n.f.* ការដំអក់(ឧ. sans plus longue demeure) (ឥឡូវប្រើតែក្នុងន័យថា il y a péril en la demeure ឬ à demeure បើដំ-

អក់នៅតទៅទៀតនឹងមានគ្រោះថ្នាក់) ។ être en demeure envers quelqu'un ជំពាក់គុណ ។ être en demeure avec quelque chose មិនសប្បាយចិត្តនឹងខ្លួនឯងព្រោះអ្វីមួយ។ mettre en demeure de ដាក់កំហិត(ឧ. mettre quelqu'un en demeure de payer); se mettre en demeure de ហ្វឹកហ្វឺនខ្លួន(ឧ. s'accoutumer à écrire comme on parle et comme on pense, n'est-ce pas déjà se mettre en demeure de bien penser ?)។

លំនៅ (ឧ. embellir sa demeure); រយៈពេលដែលស្នាក់នៅ (ឧ. faire une longue demeure à la campagne)។

Dr. ការយឺតយ៉ាវក្នុងរឿងសងបំណុល (ឧ. la demeure du créancier ការមិនព្រមទទួលសំណង) ។ mise en demeure ការដាក់កំហិត ។

Demeure mortelle ឋានកណ្ដាល, ឋានមនុស្សលោក (ផ្ទុយនឹងឋានសួគ៌) ។ demeure de l'âme កាយ (ខ្លួនមនុស្ស) ។ dernière demeure, demeure des morts, demeures souterraines ឬ sombres demeures ផ្នូរខ្មោច, ព្រៃខ្មោច។ demeure céleste ឬ éternelle មេឃ (ឋានសួគ៌)។ demeure sacrée ឬ divine វិហារ ។ faire sa demeure នៅ, ឋិតនៅ។

à demeure *loc. adv.* ជាស្ថាពរ, លែងប្រែប្រួល

demeuré,e *a.&n.* ត្រង់, ភ្លើ

demeurer *v.i.* ដំអក់ (ក្រ មក) (ឧ. demeurer longtemps à venir); ដំអក់(ក្រចេញ) (ឧ. demeurer longtemps à table); នៅ (នៅយឺត) (ឧ. demeurer une heure à écrire une lettre); បង្អង់នៅ (ឧ. mon neveu, demeurez-là); ឋិតនៅ,មានទីលំនៅ (ឧ. demeurer à l'hôtel, à la campagne); ឈប់នៅ (ឧ. où la guêpe a passé, le moucheron demeure)។

Fig. នៅ (ឧ. demeurer indécis នៅរាក; demeurer

silencieux នៅស្ងៀម); ជាប់, ឋិតថេរ (មិនរលុប) (ឧ. tache, gloire qui demeure éternellement); សល់នៅ (ឧ. ce qui demeure de ma fortune) ។ ផ្អាកទុកនៅ (ឧ. les soins publics seraient abandonnés, les affaires demeuraient) ។

Loc. adv. demeurer au théâtre ឬ demeurer នៅលេងគរវាទៀត (ឧ. certaines pièces demeurent, malgré le mauvais accueil qu'elles reçoivent au début)។ demeurer court ឬ tout court នៅស្រឡាំងកាំង ។ demeurer d'accord ព្រមព្រៀងគ្នា (ក្រោយពីមានការជជែកគ្នា ឬ ដើម្បីគិតការអ្វីមួយ)។ demeurer en repos ឬ ne pas travailler នៅស្ងៀម, មិនខ្វល់ខ្វាយ ។ demeurer en chemin ឬ demeurer en beau chemin លែងចម្រើនទៅមុខ, នៅជំនែល (ម.ព. chemin ផង)។ en demeurer là នៅតាំង, នៅស្អក, លែងបានសម្រេច។ demeurons-en là យើងត្រូវឈប់ត្រឹមនេះ។ demeurer au-dessous នៅក្រោម, នៅស្មើរ (មិនទាន់ដល់កម្រិតដែលអាចធ្វើបាន) (ឧ. il est demeuré au-dessous de lui-même) ។ demeurer en reste ឬ en arrière នៅជំពាក់, នៅជំពាក់គុណ (មិនទាន់បានរួចគ្នា); នៅក្រោយ ។ ne pas demeurer ឬ ne pouvoir demeurer en place នៅមិនសុខ (នៅមិនស្ងៀមដោយទ្រាំមិនបាន ឬ ដោយព្រួយ) ។ demeurer sur place ឬ y demeurer ស្លាប់ភ្លាម, ស្លាប់នៅកន្លែង ។ demeurer sur le cœur ឬ sur l'estomac នៅចាំមិនភ្លេច, ធ្វើឲ្យចងគំនុំជាប់; *au propre* នៅមិនរលាយ (អាហារ) ។ demeurer sur la bonne bouche ក្រោអារម្មណ៍ល្អ; *au propre* ក្រោរសធ្ងាញ់ដែលជាប់នៅមាត់ (ម.ព. bouche ផង)។ demeurer sur son appétit នៅមិនទាន់ឆ្អែត (បរិភោគមិនតាមឃ្លាន); *au fig.* មិនបណ្ដោយតាមបំណង ។ demeurer pour les gages នៅជាប់កុនម្នាក់ឯង (ចំពោះតែរឿងថ្លៃអាហារបរិភោគជាមួយគ្នា អ្នកឯទៀតគេគេច

ជាត់អស់ ខ្លួននៅជាប់តែម្នាក់ឯង)

demi,e *a.* អឌ្ឍ. ពាក់កណ្ដាល, កន្លះ(ឧ. une demi-heure)។ *Par ext.* ពាក់កណ្ដាល, ស្ទើរ (ឧ. un demi-savant); ស្រាងៗ (ខ្សោយ) (ឧ. demi-jour, demi-obscurité ពន្លឺស្រាងៗ, ងងឹតស្រាងៗ)។ et demi ពីលើ (ឧ. à menteur, menteur et demi. កុហកពីលើអ្នកកុហក)។ en diable et demi ហួសពេក, ខ្លាំងណាស់ (ឧ. battre quelqu'un en diable et demi)

demi *n.m.* ចំហៀង(ឧ. deux demis valent un entier); កែវផឹកបៀរ (ចំណុះកន្លះលីត្រ); វត្ថុក្នុងកែវ ។ *n.f.* កន្លះ(ឧ. ne pouvant en avoir une, j'en ai pris une demie)។ កន្លះម៉ោង(ឧ. entendre sonner la demie)។ *adv.* ពាក់កណ្ដាល, ហៀបនឹង(ឧ. demi-mort; demi-cuit; demi-vêtu)។ *Loc. adv.* à demi ពាក់កណ្ដាល, ស្ទើរតែ (ឧ. à demi-mort; à demi-vêtu); មិនពេញ, មិនបរិបូណ៌ (ឧ. ce n'est vivre qu'à demi que de n'oser penser qu'à demi)។ à demi-mot ម.ព. demi-mot

demi-bain *n.m.* ការងូតទឹកមួយកំណាត់ខ្លួនចុះក្រោម (ត្រឹមចង្កេះចុះទៅ) (*pl.* des demi-bains)

demi-bas *n.m.* ស្រោមជើងវែងត្រឹមស្នូង

demi-botte *n.f.* ស្បែកជើងកវែងត្រឹមស្នូង

demi-brigade *n.f.* កងវរសេនាធំ (ក្នុងសម័យបដិវត្តន៍បារាំង); ប្រជុំកងវរសេនាតូចក្រោមបញ្ជានៃវរសេនីយឯក (ឧ. une demi-brigade de chasseurs à pied) (*pl.* des demi-brigades)

demi-cercle *n.m.* អឌ្ឍមណ្ឌល (ពាក់កណ្ដាលរង្វង់មូល) (*pl.* des demi-cercles)

demi-circulaire *a.* ជាអឌ្ឍមណ្ឌល។ canaux demi-circulaires ឬ semi-circulaires រន្ធត្រចៀកក្នុង

demi-clef *n.f.* បំណងបត់ចន្លាស (*pl.* des demi-clefs)

demi-deuil *n.m.* អឌ្ឍមរណសញ្ញា, ការកាន់ទុក្ខពាក់កណ្ដាល (សំលៀកបំពាក់ពណ៌ជាស់ ឬ ខ្មៅ សដែលគេស្លៀកពាក់នៅពេលជិតផុតរយៈវេលាកាន់ទុក្ខ)

demi-dieu *n.m.* អឌ្ឍទេវតា (កូនកាត់

អាទិទេពនឹងមនុស្សសាមញ្ញ; ជនដែលគេលើកជាអាទិទេព) (*pl.* des demi-dieux)

demi-droite *n.f.Math.* អឌ្ឍដុំត (ឧ. une demi-droite n'est pas la moitié d'une droite) (*pl.* des demi-droites)

démieller *v.t.* យកទឹកឃ្មុំចេញពីក្រមួន

demi-fin,e *a.* ស្ទើរម៉ដ្ឋ (ពាក់កណ្ដាលគ្រើមពាក់កណ្ដាលម៉ដ្ឋ); ពាក់កណ្ដាលសុទ្ធ(មានលោហធាតុសុទ្ធពាក់កណ្ដាល) (ឧ. collier demi-fin) ។ *n.m.* មាសលាយ (ឧ.bracelet en demi-fin) ។ អក្សរស្ទើរល្អិត (ឧ.écrire en demi-fin)

demi-finale *n.f.* ពាក់កណ្ដាលផ្ដាច់ព្រ័ត្រ (*pl.* des demi-finales)

demi-fond *n.m.* ចម្ងាយមធ្យម (ក្នុងកីឡារត់ប្រណាំង គឺចម្ងាយ ៨០០ និង ១៥០០ ម៉ែត្រ) (ឧ. coureur de demi-fond)

demi-fortune *n.f.* រទេះសេះកង់បួនយ៉ាងទឹមសេះតែមួយ

demi-frère *n.m.* បងប្អូនប្រុសឪពុកជាមួយម្ដាយដោយខ្លួនឬម្ដាយជាមួយឪពុកដោយខ្លួន (កូនចុងនឹងកូនដើម) (*pl.* des demi-frères)(ម.ព. demi sœur ផង)

demi-gros *n.m.* ដុំមធ្យម (ជំនួញ ស្ទើរលក់ដុំស្ទើរលក់រាយ)

demi-heure *n.f.* កន្លះម៉ោង (*pl.* des demi-heures)

demi-jour *n.m.inv.* ពន្លឺស្រាងៗ (ដូចពន្លឺមុនថ្ងៃរះ)

démilitarisation *n.f.* វិយោធកម្ម, ការដកទ័ពចេញ

démilitariser *v.t.* ធ្វើវិយោធកម្ម, ដកទ័ពចេញ

demi-mal *n.m.Fam.* ផលអាក្រក់ជាមធ្យម (*pl.* demi-maux)

demi-mesure *n.f.* អឌ្ឍមាត្រា, កន្លះ (រង្វាស់រង្វាល់)។ *Fig.* វិធានការស្ទាក់ស្ទើរ (ឧ. les demi-mesures sont illusoires)

demi-mondaine *n.f.* ស្ត្រីចរិយាមិនល្អ(*pl.* des demi-mondaines)

demi-monde *n.m.* បនស្ត្រីចរិយាមិនល្អ

demi-mort,e *a.* ស្លាប់ពាក់កណ្ដាល, ស្ទើរស្លាប់

demi-mot(à) *loc.adv.* ដោយមិនបាច់និយាយឲ្យអស់សេចក្ដី(ឧ.entendre ឬcomprendre à demi-mot)

déminage *n.m.* ការកាយគ្រាប់បែកកប់ចេញ (ឧ. le déminage d'une route) (ការកាយគ្រាប់បែកកប់ក្នុងសមុទ្រហៅថា dragage)

déminer *v.t.* កាយគ្រាប់បែកកប់ចេញ

déminéralisation *n.f.* វិវនិជរោគ, រោគខ្វះជាតិអំបិលក្នុងខ្លួន

déminéraliser *v.t.* បំបាត់ជាតិអំបិលខនិជពីក្នុងខ្លួន (ឧ. la grossesse déminéralise)

démineur *n.m.* អ្នកកាយគ្រាប់បែកកប់

demi-pause *n.f. Mus.* កន្ទះបង្អង់ (*pl.* des demi-pauses)

demi-pension *n.f.* ថ្លៃអាហារតែពេលព្រឹក (ក្នុងអគារសិក្សា); ភាពជាអ្នកទទួលអាហារតែពេលព្រឹក (*pl.* des demi-pensions)

demi-pensionnaire *n.* សិស្សដែលទទួលអាហារតែពេលព្រឹក (ក្នុងអគារសិក្សា) (*pl.* des demi-pensionnaires)

demi-place *n.f.* ថ្លៃពាក់កណ្ដាល (ថ្លៃកន្លែងមើលល្ខោន ភាពយន្ត ឬថ្លៃជិះរថយន្តជាដើម) (*pl.* des demi-places)

demi-pièce *n.f.* កន្ទះដាប់ (សំពត់); កន្ទះធុង (ស្រា) (*pl.* des demi-pièces)

demi-produit *n.m.* អឌ្ឍផលិតផល (រូបធាតុដើមដែលគេបានបំប្លែងភាពម្ដងរួចទៅហើយ) (*pl.* des demi-produits)

demi-quart *n.m.* ពាក់កណ្ដាលភាគបួន (*pl.* des demi-quarts)

demi-reliure *n.f.* ការដេរសៀវភៅដាក់ស្បែកតែខាងខ្នង

demi-ronde *n.f.* ដែកអង្រួសម្យ៉ាងម្ខាងសំប៉ែតម្ខាងមូល

demi-saison *n.m.* សារទរដូវ ឬនិទាឃរដូវ ។ vêtements de demi-saison សំលៀកបំពាក់កន្ទះរដូវ (សំលៀកបំពាក់សម្រាប់ប្រើតែកន្ទះឆ្នាំ គឺប្រើក្នុងនិទាឃរដូវនឹងសារទរដូវ (រដូវក្ដៅនឹងរដូវលំហើយ)

demi-sang *n.m.inv.* សេះកាត់ពីពូជល្អ (មួយពូជល្អ មួយពូជធម្មតា) (ម.ព. pur-sang ផង)

demi-savant *n.m.* ស្ទើរប្រាជ្ញ (អ្នកចេះវិទ្យាសាស្ត្រអូនថយ)

demi-savoir *n.m.* ចំណេះស្ទើរ

demi-sel *a.inv.* ប្រៃភ្ងារ ។ *n.m. inv.* ប្រហុកស្រស់ប្រៃភ្ងារ

demi-sœur *n.f.* បងប្អូនស្រីឪពុកជាមួយម្ដាយដោយខ្លួនឬម្ដាយជាមួយឪពុកដោយខ្លួន (កូនពុងនឹងកូនដើម) (ម.ព. demi-frère ផង)

demi-solde *n.f.* អឌ្ឍបៀវត្ស, បៀវត្សពាក់កណ្ដាល

demi-sommeil *n.m.* ដំណេកលក់ស្ហា (ស្ទើរលក់ស្ទើរភ្ញាក់) (*pl.* des demi-sommeils)

demi-soupir *n.m. Mus.* កន្លះដង្ហើម (*pl.* des demi-soupirs)

démission *n.f.* ការសុំលាឈប់ពីដំណែង (ឧ. pour être effective, la démission d'un fonctionnaire doit être acceptée) ។ *Par ext.* ការបោះបង់

démissionnaire *a.&n.* ដែលសុំលាឈប់ពីដំណែង (ឧ. officier démissionnaire)

démissionner *v.i.* សុំលាឈប់ពីដំណែង (ឧ. démissionner d'un emploi) ។ *Fam.* បោះបង់

demi-tasse *n.f.* ពែងកាហ្វេចំទើរ; ចំណុះពែងកាហ្វេចំទើរ (*pl.* des demi-tasses)

demi-teinte *n.f.* ពណ៌ស្រគាំ (ស្ទើរមិនច្បាស់ពណ៌) (*pl.* des demi-teintes)

demi-tige *n.f.* ដើមផលព្រឹក្សដែលបង្រ្កិនឲ្យនៅចំទើរ (*pl.* des demi-tiges)

demi-ton *n m. Mus.* កន្លះតាន (*pl.* des demi-tons)

demi-tour *n.m.* កន្លះជុំ ។ *Par ext.* faire demi-tour បែរត្រឡប់ក្រោយ (*pl.* des demi-tours)

démobilisation *n.f.* ការបញ្ចេញពីកំណែនកងពល

démobiliser *v.t.* បញ្ចេញពីកំណែនកងពល

démocrate *a.&n.* ប្រជាធិបតេយ្យ

démocrate-chrétien,enne *a.&n.* ប្រជាធិបតេយ្យគ្រិស្តសាសនិក (ឧ. parti démocrate-chrétien)

démocratie *n.f.* លទ្ធិប្រជាធិបតេយ្យ; វណ្ណៈរាស្ត្រ ។ démocratie monarchique រាជប្រជាធិបតេយ្យ ។ démocratie parlementaire ប្រជាធិបតេយ្យអាស្រ័យសភា ។ démocratie républicaine ប្រជាធិបតេយ្យសាធារណរដ្ឋ

démocratique *a.* នៃលទ្ធិប្រជាធិប-

គេយ្យ (ឧ. constitution démocratique)

démocratiquement *adv.* តាមលទ្ធិប្រជាធិបតេយ្យ

démocratisation *n.f.* ប្រជាធិបតេយ្យូបនីយកម្ម, ការធ្វើឲ្យកាន់លទ្ធិប្រជាធិបតេយ្យ; ប្រជានុវត្តន៍

démocratiser *v.t.* ធ្វើប្រជាធិបតេយ្យូបនីយកម្ម, ធ្វើឲ្យកាន់លទ្ធិប្រជាធិបតេយ្យ (ឧ. démocratiser un pays); ធ្វើប្រជានុវត្តន៍ (ឧ. démocratiser l'enseignement); ផ្សាយដល់ប្រជារាស្ត្រ (ឧ. démocratiser la science)

démodé,e *a.* ហួសសម័យ (ឧ. habit démodé) ។ *Fig.* théorie démodée ទ្រឹស្ដីហួសសម័យ

démoder *v.t.* ធ្វើឲ្យហួសសម័យ ។ se démoder *v.pr.* ហួសសម័យ

démographe *a.&n.* អ្នកប្រជាសាស្ត្រ

demographie *n.f.* ប្រជាសាស្ត្រ

démographique *a.* ខាងប្រជាសាស្ត្រ (ឧ. étude démographique)

demoiselle *n.f.* កញ្ញា ។ demoiselle d'honneur កញ្ញាកិត្តិយស ។ demoiselle de compagnie ស្រីស្នំ ។ ស្ដ្រីព្រហ្ម ។ កន្ទុំរុយ ។ demoiselle de paveur ឬ demoiselle ឈើងំដី (ប្រដាប់បុកបង្ហាប់ដី) (ស. dame, hie)

démolir *v.t.* រុះ (ឧ. démolir une maison) ។ *Fig.* បំផ្លាញ (ឧ. démolir une doctrine) ។ *Pop.* ខ្ទិល, រំលំ

démolissage *n.m. Fig.* ការរិះគន់ខ្លាំង

démolisseur,euse *n.* អ្នករុះ ។ *Fig.* អ្នកបំផ្លាញ

démolition *n.f.* ការរុះ (ឧ. la démolition d'une maison) ។ *Pl.* គ្រឿងដែលបានពីការរុះ (ឧ. acheter des démolitions)

démon *n.m.* ទេវតារក្សាឬទេព្រក្យ (ទេវតាអ្នករក្សាមនុស្ស ឬ រក្សាអ្វីៗ) (ឧ. le démon de Socrate); ខ្មោច, បិសាច (ឧ. être possédé du démon ខ្មោចចូល) ។ *Fig.* មនុស្សកំណាច (ឧ. cette femme est un vrai démon); ក្មេងពិស

démonétisation *n.f.* ការបង្ខូច ឬ បន្ថយតម្លៃប្រាក់

démonétiser *v.t.* បង្ខូចតម្លៃប្រាក់, បន្ថយតម្លៃប្រាក់ ។ *Fig.* បន្ទាក

démoniaque *a.&n.* ដែលខ្មោចចូល

démonographie ឬ **démonologie** *n.f.* បិសាចសាស្ត្រ

démonographique ឬ **démonologique** *a.* នៃបិសាចសាស្ត្រ

démonomane *n.* អ្នកជម្ងឺខ្មោចធ្វើ

démonomanie *n.f.* ជម្ងឺខ្មោចធ្វើ

démonstrateur,trice *n.* និទស្សក, អ្នកបង្ហាញ, អ្នកពន្យល់; អ្នកបង្រៀនវិទ្យាសាស្ត្រ

démonstratif,ive *a.* និទស្ស, ដែលបង្ហាញ បំភ្លឺ ឬ ពន្យល់ (ឧ. raison démonstrative) ; ដែលសំដែងសេចក្ដីរាប់អាន ឬ អាការខ្នះខ្នែង (ឧ. personne démonstrative)

démonstration *n.f.* និទស្សន៍, ការបង្ហាញ បំភ្លឺ ឬ ពន្យល់; ការបង្រៀនដោយយកវត្ថុមានរូបរាងមកពន្យល់;ការសំដែងសេចក្ដីរាប់អានឬមិត្តភាព (ឧ. prodiguer des démonstrations); ឧបាយបំភាន់សត្រូវ

démontable *a.* អាចគម្លោះ ឬ ដោះចេញបាន

démontage *n.m.* ការដោះចេញ, ការគម្លោះ

démonté,e *a.* mer démontée សមុទ្ររំជួល

démonte-pneu *n.m.* ដែកគាស់កង់ទេយន្ត(*pl.* des démonte-pneus)

démonter *v.t.* ទម្លាក់ពីជិះ (ឧ. démonter un cavalier); គម្លោះ, ដោះចេញ (ឧ. démonter une machine)។ *Fig.* ធ្វើឲ្យទាល់គំនិត ឬទាល់ប្រាជ្ញ (ឧ. cette objection l'a démonté)។ se démonter *v.pr.* របោះ។ *Fig.* ស្ងន់, ឡប់ (ឧ. se démonter devant un examinateur)

démontrabilité *n.f.* និទស្សនភាព, ភាពអាចពន្យល់ ឬ បង្ហាញបាន

démontrable *a.* និទស្សនីយ៍, អាចពន្យល់ ឬ បង្ហាញបាន

démontrer *v.t.* ធ្វើនិទស្សន៍, បំភ្លឺ, ពន្យល់, បង្ហាញ (ឧ. sa rougeur démontre sa honte)

démoralisant,e *a.* ដែលនាំឲ្យខូចទឹកចិត្ត (ឧ. échec démoralisant)

démoralisateur,trice *a.&n.* ដែលនាំឲ្យប្រព្រឹត្តខុសសីលធម៌ (ឧ. influence démoralisatrice)

démoralisation *n.f.* ការនាំឲ្យប្រព្រឹត្តខុសសីលធម៌; ការបង្ខូចទឹកចិត្ត

démoraliser *v.t.* នាំឲ្យប្រព្រឹត្តខុសសីលធម៌ (ឧ. les mauvais exemples démoralisent); បង្ខូចទឹកចិត្ត (ឧ. la retraite démoralise les meilleures troupes)

démordre *v.i.* លែងខាំ ។ *Fig.* ប្រែប្រួលសំដីឬគំនិត (ឧ. il n'en démordra point)

démoucheter *v.t.* ប្តូរជាត់ស្នាមអុជៗ

démoucheter *v.t.* ដោះដែកស្រោបចុងដាវចេញ

démoulage *n.m.* ការដោះពុម្ព (ឧ. le démoulage d'une statue)

démouler *v.t.* ដោះពុម្ព

démultiplicateur *n.m.* គ្រឿងបន្ថយល្បឿន

démultiplication *n.f. Méc.* ការបន្ថយល្បឿន

démultiplier *v.i. Méc.* បន្ថយល្បឿន

démunir *v.t.* បង្អត់ស្បៀង; យកចេញ (ឧ. démunir du nécessaire) ។ se démunir *v.pr.* យកចេញពីខ្លួន, បោះបង់ (ឧ. se démunir de son argent)

démurer *v.t.* បើកជញ្ជាំង (ដែលសន្ទប់ទ្វារ ឬ បង្អួច)

démuseler *v.t.* ដោះឈ្នួ ។ *Fig.* បណ្តោយតាម (ឧ. démuseler les passions)

dénaire *a.* ដែលយកចំនួនដប់ជាគោល, ដែលផ្អែកលើចំនួនដប់ (ឧ. système dénaire)

dénantir *v.t.* ដោះរបស់បញ្ចាំពី (ឧ. dénantir ses créanciers) ។ se dénantir បោះបង់របស់បញ្ចាំ ។ *Par ext.* បោះបង់ (ឧ. il ne faut pas se dénantir de ce qu'on possède)

dénatalité *n.f.* ការថយចំនួនកំណើត

dénationalisation *n.f.* និជាតូបនីយកម្ម, ការលែងដាក់ជារបស់ជាតិ

dénationaliser *v.t.* លែងដាក់ជារបស់ជាតិ; ដកសញ្ជាតិ, លែងឲ្យចូលជាតិ

dénatter *v.t.* រុះកម្រង (កម្រងសក់) (ឧ. dénatter ses cheveux)

dénaturalisation *n.f.* ការដកសិទ្ធិចូលជាតិ

dénaturaliser *v.t.* ដកសិទ្ធិចូលជាតិ

dénaturant,e *a.* ដែលបំប្លែងធម្មជាតិ

dénaturation *n.f.* ការបំប្លែងធម្មជាតិ

dénaturé,e *a.* ដែលប្រាសចាកភេទដើម, ដែលត្រូវបំប្លែង (ឧ. alcool déna-

turé) ។ *Fig.* ដែលមានមនោសញ្ចេតនាខុសពីធម្មតា (ឧ. un fils dénaturé); ខុសពីធម្មតា (ឧ. une action dénaturée); គ្មានសីលធម៌ (ឧ. goûts dénaturés)

dénaturer *v.t.* បំប្លែងធម្មជាតិ; បំប្លែង (កុំឲ្យបរិភោគបាន) (ស្រា, ស្ករ, អំបិល ។ល។) (ឧ. les produits dénaturés sont assujettis à des impôts moins élevés que les produits non dénaturés) ។ *Fig.* ក្លែង, បង្កាច់ (ឧ. dénaturer les paroles de quelqu'un); ក្លែងភាពក្រៅ; បង្ខូចមនោសញ្ចេតនា

denché,e *a.* ម.ព. dentelé

dénégation *n.f.* ការប្រកែក (ក្នុងតុលាការ)(ឧ. geste, signe de dénégation) (ព.ផ. aveu)

déni *n.m.* ការមិនព្រមសង ។ déni de justice ការមិនព្រមកាត់សេចក្ដី

déniaiser *v.t.* ធ្វើកុំឲ្យឆោតពេក

dénicher *v.t.* យកចេញពីសំបុក (ឧ. dénicher des oiseaux) ។ *Fig.* បណ្ដេញចេញពីលំនៅ ; រកបាន (ឧ. dénicher un livre rare) ។ *v.i.* ចាកចេញពីសំបុក

dénicheur,euse *n.* អ្នកយកពង ឬ កូនសត្វ; អ្នកប្រសប់រក

dénicotiniser *v.t.* យកនីកូតេស [នី-កូ-រស់] ចេញខ្លះ (ម.ព. nicotine ផង)

denier *n.m.* ដឺនីយេ៉, រូបិយវត្ថុបុរាណរ៉ូម៉ុំងនឹងបារាំង ។ *pl.* ប្រាក់ (ឧ. il l'a acheté de ses propres deniers) ។ ប្រាក់ចុងការ (ឧ. argent placé au denier vingt ប្រាក់ដាក់យកចុងការមួយភាគម្ភៃ គឺប្រាំភាគរយ) ។ le denier de la veuve ទានរបស់អ្នកក្រ ។ denier du culte ទេយ្យវត្ថុដែលពួកកាតូលិកផ្គត់ផ្គង់អ្នកបួស ។ denier de Saint Pierre គ្រឿងសក្ការៈដែលគ្រិស្តសាសនិក បូជាចំពោះប៉ាប (ប្រមុខកាតូលិកសាសនា) ។ denier à Dieu ប្រាក់កក់ឲ្យបាវ ឬ កូនឈ្នួលក្នុងផ្ទះ ។ les deniers publics ប្រាក់របស់រដ្ឋ

dénier *v.t.* បដិសេធ, ប្រកែក, មិនព្រមទទួលដឹង (ឧ. dénier une dette); មិនព្រមឲ្យ (ឧ. dénier un droit à quelqu'un); មិនទទួលស្គាល់ (ឧ. dénier la justice)

dénigrant,e *a.* ដែលបន្ទុះបង្អាប់; ដែល

និយាយបង្អាប់ (ឧ. propos dénigrants សំដីបន្តុះបង្អាប់)

dénigrement *n.m.* ការបន្តុះបង្អាប់; ការនិយាយបង្អាប់

dénigrer *v.t.* បន្តុះបង្អាប់; និយាយក្លែងបង្ខូច; និយាយបង្អាប់ (ឧ. les envieux ne cessent de tout dénigrer)

dénigreur *n.m.* អ្នកនិយាយបង្អាប់

dénitrification *n.f.* ការយកអាហ្សូតចេញ

dénitrifier *v.t.* យកអាហ្សូតចេញ (ពីដី ឬ ពីវត្ថុធាតុអ្វីមួយ)

déniveler *v.t.* ធ្វើឲ្យក្រហេងក្រហូង (ឧ. déniveler un parc pour le rendre pittoresque)

dénivellation *n.f.* ឬ **dénivellement** *n.m.* វិសមត្ត, ភាពក្រហេងក្រហូង, ភាពមិនរាបស្មើ

dénoircir *v.t.* ដំរះពណ៌ខ្មៅ

dénombrable *a.* អាចរាប់ឬជំរឿនបាន

dénombrement *n.m.* ការរាប់; ការរាយរាប់; ការជំរឿន (ឧ. faire le dénombrement d'une population)

dénombrer *v.t.* រាប់; រាយរាប់; ជំរឿន (ឧ. dénombrer les habitants d'un pays)

dénominateur *n.m.* នាមកត្តា, ភាគបែង (ឧ. pour additionner deux fractions, il faut les réduire au même dénominateur)

dénominatif,ive *a.* សម្រាប់ហៅឈ្មោះ (ឧ. terme dénominatif) ។ *a.&n. Gram.* អភិធាយក [−យក់]

dénomination *n.f.* នាមករណ៍, ការកំណត់, ការហៅឈ្មោះ ឬ ដាក់ឈ្មោះ

dénommer *v.t.* កំណត់នាម, ហៅឈ្មោះ, ដាក់ឈ្មោះ (ឧ. dénommer une personne dans un acte)

dénoncer *v.t.* ប្ដឹងបរិហារ (ឧ. dénoncer un criminel) ។ រំលាយ (លែងប្រតិបត្តិតាម) ។ dénoncer un contrat រំលាយកិច្ចសន្យា ។ dénoncer un traité រំលាយសន្ធិសញ្ញា ។ *Fig.* ឲ្យដំណឹង, ឲ្យការណ៍ (ឧ. tout dénonçait en lui une bonne culture)

dénonciateur,trice *a.* ដែលប្ដឹង, ដែលបរិហារ (ឧ. lettre dénonci-

atrice) ។ *n.* អ្នកប្ដឹង, អ្នកបរិហារ

dénonciation *n.f.* ការប្ដឹង,ការបរិហារ (ឧ. la loi punit la dénonciation calomnieuse)។ *Dr.* ការឱ្យដំណឹងតាមផ្លូវច្បាប់ (ឧ. dénonciation de saisie);អប្បដិបត្តិកម្ម (ការមិនប្រតិបត្តិតាម), ការរំលាយ (ឧ. dénonciation d'un contrat ការរំលាយកិច្ចសន្យា; dénonciation d'un armistice ការរំលាយយុទ្ធសន្តិភាព)

dénoter *v.t.* ចង្អុលបង្ហាញ (ឧ. son attitude dénote un grand embarras); ដាក់សញ្ញា

dénouement *n.m.* ការស្រាយចំណង ។ *Fig.* បញ្ហាវសាន, ការដោះស្រាយ(ឧ. un heureux dénouement); ទីបញ្ចប់, សេចក្ដីបញ្ចប់(ឧ. dénouement imprévu)

dénouer *v.t.* ស្រាយចំណង; ដោះ(ឧ. dénouer les fils d'un écheveau) ។ *Fig.* ផ្ដាច់ (ឧ. dénouer une liaison); ដោះស្រាយ, បញ្ចប់ (ឧ. dénouer une intrigue) ។ dénouer la langue នាំឱ្យនិយាយ, នាំឱ្យរួសរាយ

dénoyage *n.m.* ការពង្រីងទឹកពីអណ្ដូងរ៉ែ

dénoyauter *v.t.* យកគ្រាប់ចេញ

dénoyer *v.t.* ពង្រីងទឹកពីអណ្ដូងរ៉ែ

denrée *n.f.* គ្រឿងឧបភោគបរិភោគ (ឧ. denrées alimentaires, coloniales) ។ *Fig.* une denrée rare របស់កម្រ

dense *a.* ខាប់,ក្រាស់ (ឧ.brouillard dense), ឃន [ឃៈ - នៈ], ដែលមានទម្ងន់(ឧ. l'irradium est le plus dense des métaux) ។ *Fig.* ខ្លីហើយច្បាស់ (ឧ. style dense); ណែនណាន់ (ឧ. foule dense)

densimètre *n.m.* ឃនមាត្រ (ប្រដាប់រកឃនភាពនៃវត្ថុរាវ)

densimétrie *n.f.* ឃនមាត្រវិធី

densimétrique *a.* នៃឃនមាត្រវិធី

densité (d.) *n.f.* *Sys. mét.* ឃនភាព (ឧ. la densité du fer est de 7,8); ភាពហាប់ឬខាប់ ។ densité de courant électrique កម្លាំងអគ្គិសនី ។ densité de la population សន្ទភាពប្រជាជន (ចំនួនប្រជាជនក្នុងមួយគីឡូម៉ែត្រការ៉េ)

dent *n.f.* ធ្មេញ ។ (រ.ស.) ព្រះទន្ត។ ទន្ត, ភ្លុក (ឧ. dent d'éléphant) ។

dent incisive ឬ cunéiforme ម.ព. incisif ។ dent canine ចង្កូម។dent molaire ថ្គាម។dent de lait ធ្មេញព្រៃ(ធ្មេញដំបូងនៃក្មេង)។ dent de sagesse ថ្គាមទាល់(ដុះក្នុងវ័យពី ២០ ទៅ៣០ ឆ្នាំ) ។ dent de l'œil ចង្កូមលើ។ *Par an.* អ្វីៗដែលមានសណ្ឋានស្រដៀងនឹងធ្មេញ (ឧ. dent de scie ធ្មេញរណារ; dent de peigne ធ្មេញក្រាស) ។

Loc. div. faire ses dents ដុះធ្មេញ (ក្មេងកំពុងដុះធ្មេញដំបូង)។ prendre le mors aux dents កញ្ជ្រោល (សេះ); *au fig.* ខឹង, លែងនៅព្រងើយកន្តើយ។ grincer des dents សង្កៀតធ្មេញ; ធ្វើឲ្យដឹងថាខឹងខ្លាំង។ mal de dents ស្មេហាខ្លាំង ។ arracheur de dents អ្នកដើរដកធ្មេញតាមផ្លូវសាធារណៈ។ mentir comme un arracheur de dents កុហកផ្លៀលព្រសាំង, កុហកឥតអៀនខ្មាស ។ vieille sans dents យាយចាស់គ្មានធ្មេញ, ស្ត្រីចាស់ដកខ្លាំង ។ n'avoir plus mal aux dents ស្លាប់ ។ *Pop.* avoir de la dent មានរូបរាងល្អ (ពាក្យប្រើនៅក្រុងប៉ារីស) ។ manger de toutes ses dents ស៊ីទូញមាត់ (ស៊ីដោយឃ្លានខ្លាំង)។ manger du bout des dents ស៊ីចុងមាត់ពុងក (ម.ព. bout ផង)។ rire du bout des dents ប្រឹងសើច, សើចដោយបង្ខំ ។ mordre à belles dents ស៊ីដោយរីករាយ។ déchirer à belles dents និយាយបង្កាច់គេខ្លាំង ។ ne pas perdre un coup de dent ស៊ីឥតងាកឥតបង្អង់; *au fig.* មិនជារម្ភ,មិនកើតទុក្ខ ។ avoir les dents longues ឃ្លាន ។ avoir le temps d'avoir les dents longues ត្រូវបង្អត់អាហារយូរ ។ n'avoir pas de quoi mettre sous la dent គ្មានអ្វីបរិភោគ ។ n'en tâter, n'en casser ឬ n'en croquer que d'une dent មិនបានរបស់ដែលប្រាថ្នា ។ parler entre les dents និយាយមិនបើកមាត់ (និយាយងំៗ) ។ ne pas desserrer les dents មិនហើបមាត់(មិននិយាយមួយម៉ាត់សោះ)។ montrer les dents សើចឬគម្រាម

(ដោយបញ្ចេញធ្មេញ) ។ montrer les dents à quelqu'un មិនព្រមតាម, សំដែងកិរិយាមិនញញើត ។ montrer les grosses dents ស្ដីបន្ទោសខ្លាំង ។ avoir, conserver ឬ garder une dent contre quelqu'un ខឹងឬគុំនឹងអ្នកណាម្នាក់ (បើមានថែមថា une dent de lait មានន័យថា គុំនុំ ឬ កំហឹងនោះមានយូរណាស់មកហើយ) ។ donner un coup de dent à quelqu'un ពោលពាក្យមុតៗឲ្យ ។ arracher une dent à quelqu'un ដាក់ឲ្យរងការពិបាក ។ être sur les dents ហត់ខ្លាំង, អស់កម្លាំងខ្លាំង ។ mettre quelqu'un sur les dents ធ្វើឲ្យហត់, ធ្វើឲ្យអស់កម្លាំង ។ rester sur les dents នៅក្នុងស្ថានភាពពិបាក ។ avoir la mort entre les dents ជិតស្លាប់ ។ prendre la lune avec les dents គិតការហួសវិស័យដែលធ្វើបាន ។ être armé jusqu'aux dents មានអាវុធការពារខ្លួនមាំមួន ។ être savant jusqu'aux dents ប្រាជ្ញណាស់ ។ malgré les dents de ថ្វីបើ ។ quand les poules auront des dents កាលណាសេះដុះស្នែង (កាលដែលមិនអាចកើតមានឡើងបាន) ។

Bol. ស្លឹកតូចស្រួចៗ (ឧ. les dents du calice) ។ *Dentell.* ចុងជរ (មូលឬស្រួច) ។ *Géogr.* ជុំស្រួចនៃភ្នំ ។ *Manèg.* le cheval est sur les dents សេះខាំបង្ហៀរ (ដោយហត់ខ្លាំង) ។ *Méc.* ធ្មេញស្ពឺ ។ *Pathol.* rage de dents ការឈឺធ្មេញ (ដោយដង្កូវស៊ី)

dentaire *a.* ទន្តិក, នៃធ្មេញ (ឧ. nerf dentaire) ។ chirurgie dentaire ម.ព. chirurgie

dental,e,aux *a.* & *n.f.* *Gram.* ទន្តជៈ (ចំពោះព្យញ្ជនៈដែលមានសម្លេងកើតត្រង់ប្រទល់ធ្មេញ)

denté, e *a.* ដែលមានសណ្ឋានជាធ្មេញ (ឧ. feuille dentée); ដែលមានធ្មេញ (ឧ. roue dentée)

dentée *n.f.* ការខាំ (ចំពោះឆ្កែក្ដែលខាំសត្វព្រៃ)

dentelaire *n.f.* រុក្ខជាតិមួយយ៉ាងឫសប្រើការជាថ្នាំឈឺធ្មេញ

dentelé,e *a.* ដែកធ្មេញរណារ (ឧ. les

feuilles du ricin sont dentelées)

denteler *v.t.* កាត់ឬលាក់ជាកាងធ្មេញ

dentelle *n.f.* ដរ; អ្វីៗរាងដូចដរ (ឧ. dentelle de papier)

dentellerie *n.f.* ការធ្វើគ្រឿងដរ; ជំនួញគ្រឿងដរ

dentellier,ère *a.* នៃដរ ។ *n.* អ្នកធ្វើដរ (ដាងជាក់)

dentellure *n.f.* ក្បាច់ធ្មេញរណារ; ការលាក់ជាកាងធ្មេញ។ *Bot.* បន្ទាស្លឹកឈើ (ពកស្រួចៗជុំវិញស្លឹកឈើ)

denter *v.t.* ដាក់ធ្មេញ (ធ្វើឲ្យមានធ្មេញ)

denticule *n.m.* ធ្មេញល្អិត ។ *n.m. pl.* ក្បាច់ធ្មេញរណារ

denticulé,e *a.* ដែលមានធ្មេញល្អិត

dentier *n.m.* ក្រាសធ្មេញ; ក្រាសធ្មេញដាក់ (មិនមែនធ្មេញពីកំណើត)

dentifrice *a.* សម្រាប់ដុសធ្មេញ (ឧ. pâte dentifrice) ។ *n.m.* ថ្នាំដុសធ្មេញ (ឧ. un bon dentifrice)

dentine *n.f.* សាច់ភ្លុកនៃធ្មេញ

dentiste *n.m.* ទន្តពេទ្យ [ទ័ន - តៈ-] (ពេទ្យព្យាបាលរោគធ្មេញ)

dentition *n.f.* ទន្តុប្បាទ, ដំណើរដុះនៃធ្មេញ; ធ្មេញទាំងអស់

denture *n.f.* ក្រាសធ្មេញ, ធ្មេញទាំងអស់ (ក្នុងមាត់) (ឧ. une belle denture) ។ *Méc.* ធ្មេញស្ពឺឬយកង់

dénudation *n.f.* ភាពនៅទទេ (ដូចជាធ្មេញឬឆ្អឹងរបេះសាច់អស់, ឈើរបកសំបកឬជ្រុះស្លឹកអស់, ដីនៅទទេគ្មានរុក្ខជាតិ ។ល។) (ឧ. la dénudation du sommet des montagnes)

dénuder *v.t.* បកអ្វីដែលគ្របដណ្ដប់ចេញ (ឧ. បកសំបកឈើ, ពន្លះសាច់ចេញពីឆ្អឹង; បកកៅស៊ូដែលរុំខ្សែអគ្គិសនីចេញ; សម្រាត ។ល។) ។ crâne dénudé ក្បាលត្រងោល

dénué,e *a.* ដែលគ្មាន, ដែលខ្វះ

dénuement *n.m.* ការខ្វះរបស់ចាំបាច់គ្រប់ប្រភេទ (ឧ. être dans un dénuement complet)

dénuer *v.t.* បង្អត់. ផ្ដាច់របស់ចាំបាច់គ្រប់ប្រភេទ ។ se dénuer *v.pr.* លះបង់រលីងពីខ្លួន

dénutrition *n.f.* វិបោសនា (ភាពអ្នកទទួលជាតិអាហារ ជ្រួតជ្រាបតិចជាងជាតិអាហារដែលបញ្ចេញចោល)

déodoriser *v.t.* ម.ព. désodoriser

déontologie *n.f.* ករណីយកិច្ចសាស្ត្រ (វិទ្យាសាស្ត្រខាងការដែលត្រូវធ្វើ)

déontologique *a.* នៃករណីយកិច្ចសាស្ត្រ

dépaillage *n.m.* ការយកចំបើងចេញ; ភាពអស់ចំបើង (ទ្រនាប់កៅអី)

dépailler *v.t.* យកចំបើងចេញ (ឧ. dépailler un siège)

dépaissance *n.f.* ការឲ្យសត្វស៊ីក្នុងព្រៃ (ជាបទល្មើស)

dépannage *n.m.* ការកែស្ពុនម៉ាស៊ីន

dépanner *v.t.* កែស្ពុនម៉ាស៊ីន (ឧ. dépanner une automobile)

dépanneur *a.* & *n.m.* ជាងកែស្ពុនម៉ាស៊ីន ។ *n.f.* រថយន្តកែស្ពុន

dépaquetage *n,m.* ការបើកកញ្ចប់

dépaqueter *v.t.* បើកកញ្ចប់

dépareillé,e *a.* មិនគ្រប់(ឧ. service dépareillé; tome dépareillé)

dépareiller *v.t.* រំលៀករបស់ដូចគ្នាចេញ (លែងជាក់ជិតគ្នា) (ឧ. dépareiller un service à café)

déparer *v.t.* បង្ខូចលំអ (ឧ. un seul tableau médiocre dépare une collection); យកគ្រឿងលំអចេញ (ឧ. déparer un autel)

déparier ឬ **désapparier** *v.t.* បំបែកគូ (ឧ. déparier des gants; déparier des amants)

déparler *v.i.Fam.* ឈប់និយាយ(ប្រើតែក្នុងប្រយោគបដិសេធដូចជា il ne déparle pas); និយាយខុស (ឧ. souvent une pointe de vin fait déparler ជួនកាលស្រាមួយដបធ្វើឲ្យនិយាយខុសបាន)

déparquer *v.t.* បញ្ចេញពីក្រោល (ឧ. déparquer des bœufs)

départ *n.m.* ការចេញដំណើរ (ឧ. le départ des volontaires de 1792 se fait au chant de la Marseillaise)។ être sur le départ ហៀបនឹងចេញដំណើរ ។ point de départ ទីឬកន្លែងចេញដំណើរ (ឧ. point de départ d'un train) ។ *Fig.* ពេលផ្ដើម

départ *n.m.* ការញែកពីគ្នា (ឧ. faire le départ du bien et du mal)

départager *v.t.* អាកាត់ (ឲ្យឈ្នះឬឲ្យចាញ់) (ឧ. arbitre qui départage les suffrages)

département *n.m.* ខេត្ត; ក្រសួង ។ département de l'Intérieur ក្រសួងមហាផ្ទៃ

départemental,e,aux *a.* នៃខេត្ត

(ឧ. route départementale)

départementaliser *v.t.* បែកជាខេត្ត

départir *v.t.* បំបែក (ឧ. départir les votes); ចែក (ឧ. il départ son bien entre ses enfants)។ se départir *v.pr.* លះបង់ (ឧ. il ne se départit pas de son calme)

départiteur *n.m.&a.* អ្នកចែក (ឧ. juge départiteur)

dépassant *n.m.* ជាយ, រំយោល (ដែលលូតចេញ)(ឧ.un dépassant de satin)

dépassement *n.m.* ការលើស (ឧ. dépassement de crédit)

dépasser *v.t.* ទៅហួស(ឧ.dépasser le but); ទៅមុន; រូត (លឿនជាង) (ឧ. dépasser quelqu'un à la course); ឡើងហួស(ឡើងខ្ពស់ជាង) (ឧ. cet arbre dépasse tous les autres); លយចេញ (ឧ.cette maison dépasse les autres)។ *Fig.* ហួស (ឧ. ce travail dépasse mes forces)។ ឈ្នះ, ពូកែជាង (ឧ. dépasser ses camarades)។ *Fam.* ធ្វើឲ្យទាល់គំនិត,ធ្វើឲ្យឆ្ងល់ (ឧ. cette nouvelle me dépasse)។ se dépasser *v.pr.* ឈ្នះគ្នាទៅវិញទៅមក (ឧ. les coureurs s'efforcent de **se** dépasser)

dépasser *v.t.* ដកឲ្យលយ,ដកឲ្យហួស (ឲ្យសល់ហាមឬក្លុង) (ឧ. dépasser un ruban)

dépavage *n.m.* ការគាស់ថ្ម ឬ ឥដ្ឋក្រាលចេញ

dépaver *v.t.* គាស់ថ្ម ឬ ឥដ្ឋក្រាល (ឧ. dépaver une rue)

dépaysé,e *a.* ដែលផ្លាស់ស្រុកទេស;ដែលឲ្យទាល់គំនិត ទាល់ប្រាជ្ញា ឬឲ្យវង្វេង (ឧ. vous avez l'air tout dépaysé)

dépaysement *n.m.* ទេសនិរាស (ការឃ្លាតស្រុក);ការនាំឲ្យផ្លាស់ស្រុកទេសឬផ្លាស់កន្លែង

dépayser *v.t.* ធ្វើឲ្យផ្លាស់ស្រុកទេស ឬ ផ្លាស់កន្លែង (ឧ. dépayser un soldat)។ *Fig.* ធ្វើឲ្យទាល់គំនិតទាល់ប្រាជ្ញា ឬ ឲ្យវង្វេង

dépècementឬ**dépeçage** *n.m.* ការកាត់ជាដុំ(ឧ. dépècement d'une volaille)

dépecer *v.t.* កាត់ជាដុំ (ឧ. dépecer

un poulet)

dépeceur *n.m.* អ្នកកាត់ជាដុំ

dépêche *n.f.* លិខិតផ្លូវការ (ឧ. dépêche diplomatique); ប្រកាស, សេចក្ដីផ្សាយដំណឹង (ឧ. dépêche télégraphique) ។ *Par ext.* លិខិតទូរលេខ

dépêcher *v.t.* ធ្វើដោយរួសរាន់ (ឧ. dépêcher un travail); ចាត់ឲ្យទៅដោយរៀសរវៃ (ឧ. dépêcher un courrier); សម្លាប់ (ឧ. dépêcher un rival) ។ dépêchons! ម្ដីម្នាឡើង! ។ *loc.adv.* à dépêche compagnon ដោយប្រញាប់ប្រញាល់នឹងដោយធ្វេសប្រហែស (ឧ. travail fait à dépêche compagnon) ។ se dépêcher *v.pr.* ប្រញាប់ប្រញាល់

dépeigner *v.t.* រំសាយសក់ឲ្យ (ធ្វើសក់ឲ្យរាត់រាយ)

dépeindre *v.t.* ពិពណ៌នាយ៉ាងច្បាស់ (ឧ. dépeindre un personnage, un caractère) ; ពិពណ៌នា (ឧ. Corneille a dépeint les hommes tels qu'ils devraient être, et Racine tels qu'ils sont)

dépenaillé,e *a.* រយ៉ីរយ៉ៃ (ឧ. un vêtement dépenaillé); ដែលស្លៀកពាក់រយ៉ីរយ៉ៃ

dépendage *n.m.* ការដោះរបស់ព្យួរ

dépendance *n.f.* អនិស្សរភាព, ការនៅក្នុងចំណុះ (ឧ. être dans la dépendance de quelqu'un) ។ *Pl.* វត្ថុដែលរួមបញ្ចូលជាមួយ (ឧ. les dépendances d'un domaine, d'une maison)

dépendance ឬ **dépendence** *n.f.* ប្រទេសភក្ស, ស្រុកចំណុះ

dépendant,e *a.* ដែលជាអនិស្សរភាព, ដែលនៅក្នុងចំណុះ (ឧ. être dépendant de quelqu'un); ដែលរួមបញ្ចូលជាមួយ

dépendre *v.t.* ដោះរបស់ព្យួរ (ឧ. dépendre une enseigne) ។ dépendre *v.i.* នៅក្នុងអនិស្សរភាព, នៅក្នុងចំណុះ (ឧ. l'homme ambitieux dépend de tout le monde); ជាភាគនៃ (ឧ. ce bâtiment dépend de la Banque Nationale); នៅក្នុងអំណាច (ឧ. la direction des Douanes

dépend du Ministère des Finances) ។ *Fig.* ជាផលនៃ, សម្រេចនៅត្រង់(ឧ. l'effet dépend de la cause; notre bonheur dépend de notre conduite)

dépens *n.m.pl.* ប្រដាប់, សោហ៊ុយក្ដី (ឧ. les dépens sont payés par la partie qui succombe); បំណាយ(ឧ. payer les dépens)។

Loc.pré. aux dépens de ក្នុងបន្ទុកនៃ, ដោយសារ (ឧ. tout flatteur vit aux dépens de celui qui l'écoute) ។ *Fig.* ដោយខូចប្រយោជន៍ដល់, ដោយនាំឲ្យអន្តរាយដល់ (ឧ. s'enrichir aux dépens d'autrui; s'amuser aux dépens de sa santé) ។ *Par ext.* ដោយស្ងាត់កំបាំង (ឧ. s'amuser aux dépens des absents) ។ rire aux dépens de quelqu'un សើចចំអកឲ្យ ។ à ses dépens, à ses propres dépens ឬ à ses frais et dépens ព្រោះធ្លាប់ប្រទះការលំបាករួចហើយ (ឧ. devenir sage à ses propres dépens) ។ *Fam.* faire la guerre à ses dépens ចាយឥតបានផល

dépense *n.f.* បំណាយ (ឧ. celui-là est pauvre, dont la dépense excède la récette); កន្លែងទុកស្បៀង;ចំនួនវត្ថុបំណាយក្នុងមួយពេល។ *Fig.* បំណាយ (ការប្រើប្រាស់) (ឧ. dépense de temps, d'esprit)។ បំណាយ(គណនី) (ឧ. porter en dépense) ។ *loc.* faire la dépense កាន់មុខបំណាយ។ faire de la dépense ចាយច្រើន ។ forcer la dépense ឬ les dépenses ពន្លើសបំណាយ ។ se mettre en dépense ចាយតាមធម្មតា ។ *Fin.* les dépenses engagées បំណាយវិលញ្ជិត

dépenser *v.t.* ចាយ។ *Fig.* ប្រើប្រាស់ (ឧ. dépenser ses forces) ។ se dépenser *v.pr.* ខំខ្នះខ្នែង

dépensier,ère *a.&n.* ដែលចូលចិត្តចាយ (ឧ. jeune homme dépensier); អ្នកកាន់ខាងមុខបំណាយ (ឧ. sœur dépensière ឬ la dépensière)

déperdition *n.f.* ការបាត់, ការថយ

(ឧ. déperdition de force)។ *Fig.* ការចុះទន់ខ្សោយ (ឧ. déperdition de volonté)

dépérir *v.i.* ចុះទន់ខ្សោយ(ឧ.sa santé dépérit)។ *Fig.* ចុះដុនដាប (ឧ. cette entreprise dépérit)

dépérissement *n.m.* ភាពចុះទន់ខ្សោយ, ភាពចុះដុនដាប

dépersonnalisation *n.f.* និបុគ្គលការ (កេតវិកលនៃសបណ្ដាលឲ្យអ្នកជម្ងឺមិនស្គាល់ខ្លួនឯង)

dépersonnaliser *v.t.* ធ្វើឲ្យបាត់បុគ្គលិកលក្ខណៈ

dépêtrer *v.t.* ដោះជើង(ដែលជាប់ភក់)។ *Fig.* ជួយដោះទុក្ខ (ឧ. dépêtrer quelqu'un d'une mauvaise affaire)។ se dépêtrer *v.pr.* រើខ្លួន, ដោះកុនខ្លួនឯង (ឧ. se dépêtrer d'un procès)

dépeuplement *n.m.* និប្រជាភិវឌ្ឍន៍, ការធ្វើឲ្យពាយប្រជាជន, ភាពគ្មានប្រជាជន (ឧ. le dépeuplement des campagnes)

dépeupler *v.t.* ធ្វើនិប្រជាភិវឌ្ឍន៍, ធ្វើឲ្យពាយប្រជាជន (ឧ. la guerre a dépeuplé ce pays)។ *Par ext.* dépeupler un étang ឬ une forêt ធ្វើឲ្យពាយត្រីពីបឹង ឬ ឲ្យពាយសត្វពីព្រៃ

déphosphoration *n.f.* ការយកហ្វូស្វ័រចេញ

déphosphorer *v.t.* យកហ្វូស្វ័រចេញ

dépiauter *v.t.* បកស្បែក, បកសំបក

dépiécer *v.t.* ម.ព. dépecer

dépilage *n.m.* ការជម្រុះរោមពីស្បែក (ដើម្បីសម្លាប់)

dépilation *n.f.* ការជម្រុះរោម ឬ សក់

dépilatoire *a.* សម្រាប់ជម្រុះរោមឬសក់ (ឧ. pâte dépilatoire)។ *n.m.* ថ្នាំជម្រុះរោម ឬ សក់

dépilement *n.m.* ការរើសសរក្នុងរណ្ដៅរ៉ែ (ហៅ dépilage ក៏បាន)

dépiler *v.t.* ជម្រុះរោមឬសក់ (ឧ. dépiler une peau) (បើថា épiler ត្រូវជាង)

dépiler *v.t.* *Min.* រើសសរក្នុងរណ្ដៅរ៉ែ

dépiquage ឬ **dépicage** *n.m.* ការដក (ព.ផ. repiquage ការស្ទូង); ការបោក ឬ បែនស្រូវ (មើល. battage)

dépiquer *v.t.* រុះថ្នេរ

dépiquer *v.t.* ដក (ដកកូនឈើយកទៅដាំកន្លែងផ្សេង); បោកឬបែន (មើល.

battre)

dépistage *n.m.* ការតាមដាន ។-*Spécial.* ការរកភេគខ្ទះ(ដើម្បីបំបាត់ចេញ) (ឧ. centre de dépistage antituberculeux)

dépister *v.t. Chass.* តាមដាន (ការបរបាញ់)(ឧ. dépister un lièvre)។ *Par ext.* រកឃើញដាន (ឧ. dépister un voleur); បង្វែងដាន (ឧ. dépister la recherche de la police) ។ *Fig.* រកឃើញ (ឧ. dépister une maladie)

dépit *n.m.* សេចក្ដីតូចចិត្ត (ឧ. avoir ឬ concevoir du dépit) ។ en depit de *loc. pré.* ថ្វីបើ (ឧ. faire quelque chose en dépit de quelqu'un)។ en dépit du bon sens អាក្រក់ណាស់

dépiter *v.t.* ធ្វើឲ្យតូចចិត្ត ។ se dépiter *v.pr.* តូចចិត្ត

déplacé,e *a.* ខុសកន្លែង ។ *Fig.* ឆ្គង, ឈ្លើយ (ឧ. propos déplacés)

déplacement *n.m.* ការយកចេញពីកន្លែងឬផ្លាស់កន្លែង; ការផ្លាស់ប្ដូរ(ក្រសួងការងារ) ។ frais de déplacement ម.ព. frais ។ déplacement d'un navire ទំហំទឹកដែលត្រូវនាវាកាសចេញ

déplacer *v.t.* ផ្លាស់កន្លែង; ផ្លាស់ក្រសួងការងារ ។ *Fig.* បំបែរ (ឧ. déplacer la question) ។ *Mar.* មានទំហំទឹកកាសចេញចំនួន...(ឧ. ce navire déplace 500 tonnaux) ។ se déplacer *v.pr.* ផ្លាស់កន្លែង

déplaire *v.t.* ធ្វើឲ្យទាស់ចិត្ត,ធ្វើឲ្យខឹង។ *Imp.* il me déplait de ខ្ញុំមិនចូលចិត្តនឹង ។ ne vous en déplaise សូមកុំតូចចិត្ត (ទោះបីលោកយល់យ៉ាងណាក៏ដោយ) ។ se déplaire *v.pr.* មិនសប្បាយចិត្ត, នៅមិនស្រួល (ឧ. il s'est déplu à la campagne)

déplaisant,e *a.* មិនគួរឲ្យចូលចិត្ត (ឧ. manière déplaisante)

déplaisir *n.m.* ការមិនសប្បាយចិត្ត (ឧ. éprouver un déplaisir)

de plano (aisément, sans difficulté) *loc. lat.* ដោយងាយ ។ *Dr.* ដោយអំណាច (ដោយឥតមានការអង្កេតឬឥតទម្រង់ការច្រើន) (ឧ. divorce prononcé de plano)

déplantage *n.m.* ឬ **déplantation** *n.f.* ការគាស់យកទៅដាំកន្លែងដទៃ

déplanter *v.t.* គាស់យកទៅដាំកន្លែងដទៃ

déplantoir *n.m.* ប្រដាប់គាស់កូនឈើយកទៅដាំ

déplâtrage *n.m.* ការយកម្នាងសិលាចេញ

déplâtrer *v.t.* យកម្នាងសិលាចេញ

dépliage ឬ **dépliement** *n.m.* ការលាផ្នត់

dépliant *n.m.* លិខិតឬផែនទីផ្នត់

déplier *v.t.* លាផ្នត់ (ឧ. déplier les étoffes)

déplissages *n.m.* ការបំបាត់ផ្នត់

déplisser *v.t.* បំបាត់ផ្នត់

déploiement *n.m.* ការលាត្រដាង; ភាពលាត្រដាង; ការសម្តែង, ការបញ្ចេញ (ឧ. un grand déploiement de forces)។ déploiement de troupes ការលាតទ័ពឲ្យគេស្ញែង

déplombage *n.m.* ការគាស់សំណ

déplomber *v.t.* គាស់សំណ (សំណដែលព្រួបគយផ្សារ ឬ សំណស្ទង់ធ្មេញជាដើម) (ឧ. déplomber un compteur)

déplorable *a.* គួរអាណិត (ឧ. situation déplorable); អាក្រក់, ចង្រៃ (ឧ. déplorable contretemps)។ *Fam.* អាក្រក់ណាស់ (ឧ. élève déplorable)

déplorablement *adv.* ដោយគួរអាណិត

déplorer *v.t.* អាណិតអាសូរ, ស្តាយ (ឧ. déplorer la mort d'un ami)។ *Fam.* déplorer un choix ស្តាយដោយរើសខុស

déployer *v.t.* លា, ត្រដាង (ឧ. déployer un mouchoir); លាតទ័ព (ឧ. déployer une troupe)។ បញ្ចេញ, សម្តែង (ឧ. déployer son luxe); សំដែង (ឧ. déployer un grand courage)។ rire à gorge déployée សើចក្អាកក្អាយ

déplumer *v.t.* បោចស្លាប។ *Fam.* ធ្វើឲ្យជ្រុះសក់ (ឧ. les excès déplument le crâne)។ se déplumer *v.pr.* *Fam.* ជ្រុះសក់

dépocher *v.t.* បញ្ចេញពីហោប៉ៅ

dépoétiser *v.t.* បំបាត់លំអជាកវីនិពន្ធ

dépointer *v.t.* លែងតម្រង់

dépointer *v.t.* កាត់ឆ្អេរចេញ

dépoitraillé,e *a.* ម.ព. débraillé

dépolir *v.t.* ធ្វើឲ្យស្រអាប់ (ឧ.le verre dépoli est translucide, mais non transparent)

dépolissage ឬ **dépolissement** *n.m.* ការធ្វើឲ្យស្រអាប់ (ឧ. le dépolissage des ampoules électriques)

dépolisseur,euse *n.f.* អ្នកធ្វើឲ្យស្រអាប់

dépolitiser *v.t.* បំបាត់លក្ខណៈនយោបាយ (ឧ. dépolitiser un syndicat)

dépopulation *n.f.* និប្រជាករណ៍, ការធ្វើឲ្យប្រជាពលរដ្ឋថយចុះ, ភាពគ្មានមហាជន (ឧ. dépopulation rurale)

déport *n.m.* លិខិតប្រកាសអសមត្ថកិច្ច (ឧ. déport d'un juge) ។ sans déport ភ្លាមៗ, គ្មានបង្អង់

déportation *n.f.* និរទេស, ការបំបរបង់ (ដោយហេតុនយោបាយ)

déporté,e *a.* ជនត្រូវនិរទេស

déportement *n.m.* ការងាកចេញ ។ *pl.* មារយាទអាក្រក់

déporter *v.t.* និរទេស; ធ្វើឲ្យងាកចេញពីផ្លូវ (រថយន្ត, យន្តហោះ)

déposant,e *a.&n.* ដែលឆ្លើយឲ្យការណ៍ (ឧ. témoins déposants); ដែលផ្ញើប្រាក់ទុក (ព.ផ. dépositaire)

dépose *n.f.* ការយកចេញវិញ (ឧ. la dépose d'une serrure)

déposer *v.t.* ដាក់ចុះ (ឧ. déposer un fardeau) ។ *Fig.* លះបង់ (បំបាត់) (ឧ. déposer sa fierté, sa mauvaise humeur); យកចេញ (ឧ. déposer un tapis, un tableau) ។ déposer le masque បើកមុខ (លែងលាក់ពុត)។ déposer le pouvoir ដាក់អំណាច (លែងកាន់អំណាច) ។ déposer la charge ដាក់បន្ទុក (លែងទទួលបន្ទុក)។ déposer les armes ដាក់អាវុធ (សុំចុះចាញ់) ។

Fig. ធ្វើឲ្យដាក់; ទម្លាក់ (ឧ. déposer un roi, un ministre); យកទៅដាក់ (ឧ. déposer un paquet chez son ami)។ déposer une plainte ដាក់ពាក្យប្ដឹង ។ ផ្ញើទុក (ឧ. déposer des fonds chez un banquier)។ *Fig.* déposer le pouvoir

entre les mains de quelqu'un ប្រគល់អំណាចឲ្យអ្នកណាមួយ ។ déposer son cœur និយាយប្រាប់គំនិតខ្លួនទាំងអស់ ។ ដាក់របស់ធានា (ឧ. déposer un cautionnement)។ ទម្លាក់កករ (ឧ. ce vin dépose beaucoup de lie) ។ déposer son bilan ប្រកាសធនក្ស័យខ្លួនឯង ។

v.i. ឆ្លើយឲ្យការណ៍ (ឧ. déposer un fait); ជាភ័ស្តុតាង (ឧ. son silence dépose contre lui); ដុះ (បត់ជើងធំ-តូច) ។

se déposer *v.pr.* ធ្លាក់ចុះទៅក្រោម (ឧ. le limon se dépose) ។ *Fig.* ត្រូវដោះបង់ចោល (ឧ. il est des fonctions qui ne se déposent pas)

déposeur *a.&n.* អ្នកទម្លាក់ (ឧ. les papes, déposeurs de rois)

dépositaire *n.* អ្នកទទួលរក្សាទុក (ព.ផ. déposant)

déposition *n.f.* ការទម្លាក់ (សក្តិយស) (ឧ. déposition d'un roi); ចម្លើយកសិណ; ការឆ្លើយឲ្យការណ៍

déposséder *v.t.* ដកហូតរបស់ទ្រព្យ; (វត្ថុដែលមាន) (ឧ. l'Etat peut déposséder un propriétaire pour cause d'utilité publique)

dépossession *n.f.* ការដកហូតទ្រព្យ; ភាពអ្នកដែលគេដកហូតទ្រព្យ

dépôt *n.m.* ការដាក់ (ឧ. le dépôt d'un corps dans un caveau); ការផ្ញើទុក (ឧ. le dépôt d'une somme chez un banquier); របស់ផ្ញើទុក(ឧ. s'approprier d'un dépôt); កន្លែងផ្ញើទុក (ឧ. le dépôt de parapluies est établi à l'entrée d'un théâtre); កករ ។ *Dr.* កិច្ចសន្យាផ្ញើទុក ។ mandat de dépôt ដីកាឃុំឃាំង ។ កន្លែងឃុំឃាំង។ dépôt de garantie ប្រាក់ធានា។ dépôt de fonds ការផ្ញើទុកមូលនិធិ ។ *Com.* និក្ខេបភណ្ឌ; ឃ្លាំងទុក ។ dépôt en douane និក្ខេបភណ្ឌគយ។ dépôt à préavis និក្ខេបភណ្ឌត្រូវប្រាប់មុន។ dépôt à terme និក្ខេបភណ្ឌក្នុងកាលកំណត់។ dépôt à vue និក្ខេបភណ្ឌទិដ្ឋ (និក្ខេបភណ្ឌដែលសាមីខ្លួនអាចដកយកវិញបាននៅគ្រប់ពេល)។

Mil. ក្រុមទាហានត្រៀមចាំ (មិនទាន់ទៅច្បាំង);កន្លែងក្រុមទាហានទៅត្រៀមចាំ ។ *Méd.* បូស ។ *Pl.* សំណាត់

dépotage ឬ **dépotement** *n.m.* ការយកចេញពីថូ (ឧ. le dépotage d'une fleur)

dépoter *v.t.* យកចេញពីថូ(ផ្កា ឬ ឈើ); ផ្លាស់ទីកថូ ឬ ផើង (ព.ផ. empoter)

dépotoir *n.m.* រោងចក្រចនាសំរាម (យកសំរាមមកធ្វើជាវត្ថុផ្សេងៗមានជីជាដើម);កន្លែងចាក់សំរាម

dépoudrer *v.t.* ចោសម្សៅ ឬ ធូលីចេញ

dépouille *n.f.* សំណក(ហៅ mue ក៏បាន);ស្បែកពន្លះពីសត្វ(ឧ.dépouille d'un tigre); ការបេះ ឬ ច្រូតកាត់; ទ្រព្យមនុស្សស្លាប់។dépouille mortelle សាកសព ។ *Pl.* វត្ថុយកពីសត្រូវ

dépouillement *n.m.* ការពន្លះស្បែក; ការបក; ការសម្រាត; ការពិនិត្យបញ្ជី។ dépouillement du scrutin ការរើសន្លឹកឆ្នោត

dépouiller *v.t.* ពន្លះស្បែក(ឧ.dépouiller un bœuf);បកសំបកឬលះមែក (ឧ. dépouiller un arbre de son écorce, de ses branches); សម្រាត (ឧ. dépouiller ses vêtements); ពិនិត្យបញ្ជី; រើសន្លឹកឆ្នោត។ *Fig.* ដកហូត (ឧ. dépouiller quelqu'un de ses droits) ។ dépouiller toute honte កាត់អៀនខ្មាស (បំភ្លេចសេចក្ដីអៀនខ្មាស) ។ se dépouiller *v pr.* រង (ចំពោះតែស្លឹក); សក (សត្វ)

dépourvoir *v.t.* ផ្ដាច់វត្ថុចាំបាច់

dépourvu,e *a.* ខ្វះ, គ្មាន (ឧ.dépourvu d'esprit)។ au dépourvu *loc. adv.* ដោយមិនដឹងខ្លួន

dépoussiérage *n.m.* ការចោសធូលី

dépoussiérer *v.t.* ចោសធូលី

dépoussiéreur *n.m.* ប្រដាប់ចោសធូលី

dépravation *n.f.* ការខូច (ឧ.dépravation du sang)។ *Fig.* ទុរាចារ, ការប្រព្រឹត្តខិលខូច (ឧ. dépravation des mœurs)

dépravé,e *a.* ខូច (ឧ. goût dépravé); ទុរាចារ, គ្មានគុណធម៌, ខូច (ឧ. esprit dépravé) ។ *n.m.* មនុស្សខូច

dépraver *v.t.* ធ្វើឲ្យខូច (ឧ. dépraver l'estomac) ។ *Fig.* ប្រព្រឹត្តទុរាចារ, នាំខូច

déprécatif,ive *a.* ដាប់ណាន់(ឧ. formule déprécative)

déprécation *n.f.* *Rhét.* បំណន់

déprécatoire *a.* ដែលមានលំនាំដាប់ណាន់(ឧ.formule déprécatoire)

dépréciateur,trice *n.* អ្នកបន្ថោក ឬ បញ្ចុះថ្លៃ

dépréciatif,ive *a.* ដែលបន្ថោក, ដែលបញ្ចុះតម្លៃ (ឧ. sens dépréciatif)

dépréciation *n.f.* និម្មូលវិហារណ៍, ការភយបន្ថោក; ការចុះថ្លៃ (ឧ. dépréciation de l'argent)

déprécier *v.t.* បន្ថោក, បញ្ចុះថ្លៃ (ឧ. l'abondance du papier-monnaie en déprécie la valeur)។ se déprécier *v.pr.* ចុះថ្លៃ

déprédateur,trice *n.* អ្នកប្លន់បំផ្លាញ; អ្នកខ្ជះខ្ជាយ ។ *a.* ដែលខ្ជះខ្ជាយ (ឧ. ministre déprédateur)

déprédation *n.f.* ការប្លន់ដោយមានបំផ្លាញ;ការលួច;ការខ្ជះខ្ជាយ(ក្នុងរាជការ) (ឧ. la déprédation des biens de l'Etat)

déprendre *v.t.* បំបែក ផ្ដាច់ ឬ រំលាយចេញពីគ្នា។ se déprendre *v pr.* បែកពីគ្នា, ដាច់ចេញពីគ្នា

dépressif,ive *a.* ដែលធ្វើឲ្យខ្សោយ ឬ ឲ្យស្រុត។ *Fig.* ដែលធ្វើឲ្យថយកម្លាំង (ឧ. fièvre dépressive)

dépression *n.f.* *Géogr.* ភូលទំនាប (ឧ. une vallée est une dépression du sol) ។ *Météor.* វិសម្ពាធ (ឧ. la dépression du mercure dans un tube) ។ dépression atmosphérique វិសម្ពាធនៃបរិយាកាស ។ *Fig.* ការថយកម្លាំង (កម្លាំងកាយនិងកម្លាំងចិត្ត) (ឧ. être dans une grande dépression) ។ dépression mentale ការធ្លាក់ទឹកចិត្ត (ព្រួយ)

déprier *v.t.* បដិសេធសេចក្ដីអញ្ជើញ (លែងអញ្ជើញ)

déprimant,e *a.* ដែលធ្វើឲ្យថយកម្លាំង

déprimé,e *a.* ដែលថយកម្លាំង (កម្លាំងកាយ ឬ កម្លាំងចិត្ត) (ឧ. ce malade est très déprimé)

déprimer *v.t.* ធ្វើឲ្យស្រុត; ធ្វើឲ្យថយកម្លាំង (ឧ. la fièvre déprime les malades; cette nouvelle l'a déprimé)។ *Fig.* បន្ថោក

dépriser *v.t.* បន្ថោក

depuis *pré.* តាំងពី(ចំពោះពេលៈឧ. depuis vingt ans តាំងពី២០ឆ្នាំមកហើយ); (ចំពោះទីកន្លែងៈ ឧ. depuis Phnom-Penh jusqu'à Takeo តាំងពីភ្នំពេញទៅដល់តាកែវ); (ចំពោះលំដាប់ ឬ ថ្នាក់ៈឧ. depuis le premier jusqu'au dernier តាំងពីទីមួយ (ឬលេខ១) ដល់ទីក្រោយបំផុត); (ចំពោះតម្លៃ : ឧ. livrés depuis un riel jusqu'à dix riels លក់តាំងពីថ្លៃ ១ រៀលទៅដល់ ១០ រៀល)។ depuis peu ក្នុងពេលថ្មីៗនេះ។ depuis quand? តាំងពីកាលណាមក?។ depuis toujours ជានិច្ចរៀងរាបមក។ depuis lors តាំងពីពេលនោះមក ។

Loc. conj. depuis que តាំងពីពេលដែល (ឧ. le monde, depuis qu'il est monde, se plaint qu'il s'ennuie) ។ *Adv.* តាំងពីពេលនេះទៅ (ឧ. "Et tu sais que depuis, à chaque occasion") ។ *loc. adv.* du depuis តាំងពីពេលនោះមក

dépulper *v.t.* បេះពួបចេញ (ផ្លែឈើ)

dépurateur *n.m.* ប្រដាប់ធ្វើឲ្យស្អាតឬឲ្យសុទ្ធ

dépuratif,ive *a.* សម្រាប់ត្រងឈាម (ឧ. sirop dépuratif) ។ *n.m.* ថ្នាំត្រងឈាម (ឧ. prendre des dépuratifs)

dépuration *n.f.* ការសំអាត, ការធ្វើឲ្យសុទ្ធ; ភាពសុទ្ធឬស្អាត (ឧ. la dépuration de sang)

dépuratoire *a.* សម្រាប់សំអាត ឬ ធ្វើឲ្យសុទ្ធ (ឧ. remède dépuratoire)

dépurer *v.t.* ធ្វើឲ្យស្អាតឬឲ្យសុទ្ធ; ធ្វើឲ្យស្អាតឬឲ្យសុទ្ធថែមទៀត

députation *n.f.* ការបញ្ជូនអ្នកតំណាង; ក្រុមអ្នកតំណាង (ឧ. recevoir une députation); មុខងារអ្នកតំណាង (ឧ. aspirer à la députation)

député *n.m.* អ្នកតំណាងរាស្ត្រ ឬ មហាឲ្យត្រ ។ chambre des députés សភាតំណាងរាស្ត្រ

députer *v.t.* បញ្ជូនតំណាង

déracinable *a.* អាចដកឫសបាន

déraciné,e *a.* ដែលរលើងឫស (ឧ.un arbre déraciné) ។ *Fig.* ដែលឃ្លាតចាកស្រុកកំណើត (ឧ. les déracinés)

déracinement *n.m.* ការដក; ការរំលើងឫស ។ *Fig.* ការកំចាត់បង់ (ឧ. déracinement d'un préjugé)

déraciner *v.t.* ដក(ឲ្យដោយទាំងឫស); រំលើងឫស ។ *Fig.* បំបាត់, កំចាត់បង់ (ឧ. déraciner une erreur)

dérader *v.i. Mar.* រសាត់ចេញពីជាង សមុទ្រ

dérager *v.i.* បាត់ឆ្កួត; បាត់ខឹង (ឧ. depuis deux jours il ne dérage pas)

déraidir ឬ **déroidir** *v.t.* ធ្វើឲ្យបាត់រឹង(ឧ.déraidir ses membres)។ *Fig.* បន្ទន់ (ឧ. déraidir le caractère)

déraillement *n.m.* ការភ្លាត់ចេញពីផ្លូវដែក (អយស្ម័យយាន)

dérailler *v.i.* ភ្លាត់ចេញពីផ្លូវដែក ។ *Fig. & Fam.* ងាកចេញពីផ្លូវល្អ, ប្រព្រឹត្តខុសគន្លងល្អ

dérailleur *n.m.* ប្រដាប់បំបែរផ្លូវដែក; ប្រដាប់ប្តូរល្បឿនទោចក្រយាន

déraison *n.f.* ការខ្វះវិចារណញ្ញាណ

déraisonnable *a.* ដែលខ្វះវិចារណញ្ញាណ(ឧ. projet déraisonnable)

déraisonnablement *adv.* ដោយខ្វះវិចារណញ្ញាណ

déraisonnement *n.m.* ការនិយាយមិនសមហេតុផល

déraisonner *v.i.* និយាយមិនសមហេតុផល

dérangement *n.m.* ការរើរុះ; ភាពត្រូវរើរុះ ឬ ខូច (ឧ. dérangement d'une machine); ការដើរមិនស្រួល (ឧ. ligne téléphonique en dérangement)

déranger *v.t.* រើរុះ; ធ្វើឲ្យខូច (ឧ. déranger une machine, la santé); ឲ្យទាស, ធ្វើឲ្យមិនស្រួលខ្លួន (ឧ. le melon dérange le corps)។ *Fig.* រំខាន,ឆាឆៅ (ឧ.je ne voudrais pas vous déranger)។ se déranger *v.pr.* ធ្វើឲ្យពិបាកខ្លួន, រំខានខ្លួនឯង (លះបង់សេចក្ដីសុខ ឬ ការងារ ដើម្បីបំពេញកិច្ចអ្វីមួយ)

dérapage ឬ **dérapement** *n.m.* ការរអិល, ការផ្ទាត

déraper *v.t.* រអិល,ផ្ទាត (យុថ្កា, កង់រថ)

dérasement *n.m.* ការបន្ទាប (ការបន្ថយកំពស់); ការថយកំពស់

déraser *v.t.* បន្ទាប (បន្ទយកំពស់) (ឧ. déraser un mur)

dératé,e *n.* អ្នករហ័សរហួន ឬ ស្រស់ស្រាយ (ឧ. c'est un dératé) ។ courir comme un dératé រត់យ៉ាងលឿន

dérater *v.t.* កាត់យកលំពែងចេញ (អាការៈក្នុងខ្លួនមានរោគខ្វិចលំពែង) (ឧ. dérater un chien)

dératisation *n.f.* ការបំផ្លាញកណ្ដុរ

dératiser *v.t.* បំផ្លាញកណ្ដុរ (ពីក្នុងផ្ទះ ឬ នាវា)

dérayer *v.t.* ភ្ជួរជ្រលងងារ (ភ្ជួរគន្លងចុងក្រោយបំផុតដើម្បីខណ្ឌងារដី)

dérayure *n.f.* ជ្រលងងារ (គន្លងខណ្ឌងារដី)

derbouka *n.f.* ស្គរអារ៉ាប់ម្យ៉ាង

dérechef *adv.* ជាថ្មីឡើងវិញ, ទៀត (ឧ. exhorter dérechef un enfant au travail)

déréglé,e *a.* មិនទៀងទាត់ (ឧ. pouls déréglé) ។ *Fig.* គ្មានសណ្ដាប់, ខុសគន្លងធម៌ (ឧ. mener une vie déréglée)

dérèglement *n.m.* ការមិនទៀងទាត់ (ឧ. le dérèglement des saisons) ។ *Fig.* ការប្រព្រឹត្តខុសគន្លងធម៌ (ឧ. le dérèglement des passions)

dérégler *v.t.* ធ្វើឲ្យលែងទៀងទាត់ (ឧ. le froid dérègle les horloges) ; ញុំាងឲ្យលែងករណីយកិច្ច

déréliction *n.f.* ដំណើរត្រមោចចិត្ត

dérelier *v.t.* រុះសៀវភៅ

dérider *v.t.* បំបាត់ជ្រួញ ។ *Fig.* ធ្វើឲ្យរីករាយ (ឧ. il est facile de la dérider) ។ se dérider *v.pr.* រីករាយ, សើច

dérision *n.f.* ការចំអកបញ្ឈឺចិត្ត (ឧ. tourner quelqu'un en dérision)

dérisoire *a.* ដែលធ្វើឬថាបញ្ឈឺចិត្ត (ឧ. proposition dérisoire) ។ *Fig.* តិចតួច (ឧ. prix dérisoire)

dérisoirement *adv.* ដោយស្ដួចស្ដើង

dérivateur *n.m.* ប្រដាប់បំបែរចរន្តអគ្គិសនី

dérivatif,ive *a.* ដែលពង្វាង, ដែលបំបែរ ។ *n.m.* កិច្ចធុរៈដែលនាំបំបែរគំនិត (ឧ. la lecture est un dérivatif)

dérivation *n.f.* ការពង្វាង; ការបំបែរ

(ឧ.dérivation d'une rivière); ការងាកពីផ្លូវប្រក្រតី ។ *Gram.* តទ្ធិតកម្ម, ការក្លាយនៃសព្ទវចនៈ

dérivation *n.f. Aéron. & Mar.* ការរសាត់ (ដោយខ្យល់ ឬខ្សែទឹក)

dérive *n.f.Mar.* ដំណើររសាត់ដោយខ្យល់ ឬខ្សែទឹក (យន្តហោះ, នាវា) (ឧ. calculer la dérive) ។ ការងាក, ការបែរ (នៃរថយន្ត) ។ *Fig.* être ឬ aller à la dérive បណ្តែតបណ្តោយ ។ entreprise qui va à la dérive សហគ្រាសដែលជាត់ការអាក់រអួល ។ ចង្កូតយន្តហោះ

dérivé,e *a.* ដែលរសាត់ (ឧ. bateau dérivé) ។ *n.m. Gram.* បទតទ្ធិត (សព្ទវចនៈដែលក្លាយមកពីវចនៈដទៃ) (ឧ.fruitier est un dérivé de fruit); និស្សន្ទវត្ថុ (វត្ថុដែលក្លាយមកពីវត្ថុដទៃ) (ឧ.un sel est un dérivé d'un acide)

dériver *v.i.Mar.* ឃ្លាតចេញពីច្រាំង; រសាត់ចេញពីផ្លូវ

dériver *v.t.* បំបែរ, ពង្វាង(ឧ. dériver un fleuve) ។ *v.i.* ងាកចេញពីផ្លូវ; ក្លាយមកពី (ឧ. corps qui dérive d'un autre); មកពី (ឧ. tous ces malheurs dérivent de la guerre) ។ *Gram.* មានដើមកំណើតពី (ឧ. mot qui dérive du grec)

dériver *v.t.* ដោះកន្លាស់មីន(ដោះកន្លាស់ស្លង់)

dériveur ឬ **driveur** *n m.Mar.* ក្ដោងប្រើក្នុងពេលមានខ្យល់ព្យុះ ; នាវាដែលរសាត់

dermatite *n.f.* ម.ព. dermite

dermatologie *n.f.* តចវិទ្យា [តៈ-ចៈ-] (វេជ្ជវិជ្ជាខាងរោគស្បែក)

dermatologique *a.* នៃតចវិទ្យា

dermatologiste *n.m.* តចវេទ្យ [តៈ-ចៈ-] (វេទ្យព្យាបាលរោគស្បែក)

dermatose *n.f. Méd.* តចរោគ (ជម្ងឺស្បែក) (ឧ. la gale est une dermatose)

derme *n.m.Anat.* តច, ស្បែកក្នុង

dermique *a.* នៃតច, នៃស្បែកក្នុង (ឧ. tissu dermique)

dermite *n.f.* រោគរលាកស្បែក (ឧ. l'érysipèle est une dermite)

dernier,ère *a.* បច្ឆិម, ចុងបំផុត, ក្រោយបំផុត (ឧ.la dernière maison); តូចបំផុត (ឧ. entrer dans les

derniers détails); អាក្រក់បំផុត (ឧ. le dernier des hommes); ជាទីបំផុត (ឧ. dernier degré de perfection); មុន (ចំពោះកាលបរិច្ឆេទ) (ឧ. l'année dernière; la nuit dernière; le mois dernier)។ *Fam.* avoir le dernier mot ឈ្នះ (ក្នុងការជជែកឬក្នុងវិវាទ)។

Loc. dernier bien ល្អបំផុត, វិសេសណាស់ (ឧ. coiffure du dernier bien)។ être du dernier bien avec quelqu'un ស្និទ្ធស្នាលជាមួយនឹងអ្នកណាម្នាក់ណាស់ (ឧ. Chuon est du dernier avec Phat)។ dernier mot ពាក្យចុងក្រោយ (ក្នុងការជជែកគ្នាលែងព្រមទទួលសម្របសម្រួលតាមយោបល់អ្នកម្ខាង) (ឧ. c'est mon dernier mot)។ au dernier mot គ្មានថែមថយអ្វីទៀត។ en dernier bien នៅទីបំផុត, នៅពេលក្រោយបំផុត។ en dernière analyse ដោយបញ្ចប់សេចក្ដីទៅ, ដោយសរុបទៅ។ dernier cri ម.ព. cri។

n. អ្នកក្រោយបំផុត, អ្នកចុងបំផុត (ឧ. le dernier de la classe; la dernière des créatures); របស់នេះ; អ្នកនេះ (របស់ ឬ មនុស្សដែលគេទើបនឹងនិយាយរួចភ្លាម) (ឧ. il y a plus d'outils que d'ouvriers, et de ces derniers plus de mauvais que d'excellents)។ *Prov.* aux derniers les bons សំណល់ពីគេរើសច្រើនតែជារបស់ល្អ

dernièrement *adv.* ក្នុងពេលថ្មីៗនេះ

dernier-né, dernière-née *n.* កូនពៅ (*pl.* les derniers-nés, les dernières-nées)

dérobade *n.f.* ដំណើរប្រះនៃសេះ។ *Fig.* ការគេចវេះពីកិច្ចការលំបាក

dérobé,e *a.* ស្ងាត់កំបាំង (ឧ. escalier dérobé)។ à la dérobée *loc. adv.* ដោយលាក់លៀម

dérobement *n.m.* ការលួច, ការលាក់

dérober *v.t.* លួច (ឧ. dérober de l'argent)។ *Fig.* លួចយក (ឧ. dérober un secret); បង្វេះ, នាំឲ្យរួច (ឧ. dérober quelqu'un au danger); លាក់ (ឧ. dérober sa marche); បាំង (ឧ.les nuages

dérobent le ciel au regard)។ se dérober *v.pr.* ប្រះ (សេះ); គេចវេះ (ឧ.se dérober à une discussion; se dérober à ses devoirs)។ *Fig.* ទន់(ឧ.ses genoux se dérobent)

dérobeur,euse *n.&a.* ដែលលួច ; ដែលគេចវេះ; ដែលប្រះ (សេះ) (ឧ. cheval dérobeur)

dérochage *n.m.* ការលាងសំអាតលោហជាតិ(ដោយប្រើទឹកអាស៊ីតស៊ុលហ្វួរិក)

dérochement *n.m.* ការកាយយកផ្ទាំងថ្មចេញពីផ្លូវទឹក

dérocher *v.t.* លាងសំអាតលោហជាតិ (ដោយប្រើទឹកអាស៊ីតស៊ុលហ្វួរិក); ការកាយយកផ្ទាំងថ្មចេញពីផ្លូវទឹក ឬ ពីទីដី។ *v.i.* ធ្លាក់ (ចំពោះអ្នកឡើងភ្នំ)

déroder *v.t.* រំលើងឈើមិនល្អ(ដុះមិនល្អ) ចេញពីព្រៃ

dérogation *n.f.* បដិប្បញ្ញត្តិ, ការវៀរលែង, ការតាំងបទបញ្ជាផ្ទុយ ។ par dérogation à ដោយបដិប្បញ្ញត្តិចំពោះ

dérogatoire *a.* ដែលមានបដិប្បញ្ញត្តិ, ដែលមានបទបញ្ជាផ្ទុយគ្នា (ឧ.clause dérogatoire)

dérogeance *n.f.* បដិប្បញ្ញត្តិ, អំពើដែលនាំឲ្យខូចឋានៈជាអភិជន (ឧ. l'exercice d'un métier, sauf la verrerie, était une dérogeance)

dérogeant,e *a.* ជាបដិប្បញ្ញត្តិ

déroger *v.t.&i.* បដិប្បញ្ញត្ត, តាំងបទបញ្ជាផ្ទុយ, ប្រព្រឹត្តខុសចំពោះ (ឧ. déroger à l'usage établi); ខូចសេចក្ដីថ្លៃថ្នូរ; ប្រព្រឹត្តអំពើដែលនាំឲ្យបាត់ឋានៈខ្លួនជាអភិជន (ឧ. le noble ne dérogeait pas en cultivant lui-même sa terre)

déroidir *v.t.* ម.ព. déraidir

dérougir *v.t.* បំបាត់ពណ៌ក្រហម

dérouillage ឬ **dérouillement** *n.m.* ការកោសច្រែះចេញ; ការអស់ច្រែះ

dérouiller *v.t.* កោសច្រែះចេញ (ឧ.dérouiller un couteau)។ *Fig.* ធ្វើឲ្យបាត់ស្រពន់ (ឧ. dérouiller ses jambes); បង្ហាត់ឲ្យមានរបៀប (ឧ. l'usage du monde l'a dérouillé) ។ se dérouiller *v.pr.* អស់ច្រែះ; បង្ហាត់ខ្លួនឲ្យមានរបៀប; ធ្វើឲ្យបាត់ស្រពន់ (ឧ. se dérouiller les jambes)

déroulage ឬ **déroulement** *n.m.* ការលារមូរ, ការលាតត្រដាង; ការលា ។ *Fig.* ដំណើរមានតគ្នាហូរហែ

dérouler *v.t.* លារមូរ; លាតត្រដាង (ឲ្យឃើញនឹងភ្នែក) (ឧ. le fleuve qui déroule ses eaux); រកាលាដាសន្ទឹកស្តែង (រកាវៀលឈើដុំជាសន្ទឹកស្តែង)។ *Fig.* លាតត្រដាង (ដោយបង្ហាញ ឬ ដោយរៀបរាប់) (ឧ. dérouler ses plans, ses souvenirs) ។ se dérouler *v.pr.* ប្រព្រឹត្តទៅ(ឧ. la manifestation s'est déroulée sans incident)

dérouleuse *n.f.* ម៉ាស៊ីនលា

déroutant, e *a.* ដែលឲ្យទាល់គំនិត ឬ ទាល់ប្រាជ្ញ

déroute *n.f.* ការបាក់ទ័ព ។ *Fig.* ការច្របូកច្របល់; សេចក្ដីវិនាស។ mettre en déroute វាយបំបាក់ទ័ព។ *Fig.* ធ្វើឲ្យឡប់

dérouter *v.t.* ងាកចេញពីផ្លូវ (ឧ. dérouter un navire); បំបាត់ដាន (ឧ. le lièvre déroute habilement les chiens); បង្វែងដាន (ឧ. dérouter la police) ។ *Fig.* ធ្វើឲ្យទាល់ប្រាជ្ញ, ធ្វើឲ្យឡប់ (ឧ. dérouter un candidat)

derrière *pré.* ក្រោយ (ឧ. marcher derrière quelqu'un; se cacher derrière un arbre); laisser quelqu'un derrière soi ទៅមុន, ឈ្នះ ។ *Par ext.* ក្រោយ(ចំពោះពេល) (ឧ. il se lève derrière nous une génération nouvelle) ។

Prov. il ne faut pas regarder derrière soi មិនត្រូវងាកក្រោយ; លូកព្រហក់លូកឲ្យកប់ដៃ ។

Adv. ក្រោយ (ឧ. la peur regarde derrière, la prudence regarde devant) ។

Loc. adv. par derrière ពីក្រោយ (ឧ. saisir ឬ attaquer par derrière); *au fig.* ដោយលាក់ពុត ។ de derrière ក្រោយ (ប៉ែកខាងក្រោយ) (ឧ. pattes de derrière)។ porte de derrière ទ្វារក្រោយ; *au fig.* ល្បិចដោះខ្លួន, ឧបាយដោះខ្លួន ។ roues de derrière កង់ក្រោយ ។ sens devant derrière ច្រាស (ពីមុខទៅក្រោយ)

(ឧ. mettre son bonnet sens devant derrière)

derrière *n.m.* ប៉ែកខាងក្រោយ (ឧ. le derrière d'une voiture, d'un habit, de la tête; loger sur le derrière)។ គូថ (ឧ. singes assis sur le derrière; tomber sur le derrière)។ *Pop.* montrer le derrière រត់ (ក្នុងការប្រយុទ្ធ); គេច ។ se torcher le derrière de quelque chose មិនសូវត្រូវចិត្ត, មិនយកចិត្តទុកដាក់ ។ se lever le derrière le premier ងើបពីដំណេកដោយមិនសប្បាយចិត្ត ។

Mar. កន្សៃ (ម.ព. arrière នឹង poupe ផង) ។ *Pl.* ជាយក្រុង (ប៉ែកដាច់ស្រយាល គេមិនសូវទៅមក) (ឧ. prendre les derrières pour ne pas être vu); ក្រោយ (ប៉ែកក្រោយនៃទ័ព)(ឧ. fondre sur les derrières de l'ennemi)

derviche ឬ **dervis** *n.m.* អ្នកបួសក្នុងសាសនាអ៊ីស្លាម

dès *pré.* តាំងពី, ចាប់ពី (ឧ. dès demain; ce fleuve est navigable dès sa source)។ dès en តាំងពី... ម្ល៉េះ (ឬទៅហើយ) (ឧ. dès en naissant, nous pleurons យើងយំតាំងពីកើតមកភ្លាមម្ល៉េះ ឬ យើងគ្រាន់តែកើតមកយំទៅហើយ) ។

Loc. adv. dès lors តាំងពីពេលនោះមក (ឧ. dès lors je le compte au nombre de mes amis); ដោយហេតុនេះ (ឧ. on ne peut établir ce fait capital, et, dès lors tombe toute l'accusation) ។ *loc. conj.* dès que កាលបើ, ភ្លាម (ឧ. l'admiration, comme la flamme, diminue dès qu'elle n'augmente plus); ដោយហេតុថា (ឧ. dès que vous l'affirmez)។ dès là que ភ្លាម, កាលបើ (ឧ. l'impie était proscrit dès là qu'il était connu)។ *loc. pré.* dès avant តាំងពីមុន... ម្ល៉េះ (ឧ. dès avant notre ère)

désabonner *v.t.* បញ្ឈប់ការជាវប្រចាំ។ se désabonner *v.pr.* ឈប់ជាវប្រចាំ

désabriter *v.t.* យកជម្រកចេញ

désabusé,e *a.& n.* ដែលភ្ញាក់គំនិត

désabusement *n.m.* ការធ្វើឲ្យភ្ញាក់គំនិត(ឲ្យដឹងជាខ្លួនគិតខុស);ការដឹងខ្លួន ឬភ្ញាក់ខ្លួន

désabuser *v.t.* ធ្វើឲ្យភ្ញាក់គំនិត (ឲ្យដឹងជាខ្លួនគិតខុស)។ se désabuser *v.pr.* ដឹងជាខ្លួនខុស, ភ្ញាក់គំនិត

désaccord *n.m.* សម្លេងឈ្លើយ។*Fig.* ការមិនព្រមព្រៀងគ្នា, ការខ្វែងយោបល់គ្នា (ឧ.famille en désaccord); ភាពមិនស្របគ្នា(ឧ.désaccord entre les paroles et les actes)

désaccorder *v.t.* ធ្វើឲ្យឈ្លើយសម្លេង។ *Fig.* ធ្វើឲ្យទាស់ទែងគ្នា

désaccoupler *v.t.* បំបែកគូ; ផ្ដាច់ម៉ាស៊ីន ។ se désaccoupler *v.pr.* បែកគូ, ដាច់ពីគ្នា

désaccoutumance *n.f.* ការបំបាត់ទម្លាប់

désaccoutumer *v.t.* បំបាត់ទម្លាប់ ។ se désaccoutumer *v.pr.* បាត់ទម្លាប់

désachalandage *n.m.* ការបំបាត់អ្នកទិញ(ធ្វើឲ្យអស់អ្នកទិញ)

désachalander *v.t.* បំបាត់អ្នកទិញ

désaciérer *v.t.* បំបាត់ជាតិដែក (ដោយលត់ខ្លាំង)

désadaptation *n.f.* ការលែងយកលំនាំតាម; ការធ្វើឲ្យលែងត្រូវគ្នា

désaérer *v.t.* យកខ្យល់ចេញ (ឧ.béton désaéré)

désaffectation *n.f.* អនុបយោគ, ការលែងប្រើតាមការចាត់ (ឧ. la désaffectation d'une église)

désaffecter *v.t.* លែងប្រើតាមការចាត់

désaffection *n.f.* ការខូចមិត្តភាព;ការរាគចិត្ត (ឧ. la méfiance entraîne vite la désaffection)

désaffectionner *v.t.* ធ្វើឲ្យខូចមិត្តភាព ឬឲ្យរាគចិត្ត ។ se désaffectionner *v.pr.* រាគចិត្ត

désaffubler *v.t.* ដោះសំលៀកបំពាក់ខុសបែបចេញ

désagréable *a.* អរមណីយ, មិនជាទីពេញចិត្ត(ឧ.odeur désagréable)

désagréablement *adv.* ដោយអរមណីយ, ដោយមិនពេញចិត្ត (ឧ.être désagréablement surpris)

désagrégation *n.f.* ខន្ធភេទ,ការខ្ទេច, ការបែក (ឧ. le grand froid amène la désagrégation des pierres gélives) ។ *Fig.* ការ

វិនាស; ការរលំ (ឧ. la désagrégation de l'Empire romain)

désagrégeant,e *a.* ដែលខ្ទេច, ដែលបែក

désagrégement *n.m.* ការកំទេច, ការបំបែក; ការខ្ទេច, ការបែក

désagréger *v.t.* កំទេច, បំបែក (ឧ. l'humidité désagrège un grand nombre de corps) ។ se désagréger *v.pr.* ខ្ទេច, បែក

désagrément *n.m.* ការព្រួយចិត្ត, កង្វល់ (ឧ. éprouver de vifs désagréments)

désaimantation *n.f.* ការបំបាត់ធាតុមេដែក; ការអស់ធាតុមេដែក

désaimanter *v.t.* បំបាត់ធាតុមេដែក (ឧ. désaimanter un barreau de fer)

désajustement *n.m.* ការដោះចេញ (ឧ. le désajustement d'une machine)

désajuster *v.t.* ដោះចេញ (ឧ. désajuster une coiffure)

désallaiter *v.t.* ផ្តាច់ដោះ (លែងឲ្យបៅ) (បើ sevrer ត្រូវជាង)

désaltérant,e *a.* ដែលធ្វើឲ្យបាត់ស្រេក (ឧ. l'orange est un fruit désaltérant)

désaltérer *v.t.* ធ្វើឲ្យបាត់ស្រេក (ឧ. désaltérer un blessé); ស្រោច (ឧ. la pluie désaltère les plantes) ។ se désaltérer *v.pr.* ផឹក ។ *Fig.* បំពេញចំណង់

désamarrer *v.t.* ស្រាយយុថ្កា (ទូក)

désamorçage *n.m.* ការដោះឆ្នួន; ការដាច់បារូតក្នុងទីណាមួយ

désamorcer *v.t.* ដោះឆ្នួន (ឧ. désamorcer un obus)

désannexer *v.t.* លែងដាក់ជាឧបសម្ព័ន្ធ (ដែនដី)

désannexion *n.f.* ការលែងដាក់ជាឧបសម្ព័ន្ធ (ដែនដី)

désappareiller *v.t.* ម.ព. dépareiller ។ *v.i.* *Mar.* លែងប្រុងប្រៀបចេញដំណើរ

désapparier *v.t.* ម.ព. déparier

désappointement *n.m.* ការខកចិត្ត (ឧ. laisser voir son désappointement)

désappointer *v.t.* បន្លាល, ធ្វើឲ្យទាល (ឧ. désappointer une aiguille) ។ *Fig.* ធ្វើឲ្យខកចិត្ត (ឧ.

l'issue de ce procès m'a désappointé)

désapprendre *v.t.* ភ្លេចទៅវិញ (រឿងដែលដឹងឬដែលរៀនរួចហើយ)

désapprobateur,trice *a.&n.* ដែលបន្ទោស (ឧ. murmure désapprobateur)

désapprobation *n.f.* ការបន្ទោស; ការមិនយល់ព្រម (ឧ. manifester sa désapprobation)

désapproprier *v.t.* ដកហូតកម្មសិទ្ធិ (ដកហូតរបស់ទ្រព្យ)

désapprouver *v.t.* បន្ទោស; មិនយល់ព្រម (ឧ. désapprouver un projet)

désapprovisionnement *n.m.* ការផ្តាច់ស្បៀង

désapprovisionner *v.t.* ផ្តាច់ស្បៀង

désarçonner *v.t.* ទម្លាក់ពីលើសេះ។ *Fig.* & *Fam.* ធ្វើឲ្យទាល់គំនិត ឬទាល់ប្រាជ្ញ (ឧ. cette objection l'a désarçonné)

désargenté,e *a. Fam.* គ្មានប្រាក់ (គ្មានជាតិប្រាក់)

désargenter *v.t.* បកប្រាក់ដែលស្រោបចេញ; យកជាតិប្រាក់ចេញ ។ *Fig.* & *fam.* បង្ហស់ប្រាក់ (ឧ. ces dépenses l'ont désargenté) ។ se désargenter *v.pr.* អស់ជាតិប្រាក់; របកប្រាក់

désarmant,e *a.* ដែលឲ្យទន់ចិត្ត (ឧ. une naïveté désarmante)

désarmement *n.m.* និរសព្វាវុធការ, ការដកហូតអាវុធ; ការបន្ថយកម្លាំងទ័ព; ការទម្លាក់អាវុធ (ព.ផ. armement)

désarmer *v.t.* ធ្វើនិរសព្វាវុធការ, ដកហូតគ្រឿងអាវុធ ។ *Fig.* ធ្វើឲ្យស្បើយ (ឧ. désarmer la colère) ។ *Escr.* ធ្វើឲ្យធ្លាក់អាវុធពីដៃ ។ តម្លោះ (គ្រឿងយន្ត) (ឧ. désarmer un fusil) ។ *Mar.* désarmer un navire យកយានិកនឹងសម្ភារៈចេញពីនាវា ។ ទម្លាក់អាវុធ (ឈប់ច្បាំង); បន្ថយ ឬ ផ្តាច់កម្លាំងទ័ព ។ *Fig.* អស់, រលាយ (ឧ. sa haine ne désarme pas)

désarrimage *n.m.* ការរើទំនិញ

désarrimer *v.t.* រើទំនិញ (ស្រាយចេញឲ្យរាត់រាយ)

désarroi *n m.* ច្របូកច្របល់, ភ័យរវល់, ការច្របូកច្របល់ (ឧ. les affaires sont en grand désarroi)

désarticulation *n.f.* ការធ្វើឲ្យគ្រេច ឬឲ្យភ្លាត់ឆ្អឹង (ឧ. désarticulation de l'épaule)

désarticuler *v.t. Anat.* ធ្វើឲ្យគ្រេច ឬ ឲ្យភ្លាត់ឆ្អឹង; កាត់ត្រង់តន្លាក់; បំពត់ខ្លាំងពេកត្រង់តន្លាក់

désassemblage ឬ **désassemblement** *n.m.* ការដោះរបស់ផ្គុំ; ការបំបែកខ្ញែកគ្នា

désassembler *v.t.* ដោះរបស់ផ្គុំ ។ se désassembler *v.pr.* បែកខ្ញែកគ្នា; រង្គាះ

désassimilation *n.f.* វិសមីករណ៍

désassimiler *v.t.* ធ្វើវិសមីករណ៍; បញ្ចេញវត្ថុធាតុដែលរាងកាយស្រូបបាន

désassortir *v.t.* បំបែក (វត្ថុដែលផ្សំគ្នា) (ឧ. désassortir un service de table); បើទំនិញដែលតាំងលក់ចេញ

désastre *n.m.* ហាយនៈ; ភយន្តរាយ

désastreusement *adv.* ដោយហាយនៈ; ដោយភយន្តរាយ

désastreux,euse *a.* មហាចង្រៃ (ឧ. une guerre désastreuse)

désavantage *n.m.* ការខូចអត្ថប្រយោជន៍; ការចាញ់ប្រៀបគេ (ឧ. les désavantages d'une situation; le combat tourne à son désavantage)

désavantager *v.t.* ធ្វើឲ្យខូចអត្ថប្រយោជន៍; ធ្វើឲ្យចាញ់ប្រៀបគេ (ឧ. désavantager ses enfants)

désavantageusement *adv.* ដោយខូចអត្ថប្រយោជន៍; ដោយចាញ់ប្រៀបគេ

désavantageux,euse *a.* ដែលឲ្យខូចអត្ថប្រយោជន៍, ដែលឲ្យចាញ់ប្រៀបគេ

désaveu *n.m.* ការប្រកែក, ការមិនទទួលស្គាល់ (ឧ. désaveu de paternité ការប្រកែកថាមិនមែនជាបិតា); ការបដិសេធចម្លើយសារភាព

désaveugler *v.t.* ធ្វើឲ្យបាត់វង្វេងស្មារតី

désavouable *a.* អាចបដិសេធបាន

désavouer *v.t.* ប្រកែក, បដិសេធ (ឧ. désavouer sa signature, un enfant); មិនទទួលដឹងឮ (មិនទទួលថាបានបង្គាប់ឲ្យធ្វើ) (ឧ. désavouer un ambassadeur) ។ *Fig.* បន្ទោស; មិនយល់ព្រម (ឧ. désavouer une politique)

désaxer *v.t.* ដាក់ឲ្យឃ្លាតពីស្នូល (ឬភ្លៅ) (ឧ. désaxer une roue) ។ *Fig.* ធ្វើឲ្យខូចចិត្ត (ឧ. la guerre a désaxé bien des esprits)

descellement *n.m.* ការបើកអ្វីៗដែលបិទបោះត្រា; ការបើកត្រា

desceller *v.t.* បើកអ្វីៗដែលបិទបោះត្រា

descendance *n.f.* បញ្ជានគា, បណ្ដាកូនចៅ (ឧ. une nombreuse descendance) (ព.ផ. ascendance)

descendant,e *a.* ដែលចុះ ឬស្រក (ឧ. marée descendante)។ ligne descendante ខ្សែកូនចៅ។ *n.* បញ្ជាជន, កូនចៅ (ឧ. les descendants des bâtisseurs d'Angkor)

descenderie *n.f.* ផ្លូវជម្រាល (ចុះក្នុងអណ្ដូងរ៉ែ) (ថា descente ក៏បាន)

descendre *v.i.* ចុះ (ចំពោះមនុស្ស) (ឧ. descendre d'une auto; descendre à un hôtel ចុះនៅសណ្ឋាគារ(មកដល់ ឬឈប់សំណាក់)។ *Fig.* ចុះឋានន្តរសក្តិ ឬ កិត្តិយស, បន្ថោកខ្លួន (បន្ទាបខ្លួន) (ឧ. descendre jusqu'à la bassesse); ចុះពី (ជាប់ពូជពី) (ឧ. descendre d'une illustre famille) ។ ចុះ (មានជម្រៅ) (ឧ. mine qui descend à 1500m. អណ្ដូងរ៉ែដែលចុះដល់ ១៥០០ម. (មានជម្រៅ ១៥០០ ម.); ចុះ (ថយចុះ) (ឧ. le thermomètre descend); ស្រក (ឧ. l'eau descend); ចុះ (ជម្រាល) (ឧ. chemin qui descend) ។

Loc. descendre en soi-même ឬ dans sa conscience ឬ au fond de son cœur ពិនិត្យក្នុងខ្លួន, ស្ទង់ក្នុងចិត្ត។ descendre au tombeau ឬ au cercueil ចូលមឈូស, ស្លាប់។ descendre du Trône ដាក់រាជ្យ

Dr. la justice a descendu sur les lieux តុលាការបានទៅដល់ទីកន្លែង (ដើម្បីធ្វើអង្កេត) ។

Mar. descendre à terre ឡើងគោក (ចុះពីនាវា)។ descendre en latitude ទៅជិតវិក្ខារន្ត ។ la mer descend សមុទ្រនាច(ស្រក)។

v.t. ដាក់ចុះ, ទម្លាក់ចុះ (ឧ. descendre une barrique à la cave); ចុះ (ដើរចុះ) (ឧ. descendre une colline, un escalier); ចុះ (ចុះតាមខ្សែទឹក) (ឧ. descendre une rivière ចុះតាមព្រែក)។ *Par ext.* ដាក់ (ឧ. le chemin de fer qui des-

cend beaucoup de voyageurs à son terminus); *par anal. Fam.* ផ្ដួល, សម្លាប់ (ឧ. descendre quelqu'un d'un coup de fusil) ។

Art mil. descendre la garde, descendre la tranchée ចេញពីកន្លែងខ្លួន, ចេញពីលេណដ្ឋាន (ដើម្បីទុកកន្លែងឲ្យអ្នកដទៃ) ។ *Pop.* descendre la garde ស្លាប់

descenseur *n.m.* ជណ្ដើរយន្តចុះ(ព.ផ. ascenseur)

descente *n.f.* ការចុះ;ការស្រក;ជម្រាល; ការឡើងគោក (ចុះពីនាវា); ផ្លូវចុះ (ឧ. une descente longue et rapide ផ្លូវចុះឆ្ងាយហើយចោត)។ការដាក់ចុះ (ឧ. la descente d'un tableau)។ descente de police ការចូលឆាប់នៃប៉ូលិស ។ descente de justice ការពិនិត្យកន្លែងនៃតុលាការ ។ *Archit.* បំពង់បញ្ចេញទឹក។ *Chir.* ក្លូនស្រុត (ម.ព. hernie ផង) ។ descente de lit កម្រាលក្បែរជើងគ្រែ

descripteur *n.m.* អ្នកពិពណ៌នា (ឧ. Chateaubriand est un incomparable descripteur)

descriptible *a.* អាចពិពណ៌នាបាន (ឧ. scène à peine descriptible) (ព.ផ. indescriptible)

descriptif,ive *a.* ដែលពិពណ៌នា (ឧ. la poésie descriptive fut en l'honneur à la fin du XIIIe siècle) ។ géométrie descriptive ម.ព. géométrie ។ anatomie descriptive សារីរវិទ្យាពិពណ៌នា

description *n.f.* ពិពណ៌នា (ឧ. description d'un évènement); លិខិតឬពាក្យពោលរៀបរាប់

déséchouer *v.t.* ទាញនាវាដែលកៀង

désemballer *v.t.* យកចេញពីកញ្ចប់ ពីហិប ឬ ឡាំង

désembourber *v.t.* យកចេញពីភក់ (បំពោះរបស់ជាប់ភក់)។ *Fig.* ស្រង់ពីសេចក្ដីព្រលំជាកឬពីការល្ងង់ខ្លៅ

désembourgeoiser *v.t.* បំបាត់លក្ខណៈជាគហបតី

désembrayage *n.m.* ម.ព. débrayage

désembrayer *v.t.* ម.ព. débrayer

désemmancher *v.t.* ដោះដងចេញ(ឧ.

désemmancher un outil) ។ se désemmancher *v.pr.* របូតដង, ដាច់ដង

désemparé,e *a.* navire désemparé នាវាខូចលែងបើកបាន ។ *Fig.* être désemparé វល់ប្រាជ្ញ

désemparer *v.i.* ធ្វើឲ្យទ្រុឌទ្រោមឬឲ្យដាច់បែក (ឧ. désemparer un navire); ធ្វើឲ្យរបូតៈ ឬ ឲ្យដាច់បែក (ឧ. désemparer une chaise en la laissant tomber) ។ ដោះបង់ចោលកន្លែង(ឧ.tenez-vous là et n'en désemparez pas que je ne revienne) ។ sans désemparer ដោយមិនចោលកន្លែង; *au fig.* ភ្លាមៗ, ជាប់រហូត, ឥតមានឈប់ (ឧ. discuter trois heures durant, sans désemparer)

désempeser *v.t.* លាងម្សៅចេញ(សំពត់)

désempêtrer *v.t.* ម.ព. dépêtrer

désemplir *v.t.* យកចេញខ្លះ ។ *v.i.* លែងពេញ (ប្រើតែក្នុងប្រយោគបដិសេធដូចជា : la maison ne désemplit pas ផ្ទះនៅតែពេញ)

désempoisonner *v.t.* បន្សាបគ្រឿងពុល

désemprisonner *v.t.* ដោះចេញពីគុក

désénamourer *v.t.* បំបាត់ស្នេហា

désencadrer *v.t.* ដោះក្របចេញ

désencanailler *v.t.* ធ្វើកុំឲ្យថោកទាបពេក

désenchainer *v.t.* ដោះច្រវាក់ (ឧ. désenchainer un forçat)

désenchantement *n.m.* និវេសការណ៍, ការសាបមន្តគាថា ។ *Fig.* ការភ្ញាក់ខ្លួន

désenchanter *v.t.* ដោះមន្តគាថា, ដោះស្នេហ៍ ។ *Fig.* ធ្វើឲ្យភ្ញាក់ខ្លួន

désenchanteur,teresse *a.* & *n.* ដែលដោះមន្តអាគម; ដែលឲ្យភ្ញាក់ខ្លួន

désenclaver *v.t.* ដកចេញ (យកចេញពីការព័ទ្ធហ៊ុំ)

désencombrement *n.m.* ការយករបស់ទទើសទទែងចេញ

désencombrer *v.t.* យករបស់ទទើសទទែងចេញ (ឧ. désencombrer la voie publique)

désencroûter *v.t.* យកក្អាំង ឬ កម្អោចចេញ (ឧ. désencroûter une chaudière;désencroûter des conduites d'eau) ។ *Fig.* បំបាត់គំនិតប្រកាន់ទុកមុន; ធ្វើកុំឲ្យឆ្គងពេក

désenfiler *v.t.* ហូតចេសចេញ

désenflammer *v.t.* ធ្វើឲ្យបាត់រលាក, រម្ងាប់ពិសភ្លើង

désenfler *v.t.* ធ្វើឲ្យស្រក; បន្ធូរ។ *v.i.* ស្រក

désenflure *n.f.* ឬ **désenflement** *n.m.* ការស្រក; ការធូរ

désenfourner *v.t.* យកចេញពីឡ

désenfumer *v.t.* បញ្ចេញផ្សែងពី (ឧ. désenfumer un appartement)

désengagement *n.m.* ការឲ្យរួចពីកិច្ចសន្យា; ការដកពាក្យ

désengager *v.t.* ឲ្យរួចពីកិច្ចសន្យា។ se désengager *v.pr.* ដកពាក្យ

désengorger *v.t.* បើក, ដកឆ្នុក; ធ្វើឲ្យបាត់ស្ទះ

désengrener *v.t.* ដោះ (ធ្មេញស្ពឺដែលបង្ខាំ)

désenivrer *v.t.* ធ្វើឲ្យស្វាងស្រវឹង

désenlacer *v.t.* ដោះពីអន្ទាក់; ស្រាយចំណង

désenlaidir *v.t.* ធ្វើឲ្យបាត់អាក្រក់ ។ *v.i.* អន់អាក្រក់

désennuyer *v.t.* ធ្វើឲ្យបាត់អផ្សុក (ឧ. la lecture désennuie)

désenorgueillir *v.t.* ធ្វើឲ្យបាត់ក្រអឺតក្រអោង

désenrayer *v.t.* ដោះ (គ្រឿងខ្ទាស់); ធ្វើឲ្យដើរវិញ (គ្រឿងយន្ត) (ឧ. désenrayer une arme à feu)

désenrhumer *v.t.* ធ្វើឲ្យបាត់ផ្ដាសាយ

désensablement *n.m.* ការអូសចេញពីខ្សាច់; ការកាយខ្សាច់ចេញ

désensabler *v.t.* អូសចេញពីខ្សាច់ (ឧ. désensabler une barque); កាយខ្សាច់ចេញ (ចំពោះខ្សាច់ដែលស្ទះប្រឡាយផែ ឬ ស្ទឹង ។ល។)

désensevelir *v.t.* បកស្បងចេញ

désensorceler *v.t.* ដោះអំពើ, ដោះស្នេហ៍

désensorcellement *n.m.* ការដោះអំពើ, ការដោះស្នេហ៍

désentoilage *n.m.* ការបកសំពត់ពាសចេញ

désentoiler *v.t.* បកសំពត់ពាសចេញ (ឧ. désentoiler un tableau)

désentortiller *v.t.* លា (ចំពោះអ្វីៗដែលគ្រញូញ ឬ រមួល) (ឧ. désentortiller un écheveau)។*Fig.* ដោះដំពាក់; ដោះកុន

désentraver *v.t.* ដោះទន្ទឹង,ដោះចំណងជើង (ឧ. désentraver un

cheval) ។ *Fig.* បំបាត់ឧបសគ្គ (ឧ. désentraver une affaire)

désentrelacer *v.t.* ស្រងឧប; ដោះ (ចំពោះរឿងៗ ដែលវ័ណ្ឌក្លា ឬ ដែលជាប់ ស្រែះគ្នា)

désenvaser *v.t.* យកភក់ចេញ

désenvelopper *v.t.* បើកស្រោម, លាកញ្ចប់ (ឧ. désenvelopper un paquet)

désenvenimer *v.t.* បន្សាបពិស (ធ្វើមិនឲ្យក្លាយ) ។ *Fig.* បន្ទន់កំហឹង, បន្ទន់ភាពជូរចត់ (សំដី)

déséquilibre *n.m.* វិសមតា ។ *Fig.* ការខូចសតិ

déséquilibré,e *a.&n.* អ្នកខូចសតិ, ឆ្កួត (ឧ. les criminels sont tous, plus ou moins, déséquilibrés)

déséquilibrer *v.t.* បង្ខូចសមតា ។ *Fig.* ធ្វើឲ្យខូចសតិ(ឧ. ce chagrin l'a déséquilibré)

déséquiper *v.t.* ដកគ្រឿងបរិក្ខារ

désert,e *a.* ដែលគ្មានមនុស្សនៅ,ស្ងាត់។ *n.m.* រហោឋាន; វាលខ្សាច់ (ឧ. le Sahara est un immense désert) ។ prêcher dans le désert និយាយឥតគេស្តាប់

déserter *v.t.* បោះបង់ទីកន្លែង ។ *Fig.* បោះបង់ (ឧ. déserter la bonne cause) ។ *v.i.* រត់ចោលភដិការសឹក ។ déserter à l'ennemi រត់ចូលខាងខ្មាំង

déserteur *n.m.* ទាហានរមត់, អ្នករត់ចោលភដិការសឹក; អ្នករត់ចូលខាងខ្មាំង (ឧ. la loi militaire punit de mort les déserteurs à l'ennemi)។ *Fig.* អ្នករត់ចោលបក្សពួក

désertion *n.f.* រមត់, ការរត់ចោលភដិការសឹក; ការរត់ចូលខាងខ្មាំង (ឧ. la désertion est une lâcheté)។ *Fig.* ការផ្លាស់បក្សពួក

désertique *a.* រហោ, នៃរហោស្ថាន, នៃវាលខ្សាច់ (ឧ. région désertique រហោស្ថាន)

désespéramment *adv.* គួរឲ្យអស់សង្ឃឹម (ឧ. être désespérament naïf)

désespérance *n.f.* ការអស់សង្ឃឹម

désespérant, *a.* ដែលឲ្យអស់សង្ឃឹម (ឧ. obstination désespérante); ដែលរំខាន(ឧ. un enfant

désespérant) ។ *Par ext.* ដែលធ្វើឲ្យខានសប្បាយ (ឧ. temps désespérant)។ *Fig.* ដែលធ្វើឲ្យខូចទឹកចិត្ត(ឧ. perfection désespérante)

désespéré,e *a.&n.* ដែលមានទុក្ខសោក (ឧ. famille désespérée); ដែលអស់សង្ឃឹម (ឧ. malade désespéré)

désespérément *adv.* ដោយអស់សង្ឃឹម

désespérer *v.i.* អស់សង្ឃឹម,អស់រំពឹង (ឧ. je ne désespère pas qu'il ne réussisse; je désespère qu'il réussisse)។ *v.t.* ធ្វើឲ្យអស់សង្ឃឹម (ឧ. désespérer sa famille); ធ្វើឲ្យមានទុក្ខព្រួយ ។ se désespérer *v.pr.* កើតទុក្ខខ្លាំង, អស់សង្ឃឹម

désespoir *n.m.* ការអស់សង្ឃឹម; ទុក្ខសោក(ឧ. désespoir d'un malade) ។ *Par ext.* សេចក្ដីស្ដាយខ្លាំង ; អ្វីៗដែលឲ្យកើតទុក្ខព្រួយ (ឧ. cet enfant est le désespoir de sa famille) ; អ្វីៗដែលគេធ្វើតាមមិនឆ្លិប (ឧ. teint qui est le désespoir des peintres)។ en désespoir de cause ដោយអស់ផ្លូវ (ដោយគ្មានមធ្យោបាយផ្សេងទៀត)

déshabillage *n.m.* ការសម្រាត

déshabillé *n.m.* សំលៀកបំពាក់នៅផ្ទះ។ *loc.pré.* dans le déshabillé ឬ en déshabillé ដោយស្លៀកពាក់ប្រកាច់ប្រកូវ; *au fig.* ក្នុងការស្និទ្ធស្នាល, ដោយមិនជាប់គួរសម

déshabiller *v.t.* សម្រាត ។ *Fig.* បក (ឲ្យនៅខ្លួនឬគ្រាប់ទទេ) ។ se déshabiller *v.pr.* ស្រាត ។ *loc. prov.* déshabiller saint Pierre pour habiller saint Paul ដោះបំណុល ដោយបំណុល(ខ្ចីពីម្នាក់យកទៅសងម្នាក់ទៀត); បំបាត់ឧបសគ្គដោយឧបសគ្គ (បំបាត់ឧបសគ្គចាស់ដោយបង្កើតឧបសគ្គថ្មី)

déshabituer *v.t.* បំបាត់ទម្លាប់ (ឧ. déshabituer un enfant de mentir)

désherbage *n.m.* ការជម្រះស្មៅ (ឧ. désherbage chimique des allées)

désherber *v.t.* ជម្រះស្មៅ

déshérence *n.f.* និទាយាទភាព(ដំណើរ

ឥតអ្នកត្រូវទទួលមរតក) (ឧ. les biens tombés en déshérence sont attribués à l'Etat)

déshérité,e *n.* ទិមតិក; អ្នកមិនត្រូវបានមរតក; មនុស្សអភ័ព្វ (ឧ. les déshérités de la vie)

déshéritement *n.m.* ការមិនចែកមរតក; ការមិនបានមរតក

déshériter *v.t.* មិនឲ្យចែកមរតក

désheurer *v.t.* ធ្វើឲ្យខូចពេលម៉ោង (ចំពោះការបើ៉ះពេលម៉ោងដែលបានកំណត់ទុកមកហើយ)(ឧ. un homme désheuré) ។ *v.i.* វាយខុសម៉ោង (ចំពោះនាឡិកាវាយខុសពីម៉ោងដែលទ្រនិចចង្អុល) (ឧ. cette pendule désheure)

déshonnête *a.* ទុច្ចរិត; អសុភាវណីយ (មិនសមរម្យ), ឥតខ្មាស (ឧ. paroles déshonnêtes)

déshonnêtement *n.m.* ដោយទុច្ចរិត; ដោយមិនសមរម្យ; ដោយឥតខ្មាស (ឧ. agir déshonnêtement)

déshonnêteté *n.f.* ភាពទុច្ចរិត; អសុភាវធម៌ (ភាពមិនសមរម្យ); ការឥតខ្មាស

déshonneur *n.m.* សេចក្ដីអប្បយស, ការខូចកិត្តិយស

déshonorant,e *a.* អាមាសកេរ្តិ៍, ដែលឲ្យខូចកិត្តិយស (ឧ. se livrer à des trafics déshonorants)

déshonorer *v.t.* បង្ខូចកិត្តិយស។ *Par ext.* បង្ខូច (ឧ. déshonorer une façade)។ se déshonorer *v.pr.* ខូចកិត្តិយស, កុះហើកទាប

déshuiler *v.t.* យកប្រេង ឬ ខ្លាញ់ចេញ (ឧ. déshuiler la laine)

déshydratation *n.f.* ការសម្រេងទឹក, ការធ្វើឲ្យអស់ទឹក។ *Méd.* ភាពអស់ទឹក

déshydrater *v.t.* សម្រេងទឹក, ផ្ដាច់ទឹក (ឧ. déshydrater de la chaux)។ se déshydrater *v.pr.* សោះជាតុទឹក (អាការៈក្នុងខ្លួន)

déshydrogénation *n.f.* ការយកអ៊ីដ្រូហ្សែនចេញ

déshydrogéner *v.t.* យកអ៊ីដ្រូហ្សែនចេញ

déshypothéquer *v.t.* ជម្រះនិក្ខេប, លោះរបស់បញ្ចាំ (ឧ. déshypothéquer une terre)

désiderata ម.ព. désideratum

désideratif,ive *a.* ដែលប្រាប់បំណងឬសេចក្ដីប្រាថ្នា (ឧ. verbe désideratif)

desideratum *n.m. sing.*, **désiderata** *pl.* ឥច្ឆិតា (ប្រាថ្នា) (ឧ. exprimer ses desiderata); វត្ថុ ឬ បញ្ហាដែលត្រូវរក ឬ ត្រូវដោះស្រាយ

désignatif,ive *a.* ដែលបង្ហាញ, ដែលបញ្ជាក់ (ឧ. terme désignatif)

désignation *n.f.* ការចង្អុលបង្ហាញ; ការភយមុខ; ការតាត់តាំង; ការជ្រើសរើសទុកជាមុន (ឧ.désignation d'un successeur)

désigner *v.t.* ចង្អុលបង្ហាញ; មានន័យជា (ឧ. en latin, «magister» désigne le maître); តាត់តាំង; កំណត់ (ឧ. désigner l'heure et le lieu); ជ្រើសរើសទុកជាមុន (ឧ. désigner son successeur); មានគុណសម្បត្តិ (ឧ. être tout désigné pour une telle fonction)

désillusion *n.f.* និម្មាយា, ការភ្ញាក់ខ្លួន; ការស្រងាកចិត្ត(ឧ. éprouver une désillusion)

désillusionner *v.t.* ធ្វើឲ្យភ្ញាក់ខ្លួន ឬ ស្រងាកចិត្ត

désincarnation *n.f.* និរការ, ការចេញចាករូប (ចំពោះព្រលឹង)

désincarné,e *a.* ដែលចេញចាករូប (ចំពោះព្រលឹង)

désincarner *v.t.* ចេញចាករូប (ចំពោះព្រលឹង)

désincorporation *n.f.* ការបំបែក ឬ ដកចេញ

désincorporer *v.t.* បំបែក ឬដកចេញ (ចំពោះវត្ថុដែលបញ្ចូលជិតស្និទ្ធនឹងគ្នា)

désincrustant *n.m.* ថ្នាំបំបាត់ក្អាំង(ថ្នាំបង់ក្នុងខ្ទះកដាល់កុំឲ្យមានក្អាំងនៅជាត)

désincrustation *n.f.* ការបំបាត់ក្អាំង (ក្នុងខ្ទះកដាល់)

désincruster *v.t.* បំបាត់ក្អាំង (ក្នុងខ្ទះកដាល់) (ឧ. désincruster les parois d'une chaudière)

désinence *n.f.Gram.* វិភត្តិ ។ *Bot.* ចុង (ចុងនៃអគារ, រុក្ខជាតិ)

désinfectant,e *a.* ដែលរម្ងាប់មេរោគ ។ *n.m.* ថ្នាំរម្ងាប់មេរោគ(ឧ. le chlore est un désinfectant)

désinfecter *v.t.* រម្ងាប់មេរោគ (ឧ. il faut désinfecter les lieux occupés par un typhique)

désinfecteur *a.&n.m.* សម្រាប់រម្ងាប់មេរោគ

désinfection *n.f.* ការរម្ងាប់មេរោគ;

ការអស់មេរោគ (ម.ព. antiseptie និង aseptie ផង)

désintégration *n.f.* ភេទវនកម្ម, ការធ្វើឲ្យបែកខ្ទេក (ឧ.désintégration de la matière)

désintégrer *v.t.* ធ្វើភេទវនកម្ម, ធ្វើឲ្យវិនាសបន្តិចម្ដងៗ ។ se désintégrer *v.pr.* បែកខ្ទេក

désintéressé,e *a.* មិនរវល់យកចិត្តទុកដាក់; មិនប្រាថ្នាប្រយោជន៍ (ឧ. conseil désintéressé; personne désintéressée)

désintéressement *n.m.* ការមិនប្រាថ្នាប្រយោជន៍(ឧ.faire preuve de désintéressement); ការញុំាងឲ្យលែងកោងទារ

désintéresser *v.t.* ញុំាងឲ្យលែងកោងទារ ។ se désintéresser *v.pr.* លែងប្រាថ្នាប្រយោជន៍;លែងកោងទារ; លែងយកចិត្តទុកដាក់ (ឧ. se désintéresser de son travail)

désintoxication *n.f.* ការបន្សាបជាតិពុល (ឧ.faire une cure de désintoxication); ការញុំាងឲ្យលែងស្រា លែងអាភៀន ។ល។

désintoxiquer *v.t.* បន្សាបជាតិពុល; ញុំាងឲ្យលែងស្រាលែងអាភៀន ។ល។ *Fig.* ដកតាំឲ្យចោលគំនិតអាក្រក់

désinvestissement *n.m.* អវិនិយោគ (ការដកយកប្រាក់ដែលបានដាក់ធ្វើវិនិយោគពីមុន)

désinviter *v.t.* បដិសេធការអញ្ជើញ

désinvolte *a.* ងងះ (ឧ. démarche désinvolte)។ *Fig.*កោង,ព្រហើន (ឧ. réponse désinvolte)

désinvolture *n.f.* ដំណើរ ឬ អាការៈ ងងះ ឬ អាក់អញ្ជូន ។ *Fig.* សេចក្ដីព្រហើន ឬ កោង (ឧ. agir avec désinvolture)

désir *n.m.* ប្រាថ្នា, តំណង់, បំណង (ឧ. exprimer un désir); វត្ថុដែលប៉ង (ឧ. mon seul désir est de partir)

désirable *a.* គួរឲ្យចង់បាន

désiré,e *a.* ដែលគេចង់បាន។ *n.m.* le Désiré des nations ព្រះមេស្ស៊ី

désirer *v.i.* ប្រាថ្នា, ចង់បាន, ប៉ង (ឧ. désirer le succès; désirer la fortune)។ laisser à désirer ខានខ្វះ,មិនជាទីពេញចិត្ត(ឧ.ce travail laisse à désirer)។ ne rien laisser à désirer ពិត

ខ្លាះ ។ se faire désirer ឲ្យគេរង់ចាំ

désireux,se *a.* ដែលចង់បាន, ដែលប៉ង (ឧ. désireux de plaire)

désistement *n.m.* ការលែងប្ដឹង (ឧ. le désistement de la partie civile n'interrompt pas l'action publique); ការនឹកពាក្យ; ការថយខ្លួន

désister (se) *v.pr.* លែងប្ដឹង ។ *Par ext.* ថយខ្លួន

désobéir *v.i.* មិនស្ដាប់បង្គាប់; ប្រព្រឹត្តល្មើស(ឧ.désobéir à un ordre)

désobéissance *n.f.* ការមិនស្ដាប់បង្គាប់; ការប្រព្រឹត្តល្មើស (ឧ.la désobéissance est chez les enfants un grave défaut)

désobéissant,e *a.* ដែលមិនស្ដាប់បង្គាប់; ដែលប្រព្រឹត្តល្មើស

désobligeamment *adv.* ដោយឃ្លើសឃ្លង

désobligeance *n.f.* ការប្រព្រឹត្តឃ្លើសឃ្លង

désobligeant,e *a.* ឃ្លើសឃ្លង (ឧ.remarque désobligeante)

désobliger *v.t.* ធ្វើឲ្យឃ្លើសចិត្ត (ឧ.ne désobliger personne)

désobstruction *n.f.* ការធ្វើឲ្យលែងស្ទះ; ការលែងស្ទះ

désobstruer *v.t.* ធ្វើឲ្យលែងស្ទះ (ឧ. désobstruer un chenal)

désodorisant *a.* ដែលបំបាត់ក្លិន ។ *n.m.* ថ្នាំបំបាត់ក្លិន

désodoriser *v.t.* បំបាត់ក្លិន

désœuvré,e *a.* ទំនេរ, មិនបេះរកការធ្វើ ។ *n.* អ្នកទំនេរ,អ្នកមិនបេះរកការធ្វើ

désœuvrement *n.m.* ភាពទំនេរ(ឧ. le désœuvrement est funeste pour les jeunes gens)

désolant,e *a.* ដែលឲ្យទុក្ខព្រួយ (ឧ. une nouvelle désolante)

désolateur,trice *a.&n.* ដែលធ្វើឲ្យកើតទុក្ខ; ដែលបង្ខិនបង្ខោច ឬ បំផ្លិចបំផ្លាញ (ឧ. fléau désolateur)

désolation *n.f.* ការហិនហោច; វិនាសកម្ម (ឧ. porter la désolation chez l'ennemi); ទុក្ខធ្ងន់ (ឧ. être plongé dans la désolation)

désolé,e *a.* ដែលមានទុក្ខធ្ងន់(ឧ. mère désolée)

désoler *v.t.* បំផ្លិចបំផ្លាញ, បង្ខិនបង្ខោច (ឧ. la guerre a désolé ce

pays); ធ្វើឲ្យកើតទុក្ខធ្ងន់ (ឧ. cette mort me désole)។ *Par ext.* ធ្វើឲ្យពិបាកចិត្ត (ឧ. ce retard me désole) ។ se désoler *v.pr.* កើតទុក្ខ

désolidariser *v.t.* បំបែកសាមគ្គី ។ se désolidariser *v.pr.* បែកសាមគ្គី (ឧ. se désolidariser de ses collègues)

désopilant,e *a.* ដែលធ្វើឲ្យសប្បាយ (ឧ. farce désopilante)

désopiler *v.t.* *Méd.* ធ្វើឲ្យជាស្ទះ ។ désopiler la rate ឬ désopiler នាំសប្បាយ,នាំសើច ។ se désopiler *v.pr.* *Fam.* se désopiler la rate សប្បាយ, សើចច្រើន

désordonné,e *a.* រាត់រាយ, កញ្ចះកញ្ចាយ (ឧ. maison désordonnée); ឥតសណ្ដាប់ធ្នាប់ (ឧ. écolier désordonné)។ *Fig.* ខុសគន្លងធម៌ (ឧ. vie désordonnée)

désordonner *v.t.* កញ្ចះកញ្ចាយ; ធ្វើឲ្យច្របូកច្របល់

désordre *n.m.* ដំណើរគ្មានសណ្ដាប់ធ្នាប់;ភាពឥតរបៀបរៀបរយ;ភាពរយីករយាក (ឧ. vêtement en désordre); ការច្របូកច្របល់ (ឧ. désordre dans une administration); ការជ្រួលច្របល់ (ឧ. causer du désordre)។ *Fig.* ការប្រព្រឹត្តខុសគន្លងធម៌ (ឧ. vivre dans le désordre); ការច្រឡំបល់ (ឧ. jeter le désordre dans les esprits) ។ *Pl.* ជម្លោះ; ចលាចល (ឧ. désordre dans l'Etat); ការធ្វើឲ្យខូច (ឧ. l'abus de l'alcool produit dans l'estomac des désordres irréparables)

désorganisateur,trice *a.&n.* ដែលបង្ខូចរបៀបរៀបរយ;ដែលធ្វើឲ្យច្របូកច្របល់

désorganisation *n.f.* ការធ្វើឲ្យខូច; ការធ្វើឲ្យច្របូកច្របល់; ចលាចល

désorganiser *v.t.* ធ្វើឲ្យខូច (ឧ. le chlore désorganise les tissus) ។ *Fig.* ធ្វើឲ្យខូចការណ៍ (ឧ. désorganiser des plans)

désorientation *n.f.* ការធ្វើឲ្យវង្វេងផ្លូវ; ការវង្វេងផ្លូវ

désorienté,e *a.* ដែលវង្វេងផ្លូវ។ *Fig.* ដែលទាល់ប្រាជ្ញា ឬ ទាល់គំនិត

désorienter *v.t.* ធ្វើឲ្យវង្វេងផ្លូវ។ *Fig.*

ធ្វើឲ្យទាល់ប្រាជ្ញ (ឧ. cette question l'a désorienté)

désormais *adv.* ពីថ្ងៃនេះទៅ,អំណើះតទៅ (ឧ.soyez désormais plus prudent)

désossement *n.m.* ការហូតឆ្អឹងចេញ (ឧ. le désossement d'une volaille)

désosser *v.t.* ហូតឆ្អឹងចេញ (ឧ. désosser un poulet, un poisson)។ *Fig.* ធ្វើឲ្យភ្លាត់ឆ្អឹង; បំបែក (ឧ. désosser une phrase)

désoxydant,e *a.* ដែលធ្វើឲ្យអស់ច្រែះ ឬ ស្នឹម។ *n.m.* ថ្នាំបំបាត់ច្រែះ

désoxydation *n.f.* ការយកច្រែះចេញ (ម.ព. réduction ផង)

désoxyder *v.t.* យកច្រែះចេញ (ម.ព. réduire ផង)

despote *n.m.* អត្តាវសី,អ្នកកាន់អំណាចផ្តាច់ការ (ឧ. Néron fut un cruel despote)។ *Fig.* អ្នកប្រើអំណាច។ *a.* ដែលប្រើអំណាច (ឧ.un mari despote)

despotie *n.f.* អត្តាវសាធិបតេយ្យ

despotique *a.* អត្តាវសិក, ដែលធ្វើតាមអំណាចចិត្ត, ដែលរំលោភ ឬ បំពាន

despotiquement *adv.* ដោយអត្តាវសិក, ដោយរំលោភ, ដោយបំពាន

despotisme *n.m.* អត្តាវសនិយម; អំណាចផ្តាច់ការ(ឧ. le despotisme d'un mari)

despotiste *n.m.* អ្នកអត្តាវសនិយម

desquamation *n.f.* ការស្រកា (ការយកស្រកាចេញ)។ *Méd.* ការជ្រុះស្រកា; ការបែកស្រកា (ពេទ)

desquamer *v.t.* ស្រកា (យក ស្រកា ចេញ)។ se desquamer *v.pr.* បែកស្រកា (ឧ. dans certaines maladies éruptives la peau se desquame)

desquels,desquelles *pr. rel.* ម.ព. lequel

dessablage *n.m.* ការយកខ្សាច់ចេញ (ឧ.le dessablage des allées)

dessabler *v.t.* យកខ្សាច់ចេញ (ឧ. la pluie dessable les allées); ជោសខ្សាច់ទ្រាប់ពុម្ពចេញ (ឧ. dessabler une statue)

dessaisir *v.t.* ដកសិទ្ធិ (ឧ.dessaisir un tribunal d'une affaire); ដកពាក្យ,ដកបណ្តឹង។ se dessaisir *v.pr.* លះបង់, ចោល (ឧ. se des-

saisir de ses livres)

dessaisissement *n.m.* ការដកសិទ្ធិឬដកបណ្ដឹង; ការលះបង់

déssalé,e *a.* សាប, ដែលគ្មានជាតិអំបិល ។ *Fam.* ដែលមានកលល្បិច, សប្បាយល្អល្អាច (ឧ. une fille dessalée)

dessalement *n.m.* ឬ **dessalaison** *n.f.* ឬ **dessalage** *n.m.* ការបន្សាប; ភាពសាប

dessaler *v.t.* បន្សាប (ឧ. dessaler la morue) ។ *Fig. &Fam.* ភ្ញាក់ (ឧ. il commence à dessaler)

dessangler *v.t.* ស្រាយខ្សែពុង ឬ ខ្សែអុក (ឧ.dessangler un cheval)

dessaouler *v.t.* ម.ព. dessouler

desséchant,e *a.* ដែលធ្វើឲ្យស្ងួត (ឧ. vent desséchant) ។ *Fig.* ដែលឲ្យវិនាស (ឧ. doctrine desséchante)

dessèchement *n.m.* ការពង្រីង (ឧ. le dessèchement des polders a enrichi la Hollande); ភាពរីង; ការសម្ងួត; ភាពស្ងួត; ការចុះស្គម ឬ ចុះរីងរៃ

dessécher *v.t.* ពង្រីង, សម្ងួត (ឧ. l'été dessèche les torrents); ធ្វើឲ្យស្គម, ធ្វើឲ្យរីងរៃ ។ *Fig.* ធ្វើឲ្យលែងរំភើប(ចិត្ត) (ឧ. dessécher le cœur)។ se dessécher *v.pr.* រីង, ស្ងួត ។ *Fig.* អស់កម្លាំង, វិនាស

dessein *n.m.* គម្រោងការ(ឧ. former de grands desseins); ចេតនា, បំណង (ឧ. avoir le dessein de...) ; គំនិត ឬ បំណងអាក្រក់; បំណងយកជាគូស្រករ (ឧ. avoir des desseins sur une jeune fille)។

Loc. adv. à dessein ឬ de dessein formé ដោយស្ម័គ្រចិត្ត, ដោយចេតនា(ឧ. faire quelque chose à dessein) ។ à dessein de ឬ à dessein que ដោយមានបំណងនឹង (ឧ. venir à dessein d'entretenir quelqu'un) ។ sans dessein ដោយគ្មានបំណង, ដោយគ្មានគោលបំណងច្បាស់លាស់ ។ faire dessein de មានបំណងនឹង

desseller *v.t.* ដោះកែបចេញ (ឧ. desseller un cheval)

déssemeler *v.t.* បកបាតស្បែកជើងចេញ

desserrage *n.m.* ការបន្ធូរ

desserre *n. Fam.* ការចេញប្រាក់ (ឧ. être dur à la desserre មិនងាយនឹងចេញប្រាក់)

desserrer *v.t.* បន្ធូរ (ឧ. desserrer un nœud); បង្ហើប, បង្ហា (ឧ. desserrer les dents à un malade pour le forcer à boire គាស់ធ្មេញជម្ងឺ (បង្ហាមាត់) ដើម្បីបញ្ចុកទឹក)។ *Fam.* ដាក់មួយដៃ (ឧ. desserrer un coup de poing à quelqu'un)។

Loc. adv. desserrer les nœuds de បន្ធូរចំណង; *au fig.* បន្ធូរចំណងមេត្រីភាព (បន្ថយការភ្ជាប់ទាក់)។ desserrer le cœur បន្ធូរចិត្ត (ធ្វើឲ្យស្រាកទុក្ខ)។ desserrer les dents, les lèvres ឬ la bouche ធ្វើឲ្យនិយាយ។ ne pas (ឬsans) desserrer les dents, la bouche ឬ les lèvres មិនហើបមាត់, មិននិយាយឬយមាត់ (ឧ. assister à une soirée sans desserrer les lèvres)

dessert *n.m.* បង្អែម; ពេលបង្អែម (ឧ. arriver au dessert)។ *Fig.* អ្វីៗដែលបញ្ចប់ជាស្នាពរ

desserte *n.f.* អាហារដែលបន្ថយពីស្ពក; តុដាក់អាហារបន្ថយពីស្ពក; ការទៅកាន់ (ការភ្ជាប់គមនាគមន៍)(ឧ. l'autocar assure la desserte de la plage អូតូការទៅកាន់ឆ្នេរសមុទ្រ)

dessertir *v.t.* គាស់ត្បូងចេញ

dessertissage *n.m.* ការគាស់ត្បូងចេញ

desservir *v.t.* ទៅកាន់ (គមនាគមន៍ពីដំបន់មួយទៅដំបន់មួយ) (ឧ. une ligne de chemin de fer va desservir la région sud du Cambodge; l'avion dessert telle ville)

desservir *v.t.* បន្ថយស្ពក។*Fig.*ព្យាបាទ

dessiccateur *n.m.* ប្រដាប់សម្ងួត (ប្រដាប់ធ្វើឲ្យស្ងួត)

dessiccatif,ive *a.* ដែលធ្វើឲ្យស្ងួត (ឧ. l'huile de lin est dessiccative)។ *n.m.* ថ្នាំសម្ងួត

dessiccation *n.f.* ការហាលឲ្យស្ងួត; ភាពស្ងួត

dessiller *v.t.* បើក (ភ្នែក)។*Fig.* dessiller les yeux à quelqu'un បើកភ្នែកឲ្យ, ធ្វើឲ្យភ្ញាក់ភ្នែក (ប្រាប់ឲ្យ

ញាក់ខ្លួន)

dessin *n.m.* គំនូរ; សិល្បៈខាងគំនូរ ។ dessin d'imitation គំនូរត្រាប់។ dessin linéaire គំនូរបន្ទាត់ (គំនូរសម្រាប់តែងឈើ សម្រាប់គូរផែនទីផ្ទះ ម៉ាស៊ីនជាដើម)។ les arts du dessin សិល្បៈខាងគំនូរ (និម្មាបនកម្ម, ចម្លាក់, វិចិត្រកម្ម)។ dessins animés គំនូរជីវចល ។[ជី-វៈ-ចល់] (គំនូរថតជាខ្សែភាពយន្តឃើញដូចជារស់រវើក) ។ *Fig.* គម្រោងគំនិត (ឧ. le dessin d'une intrigue théâtrale); ទម្រង់ (ឧ. dessin d'un visage)

dessinailler *v.t.* គូរភិសភក់(គូរដោយមិនផ្ចិតផ្ចង់)

dessinateur,trice *n.* ចិត្រករ, អ្នកចេះគូរ, ជាងគំនូរ

dessiner *v.t.* គូរ; ធ្វើឲ្យលេចចេញ (ឧ. robe qui dessine les formes); បង្ហាញ, រៀបរាប់ (ឧ. dessiner un caractère)។se dessiner *v.pr.* ចេញរាង (ឧ. sa taille se dessine bien); លេចឡើង (ឧ. les événements se dessinent)

dessolement *n.m.* ការដាំផ្លាស់សារវិញ (ព.ផ. assolement)

dessoler *v.t.* ដាំផ្លាស់សារវិញ (ព.ផ. assoler)

dessoler *v.t.* បកបាតក្រចកសេះ (ឧ. dessoler un cheval)

dessouder *v.t.* រំលាយបន្សារ

dessoudure *n.f.* ការរំលាយបន្សារ

dessoûler *v.t.* ធ្វើឲ្យបាត់ស្រវឹង ។ *v.i.* បាត់ស្រវឹង

dessous *adv.* ក្រោម (ឧ. s'endormir sur la table et tomber dessous) ។ mettre dessous ផ្តួល, បោះទៅដី; *au fig.* ផ្ចាញ់ (គូប្រជាំង) ។

Loc. adv. là-dessous ក្រោមនោះ (ក្រោមរបស់នោះ); *au fig.* ក្នុងរឿងនេះ, ក្នុងស្ថាននេះ ។ ici dessous ក្រោមទីនេះ, ក្រោមកន្លែងនេះ (ឧ. mettez votre livre ici dessous); *au fig.* ក្នុងរឿងនេះ, ក្នុងស្ថាននេះ។ ci-dessous ក្រោមទីនេះ, ក្រោមកន្លែងនេះ; ខាងក្រោមនេះ, បន្ទាប់ទៅនេះ, តទៅនេះ (ឧ. cela sera expliqué ci-dessous)។ au-dessous ខាង

ក្រោម (ខ. chercher trop haut un objet qui est bien au-dessous); ឯនាយ (ខ. village qui est à 2 kilomètres au-dessous); *au fig.* អន់ជាង (ខ. César fut un grand homme, Alexandre paraît bien au-dessous) ។ de dessous ក្រោម, ក្នុង (ដែលនៅក្រោមគេ ឬ ក្នុងគេ) (ខ. ne regarder que les vêtements de dessous) ។ en dessous ក្រោម (ខ. un habit tout usé en dessous); ដើយល្បិចកល់ (ខ. ruminer toujours en dessous); លាក់ពុត (ខ. un caractère tout en dessous) ។ par-dessous ពីក្រោម (ខ. au lieu de passer par-dessus, passer par-dessous); ពុកខាងក្រោម (ខ. planche vermoulue par-dessous) ។

Pré. ក្រោម (ខ. se cacher dessous la table) ។ de dessous ពីក្រោម (ខ. sortir de dessous la table) ។ par-dessous jambe ឬ la jambe ដោយងាយ, ដោយឥតប្រឹងប្រែង (ខ. battre un concurrent par-dessous jambe) ។ traiter quelqu'un, quelque chose par-dessous jambe ឬ la jambe មិនយកចិត្តទុកដាក់នឹង, មិនប្រយ័ត្ន, មិនយោគយល់, មិនសង្កាស ។

Loc. pré. au-dessous de ក្រោម (ទាបជាង, តិចជាង) (ខ. le thermomètre descend au-dessous de zéro); ខាងក្រោម (ក្រោមទឹក) (ខ. ce village se trouve au-dessous de Phnom-Penh); ក្រោម (មិនដល់, តិចជាង) (ខ. les valeurs au-dessous de mille riels); *au fig.* នៅក្រោម (អន់ជាង) (ខ. cet élève est au-dessous même des médiocres; être au-dessous de sa tâche)

dessous *n.m.* ប៉ែកខាងក្រោម (ខ. le dessous de la table); ប៉ែកខាងខ្នង (ផែនាំពត់) (ខ. le dessous d'une étoffe) ។ dessous de plat ទ្រនាប់ចាន (កាដទ្រាប់ចានស្ងួប) ។ *Fig.* អាថ៌កំបាំង (ខ.

connaître les dessus et les dessous d'une affaire)។ avoir le dessous ឬ du dessous នៅពីក្រោម; ចាញ់, ចាញ់ប្រៀប។

n.m.pl. សំលៀកបំពាក់ទ្រនាប់សម្រាប់ស្រី (ឧ. des dessous élégants)។ *Jeux* dessous des cartes មុខបៀរ (ខាងមានរូបដែលគេច្រើនតែផ្កាប់); *au fig.* ការសម្ងាត់ក្នុងរឿងអ្វីមួយ (ឧ. on ne peut juger les évènements, à moins de connaître le dessous des cartes)

dessous-de-plat *n.m. inv.* ទ្រនាប់ចាន

dessuintage *n.m.* ការជម្រះខ្លាញ់ (ឧ. le dessuintage de la laine)

dessuinter *v.t.* ជម្រះខ្លាញ់ (ឧ. on dessuinte la laine avant de la teindre)

dessus *adv.* លើ (ឧ. Mahomet coupa sa manche plutôt que de réveiller son chat endormi dessus)។ *Fig.* លើនេះ, លើរឿងនេះ, ក្នុងរឿងនេះ, ចំពោះរឿងនេះ (ឧ. ne croyez pas aux promesses des grands, ne comptez pas dessus)។ mettre dessus ពាក់មួក។

Loc. div. mettre la main dessus ចាប់, ចាប់បាន។ mettre le doigt dessus ទាយត្រូវ, ស្មានត្រូវ។ *Fam.* & *fig.* être vent dessus, vent dessous ស្រវឹង។

Loc. adv. là-dessus លើនេះ (លើរបស់នេះ) (ឧ. mettez votre main là-dessus); *au fig.* ចំពោះរឿងនេះ, ក្នុងរឿងនេះ (ឧ. il n'y a rien à craindre là-dessus); នៅពេលនេះ, ដល់ត្រង់នេះ (ឧ. là-dessus je m'en vais)។ ci-dessus ខាងលើនេះ, ពីមុនមកនេះ (ឧ. comme nous l'avons dit ci-dessus)។ au-dessus ខាងលើ (ឧ. une pierre tombale avec une inscription au-dessus); *au fig.* ប្រសើរជាង, ក្រាន់បើជាង (ឧ. Virgile est un grand poète, mais Homère est bien au-dessus)។ en dessus នាខាងលើ

(ឧ. cet oiseau est blanc en dessous et noir en dessus)។ par-dessus ពីលើ (ឧ. il faut tourner les obstacles ou passer par-dessus); នាខាងលើ (ឧ. planche brute par-dessous et travaillée par-dessus); *au fig.* passer par-dessus ធ្វេសប្រហែស, មិនគិតគូរ និយំ។ លើ, លើស ; *au fig.* ជាង (ឧ. aimer quelqu'un par-dessus tout)។ de dessus លើ, ក្រៅ(ឧ. vêtement de dessus)។ sens dessus dessous ផ្កាប់ផ្ការ; ប្រសេងប្រសាង (ឧ. placer les livres sens dessus dessous); រាត់រាយ (ឧ. mettre tout sens dessus dessous dans une maison)។

Pré. លើ (ឧ. chercher dessus et dessous la table)។

Loc. pré. au dessus de លើ (ខ្ពស់ជាង)(ឧ. Nitocris avait placé son tombeau au-dessus d'une des portes les plus remarquables de la ville); លើ (លើសពី) (ឧ. les nombres au-dessus de cent); ឯនាយ(ឧ. au-dessus de Phnom-Penh, on commence à rencontrer du coton); *au fig.* ស្មានបើជាង (ឧ. chacun s'imagine être au-dessus de son voisin; la conscience au-dessus de tout)។ être au-dessus de ses affaires បានចម្រុងចម្រើន ។ au-dessus du vent ត្រូវខ្យល់ ; *au fig.* ផុតគ្រោះថ្នាក់ ។ de dessus ពីលើ (ឧ. tomber de dessus sa chaise)។ ne pas détacher ses yeux de dessus quelqu'un មើលអ្នកណាម្នាក់មិនដាក់ភ្នែក ។ par-dessus ពីលើ (ឆ្លងកាត់ពីលើ) (ឧ. sauter par-dessus la barrière); ពីលើ (ពីក្រៅ) (ឧ. mettre une blouse par-dessus sa veste); ថែមលើ (ឧ. recevoir cent riels par-dessus le prix convenu)។ par-dessus le marché ថែមទៀត,

ថែមលើ; *fam.* ថែមទៀត (ឧ. voici un coup de poing par-dessus le marché)។ par-dessus tout លើសពីអ្វីៗទៀត, ជាងអ្វីៗទៀត។ par-dessus la tête ហួសពេក, ជ្រុលពេក, គួរឲ្យធុញទ្រាន់ (ឧ. avoir une affaire par-dessus la tête)។ par-dessus les yeux ពេញទី, ជាជាប់ទាត។ par-dessus les maisons ហួសប្រមាណ។ passer ឬ sauter par-dessus ធ្វេសប្រហែស, បំភ្លេចចោល។ par-dessus l'épaule ស្បែតនឹង (ឧ. payer ses créanciers par-dessus l'épaule ស្បែតនឹងសងបំណុល)។

Mar. par-dessus bord ឬ le bord ពីលើគែម (ពីនាវាទៅក្នុងទឹក) (ឧ. les marins révoltés jettent le capitaine par-dessus bord)

dessus *n.m.* ប៉ែកខាងលើ (ឧ. le dessus d'une cheminée); ប៉ែកខាងត្រូវ (សំពត់) (ឧ. le dessus et le dessous d'une étoffe); ថ្នាក់លើ, ជាន់លើ (ផ្ទះ) (ឧ. le dessous est occupé, mais le dessus est à louer)។ កម្រាល (ឧ. un dessus de table; un dessus de lit)។ le dessus du panier មុខ (បន្លែ ឬ ផ្លែឈើល្អៗដែលគេដាក់លើបន្លែ ឬ ផ្លែអន់ៗដើម្បីឲ្យឃើញថាជារបស់ល្អ); *au fig.* អ្វីៗដែលប្រសើរជាងគេ (ឧ. le dessus du panier de la société)។

Fig. ការឈ្នះ, ភាពត្រូវលើកឲ្យធំជាងគេ (ឧ. là où l'amour-propre a le dessus, les autres sentiments sont bien faibles)។ prendre le dessus គ្របសង្កត់លើ (ចំពោះរោគ ឬ សេចក្ដីទុក្ខព្រួយ)។ le dessus du vent អត្ថប្រយោជន៍

destin *n.m.* វាសនា (ឧ. nul ne peut fuir son destin); ជីវិត (ឧ. finir son destin)

destinataire *n.* អ្នកទទួល (អ្នកដែលគេផ្ញើរបស់អ្វីមួយឲ្យ) (ឧ. destinataire absent)

destination *n.f.* គោលបំណង (ឧ. la destination réelle des pyramides d'Egypte est

encore incertaine); គម្មដ្ឋាន, ទីដែលគេសំដៅទៅ, ទីទទួល (ឧ. remettre une lettre à sa destination); ការតម្រូវទុកជាមុន

destinatoire *a. Dr.* ដែលកំណត់គោលបំណង (ឧ. une clause destinatoire)

destinée *n.f.* ជតាកស៊ី, វាសនា (ឧ. accuser la destinée de nos malheurs est trop facile; accomplir sa destinée); ជីវិត (ឧ. trancher la destinée de quelqu'un; changer sa destinée)

destiner *v.t.* កំណត់គោលបំណង; ទុកសម្រាប់; បម្រុងទុក (ឧ. destiner son fils au barreau; destiner son argent à l'achat d'une maison); ទុកឲ្យ (ឧ. à qui destinez-vous ce livre?)

destituable *a.* អាចគម្លោះងារបាន

destituer *v.t.* គម្លោះងារ

destitution *n.f.* ការគម្លោះងារ (ឧ. prononcer la destitution d'un officier)

destrier ឬ **dextrier** *n.m.* សេះចម្បាំង

destroyer [dès-tro-yeur] (ព. អ.) *n.m.* នាវាពិឃាត

destructeur,trice *a.&n.* ដែលបំផ្លាញ

destructibilité *n.f.* និស្សាបនីយភាព, ភាពអាចបំផ្លាញបាន

destructible *a.* និស្សាបនីយ, អាចបំផ្លាញបាន

destructif,ive *a.* និស្សាបន, ដែលធ្វើឲ្យវិនាស (ឧ. le pouvoir destructif des eaux)

destruction *n.f.* និស្សាបនកម្ម, វិនាសកម្ម; ការបំផ្លាញ, ការធ្វើឲ្យវិនាស

destructivité *n.f.* និស្សាបនចិត្ត, ចិត្តជាប់ទៅខាងការបំផ្លាញ (ឧ. avoir la manie de la destructivité)

désuet,ète *a.* ដែលផុតសម័យ, ដែលគេបោះបង់ (ឧ. coutume désuète)

désuétude *n.f.* ការបោះបង់, ភាពផុតសម័យ (ឧ. loi tombée en désuétude)

désulfurer *v.t.* យកស្ពាន់ធ័រចេញ (ឧ. on désulfure la fonte avec de la chaux)

désuni,e *a.* ដែលបាក់បែកគ្នា, ដែលទាស់

ទែងគ្នា, ដែលមិនមូលត្រូវគ្នា (ឧ. famille désunie)

désunion *n.f.* ការបំបាក់បំបែក; ការមិនរួមគ្នា, ការបាក់បែក ។ *Fig.* ការទាស់ទែងគ្នា

désunir *v.t.* បំបែកគ្នា (ឧ. désunir des planches); បំបាក់បំបែក, ញែក ។ *Fig.* ធ្វើឲ្យទាស់ទែងគ្នា (ឧ. la question de l'esclavage désunit jadis les Etats américains)

détachage *n.m.* ការបំបាត់ស្នាមប្រឡាក់ (ឧ. détachage des habits)

détaché,e *a.* ដែលរួចពីចំណង; ព្រងើយកន្តើយ (ឧ. air détaché) ។ សេចក្ដីស្រង់ (ពីសៀវភៅ) (ឧ. morceaux détachés) ។ *Mus.* note détachée សនូសញ្ញាដាច់តែឯង

détachement *n.m.* សេចក្ដីព្រងើយកន្តើយ (ឧ. montrer un grand détachement des biens de la terre) ។ *Mil.* ទលសេនា (ក្រុមទាហានដែលចេញប្រតិបត្តិការ) (ឧ. détachement de liaison ទលសេនាសម្ពន្ធការ) ។ ការដាក់ក្រៅតំណែងខ្លួន (ភ្នាក់ងាររាជការ)

détacher *v.t.* បំបាត់ស្នាមប្រឡាក់ (ឧ. vêtement bien détaché) (ព. ដ. tacher)

détacher *v.t.* ស្រាយលែង (ឧ. détacher un chien); ស្រាយ, ដោះ (ឧ. détacher un cordon); ផ្ដាច់ចេញ, បំបែកចេញ (ឧ. détacher les bras du corps); បោល, ភត់ (ឧ. détacher un coup de poing) ។ *Peint.* រំលេច (ធ្វើឲ្យលេចរាងរៅ) ។ *Fig.* ផ្ដាច់ (ឧ. détacher son cœur du monde); ធ្វើឲ្យងាកចេញ (ឧ. détacher quelqu'un d'une habitude); បាត់ឲ្យទៅប្រតិបត្តិការ (ឧ. détacher une estafette); ដាក់ក្រៅតំណែង (ឧ. ដាក់ទៅក្រមម្នាក់ឲ្យធ្វើជាស្នងការប៉ូលិស) (ព.ផ. attacher)

détail *n.m.* ការបំបែកជាភាគ; ការលក់រាយ; ការរៀបរាប់ (ឧ. détail d'un procès) ។ ការរាយមុខល្អិតល្អន់ (ឧ. détail des frais d'un acte); ការណ៍រាយរង ។ *Fam.* c'est un détail ជាការណ៍រាយរង, មិនសំខាន់ទេ ។ en détail *loc. adv.*

ដោយរាយអស់សេចក្តី, ដោយរាយមុខ ល្អិតល្អន់

détaillant,e *a.&n.* ដែលលក់រាយ (ឧ. un commerçant détaillant)

détailler *v.t.* បំបែកជាភាគ (ឧ. détailler une pièce d'étoffe); លក់រាយ(ឧ. détailler du vin)។ *Fig.* រៀបរាប់អស់សេចក្តី, អធិប្រាយ (ឧ. détailler un récit)

détalage *n.m.* ការស្រាទឹម

détaler *v.t.* ស្រាទឹម ។ *v.i. Fam.* រត់បកឹងប្រញាប់ (ឧ. le lièvre détale devant les chiens)

détaxation *n.f.* ការលុបអាករ

détaxe *n.f.* ការបន្ថយ ឬ លស់លាអាករ (ឧ. obtenir une détaxe)

détaxer *v.t.* លស់លាឬបន្ថយអាករ (ឧ. détaxer les denrées destinées à l'exportation)

détecter *v.t.* រកឃើញ, ធ្វើឲ្យដឹង (ឧ. détecter des ondes, des fraudes)

détecteur,trice *a.* សម្រាប់រកលោកធាតុអាកាស (ឧ. lampe détectrice) ។ *n.m.* ប្រដាប់រកឲ្យឃើញ ឬ ឲ្យដឹង (ឧ. détecteur de gaz)

détection *n.f.* ការរកឃើញ (ឧ. la détection des sous-marins, des mines)

détective *n.m.* ភ្នាក់ងារប៉ូលីសអង្កេស, អន្ត្រិត, គិញ

déteindre *v.t.* ធ្វើឲ្យហើរឬឲ្យចេញពណ៌ (ឧ. le chlore déteint les étoffes) ។ *v.i.* ហើរឬចេញពណ៌ (ឧ. les couleurs vives déteignent facilement) ។ déteindre sur quelqu'un មានអានុភាពលើ

dételage *n.m.* ការដោះនឹម

dételer *v.t.* ដោះនឹម ។ *Fig. & fam.* ឈប់,បោះបង់ (ចំពោះកិច្ចការ ឬ ការសប្បាយដែលធ្វើឲ្យអស់កម្លាំង) (ឧ. avec l'âge il faut savoir dételer)

détendre *v.t.* បន្ធូរ (ឧ. détendre un ressort)។ *Fig.* សម្រាក (ឧ. détendre son esprit)

détendu,e *a. Fig.* ស្ងប់,ធូរថើយ (ឧ. atmosphère détendue)

détenir *v.t.* ក្តាប់ទុក, កាន់រក្សា (ឧ. détenir un secret); ឃាត់ទុក (ចំពោះទ្រព្យដែលមិនមែនជាកម្មសិទ្ធិ

ខ្លួន); ឃុំឃាំង, ដាក់គុក (ឧ. détenir arbitrairement quelqu'un)

détente *n.f.* កៃកាំភ្លើង (ឧ. presser la détente); ការបន្ធូរ។ *Fig.* ការសម្រាក (ឧ. les enfants ont besoin de détente); ការធូរថយ។ être dur à la détente ចេញប្រាក់ដោយតឹងតែង(ស្វិតស្វាញ)។ détente dans les relations ការធូរថយក្នុងកិច្ចទាក់ទង (ការចម្រើនក្នុងកិច្ចទាក់ទងគ្នា)។ détente du temps ធាតុអាកាសបានស្រួល (អន់ក្ដៅពេក ឬអន់ត្រជាក់ពេក)។ détente de la maladie ការស្រាកនៃជម្ងឺ

détenteur,trice *a.&n.* អ្នកកាន់កាប់, អ្នកកាន់រក្សា(ទោះមានសិទ្ធិក្ដីគ្មានសិទ្ធិក្ដី) (ឧ. détenteur d'une succession, d'un record)

détention *n.f.* ការកាន់រក្សា (ឧ. la détention des armes de guerre est interdite); ភាពវត្ថុដែលកាន់រក្សា; ការឃុំឃាំង; ភាពអ្នកជាប់ឃុំឃាំងក្នុងគុក។ détention préventive ការឃុំឃាំងមុនសាលក្រមកាត់ទោស ។ ការឃាត់ឃាំង។ détention de marchandises ការឃាត់ឃាំងទំនិញ

détenu,e *a.* ដែលត្រូវឃុំឃាំង។ *n.* អ្នកត្រូវឃុំឃាំង

détergent,e *a. Méd.* ដែលសំអាត, ដែលលាង (ថា détersif ក៏បាន) ។ *n.m.* ឱសថលាងសំអាត

déterger *v.t.Méd.* លាង (ឧ. déterger les intestins; déterger une plaie souillée de terre)

détérioration *n.f.* ការបង្ខូច; ការខូច

détériorer *v.t.* ធ្វើឲ្យខូច(ឧ. le temps détériore les pierres)

déterminable *a.* អាចកំណត់បាន (ឧ. quantité déterminable)

déterminant,e *a.* ដែលសម្រេច (ឧ. cause déterminante); ដែលកំណត់ ឬ បញ្ជាក់

déterminatif,ive *a. Gram.* ដែលបញ្ជាក់

détermination *n.f.* ការបញ្ជាក់; ការកំណត់ (ឧ. la détermination d'une date); ការប្ដេជ្ញា; សេចក្ដីសម្រេចចិត្ត; ភាពលុះ (ឧ. montrer de la détermination)

déterminé,e *a.* ជាក់លាក់(ឧ. heure, époque déterminée); អង់អាច,

លុះ (ឧ. soldat déterminé)

déterminer *v.t.* កំណត់; បញ្ជាក់ (ឧ. Lavoisier détermina la composition de l'air); ញុំាងឲ្យសម្រេចចិត្ត(ឧ. cet évènement m'a déterminé à...); បញ្ជាក់ន័យរបស់ពាក្យ; បណ្ដាលឲ្យ,បង្ក,ញុំាង (ឧ. Samdech Preah Upayuvareach Norodom Sihanouk détermine la renaissance du Cambodge; incident qui détermine une crise)។ se déterminer *v.pr.* សម្រេចចិត្ត, តាំងចិត្ត

déterminisme *n.m.* បច្ចយនិយម

déterministe *a.* នៃបច្ចយនិយម ។ *n.* អ្នកបច្ចយនិយម

déterré,e *n.* សពដែលគាស់ពីដី។*Fig.* &*fam.* avoir l'air d'un déterré ស្លេកស្លាំងដូចខ្មោច

déterrement *n.m.* ការគាស់ពីដី; អាការរលើង

déterrer *v.t.* គាស់ពីដី (ឧ. déterrer un trésor); លើង ។ *Fig.* រកឃើញរបស់ ឬ មនុស្សដែលពិបាករក

déterreur *n.m.* អ្នកគាស់ពីដី, អ្នកលើង ។ *Fig.* អ្នករកឃើញ (ឧ. un déterreur de manuscrit)

détersif,ve *a.&n.* ម.ព. détergent

détersion *n.f.* ការលាងសំអាត (ដោយទឹកឱសថ) (ឧ. la détersion d'une plaie)

détestable *a.* គួរស្អប់ ។ *Par ext.* អាក្រក់ណាស់ (ឧ. temps détestable; humeur détestable)

détestablement *adv.* ដោយគួរស្អប់

détestation *n.f.* សេចក្ដីស្អប់, ការស្អប់ខ្ពើម

détester *v.t.* ស្អប់ (ឧ. détester les bavardages) ; មិនចូលចិត្ត (ឧ. détester la pluie)

détirer *v.t.* ទាញសន្ធឹង

détisser *v.t.* រុះសាច់សំពត់

détonant,e *a.* ដែលឲ្យឮសូរដោយផ្ទុះ ។ explosif détonant រំសេវផ្ទុះឮសូរ

détonateur *n.m.* កិប (សម្រាប់ធ្វើឲ្យផ្ទុះ); វត្ថុធាតុដែលអាចធ្វើឲ្យផ្ទុះ

détonation *n.f.* សូរផ្ទុះ; ការផ្ទុះ

détoner *v.i.* ផ្ទុះ

détonner *v.t.Mus.* ច្រៀងដោយសម្លេងឈ្លើយ ។ *Fig.* មិនស៊ីគ្នា (ឧ. couleurs qui détonnent)

détordre *v.t.* ណា (ចំពោះវត្ថុដែលគ្រញួញ ឬ រមួល)

détorquer *v.t.* បកស្រាយមិនសូវចំ (ឧ. détorquer un texte)

détors,e *a.* រណា (ឧ. fil détors)

détorsion *n.f.* ការណា

détortiller *v.t.* ណា (ដូចរើងគ្រញួញ) (ឧ. détortiller une corde)

détour *n.m.* ការបត់; ផ្លូវបត់ (ឧ. au détours d'un sentier); របត់ (ឧ. le Mékong fait de nombreux détours); ផ្លូវវាង; ការវាង (ឧ. faire un détour) ។ *Fig.* ឧបាយកល (ឧ. les détours de la chicane) ។ s'exprimer sans détour និយាយត្រង់ ៗ ។ sans détour ដោយស្មោះត្រង់

détourer *v.t.* យកព្រំៗដែលព័ទ្ធជុំវិញចេញ (ឧ. détourer un dessin)

détourné, e *a.* វាង (ឧ. sentier détourné) ។ *Fig.* voie détournée ផ្លូវវៀច, ផ្លូវសម្ងាត់ (ដែលគ្មានគេស្គាល់); ផ្លូវវៀចវេរ ។ lieu détourné ទីដាច់ស្រយាល

détournement *n.m.* ការកែបន្លំ (ឧ. détournement de fonds); ការពង្រត់ (ឧ. détournement de mineure)

détourner *v.t.* បង្វែរ (ឧ. détourner un cours d'eau); *au fig.* បង្វែរ (ឧ. détourner la conversation); បង្វែងគំនិត (ឧ. détourner les soupçons) ។ នាំវាង (ឧ. détourner quelqu'un de son chemin); *au fig.* នាំឲ្យបោះបង់ (ឧ. détourner d'une occupation); នាំឲ្យបន្ធូរបង់ (ឧ. détourner quelqu'un de ses soucis); បែរ, ងាក (ឧ. détourner la tête); កែបន្លំ (ឧ. détourner les fonds) ។ *Fig.* បង្អាក់ (មិនឲ្យធ្វើ) (ឧ. détourner d'un projet); បំភ្លៃ (ឧ. détourner le sens d'une phrase) ។ se détourner *v.pr.* ងាកចេញ, បែរចេញ ។ *Fig.* លះបង់ (ឧ. se détourner d'un dessein)

détracter *v.t.* បន្ទាបដោយអយុត្តិធម៌; បង្អាប់គុណូបការ

détracteur,trice *n.* អ្នកបង្អាប់គុណូបការ (ឧ. les jaloux sont d'éternels détracteurs) ។ *a.* ដែល

បង្អាប់គុណូបការ (ឧ. esprit détracteur)

détraction *n.f.* ការបន្ថោក, ការបង្អាប់

détraqué,e *a.&n.* វិកលចរិត

détraquement *n.m.* ការខូច (គ្រឿងយន្ត); ភាពខូច

détraquer *v.t.* ធ្វើឲ្យខូច (គ្រឿងយន្ត) (ឧ. détraquer une pendule); បង្ខូចដំណើរ (សេះ)។ *Fig.* បង្ខូចសតិ (ឧ. détraquer l'esprit)

détrempe *n.f.* ថ្នាំពណ៌ទឹក (ថ្នាំពណ៌លាយនឹងទឹក); វត្ថុលាបថ្នាំពណ៌ទឹក

détrempe *n.f.* ការលត់ដែកឲ្យទន់

détremper *v.t.* លាយទឹក, ជ្រលក់ទឹក (ឧ. détremper de la chaux); ធ្វើឲ្យពពិចប៉ាច់ (ឧ. la pluie a détrempé le chemin)

détremper *v.t.* ស្រង់ពីទឹក; ធ្វើឲ្យស្ងួត

détremper *v.t. Ind.* លត់ដែកឲ្យទន់

détresse *n.f.* សេចក្ដីគ្មានទីពឹង (ឧ. pousser des cris de détresse); ទុក្ខភ័យ(ឧ. famille en détresse); ភ័យអាសន្ន,គ្រោះថ្នាក់ ។ navire en détresse នាវាកំពុងមានគ្រោះថ្នាក់។ គ្រោះថ្នាក់ (ឧ. signaux de détresse)

détresser *v.t.* រុះកម្រងសក់

détriment *n.m.* ការខូចខាត, ការខូចប្រយោជន៍,សេចក្ដីវិនាស (ឧ.causer un grand détriment)។ au détriment de ដោយខូចប្រយោជន៍ដល់, ជាការនាំឲ្យខូចប្រយោជន៍ដល់

détripler *v.t.* បំបែកជាបី

détritique *a. Géol.* ដែលកើតឡើងដោយកំទេច (ឧ. roches détritiques)

détritus *n.m.* កាក, កំទេច

détroit *n.m.* ដៃសមុទ្រ(ឧ. le détroit de Gibraltar relie la Méditerrranée à l'Océan); ច្រកភ្នំ

détromper *v.t.* បំភ្លឺ,បំបាត់ការកាន់ច្រឡំ

détrôné,e *a.* ដែលធ្លាក់រាជ្យ (ឧ. les souverains détrônés)

détrôner *v.t.* ទម្លាក់រាជ្យ(ឧ.détrôner un roi)។ *Fig.* ដកអំណាច, បន្ថយអានុភាព(ឧ.détrôner un usage)

détroussement *n.m.* ការលួចឆក់; ការប្លន់ (តាមផ្លូវ) (ឧ. détroussement des voyageurs)

détrousser *v.t.* ទម្លាក់ (ជើងខោ) (ឧ. détrousser le pantalon ទម្លាក់ជើងខោ) (ព.ផ. retrousser លាត់)។ *Fig.* លួចឆក់,ប្លន់,ដណ្ដើម

(តាមផ្លូវសាធារណៈ)

détrousseur,euse *n.* ចោរលួចឆក់ ឬ ប្លន់អ្នកដំណើរ

détruire *v.t.* វិទ្ធំសនា, រុះ; កំទេច (ឧ. détruire une ville); បង្ហិន, បំផ្លាញ (ឧ. détruire des animaux nuisibles); ធ្វើឲ្យវិនាស; ធ្វើឲ្យខូច(ឧ. la rouille détruit le fer) ។ *Fig.* កំចាត់, បំបាត់ (ឧ. détruire une légende, un abus) ។ se détruire *v.pr.* *Fam.* សម្លាប់ខ្លួនឯង

dette *n.f.* បំណុល (ឧ. être perdu de dettes) ។ dette active បំណុលសកម្ម (ម.ព. actif ផង) ។ dette passive បំណុលអកម្ម(ម.ព. passif ផង) ។ dette publique បំណុលសាធារណៈ (បំណុលរដ្ឋ) ។ *Fig.* បំណុល (ឧបការគុណ) (ឧ. dette de reconnaissance) ។

Loc.div. dettes criardes ម.ព. criard) ។ être perdu de dettes ជំពាក់បំណុលរើខ្លួនមិនរួច (បំណុលច្រើន) ។ *Fig.* avouer la dette ឬ confesser la dette ទទួលខ្លួនខុស ; ទទួលសារភាពថាខ្លួនបានគិតឃាក់រឿងអ្វីមួយ។ payer sa dette au pays ធ្វើទាហាន (ចូលបម្រើប្រទេសជាតិក្នុងរាជការសឹក);មានកូនច្រើន ។ payer sa dette à la nature បង់ពន្ធដី (ស្លាប់) ។ payer sa dette à la société ទទួលទោសប្រហារជីវិត ។ faire sa dette de quelque chose ឬ prendre la dette sur ធ្វើយជួសគេ ។

Prov. qui paye ses dettes s'enrichit បំណុលរលស់បានឈ្មោះថាមានធន (អ្នកសងបំណុលមានគេរាប់អានច្រើន) ។ cent ans de chagrins ne payent pas un sou de dettes ខ្លួនរស់របស់កើត(ការកើតទុក្ខជាការឥតប្រយោជន៍)

détumescence *n.f.* ដំណើរស្រក

deuil *n.m.* មរណទុក្ខ (ឧ. la mort de Turenne fut un deuil national);មរណសញ្ញា(ឧ.porter un deuil); រយៈពេលកាន់ទុក្ខ; ស្លុប (សំពត់សាកសព); ក្បួនហែសព (ឧ. suivre un deuil) ។ *Fig.* ទុក្ខព្រួយ(ឧ. jour de deuil) ។ *Poét.* ភាពងងឹតសូន្យ, ភាពអួរអាប់ (ហាក់ដូច

ការព្រាបឬតាំងទុក្ខ) (ឧ. le deuil de la nature)។ *Fig.* faire son deuil d'une chose កាត់ចិត្តចោលរបស់អ្វីមួយ

deux *a. num.* ពីរ (ឧ. deux livres); ទីពីរ (ឧ. tome deux)។ *Fig.* & *fam.* ប៉ុន្មាន (បន្តិចបន្តួច) (ឧ. à deux pas d'ici នៅប៉ុន្មានជំហានពីនេះ(នៅជិតទីនេះ)។ *n.m.* លេខ២, ថ្ងៃទី២

deuxième *a. num.* ទុតិយៈ, ទីពីរ ។ *n.* មនុស្សឬរបស់ទីពីរ ។ *n.m.* ជាន់ទីពីរ (គ្រឹះស្ថាន)

deuxièmement *adv.* ទី ២ (ក្នុងការរាប់រៀប); ជាគម្រប់ ២

deux-mâts *n.m. inv.* នាវាក្ដោងពីរ

dévalement *n.m.* ដំរុល (ឧ. un dévalement de terrains)

dévaler *v.t.* នាំចុះ (ឧ. dévaler du vin à la cave); ចុះ (ឧ. dévaler une pente)។ *v.i.* ចុះយ៉ាងលឿន, ហូរចុះយ៉ាងលឿន (ឧ. les torrents dévalent des montagnes)

dévaliser *v.i.* លួចយករបស់ជាប់នឹងខ្លួន (សំលៀកបំពាក់នឹងប្រាក់); លួច (ឧ. dévaliser une maison)

dévaliseur,euse *n.* ចោរលួចរបស់ជាប់នឹងខ្លួន

dévalorisation *n.f.* ការចុះថោក(តម្លៃ)

dévaloriser *v.t.* បន្ថោកតម្លៃ (ឧ. dévaloriser une monnaie)។ *Fig.* បង្ខូចតម្លៃ

dévaluation *n.f.* ការបញ្ចុះតម្លៃរូបិយវត្ថុ

dévaluer *v.t.* បញ្ចុះតម្លៃរូបិយវត្ថុ

devancement *n.m.* ការទៅមុនឬដល់មុន (ឧ. devancement d'appel)

devancer *v.t.* ដើរមុន, ធ្វើមុន, ទៅមុន, ដល់មុន (ឧ. les éclaireurs devancent l'armée)។ មានមុន (ឧ. l'aurore devance le jour)។ ឈ្នះ (ឧ. devancer ses rivaux)។ *Mil.* devancer l'appel ស្ម័គ្រចិត្តចូលធ្វើទាហានមុនកំណែន ។ *Fig.* ឈ្នះ

devancier,ère *n.* អ្នកមុន ។ *m. pl.* បុព្វបុរស, ដូនតា (ឧ. imiter ses devanciers)

devant *pré.* មុខ, ខាងមុខ (ឧ. s'asseoir devant le feu; passer devant la maison); ទៅមុខ (ឧ. regarder devant soi); ចំពោះមុខ (ឧ. il ne faut rien dire devant les

indiscrets; porter une affaire devant le tribunal); ចំពោះ (ឧ. tous les citoyens devraient être égaux devant la loi); ខាងមុខ, ក្នុងអនាគត (ឧ. nos aïeux ont traversé l'âge de fer, l'âge d'or est devant nous); មុន (ឧ. la poule ne doit point chanter devant le coq ម.ព. coq ផង; je mettrai désormais ma santé devant toutes choses) ។

Loc. div. devant quelqu'un ឬ devant les yeux de quelqu'un ចំពោះមុខអ្នកណាម្នាក់។ avoir de l'argent devant soi មានប្រាក់សំចៃទុក ។ avoir le temps devant soi មានពេលគ្រប់គ្រាន់ ។ aller devant soi ដើរត្រង់ទៅមុខ (មិនងាកចេញពីផ្លូវ; ដើរទៅមុខដោយគ្មានអើពើនឹងអ្វីសោះ) (ឧ. allez devant vous, Dieu ne vous manquera pas)។ paraître devant Dieu ស្លាប់ ។ *Fam.* passer devant la glace ទៅបង់ប្រាក់នៅបេឡា (ទៅក្រោយបេឡាធិការច្រើនតែមានដាក់កញ្ចក់មួយ) ។ prendre ឬ gagner le devant ឬ les devants ទៅមុន, ធ្វើមុន; *au fig.* គិតមុន (ឧ. si l'on ne prend pas les devants en affaire, on est perdu) ។

adv. ពីមុន, ពីដើម (ឧ. être Gros-Jean comme devant ម.ព. Gros-Jean ផង); មុន, ពីមុខ (ឧ. la paresse va devant, la misère la suit) ។ *Fam.* partir ឬ sortir les pieds devant ស្លាប់ (ធម្មតាគេតែងសែងមឈូសយកខាងចុងជើងទៅមុន) ។

Loc. pré. au-devant de ទៅជួប, ទៅទទួល (ឧ. aller au-devant de quelqu'un); *au fig.* ធ្វើមុន (ដោយដឹងចិត្ត)(ឧ. យើងដឹងថាមិត្តម្នាក់ចង់បានអ្វីមួយ ហើយយើងឲ្យរបស់នោះមុនគេសុំឬពឹងពាក់)។ par-devant ចំពោះមុខ (ឧ. par-devant notaire) ។

Loc. conj. devant que មុន (ឧ. devant qu'il soit deux

jours) ។

Loc.adv. au-devant ទៅជួប (ឧ. il se porte au-devant, lui parle, le cajole) ។ aller au-devant ផ្ដើមទាក់ទង ។ par devant ពីមុខ, ពីខាងមុខ (ឧ. saisir quelqu'un par devant; recevoir une blessure par devant) ។ devant derrière ឬ sens devant derrière បញ្ច្រាស, ផ្ទុយ (មុខជាក្រោយ ក្រោយជាមុខ) (ឧ. mettre son chapeau sens devant derrière) ។ *Pop.* sens devant dimanche ផ្កាប់ផ្ងារ, ច្រងេងច្រងាង ។ ci-devant ម.ក. ci ។

devantier *n.m.* អៀមពាក់ធ្វើការម្យ៉ាង

dévastateur,trice *a.* ដែលបង្ហិនបង្ហោច ។ *n.* អ្នកបង្ហិនបង្ហោច

devanture *n.f.* កន្លែងតាំងទំនិញនៅមុខផ្ទះ; បង្ហាមុខបកងលក់ទំនិញ

dévastateur,trice *a.&n.* ដែលបង្ហិនបង្ហោច

dévastation *n.f.* ការបង្ហិន, ការបំផ្លាញ; ការហិនហោចអស់ (ឧ. les dévastations de la guerre)

dévaster *v.t.* បង្ហិនបង្ហោច

déveinard *n.m.* *Fam.* អ្នកស៊យជាប់

déveine *n.f.* ការស៊យជាប់

développement *n.m.* ការបើកកញ្ចប់; ការលា (ឧ. développement d'une pièce d'étoffe); អភិវឌ្ឍន៍, សេចក្ដីចំរើន (ឧ. développement des sciences, d'un mouvement politique); អធិប្បាយ (ឧ. faire de grands développements); ការលាត្រដាង (ឧ. développement d'une situation); ការលូតលាស់; ការពង្រីក ។ *Phot.* ការលាងរូបថត

développer *v.t.* បើកកញ្ចប់ (ឧ. développer un paquet); លាត្រដាង (ឧ. développer une carte); ធ្វើឲ្យលូតលាស់ ឬ ឲ្យធំធាត់ (ឧ. la gymnastique développe le corps) ។ *Fig.* អធិប្បាយ (ឧ. développer sa pensée) ។ *Phot.* លាងរូបថត ។ se développer *v.pr.* លូតលាស់, ធំធាត់; ចំរើនឡើង (ឧ. la raison se développe avec l'âge)

devenir *v.i.* ទៅជា, ប្រែជា, ក្លាយជា

(ឧ. petit poisson deviendra grand; de riche devenir pauvre) ។ devenir à rien ចុះស្លុម; ថយខ្លាំង ។ *n.m.* ការប្រែប្រួលឆាស់ឆាប់

dévergondage *n.m.* អំពើប្រឡៃប្រហោ (ដំណើរល្បើសល្បង. ក្រឡេកខាម) ។ *Fig.* ដំណើរឃ្លាតឆ្ងាយ (ឧ. dévergondage d'imagination)

dévergondé,e *a.* ប្រឡៃប្រហោ, ដែលប្រព្រឹត្តខុសគន្លង ។ *n.* មនុស្សប្រឡៃប្រហោ

dévergonder (se) *v.pr.* ប្រកាន់កិរិយាប្រឡៃប្រហោ

déverguer ឬ **désenverguer** *v.t.* ដោះសារក្ដោងចេញ

dévernir *v.t.* បំបាត់វែរនី (ធ្វើឲ្យបាត់រលោង)

déverrouillage *n.m.* ការដករនុក

déverrouiller *v.t.* ដករនុក (ឧ. déverrouiller une porte)

devers *pré.* ខាង (ប៉ែកខាង) (ឧ. demeurer devers Takèo); នៅពេល (ឧ. s'en aller devers la fin du spectacle) ។ par devers *loc.pré.* នៅចំពោះមុខ (ឧ. par devers le juge នៅចំពោះមុខចៅក្រម); ជារបស់,ជាកំណាន់; នៅនឹងខ្លួន (ឧ. retenir des documents par devers soi)

devers,e *a.* វៀច, ទេរ, ផ្អៀង ។ *n.m.* ដម្រាល

déverser *v.i.* ផ្អៀង,ទ្រេត(ឧ.ce mur déverse); ក់ពប់; ហូរធាក់ ។ *v.t.* ចាក់,បង្ហូរ (ឧ. déverser le trop-plein d'un seau) ។ *Fig.* បន្ទោបង់, បញ្ចេញ(ឧ.déverser sa rancune sur quelqu'un)

déversoir *n.m.* កន្លែងដែលទឹកហៀរចេញ

dévêtir *v.t.* សម្រាត ។ se dévêtir *v.pr.* ស្រាត

déviateur,trice *a.* ដែលបំបែរ។*n.m.* *Aéron.* គ្រឿងទប់យន្តហោះប្រតិកម្ម

déviation *n.f.* វិមគ្គកម្ម, ការបំបែរ (ឧ. déviation d'un cours d'eau); ការបែរ, ការងាកកំ (ឧ. déviation d'une route); ការបែរ (ឧ. déviation de la lumière); ដំណើរវៀច(ឧ. déviation de la colonne vertébrale)។ *Fig.* ការប្រែប្រួលក្នុង

ពីគោល (ឧ. déviation de principe); ការគិតច្រឡំ

déviationnisme *n.m.* វិបត្តិនិយម (អាកប្បកិរិយាមិនស្របតាមលទ្ធិបក្ស-ពួកខ្លួន)

dévidage *n.m.* ការកាសូត្រឬអម្បោះ; ការស្រាវសូត្រ

dévider *v.t.* កាសូត្រ-អម្បោះ, ស្រាវសូត្រ (ឧ. dévider un cocon); ណា (ឧ. dévider une bobine); ប្រឡះ (ឧ. dévider son rosaire ប្រឡះគ្រាប់ផ្គាំ (រាប់មេធំ)) ។ *Fig.* ដោះស្រាយ, ដោះពិពាក់

dévideur,euse *n.* អ្នកកា (សូត្រ-អម្បោះ)

dévidoir *n.m.* រហាត់; រង្វឹង; រវក់; ប្រ-ដាប់សាបំពង់ជាញទឹក

dévier *v.t.* ងាកចេញ (ឧ. dévier de sa direction) ។ *Fig.* dévier du droit chemin ញ៉ាំងឲ្យប្រព្រឹត្តខុសគន្លង; បំបែរ

devin,devineresse *n.* ហោរា ។ *Fam.* je ne suis pas devin ខ្ញុំមិនមែនហោរាទេ (ខ្ញុំមិនអាចដឹងរឿងដែលគេមិនបានប្រាប់ខ្ញុំនោះបានទេ) ។ *a.* serpent devin ឬ *n.* devin ពស់រូប

devinable *a.* អាចស្មានឬទាយបាន; អាចរកឃើញ (ឧ. énigme aisément devinable)

deviner *v.t.* ទាយ (ឧ. deviner l'avenir); ស្មាន (ឧ. j'avais deviné qu'il pleuvrait); យល់, ស្គាល់ (ឧ. deviner l'homme); ស្រាយ (បញ្ហា), រក (បណ្ដៅ) (ឧ. deviner une énigme)

devinette *n.f.* បណ្ដៅ (ឧ. poser une devinette)

devineur,euse *n.Fam.* អ្នកស្មាន, អ្នកទាយ (ឧ. un plaisant devineur); ហោរា; អ្នកចេះស្រាយបញ្ហាឬចេះរកបណ្ដៅ

dévirer *v.t.* បង្វិលលា, ពន្លាត (ឧ. dévirer un cabestan) ។ dévirer un cordage ពន្លាតខ្សែ

devis *n.m.* ពាក្យសំណេះសំណាល; ការគណនា, មូលប្រមាណ, បញ្ជីតម្លៃ (ឧ. établir un devis)

dévisager *v.t.* ធ្វើឲ្យរហែកមុខ; សម្លឹង, សម្លក់ (ឧ.dévisager quelqu'un d'une manière indiscrète)

devise *n.f.* បាវចនា (ពាក្យដំបូន្មាន) (ឧ.la devise du drapeau est

«Honneur et Patrie»; plutôt souffrir que mourir, c'est la devise des hommes)។ *Fin.* រូបិយប័ណ្ណ ។ être à la devise de quelqu'un នៅបម្រើអ្នកណាម្នាក់

deviser *v.i.* និយាយសំណេះសំណាល (និយាយរៀបរាប់ភក់ទាក់ពីនេះពីនោះ)

dévissage *n.m.* ការដោះខ្ចៅ (ជួនកាលគេថា dévissement)

dévisser *v.t.* ដោះខ្ចៅ ។ *v.i.* ធ្លាក់ (ចំពោះអ្នកឡើងភ្នំ)

de visu (pour l'avoir vu) *loc. lat.* ដោយចក្ខុ, ដោយបានឃើញ (ឧ. parler d'une chose de visu)

dévitaliser *v.t.* យកបណ្តូលធ្មេញចេញ (ដើម្បីឲ្យបាត់ឈឺ) (ឧ. dévitaliser une dent)

dévitrification *n.f.* ដំណើរឡើងស្រអាប់ (ចំពោះកែវ ឬ កញ្ចក់ដែលត្រូវកំដៅយូរ) (ឧ. la dévitrification donne au verre l'aspect de la porcelaine)

dévitrifier *v.t.* ធ្វើឲ្យឡើងស្រអាប់(កែវ, កញ្ចក់)

dévoiement ឬ **dévoiment** *n.m.* រោគចុះរាក

dévoilement *n.m.* ការបើកវាំងមុខ។ *Fig.* ការបង្ហាញ, ការពន្យល់

dévoiler *v.t.* បើកវាំងមុខចេញ,បង្ហាញ (ឧ. dévoiler une statue); ពន្យល់, ប្រាប់ (ឧ. dévoiler un secret)

devoir *v.t.* ជំពាក់ (បំណុល) (ឧ. devoir mille riels)។ *Fig.* ជំពាក់គុណ (ឧ.devoir la vie à quelqu'un បានរួចជីវិតដោយសារ); ត្រូវមាន (ឧ. un fils doit le respect à son père កូនត្រូវមានសេចក្តីគោរពចំពោះឪពុក); ត្រូវតែ, តែងតែ, គង់តែ (មានការចាំបាច់នឹង) (ឧ. ce qui doit arriver; tous les hommes doivent mourir); ត្រូវតែ, គង់តែ (មានករណីយកិច្ចនឹង) (ឧ. on doit servir son pays avec amour; faire ce qu'on doit et laisser faire (le reste) aux autres); ត្រូវតែ,គង់តែ(មានបំណងនឹង) (ឧ. je devais le punir, mais sa mère s'y est opposée; il doit vous ac-

compagner); ប្រហែលជា (ឧ. c'est lui qui doit avoir fait cette sottise); គួរតែ, សមតែ, (ប្រាប់ជំនឿ ឬ សេចក្ដីទុកចិត្ត) (ឧ. vu ce que je sais de lui, il doit être incapable d'une mauvaise action); ត្រូវ(ប្រាប់អនាគត) (ឧ. je dois partir sous peu ខ្ញុំត្រូវចេញទៅក្នុងពេលឆាប់ៗនេះ) ។ devoir de ត្រូវជំពាក់គុណ (ឧ. c'est à lui que je dois d'être encore de ce monde គឺដោយសារគាត់ទើបខ្ញុំនៅរស់) ។ dussé-je, dusses-tu, dût-il ទោះបី, ទុកជា, ថ្វីបើ...ក្ដី (ឧ.dussiez-vous m'accuser; l'homme aime mieux ce qui est grand, dût cette grandeur l'écraser, que ce qui est bon, dût cette bonté le secourir) ។

Loc. div. devoir du retour ខ្វះប្រាក់ដើមខ្លះ (ក្នុងការលក់ដូរ); *au fig.* នៅជំពាក់គុណ ។ devoir plus d'argent qu'on est gros ឬ devoir à Dieu et à diable ឬ devoir au tiers et au quart ឬ devoir de tous côtés ជំពាក់គេគ្រប់ទិស, ជំពាក់គេច្រើន ។ en devoir à quelqu'un នៅជំពាក់ខ្លះទៀត; នៅមិនទាន់បានដាក់ទណ្ឌកម្មឲ្យ ។ n'en devoir guère ឬ n'en devoir rien មិនចាញ់, មិនអន់ជាង (ឧ. j'ai vu les beautés du Nil, ses bords n'en doivent rien à ceux du MéKong)។ ne s'en devoir guère មានកំហុស ឬ មានចរិតអាក្រក់ខ្លាំងដូចគ្នា ។ devoir tribut គេចមិនរួច, ចៀសមិនផុត (ឧ. une femme toujours doit tribut à la mode) ។

Dr. jusqu'à due concurrence ទាល់តែគ្រប់ចំនួនប្រាក់ (ឬចំនួនរបស់) ដូចមានចែងមកហើយ។ en bonne et due forme តាមទម្រង់ការត្រឹមត្រូវ ។

n.m.inv. របស់ដែលនៅជំពាក់, អ្វីៗដែលត្រូវបាន(ឧ.ne demander que son dû); អ្វីដែលត្រូវធ្វើ (faire le dû de sa charge) ។

Prov. qui doit a tort អ្នកណាជំពាក់ អ្នកនោះខុស(ច្បាប់តែងតែឲ្យ

ដាក់កំហុសទៅលើកូនបំណុល) (ម.ព. dette និង) ។qui a terme ne doit rien កាលកំណត់មិនទាន់ដល់ មិនត្រូវខ្វល់នឹងបំណុល (គេមិនអាចបង្ខំឲ្យសងបំណុលមុនកាលកំណត់បានឡើយ)។quand on doit, il faut payer ou agréerកាលណាជំពាក់បំណុលត្រូវតែសងឬប្រើពាក្យល្អ។fais ce que dois, advienne que pourra ករណីយកិច្ចត្រូវតែបំពេញទុកជាយ៉ាងណាក៏ដោយ

devoir *n.m.* ករណីយកិច្ច (ឧ. s'acquitter de son devoir)។ *Par plais.* ការចាំបាច់, វត្តចាំបាច់ (ឧ. le premier devoir d'une femme est d'être jolie); កិច្ចការ (ឧ. il est à son devoir); កិច្ចការស៊ើស្ប (ឧ. finir un devoir)។ *Par ext. pl.* សេចក្ដីគួរសម (ឧ. rendre ses devoirs à quelqu'un)។ សមាគមកម្មករ (ឧ. les compagnons du devoir)។

Loc. div. derniers devoirs ពិធីឈាបនកិច្ច ។ en devoir de ហៀបនឹង, ប្រុងប្រៀបជាស្រេចនឹង (ឧ. nous étions à table, plusieurs, joyeux, en devoir de bien faire)។ faire son devoir ក្លាហានក្នុងការប្រយុទ្ធ។ rentrer dans le devoir ឬ dans son devoir ព្រមចំណុះវិញ, មានចិត្តស្រួលវិញ។ramener, remettre ឬ ranger quelqu'un à son devoir បង្ខំឲ្យបំពេញករណីយកិច្ចខ្លួន។ se ranger à son devoir ធ្វើការនៃលខ្លួនត្រូវធ្វើ ។ croire du devoir ឬ de son devoir de យល់ថាគួរនឹង, យល់ថាត្រូវតែ។ il est du devoir de មានករណីយកិច្ចនឹង ។ je lui apprendrais son devoir ខ្ញុំនឹងបង្ខំឲ្យបំពេញករណីយកិច្ចឬខ្ញុំនឹងធ្វើទោសបើវាមិនបំពេញករណីយកិច្ច។ se mettre en devoir de រៀបចំ,ចាប់ផ្ដើម ។ devoir conjugal ការរួមសង្វាស

dévole *n.f. Fig.* être en dévole ចាញ់, ខាត

dévoler *v.i. Fam.* ចាញ់, ខាត

dévoltage *n.m.* ការបន្ថយកម្លាំងអគ្គិសនី

dévolter *v.t.* បន្ថយកម្លាំងអគ្គិសនី

dévolu,e *a.* ដែលធ្លាក់ពីម្នាក់ទៅម្នាក់ទៀត;

ត្រូវបានដោយសិទ្ធិ (ឧ.héritage dévolu à l'Etat) ។ *n.m.Fam.* jeter son dévolu (ឬun dévolu) sur ចង់បាន, រើសយក(ចូលចិត្ត) (ឧ. et le diable a sur nous jeté son dévolu)

dévolutif,ive *a. Dr.* ដែលឲ្យធ្លាក់ពីម្នាក់ទៅម្នាក់ទៀត (ឧ.appel dévolutif)

dévolution *n.f. Dr.* ការប្រគល់ឲ្យអ្នកណាម្នាក់នូវរបស់របរយកពីអ្នកដទៃ (ឧ. dévolution des biens de presse); ការជាប់មរតក; ការជាប់ឲ្យមានអំណាចព្យាបាល

dévorant,e *a.* ដែលខាំហែកស៊ី(ឧ.lion dévorant)។*Fig.* ដែលធ្វើឲ្យវិនាសយ៉ាងរហ័ស (ឧ. flamme dévorante); ហួសហេតុ; មិនចេះស្កប់ (ឧ. faim dévorante)

dévorateur,trice *a.* ដែលខាំហែកស៊ី; ដែលធ្វើឲ្យវិនាសយ៉ាងរហ័ស (ឧ.une passion dévoratrice)

dévorer *v.t.* ខាំហែកស៊ី (សត្វសាហាវ) (ឧ.le lion dévore sa proie); កកេរស៊ី (ឧ. les chenilles dévorent les feuilles des arbres)។ *Par anal.* ស៊ីឡើបឡប់ (ឧ. dévorer son diner)។*Fig.* ធ្វើឲ្យវិនាស (ឧ.les flammes qui dévorent des chef-d'œuvre; dévorer sa fortune)។ *Fam.* dévorer quelqu'un បង្ហិន(ឧ.le malheureux! mais ils vont le dévorer) ។ លេប (យកអស់) (ឧ. l'impôt dévore le plus clair de ce que l'on gagne)។ ខំទប់ (ឧ. dévorer ses larmes, sa douleur, un affront) ។ ទទួលដោយរីករាយ(ឧ.on écoute avidement, on dévore la calomnie)។ ប្រញាប់ (ចង់ឲ្យបានសម្រេចឆាប់)(ឧ.dévorer les minutes, l'avenir) ។ dévorer des yeux សម្លឹងមិនដាក់ភ្នែក ។ dévorer un livre អានសៀវភៅយ៉ាងរហ័ស ។ dévorer l'espace រត់យ៉ាងលឿន។ ធ្វើឲ្យរីងរៃ (ឧ.l'ennui le dévore) ។

se dévorer *v.pr.&Fig.* ព្រួយខ្លាំង, កើតទុក្ខខ្លាំង ។ *Fam.* អេះខ្វាចខ្លាំង; ប្រខាំស៊ីគ្នា (ឧ. les brochets se dévorent les uns les

autres) ។ ត្រវិនាស

dévoreur,euse *n.* អ្នកខាំហែកស៊ី; អ្នកអានយ៉ាងរហ័ស (ឧ. dévoreur de livres)

dévot,e *n.m.* ធម្មនិដ្ឋ, ដែលស៊ប់ក្នុងសាសនា (ឧ. Molière a raillé les faux dévots) ។ *Fig.* អ្នកស្ម័គ្របំពោះ (ឧ. les dévots du pouvoir)

dévotement *adv.* ដោយធម្មនិដ្ឋា, ដោយស៊ប់ក្នុងសាសនា; ដោយស្ម័គ្របំពោះ

dévotion *n.f.* ធម្មនិដ្ឋា, ការស៊ប់ក្នុងសាសនា (ឧ. l'hypocrisie de la dévotion est la plus impardonnable de toutes) ។ faire ses dévotions សារភាព ។ être à la dévotion de quelqu'un ស្ម័គ្របំពោះអ្នកណាម្នាក់

dévoué,e *a.* ភក្ដី, ស្ម័ (ឧ. un ami dévoué)

dévouement *n.m.* ភក្ដីភាព, ចិត្តភក្ដី, ចិត្តស្ម័; ការបូជាខ្លួនចំពោះ (ឧ. rien n'égale le dévouement d'une mère; compter sur le dévouement de quelqu'un)

dévouer *v.t.* បូជាចំពោះ(ឧ.dévouer ses enfants à la patrie); ដាក់ឡង់ (ឧ. dévouer quelqu'un à la haine publique) ។ se dévouer *v.pr.* មានភក្ដីភាព, បូជាខ្លួន (ឧ. se dévouer pour le salut de tous)។ se dévouer à quelqu'un មានភក្ដីភាពចំពោះ, ស្ម័គ្រ ឬ ស្ម័ស្លាប់រស់ជាមួយ

dévoyé,e *a.&n.* ដែលដើរខុសផ្លូវ (ឧ. voyageur dévoyé) ។ *Fig.* ខុសគន្លងធម៌ (ឧ. esprit dévoyé)

dévoyer *v.t.* ធ្វើឲ្យងាកចេញពីផ្លូវ ។ *Fig.* បង្វែរ។ se dévoyer *v.pr.* ងាកចេញពីផ្លូវល្អ, ដើរខុសគន្លងធម៌

dévrillage *n.m.* ការលាខ្សែ (ការធ្វើឲ្យបាត់រមួល)

dextérité *n.f.* ហត្ថកោសល្យ, ភាពប៉ិនប្រសប់ដៃដៃ (ឧ. la dextérité d'un prestidigitateur)។ *Fig.* សេចក្ដីឆ្លៀវឆ្លាស(ឧ.conduire une affaire avec dextérité)

dextralité *n.f.* ការប្រើដៃស្ដាំ

dextre *a.* ស្ដាំ, ខាងស្ដាំ ។ *n.f.* ដៃស្ដាំ

dextrement *adv.* ដោយហត្ថកោសល្យ, ដោយឆ្លៀវឆ្លាស

dextrogyre *a.* ដែលបែរទៅខាងស្តាំ; ដែលបំបែរទៅខាងស្តាំ

dextrorsum *a. inv. &adv.* ដែលទៅពីឆ្វេងទៅស្តាំ (តាមដំណើរទ្រនិចនាឡិកា) (ព.ផ. senestrorsum)

dextrose *Chim.* ម.ព. glucose

dey *n.m* ព្រះចៅដេ (ប្រមុខនៃអ័លហ្សេរីមុន គ.ស. ១៨៣០)

dia! *int.* ឆ្វេង! (សំម្រែកអ្នកបររទេះដើម្បីសេះឲ្យងាកទៅឆ្វេង) ។ n'entendre ni à huhau (ឬ à hue) ni à dia មិនព្រមស្តាប់សេចក្តីពន្យល់អ្វីសោះ

diabète *n.m.* មធុមេហរោគ, រោគទឹកនោមផ្អែម

diabétique *a.* នៃរោគទឹកនោមផ្អែម ។ *n.* អ្នកកើតរោគទឹកនោមផ្អែម

diable *n.m.* ខ្មោចបិសាច (ឧ. être possédé du diable) ។ *Par anal.* ឬ *par iron.* c'est un méchant diable គឺជាមនុស្សកំណាច ឬពិបាកដឹកនាំ ។ c'est un bon diable គឺជាមនុស្សស្លូត ។ c'est un diable que cet enfant-là ក្មេងនេះពិសហួសពេក ។ c'est un diable pour l'adresse គឺជាអ្នកប្រសប់ណាស់ ឬឆ្លាតណាស់ ។ c'est un pauvre diable គឺជាមនុស្សខ្សត់ណាស់។ c'est un grand diable គឺជាមនុស្សមាឌធំ(ហួសធម្មតា)។ c'est un diable à quatre គឺជាមនុស្សពិស, គឺជាមនុស្សគួរឲ្យខ្លាច ។ un diable de temps អាកាសក្តៅណាស់ ។ un diable de tour ល្បិចអាក្រក់ណាស់។ une diable d'affaire ការកិច្ចពិបាកដោះស្រាយឬឲ្យធុញទ្រាន់។ au diable កុំនឹកនាដល់ (ឧ. au diable les affaires, pour ce soir!)។ au diable soit, le diable soit de ឬ au diable (ពាក្យជាក់បណ្តាសា)(ឧ. au diable soit le bavard!; le diable soit de toi !)។

Loc. div. du diable ឬ de tous les diables ខ្លាំងណាស់, ព្រៃពេក, ជាទីបំផុត (ឧ. un froid du diable; un tapage de tous les diables); ក្លៀវក្លា, ខ្លាំងក្លា (ឧ. quel homme du diable!) ។ comme un diable ឬ comme un beau diable ឬ comme tous les diables ដោយខឹងខ្លាំង, ដូចជា

អ្នកខឹងខ្លាំង (ឧ. se démener comme un beau diable) ។ comme diable en miracle ឬ en miracles ដោយគ្មានហេតុផល, ដោយពាយងាយ ។ le diable et son train របស់ផ្សេងៗទៀតជាច្រើន (ឧ. mitonner une affaire de contrebande: cigares, étoffes, liquides, le diable et son train) ។ pas pour un diable ឬ pas pour un beau diable មិនវេស, ស្បិត, ស្អុះ ។ être possédé du diable ខ្មោចចូល; *au fig.* ជាប់ចិត្តខ្លាំងក្នុងកាម ។ avoir le diable au corps ហើសហួន, ប្រឡេត ។ donner son âme au diable ត្រូវគ្នានឹងខ្មោច ។ se donner au diable ខំខ្លាំង; អស់សង្ឃឹមឬខឹងខ្លាំង (ឧ. quelle vie! je me donne au diable) ។ donner ឬ envoyer au diable, à tous les diables ឬ à tous les cinq cents diables ប្រទេចផ្តាសាឬច្រានចេញដោយកំហឹង ។ aller au diable, à tous les diables ឬ au diable Vauvert ទៅឆ្ងាយណាស់, ទៅបាត់, បាត់ស្រឡះ; មិនបានសម្រេច (ម ព. vauvert ផង) ។ être au diable ទៅឆ្ងាយ, មិនដឹងជាទៅឯណា ។ faire le diable ឬ dire le diable contre quelqu'un ធ្វើអាក្រក់ចំពោះ, និយាយបង្កាច់ដោយឥតមេត្តា ។ faire le diable ឬ faire le diable à quatre បន្ទឺស្អូរគេគ្រឹកគគ្រេង; ធ្វើឡូវាយពពាយ; ប្រឡេត ។ se démener comme un diable dans un bénitier ម.ព. démener (se) ។ ne valoir pas le diable គ្មានតម្លៃអ្វីសោះ ។ ne craindre ni Dieu ni diable គ្មានខ្លាចអ្វីសោះ, គ្មានអ្វីទប់ឬរាំងបានសោះ ។ ne croire ni à Dieu ni à diable មិនជឿសោះ ។ brûler une chandelle au diable បញ្ជោរអ្នកកាន់អំណាចអយុត្តិធម៌ (ដើម្បីទាញផលប្រយោជន៍អ្វីមួយ) ។ crever l'œil du diable (ឬ au diable) បានសម្រេចទោះជាមានការច្រណែនឈ្នានីសយ៉ាងណាក្តី ។ tirer le diable par la queue រស់នៅដោយគ្រដាបគ្រដួស (ដោយពិបាកខ្លាំង) ។

loger le diable dans sa bourse គ្មានមួយសេនសោះ ។ être battu du diable គ្មានឈប់ឈរសោះ, គ្មានសម្រាកសោះ ។ le diable bat sa femme et marie sa fille ភ្លៀងចែងថ្ងៃ, ភ្លៀងល្ហាល (ភ្លៀងបើកថ្ងៃ) ។ courir comme si le diable vous emportait រត់យ៉ាងលឿន ។ le diable s'en rit ឬ le diable ne fait qu'en rire គួរឲ្យអស់សំណើចណាស់; មិនគួរឲ្យអាណិតសោះ(ចំពោះហេតុការណ៍អាក្រក់អ្វីមួយ) ។ le diable chante la grand'messe ធ្វើឫកជាអ្នកមានមេត្តាធម៌ ឬ ជាអ្នកមានចរិតល្អ (ចំពោះមនុស្សលាក់ពុត) ។ c'est le diable ឬ c'est là le diable ឬ voilà le diable នេះជាការពិបាកបំផុត ឬ ជាការអាក្រក់បំផុត ។ ce serait bien le diable si គួរឲ្យឆ្ងល់ណាស់បើ ។ c'est le diable à confesser គឺជាការពិបាកបំផុត ។ il n'est pas si diable qu'il est noir គាត់មិនមែនជាមនុស្សកាចដូចជាគេស្មាននោះទេ ។ cela se fera, ou il faudra que le diable s'en mêle (à moins que le diable ne s'en mêle, si le diable ne s'en mêle; veuille Dieu, veuille diable) ការនេះមុខជាសម្រេចទោះបីមានឧបសគ្គយ៉ាងណាក្ដី ។ le diable s'en mêle មានដំណើរមិនល្អ (ចំពោះកិច្ចការដែលបែរទៅជាមិនស្រួលវិញ) ។ quand le diable y serait ឬ quand se serait le diable ទោះជាមានឧបសគ្គយ៉ាងណាក៏ដោយ; ទោះជាប្រើមធ្យោបាយយ៉ាងណាក៏ដោយ ។ le diable n'y verrait goutte ពិបាកយល់ណាស់ ។ le diable en prendrait les armes ទុកជាអ្នកណាក៏អន់ចិត្តដែរ ។ le diable est déchaîné គួរណាស់ក្រែងមានភ័យ ឬ ទុក្ខខ្លាំង ។ le diable n'y perd rien តែសំបកក្រៅទេ (ចំពោះអ្នកដែលធ្វើឫកជាមនុស្សល្អ) ។ le diable ne lui ferait pas faire គ្មាននរណាអាចធ្វើឲ្យមនុស្សនេះបោះបង់គំនិតបានឡើយ ។ le diable pourrait mourir que je n'hériterais pas de ses cornes ខ្ញុំមិនដែលមានលាភម្ដងសោះ ។

il n'est pas plus dévot que le diable n'est saint មនុស្សនេះគ្មានជឿសាសនាបន្តិចបន្តួចសោះ។ quand il dort, le diable le berce ជាមនុស្សព្រួយបារម្ភហើយចេះតែកើនគំនិតចង់ធ្វើអាក្រក់ជានិច្ច ។ il fait le valet du diable ធ្វើលើសពីគេសុំឲ្យធ្វើ។ il mangerait le diable et ses cornes ជាអ្នកស៊ីច្រើន ។ femme qui a la beauté du diable ស្ត្រីមិនល្អទេ តែមានសម្រស់គួរឲ្យគេស្រឡាញ់ច្រើន។ avoir des diables bleus ចេះតែស្រងេះស្រងោច ។

a. ក្អេងក្អាង; អាក្រក់ (ឧ. il y a des ennemis si diables !)។

Loc. adv. en diable ជាទីបំផុត (ឧ. cette eau-de-vie est forte en diable ស្រានេះខ្លាំងជាទីបំផុត)។ à la diable អាក្រក់ណាស់ (ឧ. être coiffé à la diable; agir à la diable)។

Prov. le diable était beau quand il était jeune ឲ្យតែនៅក្មេងចេះតែល្អទាំងអស់ ។ le diable sait beaucoup parce qu'il est vieux មនុស្សចាស់មានពិសោធន៍ច្រើន ។ quand le diable fut vieux, il se fit ermite មនុស្សទិលខូចពីក្មេងច្រើនតែល្អពេលចាស់ ។ il vaut mieux tuer le diable que si le diable vous tuait គួរតែវាយពស់សម្លាប់កុំទុកឲ្យវាចឹកយើង ។ le diable n'est pas toujours à la porte d'un pauvre homme អ្នកមានទុក្ខវេទនាតែងមានពេលស្រាកខ្លះ ។ le diable est bien fin ! ប្រយ័ត្នកុំចូលអន្ទាក់តណ្ហា (ប្រយ័ត្នកុំឲ្យធ្លោយដោយចំណង់)។ ce qui vient du diable retourne au diable ទ្រព្យបានដោយទុច្ចរិតគង់តែវិនាសវិញ ។ c'est péché de calomnier le diable មិនត្រូវនិយាយបង្កាច់អ្នកណាសោះ ទោះជាជនអាក្រក់ក្តី

diablement *adv. Fam.* ដោយហួសប្រមាណ, ដោយហួសហេតុ

diablerie *n.f.* អំពើអាពាន់ (ឧ. la diablerie florissait au moyen âge); ពុតជាយ; ដំណើររពឹលរពូច (ឧ. il faut être indulgent aux

diableries des enfants) ។ *pl.* រឿងល្ហោនមានខ្មោចបិសាច

diablesse *n.f.* ខ្មោចបិសាចញី ។ *Par ext.* ស្ត្រីកំណាច។ une bonne diablesse ស្ត្រីសប្បាយរីករាយ។ une grande diablesse ស្ត្រីមាឌធំ ។ une pauvre diablesse ស្ត្រីតោកយ៉ាក ។ *a.* ពើស, កាច (ឧ. une femme diablesse est quelquefois pire qu'un vrai diable)

diableteau ឬ **diabloteau** *n.m.* កូនខ្មោចបិសាច

diablotin *n.m.* កូនខ្មោចបិសាច ។ *Fig.* ក្មេងពើស

diabolique *a.* នៃខ្មោចបិសាច (ឧ. tentation diabolique); កំណាច; អាក្រក់; ចង្រៃ (ឧ. invention diabolique); ពិបាកណាស់ (ឧ. chemin diabolique)

diaboliquement *adv.* ដោយកំណាច; ចង្រៃ

diacre *n.m.* ឌីយ៉ាក្រ៍ (អនុសង្ឃ) (ឧ. le diacre sert le prêtre ou l'évêque à l'autel)

diadème *n.m.* បញ្ចរត (ឧ. ceindre le diadème) ។ *Fig.* រាជ្យ (ឧ. usurper le diadème); ក្បាំងណា, ឋេបមុខ

diagnose *n.f.* សិល្បៈខាងរោគវិនិច្ឆ័យ; វិធីវិនិច្ឆ័យរោគ

diagnostic *n.m.* រោគវិនិច្ឆ័យ, វេជ្ជព្យាករណ៍ (ឧ. le diagnostic aide le traitement)

diagnostique *a.* នៃសញ្ញាប្រាប់រោគ (ឧ. les signes diagnostiques de la fièvre typhoïde)

diagnostiquer *v.t.* វិនិច្ឆ័យរោគ

diagonal,e,aux *a.* វិជ្ជកោណ។ *n.f.* វិជ្ជកោណ (ឧ. les diagonales d'un rectangle sont égales) ។ en diagonale បញ្ឆៀង (ឧ. traverser une rue en diagonale)

diagonalement *adv.* តាមវិជ្ជកោណ, ដោយបញ្ឆៀង (ឧ. traverser une place diagonalement)

diagramme *n.m.* វិជ្ជលេខ

dialectal,e,aux *a.* នៃគ្រាមភាសា (ឧ. forme dialectale)

dialecte *n.m.* គ្រាមភាសា (ឧ. le dialecte normand)

dialecticien,enne *n.* វិចារវិទូ

dialectique *a.* នៃវិចារវិទ្យា (ឧ. les

procédés dialectiques)។ *n.f.* វិចារវិទ្យា

dialectiquement *adv.* តាមរបៀបវិចារវិទ្យា, ដូចវិចារវិទ្យា

dialectologie *n.f.* គ្រាមភាសាវិទ្យា

dialogique *a.* ដែលសរសេរជាសេចក្ដីសន្ទនា (ឧ. discussion dialogique)

dialogisme *n.m.* សិល្បៈខាងសន្ទនា

dialogue *n.m.* សំវាទ, ការសន្ទនាគ្នាច្រើន; សៀវភៅតែងជាសេចក្ដីសន្ទនា

dialoguer *v.i.* សន្ទនា។ *v.t.* រៀបរៀងជាសេចក្ដីសន្ទនា (ឧ. dialoguer une scène)

dialoguiste *n.m.* អ្នកនិពន្ធសេចក្ដីសន្ទនាក្នុងខ្សែភាពយន្ត

dialypétale *a. Bot.* វិយុត្តទល [វិ-យុត-តៈ-ទៈ-លី], ដែលមានត្របកដាច់ពីគ្នា (ផ្កា)

dialysépale *a. Bot.* ដែលមានត្របកក្រៅដាច់ពីគ្នា

diamant *n.m.* ពេជ្រ; រង្វាន់ដល់អ្នកប្រតិបត្តិមតិកសាសន៍ ។ édition diamant សៀវភៅខ្នាតតូចណាស់

diamantaire *a.* ដែលមានពន្លឺស្រដៀងពេជ្រ (ឧ. pierres diamantaires) ។ *n.m.* ជាងច្នៃពេជ្រ; អ្នកលក់ពេជ្រ

diamanté,e *a.* ដែលដាំពេជ្រ; ដែលមានពេញកំទេចកែវ ឬ កំទេចដែក (ឧ. fleurs diamantées)

diamanter *v.t.* ធ្វើឲ្យចេញពន្លឺដូចពេជ្រ (ឧ. les rayons du soleil diamantent les gouttes de rosée)

diamantifère *a.* ដែលមានពេជ្រ (ឧ. terrain diamantifère)

diamantin,e *a.* ដែលរឹងឬមានរស្មីដូចពេជ្រ

diamétral,e,aux *a.* នៃវិជ្ឈមាត្រ (ឧ. ligne diamétrale)

diamétralement *adv.* តាមវិជ្ឈមាត្រ។ *Fig.* ដោយដាច់ខាត, ពេញទី (ឧ. le spiritualisme et le matérialisme sont diamétralement opposés)

diamètre *n.m.* វិជ្ឈមាត្រ (បន្ទាត់ពុះកណ្ដាលមណ្ឌល) (ឧ. le diamètre, qui partage la circonférence en deux parties égales, est la plus grande des cordes)

Diane *n. propre* នៃទេព

diane *n.f.* ការទូងស្គរ ឬ ផ្លុំត្រែដាស់ក្នុងពេលព្រលឹម (ឧ. battre, sonner la diane)

diapason *n.m.* ផ្លូវសម្លេង (សម្លេងតូចធំទាំងឡាយ នៃមនុស្សម្នាក់ឬគ្រឿងភ្លេងមួយ) (ឧ. le diapason d'une flûte); គ្រឿងដែកថែបម្យ៉ាងដែលញ័រហើយឮសូរ«ឡា»។ *Fig.* se mettre au diapason តែខ្សែតាម; ធ្វើតាម (ឧ. se mettre au diapason de quelqu'un)

diapasonner *v.t.* ញុំាងឲ្យធ្វើតាម

diaphane *a.* ភ្លឺពើល (ឧ. le verre dépoli est diaphane); ថ្លាឆ្វេង (ឧ. l'eau est diaphane)

diaphanéité *n.f.* ភាពថ្លាឆ្វេង (ឧ. on sait que l'opération de la cataracte consiste à enlever le cristallin qui a perdu sa diaphanéité)

diaphorèse *n.f.* ការបែកញើស

diaphorétique *a.* ដែលឲ្យបែកញើស។ *n.m.* ថ្នាំបែកញើស

diaphragmatique *a.* នៃឧរប្រាចីរ, នៃភាំង, នៃសន្ទះ

diaphragme *n.m.* ឧរប្រាចីរ (សន្ទះខណ្ឌទ្រូងនឹងពោះ) (ឧ. les contractions anormales du diaphragme provoque le hoquet); សន្ទះប្រមុះ។ *Bot.* ភាំងក្លបផ្លែឈើ ។ *Phot.* ប្រហោងសន្ទះ (សម្រាប់បញ្ចូលពន្លឺក្នុងប្រដាប់ថតតាមបំណង)

diaphragmer *v.t.* ឲ្យមានសន្ទះ។ *v.i.* បង្រួមប្រហោងសន្ទះ (ប្រដាប់ថតរូប)

diaphyse *n.f.* អដ្ឋិខណ្ឌ, ដងឆ្អឹង

diapositive *n.f.* រូបថតផ្តិតលើកែវ

diapré,e *a.* ចម្រុះពណ៌

diaprer *v.t.* ចម្រុះពណ៌ ។ *Fig.* លំអដោយពណ៌ចម្រុះ

diaprure *n.f.* ពណ៌ចម្រុះ (ឧ. les diaprures des prairies)

diarrhée *n.f.* រោគចុះរាក (ឧ. les fruits verts donnent la diarrhée)

diarrhéique *a.* នៃរោគចុះរាក (ឧ. flux diarrhéique)

diastase *n.f.* វិភេទនាស [-ភេ-ទ:-ន:-] (ឧ. toutes les transformations digestives et les réactions du métabolisme

cellulaire sont sous la dépendance des diastases)

diastasique *a.* នៃវិភេទនរស

diathermane *a.* ដែលកំដៅ ឬ ចំហាយអាចឆ្លងបាន (ឧ. le mica est très diathermane)

diathermie *n.f.* ឧណ្ហតិកិច្ចា, វិធីព្យាបាលរោគដោយប្រើកំដៅ

diatomique *a.* ទ្វិបរមាណូ (ដែលមានអណូផ្សំដោយបរមាណូពីរ)

diatrible *n.f.* ការរិះគន់ខ្លាំង, ការតិះដៀល (ឧ. lancer une diatrible contre quelqu'un)

dichotome *a.* ដែលបែកជាចំពាម (ឧ. tige dichotome)

dichotomie *n.f.* ការបែកជាចំពាម

dichotomique *a.* ដែលបែកចេញជាពីរៗ (ឧ. classification dichotomique)

dichroïsme *n.m.* ការផ្លាស់ពណ៌តាមពេល ឬ តាមទីដែលពិនិត្យ (ឧ. le zircon présente un curieux dichroïsme)

dichromatique *a.* ដែលឲ្យឃើញពណ៌ពីរ

dicotylédones ឬ **dicotylédonées** *n.f. pl.* ទ្វិពីជបត្តជាតិ។ *sing.* *a.* ទ្វិពីជបត្ត

dictamen *n.m.* ការផ្ដុសគំនិត ឬ ប្រាជ្ញា (ឧ. le dictamen de la conscience)

dictaphone *n.m.* សុតស័ព្ទ [សុ-តៈ-] ឬ សូត្រស័ព្ទ

dictateur *n.m.* *Par ext.* អ្នកប្រើលទ្ធិផ្ដាច់ការ (ឧ. le 18 Brumaire fit de Bonaparte un dictateur)

dictatorial,e,aux *a.* នៃលទ្ធិផ្ដាច់ការ (ឧ. autorité dictatoriale)

dictature *n.f.* *Par ext.* លទ្ធិផ្ដាច់ការ

dictée *n.f.* សុតលេខ ឬ សូត្រលេខ, អនុពាក្យ, ការសរសេរតាមអាន ឬ តាមថា។ dictée de contrôle អនុពាក្យត្រួត។ dictée préparée អនុពាក្យបរិច្ឆិត

dicter *v.t.* អានឬថាឲ្យសរសេរតាម (ឧ. dicter une lettre)។ *Fig.* ឲ្យគម្រូយឲ្យឆ្លើយឬឲ្យធ្វើតាម (ឧ. dicter à quelqu'un ce qu'il doit dire ou faire); ធ្វើឲ្យនឹកឃើញ (ឧ. la sagesse dicte ses paroles); បង្ខំឲ្យធ្វើ, ដាក់ច្បាប់ (ឧ. dicter des

conditions)

dicteur *n.m.* អ្នកអានឲ្យសរសេរតាម; អ្នកបង្ខំឲ្យធ្វើ

diction *n.f.* ការសូត្ររៀបរៀងពាក្យ; របៀបនិយាយ ឬ អាន (ឧ. prendre des leçons de diction)

dictionnaire *n.m.* វចនានុក្រម, អក្ខរានុក្រម ។ *Fam.* dictionnaire vivant អ្នកប្រាជ្ញ, អ្នកមានចំណេះជ្រៅជ្រះ

dicton *n.m.* ភាសិត, ពាក្យចាស់

didactique *a.* ឧបទេស, ដែលសម្រាប់បង្រៀន (សៀវភៅ) (ឧ. l'Art poétique de Boileau est le chef-d'œuvre du genre didactique) ។ *n.m.* សៀវភៅឧបទេស, សៀវភៅសម្រាប់បង្រៀន។ *n.f.* សិល្បៈឧបទេស, សិល្បៈខាងបង្រៀន

didactiquement *adv.* ដោយឧបទេស, តាមរបៀបបង្រៀន

didactyle *a.* ទ្វិអង្គុលី, ដែលមានម្រាមពីរ (ឧ. le fourmilier est didactyle)

didyme *a. Bot.* ភ្លោក (ឧ. racine didyme)

dièdre *n.m. Math.* ទ្វិតល ។ *a.* angle dièdre មុមទ្វិតល

dièse *n.m. Mus.* តម្លើង

diésel *n.m.* ម៉ាស៊ីនឌីយ៉េសែល

diéser *v.t. Mus.* ដាក់សញ្ញាតម្លើង

diète *n.f.* ទីនសភា

diète *n.f.* ការអត់ ឬ តមអាហារ (ឧ. mettre un malade à la diète) ។ diète absolue ការបង្អត់អាហារ, ការតមអាហារគ្រប់យ៉ាង។ diète lactée ការឲ្យផឹកតែទឹកដោះ។ diète hydrique ការឲ្យផឹកតែទឹក

diététique *a. Méd.* នៃការតមអាហារ។ *n.f.* ការសិក្សាអំពីអនាម័យនៃអាហារ

Dieu *n.m.* អាទិទេព (ឧ. le vrai Dieu, le Dieu fort, est le Dieu des idées (de Vigny)) ។ *Par ext.* សម្មតិទេព(មនុស្សមានឋានៈ ឬ ចរិតខ្ពង់ខ្ពស់ ឬ មានអានុភាពខ្លាំង)(ឧ. on a souvent appelé les rois les Dieux de la terre); មនុស្សដែលគេស្រឡាញ់ ឬ ដែលគេគោរពជាទីបំផុត (ឧ. quand l'homme est malade, le médecin est un Dieu pour lui); វត្ថុដែលគេប្ដូរផ្ដាច់ជាមួយ (ឧ. se faire un

Dieu de son argent)។

Loc. div. de Dieu ធំណាស់, សម្បើមណាស់ (ឧ. courage de Dieu; montagne de Dieu); *Fam.* ដែលមានតម្លៃច្រើន, ដែលគេស្រឡាញ់ (ឧ. cent beaux écus de Dieu)។ des Dieux ដែលជាទីរីករាយក្រៃលែង (ឧ. plaisir des Dieux; festin des Dieux)។ main de Dieu, bras de Dieu ការសម្តែងឫទ្ធានុភាពនៃអាទិទេព ។ homme de Dieu មនុស្សស៊ប់ស្ងួនក្នុងសាសនា ។ homme du bon Dieu មនុស្សសុភាព ស្លូតហើយទោត ។ comme un Dieu ល្អណាស់; ច្រើន (ឧ. chanter comme un Dieu)។ en Dieu ដូចជាអាទិទេព(ឧ. agir en Dieu)។ être tout en Dieu គិតដល់អាទិទេពជានិច្ច ។ Demi-Dieu អន្លាទិទេព; *au fig.* មនុស្សវិសេសជាងមនុស្សផងទាំងពួង ។ Bon Dieu អាទិទេព (ឧ. aimer le Bon Dieu)។ grâce ឬ grâces à Dieu, par la grâce de Dieu, Dieu merci, Dieu soit loué, Dieu en soit loué ដោយក៏ពល្អ។ au nom de Dieu ឬ pour Dieu សូមមេត្តា។ pour l'amour de Dieu ដោយមានចិត្តសប្បុរស (ឧ. faire l'aumône pour l'amour de Dieu); ទទេ, ដោយឥតយកកម្រៃ (ឧ. les riches seuls peuvent travailler pour l'amour de Dieu)។ comme pour l'amour de Dieu ដោយមិនរីករាយ ឬ ដោយគ្បឹតគ្បៀត (ឧ. faire une chose comme pour l'amour de Dieu)។ *Pop.* travailler à la grâce de Dieu ធ្វើការដោយមិនចូលចិត្ត ឬ ដោយបង្ខំ។ s'il plait à Dieu, avec l'aide de Dieu ឬ Dieu aidant បើគ្មានឧបសគ្គអ្វីទេ, បើគ្មានអ្វីមករាំងទេ ។ être devant Dieu ស្លាប់ ។ promettre ឬ jurer ses grands Dieux ប្រកែកខ្លាំង, ស្បថស្បែខ្លាំង។ Dieu sait ស្បថចុះ (ប្រើដើម្បី ១– បន្ថែមសេចក្តីអះអាង ឧ. Dieu sait si l'on se donne du mal pour vous satisfaire; ២ –

បញ្ជាក់សេចក្ដីបរិសុទ្ធ ៖. Dieu sait si je l'ai fait ! si je l'ai eu seulement pensé; ៣— សម្ដែងសេចក្ដីមិនដឹងច្បាស់ ៖. Dieu sait ce qui en arrivera)។ sur mon Dieu, devant Dieu, Dieu m'est témoin, Dieu m'en est témoin ឬ Dieu le sait មានទេវតាជាប្រធាន(ពាក្យបញ្ជាក់បន្ទូលសេចក្ដីអះអាង)។ Dieu le veuille! plaise à Dieu ! plût à Dieu! Dieu vous entende! ឬ plut aux Dieux ឱទេវតាអើយ! (ពាក្យលាន់មាត់ស្ដាយ)។ Dieu préserve ឬ à Dieu ne plaise សូមទេវតាជួយ (ពាក្យសំបូងសង្រួងកាលណាគេគិតការអ្វីមិនកើត ឬគេខ្លាចមានព្រឹត្តិការណ៍អ្វីមួយមិនល្អ)។ Dieu vous garde ! សួស្ដី ! (ពាក្យសម្រាប់បន្ទូលក្នុងការពិចាប់គ្នា)។ ainsi Dieu me soit en aide ! ainsi Dieu m'aide! សូមទេវតាជួយខ្ញុំ ។ Dieu me pardonne ! សូមទេវតាមើលផងចុះ(ពាក្យបន្ទូលសម្ដែងសេចក្ដីតូចចិត្ត)។ Dieu vous conserve ! ឬ Dieu vous conduise ! សូមទេវតាជួយរក្សាអ្នកផងចុះ (ពាក្យបន្ទូលក្នុងការលាគ្នា)។ Dieu vous bénisse! Dieu vous assiste ! Dieu vous contente! Dieu vous soit en aide ស្បើយ ! (ពាក្យលាន់មាត់ក្រោយពីគេកណ្ដាស់) ។

ne craindre ni Dieu ni diable មិនខ្លាចច្បាប់, គ្មានអ្វីរាំងរាជ (ម. ព. diable ផង) ។ ne relever que de Dieu et de son épée រាងតែលើកម្លាំងខ្លួន ។ entre Dieu et soi ដោយស្ងាត់កំបាំង។ aller comme il plaît à Dieu ឬ Dieu sait comme តាមតែភពទៅចុះ (និយាយចំពោះការអ្វីដែលគេមិនរវល់នឹង) ។ venir de Dieu, de la grâce de Dieu មកដល់ដោយគាប់ជួន។ il semble que Dieu lui en doive de reste ហាក់ដូចជាស្ញើយផែណកស់ (ហាក់ដូចជាធ្វើការដោយមិនប្រឹងប្រែង) ។ *Pop.* Dieu bat ses matelas ធ្លាក់ហិមៈ(ធ្លាក់ទឹកកក)។ O Dieu !, Dieu !, Dieu de Dieu!, Dieu vivant!, jour de Dieu! ឱទេវតា

អើយ ! ។

Dieu-homme, Dieu fait homme, homme-Dieu ឬ fils de Dieu ព្រះយេស៊ូគ្រិស្ត ។ mère de Dieu នាងម៉ារី (មាតាព្រះយេស៊ូគ្រិស្ត ។

Prov. la voix du peuple est la voix du Dieu ពាក្យពិត (ឬ ការពិត) នៅក្នុងមតិមហាជន (បំពោះនយោបាយ)។ ce que femme veut Dieu le veut បំណងស្ត្រីច្រើនតែបានសម្រេច (បើស្ត្រីចង់បានអ្វី ទំនួចទាល់តែបាន) ។ chacun pour soi, Dieu pour tous ម.ព. chacun។ l'homme propose et Dieu dispose ផ្លូវការការដែលយើងធ្វើ ហុចផលឲ្យខុសពីបំណងក៏មាន។ il y a un Dieu pour les ivrognes អ្នកប្រមឹកច្រើនតែបានរួចពីគ្រោះថ្នាក់ដែលគួរតែមាន ។ servir Dieu c'est régner បង្ក្រាបតណ្ហាខ្លួនបាន ឈ្មោះថាឈ្នះលើខ្លួនឯង (ដូចស្ដេចគ្រប់គ្រងប្រជារាស្ត្រ)។ Dieu donne le froid selon le drap ឬ à brebis tondue Dieu mesure le vent អាទិទេពឲ្យទុក្ខព្រួយដល់យើងល្មមតែនឹងកម្លាំងយើងទប់ទល់បាន (យើងមិនដែលមានទុក្ខព្រួយហួសពីការដែលយើងអាចនឹងទទួលបាននោះទេ) ។ la sagesse du monde est folie devant Dieu អាទិទេពមិនមានយោបល់ស្រប នឹងយើងទេ ។ qui donne au pauvre prête à Dieu ម.ព. donner។ qui du sien donne, Dieu lui redonne ទានដែលធ្វើហើយមិនសាបសូន្យឡើយ ។ là où Dieu veut, il pleut ការអ្វីក៏មានឡើងដោយបំណងអាទិទេពទាំងអស់ (បើអាទិទេពត្រូវការឲ្យមានទើបមាន)

dieudonné *n.m.* ដែលអាទិទេពឲ្យ; ពាក្យហៅព្រះរាជបុត្រ

diffamant,e *a.* ដែលបង្ខូចកេរ្តិ៍ (ឧ. propos diffamant)

diffamateur,trice *a.* ដែលបង្ខូចកេរ្តិ៍ ។ *n.* អ្នកបង្ខូចកេរ្តិ៍ (ឧ. punir un diffamateur)

diffamation *n.f.* ការបង្ខូចកេរ្តិ៍ (ឧ. la diffamation est punie par la loi)

diffamatoire *a.* ដែលមានបំណងនឹងបង្ខូចកេរ្តិ៍គេឈ្មោះ

diffamer *v.t.* បង្ខូចកេរ្តិ៍ឈ្មោះ (ឧ. diffamer un adversaire politique)

différé,e *a.* ដែលលើកពេល

différemment *adv.* ដោយរបៀបផ្សេងពីគ្នា

différence *n.f.* ការមិនដូចគ្នា, ការទីទៃ, ការមិនប៉ុនគ្នា ។ à la différence de *loc. pré.* ទីទៃពី

différenciation *n.f.* ការញែកឲ្យឃើញការខុសគ្នា

différencier *v t.* ញែកឲ្យឃើញការខុសគ្នា (ឧ. différencier les espèces animales) ។ *Math.* គណនាអនុពល

différend *n.m.* អធិករណ៍,ការប្រកែក, ការទាស់ទែងគ្នា(ឧ.les différends entre nations peuvent être soumis à la cour internationale de La Haye)។ partager le différend សម្រុះសម្រួល (រម្ងាប់អធិករណ៍ដោយសម្រេចយកផ្លូវកណ្ដាល)

différent,e *a.* ខុសគ្នា (ឧ. un mot peut avoir des sens bien différents)។ *pl.* ផ្សេងៗ, ទីទៃៗ, ច្រើន (ឧ. différentes personnes me l'ont assuré)

différentiation *n.f.* *Math.* អនុពលកម្ម

différentiel,elle *a.* *Math.*អនុពល។ calcul différentiel គណនាអនុពល (ម.ព.calculផង)។ quantité différentielleឬdifférentielle *n.f.* ចំនួនអនុពល ឬ អនុពល

différentier *v.t.* ម.ព. différencier (*Math.*)

différer *v.t.* ពន្យារពេល,លើកពេល (ឧ. différer son départ) ។ *v.i.* ខុសពីគ្នា(ឧ. mon opinion diffère de la sienne); មានយោបល់ខុសគ្នា (ឧ. nous différons sur ce point)

difficile *a.* ពិបាក (ឧ. travail difficile ; problème difficile à résoudre) ។ *Fig.* ពិបាក (ពិបាកគាប់,ដែលរើសគ្នើស) (ឧ.goût difficile; caractère difficile)។ temps difficiles គ្រាក្រ, ពេលមានការលំបាក ។ faire le ឬ la difficile ឲ្យគេពិបាកគាប់,រើសគ្នើស

difficilement *adv.* ដោយក្រ; ដោយ

ពិបាក (ឧ. se mouvoir difficilement)

difficulté *n.f.* ការពិបាក(ឧ. s'exprimer avec difficulté);ភាពពិបាក (ឧ.difficulté d'un problème); ការជំទាស់ (ឧ. soulever une difficulté);ឧបសគ្គ(ឧ.éprouver des difficultés)។ *pl.* ការទាស់ទែងគ្នា(ឧ.avoir des difficultés avec quelqu'un)

difficulteux,euse *a.* ដែលធ្វើឲ្យលំបាក ឬ ជំទាស់គ្រប់ជំពូក (ឧ. esprit difficulteux);ដែលមានការលំបាកច្រើន(ឧ. travail difficulteux)

diffluence *n.f.* ដំណើរបែកជាដៃច្រើន (ទន្លេ, ស្ទឹង ។ល។) (ឧ. à la tête d'un delta se produit la diffluence d'un cours d'eau)

difforme *a.* រល, គ្មានរាង; អាក្រក់

difformité *n.f.* រាងរល, ភាពគ្មានរាង; ទ្រង់ទ្រាយអាក្រក់។ *Fig.* ការខូចសតិ

diffracter *v.t.* ធ្វើឲ្យផ្លាតពន្លឺ (ឧ. diffracter les rayons lumineux)

diffractif,ive *a.* អាចធ្វើឲ្យផ្លាតពន្លឺបាន (ឧ. milieu diffractif)

diffraction *n.f.* ដំណើរផ្លាតពន្លឺ(ចំពោះពន្លឺដែលងាកដោយបាំងទៅត្រូវវត្ថុអ្វីមួយ)

diffus,e *a.* ឆាស(ច្រើនកន្លែង)(ឧ. une douleur diffuse)។ lumière diffuse ពន្លឺឆាស(ពន្លឺជះទៅគ្រប់ទិស ហើយមិនបោលស្រមោលអ្វីមួយឲ្យបានច្បាស់)។ abcès diffus បូសផ្កាប់មុខ (មិនច្បាស់ជាមានមុខនៅត្រង់ណា)។ *Fig.* សាំញ៉ាំ, វែងពេក (បែបនិពន្ធ) (ឧ. style diffus)

diffusément *adv.* ដោយមិនច្បាស់

diffuser *v.t.* ធ្វើឲ្យឡើងឆាស (ឧ. le verre dépoli diffuse la lumière); ផ្សាយចេញ (ឧ. diffuser une nouvelle)

diffuseur *n.m.* អ្នកផ្សាយ (ឧ.diffuseur de nouvelles); ប្រដាប់ធ្វើឲ្យពន្លឺឡើងឆាស;ប្រដាប់ផ្សាយសម្លេង; ប្រដាប់ចម្រាញ់យកទឹកគនមដៃជាវ ។ *Autom.* ប្រដាប់បន្សាចប្រេងសាំង

diffusible *a.* អាចបាចសាចចេញទៅគ្រប់ទិសបាន

diffusif,ive *a.* ដែលបាចសាចចេញទៅគ្រប់ទិស

diffusion *n.f.* ដំណើរសាយភាយ (ឧ. la diffusion de la vapeur d'eau dans l'atmosphère);

ការបែកសាយជាតិក្នុងសពាង្គកាយ ។ *Fig.* ការផ្សាយ (ឧ. diffusion de connaissance); ការធ្វើឲ្យឡើងឆាស (ឧ.diffusion de lumière); ភាពវែង (បែបនិពន្ធ) (ឧ. diffusion du style, d'un discours)

digérable *a.* ដីរណើយ, ស្រួលរំលាយ (អាហារ)

digérer *v.t.* រំលាយអាហារ(ឧ.digérer péniblement un dîner) ។ *Fig.* គិតយ៉ាងល្អិត (ឧ. le sénat devait digérer toutes les affaires)។ *Fam.* រង.ទ្រាំ,អត់ធ្មត់ (ឧ. pouvoir digérer une injure); ទទួល, ជឿ (ឧ. non, cela est par trop dur à digérer)។ *v.t.* ឆ្អិន(ដោយត្រូវកំដៅហ៊មៗ) (ឧ. faire digérer une substance à une douce chaleur); ត្រៀមទឹក (ក្លូលទឹក) (ឧ. faire digérer des herbes dans l'eau)។se digérer *v.pr.*រលាយ (អាហារ) (ឧ. ce qui se mange avec plaisir se digère ordinairement avec facilité); *au fig.* ងាយយល់ (ឧ. lectures qui se digèrent et se classent dans l'esprit);មានគេទទួល, មានគេជឿ (ឧ. racontars qui se digèrent difficilement)

digest *n.m.*សេចក្ដីបំប្រួញ (នៃសៀវភៅ ឬ អត្ថបទ); ទស្សនាវដ្ដីបំប្រួញ (ដែលចុះអត្ថបទបំប្រួញ)

digeste *a. Fam.* ងាយនឹងរំលាយ (អាហារ)

digesteur *n.m.* ប្រដាប់គាបយកទឹក

digestibilité *n.f.* ដីរណើយភាព, ភាពងាយរំលាយ (ឧ. la digestibilité des aliments est très variable)

digestible *a.* ដីរណើយ, ងាយរំលាយ (អាហារ) (ឧ. aliment très digestible)

digestif,ive *a.* ដីរណើក, ដែលជួយរំលាយអាហារ (ឧ.substance digestive) ។ appareil digestif បរិធានដីរណើក, គ្រឿងរំលាយអាហារ (អាការៈក្នុងខ្លួន) ។ glande digestive ម.ព. glande ។ *n.m.* សុកដីរណើក (ដែលជួយរំលាយអាហារ)

digestion *n.f.* ដីរណា,ការរំលាយអាហារ

digital,e,aux *a.* នៃម្រាមដៃ(ឧ. mus-

cle digital; empreintes digitales)

digité,e *a.* ដែលកាត់ឬផែកដូចម្រាមដៃ (ឧ. feuille digitée)

digitiforme *a.* ដែលមានរាងដូចម្រាមដៃ

digne *a.* គួរតែ, ល្មមតែ (ឧ. digne de récompense, de punition); ល្អ,សមរម្យ ថ្លៃថ្នូរ (ឧ. un homme digne); នឹងធឹង

dignement *adv.* ដោយថ្លៃថ្នូរ, ដោយសមរម្យ,ដោយសមតាមគុណូបការ(ឧ. récompenser dignement)

dignitaire *n.m.* អ្នកមានបណ្ដាសក្ដិ(ឧ. hauts dignitaires de l'Etat)

dignité *n.f.* ស័ក្ដិយស, មុខងារខ្ពង់ខ្ពស់ (ឧ. dignité épiscopale);សេចក្ដីថ្លៃថ្នូរ (ឧ. marcher avec dignité); ការគោរពដល់ខ្លួនឯង

digon *n.m.* ដងមេឈើម; ផ្លែលំពែង ឬ ឡូក (ម.ព. angon ផង)

digressif,ive *a.* ក្រៅរឿង; ខុសរឿង (អត្ថាធិប្បាយ)

digression *n.f.* អត្ថាធិប្បាយក្រៅរឿង (ឧ. tomber dans de digressions continuelles) ។ *Astr.* ដំណើរតាកឃ្លាតចេញពីព្រះអាទិត្យ

digue *n.f.* ទំនប់ទឹក ។ *Fig.* ទំនប់, ឧបសគ្គ (ឧ. opposer des digues aux passions)

diguette *n.f.* ភ្លឺ (ភ្លឺស្រែជាដើម)

diktat *n.m.* (ពាក្យអាល្លឺម៉ង់) របស់តម្រូវ (ប្រើនិយាយចំពោះសន្ធិសញ្ញាដែលធ្វើដោយបង្ខំ)

dilacération *n.f.* ការហែកចោល (ឧ. la dilacération d'un testament)

dilapidateur,trice *n.&a.* ដែលចាយខ្ជះខ្ជាយ; ដែលបន្លំលួច

dilapidation *n.f.* ការចាយខ្ជះខ្ជាយ; ការបន្លំលួច

dilapider *v.t.* ចាយខ្ជះខ្ជាយ (ឧ. dilapider les deniers de l'Etat, sa fortune); បំបាត់, បន្លំលួច (ឧ. dilapider les biens d'un pupille) ។ se dilapider *v.pr.* ហិនហោច

dilatabilité *n.f. Phys.* ភាពអាចរីកចេញបាន

dilatable *a.Phys.* អាចរីកចេញបាន (ឧ. les gaz sont extrêmement dilatables)

dilatant,e *a.* ដែលរីកចេញ ។ *n.m.*

Chir. ប្រដាប់បង្ហា (ពង្រីកប្រហោងក្នុងការវះកាត់)

dilatateur,trice *a.* សម្រាប់ពង្រីក ។ *n.m.Chir.* ប្រដាប់បង្ហា

dilatation *n.f.* ការពង្រីក; ការរីក ។ *Phys.* ការរីកដោយកំដៅ

dilater *v.t.* ពង្រីក (ឧ. la chaleur dilate les corps) ។ *Fig.* ធ្វើឲ្យរីករាយ (ឧ. la joie dilate le cœur) ។ se dilater *v.pr.* រីក

dilation *n.m.* ការផ្អាក, ការពន្យារពេល

dilatoire *a.* សម្រាប់ផ្អាក ឬ ពន្យារពេល (ឧ. user des moyens dilatoires); សម្រាប់ពន្យឺតដំណើរក្ដី

dilatomètre *n.m.* ប្រដាប់វាស់ទំហំដែលរីកចេញ

dilection *n.f.* បសាទចិត្ត (ការស្រឡាញ់ដោយគោរព)(ឧ.la dilection du prochain)

dilemme *n.m.Log.* ទ្វេគ្រោះ, ទ្វេបទ ។ *Par ext.* ការត្រូវរើស; បញ្ហាពិបាកដោះស្រាយ (ឧ. être devant un dilemne)

dilettante *n.m.* អ្នករវល់នឹងភ្លេង ។ *Par ext.* អ្នករវល់នឹងសិល្បៈណាមួយ (*pl.* des dilettanti ឬ des dilettantes)

dilettantisme *n.m.* ចរិតអ្នករវល់នឹងសិល្បៈ

diligemment *adv.* ដោយរៀសរវៃ, ដោយយកចិត្តទុកដាក់

diligence *n.f.* ការយកចិត្តទុកដាក់ (ឧ. examiner une affaire avec la plus grande diligence); សេចក្ដីរៀសរវៃ (ឧ. travailler avec diligence) ។ *loc.div.* faire diligence ធ្វើដោយរហ័ស ឬដោយរៀសរវៃ ។ en diligence, en toute diligence ឬ en grande diligence យ៉ាងប្រញាប់, យ៉ាងរហ័ស ។ *Dr.* faire ses diligences contre quelqu'un ប្ដឹងពីអ្នកណាមួយ។ *Procéd.* à la diligence de ដោយមានពាក្យសុំពី

diligence *n.f.* រថបន្ទុក (រទេះសេះកង់ ៤មានដំបូលទាំងមានបន្ទប់ ២ ឬ ៣)។ *Fam.* c'est la diligence embourbée មនុស្សយឺត (ធ្វើការយឺត)

diligent,e *a.* ឧស្សាហ៍ (ឧ. être diligent en ses affaires);រៀស-

ស៊ី (ឧ. messager diligent) ។ *Par ext.* ដែលយកចិត្តទុកដាក់ (ឧ. soins diligents) ។ *Dr.* partie la plus diligente អ្នកប្ដឹងមុន

diligenter *v.t.* បង្ខំ (ឲ្យរហ័ស) ។ *v.i.* ប្រញាប់, ស្រូត

diluer *v.t.* លាយទឹក (ឲ្យរាវ) ។ *Fig.* បង្អន់

dilution *n.f.* ការលាយទឹក (ឲ្យរាវ); វត្ថុលាយទឹក (ឧ. avaler une dilution)

diluvial,e,aux *a.* នៃល្បប់ (ឧ. sédiments diluviaux)

diluvien,enne *a.* នៃមហាជំនន់ (ឧ. époque diluvienne) ។ pluie diluvienne ភ្លៀងរំលា (ភ្លៀងធំ)

diluvium *n.m.* ល្បប់ (ចំពោះតែល្បប់នៃទន្លេក្នុងបច្ចុប្បន្នកាល)

dimanche *n.m.* ថ្ងៃអាទិត្យ ។ habits de dimanche ឬ du dimanche សំលៀកបំពាក់ស្អាតជាងប្រក្រតីសម្រាប់ថ្ងៃអាទិត្យនឹងថ្ងៃបុណ្យ ។ *loc. fam.* dimanche après la grand' messe មិន...សោះ ។ être mis comme un dimanche ស្លៀកពាក់ស្អាតបាត ។ *Prov.* tel qui rit vendredi dimanche pleurera ថ្ងៃនេះសើចថ្ងៃស្អែកយំ (សេចក្ដីសប្បាយមិនដែលឋិតថេរឡើយ)

dîme *n.f.* អាករទសភាគ (ឧ. la dîme fut abolie en France par la Révolution) ។ *Fig.* prélever une dîme sur quelque chose ហូតយកកម្រៃខ្លះពី

dimension *n.f.* ខ្នាត, ទំហំ (មានបណ្ដោយ, ទទឹង, កំពស់) ។ *Fig.* ទំហំ, ភាពសំខាន់ (ឧ. une faute de cette dimension) ។ *Fig.* prendre ses dimensions ចាត់វិធានការ, ប្រុងប្រយ័ត

dîmer *v.t.* ដាក់ឲ្យជាប់អាករទសភាគ ។ *v.i.* តាំងអាករទសភាគ

dîmeur *n.m.* អ្នកតាំងអាករទសភាគ

diminué,e *a.&n.* ដែលអន់ថយ (ដែលខូចសម្បទាខ្លះដោយគ្រោះថ្នាក់)

diminuendo *adv. Mus.* បញ្ចុះ, ដោយខេះតែថយចុះ

diminuer *v.t.* បន្ថយ (ឧ. diminuer la longueur d'une planche) ។ *Fig.* បន្ថោក (ឧ. diminuer le mérite de quelqu'un); បង្អន់ (ឧ. cela diminue notre

plaisir) ។ diminuer un employé បន្ថយបៀស្បៀងនិយោជិត ។ *v.i.* ថយ,អន់, ស្រាក(ឧ. la fièvre a diminué ឬ est diminuée)

diminutif,ive *a. Gram.* ឧវឌ្ឍន៍ [អេ-ភ៉ិត]. ដែលបំព្រួញ,ដែលបន្ថយ(ឧ. fillette, femmelette sont les diminutifs de fille, de femme) ។ *Par ext.* វត្ថុបំព្រួញ (វត្ថុធុនមួយតែមានទំហំតូចជាង)

diminution *n.f.* ការបន្ថយ;ការបញ្ចុះថ្លៃ (ឧ. obtenir une diminution de prix)

dimorphe *a.* ទ្វិសណ្ឋាន (ដែលអាចមានរាងពីរខុសគ្នា; ដែលអាចខះជាពីរសណ្ឋានខុសគ្នា)(ឧ.le soufre est dimorphe)

dimorphisme *n.m.* ទ្វិសណ្ឋានភាព។ *Biol.* dimorphisme sexuel លក្ខណៈសំគាល់លិង្គ ឬ ភេទ

dinanderie *n.f.* ភាជនភណ្ឌស្ពាន់ [ភា-ជៈ-នៈ—] (គ្រឿងចាន,ឆ្នាំង។ល។ ធ្វើអំពីស្ពាន់ក្រហម)

dinandier *n.m.* អ្នកធ្វើភាជនភណ្ឌស្ពាន់

dinar *n.m.* ឌីណារ(រូបិយវត្ថុមាសប្រទេសអារ៉ាប; មាត្រារូបិយវត្ថុយូហ្គោស្លាវី)

dînatoire *a. Fam.* ជាជំនួសសាយ-ភោជន៍ (ឧ.déjeuner dînatoire)

dinde *n.f.* មាន់បារាំងញី ។ *Fig.* ស្ត្រីឆោត-ល្ងីល្ងើ ។ *n.m.* មាន់បារាំង

dindon *n.m.* មាន់បារាំងឈ្មោល (cri: le dindon glouglote ឬ glougloute) ។ *Fig.* ប្រុសសម្ភក ។ *Loc. prov.* être le dindon de la farce ជាអ្នករងគ្រោះ ឬ ជាអ្នកដែលត្រូវគេសើច (ក្នុងរឿងហេតុអ្វីមួយ)

dindonneau *n.m.* កូនមាន់បារាំង

dindonner *v.t. Fam.* បញ្ឆោត,បោក

dindonnier,ère *n.* គង្វាលមាន់បារាំង

dîné *n.m.* ម.ព. dîner

dînée *n.f.* សាយភោជន៍និងចំណាយសម្រាប់សាយភោជន៍ក្នុងដំណើរ (ឧ. payer la dînée); កន្លែងលៀងសាយភោជន៍ (ឧ. la dînée est assez éloignée)

dîner *v.i.* លៀងសាយភោជន៍, បរិភោគពេលល្ងាច

dîner *n.m.* សាយភោជន៍, ពេលឬការបរិភោគល្ងាច; អាហារបរិភោគពេលល្ងាច (ឧ. avoir son dîner sur l'estomac)

dinette *n.f.* សាយភោជន៍តូច(សម្រាប់

(ក្មេង) ។ *Par ext.* ភោជនាអាហារក្នុងគ្រួសារ

dineur,euse *n.* សាយភោជនីក-និកា, អ្នកបរិភោគល្ងាច; អ្នកចូលចិត្តបរិភោគ, អ្នកបរិភោគច្រើន

dingo *n.m.* ឆ្កែព្រៃប្រទេសអូស្ត្រាលី ។ *n.&a. sing.* ឆ្កួត

dinguer *v.i. Pop.* ដួល ។ envoyer dinguer បណ្តេញច្រងាប់ច្រងិល

diocésain,e *a.* នៃឌីយ៉ូសែស

diocèse *n.m.* ឌីយ៉ូសែស (ខេត្តនៃរាជាណាចក្ររ៉ូម៉ាំងក្នុងសតវត្សទី ១៤)

dioptre *n.m.* ឌ្យុបត្រ៏ ។ dioptre plan ឌ្យុបត្រ៏ផែនរាប

dioptrie *n.f. Phys.* ឌ្យុបទ្រី

diorite *n.f.* ឋលិកសិលា

dipétale *a. Bot.* ទ្វិទលី [ទ្វិ-ទៈ-លី]; ដែលមានត្របកពីរ (ផ្កា)

diphtérie *n.f.* រោគខាន់ស្លាក់

diphtérique *a.* នៃរោគខាន់ស្លាក់ ។ *a.&n.* ដែលកើតរោគខាន់ស្លាក់ (ថា diphtéritique ក៏បាន)

diphtongue *n.f.* សំយុត្តស្រៈ (ស្រៈផ្សំ)

diphtonguer *v.t.* បំបែកជាសំយុត្តស្រៈ

diplomate *n.m.* អ្នកការទូត(ឧ.Talleyrand fut un habile diplomate); អ្នកជំនាញខាងការទូត ។ *n.&a.* អ្នកប៉ិនប្រសប់ខាងចរចា (ឧ. savoir se montrer diplomate) ។ *a.* ជាអ្នកការទូត (ឧ. ministre diplomate)

diplomatie *n.f.* ការទូត; អង្គទូត; ក្រសួងការទូត(ឧ. entrer dans la diplomatie)។ *Par ext.* សេចក្តីឈ្លាសវៃ(ឧ.user de diplomatie)

diplomatique *a.* នៃការទូត។ corps diplomatique អង្គទូត ។ *Fig.* ជារបៀបកំបាំង (ឧ. air diplomatique); ប្រយ័ត, ឈ្លាសវៃ (ឧ. avoir l'esprit diplomatique)

diplomatique *a.* នៃសញ្ញាប័ត្រ។ *n.f.* សញ្ញាប័ត្រវិទ្យា

diplomatiquement *adv.* តាមការទូត; ដោយប្រយ័ត; ដោយឈ្លាសវៃ

diplôme *n.m.* សញ្ញាប័ត្រ ។ diplôme d'Etat វេជ្ជសញ្ញាប័ត្រ ។ diplôme d'études primaires supérieures indochinoises សញ្ញាប័ត្របឋមសិក្សាជាន់ខ្ពស់ឥណ្ឌូចិន ។ diplôme d'études primaires supérieures normales cambodgiennes សញ្ញាប័ត្រ

មធ្យមសិក្សាជាន់ខ្ពស់ខាងគរុវិជ្ជាខ្មែរ ។ diplôme d'études secondaires franco - khmères សញ្ញាប័ត្រមធ្យមសិក្សាបារាំង - ខ្មែរ ។ diplôme de l'institut national d'études juridiques et économiques សញ្ញាប័ត្រវិទ្យាស្ថានបង្រៀនយុត្តិធម្មសាស្ត្រនិងសេដ្ឋកិច្ចជាតិ (section administrative et financière ផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ; section juridique ផ្នែកយុត្តិធម្មសាស្ត្រ)។ diplôme de sortie de l'école supérieure d'application des bonzes សញ្ញាប័ត្រចេញពីសាលាអនុវត្តជាន់ខ្ពស់សម្រាប់បព្វជិត ។ *Chim.* ប្រដាប់ចំហុយ

diplômé,e *a.&n.* អ្នកមានសញ្ញាប័ត្រ

diplopie *n.f.* ចក្ខុរោគដែលបណ្ដាលឲ្យឃើញអ្វីៗទ្វេជាពីរ

dipsomane ឬ **dipsomaniaque** *n.* អ្នកកើតរោគស្រេក (ស្រេកសុរា)

dipsomanie *n.f.* រោគស្រេក(ស្រេកសុរា)

diptéracé,e *a. Hist. nat.* ទ្វេបត្ត, ដែលមានស្លាបពីរ

diptère *a. Zool.* ទ្វេបត្ត, ដែលមានស្លាបពីរ

diptères *n.m. pl.* ទ្វិបត្តសត្វ (សណ្ដានសត្វល្អិតមានស្លាបពីរដូចរុយជាដើម)

dire *v.t.* និយាយ, ថា (ឧ. ne jugez point les hommes sur ce qu'ils disent, mais d'après ce qu'ils font); សូត្រ, ថ្លែង, ច្រៀង (ឧ. dire sa leçon, dire des vers); ធ្វើពិធី (ឧ. dire la messe); និទាន, រៀបរាប់ (ឧ. dites-moi les choses à fond); ប្រាប់រឿងសម្ងាត់កំបាំង (ឧ. on a le droit de dire son secret, non celui des autres); ប្រាប់, បញ្ជាក់ (ឧ. on ne peut pas dire d'où viennent certaines expressions); អះអាង, ថ្លែង (ឧ. ne dites jamais rien sans preuves); ព្រមាន, ហៅ, ទូន្មាន (ឧ. dire à quelqu'un de se reposer, de partir); បង្គាប់, បញ្ជា (ឧ. je vous dis de vous taire); ទាយ (ឧ. dire la bonne aventure); ប្រើ (ឧ. faut-il dire créance ou croyance ?) ។ *Par ext.* ចង្អុល, ជាឈ្មោះ (ឧ. la raison dit Virgile et la rime Quinault); ជឿថា, គិតថា, យល់ថា,

សម្រេច (ឧ. qu'en dites-vous? la douleur est-elle un mal?...Aux stoïciens de le dire); តិទាស់, បន្ទោស (ឧ. il n'y a rien à dire à sa conduite); ថា (បញ្ចេញគំនិតដោយពាក្យអក្សរ) (ឧ. dire dans une lettre, dans un ouvrage) ។ ប្រាប់,បង្ហាញ (ឧ. l'horloge qui dit l'heure; quand une femme vous parle, regardez ce que disent ses yeux; parfois, le silence en dit long)។ *Poét.* អួត, សរសើរ (ឧ. je dirais les exploits de ton règne paisible (Boileau); comme vous je dirai l'auteur de l'Univers (la Fontaine)។

Loc. div. on dit ពាក្យគេថា, ពាក្យចចាមអារ៉ាម ។ on dirait ឬ on aurait dit que ហាក់ដូចជា, ប្រហែលជា ។ on dirait ឬ on aurait dit de គេអាចទុកអ្នកនោះជាជា (ឧ. quand Santeul récitait ses vers, on aurait dit d'un démoniaque) (គិ-ឡូវនេះគេច្រើនស្រុប de ចោល)។ c'est comme qui dirait គឺដូចគ្នានឹង។ je vous l'avais bien dit ខ្ញុំបានប្រាប់អ្នករួចមកហើយ (ពាក្យបន្ទោសថាគេបានប្រាប់ឲ្យដឹងខ្លួនមុនអំពីហេតុដែលនឹងកើតមកដល់)។ dit-on តាមពាក្យគេថា, តាមពាក្យចចាមអារ៉ាម, តាមល្បីល្បះ ។ quoi qu'on dise, quoi qu'on en dise, quoi que dise ឬ quoi qu'en dise ទោះជាមានពាក្យគេថាក៏ដោយ, ថ្វីបើមានពាក្យគេថា ។ pour ainsi dire តាមបែបណាមួយ, គឺថា ។ pour ne pas dire ដើម្បីមិនថាជា (ដើម្បីចៀសកុំងថាជា) (ឧ. il y a des positions où le silence est une défection, pour ne pas dire une complicité) ។ disons-le យើងទទួលថាដូច្នេះហើយ ។ vous l'avez dit ពិតហើយ,មែនហើយ,ត្រូវហើយ។ qui dit...dit តែថា ... គឺថា (ឧ. qui dit conquérant dit bourreau)។ qui dirait?, qui aurait dit? តើអ្នកណាជឿបាន? (គេមិនអាចជឿបាន)។ qui vous dit que?,

qui vous a dit que? តើអ្នកណាដំណាលប្រាប់លោកថា?, លោកអាងលើអ្វីនឹងយល់ថា? ។ quelque chose me dit ឬ mon cœur me dit ខ្ញុំនឹកឃើញមានពិរោះល់ថា, ខ្ញុំជឿក្នុងចិត្តខ្ញុំថា ។ en dire, en dire de belles ឬ en dire de toutes les couleurs និយាយគ្រប់បែបគ្រប់យ៉ាង (បេះតែនិយាយតាមតែនឹកឃើញ) ។ vouloir dire ចង់ថា, មានបំណងនឹងថា (ឧ. souvent, ce que l'on veut dire vaut mieux que ce que l'on dit); មានន័យថា (ឧ. vertu vient d'un mot latin qui veut dire force) ។ pouvoir dire អាចនឹងថា...បាន, អាចនឹងអះអាងបាន ។ c'est-à-dire គឺថា, ពោលគឺ (ឧ. vous ne pouvez pas, c'est-à-dire que vous ne voulez pas) ។ ce n'est pas à dire pour cela que ឬ ce n'est pas à dire que សុំលោកកុំយល់ថា, សុំលោកកុំសន្និដ្ឋានថា ។ qui est-ce à dire ថាដូចម្ដេចហ្នឹង? ដូចម្ដេចហ្នឹង (នេះមានន័យដូចម្ដេច) ។ c'est tout dire ឬ cela dit tout គ្រប់គ្រាន់អស់ហើយ, សព្វគ្រប់អស់ហើយ (គ្មានអ្វីនឹងបន្ថែមទៀតទេ) ។ à vrai dire ឬ à dire vrai ដោយពិតទៅ (ដោយមិនកុហក) ។ y avoir à dire ឬ avoir à dire មានការគួរឲ្យឆ្លើយ, មានការត្រូវឆ្លើយ (ឧ. il y aurait beaucoup à dire sur bien des choses) ។ trouver à dire រករឿងបន្ទោសបាន ។ dire son mot ឲ្យយោបល់ខ្លួន ។ ne dire mot គ្មានចេញស្ដី, មិននិយាយមួយម៉ាត់ ។ sans mot dire ឬ sans dire le mot គ្មានហើបមាត់ (មិនថាអ្វីសោះ) ។ dire un mot ឬ dire un petit mot និយាយគ្នាលេងមួយភ្លែត, សន្ទនាគ្នាមួយភ្លែត ។ dire son fait ឬ ses vérités à quelqu'un និយាយអាក្រក់ឲ្យ ។ dire les douceurs à ថៃចង់, បញ្ចោរ ឬលួងលោម ។ dire d'or និយាយត្រូវណាស់ (គេប្រើថា parler d'or) ។ dire d'un, puis d'un autre ម្ដងថាដូច្នេះ ម្ដងថាដូច្នោះ, និយាយបាតដៃជាខ្នងដៃ ។ ne savoir ce qu'on dit និយាយដោយមិនបានគិត ឬដោយឆ្កួត ។ ce n'est pas pour dire

គឺមិនមែនជា (ពាក្យសម្រាលសេចក្ដីដែលគេត្រូវនិយាយតទៅទៀត) ។ aller sans dire មិនបាច់និយាយទេ (គឺជាការធម្មតាទេ)(ឧ.cela va sans dire) ។ vous n'avez qu'à dire លោកគ្រាន់តែថាមកបានហើយ (លោកគ្រាន់តែប្រាប់ថាចង់បានជាការស្រេច) ។ si le cœur vous en dit ប្រសិនជាលោកត្រូវការ, ប្រសិនជាលោកមានបំណង ។ cela ne me dit rien ការនេះ ឬ របស់នេះមិនត្រូវបំណងខ្ញុំទេ ។ il n'y a pas à dire គ្មានអ្វីនឹងថាទៀតទេ; ការនេះជាំបាច់ ឬពិតណាស់ហើយ ។ à qui le dites-vous? ខ្ញុំយល់ច្បាស់ពេកណាស់ទៅហើយ ។ avoir beau dire និយាយឥតប្រយោជន៍ ។ mettez ឬ prenez que je n'ai rien dit សុំទុកដូចជាខ្ញុំគ្មាននិយាយអ្វីសោះ, កុំយកពាក្យខ្ញុំជាបានការឡើយសោះ ។ cela vous plait à dire លោកថានេះគ្រាន់តែលេងទេ ។ je ne vous dit que cela ខ្ញុំគ្រាន់តែដំរាបប៉ុណ្ណោះ(មិនប្រាប់ឲ្យអស់ទេ)(ឧ.nous vous promettons une surprise, je ne vous dit que cela) ។ se le faire dire ជាំឲ្យតឿន (រួញរាខ្លាំងនឹងមុខការអ្វីមួយ) ។ ne pas se le faire dire deux fois ធ្វើភ្លាមៗ, ទទួលភ្លាម (មិនជាំឲ្យគេតឿនច្រើនដង) ។ je ne vous le fais pas dire លោកទទួលដឹង ឬ ទទួលសារភាពខ្លួនលោកទេ ។ je ne vous l'envoie pas dire ខ្ញុំនិយាយដំរាបលោកផ្ទាល់ (មិនផ្ដាំនឹងគេទេ) ។ dire pis que pendre de quelqu'un និយាយអាក្រក់ពីអ្នកណាមួយហួសពេក (ចោទធ្ងន់លើសទោសគ្នាកទៅទៀត)។ trouver à dire ឃើញថាមានខ្វះអ្វីមួយ ។ *Fam.* cela me dit របស់នេះពេញចិត្តខ្ញុំហើយ ។

Prov. & loc. prov. comme dit l'autre ដូចមានពាក្យគេថា ។ on sait ce que parler veut dire ខ្ញុំយល់ដំម្រាពាក្យលោកហើយ ។ je l'irai dire à Rome ខ្ញុំចង់តែស្រែកអាក្រាសប្រាប់គេទេ, ខ្ញុំដូចជាហួសចិត្ត (ការស្មានេះមិនសមហេតុបន្តិចសោះទេ ខ្ញុំចង់ឲ្យគេដឹងគ្រប់គ្នាផង) ។ il ne dit mot, mais il n'en

pense pas moins គិតមែនតែគាត់មិនទំនិយាយ ប៉ុន្តែគាត់ក៏មិនព្រងើយកន្តើយក្នុងរឿងនេះដែរ ។ bien faire vaut mieux que bien dire ប្រព្រឹត្តល្អ ប្រសើរជាងនិយាយល្អ ។ «on dit» est un sot ពាក្យចចាមអារ៉ាមច្រើនតែឥតសមហេតុផល។ qui ne dit mot consent នៅស្ងៀមគឺព្រម (ជួនកាលបើនៅស្ងៀមមិនចេញស្តី គឺទទួលតាមពាក្យគេថា) (ម.ព. consentir ផង ។

se dire *v.pr.* តាំងខ្លួនជា (ឧ. tous les ambitieux se croient ou se disent nécessaires); ថាខ្លួនឯង, និយាយនឹងខ្លួនឯង(ឧ.se dire des douceurs); មានគេនិយាយ, មានគេថា (ឧ. cela se dit partout; ces mots se disent fort bien)

dire *n.m.* ការនិយាយ,ការថា; សំដី (ឧ. le contraste du faire avec le dire); ការអះអាង,ការប្រកាស(ឧ. prouver ses dires)។ *loc pré.* selon leur dire ឬ au dire de តាមពាក្យរបស់។ *Dr.* ការធ្វើយល់ការណ៍(ឧ.le dire des experts); សេចក្តីថ្លែងសុំ, សំដី (ឧ. répéter les dires de la partie adverse); dire droit d'un appel បើកឲ្យឧទ្ធរណ៍។ à dire d'expert តាមយោបល់អ្នកជំនាញ

direct,e *a.* ចំ,ត្រង់ (ឧ. chemin direct; ligne directe; marche directe) ។ *Par anal.* ផ្ទាល់ (ឧ. communication directe; correspondance directe) ។

Fig. ត្រង់ៗ, ចំៗ (មិនវៀចវេរ) (ឧ. défi direct); ភ្លាម(ឧ.l'homme travaille d'autant mieux qu'il a un intérêt direct à travailler); ពេញទី, ជាដាច់ខាត (ឧ. deux opinions en contradiction directe ne peuvent être vraies l'une et l'autre) ។ *Astr.* mouvement direct ចលនាពីលិចទៅកើត (ក្នុងតារាសាស្ត្រ) *Ch.f.* អយស្ម័យយានបង្ហួស(គ្មានឈប់តាមដំណាក់ការយោង) ។ *Fin.* impôts directs ពន្ធចំពោះ (ម.ព. contribution ផង) ។ *Généal.* ផ្ទាល់ (ពីឪពុកទៅកូន) (ឧ. succession directe;

ligne directe)(ម.ព. ligneផង)។ *n.m. Boxe* ការជាល់ចំ (ជួយនឹងដាល់ខាវ) (ឧ. un direct de droit; un direct de gauche)

directement *adv.* ឆ្ពោះត្រង់ទៅ (មិនវាង) (ឧ. aller directement de Phnom-Penh à Hong Kong); ដោយផ្ទាល់ (ឧ. correspondre directement avec quelqu'un)

directeur,trice *n.* នាយក, នាយិកា។ directeur des bureaux នាយកការិយាល័យ ។ directeur général អគ្គនាយក ។ directeur de service នាយកក្រុម។ ចាងហ្វាង (ឧ. directeur d'école ចាងហ្វាងសាលារៀន)។ *a.* ប្រធាន (ឧ. plan directeur; roue directrice); នាយក (ឧ. comité directeur)

direction *n.f.* ការចាត់ការ (ឧ. une direction vigilante); ដំណែងនាយក,ដំណែងចាងហ្វាង (ឧ. obtenir la direction d'une usine); នាយកដ្ឋាន; ទីចាត់ការ (ឧ. aller à la direction)។ direction générale អគ្គនាយកដ្ឋាន ។ ទិសាភាគ, ទិសដែលបែរទៅរក (ឧ. direction d'une aiguille aimantée) ។ *Math.* ទិសាភាគ ។ *Méc.* ចង្កូត

directionnel,elle *a.* ដែលផ្សាយទៅតែទិសមួយ (ឧ. antenne directionnelle)

directive *n.f.* ការណែនាំ (ឧ. recevoir des directives)

directorat *n.m.* ដំណែងនាយក;រយៈពេលកាន់ដំណែងនាយក

directorial,e,aux *a.* នៃដំណែងនាយក ឬ ចាងហ្វាង; នៃនាយក ឬ ចាងហ្វាង (ឧ. pouvoir directorial; bureau directorial)

dirigeable *a.* អាចដឹកនាំបាន ។ *n.m.* អាកាសយានម្យ៉ាងស្រាលជាងខ្យល់

dirigeant,e *a.* ដែលដឹកនាំ (ឧ. classe dirigeante) ។ *n.* បរិនាយក, អ្នកដឹកនាំ

diriger *v.t.* តម្រង់ទៅ (ឧ. diriger ses pas vers..., son attention sur...); កាន់ចង្កូត (ឧ. diriger une barque); ចាត់ការ; ដឹកនាំ (ឧ. diriger une entreprise)

dirigisme *n.m.* ទស្សនវិស័យ [ន:-យ:-

នៈ-] (របបសេដ្ឋកិច្ចដែលរដ្ឋមាននាទីបញ្ជាត់ចែងជំនួសឯកជន)

dirigiste *n.&a.* អ្នកនិយមនិយមរ

dirimant,e *a. Dr.* ដែលបដិសេធ ឬ ដំទាស់ (ឧ. empêchement dirimant)

dirimer *v.t. Dr.* បដិសេធ, លុប (ឧ. dirimer un contrat); បំបាត់, រម្ងាប់ (ឧ. dirimer les différends)

discale *n.f.* សំណល់ ឬ សម្រកទំងន់ ដែលដាក់តាមទុក

discernable *a.* អាចមើលឃើញ (ឧ. les microbes ne sont pas discernables à l'œil nu); ដែលអាចដឹងខុសត្រូវ

discernement *n.m.* ការមើលឃើញ; ការដឹង, ការស្គាល់ (ឧ. discernement des couleurs; discernement du bien et du mal); ការដឹងខុសត្រូវ (ឧ. agir sans discernement)

discerner *v.t.* មើលឃើញ (ឧ. les daltoniens discernent mal ou confondent les couleurs); ដឹង ឬ ស្គាល់ (ឧ. discerner un bruit; discerner l'ami du flatteur ស្គាល់ថាអ្នកណាជាមិត្ត អ្នកណាជាអ្នកបញ្ចើរ) ។ *Fig.* ស្គាល់ (ឧ. discerner la vérité de l'erreur); ដឹង, យល់ (ឧ. discerner une menace, les intentions de quelqu'un)

disciple *n.m.* សិស្ស, សាវ័ក (ឧ. disciple de Platon) ។ *Fig.* បក្ខពួក, អ្នកចូលចិត្ត (ឧ. disciple de la vérité, de la liberté)

disciplinable *a.* អាចហ្វឹកហ្វឺនឲ្យកាន់វិន័យបាន; អាចផ្ចាញ់បាន; ស្លូត

disciplinaire *a.* នៃវិន័យ (ឧ. punition disciplinaire) ។ *n.m.* ទាហានក្រុមវិន័យ

disciplinairement *adv.* តាមវិន័យ

discipline *n.f.* វិន័យ (ឧ. la discipline scolaire s'est fort adoucie; la discipline cartésienne); ការកាន់វិន័យ, ការបង្ហាត់ឲ្យកាន់វិន័យ (ឧ. l'esprit de discipline fait la force des armées); ប្រដាប់ធ្វើទណ្ឌកម្ម (ឧ. se donner la discipline); វិជ្ជាបង្រៀន

discipliné,e *a.* ដែលកាន់វិន័យ (ឧ.

soldats disciplinés)

discipliner *v.t.* ហ្វឹកហ្វឺនតាមវិន័យ (ឧ. discipliner une armée) ។ *Fig.* បំពត់ (ឧ.discipliner ses instincts)

discobole *n.m.* អ្នកចោលចាស(កីឡា)

discoïde *a.* ជារាងចាស

discontinu,e *a.* ដាច់ៗ, រអាក់រអួល, ដែលមិនជាប់រៀងរាយ (ឧ. effort, mouvement discontinu)

discontinuation *n.f.* ការដាច់, ការផ្អាក, ការឈប់

discontinuer *v.t.* បញ្ឈប់, ផ្អាក (ឧ. discontinuer un travail) ។ *v.i.* ឈប់; ស្រាក(ឧ.la pluie n'a pas discontinué)

discontinuité *n.f.* ភាពរអាក់រអួល, ភាពមិនជាប់រៀងរាប

disconvenance *n.f.* ភាពមិនសមរម្យ, ភាពមិនត្រូវគ្នា(ឧ. disconvenance d'âge)

disconvenir *v.i.* មិនយល់ស្រប (ឧ. des hommes qui disconviennent d'avec tous les autres sur les principes les plus communs (Fontenelle): មិនត្រូវចិត្ត (ឧ. offre qui ne disconvient pas à quelqu'un); ប្រកែក (ឧ. je ne disconviens pas que cela ne soit ឬ soit vrai)

discophile *n.* ថាលភក្ត (អ្នកចូលចិត្តចាសម៉ាស៊ីនច្រៀង)

discord *a.* មិនស្របគ្នា(ឧ. bruit discord); ល្វើយ (ឧ. piano discord)

discordance *n.f.* ភាពល្វើយ (សំឡេង); ភាពមិនស្របគ្នា (ព.ផ. concordance)

discordant,e *a.* *Mus.* ល្វើយ(សំឡេង) (ឧ. sons discordants) ។ *Fig.* មិនស្របគ្នា, មិនត្រូវគ្នា (ឧ.caractère discordant)

discorde *n.f.* ការបាក់បែក ឬ ការទាស់ទែងគ្នា (ឧ. semer la discorde បំបាក់បំបែកគ្នា) ។ *Fig.* pomme de discorde វត្ថុជាហេតុឲ្យទាស់ទែង ឬ ឲ្យបាក់បែកគ្នា

discorder *v.i.* មានសំឡេងល្វើយ (ឧ. cet instrument discorde); មិនស៊ីគ្នា (ឧ.couleurs qui discordent); ទាស់ទែង ឬ បាក់បែកគ្នា

discothèque *n.f.* ថាសាល័យ[-ឡា-] (កន្លែងដាក់ថាសម៉ាស៊ីនច្រៀង, ទូដាក់ថាសសំឡេង)

discoureur,euse *n.* អ្នកថ្លែងសុន្ទរកថា; អ្នកនិយាយច្រើន (ឧ. un incorrigible discoureur)

discourir *v.i.* ថ្លែងសុន្ទរកថា; និយាយបរាប់ (ឧ. discourir sur la vertu); និយាយលេង (ឧ. ne perdons pas notre temps à discourir)

discours *n.m.* ពាក្យសន្ទនាគ្នា(ឧ. discours familier); សុន្ទរកថា (ឧ. les discours de Cicéron sont les chefs-d'œuvre de l'éloquence latine); កថា

discourtois,e *a.* ដែលឥតគួរសម, មិនសុភាព

discourtoisement *adv.* ដោយឥតគួរសម; ដោយមិនសុភាព

discourtoisie *n.f.* ការឥតគួរសម

discrédit *n.m.* ការខូចតម្លៃ (ឧ. la multiplication des assignats amena leur discrédit); ការខូចសេចក្ដីគប់អាន ឬ ខូចកិត្យានុភាព

discréditer *v.t.* បង្ខូចកិត្យានុភាព (ឧ. discréditer un rival)

discret,ète *a.* ដាច់ៗពីគ្នា(ឧ. quantité discrète); ដែលមិនសូវនិយាយស្ដី, មាត់ជិត(ដែលចេះលាក់ការសម្ងាត់) (ឧ. soyez sincère mais discrète); ដែលចេះលាក់អាថ៌កំបាំង (ឧ. ami discret); មិនឆើតពេក (ឧ. toilette discrète)

discrètement *adv.* ដោយមិនសម្ញែងពេក; ដោយមិនឆើតពេក

discrétion *n.f.* ការមិនសូវសម្ញែង(ដោយកាយ ឬ វាចា) (ឧ. agir avec discrétion); ការចេះលាក់អាថ៌កំបាំង (ឧ. compter sur la discrétion de quelqu'un) ។ à la discrétion de *loc. adv.* នៅក្នុងកណ្ដាប់ដៃនៃ, នៅក្នុងឧភ័យនៃ ។ s'en remettre à la discrétion de quelqu'un ផ្ដុកផ្ដាក់ឱ្យអ្នកណាម្នាក់សម្រេចតាមអំពើចិត្ត ។ à discrétion *loc. adv.* តាមអំពើចិត្ត, គ្មានល័ក្ខខ័ណ្ឌ

discrétionnaire *a.* ឆន្ទានុសិទ្ធិ, ដែលសម្រេចបានតាមអំពើចិត្ត; ដែលគ្មានល័ក្ខខ័ណ្ឌ ។ pouvoir discrétionnaire អំណាចឆន្ទានុសិទ្ធិ

(អំណាចសម្រេចបានតាមអំពើចិត្ត)

discriminant,e *a.* ដែលញែកសព្ទ

discrimination *n.f.* ការវែកញែក; ការស្គាល់ (ស្គាល់ភាពប្លែកគ្នានៃវត្ថុពីរ) (ឧ. faire la discrimination entre le vrai et le faux); ការរើសអើង (ឧ. discrimination entre les races) ។ sans aucune discrimination ដោយឥតរើសអើង

discriminer *v.t.* វែកញែក; ស្គាល់ (ស្គាល់ភាពប្លែកគ្នានៃវត្ថុពីរ)

disculpation *n.f.* វិពិរុទ្ធកម្ម, ការឲ្យរួចទោស; ការដោះខ្លួន

disculper *v.t.* ឲ្យរួចពិរុទ្ធ,ឲ្យរួចទោស ។ se disculper *v.pr.* លាងខ្លួន

discursif,ive *a.* វិចារ(ឧ.la pensée discursive s'oppose à la pensée intuitive)(ម.ព. connaissance ផង)

discussion *n.f.* សាកច្ឆា, ការពិភាក្សា (ឧ. discussion d'un projet de loi); ការជជែកគ្នា, ការប្រកែកគ្នា (ឧ. ils sont toujours en discussion) ។ *Dr.* ការរឹបអូសហើយលក់ទ្រព្យខ្លះ ។ *loc.prov.* de la discussion jaillit la lumière ការជជែកនាំឲ្យបែកប្រាជ្ញា

discutable *a.* អាចជជែកបាន, អាចប្រកែកបាន

discutailler *v.i. Fam.* ជជែកលេងឥតការណ៍

discuté,e *a.* ដែលត្រូវគេរិះគន់, ដែលមានគេប្រកែក

discuter *v.t.* ពិភាក្សា,ជជែករកខុសត្រូវ (ឧ. discuter un problème); ជជែក, ប្រកែក (ឧ.discuter les ordres d'un supérieur)។ *Dr.* រឹបអូសហើយលក់ទ្រព្យខ្លះ(ឧ.le créancier d'un mineur doit discuter les biens meubles du débiteur avant de saisir ses immeubles) ។ discuter de ប្តូរយោបល់លើ,ជជែកអំពី(ឧ.discuter de politique ឬ discuter politique) ។ *v.i.* ជជែក (ឲ្យយោបល់ផ្សេងពីគូសន្ទនា)

discuteur,euse *a.&n.* ដែលចូលចិត្តជជែក

disert,e *a.* ដែលនិយាយរួសរ៉ាវ

disertement *adv.* ដោយរួសរ៉ាវ

disette *n.f.* ទុរ្ភិក្ស (ដំណើរអត់ឃ្លាន)

disetteux,euse *a.&n.* ដែលខ្វះមុខខ្វះក្រោយ

diseur,euse *n.* ជាងសំដី ។ diseuse de bonne aventure ស្ត្រីអ្នកទាយ ។ អ្នកថ្លែងតាមវត្តស្មើ (ឧ. fin diseur)

disgrâce *n.f.* ការខូចក្ដីគាប់ (ឧ. tomber en disgrâce) ។ *Fig.* ការខូចបុណ្យ, អភ័ព្វ (ឧ. pour comble de disgrâce...)

disgrâcié,e *a.* ដែលខូចក្ដីគាប់ ។ *Fig.* ដែលខូចបុណ្យ, អភ័ព្វ

disgrâcier *v.t.* លែងអនុគ្រោះ

disgrâcieusement *adv.* ដោយមិនទន់ភ្លន់; ដោយមិនពីរោះ ឬ មិនល្អ

disgrâcieux,euse *a.* មិនទន់ភ្លន់, អក្រក់, មិនពីរោះ (ឧ. réponse disgrâcieuse)

disjoindre *v.t.* បំបែកចេញពីគ្នា។ *Dr.* disjoindre deux causes បំបែករឿងក្ដីជាពីរ(ដើម្បីជម្រះដាច់ពីគ្នា)។ se disjoindre *v.pr.* បែកចេញពីគ្នា

disjoint,e *a.* *Mus.* ឆិន្នព័

disjoncteur *n.m.* *Electr.* ប្រដាប់ផ្ដាច់ចរន្ត

disjonction *n.f.* ការបំបែកចេញពីគ្នា; ការញែកចេញពីគ្នា។ *Dr.* បំបែករឿងក្ដី

dislocation *n.f.* ការបែក (ចំពោះវត្ថុដែលខាំជាប់គ្នា) (ឧ. dislocation des pierres d'un mur); ការភ្លាត់ឆ្អឹង; ការបំបែកចេញពីគ្នា (ឧ. la dislocation d'un cortège) ។ *Fig.* ការបែកបាក់ (ឧ. la dislocation d'un Etat)

disloquer *v.t.* ធ្វើឲ្យភ្លាត់ឆ្អឹង (ឧ. disloquer un membre); បំបែក (ឧ. disloquer un rassemblement) ។ *Fig.* បំបែកបំបាក់ (ឧ. disloquer un empire)។ se disloquer *v.pr.* បាក់បែក; ភ្លាត់ (ឆ្អឹង)

dispache *n.f.* ការជួសជុលសោហ៊ុយខូចខាតតាមនាវា

disparaitre *v.i.* លិច (ឧ. le soleil disparait à l'horizon); បាត់ (ដោយគេច,ដោយចាកចេញ)(ឧ. il a disparu de chez lui); បាត់ (រកមិនឃើញ) (ឧ. mes gants sont disparus); អន្តរធាន; ក្ស័យ; ស្លាប់ (ឧ. elle a disparu dans la fleur de l'âge)

disparate *a.* រាត់រាយ; មិនស៊ីគ្នា (ឧ. couleurs disparates) ។ *n.f.* ការមិនទាក់ទងគ្នា (ឧ. ses actions et ses paroles forment une étrange disparate)

disparité *n.f.* ភាពខុសគ្នា (ឧ. disparité des caractères)

disparition *n.f.* ការបាត់; ការលិច; ការចាកចេញ; អន្តរធាន; សេចក្ដីស្លាប់

disparu,e *a.&n.* ដែលស្លាប់,ដែលបាត់ខ្លួន ឬ ដែលទុកជាស្លាប់ (ឧ. militaire porté disparu)

dispatcher *n.m.* ភ្នាក់ងាររៀបចំដំណើរអយស្ម័យយាន ឬ ចែកកម្លាំងអគ្គិសនី

dispatching *n.m.* អង្គការរៀបចំដំណើរអយស្ម័យយាន ឬ ចែកកម្លាំងអគ្គិសនី

dispendieusement *adv.* ដោយចាយច្រើន, ដោយថ្លៃច្រើន

dispendieux,euse *a.* ដែលឲ្យចាយច្រើន; ថ្លៃច្រើន

dispensable *a.* អាចលើកលែងបាន(ឧ. cas dispensable)

dispensaire *n.m.* ឱសថាល័យ, មន្ទីរចែកឱសថ (ការព្យាបាលរោគក្នុងមន្ទីរនេះមិនហួសពីមួយថ្ងៃឡើយ)

dispensateur,trice *n.* អ្នកចែក

dispense *n.f.* វិធាវិធាន, អនុញ្ញាតឲ្យរួច (អំពីកិច្ចការអ្វីមួយ) (ឧ. dispense d'âge pour un examen)

dispenser *v.t.* ចែក (ឧ. le soleil dispense la lumière) ។ dispenser l'enseignement បង្រៀន ។ អនុញ្ញាតឲ្យរួច (អំពីកិច្ចការអ្វីមួយ) (ឧ. je vous dispense de m'accompagner; dispenser quelqu'un de corvée) ។ se dispenser de *v.pr.* រួចខ្លួនអំពី, មិនបំពេញកិច្ច

dispersal *n.m.* (ពាក្យអង់គ្លេស) ចំណតអាកាសយាន (ទីលានក្រាលស៊ីម៉ង់សម្រាប់ចតអាកាសយាន)

dispersement *n.m.* ការបំបែក; ការបែកខ្ញែកគ្នា

disperser *v.t.* ករាយ (ឧ. disperser des papiers); ធ្វើឲ្យបែកខ្ញែក, កំចាត់កំចាយ (ឧ. disperser un attroupement); លក់ឲ្យបែកខ្ញែក (ឧ. disperser une collection) ។ *Fig.* ធ្វើឲ្យរាត់រាយ (ឧ. disperser ses efforts) ។ se disperser *v.pr.* បែកខ្ញែកគ្នា (ឧ. la foule se disperse)

dispersif,ive *a.* ដែលធ្វើឲ្យពន្លឺបាចសាច

dispersion *n.f.* ការរាយ; ការបំបែកគ្នា; ការបែកខ្ញែកគ្នា

disponibilité *n.f.* ភាពទំនេរ(ភាពគ្មានការធ្វើ; ភាពភ្នាក់ងាររាជការនៅទំនេរ គឺឈប់មិនកាន់មុខដំណែងមួយដងមួយកាល); អ្នកទំនេរទាំងឡាយ (ពួកជនដែលទើបនឹងចេញពីទាហានហើយដែលរាជការអាចហៅឲ្យចូលធ្វើវិញបានភ្លាមៗ) ។ *pl.* វត្ថុឬប្រាក់ទំនេរ (វត្ថុឬប្រាក់ដែលអាចប្រើប្រាស់បានភ្លាមៗ)(ឧ. utiliser ses disponibilités)

disponible *a.* ទំនេរ (ឧ. logement disponible)។ *Dr.* ទំនេរ (ចំពោះទ្រព្យសម្បត្តិដែលអាចចាត់ប្រើបាន) ។ *n.m.* ភ្នាក់ងាររាជការដែលនៅទំនេរ; ជនក្នុងពួកដែលទើបនឹងចេញពីរាជការទាហាន

dispos,e *a.* ស្រួលខ្លួន; ភ្លឺថ្លា (បញ្ញា)

disposant,e *n. Dr.* អ្នកធ្វើអំណោយ (អ្នកចាត់ទ្រព្យជាអំណោយ ឬ ជាមរតក)

disposer *v.t.* រៀប, រៀបចំ (ឧ. disposer des fleurs sur une étagère); រៀបបម្រុង (ឧ. l'étude nous dispose à la joie); បង្ខំ, ដឹកនាំ (ឧ. disposer quelqu'un à accepter une demande) ។ disposer de ទុកដាក់បានតាមអំពើចិត្ត, តម្រូវប្រើបានតាមប្រាថ្នា (ឧ. disposer de ses amis); មាន (សម្រាប់ប្រើប្រាស់) (ឧ. disposer d'une voiture) ។ vous pouvez disposer អញ្ជើញទៅចុះ (រួចកិច្ចហើយ ឬ លោកទំនេរហើយ) ។ se disposer *v.pr.* បម្រុងខ្លួន, រៀបចំខ្លួននឹង (ឧ. se disposer à partir pour la campagne)

dispositif *n.m. Mil.* របៀបរៀបគ្រឿង ឬ រៀបពល (ដើម្បីប្រយុទ្ធ) ។ *Méc.* ការរៀបចំគ្រឿងចក្រ; គ្រឿងចក្រ, គ្រឿងម៉ាស៊ីន

disposition *n.f.* ការរៀបចំ (ឧ. la disposition des mots dans la phrase); សុខភាព, ចរិត (ឧ. être en bonne disposition); លំនាំទៅរក (ឧ. disposition des prix à la hausse); ការចងចិត្តទៅលើអ្នកណាមួយ (ឧ. ses dispositions à votre égard sont excellentes); អំណាចប្រើប្រាស់តាមចិត្ត (ឧ. avoir beaucoup

de livres à sa disposition)។ *Pl.* ការរៀបចំ, ការប្រុងប្រៀប (ឧ. prendre ses dispositions pour partir); សព្ទា, ការចូលចិត្ត (ឧ. cet enfant a des dispositions pour le dessin); បទបញ្ញត្តិ (ច្បាប់), ខ (កិច្ចសន្យា) (ឧ. dispositions testamentaires)។ disposition spéciale ខ ឬ បទបញ្ញត្តិពិសេស ។ disposition transitoire អន្តរបញ្ញត្តិ, បទបញ្ញត្តិបណ្ដោះអាសន្ន។ mettre à la disposition de ដាក់ក្នុងឧភិទទៃ

disproportion *n.f.* វិសម្មាមាត្រ, ភាពមិនសមមាត្រ; ភាពខុសគ្នា (ឧ. disproportion d'âge, de longueur)

disproportionné,e *a.* វិសម្មាមាត្រ, ដែលគ្មានសម្មាមាត្រ

dispute *n.f.* ការប្រណាំងប្រជែង;ជម្លោះ

disputer *v.i.* ជជែក, ប្រឈ្លោះ; ប្រជែង (ឧ. ils disputent de zèle)។ *v.t.* ដណ្ដើម (ឧ. disputer un prix, un match)។ *Fam.* ស្ដីបន្ទោស (ឧ. disputer son fils)។ se disputer *v.pr.* ប្រឈ្លោះគ្នា, ជម្លែង

disquaire *n.m.* ជាងពាណិជ, ឈ្មួញថាសម៉ាស៊ីនច្រៀង

disqualification *n.f.* ការលែងឲ្យប្រណាំងប្រជែង (ព្រោះមានកំហុស)

disqualifier *v.t.* លែងឲ្យប្រណាំង-ប្រជែង (ព្រោះមានកំហុស) (ឧ. disqualifier un coureur)។ *Fig.* បង្ខូចកិត្យានុភាព, បង្ខូចតម្លៃ ។ se disqualifier *v.pr.* ខូចតម្លៃ, ខូចកិត្យានុភាព

disque *n.m.* ថាស, ថាសចោល (ក្នុងកីឡា)។ *Astr.* មណ្ឌល(ពារ)។ *Ch. de f.* ថាសសញ្ញា (ប្រាប់ថាផ្លូវទំនេរឬមិនទំនេរ);ថាសសព្ទ,ថាសម៉ាស៊ីនច្រៀង

dissection *n.f.* មតសរីរច្ឆេទនសាស្ត្រ [ម:-ត:-ស:-រី-ច៉ច់-ឆេ-ទ:-ន:--]; កាយវិភាគ(ការវះសង្កេតអាការៈក្នុងខ្លួន)

dissemblable *a.* មិនដូចគ្នា

dissemblance *n.f.* ភាពមិនដូចគ្នា

dissémination *n.m.* ការជម្រុះរាត់រាយ (គ្រាប់ឈើ), ការបាចសាច

disséminé,e *a.* រាត់រាយ

disséminer *v.t.* ជម្រុះរាត់រាយ, បាច-សាច, រាយ (ឧ. disséminer des graines, des troupes) ។ se

disséminer *v.pr.* ព្រុះរាត់រាយ

dissension *n.f.* ការទាស់ប្រឆាំងគ្នា

dissentiment *n.m.* ការខ្វែងគំនិត ឬ ខ្វែងយោបល់

disséquer *v.t.* ធ្វើកាយវិភាគ, វះសង្កេតអាការៈក្នុងខ្លួន (ឧ. disséquer un cadavre)។ *Fig.* វិភាគដោយល្អិតល្អន់ (ឧ. disséquer un roman)

dissertation *n.f.* បរមាធិប្បាយ

disserter *v.t.* ធ្វើបរមាធិប្បាយ(ឧ. disserter sur un texte)

dissidence *n.f.* ការបែកបក្សពួក (ឧ. entrer en dissidence); ក្រុមអ្នកបែកបក្សពួក; ការខ្វែងមតិ

dissident,e *a.* ដែលបែកបក្សពួក, ដែលមានមតិខុសពីភាគច្រើន, ដែលនៅក្រៅសាសនារបស់រដ្ឋ។ *n.* អ្នកបែកបក្សពួក

dissimilation *n.f.* វិសទិសកម្ម

dissimilitude *n.f.* វិសទិសភាព, ភាពខុសគ្នា

dissimulateur,trice *a.&n.* ដែលលាក់, ដែលបិទបាំង

dissimulation *n.f.* ការលាក់បំបាំង, ចរិតមនុស្សលាក់គំនិត; វត្ថុដែលលាក់បំបាំង

dissimulé,e *a.* ដែលធ្លាប់តែលាក់គំនិត (ឧ. caractère dissimulé)

dissimuler *v.t.* លាក់ (មិនឲ្យគេដឹង) (ឧ. dissimuler sa fortune); ធ្វើជាមិនដឹងខ្លួន; បិទបាំង(dissimuler sa joie); លាក់គំនិត ។ se dissimuler *v.pr.* លាក់ខ្លួន, ពួន, បិទបាំង (ឧ.ironie qui se dissimule derrière le sourire)

dissipateur,trice *a.&n.* អ្នកចាយខ្ជះខ្ជាយ

dissipation *n.f.* ការកំចាត់បង់; ការបង្ហិន;ការចាយវាយខ្ជះខ្ជាយ (ឧ.dissipation d'un patrimoine) ។ អំពើពាយងាយ, ភាពមនុស្សអនាចារ

dissipé,e *a.* រពឹស, ពិបាកប្រដៅ (ឧ. écolier dissipé)

dissiper *v.t.* កំចាត់បង់(ឧ. le soleil dissipe les nuages) ។ *Fig.* បំបាត់ (ឧ. dissiper les soupçons);ចាយខ្ជះខ្ជាយ,បង្ហិន(ឧ.dissiper sa fortune);បន្ទូប (ឧ.dissiper un camarade) ។ se dissiper *v.pr.* គិតតែខាងលេងជាងធ្វើការ; បែកខ្ញែកគ្នា; រសាត់រសាយ

dissociabilité *n.f.* ភាពអាចញែកចេញពីគ្នាបាន

dissociable *a.* អាចញែកចេញពីគ្នាបាន

dissocier *v.t.* ញែកចេញពី ។ *Fig.* បំបែក, ធ្វើឲ្យរាត់រាយ

dissolu,e *a.* ខិលខូច

dissolubilité *n.f.* ភាពអាចរំលាយបាន

dissoluble *a.* អាចរំលាយបាន

dissolutif,ive *a.* ដែលរំលាយ (ឧ. remède dissolutif)

dissolution *n.f.* ការរំលាយ; ដំណើររលាយ; ការប៉ះកៅស៊ូពោះវៀនកង់ ។ *Fig.* ការខូច (ឧ. dissolution des mœurs); ការបាក់បែក (ឧ. dissolution de l'empire romain) ។ dissolution de l'Assemblée Nationale ការរំលាយរដ្ឋសភា ។ dissolution d'une association ការរំលាយសមាគម

dissolvant,e *a.* ដែលសម្រាប់រំលាយវត្ថុដទៃ (ឧ. l'eau est un dissolvant) ។ *Fig.* ដែលជាហេតុឲ្យខូចមនុស្ស (ឧ. doctrine dissolvante); ដែលធ្វើឲ្យទន់ខ្សោយ (ឧ. climat dissolvant)

dissonance *n.f.* សម្លេងឈ្លើយ, សម្លេងមិនពីរោះ (ម.ព. consonance ផង)

dissonant,e *a.* *Mus.* ឈ្លើយ(សម្លេង)

dissoner *v.i.* *Mus.* មានសម្លេងឈ្លើយ

dissoudre *v.t.* រំលាយ (ឧ. l'eau dissoud le sel) ។ *Fig.* ផ្ដាច់, រំលាយ (ទុកជាមោឃៈ) (ឧ. dissoudre un mariage); រំសាយ, បំបាត់ចោល (ឧ. dissoudre une assemblée) ។ se dissoudre *v.pr.* រលាយ

dissous,oute *a.* ដែលរលាយ (ឧ. sucre dissous) ។ *Fig.* ដែលរលាយ, ដែលដាច់ (ឧ. alliance dissoute)

dissuader *v.t.* ឃាត់

dissuasion *n.f.* ការឃាត់

dissyllabe ឬ **dissyllabique** *a.* & *n.m.* ទ្វេព្យាង្គ, ដែលមានពីរព្យាង្គ

dissymétrie *n.f.* វិសមប្បមាណ (ភាគសងខាងមិនស្មើគ្នា)

dissymétrique *a.* ដែលមានវិសមប្បមាណ, ដែលមានភាគសងខាងមិនស្មើគ្នា

distance *n.f.* ចម្ងាយ (ឧ. le son faiblit à mesure que la distance augmente); ចន្លោះ (ពេលសម័យ) (ឧ. une distance de dix ans entre deux événements); ចន្លោះ(ពីវត្ថុមួយទៅមួយ)

(ឧ. laisser trop de distance entre deux colonnes); ភាពខុសគ្នា (ឧ. la distance qu'il y a de l'honnête homme à l'habile homme s'affaiblit de jour à l'autre) ។

Loc. div. de distance en distance ពីកន្លែងមួយទៅកន្លែងមួយ, ឯនេះមួយឯនោះមួយ ។ à distance ពីចម្ងាយ, ក្នុងពេលកន្លងយូរទៅ (ឧ. plus la postérité voit les grands hommes à distance, plus elle les grandit en bien comme en mal) ។ tenir quelqu'un à distance មិនឲ្យចូលជិត (ឧ. tenir l'ennemi à distance); *au fig.* មិនឲ្យស្និទ្ធស្នាល (ឧ. tenir à distance ses domestiques) ។ rapprocher les distances ធ្វើឲ្យមានភាពស្មើគ្នា (ឧ. le malheur rapproche les distances)

distancer *v.t.* ចោល, ទៅហួសមុន; ឈ្នះ

distant,e *a.* ឆ្ងាយពីគ្នា, ឃ្លាតពីគ្នា (ឧ. deux villes distantes de 100 kilomètres) ។ *Fig.* ក្រអឺតក្រទម (ឧ. il est fier et distant)

distendre *v.t.* ធ្វើឲ្យតឹងខ្លាំង (ឧ. distendre un ressort); ធ្វើឲ្យប៉ោង ឬ ឲ្យហើមខ្លាំង (ឧ. gaz qui distendent l'estomac) ។ **se distendre** *v.pr. Fig.* ធុះធូរវិញ (ឧ. leurs liens se sont distendus)

distension *n.f.* ភាពតឹង ឬ ប៉ោងខ្លាំង (ឧ. distension de l'intestin)

distillable *a.* អាចបិតបាន (ចំហុយយកញើស)

distillat *n.m.* ផលនៃការបិត (ញើសដែលចំហុយបាន)

distillateur *n.m.* អ្នកចំហុយ (យកញើស); អ្នកបិតស្រា

distillation *n.f.* ការចំហុយយកញើស; ការបិតស្រា; វត្ថុបានមកពីការចំហុយ

distiller *v.t.* ចំហុយយកញើស; បិតស្រា (ឧ. distiller du vin); សម្រក់, បញ្ចេញ (ឧ. plante qui distille du venin) ។ *Fig.* បង្កើត (ឧ. distiller l'ennui)

distillerie *n.f.* កន្លែងចំហុយយកញើស; សុរាគារ, កុងស៊ីបិតស្រា

distinct,e *a.* ផ្សេង (ឧ. objets dis-

tincts) ។ *Fig.* ច្បាស់ (ឧ. bruit distinct; termes distincts)

distinctement *adv.* ដោយផ្សេង, ដោយច្បាស់

distinctif,ive *a.* សម្រាប់សំគាល់ (ឧ. un signe distinctif)

distinction *n.f.* វិភេទ, ការសំគាល់, ការវែកញែក (ឧ. distinction des pouvoirs); ភាពខុសគ្នា (ឧ. distinction entre le bien et le mal); សេចក្ដីគោរពរាប់អាន (ឧ. recevoir une distinction); ភាពសមរម្យ (ឧ. manquer de distinction)

distingué,e *a.* ចំណាន (ឧ. écrivain distingué); ដែលល្បះគួរសម (ឧ. manières distinguées)

distinguer *v.t.* ស្គាល់ច្បាស់ (មិនអាចច្រឡំគ្នាបាន) (ឧ. distinguer une personne, une chose d'une autre ឬ d'avec une autre); សំគាល់, ចំណាំ (ឧ. distinguer les temps, les lieux); ញែក (ធ្វើឲ្យឃើញខុសគ្នា) (ឧ. la raison distingue l'homme des animaux); ទុកដោយឡែក, ចូលចិត្តខាង (ឧ. il le distingua pour cette fonction) ។ se distinguer *v.pr.* មានលក្ខណៈប្លែក, ធ្វើឲ្យគេសំគាល់ខ្លួន, ធ្វើឲ្យល្បីឈ្មោះ

distinguo *n.m.* (*mot lat.*) ការសំគាល់, ការញែក (ឧ. de subtils distinguos)

distomatose *n.f.* រោគដង្កូវថ្លើម (ចំពោះតែសត្វស៊ីស្មៅ)

distordre *v.t.* ធ្វើឲ្យរមួល (ឧ. la paralysie distord le corps humain); ការធ្វើឲ្យវេច

distors,e *a.* រមួល (ឧ. membres distors)

distorsion *n.f.* ដំណើររមួល ឬ វៀច (ឧ. distorsion de la hanche); ដំណើរខុសពីរូបភាពដើម (រូបថតមិនខ្ជិប); ដំណើរខុសពីសម្លេងដើម (សម្លេងមិនផ្ទួចក្នុងវិទ្យុ)

distraction *n.f.* *Dr.* ការបំបែកចេញ; ការដកហូតប្រាក់; ចរិតរាយមាយ, ការធ្វេសប្រហែស (ឧ. accuser quelqu'un de distraction); កិច្ចការធ្វើដោយធ្វេសប្រហែស (ឧ. commettre des distractions); ការកំសាន្ត (ឧ. lire est une saine

distraction)

distraire *v.t.* បំបែកចេញ (ឧ. somme distraite d'une autre); ដកហូតយកជាប្រយោជន៍ខ្លួន (ឧ. distraire un héritage) ។ *Fig.* បង្វែបង្វប់ (ឧ. distraire quelqu'un de son travail); នាំលេង (ឧ. distraire des enfants) ។ se distraire *v.pr.* បែកចេញ; លះបង់; កំសាន្ត

distrait,e *a.&n.* ដែលឃ្លាតចេញ ។ *Fig.* ភយមាយ (ឧ. enfant distrait)

distraitement *adv.* ដោយភយមាយ

distrayant,e *a.* ដែលនាំឲ្យសប្បាយចិត្ត

distribuable *a.* អាចចែកគ្នាបាន

distribuer *v.t.* ចែក (ឧ. distribuer des prix); ចែក, រៀបចំ (ឧ. distribuer un appartement); ឲ្យមិនរើសមុខ (ឧ. distribuer des coups; distribuer des sourires)

distributaire *a.&n.* អ្នកទទួលចំណែក

distributeur,trice *n.* អ្នកចែក (ឧ. distributeur de prospectus) ។ *n.m.* ម៉ាស៊ីនសម្រាប់ចែក (ឧ. distributeur d'engrais)

distributif,ive *a.* ដែលចែក

distribution *n.f.* ការចែក (ឧ. distribution de vivres); ការរៀបចំ, ការចែកជាបន្ទប់ (ឧ. distribution d'un appartement); ការចែកសំបុត្រដល់ផ្ទះ, ការចែកមុខរឿងឲ្យលេង (ល្ខោន); ការផ្សាយខ្សែភាពយន្ត

district *n.m.* បណ្ឌលទីតកប្ប ។ *Par ext.* ស្រុក (ភាគនៃខេត្ត)

distyle *a.* ដែលមានសសរពីរ

dit,e *a.* ដែលត្រូវសំដីគ្នាហើយ (ឧ. c'est une chose dite); ហៅ (ឧ. Chea dit Néang) ។ *n.m.* ភាសិត (ឧ. les dits mémorables de Socrate)

dithyrambe *n.m.* ស្លោក, កំណាព្យសរសើរ; ការសរសើរហួសពេក

dithyrambique *a.* នៃស្លោក, នៃកំណាព្យសរសើរ, ដែលសរសើរហួសពេក

dito *mot inv.* (do) ដូចខាងលើនេះ, ដូចគ្នា (ឧ. trois châles bleus et six dito noirs)

dit-on *n.m. inv.* ពាក្យចចាមអាចម៍ (ម.ព. dire ផង)

diurèse *n.f.* ដំណើរនោមច្រើន

diurétique *a.* ដែលឲ្យនោម (ឧ. le

thé est diurétique) ។ *n.m.* ថ្នាំនោម

diurne *a.* ដែលមានពេលថ្ងៃ (ឧ. mouvement diurne de la terre)។ *Par ext.* ដែលធ្វើក្នុងពេលថ្ងៃ (ឧ. travaux diurnes) ។ *Zool.* ទិវាចរ, ដែលរកស៊ីតែថ្ងៃ ។ *Bot.* ដែលរីកតែពេលថ្ងៃ (ផ្កា)

diva *n.f.* គីតិកាល្បីល្បាញ (ស្ត្រីចម្រៀង)

divagateur,trice *a.&n.* ដែលទៅផ្តេសផ្តាស, រវើរវាយ (ឧ. imagination divagatrice)

divagation *n.f.* ការដើរវេស, ការនិយាយផ្តេសផ្តាស, ភាពរវើរវាយ ។ *Géogr.* ដំណើរផ្លាស់កន្លែងនៃផ្លូវទឹក (ទន្លេ, ស្ទឹង ។ល។)

divaguer *v.i.* ដើរវេស។*Fig.* និយាយផ្តេសផ្តាស, និយាយរវើរវាយ

divan *n.m.* កៅអីទម្រេត; ក្រុមប្រឹក្សាព្រះចៅស៊ុលតង់ (ក្នុងសម័យបូរាណ) ។ *Par ext.* ម្លោកិជាលប្រទេសទួរគី

dive *a.f.* ទិព្វ(ឧ.la dive bouteille)

divergence *n.f.* ភាពញែកឃ្លាតពីគ្នា ។ *Fig.* ការខ្វែងគំនិត ឬ យោបល់ (ឧ. divergence d'opinions)

divergent,e *a.* ដែលញែកឃ្លាតពីគ្នា(ឧ. rayons divergents); ដែលធ្វើឲ្យញែកឃ្លាតពីគ្នា (ឧ.lentille divergente) (ម.ព. lentille ផង) ។ *Fig.* មិនស្របគ្នា, ខ្វែងគ្នា, ផ្ទុយគ្នា (ឧ. avis divergents)

diverger *v.i.* ញែកឃ្លាតពីគ្នា (បន្ទាត់, ស្មើ) ។ *Fig.* មិនស្របគ្នា, ខ្វែងគ្នា

divers,e *a.*ផ្សេងគ្នា(ឧ.pays divers); មិនទៀង (ឧ. l'homme est divers) ។ *pl.* ផ្សេងៗ, ច្រើន, ខ្លះ (ឧ. divers écrivains)

diversement *adv.* ដោយរបៀបផ្សេងគ្នា, ដោយខុសគ្នា (ឧ. phrase diversement interprétée)

diversifier *v.t.* ធ្វើឲ្យប្លែកពីគ្នា. ផ្លាស់

diversiforme *a.* ដែលមានរូបរាងច្រើនបែប (ថា hétéromorphe ក៏បាន)

diversion *n.f.* ការបង្វែង ។ *Fig.* ការពង្រៃ, ការបំបែរ(ចិត្ត,គំនិត); ការបំភ្លេចទុក្ខ (ឧ. les voyages font diversion au chagrin)

diversité *n.f.* នានាភាព, ភាពផ្សេងៗគ្នា(ឧ. diversité de goûts);ភាពទីទៃពីគ្នា (ឧ. diversité entre deux opinions)

divertir *v.t.* នាំលេង, បង្វែង, ធ្វើឲ្យ

សប្បាយ ។ se divertir *v.pr.* លេង, លេងសប្បាយ

divertissant,e *a.* ដែលឲ្យលំហែ,ដែលឲ្យសប្បាយ

divertissement *n.m.* ល្បែង, ការលំហែ, ការលេង, ការបង្វែងលួច (ឧ. divertissement de fonds) ។ *Théât.* ការកំសាន្ត (មានរាំ, ច្រៀងជាដើម) ក្នុងពេលចន្លោះឈុតល្ខោន

divette *n.f.* ស្ត្រីចម្រៀងក្នុងតៀមកាហ្វេ

dividende *n.m.Math.* តំណាងចែក (ទព្វន្ត)(ឧ. en multipliant le diviseur par le quotient et en ajoutant le reste, on retrouve le dividende); ភាគលាភ (ចំណែកប្រាក់ចំណេញ; ចំណែកដែលម្ចាស់បំណុលត្រូវបានក្នុងការបែងចែកទ្រព្យពាណិជ្ជធនក្ស័យ)

divin,e *a.* នៃអាទិទេព (ឧ. bonté divine); សម្រាប់អាទិទេព(ឧ.culte divin); ដែលគេលើកជាអាទិទេព(ឧ. le divin Auguste) ។ *Par exag.* ទិព្វ, ឧត្តម (ឧ.une musique divine) ។ *n.m.* វត្ថុទិព្វ

divinateur,trice *a.&n.* ដែលយល់, ដែលទាយទុកជាមុនបាន (ឧ. esprit divinateur)

divination *n.f.* ការទាយ (ចំពោះការទាយអនាគត) (ឧ. l'astrologie est un des nombreux procédés de divination); ការចេះទាយ; សេចក្តីភ្លឺវៃ

divinatoire *a.* នៃការទាយ

divinement *adv.* ដោយរឹទ្ធិអាទិទេព ។ *Par ext.* យ៉ាងវិសេស(ឧ.chanter divinement)

divinisation *n.f.* ការលើកជាអាទិទេព

diviniser *v.t.* លើកជាអាទិទេព (ឧ. diviniser un héros) ។ *Par ext.* ទុកជាពិសិដ្ឋ (ឧ. les païens ont divinisé la vie)

divinité *n.f.* ភាពឬលក្ខណៈជាអាទិទេព (ឧ. reconnaître la divinité de Jésus); អាទិទេព, ទេវរូប (ឧ. divinité antique)

diviser *v.t.* ចែក (ឧ. diviser une somme); ខណ្ឌ(ឧ. diviser une pièce par une cloison),បំបែក (ឧ. diviser les forces de l'ennemi)។ *Math.* ចែក។ *Fig.* បំបាក់បំបែក (ឧ. le régime des partis politiques divisa le

Cambodge) ។ se diviser *v.pr.* បែក, បែកគ្នា, បែកជាក់គ្នា (ឧ. ils se divisèrent en plusieurs groupes)

diviseur *n.m.* *Math.* ជើងហារ ។ *Fig.* អ្នកបំបែកបំបាក់

divisibilité *n.f.* *Math.* ភាពចែកដាច់

divisible *a.* អាចចែកដាច់; អាចបែងចែកបាន

division *n.f.* ការបែងចែក (ឧ. la division du Cambodge en Khèts); ការបំបែកជាភាគតូចៗ (ឧ. la division de la propriété)។ *Par anal.* ការបំបែកគ្នា (ឧ. la division des prisonniers); ការចែកមុខគ្នា (ឧ. la division des pouvoirs responsables); ការបំបែកជាពួកឬជាក្រុម (ឧ. les divisions des langues n'implique pas nécessairement des divisions de races); ការបែក (ឧ. le séjour dans l'eau amène la division des matières) ។ *Par ext.* ភាគ, ចំណែក (ឧ. la minute est une division de l'heure) ។ *Math.* លេខចែក ។ *Mil.* កងពល (ឧ. division blindée)។ *Adm.* ផ្នែក។ division cadastrale ផ្នែកសុរិយោដី ។ *Fig.* ការមិនមូលមិត្ត, ការបាក់បែក ឬ ការទាស់ទែងគ្នា (ឧ. semer la division dans une famille)

divisionnaire *a.* នៃផ្នែក (ឧ. inspecteur divisionnaire) ។ *n.m.* ឧត្តមសេនីយទោ

divorce *n.m.* ការដាច់សមគ្គសង្វាស, ការលែងលះប្ដីប្រពន្ធ ។ *Fig.* ភាពផ្ទុយគ្នា, ភាពខុសគ្នា (ឧ. il y a divorce entre la théorie et la pratique)

divorcer *v.i.* ផ្ដាច់សមគ្គសង្វាស, លែងលះប្ដីប្រពន្ធ (ឧ. elle a divorcé d'avec lui) ។ *Fig.* ផ្ដាច់ចេញពី, លែងរវល់នឹង (ឧ. divorcer avec (ឬ d'avec) le monde)

divulgateur,trice *n.* អ្នកបករឿងស្ងាត់កំបាំង

divulgation *n.f.* ការបករឿងស្ងាត់កំបាំង

divulguer *v.t.* បករឿងស្ងាត់កំបាំង (ឧ. divulguer un secret)

divulsion *n.f.* ការដក, ការបោច

dix *a.num.* ដប់,ទី១០(ឧ.Léon X)។ *n.m.* លេខ១០; ថ្ងៃទី១០ (ក្នុងខែ)

dix-cors *a.&n.m.* ម.ព. cor

dix-huit *a. num.* ដប់ប្រាំបី; ទី១៨ ។ *n.m.* លេខ ១៨; ថ្ងៃទី ១៨ (ក្នុងខែ)

dix-huitième *a. num. ord.* ទី១៨។ *n.* របស់ ឬ មនុស្សទី១៨ (ឧ. être le ឬ la dix-huitième)។ *n.m.* ភាគ ១៨

dix-huitièmement *adv.* ជាទី ១៨; ទ ១៨

dixi (j'ai dit) *loc. lat.* ខ្ញុំពោលហើយ

dixième *a. num. ord.* ទសម:, ទី ១០ ។ *n.* របស់ឬមនុស្សទី ១០ (ឧ. être le (ឬ la) dixième) ។ *n.m.* ភាគ ១០

dixièmement *adv.* ជាទី១០; ទ ១០

dix-neuf *a. num.* ដប់ប្រាំបួន; ទី១៩ (ឧ. page dix-neuf) ។ *n.m.* លេខ១៩; ថ្ងៃទី១៩ (ក្នុងខែ)

dix-neuvième *a. num. ord* ទី ១៩ ។ *n.* មនុស្ស ឬ របស់ទី ១៩ (ឧ. être le (ឬ la) dix-neuvième)។ *n.m.* ភាគ១៩

dix-neuvièmement *adv.* ជាទី១៩, ទ ១៩

dix-sept *a. num.* ដប់ប្រាំពីរ; ទី១៧ (ឧ. tome dix-sept) ។ *n.m.* លេខ ១៧; ថ្ងៃទី១៧ (ក្នុងខែ)

dix-septième *a. num. ord.* ទី ១៧ ។ *n.* របស់ ឬ មនុស្សទី១៧ (ឧ. être le(ឬla) dix-septième)។ *n.m.* ភាគ ១៧

dix-septièmement *adv.* ជាទី ១៧; ទ ១៧

dizain *n.m.* កំណាព្យដប់បាទ

dizaine *n.f.* ទសក:, ចំនួន១០, ចំនួនប្រមាណជា១០ (ឧ. une dizaine d'années)

djaïn ឬ **djaïna** *n.* ជេនមាមិក(អ្នកកាន់លទ្ធិជេន)

djaïnisme *n.m.* ជេននិយម,លទ្ធិជេន

djebel *n.m.* (ពាក្យអារ៉ាប់) ភ្នំ

djinn *n.m.* (ពាក្យអារ៉ាប់) បិសាចពួកម្រេញគង្វាល (មានល្អមានអាក្រក់)

docile *a.* សុវចៈ, មិនរឹងរូស,មិនម្នះ, ងាយស្ដីប្រដៅ, ងាយដឹកនាំ

docilement *adv.* ដោយមិនរឹងរូស, ដោយងាយស្ដីប្រដៅឬងាយដឹកនាំ

docilité *n.f.* ភាពមិនរឹងរូស, ភាពងាយស្ដីប្រដៅឬងាយដឹកនាំ

docimasie *n.f. Méd. lég.* ការក

ហេតុមរណភាព (ដោយពិនិត្យរកការៈ ខ្ទះក្នុងខ្លួន)

dock *n.m.* ឃ្លាំងនាវាភណ្ឌ, កំពង់ផែទំនិញ; អូ កប៉ាល់

docker *n.m.* កម្មករដឹកជញ្ជូនអីវ៉ាន់ឡើងចុះកប៉ាល់

docte *a.&n.* ប្រាជ្ញ

doctement *adv.* ដោយប្រាជ្ញ។ *Ironiq.* ដោយវាយឫកជាប្រាជ្ញ

docteur *n.m.* បណ្ឌិត (ឧ. docteur ès sciences)។*Absol.*វេជ្ជបណ្ឌិត; អ្នកវាយឫកជាចេះ ។ docteur en droit នីតិបណ្ឌិត

doctissime *a. Par plaisant.* ប្រាជ្ញណាស់

doctoral,e,aux *a.* នៃបណ្ឌិត (ឧ. dignité doctorale) ។ *Fig.* ក្រលរ, រឡេវម

doctoralement *adv.* ដោយរឡេវម, ដោយក្រលរ

doctorat *n.m.* ថ្នាក់បណ្ឌិត

doctoresse *n.f.* វេជ្ជបណ្ឌិត (ស្ត្រី)

doctrinaire *a.&n.m.* វាទី, អ្នកកាន់លទ្ធិខ្ជាប់

doctrinal,e,aux *a.* នៃលទ្ធិ, នៃវាទះ, នៃពាក្យប្រៀន

doctrine *n.f.* លទ្ធិ, វាទះ, ពាក្យប្រៀន

document *n.m.* ឯកសារ (ឧ.document historique; document photographique)

documentaire *a.* ដែលមានភាពជាឯកសារ;ដែលរកងលើឯកសារ(ឧ. ce livre a un interêt documentaire)។ *n.m.* documentaire ឬ film documentaire ឯកសារភាពយន្ត

documentaliste *n.* ឯកសារវិទូ (អ្នកជំនាញខាងស្រាវជ្រាវរក - ខាងស្រាវជ្រើស-ខាងរៀបចំ ឬ ខាងប្រើនិងខាងផ្សាយឯកសារ)

documentariste *n.* អ្នកធ្វើឯកសារភាពយន្ត

documentation *n.f.* ឯកសារសមោធាន, ការប្រមូលឯកសារ, ការបង្ហាញឯកសារ; ការរកងលើឯកសារ; ឯកសារទាំងឡាយ (ឧ. il a procuré une documentation fort intéressante sur la région)

documenter *v.t.* ឲ្យឯកសារ; រកងលើឯកសារ (ឧ. ouvrage documenté)។ se documenter *v.pr.* រកឯកសារ

dodécaèdre *n.m. Math.* ទ្វាទសត័ល, ប្រសព្វជ្រុងឥបំពីរ

dodécagonal,e,aux *a.* ទ្វាទសកោណ, ដែលមានឥបំពីរជ្រុង ឬ មុម

dodécagone *n.m. Math.* ទ្វាទស-កោណ

dodécastyle *a* ដែលមានសសរមុខ ១២ (វិហារសាសន៍ក្រិក)

dodécasyllabe *n.m.* ពាក្យ ១២ព្យាង្គ

dodelinement *n.m.* ការយោលក្បាល ឬយោលខ្លួនតិចៗ

dodeliner ឬ **dodiner** *v.t.* យោលតិចៗ,ងក់(ឧ.dodeliner la tète)។ *v.i.* យោលតិចៗ (យោលខ្លួនឯង)(ឧ. dodeliner de la tête)

dodo *n.m.* គ្រែ(ពាក្យក្មេង) ។ aller au dodo ឬ faire dodo ដេក

dodu,e *a.* ធាត់កណ្ដៀន,ក្រមប់ (ឧ. des joues dodues)

dogmatique *a.* នៃសិទ្ធាន្ត។ *Fig.* មុឹងម៉ាត់ (ឧ. esprit dogmatique; ton dogmatique) ។ *n.* អ្នកសិទ្ធាន្តនិយម (ឧ. les dogmatiques s'opposent aux sceptiques)។ *n.f.* សាសនសិទ្ធាន្ត(គោលសំខាន់ទាំងឡាយនៃសាសនា)

dogmatiquement *adv.* ដោយមុឹងម៉ាត់

dogmatiser *v.i.* បង្រៀនសិទ្ធាន្ត ។ *Fig.*ពោលដោយមុឹងម៉ាត់

dogmatiseur *n.m.* អ្នកនិយាយដោយមុឹងម៉ាត់

dogmatisme *n.m.* សិទ្ធាន្តនិយម; ការចូលចិត្តជឿឬចូលចិត្តអះអាងជាពិត;ការអះអាងដោយសំដីមុឹងម៉ាត់

dogme *n.m.* សិទ្ធាន្ត,គោលសំខាន់នៃលទ្ធិ ឬ វាទះ

dogue *n.m.* ឆ្កែឆ្មាំម្យ៉ាងក្បាលធំ

doguin,e *n.* ឆ្កែក្មេង

doigt *n.m.* ម្រាម (ឧ. nous avons dix doigts aux mains et dix doigts aux pieds)។ *Fig.* doigt de Dieu អំពើ ឬ អំណាចអាទិទេពលើព្រឹត្តិការណ៍ក្នុងលោក (ម.ព. Dieu ផង)។ ធ្នាប់(រង្វាស់ទទឹងម្រាមដៃ) (ឧ. un ruban de quatre doigts) ។ à deux doigts de ជិត, ជៀត (ឧ. voir un revolver à deux doigts de la tête); *au fig.* ជិតនឹង, ហៀបនឹង (ឧ. être à deux doigts de sa perte ហៀបនឹងវិនាស)។ ចំនួនបន្តិចបន្តួច (ឧ. boire un doigt de

vin) ។

Loc. div. les quatre doigts ម្រាមទាំង ៤ (ក្រៅពីមេដៃ) ។ le petit doigt កូនដៃ។ les cinq doigts ជាតដៃលា (ឧ. appliquer à quelqu'un les cinq doigts sur la joue ទះកំភ្លៀង (ពីព្រោះទះត្រូវលាជាតដៃ) ។ tirer au doigt mouillé បូលចាប់ម្រាមដៃសើម(បូលយករបស់អ្វីមួយដោយចាប់រកម្រាមដៃមួយលាបសើមខាងគល់)។ doigt de gant ម្រាមស្រោមដៃ។ compter, calculer sur ses doigts avec ses doigts ឬ par ses doigts រាប់ដៃ (គិតក្បាច់ស្រី); *au fig.* គិតគូរច្រើន ។ montrer du doigt ឬ au doigt ឬ avec le doigt ឬ du bout du doigt ចង្អុល (ដោយម្រាមដៃ); បូញមាត់បត់ជុំដៃ (ចំអកចំទយក្នុងទីប្រជុំជន) (ឧ. on montre au doigt les maris complaisants);បង្ហាញឲ្យដឹងគ្រប់គ្នាក្នុងទីប្រជុំជន(ឧ. montrer au doigt un coupable)។ avoir une bague au doigt មានរបស់ល្អតែតិតប្រយោជន៍ ។ avoir une jolie(ឬune belle) bague au doigt មានកន្លែងល្អ ឬ មានផលទុនច្រើន ។ donner sur les doigts à គោះលើម្រាមដៃនៃ; ផ្ចាញ់; វាយ; ស្តីបន្ទោស។ avoir sur les doigts ត្រូវស្តីបន្ទោស, ត្រូវទណ្ឌកម្ម ឬ ជាក់មុខ, អាម៉ាស់មុខ ។ les doigts lui démangent រមាស់ដៃ (ចង់ប្រវាយគ្នាខ្លាំង ឬ ចង់សរសេរខ្លាំង)។ mordre ses doigts ឬ se mordre les doigts ក្រាស់ក្រាល់ (នៅមិនសុខ); ខំទ្រាំអត់; ព្រួយ; ស្តាយក្រោយ ។ mettre le doigt sur la bouche ធ្វើសញ្ញាកុំឲ្យនិយាយ។ *Pop.* se mettre (ឬ se fourrer le doigt dans l'œil ច្រឡំខ្លាំង, ភាន់ខ្លាំង ។ mettre son doigt (ឬ sa main) *au fig.* អះអាងយ៉ាងមុឺងម៉ាត់ថាពិត ។ faire toucher du doigt បង្ហាញភស្តុតាងឲ្យឃើញច្បាស់ក្រឡែត ។ toucher au doigt(ឬdu doigt), toucher au doigt et à l'œil ឬ voir au doigt et à l'œil ឃើញ ឬ យល់ច្បាស់ក្រឡែត ។ toucher du doigt ហៀបនឹងបាន

សម្រេច,ដិតនឹង, រៀបនឹង (ឧ. toucher du doigt la mort) ។ toucher du bout du doigt ពាល់ (ស្ទាបឲ្យប៉ះតែនឹងចុងម្រាមដៃ); ប្រព្រឹត្តទៅស៊ើដោយប្រុងប្រយ័ត្ន (ឧ. c'est une personne, c'est un sujet qu'il ne faut toucher que du bout du doigt)។ ne pas toucher du bout du doigt មិនប៉ះពាល់,មិនរវល់នឹង(សូម្បីតែម្រាមដៃក៏មិនឲ្យទើសផង); *au fig.* មិនធ្វើអ្វីឲ្យស្រ្តីអៀន ឬ ខ្មាស។ savoir ឬ connaître sur le bout du doigt ចេះស្ទាត់, ដឹងច្បាស់, ចេះដឹង ឬ ស្គាល់ជ្រៅជ្រះ (ឧ. je vous connais sur le bout du doigt)។ aller au doigt et à l'œil ដើរមិនស្រួល (នាឡិកា) ។ conduire au doigt et à l'œil ត្រួតត្រាដោយតឹងរ៉ឹង ។ obéir (ឬ marcher) au doigt et à l'œil ស្តាប់បង្គាប់ណាស់ (គ្រាន់តែងក់ធ្វើតាមភ្នែក) ។ mettre le doigt sur ឬ (dessus) ស្មានត្រូវ,រកឃើញ (អ្វីៗដែលគេត្រូវរក) ។ mettre le doigt sur la plaie រកឃើញកន្លែងមិនស្រួល,រកសរសៃរសើបឃើញ។ avoir mal au bout du doigt ឈឺបន្តិចបន្តួច, មិនស្រួលបន្តិចបន្តួច ។ avoir des yeux au bout des doigts ពូកែស្ទាប (គ្រាន់តែស្ទាបអាចដឹងបានដូចគេឃើញនឹងភ្នែក)។ avoir une ressource au bout de ses doigts ចេះធ្វើការដោយដៃ;អាចចិញ្ចឹមជីវិតដោយធ្វើការខ្លួនឯងបាន ។ avoir dans les doigts យល់ច្បាស់, ចេះប្រាកដ; ស្ទាត់ (ឧ. avoir un morceau de musique dans les doigts) ។ avoir les doigts de fée ប្រសប់ណាស់ ។ avoir de l'esprit jusqu'au bout des doigts ឆ្លាតណាស់, ឆ្លៀវឆ្លាសណាស់ ។ ne faire œuvre de ses doigts ឥតបានធ្វើអ្វីសោះ ។ ne pas remuer le petit doigt គ្មានធ្វើកបន្តិច, គ្មានរវល់អ្វីសោះ ។ être les deux doigts (ឬ comme les deux doigts) de la main ស្និទ្ធស្នាលនឹងគ្នាណាស់។ y mettre les quatre doigts et le pouce បរិភោគដោយស្លោកគ្រោក, ប្រព្រឹត្តទាំង

កស្រោល។ croire qu'il ne s'agit que de remuer et souffler les doigts ស្មានថាជាការងាយណាស់ ។ servir à lèche doigts ឲ្យលើបលោប, ដាក់ឲ្យបរិភោគមិនបរិបូណ៌ ។ se lècher les doigts de quelque chose យល់ថាជារបស់ល្អណាស់ ឬ ឆ្ងាញ់ណាស់ ។ ça ne vous brûlera pas les doigts សូមកុំសង្ស័យលើឲ្យសោះ ។

Prov. les cinq doigts de la main ne se ressemblent point ប្អូនដោយវត្តចិត្តដោយខ្លួន(មិនអាចនឹងរកមនុស្សមានចិត្ត ឬ យោបល់ដូចគ្នាសុទ្ធសាធបានឡើយ) ។ entre l'arbre et l'écorce il ne faut pas mettre le doigt មិនត្រូវចូលជ្រៀតជ្រែកក្នុងការជជែកឬការទាស់ទែងគ្នារវាងសាច់ញាតិ ឬ រវាងមិត្តភក្តិឡើយ

doigté ឬ **doigter** *n.m.* ការដេញ (គ្រឿងភ្លេង) ។ *Fig.* ការប៉ិនប្រសប់ (ឧ. montrer du doigté)

doigter *v.t.* & *i.* ដេញ (គ្រឿងភ្លេង)

doigtier *n.m.* ស្រោមម្រាមដៃ

doit *n.m.* ផ្នែកបញ្ជីខាងចំណាយ

dol *n.m.* *Dr.* ការបន្លំ,ការបោកប្រាស់

dolce *adv.* *Mus.* ដោយតិចៗ,ដោយស្រាលៗ (ភ្លេង)

dolcissimo *adv.* *Mus.* យ៉ាងតិចៗ, យ៉ាងស្រាលៗ (ភ្លេង)

doléances *n.f. pl.* បណ្ដឹង, ការតវ៉ា (ឧ. présenter ses doléances)

dolent,e *a.* ដែលត្អូញត្អែរ (ឧ. un vieillard dolent); ដែលសំដែងសេចក្ដីឈឺចាប់ ឬ សេចក្ដីទុក្ខព្រួយ (ឧ. un ton dolent); មិនស្រួលខ្លួន (ឧ. se sentir dolent)

doler *v.t.* ពន្លា. នឹងស្លាបព្រាបាយអ

dollar ($) *n.m.* ដុល្លារ (រូបិយវត្ថុនៃសហរដ្ឋអាមេរិក)

dolman *n.m.* អាវកុត (មានប៉ាកសម្រាប់ទាហាន ឬ មន្ត្រី)

doloir *n.f.* ប្រដាប់ឈូសឈើឲ្យស្ដើង; ស្លាបព្រាបាយអ

dolorisme *n.m.* អាគុរនិយម(លទ្ធិដែលប្រកាន់ថាការឈឺចាប់មានប្រយោជន៍)

dolosif,ive *a.* នៃការបន្លំ, នៃការបោកប្រាស់

domaine *n.m.* វិស័យ; កម្មសិទ្ធិ ។ le domaine de l'Etat ឬ le domaine ទ្រព្យរដ្ឋ ឬ ទ្រព្យភណ្ឌការ ។

Par ext. ការគ្រប់គ្រងទ្រព្យរដ្ឋ ឬ ទ្រព្យរាជការ ។ domaine privé វិស័យឯកជន ។ domaine public វិស័យសាធារណៈ។ domaine municipal វិស័យក្រុង ។ domaine royal វិស័យរាជ ។ *Fig.* ដែន, តាទី (ឧ. domaine de la littérature) ។ tomber dans le domaine public ធ្លាក់ជាសម្បត្តិសាធារណៈ ។ dans tous les domaines គ្រប់មុខ ។ ceci est son domaine នេះជាតាទីរបស់គាត់ (គាត់ជាអ្នកឯកទេសក្នុងការណ៍នេះ)

domanial,e,aux *a.* ដែលជាវិស័យសាធារណៈ, ដែលជាទ្រព្យរាជការ (ឧ. forêt domaniale)

domanialité *n.f.* នីតិវិធីខាងវិស័យសាធារណៈ

dôme *n.m.* ដោម (កំពូលមានសណ្ឋានក្រឡុម) ; អ្វីៗដែលមានសណ្ឋានដូចដោម (ឧ. dôme de verdure)

domestication *n.f.* ការផ្សាំងសត្វព្រៃ

domesticité *n.f.* ភាពជាយាវព្រាវ; ពួកយាវព្រាវក្នុងផ្ទះ; ភាពសត្វស្រុក

domestique *a* គេហពន្ធ,នៃផ្ទះសម្បែង; នៃគ្រួសារ; សាំង ។ travaux domestiques ការងារក្នុងផ្ទះ។ économie domestique ម.ព. économie។animaux domestiques បសុសត្វ ។ *n.* យាវព្រាវ

domestiquer *v.t.* ផ្សាំង (សត្វព្រៃ) ។ *Fig.* ជិះជាន់, យកធ្វើជាទាសៈ (ឧ. domestiquer un peuple)

domicile *n.m.* ផ្ទះ,លំនៅ។domicile légal លំនៅតាមផ្លូវការ។domicile réel លំនៅពិត ។ domicile élu លំនៅតាំង ។ élire domicile តាំងលំនៅ ។ à domicile *loc. adv.* ដល់ផ្ទះ, ដល់លំនៅ

domiciliaire *a.* នៃលំនៅ ។ visite domiciliaire ការឆែកឆេរលំនៅ

domiciliataire *n.m.* ធនាគារវិកប្ប (ការជ្រើសធនាគារ គឺ ការចង្អុលបង្ហាញតាមផលប័ត្រពាណិជ្ជកម្ម នូវកន្លែងបើកប្រាក់នាផ្ទះធនាគារិក ឬ ក្រុមហ៊ុនដូចគ្នា) ។ banque domiciliaire ធនាគារវិកប្ប (ធនាគារដែលជាកន្លែងត្រូវបើកផលប័ត្រពាណិជ្ជកម្ម) ។ *n.* វិកប្បការី

domiciliation *n.f.* ការណាត់លំនៅ ។ *Banque* ធនាគារវិកប្ប, ការជ្រើសធនាគារ

domicilier *v.t.* ណាត់លំនៅ ។ être domicilié à មានលំនៅឯ ។ se domicilier *v.pr.* តាំងលំនៅ

dominant,e *a.* ខ្ពស់ជាងគេ, ធំជាងគេ; ដែលលេចចេញពីគេឡើង(ឧ.qualité dominante)

dominante *n.f.* ភាគដែលមានលក្ខណៈប្លែក (ឧ. la dominante d'une œuvre) ។ *Mus.* កៅនសំខាន់ ។ sous dominante គានសំខាន់ក្រោម

dominateur,trice *a* &*n.* ដែលគ្របសង្កត់; ដែលចូលចិត្តគ្រប់គ្រង

domination *n.f.* អភិភវ័ន, អំណាចចក្រ; ការគ្របសង្កត់; អំណាច (ឧ. la domination du génie)

dominer *v.i.* ប្រើអំណាចចក្រ, គ្របសង្កត់លើ (ឧ. dominer sur toute l'Europe)។*Fig.* លុបលើ (ដោយកើតជាងគេ ឬ ដោយមានចំនួនច្រើនជាងគេ) (ឧ. couleur qui domine) ។ *v.t.* គ្រប់គ្រង (ឧ. dominer un peuple); បង្ក្រាប, គ្របសង្កត់ (ឧ. dominer ses passions); ឈ្នះ (ឧ. dominer tout le monde); បិតខ្ពស់ជាង (ឧ. le fort qui domine la ville) ។ *Fig.* និងឬយល់ច្បាស់(ឧ.dominer la question) ។ se dominer *v. pr.* គ្របសង្កត់ចិត្ត

dominicain,e *n.* អ្នកបួសក្នុងលទ្ធិសង្គ-ដូម៉និក

dominical,e,aux *a.* ជារបស់អាទិទេព (ឧ.jour dominical);នៃថ្ងៃអាទិត្យ (ឧ. repos dominical)

dominion *n.m.* វិជិតភាជ, ដូមីញ៉ុន

domino *n.m.* សំលៀកបំពាក់រោំបិទមុខ; អ្នកប្រើសំលៀកបំពាក់រោំបិទមុខ; កូនដូមីណូ (ឡុកឡាក់) ។ *pl.* ដូមីណូ (ល្បែងឡុកឡាក់ម្យ៉ាង)

dommage *n.m.* ការខូចខាត (ឧ. la grêle cause de grands dommages aux vignes); ការខូចប្រយោជន៍(ឧ. tout dommage causé à autrui doit être réparé) ។ *Fig.* c'est dommage ជាការគួរឲ្យស្ដាយណាស់ ។ *pl.* dommages - intérêts ឬ dommages et intérêts ជម្ងឺចិត្ត

dommageable *a.* ដែលឲ្យខូចខាត, ដែលឲ្យខូចប្រយោជន៍

domptable *a.* អាចពង្រាប-បង្ក្រាប

ឬ ផ្សាំងបាន

domptage *n.m.* ការពង្រាប-បង្ក្រាប ឬ ផ្សាំង

dompter *v.t.* ពង្រាប, ផ្សាំង (ឧ. dompter un lion); បង្ក្រាប (ឧ. dompter des rebelles; dompter les forces naturelles)

dompteur,euse *n.* អ្នកពង្រាបឬផ្សាំង (ឧ. dompteur de lions)

don *n.m.* ដុង (សម្រាប់ហៅដោយគំរើគួរសម ចំពោះបុរសនៅប្រទេសអេស្ប៉ាញ) ។ *f.* dòna

don *n.m* ជំនូន, អំណោយ, ទាយជ្ជទាន (ឧ. recevoir un don) ។ *Fig.* និស្ស័យ (សមត្ថភាពក្នុងការអ្វីមួយ) (ឧ. avoir le don des affaires)។ les dons de Cérès ការច្រូតកាត់។ les dons de Flore ផ្កា។ les dons de Bacchus ផ្លែទំពាំងបាយជូរ

dôna,dona ឬ **donne** *n.f.* ដូណា (សម្រាប់ហៅដោយគំរើគួរសមចំពោះស្ត្រីនៅប្រទេសអេស្ប៉ាញ) ។ *m.* don

donataire *n.* បដិគ្គាហក, អ្នកទទួលអំណោយ

donateur,trice *n.* ទាយក-យិកា(អ្នកឲ្យ)

donation *n.f.* កិច្ចសន្យាធ្វើអំណោយ (ឧ. la donation de biens à venir n'est pas valable)។ ទាយជ្ជទាន, អំណោយ។ donation-partage សំបុត្រចែកមរតកដល់កូនចៅ

donc *conj.* ដូច្នេះ, ហេតុនេះ (ឧ. je pense, donc je suis); អើ! (ពាក្យសម្រាប់សង្កត់សំនួរ ឬ ការហៅរកឲ្យពិសេសឡើង) (ឧ. qu'as-tu donc? អើ ! ឯងមានការអ្វីហ្នឹង ? ; viens donc! អើ ! មកនេះ)

dondon *n.f.* *Fam.* ស្ត្រីកន្ធាត់

donjon *n.m.* ប៉មធំ

don Juan *n.m.* អ្នកចែចង់, អ្នកសង្ហា (ជាបុរសអ្នកមានសម្បទ, ហ៊ុហា, ព្រហើន, មិនជឿបុណ្យបាប, ដើរចែចង់ស្ត្រី, សម្លាប់ឪពុកយកកូនឬយកប្រពន្ធដោយឥតរួញរា ឬ ស្តាយក្រោយ)(*pl.* des dons Juans ឬ des don Juans)

donjuanesque *a.* ដែលមានចរិតឬមានលំនាំជាអ្នកសង្ហា (ឧ. promesses donjuanesques)

donnant,e *a.* ដែលចូលចិត្តឲ្យ

donne *n.f* *Jeux* ការចែកបៀ; សន្លឹក

បៀដែលចែកស្មើៗ គ្នា ។ fausse donne, mauvaise donne ឬ maldonne ការចែកបៀខុសរបៀប

donne *n.f.* ម.ព. dôna

donnée *n.f.* ទិន្នន័យ, ចំណុចសំខាន់ (ដែលគេប្រកែក ឬ គេមិនបាន) (ឧ. thèse qui manque de donnée); គោលការណ៍សំខាន់នៃសៀវភៅ (ឧ. la donnée d'une tragédie) ។ *pl. Math.* données ឬ quantités données ចំនួនដែលគេដឹងឬដែលគេប្រាប់ក្នុងចំណោទ

donner *v.t.* ឲ្យ, ជូន (ឲ្យរបស់ទ្រព្យ) (ឧ. donner son bien aux pauvres); ឲ្យ (បណ្ដាលហេតុ) (ឧ. donner de la peine); ឲ្យ (ដាក់ឲ្យទទួលឬឲ្យរង) (ឧ. donner tort); ចម្លងឲ្យ (រោគ) (ឧ. donner une maladie); សំដែងឲ្យដឹង, ធ្វើឲ្យដឹង (ឧ. donner signe de vie សំដែងឲ្យដឹងថាខ្លួននៅរស់); បូជា (ឧ. donner sa vie); ឲ្យ, កំណត់, កម្រិត (ឧ. donner une heure); ធានាថា, អះអាងថា (ឧ. donner pour bon); ដាក់ (បង្ខំឲ្យកាន់) (ឧ. donner des lois); វាយ ឬទះ (ឧ. donner un soufflet); ព្រមាន, ប្រាប់ (តាមផ្លូវច្បាប់) (ឧ. donner congé); ឲ្យ (យល់ព្រមឲ្យរៀបរការពិពាហ៍) (ឧ. donner sa fille à quelqu'un); ឲ្យ (ដាក់ឱសថឲ្យ) (ឧ. donner un remède); ឲ្យ (ដាក់ឲ្យ) (ឧ. donner du travail à un ouvrier); បោះពុម្ពផ្សាយ (ឧ. donner un roman); ឲ្យយកទៅលេង (រឿងល្ខោន) (ឧ. donner une pièce); ប្រសិទ្ធពរឲ្យ (ឧ. donner le bonjour); ដាក់ទោស (ឧ. donner une punition)។ *Arg.* បរិហារ

Loc. div. on lui en donnera! មិនបែនសម្រាប់គាត់ទេ ។ en donner du long et du large ឬ en donner tout du long de l'aune វាយខ្លាំង; *au fig.* ចំអកខ្លាំង ។ donner des gages de ធានា, អះអាង ។ donner assurance de បញ្ជាក់, អះអាង ។ donner la vie ឲ្យជីវិត; បង្កើតកូន; ធ្វើឲ្យរីករាយខ្លាំង ។ donner l'être ឬ donner le jour បង្កើត, បង្កើតកូន ។ donner jour

à ធ្វើឲ្យបានសម្រេច (ឧ. donner jour à une affaire)។ donner la mort សម្លាប់; *au fig.* ធ្វើឲ្យឈឺចាប់ខ្លាំង ។ donner un rival à quelqu'un ស្រឡាញ់ម្នាក់ទៀត ឬ មានប្រុសមួយទៀត (ចំពោះតែស្ត្រី)។ donner du fil à retordre ឬ donner du mal នាំឲ្យមានរវល់ច្រើន, ធ្វើឲ្យពិបាកចិត្ត, ធ្វើឲ្យទើសទាស់។ en donner ឬ en donner d'une ឬ en donner à garder ឬ donner une baie បន្លំឲ្យជឿ។ en donner de toutes les couleurs ធ្វើឲ្យជឿអំពើមិនសមហេតុផល ។ donner un bon tour à បង្ហាញតែខាងល្អ។ donner un mauvais tour à បង្ហាញតែខាងអាក្រក់(ឧ. donner un mauvais tour aux actions les plus innocentes)។ donner à penser (ឬ à songer ឬ à réfléchir) យកមកពិនិត្យ, ធ្វើឲ្យទើសទាស់, ធ្វើឲ្យពិបាកចិត្ត ។ donner à entendre ធ្វើឲ្យយល់, ធ្វើឲ្យដឹង, ធ្វើឲ្យមន្ទិល ។ donner prise បើកឱកាសឲ្យសត្រូវ ឬឲ្យគូប្រឆាំង។ donner sa tête à couper អះអាងរឹងម៉ាត់ (បើមិនមែនឲ្យកាត់ក្បាល) ។ en donner à quelqu'un pour son argent ឲ្យតាមទឹកប្រាក់ (ឧ. ឲ្យរបស់តាមចំនួនប្រាក់ដែលយកមកទិញ); *au fig.* ឲ្យរង្វាន់ឬប្រាក់ឈ្នួលតាមសាច់ការដែលធ្វើ ។ donner tout au monde ឲ្យអស់ពីខ្លួន (ធ្វើពលិកម្មយ៉ាងសម្បើម)។ ne pas donner une obole de មិនទុកជាមានតម្លៃអ្វីបន្តិចសោះ ។ la donner chaude ធ្វើឲ្យភ័យខ្លាំង ។ donner atteinte ធ្វើឲ្យខូចខាត។ donner lieu à បណ្ដាលឲ្យ, នាំឲ្យ, ជាហេតុឲ្យ ។ le donner au plus habile អ្នកណាក្រាន់បើណាស់ធ្វើទៅមើល (ទោះជាអ្នកពូកែណាស់ក៏ធ្វើមិនបានដែរ) ។ le donner en dix, en cent, en mille, etc... ហ៊ានឲ្យទាយ១០ដង, ១០០ដង, ១ ០០០ដង ។ល។, ហ៊ានឲ្យទាយតាមចិត្ត, ហ៊ានឲ្យធ្វើតាមចិត្ត (ព្រោះទាយមិនត្រូវ ឬធ្វើមិនកើត)។ donner son reste à quelqu'un យកជំនះលើអ្នកណាមួយក្នុងការប្រយុទ្ធ ឬ ក្នុងការជជែក ។ don-

ner procuration ប្រគល់អាសា។ donner quitus ឲ្យមុញ្ចនកិច្ច (ឲ្យរួចខ្លួន) ។

v.i. កាន់យក (ឧ. donner dans le luxe); ប្រយុទ្ធ (ឧ. les troupes n'ont pas donné); ឲ្យផលច្រើន (ឧ. le riz a beaucoup donné cette année); ធ្លាក់ក្នុង, ធ្លាក់ (ឧ. donner dans le piège ចូលអន្ទាក់); បែរទៅខាង (ឧ. cette fenêtre donne sur la rue); ទង្គិច (ឧ. donner la tête contre un arbre); ជឿដោយភ្លើ (ឧ. donner dans toutes les fariboles qui se racontent)។

Loc. div. donner au but បានដល់គោលបំណង (ដល់ទី)។ donner de cul et de tête ខំប្រឹងប្រែងខ្លាំង (ដើម្បីឲ្យបានសម្រេចតាមគោលបំណង)។ donner dedans ជឿ ឬ ទុកចិត្តដោយភ្លើ ។ donner sur les nerfs ធ្វើឲ្យញាញ់ ឬ ឲ្យខឹង ។ donner dans l'œil (ឬ dans la vue) ជាំងភ្នែក; *au fig.* ធ្វើឲ្យស្រឡាញ់ (ឲ្យព្រិលភ្នែក), ធ្វើឲ្យជាប់ចិត្ត។ donner tête baissée (ឬ tête basse) dans ធ្វើដោយគ្មានគិតក្រោយ (ធ្វើអ្វីមួយអស់ពីផ្ទៃពីដើង)។ donner à tout ជាប់នេះជាប់នោះមិនខ្ចោះត្រង់ណា ។

Chir. ធ្លាយខ្ទុះ (ឧ. tant que la plaie donne, le danger n'est pas prochain)។ *Mar.* le cordage donne ខ្សែពួរយឺត។ donner sur un danger ចាក់លើគ្រោះកាច។ donner dans un port ចូលក្នុងកំពង់ផែ ។

dans un temps donné ក្នុងរយៈពេលដែលបានកម្រិតទុក ។ sur un point donné ក្នុងចំណុចណាមួយ។ *Fig.* donné អាចនឹងឲ្យសម្រេចបាន, អាចនឹងធ្វើបាន (ឧ. nous pensons plus loin qu'il ne nous est pas donné d'atteindre)។ *Math.* ដែលដឹងហើយ, ដែលគេប្រាប់ហើយ (ឧ. cela est donné, vous n'avez pas à le démontrer; deux angles d'un triangle étant donnés, déterminez le 3e)។

étant donné *loc. pré.*

inv. ដោយយល់ ។ étant donné que *loc.conj. inv.* ដោយហេតុថា។

se donner *v.pr.* *Loc. div.* se donner pour តាំងខ្លួនជា (ធ្វើឲ្យគេថាខ្លួនជា)។ se donner du bon temps រស់នៅដោយឥតទុក្ខព្រួយអ្វីបន្តិចបន្តួចសោះ ។ s'en donner à cœur-joie លេងសប្បាយរីករាយខ្លាំង;លេងសប្បាយនឹងអ្នកណាមួយ ។ se donner l'air ឬ se donner des airs ធ្វើឫកជា, សំដែងអាការៈជា ។ se donner garde de ចៀសវាងមិន ។ se donner de វាយ-ចាក់ឬកាប់ខ្លួនឯងដោយ (ឧ. se donner de son coutelas dans le cœur); *fam.* se donner du talon dans le derrière លោតកញ្ឆែង, សំដែងសេចក្ដីសប្បាយខ្លាំង; រស់នៅដោយតាមបើគិត (គ្មានគិតខ្វាយខ្វល់នឹងអ្វីសោះ) ។

Prov. à donner donner, à vendre vendre បើថាឲ្យចំជាឲ្យបើថាលក់ចំជាលក់ (របស់បម្រុងនឹងឲ្យត្រូវតែឲ្យ របស់បម្រុងនឹងលក់ត្រូវតែលក់) ។ donner tard c'est refuser ក្រឲ្យទុកដូចជាមិនឲ្យ ។ qui donne tôt donne deux fois ឆាប់ឲ្យទុកដូចជាឲ្យពីរដង(របស់ដែលឲ្យដោយរួសរាន់មានតម្លៃស្មើនឹងរបស់ពីរ) ។ donner et retenir ne vaut ឲ្យហើយមិនត្រូវថាមិនឲ្យវិញទេ (ឲ្យទានឲ្យដោយស្មោះ កុំអាឡោះអាល័យស្ទួន)។ pour un bœuf donner un œuf ឲ្យបន្តិចបន្តួចដើម្បីនឹងបានមកវិញច្រើន ។ qui donne au commun ne donne à pas un ឲ្យមិនចំពោះមុខទុកដូចជាមិនឲ្យទៅអ្នកណាទាំងអស់ (គ្មានអ្នកណាដឹងគុណយើងត្រង់អំណោយដែលយើងឲ្យមិនចំពោះមុខទេ)

donneur,euse *n.* អ្នកឲ្យ (ឧ. donneur de sang); អ្នកចូលចិត្តឲ្យ។ *n.m.* អ្នកចែកបៀ

don-quichottisme *n.m.* ចរិត ឬ អាកប្បកិរិយាអ្នកចូលចិត្តថាឲ្យគេ (អ្នកចូលចិត្តកែកំហុសគេ)

dont *pr.rel.* ដែល (ឧ. la famille dont je descends; les parents dont je suis aimé; un pays dont le climat est agréable; l'ami dont il

est jaloux)

donzelle *n.f.* ស្ត្រីសសេរ (មានមារយាទមិនគប្បី គួរឲ្យមន្ទិល)

dopage ឬ **doping** *n.m.* ការដាក់ថ្នាំកម្លាំង

doper *v.t.* ដាក់ថ្នាំកម្លាំង, ឲ្យផឹកថ្នាំកម្លាំង (ចំពោះមនុស្ស ឬ សត្វបម្រុងប្រឡង ឬ ប្រណាំង (ឧ. doper un candidat avant un examen)

doping *n.m.* ថ្នាំកម្លាំង (សម្រាប់ឲ្យផឹកមុនពេលប្រឡង ឬ ប្រណាំង)

dorage *n.m.* ការបិទមាសឬក្រឡៃមាស

doré,e *a.* ពណ៌មាស (លឿង) (ឧ. les moissons dorées)។jeunesse dorée យុវជនអ្នកមានសម្បត្តិហើយនៅទំនេរ។ *n.m.* មាសក្រឡៃ

dorénavant *adv.* អំណើះតទៅ, តាំងពីនេះទៅ

dorer *v.t.* ហេមវិចិត្រ, ក្រឡៃមាស, បិទមាស (ឧ. dorer les tranches d'un livre); ព្រលាំងនំដោយជាតិក្រហមនៃស៊ុត ។ *Poét.* ធ្វើឲ្យឡើងពណ៌មាស (ឧ. le soleil dorait les épis) ។ *Fig.* dorer la pilule និយាយពាក្យផ្អែមល្ហែមចំពោះអំពើអាក្រក់

doreur,euse *a.&n.* អ្នកបិទ ឬ ក្រឡៃមាស

dorlotement *n.m.* ការថ្នាក់ថ្នម

dorloter *v.t.* ថ្នាក់ថ្នម (ឧ. dorloter un enfant)

dormant,e *a.* ដែលដេក; នឹង (ដែលមិនហូរ) (ឧ. les eaux dormantes sont peu saines)។ *n.m.* អ្នកដេក ។ *Constr.* គ្រោងទ្វារ ឬ បង្អួច

dormeur,euse *n.* អ្នកល្មោភដេក។ *a.* ហាក់ដូចជាដេក (ឧ. poupé dormeuse) ។ *n.f.* ទំហូពេជ្រពៀបត្រចៀក

dormir *v.i.* ដេក ។ *Fig.* ដេក, នៅក្រាំក្រែង (នៅស្ងៀម, មិនសំដែងចេញ) (ឧ. chagrin qui dort au fond du cœur); នៅនឹង (ឧ. la nature dort) ។ laisser dormir les fonds ទុកមូលធនឲ្យនៅទំនេរ (មិនប្រើយកផល) ។

Loc. div. laisser dormir une affaire ទុកកិច្ចការឲ្យដេក(មិនជាត់ការ) ។ dormir pour toujours ដេកលែងក្រោក(ស្លាប់) ។dormir debout ឬ tout debout ងុយដេកណាស់, អស់កម្លាំងណាស់ ។

c'est un conte à dormir debout រឿងមិនគួរឲ្យជឿ។ dormir sur les deux oreilles ដេកពេញភ្នែក, ឥតភ័យព្រួយខ្ទិចសោះ ។ ne dormir que d'un œil ឬ ne dormir que sur une oreille ឬ dormir les yeux ouverts ឬ dormir en lièvre (ឬ en gendarme) ដេកមិនពេញភ្នែក (ដេកមិនស្កប់លក់ដោយមានគិតគូរច្រើន)។ dormir à bâton rompu ដេកភ្ញាក់ញយ។ dormir comme un enfant Jésus ដេកស្រួល។ dormir sur le rôti ដេកលក់; *au fig.* នៅស្ងៀមក្នុងពេលដែលត្រូវធ្វើជាពិសេស។ dormir avec une femme ដេកនឹងស្ត្រី (រួមសង្វាសនឹងស្ត្រី) ។ dormir sur ធ្វើដោយយឺតយ៉ាវ ។ dormir la grasse matinée ដេកទាល់ថ្ងៃ ។ dormir comme un loir (ឬ comme une marmotte ឬ comme une souche) ដេកដូចស្លាប់ ឬ ដេកដូចគល់ឈើ (ដេកលក់ហួសប្រមាណ)។ dormir comme un sabot (ឬ comme une toupie) ដេកស្រមុក។ ne pas dormir de មិនដេកអស់រយៈពេល (ឧ. ne pas dormir de la nuit មិនដេកអស់មួយយប់ (ក្នុងមួយយប់) ។ ne savoir si l'on dort ou si l'on veille ខ្វល់ខ្វាយ, ច្រឡំស្មារតី។

Prov. il n'est pire eau que l'eau qui dort មឹះវកេះឆ្នាំងជាយធ្លុះ។ il ne faut pas éveiller le chat qui dort កុំកេះឆយឲ្យអាការ (រឿងដែលជាក់ស្ងាត់ទៅហើយមិនត្រូវប៉ះកកាយវិញទេ) (ម.ព.chat ផង) ។ qui dort dîne ដេកលក់បាត់ឃ្លាន ។ qui dort jusqu'au soleil levant, vit en misère jusqu'au couchant ឬ trop dormir cause mal vêtir ដេកយប់កុំដេកយូរ ខ្លាចក្ដីទុក្ខដំនល់ប្រាណ (ការដេកច្រើនមិននាំឲ្យចម្រើនឡើយ) ។ le bien lui vient en dormant ម.ព. bien

dormitif,ive *a.* ដែលឲ្យងងុយដេក ។ *n.m.* ថ្នាំងងុយដេក

dorsal,e,aux *a.* នៃខ្នង (ឧ. vertèbres dorsales)

dortoir *n.m.* សយនដ្ឋាន

dorure *n.f.* ការបិទ ឬ ក្រឡាមាស ;

មាសព្រៃឡៃ

dos *n.m.* ខ្នង(ឧ. sauter sur le dos d'un cheval)។ រ.ស. ប្រឹស្ឋាង្គ ។ ខ្នង (បែកខាងលើ)(ឧ. dos de la main ខ្នងដៃ; dos d'une lettre ខ្នងសំបុត្រ; dos d'un couteau ខ្នងកាំបិត; dos du pied ខ្នងជើង; dos d'un livre ខ្នងសៀវភៅ); បង្អែក (កៅអី) (ឧ. le dos d'une chaise) ។ être dans le dos នៅក្នុងស្ថានភាពពិបាក។ avoir les pieds dans le dos ត្រូវប៉ូលិសតាមរកចាប់។

Loc. div. bête à dos សត្វពាហនៈ។ battre quelqu'un dos et ventre វាយតាមតែប្រទះ (វាយពាសពេញខ្លួន, មិនរើសកន្លែង) ។ charger de bois le dos de quelqu'un វាយនឹងដំបង ។ faire pénitence sur le dos d'autrui ឲ្យគេរងទោស ឬ កំហុសខ្លួន ។ battre quelqu'un sur le dos d'un autre ស្តីបញ្ចៀសវាសវាង (ស្តីថាអ្នកគ្មានកំហុសឲ្យអ្នកប្រព្រឹត្តខុសនឹងខ្លួន) ។ être sur le dos ដេក; ឈឺ; អស់កម្លាំង ។ se laisser manger la laine sur le dos បណ្តោយឲ្យគេបញ្ឆោតយកអស់។ tondre quelqu'un sur le dos ដណ្តើមយក ឬ លួងយកអស់ពីខ្លួន ។ faire le gros dos ចំកោងខ្នង; *au fig.* ធ្វើឫកសម្បើម ។ courber ឬ ployer le dos ឱន; *au fig.* ដើរទន្ទប (ធ្វើរណបរណប) ។ tourner ឬ montrer le dos à បែរខ្នងឲ្យ; ចាកចេញភ្លាមៗ; រត់ចេញឆ្ងាយពី; បោះបង់ចោល; *au fig.* លះបង់, មិនត្រូវការ (ឧ. tourner le dos aux honneurs)។ avoir bon dos អាចទទួលបន្ទុកធ្ងន់បាន; *au fig.* ត្រូវគេចូលចិត្តចោទប្រកាន់ (ឧ. oh! j'ai bon dos, moi, c'est toujours sur moi que l'on tombe); ទទួលរងពាក្យចំអកដោយរីករាយ (ឧ. riez, riez, j'ai bon dos) ។ avoir, porter quelque chose ឬ quelqu'un sur son dos *fig.* មាននៅក្នុងបន្ទុក, ទទួលខុសត្រូវលើ; ត្រូវរំខានញយ (ក្នុងន័យនេះគេប្រើថា avoir quelqu'un ឬ quelque chose plein le dos) ។ être sur le

dos de quelqu'un *fig.* នៅក្នុងបន្ទុក, ស៊ីនៅលើយសារ; ត្រួតត្រា មិនឈប់ឈរ; រំខានខ្លាំង ។ mettre une chose sur le dos de quelqu'un *fig.* ផ្ទុកលើ; ធ្វើយដាក់ (ឧ. vous mettez sur mon dos des choses que je n'ai pas dites) ។ tomber sur le dos de quelqu'un ស្ទុះទៅវាយ; មកដល់ផ្ទះអ្នកណាមួយដោយមិនបានឲ្យដំណឹងមុន; ដាប់ផ្ទុកលើ; ប្រគល់ឲ្យ ។ avoir à dos មាននៅពីក្រោយ ។ mettre ឬ renvoyer dos à dos មិនឲ្យអ្នកណាបានឈ្នះ ។ avoir le dos tourné បែរខ្នង; ចេញដើរទៅ; *au fig.* ធ្វេសប្រហែសមួយភ្លែត ។ tourner le dos où l'on veut aller *fig.* ធ្វើការផ្ទុយនឹងគោលបំណង ។ *Pop.* scier le dos ធ្វើឲ្យអស់កម្លាំង; ធ្វើឲ្យរំខានខ្លាំង ។ faire froid dans le dos de quelqu'un *fig.* ធ្វើឲ្យរំខានខ្លាំង; ធ្វើឲ្យភ័យខ្លាំង ។ n'avoir pas une chemise sur le dos *fig.* នៅខ្លួនទទេ (រកតែកន្ទបស្លៀកគ្មាន) ។ mettre tout sur son dos *fig.* ពាយទាំងគ្រឿងពាក់តែងកាយអស់ប្រាក់ពីខ្លួន ។ jeter quelqu'un ឬ quelque chose derrière son dos *fig.* លែងរាប់អានអ្នកណាមួយ ឬ បោះបង់របស់អ្វីមួយ ។ le dos lui démange មោះខ្នង (ធ្វើខ្លួនបង្គួចឲ្យគេវាយ) ។ faire la bète à deux dos សេពសង្វាស ។ se mettre quelqu'un à dos យកជាសត្រូវ ។

Loc. adv. de dos ពីក្រោយខ្នង, ពីខាងក្រោយ ។ *loc. pré.* à dos de លើខ្នង, ដោយជិះ (បំពោះដំរីៈជាសត្វ) (ឧ. voyager à dos d'éléphant) ។ en dos d'âne ជាកង្ខែងអណ្ដើក (ឧ. pont en dos d'âne)

dosable *a.* អាចវាល់បាន, អាចស្ទង់ធាតុបាន

dosage *n.m.* ការវាល់; ការស្ទង់ធាតុ

dose *n.f.* ខ្នាតមាត្រា, កំរិតឱសថដែលត្រូវប្រើ (ឧ. dose tonique); ចំនួន (នៃវត្ថុដែលរួមបញ្ចូលគ្នា) ។ *Fig.* ទំហំ (នៃចរិយា) (ឧ. avoir une forte dose d'amour propre)

doser *v.t.* វាល់, លៃកម្រិត, ដាក់កម្រិត

ឱសថឲ្យប្រើ (ឧ.doser un remède); ដាក់ចំនួន (នៃវត្ថុដែលរួមបញ្ចូលគ្នា)។*Fig. & Fam.* ល្មៃ, ល្មើ (ឧ. doser ses efforts)

doseur *n.m.* ប្រដាប់សម្រាប់វាស់ ឬ កម្រិតចំនួន

dossard *n.m.* លេខអាវអ្នកកីឡា, ផ្ទាំងលេខបិទនៅអាវអ្នកកីឡា

dosse *n.f.* បន្ទះក្តារដាប់សំបក, បន្ទះក្តារប្រុះលេណដ្ឋាន

dossier *n.m.* បង្អែក ; សំណុំរឿង ។ dossier de dépôt សំណុំរឿងនិក្ខេបភណ្ឌ

dossière *n.f.* ខ្សែព្រនាក់ (ខ្សែស្នែង)។ *Harn.* ខ្សែខ្នង ។ *Arm.* ប៉ែកខាងខ្នងនៃក្រោះ; ខ្នងស្នូកអណ្តើក

dot *n.f.* កេរ្តិ៍ខាងស្រី(ទ្រព្យដែលប្រពន្ធបានទទួលចំណែក ក្នុងពេលរៀបអាពាហ៍ពិពាហ៍) (កេរ្តិ៍ខាងប្រុសក៏អាចហៅថា dot ផងដែរ)

dotal,e,aux *a.* នៃកេរ្តិ៍

dotalité *n.f.* លក្ខណៈជាកេរ្តិ៍

dotation *n.f.* ការផ្គត់ផ្គង់ប្រដាប់ប្រើប្រាស់(ឧ.la dotation d'un service); ទាយជ្ជទាន(ឧ. Napoléon 1er pourvut ses sénateurs d'importantes dotations)

doter *v.t.* ចែកកេរ្តិ៍ (ឧ. doter sa fille); ឲ្យទាយជ្ជទាន (ឧ. doter un hôpital); ផ្គត់ផ្គង់ប្រដាប់ប្រើប្រាស់ (ឧ. doter une cuisine d'un matériel neuf) ។ *Fig.* អនុគ្រោះ (ឧ. la nature l'a bien doté)

douaire *n.m.* ដំណែលប្តី.ទ្រព្យដែលប្តីទុកឲ្យប្រពន្ធក្រោយមរណកាល

douairière *n.f.* មេម៉ាយស្តុកស្តម្ភ(មេម៉ាយដែលមានសល់ទ្រព្យច្រើនពីខ្មោចប្តី)

douane *n.f.* គយ; សុលកាករ; ពន្ធគយ (ឧ.payer la douane); ទីជាតិការគយ ។ valeur en douane តម្លៃក្នុងគយ (តម្លៃទំនិញដែលត្រូវប្រគល់ឲ្យអ្នកទិញនៅផែ ឬ ទីស្ថាននាំចូល)

douanier *n.m.* ភ្នាក់ងារគយ

douanier,ère *a.* នៃគយ ។ union douanière សហភាពគយ (សន្ធិសញ្ញាពាណិជ្ជកម្មរវាងប្រទេស ដើម្បីលក់ដូរចេញចូលទៅវិញទៅមក) ។ rayon douanier វង់អំណាចគយ

douar *n.m.* អាកិណ្ណដំរ(ភូមិដំរសិតតនៅប្រទេសអាហ្វ្រិកខាងជើង)។ *Par ext.* ភូមិអារ៉ាប់ (នៅប្រទេសអាហ្វ្រិកខាងជើង)

doublage *n.m.* ការដាក់ទ្រនាប់, ការប៉ះតម្រួតគ្នា។ *Cin.* ការបញ្ចូលសម្លេង (ថតសម្លេងភាសាជាតិឲ្យត្រូវតាមរឿងក្នុងខ្សែភាពយន្តបរទេស)។ *Mar.* ដែកពាសនាវា

double *a.* ទ្វេ, ដែលជាពីរដង (ឧ. consonne double); ដែលមានពីរជុំគ្នា (ឧ. double semelle; double fenêtre)។ *Fig.* ដែលមានទ្រង់ទ្រាយពីរបែប; ដែលលាក់ពុត (ឧ. personne double; double jeu)។ fleur double ផ្កាត្រួត (ផ្កាដែលមានស្រទាប់ច្រើនជាន់ជាងធម្មតា)។ à double sens ដែលមានន័យពីរ។ faire double emploi លើស (ហួសពីសេចក្ដីត្រូវការ); ឥតប្រយោជន៍។ *n.m.* ទ្វេភាគ, ចំនួនពីរដងលើស (ឧ. payer double): សេចក្ដីកម្លង (ឧ. le double d'une note): ស្រមោល។ *adv.* voir double ឃើញពីរ (វត្ថុតែមួយមើលឃើញពីរ)។ *Loc.adv.* au double ច្រើនជាងខ្លាំង (ឧ. rendre au double)។ en double ជាពីរភាគ, ជាពីរច្បាប់

doublé *n.m.* គ្រឿងបិទ ឬស្រោបមាស ឬប្រាក់ (ឧ. doublé d'or; doublé d'argent); ការបាញ់សោះត្រូវសត្វពីរ

doublement *n.m.* ការដាក់ទ្រនាប់; ការដាក់ត្រួត (ឧ. le doublement d'une consonne)

doublement *adv.* ដោយហេតុពីរយ៉ាង; ជាពីរបែប

doubler *v.t.* ទ្វេគុណ, ទ្វេឡើង, បង្កើនឡើងជាពីរ (ឧ. doubler la ration); ផ្គួបជាពីរ (ឧ. doubler un fil)។ *Fig.* បន្ថែមឡើង (ធ្វើឲ្យកាន់តែមានឡើង) (ឧ. doubler les craintes de quelqu'un)។ doubler le pas បង្កើនល្បឿនឡើង (ដើរឲ្យកាន់តែលឿនឡើង)។ ស្រោប; ដាក់ទ្រនាប់ (ឧ. doubler un manteau)។ *Mar.* doubler un cap វាងជ្រោយ; *au fig.* ហួសកម្រិត, ហួសវ័យណាមួយ, ផុតពេលពិបាក (ឧ. doubler le cap de la quarantaine ហួសអាយុ៤០ឆ្នាំ)។ ដែង។ *Théât.* ជំនួសតួម្នាក់។ *Cin.* បញ្ចូលសម្លេងខ្សែភាពយន្ត។ *Sports* ឈ្នះមួយជុំ (ក្នុងកីឡា)។ *v.i.* ទៅជាពីរ, ឡើងជាទ្វេ

doublet *n.m.* ពាក្យគូ (ពាក្យដែលមាន

ឫសកែវជាមួយគ្នាតែមានរូបខុសគ្នា)(ឧ. Hôtel et Hôpital sont des doublets qui proviennent du même mot latin «hospitalem»); ត្បួងស្ទួ (ដោយបញ្ចូលវត្ថុពណ៌ក្នុងកែវ); វត្ថុទ្វេ (វត្ថុពីរដូចគ្នា)

doublier *n.m.* ជើងកស់ (ប្រដាប់មានសណ្ឋានស្រដៀងនឹងទោស់សម្រាប់ដាក់ស្មៅឲ្យសត្វស៊ីបានសងខាង)។*Archéol.* កម្រាលតុបត់ជាពីរ, កម្រាលតុធំ (អាចបត់ជាពីរបាន)

doublon *n.m.* ឌុប្លុង (រូបិយវត្ថុមាសអេស្ប៉ាញ៉ុល)

doublon *n.m.* *Arts graph.* ការប្រើពាក្យឬបន្ទាត់ស្ទួន

doublure *n.f.* ទ្រនាប់; អនុភាគ [អៈ-នុ-ភ៉ាគ]; សំពត់ប្រក់(ចីវរ); ចម្លៀកសំពត់ប៉ះតម្រួតគ្នា; វត្ថុប៉ះទ្រាប់ ឬ វត្ថុប៉ះបន្ថែម; តួជំនួស (ក្នុងល្ខោនជាដើម)

douceâtre *a.* សាបភ្លាវ

doucement *adv.* ដោយថ្នាក់ថ្នម,ដោយតិចៗឬសន្សឹមៗ(ឧ.il faut parler doucement aux enfants) ។ se porter tout doucement ប្រកបដោយសុខទុក្ខជាធម្មតា(មិនសុខពេក មិនទុក្ខពេក)។ parler doucement និយាយតិចៗ ។ *Int.* ស្ងមៗ! (កុំខ្លាំងពេក) (ឧ. doucement! mon ami)

doucereusement *adv.* ដោយផ្អែមឡែមៗ (ឬឡូមៗ); ដោយផ្អែមល្ហែម

doucereux,euse *a.* ផ្អែមឡែមៗ (ឬឡូមៗ) (ឧ. vin doucereux); ដែលធ្វើឫកជាស្លូត; ផ្អែមល្ហែម (ឧ. air doucereux)

doucet,ette *a.* ផ្អែមល្ហែមណាស់, ស្លូតណាស់; ហាក់ដូចជាស្លូតបូតណាស់

doucettement *adv.* *Fam.* តិចៗ

douceur *n.f.* ភាពផ្អែម ឬ ឆ្ងាញ់; រសផ្អែម ឬ ឆ្ងាញ់ (ឧ. la douceur du miel) ។ *Fig. Par ext.* អ្វីៗដែលផ្អែម ឬ ដែលទន់ភ្លន់ (គួរឲ្យជាប់អារម្មណ៍) (ឧ. la douceur de la voix); សេចក្ដីកក់ក្ដៅ, សេចក្ដីស្ងប់ចិត្ត(ឧ. douceur de vivre); ភាពស្រាល (មិនរឡាំងរអេក) (ឧ. mouvement plein de douceur) ។ *Fig.* មេត្តាចិត្ត (ឧ. traiter quelqu'un avec douceur) ។ *Fam.* en douceur តិចៗ (មិនបង្ខំ) ។ *pl.* បង្អែម (ឧ. donner des douceurs à

un enfant)

douche *n.f.* ទឹកផ្កាឈូក(ទឹកស្រោចងូត) (ឧ. douche froide, chaude)។ douche écossaise ការងូតទឹកឆ្លាស់ម្ដងត្រជាក់ម្ដងក្ដៅ ។ *Fig. & fam.* ការស្ដីបន្ទោសខ្លាំង;ការខកចិត្ត, ការស្រងាកចិត្ត

doucher *v.t.* ងូតទឹក។ *Fig. & fam.* ស្ដីបន្ទោសខ្លាំង; ធ្វើឲ្យខកចិត្ត, ធ្វើឲ្យស្រងាកចិត្ត

doucir *v.t.* ខាត់ (កញ្ចក់ ឬ ដែក)

doucissage *n.f.* ការខាត់(កញ្ចក់ឬដែក)

doué,e *a.* ដែលមានសម្បទាពីកំណើត

douer *v.t.* អនុគ្រោះ, ឲ្យមាន (ឧ. la nature l'a doué d'une grande intelligence)

douille *n.f.* ខ្នៀប្រហោងដង; ខ្លុយ (ឡុតគ្រាប់កាំភ្លើង; ឡូតញាត់អំពូលអគ្គិសនី)

douillet,ette *a.* ទន់ល្មៀយ (ឧ. lit douillet)។ *Fig.* ឆាប់រអើប (ឧ. enfant douillet)

douillettement *adv.* យ៉ាងទន់ល្មៀយ

douleur *n.f.* ការឈឺចាប់ (ចំពោះរាងកាយ) (ឧ. douleur aiguë); សេចក្ដីទុក្ខ ។ *pl.* ជម្ងឺសរសៃឬជម្ងឺសន្លាក់ឆ្អឹង (ឧ. avoir des douleurs)។ femme en douleurs ស្ត្រីឈឺពោះសម្រាលកូន ។

Prov. douleur de tête veut manger, douleur de ventre veut purger ឈឺក្បាលឲ្យបរិភោគ ឈឺពោះឲ្យបញ្ចុះ (*cf.* ឈឺជើងធាត់ ឈឺមាត់ស្គម) ។ pour un plaisir mille douleurs ចង់សប្បាយបន្តិច ត្រូវឲ្យរងទុក្ខលើសមួយពាន់ដង។ les grandes douleurs sont muettes អ្នកមានទុក្ខធ្ងន់មិនដែលត្អូញត្អែរទេ

douloureusement *adv.* ដោយឈឺចាប់

douloureux,euse *a.* ដែលនាំឲ្យឈឺចាប់ (ខាងរាងកាយឬខាងផ្លូវចិត្ត) (ឧ. mal douloureux; séparation douloureuse) ។ *Méd.* point douloureux កន្លែងឈឺចាប់ ។ ដែលសំដែងសេចក្ដីឈឺចាប់

doute *n.m.* វិចិកិច្ឆា, សេចក្ដីសង្ស័យ (ឧ. avoir des doutes sur quelqu'un); ការមិនជឿ ។ mettre ឬ révoquer en doute ប្រកែកថាមិនពិត, មិនជឿថាពិត ។ folie de doute វិចិកិច្ឆារោគ (រោគវិកលចរិត

ម្យ៉ាងដែលធ្វើឲ្យសង្ស័យគ្រប់មុខ) ។ être en doute សង្ស័យ,មិនជឿ, មិនទុកចិត្ត។ laisser une chose en doute ទុកឲ្យនៅសង្ស័យ, មិនបំភ្លឺ។ laisser quelqu'un en doute មិនពន្យល់ ឬ មិនប្រាប់ឲ្យអស់សង្ស័យ។ne faire aucun doute ច្បាស់ណាស់, ពិតណាស់ (ឥតសង្ស័យបាន) ។ hors de doute ផុតសង្ស័យ, ច្បាស់ណាស់ ។

Loc. adv. sans doute ប្រហែលជា (ឧ. il viendra sans doute demain); ពិតជា, ច្បាស់ជា (ឧ. vous l'aimez sans doute); sans aucun doute ពិតហើយ,មែនហើយ។ sans doute que ឬ point de doute que ពិតជា, ប្រាកដជា

douter *v.t.* មិនជឿ (ឧ. je doute de sa parole); សង្ស័យ (ឧ. je doute qu'il accepte; je ne doute pas qu'il n'accepte ឬ qu'il accepte) ។ ne douter de rien មិនរួញរា, មានសេចក្ដីក្លាហាន ។ se douter (de) *v.pr.* សង្ស័យ,ពិភាល់ (ឧ.se douter de quelque chose)

douteur,euse *a. & n.* ដែលចេះតែសង្ស័យ

douteux,euse *a.* មិនប្រាកដ (ឧ. victoire douteuse); មិនច្បាស់ (ឧ. réponse douteuse); ដែលពឹងផ្អែកលើមិនបាន, ដែលឲ្យសង្ស័យ (ឧ. un ami douteux)។ jour douteux ពន្លឺខ្សោយ (មិនសូវភ្លឺ)

douve *n.f.* ប្រឡាយទឹក (ឧ. les douves d'un château); ក្ដារសំបកធុងឈើ

douve *n.f.* ជិង្វាវល្លើម

douvelle *n.f.* បន្ទះក្ដារសំបកធុងឈើ

doux,douce *a.* ឆ្ងាញ់,ផ្អែម (ឧ.doux comme le miel); សាប (គ្មានគ្រឿង) (ឧ.potage trop doux); ស្រទន់ (voix douce); ស្រទំ (មិនចាំងភ្នែក,មិនក្ដៅ)(ឧ.lumière douce); ទន់ល្មៃ (ឧ. laine douce); ប្រសើរ (ដល់ផ្លូវចិត្ត) (ឧ. doux souvenir); ដែលផ្សាយព្រហ្មវិហារ (ឧ.regard doux); ល្អ,ភក់ទាក់(ឧ. caractère doux);ទេរ,ជ្រាល(មិនចោត)(pente douce);ស្រួល,តិចៗ, ត្រជៀក (ឧ. vent doux); ទន់ (មិន

ស្រួយ,មិនងាយដាក់)(ឧ.fer doux): ស្លូត (ឧ. un peuple doux)។ *Mus.* ស្រទន់:ស្រៃរត។très doux ស្រទន់ណាស់ ។ eau douce ទឹកសាប ។ filer doux មិនរើរូស ។ *Loc. fam.* en douce ស្ងាត់ៗ ។ tout doux *loc. adv.* តិចៗ, សន្សឹមៗ

douzaine *n.f.* ទ្វាទសកៈ, ឡូ (ចំនួនវត្ថុ ១២) (ឧ. une douzaine de mouchoirs); ចំនួនប្រមាណជា១២ (ឧ. s'absenter pour une douzaine de jours)

douze *a. num.* ដប់ពីរ; ទី១២ (ឧ. Louis XII)។ *n.m.* ថ្ងៃទី១២

douzième *a. num. ord.* ទី១២។ *n.* អ្នក ទី ១២ (ឧ. être le ឬ la douzième)។ *n.m.*ភាគ១២ (ឧ. un douzième) ។ douzième provisoire ភាគដប់ពីរបណ្ដោះអាសន្ន

douzièmement *adv.* ទី ១២ ; ជាគំរប់ ១២

doyen,enne *n.* ព្រឹទ្ធបុរស (អ្នកមានចំណាស់ជាងគេក្នុងចំណោម, ចាស់ទុំឬចាស់ស្រុក) ។ *n.m.* ព្រឹទ្ធបុរស (អភិបាលមហាវិទ្យាល័យ)

doyenne *n.m.* មុខងារព្រឹទ្ធបុរស ; មណ្ឌលត្រួតត្រារបស់ព្រឹទ្ធបុរស

doyenneté *n.f.* ភាពជាព្រឹទ្ធបុរស

draconien,enne *a.* តឹងរ៉ឹង (ឧ. des mesures draconiennes)

dragage *n.m.* ការឬរបៀបកៀរសំអាតបាតស្ទឹង; ការស្រង់ ឬបំផ្លាញគ្រាប់បែកពន្លិចទឹក

dragée *n.f.* ស្ករគុលិកា ។ *Fig.* វត្ថុមិនសូវប្រសើរ (ឧ. les dragées de de la poésie) ។ *Pop.* គ្រាប់កាំភ្លើង (ឧ.recevoir une dragée)។ se piquer la dragée ស្រវឹង ។ *Chass.* គ្រាប់កាំភ្លើងប្រមាញ់។ écarter la dragée ប្រាយគ្រាប់ (ចំពោះកាំភ្លើងប្រមាញ់ដែលគ្រាប់ចេញប្រសាច); ប្រាយទឹកមាត់ (ចំពោះមនុស្សដែលនិយាយខ្ចាតទឹកមាត់)។ *Pharm.* ថ្នាំគុលិកា ។

Loc. div. dragée d'attrape ថ្នាំគុលិកាពិជាកលេប (ដោយមារសមិនឆ្ងាញ់)។ *Fig.* donner une dragée d'attrape à quelqu'un បញ្ឆោត ។ dragée amère អំពើអាក្រក់ (កម្រអត់ធ្មត់

កាន) ។ avaler la dragée សុខចិត្តទទួលអំពើអាក្រក់ ។ tenir la dragée haute à quelqu'un ឲ្យចាំយូរ; ឲ្យចេញថ្លៃច្រើន ចំពោះវត្ថុដែលគ្នាត្រូវការ

dragéifier *v.t.* សូខគុលិកា

drageoir *n.m.* ប្រអប់គុលិកា

drageon *n.m.* មូលង្ករ, ពន្លកឫស

drageonnement ឬ **drageonnage** *n.m.* ដំណើរប៉ិចពន្លកឫស

drageonner *v.i.* ប៉ិចពន្លកឫស

dragon *n.m.* នាគ; ទាហានទ័ពសេះ ។ *Fig.* ស្ត្រីកំណាច ។ dragon de vertu អ្នកកាន់ចរិតតឹងរ៉ឹង

dragonne *n.f.* ខ្សែដងដាវ

drague *n.f.* ខ្នៀរសំអាតបាតស្ទឹង ឬ សមុទ្រ ; អញ្ចង (នេសាទឧបករណ៍) ; ប្រដាប់សម្រាប់ស្រង់ឬបំផ្លាញគ្រាប់បែកពន្លិចទឹក

draguer *v.t.* កៀរសំអាតបាតស្ទឹងឬទន្លេ (ឧ. draguer un chenal); ដឹកអញ្ចង (នេសាទដោយអញ្ចង) ; ស្រង់គ្រាប់បែកពន្លិចទឹក, កាយគ្រាប់បែក

dragueur *n.m.* អ្នកកាយខ្សាច់ ។ dragueur de mines នាវាស្រង់គ្រាប់បែកពន្លិចទឹក ។ *a.* bateau dragueur នាវាខ្នៀរ

dragueuse *n.f.* ម.ព. drague

draille *n.f.* គន្លងហ្វូងសត្វ

drain *n.m.* ប្រណាល (បំពង់សម្រេងទឹក ។ *Méd.* បំពង់បង្ហូរខ្ទុះពីដំបៅ)

drainage *n.m.* ការសម្រេងទឹក (ដោយបំពង់) (ចំពោះដីដក់ទឹកជោកជាំពេក) ។ *Méd.* ការបង្ហូរខ្ទុះពីដំបៅដោយប្រណាល

drainer *v.t.* បង្ហូរចេញ, សម្រេងទឹកដោយប្រណាល (ឧ. les terres argileuses doivent être soigneusement drainées) ។ *Méd.* ដាក់ប្រណាល (បំពង់បង្ហូរខ្ទុះពីដំបៅ) ។ *Fin.* ទាញប្រមូលមក (ឧ. drainer les capitaux)

draineur *n.m.* អ្នកសម្រេងទឹក (ដោយប្រណាល)

draisine *n.f.* ដ្រៃស៊ីន (អយរថតូចៗ សម្រាប់ដឹកនាំពួកអ្នកថែទាំផ្លូវអយស្ម័យយាន)

dramatique *a.* នៃវិនាដកម្ម (ឧ. art dramatique ; auteur dramatique) ។ *Fig.* ដែលឲ្យរំភើបខ្លាំង (ឧ. scène dramatique); ដែលប្រកបដោយគ្រោះថ្នាក់, គុនផាប (ឧ. situation dramatique)

dramatiquement *adv.* ដោយគួររំភើបខ្លាំង; យ៉ាងពុនដាប

dramatiser *v.t.* ពង្រីកជារឿងធំ (ឧ. dramatiser un récit) ។ *Par ext.* បំផ្លើសទំហំព្រឹត្តិការណ៍

dramaturge *n.* វិធានិពន្ធ, អ្នកនិពន្ធរឿងល្ខោន

dramaturgie *n.f.* វិធាននិពន្ធសាស្ត្រ, សិល្បសាស្ត្រខាងនិពន្ធរឿងល្ខោន

drame *n.m.* វិនាសកម្ម, រឿងល្ខោនដែលមានការកំប្លែងប្រកបដោយភ័យ ។ *Fig.* រឿងទុក្ខភ័យ។ drame lyrique អូប៉េក

drap *n.m.* សំពត់កម្ពល(សំពត់រោមសត្វ); កម្រាលពូក។ *Fig.* être dans de beaux draps ជាប់គុក

drapeaux *n.m.* ទង់ជាតិ។ drapeau tricolore ទង់ជាតិបារាំង (មានបីពណ៌)។ drapeau blanc ទង់ស (ជាសញ្ញាហិសុំចរចាគ្នា)។ drapeau rouge ឬ noir ទង់ក្រហម ឬ ខ្មៅ (សញ្ញានៃពួកអ្នកបដិវត្តន៍) ។

Loc. div. être sous les drapeaux បម្រើក្នុងកងទ័ព (ធ្វើទាហាន) ។ se ranger sous le drapeau de quelqu'un ចូលក្នុងបក្សពួកណាមួយ ។ honneur du drapeau កិត្តិយសទ័ព ។ déserter son drapeau បោះបង់បក្សពួកខ្លួន ។ déserter le drapeau de quelqu'un បោះបង់បក្សពួកអ្នកណាមួយ ។ mettre son drapeau dans sa poche លាក់យោបល់ខ្លួន ។ planter ឬ lever son drapeau ប្រកាសជំនឿខ្លួនក្នុងទីសាធារណៈ ។ *Pop.* planter un drapeau បរិភោគជឿ ។ au drapeau ! ក្មេងគោរពទង់ជាតិ !

drapement ឬ **drapage** *n.m.* ការគ្រប,ការដណ្ដប់

draper *v.t.* គ្រប,ដណ្ដប់ (ឧ. draper une statue); ជាប់ផ្នត់ (ឧ.draper une robe) ។ se draper *v.pr.* ដណ្ដប់ (ឧ. se draper dans une cape) ។ *Fig.* បញ្ចេញ,សម្ដែង (ឧ. se draper dans sa dignité)

draperie *n.f.* រោងដំបាញសំពត់កម្ពល; របរធ្វើ ឬ លក់សំពត់កម្ពល

drapier,ère *a.&n.* ឈ្មួញសំពត់កម្ពល

drastique *a.* & *n.m.* ដែលឲ្យពោះរាកខ្លាំង; ថ្នាំបញ្ចុះខ្លាំង

dravidien *n.m.* ទាវីឌ (ភាសាមួយបែប

ប្រើក្នុងប្រទេសអ៊ីង្គ)

drawback [drò-bak] *n.m.* (ព.អ.) ដ្រូបាក់ (ការបង្វិលឲ្យវិញនូវអាករគយលើវត្ថុនាំចូលមកធ្វើទំនិញក្នុងពេលដែលទំនិញទាំងនេះត្រូវនាំចេញទៅវិញ)

drayer *v.t.* [drè-] កោសស្បែកឲ្យមានកម្រាស់ស្មើគ្នា

drayoire [drè-yoir,] *n.f.* កាំបិតកោសស្បែកឲ្យមានកម្រាស់ស្មើគ្នា

dreadnought [drèd-nôt'] *n.m.* (ព.អ.) ដ្រេតណោត (មហានាវាក្រោះអង់គ្លេសដែលធ្វើមកទល់នឹងឆ្នាំ១៩៤៥)

drêche *n.f.* ឈាយស្រា (កាកគ្រាប់នឹងដំឡូងបាំងដែលប្រើធ្វើជាស្រា) (ឧ. la drêche sert d'aliment pour les vaches laitières)

drège *n.f.* ថ្នាំងនេសាទតាមបាតសមុទ្រ (គេសរសេរជា dreige ក៏បាន)

drelin *n.m.* (*onomat.*) ណឹងៗ (ឧទាន.) (សូរកណ្ដឹង)

dressage *n.m.* ការលើក (តម្រង់);ការតម្លើង;ការសង់; ការឬរៀបបង្ហាត់សត្វ

dresser *v.t.* លើក;ងើប (ឧ. dresser la tête)។ *Fig.* dresser l'oreille ផ្ទង់ឬផ្ទៀងត្រចៀក (ប្រុងស្ដាប់)។ បញ្ឈរ (ឧ. dresser une échelle); តម្លើង, សង់ (ឧ. dresser une tente); រៀបចំ, ដាក់បំពេញ (ឧ. dresser la table, un buffet); ធ្វើឲ្យរាបឬឲ្យរលីង (ឧ. dresser une planche); គូរ (ឧ. clôture dressée par le dessinateur); ធ្វើ, សរសេរ, តែង (ឧ. dresser un acte); បង្ហាត់, បង្វឹក (ឧ. dresser un domestique); ផ្សាំង, បង្ហាត់ (ឧ. dresser des animaux de cirque)។ *Fig.* ញុះ (ធ្វើឲ្យប្រឆាំងគ្នា) (ឧ. dresser une personne contre une autre)

dresseur,euse *n.* អ្នកបង្ហាត់ឬបង្វឹក

dressoir *n.m.* ភាជន

dribble *n.m.* ការបណ្ដើរបាល់

dribbler *v.i.* បណ្ដើរបាល់ ។ *v.t.* បណ្ដើរបាល់គេចផុតពីគូល្បែង

drift *n.m.* (ព.អ.) សំណល់គំនរទឹកកកដែលរអិលផុតទៅ

drille *n.m.* joyeux drille អ្នកសប្បាយរីករាយ

drille *n.f.* ដងស្វាន (សម្រាប់ផាងនាឡិកានិងផាងទង)

drisse *n.f.* ខ្សែលុត;ខ្សែបង្ហូតទង់

drogue *n.f.* ឱសថូបករណ៍ (គ្រឿងឱសថ)។ *Par ext.* ថ្នាំញៀនថ្នាំស្រវឹង;ពួកថ្នាំស្រវឹង (ហេរ៉ូអ៊ីនជាដើម) (ឧ. faire le trafic de la drogue)។ *Fig.* អំពើឬវត្ថុអាក្រក់ណាស់

droguer *v.t.* ឲ្យឱសថលើសប្រមាណ ។ *v.i. Fig. & Fam.* រង់ចាំយូរ (ឧ. il m'a fait droguer) ។ se droguer *v.pr.* ប្រើឱសថលើសប្រមាណ

droguerie *n.m.* ឱសថទាំងពួង; ជំនួញឱសថ

droguiste *n. & a.* ឈ្មួញឱសថ គ្រឿងអនាម័យនិងគ្រឿងលាបថ្នាំង

droit *n.m.* ច្បាប់,នីតិបញ្ញត្តិ;ធម្មសាស្ត្រ នីតិសាស្ត្រ(ឧ. étudier le droit)។ droit civil ច្បាប់រដ្ឋប្បវេណី។ droits civiques សិទ្ធិពលរដ្ឋ (មានសិទ្ធិបោះឆ្នោតជាដើម)។droit commun អាជ្ញាគតិ ។ droit constitutionnel រដ្ឋធម្មសាស្ត្រ, ច្បាប់រដ្ឋធម្មនុញ្ញ។droit coutumier ប្រពៃណីបញ្ញត្តិ, ច្បាប់ប្រពៃណី (ទំនៀមជាប់តៗ មកពីប្រពៃណីឥតមានចារឹកជាលាយលក្ខអក្សរ)។droit culturel ច្បាប់ ឬ សិទ្ធិវប្បធម៌។droit divin អាទិទេពបញ្ញត្តិ, ច្បាប់អាទិទេព (ច្បាប់ដែលអាទិទេពបញ្ញត្តទុកមក) ។ droit écrit នីតិបញ្ញត្តិជាលាយលក្ខអក្សរ។ droit économique ច្បាប់ឬសិទ្ធិសេដ្ឋកិច្ច ។ droit international ឬ droit des gens ច្បាប់អន្តរជាតិ ឬ ច្បាប់រវាងប្រទេស។ droit international privé ច្បាប់ឯកជនរវាងប្រទេស ។ droit international public ច្បាប់សាធារណជនរវាងប្រទេស ។ droit naturel ច្បាប់ធម្មជាតិ ។ droit national នីតិបញ្ញត្តិជាតិ ។ droit pénal ច្បាប់ព្រហ្មទណ្ឌ ។ droit de préemption សិទ្ធិបុព្វក្រ័យ ។ droit privéច្បាប់ឯកជន។droit public ច្បាប់សាធារណជន ។ droit social ច្បាប់ ឬ សិទ្ធិសង្គម ។ établissement de droit privé គ្រឹះស្ថានប្រើច្បាប់ឯកជន។ établissement de droit public គ្រឹះស្ថានប្រើច្បាប់សាធារណជន ។

ពន្ធ.អាករ (ឧ. droit de mutation; droit d'acte)។ droit ឬ taxe ad valorem ពន្ធ ឬ អាករតាមតម្លៃ ។ droit de péage ពន្ធ

សិល្បភណ្ឌ,ពន្ធនៃការចេញឆ្លង។ droit de quai ពន្ធផែ ។ droit spécifique ពន្ធតាមមុខ ។

តម្លៃ ។ droit d'entrée តម្លៃចូល ។

សិទ្ធិ (ឧ.droits de l'homme);យុត្តិធម៌ (ឧ. faire droit) ។ droit de discussion សិទ្ធិជជែក (សិទ្ធិបើកឲ្យអ្នកធានាប្តឹងសុំឲ្យមេបំណុលទារពីកូនបំណុលសិន ខ្វះខាតប៉ុន្មានសឹមខ្លួនសង) ។ droit de division សិទ្ធិបែងចែក (សិទ្ធិបើកឲ្យអ្នកធានារួមបែងចែកកាតព្វកិច្ចគ្នា) ។ droit fondamental សិទ្ធិសំខាន់ ។ droit de l'homme សិទ្ធិមនុស្ស ។ droit de préférence សិទ្ធិអាទិភាព (សិទ្ធិត្រូវទទួលសំណងមុនគេ)។ droit de suite សិទ្ធិបន្ត(សិទ្ធិប្តឹងទាមទារឲ្យលក់យកមកសងបំណុលខ្លួននូវវត្ថុដែលដាក់ធានា ទោះបីវត្ថុនោះនៅលើដៃជនណា ក៏ដោយ)។droit de tirage សិទ្ធិបហារណ៍ (សិទ្ធិប្រើហិរញ្ញប្បទានដែលប្រគល់ឲ្យហើយ) ។ droit de tutelle សិទ្ធិឧបត្ថម្ភ ។

Loc. adv. de droit ឬ de plein droit ដោយពេញសិទ្ធិ (គ្មានប្រកែកបាន)។ à bon droit ដោយយុត្តិធម៌, ដោយសមហេតុសមផល ។ à qui de droit ចំពោះអ្នកមានសមត្ថកិច្ច(នឹងសម្រេច)។ par qui de droit អំពីអ្នកមានសមត្ថកិច្ច (នឹងសម្រេច) ។ à tort et à droit ដោយមិនបាច់រកខុសត្រូវ ។ à tort ou à droit ដោយមានឬដោយឥតសិទ្ធិ ។ être en droit de មានសិទ្ធិត្រូវនិយាយ ឬ ត្រូវធ្វើអ្វីមួយ ។ avoir des droits sur មានកម្មសិទ្ធិលើ,មានអំណាចលើ (ឧ.le père a des droits sur ses enfants) ។ membre de droit ម.ព. membre

droit,e *a.* ត្រង់ (មិនវៀច) (ឧ. la ligne droite est le plus court chemin d'un point à un autre);ត្រង់ (ឈរត្រង់ឡើងលើ) (ឧ. mur droit);ត្រង់(មិនផ្ទួលឬមិនផេក) (ឧ.cette figure serait mieux droite que couchée); ស្តាំ (ឧ. main droite) ។ *Fig.* ត្រង់ (មិនវៀចវេរ); ត្រឹមត្រូវ (ឧ. avoir le sens droit, l'esprit droit) ។

cœur droit ចិត្តស្មោះត្រង់ ។ esprit droit ចិត្តប្រកបដោយយុត្តិធម៌ ។ droite voie ឬ voie droite ឬ droit chemin គន្លងធម៌, ផ្លូវត្រង់ (មិនវៀចវេរ), ផ្លូវសុចរិត ។

Math. angle droit មុំកែង ។

adv. ចំទៅឬត្រង់ទៅ (ឧ. aller droit devant soi; aller droit au but) ។

Numism. មុខ (រូបិយវត្ថុ, មេដាយ) (ម.ល.de avers, de face, de tète) ។ *Dr. fig.* en droit soi ម្នាក់ៗ ចំពោះតែរៀងខ្លួនឯង ។

Fam. être le bras droit de quelqu'un ជាដៃស្ដាំរបស់, ជាសហការីសំខាន់នៃអ្នកណាមួយ ។ être ឬ se tenir droit comme un jonc, comme un peuplier, comme un cierge, comme un piquet, comme un pieu, comme une statue, comme un I ឈរត្រង់ភ្លឹង; *au fig.&iron.* droit comme la jambe d'un chien ឬ droit comme mon bras quand je me mouche ត្រង់ដូចកែងដៃបត់, ត្រង់ដូចជង្គង់ (មិនត្រង់) ។ ne pas savoir distinguer sa main droite de sa main gauche មិនចេះធ្វើអ្វីសោះ ។ marcher droit ប្រព្រឹត្តត្រឹមត្រូវ, កាន់ចរិយាល្អ ។

Loc. div. en ligne droite ឬ en droite ligne ត្រង់ (មិនងាក, មិនវៀច) (ឧ. chemin tracé en ligne droite); *au fig.* suivre la ligne droite ប្រព្រឹត្តតាមគន្លងធម៌, ប្រព្រឹត្តត្រឹមត្រូវ ។ mettre une chose au droit d'une autre ដាក់ឲ្យស្មើគ្នា ឬ ដាក់ត្រង់គ្នា ។

Prov. Quand on fait l'aumône, il ne faut pas que la main gauche sache ce que fait la droite ឬ que votre gauche ne sache pas ce que fait votre droite ត្រូវធ្វើល្អដោយកុំសម្ញែងពេក ។ chacun à sa place et le bâtiment (ឬ le navire) est droit បើម្នាក់ៗ គិតតែការខ្លួន (មិនជ្រៀតជ្រែកក្នុងការគេ) ម្ល៉េះគង់ជានឹងបានស្រួលគ្រប់ៗគ្នា

droite *n.f.* ខាងស្ដាំ; ដៃស្ដាំ: ក្រុមខាងស្ដាំ (ក្រុមសភាដែលអង្គុយបែកខាងស្ដាំ

នៃប្រធាន) ។ *Math.* ខ្សែត្រង់, បន្ទាត់ត្រង់ ។ droite perpendiculaire ខ្សែកាត់កែង ។ droites parallèles ខ្សែស្រប ។

Loc. adv. à droite ខាងស្តាំ (ឧ. prendre à droite) ។ à droite et à gauche ឬ de droite et de gauche ទាំងសងខាង (ទាំងខាងស្តាំទាំងខាងឆ្វេង)។ *Fig.* prendre à droite et à gauche ទទួលយកពីសងខាង

droitement *adv.* ដោយត្រង់

droitier,ère *n.&a.* អ្នកប្រើដៃស្តាំ, អ្នកកាន់ស្តាំ ។ *n.m.&Fam.* សមាជិកខាងស្តាំនៃសភា

droiture *n.f.* យុត្តិធម៌, សេចក្តីសុចរិត (ឧ. agir avec droiture); ការយល់ត្រូវ

drolatique *a.* ដែលឲ្យសប្បាយ,ដែលឲ្យសប្បាយ; ដែលឲ្យសើច

drôle *a.* កំប្លែង (នាំឲ្យសើច) (ឧ. une anecdote très drôle) ។ *Fam.* ចម្លែក (ឧ.une drôle d'idée) ។ *n.m.* ជនអាក្រក់; មនុស្សចម្លែក; មនុស្សព្រហាម

drôlement *adv.* យ៉ាងកំប្លែង; យ៉ាងចម្លែក (ឧ. être drôlement habillé) ។ *Fam.* ណាស់,ខ្លាំងណាស់ (ឧ. il fait drôlement froid)

drôlerie *n.f.* ការកំប្លែង;ភាពកំប្លែង (ឧ. la drôlerie de cette aventure); ពាក្យ,សំដី, អាការៈកំប្លែង (ឧ. dire des drôleries) (ម.ព. bouffonnerie ផង)

drôlesse *n.f.* ស្រ្តីឥតអៀនខ្មាស (ដែលគួរឲ្យមើលងាយ)

dromadaire *n.m.* អូដ្ឋបូកមួយ (ប្រើជាជំនិះ (ហៅថា méhari) ឬ សម្រាប់ព្រនាក់អីវ៉ាន់)

drome *n.f. Mar.* គ្រឿងប្រើដែលដាក់លើក្តារក្រាលនាវា (មានឡប៉ុត, ច្រវា, ខ្សែពួរជាដើម)

drop *n.m.* ប្រដាប់ផ្ទុកទំនិញកញ្ចប់

droppage *n.m.* ការទម្លាក់មនុស្ស ឬ សម្ភារៈពីអាកាសយាន

drosser *v.t. Mar.* ពង្រេ, បំបែរពីផ្លូវ (បំពោះខ្យល់ ឬ ខ្សែទឹកដែលធ្វើឲ្យនាវាងាកចេញពីផ្លូវដែលត្រូវទៅ)

dru,e *a.* ទ្រុប, ក្រាស់, ទ្រុលទ្រុប (ឧ. riz fort dru) ។ *adv.* ញឹក,ច្រើន (ឧ. tomber dru)

drupe *n.f.* ផ្លែឈើមានលលាដ៍គ្រាប់

(ធ្វើបជាផ្លែស្វាយជាដើម)

dry [draï] *a.* & *n.m. inv.* (ត.អ.) ស្ងួត,ស្ងួត (មិនលាយទឹក)(ឧ. champagne dry) ។ dry farming ស្ងួតកសិកម្ម (ដំណាំលើដីស្ងួត)

dryade *n.f. Myth.* រុក្ខទេវតា

dû,due *a.* ម.ព. devoir ។ *n.m.* អ្វីៗដែលត្រូវបាន (ឧ. réclamer son du)

dualisme *n.m.* ទ្វិកនិយម (ការនិយមថាមានវត្ថុពីរប្រឆាំងគ្នា ដូចជារូបនិងព្រលឹង ល្អនិងអាក្រក់ ។ ល ។)

dualiste *a.* ដែលជាទ្វិកនិយម ។ *n.* អ្នកទ្វិកនិយម

dualité *n.f.* ទ្វិកភាព (ភាពអ្វីៗដែលមានអង្គពីរ); ការរួមវត្ថុពីរផ្សេងគ្នា (ឧ. la dualité de l'homme (l'âme et le corps)

dubitatif,ive *a.* ដែលសំដែងសេចក្ដីសង្ស័យ (ឧ. réponse dubitative)

dubitativement *adv.* ដោយសម្ដែងសេចក្ដីសង្ស័យ

duc *n.m.* ឌុច (ឋានៈបន្ទាប់ពីព្រះអង្គម្ចាស់); រទេះសេះម្យ៉ាង ។ *Zool.* សត្វទីទុយម្យ៉ាង(មាន៣ពូជគឺgrand duc, moyen duc និង petit duc)

ducal,e,aux *a.* ជារបស់ឌុច

duché *n.m.* ខេត្តសំរាប់ឋានៈឌុច

duchesse *n.f.* ភរិយាឌុច ។ *Fam.* ស្ត្រីកាន់ឫកធំ

ducroire *n.m.* កិច្ចសញ្ញាដែលដើងសារដំនួញទទួលរ៉ាប់រងលើអ្នកទិញ ។ ម្រាក់ដែលបានពីការទទួលរ៉ាប់រងនោះ; ដើងសារដំនួញ (ដែលទទួលរ៉ាប់រងបែបនេះ)

ductile *a.* សុត្តិយ [សុត-តី] (យឺត,ទន់, ដែលអាចហូតជាសរសៃបាន)(ឧ.l'or est très ductile)

ductilité *n.f.* សុត្តិយភាព; លក្ខណៈវត្ថុដែលអាចហូតជាសរសៃបាន

duel *n.m.* ទ្វន្ទយុទ្ធ [ទ្វ័ន-ទ:-], ការប្រយុទ្ធគ្នា

duel *n.m. Gram.* ទ្វិវចនៈ

duelliste *n.m.* ទ្វន្ទយុទ្ធិក,អ្នកប្រយុទ្ធគ្នា; អ្នករកឱកាសប្រយុទ្ធគ្នា

duettiste *n.* អ្នកច្រៀង ឬ លេងភ្លេងតែពីរនាក់

duetto *n.m.* ភ្លេងវង់តូចមានចម្រៀងតែពីរនាក់ឬ មានគ្រឿងតែពីរ

dulcification *n.f.* ការធ្វើឲ្យអន់ក្លាំង ឬឲ្យបាត់ជូរចត់ (ចំពោះវត្ថុរាវ)

dulcifier *v.t.* ធ្វើឲ្យអន់ក្លាំងឬឲ្យបាត់

ដូរបិត (ចំពោះវត្ថុ)

dulcinée *n.f.* ស្ត្រីដែលគេស្រឡាញ់

dulie *n.f.* culte de dulie ការធ្វើពលីការចំពោះទេវតា (ផ្ទុយនឹង culte de latrie ម ព. latrie)

dum-dum *n.f.* គ្រាប់កាំភ្លើងប្រ៉ាង

dûment *adv.* ដោយគប្បី,ដោយត្រឹមត្រូវ (តាមទម្រង់ការដែលបញ្ញត្តបកហើយ) (ឧ.chose dûment constatée)

dumping [deum-pin'g] *n.m.* ដិម្ពីង (ការលក់ទំនិញទៅប្រទេសក្រៅដោយគិតតម្លៃថោកជាងលក់ក្នុងស្រុក ឬ ជាងថ្លៃដើមនៃទំនិញ)

dune *n.f.* ផ្នូកខ្សាច់

dunette *n.f.* កើយខាងកន្សៀនាវា

duo *n.m.* បទភ្លេងដែលមានចម្រៀង ឬ មានគ្រឿងតែពីរ ។ *Fig. & fam.* ពាក្យឆ្លើយឆ្លងគ្នាតតួ (ឧ. duo d'injures)

duodécimal,e,aux *a.* ទ្វាទសភាគ (ដែលរាប់ដប់ពីរៗ,ដែលចែកនឹង ១២) (ឧ. système duodécimal)

duodécimo *adv.* ទី ១២

duodénite *n.f.* រោគរលាកតល់ពោះវៀន

duodénum [-nom-] *n.m.* តល់ពោះ-វៀន (ភាគពោះវៀនត្រង់ជាប់នឹងក្រពះ)

duodi *n.m.* ថ្ងៃទី២ក្នុងទសទិន

dupe *n.f.&a.* អ្នកចាញ់បោក, អ្នកដែលគេងាយបោកបញ្ឆោត

duper *v.t.* បោក, បញ្ឆោត

duperie *n.f.* ការបោកបញ្ឆោត

dupeur,euse *n.* អ្នកបោកបញ្ឆោត

duplex *a.* ទ្វេ ។ *n.m.* ការធ្វើឲ្យវាយទូរលេខឬនិយាយទូរសព្ទបានជាឯកប្ប-ហារ

duplicata *n.m.* ទុតិយតា (គំរូទី ២), សំណៅទី ២

duplicateur *n.m.* ប្រដាប់ចំឡង

duplication *n.f.* ការទ្វេគុណ,ការធ្វើឲ្យវាយទូរលេខឬនិយាយទូរសព្ទជាឯកប្ប-ហារបាន (ហៅ duplex ក៏បាន)

duplicité *n.f.* ទ្វេភាព; ចិត្តវៀច

dur,e *a.* រឹង (ឧ. bois dur); ជាប់ (ឧ. cette porte est dure); តឹង (ឧ. pistolet dur à la détente); ពិបាក (ឧ. outil dur à manier); អាក្រក់ (ពិបាកទ្រាំ) (ឧ. climat dur); ធន់ (ឧ. être dur à la souffrance); គិតសន្តោស, តឹង-រ៉ឹង (ឧ. être dur pour soi et pour les autres); ដែលបញ្ចេញចិត្តអាក្រក់ (ឧ. un regard dur);

ដែលធ្វើឲ្យឈឺចាប់ (ឧ.dire à quelqu'un de dures vérités); រពឹស (ក្មេង) (ឧ. cet enfant est très dur) ។ *Fam.* ពិបាក (ឧ. ce problème n'est pas dur) ។

Loc.div œuf dur ស៊ុតស្ងោរឆ្អិន ។ pain dur នំបុ័ងចាស់ ។ cœur dur អមេត្តចិត្ត, ចិត្តឥតមេត្តា (ផ្ទុយនឹងមុទុចិត្ត ឬ ចិត្តទន់)។ temps dur អាកាសត្រជាក់ខ្លាំង;គ្រាក្រ,ពេលពិបាក ។ vie dure ការរស់នៅដោយក្រឬលំបាក ។ vin dur ស្រាប្របកត ។ eau dure ទឹកក្លាំ (មានជាតិកំបោរច្រើនបណ្ដាលឲ្យចំអិនរបស់មិនឆ្អិននឹងដុសសាប៊ូមិនបែកពពុះ)។ tête dure ឬ intelligence dure ឬ entendement dur ប្រាជ្ញាអប្ប (ក្រយល់) ។ avoir la tête dure មុខរឹង (ចចេស)។ avoir l'oreille dure ឬ être dur d'oreille ត្រចៀកធ្ងន់ (មិនសូវឮ) ។ parole dure សំដីធ្ងន់, ពាក្យគ្រោតគ្រាត។ être dur à digérer ឬ être de dure digestion ឬ dur à avaler *Fig.* ពិបាកទ្រាំ, ពិបាកជឿ ។ rendre à quelqu'un la vie dure ធ្វើឲ្យវេទនា, ធ្វើទុក្ខបុកម្នេញ ។ être dur à la détente ឬ être dur à la desserre ចេញប្រាក់ដោយពិបាក (កំណាញ់មិនចង់ចេញប្រាក់សោះ) ។ être dur à la vente ពិបាកលក់ (លក់មិនសូវដាច់) ។ être dur à cuire ពិបាកចំអិន (ក្រឆ្អិន) (ឧ. légume dur à cuire); *au fig.* & *Fam.* ធ្មឹក, ចិត្តរឹង (ដោយធ្លាប់មានពិសោធន៍)។ brûler le dur ជិះឥតទិញសំបុត្រ (អយស្ម័យយាន) ។

adv. ដោយតឹងតែង,ដោយម៉ឺងម៉ាត់, ដោយប្រឹងប្រែងខ្លាំង (ឧ. il travaille dur)។ dormir dur ដេកលក់លង់ ។ *n.Fam.* អ្នកមុះមុត (មិនរួញរានឹងអ្វី) ។ *n.m.* construction en dur សំណង់ធ្វើដោយសម្ភារៈជាប់ (មានឥដ្ឋជាដើម) ។ *n.f.* coucher sur la dure ដេកផ្ទាល់នឹងដី ឬ ក្ដារ ។ *Arg.* la dure ផ្ទះធំ (ផ្ទុយនឹងផ្ទះបាយឬផ្ទះករយង) ។ voler à la dure លួចដោយកំហែង ។ à la dure *loc.adv.* យ៉ាងតឹងរ៉ឹង,យ៉ាងប្រិតប្រៀប (ឧ.élever un enfant à la dure)

durabilité *n.f.* ភាពប៉ិតថេរ ។ *Dr.*

រយៈពេលដែលប្រើប្រាស់ធនធានអ្វីមួយ

durable *a.* ឋិតថេរ

durablement *adv.* ដោយឋិតថេរ

duralumin *n.m.* ឌុយរ៉ា(លោហធាតុផ្សំម្យ៉ាងស ស្រាលហើយរឹង)

duramen *n.m.* ខ្លឹមឈើ

durant *pré.* ក្នុងរយៈពេល, ក្នុងចិរវេលា (ឧ.durant une heure)

durcir *v.t.* ពង្រឹង, ធ្វើឲ្យរឹង (ឧ. la gelée durcit le sol)។ *v i.* & se durcir *v.pr.* ឡើងរឹង (ឧ. le bois durcit ឬ se durcit en séchant)។ *Fig.* ឡើងដាប់, ធ្វើឲ្យដាប់

durcissement *n.m.* ការពង្រឹង;ដំណើរឡើងរឹង (ឧ. durcissement du mortier)

durée *n.f.* កំឡុងពេល,ចិរវេលា,រយៈពេល (ឧ. la durée des études) ។ durée de validité ចិរវេលាប្រើការបាន

durement *adv.* ដោយគ្មានប្រណី, ដោយគ្មានអត់អាស្រ័យ; ដោយតឹងតែង

durer *v.i.* មានចិរវេលា (ឧ. le siège de Troie dure dix ans); មានតទៅទៀត (ឧ. faire durer les hostilités); ឋិតនៅយូរ (ឧ. son souvenir durera)

dureté *n.f.* ភាពរឹង (ឧ. la dureté du marbre);ភាពគ្រោតគ្រាត (ឧ. dureté de la voix); ភាពអាក្រក់ (ឧ.dureté du climat);ភាពពិបាកទ្រាំទ្រ (ឧ. la dureté de notre époque) ។ *Fig.* ការគ្មានប្រណីឬគ្មានអត់អាស្រ័យ (ឧ. répondre avec dureté) ។ *pl.* សំដីទ្រគោះ (ឧ. dire des duretés)

durillon *n.m.* ផ្ទួ (សាច់ដែលកកើតជាពករឹងត្រង់ជើង ឬ ដៃ)

durion *n.m.* ផ្លែធុរេន

duvet *n.m.* រោមកែវ (រោមទន់នៃសត្វស្លាប, រោមខ្ចី);ពូកញាត់រោមសត្វ; ពុកបង្កាទើបនឹងដុះដំបូង; រោមផ្លែឈើ

duveter(se) *v.pr.* មានរោមកែវ

duveteux,euse *a.* ដែលមានរោមទន់ច្រើន (ឧ. fruit duveteux)

dyarchie *n.f.* ទ្វិរាជាធិបតេយ្យ(អភិបាលព្រមគ្នាដោយព្រះរាជាពីរអង្គ)។ប្រទេសទ្វិរាជ (ប្រទេសមានមហាក្សត្រិយ៍ពីរអង្គសោយរាជ្យ)

dyarchique *a.* នៃទ្វិរាជាធិបតេយ្យ, នៃប្រទេសទ្វិរាជ

dynamique *a.* ថាមវ័ន្ត, ថាមវន្ត ។ *Fam.* ស្វាហាប់ (ឧ. garçon dynamique) ។ *n.f. Méc.* ថាមកម្បនា

dynamiquement *adv.* តាមថាមកម្បនា

dynamisme *n.m.* ថាមនិយម។*Fam.* ថាមភាព

dynamiste *n.m.* អ្នកថាមនិយម

dynamitage *n.m.* ការកំទេចដោយឌីណាមីត (រំសេវគ្រាប់បែក)

dynamite *n.f.* ឌីណាមីត (រំសេវគ្រាប់បែក)

dynamiter *v.t.* កំទេចដោយឌីណាមីត

dynamiteur,euse *n.* អ្នកធ្វើឌីណាមីត; អ្នកព្យាបាទដោយឌីណាមីត

dynamo *n.m.* ឌីណាម៉ូ (គ្រឿងយន្តសម្រាប់បង្កើតកម្លាំងអគ្គិសនី)

dynamogène ឬ **dynamogénique** *a.* ដែលលើកកម្លាំង

dynamographe *n.m.* លេខថាមមាត្រ (ប្រដាប់ស្ទង់ក៏កម្លាំង)

dynamomètre *n.m.* ថាមមាត្រ,ប្រដាប់ស្ទង់កម្លាំង

dynamométrique *a* នៃការស្ទង់កម្លាំង

dynaste *n.m.* អ្នក ក សន្តតិវង្ស

dynastie *n.f.* សន្តតិវង្ស

dynastique *a.* នៃសន្តតិវង្ស

dyne *n.f.* ឌីន(មាត្រាកម្លាំង)

dysenterie *n.f.* រោគមូល។dysenterie amibienne រោគមូល(បណ្ដាលមកអំពីអាមីប) ។ dysenterie bacillaire រោគមូលកក (បណ្ដាលមកអំពីទណ្ឌាណូ)

dysentérique *a.* នៃរោគមូល ។ *n.* អ្នកកើតរោគមូល

dysménorrhée *n.f.* រោគធ្លាក់រដូវមិនស្រួល(ស្រី); ដំណើរធ្លាក់រដូវដោយឈឺចាប់ខ្លាំង

dyspepsie *n.f.* ការរំលាយអាហារដោយពិបាក

dyspepsique ឬ **dyspeptique** *a.* នៃការរំលាយអាហារដោយពិបាក។*n.* អ្នកកើតរោគរំលាយអាហារដោយពិបាក

dyspnée *n.f.* ការស្ទះដង្ហើម

dysurie *n.f.* រោគទល់នោម

dysurique *a.&n.* អ្នកកើតរោគទល់នោម

dytique *n.m.* កន្ទេះឡង់

e *n.m.* អក្សរទីប្រាំនៃអក្ខរក្រមឡាតាំង ។ *Abrév.* E. (est) ទិសខាងកើត ។ E. ឬ Exc. (Excellence : S.E. Son Excellence) ឯកឧត្តម (ឯ.ឧ.)។ E. ឬ Em. (Eminence : S. E. Son Eminence) សម្ដេច

eau *n.f.* គង្គា, ទឹក (ឧ. se jeter à l'eau) ។ eau brute ទឹកអសិទ្ធ។ service des eaux et forêts ក្រុមគង្គានិងរុក្ខា។ ភ្លៀង(ឧ.il tombe de l'eau); ស្ទឹង, បឹង, សមុទ្ទ (ឧ. promenade sur l'eau) ។ *Par anal.* ត្រូករំ ដូចជា ញើស, ទឹកមាត់, ទឹកភ្នែក ។ល។ (ឧ. être tout en eau); ទឹក (ទឹកដមផ្លែឈើ ឬប្រូជាតិខ្លះ) (ឧ. melons qui ont trop d'eau); សុរាប្រភេទខ្លះ (ឧ. eau de menthe) ។ *Fig.* ទឹកត្បូង (ឧ. diamant d'une belle eau) ។

Loc. div. eau courante ទឹកហូរ ។ eau claire ទឹកថ្លា; ទឹកសុទ្ធ(ដែលសម្រាប់ផឹកមិនជាប់លាយសុរា=ក្នុងន័យនេះអាចជា eau pure ក៏បាន); *au fig.* លទ្ធផលសូន្យ ឬ លទ្ធផលស្ដួចស្ដើង (ឧ. l'esprit, sans l'instruction et le jugement, ne donne que de l'eau claire)។ eau de vaisselle ទឹកលាងចាន ; *pop. & fig.* ទឹកស្មោរ ឥតរសជាតិ ។ eau ferrée ទឹកច្រាំដែក ឬ ទឹកជ្រលក់ដែកក្ដៅ ។ **eau**

panée ទឹកស្ងោរនំប៉័ង ។ eau de riz ទឹកបាយ ។ eau rougie ទឹកលាយស្រាទំពាំងបាយជូរក្រហម។eau de boudin ទឹកស្ងោរសាច់ក្រក (ម. ព. boudinផង) ។ *Pop. & fig.* លទ្ធផលសូន្យ (ឧ. s'en aller en eau de boudin)។eau gazeuse ទឹកឧស្ម័ន(ទឹកលាយឧស្ម័នដូចជាសូដាជាដើម)។eau de rose ទឹកអប់ផ្កាកុលាប ។ personne à l'eau de rose ជនទន់ខ្សោយ ។ de la plus belle eau ដែលជាប្រសើរបំផុត (មនុស្ស ឬ វត្ថុ) ។ porteur d'eau អ្នករែកទឹកលក់ ។ marchand de l'eau អ្នកជំនួញជើងទឹក។ gens de delà l'eau មនុស្សជ្វីជង ។ à fleur d'eau ប៉ប្រះទឹក, សើទឹក ។ sentir l'eau សាបដូចទឹក (ឧ. melons qui sentent l'eau) ។ se noyer dans un verre d'eau លង់ខ្លួនក្នុងរឿងហេតុបន្តិចបន្តួច។ tempête dans un verre d'eau ដំណើរជ្រួលច្របល់ខ្លាំងចំពោះរឿងបន្តិចបន្តួច ។ être l'eau et le feu ឬ comme l'eau et le feu មានចរិយាផ្ទុយគ្នាស្រឡះ ។

porter l'eau et le feu ម្ដងបញ្ជោរម្ដងបង្កាច់ ឬម្ដងត្រជាក់ម្ដងក្ដៅ។ se ressembler comme deux gouttes d'eau ដូចគ្នាសុទ្ធសាធ ។ mettre de l'eau dans son vin បន្ថយការទាមទារ(មិនតឹងរ៉ឹងពេក)។ne pas trouver de l'eau à la rivière ឬ à la mer រកវត្ថុងាយស្រួលពេកមិនបាន។coup d'épée dans l'eau កិច្ចការឥតផល (ដូចជាកាត់ទឹក) ។ tomber dans l'eau ធ្លាក់ទឹក; *au fig* មិនបានសម្រេច (ឧ. projet tombé dans l'eau) ។ aller à vau-l'eau ខូចខាតអស់, មិនបានសម្រេច (ឧ. l'affaire est allée à vau-l'eau) ។ battre l'eau ចំឥតអំពើ (ឧ. c'est battre l'eau, monsieur, que de répéter toujours la même chose) ។ suer sang et eau ចំប្រឹងហួសប្រមាណឬព្រួយខ្លាំង។ se fondre ឬ se résoudre en eau បង្អុរភ្លៀងខ្លាំង (មេឃ) ។ se fondre en eau ឬ être en eau បែកញើសជោគ ។ montrer son eau បង្ហាញចំណេះខ្លួន(ចំពោះកិច្ចការអ្វី

មួយ) ។ se jeter ឬ se mettre dans l'eau comme Gribouille par crainte de la pluie ចៀសភ្លៀងលោតទឹក ឬ ចៀសភក់ផាន់រេចម៍ (ចៀសវាងកំហុសបន្តិចបន្តួចទៅប្រទះកំហុសធំជាង) ។ être comme un poisson dans l'eau សប្បាយចិត្ត(នឹងស្ថានភាពខ្លួន) ។ être comme un poisson hors de l'eau មិនរីករាយ. មិនសប្បាយចិត្ត (នឹងស្ថានភាពខ្លួន) ។ être en pleine eau de ពេញទី (ឧ. nous sommes en pleine eau d'égalité) ។ revenir sur l'eau ងើបឡើងវិញ, បានចម្រើនឡើងវិញ(ខាងមុខរបរ);បានស្រួលឡើងវិញ(ខាងសុខភាព)។ faire venir l'eau à son moulin ធ្វើឲ្យធ្លាក់ផលមកលើខ្លួន(ទោះបីខូចប្រយោជន៍អ្នកដទៃក៏ដោយ) ។ faire venir l'eau au moulin de quelqu'un ផ្តល់ប្រយោជន៍ឲ្យអ្នកណាមួយ ។ pêcher en eau trouble ឆ្លៀតយកប្រយោជន៍ពីការវិបត្ត ។ faire quelque chose les pieds dans l'eau ធ្វើអ្វីមួយ ដោយចចេសខ្លាំង ។ aller à la bonne eau ទៅជំនុំយូរ (ដូចគេទៅឆ្ងាយរកនឹងទឹកល្អព្រោះបាន) ។ aller à l'eau chez l'autre លូកដៃចូលក្នុងកិច្ចការអ្នកណាម្នាក់ ។ laisser couler l'eau មិនយកជើងភទឹក (មិនជំទាស់ក្នុងកិច្ចការអ្វីមួយ); ទ្រាំទាំ ។ suivre le fil de l'eau ឬ aller à vau-l'eau ចុះតាមទឹក, បណ្តែតតាមទឹក; *au fig.* បណ្តោយតាមហេតុការណ៍ ឬ តាមយោបល់គេ ។ ne pas avoir de l'eau à boire គ្មានវត្ថុចាំបាច់បំផុត ។ ne pas donner de l'eau à boire គ្មានផ្តល់ធនធានអ្វីសោះ ។ être au pain et à l'eau ត្រូវទោស (តម្រូវឲ្យស៊ីបាយសាប) ។ mettre quelqu'un au pain et à l'eau ដាក់ទោស (តម្រូវឲ្យស៊ីបាយសាប) ។ faire quelque chose comme si l'on buvait un verre d'eau ធ្វើការអ្វីមួយដោយងាយឬដោយរីករាយ ។ il ne gagne pas l'eau qu'il boit ខ្ជិលណាស់ (សព្វបើទឹកផឹកក៏រកមិនបានដែរ) ។ c'est une goutte d'eau dans la mer ទឹកមួយ

ធំណក់ក្នុងសមុទ្រ (ស្ដួចស្ដើងណាស់, មិនសំខាន់សោះ) ។ porter ឬ jeter de l'eau à la mer ឬ à la rivière ធ្វើការឥតប្រយោជន៍ (ដូចគេបាចទឹកបញ្ចូលសមុទ្រ) ។ être dans les eaux grasses កាន់មុខដំណែងល្អ; ជាអ្នកមានស្ដុកស្ដម្ភ ។ eaux basses ការខ្វះក្រាក់ ។ se tenir dans les eaux de quelqu'un នៅជិតអ្នកណាម្នាក់ឬមានការទាក់ទងជាមួយអ្នកណាម្នាក់ ។ être dans les eaux de quelqu'un នៅក្នុងក្រុម ឬ ក្នុងបក្សពួកជាមួយ; រាប់អានគ្នាជិតស្និទ្ធ ។ nager entre deux eaux កាន់អព្យាក្រឹត(មិនចូលខាងណា ឬ ត្រូវទាំងពីរខាង)

eau-de-vie *n.f.* សុរាអូឌីវី

eau-forte *n.f.* ទឹកក្រូតធម្មតា (*pl.* des eaux-fortes)

ébahi,e *a.* ដែលភ្ញាក់ភ្ញាំង,ស្រឡាំងកាំង

ébahir *v.t.* បំភ្ញាក់បំភ្ញាំង,ធ្វើឲ្យស្រឡាំងកាំង (ឧ. cette nouvelle m'a ébahi)

ébahissement *n.m.* ដំណើរឆ្ងល់ខ្លាំង; ការកោតសរសើរ

ébarber *v.t.* កាត់ជាយចេញ(ចំពោះក្រដាសដែលលួតចេញក្នុងការចងសៀវភៅ) ។ *Techn.* ខាត់ឬកោសរំលីងលោហធាតុ; កាត់រោមរុក្ខជាតិចេញ

ébarbeuse *n.f.* ម៉ាស៊ីនកាត់ជាយក្រដាស

ébarboir *n.m.* ប្រដាប់កោសរំលីង ឬ ខាត់លោហធាតុ

ébarbure *n.f.* ចំទៀរក្រដាសដែលកាត់ចេញ; ស្នាមពុម្ព

ébats *n.m. pl.* ការលេងប្លែង; ល្បែង (ឧ. prendre ses ébats)

ébattre (s') *v.pr.* លេងប្លែង

ébaubi,e *a. Fam.* ដែលឆ្ងល់ស្រឡាំងកាំង (ឆ្ងល់ខ្លាំង)

ébaubir (s') *v.pr.* ឆ្ងល់ស្រឡាំងកាំង (ឆ្ងល់ខ្លាំង)

ébauchage *n.m.* ការព្រាង

ébauche *n.f.* របស់ព្រាង (ឧ. l'ébauche d'un tableau) ។ *Par ext.* របស់ធ្វើមិនទាន់ស្រេច (នៅខ្វះតែចំណុចបន្ទាប់បន្សំ) ។ *Fig.* ការផ្ដើម (ឧ. l'ébauche d'un sourire)

ébaucher *v.t.* ព្រាង ។ *Fig.* ផ្ដើម (ឧ. ébaucher un geste); រៀបចំ (ប្រុងប្រៀប) (ឧ. ébaucher un projet)

ébaucheur *n.m.* ជាងអ្នកព្រាង

ébauchoir *n.m.* ប្រដាប់ព្រាង (ប្រដាប់ជាងចម្លាក់ឬជាងឈើ)

ébaudir (s') *v.pr.* លេងសប្បាយ

ébavurer *v.t.* កោសស្នាមពុម្ពចេញ (ស្នាមមុខដំណពុម្ព)

ébène *n.f.* ឈើខ្មៅ។ *Fig.* ពណ៌ខ្មៅស្រិល (ឧ. cheveu d'ébène)

ébénier *n.m.* ដើមឈើខ្មៅ

ébéniste *n.m.* ជាងធ្វើតុទូបិទបន្ទះក្តារ ។ *Par ext.* ជាងតុទូ

ébénisterie *n.f.* រោងជាងតុទូ; ជំនួញ ឬ កិច្ចការជាងតុទូ

éberlué,e *a.* ធ្ងល់ស្រឡាំងកាំង

éberluer *v.t.* ធ្វើឲ្យព្រិលភ្នែក;ធ្វើឲ្យធ្ងល់

éblouir *v.t.* ធ្វើឲ្យស្រវាំងភ្នែក (ឧ. la lumière du soleil nous éblouit); ធ្វើឲ្យព្រិលភ្នែក (ឧ. sa beauté les éblouit) ។ *Fig.* បំភាន់ (ឧ. se laisser éblouir par les apparences); ជំរើងឫក (ឡើងក្រអឺតក្រអោង) (ឧ. ses succès l'ont ébloui)

éblouissant,e *a.* ដែលចាំងភ្នែក, ដែលឲ្យស្រវាំងភ្នែក; ស្វាច, ចិញ្ចាច (ឧ. une couleur éblouissante)។ *Fig.* អធិកអធម (ឧ. fête éblouissante)

éblouissement *n.m.* ដំណើរស្រវាំងភ្នែក(ដោយពន្លឺខ្លាំង);ដំណើរព្រិលភ្នែក (ដោយមិនស្រួលខ្លួន) (ឧ. avoir des éblouissements); ដំណើរវិលស្មារតី ។ *Fig.* សេចក្តីស្ញប់ស្ញែង

ébonite *n.f.* អេបូនីត (កៅស៊ូរឹងខ្មៅ)

éborgnage *n.m.* *Hort.* ការលួសភ្នែកឈើចោល

éborgner *v.t.* ធ្វើឲ្យខ្វាក់ម្ខាង; លួសភ្នែកឈើចោល

éboueur *n.m.* ម.ព. boueur

ébouillantage *n.m.* ការស្រុស; ការស្រោចទឹកក្តៅ

ébouillanter *v.t.* ស្រុស;ស្រោចទឹកក្តៅ

éboulement *n.m.* ដំណើររលំ; របស់ដែលរលំ

ébouler *v.t.* រំលំ។ s'ébouler *v.pr.* រលំ, ស្រុត

éboulis *n.m.* គំនរកំទេចវត្ថុរលំ (ឧ. un éboulis de roches)

ébouqueter *v.t.* កាត់ខ្នែងស្លឹកចោល (ដើម្បីឲ្យខ្នែងផ្លែលូតលាស់ល្អ)

ébourgeonnement ឬ **ébourgeonnage** *n.m.* ការកាត់ពន្លក ឬ ខ្នែងដែលឥតប្រយោជន៍ចេញ

ébourgeonner *v.t.* កាត់ពន្លក ឬ ខ្នែង ដែលឥតប្រយោជន៍ចេញ

ébouriffant,e *a.* ប្លែក; មិនគួរឲ្យជឿ (ឧ. histoire ébouriffante)

ébouriffé,e *a.* ដែលមានសក់ភក់ភយ

ébouriffer *v.t.* ញក់ញីសក់ ។ *Fig.* ធ្វើឲ្យឆ្ងល់ (ឧ. cette nouvelle m'a ébouriffé)

ébourrer *v.t.* បោច ឬ កោសរោមចេញ (ពីស្បែកសត្វ)

ébouter *v.t.* កាត់ចុង (ឧ. ébouter une pièce de bois)

ébranchage ឬ **ébranchement** *n.m.* ការលះមែកឈើ

ébrancher *v.t.* លះមែកឈើ

ébranchoir *n.m.* កាំបិតលះមែកឈើ

ébranlable *a.* អាចអង្រួនបាន

ébranlement *n.m.* ការរញ្ជួយ ។ *Fig.* ការរញ្ជួយ; គ្រោះថ្នាក់និងអន្តរាយ (ឧ. l'ébranlement d'un empire); ការរំជួលចិត្ត (ឧ. ébranlement nerveux)

ébranler *v.t.* អង្រួន (ឧ. ébranler un arbre); ធ្វើឲ្យរញ្ជួយ (ឧ. les camions ébranlent la rue) ។ *Fig.* ធ្វើឲ្យទន់ខ្សោយ, ធ្វើឲ្យខូច (ឧ. ébranler la santé); ធ្វើឲ្យរើបចិត្ត, ធ្វើឲ្យឡប់ស្មារតី (ឧ. ces raisons l'ont ébranlé) ។ s'ébranler *v.pr.* កំរើក, កម្រើក, រញ្ជួយ

ébrasement *n.m.* ការពង្រីកមាត់ក្នុង

ébraser *v.t.* ពង្រីកមាត់ក្នុង

ébrasure *n.f.* ឬ **ébrasement** *n.m.* មាត់បង្អួចដែលគេពង្រីកខាងក្នុង

ébrèchement *n.m.* ការធ្វើឲ្យឆែប

ébrécher *v.t.* ធ្វើឲ្យឆែប (ឧ. ébrécher un couteau) ។ *Fig.* រំលស់, ធ្វើឲ្យថយចុះ ឬ ឲ្យនៅតិច (ដោយយកប្រើខ្ជះ)(ឧ. ébrécher sa fortune)

ébréchure *n.f.* ស្នាមឆែប

ébriété *n.f.* ការស្រវឹង

ébrouement *n.m.* ការកណ្ដាស់(សត្វ)

ébrouer (s') *v.pr.* ផ្ទុះស្លាប (ដើម្បីជម្រុះធូលីពីខ្លួន) (ឧ. moineaux qui s'ébrouent dans le sable); រលាស់ខ្លួន (ឧ. s'ébrouer après le bain)

ébruitement *n.m.* ការផ្សាយ (ឲ្យគេឯងដឹងឮគ្រប់គ្នា)

ébrouiter *v.t.* ផ្សាយ (ឲ្យគេឯងដឹងឮគ្រប់គ្នា)

ébulliométrie ឬ **ébullioscopie** *n.f.* វិធីស្ទង់កំដៅវត្ថុ

ébullioscope *n.m.* ប្រដាប់ស្ទង់កំដៅវត្ថុ

ébullition *n.f.* ដំណើរពុះ(ទឹក)។ *Fig.* ចលាចល, ការរំជើបរំជួល (មួយរងមួយកាល)(ឧ. foule en ébullition)

éburné,e ឬ **éburnéen,enne** *a.* ដែលមានពណ៌ដូចភ្លុក; ដែលដាប់ដូចភ្លុក ។ substance éburnée ភ្លុកធ្មេញ

écacher *v.t.* កំទេច, បំបែក (ឧ. écacher une noix); កិនឲ្យស្ដើង (ឧ. écacher un fil)

écaillage *n.m.* ការស្រកា (ការយកស្រកាចេញ); ការបកគ្រំឬងាវ; ដំណើររបក (ថ្នាំលាប)

écaille *n.f.* ស្រកា; ស្នូកអណ្ដើក; សំបកគ្រំ លៀស ។ល។ (ឧ. une écaille d'huitre); ក្បាច់ស្រកានាគ; អ្វីៗដែលរបកធ្លាក់ជាបន្ទះៗ (ឧ. mur qui s'en va par écailles)

écailler *v.t.* ស្រកា (យកស្រកាចេញ) (ឧ. écailler un poisson); បក (គ្រំ លៀសឬងាវ)(ឧ. écailler des huitres)។ s'écailler *v. pr.* របក (ថ្នាំលាប) (ឧ. peinture qui s'écaille); របកស្រកា

écailler,ère *n.* អ្នកបកឬលក់សំបកគ្រំ លៀស ឬ ងាវ

écailleux,euse *a.* ដែលមានស្រកា(ឧ. poisson écailleux); ដែលរររ; ដែលរបកធ្លាក់ជាបន្ទះៗ (ឧ. ardoise écailleuse)

écaillure *n.f.* ដុំរបកស្រកា

écale *n.f.* សណក (ផ្លែឈើ)

écaler *v.t.* បកសំបករឹងចេញ

écang *n.m.* ប្រដាប់កិនដើមក្រចៅ

écanguer *v.t.* កិនដើមក្រចៅ(ដើម្បីយកសំបក)

écarlate *n.f.* ពណ៌ក្រហមឆ្អៅ; សំពត់ក្រហមឆ្អៅ (ឧ. manteau d'écarlate)។ *a.* ក្រហមឆ្អៅ (ឧ. rubans écarlates)

écarquiller *v.t.* កន្ទក (ឧ. écarquiller les jambes); បើកធំៗ (ឧ. écarquiller les yeux)

écart *n.m.* ការបែក, ការងាក ឬ បំបែក; ការកន្ទក(ឧ.écart des jambes); ដំណើរងាកចេញពីផ្លូវ (ឧ. les chevaux peureux font souvent des écarts); ចម្ងាយ, ចន្លោះ, ការ

ខុសគ្នា (ឧ. diminuer l'écart entre le prix d'achat et le prix de vente); ទីជាប់ស្រយាល, ភូមិជាប់ស្រយាល; ការប្រែប្រួល (ឧ. les écarts d'un baromètre)។ faire un écart ងាកចេញទៅខាង, ស្ទុះចេញទៅខាង ។ faire le grand écart កន្ធែកជើងឲ្យភ្លៅទើសដី ។ *Fig.* ការប្រព្រឹត្តខុសគន្លងធម៌ ខុសច្បាប់គួរសម ឬ ខុសទំនង (ឧ. écart de jeunesse, de langage)។ à l'écart *loc. adv.* ឃ្លាតពីគេ, ម្នាក់ឯង (ឧ. se tenir à l'écart); ដោយឡែក (ជាសំងាត់) (ឧ. mettre de l'argent à l'écart); ដាក់ចោល, ទាត់ចោល (ឧ. mettre une question à l'écart) ។ se jeter à l'écart និយាយខុសរឿង ។ à l'écart de *loc. pré.* ឆ្ងាយពី (ឧ. se tenir à l'écart des affaires publiques)

écarté,e *a.* ដែលនៅម្នាក់ឯង, ដែលនៅឃ្លាតពីគេ (ឧ. endroit écarté) ។ *n.m.* ការតេ (ល្បែងបៀជាកម្យ៉ាង លេងគ្នាពីរ បី ឬ បួននាក់)

écartellement *n.m.* ទោសត្រូវចងសន្ទឹងទាញផ្ដាច់ដៃជើង

écarteler *v.t.* ចងសន្ទឹងទាញផ្ដាច់ដៃជើង

écartement *n.m.* ការញែក;ការកន្ធែក; ប្រឡះ (ឧ. écartement des rails)

écarter *v.t.* រែក,ញែក,ច្រាន(ឧ.écarter la foule); បំបែក, កន្ធែក (ឧ. écarter les jambes) ។ *Fig.* បំបែកចេញ,ធ្វើឲ្យងាកចេញ(ឧ. écarter quelqu'un du droit chemin); បំបាត់, កំចាត់ (ឧ. écarter les obstacles); កំចាត់ (បណ្ដេញដោយឧបាយ) (ឧ. écarter des concurrents)។s'écarter *v.pr.* ចេញឆ្ងាយពី, ងាកចេញ

écarter *v.t. Jeux* ទំលាក់បៀ (ទំលាក់ចេញខ្លះដើម្បីរើសយកថ្មីទៀត)

écarteur *n.m.* ប្រដាប់បង្ហាមុខដំបៅ

ecchymose *n.f.* សាច់ជាំ

ecclésiastique *a.* នៃសាសនា, នៃសមណធម្មិក ។ *n.m.* បព្វជិត

écervelé,e *a.* ល្ងេល្ងើ, ភ្លីភ្លើ (ឧ. tête écervelée)

échafaud *n.m.* ខ្នា; វេទិកាបណ្ដោះអាសន្ន;រានពិឃាតមនុស្សទោស។ *Par*

ext. ម៉ាស៊ីនកាត់ក;ទោសប្រហារជីវិត (ឧ. mériter l'échafaud)

échafaudage *n.m.* រន្ទា។*Par ext.* គំនរ (ឧ. un échafaudage de livres) ។ *Fig.* អ្វីៗ សម្រាប់ធ្វើ ឬ សម្រាប់បង្កើត (ឧ. l'échafaudage d'une fortune); ការគិតគ្រោង

échafauder *v.i.* ដំរន្ទា។*v.t.* តម្រួតលើគ្នា,គរ។*Fig.*គិតគ្រោង(ឧ.échafauder des projets)

échalas *n.m.* ជន្ទល់,ទ្រើង ។ *Fig.& Fam.* មនុស្សក៏តោរ៉,មនុស្សខ្ពស់ស្គម

échalasser *v.t.* បោះជន្ទល់, ដាក់ទ្រើង (ឧ. échalasser une vigne)

échalier *n.m.* ជណ្ដើរកាច់ (សម្រាប់ឆ្លងរបង); របងចំការ

échancrer *v.t.* លុង ឬ កាត់ជាវង់អឌ្ឍចន្ទ (ឧ. échancrer le col d'une robe)

échancrure *n.f.* ប្រហោងដែលលុងឬកាត់ជាវង់អឌ្ឍចន្ទ;ឈូងឆកក្ដួលក្នុងច្រាំង

échange *n.m.* ការដូរ (ឧ. faire un échange avantageux)។ *Fig.* ការប្ដូរ (ឧ.échange de politesses) ។ en échange *loc.adv.* ជាថ្នូរ, ជាសំណង ។ en échange de *loc.pré.* ជាជំនួស ។ *Com.* échange compensé ការប្ដូរទូទាត់

échangeable *a.* អាចដូរឬប្ដូរបាន

échanger *v.t.* ដូរ,ប្ដូរ (ឧ. échanger des timbres, des lettres) ។ *Fig.* ប្ដូរ (ឧ. échanger des sourires)

échangiste *n.m.* អ្នកធ្វើជំនួញប្ដូរ

échantillon *n.m.* សំណាក,អ្វីៗ ដែលតាំងតែបន្តិចឲ្យមើល (ឧ. échantillon d'écriture) ។ *Fig.* ឧទាហរណ៍,តួយ៉ាង (ឧ. donner un échantillon de son talent)

échantillonnage *n.m.* ឈុតគំរូ ឬ សំណាក; ការផ្ទឹងសំណាក; ការកាត់ធ្វើជាសំណាក

échantillonner *v.t.* ផ្ទឹងសំណាក; កាត់ធ្វើជាសំណាក

échanvrer *v.t.* បកសំបកធ្មៃឬព្រៅ

échanvroir *n.m.* ប្រដាប់បកសំបកធ្មៃឬព្រៅ

échappatoire *n.f.* ឧបាយដោះខ្លួន, ល្បិច (ឧ.trouver une échappatoire)

échappé,e *n.* អ្នកចេញ, អ្នកលបរត់ ។ échappé des Petites-Mai-

sons ឬ de Charenton មនុស្សឆ្កួត

échappée *n.f.* ការរត់ផុតគូប្រណាំងយ៉ាងហ័ស (ឧ.l'échappée d'un coureur); ច្រក ឬ ប្រឡោះ (អាចឲ្យមើលឃើញរបស់អ្វីមួយ) (ឧ. échappée sur la mer); ច្រកឬចន្លោះ (សម្រាប់ចេញចូល) (ឧ. échappée d'un garage); ប្រឡោះជណ្ដើរ (ចន្លោះពីកាំជណ្ដើរទៅពិតានលើជណ្ដើរ) *Fig.* មួយភ្លែត (ពេលដ៏ខ្លី) (ឧ. une échappée de beau temps)

échapper *v.i.* រត់ (រៀសខ្លួន) (ឧ. laisser échapper un prisonnier) ។ *v.t. ind.* (à, de) រួចពី (ឧ. échapper au danger); ធ្លាក់ពី, របូតពី (ឧ. échapper de la main); មើលមិនឃើញ ឬ ស្ដាប់មិនឮ (ឧ. insectes qui échappent à la vue); មិនឃើញ (ឧ. faute qui a échappé au correcteur); នឹកមិនឃើញ (ឧ. le terme exact m'échappe) ។ ce mot m'a échappé ពាក្យនេះរបូតពីមាត់ខ្ញុំ (ខ្ញុំពុំបានគិត) ។ *v.t.* l'échapper belle រួចខ្លួនពីភ័យដោយប្រផុតប្រផើយ ។ s'échapper *v.pr.* រត់, គេច, រៀសខ្លួន

écharde *n.f.* ចម្រាស (កំទេចឈើឬអ្វីៗដែលមុតច្រាសចូលក្នុងសាច់)

écharnement ឬ **écharnage** *n.m.* ការពន្លះសាច់ចេញពីស្បែក

écharner *v.t.* ពន្លះសាច់ចេញពីស្បែក

écharnoir *n.m.* កាំបិតពន្លះសាច់ចេញពីស្បែក (មានដងពីរ)

écharpe *n.f.* ឥន្ទធនូ (ផ្ទាំងសំពត់តូចវែង ចម្រុះពណ៌សម្រាប់ស្ពាយឆៀងជាគ្រឿងឥស្សរិយយស)(ឧ.l'écharpe d'un maire); សំពត់ព្យួរដៃរបួស; ភាហ៊ុម, ក្រមា ។ en écharpe *loc. adv.* ស្ពាយឆៀង; ពាធា; ពីចំហៀង, ពីទទឹង (ឧ. automobile prise en écharpe par une autre)

écharper *v.t.* បំបែក; ធ្វើឲ្យមានរបួស (ឧ. écharper le visage de quelqu'un); កាត់ជាកំណាត់ (ឧ. écharper l'ennemi)

échars,e *a.* មិនសុទ្ធ (រូបិយវត្ថុ)

échasse *n.f.* ជើងទោម (ឈើ ត ជើង)

échassiers *n.m.pl.* ទីឃបាទបក្សី (ពួកបក្សីជើងវែងដូចជាទោម ក្រសារ។ល។)

échauboulure *n.f.* កមសត្វ(ពងខ្ទុះលើស្បែកសត្វទំហំប៉ុនកាក់ឬ ធំជាងកាក់)

échaudage *n.m.* ការលាងទឹកក្ដៅ,ការស្រុស; ការលាបទឹកកំបោរ; ទឹកកំបោរសម្រាប់លាបជញ្ជាំង

échaudement *n.m.* ភាពស្អុក (ស្រូវ)

échauder *v.t.* លាងទឹកក្ដៅ,ស្រុស (ឧ. on échaude une bête tuée pour la dépouiller facilement de son poil) ; ស្រោកទឹកក្ដៅ ។ riz échaudé ស្រូវស្អុក ។ *Fig.* នាំឲ្យរងគ្រោះកាច (ឧ.échauder un ambitieux) ; កោរ, ឲ្យចេញថ្លៃហួសកំណត់ (ឧ. échauder un client) ។

Prov. chat échaudé craint l'eau froide ម.ព. chat

échauder *v.t.* ព្រំទឹកកំបោរ; លាបទឹកកំបោរ

échaudoir *n.m.* កន្លែងសម្លាប់និងកោរសាច់ (ក្នុងទីសត្តឃាត); ភាជន៍ដាក់ទឹកក្ដៅស្រុស

échauffant,e *a.* ក្ដៅ (ដែលធ្វើឲ្យឡើងកំដៅក្នុងខ្លួន)(ឧ. le gibier est une nourriture échauffante)

échauffé *n.m.* ក្លិនចំហាយ (ក្លិនកាយចេញពីចំហាយក្ដៅ);ក្លិនឆ្អួម

échauffement *n.m.* ការកំដៅ;ដំណើរក្ដៅខ្លួន; ដំណើរឡើងឆ្អួម (ស្រូវ ឬ ធញ្ញជាតិផ្សេងៗ); ដំបៅរលាក (រលាកភ្លើងឬទឹកក្ដៅ)។ *Fig.* ការជ្រួលច្របល់

échauffer *v.t.* ធ្វើឲ្យក្ដៅ, កំដៅ, ធ្វើឲ្យក្ដៅខ្លួន; ធ្វើឲ្យឡើងឆ្អួម, ធ្វើឲ្យពុក (ឧ. après la pluie, le soleil échauffe les bois) ។ *Fig.* échauffer la bile ឬ les oreilles ធ្វើឲ្យខឹង(ធ្វើឲ្យក្ដៅស្លឹកត្រចៀក)។ s'échauffer *v.pr.* ក្ដៅក្ដា; រឹតតែក្ដៅឡើង, រឹតតែខ្លាំងឡើង (ឧ. la dispute s'échauffe)

échauffourée *n.f.* ជម្លោះ; ការវាយប្រឡុកបន្តិចបន្តួច

échauguette *n.f.* ប៉មយាមនៅត្រង់មុមកំពែងបន្ទាយ

échauler *n.f.* ម.ព. chauler

èche *n.f.* ម.ព. aiche

échéance *n.f.* គណប្រតិទាន (ថ្ងៃសងបំណុល ឧ. respecter ses échéances;រយៈពេលសងបំណុល; រយៈពេលពីថ្ងៃជំពាក់ទៅដល់ថ្ងៃសង ឧ. emprunter à longue

échéance) ។ *Fig.* កាលបរិច្ឆេទសាទោស

échéancier *n.m.* បញ្ជីឥណប្រតិទាន (បញ្ជីថ្ងៃសងបំណុល)

échéant,e *a.* ដែលដល់កំណត់ពេល ។ le cas échéant ប្រសិនជាមាន, ប្រសិនជាត្រូវធ្វើ

échec *n.m.* ការមិនបានសំរេច, បរាជ័យ (ឧ. subir un échec); ការប្រឡងធ្លាក់

échecs *n.m.pl.* ល្បែងចត្រង្គ

échelette *n.f.* ជណ្ដើរតូច

échelier *n.m.* បង្គោង

échelle *n.f.* ជណ្ដើរ ។ *Fig.* មាត្រដ្ឋាន (ឧ. problème à l'échelle mondiale); ថ្នាក់, លំដាប់ (ឧ. échelle diatonique); កម្រិត (ឧ. échelle thermométrique) ។ échelle d'une carte មាត្រដ្ឋានផែនទី ។ échelle mobile មាត្រដ្ឋានចល័ត(ដំណើរប្រែប្រួលប្រាក់ឈ្នួលតាមតម្លៃទំនិញ) ។ *Fig.* tirer l'échelle après une personne ឬ une chose ទទួលស្គាល់ថាមនុស្សឬវត្ថុនេះមិនមានតម្លៃអ្វីលើសទេ។monter à l'échelle យកជាការនូវពាក្យនិយាយលេងឬពាក្យតិះ ។ échelle sociale ថ្នាក់ ឬ វណ្ណៈក្នុងសង្គម

échelon *n.m.* កាំជណ្ដើរ។*Fig.* លំដាប់, ជាន់,ថ្នាក់(ឧ.gravir les échelons de la hiérarchie)។à l'échelon supérieur ក្នុងលំដាប់ខ្ពស់

échelonnement *n.m.* ការចែកជាថ្នាក់; ការរាយ

échelonner *v.t.* តំរៀបតាមលំដាប់; ចែកជាថ្នាក់;រាយ,ប្រដាក់(ឧ.échelonner des troupes) ។ *Fig.* ធ្វើជាច្រើនលើក (ឧ. échelonner des paiements បង់ប្រាក់ជាច្រើនលើក)

échenillage *n.m.* ការចាប់ដង្កូវ ឬ ការបំផ្លាញសំបុកដង្កូវ

écheniller *v.t.* ចាប់ដង្កូវពីដើមឈើ; បំផ្លាញសំបុកដង្កូវ

échenilloir *n.m.* ប្រដាប់ចាប់ដង្កូវពីដើមឈើ

écheoir *v.i.* ម.ព. échoir

écheveau *n.m.* ហុង (អំបោះ សូត្រ); ការស្មុគស្មាញ (ឧ. démêler l'écheveau d'une intrigue, d'un récit)

échevelé,e *a.* ដែលមានសក់រាតត្បាយ;

កន្ទ្រើង ។ *Fig.* ដែលស្ទុះស្ទា, ដែលគ្មានរបៀប (ឧ.danse échevelée)

écheveler *v.i.* ឈ្វើសក់ឡើងរញ៉េរញ៉ៃ (ឧ. femme que le vent a échevelée)

échevette *n.f.* ហុងតូច(ស្វ្រក អំបោះ)

échiffre *n.f.* mur d'échiffre ជញ្ជាំងទ្រកាំជណ្ដើរ

échine *n.f.* ឆ្អឹងខ្នង (ពាក្យសាមញ្ញ) (ឧ. se rompre l'échine)។ *Fig.& Fam.* avoir l'échine souple បេះលុតក្រាប

échinée *n.f.* ខ្នងជ្រូក

échiner *v.t.* បំបាក់ឆ្អឹងខ្នង។*Par ext.* វាយ, ពិឃាត (ឧ. se faire échiner dans un combat)។ s'échiner *v.pr.* ខំប្រឹងហួសកម្លាំង

échinocoque [-Ki-] *n.m.* ព្រូនមំសាសី (ព្រូនសត្វស៊ីសាច់ជាអាហារ)

échinodermes [-Ki-] *n.m. pl.* សល្យគ័ច (សត្វានសត្វសមុទ្រ ស្បែកមានបន្លា)

échiquier *n.m.* ជាសក [ជាស្កា] ។ échiquier mondial ជាសកាពិភពលោក។ការតម្រៀបជាក្រឡាចត្រង្គ (ឧ. arbres plantés en échiquier) ។ Chancelier de l'Echiquier រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ (នៅប្រទេសអង់គ្លេស) ។ កន្លែងដែលមានបញ្ហា ឬ មានប្រយោជន៍ប្រឆាំងគ្នា (ឧ. échiquier parlementaire)

écho [-Ko-] *n.m.* ប្រតិធ្វនី (សំលេងបញ្ចេញទៅប៉ះនឹងវត្ថុអ្វីមួយ ហើយត្រឡប់មកវិញ) (ឧ. les phénomènes d'écho sont utilisés pour le sondage acoustique des mers); រំពង, ស្នូរខ្ទរ (ឧ. l'écho de la vallée); កន្លែងខ្ទរសម្លេង;កន្លែងដែលគេនឹងរឿង ។*Fig.* ដំណឹងខ្លីៗ (ឧ. les échos d'un journal);ពាក្យដែលគេនិយាយបន្ត, ពាក្យដែលគេនាំយកមកនិយាយ(ឧ.il ne faut pas se fier aux cancans, aux échos); អ្នកដែលយកតាមគេរបស់គេ (ដោយឥតពិចារណា) (ឧ. il n'est que l'echo de quelqu'un qu'il vient de quitter); របស់ដែលមានតែភាសាក្រៅ (ឧ.discours qui n'est qu'un écho verbeux); ការយល់ស្រប, ការចូលចិត្ត

គាំទ (ឧ. motion qui ne trouve pas d'écho) ។

Loc.div. se faire l'écho de ខ្ទរ; នាំយកទៅនិយាយ,និយាយបន្ត,ផ្សាយ (ឧ.il ne faut jamais se faire l'écho de la médisance) ។ en écho ដោយនាំយកទៅផ្សាយ

échoir *v.i.* ដល់ឬបានដោយជួន (ឧ. le gros lot lui échut); ដល់កំណត់ពេល(ដែលត្រូវសងបំណុល ឬ ដែលកំណត់ក្នុងកិច្ចសន្យា) (ឧ. le terme échoit demain)

écholalie [-Ko-] *n.f.* ការថាតាមដោយមិនបានគិត (ឧ. l'écholalie se rencontre surtout chez les enfants, les émotifs et les débiles mentaux)

échoppe *n.f.* តូបលក់ទំនិញ

échoppe *n.f.* ដែកឆាប់, ដែកឆ្លាក់

échopper *v.t.* ឆាប់, ឆ្លាក់

échotier [-Ko-] *n.m.* អ្នកនិពន្ធដំណឹងខ្លីៗ ក្នុងកាសែត

échouage *n.m.* កន្លែងបង្អែលនាវា; ភាពនាវាកៀង

échouement *n.m.* ការបង្អែលនាវា; ការមិនបានសម្រេច

échouer *v.i.* ទង្គិចនឹងថ្ម;កៀង(នាវា) ។ *Fam.* ចាប់នៅកន្លែងណាមួយ ។ *Fig.* មិនបានសម្រេច (ឧ. l'entreprise a échoué); ធ្លាក់(ប្រឡង)។ *v.t.* បង្អែល (នាវា) (ឧ. échouer un navire) ។ s'échouer *v.pr.* កើល,កៀង

écimage *n.m.* ការក្រៀវ (ដើមឈើ)

écimer *v.t.* ក្រៀវ(ដើមឈើ),កាត់ចុងឈើ

éclaboussement *n.m.* ការសាចភក់លើ

éclabousser *v.t.* សាចភក់ ឬ ទឹកលើ; ធ្វើឲ្យគេប្រណិតការទៀត(ដោយបញ្ចេញមានបានខ្លួន)(ឧ.le parvenu veut éclabousser tout le monde)

éclaboussure *n.f.* ភក់ដែលសាច ។ *Fig.* ផលអាក្រក់ដែលសាចលើអ្នកដទៃ (ឧ. les éclaboussures d'un scandale)

éclair *n.m.* ផ្លេកបន្ទោរ; ពន្លឺដែលមានរយៈតែមួយភ្លែត (ឧ. le diamant jetait des éclairs) ។ *Fig.* ពន្លឺ, ពន្លឺភ្នែក (ឧ. des yeux qui lancent des éclairs); ពេលរហ័សភ្លែត (ឧ. un éclair de génie)។

passer comme l'éclair ទៅលឿនភ្លែត (ឬ រហ័សភ្លែត)។ *a.* រហ័សភ្លែត (ឧ. une guerre éclair)

éclairage *n.m.* ការបំភ្លឺ; ប្រដាប់បំភ្លឺ; របៀបបំភ្លឺ (ឧ. éclairage défectueux)។ *Fig.* យោបល់ (ឧ. sous cet éclairage)

éclairagiste *n.m.* អ្នកតុបតែងពន្លឺ (ឧ. ingénieur éclairagiste)

éclairant,e *a.* ដែលបំភ្លឺ (ឧ. le pouvoir éclairant de l'acétylène est considérable)

éclaircie *n.f.* បណ្ដាលស្រឡះ (ក្នុងមេឃខ្ទឹម); អាកាសល្អមួយភ្លែត; ចន្លោះ; វាលក្នុងព្រៃ; ការប្រែប្រួលសមតាមបំណង

éclaircir *v.t.* ធ្វើឲ្យស្រឡះ (ឧ. vent qui éclaircit le ciel); ធ្វើឲ្យអន់ខាប់ (ឧ.éclaircir une sauce); រំលស់ (កុំឲ្យចង្អៀត ឬ ញឹកពេក) (ឧ. éclaircir une futaie); ធ្វើកុំឲ្យដិតពេក(ពណ៌)(ឧ.éclaircir une étoffe)។ *Fig.* បំភ្លឺ, ធ្វើឲ្យច្បាស់សេចក្ដី, ពន្យល់ (ឧ. éclaircir une question)។ s'éclaircir *v.pr.* ឡើងស្រឡះ។ *Fig.* ងាយយល់

éclaircissage *n.m.* ការរំលស់(កូនឈើក្នុងថ្នាល ឬ ឈើក្នុងព្រៃ)

éclaircissant,e *a.* ដែលធ្វើឲ្យភ្លឺ ឬ ឲ្យស្រឡះ

éclaircissement *n.m.* ការពន្យល់, ការបំភ្លឺ

éclairé,e *a. Fig.* ដែលមានចំណេះវិជ្ជាច្រើន, ដែលមានពិសោធន៍, ដែលចេះដឹង (ឧ. esprit éclairé)។ public éclairé សាធារណជនចេះយល់ការណ៍

éclairement *n.m.* ការបំភ្លឺ; ពន្លឺ

éclairer *v.t.* បំភ្លឺ (ឧ. le soleil éclaire la terre)។ *Fig.* បំភ្លឺ (ធ្វើឲ្យយល់) (ឧ. ce témoignage éclaire la question); ធ្វើឲ្យចេះ, ធ្វើឲ្យឈ្វេងយល់(ឧ. l'expérience nous éclaire); ដឹកនាំ (ឧ. l'aviation éclairait l'armée)។ *v.i.* បញ្ចេញពន្លឺ (ឧ. la nuit, les yeux du chat éclairent)។ *v.impers.* il éclaire មានផ្លេកបន្ទោរ

éclaireur *n.m.* ទាហាន ឬ នាក់នាំផ្លូវ

éclaireur,euse *n.* កាយរឹទ្ធិ

éclat *n.m.* បំណែក, អំបែង, កំទេច

(ឧ. éclat de verre); ពន្លឺចិញ្ចាច (ឧ. éclat du soleil); ភាពឆើត (នៃពណ៌) (ឧ. éclat des coloris); ផ្ទុះ, ស្គរ (ស័ព្ទលាន់ឮខ្លាំង) (ឧ. éclat de tonnerre, de voix)។ *Fig.* ការរុងរឿង (ឧ. l'éclat des grandeurs) ; ពាក្យចចាមអារ៉ាម (ដែលលេចឮសុសសាយ); រឿងអាស្រូវ (ឧ. ce procès fera éclat) ។ action d'éclat អំពើប្រសើរ

éclatant,e *a.* ភ្លឺចិញ្ចាច (ឧ. cuivres éclatants)។ *Fig.* ដែលមានកិត្តិសព្ទ, ឧត្តុង្គឧត្តម (ឧ. victoire éclatante); ជាសាធារណៈ; ស្តែង (ឧ. vengeance éclatante); គ្រលួច (ឧ. le son éclatant de la trompette)

éclatement *n.m.* ការផ្ទុះ(ឧ. éclatement d'un obus)។ *Fig.* ការបែក (ឧ. éclatement d'un groupe)

éclater *v.i.* ផ្ទុះ (ឧ.obus qui éclate); លាន់ស្គរខ្លាំង (ឧ. la foudre éclate)។ *Fig.* ខឹង (ឧ. éclater en reproches); ចេញឲ្យឃើញ (ឧ. la joie éclate dans ses yeux); ចេញពន្លឺ (ឧ. l'or et les diamants éclataient de toutes parts) ។ éclater de rire ធ្លាយសំណើច

éclectique *a.&n.* ឧទ្ទារ, អ្នកជ្រើសរើស, អ្នកសំរាំង (ឧ. être éclectique en littérature) ។ *a.* ឧទ្ទារ,ចម្រុះ (ឧ. goût éclectique)

éclectisme *n.m.* ឧទ្ទារនិយម

éclipse *n.f. Astr.* គ្រាស ។ éclipse solaire សូរ្យគ្រាស ។ éclipse lunaire ចន្ទ្រគ្រាស ។ ដំណើរបាំង, ដំណើរលេច (ពន្លឺ) (ឧ. phare à éclipses) ។ *Fig.* ដំណើរលេចបាត់មួយភ្លែត; សេចក្ដីភ្លាំងភ្លាត់

éclipser *v.t.* បាំង(រាំងការ)(ឧ. la lune éclipse quelquefois le soleil) ; បាំង (មិនឲ្យឃើញ) (ឧ. nuage qui éclipse le soleil)។ *Fig.* ឈ្នះ, លុបលើ (ឧ. éclipser ses rivaux)។ s'éclipser *v.pr.* លបបាត់, គេចបាត់ (ឧ. s'éclipser avant la fin du spectacle); វិនាស, អន្តរធាន (លែងមាន)

écliptique *n.f. Astr.* ក្លបថ (គោចរនៃផែនដី)

éclisse *n.f.* ស្នៀត; ព្រួល(ប្រដាប់អបអវយវៈបាក់) (ថាclisseក៏បាន);ចម្រៀក ឬ បន្ទះឈើ (សម្រាប់ធ្វើរបស់តូចតាច); បន្ទះក្តារធ្វើលាដំរូវ; ប្រវាស (ប្រើសម្រក់ទឹកប្រូម៉ាស); បន្ទះដែកស្លូបមុខដំណផ្លូវអយស្ម័យយាន

éclisser *v.t.* អបដោយព្រួល(អបអវយវៈបាក់)(ឧ.éclisser un bras cassé)

éclopé,e *a.* & *n.* ខ្វក, ដែលដើរបានដោយលំបាក(ឧ.aider un éclopé)

écloper *v.t.* ធ្វើឲ្យខ្វក

éclore *v.i.* ញាស់ (កូនបក្សី); រីក (ផ្កា); លេចឡើង, រះឡើង (ឧ. le jour vient d'éclore ព្រះអាទិត្យទើបនឹងរះ); លេចឡើង, កើតឡើង, មានឡើង (ឧ. son projet est près d'éclore)

éclosion *n.f.* ការញាស់ (ឧ. l'éclosion d'une couvée) ; ការរីក (ឧ.l'éclosion d'une fleur)។ *Fig.* ការលេចឡើង, ការកើត ឬ មានឡើង(ឧ.l'éclosion d'une idée); ការសំដែង

éclusage *n.m.* ការបិទសន្ទះទឹក

écluse *n.f.* សន្ទះទឹក

éclusée *n.f.* ចំនួនទឹកហូរក្នុងរយៈពេលដែលបើកសន្ទះទឹក

écluser *v.t.* បិទសន្ទះទឹក ។ écluser un bateau បម្លងនាវាតាមសន្ទះទឹក

éclusier,ère *a.* នៃសន្ទះទឹក(ឧ.porte éclusière)។*n.* អ្នកកាន់កាប់សន្ទះទឹក

écobuage *n.m.* ការដុតដំណាំដោយដីកប្លកស្មៅបំពក់ធ្វើជី

écobuer *v.t.* ដុតដំណាំដោយដីកប្លកស្មៅបំពក់ធ្វើជី

écœurant,e *a.* ដែលឲ្យញ័រពោះឆ្អង(ឧ. odeur écœurante) ។ *Fig.* ដែលឲ្យខ្ពើមរអើម, ដែលឲ្យស្អប់ (ឧ. specta :le, travail écœurant)

écœurement *n.m.* ការធ្វើឲ្យញ័រពោះ-ឆ្អង; សេចក្តីខ្ពើមរអើម, ការស្អប់; ភាពអ្នកញ័រពោះឆ្អង

écœurer *v.t.* ធ្វើឲ្យញ័រពោះឆ្អង (ឧ. odeur qui écœure) ។ *Fig.* ធ្វើឲ្យខ្ពើម ឬ ឲ្យស្អប់

école *n.f.* សាលារៀន (ឧ. ouvrir une école aujoud'hui c'est fermer une prison dans vingt ans)។ *Partic.* សាលាបឋមសិក្សា (ឧ. aller à l'école); សិក្ខាគារ, អគារសិក្សា (ឧ. construire une école);ការបង្រៀន (ឧ.faire l'é-

cole à des enfants); សិស្ស ឬបុគ្គលិកក្នុងសាលារៀន (ឧ. école nombreuse)។ maître d'école គ្រូបង្រៀនក្នុងសាលាបឋមសិក្សា ។ école ambulante សាលាចល័ត។ école d'application សាលាអនុវត្តន៍ ។ école de brousse សាលាអរញ្ញស្រ្គាម។ école dentaire សាលាទន្តពេទ្យ ។ école d'électricité et de mécanique industrielle សាលាអគ្គិសនីនិងយន្តសាស្ត្រឧស្សាហកម្ម ។ école à feu ការហាត់បាញ់កាំភ្លើងធំ ។ école du livre សាលារៀនធ្វើសៀវភៅ។ école des maîtres chaussures et bottiers សាលារៀនធ្វើស្បែកជើង។ école maternelle មត្តេយ្យសាលា [ម័ត-តៃ-យៈ-] (សាលាបង្រៀនទារកទារិកាមានគ្រូស្រីជួយជាមាតា) ។ école nationale de vétérinaire សាលាជាតិបសុពេទ្យ។ école normale nationale d'apprentissage សាលាគរុវិជ្ជាជាតិខាងការហាត់រៀន ។ école des officiers សាលានាយទាហាន ។ école des officiers de santé សាលាមន្ត្រីសុខាភិបាល ។ école de plein exercice សាលាបូរណសិក្សា ។ école professionnelle សាលាសិក្សាខាងវិជ្ជាជីវៈ ។ école rénovée សាលានវីករណ៍, សាលាសិក្សាបែបថ្មី។ école royale d'administration សាលាភូមិន្ទរដ្ឋបាល។ école royale de médecine សាលាភូមិន្ទវិជ្ជាពេទ្យ ។ école spéciale des travaux publics សាលាពិសេសសាធារណការ ។

Fig. និកាយ (ឧ. école rationaliste); សាលា (អ្វីៗដែលនាំឲ្យមានវិជ្ជាឬឲ្យមានពិសោធន៍)(ឧ. l'œuvre de Corneille est une école de grandeur d'âme)។

Loc. div. tenir école បង្រៀន ។ faire école មានសាវ័កច្រើន, មានអ្នកយកតម្រាប់តាមច្រើនគ្នា; សាយភាយ (ឧ. une idée qui fait école) ។

Loc. fam. révéler les secrets de l'école និយាយប្រាប់ការសម្ងាត់ដែលធ្វើក្នុងសង្គម (សមាគម) ។ renvoyer quelqu'un à

l'école បន្ទោសរំពឹកការលេងក្នុងមុខការណាមួយ (ឲ្យទៅរៀនម្ដងទៀត) ។ aller à une école ឬ être à une école សេពគប់អ្នកចេះវិជ្ជា (ឧ. aller ឬ être à une bonne école) ។ aller à l'école de quelqu'un ពឹងចំណេះ ឬ ពិគ្រោះអ្នកណាម្នាក់ ។ sentir l'école មានបែបបទជាអ្នកក្លែងហើយភ័យឬក ។ faire l'école buissonnière ម. ព. buissonnier

écolier,ère *n.* កូនសិស្ស ។ *Fig.* មនុស្សខ្វះសេចក្ដី (មិនប៉ុនប្រសប់ក្នុងរបរខ្លួន) (ឧ. faute d'écolier) ។ le chemin des écoliers ផ្លូវវាង

écologie *n.f.* បរិស្ថានវិទ្យា (វិទ្យាសាស្ត្រខាងការទាក់ទងរវាងសត្វមានជីវិតនិងទីឋានដែលសត្វនោះរស់នៅ)

écologique *a.* នៃបរិស្ថានវិទ្យា

éconduire *v.t.* បណ្ដេញ; មិនទទួលរាក់ទាក់; មិនព្រមចរចាជាមួយ (ឧ. éconduire un visiteur)

économat *n.m.* អគារូបដ្ឋាន; មុខងារអគារូបដ្ឋាក ។ *Par ext.* ឃ្លាំងជំនួញ (ឧ. les économats de la régie des chemins de fer royaux)

économe *n.m.* អគារូបដ្ឋាក ។ *a.* ដែលសំចៃ ឬ សន្សំ (ឧ. femme économe)

économie *n.f.* ការគ្រប់គ្រងចំណាយក្នុងផ្ទះ ឬ ក្នុងគ្រួសារ; ការសន្សំ, ការសំចៃ (ឧ. vivre avec économie) ។ économie de frais ការសំចៃសោហ៊ុយ ។ économie de temps ការសំចៃពេល ។ អ្វីៗដែលសំចៃបាន (ឧ. réaliser une économie de temps) ។

សេដ្ឋកិច្ច (ឧ. économie dirigée) ។ économie agricole ឬ rurale សេដ្ឋកិច្ចកសិកម្ម ជនបទ ។ économie domestique ឬ privée សេដ្ឋកិច្ចគ្រួសារឬឯកជន ។ économie industrielle សេដ្ឋកិច្ចឧស្សាហកម្ម ។ économie mixte សេដ្ឋកិច្ចចម្រុះ ។ économie sociale សេដ្ឋកិច្ចសង្គម ។ économie politique សេដ្ឋសាស្ត្រ ។

Fig. របៀប, សណ្ដាប់ធ្នាប់ (ឧ. économie d'une pièce de théâtre) ។ *Fam.* économie de bouts de chandelles

ការសំចៃកន្ទុយទៀន (ការសំចៃហួសពេក) ។ il n'y a pas de petites économies ការសំចៃទោះបីបន្តិចបន្តួចក៏សុទ្ធតែមានប្រយោជន៍ទាំងអស់។ *pl.* របស់ឬប្រាក់ដែលសំចៃទុក(ឧ. prendre sur ses économies)

économique *a.* នៃសេដ្ឋសាស្ត្រ (ឧ. problèmes économiques); ដែលឲ្យថយចំណាយ ឬ សោហ៊ុយ (ឧ. chauffage économique)

économiquement *adv.* ដោយសំចៃ (ឧ.vivre économiquement); ដោយសេដ្ឋកិច្ច ។ économiquement faible អ្នកសេដ្ឋកិច្ចទន់ខ្សោយ (អ្នកមានធនធានប្រើប្រាស់មិនគ្រប់គ្រាន់)

économiser *v.t.* សំចៃ, សន្សំ (ឧ. économiser son argent) ។ *Fig.* សំចៃ (ឧ. économiser son temps)

économiseur *n.m.* ប្រដាប់សំចៃ (ប្រដាប់សម្រាប់សំចៃឧស្ម័ន ប្រេងសាំង។ល។)

économiste *n.m.* អ្នកសេដ្ឋសាស្ត្រ

écopeឬ**escope** *n.f.* ស្នាចទឹក។écope à balancier ស្នាចជ្រោង

écoper *v.t.* បាចទឹកនឹងស្នាច(ឧ.écoper un bateau) ។ *v.i. Fam.* ត្រូវបន្ទោស, ទទួលទោស, ត្រូវគេវាយ

écoperche *n.f.* សសររន្ទា(ម.ព.escoperche ផង)

écorçage ឬ **écorcement** *n.m.* ការបកសំបក, ការស្ទោះ

écorce *n.f.* សំបក ។ *Géol.* écorce terrestre សំបកផែនដី (ស្រទាប់ខាងក្រៅ១០០គ.ម.ជាអតិបរិមាណ)។ *Fig.* សំបកក្រៅ, អាការៈក្រៅ

écorcer *v.t.* បកសំបក, ស្ទោះសំបក

écorceur *n.m.* កម្មករស្ទោះ ឬ បកសំបក

écorché *n.m.* រូបមនុស្ស ឬ សត្វដែលពន្លះស្បែក(ដើម្បីឲ្យឃើញសាច់-សរសៃ សន្លាក់ ឆ្អឹង ។ល។); គំនូរគ្រឿងក្នុងនៃម៉ាស៊ីនឬសំណង់ផ្សេងៗ

écorchement *n.m.* ការពន្លះស្បែក; ការធ្វើឲ្យរលាត់ស្បែក

écorcher *v.t.* ពន្លាត់ ឬ ពន្លះស្បែក (ឧ. écorcher une grenouille); ធ្វើឲ្យរលាត់ស្បែក (ឧ. elle s'est écorché la jambe) ។ *Fig.* ធ្វើឲ្យសង្កៀរ (ត្រចៀក) (ឧ. sa voix m'écorche les oreilles);កោរ (ឲ្យចេញប្រាក់ច្រើនពេក) (ឧ. écorcher un touriste); និយាយខុស

(ភាសា) (ឧ. écorcher le français)

écorcheur *n.m.* អ្នកពន្លាត់ ឬ ពន្លះស្បែក។ *Fig.* អ្នកកោរ (ឲ្យចេញប្រាក់ច្រើនពេក)

écorchure *n.f.* ស្នាមស្បែករលាត់; ស្នាមកន្ទួល

écorner *v.t* បំបាក់ស្នែង(ឧ. écorner un taureau); បង្ខូច-បំបាក់ឬកាច់ជ្រុង (ឧ. écorner un livre) ។ *Fig.* បំផ្លាញ (ឧ. écorner sa fortune)

écornifler *v.t.* ស៊ីឆ្នាញ់ដោយសារគេ; រកប្រាក់កាសដោយសារគេ

écornifleur,euse *n.* អ្នកស៊ីឆ្នាញ់ដោយសារគេ; អ្នករស់ដោយសារគេ

écornure *n.f.* ជ្រុងថ្ម ឬ ឥដ្ឋ

écossais,e *a.* នៃប្រទេសអេកុស្ស ។ *n.* ជនជាតិអេកុស្ស។ tissu écossais សំពត់ក្រឡាពណ៌

écosser *v.t.* បកសំបក(សណ្ដែកជាដើម)

écosseur,euse *a.&n.* អ្នកបកសំបក

écot *n.m.* ដើមឈើដែលលួសមែកចេញខ្លះ

écot *n.m.* ចំណែកដែលត្រូវចេញរៀងខ្លួន(ក្នុងការបរិភោគរួមគ្នា) (ឧ. payer son écot)

écoté,e *a* ដែលលួសមែកចេញខ្លះ

écoulement *n.m.* ការហូរ; ការលក់ទំនិញ (ឧ. marché sans écoulement)

écouler *v.t.* លក់ (ឧ. écouler des marchandises) ។ s'écouler *v.pr.* ហូរចេញ,ថយចេញ,ចេញ (ឧ. la foule s'écoule)។ *Fig.* កន្លងទៅ,បាត់បង់ទៅ (ឧ.le temps s'écoule vite)

écourter *v.t.* ច្រឹប, កាត់ឲ្យខ្លី (ឧ. écourter un manteau)។ *Fig.* បំប្រួញ, កាត់ឲ្យខ្លី (ឧ. écourter une citation)

écoute *n.f.* *Mar.* ខ្សែក្ដោង

écoute *n.f.* ការស្ដាប់; កន្លែងពួនស្ដាប់ (ឧ. poste d'écoute); ការស្ដាប់ (វិទ្យុ)(ឧ.se mettre à l'écoute)។ être à l'écoute ប្រុងស្ដាប់ ។ être aux écoutes ពួនឬឈ្លបចាំស្ដាប់ ។ table d'écoute កន្លែងឈ្លបចាំស្ដាប់ ។ ការសន្ទនាតាមទូរស័ព្ទរវាងឯកជន ។ *pl. n.* *Véner.* ត្រចៀកជ្រូកព្រៃ

écouter *v.t.* ស្ដាប់ (ឧ. écouter la

musique) ។ *Fig.* ស្ដាប់ (ធ្វើតាមពាក្យ) (ឧ. écouter une requête); ស្ដាប់ (គិតតាម,យកតាម) (ឧ. écouter les conseils d'un ami); ស្ដាប់ (បណ្ដោយតាម,ធ្វើតាម) (ឧ. n'écouter que son cœur)។ s'écouter *v.pr.* គិតតែពីយោបល់ឬពីសំដីខ្លួន;គិតគូរខាងសុខភាពខ្លួនខ្លាំងពេក។ s'écouter parler និយាយមួយៗហើយធ្វើគ្រាន់បើ (ហាក់ដូចជាចាំស្ដាប់សំដីខ្លួន)

écouteur,euse *n.* អ្នកលួចស្ដាប់ ។ *n.m.* ប្រដាប់ស្ដាប់ (ទូរស័ព្ទ)

écoutille *n.f. Mar.* សន្ទះល្វែងនាវា

écoutillon *n.m.* អំពោសឬប្រែងកន្ទុយកំប្រុក (អំពោសសំពត់សម្រាប់ពោសខ្ទេះបំពង់ភ្លើង; ព្រាសសំអាតរន្ធកាំភ្លើង)

écoutillonnage *n.m.* ការពោសដោយអំពោសឬប្រែងកន្ទុយកំប្រុក

écoutillonner *v.t.* ពោសដោយអំពោស ឬ ប្រែងកន្ទុយកំប្រុក

écrabouillage ឬ**écrabouillement** *n.m. Fam.* ការកិនបំបែក

écrabouiller *v.t. Fam.* កិនបំបែក

écran *n.m.* របាំង; ឡប់ឡែ; ប, ផ្ទាំងសំពត់សម្រាប់បញ្ចាំងកាពយន្ត ។ *Par ext.* កាពយន្ត (ឧ. les vedettes de l'écran)

écrasant,e *a.* ដែលសង្កត់, ដែលដាក់បន្ទុកធ្ងន់ទៅលើ(ឧ. charge écrasante)។ *Fig.* ដែលឲ្យរាបមុខឬឲ្យទាបហោក (ឧ. une écrasante défaite); ច្រើនលើសលុប (ឧ. force écrasante)

écrasement ឬ **écrasage** *n.m.* ការកិន-ញោចឬគាប

écraser *v.t.* កិនឬគាបបំបែក;ញោច;បុកកំទេច(ឧ. écraser du ricin dans le fouloir)។ *Par exag.* សង្កត់ ឬ គាប,ជាន់ (ឧ. écraser le pied de quelqu'un) ។ *Fig.* ផ្ចាញ់, បំផ្លាញ, កំទេច (ឧ. écraser l'ennemi); ដាក់បន្ទុកលើពន្ធធ្ងន់ (ឧ. écraser d'impôt); បង្អាប, ធ្វើឲ្យរាបមុខ(ឧ. écraser ses voisins par son luxe)

écraseur,euse *a.* ដែលសម្រាប់កិន។ *n.* អ្នកកិន

écrémage *n.m.* ការកេបយកក្រែមចេញពីទឹកដោះ

écrémer *v.t.* កេបយកក្រែមចេញពីទឹកដោះគោ ។ *Fig.* រើសសម្រាំង (ឧ.

écrémer une bibliothèque)

écrémeuse *n.f.* ម៉ាស៊ីនភិយយកក្រែមចេញពីទឹកដោះ

écrêtement *n.m. Mil.* ការបាញ់បំបាក់និមួលឬកំពូលកំពែង

écrêter *v.t.* កាត់សិរ; បាញ់បំបាក់និមួល ឬ កំពូលកំពែង

écrevisse *n.f.* កំពឹស, បង្កា

écrier (s') *v.pr.* ស្រែកថា (ឧ. «tout est perdu!», s'écria-t-il)

écrille *n.f.* ព្រួលទស់ខាំងត្រី (កុំឲ្យចេញពីបឹង)

écrin *n.m.* ប្រអប់ដាក់គ្រឿងមាសពេជ្រ

écrire *v.t.* សរសេរ,ចារ (ឧ. savoir écrire); និពន្ធ (ឧ. écrire un ouvrage); សរសេរសំបុត្រ (ឆ្លើយឆ្លងតាមសំបុត្រ) (ឧ. je lui écris que j'accepte); រះរាង; ចុះទុកសន្យាដោយលាយលក្ខអក្សរ (ឧ. la parole ne suffit point, il vous faut écrire) ។ *Fig.* មាន, ឃើញ (ឧ. sa honte est écrite sur son front); បង្ហាញ (ឧ. son sang sur la poussière écrivait mon devoir) ។

Loc.div. bien écrire សរសេរល្អ (សរសេរត្រឹមត្រូវ) ។ écrire de bonne encre ឬ de la bonne encre សរសេរពាក្យធ្ងន់ៗ; សរសេរតឹងៗ ឬ ច្បាស់ៗ ។ écrire à la diable សរសេរអក្សរព្រងេងព្រងាង; សរសេរហ៊ុសពេក; សរសេរខុសច្រើន ។ écrire des volumes និពន្ធសៀវភៅច្រើន ។ écrire à quelqu'un សរសេរទៅប្រាប់ឬទៅសួរយោបល់ ។ écrire comme un chat សរសេរអក្សរដូចជើងក្ដាម (ម.ព. chat ផង) ។ il est écrit ដែលសរប្រចហើយ, ដែលចៀសមិនរួច ។ c'était écrit នេះជាផលពីជាតិមុន (ចៀសមិនរួច) ។

Loc. prov. avoir une belle voix pour écrire et une belle main pour chanter មានសម្លេងឈ្លើយនឹងអក្សរអាក្រក់ ។

s'écrire *v.pr.* សរសេរឆ្លើយឆ្លងគ្នា; ត្រូវសរសេរ, ត្រូវដាក់ (ឧ. comment votre nom **s'écrit-il?**)

écrit *n.m.* អ្វីៗដែលសរសេរ; ក្រដាសដែលសរសេរហើយ (ឧ. tirer un écrit de sa poche); លិខិត, កិច្ចសញ្ញា

ជាលាយលក្ខអក្សរ(ឧ. entre gens d'honneur, une parole donnée vaut un écrit);វិញ្ញាសាសរសេរ (ក្នុងការប្រឡង) ។ *pl.* សៀវភៅ (ឧ. les écrits de Voltaire) ។

Loc.adv. par écrit ដោយលាយលក្ខអក្សរ (ដោយសរសេរ) (ឧ. mentionner par écrit) ។ coucher par écrit សរសេរ ។ preuve par écrit ភស្តុតាងជាលាយលក្ខអក្សរ

écriteau *n.m.* ក្ដារជ័យ,ក្ដារប្រកាស

écritoire *n.f.* ប្រដាប់ដាក់គ្រឿងសរសេរ

écriture *n.f.* ការសរសេរ (ឧ. la peinture des objets mêmes fut la première écriture); អក្សរ (ឧ. écriture difficile à lire; reconnaître l'écriture de quelqu'un); អក្សរផ្ចង់; បែបនិពន្ធ (ឧ. l'écriture artiste des Goncourt) ។

Pl. Comm. លេខា (សារលិខិតផ្សេងៗ; បញ្ជី) (ឧ. tenir les écritures)។ écritures publiques លិខិតជាផ្លូវការណ៍(លិខិតចេញពីអ្នកកាន់ការ)។

Relig. l'Ecriture **sainte** ឬ les Ecritures ឬ les **saintes** Ecritures គម្ពីរគ្រិស្តសាសនា ។

Loc. fam. entendre les Ecritures ប្រសប់,ឆ្លាត ។ concilier les Ecritures ផ្សំ ឬ តម្រូវវត្ថុខុសគ្នា ។

Prov. est un âne de nature, qui ne sait lire son écriture អ្នកអានអក្សរខ្លួនឯងមិនជាប់ជាមនុស្សល្ងើបំផុត

écrivailler *v.i. Fam.* និពន្ធដោយខ្ជីខ្ជា

écrivailleur *n.m. Fam.* អ្នកនិពន្ធសៀវភៅច្រើនប៉ុន្តែមិនចំណាន

écrivain *n.m.* គន្ថការ, អ្នកនិពន្ធ

écrivasser *v i. Fam.* សរសេរច្រើនហើយមិនត្រឹមត្រូវ

écrivassier,ère *n. Fam.* អ្នកចូលចិត្តសរសេរ; អ្នកសរសេរច្រើនហើយមិនត្រឹមត្រូវ

écrou *n.m.* ខ្ចៅកន្ទុយត្រី

écrou *n.m.* ការទទួលអ្នកទោសដាក់គុក។ levée d'écrou ការដោះលែងអ្នកទោស

écroue *n.f.* ស្បែកសត្វសម្រាប់សរសេរ; បញ្ជីអ្នកជាប់ពន្ធ (ក្នុងសម័យបូរាណ) ។

pl. les écroues de la maison du roi បញ្ជីចំណាយក្នុងព្រះរាជដំណាក់ (សម្រាប់ព្រះស្ងោយ)

écrouer *v.t.* ចុះក្នុងបញ្ជីគុក; ដាក់គុក (ឧ. écrouer un malfaiteur)

écrouir *v.t.* ដំដែកត្រជាក់

écrouissage *n.m.* ការដំដែកត្រជាក់ (ឧ.l'écrouissage d'un métal le durcit, mais le rend plus fragile)

écroulement *n.m.* ការរលំ ។ *Fig.* ការហិនហោច (ឧ.l'écroulement d'une fortune)

écrouler(s') *v.pr.* រលំ, ស្រុត ។ *Fig.* វិនាស (ឧ. empire qui s'écroule) ។ *Fig.* ដួលធ្ងន់

écroûter *v.t.* បកក្រមរ ឬ ក្តាំងចេញ

écru,e *a.* ដែលនៅជាធម្មជាតិ ។ soie écrue, fil écru សូត្រឆៅ, អំបោះឆៅ (មិនទាន់ប្រមោក) ។ toile écrue សំពត់មិនទាន់ជ្រលក់ស

ectoderme *n.m.* ម.ព. exoderme

ectropion *n.m.* ភាពត្របកភ្នែកត្រឡប់ឡើងលើ

écu *n.m.* ខែលបុរាណ; អេគុយ (រូបិយវត្ថុបុរាណធ្វើអំពីប្រាក់) ។ *pl.* ប្រាក់, ធនធាន (ឧ. cacher ses écus)

écubier *n.m.Mar.* ប្រហោងបោះយុថ្កា (ខាងក្បាលនាវា)

écueil *n.m.* ថ្មប៉ប្រះទឹក; ឧបសគ្គរាំងស្ទះ (សភាពដែលបណ្តាលឲ្យខូចកេរ្តិ៍ឈ្មោះ ឬ ឲ្យខាតបង់ប្រយោជន៍)

écuelle *n.f.* ចាន, ស្នូក (សម្រាប់ដាក់អាហារ); រង្វាល់ចាន

écuellée *n.f.* ចំណុះចាន ឬ ស្នូក

écuisser *v.t.* បំបែកដើមឈើ (ដោយកាប់រំលំ)

éculer *v.t.* ធ្វើឲ្យខូចកែងស្បែកជើង

écumage *n.m.* ការដួសពពុះចេញ

écumant,e *a.* ដែលបែកពពុះ (ឧ.mer écumante) ។ *Fig.* ពុះពោរ (ខឹងខ្លាំង) (ឧ. écumant de colère)

écume *n.f.* ពពុះ; ពពុះមាត់សត្វ, ញើសសេះ ។ *Fig.* ពួកជនថោកទាប (ឧ. l'écume de la société)

écumer *v.t.* ដួសពពុះ ។ *Fig.* écumer les mers ប្លន់តាមសមុទ្រ ។ *v.i.* បែកពពុះ (ឧ. le vin écume) ។ *Fig.* ខឹងប្រឡូក (ឧ. écumer de colère)

écumeur *n.m.* écumeur de mer ចោរប្លន់តាមសមុទ្រ

écumeux,euse *a.* ដែលមានពពុះពាសពេញ (ឧ. flot écumeux)

écumoire *n.f.* វែកគស្រង់, វែកឆ្វឹសពពុះ

écurage *n.m.* ការជម្រះ, ការសំអាត

écurer *v.t.* ជម្រះ, សំអាត, ស្អារ (ឧ. écurer un puits)

écureuil *n.m.* កំប្រុក

écureur,euse *n.* អ្នកជម្រះ ឬ សំអាត

écurie *n.f.* ក្រោលសេះ;សត្វមួយក្រោល

écusson *n.m.* សញ្ញាប័ន(គ្រឿងសំគាល់មុខការ)។ *Techn.* ដប្បារនូសោ ឬ ដប្បារនៃទ្វារ។ *Entom.* ក្រយៅគល់ស្លាបសត្វ ។ *Abor.* ភ្នែកឈើសម្រាប់បំពៅ

écussonnage *n.m.* ការបំពៅ (ឈើ)

écussonner *v.t.* បំពៅ (ឈើ) (ឧ. écussonner un rosier); ពាក់សញ្ញាប័ន (នៅសំលៀកបំពាក់ទាហាន)

écussonnoir *n.m.* កាំបិតបំពៅឈើ

écuyer *n.m.* អស្សាចារ្យ, អ្នកជិះសេះ; គ្រូបង្ហាត់ជិះសេះ ; អស្សកោវិទ, អ្នកជំនាញខាងជិះសេះ (ក្នុងល្បែងសៀក)

écuyère *n.f.* ស្ត្រីអ្នកជិះសេះ, ស្ត្រីអ្នកជំនាញខាងជិះសេះ (ក្នុងល្បែងសៀក)

eczéma *n.m.* ត្រអក(រោគស្បែកម្យ៉ាង)

eczémateux,euse *a.* នៃត្រអក។ *n.m.* អ្នកកើតត្រអក

Eden *n.m.* ឋានសួគ៌លើដី ។ *Fig.* éden របៀងស្ថាន

édénien,enne ឬ **édénique** *a.* នៃរបៀងស្ថាន(ឧ.période édénienne)

édenté,e *a.* ទិន្នន្ត, ដែលអស់ធ្មេញ (ឧ. vieillard édenté) ។ *n.m. pl.* ទិន្នន្តិក, ពួកសត្វឥតធ្មេញ

édenter *v.t.* កាច់ធ្មេញណារ ឬ ក្រាស់

édicter *v.t.* ប្រកាសឲ្យប្រើ

édicule *n.m.* សាលាសំណាក់

édifiant,e *a.* ដែលនាំឲ្យមានគុណធម៌ (ឧ. lecture édifiante)

édification *n.f.* ស្ថាបនកម្ម, ការសាង (ឧ.l'édification d'un temple); ការតាំង, ការក (ឧ. l'édification d'un empire)។ *Fig.* សប្បុរិសកម្ម (ឧ. une vie pleine d'édification)

édifice *n.m.* ភវន, មហាគ្រឹះ, ផ្ទះធំ ។ *Fig.* គ្រឹះស្ថានអប់រំ (ឧ. l'édifice social)

édifier *v.t.* ស្ថាបនា, សាង ។ *Fig.* តាំង (ឧ. édifier une théorie); នាំប្រព្រឹត្តល្អ (ដោយឲ្យគម្រាប់) (ឧ. édifier son prochain)។ *Par ext.* បង្ហាញ, ឲ្យការណ៍ (ឧ. il vous

a édifié sur mes intentions)

édit *n.m.* ច្បាប់រាជ, បញ្ញត្តិ ។-édit royal ព្រះរាជឱង្ការ

éditer *v.t.* បោះពុម្ពផ្សាយ

éditeur,trice *n.* អ្នកបោះពុម្ពផ្សាយ

édition *n.f.* ការបោះពុម្ពផ្សាយ; សរុបសៀវភៅដែលបោះពុម្ពក្នុងមួយលើក; សៀវភៅមួយក្បាលក្នុងចំណោមសៀវភៅដែលបោះពុម្ពមួយលើក(ឧ. je lis mon édition de Molière); ជំនួញសៀវភៅ (ឧ. travailler dans l'édition); សរុបកាសែតដែលបោះពុម្ពក្នុងមួយលើក(ឧ.édition spéciale)

éditorial,e,aux *a.* ដែលចេញពីទីជាត់ការសារពត៌មាន, ដែលសម្តែងយោបល់ទីជាត់ការសារពត៌មាន (ឧ. note éditoriale)។ *n.m.* វិចារណកថា

éditorialiste *n.* អ្នកនិពន្ធវិចារណកថា

édredon *n.m.* រោមទន់នៃសត្វស្លាប;ពូកញាត់រោមសត្វ

éducable *a.* អាចអប់រំបាន

éducateur,trice *n.* អ្នកអប់រំ

éducatif,ive *a.* នៃការអប់រំ (ឧ. méthode éducative)

éducation *n.f.* ការសិក្សា, ការប្រៀនប្រដៅ, ការអប់រំ (ឧ. l'éducation de la jeunesse); សុជីវធម៌ (ឧ. homme sans éducation); វិធីចិញ្ចឹមសត្វ (ឧ. éducation des abeilles) ។ maison d'éducation គ្រឹះស្ថានអប់រំ ។ éducation nationale ការអប់រំជាតិ ។ éducation physique កាយសិក្សា ។ éducation corporelle ការអប់រំខាងរាងកាយ ។ éducation intellectuelle ការអប់រំខាងប្រាជ្ញា ។ éducation morale ការអប់រំខាងផ្លូវចិត្ត ឬ ចរិយាសិក្សា ។ éducation pratique ការអប់រំខាងប្រតិបត្តិ

édulcoration *n.f.* ការបង់ស្ករ (ក្នុងឱសថឬម្ហូបល្វីង ឬ ចត់)

édulcorer *v.t.* បង់ស្ករ(ក្នុងឱសថឬម្ហូបល្វីងឬចត់)(ឧ. édulcorer une tisane);ប្រជាប់លាងឲ្យអស់ជាតិជូរ។ *Fig.* បន្ទន់, សម្រាល (ឧ. édulcorer un blâme)

éduquer *v.t.* *Fam.* អប់រំ, បង្ហាត់បង្រៀន

E.F.Ac. (Compte) (ពាក្យបំព្រួញនៃ Exportation, Frais géné-

raux Accessoires) (គណនី) ទី. គេភ.ប. (ទីហរ័ណ, គេហហ៊ុយទូទៅនឹងបន្ទាប់បន្សំ)

éfaufiler *v.t.* ហូតសរសៃសំពត់

effaçable *a.* អាចលុបបាន

effacement ឬ **effaçage** *n.m.* ការលុប; ការរលុប ។ *Fig.* ភាពបស់គេភ្លេច; ភាពជាត់ស្នាម (ឧ. l'effacement d'une faute); ភាពអ្នកលាក់មុខ

effacé,e *a.* ដែលលុបចោល, រលុប ។ *Fig.* ដែលលាក់មុខ, ស្ងាត

effacer *v.t.* លុប (ឧ. effacer des traces de crayon); លុបចោល, ឆូតចោល (ឧ.effacer un mot)។ *Fig.* បំភ្លេច (ឧ. effacer une faute); លើស, គ្រប (ឧ. elle efface les autres femmes par sa beauté) ។

S'effacer *v.pr.* រលុប ។ *Fig.* ជៀស (ឧ. s'effacer pour laisser entrer quelqu'un); លាក់មុខ; បង្អោនខ្លួនចំពោះមុខ (ឧ. s'effacer devant quelqu'un)

effaçure *n.f.* ស្នាមលុប

effaner *v.t.* ក្តិបព្រួយ (ឧ. effaner les blés)

effaneur, euse *n.* អ្នកក្តិបព្រួយ

effanures *n.f. p.l.* ស្លឹកដែលគេក្តិបចោល

effarant,e *a.* ដែលធ្វើឲ្យស្លន់ឬឲ្យភ័យ (ឧ. une histoire effarante)

effaré,e *a.* ដែលស្លន់, ស្រឡាំងកាំង (ឧ. un air effaré)

effarement *n.m.* ការស្លន់; ការភ័យ (ឧ.jeter dans l'effarement)

effarer *v.t.* ធ្វើឲ្យស្លន់, បំភ័យ

effarouchant,e *a.* ដែលធ្វើឲ្យផ្អើល ឬឲ្យសង្ស័យ

effarouchement *n.m.* ការធ្វើឲ្យផ្អើល; ភាពផ្អើល

effaroucher *v.t.* បផ្អើល, ធ្វើឲ្យរអើស (ឧ. effaroucher le gibier) ។ *Par ext.* បំភ័យ, បន្លាច (ឧ. effaroucher un candidat); ធ្វើឲ្យលែងទុកចិត្តឬឲ្យតូចចិត្ត

effectif,ive *a.* ដែលមានពិតៗ (ឧ. un capital effectif); ជាក់លាក់។ *n.m.* ចំនួនពិត (នៃទាហាន, អ្នកការងារ, កូនសិស្ស ។ល។)

effectivement *adv.* ដោយពិត

effectuer *v.t.* ធ្វើ, ប្រតិបត្តិ, បំពេញកិច្ច

(ឧ. effectuer un paiement បើកប្រាក់ឲ្យ)

effémination *n.f.* ការធ្វើឲ្យទន់ឬឲ្យខ្សោយដូចស្ត្រី; ភាពទន់ឬខ្សោយដូចស្ត្រី

efféminé,e *a.* នៃស្ត្រី; ទន់, លូកលៃ

efféminer *v.t.* ធ្វើឲ្យទន់ ឬ ឲ្យខ្សោយដូចស្ត្រី

efférent,e *a.* ដែលនាំចេញ

effervescence *n.f.* ការពុះខ្លាល (ឧ. chaux vive en effervescence)។ *Fig.* អភិចលតា, ការជ្រួលច្របល់ខ្លាំង (ឧ. effervescence populaire); ការជ្រួលចិត្ត (ឧ. l'effervescence des passions)

effervescent,e *a.* ដែលពុះខ្លាល ។ *Fig.* ដែលជ្រួលច្របល់ខ្លាំង

effet *n.m.* ផល (ឧ. il n'y a pas d'effet sans cause); សេចក្ដីសម្រេចផល (ឧ. en venir à l'effet); អំពើ (ឧ. il faut s'attacher aux effets et non aux paroles) ។ effet rétroactif ផលប្រតិកម្ម, អំពើមុនបញ្ញត្តិ (ឧ. aucune loi pénale ne peut avoir d'effet rétroactif)។ អានុភាព (ឧ. l'effet d'un remords; l'effet de la crainte; avoir le même effet qu'un contrat); ការស្ញែង (ឧ. viser à l'effet ឬ à faire de l'effet ប្រាថ្នាបញ្ចេញឲ្យគេស្ញែង); ការសំដែងអាការៈក្រៅ (ឧ. faire l'effet d'un homme vertueux ធ្វើឲ្យគេឃើញជាមនុស្សប្រកបដោយគុណធម៌)។ *Fam.* faire des effets de បញ្ចេញ (ចង់ឲ្យគេស្ញែង) (ឧ. faire des effets de linge, d'érudition, de main, de bras, de jambe) ។

Pl. ប្រដាប់ប្រើប្រាស់ (សម្រាប់មនុស្សម្នាក់)(ឧ. serrer ses effets dans une malle; effets de literie)។ *Partic.* សំលៀកបំពាក់ (ឧ. ménager ses effets) ។ *Fig.* ménager ses effets បញ្ចេញបន្តិចម្ដង (ទុករបស់ល្អជាងគេសម្រាប់បញ្ចេញក្រោយគេបង្អស់) ។

Com. ផលប័ត្រ (ឧ. souscrire, payer un effet) ។ effet au porteur ផលប័ត្រចំពោះគាហក [-ហ៊ក] (អ្នកកាន់)។ effet à payer ផលប័ត្រសម្រាប់បង់។ effet à recevoir ផលប័ត្រសម្រាប់ទទួល ។

effet de commerce ផលប័ត្រពាណិជ្ជ ។ effet de complaisance ផលប័ត្រអនុគ្រោះ ។ effets publics ផលប័ត្រសាធារណៈ(ផលប័ត្ររបស់រដ្ឋាភិបាល) ។

Dr. ធនធាន,ទ្រព្យ (ឧ. effets mobiliers, immobiliers; les effets d'une succession)។

Loc. div. pour cet effet, តាមដំណើរនេះ,ដើម្បីគោលបំណងនេះ។ à quel effet? ដើម្បីអ្វី?។ à l'effet de ដើម្បីនឹង។ plus de paroles que d'effets បានតែមាត់ទេ (ងាយមាត់ខាងសន្យាប៉ុន្តែមិនសូវប្រតិបត្តិតាម)។ *Pop.* effets de biceps ការសំដែងកម្លាំង ។ effets de poche ការចេញប្រាក់; ការបញ្ចេញប្រាក់សំដែង ។

en effet *loc. adv.* មែនទែន (ឧ. tous ceux qui sont en effet vertueux); ពិតមែន (ឧ. je n'aspire en effet qu'à l'honneur de vous suivre); ព្រោះ (ឧ. il ne mérite aucune récompense, en effet il n'a pas travaillé)

effeuillage *n.m.* ការបេះស្លឹក

effeuillaison *n.f.* រដូវជ្រុះស្លឹក;ដំណើរជ្រុះស្លឹក

effeuillement *n.m.* ដំណើរជ្រុះស្លឹក; ភាពដើមឈើជ្រុះស្លឹកអស់

effeuiller *v.t.* បេះស្លឹក(ឧ. effeuiller un arbre); បេះត្របកផ្កា (ឧ. effeuiller des roses) ។ s'effeuiller *v.pr.* ជ្រុះស្លឹក,រោយ(ផ្កា)

efficace *a.* ស័ក្តិសិទ្ធិ,ធុត(ឧ.remède efficace)។ *n.f.* ភាពស័ក្តិសិទ្ធិឬធុត

efficacement *adv.* យ៉ាងស័ក្តិសិទ្ធិ

efficacité *n.f.* ភាពស័ក្តិសិទ្ធិ,ប្រសិទ្ធិភាព(ឧ.efficacité d'un moyen)

efficience *n.f.* ការអាចឲ្យផលខ្លះ;ការឲ្យផលតាមចិត្ត (ឧ. l'efficience d'une technique, d'une entreprise)

efficient,e *a.* ជាដើមហេតុ(ឧ.le soleil est la cause efficiente de la chaleur); ដែលបានលទ្ធផលល្អ; ដែលមានសមត្ថភាព(ឧ.homme efficient)

effigie *n.f.* បដិរូប(រូបសំណាក ឧ.prendre quelqu'un en effigie; រូបបុរស លើរូបិយវត្ថុ ឬមេដាយ ឧ.

monnaie à l'effigie de Sa Majesté Norodom) -

effilage *n.m.* ការហូតសរសៃសំពត់

effilé,e *a.* ឆ្មារ,ស្ដើងហើយវែង(ឧ.taille effilée)។ *n.m.* រំយោលសំពត់

effilement *n.m.* ការហូតសរសៃសំពត់

effiler *v.t.* ហូតសរសៃសំពត់។ *Chass.* effiler les chiens ធ្វើឲ្យឆ្កែហត់

effilochage *n.m.* ការរុះសរសៃអំបោះ

effiloche ឬ **effiloque** *n.f.* ព្រែស្ដើងដែលគេទុកចោល; រងជើងសំពត់ព្រែ

effilochement *n.m.* ការរុះសរសៃអំបោះ

effilocher *v.t.* រុះសរសៃអំបោះ។ s'effilocher *v.pr.* រសាត់ (រឹមសំពត់)

effilocheur,euse ឬ **effileur,euse** *n.* អ្នករុះសរសៃសំពត់ (សម្រាប់ធ្វើក្រដាស)។ *n.f.* ម៉ាស៊ីនរុះសរសៃសំពត់

effilochure ឬ **effilure** *n.f.* កប្បាស ឬ សូត្របានមកអំពីការរុះសរសៃ

efflanqué,e *a.* ស្គមកំព្រឹង (ឧ.cheval efflanqué)។ *Fig.* សោះកក្រោះ

efflanquer *v.t.* ធ្វើឲ្យស្គម

effleurage *n.m.* ការចាប់សរសៃ ឬ ប្រដាប់ (ដោយដៃស្រាលៗ)

effleurement ឬ **effleurage** *n.m.* ការឆូត; ការស្ទាប ឬ ប៉ះសើរៗ

effleurer *v.t.* ស្ទាបសើរៗ(ឧ.effleurer le visage); ឆូតសើរៗ(ឧ. effleurer la peau)។ *Fig.* ពិនិត្យដោយស្រួសៗ (ឧ.effleurer une question)

effleurir *v.i.* ឬ **s'effleurir** *v.pr.* *Chim. &Minér.* ឡើងផុស(ក្លាយទៅជាផង់) (ឧ. certains sels s'effleurissent à l'air) ។ s'effleurir *v.pr.* ចាប់មានផ្កា

effloraison *n.f.* ដំណើរមានផ្កា

efflorescence *n.f.* *Bot.* ម្សៅសើសំបកផ្លែឈើ ។ *Hort.* បុប្ផារម្ភកាល, ដើមរដូវផ្កា ។ *Par ext.* ការចំរើន (ឧ. l'efflorescence de l'art gothique) ។ *Pathol.* ការកើតជម្ងឺសើស្បែក

efflorescence *n.f.* *Chim &Minér.* ដំណើរឡើងផុស (ដំណើរក្លាយជាផង់)

efflorescent,e *a.* ដែលផិតផ្កា

effluent,e *a.* ដែលផុសចេញ (ទឹកដែលចេញពីក្នុងដី) ។ *n.m.* ទឹកផុស (ឧ.les effluents d'une fosse)

effluve *n.f.* ក្លិនកាយពីមនុស្ស ឬ សត្វ

(ឧ. effluves odorantes)

effondrement *n.m.* ការជីកគាស់ដី; ការស្រុត ។ *Fig.* ការវិនាស (ឧ. l'effondrement d'une fortune); ដំណើរចុះភ្លាមៗ (ឧ. l'effondrement des cours)

effondré,e *a.* ស្រយុតស្រយង់ (ឧ. depuis qu'il a appris cette nouvelle, il est effondré)

effondrer *v.t.* ជីកគាស់ដី (ឧ. effondrer un sol pierreux); បំបែក, ទម្លាយ (ឧ. effondrer un coffre); សម្រុត (ឧ. effondrer un plancher) ។ s'effondrer *v.pr.* រលំ, ខ្ទប, ស្រុត (ឧ. plancher qui s'effondre; projets qui s'effondrent)

effondrilles *n.f.pl.* កាក (ដែលនៅបាតឆ្នាំង) (ឧ. les effondrilles du bouillon)

efforcer (s') (de ឬ à) *v.pr.* ខំប្រឹង, ខ្នះខ្នែង (ឧ. s'efforcer de travailler; s'efforcer à plaire)

effort *n.m.* ការខំប្រឹង (ឧ. faire un effort pour soulever un fardeau; un effort de mémoire)

effraction *n.f.* ការទម្លុះទម្លាយដើម្បីលួច (ឧ. le vol avec effraction est qualifié de crime)

effraie *n.f.* មៀម

effrangement *n.m.* ការហូតដាយសំពត់ធ្វើរំយោល; ដំណើរដាច់ជារំយោល

effranger *v.t.* ហូតដាយសំពត់ធ្វើរំយោល ។ s'effranger *v.pr.* ដាច់ជារំយោល

effrayant,e *a.* គួរឲ្យខ្លាច (ឧ. un bruit effrayant) ។ *Fam.* សំបើម (ឧ. un appétit effrayant)

effrayer *v.t.* ធ្វើឲ្យខ្លាច, បន្លាច (ឧ. ce silence a effrayé tout le monde; l'importance du travail effraie quelquefois) ។ s'effrayer *v.pr.* ខ្លាច

effréné,e *a.* គ្មានទំនប់, គ្មានគ្រឿងឃាត់, ហួសពេក (ឧ. audace effrénée)

effritement *n.m.* ការកំទេចជាធូលី, ភាពបែកជាធូលី ។ *Fig.* ការបែកខ្ញែក (ឧ. effritement des voix de la majorité)

effriter *v.t.* កំទេចជាធូលី, ធ្វើឲ្យផុយ (ឧ. le gel effrite les roches

les plus dures) ។ s'effriter *v.pr.* របេះជាធូលី (ឧ. les bas-reliefs qui s'effritent)។ *Fig.* បែកខ្ញែក, រលាយ (ឧ. la majorité gouvernementale s'est effritée)

effroi *n.m.* ភ័យរន្ធត់ (ឧ. répandre l'effroi);មនុស្សឬវត្ថុដែលធ្វើឲ្យគេខ្លាច

effronté,e *n.&a.* គឃ្លើន

effrontément *adv.* យ៉ាងគឃ្លើន

effronterie *n.f.* ភាពគឃ្លើន

effroyable *a.* ដែលឲ្យភ័យខ្លាំងឬឲ្យខ្លាចខ្លាំង ។ *Fig.* អាក្រក់ណាស់ (ឧ. visage effroyable); សំបើម

effusion *n.f.* ការបង្ហូរ (ឧ. grande effusion de sang dans un combat) ។ *Fig.* ការសំដែង ឬ បញ្ចេញមនោសញ្ចេតនា(ឧ.effusion de tendresse)

éfourceau *n.m.* រទេះដឹកឈើ

égaiement *n.m.* ការធ្វើឲ្យសប្បាយ

égailler (s') *v.pr.* បែកខ្ញែកគ្នា

égal,e,aux *a.* ដូច, ស្មើ, ប៉ុន(ឧ. deux quantités égales à une même troisième sont égales entre elles); នឹង, ស្មើ(ដែលមិនប្រែប្រួល)(ឧ. température égale); ដែលមានចិត្តនឹង;រាបស្មើ(ឧ.chemin égal) ។ cela m'est égal មិនអ្វីទេ; ដូចម្ដេចក៏បាន ។

n. សមជន, អ្នកមានសក្ដិស្មើគ្នា (ឧ. vivre avec des égaux) ។ n'avoir point d'égal ឬ être sans égal គ្មានអ្នកណាស្មើ, គ្មានអ្នកណាប្រៀបបាន ។ n'avoir d'égal que គ្មានអ្វីប្រៀបបានក្រៅអំពី (ឧ. sa fatuité n'a d'égal que sa sottise) ។ égal à ត្រូវជា ។ à l'égal de *loc. pré.* ប្រហែលនឹង, ស្មើនឹង

égalable *a.* អាចធ្វើឲ្យស្មើបាន

également *adv.* យ៉ាងស្មើគ្នា (ឧ. aimer également tous ses enfants); ដែរ (ឧ. vous l'avez vu, je viens de le voir également)

également *n.m.* ការចែកបន្ថែមឲ្យស្មើ (ក្នុងការចែកមរតក)

égaler *v.t.* មានចំនួនឬមានទំហំប៉ុនឬស្មើនឹង (ឧ. la recette égale la dépense);ត្រូវជា(ឧ. deux multiplié par deux égale qua-

tre); ធ្វើឲ្យស្មើ (ឧ. la mort égale tous les hommes); ប្រៀបផ្ទឹម (ឧ. le talent ne saurait égaler la vertu); ទុកជាស្មើគ្នា (ឧ. égaler Racine et Corneille)

égalisation *n.f.* សមកម្ម [សៈ-មៈ—] (ការធ្វើឲ្យស្មើ, ការធ្វើឲ្យរាប)

égaliser *v.t.* ធ្វើឲ្យស្មើ (ឧ. égaliser les lots); ពង្រាប (ឧ. égaliser un terrain)

égalitaire *a.* អ្នកសមភាពនិយម (ដែលប្រាថ្នាសមភាពខាងផ្នែកពលរដ្ឋ - ផ្នែកនយោបាយនឹងផ្នែកសង្គមកិច្ច)

égalitarisme *n.m.* សមភាពនិយម

égalité *n. f.* សមភាព, ភាពស្មើដូចគ្នា (ឧ. égalité politique, civile); ភាពប៉ុនគ្នា ឬ ស្មើគ្នា (ឧ. égalité de deux nombres); ភាពរាបស្មើ (ឧ. égalité du terrain); ភាពចិត្តនឹង (ឧ. égalité d'humeur)

égard *n.m.* មាននភាព [មា-នន់-នៈ—], សេចក្ដីរាប់អាន, សេចក្ដីគោរព (ឧ. il faut avoir égard au mérite des personnes; témoigner de grands égards à quelqu'un)។ avoir égard រាប់អាន។ eu égard à *loc. pré.* ដោយយល់ដល់ (ឧ. eu égard à son âge)។ à l'égard de *loc. pré.* ចំពោះ (ឧ. à l'égard de ses amis)។ sans égard pour ឥតយល់ដល់។ *Loc. adv.* à cet égard ក្នុងចំណុចនេះ, ខាងផ្លូវនេះ។ à tous les égards ឬ à tous égards គ្រប់ចំណុច, គ្រប់ផ្លូវ

égaré,e *a.* មមិងមមាំង (ឧ. un air égaré); ដែលវង្វេង

égarement *n.m.* មោហៈ ឬ មោហ៍, ការវង្វេង (ឧ. les égarements de la raison)។ *Fig.* ការកាន់ច្រឡំ; ការប្រព្រឹត្តខុសសីលធម៌ (ឧ. les égarements de la jeunesse); ភាពស្រឡាំងកាំង; ការមើលមាយ

égarer *v.t.* ធ្វើឲ្យវង្វេងផ្លូវ (ឧ. une indication inexacte égare le touriste); វង្វេងដៃ (ឧ. égarer ses lunettes)។ *Fig.* ធ្វើឲ្យវង្វេង; នាំឲ្យប្រព្រឹត្តខុស (ឧ. les mauvais exemples égarent la jeunesse); ធ្វើឲ្យភាំងស្មារតី (ឧ. égarer les esprits)។ s'égarer *v.pr.* វង្វេង; កាន់ច្រឡំ

égayant,e *a.* ដែលធ្វើឲ្យសប្បាយ (ឧ. récits égayants)

égayer *v.t.* ធ្វើឲ្យសប្បាយ;តាក់តែងលំអ (ឧ. égayer un appartement)

égérie *n.f.* ស្ត្រីអ្នកឲ្យឱវាទដោយសម្ងាត់

égermage *n.m.* ការក្ដិចដីភក្លួពោល (ក្ដិចពន្លកគ្រាប់)

égermer *v.t.* ក្ដិចដីភក្លួពោល (ក្ដិចពន្លកគ្រាប់)

égide *n.f.* *Myth.* ខែលរបស់ប៉ុល្លាស់ (ទេវតាខាងសង្គ្រាម) ។ *Fig.* ការឧបត្ថម្ភ, ការគាំទ្រ (ឧ. se mettre sous l'égide de quelqu'un)

église *n.f.* គណៈសង្ឃនៃសាសនាគ្រិស្ត; វិហារកាតូលិក (ឧ. le clocher d'une église)

égo- altruisme *n.m.* អត្តបរទត្ថនិយម (ទ្រឹស្ដីនិយមថាគួរគិតប្រយោជន៍ផ្ទាល់ខ្លួនផង ប្រយោជន៍អ្នកដទៃផង ព្រោះសុភមង្គលរបស់យើង ទាក់ទងនឹងសុភមង្គលអ្នកដទៃ)

égocentrique *a.* មជ្ឈត្តិកៈ[ម៉ុជ-ឈ័ត-តិ-កៈ](ដែលគិតថាខ្លួនជាដើមក្នុងលោក)

égocentrisme *n.m.* មជ្ឈត្តនិយម [ម៉ុជ - ឈ័ត - តៈ—]

égoïsme *n.m.* អត្តទត្ថភាព, ភាពអ្នកគិតតែខ្លួនឯង

égoïste *a.&n.* អត្តទត្ថបុគ្គល, ដែលគិតតែខ្លួនឯង

égoïstement *adv.* ដោយអត្តទត្ថភាព

égorgement *n.m.* ការអារក; ការសម្លាប់

égorger *v.t.* អារក; សម្លាប់ ។ *Fig.* ធ្វើបាប; បង្ខិតបង្ខំ; លក់អារក (លក់ថ្លៃពេក) (ឧ. hôtelier qui égorge ses clients)

égorgeur *n.m.* អ្នកអារក; អ្នកសម្លាប់

égosiller (s') *v.pr.* ស្រែកខ្លាំងហើយបង្អូស

égotisme *n.m.* អហង្ការនិយម

égotiste *a.&n.* អ្នកអហង្ការនិយម

égout *n.m.* ការសម្រក់ទឹក; ទឹកដែលស្រក់; រងស្បូវ; ជំរាលដំបូល ។ *Par ext.* រងទឹក; លូទឹកស្អុយ (ឧ. les égouts de Phnom-Penh) ។ tout - à - l'égout របៀបបង្ហូរទឹកកខ្វក់ពីផ្ទះឯកជនចូលក្នុងលូទឹកស្អុយ ។ *Fig.* កន្លែងប្រជុំមនុស្ស ឬរបស់មិនបរិសុទ្ធ

égouttier *n.m.* អ្នកថែលូទឹកស្អុយ

égouttage ឬ **égouttement** *n.m.* ការពូត;ការសម្រក់ទឹក, ការធ្វើឲ្យស្ងួតដី

égouttement *n.m.* ការពូត;ការសម្រក់ទឹក; ដំណើរស្រក់ទឹក

égoutter *v.t.* ពូត (ឧ. égoutter du linge); សម្ងួត (ឧ. égoutter la vaisselle) ។ *Fig.* សម្រក់ទឹក ។ *Agr.* បង្ហូរទឹកចេញ (ឲ្យស្ងួតដី) ។ s'égoutter *v.pr.* ឡើងស្ងួត; ស្រក់តក់ៗ

égouttis *n.m.* ម.ព. égouttement

égouttoir *n.m.* ប្រដាប់សម្រក់ទឹក

égoutture *n.f.* ទឹកដែលស្រក់ (អំពីរបស់អ្វីមួយ)

égrainer *v.t.* ម.ព. égrener

égrappage *n.m.* ការប្រលេះផ្លែឈើ

égrapper ឬ **égrappiller** *v.t.* ប្រលេះផ្លែឈើ (ពីស្នែង ឬ ពីចង្កោម) (ឧ. égrapper des raisins)

égrappoir *n.m.* ប្រដាប់ប្រលេះផ្លែទំពាំងបាយជូរ

égratigner *v.t.* ធ្វើឲ្យរលាត់ស្បែក; កោស (ឧ. égratigner un meuble); ខ្វាច ។ *Fig.* ធ្វើឲ្យអន់ចិត្តបន្តិចបន្តួច (ឧ. prendre plaisir à égratigner ses camarades)

égratigneur, euse *a.* ដែលធ្វើឲ្យរលាត់ស្បែក,ដែលកោស ឬ ខ្វាច

égratignure *n.f.* ស្នាមរលាត់ស្បែក; ស្នាមកោស ឬ ខ្វាច ។ *Fig.* ដំណើរអន់ចិត្តបន្តិចបន្តួច

égravillonner *v.t.* បេះដីចេញពីឫសដើមឈើដែលគេដាំកន្លែងថ្មី

égrenage ឬ **égrainage** *n.m.* ការប្រលេះគ្រាប់

égrenerឬ**égrainer** *v.t.* ប្រលេះគ្រាប់; égrener le coton បោះកប្បាស (ប្រលេះគ្រាប់កប្បាសចេញពីសំឡី) ។ égrener un chapelet ប្រលេះគ្រាប់ផ្គាំ (រាប់មេធម៌) ។ s'égrener *v.pr.* ដង្ហែគ្នាជាជួរ (ឧ. les passants s'égrenaient le long de l'avenue)

égreneuse *n.f.* ម៉ាស៊ីនប្រលេះគ្រាប់

égrillard,e *a.* សប្បាយណាស់

égrisage *n.m.* ការជុសខាត់ត្បូង

égrisée *n.f.* ផង់ពេជ្រសម្រាប់ខាត់ត្បូង

égriser *v.t.* ជុសខាត់ត្បូង

égrotant,e *a.* ឈឺច្រើន

égrugeage *n.m.* ការបុកឲ្យម៉ដ្ឋ

égrugeoir *n.m.*ត្បាល់បុក

égruger *v.t.* បុកឲ្យម៉ដ្ឋ

égueulé,e *a.* *Géogr.* cratère égueulé មាត់ភ្នំភ្លើងដែប (ដោយភ្នំ

ភ្លើងផ្ទុះខ្លាំងពេក)

égueulement *n.m.* ដំណើរបែបមាត់ (មាត់ប្រែកាំភ្លើង មាត់ជើងធាជើង)

égueuler *v.t.* ធ្វើឲ្យបែបមាត់ (មាត់ប្រែកាំភ្លើង មាត់ជើងធាជើង)

égyptien,enne *a.* នៃប្រទេសអេហ្ស៊ីប។ *n.* ជនជាតិអេហ្ស៊ីប

égyptologie *n.f.* ការសិក្សាប្រទេសអេហ្ស៊ីបសម័យបុរាណ

égyptologue *n.* អ្នកសិក្សាប្រទេសអេ-ហ្ស៊ីបសម័យបុរាណ

eh ! *int.* ហើ! (ឧ. eh! vous voilà!; eh! que c'est beau) ។ eh bien! ម.ព. bien

éhonté,e *n.&a.* ដែលឥតខ្មាស (ឧ. voleur éhonté)

eider *n.m.* ទាមួយយ៉ាង

éjaculation *n.f.* ដំណើរបាញ់ចេញពីក្នុងខ្លួន (ដូចទឹកកាមជាដើម)។ *Par ext.* ការបញ្ចេញពន្លឺ; ការផ្ទុះនៃភ្នំភ្លើង; ការបាញ់។ *Ascét.* ការការពារយ៉ាងខ្លាំងក្លា

éjaculer *v.t.* បាញ់ចេញពីក្នុងខ្លួន (ដូចទឹកកាមជាដើម)

éjectable *a.* អាចផ្ងាត់ចេញបាន ។ siège éjectable កៅអីផ្ងាត់ចេញបាន (កៅអីយន្តហោះ អាចផ្ងាត់ចេញបាននៅពេលអាសន្ន)

éjecter *v.t.* ផ្ងាត់ចេញ; បាញ់ចេញ

éjecteur *n.m.* ប្រដាប់បាញ់ទឹក; ប្រដាប់ផ្ងាត់ឡុតគ្រាប់កាំភ្លើងចេញ ។ *a.* tuyau éjecteur បំពង់បាញ់ទឹក

éjection *n.f.* ការផ្ងាត់ចេញ; ការព្រួសធាតុចេញពីភ្នំភ្លើង ។ *Physiol.* ការបន្ទោបង់ (ឧ. l'éjection de l'urine)

éjointer *v.t.* កាត់ចុងស្លាបសត្វ (ឧ. éjointer un canard)

élaboration *n.f.* របិតកម្ម [រះ-បិ-តះ—] (ការតាក់តែង; ការតែង; ការធ្វើ; កិច្ចការដែលធ្វើជាលំដាប់; ការធ្វើឲ្យជ្រួតជ្រាបបាន) (ឧ. l'élaboration de la sève ។ *Fig.* élaboration d'un plan, d'un système)

élaboré,e *a.* របិត។ sève élaborée រុក្ខរសរបិត

élaborer *v.t.* របិត(ធ្វើឲ្យជ្រួតជ្រាបបាន) (ឧ. l'estomac élabore les aliments)។ *Fig.* រៀបចំ,តាក់តែង (ឧ. élaborer un projet de loi)

élagage *n.m.* ការលះមែកចោល (ឧ. l'élagage assure la crois-

sance des arbres)

élaguer *v.t.* លះមែកឥតប្រយោជន៍ចោល។ *Fig.* កាត់កាឥតប្រយោជន៍ចេញ (សៀវភៅ)

élagueur *n.m.* អ្នកលះមែកឈើ;កាំបិតលះមែកឈើ

élaïomètre *n.m.* ប្រដាប់ស្ទង់ប្រេង (ដើម្បីឲ្យដឹងជាសុទ្ធ ឬ មិនសុទ្ធ)

élan *n.m.* ជំនះ; សំទុះ (ឧ. prendre son élan);កំឡាំងដែលស្ទុះ; ទំហឹង; ការលោត; សំទុះលោត។ *Fig.* សំទុះចិត្ត (ឧ. les élans du cœur)

élan *n.m.* អេឡង់ (សត្វពួកក្តាន់នៅប្រទេសត្រជាក់)

élancé,e *a.* លលៃ, ស្រាវ, ខ្ពស់ស្រឡះ

élancement *n.m.* ដំណើរឈឺចាប់កើតខ្ទួលៗ ។ *Fig.* ការចាប់ចិត្តខ្លាំង

élancer *v.t.* ចោះ, ចោល ។ *v.i.* ធ្វើឲ្យកើតខ្ទួលៗ (ឧ. le doigt m'élance) ។ s'élancer *v.pr.* លោតស្ទុះទៅ

élargir *v.t.* ពង្រីក, ភិត (ឧ. élargir une route); ដោះលែងពីគុក (ឧ. élargir un détenu) ។ *Fig.* ពង្រីក (ឧ. élargir le cercle de ses connaissances ; les voyages élargissent l'intelligence)

élargissement *n.m.* ការពង្រីក; ការដោះលែង (ឧ. élargissement d'un prisonnier) ។ ordre d'élargissement ដីកាបង្គាប់ឲ្យដោះខ្លួន

élargissure *n.f.* ភាគប៉ះបន្ថែមដើម្បីឲ្យបានធំ (គុទ្ធ, សំលៀកបំពាក់)

élasticité *n.f.* ភាពយឺត(ដូចកៅស៊ូ) ។ *Par ext.* ភាពទន់ភ្លន់ (ឧ. élasticité des membres); ភាពមិនតឹងរ៉ឹង(ឧ.élasticité d'une morale)

élastique *a.* យឺត (ដូចកៅស៊ូ) ។ *Fig.* ទន់ភ្លន់; មិនតឹងរ៉ឹង (ឧ. avoir une conscience élastique); ដែលអាចប្រែប្រួលបាន។ gomme élastique ម.ព. gomme ។ *n.m.* កៅស៊ូ, ខ្សែយឺត

élavé,e *a.* ព្រលែត (ឧ. chien au poil élavé)

eldorado *n.m.Par ext.* រមណីយដ្ឋាន, ទីសប្បាយ

électeur,trice *n.* អ្នកមានសិទ្ធិបោះឆ្នោត ។ *a.* ដែលមានសិទ្ធិជ្រើសតាំង

électif,ive *a.* ដែលគេជ្រើសតាំង (ឧ.

président électif; charge élective); ដែលគេជ្រើស (ឧ. les affinités électives)

élection *n.f.* ការបោះឆ្នោត (ឧ. élection au suffrage universel); ការជ្រើសតាំង ។ élection de domicile ការតាំងលំនៅ

électivité *n.f.* ភាពត្រូវគេជ្រើសតាំង (ឧ. l'électivité d'un président)

électoral,e,aux *a.* នៃការបោះឆ្នោត។ collège électoral ម. ព. collège

électorat *n.m.* សិទ្ធិបោះឆ្នោត

électricien,enne *n.&a.* ដែលចេះគ្រឿងអគ្គិសនី (ឧ. ouvrier électricien ជាងអគ្គិសនី)

électricité *n.f.* អគ្គិសនី ។ électricité positive អគ្គិសនីវិជ្ជមាន ។ électricité négative អគ្គិសនីអវិជ្ជមាន

électrification *n.f.* អគ្គិសនីកម្ម (ការប្រើឬការដាក់អគ្គិសនី)

électrifié,e *a.* ដែលមានអគ្គិសនី (ឧ. ligne électrifiée)

électrifier *v.t.* ធ្វើអគ្គិសនីកម្ម, ដាក់អគ្គិសនី(ដាក់ឲ្យដើរដោយចរន្តអគ្គិសនី) (ឧ. électrifier une ligne de chemin de fer)

électrique *a.* នៃអគ្គិសនី (ឧ.courant électrique);ដែលដើរដោយអគ្គិសនី (ឧ. fer électrique)។ *Fig.* ដែលផ្សាយយ៉ាងរហ័ស

électriquement *adv.* ដោយអគ្គិសនី (ឧ. horloge mue électriquement)

électrisable *a.* អាចបញ្ចូលអគ្គិសនីបាន (ឧ. la résine est facilement électrisable)

électrisant,e *a.* ដែលបញ្ចូលអគ្គិសនី។ *Fig.* ដែលសម្រើប

électrisation *n.f.* ការឬរបៀបបញ្ចូលអគ្គិសនី

électrisé,e *a.* *Fig.* ដែលស្រើប

électriser *v.t.* បញ្ចូលអគ្គិសនី ។ *Fig.* សម្រើប; ធ្វើឲ្យក្លៀវក្លា (ឧ. électriser une assemblée par la parole)

électro-aimant *n.m.* មេដែកសម្រាប់បញ្ចូលអគ្គិសនី (ឧ. l'électro-aimant sert à la production des champs magnétiques) (*pl*, des électro-aimants)

électrocardiogramme *n.m.* អគ្គិសនីហឫទយលេខ

électrocardiographe *n.m.* អគ្គិសនីហឫទយបរិគាន

électrocardiographie *n.f.* អគ្គិសនីហឫទយលេខសាស្ត្រ

électrocautère *n.m.Méd.* ដែកអាលអគ្គិសនី

électrochimie *n.f.* អគ្គិសនីគីមី

électrochimique *a.* នៃអគ្គិសនីគីមី

électrochoc *n.m. Méd.* ការព្យាបាលជម្ងឺឆ្កួតដោយអគ្គិសនី

électrocuter *v.t.* សម្លាប់ដោយអគ្គិសនី

électrocuteur,trice *a.* ដែលសម្លាប់ដោយអគ្គិសនី (ឧ. courant électrocuteur)

électrocution *n.f.* ការស្លាប់ដោយអគ្គិសនី(ឧ. aux Etats Unis, on exécute, dans certains Etats, les condamnés à mort par électrocution sur la chaise électrique)

électrode *n.f.* អសនីបថ។ électrode positive អសនីបថវិជ្ជមាន ។ électrode négative អសនីបថអវិជ្ជមាន

électrodiagnostic *n.m.* អគ្គិសនីរោគវិនិច្ឆ័យ (ការវិនិច្ឆ័យរោគដោយចរន្តអគ្គិសនី)

électrodynamique *n.f.* អគ្គិសនីថាមកប្បនា

électrodynamomètre *n.m.* អគ្គិសនីថាមមាត្រ

électrogène *a.&n.* ដែលបង្កើតអគ្គិសនី (ឧ. l'appareil électrogène du gymnote)

électrolysable *a.* អាចធ្វើអគ្គិសនីវិភាគបាន

électrolyse *n.f.* អគ្គិសនីវិភាគ, ការបំបែកធាតុដោយអគ្គិសនី (ឧ. on prépare l'aluminium par électrolyse de l'alumine)

électrolyser *v.t.* ធ្វើអគ្គិសនីវិភាគ, បំបែកធាតុដោយអគ្គិសនី

électrolyseur *n.m.* ប្រដាប់ធ្វើអគ្គិសនីវិភាគ

électrolyte *n.m.* វត្ថុដែលធ្វើអគ្គិសនីវិភាគបាន

électrolytique *a.* ដោយអគ្គិសនីវិភាគ (ឧ. décomposition électrolytique)

électromagnétique *a.* អសនីចុម្ពក (ឧ.force électromagnétique)

électromagnétisme *n.m.* អសនី-ចុម្ពិត

électromécanicien *a.&n.m.* ជាង អគ្គិសនីយន្ត

électromécanique *a.* នៃអគ្គិសនី-យន្ត។ *n.f.* អគ្គិសនីយន្តសាស្ត្រ

électrométallurgie *n.f.* អគ្គិសនី-លោហុស្សាហកម្ម

électromètre *n.m.* អគ្គិសនីមាត្រ

électrométrie *n.f.* អគ្គិសនីមាត្រវិធី

électromoteur,trice *a.* អគ្គិសនី-ចលករ, ដែលបង្កើតអគ្គិសនីដោយអំពើគីមីឬអំពើយន្ត ។ force électromotrice (ដាក់បំប្រួញជា f.é.m.) ពលអគ្គិសនីចលករ។ *n.m.* អគ្គិសនី-ចលករ

électron *n.m.* អសនត្រាណូ [អៈ-សៈ-នត្រ៉ា-ណូ]

électronicien *n.m.* អសនត្រាណូវិទូ

électronique *a.* នៃអសនត្រាណូ (ឧ. microscope électronique)។ *n.f.* អសនត្រាណូវិទ្យា

électrophone *n.m.* អគ្គិសនីសព្ទ

électrophore *n.m.* អគ្គិសនីករ

électroponcture *n.f.* អគ្គិសនីវេធ

électroradiologie *n.f.* អគ្គិសនីវិទ្យុ-សាស្ត្រ

électroradiologiste *n.m.* អគ្គិសនី-វិទ្យុពេទ្យ

électroscope *n.m.* អគ្គិសនីទស្សន៍

électroscopie *n.f.* អគ្គិសនីទស្សនវិជ្ជា

électrostatique *a.* នៃអគ្គិសនីស្ថិតិ ។ *n.f.* អគ្គិសនីស្ថិតិ

électrotechnicien *n.m.* អគ្គិសនី-បច្ចេកវិទូ (អ្នកចេះដោយឡែកខាងអគ្គិសនី)

électrotechnique *a.* នៃអគ្គិសនីបច្ចេ-កទេស ; ដែលប្រើក្នុងអគ្គិសនីបច្ចេក-ទេស។ *n.f.* អគ្គិសនីបច្ចេកវិជ្ជា

électrothérapie *n.f.* អគ្គិសនីតិកិច្ឆា, ការព្យាបាលរោគដោយអគ្គិសនី

électrothermie *n.f.* អគ្គិសនីឧណ្ហវិជ្ជា

élégamment *adv.* យ៉ាងសង្ហា; យ៉ាងសមសួន

élégance *n.f.* ភាពសង្ហា; ភាពសមសួន (ឧ. l'élégance de la taille, de la toilette; se présenter avec aisance et élégance)។ *Fig.* ការប៉ិនប្រសប់ខាងសំដីនិងខាងសំណេរ: (ឧ. parler, écrire avec élégance)

élégant,e *a.* សង្ហា, សមសួន (ឧ. cos-

tume élégant; tournure élégante)។ *n.* អ្នកលេងសំដីឬលោងខ្លួន

élégie *n.f.* កាព្យនិទានខ្ទឹង

élément *n.m.* វត្ថុធាតុ (ឧ. les éléments d'un ouvrage) ; ធាតុ (ឧ. l'oxygène, le fer, le soufre sont des éléments) ។

Fig. ទីនៅ (ឧ. l'eau est l'élément des poissons); កន្លែងដែលចូលចិត្ត (ឧ. être dans son élément); ជន (ដែលនៅក្នុងក្រុម) (ឧ. cette classe a de bons éléments); ក្រុម (ដែលនៅក្នុងពួក) (ឧ. des éléments ennemis ont pénétré dans nos lignes)។

pl. កម្លាំងធម្មជាតិ (មានខ្យល់, ភ្លៀង, រលកជាដើម) (ឧ. luttes contre les éléments déchaînés); គោលសំខាន់ (ឧ. éléments de physique) ។ les quatre éléments (l'eau,la terre,le feu et l'air)ធាតុទាំងបួន (ដី, ទឹក, ភ្លើងនឹងខ្យល់) ។ pour éléments de réponse ដើម្បីទិន្នន័យ ។

élémentaire *a.* នៃវត្ថុធាតុ(ឧ.analyse chimique élémentaire); ជាន់ដំបូង (ឧ. livre élémentaire) ។ cours élémentaire ម. ព. cours ។ enseignement élémentaire ម. ព. enseignement

éléphant *n.m.* ដំរី(cri: l'éléphant barète ឬ barrit)

éléphanteau *n.m.* កូនដំរី

éléphantesque *a. Fam.* ធំសំបើម

éléphantin,e *a.* ដូចដំរី; នៃដំរី

élevable *a.*អាចអប់រំបាន;អាចចិញ្ចឹមបាន

élevage *n.m.* បសុព្យាបាល; បសុកម្ម, ការចិញ្ចឹមសត្វ

élévateur, trice *a.* សម្រាប់លើក ។ *n.m.*សាច់ដុំសម្រាប់លើក (ឧ. l'élévateur de la paupière); ប្រដាប់លើក

élévation *n.f.* ការលើក (ឧ. élévation des bras au-dessus de la tête);ការឡើង(ឧ.l'élévation du niveau des eaux) ; កំពស់ (ឧ. il faut donner plus d'élévation à ce mur); ទួល (ឧ. gravir une élévation) ។ *Fig.* ការតម្កើងសក្តិ (ឧ. éléva-

tion au grade d'officier) ។ élévation de prix ការតម្លើងថ្លៃ ។ សេចក្ដីថ្លៃថ្នូរ (ឧ. une grande élévation de sentiments) ។ élévation de la voix ការតម្លើងសម្លេង

élévatoire *a.* សម្រាប់លើករបស់ធ្ងន់ (ឧ. appareil élévatoire)

élève *n.* សិស្ស; សត្វដែលគេចិញ្ចឹមពីកំណើត; ដើមឈើដែលគេកំរិតការលូតលាស់ ។ *n.f.* ការចិញ្ចឹម

élevé,e *a.* ខ្ពស់ (ឧ. lieu élevé) ។ *Fig.* ថ្លៃថ្នូរ (ឧ.style élevé); ដែលបានទទួលការអប់រំ (ឧ. un homme bien élevé អ្នកមានពូជ)

élever *v.t.* លើក (ឧ. élever des fardeaux); តម្លើង (ឧ. élever un mur); ស្ថាបនា, សង់ (ឧ. élever un monument) ។ *Fig.* ឲ្យឡើងបុណ្យ, ឲ្យឡើងសក្តិ (ឧ. élever au pouvoir); ឲ្យមានសន្តានចិត្តខ្ពស់ (ឧ. la lecture élève l'esprit); តម្លើង (ឧ. élever le prix); ចិញ្ចឹម (ឧ. élever des animaux); អប់រំ (ឧ. bien élever ses enfants); បង្កើតថ្មី (ឧ. élever un système) ។ បង្ក, នាំឲ្យមាន (ឧ. élever une protestation) ។ élever la voix តម្លើងសម្លេង ។ élever la voix pour និយាយកាន់ជើង ។ élever jusqu'aux nues អួតហួសហេតុ ។

S'élever *v.pr.* មានកំពស់ (ឧ. le clocher s'élève à vingt mètres); មានចំនួន (ឧ. la foule s'élève à mille personnes); ឡើងឋានៈ (ឧ. s'élever au-dessus de sa condition sociale) ។ s'élever contre តវ៉ា ប្រឆាំង (ឧ. s'élever contre les abus)

éleveur, euse *n.* អ្នកចិញ្ចឹមសត្វ ។ *n.f.* ប្រដាប់ភ្ញាស់ស៊ុត

élevure *n.f.* ពងលើស្បែក

elfe *n.m.* វិលាហកទេវតា (ទេវតាបង្កើតភ្លៀងនឹងខ្យល់)

élider *v.t.* ធ្វើលោបកម្ម, កាត់អក្ខរៈឬកាត់សំឡេងចេញពីពាក្យខ្លះ

éligibilité *n.f.* ភាពអាចជ្រើសតាំងបាន (ឧ. l'âge d'éligibilité au Conseil du Royaume est de 40 ans au moins)

éligible *a.&n.* អាចជ្រើសតាំងបាន

élimage *n.m.* ការសឹក

élimer *v.t.* ធ្វើឲ្យសឹក (សំលៀកបំពាក់)

éliminateur, trice *a.* ដែលទម្លាក់; ដែលយកចេញ

élimination *n.f.* ការទម្លាក់; ការបំបាត់; ការយកចេញ

éliminatoire *a.&n.f.* សម្រាប់ទម្លាក់។ épreuve éliminatoire វិញ្ញាសាទម្លាក់។ note éliminatoire ពិន្ទុទម្លាក់

éliminer *v.t.* ទម្លាក់(ឧ.éliminer un candidat); បញ្ចេញចោល(ឧ. éliminer des matières toxiques)

élingue *n.f.* *Mar.* ពួរមានទំពក់

élire *v.t.* រើស (ឧ. élire un arbitre); ជ្រើសតាំង; បោះឆ្នោត (ឧ. élire un député) ។ élire domicile តាំងលំនៅ

élisant,e *a.* ដែលទទួលភារៈជ្រើសតាំង; ដែលចូលរួមក្នុងការបោះឆ្នោត (ឧ. les membres élisants d'une communauté)

élision *n.f.* លោប [លោ-ប៉ះ]; ការកាត់អក្ខរៈឬកាត់សំឡេងចេញពីពាក្យខ្លះ

élite *n.f.* វរជន (ឧ. l'élite de la société; un soldat d'élite)

élixir *n.m.* ស្រាថ្នាំ (ឧ. élixir tonique)

elle *pr. pers. f.* វា, គាត់ (ឥត្ថីលិង្គនៃ il) ។ d'elle-même ដោយខ្លួនឯង

ellipse *n.f.* *Math.* រង្វង់ពងក្រពើ, រង្វង់មូលទ្រវែង ។ *Gram.* លោបកម្ម [លោ-ប៉ះ–] (ឧ. ellipse du sujet, du verbe)

ellipticité *n.f.* រាងពងក្រពើ

elliptique *a.* *Math.* ជារាងពងក្រពើ, មូលទ្រវែង (ឧ. courbe elliptique) ។ *Gram.* ដែលមានលោបកម្ម (ឧ. tour elliptique)

elme (**feu saint-**) ម. ព. feu

élocution *n.f.* វចនវិធី (ឧ. élocution facile, lente, rapide)

éloge *n.m.* ជោមភិទ, ពាក្យសរសើរ, ពាក្យបញ្ជោរ

élogieusement *adv.* ដោយសរសើរ

élogieux, euse *a.* ដែលសរសើរ (ឧ. paroles élogieuses)

éloigné, e *a.* ឆ្ងាយ, យូរ ។ parent éloigné បងប្អូនឆ្ងាយ

éloignement *n.m.* ការទៅឆ្ងាយ, ការនាំចេញឆ្ងាយ; ភាពឆ្ងាយ (ឧ. vivre dans l'éloignement du monde)។ *Fig.* សេចក្ដីមិនចូលចិត្ត (ឧ. l'enfant qui montre de l'éloignement pour le travail); ការស្អប់ (ឧ. éprouver de l'éloignement pour quelqu'un)។ en éloignement ទៅឆ្ងាយ, ទៅអនាគត

éloigner *v.t.* ឲ្យទៅឆ្ងាយ, ឲ្យចេញឆ្ងាយ, នាំទៅឆ្ងាយ (ឧ. éloigner quelqu'un de son pays; éloigner les flatteurs)។ *Fig.* ទាត់ចោល (ឧ. éloigner une pensée)។ éloigner les sympathies ធ្វើមិនឲ្យគេចូលចិត្ត។ s'éloigner *v. pr.* ទៅឆ្ងាយ, បញ្ចៀស (ឧ. le travail éloigne de nous trois grands maux: l'ennui, le vice et le besoin (Voltaire))។ être éloigné de compte ឬ être loin de son compte ខុសគ្នាឆ្ងាយណាស់ (មិនអាចនឹងយល់ព្រមបាន)។ être éloigné de son compte គិតច្រឡំ

élonger *v.t. Mar.* ទាញឲ្យវែង (ឧ. élonger un câble); ដើរ ឬ បរ បណ្ដោយ (ឧ. élonger une côte)

éloquemment *adv.* ដោយវោហារកោសល្យ; ដោយជាក់ស្ដែង

éloquence *n.f.* វោហារកោសល្យ, វចីកោសល្យ

éloquent,e *a.* វោហារកោសល្យ, វចីកោសល្យ (ឧ. parler en termes éloquents)។ *Par ext.* មានខត មានភ័ក្ត (ឧ. silence éloquent); ស្ដែងណាស់ (ឧ. chiffres éloquents)

élu,e *n.* អ្នកដែលគេជ្រើសតាំង (ឧ. les élus du suffrage universel); អ្នកបានសម្រេចមគ្គផល

élucidation *n.f.* ការបំភ្លឺ

élucider *v.t.* បំភ្លឺ (ឧ. élucider une question)

élucubration *n.f.* សៀវភៅសរសេរ ដោយប្រឹងប្រែងខ្លាំង។ *Par ext.* ការនិយាយផ្ដេសផ្ដាស (ឧ. écouter les élucubrations de quelqu'un)

élucubrer *v.t. Péjor.* សរសេរសៀវភៅដោយប្រឹងប្រែងខ្លាំង

éluder *v.t.* បង្វៀរឬគេចដោយប៉ិនប្រសប់

(ឧ. éluder une loi, une difficulté, une question)

élysée *n.m. Myth.* ឋានសួគ៌។ *Par ext.* មេណើយដ្ឋាន

élyséen,enne *a.* នៃឋានសួគ៌ឬមេណើយដ្ឋាន (ផ្លូវកាលទៅជាពហុវចន គេថា Elysées ឧ. champs Elysées)

élytre *n.m.* ស្រោមស្លាប(ស្លាបរឹងនៃពពួកសត្វល្អិតខ្លះដូចជាកំពោង,កញ្ចែ)

émaciation *n.f.* ភាពស្គមកំព្រឹង (ស្គមស្រលែង)

émacié,e *a.* ស្គមកំព្រឹង (ឧ. visage émacié)

émacier (s') *v.pr.* ចុះស្គមកំព្រឹង

émail *n.m.* កាចា (ញ៉ាំញី); សាច់រឹងនៃធ្មេញ ។ *Fig.* ពណ៌ចម្រុះនៃផ្កា (ឧ. l'émail d'une prairie)

émaillage *n.m.* ការលាបកាចា

émailler *v.t.* លាបកាចា (ឧ. émailler un vase) ។ *Fig.* លំអ (ឧ. émailler un discours de citations)។ *Poét.* លំអដោយពណ៌ចម្រុះ (ឧ. mille fleurs émaillent la prairie)

émaillerie *n.f.* សិល្បៈនៃអ្នកលាបកាចា

émailleur *n.&a.m.* អ្នកលាបកាចា

émaillure *n.f.* សិល្បៈលាបកាចា; ការលាបកាចា

émanation *n.f.* ការកាយចេញ (ឧ. les odeurs sont les émanations) ។ *Fig.* ការសំដែង (ឧ. émanation de l'autorité)

émancipateur,trice *a.&n.* ដែលឲ្យផុតពីអត្តាធីនភាព (អាណាព្យាបាល) (ឧ. loi émancipatrice)

émancipation *n.f.* អត្តាធីនភាព(រកផុតពីអាណាព្យាបាល) (ឧ. l'émancipation des derniers serfs, en France, est l'œuvre d'un édit d'août 1779)

émancipé,e *a. Fig.* ល្ហូរល្ហាន (មិនស្រគត់ស្រគំ)

émanciper *v.t.* ដាក់ឲ្យផុតពីអត្តាធីនភាព(អាណាព្យាបាល) (ឧ. émanciper un mineur)។ *Fig.* ឲ្យរួចជាអ្នកជា, ដោះចំណង (ឧ. émanciper un peuple) ។ s'émanciper *v.pr. Fam.* មិនរវែងចិត្តអ្នកផង, ធ្វើតាមចិត្តខ្លួន

émaner *v.i.* កាយចេញ (ឧ. le parfum qui émane des fleurs)។ *Fig.* ចេញអំពី, មានដើមកំណើត (ឧ.

le pouvoir législatif émane du peuple)

émargement *n.m.* ការកាត់រឹមឬហាមចេញ ; ការចុះហត្ថលេខានៅរឹមទំព័រ ; សេចក្ដីដែលចុះនៅរឹមទំព័រ

émarger *v.t.* កាត់រឹម ឬ ហាមចេញ ; សរសេរលើរឹមទំព័រ; ចុះហត្ថលេខានៅរឹមទំព័រ ។ *v.i.ind.* (à) *Fig.* បើកប្រាក់ (បៀវត្ស, បំណាច់ឧបត្ថម្ភកធន) (ឧ. émarger au budget)

émasculation *n.f.* ការក្រៀវ (សត្វឈ្មោល)

émasculer *v.t.* ក្រៀវ(សត្វឈ្មោល) ។ *Fig.* ធ្វើឲ្យខ្សោយ; ធ្វើឲ្យទន់ដូចស្រ្តី; បង្អាប់ប្រាជ្ញា

emballage *n.m.* ការខ្ចប់; សំបក

emballement *n.m.* *Mécan.* ដំណើរម៉ាស៊ីនរេក៑(ម៉ាស៊ីនវិលញាប់)។*Fam.* ការដាល(សេះ); ការខឹងប្រឡេត; ការស្រើបស្រាល

emballer *v.t.* ខ្ចប់,ដាក់ឡាំង។emballer un moteur ធ្វើឲ្យម៉ាស៊ីនរេក៑ (ម៉ាស៊ីនវិលញាប់) ។ *Fig.&fam.* សរប្រើប, ធ្វើឲ្យជាប់ចិត្ត ។ *Fam.* ស្ដីបន្ទោស ។ s'emballer *v.pr.* ដាល(សេះ)។*Par ext.* ខឹងប្រឡេត; ស្រើបស្រាល។*Méc.* រេក៑ (ម៉ាស៊ីនវិលញាប់)

emballeur *n.m.* អ្នកខ្ចប់។ *Fam.* អ្នកបញ្ឆោត, អ្នកអំនួត

embarbouiller *v.t.* ប្រឡាក់។*Fam.* ធ្វើឲ្យភ្លេចការកំពុងគិត ។ s'embarbouiller *v.pr.* *Fam.* ភ្លេចសំដី (ដែលកំពុងនិយាយ) (ឧ. s'embarbouiller dans ses explications)

embarcadère *n.m.* *Mar.* កំពង់សម្រាប់ផ្ទុកទំនិញ ឬ ឲ្យអ្នកដំណើរឡើងចុះនាវា។ *Ch.de f.* កន្លែងសម្រាប់ផ្ទុកទំនិញឬឲ្យអ្នកដំណើរឡើងចុះរថ

embarcation *n.f.* *Mar.* ជលយាន, នាវាតូច,·ទូកតូច

embardée *n.f.* ការឃ្លាតចេញពីផ្លូវ (នាវា, រថយន្ត)

embargo *n.m.* និន្នការណ៍, ការហាមឃាត់ជាបណ្ដោះអាសន្នមិនឲ្យនាវាចេញពីកំពង់(ឧ.lever l'embargo);ការហាមឃាត់មិនឲ្យផ្សាយ; ការរឹបអូស (ឧ. mettre l'embargo sur des livres, des journaux)

embarquement *n.m.* ការដាក់ទំនិញ; ការឡើងជិះយានជំនិះ, ការចុះនាវា; ការ

ផ្ទុកក្នុងនាវា

embarquer *v.t.* ផ្ទុកនាវា;ត្រូវរលកលោកចូល(នាវា) (ឧ. embarquer une lame)។ *Fam.* នាំយកទៅដាក់គុក (ឧ. embarquer un voleur)។ *Fig.* នាំឲ្យជាប់ (ឧ. embarquer quelqu'un dans une méchante affaire)។ *v.i.* ចុះនាវា។ *Par ext.* ឡើងរថយន្តឬរថផ្សេងៗ; ចេញដំណើរ; លោកចូលក្នុងទូក (រលក)។ **s'embarquer** *v.pr.* ចុះនាវា; ចូល, ជាប់ការ (ឧ. s'embarquer dans un procès)។

Loc.prov. s'embarquer sans bisquit ឬ sans boussole ធ្វើសង្គ្រាមដោយគ្មានសស្ត្រាវុធ

embarras *n.m.* ការទទើសទទាស់ (ឧ. embarras de voitures)។ *Fig.* សេចក្ដីទញ់គុះ (ឧ. être dans un grand embarras); ការទាល់ច្រក (ឧ. se trouver dans l'embarras); ការឡប់ស្មារតី (ឧ. excusez mon embarras); ស្ពានការណ៍ពិបាក, កង្វល់ (ឧ. tirer quelqu'un d'embarras)។ faire ses embarras ឬ son embarras ធ្វើឫកក្អេង។ faiseur, faiseuse d'embarras អ្នកធ្វើឫកក្អេង។ mettre une fille dans l'embarras បំពើមស្រីក្រមុំ។ n'avoir que l'embarras du choix ពិបាកតែរើស (មានច្រើនឲ្យរើសតាមចិត្ត)។ causer de l'embarras à quelqu'un រំខានគេ

embarrassant,e *a.* ដែលឲ្យទទើសទទាស់ (ឧ. colis embarrassant);ដែលឲ្យខ្វល់(ឧ.problème embarrassant)

embarrassé, e *a.* ទទឹមទទាម, ដែលទញ់គុះ

embarrasser *v.t.* ធ្វើឲ្យទទើសទទាស់ (ឧ. embarrasser une rue); ទើសទាក់ (ឧ. ce manteau m'embarrasse)។ *Fig.* បង្កើតឧបសគ្គ; ធ្វើឲ្យស្មុគស្មាញ (ឧ. embarrasser une affaire); ធ្វើឲ្យខ្វល់ចិត្ត, ធ្វើឲ្យទាល់គំនិតឬទាល់ប្រាជ្ញា (ឧ.votre question m'embarrasse)។ **s'embarrasser** *v.pr.* ខ្វល់ចិត្ត (ឧ. il ne s'embarrasse pas de son travail); ឡប់ស្មារតី

embastillement *n.m.* ការដាក់គុក;

ការធ្វើជាការជុំវិញ

embastiller *v.t.* ដាក់គុក; ធ្វើជាការជុំវិញក្រុង

embâter *v.t.* ចងកែប(មានសេះជាដើម)

embattage ឬ **embatage** *n.m.* ការដាក់វ័ណ្ឌកង់រទេះ

embattre ឬ **embatre** *v.t.* ដាក់វ័ណ្ឌកង់រទេះ

embauchage *n.m.* ឬ **embauche** *n.f.* ការជួល (ឧ. embauchage d'ouvriers); ទោសនាំទាហានគេ (បទនេះត្រូវមានទោសដល់ជីវិត)

embauche *n.f.* ព.ម.embauchage

embaucher *v.t.* ជួល(កម្មករ); ល្បួងទាហានបច្ចាមិត្តឲ្យចូលខាងទ័ពខ្លួន ។ *Fam.* នាំ

embaucheur,euse *n.* អ្នកជួល

embauchoir *n.m.* ទ្រនាប់ស្បែកជើង (គេហៅ embouchoir ក៏បាន)

embaumement *n.m.* ការអប់(ក្លិន); ការបោលក្លិន; ការញ្ញាសាកសពទុក

embaumer *v.t.* អប់ (ឧ.embaumer une chambre); បោលក្លិន។ *Absol.* រញ្ញាសាកសពទុកកុំឲ្យរលួយ ។ *v.i.* បោលក្លិនក្រអូប (ឧ. ces fleurs embaument)

embaumeur *n.m.* អ្នកធ្វើសាកសពឲ្យទុកបានយូរ

embecquer *v.t.* បញ្ចុកចំណី(កូនបក្សី)។ embecquer l'hameçon ប៉ះនុយ

embéquiner *v.t.* បំពាក់កាតិបតូច ។ *Fig.* ធ្វើឲ្យងប់ ។ s'embéquiner *v.pr.* ងប់ (ឧ.elle s'est embéquinée de cette nouvelle mode)

embellie *n.f.* *Mar.* មេឃស្រឡះ (នៅពេលក្រោយព្យុះ)

embellir *v.t.* ធ្វើឲ្យល្អ,តែងលំអ(ឧ.embellir sa maison)។*Fig.* le rêve embellit la réalité សុបិនលំអសេចក្ដីពិត ។ embellir une histoire និទានរឿងដោយបញ្ចេញបញ្ចូល ។ *v.i.* ឡើងល្អ (ឧ. le temps embellit)

embellissement *n.m.* ការលំអ(ឧ.les embellissements d'une ville)

emberlificoter *v.t.* *Pop.* ធ្វើឲ្យទាល់គំនិត; ល្បួងឲ្យចូលអន្ទាក់

emberlificoteur, euse *a.&n.* អ្នកធ្វើឲ្យទាល់គំនិត;អ្នកល្បួងឲ្យចូលអន្ទាក់

embesogné,e *a.* រវល់ខ្លាំង

embêtant, e *a.* *Pop.* ដែលរំខាន

embêtement *n.m. Pop.* ការខាន; ការធុញទ្រាន់; ការរំអុក; សេចក្តីអផ្សុក

embêter *v.t. Pop.* នាំឲ្យខាន ឬ ឲ្យអផ្សុក; ធុញទ្រាន់; រំអុក។ s'embêter *v.pr.* អផ្សុកខ្លាំង

emblavage ឬ **emblavement** *n.m.* ការសាប ឬ ព្រោះស្រូវសាលី; ពង្រោះ, ការសាបព្រោះ

emblave *n.f.* ដីដែលមានស្រូវសាលីទើបនឹងដុះ

emblaver *v.t.* សាបឬព្រោះស្រូវសាលី។ *Par ext.* សាប, ព្រោះ

emblavure *n.f.* ដីពង្រោះស្រូវសាលី

emblée (d') *loc. adv.* តាំងពីដំបូងដៃ; ដោយងាយ

emblématique *a.* ដែលជាបដិរូប (ឧ. figure emblématique)

emblématiquement *adv.* ដោយជាបដិរូប

emblème *n.m.* បដិរូប (ឧ. le coq est l'emblème de la vigilance)

embobeliner *v.t. Fam.* លួងលោមដោយពាក្យបញ្ជោរ

embobiner *v.t.* ការស្ទូត្រអំពោះដាក់ខ្នារ។ *Fig.* លួងលោមដោយពាក្យបញ្ជោរ

emboire *v.t.* លាបពុម្ពសិតដោយក្រមួន ឬប្រេង។ s'emboire *v.pr.* ឡើងស្រអាប់ដោយត្រូវប្រេង

emboitage *n.m.* ការបង្ហាំដំណាប់

emboitement *n.m.* ភាពនៃវត្ថុខាំជាប់គ្នា

emboiter *v.t.* បង្ហាំដំណាប់; បញ្ចូល ។ emboîter le pas ដើរតាមប្រកិត; *au fig.* យកតម្រាប់គេ ។ *Fam.* សំដែងការមិនចូលចិត្ត(ឧ.emboîter un acteur)

emboîture *n.f.* កន្លែងបង្ហាំ;របៀបបង្ហាំ

embolisme *n.m.* ការលើកខែ (ដើម្បីឲ្យឆ្នាំចន្ទគតិត្រូវនឹងឆ្នាំសុរិយគតិ)

embolismique *a.* នៃការលើកខែ

embonpoint *n.m.* ថូលភាព[ថូ-ល:—], ភាពធាត់ដុះពោះ

embouche ឬ **embauche** *n.f.* វាលស្មៅបំប៉នសត្វឲ្យធាត់; ការចិញ្ចឹមគោ

embouché, e *a. Fam.* mal embouché គម្រោះ

emboucher *v.t.* បៀមផ្លុំ(គ្រឿងភ្លេង)។ *Fig.* emboucher la trompette ដំឡើងសម្លេង

embouchure *n.f.* ពាម(ឧ.le Havre est l'embouchure de la Seine dans la Manche); បង្ហាំ

(ផ្នែកបង្ហៀរដែលចូលក្នុងមាត់គេ) ។ *Mus.* អណ្តាតគ្រឿងភ្លេងផ្លុំ

embouquement *n.m. Mar.* ការចូលក្នុងច្រកបង្កៀត

embouquer *v.i. Mar.* ចូលក្នុងច្រកបង្កៀត ។ *v.t.* embouquer un canal ចូលក្នុងព្រែក

embourber *v.t.* ធ្វើឲ្យកប់ភក់ ។ *Fig.* នាំឲ្យជាប់ក្នុងរឿងមិនល្អ ☞ s'embourber *v.pr.* ជាប់ភក់; ស៊ុងខ្លួន; ចុះថោកទាប

embourgeoisé,e *a.* គ្មានសេចក្តីថ្លៃថ្នូរ (ឧ. morale embourgeoisée)

embourgeoisement *n.m.* ការយកលំនាំជាគហបតី

embourgeoiser (s') *v.pr.* យកលំនាំជាគហបតី

embourrer *v.t.* ញាត់សំឡី ឬ រោមសត្វ ឬ កំទេចផ្សេងៗ

embourrure *n.f.* ការញាត់សំឡី-រោមសត្វឬកំទេចផ្សេងៗ; សំពត់ពួក

embout *n.m.* ចង្កំពុងដំបងឬឆ័ត្រ

embouteillage ឬ **embouteillement** *n.m.* ការច្រកដប ។ *Mar.* ការខ្ទប់កងនាវាមិនឲ្យចេញរួច ។ *Par ext.* ការស្ទះផ្លូវ

embouteiller *v.t.* ច្រកដប (ឧ. embouteiller du cidre) ។ *Fig.* ខ្ទប់មិនឲ្យនាវាចេញរួច ។ *Fig.* ធ្វើឲ្យស្ទះផ្លូវ (ឧ. embouteiller un carrefour)

embouter *v.t.* ដាក់ចង្កំពុង

emboutir *v.t.* ដំលោហធាតុយករាងតាមត្រូវការ; ទ្រាប់ដែក (ឧ. emboutir une corniche) ។ *Fam.* ទង្គិចខ្លាំង (ឧ. emboutir l'aile d'une voiture)

emboutissage *n.m.* ការដំលោហធាតុយករាងតាមត្រូវការ

emboutisseur *n.m.* អ្នកដំលោហធាតុ

emboutissoir *n.m.* ឬ **emboutisseuse** *n.f.* ញញួរ ឬ ម៉ាស៊ីនដំលោហធាតុ

embranchement *n.m.* ការបែកមែកបែកធាង; ផ្លូវបែក; សាខា; បំពង់បំបែក ។ *Ch. de fer* សាខាបថ ។ *Sc.* សាខា (ឧ. les vertébrés forment un embranchement du règne animal)

embrancher *v.t.* ភ្ជាប់ផ្លូវច្រើនឬភ្ជាប់បំពង់ច្រើន ។ s'embrancher *v.pr.* បែកជាផ្លូវច្រើន

embraquer *v.t. Mar.* ទាញខ្សែពួរឲ្យតឹង

embrasement *n.m.* មហាអគ្គិភ័យ;ពន្លឺកំជ្រួច; ពន្លឺរន្ទាល ។ *Fig.* ការជ្រួលច្របល់

embraser *v.t.* ឲ្យមានពន្លឺរន្ទាល(ឧ.ciel qu'embrase le soleil couchant)។*Fig.*បង្កចលាចល(ឧ.embraser un Etat); ធ្វើឲ្យរំជួលខ្លាំង

embrassade *n.f.* ការឱបឬថើបគ្នា

embrasse *n.f.* ខ្សែក្តក់វាំងនន

embrassement *n.m.* ការឱបថើបគ្នា; ការក្រសោប; ការរួបរឹត

embrasser *v.t.* កៀក,ឱប;ថើប។*Fig.* ព័ទ្ធ (ឧ. l'océan embrasse la terre); មាន, បញ្ចូល (ឧ. l'étude de la philosophie embrasse tout); កាន់យក, រើសយក (ឧ. embrasser une religion, un parti); ក្រសោប, ជាប់ការ (ឧ. qui trop embrasse mal étreint អ្នកក្រសោបការច្រើនពេកឱបមិនជុំ (គឺធ្វើការនោះមិនបានល្អ) (ភាសិតខ្មែរថា: ខ្លួនទាបកុំពោងដៃខ្លីកុំឈោងប្រភឱបភ្នំ)

embrasseur,euse *n.* អ្នកចូលចិត្តឱប

embrasure *n.f.* ប្រឡោះទ្វារ ឬ បង្អួច; ប្រហោងជញ្ជាំងដាក់កាំភ្លើងបាញ់

embrayage *n.m.* ការដាក់លេខម៉ាស៊ីន; អំប្រាយ៉ាស (គ្រឿងដាក់ឬដោះលេខម៉ាស៊ីន) (ឧ. embrayage automatique)

embrayer *v.t.* ដាក់លេខម៉ាស៊ីន

embrayeur *n.m.* អំប្រាយ៉េរ (ប្រដាប់ដាក់លេខម៉ាស៊ីន)

embrigadement *n.m.* ការបញ្ចូលជាកង

embrigader *v.t.* បញ្ចូលជាកង ។ *Fig.* បញ្ចូលក្នុងក្រុមតែមួយ (ឧ. embrigader des partisans)

embrocation *n.f. Méd.* ការរឹតដោយថ្នាំប្រេង; ថ្នាំប្រេងរឹត

embrochement *n.m.* ការច្រនួច(ការដោតជាចង្កាក់)

embrocher *v.t.* ច្រនួច(ដោតជាចង្កាក់)។ *Par anal.* ដោតធ្លាយពីម្ខាងទៅម្ខាង

embrouillage *n.m.* ការផ្សាយបំភាន់ (វិទ្យុ)

embrouillamini *n.m.* ម.ព.brouillamini

embrouillement *n.m.* ការបន្លប់,ការបំភាន់ (ឧ. l'embrouillement des questions)។ *Fig.* ការធ្វើឲ្យ

ច្រឡំ, ការទទើសទទាស់, ការច្របូក-ច្របល់

embrouiller *v.t.* ច្របល់ (ឧ. embrouiller du fil)។ *Fig.* បំភាន់, ធ្វើឲ្យច្របូកច្របល់ឬឲ្យស្មុគស្មាញ (ឧ. embrouiller une question)។ s'embrouiller *v.pr.* ឡប់ (ឧ. s'embrouiller dans un discours, dans une affaire)

embroussaillé,e *a.* ដែលមានគុម្ពបន្លាពាសពេញ; រសេមរសាម; កន្ទ្រើង (ឧ. cheveux embroussaillés)

embruiné,e *a.* ដែលមានរលឹមត្រជាក់

embrumer *v.t.* គ្របដណ្ដប់ដោយអ័ព្ទ។ *Fig.* ធ្វើឲ្យងងឹត-ឲ្យសៅហ្មងឬឲ្យព្រួយ

embrun *n.m.* មេឃចុះអ័ព្ទ។ *pl.Mar.* ផ្សែងរលក (ដំណក់ទឹកខ្ទាតៗបែកចេញពីរលក)

embrunir *v.t.* ឲ្យមានសម្បុរតាំដែង (ឧ. la nuit tombante embrunit le ciel)

embryogenèse ឬ **embryogénie** *n.f.* ការក្លាយរូបនៃសត្វឬរុក្ខជាតិតាំងពីពេលកកើតរហូតដល់ពេញរូបរាង

embryogénique *a.* នៃការក្លាយរូបសត្វឬរុក្ខជាតិ

embryologie *n.f.* ព្រូណវិទ្យា, វិទ្យាសាស្ត្រខាងការក្លាយរូបសត្វ

embryologique *a.* នៃព្រូណវិទ្យា, នៃវិទ្យាសាស្ត្រខាងការក្លាយរូបសត្វ

embryologique *n.* ព្រូណវិទូ, អ្នកវិទ្យាសាស្ត្រខាងការក្លាយរូបសត្វ

embryon *n.m.* ព្រូណ, ទារកទើបនឹងកក្នុងផ្ទៃ;ពន្លករុក្ខជាតិ;ឫសគល់។ *Fig.* ដើមកំណើត (ឧ. la famille est l'embryon de l'Etat) ; អ្វីៗដែលទើបនឹងផ្ដើមឬមិនទាន់ស្រេច (ឧ. cet ouvrage n'est qu'un embryon)

embryonnaire *a.* ដែលទើបនឹងកក ។ *Fig.* ដែលទើបនឹងផ្ដើម

embryopathie *n.f.* រោគនៃព្រូណ (ឧ. beaucoup de malformations congénitales sont dues à des embryopathies)

embryotomie *n.f.* ព្រូណច្ឆេទនកម្ម (ការកាត់ជាកំណាត់ នូវកូនដែលស្លាប់ក្នុងផ្ទៃមាតាហើយសម្រាលមិនរួច)

embu,e *a.* ស្រអាប់ (ឧ. tableau embu)។ *n.m.* ពណ៌ស្រអាប់

embûche *n.f.* អន្ទាក់; ការពួនស្ទាក់(ឧ. tendre, dresser des embû-

ches) ។ *Fig.* ឧកាយកល

embûcher *v.t.* ដាក់ឲ្យពួនស្ទាក់ (ឧ. embûcher des assassins) ។ *Sylv.* ផ្ដើមកាប់(ឧ.embûcher un bois) ។ *Véner.* ធ្វើឲ្យចូលព្រៃវិញ (embûcher un cerf) ។ s'embûcher *v.pr.* ចូលព្រៃវិញ (ក្តាន់); ពួនស្ទាក់

embuer *v.t.*ធ្វើឲ្យស្រអាប់ដោយចំហាយទឹក (ឧ. yeux embués de larmes)

embuscade *n.f.* អំពើ-កន្លែង ឬ ទ័ពពួនស្ទាក់ (ឧ. tomber dans une embuscade)

embusqué *n.&a.m.* ទាហានដែលបានកន្លែងគ្មានគ្រោះថ្នាក់(ឆ្ងាយពីសមរភូមិ) ។ *Particul.* ទាហានដែលគេដាក់ឲ្យនៅកន្លែងគ្មានគ្រោះថ្នាក់ (ក្នុងពេលចំបាំង)

embusquer *v.t.* ដាក់ឲ្យពួនស្ទាក់ (ឧ. embusquer une troupe dans un défilé) ។ *Fam.* ដាក់ឲ្យនៅកន្លែងគ្មានគ្រោះថ្នាក់ ។ s'embusquer *v.pr.* ពួនស្ទាក់ ។ *Particul.* សុំនៅកន្លែងគ្មានគ្រោះថ្នាក់; *au fig.* សុំនៅកន្លែងសប្បាយ

émécher *v.t.* ក្រង (សក់) ។ *Fam.* être éméché ស្រវឹងស្រៀងៗ

émendation *n.f.* ការកែអត្ថបទ

émender *v.t. Dr.* កែ; កែប្រែ (ឧ. émender un texte)

émeraude *n.f.* កែវ ឬ ត្បូងមរកត ។ vert d'émeraude ឬ émeraude បៃតងឆើត

émergement *n.m.* ម.ព.émersion

émergence *n.f.* ដំណើរផុសចេញនៃទឹក (ឧ.les geysers dépassent la température de 100° au point d'émergence) ។ *Fig.* ការផុស (ឧ. l'émergence des idées nouvelles ការផុសគំនិតថ្មី); ពេលបន្ទាន់ (ឧ. dans cette émergence, il faut se décider)

émergent,e *a.*ដែលផុសឡើង។*Phys.* rayons émergents កាំរស្មីដែលផុសចេញ

émerger *v.i.* លេចឡើងពីទឹក (ឧ. rocher qui émerge à peine); ងើបពីទឹក (ឧ. sous-marin qui émerge)។ *Par ext.* ផុសពីដី (ឧ. source qui émerge); ចេញពី

(ឧ. le soleil émerge de l'horizon) ។ *Fig.* ផុសចេញ, ចេញឲ្យឃើញ (ឧ. la vérité émerge peu à peu)

émeri *n.m.* ថ្មខាត់លោហធាតុ។ papier d'émeri ក្រដាសខាត់ ។ toile d'émeri សំពត់ខាត់ ។ *Fig.* & *Fam.* bouché à l'émeri ល្ងើពេញទី

émeriser *v.t.* លាយថ្មខាត់

éméritat *n.m.* ភាពជាញជ័យ

émérite *a.* ជាញជ័យ (ឧ. professeur émérite; calculateur émérite)

émersion *n.f.* ការលេចឡើងពីក្នុងទឹក; ការងើបពីទឹក; ការផុសឡើង

émerveillement *n.m.* ភាពស្ញប់ស្ញែង

émerveiller *v.t.* ធ្វើឲ្យស្ញប់ស្ញែង (ឧ. Mozart enfant émerveillait ses auditeurs par sa virtuosité précoce)

émétique *a.* ដែលធ្វើឲ្យក្អួត ។ *n.m.* ថ្នាំឲ្យក្អួត

émétiser *v.t.* លាយថ្នាំឲ្យក្អួត(ឧ.émétiser une potion); ដាក់ថ្នាំឲ្យក្អួត

émetteur,trice *n.&a.* ដែលផ្សាយ; ដែលបញ្ចេញឲ្យប្រើ(ឧ. l'émetteur d'un effet de commerce)។ un émetteur ប៉ុស្តផ្សាយ ។ station émettrice ស្ថានីយផ្សាយ

émettre *v.t.* បញ្ចេញ (ឧ. émettre des rayons, des ondes); បញ្ចេញឲ្យប្រើ (ឧ. émettre de la fausse monnaie); ថ្លែង (ឧ. émettre des vœux) ។ *v.i.* ផ្សាយ (វិទ្យុ ឬ ទូរទស្សន៍)

émeute *n.f.* កុប្បកម្ម, ចលាចល

émeutier,ère *n.* កុប្បករ,អ្នកនាំចលាចល

émier *v.t.* កញ្ចើននឹងដៃ

émiettement *n.m.* ការបេះជាកំទេច; ការពង្រាយ ។ *Fig.* ការបំបែក (ឧ. émiettement du pouvoir)

émietter *v.t.* បេះជាកំទេចតូចៗ (ឧ. émietter du pain) ។ *Fig.* បំបែក (ឧ. émietter un domaine)

émigrant,e *n.* និប្រវេសន្ត-សន្តី (ជនដែលចេញទៅតាំងនៅប្រទេសក្រៅ)

émigration *n.f.* និប្រវេសន៍(ការចេញទៅតាំងនៅប្រទេសក្រៅ); ដំណើរសត្វផ្លាស់រកកាសធាតុ (ឧ. l'émigration des hirondelles)

émigré,e *n.&a.* ដែលបានចាកចេញពីស្រុក

émigrer *v.i.* ធ្វើនិរប្រវេសន៍ (ចេញទៅតាំងនៅប្រទេសក្រៅ); ផ្លាស់អាកាសធាតុ (សត្វ) (ឧ. les palombes émigrent)

émincé *n.m.* សាច់ចំណិតស្តើងៗ

émincer *v.t.* ហាន់ជាចំណិតស្តើងៗ

éminemment *adv.* យ៉ាងបវរ; យ៉ាងឧត្តម

éminence *n.f.* ដីទួល ។ *Par ext.* កន្លែងដែលលយចេញ។ *Fig* បវរភាព; គោរមងាររបស់ការឌីណាល។ l'Eminence grise គោរមងាររបស់ការឌីណាលហ្វ៉ាសេហ្វជាទីប្រឹក្សានៃរីស៊ើល្យើ; *au fig.* ទីប្រឹក្សាសម្ងាត់ហើយមានអំណាច

éminent,e *a.* ខ្ពស់ (ឧ. lieu éminent)។ *Fig.* បវរ, ឧត្តម (ឧ. littérateurs éminents; vertus éminentes)

éminentissime *a.* បវរក្រៃលែង

émissaire *n.m.* ដែលសម្រាប់បញ្ចេញ (ឧ. canal émissaire) ។ bouc émissaire ម.ព. bouc ។ *n.m.* បេសកជន, អ្នកនាំការ (ឧ. être prévenu par un émissaire); ប្រឡាយ ឬ ស្ទឹងបញ្ចេញទឹក (ឧ. le Rhône est l'émissaire du lac de Genève)

émissif,ive *a. Phys.* ដែលបញ្ចេញពន្លឺ (ឧ. pouvoir émissif)

émission *n.f.* ការផ្សាយ; ការបញ្ចេញ (ឧ. émission de lumière); ការបញ្ចេញឲ្យប្រើ ឬ ឲ្យចាយ (ឧ. émission d'actions); ការផ្សាយ (វិទ្យុ ឬ ទូរទស្សន៍) ។ *Méd.* émissions sanguines ការចេញឈាម ។ *Gram.* émission de voix ការបញ្ចេញសំឡេង

emmagasinage ឬ **emmagasinement** *n.m.* ការដាក់ឃ្លាំង

emmagasiner *v.t.* ដាក់ឃ្លាំង។ *Phys.* ផ្ទុំ, ប្រមូល (ឧ. emmagasiner de l'énergie)។ *Fig.* ប្រមូល (ឧ. emmagasiner des souvenirs)

emmailler (s') *v.pr.* ជាប់សំណាញ់

emmaillotement *n.m.* ការរុំកំណាត់ (ឧ. emmaillotement des enfants)

emmailloter *v.t.* បំពាក់អាវ; រុំកំណាត់ (ឧ. emmailloter un bébé)។

Fig. រឹតយ៉ាងណែន

emmanchement *n.m.* ការដាក់ដង

emmancher *v.t.* ដាក់ដង (ឧ. emmancher une hache) ។ *Fig.* ចាប់ធ្វើ (ឧ. emmancher une affaire)។ s'emmancher *v.pr.* *Fig.&fam.* ចាប់ផ្ដើម (ឧ. l'affaire s'emmanche mal)

emmancheur *n.m.* ជាងដាក់ដង

emmanchure *n.f.* រង្វះសំរាប់ភ្ជាប់ដៃអាវ

emmêlement *n.m.* ការលាយ, ការច្របល់; ការធ្វើឲ្យស្មុគស្មាញ

emmêler *v.t.* លាយ, ច្របល់, ធ្វើឲ្យស្មុគស្មាញ(ឧ.emmêler un écheveau) ។ *Fig.* ធ្វើឲ្យច្របូកច្របល់ (ឧ. emmêler une affaire)

emménagement *n.m.* ការរៀបចំផ្ទះថ្មី ។ *Mar.* ការចែកនាវាជាបន្ទប់

emménager *v.i.* រៀបចំផ្ទះថ្មី ។ *v.t.* ឡើងផ្ទះថ្មី; ជួយជញ្ជូនអីវ៉ាន់

emménagogue *a.&n.m.* ថ្នាំឲ្យមានរដូវ (សំរាប់ស្រី)

emmener *v.t* នាំទៅ (ឧ.emmener un ami à la campagne)

emmenotter *v.t.* ដាក់ខ្នោះ (ឧ. emmenotter un voleur)

emmétrer *v.t.* រៀបចំឲ្យស្រួលរាប់ (ឧ. emmétrer des matériaux)

emmétrope *n.&a.m.* ដែលមើលឃើញធម្មតា (ភ្នែក)

emmétropie *n.f.* ភាពភ្នែកដែលមើលឃើញធម្មតា

emmiellé,e *a.* ដែលលាបទឹកឃ្មុំ។ *Fig.* paroles emmiellées មធុរភាព, សំដីផ្អែមល្ហែម

emmieller *v.t.* លាប ឬ លាយទឹកឃ្មុំ (ឧ. emmieller une tisane)

emmitonner *v.t.* គ្របដណ្ដប់ដោយរបស់ទន់ ។ *Fig.* បំភាន់

emmitoufler *v.t.* គ្របដណ្ដប់ដោយសំពត់ឬរោមសត្វ។ s'emmitoufler *v.pr.* ស្លៀកពាក់យ៉ាងកក់ក្ដៅ

emmortaiser *v.t.* បង្កប់ដំណាប់

emmotté,e *a.* ដែលមានដីក្ដោបឫស (ដើមឈើ)

emmurer *v.t.* ហ៊ុំព័ទ្ធដោយជញ្ជាំង ឬ កំពែង (ឧ. emmurer une ville)

émoi *n.m.* សេចក្ដីរំភើបចិត្ត ; កង្វល់ ; ការជ្រួលជ្រើម (ឧ. la ville est en émoi)

émollient,e *a.* ដែលបន្ធូរ; ដែលបន្ទន់ (ឧ. emplâtre émollient)

émolument *n.m.* បរិលាភ (ឧ. recevoir des émoluments)

émondage ឬ **émondement** *n.m.* ការលះមែក (ឧ. l'émondage favorise la croissance)

émonder *v.t.* លះមែក ។ *Fig.* យករបស់ឥតប្រយោជន៍ចេញ

émondes *n.f.pl.* មែកដែលគេលះចោល

émondeur *n.m.* អ្នកលះមែក

émondoir *n.m.* ប្រដាប់លះមែក

émorfilage *n.m.* ការឆាបទ្រនុងមុតចេញ

émorfiler *v.t.* ឆាបទ្រនុងមុតចេញ (របស់ធ្វើអំពីលោហធាតុ) (ឧ. émorfiler un couteau)

émotif, ive *a.* នៃការរំជួលចិត្ត (ឧ. troubles émotifs) ; ងាយនឹងរំជួលចិត្ត (ឧ. personne émotive)

émotion *n.f.* ការដើរមិនស្រួល (អាការៈក្នុងខ្លួន) (ឧ. avoir de l'émotion dans le pouls) ។ *Autref.* ការជ្រួលច្រើមនៃប្រជារាស្ត្រ ។ *Fig.* អាវេគ, ការរំជួលចិត្ត (ឧ. la femme est avide d'émotion); ចិត្តរំជួល

émotionnable *a.* ឆាប់រំជួលចិត្ត (ឧ. enfant émotionnable)

émotionner *v.t.* ធ្វើឲ្យរំជួលចិត្ត (ឧ. émotionner les spectateurs) ។ s'émotionner *v.pr.* រំជួលចិត្ត

émotivité *n.f.* អាវេគភាព, ភាពឆាប់រំជួលចិត្ត (ឧ. l'émotivité des foules)

émottage ឬ **émottement** *n.m.* ការបំបែកអាចម៍បំណះ

émotter *v.t.* បំបែកអាចម៍បំណះ

émotteur, euse *a.* ដែលបំបែកអាចម៍បំណះ ។ *n.f.* ម៉ាស៊ីនបំបែកដី

émottoir *n.m.* អន្ទូងបំបែកដី

émoucher *v.t.* ដេញរុយ (ឧ. émoucher un cheval)

émoucheur, euse *n.* អ្នកដេញរុយ

émouchoir *n.m.* ស៊ែ (ប្រដាប់ដេញរុយ)

émoudre *v.t.* សំលៀង (ឧ. émoudre un couteau)

émoulage *n.m.* ការសំលៀង

émouleur *n.m.* អ្នកសំលៀង

émoulu, e *a.* សំរួច, ដែលសំលៀង ។ se battre à fer émoulu ប្រយុទ្ធដោយអាវុធស្រួច ។ *Fig.* être frais émoulu de ទើបនឹងចេញថ្មីៗពី (សាលា) (ឧ. un ingénieur frais émoulu de centrale)

émousser *v.t.* ធ្វើឲ្យទាល ឬ ឲ្យរិល ។

Fig. ធ្វើឲ្យទន់ខ្សោយ; ពង្រឹល (ឧ. l'oisiveté émousse le courage)

émoustillant, e *a.* ដែលធ្វើឲ្យសប្បាយ

émoustiller *v.t. Fam.* ធ្វើឲ្យសប្បាយ (ឧ. le champagne émoustille)

émouvant, e *a.* ដែលឲ្យរំជួលចិត្ត-ឲ្យញាប់ញ័រ ឬ ឲ្យករុណាត

émouvoir *v.t.* ធ្វើឲ្យដើរមិនស្រួល (ឧ. toute agitation émeut le pouls) ។ *Par anal.* ញុះញង់; នាំឲ្យរំដើបរំជួល (ឧ. émouvoir une sédition, le peuple, un pays) ។ *Fig.* នាំឲ្យរំជួលចិត្ត (ឧ. émouvoir quelqu'un par ses larmes); បំភ័យ (ឧ. émouvoir quelqu'un par des menaces) ។ s'émouvoir *v.pr.* កំរើក។ *Fig.* រំជួលចិត្ត;ភ័យ; ឡប់ ។

Prov. il ne faut pas émouvoir les frelons មិនគប្បីធ្វើឲ្យមានសត្រូវទេ

empaillage ឬ **empaillement** *n.m.* ការញាត់ចំបើង (ឧ. l'empaillage des oiseaux)

empailler *v.t.* ញាត់ចំបើង (ឧ. empailler une chaise);ញាត់ចំបើងក្នុងស្បែកសត្វ (ឧ. empailler un écureuil)

empailleur,euse *n.* អ្នកញាត់កៅអី ឬចំបើងក្នុងស្បែកសត្វ

empalement *n.m.* ការដង់នឹងជ្រនង់

empaler *v.t.* ដង់នឹងជ្រនង់

empan *n.m.* ចំអាមកូនដៃ

empanacher *v.t.* លំអដោយសំពៅស្លាបសត្វ

empanner *v.t.* ធ្វើឲ្យខ្វប (ឧ.empanner un navire)

empaquetage *n.m.* ការខ្ចប់, ការវេច (ឧ. l'empaquetage des hardes)

empaqueter *v.t.* ខ្ចប់, វេច

emparer (s') *v.pr.* ដណ្ដើមយក (ឧ. s'emparer d'une ville); ឆក់យក (ឧ. s'emparer de quelqu'un) ។ *Fig.* សណ្ឋិត (ឧ. la mollesse et la volupté s'emparent de mon cœur (Fénelon)

empâté,e *a.* ដែលឡើងស្គុល(ឧ. visa-

ge empâté par la graisse) ។ *Méd.* ហើម (ឧ. avoir le cou empâté)

empâtement *n.m.* ភាពស្អិត (ឧ. empâtement de la bouche) ។ *Ec. rur.* ការបំប៉នបញ្ចុកដោយម្សៅ (ឧ. empâtement des oies) ។ *Méd.* ដំណើរហើមសាច់ដែលចុចទៅនៅមានស្នាមទ្រុត) ។ *Peint.* ការដាក់ថ្នាំក្រាស់; ភាពឡើងស្តុល

empâter *v.t.* ញាត់ម្សៅ; ធ្វើឲ្យស្អិត (ឧ. empâter la langue) ។ *Ec. rur.* បំប៉នបញ្ចុកឲ្យធាត់ ។ *Peint.* ដាក់ថ្នាំក្រាស់ ។ s'empâter *v.pr.* ឡើងស្អិត

empattement ឬ **empattage** *n.m.* ការវេញខ្សែដែលរណា; គល់ (គល់ដើមឈើ ឬ គល់មែកធំ); ខ្សែរុំមុខដំណា; កំណាល់និងសន្ទូច

empêchement *n.m.* ឧបសគ្គ, ទំនាស់; ការជំទាស់ (ឧ. apporter de l'empêchement à quelque chose); ភាពទើសទាក់ (ឧ. un empêchement de la langue) ។ *Dr.* ភាពខ្វះលក្ខខណ្ឌដើម្បីរៀបអាពាហ៍ពិពាហ៍

empêcher *v.t.* ឃាត់, ធ្វើឲ្យរាក់ខាន (ឧ. la pluie empêche le départ) ។ s'empêcher *v.pr.* តម; អត់; ទៀស; ទប់ (ឧ. il ne put s'empêcher de rire)

empêcheur, euse *n.* អ្នកធ្វើឲ្យរាក់ខាន ។ *Fam.* **empêcheurs de danser en rond** សត្រូវខាងការសប្បាយ, អ្នករំខាន

empeigne *n.f.* ខ្នងស្បែកជើង

empeloter *v.t.* រុំបញ្ចូលហុង

empennage *n.m.* ស្លាបព្រួញ; ស្លាប (សម្រាប់ប្រើដូចជាចង្កូត ដាក់នៅកន្ទុយគ្រាប់បែក ព្រួញជាដើម)

empenne *n.f.* ស្លាបព្រួញ

empenné, e *a.* ដែលមានស្លាប (ឧ. flèche empennée)

empenner *v.t.* ដាក់ស្លាបព្រួញ

empereur *n.m.* រាជាធិរាជ (ឧ. Napoléon Ier se fit décerner le titre d'empereur)(*f.* impératrice)

emperler ដាំគជ់ ឬ ពេជ្រ ។ *Fig.* la sueur emperle ses joues ដំណក់ញើសហូរលើថ្ពាល់ (ភ្លឺដូចពេជ្រ)

empesage *n.m.* ការជ្រលក់ម្សៅ (ឧ.

l'empesage d'une chemise) ។ *Fig.* ភាពរឹង, ភាពឆ្គង (ឧ. l'empesage d'une politesse maniérée)

empesé,e *a.* ដែលអ៊ុតដាក់ម្សៅ; ដែលជ្រលក់ដីរ។ *Fig.* រឹង,ឆ្គង (ឧ. l'air empesé); ដែលធ្វើឫកពា

empeser *v.i.* ជ្រលក់ម្សៅ, ឲ្យជាយ(ឧ. empeser du linge)។ *Fig.* ធ្វើឫកពា, ធ្វើឲ្យឆ្គង (ឧ. empeser son style)។ *Mar.* empeser les voiles យកក្ដោងត្រាំទឹក ។ s'empeser *v.pr.* ត្រូវឲ្យជាយ

empeseur,euse *n.* អ្នកឲ្យជាយ

empester *v.t.* ចម្លងរោគប៉េស្ដឬរោគឆ្លងផ្សេងៗ ។ *Fig.* ចោលពូជអាក្រក់; ធ្វើឲ្យប្រឡាក់ឬឲ្យខូច (ឧ. empester le monde de mauvaises doctrines)

empêtré,e *a.* ឆ្គង, ងាស់ (ឧ. avoir l'air empêtré)

empêtrement *n.m.* អ្វីដែលរណ្ដាជើង; ការរណ្ដាជើង

empêtrer *v.t.* រណ្ដាជើង,ដាក់ទន្ទឹង (ឧ. empêtrer un cheval pour le mettre en pâture); ធ្វើឲ្យជំពាក់ឬឲ្យជាប់ (ឧ. empêtrer ses pieds dans une corde)។ *Fig.* ធ្វើឲ្យរណ្ដាកឬឲ្យជាប់ជំពាក់(ឧ. empêtrer quelqu'un dans une mauvaise affaire); ធ្វើឲ្យពិបាកដោះស្រាយ (ឧ. empêtrer quelqu'un par des questions déplacées) ។

s'empêtrer *v.pr.* ជំពាក់ជើង ឬ រណ្ដាជើង (ឧ. cheval qui s'empêtre dans ses traits)។ *Fig.* រណ្ដាក , ជាប់ជំពាក់ខ្លួន (ឧ. il s'empêtre souvent dans des affaires douteuses)

emphase *n.f.* ការបំភ្លៃវោហារ(ឧ. Racine a raillé dans ses Plaideurs l'emphase des avocats de son temps)

emphatique *a.* ដែលបំភ្លៃវោហារ (ឧ. discours emphatique)

emphatiquement *adv.* ដោយបំភ្លៃវោហារ (ឧ. parler emphatiquement)

empierrement *n.m.* ការក្រាលថ្មផ្លូវ; ថ្មក្រាលផ្លូវ

empierrer *v.t.* ក្រាលថ្ម (ឧ. em-

pierrer un chemin)

empiétement *n.m.* ការទន្ទ្រាន (ឧ. les empiétements sont la source de nombreux procès); ការទន្ទ្រានទឹ (ឧ. empiétement de la mer sur la terre)។ *Fig.* ការលោភ (ឧ. les empiétements du pouvoir)

empiéter *v.t.* ទន្ទ្រាន (ឧ. empiéter un terrain); ដណ្ដើមយករបស់អ្នកដទៃ។ *v.i.* ទន្ទ្រានលើ (ឧ. empiéter sur son voisin)។ *Fig.* រំលោភសិទ្ធិ (ឧ. empiéter sur quelqu'un)

empiffrer *v.t.* *Fam.* បង្អកចំណី។ s'empiffrer *v pr.* បរិភោគហួសកំណត់

empilage *n.m.* ការប្រឹបសន្ទូច (ការទាក់ភ្ជាក់ខ្សែនឹងតួសន្ទូច) (ur. empilement)

empile *n.f.* ប្រឹបសន្ទូច

empilement *n m.* ការតម្រួតប្រួតលើគ្នា (ម.ព. empilage ផង)

empiler *v.t.* គរលើគ្នា, តម្រួតគ្នា (ឧ. empiler des fagots, des livres)។ *Arg.* បញ្ឆោត។ s'empiler *v.pr.* ឡើងត្រួតលើគ្នា

empileur, euse *n.* អ្នករៀបតម្រួត (ទំនិញ)

empire *n.m.* អំណាច, ការត្រួតត្រា (ឧ. exercer un empire despotique); រាជាធិរាជាណាចក្រ; អាណាចក្រ (ឧ. l'empire colonial français)។ *Fig.* ឥទ្ធិពល; កិត្យានុភាព (ឧ. l'empire des passions)

empirer *v.t.* បង្ខូចថែម, ធ្វើឲ្យរឹតតែខ្លាំង (ឧ. les remèdes ont empiré son mal)។ *v.i.* រឹតតែអាក្រក់, រឹតតែធ្ងន់ (ឧ. son mal empire)

empirique *a.* ដែលអាងលើពិសោធន៍ (ឧ. médecine empirique)។ *n.m.* គ្រូ (ពេទ្យ) ផ្ដេសផ្ដាស

empiriquement *adv.* ដោយអាងតែលើពិសោធន៍; ក្បួនគ្រូបោកប្រាស់

empirisme *n.m.* ពិសោធននិយម

empiriste *n.m.* អ្នកពិសោធននិយម

emplacement *n.m.* ទី, កន្លែង (ឧ. l'emplacement de Troie a été retrouvé près de Hissarlik)

emplanture *n.f.* បាតដងក្ដោង

emplâtre *n.m.* កៅយក់ (ថ្នាំសម្រាប់

បិទ)។*Fig.*& *Fam.*មនុស្សកំសោយ។ *Pop.* ស្អប់

emplette *n.f.* ការទិញទំនិញ(ឧ.faire des emplettes); ទំនិញ

emplir *v.t.* បំពេញ (ឧ. emplir un verre);ហយពាសពេញ(ឧ.la foule emplit les rues)។ *Fig.* emplir de joie ធ្វើឲ្យត្រេកអរ

emplissage *n.m.* ម.ព. remplissage

emploi *n.m.* និយោជន៍, ការប្រើប្រាស់ (ឧ. emploi d'un appareil); របៀបប្រើប្រាស់ (ឧ. l'emploi d'une somme, d'un mot); មុខងារ, របរ (ឧ. obtenir un emploi); កំណែង (ឧ. donner de l'emploi) ។ *Théâtr.* តួ (ឧ. emploi de père noble)។ double emploi ការមានស្ទួន ។ plein emploi ម.ព. plein emploi ។ emploi de temps វិភាគកាល

employable *a.* អាចប្រើប្រាស់បាន (ឧ. matériaux employables)

employé,e *n.* និយោជិត-ជិកា,អ្នកបម្រើ (ឧ. une employée de magasin) ។ employé de maison ជាប្រោព្រឹងផ្ទះ

employer *v.t.* ប្រើ (ឧ. employer des termes impropres; employer mille ouvriers); ពឹង (ឧ. employer ses protecteurs) ។ **s'employer** *v.pr.* មានគេប្រើ (ឧ. ce mot ne s'emploie plus)។ **s'employer à** ខំប្រឹង (ឧ. s'employer à bien faire)

emplumer *v.t.* បំពាក់រោមស្លាប

empocher *v.t. Fam.* ដាក់ក្នុងហោប៉ៅ (ឧ. empocher de l'argent) ។ *Fig.*& *fam.* ត្រូវ (ឧ. empocher des coups)

empoignade *n.f. Fam.* ការទាស់ទែងខ្លាំង

empoignant,e *a.* ដែលឡប់ម; ដែលឲ្យរំភើបខ្លាំង (ឧ. spectacle empoignant)

empoigne *n.f.* ការឡប់ម។ *Fam.* acheter une chose à la foire d'empoigne លួច

empoigner *v.t.* ក្របួច, ឡប់ម, ក្តាប់ ។ *Fam.* ចាប់ (ឧ. empoigner un voleur)។ *Fig.* ធ្វើឲ្យរំភើបចិត្ត (ឧ.

vanité n'est généreux que par emprunt)។ d'emprunt *loc. adv.* ខ្ចីគេ (ឧ. des meubles d'emprunt); ក្លែង (ឧ. nom, vertu d'emprunt) ។ par emprunt *loc. adv.* ដោយខ្ចី

emprunté,e *a.* ដែលខ្ចីគេ។ *Par ext.* ដែលខ្ចីអំពី, ដែលមកអំពី (ឧ. mots empruntés au latin); ក្លែង (ឧ. des vertus empruntées); ឆ្គង (ឧ. avoir l'air emprunté)

emprunter *v.t.* ខ្ចី (ឧ. emprunter de l'argent à quelqu'un) ។ *Fig.* ទទួលពី (ឧ. la lune emprunte sa lumière au soleil); យកមកប្រើ (ឧ. le français emprunte de nombreux mots à l'anglais); ពឹង (ឧ. emprunter la main d'un secrétaire); ក្លែងឫក (ឧ. emprunter l'aspect de la vertu)។ *Fig.* ស្រង់, ស្រាប់ (ឧ. emprunter une pensée à un auteur); ដើរតាម (ឧ. quelle route avez-vous empruntée)

emprunteur,euse *n.&a.* ដែលខ្ចី; ដែលធ្លាប់តែខ្ចីគេ

empuantir *v.t.* ធ្វើឲ្យធុំក្លិនអាក្រក់

empuantissement *n.m.* ភាពធុំក្លិនអាក្រក់

émulation *n.f.* សាមគ្គ, ការដណ្ដើមតើងគ្នា; ចិត្តប្រណាំងប្រជែង (ឧ. encourager l'émulation chez les enfants)

émule *n.&a.* អ្នកប្រណាំងប្រជែង (ឧ. Racine fut l'émule de Corneille); គូប្រណាំងប្រជែង

émulsif,ive *a.* ដែលគេគាបយកប្រេងបាន

émulsion *n.f.* គេល្វក [គេ-ល្វ-ក:—] (ឧ. le lait est une émulsion de graisse dans l'eau) ។ émulsion photographique គេល្វកថតរូប

émulsionner *v.t.* ធ្វើគេល្វក (ឧ. émulsionner une potion)

en *pré.* នៅ(កន្លែង) (ឧ. en France); នៅ(ក្នុងពេល) (ឧ. en été) ។ je suis en bonne santé ខ្ញុំមានសុខភាពល្អ ឬ ខ្ញុំសុខសប្បាយ ។ de mal en pis រឹតតែខ្លាំងឡើង ។ il est en colère គាត់កំពុងខឹង។

il est en deuil គាត់កំពុងកាន់មរណសញ្ញា ឬ កាន់ទុក្ខ ។ en hâte ដោយប្រញាប់ ។ se conduire en ami ប្រព្រឹត្តជាមិត្ត។ en honneur de ជាកិត្តិយសចំពោះ។ mettre en vente ដាក់លក់ ។ អំពី, ដោយ (ឧ. en bois, en marbre, etc...)

en *adv. de lieu* នោះ (ទីនោះ) (ឧ. j'en viens; s'en aller)

en *pr.pers. inv.* អំពី (ឧ. c'est un ami, je n'oublierai pas les services que j'en ai reçus); របស់នោះ (ឧ. vous avez de belles fleurs, donnez-m'en quelques unes); ដោយហេតុនោះ។ en être pour ខាតឥតប្រយោជន៍ (ឧ. en être pour sa peine ខាតកម្លាំងឥតប្រយោជន៍)

enamourer ឬ **énamourer** *v.t.* បង្កើតស្នេហា។ s'enamourer ឬ **s'énamourer** *v.pr.* ជាប់ចិត្តស្នេហា

encabanage *n.m.* ការបន្ទំនាង (ការដាក់នាងឲ្យពោងមែកឈើព័ទ្ធសំបុក)

encabaner *v.t.* បន្ទំនាង (ដាក់នាងឲ្យពោងមែកឈើព័ទ្ធសំបុក)

encablure *n.f. Mar.* រង្វាស់ប្រវែង ១២០ព្យាម (គឺប្រហែល ២០០ម៉ែត្រ)

encadrement *n.m.* ការដាក់ក្រប (ឧ. l'encadrement d'une porte; l'encadrement d'un tableau); ក្របជុំវិញ, ជាយ (ឧ. encadrement de gazon) ។ *Fig.* ការដាក់ឲ្យមានក្របខ័ណ្ឌ (ឧ. procéder à l'encadrement des recrues)

encadrer *v.t.* ដាក់ក្រប (ឧ. encadrer un tableau); ដាក់ហាមឬវណ្ឌ (ឧ. encadrer un journal de noir)។ *Par anal.* ព័ទ្ធ (ឧ. potager qu'encadre une bordure de buis); ដាក់ឲ្យមានក្របខ័ណ្ឌ (ឲ្យមាននាយបង្ហឹកអប់រំ) (ឧ. encadrer de jeunes recrues; troupes bien encadrées)។ *Par ext.* ដាក់ឲ្យមានអ្នកត្រួត (ឧ. encadrer un prisonnier)។ *Fig.* លៃដាក់ក្នុង (ឧ. encadrer un monument dans un paysage)។ *Ironiq.* être à encadrer ឈ្លើយ, ចំឡែក។ *Mil.* ឲ្យមានក្របខ័ណ្ឌ, ឲ្យមានអ្នកដឹកនាំ ។ encadrer une troupe ឲ្យមាន

តាយអាហារគ្រប់គ្រាន់

encadreur *n.m.* អ្នកដាក់ក្រប

encagement *n.m.* ការដាក់ទ្រុង

encager *v.t.* ដាក់ទ្រុង។ *Fam.* ដាក់គុក

encaissable *a.* អាចទារ-ទទួល ឬ ដាក់ហិបបាន (ឧ. sommes encaissables)

encaissage *n.m.* *Com.* ការដាក់ហិប (ឧ.encaissage de marchandises); ភាពវត្ថុដាក់ក្នុងហិប (ឧ. un encaissage défectueux) ។ *Hort.* ការដាំក្នុងហិប ឬ ឡាំង

encaissant,e *a.* ដែលស្រោបរំ (ឧ. roche encaissante)

encaisse *n.f.* ប្រាក់ឬតម្លៃដែលមានក្នុងហិប

encaissé,e *a.* ដែលមានច្រាំងចោត(ទន្លេ) (ឧ. rivière encaissée); ចង្អៀត (ផ្លូវ) (ឧ. chemin encaissé)

encaissement *n.m.* ការដាក់ហិប(ឧ. l'encaissement des marchandises)។ *Com.* បេឡានិយ័យ, ការដាក់ហិប,ការទទួលប្រាក់ទុក។ភាពទន្លេដែលមានច្រាំងចោត;ភាពផ្លូវចង្អៀត

encaisser *v.t.* ដាក់ហិប (ឧ. encaisser des marchandises) ។ *Com.* ទារប្រាក់, ទទួលប្រាក់ទុក, ទទួល (ឧ. encaisser un effet)។ *Pop.* ត្រូវ,ងារគ្រោះ(ឧ. encaisser une gifle)

encaisseur *n.m.* អ្នកទារប្រាក់, អ្នកទទួលប្រាក់ (ឧ. l'encaisseur d'un effet)

encalminé,e *a.* *Mar.* ដែលទៅមិនរួចដោយគ្មានខ្យល់(ឧ.voilier encalminé)

encan *n.m.* ការលក់ឡាយឡុង(ឧ.vendre des meubles à l'encan) ។ *Fig.* អំពើប្រព្រឹត្តថោកទាប (ឧ. mettre sa conscience à l'encan)

encanaillement *n.m.* ការធ្វើឲ្យថោកទាប; ការចុះថោកទាប

encanailler *v.i.* ឲ្យចូលនឹងជនថោកទាប (ឧ. autrefois, un noble encanaillait sa fille en la mariant à un riche financier); បញ្ចូលជនថោកទាប (ឧ. encanailler sa maison)។ *Fig.* ធ្វើឲ្យថោកទាប ។ s'encanailler *v.pr.* ចូលរួមនឹងជនថោកទាប; ចុះថោកទាប (ឧ.il est vrai que le

siècle s'encanaille furieusement (Molière)

encaper *v.i.* ចូលចន្លោះជ្រោយពីរ (ឧ. le navire a encapé)។ *v.t.* បើកចូលចន្លោះជ្រោយពីរ (ឧ. encaper un navire)។ *Pop.* ចាប់យក

encapuchonner *v.t.* បំពាក់មួកមួយយ៉ាង (ឧ. encapuchonner la tête d'un enfant)។ *Fam.* បំបួស។ s'encapuchonner ពាក់មួកមួយយ៉ាង។ *Fam.* ចូលបួស

encaquer *v.t.* រៀបត្រីដាក់ក្នុងធុង។ *Fig.* ជិះរថយន្ត ឬ នៅក្នុងបន្ទប់ប្រជ្រៀតគ្នា

encart *n.m.* សន្លឹកក្រដាសដែលគេស៊កក្នុងសៀវភៅ

encartage *n.m.* ការស៊កក្រដាស; ការភ្ជាប់លើក្រដាសក្រាស់

encarter ឬ **encartonner** *v.t.* ស៊កក្រដាស; ភ្ជាប់លើក្រដាសក្រាស់ (ឧ. encarter des boutons)

encarteuse *n.f.* ម៉ាស៊ីនភ្ជាប់ឡេវ ឬ របស់តូច ៗ លើក្រដាសក្រាស់

en-cas ឬ **encas** *n.m. inv.* វត្ថុទុកបម្រុងពេលអាសន្ន; ឆ័ត្រម្យ៉ាង; អាហារស្រស់ស្រួប

encaserner *v.t.* បង្ខាំងក្នុងបន្ទាយ

encastrement *n.m.* ការស៊ក, ការសៀត។ *Techn.* ដំណាប់

encastrer *v.t.* បញ្ចុះដំណាប់

encaustiquage *n.m.* ការខាត់នឹងក្រមួន

encaustique *n.f.* ក្រមួនខាត់

encaustiquer *v.t.* ខាត់នឹងក្រមួន (ឧ. encaustiquer un meuble, un parquet)

encavement *n.m.* ការដាក់ក្នុងភូមិគ្រឹះ; ភាពវត្ថុនៅក្នុងភូមិគ្រឹះ (ឧ. l'encavement améliore le vin)

encaver *v.i.* ដាក់ក្នុងភូមិគ្រឹះ

enceindre *v.t.* ព័ទ្ធដោយរបងឬកំពែង; បិទបាំង (ឧ. enceindre une ville de murailles)

enceinte *n.f.* គព្ភវតី [គ័ព-ភៈ-វៈ-តី], កំពែង, បរិវេណ (ឧ. l'enceinte de murailles; l'enceinte de Paris)

enceinte *a.f.* ដែលមានគភ៌, ដែលដើម

encellulement *n.m.* ការឃុំក្នុងបន្ទប់តូច

encelluler *v.t.* ឃុំក្នុងបន្ទប់តូច

encens *n.m.* គ្រឿងក្រអូបសំរាប់ដុត (ឧ. le meilleur encens vient

d'Arabie) ។ *Fig.* ការគោរពបូជា (ឧ. l'encens de la flatterie)

encensement *n.m.* ការបង្ហុយក្លិនក្រអូប (ឧ. l'encensement de l'autel)។ *Fig.* ការបញ្ជោរ

encenser *v.t.* បង្ហុយគ្រឿងក្រអូបលើ។ *Fig.* គោរពបូជា;បញ្ជោរ(ឧ. encenser un ministre puissant)

encenseur *n.m* អ្នកសរសើរ,អ្នកបញ្ជោរ

encensoir *n.m.* ភាជន៍ដុតគ្រឿងក្រអូប។ donner des coups d'encensoir ឬ casser l'encensoir sur le nez បញ្ជោរហួសពេក

encéphalalgie *n.f.* ឈឺក្នុងខួរក្បាល

encéphale *n.m.* ខួរក្បាល

encéphalique *a.* នៃខួរក្បាល (ឧ. douleur encéphalique)

encéphalite *n.f.* រោគរលាកខួរក្បាល (ឧ. encéphalite aiguë)

encéphalopathie *n.f.* រោគខួរក្បាល

encerclement *n.m.* ការវ័ណ្ឌ; ការឡោមព័ទ្ធ

encercler *v.t.* វ័ណ្ឌ; ឡោមព័ទ្ធ (ឧ. encercler une armée, une ville)

enchainement *n.m.* ការដាក់ច្រវាក់; ការភ្ជាប់គ្នា (ឧ. l'enchainement des idées)។ *Mus.* សន្តតិសព្ទ

enchainer *v.t.* ដាក់ច្រវាក់ (ឧ. enchainer un chien)។ *Fig.* ជិះជាន់,ដាក់ពាចិណុះ(ឧ. enchainer un peuple); ធ្វើឲ្យតាំងនៅជាប់ (ឧ. le destin nous enchaine en cet endroit); ធ្វើឲ្យជាប់ចិត្ត (ឧ. enchainer les cœurs); សម្របសម្រួល (ឧ. bien enchainer ses idées)។ *Abs.* និយាយបន្តភ្ជាមៗ

enchanté,e *a.* ត្រូវស្នេហ៍។ *Fig.* សប្បាយចិត្តជាអនេក,រីករាយ (ឧ. enchanté de vous faire connaissance)

enchantement *n.m.* វសករណ៍ (ការធ្វើឲ្យនៅក្នុងអំណាច ពីបង្គាប់បានដូចចិត្ត;ការដាក់ស្នេហ៍(ឧ. croire aux enchantements); វត្ថុអស្ចារ្យ(ឧ. cette fête était un enchantement)។ comme par enchantement ដូចជានិមិត; ដោយអស្ចារ្យ; ដោយមិនដឹងមុន (ឧ. la douleur a disparu comme par enchantement) ។ *Fig.* ប្រមោទ្យ, សេចក្តីរីករាយ, អំណរយ៉ាង

ខ្លាំង (ឧ. être dans l'enchantement)

enchanter *v.t.* ដាក់ស្នេហ៍។ *Fig.* ធ្វើឲ្យកើតស្នេហា; ធ្វើឲ្យរីករាយខ្លាំង (ឧ. sa grâce m'enchante)

enchanteur, eresse *a.&n.* *Fig.* ដែលឲ្យកើតស្នេហា(ឧ.regard enchanteur); ពីរោះ (ឧ. voix enchanteresse)។ *n.m.* គ្រូស្នេហ៍, គ្រូអំពើ(ឧ.l'enchanteur Merlin)

enchaperonner *v.t.* បំពាក់មួកម្យ៉ាង

enchâssement *n.m.* ការបញ្ចុះដំណាប់; របៀបបញ្ចុះដំណាប់

enchâsser *v.t.* ដំកល់ក្នុងក្លង (សារីរិក-ធាតុ) (ឧ. enchâsser des reliques); បញ្ចុះដំណាប់; ដាំ (ឧ. enchâsser un diamant) ។ *Fig.* បញ្ចូល(ឧ. enchâsser une citation dans un discours)

enchâssure *n.f.* ការដាំពេជ្រ(ឧ.confier à un joaillier l'enchâssure d'un diamant); សំបក (សំបកដាំពេជ្រ) (ឧ. enchâssure richement travaillée)។ *Fig.* les mots ne doivent être que l'enchâssure des idées ពាក្យគ្រាន់តែជាគ្រឿងតាំងទ្រគំនិត

enchatonnement *n.m.* ការតាប់ត្បូងចិញ្ចៀន

enchatonner *v.t.* តាប់ត្បូងចិញ្ចៀន (ឧ. enchatonner un rubis)

enchausser *v.t.* គ្របបន្លែដោយចំបើង ដើម្បីឲ្យឡើងស

enchemisage *n.m.* ការដាក់ស្រោម

enchemiser *v.t.* ដាក់ស្រោម (ឧ. enchemiser un livre, un obus)

enchère *n.f.* ការដេញថ្លៃ,ការលក់ឡាយឡុង (ឧ. vendre sa maison aux enchères)។ *Fig.* être à l'enchère ព្រមធ្វើការឲ្យអ្នកដែលហ៊ានថ្លៃជាងគេ ។ folle enchère អំពើអ្នកដេញថ្លៃបានប៉ុន្តែគ្មានប្រាក់បង់

enchérir *v.t.* ដេញថ្លៃ (ឧ. enchérir un immeuble); ដំឡើងថ្លៃ។ *v.i.* ឡើងថ្លៃ (ឧ. le vin enchérit)។ enchérir sur ដេញដំឡើងថ្លៃ ។ *Fig.* បំផ្លើស(ឧ.Néron enchérit sur la cruauté de Tibère)

enchérissement *n.m.* ការឡើងថ្លៃ(ឧ. l'enchérissement du riz, des loyers)

enchérisseur *n.m.* អ្នកដេញថ្លៃ (ឧ.

le dernier et plus offrant enchérisseur)

enchevalement *n.m.* ការទល់ផ្ទះ ដែលគេចង់ជួសជុល

enchevaucher *v.t.* ដាក់គងលើគ្នា(ដូចក្បឿងប្រក់ផ្ទះ)

enchevêtrement *n.m.* ការប្រទាក់ទាក់គ្នា។ *Fig.* ការច្របូកច្របល់ (ឧ. enchevêtrement de pensées)

enchevêtrer *v.t.* ទាក់កសត្វ(ឧ. enchevêtrer un cheval):ដាក់គោ។ *Par ext.* ធ្វើឲ្យប្រទាក់ទាក់គ្នា (ឧ. enchevêtrer du fil)។*Fig.* ធ្វើឲ្យជាប់គ្នាហូរហែ(ឧ. enchevêtrer les péripéties d'un roman)។

s'enchevêtrer *v.pr.* ជាប់ជើង (សត្វជំពាក់ជើងនឹងខ្សែ) ។ *Fig.* ឡប់គំនិត (ឧ. s'enchevêtrer dans un long raisonnement); ច្រឡំបល់ (ឧ. des phrases qui s'enchevêtrent);ជំពាក់ (ឧ. fil qui s'enchevêtre)

enchevétreur *n.m.* អ្នកធ្វើអ្វីៗដែលស្មុគស្មាញ

encheviller *v.t.* ដោតកន្លាស់; ភ្ជាប់កន្លាស់

enchifrené,e *a.* តឹងច្រមុះ

enchifrènement *n.m.* ការតឹងច្រមុះ

enchifrener *v.t.* ធ្វើឲ្យតឹងច្រមុះ (ឧ. le rhume nous enchifrène)

enclave *n.f.* បរិវទ្ធភូមិ[ប៉ៈ-រិ-វ័ទ-ធៈ-] (ដីដែលមានដីឯទៀតព័ទ្ធជុំវិញ)(ឧ. la frontière franco-espagnole comprend plusieurs enclaves)

enclavement *n.m.* បរិវទ្ធកម្ម; បរិវទ្ធ-ការ

enclaver *v.t.* បរិវ័ទ្ធ , ព័ទ្ធជុំវិញ (ដី); ស៊កបញ្ចូល

enclin,e *a.* ដែលលំឱន, ដែលមានចិត្តទាក់ទៅ (ឧ.être enclin au mal)

encliquetage *n.m.* ស្លក្បាលឆ្កែ

encliqueter *v.t.* ដាក់ស្លក្បាលឆ្កែ

encloitrer *v.t.* ម.ព. cloitrer

enclore *v.t.* ហ៊ុំរបង, ធ្វើរបងព័ទ្ធជុំវិញ (ឧ. enclore un jardin) ; ព័ទ្ធជុំវិញ (ឧ. mur qui enclòt un terrain)

enclos *n.m.* ហ៊ានវតី[-វៈ-ដី](ផ្ទៃដីដែលមានរបងព័ទ្ធជុំវិញ) (ឧ. habiter un enclos)

enclouage *n.m.* ការញាស់មាត់ត្រែកាំ-

ភ្លើងធំ(មិនឲ្យឈាញ់កើត)។ *Chir.* ការមិនឆ្អឹងបែកដោយដែកគោល ។ *Art vétér.* ការធ្វើឲ្យមុតទឹងដែកគោល (ដោយបោះដែកក្រចកសេះ) (ម.ព. enclouure ផង)

encloué,e *n.Fig.* មនុស្សឆ្គង

enclouer *v.t.*ហ៊ុមរបង(ឧ. enclouer son domaine)។ *Autref.* ភ្ជស់មាត់ក្រែកាំភ្លើងធំ (មិនឲ្យឈាញ់កើត)។ ភ្ជាប់ ។ *Pop.* បញ្ចាំ (ឧ. enclouer sa toquante)។ *Fig.* ធ្វើឲ្យខូច ឬ ឲ្យគាំង (ឧ. la douleur encloue l'esprit comme le courage (H. de Balzac) ។ *Art vétér.* ធ្វើឲ្យមុតនឹងដែកគោលដោយបោះក្រចក (ឧ. enclouer un cheval en le ferrant) ។

s'enclouer *v.pr.* មុតនឹងដែកគោល(ដែកគោលបោះក្រចកសេះ)។ *Fig.* ទាល់ប្រាជ្ញ

enclouure *n.f.* របួសនឹងដែកគោល (ក្នុងការបោះក្រចកសេះ)

enclume *n.f.* ដែកទ្រនាប់។ remettre un ouvrage sur l'enclume ធ្វើការអ្វីមួយឡើងវិញ។ se trouver entre l'enclume et le marteau ចុះទឹកក្រពើឡើងលើខ្លា

enclumeau ឬ **enclumot** *n.m.* ឬ **enclumette** *n.f.* ដែកទ្រនាប់តូច

encoche *n.f.* គុជាងធ្វើស្បែកជើងឈើ; ស្នាមក្រិត

encochement *n.m.* ការក្រិត ឬ ឈាក់ចំណាំ

encocher *v.t.* ក្រិត, ឈាក់; យកស្នា

encoffrer *v.t.* ដាក់ក្នុងហិប

encoignure [-ko-] *n.f.* មុំជញ្ជាំង; តុទូមុំជញ្ជាំង

encollage *n.m.* ការលាបកាវ ឬ ឲ្យជាយ; ភាពវត្ថុលាបកាវ ឬ ជាយម៉ាន

encoller *v.t.* លាបកាវ; ឲ្យជាយ (ឧ. encoller une étoffe)

encolleur,euse *a.&n.* ដែលលាបកាវ ឬ ឲ្យជាយ ។ *n.f.* ម៉ាស៊ីនឲ្យជាយ

encolure *n.f.* កសេះ; ករាវ (ឧ. encolure d'une chemise) ; ក (ឧ. homme d'une robuste encolure) ។ *Fig.* ដំណើរ

encombrant,e *a.* ប្រគឹងប្រគាង, ទទើសទទែង, សំពីងសំពោង (ឧ. colis encombrant) ។ *Fig.* ដែលនាំឲ្យរំខាន ឬ ឲ្យខ្វល់ (ឧ. personne encombrante)

encombre *n.m.* ឧបសគ្គ; គ្រោះថ្នាក់ ។ sans encombre *loc. adv.* ដោយគ្មានឧបសគ្គ

encombrement *n.m.* ការទទើសទទែង; របស់ច្រកឹងច្រកាង (ឧ. un encombrement de voitures)

encombrer *v.t.* ធ្វើឲ្យទទើសទទែង(ឧ. encombrer un corridor) ។ *Fig.* ផ្ទុកច្រើនពេក (ឧ.il encombre sa mémoire de petits détails)។ s'encombrer *v.pr.* *Fam.* s'encombrer de quelqu'un យកមនុស្សម្នាក់មកឲ្យរំខាន

encontre de (à l') *loc. pré.* ដោយប្រាស។*Fig.* ដោយជំទាស់ ។ aller à l'encontre de ជំទាស់, ពាំង

encorbellement *n.m.* ញកផ្ទះ

encorder (s') *v.pr.* ចងបន្តា

encore *adv.* ទៀត, ថែមទៀត (ឧ. je veux encore essayer; riche, on veut s'enrichir encore)។ ដោយហោចទៅ (ឧ. si encore il comprenait)។ នៅឡើយ ។ pas encore មិនទាន់ ។ non seulement... mais encore... មិនត្រឹមតែ... ថែមទាំង... ទៀត ។ encore que *loc. conj.* ថ្វីបើ (ឧ. encore qu'il soit jeune)។ encore! ទៀតហើយ! (ឧ. encore vous !)

encorné,e *a.* ដែលមានស្នែង (ឧ.bouc haut encorné)

encorner *v.t.* ហនស្នែង, ប៉ោកស្នែង; វែធ (នឹងស្នែង)

encourageant,e *a.* ដែលលើកទឹកចិត្ត, ជាទីកក់ក្តៅ (ឧ. un sourire encourageant)

encouragement *n.m.* ការធ្វើឲ្យមានសេចក្តីក្លាហាន, ការលើកទឹកចិត្ត; អ្វីៗដែលលើកទឹកចិត្ត (ឧ. prodiguer des encouragements) ; ការជួយជំរុញ, ការអនុគ្រោះ

encourager *v.t.* ធ្វើឲ្យមានសេចក្តីក្លាហាន,លើកទឹកចិត្ត(ឧ. encourager des élèves); អនុគ្រោះ (ឧ. encourager l'industrie); ជួយជំរុញ

encourir *v.i.* ទទួលរង(ឧ. encourir la haine générale)

encrage *n.m.* ការលាបទឹកខ្មៅឲ្យម៉ាស៊ីនបោះពុម្ព

encrassement *n.m.* ការធ្វើឲ្យមាន

ក្អែល; ការជាប់ក្អែល; ភាពជាប់ក្អែល

encrasser *v.t.* ធ្វើឲ្យមានក្អែល (ឧ. la poussière encrasse les vêtements)។ s'encrasser *v.pr.* ជាប់ក្អែល ។ *Fig.* មានសៅហ្មង, ចុះថោកទាប

encre *n.f.* ទឹកខ្មៅ (ឬ ទឹកសរសេរ), ទឹកមឹក។ encre d'imprimerie ទឹកខ្មៅពុម្ព។ encre de chine ទឹកខ្មៅចិន ។ encre sympathique ទឹកខ្មៅសម្ងាត់ (ទាល់តែចេះមើលទើបឃើញ) ។ *Fig.* bouteille à l'encre រឿងស្មុគស្មាញ(ពិបាកយល់)

encrer *v.t.* លាបទឹកខ្មៅ; ព្រាកទឹកខ្មៅ

encreur *n.&a.m.* សំរាប់លាបទឹកខ្មៅ (ឧ. rouleau encreur d'une presse d'imprimerie)

encrier *n.m.* ដបទឹកខ្មៅ

encroûtant,e *a.* ដែលទៅជាក្អាំង; ដែលមានក្អាំង ឬ ក្រមរ

encroûté,e *a.* ដែលមានក្អាំង ឬ ក្រមរ; ដែលមានបូកជាយអរ ។ *Fig.* មានះ (ឧ. encroûté de préjugés)

encroûtement *n.m.* ភាពមានក្អាំង ឬ ក្រមរ ។ *Fig.* ការបន្ថយផ្លូវគំនិត (ឧ. l'encroûtement d'un vieux rond-de-cuir)

encroûter *v.t.* គ្របដោយក្អាំងឬក្រមរ; បូកជាយអរ ។ *Fig.* បង្អាប់មិនឲ្យចេះដឹង ។ s'encroûter *v.pr.* មានក្អាំង ឬ ក្រមរ (ឧ. les chaudières à vapeur s'encroûtent facilement)។ *Fig.* មានះក្នុងទម្លាប់មិនល្អ

encuvage ឬ **encuvement** *n.m.* ការដាក់ក្នុងធុងឈើ

encuver *v.t.* ដាក់ក្នុងធុងឈើ

encyclopédie *n.f.* វិជ្ជាសមោធាន, ប្រជុំវិជ្ជា, វិជ្ជាគ្រប់ប្រភេទ (ឧ. l'Encyclopédie de Diderot et d'Alambert est l'œuvre maîtresse du XVIIIe siècle)។ *Fig.* l'encyclopédie vivante អ្នកចេះវិជ្ជាគ្រប់ប្រភេទ

encyclopédique *a.* នៃវិជ្ជាសមោធាន, ដែលមានវិទ្យាសាស្ត្រគ្រប់ប្រភេទ (ឧ. dictionnaire encyclopédique); ដែលចេះវិជ្ជាគ្រប់ប្រភេទ (ឧ. esprit encyclopédique)

encyclopédisme *n.m.* វិជ្ជាសមោធាននិយម

encyclopédiste *n.m.* អ្នកចិតវិជ្ជា-

សមោធាន(ឧ. Bayle fut le maître véritable des encyclopédistes)។ *a.* école encyclopédiste សាលាវិជ្ជាសមោធាន

endaubage *n.m.* ការខ្វៃសាច់ក្នុងឡ; សាច់គោប្រអប់

endauber *n.f.* ខ្វៃសាច់ក្នុងឡ

endémie *n.f.* ជម្ងឺដោយឡែកតាមតំបន់; ជម្ងឺភគត្បាតត្រាំត្រែង

endémique *a.* ដែលភគត្បាតត្រាំត្រែង (រោគ) (ឧ. la peste est endémique dans l'Hindoustan); ត្រាំត្រែង (ដែលមានជានិច្ច) (ឧ. chômage endémique)

endenté,e *a.* ដែលមានធ្មេញ ។ gens bien endentés អ្នកបរិភោគបានច្រើន

endenter *v.t.* ដាក់ធ្មេញចក្រ; បង្កាំដោយធ្មេញ

endettement *n.m.* ការជំពាក់បំណុល

endetter *v.t.* នាំឲ្យជំពាក់បំណុល (ឧ. ses dépenses l'ont endetté)។ s'endetter *v.pr.* ជំពាក់បំណុល

endeuiller *v.t.* ធ្វើឲ្យមានមរណទុក្ខ; ធ្វើឲ្យមានទុក្ខព្រួយ

endêvé,e *a.* ក្បៀវក្បា; គ្មានវិន័យ

endéver *v.i.Fam.* ខឹងណាស់។ faire endêver ធ្វើឲ្យពិបាកចិត្ត

endiablé,e *a.* ដែលខ្មោចចូល; ខឹល (ឧ. enfant endiablé); ក្បៀវក្បា (ឧ. allure endiablée)

endiabler *v.t.Fam.* ខឹងច្រឡោត(ឧ. faire endiabler quelqu'un)

endiamanté,e *a.* ដែលលំអដោយពេជ្រ ឬ របស់ភ្លឺដូចពេជ្រ

endiguement ឬ **endigage** *n.m.* ការលើកទំនប់ (ការរាំងដោយទំនប់)

endiguer *v.t.* លើកទំនប់ (រាំងដោយទំនប់) (ឧ. endiguer un fleuve)។ *Fig.* ទប់, រាំង (ឧ. endiguer la marche du progrès)

endimancher *v.t.* ស្លៀកពាក់ឲ្យដោយល្អដើតឆាយ (ឧ. endimancher des enfants)។ être endimanché វាយឫកមិនសមដោយស្លៀកពាក់ល្អដើតឆាយ

endive *n.f.* សាឡាត់ក្រញាញ់(ដែលគេដាំក្នុងម្លប់ឲ្យស)

endivisionner *v.t.* បែកជាកងពលធំ; បញ្ចូលក្នុងកងពលធំ

endocarpe *n.m.* សំបកគ្រាប់

endoctrinement *n.m.* ការបង្រៀន,

ការឲ្យជំពូន្មាន; ការបញ្ចុះបញ្ចូល

endoctriner *v.t.* បង្រៀន, ឲ្យដំបូន្មាន; បញ្ចុះបញ្ចូល (ឧ. endoctriner un électeur hésitant)

endoderme *n.m.* អន្តោត៌ច [អន់-តោ-តាច់]. ស្បែកក្នុង

endogène *a.* ដែល ក ពីក្នុង

endolorir *v.t.* ធ្វើឲ្យឈឺចាប់ (ឧ. pieds endoloris par la marche) ។ *Fig.* nouvelle qui endolorit le cœur ដំណឹងដែលធ្វើឲ្យឈឺចិត្ត

endolorissement *n.m.* ការឈឺចាប់

endommagement *n.m.* ការធ្វើឲ្យខូចខាត; ការខូចខាត

endommager *v.t.* ធ្វើឲ្យខូចខាត (ឧ. la grêle endommage les récoltes)

endoparasite *a.&n.m.* *Biol.* អន្តោបរាសិត (សត្វបរាសិតដែលរស់នៅក្នុងខ្លួន ដូចព្រូនជាដើម)

endormant,e *a.* ដែលធ្វើឲ្យដេកលក់ (ឧ. discours endormant)

endormeur,euse *n.* ចោរសណ្ដំ ឬធ្វើឲ្យដេកលក់ ។ *Fig.* អ្នកនាំឲ្យអំពល់; អ្នកលួងលោមឲ្យភ្លេចខ្លួន

endormi,e *a.* ដែលដេកលក់ ។ *Fig.* មិនស្មូវរហ័សរហួន; ខ្ជិល (ឧ. écolier un peu endormi); ស្រងំ (ដូចជារបស់ទាំងឡាយដេកលក់)(ឧ. campagne endormie)

endormir *v.t.* ធ្វើឲ្យដេកលក់ ។ *Fig.* លួងលោមឲ្យភ្លេចខ្លួន; នាំបន្ធូរ (ឧ. endormir la vigilance); ធ្វើឲ្យស្រាក (ឧ. endormir la douleur); ធ្វើឲ្យដេកលក់ (ដោយដាក់ថ្នាំស្ពឹកជាដើម); សណ្ដំ ។ *Par ext.* ធ្វើឲ្យអផ្សុក (ឧ. ses discours m'endorment) ។

s'endormir *v.pr.* ដេកលក់ ។ *Fig.* ភ្លេចខ្លួន; នៅស្ងៀម (គ្មានសកម្មភាព); ធ្វេសប្រហែស

endos ឬ **endossement** *n.m.* បិដ្ឋិលេខ, ការចារខ្នង, ការចុះហត្ថលេខាលើខ្នងរូបិយប័ណ្ណដំនួញប្រគល់ឲ្យម្ចាស់ថ្មី ។ endossement en blanc បិដ្ឋិលេខទុកស ។ endossement translatif បិដ្ឋិលេខផ្ទេរឲ្យ ។ endossement à titre de gage បិដ្ឋិលេខទុកជាតំណាង

endoscope *n.m.* *Méd.* អន្តោទស្សន៍ (ប្រដាប់សម្រាប់ឆ្លុះមើលក្នុងខ្លួនដូចជាបំពង់ក ទ្វារគ្រៀកជាដើម)

endoscopie *n.f.* អន្តោទស្សនកម្ម (ការឆ្លុះមើលក្នុងខ្លួន)

endoscopique *a.* នៃអន្តោទស្សនកម្ម

endosmose *n.f.* អភិសារណ៍ចូល (ម.ព. osmose ផង)

endossataire *n.* បដិគ្គាហក [–គា-ហ៊ក់] (អ្នកទទួលបដ្ឋិលេខ)

endosse *n.f.* ការទទួលខុសត្រូវ (ឧ. avoir toute l'endosse d'une affaire) ។ *Arg.* ស្មា; ខ្នងអាវ

endossement *n.m.* ម. ព. endos

endosser *v.t.* ពាក់ (ឧ. endosser son veston) ។ *Fig.* ទទួលខុសត្រូវលើខ្លួន (ឧ. endosser les bêtises des autres); ឲ្យទទួលរងការអ្វីដែលគេមិនចូលចិត្ត (ឧ. il m'a endossé de cette affaire) ។ endosser un enfant ទទួលយកជាកូន ។ endosser la cuirasse ឬ l'uniforme ចូលធ្វើទាហាន ។ endosser la soutane ចូលបួស (ក្នុងសាសនាគ្រិស្ត) ។ endosser l'écarlate ចូលធ្វើចៅក្រម ។ *Com.* ធ្វើបដ្ឋិលេខ,ធានាខ្នង ។ *Techn.* ពត់ខ្នងសៀវភៅឲ្យកោង (ក្នុងការចងសៀវភៅ)

endosseur *n.m.* អ្នកធ្វើបដ្ឋិលេខ

endossure *n.f.* ឬ **endossage** *n.m.* ការលាបកាវខ្នងសៀវភៅដើម្បីចង

endothermique *a.* ដែលស្រូបចំហាយ (ព.ផ. exothermique)

endroit *n.m.* ទី, កន្លែង (ឧ. un endroit écarté); ខាងត្រូវ(សំពត់)(ឧ. l'envers est opposé à l'endroit) ។ *Fam.* le petit endroit បង្គន់ ។ à l'endroit *loc. adv.* ត្រូវកន្លែង ។ à l'endroit de *loc. pré.* ចំពោះ (ឧ. il a mal agi à mon endroit)

enduire *v.t.* លាប,បូក,បៀក,លាបថ្នាំ, បន្សៀរឬពាត់

enduit *n.m.* ដីឬថ្នាំទឹកខាប់សំរាប់លាប

endurable *a.* អាចទ្រាំ ឬ ធន់បាន

endurance *n.f.* ការព្យែកធន់. ការមានអំណត់ (ឧ. les exercices du corps augmentent l'endurance physique)

endurant,e *a.* ដែលធន់, ដែលមានអំណត់

endurci,e *a.* ដែលថ្មឹក (ឧ. pécheur endurci); ដែលមានយូរហើយ (ឧ. haine endurcie); គ្មានមេត្តា (ឧ.

cœur endurci)

endurcir *v.t.* ធ្វើឲ្យរឹង (ឧ. le gel endurcit le sol); ធ្វើឲ្យធន់ (ឧ. le sport endurcit); ធ្វើឲ្យថ្នឹក (ឧ. endurcir à la fatigue)។ *Fig.* ធ្វើចិត្តឲ្យរឹង ឬ ឲ្យលែងមានមេត្តា (ឧ. l'avarice endurcit le cœur)។

s'endurcir *v.pr.* ឡើងរឹង, ថ្នឹក (ឧ. s'endurcir au froid, au travail)។*Fig.*លែងមានមេត្តា

endurcissement *n.m.* ភាពរឹង; ការធ្វើឲ្យធន់បាន (ឧ. endurcissement à la fatigue)។*Fig.*ភាពនៃចិត្តលែងមានមេត្តា (ឧ. l'endurcissement du cœur)

endurer *v.t.* ទ្រាំ (ឧ. endurer le froid, la faim); អត់ធន់ (ឧ. endurer les insolences de quelqu'un)

énergétique *a.* នៃថាមពល ។ *n.f.* *Méc.* ថាមពលវិទ្យា

énergie *n.f.* *Phys.* ថាមពល, កម្លាំង; (ឧ. énergie nucléaire); ការសក្តិសិទ្ធិ (ឧ. énergie d'un remède)។ *Fig.* ស្វាហាប់, សេចក្តីម៉ឺងម៉ាត់ (ឧ. montrer de l'énergie)

énergique *a.* ថាមវន្ត,ស្វាហាប់(ឧ. officier énergique; visage énergique)

énergiquement *adv.* ដោយស្វាហាប់ (ឧ. soutenir énergiquement une opinion)

énergumène *n.* មនុស្សខ្មោចចូល ។ *Fig.* មនុស្សច្រងេងច្រងាងឬឡូឡា

énervant,e *a.*ដែលធ្វើឲ្យអស់កម្លាំង(ឧ. chaleur énervante); ដែលឲ្យញាញ់ (ឧ. discussions énervantes)

énervation *n.f.* ការធ្វើឲ្យអស់កម្លាំងឬឲ្យញាញ់; ការផុតកែងជើងនឹងក្បាលជង្គង់(ទារុណកម្មជាន់ដើម)

énervé,e *a.&n.* ដែលអស់កម្លាំង;ដែលញាញ់;ដែលផុតកែងជើងនឹងក្បាលជង្គង់

énervement *n.m.* ភាពអស់កម្លាំង; សេចក្តីមួម៉ៅ (ឧ. l'énervement de l'attente); ការធន្ធធ្វេញ; សេចក្តីញាញ់

énerver *v.t.* ធ្វើឲ្យញាញ់ឬឲ្យអស់កម្លាំង; ផុតកែងជើងនឹងក្បាលជង្គង់ (ទារុណកម្ម)។*Fig.*ធ្វើឲ្យទន់ឬឲ្យលែងប្រឹង(ឧ.

plaisirs qui énervent); ធ្វើឲ្យទីង,ធ្វើឲ្យញាញ់(ឧ. une réponse qui énerve)

enfaîteau *n.m.* ក្បឿងព្រំ

enfaîtement *n.m.* ម.ព. faîtage

enfaîter *v.t.* ព្រំ;ដាក់ឲ្យពេញហៀរ (ឧ. enfaîter une cuiller)

enfance *n.f.* កុមារភាព។ première enfance បឋមកុមារភាព (ពីកើតដល់អាយុពីរឆ្នាំ គឺពេលដុះធ្មេញព្រៃហើយស្រេច) ។ seconde enfance មធ្យមកុមារភាព(ពីអាយុពីរឆ្នាំដល់ប្រាំពីរឆ្នាំ)។ កុមារកុមារី (ឧ. l'enfance est espiègle) ។ *Fig.* ភាពចាស់វង្វេង (ឧ. tomber en enfance); ភាពក្មេង (ឧ. l'enfance du monde)

enfant *n.* កុមារ,កុមារី (ឧ. charmante enfant);កូន(ឧ.cet homme a quatre enfants); កូនចៅ (ឧ. enfants d'Adam); កូនប្រុស(ឧ. les enfants de la France)។ faire l'enfant លេងដូចក្មេង ។ enfant gâté កូនទំរើស ។ enfant adoptif កូនចិញ្ចឹម។enfant légitime កូនពេញច្បាប់,កូនមានខាន់ស្លា។ enfant légitimé កូនបំពេញច្បាប់។ enfant naturel កូនព្រៃ, កូនគិតខាន់ស្លា ។ enfant reconnu កូនទទួលស្គាល់។ enfant trouvé កូនរើសបាន ។ *Fig.* ផល (ឧ. l'amour est l'enfant du loisir) ។ enfant d'Apollon កវី ។ enfant de Mars យោធិន, អ្នកចម្បាំង ។ bon enfant មនុស្សល្អ, មនុស្សស្លូតបូត

enfantement *n.m.* ប្រសូតិ, ការសម្រាលកូន,ការឆ្លងទន្លេ។ *Fig.* ការបង្កើត(ឧ. le pénible enfantement des chefs-d'œuvre)

enfanter *v.t.* ប្រសូត, បង្កើតកូន, ឆ្លងទន្លេ ។ *Fig.* បង្កើត, ប្រឌិត (ឧ. enfanter un projet)

enfantillage *n.m.* ល្បែងក្មេង,សំដីឬកិច្ចរបស់កូនក្មេង (ឧ.perdre son temps en enfantillage)

enfantin,e *a.* ដែលមានលក្ខណៈឬបែតជាក្មេង (ឧ. grâce enfantine) ។ *Par ext.* ងាយ(ឧ.question enfantine) ។ cours enfantin ម.ព. cours

enfariné,e *a.* ប្រឡាក់ម្សៅ,ដែលលាប

ម្សៅ (ឧ. visage enfariné)។ *Pop.* la gueule (ឬla-bouche) enfarinée សេចក្ដីទុកចិត្តខ្លួនឲ្យអស់សំណើច

enfariner *v.t.* ប្រឡាក់ឬរោយម្សៅ

enfer *n.m.* នរក, យមលោក (ឧ. les tourments de l'enfer)។ *Par ext.* បិសាចមកពីនរក (ឧ. les suggestions de l'enfer)។ *Fig.* នរក(កន្លែងវេទនា, កន្លែងគ្មានសណ្ដាប់ធ្នាប់)(ឧ. cette maison est un enfer); សេចក្ដីលំបាកចិត្ត(ឧ. avoir l'enfer dans le cœur); d'enfer ខ្លាំងណាស់។ feu d'enfer ភ្លើងនរក, ភ្លើងក្ដៅណាស់

enfermé *n.m.* ក្លិនខ្លួរ (ដោយអាប់អួរ) (ឧ. sentir l'enfermé)

enfermer *v.t.* បង្ខាំង(ឧ. enfermer des chevaux dans une écurie); ឃុំឃាំង; ដាក់សោទុក(ឧ. enfermer des papiers); មាន (ឧ. passage qui enferme des erreurs)។ s'enfermer *v.pr.* នៅតែម្នាក់ឯង

enferrer *v.t.* ចាក់នឹងដាវ។ s'enferrer *v.pr.* ស្ទុះទៅរងមុខដាវ។ *Fig.* ជាប់អន្ទាក់ឯង (កុហកខ្លួនឯងហើយជឿខ្លួនឯង)

enfeu *n.m.* ម៉ុង

enfieller *v.t.* ធ្វើឲ្យល្វីង។ *Fig.* ធ្វើឲ្យកាច

enfièvrement *n.m.* ការធ្វើឲ្យរំជើបរំជួល; ការរំជើបរំជួល

enfièvrer *v.t.* បណ្ដាលឲ្យគ្រុន។ *Fig.* ធ្វើឲ្យរំជើបរំជួល (ឧ. l'argent, le gain l'enfièvrent)

enfilade *n.f.* របស់រៀបជាជួរ, ជន្ទាស

enfilage *n.m.* ការដោតចេស

enfilée *n.f.* ម.ព. enfilade

enfiler *v.t* ដោតចេស; ដាក់ពីម្ខាងធ្លាយទៅម្ខាង។ enfiler un chemin ដើរតាមផ្លូវ។ *Fam.* ស្លៀក, ពាក់ (ឧ. enfiler un pantalon)។ *Artill.* បាញ់បណ្ដោយ (ឧ. enfiler une tranchée)

enfileur,euse *n.* អ្នកដោតចេស (ឧ. une enfileuse de perles)

enfin *adv* ដោយខ្លីទៅ, ក្នុងទីបំផុត

enflammé,e *a.* ដែលឆេះ; ដែលរលាក (ឧ. plaie enflammée)។ *Fig.* ដែលមានរន្ទះ (ឧ. yeux enflammées); ប្រឡោត (ឧ. en-

flammé de colère)

enflammer *v.t.* ដុត (ឧ. enflammer un bûcher); ធ្វើឲ្យក្ដៅខ្លាំង។ *Fig.* ធ្វើឲ្យខឹង; ធ្វើឲ្យក្ដៅក្រហាយ; សម្រើប (ឧ. ce discours enflamme leur courage)

enflé,e *a.* ដែលឡើងប៉ោង។ *Fig.* ដែលឡើងក្អេង (ឧ. enflé de ses succès); ពោរពេញ (ឧ. enflé d'orgueil)

enfléchure *n.f.* *Mar.* ជណ្ដើរខ្សែឡើងដងក្ដោង

enfler *v.t.* បំប៉ោង (ឧ. enfler ses joues); សប់បំប៉ោង (ឧ. enfler un ballon); ធ្វើឲ្យហើម (ឧ. les chaussures trop étroites enflent les pieds); ធ្វើឲ្យកើនឡើង; ធ្វើឲ្យជោរជន់ (ឧ. les pluies ont enflé la rivière)។ *Fig.* បំផ្លើស (ឧ. enfler un récit)។ *v.i.* ប៉ោង, ហើម (ឧ. ses jambes enflent)។

s'enfler *v.pr.* ឡើងប៉ោង (ឧ. le voile s'enfle); ហើម។ *Fig.* ឡើងឆ្មើងកន្ទ្រើង, ឡើងក្អេង

enfleurage *n.m.* ការអប់ផ្កា (ប្រេងឬក្រមួន)

enfleurer *v.t.* អប់ផ្កា (ប្រេងឬក្រមួន)

enflure *n.f.* ការប៉ោង ឬ ហើម។ *Fig.* ការបំផ្លើស, ការបំភ្លៃ (ឧ. l'enflure du style)

enfoncé,e *a.* ខួង, រូង (ឧ. avoir les yeux enfoncés dans la tête); ជ្រៅ (ឧ. une alcôve enfoncée)

enfoncement *n.m.* ការបុកទម្លាយ (ឧ. l'enfoncement d'une porte); ការវាយពន្លិច (ឧ. l'enfoncement d'un clou); ការរុក; កន្លែងដែលខួង ឬ ជ្រៅ; ភាពរវេងរវង (ឧ. les enfoncements de la côte bretonne)។ *Arch.* ជំជ្រៅ ឬសង្ហ:

enfoncer *v.t.* រុក; បុកទម្លាយ (ឧ. enfoncer une porte); វាយពន្លិច (ឧ. enfoncer un clou dans un mur); ទម្លុះ។ *Fam.* ជំនះ (ឧ. enfoncer un adversaire)។ *Par ext.* បំបែកខ្ទាត់ខ្ទាយ។ *Fig.* ធ្វើឲ្យចូលក្នុងខួរ (ឲ្យចាំបានយូរ)។ enfoncer une porte ouverte ទំបុកទម្លាយទ្វារបើកស្រាប់ (ទំពន្យល់របស់ស្ដែងស្រាប់)។

v.i. លិច (ឧ. ce navire

enfonce)។

s'enfoncer *v.pr.* ស្រុត (ឧ. le plancher s'enfonce); ចូលជ្រៅ, មុជជ្រៅ (ឧ. s'enfoncer dans l'eau); លិចបាត់ (ឧ. il s'enfonça dans la brume)។ *Fig.* លិចលង់ (វិនាស) (ឧ. avec de telles affaires, il a fini par s'enfoncer); លង់ខ្លួន (ឧ. il s'enfonce dans le désespoir)

enfonceur,euse *n.* អ្នកបុកទម្លាយ ។ un enfonceur de porte ouverte អ្នកបុកទម្លាយទ្វារបើកស្រាប់ (អ្នកពន្យល់របស់ស្ដែងស្រាប់)

enfonçoir *n.m.* ប្រដាប់បុកទម្លាយ

enfonçure *n.f.* កន្លែងផតឬខូង; បាតធុងឈើ

enforcir *v.t.* ធ្វើឲ្យរឹតតែខ្លាំង ។ *v.i.* ឡើងរឹតតែខ្លាំង

enformer *v.t.* ផ្ដិតពង

enfouir *v.t.* កប់ក្នុងដី (ឧ. enfouir des graines)។ *Fig.* លាក់; ទុកចោលឥតប្រយោជន៍ (ឧ. enfouir son talent)។ s'enfouir *v.pr.* កប់ខ្លួន; លាក់ខ្លួន (ឧ. aller s'enfouir au fond de sa province)

enfouissement *n.m.* ការកប់ក្នុងដី; ការលាក់

enfouisseur *n.m.* អ្នកកប់; អ្នកលាក់

enfourchement *n.m.* *Techn.* បែង ។ ដំណាមុខគ្នាជាចំពាម

enfourcher *v.t.* ដាក់ជើងយព្លូក; ជិះប្រកការ (ឧ. enfourcher une bicyclette)។ *Fam.* ជិះសេះ ។ enfourcher son dada និយាយពីរឿងដែលខ្លួនចូលចិត្ត

enfourchure *n.f.* *Bot.* ចំពាម, ប្រគាប ។ *Techn.* ចង្កេះជើងខោ

enfournage ឬ **enfournement** *n.m.* ឬ **enfournée** *n.f.* ការរៀបបញ្ចូលក្នុងឡ

enfourner *v.t.* បញ្ចូលក្នុងឡ ។ *Fig.* ចាប់ធ្វើការ (ឧ. mal enfourner une affaire)។ *Pop.* លេបឡៀបឡេប់

enfourneur *n.m.* អ្នកបញ្ចូលក្នុងឡ

enfreindre *v.i.* ប្រព្រឹត្តល្មើស (ឧ. enfreindre la règle)

enfuir (s') *v.pr.* រត់, គេច, ភៀសខ្លួន (ឧ. s'enfuir de prison); ហូរចេញ (ឧ. le vin s'enfuit du tonneau); ស្រុត (ឧ. le terrain

s'enfuit sous les pas)។ *Fig.* រលាយបាត់, កន្លងទៅ (ឧ. le bonheur, le temps s'enfuit)

enfumage *n.m.* ការបំពក់(បង្ហុយផ្សែងយកឃ្មុំ)

enfumer *v.t.* បង្ហុយផ្សែង; បំពក់(ភោលផ្សែង) (ឧ. enfumer les abeilles)។ enfumer un terrier បំពក់រូងសត្វ (បង្ហុយផ្សែងដាក់រូងសត្វដើម្បីធ្វើឲ្យវាចេញ)

enfûtage *n.m.* ការច្រកធុង(ឧ. enfûtage du vin)

enfûtailler *v.t.* ច្រកធុង

engagé *a.* ទាហានជាប់កិច្ចសន្យា ។ *a. Fin.* សេញ្ជិត ។ dépenses engagées ម.ព. dépense

engageable *a.* អាចបញ្ចាំបាន

engageant,e *a.* ដែលឲ្យជាប់ចិត្ត, ដែលបញ្ចូលចិត្ត(ឧ. manières engageantes) ។ *n.m.* បូចងនៅទ្រូង

engagement *n.m.* ការសន្យា; កិច្ចសន្យា (ឧ. signer un engagement); ការកំជាប់ពាក្យ (ក្នុងទម្រង់មង្គលការ) ។ faire honneur à ses engagements កាន់តាមកិច្ចសន្យា ។ ការបញ្ចាំ (ឧ. engagements au mont-de-piété); ការចូលធ្វើទាហានដោយស្ម័គ្រ; ការដាក់ឲ្យចូលប្រយុទ្ធ (ឧ. l'engagement des réserves); ការជាប់ដៃប្រយុទ្ធ ការប៉ះទង្គិច ។ *Fin.* សេញ្ចនកិច្ច

engager *v.t.* បញ្ចាំ (ឧ. engager son bien) ។ *Fig.* នាំឲ្យជាប់ (ឧ. un serment nous engage)។ engager sa parole កំជាប់ពាក្យ, សន្យា ។ ជួល (ឧ. engager un domestique); ដាស់តឿន, ជម្រុញ (ឧ. engager à travailler); អញ្ជើញ(ឧ. engager à diner); នាំឲ្យជាប់ដៃ (ឧ. engager dans de fâcheux démêlés); ដាក់ឲ្យប្រយុទ្ធ (ឧ. engager une division); បញ្ចូល; ផ្ដើម, ជាប់ធ្វើ (ឧ. engager le combat; engager une négociation)។ engager des capitaux បណ្ដាក់ទុន ។ cheval engagé សេះជាប់ឈ្មោះក្នុងបញ្ជីប្រណាំង ។ navire engagé នាវាផ្អៀង (ដោយត្រូវខ្យល់ ហើយងើបវិញមិនរួច) ។

s'engager *v.pr.* ចូលធ្វើទាហាន; ចូលកាន់ (ឧ. s'engager

dans un sentier); ចូលរួម (s'engager dans un championnat); សន្យា

engainant,e *a.Bot.* ដែលស្រោប (ឧ. feuilles engainantes)

engainer *v.t.* ដាក់ក្នុងស្រោម (ឧ. engainer un couteau); រុំ,ស្រោប (ឧ. les feuilles du blé engainent la tige)

engamer *v.i.* លេបសន្ទូច (ត្រី)

engazonnement *n.m.* ការដាំស្មៅ (ឧ. l'engazonnement d'un tertre)

engazonner *v.t.* ព្រោះឬដាំស្មៅ (ឧ. engazonner un tertre)

engeance *n.f.* ពូជ (ប្រើនិយាយចំពោះមនុស្សដែលគេមើលងាយ) (ឧ. maudite engeance)

engeancer *v.t.* រំខាន

engelure *n.f.* រោគប្រេះដៃ ឬជើង (ដោយត្រជាក់ជាដើម)

engendrement *n.m.* ការបង្កើត; ការបណ្ដាល

engendrer *v.t.* បង្កើត,បណ្ដាលឲ្យកើត, នាំឲ្យ ។ *Fig.* l'oisiveté engendre le vice ភាពទំនេរនាំឲ្យកើតបាបធម៌ (នាំឲ្យមនុស្សខូច)

engerbage *n.m.* ការចងជាកណ្ដាប់

engerber *v.t.* ចងជាកណ្ដាប់

engin *n.m.* ប្រដាប់, ឧបករណ៍, អាវុធ, អន្ទាក់ (ឧ. les engins destructeurs de la guerre)

englober *v.t.* ប្រមូល; មានរួមបញ្ចូល; ភប់បញ្ចូល

engloutir *v.t.* លេប ។ *Par ext.* ពន្លិច (ឧ. la mer a englouti bien des navires សមុទ្រពន្លិចនាវាអស់ច្រើន ។ *Fig.* ស្រូប; ធ្វើឲ្យរលាយ (ឧ. engloutir sa fortune dans une affaire)

engloutissement *n.m.* ការលេប; ការស្រូប; ការលិចចុះ; ការពន្លិច; ការធ្វើឲ្យរលាយ

engloutisseur,euse *n.* អ្នកលេប

engluement ‖ **engluage** *n.m.* ការដាក់ជ័រជាម; អ្វីៗដែលធ្វើឲ្យស្អិតជាប់

engluer *v.t.* លាបអ្វីដែលស្អិត; ដាក់ជ័រជាម (ឧ engluer des oiseaux) ។ *Fig.* បញ្ឆោតជាប់ដោយឧបាយ

engommage *n.m.* ការលាបជ័រ (ឧ. engommage des toiles)

engommer *v.t.* លាបជ័រ

engorgement *n.m.* ការស្ទះ (បំពង់ឬលូទឹក)

engorger *v.t.* ធ្វើឲ្យស្ទះ; ខ្ទប់

engouement ឬ **engoûment** *n.m.* ការស្ទះ។ *Fig.* ការកោតសរសើរហួសហេតុ (ឧ. l'engouement du public pour un acteur)

engouer *v.t.* ធ្វើឲ្យស្ទះឬឲ្យហួត។ s'engouer *v.pr.* ស្រឡាញ់ណាស់ (ឧ. s'engouer d'un meuble, d'un artiste)

engouffrement *n.m.* ដំណើរហូរចូលយ៉ាងខ្លាំង (ឧ. l'engouffrement du vent dans une cheminée); ការលោយបាត់ (ឧ. l'engouffrement d'une fortune)

engouffrer *v.t.* ធ្វើឲ្យលិចបាត់ក្នុងអន្លង់ (ឧ. la mer engouffre de nombreux vaisseaux)។ *Fig.* ត្របាក់; លេប (ឧ. engouffrer de la nourriture); ធ្វើឲ្យលោយ (ឧ. engouffrer son patrimoine)។ s'engouffrer *v.pr.* លិចក្នុងអន្លង់; ហួចចូលយ៉ាងខ្លាំង (ខ្យល់), ហូរចូលយ៉ាងខ្លាំង (ទឹក); ស្ទុះចូល (ឧ. s'engouffrer dans le métro)

engouler *v.t.* *Pop* លេបលើយរឡៀបរឡប់

engoulement *n.m.* ពញាក់ (បក្សីមួយយ៉ាង)

engourdir *v.t.* ធ្វើឲ្យស្រយង់ឬឲ្យស្រពន់ (ឧ. le froid engourdit)។ *Fig.* ធ្វើឲ្យខ្ជិល (ឧ. l'oisivité engourdit l'esprit)

engourdissement *n.m.* ការស្រយង់ឬស្រពន់។ *Fig.* ការមិនភិងវៃ (ឧ. engourdissement de l'esprit)

engrainer *v.t.* ម.ព. engrener

engrais *n.m.* ការបំប៉នឲ្យធាត់ (ឧ. mettre des bœufs à l'engrais); ស្មៅបំប៉នសត្វ; ចំណីបំប៉នសត្វស្លាប ។ *Agr.* ជី។ engrais azoté ជីអាសូត។ engrais chimique ជីគីមី។ engrais humain ជីករស [-ក:-រេស], ជីលាមក ។ engrais minéraux ជីខនិជ ។ engrais organique ជីសរីរាង្គ ។ engrais phosphaté ជីផូស្វាត ។ engrais potassique ជីប៉ូតាស ។ engrais vert ជីបៃតង (រុក្ខជាតិដែលភ្ជួរបង្កប់ក្នុងដីធ្វើជី), ជីស្រស់

engraissement ឬ **engraissage** *n.m.* ការបំប៉នឲ្យធាត់; ភាពឡើងធាត់ដោយបំប៉ន

engraisser *v.t.* បំប៉នឲ្យធាត់ (ឧ. engraisser les canards); ដាក់ជី (ឧ. le fumier engraisse la terre); ប្រឡាក់ខ្លាញ់។ *Fig.* បំពេញទ្រព្យសម្បត្តិ។ *v.i.* ឡើងធាត់ (ឧ. il a engraissé ឬ il est engraissé)

engraisseur *n.m.* អ្នកបំប៉នសត្វ

engrangement *n.m.* ការដាក់ក្រង់ឬដាក់ជង្រុក (ឧ. l'engrangement des blés)

engranger *v.t.* ដាក់ក្រង់, ដាក់ជង្រុក (ឧ. engranger du blé)

engravement *n.m.* ភាពកៀង; ការជាប់ក្រួសក្នុងកំពង់ផែ

engraver *v.t.* កៀង; ក្រាលក្រួស (ឧ. engraver un chemin)។ s'engraver *v.pr.* កើលជាប់(នឹងខ្សាច់ ឬ ក្រួស)

engraver *v.t.* ឈាក់ (ធ្វើឲ្យមានគន្លាក់)

engrenage *n.m.* *Méc.* ស្ពឺចក្រ។ *Fig.* រឿងហេតុស្មុគស្មាញ (ឧ. être pris dans un engrenage)

engrènement *n.m.* ការចាក់ស្រូវក្នុងគោត្បាល់កិន

engrener *v.t.* ចាក់ស្រូវក្នុងគោត្បាល់កិន; បំប៉នដោយឲ្យគ្រាប់ស៊ី

engrener *v.t.* បង្ខាំធ្មេញស្ពឺ។ *Fig.* រៀបចំ, ចាប់ផ្ដើមធ្វើ។ *v.i.* & s'engrener *v.pr.* ខាំគ្នា (ឧ. une roue qui engrène ឬ qui s'engrène bien)

engreneur *n.m.* កម្មករឬប្រដាប់ចាក់ស្រូវក្នុងគោត្បាល់កិន

engrenure *n.f.* របៀបបង្ខាំធ្មេញស្ពឺ

engrois *n.m.* ស្នៀតលោហពូថៅ ឬ ញញួរ

engueulement *n.m.* ឬ **engueulade** *n.f.* *Pop.* ការជេរស្ដី

engueuler *v.t.* *Pop.* ជេរស្ដី

enguichure *n.f.* ខ្សែស្ពាយស្នែងផ្លុំ; ព្រ័ត្រពាក់ខែល

enguignonné,e *a.* កំសៀយ (ឧ. joueur enguignonné)

enguirlander *v.t.* ពាក់តែងដោយកម្រងឬយោល (ឧ. enguirlander un arbre)។ *Fig.* ចេចង់; ជេរស្ដី

enhachement *n.m.* ភាគដីដែលលយចូលក្នុងដីជិតខាង

enhardir *v.t.* ធ្វើឲ្យហ៊ាន, ធ្វើឲ្យមានចិត្តលុះ: (ឧ. le succès enhardit)។

s'enhardir *v.pr.* ហ៊ាន, ឡើងចាង, បានចិត្ត

enharnachement *n.m.* ការឬរបៀបបំពាក់គ្រឿងសេះ

enharnacher *v.t.* បំពាក់គ្រឿងសេះ។ *Fig.* ស្លៀកពាក់មិនត្រូវរបៀប

enherber *v.t.* ដាំស្មៅ; ទុកឲ្យស្មៅដុះ

énigmatique *a.* បិទមុខ(ឧ. propos énigmatique); ដែលជាប្រស្នា (ឧ. conduite énigmatique); ដែលជាពាក្យបណ្ដៅ; ដែលគេពន្យល់មិនបាន

énigmatiquement *adv.* ដោយប្រស្នា, ដោយបិទមុខ

énigme *n.f.* ប្រស្នា,បណ្ដៅ (ឧ. Œdipe devina l'énigme du sphinx)។ *Fig.* សំដីស្ដាប់មិនបាន; របស់មិនអាចស្គាល់ច្បាស់បាន (ឧ. la nature est une énigme)។ le mot de l'énigme សម្រាយបណ្ដៅ, ពាក្យដោះប្រស្នា

enivrant,e [an-ni—] *a.* ដែលធ្វើឲ្យស្រវឹង (ឧ. les boissons alcooliques sont enivrantes)។ *Fig.* ដែលសម្រើប (ឧ. parfum, orgueil enivrant)

enivrement *n.m.* [an-ni—] ការធ្វើឲ្យស្រវឹង; ភាពស្រវឹង ។ *Fig.* ការស្រវឹង(សម្រើប) (ឧ. l'enivrement de la victoire)។ l'enivrement des passions ការស្រវឹងដោយតណ្ហា

enivrer *v.t.* [an-ni—] ធ្វើឲ្យស្រវឹង។ *Fig.* សម្រើប, ធ្វើឲ្យវង្វេង (ឧ. la prospérité l'enivre វិបុលភាពធ្វើឲ្យគាត់ស្រវឹង(ធ្វើឲ្យវង្វេង))។ **s'enivrer** *v.pr.* ស្រវឹង

enjambée *n.f.* ការឈាន; ជំហាន (ឧ. faire de grandes enjambées)

enjambement *n.m.* ទណ្ឌាភិក្យ

enjamber *v.t.* ឆ្លង (ឧ. enjamber le ruisseau)។ *v.i.* ដើរបោះជំហានវែង។ *Fig.* បំពាន, រំលោភ (ឧ. enjamber sur le champ du voisin)

enjaveler *v.t.* ដាក់ដៃស្រូវជាគំនរ (មិនទាន់ចងជាកណ្ដាប់)

enjeu *n.m.* ប្រយាគណាំង (ឧ. perdre son enjeu)។ *Fig.* របស់ដែលគេប្រថុយខាត (ឧ. l'enjeu d'une guerre)

enjoindre *v.t.* បង្គាប់; បង្គាប់ដោយដាច់ខាត

enjôlement *n.m. Fam.* ប្រិយភាព, ការលួងលោម ឬ បែបង់ -

enjôler *v.t. Fam.* បានដោយបែបង់(ឧ. enjôler une fille); លួងលោម, បញ្ជោរ (ឧ. se laisser enjôler)

enjôleur,euse *n.&a.* អ្នកលួងលោម ឬ បែបង់

enjolivement *n.m.* ការតែងលំអ (ឧ. faire des enjolivements à sa maison)

enjoliver *v.t.* តែងលំអ (ឧ. enjoliver une robe); បន្ថែម (ឧ. enjoliver un récit)

enjoliveur *n.m.* អ្នកតែងលំអ; របស់សម្រាប់តែងលំអ

enjolivure *n.f.* ការតែងលំអបន្តិចបន្តួច

enjoué,e *a.* ដែលរីករាយជាធម្មតា (ឧ. esprit enjoué)

enjouement ឬ **enjoûment** *n.m.* សេចក្តីរីករាយជាធម្មតា (ឧ. affecter de l'enjouement)

enjouer *v.t.* ធ្វើឲ្យរីករាយ (ឧ. il a enjoué toute la compagnie)

enjouer *v.t.* តម្រង់បាញ់(ឧ. enjouer un fusil)

enjuguer *v.t.* ទឹម (ឧ. enjuguer deux bœufs)

enjuponner *v.t.* ឲ្យស្លៀកសំពត់ទ្រនាប់

enkysté,e *a.* ដែលបញ្ចុះក្នុងសាច់

enkystement *n.m.* ការបញ្ចុះក្នុងសាច់

enkyster (s') *v.pr.* ឡើងពក (ឧ. tumeur qui s'enkyste)

enlacement *n.m.* ការប្រទាក់។ *Fig.* ការឱបរឹត, ការរឹតរួត

enlacer *v.t.* ចងប្រទាក់គ្នា(ឧ. enlacer des cordons)។ *Fig.* រឹត,ឱប(ឧ. enlacer son adversaire de ses bras)។ *Charp.* មឹនពន្លួញតំណាប់ (ភ្ជាប់ភ្ជាប់ពន្លួញក្នុងតំណាប់)

enlaçure ឬ **enlassure** *n.f.* ការមឹនពន្លួញតំណាប់

enlaidir *v.t.&i.* ធ្វើឲ្យអាក្រក់ (ឧ. peintre maladroit qui enlaidit son modèle)។ *v.i.* ទៅជាអាក្រក់ (ឧ. il a enlaidi ឬ il est enlaidi)

enlaidissement *n.m.* ការធ្វើឲ្យអាក្រក់

enlevage *n.m.* ការបំបាត់ពណ៌ចាស់ចេញ (ដោយលាងចោល ឬ ដោយផ្តិតពណ៌ថ្មីថែមពីលើ) (សំពត់)

enlevé,e *a. Fig.* ស្រស់ (ឧ. portrait enlevé)

enlèvement *n.m.* ការយកចេញ (ឧ. enlèvement des boues)។ *Fig.* ការពង្រត់ (ឧ. l'enlèvement des Sabines)

enlever *v.t.* លើកឡើងខ្ពស់;យកចេញ(ឧ. enlever des meubles)។*Fig.* ពង្រត់ (ឧ. enlever une mineure); ធ្វើឲ្យបាត់ឬឲ្យលុប (ឧ. enlever une tâche); សម្រើប (ឧ. enlever l'auditoire);បានដោយងាយ(ឧ. enlever les suffrages); ដណ្ដើម (ឧ. enlever à quelqu'un son commandement); លួច (ឧ. enlever une montre); វាយឆ្មក់បាន (ឧ. enlever un poste)។*Pop.* ស្ដីបន្ទោស

enliasser *v.t.* ដាក់ជាបាច់ឬជាសំណុំ

enlier *v.t.* រៀបខ្វែងគ្នា (ដូចឥដ្ឋជញ្ជាំង)

enlignement *n.m.* ការរៀបបន្តគ្នា; ភាពនៅតគ្នា

enligner *v.t.* រៀបបន្តគ្នា (ឧ. enligner des briques)

enlisement *n.m.* ដំណើរលង់ខ្សាច់, ដំណើរផុង

enliser ឬ **enlizer** *v.t.* ធ្វើឲ្យលង់ខ្សាច់,ធ្វើឲ្យផុង។ s'enliser *v.pr.* លង់ខ្សាច់, ផុង

enluminer *v.t.* ដាក់ពណ៌ (ឧ. enluminer des gravures); តែងលំអដោយរូបពណ៌។ *Fig.* លំអដោយពណ៌ឆើតពេក(ឧ.enluminer son style); ឲ្យឡើងក្រហម(ឧ. la fièvre enlumine le visage)

enlumineur,euse *n.* អ្នកតែងលំអដោយរូបពណ៌(ឧ. Jean Fouquet fut un grand enlumineur)

enluminure *n.f.* ការដាក់ពណ៌; រូបពណ៌លំអ។*Fig.* របៀបនិពន្ធឆើតពេក

ennéagonal,e,aux *a.* ជានព្វកោណ, ដែលមានមុំប្រាំបួន

ennéagone *n.m.* នព្វកោណ (ពហុកោណមុំប្រាំបួន)

enneigement *n.m.* ភាពតំបន់ដែលមានហិមៈពាសពេញ

enneiger *n.f.* គ្របដោយហិមៈ

ennemi,e *n.* ខ្មាំង, សត្រូវ,បច្ចាមិត្ត (ឧ. ennemi mortel; ennemi du tabac); ខ្ពប់ខ្ពែង ។ armée ennemie កងទ័ពបច្ចាមិត្ត

ennoblir *v.i.* ធ្វើឲ្យថ្លៃថ្នូរ; តម្កើងឋានៈ (ឧ. la vertu ennoblit l'homme)

ennoblissement *n.m.* ការធ្វើឲ្យថ្លៃថ្នូរ, ការតម្កើងឋានៈ

ennuager (s') *v.pr.* បាំងពពក

ennui *n.m.* ការអផ្សុក,ការធុញទ្រាន់ (ឧ. spectacle qui engendre l'ennui);ការពិបាកចិត្ត(ឧ.procès qui cause beaucoup d'ennuis)

ennuyant,e *a.* ដែលរំខាន;ដែលនាំឲ្យអផ្សុក(ឧ. un temps ennuyant)

ennuyer *v.t.* ពិបាកចិត្ត (ឧ. je suis ennuyé de vous faire attendre); ធ្វើឲ្យអផ្សុក,ធ្វើឲ្យធុញទ្រាន់(ឧ. ce livre m'a fort ennuyé)។ s'ennuyer *v.pr.* អផ្សុក,ធុញទ្រាន់

ennuyeusement *adv.* ដោយនាំឲ្យអផ្សុក ឬ ឲ្យធុញទ្រាន់

ennuyeux,euse *a.* ដែលនាំឲ្យអផ្សុក ឬឲ្យធុញទ្រាន់ (ឧ. conversation ennuyeuse)

énoncé *n.m.* វិញ្ញប័ន, ការថ្លែង (ឧ. l'énoncé d'une clause; l'énoncé d'un problème, d'une question)

énoncer *v.t.* ថ្លែង (ដោយវាចាឬដោយលិខិត)(ឧ.énoncer un axiome)

énonciatif,ive *a.* សំរាប់ថ្លែង(ឧ.terme énonciatif)

énonciation *n.f.* វិញ្ញាបនា,កិច្ចឬរបៀបថ្លែង(ឧ.énonciation d'un fait)

énorme *a.* ធំសំបើម,ធំហួសខ្នាត(ឧ. le baobab est un arbre énorme)។ *Fig.* fortune énorme សម្បត្តិច្រើនសំបើម

énormément *adv.* ដោយហួសប្រមាណ, យ៉ាងសំបើម

énormité *n.f.* ភាពធំសំបើម, ភាពធំហួសខ្នាត ។ *Fig.* សំដីឈ្លើយ (ឧ. dire des énormités)

enquérir (s') *v.pr.* សួរដំណឹង, សើបសួរ (ឧ. s'enquérir d'une adresse)

enquête *n.f.* អង្កេត (ឧ. le tribunal ordonne une enquête)។ enquête de commodo et incommodo អង្កេតសុវិធាន និងអសុវិធាន

enquêter *v.i.* ធ្វើអង្កេត (ឧ. enquêter sur un crime)

enquêteur,euse *a.* ដែលធ្វើអង្កេត (ឧ. commissaire enquêteur)។ *n.* អ្នកធ្វើអង្កេត

enquinauder *v.t.* ធ្វើឲ្យអៀន;បញ្ឆោត

enquiquiner *v.t. Fam.* ធ្វើឲ្យអផ្សុក ឬឲ្យធុញទ្រាន់

enracinement *n.m.* ការធ្វើឲ្យចាប់ឫស; ការចាប់ឫស

enraciner *v.t.* ធ្វើឲ្យចាប់ឫស (ឧ. enraciner un arbre)។ *Fig.* ធ្វើឲ្យជ្រះឫស (ធ្វើឲ្យតាំងនៅជាប់) (ឧ. idée que le temps a enracinée dans l'esprit) ។ s'enraciner *v.pr.* ចាប់ឫស ។ *Fig.* ជ្រះឫស,តាំងនៅជាប់ (ឧ. les préjugés s'enracinent facilement)

enragé,e *a.* ឆ្កួត(ឧ. chien enragé); ខឹង; ខ្លាំងក្លា; ហួសកំរិត (ឧ. joueur enragé; passion enragée)

enrageant,e *a.* ដែលធ្វើឲ្យខឹងឬឲ្យក្ដៅចិត្ត (ឧ. des contradictions enrageantes)

enrager *v.i.* ក្ដៅចិត្ត,ខឹង (ឧ.il enrage de ne pouvoir parler) ។ faire enrager ញីញ

enraiement ឬ **enrayement** *n.m.* ការឃាត់កាំ(ឧ.enraiement d'une roue) ។ *Méc.* ការគាំង

enrayage *n.m.* ការឃាត់កាំ;ការធ្វួត ។ *Méc.* ដំណើរគាំង

enrayer *v.t.* ឃាត់កាំ (ឧ. enrayer une roue); ទប់ (ទប់កង់មិនឲ្យវិលឬទប់ម៉ាស៊ីនមិនឲ្យដើរ); ធ្វួត ។ *Fig.* enrayer une maladie មើលជម្ងឺឲ្យជាស្រឡះ ។ s'enrayer *v.pr.* មិនដើរ, មិនរេះ (គ្រឿងម៉ាស៊ីន)

enrayoir *n.m.* ប្រដាប់ទប់រទេះ

enrayure *n.f.* ប្រដាប់ទប់កង់ ។ *Techn.* កាំ ។ *Agr.* គន្លងនង្គ័លដំបូង

enrégimenter *v.t.* ធ្វើជាកងវរសេនាធំ; បញ្ចូលក្នុងកងវរសេនាធំ ។ *Fig* ប្រមូល, ប្រជុំ,បញ្ចូលក្នុងក្រុមតែមួយ(ឧ. enrégimenter des mécontents dans une conspiration)

enregistrable *a.* អាចចុះបញ្ជីឬកត់ត្រាទុកបាន

enregistrement *n.m.* កិច្ចបញ្ជិកា, ការចុះបញ្ជី; បញ្ជិកាឋាន; ក្រុមប្រដាប់ត្រា ។ pour enregistrement ដើម្បីប្រដាប់ត្រា ។ ពំនូសដែលម៉ាស៊ីនកត់ត្រា; សម្លេងដែលថតបាន

enregistrer *v.t.* ប្រដាប់ត្រា; ចុះបញ្ជី។ *Par ext.* កត់ត្រាទុក (ឧ. enregistrons ce fait); កត់ចំនួន (ឧ. enregistrer des bagages); ថតបញ្ចូលសម្លេង (ឧ. enregistrer

une symphonie sur disque); ថា (មិនភ្លេច)

enregistreur,euse *a.* អ្នកកត់ត្រា;អ្នកចុះបញ្ជី។ *a.*សម្រាប់កត់ត្រា(ឧ.baromètre enregistreur; (សម្រាប់ថតបញ្ចូលសម្លេង

enrhumer *v.t.* នាំឲ្យផ្ដាសាយ។ s'enrhumer *v.pr.* ផ្ដាសាយ

enrichi,e *a.&n.* ដែលទើបមានទ្រព្យធនថ្មី

enrichir *v.t.* ឲ្យមានទ្រព្យធន (ឧ. le commerce enrichit Carthage)។ *Par ext.* បង្កើន, ធ្វើឲ្យល្អគាប់(ឧ.enrichir un musée)។ *Fig.* លំអ (ឧ. enrichir son esprit) ។ s'enrichir *v.pr.* មានទ្រព្យធនច្រើន

enrichissement *n.m.* ការបានទ្រព្យធន; គ្រឿងលំអ, គ្រឿងតុបតែង

enrobage ឬ **enrobement** *n.m.* ការរុំ; ការគ្រប; ការខ្ចប់

enrober *v.t.* រុំ; គ្រប; ខ្ចប់។ *Fig.* កាឡៃ, ក្លែង (ឧ. information enrobée de commentaires)

enrôlé *n.m.* អ្នកមានឈ្មោះក្នុងបញ្ជី

enrôlement *n.m.*ការចុះបញ្ជី;ការរើសទាហាន; ការចូលធ្វើទាហាន; ការដាក់ជំនុំជម្រះ

enrôler *v.t.* ចុះបញ្ជី(ឧ.enrôler des ouvriers);រើសទាហាន(ឧ. enrôler des soldats)។ *Fig.* បញ្ចូលក្នុងបក្សពួក (ឧ.enrôler des mécontents) ។ s'enrôler *v.pr.* ចូលធ្វើទាហាន, ចូលបក្សពួក

enrouement ឬ **enroûment** *n.m.* ការស្អកស្អា

enrouer *v.t.* ធ្វើឲ្យស្អកស្អា

enrouillement *n.m.* ដំណើរច្រែះចាប់

enrouiller *v t.* ធ្វើឲ្យច្រែះចាប់។ s'enrouiller *v.pr.* ច្រែះចាប់

enroulement ឬ **enroulage** *n.m.* ការមូរ; រមូរ

enrouler *v.t.* មូរ (ឧ.enrouler un drapeau autour de sa hampe)

enrouleur,euse *a.* សំរាប់មូរ

enrubanner *v.t.* គ្របឬតែងលំអដោយចង្រៀកសំពត់បូ(ឧ.enrubanner un chapeau,un enfant)

enrue *n f.* គន្លងនង្គ័លធំ

ensablement *n.m.* ផ្នូកខ្សាច់ (បង្កឡើងដោយទឹក ឬ ខ្យល់)

ensabler *v.t.* ក្រាលឬក្របដោយខ្សាច់ (ឧ. les inondations ensablent souvent les terres); បង្កើលលើខ្សាច់ (ឧ. passeur qui a ensablé son bac)។ s'ensabler *v.pr.* កៀងនឹងខ្សាច់ ។ *Fig.* កៀង, ទញ់ទាល់ដំណើរ

ensachement ឬ **ensachage** *n.m.* ការច្រកបាវឬការុង (ឧ. l'ensachement des grains)

ensacher *v.i.* ច្រកបាវឬការុង

ensanglanter *v.t.* ប្រឡាក់ឈាម (ឧ. lady Macbeth croyait toujours voir sa main ensanglantée)។ *Par ext.* បង្ហូរឈាមទៅ (ឧ. la guerre a ensanglanté l'Europe)។ *Fig.* ធ្វើឲ្យសៅហ្មងដោយមានបង្ហូរឈាម(ឧ. ensanglanter son règne)

enseignable *a.* អាចបង្ហាត់បង្រៀនបាន

enseignant,e *a.* ដែលបង្ហាត់បង្រៀន។ le corps enseignant អង្គគ្រូបង្រៀន

enseigne *n.f.* សមញ្ញាប័ន ឬ សញ្ញាណប័ន, យីហោ (ឧ. enseigne lumineuse)។ *Fig.* សញ្ញា (ឧ. la sincérité est l'enseigne de l'honnêteté); ទង់, ទង់ជាតិ (ឧ. marcher enseignes déployées); ការដឹកនាំ(ឧ. marcher sous les enseignes de quelqu'un)។ à telle enseigne ឬ à telles enseignes que ទាល់តែ, ភស្តុតាងគឺ (ឧ. l'évolution sociale se fera; à telles enseignes qu'elle a déjà commencé)។ à bonnes enseignes ដោយស្គាល់ច្បាស់, ដោយប្រាកដណាស់(ឧ. ne payer qu'à bonnes enseignes)។

Loc. adv. à bon vin point d'enseigne របស់ល្អគង់តែគេស្គាល់(ដោយមិនបាច់ធ្វើឃោសនា)។ être logé à la même enseigne មានភិសនា ឬ មានទុក្ខដូចគ្នា ។ loger à l'enseigne de la lune ដេកកណ្តាលវាល ។

n.m. Autref. នាយទាហានកាន់ទង់ជាតិ។ *Mar.* enseigne de vaisseau អនុនាវី ។ enseigne de vaisseau de 1ère classe អនុនាវីទោ ។ enseigne de vais-

seau de 2e classe អនុនាវីត្រី

enseignement *n.m.* ការប្រៀបៀប បង្ហាត់បង្រៀន; សិក្ខាបទ(ឧ.donner de bons enseignements); សិក្សាធិការ (ឧ. être dans l'enseignement)។enseignement public សាធារណសិក្សាធិការ ។ enseignement libre សិក្សាធិការសេរី ។ enseignement élémentaire អាទិសិក្សា, សិក្សាជាន់ដំបូង ។ enseignement primaire បឋមសិក្សា។ enseignement secondaire មធ្យមសិក្សា។ enseignement secondaire moderne national មធ្យមសិក្សាទំនើបរបស់ជាតិ។ enseignement supérieur ឧត្តមសិក្សា ។ enseignement technique បច្ចេកទេសសិក្សា

enseigner *v.t.* បង្ហាត់បង្រៀន (ឧ. enseigner des enfants); បង្រៀន (ឧ. enseigner la grammaire); បង្ហាញ (ឧ. enseigner un chemin)

ensellé,e *a.* អែនសែ (ខ្នងសេះ)

ensellement *n.m.* *Géogr.* ភាពដីកណ្ដាក់(ខ្ពង់កណ្ដាលហើយខ្ពស់សងខាង)

ensellure *n.f.* ភាពអែនសែ (ខ្នងសេះ)

ensemble *adv.* សាមគ្គី,ជាមួយគ្នា (ឧ. vivre ensemble); ព្រមគ្នា(ឧ.ils ont commencé ensemble)

ensemble *n.m.* សាមគ្គី,ប្រជុំ (ឧ. un bel ensemble; l'ensemble des élèves)។ mouvements d'ensemble ចលនាសាមគ្គី (ឬ ព្រមគ្នា) ។ ការព្រមព្រៀង (ឧ. avec ensemble)។ d'ensemble ទាំងអស់.ទូទៅ(ឧ.vue d'ensemble)។ dans l'ensemble ដោយសរុប

ensemencement *n.m.* ការសាប ឬ ព្រោះ (ឧ. l'ensemencement d'un champ)

ensemencer *v.t.* សាប, ព្រោះ, បណ្ដុះ (ឧ. ensemencer une terre)

enserrer *v.i.* ទប់; បង្ខាំង; រួបរឹត (ឧ. le boa enserre sa victime)

ensevelir *v.t.* ស្នប (ឧ. ensevelir un cadavre)។*Par ext.* s'ensevelir *v.pr.* *Fig.* s'ensevelir dans la retraite ពួនបុន (ទៅនៅឆ្ងាយពីគេ)

ensevelissement *n.m.* ការស្នប;ការ

កប់

ensevelisseur,euse *n.* ស្មុំ, អ្នករុំស្មប

ensiforme *a.* ជារាងដាវ

ensilage ឬ **ensilotage** *n.m.* ការទុកក្នុងផលាភជី

ensilerឬ**ensiloter** *v.t.* ទុកក្នុងផលាភជី (ឧ. ensiler des céréales)

ensoleillé,e *a.* ដែលទទួលពន្លឺព្រះអាទិត្យ (ឧ. paysage ensoleillé)

ensoleiller *v.t.* ឲ្យមានពន្លឺព្រះអាទិត្យ ឬ ពន្លឺផ្លេកៗ (ឧ. diamants qui ensoleillent une toilette)។ *Fig.* ធ្វើឲ្យសប្បាយ(ឧ. ce succès a ensoleillé toute sa vie)

ensommeillé,e *a.* ដែលងងុយដេក។ *Fig.* មិនរវៀករវៃ

ensorcelant,e *a* ដែលធ្វើអំពើ ឬ ដាក់ស្នេហ៍។ *Fig.* ដែលធ្វើឲ្យស្រឡាញ់

ensorceler *v.t.* ធ្វើអំពើ, ដាក់ស្នេហ៍។ *Fig.* ធ្វើឲ្យស្រឡាញ់ងប់

ensorceleur,euse *a.* ដែលធ្វើអំពើ, ដែលដាក់ស្នេហ៍។ *n.* គ្រូអំពើ គ្រូស្នេហ៍ (ឧ. on brûlait jadis les ensorceleurs)

ensorcellement *n.m.* ការធ្វើអំពើ, ការដាក់ស្នេហ៍។ *Fig.* ការចែបង់, ការចាប់ចិត្ត

ensoufrer *v.t.* លាបស្ពាន់ធ័រ

ensouple *n.f.* ensouple dérouleuse ក្ដារប្រូ(សម្រាប់មូរអំបោះអន្លង) ensouple enrouleuse ឬ ensoupleau *n.m.* ដំរ(គ្រឿងតំបាញសម្រាប់មូរសាច់សំពត់ត្បាញហើយ)

ensoutaner *v.t. Fam.* បំបួស (ក្នុងសាសនាកាតូលិក)

ensuifer *v.t.* លាបខ្លាញ់ (ខ្លាញ់គោ ឬ ប្រេងរុក្ខជាតិ)

ensuite *adv.* រួច, តទៅទៀត (ឧ. il avança, ensuite venaient ses frères et sœurs); រួចសឹម (ឧ. travaillez d'abord, vous vous amuserez ensuite)

ensuivre (s') *v.pr.* តាម, ជាផល (ឧ. les dépenses étaient trop fortes, la ruine s'ensuivit)។ *v. imp.* ជាហេតុឲ្យ (ឧ. il s'ensuit que...)

entablure *n.f.* ត្រចៀកកន្ត្រៃ (កន្លែងដែលផ្នែកកន្ត្រៃជាប់គ្នា)

entacher *v.t.* ធ្វើឲ្យប្រឡាក់, ធ្វើឲ្យសៅហ្មង(ឧ. faute qui entache l'honneur)។ acte entaché

de nullité សិទ្ធិគេសៅហ្មងដោយ មោឃភាព

entaillage *n.m.* ការកាប់,ការឈាក់

entaille *n.f.* ស្នាមកាប់; ស្នាមឈាក់; សម្លាក

entailler *v.t.* កាប់,ឈាក់(ឧ.entailler du bois)

entaillure *n.f.* ស្នាមកាប់,ស្នាមឈាក់

entamer *v.t.* កាត់ដំបូង (របស់ដែលនៅទាំងមូល)(ឧ.entamer un pain); ធូកសើរ (ឧ.entamer la peau); ទម្លាយ (ឧ. entamer la première ligne ennemie)។ *Fig.* ចាប់ផ្ដើម (ឧ.entamer une conversation); បង្ខូច (ឧ. entamer la réputation de quelqu'un)

entassement *n.m.* ការគរ; គំនរ (ឧ. entassement de débris)

entasser *v.t.* គរ (ឧ. entasser des gerbes)។ *Par exagér.* ញាត់ (ឧ. entasser des voyageurs dans un wagon)។ *Fig.* ធ្វើហើយធ្វើទៀត (ឧ. entasser crime sur crime)

entasseur *n.m.* អ្នកប្រមូល (ឧ. un entasseur d'écus)

ente *n.f.* មែកផ្សាំសាច់; ដើមផ្សាំសាច់; និងអម្រែសស្លាបសត្វ

entendement *n.m.* វិមំសា,បញ្ញា (ឧ. l'entendement n'est autre que l'intelligence); ការយល់, ការវិនិច្ឆ័យ (ឧ. perdre l'entendement លែងយល់)

entendeur *n.m.* អ្នកចាប់យល់។ à bon entendeur salut អ្នកដែលស្ដាប់បានគួរយកទុកជាប្រយោជន៍ខ្លួនចុះ

entendre *v.t.* ឮ (ឧ. entendre un bruit)។ entendre mal ឮ dur ត្រចៀកធ្ងន់ (មិនសូវឮ)។ entendre clair ត្រចៀកវៃ ។ *Absol.* ne pas entendre ថ្លង់ ។

ស្ដាប់ (ឧ. ne vouloir rien entendre; entendre des témoins); បំពេញចំណង់(ឧ. entendre la prière des malheureux)។

Fig. យល់ (ឧ. entendre à demi-mot)។ ne rien entendre à មិនយល់, មិនចេះ (ឧ. il n'entend rien à la musique)។ l'entendre bien ចេះ, ប្រសប់ ។ l'entendre mal មិន

ទេះ, មិនប្រសប់ ។

ចង់និយាយថា (ន. qu'entendez-vous par là ?); ចូលចិត្ត; ចេះច្បាស់ណាស់(ន. entendre le commerce); ចង់ (ន. j'entends qu'on m'obéisse) ។

entendre raison ស្តាប់បាន, ព្រមតាម (ការសមហេតុផល)។ n'entendre ni rime ni raison មិនទទួលស្តាប់អ្នកណាទាំងអស់ ។ entendre ses intérêts ប្រសប់ចាត់ការរបស់ខ្លួន ។ entendre la raillerie ឬ la plaisanterie ចូលចិត្តកំប្លែង; មិនខឹងបំពោះការចំអន់លេង ។ ne pas entendre raillerie មិនចូលចិត្តនឹងការចំអន់លេង។

à l'entendre តាមសំដីគាត់(ន. à l'entendre, il sait tout faire)។ comme vous l'entendrez តាមចិត្តលោក ។ donner à entendre, laisser entendre ឬ faire entendre ពោលសំដី, ធ្វើឲ្យគេនឿថា។ ne pas entendre de cette oreille-là មិនចូលចិត្តរបៀបនោះទេ ។

se faire entendre ឮ (ន. le bruit du tonnerre se fait entendre à une prodigieuse distance) ។

Prov. il n'est pire sourd que celui qui ne veut pas entendre ថ្លង់អ្វីមិនស្មើនឹងអ្នកមិនចង់ស្តាប់។ qui n'entend qu'une cloche n'entend qu'un son ម.ព. cloche ។

s'entendre *v.pr.* ចេះច្បាស់ខាង, ប្រសប់ខាង (ន. s'entendre en poésie, en musique)។

Pop. s'y entendre comme à faire un coffre, comme à ramer des choux, comme une truie à dévider de la soie មិនយល់ទាល់តែសោះ។ *Fam.* cela s'entend ជាធម្មតាទេ, ងាយយល់ទេ ។ s'entend ពិតជ្រះហើយ, មិនបាច់និយាយទេ (ន. je payerai, après livraison s'entend)។

ព្រមព្រៀងគ្នា, ត្រូវគ្នា, យល់គ្នា(ន. des gens qui ont pleuré ensemble s'entendent vite; s'entendre pour duper un

voisin) ។ **s'entendre comme larrons en foire** ត្រូវគ្នាដើម្បីប្រព្រឹត្តអំពើទុច្ចរិត ។

ឮ(ឧ.cloche qui s'entend); យល់ (ឧ.proposition qui s'entend sans peine); យល់បាន ឬ បកស្រាយបាន (ឧ. passage qui s'entend de deux façons)

entendu,e *a.* ព្រមព្រៀងហើយ, សំរេចហើយ (ឧ. c'est une affaire entendue); ឆ្លាត,ប្រសប់ (ឧ. un homme entendu aux affaires) ។ prendre un air entendu ធ្វើឫកជាយល់ច្បាស់ ។ *n.* faire l'entendu ធ្វើគ្រាន់បើ ។ bien entendu *loc.adv* ប្រាកដមែន, ពិតហើយ

enténébrer *v.t.* ធ្វើឲ្យងងឹតសូន្យ ។ *Fig.* ធ្វើឲ្យល្ងង់ខ្លៅ

entente *n.f.* ន័យ (ឧ. le calomniateur recherche les mots à double entente); ប្រាជ្ញា, ការយល់ (ឧ. avoir l'entente des affaires); ការព្រមព្រៀងគ្នា (ឧ. époux entre lesquels il n'y a pas d'entente) ។

Pol. សន្ធិដ្ឋិភាព ។ entente cordiale សន្ធិដ្ឋិភាពស្ម្រុំ ។

Loc. prov. l'entente est au diseur ការយល់សម្រេចទៅលើអ្នកនិយាយ (អ្នកនិយាយរមែងយល់សំដីរបស់ខ្លួន)

enter *v.t.* ផ្សាំមែក (ឧ. enter un sauvageon) ។ *Par ext.* បញ្ចូល ។ *Fig.* ផាក់លើ; លកភ្ជាប់គ្នា(ឈើពីរដុំ) ។ canne entée ដំបងត ។ s'enter *v.pr.* ជាប់គ្នាជាសម្ពន្ធញាតិ

entéralgie *n.f. Méd.* ការឈឺពោះវៀន

entérinement *n.m.* ការឲ្យសព្វាប័ន (ឧ. l'entérinement des lettres de grâce)

entériner *v.t.Dr.* ឲ្យសព្វាប័ន (ឧ. entériner des lettres de grâce)

entérique *a.* នៃពោះវៀន (ឧ.inflammation entérique)

entérite *n.f.* ជម្ងឺរលាកពោះវៀន

entérocolite *n.f.* ជម្ងឺរលាកពោះវៀនតូចនឹងពោះវៀនធំ

entérovaccin *n.m.* ការចាក់ថ្នាំបង្ការរោគពោះវៀន

enterrage *n.m.* ការពូនដីជុំវិញគុម្ពសាក

enterrement *n.m.* ការកប់ក្នុងដី; ការកប់ខ្មោច, បុណ្យបញ្ចុះសព (ឧ. l'enterrement de Victor Hugo fut une manifestation nationale); ក្បួនហែខ្មោច (ឧ. voir passer un enterrement); សោហ៊ុយបញ្ចុះសព (ឧ. payer un enterrement)។ *Fig.* ការបង្កប់ចោល; ការលែងប្រើ (ឧ. enterrement d'une loi)

enterrer *v.t.* កប់ក្នុងដី; បញ្ចុះសព, ធ្វើបុណ្យបញ្ចុះសព; រស់នៅយូរជាង (ឧ. vieillard qui enterre tous ses héritiers); សម្លាប់។ *Par ext.* បង្ខាំងនៅទីដាច់ស្រយាល (ឧ. enterrer quelqu'un à la campagne)។ *Fig.* បង្កប់ចោល, បំភ្លេចចោល (ឧ. enterrer un projet)។ s'enterrer *v.pr.* ទៅនៅឆ្ងាយពីគេ

en-tête *n.m.* ក្បាលសំបុត្រឬលិខិតផ្សេងៗ (*pl.* des en-têtes)

entêté,e *n.&a.* ចចេស (ឧ. caractère entêté)

entêtement *n.m.* *Fig.* ការចចេស, ភាពមុខរឹង (ឧ. son entêtement le perdra)

entêter *v.t.* ធ្វើឲ្យឈឺក្បាល (ដោយក្លិនឬដោយចំហាយ) (ឧ. l'odeur du lis entête) ។ *Fig.* ធ្វើឲ្យឆ្មើងកន្ត្រើង។ s'entêter *v.pr.* ចចេស (ឧ. il s'entête à refuser)

enthousiasme *n.m.* ការសរសើរដោយមានអាទិទេពសណ្ឋិត (ឧ. enthousiasme des prophètes)។ *Par anal.* សេចក្តីស្រើប (នៃអ្នកនិពន្ធ, សិល្បករ) (ឧ. l'enthousiasme est la chaleur de l'imagination au plus haut degré; សេចក្តីស្រើបចិត្ត (ឧ. enthousiasme guerrier; rien ne se fait sans un peu d'enthousiasme (Voltaire); សេចក្តីសប្បាយរីករាយខ្លាំង (ឧ. accueillir avec enthousiasme); ការស្ងើចសរសើរ (ឧ. parler d'un auteur avec enthousiasme)

enthousiasmer *v.t.* សរសើរ (ឧ. enthousiasmer la foule) ។ s'enthousiasmer *v.pr.* ស្រើប (ឧ. s'enthousiasmer pour le progrès)

enthousiaste *a.&n.* ស្រើប, ដែលរំភើប

ខ្លាំង (ឧ. esprit enthousiaste)

entiché,e *a.* ជើលងប់(ឧ.être entiché de ses opinions)

entichement *n.m.* ការងប់; កពងប់

enticher *v.t.* ធ្វើឲ្យងប់(ឧ.qui vous a entiché de cette personne?)។s'enticher *v.pr.* ងប់ចិត្ត(ឧ. s'enticher d'une opinion)

entier,ère *a.* ទាំងអស់, ទាំងមូល (ឧ. un pain entier)។ *Fig.* ពេញ, បរិបូណ៌(ឧ. jouir d'une liberté entière); ដដែល (ឧ. la question reste entière); មិនអត់អស្រ័យ (ឧ. esprit entier); មិនក្រៀវ(ឧ.cheval entier)។*Arith.* nombre entier ចំនួនគត់ ។

n.m. ទាំងស្រុង, ទាំងមូល (ឧ. lisez-le dans son entier) ។ en entier ទាំងអស់

entièrement *adv.* ដោយពេញលេញ, គ្រប់ទាំងអស់,ដោយបរិបូណ៌,ទាំងស្រុង (ឧ. être entièrement acquis à une opinion)

entité *n.f. Phil.* អង្គភាព

entoilage *n.m.* ការពាសសំពត់ (ឧ. l'entoilage d'un tableau); សំពត់សម្រាប់ពាស

entoiler *v.t.* ពាសសំពត់ (ឧ. entoiler une carte de géographie);គ្របដោយសំពត់ឬស្បែកក្រាស់

entoir *n.m.* កាំបិតផ្សាំ(សម្រាប់ផ្សាំមែកឈើ)

entôlage *n.m.* ការលួច(នៃស្រីពេស្យា)

entôler *v.t.* លួច(ចំពោះស្រីពេស្យា)

entomologie *n.f.* ឍណកសាស្ត្រ, វិទ្យាសាស្ត្រខាងសត្វល្អិត

entomologique *a.* នៃឍណកសាស្ត្រ (ឧ. science entomologique)

entomologiste *n.m.* អ្នកឍណកសាស្ត្រ

entomophage *a.* ឍណកាហារសត្វ

entonnage ឬ **entonnement** *n.m.* ឬ **entonnaison** *n.f.* ការដាក់ក្នុងធុង

entonner *v.t.* ដាក់ក្នុងធុង (ឧ.entonner du vin);ច្រក,បង្អក។ s'entonner *v.pr. Fig.* ចូល

entonner *v.t.* បើកបទ; ផ្តើមច្រៀង ។ *Poét.* សរសើរដោយពាក្យកាព្យ (ឧ. entonner les louanges de quelqu'un)

entonnoir *n.m.* ជីវឡាវ (កន្តាង

សម្រាប់ដាក់វត្ថុរឺដាក់ធនឬធុង); ប្រកៀងដីស្នាមគ្រាប់បែកផ្ទុះ

entorse *n.f.* ការគ្រេច (ឧ.se donner une entorse) ។ *Fig.* វិក្រម, ការបំពាន (ឧ. donner une entorse à la loi, à un texte)

entortillage *n.f.* ការខ្ចប់គ្រញូញ ។ *Fig.* ឧបាយកល; សំដីពាំគ្រលោត

entortillement *n.m.* ការគ្រញូញ ឬរមូល; ការរមូល ។ *Fig.* សេចក្តីទញ់ទាល់; សេចក្តីស្តាប់មិនបាន

entortiller *v.t.* ខ្ចប់គ្រញូញ (ឧ. entortiller un bonbon ,dans du papier)។ *Fig.* និយាយដោយទើសទាក់ (ឧ. entortiller ses pensées)។ *Fam.* ប្រលោម(ដោយពាក្យផ្អែមល្ហែម) (ឧ. chercher à entortiller quelqu'un)

entour *n.m.* ទីជិតខាង (ឧ. les entours d'une place)។ *Par ext.* អ្នកជិតខាង ។ à l'entour *loc. adv.* នៅជិតខាង ។ à l'entour de *loc. pré.* នៅជុំវិញ

entourage *n.m.* អ្វីៗដែលដាក់ជុំវិញដើម្បីលំអ (ឧ. entourage de perles) ។ *Fig.* អ្នកអបអម (ឧ. se méfier de son entourage

entourer *v.t.* ដាក់ជុំវិញ (ឧ. entourer une statue de fleurs);ព័ទ្ធជុំវិញ (ឧ. des remparts entouraient jadis Paris) ។ *Fig.* entourer de soins ថ្នាក់ថ្នម ។ s'entourer *v.pr.* ដាក់ជុំវិញខ្លួន ។ *Fig.* ឱ្យនៅអបអម ។ s'entourer de mystère ប្រព្រឹត្តដោយលាក់លៀមឬដោយអាថ៌កំបាំង ។ s'entourer de précaution ប្រព្រឹត្តដោយប្រុងប្រយ័ត្ន

entournure *n.f.* ក្លៀកអាវ ។ *Fig.* gêné aux ឬ dans les entournures ទទើសទទាក់, មិនស្រួល

en-tout-cas *n.m.* ម.ព. en-cas

entozoaire *n.m.* ប្រាណាស័យ, សត្វដែលអាស្រ័យនៅក្នុងខ្លួនសត្វឯទៀត

entraccorder (s') *v.pr.* ព្រមព្រៀងគ្នា

entraccuser (s') *v.pr.* ចោទប្រកាន់គ្នាទៅវិញទៅមក

entracte *n.m.* ពេលចន្លោះឈុត(ឧ.un entracte de musique)។ *Fig.* ពេលសម្រាក

entradmirer (s') *v.pr.* ស្ងើចគ្នាទៅវិញទៅមក

entraide *n.f.* ការជួយគ្នាទៅវិញទៅមក

entraider (s') *v.pr.*-ជួយគ្នាទៅវិញទៅមក

entrailles *n.f. pl.* ពោះវៀន; សរពាង្គក្នុងពោះនិងក្នុងទ្រូង(ឧ. les anciens consultaient les entrailles des victimes et tiraient des augures des palpitations du cœur) ។

Par ext. ពោះ(ឧ. mes entrailles crient, et je ne vois ici ni pain ni pinte (Piron); ឧទរ, ផ្ទៃ (ឧ. il ne sort pas un enfant des entrailles de sa mère, qui ne soit un ennemi de la vieille société (Chateaubriand);មាត,ម្ដាយ(ឧ. respectez les entrailles qui vous ont porté (Coran) ។

Par anal. ផ្នែកខាងក្នុង (ឧ. les entrailles de la terre) ។ *Fig.* សាច់ឈាម (ឧ. s'armer contre ses propres entrailles);ផ្ទៃក្នុង (ឧ. la guerre civile déchire les entrailles de la patrie);ខ្លឹមបេះដូង (ឧ. les œuvres sont les entrailles mêmes du genre humain (Chateaubriand); ចិត្ត (ឧ. un homme sans entrailles) ។ avoir des entrailles ចិត្តទន់

entr'aimer (s') *v.pr.* ស្រឡាញ់គ្នាទៅវិញទៅមក

entrain *n.m.* របៀបរហ័សរហួន (ឧ. cet homme a de l'entrain) ; ចលនារហ័ស (ឧ. il y a de l'entrain dans cette comédie); ការសប្បាយក្រៀវក្រា (ឧ. l'entrain d'une fête)

entraînable *a.* អាចដឹកនាំបាន

entraînant,e *a.* ដែលសម្រើប (ឧ. l'éloquence entraînante de Mirabeau; musique entraînante)

entraînement *n.m.* ការដឹកនាំ (ឧ. céder à l'entraînement des passions) ។ *Partic.* ការបង្វឹក (ឧ. mettre un cheval à l'entraînement)

entraîner *v.t.* ទាញ(ឧ.locomotive qui entraîne un lourd convoi); ធ្វើឲ្យដើរ (ឧ. moteur qui

entraîne une pompe); អូស ប្រទាញ(ឧ.entraîner quelqu'un en prison); នាំទៅ (ឧ. il l'entraîna vers la sortie); ពង្រត់; បង្វឹក(ឧ. entraîner un cheval sur les obstacles)។

Fig. នាំឱ្យបង្ខំ (ឧ. entraîner quelqu'un dans un parti); បណ្ដាលឱ្យមាន (ឧ. la guerre entraîne des maux)។

s'entraîner *v.pr.* សម, ហាត់ហ្វឹក

entraîneur,euse *n.m.* អ្នកបង្វឹក

entraîneuse *n.f.* ស្រីអ្នកនាំឱ្យគេរាំ (ក្នុងអគាររាត្រី)

entrait *n.m.* ធ្នឹម

entrant,e *n.&a.* អ្នកចំណូល (ឧ. les entrants et les sortants)។ *Fig. & fam.* ប្រុសប់បញ្ចុះបញ្ចូល

entr'apercevoir *v.t.* ឃើញស្រពេចស្រពិល (ឧ. je n'ai fait que l'entr'apercevoir)

entrappeler (s') *v.pr.* ហៅគ្នាទៅវិញទៅមក

entrave *n.f.* ទន្ទឹង, ណែងណង។ *Fig.* ឧបសគ្គ, របស់ទទើសទទែង(ឧ. apporter des entraves à l'exercice d'un droit)

entraver *v.t.* ចួង, ដាក់ណែងណង។ *Par ext.* ធ្វើឱ្យទទើសទទែង (ឧ. entraver la marche d'une armée); បង្កើតឧបសគ្គ(ឧ.entraver une négociation)

entravertir (s') *v.pr.* ព្រមានគ្នាទៅវិញទៅមក

entre *pr.* នាកណ្ដាល, ក្នុងចន្លោះ (ឧ. entre Phnom-Penh et Takhmau): ក្នុងចន្លោះពេល (ឧ. entre onze heures et midi); រវាង (ឧ.entre parents; entre amis)

entrebâillement *n.m.* ប្រហោងបង្អើប

entrebâiller *v.t.* បង្អើប (ឧ. entrebâiller une porte)

entrebattre (s') *v.pr.* វាយគ្នាទៅវិញទៅមក

entrechat *n.m.* ការលោតទះជាក់ជើង

entrechoquer *v.t.* បញ្ចល់(ឧ. entrechoquer des verres)។ s'entrechoquer *v.pr.* ល្មុំគ្នា, ទង្គិចគ្នា

entrecolonne ឬ **entrecolonnement** *n.m.* ចន្លោះសសរ

entrecôte *n.f.* សាច់បន្ទោះឆ្អឹងជំនីរ

entrecouper *v.t.* កាត់ច្រើនអន្លើ ។ *Par ext.* បញ្ឈប់រឿយៗ (ឧ. entrecouper ses paroles de soupirs)

entrecroisement *n.m.* ការប្រទាក់គ្នាខ្វាត់ខ្វែង

entrecroiser *v.t.* ប្រទាក់គ្នាខ្វាត់ខ្វែង។ **s'entrecroiser** *v.pr.* ប្រទាក់គ្នា (ឧ. fils qui s'entrecroisent)

entrecuisse *n.f.* សាច់បន្ទោះភ្លៅ

entre-déchirer (s') *v.pr.* ប្រហែកប្រហួរគ្នា។ *Fig.* និយាយអាក្រក់ពីគ្នា

entre-détruire (s') *v.pr.* បំផ្លាញគ្នាទៅវិញទៅមក។ *Fig.* បដិសេធគ្នា (ឧ. puisque vos raisons s'entre-détruisent)

entre-deux *n.m. inv.* ចន្លោះ (ឧ. l'entre-deux des fenêtres); ក្ដារចន្លោះបង្អួច; ជរ ។ *Fig.* ការជាកណ្ដាល ។ *loc.adv.* មិនខ្លោះទៅខាងណា; មិនល្អមិនអាក្រក់; ជាកណ្ដាល

entre-deux-guerres *n.m.* ou *f. inv.* ពេលចន្លោះសង្គ្រាម

entre-dévorer (s') *v.pr.* ប្រហែកប្រហួរគ្នាស៊ី

entre-donner (s') *v.pr.* ឲ្យគ្នាទៅវិញទៅមក

entrée *n.f.* ការចូល; ផ្លូវចូល។ *Fig.* ការចូលដំរូង (ឧ. entrée en fonctions); ដើម, ដើមដំបូង (ឧ. à l'entrée de l'hiver)។ avoir ses entrées dans un théâtre មានសិទ្ធិចូលមើលល្ខោនទទេ (ឥតចេញថ្លៃ)។ *Douane* ពន្ធចូល (ឧ. les tabacs étrangers paient une forte entrée)។ *Com.* ចំណូល

entrefaite *n.f.* sur ces entrefaites ក្នុងពេលនោះ

entrefermer *v.t.* បិទបង្អៀប (មិនឲ្យជិត)

entrefilet *n.m.* អត្ថបទខ្លីៗក្នុងកាសែត (ឧ. un entrefilet venimeux)

entre-frapper (s') *v.pr.* ប្រវាយគ្នា, វាយគ្នាទៅវិញទៅមក

entregent *n.m.* ការប្រសប់ធ្វើឲ្យគេរាប់អាន (ឧ. avoir de l'entregent)

entr'égorger (s') *v.pr.* កាត់ក គ្នាទៅវិញទៅមក

entre-haïr (s') *v.pr.* ស្អប់គ្នាទៅវិញទៅមក

entre-heurter (s') *v.pr.* ទង្គិចគ្នាទៅវិញទៅមក

entrelacement *n.m.* ការពាក់ស្រែះគ្នា, ការឆ្វាក់គ្នា (ឧ. les entrelacements de guirlandes); ការត្បាញ, ការខ្វាស់

entrelacer *v.t.* ឆ្វាក់ (ឧ. entrelacer des rubans); ដាក់ឡៀវល្វេគ្នា (ឧ.entrelacer des branches); ត្បាញ, ខ្វាស់ ។ s'entrelacer *v. pr.* ឆ្វាក់គ្នា, ពាក់ស្រែះគ្នា

entrelardé,e *a.* ដែលមានសាច់និងខ្លាញ់លាយគ្នា (ឧ. morceau de bœuf entrelardé)

entrelardement *n.m.* ការដាក់ខ្លាញ់សាច់; ការសាច់ដាក់ខ្លាញ់

entrelarder *v.t.* ដាក់ខ្លាញ់សាច់ ។ *Fig. & Fam.* លាយ (ឧ. entrelarder un discours de citations)

entre-ligne *n.m.* ចន្លោះបន្ទាត់ (*pl.* des entre-lignes)

entre-louer (s') *v.pr.* សរសើរគ្នាទៅវិញទៅមក

entre-luire *v.i.* ភ្លឺព្រាងៗ (ឧ. le jour entre-luit à peine)

entre-manger (s') *v.pr.* ស៊ីគ្នាទៅវិញទៅមក

entremêlement *n.m.* ការច្រុកព ច្របូកច្របល់គ្នា

entremêler *v.t.* លាយគ្នា, ច្របូកច្របល់គ្នា (ឧ. entremêler des fleurs et des rubans)

entremetteur,euse *n.* អ្នកនាំការណ៍ ។ *En mauv. part* មេអណ្ដើក

entremettre (s') *v.pr.* នាំការណ៍ (ឧ. s'entremettre pour rétablir la concorde entre deux puissances)

entremise *n.f.* ការនាំការណ៍; ការនាំសម្រុះសម្រួលគ្នា ។ *Mar.* ឈើញែក

entre-nœud *n.m.* សាច់ចន្លោះថ្នាំង

entre-nuire (s') *v.pr.* ព្យាបាទគ្នាទៅវិញទៅមក

entre-percer (s') *v.pr.* ប្រហាក់គ្នា, ចាក់គ្នាទៅវិញទៅមក

entreposage *n.m.* ការដាក់ឃ្លាំងទុក

entreposer *v.t.* ដាក់ឃ្លាំងទុក ។ *Par ext.* ផ្ញើ

entreposeur *n.m.* អ្នកកាន់កាប់ឃ្លាំង (ឧ.entreposeur des tabacs); អ្នកកាន់កាប់លក់វត្ថុផ្ដាច់មុខ

entrepositaire *n.&a.* ភណ្ឌាគារិក, អ្នកផ្ញើឬទទួលទុក

entrepôt *n.m.* ភណ្ឌាគារ,ឃ្លាំងទុក(ឧ. les ports de commerce sont pourvus de vastes entrepôts) ។ entrepôt réel ភណ្ឌាគារសព្វធន, ភណ្ឌាគារប្រត្យក្ស។ entrepôt fictif ភណ្ឌាគារសន្មត។ entrepôt spécial ភណ្ឌាគារពិសេស

entre-pousser (s') *v.pr.* ច្រានគ្នាទៅវិញទៅមក

entreprenant,e *a.* ហ៊ាន,ក្លាហាន(ឧ. général entreprenant)

entreprendre *v.t.* ផ្ដើមធ្វើ (ឧ. Colomb entreprit la découverte d'un continent occidental); ទទួលធ្វើ, ធ្វើសហគ្រាស (ឧ. entreprendre des travaux)។

Fam. បកបី (ឧ. Alexandre voulut s'affermir avant que d'entreprendre son rival (Bossuet); ឧបត្ថម្ភ (ឧ. je vous prie d'entreprendre la fille de notre paysanne pour la bien instruire (Mme de Maintenon); លួងលោម ។

v.i. entreprendre de ល្បង, ចង់ (ឧ. c'est un dessein très dangereux Que d'entreprendre de te plaire (La Fontaine)។ entreprendre sur ឬ contre រំលោភលើ,បំពានលើ (ឧ. César entreprit sur la liberté du peuple romain)

entrepreneur,euse *n.* អ្នកផ្ដើមធ្វើ; សហគ្រិន (ឧ. entrepreneur de travaux)

entrepris,e *a.* *Fig.* ញញើតញញើប

entreprise *n.f.* ការចាប់ផ្ដើមធ្វើ, ការទទួលធ្វើ (ឧ. l'entreprise du canal de Suez fut une œuvre colossale); សហគ្រាស (ឧ. entreprise d'Etat រដ្ឋសហគ្រាស)

entrer *v.i.* ចូល;មានយកមកប្រើក្នុង(ឧ. l'eau entre pour beaucoup dans certaines boissons); មានចំណែកក្នុង ។ *Fig.* មានខ្លះ (ឧ. il entrait de l'orgueil dans son attitude); entrer en religion ចូលបួស ។ entrer dans une famille ចូលក្នុងគ្រួសារមួយ

(ជាសមាជិកញាតិ)។ entrer au service ចូលធ្វើទាហាន ។ entrer en condition ចូលធ្វើខ្ញុំបម្រើគេ ។ entrer dans une famille ចូលជាសមាជិកញាតិក្នុងគ្រួសារមួយ ។ entrer en matière ផ្ដើម,ចាប់រកទំនង ។ entrer en accommodement សម្រុះសម្រួលគ្នា ។ entrer en colère ខឹង ។

v.t. បញ្ចូល (ឧ. entrer du vin en ville)

entre-rail *n.m.* ចន្លោះផ្លូវដែក

entre-regarder *v.t.* មើលមុខគ្នា ។ s'entre-regarder *v.pr.* មើលគ្នាទៅវិញទៅមក

entresol *n.m.* ទៀបក្រោម (ផ្នែកផ្ទះជាចន្លោះជាន់ក្រោមបំផុតនឹងជាន់ទីមួយ)

entre-soutenir (s') *v.pr.* ជាប្រគ្នា ទៅវិញទៅមក

entre-temps *adv.* ក្នុងចន្លោះពេលនោះ (ឧ. entre-temps, il arriva)។ *n.m.* ចន្លោះពេល

entreteneur,euse *n.* អ្នកថែទាំឬផ្គត់ផ្គង់

entretenir *v.t.* ថែទាំ (ឧ. entretenir une maison); ផ្គត់ផ្គង់ (ឧ. entretenir une famille); រក្សាឲ្យគង់នៅ (ឧ. entretenir la paix)។ entretenir quelqu'un de និយាយសំដែងសំណាលជាមួយអ្នកណាម្នាក់អំពី ។ femme entretenue ស្រីដែលមានប្រុសចិញ្ចឹម ។

Fig. s'entretenir *v.pr.* សន្ទនា (ឧ. s'entretenir d'une personne, d'une chose)

entretien *n.m.* ការថែទាំ (ឧ. l'entretien du linge); ចំណាយដើម្បីថែទាំ;ការផ្គត់ផ្គង់;វត្ថុផ្គត់ផ្គង់; ការសន្ទនា(ឧ.avoir un entretien); រឿងសន្ទនា

entretisser *v.t.* ត្បាញបញ្ចូល

entretoise *n.f.* *Techn.* ឈើឬដែកទាម

entretoisement *n.m.* ការដាក់ឈើឬដែកទាម

entretoiser *v.t.* ដាក់ឈើ ឬ ដែកទាម

entre-tuer (s') *v.pr.* សម្លាប់គ្នាទៅវិញទៅមក (ឧ. les Horaces et les Curiaces s'entre-tuent)

entrevoie *n.f.* ចន្លោះផ្លូវដែកពីរជិតគ្នា

entrevoir *v.t.* ឃើញស្រពេចស្រពិល (ឧ. entrevoir un objet dans le brouillard); ក្រឡេកឃើញ ។ *Fig.* ពាកល់ (ឧ. entrevoir un

malheur)

entrevous *n.m.* ចន្លោះរត

entrevue *n.f.* ការជួបគ្នាដោយមត់ទុក (ឧ. l'entrevue de Tilsit, entre Napoléon 1er et Alexandre 1er)

entrobliger (s') *v.pr.* យកអាសាគ្នាទៅវិញទៅមក

entrouvert,e *a.* ដែលបង្ហើប, ដែលហើប (ឧ. porte, fenêtre entrouverte)

entrouvrir *v.t.* បង្ហើប, បើកពាក់កណ្ដាល (ឧ. entrouvrir les rideaux d'une fenêtre)។s'entrouvrir *v.pr.* ហើប, របើក

énucléation *n.f.* ការគ្លៀសចេញ (ឧ. l'énucléation de l'œil)

énucléer *v.t.* គ្លៀសចេញ

énumératif,ive *a.* ដែលរាយឈ្មោះ(ឧ. dresser un état énumératif)

énumération *n.f.* ការរាយឈ្មោះ,ការរាប់។ *Rhét.* ការរាប់រៀប

énumérer *v.t.* រាយឈ្មោះ, រាប់រៀប

envahir *v.t.* លុកលុយ, រុករាន ។ *Par ext.* ចូលពាសពេញ(ឧ. les eaux ont envahi toute la contrée; la foule envahit les rues) ។ *Fig.* កើត (ឧ. le doute l'envahit)

envahissant,e *a.* ដែលរុករាន (ឧ.armée envahissante)

envahissement *n.m.* ការលុកលុយ, ការរុករាន។ *Fig.* ការចូលពាសពេញ; ការរំពាន (ឧ. les envahissements du pouvoir)

envahisseur *n.&a.m.*ដែលលុកលុយ ឬរុករាន (ឧ. repousser les envahisseurs)

envasement *n.m.* ការបំពេញដោយភក់,ការមានភក់(ឧ.l'envasement d'un canal, d'un port)

envaser *v.t.* បំពេញដោយភក់ (ឧ. port envasé); ជ្រមុជក្នុងភក់

enveloppage *n.m.* ការគ្របដណ្ដប់; វត្ថុគ្របដណ្ដប់

enveloppant,e *a.* ដែលព័ទ្ធជុំវិញ (ឧ. ligne enveloppante) ។ *Fig.* ដែលធ្វើឲ្យជាប់ចិត្ត (ឧ. gestes enveloppants)

enveloppe *n.f.*ស្រោម;ស្រោមសំបុត្រ; សំបកកង់។ *Fig.*វត្ថុដែលបិទបាំង;សំបក (អាការៈក្រៅ) (ឧ. l'envelop-

pe est souvent trompeuse)

enveloppement *n.m.* ការគ្របដណ្ដប់; វត្ថុគ្របដណ្ដប់ (ឧ. faire à un malade un enveloppement humide)

envelopper *v.t.* គ្របដណ្ដប់ (ឧ. envelopper un enfant dans des langes)។ *Par ext.* ព័ទ្ធជុំវិញ (ឧ. les flots enveloppent la terre)។ *Fig.* លាក់, ល្បៀង (ឧ. envelopper sa pensée dans d'habiles périphrases); បញ្ចូល (ឧ. envelopper quelqu'un dans une proscription)។ *Mil.* ព័ទ្ធ (ឧ. envelopper l'ennemi)

envenimement *n.m.* ការក្លាយ (ឧ. l'envenimement d'une plaie)

envenimer *v.t.* បញ្ចូលពិស (ឧ. il y a des reptiles qui enveniment les herbes dans lesquelles ils séjournent); ធ្វើឲ្យក្លាយ (ឧ. envenimer une plaie en la grattant)។ *Fig.* ធ្វើឲ្យក្លាយជាជម្លោះ (ឧ. envenimer une discussion)។

s'envenimer *v. pr.* ក្លាយ (ឧ. plaie qui s'envenime); រឹតតែខ្លាំងឡើង (ឧ. la querelle s'envenima)

enverguer *v.t.* *Mar.* ចងទឹងសំពត់ក្ដោង (ឧ. enverguer une voile, un pavillon)

envers *pré.* ចំពោះ (ឧ. loyal envers ses amis)។ envers et contre tous ប្រឆាំងចំពោះទាំងអស់គ្នា

envers *n.m.* ខាងខុស (ឧ. l'envers d'une étoffe, d'un papier de tenture)។ *Par anal.* ខ្នង (ប៉ែកខាងក្រោមនៃវត្ថុ) (ឧ. l'envers d'une feuille d'arbre)។ étoffe à deux envers សំពត់ប្រើបានទាំងសងខាង។ *Fig.* សេចក្ដីផ្ទុយ (ឧ. l'envers de la vérité)។ à l'envers *loc. adv.* ពីខាងខុស (ឧ. mettre ses bras à l'envers); ក្រាស, ពីខាងអាក្រក់; ត្រឡប់ត្រឡិន

envergure *n.f.* កំណាង (ទទឹងក្ដោងខាងក្រោម, បណ្ដោយស្លាបយន្តហោះ, ប្រវែងស្លាបចំពាង) (ឧ. កំណាងស្លាបសត្វ-ស្លាបយន្តហោះ)។ *Fig.* វិសាល-

គម, ជាប្រាជ្ញវៃបញ្ញា (ឧ. Napoléon Ier était un génie d'une puissante envergure); ទំហំ (ឧ. une manœuvre d'une grande envergure) ។ d'envergure ធំ (ឧ. manœuvre d'envergure)

envi (à l') *loc. adv. & pré.* ដោយប្រណាំងប្រជែង (ឧ. ils travaillent à l'envi); តាមអំពើចិត្ត

enviable *a.* គួរឲ្យចង់បាន (ឧ. le sort des souverains est au fond peu enviable)

envider *v.t.* រើអំបោះចាក់

envie *n.f.* ឥច្ឆា (ឧ. l'envie se compose de jalousie et de haine); ចំណង់,បំណង (ឧ. avoir envie de rire; avoir envie de manger); ផ្ចិត,ខ្ចី (ស្នាមខ្ចី ឬ ប្រជ្រុយនៅស្បែកមានមកពីកំណើត)

envier *v.t.* មានឥច្ឆា;ចង់បាន (ឧ. envier le pouvoir); ច្រណែន

envieusement *adv.* ដោយឥច្ឆា

envieux, euse *a.&n.* ដែលមានឥច្ឆា (ឧ les envieux sont toujours malheureux)

environ *adv.* ប្រហែលជា,ប្រមាណជា, រាង (ឧ. environ cent personnes) ។ *n.m. pl.* តំបន់ជុំវិញ (ឧ. les environs de Phnom-Penh) ។ aux environs de *loc. pré.* ត្រង់ម្តុំ,នៅជិត

environnant,e *a.* ដែលនៅជុំវិញ (ឧ. lieux environnants)

environner *v.t.* ដាក់ជុំវិញ (ឧ. environner de murs un jardin); ព័ទ្ធជុំវិញ; (ឧ. montagnes qui environnent la ville) ។ *Fig.* នៅជុំវិញ (ឧ. les dangers qui l'environnent)

envisager *v.t.* សម្លឹងមុខ ។ *Fig.* ពិនិត្យ (ឧ. envisageons cette question); គិតចង់ (ឧ. envisager de partir); ប្រមើល (ឧ. envisager l'avenir) ។ envisager la possibilité de លៃលក

envoi *n.m.* ការផ្ញើ,ការបញ្ជូន (ឧ. faire l'envoi); របស់ផ្ញើ ឬ បញ្ជូន

envoisiner *v.t.* ឲ្យមានអ្នកជិតខាង (ឧ. être bien ou mal envoisiné)

envol *n.m.* ការហើរ ឬ ហោះឡើង (ឧ. l'envol d'un avion)

envolée *n.f.* ការហើរឬហោះឡើង ។ *Fig.* សំទុះចិត្តទៅរកឧត្តមគតិ (ឧ. certaines pièces lyriques de Victor Hugo sont d'une magnifique envolée)

envolement *n.m.* ការហើរ ឬ ហោះឡើង

envoler (s') *v.pr.* ហើរ ឬ ហោះឡើង (ឧ. l'avion s'envole) ។ *Par anal.* papier qui s'envolent ក្រដាសហើរ ។ *Fig.* ផុតលត់ (ឧ. la jeunesse s'envole souvent avant qu'on en ait joui); កន្លងទៅ (ឧ. le temps, l'occasion s'envolent) ។

Loc. fam. les oiseaux se sont envolés ឬ sont envolés អ្នកដែលគេរកចេញផុតហើយ

envoûtement *n.m.* អំពើធ្វើដោយឧបកិច្ចនឹងរូបព្រមូន ។ *Fig.* អនុភាពលើចិត្ត (ដូចជាត្រូវអំពើ) (ឧ. la lecture de certains livres produit l'effet d'un envoûtement)

envoûter *v.t.* ធ្វើអំពើដោយឧបកិច្ចនឹងរូបព្រមូន ។ *Fig.* ធ្វើឲ្យជាប់ចិត្ត (ដូចជាត្រូវស្នេហ៍); បង្ក្រាប

envoyé,e *n.* បេសកៈ-សកា, ជនដែលគេបញ្ជូនទៅ។ *n.m.* ប្រេសិត។ envoyé extraordinaire ប្រេសិតវិសាមញ្ញ (អ្នកដែលគេបញ្ជូនទៅដើម្បីបំពេញការពិសេសណាមួយ)

envoyer *v.t.* បញ្ជូន (ឧ. envoyer un enfant à l'école); ផ្ញើ (ឧ. envoyer une lettre); ចោល, បោះ (ឧ. envoyer une balle, des pierres); ចាត់ប្រេសិតឬទូត។ envoyer les couleurs បង្ហូតទង់ជាតិ (ដើម្បីគោរព) ។

Fig. envoyer promener, paitre ឬ coucher បណ្ដេញដោយគម្រោះគម្រើយ ។

s'envoyer *v.pr.* *Pop.* ផឹក, លេប (ឧ. s'envoyer un verre de vin)

envoyeur,euse *n.* អ្នកផ្ញើ ឬ បញ្ជូន

enwagonner *v.t.* ផ្ទុកក្នុងទូរអយស្ម័យ-យាន

épagneul,e *n.* អេប៉ាញ៉ុល (ឆ្កែម្យ៉ាងរោមវែង ស្លឹកត្រចៀកធ្លាក់ខួប)

épais,aisse *a.* ក្រាស់ (ឧ. étoffe épaisse; brouillard épais);

ញឹក (ឧ. bois épais); ខាប់ (ឧ. encre épaisse) ។ nuit épaisse យប់ជ្រៅ ។ *Fig.* ល្ងីល្ងើ; កម្រាស់; ក្រាស់ (ឧ. esprit épais) ។ avoir la taille épaisse រាងក្រាស់ ។

Loc. div. langue épaisse អណ្ដាតរឹង (និយាយមិនស្រួល) ។ air épais ឬ atmosphère épaisse អាកាសអាប់អួ (ពិបាកដកដង្ហើម) ។ épais à couper au couteau ក្រាស់ណាស់, ខាប់ណាស់ (ឧ. vin épais à couper au couteau); *au fig.* កម្រាស់ណាស់ ។

n.m. កម្រាស់ (ឧ. plusieurs pieds d'épais) ។

adv. យ៉ាងក្រាស់, យ៉ាងញឹក (ឧ. semer épais)

épaisseur *n.f.* កម្រាស់ (ឧ. l'épaisseur d'une brique); ភាពក្រាស់; ភាពខាប់; ភាពងងឹតជាក់ភ្នែកមិនឃើញ (ឧ. épaisseur des ténèbres) ។ *Fig.* ភាពកម្រាស់; ភាពយឺតយ៉ាវ (ឧ. épaisseur de l'intelligence)

épaissir *v.t.* ធ្វើឲ្យឡើងក្រាស់; ធ្វើឲ្យឡើងខាប់ (ឧ. épaissir un sirop) ។ *v.i.* & s'épaissir *v.pr.* ឡើងក្រាស់; ឡើងខាប់ (ឧ. le sirop épaissit ឬ s'épaissit)

épaississant,e *a.* ដែលឡើងខាប់

épaississement *n.m.* ការធ្វើឲ្យក្រាស់ ឬឲ្យខាប់; ភាពឡើងក្រាស់ឬឡើងខាប់

épamprage ឬ **épamprement** *n.m.* ការបេះបង្កាមស្លឹកនិងផ្លែទំពាំងបាយជូរ

épamprer *v.t.* បេះបង្កាមស្លឹកនឹងផ្លែទំពាំងបាយជូរ

épanchement *n.m.* ការហូរ ។ *Fig.* ការសារភាព; ការដាក់ចិត្តឬទោរទន់ចិត្តទៅរក (ឧ. épanchement de cœur)

épancher *v.t.* សំរឹតទឹក, ច្រួចទឹក ។ *Fig.* សារភាពដោយស្មោះអស់ពីពោះ (ឧ. épancher son ressentiment) ។ s'épancher *v.pr.* និយាយដោយទុកចិត្ត (ដោយស្មោះអស់ពីពោះ)

épandage *n.m.* ការរាយ

épandeur,euse *n.* ម៉ាស៊ីនរាយ (មានរាយជីជាដើម)

épandre *v.t.* រាយ (ឧ. épandre

des engrais) ។ *Poét.* បង្កើត; ឲ្យច្រើនហូរហៀរ

épanouir *v.t.* ធ្វើឲ្យរីក (ឧ. le printemps épanouit les fleurs) ។ *Fig.* ធ្វើឲ្យរីករាយ ឬ ឲ្យស្រស់ស្រាយ (ឧ. le bonheur épanouit le cœur) ។ s'épanouir *v.pr.* រីក (ផ្កា) ។ *Fig.* ឡើងរីករាយ, ឡើងស្រស់ស្រាយ (ឧ. son visage s'épanouit)

épanouissement *n.m.* ការរីក (ឧ. épanouissement des fleurs) ។ *Fig.* ភាពសប្បាយរីករាយ

épargnant,e *a.* ដែលសំចៃ

épargne *n.f.* សញ្ចយ, ការសំចៃ (ឧ. l'épargne ne doit pas dégénérer en avarice); ការប្រើដោយសំចៃ ។ caisse d'épargne ហិបសំចៃ ។ aliments d'épargne អាហារសំចៃ (មានតែ, កាហ្វេ, កូកា, កាកាវជាដើមដែលឲ្យយើងបរិភោគតិច ប៉ុន្តែឲ្យមានកម្លាំង ព្រោះប្រើជាបពលបម្រុងទុកក្នុងសពាង្គកាយ) ។ *pl.* ប្រាក់សំចៃ

épargner *v.t.* សំចៃ (ឧ. Sully épargna près de quarante millions) ; ប្រើដោយសំចៃ (ឧ. épargner ses ressources); កុំធ្វើឲ្យពិបាក (ឧ. épargnez-nous des explications កុំធ្វើឲ្យយើងពិបាកពន្យល់; épargner des ennuis à quelqu'un កុំធ្វើឲ្យកើតទុក្ខ) ។ *Fig.* សំចៃ (ឧ. épargner ses forces); ប្រណី, មិនធ្វើបាប, មិនសម្លាប់ (ឧ. épargner la vieillesse; épargner les captifs); មិនធ្វើឲ្យវិនាស (ឧ. le bombardement a épargné cet immeuble)

éparpillement *n.m.* ការរាត់រាយ ; ភាពរាត់រាយ

éparpiller *v.t.* ធ្វើឲ្យរាត់រាយ, ពង្រាយ (ឧ. éparpiller des papiers) ។ *Fig.* éparpiller ses efforts ធ្វើឲ្យរាត់រាយកម្លាំង (ដោយធ្វើការច្រើនមុខ)

épars,e *a.* ដែលរាត់រាយ (ឧ. restes épars) ; កញ្ជ្រឹង (ឧ. cheveux épars)

épar ឬ **épart** *n.m.* *Techn.* ឆ្កឹង; ឈើញែក

épart *n.m.* មហារីកឬស្មាញាក់ចិញ្ចៀម

(ផ្កាយខ្លះដែលចេញពន្លឺព្រិចៗព្រែតៗ ច្រើនឃើញតែក្នុងវេលាយប់)។

épatamment *adv.Fam.* យ៉ាងឆើត, យ៉ាងចំណាប់

épatant,e *a.Fam.* ល្អ, ឆើត, ចំណាប់ (ឧ. un temps, un film épatant)

épate *n.f. Pop* ការឲ្យគេស្ញើច (ឧ. faire de l'épate)

épaté,e *a.* nez épaté ច្រមុះពៀច ឬ សំប៉ែត

épatement *n.m.* ភាពសំប៉ែត (ឧ. l'épatement du nez est un des caractères de la race noire)។ *Fig. &fam.* ការឆ្ងល់ (ឧ.l'épatement d'un cancre d'être reçu à son examen)

épater *v.t.* កាច់ជើង, បំបាក់ជើង (ឧ. épater un chien; épater un verre)។ *Pop.* ធ្វើឲ្យដួល, បោកដួល(ឧ.épater son adversaire d'un coup de poing)។ *Par ext.* ធ្វើឲ្យសំប៉ែត (ឧ. la nature a épaté le nez des nègres)។ *Fig.& fam.* ធ្វើឲ្យឆ្ងល់ ឬ ឲ្យស្ញើច (ទាល់តែទន់ជើងដួល) (ឧ. ils ne songent qu'à épater les bourgeois)។

s'épater *v.pr.* មានសណ្ឋានសំប៉ែត (ឧ. nez qui s'épate)។ *Fig. & fam.* ឆ្ងល់, ស្ញើច(ឧ.il ne s'épate de rien)។ *Pop.* ដួល

épateur,euse *n.&a.Fam.* អ្នកធ្វើឲ្យគេឆ្ងល់ ឬ ស្ញើច

épaule *n.f* ស្មា។ donner un coup d'épaule ជួយ។ porter une personne sur ses épaules មានមនុស្សម្នាក់ក្នុងបន្ទុក។ hausser les épaules ញាក់ស្មា (សំដែងសេចក្ដីមើលងាយ)។ par-dessus l'épaule ដោយខ្ជីខ្ជា, ដោយធ្វេស-ធ្វៃ, ដោយមើលងាយ

épaulée *n.f.* ការកិតនឹងស្មា (ឧ. enfoncer une porte d'une seule épaulée)

épaulement *n.m.* កំពែងសម្រាប់ជ្រកគ្រាប់កាំភ្លើង (ឧ. batterie couverte par un épaulement); ជញ្ជាំងជ្រែង

épauler *v.t.* បំបាក់ស្មា (ឧ. épauler un cheval): ផ្ទង់លើស្មា(ឧ.épauler un fusil)។ *Fig.* ជួយ,គាំទ្រ

(ឧ. épauler quelqu'un auprès d'un ministre) ។ *Art mil.* ការពារដោយកំពែង (ឧ. épauler un bataillon, une pièce d'artillerie) ។ *Mar.* épauler la lame កាត់ប៉ំណាត ព្រសក់ (កាត់រលក) ។ *Techn.* ផែះពន្លួញ (ឲ្យល្មមនឹងជំណាប់)

épaulette *n.f.* ជានស្មា (ឧ. suivant leurs armes, les officiers portaient des épaulettes d'or ou d'argent) ។ *Par ext.* សក្តិនាយទាហាន (ឧ. accéder à l'épaulette) ; ទ្រនាប់ស្មា (សម្រាប់ក្រាប់ស្មាអាវឲ្យខ្ពស់)

épaulière *n.f. Cost.* ខ្សែព្រយុងខោ ។ *Art mil.* ក្រោះស្មា

épave *n.f.* សំណាត់; របឹស (របស់បាត់កេម្ចាស់មិនឃើញ)។ *Fig.* កំទេចកំទី (ឧ. recueillir les épaves d'une fortune): អ្នកធ្លាក់ខ្លួនក្រីក្រ លំបាកក្រៃពេក

épée *n.f.* ដាវ ។ *Fig.* ការជាទាហាន (ឧ.préférer la robe à l'épée); ឧត្តមសេនីយ(ឧ. appeler au ministère une illustre épée); អ្នកខ្លាំងពូកែខាងគុនដាវ (ឧ.d'Artagnan était une fine épée) ។ *Fig.* ការប្រយុទ្ធដោយអាវុធ (ឧ. l'épée détruit le travail de la charrue) ។

Loc. div. l'épée haute ដោយលើកដាវខ្ពស់ (ដើម្បីប្រយុទ្ធ) (ឧ. s'avancer l'épée haute) ។ épée à deux mains ដាវកាន់ដៃពីរ ។ épée à deux tranchants ដាវមុខពីរ; *au fig.* ឧបាយដែលអាចឲ្យទោសដល់អ្នកប្រើវិញ; ចំណេះដឹងកង ។ épée de chevet ដាវដាក់ក្បាលគ្រែ (សម្រាប់ប្រើការនៅពេលអាសន្ន); រឿងដែលគេចៀសមិនរួច; សំដីដែលគេទន្ទេញញយៗ (ឧ. toujours parler d'argent! voilà leur épée de chevet)។ brave comme son épée, comme une épée ក្លាហានណាស់ ។ traîneur d'épée អ្នកធ្វើឫកជាក្លាហាន ។ chevalier de la petite épée អ្នកឆបោក។ plat d'épée ស្លាបដាវ (ផ្នែកសំប៉ែតនៃដាវ) ។ à la pointe de l'épée ដោយអាវុធ, ដោយប្រើកម្លាំង, ដោយខំប្រឹងប្រែង

ខ្លាំង(ឧ.emporter une nomination à la pointe de l'épée)។ porter l'épée ព្យួរដាវនៅចង្កេះ; ជានាយទាហាន ។ tirer l'épée ឬ mettre l'épée hors du fourreau ហូតដាវ;ប្រកាសសង្គ្រាម; ផ្ដើមប្រទូស។ remettre l'épée dans le fourreau ឬ poser l'épée ស៊កដាវក្នុងស្រោមឬដាក់ដាវចុះ;លែងប្រទូស ។ rendre son épée ចុះចាញ់(ចំពោះនាយទាហាន)។demander l'épée à un officier ចាប់នាយទាហាន ។ rendre l'épée à un officier លែងឬឲ្យរួចខ្លួនដោយទុកកិត្តិយសឲ្យ (ចំពោះនាយទាហាន)។ briser son épée លែងធ្វើទាហានដោយឈឺចិត្ត ។ mettre son épée au service de l'étranger ក្លាយធ្វើទាហានបម្រើកងទ័ពបរទេស ។passer au fil de l'épée សម្លាប់ដោយគ្មានប្រណី។poursuivre ឬpresser l'épée dans les reins ដេញប្រកិត (ចំពោះសត្រូវដែលចាញ់ទ័ព); *au fig.* តាមយាយីមិនលែង។mettre ឬfaire passer quelque chose du côté de l'épée ដែលទុកកម្រៃខ្លះបម្រុងការ(ប្រើខាងផ្លូវអាក្រក់);ល្បួចតែយកកម្រៃ។ mourir d'une belle épée ស្លាប់ដោយមានកិត្តិគុណ ។ mourir d'une vilaine épée ស្លាប់ដោយគ្មានកិត្តិគុណ ។ n'avoir que la cape et l'épée ម.ព. cape ។ avoir l'épée sur la gorge ត្រូវគេយកដាវភ្ជាប់ក; ត្រូវគេបង្ខំយ៉ាងតឹងរ៉ឹង។ mettre ឬ tenir à quelqu'un l'épée ឬ le couteau sur la gorge យកកាំបិតភ្ជាប់ក; បង្ខំ។en être aux épées et aux couteaux ទាស់ទែងគ្នាខ្លាំង(ហៀបនឹងប្រកាប់ប្រចាក់គ្នា) ។ coucher comme l'épée du roi dans son fourreau ម.ព. coucher ។ n'avoir jamais vu d'épée nue que chez le fourbisseur មិនដែលប្រយុទ្ធសោះ ។ se battre de l'épée qui est chez le fourbisseur ឈ្លោះគ្នាអំពីរបស់ដែលនៅក្រៅអំណាចខ្លួន ។ se faire ឬ faire blanc de son épée អាងលើអំណាច ឬ លើសេចក្ដីក្លាហានរបស់ខ្លួនដើម្បីធ្វើឲ្យមានជោគជ័យ។ se

blesser avec son épée វិនាសខ្លួនឯងដោយចង់ញាំញីគេ ។ son épée est trop courte មានធនធាន ឬ មានអំណាចមិនគ្រប់គ្រាន់ ។ son épée ne tient pas au fourreau គាត់ចេះតែចង់កើតរឿងឬចង់ប្រយុទ្ធ ។ son épée est vierge គាត់មិនទាន់ដែលប្រយុទ្ធសោះ។ coup d'épée dans l'eau ការកាត់ទឹក (អំពើឥតផល, ការខំប្រឹងឥតប្រយោជន៍) (ម.ព. coup ផង) ។ *Iron.* il a fait un beau coup d'épée គាត់ប្រព្រឹត្តខ្លងណាស់ ។ l'épée ឬ la lame use le fourreau គោលៀនសំពក ។

Prov. la gourmandise tue plus de gens que l'épée ការល្មោភស៊ីសម្លាប់មនុស្សអស់ច្រើនជាងអាវុធ ។ il vaut mieux être percé d'une épée bien luisante que d'une épée rouillée ការវិនាសដោយកិត្តិគុណប្រសើរជាងការរងទុក្ខដោយអាម៉ាសមុខ ។ à vaillant homme courte épée មនុស្សក្លាហានមិនចាំបាច់មានដាវវែងទេ (អាចការពារខ្លួនបាន); មនុស្សប្រសប់មិនចាំបាច់មានប្រដាប់ច្រើនទេ (ម.ព. court ផង) ។ quiconque se sert de l'épée périra par l'épée អ្នកពូកែខាងអាវុធនឹងស្លាប់ដោយអាវុធ

épéiste *n.m.* អ្នកគុនដាវ

épeler *v.t.* ធ្វើអក្ខរវិញ្ញាស, រាប់អក្សរ ។ *Fig.* ចាប់រៀនដំបូង

épellation *n.f.* អក្ខរវិញ្ញាស, ការរាប់អក្សរ

éperdu,e *a.* ដែលភាំងស្មារតី, ដែលភ្លេចខ្លួន (ឧ. éperdu de joie); ខ្លាំង (ឧ. amour éperdu)

éperdument *adv.* ដោយភាំងស្មារតី; យ៉ាងខ្លាំង

éperon *n.m.* ក្រចាប់ទាក់សេះ ; ដែកស្រោបផ្ចាល់មាន់; កុងត្របកន្ត្រា ។ *Fam.* ជ្រួញក្នុងភ្នែក ។ *Fig.* គ្រឿងដាក់ចិត្តឲ្យស្ទុះ (ឧ. l'ambition est un excellent éperon) ។

Fortif. ញកការពារ ។

Géogr. ញកភ្នំ ។

Manèg. souffrir l'éperon ស្លូត, ដាក់មិនស្ទុះ (សេះ) ។ avoir l'éperon fin ឬ délicat ឬ fuir l'éperon ឬ s'attacher à l'éperon ឬ connaître l'éperon

ស្មុះណាស់ (សេះជាក់ស្មុះ)។ n'avoir ni bouche ni éperon ស្លូតណាស់ (ចំពោះសេះដែលញាក់បង្ហៀរក៏មិនងាក ជាក់ក៏មិនស្ទុះ; ចំពោះមនុស្សដែលមិនអាចដឹកនាំដោយមក្សេជាយណាបានសោះ)។

Zool. ធ្នាល់ ។

Loc. div. chausser de près les éperons à quelqu'un ដេញតាមប្រកិត(ដេញមនុស្សដែលរត់)។ gagner ses éperons ចេញប្រយុទ្ធដំបូងដោយមានថ្វីដៃ; មានកេរ្តិ៍ឈ្មោះដោយសារស្នាដៃខ្លួន។ donner un coup d'éperon jusqu'à...ទៅដល់...ដោយប្រញាប់ប្រញាល់។ cet homme a besoin d'éperon មនុស្សនេះត្រូវការឲ្យជម្រុញ(ម.ព. bride ផង)។ n'avoir ni bouche, ni éperon ស្លូតណាស់, ភ្លើណាស់

éperonné,e *a.* ដែលពាក់ក្រចាប់ជាក់សេះ (ឧ. monter à cheval botté et éperonné)

éperonner *v.t.* ជាក់នឹងក្រចាប់ (ឧ. éperonner un cheval paresseux); ស្រោបធ្នាល់មាន់ (ឧ. éperonner un coq de combat)។

Fig. ជម្រុញ (ឧ. personne qui est éperonnée par la faim)

éperonnerie *n.f.* ការធ្វើ ឬ ជំនួញក្រចាប់ជាក់សេះនិងប្រដាប់សេះ

éperonnier *n.m.* អ្នកធ្វើឬឈ្មួញក្រចាប់ជាក់សេះនិងប្រដាប់សេះ

épervier *n.m.* ប្រមង់; សំណាញ់បង់ត្រី (ឧ. jeter l'épervier បង់សំណាញ់)

épeuré,e *a.* ម.ព. apeuré

éphèbe *n.m.* មនុស្សពេញកម្លោះ ។ *Par ext.* ក្មេងកំព្រើល

éphélide *n.f.* អាចម៍រុយ

éphémère *a.* ដែលឋិតនៅបានតែមួយថ្ងៃ (ឧ. insecte éphémère)។ *Fig.* អចិរ (មិនឋិតថេរ) (ឧ. la beauté est chose éphémère)។ *n.m.* សត្វមេភ្លៀង

éphéméride *n.f.* ឯកទិន

éphyse *n.f.* អន្ទិកោជ,ចុងភ្លឹង

épi *n.m.Bol.* កួរ (ចង្កោមផ្លែ)។ *T.P.* ទំនប់ទឹក ឬ ខ្សាច់; ក្របៅ

épiage *n.m.* ការបែកកួរ (ឧ. une chaleur humide favorise l'épiage)

épiaison *n.f.* ការកើតកួរ

épice *n.f.* គ្រឿងហឹរ, គ្រឿងទេស

épicer *v.t.* ដាក់គ្រឿងទេស ។ *Fig.* ថែមសំដីឲ្យសៅប (ឧ. récit un peu épicé)

épicerie *n.f.* របរ ឬ ជំនួញ ឬ ហាងលក់បន្លែនិងគ្រឿងសម្ល

épicier,ère *n.&a.* ឈ្មួញគ្រឿងសម្ល

épicurien,enne *a.&n.* នៃអេពីគួរ (ទស្សនវិទូជាតិក្រិក) (ឧ. morale épicurienne); ដែលត្រេកនឹងកាម (ឧ. avoir des mœurs épicuriennes)

épicurisme ឬ **épicuréisme** *n.m.* អេពីគួរនិយម

épidémicité *n.f.* ភាពរោគរាតត្បាត

épidémie *n.f.* រោគរាតត្បាត (ឧ. les mauvaises conditions hygiéniques favorisent l'extension des épidémies) ។ *Fig.* រោគរាលដាល (ឧ. une épidémie de suicides)

épidémiologie *n.f.* ការសិក្សារោគរាតត្បាត

épidémique *a.* រាតត្បាត (ឧ. maladie épidémique) ។ *Fig.* ដែលរាលដាល (ឧ. enthousiasme épidémique)

épiderme *n.m.* *Anat.* អធិចប៌, ស្បែកស្រើ (ឧ. poils, plumes, cornes, ongles, griffes, sabots sont des productions de l'épiderme) ។ *Fig.* avoir l'épiderme sensible ចិត្តច្រើន, ឆាប់ខឹង

épidermique *a.* *Anat.* នៃអធិចប៌ (ឧ. tissu épidermique)

épidiascope *n.m.* ឆាយាទេបន៍

épier *v.i.* បែកគួរ (ឧ. les blés commencent à épier)

épier *v.t.* ឈ្លបមើល, លបលួចមើល (ឧ. épier un suspect), គន់មើល, ឆ្កាល (ឧ. épier les défauts d'autrui); ឃ្លាំមើល

épierrage ឬ **épierrement** *n.m.* ការយកថ្មចេញ

épierrer *v.t.* យកថ្មចេញ

épierreuse *n.f.* ម៉ាស៊ីនរើសដុំថ្មក្នុងចំការ

épieu *n.m.* ស្នូ, លំពែង (ឧ. l'épieu était surtout employé dans la chasse au sanglier)

épieur,euse *n.* អ្នកឈ្លបមើល

épigastre *n.m.* ចុងដើមទ្រូង

épigastrique *a.* នៃចុងដង្ហើម(ឧ. douleur épigastrique)

épiglotte *n.f.* កន្ទើត

épigone *n.m.* កូនចៅជំនាន់ក្រោយ

épigramme *n.f.* អក្សរចារឹកនៅបូជនីយដ្ឋាន; កវីនិពន្ធខ្លីៗ; សំដីដៀលដគ

épigraphe *n.f.* អក្សរចារឹក (ឧ. le Panthéon de Paris porte pour épigraphe: « Aux Grands Hommes la Patrie reconnaissante»); សេចក្ដីស្រង់ដាក់ដើមសៀវភៅ ឬ ដើមវគ្គ

épigraphie *n.f.* ចារឹកសាស្ត្រ [ចារឹ-ក:—](ឧ. l'épigraphie est utile pour l'histoire de l'antiquité)

épigraphique *a.* នៃចារឹកសាស្ត្រ

épigraphiste *n.m.* អ្នកចារឹកសាស្ត្រ

épilage *n.m.* ឬ **épilation** *n.f.* ការដករោម ឬ សក់

épilatoire *a.* សម្រាប់ដករោម ឬ សក់

épilepsie *n.f.* ជំងឺស្កន្ធ ឬ ឆ្កួតជ្រូក

épileptiforme *a.* ដូចស្កន្ធ ឬ ឆ្កួតជ្រូក (ឧ. crise épileptiforme)

épileptique *a.* នៃជំងឺស្កន្ធ ឬ ឆ្កួតជ្រូក (ឧ. convulsions épileptiques) ។ *Fig.* ក្រវេងក្រវាង (ឧ. gestes épileptiques) ។ *n.* មនុស្សឆ្កួតជ្រូក (ឧ. c'est un épileptique)

épiler *v.t.* ដក ឬ ជម្រះរោម ឬ សក់

épileur,euse *n.* អ្នកដករោម ឬ សក់

épillet *n.m.* ស្នែង(ស្នែងផ្កាស្រូវជាដើម)

épilogue *n.f.* អវសានបទ ។ *Par ext.* សេចក្ដីបញ្ចប់ (ឧ. l'épilogue d'une aventure)

épiloguer *v.i.* រិះគន់(ឧ. épiloguer sur les mœurs du siècle) ។ *v.t.* បន្ទោស, រិះគន់

épiloir *n.m.* ចង្កាសដកសក់ ឬ រោម

épinaie *n.f.* កន្លែងដុះរុក្ខជាតិមានបន្លា

épinard *n.m.* អេពីណារ (បន្លែម្យ៉ាង) ។ *Fam.* plat d'épinard រូបទេសភាពដែលមានពណ៌ខៀវច្រើនពេក

épincer *v.t.* *Bot.* ក្ដិបខ្នែងចោល

épinceter, épinceler ឬ **épincer** *v.t.* បេះសាច់ក្រើមចេញ (សាក្លាត)

épine *n.f.* បន្លា ។ *Par ext.* រុក្ខជាតិមានបន្លា ។ épine dorsale ឆ្អឹងខ្នង ។ *Fig.* បន្លា (សេចក្ដីវេទនា ឬ ការលំបាក) (ឧ. la vie est hérissée d'épines) ។ tirer une

épine du pied ជួយដកបន្លា, ជួយដោះកង្វល់ ។ être sur des épines មានកង្វល់ច្រើន (ដូចនៅក្នុងបន្លា)

épiner *v.t.* ស្រាស់បន្លា

épinette *n.f.* គ្រឿងភ្លេងបុរាណម្យ៉ាង (ឧ. l'épinette est l'ancêtre du piano); ទ្រុងបំប៉នបក្សី

épineux,euse *a.* ដែលមានបន្លា ។ *Fig.* ចម្រូងចម្រាស (ឧ. affaire épineuse)

épinglage *n.m.* ការខ្ទាស់ម្ជុល

épingle *n.f.* ម្ជុលក្ទាស់, ដង្កៀប, កន្ទាស់ ។ épingle de nourrice ម្ជុលខ្ទាស់ ។ coup d'épingle សំដីចាក់ដោត ។ tirer son épingle du jeu ដកខ្លួនឲ្យរួចអំពីរឿងពិបាក ។ chercher une épingle (ឬ une aiguille) dans une botte de foin ម.ព. aiguille ។ être tiré à quatre épingles តែងខ្លួនស្អាតបាត ។ *Fam.* monter en épingle ដាក់សម្ញាច ។ virage en épingle à cheveux បត់អន្ទង់អាំង

épingler *v.t.* ភ្ជាប់ ឬ ខ្ទាស់ដោយម្ជុល (ឧ. épingler un papillon); ចាក់នឹងម្ជុលឲ្យជាប់ស្ទះ (ឧ. épingler un bec de gaz) ។ *Fig.* & *fam.* ចាប់, ដាក់គុក

épinglette *n.f.* ដែកចាក់បំពង់កាំភ្លើង; សញ្ញាអ្នកបាញ់ត្រង់

épinglier,ère *n.* ឈ្មួញម្ជុល ។ *n.m.* បំពង់ម្ជុល

épinier *n.m.* ព្រៃបន្លា

épinière *a.f.* នៃឆ្អឹងខ្នង (ឧ. moelle épinière មិញ្ជាឆ្អឹងខ្នង)

épiphyse *n.f.* អដ្ឋិសិរ, ក្បាលឆ្អឹង

épique *a.* នៃយុទ្ធកថា (ឧ. les poèmes épiques d'Homère; style épique) ។ *Par ext.* ចម្លែក (ឧ. discussion épique)

épiscopal,e,aux *a.* នៃអេវ៉េក (ឧ. palais épiscopal)

épiscopat *n.m.* ឋានៈអេវ៉េក; អង្គអេវ៉េក

épisode *n.m.* ឧបកថា, សង្កាត់ (ឧ. film en plusieurs épisodes) ។ *Par ext.* ឧបការណ៍ (ហេតុការណ៍បន្ទាប់បន្សំនៃរឿងមួយ) (ឧ. les épisodes de la Révolution française)

épisodique *a.* នៃឧបកថា; ភយាង (ឧ. personnage épisodique)

épisodiquement *adv.* ជាភយាង

épisperme *n.m.* សំបកស្តើងដែល

ស្រោបក្រាប់

épisser *v.t.* ត្របះ(តខ្សែដោយវេញសរសៃបញ្ចូលគ្នា)

épissière *n.f.* មុងស្រោបក្បាលសេះ

épissure *n.f.* ការត្របះ(ការតខ្សែដោយវេញសរសៃបញ្ចូលគ្នា)

épistaxis *n.f.* ដំណើរឈាមច្រមុះ

épistolaire *a.* នៃរបៀបសរសេរសំបុត្រ (ឧ.style, genre épistolaire)។ *n.m.* អ្នកនិពន្ធខាងសរសេរសំបុត្រ

épistolier,ère *n. Fam.* អ្នកសរសេរសំបុត្រច្រើន, អ្នកកើតខាងសរសេរសំបុត្រ

épitaphe *n.m.* ពាក្យចារិកមុខផ្នូរ

épithalame *n.m.* កាព្យជូនពរអ្នករៀបមង្គលការ

épithélial,e,aux *a.* នៃស្រទាប់ជាលិកា

épithélium *n.m. Méd.* ស្រទាប់ជាលិកា (ឧ. l'épiderme est un épithélium)

épithète *n.f.* វិសេសសព្ទ

épitomé *n.m.* សង្ខិតបទ, សេចក្ដីសង្ខេប (ឧ. lire un épitomé)

épitre *n.f.* អក្ក, សារជាពាក្យកាព្យ (ឧ. les épîtres de Boileau)។ *Fam.* សំបុត្រ (ឧ. écrire à un ami une épître chaleureuse)។ épître dédicatoire លិខិតឧទ្ទិស (ឧទ្ទិសសៀវភៅចំពោះអ្នកណាម្នាក់)

épizootie *n.f.* រោគរាតត្បាតសត្វ

épizootique *a.* ដែលរាតត្បាតសត្វ (ឧ. maladie épizootique)

éploré,e *a.* ដែលយំសស្រាក់; ដែលមានទុក្ខធ្ងន់ (ឧ.une veuve éplorée)

éployer *v.t.* លាត្រដាង; កាង; សន្ធឹង

épluchage ឬ **épluchement** *n.m.* ការបក, ការសក, ការចិតសំបក (ឧ. l'épluchage des pommes de terre); ការបេះផ្លែឈើចោលខ្លះកុំឲ្យធ្ងន់ដើមពេក។ *Fig.* ការពិនិត្យដោយល្អិតចត់ (ឧ. l'épluchage d'un livre)

éplucher *v.t.* បក, សក, ចិតសំបក (ឧ. éplucher des pommes de terre); បេះអ្វីដែលខូចចោល (ឧ. éplucher la salade); បេះរោមចប់ជង្គូរសំពត់ (ឧ. éplucher un drap); ដកស្មៅរង្រាក់ចេញ (ឧ. éplucher un champ)។ *Fig.* រិះរកកំហុស (ឧ. éplucher la conduite; éplucher un compte, un témoin)

éplucheur,euse *n.* អ្នកបកឬសក ។ *n.m.* ប្រដាប់ចិតសំបក (កាំបិត,ដំឡូង ។ល។)។ *Fig.* អ្នកពិនិត្យដោយហ្មត់ចត់

épluchoir *n.m.* កាំបិតសក

épluchure *n.f.* សំបក,សំណក(សំបកដែលគេសក) (ឧ. balayer les épluchures)

épointage *n.m.* ការកាត់ឬបន្ទាលចុង

épointé,e *a.* chien épointé ឆ្កែដាច់កណោង

épointement *n.m.* ភាពមានចុងរិល

épointer *v.t.* បំបាក់ចុង, កាត់ឬបន្ទាលចុង (ឧ. épointer un crayon)

éponge *n.f.* សត្វផ្កាទឹក; ផ្កាទឹកស្អុត; ពពុះទឹក; វត្ថុមានភាពដូចពពុះទឹក ។ éponge végétale ននោងព្រហើរ។ passer l'éponge sur បំភ្លេច, អត់ទោសឲ្យ

éponge *n.f.* ចុងដែកក្រចកសេះ

épongeage *n.m.* ការជូតឬផ្ចិតដោយពពុះទឹក(ឬរបស់អ្វីដែលផឹកទឹក)

éponger *v.t.* ជូតឬផ្ចិតដោយពពុះទឹក (ឬរបស់អ្វីដែលផឹកទឹក) (ឧ. éponger une table humide)។ s'éponger *v.pr.* ជូតឬផ្ចិត(ឧ.s'éponger le front)

épontille *n.f. Mar.* បង្គោលសម្រាប់ទប់អ្វីមួយឲ្យមាំ

épopée *n.f.* យុទ្ធកថា។*Fig.* វីរកម្ម(ឧ. la marche des troupes de Leclerc,du Tchad à Strasbourg, est une magnifique épopée)

époque *n.f.* ជំនាន់,សម័យ (ឧ. époque angkorienne);រដូវ(ឧ.époque des vendanges)។ notre époque សម័យយើងឥឡូវ ។ *Par ext.* កាលសំខាន់ (ឧ. on a dit avec raison que la découverte de l'imprimerie demeure «la grande époque de l'histoire du genre humain» ។

Loc. div. faire époque ធ្វើឲ្យគេសំគាល់, ធ្វើឲ្យគេចាំបានយូរ (ឧ. un procès qui fera époque)។ brouiller les époques ច្រឡំកាលបរិច្ឆេទ ។ les époques d'une femme រដូវនៃស្ត្រី។ à pareille époque នៅកាលដូចគ្នា(នៅឆ្នាំដទៃទៀត តែកាលបរិច្ឆេទដូចពេលឥឡូវនេះ) ។ la Belle Epoque

សម័យដើមសតវត្ស ទី ២០

épouffer (s') *v.pr. Fam.* ហត់ដាច់ខ្យល់។ s'épouffer de rire សើចរឹងពោះ។ *Pop.* គេច, រត់

épouiller *v.t.* រកចៃ

épоumonner (s') *v.pr.* ខំប្រឹងស្រែក, ខំប្រឹងនិយាយ (ឲ្យហត់ស្អួត) (ឧ.s'époumonner à répéter une chose)

épousailles *n.f. pl.* ពិធីរៀបមង្គលការ (ឧ. jour des épousailles)

épouse *n.f.* ភរិយា, ប្រពន្ធ

épousée *n.f.* ស្ត្រីដែលទើបនឹងរៀបមង្គលការហើយ ឬ ដែលបម្រុងនឹងរៀបមង្គលការ

épouser *v.t.* យកជាប្តីឬប្រពន្ធ ។ *Fig.* ចូល(យកធ្វើជារបស់ខ្លួន) (ឧ. épouser un parti) ។ épouser la forme de យកសណ្ឋានតាម ។ épouser Dieu ចូលធ្វើដូនជី ។

Argot. épouser la camarde ស៊ុជី, ស្លាប់ ។ épouser la veuve ត្រូវស្លាប់ដោយម៉ាស៊ីនកាត់ក (la veuve ក្នុងទីនេះគឺម៉ាស៊ីនកាត់ក) ។

Loc. prov. tel fiance qui n'épouse pas អ្នកឡើងបានតែរបេះ អ្នកប្រឡេះមិនបានស៊ី។

s'épouser *v pr.* យកគ្នាជាស្វាមីភរិយា

épouseur *n.m.* អ្នកប្រាថ្នារកប្រពន្ធ(ឧ. fille trop fière qui éloigne les épouseurs)

époussetage *n.m.* ការបោសធូលី

épousseter *v.t.* បោសធូលី(ឧ.épousseter des meubles, des habits)។ *Fig.* សំអាត។ *Fam.* វាយ, រឹះគន់ខ្លាំង។ *Manèg.* ជូតកេមសេះ ។

s'épousseter *v.pr.* បោសធូលីខ្លួនឯង។ *Fam.* ប្រវាយគ្នា

épousseteur,euse *n.* អ្នកបោសធូលី

époussetoir *n.m.* ច្រាសជុសពេជ្រ

époussette *n.f.* អំបោសបោសធូលី

époustouflant,e *a. Fam.* ចំឡែក, គួរឆ្ងល់

époustoufler *v.t. Fam.* ធ្វើឲ្យឆ្ងល់ ឬឲ្យភ្ញាក់

épouti *n.m.* សម្រាមជាប់នឹងសំពត់សាក្លាត

épouvantable *a.* ដែលធ្វើឲ្យខ្លាចខ្លាំង (ឧ.bruit épouvantable)។ *Par exagér.* សំបើម (ឧ. laideur

épouvantable)

épouvantablement *adv.* แก่ง ស់បើម

épouvantail *n.m.* ទីងមោង ។ *Fig.* រឿងដែលធ្វើឲ្យខ្លាចឥតប្រយោជន៍

épouvante *n.f.* បរោភ័យ (ដែលកើតឡើងភ្លាម)(ឧ. la vue d'une éclipse frappait parfois d'épouvante les armées anciennes)

épouvanter *v.t.* បំភ័យ,ធ្វើឲ្យតក់ស្លុតខ្លាំង

époux, épouse *n.* ប្ដី, ប្រពន្ធ ។ *pl.* ស្វាមីភរិយា, ប្ដីប្រពន្ធ (ឧ. époux assortis)

épreindre *v.i.* ច្របាច់យកទឹកចេញ

épreinte *n.f.* ការឈឺពោះទុក្ខសត្វធំ, ការឈឺជុះ។ *Véner.* អាចម៍ភេ

éprendre (s') *v.pr.* ស្រឡាញ់ណាស់ (ឧ. s'éprendre de la liberté)

épreuve *n.f.* ការសាក, ការល្បង (ឧ. faire l'épreuve d'un remède); ទុក្ខវេទនា ។

à l'épreuve ជាការល្បង (ឧ. acheter un cheval à l'épreuve)។ à l'épreuve de អាចធន់បាន (ឧ. abri à l'épreuve de la bombe)។ mettre à l'épreuve de ល, ល្បង។ à toute épreuve គ្មានអ្វីបំផ្លាញបាន (អាចទប់ទល់បាននឹងឧបសគ្គគ្រប់យ៉ាង) (ឧ. courage à toute épreuve; un ami à toute épreuve)។

វិញ្ញាសា (ដើម្បីដឹង) ។ épreuve d'admissibilité វិញ្ញាសាប្រវេសនីយភាព ។ épreuve d'admission វិញ្ញាសាប្រវេសន៍ ។ épreuve éliminatoire វិញ្ញាសាទម្លាក់។ épreuve écrite វិញ្ញាសាសរសេរ ។ épreuve orale វិញ្ញាសាស្ដារ។ épreuve pratique វិញ្ញាសាប្រតិបត្តិ ។ épreuve obligatoire វិញ្ញាសាបង្ខំ។ épreuve facultative វិញ្ញាសាតាមចិត្ត

épris,e *a.* ដែលស្រឡាញ់

éprouver *v.t.* សាក,ល្បង,ជាក់តេស្ត (ឧ. éprouver un pont, l'honnêteté de quelqu'un)។ éprouver de la joie សប្បាយ។ éprouver de la crainte ខ្លាច។ éprouver des difficultés ប្រទះឧបសគ្គ, មានការលំបាក។ ធ្វើឲ្យ

កើតទុក្ខ (ឧ. ce malheur l'a cruellement éprouvé)

éprouvette *n.f.* កែវបំពង់(សម្រាប់ធ្វើការពិសោធន៍); ប្រដាប់សម្រាប់ល្បង

épucer *v.t.* ចាប់ចៃ ឬ ស្រមើលសត្វ

épuisable *a.* អាចអស់បាន

épuisant,e *a.* ដែលធ្វើឲ្យអស់កម្លាំង(ឧ. le climat tropical est épuisant)

épuisé,e *a.* ដែលអស់កម្លាំង ។ livre épuisé សៀវភៅអស់ (គ្មាននៅសល់ដាក់លក់)

épuisement *n.m.* ការពង្រីង, ការធ្វើឲ្យស្ងួត,ការធ្វើឲ្យអស់ (ឧ.l'épuisement d'une source) ។ *Fig.* ការអស់កម្លាំង (ឧ. mourir d'épuisement);ដំណើរអស់ (ឧ.l'épuisement des finances)

épuiser *v.t.* ពង្រីង,ធ្វើឲ្យស្ងួត(ឧ.épuiser une citerne); បរិភោគអស់, ប្រើអស់ (ឧ. épuiser ses munitions);បង្ហិន,ធ្វើឲ្យក្រ (ឧ. épuiser un Etat);ធ្វើឲ្យស្គោះ,ធ្វើឲ្យអស់ជីជាតិ(ឧ.épuiser un terrain); ធ្វើឲ្យពុះទន់ខ្សោយឬឲ្យអស់កម្លាំង (ឧ. épuiser le corps, l'esprit)។ *Fig.* ពិចារណាឲ្យអស់អេចសេចក្ដី (ឧ.épuiser un sujet)។épuiser la patience ធ្វើឲ្យលែងអត់បាន ។ **s'épuiser** *v.pr.* រីង; អស់កម្លាំង; អស់

épuisette *n.f.* រុងគួប; សំណាញ់តូចសម្រាប់ចាប់បក្សីក្នុងទ្រុងៈស្ទូចទូក

épulide ឬ **épulie** *n.f.* ការហើបអញ្ចាញធ្មេញ

épulotique *a.* សម្រាប់ផ្សះ។ *n.m.* ថ្នាំផ្សះ

épulpeur *n.m.* ប្រដាប់ពូតយកទឹកពីសាប៉ី

épurateur *n.&a.m.* ប្រដាប់ធ្វើឲ្យសុទ្ធ

épuratif,ive ឬ **épuratoire** *a.* សម្រាប់ធ្វើឲ្យសុទ្ធ(ឧ.appareil épuratif)

épuration *n.f.* វិសុទ្ធកម្ម,ការធ្វើឲ្យសុទ្ធ។ *Fig.* ការធ្វើឲ្យបរិសុទ្ធ (ឧ. l'épuration des mœurs); ការជំរះ ឬ សំអាតចិត្ត ; ការបំបាត់ពួកអ្នកមិនល្អចេញ (ឧ. l'épuration de 1915)

épuratoire *a. Ind.* សម្រាប់ធ្វើឲ្យសុទ្ធ

épurement *n.m.* ការធ្វើឲ្យល្អ(ឧ.l'épurement du style)

épurer *v.t.* ធ្វើឲ្យសុទ្ធ (ឧ.épurer de l'huile)។ *Fig.* ធ្វើឲ្យបរិសុទ្ធ, ជំរះឬសំអាតចិត្ត(ឧ.Boileau s'attacha

à épurer le goût de son temps); បំបាត់ពួកអ្នកមិនល្អចេញ

épurge *n.f.* ដើមឈើម្យ៉ាងប្រើជាថ្នាំបញ្ចុះ

équanimité *n.f.* ភាពចិត្តនឹង

équarrir *v.t.* ធ្វើឲ្យទៅជាបួនជ្រុង (ឧ. équarrir un bloc de marbre); ចាំងជាជ្រុង (ឧ. équarrir une poutre); វះប្រហោងឲ្យធំ;ពន្លះសត្វ។ *Fig.* mal équarri គគ្រោល

équarrissage ឬ **équarrissement** *n.m.* ការចាំងជាជ្រុង; ភាពចាំងជាជ្រុង; ការពន្លះសត្វ

équarrisseur *n.m.* អ្នកពន្លះសត្វ

équarrissoir *n.m.* ទីសម្លាប់សត្វដែលគេមិនយកសាច់; កាំបិតពន្លះសត្វ; ប្រដាប់វះប្រហោង

équateur *n.m.* ភូមធ្យរេខា [ភូ-មៈ-ធ្យៈ-រេ-] ។ équateur céleste ភូមធ្យរេខានភាកាស ។ équateur magnétique ភូមធ្យរេខាចុម្ពិត ។ équateur terrestre ភូមធ្យរេខាផែនដី

équation *n.f. Math.* សមីការ ។ équation du 1er degré សមីការ១ជាន់។ équation du 2e degré សមីការ ២ ជាន់ ។ équation bicarrée សមីការភ្លោះ។ équation algébrique សមីការពីជគណិត ។ équation différentielle សមីការអវកល។ équation intégrale សមីការអនុកល ។ racine d'une équation ឫសសមីការ

équatorial,e,aux *a.* នៃភូមធ្យរេខា(ឧ. ligne équatoriale)។ coordonnées équatoriales d'une étoile និយាមកាភូមធ្យរេខានៃតារា។ climat équatorial អាកាសធាតុភូមធ្យរេខា (ក្ដៅជានិច្ចហើយភ្លៀងច្រើន) (ម.ព. climat ផង)។ *n.m.* កែវឆ្លុះមើលតារាម្យ៉ាង

équatorien,enne *n.&a.* នៃភូមធ្យរេខា

équerre *n.f.* កែង;វត្ថុដែលមានមុមត្រង់។ d'équerre តកែង (ឧ. ce bâtiment n'est pas d'équerre)

équestre *a.* នៃការជិះសេះ (ឧ. exercices équestres) ។ statue équestre រូបមនុស្សជិះសេះ

équeutage *n.m.* ការក្ដិចកន្ទុយផ្លែឈើ

équeuter *v.t.* ក្ដិចកន្ទុយផ្លែឈើ

équiangle *a.* ដែលមានមុមស្មើគ្នា (ឧ. un triangle équiangle est

aussi équilatéral)

équidés *n.m. pl.* អស្សសាទិសសត្វ, ពពួកសត្វសន្តានសេះ,លា ។ល។

équidistance *n.f.* ភាពមានចម្ងាយស្មើគ្នា

équidistant,e *a.* ដែលមានចម្ងាយស្មើគ្នា(ឧ.tous les points de la circonférence sont équidistants du centre)

équilatéral,e,aux ឬ **équilatère** *a.* សមបាត [សៈ-មៈ—], ដែលមានជ្រុងស្មើគ្នា ។ triangle équilatéral ត្រីកោណសមបាត

équilibrage *n.m.* សមតាកម្ម, ការធ្វើឲ្យមានសមតា

équilibrant,e *a.* ដែលធ្វើឲ្យមានសមតា

équilibre *n.m.* សមតា [សៈ-មៈ-តា] équilibre stable សមតាប៉ិវត្ត។ équilibre instable សមតាអប៉ិវត្ត។ perdre l'équilibre ដួល ។ *Fig.* សមតា, ការថ្លឹងឲ្យស្មើ ។ équilibre des pouvoirs សមតាអំណាច ។ équilibre politique សមតានយោបាយ ។ équilibre économique សមតាសេដ្ឋកិច្ច ។ équilibre budgétaire សមតាថវិកា ។ ភាពស្ងប់ (ឧ. l'équilibre de l'esprit)

équilibré,e *a.* ដែលមានសមតា; ដែលមានន័យស្មើ (ឧ. esprit équilibré)

équilibrer *v.t.* ធ្វើឲ្យមានសមតា (ឧ. équilibrer un budget)។*Fig.* ថ្លឹងឲ្យស្មើ (ឧ. équilibrer les deux plateaux d'une balance)។ *Fig.* លៃឲ្យស្មើ

équilibreur *n.m.* ប្រដាប់ថ្លឹងឲ្យស្មើ(ឧ. les avions sont munis d'équilibreurs automatiques)

équilibrisme *n.m.* វិជ្ជាសៀកសមតា

équilibriste *n.* អ្នកលេងសៀកសមតា

équin,e *a.* នៃសេះ

équinoxe *n.m.* អយនកាល [អៈ-យៈ-នៈ—] (កាលក្នុងរដូវដែលមានវេលាថ្ងៃនឹងយប់ស្មើគ្នាគឺនៅថ្ងៃទី ២១ ឬ ២២ មិនា នឹងថ្ងៃទី ២២ ឬ ២៣ កញ្ញា)

équinoxial,e,aux *a.* នៃអយនកាល

équipage *n.m.* បរិជន; ក្រុមបរិវារនឹងយានជំនិះទាំងឡាយ(ឧ.l'équipage d'un prince); របស់ប្រើគឺគនាយ (ឧ. avoir un équipage); របៀបស្លៀកពាក់ (ឧ.arriver en piteux équipage)។ *Mil.* យានិក,កងនា-

វឹក. ក្រុមអ្នកធ្វើការក្នុងកងនាវា ឬ យន្តហោះ។ équipage de la flotte កងនាវិក

équipe *n.f.* យុគ្គ; កង ។ *Fig.* ក្រុម, ពួក។ esprit d'équipe គតិយុគ្គ (សាមគ្គីភាពរវាងអ្នកនៅក្នុងក្រុមជាមួយ)

équipé,e *a.* ដែលមានបរិក្ខារ

équipement *n.m.* បរិក្ខារកិច្ច,ការផ្គត់ផ្គង់បរិក្ខារ; បរិក្ខារ។ l'équipement militaire យោធបរិក្ខារ

équiper *v.t.* ផ្គត់ផ្គង់បរិក្ខារឬសំលៀកបំពាក់ (ឧ. équiper une armée)

équipier, ère *a.* យោធិក [—ធិក], អ្នកចូលក្នុងកងឬក្រុម

équipollence *n.f.* ម. ព. équivalence

équipollent,e *a.* ម.ព.équivalent

équipoller *v.t.&i.* ធ្វើឲ្យមានសមមូលភាព [សៈ-មៈ-មូ-លៈ—] ឬឲ្យស្មើគ្នា

équipotentiel,elle *a.*សមសក្តានុរូប [សៈ-មៈ-សៈ-ក្កា—]

équitable *a.* ដែលទៅនសមធម៌ [សៈ-មៈ—] (ឧ. juge équitable); សមតាមសមធម៌(ឧ. sentence équitable)

équitablement *adv.* ដោយសមធម៌ [សៈ-មៈ—] (ឧ. partager équitablement un héritage)

équitation *n.f.* អស្សសិល្បៈ, អស្សារោហនវិជ្ជា, សិល្បៈជិះសេះ

équité *n.f.* សមធម៌ [សៈ-មៈ—] (ឧ. l'équité d'un partage)

équivalence *n.f.* សមមូលភាព, [សៈ-មៈ-មូ-លៈ—], តម្លៃស្មើគ្នា (ឧ. équivalence de diplômes); ភាពស្មើគ្នា

équivalent,e *a.&n.* សមមូល [សៈ-មៈ-មូល] ដែលមានតម្លៃស្មើគ្នា (ឧ. quantités équivalentes); ដែលមានន័យស្មើគ្នា (ឧ. expression équivalente) ។

n.m. សមមូលវត្ថុ [សៈ-មៈ-មូ-លៈ—] (ឧ. offrir l'équivalent de ce qui a été donné)

équivaloir *v.i.* មានតម្លៃស្មើគ្នា(ឧ. désir qui équivaut à un ordre)

équivocité *n.f.* ការមានន័យពីរ

équivoque *a.* ដែលមានន័យពីរ (ឧ. mot équivoque)។ *Fig.*ដែលធ្វើឲ្យមន្ទិល (ឧ. sincérité équivoque)។

n.f. ន័យឬអត្ថមិនច្បាស់លាស់;

ការប្រើពាក្យឬវត្ថុ; ទ្វេយភេទ [ទ្វេ-យេះ-], ឃ្លាដែលមានន័យពីរ; ការលេងសំដី

équivoquer *v.i.* ប្រើទ្វេយភេទ, ប្រើសំដីចាក់ក្រលោក

éradication *n.f.* ការដក

éraflement *n.m.* ការឆូតសើ, ការធ្វើឲ្យរលាត់

érafler *v.t.* ឆូតសើ, ធ្វើឲ្យរលាត់

éraflure *n.f.* ស្នាមរលាត់, ស្នាមកន្ទួល (ឧ. duel qui s'est terminé par une éraflure)

éraillé,e *a.* ដែលមានសរសៃធូរ (ឧ. dentelle éraillée); ដែលមានឆូតឬរលាត់សើ (ឧ. des murs éraillés)។ l'œil éraillé ភ្នែកមានកន្ទុយថ្លែន, គ្របភ្នែកពន្លាត់។ *Fig.* voix éraillée សំឡេងស្អកស្អ

éraillement *n.m.* ការពន្លាត់គ្របភ្នែក; ការបន្ធូរសរសៃសំពត់

érailler *v.t.* បន្ធូរសរសៃសំពត់ (ឧ. érailler du linge)។ *Par ext.* ឆូតសើ, ធ្វើឲ្យរលាត់ (ឧ. érailler du cuir)។ *Par anal. & v. pr.* s'érailler la voix ធ្វើសម្លេងឲ្យស្អកស្អ

éraillure *n.f.* ស្នាមសរសៃអំពោះធូរ (លើសាច់សំពត់); ស្នាមរលាត់

ère *n.f.* សករាជ។ ère bouddhique ពុទ្ធសករាជ។ ère chrétienne គ្រិស្តសករាជ។ សម័យ, យុគ (ឧ. la Révolution française a marqué pour la France une ère nouvelle)។ ស័ក។ ère géologique ស័កនៃភូគព្ភសាស្ត្រ។ ère primaire បឋមស័ក។ ère secondaire ទុតិយស័ក។ ère tertiaire តតិយស័ក ។ ère quaternaire ចតុត្ថស័ក ។ *Fig.* ère de prospérité សម័យរុងរឿង

érectile *a.* អាចបះបាន (រីកធំហើយឡើងរឹងដូចយ៉ាងលិង្គជាដើម) (ឧ. tissu érectile)

érectilité *n.f.* ភាពអាចបះបាន (រីកធំហើយឡើងរឹង)

érection *n.f.* ការសង់, ការសាង (ឧ. l'érection d'une statue, d'un monument); ការបង្កើត, ការតាំង (ឧ. l'érection d'un tribunal); ភាពបះ (រីកធំហើយឡើងរឹង)

éreintant,e *a.* ដែលធ្វើឲ្យធាក់កំឡាំង (ឧ travail éreintant)

éreintement *n.m.* ការបំធាក់កំឡាំង។

Fig. ការស្តីបន្ទោសខ្លាំង

éreinter *v.t.* ផាត់បង្កេះ, កាច់បង្កេះ។ *Fig.* ធ្វើឲ្យអស់កំឡាំង,ធ្វើឲ្យហត់ (ឧ. éreinter un cheval)។ *Fam.* វាយ,រិះគន់ដោយសំអប់ (ឧ. éreinter une pièce nouvelle)

éreinteur *n.m.* *Fam.* អ្នកធ្វើឲ្យហត់ ឬ ឲ្យអស់កម្លាំង ។ *a.* un critique éreinteur អ្នករិះគន់ដោយសំអប់

érémitique *a.* នៃឥសី; ដែលរស់នៅតែម្នាក់ឯង (ឧ. la vie érémitique est née en Egypte)

érésipèle ឬ **érysipèle** *n.m.* ពិសស្បែក

éréthisme *n.m.* *Fig.* តណ្ហាបរិឡាហ៍, សំរើបនៃតណ្ហា

éreutophobie *n.f.* ការខ្លាចឡើងមុខក្រហម

erg *n.m.* *Méc.* អ៊ែគ្គ(មានទំណាខាងរូបនិយម)

ergastule *n.m.* គុកក្នុងដី

ergo *conj.* (ពាក្យឡាតាំង) ដូច្នេះ,ហេតុដូច្នេះ

ergot *n.m.* ក្នាល់មាន់;ក្រចកក្រោយនៃជើងឆ្កែ ។ *Fig.* se dresser sur ses ergots អួតអាក់,បញ្ចេញចង្កូម។ *Pop.* se fendre l'ergot រត់ ។ *Bot.* រោគម្យ៉ាងនៃធញ្ញជាតិ, ជម្ងឺធញ្ញជាតិ

ergotage,ergotement *n.m.* ឬ **ergoterie** *n.f.* *Fam.* ការចូលចិត្តតវ៉ា

ergoté,e *a.* ដែលមានក្នាល់ (ឧ. coq bien ergoté); ដែលមានជម្ងឺ (ឧ. seigle ergoté)

ergoter *v.i.* *Fam.* តវ៉ា ឬ ជជែកចំពោះរឿងបន្តិចបន្តួច (ឧ. ergoter sur un texte de loi)

ergoteur,euse *a.&n.* ដែលចូលចិត្តតវ៉ា (ឧ. un avocat ergoteur)

ériger *v.t.* សាង, សង់ (ឧ. ériger une statue); បង្កើត, តាំង (ឧ. ériger un tribunal) ។ *Fig.* លើកឋានៈ (ឧ. ériger une église en cathédrale) ។

s'ériger *v.pr.* តាំងខ្លួន (ឧ. s'ériger en censeur)

ermitage *n.m.* អាស្រមបទ. អាស្រមឥសី ។ *Par ext.* ផ្ទះដាច់ស្រយាល

ermite *n.m.* ឥសី,តាបស។ *Fig.* អ្នកនៅឆ្ងាយពីគេ

éroder *v.t.* ហូរច្រោះ(ឧ.l'eau érode le fond du lit des rivières);

កាត់, ស៊ី

érosif,ive *a.* ដែលច្រោះ (ឧ.le pouvoir érosif des glaciers est considérable); ដែលកាត់, ដែលស៊ី

érosion *n.f.* ចម្រោះ, ការហូរច្រោះ (ឧ. l'eau est le principal agent d'érosion)។ cycle d'érosion ម.ព. cycle។ ការកាត់ឬស៊ី

érotique *a.* នៃស្នេហ៍; ខុសសីលធម៌ (ឧ.littérature érotique)

érotiquement *adv.* ដោយខុសសីលធម៌

érotisme *n.m.* *Méd.* រោគស្នេហា

érotomane ឬ **érotomaniaque** *n.* &*a.* ស្នេហាម័ត្ត, ឆ្កួតស្នេហា

érotomanie *n.f.* ស្នេហម័ទ, ការឆ្កួតស្នេហា

erpétologie ឬ **herpétologie** *n.f.* ឧរង្គសាស្ត្រ, វិទ្យាសាស្ត្រខាងសត្វលូន

erpétologique *a.* នៃឧរង្គសាស្ត្រ (ឧ. collections erpétologiques)

erpétologiste *n.* ឧរង្គវិទូ

errance *n.f.* ការដើរចរប្រប់

errant,e *a.* ដែលដើរចរប្រប់, ដែលគ្មានលំនៅខ្ជាប់ខ្ជួន (ឧ.tribus errantes)

errata *n.m. inv.* បញ្ជីពាក្យខុស (ឧ. dresser un errata, des errata)

erratique *a.* *Méd.* លស់ (ឧ. fièvre erratique គ្រុនលស់)

erratum *n.m.* ពាក្យខុសក្នុងសៀវភៅ (ឧ. découvrir un erratum)

erre *n.f.* ដំណើរ, របៀបដើរ។ aller à grand-erre ឬ à belle erre ដើរលឿនណាស់; *au fig.* ចាយធំ។ revenir à ses premières erres ប្រព្រឹត្តរបៀបដើមឡើងវិញ។ aller sur les erres de quelqu'un យកតម្រាប់តាម, តាមយោបល់។ *Mar.* ដំរុល (ល្បឿននាវាដែលម៉ាស៊ីនឈប់ដើរ)។ casser l'erre បញ្ឈប់នាវា។ *Vener.* ដានសត្វ

errements *n.m. pl.* របៀបប្រព្រឹត្ត (ឧ. les errements de l'Administration)។ *Péjor.* ការប្រព្រឹត្តខុស (ឧ.retomber dans ses anciens errements)។ *Par ext.* ការដើរចរប្រប់

errer *v.i.* ដើរចរប្រប់, ដើរមិនផ្ដោះទៅកន្លែងណា (ឧ. errer dans la campagne)។ *Fig.* ភាន់ច្រឡំ

erreur *n.f.* មតិខុស, កំហុស (ឧ. commettre une erreur); ការភាន់ច្រឡំ (ឧ. erreur de calcul)។

pl. ការប្រព្រឹត្តខុស (ឧ. erreurs de jeunesse)។ *Prov.* erreur n'est pas compte ការគិតច្រឡំរកចំកែបាន

erroné,e *a.* ដែលមានការភាន់ច្រឡំ (ឧ. proposition erronnée)

ersatz *n.m.* វត្ថុជំនួស

érubescence *n.f. Méd.* ការឡើងក្រហម

érubescent,e *a.* ដែលឡើងក្រហម(ឧ. fruits érubescents)

éruciforme *a. Zool.* ដែលមានរាងជាដង្កូវ

éructation *n.f.* ភើ

éructer *v.i.* ភើ ។ *v.t. Fig.* éructer des injures ជេរ

érudit,e *a.&n.* ពហុស្សូត (ឧ. historien érudit),ដែលមានវិជ្ជាជ្រៅជ្រះ (ឧ. ouvrage érudit)

érudition *n.f.* ពហុស្សុតភាព; វិជ្ជាជ្រៅជ្រះ

érugineux,euse *a.* នៃច្រែះ

éruptif,ive *a.* ឧទ្គម (ឧ. roches éruptives ម.ព. roche); ដែលធ្លាយចេញ,ដែលផុសឬខ្ទុះចេញ។ *Méd.* ដែលកេនពិសស៊ើស្បែក (ឧ. fièvre éruptive)

éruption *n.f.* ឧទ្គមន៍,ការផ្ទុះ,ការផុសឬខ្ទុះចេញ ។ *Méd.* ដំណើរចេញពិសស៊ើស្បែក,ការធ្លាយ។éruption des dents ដំណើរដុះធ្មេញ។ éruption volcanique ការផ្ទុះភ្នំភ្លើង

érysipélateux,euse *a.* ដែលចេញមុនឬចេញក្រោយពិសស្បែក

érysipèle *n.m.* ម.ព. érésipèle

érythrocyte *n.m.* ម.ព. hématie

ès *pré.* ប៉ែកខាង។docteur ès sciences បណ្ឌិតខាងវិទ្យាសាស្ត្រ ។ ès qualité ផ្ទាល់ខ្លួន។ès mains ផ្ទាល់ដៃ (ឧ. payer une somme ès mains de quelqu'un)

esbigner (s') *v.pr. Pop.* រត់(គេចខ្លួន)

esbroufe *n.f. Pop.* ការធ្វើឫកខ្ពត(ឧ. faire de l'esbroufe) ។ *Arg.* vol à l'esbroufe ការលួចឆក់ដោយដើរប្របៀត

esbroufer *v.t. Pop.* ធ្វើឫកខ្ពតឲ្យគេស្ញើច ។ *Arg.* លួចឆក់ដោយដើរប្រមៀត

esbroufeur,euse *n. Pop.* អ្នកធ្វើឫកខ្ពត ។ un air esbroufeur ឫកខ្ពត

escabeau *n.m.* ឬ **escabelle** *n.f.* ជើងកាំង,ជើងម៉ា

escadre *n.f.* កងនាវាចម្បាំង ។ chef d'escadre *Autref.* នាយកងនាវា (សក្តិស្មើនឹងឧត្តមនាវីត្រី)។ *Auj.* កងធំនៃអាកាសយាន

escadrille *n.f.* កងនាវាចម្បាំង; កងអាកាសយាន

escadron *n.m.* អស្សានីក [អ័ស-សា-និក], កងទ័ពសេះ; កងអនុសេនាធំ (ខាងទ័ពសេះ, ទ័ពរថក្រោះ។ល។) (ឧ. l'escadron est commandé par un capitaine ou chef d'escadron) ។ *Par ext.* ហ្វូង (មនុស្ស ឬ សត្វ)

escalade *n.f.* ការវាយលុកដោយឡើងតាមជណ្តើរ;ការឡើងតាមរបង (ឧ.escalade d'un mur);ការឡើង(ឧ. escalade d'un rocher); ការលួចចូល (តាមបង្អួចឬតាមដំបូល)

escalader *v.t.* វាយលុកដោយឡើងតាមជណ្តើរ,ឡើងឆ្លង(ឧ.escalader une grille); ឡើងដោយប្រឹងប្រែង (ឧ. escalader une montagne) ។ *Fig.* escalader le pouvoir ឡើងកាន់អំណាច

escalator *n.m.* ជណ្តើរម៉ាស៊ីន

escale *n.f.* ចំណតយកស្បៀង (នាវា; យន្តហោះ)(ឧ.Suez, Singapour et Saïgon sont d'importantes escales sur la route d'Extrême-Orient) ។ faire escale សំចត

escalier *n.m.* ជណ្តើរ ។ escalier tournant ជណ្តើរវិល ។ escalier en colimaçon ជណ្តើរហៀន ។ escalier roulant ជណ្តើរយាន

escalope *n.f.* ចំណិតសាច់ស្តើង (ឧ. escalope de veau, de thon)

escamotable *a.* អាចពន្លឹបចូលបាន(ឧ. train d'atterrissage escamotable)

escamotage *n.m.* ការពន្លឹប (ឧ. escamotage d'une carte); ការឆ្លើយដោយបន្លំ (ឧ. escamotage d'une question) ។ *Fig.* ការបន្លំលួច

escamoter *v.t.* ពន្លឹប (ឧ. escamoter des cartes; escamoter le train d'atterrissage d'un avion); លួចឆក់ (ដោយប៉ិនប្រសប់) (ឧ. escamoter un porte-

feuille)។ *Fig.* អានគោយបន្ទំ (ឧ. escamoter des mots); ឆ្លើយ គោយបន្ទំ (ឧ. escamoter une question)

escamoteur,euse *n.* អ្នកពន្ធ័ប; អ្នកបន្ទំលួច

escampativos *n.m.pl.Fam.* ការរត់, ការគេច

escamper *v.t.* រត់ (គេចខ្លួន)

escampette *n.f.* *Pop.* prendre la poudre d'escampette ឆាត់មេឆាយ (រត់)

escapade *n.f.* ការគេចឬវេះ (ឧ. c'est une escapade d'écolier)

escape *n.f.* តួសសរ

escarbille *n.f.* ផ្កាភ្លើង (ឧ. les escarbilles d'une locomotive)

escarboucle *n.f.* អ៊ីវ ដែលភ្លឺដូចរងើកភ្លើង (ឧ. ses yeux brillaient comme deux escarboucles)

escarcelle *n.f.* ថង់ប្រាក់ព្យួរនៅចង្កេះ (ឧ. fouiller à l'escarcelle)

escargot *n.m.* ខ្យងហៀន។ escalier en escargot ឬ en colimaçon ម.ព. escalier។ aller en escargot ដើរតើមៗ(ដូចខ្យង), ដើររាប់ស្លា

escargotière *n.f.* កន្លែងចិញ្ចឹមខ្យងហៀន

escarmouche *n.f.* ការប្រយុទ្ធនៃទ័ពស្រួច (ឧ. escarmouche d'avant-postes)។ *Fig.* ការប្រយុទ្ធបន្តិចបន្តួច

escarmoucher *v.i.* ប្រយុទ្ធដោយទ័ពស្រួច ។ *Fig.* ឈ្លោះបន្តិចបន្តួច

escarmoucheur *n.m.* អ្នកប្រយុទ្ធ ឬ ឈ្លោះបន្តិចបន្តួច

escarpe *n.f.* *Fortif.* ភ្លឺប្រឡាយសម្រាប់ការពារ

escarpe *n.m.Arg.* ចោរប្លន់

escarpé,e *a.* ចោត (ឧ. rocher escarpé; chemin escarpé) ។ *Fig.* ពិបាក

escarpement *n.m.* ចំណោត

escarper *v.t.* មានចំណោត, ចំហុង

escarpin *n.m.* ស្បែកជើងផ្ទាត់

escarpolette *n.f.* ទោង

escarre ឬ **eschare** *n.f.* ក្រមរក្រិន

escarrifier *v.t.* ធ្វើឲ្យមានក្រមរក្រិន (ឧ. escarrifier une plaie en la brûlant)

esche *n.f.* ម.ព. aiche

escient *n.m.* à bon escient ឬ

à son escient *loc. adv.* ដោយដឹងខ្លួនច្បាស់

esclaffer (s') *v.pr.* សើចក្អាកក្អាយ

esclandre *n.m.* ហេតុអាស្រូវ ; ការស្រែកដេរ; ស្នូរក្ដុងក្ដាំង (ឧ. faire une esclandre)

esclavage *n.m.* ទាសភាព (ឧ. les Spartiates réduisirent en esclavage les Messéniens vaincus)។ *Fig.* ភាពលុះក្នុងអំណាចគេ (ឧ. l'esclavage des passions)

esclavagisme *n.m.* ទាសនិយម

esclavagiste *n.* អ្នកទាសនិយម ។ *a.* នៃទាសនិយម (ឧ. doctrine esclavagiste)

esclave *a.&n.* ទាសៈ,ទាសី,មនុស្សខ្ញុំគេ (ឧ.Esope fut esclave)។ *Par ext.* ដែលលុះក្នុងអំណាចគេ ។ *Fig.* être esclave de sa parole កាន់ពាក្យសច្ចៈ,កាន់ពាក្យសន្យា

escoffier *v.t.Pop.* សម្លាប់

escogriffe *n.m.* អ្នកយកទ្រព្យគេដោយឥតញញើត (ឧ.tour d'escogriffe)។ *Fig. &fam.* មនុស្សចង្គ្រាង

escomptable *a.* អបហារីយ(ឧ.billet escomptable)

escompte *n.m.* អបហារ [អៈ-ប៉ៈ-ហារ] (កំរៃដែលបង្វិលឲ្យអ្នកសងមុនពេលកំណត់) (ឧ.faire un escompte de 6%)។ règle d'escompte វិធានអបហារ។ escompte en dehors អបហារក្រៅ ។ escompte en dedans អបហារក្នុង

escompter *v.t.* ធ្វើអបហារ, សងមុនកំណត់ពេលដើម្បីយកកំរៃ ។ *Fig.* ចាយមុន(ឧ.escompter un héritage);សប្បាយមុន (ឧ.escompter l'avenir); ធ្វើឲ្យខូចមុនពេល (ឧ. escompter sa jeunesse) ; សង្ឃឹម(ឧ.escompter le succès d'une affaire)

escompteur *a. &n.m.* អបហារី (ឧ. banquier escompteur)

escorte *n.f.* ទ័ពហ៊ាំង(ឧ. le général et son escorte)។ vaisseau d'escorte នាវាហ៊ាំង ។ បរិវារ (ឧ. l'escorte d'un grand)។ *Fig.* អ្វីៗដែលតាមជាប់ជាមួយ (ឧ. l'ambition et son escorte de vices) ។ faire escorte ជូន

escorter *v.t.* តាមហ៊ាំង, តាមការពារ;

អម; ហែ; ជូន (ឧ. escorter un ami)

escorteur *n.m.* នាវាយាំង

escouade *n.f.* កងតូច (ក្រោមបញ្ជានៃនាយទោ)

escourgée ឬ **écourgée** *n.f.* រំពាត់មួយយ៉ាង; ការវាយដោយរំពាត់

escrime *n.f.* គុនដាវ

escrimer *v.i.* លេងគុនដាវ ។ *Fig.* ប្រយុទ្ធគ្នា; ជជែក ។ s'escrimer *v.pr.* ខំខ្នះខ្នែងដោយគ្មានលទ្ធផល (ឧ. s'escrimer à faire des vers)

escrimeur,euse *n.* អ្នកគុនដាវ (ឧ. un habile escrimeur)

escroc *n.m.* អ្នកឆបោក

escroquer *v.t.* ឆបោក, បោកប្រាស់ (ឧ. escroquer de l'argent ឆបោកយកប្រាក់; escroquer quelqu'un ឆបោកអ្នកណាម្នាក់)

escroquerie *n.f.* ការឆបោក, ការបោកប្រាស់ (ឧ. l'escroquerie est un délit)

Esculape *n. prop.* ទេវពេទ្យ

esculape *n.f. Fam.* គ្រូពេទ្យ

espace *n.m.* វេហា [--ហ៍] (ឧ. l'espace est supposé à trois dimensions), ប្រទេះ (ឧ. un grand espace; un petit espace) ។ *Abs.* អាកាស (ឧ. les corps célestes roulent dans l'espace); ចន្លោះពេល (ឧ. dans l'espace d'un an) ។ espace vital ម.ព. vital ។ *n.f. Arts graph.* ចន្លោះអក្សរ

espacement *n.m.* ការធ្វើឲ្យមានចន្លោះ ឬ ឲ្យរង្វើល; ចន្លោះ ។ *Arts graph.* របៀបដាក់ចន្លោះអក្សរ ឬ ចន្លោះបន្ទាត់

espacer *v.t.* ដាក់ឲ្យរង្វើល ឬ ឈារ (ឧ. espacer des arbres); ទុកឲ្យមានចន្លោះពេល (ឧ. espacer ses visites) ។ *Arts graph.* ទុកចន្លោះអក្សរ

espadon *n.m.* ដាវម្យ៉ាងធំកាន់ដៃពីរ (ឧ. se battre à l'espadon) ។ *Zool.* ត្រីម្យ៉ាង

espadrille *n.f.* ស្បែកជើងសំពត់បាតខ្សែក្បាញ

espagnol,e *a.* អេស្ប៉ាញ៉ុល ។ *n.* ជនជាតិអេស្ប៉ាញ៉ុល ។ *n.m.* ភាសាអេស្ប៉ាញ៉ុល

espagnolette *n.f.* រនុកបញ្ឈរ

espalier *n.m.* ដើមឈើដែលគេដាំផ្អោបនឹងជញ្ជាំង

espar *n.f. Mar.* ឈើវែងសម្រាប់ប្រើជាដងរន្ទាង សារន្ទាង ។ល។

espèce *n.f.* ពួក (ឧ. l'espèce se divise en variétés); ពូជ (ឧ. espèce humaine); គុន ,ប្រភេទ (ឧ. les diverses espèces de délits; bonne espèce de fruits); បែប (ឧ. une espèce de marchand, de comédie)។ *Fam.* មនុស្សថោកទាប (ឧ. se compromettre pour une espèce) ។ espèce de. . . អាកំពូជ. . . (សម្រាប់ជេរ) ។ en l'espèce ក្នុងរឿងនេះ ។ cas d'espèce ការណ៍យេដោយឡែក ។ *pl.* ប្រាក់(រូបិយវត្ថុ) (ឧ. la loi interdit le paiement en espèces des sommes importantes et exige l'emploi du chèque)

espérable *a.* អាចសង្ឃឹមបាន,គួរសង្ឃឹម

espérance *n.f.* ការសង្ឃឹម (ឧ. l'espérance est une grande consolatrice); វត្ថុដែលសង្ឃឹម(ឧ. c'est toute mon espérance)។ *n.f.pl.* ការអាចបានទ្រព្យមរតកនៃញាតិ; មរតកដែលសង្ឃឹមថាបាន (ឧ. oncle, tante à espérance)

espérant,e *a.* ដែលមានសេចក្ដីសង្ឃឹម

espérantiste *a.&n.* នៃភាសាអេស្ប៉េរ៉ង់តូ

espéranto *n.m.* ភាសាអេស្ប៉េរ៉ង់តូ (ភាសាអន្តរជាតិ)

espère *n.f.* ត្រៈ

espérer *v.t.* សង្ឃឹម (ឧ. espérer le succès) ។ *v.i.* ទុកចិត្តលើ

espiègle *a.&n.* រពិស,ប៉ិប៉ុលប៉ប៉ូច,ដែលចូលចិត្តលេង(ឧ.enfant espiègle)

espièglerie *n.f.* ល្បែង,ដំណើរប៉ិប៉ុលប៉ប៉ូច (ឧ. il faut être indulgent aux espiègleries des enfants)

espion,onne *n.* ចារបុរស, ចារស្ត្រី

espionnage *n.m.* ចារកិច្ច; មុខការរបស់ចារបុរស (ឧ.pratiquer l'espionnage)

espionner *v.t.* ធ្វើចារកិច្ច, លបយកការណ៍(ឧ.espionner l'ennemi)

esplanade *n.f.* ប្រាង្គណ៍, លានមុខជាការស្អាន ។ *Par ext.* លានមុខគ្រឹះស្ថានធំ (ឧ. l'esplanade des Invalides)

espoir *n.m.* សេចក្ដីសង្ឃឹម (ឧ. perdre tout espoir) ។ *Fig.* អ្នក

ដែលជាទីសង្ស័យ; វត្ថុដែលសង្ស័យ

esprit *n.m.* ព្រលឹង,វិញ្ញាណ,គំនិត (ឧ. soumettre le corps à l'esprit); ភូត (ឧ.Dieu, les anges sont des esprits); អសុរកាយ (អទិស្សមានកាយដូចយ៉ាងខ្មោចអារក្ស ជាដើម)(ឧ.croire aux esprits); ប្រាជ្ញា (ឧ.cultiver son esprit; avoir l'esprit); ព្រលឹង, សតិ (ឧ. où avait-il l'esprit en agissant ainsi);ចរិត (ឧ.esprit remuant); ការកំប្លែង (ឧ. avoir de l'esprit); អ្នកប្រាជ្ញ (ឧ. les grands esprits forment les grandes nations); ន័យ, អត្ថ (ឧ.entrer dans l'esprit de la loi) ។ គតិ (ឧ.esprit de fraternité គតិភាតរភាព) ។ avoir l'esprit de l'escalier ប្រាជ្ញាមិនរហ័ស(រកពាក្យដែលត្រូវនិយាយមិនទាន់ពេល) ។ bel esprit ការស្រឡាញ់អក្សរសាស្ត្រ;អ្នកប្រាជ្ញប្រាក(ឧ.une femme bel esprit) ។ esprit fort អ្នកមិនជឿផ្ដេសផ្ដាស ។ esprit malin ឬ esprit des ténèbres សាតាំង (បិសាចកាចឫក) ។ esprit follet ប្រេតកង្វាល ។ esprit de vin ស្រា ។ faire de l'esprit ប្រាជ្ញប្រាក ។ perdre l'esprit ឡប់ស្មារតី,ឆ្កួត ។ présence d'esprit ប្រាជ្ញារហ័ស (រកចេះដោះស្រាយបញ្ហាបានភ្លាមៗ) ។ rendre l'esprit រលត់ខន្ធ, ស្លាប់ ។ reprendre ses esprits ដឹងខ្លួនវិញ, លែងស្លន់ ។ trait d'esprit ឬ mot d'esprit សំដីឆើត ។ vue de l'esprit គំនិតមិនសមហេតុផល ។ mauvais esprit អសុរ; មនុស្សគំនិតខូច ។ avoir l'esprit du commerce ចូលចិត្តខាងជំនួញ

esquif *n.m.* ទូកតូច

esquille *n.f.* កំទេចឆ្អឹងដែលបាក់ (ឧ. les esquilles peuvent occasionner de graves accidents)

esquimau *a.&n.* អេស្គីម៉ូ (ជនជាតិរស់នៅប៉ូល)

esquintant,e *a.Fam.* ដែលធ្វើឲ្យហត់

esquinter *v.t. Fam.* ធ្វើឲ្យហត់; ធ្វើឲ្យខូច ។ *Fig.* បង្ខូចកេរ្តិ៍ឈ្មោះ (ឧ. esquinter un auteur, une pièce)

esquisse *n.f.* គំនូរព្រាង (ឧ. jeter

une esquisse sur le papier); ការគែលទើបនឹងព្រាង; សេចក្ដីព្រាង; សេចក្ដីសង្ខេប; ព្រោង (ឧ.esquisse d'un roman។ *Fig.* ការចាប់ផ្ដើម (ឧ. esquisse d'un sourire)

esquisser *v.t.* គូរគំរូ (ឧ.esquisser un portrait); គំរូ; ព្រាង, ព្រោង (ឧ. esquisser le plan d'un roman) ។ *Fig.* ចាប់ផ្ដើម (ឧ. esquisser un geste de défense)

esquive *n.f.* ការគេច

esquiver *v.t.* គេច (ឧ. esquiver une difficulté) ។ s'esquiver *v.pr.* គៀសខ្លួន, គេចវេះ

essai *n.m.* ការល្បង (ឧ.faire l'essai d'une automobile) ។ coup d'essai ការល្បងដំបូង ។ *Litt.* និពន្ធល្បង

essaim *n.m.* ហ្វូងឃ្មុំ ។ *Par ext.* ហ្វូង (ឧ.un essaim d'écoliers)

essaimage *n.m.*ការបំបែកហ្វូងឃ្មុំ; រដូវបែកហ្វូង (ឃ្មុំ)

essaimer *v.i.* បែកហ្វូង (ឃ្មុំ) ។ *Fig.* តាំងគ្រឹះស្ថានថ្មី ។ *Fam.*ចេញទៅតាំងនៅឯប្រទេសក្រៅ

essangeage *n.m.* ការត្រាំទឹកក្ដៅ(មុននឹងបោកលាង)

essanger *v.t.* ត្រាំទឹកក្ដៅ (មុននឹងបោកលាង)

essartement ឬ **essartage** *n.m.* ការឆ្ការគល់ព្រៃគុម្ពោធ

essarter *v.t.* ឆ្ការគល់ព្រៃគុម្ពោធ

essarts *n.m.* *pl.* កន្លែងឆ្ការគល់ព្រៃគុម្ពោធ

essayage *n.m.* ការល្បង - ល ឬ សាក (ឧ.salon d'essayage)

essayer *v.t.* ល្បង (ឧ.essayer une machine) ។ essayer un habit លសំលៀកបំពាក់ ។ essayer de l'or សាកមាស ។

v.i. essayer de ខំប្រឹងល (ឧ. essayer d'un engin; essayer de nager)។

s'essayer à *v.pr.* ហាត់(ឧ. s'essayer à monter à cheval)

essayeur,euse *n.* មន្ត្រីសាកប្រិយវត្ថុមាសនឹងប្រាក់; ជាងលសំលៀកបំពាក់

essayiste *n.m.* អ្នកនិពន្ធល្បង (ឧ. la littérature anglaise est riche en essayistes)

essence *n.f.* សារៈ, ខ្លឹម; ទឹកអប់ស៊ុយ

(ឧ. essence de rose); ជាតិចំរាញ់ខាប់ (ឧ. essence de café) ។ essence minérale ឬ *Abs.* essence ប្រេងសាំង ។ par essence តាមអត្ថន័យ ។ ពួក (ដើមឈើ)

essentiel,elle *a.* សារវន្ត (ឧ. la raison est essentielle à l'homme); សំខាន់ ។ *n.m.* ចំណុចសំខាន់ (ឧ. l'essentiel est d'être honnête)

essentiellement *adv.* ជាសារវន្ត, យ៉ាងសំខាន់

esseulé,e *a.* ដែលនៅម្នាក់ឯង

esseulement *n.m.* ការនៅម្នាក់ឯង

esseuler *v.t.* ទុកឲ្យនៅម្នាក់ឯង

essieu *n.m.* ភ្លៅរទេះ

essor *n.m.* ការហើរឡើង (ឧ. prendre son essor) ។ *Fig.* សំទុះ (ឧ. l'essor de l'imagination) ; ការលូតលាស់ (ឧ. l'essor de l'industrie)

essorage *n.m.* ការពូត

essorer *v.t.* ពូត (ឧ. essorer du linge) ។ *Agr.* essorer un terrain ធ្វើឲ្យស្ងួតដី

essoreuse *n.f.* ម៉ាស៊ីនពូតសំពត់

essorillement *n.m.* ការកាត់ត្រចៀក

essoriller *v.t.* កាត់ត្រចៀក (ឧ. essoriller un chien)

essouchement *n.m.* ការរំលើងជង្គត់ឈើ

essoucher *v.t.* រំលើងជង្គត់ឈើ (ឧ. essoucher une vigne)

essoufflement *n.m.* ដំណើរដង្ហក់

essouffler *v.t.* ធ្វើឲ្យដង្ហក់ឬឲ្យហត់ (ឧ. une course trop rapide essouffle)

essuie-glace *n.m.* ប្រដាប់ជូតកញ្ចក់រថយន្ត (*pl.* des essuie-glaces)

essuie-main *n.m.* សំពត់ជូតដៃ (*pl.* des essuie-mains)

essuie-meubles *n.m. inv.* សំពត់ជូតតុទូ

essuie-pieds *n.m. inv.* ទ្រនាប់ជូតជើង

essuie-plume *n.m.* ប្រដាប់ជូតស្លាបប៉ាកកា (*pl.* des essuie-plumes)

essuie-verres *n.m. inv.* សំពត់ជូតកញ្ចក់

essuyage *n.m.* ការជូត

essuyer *v.t.* ជូត (ឧ. essuyer une

table); ធ្វើឲ្យស្ងួត (ឧ. le vent a essuyé les chemins) ។ *Fig.* ទទួលទុក្ខ; រង(ឧ. essuyer le feu de l'ennemi) ។ essuyer les platres នៅផ្ទះថ្មីពេក; *au fig.* រងអំពើលំបាកនៃការដែលទើបចាប់ធ្វើដំបូង ។ essuyer les larmes លួង

essuyeur,euse *n.* អ្នកជូត

est *n.m.* ទិសបូព៌, ទិសខាងកើត

estafette *n.f.* អ្នកជិះសេះនាំសារ

estafilade *n.f.* សម្នាកវែងនៅមុខ (ឧ. recevoir une estafilade)

estafilader *v.t.* ធ្វើឲ្យមានសម្នាកវែងនៅមុខ

estaminet *n.m.* តៀមកាហ្វេតូច ។ *Fam.* pilier d'estaminet អ្នកនៅតែក្នុងតៀមកាហ្វេ

estampage *n.m.* *Techn.* ការចាប់រូប (មានផ្តិតចម្លងរូបចម្លាក់ជាដើម)

estampe *n.f.* រូបចាប់ (ផ្តិតចម្លងរូបចម្លាក់); ប្រដាប់ចាប់រូប

estamper *v.t.* ចាប់រូប(ឧ. estamper des monnaies) ។ *Fig.* & *Fam.* កេងយកប្រាក់

estampeur *n.*&*a.m.* អ្នកចាប់រូប

estampillage *n.m.* ការបោះអង្គា(ការបោះត្រាសំគាល់)

estampille *n.f.* អង្គា (ត្រាសំគាល់ឬបញ្ជាក់, តែមប្រើបញ្ជាក់) ។ donner son estampille à une production ឧបត្ថម្ភផលិតកម្ម

estampiller *v.t.* បោះអង្គា (បោះត្រាសំគាល់ ឬ បញ្ជាក់) (ឧ. estampiller un livre)

estarie ឬ **starie** *n.f.* *Mar.* កំណត់ពេលរើទំនិញនាវា

ester *v.i.* *Dr.* ប្តឹងតុលាការ (ឧ. une femme peut ester en justice sans y être autorisée par son mari)

ester *n.m.* *Chim.* អែស្ទែរ (ហៅ éther-sel ក៏បាន)

estérification *n.f.* *Chim.* អែស្ទែរកម្ម, ការធ្វើឲ្យប្រែជាអែស្ទែរ

estérifier *v.t.* *Chim.* ធ្វើអែស្ទែរកម្ម, ធ្វើឲ្យប្រែជាអែស្ទែរ

esthète *n.m.* អ្នកចូលចិត្តល្អ

esthéticien,enne *n.* សោភណវិទូ ។ *n.f.* ស្រីអ្នកតែងខ្លួនឲ្យគេ

esthétique *n.f.* សោភណវិជ្ជា ។ *a.* នៃសោភណវិជ្ជា (ឧ. sens esthétique); សោភ័ណ, ហ្មត់ហ្មង (ឧ. un

geste esthétique)។chirurgie esthétique ឬ correctrice សោភណសល្យសាស្ត្រ(សល្យសាស្ត្រកែរូបរាងឲ្យបានល្អ)

esthétiquement *adv.* យ៉ាងសោភ័ណ

esthétisme *n.m.* សោភណនិយម

estimable *a.* គួររាប់អាន(ឧ.homme estimable);គួរចូលចិត្ត(ឧ. livre estimable);ដែលមានតម្លៃគួរសម

estimateur *n.m.* អ្នកដឹងតម្លៃ (ឧ. s'en rapporter à un estimateur)។*Fig.* អ្នកស្គាល់តម្លៃមនុស្ស (ឧ. un peuple mauvais estimateur du mérite)

estimatif,ive *a.*ដែលសម្រាប់វាយតម្លៃ ឬមានដាក់តម្លៃ (ឧ. dresser un devis estimatif)

estimation *n.f.* ការវាយតម្លៃ (ឧ. faire une estimation au-dessous de la vérité)

estimatoire *a.* នៃការវាយតម្លៃ

estime *n.f.*សេចក្ដីរាប់អាន(ឧ.l'agriculture fut d'une grande estime chez les Egyptiens) ។ *Mar.* ការដាន់ផ្លូវបើកក្បាលហើយ។ **à l'estime** ដោយស្មាន,ដោយដាន់

estimer *v.t.* វាយតម្លៃ (ឧ. estimer une maison); រាប់អាន (ឧ. estimer la vertu);គិត,ស្មាន,យល់ឃើញ (ឧ. j'estime que vous pourriez mieux faire)។s'estimer *v.pr.* ទុកខ្លួនជា(ឧ.s'estimer perdu)

estivage *n.m.* ការនាំសត្វឲ្យស៊ីស្មៅលើភ្នំក្នុងវស្សានរដូវ

estivage *n.m.* ការហាត់ទំនិញដែលផ្ទុក; ការផ្ទុកទំនិញក្នុងនាវាជំនួញ

estival,e,aux *a.* ដែលកើតឬឲ្យផលក្នុងវស្សានរដូវ (ឧ.plante estivale); ដែលគេទៅកំសាន្តក្នុងវស្សានរដូវ; នៃវស្សានរដូវ (ឧ.toilette estivale)

estivant *n.m.*អ្នកដើរកំសាន្តក្នុងវស្សានរដូវ

estivation *n.f.* ការស្រយុតស្រយេងនៃសត្វខ្លះក្នុងវស្សានរដូវ

estiver *v.i.* នៅក្នុងវាលស្មៅលើភ្នំក្នុងវស្សានរដូវ ។ *v.t.* ឲ្យសត្វស៊ីស្មៅក្នុងវស្សានរដូវ

estiver *v.t.* ហាត់ទំនិញក្នុងនាវា

est-nord-est (E.-N.-E.) ចន្លោះទិសបូព៌ានឹងឦសាន(ប.ឦ.)

estoc *n.m.* ដាវតូចវែង(សម្រាប់ចាក់)។

frapper d'estoc ចាក់ ។ frapper d'estoc et de taille ចាក់នឹងកាប់; *au fig.* ដោយប្រថុយ ។ estoc volant ល្បុក្កតោ(ដំបងខ្លី) ។

Arbor. ជង្គត់ (ឧ. un bel estoc) ។ couper un arbre à blanc estoc កាប់ដើមឈើកប់នឹងដី ។ faire une coupe à blanc estoc កាប់ឈើភ្លៀនទុកកូន ។

Dr. anc. ពូជ (ឧ. être de bon estoc) ។ មរតកនៃញាតិខ្សែផ្ទាល់ ។ biens de côté estoc et ligne មរតកនៃញាតិខ្សែផ្ទាល់

estocade *n.f.* ដាវម្យ៉ាងមុខធំបុងស្រួច; ការចាក់នឹងដាវ។ *Fig.* ការវាយលុកភ្លាមៗយ៉ាងខ្លាំង

estocader *v.i. & t.* ចាក់ដាវ

estomac *n.m.* ក្រពះ,ពោះ(ឧ. l'estomac des ruminants a quatre compartiments) ។ *Fam.* avoir un estomac d'autruche មានក្រពះល្អ (រំលាយអាហាររហ័ស) ។ avoir l'estomac creux ពោះទទេ ។ sentir son estomac dans les talons ឃ្លាន ។ *Fig. & Fam.* avoir de l'estomac ហ៊ាន, ក្លាហាន, មិនស្លុត

estomaquer *v.t. Fam.* ធ្វើឲ្យពិបាកចិត្តខ្លាំង (ឧ. cette nouvelle m'a estomaqué)។ s'estomaquer *v.pr.* ខឹងនឹងអ្នកណាម្នាក់; ហត់ដោយនិយាយឬដោយស្រែក

estompage ឬ **estompement** *n.m.* ការផាត់ពណ៌

estompe *n.f.* រមូរស្បែក ឬ ក្រដាសសំរាប់ផាត់ពណ៌; គំនូរផាត់ពណ៌

estomper *v.t.* ផាត់ពណ៌។ *Par ext.* ផាត់ស្រមោល ។ *Fig.* សម្រួល (ឧ. estomper un récit un peu cru)។ **s'estomper** *v.pr.Fig.* រលុប,នៅស្រពេចស្រពិល(ឧ. souvenirs qui s'estompent)

estouffade *n.f.* ម.ព. étouffée

estourbir *v.t. Pop.* សំពង,សម្លាប់

estrade *n.f.* ជើងដំកល់។ battre l'estrade ដើរឡើងចុះតាមផ្លូវ (ដើម្បីឃ្លាំមើលសត្រូវឬ លួចឆក់ទ្រព្យអ្នកដំណើរ)

estramaçon *n.m.* ដាវប្លូកណាផ្លែធំមុខសងខាង

estran *n.m.* ច្រាំងដែលលិចទឹកនៅពេលទឹកជោរហើយគោកវិញនៅពេលទឹកនាច

estrapade *n.f.* ការចងសណ្ដោង(ទារុណ-

កម្ម) ; បង្គោលសម្រាប់ចងសណ្ដូន ។ *Fig.* donner l'estrapade à ធ្វើទារុណកម្ម, ធ្វើបាប (ឧ. donner l'estrapade à son esprit)

estrapader *v.t.* ចងសណ្ដូន (ឧ. estrapader un matelot)

estrapasser *v.t.* បង្ហាត់សេះទាល់តែហត់

estrope *n.f. Mar.* ចំពៀនខ្សែ

estropié,e *a.&n.* ខ្វិន, ពិការ

estropier *v.t.* ធ្វើឲ្យពិការ ។ *Fig.* ធ្វើឲ្យខូច; បំប្លែង (ឧ. estropier un nom); ធ្វើឲ្យខូច (ឧ. estropier un vers)

estuaire *n.m.* អាវសមុទ្រ (ឧ. l'estuaire de la Garonne se nomme Garonde)

estudiantin,e *a.* នៃនិស្សិត (ឧ. la vie estudiantine)

et *conj.* នឹង, ហើយនឹង, ផង

établage *n.m.* ឈ្នួលក្រោល

étable *n.f.* ក្រោល

établer *v.t.* បញ្ចូលក្រោល

établi *n.m.* តុជាង (ជាងឈើ, ជាងដែក, ជាងកាត់ដេរ ។ល។)

établir *v.t.* តាំង (ឧ. établir sa résidence à Phnom Penh; établir un camp; établir un tribunal); ដំកល់; បង្កើត (ឧ. établir un usage); រៀបចំ (ឧ. établir un compte); ទុកដាក់ (ឲ្យមានការធ្វើឬឲ្យមានប្ដីប្រពន្ធ)(ឧ. établir ses enfants)។ *Fig.* ថ្លែង (ឧ. établir un principe); ពន្យល់, បង្ហាញភស្ដុតាង (ឧ. établir un fait)។ s'établir *v.pr.* តាំងលំនៅ

établissement *n.m.* ការតាំង (ឧ. l'établissement d'une banque); ការបង្កើត; ការរៀបចំ; គ្រឹះស្ថាន ។

établissement financier គ្រឹះស្ថានហិរញ្ញវត្ថុ ។ établissement de droit privé ម.ព. droit ។ établissement de droit public ម.ព. droit ។ établissement public គ្រឹះស្ថានសាធារណៈ ។ établissement semi-public គ្រឹះស្ថានអឌ្ឍសាធារណៈ ។ établissement d'intérêt public គ្រឹះស្ថានផ្ដល់កំរៃសាធារណៈ ។ établissement d'utilité publique គ្រឹះស្ថានផ្ដល់ប្រយោជន៍សាធារណៈ ។

ការទុកដាក់ (ឲ្យមានការធ្វើឬឲ្យ

មានប្ដីប្រពន្ធ); អាណានិគម (ឧ. les établissements français de l'Océanie)

étage *n.m.* ឧបរិភូមិ [អ៊ុ-ប៉ៈ-រ៉ិ-],ល្វែង.ជាន់ខាងលើ,ជាន់ (ឧ. un immeuble de huit étages)។*Par ext.* ថ្នាក់ (ឧ. compresseur à neuf étages) ។ *Fig.* ថ្នាក់, ប្រភេទ។*Fig.* gens de bas étage មនុស្សគុណទាប (វណ្ណៈទាបថោក)

étagement *n.m.* ការរៀបជាថ្នាក់ឬជាជាន់ (ឧ. étagement des cultures au flanc d'une montagne)

étager *v.t.* រៀបជាថ្នាក់ (ឧ. étager des batteries); ដាក់ឲ្យរង្វើល

étagère *n.f.* ទូមានថ្នាក់; ធ្នើរ

étai *n.m.* ចន្ទល់,បង្កាញ់។ *Mar.* ខ្សែព្រង។ *Fig.* អ្វីៗដែលទល់ទ្រ

étaiement *n.m.* ការទល់,របៀបទល់

étain *n.m.* សំណប៉ាហាំង

étal *n.m.* តុលក់សាច់; តៀមលក់សាច់; តុតាំងទំនិញលក់ (*pl.* des étaux ឬ des étals)

étalage *n.m.* ការតាំងទំនិញ; អាបណពណ្ណ(ឧ. un opulent étalage); ទំនិញដែលតាំង; ពន្ធតាំងទំនិញ។*Fig.* ការសំញែង(ឧ.étalage d'esprit, de beaux sentiments)

étalager *v.t.* តាំងទំនិញ

étalagiste *a.&n.* អ្នកតាំងទំនិញ (ឧ. marchand étalagiste);ភ្នាក់ងារខាងតាំងទំនិញ

étale *a.* នឹង(មិនឡើងមិនស្រក)(ឧ.mer étale)។ navire étale នាវានឹង (ឈប់ស្ងៀម)។ *n.m.* ពេលទឹកនឹង

étalement *n.m.* ការតាំងទំនិញ; ការលាត្រដាង

étaler *v.t.* តាំងលក់ (ឧ. étaler des marchandises); ដាក់រាយ (ឧ. étaler des papiers sur le bureau); លា,ត្រដាង (ឧ. étaler une carte)។*Par anal.* ធ្វើបន្តិចម្ដងៗ ឲ្យបានយូរ (ឧ. étaler des paiements សងច្រើនដង;étaler les vacances ចែកវិស្សមកាលជាច្រើនលើក។ *Fig.* សំញែង (ឧ. étaler un grand luxe) ។ *Fam.* ទម្លាក់ ។ étaler son jeu ត្រដាងបៀឲ្យគេមើល ។ *Mar.* ធន់បាន (ឧ. étaler un coup de vent)។ s'étaler *v.pr.* ដេកសន្ធឹង (ឧ. s'étaler dans un fauteuil)។

Fam. ធ្លាក់, ដួល (ឧ. s'étaler par terre)

étaleur,euse *n.* អ្នកតាំងទំនិញ

étaleuse *n.f.* ម៉ាស៊ីនត្រដាងសំពត់

étalier,ère *n.* & *a.* អ្នកស៊ីឈ្នួលលក់សាច់

étalon *n.m.* មាត្រាខ្នាតរង្វាស់រង្វាល់ ឬទម្ងន់; លោហមាត្រា (ទម្ងន់លោហធាតុមានតម្លៃដែលទុកជាគោលនៃរបៀបរូបិយវត្ថុ) (ឧ. étalon-or)។ monnaie-étalon ម.ព. monnaie

étalon *n.m.* សេះបា

étalonnage ឬ **étalonnement** *n.m.* ការក្រិតរង្វាស់រង្វាល់

étalonner *v.t.* ផ្ទៀងខ្នាតរង្វាស់រង្វាល់; ក្រិតរង្វាស់រង្វាល់ដែលគេពិនិត្យហើយ

étalonneur *n.m.* អ្នកក្រិតរង្វាស់រង្វាល់

étalonnier,ère *a.* នៃសេះបា, នៃការបង្កាត់សត្វ។ *n.* អ្នកមានសេះបាជួលបង្កាត់; អ្នកបង្កាត់សត្វ

étamage *n.m.* ការស្រោបសំណប៉ាហាំង; ភាពវត្ថុស្រោបសំណប៉ាហាំង

étambot *n.m.* *Mar.* ខ្នងក្បៀកប៉ាល់

étamer *v.t.* ស្រោបសំណប៉ាហាំង (ឧ. on étame les casseroles en cuivre)

étameur *n.m.* អ្នកស្រោបសំណប៉ាហាំង

étamine *n.f.* ស្បៃ(សំរាប់ត្រង)។ *Fig.* ការពិនិត្យដោយហ្មត់ចត់

étamine *n.f.* *Bot.* ទងលំអងផ្កាឈ្មោល

étaminier *n.m.* អ្នកធ្វើស្បៃ

étampage *n.m.* ការវាយពុម្ពដែក; ការចោះប្រហោងដែកក្រចកសេះ

étampe *n.f.* ពុម្ពវាយដែក; ប្រដាប់ចោះប្រហោងដែកក្រចកសេះ

étamper *v.t.* វាយពុម្ពដែក; ចោះប្រហោងដែកក្រចកសេះ

étamperche *n.f.* សសររន្ទា(ជា étemperche ឬ écoperche ក៏បាន)

étampeur *n.m.* ជាងវាយពុម្ពដែក; ជាងចោះប្រហោងដែកក្រចកសេះ

étanche *a.* ជត់ (ដែលមិនជ្រាបទឹក)(ឧ. vase parfaitement étanche); ដែលមិនឲ្យចេញឬចូលបាន ។ *n.f.* à étanche d'eau ឲ្យជត់ (ឧ. entretenir une toiture à étanche d'eau) ។ *Mar.* navire étanche នាវាជត់

étanchéité *n.f.* ភាពជត់ (ឧ. l'étanchéité d'une cuve)

étanchement *n.m.* ការទប់មិនឲ្យហូរ; ការធ្វើឲ្យជត់

étancher *v.t.* ទប់ (មិនឲ្យហូរ) (ឧ.

étancher le sang ឃាត់ឈាម); បិទឬចុក (ដើម្បីឲ្យគត់) (ឧ. étancher un tonneau)។étancher une voie d'eau ចុករន្ធមិនឲ្យទឹកហូរ។ *Fig.* ធ្វើឲ្យស្រាកឬឲ្យស្ងប់(ឧ. étancher la soif ផឹកទឹក (ដើម្បីឲ្យអន់ស្រេក

étançon *n.m.* បន្ទល់

étançonnement *n.m.* ការទល់

étançonner *v.t.* ទល់ (ឧ.étançonner une maison)

étang *n.m.* បឹង

étape *n.f.* ដំណាក់,ចំណតឈប់សម្រាក; ចម្ងាយពីដំណាក់មួយ ទៅដំណាក់មួយ (ឧ. une longue et pénible étape) ។ brûler l'étape ទៅបង្ហួស(មិនឈប់នៅដំណាក់)។*Fig.* ដំណាក់(ឧ.procéder par étapes)

étarquer *v.t. Mar.* សន្ទឹងយ៉ាងតឹង (ឧ. étarquer un cordage)

état *n.m.* ភាព, ការៈ,សភាព (ឧ. état de santé) ។ bon état ភាពល្អ (ឧ. marchandises en bon état)។mauvais état ភាពអាក្រក់ (ឧ. bâtiment en mauvais état)។ état de nature ភាពធម្មជាតិ(ភាពមនុស្សកាលមិនទាន់មានអរិយធម៌)។ être au-dessus de son état លើសភាពខ្លួន ឬលើសឋានៈខ្លួន (មានគំនិត មានទឹកចិត្តលើសពីអ្នកមានឋានៈដូចគ្នា)។

ឋានៈត្រាន់បើ (ឧ. avoir un état dans le monde)។ état militaire ភាពជាទាហាន ។ état sanitaire ការៈនៃសុខភាព ។ *Par ext.* ដំណើរដើរភាព (ឧ. un grand état de maison); របៀបស្លៀកពាក់; សំលៀកបំពាក់ ។

état d'alerte ភាពប្រុងការ។ état de guerre ភាពសង្គ្រាម ។ état de siège ភាពវិក្រឹតកាល ។ état de risque ភាពហានិភ័យ ។ état d'urgence ភាពបន្ទាន់, ភាពអាសន្ន ។

តារាង ។ état comparatif តារាងធៀប។ état de solde តារាងបៀវត្ស។ état signalétique des services militaires តារាងលក្ខណរូបនៃបរិចារកិច្ចទាហាន ។

បញ្ជី ។ état des sommes à rembourser បញ្ជីទឹកប្រាក់ដែលត្រូវសង ។

Pol. រដ្ឋ ។ Etat associé សមាគតរដ្ឋ [សះ-ម៉ា-គះ-តះ-] ។ Etat autonome រដ្ឋស្វ័យភាព ។ Etat fédéré សហរដ្ឋ ។ Etat protégé រដ្ឋក្នុងអាណាព្យាបាល ។ Etat tampon ម.ព. tampon ។ coup d'Etat រដ្ឋប្រហារ (ម.ព.coup ផង) ។ ministre d'Etat ទេសរដ្ឋមន្ត្រី ។ secrétaire d'Etat រដ្ឋលេខាធិការ ។ sous-secrétaire d'Etat អនុរដ្ឋលេខាធិការ ។

Dr. état des personnes ឬ état civil អត្រានុកូលដ្ឋាន ។ actes de l'état civil សាលិខិតអត្រានុកូលដ្ឋាន ។ officier de l'état civil មន្ត្រីអត្រានុកូលដ្ឋាន ។ état des lieux លិខិតបញ្ជាក់ភាពលំនៅ (លិខិតបញ្ជាក់ភាពរបស់ផ្ទះមដែលជួល នៅពេលអ្នកជួលចូលនៅ) ។

Dr. adm. état de services តារាងបរិយាកិច្ច ។

Loc. div. état de choses ភាពនៃវត្ថុ; ទេសកាលៈ (ឧ. état de choses qui ne peut durer) ។ état de fait ការណ៍ភាព, ការៈនៃការណ៍ ។ état d'âme ទឹកចិត្ត ។ être en état រួចស្រេច (ឧ. dossier qui est en état) ។ être en état de អាចនឹង (ឧ. je suis en état de payer) ។ être hors d'état លែងធ្វើអ្វីកើត, លែងប្រើការកើត ។ en l'état ក្នុងភាពនេះ (ឧ. en l'état j'ai dû m'abstenir) ។ en tout état de cause បើគិតសព្វគ្រប់ទៅ (ឧ. en tout état de cause, un dénonciateur qui se cache joue un rôle odieux) ។ mettre en état រៀបចំ ។ tenir en état រក្សាទុក, បម្រុងស្រេច ។ faire état de យកជាការ (ឧ. fais peu d'état des promesses des grands) ។ សង្ឃឹមលើ (ឧ. faites état de cette somme); ប្រព្រឹត្តជា (ឧ. faire état de chef); មានបំណង (ឧ. faire état de partir) ។ faire état que គិតស្មាន (ឧ. je fais état qu'il ne sera pas de retour avant six semaines); ជឿ (ឧ. faire état qu'on pouvait terminer la guerre); សង្ឃឹម (ឧ. faites état que vous aurez cette somme

dans quinze jours) ។ *Fam.* être ឬ se mettre dans ses états អន្ទះអន្ទែងខ្លាំងណាស់។ *Iron.* être dans un bel état ប្រទូ

étatisation *n.f.* រដ្ឋូបនីយកម្ម

étatiser *v.t.* ធ្វើរដ្ឋូបនីយកម្ម, ដាក់ឲ្យរដ្ឋអភិបាល

étatisme *n.m.* រដ្ឋនិយម

étatiste *a.* នៃរដ្ឋនិយម។ *n.m.* អ្នករដ្ឋនិយម

état-major *n.m.* សេនាធិការ; សេនាធិការដ្ឋាន ។ *Par ext.* ក្រុមសហការីនៃវរជនម្នាក់ (ឧ. l'état-major d'un ministre); ពួកវរជនក្នុងក្រុមមួយ (ឧ. l'état-major d'un parti)(*pl.* des états-majors)

étau *n.m.* អង្គំ។ *Fig.* être pris ឬ serré comme dans un étau ត្រូវកៀបជាប់

étau-limeur *n.m.* ម៉ាស៊ីនរូសដែក

étayage ឬ **étaiement** *n.m.* ការទល់, ការទ្រ

étayer *v.t.* ទល់ (ឧ. étayer un mur) ។ *Fig.* ជួយ,គាំទ្រ (ឧ. une thèse étayée de bons documents)

et cætera [èt-sé-té-ra] (etc.) *loc. adv.* បេយ្យាល (។ល។)

été *n.m.* វស្សានរដូវ(រដូវភ្លៀង)(ឧ. les chaleurs de l'été) ។ se mettre en été ស្លៀកពាក់ខោអាវស្តើង

éteigneur,euse *n.* អ្នកលត់ភ្លើង

éteignoir *n.m.* ប្រដាប់លត់ទៀន ។ *Fig.* អ្វីៗដែលធ្វើមិនឲ្យភ្លឺ ។ *Fam.* អ្នកធ្វើឲ្យខានសប្បាយ។ *Pop.* កាតិបពាក់ដេក

éteindre *v.t.* លត់ (ឧ. éteindre le feu);ធ្វើឲ្យហើរពណ៌ (ឧ. le soleil éteint les couleurs claires)។ *Fig.* ធ្វើឲ្យស្រាក,បង្អន់ (ឧ. éteindre la soif) ; សម្លាប់ទាំងអស់ (ឧ. éteindre une race សម្លាប់ផ្តាច់ពូជ); សងអស់ (ឧ. éteindre une rente)។éteindre de la chaux ចាក់ទឹកលើកំបោរ (ឲ្យទៅជាកំបោរងាប់) ។ **s'éteindre** *v.pr.* រលត់ (ឧ.le feu s'éteint)។ *Fig.* ស្លាប់ដោយស្រួល (ឧ. vieillard qui s'éteint)

éteint,e *a.* រលត់,គ្មានរស្មី (ឧ.regard éteint) ។ chaux éteinte ម.ព. chaux

étemperche *n.f.* ម.ក.étamperche

étendage *n.m.* ការហាល; ការចងខ្សែហាលខោអាវ

étendard *n.m.* ទង់ជ័យបតាក, ទង់ជ័យបំបាំង។ lever l'étendard de la révolte បះបោរ

étendoir *n.m.* ខ្សែស្តៀង ឬ ខ្សែស្បៀង, ឈើ ឬ ខ្សែហាលសំលៀកបំពាក់

étendre *v.t.* កយ,ក្រាល(ឧ. étendre de la paille); ហាល, ត្រដាង (ឧ. étendre du linge); លា (ឧ. étendre les bras); ផ្ដេក (ឧ. étendre un blessé sur un matelas); លាយទឹក (ឲ្យខ្សោយ ឬ ឲ្យរាវ) (ឧ. étendre du lait, de l'alcool)។ *Fig.* ពង្រីក, ភាគ (ឧ. étendre les limites de son domaine)។ *Fam.* ទម្លាក់ (ឧ. étendre un candidat)។ *Poét.* étendre un voile sur លាក់ (កុំឲ្យគេឃើញ, កុំឲ្យគេដឹង)

s'étendre *v.pr.* ដេកសន្ធឹង, លាត្រដាង។ *Fig.* រីកតែខ្លាំងឡើង;រាលដាល (ឧ. le mal s'est étendu)

étendu,e *a.* វែសាល, ធំ (ឧ. plaine très étendue); លា, កាង (ឧ. ailes étendues); ដែលលាយទឹក (ឧ. alcool étendu)

étendue *n.f.* វែសាលភាព, ទំហំ (ឧ. vaste étendue de mer); ចម្ងាយ (ឧ. étendue de la vue ចម្ងាយមើលឃើញ); រយៈពេល (ឧ. étendue de la vie); អត្ថាធិប្បាយ (ឧ. étendue d'un discours)។ *Fig.* វែសាលភាព,ទំហំ(ឧ.étendue d'un désastre)

éternel,elle *a.* អនន្ត (ដែលគ្មានទីបំផុត) (ឧ. damnation éternelle); មិនចេះចប់ (ឧ. d'éternelles discussions)។ reconnaissance éternelle ការដឹងគុណរកទីបំផុតគ្មាន។ sommeil éternel និរណ៍ស្លាប់។ royaume ឬ séjour éternel ឬ éternel dimanche ឋានសួគ៌។ feu éternel នរក។ le père éternel អាទិទេព។ la ville éternelle ក្រុងរ៉ូម។ *n.m.* អ្វីៗដែលគ្មានទីបំផុត; អាទិទេព

éternellement *adv.* ជាអនន្ត, រហូត

éterniser *v.t.* ធ្វើឲ្យបីតទៅបើរកាល(ឧ. éterniser un nom);បណ្ដោយឲ្យយូរ (ឧ. les hommes de loi

éternisent les procès)។ s'éterniser *v.pr.* នៅជាអនន្ត,នៅបើតទើរ។ *Fam.* នៅយូរ (ឧ.s'éterniser à la campagne)

éternité *n.f.* អនន្តកាល [អៈ-ណន់-តៈ-] ឬ អនាគតជាតិ (ឧ. songer à l'éternité) ។ *Par ext.* ចិរកាល, ពេលយូរ (ឧ. rester une éternité à ...) ។ de toute éternité តាំងពីយូរយារណាស់មកហើយ

éternuement *n.m.* ការកណ្ដាស់

éternuer *v.i.* កណ្ដាស់

éternueur,euse *n.* អ្នកកណ្ដាស់

étêtage ឬ **étêtement** *n.m.* ការកាត់ចុងឈើ

étêter *v.t.* កាត់ចុងឈើ,កាត់ក្បាល (ឧ. étêter un poisson; étêter un clou)

éteuf *n.m.* កូនបាល់ ។ renvoyer l'éteuf បញ្ជូនកូនបាល់ទៅវិញ; តប; *au fig.* ឆ្លើយតប

éteule *n.f.* ជញ្ជ្រាំង

étane *n.m.* *Chim.* អេតាន

éther *n.m.* អេទែរ ។ *Poét.* អាកាស ។ éther-sel ម.ព. ester

éthéré,e *a.* *Chim.* នៃអេទែរ (ឧ.substance éthérée)។ *Fig.* ស្រាលហើយបរិសុទ្ធដូចខ្យល់ (ឧ. une âme éthérée) ។ *Poét.* la voûte éthérée វេហា; មេឃ

éthérification *n.f.* ម.ព. estérification

éthérifier *v.t.* ម.ព. estérifier

éthérisation *n.f.* ការឲ្យហិតអេទែរ (ដើម្បីឲ្យសន្លប់) (ឧ. l'éthérisation est une anesthésie de qualité)

éthériser *v.t.* លាបអេទែរ; ឲ្យហិតអេទែរ (ដើម្បីឲ្យសន្លប់)

éthérisme *n.m.* *Méd.* ភាពសន្លប់ដោយហិតអេទែរ

éthéromane *a.&n.* អ្នកញៀនអេទែរ, អ្នកចូលចិត្តហិតអេទែរឲ្យស្រវឹង

éthéromanie *n.f.* ការញៀនអេទែរ, ការចូលចិត្តហិតអេទែរឲ្យស្រវឹង

éthiopien,enne *a.&n.* នៃប្រទេសអេទីយ៉ូពី

éthiopique *a.* នៃប្រទេសអេទីយ៉ូពី និងជនជាតិអេទីយ៉ូពី (ឧ.année éthiopique)

éthique *a.* អភិសមាចារ,នៃសីលធម៌ (ឧ. science éthique) ។ *n.f.* អភិ-

សទាចារ, វិទ្យាសាស្ត្រខាងសីលកម្ម (ឧ l'éthique de Spinoza)

éthnie *n.f.* ជាតិពន្ធុ(ប្រជុំនៃមនុស្សដែលមានភាសានិងវប្បធម៌ដូចគ្នា)

ethnique *a.* នៃជាតិពន្ធុ (ឧ. influences ethniques; nom ethnique)

ethnographe *n.m.* អ្នកជាតិពន្ធុសាស្ត្រ

ethnographie *n.f.* ជាតិពន្ធុសាស្ត្រ [ជា-តិ-ព័ន-ធុ-]

ethnographique *a.* នៃជាតិពន្ធុសាស្ត្រ

ethnologie *n.f.* ជាតិពន្ធុវិទ្យា

ethnologique *a.* នៃជាតិពន្ធុវិទ្យា

ethnologue ឬ **ethnologiste** *n.* ជាតិពន្ធុវិទូ

éthologie ឬ **éthographie** *n.f.* អាចារសាស្ត្រ, វិទ្យាសាស្ត្រខាងទំនៀមទម្លាប់

éthologique *a.* នៃអាចារសាស្ត្រ

éthylène *n.m.* អេទីឡែន

éthylique *a.* នៃអេតាន ។ alcool éthylique ស្រា

éthylisme *n.m.* *Pathol.* ម.ព. alcoolisme

étiage *n.m.* កម្រិតទឹកស្រកទាបបំផុត។ débit d'étiage ធារទឹកសម្រក (កំពស់បញ្ចប់នៃទឹកសម្រក)

étier *n.m.* ព្រែកនាំទឹកសមុទ្រចូលស្រែអំបិល

étincelant,e *a.* ដែលព្រាយផ្កាភ្លើង, ត្រចះត្រចង់ (ឧ. soleil étincelant); ចិញ្ចាច(ឧ.couleurs étincelantes)។ *Fig.* ឆើត (ឧ. esprit étincelant)

étinceler *v i.* ព្រាយផ្កាភ្លើង (ឧ. tison qui étincelle) ; ភ្លឺត្រចះត្រចង់; បញ្ចេញរស្មី (ឧ. les étoiles étincellent)។ *Fig.* មានភាពរុងរឿង

étincelle *n.f.* ផ្កាភ្លើង(ឧ.jeter des étincelles)។ *Fig.* ពន្លឺផ្លេក (ឧ. diamant qui jette des étincelles); រស្មី (ឧ. étincelle de génie)

étincellement *n.m.* ភាពភ្លឺត្រចះត្រចង់ (ឧ.l'étincellement des étoiles)

étiolement *n.m.* ភាពស្រពោន, ដំណើរឡើងស្លាំង (ស្លែកដែលមិនត្រូវពន្លឺ) ។ *Fig.* ភាពទន់ខ្សោយ, ភាពអប្ប(ឧ.étiolement de l'intelligence)

étioler *v.t.* ធ្វើឱ្យស្រពោន (ឧ. l'obscurité étiola les plantes)។

s'étioler *v.pr.* ស្រពោន, ចុះទន់ខ្សោយ

étiologie *n.f.* សមុដ្ឋានសាស្ត្រ

étique *a.* ស្គមរីងរៃ, ស្គមកំព្រឹង (ឧ. cheval étique)

étiquetage *n.m.* ការបិទស្លាក

étiqueter *v.t.* បិទស្លាក (ឧ. il étiquette des marchandises)

étiqueteur,euse *n.* អ្នកបិទស្លាក

étiquette *n.f.* ស្លាក ។ *Fig.* ពិធីការ (ឧ. observer l'étiquette)

étirable *a.* យឺត, អាចទាញឲ្យវែងបាន (ឧ. le caoutchouc est très étirable)

étirage *n.m.* ការទាញឲ្យវែង ។ *Ind.* banc d'étirage ម៉ាស៊ីនហូតលួស

étirer *v.t.* សន្ធឹង, ទាញឲ្យវែង ។ s'étirer *v.pr.* *Fam.* មឹតពត់

étireuse *n.f.* ម៉ាស៊ីនហូតលួស (ឃ. banc d'étirage)

étisie *n.f.* ភាពស្គមរីងរៃ

étoc *n.m.* *Mar.* កំពូលថ្ម (ដែលលេចចេញផុតពីទឹក)

étoffe *n.f.* សំពត់ (ឧ. étoffe moelleuse) ។ *Fig.* រូបធាតុសម្រាប់ធ្វើរូបយ (ឧ. il n'y a pas assez d'étoffe dans ce chapeau); និស្ស័យ, សម្បទាពីកំណើត (ឧ. il y a de d'étoffe dans cet enfant ក្មេងនេះមាននិស្ស័យ (ពាក្យសាមញ្ញថា ក្មេងនេះប្រុងនឹងដុះ)

étoffé,e *a.* ពេញ, សម្បូណ៌, ច្រើន, ពិស្តារ (ឧ. un roman bien étoffé); ធាត់ (ឧ. cheval étoffé) ។ voix étoffée សម្លេងរពង

étoffer *v.t.* ប្រើសំពត់ល្មម (ឧ. étoffer un habit) ។ *Fig.* ធ្វើឲ្យពិស្តារ (ឧ. étoffer un roman)

étoile *n.f.* តារា, ផ្កាយ (ឧ. Sirius est une des plus brillantes parmi les étoiles); នក្ខត្តឫក្ស (ឧ. l'étoile qui préside à la naissance នក្ខត្តឫក្សនៃកំណើត) ។ *Fig.* វាសនា (ឧ. être né sous une bonne étoile មានវាសនាល្អ; être né sous une mauvaise étoile មានវាសនាអាក្រក់) ។ *Par anal.* ស្នាមប្រេះជារាងផ្កាយ; កុងសក់កម្រង; កន្លែងផ្លូវប្រសព្វគ្នាច្រើន (ឧ. le rond-point de l'Etoile, à Paris); ផ្កាយ (របស់ដែលភ្លឺដូចផ្កាយឬមានរាងដូចផ្កាយ) ។ *Par ext.*

តារា (តួឯកយ៉ាងឆើតនៃភាពយន្ត ឬ ល្ខោន)។ *Impr.* ម.ព. astérisque។

Astr. étoile du berger, du soir ឬ du matin ផ្កាយចោរ, ផ្កាយព្រឹក (ផ្កាយព្រះសុក្រ) (ម.ព. Vénus ផង)។ étoiles filantes ឬ tombantes ទេពច្យុតិ។ étoile polaire ផ្កាយមេរុ (នៅចុងច្រមុះផ្កាយក្រពើ)។

Echin. étoile de mer ម.ព. astérie។

Hippol. ផ្កាយ (សម្បុរពពាល ត្រង់ក្បាលលំនាំរូបផ្កាយ (ឧ. គោផ្កាយក្បាល)។

Mil. ផ្កាយ(សញ្ញានាយទាហាន)។ recevoir les étoiles ត្រូវតែងតាំងជាឧត្តមសេនីយ។

Loc. div. voir les étoiles en plein midi ឃើញអំពិលអំពែក។ à la belle étoile កណ្ដាលវាល (ឧ. dormir à la belle étoile)

étoilé,e *a.* ដែលរាយផ្កាយ (ឧ. ciel étoilé); ជារាងផ្កាយ; ដែលប្រេះជារាងផ្កាយ។ bannière étoilée ទង់ជាតិសហរដ្ឋអាមេរិក

étoilement *n.m.* ស្នាមប្រេះជារាងផ្កាយ; ពន្លឺព្រាយនៃដែកស្ពឹតពេភាយ

étoiler *v.t.* រាយផ្កាយ ឬ រាយវត្ថុរាងដូចផ្កាយ; ធ្វើឲ្យប្រេះជារាងផ្កាយ(ឧ. étoiler un carreau)

étonnamment *adv.* យ៉ាងចំឡែក; ដោយគួរឆ្ងល់ (ឧ. frères qui se ressemblent étonnamment)

étonnant,e *a.* គួរឆ្ងល់(ឧ. nouvelle étonnante); ចំឡែក(ឧ. homme étonnant); គួរស្ញើច(ឧ. peintre étonnant)

étonnement *n.m.* ការឆ្ងល់

étonner *v.t.* ធ្វើឲ្យឆ្ងល់; ធ្វើឲ្យរំជួល; ធ្វើឲ្យប្រេះ (ឧ. étonner une voûte)។ s'étonner *v.pr.* ឆ្ងល់ (ឧ. ne s'étonner de rien)

étouffade *n.f.* ម.ព. étouffée

étouffage *n.m.* ការធ្វើឲ្យថប់, ការបង្អប់។ *Spécial.* ការបង្អុយឃ្មុំ

étouffant,e *a.* ហប់, ស្ទុះស្អាប់, ដែលឲ្យថប់ (ឧ. la chaleur étouffante d'une salle)

étouffée *n.f.* ការហប់ចំអិន

étouffement *n.m.* ការបង្ខប់, ការធ្វើឲ្យថប់; ការថប់; ដំណើរពិបាកដកដង្ហើម (ឧ. l'asthme donne des

étouffements) ; បរិយាកាសហប់. បរិយាកាសស្អុះស្អាប់

étouffer *v.t.* បន្ទប់, សម្លាប់ដោយធ្វើឲ្យថប់ដង្ហើម ; សត់ភ្លើងដោយបង្ហប់ (ឧ. étouffer du charbon); ធ្វើឲ្យពិបាកដកដង្ហើម (ឧ. chaleur qui étouffe) ។ *Fig.* ទប់ (ឧ. étouffer ses sanglots); បង្ក្រាប, ពង្រាប (ឧ. étouffer une révolte); បង្អន់, រំលស់ (ឧ. tapis qui étouffe les pas កម្រាលដែលធ្វើមិនឲ្យឮស្នូរជើង); បំបិទ, លាក់ (ឧ. étouffer un scandale) ។ *v.i.* ថប់ដង្ហើម (ឧ. on étouffe ici) ។ *Fam.* étouffer de rire សើចរឹងពោះ

étouffeur,euse *n.* អ្នកធ្វើឲ្យថប់

étouffoir *n.m.* ប្រដាប់បង្ហប់(សត់ភ្លើង)។ *Fig.* បន្ទប់ខ្វះខ្យល់(នាំឲ្យថប់ដង្ហើម)

étoupe *n.f.* កំទេចខ្សែធ្មៃ។*Fig.* mettre le feu aux étoupes អុជអាលឲ្យឈ្លោះគ្នា

étoupement *n.m.* ការចុកដោយកំទេចខ្សែ

étouper *v.t.* ចុកដោយកំទេចខ្សែ (ឧ. étouper une fente)

étoupille *n.f.* ឆ្នួនរំសេវ

étoupiller *v.t.* ដាក់ឆ្នួនរំសេវ

étourderie *n.f.* ចរិតឬអំពើពាយងាយ ឬងេងងោង (ឧ. l'étourderie est commune chez les enfants); អំពើពាយងាយ (ឧ. commettre des étourderies)

étourdi,e *n.&a.* ពាយងាយ, ងេងងោង (ឧ.l'écolier étourdi)។ à l'étourdie *loc.adv.* ដោយពាយងាយ

étourdiment *adv.* ដោយពាយងាយ

étourdir *v.t.* ធ្វើឲ្យងៀងឬធ្វើឲ្យស្រងល់ (ឧ. étourdir d'un coup de bâton); ធ្វើឲ្យរងស៊ុង (ឧ. cet enfant m'étourdit) ។ étourdir la douleur ធ្វើឲ្យអន់ឈឺចាប់ ។ s'étourdir *v.pr.* បន្ទប់គំនិត(ដើម្បីបំភ្លេចរឿងទុក្ខ)

étourdissant,e *a.* ដែលឲ្យងេងងោង ឬរងស៊ុង ។ *Fam.* ចំឡែក(ឧ.nouvelle étourdissante)

étourdissement *n.m.* ភាពងេងងោង ឬរងស៊ុង ។ *Fig.* ភាពស្រឡាំងកាំង; ការបន្ទប់ស្មារតី

étourneau *n.m.* បក្សីមួយយ៉ាង។*Fig.* ក្មេងពាយងាយ

étrange *a.* ប្លែក, ចំឡែក, យ៉ាងអស្ចារ្យ

(ឧ. recevoir une étrange nouvelle)

étrangement *adv.* យ៉ាងប្លែក, យ៉ាងអស្ចារ្យ (ឧ. un récit étrangement risqué)

étranger,ère *n.&a.* បរទេស, អ្នកក្រៅ; ដទៃ, ក្រៅរឿង(ឧ. dissertation étrangère au sujet); ដែលមិនចេះ(ឧ. étranger à une science, à un art); ដែលគេមិនស្គាល់(ឧ. visage étranger)។ *Méd.* corps étranger អង្គដទៃ ។ *n.* ជនបរទេស។ *n.m.* បរទេស, ប្រទេសក្រៅ។ à l'étranger នៅបរទេស, នៅក្រៅប្រទេស

étrangeté *n.f.* ភាពប្លែក,វត្ថុប្លែកឬខុសធម្មតា

étranglé,e *a.* ស្ទួច, រួម (ឧ.passage étranglé) ។ voix étranglée សំឡេងអួល

étranglement *n.m.* ការច្របាច់ក; ភាពស្ទួច, ភាពរួម (ឧ. l'étranglement d'une vallée)

étrangler *v.t.* ច្របាច់ក; រឹត ក (ឧ.sa cravate l'étrangle) ។ *Fig.* ខ្ទប់, បំបិទ (ឧ. étrangler une affaire); បង្ហួនបង្ក្រួប ។ *v.i.* ធ្វើឲ្យស្អួលដើម ក (ឧ. étrangler de colère); ស្អួល

étrangleur,euse *n.* អ្នកច្របាច់ ក

étrape *n.f.* កណ្ដៀវតូច

étraper *v.t.* ច្រូតដោយកណ្ដៀវតូច

étrave *v.t. Mar.* ខ្តក្បាលកប៉ាល់

être *v.t.* មាននៅ(ឧ.je pense, donc je suis);ជា (ឧ.je suis élève); ជាកម្មសិទ្ធិរបស់(ឧ.cet objet est à moi);មានភាព (ឧ. la neige est blancheហិមៈមានពណ៌ស;je suis bien ខ្ញុំមានសុខភាពល្អ,ខ្ញុំស្រួលខ្លួន)។ n'être plus ស្លាប់ ។ être pour ចូលដៃខាង ។ en être pour sa peine ខាតកម្លាំង។ être en uniforme ស្លៀកពាក់ជាឯកសណ្ឋាន ។ être à នៅ (ឧ. être à Phnom Penh នៅភ្នំពេញ ; être à deux heures de Phnom Penh នៅចម្ងាយពីរម៉ោងពីភ្នំពេញ)។cette maison est à moi ផ្ទះនេះជារបស់ខ្ញុំ ។ n'être plus à soi-même លែងគ្រងខ្លួនឯងបាន។ être de មកពី,នៅក្នុង(ឧ.être du Cambodge មកពីប្រទេសកម្ពុជា; être d'un parti

politique នៅក្នុងគណបក្សនយោបាយ) ។ être de robe ជាអ្នកច្បាប់ ។ *Impers.* il n'est que de. . . គ្រាន់តែ. . .

être *n.m.* សភាវៈ; វត្ថុទៅដែលមានរូបរាង; សត្វលោក; ជន (ឧ. un être détestable)។l'Être suprême អាទិទេព។ l'être fini មនុស្ស

étrécir *v.t.* ធ្វើឲ្យស្ទួច,បង្រួម (ឧ.étrécir un habit) ។ s'étrécir *v. pr.* ឡើងស្ទួច,រួម

étrécissement *n.m.* ការធ្វើឲ្យស្ទួច, ការបង្រួម; ភាពស្ទួច ឬ រួម

étreindre *v.t.* ចងរឹត; ឱបរឹត (ឧ. étreindre dans ses bras) ។ *Fig.* ធ្វើឲ្យរួលដើម ក (ឧ. l'émotion étreignait les spectateurs)

étreinte *n.f.* ការចងរឹត; ការរឹតរួត; ការឱបរឹត; កម្លាំងរឹត

étrenne *n.f.* ជំនូនឬអំណោយក្នុងឱកាសចូលឆ្នាំ (ឧ. recevoir, donner des étrennes); ជំនូន។*Par ext.* ថ្ងៃបើកលក់ដំបូង; ការប្រើប្រាស់ដំបូង (ឧ. avoir l'étrenne d'une chose)

étrenner *v.t.* ទៅឆាយ (ទិញមុនគេបង្អស់); ប្រើដំបូង (ឧ. étrenner une robe) ។ *v.i.* បើកលក់ដំបូង; រងការលំបាកមុនគេ។ *Pop.* ត្រូវវាយ, ត្រូវស្តីបន្ទោស

êtres ឬ **aitres** *n.m. pl.* ភាគផ្សេងៗនៃផ្ទះ (ឧ. connaître les êtres d'une maison)

étrésillon *n.m.* ឈើច្រុះ (កុំឲ្យបាក់ដី)

étrésillonnement *n.m.* ការច្រុះ (កុំឲ្យបាក់ដី)

étrésillonner *v.t.* ច្រុះ (កុំឲ្យបាក់ដី)

étrier *n.m.* ឈ្នាន់កែបសេះ។ à franc étrier យ៉ាងលឿន (ដោយជិះសេះ)។ coup de l'étrier ការផឹកលើកក្រោយបង្អស់ (ម.ព. coup ផង) ។ vider les étriers លែងជើងពីឈ្នាន់; ធ្លាក់ពីលើសេះ; *au fig.* ចាញ់ (ក្នុងការជជែក)។ avoir le pied à l'étrier ត្រៀមខ្លួនប្រុងជិះសេះ ឬ ចេញដំណើរ; *au fig.* ត្រៀមខ្លួនហើយស្រេច; មានជំហររឹង ។ tenir l'étrier à quelqu'un ជួយកាន់សេះឲ្យគេឡើងជិះ; *au fig.* ជួយគាំទ្រឲ្យបានសម្រេចបំណង

étrille *n.f.* ខ្នាសដែកសំរកតរោមសេះ

étriller *v.t.* កោសសំអាតសេះ(ដោយខ្នាសដែក)។*Fig.* ធ្វើបាប(ឧ.étriller quelqu'un d'une rude manière) ។ *Fam.* កោរ (លក់ឲ្យថ្លៃពេក) (ឧ. ce marchand veut nous étriller)

étripage *n.m.* ការវះពោះត្រី

étriper *v.i.* វះយកពោះវៀនចេញ (ឧ. étriper un lapin) ។ à étripe-cheval យ៉ាងលឿន(ជិះសេះ)

étriqué,e *a.* ចង្អៀតពេក (ឧ. habit étriqué) ។ *Fig.* ខ្លីពេក (ឧ. discours étriqué); ថោកទាប (ឧ. esprit étriqué)

étriquer *v.t.* ធ្វើឲ្យចង្អៀតពេក(ឧ.étriquer un habit)។*Fig.* អធិប្បាយខ្លីពេក(ឧ.étriquer un discours)

étroit,e *a.* តូច, ចង្អៀត។ *Fig.* esprit étroit ប្រាជ្ញាខ្លី ។ ជិតស្និទ្ធ (ឧ. amitié étroite); តឹងតែង (ឧ. étroite obligation)។ à l'étroit ដោយក្រោកយ៉ាក (ឧ. vivre à l'étroit); ដោយចង្អៀតចង្អល់ (ឧ. logé à l'étroit)

étroitement *adv.* យ៉ាងចង្អៀត។*Fig.* ដោយជិតស្និទ្ធ (ឧ. amis étroitement unis)

étroitesse *n.f.* ភាពចង្អៀត ។ *Fig.* ភាពប្រាជ្ញាតិច; គំនិតខ្លី (ឧ. étroitesse de vue)

étron *n.m.Pop.* លាមករឹង

étronçonner *v.t.* លះមែកចេញទាំងអស់ទុកតែគុង

étude *n.f.* វិជ្ជាករណ៍ (ឧ.se livrer à l'étude); ចំណេះ ។ *Par ext.* ការពិតមុន, ការពិនិត្យគ្រោងការ(ឧ.étude d'un canal, d'un chemin de fer); ការយកចិត្តទុកដាក់ (ឧ. faire son étude de plaire à quelqu'un)។ *Bx arts* គំរូគំនូរ។

Dr. ការិយាល័យ (នៃសារការី, មេធាវី។ល។)(ឧ.étude de notaire ការិយាល័យនៃសារការី ; étude d'agent de change ការិយាល័យនៃភ្នាក់ងារដូររូបិយវត្ថុ)។មុខងារ(នៃសារការី)(ឧ.acheter une étude) ។

Ens. ការសិក្សា (ឧ. commencer ses études)។salle d'étude ឬ étude បន្ទប់សិក្សា(ក្រៅម៉ោងដែលមានគ្រូបង្រៀន)(ឧ. aller à l'étude)។

pour étude et propo-

sition ដើម្បីពិនិត្យគ្រោងការព្រមទាំងស្នើ

étudiant,e *n.* និស្សិត, និស្សិតា

étudié,e *a.* ដែលធ្វើដោយផ្ចិតផ្ចង់(ឧ. carrosserie étudiée)។ prix étudié តម្លៃថោកបំផុត ។ ក្លែង,ដែលធ្វើឫក(ឧ.des gestes étudiés)។ douleur étudiée ការពុតធ្វើឈឺ

étudier *v.t.* សិក្សា (ឧ. étudier la peinture; étudier un auteur); រៀន, ទន្ទេញ (ឧ. étudier sa leçon); ពិនិត្យគ្រោងការ (ឧ. étudier un projet de loi); សង្កេតដោយហ្មត់ចត់ (ឧ. étudier un homme, la nature)។ *v.i.* សិក្សា,រៀនវិជ្ជា ។ s'étudier *v.pr.* ខំប្រឹង (ឧ. s'étudier à plaire); ពិនិត្យខ្លួនឯងខ្លាំងពេក

étui *n.m.*ស្រោម(ឧ. étui à lunettes); សំបក។étui de cartouche ឡតគ្រាប់កាំភ្លើង

étuvage ឬ **étuvement** *n.m.* ការហប់ចំអិន

étuve *n.f.* បន្ទប់ក្ដៅឲ្យបែកញើស;ជើងក្រានសម្រាប់ធ្វើឲ្យស្ងួត ; ប្រដាប់រំងាប់មេរោគ(ដោយខ្យល់ក្ដៅឬចំហាយទឹក)។ *Fig.* cette chambre est une étuve បន្ទប់នេះក្ដៅណាស់

étuvée *n.f.* ម.ព. étouffée

étuver *v.t.* ហប់ចំអិន; កំដៅឲ្យស្ងួត;ផ្ដុងឲ្យបែកញើស ។ *Méd.* លាងដោយស្រាលដៃ(ឧ. étuver une plaie)

étuveur *n.m.* ឬ **étuveuse** *n.f.* ប្រដាប់ហប់

étymologie *n.f.* និរុត្តិសាស្ត្រ,ដើមមូល, ឫសពាក្យ (ឧ. la plus grande partie des mots cambodgiens ont une étymologie palie)

étymologique *a.* នៃនិរុត្តិសាស្ត្រឬឫសពាក្យ(ឧ. dictionnaire étymologique)

étymologiquement *adv.* តាមនិរុត្តិសាស្ត្រ, តាមដើមមូល

étymologiste *n.m.* អ្នកនិរុត្តិសាស្ត្រ

eugénique *n.f.*ឬ**eugénisme** *n.m.* សុជាតិវិទ្យា(វិជ្ជាបង្កើតកូនឲ្យបានល្អ)

eugéniste *n.* សុជាតិវិទូ

euh! *int.* យី ! (ឧទានសព្ទ សំដែងសេចក្ដីឆ្ងល់, សេចក្ដីសង្ស័យ)

eunuque *n.m.* មនុស្សកម្រៀវ

euphémique *a.*សម្រាប់សម្រាលពាក្យ

(ឧ. expression euphémique)

euphémisme *n.m.* ការសម្រួលពាក្យ (ឧ. ដើម្បីជា «អាក្រក់» គេសម្រួលពាក្យជា «មិនសូវល្អ» វិញ)

euphonie *n.f.* ការរៀបសម្លេងឲ្យពីរោះ; សម្លេងពីរោះ។ *Gram.* សន្ធិ(វិធីតអក្សរ ដូចជា «គមនៈ» (ការទៅ,ដំណើរទៅ) + «អាគមនៈ» (ការមក, ដំណើរមក) តភ្ជាប់ជា «គមនាគមន៍» (ព. ផ. cacophonie)

euphonique *a.* នៃសន្ធិ (ឧ. lettre euphonique: t (dans viendra -t- il)

euphoniquement *adv.* ដោយសន្ធិ

euphorie *n.f.* សុខវេទន៍ [សុ-ខៈ-វេត] (ដំណើរសប្បាយក្នុងខ្លួន,ការសប្បាយចិត្ត)

euphorique *a.* នៃសុខវេទន៍ (ឧ. état euphorique)

euristique *a.* សម្រាប់រក

eurasien,enne *a.&n.* នៃទ្វីបអឺរ៉ុបនិងអាស៊ី

européaniser *v.t.* យករបៀបទ្វីបអឺរ៉ុប (ឧ. le Japon s'est rapidement européanisé)

européanisme *n.m.* អឺរ៉ុបនិយម, លក្ខណៈនៃប្រទេសអឺរ៉ុប

européen,enne *a.* នៃទ្វីបអឺរ៉ុប។ *n.* ជនជាតិអឺរ៉ុប

eutexie *n.f.* point d'eutexie កំរិតសីតុណ្ហភាពដែលលោហធាតុផ្សំរលាយ

euthanasie *n.f.* សុមរណ៍ (ការស្លាប់ដោយស្រួលគឺគ្មានឈឺចាប់; ទ្រឹស្តីថ្លែងថាគួរតែជួយផ្តាច់ជីវិតអ្នកជំងឺដែលមើលមិនជា) (ឧ. l'euthanasie est condamnée par les tribunaux français et par l'Eglise catholique)

euthanasique *a.* ដែលស្លាប់ដោយគ្មានឈឺចាប់; នៃសុមរណ៍, នៃការស្លាប់ដោយគ្មានឈឺចាប់

eutocie *n.f.* ការសម្រាលកូន(ឆ្លងទន្លេ) ដោយធម្មតា

eux *pr.pers.m.pl.* គេ, គាត់ (ទាំងឡាយ)

E. V. (ពាក្យបំព្រួញនៃ En Ville) ក.ក. (ក្នុងក្រុង)

évacuant,e ឬ **évacuatif,ive** *a.* *Méd.* ដែលបញ្ចេញពីក្នុងខ្លួន; ដែលលាង (ឧ. purgatif évacuant ឬ évacuatif)

évacuateur *a.* សម្រាប់បញ្ចេញ។ *n.m.* évacuateur des crues ប្រឡាយ

បញ្ចេញទឹកកំនន់ (ដើម្បីកុំឲ្យទឹកក្នុងទំនប់ឡើងខ្ពស់ពេក)

évacuation *n.f. Méd.* ដំណើរភ្លូត ឬពុះ;វត្ថុដែលបញ្ចេញដោយភ្លូតឬបញ្ចុះ; ការហូរចេញ (ឧ. orifice d'évacuation) ។ *Fig.* ការចាកទី; ការបញ្ចេញពីកន្លែង (ឧ. évacuation des malades)

évacuer *v.t.* បញ្ចេញពីក្នុងខ្លួន (ឧ. évacuer de la bile); បង្ហូរចេញ (ឧ. évacuer les eaux d'égout); បញ្ចេញពីកន្លែង (ឧ. évacuer des blessés); បង្វេះចេញពី (ឧ. évacuer un pays); ចាកចេញដោយគ្នាច្រើន (ឧ. évacuer une salle de spectacle)

évader (s') *v.pr.* លួចរត់(ឧ. s'évader d'une prison)។ *Fig.* ដោះខ្លួន (អំពីការលំបាក) (ឧ. s'évader de sa condition)

évadé,e *a.&n.* អ្នកលួចរត់(ឧ.un forçat évadé; les évadés)

évaluable *a.* អាចវាយតម្លៃបាន

évaluation *n.f.* ការដាក់តម្លៃ,ការវាយតម្លៃ; ការប្រមាណ

évaluer *v.t.* វាយតម្លៃ, ដាក់តម្លៃ, ថៃ តម្លៃ(ឧ. évaluer un tableau); ថៃរ, ប្រមាណ (ឧ. évaluer une distance; évaluer la valeur d'un terrain)

évanescence *n.f.* ភាពដែលរលាយបាត់

évanescent,e *a.* ដែលរលាយបាត់ (ឧ.impression évanescente)

évangéliaire *n.m.* គម្ពីរលទ្ធិព្រះយេស៊ូ

évangélique *a.*នៃលទ្ធិព្រះយេស៊ូ;ត្រឹមត្រូវតាមលទ្ធិព្រះយេស៊ូ(ឧ.vie évangélique)

évangéliquement *adv.* ដោយត្រឹមត្រូវតាមលទ្ធិព្រះយេស៊ូ

évangélisateur,trice *a.* ដែលផ្សាយលទ្ធិព្រះយេស៊ូ ។ *n.m.* អ្នកប្រដៅតាមលទ្ធិព្រះយេស៊ូ(ឧ. Saint Paul fut le principal évangélisateur des gentils)

évangélisation *n.f.* ការផ្សាយលទ្ធិព្រះយេស៊ូ

évangéliser *v.t.* ផ្សាយលទ្ធិព្រះយេស៊ូ

évangélisme *n.m.* លក្ខណៈត្រឹមត្រូវតាមលទ្ធិព្រះយេស៊ូ

évangéliste *n.m.*អ្នកនិពន្ធជីវប្រវត្តិនិងលទ្ធិព្រះយេស៊ូ

évangile *n.m.* លទ្ធិព្រះយេស៊ូ;ប្រជុំគម្ពីរលទ្ធិព្រះយេស៊ូ ។ *Fig.* ឯកសារ ឬ សៀវភៅក្បួន ។ parole d'évangile របស់ប្រាកដណាស់

évanouir (s') *v.pr.* សន្លប់។ *Par ext.* លិច,រលាយបាត់ (ឧ. la beauté s'évanouit)

évanouissement *n.m.* ដំណើរសន្លប់។ *Par ext.* ការលិច, ការរលាយបាត់, ការរលុប

évaporable *a.* អាចហួតបាន

évaporateur *n.m.* ប្រដាប់ធ្វើឲ្យស្ងួត (យកទឹកចេញពីផ្លែឈើ, បន្លែ, ទឹកដោះ។ល។)

évaporation *n.f.* ការចេញចំហាយទឹក, ការហួត

évaporatoire *a.* សម្រាប់បង្ហួត (ឧ. groupe évaporatoire)

évaporé,e *a.&n.* *Fig.* ងេងងោង, រឡិករឡក់ (ឧ. tête évaporée; c'est un évaporé)

évaporer *v.t.* បង្ហួត (ឧ. évaporer un liquide) ។ s'évaporer *v.pr.* ចេញជាចំហាយទឹក, ហួត ។ *Fig.* រលាយ (ឧ. sa colère s'évapore en menaces); ទៅជា ងេងងោង ឬ រឡិករឡក់

évasé,e *a.* រីកភាស,ដែលរីកមាត់លើ

évasement *n.m.* ភាពរីកភាស

évaser *v.t.* ពង្រីកមាត់ (ឧ. évaser un trou, un tuyau)

évasif,ive *a.* មិនប្រាកដ; សម្រាប់ដោះដៃ (ឧ. faire une réponse évasive)

évasion *n.f.* ការលបរត់ (ភៀសខ្លួន)(ឧ. méditer une évasion)។ *Fig.* ការផ្លាស់ប្តូរ;ការលំហែ (ឧ. besoin d'évasion)

évasivement *adv.* ដោយមិនប្រាកដ; ដោយដោះដៃ (ឧ. répondre évasivement à une question)

évasure *n.f.* មាត់រន្ធរីកភាស, មាត់រន្ធធំ

évêché *n.m.* អេវែគខ្លួនឬស្ថានអេវែគ (ឧ. se rendre à l'évêché)

éveil *n.m.* ការភ្ញាក់ ឬ ដាស់ពីដំណេក។ *Fig.* donner l'éveil ដាស់តឿនឲ្យប្រយ័ត្ន ។ être ឬ se tenir en éveil ប្រុងប្រយ័ត្ន ។ éveil de l'intelligence ការផុះនៃបញ្ញា

éveillé,e *a.* *Fig.* សប្បាយ, វៃ (ឧ. mine éveillée)

éveiller *v.t.* ដាស់ពីដំណេក(ឧ.éveil-

ler un dormeur)។ *Fig.* ដាស់, តឿន,បង្ក,បង្កើត(ឧ.éveiller l'attention)

éveilleur,euse *a.* ដែលដាស់

événement *n.m.* ព្រឹត្តិការណ៍; ការបញ្ចប់ (ឧ. attendre l'événement pour juger de la valeur d'une entreprise)

événementiel,elle *a.* histoire événementielle ប្រវត្តិសាស្ត្រព្រឹត្តិការណ៍(ប្រវត្តិសាស្ត្រដែលរៀបរាប់តែព្រឹត្តិការណ៍)

évent *n.m.* ការចូលខ្យល់,ការធុំខ្យល់(ឧ. ce vin sent l'évent); កណ្ដាលវាល (ឧ. mettre une cargaison à l'évent); រន្ធបង្ហុយ។ *Fig.* tête à l'évent មនុស្សពាយងាយ

éventail *n.m.* ផ្លិត (ឧ. éventail de plumes)

éventaillerie *n.f.* ឧស្សាហកម្មផ្លិត; ជំនួញផ្លិត

éventaillier *n.m.* ឈ្មួញផ្លិត

éventailliste *n.m.* អ្នកធ្វើផ្លិត;ឈ្មួញផ្លិត

éventaire *n.m.* កញ្ច្រែងស្ពាយពីមុខ (សម្រាប់ដាក់ទំនិញលក់) (ឧ. éventaire d'une marchande de fleurs)។ *Par ext.* ភនលក់ទំនិញក្រៅតៀម

éventé,e *a.* ចូលខ្យល់ (ឧ.vin éventé)។ *Fig.* រឡើករឡក់ (ឧ.personne éventée)

éventer *v.t.* ហាលខ្យល់ (ឧ. éventer des vêtements);បក់(ឧ. se faire éventer ឲ្យគេបក់ឲ្យ); ធ្វើឲ្យចូលខ្យល់(ខូច) (ឧ. éventer le vin)។ éventer le grain ទទាក់គ្រាប់ (ដើម្បីកុំឲ្យក្ដៅ) ។ éventer une mine, une mèche ក្ដិបឆ្នូនគ្រាប់បែកកប់; *au fig.* ដឹងគំនិតអាក្រក់ ហើយធ្វើកុំឲ្យគំនិតនោះបានសម្រេច ។ *Par ext.* ស្រង់ក្លិន (ឧ. un chien vint sur l'herbe éventer les traces de ses pas) ។ *Fig.* ដឹងក្លិន, ដឹងរឿង (ឧ.éventer un complot, un secret) ។ *Mar.* éventer une voile បំបែរក្ដោងឲ្យត្រូវខ្យល់ ។ **s'éventer** *v.pr.* បក់ផ្លិត; ចូលខ្យល់ (ខូច) (ឧ. parfum qui s'est éventé)

éventoir *n.m.* ផ្លិតបក់បង្កាត់ភ្លើង

éventrer *v.t.* វះពោះ ។ *Par anal.*

ទ្វារ (ឧ. éventrer une porte); ពុះ, វះ (ឧ. éventrer un pâté, une valise)

éventreur *n.m.* អ្នកវះពោះ

éventualité *n.f.* យថាភាព, យថាហេតុ (ឧ. parer à toute éventualité)

éventuel,elle *a.* ជា យថាហេតុ (ឧ. faire une concession éventuelle)។ *n.m.* យថាហិរញ្ញ

éventuellement *adv.* តាមយថាហេតុ

évêque *n.f.* អេវ៉ែក

évertuer (s') *v.pr.* ខំប្រឹងប្រែងឲ្យបានសម្រេច (ឧ. s'évertuer à faire de l'esprit)

éviction *n.f. Dr.* ការរឹបអូសរបស់បានដោយសុទ្ធចិត្ត (ដោយរបស់នោះជារបស់តតិយជន) (ឧ. le vendeur est garant de l'éviction que l'acquéreur peut souffrir អ្នកលក់ជាអ្នកធានានៅពេលដែលគេរឹបអូសរបស់ពីអ្នកទិញ); ការដណ្ដើមយក (ដោយកម្លាំងឬដោយឧបាយ)។ éviction scolaire រយៈពេលហាមមិនឲ្យសិស្សទៅរៀនឯសាលា (ដោយហេតុកើតរោគឆ្លង) (ឧ. les colons irlandais ont été victimes de nombreuses évictions scolaires)

évidage *n.m.* ការលុង; ការលោក

évidement *n.m.* ការលុង; ភាពលុង; គន្លាក់។ *Chir.* ការលុងឆ្អឹង

évidemment *adv.* ដោយប្រត្យក្ស, ដោយជាក់, ប្រាកដមែន

évidence *n.f.* ប្រត្យក្សភាព, ភាពជាក់ស្ដែង (ឧ. l'évidence d'une preuve); របស់ជាក់ស្ដែង។ mettre en évidence ធ្វើឲ្យឃើញជាក់ស្ដែង (ឧ. mettre en évidence les défauts, la mauvaise foi de quelqu'un); ដាក់សម្ដាប.ដាក់ឲ្យឃើញច្បាស់ (ឧ. mettre des marchandises en évidence dans des vitrines)។ se mettre en évidence បញ្ចេញមុខឲ្យគេឃើញច្បាស់ (ឈរឬអង្គុយកន្លែងណាឲ្យគេឃើញខ្លួនច្បាស់)។ dernière évidence ភាពជាក់ស្ដែងពេកស់។

Loc. div. se rendre à l'évidence ទទួលស្គាល់ជាពិតមែន។ se refuser à l'évidence ឬ aller contre l'évidence មិន

ព្រមទទួលស្គាល់របស់ដែលជាក់ស្តែង។

de toute évidence *loc. adv.* ជាក់, ប្រាកដ

évident,e *a.* ប្រត្យក្ស, ជាក់ស្តែង (ឧ. vérité évidente)

évider *v.t.* លុង; ឈាក់

évidoir *n.m.* ប្រដាប់លុង

évier *n.m.* ជើងលាងចាន; ប្រឡាយទឹកផ្ទះបាយ

évincement *n.m.* ការដណ្តើមកន្លែង; ភាពត្រូវគេដណ្តើមកន្លែង

évincer *v.t. Dr.* រឹបអូសរបស់បានដោយសុទ្ធចិត្ត។ *Par ext.* ដណ្តើមកន្លែងដោយឧបាយ (ឧ. évincer frauduleusement un concurrent)

évitable *a.* អាចចៀសវាងបាន, អាចគេចវេះបាន

évitage *n.m.* ឬ **évitée** *n.f.* ដំណើរនាវារេជុំវិញយុថ្កា, កន្លែងសម្រាប់នាវារេ

évitement *n.m.* ការចៀស។ *Ch. de fer* voie d'évitement ផ្លូវសំចតក្បែរផ្លូវធំ

éviter *v.t.* ចៀស (ឧ. éviter un danger); ចៀសវាង (ឧ. éviter les mots oiseux); ឲ្យរួចខ្លួន(ឧ. éviter une corvée à quelqu'un)។ *v.i. Mar.* រេជុំវិញយុថ្កា

évocable *a.* អាចរំឭកបាន

évocateur,trice *a.&n.* ដែលនាំឲ្យនឹកឃើញ (ឧ. un style évocateur)

évocation *n.f.* ការអន្ទងហៅដោយមន្តគាថា (ឧ. évocation des esprits); ការនឹកដល់; ការហៅរក; ការរំឭក(ឧ. l'évocation de ses souvenirs)។ *Dr.* ការសំអាងហេតុ

évocatoire *a. Dr.* សម្រាប់សំអាង(ឧ. cause évocatoire); សម្រាប់អន្ទង (ឧ. cérémonie évocatoire)

évolué,e *a.* វិវឌ្ឍ(ឧ. peuple évolué)

évoluer *v.i.* ធ្វើសមយុទ្ធ, ធ្វើចលនា (ឧ. escadre qui évolue)។ *Fig.* វិវឌ្ឍ, ចំរើនឡើង (ឧ. l'humanité évolue sans cesse)។ *Par ext.* ផ្លាស់មតិ

évolutif,ive *a.* អាចវិវឌ្ឍបាន; ដែលនាំឲ្យវិវឌ្ឍ; ដែលចម្រើន

évolution *n.f.* សមយុទ្ធ, ចលនា។ *Fig.* វិវឌ្ឍន៍, សេចក្តីចំរើន (ឧ. l'évolu-

tion des idées) ។ *Biol.* វិវត្តន៍ (ឧ. Darwin a soutenu la doctrine de l'évolution) ។ *Méd.* évolution d'une maladie វិវត្តន៍នៃរោគ ។ *Phil.* ម.ក. évolutionnisme

évolutionnisme *n.m.* វិវត្តនិយម (ឧ. Spencer est le principal représentant de l'évolutionnisme anglais)

évolutionniste *n.&a.* អ្នកវិវត្តនិយម

évoquer *v.i.* ខាប, ហៅ ឬ អញ្ជើញដោយមន្តគាថា (ឧ. évoquer les esprits) ។ *Par ext.* រំឭក (ឧ. évoquer le passé) ។ évoquer une question លើកបញ្ហា ។ *Dr.* មិនសម្រេច, មិនវិនិច្ឆ័យ (ឧ. évoquer une affaire)

ex *préf.* អតីត [អតិត] (ឧ. ex-ministre អតីតរដ្ឋមន្ត្រី)

ex abrupto ឬ **ab abrupto** *loc. lat.* ភ្លាមៗ, ដោយឥតព្រាងទុកជាមុន (ឧ. monter à la tribune et parler ex abrupto)

exacerbation *n.f.* ការរើ (រឹតតែខ្លាំងឡើង) (ជម្ងឺ)

exacerber *v.t.* ធ្វើឲ្យរើ (ធ្វើឲ្យធ្ងន់ឬឲ្យខ្លាំងឡើង) (ជម្ងឺ) (ឧ. le frottement exacerbe la douleur)

exact,e *a.* ត្រូវ (ឧ. calcul exact); ម៉ឺងម៉ាត់ (ឧ. suivre une diète exacte); ទៀងពេល (ឧ. un employé exact; une montre exacte) ។ les sciences exactes គណិតសាស្ត្រ

exactement *adv.* ដោយពិត; ដោយទៀងពេល; យ៉ាងត្រឹមត្រូវ (ឧ. régler exactement un compte); គត់

exacteur *n.m.* អ្នកទាមទារអ្វីដែលត្រូវបាន (ឧ. un sévère exacteur de ses droits); អ្នកអធិការដែលរំលោភ

exaction *n.f.* ការបៀតជាន់; ការទារសួយ ឬ អាករ; ការរំលោភនៃអ្នកអធិការ

exactitude *n.f.* ភាពត្រូវ, ភាពត្រឹមត្រូវ (ឧ. vérifier l'exactitude d'un calcul); ភាពទៀងពេល (ឧ. l'exactitude, disait Louis XIII, est la politesse des rois)

ex aequo *loc. lat.* សមានរូប, ស្មើគ្នា

exagérateur,trice ឬ **exagéreur,**

euse *n.&a.* ដែលបំផ្លើសឬពន្លើស

exagératif, ive *a.* នៃការបំផ្លើស (ឧ. expression exagérative)

exagération *n.f.* ការបំផ្លើសឬពន្លើស

exagéré,e *a.* ដែលមានបំផ្លើសឬពន្លើស (ឧ. récit exagéré); ដែលបំផ្លើស (ឧ. personne exagérée) ។ *n.m.* អ្វីៗដែលបំផ្លើស

exagérément *adv.* ដោយបំផ្លើស

exagérer *v.t.* បំផ្លើស,ពន្លើស(ឧ.exagérer un récit) ; ធ្វើឲ្យហួសហេតុ (ឧ. exagérer un maquillage)

exaltation *n.f.* ការលើកតំកើង, ការតម្កើងទឹកចិត្ត (ឧ. exaltation de la vertu); ការធ្វើឲ្យខ្លាំងក្លា (ឧ. le café produit une exaltation passagère); សេចក្ដីស្រើបស្រាលរំភើបរីករាយ (ឧ parler avec exaltation)

exalté,e *a.* ដែលស្រើបស្រាលរំភើបរីករាយ(ឧ. tête exaltée)

exalter *v.t.* លើកតំកើង; តម្កើងទឹកចិត្ត; អួតអាង,សរសើរ (ឧ. exalter les vertus des héros) ។ *Fig.* ធ្វើឲ្យរំជួល - ឲ្យមានចំណង់ខ្លាំង - ឲ្យប្រឡូកឡើង-ឲ្យខ្លាំងក្លា (ឧ. certaines lectures exaltent l'imagination) ។ s'exalter *v.pr.* ស្រើបស្រាលរំភើបរីករាយ (ឧ. tel qui a du courage quand il s'exalte, n'en a pas quand il réfléchit)

examen *n.m.* ពិនិត្យ(ឧ. faire son examen de conscience) ។ pour examen ដើម្បីពិនិត្យ ។ libre examen សេរីភាពខាងការយល់ឃើញ ។ ការប្រឡង (ឧ.passer un examen)

examinateur,trice *n.&a.* អ្នកប្រឡងពិនិត្យ

examiner *v.t.* ពិនិត្យ(ឧ.examiner une affaire); ដើញប្រយោគ

exanthémateux,euse ឬ **exanthématique** *a.* នៃរោគស៊ើស្បែក

exanthème *n.m.* រោគស៊ើស្បែក

exarthrose *n.f.* ដំណើរធ្លាក់ឆ្អឹង

exaspérant,e *a.* ដែលធ្វើឲ្យក្ដៅក្រហាយខ្លាំងពេក

exaspération *n.f.* ក្រេវក្រោធ (ឧ. l'exaspération est la force dernière de la colère); ភាពធ្ងន់ធ្ងរខ្លាំង(ឧ. exaspération

d'une maladie); សម្រើប (ឧ. exaspération d'un désir)

exaspérer *v.t.* ធ្វើឲ្យក្ដៅក្រហាយខ្លាំងពេក; ធ្វើឲ្យរើ (ឲ្យខ្លាំងឡើង)(ឧ.exaspérer la douleur) ។ s'exaspérer *v.pr.* ក្ដៅក្រហាយ; ខឹងខ្លាំង

exaucement *n.m.* ការបំពេញបំណង; ការធ្វើឲ្យសម្រេច

exaucer *v.t.* បំពេញបំណង; ធ្វើឲ្យសម្រេច (ឧ. exaucer un vœu)

excavateur *n.m.* ឬ **excavatrice** *n.f.* ប្រដាប់ជីកដី (ឧ. excavateur à air comprimé)

excavation *n.f.* ការជីកដី; ដីក្រហូង (ឧ. les cavernes sont des excavations naturelles)

excaver *v.t.* ជីក (ឧ. excaver le sol)

excédant,e *a.* អតិរេក, សល់, ដែលលើសពីកំណត់; ដែលរំខានពេក (ឧ. enfant excédent)

excédent *n.m.* ចំនួនលើស, របស់អតិរេក, របស់សល់(ឧ. excédent budgétaire; excédent de bagages)

excédentaire *a.* ដែលលើស (ឧ. production excédentaire)

excéder *v.t.* លើស, ហួស (ឧ. les recettes excèdent les dépenses); ធ្វើឲ្យលើស ឬ ឲ្យហួស (ឧ.excéder son pouvoir) ។ *Fig.* ឲ្យហត់ពេក(ឧ.cette course m'a excédé); រំខាន (ឧ.les facheux nous excèdent)។ s'excéder *v.pr.* ហត់ពេក

excellemment *adv.* យ៉ាងប្រសើរ, យ៉ាងឧត្ដម, យ៉ាងប្រពៃ

excellence *n.f.* ឧត្ដមភាព, ភាពប្រសើរ (ឧ. l'excellence du goût) ។ Son Excellence (S.E.) ឯកឧត្ដម (ឯ.ឧ.) ។ par excellence *loc. adv.* យ៉ាងឧត្ដម, យ៉ាងប្រពៃ

excellent,e *a.* ឧត្ដម, ប្រសើរ, ប្រពៃ (ឧ. (ឧ. mets excellents)

excellentissime *a.* ប្រសើរណាស់, ឧត្ដមណាស់, ប្រពៃណាស់

exceller *v.i.* ជាប្រសើរលើសគេ ។ exceller à ប៉ិនប្រសប់ណាស់ខាង

excentricité *n.f.* អញ្ញាភិភាព, ភាពនៅឆ្ងាយពីមជ្ឈមណ្ឌល (ឧ. excentricité d'un quartier)។ *Fig.* ភាពប្លែក, ភាពឈ្លើយ (ខុសគេ) (ឧ. se livrer à mille excentri-

cités)

excentrique *a. Math.* អញ្ញនាភិ (ឧ. cercles excentriques) ។ ដែលនៅឆ្ងាយពីមជ្ឈមណ្ឌល (ឧ. quartiers excentriques de Phnom Penh) ។ *Fig.* ឈ្លើយ, ខុសគេ (ឧ.tenue excentrique)។ *n. Fig.* មនុស្សឈ្លើយ (ខុសគេ)

excentriquement *adv.* ដោយឈ្លើយ, ដោយខុសគេ

excepté *pré* & *a.* អញ្ញត្រ [អ័ញ-ញ័ត], លើកលែងតែ, វៀរតែ (ឧ. excepté les vieillards; les vieillards exceptés)

excepter *v.t.* លើកលែង (ឧ. excepter certains condamnés d'une amnistie)

exception *n.f.* អញ្ញត្រកម្ម [អ័ញ-ញ័ត-ត្រៈ–], ការលើកលែង; អញ្ញត្រករណ៍, របស់ដោយឡែក; អញ្ញត្រសព្ទ (ឧ. les exceptions confirment la règle) ។ faire exception ត្រូវលើកលែង (មិនត្រូវអនុវត្តច្បាប់ធម្មតា) ។ *Dr.* loi d'exception ច្បាប់ពិសេស ។ à l'exception de *loc.pré* លើកលែងតែ ។ *Prov.* il n'y a pas de règle sans exception ច្បាប់តែងមានអញ្ញត្រកម្ម (គ្មានច្បាប់ណាអាចអនុវត្តបានគ្រប់ករណីទេ)។ l'exception confirme la règle អញ្ញត្រកម្មបញ្ជាក់ច្បាប់(បើគ្មានអញ្ញត្រកម្មច្បាប់ក៏គ្មានដែរ)

exceptionnel,elle *a.* ពិសេស (ឧ. faveur exceptionnelle); ប្លែកពីធម្មតា

exceptionnellement *adv.* ជាពិសេស, ដោយឡែក

excès *n.m.* អតិរេកភាព, ចំនួនលើស (ឧ. l'excès d'un nombre sur un autre); ភាពហួសកំណត់ (ឧ. l'excès dans le manger ការបរិភោគហួសកំណត់) ។ *Dr.* excès de pouvoir ការលោភអំណាច ។ à l'excès *loc.adv.* ហួសប្រមាណ, ហួសពេក ។ *pl.* អំពើឃោរឃៅ (ឧ. d'inévitables excès accompagnent les révolutions); ការប្រព្រឹត្តខុសគន្លង (ឧ. les excès abrègent la vie)

excessif,ive *a.* ហួសប្រមាណ, ហួសហេតុ (ឧ. montrer une tolé-

rance excessive); ដែលធ្វើឲ្យហួសកំណត់

excessivement *adv.* ដោយហួសប្រមាណ, ដោយហួសហេតុ (ឧ. arbre excessivement âgé)

exciper (de) *v.i.Dr.* ឆ្លើយសំអាងលើ (ឧ. exciper de sa bonne foi ឆ្លើយសំអាងលើសុទ្ធចិត្តខ្លួន)

excipient *n.m.* វត្ថុផ្សំជាតិថ្នាំ (ឧ. le miel est un précieux excipient)

excise *n.f.* ពន្ធលើគ្រឿងឧបភោគបរិភោគខ្លះ (នៅប្រទេសអង់គ្លេស)

exciser *v.t.* កាត់ចេញ (ឧ. exciser une tumeur)

excision *n.f.* ការកាត់ចេញ

excitabilité *n.f.* ភាពអាចសម្រើបបាន (ឧ. l'excitabilité est une propriété des tissus vivantes)

excitable *a.* អាចសម្រើបបាន

excitant,e *a.Méd.* ដែលដាស់ឲ្យមានកម្លាំង (ឧ. le café est un excitant)។ *Fig.* ដែលធ្វើឲ្យមានតម្រេក, ដែលសម្រើប (ឧ. lecture excitante)។ *n.m.* គ្រឿងលើកកម្លាំង

excitateur,trice *a.* ដែលដាស់ឲ្យកម្រើក; ដែលសម្រើប ។ *n.m.* អ្នកញុះញង់ (ឧ. un excitateur de troubles)

excitatif,ive *a.* សម្រាប់លើកកម្លាំង (ឧ. remède excitatif)

excitation *n.f.* ការធ្វើឲ្យមានកម្លាំង; ការសម្រើប; សម្រើបនៃសព៌ាង្គកាយ ។ *Fig.* ការញុះញង់, ការជម្រុញ (ឧ. excitation à la violence)

exciter *v.t.* ដាស់ឲ្យកម្រើក (ឧ. exciter le système nerveux); ជម្រុញ (ឧ. exciter les combattants) ។ *Fig.* បណ្ដាលឲ្យកើត (ឧ. exciter la soif បណ្ដាលឲ្យស្រេក; exciter la pitié បណ្ដាលឲ្យអាណិត); ពង្យុះ, បង្ហា (ឧ. exciter un chien); សម្រើប។ **s'exciter** *v.pr.* ជម្រុញខ្លួនឯង; ស្រើប

exclamatif,ive *a.* ដែលសំដែងឧទានសព្ទ (ឧ. phrase exclamative)

exclamation *n.f.* ឧទានសព្ទ, ការលាន់មាត់ (ឧ. pousser une exclamation de joie) ។ point d'exclamation ឧទានសញ្ញា (ម. ព. point ផង)

exclamer *v.i.* លាន់មាត់ (ឧ. vrai-

ment! exclama-t-il) ។ **s'exclamer** *v.pr.* បញ្ចេញខានសព្ទ, លាន់មាត់, ស្រែកហៅ

exclure *v.t.* បណ្ដេញចេញ (ឧ. il a été exclu de son syndicat); ហាមមិនឲ្យចូល(ឧ.exclure quelqu'un d'une charge)។*Fig.* មិនចុះសម្រុងនឹង(ឧ. la bonté exclut l'avarice); បដិសេធ

exclusif,ive *a.* ដែលមិនចុះសម្រុងនឹង (ឧ.droit exclusif d'un autre); សម្រាប់តែ, ជារបស់ពិសេសនៃ(ឧ. la gourmandise est l'apanage exclusif de l'homme); ដែលមានឯកសិទ្ធិពិសេស; ដាច់ឡែក; ដែលមិនអាចចែកបាន (ឧ. l'amour exclusif par essence); លំអៀង (ឧ. homme exclusif dans ses idées)

exclusion *n.f.* អបរិយាប័ន្ន; ការដេញចេញ; ការហាមមិនឲ្យចូល; បដិសេធន៍។ à l'exclusion de *loc. pré.* លើកលែងតែ; ដោយមិនទាន់គិតដល់

exclusive *n.f.* បដិសេធន៍ (ឧ. prononcer l'exclusive contre quelqu'un)

exclusivement *adv.* ដោយអបរិយាប័ន្ន (ដោយគ្មានគិតរួមចូល)។ s'occuper exclusivement d'affaires politiques កាន់រឿងនយោបាយដោយអបរិយាប័ន្ន, កាន់តែរឿងនយោបាយ (គ្មានកាន់រឿងដទៃទៀត)

exclusivisme *n.m.* អបរិយាប័ន្ននិយម

exclusiviste *n.&a.* អ្នកអបរិយាប័ន្ននិយម

exclusivité *n.f.* ការមានដាច់មុខ (គ្មានចែកនឹងអ្នកឯណា); សិទ្ធិដាច់មុខ

excommunication *n.f.* និក្កឌ្ឍនកម្ម [និក-ក័ត-ធៈ-នៈ-]; ការដេញចេញពីសាសនា, ការដេញចេញពីពួក

excommunier *v.t.* ធ្វើនិក្កឌ្ឍនកម្ម, ដេញចេញពីសាសនា; ដេញចេញពីពួក

excoriation *n.f.* ស្នាមរលាត់សើស្បែក

excorier *v.t.* ឲ្យរលាត់សើស្បែក

excrément *n.m.* ឧច្ចារៈ, អាចម៍ ។ *Fig.* របស់លាមក, របស់ថោកទាប។ excrément de la terre កាកមនុស្ស, មនុស្សថោកទាប

excrémenteux,euse ឬ **excrémentiel,elle** ឬ **excrémentitiel,elle** *a.* នៃអាចម៍

excréter *t.v.* ធ្វើមលមោចនា [មៈ-លៈ-

រេ-ច:-ណក], បន្ទោបង់អាការ:ឥតប្រយោជន៍ពីក្នុងខ្លួន

excréteur,trice ឬ **excrétoire** *a.* មលមោចនីក [ម:-ល:-មោ-ច:-និក], សម្រាប់បន្ទោបង់អាការ:ឥតប្រយោជន៍ពីក្នុងខ្លួន។canal excréteur ព.ប. canal

excrétion *n.f.* មលមោចនា [ម:-ល:-មោ-ច:-ណក], ការបន្ទោបង់អាការ:ឥតប្រយោជន៍ពីក្នុងខ្លួន (មាន ឧច្ចារ: បស្សាវ:, ញើសជាដើម)

excroissance *n.f.* ពក (ដុំដែលដុះលើសាច់មនុស្សដូចជាប្រគ្រុយ ឬដុំដែលដុះលើសាច់ឈើ)

excursion *n.f.* ដំណើរកំសាន្ត(ឧ. excursion dans la montagne); ដំណើរត្រួតការ; ដំណើរស្វែងរក; ការចូលឆ្លក់ក្នុងប្រទេសបច្ចាមិត្ត

excursionner *v.i.* ដើរកំសាន្ត

excursionniste *n.* អ្នកដើរកំសាន្ត

excusabilité *n.f.* ភាពអាចលើកទោសបាន

excusable *a.* អាចលើកទោសបាន

excuse *n.f.* សេចក្តីដោះសា (ឧ. chercher, fournir une excuse)។ *Pl.* សេចក្តីសុំទោស (ឧ faire des excuses)

excuser *v.t.* លើកទោស(ឧ. excuser un coupable);ជាហេតុឲ្យរួចទោស (ឧ. rien ne peut vous excuser); ព្រមអត់ទោស (ឧ. je vous excuse); អត់ទោស (ឧ. excuser les fautes de la jeunesse)។ s'excuser *v.pr.* ដោះសា;សុំទោស

exéat *n.m.* អនុញ្ញាតឲ្យចេញ(ពីសាលា ឬពីមន្ទីរពេទ្យ)។*Fig.* donner son exéat à quelqu'un បណ្តេញ

exécrable *a.* គួរឲ្យរន្ធត់ (ឧ. crime exécrable); គួរឲ្យស្អប់ខ្ពើម។ *Par ext.* អាក្រក់ណាស់ (ឧ. humeur exécrable)

exécrablement *adv.* ដោយគួរឲ្យរន្ធត់; ដោយគួរឲ្យស្អប់ខ្ពើម; ដោយអាក្រក់ណាស់

exécration *n.f.* ការរន្ធត់ (ឧ. crime qui suscite l'exécration); ការស្អប់ខ្ពើម (ឧ. vouer un criminel à l'exécration), មនុស្ស ឬ វត្ថុដែលជាទីស្អប់ខ្ពើម (ឧ. cet homme est l'exécration du genre humain); បណ្តាសា (ឧ. proférer mille exécrations)

exécrer *v.t.* ខ្ពើមខ្ពត់;ស្អប់ខ្ពើម។ *Par ext.* ស្អប់,មិនចូលចិត្ត (ឧ. exécrer le tabac)

exécutable *a.* អាចប្រតិបត្តិបាន (ឧ. projet difficilement exécutable)

exécutant,e *a.* អ្នកកាន់គ្រឿងភ្លេង; អ្នកប្រតិបត្តិ

exécuter *v.t.* ប្រតិបត្តិ(ឧ. exécuter un projet); ធ្វើ (ឧ. exécuter un bas-relief);លេង(ឧ.exécuter un morceau de musique)។exécuter un condamné ប្រហារជីវិតមនុស្សទោស។ exécuter un débiteur រឹបអូសទ្រព្យឥណទាយក (ដើម្បីលក់ឡាយឡុង) ។

s'exécuter *v.pr.* សុខចិត្តធ្វើ (ឧ. s'exécuter de bonne grâce)

exécuteur,trice *a.* ប្រតិបត្តិកៈ-ត្តិកា, អ្នកប្រតិបត្តិ ។ exécuteur testamentaire ប្រតិបត្តិកៈមតកសាសន៍ (អ្នកទទួលបន្ទុកប្រតិបត្តិតាមមតកសាសន៍)។ exécuteur des hautes œuvres ពេជ្ឈឃាត

exécutif,ive *a.* ដែលប្រតិបត្តិ។pouvoir exécutif ឬ l'exécutif *n.m.* អំណាចនីតិប្រតិបត្តិ

exécution *n.f.* ការប្រតិបត្តិ(ឧ. passer un projet à l'exécution); របៀបលេង (ខាងសិល្បៈ)។ exécution capitale ឬ *abs.* exécution ការប្រហារជីវិត ។ exécution d'un débiteur ការរឹបអូសទ្រព្យឥណទាយក។ pour exécution ដើម្បីប្រតិបត្តិ

exécutoire *a.* ដែលឲ្យអំណាចប្រតិបត្តិ (ឧ. jugement exécutoire, nonobstant appel) ។ *n.m.* អំណាចប្រតិបត្តិ (ឧ. délivrer un exécutoire)

exécutoirement *adv.Dr.* ដោយអំណាចប្រតិបត្តិ

exégèse *n.f.* អត្ថកថា (ឧ. exégèse sacrée)

exégète *n.m.* អត្ថកថាចារ្យ

exégétique *a.* នៃអត្ថកថា (ឧ. note exégétique)

exemplaire *a.* អនុករណីយ, គួរយកជាគំរូ(ឧ. mener une vie exemplaire); គួរយកជាមេរៀន; គួរទុកជាការព្រមាន (ឧ. punition exem-

plaire)

exemplaire *n.m.* គំរូ (ឧ. exemplaire de vertu); ក្បាល. ក្បាប់ (របស់ជាសន្លឹក)(ឧ.un exemplaire du dictionnaire); ប្រតិលេខ

exemplairement *adv.* ជាគំរូ

exemple *n.m.* គំរូ, តម្រាប់ (ឧ. cet écolier est un exemple pour ses camarades); ឧទាហរណ៍ (ឧ. appuyer son raisonnement d'un exemple)។ montrer l'exemple ឱ្យតម្រាប់។ par exemple *loc.adv.* ឧបមាដូចជា; *Int.* យីអើ (សំដែងសេចក្ដីឆ្ងល់ខ្លាំង)។ à l'exemple de *loc. pré.* ដោយអនុកិរិយា, ដោយយកតម្រាប់តាម

exempli gratia (e.g.) *loc. lat.* ឧបមាដូចជា(ថា verbi gratia ក៏បាន)

exempt,e *a.* ដែលរួចខ្លួន (ឧ.exempt du service militaire); ដែលផុតបាក (ឧ. exempt de blâme, de souci)

exempté,e *a.&n.* អ្នកដែលរួចខ្លួន (ពីកិច្ចអ្វីមួយ)(ឧ.conscrit exempté; les exemptés de service)

exempter *v.t.* ឱ្យរួចខ្លួន (ឧ.exempter du service militaire); ឱ្យផុតបាក

exemption *n.f.* ការរួចខ្លួន(ឧ. obtenir une exemption d'impôts បានរួចពន្ធ); ប័ណ្ណលស់ (ប័ណ្ណបែកឱ្យសិស្សដែលធ្វើការល្អ សម្រាប់លស់ទណ្ឌកម្ម)

exequatur [èk-sé-koua—] *n.m. inv.* ឧកាសទាន

exerçant,e *a.* ដែលប្រតិបត្តិ, ដែលកាន់កាប់មុខរបរ (ឧ. médecins exerçants គ្រូពេទ្យប្រតិបត្តិ, គ្រូពេទ្យដែលព្យាបាលជម្ងឺ (ផ្ទុយនឹងគ្រូពេទ្យដែលមានមុខរបរដទៃទៀត)

exercé,e *a.* ថ្នឹក (ឧ. oreille exercée)

exercer *v.t.* បង្ហាត់(ឧ.exercer des soldats au maniement des armes); ហាត់ (ឧ. exercer le corps, l'esprit)។

Par ext. បំពេញ (ឧ. exercer des fonctions); កាន់កាប់, ធ្វើ(ឧ. exercer la médecine ធ្វើគ្រូពេទ្យ); ប្រើ (ឧ. exercer un

droit); សាក, ល្បង (ឧ. exercer la patience) ។ *Fin.* ដាក់ក្រោមការត្រួតត្រាតែភ្នាក់ងាររដ្ឋការ(ឧ.exercer les débitants de boissons)។ exercer un droit យកសិទ្ធិមកប្រើ ។

s'exercer *v.pr.* ហាត់ (ឧ. s'exercer à l'escrime)

exercice *n.m.*ការយកអញ្ញ; ការកាន់កាប់, ការធ្វើ (ឧ. se livrer à l'exercice de la médecine); ការហាត់ (ឧ cela ne s'apprend que par un long exercice)។exercice physique ឬ exercice ការហាត់ប្រាណ (ឧ. le défaut d'exercice nuit à la santé)។ ការបំពេញមុខរបរ,ការធ្វើ (ឧ. l'exercice de la médecine ការធ្វើពេទ្យ); ការយកិច្ច(កិច្ចការសិស្ស)។ exercice écrit ការយកិច្ចសរសេរ ។ exercice oral ការយកិច្ចភាសា។ école de plein exerciceម.ក.école។ ការប្រព្រឹត្ត(ឧ.l'exercice de toutes les vertus); ការយកមកប្រើ (ឧ. l'exercice de ses droits) ។ *Fin.* ការយបរិច្ឆេទ ។ exercice du pouvoir ការកាន់អំណាច ។ entrer en exercice ចូលធ្វើការ។ *pl.* exercices spirituels ការប្រតិបត្តិតាមសាសនា

exfoliation *n.f.* ការបេះស្បែក ។ *Bot.* ដំណើររបកសំបក(ឈើ)។ *Méd.* ការសក, ការបក (ម.ក. desquamation ផង)

exfolier *v.t.* បេះស្បែក; បិតស្តើងៗ (ឧ. exfolier une roche, des ardoises)

exhalaison *n.f.* ចំហាយឬក្លិនដែលកាយចេញ (ឧ. des exhalaisons fétides)

exhalation *n.f. Méd.* ការកាយក្លិនឬចំហាយ; ការបកស្បែក

exhaler *v.t.* កាយចំហាយឬក្លិន (ឧ. l'acide sulfhydrique exhale une odeur fétide) ។ *Fig.* បញ្ចេញសំឡេង,បន្ទំសំដី(ឧ.exhaler des plaintes);បញ្ចេញគ្នានទប់(ឧ. exhaler sa colère)។ exhaler le dernier soupir ដាច់ខ្យល់, ស្លាប់ ។ **s'exhaler** *v.pr.* កាយក្នុងអាកាស (ចំពោះក្លិនជាដើម)

exhaussement *n.m.* ការលើក, ការ

ពូន (ឧ. exhaussement d'une chaussée)

exhausser *v.t.* លើក ឬតម្លើងឲ្យខ្ពស់ (ឧ. exhausser une maison d'un étage)

exhaustif,ive *a.* ដែលឲ្យសោះដី ។ *Fig.* ចប់រឿង (ឧ. une étude exhaustive)

exhaustivement *adv.* ដោយចប់រឿង

exhaustion *n.f.* ការស្រូបខ្យល់ ឬ រំលីនធាតុឲ្យអស់ពីធុង ។ *Fig.* ការប្រើឲ្យអស់

exhérédation *n.f.* ការផ្ដាច់មត៌ក;ភាពមិនបានមត៌ក

exhéréder *v.t.* ផ្ដាច់មត៌ក (ឧ. exhéréder un parent)

exhiber *v.t.* បង្ហាញឬបញ្ចេញឲ្យឃើញ (ឧ. exhiber un passeport)។ *Dr.* បង្ហាញ(ឧ.exhiber un titre authentique)។ *Fig.* បញ្ចេញ(ឲ្យគេដឹង ឬឲ្យគេឃើញ) ។ s'exhiber *v.pr.* ចេញមុខឲ្យគេឃើញច្បាស់

exhibition *n.f.* ប្រទស្សន៍,ការបង្ហាញឬបញ្ចេញ (ឧ. exhibition d'animaux savants); ប្រជុំមនុស្ស ឬរបស់ឲ្យគេចង់មើល ។ *Dr.* ការបង្ហាញ (ជាផ្លូវច្បាប់) ។ *Fig.* ការបញ្ចេញ (ឲ្យគេដឹង ឬ ឲ្យគេឃើញ)

exhilarant,e *a.* ដែលនាំឲ្យសប្បាយ

exhortation *n.f.* ឧបទេស, ការដំរុញ ឬតឿនព្រើន

exhorter *v.t.* ឲ្យឧបទេស, ដំរុញ; តឿនព្រើន (ឧ. exhorter quelqu'un à la patience)

exhumation *n.f.* ការគាស់ចេញពីក្នុងដី។ *Fig.* ការសើរើរបស់ដែលគេបង្កប់ចោល

exhumer *v.t.* គាស់ចេញពីក្នុងដី (ឧ. exhumer un cadavre)។ *Fig.* សើរើរបស់ដែលគេបង្កប់ចោល (ឧ. exhumer de vieux documents)

exigeant,e *a.* ដែលត្រូវថែទាំច្រើន; ដែលទាមទារច្រើន; ដែលប្រិតប្រៀន (ឧ. un maître exigeant)

exigence *n.f.* ការតឹងរ៉ឹង; ការទាមទារច្រើន,សេចក្ដីប្រិតប្រៀន (ឧ.fatiguer par ses exigences); ការចាំបាច់, ការត្រូវការ (ឧ. l'exigence du temps);កាតព្វកិច្ច(ឧ.les exigences d'une profession)

exiger *v.t.* តឹងរ៉ឹង, ទារ (ឧ. exiger

le paiement d'une dette) ។ *Fig.* តម្រូវ, ត្រូវការ (ឧ. son état exige beaucoup de soins)

exigibilité *n.f.* អាវស្សការ, ភាពអាចទារបាន (ឧ. l'exigibilité d'une dette)

exigible *a.* អាចទារបាន (ឧ. l'impôt n'est exigible qu'après la répartition)

exigu,ë *a.* តូចណាស់, ចង្អៀតណាស់ (ឧ. salle exiguë); តិចណាស់ (ឧ. revenu exigu)

exiguïté *n.f.* ភាពតូច ឬ ចង្អៀត (ឧ. l'exiguïté d'un appartement); ភាពស្តួចស្តើង

exil *n.m.* និរទេស (ឧ. Victor Hugo passa dix-huit ans en exil) ។ *Par ext.* កន្លែងដែលអ្នកនិរទេសរស់នៅ ។ *Fig.* កន្លែងរងទុក្ខ ។ *Mystic.* ស្ថានកណ្ដាល (ផ្ទុយនឹងស្ថានសួគ៌)

exilé,e *a.* និរទេសក៍, ដែលត្រូវនិរទេស (ឧ. famille exilée) ។ *n.* និរទេសកជន, ជនត្រូវនិរទេស (ឧ. l'exilé partout est seul)

exiler *v.t.* ធ្វើនិរទេស, បំបរបង់ (ឧ. exiler un condamné politique) ។ *Par ext.* ដេញឲ្យទៅនៅឆ្ងាយ ។ s'exiler *v.pr.* ចាកចោលស្រុកកំណើត; ទៅនៅឆ្ងាយពីគេ

exinscrit,e *a. Math.* ចារិកក្រៅ (ឧ. triangle exinscrit)

existant,e *a.* ដែលមាននៅ, ដែលរស់នៅ; បច្ចុប្បន្ន (ឧ. les lois existantes)

existence *n.f.* អត្ថិភាព; ការកើតនៅ; ការមាននៅ (ឧ. l'existence des êtres et des choses); ជីវិត (ឧ. finir son existence); ការរស់នៅ; រយៈពេល (ឧ. gouvernement qui a trois mois d'existence); ជីវភាព, របៀបរស់នៅ (ឧ. une existence heureuse)

existentialisme *n.m.* អត្ថិភាពនិយម

existentialiste *a.* នៃអត្ថិភាពនិយម ។ *n.* អ្នកអត្ថិភាពនិយម

existentiel,elle *a.* នៃអត្ថិភាព ។ philosophie existentielle ម.ព. existentialisme

exister *v.i.* ឋិតនៅ; មាននៅ, រស់នៅ (ឧ. tous les animaux qui existent); មានមក (ឧ. le Code civil français existe depuis

plus d'un siècle); មានសារៈសំខាន់(ឧ. cet échec n'existait pas pour lui)

exode *n.m.* អពយព [អប់-យប់] (ការនាំគ្រួសារ ឬ លើកគ្នាទាំងពួក ទាំងក្រុម ចេញចោលកន្លែងដែលធ្លាប់នៅ) (ឧ. Moïse conduisit l'exode des Hébreux; l'exode vers la ville); ការចេញទៅទាំងហ្វូង ។ exode des capitaux អពយព នៃមូលធន (ដំណើរនៃមូលធនចេញទៅបរទេស)

exoderme *n.m.* ពហិត៌ច [—តាប់]

exonder (s') *v.pr.* គោកវិញ, លែងលិចទឹក (ឧ. terrains exondés)

exonération *n.f.* ការលើកលែង;ការលស់-លាពន្ធ (ឧ. exonération d'une taxe)

exophtalmie *n.f.* ដំណើរលៀនភ្នែក (ចេញពីចក្ខុាយតនៈ)

exophtalmique *a.* នៃដំណើរលៀនភ្នែក (ចេញពីចក្ខុាយតនៈ)

exorable *a.* អាចធ្វើឲ្យទន់ចិត្តបាន

exorbitance *n.m.* ភាពហួសប្រមាណ ឬហួសកំណត់ (ឧ. l'exorbitance des prétentions d'un vendeur); របស់ឬអំពើហួសហេតុ (ឧ. les exorbitances des partis vainqueurs provoquent des réactions)

exorbitant,e *a.* ហួសប្រមាណ, ហួសកំណត់ (ឧ. demander des prix exorbitants); ខុសទំនង

exorbité,e លៀន (ចំពោះភ្នែកដែលដូចជាលៀនចេញពីចក្ខុាយតនៈ)

exorcisation *n.f.* ការបណ្ដេញខ្មោចដោយមន្តគាថា

exorciser *v.t.* បណ្ដេញខ្មោចដោយមន្តគាថា។ *Fig.* តៀនក្រើនដោយម៉ឺងម៉ាត់

exorciseur *n.m.* អ្នកបណ្ដេញខ្មោច

exorcisme *n.m.* ពិធី ឬ មន្តគាថាបណ្ដេញខ្មោច

exorciste *n.m.* អ្នកបណ្ដេញខ្មោច

exorde *n.m.* ភាគដើមនៃសុន្ទរកថា ។ *Par ext.* ការចាប់ផ្ដើម

exosmose *n.f.* *Phys.* អាស្រ័ណចេញ (ព.ផ. endosmose ។ ម.ព. osmose ផង)

exothermique *a.* ដែលបញ្ចេញកំដៅ (ព.ផ. endothermique)

exotique *a.* ពីប្រទេសក្រៅ (ឧ. plantes exotiques); នៃប្រទេសឆ្ងាយ

(ឧ. la littérature exotique)

exotisme *n.m.* លក្ខណៈមកពីប្រទេសក្រៅ ឬ មកពីប្រទេសឆ្ងាយ; ការចូលចិត្តរបស់មកពីប្រទេសក្រៅ

expansibilité *n.f.* វិត្ថារិយភាព(លក្ខណៈរីក ឬ រីក)

expansible *a.* វិត្ថារិយ, អាចរីក ឬពង្រីកបាន

expansif,ive *a.* អាចរីកឡើងបាន (ឧ. ciment expansif)។ *Fig.* រួសរាយខ្លាំង (ឧ. âme expansive)

expansion *n.f.* វិត្ថារកម្ម, ការរីកឡើង (ឧ. l'expansion des gaz); វត្ថុរីកឬចំរើនឡើង ។ *Fig.* ការរីក; ការពង្រីក (ឧ. expansion coloniale) ។ *Fig.* ភាពរួសរាយ (ឧ. expansion du cœur)

ក្លែងក្លាយ (ឧ.fausse monnaie); ប្រកបដោយអសុទ្ធចិត្ត (ឧ. fausse promesse); បញ្ឆោត (ឧ. fausse porte); ខុស (ឧ. calcul faux); ឈ្លើយ (ឧ. voix fausse); ដែលលាក់ពុត(ឧ. il est faux comme un jeton)។ fausse couche ធំ-ពោះរលូតកូន(យ. avortement)។ faire faux bond មិនកាន់ពាក្យសច្ចៈ, មិនប្រព្រឹត្តតាមកិច្ចសន្យា ។

adv. ដោយខុស, ដោយឈ្លើយ (ឧ. jouer, chanter faux)

faux *n.m.* អ្វីៗដែលមិនពិត (ឧ. distinguer le faux du vrai); ការក្លែង (ឧ. le faux en matière civile et commerciale est un crime) ។ s'inscrire en faux ប្ដឹងថាខុស ឬ ក្លែង; ឆ្លើយបដិសេធ ។ à faux *loc. adv.* ដោយខុស, ដោយអយុត្តិធម៌

faux-bourdon *n.m.Entom.* ប.ព. bourdon

faux-fuyant *n.m.* ផ្លូវសំរាប់គេច, បរាជ័យ, ល្បិចដោះខ្លួន (*pl.* des faux-fuyants)

faux-monnayeur *n.m.* អ្នកក្លែងរូបិយវត្ថុ(*pl.* des faux-monnayeurs)

faux-semblant *n.m.* ឧបាយគ្រាន់តែបញ្ឆោត (*pl.* des faux-semblants)

faveur *n.f.* អនុគ្រោះ (ឧ.implorer la faveur de quelqu'un); សេចក្ដីគាប់ (ឧ. sa faveur diminue); បន្ទះសំពត់សូត្រតូច ។ *pl.* ការឲ្យដៃ (ការសំដែងស្នេហារបស់ស្ត្រីទៅរកប្រុស) ។ en faveur de *loc. pré.* ដោយយល់ដល់, ជាគុណប្រយោជន៍ដល់, ជាកម្រៃដល់ ។ à la faveur de *loc.pré.* ដោយសារ, អាស្រ័យ

favorable *a.* ដែលអនុគ្រោះ; ដែលគួរ (ឱកាស) (ឧ. occasion favorable); ដែលសំដែងសេចក្ដីអនុគ្រោះ(ឧ. regard favorable)

favorablement *adv.* ដោយអនុគ្រោះ

favori,ite *a.* សំណប់ (ឧ. livre favori)។ *n.* មនុស្សសំណប់។ *n.m.pl.* អមគាង(ពុកចង្កាដែលដុះត្រង់ថ្ពាល់) ។ *n.f.* មហេសីសំណប់

favoriser *v.t.* អនុគ្រោះ; យោគយល់; ជួយ(ឧ.favoriser le commer-

ce; l'obscurité favorisa sa fuite)

favoritisme *n.m.* បក្ខនុគ្រោះ, អនុគ្រោះនិយម

f.c.é. *n.f.* (ពាក្យបំព្រួញនៃ force contre-électromotrice ពលប្រតិ-អគ្គិសនីចលករ)

fébrifuge *a.* ដែលធ្វើឲ្យបាត់គ្រុន ។ *n.m.* ថ្នាំគ្រុន (ឧ.la quinine est un fébrifuge)

fébrile *a.* នៃរោគគ្រុន (ឧ. mouvements fébriles) ។ *Fig.* ញោក់ញ័រ, ដែលច្រាស់ច្រាល់ (ឧ. impatience fébrile; se montrer fébrile)

fabrilement *adv.* ដោយញោក់ញ័រ, ដោយច្រាស់ច្រាល់

fébrilité *n.f.* ភាពញោក់ញ័រឬច្រាស់-ច្រាល់

fécal,e,aux *a.* នៃលាមកមនុស្ស ។ matières fécales លាមកមនុស្ស

fécer *v.t.* កជាកករ

fèces *n.f.pl.Chim.* កករ។*Physiol.* លាមកមនុស្ស(លាមករឹង)

fécond,e *a.* សម្រាប់តពូជ។ *Par ext.* ពហុផល (ឧ. terre féconde ដីពហុផល (ដីមានដីជាតិល្អអោយផលដំណាំបានច្រើន); écrivain fécond អ្នកនិពន្ធពហុផល (អ្នកសរសេរសៀវភៅបានច្រើន);សម្បូណ៌(ឧ.journée féconde en événements)

fécondant,e *a.* ដែលធ្វើឲ្យមានផល

fécondateur,trice *a.* ពហុផលករ, ដែលធ្វើឲ្យមានផល

fécondation *n.f.* ពហុផលការ, ការធ្វើឲ្យមានផល; ផល

féconder *v.t.* ធ្វើឲ្យមានផល (ឧ. les pluies fécondent la terre)

fécondité *n.f.* ពហុផលភាព, ភាពបរិបូណ៌ដោយផល (ឧ. la fécondité d'un terrain; la fécondité d'un auteur)

fécule *n.f.* ម្សៅធញ្ញជាតិឬឫសឈើ

féculence *n.f.* ភាពវត្ថុដែលមានម្សៅ; ភាពវត្ថុរាវដែលមានកករ

féculent,e *a.* ដែលមានម្សៅ (ឧ. la pomme de terre est féculente); ខាប់;ដែលមានកករ ។ *n.m.* បន្លែជាតិម្សៅ

féculer *v.t.* កិនជាម្សៅ

féculerie *n.f.* កន្លែងធ្វើម្សៅ

féculeux,euse *a.* ដែលមានម្សៅ

fédéral,e,aux *a.* នៃសហព័ន្ធ

fédéraliser *v.t.* បង្កបង្កើតសហព័ន្ធ

fédéralisme *n.m.* សហព័ន្ធនិយម

fédéraliste *a.* នៃសហព័ន្ធនិយម ។ *n.* អ្នកសហព័ន្ធនិយម

fédératif,ive *a.* ដែលបង្កបង្កើតជាសហព័ន្ធ (ឧ. république fédérative)

fédération *n.f.* សហព័ន្ធ(ឧ.la Suisse et les Etats-Unis d'Amérique sont des fédérations; fédération cambodgienne de boxe) ។ fédération nationale des coopératives de consommation ប្រជុំក្រុមសហករណ៍ជាតិ (ឬ សហព័ន្ធជាតិនៃសហករណ៍) ខាងឧបភោគបរិភោគ

fédéré,e *a.* ដែលចូលក្នុងសហពន្ធ

fédérer *v.t.* បង្កើតសហព័ន្ធ;ចងសហព័ន្ធ

fée *n.f.* ទេពធីតា ។ conte de fées រឿងទេពធីតា(រឿងព្រេងដែលមានទេព-ធីតា); រឿងប្រឌិត ។ travail ឬ ouvrage de fée ការងារឥតខ្ចោះ ។ pays des fées ប្រទេសអស្ចារ្យ (មានតែក្នុងមនោគតិ) ។ ទេពធីតា (ស្រីមានរូបឆើតបញ្ញាច្រើនទាំងមានចិត្តល្អ)។ vieille fée ស្ត្រីញ៉េញ៉ើវ

féerie *n.f.* អានុភាពនៃទេពធីតា ; រឿងដ៏ល្អអស្ចារ្យ (ឧ. paysage de féerie)

féerique *a.* នៃអានុភាពរបស់ទេពធីតា; ល្អអស្ចារ្យ (ឧ. spectacle féerique)

feignant,e ឬ **faignant,e** *a.&n.* *Pop.* កម្ជិល

feindre *v.t.* ធ្វើពុត,ធ្វើពើ(ឧ. feindre la colère)។ feindre de ធ្វើជា។ *v.i.* លាក់ពុត, កុហក (ឧ. habile dans l'art de feindre) ; ខ្វក បន្តិច (សេះ)

feinte *n.f.* ពុត, កលការពើ, ការលាក់-លៀម (ឧ.parler sans feinte)។ *Sports* ស្ទៀតបញ្ឆោត ។ *Fam.* ឧបាយកល

feinter *v.i.* បញ្ឆោត(ស្ទៀតគុន)។ *v.t.* *Fam.* បញ្ឆោត

feldspath *n.m.* ក្រួលស្ប៉ាធ

feldspathique *a.* ដែលមានក្រួលស្ប៉ាធ

fêle ឬ **felle** *n.f.* បំពង់ផ្លុំកែវ

fêlé,e *a* ប្រេះ, ស្រាំ ។ *Fig.&Fam.* avoir le cerveau fêlé លេលា, ពក្លីពក្លើ

fêler *v.t.* ធ្វើឲ្យស្រាំ (ឧ. fêler un verre)

félicitation *n.f.* មោទនាការ [-ម៉ះ-នា-], ការសរសើរ; ពាក្យសរសើរ (ឧ. recevoir des félicitations)

félicité *n.f.* បរមសុខ

féliciter *v.t.* សរសើរ។ se féliciter *v.pr.* សរសើរខ្លួនឯង

félidés *n.m. pl.* វិឡារសាទិសសត្វ (សន្តានសត្វស៊ីសាច់ដូចឆ្មា)

félin,e *a.* នៃសត្វឆ្មា(ឧ. la souplesse féline); ដែលមានពុតត្បុត ។ *Fig.* ទន់ភ្លន់(ដូចសត្វឆ្មា) (ឧ. une allure toute féline)។ *n.m.* មំសាហារសត្វពួកឆ្មា

félon,onne *a.* វៀចវេរ, ដែលក្បត់ (ឧ. vassal félon)

félonie *n.f.* ការក្បត់

fêlure *n.f.* ស្នាមស្រាំ (ឧ. la fêlure d'une vitre)។*Fig.* ការឃ្លៀងចិត្ត (ឧ. trop de ménages ont une fêlure); ភាពលេលា (ឧ. ...Grâce au ciel, ma tête est sans fêlure (La Fontaine)

f.é.m. (ពាក្យបំព្រួញនៃ force électromotrice ម.ព. électromoteur)

femelle *n.f.* សត្វញី; ដំណាប់លកញី។ *a.* ញី

féminéité *n.f.* ម.ព. féminité

féminin,e *a.* នៃស្ត្រី(ឧ. grâce féminine); ស្ត្រី (ដូចស្ត្រី) (ឧ. voix féminine)។ *n.m.Gram.* ឥត្ថីលិង្គ

féminisation *n.f.* ដំណើរក្លាយជាស្ត្រី

féminiser *v.t.* ឲ្យមានលក្ខណៈជាស្ត្រី; ធ្វើឲ្យក្លាយជាស្ត្រី; ធ្វើឲ្យទន់ឬឲ្យខ្សោយដូចស្ត្រី; ដាក់ពាក្យជាឥត្ថីលិង្គ

féminisme *n.m.* ស្ត្រីនិយម, ការនិយមដំកើងឋានៈស្ត្រី

féministe *n.&a.* អ្នកស្ត្រីនិយម

féminité *n.f.* លក្ខណៈស្ត្រី; ស្ត្រីភាព

femme *n.f.* ស្រី; ប្រពន្ធ; ស្រីមានប្ដី ឬធ្លាប់មានប្ដីហើយ; ស្ត្រីពេញរូបរាង (ឧ. la voilà bientôt femme)។

Loc. div. femme de chambre ស្ត្រីអ្នកបម្រើម្ចាស់ស្ត្រី ។ femme de charge ស្ត្រីបម្រើជាក់ការក្នុងផ្ទះ ។ femme de lettres ស្ត្រីអ្នកនិពន្ធ។ maîtresse femme ស្ត្រីអ្នកប៉ិនជាក់ការ ។ femme publique ស្ត្រីពេស្យា ។ femme de mauvaise vie ឬ femme perdue ស្ត្រីខូច (ស្ត្រីប្រព្រឹត្តអនាចារ) ។

bonne femme ស្ត្រីចិត្តល្អ; ស្ត្រីមិនភិយឫក; ស្ត្រីចំណាស់; ស្ត្រីសាមញ្ញ។ conte de bonne femme រឿងមិនសមហេតុផល ។ remède de bonne femme ថ្នាំអ្នកស្រុក (ថ្នាំដែលអ្នកស្រុកឬយាយតាស់ៗធ្លាប់ប្រើ)។ prendre femme យកប្រពន្ធ ។

Prov. & loc.prov. qui femme a, guerre a ឲ្យតែមានគ្រួសារមានទុក្ខ ។ le diable bat sa femme et marie sa fille ម.ព. diable (*loc. div.*) ។ ce que femme veut, Dieu le veut ម.ព. dieu (*prov.*) ។ prendre maison faite et femme à faire ម.ព. faire

femmelette *n.f.* ស្ត្រីមាឌតូច ។*Fig.* មនុស្សញី (ខ្សោយ,មិនស្វាហាប់)

fémoral,e,aux *a.* នៃឆ្អឹងភ្លៅ (ឧ. artère fémorale)

fémur *n.m.* ឆ្អឹងភ្លៅ

fenaison *n.f.* ការច្រូតស្មៅទុកធ្វើចំណីសត្វ; រដូវច្រូតស្មៅ

fendage *n.m.* ការពុះ

fendant *n.m.* ការកាប់នឹងដាវ។*n.&a.m.* faire le fendant ធ្វើឫកឡឹក

fendeur *n.m.* អ្នកពុះ

fendillé,e *a.* ប្រេះ (ឧ. émail fendillé)

fendillement *n.m.* ការធ្វើឲ្យប្រេះ; ដំណើរប្រេះ

fendiller *v.t.* ធ្វើឲ្យប្រេះ ។ se fendiller *v.pr.* ប្រេះ, ឆា

fendoir *n.m.* ប្រដាប់ពុះ

fendre *v.t.* ពុះ(ឧ.fendre du bois); ធ្វើឲ្យបែកក្រហែង(ឧ.la sécheresse fend la terre)។fendre le cœur ពុះបេះដូង,ធ្វើឲ្យកើតទុក្ខខ្លាំង ។ fendre la tête រំខានដោយស្បែខ្លាំង ។ geler à pierre fendre កកខ្លាំង ។ fendre l'air ឆ្លងកាត់យ៉ាងលឿន ។ fendre la foule ជ្រែកហ្វូងមនុស្ស ។ se fendre *v.pr.* បែករបេះ។ *Pop.* ឲ្យ; ចេញប្រាក់

fenestré,e *a.* ដែលបែកក្រហែង

fenêtrage ឬ**fenestrage** *n.m.* បង្អួចទាំងអស់ក្នុងផ្ទះមួយ

fenêtre *n.f.* បង្អួច ។ fausse fenêtre បង្អួចបញ្ឆោត ។ *Fig.* jeter son argent par les fenêtres ចាយប្រាក់ខ្ជះខ្ជាយ

fenêtrer *v.t.* ចោះបង្អួច; ចោះប្រហោង

ឡខ្យល់ក្ងួល

fenil *n.m.* ឬ **fenière** *n.f.* ជង្រុកដាក់ស្មៅ

fenouil *n.m.* ជីរអង្កាម

fente *n.f.* ប្រហោង,ក្រហែង

féodal,e,aux *a.* នៃសក្តិភូមិ; នៃច្បាប់សក្តិភូមិ

féodalement *adv.* តាមច្បាប់សក្តិភូមិ

féodalisme *n.m.* សក្តិភូមិនិយម [ស័ក-ក្តិ—]

féodalité *n.f.* សក្តិភូមិ [ស័ក-ក្តិ-] (ទំនៀមទំលាប់និងច្បាប់ក្នុងយុគកណ្តាល)

fer *n.m.* ដែក។ fer aigre ដែកស្រួយ។ fer battu ដែកបញ្ចាន់។ fer brut ដែកក្រពើ។ fer doux ដែកទន់(អាចដំគ្រដាក់បាន) ។ fer galvanisé ដែកពាសស័ង្កសី ។ ផ្លែញ្ញក - លំពែង ។ល។; សស្ត្រ, ដាវ (ឧ. croiser le fer) ។ *Poét.* អាវុធ (ឧ. un fer homicide)។ ដែកក្រចកសេះ; ប្រដាប់ធ្វើអំពីដែក ។ fer à friser ដែកអ៊ុតសក់។ fer à repasser ឆ្នាំងអ៊ុត។ fer à souder ដែកក្បាលមាន់ (សម្រាប់ផ្សារ) ។ coup de fer ការអ៊ុតឡើងវិញត្រួសៗ ។ tomber les quatre fers en l'air ដួលផ្ងារពោះ (សេះ); *par ext.* ដួលបះជើងទ្រោង ។

Fig. de fer មាំ (ដូចដែក) (ឧ. corps de fer); រឹង (ចចេស) (ឧ. tête de fer); តឹងរ៉ឹង (ឧ.discipline de fer) ។ sceptre de fer រជ្ជកាលតឹងរ៉ឹង (កាន់អំណាចផ្តាច់ការ) ។ âge de fer កលិយុគ, យុគដែលមនុស្សប្រើឧបករណ៍ធ្វើអំពីដែក (ម.ព. âge ផង) ។

pl. ច្រវាក់, ខ្នោះ (ឧ. avoir les fers aux pieds) ។ *Fig.* ការឃុំឃាំង ; ទាសភាព (ឧ. gémir dans les fers) ។ jeter dans les fers ដាក់គុក

fer-blanc *n.m. Ind.* ដែកស៊ីវិឡាត

ferblanterie *n.f.* របរ-ជំនួញ ឬ ហៀបលក់គ្រឿងដែកស៊ីវិឡាត

ferblantier *n.&a.* អ្នកធ្វើ ឬ អ្នកលក់គ្រឿងដែកស៊ីវិឡាត

férial,e,aux *a.* នៃថ្ងៃឈប់

férie *n.f.* ថ្ងៃឈប់ (តាមទំនៀមទម្លាប់រ៉ូម៉ាំង)

férié,e *a.* jour férié ថ្ងៃឈប់ (ឧ. toute échéance tombant un jour férié est reporté au

lendemain)

férir *v.t.* វាយ ។ sans coup férir ដោយមិនបាច់ប្រយុទ្ធ; *au fig.* ដោយងាយ

ferler *v.t. Mar.* រុំក្ដោងផ្ទាប់នឹងដង

fermage *n.m.* ការប្រវាស់ដី ; ពន្ធប្រវាស់ដី (ឧ. toucher ses fermages)

fermail *n.m.* ឡេវទំពក់; ក្បាលខ្សែក្រវាត់ (ឧ. des fermaux en argent)

fermant,e *a.* ដែលបិទខ្លួនឯង

ferme *a.* រឹង, មាំ (ឧ. terrain ferme); មិនញ័រ, មិនរន្ធត់ (ឧ. être ferme sur ses jambes); ណែន, ហាប់ (ឧ. chair ferme) ។ terre ferme ដីគោក, ទ្វីប ។ *Fig.* មិនស្ទាក់ (ឧ. ton ferme); នឹង (មិនប្រែប្រួល); ខ្ជាប់ខ្ជួន (ឧ. ferme dans ses résolutions); ប្រាកដ (ឧ. achat, vente ferme); នឹង (ចំពោះតម្លៃដែលមិនឡើងចុះ) (ឧ. les pétroles sont fermes); ម៉ឺងម៉ាត់ (ឧ. soyez fermes avec vos enfants) ។ *adv.* ដោយមិនស្ទាក់ (ឧ. parler ferme); ច្រើន (ឧ. travailler ferme)

ferme *n.f.* កិច្ចសន្យាប្រវាស់ដី (ឧ. prendre une propriété à ferme); ដីចំការដែលប្រវាស់; កសិដ្ឋាន ។ ferme de colonisation កសិដ្ឋានឧបនិវេសន៍ ។ ភាគី (ឧ. la ferme du sel)

fermé,e *a.* ដែលចូលមិនចុះ, ដែលបិទជិត (ឧ. fermé à l'amour; société fermée)

fermement *adv.* យ៉ាងម៉ឺងម៉ាត់, យ៉ាងប្រាកដ (ឧ. croire, s'appuyer fermement)

ferment *n.m.* មេដំបែ ។ *Fig.* មេគំនុំ (ឧ. ferment de discorde)

fermentable ឬ **fermentescible** *a.* អាចឡើងឬក្លាយបាន (ដោយអំណាចមេ)

fermentation *n.f.* កិណ្វកម្ម [កិន-វ៉ែន-], ដំណើរឡើងឬក្លាយ (ដោយអំណាចមេ) (ឧ. fermentation alcoolique ដំណើរឡើងស្រា (ដំណើរទឹកដមផ្អែមក្លាយជាស្រា); fermentation acétique ដំណើរឡើងទឹកខ្មេះ (ដំណើរស្រាក្លាយជាទឹកខ្មេះ); fermentation lactique ដំណើរទឹកដោះកកជាដុំ) ។ *Fig.* ការរំជើបរំជួល

ក្នុងចិត្ត

fermenter *v.i.* ឡើងឫក្ដាយ (ដោយកំណកមេ) (ឧ. le moût de raisin fermente dans la cuve)។ *Fig.* រំជើបរំជួល (ឧ. les esprits fermentent)

fermentescible *a* ប.ក. fermentable

fermer *v.t.* រាំង,បិទ(ឧ.fermer une porte; fermer une chambre); រាំងរបង (ឧ. fermer un jardin)។ *Par ext.* បិទ, បិទច្រកចូល(ឧ.fermer les frontières); បិទ, ខ្ទប់ (ឧ. fermer un sac)។ fermer la marche ដើរក្រោយគេបង្អស់។ fermer les yeux ធ្មេចភ្នែក,ដេកលក់; *au fig.* ធ្មេចភ្នែក,ធ្វើជាមិនឃើញ(ឧ. fermer les yeux sur les fautes de quelqu'un)។ fermer la bouche à quelqu'un បំបិទមាត់, មិនឲ្យហើបមាត់, មិនឲ្យនិយាយ។ fermer boutique បិទហាង ; បញ្ឈប់របរជំនួញ ។ fermer sa porte មិនទទួល ។

v.i. cette porte ferme mal ទ្វារនេះបិទមិនជិត

fermeté *n.f.* ភាពរឹង, ភាពមាំ (ឧ. la fermeté d'un pont) ។ *Fig.* សេចក្ដីម៉ឺងម៉ាត់ (ឧ. fermeté d'un jugement; répondre avec fermeté); សេចក្ដីតឹងរ៉ឹង(ឧ.montrer de la fermeté); សេចក្ដីខ្ជាប់ខ្ជួន; កម្លាំងចិត្ត

fermeture *n.f.* ប្រដាប់សម្រាប់បិទ(ឧ. fermeture automatique) ; ការបិទ;ពេលបិទ(ឧ.la fermeture des théâtres)

fermier,ère *n.* ចៅកៀ; អ្នកទទួលជួលដី; មេសែរៀន (ទេសាទ)

fermoir *n.m.* ក្ដៀបបិទសៀវភៅ ឬ កាបូបប្រាក់

féroce *a.* សាហាវ,កាច(ឧ.le tigre est féroce; homme féroce; regards féroces)

férocement *adv.* យ៉ាងសាហាវ,យ៉ាងកាច

férocité *n.f.* ភាពសាហាវ(ឧ.la férocité d'un tigre); ភាពគ្មានអារ្យធម៌, អនារ្យធម៌, អំពើឃោរឃៅ (ឧ. réprimer une révolte avec férocité)

ferrade *n.f.* ការបោះត្រាដែកក្ដៅ (លើស្បែកគោ)

ferrage *n.m.* ការពាសដែក; ការចងចង្កុំដែក; ការបោះក្រចកជើងសត្វ

ferraillage *n.m.Constr.* ដែកទាំងអស់ប្រើក្នុងសំណង់មួយ

ferraille *n.f.* កំទេចដែក, ដែកចាស់

ferraillement *n.m.* ការប្រកាប់ ឬ ប្រចាក់គ្នា (ដោយដាវ)

ferrailler *v.i.* ប្រកាប់ ឬ ប្រចាក់គ្នា (ដោយដាវ) ។ *Escr.* លេងគុនដាវដោយឆ្លង ។ *Constr.* ដាក់ឆ្អឹងដែក (បេតុងអារមេ)។ *Fig.&fam.* ប្រកាប់ប្រចាក់គ្នា (ឈ្លោះគ្នាខ្លាំង)

ferrailleur *n.m.* ឈ្មួញកំទេចដែក ។ *Constr.* ជាងចងឆ្អឹងដែក (បេតុង-អារមេ)។ *Fam.* អ្នកចូលចិត្តប្រកាប់ឬប្រចាក់គ្នា (ដោយដាវ) ។ *Fam.* អ្នកហៃប្រឈ្លោះ

ferré,e *a.* ដែលពាសដែក, ដែលចងចង្កុំដែក។ chemin ferré ផ្លូវក្រាលថ្ម។ voie ferrée ផ្លូវអយស្ម័យយាន ។ *Fig. & fam.* être ferrée sur une matière ចេះឬដឹងការជ្រៅជ្រះ

ferrement *n.m.* របស់ធ្វើអំពីដែក ឬ ដែកសព (ឧ. les ferrements d'un coffre)

ferrer *v.t.* បោះក្រចកជើងសេះ ; ពាសដែក;ចងចង្កុំដែក។ ferrer à glace បោះក្រចកមានក្រចាប់ (កុំឲ្យរអិលនឹងទឹកកក) ។ ferrer un poisson វាត់សន្ទូចឲ្យជាប់មាត់ត្រី

ferret *n.m.* ដែកបង្ហាំចុងខ្សែស្បែកជើង ឬចុងខ្សែអ្វីផ្សេងៗ

ferretier *n.m.* ញញួរដំដែកក្រចកសេះ (ថា ferratier ក៏បាន)

ferreur *n.&a.m.* ជាងបោះក្រចកជើងសេះ; ជាងបង្ហាំដែកចុងខ្សែ

ferreux *a.m.* ដែលមានជាតិដែក (ឧ. minerais ferreux)

ferrière *n.f.* ថង់ដាក់ប្រដាប់ជាងបោះក្រចកសេះ ឬ ជាងសោ

ferrifère *a.* ដែលមានដែក (រណ្ដៅរ៉ែ)

ferrite *v.t.* រ៉ែដែកមានជាតិមេដែកច្រើន

ferro-alliage *n.m.* លោហធាតុផ្សំមានបញ្ចុះដែក (*pl.* des ferro-alliages)

ferromagnétique *a.* អយស្ម័យចុម្ពក

ferromagnétisme *n.m.* អយស្ម័យ-ចុម្ពកពល

ferronnerie *n.f.* កន្លែងធ្វើឬលក់គ្រឿងដែកធំៗ; គ្រឿងដែកធំៗក្នុងសំណង់

ferronnier,ère *n.* អ្នកធ្វើឬលក់គ្រឿងដែកធំៗ

ferroviaire *a.* នៃអយស្ម័យយាន (ឧ. trafic ferroviaire)

ferrugineux,euse *a.* ដែលមានដែក (ឧ. eau minérale ferrugineuse)។*n.m.* ឱសថមានផ្សំជាតិដែក

ferrure *n.f.* គ្រឿងតុបតែងធ្វើអំពីដែក; ការឬរបៀបដោះក្រចកជើងសេះ

ferry-boat *n.m.* នាវាចំឡងអយស្ម័យយាន (*pl.* des ferry-boats)

fertile *a.* ដែលមានជីជាតិ, ដែលមានផល ។ *Fig.* សម្បូណ៌ (ឧ. année fertile en événements) ។ esprit fertile បញ្ញាសម្បូណ៌ខាងបនោគតិ (ប៉ិនប្រសប់ខាងប្រឌិត)

fertilement *adv.* ដោយមានជីជាតិ; ដោយមានផល

fertilisable *a.* អាចធ្វើឲ្យមានផលបាន

fertilisant,e *a.* ដែលធ្វើឲ្យមានផល

fertilisation *n.f.* ការធ្វើឲ្យមានផល

fertiliser *v.t.* ធ្វើឲ្យមានផល (ឧ. les engrais fertilisent la terre)

fertiliseur *n.m.* វត្ថុដែលធ្វើឲ្យមានផល

fertilité *v.i.* ភាពមានជីជាតិ; ភាពមានផល

féru,e *a. Fig.* féru de ជាប់នឹង, ដែលជាប់ចិត្តទៅលើ (ឧ. féru de sciences)

férule *n.f.* រំពាត់ ។ *Fig.* អំណាច (ឧ. être sous la férule de quelqu'un)

fervent,e *a.* ក្លៀវក្លា, ដែលប្រឹងប្រែង (ឧ. prière fervente; disciple fervent)

ferveur *n.f.* ពលសទ្ធា (សទ្ធាមុះមុត); សេចក្ដីក្លៀវក្លា; សេចក្ដីប្រឹងប្រែង (ឧ. prier avec ferveur; aimer avec ferveur)

fesse *n.f.* កំពឹងគូទ, ថ្គាល់ក្ដិត, គូទ, ត្រគាក

fessée *n.f.* ការវាយគូទ

fesse-mathieu *n.m.* អ្នកយកការប្រាក់ហួសប្រមាណ; អ្នកកំណាញ់ (*pl.* des fesse-mathieux)

fesser *v.t.* វាយគូទ

fesseur,euse *n.* អ្នកវាយគូទ

fessier,ère *a.* នៃគូទ (ឧ. les muscles fessiers)។ *n.m.* ថ្គាល់ក្ដិត, កំប៉េះគូទ

fessu,e *a.* ដែលមានកំពឹងគូទធំ

festin *n.m.* ការជប់លៀង; អាហារពោរពាស

festiner *v.t.* លៀង ។ *v.i.* ជប់លៀង; លេងសប្បាយ

festival *n.m.* មហោស្រពធំ (*pl.* des festivals)

festivité *n.f.* មហោស្រព, បុណ្យ

festoiement *n.m.* ការជប់លៀង

feston *n.m.* កម្រង ឬ សំណុំផ្កា-ស្លឹកនឹងមែក; របៀបដាក់ជារូបមែក-ស្លឹកនឹងផ្កា

festonner *v.t.* តែងលំអដោយមែក-ស្លឹកនឹងផ្កា; ដាក់ជារូបមែក-ស្លឹកនឹងផ្កា

festoyer *v.t.* ទទួលដោយរាក់ទាក់ (ឧ. festoyer ses amis) ។ *v.i.* ជប់លៀង (ឧ. aimer à festoyer)

fétard *n.m. Fam.* អ្នកគិតតែខាងសប្បាយ

fête *n.f.* បុណ្យ; មហោស្រព; ការសប្បាយ។ fête nationale បុណ្យជាតិ ។ fête royale ព្រះរាជពិធី ។ faire fête à quelqu'un ទទួលដោយរាក់ទាក់។ faire la fête លេងសប្បាយ។ être à la fête សប្បាយចិត្តខ្លាំងណាស់

fêter *v.t.* ឈប់បុណ្យ,ធ្វើបុណ្យ។ *Fig.* fêter quelqu'un ទទួលដោយរាក់ទាក់

fétiche *n.m.* សារណវត្ថុ។ *Par ext.* វត្ថុដែលនាំឲ្យចម្រុងចម្រើន

féticheur *n.m.* គ្រូខាងសារណវត្ថុ

fétichisme *n.m.* សារណវត្ថុនិយម

fétichiste *a.* នៃសារណវត្ថុនិយម ។ *a.* & *n.* អ្នកសារណវត្ថុនិយម

fétide *a.* ដែលមានក្លិនអសោចខ្លាំង,ស្អុយ

fétidité *n.f.* ភាពស្អុយ; សំអុយ

fétu *n.m.* ទងចំបើង។ *Fig.* វត្ថុគ្មានតម្លៃ។ cela ne vaut pas un fétu របស់នោះគ្មានតម្លៃ។

feu *n.m.* អគ្គី, ភ្លើង (ឧ. le feu du fourneau n'est pas assez vif; c'est l'heure de l'extinction des feux); អគ្គីភ័យ (ឧ. les pompiers se sont enfin rendus maîtres du feu) ។
Par ext. ឧស្មាគារ [អ៊ុស-ម៉ៈ-គា] (ឧ. logement qui n'a pas de chambre à feu)។ le coin du feu កៀនឧស្មាគារ (សម្រាប់អាំងភ្លើង); គ្រួសារ ។
Par anal. រូបធាតុភូតមានពន្លឺ; ផ្កាយ (ឧ. les feux du firmament)។ *Par ext.* ខ្នះភ្លើង, ខ្នះពន្លឺ, ពន្លឺភ្នែក (ឧ. les feux d'un diamant; le feu des regards) ;

ការបាញ់កាំភ្លើង. គ្រាប់កាំភ្លើង (ដែលបាញ់) (ឧ. faire feu; tel qui affronte le feu du canon hésite à traverser un fleuve à la nage); ការរលាក; ក៏ដៅក្នុងខ្លួន (ឧ. avoir la bouche en feu; le feu de la fièvre); សេខ្លាំងនៃស្រា (ឧ. Rhum qui a du feu)។

Poét. កំដៅខ្លាំង (ឧ. les feux de l'été)

Fig. សេចក្ដីខ្លាំងក្លា (ឧ. le feu de la colère, de l'imagination; travailler avec feu ធ្វើការក្ដៅដូចភ្លើង) ; ការផុសគំនិត ឬ ប្រាជ្ញា (ឧ. le feu du génie); ការច្រួលច្របល់, ការបះបោរ (ឧ. toute l'Europe est en feu (Mme de Sévigné) ; ភ្លើង (ហេតុដែលធ្វើឲ្យវិនាស) (ឧ. la langue du détracteur est un feu dévorant (Massillon)។

Art culin. coup de feu ការបង្ហុំភ្លើង; ដំណើរខ្លោច (ឧ. rôti qui a reçu un coup de feu) ; ពេលកំពុងចំអិន ។

Art mil. arme à feu កាំភ្លើង ។ bouche à feu អ.ព. bouche ។ feu ការបាញ់កាំភ្លើង ។ feu à commandement ការបាញ់តាមបញ្ជា ។ feu à volonté ការបាញ់តាមចិត្ត ។ feu rapide ការបាញ់ញាប់(បាញ់យ៉ាងរហ័សហើយព្រកគ្រាប់វិញភ្លាមៗ) ។ feu de salve ការបាញ់ស្រះព្រម។ feu par rafale! បាញ់មួយកំរៗ! (បាញ់ម្ដង ៧ឬ៨ គ្រាប់) ។ feu coup par coup! បាញ់ម្ដងមួយគ្រាប់! (សម្រាប់បញ្ជាឲ្យបាញ់កាំភ្លើងមីត្រៃយ៉ើរ) ។ commencez le feu! ចាប់បាញ់ទៅ! ។ feu! បាញ់! ។ halte au feu! ឈប់បាញ់សិន (ប៉ុន្តែឲ្យនៅប្រុងបាញ់ទៀត)។ cessez le feu! ឈប់បាញ់។ feu en retraite ការបាញ់ដោះខ្លួន ។ feu direct ការបាញ់តម្រង់គោលដែលមើលមិនឃើញ ។ feu de guerre ការហោតបាញ់ដូចនៅពេលសង្គ្រាម ។ feux croisés ការបាញ់ចម្រុះ។ entre deux feux ត្រូវគេបាញ់ពីសងខាង ។ éteindre le feu de l'ennemi បំផ្លាញពង់កាំភ្លើងធំបច្ចាមិត្តដោយកាណុង ។ faire feu បាញ់ (កាំភ្លើង)។ coup

de feu ណាត់ (ការបាញ់កាំភ្លើង); របួសដោយគ្រាប់កាំភ្លើង ។ *Abs.* le feu ការប្រយុទ្ធ ។ voir le feu, aller au feu ចូលប្រយុទ្ធ ។ recevoir le baptême du feu ចូលប្រយុទ្ធដំបូង ។ exercice ឬ école à feu ការហាត់បាញ់ ។

Dr. ទៀន (សម្រាប់អុជកំណត់រយៈពេលក្នុងការលក់ដេញថ្លៃ) ។

Dr. crim. anc. supplice du feu ឬ feu ទោសដុតទាំងរស់ ។ brûler à petit feu ដុតបន្តិចម្ដងៗ (ការុណកម្ម) ។

Météor. feu Saint Elme ភ្លើងព្រាយហោះ (ភ្លើងដែលគេឃើញភ្លឺម្ដងៗនៅចុងក្ដោង ឬ អ្វីដែលខ្ពស់ បណ្ដាលដោយអគ្គិសនីនៃបរិយាកាស)។ feu follet ភ្លើងព្រាយ(ម.ព.follet ផង) ។

Pathol. feu volage ដំណើរឡើងក្រហមមុខនឹងក(ចំពោះក្មេងនឹងស្ត្រីដែលធ្លាក់ផ្លូវមិនស្រួល) ។ feu de dents ដំណើរក្ដៅមុខនៅពេលដុះធ្មេញដំបូង ។

Pyrotechn. feu d'artifice កាំជ្រួច ។ feu de Bengale កាំជ្រួចភ្លើងពណ៌ ។ feu grégeois គ្រាប់ដុត។ feux de terre កាំទៀន។ feu chinois កាំភ្លើង ។ lance à feu ដងឆ្នូន (សម្រាប់អុជកាំជ្រួចជាដើម) ។ pot à feu កាជីនដុតក្នុងផ្សេងៗនៅពេលបុណ្យ ។

Théâtr. ភ្លោនព្រៅ (សម្រាប់សិល្បករនឹងតួផ្សេងៗ) ។

Théol. feu de l'enfer ភ្លើងនរក ។ le feu impur កាមតណ្ហា ។

Loc. div. le dieu du feu អគ្គីទេព, អាទិទេពនៃភ្លើង (ទេវតាដែលនាំភ្លើងមកឲ្យមនុស្សលោក ប្រើឈ្មោះវុលកាំង) ។ faire du feu d'une chose ឲ្យជាចំណីភ្លើង (ដុត)។ *Fig.* faire trop grand feu du bois de quelqu'un ប្រើរបស់គេដោយគ្មានសំចៃ។ feu de cheminée ដំណើរឆេះម្រែងភ្លើងក្នុងបំពង់ភ្លើង ។ feu de paille ភ្លើងចំបើង (ទឹកចិត្ត ឬ ចលនាខ្លាំងប៉ុន្តែមិនបិតថេរ) (ឧ. amour qui ne fut qu'un feu de paille); ចលាចលដែលមានតែមួយភ្លែត (ឧ. cette sédition ne fut qu'un feu de paille)។

feu de joie ភ្លើងដុតជាសញ្ញានៃការរីករាយ។ *Fig.* feu de file ឬ feu roulant អ្វីៗដែលមានតគ្នាមិនដាច់; *arg. mil.* ប្រតិបត្តិការក្នុងរយៈពេលយូរ; *au fig.* ne pas s'embrouiller dans les feux de file ចេះមិនចំណុះគេ ។ être entre deux feux ត្រូវគេលាញ់ ឬ រងគ្រោះពីសងខាង។ feu du ciel រន្ទះ។ coup de feu ភ្លើងខ្លាំង(ភ្លើងដែលឆេះខ្លាំង); *au fig.* être dans le coup de feu កំពុងតែប្រញឹកការខ្លាំង(ឧ.commerçant qui est dans son coup de feu); ចាប់ស្រវឹងបន្តិចៗ (ឧ. Poivrot qui a un coup de feu) ។ feu d'enfer ភ្លើងក្តៅណាស់(ដូចភ្លើងនរក)។ feu du rasoir ដំណើរសង្កៀរមុខដោយមុខកាំបិតកោរ(នៅពេលកោរពុកមាត់រួច)។ couleur feu ពណ៌ក្រហមឆ្អៅ (ដូចភ្លើង) (ឧ. un ruban couleur feu)។ crier au feu ស្រែកថាភ្លើងឆេះផ្ទះ។ *Fig.* jeter des cris de feu ស្រែករកគេជួយ (ដូចជាភ្លើងឆេះផ្ទះ) ។ on y court comme au feu គេរត់ទៅដោយប្រញាប់ប្រញាល់ (ដូចទៅជួយភ្លើងឆេះផ្ទះ) ។ *Fig.* le feu est à ces marchandises ទំនិញនោះលក់ដាច់ណាស់(គេទិញទំនិញនោះដូចជាគេជួយដណ្តើមអីវ៉ាន់ដែលភ្លើងឆេះ)។ *Fig.* le feu n'est pas à la maison យើងនៅមានពេល (យើងមិនបាច់ប្រញាប់ដូចភ្លើងឆេះផ្ទះទេ) ។ *Fig.* le feu dans la maison ជ្រួលច្របល់(ដូចភ្លើងឆេះផ្ទះ) (ឧ. sa nièce arrivant, c'est le feu dans la maison) ។ couper le feu ឬ faire la part du feu ស្កាត់ភ្លើង (រុះ ឬ វាយកំទេចរបស់ដែលនៅជុំវិញភ្លើងដើម្បីកុំឲ្យរាលដាល); *au fig.* បោះបង់ចោលរបស់ខ្លះដើម្បីជួយស្រោចស្រង់របស់ឯទៀត។ attiser ឬ souffler le feu បង្កាភ្លើង ឬ ផ្លុំភ្លើង; *au fig.* អុជអាលថែមឲ្យខ្លាំង (ក្នុងជម្លោះ) ។ mettre le feu aux poudres ឬ aux étoupes យកភ្លើងទៅដុត, អុជអាលឲ្យរឹតតែឈ្លោះគ្នា ។ n'y voir que du feu ស្រវាំងភ្នែក,មិនយល់អ្វីសោះ។ faire feu បែកភ្លើង(ខ្ទាតចេញភ្លើង) (ឧ. la porcelaine fait feu comme le silex)។ faire long

feu នៅយូរ, មិនបានសម្រេច (ឧ. projet qui a fait long feu)។ ne pas faire long feu បឹត នៅមិនយូរ(ឧ. un héritage, aux mains d'un prodigue, ne fait pas long feu)។ faire feu des quatre pieds ឆាបចេញភ្លើងពីជើងទាំងបួន(សេះ); *au fig.* ប្រឹងប្រែងអស់ទំហឹងដើម្បីឲ្យបានសម្រេច ។ *Pop.* péter du feu ប្រតិបត្តិតាមបញ្ជា ឬ បំពេញបេសកកម្មយ៉ាងរហ័សហើយដោយប្រញាប់ប្រញាល់ ។ *Fig.* prendre feu ឆេះ; ខឹងក្រឡេក; រំជួលចិត្ត; ជាប់ចិត្តស្នេហា ។ mettre à quelqu'un le feu sous le ventre ជឿនយ៉ាងញាប់, ជំរុញ ។ *Fam.* avoir le feu au derrière ប្រញាប់ណាស់; ញាក់ញ័រណាស់ ។ jeter son feu ឬ tout son feu ស្ទុះដោយងងឹតងងល់តែមួយភ្លែតរួចស្ងំស្ងៀមទៅវិញ ; បញ្ចេញស្នាដៃតែមួយគ្រា រួចធ្វើអ្វីក៏មិនបានល្អ (ឧ. auteur qui a jeté son feu dans son premier roman) ។ jeter feu et flamme ខឹងក្រឡេកខ្លាំង ។ jeter de l'huile sur le feu បោកប្រេងទៅចាក់លើភ្លើង; ធ្វើឲ្យរឹតតែឈ្លោះគ្នាខ្លាំងឡើង។ *Fig.* employer le fer et le feu ប្រើវិធានការខ្លាំង ។ mettre à feu et à sang បំផ្លាញឲ្យខ្ទេចខ្ទីអស់។ *Fig.* se jeter au feu pour quelqu'un ធ្វើអំពើគ្រប់មុខដើម្បីសំដែងសេចក្តីស្នេហា ។ mettre sa main au feu que... ហ៊ានស្បថលូកភ្លើងថា...។ craindre comme le feu ខ្លាចជាទីបំផុត ។ jouer avec le feu លេងភ្លើង; ចាប់កាន់ការធំធុំដោយលេងៗ ។ n'avoir ni feu ni lieu គ្មានទីលំនៅ, ជាមនុស្សអនាថា។ *Fig.* faire feu qui dure សំចៃធនធាន; ថែសុខភាព ។ être tout feu, être de feu ឬ tout de feu ក្លៀវក្លាណាស់ ; កំពុងតែចង់ខ្លាំងណាស់ ។ c'est le feu et l'eau គឺជាទឹកនឹងភ្លើង (មនុស្សពីរនាក់នេះឬរបស់ពីរនេះផ្ទុយគ្នាស្រឡះ)។

Loc. adv. en feu ឆេះ, ក្តៅ (ឧ. avoir l'estomac en feu); *au fig.* ក្លៀវក្លា។ mettre en feu ដុត; *au fig.* ធ្វើឲ្យជ្រួលច្របល់ ។ à petit feu ភ្លើងតិច; មិនសូវក្លៀវក្លា ។

faire mourir quelqu'un à petit feu ធ្វើឲ្យរីងខ្លួនដោយកង្វល់គ្រប់យ៉ាង ។

Prov. il n'y a pas de fumée sans feu តែមានផ្សែងមុខជាមានភ្លើង(មិនដែលមានរឿងដោយឥតហេតុទេ)។ il n'est feu que de bois vert យើងមានសេចក្ដីក្លៀវក្លាតែកាលនៅក្មេង

feu,e *a.* ខ្មោច, ដែលស្លាប់ទៅហើយ (ឧ. ma feue tante; feu ma tante ខ្មោចម្ដាយមីងខ្ញុំ)

feudataire *n.* អ្នកមានដីទទួលអំពីអធិភាព; ប្រទេសរាជ

feudiste *n.m.* អ្នកជំនាញខាងច្បាប់សក្ដិភូមិ

feuillage *n.m.* ស្លឹកឈើទាំងដើម; មែកឈើទាំងស្លឹក; គំនូររូបម្លាក់ស្លឹកឈើ

feuillagiste *n.* អ្នកឯកទេសខាងស្លឹកសិប្បនិម្មិត(ស្លឹកក្លែង)

feuillaison *n.f.* ការដុះស្លឹក; ដំណើរលាស់ស្លឹកថ្មី (ឧ. le printemps est l'époque de la feuillaison)

feuille *n.f.Bot.* ស្លឹក។ feuille dentée ស្លឹកឆែក។ feuille échancrée ស្លឹកឆែកឆក។feuille lobée ស្លឹកឆក។feuille composée ស្លឹករួមទង។feuille alterne ស្លឹកឆ្លាស់។ feuille opposée ស្លឹកទល់ទង ។ feuille disposée en couronne ស្លឹកដុះជុំវិញក្រពិ។feuille morte ស្លឹកងាប់ ។ *Par ext.* ត្របកផ្កា (ឧ. des feuilles de rose)។

Fig. សន្លឹក (បន្ទះស្ដើង) (ឧ. feuille de carton, d'or, etc ...); សន្លឹកក្រដាស ។ feuille volante សន្លឹកក្រដាសរាយ (ផ្ដាច់ចេញពីសៀវភៅ)។

Par ext. កាសែត (ឧ. cette feuille a cessé de paraître) ។ ចម្លាក់ញ្ញាប់សន្លឹក ។ ប័ណ្ណ ។ feuille de route ប័ណ្ណដើរផ្លូវ ។ feuille de chargement ប័ណ្ណផ្ទុក (លិខិតស្រង់ទំនិញដែលបានផ្ទុកហើយ)។

feuille anglaise បន្ទះកៅស៊ូស្ដើង

feuillé,e *a.* ដែលមានស្លឹកពាសពេញ

feuillée *n.f.* ស្លឹកឈើទាំងដើម; ដំបូលប្រក់ដោយស្លឹកឈើ ។ *pl.* របណ្ដាបង្គន់

feuille-morte *a. inv.* ពណ៌ស្លឹកឈើ

ងាប់ (ឧ. des étoffes feuille-morte) (ម.ព. feuille ងាប់)

feuiller *v.i.* លាស់ស្លឹក (ឧ. arbres qui ont feuillé)

feuilleret *n.m.* ដែកឈូសលក

feuillet *n.m.* បណ្ណ, កូនស្លឹក (ផ្នែកនៃព្រឹក្សសបត់); កូនបន្ទះក្ដារស្តើង; ក្រពះស្រទាប់ (សត្វទំពារអៀង)

feuilletage *n.m.* ការលាយម្សៅដើម្បីឲ្យឡើងជាស្រទាប់ ; នំធ្វើដោយម្សៅស្រទាប់

feuilleté,e *a.* ដែលជាស្រទាប់ៗ។ *n.m.* ម្សៅស្រទាប់

feuilleter *v.t.* ត្រឡប់សន្លឹក(បើកសៀវភៅ)(ឧ.feuilleter un livre, un registre);អានដោយហ្មត់ចត់,ពិនិត្យ (ឧ.feuilleter assidûment les écrivains grecs; on feuillette jour et nuit les Oraisons funèbres de Bossuet (Chateaubriand); អានត្រួសៗ (ឧ.feuilleter des volumes)។ *Fig.* សិក្សា (ឧ. il est sain de toujours feuilleter la nature (V.Hugo)។

Techn. feuilleter de la pâte លាយម្សៅដើម្បីឲ្យឡើងជាស្រទាប់ ។

Géol. roche feuilletée ម.ព. roche។ argiles feuilletées ដីឥដ្ឋស្រទាប់ (មានលាយដីខ្សាច់ខ្លះ ហើយរបេចបកជាស្រទាប់បាន)

feuilletis *n.m.* ជ្រុងពេជ្រឬត្បូងថ្ម

feuilleton *n.m.* កាពរឿងប្រលោមលោកឬវិទ្យាសាស្ត្រចុះក្នុងកាសែត ។ roman-feuilleton ប្រលោមលោកចុះក្នុងកាសែត

feuilletoniste *n.* អ្នកនិពន្ធប្រលោមលោកចុះកាសែត

feuillu,e *a.* ដែលមានស្លឹកច្រើន (ឧ. le frêne est feuillu); ទ្រលទ្រុប

feuillure *n.f.* រណ្ដាលក

feulement *n.m.* សម្លេងខ្លា ឬឆ្មាគ្រហឹម

feuler *v.i.* គ្រហឹម(ចំពោះខ្លា និង ឆ្មា)

feutrage *n.m.* ការកិនធ្វើជាហ្វិត; ការក្រាប់ហ្វិត

feutre *n.m.* ហ្វិត (សំពត់ឧណ្ណាម័យ ឬសំពត់រោមសត្វកិនភ្ជាប់គ្នា) ; មួកសំបុក

feutré,e *a.* ដូចហ្វិត ។ pas feutré ដំណើរមិនឮសូរជើង(ដូចអ្នកពាក់ស្បែកជើងបាតហ្វិតឬសំពត់)

feutrer *v.t.* ក្រាប់ហ្វិត; ញាត់ហ្វិត

feutrier,ère *n.&a.* អ្នកធ្វើហ្វឹត

février *n.m.* ខែកុម្ភៈ

fez *n.m. inv.* កាតិប

fi! *int.* ថ្មីយ! (សំដែងសេចក្ដីខ្ពើម-សេចក្ដីមើលងាយ)។ faire fi de មើលងាយ

fiacre *n.m.* រទេះសេះឈ្នួលមួយបែប

fiançailles *n.f. pl.* ខាន់ស្លា ; ពិធីលើកស្លាកំផាប់ពាក្យ; រយៈពេលពីលើកស្លាដល់ពេលរៀបអាពាហ៍ពិពាហ៍

fiancé,e *n.* គូកំណាន់ចិត្ត,គូកំផាប់ពាក្យ

fiancer *v.t.* លើកស្លា, កំផាប់ពាក្យ

fiasco *n.m. Fam.* បរាជ័យ

fiat *n m.*(ពាក្យឡាតាំងមានន័យថា que cela soit) *Psych.* ការសម្រេចចិត្ត (ឧ. le fiat suppose la liberté)។ *int.* សាធុ!,ឱ្យទៅចុះ!

fibranne *n.f.* ហ្វីប្រាន (សំពត់សូម្យ៉ាង)

fibre *n.f.* សរសៃ (សរសៃសាច់ដុំ សរសៃឈើ សរសៃកប្បាសជាដើម)(ឧ. fibre musculaire; fibre ligneuse; on fabrique des textiles avec les fibres du lin)។ *Fig.* ការជាប់ជំពាក់ចិត្ត (ឧ. avoir la fibre sensible)

fibreux,euse *a.* ដែលមានសរសៃ; សាញ (សាច់ឈើ)

fibrille *n.f.* សរសៃល្អិត (ក្រៅពីសរសៃឈាម)

fibrilleux,euse *a.* ដែលមានសរសៃល្អិត

fibrine *n.f.* រត្តសេតល្អជាតិ

fibrociment *n.m. Constr.* ហ្វីប្រូស៊ីម៉ង់

fic *n.m.* ប្រឡៀយ សេះ-គោ ។ល។

ficelage *n.m.* ការចង

ficelé,e *a.* ជាប់ចំណង ។ *Fig.&fam.* ដែលស្លៀកពាក់ (ឧ. être mal ficelé)

ficeler *v.t.* ចងដោយខ្សែគ្នារ

ficelle *n.f.* ខ្សែគ្នារ ។ *Fig.* កល (ឧ. connaître toutes les ficelles)។ *a. Fam.* ដែលមានឧបាយកល, រៀចរេរ

ficellerie *n.f.* កន្លែងធ្វើខ្សែ

fichant,e *a.* ផ្ដោត(ឧ. tir fichant)។ *Pop.* ដែលធុញទ្រាន់

fiche *n.f.* បង្គោលឈើឬដែក;សលាកប័ត្រ [សៈ - ឡា-កៈ-បាត់] (ឧ. les fiches d'une bibliothèque)។ *Jeux* ក្បាច់ឬកាស (សម្រាប់ជំនួសប្រាក់ភ្នាល់ក្នុងល្បែង)។ fiche de consolation សលាកប័ត្រលួងចិត្ត

(សម្រាប់លួងចិត្តអ្នកចាញ់ក្នុងល្បែង); *au fig.* ការជួសជុលខ្លះក្នុងការខូចខាត ។ fiche de renseignements សលាកប័ត្រព័ត៌មាន

ficher *v.t.* បោះ (បង្គោល) (ឧ. ficher un pieu en terre); ចុះក្នុងសលាកប័ត្រ(ឧ. ficher des renseignements); បណ្ដេញ, បោះចោល (ឧ. ficher quelqu'un à la porte) ។ ficher une gifle ទះកំផ្លៀង ។ se ficher (de) *v.pr. Fam.* មិនខ្ចីរវល់នឹង

fichier *n.m.* ប្រជុំសលាកប័ត្រ; ទូឬប្រអប់ដាក់សលាកប័ត្រ

fichoir *n.m.* ដំបៀតឈើ

fichtre ! *int.* យី! អូយ! (សំដែងសេចក្ដីឆ្ងល់-សេចក្ដីសរសើរ-សេចក្ដីឈឺចាប់)

fichtrement *adv.Fam.* ជាទីបំផុត (ឧ. c'est fichtrement bon!)

fichu,e *a.Fam.* មិនល្អ, គួរឲ្យអស់សំណើច (ឧ. un fichu nez); គួរឲ្យស្អប់ (ឧ. un fichu caractère); បាត់, ខូច (ឧ. santé fichue) ។ fichu de អាច...បាន(ឧ. il n'est pas fichu de gagner sa vie)

fichu *n.m.* កន្សែងបង់ក

fictif,ive *a.* ដែលប្រឌិត, មិនពិត (ឧ. personnage fictif); តាមសន្មតិ (ឧ. les billets de banque n'ont qu'une valeur fictive)

fictivement *adv.* ដោយសន្មតិ

fiction *n.f.* រឿងប្រឌិត, សេចក្ដីសន្មត

fidéisme *n.m.* សទ្ធានិយម (លទ្ធិនិយមអោយសទ្ធាធំជាងវិចារណញ្ញាណ)

fidéiste *a.&n.* នៃសទ្ធានិយម

fidéjusseur *n.m.* អ្នកធានាឲ្យគេ

fidéjussion *n.f.* កិច្ចសន្យាធានា

fidéjussoire *a.* នៃកិច្ចសន្យាធានា (ឧ. engagement fidéjussoire)

fidèle *a.* ភក្ដី; ស្មោះចំពោះ (ឧ. serviteur fidèle); ទៀង(ដែលធ្វើតាមកិច្ចសន្យា); ដែលមិនប្រែប្រួល (ឧ. ami fidèle); ដែលមានព្យាយាម; មិនឃ្លៀងពីសេចក្ដីពិត (ឧ. historien fidèle); ត្រឹមត្រូវ, ដូចដើម(ឧ. copie fidèle); ដែលមានសច្ចៈ(ឧ. fidèle à ses promesses); គួរទុកចិត្ត(ឧ. guide fidèle); ដែលចាំបានយូរ(ស្មារតី) (ឧ. mémoire fidèle) ។ *n.m.* សាសនិក; អ្នកមានចិត្តភក្ដី

fidèlement *adv.* ដោយទៀងទាត់;

ដោយសច្ចៈ ; ដោយភក្ដី

fidélité *n.f.* ស្វាមីភក្ដិ,សេចក្ដីទៀងត្រង់ (ឧ. jurer fidélité à quelqu'un); សេចក្ដីស្មោះត្រង់ (ឧ.fidélité d'un ami); សច្ចៈ,ការពិត,ការត្រឹមត្រូវ(ឧ.fidélité d'un récit)។ *Phys.* ដំណើរទៀងទាត់ (រង្វាស់-រង្វាល់);ការមានសម្លេងសុទ្ធ(ដូចសម្លេងដើម) (ឧ. magnétophone de haute fidélité)

fiduciaire *a.* ដែលមានតម្លៃដោយសន្មតិ ។ monnaie fiduciaire ធនប័ត្រ, ប្រាក់ក្រដាស

fief *n.m.* ដីដែលសាមន្តកជនទទួលមកអំពីអធិកធិ។ *Fig.* សម្បត្តិផ្ទាល់ខ្លួន; ដែនអំណាច (ឧ. fief électoral)

fieffé,e *a.* ដែលយកឬឲ្យជាសម្បត្តិផ្ទាល់ខ្លួន ។ *Fam.* ខូចឬអាក្រក់កែមិនឡើង (ឧ. ivrogne fieffé)

fieffer *v.t.* ឲ្យជាសម្បត្តិផ្ទាល់ខ្លួន; ប្រគល់ដែនអំណាច

fiel *n.m.* ប្រមាត់ ។ poche du fiel ថ្លោកប្រមាត់ ។ *Fig.* សេចក្ដីទុក្ខព្រួយ, សេចក្ដីឈឺចាប់ខ្លាំង (ឧ. discours plein de fiel)

fielleux,euse *a.* នៃប្រមាត់;ល្វីង (ដូចប្រមាត់) (ឧ. propos fielleux)

fiente *n.f.* អាចម៍សត្វ (ឧ. fiente de poule, de vache)

fienter *v.i.* ជុះអាចម៍(សត្វ)

fier,fière *a.* កោង,ក្រអឺតក្រអោង,ខេង, ដែលមានឫកពាខ្ពស់ (ឧ. une femme fière); ដែលពេញចិត្ត, រីករាយ (ឧ. être fier de sa fortune); ថ្លៃថ្នូរ, ឧត្ដម, ខ្ពង់ខ្ពស់ (ឧ. âme fière)។ *Fam.* ធំ,សម្បើម,ខ្លាំង (ឧ. un fier imbécile)

fier (se) (à) *v.pr.* ជឿ,ទុកចិត្តលើ (ឧ. ne vous fiez pas aux flatteurs)

fier-à-bras *n.m.* មនុស្សអួតធ្វើឫកក្លាហាន (*pl.* des fiers-à-bras ឬ des fier-à-bras)

fièrement *adv.* ដោយក្រអឺតក្រអោង, យ៉ាងខេង; ងងើល (ឧ. accepter fièrement un défi) ។ *Fam.* យ៉ាងខ្លាំង (ឧ. je l'ai fièrement tancé)

fiérot,e *a.* ចចើងពេក, ក្រអឺតក្រអោងពេក (គួរអស់សំណើច) (ឧ. être fiérot)។ *n.* អ្នកចចើង, អ្នកក្រអឺតក្រអោង (ឧ. faire le fiérot)

fierté *n.f.* មោទនភាព, ភាពក្រអឺតក្រអោង(ឧ.la fierté de manière est un défaut); ឫកខ្ពស់; ឫកខ្ទេង;សេចក្តីថ្លៃថ្នូរ (ឧ. c'est un homme sans fierté គឺជាមនុស្សខ្វះសេចក្តីថ្លៃថ្នូរ); សេចក្តីរីករាយ, សេចក្តីពេញចិត្ត

fièvre *n.f.* គ្រុន,រោគក្តៅខ្លួន។ fièvre jaune គ្រុនលឿង ។ fièvre de Malte គ្រុនម៉ាល្តិ។ fièvre récurrente គ្រុនលស់។ fièvre typhoïde ម.ព. typhoïde ។ fièvre paratyphoïde គ្រុនសន្និប្រាល ។ *Fig.* ការរំជើបរំជួល (ឧ. fièvre politique); បំណងខ្លាំង(ឧ.fièvre de collectionner)

fiévreusement *adv.* ដោយរំជើបរំជួល

fiévreux,euse *a.* ដែលកើតរោគគ្រុន, ដែលធ្វើឲ្យដឹងថាកើតរោគគ្រុន (ឧ. yeux fiévreux); ដែលបណ្តាលឲ្យគ្រុន (ឧ. climat fiévreux) ។ *a.&n. Fam.* ញៀវញ៉ា, រំជើបរំជួល, ក្រស់ក្រាល់

fifre *n.m.* ប៉ីតូច; អ្នកផ្លុំប៉ី

fifrelin *n.m. Fam.* វត្ថុគ្មានតម្លៃ

figaro *n.m. Fam.* ជាងកាត់សក់

figé,e *a.* នឹងថ្កល់ (ឧ. expression figée)

figement *n.m.* ការកក (ជាតិខ្លាញ់); ភាពវត្ថុកក

figer *v.t.* ធ្វើឲ្យកក (ជាតិខ្លាញ់)(ឧ. le froid fige la graisse); ធ្វើឲ្យនៅនឹងថ្កល់ (ឧ. il resta figé sur place)

fignola *n.m.* ការសំអិតសំអាង

fignoler *v.t.* ឬ *v.i.* ធ្វើការដោយផ្ចិតផ្ចង់; សំអិតសំអាង

figue *n.f.* ផ្លែល្វា។ *Fig.* mi-figue, mi- raisin ស្មើល្អ ស្មើអាក្រក់; សោះអង្គើយ, ល្ងើយ(ឧ. un accueil mi-figue, mi-raisin

figuerie *n.f.* ចំការល្វា

figuier *n.m.* ដើមល្វា,ដើមឧទុម្ពរ;ដើមជ្រៃ

figuline *n.f.* គ្រឿងបានឆ្នាំងដី

figurant,e *n.* តួរាយរង (ល្ខោន)។ *Par ext.* មនុស្សរាយរង

figuratif,ive *a.* ដែលជាតំណាង,ដែលជានិមិត្តរូប (ឧ. plan figuratif)។ art figuratif សិល្បៈគំនូររូបមើលស្គាល់។ *n.m.* ជាងគំនូររូបមើលស្គាល់

figuration *n.f.* ការគូរឬឆ្លាក់តំណាង,

ក្រុមតួកាយរងក្នុងរោង; មុខរបរនៃតួកាយរង

figure *n.f.* ឆម្មានរូប, រូបកាយខាងក្រៅ (ឧ. il n'a pas figure humaine); មុខ (មនុស្ស) (ឧ. figure aimable) ។ *Fig.* ភាព, ឫកពា (ឧ. faire bonne figure); និមិត្តរូប, បដិរូប, រូបតំណាង (ឧ. l'Agneau pascal est une figure de l'eucharistie) ។

Loc.div. prendre figure មានដំណើរការ ។ avoir figure មានសភាព, មានទឹកមុខ ។ faire triste figure មានទឹកមុខអាប្រក់, មានទឹកមុខស្រពោន; *au fig.* នៅក្នុងឋានៈពិបាក ។ figure d'accident មុខភ័យ ។ figure de papier mâché មុខស្លេកស្លាំងហើយ ហែបអស់កម្លាំង ។ avoir une figure comme le cul d'un pauvre homme មានមុខធំ ប្រហម ។

Math. គំនូសបន្ទាត់ឬផ្ទៃ ។

Gram. ន័យដោយឡែកនៃពាក្យខ្លះ

figuré,e *a.* prononciation figurée សញ្ញាដាក់ឲ្យអានឬឲ្យថា ។ sens figuré អត្ថបដិរូប, ន័យប្រៀប ។ *n.m.* ន័យជាអត្ថបដិរូប (ឧ. au propre et au figuré)

figurément *adv.* ដោយប្រើអត្ថបដិរូប (ឧ. parler figurément)

figurer *v.t.* គូរឬឆ្លាក់តំណាង (ឧ. figurer Vichnou en cire); គូសជាសញ្ញាសំគាល់ (ឧ. sur les cartes géographiques on figure souvent les évêchés par une croix); ធ្វើរូបតំណាង(សព្វគ្រប់រូប) (ឧ. on figure la Justice, la Fortune, avec un bandeau sur les yeux គេធ្វើរូបតំណាងទេពតាខាងតុលាការ ទេពតាខាងលោកភិសនាដោយមានសំពត់បិទមុខ (ជាសញ្ញាថាទេពតាទាំងពីរនេះមិនត្រូវការយល់មុខ ឬរើសមុខទេ)។ *v.i.* មានក្នុង (ឧ. figurer sur une liste); ដើរតួកាយរង(រោង) (ឧ. figurer dans une pièce); មានមុខមាត់ (ឧ. pour figurer dans le monde, l'argent seul est indispensable) ។ figurer avec លេងឬដើរតួជាមួយ។ *Théât.* ដើរតួកាយរង (ឧ. plusieurs célébrités théâtrales ont com-

mencé par figurer sur des scènes de dernier ordre) ។ se figurer *v.pr.* នឹកស្មាន,ជឿថា (ឧ.elle s'était figuré qu'elle réussirait facilement)

figurine *n.f.* រូបចំឡាក់ ឬ រូបស្មិតតូចៗ

figuriste *n.m.* ជាងចំឡាក់ឬជាងស្មិតរូប

fil *n.m.* ខ្សែ, សរសៃសូត្រ-អំបោះ។ល។, លួស(ឧ. fil de fer, de cuivre, etc...) ; មុខ (មុខកាំបិត) (ឧ. fil d'un rasoir) ។ fil de fer barbelé លួសបន្លា ។ fil à plomb កូនប្រយោល ។ fil de la vierge ម.ព. filandre ។ សរសៃថ្មីខ្ចី ។

Fig. ដំណើរជាប់ទាក់ទងគ្នា (ឧ. fil d'un discours) ។ fil de l'eau ខ្សែទឹក ។ fil de la vie ខ្សែជីវិត។ fil des idées ខ្សែគំនិត។ បញ្ចេញបាយស្ងាត់ (ឧ. tenir tous les fils d'une affaire) ។

Loc. adv. aller contre le fil de l'eau *fig.* ធ្វើការខុសកាលទេសៈ ។ passer au fil de l'épée កាប់សម្លាប់ ។ le fil du bois សរសៃសាច់ឈើ ។ bois de fil ឈើប្រើការតាមបណ្ដោយសាច់ ។ le fil de viande បណ្ដោយសាច់។ le fil d'Ariane អ្វីៗសម្រាប់នាំផ្លូវ ឬ សម្រាប់ដឹកនាំ ។ de fil en aiguille បន្តិចម្ដងៗ ; ពីនេះពីនោះ (ការនិយាយ) ។ cousu de fil blanc នៅលើគោក (លាក់បាំងមិនជិតខ្ទប់យកបេសសទៅនេះនៅសំពត់ខ្មៅ) ។ avoir le fil មុត (កាំបិត); *au fig.* ប៉ិនប្រសប់ណាស់, ឆ្លាតណាស់ ។ langue qui a le fil មាត់រអាក្រក់(ចូលចិត្តនិយាយអាក្រក់ពីគេ)។ ne tenir qu'à un fil ងាយណាស់ (មានតែអ្វីបន្តិចបន្តួចអាចឲ្យវិនាសបាន) (ឧ. notre vie ne tient qu'à un fil ជីវិតយើងងាយណាស់) ។ donner du fil à retordre ធ្វើឲ្យមានការពិបាក, ធ្វើទំនាស់ (ម.ព. donner(*loc.div.*) ផង)។ il y a un fil de manqué មានអ្វីមួយមិនស្រួល ។ *Fam.* n'avoir pas inventé le fil à couper le beurre មិនឆ្លាតទេ ។ *Pop.* ne plus avoir de fil sur la bobine ទំពែក ។ n'avoir pas un fil de sec ទទឹកជោក (ដោយបែកញើសឬដោយ

ទទឹកភ្លៀង) ។ donner ឬ passer un coup de fil ហៅនិយាយតាមទូរស័ព្ទ

fil-à-fil *n.m.inv.* សំពត់ទាក់សរសៃឆ្លាស់ពណ៌(ច្រើនតែសំពត់កម្ពល)

filage *n.m.* ការរវៃអំបោះ (ធ្វើសរសៃរុក្ខជាតិឲ្យទៅជាអំបោះត្បាញបាន)

filament *n.m.* សរសៃឆ្មារ; ខ្សែល្អិតឆ្មារ ។ filament chromatique វណ្ណសូត្រ [វ័ន-ណៈ–], សូត្រពណ៌

filamenteux,euse *a.* ដែលមានសរសៃឆ្មារ(ឧ.viande filamenteux)

filandière *n.f.* ស្រីអ្នករវៃសូត្រ-អំបោះ។ *Poét.* les sœurs filandières យមបាល [យៈ-មៈ-]

filandre *n.f.* អំបោះព្រះ, អំបោះខ្មោច ឬ សរសៃល្អិត (សរសៃពីងពាងរសាត់តាមអាកាស) (ពាក្យសាមញ្ញហៅថា fil de la Vierge); សរសៃឆ្មារៗក្នុងសាច់ស៊ុត

filandreux,euse *a.* ដែលមានតែសរសៃ (ឧ. viande filandreuse)។ *Fig.* ស្មុគស្មាញ, វែងហើយមិនច្បាស់លាស់ (ឧ. explications filandreuses)

filant,e *a.* ដែលហូររន្ទាយ (ឧ. liquide filant) ។ étoile filante ទេពក្សត្រ

filanzane *n.m.* កៅអីស្នែង (ប្រើនៅកោះម៉ាដាហ្គាស្ការ)

filao *n.m.* ដើមស្រល់

filasse *n.f.* សំណុំសរសៃធ្មៃប្រហៅ ។ *a. inv.* cheveux de filasse សក់លឿងការ

filateur *n.m.* ជាងហ្វូងរោងចក្រធ្វើអំបោះ

filature *n.f.* រោងចក្ររវៃអំបោះ; ការរវៃអំបោះ; ការតាមឃ្លាំមើល

file *n.f.* ជួរ, ការឈរឬរៀបបន្ទាប់ៗគ្នា។ chef de file មេខ្លាង,អ្នកមុខគេក្នុងជួរ ។ feu de file ការបាញ់បន្តគ្នា។ ligne de file បន្ទាត់ជួរ(នាវារៀបបន្តគ្នាជាជួរដើម្បីប្រយុទ្ធ) ។ à la file *loc. adv.* ជាជួរ(មុខក្រោយ)។ à la file ឬ en file ឬ en file indienne បន្តៗគ្នា

filé *n.m.* អំបោះសំរាប់ត្បាញ ឬ វេញ; សរសៃមាសឬប្រាក់ដែលគេហូត

filer *v.t.* រវៃ(ឧ. filer la laine); ការសូត្រឬអំបោះ; ព័ទ្ធសំបុក(បញ្ចេញសរសៃឆ្មារ) (ពីងពាង); តាមឃ្លាំមើល (ឧ. filer un suspect)។ filer ses

jours ស៊ស់នៅ ។ *Mar.* filer un câble បណ្ដោយពួរ ។ filer 25 nœuds រត់ល្បឿន២៥ណ៏ (ក្នុងមួយម៉ោង) ។

v.i. ហូរអន្លាយដូចប្រេង (ឧ. ce vin file); ផ្សែង (ចង្កៀងដែលមានអណ្ដាតភ្លើងខ្ពស់នាំឲ្យផ្សែង) (ឧ. cette lampe file ចង្កៀងនេះផ្សែង) ។ *Fam.* ទៅយ៉ាងលឿន ។

filer à l'anglaise ដើរចេញដោយឥតលា ឬ ដោយឥតអនុញ្ញាត ។ *Fig.* filer doux កាន់ចរិយារៀងរួស; ចុះចាញ់ឬប្រតិបត្តិតាមដោយខ្លាច

filerie *n.f.* កន្លែងវេញខ្សែ

filet *n.m.* ជាលភណ្ឌ [ជា-លៈ—] (នេសាទុបករណ៍ដែលចងជាសំណាញ់ដោយសរសៃខ្សែជាដើម ដូចយ៉ាងមង, សំណាញ់,អួន។ល។); សំណាញ់គ្របសក់; ជរប្រឡាក់ភ្នែកព្រួច ។ *Bouch.* សាច់ចម្លូក ។ ។ *Techn.* ធ្មេញខ្ចៅ (ខ្ចៅឡោស៊ី)។ *Fig.* ចំនួនបន្តិចបន្តួច (ឧ. filet d'eau) ។ filet de voix សម្លេងខ្សោយណាស់ (តិច)

filetage *n.m.* ការហូតល្អស(ហូតលោហជាតិជាសរសៃ); ការបន្សើធ្មេញខ្ចៅឡោស៊ី; ការបរបាញ់ឬនេសាទលួចលាក់ដោយប្រើជាលភណ្ឌ (សំណាញ់, បន្ទង ។ល។)

fileté *n.m.* សំពត់ដែលមានសរសៃអង្គង ធំជាងសរសៃចាក់

fileter *v.t.* ហូតល្អស (ហូតលោហជាតិជាសរសៃ); បន្សើធ្មេញខ្ចៅឡោស៊ី

fileterie *n.f.* រោងចក្រធ្វើអំបោះដេរ

fileur,euse *n.&a.* កម្មករវេរឬការអំបោះ; ចាងហ្វាងរោងចក្រធ្វើអម្បោះ

filial,e,aux *a.* ដែលជាករណីយកិច្ចរបស់កូន (ឧ. amour filial)

filiale *n.f.* សាខា (នៃផ្ទះជំនួញឬធនាគារ)

filialement *adv.* តាមករណីយកិច្ចរបស់កូន

filiation *n.f.* កូនចៅទាំងឡាយ, ញាតិ, ខ្សែលោហិត ។ *Fig.* ការទាក់ទងគ្នាពីមួយទៅមួយ (ឧ. filiation des idées, des mots)

filière *n.f.* ប៉ែនហូតល្អស(ហូតលោហជាតិជាសរសៃ); ប្រដាប់បន្សើធ្មេញខ្ចៅឡោស៊ី ។ *Zool.* រន្ធបញ្ចេញសរសៃ (ជន្លួរ,ពីងពាង ។ល។)។ *Fig.* ទម្រង់ការផ្សេងៗ (ដែលត្រូវបំពេញមុននឹងសម្រេចការអ្វីមួយ) (ឧ. la filière administrative)

filiforme *a.* ស្ដារ (ដូចសរសៃអំបោះ) ។

Méd. pouls filiforme ជីពចរខ្សោយណាស់

filigrane *n.m.* គ្រឿងមាសប្រាក់ចេញាខ្ចះផាសរសៃៗ; លួសស្ពាន់រុំនឹងផារ; រូបស្រមោលមើលឃើញធ្លុះក្នុងក្រដាស (ឧ. les filigranes des billets de banque)

filigraner *v.t.* របធាគ្រឿងមាសប្រាក់ដោយខ្ចះផាសរសៃ (ឧ. filigraner des bijoux); ផ្តិតរូបស្រមោល(ឲ្យឃើញធ្លុះក្នុងក្រដាស)

filin *n.m. Mar.* ខ្សែ,ពួរ (ប្រើក្នុងនាវា)

fille *n.f.* កូនស្រី;ក្រមុំ,កញ្ញា(ស្រីមិនទាន់មានប្តី)(ឧ. rester fille); កូនឈ្នួលស្រី (ឧ. fille d'auberge); ស្ត្រីចរិយាមិនល្អ ។ vieille fille សៅកែ (ក្រមុំចាស់)។ fille mère មាតានារី (ស្ត្រីមានកូនតែគ្មានប្តី) ។ fille d'honneur ម.ព. honneur

fillette *n.f.* ស្រីជំទង់

filleul,e *n.* កូនធម៌ ។ filleul de guerre ទាហានដែលមានស្រីម្នាក់ទំនុកបម្រុងក្នុងពេលចម្បាំង

film *n.m.* ហ្វីល្ម (សំរាប់ថត); ខ្សែភាពយន្ត (ឧ.film documentaire)។ *Fig.* ដំណើរមានតម្រូហូរហែ (ឧ. film des événements)

filmer *v.t.* ថតភាពយន្ត

filmologie ភាពយន្តសាស្ត្រ (វិទ្យាសាស្ត្រខាងភាពយន្តនិងឥទ្ធិពលនៃភាពយន្តមកលើសង្គម)

filmothèque *n.f.* កន្លែងដាក់ខ្សែភាពយន្ត

filon *n.m. Minér.* ខ្សែរ៉ែ (ក្នុងដី) ។ *Fig.&Fam.* ភ័ព្វល្អ, លាភល្អ ; ស្ថានភាពល្អ

filoselle *n.f.* ក្បាលសូត្រ (ឧ. gants de filoselle)

filou *n.m.* ចោរប៉ិនប្រសប់ (ឧ. les filous sont nombreux dans les grandes villes) ។ *Par ext.* អ្នកឆបោក; អ្នកលេងបំបាត់ក្នុងល្បែង

filoutage *n.m.* ការលួចដោយប៉ិនប្រសប់; ការបំបាត់ក្នុងល្បែង

filouter *v.t. Fam.* លួចដោយប៉ិនប្រសប់ (ឧ. filouter une montre) ។ *v.i.* បំបាត់ក្នុងល្បែង

filouterie *n.f.* អំពើនៃចោរប៉ិនប្រសប់

fils *n.m.* កូនប្រុស; កូន (ពាក្យសំដែងមិត្តភាព) (ឧ. mon fil); កូនចៅ (ឧ. les fils des Khmers) ។

Fam. fils à papa កូនអ្នកមានទ្រព្យឬមានអំណាច ។ le Fils de l'homme ព្រះយេស៊ូគ្រិស្ត ។ fils d'Apollon កវី ។ fils de Mars យោធិន, អ្នកចម្បាំង ។ *Fig.* être fils de ses œuvres បានមានះខ្លួនដោយសារតែខ្លួនឯង

filtrage *n.m.* ការត្រងឬច្រោះ;លទ្ធផលនៃការត្រង។ *Fig.* ការឃ្លាំ,ការពិនិត្យ (ដើម្បីរកមុខ) (ឧ. le filtrage des suspects par la police)

filtrant,e *a.* សំរាប់ត្រង (ឧ. papier filtrant); ដែលអាចជ្រាបចេញពីតម្រងបាន (ឧ. virus filtrant)

filtrat *n.m.* វត្ថុរាវដែលគេត្រង ឬ ច្រោះហើយ

filtration *n.f.* ការហូរជ្រាបចេញតាមតម្រង-តាមដីឬតាមថ្ម

filtre *n.m.* តម្រង; តម្រងសម្លេងវិទ្យុ

filtre-presse *n.m.* តម្រងសម្ពាធ(*pl.* des filtre-presses)

filtrer *v.t.* ត្រង, ច្រោះ ។ *Fig.* ឃ្លាំ, ពិនិត្យ(ឧ.filtrer des passants)។ *v.i.* ជ្រាប (ឧ. l'eau filtre à travers les terres) ។ *Fig.* លេចឬធ្លាយ (ដោយស្ងាត់កម្បាំង) (ឧ.laisser filtrer une nouvelle)

fin *n.f.* អវសាន, ចុង, ទីបំផុត, ទីបញ្ចប់ (ឧ. fin d'un livre); ដំណាច់(ឧ. fin de l'année); ការអស់ (ឧ. fin d'une misère)។*Par ext.* មរណភាព, ការវិនាសបាត់ (ឧ. fin d'un empire);គោលដៅ, គោលបំណង(ឧ.en venir à ses fins); ការតម្រូវទុក(ឧ. la fin de l'homme); លទ្ធផល (ឧ. mener une entreprise à bonne fin) ។

Com. fin de mois បញ្ជីដំណាច់ខែ (បង្ហាញលទ្ធផលជំនួញក្នុងមួយខែ)។ fin de mois chargé ដំណាច់ខែដែលត្រូវចេញប្រាក់ច្រើន ។ fin courant ដំណាច់ខែនេះ ។ fin prochain ដំណាច់ខែក្រោយ ។

Adm. pour toutes fins utiles ដើម្បីជាការគាប់គួរ ។

Dr. n'étant à autre fin ដោយគ្មានបំណងអ្វីផ្សេងទៀត។ à ces fins ឬ cette fin សេចក្ដីនេះ,ដោយហេតុនេះ ។ à telle fin que de raison ដើម្បីប្រើតាមត្រូវការ ។ fin de non-recevoir ការមិនទទួលបណ្ដឹង(ដោយមានសំអាងថាបណ្ដឹងមិន

សមហេតុផលឬមិនត្រឹមត្រូវ) ; *par ext.* ការប្រកែក, ការមិនព្រម ។

Hippol. cheval à toute fin សេះសម្រាប់ប្រើការគ្រប់យ៉ាង (ជិះក៏បានទឹមក៏បាន) ។

Ind. courroie (ឬ câble ឬ chaîne) sans fin ព្រួតពុងភ្ជាប់គ្នា (ឡើងទៅជារង្វង់មូលដូចខ្សែពានជាដើម) ។

Philos. fin soi វត្ថុដែលវិសេសជាងគេបំផុត ។

Véner. être sur ses fins រត់លែងរួច (ចំពោះសត្វដែលគេប្រដេញ)។

Loc. adv. sans fin ឥតព្រំដែន; ជានិច្ច។ à la fin នៅទីបំផុត, ក្រោយមក ។ en fin de compte ក្នុងទីបំផុត, ដោយគិតឲ្យហ្មត់ចត់ទៅ ។

Loc. div. fin du monde ប្រល័យលោក(ការវិនាសពិភពលោក)។ *Fam.* fin des fins ឬ fin finale ទី (ឬពេល) ក្រោយបំផុត (ឧ. la fin du monde sera la fin des fins)។ en fin finale ជាទីក្រោយបំផុត ។ faire une fin សម្រេចនៅក្នុងស្ថានភាពណាមួយ ; យកប្រពន្ធ (ឬ ប្តី); ស្លាប់ (ឧ. faire une fin exemplaire)។ mettre fin à បញ្ចប់,បញ្ឈប់។ mener à bonne fin បង្ហើយ, ធ្វើឲ្យបានសម្រេច ។ à bonne fin ដោយមានចេតនាល្អ ។ à mauvaise fin ដោយមានចេតនាអាក្រក់ ។ prendre fin ចប់, ឈប់,អស់។ tirer à sa fin ឬ être sur sa fin ជិតចប់, ជិតអស់, ក្បែរនឹងវិនាសអស់,ជិតឈប់។ à ces fins ដើម្បីនឹងសម្រេចតាមគោលបំណងនេះ។ à toute fin ទោះជាយ៉ាងណាក៏ដោយ ។ opposer une fin de non-recevoir មិនព្រមទទួល ។

Prov. la fin justifie les moyens មធ្យោបាយណាក៏ល្អទាំងអស់ឲ្យតែបានសម្រេច ។ qui veut la fin veut les moyens ចង់ឲ្យបានសម្រេច ត្រូវតែប្រើមធ្យោបាយ

fin, fine *a.* ឆ្មារ, ល្អិត (ឧ. écriture fine); ស្តើង (ដែលមានមាឌស្រឡូនហើយស្អាតស្អំ) (ឧ. taille fine); ស្រួចរលែម(ស្រួចណាស់)(ឧ.pointe fine); ម៉ដ្ឋ (ដែលមានសាច់ល្អិតជិតស្និទ្ធ) (ឧ. tissu fin) ; ប្រឆ្នៀរ (ឧ. visage fin) ; ដើត, ប្រពៃ, លេខមួយ(ដែលមានគុណភាពល្អជាងគេ)(ឧ.

vin fin; lingerie fine);ល្អ(ចំពោះត្រចៀកណាដែលឆាប់ទទួលអារម្មណ៍) (ឧ. oreille fine); រើសគ្លើស(ឧ. goût fin); សុទ្ធ (ឧ. or fin)។

Fig. ឆ្លាត (ដែលបង្ហាញការឈ្លាសវៃ) (ឧ. un regard fin); ដែលមានឧបាយកល, ប៉ិនប្រសប់,ពូកែ (ឧ. c'est un fin regard) ។

Loc.div. pluie fine រលឹម។ *Fig.&fam.* nez fin ឬ odorat fin ច្រមុះល្អ។ partie fine ការលេងកំសាន្តដោយមានសេចក្តីស្នេហាលួចលាក់។ fine mouche ឆ្លាតណាស់ឬប៉ិនប្រសប់ណាស់(ច្រើនតែស្រី)។ fine fleur de farine ម្សៅសុទ្ធ; *au fig.* fine fleur វត្ថុប្រណិត, វត្ថុវិសេសបំផុត (ឧ. la fine fleur de la littérature française) ។ fine lame អ្នកពូកែគុនដាវ, ស្ត្រីមានកលល្បិចហើយនិយាយច្រើន ។ *Fig* fin fond ជម្រៅ,ចំណុចសំខាន់ (ឧ. savoir le fin fond d'une chose); ទីដាច់ស្រយាល។ fin mot ពាក្យចុងក្រោយ, ពាក្យត្រូវ, ន័យពិត (ឧ. savoir le fin mot d'une affaire) ។

adv. ស្រេច(សព្វគ្រប់អស់ហើយ) (ឧ. il est fin prêt) ។

n.m. អ្វីដ៏ប្រសើរជាងគេ (ឧ. il faut être théologien pour en voir le fin); មនុស្សឆ្លាត (ឧ. les fins, les fines)។ *Fam.* gros fin មនុស្សកញ្ចោតកំយឬកធ្វើឆ្លាត។ jouer au fin ឬ au plus fin លេងឆ្លាត(រកកលបោកបញ្ឆោតគ្នា)។ អក្សរល្អិត (ឧ. écriture en fin)។សំពត់ម៉ដ្ឋ(ឧ.blanchisseuse de fin) ។

Loc. div. faire le fin ឬ la fine ធ្វើឫកជាឆ្លាត (ដើម្បីលាក់បំបាំងអ្វីមួយ) ។ savoir le fin (ឬ le fin du fin ឬ le fort et le fin) d'une affaire ឬ d'un objet, d'un métier, etc... យល់ច្បាស់, ស្គាល់ច្បាស់,ចេះច្បាស់។

Prov. fin contre fin ne vaut rien pour doublure ឆ្លាតនឹងឆ្លាតដូចគ្នាស៊ីគ្នាមិនបែក (មនុស្សឆ្លាតគ្មានប្រយោជន៍អ្វីនឹងសេពគប់មនុស្សឆ្លាតដូចគ្នាទេ)

finage *n.m.* ទំហំឃុំ

finage *n.m.* ការធ្វើដែកស្និតឲ្យសុទ្ធ

(ដោយនេញវត្ថុធាតុលាយឡំចេញ)

final,e,als *a.* ផ្តាច់ព្រ័ត្រ, ដែលបញ្ចប់ (ឧ. un point final) ។ cause finale ហេតុសម្រេច (ហេតុក្រោយបំផុត ដែលនាំឲ្យសម្រេចបំណង) ។ *Gram.* ដែលប្រាប់បំណង ឬ ប្រាប់គោលដៅ (ឧ. les propositions finales sont introduites par les conjonctions «afin que», «pour que» etc...)។ *a.* & *n.f.* ព្យាង្គ ឬ ព្យញ្ជនៈចុងក្រោយបំផុតនៃពាក្យ ។ *Sports* វគ្គផ្តាច់ព្រ័ត្រ (ក្នុងកីឡា) ។ *Mus.* សម្លេងបញ្ចប់

finale ឬ **final** *n.m.Mus.* បទឬល្បះបញ្ចប់

finalement *adv.* ទៅទីបំផុត

finalisme *n.m.* អវសាននិយម

finaliste *n.m.* *Sports* អ្នកប្រកួតផ្តាច់ព្រ័ត្រ (ក្នុងកីឡា) ។ *Philos.* អ្នកអវសាននិយម

finalité *n.f.* ភាពវត្ថុដែលមានទីបញ្ចប់ឬដែលមានគោលដៅ

finance *n.f.* ប្រាក់ (ឧ. moyennant finance); វិជ្ជាជីវៈហេរញ្ញិក (ឧ. entrer dans la finance); ក្រុមហេរញ្ញិក (សរុបពួកហេរញ្ញិក)។ *pl.* ហិរញ្ញវត្ថុ(ឧ.l'administration des finances) ។ finances publiques ហិរញ្ញវត្ថុសាធារណៈ (ធនធានសាធារណៈ និងច្បាប់សម្រាប់ផ្គត់ផ្គង់ធនធាននោះ) ។ loi de finances ច្បាប់ហិរញ្ញវត្ថុ (ច្បាប់ស្តីអំពីការតាំងមុខចំណាយនឹងចំណូល) ។ *Fam.* ធនធាន, ប្រាក់ចំណូល (ឧ. ses finances sont en baisse)

financement *n.m.* ហិរញ្ញប្បទាន, ការផ្តល់ហិរញ្ញវត្ថុ

financer *v.i.* ធ្វើហិរញ្ញប្បទាន, ផ្តល់ហិរញ្ញវត្ថុ, ផ្តល់ប្រាក់(ឧ.on l'a fait financer); ផ្តល់ទុន ។ *v.t.* ទ្រទ្រង់ដោយហិរញ្ញវត្ថុ (ឧ. financer une entreprise)

financier,ère *a.* នៃហិរញ្ញវត្ថុ(ឧ. système financier)។*n.m.* ហិរញ្ញធិការ, ហិរញ្ញទិយុត្ត, អ្នកជំនាញខាងហិរញ្ញវត្ថុ; ឈ្មួញប្រិយវត្ថុ

financièrement *adv.* ខាងហិរញ្ញវត្ថុ

finasser *v.i.* ប្រើទីលោភាយ

finasserie *n.f.* ទីលោភាយ, ឧបាយកលអាក្រក់

finasseur,euse ឬ **finassier,ère** *n.* *Fam.* អ្នកប្រើទីលោភាយ

finaud,e *a.&n.* ឆ្លាត,ប៉ិនប្រសប់,ដែលមានកលល្បិច (មានឫកពាហោក់ដូចជាល្ងង់) (ឧ. paysan finaud)

finauderie *n.f.* ចរិតអ្នកឆ្លាតហើយធ្វើឫកដូចល្ងង់

finement *adv.* ដោយឆ្លាត, ដោយប៉ិនប្រសប់ (ឧ. s'exprimer finement)

finesse *n.f.* ភាពឆ្មារឬល្អិត(ឧ.finesse des cheveux); ភាពម៉ដ្ឋ [—ម៉ត់] (ឧ. finesse d'une étoffe); ភាពប្រសើរ ឬ ល្អិតល្អន់ (ឧ. finesse d'un vin, d'un parfum) ។ *Fig.* សេចក្ដីឆ្លាត,សេចក្ដីវាងវៃ (ឧ. finesse de l'esprit); របស់ពិបាកយល់ (ឧ. les finesses d'un jeu); វៃ (ឆាប់ចាប់ភាសាឬសូរ) (ឧ. finesse de l'ouïe)

fini,e *a.* ដែលមានព្រំដែន(ឧ.l'esprit de l'homme est fini); ហើយស្រេច; ឥតខ្ចោះ,ពេញលក្ខណៈ(ឧ.un coquin fini) ។ homme fini មនុស្សអស់ផ្លូវកែ (ដុនដាបខាងកម្លាំងកាយឬខាងកម្លាំងចិត្ត) ។ produit fini ម.ព. produit ។

n.m. អ្វីៗដែលមានព្រំដែន (ឧ. le fini et l'infini); ភាពឥតខ្ចោះ (ឧ. le fini d'un ouvrage)

finir *v.t.* បង្ហើយ,បញ្ចប់ (ឧ.finir une tâche); នៅខាងចុង (ឧ.le verbe, en latin, finit la phrase) ។

v.i. ផុត, ចប់;មានចុងជារាង... (ឧ.finir en pointe);ដល់កំរិត,ដល់ទីបញ្ចប់ (ឧ. son bail finit au Nouvel-An); ស្លាប់ (ឧ. il a fini dans la misère) ។

Loc.div. en finir បញ្ចប់, បង្ហើយ (ឧ. il est temps d'en finir) ។ n'en pas finir មិនចប់ (ឧ. avoir des disputes à n'en pas finir); *par ext.* ដែលនិយាយច្រើនពេក,វែងពេក(ឧ. c'est un homme qui n'en finit jamais); ធំវែងពេក (ឧ. avoir des bras qui n'en finissent pas)។ en finir avec quelqu'un ឬ avec quelque chose ដាត់ចេញ, រលាស់ចោល, លែងរវល់នឹង, យកចេញ។ finir de ឈប់, លែង (ឧ. finir de parler, de manger)។finir par ធ្វើ ឬ បានសម្រេចឬមានឡើងក្នុងទីបំផុត(ឧ.finir

par trouver; la raison finira par avoir raison-(D'Alembert)

finish *n.m.* (ព.អ.) ការខំប្រឹងផ្តាច់ព្រ័ត្រ (កីឡា)

finissage *n.m.* កិច្ចបង្ហើយ,ការសម្រេច

finisseur,euse *n.* អ្នកបង្ហើយ, អ្នកសម្រេច

finition *n.f.* ការបង្ហើយ , ការសម្រេច; ពេលបង្ហើយ

finlandais,e, *a.* នៃប្រទេសហ្វាំងឡង់។ *n.* ជនជាតិហ្វាំងឡង់

fiole *n.f.* កូនដប, ខួប

fion *n.m.Pop.* កិច្ចបង្ហើយ (ឧ. donner le coup de fion ធ្វើបង្ហើយ)

fioriture *n.f.* ការបំភ្លៃ (ក្នុងតន្ត្រី) ។ *Par ext.* គ្រឿងលំអបន្ទាប់បន្សំ; ពាក្យក្អែម(បន្ថែមឲ្យពីរោះ)(ឧ. parler sans fioriture)

firmament *n.m.* នភាល័យ, ផ្ទៃមេឃ

firman *n.m.* (ពាក្យទួរគី) រាជបញ្ញត្តិ(ជាលាយលក្ខអក្សរ)

firme *n.f.* ហ្វៀម (អង្គការឧស្សាហកម្ម ឬ ពាណិជ្ជកម្ម)

fisc *n.m.* គេនសម្បត្តិរដ្ឋ; ក្រុមការសារពើពន្ធ

fiscal,e,aux *a.* នៃសារពើពន្ធ

fiscalement *adv.* តាមសារពើពន្ធ

fiscaliser *v.t.* ដាក់ឲ្យជាប់ពន្ធ; តម្លើងពន្ធលើ

fiscalité *n.f.* ច្បាប់សារពើពន្ធ;សារពើពន្ធ; ការលំអៀងទៅរកដំឡើងពន្ធហួសប្រមាណ

fissile *a.* ងាយបែកជាបន្ទះ ឬ ជាសន្លឹកស្តើងៗ(ឧ. l'ardoise est fissile); អាចផ្ទុះបាន (បរមាណូ) (ឧ. matière fissile)

fission *n.f.* ការបែកជាភាគ ឬ ជាបន្ទះ, ការផ្ទុះ (បរមាណូ)

fissuration *n.f.* ការបែកប្រហែង

fissure *n.f.* ប្រហែងឬស្នាមប្រេះតូច ។ *Fig.* ការដាច់ (ឧ. les fissures d'un raisonnement)

fissurer *v.t.* ធ្វើឲ្យបែក,ធ្វើឲ្យបែកប្រហែង

fiston *n.m.Pop.* កូន (ពាក្យសាមញ្ញ)

fistol *n.m. Arg.mil.* សិស្សឆ្នាំទីមួយនៃសាលានាយទាហានជើងទឹក

fistulaire *a.* ដែលមានរន្ធតាមបណ្តោយបេសាប់(ឧ. stalactite fistulaire); តាមរន្ធបញ្ចេញសេមោចនា

fistule *n.f. Méd.* រន្ធបញ្ចេញសេមោចនា [រៈ-សៈ-មោ ចៈ-ណា] (ឧ. fis-

tule lacrymale រន្ធទឹកភ្នែក)

fistuleux,euse *a.* ជារន្ធបញ្ចេញសេ-មោចនា (ឧ. canal fistuleux)

five-o'clock [faï-vo-klok] *n.m.* (ព.អ.) អាហារស្រស់ស្រូបពេលម៉ោងប្រាំរសៀល

fixage *n.m.* ការភ្ជាប់, ការដៅទុក

fixateur,trice *a.* ដែលភ្ជាប់; សម្រាប់ភ្ជាប់ ។ *n.m.* ថ្នាំភ្ជាប់គំនូរ(មិនឲ្យហើរពណ៌)

fixatif,ive *a.* ដែលសម្រាប់ភ្ជាប់។ *n.m.* ថ្នាំភ្ជាប់គំនូរ (មិនឲ្យហើរពណ៌)

fixation *n.f.* ការធ្វើឲ្យនឹង,ការភ្ជាប់;ការដៅ; ការកម្រិត, ការតាំង (ឧ. fixation de l'impôt)

fixe *a.* នឹង (មិនកម្រើក) (ឧ. point fixe)។ roue fixe កង់ជាប់នឹងដុំឬភ្លៅ (ផ្ទុយនឹង roue libre)។ ជាប់នៅមួយកន្លែង (ឧ.regard fixe ការមើលមិនដាក់ភ្នែក); មិនប្រែប្រួល (ឧ. encre bleu fixe);ទៀង(ឧ.heure fixe); នឹង(ដែលកម្រិតទុកជាមុន) (ឧ. prix fixe)។ idée fixe គំនិតប្រកាន់ជាប់។

Chim. corps fixe អង្គភសិត (មិនហើរ)។ *n.m.* ផ្នែកនឹងនៃបៀវត្ស (ផ្នែកដែលមិនប្រែប្រួល) ។ *Int.* fixe! ស្ងៀម! (បញ្ជាទាហានឲ្យឈរស្ងៀម)

fixement *adv.* ដោយមិនប្រែប្រួល ។ regarder fixement មើលមិនដាក់ភ្នែក

fixer *v.t.* ធ្វើឲ្យនឹង, ធ្វើកុំឲ្យប្រែប្រួល; ភ្ជាប់, ចង (ឧ. fixer un tableau sur le mur); តម្រង់ភ្ជាប់ទៅ (ឧ. fixer les yeux au ciel)។*Fig.* សម្លឹង (ឧ. fixer quelqu'un) ។ *Fig.* កំណត់, បញ្ជាក់ (ឧ. fixer une heure); សម្រេច (ជាស្ថាពរ) (ឧ. fixer son choix); តាំងលំនៅ (ឧ. fixer sa résidence). ធ្វើឲ្យប្រុងឬឲ្យចាប់អារម្មណ៍(ឧ. fixer un esprit léger); ដាក់ថ្នាំភ្ជាប់ ។

se fixer *v.pr.* នៅជាប់(តាំងលំនៅជាប់) (ឧ. il s'est fixé à Kompong Cham)

fixité *n.f.* ភាពនឹង (ឧ. la fixité du regard) ។ *Fig.* ភាពមិនប្រែប្រួល (ឧ. la fixité des opinions)

flac! *int.* ផ្លាប់ (សូរវត្ថុទង្គិចគ្នា)

flaccidité *n.f.* ភាពទន់យោក,ភាពស្លេត

flache *a.* ទន់ (ឧ. avoir l'oreille

flache)

flache *n.f.* កន្លែងខ្វាក់គ្រើង (ឈើអាររឬឈូស); ភាពកម្រាលឥដ្ឋមិនរាបស្មើ (ដោយស្រុតដី); កន្លែងផ្លូវស្រុត (ផ្លូវអយស្ម័យយាន); ត្រពាំង (ក្នុងព្រៃ)

flacherie *n.f.* ជំងឺដង្កូវនាង

flacheux,euse *a.* ដែលខ្វាក់គ្រើង (ឈើ); ដែលស្រុត

flacon *n.m.* កូនដបផ្នែកកែវ; ដប (វត្ថុក្នុងដប) (ឧ. vider un flacon de parfum)

flaconnage *n.m.* សរុបកូនដប

flaconnier *n.m.* ស្រោមកូនដប

fla-fla *n.m. inv.* ការបញ្ចេញ,ការសំដែង (ឧ. faire du fla-fla ឬ des fla-fla)

flagellateur *n.m.* អ្នកវាយនឹងរំពាត់

flagellation *n.f.* ការវាយនឹងរំពាត់; ការវាយខ្លួនឯង

flageller *v.t.* វាយនឹងរំពាត់,ត្មះតិះដៀល

flageoler *v.i.* ញ័រជើង;មានដំណើរទ្រេតទ្រោត(ដោយរន្ធត់ ឬ ដោយអស់កម្លាំង)

flagorner *v.t.* បញ្ជោរដោយបោកទាប (ដោយដាក់ខ្លួន)

flagornerie *n.f.* ការបញ្ជោរដោយបោកទាប(ដោយដាក់ខ្លួនដើម្បីទាញប្រយោជន៍)

flagorneur,euse *n.* អ្នកបញ្ជោរដោយបោកទាប

flagrance *n.f.* ភាពស្តែង

flagrant,e *a.* ស្តែង (ឧ. une injustice flagrante) ។ flagrant délit បទល្មើសស្តែង (ដែលគេទាន់ក្នុងពេលកំពុងប្រព្រឹត្ត)

flair *n.m.* ឃានវិញ្ញាណឆ្កែ;ឃានវិញ្ញាណ, ការដឹងក្លិន ។ *Fig.* សេចក្តីឈ្លាសវៃ

flairer *v.t.* ស្រង់ក្លិន,ហិត (ឧ. flairer une rose) ។ *Fig.* ពិការ, មានប្រផ្នូល, ដឹងមុន (ឧ. flairer un danger)

flamant *n.m.* រនាល

flambage *n.m.* ការឆេះ

flambant,e *a.* ដែលឆេះ ។ charbon flambant ធ្យូងដុតឆេះល្អ ។ *Fam.* flambant neuf ថ្មីទេង(ថ្មីណាស់)

flambard ឬ **flambart** *n.m. Fig.& Fam.* មនុស្សអំនួត, មនុស្សក្រអឺតក្រអោង (ឧ. faire le flambard)

flambe *n.f.* ដាវផ្លែកង្កាញ់

flambeau *n.m.* ចន្លុះ, ចង្កៀងគោម, ប្រទីបទៀន (ឧ. retraite aux flambeaux); ជើងទៀន(ឧ. flambeau d'argent) ។ *Fig.* ស្មើបំភ្លឺ

ជ្ជា (ឧ. le flambeau de la science)

flambée *n.f.* ភ្លើងឆេះឆ្លា (ភ្លើងឆេះសម្រាបឬំកាច់ឈើភ្លឺឆ្លោឡើង)

flambement *n.m.* ការរោល; ការឆេះឆ្លោ

flamber *v.t.* រោលភ្លើង (ឧ.flamber une volaille) ។ *v.i.* ឆេះភ្លឺឆ្លោ (ឧ. bois qui ne flambe pas)។ *Fam.* être flambé វិនាស,ហិនហោច

flamberge *n.f.* ដាវវែង(សម្រាប់ប្រយុទ្ធគេប្រើក្នុងសតវត្សទី ១៧ និង ១៨)

flamboiement *n.m.* ពន្លឺរន្ទាល

flamboyant,e *a.* ស្វាច, រន្ទាល (ឧ. épée flamboyant) ។ *Blas.* ដែលមានភាពដូចអណ្ដាតភ្លើង ។ *n.m.* *Bot.* ដើមក្ងោក

flamboyer *v.i.* ឆេះឆ្លា, ឆេះរន្ទាល ។ *Par ext.* ភ្លឺពន្លឺដូចអណ្ដាតភ្លើង (ឧ. des yeux qui flamboient)

flamme *n.f.* អណ្ដាតភ្លើង ។ *Mar.* បេលឺមដាក់ចុងដងក្ដោងនាវាចម្បាំង (រាងត្រីកោណវែង) ។ *Mil.* បដាក្នុងលំពែង(មានកន្ទុយដែកវែង)។*Fig.* សេចក្ដីក្លៀវក្លា (ឧ.discours plein de flamme); សេចក្ដីស្នេហាខ្លាំង (ឧ. déclarer sa flamme) ។ *pl.* ទណ្ឌកម្មដុត (ឧ. livrer aux flammes ដាក់ទណ្ឌកម្មដុត) ។ les flammes éternelles ភ្លើងនរក

flammé,e *a.* ដែលមានស្នាមដូចរោលភ្លើង (ឧ. du grès flammé)

flammèche *n.f.* ផ្កាភ្លើង (កំទេចភ្លើងដែលហើរចេញពីភ្លើងឆេះ)

flammerole *n.f.* ភ្លើងអាប

flan *n.m.Pop.* ពាក្យចំអន់លេង (ឧ. c'est du flan) ។ à la flan ដោយខ្ជីខ្ជា, ដោយមិនយកចិត្តទុកដាក់

flanc *n.m.* កញ្ចៀតខ្លួន (អវយវៈប៉ែកត្រង់ចង្កេះ) ។ *Par ext.* ជំនីរ (ឧ. se coucher sur le flanc ដេកផ្អៀង)។ *Poét.*ផ្ទៃមាតា។*Par anal.* ខាង,ជំនីរ (ឧ. flancs d'un vaisseau, d'une montagne) ។ *Fig.* se battre les flancs ខំប្រឹងខ្លាំងដោយគិតបានផលប៉ុន្មាន ។ être sur le flanc ដេកដាប (ដោយមានជម្ងឺ); អស់កម្លាំង ។ prêter le flanc បើកឱកាសឲ្យ (ឧ. prêter le flanc à la calomnie) ។ *Pop.* tirer au flanc

គេចខ្លួនពីកាតព្វកិច្ច

flancher *v.i Fam.* ដក់ចោល, ទប់ទល់មិនបាន; មិនស៊ី

flandrin *n.m. Fam.* មនុស្សចង្រ្កាង

flanelle *n.f.* ហ្វ្លាណែល, សំពត់ស្តើង

flâner *v.i.* ដើរត្រេតត្រត (ឧ. flâner sur les boulevards); ខាតពេលវេលា

flânerie *n.f.* ការដើរត្រេតត្រត

flâneur,euse *n.* អ្នកដើរត្រេតត្រត

flanquement *n.m.* ការការពារពីខាងៗ tir de flanquement ការបាញ់ពីខាងឬពីចំហៀង

flanquer *v.t. Fortif.* ការពារពីខាង (ឧ. flanquer de tours des remparts)។ *Mil.* វាយឬបាញ់ពីខាងឬពីចំហៀង (ឧ.flanquer une position par des tirs de mitrailleuse); ត្រូវដាក់ពីខាង, ត្រូវដាក់ក្បៀត (ឧ.quatre plats flanquaient ce pâté); មានទៅជាមួយ (ឧ.flanquer de quelques complices); អមសងខាង

flanquer *v.t. Fam.* ចោល, បោះឬទះ យ៉ាងខ្លាំង (ឧ. flanquer une assiette par terre)។ flanquer quelqu'un à la porte បណ្តេញចេញ

flapi,e *a.* អស់កម្លាំង

flaque *n.f.* ថ្លុក

flash *n.m.* (ព.អ.) ចង្កៀងថតរូប (*pl.* des flashes)

flasque *a.* ទន់ឃោក, ស្លុត (ឧ. des joues flasques)

flat *a.m.* ដែលកើតជម្ងឺ (ដង្កូវនាង)

flatter *v.t.* អង្អែល (ឧ. flatter un cheval); ធ្វើឲ្យចាប់អារម្មណ៍, ធ្វើឲ្យស្រួល (ឧ. la musique flatte l'oreille); បញ្ជោរ, ប្រចុប, បញ្ចើច; តែងលំអ (ឧ. flatter un portrait)។ se flatter (de) *v.pr.* សង្ឃឹម; អួតខ្លួនថា (ឧ. se flatter d'être habile)

flatterie *n.f.* ចោមភិទ; ការបញ្ជោរ

flatteur,euse *n.* ចោមភិទ-ទិន, អ្នកបញ្ជោរ។ *a.* ដែលធ្វើឲ្យរីកចិត្ត ឬ ឲ្យធំមុខ (ឧ. éloge flatteur)។ *Par ext.* ដែលលើក, ល្អជាងសេចក្តីពិត (ឧ. portrait flatteur)

flatteusement *adv.* ដោយបញ្ជោរ, ដោយឲ្យធំមុខ

flatueux,euse *a.* ដែលឲ្យហើមពោះ

(ឧ. légume flatueux)

flatulence *n.f. Méd.* ការហើមពោះ; ការមានខ្យល់ឆក់ក្នុងខ្លួន; ការផោម

flatulent,e *a.* ដែលបណ្ដាលអំពីការហើមពោះ (ឧ. affection flatulente)

flatuosité *n.f. Méd.* ខ្យល់ឆក់ក្នុងពោះ (ដែលចេញតាមផោម ឬ តាមភើ)

flavescent,e *a.* លឿងទុំ

fléau *n.m.* ដំបៀតបោកស្រូវ; ដងជញ្ជីង; ដងរ៉ែក; ដែកទ្រុកទ្វារ ។ *Fig.* វិបត្តិភ័យ, មហាភ័យ (ឧ. la famine, la guerre sont de terribles fléaux); អ្នកបង្កវិបត្តិភ័យ ។ *Par exag.* អ្នករំខាន (ឧ. le bavard est un fléau dans une société)

fléchage *n.f.* ការដាក់សញ្ញាបង្ហាញផ្លូវ

flèche *n.f.* សរ, ព្រួញ; វត្ថុដែលមានរាងដូចព្រួញ; កំពូលរោងជួង ។ *Agric.* មែកឈើឡើងលើ (ឈើ); ដើមហេន (ដូចជាអំពៅ, ស្លាដាដើម)។ *Techn.* ចន្ទោល ។

Loc. div. en fer de flèche ជារាងចតុរង្សទ្រវែងស្រួច ។ en flèche តាមបន្ទាត់ត្រង់; *au fig.* លឿនភ្លែត (លឿនណាស់) (ឧ. monter en flèche) ។ chevaux en flèche សេះទឹមមុខក្រោយ ។ *Fig.* faire flèche de tout bois ប្រើមធ្យោបាយគ្រប់បែបឱ្យបានសម្រេចតាមបំណង។ ne savoir de quel bois faire flèche អស់ផ្លូវ, អស់មធ្យោបាយ

flèche *n.m.* បន្ទះខ្លាញ់ជំនីរជ្រូក (ពីស្មាទៅភ្លៅ)

fléché,e *a.* ដែលលំអរដោយព្រួញ

flécher *v.t.* ដាក់សញ្ញាព្រួញបង្ហាញផ្លូវ

fléchette *n.f.* ព្រួញតូច

fléchir *v.t.* ពត់, បន្ទន់ (ឧ. fléchir le genou); ធ្វើឱ្យទន់ចិត្តឬឱ្យអាណិត (ឧ. fléchir ses juges) ។ *v.i.* ផត, ពាប់ (ដោយរងបន្ទុកធ្ងន់ពេក) (ឧ. poutre qui fléchit); ចុះទន់ខ្សោយ, បោះបង់ចោល (ឧ. l'ennemi commençait à fléchir); ចុះថយ (ឧ. les prix ont fléchi)។ *Fig.* ចុះចាញ់ (ឧ. tout fléchissait sous lui)

fléchissement *n.m.* ការពត់, ការបន្ទន់; ការទន់ចិត្ត; ការពាប់, ការចុះ (ឧ. le fléchissement d'une poutre, des prix)

fléchisseur *a.m.Anat.* ដែលយឹត, ដែលនាំឲ្យពត់បាន(សាច់ដុំ)(ឧ. muscle fléchisseur du bras) ។ *n.m.* សាច់ដុំយឹត

flegmatique *a.* ដែលបេះទប់សេចក្ដីរំភើបចិត្តបាន; ដែលមិនសូវនិយាយស្ដី; ដែលមិនបញ្ចេញអាការៈ, ដែលធ្វើធ្ងង

flegmatiquement *adv.* ធ្ងង, ទ្រមឹង

flegme *n.m.* ចរិតមនុស្សមិនសូវនិយាយស្ដីឬមិនងាយនឹងធ្វើឲ្យរំភើប; ស្រាសុទ្ធ; កំហាក, ស្លេស្ម (ក្នុងន័យនេះគេសរសេរជា phlegme ក៏បាន)

flegmon *n.m.* ម.ព. phlegmon

flein *n.m.* កញ្ច្រែង ឬ កន្ត្រកដាក់ផ្លែឈើ

flemmard,e *n.&a.Pop.* កម្ជិល

flemme *n.f.Pop.* សេចក្ដីខ្ជិលច្រអូសខ្លាំង (កម្ជិលដៃ) (ឧ. avoir la flemme) ។ battre ឬ tirer sa flemme មិនធ្វើអ្វីសោះ

flétrir *n.f.* ធ្វើឲ្យស្រពោន-ឲ្យស្រពាប់ឬឲ្យបាត់សម្រស់ (ឧ. le vent flétrit les fleurs) ។ *Fig.* ធ្វើឲ្យទន់ខ្សោយឬឲ្យខូច(ឧ. l'abus des plaisirs flétrit la jeunesse) ។ se flétrir *v.pr.* ស្រពោន, ស្វោក

flétrir *v.t. Fig.* បន្ទោស, ត្មះតិះដៀល (ឧ. flétrir le vice, l'injustice)

flétrissure *n.f.* ការស្រពោន,ការស្វោក

flétrissure *n.f.Fig.* ទុយស

fleur *n.f.* បុប្ផា, ផ្កា ។ *Par ext.* បុប្ផព្រឹក្ស, រុក្ខជាតិដែលមានផ្កា, ដើមផ្កា (ឧ. la culture des fleurs); គំនូរឬរូបផ្កា, លំអង (ឧ. fleur de farine); បឋមវ័យ(វ័យដែលនៅមានកម្លាំងនិងមានលំអកាយបរិបូណ៌) (ឧ. être à la fleur de l'âge នៅក្នុងបឋមវ័យ); ជំរើស, សម្រាំង (ឧ. fleur de la jeunesse); ម្សៅផ្លែពេរ (ឧ. fleur de la prune) ។ *Fig.* សម្រស់ (ឧ. la fleur du teint); សម្រស់ឆាប់វិនាស (មិនថិតថេរយូរ) (ឧ. cette étoffe est d'une belle couleur, mais elle n'a que la fleur); តម្រេក, លំអឬសោភពបញ្ឆោត (ឧ. semer de fleur le chemin de la vie); ការបានឃើញ ឬ បានប្រើមុនគេ (ចំពោះរបស់ទើបនឹងមាន) (ឧ. j'ai eu la fleur de cette étoffe) ។ *pl.* ផ្សិត (ដុះលើស្រា, បារែឬទឹកខ្មេះត្រូវខ្យល់)។

Loc. pré. à fleur de

នៅប៉ប្រះ, នៅស្មើ (ឧ. à fleur du sol; à fleur de l'eau): *au fig.* នៅស្មើ (ឧ. la sensibilité est à fleur de la peau)។ à fleur de la tête ត្រឹមថ្ងាស។

Loc. div. la fleur du lis រាជាធិបតេយ្យ។ fleur de virginité ឬ fleur ព្រហ្មចារ្យ (ឧ. une fille ne rougit plus de perdre sa plus belle fleur)។ fleur de macadam ស្រីផ្កាមាស។ serpent caché sous des fleurs គ្រោះថ្នាក់ឬអំពើអាក្រក់ដែលបំពួនក្នុងសភាពក្រៅល្អ។ semer ឬ jeter ឬ répandre des fleurs sur la tombe de quelqu'un សរសើរបុគ្គលស្លាប់ទៅហើយ។ couvrir quelqu'un de fleurs សរសើរ

fleurage *n.m.* ផ្ការចនានៅផ្ទៃសំពត់ ក្រដាសជញ្ជាំង ឬ នៅផ្ទៃកម្រាល

fleuraison *n.f.* ម ព. floraison

fleurant,e *a.* ដែលកាយក្លិន

fleurer *v.i.* កាយក្លិន(ឧ. cela fleure bon)

fleuret *n.m.* ដាវស្រោបក្បុង (សំរាប់គុនដាវ); ប្រដាប់ដឹកថ្មក្នុងអណ្ដូងរ៉ែ; សរសៃក្រណាត់សូត្រ

fleurette *n.f.* ផ្កាតូច។ *Fig.* សំដីលៃបចង់ (ឧ. conter fleurette)

fleuri,e *a.* ដែលមានផ្កាផើរផាស (ឧ. jardin fleuri) ។ *Fig.* style fleuri របៀបនិពន្ធមានលំអ ។ teint fleuri សម្បុរស្រស់ ឬ ឆើត

fleurir *v.i.* ផ្កា, មានផ្កា (ឧ. les perce-neige fleurissent de bonne heure) ។ *Fig.* ចំរើន, ដុះដាល, លូតលាស់ (ឧ. le commerce fleurit) ។ *v.t.* តែងលំអដោយផ្កាភ្ញី (ឧ. fleurir sa chambre)

fleurissant,e *a.* ដែលមានផ្កាផើរផាស

fleuriste *n.&a.* ដែលដាំ ឬ លក់ផ្កា; ដែលធ្វើឬលក់បុប្ផសិប្បនិម្មិត(ផ្កាក្លែង)

fleuron *n.m.* ភ្ញីទេស, ក្បាច់រូបផ្កា។ *Fig.* le plus beau fleuron គុណវិសេសបំផុត ។ ផ្កាតូចៗក្នុងកញ្ចុំ ។ *Art graph.* ភ្ញីទេសដាក់លំអនៅចុងវគ្គសៀវភៅ

fleuronnée *a.* លំអដោយភ្ញីទេស (ឧ. diadème fleuronné) ។ *Bot.* ដែលមានសុទ្ធតែកូនផ្កាតូចៗ

fleuronner *v.t.* លំអដោយភ្ញីទេស

fleuve *n.m.* ទន្លេ។ *Fig.* អ្វីៗដែលហូរ

មិនដាច់ (ឧ. des fleuves de larmes)

flexibilité *n f.* ភាពទន់, ភាពអាចពត់បាន

flexible *a.* រលាស់,អាចពត់បាន(ឧ. roseau flexible) ។ *Fig.* caractère flexible ដែលចេះបង្អោនតាមកាលទេសៈ ។ esprit flexible ដែលអាចសិក្សាបានគ្រប់មុខ

flexion *n.f.* ការពត់, ការបត់ (ឧ. flexion du genou);ភាពលាស់ (ឧ. flexion d'un ressort) ។ *pl. Gram.* ការឡើងចុះនៃសម្លេងត្រង់ចុងពាក្យ

flexionnel,elle *a. Gram.* ដែលមានសម្លេងចុងពាក្យឡើងចុះ(ឧ. l'allemand est une langue flexionnelle)

flexueux,euse *a.* យេកយោក (ដែលទន់ទោរទៅគ្រប់ទិស)

flexuosité *n.f.* ភាពយេកយោក (ឧ. la flexuosité d'une tige)

flibuste *n.f.* អំពើប្លន់; ការប្លន់តាមសមុទ្រ, ក្រុមចោរប្លន់

flibuster *v.i.&t.* លួច, ប្រវ័ញ្ច

flibustier *n.m.* ចោរប្លន់តាមសមុទ្រ ។ *Par ext.* អ្នកប្រវ័ញ្ច

flic *n.m.Pop.* ភ្នាក់ងារប៉ូលិស

flingot *n.m.Pop.* កាំភ្លើងចម្បាំង

flirt *n.m.* [fleurt'](ព.អ.)ការចែចង់; ការទាក់ទងគ្នាដោយស្នេហា; អ្នកដែលគេចែចង់ ។ *a.* ដែលជាប់ចិត្តទៅខាងចែចង់គ្នា (ឧ. jeune fille flirt)

flirter *v.i.* [fleur-te] ចែចង់; ទាក់ទងគ្នាដោយស្នេហា

flirteur,euse *a.* ដែលចែចង់, អ្នកចែចង់

floc! *int.* ផ្លូក !

floche *a.* ទន់ល្វៀយ; ដែលមានរោមពាសពេញ ។ soie floche សូត្រមិនធំពាក់

flocon *n.m.* សំណុំសូត្រ, សំណុំរោមសត្វ; ដុំតូចស្រាល ។ *pl.* គ្រាប់ធញ្ញជាតិកិនបំបែក

floconner *v.i.* កជាសំណុំ, កជាដុំ

floconneux,euse *a.* ជាសំណុំ,ជាដុំតូច

flopée *n.f.Pop.* ចំនួនច្រើន

floraison *n.f.* បុប្ផការ, ដំណើររីកផ្កា; បុប្ផកាល, រដូវផ្កា

floral,e,aux *a.* នៃផ្កា(ឧ.enveloppe florale)

flore *n.f.* ពពួករុក្ខជាតិដុះក្នុងតំបន់មួយ

florée *n.f.* ធ្នះធុនអន់

florès [—rèss] *Fam.* faire florès

កើតក្នុងចំណោម, ត្រូវសម័យ (សៀវភៅ ពាក់)

floricole *a.* បុប្ផាស្រ័យ, ដែលរស់នៅលើផ្កា (ឧ. insecte floricole)

floriculture *n.f.* បុប្ផវប្បកម្ម(ការដាំផ្កា)

florifère *a.* ដែលមានផ្កា, ដែលផ្កាច្រើន (ឧ. rameaux florifères)

florilège *n.m.* កម្រងកវីនិពន្ធ

florissant,e *a.* រុងរឿង, ចម្រុងចម្រើន (ឧ. pays florissant); បរិបូណ៌; ស្រស់បំប្រែ (ដោយមានសុខភាពល្អ) (ឧ. mine florissante)

flot *n.m.* ទឹករំជួល,រលក (ឧ. flot de la mer); ទឹកជោរ (ឧ. attendre le moment du flot)។ *Fig.* ហ្វូង,ចំនួនច្រើន (ឧ. flots d'auditeurs; flot de sang) ។ *pl. Poét.* សមុទ្រ, ទឹកសមុទ្រ-ទន្លេធំ (ឧ. la fureur des flots) ។

Loc. div. être à flot អណ្តែត(នាវា); *au fig.* លែងត្រូវរះពីកិច្ចការឬអំពីការខ្វះប្រាក់;លែងលំបាកក្នុងមុខរបរ (ក្នុងន័យនេះគេអាចថា: avoir sa barque à flot ឬ se remettre à flot ក៏បាន)។ faire couler des flots d'encre ជាហេតុឱ្យគេសរសេរច្រើន (សរសេរចុះកាសែតឬសៀវភៅ) ។ des flots de bile សំដីទ្រគោះខ្លាំងចំពោះអ្នកណាម្នាក់ ។

Loc. adv. à flots យ៉ាងច្រើន, ដោយបរិបូណ៌

flottabilité *n.f.* ភាពអាចអណ្តែតបាន

flottable *a.* អាចអណ្តែតបាន(ឧ. bois flottable); អាចបណ្តែតឈ្នួនបាន (ឧ. rivière flottable)

flottage ឬ **flot** *n.m.* ការបណ្តែតឈ្នួនឈើ

flottaison *n.f. Mar.* កន្លែងដែលផ្ទៃទឹកនឹងប៉ះសំពៅ ។ ligne de flottaison បន្ទាត់ផ្ទៃទឹកលើស្មុកនាវា

flottant,e *a.* ដែលអណ្តែត; ទូលាយ; ដែលបក់រំភើយ (ឧ. robe flottante)។ *Fig.* សាញ,មិនដាច់ស្រេច,មិននឹង (ឧ.esprit flottant)។ dette flottante បំណុលមិននឹង(អាចឡើងឬចុះបាន)

flottard *n.m. Arg. scol.* សិស្សរៀនប្រឡងចូលសាលានាវាសឹក

flotte *n.f.* កងនាវាសមុទ្ទ,កំឡាំងទ័ពជើងទឹកនៃប្រទេសមួយ (ឧ.flotte française); កងអាកាសយាន (ឧ. une

flotte aérienne)។ *Pop.* ទឹក(ឧ. piquer une tête dans la flotte); ភ្លៀង (ឧ. il tombe de la flotte)

flotte *n.f.* កំសួល; ពោង

flottement *n.m.* ភាពអណ្ដែត, ដំណើរមិនរៀបរយ (ចំពោះកងទ័ពកំពុងដើរ)។ *Fig.* ការស្ទាក់ស្ទើរ, ការរារែក

flotter *v.i.* អណ្ដែត, ហើររំភើយ (ឧ. ses longs cheveux flottaient au vent) ។ *Fig.* ស្ទាក់ស្ទើរ, រារែក (ឧ. flotter entre l'espérance et la crainte)។ bois flotté ឈើបណ្ដែតតាមស្ទឹង ។ *v.imp. Pop.* ភ្លៀង(ធ្លាក់ភ្លៀង)

flotteur *n.m.* អ្នកបណ្ដែតឈើ ; វត្ថុដែលអណ្ដែត, កំសួល (ឧ. flotteur d'une ligne de pêche); ពោង (ឧ. flotteur d'un hydravion)

flottille *n.f.* កងនាវាតូច (ឧ. flottille de torpilleurs): កងអាកាសយាន ។ service de la flottille du Royaume ក្រុមពិភក្ដិនាវានៃព្រះរាជអាណាចក្រ

flou,floue *a.* មិនច្បាស់(ឧ. un dessin flou)។ *Cout.* មិនបានរឹតឲ្យត្រូវខ្លួន(សំលៀកបំពាក់) ; ស្រអាប់, ពើល (ឧ. tout devient flou avec la nuit); មិនច្បាស់លាស់ (ឧ. idée floue)

fluage *n.m.* ការហូរ (ចំពោះលោហធាតុត្រូវកំដៅខ្លាំង)

fluctuation *n.f.* ដំណើរងើបងោចនៃទឹក ។ *Fig.* អចិរភាព, ដំណើរប្រែប្រួល(ឧ. fluctuation des prix)

fluctuer *v.t.* យោល; ប្រែប្រួល; ស្ទាក់ស្ទើរ

fluer *v.i.* ហូរ

fluet,ette *a.* កំប្រៀវ, ចង្អៀវ (ឧ. une taille fluette)

fluide *a.* សន្ទនីយ, ងាយប្រែទ្រង់ទ្រាយ (ដោយគ្មានរូបខ្លួនឯងដូចយ៉ាងខ្យល់ទឹកជាដើម) ។ *Par ext.* សន្ទនីយ, រាវ (មិនខាប់) (ឧ. encre trop fluide) ។ *n.m.* សន្ទនីយវត្ថុ

fluidifier *v.t.* ធ្វើឲ្យទៅជាសភាពសន្ទនីយ

fluidique *a.* នៃអង្គសន្ទនីយ

fluidité *n.f.* សន្ទនីយភាព, ភាពរាវ ។ *Fig.* ភាពស្រួល ឬ រអិល

fluor *n.m.* ហ្វ្លុយអ័រ (ឧស្ម័នមួយយ៉ាង)

fluorescence *n.f.* លក្ខណៈនៃវត្ថុដែលទទួលពន្លឺពីគេហើយបញ្ចាំងពន្លឺនោះទៅ

វិញ

fluorescent,e *a.* ដែលទទួលពន្លឺពីគេ ហើយបញ្ចាំងពន្លឺនោះទៅវិញ

fluorure *n.m.* ហ្វ្លុយអរួ

flûte *n.f.* ខ្លុយ, ប៉ី; អ្នកផ្លុំខ្លុយ; នំប៉័ងតូចវែង; កែវជើង ។ *pl.Fam.* ជើង ។ jouer des flûtes រត់ (ឲ្យរួចខ្លួន)

flûté,e *a.* ពីរោះ (ដូចសម្លេងខ្លុយ) (ឧ. voix flûtée)

flûter *v.i.* ផ្លុំខ្លុយឬប៉ី; កញ្ជ្រៀវ (សារិកាកែវ)

flûtiste ឬ **flûteur,euse** *n.* អ្នកផ្លុំខ្លុយឬប៉ី

fluvial,e,aux *a.* នៃផ្លូវទឹក (ទន្លេ-ស្ទឹង ។ល។) (ឧ. érosion fluviale)

fluviatile *a.* នៃទន្លេ, នៃទឹកហូរ (ឧ. des dépôts fluviatiles)

fluviomètre *n.m.* ប្រដាប់ស្ទង់កំពស់ទឹកទន្លេ

flux *n.m.* ជំណោរជោរ (ទឹកសមុទ្រ) ។ *Fig.* ចំនួនច្រើន (ឧ. un flux de paroles)។ *Méd.*ការហូរ(ឧ.flux de sang) ។ flux du ventre រោគចុះរាក

fluxion *n.f.* ការពងខ្ទុះ (ឧ. une fluxion à la joue)

F.O.B. (ពាក្យបំព្រួញនៃ Free On Board) តម្លៃដល់នាវា

foëne ឬ **fouëne** *n.f.* ស្នូធំ

fœtal,e,aux *a.* នៃគភ៌ (ទារកដែលនៅក្នុងផ្ទៃ)

fœtus *n.m.* គភ៌, ទារកដែលនៅក្នុងផ្ទៃ (ពី ៤ ខែដល់ប្រសូត)

foi *n.f.* ពាក្យសច្ចៈ(ចំពោះកិច្ចសន្យា);ចិត្តភក្តី,សេចក្តីស្មោះត្រង់ (ឧ. donner un gage de sa foi); ការគាំពារ (ឧ. la foi des traités); ការជឿឬការទុកចិត្ត (ឧ. témoin digne de foi; avoir foi en l'avenir); សទ្ធា,ជំនឿចំពោះសាសនា(ឧ.avoir foi);សាសនាដែលគេជឿ (ឧ.mourir pour la foi); អធិមោក្ខ,ជំនឿផ្តាប់មុខ (ឧ. foi patriotique) ។

Loc. div. bonne foi សុទ្ធចិត្ត ។ mauvaise foi អសុទ្ធចិត្ត ។ en bonne foi ឬ de bonne foi ដោយសុទ្ធចិត្ត ។ de mauvaise foi ដោយអសុទ្ធចិត្ត (ដោយដឹងច្បាស់ជាខ្លួននិយាយមិនពិត)។ sur la foi de ដោយទុកចិត្តលើ ។ sur la foi des traités ដោយអនុលោមតាមអាកប្បកិរិយាជនសុចរិត ។

faire foi គួរឲ្យជឿ (ឧ. un témoignage ne fait foi que lorsqu'il est désintéressé); ជាភស្តុតាង, ជាបន្ទាល់ (បង្ហាញភស្តុតាង) (ឧ. papiers qui font foi d'un paiement) ។ foi de ខ្ញុំសុំស្បថដោយសំអាងលើ ។ jurer sa foi ស្បថដោយសំអាងលើកិត្តិយសខ្លួន ។ foi jurée កាតព្វកិច្ចដែលត្រូវបំពេញតាមសំបថខ្លួន ។ article de foi សិទ្ធន្តជំនឿ (ចំណុចក្នុងគ្រិស្តសាសនាដែលត្រូវតែជឿតាម); វត្ថុដែលគួរឲ្យជឿពេញទី (ឧ. vos paroles sont pour moi des articles de foi) ។ acte de foi ការយល់ព្រមតាមសិទ្ធន្តសាសនា; ការយល់ព្រមតាមដោយឥតពិចារណា (ឧ. toute science commence par un acte de foi) ។ n'avoir ni foi ni loi គ្មានសាសនាគ្មានមនសិការ (មិនខ្លាចបុណ្យបាបឬខ្លាចទោសអ្វីសោះ) ។ voir quelque chose des yeux de la foi ជឿដោយមិនបានពិនិត្យផ្ទាល់ខ្លួន ។ foi qui transporte les montagnes តែមានជំនឿហើយធ្វើអ្វីកើតទាំងអស់ ។ en foi de quoi ជាបន្ទាល់ក្នុងកិច្ចនេះ ។ profession de foi ការថ្លែងមតិឬថ្លែងជំនឿ ។ ma foi, par ma foi ឬ sur ma foi ដោយពិត

foie *n.m.* ថ្លើម ។ foie gras ថ្លើមក្ងានបំប៉នចំណី (ឧ. pâté de foie gras) ។ *Pêch.* ត្រីចង្វាសម្រាប់ធ្វើនុយ ។

Loc. div. chaleur de foie ផ្ដួតនៅមុខ (ដែលគេស្មានថាបណ្ដាលមកអំពីភេគថ្លើម); *fig.* កំហឹងខ្លាំង ។ avoir bon foie ចិត្តធ្ងន់, មិនរឹង ។ avoir foie blanc មិនធ្វើអ្វីដូចគេឯង ។ le cœur lui devient foie អស់សេចក្ដីក្លៀវក្លា ។ foie chaud ភេគឃ្លានច្រើន ។ il a le foie trop chaud ការប្រពន្ធលើសពីពីរដង ។ *Pop.* avoir les foies ខ្លាច

foin *n.m.* ស្មៅស្ងួត; ស្មៅ (ដែលគេច្រូតហាលទុកជាចំណីសត្វ)(ឧ. faire les foins); ស្មៅដែលគេបំរុងនឹងច្រូត ។ *Fig.* être bête à manger du foin ល្ងង់ដូចសត្វ ។ avoir du foin dans ses bottes មានធនធាន ។ mettre du foin dans

ses bottes សំរៃប្រាក់ទុកទៅអនាគត ។ chercher une aiguille daus une botte de foin ម.ព. chercher ។ faire ses foins បានកំរៃ ។ *Pop.* faire du foin ធ្វើឲ្យឮ

foirail ឬ **foiral** *n.m.* ទីតាំងផ្សារណាត់

foire *n.f.* ផ្សារណាត់;ការតាំងមហោស្រពពិព័រណ៍ពាណិជ្ជកម្ម)។ foire internationale ការតាំងមហោស្រពអន្តរជាតិ ។ champ de foire ទីតាំងផ្សារណាត់។ *Fam.* ដំណើរអ៊ូអែ, ការជ្រួលច្របល់

foire *n.f.Pop.* រោគចុះរាក

foirer *v.i.Pop.* ព្រាធះ, យឺត (ចំពោះកាំភ្លើងដែលបាញ់ព្រាចេញ)(ឧ. fusée qui foire); ឡេក (ចំពោះធ្មេញខ្វៅឡេកស៊ីដែលរេចរស់លែងជាប់) ; មិនបានសម្រេច(ឧ.affaire qui foire)

foireux,euse *n.&a Pop.* ដែលចុះរាក ។ *Fig. & Pop.* កម្សាក

foirolle *n.f.* រុក្ខជាតិម្យ៉ាងប្រើជាថ្នាំបញ្ចុះ

fois *n.f.* ដង, គ្រា, កាល (ឧ. il est venu deux fois) ។

Loc.adv. une fois កាលនោះ (ឧ. il y avait une fois... កាលនោះមាន...) ។ une fois pour toutes ឲ្យស្រេចតែម្តង, ជាស្ថាពរ។ à la fois ឬ tout à la fois ជាមួយគ្នា, ស្មើគ្នា, ព្រមគ្នា ។ par fois ក្នុងពេលខ្លះ,ជួនកាល(ច្រើនតែសរសេរជាប់គ្នាជា parfois) ។ de fois à autre (ឬ fois et autre) យូរៗម្តង,ម្តងៗ ។

Loc. div. cette fois ក្នុងកាលៈទេសៈនេះ; ម្តងនេះ។ d'autre fois ក្នុងកាលៈទេសៈដទៃទៀត ។ toutes les fois que រាល់ដងដែល ។ une bonne fois ឬ une bonne fois pour toutes ក្នុងទីបំផុត, ដោយដាច់ខាត ។ des fois ដោយជាប់ជួន; *pop.* ជួនកាល។ une fois que កាលបើ។ y regarder à deux fois ឬ à plusieurs fois គិតឲ្យល្អិតល្អន់មុននឹងធ្វើ។ encore une fois ម្តងទៀត ។ pour la dernière fois (ខ្ញុំជា ឬ ប្រាប់) ជាលើកក្រោយបង្អស់ ។ ne pas se faire dire une chose deux fois កុំចាំឲ្យគេនិយាយ (ត្រូវធ្វើភ្លាម)

foison *n.f.* ភិយ្យោភាព,ចំនួនច្រើនក្រៃលែង ។ à foison *loc. adv.* ជា

ភិយោភាព,ដោយបរិបូណ៌,ដោយច្រើន

foisonnant,e *a.* ដែលមានច្រើន

foisonnement *n.m.* ការមានច្រើន (ឧ. foisonnement de mauvaises herbes); ការរីក (ចំរើនទំហំ)

foisonner *v.i.* មានច្រើន; រីក (ចំរើនទំហំ) (ឧ. la chaux vive foisonne sous l'action de l'eau)

fol,folle *n.&a.* ម.ព. fou

folâtre *a.* សប្បាយ, ដែលចូលចិត្តលេងសើច (ឧ. les enfants sont folàtres); សម្រាប់អ្នកសប្បាយ (ឧ. jeux folàtres)

folâtrer *v.i.* ចូលចិត្តលេងសើច, លេងសើចដូចក្មេង

folâtrerie *n.f.* ការលេងសើចសប្បាយ; ចរិតអ្នកលេងសើចសប្បាយ

foliacé,e *a.* ដែលជាស្លឹក, ដូចស្លឹក (ឧ. pétioles foliacés)

foliaire *a.* នៃស្លឹក

foliation *n.f.* របៀបស្លឹកដុះលើមែក; រដូវបែកស្លឹក

folichon,onne *a. Fam.* ដែលសប្បាយដូចឆ្កួត; ដែលមានលំនាំសប្បាយដូចឆ្កួត (ឧ. des airs folichons)

folichonner *v.t. Fam.* លេងសើចសប្បាយ (ដូចក្មេង)

folie *n.f* ភេតវិកលចរិត; ដំណើរឆ្កួត (ឧ. un accès de folie); អំពើល្ងង់ឬឆ្វេសប្រហែស (ឧ. faire une folie); ការប្រព្រឹត្តខុសឥតខ្វល់ (ឧ. folie de jeunesse) ។ aimer à la folie ឬ avec folie ស្រឡាញ់ឆ្កួត (ស្រឡាញ់វក់)

folié,e *a. Bot.* នៃដើមរុក្ខជាតិត្រង់មានស្លឹក ។ *Chim.* ដែលមានសណ្ឋានជាបន្ទះស្តើងៗ

folio *n.m.* សន្លឹក(សៀវភៅឬបញ្ជី); លេខទំព័រ ។ folio recto ឬ recto ម.ព. recto ។ folio verso ឬ verso ម.ព. verso ។ in-folio ម.ព. in folio (*pl.* des folios)

foliole *n.f.* កូនស្លឹក

foliotage *n.m.* ការបង់លេខទំព័របញ្ជី

folioter *v.t.* បង់លេខទំព័របញ្ជី

folklore ឬ **folk-lore** *n.m.* ប្រពៃណីនិងទំនៀមទម្លាប់អ្នកស្រុក

folklorique *a.* នៃប្រពៃណីនិងទំនៀមទម្លាប់អ្នកស្រុក

folkloriste *n.* អ្នកសិក្សាប្រពៃណីនិង

ទំនៀមទម្លាប់អ្នកស្រុក

folle *n.f.* មងសាទុំបករណ៍ចាប់ត្រី (មានក្រឡាធំៗសម្រាប់ចងសន្ទូង)

folle *a.&n.* ម.ព. fou

follement *adv.* ដោយឆ្កួត, ហួសពេក

follet,ette *a.* ដែលធ្លាប់តែធ្វើឬនិយាយផ្តេសផ្តាស (ដូចឆ្កួត) ។ poil follet ពុកចង្កាដុះដំបូង; រោមកៅកូនបក្សី ។ lutin follet បិសាចប៉ប៉ុលប៉ប៉ូច ។ feu follet ម.ព. feu ។ esprit follet ម.ព. esprit

follicule *n.m.* ផ្លែឈើមានស្រោម;ផ្លាក (អាការៈក្នុងខ្លួន)

fomentateur,trice *n.&a.* ដែលញុះញង់; អ្នកបង្កចលាចល

fomentation *n.f.* ការស្អំ ឬ ពពោកថ្នាំ; ការញុះញង់

fomenter *v.t.* ស្អំ,ពពោកថ្នាំ, ញុះញង់, បង្កចលាចល (ឧ. fomenter des troubles)

fonçage *n.m.* ការជីករន្ធ;ការដាក់ពណ៌ហើន ឬ ផ្ទៃ

foncé,e *a.* ចាស់, ក្រមៅ (សម្បុរ) (ឧ. étoffe d'un vert foncé)

foncement *n.m.* ការជីក(ឧ.foncement d'un puits)

foncer *v.t.* ដាក់បាតធុង; ជីក (ជីកត្រង់ទៅក្រោម)(ឧ.foncer un puits); ទ្រាប់បាត(គ្រឿងបំពីនមានផ្ទាំងជាដើម) (ឧ. foncer un moule à gâteaux);ធ្វើឲ្យឡើងពណ៌ក្រមៅ។ *v.i.* សម្រុកចូល, រុល (ឧ. foncer sur l'ennemi)។ *Fam.* រត់,ទៅយ៉ាងលឿន

foncier,ère *a.* នៃដីជាមូលនិធិ (ឧ. propriété foncière) ; ដែលបានមកពីដីមូលនិធិ (ឧ. revenu foncier); ដែលជាម្ចាស់អចលនវត្ថុ (ដី,ផ្ទះជាដើម) (ឧ. propriétaire foncier) ។ *Fig.* សំខាន់(លក្ខណៈសំខាន់នៃចរិត) (ឧ. qualité foncière)។ *n.m.* ពន្ធដី ។ bureau foncier ការិយាល័យភូមិបាល

foncièrement *adv.* ណាស់, ជាដាច់ខាត (ឧ. être foncièrement honnête)

fonction *n.f.* ប្រព្រឹត្តិការណ៍; ការកាន់ដំណែង (ឧ.entrer en fonction ចូលកាន់ដំណែង); មុខការ, មុខងារ, ដំណែង (ឧ. s'acquitter de ses fonctions បំពេញមុខការខ្លួន) ។ faire fonction de មានមុខងារជា,

បំពើង។ *Loc. pré.* en fonction de តាមការប្រែប្រួលនៃ។ fonction de nutrition មុខងារនៃពោសនា

fonctionnaire *a.* អ្នករាជការ, មន្ត្រី ។ fonctionnaire détaché អ្នករាជការផ្លាប់តំណែង

fonctionnarisation *n.f.* ការបញ្ចូលជាមន្ត្រី;ការរៀបចំជាក្រសួងសាធារណៈ

fonctionnariser *v.t.* បញ្ចូលជាមន្ត្រី; រៀបចំជាក្រសួងសាធារណៈ

fonctionnarisme *n.m.* មន្ត្រីនិយម (ការនិយមប្រើវិន័យនឹងរបៀបតាក់ការយ៉ាងតឹងតែង)

fonctionnel,elle *a.* នៃដំណើរអាការៈក្នុងខ្លួន (ឧ. troubles fonctionnels); ដែលសម្រាប់ប្រើការក្នុងមុខណាមួយ (ឧ. l'architecture fonctionnelle)

fonctionnement *n.m.* ការប្រព្រឹត្តទៅ; ការដើរ (ម៉ាស៊ីន)

fonctionner *v.i.* ប្រព្រឹត្តទៅ; ដើរ(ម៉ាស៊ីន) (ឧ. machine qui fonctionne automatiquement)

fond *n.m.* បាត (ឧ. le fond d'un puits, d'une mer); វត្ថុដែលសល់នៅបាត (ឧ. le fond de la bouteille ស្រា (ឬវត្ថុអ្វីផ្សេងៗ) នៅបាតដប ; ទីក្នុងបំផុត (ឆ្ងាយពីផ្លូវចូល) (ឧ. le fond d'une boutique); ទីដាច់ស្រយាល, ទីកៀនកោះ (ឆ្ងាយពីទីប្រជុំជន) (ឧ. le fond d'une province); កៀន(ទីឆ្ងាយពីភ្នែកគេ) (ឧ. le fond d'une armoire); ហ្វាន, ផ្ទៃ (គំនូរ) (ឧ. un fond de paysage) ; អត្ថសេ (ឧ. comédie qui diffère par le fond) ។ le fond et la forme អត្ថសេនឹងទម្រង់ ។ *Fig.* ទីកំបាំង, ទីជម្រៅ (ឧ. le fond du cœur; aller au fond des choses); របស់សំខាន់បំផុត (ឧ. le fond du caractère ចរិតសំខាន់)។ course de fond ការរត់អំណត់ ។

Loc. adv. fond de culotte ឬ de pantalon គូថខោ ។ boîte à double fond ឬ à deux fonds ប្រអប់បាតពីរ(មានសន្ទះក្នុងមួយទ្វបជាបាត) ។ *Fig.* le fond du sac គំនិតស្ងាត់កំបាំង (គំនិតនៅតែក្នុងខ្លួនពិតបានបញ្ចេញឲ្យគេដឹង) ។ le fond de la coupe ឬ du calice អ្វីដែលពិបាកទ្រាំបំផុត ។

Loc. adv. à fond ម៉ែនទែន, ពេញទី (ឧ. connaître une affaire à fond) ។ à fond de train លឿនអស់ទំហឹង (ឧ. courir à fond de train) ។ dans le fond ឬ au fond ដោយពិត, ដោយពិនិត្យឲ្យហ្មត់ចត់ទៅ ។ de fond en comble តាំងពីក្រោមដល់លើ, ទាំងមូល, ទាំងអស់ (ឧ. démolir une maison de fond en comble) ។ couler à fond ពន្លិចឲ្យស្រឡះ (ឲ្យលិចដល់បាតដី); លិច ឬ លង់ទឹក ។ *Fig.&Fam.* couler quelqu'un à fond ពន្លិច (បង្ខិន ឬធ្វើឲ្យវិនាសស្រឡះ) ។ couler une affaire à fond ធ្វើកុំឲ្យសម្រេចជាស្ថាពរ; បង្ហើយជាស្ថាពរ

fondamental,e,aux *a.* ដែលជាគ្រឹះ (ឧ. pierre fondamentale) ។ *Fig.* សំខាន់, សារវន្ត, ជាគោល (ឧ. vérité fondamentale)

fondamentalement *adv.* យ៉ាងសំខាន់

fondant,e *a.* ដែលធ្វើឲ្យរលាយ; ដែលរលាយ(ឧ. glace fondante); ដែលមានទឹកដមច្រើន(ហាក់ដូចជារលាយក្នុងមាត់) (ឧ. mangue fondante) ។ *n.m.* ស្ករគ្រាប់ ។ *Ind.* វត្ថុធាតុសម្រាប់ដាក់ឲ្យវត្ថុឯទៀតឆាប់រលាយ

fondateur,trice *n.&a.* ស្ថាបនជន ឬ ជនកជន [ជៈ-នៈ-កៈ-ជន់] (អ្នកបង្កើតរបស់អ្វីមួយដំបូងគេ, អ្នកសាងអាណាចក្រ-សាសនា ។ល។) ។ membre fondateur ម.ព. membre

fondation *n.f.* មូលស្ថាបនា; ការចាក់ឫសផ្ទះ (ឧ. commencer les fondations d'un bâtiment); រណ្ដៅឫសផ្ទះ; ឫសផ្ទះ ។ *Fig.* ការស្ថាបនា, ការបង្កើត, ការសាង (ឧ. fondation d'une académie); ការចាត់មូលនិធិ

fondé,e *a.* ដែលបានទទួលអនុញ្ញាត (ឧ. être fondé à dire); ដែលមានមូលហេតុ, ត្រឹមត្រូវ(ឧ. accusation fondée) ។ *n.m.* fondé de pouvoir អញ្ញត្តិការី ។ bien-fondé ម.ព. bien-fondé ។ non fondé អមូលកភាព

fondement *n.m.* គ្រឹះ, ឫសសំណង់; វច្ចមគ្គ ។ *Fig.* មូលហេតុ, មូលការណ៍ (ឧ. bruit sans fondement); គ្រឹះ (ឧ. la justice est le fon-

dement d'un Etat) ។ fondement de la liberté គ្រឹះសេរីភាព ។ fondement de l'autorité គ្រឹះអំណាច

fonder *v.t.* ដាក់ឫសសំណង់ (ឧ. fonder un édifice sur pilotis) ; ស្ថាបនា,សង់,បង្កើត,សាង (ឧ. fonder une université); ដាក់មូលនិធិ (សំរាប់សាងរបស់មានប្រយោជន៍) (ឧ. fonder un prix) ។ *Fig.* សំអាងលើ,អាងហេតុលើ(ឧ. fonder ses soupçons sur...)

fonderie *n.f.* រោងចក្រស្ងរំលាយនឹងសិតលោហធាតុ; សិល្បៈខាងស្ងរំលាយ

fondeur,euse *a.&n.* ជាងស្មិត,ជាងស្ងរំលាយលោហធាតុ-ក្រមួន ។ល។

fondeuse *n.f.* ម៉ាស៊ីនសម្រាប់ស្ងរំលាយ

fondoir *n.m.* កន្លែងចំហៀរខ្លាញ់ (រោងសត្តឃាដ)

fondre *v.t* ស្ង, រំលាយ (ឧ. fondre du fer); សិត (រំលាយដាក់ពុម្ព) (ឧ. fondre une statue) ។ *Fig.* រំលាយបញ្ចូលគ្នា (ឧ. fondre un ouvrage avec un autre) ; លាយ(ឧ.fondre les couleurs)។

v.i. រលាយ(ឧ.la glace fond); រលាយអស់, ចយពុះ (ឧ. l'argent fond entre ses mains); ស្ទុះទៅលើ, សង្គ្រុប (ឧ.l'épervier fond sur sa proie)។ *Fam.* ពុះស្គម ។ fondre en larmes យំ ។

se fondre *v.pr. Fig.* ចូលគ្នា (ចូលរួមជាមួយ) (ឧ. ces peuples ont voulu se fondre en un seul)

fondrière *n.f.* ក្រហែងដី; ភក់ភក់

fondrilles *n.f.pl.* ម.ព. effondrilles

fonds *n.m.* មូលនិធិ ។ fonds du budget មូលនិធិថវិកា ។ fonds de commerce មូលនិធិពាណិជ្ជកម្ម ។ fonds de contrepartie មូលនិធិបដិភាគ ។ fonds de réserve មូលនិធិបម្រុង ។ fonds de roulement មូលនិធិឬប្រាក់បង្វិល។ fonds publics មូលនិធិសាធារណៈ ។ fonds secrets ប្រាក់សម្ងាត់។ ប្រាក់ដើម (ឧ. manger le fonds et le revenu); ដី, គ្រឹះស្ថានជំនួញ, ទៀមដែលមានទំនិញ ។

pl. ប្រាក់ទំនេរ(ឧ. chercher des fonds) ។

Fig. មារយាទ-បំណេះឬសមត្ថ-

ភាពនៃមនុស្សម្នាក់ (ឧ. un grand fonds de probité) ។ bien fonds ម.ព. bien-fonds

fondu,e *a.* រលាយ(ឧ.plomb fondu)។ *n.m.* ការស្រអាប់បន្តិចម្ដងៗ (ឧ. le fondu des couleurs) ។ *Cin.* របៀបធ្វើឲ្យរូបលេចឡើងឬបាត់ទៅវិញបន្តិចម្ដងៗ (ក្នុងភាពយន្ត)

fongible *a. Dr.* អាចប្រើអស់

fongicide *a.&n.m.* ភពកឃាន [ភះ-ពះ-ភះ—] (ថ្នាំបំផ្លាញផ្សិត)

fongiforme *a.* ដែលមានសណ្ឋានដូចផ្សិត

fongosité *n.f.* ភាពស្អោត (ដូចផ្សិត ឬពពុះទឹក); សាច់ដុះលៀនក្នុងដំបៅ (រាងស្រួចៗ ស្អោតៗ)

fongueux,euse *a.* ដែលជាសាច់ដុះលៀនក្នុងដំបៅ; ដែលមានសណ្ឋានដូចផ្សិត ឬ ដូចពពុះទឹក

fongus *n.m.* សាច់ដុះលៀនក្នុងដំបៅ (រាងស្រួចៗ ស្អោតៗ)

fontaine *n.f.* ក្បាលទឹក (ទឹកផុសពីដី); ក្បាលម៉ាស៊ីនទឹក; ផ្ទះសាធារណៈចែកទឹក; ពាងឬក្អមដាក់ទឹក

fontainier *n.m.* ជាងម៉ាស៊ីនទឹក

fontanelle *n.f.* បង្ហើយ(អវយវៈទីបំផុតនៃក្បាលមនុស្ស) (ឧ. la grande fontanelle, ou bregma se ferme à l'âge d'un an)

fonte *n.f.* ការរលាយឬរលាយ (ឧ. la fonte des neiges); ការស្ងោរលោហធាតុ (ដើម្បីយកលោហធាតុសុទ្ធ); ការសិត(ឧ.fonte d'une statue); ដែកស្វិត

fontis ឬ **fondis** *n.m.* ដំណើរដីស្រុត

fonts *n.m. pl.* អាងទឹកប្រសិទ្ធ

football *n.m.* កីឡាបាល់ទាត់

footballeur *n.m.* អ្នកកីឡាបាល់ទាត់

footing [fou-tin'g] *n.m.* ការដើរ (ដោយជើង)

for *n.m.* តុលាការ(សាលាកាត់ក្ដី)។ for intérieur សម្បជញ្ញៈ។ for extérieur អំណាចតុលាការ

forage *n.m.* ការខួង; ការជីករណ្ដៅ

forain,e *a.* ក្រៅទីប្រប្រាក់, ដែលមកពីទីផ្សេង ។ marchand forain អ្នកលក់ក្នុងផ្សារណាត់ ។ audience foraine ម.ព. audience

foraminé,e *a.* ដែលមានរន្ធតូចៗ (ឧ. coquillage foraminé)

forban *n.m.* ចោរប្លន់ ។ *Par ext.* ជនឥតអាសង្កា (គ្មានចិត្តអៀន)

forçage *n.m.* វិធីធ្វើឲ្យដំណាំបានផល

មុនរដូវ(ផ្កា,ផ្លែឬបន្លែ)

forçat *n.m.* អ្នកជាប់ទោសឧក្រិដ្ឋដែលត្រូវបង្ខំឲ្យធ្វើការធ្ងន់ ។ *Fig.* មនុស្សក្រលំបាក

force *n.f.* កម្លាំង (ឧ. l'eau, l'air, etc...sont des forces naturelles); ទំហឹង (ឧ. frapper de toute force វាយអស់ទំហឹង); ការបង្ខំ (ឧ. céder à la force); អានុភាព (ឧ. force d'un Etat); ភាពមាំឬជាប់ (ឧ. force d'un mur); កម្លាំង (ពលតា) (ឧ. force d'une machine); ឥទ្ធិពល (ឧ. force d'un poison)។ *Fig.* ការប៉ិនប្រសប់, ចំណេះ (ឧ. être de même force au jeu); អំណាច (ឧ. les lois étaient sans force)។ *pl.* កម្លាំងទ័ព(របស់រដ្ឋមួយ) (ឧ. les forces de terre, de l'air et de mer)។

Loc. div. force d'âge អាយុពេញកម្លាំង ។ force d'inertie កម្លាំងដាររកឬ(កម្លាំងទប់)។ force des choses ការជៀសមិនរួច។ tour de force ការខំប្រឹងខ្លាំង; *fig.* លទ្ធផលដែលគេប្រចដោយខំប្រឹងប្រែងឬដោយប៉ិនប្រសប់ ។ faire force បង្ខំ ។ être à bout de force អស់កម្លាំង។ être en force មានកម្លាំងទ័ពគ្រប់គ្រាន់ ។ force armée សេនាឆ្លុភាព ។ force vive ជីវពល ។ force publique ក្រុមសន្តិសុខជាតិ។ faire force de rames ខំប្រឹងអុំឬចែវទូក។ force d'âme សេចក្ដីក្លាហាន ។ force morale កម្លាំងចិត្ត ។ force physique កម្លាំងកាយ ។

Phys. ពល។ force motrice ចលករពល ។ force de cohésion សំនិទ្ធពល(ម.ព. attraction moléculaire ផង) ។

Loc. adv. à force យ៉ាងច្រើន,យ៉ាងខ្លាំង,ដោយខំប្រឹង។ à toute force ដោយប្រើមធ្យោបាយគ្រប់បែប,ដោយដាច់ខាត,ទោះជាយ៉ាងណាក៏ដោយ។ de force ឬ par force ដោយខំប្រឹងប្រែង; ដោយបង្ខំ; ដោយប្រើកម្លាំង។ de gré ou de force ដោយស្ម័គ្រចិត្តឬដោយបង្ខំ។ de toute sa force ឬ de toutes ses forces ដោយអស់ទំហឹង (មិនសល់បៃកម្លាំង)។ de vive force ដោយប្រើ

កម្លាំង។

Loc. pré. à force de ដោយខំទូច, ដោយធ្វើញយៗ។ à force de bras ដោយប្រើតែដៃសុទ្ធ (គ្មានអ្វីជាជំនួយក្រៅពីដៃ) ។ force est de ត្រូវតែ (ឧ. force est d'obéir)។ être de force à អាចនឹង ។

Dr. force majeure ប្រធានសក្តិ (ហេតុហួសវិស័យ)។ force de loi អានុភាពនៃច្បាប់ (ត្រូវតែប្រតិបត្តិតាមនូវច្បាប់ ដោយចៀសមិនរួច) (ឧ. l'usage, dans certain cas, a force de loi)។ force de chose jugée អំណាចព្រមអស់ជំនុំ (ម.ព. chose និង)។ force exécutoire អំណាចព្រមបង្ខំឲ្យប្រតិបត្តិ

forcé,e *a.* ក្លែង; ដែលធ្វើដោយបង្ខំ (ឧ. rire forcé; marche forcée)។ *Fig. & Fam.* ខានមិនបាន, ចៀសមិនរួច; ដាក់ស្តែង (ឧ. il gagnera, c'est forcé, il est le plus fort) ។ culture forcée ដំណាំបង្ខំ (បង្ខំឲ្យលូតលាស់ ឬ ឲ្យបានផលឆាប់)។ cours forcé តម្លៃបង្ខំ (បង្ខំឲ្យប្រើ) ។ avoir la main forcée ធ្វើដោយបង្ខំ ។ travaux forcés ម.ព. travail

forcement *n.m.* ការបំបែក, ការទម្លាយ (ឧ. forcement d'un coffre)

forcément *adv.* ដោយបង្ខំ, ដោយខានមិនបាន

forcené,e *a.&n.* ដែលខឹងជ្រុលពេក (ឧ. maîtriser un forcené); ខ្លាំង (ឧ. une résistance forcenée)

forceps *n.m.* ដំបៀត (ប្រើគៀតទាញទារកក្នុងការឆ្លងទន្លេពិបាក)

forcer *v.t.* បំបែក, បំបាក់, ទម្លាយ (ឧ. forcer une porte); យកដោយប្រើកម្លាំង (ឧ. forcer une ville); ធ្វើឲ្យខូច (ឧ. forcer une clef); ខំប្រឹងខ្លាំងពេក (ឧ. forcer sa voix ខំប្រឹងស្រែកខ្លាំងពេក); បន្ថែម, ពន្លើស (ឧ. forcer la dose d'un médicament); បង្ខំ (ឲ្យឆាប់ទុំ) (ឧ. forcer des raisins)។ *Fig.* បង្ខំ (ឧ. forcer de partir); បំភ្លើស (ឧ. forcer le sens d'un mot) ។

Loc. adv. forcer la nature ធ្វើហួសកម្លាំង ឬ ហួសសមត្ថភាព ។ forcer la consigne ល្មើសបញ្ជា (មិនស្តាប់បង្គាប់) ។ for-

cer le pas ឬ la marche បង្ខំដំណើរ ។ forcer un cheval បង្ខំសេះ ។ forcer un cerf ប្រដេញក្តាន់ (ឲ្យទាល់តែខ្ជិល) ។ forcer la porte de quelqu'un ចូលផ្ទះគេដោយបង្ខំ (ដោយម្ចាស់ផ្ទះមិនចង់ឲ្យចូល) ។ forcer la main à quelqu'un បង្ខំឲ្យធ្វើ ។ forcer l'attention បង្ខំឲ្យស្តាប់ ។ forcer une femme កំហែងចាប់ចង់ ។ forcer la voix ខំស្រែកច្រៀង (ស្រែកហួសពីសម្លេងធម្មតារបស់ខ្លួន)។ forcer un chiffre បង្កើនលេខ ។

v.i. ប្រឹង, ខំប្រឹង ។ *Mar.* forcer de voile បើកក្តោងទាំងអស់ ។ forcer sur les avirons ខំចែវខ្លាំង ។ le vent force ខ្យល់បក់ខ្លាំងថែមឡើង ។

se forcer *v.pr.* បង្ខំខ្លួន; ខំប្រឹង

forcerie *n.f.* កន្លែងដាំដំណាំបង្ខំ (បន្ទប់កញ្ចក់)

forces *n.f. pl.* កន្ត្រៃកាត់រោមចៀម

forcipressure *n.f. Chir.* ការគៀបសរសៃកុំឲ្យឈាមរត់

forcir *v.i. Fam.* ឡើងខ្លាំង, ឡើងធំ

forclore *v.t.* ផុតសិទ្ធិប្តឹងដោយហួសកំណត់ពេល

forclos,e *a.* នៃអ្នកផុតសិទ្ធិប្តឹង

forclusion *n.f.* ការផុតសិទ្ធិប្តឹង(ដោយហួសកំណត់ពេល)

forer *v.t.* ចោះ, ខួង (ឧ. forer un puits)

forestier,ère *a.* នៃព្រៃឈើ (ឧ.code forestier) ។ *n.m.* រុក្ខាបាល, វនបាល, អរញ្ញបាល, អ្នករក្សាព្រៃឈើ

foret *n.m.* ដែកខួង

forêt *n.f.* វន [វៈ-នៈ], អរញ្ញ, ព្រៃ ។ forêt galerie ព្រៃសងខាងមាត់ស្ទឹង ។ forêt vierge ព្រៃញឹក (មិនដែលមានមនុស្សចូលរួច)។ *Fig.* ចំនួនច្រើន (ឧ. une forêt de mâts)

foreur *n.& a.m.* ជាងខួង

foreuse *n.f.* ម៉ាស៊ីនខួង

for ever! សាធុ!

forfaire *v.t. ind.* ប្រព្រឹត្តខុសនឹងករណីយកិច្ច ឬ ខុសនឹងកិត្តិយស (ជាហេតុឲ្យខូចកិត្តិយស)(ឧ. forfaire à ses engagements មិនកាន់តាមកិច្ចសន្យាខ្លួន)

forfait *n.m.* បទឧក្រិដ្ឋ(ឧ. commettre un forfait)

forfait *n.m.* ប្រាក់ដែលម្ចាស់សេះត្រូវបង់បើខ្លួនមិនយកសេះទៅប្រណាំង ។ déclarer forfait សុំឈប់

forfait *n.m.* ការម៉ៅផ្តាច់,ការទទួលបង់ពន្ធសរុប

forfaitaire *a.* ដែលម៉ៅផ្តាច់;ដែលសរុប (ឧ. prix forfaitaire)

forfaiture *n.f.* បទឧក្រិដ្ឋប្រព្រឹត្តលើនាយទៅហ្វាយ; បទឧក្រិដ្ឋនៃមន្ត្រីក្នុងពេលបំពេញមុខងារខ្លួន; ការក្បត់

forfanterie *n.f.* អំពើក្អេងក្អាង

forge *n.f.* រោងចក្រស្លដែក, រោងដំដែក; ឡដុតដែក

forgeable *a.* អាចដំបាន

forger *v.t.* ដំ,ច្រុង ។ forger à froid ដំដែកត្រជាក់(មិនដុត) ។ *Fig.* ប្រឌិត (ឧ. forger une nouvelle)

forgeron *n.m.* លោហការី, ជាងដែក

forgeur *n.m.* អ្នកដំឬច្រុង ។ *Fig.* forgeur de nouvelle អ្នកប្រឌិតរឿង

forjeter *v.t.* ធ្វើឲ្យលៀនចេញ(ក្បាច់ក្នុងសំណង់) ។ *v.i.* លៀនចេញ(ក្បាច់)

forlancer *v.t.* ដេញឲ្យចេញពីជម្រក (សត្វ) (ឧ. forlancer un cerf)

formage *n.m.* ការធ្វើឲ្យមានរាង(របស់ធ្វើក្នុងរោងចក្រ)

formaliser (se) *v.pr.* ខឹង(ឧ.se formaliser d'une plaisanterie)

formalisme *n.m.* ទម្រង់និយម, ការប្រកាន់តាមទម្រង់ការពេក(ឧ.formalisme administratif)

formaliste *n.m.* អ្នកទម្រង់និយម,អ្នកប្រកាន់តាមទម្រង់ការពេក

formalité *n.f.* ទម្រង់ការ, ក្បួនច្បាប់សម (ឧ. il s'assit sans plus de formalité) ។ une simple formalité គ្រាន់តែជាទម្រង់ការ (កិច្ចមិនសូវសំខាន់)

format *n.m.* ទំហំ, ខ្នាត

formateur,trice *a.* &*n.* ដែលបង្ក, ដែលបង្កើត (ឧ. intelligence formatrice)

formatif,ive *a.* ដែលសម្រាប់បង្កឬបង្កើត

formation *n.f.* និម្មិតកម្ម, ការបង្កឬបង្កើត;ការកឬកើត(ឧ.formation d'un abcès); ការជម្រើសរូបរាង ។ *Spécial.* ភាពជាកម្លោះក្រមុំ ; ការអប់រំ,ការបង្ហាត់បង្រៀន (ឧ. la formation d'un enfant) ។ formation professionnelle ការអប់រំវិជ្ជាជីវៈ ។ ស្រទាប់ដី (ឧ. for-

mation tertiaire); ការតាំងទ័ព (ឧ. formation navale); របៀបក្បួនទ័ព; របៀបក្បួនប្រយុទ្ធ (ឧ. formation d'attaque)។ formation des mots ការបង្កើតសព្ទ ។ formation populaire ការបង្កើតដោយប្រជាជន ។ formation savante ការបង្កើតដោយអ្នកប្រាជ្ញ

forme *n.f.* សណ្ឋាន, ទ្រង់ទ្រាយ (ឧ. la forme d'une table, d'une maison); រាង,រាងរៅ (នៃខ្លួនមនុស្ស) (ឧ. vêtement qui moule les formes); ភាព; ទំនង; ទម្រង់ (ឧ. juger sur la forme); របៀបការប្រកា (ឲ្យត្រូវតាមច្បាប់គួរសម) (ឧ. agir dans les formes); បែបបទគួរសម (ឧ. en y mettant les formes); ទម្រង់ (ឧ.la cour de cassation peut annuler un jugement pour vice de forme); របបគ្រប់គ្រង (តាមរដ្ឋធម្មនុញ្ញ) (ឧ. forme monarchique, républicaine) ។ *Gram.* វិបាក: (ទម្រង់ពាក្យ) ។ forme active កត្តុវិបាក:។ forme passive កម្មវិបាក: ។ ពុម្ព (សម្រាប់ប្លូក, ស្បែកជើង ។ល។); រាង (ឧ. la forme de ce vêtement n'est pas gracieuse) ។ *Fam.* រូបកាយរឹងប៉ឹង(មានសុខភាពល្អ) (ឧ.être en forme) ។

Loc.div. en forme ឬ en bonne forme ឬ en bonne et due forme ឬ dans les formes ដោយត្រឹមត្រូវតាមទម្រង់ច្បាប់, តាមផ្លូវច្បាប់។ pour la forme តែខាងក្រៅ, យកតែនាម ។ en forme de ដោយមានទម្រង់ជា (ឧ. une promesse en forme de contrat)។ par forme de ដោយទុកជា (ឧ. dire quelque chose par forme d'avis)។ vice de forme ម.ព. vice

formel,elle *a.* ជាក់លាក់ (ឧ. recevoir un ordre formel) ; ដែលមានតែទម្រង់ ឬ ខាងក្រៅ (ឧ. politesse formelle)

formellement *adv.* ដោយជាក់លាក់

formème *n.m.Chim.* ម.ព. méthane

former *v.t.* បង្ក,បង្កើត(ជារូបរាង)(ឧ.ils semblaient avoir été formés

l'un pour l'autre); ធ្វើឬឆាក់អក្សរមានរូបរាង (ឧ. former des lettres); មានសភាពឬទ្រង់ទ្រាយជា (ឧ. collines qui forment un amphithéâtre)។ *Fig.* គិត,គ្រោង(ឧ. former un projet) ; បណ្តុះ (ឧ. former l'esprit); បង្ហាត់បង្រៀន, អប់រំ (ឧ. former un jeune homme); រួមជា, មានជា (ឧ. la bonté forme le fond de son caractère)។ se former *v.pr.* ក, កើតរូបរាង; ឡើងធ្លាត

formication *n.f.* ម.ព.fourmillement

formidable *a.* សំបើម, គួរខ្លាច (ឧ. une puissance formidable)។ *Fam.* អស្ចារ្យ, ហួសប្រមាណ (ឧ. des dépenses formidables); គួរតែសំគាល់

formidablement *adv.* យ៉ាងសំបើម, យ៉ាងអស្ចារ្យ

formulable *a.* អាចពោល ឬ ថ្លែងបាន

formulaire *n.m.* ប្រជុំរូបមន្ត (ឧ. le codex est un formulaire pharmaceutique); ប្រជុំសំណាកសារលិខិត(ឧ.le formulaire des notaires); ក្បួន, គម្រូ

formule *n.f.* រូបមន្ត; គំរូលិខិត (ឧ. formule légale) ; របៀបថ្លែង ឬ ធ្វើ (តាមទំនៀមទម្លាប់) (ឧ. formule de politesse) ។ *Chim.* អក្សរសញ្ញា ។ *Fig.* របៀបដោះស្រាយ (ឧ. formule politique របៀបដោះស្រាយនយោបាយ) ។ formule exécutoire រូបមន្តប្រតិបត្តិ

formuler *v.t.* សរសេរ ឬ តែងតាមរូបមន្ត ឬ តាមគំរូ (ឧ. formuler une ordonnance médicale); ពោល ឬ ថ្លែង (ដោយសំដីដាក់ណាត់) (ឧ. formuler des griefs)

fornicateur,trice *n.m.* អ្នកមានជាប់ខាងបទកាមមុច្ឆា (ការងប់ក្នុងកាមគុណ)

fornication *n.f. Relig.* ជាប់ខាងបទកាមមុច្ឆា (ការងប់ក្នុងកាមគុណ)

forniquer *v.i.* ធ្វើអំពើជាប់ខាងបទកាមមុច្ឆា

fors *pré.* ក្រៅអំពី, លើកលែងតែ (ឧ. tout est perdu, fors l'honneur)

fort,e *a.* ខ្លាំង (ឧ. un homme fort); ដែលការពារដោយមាំទាំ (ឧ.

ville forte); មាំ, ជាប់ (ឧ. étoffe forte); ខ្លាំង (ឧ. voix forte); ធ្ងន់ (ឧ. forte fièvre); ខ្លាំង (ចំពោះរសជាតិ ឬ ក្លិន) (ឧ. café, tabac fort); ឆ្អាប, ហាង, មិនឆ្ងាញ់ពិសា (ឧ. beurre fort) ។ *Fig.* ពូកែ, ខ្លាំង (ឧ. âme forte); សំបើម, ច្រើន (ឧ. forte somme); ពិបាក (ឧ. forte tâche) ; ពូកែ, ដែលចេះច្រើន, ដែលមានពិសោធន៍ច្រើន, ប៉ុនប្រសប់ (ឧ. fort en histoire; fort aux échecs) ។

Loc. adv. terre forte ដីមានជីជាតិ, ដីពិបាកភ្ជួរ។ esprit fort អ្នកអួតថាមិនជឿសាសនា; *par ext.* អ្នកមិនតាមយោបល់គេ។ forte tête ក្បាលរឹង (មនុស្សមានះ, ចចេស) ។ se faire fort de សន្យាថា, អួតអាងថា (ឧ. elle se fait fort de le convaincre) ។ colle forte ម.ព. colle ។ poids fort ទម្ងន់សរុប (ទាំងសំបក) ។ prix fort តម្លៃហួសប្រមាណ (ថ្លៃពេក) ។ à plus forte raison ជាពិសេសទៅទៀត ។ cela est plus fort que moi របស់នោះហួសវិស័យខ្ញុំ (ខ្ញុំទប់ទល់មិនបាន) ។ ce n'est pas fort មិនប្រាជ្ញទេ, មិនប្រសប់ទេ, មិនសំបើមទេ ។ល។ c'est fort! ឬ c'est un peu fort! ពិបាកយល់ណាស់! ឬ ពិបាកជឿណាស់! ។ fort en gueule ពូកែតែសំដី, ប៉ុនឆ្លើយសឹកសៀត ។ *Pop.* fort en mie មនុស្សធំកន្ទ្រល ។ se porter fort pour quelqu'un ធានាលើអ្នកណាម្នាក់។ être fort comme un bœuf ឬ comme un Turc ខ្លាំងដូចគោ (ខ្លាំងណាស់) ។ fort en thème អ្នករៀនពូកែ (ក្នុងសាលា); *ironiq.* ពូកែតែក្នុងសាលា (ក្រៅពីការរៀនសូត្រមិនចេះអ្វីសោះ) ។ le fort armé បិសាច ។ femme forte ស្ត្រីក្លាហាន ។ fort de côté តឹង, មិនឃ្លាង (នាវា) ។ mer forte សមុទ្ររំជួលខ្លាំង (រលកជ្រោះ) ។ denier fort ប្រាក់បន្ថែម (លើប្រាក់ជំពាក់) ។ prêter au denier fort ចងការអារក (យកចុងការថ្លៃពេក) ។

Prov. la raison du plus fort est toujours la meilleure ពងមាន់កុំបង់ជល់នឹងថ្ម

fort *adv.* យ៉ាងខ្លាំង (ឧ. frapper

fort; crier fort); ណាស់ (ឧ. être fort inquiet); ខ្លាំង (ច្រើន) (ឧ. se tromper fort)។ *Pop.* aller fort ហួសហើស

fort *n.m.* បន្ទាយតូច (ឧ. les forts de Metz); អ្នកខ្លាំងពូកែ, អ្នកមានកេតទ្រព្យ (ឧ. protéger le faible contre le fort); ជម្រកសត្វសាហាវ (ឧ.traquer un sanglier dans son fort)។ fort de la Halle ឬ des Halles អ្នកលីសែងក្នុងផ្សារ (នាក្រុងប៉ារីស)។ *Fig.* ឫទ (ការ) ដែលខ្លួនពូកែ (ឧ. l'algèbre est son fort); ពេញកណ្ដាល (ឧ. au fort de l'été)។

Loc. adv. du fort au faible ឬ le fort portant le faible ដោយទូទាត់គ្នា។

Mar. fort d'un navire ភាគធំនៃនាវា (ត្រង់ចំកណ្ដាល) (ថា: largeur au fort ក៏បាន)។ fort d'une pièce de bois បន្ទាឈើជាអតិបរមាណ

fortement *adv.* យ៉ាងខ្លាំង

forteresse *n.f.* បន្ទាយ។ forteresse volante ឬ superforteresse យន្តហោះទម្លាក់គ្រាប់បែកធំរបស់អាមេរិកាំង

fortifiant,e *a.* ដែលលើកកំឡាំង។ *Fig.* ដែលលើកទឹកចិត្ត។ *n.m.* ថ្នាំប៉ូវ, ថ្នាំលើកកម្លាំង (ឧ.le quinquina est fortifiant)

fortification *n.f.* ជាការផ្ទាន, ការរៀបចំការពារសឹកសត្រូវ (ឧ. entreprendre la fortification des frontières); សំណង់ការពារសឹកសត្រូវ; គ្រឿងការពារ (ឧ. les fortifications de Paris)

fortifier *v.t.* លើកកំឡាំង (ឧ. l'exercice fortifie le corps); រៀបចំការពារសត្រូវ (ឧ. fortifier une place)។ *Fig.* លើកទឹកចិត្ត, គាំទ្រ (ខាងផ្លូវចិត្ត) (ឧ. fortifier quelqu'un dans une résolution); បញ្ជាក់, ពង្រឹង (ឧ. ce témoignage fortifie votre opinion)

fortin *n.m.* ប៉ុប

fortiori (à) *loc. adv.* ចំណោះបើ, ជាពិសេសទៅទៀត

fortrait,e *a.* ហត់ខ្លាំង, អស់ខ្លាំង (សេះ)

fortuit,e *a.* ដែលមកដល់ដោយជួន, ដែលកើតបតៈ, មិនបានគិតទុក។ cas

fortuit ករណីហួសហេតុ

fortuitement *adv.* ដោយជួន, ដោយពើបពះ

fortune *n.f.* ចៃដន្យ, លាភ (ឧ. la fortune est aveugle); ភ័ព្វសំណាង, ជោគវាសនា (ស្ថានភាពប្រសើរ) (ឧ. être l'artisan de sa fortune); កេរ្តិ៍ទ្រព្យ, ធនធាន (ឧ. acquérir de la fortune)។

Loc. adv. bonne fortune ភ័ព្វល្អ, គ្រោះជា។ mauvaise fortune ភ័ព្វអាក្រក់, គ្រោះកាច។ revers de fortune គ្រោះថ្នាក់ដែលធ្វើឲ្យខូចវាសនា (ដូចជាឲ្យមានហើយធ្លាក់ក្រវិញ)។ retour de fortune ការប្រែប្រួលវាសនា (ពីល្អទៅអាក្រក់ពីអាក្រក់ទៅល្អ)។ biens de la fortune ទ្រព្យសម្បត្តិ។ homme de fortune អ្នកឡើងភសី (ធ្លាប់ក្រស្រាប់តែឡើងមាន)។ homme à bonne fortune មនុស្សស្ទាក់ស្រី។ soldat de fortune ទាហានផ្លោះថ្នាក់ (ដែលឡើងពីថ្នាក់ទាបបំផុតទៅថ្នាក់ខ្ពស់បំផុតតែម្ដងដោយសារតែសមត្ថភាពខ្លួន)។ officier de fortune ពួនទាហានដែលឡើងដល់ថ្នាក់នាយទាហាន; នាយទាហានស៊ីឈ្នួល។ jeux ឬ coups ឬ caprices de la fortune ការប្រែប្រួលយ៉ាងខ្លាំងនៃមនុស្សនឹងវត្ថុ។ roue de la fortune កង់ត្រាចកង់ធ្លាក់ (វាសនាឡើងចុះៗ)។ roue de fortune កង់បង្វិលចេញឆ្នោត។ fortune du pot មាត់មានលាភ ឬ គិតលាភ (ភ័ព្វបានបរិភោគឆ្ងាញ់ ឬ មិនបានឆ្ងាញ់) (ចំពោះអ្នកទៅអាស្រ័យនៅផ្ទះដែលគេមិនបានប្រុងប្រៀបចាំទទួល)។ faire fortune ឬ faire sa fortune មានទ្រព្យសម្បត្តិ; សម្រេចផលល្អ, មានវាសនា។ tenter fortune ប្រថុយ, ផ្សងវាសនា។ chercher fortune ស្វែងរកសម្បត្តិ។ brusquer la fortune ចង់មានឬចង់សម្រេចដោយបង្ខំពេក។ adorer ឬ encenser la fortune ឬ sacrifier à la fortune ស្រឡាញ់រាប់អានអ្នកមានទ្រព្យឬអ្នកមានយសសក្តិ។ les grandes fortunes អ្នកមានយសសក្តិខ្ពង់ខ្ពស់។ faire contre fortune ឬ contre mauvaise fortune bon cœur មិនខូចទឹកចិត្ត ឬ មិនអស់សង្ឃឹមដោយហេតុ

ដែលមិនបានសម្រេចការ ។

Loc. adv. de fortune ដោយចៃដន្យ; តាមតែប្រទះ,ឲ្យតែបាន (ឧ. installation de fortune)

fortuné,e *a.* ដែលមានជោគភាសនា (ឧ. peuple fortuné) ; ប្រកបដោយសុភមង្គល (ឧ. union fortunée); ដែលមានទ្រព្យសម្បត្តិ (ឧ. une famille fortunée)

forum [-rom'] *n.m.* សមោសរដ្ឋាន

forure *n.f.* រន្ធខ្លង; រន្ធកូនសោ (រន្ធក្នុងកូនសោ)

fosse *n.f.* រណ្ដៅ; រណ្ដៅសមុទ្រ (ជម្រៅលើសពី ៦.០០០ម.) (ក្នុងន័យនេះគេហៅ fossé, abysse, ravin ក៏បាន); រណ្ដៅកប់ខ្មោច ។ avoir un pied dans la fosse ឬ être sur le bord de la fosse ជិតចូលរណ្ដៅ(ជិតស្លាប់)។fosse commune រណ្ដៅរួម (រណ្ដៅតែមួយសម្រាប់កប់ខ្មោចច្រើន)។fosse d'aisance រណ្ដៅលាមក(បង្គន់)។ fosse septique រណ្ដៅបង្គន់ (បិទជិតទាំងអស់) ។ *Anat.* រន្ធ (ឧ.fosse nasale)

fossé *n.m.* ស្នាមភ្លោះ;ប្រឡាយ។ *Fig.* រណ្ដៅ (អ្វីៗដែលបំបែកពីគ្នាឬដែលទាំងមិនឲ្យទាក់ទងគ្នាបាន) (ឧ. le fossé s'élargit entre les parties)

fossette *n.f.* ឬ (រន្ធតូច); ខួច (ប្រហោងនៅថ្ពាល់ ឬ ចង្កាមានឡើងកាលណាគេសើច)

fossile *n.m.&a.* ជាសាណីភូត (ស្នាមកំទេចរុក្ខជាតិឬសត្វដែលជាប់លើថ្មច្រើនយុគមកហើយ) ។ combustible fossile ធ្យូងថ្ម, ប្រេងកាត ។ *Fig.* ជនមិនទាន់សម័យ (មានគំនិតមិនទាន់សម័យ); វត្ថុផុតសម័យ (ឧ. modes fossiles)

fossilifère *a.* ដែលមានជាសាណីភូត (ឧ.calcaire fossilifère)

fossilisation *n.f.* ដំណើរទៅជាជាសាណីភូត

fossiliser *v.t.* ធ្វើឲ្យទៅជាជាសាណីភូត

fossoir *n.m.* ចបកាប់មួយយ៉ាង

fossoyeur *n.m.* អ្នកជីករណ្ដៅកប់ខ្មោច

fou ឬ **fol,folle** *n.&a.* វិកលចរិត,ឆ្កួត (ឧ. une maison de fous) ។ *Par exagér.* ទប់មិនបាន(មានអាការដូចឆ្កួត) (ឧ. fou de joie;fou de douleur); មិនសមហេតុផល (ឧ.une folle passion; un fol espoir); ភ្លើ, លលា (ឧ. les co-

quettes sont folles) ; ច្រើនហួសពេក;អស្ចារ្យ (ឧ. folles dépenses; succès fou) ; ឆោត (ឧ. bien fou qui s'y fie)។

Loc. div. fou de ឆ្កួតនឹង, ងប់នឹង;ព្រៃលែង។ fou rire សើចក្អាកក្អាយ (ទប់មិនបាន) ។ herbes folles ស្មៅព្រៃ(ស្មៅទ្រុបទ្រុលដុះឥតគេដាំ) ។ tourner fou វិលទទេ (ដោយឥតទាញបង្វិលភ្លៅជាមួយផង)។ chien fou ឆ្កែឆ្កួត។ gaieté folle ការសប្បាយហ្លួរហ្លាប (ឥតទប់ទល់) ។ fou à lier ឆ្កួតពេញទី ។ faire devenir fou ឬ rendre fou ធ្វើឲ្យទ្រាំមិនបាន,ធ្វើឲ្យលែងដឹងខុសត្រូវ។ fou furieux មនុស្សឆ្កួតកាច។ folle du logis មនោគតិ ។ rire comme un fou សើចក្អាកក្អាយ។ faire le fou ធ្វើឆ្កួត ។

n.m. fou du roi ឬ fou ចំកួតហ្លួង, តួកក្នុងវាំង (សម្រាប់ស្ដេចព្រសាល)។ *Echecs* គោល(កូនចត្រង្គ)

fouace *n.f.* នំដុត

fouage *n.m.* ពន្ធផ្ទះ

fouaille *n.f.* ពោះជ្រូកព្រៃដែលគេឲ្យឆ្កែស៊ី (បើពោះប្រើសឬឈ្លូសគេហៅថា curée)

fouailler *v.t.* វាយនឹងរំពាត់ ។ *Fig.* ជៀលត្ថះ

foucade *n.f.* ការប៉ិលប៉ូចឬសាវ៉ាមួយឆាប

foudre *n.f.* អសនី,រន្ទះ។ *Fig.* coup de foudre ស្នេហាដែលមានឡើងភ្លាមៗ;រឿងហេតុអាក្រក់ដែលមានឡើងដោយមិនដឹងខ្លួនជាមុន ។ *n.m.* un foudre de guerre នាយទាហានខ្លាំងពូកែ (គួរឲ្យស្ញប់ស្ញែង) ។ un foudre d'éloquence វាគ្មិនចំណាន ។ *n.f. pl.* les foudres de l'Eglise ការបណ្ដេញពីសាសនា

foudre *n.m.* ធុងធំ

foudroiement ឬ **foudroiment** *n.m.* ការបាញ់នៃរន្ទះ;ការសម្លាប់ភ្លាមៗ

foudroyant,e *a. Fig.* ដែលឲ្យរំភើបចិត្តខ្លាំង (ឧ. nouvelle foudroyante); ដែលធ្វើឲ្យស្លាប់ភ្លាមៗ (ឧ. poison foudroyant)

foudroyer *v.t.* បាញ់នឹងរន្ទះ (ឧ. Jupiter foudroya les Titans); សម្លាប់ភ្លាមៗ (ជាពិសេសដោយកម្លាំងអគ្គិសនី) ។ *Fig.* ធ្វើឲ្យរំភើបចិត្ត, ធ្វើឲ្យស្រឡាំងកាំង (ឧ. foudroyer

quelqu'un du regard)

fouée *n.f.* ការធ្នះបក្សី (ការចាប់បក្សីដោយធ្នះនឹងភ្លើង); ភ្លើងកំដៅឡ

fouëne *n.f.* ម.ព. foëne

fouet *n.m.* រំពាត់ខ្សែតី; ការវាយប្រដៅនឹងរំពាត់ (ឧ. donner le fouet); កេមកន្ទុយសត្វ ។ fouet de l'aile សន្ទាក់ស្លាបបក្សី ។ tir de plein fouet បាញ់ត្រង់ (បាញ់ត្រូវមើលឃើញច្បាស់) ។ coup de fouet ដម្ងើត (ដោយឥតចំពាសសៃឬសាច់ដុំ); *au fig.* រឿងដែលធ្វើឲ្យក្លៀវក្លា ឬ ដែលសម្រើប-សម្រាល

fouettard *a.m.* ដែលវាយដោយរំពាត់ខ្សែតី

fouetté,e *a.* ដែលត្រូវវាយឬកូរកើក (ឧ. œufs fouettés)

fouettée *n.f.* ការវាយប្រដៅ; ការវាយដោយរំពាត់ខ្សែតី

fouettement *n.m.* ការវាយកិត; ការប៉ះយ៉ាងខ្លាំង (ឧ. le fouettement de la pluie contre les vitres)

fouetter *v.t.* វាយនឹងរំពាត់ខ្សែតី (ឧ. fouetter son cheval); វាយប្រដៅ (ឧ. fouetter un enfant désobéissant); វាយ, កិត, កូរ, វើក (ឧ. fouetter la crème); វាយកិត, ប៉ះយ៉ាងខ្លាំង (ឧ. la pluie fouette les vitres)

fouger *v.i.* ល្ហុសដី (ជ្រូកព្រៃ)

fougeraie *n.f.* ចំការបណ្ណង្គជាតិ

fougère *n.f.* បណ្ណង្គជាតិ [ប៉ន់-ណ័ង-គះ-]

fougerole *n.f.* បណ្ណង្គជាតិតូច

fougue *n.f.* សេចក្ដីក្លៀវក្លា, សេចក្ដីស្ទុះស្ទា (ឧ. cheval plein de fougue) ។ *Fig.* សេចក្ដីស្រើបស្រាលខ្លាំង, ការហ័សក្មេង (ឧ. la fougue de la jeunesse)

fougueusement *adv.* ដោយស្ទុះស្ទា, ដោយក្លៀវក្លា

fougueux,euse *a.* ដែលស្ទុះស្ទា, ក្លៀវក្លា

fouille *n.f.* ការជីកដីរកបូរាណវត្ថុ (ឧ. les fouilles d'Angkor Wath); ការកកូរកកាយមើល, ការរុករើក (ឧ. la fouille d'une armoire, d'une poche)

fouiller *v.t.* ជីកដីរក (ឧ. fouiller l'emplacement d'une ville détruite); រុករើ, ដើរមើលដោយល្អិតចត់ (ឧ. fouiller un quartier); ឆែកឆេរ (ឧ. fouiller quel-

qu'un) ; ស្រាវជ្រាវ (ឧ. fouiller une étude) ។ *v.i.* កកាយកកាយ ឬ រុករើក (ឧ. fouiller dans une armoire)

fouilleur,euse *n.* អ្នកជីកជីករក ; អ្នកកកាយរក ; អ្នកឆែកឆេរ

fouillis *n.m.* ការច្របូកច្របល់, ការភាន់ភាំង (ឧ. un fouillis de papiers)

fouinard,e *a.* & *n.Fam.* ដែលចង់ដឹងចង់ឃើញ (ការសម្ងាត់) ; ដែលមានឧបាយកល

fouine *n.f.* សំពោច ។ *Fig.* មនុស្សពេនឧបាយកល

fouine *n.f.* ឈ្នក, ស្នស្រ្តី

fouiner *v.i.Fam.* លូកដៃចូលក្នុងកិច្ចការអ្នកដទៃ

fouineur,euse *a.*&*n.* អ្នកលូកដៃចូលក្នុងកិច្ចការអ្នកដទៃ

fouir *v.t.* កកាយ, ជីក

fouissement *n.m.* ការកកាយ,ការជីក

fouisseur,euse *a.*&*n.* ដែលកកាយ; សម្រាប់កកាយ (ឧ. les pattes fouisseuses de la courtilière)។ *n.m.* សត្វកកាយដី

foulage *n.m.* ការកិន (ឧ. le foulage de la pâte à papier); ការជាន់, ការបញ្ជាន់

foulant,e *a. Pop.* ហត់កម្លាំង; ដែលកិន,ដែលជាន់, ដែលសង្កត់។ pompe foulante ស្នប់បាញ់ទឹក (បូមទឹកដោយជំរុញ)(ម.ព.pompeផង)

foulard *n.m.* សំពត់ព្រែស្លឹង; កន្សែងរុំក

foule *n.f.* ហ្វូង,ជនសាមញ្ញ(ឧ.se distinguer de la foule) ។ en foule *loc. adv.* ទាំងហ្វូង,ជាច្រើន

foulée *n.f.* ជានជើងសត្វ(លើស្មៅឬលើស្លឹកឈើ) ។ *Sports* ជំហាន

fouler *v.t.* សង្កត់, កិន (ឧ. fouler le raisin); ច្របាច់ទឹក (ជ្រលក់ច្របាច់ក្នុងទឹកឲ្យទន់);កិនសំពត់(ឲ្យជិតសាច់); ជាន់ (ឧ. fouler le sol natal); ធ្វើឲ្យគ្រេច (ឧ. fouler le poignet) ។ *Fig.* ជិះជាន់ (ឧ. fouler le peuple)។fouler aux pieds ឈ្នីទាំងជើង; មើលងាយ ។ se fouler *v.pr.* គ្រេច ។ *Pop.* ទំរើយនឿយហត់

foulerie *n.f.* កន្លែងកិនសំពត់ (ឲ្យជិតសាច់)

fouloir *n.m.* ប្រដាប់កិនសំពត់

foulon *n.m.* កម្មករកិនសំពត់ ។ terre à foulon ដីឥដ្ឋស្រូបជាតិខ្លាញ់ ឬ ប្រេង ។ moulin à foulon ឃ្នាបកិនសំពត់

foulonnier *a.&n.m.* អ្នកត្រួតឃ្នាបកិនសំពត់; កម្មករកិនសំពត់

foulque *n.f.* មាន់ទឹក

foulure *n.f.* ដំណើរផ្លាស់(ម.entorse)

four *n.m.* ឡ (ឧ. four à chaux) ។ *Fig.&Fam.* ដំណើរមិនសំរេចផល (ចំពោះសៀវភៅអក្សរសាស្ត្រ) ។ petit four នំ (ធ្វើអំពីម្សៅដុត) ។ four crématoire ម.ព. crématoire ។ four de campagne ជើងក្រានឡ (យួរបាន)

fourbe *a.* ដែលមានពុតអាក្រក់ ។ *n.* ជនប្រវ័ញ្ច

fourberie *n.f.* ពុតអាក្រក់; ប្រវ័ញ្ច, ការបោកបញ្ឆោត; ទម្លាប់បោកបញ្ឆោត

fourbi *n.m.Fam.* វត្ថុគ្រប់យ៉ាង; កិច្ចការគ្រប់យ៉ាង

fourbir *v.t.* ដុសឬខាត់ឲ្យភ្លឺ (ឧ. fourbir des armes)

fourbissage ឬ **fourbissement** *n.m.* ការដុសឬខាត់

fourbisseur *n.&a. m.* អ្នកខាត់និងដំឡើងគ្រឿងសស្ត្រ

fourbu,e *a.* ដែលស្លាក់ឈាមជើង (សេះ) ។ *Fig.* ហត់, អស់កម្លាំង

fourbure *n.f.* ដំណើរស្លាក់ឈាមជើង (សេះ)

fourche *n.f.* ច្បូក; ចំពាមឈើ; ផ្លូវបែក

fourcher *v.i.* បែកជាចំពាម ។ *Fig.&Fam.* la langue lui a fourché និយាយខុសពាក្យ (ចង់ថាពាក្យនេះទៅជាថាពាក្យនោះវិញ)

fourchet *n.m.* រោគរលាកជើង (ពួកគោ)

fourchetée *n.f.* ចំនួនមួយសម

fourchette *n.f.* សម; គ្រឿងយន្តមានសណ្ឋានដូចសម(ឧ. la fourchette d'une boîte de vitesse) ។ *Fig.* belle fourchette អ្នកស៊ីច្រើន ។ *Pop.* fourchette du père Adam ម្រាមដៃ ។ coup de la fourchette ការចុកភ្នែកដោយម្រាមដៃពីរ

fourchon *n.m.* ធ្មេញសម ឬ ច្បូក

fourchu,e *a.* បែក, ព្រែក (ដែលបែកជាចំពាម)(ឧ.chemin fourchu) ។ pied fourchu ជើងចំពាម (ជើងសត្វទំពារអៀង); ជើងខ្មោចបិសាច

fourchure *n.f.* កន្លែងព្រែក ឬ បែកជា

ចំពាម

fourgon *n.m.* ភណ្ឌរថ-រថបន្ទុក; ទូ-ទំនិញ (អយស្ម័យយាន); រថយន្តទ័ពសំរាប់ដឹកស្បៀងឬគ្រាប់រសេវ។ fourgon funèbre រថដឹកសព

fourgon *n.m.* ប្រដាប់កាយឬចាប់រងើកភ្លើង

fourgonner *v.i.* កាយរងើកភ្លើង ។ *Fig.* រើ, កកាយ

fourgonnette *n.f.* ភណ្ឌរថតូច

fourgue ឬ **fourgat** *n.m.* *Arg.* អ្នកលក់របស់ចោរ; អ្នកលក់បំពួន

fourmi *n.f.* ស្រមោច, សង្កា, អង្ក្រង ។ fourmis blanches កណ្ដៀរ ។ *Fig.&Fam.* avoir des fourmis ស្ពៀប

fourmilier *n.m.* សត្វស៊ីស្រមោច (ដោយលិទ្ធនឹងអណ្ដាត)

fourmilière *n.f.* សំបុកស្រមោច; ស្រមោចមួយសំបុក ។ *Fig.* កន្លែងមានមនុស្សច្រើនញឹកញៀវ; មនុស្សញឹកញៀវ (ឧ. Paris est une fourmilière)

fourmi-lion ឬ **fourmilion** *n.m.* ចៃដី (សត្វដែលធ្វើរណ្ដៅក្រហូចៗក្នុងដីខ្សាច់ដើម្បីចាប់ស្រមោចស៊ី) (*pl.* des fourmis-lions)

fourmillement *n.m.* ដំណើរមានច្រើន-ញឹកញៀវ(ដូចស្រមោច); ដំណើរស្ពៀប

fourmiller *v.i.* មានច្រើនញឹកញៀវ (ឧ.les vers fourmillent dans ce fromage); មានពាសពេញ (ឧ. devoir qui fourmille de fautes); ធ្វើឲ្យស្ពៀប(ឧ.les pieds me fourmillent)

fournaise *n.f.* ឡធំ; ភ្លើងសន្ធោ។ *Par ext.* កន្លែងក្ដៅខ្លាំង

fourneau *n.m.* ជើងក្រាន, ឡ (ឧ. fourneau à gaz); ក្បាលខ្សៀ(ឧ. fourneau d'une pipe)។ haut fourneau ឡរំលាយរ៉ែដែក

fournée *n.f.* ចំនួននំប៉័ងមួយឡ។ *Fig. & Fam.* ជនដែលត្រូវតែងតាំងជាមួយគ្នាឲ្យធ្វើការដូចគ្នា(ឧ. une fournée de décorés)

fourni,e *a.* ក្រាស់, ញឹក (ឧ. barbe fournie); ដែលមានទំនិញពេញ(ឧ. magasin bien fourni)

fournier *n.m.* អ្នកថែឡ

fournil [— ni ឬ nil] *n.m.* បន្ទប់ដុតនំប៉័ង

fourniment *n.m.* បរិក្ខារនៃទាហានម្នាក់

fournir *v.t.* ផ្គត់ផ្គង់ (ឧ.fournir une maison de riz); ផ្តល់, ឲ្យ (ឧ.fournir de l'argent)។ *Fig.* ប្រគល់ឲ្យ, រកឲ្យ; បង្ហាញ (ឧ.fournir un alibi); បំពេញកិច្ច, ធ្វើ (ឧ. fournir un long effort)។ *v.t. ind.* (à) ជួយផ្តល់, ផ្គត់ផ្គង់ (ឧ. fournir aux besoins de quelqu'un)

fournissement *n.m.* មូលនិធិនៃសមាជិកក្រុមហ៊ុនម្នាក់ៗ

fournisseur *n.m.* អ្នកផ្តល់, អ្នកផ្គត់ផ្គង់; អ្នកដែលគេធ្លាប់តែទិញ

fourniture *n.f.* ការផ្តល់, គ្រឿងផ្តល់, គ្រឿងផ្គត់ផ្គង់ (ឧ. fourniture de riz); វត្ថុបន្ទាប់បន្សំ

fourrage *n.m.* ស្មៅ-ចំបើង។ល។ សំរាប់ជាចំណីសត្វ

fourrager *v.i.* ទៅស៊ីស្មៅ ។ *Fig.*& *Fam.* រើដុះរក (ឧ. fourrager dans un tiroir)

fourragère *a.f.* សំរាប់ជាចំណីសត្វ (ឧ. espèces fourragères) ។ *n.f.* ដីដាំតិណជាតិសំរាប់សត្វ; ខ្សែពីរសរសៃយេសក្នុងកងទ័ព

fourré *n.m.* ព្រៃស្អាប់ (ព្រៃញឹកស៊ិបទ្រុប)·

fourré,e *a.* ដែលពាសលោមចម្ម (ស្បែកជាប់រោម) (ឧ. manteau fourré); ញឹក, ទ្រុបទ្រុល, ស៊ិបទ្រុប, ក្រាស់

fourreau *n.m.* ស្រោម (ឧ.fourreau d'épée); អាវចង្អៀតតឹង

fourrer *v.t.* ពាសលោមចម្ម (ស្បែកជាប់រោម) (ឧ. fourrer une robe) ។ *Fam.* ញាត់-ស៊កឬច្រកក្នុង (ឧ. fourrer la main dans sa poche); បញ្ចូលក្នុង (ឧ. fourrer quelque chose dans la tête de quelqu'un); បង្ខាំង, ឃុំឃាំង (ឧ. fourrer en prison) ; ឲ្យបញ្ចោរ (ឲ្យច្រើនពោរពាសពេក) (ឧ. fourrer des friandises à un enfant) ។ fourrer son nez dans ចូលជ្រៀតជ្រែកក្នុង ។

se fourrer *v.pr.Fam.* ចូលក្នុង (ឧ. se fourrer dans une société)

fourre-tout *n.m.inv.* បន្ទប់ដាក់វត្ថុទទើសទទែង ; ថង់ដំណើរ (សម្រាប់ដាក់អីវ៉ាន់ធ្វើដំណើរ)

fourreur *n.m.* ឈ្មួញលោមចម្ម; អ្នកធ្វើលោមចម្ម

fourrier *n.m.* នាយទាហានចែកស្បៀងនឹងរកកន្លែងសំណាក់ឲ្យកូនទា-

ហាន; អ្នកនាំមុខ

fourrière *n.f.* មន្ទីររបើស

fourrure *n.f.* រោមចម្ម (ស្បែកដែលនៅជាប់រោមសំរាប់ធ្វើអាវដាំអម្ពុជា ទ្រនាប់); សំលៀកបំពាក់រោមចម្ម ; ស្បែកសត្វហានរោមក្រាស់

fourvoiement *n.m.* ការវង្វេង

fourvoyer *v.t.* ធ្វើឲ្យវង្វេងផ្លូវ;ធ្វើឲ្យងាកពីផ្លូវ (ឧ. guide qui a fourvoyé des touristes) ។ *Fig.* ធ្វើឲ្យប្រព្រឹត្តខុស (ឧ. les mauvais exemples fourvoient les jeunes gens)។ se fourvoyer *v.pr.* ច្រឡំ, ខុស, វង្វេង

fox-terrier ឬ **fox** *n.m.* ម.ព. terrier

fox-trot *n.m.* ហ្វុកត្រុត (របាំចង្វាក់ពីរ)

foyer *n.m.* ជើងក្រាន (កន្លែងដុតអុស); ក្រាន, ក្រានគ្រួ (ផ្ទះជាទីសំណាក់នៃគ្រួសារ)(ឧ. trouver son foyer désert); គ្រួសារ, ត្រកូល (ឧ. fonder un foyer); ឆាក (កន្លែងប្រជុំក្រុមតួល្ខោនក្នុងរោង); សាលសំរាក (សម្រាប់សាធារណជនក្នុងរោងល្ខោនឬសម្រាប់ភោជន)។ *Fig.* មជ្ឈមណ្ឌលប្រធាន (ឧ. le foyer de la rébellion, d'une maladie) ; មណ្ឌលសកម្ម (ឧ. foyer d'un séisme)។ *pl.* ស្រុកកំណើត,លំនៅគ្រួសារ (ឧ. rentrer dans ses foyers)

frac *n.m.* សំលៀកបំពាក់ពិធីពណ៌ខ្មៅ

fracas *n.m.* ការបែក ឬ ធ្លាក់ដោយឮសូរខ្លាំង (ឧ. le fracas des vagues sur les rochers)។ *Par ext.* សូរសន្ធឹក (ដូចវត្ថុបែក) (ឧ. le fracas du tonnerre)

fracassement *n.m.* ការបំបែក ឬ បំធ្លាក់ (ដោយឮសូរសន្ធឹក)

fracasser *v.t.* បំបែក, បំធ្លាក់ (ដោយមានសូរសន្ធឹក)(ឧ. le vent fracasse les arbres) ។ se fracasser *v.pr.* បែក, ធ្លាក់ (ឧ. se fracasser la jambe)

fraction *n.f.* ការកាច់ (ឧ. la fraction du pain) ; ភាគ (ឧ. une fraction de l'Assemblée) ។ *Math.* ប្រភាគ

fractionnaire *a.* *Math.* នៃប្រភាគ

fractionnel,elle *a.* សម្រាប់បំបែកបំធ្លាក់ (ឧ. les menées fractionnelles)

fractionnement *n.m.* ការបំបែកជា

ភាគ ; ភាគ

fractionner *v.t.* បំបែកបំបាក់ (ឧ. fractionner un parti) ; ចែកជាភាគ; បែង

fractionnisme *n.m.* អំពើសម្រាប់បំបាក់បំបែកគណៈបក្សនយោបាយ

fractionniste *a.&n.* សម្រាប់បំបាក់បំបែកគណៈបក្សនយោបាយ;អ្នកបំបាក់បំបែកគណៈបក្សនយោបាយ

fracture *n.f.* ការកាច់,ដំណើរបាក់ បែក ឬដាច់ ។ *Chir.* ដំណើរបាក់ឆ្អឹង

fracturer *v.t.* កាច់បំបាក់; បំបែក (ឧ. fracturer un coffre fort)

fragile *a.* ស្រួយ (ឧ. le verie est très fragile) ; ផុយ, ឆាប់ខូច (ឧ. meuble fragile)។ *Fig.* មិនរឹងប៉ឹង (ឧ. santé fragile)

fragilité *n.f.* ភាពស្រួយ , ភាពឆាប់ខូច (ឧ. la fragilité de la porcelaine) ។ *Fig.* ភាពមិនឋិតថេរ (ឧ. fragilité des choses humaines)

fragment *n.m.* កំបែង,បំណែក,ភាគ, ផ្នែក; សំណល់បុរាណវត្ថុ; សេចក្ដីស្រង់ពីសៀវភៅឬពីសុន្ទរកថា

fragmentaire *a.* ដែលចែកជាផ្នែកឬជាភាគ

fragmentation *n.f.* ការចែកជាផ្នែកឬជាភាគ

fragmenter *v.t.* ចែកជាផ្នែក ឬ ជាភាគ (ឧ. fragmenter un ouvrage)

fragrance *n.f.* ក្លិនស្រួល (ក្លិនគួរឲ្យរីករាយ)

frai *n.m.* ការពង (ត្រី); រដូវត្រីពង (ឧ. la pêche est interdite pendant le frai); ពងត្រី; កូនត្រី

frai *n.m.* ការថយទម្ងន់នៃរូបិយវត្ថុព្រោះសឹក

fraichement *adv.* យ៉ាងត្រជាក់ (នៅទីត្រជាក់) (ឧ. être couché fraichement); ថ្មីៗ(ឧ.fraichement arrivé) ។ *Fam.* ដោយមិនសូវរួសរាយ, មិនសូវរាក់ទាក់ (ឧ. être reçu fraichement)

fraicheur *n.f.* ភាពត្រជាក់ស្រួល (ឧ. la fraicheur des soirs d'automne; la fraicheur d'une boisson)។*Fam.* ជម្ងឺកើតឡើងអំពីអាកាសត្រជាក់សើម។*Fig.* ភាពស្រស់ ឬឆើតឆាយ(ផ្កា,ពណ៌); ភាពនៅថ្មី (មិនទាន់សឹក)(ឧ. la fraicheur d'un costume)

fraichir *v.i.* ឡើងត្រជាក់ស្រួល (ធាតុអាកាស, ខ្យល់)។ *Mar.* បក់ខ្លាំងឡើង (ខ្យល់) (ឧ. la bise fraichit)

frais, fraiche *a.* ត្រជាក់ស្រួល (ឧ. vent frais); ស្តើយ(ឧ. vêtement frais); ស្រស់ (ឧ. teint frais); ថ្មី (មិនទាន់ហត់, មិនទាន់អស់កម្លាំង) (ឧ. troupe fraiche); ថ្មី, ស្រស់ (មិនទាន់ខូច)(ឧ. poisson frais)។ *Fig.* ថ្មី(មិនទាន់យូរ)(ឧ. nouvelle de fraiche date)។

n.m. អាកាសត្រជាក់ស្រួល (ឧ. prendre le frais)។

n.f. ពេលត្រជាក់ស្រួល (ឧ. sortir à la fraiche)។

adv. ត្រជាក់ (ឧ. boire frais ផឹកភេសជ្ជៈត្រជាក់); ថ្មីៗ (ឧ. fleur fraiche cueillie)។ frais émoulu du collège ទើបនឹងចេញថ្មីៗពីអនុវិទ្យាល័យ

frais *n.m.pl.* ចំណាយ, សោហ៊ុយ (ឧ. faire de grands frais); ខាត; ប្តៃ, ក្រឡាក្រមឬប្រដាប់ក្តី (ឧ. être condamné aux frais)។

Loc. div. faire ses frais យកឡប់ថ្លៃ (មិនចំណេញមិនខាត)។ frais généraux សោហ៊ុយសរុប។ faux frais សោហ៊ុយបន្ទាប់បន្សំ (សោហ៊ុយបន្តិចបន្តួចដែលមិនបានគ្រោងទុកជាមុន)។ frais de déplacement សោហ៊ុយផ្លាស់កន្លែង។ frais de route សោហ៊ុយដើរផ្លូវ។ frais de séjour សោហ៊ុយស្នាក់អាស្រ័យ។ frais de voyage សោហ៊ុយធ្វើដំណើរ។ frais de tournée សោហ៊ុយទស្សនាចរ។ frais de représentation សោហ៊ុយតំណាង។ frais de port សោហ៊ុយដឹកនាំ។ *Fam.* se mettre en frais ចាយលើសពីធម្មតា; *au fig.* ខំប្រឹង (ឧ. se mettre en frais d'amabilités)។ faire les frais de la conversation បើកមុខជជែក ឬ ជាដើមហេតុឲ្យគេជជែកអំពីខ្លួន។ à grands frais ដោយចំណាយច្រើន; *au fig.* ដោយខំប្រឹងខ្លាំង, ដោយនឿយហត់ខ្លាំង។ à peu de frais ដោយចំណាយតិច; *au fig.* ដោយមិនសូវខំប្រឹង, ដោយមិនសូវនឿយហត់។ à frais commun ដោយចំណាយរួម; *au fig.* ដោយរួមកម្លាំងគ្នា។ **sur nou-**

veaux frais ឬ sur de nouveaux frais ដោយចំប្រឹងថែមទៀត (ឬជាថ្មីទៀត) ។ faire des frais ធ្វើឲ្យខូចខាត(នាំឲ្យអស់សោហ៊ុយជួសជុល) ។ faire les frais de quelque chose ទទួលបន្ទុកចំណាយ, ទទួលបន្ទុក ។ être de grands frais ឲ្យចាយច្រើន ។ en être pour ses frais ខាតតែសោហ៊ុយឥតប្រយោជន៍

fraisage *n.m.* ការរៀល

fraise *n.f.* ស្បែកចង្កាមាន់បារាំង

fraise *n.f.* ដែករៀល

fraiser *v.t.* រៀល (ឲ្យរីកប្រហោង); លាញ់ម្សៅ (ក្នុងន័យនេះគេថា fraser ក៏បាន)

fraiseur,euse *n.* ជាងឬគ្រឿងរៀល ។ *n.f.* ម៉ាស៊ីនរៀល

fraisil *n.m.* ដែះធ្យូង (ពោលមិនអស់)

fraisure *n.f.* រង្វង់រៀល

framée *n.f.* លំពែងវែងមួយបែប

franc (F.) *n.m.* ហ្វ្រង់, ត្រណោត (រូបិយវត្ថុបារាំង,បែលស៊ិកនិងស្វិស្ស)

franc,franche *a.* ដែលរួចពន្ធ (ឧ. ville franche ក្រុងរួចពន្ធ; port franc កំពង់ផែរួចពន្ធ; zône franche មណ្ឌលរួចពន្ធ)។ lettres franches de port សំបុត្រផ្ញើឥតថ្លៃ ។ *Fig.* ស្មោះត្រង់ (ឧ. langage franc); ពិតជា, ពេញទី (ឧ. franc pédant); គត់,ពេញ (ឧ.assigner à 8 jours francs) ។

adv. ដោយត្រង់ (មិនលាក់) (ឧ. je vous parle franc)។

Loc.div. avoir ses coudées franches ឥតទើសទាស់ (ធ្វើដោយស្រួលគ្មានអ្វីមកជំទាស់) ។ avoir son franc parler និយាយត្រង់ៗ; មានសិទ្ធិនិយាយតាមត្រង់ ។ avoir le port franc រួចពន្ធប្រៃសណីយ ។ avoir part franche បានចំណែកទទេ (ឥតចេញថ្លៃ)

français,e *a.&n.* បារាំង ។ *n.m.* ភាសាបារាំង

franchement *adv.* ដោយស្មោះត្រង់ (ឧ. parler franchement); ត្រង់ៗ, មិនញញើតញញើម (ឧ.sauter franchement)

franchir *v.t.* លោតផ្លោះ, លោតរំលង (ឧ.franchir un fossé); ឆ្លង,ឆ្លងកាត់ (ឧ. franchir un défilé; franchir les mers) ។ *Fig.*

ពុះពារ, ជំនះ (ឧ. franchir les obstacles)

franchise *n.f.* ការមិនជាប់ពន្ធ; ការលើកលែងពន្ធ (ឧ. les franchises communales)។ franchise postale ការរួចថ្លៃដឹកនាំតាមប្រៃសណីយ ។ *Fig.* សេចក្ដីស្មោះត្រង់ (ឧ. parler avec franchise)

franchissable *a.* អាចលោតផ្លោះ ឬឆ្លងកាត់បាន

franchissement *n.m.* ការលោតផ្លោះ, ការឆ្លងកាត់

francisation *n.f.* ការឲ្យមានលំនាំជាបារាំង (ឧ. la francisation d'un mot étranger); សិទ្ធិបញ្ជាក់នាវាជារបស់បារាំង

franciser *v.t.* ឲ្យមានលំនាំជាបារាំង ។ franciser un mot ឲ្យមានលំនាំជាពាក្យបារាំង

francisque *n.f.* ពូថៅចម្បាំង

franc-maçon *n.m.* ហ្វ្រង់ម៉ាសុង (សមាជិកក្រុមសម្ងាត់មួយពួក) (*pl.* des francs-maçons)

franc-maçonnerie *n.f.* សមាគមហ្វ្រង់ម៉ាសុង (ក្រុមសម្ងាត់មួយពួកដែលមាននយោបាយនៅពាសពេញក្នុងពិភពលោក)

franc-maçonnique *a.* នៃសមាគមហ្វ្រង់ម៉ាសុង (ឧ. signes franc-maçonniques) (ថា maçonnique ក៏បាន)

franco *adv.* រួចសោហ៊ុយដឹកនាំ (ឧ. recevoir un paquet franco de port)

franco-khmer បារាំងខ្មែរ (ឧ. traité franco-khmer)

franco-bord *n.m.* ម.ព. F.O.B.

francophile *a.&n.* នៃសកូលចិត្តបារាំង

francophilie *n.f.* ការកូលចិត្តបារាំង

francophobe *a.&n.* នៃសស្អប់បារាំង

francophone *a.&n.* នៃសចេះនិយាយភាសាបារាំង

franc-parler *n.m.* ការនិយាយត្រង់, ការមិនលាក់ពាក្យសំដី

franc-pied *n.m.* ពូជបណ្ដុះ (មើល arbre franc de pied ក៏បាន)

franc-tireur *n.m.* ទាហានព្រៃទ័ព (ទាហាននៃសមិនកូលក្នុងទ័ពរៀបរយ) (*pl.* des francs-tireurs)

frane *n.m.* ដំណើរអិលផ្លាំងដីពន្លៃ (ឧ. les franes sont fréquents dans l'Alpennin)

frange *n.f.* ជាយ, រំយោល; អ៊ីវ ផ្លូវ

រំយោល(ឧ.frange de cheveux)។ *Fig.* ព្រំដែនមិនច្បាស់លាស់ (ឧ. frange de conscience)

frangeant,e *a.* ដែលជាជាយឬរំយោល (ឧ. récif frangeant)

franger *v.t.* ដាក់ជាយ ឬ រំយោល

frangin,e *n.Pop.* បងប្អូនបង្កើត(ប្រុស ឬ ស្រី)

frangipane *n.f.* ទឹកអប់មកពីប្រទេសអ៊ីតាលី (ក្លិនដូចផ្កាចម្ប៉ា); នំម្យ៉ាង

frangipanier *n.m.* ដើមចម្ប៉ា

franquette *n.f.Fam.* à la bonne franquette ដោយស្មោះត្រង់,ដោយមិនបាច់គួរសមច្រើន

franquiste *a.* នៃរដ្ឋាភិបាលឧត្តមសេនីយហ្វ្រង់កូ ។ *n.* បក្សពួកខាងឧត្តមសេនីយហ្វ្រង់កូ

frappage ឬ **frappement** *n.m.* ការបោះ(ឲ្យមានស្នាម)(ឧ.le frappage de la monnaie; un frappage bien réussi)

frappant,e *a.* ដែលឲ្យមានការចាប់អារម្មណ៍ខ្លាំង; ដែលឲ្យឆ្ងល់,ស្តែងណាស់ (ឧ.preuves frappantes ភស្តុតាងស្តែងណាស់) ។ ressemblance frappante ភាពដូចបេះបិទ

frappe *n.f.* ការបោះប្រាក់; រូបបោះលើប្រាក់;ការវាយ (វាយម៉ាស៊ីនអង្គុលីលេខ ឬ វាយបាល់) ; ប្រដាប់បោះអក្សរពុម្ព; មនុស្សខូច

frappé,e *a.* កក ឬ ត្រាំទឹកកក (ឧ. champagne frappé) ។ vers bien frappé កំណាព្យស្វាហាប់ហើយពីរោះ ។ ouvrage frappé au bon coin ស្នាដៃល្អ ។ temps frappé (ឬfrappé *n.m.*) ចង្វាក់ដែលគោះ

frappe-devant *n.m.inv.* ភ្លើន (ញញួរធំ និងវែងសម្រាប់វាយដែកដោយដៃទាំងពីរ)

frapper *v.t.&i.* ប្រហារ(វាយ,ទាត់,ដាក់, សំពង, ចាក់, កាប់) (ឧ. frapper la terre du pied;frapper au but; frapper d'un coup de poignard); បោះ (ធ្វើឲ្យមានស្នាម) (ឧ.frapper de la monnaie) ។ *Fig.* frapper d'une infirmité ធ្វើឲ្យពិការ ។ ដាប់រូប (ឧ. velours frappé); ទទួលរងការសម្រេចនៃតុលាការឬរដ្ឋបាល។ frapper une marchandise d'un impôt ដាក់ពន្ធលើទំនិញ ។ *Mar.* ចង ។

ធ្វើឲ្យឮសូរ(ឧ. frapper l'air de ses cris): ធ្លាក់ឬចោលទៅលើ(ឧ. la lumière frappe les objets)។ frapper quelqu'un de stupeur ធ្វើឲ្យស្រឡាំងកាំង។ frapper l'attention ញាំងឲ្យប្រយ័ត្ន (ដាស់សតិឲ្យប្រយ័ត្ន) ។ frapper un grand coup ដាក់ការម៉ឺងម៉ាត់បង្ហើយ ។ ត្រាំទឹកកក (ឧ. frapper du champagne) ។ frapper les yeux ចេញស្ដែងនឹងភ្នែក ។

v.i. frapper à la porte de quelqu'un សុំពឹងគេ។ *Fig. & fam.* frapper à toutes les portes សុំពឹងគេគ្រប់គ្នា ។

se frapper *v.pr.* ប្រហារខ្លួនឯង; តក់ស្លុតបំពោះភ័យខ្លាច

frappeur,euse *a.&n.* អ្នកវាយ ។ esprit frappeur ខ្មោចលងវាយគោះ(ខ្មោចដែលលងដោយវាយឬទះតុជញ្ជាំង។ល។)។*Techn. n.m.* ជាងជំនួយកាន់ញញួរ (ជាងដែក)

frasque *n.f.* អំពើផ្ដេសផ្ដាស,ការប្រព្រឹត្តខុសគន្លងធម៌ (ឧ. frasques de jeunesse)

fraternel,elle *a.*នៃបងប្អូន;ប្រកបដោយភាតរភាព

fraternellement *adv.* ដោយភាតរភាព

fraternisation *n.f.* ការសំដែងភាតរភាព

fraterniser *v.i.* សំដែងភាតរភាព; រាប់រកគ្នាដូចបងប្អូន (ឧ. troupes qui fraternisent)

fraternité *n.f.* ភាតរភាព, ភាវៈនៃបងប្អូន ។ *Fig.* ភាតរភាព,សេចក្ដីរាប់រកគ្នាដូចបងប្អូន (ឧ. élan de fraternité)

fratricide *n.m.* ភាតុឃាត, ការសម្លាប់បងប្អូនឯង ។ *a.&n.* ភាតុឃាតកៈ, អ្នកសម្លាប់បងប្អូនឯង ។ *a.* នៃភាតុឃាត; រវាងបងប្អូន(ឧ. luttes fratricides)

fraude *n.f.* ការបន្លំលួច,ការបំភាន់,ការបំបាត់,អំពើដែលធ្វើដោយអសុទ្ធចិត្ត(ឧ. prendre en fraude);ការគេចពន្ធ (ឧ. faire la fraude) ។ fraude fiscale ការបន្លំសារពើពន្ធ ។ en fraude *loc.adv.* ដោយបន្លំលួច, ដោយបំភាន់

frauder *v.t.* បន្លំលួច, ស៊ីឡឹប, បំបាត់ (ឧ. frauder la douane)។ *v.i.* បន្លំ , ប្រព្រឹត្តអំពើទុច្ចរិតដោយបន្លំ (ឧ.

frauder dans un examen)

fraudeur,euse *a.&n.* ដែលបន្លំលួច, ដែលបំបាត់

frauduleusement *adv.* ដោយបន្លំលួច, ដោយបំបាត់

frauduleux,euse *a.* ល្បៀងទៅរកការបំបាត់ ឬ បន្លំលួច, សៅហ្មងដោយការបំបាត់ ឬ បន្លំលួច(ឧ. banqueroute frauduleuse)

frayer *v.t.* វែក, ព្រាយ, ឆ្កា (ឧ. frayer un sentier)។ frayer le chemin ឬ la voie à quelqu'un ព្រាយផ្លូវឲ្យ។ *v.i.* ពង (បំពោះត្រី)។ *Fig.* frayer avec quelqu'un សេពគប់ជាមិត្ត។ se frayer *v.pr.* វែកផ្លូវខ្លួនឯង, ឈ្លុស

frayère *n.f.* កន្លែងត្រីពង

frayeur *n.f.* ដំណើរខ្លាច, ដំណើរភ័យ (ឋ.effroi, épouvante, peur, saisissement, terreur)

fredaine *n.f. Fam.* អំពើពាលក្នុងវ័យក្មេង

fredon *n.m.* ដំណើរលោកឬបង្អួសសម្លេង

fredonnement *n.m.* ការច្រៀងហ៊ុមៗ; ចម្រៀងហ៊ុមៗ

fredonner *v.t. & i.* ច្រៀងហ៊ុមៗ

frégate *n.f. Mar.* នាវាចម្បាំង។ capitaine de frégate ម.ព. capitaine។ *Ornith.* បក្សីមួយយ៉ាង

frégaton *n.m. Arg.mil.* វរនាវីទោ

frein *n.m.* បង្ហៀរ ; គ្រឿងទប់ (ឧ. frein de la langue)។ *Méc.* ហ្វ្រាំង (ប្រដាប់សំរាប់ទប់បញ្ឈប់ម៉ាស៊ីនរថ)។ *Fig.* គ្រឿងទប់ (ឧ. mettre un frein à ses désirs)។ ronger son frein ទ្រាំអំពើអ្វីមួយដោយក្តៅក្រហាយ។ frein de tire ដៃកាំភ្លើងធំ

freinage *n.m.* ការទប់ហ្វ្រាំង (ឧ. un freinage puissant)

freiner *v.t.&i.* ទប់ហ្វ្រាំង។ *v.t.Fig.* ទប់,បញ្ឈប់ (ឧ. freiner son enthousiasme)

freinte *n.f.* សម្រកទំងន់ (ដោយហើ, ដឹកនាំ ។ល។)

frelatage *n.m.* ការលាយបន្លំ (វត្ថុអ្វីមួយដោយលាយនឹងជាតិដទៃ)

frelaté,e *a.Fig.* សៅហ្មង (ឧ. vie frelatée)

frelater *v.t.* លាយបន្លំ (វត្ថុអ្វីមួយ

ដោយលាយនឹងជាតិដទៃ) (ឧ. frelater du vin)

frêle *a.* ខ្សោយ, ទន់ (ឧ. un frêle roseau) ។ *Fig.* មិនឋិតថេរ, អាច រំសាយបាន (ឧ. frêles espérances)

frelon *n.m.* ឪម៉ាល់នៃទ្វីបអឺរ៉ុប

freluche *n.f.* កញ្ចុំសូត្រ

freluquet *n.m.Fam.* មនុស្សសាវ៉ា មិនបានការអ្វី

frémir *v.i.* ញ័រ (ឧ. frémir de tous ses membres) ។ *Fig.* ញ័រ (ដោយខ្លាច, ដោយខឹង, ដោយភ័យ)

frémissant,e *a.* ដែលញ័រ

frémissement *n.m.* ដំណើរញ័រ (ឧ. frémissement des lèvres) ; រំជួលទឹកដែលជិតពុះ ។ *Fig.* ដំណើរញ័រ (ដោយខ្លាច, ដោយខឹង, ដោយភ័យ) (ឧ. frémissement de colère)

frénésie *n.f.* ការវក់, ការវង្វេង; ដំណើរឆ្កួតវក់ (ឧ. accès de frénésie) (ម. aveuglement, emportement, folie, fureur)

frénétique *a.* ដែលវក់ខ្លាំង (ឧ. rires frénétiques)

frénétiquement *adv.* ដោយវក់

fréquemment *adv.* ញយ, រឿយៗ

fréquence *n.f.* ដំណើរដួន; ភាពដែលមានឡើងរឿយៗ ។ fréquence du pouls ល្បឿនជីពចរលោត

fréquent,e *a.* ដែលមានរឿយៗឬច្រើនដង ។ pouls fréquent ជីពចរញាប់

fréquentable *a.* អាចសេពគប់បាន; អាចទៅកាន់ញឹកញយបាន

fréquentation *n.f.* ការទៅកាន់ញឹកញយ; ការសេពគប់ (ឧ. éviter les mauvaises fréquentations); ការប្រើញយៗ (ឧ. la fréquentation des livres)

fréquenter *v.t.* សេពគប់ (ឧ. fréquenter quelqu'un) ; ទៅកាន់ញឹកញយ (ឧ. fréquenter les théâtres)។ *Fig.* មានជាប់ចិត្តស្នេហា

frère *n.m.* បងប្អូនប្រុសបង្កើត ។ frère germain បងប្អូនប្រុសបង្កើត (ឪពុកម្ដាយជាមួយ)។ frère consanguin សហបិតុកៈ (បងប្អូនឪពុកជាមួយម្ដាយទីទៃ) ។ frère utérin សហោទរ (បងប្អូនរួមឧទរ គឺម្ដាយជាមួយ ឪពុកទីទៃ) ។ frères jumeaux បងប្អូនប្រុសភ្លោះ ។ frères de lait បងប្អូនរួមទឹកដោះ (កូនដែលបៅដោះ បំបៅជាមួយក្នុងពេលជាមួយគ្នា) ។

Par anal. បងប្អូន (មនុស្សទាំងឡាយដែលទុកដូចជាបងប្អូនបង្កើត) (ឧ.on doit toujours secourir ses frères) ; បងប្អូន (ដោយមានចំណងផ្សេងៗ) (ឧ. frère par adoption; frère d'esprit) ។

Fig. បងប្អូន (រឿងៗដែលដូចគ្នា ឬមានឫសគល់ដូចគ្នា) (ឧ. les vices sont frères (La Fontaine); fille du paupérisme, la guerre a la cupidité pour marraine, et son frère est le crime (Proudhon) ។

Loc.div. frère d'armes អ្នករួមសុខទុក្ខក្នុងការគយុទ្ធ ។ faux frère អ្នកក្បត់សង្គម ឬ បក្សពួកខ្លួន

frérot *n.m. Fam.* ប្អូនប្រុស

fresque *n.f.* គំនូរនៅជញ្ជាំង ។ *Fig.* ការនិពន្ធអំពីសម័យមួយ

fresquiste *n.* ជាងគូរនៅជញ្ជាំង

fressure *n.f.* រករាះក្នុងទាំងឡាយនៃសត្វ (បេះដូង. ថ្លើម, ថ្លើមនិងសួត)

fret *n.m.* នាវាវេតន៍, តម្លៃដឹកនាំតាមនាវា, តម្លៃជួលនាវា ; ទំនិញផ្ទុកក្នុងនាវា (ឧ. fret d'aller; fret de retour)

frètement *n.m.* ការជួលនាវា ; ការផ្ទុកទំនិញក្នុងនាវា

fréter *v.t.* ជួលនាវា ឬ រថ; ផ្ទុកទំនិញក្នុងនាវា, ប៉ុក

fréteur *n.m.* អ្នកជួលនាវា (ព. ផ. affréteur)

frétillant,e *a.* ដែលកំរើកឬបំរះ

frétillement ឬ **frétillage** *n.m.* ការកំរើក, ការបំរះ

frétiller *v.i.* កំរើក,បំរះ; លោតកញ្ឆេង (ឧ. frétiller de joie)

frétillon *n.m.Fam.* មនុស្សកម្រើកគ្មានឈប់

fretin *n.m.* ត្រីល្អិតល្អោច (ឧ. rejeter le fretin) ។ *Fig.* មនុស្ស ឬ វត្ថុគ្មានតម្លៃ

frettage *n.m.* ការដាក់ចង្កំ,ការចងមៀន

frette *n.f.* ចង្កំ មៀន

fretter *v.t.* ដាក់ចង្កំ, ចងមៀន

freux *v.t.* បក្សីម្យ៉ាងស្រដៀងក្អែក

friabilité *n.f.* ភាពស្រួយ, ភាពផុយ

friable *a.* ស្រួយ, ផុយ

friand,e *a.* ឆ្ងាញ់; ដែលចូលចិត្តចំណីឆ្ងាញ់ (ឧ. friand de miel) ។ *Fig.* ដែលចូលចិត្ត (ឧ. friand de louanges)

friandise *n.f.* ការចូលចិត្តចំណីឆ្ងាញ់ ។

pl. បង្អែម

fric *n.m.Arg.* ប្រាក់

fricassée *n.f.* ឆុំសាច់ស្ងោរ (ឧ. une fricassée de poulet)

fricasser *v.t.* ស្ងោរឆុំសាច់ ។ *Fig.* ធ្វើឲ្យវិនាសយ៉ាងរហ័ស (ឧ. il a fricassé tout son bien)

fricasseur *n.m.* ចុងភៅមិនប្រសប់

fricatif,ive *a.Gram.* ឧដ្ឋជៈ [អោត-ឋៈ-ជៈ](ដែលមានសូរសម្លេងកើតត្រង់រឹមបបូរមាត់ គឺមានសូរះបបូរមាត់ចេញមក ដូចជា: ហ្វ, f, v, s, z, ch, j)

friche *n.f.* ដីខ្ទម(ដែលគេបោះបង់ចោលទៅជាព្រៃខ្ទះ)។en friche *loc.adv.* គ្មានដំណាំ; *au fig.* គ្មានថែទាំ

frichti *n.m.Pop.* សាច់

fricot *n.m. Fam.* សាច់; ម្ហូប

fricoter *v.i. Pop.* រកកម្រៃដោយខុសច្បាប់ ។ *v.t.* ធ្វើភក្ត (ម្ហូបបារាំង) ។ *Pop.* ប្រើឧបាយសម្ងាត់

fricoteur,euse *n.Pop.* អ្នករកកម្រៃខុសច្បាប់; អ្នកប្រើឧបាយសម្ងាត់

friction *n.f.* ការរឹត;ការត្រដុស;ការកក់ក្បាលដោយគ្រឿងក្រអូប ។ *Fig.* ការប៉ះទង្គិច;ការរង្កៀសឬឃ្នើសចិត្ត;សេចក្តីមោះហ្មង

frictionner *v.t.* រឹត,ច្របាច់ (ឧ. frictionner un malade, un bras)

frigidaire *n.m.* ទូទឹកកក

frigide *a.* ត្រជាក់

frigidité *n.f.* ភាពត្រជាក់ (ឧ. la frigidité du marbre)

frigo *n.m.Pop.* សាច់ត្រាំទឹកកក;សីតកណ្ឌ [សី-តៈ—] (ប្រដាប់ធ្វើឲ្យត្រជាក់)

frigorifier *v.i.* ធ្វើឲ្យត្រជាក់ ។ *v.t.* ទុកក្នុងទីត្រជាក់(មានត្រាំទឹកកកជាដើម)

frigorifique *a.* ដែលធ្វើឲ្យត្រជាក់ (ឧ. armoire frigorifique)។ *n.m.* រោងឧស្សាហកម្មធ្វើឲ្យត្រជាក់ ; សីតកណ្ឌ (ប្រដាប់ធ្វើឲ្យត្រជាក់)

frigoriste *a.&n.m.* សីតវិទូ , អ្នកបច្ចេកទេសខាងសីតកណ្ឌ

frileusement *adv.* ដោយខ្លាចត្រជាក់

frileux,euse *a.* សីតភិត , ដែលញញើតត្រជាក់, ដែលខ្លាចត្រជាក់

frimas *n.m.* អព្ទត្រជាក់ហើយក្រាស់

frime *n.f. Fam.* ការសំដែងអាការៈក្រៅបញ្ឆោត (ឧ. ce n'est que pour la frime) ; របស់ប៉ិចប៉ុ (ឧ. c'est de la frime)

frimousse *n.f.Fam.* មុខ (ពាក្យ

សាមញ្ញ)

fringale *n.f.Fam.* ដំណើរឃ្លានរមួលពោះ

fringant,e *a.* រៃ, រហ័ស, សមសួន

fringuer *v.i.* រាំ; លោតអញ្ចើលៗ

fringues *n.f.pl.Arg.* ខោអាវ (សំលៀកបំពាក់)

fripe *n.f.* កន្ទប; វត្ថុដែលអាចលាបលើនំបុ័ងបាន (ខ្លាញ់ជាតិទឹកដោះ, ដំណាប់ ។ល។); អ្ហូប

friper *v.t.* ញី (ឧ. friper une robe); ធ្វើឲ្យទក់

friperie *n.f.* សំលៀកបំពាក់ឬគុទ្ធចាស់ៗ; ជំនួញសំលៀកបំពាក់ ឬ គុទ្ធចាស់ៗ

fripier,ère *n.&a.* អ្នកលក់សំលៀកបំពាក់ ឬ គុទ្ធចាស់ៗ

fripon,onne *n.&a.* ដែលឆបោកដោយប៉ិនប្រសប់, ដែលមានពុតរក្រក់ (ឧ. se laisser duper par un fripon) ។ petit fripon ក្មេងទិល ។ air fripon ទំនងឆ្លាត ។ œil fripon ភ្នែកឆ្លាត

friponner *v.t.* ឆបោក, លួច

friponnerie *n.f.* អំពើឆបោក

fripouille *n.f. Pop.* ជនថោកទាប, មនុស្សពាល

fripouillerie *n.f.* អំពើថោកទាប

friquet *n.f.* ចាបស្រុកល្បើង

frire *v.&i.* ចៀន, ឆា ។ être frit វិនាសដោយគ្មានមធ្យោបាយដោះខ្លួន

frisage *n.m.* ការធ្វើឲ្យរួញឬឲ្យក្រញាញ់

frise *n.f.* បង្រឹងដែក ឬ ឈើដោះជាបន្ទាក់ងផ្ទឺ

frisé,e *a.* រមួល រួញ,ក្រញាញ់ (ឧ.cheveux, poils frisés)

friser *v.t.* ធ្វើឲ្យរួញ ឬ ឲ្យក្រញាញ់ (ឧ. friser les cheveux អ៊ុតសក់) ។ *Fig.* ប៉ះយ៉ាងស្រាល (ឧ. la balle lui a frisé le visage); ជិតដល់, ប្រមេះនឹង (ឧ.friser la quarantaine; sa hardiesse frise l'impertinence) ។ *v.i.* រួញ (ឧ. ses cheveux frisent naturellement)

frisette *n.f.* ផ្នត់តូចនៃសក់ដែលរួញ

frisoir *n.m.* ដែកអ៊ុតសក់

frison *n.m.* ផ្នត់សក់អ៊ុត

frisotter *v.t.&i.* ធ្វើឲ្យរួញ ឬ ឲ្យក្រញាញ់បន្តិចៗ

frisquet,ette *a.Fam.* រងាខ្លាំង (ឧ. vent frisquet)

frisson *n.m.* រងាញាក់; ការញាក់ (ឧ.

la fièvre est souvent précédée de frissons)។ *Fig.* ការញាក់ (ដោយភ័យ ឬ ដោយរំភើបខ្លាំង) (ឧ. frisson d'épouvante)

frissonnement *n.m.* ការញាក់បន្តិចបន្តួច

frissonner *v.i.* ញាក់, ញ័រ (ឧ. les feuilles frissonnent) ។ *Fig.* ញាក់(ឧ.frissonner d'horreur)

frisure *n.f.* ភាពរួញ ឬ ក្រញាញ់; របៀបធ្វើឲ្យរួញ; សក់រួញ

frit,e *a.* ចៀន, ឆា

frite *n.f.* ដំឡូងបារាំងចៀន

friterie *n.f.* គ្រឹះស្ថាន ឬ បន្ទប់សម្រាប់ចៀន

friteuse *n.f.* ប្រដាប់សម្រាប់ចៀន

friture *n.f.* ការ ឬ របៀបចៀន; ខ្លាញ់សម្រាប់ចៀនត្រី; ត្រីចៀន (ឧ. friture de goujons); សូរព្រែកព្រែកក្នុងទូរសព្ទ

fritz *n.m. Fam.* ទាហានអាល្លឺម៉ង់

frivole *a.* ឥតបានការ, មិនសំខាន់ (ឧ. discours frivoles); ដែលចូលចិត្តលេង, ដែលចូលចិត្តរបស់ឥតខ្លឹមសារ (ឧ. esprit frivole)

frivolement *adv.* ដោយឥតបានការ, ដោយមិនសំខាន់

frivolité *n.f.* ភាពឥតបានការ; ភាពមិនសំខាន់; ភាពមនុស្សចូលចិត្តតែលេង (ឧ. elle est d'une extrême frivolité); របស់មិនសំខាន់ ឬ គ្មានខ្លឹមសារ (ឧ. acheter des frivolités); ជរអំបោះ

froc *n.m.* គ្រឿងស្លៀកដណ្ដប់អ្នកបួស ។ *Fig.* ផ្នួស ។ prendre le froc បួស ។ jeter le froc aux orties សឹកចាកផ្នួស។ *Pop.* ខោ

frocard *n.m. Pop.* អ្នកបួស

froid,e *a.* ត្រជាក់(ឧ. air froid); រងា; មិនកក់ក្ដៅ (ឧ. le coton est plus froid que la laine); ត្រជាក់(លែងក្ដៅ)(ឧ.viandes froides)។ *Fig.* នឹងធឹង; ដើយ, មិនរួសរាយ (ឧ. homme froid); មិនរំភើប(ឧ.ce spectacle l'a laissé froid); គ្រោះគគ្រោះ (ឧ. style froid) ។ battre froid à quelqu'un ទទួលដោយមិនសូវរាក់ទាក់ខ្លួនធម្មតា។ à froid *loc. adv.* ដោយត្រជាក់; *au fig.* ដោយគ្មានរំភើប ។ *Chir.* ដោយគ្មានគ្រុន(ឧ.opérer à froid)

froid *n.m.* ភាពត្រជាក់; ភាពរងា (ឧ.

froid rigoureux)។ froid industriel សីតវិធីឧស្សាហកម្ម (របៀបទុកម្ហូបឲ្យបានយូរដោយត្រជាក់)។ chaîne de froid ម.ព.chaîne។ អាការព្រងើយកន្តើយ (ឧ. il y a du froid entre eux)។ jeter un froid ធ្វើឲ្យមានការបង្អៀតចង្អល់ ឬការទើសទាល់

froidement *adv.* ដោយត្រជាក់, ដោយព្រងើយកន្តើយ

froideur *n.f.* ភាពត្រជាក់ (ឧ. froideur du marbre)។ *Fig.* ការព្រងើយកន្តើយ (ឧ. témoigner de la froideur à quelqu'un)

froidure *n.f.* ធាតុត្រជាក់ក្នុងអាកាស; សិសិររដូវ (រដូវរងា); សីតរោគ, រោគបណ្ដាលអំពីត្រជាក់

froissable *a.* ឆាប់ទក់

froissement *n.m.* ការពញី (ឧ. froissement d'une étoffe)។ *Fig.* សេចក្ដីថ្នាំងថ្នាក់, សេចក្ដីឈ្នើសចិត្ត (ឧ. le froissement des intérêts; le froissement de l'amour-propre)

froisser *v.t.* ធ្វើឲ្យរបួស (ដោយការខ្ទាំង ឬដោយប៉ះទង្គិច) (ឧ. se froisser un membre); ពញី (ធ្វើឲ្យទក់) (ឧ. froisser du drap)។ *Fig.* ធ្វើឲ្យថ្នាំងថ្នាក់, ធ្វើឲ្យឈ្នើសចិត្ត ។ se froisser *v.pr.* ឡើងទក់; ថ្នាំងថ្នាក់, ឈ្នើសចិត្ត

froissure *n.f.* ស្នាមទក់

frôlement *n.m.* ការប៉ះយ៉ាងស្រាល; សូរប៉ះយ៉ាងស្រាល

frôler *v.t.* ប៉ះយ៉ាងស្រាល។ *Fig.* frôler l'accident រំពឹះមានគ្រោះថ្នាក់

frôleur,euse *a.* ដែលប៉ះយ៉ាងស្រាល, ដែលអង្អែល (ឧ. de cette voix caressante et frôleuse qu'ont les mères (A. Daudet)

frôleur *n.m.* អ្នកចូលចិត្តប្រជ្រៀតឲ្យប៉ះនឹងស្រី

frôleuse *n.f.* ស្រីពេស្យាតាមផ្លូវ

fromage *n.m.* ប្រូម៉ាស ។ *Fig.* entre la poire et le fromage នៅក្នុងពេលបាយ (នៅពេលកំពុងមានសេចក្ដីរីករាយ នឹងសេចក្ដីស្និទ្ធស្នាលកាន់តែខ្លាំងឡើង) ។ *Fam.* មុខការស្រួល

fromagé,e *a.* ដែលលាយនឹងប្រូម៉ាស

fromageon *n.m.* ប្រូម៉ាសធ្វើអំពីទឹកដោះចៀម

fromager *n.m.* ដើមស្លង់

fromager,ère *n.* អ្នកធ្វើ ឬ លក់ហ្វ្រូម៉ាស។ *n.m.* ធុងថោះជាតសម្រាប់សម្រក់ទឹកហ្វ្រូម៉ាស

fromagerie *n.f.* កន្លែងធ្វើឬកន្លែងលក់ហ្វ្រូម៉ាស

froment *n.m.* ហ្វ្រូម៉ង់ (ស្រូវសាលីម្យ៉ាង) (ឧ. farine de froment)

fromental,e,aux *a.* នៃហ្វ្រូម៉ង់

fromental *n.m.* ហ្វ្រូម៉ង់ពាល

fronce *n.f.* ការដឹប

froncement *n.m.* ការចងចិញ្ចើម; ដំណើរជ្រួញ (ថ្ងាស)

froncer *v.t.* ចងចិញ្ចើម, ធ្វើឲ្យជ្រួញ (ថ្ងាស)(ឧ.froncer les sourcils); ដឹប (ឧ. froncer une robe)

froncis *n.m.* ផ្នត់ដឹបទាំងឡាយ

fronde *n.f.* ខ្នងក់(ធ្វើអំពីស្បែក)។ *Par anal.* ប្រដាប់ក្មេងលេងបាញ់ជ័រ

fronder *v.t.* ចោលខ្នងក់។ *Fig.* រិះគន់ដោយរករឿង (ឧ. fronder le pouvoir)

frondeur,euse *n.* អ្នកចោលខ្នងក់។ *a.&n.* *Fig.* ដែលចូលចិត្តរិះគន់ ឬស្តីបន្ទោស

front *n.m.* ថ្ងាស; មុខ (ទឹកមុខ) (ឧ. la rougeur lui monte au front)។ *Poét.* ក្បាល (ឧ. courber le front)។ ប៉ែកខាងមុខ (ឧ. le front d'une montagne); រណសិរ្ស [រៈ-ណៈ-សេ] (ឧ.passer devant le front d'un bataillon)។ *Par ext.* ក្បាលទ័ព (ឧ. le front français de 1918); មណ្ឌលប្រយុទ្ធ(ឧ.partir pour le front)។ front de mer រណសិរ្សសមុទ្រ (ផ្នែកការពារឆ្នេរសមុទ្រ)។ *Géogr.* ព្រំអាកាស (ឧ. le front polaire)។ faire front ឈមមុខតទប់។ *Fig.* សេចក្ដីអង់អាច;មុខក្រាស់(ដំណើរគ្មានរៀនខ្មាស)(ឧ.vous avez le front de soutenir ce qu'il a dit)។ de front *loc. adv.* ពីមុខ (ឧ. attaquer de front); ទន្ទឹមគ្នា (ឧ. aller de front); ព្រមគ្នា (ឧ. mener deux affaires de front); គ្មានយោគយល់ (ឧ.heurter de front les opinions de quelqu'un)

frontail *n.m.* ក្រវាត់ថ្ងាស (ផ្នែកបង្ហៀរដែលព័ទ្ធលើថ្ងាស)

frontal,e,aux *a.* នៃថ្ងាស (ឧ. os

frontal) ។ *n.m.* ឆ្អឹងថ្ងាស

frontalier,ère *a.&n.* ដែលនៅព្រំដែន

fronteau *n.m.* ជានថ្ងាស (បន្ទះសំពត់សម្រាប់ពាក់លើថ្ងាស)

frontière *n.f.* ព្រំដែន, ព្រំប្រទល់, ខេត្តសីមា ។ frontière naturelle ព្រំដែនធម្មជាតិ (ស្ទឹង, ទន្លេ, ភ្នំ) ។ *a.* ដែលនៅត្រង់ព្រំប្រទល់ (ឧ. place frontière)

frontispice *n.m.* មុខគ្រឹះ; ចំណងជើងពិស្តារ; រូបចំណងជើងសៀវភៅ

fronton *n.m.* ស៊ុមទ្វារ (ឧ. le fronton du Panthéon); ជញ្ជាំងសម្រាប់គោលបាល់

frottage *n.m.* ការជុសខាត់, ការដូត

frottée *n.f.* *Pop.* ការប្រវាយគ្នា; ភេតកបរមាស់

frottement *n.m.* ការកកិតគ្នា ; ការត្រដុស

frotter *v.i.* ត្រដុស (ឧ. frotter ses mains); ដូត,ជុសខាត់(ឧ.frotter un parquet) ។ *Fam.* វាយ, ធ្វើបាប (ឧ. frotter les oreilles à quelqu'un) ។ *v.i.* កកិតគ្នា។ se frotter (à) *v.pr.* *Fam.* កកៀង, បង្កហេតុ

frotteur,euse *n.* អ្នកជុសខាត់ក្តារ ឬ ឥដ្ឋក្រាល ។ *n.f.* ក្រាសជុសខាត់ក្តារ ឬឥដ្ឋក្រាល

frottis *n.m.* ពណ៌ស្តើងហើយថ្លា;ការវែកធាតុដែលត្រូវពិនិត្យក្នុងអតិសុខុមទស្សន៍

frottoir *n.m.* ប្រដាប់ដូត ឬ ខាត់

frouer *v.i.* ព្រាប់សម្លេងបក្សី (ក្នុងការបរបាញ់)

frou-frou ឬ **froufrou** *n.m.* សូរព្រូៗ (សូរស្លឹកឈើឬសំពត់) (*pl.* des frous - frous)

froufrouter *v.i.* ធ្វើឲ្យឮសូរព្រូៗ

froussard,e *a.&n.Pop.* មនុស្សកម្សាក

frousse *n.f.* *Pop.* សេចក្តីខ្លាចព្រឺរោម

fructifère *a.* ដែលមានផ្លែ(ឧ.rameau fructifère) (ថា frugifère ក៏បាន)

fructification *n.f.* ផលការ [ផល់-ការ], ដំណើរមានផ្លែ;ផលកាល [ផល់-កាល]; រដូវផ្លែ

fructifier *v.i.* ផ្លែ។ *Fig.* ឲ្យផល (ឧ. idée qui fructifie; somme qui a fructifié)

fructose *n.m.* ស្ករក្នុងទឹកឃ្មុំនិងផ្លែឈើ

fructueusement *adv.* ដោយបានផល ឬ អត្ថប្រយោជន៍

fructueux, euse *a.* ដែលឲ្យផលល្អ,

ដែលឲ្យអត្ថប្រយោជន៍(ឧ.commerce fructueux)

frugal,e, aux *a.* ដែលមិនល្មោភស៊ី; អត្តខាត (ឧ. nourriture frugale); តឹងរ៉ឹង (ឧ. vie frugale)

frugalement *adv.* ដោយមិនល្មោភស៊ី; ដោយអត្តខាត

frugalité *n.f.* ភាពមិនល្មោភស៊ី, ភាពអត្តខាត

frugivore *a.* ផលាសី, ដែលស៊ីផ្លែឈើជាអាហារ (ឧ. l'écureuil est frugivore)

fruit *n.m.* ផ្លែ, ផល ។ fruit sec ផ្លែឈើគ្មានសាច់; *au fig* អ្នកដែលមិនបានសម្រេចផល។ fruit défendu ផ្លែឈើដែលអាទិទេពហាម (ក្នុងរឿងគម្ពីរ); *au fig.* អ្វីៗដែលគេហាម។

Fig. ផល, កម្រៃ (ឧ. le fruit de l'étude, de l'expérience) ។

Dr. fruits pendants par les racines ផលដំណាំមិនទាន់ប្រមូលកាត់ (នៅជាប់នឹងឫស) ។ fruits pendants par les branches ផលផ្លែឈើមិនទាន់បេះ (នៅជាប់នឹងមែក) ។ fruits civils ផលជាប្រាក់ដែលបានអំពីរបស់ (មានការប្រាក់ឬឈ្នួលផ្ទះជាដើម)

fruiterie *n.f.* ជំនួញឬតៀមលក់ផ្លែឈើ; កន្លែងទុកផ្លែឈើ

fruitier,ère *a.* ដែលមានផ្លែ(ឧ.arbre fruitier) ។ *a.&n.* ឈ្មួញផ្លែឈើ។ *n.m.* បន្ទប់ឬថ្នាក់ដាក់ផ្លែឈើ ។ *n.f.* សមាគមធ្វើនឹងលក់ហ្រ្វូម៉ាស

frusques *n.f pl.Fam.* សំលៀកបំពាក់ឬគុរុភាសរ៉ៗ

fruste *a.* គគ្រើម (ឧ. un marbre encore fruste)។*Fig.* កញ្ច្រោល; ល្ងង់;មិនសង្ហា(ឧ.homme fruste); ក្រាប (ភេគ)

frustration *n.f.* ការបំបាត់ (មិនឲ្យវត្ថុដែលគេត្រូវបាន)

frustratoire *a.* ដែលធ្វើដើម្បីបំបាត់

frustrer *v.t.* បំបាត់ (មិនឲ្យវត្ថុដែលគេត្រូវបាន);ធ្វើឲ្យខក (ឧ être frustré dans son attente)

fuel ឬ **fuel-oil** *n.m.* ម៉ាស៊ូត (*បរ.* mazout)

fugace *a.* ដែលបាត់ទៅវិញឆាប់ៗ, ដែលមានតែមួយឆាប (ឧ. désir, parfum fugace)

fugacité *n.f.* ភាពបាត់ទៅវិញឆាប់ៗ,

ភាពមានតែមួយឆាប

fugitif,ive *a.&n.* ដែលរត់គេច (ឧ. arrêter un fugitif)។ *Fig.* ដែលឆាប់បាត់ទៅវិញ, ដែលមិនឋិតថេរ (ឧ. bonheur, espoir fugitif)

fugitivement *adv.* ដោយរត់គេច; ដោយឆាប់បាត់ទៅវិញ

fuir *v.i.* រត់ (គេចខ្លួន) (ឧ. fuir à travers champs); កន្លងទៅឬបាត់ទៅយ៉ាងរហ័ស (ឧ. l'hiver a fui); ទ្រេត, ទាប (ចំពោះថ្ងាស) (ឧ. front qui fuit); លេច (ឧ. mon stylo fuit)។

v.t. គេច,ចៀស (ឧ. fuir le danger) (*ស.* décamper, déguerpir, s'esquiver, s'évader, se sauver)

fuite *n.f.* ការរត់គេចខ្លួន(ឧ. prendre la fuite រត់(គេចខ្លួន); ដំណើរធ្លាយ (ជ្រាបចេញ); ស្នាមលេច (ដែលជ្រាបទឹកចេញ); ដំណើរលេចឮ (ចំពោះការសម្ងាត់ដែលមានគេដឹង)។ *Fig.* ការចៀសឬគេច (មិនព្រមទទួល) (ឧ. fuite devant les responsabilités)។ délit de fuite បទល្មើសអំពីការរត់(ចំពោះអ្នកបើករថយន្តដែលមានគ្រោះថ្នាក់ហើយរត់)

fulgurant,e *a.* ភ្លឺផ្លេក,ដែលបញ្ចេញពន្លឺដូចផ្លេកបន្ទោរ។ *Fig.* រហ័ស, ដែលធ្វើឲ្យភ្ញាក់ (ឧ. réponse fulgurante)។ douleur fulgurante ការឈឺចាប់ខ្លាំងហើយឆាប់បាត់

fulguration *n.f.* ផ្លេកបន្ទោរឥតផ្គរ។ *Fig.* ការភាយចេញភ្លាមៗ

fulgurer *v.i.* ភ្លឺផ្លេក, ភ្លឺត្រចះ

fuligineux,euse *a.* ខ្មៅដូចផ្សែងភ្លើង (ឧ. enduit fuligineux); ផ្សែងច្រើន (ឧ. flamme fuligineuse)

fulmi-coton *n.m.* ម.ព. coton-poudre

fulminant,e *a.* ដែលបាញ់ (ផ្ទុះ)។ *Chim.* ដែលផ្ទុះឮសូរ (ឧ. poudre fulminante)។ *Fig.* ដែលកំហែង (ឧ. regards fulminants)

fulmination *n.f.* ការផ្ទុះ; ការកំហែង

fulminer *v.i.* ផ្ទុះ។ *Fig.* ខឹងប្រឡោត; កំហែង។ *v.t.* ដាក់ទណ្ឌកម្មជាទម្ងន់(ដូចផ្ទុះបាញ់)(ឧ. fulminer une excommunication); និយាយសំដីខ្លាំង (ឧ. fulminer des reproches បន្ទោសដោយសំដីខ្លាំង)

fumage *n.m.* ការឆ្អើរ (ឧ. le fuma-

ge des jambons); ការការខ្ញី ព្រាក់សាមាសដោយផ្សែ

fumage *n.m.* ឬ **fumaison** *n.f.* ការដាក់ជីរកេបម៉តោ

fumant,e *a.* ហុយៗ (ដែលហុយផ្សែង) (ឧ. cendre fumante) ។ *Fig.* ដែលក្តៅចិត្តខ្លាំង , ដែលពុះពោរ (ឧ. fumant de colère)

fume-cigare ឬ **fume-cigarette** *n.m.* ខ្សៀជក់បារី

fumée *n.f.* ផ្សែង ។ *Fig.* របស់គ្មានខ្លឹមសារ (ឧ. la fumée de la gloire)។ *pl. Fig.* ការស្រវឹង (ឧ. la fumée de vin)

fumer *v.i.* ហុយផ្សែង។ *Fig.&Pop.* ខឹង, អន់ចិត្ត ។ *v.t.* ផ្សើរ(ឧ. fumer des jambons); ជក់(ឧ. fumer une cigarette)។ lunettes fumées វ៉ែនតាស្រទំ

fumer *v.t.* ដាក់ជីរកេបម៉តោ

fumerie *n.f.* ដំណើរជក់បារី; កៀម ជក់អាភៀន

fumeron *n.m.* ឈើដែលឆេះហុយផ្សែង

fumet *n.m.* ក្លិនស្រា, ក្លិនសាច់ ។ *Chass.* ក្លិនសត្វព្រៃ

fumeur, euse *n.* អ្នកជក់

fumeux, euse *a.* ដែលមានផ្សែង ។ *Fig.* មិនស្សវច្បាស់ (ឧ. idées fumeuses)

fumier *n.m.* ចំបើងលាយនឹងរកេបម៉តោ; ដីអាចម៍សត្វ។ fumier de ferme ជីក្រោល(ជីអាចម៍គោ)។ *Fig.* មនុស្សថោកទាប

fumigateur *n.m.* ឆ្នាំងដុត; ប្រដាប់ដុតបង្ហុយផ្សែង

fumigation *n.f.* ធូបនកម្ម (ការបញ្ចេញថ្នាំឲ្យចេញជាផ្សែង)

fumigatoire *a.* នៃធូបនកម្ម

fumigène *a.* ដែលបង្កើតផ្សែង(ឧ. les mélanges fumigènes sont employés pour la production de nuages artificiels)

fumiger *v.t.* ដាក់ពេលផ្សែងហើង, ផ្សើរ; ដុត; រុំ; បំហុយ

fumiste *n.m.* ជាងធ្វើសជុលបំពង់ផ្សែង និងឆ្នាំងខ្វះ។ *Fig.&fam.* អ្នកលេងកំប្លែងផ្តេសផ្តាស

fumisterie *n.f.* របរឬជំនួញនៃអ្នកធ្វើសជុលបំពង់ផ្សែងនឹងឆ្នាំងខ្វះ។ *Fig.* ការកំប្លែងផ្តេសផ្តាស

fumivore *a. & n.m.* ដែលស្រូបផ្សែង (ឧ. appareil fumivore)

fumoir *n.m.* ចង្កៀរត្រី ឬ សាច់ ; បន្ទប់ដែលគេប្រជុំគ្នាជក់

fumure *n.f.* ការដាក់ដីអាចម៍គោ ។ fumure de fond ការដាក់ដីជម្រៅ។ fumure d'entretien ការដាក់ដីថែ

funambule *n.* អ្នកស្ទូខ្សែ ឬ ព្រ័ត្រ

funambulesque *a.* នៃអ្នកស្ទូខ្សែ ។ *Fig.* ចំឡែក

funèbre *a.* នៃបុណ្យខ្មោច(ឧ. chant funèbre); នៃសេចក្ដីស្លាប់ ; ដែលនាំឲ្យព្រួយ (ឧ. cri funèbre)

funérailles *n.f. pl.* ឈាបនកិច្ច, បុណ្យខ្មោច

funéraire *a.* សម្រាប់បុណ្យខ្មោច (ឧ. frais funéraire)

funeste *a.* ដែលនាំមកនូវសេចក្ដីស្លាប់ ឬ សេចក្ដីទុក្ខ (ឧ. dessein funeste; funeste accident); អកុសល,អព្រក់, ចង្រៃ(ឧ. conseil funeste)

funestement *adv.* ដោយនាំមកនូវសេចក្ដីស្លាប់ ឬ សេចក្ដីទុក្ខ ; ដោយអកុសល

funiculaire *a. Méd.* នៃទងបុដ្ឋាណ្ឌ

funicule *n.m.* ទងបុដ្ឋាណ្ឌ

fur *n.m.* au fur et à mesure *loc. adv.* បណ្ដើរៗ,បន្ដៗគ្នា

furet *n.m.* សំពោចស្សូរ ។ *Fig.* អ្នកចង់ដឹងមិនចេះស្ងប់

furetage *n.m.* ការរើក,ការរកដោយហ្មត់ចត់

fureter *v.i.* ប្រដេញសំពោចស្សូរ ។ *Fig.* រើក, រកដោយហ្មត់ចត់

fureteur,euse *n.* អ្នកប្រដេញសំពោចស្សូរ ។ *a.&n.* អ្នកចង់ដឹងមិនចេះស្ងប់

fureur *n.f.* ក្រោធពិរោធ,កំហឹងខ្លាំង (ឧ. entrer en fureur); ការងប់ (ឧ. la fureur du jeu)។ *Fig.* អំពើឃោរឃៅ (ឧ. la fureur de la guerre)។ faire fureur មានគេនិយមច្រើន ។ à la fureur *loc. adv.* ជាទីបំផុត (ស. emportement, frénésie, furie, passion, rage)

furfuracé,e *a.* ដូចកន្ទក់ (ឧ. desquamation furfuracée)

furibond,e *n.&a.* ដែលខឹងខ្លាំង,ងាយខឹងច្រឡោត ។ *a.* ដែលសំដែងកំហឹងខ្លាំង (ឧ. regards furibonds)

furie *n.f.* ក្រេវក្រោធ, កំហឹងខ្លាំង (ឧ. se mettre en furie; un taureau en furie)។ *Fig.* រំជួលខ្លាំង (ដូចកំហឹង) (ឧ. les va-

gues en furie); ស្ដីកំណាច

furieusement *adv.* ដោយខឹងខ្លាំង; សំបើម

furieux, euse *a.* ដែលខឹងខ្លាំង។ *Fig.* ដែលសំដែងកំហឹងខ្លាំង (ឧ. un regard furieux); ខ្លាំងណាស់ (ឧ. combat furieux)។ *Fam.* ខ្លាំង, ជាទីបំផុត (ឧ. donner un furieux coup à la tête)

furoncle *n.m.* ពងស្បែក; បូសទ្រនិច

furonculeux, euse *a.* នៃរោគពងស្បែក; នៃបូសទ្រនិច

furonculose *n.f.* បូសរយ

furtif, ive *a.* ដែលធ្វើដោយលាក់លៀម; ដែលលបៗ (ឧ. entrer d'un pas furtif)

furtivement *adv.* ដោយលាក់លៀម; ដោយលបៗ

fusant,e *a.* ដែលរលាយ (ឧ. poudre fusante)។ *a.&n.m. Mil.* ដែលផ្ទុះលើអាកាស (គ្រាប់បែក)

fuscine *n.f.* ល្បូក

fuseau *n.m.* ខ្នារ។ jambes en fuseau ជើងតូច។ កដិព័ន្ធ។ fuseau horaire កដិព័ន្ធនាឡិកា

fusée *n.f.* សរសៃសូត្រ ឬ អំបោះរុំនឹងខ្នារ; កាំជ្រួចហោះ; កំភ្លូន; កាំជ្រួចហោះដោយកម្លាំងខ្យល់ឆាក់។ fusée cosmique កាំជ្រួចលោកធាតុ

fuselage *n.m.* តួយន្តហោះ

fuselé,e *a.* ស្រលូន, ដែលមានរាងដូចខ្នារ។ doigt fuselé ម្រាមដៃរៀវ

fuseler *v.t.* ធាំងជារាងខ្នារ

fusement *n.m.* ដំណើរឆេះដោយគ្មានផ្ទុះ (រំសេវ)

fuser *v.i.* រលាយដោយចំហាយក្ដៅ (ឧ. cette bougie fuse); ឆេះដោយគ្មានផ្ទុះ (រំសេវ)។ *Par ext.* ឮឡើងភ្លាមៗ (ឧ. des rires fusèrent de tous cotés); ផ្ទុះ (អំបិលដែលគេបង់ក្នុងភ្លើង)

fusette *n.f.* ហុងក្រដាស (សម្រាប់រុំអំបោះ)

fusibilité *n.f.* ភាពអាចរលាយបាន

fusible *a.* អាចរលាយបាន; ឆាប់រលាយ (ឧ. l'étain est le plus fusible des métaux usuels)

fusiforme *a. Bot.&Zool.* ដែលមានរាងដូចខ្នារ

fusil *n.m.* កាំភ្លើងវែង។ *Par ext.* ខ្មាន់កាំភ្លើង (ឧ. c'est un excellent fusil; en 1914 une

compagnie comprenait 250 fusils); នៃកាំភ្លើង ; ចាន្លើសនៃកម៉ែប សម្រាប់សៀងកាំបិត ; ឬសៀងខ្វែរបក

fusilier *n.m.* ខ្មាន់កាំភ្លើង (ឧ. fusilier voltigeur; fusilier marin)

fusillade *n.f.* ការបាញ់កាំភ្លើងចម្រុះ ; ការបាញ់គ្នាដោយកាំភ្លើង; ការប្រហារជីវិតដោយបាញ់ចម្រុះ

fusiller *v.t.* ប្រហារដោយកាំភ្លើង

fusilleur *n.m.* អ្នកបាញ់កាំភ្លើង

fusion *n.f.* ដំណើររលាយដោយចំហាយភ្លើ ។ *Fig.* ការរំលាយបញ្ចូលគ្នា (ឧ. la fusion de deux partis)

fusionnement *n.m.* ការលាយ, ការបញ្ចូលគ្នា; ការចូលជាសមាគម

fusionner *v.t.* រំលាយបញ្ចូលគ្នា (ឧ. fusionner deux entreprises)។ *v.i.* ចូលគ្នា (ឧ. les compagnies de chemin de fer ont fusionné)

fustibale ឬ **fustiballe** *n.f.* ដង្ហក់មានដង

fustigation *n.f.* ការវាយនឹងរំពាត់ឬដំបង ។ *Fig.* ការជៀលត្មះ

fustiger *v.t.* វាយនឹងរំពាត់ ឬ ដំបង ។ *Fig.* ជៀលត្មះ (ឧ. fustiger l'hypocrisie)

fût *n.m.* កាតដើមឈើដែលគ្មានមែក;កាតសសរពីគល់ដល់ក្បាច់ក្បាល; ជើងឈើទ្រមំពង់កាំភ្លើង; ធុង; សំបកហិបឬឡាំង

futaie *n.f.* ព្រៃស្រោង ។ *Par ext.* ដើមឈើធំ ។ haute futaie ព្រៃស្រោងធុំៈអស់កំពស់

futaille *n.f.* ធុងគ្រក

futaine *n.f.* សំពត់រោមធ្វើពីកប្បាស

futé,e *a.&n.Fam.* ឆ្លាត, វៃ

futée *n.f.* ជ័រលាយរោចម៍ឈើសម្រាប់បិទប្រហោង

futile *a.* សាក៏,អសារ, ដែលគ្មានខ្លឹមសារ

futilement *adv.* ដោយសាក៏, ដោយគ្មានខ្លឹមសារ

futilité *n.f.* ភាពសាក៏;អសារភាព;របស់គ្មានខ្លឹមសារ (ឧ. dire des futilités)

futur,e *a.* នៃអនាគត ។ *n.* អ្នកឬនាងដែលគេបម្រុងនឹងយកជាប្តី ឬប្រពន្ធ ។ *n.m.* អនាគតកាល

futurisme *n.m.* អនាគតនិយម (វិចិត្រកម្ម)

futuriste *n.&a.* អ្នកអនាគតនិយម ។ *a.* សមតាមអនាគតនិយម

fuyant,e *a.* ដែលរត់គេច,ដែលបាត់ទៅ, ដែលដូចជាទៅឆ្ងាយ (ឧ. horizon fuyant) ។ jour fuyant ថ្ងៃជ្រេពីត្រង់ ។ front fuyant ថ្ងាសទ្រេត

fuyard,e *a.* អ្នករត់គេចខ្លួន, ដែលធ្លាប់តែរត់ ។ *n.m.* ទាហានដែលរត់ចោលសឹក



g *n.m.* អក្សរទី ៧ នៃអក្ខរក្រមឡាតាំង

gabadine *n.f.* ក្លាបាឌីន, សំពត់រោមសត្វ; អាវភ្លៀង

gabare *n.f.* នាវាបន្ទុក ។ *Pêch.* មង យ៉ាង

gabariage *n.m.* ការវាស់នឹងស៊ុមមាឌ

gabarier *n.m.* ម្ចាស់ ឬ អ្នកធ្វើការក្នុង នាវាបន្ទុក

gabarit *n.m.* ស៊ុមមាឌ; ទំងំមាត្រ ។ *Fig. & Fam.* កាពស់ខាន់; ទំហំ

gabegie *n.f. Fam.* ការគ្រប់គ្រងដោយមិនគិតដល់នាំឲ្យបន្លំលួចបាន

gabelle *n.f.* ពន្ធអំបិល ; ឃ្លាំងអំបិល; ផ្នែករាជការខាងយកពន្ធអំបិល

gabelou *n.m. Autref.* ភ្នាក់ងារយកពន្ធអំបិល ។ *Péjor. Auj.* ភ្នាក់ងារគយ, ភ្នាក់ងារអាករមិនចំពោះ

gabie *n.f.* ជាយក្ដោង, ត្រើរនៅផងក្ដោង

gabier *n.m.* កម្មករនាវាអ្នកយាមបរនៅ ជាយក្ដោង

gabion *n.m.* ដាលក្ដាងជាគល់រាប់ប្រក ដីការពារទាហាន, កញ្ច្រ

gâchage *n.m.* ការលាយម្នាងសិលា ឬ បាយអ, ការខ្ជះខ្ជាយ

gâche *n.f.* រន្ធសម្រាប់ពន្លូញសោ; ប្រដាប់ លាយបាយអ

gâcher *v.i.* លាយម្នាងសិលាឬបាយអ ។ *Fig.* ធ្វើការខ្ជីខ្ជា; ខ្ជះខ្ជាយ (ឧ. gâcher sa fortune) ។ gâcher le métier ធ្វើការយកឈ្នួលថោកពេក (ឡូខូចថ្លៃ)

gachette *n.f.* កៃកាំភ្លើង; គន្លឹះសោ

gâcheur, euse *a.* & *n.* អ្នកលាយបាយអ ។ *Fig.* អ្នកធ្វើការខ្ជីខ្ជា

gachis *n.m.* បាយអ ; ដីប៉ះប៉ាច់ដោយទឹកភ្លៀង ; គំនរបស់ខ្ចះខ្ចាយ ឬ ដែលធ្វើឱ្យខ្ជីខ្ជា ។ *Fig.&fam.* រឿងឬស្ថានភាពស្មុគស្មាញ

gadoue *n.f.* ដីលាមក, ដីសម្រាម ; ភក់ (ឧ. patauger dans la gadoue)

gaffe *n.f. Mar.* ឃ្នោលទំពក់ ។ *Fig.* & *fam.* អំពើឆ្គង (ឧ. faire une gaffe)

gaffer *v.t.* ចាប់នឹងឃ្នោលទំពក់ ។ *Fam.* ធ្វើអំពើឆ្គង

gaffeur, euse *n. Fam.* អ្នកប្រព្រឹត្តអំពើឆ្គង

gag *n.m.* ការកំប្លែងដោយពញ្ញាក់

gaga *a.* & *n. Fam.* ដែលវង្វេងដូចក្មេង

gage *n.m.* កិច្ចសន្យាបញ្ចាំ (ឧ. lorsque le gage est immobilier, il porte le nom d'«antichrèse»); វត្ថុដាក់បញ្ចាំ (ឧ. prêter sur gages); ប្រយា-ដំណាំង ។ *Fig.* ការធានាអះអាង (ឧ. donner des gages de sa bonne foi); សក្ខីភាព, ភស្តុតាង (ឧ. gage de sympathie) ។ *pl.* ប្រាក់ឈ្នួលអ្នកបម្រើក្នុងផ្ទះ

gagé,e *a.* meubles gagés របស់រឹបអូសដើម្បីធានាបំណុល

gager *v.t.* ភ្នាល់

gagerie *n.f.* ការរឹបអូស ។ saisie gagerie ការរឹបអូសធានា (ធ្វើមុនជំនុំជំរះ)

gageur,euse *n.Dr.* ដែលភ្នាល់

gageure [—jur'] *n.f.* ការភ្នាល់, ប្រយា-ដំណាំង (ឧ. tenir une gageure) ។ *Fig.&fam.* c'est une gageure ចម្លែកណាស់ (គួរឲ្យចង់ភ្នាល់)

gagiste *a.&n.* ដែលទទួលរបស់បញ្ចាំ (ឧ.créancier gagiste)

gag-man *n.m.* អ្នកកំប្លែងដោយពញ្ញាក់

gagnable *a.* អាចចំណេញឬឈ្នះបាន

gagnage *n.m.* កន្លែងសត្វរកចំណី

gagnant,e *a.&n.* ដែលឈ្នះល្បែង; ដែលត្រូវ (ឆ្នោត) (ឧ. numéro gagnant)

gagne-pain *n.m. inv.* ប្រដាប់ប្រដារកស៊ី; របររកស៊ី

gagne-petit *n.m.inv.* អ្នកដែលរកស៊ីបានដោយស្ទួចស្ទើង

gagner *v.t.* ចំណេញ (ឧ.gagner de l'argent); ឈ្នះ (ឧ gagner une

course, un procès); ត្រូវឆ្នោត (ឧ. gagner un lot); គួរតែបាន (ឧ. il l'a bien gagné); ទៅដល់ (ឧ. gagner la frontière) ។ gagner du terrain ទៅមុន; *au fig.* បានចម្រើន (ទាំងខាងល្អទាំងខាងអាក្រក់) (ឧ. idées qui gagnent du terrain)។ *Fig.* បាន (ឧ. gagner l'affection បានគេស្រឡាញ់) ។

v.i. រឹតតែល្អឡើង (ឧ. le vin gagne à vieillir); បានចម្រើន, មានប្រៀប (ឧ. il gagne à être connu) ; រាលដាល (ឧ. le feu gagne rapidement) ។

se gagner *v.pr.* ឆ្លង (ឧ. maladie, habitude qui se gagne)

gagneur, euse *n.* អ្នករកបាន , អ្នកចំណេញ (ឧ. un gagneur d'argent); អ្នកឈ្នះ (ឧ. Napoléon était un grand gagneur de batailles): អ្នកឈ្នះក្នុងល្បែង

gai,e *a.* សប្បាយ, រីករាយជាធម្មតា (ឧ. conversation gaie; chanson gaie) ។ *Fam.* ស្រវឹងបន្តិចៗ

gaiement ឬ **gaîment** *adv.* ដោយសប្បាយ

gaieté ឬ **gaîté** *n.f.* សេចក្ដីសប្បាយ (ឧ. montrer de la gaieté)។ de gaieté de cœur *loc. adv.* ដោយសប្បាយចិត្ត; ដោយឥតបង្ខំ

gaillard,e *a.* សប្បាយ, ស្រួលខ្លួន (ឧ. frais et gaillard) ; ឥតទប់មាត់ (ឧ. propos gaillards); រហ័សរហួន ។ *n.m.* មនុស្សមាំ; មនុស្សប្រសប់, មនុស្សឆ្លាត (ឧ. je vous vois venir mon gaillard !) ។ *n.f.* une gaillarde ស្ត្រីល្អល្អាច

gaillardement *adv.* ដោយសប្បាយ, ដោយរហ័សរហួន

gaillardise *n.f.* ភាពសប្បាយ; ភាពស្រួលខ្លួន ; ភាពរហ័សរហួន ។ *pl.* សំដីឥតទប់មាត់

gailleterie *n.f.* ធ្យូងដុំធំៗ

gailletin *n.m.* ធ្យូងដុំមធ្យម (កណ្ដាល) (tff. tête-de-moineau)

gain *n.m.* ចំណេញ, លាភ (ឧ. l'appât du gain); ជោគជ័យ, អត្ថប្រយោជន៍ (ឧ. le gain d'un parti); ប្រាក់ឈ្នួល, ក្ងាន់ (ឧ. un gain médiocre) ។ obtenir gain de

cause ក្ដីៈ(ក្នុងរឿងក្ដី,ក្នុងការពិភាក្សា)

gaine *n.f.* ស្រោម ។ *Bot.* គល់ទង(ស្លឹក)។*Mil.* រន្ធក្នុងដី(ភ្ជាប់ជាការដ្ឋាន)

gainer *v.t.* ដាក់ស្រោម

gainerie *n.f.* រោងចក្រធ្វើស្រោម;សិល្បៈជំនួញ ឬ ការធ្វើស្រោម

gainier *n.m.* អ្នកធ្វើ ឬ អ្នកលក់ស្រោម

gala *n.m.* មហោស្រព, សមោសរ, ការជប់លៀងជាឧឡារិក (ឧ. gala de bienfaisance; soirée de gala)

galactique *a. Astron.* នៃគន្លងតារាសេ(ផ្កាយ)

galactogène ឬ **galactagogue** *a. & n.* ដែលមានទឹកដោះ

galactomètre *n.m.* រង្វាស់,ប្រដាប់ស្ទង់ទឹកដោះ (ហៅ pèse-lait ក៏បាន)

galactose *n.m.* ស្ករកើតពីទឹកដោះរម្ងាស់

galamment *adv.* ដោយយកចិត្តទុកដាក់នឹងស្ត្រី; យ៉ាងប្រសប់

galandage *n.m.* ជញ្ជាំងទ្រុងឥដ្ឋ

galange *n.m.* មើមប្រទាះ

galant,e *a.* ដែលយកចិត្តទុកដាក់នឹងស្រីៗ (ឧ. agir, se conduire en homme galant); ដែលសំដែងស្នេហា(ឧ. propos galants); សមសួន ។ femme galante ស្រីចើក ។ *n.m.* vert galant មនុស្សចាស់នៅទិលនឹងស្រី

galanterie *n.f.* ការយកចិត្តទុកដាក់នឹងស្រីៗ; អំពើឬសំដីសមរម្យ ; សេចក្ដីគួរសម(ដោយសំដីនឹងដោយអាកប្បកិរិយា); រឿងស្នេហា

galantin *n.m.* អ្នកសមគួរខុសហេតុ

galapiat *n.m. Fam.* មនុស្សពាលល្មៀត

galaxie *n.f.* តារាសេ, កញ្ចុំផ្កាយ

galbe *n.m.* រាង

galbé, *a.* កំពុងកណ្ដាល (ឧ.colonne galbée)

galber *v.t.* ធ្វើឲ្យកំពុងកណ្ដាលឬឲ្យមានរាងល្អ

gale *n.f.* កមរមាស់ (ឧ. on guérit la gale par des frictions aux sulfures ou au benzoate de benzyle) ។ *Fig. & fam.* មនុស្សមាត់ខូច; មនុស្សញ៉ាំញ៉ី

galéjade *n.f.* ការលេងកំប្លែងបន្ទំបំភាន់

galéjer *v.i.* លេងកំប្លែងបន្ទំបំភាន់

galère *n.f.* នាវាចំបាំងជាន់ដើមដើរដោយក្ដោងនឹងចែវ ។ *Par ext.* ទណ្ឌកម្ម

គម្រូវឲ្យអ៊ុំទូកចំបាំង ឬ ឲ្យធ្វើការដោយបង្ខំ ។ *Fig* ការងារឬស្ថានភាពពិបាកក្រាំ (ឧ. vie de galère)

galerie *n.f.Archit.* ផ្លូវច្រកក្នុងគេហដ្ឋាន;បន្ទប់តូចវែង,ញក;ថែវ,វិចិត្រសាល, បន្ទប់តាំងសិល្បវត្ថុ (ឧ. les galeries du Louvre); ការប្រមូលសិល្បវត្ថុ;ប្រជុំអ្នកមើល;រូងក្នុងដី (ឧ. galeries de siège; galeries de termites)។ *Min.* រូងយករ៉ែ

galérien *n.m.* អ្នកជាប់ទោសអ៊ុំទូកចំបាំងឬធ្វើការដោយបង្ខំ ។ *Fig.* vie de galérien ជីវភាពពិបាកជាទីបំផុត

galet *n.m.* គ្រួស

galetas *n.m.* ថ្នើរសម្រាប់នៅ; លំនៅគោកគោក

galette *n.f.* នំសំប៉ែតធ្វើពីម្សៅ។ *Pop.* ប្រាក់

galetteux,euse *a.Pop.* អ្នកមាន

galeux,euse *a.&n.* ដែលកើតកមរ ។ *Fig.* brebis galeuse មនុស្សពាលដែលមិនគួរនឹងសេពគប់

galfâtre *n.m.Fam.* មនុស្សពោលម្សៀត

galhauban *n.m.Mar.* ខ្សែរយោង

galibot *n.m.* កូនជាងអណ្តូងរ៉ែ (អាយុតិចជាង១៨ ឆ្នាំ)

galimafrée *n.f.* ម្ហូបផ្សំគ្រឿងដោយខ្ជីខ្ជា

galimatias *n.m.* សំដីសាំញ៉ាំ

galion *n.m.* នាវាបន្ទុកជាតិអេស្ប៉ាញជាន់ដើម

galiote *n.f.Mar.* នាវានេសាទហុល្លង់ដេ

galipette *n.f.Fam.* ការលោតកំទីង

galipot *n.m.* ជ័រស្រល់សមុទ្រ

galipoter *v.t.* ពារជ័រស្រល់

gallican,e *a.* គ័ល្លីកាន (នៃសាសនាកាតូលិកនៅប្រទេសបារាំង) (ឧ. l'Eglise gallicane)។ *n.* អ្នកគ័ល្លីកាននិយម

gallicanisme *n.m.* គ័ល្លីកាននិយម (លទ្ធិសាសនាកាតូលិកនៅប្រទេសបារាំង)

gallicime *n.m.* របៀបនិយាយពោលប្លែកនៃភាសាបារាំង

gallinacé,e *a.* កុក្កុដៈ(នៃមាន់-ក្ងោក-មាន់បារាំង។ល។)។ *n.m.pl.* កុក្កុដបក្សី (ពពួកសត្វស្លាប មានមាន់ជាដើម)

gallomanie *n.f.* ការស្ញើចងប់នឹងសញ្ជាតិបារាំង

gallon *n.m.* គ័ល្លុង (រង្វាស់រង់គ្រួសប្រមាណ ៦៤, ៥៤ ល.

gallo-romain,e *a.* នៃជនជាតិហ្គោលនឹងរ៉ូម៉ាំង ។ *n.m.* ជនជាតិហ្គោលបំណុះរ៉ូម៉ាំង

gallophobe *a.&n.* ដែលស្អប់បារាំង

gallophobie *n.f.* ការស្អប់បារាំង

gallup *n.m.* ការស្ទង់មតិសាធារណៈដោយសំនួរមានន័យជាក់លាក់

galoche *n.f.* ស្បែកជើងបាតឈើ ។ *Fam.* menton de galoche ឬ en galoche ចង្កាវែងស្រួចហើយខួប

galon *n.m.* បន្ទះមាសប្រាក់ ឬសូត្រលំអសំលៀកបំពាក់ ភាំងនន ។ល។; ប៉ាន ; ប៉ានសក្តិ

galonner *v.t.* ដាក់ប៉ាន , បំពាក់សក្តិ; លំអដោយបន្ទះមាសប្រាក់ ឬសូត្រ (ឧ. galonner un habit)

galonnier *n.m.* អ្នកត្បាញប៉ានសក្តិដោយកីយន្ត

galop *n.m.* ល្បឿនសេះផាយ; ដំណើរឬការរត់យ៉ាងលឿន; សូរចម្លែកនៃរបះដូង

galopade *n.f.* ការផាយ; ចម្ងាយមួយល្បើកសេះ ។ *Par ext.* ការរត់យ៉ាងលឿន

galopant,e *a.* ដែលផាយ

galoper *v.i.* ផាយ ។ *Fig. & fam.* ដើរ ឬ រត់យ៉ាងលឿន ។ *v.t.* បំផាយ

galopeur,euse *a.&n.* ដែលផាយ

galopin *n.m.* ក្មេងអ្នកទទួលបេសកកម្ម។ *Fam.* ក្មេងទិល

galurin *n.m.Pop.* មួក

galvanisation *n.f.* ការពាសសំណប៉ាហាំង (ឧ. la galvanisation du fer le rend inoxydable)

galvaniser *v.t.* ដាក់ខ្សែភ្លើងពិល; ពាសសំណប៉ាហាំង (ឧ. galvaniser le fer); ធ្វើឲ្យមានកម្លាំង

galvanomètre *n.m.* ប្រដាប់ស្ទង់ចរន្តអគ្គិសនីខ្សោយ

galvauder *v.t.Fam.* ធ្វើដោយឆ្គង (ឧ. galvauder un travail)។ *Fig. &fam.* ប្រើខុស (ឧ. galvauder son talent)។ *v.i.* ដើរអាភ៉ាសែ

galvaudeux,euse *n.Fam.* មនុស្សអាភ៉ាសែ; មនុស្សចោលម្សៀត

gambade *n.f.* ការលោតកញ្ឆេង

gambader *v.i.* លោតកញ្ឆេង (ឧ. gambader de joie)

gambiller *v.i.Pop.* រាំ

gamelle *n.f.* កាម៉ែល,ចានដែកសម្រាប់ទាហាន;ម្ហូបអាហារទាហាន

gamin,e *a.&n.* ក្មេងទិលដែលលេងតាមថ្នល់ (ឧ. Gavroche est le type

du gamin de Paris); កូនក្មេង

gaminer *v.i.* លេងដូចក្មេង

gaminerie *n.f.* ល្បែងក្មេង; អំពើឬសំដីក្មេង

gamme *n.f.Mus.* លំដាប់សម្លេងទាំងប្រាំពីរ (ដូ,រេ,មី,ហ្វា,សូល,ឡា,ស៊ី)។ *Fig.* លំដាប់វត្ថុរៀងតាមថ្នាក់តាមគុណ ឬតាមពណ៌ (ឧ. gamme de couleurs, de saveurs)។ changer de gamme ផ្លាស់សម្លេង; ផ្លាស់បរិយា

gammé,e *a.* croix gammée ម.ព. croix

gamopétale *a.* យុគ្គទលី [យុគ-គៈ-ទៈ—]

ganache *n.f.* គែមថ្គាមក្រោមនៃសេះ។ *Fig. & fam.* មនុស្សប្រាជ្ញាតិចឬគ្មានសមត្ថភាព

gandin *n.m.* ក្មេងសង្ហាគួរឲ្យអស់សំណើច

Ganéça គណេស [គៈ-ណេស] (ឈ្មោះទេវតាជាបុត្រព្រះឥស្សរមានក្បាលជាដំរី)

gang *n.m.* បនចោរឬមនុស្សខូចកាច

ganglion *n.m.* កូនកណ្ដុរ

ganglionnaire *a.* នៃកូនកណ្ដុរ (ឧ. système ganglionnaire)

gangrène *n.f.* ដំបៅរលួយ; ជម្ងឺរុក្ខជាតិ; ការខូចមារយាទ

gangrené,e *a.* ដែលកើតដំបៅរលួយ (ឧ. membre gangrené)។ *Fig.* ពុករលួយ (មារយាទខូច)

gangrener *v.t.* បង្កើតដំបៅរលួយ ។ *Fig.* បង្ខូចមារយាទ។ se gangrener *v.pr.* កើតដំបៅរលួយ ។ *Fig.* ខូចមារយាទ

gangréneux ឬ **gangreneux,euse** *a.* ដែលមានភាពជាដំបៅរលួយ

gangster *n.m.* ចោរឬមនុស្សខូចកាចដែលផ្គុំគ្នាជាបន

gangue *n.f.* ដីស្រោបរ៉ែ ឬ ស្រោបពេជ្រ (ឧ. on élimine la gangue par fusion du minerai avec un fondant, qui se combine aux impuretés)

gant *n.m.* អង្គុលីវេស្ដ, ស្រោមដៃ, ស្នាប់ដៃ (ឧ. gant de toilette, du boxeur)។ *Par ext.* អ្នកលេងពាក់ស្រោមដៃ(ក្នុងកីឡា)។ aller comme un gant ត្រូវល្មម (គ្មានខ្វះ)។ jeter le gant បបួលគេប្រយុទ្ធ ។ relever le gant ព្រមប្រយុទ្ធតាមគេបបួល។ se donner des gants អួតខ្លួនថាជាអ្នកនាំឲ្យមានជោគជ័យ ។ souple comme un gant ទន់

(ងាយនឹកតាំ) ។ avoir les gants de មានកិត្តិយសនឹង, មានប្រយោជន៍នឹង ។ mettre des gants ឬ prendre des gants ប្រព្រឹត្តដោយល្មមឈាក់ ឬ ដោយប្រុងប្រយ័ត្នណាស់

gantelet *n.m.* ស្រោមដៃដែក

ganter *v.t.* បំពាក់ស្រោមដៃ ។ *Fig.* &*fam.* cela me gante របស់នោះត្រូវបំណងឬត្រូវចិត្តខ្ញុំ ។ *v.i.*ពាក់ស្រោមដៃលេខ (ឧ. ganter du 8 ពាក់ស្រោមដៃលេខ ៨)

ganterie *n.f.* ជំនួញស្រោមដៃ;កន្លែងធ្វើ ឬ លក់ស្រោមដៃ

gantier,ère *n.*&*a.* ដែលធ្វើ ឬ លក់ស្រោមដៃ (ឧ. ouvrier gantier)

garage *n.m.* ការចត (រថ ឬ នាវា) ។ voie de garage ផ្លូវចត(អយស្ម័យយាន)។ យានដ្ឋាន

garagiste *n.m.* អ្នកកាន់កាប់យានដ្ឋាន

garançage *n.m.* ការជ្រលក់ពណ៌ក្រហម

garance *n.f.* រុក្ខជាតិម្យ៉ាងឲ្យពណ៌ក្រហម ។ *a.inv.* ដែលជ្រលក់ក្រហម

garancer *v.t.* ជ្រលក់ពណ៌ក្រហម

garant,e *a.*&*n.* អ្នកធានា (ឧ. se porter garant du paiement d'une dette) ។ *n.m. Fig.* ការធានា (ឧ.son passé est le plus sûr garant de l'avenir) ។ *Mar.* ខ្សែរ៉កយោងអីកាំ

garantie *n.f.* ការធានា (ឧ. garantie du transporteur) ។ garantie totale ការធានាទាំងអស់ (ការសន្យានៃអ្នកធ្វើដែលក៏បង់ចេញសោហ៊ុយទាំងអស់សម្រាប់ជួសជុលរបស់ធ្វើមិនល្អ) ។ sans garantie du gouvernement (S.G.D.G.) គ្មានការធានាអំពីរដ្ឋាភិបាល(រូបមន្តដាក់នៅប្រកាសនីយប័ត្រតក្កកម្មមានន័យថារដ្ឋមិនធានាអំពីគុណសម្បត្តិ ឬ អាទិភាពនៃតក្កកម្ម) ។ contrat de garantie កិច្ចសន្យាធានា។ ប្រាក់ធានា; របស់បញ្ចាំ។ garantie bancaire ប្រាក់ធានានៅធនាគារ

garantir *v.t.* ធានា (ឧ. garantir une montre pour un an) ។ *Fig.* ធានា (ឧ. le passé ne garantit pas toujours l'avenir); អះអាង (ឧ. garantir une nouvelle); ឧបត្ថម្ភ; ការពារ (ឧ. garantir du froid)

garce *n.f.Autref.* ក្មេងស្រី ។ *Fam.*

ស្ត្រីខូច ។ *Fam.* ស្ត្រីកាច

garcette *n.f.Mar.* ខ្សែសម្រាប់ចងឆាក

garçon *n.m.* កុមារ,កូនប្រុស,ក្មេងប្រុស; កំឡោះ (ឧ. un vieux garçon); មនុស្សប្រុស;អ្នកបម្រើក្នុងភោជនីយដ្ឋាន, អ្នកបម្រើឬកូនឈ្នួលប្រុស(ឧ.un garçon tailleur) ។ garçon de laboratoire et de manipulation អ្នកបម្រើក្នុងទីពិសោធន៍ និងលាយថ្នាំ ។ gaçon d'honneur ម.ព. honneur

garçonne *n.f.* ក្មេងស្រីឫកដូចប្រុស

garçonnet *n.m.* ក្មេងប្រុសជំទង់

garçonnière *a.f.* ដែលមានឫកពាដូចប្រុស ។ *n.f.* លំនៅក្មេងប្រុសៗ

gardable *a.* អាចយាមឬកាន់កាប់បាន

garde *n.f.* ការយាម(ឧ. la garde des frontières, d'un trésor); ការឃ្លាំ, ការរក្សា, ការកាន់កាប់ (ឧ. confier la garde de sa maison)។ droit de garde សិទ្ធិបីបាច់ (សិទ្ធិឪពុកបីបាច់កូនជាដើម)។អ្នកយាម, អ្នករក្សា;កងរក្សា,ក្រុមរក្សា ។ garde nationale កងរក្សាជាតិ ។ garde provinciale កងរក្សាខេត្ត ។ garde royale ក្រុមរក្សាព្រះអង្គ, *Escr.* ទាំងដាវ ។ *Sports* ស្ទៀតរង ឬ កាត់ (ឧ. se mettre en garde) ។ *Arts graph.* សន្លឹកក្រដាសដើមនឹងក្របសៀវភៅ។ garde à vous! ប្រុង! ។ *n.m.* ការប្រុង (ឧ. se mettre au garde-à-vous) ។

Loc.div. prendre garde ប្រយ័ត្ន (ឧ. prenez garde de tomber!) ។ être sur **ses** gardes ប្រុងស្ទៀត ។

pl. គន្លឹះសោ

garde *n.m.* អ្នកយាម; ទាហានក្រុមអង្គរក្ស (ឧ. garde républicain); ឆ្មាំ,អ្នករក្សា(ឧ.garde des archives) ។ garde des Sceaux រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ (នៅប្រទេសបារាំង)

garde *n.f.* ស្ត្រីអ្នករក្សា ឬ ទ្រាំជម្ងឺ

garde - barrière *n.* អ្នកចាំប្តូល កាត់ផ្លូវអោយស្វ័យយាន (*pl.* des gardes-barrière ឬ barrières)

garde-bœuf *n.m.* ក្ុក (ដែលទំលើខ្នងគោក្របីចាំស៊ីសត្វល្អិត)(*pl.* des gardes - boeufs ឬ bœuf)

garde-boue *n.m.* ជាំងភក់ (គ្រឿងរថ

មានសណ្ឋានព្រលួយឬសំប៉ែតដាក់បន្តែក ឲ្យហើយគ្របពីខាងលើកង់ សម្រាប់ជាំងកង់មិនឲ្យភក់ ឬ ធូលីខ្ទាតហុយមកខាងលើ)

garde-chaine *n.m.* ជាំងច្រវាក់ (គ្រឿងទោចក្រយានសម្រាប់ជាំងកង់ច្រវាក់មិនឲ្យប៉ះនឹងជើងទោ)

garde-champêtre *n.m.* ព្យព្រាព្យ, ឆ្មាំស្រែចំការ

garde-chasse *n.m.* ឆ្មាំប្រមាញ់ (*pl.* des gardes-chasse ឬ chasses)

garde-chiourme *n.m.* ឆ្មាំមនុស្សទោសឧក្រិដ្ឋ (*pl.* des gardes-chiourme)

garde-corps *n.m.* *inv.* *Mar.* ភ្ជាក់ដៃ

garde-côte *n.m.* *Autref.* ឆ្មាំឆ្នេរសមុទ្រ (*pl.* des gardes-côtes)។ *Auj.* នាវាល្បាតឆ្នេរសមុទ្រ (*pl.* des garde-côtes)

garde-feu *n.m.* *inv.* ជាំងភ្លើង (បណ្ដាញ ឬ បន្ទះលោហធាតុសម្រាប់ការពារភ្លើង)

garde-forestier *n.m.* រុក្ខាព្យ

garde-fou *n.m.* បង្កាន់ដៃ (*pl.* des garde-fous)

garde-frein *n.m.* ឆ្មាំគ្រឿងទប់ (អយស្ម័យយាន) (*pl.* des gardes-frein ឬ freins)

garde-magasin *n.m.* ឆ្មាំឃ្លាំង (*pl.* des gardes-magasin ឬ magasins)

garde-main *n.m.* ក្រដាសទ្រនាប់ដៃ

garde-malade *n.* គិលានុបដ្ឋាយកៈ-ណិកា, អ្នកថែជម្ងឺ (*pl.* des gardes-malades)

garde-manger *n.m.* *inv.* ទូទុកម្ហូបចំណី

garde-marine *n.m.* សិស្សនាយទាហានជើងទឹក(ជាន់ដើម) (*pl.* des gardes-marines)

garde-meuble *n.m.* ឃ្លាំងទុកតុទូ (*pl.* des gardes-meuble ឬ meubles)

garde-mites *n.m.* *inv.* *Fam.* ឆ្មាំឃ្លាំង

garden-party *n.m.* ឧទ្យានភត្ត (ការជប់លៀងឬមហោស្រពធ្វើក្នុងសួនច្បារ) (*pl.* des garden-parties)

garde-pêche *n.m.* នេសាទារក្ស, ឆ្មាំនេសាទ (*pl.* des gardes-pêche); នាវាឆ្មាំនេសាទ (*pl.* des garde-

pèche)

garde-port *n.m.* ឆ្មាំកំពង់ផែ (ភ្នាក់ងារដែលទទួលហើយរៀបចំទំនិញក្នុងកំពង់ផែទន្លេ) (*pl.* des gardes-port ឬ ports)

garder *v.t.* ការពារ (ឧ. garder un passage); រក្សា,ឃ្វាល (ឧ.garder un enfant, des moutons); យាម (ឧ. garder des prisonniers); ទុក (ឧ. garder le double d'un acte; garder un employé; il est des fruits qu'on ne peut garder longtemps); កាន់កាប់ ។ garder la chambre មិនចេញពីបន្ទប់ ។ garder le chapeau មិនបើកមួក ។

Fig. garder un secret រក្សាការសម្ងាត់មិនឲ្យលេចឮ ។ garder le silence នៅស្ងៀម, មិនចេញស្តី ។ garder son rang រក្សានាទីខ្លួន(ឲ្យនៅនឹងដែល)។ garder ses habitudes មិនចោលទម្លាប់ ។ garder une orange pour la soif ទុកក្រូចពោធិ៍សាត់មួយសម្រាប់ពេលស្រេក ។

se garder *v.pr.* ចៀសវាង (ឧ. gardez-vous de mentir); ការពារខ្លួន (ឧ. se garder du froid)

garde-rats *n.m.inv.Mar.* ជាំងកណ្ដុរ(បន្ទះដែកស៊កខ្សែដើម្បីកុំឲ្យកណ្ដុរឡើងលើនាវា)

garderie *n.f.* កន្លែងរក្សាក្មេង; ព្រៃនៅក្រោមការត្រួតត្រានៃឆ្មាំព្រៃម្នាក់

garde-rivière *n.m.* ឆ្មាំស្ទឹង,ភ្នាក់ងារយាមស្ទឹង (*pl.* des gardes-rivière ឬ rivières)

garde-robe *n.f.* ទូដាក់សំលៀកបំពាក់; សំលៀកបំពាក់សម្រាប់មនុស្សម្នាក់ ; បង្គន់(ឧ.aller à la garde-robe) (*pl.* des garde-robes) ។ *n.f. pl* លាមក

gardeur,euse *n.&a.* គង្វាល,អ្នករក្សា

garde-voie *n.f.Ch.de f.* បយារក្ស, ឆ្មាំផ្លូវ (*pl.* des gardes-voie ឬ voies)

garde-vue *n.m.inv.* ជាំងភ្នែក (ក្បាំងសម្រាប់ពាក់កុំឲ្យពន្លឺចាំងភ្នែក)

gardien,enne *n.* ឆ្មាំ; អ្នកថែទាំ; អ្នកការពារ (ឧ. gardien des traditions)។ gardien de la paix សន្តិបាល (ភ្នាក់ងារប៉ូលីសនៅក្រុងជា-

ស) ។ gardien de but ឬ gardien អ្នកចាំទី (ក្នុងកីឡាបាល់) ។ *a.* ដែលរក្ស (ឧ. ange gardien ទេវរក្ស ឬ ទេវតារក្ស)

gardiennage *n.m.* មុខងារថែឆ្មាំ ឬអ្នកថែទាំ; ក្រុមឆ្មាំកំពង់ផែ

gare *n.f.* ស្ថានីយ៍រថស្វ័យយាន; ផែ ។ gare aérienne ចំណតអាកាសយាន ។ gare de jonction ស្ថានីយ៍ប្រសព្វ

gare! *int.* ប្រយ័ត្ន!

garenne *n.f.* កន្លែងទន្សាយព្រៃ; កន្លែងនេសាទរក្សាទុក ។ *n.m.* ទន្សាយព្រៃ

garer *v.t.* បញ្ចូលក្នុងស្ថានីយ៍ឬយានដ្ឋាន (ឧ.garer un train; garer une bicyclette); ចត (ឧ. garer sa voiture dans la cour)។ *Fam.* ទុកដាក់ឲ្យផុតអន្តរាយ (ឧ. garer sa fortune) ។ se garer *v.pr.* ចៀសផ្លូវ; ចៀសឲ្យផុតឬឲ្យរួចខ្លួន (ឧ. se garer des coups)

gargantua *n.m.* មនុស្សស៊ីច្រើន

gargariser (se) *v.pr.* ខ្ពុរមាត់។ *Fig. & fam.* ត្រេកត្រអាលនឹងរបស់អ្វីមួយ

gargarisme *n.m.* ថ្នាំខ្ពុរមាត់

gargote *n.f.* ភោជនីយដ្ឋាន (លក់អាហារថោកៗ)

gargotier,ère *n.* នាយភោជនីយដ្ឋាន

gargouille *n.f.* មាត់ទ; បំពង់បង្ហូរទឹក

gargouillement *n.m.* សូរក្អូរពោះ; សូរទឹក ឬ ខ្យល់ក្រួកៗ

gargouiller *v.i.* ក្អូរពោះ; កក្រោកទឹក

gargouillis *n.m.* សូរទឹកធ្លាក់ពីទ

gargoulette ឬ **gargouillette** *n.f.* ក្អមដាក់ទឹក

gargousse *n.f.* ឡតរំសេវកាំភ្លើងធំ

garnement *n.m.* មនុស្សខូច; ក្មេងខិលទ្រាំពុំបាន

garni,e *a.* ដែលមាន; ដែលមានគ្រឿង (ឧ. chambre garnie) ។ *n.m.* ផ្ទះឬបន្ទប់ប្រដាប់ដោយគ្រឿង (ឧ. habiter un garni ឬ en garni)

garnir *v.t.* ផ្គត់ផ្គង់របស់ចាំបាច់(ឧ.garnir une maison de meubles); តែងលំអ (ឧ. garnir une robe de broderies); ពាក់តែងដោយគ្រឿង; ក្រាប់, សែមថែមឲ្យមាំ (ឧ. garnir des bas); បំពេញ (ឧ. la foule garnissait la rue) ។ se garnir *v.pr.* ឡើងណែនណាន់ (ឧ. la salle se garnit)

garnison *n.f.* យោធភូមិ (ទ័ពប្រចាំទី-

ព្រុងមួយ) ។ *Par ext.* យោធភូមិ, ព្រុងដែលមានទ័ពប្រចាំ(ឧ. changer de garnison)

garnissage *n.m.* ការតែងលំអ; ការទ្រាប់; ការបំពេញ

garniture *n.f.* គ្រឿងតែងលំអ (ឧ. garniture de chapeau); បន្លែសម្រាប់តែងលំអ (ឧ.garniture de persil); សម្រាប់, ប្រដាប់ (ឧ.garniture de boutons ឡេវមួយសម្រាប់)

garrot *n.m.* ស្មាសត្វ

garrot *n.m.* កូនកំព្រា (ឬមេកំព្រា) (ឧ. le garrot d'une scie)

garrottage *n.m.* ការក្រឡែងកូនកំព្រា

garrotter *v.t.* ក្រឡែងកូនកំព្រា; ចងរឹត (ឧ. garrotter un prisonnier)

gars *n.m.* *Fam.* ក្មេងប្រុស, កម្លោះ

garuda *n.m.* គ្រុឌ

gascon,onne *a.* & *n.* នៃស្រុកហ្គាស្កុញ (ឧ. l'accent gascon) ។ *n.m.* ភាសាស្រុកហ្គាស្កុញ។ *n.*&*a.* *Par ext.* មនុស្សអំនួត; មនុស្សប៉ុនប្រសប់ ឬ ឈ្លាសវៃ; អ្នកនិយាយលេង; អ្នកចំអក

gasconnade *n.f.* អំនួត; ការបំផ្លើស

gasconner *v.t.* និយាយរបៀបអ្នកហ្គាស្កុញ; អួត, បំផ្លើស

gas-oil ឬ **gasoil** [ga-zoual] *n.m.* ហ្គាស្វាល់ (ប្រេងសាំងខាប់)

gaspillage *n.m.* ការខ្ជះខ្ជាយ;ការចាយ ឬ ប្រើប្រាស់ឥតប្រយោជន៍

gaspiller *v.t.* ខ្ជះខ្ជាយ,ប្រើប្រាស់ឥតប្រយោជន៍(ឧ. gaspiller son argent)។ *Fam.* មិនចេះប្រើ, ប្រើឲ្យខាត (ឧ. gaspiller son talent)

gaspilleur,euse *n.* & *a.* ដែលខ្ជះខ្ជាយ, ដែលប្រើប្រាស់ឥតប្រយោជន៍

gastéropodes *n.m. pl.* ខ្យងខ្យាវ (ឬ gastropodes ក៏បាន)

gastralgie *n.f.* ការឈឺចាប់ក្រពះ

gastralgique *a.* នៃការឈឺចាប់ក្រពះ (ឧ. douleur gastralgique)

gastrectomie *n.f.* *Chir.* ការកាត់ក្រពះចោល

gastrique *a.* នៃក្រពះ (ឧ. veines gastriques)។ glande gastrique ម.ព. glande ។ suc gastrique ម.ព. suc

gastrite *n.f.* រោគរលាកក្រពះ (ឧ. la gastrite est fréquente chez

les alcooliques)

gastro-entérite *n.f.* រោគរលាកក្រពះនិងពោះវៀន (*pl.* des gastro-entérites)

gastro-entérologie *n.f.* វិជ្ជាពេទ្យខាងក្រពះនិងពោះវៀន

gastro-entérologue *n.m.* ពេទ្យខាងរោគក្រពះនិងពោះវៀន

gastrologie *n.f.* អាហារវិទ្យា

gastrologique *a.* នៃអាហារវិទ្យា

gastromane *n. & a.* អាហារម៉េត

gastromanie *n.f.* អាហារម៉េទ

gastronome *n.m.* អាហារសិល្បិន, អ្នកជំនាញខាងម្ហូបឆ្ងាញ់

gastronomie *n.f.* អាហារសិល្បៈ, សិល្បៈខាងបរិភោគម្ហូបឆ្ងាញ់ៗ

gastronomique *a.* នៃអាហារសិល្បៈ

gastropodes *n.m. pl.* ម.ក. gastéropodes

gastroscope *n.m.* ប្រដាប់ឆ្លុះមើលក្រពះ

gastroscopie *n.f.* ការឆ្លុះមើលក្រពះ

gastrotomie *n.f.* ការវះក្រពះយកវត្ថុដទៃចេញ

gâté,e *a.* ខូច ។ *n.m.* ភាគដែលខូច ។ enfant gâté ក្មេងទម្រើស (ដែលគេថ្នមពេក)

gâteau *n.m.* នំ; វត្ថុដែលមានសណ្ឋានដូចនំ (ឧ. gâteau de plomb); សំបុកឃ្មុំ ។ partager le gâteau ចែកកម្រៃ ។ *a. Fam.* ស្លូតពេក (ឧ. papa gâteau)

gâte-métier *n.m.* អ្នកធ្វើការយកឈ្នួលថោកពេក (*pl.* des gâte-métier ឬ métiers)

gâte-papier *n.m.* អ្នកនិពន្ធថោកទាបផ្សេងៗ

gâter *v.t.* ធ្វើឲ្យខូចឬឲ្យស្អុយ (ឧ. l'humidité gâte des fruits) ។ *Fig.* ប្រព្រឹត្តល្អពេក, ជូនជំនូនច្រើនពេក (ឧ. vous me gâtez) ។ gâter le métier ស៊ីឈ្នួលថោកពេក ។ gâter un enfant ទម្រើសក្មេង (ថ្នមជំនួយទាល់តែជាប់ចិត្ត) ។ se gâter *v.pr.* ខូច, ស្អុយ (ឧ. la viande se gâtent facilement) ។ le temps se gâtent មេឃឬអាកាសកាន់តែមិនស្រួល (រកកល់ភ្លៀង)

gâterie *n.f.* ការជំនួយហួសហេតុ; ជំនូនបន្តិចបន្តួច ។ *Spécial.* បង្អែម

gâte-sauce *n.m.* ចុងភៅមិនចេះការ; កូនចុងភៅ (ក្មេងរៀនធ្វើម្ហូប)

gâteux,euse *a.&n.* ដែលវង្វេងវង្វាន់ (មនុស្សចាស់)

gâtine *n.f.* ដីជក់ទឹកហើយគ្មានជីជាតិ

gauche *a.* ឆ្វេង (ឧ. côté, œil gauche) ។ *Fig.* ឆ្គង (ឧ. avoir des manières gauches)

gauche *n.f.* ដៃឆ្វេង; ខាងឆ្វេង (ឧ. prendre la gauche); ភាគខាងឆ្វេងនៃសភា; ពួកអ្នកវាមនិយម (ផ្ទុយនឹងពួកអភិរក្សនិយម)

gauchement *adv.* ដោយឆ្គង

gaucher, ère *a.&n.* អ្នកប្រើដៃឆ្វេង

gaucherie *n.f. Fam.* អំពើឆ្គង; ភាពឆ្គង

gauchir *v.i.* ពោរ; ខូចរូបរាងឬទ្រង់ទ្រាយ (ឧ. cette planche gauchit) ។ *v.t.* ធ្វើឲ្យឆ្គង

gauchissant,e *a.* ដែលងាកទៅខាងឆ្វេង (ចំពោះគំនិតនយោបាយ)

gauchissement *n.m.* ការធ្វើឲ្យឆ្គង; ភាពពោរឬខូចទ្រង់ទ្រាយ

gaucho *n.m.* គង្វាលសត្វនៅប្រទេសអាហ្សង់ទីន

gaudriole *n.f. Fam.* សំដីលេងសើច

gaufrage *n.m.* ការបោះពុម្ពលើស្បែកឬសំពត់ដោយដែកក្ដៅ

gaufre *n.f.* សំបុកឃ្មុំ; នំស្តើងផុតដោយពុម្ព

gaufrer *v.t.* បោះពុម្ពលើស្បែកឬសំពត់ដោយដែកក្ដៅ

gaufrette *n.f.* នំផុតពុម្ព

gaufreur,euse *n.* ជាងបោះពុម្ពលើស្បែក ឬ សំពត់ដោយដែកក្ដៅ

gaufrier *n.m.* ពុម្ពផុតនំ

gaufroir *n.m.* ដែកបោះពុម្ពលើស្បែកឬសំពត់

gaufrure *n.f.* ស្នាមពុម្ពបោះលើស្បែកឬសំពត់

gaulage *n.m.* ការវាយជម្រុះផ្លែឈើដោយដំពក់

gaule *n.f.* ដំពក់; ដងសន្ទូច

gauler *v.t.* វាយជម្រុះផ្លែឈើដោយដំពក់ (ឧ. gauler un pommier)

gaullisme *n.m.* ការប្រកាន់បក្សឧត្តមសេនីយដឺហ្គោល

gaulliste *a. & n.* អ្នកប្រកាន់បក្សខាងឧត្តមសេនីយដឺហ្គោល

gaulois,e *a.&n.* នៃស្រុកហ្គោល(ប្រទេសបារាំងក្នុងបុរាណកាល) ។ *Fig.* ដែលលេងមិនសូវទប់មាត់ (ឧ. propos gaulois)។ *n.m.* ភាសាជាតិហ្គោល

gauloisement *adv.* ដោយលេងមិនសូវទប់មាត់

gauloiserie *n.f.* ការកំប្លែងលេងដោយមិនសូវទប់មាត់

gaupe *n.f. Pop.* ស្រីខូច

gaur *n.m.* ខ្ទីង

gausser (se) *v.pr.* ចំអកឡកឡាយ

gavage *n.m.* ការបញ្ជ្រូកចំណី; ភាពត្រូវបំប៉នចំណី

gave *n.m.* ជ្រោះធ្លាក់ពីលើភ្នំពីរ៉េណេ(ឧ. le gave de Pau)

gaver *v.t.* បញ្ជ្រូកចំណី(ឧ. gaver des oies)។ *Par anal.* បំប៉នចំណី(ឧ. gaver un enfant de bonbons)។ se gaver *v.pr.* ស៊ីហួសប្រមាណ

gaz *n.m.* ឧស្ម័ន ។ gaz de combat ឧស្ម័នប្រយុទ្ធ (ឧស្ម័នពុលប្រើជាអាវុធសង្គ្រាម)។ gaz d'éclairage ឬ gaz de ville ឧស្ម័នបំភ្លឺ ឬ ឧស្ម័នក្រុង (សម្រាប់ដុត បំភ្លឺ កំដៅ ។ ល។)។gaz de marais មេតាន។ gaz naturel ឧស្ម័នធម្មជាតិ (ដែលផុសពីក្នុងដី)។ mettre le gaz បង្កំល្បឿនយន្ត។ *Absol.* ឧស្ម័នបំភ្លឺ;ក្រុមហ៊ុនឧស្ម័ន(ឧ. un employé du gaz)។ *Par ext.* ជាតិខ្យល់ក្នុងពោះ

gazage *n.m.* ការទ្រាប់ស្បៃ (ឧ. gazage d'un chapeau)

gaze *n.f.* ស្បៃ

gazé,e *a. & n.* ពុលដោយឧស្ម័ន

gazéification *n.f.* ឧស្ម័នកម្ម, ការធ្វើឲ្យក្លាយជាឧស្ម័ន

gazéifier *v.t.* ធ្វើឲ្យក្លាយជាឧស្ម័ន; រំលាយឧស្ម័នការបូនិកក្នុងទឹក

gazéiforme *a.* ដែលមានភាពជាឧស្ម័ន

gazer *v.t.* គ្របឬទ្រាប់ស្បៃ។*Fig.*គ្រប; បិទបាំង (ឧ. la politesse gaze les vices (Missillon); សម្រួលដោយល្បិចសំដី (ឧ. gazer une pensée scabreuse)

gazer *v.t.* រោលស្បៃឲ្យអស់រោមស្របុយ (ឱ flamber ឬ griller ក៏បាន)។ *Mil.* បំពុលដោយឧស្ម័ន ។ *v.i.* *Fam.* បង្កំល្បឿន ។ *Par ext.* បានប្រកបស្រួល

gazeté,e *a.* ដែលមានលក្ខណៈដូចកាសែត(ឧ. la phrase gazetée et le parler de table d'hôte (Töppfer)

gazetier *n.m.* អ្នកផ្សាយកាសែត

gazette *n.f.* កាសែត ។ *Fig.* មនុស្សនិយាយច្រើន

gazeux,euse *a.* ដែលជាឧស្ម័ន (ឧ. fluide gazeux)។eau gazeuse ទឹកឧស្ម័ន

gazier, ière *a.* នៃឧស្ម័ន ។ *n.m.* និយោជិកក្រុមហ៊ុនឧស្ម័ន

gazogène *n.m.* ប្រដាប់ធ្វើឧស្ម័ន(ដោយប្រើអុសឬធ្យូង)

gazoline *n.f.* ហ្គាសូលីន

gazomètre *n.m. Ind.* ឧស្ម័នមាត្រ

gazométrie *n.f.* ឧស្ម័នមាត្រវិធី

gazon *n.m.* ស្មៅល្អិតហើយខ្លីៗ; ធ្លាស្មៅ

gazonnant, e *a.* ដែលជាស្មៅល្អិត

gazonnée *n.f.* កំលដុំស្មៅល្អិត

gazonnement ឬ **gazonnage** *n.m.* ការដាំស្មៅល្អិត

gazonneux, euse *a.* ដូចស្មៅល្អិត (ឧ. prairie gazonneuse)

gazouillant, e *a.* ដែលយំដូចបក្សី

gazouillement *n.m.* សម្លេងបក្សីយំ; សូរទឹកហូរ

gazouiller *v.i.* យំ (បក្សី) (ឧ. les oiseaux gazouillent); បន្លឺសូរបន្តិចៗ (ទឹកហូរ) (ឧ. un ruisseau qui gazouille) ។ *Par ext.* និយាយកកកក (ឧ. bébé qui gazouille)

gazouilleur, euse *a.* ដែលយំដូចបក្សី

gazouillis *n.m.* សម្លេងបក្សីយំ (ឧ. le gazouillis des oiseaux)។ *Par ext.* សូរតិចៗ (ឧ. au gazouillis des ruisseaux de ce bois) (La Fontaine)

geai *n.m.* ទៀវ(បក្សី)

géant, e *a.* ធំសម្បើម, ធំហួសខ្នាត ។ *n.* មនុស្សធំខ្ពស់, យក្ស ។ à pas de géant លឿនណាស់

gecko ឬ **gekko** *n.m.* សត្វតុកកែ (ឬ តុកកែ)

géhenne *n.f.* នរក (ឧ. le feu de la géhenne)

geignard, e *a.* &*n. Fam.* ដែលថ្ងូរទាំ ឬ ត្អូញត្អែរមិនឈប់

geignant, e *a.* ដែលថ្ងូរទាំ, ដែលធ្លាប់តែថ្ងូរទាំ

geignard, e ឬ **geigneur, euse** *a.* ដែលធ្លាប់តែថ្ងូរទាំ

geignement *n.m.* ការថ្ងូរទាំ, ការត្អូញត្អែរ

geindre *v.i.* ថ្ងូរទាំ ។ *Fam.* ត្អូញត្អែរមិនឈប់

gel *n.m.* ដំណើរកកទឹកដោយត្រជាក់; អាកាសត្រជាក់; ពេលកកទឹក

gélatine *n.f.* ជាតិខាប់អន្ទិលធ្វើអំពីឆ្អឹង; ចាហួយ

gélatineux, euse *a.* នៃជាតិខាប់អន្ទិល

ធ្វើអំពីឆ្អឹង; ទាប់អន្ទិល

gelé,e *a.* crédits gelés ឥណទានជាប់

gelée *n.f.* ដំណើរកកទឹកដោយអាកាសត្រជាក់, ទឹកដមកក (ឧ. poulet à la gelée; gelée de groseilles)។ gelée blanche ហិមានី, ទឹកសន្សើមកក

geler *v.t.* ធ្វើឲ្យកក (ឧ. le froid gèle l'eau des fontaines); ធ្វើឲ្យរបួសដោយត្រជាក់ (ឧ. le froid lui a gelé les pieds) ។ *v.i.* កក (ឧ. la rivière a gelé); រងាណាស់ (ឧ. on gèle dans cette pièce បន្ទប់នេះរងាណាស់)

gélification *n.f.* ការកក

gélivure *n.f.* ស្នាមប្រេះដោយទឹកកកខ្លាំង (ដើមឈើ, ថ្ម)

gélos *n.f.* ម.ព. agar-agar

gélure *n.f.* អំណាចត្រជាក់លើកោសិការស់ (សាច់មនុស្សឬសត្វ)

gémeau *n.m*, **gémelle** *n.f.* បងប្អូនភ្លោះ (ឧ. deux gémeaux; deux gémelles)

gémeaux *n.m. pl. Astr.* មិថុនរាសី

gémellaire *a.* នៃបងប្អូនភ្លោះ

gémellipare *a.* ដែលកើតកូនភ្លោះ (ឧ. femelle gémellipare)

géminé, e *a.* ភ្លោះ (វត្ថុ) (ឧ. colonnes géminées)។ école géminée សាលារៀនចម្រុះប្រុសនិងស្រី

géminer *v.t.* ផ្គួបជាគូៗ

gémir *v.i.* ថ្ងូរ (ដោយឈឺចាប់); ថ្ងូរ (ព្រាប); បួល (លលក) (ម.ព. roucouler ផង); ធ្វើឲ្យឮសូរដូចថ្ងូរ (ឧ. le vent gémit dans la forêt) ។ *Fig.* រងទុក្ខទោស (ឧ. gémir dans les fers)

gémissant,e *a.* ដែលថ្ងូរ

gémissement *n.m.* ការថ្ងូរ (ឧ. pousser de longs gémissements) ។ សម្រែកដូចថ្ងូរ (ឧ. les gémissements de la tourterelle) ; គំអូញ; ចម្រៀងគំអូញ ។ *Par ext.* សូរដូចថ្ងូរ (ឧ. les gémissements du vent)

gémissant, e *a.* ដែលថ្ងូរ, ដែលត្អូញ

gémisseur,euse *n. Ironiq. &fam.* អ្នកហៃត្អូញ

gemmage *n.m.* ការពោះដើមស្រល់យកជ័រ

gemmation *n.f.* ដំណើរដុះខ្នែង; រដូវដុះខ្នែង; ខ្នែងទាំងឡាយ

gemme *n.f.* ត្បូង; ខ្នុង; អំបិលស្រស់ ។ *a.* pierre gemme ត្បូងថ្ម ។ sel gemme អំបិលដី (ដែលជីកយកពីក្នុងដី) (ម.ព. sel ផង)

gemmé, e *a.* លំអដោយត្បូង

gemmer *v.i.* ពន្លក។ *v.t.* gemmer des pins ចោះដើមស្រល់យកជ័រ

gemmeur *n.&a.m.* អ្នកចោះដើមស្រល់យកជ័រ

gemmifère *a.* ដែលមានត្បូងថ្ម; ដែលមានខ្នុង

gemmule *n.f. Bot.* ពីកាណូ(ពន្លកដំបូងនៃរុក្ខជាតិ)

gémonies *n.f. pl. Fig.* vouer quelqu'un aux gémonies ធ្វើឱ្យសាធារណជនស្អប់ ។ traîner quelqu'un aux gémonies ជេរប្រមាថយ៉ាងធ្ងន់

gênant,e *a.* ដែលរំខាន

gencive *n.f.* ជើងធ្មេញ

gendarme *n.m.* អាវុធហត្ថ, ទាហានទទួលការរក្សាសេចក្តីរៀបរយក្នុងស្រុក; ដុំថ្មចោតលើភ្នំខ្ពស់ ; ប្រជ្រុយពេជ្រ ។ *Fam.* ស្ត្រីមានឫកពាអ្នកប្រើអំណាច

gendarmer (se) *v.pr.* ទឹងខុសបទ; តវ៉ាយ៉ាងខ្លាំង

gendarmerie *n.f.* ក្រុមអាវុធហត្ថ; អាវុធហត្ថដ្ឋាន

gendre *n.m.* ប្អូនប្រសាប្រុស

gêne *n.f.* ការទទួលសារភាពដោយទារុណកម្ម; ទារុណកម្ម; គ្រឿងសំរាប់ធ្វើទារុណកម្ម; ភាពចង្អៀតចង្អល់។ *Fig.* សេចក្តីទើសទាល់ ; ការអៀន (ឧ. éprouver de la gène en face de quelqu'un); ការខ្វះប្រាក់ ។ *Fam.* sans gêne ដោយគ្មានអៀនចិត្តទេ

gêné,e *a.* មិនស្រួល, ទើសទាល់, ចង្អៀតចង្អល់ ។ *Fig.* ច្រេញច្រួញ, ដែលខ្វះប្រាក់

généalogie *n.f.* ពង្សាវលី, បញ្ជីរាយនាមឪពុកជីតាមនុស្សម្នាក់, ពង្សាវិទ្យា

généalogique *a.* នៃពង្សាវលី ។ arbre généalogique តារាងពង្សាវលី

généalogiste *n.* ពង្សាវិទូ, អ្នកធ្វើតារាងពង្សាវលី

gêner *v.t.* ធ្វើឲ្យទើសទាល់-ឲ្យទើសទាក់ឬឲ្យចង្អៀតចង្អល់ (ឧ. chaussures qui gênent)។ *Fig.* បង្កើតឧបសគ្គ (ឧ. gêner le commerce) ; នាំឲ្យរំខាន , នាំឲ្យទើសទាល់ , នាំឲ្យ

ពិបាកចិត្ត (រអែងចិត្ត) (ឧ. sa présence me gêne); នាំឲ្យខ្វះប្រាក់ (ឧ.cette dépense me gêne)។

se gêner *v.pr.* ទើសទាល់, រអែងចិត្ត (ឧ. que personne ne se gêne chez moi)

gêneur,euse *n.* អ្នកនាំរំខាន

général,e,aux *a.* ទូទៅ, ទាំងអស់ (ឧ. intérêt général; opinion générale)។ *Par ext.* មិនច្បាស់ (ឧ. parler en termes généraux);អគ្គ(ឧ. trésorier général អគ្គហេរញ្ញិក); ឧត្តម,ឧកាស,សាកល។ répétition générale ឬ générale ការហាត់បង្ហើយ (ស្មោនមុននឹងចេញលេងមែនទែន)។ *n.m.* ឧកាសហេតុ (ឧ. conclure du particulier au général)។ en général *loc. adv.* តាមធម្មតា, ដោយទូទៅ, ជាទាំងអស់

général *n.m.* ឧត្តមសេនីយ។ général de brigade ឧត្តមសេនីយត្រី។ général de division ឧត្តមសេនីយទោ។ général de corps d'armée ឧត្តមសេនីយឯក។ général d'armée ឧត្តមសេនីយនាយក

généralat *n.m.* សក្តិយស ឬ តំណែងនៃឧត្តមសេនីយ

générale *n.f.* ភរិយានៃឧត្តមសេនីយ; ការវាយស្គរ ឬ ផ្លុំត្រែប្រមូលហៅពលក្នុងពេលអាសន្ន (ឧ. sonner la générale)

généralement *adv.* ជាឧកាស, តាមធម្មតា

généralisable *a.* ឧកាសិយ, អាចធ្វើឲ្យទៅជាឧកាស-សាកល ឬ ទាំងអស់បាន (ឧ. proposition facilement généralisable)

généralisateur,trice *a.* ឧកាសកៈ, នៃលធ្វើ ឬ និយាយសរុប (ឧ. esprit généralisateur)

généralisation *n.f.* ឧកាសកម្ម, ការធ្វើឬនិយាយសរុប(ឧ.une généralisation hâtive)

généraliser *v.t.* ធ្វើឧកាសកម្ម, ធ្វើ ឬ និយាយសរុប , ផ្សាយឲ្យទៅជាទាំងអស់ (ឧ.généraliser une idée,une méthode)

généralissime *n.m.* អគ្គសេនាធិបតី; ឯកអគ្គនាយក (ឧ. Foche fut en 1918 le généralissime des armées alliées)

généralité *n.f.* ឧកាសភាព, ភាពនៃវត្ថុដែលមានទូទៅឬដែលមានច្រើនជាងគេ (ឧ. la généralité des hommes) ។ *pl.* ឧភាសការណ៍, សេចក្ដីឧភ៉ាល់, គំនិតទូទៅ (ឧ. s'en tenir aux généralités)

générateur,trice *a.* ដែលបង្កើត, ដែលបណ្ដាល ។ *n.m.Méc.* ខ្ទះដុតយកចំហាយ

génératif,ive *a.* នៃឧកាសកម្ម

génération *n.f.* កំណើត ; ការបង្កើត (ឧ.le principe de la famille antique n'est pas uniquement la génération (Fustel de Coulanges) ។ génération spontanée សំសេទជាតិ (កំណើតសត្វពីញើសក្អែល ឬ ពីធូលី)។ *Par ext.* ពូជ(ឧ.la génération de Noë);តំណ (ឧ.il y a deux générations, du grand-père au petit-fils); ជំនាន់ (ក្រុមមនុស្សដែលមានអាយុដំណាលគ្នា) (ឧ. la jeune génération; les générations futures) ។ *Fig.* កំណើត (ឧ.la génération des idées)

généreusement *adv.* ដោយចិត្តទូលាយឬសប្បុរស (ឧ. se sacrifier généreusement pour son pays)

généreux,euse *a.* ចិត្តទូលាយ (ឧ. patron généreux); ចិត្តបុណ្យ (ឧ.ennemi généreux);ក្លាហាន (ឧ. de généreux soldats)។ *Fig.* ដែលមានជីជាតិ (ឧ. terre généreuse) ។ vin généreux ស្រាទំពាំងបាយជូរខ្លាំងល្អ។coursier généreux សេះចំបាំងក្លៀវក្លា

générique *a.*នៃប្រភេទ(ឧ.caractère générique) ។ *n.m.* ការបង្ហាញចំណងជើងនិងក្រុមអ្នកដើរតួ (ខ្សែភាពយន្ត)

génériquement *adv.* ដោយប្រភេទ

générosité *n.f.*ចិត្តបុណ្យ,ចិត្តសប្បុរស, ចិត្តទូលាយ (ឧ. la générosité est la vertu des grandes âmes); អធិកភាព ។ *pl.* ទាន, អំណោយ; ការអនុគ្រោះ (ឧ. faire des générosités)

genèse *n.f.* ដើមកំណើត ។ *Fig.* បុព្វហេតុ (ឧ. la genèse d'un drame)

génésique *a.* នៃការបង្កើត(ឧ.instinct génésique សភាវគតិនៃការបង្កើត (នាំសត្វឲ្យបង្កើតកូនជាតំណវង្ស)

genet *n.m.* សេះប្រទេសអេស្ប៉ាញ

généticien *n.m.* ពន្ធុវិទូ(អ្នកប្រាជ្ញខាងពន្ធុវិជ្ជា)

génétique *n.f.* ពន្ធុវិជ្ជា, វិជ្ជាស្រាវជ្រាវពូជពង្ស

génétiste *n.m.* អ្នកពន្ធុវិជ្ជា(អ្នកជំនាញខាងពូជសត្វជាតិនិងរុក្ខជាតិ)

gêneur,euse *n.f.* អ្នកនាំរំខាន

génial,e,aux *a.* តាមធម្មជាតិមនុស្ស; ដែលមានទេពកោសល្យ (ឧ. poète génial); ដែលបញ្ចេញទេពកោសល្យ (ឧ. idée géniale)

génialement *adv.* ដោយទេពកោសល្យ

géniculation *n.f.* របត់ក្បាលជួបជង្គង់

génie *n.m.* ទេពារក្ស (ទេវតាអ្នករក្សាជនម្នាក់ៗ) (ឧ. bon ឬ mauvais génie); ប្រេញកង្វាល, ភូត, បិសាច (ឧ. un génie lui apparut); ទេពកោសល្យ (សេចក្ដីឈ្លាសវៃយ៉ាងឆ្នើមបំផុត) (ឧ. avoir du génie pour la musique); មនុស្សទេព (អ្នកមានទេពកោសល្យ) (ឧ.ce sont les grands génies qui enfantent les grands desseins (Fontenelle)។ *Mil.* កងទាហានជាង ។ génie civil សិល្បស្ថាបនា; ជាងស៊ីវិល (ក្រុមវិស្វករ) ។ génie maritime កងទាហានជាងស្ថាបនានាវា ។ génie d'une langue បច្ចេកលក្ខណៈនៃភាសា

génisse *n.f.* គោក្រមុំ ។ *Poét.* គោញី

génital,e,aux *a.* នៃអង្គជាត ។ organes génitaux អង្គជាត

géniteur,trice *n.&a.* ដែលបង្កើត

génitif *n.m.* ឆដ្ឋីវិភត្តិ, វិភត្តិទី ៦

génito-urinaire *a.* នៃអង្គជាតបស្សាវៈ (ឧ. tuberculose génito-urinaire)

géniture *n.f.* កូនទាំងឡាយ

génocide *n.m* ជនឃាត, ការសម្លាប់មហាជន

genou *n.m.* *Anat.* ក្បាលជង្គង់ ។ *Fam.* ក្បាលទំពែក ។ à genou ឬ à genoux លុតជង្គង់ ។ être aux genoux de quelqu'un ស្រឡាញ់ព្រៃពេក ។ fléchir le genou បន្ទាបខ្លួន,លុតក្រាប(ឧ. fléchir le genou devant les puissants)

genouillère *n.f.* ក្រោះជង្គង់; ស្បែក

ទ្រនាប់ជង្គង់;គ្រឿងការពារជង្គង់

genre *n.f.* ប្រភេទ(ឧ.le genre humain); របៀប (ឧ. genre de vie); បែប (ឧ. robe d'un bon genre; marchandises de tout genre); ឫក (ឧ. avoir mauvais genre)។ *Fam.* faire du genre ធ្វើឫក។ *Hist. nat.* ប្រភេទ (ឧ. le loup est une espèce du genre chien)។

Gram. លិង្គ,ភេទ។ genre masculin បុំលិង្គឬបុល្លិង្គ។ genre féminin ឥត្ថីលិង្គឬស្ត្រីលិង្គ។ genre neutre នបុំសកលិង្គ

gens *n.pl.* មនុស្ស,ជន(ឧ. les gens de biens); ប្រជាជាតិ (ឧ. le droit des gens)។ *Par ext.* ជនមួយក្រុម,គ្នា(ឧ. tous nos gens sont arrivés qu'on serve le dîner); ជាវក្រាវ, អ្នកបម្រើ (ឧ.dites aux gens de monsieur qu'ils aillent quérir des violons (Molière)។

gens d'église អ្នកបួស (សាសនាគ្រិស្ត)។ gens d'épée អភិជន, ទាហាន។ gens de mer អ្នកដើរសមុទ្រ។ gens de robe ចៅក្រម,មេធាវី។ gens de lettres អ្នកនិពន្ធ។ gens de maison ជាវក្រាវ។ gens de pied ពលថ្មើរជើង។ gens de cheval អស្សសាទិន, ទាហានទ័ពសេះ។ gens de ville អ្នកក្រុង។ gens de campagne អ្នកស្រែ។ bonnes gens មនុស្សល្អ, មនុស្សស្លូត។ gens de sac et de corde មនុស្សហោនៃយ៉ុ [ហ:-នៃ-យ៉ុង]។

Loc.div. à la barbe des gens មិនរវែងពាក្យអ្នកផង។ se moquer des gens និយាយពិនទំនង

gent *n.f.* ជាតិ, ពូជ។ la gent marécageuse កង្កែប។ la gent moutonnière ចៀម; *au fig.* អ្នកក្រាប់។ la gent trotte menu កណ្ដុរ

gentil,ille *a.* ថ្លៃថ្នូរ។ *Auj.* សេដ្ឋាចារី, សមរម្យ

gentil *n.m.* *Hébreux* ជនបរទេស។ *Chrétiens* ពាហិរជន

gentilhomme *n.m.* អ្នកមានត្រកូលជាអភិជន។ vivre en gentilhom-

me រស់នៅដោយឥតធ្វើការ

gentilhommer *v.i. Fam.* ប្រកាន់ឫកជាអភិជន

gentilhommerie *n.f. Fam.* ឋានៈជាអភិជន;អភិជនទាំងឡាយនៃប្រទេសមួយ

gentilhommière *n.f.* ផ្ទះអភិជនជាន់ទាប ។ *a.* នៃអភិជន (ឧ. bravoure gentilhommière)

gentilité *n.f.* ជាតិបរទេស;ពាហិរជនតា

gentillâtre *n.m.Fam.* អភិជនជាន់ទាប

gentillesse *n.f.* សេដ្ឋាចារ, ភាពជាទីពេញចិត្ត(ឧ.la gentillesse d'un enfant); ឫកពារទន់ភ្លន់, សំដីគួរឲ្យជាប់ចិត្ត(ឧ.cet enfant dit mille gentillesses)

gentillet, ette *a.* សេដ្ឋាចារីគួរសម, សមរម្យគួរសម ។ *Fam.* តូចច្រឡឹង

gentiment *adv.* ដោយសេដ្ឋាចារី, ដោយសមរម្យ

gentleman *n.m.* អ្នកមានការអប់រំល្អ; អ្នកបេះគួរសម (*pl.* des gentlemen)

génuflecteur,trice *n.&a.* អ្នកលុតជង្គង់ ។ *Fig.* អ្នកបញ្ជោរដោយថោកទាប

génuflexion *n.f.* ការបត់ជង្គង់ ។ *Fig.&Fam.* ការបញ្ជោរ,ការលុតក្រាប (ឧ. je n'ai que faire de vos génuflexions)

géocentrique *a. Astr.* ភូគព្ភនាភិ, ដែលមានស្នូលផែនដីជាមជ្ឈមណ្ឌល

géodésie *n.f.* ប្រថពីវិភាគ,វិទ្យាសាស្ត្រខាងវាស់ក្រឡាផ្ទៃដី

géodésique *a.* នៃប្រថពីវិភាគ(ឧ.opération géodésique) ។ *n.m.* បន្ទាត់កាត់

géogénie *n.f.* កំណើតផែនដី

géogénique *a.* នៃកំណើតផែនដី

géogonie *n.f.* ម.ព. géogénie

géographe *n.m.* ភូមិសាស្ត្រិន , អ្នកភូមិសាស្ត្រ; ភូមិសាស្ត្រាចារ្យ ; ភូមិសាស្ត្រលេខាធិការ (អ្នកគូរផែនទី)

géographie *n.f.* ភូមិសាស្ត្រ។ géographie économique ភូមិសាស្ត្រសេដ្ឋកិច្ច ។ géographie humaine ភូមិសាស្ត្រមនុស្ស ។ géographie physique ភូមិសាស្ត្ររូបនិយម ។ géographie politique ភូមិសាស្ត្រនយោបាយ

géographique *a.* នៃភូមិសាស្ត្រ (ឧ.

vue géographique)

géographiquement *adv.* តាមភូមិសាស្ត្រ,តាមរបៀបភូមិសាស្ត្រ

geôlage *n.m.* ពន្ធឆ្មាំគុក

geôle *n.f.* គុក

geôlière *n.f.* ភរិយាឆ្មាំគុក

géologie *n.f.* ភូគព្ភសាស្ត្រ។ géologie générale ភូគព្ភសាស្ត្រទូទៅ។ géologie historique ភូគព្ភប្រវត្តិសាស្ត្រ

géologique *a.* នៃភូគព្ភសាស្ត្រ

géologiquement *adv.* តាមភូគព្ភសាស្ត្រ

géologue *n.m.* ភូគព្ភវិទូ

géomancie *n.f.* ការបួលដោយរោយដី

géométral, e, aux *a. Math.* រេខាគណិតមាត្រ,ដែលបង្ហាញខ្នាតតាមទំហំពិតឬតាមមាត្រសាស្ត្រ (ឧ. plan géométral)

géomètre *n.m.* រេខាគណិតក។ géomètre civil រេខាគណិតកស៊ីវិល។ géomètre conservateur រេខាគណិតកអភិរក្ស ។ géomètre expert រេខាគណិតកជំនាញការ

géométrie *n.f.* រេខាគណិត ។ géométrie dans l'espace រេខាគណិតនាវេហាស៍ ។ géométrie plane រេខាគណិតរាប ។ géométrie descriptive ឬ projective រេខាគណិតពិពណ៌នា ។ géométrie analytique រេខាគណិតវិភាគ ។ géométrie infinitésimale រេខាគណិតអត្យណូ

géométrique *a.* នៃរេខាគណិត (ឧ. plan géométrique) ។ *Fig.* ស្មើ (ដូចរូបរេខាគណិត)

géométriquement *adv.* តាមរេខាគណិត

géométrisme *n.m. Phil.* រេខាគណិតនិយម

géomorphologie *n.f.* ភូមិសណ្ឋានវិទ្យា

géophage *a.&n.* បឋវីស៊ី, ដែលស៊ីដី

géophagie *n.f.* ការស៊ីដី, ការចង់បរិភោគវត្ថុមិនមែនជាអាហារ

géophysique *a.* ភូគព្ភរូបនិយម

géorama *n.m.* ភូគព្ភទស្សន៍, រូបតំណាងផែនដី

géorgique *a.* នៃការងារកសិកម្ម (ឧ. poème géorgique) ។ *n.f. pl.* កំណាព្យថ្លែងអំពីការងារកសិកម្ម (ឧ. les géorgiques de Virgile)

géothermie *n.f.* កំដៅខាងក្នុងផែនដី

géothermique *a.* នៃកំដៅខាងក្នុងផែនដី

géotropisme *n.m.* ដំណើរដើមឈើ ដែលងាកបែររកទិស

gérance *n.f.* មុខងារបណ្ណាធិការ; រយៈ-ពេលចាត់ការ

gérant, e *n.* បណ្ណាធិការ, អ្នកចាត់ការ

gerbage *n.m.* ការរើកណ្ដាប់ចេញពីស្រែ; ការចងជាកណ្ដាប់

gerbe *n.f.* កណ្ដាប់ (ឧ. une gerbe de paddy)។ *Par ext.* ជាច់ (ឧ. une gerbe de fleurs)។ *Fig.* អ្វីៗដែលមើលទៅឃើញដូចកណ្ដាប់ (ឧ. une gerbe de feu)

gerbée *n.f.* ចៅ (កណ្ដាប់ចំបើងដែលនៅជាប់គ្រាប់ខ្លះ)

gerber *v.t.* ចងជាកណ្ដាប់ (ឧ. gerber le paddy)។ *Techn.* គរត្រួតគ្នា។ *Mar.* រៀបចំបន្ទុកនាវា។ *v.i.* បានច្រើនកណ្ដាប់ (ឧ. paddy qui gerbe bien); មានទ្រង់ទ្រាយដូចកណ្ដាប់ (ឧ. jets d'eau qui gerbent admirablement)

gerbeur, euse *a.* សម្រាប់រើកណ្ដាប់ចេញពីស្រែ។ *n.f.* ម៉ាស៊ីនចងកណ្ដាប់

gerbier *n.m.* គំនរកណ្ដាប់

gerbière *n.m.* រទេះដឹកកណ្ដាប់

gerce *n.m.* ស្នាមប្រេះ (ឧ. le froid produit des gerces sur la peau); ក្រហែង

gercement *n.m.* ការប្រេះ, ការបែកក្រហែង

gercer *v.t.* ធ្វើឲ្យប្រេះឬបែកក្រហែង (ឧ. le soleil gerce la terre)។ *v.i.* ឬ se gercer *v.pr.* la peau gerce à l'air sec ស្បែកប្រេះដោយខ្យល់ស្ងួត

gerçure *n.f.* ស្នាមប្រេះស្បែក (ឧ. on traite les gerçures par l'eau boriquée ou par des onctions de vaseline ou de glycérine); ស្នាមប្រេះលើសំបកឈើ

gérer *v.t.* ចាត់ចែង, គ្រប់គ្រង (ឧ. gérer un domaine)

germain, e *a.* cousins germains បងប្អូនជីដូនមួយ។ cousins issus de germains បងប្អូនជីទួតមួយ។ *Dr.* frères germains បងប្អូនប្រុសបង្កើត (ឪពុកម្ដាយជាមួយ) (ប.ព. cousin និង frère ផង)

germain, e *a.&n.* នៃប្រទេសហ្សែរ-ម៉ានី (អាល្លឺម៉ង់)

germanique *a.* នៃប្រទេសឬជនជាតិហ្សែរម៉ានី (អល្លឺម៉ង់)

germanisant,e *a.&n.* ដែលសិក្សាភាសាឬរក្សាធម៌អល្លឺម៉ង់

germanisation *n.f.* ការធ្វើឲ្យទៅជាអល្លឺម៉ង់; ការឲ្យមានរបៀបត្រួតត្រាជាអល្លឺម៉ង់

germaniser *v.t.* ធ្វើឲ្យទៅជាអល្លឺម៉ង់; ឲ្យមានរបៀបត្រួតត្រាជាអល្លឺម៉ង់។ *v.i.* និយាយរបៀបអល្លឺម៉ង់

germanisme *n.m.* របៀបនិយាយដោយឡែកនៃភាសាអល្លឺម៉ង់

germaniste *a.&n.* ដែលសិក្សាភាសានិងច្បាប់អល្លឺម៉ង់

germanophile *a.* ដែលចូលចិត្តជនជាតិអល្លឺម៉ង់

germanophilie *a.* ការចូលចិត្តជនជាតិអល្លឺម៉ង់

germanophobe *a.* ដែលស្អប់ជនជាតិអល្លឺម៉ង់

germanophobie *n.f.* ការស្អប់ជនជាតិអល្លឺម៉ង់

germe *n.m.* ដីភណ្ឌ [ដី-ភ៉-] (ភេទៈដំបូងដែលកើតទៅជារូបសត្វ)(ឧ.tout être vivant est issu d'un germe); ពន្លក ។ *Fig.* ដើមហេតុ; មេរោគ (ឧ. les eaux malpropres véhiculent le germe de la fièvre typhoïde ទឹកកខ្វក់ដឹកនាំមេរោគគ្រុនសន្និ)

germer *v.i.* ចេញដីភណ្ឌ, ចេញពន្លក; កកើត,ចាប់ចម្រើនឡើង(ឧ. la vertu germe dans son cœur)

germicide *a.* ដីភណ្ឌឃាត(ឧ.lampe germicide à rayons ultra-violets)

germinal, e, aux *a.* នៃដីភណ្ឌ

germinateur, trice *a.* ដែលធ្វើឲ្យចេញដីភណ្ឌឬចេញពន្លក

germinatif,ive *a.* នៃដីភណ្ឌកិច្ច (ឧ. le blé conserve très longtemps son pouvoir germinatif)

germination *Bot. n.f.* ដីភណ្ឌកិច្ច,ការចេញពន្លក, ការពន្លក (ឧ. la germination exige un minimum de chaleur et d'humidité)។ *Fig.* la germination des idées ការកើតនៃគំនិត

germoir *n.m.* កន្លែងបណ្ដុះ (សម្រាប់បណ្ដុះគ្រាប់)

géronte *n.m.* ចាស់ព្រើល (តួឲ្យសើ

សំណើច)

gérontisme *n.m.* ការជាស់វង្វេង

gérontocratie *n.m.* ការគ្រប់គ្រងដោយមនុស្សចាស់

gérontologie *n.f.* ផ្នែកសាស្ត្រ, ការសិក្សាអំពីការចាស់

gerseau *n.m.* ខ្សែរ៉ក, ខ្សែធ្នាក់រ៉ក

gésier *n.m.* ក្រពះ (បក្សី) (ឧ. les parois du gésier sont musculeuses très épaisses)

gésine *n.f.* ការស្ត្រីកំពុងសម្រាលកូន; បន្ទប់សម្រាលកូន (ក្នុងមន្ទីរពេទ្យ)

gésir *v.i.* ដេកស្តូក (ឧ. il gisait sur le sol); មាននៅ (ឧ. les minéraux qui gisent dans le sol) ។ *Fig.* នៅត្រង់ (ឧ. là gît la difficulté) ; ci-gît បញ្ចុះនៅទីនេះ (ពាក្យចារឹកលើផ្នូរ)

gestation *n.f.* គភ៌; ការមានគភ៌; រយៈពេលមានគភ៌ ។ *Fig.* រយៈពេលគិតការអ្វីមួយ (ឧ. la gestation d'une pièce de théâtre)

gestatoire *a.* ដែលសម្រាប់ទ្រ (ឧ. chaise gestatoire)

geste *n.m.* កាយវិការ

geste *n.f.* រឿងរ៉ាវ (ឧ. la geste de Roland); រឿងឬ ។ *pl.* faits et gestes de quelqu'un គំនិតមារយាទនៃជនម្នាក់

gesticulant,e *a.* ដែលធ្វើកាយវិការ, ដែលគ្នាដៃ

gesticulation *n.f.* ការធ្វើកាយវិការច្រើន, ការគ្នាដៃ

gesticuler *v.i.* ធ្វើកាយវិការ, គ្នាដៃ

gestion *n.f.* ការកាន់កាប់, ការគ្រប់គ្រង (ឧ. la gestion d'une entreprise)

gestionnaire *a.* នៃការកាន់កាប់,នៃការគ្រប់គ្រង (ឧ. compte gestionnaire គណនីគ្រប់គ្រង ។ *n.m.* អ្នកគ្រប់គ្រង។ gestionnaire comptable អ្នកគ្រប់គ្រងគណនេយ្យករ

geyser ឬ **geiser** *n.m.* ប្រភពទឹកក្តៅ (ដែលបាញ់ឡើងពីក្នុងដី)

gibbeux,euse *a.* គក

gibbon *n.m.* ទោច

gibbosité *n.m.* គក, ប៉ូក

gibecière *n.f.* ហោប៉ៅខ្សែព្រាត់ ។ *Auj.* ហោប៉ៅស្បែក (សម្រាប់ព្រាននិងសិស្ស) ។ tour de gibecière ការបន្លំលួច

gibelet *n.m.* ដែកខួងតូច

giberne *n.f.* ថ្លោកគ្រាប់ (សម្រាប់ទាហាន)។ *Fig. & fam.* avoir son bâton de maréchal dans sa giberne អាចឡើងជាសេនាប្រមុខបាន; អាចឡើងឋានៈខ្ពស់

gibet *n.m.* ឈើត្លោក

gibier *n.m.* សត្វដែលគេបរបាញ់(ឧ. gibier à poil, à plume)។ *Fig.* gibier de potence មនុស្សគួរត្លោក; មនុស្សកាចខូច

giboulée *n.f.* ភ្លៀងធ្លាក់ព្រឹល

giboyer *v.i.* បរបាញ់

giboyeur *n.m.* អ្នកប្រមាញ់ធំ

giboyeux,euse *a.* ដែលសម្បូរសត្វ(ឧ. plaine giboyeuse)

giclement *n.m.* ការសាចឬព្រួសចេញ

gicler *v.i.* សាចឬព្រួសចេញ

gicleur *n.m.* ហ្ស៊ីគ្លើរ (ទុយោបាញ់ប្រេង)

gifle *n.f.* ការទះកំផ្លៀង (ឧ. recevoir, donner une gifle); ការអាម៉ាស់មុខ (ឧ. cet échec a été une gifle pour lui)

gifler *v.t.* ទះកំផ្លៀង

gigantesque *a.* ធំដូចយក្ស (ឧ. taille gigantesque)។ *Fig.* ធំសំបើម (ឧ. entreprise gigantesque)។ *n.m.* អ្វីៗដែលធំសំបើម

gigantisme *n.m.* ការលូតលាស់នៃផ្នែកអវយវៈណាមួយធំហួសពេក

gigantomacie *n.f.* ចំបាំងនៃយក្ស

gigot *n.m.* ភ្លៅចៀម។ *Par plais.* ជើងឬភ្លៅមនុស្ស (ឧ.avoir de bons gigots)។ *Mod.* manche à gigot ដៃអាវប៉ោងស្មា។ *Manèg.* ជើងក្រោយនៃសេះ

gigoté,e *a.* un cheval bien gigoté សេះមានភ្លៅល្អ

gigoter *v.i.* ប្រកាច់ៗធាក់ជើង (ទន្សាយដែលស្លាប់)។ *Fam.* ៗធាក់ជើង

gigue *n.f.* ភ្លៅប្រើស។ *Fam.* ជើង។ *Pop.* ស្ត្រីចង្រ្កាង

gilet *n.m.* អាវកាក់

giletier,ère *n.&a.* អ្នកដេរអាវកាក់។ *n.f.* ខ្សែនាឡិកាប៉ូង

gille *Fig.* មនុស្សកំប្លែង (ឧ. jouer les gilles)

gimbelette *n.m.* នំកង់

gin *n.m.* ហ្ស៊ីន, ស្រាមួយយ៉ាងធ្វើនៅប្រទេសអង់គ្លេស

gindre ឬ **geindre** *n.m.* ជាងលាយម្សៅនំប៉័ង

gingas *n.m.* សំពត់ក្រឡាបន្ទូក

gingembre *n.m.* ខ្ញី

gingival,e,aux *a.* នៃជើងធ្មេញ

gingivite *n.f.* រលាកធ្មេញ,ជម្ងឺរលាកជើងធ្មេញ

ginglard *n.m. Pop.* ស្រាយួរយ៉ាងមានរសជូរ

ginguer *v.i.* លោតកញ្ឆែង; កញ្ជ្រោល

ginguet,ette *a. Fam.* ជូរបន្តិចៗ។ *Fig.* ថោក (ឧ. robe ginguette)

ginseng *n.m.* គោស៊ីម (មើមម្យ៉ាងចិនប្រើជាថ្នាំ)

giorno (a) *adv.* [djor-] ភ្លឺដូចថ្ងៃ (ឧ. jardins éclairés "a giorno")

girafe *n.f.* ហ្សីរ៉ាហ្វ (ម្រឹគម្យ៉ាងមានជើងនិងកវែងៗ)

girondole *n.f.* ជើងទៀនមានខ្នែងច្រើន។ *Joaill.* រយ៉ា

giration *n.f.* ការវិលវង់

giratoire *a.* ជាវង់មូល (ឧ. les cyclones sont animés d'un mouvement giratoire)

girie *n.f. Fam.* មាយា

girl [gheurl] *n.f.* ស្រីរាំទង់; ស្រីរាំ

girofle *n m.* clou de girofle ផ្កាក្លាំពូ

girond,e *a. Pop.* ល្អ(រូបរាង) (ឧ. une fille gironde)

girouette *n.f.* ព្រួញចង្អុលទិសខ្យល់បក់។ *Fig.* ជនដែលផ្លាស់ចិត្តគំនិតញយ

gisant,e *a.* ដែលដេកស្តូកស្តឹង។ *n.m.* រូបចម្លាក់មនុស្សដេក(ម.ព. orant ផង)

gisement *n.m.* ស្រទាប់លោហជាតិក្នុងដី; ដុំលោហជាតិ

gîte *n.m.* លំនៅ (ឧ. rentrer à son gîte); ជម្រកទន្សាយ; ផ្ទាំងលោហជាតិក្នុងដី។ gîte minéral កំណប់រ៉ែ។ *Bouch.* gîte à la noix សាច់ភ្លៅគោ។ *n.f. Mar.* ការផ្អៀងនៃនាវា (ឧ. donner la gîte ផ្អៀង)

gîter *v.i.* នៅ, ដេក, ជ្រក, ពួន (ឧ. le lièvre gîte assez près des maisons)។ *Mar.* ផ្អៀង។ *v.t.* ឱ្យស្នាក់ (ឧ. gîter un voyageur)

givrage *n.m.* ទឹកកកតោង (សន្សើមកកលើស្លាបឬកង្ហារយន្តហោះ)

givre *n.m.* ឧស្សាវៈ, ទឹកកកតោង

givrer *v.t.* ឱ្យជាប់ទឹកកកតោង; រោយកំទេចកែវ (ធ្វើឱ្យដូចសន្សើមកក)

glabelle *n.f. Anat.* ប្រជុំចិញ្ចើម

glabre *a. Bot.* គ្មានរោម។ *Fig.* គ្មានពុកចង្កា (ឧ. menton glabre)

glaçage *n.m.* ការខាត់ឬជ្រលក់ឱ្យរលោង

glaçant,e *a.* ដែលខាត់ឲ្យរលោង (ឧ. vent glaçant); មិនរាក់ទាក់ (ឧ. accueil glaçant)

glace *n.f.* ទឹកកក (ឧ. la glace est plus légere que l'eau); *Fig.* ការមិនរាក់ទាក់ ។ être de glace គ្មានមេត្តា ។ rompre la glace ធ្វើឲ្យលែងអែងចិត្តគ្នា (ធ្វើឲ្យរាក់ទាក់) ។ ក្រេមកក (ឧ. glace au café); កញ្ចក់ (ឧ. briser les glaces d'une voiture; se regarder dans une glace) ។ *Com.* ប្រជ្រុយពេជ្រ ។ *Arg.* សាលា (តុលាការ) (ឧ. passer devant la glace ឡើងសាលា)

glacé,e *a.* ត្រជាក់ដូចទឹកកក, ត្រជាក់ណាស់ (ឧ. terre glacée; avoir les mains glacées); ភ្លឺរលោង (ឧ. gants glacés) ។ *Fig.* ឥតមេត្តា (ឧ. cœur glacé); មិនរាក់ទាក់, ស្ញៀក (ឧ. air glacé; accueil glacé)

glacer *v.t.* ធ្វើឲ្យកក (ឧ. glacer un crème); ត្រាំទឹកកក (ឧ. glacer du champagne); ធ្វើឲ្យរងាខ្លាំង (ឧ. le vent m'a glacé) ។ *Fig* ធ្វើឲ្យតាញ់រងា (ឧ. l'âge glace le sang); ធ្វើឲ្យអស់មានមេត្តា (ឧ. l'âge glace le cœur) ។ គម្រាម, ធ្វើឲ្យស្លុត (ឧ. son aspect me glace); ដិតស្ករ (ឧ. glacer des marrons); ខាត់ឬស្រលាក់ឲ្យរលោង (ឧ. glacer une étoffe)

glacerie *n.f.Ind.* សិល្បៈ ឬ កន្លែងធ្វើទឹកកក, សិល្បៈ ឬ កន្លែងធ្វើកញ្ចក់

glaceur *n.m.* អ្នកខាត់ឬស្រលាក់ឲ្យរលោង

glaceux,euse *a.* ដែលមានប្រជ្រុយ (ពេជ្រ)

glaciaire *a.* នៃទឹកកក; នៃគំនរទឹកកក ។ période glaciaire ប្រវត្តិកាលទឹកកក

glacial,e,als *a.* ត្រជាក់ស្រេង (ឧ. vent glacial) ។ *Fig.* abord glacial របៀបទទួលដោយមិនរាក់ទាក់

glacialement *adv.* ដោយមិនរាក់ទាក់

glaciation *n.f.* ការធ្វើឲ្យកក (ឧ. la glaciation de l'eau)

glacier *n.m.* គំនរទឹកកកលើភ្នំ; អ្នកលក់ទឹកកក; ជាងកញ្ចក់; អ្នកលក់កែវឬកញ្ចក់

glacière *n.f.* ទូទឹកកក; ម៉ាស៊ីនទឹកកក ។ *Fig.* កន្លែងត្រជាក់ណាស់

glaciologie *n.f.* វិទ្យាសាស្ត្រខាងទឹកកក

glaciologue *n.* អ្នកវិទ្យាសាស្ត្រខាងទឹកកក

glacis *n.m.* ទីជំរាល; ដីជំរាលបន្តិចៗ ។ *Peint.* ពណ៌ថ្លា (លាបលើពណ៌ស្ងួត)

glaçon *n.m.* ដុំទឹកកក។ *Fam.* មនុស្សមិនរាក់ទាក់

glaçure *n.f.* ថ្នាំពារ, ជ័រពារ

gladiateur *n.m.* អ្នកប្រយុទ្ធក្នុងនាដកីឡានាក្រុងរ៉ូម

glaire *n.f.* រំអិល, សំបោរ, ស្លេស្ម; ជាតិសនៃស៊ុតឆៅ

glaireux,euse *a.* ដែលមានលក្ខណៈជារំអិល ជាសំបោរឬជាស្លេស្ម(ឧ.liquide glaireux)

glaise *n.f.* ដីឥដ្ឋ ។ *a.* terre glaise ដីឥដ្ឋ

glaiser *v.t.* លាប ឬ ប្លុកដីឥដ្ឋ (ឧ.glaiser un bassin); ដាក់ដីដីឥដ្ឋ (ឧ. glaiser un champ)

glaiseux,euse *a.* ជាដីឥដ្ឋ (ឧ. sol glaiseux)

glaisière *n.f.* កន្លែងយកដីឥដ្ឋ

glaive *n.m.* ដាវមុខ ។ *Fig.* ចំបាំង ។ tirer le glaive ហូតដាវ; ប្រកាសសង្គ្រាម;ច្បាំង។ *Fig.* អំណាចលើជីវិត (អាចសម្លាប់បាន)(ឧ.le glaive des lois)។ le glaive de la justice អំណាចនៃយុត្តិធម៌

glanage *n.m.* ការរើស ក ធូរ (ធូរស្រូវដែលជ្រុះ)

glande *n.f.* ក្រន្ថិ [ក្រាន់-ថិ] (រោគារៈឡើងៗ ក្នុងខ្លួនដែលបញ្ចេញរំការាត់, ញើស។ល។)។ glande digestive ក្រន្ថិជីរណ៌ក [-ជី រ-ណ៌ក] ។ glande gastrique ក្រន្ថិក្រពះ ។ glande intestinale ក្រន្ថិពោះវៀន ។ glande lacrymale អស្សុក្រន្ថិ [អ័ស-សុ-]។glande maxilaire ក្រន្ថិហនុក ។ glande à mucus ក្រន្ថិសំបោរ ។ glande parotide ក្រន្ថិឧបកណ្ណ។ glande salivaire ក្រន្ថិខេឡក ។ glande sébacée ស្លាក្រន្ថិ ។ glande sudoripare សេទក្រន្ថិ ។ កូនកណ្ដុរ

glandulaire ឬ **glanduleux,euse** *a.* ដូចក្រន្ថិ (ឧ. corps glandulaire)

glandule *n.f.* អនុក្រន្ថិ

glane *n.f.* កធូរ, ធូរស្រូវដែលរើសបាន

glanement *n.m.* ការរើស ក ធូរ

glaner *v.t.* រើស ក ធូរ។ *Fig.* សង្រេសង្រៃ, ប្រមែប្រមូល(ឧ.glaner des

anecdotes)

glaneur,euse *n.* អ្នករើស ក គួរ

glanure *n.f.* ផលរើសកគួរ

glapir *v.i.* យំ (កញ្ជ្រោង, កូនឆ្កែ) ។ *Par ext.* ស្រែកឆ្អូក។ *v.t.* glapir des injures ស្រែកជេរ

glapissant,e *a.* ដែលយំ (កញ្ជ្រោង, កូនឆ្កែ);ឆ្អូក(ឧ.voix glapissante)

glapissement *n.m.* សម្រែកកញ្ជ្រោង ឬ កូនឆ្កែ ។ *Par ext.* ការស្រែកឆ្អូក

glas *n.m.* សូរជួងប្រាប់មរណភាពនៃអ្នកឯណាមួយ (ឧ. le glas funèbre)

glauque *a.* ស្មើរខៀវស្មើរបៃតង (ឧ. mer glauque)

glèbe *n.f.* រកបំបំពេញ; ដីដាំដំណាំ

glène *n.f.* បង្ហាយខ្សែ

gléner *v.t.Mar.* ធ្លាយខ្សែ

gleucomètre *n.m.* ម.ព. glycomètre

glissade *n.f.* ការរអិល, កន្លែងក្មេងរអិលខ្លួនលេង

glissage *n.m.* ការទម្លាក់ដោយរអិល

glissant,e *a.* រអិល (ឧ. la pluie rend le sol glissant) ។ *Fig.* terrain, sentier glissant ឬ pente glissante រឿងពិបាក

glissement *n.m.* ដំណើររអិល, ដំណើររបូត (ដែក)

glisser *v.i.* រអិល (ឧ. l'échelle a glissé; le cygne glisse sur l'eau);រអិល(ឧ.savoir glisser)។ *Fig.* និយាយសើរ; ផ្លាត (ឧ. le coup de poignard glissa sur la cuisse)។ glisser des mains របូតពីដៃ ។

v.t. លួក (ឧ. glisser sa main dans la poche de son voisin); ស៊ក, សៀត (ឧ. glisser un papier sous la porte)។ *Fig.* បញ្ចូល (ឧ. glisser une clause dans un contrat); ខ្សឹប (ឧ. glisser un secret à l'oreille de quelqu'un) ។

se glisser *v.pr.* លួចចូល (ចូលដោយប្រយ័ត្ន)

glisseur,euse *n.* អ្នករអិលលើទឹកកក

glissière *n.f.* ចង្អូររអិល;ឡើង

glissoire *n.f.* កន្លែងក្មេងរអិលលេង; ផ្លូវរអិល(សម្រាប់ទម្លាក់ឈើពីលើភ្នំ)

globaire *a.* ដែលធ្វើដោយគោលីក

global, e, aux *a.* ដែលរួបរួមជាដុំ; សរុប,ទាំងអស់(ឧ.somme globale)

globalement *adv.* ដោយសរុប, ទាំងអស់

globe *n.m.* គោល, ដុំមូល។ globe de l'œil ទេត្រគោល ។ le globe terrestre|notre globe ភូគោល, ផែនដី ។ គ្រាប់កែវកងមូល

globe-trotter [-teur] *n.m.* អ្នកធ្វើដំណើរជុំវិញពិភពលោក (*pl.* des globe-trotters)

globulaire *a.* ដែលមានសណ្ឋានជាដុំមូល ។ *Méd.* numération globulaire ការរាប់គោលិកាឈាម (ម.ព. globule ផង)

globule *n.m.* គោលិកា, ដុំតូចមូល ។ globule sanguin គោលិកាឈាម ។ globule blanc គោលិកាស។ globule rouge គោលិកាក្រហម ។ *Pharm.* ឱសថគោលិកា

globuleux,euse *a.* ដែលផ្សំដោយគោលិកា; ដែលមានសណ្ឋានជាគោលិកា។ œil globuleux ភ្នែកលៀន

globuliforme *a.* ជារាងគោលិកា

gloire *n.f.* កិត្តិគុណ, ភាពរុងរឿង (ឧ. gloire littéraire; la gloire du siècle de Louis XIV) ។ *Peint.* ពន្លឺរស្មី ។ បរមសុខ (ឧ. gloire éternelle) ។ se faire gloire de យកមកអួត។ travailler pour la gloire ធ្វើការដើម្បីកិត្តិគុណ (គ្មានប្រាថ្នាគុណប្រយោជន៍)

glorieusement *adv.* ដោយកិត្តិគុណ; យ៉ាងរុងរឿង

glorieux,euse *a.* ប្រកបដោយកិត្តិគុណ (ឧ. de glorieux soldats; victoire glorieuse)។ *n.* មនុស្សអំនួត (ឧ les glorieux se font haïr)

glorificateur,trice *n.* អ្នកធ្វើឧក្កសនា, អ្នកលើកដំកើង

glorification *n.f.* ឧក្កសនា (អ៊ុក-ក័ង-សៈ នា), ការលើកដំកើង; ការធ្វើឲ្យមានកិត្តិគុណ

glorifier *v.t.* ធ្វើឧក្កសនា, លើកដំកើង; ធ្វើឲ្យមានកិត្តិគុណ (ឧ. glorifier ceux qui sont morts pour la patrie)។ **se glorifier** *v.pr.* លើកខ្លួន, អួតខ្លួន (ឧ. se glorifier de ses richesses)

gloriole *n.f.* ភាពឡូត

glose *n.f.* អត្ថ(សេចក្ដីពន្យល់ពាក្យប្រែស្រាយ) ។ *Fam.* ការរិះគន់ (ឧ les gloses des commères)

gloser *v.i.* អត្ថាធិប្បាយ (ឧ.gloser sur les lois)។ *v.t.* រិះគន់ (ឧ.gloser

un auteur)

glossaire *n.m.* អក្ខរានុក្រមនៃពាក្យពុំសូវប្រើ

glossateur *n.m.* អ្នកតែងអត្ថ (សេចក្ដីពន្យល់, ពាក្យប្រែស្រាយ)

glossite *n.f.* គ្រុំងអណ្ដាត

glosso-pharyngien,enne *a.* នៃជិវ្ហាគ្រសនី (អណ្ដាតនឹងក្រអឺត) (ឧ. nerf glosso-pharyngien)

glossotomie *n.f.* ការកាត់អណ្ដាត

glouglou *n.m.Fam.* សូរឃ្លុកៗ (សូរក្រាប់ទឹកហូរចេញពីដប) ; សម្រែកមាន់បារាំង

glouglouter *v.i.* ស្រែក (មាន់បារាំង)

gloussant,e *a.* ដែលធ្វើក្រុកៗ

gloussement *n.m.* សម្រែកមេមាន់ហៅកូន (ធ្វើក្រុកៗ)

glousser *v.i.* ធ្វើក្រុកៗ(មេមាន់ហៅកូន)។ *Fam.* សើចតិចៗ

glouton,onne *a.&n.* អ្នកល្មោភស៊ី, អ្នកស៊ីច្រើនហើយឡេវឡាវ (ឧ. enfant glouton)

gloutonnement *adv.* ដោយឡេវឡាវ (ឧ.manger gloutonnement)

gloutonnerie *n.f.* ការស៊ីច្រើនហើយឡេវឡាវ

glu *n.f.* ជ័រជាម (សម្រាប់ដាក់ឲ្យជាប់សត្វ)។ *Fig.* អ្វីៗជាការប្រលោមឬជាគ្រឿងទាក់ចិត្ត (ឧ. le plaisir est une glu)

gluant,e *a.* ស្អិត(ដូចជ័រជាម) (ឧ. liquide gluant); អន្ទាយ។ *Fig.* ស្អិតស្អាញ,។ riz gluant អង្ករដំណើប, បាយដំណើប

gluau *n.m.* មែកលាបជ័រជាម (ដើម្បីឲ្យជាប់សត្វ)

glucomètre *n.m.* មធុរមាត្រ (ពី. gleucomètre, glycomètre ឬ pèse-moût)

glucose ឬ **glycose** *n.f.* មធុរជាតិ

glucoserie *n.f.* កន្លែងធ្វើមធុរជាតិ

gluer *v.t.* លាបជ័រជាម;ធ្វើឲ្យប្រឡាក់ស្អិត (ឧ.les confitures gluent les mains)។ *v.i.* ជាប់ស្អិត (ដូចជ័រ)

gluten *n.m.* [-tèn] ស្និទ្ធជាតិ, ជាតិស្អិតនៃម្សៅ

glutinatif,ive *a.* ម.ព.agglutinatif

glutineux,euse *a.* ដូចស្និទ្ធជាតិ; ដែលមានស្និទ្ធជាតិ;ស្អិត,ល្អិត

glutinosité *n.f.* ភាពស្អិត ឬ ល្អិត

glycéré ឬ **glycérat** ឬ **glycérolé** *n.m.* ឱសថជាតិគ្លីសេរីន

glycérine *n.f.* គ្លីសេរីន (វត្ថុរាវដែលគេចម្រាញ់ចេញពីជាតិខ្លាញ់) –

glycériner *v.t.* លាបគ្លីសេរីន

glycérol *n.m.* ដដ. នៃ glycérine

glycérolé *n.m.* ម.ព. glycéré

glycomètre *n.m.* ម.ព. glucomètre

glyphe *n.m.* ចម្លាក់ខ្វង

glypte *n.f.* សិល្បៈឆ្លាក់ថ្ម

G.M.T. (Greenwich mean time= heure moyenne de Greenwich) ឬ **T.U.** (Temps Universel) ម៉ោងមធ្យមនៃគ្រីនវិច ឬ ម៉ោងសាកល

gnaf ឬ **gniaf** *n.m.Pop.* អ្នកជួសជុលស្បែកជើង

gnangnan *n.&a.inv.Fam.* ញ៉ែងញ៉ង

gneiss *n.m.* ញែស (ថ្មមានសណ្ឋានជាសន្លឹក)

gnognote *n.f.* *Pop.* របស់ឥតតម្លៃ (ឧ. c'est une gnognote)

gnole, gniole, gnôle, gnaule ឬ **niaule** *n.f.Arg.* ស្រា(អូឌីវី) ។ *a.* *Fam.* កញ្ចាត

gnome *n.m.* បង់បត់ក្រកំណប់ ។ *Fam.* មនុស្សកន្ទៀ

gnomide *n.m.* យាយទេពរក្សាកំណប់

gnomique *a.* ដែលមានសុភាសិត (ឧ. poésie gnomique)

gnomon *n.m.* នាឡិកាព្រះអាទិត្យ (ប្រដាប់សំគាល់ម៉ោងដោយស្រមោល)

gnomonique *n.f.* របៀបសំគាល់ម៉ោងដោយស្រមោល ។ *a.* នៃការសំគាល់ម៉ោងដោយស្រមោល

go (tout de) *loc.adv.* *Pop.* ត្រង់ៗ, ភ្លាមៗ (ឧ. aborder une question tout de go)

goal [gol] *n.m.* ទី (ពីឡូជាល់ទាត់)។ *Par ext.* អ្នកចាំទី

goal-average *n.m.* *Football* ចំនួនទីដែលចាញ់ ឬ ឈ្នះ

gobbe ឬ **gobe** *n.f.* ដុំចំណីតូចៗសម្រាប់បំប៉នសត្វស្លាបឬបំពុលសត្វចង្រៃ

gobelet *n.m.* កែវសម្រាប់ផឹក; កំប៉ុងសម្រាប់លេងប៉ិនប្រែក

gobeletterie *n.f.* ការធ្វើ ឬ ជំនួញកែវ

gobeletier *n.* & *a.m.* អ្នកធ្វើកែវ; ឈ្មួញកែវ

gobelin *n.m.* ប្រេញតង្វាល, បិសាច

gobelotter ឬ **gobeloter** *v.i.Fam.* ផឹកផឹបៗ ; ផឹកស៊ីជប់លៀង

gobe-mouches *n.m.* *inv.* ចាបណ-

ការហាបញ្ចូលមួយយ៉ាង ។ *Fig.* មនុស្សកញ្ជោត

gober *v.i.* គ្រលេវលេប (លេបដោយឥតទំពា) (ឧ. gober une huître)។ *Fig.* ជឿដោយឥតពិចារណា (ឧ. le gogo gobe tout) ។ *Pop.* ស្រឡាញ់, ចាប់អារម្មណ៍

goberger (se) *v.pr.* លេង ។ *Fam.* លេងសប្បាយ (ឧ. ils se gobergent en ville depuis trois jours); ប្រកាន់ឥរិយាបថស្រួល (ឧ. se goberger dans un fauteuil អង្គុយយ៉ាងស្រួលលើកៅអីក្ដារដៃ); ស៊ីផឹក

gobeur,euse *n.* អ្នកគ្រលេវលេប (អ្នកលេបដោយឥតទំពា)។ *Fig.&Fam.* មនុស្សកញ្ជោត

gobichonner *v.i.Fam.* ផប់ស្មៀង

godage *n.m.* សាច់ជ្រួញ(សំពត់,ក្រដាស)

godailler *v.i.Fam.* ស៊ីផឹកហួសហេតុ

godan ឬ **godant** *n.m.* រឿងព្រេង; ការបោក ។ donner dans le godan ជាប់បោក

godasse *n.f. Pop.* ស្បែកជើង

godelureau *n.m.Fam.* កម្លោះនាក់ពួល បិត្តចង់ស្រី

goder *v.i.* ជ្រួញ(ឧ.robe qui gode; le papier qui gode)

godet *n.m.* ពែងចក;បំពង់; ក្បាលខ្សៀ; សាច់ជ្រួញ (ក្រដាស, សំពត់)

godiche *n.&a.Fam.* ល្ងើ;ឆ្គង;កញ្ជោត

godichon,onne *n. & a. Fam.* កញ្ជោត; ឆ្គង

godille *n.f.* ចែវចាក់ពីកន្សៃទូក

godiller *v.i.* ចែវទូកពីកន្សៃ

godilleur *n.m.* អ្នកចែវទូកពីកន្សៃ

godron *n.m.* ក្បាច់ចកគងក្រពើ(ក្បាច់រាងមូលទ្រវែង)

godronnage *n.m.* ការធ្វើក្បាច់ចកគងក្រពើ (ឧ. godronnage de la vaisselle)

godronner *v.t.* ធ្វើក្បាច់ចកគងក្រពើ; លំអដោយក្បាច់ចកគងក្រពើ

goéland *n.m.* វិហកសមុទ្រ (មានធំ)

goélette *n.f.* ត្រចៀកកាំសមុទ្រ; ទូកម៉្យាងជងក្ដោងពីរ(ឧ. les goélettes sont des navires rapides)

goémon *n.m.* សារាយសមុទ្រ

goétie *n.f.* មន្តអាបខ្មោច

gogaille *n.f.* ការបរិភោគកាយដោយរីករាយ

gogo *n.m.* មនុស្សងាយបញ្ឆោត

gogo (à) *loc.adv. Fam.* ដោយបរិបូណ៌ (ឧ. avoir tout à gogo)

goguenard,e *a.&n.* ដែលចំអក (ឧ. ton goguenard)

goguenarder *v.i.* ចំអក; និយាយឡក

goguenardise *n.f.* ពាក្យចំអក

goguenot ឬ **gogueneau** *n.m.Pop.* កន្ត្រា ។ *Par ext.* បង្គន់

goguette *n.f.Fam.* ការនិយាយសើចលេង; ការឆប់ច្រៀងយ៉ាងសប្បាយ ។ être en goguette សប្បាយដោយបានផឹកស្រាខ្លះ

goinfre *n.m.* មនុស្សល្មោភហើយស្មោកគ្រោក

goinfrer *v.i.Fam.* ស៊ីឡើបឡប់ហើយដោយស្មោកគ្រោក

goinfrerie *n.f.* ការស៊ីឡើបឡប់ហើយដោយស្មោកគ្រោក

goitre *n.m.Méd.* ពកក

goitreux,euse *a.* នៃរោគពកក។ *n.* មនុស្សពកក

golf *n.m.* ហ្គូលហ្វ៍,កីឡាបោះជាល់ចូលរន្ធ

golfe *n.m.* ឈូងសមុទ្រ (ឧ. Golfe du Siam)

gommage *n.m.* ការលាបជ័រ (ឧ. le gommage des étoffes); ការលុបដោយជ័រលុប

gomme *n.f.* ជ័រ ។ gomme élastique ឬ gomme à effacer ជ័រលុប ។ gomme laque ឬ.ក. laque ។ *Pop.* ក្រុមអ្នកលេងខ្លួនជម្ញើយ ។ *Arg.* mettre la gomme បង្កើនដំណើរ

gomme-gutte *n.f.* រង្គ(ជ័រមានសម្បុរលឿងប្រើជាថ្នាំគំនូរឬជាថ្នាំបញ្ចុះ) (*pl.* des gommes-guttes)

gommer *v.t.* លាបជ័រ (ឧ. gommer une étiquette); លុប(ដោយជ័រលុប) (ឧ. gommer un trait de crayon)

gommeux,euse *a.* ដែលជាជ័រ (ឧ. suc gommeux); ដែលឲ្យជ័រ (ឧ. arbre gommeux) ។ *n. Pop.* មនុស្សលេងខ្លួនដោយជម្ញើយ

gommier *n.m.* ដើមឈើមានជ័រ

gommifère *a.* ដែលឲ្យជ័រ

gond *n.m.* ត្រចៀកទ្វារ ។ *Fig. & Fam.* sortir de ses gonds ខឹងច្រឡោត

gondolage ឬ **gondolement** *n.m.* ដំណើរពោរ (ដំណើរប៉ោង ឬ ង) (ឧ. le gondolage du bois est

un effet de l'humidité)

gondole *n.f.* ទូកម្យ៉ាងប្រើនៅស្រុកវ៉ឺនីស

gondoler *v.i.* ពោរ;មានសណ្ឋានង(ដូចទូកង); ពង, ប៉ោង (ឧ. certains vernis gondolent)។ se gondoler *v.pr.* ពោរ, ឡើងង (ឧ. planche qui se gondole)។ *Fam.* សើចរមួលខ្លួន

gondolier *n.m.* អ្នកអុំទូក (នៅស្រុកវ៉ឺនីស)(ឧ. le gondolier venitien)

gonfalon ឬ **gonfanon** *n.m.* ទង់ចម្បាំង

gonfalonnier ឬ **gonfanonier** *n.m.* អ្នកកាន់ទង់ចម្បាំង

gonflage *n.m.* ការបំប៉ោង

gonflé,e *a.* ប៉ោង(ឧ.gonflé d'air); ពុះពោរ (ឧ. cœur gonflé de chagrin)។ *Pop.* ក្លាហាន, អង់អាច

gonflement *n.m.* ការបំប៉ោង; ភាពប៉ោងឬហើម

gonfler *v.t.* បំប៉ោង (ឧ. gonfler un ballon);ធ្វើឲ្យឡើងធំ(ឧ. la pluie gonfle les torrents)។ *Fig.* gonfler d'orgueil ធ្វើឲ្យឡើងឫក។ *v.i.* ប៉ោង, រីក (ឧ. le bois gonfle à l'humidité)។ **se gonfler** *v.pr.* ហើម, ឡើងប៉ោង។ *Fig.* ឡើងក្រអឺតក្រអោង

gonfleur *n.m.* ប្រដាប់សប់បំប៉ោង

gong *n.m.* គង, ឃ្មោះ; សញ្ញាឲ្យផ្អាកការប្រដាល់

gonin *n.m.* អ្នកឆបោកប៉ិនប្រសប់

goniomètre *n.m.* កោណមាត្រ

goniométrie *n.f.* កោណមាត្រវិធី

gonne *n.f.* ធុងស្រា; ធុងដ៏រប្រ៉េក្យណ៍

gonocoque *n.m.* មេរោគប្រមេះ

gordien, enne *a.* nœud gordien ចំណងភ្ជ័រឌីយ៉ុស; *au fig.* ឧបសគ្គពុំអាចពុះពារបាន។ trancher le nœud gordien ដោះស្រាយដោយកម្លាំងបាយ

goret *n.m.* ជ្រូកជំទង់។ *Fam.* មនុស្សស្មោកគ្រោក។ *Mar.* អំបោសរឹង

gorge *n.f.* បំពង់ក (ឧ. mal de gorge)។ *Loc div.* couper la gorge de quelqu'un អារក; សម្លាប់; *au fig.* បំផ្លាញ។ se couper la gorge អារកគ្នាឬសម្លាប់គ្នាទៅវិញទៅមក។ serrer quelqu'un à la gorge ច្របាច់ក; *au fig.* បង្ខំឲ្យធ្វើអ្វីមួយ។ tendre la gorge ហុច

កន្សៀ (គោរ); *au fig.* គ្មានគស្ញ ។ rire ឬ crier à gorge déployée ឬ à pleine gorge សើចឬស្រែកតឹងបំពង់ក (យ៉ាងខ្លាំង) ។ faire des gorges chaudes ចំអកចំពោះមុខ ។ faire rentrer à quelqu'un les paroles dans la gorge បង្ខំឲ្យបដិសេធសំដីខ្លួនដោះ ។ rendre gorge ក្អួត (ដោយស៊ីឬផឹកច្រើនពេក) ; *au fig.* សង (របស់អ្វីដែលយកដោយខុសច្បាប់) ។

Géogr. ច្រកភ្នំ ។ *Méc.* gorge d'une poulie ចង្អូររ៉ក

gorge-de-pigeon *a. inv. & n.m.* ពណ៌កទា (ពណ៌ដែលមានពន្លឺរលកដូចកទា)

gorgée *n.f.* ក្អឹក, ក្រេប (ចំនួនទឹកមួយលេប)(ឧ. une gorgée de vin)

gorger *v.t.* បំប៉នចំណី (ឧ. on gorge les volailles pour les engraisser) ។ *Fig.* បំពេញឲ្យយ៉ាងហូរហៀរ (ឧ. gorger de biens)

gorgerette *n.f.* ស្រង ក

gorgerin *n.m.* ក្រោះការពារក

gorget *n.m.* ដែកឈូសលកវង់ក្របក

gorille *n.m.* ស្វាម្យ៉ាងមានខធំនៅទ្វីបអាហ្វ្រិក

gosier *n.m.* ដើមក ។ chanter à plein gosier ច្រៀងអស់សម្លេង

gosse *n.m. Fam.* ក្មេង (ប្រុសឬស្រី)

gothique *a.* ហ្គោទិក ។ *Fam.* បូរាណ, ចាស់ហួសសម័យ (ឧ. habit gothique) ។ *n.f.* អក្សរជ្រុង

gouache *n.f.* ថ្នាំគំនូរលាយទឹក; គំនូរដោយថ្នាំលាយទឹក

gouacher *v.t.* ផាត់ពណ៌ដោយថ្នាំលាយទឹក

gouaille *n.f.* ការនិយាយចំអក

gouailler *v.t.&i. Fam.* និយាយចំអក; និយាយលេង

gouaillerie *n.f. Fam.* ពាក្យចំអក; ពាក្យនិយាយលេង

gouailleur, euse *a. Fam.* ដែលនិយាយចំអក; ដែលនិយាយលេង (ឧ. ton gouailleur)

gouape *n.f. Pop.* មនុស្សកម្ជិល, មនុស្សព្រែលព្រួល

gouaper *v.i.* ធ្វើព្រែលព្រួល, មិនធ្វើការអ្វី

gouapeur, euse *n.* មនុស្សព្រែលព្រួល

goudron *n.m.* ជ័រប្រេងកាត; កៅស៊ូក្រាលថ្នល់

goudronnage *n.m.* ការលាបជ័រប្រេងកាត; ការចាក់កៅស៊ូថ្នល់

goudronner *v.t.* លាបជ័រប្រេងកាត(ឧ. goudronner une route); ចាក់កៅស៊ូថ្នល់

goudronneur *n.m.* ជាងលាបជ័រប្រេងកាត

goudronneux,euse *a.* ដូចជ័រប្រេងកាត។ *n.f.* ម៉ាស៊ីនលាបជ័រប្រេងកាត

gouet *n.m.* កាំបិតកាត់មែកឈើមួយយ៉ាង

gouffre *n.m.* អន្លង់ជ្រៅ, ជ្រោះ (ឧ. tomber dans un gouffre); ទឹកក្ដួច។ *Fig.* ហេតុនៃការអន្តរាយ(ឧ. le gouffre du jeu)។ un gouffre d'argent អ្នកចាយខ្ជះខ្ជាយ

gouge *n.f.* ពន្លាកវែងក្រចក

goujat *n.m.* កូនជាងកំបោរ;មនុស្សឆ្គងឆ្គង

goujaterie *n.f.* អំពើឆ្គងឆ្គង

goujon *n.m.* ត្រីតូចម្យ៉ាង

goujon *n.m.* *Techn.* ដែកកន្លាស់

goujonner *v.t.* ភ្ជាប់ដោយដែកកន្លាស់

goujonnier *n.m.* សំណាញ់ក្រឡាញឹក

goulée *n.f.* *Fam.* ម៉ាត់ធំ (ចំនួនល្មមនឹងមាត់)។ *Prov.* brebis qui bêle perd sa goulée អ្នកនិយាយច្រើនខាតពេល (សុភាសិតខ្មែរមានន័យថា និយាយច្រើនគេពុំស្ដាប់អញ្ជ្រាញ)

goulot *n.m.* *Mar.* ច្រកចូលកំពង់ផែ។ *Géogr.* ច្រកភ្នំ។ *Pêch.* ប្រឹសទ្រូ

goulot *n.m.*ក(ដប, ថូ) (ឧ. le goulot d'une carafe)

goulotte ឬ **goulette** *n.f.* ចង្អូរទឹក

goulu,e *a.&n.* អ្នកស៊ីច្រើនហើយរឡេះរឡប់

goulûment *adv.* ដោយល្មោភហើយរឡេះរឡប់

goupil *n.m.* កញ្ជ្រោង

goupille *n.f.* កន្លាស់ខ្ទាស់គ្រឿងម៉ាស៊ីន

goupiller *v.t.* ខ្ទាស់ដោយដែកកន្លាស់តូច។ *Fig.* & *Pop.* រៀបចំ

goupillon *n.m.* ប្រដាប់ស្រោចទឹក (ប្រើក្នុងវិហារកាតូលិក); ច្រាសកន្ទុយកំប្រុក

goupillonner *v.t.* ជម្រះដោយច្រាសកន្ទុយកំប្រុក

gourd,e *a.* ស្រពន់ (ដោយត្រជាក់)។ *n.&a.f.* *Fam.* ភ្លើ (ឧ. elle a l'air gourd)

gourde *n.f.* ឃ្លោក;នបរាងដូចផ្លែឃ្លោក។ *Fig.* មនុស្សល្ងីល្ងើ

gourdin *n.m.* ព្រនង់

goure *n.f.* ឧសថក្លែងក្លាយ

gourer *v.t.* ក្លែងក្លាយឧសថ។ *Fig. & Pop.* se gourer ច្រឡំ

gourgandine *n.f.Fam.* ស្រីថោក

gourmade *n.f.* ការដាល់; ការដាល់ត្រូវមុខ(ឧ.recevoir une gourmade)

gourmand,e *n.&a.* ដែលល្មោភស៊ី។ *Bot.* branche gourmande ឬ gourmand *n.m.* មែកឥតប្រយោជន៍ (មែកក្រោមមែកសាក)

gourmander *v.t.* ស្តីបន្ទោសខ្លាំង (ឧ. gourmander un écolier paresseux)

gourmandise *n.f.* សេចក្តីល្មោភស៊ី; ចំណីឆ្ងាញ់ (ឧ.offrir des gourmandises)

gourme *n.f.Méd.* រោគស្បែកម្យ៉ាង ។ *Vétér.* រោគហៀរសម្បោរនៃសេះជំទង់ ។ *Fig. &Fam.* jeter sa gourme ប្រព្រឹត្តផ្តេសផ្តាសតាំងពីក្មេង

gourmé,e *a. Fig.* រឹងឆ្អយ; ក្រអឺត(ឧ. prendre des airs gourmés)

gourmer *v.t. Fam.* ដាល់ ។ *Fig.* បន្ទោស(ឧ. je cherche la fréquentation de ceux qui me gourment) ។ se gourmer *v.pr.* ប្រដាល់គ្នា ។ *Fig.* ធ្វើឆ្អឹង; ធ្វើឫកក្រអឺត

gourmet *n.m.* អ្នកស្គាល់ម្ហូបឆ្ងាញ់; អ្នកភ្លក្ស (ឧ.un fin gourmet)

gourmette *n.f.* ខ្សែច្រវាក់ (គ្រឿងបង្ហៀរសេះ); ខ្សែតាឡីកាសំប៉ែត

gournable *n.f.* កន្លាស់ឈើសម្រាប់ស្នង

gournabler *v.t.* ស្នងដោយឈើកន្លាស់ (ឧ. gournabler des bordages)

gouspin ឬ **goussepain** *n.m. Pop.* ក្មេងបំបង់កាយ

gouspiner *v.i. Pop.* បំបង់កាយ

gousse *n.f. Bot.* ផ្លែ (ផ្លែសាកជាតិ) (ឧ. gousse de pois ផ្លែសណ្តែកដាក់); កំពឹស (ឧ. gousse d'ail កំពឹសខ្ទឹមស) ។ *Pêch.* gousses de plomb សំណដឹងមង

goussepain *n.m.* ម.ព. gouspin

gousset *n.m.* ក្លៀក; ហោប៉ៅតូចនៃខោ អាវ ។ avoir le gousset vide ហោប៉ៅទទេ(គ្មានប្រាក់)

goût *n.m.* ជិវ្ហាវិញ្ញាណ (ឧ. la langue et le palais sont le siège du goût) ; រស, រសជាតិ (ឧ. mets d'un goût exquis) ។ *Pop.* ក្លិន(ឧ. goût de pourri);

ចំណង់ (ឧ. n'avoir goût à rien)។ *Fig.* ការស្គាល់របស់ល្អ (ឧ. avoir le goût sûr); ការចូលចិត្ត (ឧ. goût pour la peinture); ភាពសមសួន (ឧ. être mis avec goût ស្លៀកពាក់ដោយសមសួន); របៀប (ឧ. dans le goût du XVIII e siècle)។

Loc.div. de haut goût ប្រៃពេក, ហឹរពេក; *au fig.* ខ្លាំងពេក។ hommes, gens de goût ឬ de bon goût អ្នកស្គាល់របស់ល្អ។ être au goût ឬ du goût de quelqu'un ត្រូវចិត្ត ឬ ពេញចិត្តអ្នកណាមួយ។ prendre goût à quelque chose កាន់តែចូលចិត្តរបស់អ្វីមួយ។ mettre quelqu'un en goût ញុំាងឲ្យចង់ (ចង់បាន ឬ ចង់ធ្វើ)។

Pop. avoir perdu le goût du pain ស្លាប់។ faire passer le goût du pain à quelqu'un សម្លាប់។

Prov. morceau avalé n'a plus de goût ចំណីដែលលេបផុតហើយ លែងមានរសជាតិ; ផលកម្មដែលយើងសោយហើយ(ទោះជាសុខក្តីទុក្ខក្តី) យើងលែងទទួលអារម្មណ៍ជាសុខឬជាទុក្ខទៀតហើយ។ des goûts et des couleurs il ne faut pas disputer បួសដោយវត្ត ចិត្តដោយខ្លួន។ tous les goûts sont dans la nature កុំគប្បីប្រកាន់បើគេចូលចិត្តខុសពីយើង (ចំពោះអ្នកដែលចូលចិត្តរបស់ខុសគេ)។ le coût en fait perdre le goût របស់ដែលថ្លៃពេក គេលែងចង់ទិញ

goûter *v.t.* ភ្លក្ស (ឧ. le cuisinier goûte les mets)។ *Fig.* ចូលចិត្ត (ឧ. goûter la musique); យល់ស្របតាម (ឧ. goûter un projet); ក្រេបរសជាតិ(ឧ. goûter le bonheur)។ *v.i.* (de ឬ à) ភ្លក្សសាកមើល (ឧ. goûter d'un mets)។ *Fig.* សាក, ល្បង (ឧ. goûter d'un métier)។ *Absol.* ស្រស់ស្រូបពេលរសៀល(ឧ.donner à goûter aux enfants)

goûter *n.m.* ការស្រស់ស្រូបពេលរសៀល

goutte *n.f.* ពិន្ទុ, ដំណក់ (ឧ. goutte de pluie); ចំនួនតិចតួច (ឧ. boire une goutte de vin)។ *Fam.*

ក្លនកែងស្រា(ឧ.boire la goutte)។

Adv. ne... goutte គ្មាន... បន្តិចសោះ (ឧ. ne voir goutte មិនឃើញបន្តិចសោះ; n'entendre goutte មិនយល់បន្តិចសោះ) ។ goutte à goutte *loc. adv.* មួយតំណក់ម្ដងៗ, តក់ៗ ។

Prov. goutte à goutte l'eau use la pierre ទឹកស្រក់តក់ៗរាបធ្វើឲ្យសឹកថ្មបាន; សេចក្ដីព្យាយាមជាកម្លាំងធំ

goutte *n.f.* ប្រគ្រីវ

gouttelette *n.f.* តំណក់តូច

goutter *v.i.* បន្តក់,ធ្វើឲ្យស្រក់ជាតំណក់ (ឧ. les feuilles des arbres gouttent après la pluie)

goutteux, euse *a.&n.* ដែលកើតប្រគ្រីវ; នៃរោគប្រគ្រីវ

gouttière *n.f.* ទឹ; តំបូល

gouvernail *n.m.* ចង្កូត (ទូក, យន្តហោះ) ។ gouvernail de direction, gouvernail de profondeur ចង្កូតកន្ទុយយន្តហោះ ។ *Fig.* ការគ្រប់គ្រង (ឧ. tenir le gouvernail de l'État) ។ tenir le gouvernail កាន់ចង្កូត; គ្រប់គ្រង

gouvernant,e *a.* ដែលគ្រប់គ្រង ឬរាភិបាល (ឧ. le parti gouvernant) ។ *n.f.* ភរិយារេសាភិបាល; ស្ត្រីអ្នកទទួលថែទាំនឹងអប់រំក្មេង; ស្ត្រីអ្នកថែទាំផ្ទះ។*n.m.pl.*អ្នកគ្រប់គ្រងរដ្ឋ

gouverne *n.f.* គតិ; ក្បួនចរិយា (ឧ. je vous dis cela pour votre gouverne) ។ *pl.* គ្រឿងចង្កូតយន្តហោះ

gouvernement *n.m.* រដ្ឋាភិបាល; ក្រុមអ្នកគ្រប់គ្រងរដ្ឋ ។ gouvernement royal ព្រះរាជរដ្ឋាភិបាល ។ gouvernement général អគ្គរដ្ឋាភិបាល ។ gouvernement du salut public រដ្ឋាភិបាលរំដោះទុក្ខភ័យសាធារណជន

gouvernemental,e,aux *a.* នៃរដ្ឋាភិបាល(ឧ. système gouvernemental); ដែលគាំទ្ររដ្ឋាភិបាល (ឧ.député gouvernemental)

gouvernementalisme *n.m.* រដ្ឋាភិបាលនិយម

gouvernementaliste *n.* អ្នករដ្ឋាភិបាលនិយម

gouverner *v.t.* ដឹកនាំ, បើក (ឧ.

gouverner un vaisseau); គ្រប់គ្រង,អភិបាល (ឧ. gouverner un Etat); ថែទាំនិងអប់រំក្មេង ។ ដឹកនាំ (ឧ. gouverner les passions)។ *v.i.* ស្រួលកាច់ចង្កូត, ចង្កូតស៊ី (ឧ. bâtiment qui ne gouverne plus)

gouverneur *n.m.* ទេសាភិបាល ។ gouverneur de la Banque Nationale ទេសាភិបាលធនាគារជាតិ។ gouverneur général អគ្គទេសាភិបាល ។ gouverneur d'état ចៅហ្វាយរដ្ឋ ។ gouverneur de province ចៅហ្វាយខេត្ត

gouvernorat *n.m.* ឋានៈទេសាភិបាល

goyave *n.f.* ផ្លែត្របែក

goyavier *n.m.* ដើមត្របែក

grabat *n.m* គ្រែមិនល្អ ។ *Fig.* être sur les grabats វិនាសអស់

grabataire *n. Fam.* អ្នកឈឺជាប់នៅគ្រែ

grabuge *n.m. Fam.* ស្បូសន្ទឹក; ជម្លោះ (ឧ. il y a du grabuge dans ce ménage); ល្បែងបៀ

grâce *n.f.* ភាពល្អ, ភាពសមរម្យ (ឧ. marcher avec grâce; geste plein de grâce); អនុគ្រោះ (ឧ. accorder une grâce) ។ être en grâce auprès de quelqu'un មានក្ដីគាប់, ទទួលឧបត្ថម្ភពី ។ delai de grâce រយៈពេលបន្ថែម(ដើម្បីឲ្យបំពេញកាតព្វកិច្ច)។ bonnes grâces អនុគ្រោះ; ការទទួលដោយរាក់ទាក់ ។ bonne grâce សោភណភាព។ mauvaise grâce អសោភណភាព(ភាពមិនសមសួន) ។ demander en grâce ទទូចសុំឲ្យអនុគ្រោះ។ accorder la grâce លើកទោស (ឧ. accorder la grâce d'un condamné à mort)។ faire grâce អត់ទោស; លើកលែងឲ្យ, ឲ្យរួចពី (ឧ. faire grâce à quelqu'un d'une dette)។ rendre grâce ឬ grâces អរគុណ។ de bonne grâce ដោយរីករាយ, ដោយចិត្តឯង ។ de mauvaise grâce ដោយមិនរីករាយ, ដោយបង្ខំ ។ coup de grâce ការបង្ហើយ (ឲ្យស្លាប់; *au fig.* ឲ្យអន្តរាយ)។ faire grâce à quelqu'un de quelque chose មិន

ទារ (ឧ. faire grâce d'une dette);មិនជាប់ឲ្យ(លើកលែងឲ្យ)(ឧ. faire grâce d'une visite); action de grâces អំណរគុណ។ de grâce ឬ par grâce ដោយមេត្តាធម៌ ។ en grâce ដោយអនុគ្រោះ ។ faire une grâce à quelqu'un ឲ្យដោយមេត្តា (វត្ថុដែលអ្នកនោះគ្មានសិទ្ធិទាមទារ)។ faire des grâces ធ្វើប្រិកប្រិក,ធ្វើឫក។ faire la grâce de បំពេញ (ឧ. faites nous la grâce de déjeuner avec nous) ។ faire trop de grâce អនុគ្រោះពេក ។ grâce! សូមអភ័យទោស ! ។

de grâce *loc.adv.* សុំទោសទៅ, សុំអង្វរទៅ ។ grâce à *loc. pré.* ដោយសារ (ឧ. grâce à votre aide)។grâce à Dieux ដោយភ័ព្វល្អ ។ grâce de *loc. adv.* ដោយមេត្តាធម៌

grâciable *a.* អាចលើកទោសបាន

grâcier *v.t.* លើកទោស, អត់ទោស

grâcieusement *adv.* យ៉ាងសមរម្យ (ឧ. saluer grâcieusement); ដោយឥតយកកម្រៃ(ឧ. offrir grâcieusement ses services)

grâcieuser *v.t. Fam.* បញ្ចេញកេរ្តិ៍ ភក់ទាក់ ឬ ស្និទ្ធស្នាល

grâcieuseté *n.f.* សេចក្ដីគួរសម;សេចក្ដីភក់ទាក់

grâcieux, euse *a.* សមសួន, ល្អ (ឧ. prendre une pose grâcieuse); រួសរាយ (ឧ. accueil grâcieux); ឥតយកកម្រៃ(ឧ. obliger quelqu'un à titre grâcieux)។ *n.m.* អ្វីៗដែលល្អ ឬ សមសួន

gracile *a.* ស្ដើង (ស្គមខ្ពស់); ឆ្មារ

gracilité *n.f.* ភាពស្ដើង, ភាពឆ្មារ (ឧ. la gracilité des membres)

grâcioso *n.m.* តួកំប្លែងអេស្ប៉ាញ៉ុល

gradation *n.f.* ការចម្រើន ឬ ថយជាលំដាប់ (ឧ. gradation de la chaleur)

grade *n.m.* សក្តិ, ឋានន្តរស័ក្តិ (ឧ. le grade de lieutenant; monter en grade) ។ grade universitaire សញ្ញាបត្រ ។ *Géom.* (gr.) ក្រាដ (មួយភាគរយនៃមុំកែង)

gradé *a.& n.m.* អ្នកមានស័ក្តិ (តូចជាងនាយទាហាន)

gradin *n.m.* វេទិកាបៗ, ថ្នាក់វេទិកា

gradine *n.f.* ពន្លាករ៉

gradiner *v.t.* រ៉ែដោយពន្លាករ៉

graduation *n.f.* ការចែកជាអង្សា; ការក្រិត; ការបង្កើនជាលំដាប់

gradué, e *a.* ដែលចែកជាអង្សា, ដែលក្រិត(ឧ. échelle graduée);ដំណើរជាលំដាប់ (ឧ. exercices gradués)។ *n. Fig.* អ្នកមានសញ្ញាប័ត្រ (ឧ. une graduée de droit)

graduel, elle *a.* ជាលំដាប់ (ឧ. diminution graduelle ការបន្ថយជាលំដាប់)

graduellement *adv.* ជាលំដាប់,តាមលំដាប់

graduer *v.t.* ចែកជាអង្សាឬដាក់ក្រិត (ឧ. graduer un thermomètre)។ *Fig.* បង្កើនជាលំដាប់ (ឧ. graduer des exercices de grammaire)

graffite *n.m.* អក្សរឬគំនូរដែលនៅប្រាសាទ (ឧ. les graffiti de Pompéi)។ *Par ext.* គំនូរតាមជញ្ជាំង (*pl.* des graffites ឬ graffiti)

grafigner *v.t. Pop.* កេសកន្ទប;កោសឲ្យរលាត់

graillement *n.m.* សម្លេងស្អក

grailler *v.i.* និយាយដោយសម្លេងស្អក; ផ្លុំស្នែងហៅឆ្កែ

graillon *n.m.* សំណល់ម្ហូប; ក្ងួនខ្ញាញ់ខ្មោច; កំហាកស្លេង

graillonner *v.i.* ផ្លុំក្ងួនខ្ញាញ់ខ្មោច។ *Pop.* ខាកកំហាកស្លេង

grain *n.m. Bot.* គ្រាប់ (ឧ. grain de blé, de poivre, de riz; grain de sable; grain d'un chapelet); ធញ្ញជាតិ (ឧ. les grains sont en hausse)។ *Météor.* & *Mar.* ខ្យល់កា (ភ្លៀងមានខ្យល់ព្យុះ)។ (ឧ. recevoir un grain)។ *Fig.* & *fam.* veiller au grain ចាយហើយបង្ការគ្រោះថ្នាក់

grainage *n.m.* ផលិតកម្មពងដង្កូវនាង (ម.ព. grenage ផង)

graine *n.f.* គ្រាប់ពូជ (ឧ. le vent emporte au loin les graines)។ monter en graine ជាក់គ្រាប់។ *Fam.* ឡើងធំ។ *Zool.* graine de ver à soie ឬ graine ពងដង្កូវនាង។ *Fig.* mauvaise graine មនុស្សពាលខូច។ prendre de la graine យកតម្រាប់

grainer *v.t.* ម.ព. greiner

grainetterie *n.f.* ធញ្ញពាណិជ្ជកម្ម, ជំនួញធញ្ញជាតិ; ធញ្ញភណ្ឌាគារ, ឃ្លាំងគ្រាប់ធញ្ញជាតិ

grainetier,ère *n.&a.* ធញ្ញពាណិជ, ឈ្មួញគ្រាប់ធញ្ញជាតិ

grainier,ère *n.&a.* អ្នកលក់គ្រាប់ពូជ ។ *n.m.* ការសម្រាំងគ្រាប់ពូជ

graissage *n.m.* ការលាប - ប្រឡាក់ ឬដាក់ប្រេង ឬខ្លាញ់

graisse *n.f.* ខ្លាញ់, ប្រេង ។ prendre de la graisse ឡើងធាត់ ។ la graisse ne l'étouffe pas ឬ ne l'empêche pas de courir ស្គម ។ de haute graisse *loc. rabelaisienne* ធាត់កណ្ដៀន; *au fig.* សិទាន់

graisser *v.t.* លាបខ្លាញ់ ឬ ប្រេង, ដាក់ប្រេង(ឧ. graisser une machine); ធ្វើឲ្យប្រឡាក់ប្រេង ឬ ខ្លាញ់ (ឧ. graisser ses vêtements) ។ *Fig.* graisser la patte សូក ។ *v.i.* ខូច (ចំពោះស្រាដែលឡើងដូចជាប្រេង) (ឧ. ce vin graisse)

graisset *n.m.* កញ្ចាញ់ចេកបៃតង

graisseur,euse *a.* ដែលលាបប្រេង ឬ ដាក់ប្រេង ។ *n.m.* អ្នកដាក់ប្រេង

graisseux,euse *a.* នៃប្រេង; ប្រឡាក់ប្រេង ឬខ្លាញ់ (ឧ. habit graisseux)

graminacées *n.f. pl.* បកសកូល

graminée *n.f.* ឃាសជាតិ(ធញ្ញជាតិពួកស្រូវសាលី,ពោត)

grammaire *n.f.* វេយ្យាករណ៍

grammairien,enne *n.* វេយ្យាករណិក - ណិកា, អ្នកវេយ្យាករណ៍; អ្នកចេះ-អ្នកបង្រៀនឬអ្នករៀបរៀងវេយ្យាករណ៍ ។ *Antiq.* និរុត្តិវិទូ (អ្នកប្រាជ្ញខាងកែប្រែរបៀបអក្សរ)

grammatical,e,aux *a.* នៃវេយ្យាករណ៍ ។ analyse grammaticale សម្ពន្ធវេយ្យាករណ៍ (ម.ព.analyse ផង) ។ ត្រឹមត្រូវតាមវេយ្យាករណ៍

grammaticalement *adv.* តាមក្បួនវេយ្យាករណ៍

grammatiste *n.m.* *Antiq.* អ្នកបង្រៀនក្មេងឲ្យចេះសរសេរនិងអាន ; វេយ្យាករណិក ។ *Auj.* អ្នកមិនសូវចេះវេយ្យាករណ៍; អ្នកវិយ្យាករណៈ

gramme (g.) *n.m.* ក្រាម(ក.)

grand,e *a.* ធំ (ឧ. une grande ville); ឆ្នើម (ឧ. un grand poète); ខ្ពស់ (ឧ. un enfant

grand pour son âge); ខ្លាំង(ឧ. un grand vent; un grand bruit)។grand mât ទូកក្ដោងធំ ។ le Grand Océan មហាសមុទ្រប៉ាស៊ីហ្វិក ។

Loc. div. grande jeunesse កាលក្មេងកំពុងពេញវ័យ(ឧ. il faut lui pardonner à cause de sa grande jeunesse)។ grand air កណ្ដាលវាល ។ avoir grand air កាន់ឫកជាអ្នកធំ។ plus grand que nature ធំជាងមែនទែន(ចំពោះរូប); *au fig.* ហួសវិស័យ ។ tout grand ouvert ឬ tout grand ចំហយ៉ាងធំ។ grand jour ថ្ងៃពេញពន្លឺ (ថ្ងៃក្រឡែត) ។ grand âge អាយុច្រើន, ចាស់ណាស់។ faire grand ធ្វើឲ្យឃើញធំ ឬ សំបើម ។ voir grand គិតទុកមុនឲ្យធំ ឬ សំបើម ។ grands gestes កាយវិការសំបើម (ការក្លាដៃក្លាជើងឲ្យឃើញសំបើម)។ grands mots ពាក្យសំបើម (ពាក្យប្រើដោយបំភ្លៃដើម្បីឲ្យគេស្ញើម) ។ ouvrir de grands yeux បើកភ្នែកធំៗ (បើកភ្នែកធំដោយភ្ញាក់ ឬ ដោយចង់ដឹង) ។ avoir plus grands yeux que grand ventre ភ្នែកចង់ឃើញជាងពោះឃ្លាន (ការដែលចង់បានខ្លាំងជាងការដែលត្រូវការមែនទែន)។ nager en grande eau សម្បូណ៌សប្បាយ ។

Prov. petite pluie abat grand vent ម.ព. abattre ។ aux grands maux les grands remèdes ម.ព. mal ។

n.m. មនុស្សពេញការ; អ្នកធំ (ឧ. les grands de la terre); យ៉ាងដែលថ្លៃថ្នូរ។ en grand *loc.adv.* តាមទំហំពិត,ប៉ុនមែនទែន(ឧ. se faire peindre en grand) ។ à la grande តាមរបៀបអ្នកធំ (ឧ. on ne peut voyager ni plus agréablement, ni plus à la grande (Mme de Sévigné) ។ faire une chose en grand ធ្វើមុតមាំ,ធ្វើពិតសំដៃ ។ travailler en grand ធ្វើការធំ

grand chien *n.m.* ម.ព. Sirius

grand-chose *n.* cala ne vaut pas grand-chose របស់នោះមិនប៉ុន្មានទេ (មិនច្រើន , មិនថ្លៃឬមិនល្អ

ណាស់ណា។) ។ *Fam.* un, une des pas grand-chose-មនុស្ស មិនគួររាប់អាន

grand-croix *n.f. inv.* មហាសិរីវឌ្ឍន៍ (គ្រឿងឥស្សរិយយសខ្ពស់បំផុត) ។

grand-croix *n.m.* អ្នកមានមហាសិរីវឌ្ឍន៍(*pl.* des grands-croix)

grand-duc *n.m.* ព្រង់ឌុច, ឋានន្តរនៃមហាក្សត្រខ្លះ(ឧ le grand-duc de Lituanie); ព្រះអង្គម្ចាស់នៃរាជវង្សរុស្ស៊ី (*pl.* des grands-ducs)

grand-ducal,e,aux *a.* នៃព្រង់ឌុច ឬ ប្រទេសព្រង់ឌុច

grand-duché *n.m.* ប្រទេសព្រង់ឌុច (ឧ. le grand-duché de Luxembourg) (*pl.* des grands-duchés)

grande-duchesse *n.f.* ភរិយានៃព្រង់ឌុច (*pl.* des grandes-duchesses)

grandelet,ette *a.* ធំបន្តិចហើយ (ឧ. enfant grandelet)

grandement *adv.* យ៉ាងធំទូលាយ; យ៉ាងច្រើន; យ៉ាងខ្លាំង(ឧ. se tromper grandement)

grandet,ette *a.* ធំគួរសម

grandeur *n.f.* ទំហំ (ឧ. grandeur d'une maison); មហិមា; គោរមងារនៃអេវ៉េក (ឧ. Sa grandeur l'évêque de...) ។ *Fig.* ភាពធំថ្លៃថ្នូរ ឬ វិសេស (ឧ. grandeur de caractère); ភាពធំសំបើម (ឧ. grandeur d'un crime); អំណាច,អានុភាព(ឧ.la grandeur souveraine; la grandeur et la décadence des Romains); សេចក្តីថ្កុំថ្កើង (ឧ. naître au sein des grandeurs) ។ grandeur d'âme មហាគុណ (ចិត្តដ៏ប្រសើរ,ចិត្តទូលាយ) ។ *Fig.* du haut de sa grandeur ដោយព្រហើនព្រហើន ។ folie des grandeurs ម.ព. mégalomanie

grandiloquence *n.f.*ការបំភ្លៃពាក្យ

grandiloquent,e *a.* នៃសម្តីបំភ្លៃពាក្យ

grandiose *a.* សំបើម(ដោយទំហំ,ដោយសេចក្តីថ្លៃថ្នូរ) (ឧ. édifice grandiose)

grandiosement *adv.* យ៉ាងសំបើម

grandir *v.i.* ឡើងធំ (ឧ. enfant qui a grandi trop vite)។*v.t.* ធ្វើឲ្យឡើងធំ(ឧ. ses chaussures le

grandissent); បន្កើនឬពង្រីក ។ *Fig.* លើកឡើងថ្កើងថ្កើង (ឧ. cela le grandira dans l'estime publique)

grandissant,e *a.* ដែលកាន់តែធំឡើង (ឧ. pouvoir sans cesse grandissant)

grandissement *n.m.* ការឡើងធំ; ការធ្វើឲ្យធំ ។ *Optiq.* ការរីក

grandissime *a. Fam.* ធំក្រៃលែង

grand-livre *n.m.* សៀវភៅធំ(បញ្ជីរាយឈ្មោះម្ចាស់បំណុលរដ្ឋ, សៀវភៅចុះគណនីនៃអគ្គិបតិជន) (*pl.* des grands-livres)

grand-maman ឬ **grand-mère** *n.f.* ជីដូនបង្កើត។ រ.ស. ព្រះអយ្យិកា (*pl.* des grand-mamans, des grand-mères)

grand-oncle *n.m.* ជីតាមា (*pl.* des grands-oncles)

grand-papa ឬ **grand-père** *n.m.* ជីតាបង្កើត។ រ.ស. ព្រះអយ្យកោ (*pl.* des grands-papas, des grands-pères)

grand-peine (à) *loc. adv.* ដោយលំបាក

grands-parents *n.m. pl.* ជីដូនជីតា (*pl.* des grands-parents)

grand-tante *n.f.* ជីដូនមីង (ឧ. des grand-tantes)

grand-voile *n.f.* ក្តោងធំ (*pl.* des grand-voiles)

grange *n.f.* ជ្រង់, ជង្រុក

grangée *n.f.* ចំណុះជ្រង់ ឬ ជង្រុក

granit *n.m. Minér.* កណសិលា[ក-ណ-សិ-ឡា], ថ្មក្រំ ។ *Fig.* cœur de granit ចិត្តដែក (មនុស្សគ្មានមេត្តា, មនុស្សពិតធម៌)

granité,e *a.* កណិក (ដែលមានគ្រាប់ដូចកណសិលា)។ *n.m.* សំពត់សាច់គ្រើម

graniter *v.t.* លាបថ្នាំដូចកណសិលា(ឲ្យឃើញគ្រាប់គ្រើមៗ) (ឧ. graniter des stucs)

graniteux,euse *a.* ដែលកើតកណសិលា (ឧ. roche graniteuse)

granitique *a.* ជាជាតិកណសិលា (ឧ. sol granitique)

granitoïde *a.* កណសិលាសណ្ឋាន(ឧ. structure granitoïde)

granivore *a.&n.* សិទ្ធិកាសី, ដែលស៊ីគ្រាប់ជាអាហារ

granulage *n.m.* ការស្ងួនជាគ្រាប់តូចៗ

(ឧ.le granulage de la poudre)

granulaire *a.* ដែលផ្សំដោយគ្រាប់តូចៗ (ឧ. roche granulaire)

granulation *n.f.* ការបំបែកឬស្ងួនជាគ្រាប់តូចៗ

granule *n.f.* គ្រាប់តូច; គុលិកាតូច

granulé,e *a.* ដែលមានគ្រាប់តូចៗ ។ *n.m. Pharm.* គុលិកាតូច

granuler *v.t.* បំបែកឬស្ងួនជាគ្រាប់តូចៗ (ឧ.granuler du plomb)

granuleux,euse *a.* ដែលបំបែកជាគ្រាប់តូច(ឧ.terre granuleuse)។ *Méd.* ដែលមានគ្រាប់តូចៗ (ឧ. tumeur granuleuse)

granulie *n.f.* រោគរបេងមួយយ៉ាង

granuliforme *a.* ដែលមានសណ្ឋានជាគ្រាប់តូចៗ

granulite *n.f.* គណិកសិលា [កៈ-ណិ-កៈ—], ថ្មគ្រាប់ៗ

grape-fruit *n.m.* (ព.អ.) ក្រូចថ្លុង (ម.ព. pamplemousse ផង)

graphie *n.f.* លេខនាការ, ការសរសេរ; របៀបសរសេរ (ថា graphisme ក៏បាន) ; ពាក្យបំព្រួញនៃ radiographie

graphique *a.* ពិន្ទុរេខីយ (ឧ. dessin graphique)។ signes graphiques d'une langue អក្សរនៃភាសាមួយ ។ *n.m. Géom. &Sc.* ពិន្ទុរេខីយ

graphiquement *adv.* ដោយពិន្ទុរេខីយ

graphisme *n.m.* ម.ព. graphie

graphite *n.m.* ក្រាហ្វិត(ធ្យូងសុទ្ធខ្មៅទន់)

graphiteux,euse ឬ **graphitique** *a.* ដែលមានក្រាហ្វិត

graphologie *n.f.* លេខនាវិទ្យា (ក្បួនទំនាយតាមអក្សរសរសេរដៃ)

graphologique *a.* នៃលេខនាវិទ្យា

graphologue *n.* លេខនាវិទូ(ហោរទាយតាមអក្សរ)

graphomètre *n.m.* លេខនមាត្រ

graphométrie *n.f.* លេខនមាត្រវិធី

grappe *n.f. Bot.* ចង្កោម។ *Par ext.* ចង្កោម (មនុស្សឬវត្ថុ)

grappillage *n.m.* ការបេះផ្សៀផ្សំ (ផ្លែទំពាំងបាយជូរដែលសល់)។ *Fig. & fam.* ការឆ្លៀតរកកម្រៃតាមក្រោយ

grappiller *v.i.* បេះផ្សៀផ្សំ (ផ្លែទំពាំងបាយជូរដែលសល់)។ *v.t. & i.Fig. &fam.* រកផ្សៀផ្សំ; ឆ្លៀតរកកម្រៃតាមក្រោយ

grappilleur,euse *n.&a.* អ្នកបេះ

ស្បៀតស្បៀ

grappillon *n.m.* ចង្កោមតូចៗ

grappin *n.m.* ដែកដំពក់មានថ្នែច្រើន ។ *Fig.* & *fam.* jeter ឬ mettre le grappin sur quelqu'un តាមស្អិត; ទាក់ទិត

gras,grasse *a.* ជាជាតិខ្លាញ់ឬប្រេង(ឧ. le beurre est un corps gras); ធាត់, ដែលមានខ្លាញ់ច្រើន (ឧ. un porc gras); ប្រឡាក់ឬប្រឡាក់ខ្លាញ់; ដែលធ្វើអំពីសាច់ (ឧ. bouillon gras) ។

jours gras ថ្ងៃដែលបរិភោគសាច់បាន(តាមសាសនាគ្រិស្ត)។ ធ្លោស (អក្សរ) ។ terre grasse ដីមានជីជាតិ ។ plantes grasses ពួកតាមស្លឹកក្រាស់ហើយសាច់ច្រើន ។ dormir la grasse matinée ដេកដំរាក់ដល់ថ្ងៃ ។ *Chim.* corps gras ម.ព. corps ។

n.m. ខ្លាញ់ ។ faire gras បរិភោគសាច់។ gras de jambe កំភួនជើង ។ *Techn.* avoir du gras ធាត់ពេក ។

adv. peindre gras លាបថ្នាំក្រាស់ ។ parler gras អានអក្សរ «r» ក្នុងបំពង់ក; និយាយស៊ីជ្ជជង

gras-double *n.m.* ពោះកណ្ដាប់ចង្កៀរ (ពោះគោ) ។ *Arg.* សង្កស៊ីប្រាក់ខ្លះ ។ la faire au gras-double លួចសង្កស៊ី ។(*pl.* des gras-doubles)

grassement *adv.* យ៉ាងស្រួល (ឧ. vivre grassement); ដោយចិត្តសប្បុរស(ឧ.payer grassement)

grasserie *n.f.* ជម្ងឺរុយ (កេតបណ្ដាលឲ្យដង្កូវនាងហើមខ្លួន)

grasset,ette *a.* ធាត់បន្តិច

grasseyement *n.m.* ការអានអក្សរ «r» ក្នុងបំពង់ក (ឧ le grasseyement est commun à Paris)

grasseyer *v.i.* អានអក្សរ«r»ក្នុងបំពង់ក

grasseyeur,euse *n.* អ្នកអានអក្សរ «r» ក្នុងបំពង់ក

grassouillet,ette *a.* *Fam.* ធ្លោស (ឧ. enfant grassouillet)

graticulation *n.f.* ការវាយក្រឡាគំនូរ (ដើម្បីចម្លង)

graticuler *v.t.* វាយក្រឡាគំនូរ (ដើម្បីចម្លង)

gratification *n.f.* ធនានុគ្រោះ (ប្រាក់ឲ្យថែមជារង្វាន់)

gratifier *v.t.* ធនានុគ្រោះ, ឲ្យរង្វាន់

(ឧ. gratifier quelqu'un d'une pension)

gratin *n.m.* ម្សៅដាប់ជាគខ្ទះ ។ *Pop.* ពួកអ្នកហ៊ឺហា

gratiner *v.t.* ចំអិនឲ្យដាប់ជាគខ្ទះ ។ *v.i.* ដាប់ជាគខ្ទះ; រាំងឲ្យឡើងក្រហម

gratis *adv.* ដោយឥតយកថ្លៃ, ទទេ

gratitude *n.f.* កតវេទិតា; ការដឹងគុណ (ឧ. témoigner sa gratitude)

grattage *n.m.* ការកោស ឬ កកាយ

gratte *n.f.* ចបធ្វើស្មៅ ។ *Fam.* ការកោសរូស, កប្រែខុសច្បាប់ (ឧ. faire de la gratte)

gratte-ciel *n.m. inv.* វិប្លុទ្ធគ្រឹះ, គ្រឹះស្ថានច្រើនជាន់

gratte-dos *n.m.inv.* ដៃទាចឬដៃអេះ (ប្រដាប់សម្រាប់អេះខ្នង)

gratteler *v.t.* កោសរំលីង

grattelle *n.f.* កមរមាស់

gratte-papier *n.m.inv.Fam.* អ្នកចម្លង

gratte-pieds *n.m.inv.* ដែកប្រទាសជូតជើង

gratter *v.t.* អេះ (ឧ. gratter sa jambe); កកាយ; កោស (ឧ. gratter un mur) ; កោសលុប (ឧ. gratter une inscription) ។ *Fig. & Fam.* កោសរូស, កែកប្រែខុសច្បាប់ ។ *Pop.* ធ្វើការ ។ *Pop.* ផែង (រថយន្ត) ។ *Arg. Sports* ផ្តាច់ (រត់លឿនជាងគេ) (ឧ. gratter un concurrent) ។ *v.i.* គោះ, គោះតិចៗ (ឧ. gratter à la porte)

gratteur *n.m.* អ្នកកោស, អ្នកអេះ ។ gratteur de papier អ្នកនិពន្ធផ្តេសផ្តាស

grattoir *n.m.* កាំបិតកោសលុប; ប្រដាប់អេះ ។ *Pop.* កាំបិតកោរ ។ *Agr.* នង្គ័លសម្រាប់ភ្ជួរស៊ើច ។ *Techn.* ប្រដាប់កោស

gratture *n.f.* កំទេចដែលកោស (ឧ. des grattures de cuivre)

gratuit,e *a.* មុធា, ដែលធ្វើឬឲ្យឥតយកថ្លៃ, ទទេ (ឧ. consultation gratuite) ។ école gratuite សាលាមិនយកលុយ ។ à titre gratuit គ្មានថ្លៃ, ទទេ ។ aliénation à titre gratuit សាមីបរិវត្តន៍ដោយមុធា ។ *Fig.* មិនសមហេតុផល (ឧ. méchanceté gratuite; supposition gratuite)

gratuité *n.f.* មុធាភាព, ភាពឥតមានថ្លៃ

(ឧ.la gratuité de l'enseignement)

gratuitement *adv.* ដោយមុធា,ដោយឥតយកថ្លៃ, ។ល។

grau *n.m.* ព្រែកជីក(ភ្ជាប់ស្ទឹងទៅសមុទ្រ); ផ្លូវភ្នំ; បឹងទឹកប្រៃ

gravats *n.m.pl.* កំទេចមកពីការរុះរើ

grave *a.* *Phys.* ធ្ងន់ (ឧ. les corps graves) ។ *Fig.* ធឹងធង, រម្យទម (ឧ.homme grave;contenance grave);ធំ(ឧ.affaire grave); ធ្ងន់ (ឧ. maladie grave)។*Mus.* គ (ឧ. note grave) ។ -*n.m.* សំឡេងគ(ឧ.de l'aigu au grave)

gravelage *n.m.* ការក្រាលក្រួស

gravelée *n.f.* ផេះកាកស្រា

graveler *v.t.* ក្រាលក្រួស

graveleux,euse *a.* លាយក្រួសតូចៗ (ឧ. terrain graveleux)។*Fig.* អាសគ្រាម (ឧ. tenir des propos graveleux)

gravelle *n.f.* ប្រមេះគ្រាប់ (ម. ព. lithiase urinaire ផង)

gravelure *n.f.* ពាក្យអាសគ្រាម

gravement *adv.* ដោយរម្យទម,យ៉ាងធ្ងន់

graver *v.t.* ឆ្លាក់ (ឧ. graver une inscription) ; បញ្ចេញឲ្យឃើញច្បាស់ (ឧ. l'ennui est gravé sur son visage); ផ្ចិតយ៉ាងជាប់ (ឧ.graver dans sa mémoire, dans son cœur)

graves *n.f.pl.* ដីក្រួស ។ *n.m.* ស្រាទំពាំងបាយជូរសដាំនៅដីក្រួស

graveur *n.m.* ជាងឆ្លាក់

gravier *n.m.* ក្រួសល្អិត(ខ្សាច់ធំៗលាយក្រួសអាចម៍ផ្កាយ)។*Path.* គ្រាប់ប្រមេះ

gravifique *a.* នៃការពល [កា.រៈ.ពល់]

gravillon *n.m.* ក្រួសតូចៗ

gravillonnage *n.m.* ការរាយក្រួសតូចៗ

gravillonner *v.t.* រាយក្រួសតូចៗ

gravimètre *n.m.* ការពលមាត្រ

gravimétrie *n.f.* ការពលមាត្រវិធី(ឧ. prospection du pétrole par gravimétrie)

gravir *v.t.&i.* ឡើងដោយលំបាក (ឧ. gravir une montagne)

gravitant,e *a.* ដែលស្រូបទាញ

gravitation *n.f.* ការ ឬ កម្លាំងស្រូបទាញគ្នាទៅវិញទៅមក (ឧ. Newton formula le premier la loi de la gravitation universelle) (ម.ព. attraction ផង)

gravité *n.f. Phys.* ការពល[កា-រៈ-] (កម្លាំងស្រូបទាញនៃផែនដី)។ centre de gravité មជ្ឈមណ្ឌលការពល ។ *Acoust.* ភាពធ្ងន់ (សំឡេង) ។ *Fig.* ភាពម៉ឺងម៉ាត់ (ឧ. la gravité d'un magistrat); ភាពធ្ងន់ (ឧ. gravité d'une faute) ; ភាពធ្ងន់, ភាពធំដុំ (ឧ. la gravité d'une blessure)

graviter *v.i. Phys.* ស្រូបទាញ។ *Fig.* វិលវល់ជុំវិញ (ឧ. il gravite dans l'entourage du ministre); វិលជុំវិញ

gravois *n.m.pl.* ម.ព. gravats

gravure *n.f.* ចម្លាក់, រូប

gré *n.m.* ទំនើងចិត្ត (ឧ. agir à son gré ប្រព្រឹត្តតាមទំនើងចិត្ត) ។

Loc. div. avoir, recevoir, prendre quelque chose en gré ពូលចិត្ត, ទទួល (ឧ. prenons en gré les afflictions que la Providence nous envoie)។ prendre quelqu'un en gré ត្រូវគ្នានឹង។ savoir bon gré à quelqu'un ពេញចិត្តនឹង ។ savoir mauvais gré à quelqu'un ទាស់ចិត្តនឹង, មិនពេញចិត្ត (ឧ. on vous saura mauvais gré d'avoir agi si vite) ។ se savoir bon gré d'avoir fait quelque chose ពេញចិត្តនឹងខ្លួនឯងដោយបានធ្វើអ្វីមួយ ។ à gré d'eau តាមដំណើរទឹក ។ de gré à gré *loc.adv.* ដោយស្រុះស្រួលគ្នា, ដោយព្រមព្រៀងគ្នា (ឧ. vente de gré à gré)។ marché de gré à gré អាជីវកម្មសញ្ញាព្រមព្រៀង ។ de gré ou de force ឬ bon gré mal gré *loc. adv.* ទោះស្ម័គ្រចិត្តមិនស្ម័គ្រចិត្ត

gréage *n.m.* ការដាក់ក្ដោង

grec,grecque *a.&n.* នៃប្រទេសក្រិក។ *n.m.* ភាសាក្រិក

gréciser *v.t.* យកលំនាំតាមភាសាក្រិក

grécité *n.f.* លក្ខណៈជាសព្ទក្រិក

gréco-latin,e *a.* នៃក្រិកនឹងឡាតាំង (ឧ. les langues gréco-latines)

gréco-romain,e *a.* នៃក្រិកនឹងរ៉ូម៉ាំង (ឧ. architecture gréco-romaine)

gredin,e *a.* មនុស្សថោកទាបឬទុច្ចរិត

gredinerie *n.f.* អំពើថោកទាប

gréement *n.m. Mar.* គ្រឿង (ដីងសារក្ដោង, ខ្សែសាក្ដោង)

gréer *v.t. Mar.* ដាក់ក្តោង (ឧ. gréer un navire en goélette)

gréeur *n.m.* អ្នកដាក់ក្តោង

greffage *n.m.* ការផ្សាំសាប់

greffe *n.m.* ការិយាល័យក្រឡាបញ្ជី

greffe *n.f.* មែកផ្សាំសាប់ (ហៅ. នៃពាក្យ ente); ការផ្សាំសាប់

greffer *v.t.* ផ្សាំសាប់ (ឧ. greffer un pommier) ។ se greffer *v.pr. Fig.* បន្ថែម (ឧ. sur cette affaire s'en greffe une autre)

greffeur *n.m.* អ្នកផ្សាំសាប់

greffier *n.m.* ក្រឡាបញ្ជី

greffoir *n.m.* កាំបិតផ្សាំសាប់

greffon *n.m.* កូនផ្សាំសាប់ (ឈើ)

grégaire ឬ **grégarien, enne** *a.* ដែលរស់នៅជាក្រុម, នៃក្រុម(ជនរស់នៅជាក្រុម) (ឧ. illusion grégaire) ។ instinct grégaire សភាវគតិនៃក្រុម(សភាវគតិដែលញុំាងមនុស្សឲ្យរស់នៅជាក្រុម);ដែលមានដុំះច្រើននៅកន្លែងមួយ

grège *a.* ឆៅ (សូត្រ)

grégeois *a. m.* feu grégeois ម.ព. feu

grègues *n.f. pl.* ខោជើងជើង ។ mettre de l'argent dans ses grègues មានប្រាក់ច្រើន ។ tirer ses grègues រត់ជើងខោ (ដោយលាត់ជើងខោ)

grêle *a.* តូចវែង (ឧ. jambes grêles); ស្តើង(ស្តួមខ្ពស់);ថ្លា (ឧ. voix grêle) ។ intestin grêle ពោះវៀនតូច

grêle *n.f.* ព្រឹល ។ *Fig.* ចំនួនច្រើន (ឧ. une grêle de pierre, de traits) ។ méchant comme la grèle កាចអាក្រក់

grêlé,e *a.* ខូចដោយត្រូវព្រឹល; អុត (ឧ. visage grêlé មុខអុត)

grêler *v. imp.* ធ្លាក់ព្រឹល ។ *v.t.* ធ្វើឲ្យខូចដោយព្រឹល (ឧ. l'orage a grêlé les vignes)

grêleux,euse *a.* ដូចព្រឹល

grelin *n.m. Mar.* ពួរចងនាវាក្នុងផែ

grêlon *n.m.* គ្រាប់ព្រឹល

grelot *n.m.* ចង្រ្កង់, គ្រដោក ។ *Fig.* attacher le grelot ផ្តើមគំនិត ។ ការសប្បាយដូចក្លូត(ឧ. les grelots du carnaval) ។

Loc. div. faire sonner son grelot ធ្វើឲ្យគេចាប់ភ្នែកដល់ខ្លួន

(ឲ្យគេមើលខ្លួន); និយាយរួសរាយ ។ mettre une sourdine à son grelot ទប់សំដី (មិននិយាយច្រើនពេក); ទប់សម្រើប

grelottant,e *a.* រងាញាក់

grelottement *n.m.* ដំណើររងាញាក់

grelotter *v.i.* ញាក់

grenade *n.f.* ផ្លែទទឹម។ *Mil.* គ្រាប់បែកដៃ

grenader *v.t. Mil.* បោះគ្រាប់បែកដៃ (ឧ. grenader un sous-marin)

grenadier *n.m.* ដើមទទឹម

grenadier *n.m.* ទាហានចោលគ្រាប់បែកដៃ; ទាហានជម្រើស (ឧ. grenadier de la garde consulaire)

grenadière *n.f.* ថង់គ្រាប់បែកដៃ; ខ្សែស្ពាយកាំភ្លើង

grenage ឬ **grainage** *n.m.* ការកិនរំសេវកាំភ្លើងជាគ្រាប់តូចៗ; ភាពស្ករក្រាម; ការរើសពងដង្កូវនាង

grenaille *n.f.* លោហធាតុកិនជាដុំតូចៗ; គ្រាប់ប្រាយ (ឧ. grenaille de plomb); គ្រាប់ធញ្ញជាតិដែលឲ្យជាចំណីបក្សី

grenailler *v.t.* កិនលោហធាតុជាដុំតូចៗ

grenaison *n.f.* ការចាក់គ្រាប់(ធញ្ញជាតិដែលកើតមានគ្រាប់)

grenat *n.m.* ត្បូងទទឹម ។ *a.inv.* ក្រហមជាំ (ឧ. velours grenat)

grené,e *a.* កិនជាគ្រាប់តូច(ឧ. poudre grenée); ដែលមានក្បាច់ពងត្រីល្អិត (ឧ. dessin grené) ។ *n.m.* ភាពជាចំណុចតូច; ផ្នែកមានក្បាច់ពងត្រីល្អិត

greneler *v.t.* លំអដោយក្បាច់ពងត្រីល្អិត (ចំណុចតូច)

grener *v.i.* ចាក់គ្រាប់ (ធញ្ញជាតិដែលកើតមានគ្រាប់)។ *v.t.* កិនជាគ្រាប់តូចៗ (ឧ. grener du sel); លំអដោយក្បាច់ពងត្រី (ពកតូចៗ)

grènetis *n.m.* ក្បាច់ពងត្រី (ក្បាច់គ្រាប់នៃហាមម៉េដាយឬប្រាក់)

greneuse *n.m.* ម៉ាស៊ីនបោះក្បាច់ពងត្រី (លើស្បែក)

grenier *n.m.* ក្រង់, ជង្រុក; ពុក (ឧ. être logé au grenier) ។ *Fig.* ជង្រុក (ស្រុកដែលឲ្យផលស្រូវច្រើន) (ឧ. Battambang est le grenier du Cambodge) ។ *Mar.* en grenier ដោយគរនៅបាត (ការផ្ទុកទំនិញនៅបាតនាវា)

grenouille *n.f.* កង្កែប ។ la grenouille coasse កង្កែបយំ។ *Pop.*

បេឡា, ហិបរូម។ manger la grenouille លួចឬគៃបន្លំប្រាក់ដែលគេផ្ញើក្នុងហិបរូម

grenouillère *n.f.* ស្រះមានកង្កែបច្រើន ។ *Fam.* ទឹកហូរកក់សម្រាប់ឲ្យអ្នកមិនចេះហែលងូត

grenu,e *a.* ដែលមានគ្រាប់ច្រើន (ឧ. épis grenu); ដែលមានក្បាច់ពងត្រី (ពកជាគ្រាប់ៗ) (ឧ. cuir grenu)

grenure *n.f.* ការលំអដោយក្បាច់ពងត្រី (ពកតូចៗ)

grès *n.m.* ថ្មភក់, ថ្មផុស, ថ្មសំលៀង ។ grès bitumeux ថ្មប៉ិទុម ។ *loc. prov.* casser du grès à quelqu'un បណ្ដេញ

gréser *v.t.* រំលីងដោយថ្មផុស; ប៉ះដោយដែកប៉ះ

gréseux,euse *a.* នៃថ្មភក់ ឬ ថ្មផុស

grésière *n.f.* កន្លែងយកថ្មភក់ឬថ្មផុស

grésil *n.m.* ព្រិលគ្រាប់ល្អិត

grésillement *adv.* សំឡេងចង្រិតយំ; ការធ្លាក់ព្រិល; ការរួញឬងរដោយត្រូវកំដៅ

grésiller *v.imp.* ធ្លាក់ព្រិល (ឧ. il grésille) ។ *v.t.* ធ្វើឲ្យរួញ ឬ ង (ដោយកំដៅ) (ឧ. le feu a grésillé ce parchemin); ធ្វើឲ្យព្រួសរ (ប្រេះៗដូចធ្លាក់ព្រិល) ។ *Fig.* បំផ្លាញ; សម្លាប់

grésillon *n.m.* កំទេចធ្យូង; ម្សៅគ្រៀមៗ

grésoir *n.m.* ដែកប៉ះគ្រឿងកញ្ចក់

gressin *n.m.* នំប៉័ងវែងដូចចង្កឹះ

grève *n.f.* ឆ្នេរសមុទ្រដែលមានខ្សាច់និងក្រួស ។ *Par ext.* កូដកម្ម (ឧ. se mettre en grève; faire la grève) ។ grève sur le tas កូដកម្មក្នុងទី (ដោយនៅក្នុងកន្លែងធ្វើការ)។ grève perlée កូដកម្មដោយបង្អង់ការ។ *Par ext.* កូដកម្ម(ការមិនទទួល) ។ grève de la faim កូដកម្មឃ្លាន (ដោយអត់អាហារ)

grever *v.t.* ដាក់បន្ទុកធ្ងន់ (ឧ. héritage grevé de nombreuses dettes មរតកជាប់បំណុលច្រើន ; grever le pays d'impôts) ។ grever son budget ចាយច្រើនពេក

gréviste *a.* កូដករ, អ្នកធ្វើកូដកម្ម

gribouillage *n.m.* គំនូរអាក្រក់; អក្សរអាក្រក់

gribouille *n.m. Fam.* មនុស្សគំនិតកញ្ជះកញ្ជាយ

gribouiller *v.i.& t.Fam.* គូរគំនូរ

អាក្រក់; សរសេរអក្សរអាក្រក់

gribouillette *n.f.* ល្បែងបោះវត្ថុអ្វីមួយឲ្យក្មេងដណ្ដើមគ្នា។ à la gribouillette ដោយឲ្យក្មេងប្រេង

gribouilleur,euse *a.* អ្នកគូរអាក្រក់; អ្នកសរសេរអាក្រក់

gribouillis *n.m.* អក្សរអានមិនដាច់

grièche *a.* ម.ព. pie-grièche

grief,ève *a.* ធ្ងន់, ធំណាំ (ឧ. grièvemaladie)

grief *n.m.* ការខូចខាត; បទបណ្ដឹង, ពិរុទ្ធសាទុក្ខ ។ formuler ses griefs ប្ដឹងសាទុក្ខ ។ faire grief de quelque chose à quelqu'un បន្ទោសអំពីរឿងអ្វីមួយ

grièvement *adv.* យ៉ាងធ្ងន់,យ៉ាងធំណាំ (ឧ. grièvement blessé)

grièveté *n.f.* ភាពធ្ងន់, ភាពធំណាំ (ជម្ងឺ, របួស)

griffade *n.f.* ការក្រចៅ (ឬ ក្រញៅ)

griffe *n.f.* ក្រញាំ, ក្រចកសត្វ; ការជិះជាន់, ការធ្វើបាប (ឧ. enfant qui est dans les griffes d'une marâtre) ។ coup de griffe ការរិះគន់ខ្លាំង ។ montrer les griffes បង្ហាញក្រចក(កំហែង)។ ក្រា; ហត្ថលេខា ។ *Bot.* មើម (ឧ. griffe d'asperge)។

Prov. à la griffe on reconnaît le lion គេស្គាល់សិង្ហដោយក្រចក ; គេស្គាល់មនុស្សដោយស្នាដៃ

griffer *v.t.* ក្រចៅ, ក្រញៅ, ខ្វាច

griffeur,euse *a.* ដែលក្រចៅ ឬ ក្រញៅ ឬ ខ្វាច

griffon *n.m.* ឆ្កែតភ្លើង; គ្រីហ្វុង(សត្វក្នុងរឿងល្បើក ខ្លួនជាសិង្ហ ក្បាលនឹងស្លាបជាឥន្ទ្រី ត្រចៀកជាសេះហើយមានសិរ មានព្រុយខ្លួចត្រី; ឆ្កែម្យ៉ាងកេបរែងហើយរឹង); ផ្លែសន្ធួចធំ

griffonnage *n.m.* ការសរសេរខ្វៀក; អក្សរអានមិនដាច់

griffonnement *n.m.* *Bx-arts* រូបជាន់ (រូបធ្វើដោយក្រមួន ឬ ដីឥដ្ឋដើម្បីជាកំពុម្ព)

griffonner *v.i.* សរសេរអក្សរអាក្រក់; សរសេរខ្វៀក (ឧ. griffonner des notes); តែងដោយខ្ជីខ្ជា; គូរហ័ស(ឧ. griffonner un dessin)

griffonneur *n.m.* អ្នកសរសេរខ្វៀក; អ្នកគូរហ័ស

griffu,e *a.* ដែលមានក្រញាំ ឬ ក្រចក

griffure *n.f.* ការខេះនឹងក្រញាំ,ការខ្វាច-ក្រចៅ ឬ ខ្វាំ

grigne *n.f.* ផ្នត់

grigner *v.i.* ឡៀងយ៉ោង; មានផ្នត់

grignon *n.m.* សាច់រឹងនៃនំបុ័ង;កាកប្រេង

grignotement *n.m.* ការខែះ, ការកកេរស៊ី

grignoter *v.t.* ខែះ, កកេរស៊ី (ឧ. grignoter un gâteau)។ *Fig. & fam.* ប្រមិចប្រមោច, កេកប្រែ (ឧ. il trouve toujours quelque chose à grignoter); បំផ្លាញបន្តិចម្តងៗ (ឧ. grignoter l'ennemi)

grignoteur,euse *n.&a.* ដែលខែះឬកកេរស៊ី

grigou *a.&n.Pop.* កំណាញ់ហួសពេក

gri-gri ឬ **grigri** *n.m.* របស់ស័ក្តិសិទ្ធិ (សម្រាប់ការពារ); អ្នកដែលមានរបស់ស័ក្តិសិទ្ធិសម្រាប់ការពារ (*pl.* des gris-gris ឬ des grigris)

gril *n.m.* ចង្អើរ ។ *Fig. & fam.* être sur le gril ជាអ្នកហើយអន្ទះអន្ទែង ។ gril costal ស្រោងឆ្អឹងជំនីរ

grillade *n.f.* ការឆ្អើរលើចង្អើរ; សាច់ឆ្អើរ(ឧ. une grillade de bœuf)

grillage *n.m.* ការឆ្អើរ; ការរោលសំពត់ឲ្យឆេះរោមអស់; សំណាញ់ដែក(នៅទ្វារ ឬ បង្អួច)

grillager *v.t.* ដាក់សំណាញ់ដែក (ឧ. grillager un soupirail)

grillagerie *n.f.* ការឬរបរធ្វើសំណាញ់ដែក

grillageur *n.m.* អ្នកធ្វើ ឬ អ្នកដាក់សំណាញ់ដែក

grille *n.f.* ចម្រឹងដែកឬឈើ,ដែកប្រទាសជើងក្រាន

grille-pain *n.m.inv.* ចង្អើរនំបុ័ង

griller *v.t.* ខ្វៃ,ឆ្អើរ,លីង (ឧ. griller du café), រោល ។ *Fig.* ដុត; ធ្វើឲ្យរួញឬស្វិត (ឧ. la gelée grille les bourgeons); ធ្វើឲ្យឆេះ, ធ្វើឲ្យដាច់ (ឧ. griller un fer électrique, une ampoule électrique)។

v.i. ក្តៅខ្លាំង (ឧ. l'été, on grille)។ *Fig.* griller de ចង់អន្ទះអន្ទែង (ឧ. je grille de le voir)

griller *v.t.* ដាក់ចម្រឹង (ឧ. griller une fenêtre); បង្ខាំង, ឃុំ (ឧ.

griller un malfaiteur)

grilloir *n.m.* ជើងក្រានឆ្អើរឬលីង, ជើង-ក្រានពេលរោមសំពត់

grillon *n.m.* ចង្រិត

grill-room *n.m.* (ព.អ.) បន្ទប់ឆ្អើរសាច់ (ក្នុងភោជនីយដ្ឋាន)

grimaçant,e *a.* ដែលញញាក់មុខ (ឧ. visage grimaçant)

grimace *n.f.* ការញញាក់មុខ (ឧ. les grimaces des clowns amusent les enfants)។ *Fig.* ការពេបមាត់ (ឧ. faire la grimace à une proposition); ការលាក់ពុត (ឧ. les politesses ne sont souvent que des grimaces)។ *pl.* ការធ្វើឫកពា (ឧ.les grimaces d'une coquette)

grimacer *v.i.* ញញាក់មុខ ។ *Fig.* ពេបមាត់; ធ្វើឫកពា

grimacerie *n.f.* ការញញាក់មុខ ; ការពេបមាត់

grimacier,ère *n.&a.* ដែលចូលចិត្តញញាក់មុខ (ឧ. fillette grimacière) ។ *Fig.* ដែលធ្វើញឹកញ៉ាក់(ឧ. une femme grimacière); ដែលធ្វើហាក់ដូចជា

grimage *n.m.* ការតែងតួជាចាស់

grimaud,e *a.* ស្រពោន, ស្រពាប់ ។ *n.m.* សិស្សថ្នាក់ទាប; សិល្បករជាន់ទាប; អ្នកនិពន្ធមិនប្រសប់

grime *n.m.* តួចាស់; អ្នកដើរតួចាស់; សិស្សមិនល្អ

grimer *v.t.* ធ្វើឲ្យមានជ្រួញ; តែងតួឲ្យ (ឧ. grimer un acteur)។ **se grimer** *v.pr.* តែងតួធ្វើចាស់;តែងតួ

grimoire *n.m.* គម្ពីរមន្តអាគម។ *Fig.* សុន្ទរកថាដែលស្ដាប់មិនបាន; សៀវភៅ ឬ អក្សរដែលអានមិនដាច់

grimpant,e *a.* ដែលឡើង។ *Bot.* ដែលឡើងទ្រើង

grimper *v.i.* ឡើង (ឧ. grimper aux arbres; chemin qui grimpe dans la montagne); ឡើងទ្រើង។ *v.t.* ឡើង (ឧ. grimper un escalier)

grimpette *n.f.* ផ្លូវឡើងកាត់

grimpeur,euse *n.* អ្នកឡើង; អ្នកចូលចិត្តឡើង ។ *n.m.* អ្នកប្រណាំងកង់ទោត ។ *n.m. pl.* សារសបក្សី [សា-រៈ-សៈ-], ខល្គួបក្សី [អ៊ុល-លុំ-ពៈ-] (ពពួកបក្សីដូចជាសេក-ត្រសេះ ។ល។)

grincement *n.m.* ការលាន់សូរង៉ែក-

ង៉ត; ការសង្កៀត; សូរសង្កៀត (ឧ. le grincement d'une porte)

grincer *v i.* លាន់សូរង៉េតង៉ត (ឧ. des roues qui grincent); សង្កៀត។ grincer des dents (ឬ les dents) សង្កៀតធ្មេញ

grincher *v.i.* ម.ព. grincer

grincheux,euse *a.&n.* ហៃក្លួញថ្នេរ (ឧ. un client grincheux)

gringalet,ette *n. Fam.* មនុស្សស្គមសង្កិល

grippage ឬ **grippement** *n.m. Méc.* ដំណើរគាំង ឬ ស្ទាតជាប់គ្នា (លោហធាតុដែលសង្កៀតគ្នាដោយស្ងួតប្រេង)។ ការដើបសំពត់

grippal,e *a.* នៃរោគគ្រុនគ្រើប្ប(គ្រុនផ្តាសាយ) (ឧ. affection grippale)

grippe *n.f.* គ្រុនគ្រើប្ប, គ្រុនផ្តាសាយធ្ងន់។ *Fig.* សេចក្តីស្អប់ (ឧ. prendre en grippe ស្អប់)

grippé,e *a.&n.* ដែលគ្រុនផ្តាសាយ។ *a.* ដែលគាំងដោយស្ងួតប្រេង

grippeminaud *n.m.* មនុស្សប្រសប់លាក់ពុត

gripper *v.t.* ចាប់ (ឧ. gripper un voleur)។ *Par ext.* លួច (ឧ. gripper de l'argent à quelqu'un)។ *v.i. Méc.* គាំង ឬ ស្ទាត ជាប់គ្នាដោយស្ងួតប្រេង។ se gripper *v.pr.* គាំង

grippe-sou *n.m.* មនុស្សកំណាញ់ស្វិតជិត (*pl.* des grippe-sou ឬ grippe-sous)

grippeur,euse *n. & a.* ដែលចេះនឹងប្រចក

gris,e *a.* ប្រផេះ (ឧ. robe grise)។ temps gris មេឃស្រទំហើយគួរជាក់។ *Fig. & Fam.* ស្រវឹងស្រៀងៗ។ *n.m.* ពណ៌ប្រផេះ។ gris de perle ឬ gris perle ប្រផេះភ្លឺ (ដូចគជ់)

grisaille *n.f.* គំនូរពណ៌ប្រផេះ

grisailler *v.t.* លាបពណ៌ប្រផេះ។ *v.i.* ឡើងប្រផេះស្ទើរ

grisant,e *a.* ដែលធ្វើឲ្យស្រវឹង (ឧ. succès grisant)

grisâtre *a.* ស្ទើរប្រផេះ

grisbi *n.m. Arg.* ប្រាក់

grisé,e *n.m.* ពណ៌ប្រផេះ (នៃគំនូរ)

griser *n.f.* បង្ហាឲ្យស្រវឹងស្រៀងៗ (ឧ. griser un conscrit); ធ្វើឲ្យស្រវឹងស្រៀងៗ។ *Fig.* ញុំាងឲ្យញៀ-

ក្លា ឬ ឲ្យវង្វេងស្មារតី(ឧ. le succès grise l'homme)។ se griser *v.pr. Fam.* ស្រវឹងស្រៀងៗ ស្រវឹង

griserie *n.f.* ភាពស្រវឹងស្រៀងៗ។ *Fig.* សេចក្ដីស្រើបស្រាល ។ la griserie du succès ការស្រវឹងដោយជោគជ័យ

grisoller *v.i.* អ៊ុត(ក្រួច)

grison,onne *a.* ប្រផេះ (ឧ. poil grison); ដែលមានសក់ស្កូវល្បាយ។ *n.m. Fam.* ដែលមានរោមពណ៌ប្រផេះ (ឧ. un grison); អ្នកបម្រើការសម្ងាត់ (ស្លៀកពាក់ប្រផេះ)

grison *n.m.* លា (សត្វលា)

grisonnant,e *a.* ស្កូវល្បាយ (ឧ. cheveux grisonnants)

grisonnement *n.m.* ការស្រលក់ប្រផេះ; ការឡើងប្រផេះ

grisonner *v.i.* ឡើងស្កូវល្បាយ

grisou *n.m.* គ្រីស៊ូ (ឧស្ម័នកាយចេញពីធ្យូងថ្ម)

grisoumètre *n.m.* គ្រីស៊ូមាត្រ(ប្រដាប់ស្ទង់គ្រីស៊ូក្នុងអណ្ដូងរ៉ែ)

grisouteux,euse *a.* ដែលមានគ្រីស៊ូ (ឧ. mine grisouteuse)

grive *n.f.* សត្វជាល់អំបុក ។ *Prov.* faute de grives on mange les merles បើមិនបានរបស់ផ្ចិតផ្ចង់ទេ គួរតែពូលចិត្តរបស់ដែលមានស្រាប់ (សុភាសិតខ្មែរយើងមានន័យថា ដិះក្របីចម្លងភក់ស្រណុកជាងហែល)

grivelé,e *a.* ពពាល

griveler *v.t.&i.* បានដោយខុសច្បាប់; ស៊ីខោល (បរិភោគអាហារក្នុងភោជនីយដ្ឋានដោយគ្មានប្រាក់ចេញ)

grivèlerie *n.f.* ការបានដោយខុសច្បាប់; ការស៊ីខោល

griveleur *n.m.* អ្នកស៊ីខោល

griveton *n.m. Pop.* កូនទាហាន

grivois,e *a.* អាសអាភាស(ឧ.chanson grivoise)

grivoiserie *n.f.* អំពើឬសំដីអាសអាភាស(ឧ.dire des grivoiseries)

groenlandais,e *a. & n.* នៃកោះគ្រូអិនឡង់

grog [grogh] *n.m.* (ព.អ.) ក្រុក (ស្រាលាយទឹកក្ដៅ ស្ករនិងក្រូចឆ្មារ)

groggy *n.m.* (ព.អ) អ្នកប្រដាល់ដែលដួលសន្លប់ប៉ុន្តែមិនទាន់ចាញ់ ។ *Par ext.* ដំណើរវេងវោង

grognard,e *n.&a.* រអ៊ូរទាំ ។ *n.m.* ទាហានរក្សាព្រះអង្គនៃព្រះចៅណាប៉ូឡេអុងទី១(ឧ.Napoléon aimait

tirer l'oreille à ses grognards); ទាហានចាស់

grognement *n.m.* សម្រែកកូនជ្រូក ។ *Fam.* សំដីរអ៊ូរទាំ

grogner *v.i.* ស្រែក (ជ្រូក, ខ្លាឃ្មុំ) ។ *v.i.* *Fig.* រអ៊ូរទាំ

grognerie *n.f.* ការរអ៊ូរទាំ

grogneur,euse *a.* ដែលរអ៊ូរទាំ (ឧ. vieillard grogneur) ។ *n.* អ្នករអ៊ូរទាំ

grognon,onne *n.&a.* ដែលចូលចិត្តរអ៊ូរទាំ (ឧ. un insupportable grognon); រញ៉ាំរញ៉ូវ (ឧ. homme, femme grognon)

grognonner *v.i.* *Fam.* ស្រែកដូចកូនជ្រូក; រអ៊ូរទាំឥតហេតុ

groin *n.m.* ច្រមុះជ្រូក ។ *Fig.* & *Fam.* មុខដូចសត្វ

grole ឬ **grolle** *n.f.* បក្សីពួកក្អែក-តាវៅ ។ *Pop.* ស្បែកជើង

grommeler *v.i.* ទន្ទេញទន្ទូរ; ស្រែក (ជ្រូកព្រៃ) ។ *v.i.* grommeler des injures ស្រែកជេរ

grommellement *n.m.* ការទន្ទេញ-ទន្ទូរ; ពាក្យទន្ទេញទន្ទូរ

grondant,e *a.* ដែលលាន់រំពង

grondement *n.m.* ស្នូរគ្រហឹម (ឧ. la voix de l'ours est un grondement) ។ *Par ext.* ស្នូរសន្ធឹក, ស្នូរលាន់រំពង (ឧ. grondement du tonnerre, du canon)

gronder *v.i.* ទន្ទេញទន្ទូរ ; គ្រហឹម (ខ្លាឃ្មុំ) ។ *Fig.* លាន់ស្នូរសន្ធឹក (ឧ. l'orage, la mer le canon gronde) ។ *v.t.* ស្តីបន្ទោស (ឧ. gronder un écolier paresseux)

gronderie *n.f.* ការស្តីបន្ទោស

grondeur,euse *n.* អ្នកហៃស្តីបន្ទោស ។ *a.* នៃការស្តីបន្ទោស (ឧ. voix grondeuse)

groom [groum] *n.m.* (ព.អ.) អ្នកបម្រើដែលស្លៀកពាក់ដោយឡែក

gros,grosse *a.* ធំ (ឧ. un gros arbre); គ្រើម (ឧ. gros drap); គម្រាំង (ឧ. de gros souliers); មិនសូវល្អ (ឧ. du gros vin); ហើម (ឧ. avoir les yeux gros) ។ *Fig.* ច្រើន, សំបើម (ឧ. toucher une grosse somme). ធំ (មានទ្រព្យច្រើន) (ឧ. gros marchand);

ខ្លាំង (ឧ. grosse fièvre) ។

Econ. rur. gros bétail ម.ព. bétail ។

Mar. grosse mer សមុទ្ររំជួលខ្លាំង ។ gros temps ពេលមានព្យុះខ្លាំង ។ gros vent ខ្យល់ត្រជាក់ណាស់ ។

Loc div. gros lot លេខធំ (លេខឆ្នោតដែលត្រូវរង្វាន់ធំបំផុត) ; *au fig.* លាភធំ ។ gros bonnet ឬ gros légume អ្នកធំ ។ gros ouvrage ឬ grosse besogne ការធ្ងន់, ការលំបាកជាងគេ ។ grosses dents ថ្គាម ។ grosse voix សម្លេងធំ; សម្លេងគម្រាម ។ grosses vérités សេចក្ដីពិតមែន; អ្វីៗដែលប្រាកដប៊ិនកើត (ឧ. dire à quelqu'un de grosses vérités) ។ gros rire សំណើចក្អាកក្អាយ ។ gros sel ការកំប្លែងគ្រោតគ្រាត ។ gros mots សំដីធ្ងន់ៗ (ពាក្យគ្រោះ, ពាក្យជេរ) ។ grosses paroles ពាក្យជេរយ៉ាងគ្រោះ ។ jouer gros jeu ឬ jouer gros លេងធំ (ដាក់ព្រយាត់ណាំងច្រើន) ។ gros joueur អ្នកលេងធំ (អ្នកហ៊ានដាក់ព្រយាជំណាំងច្រើន) ។ faire le gros dos បំពោងខ្នង (ប៉ពោះឆ្មាដែលខឹង) ; *au fig.* ធ្វើឫកគ្រាន់បើ ។ faire les gros yeux សម្លក់ដោយបើកភ្នែកធំៗ ។ avoir les yeux gros ចង់យំ ។ avoir gros cœur ឬ le cœur gros កើតទុក្ខ, ព្រួយចិត្ត ។ *Fig.* se tenir au gros de l'arbre តាប់តោងមែកធំ គឺរកងលើរបស់ប្រាកដជាងគេ ។

Prov. & loc. prov. il a coûté plus qu'il n'est gros គេបានចាយច្រើន ហើយចំពោះល្មើសប្រា ។ les gros poissons mangent les petits ត្រីធំស៊ីត្រីតូច (អ្នកមានកម្លាំងធ្វើបាបអ្នកខ្សោយ) ។

n.m. ភាគធំបំផុត, ភាគសំខាន់បំផុត (ឧ. le gros d'un mât; le gros d'une armée; le gros de la besogne) ។

Com. ដំនួញដុំ (ឧ. vente en gros; faire le gros et le détail) ។

Adv. ច្រើន (ឧ. coûter, gagner gros) ។

Loc. div. écrire gros

សរសេរអក្សរធំៗ។ coucher gros ដាក់ព្រយាធំណាស់ឬច្រើន;ប្រថុយច្រើន។ il y a gros à parier que គេអាចស្មានបាន។ gros comme ឬ aussi gros que ធំប៉ុន; *au fig.* gros comme le bras ម.ព. bras ។

Loc.adv. en gros ដុំ (ឧ. vendre en gros); តែគោលធំៗ (ឧ. raconter une affaire en gros)។ tout en gros សរុប, ទាំងអស់ (ឧ. dépenser cent francs tout en gros)

Gros-Jean (ឈ្មោះសម្រាប់ហៅមនុស្សអាក្រក់)។ *Prov.* Gros-Jean en remonte à son curé ម. ព. curé ។ être Gros-Jean comme devant នៅតែរងទុក្ខដូចដើមដដែល

grosse *n.f.* ចំនួន១២ឡូ (ឧ. une grosse de boutons); សេចក្ដីចម្លងនៃកិច្ចសន្យាជាអក្សរធំៗ; អក្សរធំ

grossement *adv.* ព្រួសៗ

grosserie *n.f.* ការធំនៃជាងគ្រឿងអារ (ឬកាត់) ; ដុំទូញដុំ; ការជនកណ្ដាប្រាក់

grossesse *n.f.* ភាពមានគភ៌; រយៈពេលមានគភ៌ (មាន ២៦០ ទៅ ២៨០ថ្ងៃ)

grosseur *n.f.* ទំហំ (ឧ. la grosseur d'une personne, d'un mur); គក (ឧ. grosseur à la gorge)

grossier,ère *a.* គគ្រើម, គ្រើម (ឧ. drap grossier); សាមញ្ញ, រយ(ឧ. nourriture grossière); ខ្ជីខ្ជា (ឧ. travail grossier) ។ *Fig.* កម្រោល; គ្រោតគ្រាត, ព្រោះពោះពោក, ព្រហ្មោះពោះ, ឆ្គងឆង (ឧ. parole grossière); មិនសម (ឧ. erreur grossière) ។ *n.m.* របស់កម្រោល

grossièrement *adv.* ដោយឆ្គងឆង (ឧ. répondre grossièrement); ដោយខ្ជីខ្ជា; ដោយកម្រោល

grossièreté *n.f.* ភាពគគ្រើម, ភាពគ្រើម; ភាពសាមញ្ញ (មិនវិសេស) (ឧ. la grossièreté d'un aliment); ភាពខ្ជីខ្ជា; ភាពកម្រោល; ភាពគ្រោតគ្រាត; សំដីឬអំពើឆ្គងឆង (ឧ. répondre des grossièretés)

grossir *v.t.* ធ្វើឲ្យឡើងធំ (ឧ. grossir la taille), ពង្រីក (ឧ. les lentilles biconvexes grossis-

sent les objets)។ *Fig.* បំផ្លើស, ពន្លើស (ឧ. la peur grossit tout) ។

v.i. ឡើងធំ (ឧ. la raison grossit) ។ la mer grossit សមុទ្រមានរលក

grossissant,e *a.* ដែលកាន់តែធំឬកាន់តែច្រើនឡើង (ឧ. foule grossissante); ដែលពង្រីក (ឧ. verres grossissantes)

grossissement *n.m.* ការឡើងធំ; ការឡើងច្រើន; ការពង្រីក; ការបំផ្លើស

grossiste *n.m.* ឈ្មួញដុំ

grosso modo *loc. adv.* (d'une manière grossière) ដោយគ្រួសៗ;ដោយគោលៗ(ឧ. exposer un projet grosso modo)

grossoyer *v.t.* ចម្លងអក្សរធំ

grotesque *a.* អាក្រក់ (ឧ. dessin grotesque) ។ *Fig.* គួរឲ្យអស់សំណើច,ចំឡែក (ឧ. idée grotesque) ។ *n.* មនុស្សគួរឲ្យអស់សំណើច (ឧ. un grotesque; une grotesqre) ។ *n.m.* អ្វីៗដ៏ចំឡែកគួរឲ្យសើច ។ *n.m. pl.* ក្បាច់ភ្ញីចំឡែក

grotte *n.f.* គុហា, រូងភ្នំ (ឧ. les premiers hommes ont habité les grottes)

grouillant,e *a* កុះករ, ដេរដាស; ដែលកញ្ជ្រោករំពើក

grouillement *n.m.* ដំណើរកុះករ; ដំណើរកញ្ជ្រោករំពើក (ឧ. le grouillement de la foule)

grouiller *v.i.* មានកុះករ។ *Pop.* កញ្ជ្រោករំពើក ។ *Pop.* se grouiller *v.pr.* ប្រញ៉ាប់ ; ប្រើក្លៀវក្លា ; ប្រញាប់ប្រញាល់

group *n.m.* ថង់ប្រាក់ដែលផ្ញើពីកន្លែងមួយទៅកន្លែងមួយ

groupage *n.m.* ការផ្តុំ (កញ្ចប់ទំនិញដែលផ្ញើទៅកន្លែងជាមួយគ្នា)

groupe *n.m.* សមូហ, ពួក, ក្រុម (ឧ. un groupe de curieux; un groupe politique) ។ *Méd.* groupe sanguin ប្រភេទឈាម ។ *Mil.* កង។ groupe de combat កងប្រយុទ្ធ ។ groupe mobile កងចល័ត

groupement *n.m.* សមូហភាព,វគ្គភាព, ការប្រមូលជាពួកឬជាកង; ភាពផ្តុំជាពួកឬជាកង (ឧ. groupement politique)

grouper *v.t.* ផ្គុំជាពួកឬជាកង; ប្រមូល, ប្រជុំ (ឧ. grouper les faits)

gruau *n.m.* អង្ករសម្រូប

gruau ឬ **gruo** *n.m.* កូនក្រៀល

grue *n.f.* ក្រៀល (cri: la grue glapit, trompette, craque)។ *Fig.* faire le pied de grue ឈរចាំយូរ ។ *Fam.* ស្រីខូច ។ *Mécan.* ម៉ាស៊ីនស្ទូច

gruger *v.t.* ទំពាំបែក, ទំពាំទំពា (ឧ. gruger du sucre) ។ *Fig.* ស៊ីជីង (ស៊ីដោយសារគេ) (ឧ. gruger un naïf); បោក, លួច (ឧ. gruger quelqu'un)

grugeur,euse *n.Fam.* អ្នកស៊ីជីងគេ

grume *n.f.* សំបកឈើហុប ។ bois de grume ឬ bois en grume ឈើហុបទាំងសំបក

grumeau *n.m.* ដុំតូច (នៃវត្ថុដែលកកស្អិត) (ឧ. grumeau de sang)

grumeler (se) *v.pr.* កកជាដុំតូចៗ(ឧ. le lait tourné se grumelle)

grumelleux,euse *a.* ដែលកកជាដុំតូចៗ; ដែលមានពកតូចៗ

grumelure *n.f.* ប្រហោងសាច់លោហធាតុស្អិត

grutier *n.m.* ជាងកាន់ម៉ាស៊ីនស្ទូច

gruyer,ère *a.* ដូចក្រៀល

gruyère *n.m.* ប្រហុកម៉ាសក្រុយយែរ (ធ្វើនៅប្រទេសស្វីស)

guano *n.m.* ដីអាចម៍សត្វ; ដីកាកត្រី

gué *n.m.* កន្លែងដែលគេលុយឆ្លងបាន (ស្ទឹង)

guéable *a.* អាចលុយឆ្លងបាន

guéer *v.t.* លុយឆ្លង,បោកឬលាងក្នុងទឹកហូរ (ឧ. guéer du linge, des chevaux)

guenille *n.f.* កន្ទប (ឧ. mendiant couvert de guenille) ។ *pl.* សំលៀកបំពាក់ចាស់

guenilleux,euse *n.&a.* ដែលស្លៀកកន្ទប

guenillon *n.m.* កន្ទបតូច

guenipe *n.f.Fam.* ស្រីស្មោកគ្រោកឬថោកទាប; ស្រីពេស្យា

guenon *n.f.* ស្វាញី ។ *Vulg.* ស្វាញី។ *Par ext.* ស្រីរូបអាក្រក់

guenuche *n.f.* ស្វាតូច ។ *Par ext.* ស្រីមាឌតូចរូបអាក្រក់

guépard *n.m.* ខ្លាប៉ាំងដូចខ្លារខិន

guêpe *n.f.* ឪម៉ាល់ (ឧ. les piqûres de la guêpe sont très dou-

loureuses)។ taille de guêpe កង់រៀវ ។ *Fig.* មនុស្សខ្ជួប (ចូលចិត្តរំភទ់ ចាក់ដោត ឬខាំនេត) ។

Prov. où la guêpe a passé, le moucheron demeure ការធ្វើដែលអ្នកធំធ្វើបាន អ្នកតូចរកបធ្វើមិនបាន ; ខ្វនតូចកុំប្រជួបនឹងអ្នកធំ

guêpier *n.m.* សំបុកឪម៉ាល់ ។ *Fig.* ការលួន (ន. tomber dans un guêpier); បក្សីស៊ីឪម៉ាល់

guère *adv.* មិនសូវ (ន. cet écolier n'est guère sérieux)

guérêt *n.m.* ដីភ្ជួរផ្ងាក់(ដីភ្ជួរមិនទាន់សាប) (ន. laisser une terre en guérêts) ; ដីទុកទំនេរ (ន. lever ឬ relever les guérêts) ។ *Par ext.* ភិលស្មើរញ (មិនសូវសេរម្សៅ) ។ *Poét.* ចំការនឹងផលនៃចំការ

guéreter *v.t.* ភ្ជួរផ្ងាក់; ទុកទំនេរ (ដី) (ន. guéreter une jachère)

guéridon *n.m.* តុមូលជើងតែមួយ, តុរ៉ៃ

guérilla *n.f.* ទ័ពព្រៃ; ចំបាំងដោយទ័ពព្រៃ

guérillero *n.m.* ទាហានទ័ពព្រៃ (*pl.* des guérilleros)

guérir *v.t.* មើលឲ្យជា ។ *Fig.* ធ្វើឲ្យបាត់ (ឲ្យជា) (ន. guérir un enfant de sa timidité); ធ្វើឲ្យផុតពាក (ន. la vieillesse nous guérit de bien des illusions) ។ *v.i.* ជាពេក, សះស្បើយ (ន guérir rapidement) ។ *Fig.* ផុតពាក

guérison *n.f.* ដំណើរជា ឬ ផុតពាក (ន. guérison lente)

guérissable *a.* អាចមើលឲ្យជាបាន (ន. la passion du jeu est difficilement guérissable)

guérisseur *n.m.* គ្រូមើលជម្ងឺ (ន. les guérisseurs des campagnes sont souvent d'audacieux charlatans)

guérite *n.f.* តូបអ្នកយាម ។ *Pop.* officier de guérite ក្វនទាហាន។ ជំរ្រុក ។ gagner la guérite រត់រកជំរ្រក ។ ទៅរកផ្លូវមានជំបូល

guerre *n.f.* សង្គ្រាម, ចំបាំង ។ *Par ext. Art mil.* យុទ្ធសាស្ត្រ (ន. étudier la guerre; école de guerre) ។ *Par an.* ការប្រទាំគ្នា (ន. les lions ne font point la guerre aux lions (Fénelon)។ *Poét.* ប្រមាញ់, នេសាទ (ន. faire

la guerre aux cailles)។*Fig.* ការប្រយុទ្ធ (ឧ. on entre en guerre en entrant dans le monde (Voltaire) ។

Adm. Conseil de guerre ម.ព. conseil ។

Loc. div. guerre étrangère សង្គ្រាមបរទេស(រវាងប្រជាជាតិមួយនឹងប្រជាជាតិមួយ) ។ guerre civile ឬ intestine សង្គ្រាមក្នុងប្រទេស ឬ សង្គ្រាមគ្នាឯង ។ guerre de religion សង្គ្រាមសាសនា ។ guerre sainte សន្តសង្គ្រាម (សង្គ្រាមនៃពួកគ្រិស្តសាសនិក ដើម្បីដណ្ដើមយកក្រុងប៉ាឡេស្ទីនជាដើម) ។ guerre à mort, guerre d'extermination ឬ guerre à outrance សង្គ្រាមគ្មានប្រណី (ទាល់តែស្លាប់ម្ខាងៗ); *au fig.* ការព្យាយាមបំផ្លាញអ្វីមួយមិនឈប់ ។ petite guerre សង្គ្រាមតូច(ការប្រយុទ្ធបន្តិចបន្តួច ដើម្បីយាយី ឬ ល្បងកម្លាំងបច្ចាមិត្រ);សង្គ្រាមសម(ការហាត់ច្បាំងរវាងគ្នាឯង) ។ bonne guerre សង្គ្រាមដោយគ្មានកលល្បិច;របៀបការពារសិទ្ធិខ្លួនដោយត្រង់ ។ guerre ouverte សង្គ្រាមចំហ (ការប្រទូសរ៉ាយដោយចេញមុខ) ។ de guerre lasse ដោយលែងទ្រាំបាន ។ déclaration de guerre ការប្រកាសសង្គ្រាម ។ homme de guerre អ្នកសង្គ្រាមជំនាញ ។ foudre de guerre អ្នកសង្គ្រាមដែលគេស្ញែង(ឥឡូវនេះសម្រាប់តែនិយាយចំអក)។nom de guerre យុទ្ធនាម (ឈ្មោះដែលគេដាក់ឲ្យនៅពេលចូលកាន់កងទ័ព) ។ honneurs de la guerre កិត្តិយសនៃសង្គ្រាម (កិត្តិយសទុកឲ្យអ្នកចាញ់នៅកាន់អាវុធ); *au fig.* ការនៅមានប្រៀបក្នុងកិច្ចជជែក; កិត្តិយសនៃជ័យជំនះ ។ tour de vieille guerre កលដែលចេះដោយបានពិសោធមកយូរហើយ ។ faire la guerre à quelqu'un ប្រយុទ្ធនឹងអ្នកណាម្នាក់;*au.fig.*ជំទាស់គោលបំណងអ្នកណាម្នាក់ ; ស្ដីប្រដៅ (ឧ. faire la guerre à un écolier paresseux); ជន្ទះជន្ទេញមិនឈប់; រិះគន់, ស្ដីបន្ទោស ។ faire la guerre à quelque chose ខំប្រឹងបំផ្លាញអ្វីមួយ (ឧ. faire la guerre à ses passions) ។ être à la guerre ទៅច្បាំង

កើតសង្គ្រាម (ឧ.les évènements sont à la guerre); នាំឲ្យកើតសង្គ្រាម(ឧ.un empire militaire est toujours à la guerre)។ s'en aller en guerre ទៅច្បាំង, ចេញធ្វើសង្គ្រាម (ចេញដំណើរដើម្បីទៅធ្វើសង្គ្រាម); ចូលធ្វើសង្គ្រាម ។

Prov. & loc. prov. à la guerre comme à la guerre បើទៅច្បាំងគិតតាមទៅច្បាំង (ត្រូវចេះអត់ទ្រាំការខ្វះខាតតាមទេសៈកាលៈ) ។ qui terre a guerre a មានទ្រព្យមានជម្លោះ(ទ្រព្យសម្បត្តិ ជាហេតុនាំឲ្យឈ្លោះគ្នា)។ la guerre nourrit la guerre សង្គ្រាមចិញ្ចឹមសង្គ្រាម(របស់ដែលយកបានពីសត្រូវក្នុងពេលសង្គ្រាមអាចចិញ្ចឹមទ័ពបាន) ។ si tu veux la paix, tiens-toi prêt à faire la guerre បើអ្នកចង់សុខត្រូវប្រុងប្រៀបធ្វើសង្គ្រាម (ព្រោះអ្នកដែលមានកម្លាំង គ្មានអ្នកឯណាហ៊ានជិះជាន់ទេ)

guerrier,ère *a.* នៃចំបាំង(ឧ. exploit guerrier); ដែលចូលចិត្តច្បាំង (ឧ. nation guerrière) ។ *n.m.* យោធិន, អ្នកច្បាំង ។ *Poét.* ពល, ទាហាន

guerroyant,e *a.* ដែលចូលចិត្តធ្វើសង្គ្រាម (ឧ. être d'humeur guerroyante)

guerroyer *v.i.* ធ្វើសង្គ្រាម, ច្បាំង (ឧ. aimer à guerroyer)

guerroyeur *n.&a.m.* ដែលចូលចិត្តសង្គ្រាម (ឧ. Charles le Téméraire fut guerroyeur)

guet *n.m.* ការលប, ការឈ្លប, ការឃ្លាំមើល (ឧ. faire le guet)

guet-apens [ghè-ta-pan] *n.m.* អំពើលួចស្ទាក់ (ឧ. le guet-apens est une circonstance aggravante du crime)។ *Fig.* បំណងនឹងបំផ្លាញ(*pl.* des guets-apens)

guêtre *n.f.* ស្រោមស្មងជើង

guêtrer *v.t.* ពាក់ស្រោមស្មងជើង

guetter *v.t.* ឃ្លាំមើល (ឧ. guetter l'ennemi)។ *Fam. & Fig.* ស្ទាក់; រង់ចាំ (ឧ. guetter l'occasion រង់ចាំឱកាស)

guetteur *n.m.* អ្នកឃ្លាំមើល; អ្នកយាម

gueulard,e *n.Pop.* អ្នកឡូឡា។ *Pop.* មនុស្សល្មោភ ។ *n.m.Mar.* ប្រដាប់បំពងសំឡេង

gueule *n.f.* មាត់សត្វ។ *Fig.* gueule d'un four មាត់ឡ។ gueule d'un tunnel មាត់ឧមង្គ ។ tonneau à gueule bée ធុងបំហមាត់ម្ខាង ។ *Mar.* gueule-de-raie ឈ្មោះចំណងម្យ៉ាង។ *Pop.* មាត់ (ឧ. avoir une grande gueule); មុខ ។ *Par ext.* មនុស្សល្មោភស៊ី (ឧ. la gueule et le luxe sont la ruine des petits ménages) ។

Loc. fam. ឬ *pop.* gueule ferrée មនុស្សសំដីតកោះតបើយ ។ fine gueule អ្នកស្គាល់ម្ហូបឆ្ងាញ់ ។ gueule fraîche អ្នកស៊ីច្រើន ។ venir la gueule fraîche មកដោយឃ្លានខ្លាំង ។ donner sur la gueule à quelqu'un វាយ ឬ ទាស់ត្រូវមុខយ៉ាងខ្លាំង; *au fig.* ធ្វើឲ្យឈប់និយាយ ។ être fort en gueule និយាយច្រើនហើយមាត់អាក្រក់ ។ des mots de gueule សំដីអាក្រក់(ថ្វោះ,ប្រឡោះបោះ,ខ្ទោះខ្ទារ)។ avoir la gueule ouverte ឡូឡាច្រើន ។ avoir la gueule morte បាត់មាត់ (ស្ងៀមឈឹងលែងហើបហាមាត់បេញស្តី) ។ il n'y a que de la gueule បានតែមាត់,បេះតែថា (បានតែខាងថា ប៉ុន្តែមិនសូវធ្វើ)។ avoir la gueule pavée បរិភោគក្តៅ ឬ ហឹរ (ដោយមិនរលាក ឬ មិនក្តៅមាត់)។ venir la gueule enfarinée មកដោយទុកចិត្តស្លុង។ faire la gueule ងៀកងរ, កិកកុក ។ faire une gueule ធ្វើឡិងឡង់; ធ្វើមុខក្រញូវ ។ avoir une bonne gueule មានមុខស្រស់បស់ឬមានមុខអាក្រក់,គាយទាញ់ចោកគេ។ fermer sa gueule បិទមាត់(លែងនិយាយ)។ avoir la gueule de bois មិនស្រួលខ្លួន (ស្ងួតមាត់ហើយធ្ងន់ក្បាលដោយបរិភោគច្រើនពេកពីល្ងាច) ។ rincer la gueule បេញថ្លៃឲ្យផឹក។ être porté sur la gueule ចូលចិត្តស៊ីផឹក ។ sale gueule, gueule de raie ឬ gueule d'empeigne មុខអាក្រក់ ។ donner un coup de gueule ច្រៀង, ស្រែក។ mettre ឬ laisser quelqu'un à la gueule du loup នាំឲ្យពើបប្រទះគ្រោះថ្នាក់ធំ; ទុកឲ្យរងគ្រោះថ្នាក់ធំ ។

Prov. la gueule tue plus

de gens que le glaive សេចក្ដីល្មោភធ្វើឲ្យមនុស្សវិនាសច្រើនជាងអាវុធទៅទៀត ។

Véner. ព្រុសចេញ (ឆ្កែ)

gueuler *v.i. Pop.* ឡូឡា, ស្រែក ។ *v.t.* gueuler des chansons ស្រែកច្រៀង

gueuleton *n.m. Pop.* ការជប់លៀងដោយម្ហូបពោរពាស

gueuletonner *v.i. Pop.* ជប់លៀងដោយម្ហូបពោរពាស

gueusaille *n.f. Fam.* ហ្វូងមនុស្សពោកយ៉ាក ឬ មនុស្សខូច

gueusailler *v.i.Fam.* រស់ដោយពោកយ៉ាក

gueuse *n.f. Ind.* ដុំដែកស្អិតដាក់ក្នុងពុម្ពដីខ្សាច់; ពុម្ពដីខ្សាច់សម្រាប់ដាក់ដែកស្អិត ។ *Sports* ដុំដែក (សំរាប់លើកហាត់)

gueuser *v.i.* ធ្វើជាមនុស្សពោកយ៉ាក; សុំទាន ។ gueuser une place សុំកន្លែង

gueuserie *n.f.* លក្ខណៈឬទម្លាប់មនុស្សពោកយ៉ាក; សេចក្ដីពោកយ៉ាក; ការសុំទាន; របស់ថោកទាប

gueux,euse *n.&a.* មនុស្សពោកយ៉ាក (ឧ.on peut être pauvre sans être gueux)។ *Par ext.* មនុស្សខូច

gui *n.m.* បញ្ញើក្អែក(ឧ. le gui était, pour les Gaulois, une plante sacrée)

guibolle *n.f. Pop.* ជើង

guiche *n.f.* ព្រំត្រឡូវខែល

guichet *n.m.* បញ្ជរ (ប័ញ-ជ), ប្រហោងតោះនៅជញ្ជាំង។ guichet de contrôle បញ្ជរពិនិត្យ

guichetier *n.m.* បញ្ជរបាល (ប័ញ-ជ:-រ:-បាល)

guide *n.m.* មគ្គុទ្ទេសក៍, អ្នកនាំផ្លូវ (ឧ. guide d'Angkor)។ *Mil.* មេជួរ (អ្នកដែលឈរឲ្យគេតម្រង់ជួរតាម) ។ *Fig.* មគ្គុទ្ទេសក៍,អ្នកឲ្យឱវាទ,អ្នកបង្ហាត់បញ្ញា(ឧ.guide éclairé)។ guide de papier គន្លងក្រដាស

guide *n.f.* ខ្សែបង្ហៀរ ។ *pl.* ខ្សែរទេះ (ល្បួលជិះរទេះ)។ *Fig.* mener la vie à grandes guides ចាយធំ

guide-âne *n.m.* គម្រោ; ក្រដាសឆ្នូសម្រាប់ផ្ទាប់សរសេរពីលើ (*pl.* des guide-ânes)

guider *v.t.* នាំផ្លូវ (ឧ. guider un

aveugle); បរ (ឧ. guider une automobile)។ *Fig.* ណែនាំ(ឧ. guider un enfant dans ses études); បង្ហាញផ្លូវ; គ្រប់គ្រង

guidon *n.m.* ឧទ្ទេសសញ្ញា; អ្នកកាន់ឧទ្ទេសសញ្ញា; ស្លាមកន្ទួលលើបំពង់កាំភ្លើងសម្រាប់តម្រង់; ដៃកង់ (ចង្កូតទោចក្រយាន)

guignard,e *a.* ស៊យ, អភ័ព្វ(ក្នុងល្បែង) (ឧ. un joueur guignard)

guigne *n.f.* ឬ **guillon** *n.m.* ផ្លែសារីសម្យ៉ាង ។ *Fam.* កាពស៊យឬអភ័ព្វក្នុងល្បែង

guigner *v.i.* មើលតាមកន្ទុយភ្នែកដោយធ្វើភ្នែកព្រិមៗ។ *v.t.* លួចមើល។ *Fig. &fam.* សំឡឹងរៀកៗ; ចង់បាន (ឧ. guigner un emploi)

guignier *n.m.* ដើមសារីសម្យ៉ាង

guignol *n.m.* រូបអាយ៉ង ។ *Par ext.* ល្ខោនរូបអាយ៉ង (ឧ. monter un guignol) ។ *Fig.* មនុស្សកំប្លែង (ឧ. faire le guignol)

guignolant,e *a.* ម.ព.guignonnant

guignon *n.m.* *Fam.* កាពស៊យ (ឧ. avoir du guignon) ។ porter guignon ស៊យ, ចង្រៃ

guignonnant,e ឬ **guignolant,e** *a.* *Fam.* ស៊យ។ guignon guignonnant ឬ guignolant កាពស៊យណាស់

guillaume *n.m.* ដែកឈូសឈក

guilledou *n.m.* *Fam.* courir le guilledou ទៅកាន់កន្លែងមិនល្អញយៗ

guillemet *n.m.* អញ្ញប្រកាស « ... » (ឧ. ouvrir, fermer les guillemets)

guillemeter *v.t.* ដាក់អញ្ញប្រកាស(ឧ. guillemeter une citation)

guilleret,ette *a.* ហ៊ើសហើយរីករាយ (ឧ. air guilleret; un vieillard tout guilleret)

guilleri *n.m.* សូរចាបស្រុកយំ។compère guilleri តួនៃចម្រៀងអ្នកស្រុក

guillotine *n.f.* ម៉ាស៊ីនកាត់ក; ទោសប្រហារជីវិត

guillotiné,e *a.* ដែលត្រូវកាត់កដោយម៉ាស៊ីន

guillotinement *n.m.* ការកាត់កដោយម៉ាស៊ីន

guillotiner *v.t.* កាត់កដោយម៉ាស៊ីន(ឧ. Robespierre fut guillotiné)

guillotineur *n.m.* *Fam.* អ្នកកាត់

ទោសប្រហារជីវិតដោយម៉ាស៊ីនកាត់ក ; ពេជ្ឈឃាដប្រើម៉ាស៊ីនកាត់ក

guimbarde *n.f. Fam.* រទេះចាស់ ; សម្រាប់កោសកន្លែងដិត ; រទេះអ្បាំង សម្រាប់ដឹកស្រូវ ។ *Par ext.* រទេះ មិនល្អ ។ *Mus.* អង្គួច

guindage *n.m.* ការលើកដាក់ដោយ គ្រឿងយន្ត

guindal *n.m.* គ្រឿងយន្តលើកដាក់ ទំនិញក្នុងនាវា

guindant *n.m. Mar.* កំពស់ទង់ទង់ (បណ្តោយគេហៅថា ballant)

guindé,e *a.* ដែលធ្វើឫកពា (ឧ. personnage guindé)

guindeau ឬ **guindas** *n.m. Mar.* កង្ហារខារយុថ្កា

guinder *v.t.* លើកដាក់ដោយគ្រឿង យន្ត ។ *Théâtr.* guinder les portes ចងទ្វារដោយខ្សែ ។ *Fig.* ធ្វើឫកពា; ក្រឹង (ឧ. guinder son style) ។ se guinder *v.pr.* ឡើងដោយលំបាក (ឧ. nous nous guindons à un sixième; se guinder au huitième étage); ឡើងខ្ពស់ (ឧ. se guinder sur des échasses) ។ se guinder sur la pointe des pieds ចំអើត ។ *Fig.* ធ្វើឫកពា; ធ្វើឫកខ្ពស់

guinderesse *n.f.* ពួរធំ

guinée *n.f.* ហ្គីណេ, រូបិយវត្ថុពណ៌អង់គ្លេស ; ទេសឯកត្បាញនៅប្រទេសអង់គ្លេស

guingois *n.m.* ភាពវៀច ឬ ទៀរ ។ de guingois *loc adv.* ខុស (ឧ. marcher de guingois)

guinguette *n.f.* តៀមស្រានៅជាយក្រុង

guipage *n.m.* ស្រោមខ្សែអគ្គិសនី

guiper *v.t.* ត្បូបលើខ្សែកខ; រុំខ្សែ អគ្គិសនីកុំឲ្យឆ្លងភ្លើង

guirlande *n.f.* កម្រងផ្កាឬស្លឹក, ផ្កង

guirlander *v.t.* ក្រង; តែងលំអដោយ កម្រងផ្កាឬស្លឹក

guisarme *n.f.* ដាវមានងៀង

guise *n.f.* របៀប;បែប (ឧ. chacun se gouverne à sa guise) ។ en guise de *loc. pré.* ជាជំនួស (ឧ. se servir d'un bâton en guise de canne) ។ faire à sa guise ធ្វើតាមអំពើចិត្តខ្លួន

guitare *n.f.* ហ្គីតា, ចាប៉ីខ្សែប្រាំមួយ ។ *Fig. & Fam.* សំដីស្រដៀង

guitariste *n.* អ្នកកាន់ហ្គីតា

guitoune *n.f.Arg.mil.* ជំរំសំពត់ (ឧ. couchier sous la guitoune)

gummifère *a.* ដែលឲ្យជ័រ(ឧ. arbre gummifère)

gustatif,ive *a.* នៃជីវ្ហាប្រសាទ

gustation *n.f.* ការភ្លក់; ការដឹងនូវជារស

gutte *n.f.* ម.ព. gomme-gutte

guttural,e,aux *a.* នៃបំពង់ក (ឧ. angine gutturale)។ *n.f. Gram.* កណ្ឋជៈ, ដែលអានតាមបំពង់ក ។ *a.* consonne gutturale ព្យញ្ជនៈកណ្ឋជៈ (ក, គ, k, q)

gymnase *n.m.* គ្រឹះស្ថានអប់រំឬហ្វឹកហ្វឺន

gymnaste *n.m.* គ្រូហ្វឹកហ្វឺន

gymnastique *a.* នៃការហ្វឹកហ្វឺន ។ pas gymnastique ការរត់ត្រូវចង្វាក់ ។ *n.f.* ការហាត់ប្រាណ (ឧ. la gymnastique fut très en honneur chez les Anciens)។ *Fig.* ការហ្វឹកហ្វឺន(ឧ. la gymnastique de la mémoire)

gymnique *n.f.* វិជ្ជាហាត់ប្រាណ

gymnospermes *n.f. pl. Bot.* អក្ខុនបុប្ផណ្ឌជាតិ ។ *sing.* le pin est un gymnosperme

gynécée *n.f.* ថែវសម្រាប់ស្ត្រី ។ *Bot.* ស្បូនផ្កា

gynécologie *n.f.* វិទ្យាសាស្ត្រខាងសរីរៈស្ត្រី; វិជ្ជាពេទ្យខាងភេទរបស់ស្ត្រី

gynécologue ឬ **gynécologiste** *n.m.* ពេទ្យជំនាញខាងសរីរៈស្ត្រី

gypse *n.m.* អាចុណ្ណសិលា

gypseux,euse *a.* ដូចអាចុណ្ណសិលា; ដែលមានលាយអាចុណ្ណសិលា

gypsomètre *n.m.* អាចុណ្ណមាត្រ

gyromancie *n.f.* ការទាយដោយបង្វិលអក្សរ

gyroscope *n.m.* ប្រដាប់សំរាប់បង្ហាញភស្តុតាងជាដីវិល; គ្រឿងទប់មិនឲ្យឃ្លោង

gyrostat *n.m.* អ្វីៗដែលវិលជុំវិញស្នូល

h *n.m.* អក្សរទី ៨ នៃអក្ខរក្រមឡាតាំង ។ l'heure H ម៉ោង ម (ម៉ោងភយលុក ឬម៉ោងកំណត់ទុកមុនដើម្បីប្រតិបត្តិការអ្វីមួយ)

ha ! *int.* យីអើ! (សំនែងសេចក្ដីឆ្ងល់) ។ ha! ha! ហា! ហា! (សូរសើចខ្លាំងព្រមគ្នា) (ឧ. ha! ha! que c'est drôle) ។ *n.m. inv.* pousser des ha ឈាន់មាត់ ថា អា! ឬ អៃយ៉ា!

habile *a.* ប្រសប់ (ឧ. un habile ouvrier)។ *Dr.* អាចនឹង,មាននីតិសម្បទា(ឧ. habile à tester)

habilement *adv.* យ៉ាងប្រសប់

habileté *n.f.* ការប្រសប់ (ឧ. la plus grande habileté consiste souvent à n'en pas montrer)

habilitation *n.f. Dr.* ការឲ្យមាននីតិសម្បទា

habilité *n.f. Dr.* នីតិសម្បទា (ឧ. l'habilité à succéder cesse après le sixième degré de parenté)

habiliter *v.t. Dr.* ឲ្យមាននីតិសម្បទា (ឧ. habiliter un mineur)

habillable *a.* អាចស្លៀកពាក់ឲ្យបាន; អាចកាត់សំលៀកបំពាក់ឲ្យសមបាន(ឧ. homme contrefait difficilement habillable)

habillage *n.m.* ការស្លៀកពាក់ឲ្យ ។ *Arbor.* ការកាស់ (ការកាត់ឫស ឬ

កាត់ក្បាលមែកខ្ចះចេញ) ។ *Art culin.* ការធ្វើ(ស្រកា,ដោចកេម,ពះពោះវៀន។) (ឧ. habillage d'un lièvre, d'une perdrix, d'un poisson)។ *Com.* សំល្បះតាំងទំនិញ (ឧ. habillage de draps, de cotonnades) ។ *Ind.* ការបិទស្លាក (មុននឹងដាក់លក់) ។ *Nav. fluv.* ការចងក្បូនភ្ជាប់គ្នា ។ *Pêch.*ការកាត់ស្រកីត្រី (នៃលមេត្រូវការប្រឡាក់អំបិល) ; ការពះពោះត្រី ។ *Techn.* ការសំអាតបង្ហើយ,ការដាក់គ្រឿងបន្ទាប់បន្សំបង្ហើយ ។ habillage d'une meule ការដាក់ធ្មេញក្បាលកិនឡើងវិញ, ការដាប់ធ្មេញក្បាលកិនឡើងវិញ ។ *Typogr.* ការរៀបចំទំព័រសៀវភៅ (រោងពុម្ព)

habillant,e *a.* សម (ឧ. étoffe habillante)

habillement *n.m.* ការស្លៀកពាក់ខ្លួន; ការផ្តល់សំលៀកបំពាក់ (ឧ. l'habillement des troupes);សំលៀកបំពាក់; របៀបស្លៀកពាក់ (ឧ. dans l'habillement se reflète le caractère des individus aussi bien que l'esprit d'une époque) ។ l'habillement de tête មួក

homme de couleur ជនស្បែកខ្មៅ (ម.ព. couleur ផង) ។ homme d'église អ្នកបួស(គ្រិស្តសាសនា) ។ homme de guerre ទាហាន ។ homme de troupe ពលទាហាន,កូនទាហាន។ homme de rue មនុស្សតាមតែប្រទះ, មនុស្សសាមញ្ញ។ homme à មនុស្សអាចប្រើប ឬ សម្រាប់ (ឧ. homme à tout entreprendre); មនុស្សដែលគួរ... (ឧ. un homme à ménager មនុស្សដែលគួរសំចៃ) ។

je suis votre homme ខ្ញុំស៊ូប្តូរនឹងលោកហើយ ។ voici justement notre homme នេះ៖ គឺជាមនុស្សដែលយើងត្រូវការ ឬ ដែលយើងនិយាយ ។

Prov. tant vaut l'homme, tant vaut la terre ដីឲ្យផលតាមកម្លាំងអ្នកធ្វើ

homme-sandwich *n.m.* អ្នកពាក់ប្រកាសនាដើមទ្រូង ឬនាខ្នងដើរផ្សាយ (ឧ. des hommes-sandwichs ឬ sandwiches)

homogène *a.* សភាគ [សៈ-ភាគ] ។ *Fig.* រួបរួមគ្នា,ស្មើដៃគ្នា (ឧ. équipe, groupe homogène)

homogénéifier ឬ **homogénéiser** *v.t.* ធ្វើឲ្យសភាគ

homogénéisation *n.f.* សភាគកម្ម [សៈ-ភា-គៈ-]

homogénéité *n.f.* សភាគភាព

homographe *a.* ដែលសរសេរដូចគ្នា (ចំពោះសទិសសព្ទ) (ឧ. bière ភេសជ្ជៈ និង bière មឈូស)

homologation *n.f.* សទិសានុញ្ញាត (ការយល់ព្រមពីរដ្ឋាភិបាល ឬតុលាការ) (ឧ. l'homologation d'un concordat)

homologie *n.f.* សទិសភាព, ភាពដូចគ្នា

homologue *a.* សទិសៈ, ដូចគ្នា

homologuer *v.t.* សទិសានុញ្ញាត (យល់ព្រមពីរដ្ឋាភិបាលឬតុលាការ) (ឧ. homologuer un record; prix homologués)

homonyme *Gram. a.&n.* សទិសសព្ទ [សៈ-ទិ-សៈ-] ។ *n.m.* មាននាមដូចគ្នា

homonymie *n.f.* ភាពជាសទិសនាម

homopétal *a.* សទិសទលី [សៈ-ទិ សៈ-ទៈ-លី-], ដែលមានត្របកដូចគ្នា(ផ្កា)

homophone *a.* ដែលមានសំឡេង

ដូចគ្នា (ឧ. mots homophones)

homophonie *n.f. Gram.* ភាពមានសំឡេងដូចគ្នា

homosexualité *n.f.* លក្ខណៈចិត្តប្រតិពទ្ធចំពោះមនុស្សភេទដូចគ្នា

homosexuel,elle *a.&n.* ដែលមានចិត្តប្រតិព័ទ្ធចំពោះមនុស្សភេទដូចគ្នា

homuncule ឬ **homoncule** *n.m.* កូនក្រក ។ *Fam.* មនុស្សកញ្ជ្រឹក (មាឌតូច)

hongre *n.&a.m.* ក្រៀវ (ចំពោះសេះដែលគេក្រៀវតាមរបៀបប្រទេសហុងគ្រី)

hongrer *v.t. Vétér.* ក្រៀវតាមរបៀបប្រទេសហុងគ្រី

hongreur *n.m.* អ្នកក្រៀវសេះតាមរបៀបប្រទេសហុងគ្រី

hongrois,e *a.* នៃប្រទេសហុងគ្រី ។ *n.* ជនជាតិហុងគ្រី ។ *n.m.* ភាសាហុងគ្រី

hongroyer *v.t.* សម្លាប់ស្បែកតាមរបៀបប្រទេសហុងគ្រី

hongroyeur *n.m.* ជាងសម្លាប់ស្បែកតាមរបៀបប្រទេសហុងគ្រី

honnête *a.&n.* ទៀងត្រង់(ឧ.garçon honnête); សមរម្យ (ឧ. récompense honnête); គួរសម; ប្រកបដោយគុណធម៌ ។ *n.m.* សេចក្ដីទៀងត្រង់ ឬសមរម្យតាមគុណធម៌(ឧ.préférer l'honnête à l'utile)

honnêtement *adv.* ដោយទៀងត្រង់; ដោយសមរម្យ (ឧ. gagner honnêtement sa vie)

honnêteté *n.f.* សេចក្ដីទៀងត្រង់ (ឧ. l'honnêteté est essentielle en affaires); សេចក្ដីសមរម្យ; ភាពមានអៀនខ្មាស (ឧ. femme remplie d'honnêteté);សេចក្ដីគួរសម (ឧ. faire mille honnêtetés à quelqu'un)

honneur *n.m.* កិត្តិយស (ឧ. le véritable honneur réside dans la vertu) ។

Par ext. être l'honneur de ជាកិត្តិយសនៃ(ឧ. être l'honneur de son pays); ជាលំអនៃ (ឧ. la rose est l'honneur des jardins); កិត្តិយស(សេចក្ដីគោរព) (ឧ. donner une fête en l'honneur de quelqu'un)។

Mar. ranger à l'honneur បើកប្របេះប៉ុន្តែមិនឲ្យប៉ះ (ឧ. ranger à l'honneur un

écueil, un navire); faire honneur à មិនចូលជិតពេក (ឧ. faire honneur à un rocher, à une jetée) ។

Loc.adv. en l'honneur de ជាកិត្តិយសចំពោះ ។ en tout bien et en tout honneur ឬ en tout bien, tout honneur ដោយបំណងល្អ ។ pour l'honneur de ឬ à l'honneur de ដើម្បីកេរ្តិ៍ឈ្មោះនៃ ។ pour l'honneur ដើម្បីកិត្តិយស (គ្មានកម្រៃអ្វីក្រៅអំពីកិត្តិយស)។ honneur à កិត្តិយសចូរមានដល់ (ឧ. honneur aux braves, aux talents!)។ faux honneur កិត្តិយសខុសកាល។ honneurs funèbres ឬ honneurs de la sépulture ឬ honneurs suprêmes ឈាបនកិច្ច ។ honneurs de la guerre ម.ព. guerre ។ sans honneur ដោយអប្បយស ។ sur l'honneur ឬ sur mon honneur ឬ d'honneur ឬ foi d'homme d'honneur លើកិត្តិយស (ការស្បថយកកិត្តិយសជាប្រធាន)។ parole d'hønneur ពាក្យសត្យ (ការសន្យាដែលយកកិត្តិយសជាប្រធាន) ។ champ d'honneur ម.ព. champ ។ point d'honneur ចំណុចកិត្តិយស (អ្វីៗដែលប៉ះពាល់ដល់កិត្តិយស) ។ affaire d'honneur រឿងកិត្តិយស; ការប្រយុទ្ធគ្នា ។ prix d'honneur រង្វាន់កិត្តិយស។ être en honneur មានគេគោរព; មានគេរាប់អាន (ឧ. la beauté n'a été nulle part plus en honneur qu'en Grèce) ។ mettre en honneur លើកដំកើង (ឧ. il a mis les humanités en honneur)។ faire honneur à គោរព, ដំកើង, លើកកិត្តិយស (ឧ. faire honneur à son siècle, à son nom); ឲ្យផល, ឲ្យកម្រៃ (ឧ. on dit d'un homme gras à lard que ce qu'il mange lui fait honneur)។ faire honneur à un dîner បរិភោគបានច្រើន ។ faire honneur à ses engagements ឬ à sa parole កាន់ពាក្យសន្យា ។ faire honneur à une lettre

de change សងប្រាក់គ្រប់ចំនួនតាមរូបិយាណត្តិ ។ faire honneur à quelqu'un d'une chose ឲ្យរបស់អ្វីទៅអ្នកណាម្នាក់ ។ se faire honneur de quelque chose ឬ s'en donner l'honneur អួតថារបស់អ្វីមួយកើតដោយសារខ្លួន (ឧ. se faire honneur des succès d'un ami) ។ faire les honneurs de ធ្វើជាប្រធានក្នុង; ទទួលភ្ញៀវ, ទទួលដោយគួរសម (ឧ. faire les honneurs de sa table, de sa maison, d'un bal) ។ mettre son honneur à យកកិត្តិយសជាត្រើមុខដោយ ។ tenir à honneur ទុកដាក់ជាប្រកបដោយកិត្តិយស ។ piquer quelqu'un d'honneur ពន្យល់ថាជាការប៉ះពាល់ដល់កិត្តិយស ។ se piquer d'honneur ខំប្រឹងប្រែងយកកិត្តិយស ។ dame d'honneur ស្រីស្នំ ។ demoiselle d'honneur កញ្ញាកិត្តិយស (កញ្ញាអ្នកហែហមកូនក្រមុំក្នុងពិធីអាពាហ៍ពិពាហ៍) ។ fille d'honneur កុមារីកិត្តិយស ។ garçon d'honneur កុមារកិត្តិយស (អ្នកហែហមកូនកម្លោះក្នុងពិធីអាពាហ៍ពិពាហ៍) ។

Prov. à tout seigneur, tout honneur ត្រូវគោរពមនុស្សតាមឋានៈរបស់គេ ។ les honneurs changent les mœurs អ្នកធ្វើធំច្រើនតែមិនយល់ញាតិ; យល់ញាតិឃ្លាតច្បាប់

honnir *v.i.* បំបាក់មុខ ឬធ្វើឲ្យអាម៉ាស់មុខកណ្ដាលបំណោម

honorabilité *n.f.* កិត្តិភាព, ភាពប្រកបដោយកិត្តិយស; ភាពគួរគោរព

honorable *a.* គួរនឹងកិត្តិភាព, ប្រកបដោយកិត្តិយស (ឧ. action honorable); គួរគោរព (ឧ. caractère, homme honorable)

honorablement *adv.* ដោយកិត្តិយស, យ៉ាងថ្លៃថ្នូរ

honoraire *a.* ដែលមានងារជាកិត្តិយស (ឧ. conseiller honoraire) ។ *n.m. pl.* ប្រាក់សគុណ; ខាន់ស្លា ។ honoraire d'un médecin កំណាល់ពេទ្យ ។ honoraire d'un avocat រង្វាន់មេធាវី

honorariat *n.m.* ងារជាកិត្តិយស

honorer *v.t.* គោរព (ឧ. honorer

la droiture; honorer les savants) ។ honorer une réunion de sa présence ទៅកាន់ទីប្រជុំ។ ធ្វើកិត្តិយសចំពោះ (ឧ. honorer son pays); ជូនកំណស់ពេទ្យឬមេធាវី,ជូនខាន់ទៅ(ឧ. honorer un médecin)

honorifique *a.* ដែលឲ្យមានកិត្តិយស (ឧ. charge honorifique); គ្រាន់តែជាកិត្តិយស(ឧ. un titre honorifique)

honorifiquement *adv.* ដោយគ្រាន់តែជាកិត្តិយស

honoris causa ជាកិត្តិយស

honte *n.f.* ហិរិ, សេចក្ដីខ្មាស (ឧ. rougir de honte); អ្វីៗដែលធ្វើឲ្យខ្មាស(ឧ.c'est une honte)។ avoir honte អៀន, ខ្មាស (ឧ. avoir perdu toute honte ឬ avoir toute honte bue លែងបេះអៀនខ្មាស ។ faire honte de បន្ទោស,បង្អាប់(ឧ. faire honte à un écolier de sa paresse)។ faire honte à ធ្វើឲ្យខ្មាសដល់ (ឧ. faire honte à ses parents ធ្វើឲ្យខ្មាសដល់ឪពុកម្ដាយ, ធ្វើឲ្យឪពុកម្ដាយខ្មាសគេ)

honteusement *adv.* ដោយខ្មាស, ដោយអៀន (ឧ. s'enfuir honteusement)

honteux,euse *a.* ដែលខ្មាស,អៀន(ឧ. honteux de sa conduite); ដែលនាំឲ្យខ្មាសឬឲ្យខូចកិត្តិយស (ឧ. fuite honteuse); អួរអុះ

hôpital *n.m.* មន្ទីរពេទ្យ ។ réduire à l'hôpital បង្ហិន ។ hôpital psychiatrique មន្ទីរពេទ្យវិកលចរិត

hoquet *n.m.* ការស្អឹក

hoqueter *v.i.* ស្អឹក

horaire *a.* នៃម៉ោង ។ salaire horaire ប្រាក់ឈ្នួលម៉ោង ។ *Astr.* នៃនាឡិកា ។ cercles horaires មណ្ឌលនាឡិកា ។ *n.m.* តារាងពេលម៉ោង (ឧ. horaire des trains)

horde *n.f.* ក្រុមជាតិដែលគ្មានកន្លែងនៅជាប់; កងទ័ពមិនរៀបរយ (ឧ. horde de brigands)

horizon *n.m.* ជលជាទ, ជើងមេឃ ។ *Fig.* ព្រំដែន (ឧ. l'horizon des connaissances humaines s'agrandit de jour en jour); អនាគត (ដែលប្រមើលឃើញ) (ឧ.

l'horizon politique s'éclaircit)។ *Peint.* ផ្ទៃមេឃក្នុងគំនូរ

horizontal,e,aux *a.* ទកាបទី; ផ្ដេក (ឧ. écriture horizontale) ។ *n.f. Math.* ទកាបទី, បន្ទាត់ផ្ដេក

horizontalement *adv.* ដោយផ្ដេក

horizontalité *n.f.* ភាពផ្ដេក (ឧ. l'horizontalité du plan)

horloge *n.f.* នាឡិកា។ *Fig.* réglé comme une horloge ទៀងទាត់ដូចនាឡិកា (ដែលមានទម្លាប់ទៀងទាត់ណាស់)

horloger *n.m.* ជាងនាឡិកា

horloger,ère *a.* នៃនាឡិកា (ឧ. l'industrie horlogère)

horlogerie *n.f.* កន្លែងធ្វើឬលក់នាឡិកា

hormis *pré.* លើកតែ (ឧ. hormis deux ou trois)។ hormis que *loc. conj.* គ្រាន់តែ

horoscope *n.m.* នក្ខត្តយោគព្យាករណ៍ (ការទាយតាមដួងជាតា); ទំនាយ

horoscopie *n.f.* នក្ខត្តយោគវិទ្យា

horreur *n.f.* សេចក្ដីរន្ធត់ (ឧ. être saisi d'horreur); សេចក្ដីស្អប់ខ្ពើម (ឧ. avoir horreur du mensonge); ភាពគួររន្ធត់ (ឧ. l'horreur d'un crime); មនុស្សរូបអាក្រក់ ។ *Fam.* quelle horreur! អាក្រក់អ្វីម៉្លេះ! ។ *pl.* អ្វីៗដែលគួរឲ្យរន្ធត់ (ឧ. les horreurs de la guerre); អំពើគួរឲ្យរន្ធត់ (ឧ. commettre des horreurs); សំដីអាសគ្រាម (ឧ. dire des horreurs)

horrible *a.* គួររន្ធត់ (ឧ. un spectacle horrible) ។ *Fam.* អាក្រក់ហួសប្រមាណ (ឧ. un bruit horrible) ។ *Par exag.* temps horrible អាកាសមិនល្អ

horriblement *adv.* ដោយគួរឲ្យរន្ធត់ឬដោយគួរឲ្យស្អប់ខ្ពើមក្រៃពេក (ឧ. horriblement cher)

horrifier *v.t.* ធ្វើឲ្យរន្ធត់, បំភ័យ

horrifique *a.* ដែលធ្វើឲ្យរន្ធត់

horripilant,e *a.* ដែលធ្វើឲ្យព្រឺរោម ។ *Fam.* ដែលឲ្យរន្ធត់ ។ *Par ext.* ដែលឲ្យខ្ញាញ់ (ឧ. spectacle horripilant)

horripilation *n.f.* ដំណើរព្រឺរោម (ឧ. on appelle familièrement l'horripilation «chair de poule» ou «petite mort»)។

Fig. សេចក្ដីក្នាញ់

horripiler *v.t.* តម្លើងរោម, ធ្វើឲ្យព្រឺរោម; ធ្វើឲ្យរន្ធត់ ។ *Par ext. & fam.* ធ្វើឲ្យក្នាញ់ (ឧ. ses manières m'horripilent)

hors *pré.* ក្រៅ (ឧ. hors série); ក្រៅពី, លើកតែ (ឧ. hors deux ou trois; hors cela) ។ mettre hors la loi ដាក់ក្រៅច្បាប់ ។ hors ligne ពិសេស, លើសលែង (ឧ. talent hors ligne)។ être hors concours ហួសថ្នាក់ប្រឡងប្រជែង។ hors texte ក្រៅអត្ថបទ (ម.ព. hors texte ផង) ។ hors tout ធំជាងគេ (ឧ. longueur hors tout) ។ hors de *loc. pré.* ខាងក្រៅ (ឧ. hors de chez soi)។ *Fig.* ផុតបាក (ឧ. être hors d'affaire ផុតបាកកង្វល់ឬឧបសគ្គ)។ hors d'atteinte ផុតដៃ (ចាប់លែងបាន) ។ hors de danger ផុតបាកគ្រោះថ្នាក់។ hors de doute ផុតសង្ស័យ ។ être hors de combat លែងប្រយុទ្ធកើត (ដោយត្រូវដំណំ)។ être hors d'usage ឬ de service លែងប្រើកើត (របស់ខូច) ។ être hors de prix លើសតម្លៃធម្មតា ។ être hors de pair ឬ hors pair គ្មានអ្វីផ្ទឹមបាន។ être hors de soi ខឹងប្រឡោកខ្លាំង ។ hors d'ici ! ចេញទៅ !

hors-bord *n.m.inv.* ឡូងបុត (ដែលមានម៉ាស៊ីនដាក់ក្រៅតួ)

hors-concours *n.m.* ហួសប្រជែង, មនុស្ស ឬ របស់ដែលហួសថ្នាក់ប្រឡងប្រជែង

hors-de-cause *n.m.inv.* អ្នកបានរួចខ្លួន (ដោយគេចោទប្រកាន់ខុស)

hors-d'œuvre *n.m. inv. Constr.* ញកផ្ទះ ។ របស់ថែម (ផ្នែកបន្ទាប់បន្សំដែលគេអាចដកហូតចេញបាន) (ឧ. rôle, épisse qui est un hors-d'œuvre) ។ *Cuis.* ម្ហូបថែម

hors-la-loi *n.m.inv.* ជនក្រៅច្បាប់

hors-texte *n.m.inv.* ពាហិររូប, រូបក្រៅអត្ថបទ (រូបដោយឡែកពីរឿងក្នុងសៀវភៅ)

horticole *a.* នៃសាកវប្បកម្ម (ឧ. la science horticole)

horticulteur *n.m.* សាកវប្បករ

horticulture *n.f.* សាកវប្បកម្ម

hospice *n.m.* សមាវសថាគារ, សាលា

សំណាក់; សង្គហដ្ឋាន (កន្លែងសង្គ្រោះក្មេងកំព្រា - មនុស្សពិការ - មនុស្សចាស់ ។ល។)

hospitalier,ère *a.* សមារីសចិ; នៃមន្ទីរពេទ្យ; នៃសង្គហដ្ឋាន; ដែលទទួលឲ្យនៅអាស្រ័យដោយឥតយកថ្លៃ

hospitalisation *n.f.* ការចូលព្យាបាលរោគក្នុងមន្ទីរពេទ្យ (ការចូលដេកពេទ្យ)

hospitaliser *v.t.* ឲ្យចូលព្យាបាលរោគក្នុងមន្ទីរពេទ្យ (ឲ្យចូលដេកពេទ្យ) (ឧ. hospitaliser un malade)

hospitalité *n.f.* សមារីសចិភាព; ការទទួលឲ្យសំណាក់អាស្រ័យឥតថ្លៃ (ឧ. donner hospitalité)

hostellerie *n.f.* ម.ព. hôtellerie

hostie *n.f.* សត្វដែលបូជាយញ្ញ

hostile *a.* អរិភូត, ដែលជាសត្រូវ (ឧ. attitude hostile)

hostilité *n.f.* ការជំទាស់ (ឧ. hostilité de principe) ។ *pl.* អរិភាព, ភាពជាសត្រូវ; ចំបាំង, ភាពកំពុងច្បាំង (ឧ. reprendre les hostilités)

hôte,hôtesse *n.* បាហុនកៈ-និកា, ម្ចាស់ផ្ទះ; អ្នកសំណាក់; នាយសណ្ឋាគារ; អ្នកស្រុក; ភ្ញៀវ។ *Poét.* les hôtes des airs បក្សី ។ les hôtes de la mer មច្ឆា, ត្រី។ *Av.* hôtesse de l'air អាកាសបាហុនិកា, ស្ត្រីអ្នកទទួលភ្ញៀវក្នុងយន្តហោះ

hôtel *n.m.* សណ្ឋាគារ (ឧ. descendre à l'hôtel) ។ hôtel de ville សណ្ឋាគារក្រុង ។ maître d'hôtel គប្រួតសណ្ឋាគារ

hôtel-Dieu *n.m.* មន្ទីរពេទ្យធំ (*pl.* des hôtels-Dieu)

hôtelier,ère *n.* សណ្ឋាគារិក - រិកា, អ្នកកាន់កាប់សណ្ឋាគារ ។ *a.* នៃសណ្ឋាគារ (ឧ. industrie hôtelière)

hôtellerie *n.f.* សណ្ឋាគារ

hotte *n.f.* ជាលព្រនរ

hottée *n.f.* ចំណុះជាលព្រនរ

hotter *v.t.* ដឹកដោយជាលព្រនរ (ឧ. hotter la vendange)

hottereau *n.m.* កូនជាលព្រនរ

houache *n.f.* ស្នាមនាវាបើក

houblon *n.m.* ហ៊ូប្លុង (លតាជាតិម្យ៉ាងដែលគេយកផ្លែអប់ស្រាបៀរ)

houblonnage *n.m.* ការបង់ហ៊ូប្លុងក្នុងកេសជ្ជៈ

houblonner *v.t.* បង់ហ៊ូប្លុងក្នុងកេសជ្ជៈ (ឧ. houblonner la bière)

houblonnier,ère *a.* នៃហ៊ូប្លុង

houdan *n.f.* មាន់ញីពូជហ៊ូដង់(ប្រទេសបារាំង)

houe *n.f.* ចបកាប់

houer *v.t.* កាប់ដីដោយចបកាប់

houille *n.f.* ធ្យូងថ្ម ។ houille blanche កម្លាំងទឹកឈូ។ houille bleue កម្លាំងរំជួលទឹក,កម្លាំងទឹកជោរនាច ។ houille incolore ឬ houille éolienne កម្លាំងខ្យល់ ។ houille d'or កម្លាំងរស្មីព្រះអាទិត្យ ។ houille rouge កម្លាំងកំដៅព្រះធរណី ។ houille minérale សិលាជតេល [–ជៈ-តៃល] (ប្រេងកាត,ប្រេងសាំង)

houiller,ère *a.* ដែលមានធ្យូងថ្ម (ឧ. terrain houiller); នៃធ្យូងថ្ម

houillère *n.f.* អណ្ដូងធ្យូងថ្ម

houilleux,euse *a.* ដែលមានធ្យូងថ្ម (ឧ. roche houilleuse)

houle *n.f.* រលកខ្ទោល, រំជួលសមុទ្រ

houler *v.i.* រំជួល (ទឹកសមុទ្រ); ជ្រួល

houlette *n.f.* ដង្កាក់(ប្រដាប់គោលគ្រវែងផ្លោងដុំដីបង្អើលសត្វ); កូនចបដីក

houleux,euse *a.* ញ័រយោលដោយរលក ។ *Fig.* ដែលរំជួល; ដែលកញ្ច្រោកកំរើក (ឧ. auditoire houleuse)

houppe *n.f.* កញ្ចុំរោមសត្វ-សូត្រ ។ល។ (ឧ. houppe à poudre de riz)

houppelande *n.f.* អាវក្រៅអ្យ៉ាងទូលាយ

houpper *v.t.* ចងជាកញ្ចុំ ។ houpper la soie សសិតសូត្រ។ houpper la laine សសិតរោមសត្វ

houppette *n.f.* កញ្ចុំរោមតូច

houppier *n.m.* ដើមឈើលះមែកអស់សល់តែត្រួយ; ត្រួយដើមឈើដែលគេលះមែកអស់

houri *n.f.* ស្រីសួគ៌ក្នុងសាសនាមហាម៉ាត់ ។ *Par ext.* ស្រីរូបល្អ

hourra *n.m.* សម្រែកសន្ទាប់, សម្រែកកិត្តិយស ។ *Par ext.* សម្រែកបន្លឺ

hourvari *n.m.* សម្រែកហៅឆ្កែឲ្យមករកកន្លែងដើមវិញ (ក្នុងការប្រដេញសត្វ) ។ *Fig. & fam.* សូរគឹកកង

houspiller *v.t.* ធ្វើបាប (ដោយស្ដីបន្ទោស)

houspilleur,euse *n.* អ្នកចូលចិត្តស្ដីបន្ទោស

housse *n.f.* ទ្រនាប់ខ្នងសេះ ; គម្រប, ស្រោម

housser *v.t.* បោសដោយអំបោសស្លាប

មាន់ ឬ ក្រែង

houssoir *n.m.* អំបោសស្លាបមាន់ ឬ អំបោសក្រែង

houx *n.m.* ហ៊ូ(រុក្ខជាតិប្រភេទស្លឹកមានបន្លា)

hoyau *n.m.* ចបកាប់ម្យ៉ាង

hublot *n.m.* បង្អួចនាវា ឬ យន្តហោះ

huche *n.f.* ស្នូកឈើរក្សានំបុ័ង

hucher *v.t.* បង្ហកហៅ

hue! *int.* ហ៊ុយ! (សម្រែកដេញសត្វឲ្យលឿន) ។ *Fig.* tirer à hue et à dia ធ្វើអ្វីដោយគ្មានសណ្ដាប់ធ្នាប់ (ប្រទាញទៅស្ដាំម្ដងទៅឆ្វេងម្ដង) (ម.ព. dia ផង)

huée *n.f.* ស្នូរដេញសត្វ ។ *Fig.* សម្រែកសង្កៀក (ឧ. il s'enfuit sous les huées)

huer *v.t.* ស្រែកសង្កៀក (ឧ. il se fit huer par la foule)។ *v.i.* យំ (ទីទុយ)

huhau! *int.* ស្ដាំ ! (សំដីឲ្យសញ្ញានិស្សេះឲ្យងាកស្ដាំ)

huilage *n.m.* ការដាក់ប្រេង

huile *n.f.* ប្រេង,ខ្លាញ់។ huile minérale ប្រេងកាត ។ *Fig.* faire tache d'huile រីកបន្តិចម្ដងៗ ។ mer d'huile សមុទ្រស្ងប់ឈឹង ។ verser ឬ jeter de l'huile sur le feu ដុតថែម;ញុះញង់ឲ្យរឹតតែឈ្លោះគ្នាខ្លាំង ។ sentir l'huile ឃើញថាប្រឹងប្រែងមែន (ដូចជាពុំទានប្រេងដែលអុជបំភ្លឺធ្វើការ) ។ il n'y a plus d'huile dans la lampe សោះអស់កម្លាំង (ស្លាប់ដោយអស់កម្លាំង) ។ *Fam.* les huiles អ្នកកាន់អំណាច, អ្នកធំ

huiler *v.t.* លាបប្រេង, ដាក់ប្រេង (ឧ. huiler les rouages)

huilerie *n.f.* កន្លែងធ្វើប្រេង,ហាងប្រេង

huileux,euse *a.* នៃប្រេង, នៃខ្លាញ់; ដែលមានប្រេង; ជើម (ឧ. peau huileuse)

huilier *n.m.* ដបដាក់ប្រេងនឹងទឹកខ្មេះ។ *n.&a.m.* អ្នកលក់ ឬ ធ្វើប្រេង

huis *n.m.* ទ្វារ ។ à huis clos ដោយបិទទ្វារ, គ្មានសាធារណៈ(បិទឲ្យសាធារណជនចូល) (ឧ. la cour siégeait à huis clos, étant donné l'aspect scandaleux du procès) ។ demander le huis clos សុំឲ្យជំនុំជម្រះដោយអសាធារណៈ

huisserie *n.f.* *Constr.* ក្រោងទ្វារ ឬ

បង្អួច

huissier *n.m.* ឆ្មាំទ្វារមហាក្សត្រ ឬ មន្ត្រីធំ; អាជ្ញាសាលា

huit *a.num.card.* ប្រាំបី; ទីប្រាំបី (ឧ. Charles VIII)។ *n.m. inv.* ថ្ងៃទី៨; លេខ ៨ (ឧ. un huit mal fait)

huitain *n.m.* កំណាព្យប្រាំបីឃ្លា

huitaine *n.f.* អដ្ឋកៈ, ប្រមាណជាប្រាំបី (ឧ. une huitaine de litres); រយៈពេលប្រាំបីថ្ងៃ។ *Par ext.* មួយអាទិត្យ ។ à huitaine ប្រាំបីថ្ងៃទៀត (ថ្ងៃខួបក្នុងអាទិត្យក្រោយ គឺជាបើគេនិយាយនៅថ្ងៃចន្ទ ដល់ថ្ងៃចន្ទក្រោយទៀត)

huitième *a.num. ord.* អដ្ឋមៈ, ទីប្រាំបី។ *n.* អ្វីៗដែលជាទីប្រាំបី ។*n.m.* ភាគប្រាំបី; ជាន់ទីប្រាំបី

huitièmement *adv.* ទ ៨, គំរប់ ៨

huître *n.f.* ងាវ។ huître perlière ងាវដែលមានគជ់ ។ *Fig.&Fam.* មនុស្សសម្ពឹក

huîtrier,ère *a.* នៃងាវ (ឧ.l'industrie huîtrière) ។ *n.f.* កន្លែងងាវ

hululer *v.i.* ម.ព. ululer

humage *n.m.* ការស្រូប ឬ បឺត

humain,e *a.* នៃមនុស្ស(ឧ. le corps humain; l'espèce humaine); ដែលមានមេត្តា, ដែលចេះជួយសង្គ្រោះ (ឧ. se montrer humain envers ses semblables) ។ le genre humain មនុស្សទាំងឡាយ, មនុស្សជាតិ ។ respect humain រអែងចំពោះពាក្យអ្នកផង។ *n.m. pl. Poét.* មនុស្ស

humainement *adv.* ជាមនុស្ស; តាមកម្លាំង ឬ សមត្ថភាពមនុស្ស; ដោយមនុស្សធម៌ (ឧ.traiter humainement un prisonnier)

humanisation *n.f.* ការធ្វើឲ្យកាន់តែល្អ ឬ ឲ្យកាន់តែសប្បុរស

humaniser *v.t.* ធ្វើឲ្យល្មមវិស័យមនុស្ស (ឧ.humaniser une doctrine); ធ្វើឲ្យកាន់តែល្អ ឬ ឲ្យកាន់តែសប្បុរស; ញ៉ាំងឲ្យមានអរិយធម៌ ។ s'humaniser *v.pr.* កាន់តែស្លូត

humanisme *n.m.* បុរាណភាសានិយម (ការលើកតំកើងភាសានិងអក្សរសាស្ត្របុរាណ); មនុស្សនិយម (ការនិយមលើកតំកើងមនុស្ស)

humaniste *n.m.&a.* អ្នកបុរាណភាសានិយម; អ្នកមនុស្សនិយម

humanitaire *a.* ប្រកបដោយមនុស្សធម៌ (ដែលជាប្រយោជន៍មនុស្សជាតិ) (ឧ. institutions humanitaires)។ *n. & a.* អ្នកប្រកបដោយមនុស្សធម៌ (ដែលយកចិត្តទុកដាក់នឹងប្រយោជន៍មនុស្សជាតិ) (ឧ. philosophe humanitaire)

humanitarisme *n.m.* មនុស្សធម្មនិយម

humanité *n.f.* មនុស្សជាតិ (ឧ. les faiblesses de l'humanité); មនុស្សទាំងឡាយ (ឧ. bienfaiteur de l'humanité); មនុស្សធម៌ (សេចក្ដីល្អ, មេត្តាចិត្ត) (ឧ. traiter quelqu'un avec humanité)។ *n.f. pl.* សិក្សាបុរាណកាលសា (ផ្នែកមធ្យមសិក្សាថ្នាក់ទី ៣, ទី២ និង ទី១) (ឧ. faire ses humanités)

humble *a.* ដែលដាក់ខ្លួន, រាបសា (ឧ. un homme humble); ដ៏តូចទាប, ដ៏ខ្សត់ខ្សោយ (ជាកិច្ចបន្ទាបខ្លួនដើម្បីសុំនែងការគោរព) (ឧ.humble prière; humble requête); ទន់ទាប (ឧ. humble fortune; humbles fonctions); តូចទាប (ឧ. humble chaumière)

humblement *adv.* ដោយរាបសា, ដោយខ្សត់ខ្សោយ

humectation *n.f.* ការជ្រមើម;ការសើម

humecter *v.t.* ជ្រមើម, ជ្រលក់ទឹក (ឧ. humecter du linge)។ s'humecter *v.pr.* ឡើងសើម។ *Pop.* s'humecter le gosier ផឹក

humer *v.t.* លេប, ស្រូប, ហុត (ឧ.humer un œuf); ហិត (ឧ. humer l'odeur d'un mets)

huméral,e,aux *a.* នៃឆ្អឹងដើមដៃ; នៃដើមដៃ

humérus *n.m.* ឆ្អឹងដើមដៃ (ពីស្មាដល់កែងដៃ)

humeur *n.f.* អាបោធាតុ (ធាតុទឹកក្នុងខ្លួន)។ humeur aqueuse អាបោធាតុរាវ។ humeur vitrée អាបោធាតុថ្លា។ *Fig.* អារម្មណ៍ ។ être de bonne humeur មានអារម្មណ៍ល្អ, សប្បាយចិត្ត។ être de mauvaise humeur មានអារម្មណ៍មិនល្អ,មួម៉ៅ។ humeur noire ទុក្ខព្រួយ

humide *a.* សើម, ទទឹក (ឧ. linge humide)។ *n.m.* អ្វីៗដែលសើម (ឧ.le sec et l'humide)។ yeux humides ភ្នែកសើមរលោង (ដោយ

ល៉ៃ) ។ l'humide élément ទឹក

humidement *adv.* ដោយសើមឬទទឹក

humidification *n.f.* ការផ្សើម,ការធ្វើឲ្យទទឹក,ការធ្វើឲ្យសើម

humidifier *v.t.* ផ្សើម, ធ្វើឲ្យទទឹក, ធ្វើឲ្យសើម

humidité *n.f.* សំណើម, ភាពសើម, ភាពទទឹក (ឧ. l'hygromètre mesure l'humidité de l'air)

humiliant,e *a.* ដែលឲ្យអាម៉ាស់មុខ

humiliation *n.f.* ការអាម៉ាស់មុខ, ការប្រមាថ (ឧ. essuyer une humiliation); ការបន្ទាបខ្លួន, ភាពមនុស្សកបទាប ; ភាពអាម៉ាស់មុខ (ឧ. tomber dans l'humiliation)

humilier *v.t.* ធ្វើឲ្យអាម៉ាស់មុខ, បំបាក់មុខ, បន្ទាប (ឧ. humilier l'orgueil de quelqu'un); បង្អាប់ (ឧ. humilier un paresseux)។ s'humilier *v.pr.* បន្ទាបខ្លួន

humilité *n.f.* នតិភាព, ការបន្ទាបខ្លួន, ការបន្ទោនកាយ (ឧ. pratiquer l'humilité); អំពើកបទាប; សេចក្តីគោរព ។ en toute humilité ដោយមិនលើកខ្លួន, ដោយបន្ទាបខ្លួន

humoral,e,aux *a.* នៃអាបោធាតុ (ឧ. les hormones sont des substances humorales); នៃអារម្មណ៍; ដែលបណ្តាលពីអារម្មណ៍

humoriste *n. &a.* អ្នកកំប្លែងស្លូត; អ្នកអារម្មណ៍និយម (គ្រូពេទ្យដែលជឿថាអារម្មណ៍មានអំណាចសំខាន់លើសុខភាព)

humoristique *a.* ដែលកំប្លែងស្លូត (ឧ. œuvre humoristique)

humour *n.m.* ការកំប្លែងស្លូត (ឧ. des propos pleins d'humour)។ l'humour noir ការកំប្លែងរិះគន់

humus *n.m.* បង្សុជាតិ (ដីដី)

hune *n.f.* ជាយក្អែក, កនទៅនិងក្តោង

hunter [heun-tèr] *n.m.* សេះសំរាប់បរបាញ់

huppe *n.f.* សំណុំរោមលើក្បាលបក្សី (ឧ.alouette à huppe) ; ត្រសេះ

huppé,e *a.* ដែលមានសំណុំរោមលើក្បាល (ចំពោះបក្សី) ។ *Fig. & fam.* ដែលមានសម្បត្តិ

hurlant,e *a.* ដែលលូ, ដែលស្រែក

hurlement *n.m.* សំឡេងលូ, សំឡេងថ្ងូរ ឬស្រែកគំហក ។ *Poét.* សូរខ្យល់, សន្ធឹកខ្យល់ព្យុះ

hurler *v.i.* លូ ។ *Fig.* ស្រែកថ្ងូរ (ឧ.

hurler de douleur); ស្រែកច្រៀង ។ *v.i.* ស្រែកចំឡកល (ឧ. hurler une chanson)

hurleur,euse *n.* ដែលព្យួរ ឬ ថ្ងូរ, ដែលស្រែកចំឡកល ។ *n.m.&a.* ស្វាម្យ៉ាង មានធំនៅប្រទេសអាមេរិក

hurluberlu *n.m.Fam.* មនុស្សល្ងីល្ងើ

huron,onne *n.&a Fam.* មនុស្សកម្រោល (ឧ. un vrai huron)

hurrah! *int.&n.* ម.ព. hourra

hurricane *n.m.* (ព.អង់គ្លេស) ចម្រាភគនិវត្ត (ព្យុះកំបុតត្បូងនៅប្រទេសក្តៅ)

hussard *n.m.* ទាហានទ័ពសេះ

hutte *n.f.* ខ្ទមតូច

hutter (se) *v.pr.* សង់ខ្ទម; នៅក្នុងខ្ទម

hyacinthe *n.f.* ត្បូងទទឹម

hybridation *n.f.* ប្រសង្ករណ៍, ការបង្កាត់ពូជ

hybride *n.m.& a.* ប្រសង្ករ, កូនកាត់ (ឧ. le mulet est un hybride de l'âne et de la jument)

hybrider *v.t.* បង្កាត់ពូជ

hybridité *n.f.* ឬ **hybridisme** *n.m.* ប្រសង្ករភាព, ភាពជាកូនកាត់

hydracide *n.m.* *Chim.* អ៊ីដ្រាស៊ីដ

hydratable *a.* អាចជាសំសន្ធឹម (អាចស្រូបយកទឹកបាន) (ឧ. le plâtre est facilement hydratable)

hydratation *n.f.* *Chim.* ដំណើរស្រូបទឹក

hydrate *n.m.* *Chim.* អាជាសំ-សន្ធកម្ម, ដំណើរវត្ថុអ្វីមួយផ្សំនឹងទឹក (ឧ. hydrate salin)

hydrater *v.t.* *Chim.* ផ្សំនឹងទឹក

hydraulicien *n.m.Ind.* ជលគតិវិទូ (វិស្វករខាងទឹក)

hydraulique *n.f.* ជលគតិវិជ្ជា ។ hydraulique agricole ជល-គតិវិជ្ជាកសិកម្ម ។ *a.* ជលគតិ, នៃទឹក; ដែលដើរដោយទឹក (ឧ. frein hydraulique)

hydravion *n.m.* ជលាកាសយាន, យន្តហោះចុះទឹក

hydrique *a.* នៃទឹក (ឧ. diète hydrique)

hydrobase *n.f.* ជលមូលដ្ឋាន(មូលដ្ឋានសម្រាប់ជលាកាសយាន)

hydrobiologie *n.f.* ជលជីវសាស្ត្រ

hydrocarbure *n.m.* ឧទង្គារ

hydrodynamique *n.f.* ជលថាម-កម្មវិធា ។ *a.* ជលថាមវត្ត-វត្តី

hydro-électrique *a.* ជលាគ្គិសនី (ឧ. une centrale hydro-électrique)

hydrofuge *a.* ដែលមិនឲ្យទឹកឬមិនឲ្យជ្រាបទឹក

hydrofuger *v.t.* ធ្វើមិនឲ្យទឹកឬមិនឲ្យជ្រាបទឹក

hydrogénation *n.f.* ការលាយនឹងអ៊ីដ្រូហ្សែន

hydrogène *n.m.* អ៊ីដ្រូហ្សែន (ឧស្ម័នម្យ៉ាង)

hydrogéné,e *a.* ដែលលាយនឹងអ៊ីដ្រូហ្សែន

hydrographe *n.m.* អ្នកជលធារាសាស្ត្រ។ ingénieur hydrographe វិស្វករជលធារាសាស្ត្រ

hydrologie *n.f.* ជលវិទ្យា

hydrologique *a.* នៃជលវិទ្យា (ឧ. étude hydrologique)

hydrologiste *n.&a.* ជលវិទូ

hydrolyse *n.f.* ឧទកកម្ម, ការញែកធាតុដោយទឹក

hydrolyser *v.t.* ធ្វើឧទកកម្ម, ញែកធាតុដោយទឹក

hydromancie *n.f.* ជលបេក្ខវិជ្ជា(វិជ្ជាទាយដោយសម្លឹងទឹក)

hydrographie *n.f.* ជលធារាសាស្ត្រ(ឧ. hydrographie du Cambodge)

hydromécanique *a.* ដែលដើរដោយកម្លាំងទឹក

hydrométéore *n.m. Phys.* ជលធាតុភូត

hydromètre *n.m. Techn.* អាបោមាត្រ

hydromètre *n.f.* ស្រគោម (គេច្រើនហៅថា araignée d'eau)

hydrométrie *n.f.* អាបោមាត្រវិធី

hydrométrique *a.* នៃអាបោមាត្រវិធី

hydropathe *a.* ដែលព្យាបាលដោយទឹក

hydrophile *a.* ដែលកូលចិត្តទឹក; ដែលផឹកទឹក

hydrophobe *a.&n.* ដែលខ្លាចទឹក

hydrophobie *n.f.* ការខ្លាចទឹក

hydrothérapie *n.f.* អាបោតិកិច្ឆា (ការព្យាបាលរោគដោយទឹកត្រជាក់នឹងទឹកក្ដៅ)

hydrothérapique *a.* នៃអាបោតិកិច្ឆា (ឧ. traitement hydrothérapique)

hyène *n.f.* សត្វហ្វាន (cri: l hyène hurle) ។ *Fig.* មនុស្សកាចហើយថោកទាប

hygiène *n.f.* អនាម័យ(អ:-ណា-ម័យ)។

hygiène rurale អនាម័យជនបទ

hygiénique *a.* នៃអនាម័យ; ត្រូវតាមអនាម័យ(ឧ. soins hygiéniques)

hygiéniquement *adv.* តាមអនាម័យ

hygiéniste *n.* អ្នកអនាម័យ

hygromètre *n.m.* មេឃមាត្រ (ប្រដាប់ស្ទង់សំណើមខ្យល់)

hygrométricité *n.f.* សំណើមខ្យល់, កម្រិតសើមនៃខ្យល់

hygrométrie *n.f.* មេឃមាត្រវិធី (វិធីស្ទង់សំណើមខ្យល់)

hygrométrique *a.* នៃមេឃមាត្រវិធី (ឧ. état hygrométrique de l'air)

hygroscope *n.m.* មេឃទស្សន៍ (ប្រដាប់មើលសំណើមខ្យល់)

hygroscopie *n.f.* ម.ព. hygrométrie

hygroscopique *a.* ដែលស្រូបសំណើមខ្យល់

hymen ឬ **hyménée** *n.m.* *Par ext.* អាពាហ៍ពិពាហ៍; ការផ្សំផ្គុំគ្នា

hyménoptères *n.m. pl.* កមរជាតិ

hymne *n.m.* ចម្រៀងថ្វាយអាទិទេព; ការសំដែងសេចក្ដីសរសើរ។ hymne national ភ្លេងជាតិ

hyperbole *n.f.* ការបំផ្លើសសំដីដើម្បីឲ្យជាប់អារម្មណ៍ (ឧ. គេប្រើពាក្យ «យក្ស» ដើម្បីហៅមនុស្សមាឌធំ)

hyperbolique *a.* ដែលបំផ្លើស (ឧ. expression hyperbolique)

hyperboliquement *adv.* ដោយបំផ្លើស (ឧ. parler hyperboliquement)

hyperborée ឬ **hyperboréen,enne** *a.* ដែលនៅខាងជើងបំផុត

hypermétrope *a.* &*n.* អទិស្សមាន

hypermétropie *n.f.* អទិស្សមានភាព (ភាពភ្នែកមើលមិនច្បាស់) (ឧ. on corrige l'hypermétropie par des verres convergentes)

hypersonnique *a.* លឿនជាងសម្លេង

hyperthermie *n.f.* ដំណើរឡើងកំដៅ (ខ្លួនយ៉ាងកេតគ្រុនជាដើម)

hypertendu,e *a.* ដែលឡើងឈាម (ឈាមច្រើនជាងធម្មតា)

hypertension *n.f.* ដំណើរឡើងឈាម (ឈាមច្រើនជាងធម្មតា)

hypertrophie *n.f.* ដំណើររីកហួសប្រមាណនៃសរីរការ (ឧ. hypertrophie du cœur)។ *Fig.* ការចម្រើនហួសប្រមាណ (ឧ. hypertrophie

d'un sentiment)

hypertrophié,e *a.* ដែលរីកហួសប្រមាណ (សរីរការ)

hypertrophier *v.t.* ធ្វើឲ្យរីកហួសប្រមាណ

hypertrophique *a.* ដូចជារីក; ដែលបណ្ដាលឲ្យរីក (សរីរការ)

hypervitaminose *n.f.* រោគបណ្ដាលដោយទទួលជីវជាតិច្រើនពេក

hypnose *n.f.* ការសណ្ដំ

hypnotique *a.* នៃការសណ្ដំ (ឧ. sommeil hypnotique)។ *a. & n.m.* ដែលសម្រាប់សណ្ដំ

hypnotiser *v.t.* សណ្ដំ។ *Par ext.* ធ្វើឲ្យសម្រាំងស្មារតីលើរបស់អ្វីមួយ។ **s'**hypnotiser *v.pr. Fig.* សម្រឹងស្មារតី (ឧ. s'hypnotiser sur une idée)

hypnotiseur *n.m.* អ្នកសណ្ដំ

hypnotisme *n.m.* ភាពត្រូវសណ្ដំ; វិទ្យាសាស្ត្រខាងសណ្ដំ

hypocondre *n.m.* កណ្ដៀតក្អួម(អវយវៈមនុស្សប៉ែកត្រង់ចង្កេះ)

hypocondre *a.&n.* ដែលចេះតែព្រួយ (ឧ. un malade hypocondre)។ *a. Fig.* ព្រួយ; គម្រោះគម្រើយ; មិនដឹងខុសត្រូវ (ឧ. un homme hypocondre)

hypocondriaque *a. Fig.* ដែលចេះតែបារម្ភពីសុខភាពខ្លួន(ឧ. les souffrances de l'hypocondriaque sont réelles (Brachet)

hypocondrie *n.f.* រោគបណ្ដាលឲ្យព្រួយប្លែក

hypocrisie *n.f.* ការលាក់ពុត

hypocrite *n.* មនុស្សលាក់ពុត។ *a.* ដែលលាក់ពុត

hypocritement *adv.* ដោយលាក់ពុត

hypoderme *n.m. Anat.* អធោត័ច, ភាគក្រោមនៃស្បែកក្នុង; រុយបែងស្បែកសត្វ

hypodermique *a.* ដែលសម្រាប់ចាក់ក្រោមស្បែក (ថ្នាំ) (ឧ. injection hypodermique)

hypogastre *n.m.* ក្បាលពោះ

hypogastrique *a.* នៃក្បាលពោះ (ឧ. le plexus hypogastrique)

hypogée *n.m.* ឧម្មង្គសព

hypophyse *n.f.* អាការៈក្នុងខួរសណ្ឋានដូចកូនកណ្ដុរនៅក្រោមលលាដ៍ក្បាល

hypotendu,e *a.&n.* ដែលចុះឈាម (ឈាមតិចជាងធម្មតា)

hypotension *n.f.* ដំណើរចុះឈាម (ឈាមតិចជាងធម្មតា)

hypoténuse *n.f. Math.* កណ្ណរេខា (ឧ. le carré de l'hypoténuse est égal à la somme des carrés des deux autres côtés)

hypothécable *a.* និក្ខេបិយ, អាចបញ្ចាំបាន (ឧ. terre hypothécable)

hypothécaire *a.&n.* និក្ខេបគ្គាហក [និក-ខេ-ប៉ុក-គា-ហ៉ក់] (ឧ. dette hypothécaire)

hypothécairement *adv.* ដោយនិក្ខេប (ឧ. créance garantie hypothécairement)

hypothèque *n.f.* និក្ខេប ។ *Fig.* lever une hypothèque បំបាត់ឧបសគ្គ ។ prendre une hypothèque sur l'avenir ប្រើឬចាយមុនរកបាន

hypothéquer *v.t.* បញ្ចាំ (ឧ. hypothéquer une terre) ។ *Fig.* ចាយមុន ឬប្រើមុនរកបាន (ឧ. hypothéquer l'avenir) ។ *Fam.* mal hypothéqué ឈឺធ្ងន់, ជិតងាប

hypothèse *n.f.* សម្មតិកម្ម [ស័ម-មៈ-តិ—], ការស្មាន

hypothétique *a.* ដែលជាសម្មតិកម្ម, ដែលជាការស្មាន, មិនប្រាកដ

hypothétiquement *adv.* ដោយសម្មតិកម្ម, ដោយស្មាន

hypotrophie *n.f.* ការទទួលអាហារមិនគ្រប់គ្រាន់



i *n.m.* អក្សរទី ៩ នៃអក្ខរក្រមឡាតាំង ។ droit comme un I ត្រង់ឆ្កឹង។ mettre les points sur les «i» សំដែងដោយក្បាស់លាស់ហើយដោយល្អិតល្អន់ ។ I (លេខរូម៉ុង) ១

ibéro-américain,e *a.* ម.ព. latino-américain

ibis *n.m.* សត្វ ។ ibis rose ទោល

iceberg *n.m.* ផ្ទាំងទឹកកកអណ្ដែត

ice-cream [aïs'-Krim] *n.m.* (ព.អ.) ក្រែមកក

ichtyocolle *n.f.* កាវថ្លាកត្រី

ichtyoïde *a.* ដូចត្រី

ichtyologie *n.f.* មច្ឆសាស្ត្រ (វិទ្យាសាស្ត្រខាងត្រី)

ichtyologique *a.* នៃមច្ឆសាស្ត្រ

ichtyologiste *n.* អ្នកមច្ឆសាស្ត្រ

ichtyophage *a.&n.* មច្ឆភក្ស (ឧ. peuplade ichtyophage)

ichtyophagie *n.f.* មច្ឆភក្សា

ici *adv.* ឯនេះ, នៅទីនេះ, នៅពេលនេះ។ ici-bas ឥធលោក, ក្នុងលោកនេះ ។ *Par ext.* ក្នុងស្រុកនេះ (ឧ. les gens d'ici); ក្នុងពេលឥឡូវនេះ (ឧ. d'ici à demain)

icône *n.f.* បដិមា (ក្នុងវិហាររុស្សុីនិងវិហារក្រិក)

iconoclasme *n.m.* លទ្ធិអ្នកបំផ្លាញបដិមា

iconoclaste *n.&a.* អ្នកកាន់លទ្ធិបំផ្លាញបដិមា (ក្នុងសតវត្សទី១៣)

iconographe *n.* បដិមាគន្ថី

iconographie *n.f.* បដិមាសាស្ត្រ

iconographique *a.* នៃបដិមាសាស្ត្រ

iconolâtre *n.* អ្នកធ្វើសក្ការៈចំពោះបដិមា

iconolâtrie *n.f.* បដិមាបូជា, ការធ្វើសក្ការៈចំពោះបដិមា

iconologie *n.f.* បដិមាវិជ្ជា

iconologiste ឬ **iconologue** *n.* បដិមាវិទូ

icosaèdre *n.m. Math.* វីសតិតល (ប្រសព្វជ្រុងម្ភៃ) (ឧ. l'icosaèdre régulier a pour faces des triangles équilatéraux)

ictère *n.m.* បណ្ដុរោគ, រោគលឿង

ictérique *a.* នៃបណ្ដុរោគ, នៃរោគលឿង (ឧ. teint ictérique) ។ *a. &n.* ដែលកើតរោគលឿង

idéal,e,als ឬ **aux** *a.* ដែលមានតែក្នុងគំនិត (ឧ. monde idéal); ល្អឥតខ្ចោះ (ឧ. beauté idéale) ។ *n.m.* ឧត្តមគតិ(ឧ. l'artiste doit viser à l'idéal; réaliser son idéal)

idéalement *adv.* ដោយឧត្តមគតិ, ដោយឥតខ្ចោះ

idéalisation *n.f.* ការតម្រូវតាមឧត្តមគតិ

idéaliser *v.t.* តម្រូវតាមឧត្តមគតិ (ឧ. idéaliser un personnage, un modèle)

idéalisme *n.m.* ឧត្តមគតិនិយម (ឧ. idéalisme Kantien); មនោគតិនិយម (ឧ. l'idéalisme s'oppose au réalisme)

idéaliste *n.* ឧត្តមបុគ្គលឬឧត្តមគតិបុគ្គល

idéalité *n.f.* ឧត្តមគតិភាព

idéation *n.f.* ដំណើរកើតនៃគំនិត

idée *n.f.* គំនិត (ឧ. changer d'idées) ។ *Par ext.* គំនិតរវើរវាយ (ឧ. vivre à son idée) ។ *Pop.* ចំនួនបន្តិច (ឧ. prenez une idée de cette liqueur; reculez une idée vers la gauche) ។

Loc. div. idée fixe គំនិតមមៃ (គំនិតដែលមិនអាចបំភ្លេចបាន) ។ avoir idée, une idée ឬ l'idée de គិតឃើញ ។ idée chimérique គំនិតហួសហេតុ ។

Pl. គំនិតមិនសមហេតុផល (ឧ. se faire des idées)

idem [—dèm] **(id.)** *adv.* (ព.ឡាតាំង) ដូចគ្នា

identificateur *n.m.* អ្នកកត់ភិន ។ identificateur de bétail អ្នក

កត់ភិនសត្វ

identification *n.f.* អត្តសញ្ញាណកម្ម; ការប្រកាសថាដូចគ្នា (ឧ. l'identification de la pensée et de l'être); ការរកឃើញ; ការស្គាល់; ការរកឃើញអត្តសញ្ញាណ(ឧ.l'identification d'un accusé)

identifier *v.t.* ធ្វើឲ្យដូចគ្នា,ប្រកាសថាដូចគ្នា(ឧ.identifier deux genres); រកឃើញអត្តសញ្ញាណ, ស្គាល់ (ឧ. l'anthropométrie permet d'identifier les criminels); កត់ភិន (ឧ. identifier des plantes) ។ identifier un nom de lieu រកឃើញឈ្មោះនៃទីណាមួយ (រកឃើញឈ្មោះចាស់នៃទីមួយដែលមានឈ្មោះផ្សេង) ។

s'identifier *v.pr.* ទៅជាដូចគ្នា, មានសន្ដានចិត្តដូចគ្នា (ឧ. un romancier s'identifie à ses personnages)

identique *a.* ដូចសុទ្ធសាធ (ឧ.propositions identiques; des êtres identiques)

identiquement *adv.* យ៉ាងដូចសុទ្ធ-សាធ

identité *n.f.* ភាពដូចគ្នា; អត្តសញ្ញាណ (ឧ. vérifier l'identité de quelqu'un; une pièce d'identité) ។ carte d'identité ម.ព. carte

idéogramme *n.m.* បិត្តានុលេខ (ឧ. les caractères égyptiens étaient des idéogrammes)

idéographie *n.f.* បិត្តានុលេខនា

idéographique *a.* នៃបិត្តានុលេខនា (ឧ. écriture idéographique)

idéologie *n.f.* គតិវិជ្ជា (វិទ្យាសាស្ត្រខាងគំនិត) ។ *Péj.* លទ្ធិដែលប្រកាន់ឧត្តមគតិមិនសមហេតុផល

idéologique *a.* នៃគតិវិជ្ជា

idéologue *n.* អ្នកប្រកាន់គតិណាមួយដោយដាច់ខាត; អ្នកប្រកាន់ឧត្តមគតិមិនសមហេតុផល

idiomatique *a.* នៃភាសាដោយឡែក

idiome *n.m.* ភាសាដោយឡែកនៃជាតិ ឬនៃភូមិភាគមួយ(ឧ.idiome cambodgien)

idiot *n.&a.* ល្ងង់, ភ្លើ, លលា (ឧ. un air idiot)

idiotie *n.f.* វិកមតិ[វិ-កៈ-ម៉ៈ-តិ], ដំណើរល្ងង់ដោយខូចខួរក្បាល; ភាពភ្លើ; ភាព

លលា ។ *Fam.* អំពើ ឬ សំដីភ្លើ (ឧ. faire, dire des idioties)

idiotisme *n.m. Gram.* វាក្យវិបល្លាស

idoine *a.* សមរម្យ, ត្រូវ

idolâtre *a. & n.* ដែលធ្វើសក្ការបូជាចំពោះបដិមា ។ *Fig.* ដែលស្រឡាញ់ហួសពេក (ឧ. cette mère est idolâtre de ses enfants)

idolâtrer *v.t.* ស្រឡាញ់ងប់ ។ *v.i.* ធ្វើសក្ការបូជាចំពោះបដិមា

idolâtrie *n.f.* សរណវត្ថុបូជា (ការធ្វើសក្ការបូជាចំពោះអាទិទេពបដិមា) ។ *Fig.* ការស្រឡាញ់ងប់

idolâtrique *a.* នៃសរណវត្ថុបូជា

idole *n.f.* គារូប (អាទិទេពបដិមា ឬ មនុស្សជាទីសក្ការបូជា)។ *Fig.* មនុស្សដែលគេសរសើរជ្រុល ឬ ដែលគេស្រឡាញ់ងប់ (ឧ. il est l'idole du peuple)

idylle *n.f.* និពន្ធអំពីស្នេហា (ឧ. les idylles de Théocrite)។ *Fig.* ស្នេហា

idyllique *a.* នៃស្នេហា

igloo *n.m.* អ៊ីគ្លូ (ខ្ទមធ្វើអំពីទឹកកក)

igname *n.f.* ដំឡូងស្វា

ignare *a.&n.* ល្ងង់ខ្លៅ, ឥតវិជ្ជា

igné,e *a.* ដែលមានលក្ខណៈដូចភ្លើង (ឧ. matière ignée); ដែលកើតឡើងដោយអំពើនៃភ្លើង (ឧ. roches ignées)

ignicole *n.&a.* អ្នកគោរពបូជាភ្លើង

ignifère *a.* ដែលនាំភ្លើង

ignifugation *n.f.* ការធ្វើមិនឲ្យភ្លើងឆេះ; ភាពភ្លើងមិនឆេះ

ignifuge *a.&n.m.* សម្រាប់ធ្វើមិនឲ្យភ្លើងឆេះ (ឧ. le silicate de potassium est un ignifuge)

ignifuger *v.t.* ធ្វើមិនឲ្យភ្លើងឆេះ (ឧ. les décors de théâtre doivent être ignifugés)

ignipuncture *n.f.* ការអាលដោយម្ជុល

ignition *n.f.* ភាពវត្ថុកំពុងឆេះ

ignivome *a.* ដែលព្រួសភ្លើង (ឧ. cratère ignivome)

ignivore *a.* ដែលស៊ីភ្លើង

ignoble *a.* ថោកទាប, អពមង្គល (ឧ. conduite ignoble)

ignoblement *adv.* ដោយថោកទាប, ដោយអពមង្គល

ignominie *n.f.* ភាពថោកទាបបំផុត, ភាពទុយ៌ស (ឧ. la trahison est une ignominie)

ignominieusement *adv.* ដោយថោកទាប ឬ ទុយ៌ស

ignominieux,euse *a.* ដែលបន្ថោកបន្ទាប ឬ ឲ្យអាប់យស (ឧ.supplice ignominieux)

ignorance *n.f.* អវិជ្ជា, ភាពខ្លៅឬឥតចំណេះ; ការមិនចេះ, ការមិនដឹង (ឧ. l'ignorance des usages du monde)

ignorant,e *n.&a.* ខ្លៅ, ល្ងង់, ដែលឥតចំណេះ, ដែលមិនដឹង (ឧ. ignorant d'une nouvelle)

ignorantisme *n.m.* អវិជ្ជានិយម, ការនិយមថាវិជ្ជានាំឲ្យអន្តរាយ

ignoré,e *a.* ដែលគេមិនដឹងឬមិនស្គាល់

ignorer *v.t.* មិនចេះ (ឧ. nul n'est censé ignorer la loi); មិនដឹង, មិនស្គាល់ (ឧ. ignorer le malheur, le mensonge)

iguane *n.m.* ទន្សង

il *pr. pers. m.* (*pl.* ils) វា, គាត់, លោក, របស់ទាំងនោះ

ilang-ilang *n.m.* ដើមក្ដាំងងា(សរសេរថា ylang-ylang ក៏បាន)

île *n.f.* កោះ

iles *n.m.pl.* កណ្ដៀតក្អម (ឧ. les os des iles forment les hanches)

ilet *n.m.* ឬ **ilette** *n.f.* កោះតូច

iléus *n.m.* ដំណើរស្ទះពោះវៀន (ឧ. l'iléus produit les coliques de miserere) (*iff.* occlusion intestinale)

iliaque *a.* នៃកណ្ដៀតក្អម, នៃត្រគាក ។ os iliaque ឆ្អឹងត្រគាក

illégal,e,aux *a.* អនីត្យានុកូល, ផ្ទុយនឹងច្បាប់, ដែលល្មើសច្បាប់(ឧ. mesure illégale)

illégalement *adv.* ដោយផ្ទុយនឹងច្បាប់

illégalité *n.f.* អនីត្យានុកូលភាព, ភាពផ្ទុយនឹងច្បាប់(ឧ.illégalité d'une convention);អំពើផ្ទុយនឹងច្បាប់(ឧ. commettre une illégalité)

illégitime *a.* ឥតខាន់ស្លា, មិនគ្រប់លក្ខណៈច្បាប់ (ឧ. union illégitime; enfant illégitime); អធម្មានុរូប, មិនត្រូវច្បាប់ (ឧ. prétention illégitime)

illégitimement *adv.* ដោយឥតខាន់ស្លា

illégitimité *n.f.* ភាពមិនត្រូវច្បាប់ (ឧ. illégitimité d'un titre)

illettré,e *a.&n.* ដែលមិនចេះអក្សរ (ឧ. le nombre des illettrés di-

minue)

illicite *a.* ខុសច្បាប់, ខុសសីលធម៌ (ឧ. gain illicite)

illicitement *adv.* ដោយខុសច្បាប់

illico *adv.Fam.* ភ្លាម (ឧ. partir illico)

illimitable *a.* ពុំអាចឲ្យមានព្រំដែនបាន

illimité,e *a.* ដែលគ្មានព្រំដែន

illisibilité *n.f.* ភាពអានមិនដាច់

illisible *a.* ដែលអានមិនដាច់ (ឧ. écriture illisible); ដែលអានមិនកើត (ព្រោះខ្វះចិត្តជាដើម) (ឧ. roman illisible)

illisiblement *adv.* ដោយអានមិនដាច់

illogique *a.* ដែលមិនសមតាមតក្កវិជ្ជា (ឧ. conclusion illogique); ដែលគ្មានគំនិតខ្ជាប់ខ្ជួន (ឧ. esprit illogique)

illogiquement *adv.* ដោយមិនសមតាមតក្កវិជ្ជា

illogisme *n.m.* ភាពមិនសមតាមតក្កវិជ្ជា ឬ គ្មានគំនិតខ្ជាប់ខ្ជួន

illuminable *a.* អាចបំភ្លឺបាន

illuminant,e *a.* ដែលបំភ្លឺ

illuminateur *n.m.* អ្នកបំភ្លឺ

illumination *n.f.* ការបំភ្លឺ; ពន្លឺព្រោងព្រាត; ការតែងលំអដោយពន្លឺ; ការបានត្រាស់ដឹង; ការនឹកឃើញភ្លាម

illuminé,e *n.&a.* ដែលបានត្រាស់ដឹង

illuminer *v.t.* បំភ្លឺព្រោងព្រាត; តែងលំអដោយពន្លឺ ។ *Fig.* បំភ្លឺគំនិត ឬ ប្រាជ្ញា

illusion *n.f.* មាយាការ, សេចក្ដីកាន់នៃវិញ្ញាណឬគំនិត (ឧ. le mirage est une illusion de la vue); គំនិតឬសេចក្ដីសង្ឃឹមមិនសមហេតុផល (ឧ. se nourrir d'illusions); ការប៉ិនភ្នែក ។ se faire illusion ច្រឡំ, កាន់

illusionner *v.t.* បំកាន់ (ឧ. chercher à illusionner quelqu'un)។ s'illusionner *v.pr.* ច្រឡំ, កាន់ (ឧ. les parents s'illusionnent parfois sur leurs enfants)

illusionnisme *n.m.* ការក្លួលចិត្តកាន់ច្រឡំ; ការប៉ិនភ្នែក (ឧ. l'illusionnisme des prestidigitateurs)

illusionniste *n.m.* អ្នកប៉ិនភ្នែក

illusoire *a.* ដែលចង់បំកាន់ (ឧ. proposition illusoire); ដែលមិនបានសម្រេចសោះ (ឧ. espoir illu-

soire)

illusoirement *adv.* ដោយឥតបានការ; ដោយមិនបានសម្រេច

illustrateur *n.m.* វិចិត្រករ, អ្នកគូរ លំអសៀវភៅ

illustration *n.f.* វិស្សុតកម្ម (ការធ្វើឲ្យមានកិត្តិនាម); វិស្សុតភាព (ភាពប្រកបដោយកិត្តិនាម) (ឧ. contribuer à l'illustration de la patrie); វិចិត្ររូប, ភាពលំអដោយរូប; រូបក្នុងសារពត៌មាន

illustre *a.* វិស្សុត, ល្បីល្បាញ, ចំណាន, ប្រកបដោយកិត្តិនាម (ឧ. famille illustre)

illustré,e *a.* វិចិត្រឬពិចិត្រ, ដែលតែងលំអដោយរូប (ឧ. livre illustré)។ *n.m.* កាសែត ឬ ទស្សនាវដ្ដីវិចិត្រ (លំអដោយរូប)

illustrer *v.t.* ធ្វើឲ្យវិស្សុត ឬ ឲ្យល្បីល្បាញ (ឧ. auteur qui illustre son pays par ses ouvrages); វិចិត្រ, តែងលំអដោយរូប ។ s'illustrer *v.pr.* ឡើងល្បីល្បាញ, មានកិត្តិនាម

illustrissime *a.* វិស្សុតជាទីបំផុត

ilot *n.m.* កោះតូច, កូនកោះ; ប្រជុំផ្ទះក្នុងក្រុង (ឧ. îlot insalubre)

ilote *n.m.* អ្នកងារនៅប្រទេសស្ប៉ាត ។ *Fig.* ជនថោកទាបបំផុត (ក្នុងន័យនេះ សរសេរជា hilote ក៏បាន)

ilotisme *n.m.* ភាពជាអ្នកងារ (នៅប្រទេសស្ប៉ាត)។ *Fig.* ភាពថោកទាបហើយល្ងង់ខ្លៅ

image *n.f.* ធម្មារម្មណ៍; រូបភាព; បដិមាករ; និមិត្តរូប; រូបប្រៀប; ភាពដូច, អ្វីៗដែលដូច (ឧ. cet enfant est l'image de son père; la chasse est l'image de la guerre)

imagé,e *a.* សម្ដែងដោយរូបប្រៀប (ឧ. style imagé)

imager *v.t.* លំអដោយរូបប្រៀប

imagerie *n.f.* កន្លែងធ្វើ ឬ លក់រូប; រូបទាំងឡាយ

imagier *n.m.* ជាងរូប; វិចិត្រករ, ជាងចម្លាក់ (ក្នុងយុគកណ្ដាល) ។ *a.* នៃរូប (*f.* imagière)

imaginable *a.* អាចនឹកឬគិតឃើញ ឬប្រឌិតបាន (ឧ. scène facilement imaginable)

imaginaire *a.* មនោគត; ដែលមានតែក្នុងមនោគតិ (ឧ. un bien imaginaire) ។ malade imagi-

naire ជម្ងឺមនោគត (អ្នកដែលស្មានថាខ្លួនឈឺប៉ុន្តែគ្មានឈឺសោះ) ។ *n.m.* វិស័យមនោគត (ឧ.dans certains troubles mentaux, l'imaginaire prend le pas sur le réel)

imaginatif,ive *a.* ដែលចូលចិត្តនឹក ឬ គិតក្នុងចិត្ត (ឧ. esprit imaginatif)

imagination *n.f.* មនោគតិ, ដំណើរចិត្ត (ឧ. avoir l'imagination vive);ប្រឌិតញាណ(ឧ.artiste qui a beaucoup d'imagination); របស់ប្រឌិត (ឧ. imaginations invraisemblables); គំនិត, ការយល់;មតិមិនសមហេតុផល (ឧ.c'est une pure imagination)

imaginative *n.f. Fam.* មនោញាណ

imaginer *v.t.* នឹកក្នុងមនោគតិ (ឧ. imaginer un colosse de six pieds); ប្រឌិត (ឧ. Torricelli imagina le baromètre) ។ s'imaginer *v.pr.* នឹកស្មាន (ឧ. il s'imagine être un savant)

imago *n.f.* បុណ្ណកាល[ប៊ុន-ណៈ-កាល] (ខណៈដែលជាណកសត្វពេញរូបរាង ហើយអាចបង្កើតកូនបាន)

imbattable *a.* មិនចេះចាញ់ (ឧ. coureur, record imbattable)

imbécile *a.&n.* ល្ងីល្ងើ, ភ្លើ

imbécilement *adv.* ដោយល្ងីល្ងើ

imbécilité *n.f.* ភាពល្ងីល្ងើ;អំពើល្ងីល្ងើ (ឧ.c'est pure imbécilité que d'agir ainsi)

imberbe *a.* ឥតពុកចង្កា ។ *Par ext.* ក្មេងណាស់

imbiber *v.t.* ជ្រលក់ឲ្យជោក,ជ្រៀប (ឧ. imbiber d'eau une éponge)

imbibition *n.f.* ការជ្រៀប, ការជ្រលក់ឲ្យជោក

imbrication *n.f.* ភាពស្រកាលេញ, ភាពគងលើគ្នា (ដូចក្បឿងប្រក់ផ្ទះ)

imbriqué,e *a.* ដែលគងលើគ្នា

imbriquer *v.t.* គងលើគ្នា(ដូចក្បឿងប្រក់ផ្ទះ)

imbrisable *a.* មិនចេះបាក់,មិនចេះបែក

imbroglio *n.m.* ភាពច្របូកច្របល់ (ឧ. démêler un imbroglio);រឿងស្មុគស្មាញ (រឿងល្ខោន)

imbrûlable *a.* មិនអាចឆុតឆេះ

imbrûlé,e *a.&n.m.* ដែលឆេះមិនសុស

imbu,e *a.* ជោកជាំ (ឧ. imbu de

préjugés)

imbuvable *a.* ដែលផឹកមិនកើត (ឧ. l'eau de mer est imbuvable)។ *Fig.* & *fam.* មិនអាចទ្រាំទ្របាន (ឧ. un homme imbuvable)

imitable *a.* អាចត្រាប់បាន

imitateur,trice *n.&a.* អ្នកត្រាប់; អ្នកចូលចិត្តត្រាប់ (ឧ. le singe est naturellement imitateur)

imitatif,ive *a.* ដូចត្រាប់ (ឧ. harmonie imitative)

imitation *n.f.* តម្រាប់; ការត្រាប់ (ឧ. avoir la manie de l'imitation) ; របស់ត្រាប់ (ឧ. bronze d'imitation ; bijoux en imitation)។ à l'imitation de *loc. pré.* តាមតម្រាប់នៃ, ដោយយកតម្រាប់តាម

imiter *v.t.* ត្រាប់, យកតម្រាប់ (ឧ. imiter ses camarades); ក្លែង, ចម្លង (ឧ. imiter une signature); ធ្វើតាម (ឧ. imiter ses ancêtres); ដូច (ឧ. le cuivre doré imite l'or)

immaculé,e *a.* និម្មល, គ្មានមន្ទិល, ល្អស (ឧ.blancheur immaculée)។ *Fig.* គ្មានសៅហ្មង (ឧ. innocence immaculée)

immanence *n.f.* ភាពមានឡើង ឬ ប្រព្រឹត្តទៅដោយឯកឯង

immanent,e ដែលមានឡើង ឬ ប្រព្រឹត្តទៅដោយឯកឯង; ឋិតថេរ ។ justice immanente យុត្តិធម៌ដែលអាចសំដែងឡើងខ្លួនឯងក្នុងថ្ងៃណាមួយ

immangeable *a.* ដែលបរិភោគមិនបាន ឬ មិនកើត (ឧ. ragoût immangeable)

immanquable *a.* ដែលមកដល់មិនខាន; ប្រាកដ; មិនចេះខុស (ឧ. cible immanquable)

immanquablement *adv.* ជាមិនខាន

immarcescible *a.* មិនចេះស្រពោន; មិនអាចសៅហ្មងបាន (ឧ. gloire immarcescible)

immatérialiser *v.t.* ធ្វើឲ្យទៅជាអសម្ភារៈ (ដោយពិចារណា) (ឧ. immatérialiser les forces de la nature)

immatérialisme *n.m.* អសម្ភារនិយម (ឧ. l'immatérialisme de Berkeley)

immatérialiste *a.* នៃអសម្ភារនិយម (ឧ. doctrine immatérialiste) ។ *n.* អ្នកអសម្ភារនិយម

immatérialité *n.f.* អសម្ភារភាព (ឧ. l'immatérialité de l'âme)

immatériel,elle *a.* អសម្ភារៈ, ដែលឥតរូប (ឧ. l'esprit est immatériel)

immatriculation *n.f.* ការចុះបញ្ជី; ភាពមានចុះក្នុងបញ្ជីហើយ (ឧ. l'immatriculation d'un soldat; numéro d'immatriculation លេខក្នុងបញ្ជី)

immatricule *n.f.* ការចុះក្នុងបញ្ជីសាធារណៈ

immatriculer *v.t.* ចុះបញ្ជី

immature *a. Hist. nat.* មិនទាន់ទុំ

immaturité *n.f.* ភាពមិនទាន់ទុំ

immédiat,e *a.* ផ្ទាល់ (ឧ. successeur immédiat; cause immédiate); ភ្លាម (ឧ. soulagement immédiat); ជិត

immédiatement *adv.* ភ្លាម,មួយរំពេច

immédiateté *n.f. Philos.* ភាពភ្លាម

immémorable *a.* ម.ព. immémorial

immémorial,e,aux *a.* យូរយារ, យូរអង្វែង (ដែលគេភ្លេចដាច់ទៅហើយ)(ឧ. usage immémorial)

immense *a.* ធំមហិមា (ឧ. la mer immense); សំបើម (ឧ. fortune immense)

immensément *adv.* យ៉ាងធំមហិមា, យ៉ាងសំបើម

immensité *n.f.* ភាពធំមហិមា (ឧ. l'immensité des cieux); ទំហំឬភាពល្ហល្ហៃ (ឧ. l'immensité des mers)

immensurable *a.* មិនអាចនឹងវាស់បាន

immerger *v.t.* ជ្រមុជទឹក; ទម្លាក់ក្នុងទឹក (ឧ. immerger le corps d'un matelot décédé en cours de route)

immérité,e *a.* មិនសម, មិនត្រូវបាន, មិនត្រូវទទួល (ឧ. reproche imméritée)

immersif,ive *a.* ដែលធ្វើដោយជ្រមុជទឹក

immersion *n.f.* ការជ្រមុជ,ទឹកការមុជក្នុងទឹក (ឧ. l'immersion d'un sous-marin)

immeuble *a.* អសង្ហារិម ។ *n.m.* អសង្ហារិមភណ្ឌ, ផ្ទះ (ឧ. vendre un

immeuble) ។ *Dr.* អសង្ហារិមវត្ថុ (វត្ថុដែលមិនអាចផ្លាស់កន្លែងបាន)

immigrant,e *n.&a.* អន្តោប្រវេសន្ត-សន្តី(ដែលចេញពីប្រទេសក្រៅ មកតាំងនៅក្នុងប្រទេសណាមួយ)

immigration *n.f.* អន្តោប្រវេសន៍

immigré,e *n.&a.* អន្តោប្រវេសី-សិនី, ដែលចេញពីប្រទេសខ្លួនទៅតាំងនៅក្នុងប្រទេសដទៃ

immigrer *v.t.* ធ្វើអន្តោប្រវេសន៍

imminence *n.f.* អច្ចាសន្នភាព, ភាពជិតមកដល់ណាស់; ភាពជិតណាស់ ឬ កិតណាស់ (ឧ. l'imminence du danger)

imminent,e *a.* អច្ចាសន្ន, ជិតមកដល់ណាស់ (ឧ. ruine imminente); ជិតណាស់, កិតណាស់ (ឧ. départ imminent)

immiscer *v.t.* ជ្រៀតជ្រែក, បញ្ចូល ។ s'immiscer *v.pr.* ជ្រៀតជ្រែកចូល (ឧ. s'immiscer dans les affaires d'autrui)

immixtion *n.f.* ការជ្រៀតជ្រែក

immobile *a.* និច្ចល, នឹងថ្កល់; រឹងប៉ឹង

immobilier,ière *a.* អចលៈ [អៈ-ច-លៈ] (ឧ.biens immobiliers)

immobilisation *n.f.* អចលកម្ម, ការធ្វើឲ្យនៅនឹងថ្កល់; អចលភាព, ភាពនៅនឹងថ្កល់ (ឧ. l'immobilisation du corps) ។ *Dr.* អសង្ហារិមកម្ម (ឧ. l'immobilisation des actions de la Banque de France)

immobiliser *v.t.* ធ្វើឲ្យនៅនឹងថ្កល់(ឧ. immobiliser un malade); ផ្អាប់មេព្យាយ, មិនឲ្យធ្វើអ្វីកើត (ឧ. immobiliser des troupes); ធ្វើអសង្ហារិមកម្ម

immobilisme *n.m.* និច្ចលនិយម

immobilité *n.f.* និច្ចលភាព, ភាពនឹងថ្កល់; ភាពឥតចំរើន ឬ ឥតដុះដាល

immodéré,e *a.* អមជ្ឈត្តិកៈ, ហួសប្រ-មាណ(ឧ. un prix immodéré; des propos immodérés)

immodérément *adv.* ដោយហួសប្រមាណ

immodeste *a.* មិនសុភាព, ឥតអៀនខ្មាស (ឧ. tenue immodeste)

immodestement *adv.* ដោយមិនសុភាព, ដោយឥតអៀនខ្មាស

immodestie *n.f.* ការខ្វះកិរិយាសុភាព, សេចក្ដីឥតអៀនខ្មាស

immolateur *n.m.* អ្នកសម្លាប់

immolation *n.f.* ការសម្លាប់; យញ្ញ

immoler *v.t.* បូជាយញ្ញ (ឧ. immoler des agneaux)។ *Par ext.* សម្លាប់ (ឧ. la guerre immole d'innombrables victimes)។ *Fig.* ធ្វើពលីកម្ម (ឧ. il est immolé aux intérêts de sa famille)

immonde *a.* អសោច, កខ្វក់ណាស់ (ឧ. un taudis immonde); មិនបរិសុទ្ធ (តាមជំនឿសាសនាខ្លះ) (ឧ. d'après la loi de Moïse, le porc est un animal immonde)។ l'esprit immonde បិសាច ។ *Fig.* អពមង្គល, គួរខ្ទើម (ឧ. des propos immondes)

immondices *n.f.pl.* ភក់; សម្រាម, ភាពមានសៅហ្មង (សាសនា)

immoral,e,aux *a.* ដែលប្រព្រឹត្តផ្ទុយនឹងសីលធម៌ (ឧ. un homme immoral); ផ្ទុយនឹងសីលធម៌ (ឧ. ouvrage immoral)

immoralement *adv.* ដោយផ្ទុយនឹងសីលធម៌

immoralité *n.f.* ភាពផ្ទុយនឹងសីលធម៌ (ឧ. l'immoralité d'un livre); ការខ្វះសីលធម៌

immortaliser *v.t.* ធ្វើឲ្យមិនចេះស្លាប់; ធ្វើឲ្យមិនភ្លេចឬមិនសូន្យ។ s'immortaliser *v.pr.* ទៅជាមិនចេះស្លាប់ ឬ មិនចេះសូន្យ

immortalité *n.f.* អមតភាព, ដំណើរមិនចេះស្លាប់ (ឧ. l'immortalité de l'âme)។ *Fig.* ការគេមិនភ្លេច; ភាពមិនចេះសូន្យ (ឧ. aspirer à l'immortalité)

immortel,elle *a.* អមតៈ, ដែលមិនស្លាប់ (ឧ. les dieux immortels)។ *Fig.* មិនសូន្យ, ដែលគេមិនភ្លេច (ឧ. gloire immortelle)។ *n.m.* សមាជិកបណ្ឌិតសភាបារាំង

immortellement *adv.* ដោយអមតៈ; ដោយមិនចេះស្លាប់

immotivé,e *a.* អហេតុ, ដែលគ្មានហេតុ; ដែលមិនចង្អុលហេតុ (ឧ. accusation immotivée)

immuabilité *n.f.* ម.ព. immutabilité

immuable *a.* មិនចេះប្រែប្រួល (ឧ. les lois humaines ne sont pas immuables)

immuablement *adv.* ដោយមិនចេះ

ប្រែប្រួល

immunisant,e *a.* ដែលធ្វើឲ្យស៊ាំនឹងរោគ(ឧ. sérum immunisant)

immunisation *n.f.* ការធ្វើឲ្យស៊ាំនឹងរោគ

immuniser *v.t.* ធ្វើឲ្យស៊ាំនឹងរោគ ។ *Fig.* នាំឲ្យផុតអំពីអំណាចអាក្រក់

immunité *n.f.* ការលើកលែងពន្ធ-បន្ទុក។ល។ (ឧ. les immunités féodales)។ *Biol.* ភាពស៊ាំនឹងរោគ ។ *Dr.* អភ័យឯកសិទ្ធិ (ឧ. les membres du corps diplomatique et les parlementaires bénéficient d'une immunité de juridiction)។immunité parlementaire អភ័យឯកសិទ្ធិសភា

immutabilité ឬ **immuabilité** *n.f.* ភាពមិនប្រែប្រួល ; ភាពមិនអាចកែប្រែបាន (ឧ. l'immutabilité des conventions matrimoniales)

impact *n.m.* ដំណើរគ្រាប់ទង្គិចគ្នា ។ point d'impact កន្លែងត្រូវគ្រាប់

impair,e *a.* សេស ។ nombre impair ចំនួនសេស ។ *n.m.* *Fam.* អំពើឆ្គង (ឧ. commettre un impair)

impalpabilité *n.f.* ភាពមិនអាចស្ទាបដឹង (ព្រោះឆ្ងាយណាស់ឬល្អិតណាស់)

impalpable *a.* មិនអាចស្ទាបដឹង

impaludisme *n.m.* ម.ព. paludisme

impardonnable *a.* មិនគួរអភ័យទោស

imparfait,e *a.* មិនគ្រប់លក្ខណ៍; មិនទាន់ហើយ (ឧ. maison imparfaite); ខ្វះ (ឧ. ouvrage imparfait)

imparfaitement *adv.* ដោយមិនទាន់ហើយ; ដោយខ្វះ

imparité *n.f.* ភាពសេស

impartageable *a.* មិនអាចចែកបាន

impartial,e,aux *a.* អនាគតិញាយ , មិនលំអៀង (ឧ. historien, jugement impartial)

impartialement *adv.* ដោយអនាគតិ, ដោយមិនលំអៀង

impartialité *n.f.* អនាគតិ, ការគ្មានអគតិ, ភាពមិនលំអៀង

impartir *v.t.* ព្រមឲ្យ (ឧ. impartir un délai)

impasse *n.f.* ផ្លូវទ័ល ។ *Fig.* ស្ថានភាពទ័លច្រក ។ être dans une impasse ទ័លច្រក

impassibilité *n.f.* ភាពឆើយ, ភាពមិនរន្ធត់

impassible *a.* ឆើយ, មិនរន្ធត់ (ឧ. rester impassible en présence du danger)

impassiblement *adv.* ដោយឥតរន្ធត់

impatiemment *adv.* ដោយអក្ខន្តី, ដោយប្រាស់ប្រាល់, ដោយអន្ទះអន្ទែង

impatience *n.f.* អក្ខន្តិភាព, ដំណើរខ្វះអំណត់ (ឧ. témoigner de l'impatience) ។ *pl.* ការប្រាស់ប្រាល់, ការអន្ទះអន្ទែង (ឧ. avoir des impatiences)

impatient,e *a.* អក្ខន្តី, ខ្វះអំណត់ (ឧ. un malade impatient); ដែលប្រាស់ប្រាល់, អន្ទះអន្ទែង (ឧ. être impatient de partir)

impatientant,e *a.* ដែលនាំឲ្យខ្វះអំណត់; ដែលនាំឲ្យប្រាស់ប្រាល់

impatienter *v.t.* នាំឲ្យបាត់អំណត់; ធ្វើឲ្យប្រាស់ប្រាល់, ធ្វើឲ្យអន្ទះអន្ទែង ។ s'impatienter *v.pr.* បាត់អំណត់; អន្ទះអន្ទែង, ប្រាស់ប្រាល់

impatronisation *n.f.* ការតាំងខ្លួនជាម្ចាស់

impatroniser *v.t.* បញ្ចូលដោយអំណាច ។ s'impatroniser *v.pr.* តាំងខ្លួនជាម្ចាស់

impavide *a.* ឥតបេះខ្លាច

impayable *a.* មិនអាចបង់ថ្លៃច្រើនបាន; គ្មានតម្លៃ; ថ្លៃហួស ។ *Fig. & Fam.* កំប្លែង, គួរឲ្យអស់សំណើច (ឧ. aventure impayable)

impayé,e *a.* មិនទាន់សងថ្លៃ

impeccabilité *n.f.* ភាពមិនអាចធ្វើខុសបាន

impeccable *a.* *Théol.* មិនអាចធ្វើខុសបាន ។ *Par ext.* ឥតខ្ចោះ (ឧ. tenue impeccable)

impeccablement *adv.* ដោយឥតខ្ចោះ

impécuniosité *n.f.* ការខ្វះប្រាក់

impédimenta *n.m. pl. Fig.* របស់ទទើសទទែង

impénétrabilité *n.f.* ភាពមិនអាចចូលគ្នាបាន ។ *Fig.* ភាពមិនអាចស្គាល់ចិត្ត ឬ យល់បាន

impénétrable *a.* មិនអាចចូលឬធ្លុះបាន (ឧ. cuirasse impénétrable)។ *Fig.* មិនអាចពន្យល់បាន (ឧ. mystère impénétrable); មិនអាចស្គាល់ចិត្តបាន

impénitence *n.f. Théol.* ដំណើរលែងខ្វាយបាប ។ *Fig.* ការចចេសក្នុងកំហុស

impénitent,e *a.* ដែលលែងខ្វាយបាប; ដែលមិនចេះស្តាយក្រោយ (ដោយបានធ្វើខុស); ដែលចចេសក្នុងកំហុស (ឧ. un buveur impénitent)

impensable *a.* មិនអាចគិតឃើញ; មិនអាចនឹកបាន

impense *n.f. Dr.* ចំណាយដើម្បីថែរក្សា ឬលំអរបស់អ្វីមួយ

impératif,ive *a.* ដែលបង្គាប់បញ្ជា (ឧ. ton impératif)

impérativement *adv.* ដោយបញ្ជា, ជារបៀបបញ្ជា (ឧ. parler impérativement)

impératrice *n.f.* រាជាធិរាជិនី (ឧ. l'impératrice Joséphine ; Catherine II, impératrice de Russie)

imperceptibilité *n.f.* អសញ្ញានីយភាព

imperceptible *a.* អសញ្ញានីយ, មិនអាចចាប់យកដោយវិញ្ញាណបាន(ព្រោះតូចពេកឬតិចពេក) ។ *Fig.* ស្តួចស្តើងពេក (ឧ. progrès imperceptible)

imperceptiblement *adv.* ដោយអសញ្ញានីយ, ដោយតូចពេក - តិចពេក ឬស្តួចស្តើងពេក

imperdable *a.* មិនអាចបាត់បាន

imperfectibilité *n.f.* ភាពមិនអាចធ្វើឲ្យសុក្រឹតបាន

imperfectible *a.* មិនអាចធ្វើឲ្យសុក្រឹតបាន, មិនអាចកែឲ្យល្អបាន

imperfection *n.f.* អសុក្រឹតភាព, ភាពមិនគ្រប់លក្ខណ៍ ។*Par ext.* ភាពមិនទាន់ហើយ; សេចក្តីខ្វះ; គុណវិបត្តិ (ឧ. les imperfections d'un ouvrage)

imperforation *n.f. Méd.* ភាពគ្មានរន្ធ (ភាពកន្លែងដែលត្រូវមានរន្ធ ហើយបែរជាបិទជិតទៅវិញ) (ឧ. imperforation de l'anus)

imperforé,e *a.* មិនទាន់ចោះទម្លាយ

impérial,e,aux *a.* នៃរាជាធិរាជ (ឧ. dignité impériale)

impériale *n.f.* ថ្នាក់លើបំផុតនៃរថ

impérialement *adv.* ជារាជាធិរាជ

impérialisme *n.m.* ចក្រពត្តិនិយម

impérialiste *a.&n.* អ្នកចក្រពត្តិនិយម

impérieusement *adv.* ដោយរឹង;

ដោយបន្ទាន់

impérieux,euse *a.* ឆ្មើង, ដែលបង្គាប់បញ្ជាដោយសំដីខ្ពស់ (ឧ. un ton impérieux)។ *Fig.* ទប់មិនល្អះ; បន្ទាន់ (ឧ. nécessité impérieuse)

impérissable *a.* មិនអាចស្លាប់ ឬ ហិនហោចបាន ; ចិរថេរ (ឧ. gloire impérissable)

impéritie *n.f.* ដំណើរមិនប្រសប់, ការខ្វះពិសោធន៍

imperméabilisation *n.f.* ការធ្វើមិនឲ្យជ្រាបទឹក

imperméabiliser *v.t.* ធ្វើមិនឲ្យជ្រាបទឹក (ឧ. imperméabiliser un tissu)

imperméabilité *n.f.* ភាពមិនជ្រាបទឹក

imperméable *a.* មិនជ្រាបទឹក (ឧ. l'argile est imperméable)។ *Fig.* មិនអាចបញ្ចុះបញ្ចូលបាន (ឧ. imperméable à certaines influences) ។ *n.m.* សំលៀកបំពាក់មិនជ្រាបទឹក, អាវភ្លៀង

impermutable *a.* មិនអាចប្តូរបាន

impersonnalité *n.f.* អបុគ្គលិកភាព, ដំណើរខ្វះបុគ្គលិកលក្ខណៈ

impersonnel,elle *a.* មិនចំពោះមុខ, មិនមែនជារបស់អ្នកណាមួយដាច់ឡែក(ឧ.la raison est impersonnelle); អបុគ្គលិក, ខ្វះបុគ្គលិកលក្ខណៈ, សាមញ្ញ (ឧ. style impersonnel)

impersonnellement *adv.* ដោយមិនចំពោះមុខ

impertinemment *adv.* ដោយទ្រគោះ

impertinence *n.f.* សេចក្តីព្រហើន (ឧ. rien n'égale son impertinence); សំដី ឬ អំពើទ្រគោះ (ឧ. dire, faire des impertinences)

impertinent,e *a.* ដែលនិយាយដោយទ្រគោះ, ព្រហើន (ឧ. ton impertinent)

imperturbabilité *n.f.* ភាពមិនរំភើបនឹងអ្វីសោះ

imperturbable *a.* មិនរំភើបនឹងអ្វីសោះ

imperturbablement *adv.* ដោយមិនរំភើបនឹងអ្វីសោះ

impétrant,e *n.* ផលគត, អ្នកបានមុខងារ ឬ បានសញ្ញាប័ត្រ ។ល។

impétration *n.f.* ការសុំបាន (អំពីក្រសួងមានសមត្ថកិច្ច) (ឧ.impétra-

tion d'une grâce)

impétrer *v.t.* សុំបាន (អំពីក្រសួងមានសមត្ថកិច្ច) (ឧ. impétrer des lettres de grâce)

impétueusement *adv.* យ៉ាងខ្លាំង; ដោយប្រឡោក

impétueux,euse *a.* ដែលកម្រើក ឬ រំជួលខ្លាំង (ឧ. vent, torrent impétueux); ស្ទុះស្ទា, ដែលប្រឡោក (ឧ. caractère impétueux)

impétuosité *n.f.* ភាពខ្លាំង(ឧ.l'impétuosité d'une attaque); ភាពកម្រើក ឬ រំជួលខ្លាំង (ឧ. l'impétuosité des flots); ដំណើរប្រឡោក ; ភាពក្លៀវក្លា (ឧ. agir avec impétuosité)

impie *n.&a.* គ្មានសាសនា ; ផ្ទុយនឹងសាសនា (ឧ. discours impie)

impiété *n.f.* ការប្រមាថសាសនា, ការប្រមាថវត្ថុគោរព; អំពើ ឬ សំដីផ្ទុយនឹងសាសនា (ឧ. faire, dire des impiétés); ការខ្វះសេចក្ដីគោរព (ឧ. l'impiété d'un fils)

impitoyable *a.* គ្មានមេត្តា (ឧ.juge impitoyable); ឥតប្រណី (ឧ. critique impitoyable)

impitoyablement *adv.* ដោយគ្មានមេត្តា, ដោយឥតប្រណី

implacabilité *n.f.* ភាពមិនអាចធ្វើឲ្យស្ងប់បាន

implacable *a.* មិនអាចធ្វើឲ្យស្ងប់បាន (ឧ. haine implacable)

implacablement *adv.* ដោយមិនអាចធ្វើឲ្យស្ងប់បាន

implantation *n.f.* ការបញ្ចូល;ការចូល

implanter *v.t.* បញ្ចូល, ដាក់ចូល (ឧ. certains végétaux implantent leurs racines à une profondeur considérable); ដាំ; បោះគោល។ *Fig.* បញ្ចូល, តាំង (ឧ. implanter de nouveaux usages) ។

s'implanter *v.pr.Fig.&Fam.* ចូល (ឧ. s'implanter dans une société)

implicite *a.* ភទ្ទរហិត, គ្មានភាព, ដែលមាននៅក្នុងដោយមិនបាច់ថ្លែងឲ្យច្បាស់ (ឧ.clause implicite)

implicitement *adv.* ដោយភទ្ទរហិត, ដោយមិនបាច់ថ្លែងឲ្យច្បាស់ (ឧ. proposition implicitement contenue dans une autre)

impliquer *v.t.* រួមបញ្ចូល (ឧ. impliquer quelqu'un dans une accusation) ។ l'amitié implique la sincérité មិត្តភាពមានលុះណាតែមានសេចក្តីស្មោះ (សេចក្តីស្មោះត្រូវឲ្យមានជាប់ជាមួយនឹងមិត្តភាព)

implorable *a.* អាចអង្វរសុំបាន

implorant,e *a.* ដែលអង្វរសុំ

implorateur,trice *n.* អ្នកអង្វរសុំ

imploration *n.f.* ការអង្វរសុំ

implorer *v.t.* អង្វរសុំ (ឧ. implorer le pardon)

impluvium *n.m.* អាងទឹកភ្លៀង

impoli,e *a.* អសុភាព, ឥតគួរសម (ឧ. visiteur impoli)

impoliment *adv.* ដោយឥតគួរសម

impolitesse *n.f.* ដំណើរឥតគួរសម ; អំពើឥតគួរសម

impolitique *a.* ខុសនឹងនយោបាយល្អ (ឧ. mesure impolitique)

impondérabilité *n.f.* ភាពមិនអាចថ្លឹងបាន

impondérable *a.* មិនអាចថ្លឹងបាន។ *n.m. Fig.* អប្បមាណហេតុ, ហេតុពិបាកនឹងប្រមាណឬនឹងប្រុងទុកមុនបាន (ឧ. les impondérables de la politique)

impondéré,e *a.* ដែលមិនចេះប្រមាណ (ឧ. caractère impondéré)

impopulaire *a.* អប្រជាប្រិយ, ខុសនឹងបំណងរាស្ត្រ;ដែលរាស្ត្រមិនចូលចិត្ត(ឧ. loi impopulaire; ministre impopulaire)

impopularité *n.f.* អប្រជាប្រិយភាព, ភាពរាស្ត្រមិនចូលចិត្ត (ឧ. impopularité d'un gouvernement)

importable *a.* អាចហៅណើយ, អាចនាំចូលបាន (ឧ. marchandise importable)

importance *n.f.* ការសំខាន់; សារៈសំខាន់ (ឧ. affaire de haute importance) ។ importance vitale សារៈសំខាន់ស្មើជីវិត។ អំណាច, កិត្យានុភាព (ឧ. sa place lui donne beaucoup d'importance dans le monde) ; ភាពក្រអឺតក្រអង (ឧ. prendre un ton d'importance)។ se donner des airs d'importance ធ្វើឫកក្រអឺតក្រអោង (ធ្វើឫកឲ្យគេស្ញើម)។ d'importance *loc. a.*

សំខាន់ (ឧ. une affaire d'importance); *loc.adv.* ជាទីបំផុត, ខ្លាំងណាស់ (ឧ. il a été rossé d'importance)

important,e *a.* សំខាន់ (ឧ. avis important); ដែលមានអំណាច, ដែលកាន់មុខងារធំ (ឧ. un personnage important); ក្រអឺតក្រអោង (ឧ. se donner des airs importants) ។ *n.m.* ការសំខាន់ (ឧ. l'important est de...); មនុស្សក្រអឺតក្រអោង (ឧ. faire l'important)

importateur,trice *n.&a.* អាហារិន-រិនី, អ្នកនាំទំនិញចូល

importation *n.f.* អាហរណកម្ម [អា-ហ:-រ:-ណ:-], ការនាំទំនិញចូល ។ *pl.* អាហរណភណ្ឌ, ទំនិញនាំចូល

importer *v.t.* នាំចូល ។ *Fig.* នាំចូល, បញ្ចូល (ឧ. importer une mode)

importer *v.i.* ជាសំខាន់ (មានភាពសំខាន់) ។ *v.imp.* il importe សំខាន់, គួរតែ ។ qu'importe ? បានការអ្វី? ។ *pr. indéf.* n'importe quoi តាមតែប្រទះ, អ្វីក៏ដោយ (ចំពោះវត្ថុ) ។ n'importe qui តាមតែប្រទះ, អ្នកណាក៏ដោយ (ចំពោះមនុស្ស)

importun,e *n.&a.* ដែលរំខាន (ឧ. éloigner un importun; une question importune)

importunément *adv.* ដោយរំខាន

importuner *v.t.* រំខាន (ឧ. importuner quelqu'un de sollicitations)

importunité *n.f.* ការរំខាន (ឧ. l'importunité de certaines questions); ការរំខាន (ឧ. poursuivre quelqu'un de ses importunités)

imposable *a.* អាចដាក់ពន្ធបាន, ដែលជាប់ពន្ធ (ឧ. revenu imposable)

imposant,e *a.* គួរកោតញញើត, គួរគោរព (ឧ. figure imposante); សំបើម (ឧ. des forces imposantes)

imposé,e *a.* ជាប់ពន្ធ ។ *n.* អ្នកជាប់ពន្ធ

imposer *v.t.* ដាក់លើ (ន័យនេះមានតែក្នុងសំនួនសេចក្ដីប្រើក្នុងរឿងសាសនាជា imposer les mains) ។ *Fig.* ឲ្យបង់ពន្ធ (ឧ. imposer des contribuables); ឲ្យជាប់ពន្ធ (ឧ. imposer les boissons, une

province) ។

imposer sa volonté បង្ខំឲ្យតាមឆន្ទៈខ្លួន ។ imposer de dures conditions ដាក់លក្ខខណ្ឌតឹងរ៉ឹង ។ imposer silence បង្ខំឲ្យនៅស្ងៀម (លែងឮមាត់) ។

v.t. ind. en imposer à ឲ្យគេគោរព, ឲ្យគេខ្លាច (ឧ. en imposer à ses subordonnés) ។

s'imposer *v.pr.* ឲ្យគេព្រមទទួលដោយសេចក្ដីគោរពឬដោយខ្លាច (ឧ. s'imposer dans une société ឲ្យគេព្រមទទួលក្នុងសង្គមមួយដោយគេគោរព ឬ ដោយគេខ្លាច)

imposition *n.f.* ការដាក់ដៃលើ; ការបង្ខំឲ្យទទួល; ពន្ធ

impossibilité *n.f.* ភាពប្រព្រឹត្តទៅមិនបាន; អ្វីៗដែលធ្វើពុំកើត (ឧ. impossibilité matérielle)

impossible *a.* មិនអាចធ្វើឬប្រព្រឹត្តទៅបាន ។ *Par ext.* ពិបាកណាស់ (ឧ. il lui est impossible de se taire) ។ *Fam.* ចំឡែក (ឧ. des goûts impossibles) ។

n.m. អ្វីៗដែលធ្វើសឹងតែមិនកើត (ឧ. tenter l'impossible)

imposteur *n.m.* អ្នកបោកប្រាស់ដោយក្លែង ឬ ដោយកុហក

imposture *n.f.* ការបោកប្រាស់ដោយក្លែង ឬ ដោយកុហក (ឧ. toute sa vie n'a été qu'une imposture)

impôt *n.m.* ពន្ធ ។ impôt direct ពន្ធចំពោះ ។ impôt indirect ពន្ធមិនចំពោះ ។ impôt général sur les revenus ពន្ធទូទៅលើផលទុន ។ impôt sur le bénéfice ពន្ធលើកម្រៃ ។ impôt sur les traitements et salaires ពន្ធលើបៀវត្ស ។ impôt du sang ពន្ធឈាម (កាតព្វកិច្ចត្រូវធ្វើទាហាន)

impotence *n.f.* ភាពមានអង្គវិបត្តិ, ភាពខ្វិន

impotent,e *n.&a.* ដែលមានអង្គវិបត្តិ, ខ្វិន (ឧ. un vieillard impotent)

impraticabilité *n.f.* អប្រតិបត្តិភាព, ភាពមិនអាចធ្វើ ឬ ប្រតិបត្តិបាន

impraticable *a.* អប្រតិបត្តិយ, មិនអាចធ្វើ ឬ ប្រតិបត្តិបាន (ឧ. projet impraticable) ។ chemin impraticable ផ្លូវពិបាក

imprécateur,trice *n.&a.* អ្នកដាក់បណ្ដាសា

imprécation *n.f.* បណ្ដាសា

imprécatoire *a.* ជាបណ្ដាសា (ឧ. formule imprécatoire)

imprécis,e *a.* មិនច្បាស់លាស់ (ឧ. un signalement trop imprécis)

imprécision *n.f.* ភាពមិនច្បាស់លាស់

imprégnable *a.* អាចជ្រាំឬបញ្ជ្រាបបាន

imprégnation *n.f.* ការជ្រាំ, ការបញ្ជ្រាប ឬ ជ្រាប (ឧ. imprégnation des bois)

imprégné,e *a.* ជោកជាំ, ជោក (ឧ. être imprégné de préjugés)

imprégner *v.t.* ជ្រាំ, បញ្ជ្រាបឬជ្រាប។ *Fig.* ស៊ប់, ធ្វើឲ្យស៊ប់

imprenable *a.* មិនអាចនឹងដណ្ដើមយកបាន

impréparation *n.f.* ការមិនបានរៀបចំមុន

imprésario *n.m.* ថៅកែល្ខោន (*pl.* des imprésarios)

imprescriptibilité *n.f.* ភាពមិនអាចផុតរលត់បាន

imprescriptible *a.* មិនអាចផុតរលត់បាន (ឧ. la liberté de conscience est un droit imprescriptible)

impression *n.f.* ការផ្ដិត, ស្នាមផិត; ការបោះពុម្ព (ឧ. l'impression d'un livre); ការដឹងសម្ផស្ស (ឧ. impression de froid); ការជាប់អារម្មណ៍ (ឧ. ressentir une vive impression); ការរំភើប

impressionnabilité *n.f.* ភាពងាយរំភើប

impressionnable *a.* ងាយនឹងរំភើប (ឧ. les femmes sont plus impressionnables que les hommes)

impressionnant,e *a.* ដែលធ្វើឲ្យរំភើប; សំបើម

impressionner *v.t.* ផ្ដិតឲ្យមានស្នាម (ឧ. la lumière impressionne la plaque photographique) ។ *Fig.* ធ្វើឲ្យរំភើប

impressionnisme *n.m.* អារម្មណ៍និយម (ខាងសិល្បៈ និង អក្សរសាស្ត្រ)

impressionniste *n.m.* អ្នកអារម្មណ៍និយម

imprévisible ឬ **imprévoyable** *a.* មិនអាចគិតទុកជាមុនបាន (ឧ. l'avenir est presque entièrement imprévisible)

imprévision *n.f.* ការមិនបានគិតទុក

imprévoyance *n.f.* ការឥតគំនិត

imprévoyant,e *a.* ឥតគំនិត

imprévu,e *a.* មិនបានគ្រោងទុក, មិនបានគិតទុក ។ *n.m.* អ្វីៗដែលមិនបានគិតទុកជាមុន

imprimable *a.* គួរបោះពុម្ព, អាចបោះពុម្ពបាន

imprimé *n.m.* សៀវភៅ, ក្រដាសបោះពុម្ព

imprimer *v.t.* ធ្វើឲ្យមានស្នាម(ឧ.imprimer ses pas dans la neige); ផ្តិត (ឧ. imprimer une lithographie); បោះពុម្ព (ឧ.imprimer un livre) ។ imprimer un mouvement ធ្វើឲ្យដើរ, ធ្វើឲ្យមានចលនា ។ *Fig.* ធ្វើឲ្យមានផ្តិតក្នុងគំនិត ឬ ក្នុងចិត្ត (ឧ. imprimer la crainte, le respect)

imprimerie *n.f.* ការបោះពុម្ព; សម្ភារៈសម្រាប់បោះពុម្ព; រោងពុម្ព

imprimeur *n.&a.m.* ម្ចាស់រោងពុម្ព ; កម្មកររោងពុម្ព

imprimeuse *n.f.* ម៉ាស៊ីនបោះពុម្ព

improbabilité *n.f.* អភព្វីយភាព, ភាពមិនគួរមានឬ មិនគួរជឿ

improbable *a.* អភព្វីយ, មិនគួរមាន, មិនគួរជឿ (ឧ. événement très improbable)

improbateur,trice *a.* មិនយល់ព្រម (ឧ. geste improbateur)

improbatif,ive *a.* ដែលសំដែងការមិនយល់ព្រម

improbation *n.f.* ការមិនយល់ព្រម (ឧ.exprimer sans ménagement son improbation)

improbité *n.f.* សេចក្តីមិនទៀងត្រង់(ឧ. s'enrichir par de constantes improbités)

improductif,ive *a.* អផលិត, មិនឲ្យផល (ឧ. les jachères sont des terres improductives)

improductivement *adv.* ដោយអផលិត, ដោយមិនឲ្យផល

improductivité *n.f.* អផលិតភាព, ភាពមិនឲ្យផល

impromptu *adv.* ភ្លាមៗ, ដោយឥតបម្រុងទុក (ឧ. parler impromptu) ។ *a. inv.* ដែលធ្វើភ្លាមៗ, ឥតបម្រុងទុក (ឧ. visite impromptu)។ *n.m.* កាព្យដែលឥតគ្រោង

imprononçable *a.* ដែលថ្លែង ឬ ថាមិនបាន (ឧ. certains mots anglais sont réellement imprononçables pour des Français)

impropre *a.* ដែលប្រើការមិនបាន (ឧ. conscrit impropre au service); មិនចំ, មិនត្រូវ (ឧ. expression impropre)

improprement *adv.* ដោយមិនចំឬមិនត្រូវ (ឧ. s'exprimer improprement)

impropriété *n.f.* សេចក្ដីមិនចំ(ភាសា) (ឧ. critiquer l'impropriété d'une locution)

improuvable *a.* មិនអាចបង្ហាញភស្តុតាងបាន

improuver *v.t.* មិនយល់ព្រម

improvisateur,trice *n.* អ្នកធ្វើសុន្ទរកថាដោយឥតព្រាងទុក

improvisation *n.f.* ការធ្វើសុន្ទរកថាដោយឥតព្រាងទុក (ឧ. négligence de style échappées dans le feu de l'improvisation); ពាក្យ ឬ សុន្ទរកថាដែលឥតបានព្រាងទុក (ឧ. les éloquentes improvisations de Gambetta)

improviser *v.t. & i.* ធ្វើសុន្ទរកថាដោយឥតព្រាងទុក

improviste (à l') *loc. adv.* ដោយមិនបានដឹងខ្លួនជាមុន (ឧ. survenir à l'improviste)

imprudemment *adv.* ដោយធ្វេសប្រហែស

imprudence *n.f.* ការធ្វេសប្រហែស (ឧ. malade qui commet des imprudences)

imprudent,e *a.* ដែលធ្វេសប្រហែស (ឧ. nageur imprudent)

impubère *a.* មិនទាន់គ្រប់ការ

impuberté *n.f.* ភាពមិនទាន់គ្រប់ការ

impubliable *a.* មិនអាចផ្សាយបាន

impudemment *adv.* ដោយឥតអៀនខ្មាស

impudence *n.f.* ការ-អំពើឬសំដីឥតអៀនខ្មាស

impudent,e *a.* ឥតអៀនខ្មាស

impudeur *n.f.* ការឥតអៀនខ្មាស

impudique *a.* ឥតគិតពីអៀនខ្មាស, អាស (ឧ. gestes impudiques)

impudiquement *adv.* ដោយឥតបើគិតពីអៀនខ្មាស

impuissance *n.f.* អនានុភាព, ដំណើរឥតអានុភាព ឬ គ្មានមធ្យោបាយ (ឧ. réduire à l'impuissance un criminel)

impuissant,e *a.* ឥតអានុភាព, ឥតអំណាច (ឧ. Turgot fut impuissant à réformer les abus de l'Ancien Régime)

impulsif,ive *a.* ដែលដាក់ ឬ រុញ (ឧ. force impulsive de la poudre); ដែលប្រព្រឹត្តទៅដូចមានគេប្រាន។ *n.* អ្នកដែលធ្វើអ្វីដោយមិនដឹងខ្លួន (ដូចមានគេប្រាន) (ឧ. les impulsifs sont souvent irresponsables de leurs actes)

impulsion *n.f.* ពលវេគ, ការដាក់ ឬរុញ (ឧ. donner l'impulsion à une machine); កម្លាំងជំរុលចិត្តឲ្យធ្វើ (ឧ.agir sous l'impulsion de la colère)

impulsivité *n.f.* ចរិតធ្វើអ្វីដោយមិនដឹងខ្លួន (ដូចមានគេប្រាន)

impunément *adv.* ដោយនិទ្ទណ្ឌ, ដោយគ្មានទទួលទោស ឬ ផលអាក្រក់ (ឧ. malade qui ne sortira pas impunément)

impuni,e *a.* និទ្ទណ្ឌ, គ្មានទទួលទោស (ឧ. trop de crimes restent impunis)

impunité *n.f.* និទ្ទណ្ឌភាព, ការគ្មានដាក់ទោស (ឧ. l'impunité rend hardi)

impur,e *a.* អសុចិ,មិនសុទ្ធ (ឧ.plomb impur)។*Fig.*អបរិសុទ្ធ,មិនបរិសុទ្ធ; អប្រិយ; សៅហ្មង; ខុសពីសីលធម៌ (ឧ. mœurs impures)

impurement *adv.* ដោយមិនសុទ្ធ; ដោយមិនបរិសុទ្ធ ឬ ដោយខុសសីលធម៌

impureté *n.f.* អសុចិភាព, ភាពមិនសុទ្ធ (ឧ. impureté de l'ieau); វត្ថុដែលនាំឲ្យសៅហ្មង ។ *Fig.* សេចក្ដីសៅហ្មង; ភាពឥតបើគិតពីរៀនខ្មាស (ឧ. vivre dans l'impureté); សំដីឬអំពើអាសគ្រាម

imputabilité *n.f.* ភាពគួររាប់បញ្ចូល; ឬ គួរទម្លាក់ទោសលើ; ការទទួលខុសត្រូវខាងផ្លូវចិត្ត

imputable *a.* គួររាប់បញ្ចូល; គួរទម្លាក់ទោសលើ ។ *Fin.* អាចដាក់បន្ទុកចំណាយលើបាន (ឧ. somme imputable sur une réserve)

imputation *n.f.* ការចោទទោស(ដោយ

គ្មានកស្តាង); ការទម្លាក់ទោស; ការដាក់បញ្ចូល ។ *Fin.* បន្ទុកចំណាយ

imputer *v.t.* ទម្លាក់ទោស ។ *Fin.* ដាក់បន្ទុក (ចំណាយ) (ឧ. imputer une dépense sur un chapitre du budget)

imputrescibilité *n.f.* ភាពមិនពុករលួយ

imputrescible *a.* មិនពុករលួយ (ឧ. des injections de créosote rendent le bois imputrescible)

inabordable *a.* មិនអាចចូលជិតបាន (ឧ. côte inabordable) ។ *Fig.* មិនអាចចូលជួបបាន (ឧ. ministre inabordable); ថ្លៃពេក (លក់មិនចុះ) (ឧ. denrées inabordables)

inabrité,e *a.* គ្មានជម្រក (ឧ. mouillage inabrité)

inabrogeable *a.* មិនអាចលុបចោលបាន (ឧ. les lois naturelles sont inabrogeables)

inacceptable *a.* មិនអាចទទួលយក ឬ ព្រមព្រៀងបាន (ឧ. refuser une proposition inacceptable)

inacceptation *n.f.* ការមិនទទួលយក ឬ មិនព្រមព្រៀង

inaccessibilité *n.f.* ទុគ៌មភាព, ភាពចូលមិនចុះឬទៅមិនដល់ ។ *Fig.* ភាពគិតមិនយល់

inaccessible *a.* ទុគ៌ម, ដែលចូលមិនចុះឬទៅមិនដល់ (ឧ. la cime du mont Blanc fut longtemps inaccessible) ។ *Fig.* មិនអាចយល់បាន (ឧ. le mystère de la création est inaccessible à l'esprit humain) ។ inaccessible à la pitié ដាច់មេត្តា

inaccompli,e *a.* មិនទាន់សម្រេចផល; មិនបានបំពេញកិច្ច

inaccomplissement *n.m.* ដំណើរមិនបានបំពេញកិច្ច

inaccordable *a.* មិនអាចព្រមឲ្យបាន (ឧ. demande inaccordable); មិនអាចធ្វើឲ្យចុះសម្រុងគ្នាបាន (ឧ. caractères inaccordables)

inaccoutumé,e *a.* មិនធ្លាប់ (ឧ. inaccoutumé au travail); មិនធ្លាប់មាន (ឧ. honneur inaccoutumé)

inachevé,e *a.* មិនទាន់ហើយ, មិនទាន់សម្រេច (ឧ. un livre ina-

chevé)

inachèvement *n.m.* ភាពមិនទាន់ហើយ ឬ មិនទាន់សម្រេច

inactif,ive *a.* និស្សកម្ម,ដែលនៅស្ងៀម

inaction *n.f.* និស្សកម្ម. ដំណើរគ្មានធ្វើអ្វីសោះ (ឧ. vos forces s'émoussent dans l'inaction)

inactivité *n.f.* និស្សកម្មភាព(ឧ.fonctionnaire qui demande un congé d'inactivité)

inactuel,elle *a.* គ្មានបច្ចុប្បន្នភាព

inadapté,e *a.* មិនត្រូវ; មិនគ្នំ;មិនបេះយកលំនាំតាម

inadéquat,e *a.* មិនពេញលេញ, មិនជួនល្មម; មិនត្រូវ

inadmissibilité *n.f* អប្រវេសនីយភាព, ភាពមិនអាចទទួល ឬ ទុកជាត្រូវបាន

inadmissible *a.* អប្រវេសនីយ, មិនអាចទទួល ឬ ទុកជាត្រូវបាន (ឧ.prétention inadmissible)

inadmission *n.f.* អប្រវេសន៍, ការមិនទទួល, ការមិនឲ្យត្រូវ

inadvertance *n.f.* ប្រមាទកិច្ច, អំពើធ្វើដោយធ្វេស

inaliénabilité *n.f.* ភាពមិនអាចលក់ ឬ ផ្ទេរសិទ្ធិបាន

inaliénable *a.Dr.* មិនអាចលក់ឬបញ្ចាំបាន (ឧ.les biens composant le domaine public sont inaliénables et imprescriptibles)

inaliéné,e *a.* អបល្លាស, មិនផ្ទេរសិទ្ធិ (ឧ. droit inaliéné)

inalliable *a.* មិនអាចលាយ ឬ បញ្ចុះបាន(លោហធាតុ) ។ *Fig.* មិនអាចផ្សំ ឬ ប្រួបរួមគ្នាបាន (ឧ.idées inalliables)

inaltérabilité *n.f.* ភាពមិនអាចធ្វើឲ្យខូចបាន

inaltérable *a.*មិនអាចធ្វើឲ្យខូចបាន(ឧ. l'or est inaltérable) ។ *Fig.* amitié inaltérable មិត្តភាពខ្ជាប់ខ្ជួន (មិនអាចរលាយបាន)

inaltéré,e *a.* ខ្ជាប់ខ្ជួន, មិនខូច

inamical,e *a.* ដែលសំដែងអមិត្តភាព

inamovibilité *n.f.* អចរនីយភាព[អ:-ច:-រ-នី-យ:], ភាពមិនអាចហូតងារបាន (ឧ. l'inamovibilité des magistrats est une garantie de leur indépendance)

inamovible *a.* អចរនីយ[អ:-ច:-រ:-នី], មិនអាចហូតងារបាន (ឧ. la magi-

strature française est inamovible; fonction inamovible)

inanimé,e *a.* អជីវបល, គ្មានជីវិត (ឧ. corps inanimé); មិនកម្រើក; មិនអ៊ូអរ

inanité *n.f.* និរត្ថភាព, ភាពឥតប្រយោជន៍ (ឧ. inanité des choses d'ici-bas)

inanition *n.f.* ភាពចិមចិយដោយអត់អាហារ (ឧ. mourir d'inanition)

inapaisable *a.* មិនអាចធ្វើឲ្យស្ងប់ឬឲ្យស្រាកបាន (ឧ. soif inapaisable)

inapaisé,e *a.* មិនទាន់ស្ងប់, មិនទាន់ស្រាក

inaperçu,e *a.* ដែលគេមិនបានសំគាល់ ឬ មិនបានឃើញ (ឧ. passer inaperçu dans une foule)

inapparent,e *a.* មិនស្ដែង

inappétance *n.f.* ការមិនឃ្លាន, ការធុំអាហារ

inapplicable *a.* មិនអាចអនុវត្តបាន (ឧ. abroger une loi devenue inapplicable)

inapplication *n.f.* អនានុវត្តន៍ ; ការមិនសម្ដី ឬ មិនផ្ចិតផ្ចង់

inappréciable *a.* មិនអាចវាយតម្លៃបាន; ស្ទួចស្ដើង (ឧ. différence inappréciable) ។ *Fig.* មិនអាចយកជាការបាន (ឧ. talent, faveur inappréciable)

inappréciablement *adv.* ដោយស្ទួចស្ដើង; ដោយមិនអាចយកជាការបាន

inapprécié,e *a.* គ្មានតម្លៃ; ដែលគេមិនរាប់អាន

inapprivoisable *a.* មិនអាចផ្សាំងបាន (ឧ. le tigre est inapprivoisable)

inapprivoisé,e *a.* មិនទាន់ស៊ាំង

inapte *a.* គ្មានសម្បទា (ឧ. personne inapte aux affaires)

inaptitude *n.f.* អសម្បទា, ដំណើរខ្វះសម្បទា

inarticulé,e *a.* មិនច្បាស់ (ឧ. cris inarticulés)

inaspiré,e *a.* សិថិល (ព្យញ្ជនៈ)

inasservi,e *a.* គ្មានគេជិះជាន់, គ្មានគេយកធ្វើជាខ្ញុំ

inassimilable *a.* មិនអាចជ្រួតជ្រាបឬយល់ជាក់បាន; មិនអាចប្រៀបធៀបបាន

inassouvi,e *a.* មិនទាន់ឆ្អែត, មិនឆ្អែតឆ្អន់ (ឧ. désir inassouvi)

inassouvissement *n.m.* អាការមិនទាន់ឆ្អែត - មិនបោះឆ្អែតឆ្អន់ ឬ មិនពេញបំណង

inattaquable *a.* មិនអាចវាយលុកបាន; មិនអាចចោទប្រកាន់ ឬ ជាប់ថ្នាក់បាន (ឧ. droit inattaquable)

inattendu,e *a.* មិនបានរង់ចាំ ; មិនបានប្រុងទុក (ឧ. recevoir une visite inattendue)

inattentif,ive *a.* មិនប្រុងស្មារតី,ធ្វេសប្រហែស(ឧ.gardien inattentif)

inattention *n.f.* ការធ្វេសប្រហែស

inaudible *a.* អសវនីយ, មិនអាចស្ដាប់ឮដោយត្រចៀក (ឧ. vibrations inaudibles)

inaugural,e,aux *a.* សម្ពោធ (ឧ. séances inaugurales d'un congrès)

inaugurateur,trice *n.* សម្ពោធី-ធិនី, អ្នកសម្ពោធ

inauguration *n.f.* សម្ពោធន៍, ពិធីឆ្លង ឬឡើង ។ *Fig.* ដើមដំបូង

inaugurer *v.t.* សម្ពោធ, ឆ្លង (ឧ. inaugurer une statue); ឡើង (ឧ.inaugurer une maison)។ *Fig.* ផ្ដើម (ឧ.événement qui inaugura une ère de troubles)

inauthenticité *n.f.* នយថាភាព[ន:- យ:-](ឧ. démontrer l'inauthenticité d'un acte)

inauthentique *a.* នយថាភូត[ន:-យ:-]

inavouable *a.* មិនអាចឆ្លើយទទួលសារភាពបាន,គួរឲ្យខ្មាស(ឧ.mœurs inavouables)

inavoué,e *a.* ដែលគេមិនឆ្លើយទទួលសារភាព

incalculable *a.* អគណនីយ, មិនអាចគណនាបាន, មិនអាចរាប់បាន (ឧ. le nombre des étoiles est incalculable) ។ *Fig.* មិនអាចស្ទង់-គិតឬត្រិះរិះបាន(ឧ.la bataille de Waterloo eut des conséquences incalculables)

incalculablement *adv.* ដោយមិនអាចគណនាបាន

incandescence *n.f.* ភាពវត្ថុដុតក្ដៅឡើងស; ភាពរង្គាល ។ *Fig.* សេចក្ដីស្រើបស្រាលខ្លាំង (ឧ. l'incandescence des passions)

incandescent,e *a.* ដែលដុតក្ដៅឡើងស; រង្គាល ។ *Fig.* ដែលស្រើប-

ស្រាលខ្លាំង

incantation *n.f.* ការសែកមន្តគាថា

incantatoire *a.* នៃការសែកមន្តគាថា

incapable *n.&a.* អសមត្ថ, គ្មានសមត្ថភាព (ឧ. chef incapable de diriger) ។ *Dr.* អសមត្ថជន (ជនប្រាសចាកសិទ្ធិ) (ឧ. les interdits, les mineurs sont des incapables) ។ មិនអាច (ឧ. incapable de lâcheté មិនអាចប្រព្រឹត្តអំពើថោកទាបបាន)

incapacité *n.f.* អសមត្ថភាព (ការខ្វះសមត្ថភាព, ភាពប្រាសចាកសិទ្ធិ)

incarcération *n.f.* ពន្ធនកម្ម, ការដាក់គុក (ឧ. incarcération d'un criminel); ភាពជាប់គុក ឬ ជាប់ឃុំ

incarcérer *v.t.* ដាក់គុក, ដាក់ក្នុងឃុំ (ឧ. incarcérer préventivement un inculpé)

incarnat,e *a.&n.m.* ពណ៌ឈាមជ្រូក

incarnation *n.f.* ការចូលរូប; ការជាប់កក (ឧ. le mystère de l'incarnation)

incarner *v.t.* បញ្ចូលរូប, ឲ្យមានរូប ។ démon incarné *a.* មនុស្សកំណាច ។ ongle incarné ក្រចកកប់ (ក្រចកដុះជាប់ក្នុងសាច់ហើយបណ្ដាលឲ្យឈឺជា)។ *Fig.* ធ្វើឲ្យមានរូបរាង; តំណាង (ឧ. magistrat qui incarne la justice) ។ s'incarner *v.pr.* ចូលរូប, ជាប់កក

incartade *n.f.* ការដើរប្រមាថដោយមិនសមហេតុផល, ភាពឈ្លើយ; អំពើឆ្គួសឆ្គាស(ឧ.faire mille incartades)

incassable *a.* មិនបែក

incendiaire *n.* អ្នកបង្កអគ្គីភ័យ។ *a.* ដែលអុជអាល ។ bombe incendiaire ម.ព. bombe ។ *Fig.* ដែលញុះញង់ (ឧ. écrit incendiaire)

incendie *n.m.* អគ្គីភ័យ, អគ្គិភ័យ (ឧ. l'incendie volontaire d'une maison habitée est passible de la peine de mort)។ *Fig.* វិបត្តិ (ក្នុងរដ្ឋ) (ឧ. la France sortit rajeunie de l'incendie révolutionnaire)

incendié,e *a.&n.* អន្តរាយពីអគ្គី (ឧ. maison incendiée); អ្នករងអគ្គីភ័យ (ឧ. accorder des secours aux incendiés)

incendier *v.t.* ដុត, អុជ ។ *Fig.* អុជ-

អាល, ញុះញង់

incertain,e *a.* មិនប្រាកដ (ឧ.succès incertain); អាចប្រែប្រួល (ឧ. temps incertain); មិនទៀង (ឧ. l'heure incertaine de notre mort); ទទើរ (ស្ទាក់ស្ទើរ) (ឧ.être incertain de ce qu'on doit faire) ។

n.m. អ្វីៗដែលមិនប្រាកដឬមិនទៀង, អ្វីៗដែលប្រែប្រួល (ឧ. quitter le certain pour l'incertain)

incertitude *n.f.* ភាពមិនប្រាកដឬមិនទៀង (ឧ. l'incertitude d'une nouvelle); ភាពអាចប្រែប្រួល (ឧ. incertitude du temps) ; ភាពមិនទៀង (ឧ. l'incertitude de la fortune); ភាពទទើរ (ឧ. être dans l'incertitude)

incessamment *adv.* ឥតឈប់ (ឧ. l'avare amasse incessamment) ; ក្នុងពេលឆាប់ៗ , ភ្លាម (ឧ. venez me voir incessamment)

incessant,e *a.* ដែលមិនឈប់

incessibilité *n.f.Dr.* អនានុប្បទានីយភាព, ភាពផ្ទេរឬប្រគល់មិនបាន (ឧ. l'incessibilité d'un droit)

incessible *a.* អនានុប្បទានីយ, មិនអាចផ្ទេរឬប្រគល់បាន

inceste *n.f.* ស្មន្តការ, ដំណើរស្មន់នឹងគ្នា (ចំពោះញាតិដែលច្បាប់ហាមមិនឲ្យយកគ្នាជាប្ដីប្រពន្ធ) ។ *n.* ស្មន្តការី.អ្នកស្មន់ (ដោយយកញាតិដែលច្បាប់ហាមជាប្ដីប្រពន្ធ)

incestueusement *adv.* ដោយស្មន់នឹងគ្នា

incestueux,euse *n.&a.* ស្មន្តការី-រិនី, ដែលស្មន់នឹងគ្នា

inchangé,e *a.* ឥតផ្លាស់ប្ដូរ (ឧ. situation inchangée)

inchangeable *a.* មិនអាចផ្លាស់ប្ដូរបាន

inchavirable *a.* មិនអាចផ្កាប់-ក្រឡាប់ឬលិចបាន (ឧ. les canots de sauvetage sont inchavirables)

incidemment *adv.* ជាបន្ទាប់បន្សំ ; ដោយពេល

incidence *n.f.Fig.* ដំណើរធ្លាក់; ការទាក់ទិន

incident *n.m.* ឧប្បត្តិហេតុ

incident,e *a.* ដែលធ្លាក់ប៉ះលើផ្ទៃ (ឧ. rayon incident) ។ *Pratiq.* ដែលលេចឡើងក្នុងពេលជំនុំ (ឧ.ques-

tion incidente) ។ demande incidente ម.ព. demande

incidenter *v.t.* បង្កើតឧប្បត្តិហេតុ ឬ ឧបសគ្គ

incinération *n.f.* ឈាបនកិច្ច, ការដុតរំលាយ (ឧ. les Cambodgiens pratiquent l'incinération des morts); ភាពសុសជាផេះ

incinérer *v.t.* ធ្វើឈាបនកិច្ច, ដុតរំលាយ (ឧ. incinérer un cadavre)

incirconcis *n.&a.* ដែលគ្មានកាត់ស្បែក (ម.ព. circoncis ផង)

incirconcision *n.f.* ភាពគ្មានកាត់ស្បែក (ម.ព. circoncision ផង)

inciser *v.t.* កាត់, វះ

incisif,ive *a.* មុត (ឧ. critique incisive) ។ *n. & a.f.* dents incisives ធ្មេញមុខ ឬ ធ្មេញសើប

incision *n.f.* ការកាត់, ការវះ (ឧ. faire une incision avec un bistouri)

incitateur,trice *a.&.n.* អ្នកញុះញង់

incitation *n.f.* ការញុះញង់

inciter *v.t.* ញុះញង់ (ឧ. inciter à la révolte)

incivil,e *a.* មិនសុភាព, ឥតគួរសម (ឧ. homme, langage incivil)

incivilement *adv.* ដោយឥតគួរសម

incivilisé,e *a.* អនារ្យ, គ្មានអារ្យធម៌

incivilité *n.f.* ភាពឥតគួរសម; អំពើ ឬ សំដីឥតគួរសម (ឧ. commettre une incivilité)

incivique *a.* ដែលខ្វះរដ្ឋនិយម, មិនស៊ូប្ដូរនឹងរដ្ឋ

incivisme *n.m.* ការខ្វះរដ្ឋនិយម, ការមិនស៊ូប្ដូរនឹងរដ្ឋ

inclémence *n.f.* ភាពគ្មានសេចក្ដីអត់ឱន ។ *Fig.* ភាពពិបាកទ្រាំ (ឧ. l'inclémence de la température)

inclément,e *a.* គ្មានសេចក្ដីអត់ឱន ។ *Fig.* ពិបាកទ្រាំ (ឧ. saison inclémente)

inclinaison *n.f.* បង្អៀង, ភាពទេរ-ផ្អៀង ឬ ទ្រេត

inclination *n.f.* ការងក់ក្បាល (សំដែងសេចក្ដីយល់ព្រមឬសេចក្ដីគោរព)។ *Fig.* ការចូលចិត្ត, ការលំអៀង (ឧ. inclination vicieuse); ស្នេហា (ឧ. mariage d'inclination)។ *Fam.* អ្នកដែលគេស្រឡាញ់

incliné,e *a.* ទ្រេត, ផ្អៀង, ទេរ, លំអៀង

incliner *v.t.* ងក (ឧ. incliner la tête)។ *v.i.* ទេរ, ទ្រេត (ឧ. ce mur incline) ។ *Fig.* មានសេចក្ដីលំអៀង (ឧ. incliné à la miséricorde)។ s'incliner *v.pr.* បន្ទន់ខ្លួនឬឱនដោយខ្លាចឬដោយគោរព; ព្រមចាញ់ ។ *Fig.* សំដែងសេចក្ដីគោរព

inclure *v.t.* បញ្ចូល, ចុះផ្សាយក្នុង (ឧ. inclure une note dans une lettre)

inclus,e *part. passé* ជាបរិយាបន្ន (ឧ.le 20 inclus ថ្ងៃ២០ជាបរិយាបន្ន); មាននៅក្នុង

inclusif,ive *a.* ដែលមាននៅក្នុងស្រាប់

inclusion *n.f.* ការរាប់បញ្ចូល; ភាពនៅពីក្នុង

inclusivement *adv.* ដោយបរិយាបន្ន, ដោយរាប់បញ្ចូល

incoagulable *a.* មិនអាចកកឬខាប់បាន

incoercibilité *n.f.* ភាពមិនអាចសង្កត់ឲ្យណែន ឬ ទប់បាន

incoercible *a.* មិនអាចសង្កត់ឲ្យណែនបាន (ឧ. fluide incoercible); មិនអាចទប់បាន (ឧ.rire incoercible)

incognito *adv.* អញ្ញាតកវេស [អ័ញ-ញ៉ា-ត-ក:-វេស] (ដោយក្លែងភេទមិនឲ្យគេស្គាល់) (ឧ.les souverains voyagent souvent incognito) *n.m.* អញ្ញាតកវេស ។ garder l'incognito រក្សាអញ្ញាតកវេស, ក្លែងភេទមិនឲ្យគេស្គាល់

incognoscible *a.* ហួសវិស័យបញ្ញាមនុស្សលោក

incohérence *n.f.* ភាពគ្មានទាក់ទងគ្នា ។ *Fig.* incohérence des idées ភាពគំនិតដែលមិនហូរហែ ឬរើរាយ

incohérent,e *a.* គ្មានទាក់ទងគ្នា (ឧ. assemblage incohérent) ។ *Fig.* មិនហូរហែ, រើរាយ (ឧ. mots incohérents)

incohésion *n.f.* ភាពមិនជាប់គ្នា

incolore *a.* ឥតពណ៌ (ឧ. l'alcool pur est incolore) ។ *Fig.* មិនឆើត (ឧ. style incolore)

incomber *v.i.* ធ្លាក់លើ (ឧ. cette tâche lui incombe)

incombustibilité *n.f.* អទិន្ធនភាព [អ-ទិន-ធ:-ន:-]. ភាពដុតមិនឆេះ

incombustible *a.* អទិន្ធន: [អ:-ទិន-

ធៈ-នៈ], មិនឆេះ (ឧ. l'amiante est incombustible)

incomestible *a.* ដែលបរិភោគមិនបាន

income-tax [in'-kom'-taks] *n.m.* (ព.អ.) ពន្ធផលរុន

incommensurabilité *n.f.* ភាពវាស់នឹងគ្នាមិនបាន; អប្បមាណភាព, ភាពធំហួសប្រមាណ

incommensurable *a.* ដែលវាស់នឹងគ្នាមិនបាន (ឧ. le périmètre du cercle est incommensurable avec son diamètre) ។ *Abus.* អប្បមាណ, ធំហួសប្រមាណ (ឧ. espace incommensurable)

incommensurablement *adv.* ដោយវាស់នឹងគ្នាមិនបាន

incommodant,e *a.* ដែលរំខាន, ដែលធ្វើឲ្យមិនស្រួលខ្លួន (ឧ. l'odeur incommodante du phénol)

incommode *a.* មិនស្រួល, មិនស្រួលប្រើ (ឧ. outil incommode); ដែលនាំឲ្យមិនស្រួលខ្លួន, ឲ្យហត់ឬឲ្យអផ្សុក (ឧ. chaleur, bruit incommode); ដែលរំខាន (ឧ. voisin incommode)

incommodé,e *a.* មិនសូវស្រួលខ្លួន

incommodément *adv.* ដោយមិនស្រួលខ្លួន (ឧ. être assis incommodément)

incommoder *v.t.* ធ្វើឲ្យទើសទែង, នាំឲ្យលំបាក, នាំឲ្យមិនស្រួលខ្លួន (ឧ. son rhume l'incommode) ។ *Fig.* នាំឲ្យរំខាន

incommodité *n.f.* ភាពមិនស្រួល; ការទើសទែង; ការរំខាន; ភាពមិនសូវស្រួលខ្លួន (ឧ. la vieillesse entraîne d'inévitables incommodités)

incommunicable *a.* មិនអាចផ្ទេរ ឬ ឲ្យដំណឹងបាន (ឧ. des honneurs, des droits incommunicables)

incommutabilité *n.f.Dr.* ភាពមិនអាចដកហូតធនធានបាន; ភាពមិនអាចដូរម្ចាស់បាន

incommutable *a.Dr.* មិនអាចដកហូតធនធានបាន (តាមផ្លូវច្បាប់); មិនអាចដូរម្ចាស់បាន (ឧ. propriété incommutable)

incomparable *a.* ឥតឧបមា, មិនអាចប្រៀបផ្ទឹមបាន (ឧ. éclat incomparable)

incomparablement *adv.* ដោយ

ប្រៀបផ្ទឹមមិនបាន

incompatibilité *n.f.* វិសមិតភាព, ភាពមិនត្រូវគ្នា (ឧ. incompatibilité d'humeur) ។ *Dr.* ការកាន់ត្រួតគ្នាមិនបាន (ដំណែងខ្លះ) (ឧ. il y a incompatibilité entre les fonctions de député et celle de préfet)

incompatible *a.* វិសមិត, មិនត្រូវគ្នា (ឧ. caractères incompatibles) ។ *Méd.* ដែលកើតជាមួយគ្នាស្មើរូបតែមួយមិនបាន (រោគ) ។ *Pharm.* ដែលលាយគ្នាមិនបាន (សារធាតុ) ។ *Dr.* ដែលកាន់ត្រួតគ្នាមិនបាន (ដំណែង)

incompatiblement *adv.* ដោយវិសមិត

incompétence *n.f.* អសមត្ថកិច្ច, អសមត្ថភាព, ភាពគ្មានសមត្ថកិច្ច ឬ គ្មានសមត្ថភាព (ឧ. soulever l'incompétence d'un tribunal)

incompétent,e *a.* គ្មានសមត្ថកិច្ច, គ្មានសមត្ថភាព (ឧ. tribunal qui se déclare incompétent)

incomplet,ète *a.* មិនគ្រប់ចំនួន, មិនពេញ, មិនទាន់ហើយ

incomplètement *adv.* ដោយមិនគ្រប់ចំនួន, ដោយមិនទាន់ហើយ

incompréhensibilité *n.f.* ភាពមិនអាចយល់បាន

incompréhensible *a.* មិនអាចយល់បាន (ឧ. raisonnement incompréhensible); មិនអាចពន្យល់បាន (ឧ. texte incompréhensible); ចំឡែក (ឧ. homme, caractère incompréhensible)

incompréhensif,ive *a.* មិនយល់

incompréhension *n.f.* ដំណើរមិនយល់

incompressibilité *n.f.* ភាពមិនអាចកិនបង្ហាប់បាន

incompressible *a.* មិនអាចកិនបង្ហាប់បាន (ឧ. l'eau est à peu près incompressible)

incompris,e *n.&a.* ដែលគេមិនយល់ឬមិនស្គាល់តម្លៃ (ឧ. poète incompris)

inconcevable *a.* មិនអាចយល់បាន ។ *Par ext.* ប្លែកអស្ចារ្យ (ឧ. une méprise inconcevable; homme inconcevable)

inconcevablement *adv.* ដោយមិនអាចយល់បាន; ដោយប្លែកអស្ចារ្យ

inconciliabilité *n.f.* ភាពមិនអាចផ្សះផ្សា ឬ មិនអាចនៅជាមួយគ្នាបាន

inconciliable *a.* មិនអាចផ្សះផ្សាបាន (ឧ. des plaideurs inconciliables); មិនអាចនៅជាមួយគ្នាបាន (ឧ. la bienveillance et l'égoïsme sont inconciliables)

inconciliation *n.f.* ការមិនព្រមស្រុះស្រួលគ្នា; ភាពមិនស្រុះស្រួលគ្នា

inconditionné,e *a.* គ្មានលក្ខខណ្ឌ; ដាច់ខាត

inconduite *n.f.* ការប្រព្រឹត្តមិនល្អ

inconfort *n.m.* អផាសុកភាព

inconfortable *a.* អផាសុក

incongelable *a.* មិនអាចបង្កកបាន

incongru,e *a.* អប្បដិរូប, ខុសពីសុជីវធម៌; ពុំគប្បី (ឧ. réponse incongrue)

incongruité *n.f.* អប្បដិរូបភាព; អំពើ ឬ សំដីប្រឡែះបោះ

incongrûment *adv.* ដោយខុសសុជីវធម៌; ដោយប្រឡែះបោះ

inconnaissable *a.* អញ្ញាតិយ, មិនអាចដឹង ឬ ស្គាល់បាន (ឧ. la raison dernière du monde est inconnaissable) ។ l'inconnaissable *n.m.* អញ្ញាតិយវត្ថុ(វត្ថុដែលគេមិនអាចស្គាល់បាន)

inconnu,e *a.* អញ្ញាត, ដែលគេមិនស្គាល់, មិនល្បី (ឧ. artiste inconnu); ដែលគេមិនទាន់ដឹង(ឧ. sensations inconnues) ។ *n.* អញ្ញាតជន, មនុស្សដែលគេមិនស្គាល់ ។ *n.m.* អញ្ញាតវត្ថុ, វត្ថុដែលគេមិនស្គាល់ (ឧ. passer du connu à l'inconnu) ។ *n.f. Math.* ចំនួនបិទមុខ, ចំនួនមិនដឹង

inconsciemment *adv.* ដោយមិនដឹងខ្លួន (ឧ. se rendre inconsciemment complice d'une vilénie)

inconscience *n.f.* អសម្បជញ្ញៈ, ភាពគ្មានសម្បជញ្ញៈ ឬ មិនដឹងខ្លួន

inconscient,e *a.* គ្មានសម្បជញ្ញៈ, មិនដឹងខ្លួន (ឧ. beaucoup de phénomènes physiques importants sont inconscients); គ្មានគិត ។ l'inconscient *n.m.* អសម្បជញ្ញការ, អ្វីៗដែលគេមិនដឹង

inconséquemment *adv.* ដោយអនានុយោគ, ដោយមិនសមហេតុផល

inconséquence *n.f.* អនានុយោគ, គំនិត ឬ អំពើមិនសមហេតុផល

inconséquent,e *a.* អនានុយាត, មិនសមហេតុផល (ឧ. conduite inconséquente) ; ដែលគេមិនបានរើងហេតុផល (ឧ. démarche inconséquente) ; ដែលមានកិរិយាមិនទៀង, ក្រឡប់ក្រឡិន (ឧ. homme inconséquent)

inconsidéré,e *a.* ដែលឆ្វេស, ពាយងាយ; ដែលធ្វើ ឬ និយាយដោយឥតពិចារណា (ឧ. proposition inconsidérée)

inconsidérément *adv.* ដោយឆ្វេស (ឧ. s'engager inconsidérément dans une spéculation)

inconsistance *n.f.* ភាពមិនរឹង ។ *Fig.* ភាពមិនសមហេតុផល; ភាពមិនខ្ជាប់ខ្ជួន(ឧ. l'inconsistance des idées)

inconsistant,e *a.* មិនរឹង ។ *Fig.* មិនសមហេតុផល; មិនខ្ជាប់ខ្ជួន

inconsolable *a.* មិនអាចលួងចិត្តបាន

inconsolablement *adv.* ដោយមិនអាចលួងចិត្តបាន

inconsolé,e *a.* មិនស្រាកទុក្ខ (ឧ. mère inconsolée)

inconsommable *a.* អនុបភោគីយ, មិនអាចបរិភោគ ឬ ប្រើប្រាស់បាន

inconstance *n.f.* ចរិតសាវ៉ា ។ *Fig.* អស្ថិរភាព (ឧ. l'inconstance du temps, de la fortune, etc...)

inconstant,e *a.* សាវ៉ា (ឧ. inconstant dans ses amitiés); អស្ថិរ, វិបរិត, ដែលប្រែប្រួល (ឧ. saison inconstante)

inconstitutionnalité *n.f.* អធម្មនុញ្ញភាព, ភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ

inconstitutionnel,elle *a.* អធម្មនុញ្ញ, ផ្ទុយនឹងរដ្ឋធម្មនុញ្ញ (ឧ. proposition inconstitutionnelle)

inconstitutionnellement *adv.* ដោយអធម្មនុញ្ញ, ដោយផ្ទុយនឹងរដ្ឋធម្មនុញ្ញ

incontestabilité *n.f.* ភាពមិនអាចប្រកែក ឬ តវ៉ាបាន

incontestable *a.* មិនអាចប្រកែកឬតវ៉ាបាន

incontestablement *adv.* ដោយមិនអាចប្រកែក ឬ តវ៉ាបាន (ឧ.vérité incontestable)

incontesté,e *a.* គ្មានគេប្រកែក ឬ តវ៉ា (ដែលគេព្រមទាំងអស់គ្នា) (ឧ. droit incontesté)

incontinence *n.f.* មេថុនអវិរតិ;អព្រហ្មចរិយភាព (ភាពខូចព្រហ្មចារី)។ *Méd.* ការនោមឬជុះដោយមិនដឹងខ្លួន ។ incontinence de langage ការនិយាយមិនសូវប្រយ័ត្នពាក្យសំដី ។

incontinent,e *a.* មេថុនអវិរតិ; អព្រហ្មចារី; មិនសូវប្រយ័ត្នពាក្យសំដី

incontinent *adv.* ភ្លាមៗ (ឧ.ordre de déguerpir incontinent)

incontrôlable *a.* មិនអាចត្រួតត្រាបាន

inconvenance *n.f.* ភាពមិនគប្បី; អំពើឬសំដីមិនគប្បី (ឧ. commettre une inconvenance)

inconvenant,e *a.* មិនគប្បី (ឧ. propos inconvenant)

inconvénient *n.m.* អត្ថទោស,ទំនាស់; ទុក្ខល, ផលអាក្រក់

inconvertible ឬ**inconvertissable** *a.* មិនអាចបញ្ចូលក្នុងសាសនាបាន; មិនអាចប្តូរបាន (ឧ. papier-monnaie inconvertible en espèces)

incoordination *n.f.* ភាពខ្វះការសម្របសម្រួល (ឧ. l'incoordination des mouvements accompagne souvent les lésions du cervelet)

incorporable *a.* អាចបញ្ចូលបាន

incorporation *n.f.* ការបញ្ចូល, ការចូលលាយ (ឧ. l'incorporation des recrues dans un régiment); ភាពចូលលាយ

incorporéité *n.f.* អរូបភាព,ភាពឥតរូប

incorporel,elle *a.* អរូប, ឥតរូប ។ bien incorporel អរូបទ្រព្យ

incorporer *v.t.* ផ្សំធាតុ, លាយបញ្ចូល (ឧ. incorporer de l'huile dans la cire);បញ្ចូល(ឧ.incorporer un conscrit)

incorrect,e *a.* មិនត្រឹមត្រូវ,មិនរៀបរយ, ខុស (ឧ. tenue incorrecte)

incorrectement *adv.* ដោយមិនត្រឹមត្រូវ ឬ មិនរៀបរយ, ដោយខុស (ឧ. s'exprimer incorrectement)

incorrection *n.f.* ភាពមិនត្រឹមត្រូវ ឬ មិនរៀបរយ (ឧ. incorrection de style); កន្លែងខុស; អំពើមិនគប្បី

incorrigibilité *n.f.* អទមិយភាព,ភាពទូន្មានមិនបាន

incorrigible *a.* អទមិយ, ដែលទូន្មានមិនបាន (ឧ. un paresseux incorrigible)

incorrigiblement *adv.* ដោយអនុ-ម័យ, ដោយប្រដៅមិនបាន

incorruptibilité *n.f.* ភាពមិនអាចពុករលួយបានឬមិនអាចក្លៀវក្លួបបាន(ឧ. l'incorruptibilité d'un juge)

incorruptible *a.* មិនអាចពុករលួយបាន (ឧ. le bois goudronné est presque incorruptible); មិនអាចក្លៀវក្លួបបាន (ឧ. magistrat incorruptible)

incorruptiblement *adv.* ដោយមិនអាចពុករលួយ ឬ មិនអាចក្លៀវក្លួបបាន

incrédibilité *n.f.* ហេតុមិនគួរជឿ

incrédule *a.* ដែលកម្រនឹងជឿ (ឧ. auditoire incrédule); ដែលមិនជឿ (សាសនាជាដើម)

incrédulité *n.f.* ដំណើរកម្រជឿ (ឧ. nouvelle accueillie par une incrédulité générale); ដំណើរមិនជឿ

increé,e *a.* ដែលមានឡើងដោយគ្មានគេបង្កើត

increvable *a.* មិនបែក ឬ មិនធ្លាយ (ឧ. un pneu increvable)

incriminable *a.* អាចបន្ទោស ឬ ចោទប្រកាន់បាន

incrimination *n.f.* ការបន្ទោស; ការចោទប្រកាន់

incriminer *v.t.* ចោទបទឧក្រិដ្ឋ ; សង្ស័យ, ចោទប្រកាន់ (ឧ. incriminer la conduite de quelqu'un)

incristallisable *a.* មិនអាចឡើងក្រាមបាន

incrochetable *a.* មិនអាចដួក់បើកបាន (ឧ. serrure incrochetable)

incroyable *a.* មិនគួរឲ្យជឿ (ឧ. récit incroyable); ប្លែកអស្ចារ្យ (ឧ. bonheur incroyable)

incroyablement *adv.* ហួសប្រមាណ (ឧ. un homme incroyablement riche)

incroyance *n.f.* អសទ្ធា, ភាពអ្នកមិនជឿ

incroyant,e *n.&a.* គ្មានសទ្ធា, គ្មានជំនឿ

incrustation *n.f.* ការបញ្ចុះ, ការដាំបង្កប់

incruster *v.t.* បញ្ចុះ, ដាំបង្កប់ (ឧ. incruster la nacre dans l'ébène)។ s'incruster *v.pr.* ជាប់ស្អិត។ *Fig.* ផ្តិតជាប់ (ឧ. préjugés qui s'incrustent dans l'esprit)។ *Fam.* តាមស្អិត; នៅយូរពេក (ចំពោះ

អ្នកមកលេង ឬ មកសួរ)

incrusteur,euse *n.* អ្នកបញ្ចុះ, អ្នកដាំត្បូង

incubateur,trice *a.* ដែលភ្ញាស់ (ឧ. appareils incubateurs ប្រដាប់ភ្ញាស់)។ *n.m.* ម.ព. couveuse

incubation *n.f.* ការក្រាបពង។ incubation artificielle ការភ្ញាស់ដោយសិល្បនិម្មិតកណ្ដ។ *Méd.* រយៈពេលបង្កភេទ (ឧ. l'incubation de la typhoïde dure une ou deux semaines)

incuber *v.t.* ភ្ញាស់

incuit,e *a.* ឆៅ (មិនឆ្អិន)

inculcation *n.f.* ការបណ្ដុះគំនិត

inculpable *a.* ពិរុទ្ធិយ, អាចឲ្យជាប់ពិរុទ្ធបាន

inculpation *n.f.* ពិរុទ្ធកម្ម, ការឲ្យជាប់ពិរុទ្ធ

inculpé,e *n.* អ្នកជាប់ពិរុទ្ធ (អ្នកជាប់ចោទដែលសុភាចារបុរសរកឃើញថាបានប្រព្រឹត្តបទល្មើស)

inculper *v.t.* ឲ្យជាប់ពិរុទ្ធ (ឧ. Louis XVI fut inculpé de haute trahison)

inculquer *v.t.* បណ្ដុះគំនិត

inculte *a.* គ្មានដាំដំណាំ។ *Fig.* ដែលគេមិនសូវថែទាំ(ឧ.barbe inculte); គ្មានវិជ្ជា (ឧ. esprit, nature inculte)

incultivable *a.* ដែលដាំដំណាំមិនកើត

incultivé,e *a.* គ្មានដាំដំណាំ —

incurabilité *n.f.* អតេកិច្ឆភាព, ភាពមើលមិនជា (រោគ)

incurable *a.*អតេកិច្ឆ:-កិច្ឆា, ដែលមើលមិនជា (រោគ)(ឧ.la tuberculose n'est pas toujours incurable)

incurablement *adv.*ដោយអតេកិច្ឆ:, ដោយមើលមិនជា (ឧ. être incurablement paresseux)

incurie *n.f.* ការធ្វេសប្រហែស (ឧ. incurie administrative)

incurieux,euse *a.* ដែលមិនចង់ដឹង ឬ មិនចង់ឃើញ; ព្រងើយ

incuriosité *n.f.* ការមិនចង់ដឹង ឬ មិនចង់ឃើញ

incursion *n.f.* ការលុកលុយ (ឧ. la Gaule fut désolée par les incursions des Normands); ការដើរមើលស្រុកទេស ។ *Fig.* ការដែលធ្វើក្រៅពីវិជ្ជាពិសេសរបស់ខ្លួន

incurvation *n.f.* ការបង្ខុប; ភាពខុប

incurver *v.t.* បង្ខុប

inde *n.m.* ពណ៌ចូះ

indébrouillable *a.* មិនអាចដោះជំពាក់បាន(ឧ.écheveau indébrouillable)

indécachetable *a.* មិនអាចបើកស្រោមបាន(ឧ.lettre indécachetable)

indécemment *adv.* ដោយឥតអៀនខ្មាស ឬ ឥតសមរម្យ

indécence *n.f.* ភាពមិនសមរម្យ; សំដី ឬ អំពើមិនសមរម្យ

indécent,e *a.* មិនសមរម្យ; មិនទៀងត្រង់

indéchiffrable *a.* ដែលអានមិនដាច់។ *Fig.* មិនអាចពន្យល់បាន; មិនអាចយល់បាន

indéchirable *a.* មិនអាចហែកដាច់

indécis,e *a.* រួញាក, មិនដាច់ស្រេច (ឧ. homme indécis); មិនប្រាកដ, មិនច្បាស់(ឧ.question, victoire indécise)

indécision *n.f.* ការមិនដាច់ស្រេច,ភាពរួញាក; ភាពមិនប្រាកដ ឬ មិនច្បាស់

indéclinabilité *n.f.* ភាពចៀសមិនរួច

indéclinable *a.* ដែលចៀសមិនរួច (ឧ. loi indéclinable)

indécollable *a.* ដែលបកចេញមិនបាន

indécomposable *a.* មិនអាចបំបែកធាតុបាន (ឧ. les corps simples sont indécomposables)

indécousable *a.* មិនអាចរុះថ្នេរបាន

indécrottable *a.* មិនអាចដំរះអាចម៍សត្វ ឬ ភក់បាន (ឧ. chaussures indécrottables) ។ *Fig.* ប្រដៅមិនបាន(ឧ. c'est un paresseux indécrottable)

indéfectibilité *n.f.* និបុណ៌យភាព, ភាពមិនអាចធ្វើខុសឬមិនអាចសាបសូន្យទៅបាន (ឧ. les théologiens catholiques affirment l'indéfectibilité de l'Eglise)

indéfectible *a.* និបុណ៌យ [-ប៉ុ-ណ៌], មិនអាចធ្វើខុស, មិនអាចសាបសូន្យទៅបាន

indéfectiblement *adv.* ដោយមិនអាចធ្វើខុស ឬ មិនអាចសាបសូន្យទៅបាន

indéfendable *a.* មិនអាចការពារបាន (ឧ. théorie indéfendable)

indéfini,e *a.* គ្មានកំណត់ព្រំដែន (ឧ. la suite des nombres pre-

miers est indéfinie); មិនប្រាកដ, មិនច្បាស់ (ឧ. sensation indéfinie)

indéfiniment *adv.* ជាអនន្តកាល, ដោយគ្មានកំណត់ព្រំដែន (ឧ. ajourner indéfiniment une solution)

indéfinissable *a.* មិនអាចឲ្យអត្ថន័យបាន (ឧ. couleur indéfinissable)។ *Fig.* មិនអាចពន្យល់ឬប្រាប់កើត (ឧ. trouble indéfinissable)

indéformable *a.* មិនអាចខូចរាងបាន

indéfrichable *a.* មិនអាចរានស្រែចំការបាន (ឧ. sol indéfrichable)

indéfrisable *a.* មិនរលា ។ *n.f.* ការអ៊ុតសក់មិនរលា

indélébile *a.* ដែលលុបមិនជ្រះ (ឧ. encre indélébile)។ *Fig.* មិនអាចនឹងសាបសូន្យទៅបាន (ឧ. la gloire indélébile des écrivains de génie)

indélébilité *n.f.* ភាពលុបមិនជ្រះ (ឧ. l'indélébilité d'une encre)

indélibéré,e *a.* ដែលធ្វើដោយឥតពិគ្រោះ ឬ ឥតពិចារណា (ឧ. acte indélibéré)

indélicat,e *a.* មិនទឹករអែង ; មិនសូវសុចរិត (ឧ. procédé indélicat)

indélicatement *adv.* ដោយមិនទឹករអែង; ដោយមិនសុចរិត (ឧ. agir indélicatement)

indélicatesse *n.f.* សេចក្ដីមិនទឹករអែង; អំពើមិនសុចរិត (ឧ. domestique congédié pour indélicatesse)

indémaillable *a.* មិនរោតសរសៃ (ឧ. tissu indémaillable)

indemne *a.* ឥតខូចខាត (ឧ. sortir indemne d'une affaire délicate)

indemnisable *a.* គួរជួសជុលសោហ៊ុយ, គួរសង (ឧ. tout propriétaire exproprié pour cause d'utilité est indemnisable)

indemnisation *n.f.* ការជួសជុលសោហ៊ុយ, ការសង

indemnitaire *n.* អ្នកទទួលបំណាច់, អ្នកទទួលសំណង

indemnité *n.f.* បំណាច់; សំណង ។ indemnité de chaire បំណាច់ភាសនៈ ។ indemnite de dépaysement បំណាច់ទេសនិកស ។

indemnité de fonction បំណាច់មុខងារ។ indemnité des heures supplémentaires បំណាច់ម៉ោងបន្ថែម ។ indemnité de route et de séjour បំណាច់ផ្លូវនឹងសំចត។ indemnité parlementaire បំណាច់សភា ។ indemnité pour charges de famille បំណាច់បន្ទុកគ្រួសារ ។ indemnité pour enfants បំណាច់កូន

indémontable *a.* មិនអាចដំឡោះ ឬ ដោះចេញបាន

indémontrable *a.* មិនអាចពន្យល់ ឬ បង្ហាញបាន

indéniable *a.* មិនអាចប្រកែកឬបដិសេធបាន (ឧ. preuve indéniable)

indénouable *a.* មិនអាចស្រាយចំណងបាន

indentation *n.f.* ការរេងរទូង (ដូចស្លាបធ្មេញ) (ឧ.les indentations de la côte bretonne)

indépendamment *adv.* ដោយគ្មានទាក់ទងជាមួយ; ដោយគ្មានយល់ដល់; ក្រៅពី (ឧ. indépendamment de ces avantages)

indépendance *n.f.* ឯករាជ្យ (ឧ. le Cambodge a recouvré sa complète indépendance le 9 novembre 1953)

indépendant,e *a.* ឯករាជ; មិនចូលចិត្តចំណុះគេ (ឧ. caractère indépendant); គ្មានទាក់ទងជាមួយ (ឧ. point indépendant de la question)

indéracinable *a.* មិនអាចដកឫសបាន; មិនអាចកំចាត់បាន (ឧ. préjugé indéracinable)

indéréglable *a.* មិនអាចធ្វើឲ្យលែងទៀងទាត់បាន

indescriptible *a.* មិនអាចពិពណ៌នាបាន (ឧ. joie indescriptible)

indésirable *a.&n.* មិនគួរឲ្យប្រាថ្នា ។ *Spécial.* ដែលគេមិនចង់ឃើញមុខ

indesserrable *a.* មិនអាចមួលបន្ធូរបាន (ឧ. écrou indesserrable)

indestructibilité *n.f.* ការមិនអាចបំផ្លាញបាន

indestructible *a.* មិនអាចបំផ្លាញបាន (ឧ.l'imprimerie a rendu indestructibles les chefs-d'œuvre de l'esprit humain)

indestructiblement *adv.* ដោយ

មិនអាចបំផ្លាញបាន

indéterminable *a.* មិនអាចកំណត់បាន, មិនអាចបញ្ជាក់បាន

indétermination *n.f.* ភាពមិនច្បាស់លាស់; សេចក្ដីព្រាក

indéterminé *a.* គ្មានកំណត់ (ឧ. temps indéterminé); ព្រាក

indéterminisme *n.m.* អបច្ចយនិយម (ព.ផ. déterminisme)

indéterministe *n.m.* អ្នកអបច្ចយ-និយម ។ *a.* នៃអបច្ចយនិយម

indévot,e *a.* មិនកាន់សាសនា

indévotion *n.f.* ការមិនកាន់សាសនា

index *n.m.* ចង្អុលដៃ (ឧ. saisir un objet entre le pouce et l'index); តារាងអក្សររៀងនៃសៀវភៅ ។ *Méc.* ទ្រនិច ។ *Fig.* mettre une personne ឬ une chose à l'index បដិសេធ, ទាត់ចោល, ឲ្យការណ៍ថាត្រូវប្រយ័ត្ននឹងមនុស្សណាមួយ

indexer *v.t.* ចុះក្នុងតារាងអក្សររៀងនៃសៀវភៅ; ដាក់តម្លៃថា (របស់អ្វីមួយដែលមិនឡើងចុះ) (ឧ.indexer un emprunt sur l'or, sur le charbon)

indianisme *n.m.* លក្ខណៈដោយឡែកនៃភាសាឥណ្ឌា; វិទ្យាសាស្ត្រខាងភាសានិងអារ្យធម៌ឥណ្ឌា

indianiste *n.m.* អ្នកប្រាជ្ញខាងភាសានិងអារ្យធម៌ឥណ្ឌា

indicateur,trice *a.* ដែលចង្អុល ឬបង្ហាញ ។ *n.* អ្នកនាំផ្លូវ; អ្នកឲ្យការណ៍ ។ *n.m.* ទ្រនិច (ឧ. un indicateur de vitesse); សៀវភៅមគ្គុទ្ទេសក៍ (ឧ. l'indicateur des rues de Paris)

indicatif,ive *a.* ដែលចង្អុល, ដែលឲ្យដំណឹង (ឧ. symptôme indicatif)

indication *n.f.* សូចនា, ការចង្អុលឬបង្ហាញ; ការណ៍ (ឧ. donner une fausse indication); អ្វីៗដែលចង្អុល ឬ ដែលឲ្យដំណឹង

indice *n.m.* ភស្តុតាង, សញ្ញា ។ *Math.* សន្ទស្សន៍ [សន់-ទស់]

indicible *a.* មិនអាចសំដែងបានដោយវាចា (ឧ. joie indicible)

indiciblement *adv.* ដោយមិនអាចសំដែងបានដោយវាចា

indien,enne *a.&n.* នៃប្រទេសឥណ្ឌា

indienne *n.f.* សំពត់អំបោះពណ៌ ឬ ផ្កា

indiennerie *n.f.* ការបោះពុម្ពសំពត់

អម្បោះពណ៌ ឬ ផ្កា; សិតត់អម្បោះពណ៌ ឬ ផ្កា

indifféremment *adv.* ព្រងើយ, ដោយដើយ; មិនរើស (ឧ. manger de tout indifféremment)

indifférence *n.f.* អនាទរ, សេចក្តីព្រងើយកន្តើយ, ភាពមិនសូវរួសរាន់

indifférent,e *a.* មិនចូលចិត្តខាងណាជាងខាងណា (ឧ. ce chemin ou l'autre m'est indifférent); មិនអើពើ (ឧ. cela m'est indifférent ខ្ញុំមិនអើពើនឹងរបស់នោះទេ); ស្លូតស្លើង; ដែលគ្មានចាប់ចិត្ត (ឧ. parler de choses indifférentes); ពោះតើយ (ឧ. visage indifférent)។ *n.* faire l'indifférent ធ្វើពោះតើយ, ធ្វើដើយ។ *n.m.pl.* les indifférents អ្នកធ្វើពោះតើយ, អ្នកមិនអើពើ

indifférentisme *n.m.* អនាទរនិយម

indigénat *n.m.* អន្តោក្រាមភាព; អន្តោក្រាមជនក; សិទ្ធិពលរដ្ឋ

indigence *n.f.* ទលិទ្ទភាព, ភាពទ័លក្រ។ *Fig.* ភាពខ្វះ (ឧ. indigence d'idées); ជនទ័លក្រទាំងឡាយ (ឧ. secourir l'indigence)

indigène *n.&a.* អន្តោក្រាម, ដែលកើតក្នុងស្រុក (ឧ. plante indigène)

indigent,e *a.* ទលិទ្ទ, ខ្សត់។ *n.* ទលិទ្ទជន, ជនទ័លក្រ (ឧ. distribuer des secours aux indigents)

indigeste *a.* ក្រលាយ (អាហារ) (ឧ. le homard, le foie gras sont indigestes)។ *Fig.* សាំញ៉ាំ, ពិបាកយល់ (ឧ. compilation indigeste)

indigestion *n.f.* អជីរណា, ជំងឺចាក់ព្រាស។ *Fig.* ភាពឆ្អែតហួសប្រមាណ។ *Fam.* avoir une indigestion d'une chose មានចាក់ព្រាស (មានច្រើនហួសប្រមាណទាល់តែធុញទ្រាន់)

indignation *n.f.* ការឈឺចិត្ត, សេចក្តីតូចចិត្ត (ឧ. exprimer son indignation)

indigne *a.* មិនសម (ឧ. indigne de vivre); កំណាច, គួរឲ្យស្អប់ (ឧ. traitement indigne); ថោកទាប (ឧ. conduite indigne)

indignement *adv.* ដោយកំណាច; ដោយថោកទាប (ឧ. traiter indignement un prisonnier)

indigner *v.t.* ធ្វើឲ្យឈឺចិត្តឬឲ្យតូចចិត្ត ។ s'indigner *v.pr.* ឈឺចិត្ត, តូចចិត្ត

indignité *n.f.* ភាពមិនសមរម្យឬថោកទាប; អំពើកំណាច, អំពើអាក្រក់; ការប្រមាថ (ឧ. on lui a fait mille indignités)

indigo *n.m.* ធ្នះ; ពណ៌ធ្នះ ។ *a.inv.* ពណ៌ធ្នះ (ឧ. des rubans indigo)

indigoterie *n.f.* ចំការត្រំ; កន្លែងធ្វើធ្នះ

indigotier *n.m.* ត្រំ

indigotine *n.f.* ជាតិពណ៌នៃធ្នះ

indiquer *v.t.* ចង្អុល; បង្ហាញ (ឧ. indiquer une rue) ។ *Fig.* សំឲ្យឃើញ (ឧ. cela indique une grande méchanceté); ដៅ

indirect,e *a.* មិនចំ; វាង (ឧ. chemin indirect) ។ *Fig.* មិនចំពោះ; ដែលបញ្ឆិតបញ្ឆៀង (ឧ. critique indirecte) ។ contribution indirecte ម.ក. contribution

indirectement *adv.* ដោយមិនចំ; ដោយមិនចំពោះ; ដោយបញ្ឆិតបញ្ឆៀង

indiscernable *a.* មិនអាចចំណាំបាន

indisciplinable *a.* មិនអាចបង្ខឹកតាមវិន័យបាន, រឹងរូស

indiscipline *n.f.* អវិន័យ, ដំណើរឥតវិន័យ (ឧ. l'indiscipline d'une armée amène sa défaite)

indiscipliné,e *a.* អវិន័យ (ឧ. écolier indiscipliné)

indiscret,ète *a.* ដែលចង់ដឹងរឿងគេ (ឧ. question indiscrète); មាត់មិនដិត; មិនចេះលាក់អាថ៌កំបាំង (ឧ. parole indiscrète) ។ *n.* អ្នកចង់ដឹងរឿងគេ; អ្នកមាត់មិនដិត (ឧ. c'est un indiscret)

indiscrètement *adv.* ដោយមិនចេះទប់មាត់ ឬមិនចេះលាក់អាថ៌កំបាំង

indiscrétion *n.f.* ការមិនចេះទប់មាត់ ឬមិនចេះលាក់អាថ៌កំបាំង; ការចង់ដឹងអាថ៌កំបាំងគេ

indiscutable *a.* មិនអាចប្រកែកបាន

indiscutablement *adv.* ដោយមិនអាចប្រកែកបាន

indiscuté,e *a.* គ្មានគេប្រកែក (ឧ. supériorité indiscutée)

indispensable *a.* ខានមិនបាន, ចៀសមិនរួច (ឧ. outil indispensable)

indispensablement *adv.* ដោយខានមិនបាន

indisponibilité *n.f.* ភាពមិនទំនេរ

indisponible *a.* ជាប់, មិនទំនេរ

indisposer *v.t.* នាំឲ្យមិនស្រួលខ្លួន (ឧ. la chaleur indispose les personnes sanguines) ។ *Fig.* ធ្វើឲ្យអន់ចិត្ត, ធ្វើឲ្យខឹង (ឧ. on l'a indisposé contre moi)

indisposition *n.f.* ដំណើរមិនស្រួលខ្លួន

indissolubilité *n.f.* ការមិនអាចរំលាយ ឬ ស្រាយបាន

indissoluble *a.* មិនអាចរំលាយបាន (ឧ. métal indissoluble) (ក្នុងន័យនេះគេប្រើជា insoluble ជាង)។ *Fig.* មិនអាចស្រាយបាន (ឧ. attachement indissoluble)

indissolublement *adv.* ដោយមិនអាចរំលាយបាន

indistinct,e *a.* មិនសូវច្បាស់, ពិបាកស្គាល់ (ឧ. voix indistincte)

indistinctement *adv.* ដោយមិនសូវច្បាស់ (ឧ prononcer indistinctement) ; ដោយមិនរើសមុខ (ឧ. on les tua tous indistinctement)

individu *n.m.* ឯកត្តភូត ។ *Fam.* មនុស្ស, ជន (ឧ. quel est cet individu ?)។ soigner son individu ថែខ្លួន

individualisation *n.f.* ឯកត្តករ (ការពិនិត្យ ឬ បង្ហាញរបស់អ្វីៗដោយឡែកពីគ្នា)

individualisme *n.m.* ឯកត្តនិយម (ឧ. les cités antiques n'ont guère connu l'individualisme)

individualiste *a.* នៃឯកត្តនិយម (ឧ. les théories individualistes) ។ *n.m.* អ្នកឯកត្តនិយម

individualité *n.f.* ឯកត្តភាព(លក្ខណៈសម្រាប់ស្គាល់ជនទីមួយៗ)

individuation *n.f.* ឯកត្តលក្ខណៈ

individuel,elle *a.* នៃឯកត្តភូត (ឧ. qualité individuelle); ចំពោះឯកត្តជន

individuellement *adv.* ដោយឯកត្តភូត ; រៀងខ្លួន

indivis,e *a.* អវិភាគ, ដែលនៅទាំងមូល (ឧ. succession indivise); ដែលទទួលកម្មសិទ្ធិទាំងមូល (ឧ. héritiers indivis)។ part indivise ចំណែកអវិភាគ ។ par indivis *loc. adv.* ដោយអវិភាគ, ទាំងមូល (ឧ. maison possédée par indivis)

indivisément *adv.* ដោយអវិភាគ,

ទាំងមូល

indivisibilité *n.f.* អវិភាគិយភាព, ភាពថែកមិនបាន

indivisible *a.* អវិភាគិយ, ដែលថែកមិនបាន (ឧ. les atomes sont indivisibles)

indivision *n.f.* អវិភាគភាព (ភាពរបស់បានទាំងមូល, ភាពអ្នកទទួលកម្មសិទ្ធិទាំងមូល) (ឧ. nul n'est tenu de rester dans l'indivision)

in-dix-huit [in-di-zuit'] *n.m.* & *a.inv.* ទំហំបត់ជាដប់ប្រាំបី (ក្រដាសបោះពុម្ពដែលបត់ជា ១៨ សន្លឹក គឺមាន ៣៦ ទំព័រ)

indochinois,e *a.* ឥណ្ឌូចិន៍ក-និក, នៃប្រទេសឥណ្ឌូចិន (ឧ. les populations indochinoises) ។ *n.* ឥណ្ឌូចិនិកជន

indocile *a.* រឹងរូស (ឧ. enfant indocile)

indocilement *adv.* ដោយរឹងរូស

indocilité *n.f.* ចរិតរឹងរូស

indo-européen,enne *a.*&*n.* ឥណ្ឌូ, អឺរ៉ុប

indo-germanique *a.*&*n.* *m.* នៃសព្ទ indo-européen (តាមការនិយម ប្រើនៅប្រទេសអល្លឺម៉ង់)

indolemment *adv.* ដើយ (ឧ. se balancer indolemment dans un hamac)

indolence *n.f.* ចិត្តព្រងើយកន្តើយ; ភាពដើយ ឬ សោះអង្គើយ

indolent,e *a.* ព្រងើយកន្តើយ; ដើយ, សោះអង្គើយ

indolore *a.* គ្មានបណ្ដាលឲ្យឈឺ (ឧ. tumeur indolore)

indomptabilité *n.f.* ភាពមិនអាចផ្សាំង-ពង្រាប ឬ បង្ក្រាបបាន

indomptable *a* មិនអាចផ្សាំងឬបង្ក្រាបបាន (ឧ. caractère indomptable)

indomptablement *adv.* ដោយមិនអាចផ្សាំង-ពង្រាប ឬ បង្ក្រាបបាន

indompté,e *a.* មិនទាន់ផ្សាំងបាន (ឧ. un cheval indompté) ។ *Fig.* ដែលទប់ ឬ ពង្រាបមិនបាន (ឧ. courage, orgueil indompté)

in-douze *n m.* & *a. inv.* ទំហំបត់ជាដប់ពីរ (ក្រដាសបោះពុម្ពដែលបត់ជា ១២ សន្លឹក គឺមាន ២៤ ទំព័រ)

Indra *n. propre* ព្រះឥន្ទ្រ

indu,e *a.* ខុសច្បាប់-ទំនៀមទំលាប់ ឬ

វិធារណញ្ញាណ (ឧ. rentrer chez soi à une heure indue) ។ heure indue ម.ក. heure ។ មិនត្រូវបាន (ឧ.somme indue) ។ *n.m.* អ្វីៗមិនត្រូវបាន (ឧ. réclamer la restitution de l'indu)

indubitable *a.* មិនអាចសង្ស័យបាន, ប្រាកដ (ឧ. succès indubitable)

indubitablement *adv.* យ៉ាងប្រាកដ

inductif,ive *a.* វិសេសានុមាន ។ méthode inductive ម.ក. méthode

induction *n.f.Philos.* វិសេសានុមាន

induire *v.t.* នាំឲ្យ (ឧ. induire en erreur); ធ្វើវិសេសានុមាន (ឧ. de là, j'induis que...)

indulgemment *adv.* ដោយមិនប្រកាន់ទោស

indulgence *n.f.* ការមិនប្រកាន់ទោស (ឧ. l'indulgence envers les enfants ne doit pas dégénérer en faiblesse)

indulgent,e *a.* មិនប្រកាន់ទោស (ឧ. une mère est toujours indulgente)

indûment *adv.* ដោយខុសរបៀប-ខុសច្បាប់ឬខុសទំនៀមទម្លាប់ (ឧ. procéder indûment contre quelqu'un)

induration *n.f.Méd.* សាច់ក្រិន; ការក្រិន

indurer *v.t.* ធ្វើឲ្យឡើងរឹងឬឲ្យក្រិន (ឧ. la vieillesse indure tous les tissus)

industrialisation *n.f.* ឧស្សាហូបនីយកម្ម, ការធ្វើឲ្យមានលក្ខណៈជាឧស្សាហកម្ម

industrialiser *v.t.* ធ្វើឧស្សាហូបនីយកម្ម, ធ្វើឲ្យមានលក្ខណៈជាឧស្សាហកម្ម ។ s'industrialiser *v.pr.* មានលក្ខណៈជាឧស្សាហកម្ម

industrialisme *n.m.* ឧស្សាហកម្មនិយម (ឧ. l'industrialisme anglais)

industrie *n.f.* ការប៉ិនប្រសប់ ; បញ្ញា (ឧ. avoir de l'industrie) ; អាជីវៈ, វិជ្ជាជីវៈ (ឧ. exercer une industrie); ឧស្សាហកម្ម (ឧ. l'industrie agricole, manufacturière) ។ *Fig.* ចំណេះខាងខ្លួន (ឧ. vivre d'industrie) ។ chevalier d'industrie អ្នកកេងស៊ី

កញ្ឆក់កណ្ដៀត

industriel,elle *a.* នៃឧស្សាហកម្ម (ឧ. professions industrielles) ។ centre industriel មជ្ឈមណ្ឌលឧស្សាហកម្ម ។ *n.m.* ឧស្សាហករ, អ្នកឧស្សាហកម្ម

industriellement *adv.* ដោយឧស្សាហកម្ម

industrieusement *adv.* ដោយប៉ិនប្រសប់ (ឧ. l'araignée travaille industrieusement)

industrieux,euse *a.* ប៉ិន,ប្រសប់ (ឧ. l'homme industrieux; l'industrieuse abeille)

inébranlable *a.* មិនអាចរញ្ជួយបាន(ឧ. monument inébranlable) ។ *Fig.* មិនស្លុត (ឧ. Rome montra pendant la deuxième guerre punique un courage inébranlable); រឹងប៉ឹង

inébranlablement *adv.* ដោយរឹងប៉ឹង

inéchangeable *a.* មិនអាចប្ដូរបាន (ឧ. marchandise inéchangeable)

inédit,e *a.* មិនដែលបោះពុម្ពផ្សាយ (ឧ. poème inédit)។ *Fam.* ថ្មី, ប្លែក (ឧ. spectacle inédit)។ *n.m.* អ្វីៗដែលប្លែក

inéducable *a.* មិនអាចអប់រំបាន

ineffabilité *n.f.* ភាពមិនអាចសំដែងដោយភាសាបាន

ineffable *a.* មិនអាចសំដែងដោយភាសាបាន (ឧ. joie ineffable)

ineffablement *adv.* ដោយមិនអាចសំដែងដោយភាសាបាន

ineffaçable *a.* មិនអាចលុបបាន (ឧ. caractères ineffaçables) ។ *Fig.* មិនអាចកំចាត់បាន (ឧ. impression ineffaçable)

ineffaçablement *adv.* ដោយមិនអាចលុបបាន; ដោយមិនអាចកំចាត់បាន(ឧ. souvenir ineffaçablement gravé dans la mémoire)

inefficace *a.* មិនស័ក្ដិសិទ្ធិ(ឧ. remède, moyen inefficace)

inefficacité *n.f.* ភាពមិនស័ក្ដិសិទ្ធិ

inégal,e,aux *a.* វិសមៈ(វិ-សៈ-មៈ), មិនស្មើគ្នា (ឧ. lignes inégales); មិនរាបស្មើ, រដិបរដុប (ឧ. terrain inégal) មិនទៀង, មិនស្មើ (ឧ. mouvement inégal)។ *Fig.* មិនស្មើ (ឧ. style inégal)

inégalement *adv.* ដោយមិនស្មើគ្នា(ឧ.

membres inégalement développés)

inégalité *n.f.* វិសមភាព, ភាពមិនស្មើគ្នា (ឧ. l'inégalité des aptitudes); ភាពមិនរាបស្មើ (ឧ. inégalité du sol); ភាពមិនទៀង ឬ មិននឹង (ឧ. inégalité de caractère); ភាពឆ្លាប់ឆ្លាស់ប្ដូរ

inélastique *a.* មិនយឺត, មិនទន់

inélégamment *adv.* ដោយមិនសមសួន, ដោយមិនសង្ហា (ឧ. s'habiller inélégamment)

inélégance *n.f.* ភាពមិនសមសួន ឬ មិនសង្ហា

inélégant,e *a.* មិនសមសួន, មិនសង្ហា (ឧ. mise inélégante)

inéligibilité *n.f.* ភាពមិនអាចជ្រើសតាំងបាន (ឧ. la qualité d'étranger est une cause d'inéligibilité)

inéligible *a.* មិនអាចជ្រើសតាំងបាន (ឧ. candidat inéligible)

inéluctable *a.* មិនអាចប្រឆាំងបាន ; ដែលចៀសមិនរួច (ឧ. mort, malheur inéluctable)

inéluctablement *adv.* ដោយមិនអាចប្រឆាំងបាន ; ដោយចៀសមិនរួច (ឧ. navire inéluctablement perdu)

inéludable *a.* មិនអាចគៀសវាង ឬ គេចផុត

inemployable *a.* មិនអាចប្រើប្រាស់បាន

inemployé,e *a.* មិនទាន់ដែលប្រើប្រាស់

inénarrable *a.* មិនអាចនិទានបាន (ឧ. merveilles inénarrables)

inepte *a.* គ្មានសម្បទា, គ្មានសមត្ថភាព; មិនបេះ, មិនប្រសប់; ល្ងង់, ល្ងីល្ងើ

ineptie *n.f.* ភាពគ្មានសម្បទា ឬ គ្មានសមត្ថភាព; ភាពមិនប្រសប់; ភាពល្ងង់

inépuisable *a.* មិនចេះអស់

inépuisablement *adv.* ដោយមិនចេះអស់

inépuisé,e *a.* មិនទាន់អស់ (ឧ. des trésors inépuisés)

inéquation *n.f.* វិសមីការ

inéquitable *a.* គ្មានសមធម៌ (ឧ. répartition inéquitable des impôts)

inéquité *n.f.* វិសមធម៌

inerme *a.* ឥតបន្លា, ឥតទំពក់

inerte *a.* និច្ចល[និច-ចល់], មិនកម្រើក (ឧ. cadavre inerte) ។ *Fig.*

អប្ប (ឧ. esprit inerte)

inertie *n.f.* និច្ចលភាព,ភាពមិនកម្រើក។ *Fig.* ភាពអប្ប ។ principe d'inertie លក្ខណៈនិច្ចល(ចំពោះរូបធាតុដែលមិនចេះកម្រើក) ។ *Fig.* ការប្រឆាំងជាអកម្ម (ដោយមិនស្ដាប់បង្គាប់)

inescomptable *a.* មិនអាចធ្វើអបហារបាន(ឧ.billet inescomptable); មិនអាចសង្ឃឹមបាន

inespéré,e *a.* ដែលគេគ្មានសង្ឃឹមទុក (ឧ. chance inespérée)

inesthétique *a.* អសោភ័ណ, មិនល្អមើល

inestimable *a.* មិនអាចដាក់តម្លៃឲ្យគួរល្មមបាន (ឧ.la franchise est une qualité inestimable); លើសលុប

inétendu,e *a.* គ្មានវិសាលភាព, គ្មានទំហំ(ឧ. le point géométrique est inétendu)

inévitable *a.* មិនអាចចៀសរួច (ឧ. danger inévitable)

inévitablement *adv.* ដោយចៀសមិនរួច

inexact,e *a.* មិនត្រឹមត្រូវ, ខុស (ឧ. calcul inexact); មិនពិត (ឧ. nouvelle inexacte); មិនទៀងពេល (ឧ. employé inexact)

inexactement *adv.* ដោយមិនត្រឹមត្រូវ, ដោយខុស, ដោយមិនពិត (ឧ. rapporter inexactement un entretien)

inexactitude *n.f.* ភាពមិនទៀង; កំហុស, សេចក្ដីមិនត្រឹមត្រូវឬមិនពិត (ឧ. les inexactitudes d'un récit)

inexaucé,e *a.* មិនបានសម្រេច (ឧ. vœu inexaucé)

inexhaustible *a.* មិនអាចធ្វើឲ្យអស់បាន

inexcusable *a.* មិនគួរលើកទោស (ឧ. faute inexcusable)

inexcusablement *adv.* ដោយមិនគួរលើកទោស

inexécutable *a.* មិនអាចធ្វើឲ្យសំរេចផលបាន, មិនអាចប្រតិបត្តិបាន (ឧ. projet inexécutable)

inexécuté,e *a.* មិនបានប្រតិបត្តិ

inexécution *n.f.* ការមិនប្រតិបត្តិ (ឧ. l'inexécution d'un contrat peut donner lieu à des dommages-intérêts)

inexercé,e *a.* មិនបានហ្វឹកហ្វឺន, មិនប្រសប់

inexigibilité *n.f.* ភាពមិនអាចទារបាន

inexigible *a.* មិនអាចទារបាន (ឧ. dette présentement inexigible)

inexistant,e *a.* គ្មាន

inexistence *n.f.* នត្ថិភាព, ភាពគ្មាន

inexorabilité *n.f.* ភាពមិនអាចអង្វរករ ឬធ្វើឲ្យទន់ចិត្តបាន; ភាពតឹងតែង (ឧ. l'inexorabilité du sort)

inexorable *a.* មិនអាចអង្វរករ ឬធ្វើឲ្យទន់ចិត្តបាន (ឧ. juge inexorable)។ *Fig.* រឹង, តឹងតែង (ឧ. les lois inexorables de Dracon)

inexorablement *adv.* ដោយមិនអាចអង្វរករបាន; យ៉ាងតឹងតែង

inexpérience *n.f.* ដំណើរខ្វះពិសោធន៍ (ឧ. l'inexpérience de la jeunesse)

inexpérimenté,e *a.* គ្មានពិសោធ (ឧ. ouvrier inexpérimenté); មិនទាន់ពិសោធ (ឧ. procédé inexpérimenté)

inexpiable *a.* មិនអាចលាងកំហុស ឬលាងទោសបាន (ឧ. crime inexpiable)

inexpié,e *a.* មិនទាន់លាងកំហុសឬលាងទោស

inexplicable *a.* មិនអាចពន្យល់បាន (ឧ. énigme inexplicable); ប្លែក, អស្ចារ្យ (ឧ. homme, caractère inexplicable)

inexpliqué,e *a.* មិនទាន់ពន្យល់បាន

inexploitable *a.* មិនអាចធ្វើអាជីវកម្មបាន (ឧ. gisement minier inexploitable)

inexploité,e *a.* គ្មានគេធ្វើអាជីវកម្ម (ឧ. mine depuis longtemps inexploitée)

(ម.ព. courant ផង) ។ lecture expressive ការអានមានបែបបទ (ម.ព. expressif ផង)។ អ្វីៗដែលគេអាន (ឧ. des lectures édifiantes); សិល្បៈខាងអាន (ឧ. enseigner la lecture aux enfants); ការពិភាក្សានៃសភាអំពីសេចក្ដីព្រាងច្បាប់

légal,e,aux *a.* នីត្យានុកូល (តាមច្បាប់, ពេញលក្ខណៈច្បាប់)

légalement *adv.* ដោយនីត្យានុកូល, តាមច្បាប់បញ្ញត្ត

légalisation *n.f.* នីត្យានុកូលកម្ម, ការបញ្ជាក់ហត្ថលេខា

légaliser *v.t.* ធ្វើនីត្យានុកូលកម្ម, បញ្ជាក់តាមច្បាប់, បញ្ជាក់ហត្ថលេខា (ឧ. faire légaliser un certificat de vie); ឲ្យមានឡាក់ហានពេញច្បាប់ (ឧ. il est plus facile de légaliser certaines choses que de les légitimer)

légaliste *n.m.* អ្នកនីតិនិយម

légalité *n.f.* នីត្យានុកូលភាព, ភាពពេញលក្ខណៈច្បាប់ (ឧ. la légalité d'un acte); អ្វីៗដែលច្បាប់បញ្ញត្ត (ឧ. rester dans la légalité)

légat *n.m.* សមណប្រេសិត

légataire *n.* អ្នកទទួលអច្ច័យទាន (អ្នកទទួលអំណោយមនុស្សស្លាប់)

légation *n.f.* ស្ថានអគ្គរដ្ឋទូត ឬ រាជទូត

lège *a.* ដែលផ្ទុកមិនគ្រប់ចំណុះ (នាវា)

légendaire *a.* នៃរឿងព្រេង (ឧ. récit légendaire); ដែលចូលជារឿងព្រេង (ឧ. le chapeau légendaire de Napoléon 1er) ។ *n.m.* អ្នកនិពន្ធរឿងព្រេង; សៀវភៅរឿងព្រេង ។ *a.* នៃរឿងព្រេង

légende *n.f.* រឿងព្រេង (ឧ. la légende de Roland) ។ *Péjor.* រឿងភរ ។ ចំណងជើងរូប ឬ ផែនទី

léger,ère *a.* លហុ, ស្រាល (ឧ. terre légère); ស្ដើង, មិនខាប់ (ឧ. tissu léger; vapeur légère); ងាយរំលាយ (អាហារ) (ឧ. aliment léger); ខ្សោយ(ស្រា), ស្ដើង(តែ) (ឧ. thé léger); អត្តខាត(ឧ. repas léger); ស្រាលខ្លួន, ស្រួលខ្លួន (ឧ. se sentir léger); ញាប់, រហ័ស (ឧ. danse légère); ដែលថ្នាក់ថ្នម(ឧ. touche légère) ។ *Fig.* ស្រាល (មិនពិឃាកក្រាំ) (ឧ. peines légères); ពាយងាយ (ឧ. propos

légers); ស្រាល (ឧ. faute légère); រាក់ (ឧ. esprit léger); ឡើក (ឧ. femme légère) ។

avoir la main légère ងាយដៃ(រហ័សខាងវាយ); ដៃស្រាល, ប្រសប់ខាងវះកាត់ ។ cœur léger គ្មានទុក្ខព្រួយ ។ poésies légères កវីនិពន្ធអំពីរឿងមិនសំខាន់ ។ sommeil léger ដំណេកទន្ទ្រាយ(ដំណេករហ័ស) ។ à la légère *loc. adv.* ដោយកាយងាយ (ឧ. être vêtu à la légère); ដោយគ្មានគិត (ឧ. parler à la légère)

légèrement *adv.* បន្ទើរ (ឧ. marcher légèrement); ដោយស្រាល (ឧ. être vêtu légèrement); ដោយកាយងាយ, ដោយធ្វេស (ឧ. agir légèrement); យ៉ាងស្រាល (ឧ. blesser légèrement)

légèreté *n.f.* ភាពស្រាល; ភាពរហ័សរហួន (ឧ. légèreté du cerf) ។ *Fig.* ភាពកាយងាយ (ឧ. légèreté de caractère); ការធ្វេសប្រហែស (ឧ. légèreté de conduite)

legging [lè - ghinn] (ព.អ.) *n.f.* ស្រោមជើងស្បែក ឬ សំពត់ក្រាស់

légiférer *v.i.* តែងច្បាប់

légion *n.f.* កងអាវុធហត្ថ; ហ្វូង (ឧ. une légion de solliciteurs) ។ légion étrangère កងអាសាបរទេស

légionnaire *n.m.* ទាហានកងអាសាបរទេស

législateur, trice *n.* នីតិនិពន្ធ, អ្នកតែងច្បាប់ ។ *Fig.* អ្នកតែងក្បួន (ឧ. le législateur du Parnasse) ។ *n.m.* អំណាចតែងច្បាប់; ច្បាប់ (ឧ. le législateur a voulu que. . .)

législatif, ive *a.* នៃច្បាប់ (ឧ. acte législatif); នីតិបញ្ញត្តិ, ដែលមានសិទ្ធិតែងច្បាប់ (ឧ. pouvoir législatif អំណាចនីតិបញ្ញត្តិ)

législation *n.f.* នីតិការ, នីតិកម្ម, ការតែងច្បាប់; ច្បាប់ (ឧ. législation cambodgienne) ។ législation du travail ច្បាប់ការងារ

législativement *adv.* តាមច្បាប់

législature *n.f* អង្គនីតិបញ្ញត្តិ; នីតិកាល

légiste *n.m.* នេតិបណ្ឌិត, អ្នកចេះច្បាប់;

អ្នករៀនច្បាប់

légitimation *n.f.* ធម្មានុរូបកម្ម, ការទទួលស្គាល់ជាកូន

légitime *a.* ធម្មានុរូប, ត្រូវច្បាប់ (ឧ. demande légitime) ពេញច្បាប់ (ឧ. mariage légitime; enfant légitime) ។ légitime défense ការពារត្រូវច្បាប់ ។ ត្រូវគន្លង ។ *n.f. Pop.* ប្រពន្ធ

légitimé,e *a.* បំពេញច្បាប់, ដែលមានការទទួលស្គាល់(កូន) (ឧ. fils légitimé)

légitimement *adv.* ជាធម្មានុរូប, ដោយត្រូវច្បាប់-ត្រូវគន្លង(ឧ. fortune légitimement acquise)

légitimer *v.t.* ធ្វើធម្មានុរូបកម្ម; ធ្វើឲ្យទទួលស្គាល់ជាត្រឹមត្រូវតាមច្បាប់ (ឧ. rien ne légitime une mauvaise action); បំពេញច្បាប់, ទទួលស្គាល់ជាកូន (ឧ. les enfants incestueux et adultérins peuvent parfois être légitimés)

légitimiste *a.&n.* អ្នកធម្មានុរូបនិយម

légitimité *n.f.* ធម្មានុរូបភាព, ភាពត្រូវច្បាប់ឬត្រូវគន្លង (ឧ. contester la légitimité d'un droit); ភាពពេញច្បាប់(ភាពកូនដែលគេទទួលស្គាល់)

legs *n.m.* អច្ច័យទាន (អំណោយរបស់បុគ្គលស្លាប់)

léguer *v.t.* ចែកអច្ច័យទាន, ឲ្យតាមបណ្តាំខ្មោច ។ *Fig.* ចម្លង; ចែកជាកេរ្តិ៍ (ឧ. léguer ses vertus à ses enfants)

légume *n.m.* សាកជាតិ, បន្លែអន្លក់ ។ *n.f. Fam.* grosse légume អ្នកធំ

légumier,ère *a.* ដែលមានដាំបន្លែ (ឧ. jardin légumier) ។ *n.m.* ចានបន្លែ (ចានសម្រាប់ដាក់បន្លែ)

légumineux,euse *a.* ជាសាកជាតិ, ជាជាតិបន្លែ ។ *n.f.pl.* សិម្ពិកូល (ក្រកូលបន្លែផ្លែមានគូ)

leitmotiv *n.m. Par ext.* ឃ្លា ឬរូបមន្តដែលគេទន្ទេញមិនឈប់ (*pl.* des leitmotive)

lendemain *n.m.* ថ្ងៃស្អែកឡើង, ថ្ងៃបន្ទាប់ ។ du jour au lendemain ភ្លាមៗ (ឧ. changer d'idée du jour au lendemain)

lendore *n.* មនុស្សស្ងក់

lénifiant,e *a.* ដែលរម្ងាប់; ដែលធ្វើឲ្យស្រាក

lénifier *v.t.* រម្ងាប់; ធ្វើឲ្យស្រាក ។ *Fig.*

បន្ធូរ; សម្រាល

léninisme *n.m.* លេនីននិយម

lénitif,ive *a.* ដែលរំងាប់ ឬ ធ្វើឲ្យស្រាក (ឧ. un remède lénitif)

lent,e *a.* យឺត (មិនរហ័ស) (ឧ. esprit lent; exécution lente)

lente *n.f.* ពងចៃ

lentement *adv.* យ៉ាងយឺតៗ, មួយៗ

lenteur *n.f.* ការយឺត (ឧ. marcher, parler avec lenteur)

lenticelle *n.f.Bot.* រន្ធនៃស្លឹមសំបកឈើ

lenticulaire ឬ **lentiforme** *a.* មសូរសណ្ឋាន [មៈ-សូរ-], ដែលរាងមសូរ (ឧ. verre lenticulaire) (ថា lenticulé,e ក៏បាន)

lentigo *n.m.Méd.* អាចម៍រុយ (ឃ. éphélide, tache de rousseur)

lentille *n.f.* សណ្ដែកបាយ; គ្រាប់សណ្ដែកបាយ ។ lentille d'eau ចក ។ *Phys.* មសូរ [មៈ-សូ] ។ lentille convergente មសូរប្រមូល ។ lentille divergente មសូររាក ។ lentille cornéenne មសូរភ្នែក (កែវតែងពាក់ផ្ទាល់នឹងភ្នែក) ។ *pl.* អាចម៍រុយ

lento *adv. Mus.* យឺតៗ

léonin,e *a.* នៃសិង្ហ ។ *Fig.* ដែលយកចំណែកធំ (ឧ. marché léonin; contrat léonin)

léontine *n.f.* ខ្សែនាឡិកាស្រី

léopard *n.m.* ខ្លាល្ហិន

léopardé,e *a.* ដែលមានពពែអុជៗដូចខ្លាល្ហិន

lépidoptères *n.m.pl.* ពពួកបក្ខសត្វ (ពួកមេអំបៅ)

lépisme *n.m.* សត្វកន្ទុយពីរ (ពាក្យសាមញ្ញ: petit poisson d'argent)

lèpre *n.f.*ឃ្លង់ ។ *Fig.* អំពើទីលខូចដែលឆ្លង (ដូចឃ្លង់)

lépreux,euse *n.&a.* ពិឃ្លង់

léproserie *n.f.* មន្ទីរព្យាបាលរោគឃ្លង់ (ឧ. la léproserie de Trœung)

lequel, laquelle, lesquels, lesquelles *pr.rel.* របស់នោះៗ, របស់ទាំងនោះ (ឧ. le bateau sur lequel nous naviguions កប៉ាល់ដែលយើងជិះ) ។ *pr. inter.* របស់ណា (ឧ. voici deux étoffes, laquelle choisissez-vous ?)

lèse-majesté *n.f.* ការប្រមាថព្រះកេរ្តិ៍ (ឧ. crime de lèse-majesté)

léser *v.t.* ធ្វើឱ្យខូចប្រយោជន៍ (ឧ. léser les intérêts d'autrui) ; ធ្វើឱ្យរបួស

lésine ឬ **lésinerie** *n.f.* ស្វិតកាត, ការរឹតត្បិតតិចតួច

lésiner *v.i.* ស្វិត, រឹតត្បិតតិចតួច

lésineur,euse *a.&n.* ស្វិតជន, ដែលរឹតត្បិតតិចតួច

lésion *n.f.* សរីរាង្គរបួស (ដូចជាដំបៅ, ផ្លាំ, រលាក, ពកជាដើម) (ឧ. blessé atteint de lésions internes) ។ *Dr.* ហានិភ័យ, ការខូចប្រយោជន៍

lésionnaire *a.Dr.* ជាហានិភ័យ,ដែលឱ្យខូចប្រយោជន៍ (ឧ. condition lésionnaire)

lésionnel,elle *a.* នៃសរីរាង្គរបួស

lessivage *n.m.* ការបោកលាងសំលៀកបំពាក់

lessive *n.f.* ទឹកក្បុងសម្រាប់បោកលាងសំលៀកបំពាក់; ថ្នាំបោកលាង; សំលៀកបំពាក់ដែលត្រូវបោកលាង (ឧ. forte lessive); ការបោកលាង ។ faire la lessive បោកលាងសំលៀកបំពាក់

lessiver *v.t.* បោកលាងសំលៀកបំពាក់

lessiveuse *n.f.* កាដំបោកលាងសំលៀកបំពាក់

lest *n.m.* ទំងន់, ក្ងួនសណ្ដូន (វត្ថុសម្រាប់សង្កត់នាវាដើម្បីកុំឱ្យឃ្លោង) ។ navire sur lest នាវាគ្មានបន្ទុក (នាវាដែលបើកគ្មានទំនិញ) ។ *Fig.* jeter du lest ធ្វើពលីកម្មដើម្បីដោះកូន

lestage *n.m.* ការសណ្ដូន

leste *a.* រហ័សរហួន, រឿសរវៃ (ឧ. ce vieillard est encore leste)។ *Fig.* អាសគ្រាម (ឧ. propos leste)។ avoir la main leste ងាយដៃ (ខាងវាយគប់)

lestement *adv.* ដោយរហ័សរហួន

lester *v.t.* សណ្ដូន ។ se lester *v.pr. Fig. & Fam.* បរិភោគឱ្យឆ្អែត

létal,e,aux *a. Méd.* នៃហេតុនាំឱ្យទារកស្លាប់ក្នុងផ្ទៃ (មុនសម្រាល) (ឧ. facteur létal)

létalité *n.f.* មរណភាព (ឧ. établir des tables de létalité)

letchi ឬ **litchi** *n.m.* ទូលេន ។ letchi chevelu សាវម៉ាវ

léthargie *n.f.* និទ្រាលុកាព, និរពេលផ្ទាំង (ឧ. tomber en léthargie) ។ *Fig.* និទ្រាលុកាព, ភាពស្លុកស្តឹង, និរពេលប្រឹម្សស្ញេពេក (ឧ. tirer quelqu'un de sa léthargie)

léthargique *a.* និទ្រាលុ (ឧ. sommeil léthargique); ស្លុកស្តឹង, ប្រឹម្សស

lettion,onne *a.* & *n.* នៃប្រទេសឡេត្តូនី

lettrage *n.m.* ការដាក់សញ្ញាដោយអក្សរ (ឧ. lettrage d'un catalogue)

lettre *n.f.* អក្សរ; តួអក្សរ (ឧ. l'alphabet français a vingt six lettres); ព្យញ្ជនៈ, ន័យពង្រៀត (ឧ. préférer l'esprit à la lettre) ។ traduire à la lettre ប្រែផ្ទុំ, ប្រែតាមព្យញ្ជនៈ ។ លិខិត, សារ, សំបុត្រ ។ lettre de faire-part លិខិតជូនដំណឹង ។ lettre d'agrément សារអនុលោម (សារនៃរដ្ឋបុរសមន្ត្រីឆ្លើយថា យល់ព្រមឲ្យតាំងទូតបរទេស) ។ lettre d'avis លិខិតប្រកាស ។ lettre de cachet លិខិតបង្គាប់ឲ្យចាប់ ។ lettre de créance ម.ព. créance ។ lettre de change ឬ traite រូបិយាណត្តិ ។ lettre de change à vue រូបិយាណត្តិទស្សនា ។ lettre de change à delai de date រូបិយាណត្តិកាលបរិច្ឆេទ ។ lettre de change à délai de vue រូបិយាណត្តិភាវទស្សនា ។ lettre de change à jour fixe រូបិយាណត្តិកំណត់ថ្ងៃ ។ lettre d'exéquatur សារនិទេសទាន (សារនៃរដ្ឋបុរសមន្ត្រីបើកឱកាសឲ្យកុងស៊ុលបរទេសបំពេញមុខនាទី) ។ lettre valant marché សមាបណលិខិត [សមាៈ- ម៉ាៈ- ប៉ៈ- ណាៈ-] ។ lettre de voiture រថលិខិត (កិច្ចសន្យារវាងអ្នកផ្ញើទំនិញនឹងអ្នកនាំ) ។

Fig. lettre morte មិនបានការ ។ *pl.* les belles lettres ម.ព. beau ។ homme, femme ឬ gens de lettres អ្នកនិពន្ធ, អ្នកអក្សរសាស្ត្រ ។

en toutes lettres ជាអក្សរពេញតួ (មិនបំព្រួញឬមិនដាក់ជាលេខ) ។

à la lettre ដោយឥតល្អៀង (ឧ. exécuter des ordres à la lettre)

lettré,e *a.&n.* អក្សរសាស្ត្រ; អ្នកមានចំណេះ

leu *n.m.* à la queue leu leu បន្តកន្ទុយគ្នា, តង្គ្នា

leucocyte *n.m.* គោលិកាស [គោ-លិ-កា-ស]

leucocytose *n.f.* ដំណើរកើនចំនួនគោលិកាស (ក្នុងឈាម)

leucopénie *n.f.* ដំណើរថយចំនួនគោ-លិកាស (ក្នុងឈាម)

leucorrhée *n.f.* ដំណើរធ្លាក់ស (រោគរបស់ស្ត្រី)

leur *pr. pers.* ចំពោះវា, ចំពោះគាត់, ចំពោះលោកទាំងឡាយ (ឧ. un enfant qui aime ses parents leur obéit)

leur *a. poss. & pr.poss.* របស់វា, របស់គាត់, របស់លោកទាំងឡាយ (ឧ. les enfants doivent du respect à leurs parents; les gens sages gardent leurs amis, les fous perdent les leurs) ។ *n.m.* របស់វាទាំងឡាយ, របស់គាត់ទាំងឡាយ (ឧ. ils y mettent du leur) ។ *n.m. pl.* ពួកវា, ពួកគាត់

leurre *n.m.* នុយបញ្ឆោត; របស់បញ្ឆោត (ឧ. la loterie est un leurre)

leurrer *v.t. Fig.* បញ្ឆោត, នាំឲ្យសង្ឃឹមខុស (ឧ. il s'est laissé leurrer) ។ se leurrer *v.pr.* ជាប់បញ្ឆោត; សង្ឃឹមខុស (ឧ. se leurrer d'une illusion)

levage *n.m.* ដំណើរឡើង (ឧ. le levage de la pâte); ការលើក; ការយកចេញ ។ appareil de levage ប្រដាប់លើក

levain *n.m.* ដំបែ ។ *Fig.* មេញុះញង់ (ឧ. levain de haine)

levant,e *a.* នៃរះ (ប្រើតែជាមួយពាក្យ soleil) (ឧ. maison tournée au soleil levant) ។ soleil levant អរុណោទ័យ; *au fig.* ជនោទ័យ (ជនដែលទើបមានអានុភាព) (ឧ. flatter le soleil levant) ។ *Géogr.* Empire du Soleil levant ឧទ័យប្រទេស, ប្រទេសជប៉ុន ។ *Subst. m.* អរុណោទ័យ, ទិសបូព៌ (ទិសដែលព្រះអាទិត្យរះ)

lève *n.f.* កង់មានស្ពី(សម្រាប់ធ្វើឲ្យគ្រឿងចក្រដើរ)

levé,e *a.* voter par assis et levé បោះឆ្នោតដោយអង្គុយនឹងក្រោកឈរ (សំដែងមតិដោយអង្គុយ ឬដោយក្រោកឈរ)។ au pied levé ដោយគ្មានប្រុងទុក, ដោយឥតព្រាង ។ tête levée ឬ front levé ដោយងើបមុខ; ដោយឥតរួញរា ។ *n.m.* ម.ព. lever *n.m.*

levée *n.f.* ការលើក, ការយកចេញ (ឧ. la levée des scellés); ពេលលើកឬបិទសម័យប្រជុំ (ឧ. levée de la séance); ការប្រមូល; ការទារ(ពន្ធ)(ឧ. levée des impôts); ការកេណ្ឌ(ឧ. levée de troupe)។ levée en masse ការកេណ្ឌទាំងអស់គ្នា (ដើម្បីការពារប្រទេស) ។ levée d'un siège ម.ព. siège។ levée de boucliers ការបះបោរ។ *Dr.* levée de jugement ការសុំចម្លងសាលក្រម។ *T.P* ដីលើក (ធ្វើថ្នល់ ឬ ទំនប់ទឹក) (ឧ. se promener sur la levée) ។ *Bot.* ដំណើរពន្លក; ពេលពន្លក

lever *v.t.* លើក, លើកឡើង (ឧ. lever un poids); ងើប (ឧ. lever la tête); យកចេញ (ឧ. lever les scellés); កាត់យកមួយកាត (ឧ. lever une cuisse de poulet)។ *Fig.* កេណ្ឌ (ឧ. lever une armée); ប្រមូល; ទារពន្ធ(ឧ. lever des impôts); ទទួល (ឧ. lever des titres); គូរ (ឧ. lever un plan); ហិស ។

faire lever un lièvre ដេញទន្សាយ ។ lever l'ancre ប្រុងប្រៀបចេញ(ស្រាវយុថ្កា)។ lever les épaules ញាក់ស្មា (សំដែងសេចក្ដីមើលងាយ) ។ lever un interdit លើកបំរាម (លែងហាម)។ lever le masque បើកមុខ, ចេញមុខ, លែងលាក់មុខ ។ lever le pied លួចរត់ ។ lever la main sur quelqu'un វាយ ។ lever le siège លែងឡោមព័ទ្ធ; *au fig.* ដើរចេញ ។ lever une difficulté បំបាត់ឧបសគ្គ ។ lever la séance លើកពេលប្រជុំ ។ lever les yeux sur quelqu'un ងើបមើលមុខអ្នកណាម្នាក់។

v.i. ចេញពីដី, ដុះ (ឧ. les

blés lèvent); ឡើង(ដោយអំណាចមេ) (ឧ. la pâte lèvera) ។

se lever *v.pr.* ងើប (ងើបឈរ, ងើបពីដំណេក); រះ (ព្រះអាទិត្យ, ផ្កាយ) ។ le vent se lève ខ្យល់ចាប់បក់ ។ se lever de table ចាកតុបាយ, លែងបរិភោគ

lever *n.m.* ពេលងើបឬក្រោកពីដំណេក; ការបើកវាំងននល្ខោន ។ lever de rideau រឿងបើកឆាក (រឿងខ្លីដែលគេលេងមុនរឿងធំ) ។ *Astr.* ឧទយកាល [ឧ-ទ:-យ:-], ពេលរះ (ព្រះអាទិត្យ, ផ្កាយ ។ល។) ។ lever ឬ levé des plans ការគូរផែនទី ។ lever et immatriculer des terres វាស់ចុះក្នុងបញ្ជីដី ។ lever par cheminement វាស់ដោយវិធីបន្ត ។ lever par intersection វាស់ដោយវិធីបន្ទាត់កាត់គ្នា ។ lever par rayonnement វាស់ដោយវិធីរស្មី ។ lever par relèvement វាស់ដោយវិធីសាជាន

levier *n.m.* គម្លាស់, ដងថ្លឹង ។ levier de dégagement du charriot គម្លាស់គម្លោះរថ ។ levier de dégagement du papier គម្លាស់បន្ទះក្រដាស ។ levier interligne គម្លាស់ចន្លោះបន្ទាត់ ។ *Fig.* មធ្យោបាយ; កម្លាំងជួយពុះពារ (ឧ. l'intérêt est un puissant levier)

lévigation *n.f.* ការបំផង់(ដោយរំលាយក្នុងទឹក)

léviger *v.t.* បំផង់ (ដោយរំលាយក្នុងទឹកហើយទុកឲ្យរង)

lévitation *n.f.* *Spirit.* ការលើករបស់ដោយប្រើកម្លាំងចិត្ត(ដូចពួកយោគីជាដើម)

levraut *n m.* កូនទន្សាយ

lèvre *n.f.* បបូរមាត់ ។ *pl.* កណ្ដាប់ដំបៅ ។ du bout des lèvres ចុងមាត់ចុងក (ដោយមើលងាយ) ។ sourire du bout des lèvres ញញឹមស្ងួត, ញញឹមដោយបង្ខំ ។ avoir le cœur sur les lèvres រាក់ទាក់, ទ្រើមណាស់; ស្មោះត្រង់ណាស់ ។ se mordre les lèvres ខាំមាត់, ទំរប់មិនសើច; ស្ដាយក្រោយ

levrette *n.f.* ឆ្កែញីសម្រាប់ប្រដេញ (ឈ្មោលហៅ levrier)

levretté,e *a.* ស្រឿ (ដូចឆ្កែប្រដេញ) (ឧ. épagneul levretté)

levretter *v.t.* កើតកូន (ចំពោះមេឆ្កែ

ប្រមាញ់)

levrier *n.m.* ឆ្កែប្រមាញ់ទន្សាយ (ញីហៅ levrette)

levron,onne *n.* ឆ្កែប្រមាញ់ម្យ៉ាង

lévulose *n.m.Chim.* ម. ព. fructose

levure *n.f.* ផ្សិតដំបែ

lexical,e,aux *a.* នៃសព្ទានុក្រម

lexicographe *n.* អ្នកនិពន្ធសព្ទានុក្រម

lexicographie *n.f.* សិល្បៈរៀបចំសព្ទានុក្រម

lexicographique *a.* នៃសិល្បៈរៀបចំសព្ទានុក្រម

lexicologie *n.f.* មូលស័ព្ទសាស្ត្រ

lexicologue *n.m.* មូលស័ព្ទបណ្ឌិត

lexique *n.m.* សព្ទានុក្រម

lez ឬ **lès** *pré.* ជិត (ឧ. Plessis-lez-Tours)

lézard *n.m.* ថ្លែន, បង្កួយ; មនុស្សកំជិល ។ *Fam.* faire le lézard ដេកអាំងថ្ងៃ

lézarde *n.f.* ស្នាមប្រេះនៅជញ្ជាំងឥដ្ឋ; ជាន់សក្តិនាយទាហាន

lézardé,e *a.* ដែលប្រេះ; ដែលបែកក្រហែង

lézarder *v.t.* ធ្វើឲ្យប្រេះ ឬ ឲ្យបែកក្រហែង ។ se lézarder *v.pr.* ប្រេះ, បែកក្រហែង (ជញ្ជាំង)

li *n.m.* លី (រង្វាស់ចិនបុរាណប្រវែងប្រហែល ៥៧៦ ម.)

liage *n.m.* ការចង

liaison *n.f.* សម្ពន្ធការ, ការទាក់ទង; ការរួបរួម; ការតភ្ជាប់ ។ officier de liaison នាយទាហានសម្ពន្ធការ ។ *Mus.* ពន្ធសញ្ញា ។ *Fig.* ការទាក់ទងគ្នា (ឧ. liaison dans les idées); សម្ពន្ធភាព (ឧ. liaison durable) (ttl. affinité, amitié, attachement, connexion, lien, parenté)

liane *n.f.* លតា, វល្លិ ។ liane quinine វល្លិបណ្តូលពេជ្រ

liant *n.m.* លំពាស់, ភាពរលាស់ (ឧ. le liant de l'acier) ។ *Fig.* ភាពរួសរាយ, ភាពចុះចំណោម (ឧ. avoir du liant)

liant,e *a.* ទន់, រលាស់ (ឧ. du bois liant) ។ *Fig.* ស្លូត, រួសរាយ, ចុះចំណោម (ឧ. caractère liant)

liard *n.m.* លីយ៉ារ (រូបិយវត្ថុបុរាណតម្លៃមួយភាគបួននៃសេន)

liarder *v.i. Fam.* រកត្បិតខ្លាំងពេក;

ផ្នែកចំពោះប្រាក់បន្តិចបន្តួច

liasse *n.f.* បាច់, សំណុំក្រដាស (ឧ. liasse de lettres)

libelle *n.m.* អត្ថបទបង្ខូចកេរ្តិ៍ឈ្មោះ

libellé *n.m.* សេចក្ដីតែង (ឧ. le libellé d'un jugement, d'un exploit)

libeller *v.i.* តែងសេចក្ដី (ឧ. libeller une demande)

libelliste *n.m.* អ្នកតែងអត្ថបទបង្ខូចកេរ្តិ៍ឈ្មោះ

libellule *n.f.* កន្ទុំរុយ(កន្ទុំរុយតូចសម្បុរខៀវ ឬ ក្រហម ហៅ demoiselle)

liber [—bèr] *n.m.* លីប៊ែរ (សរសៃនាំរុក្ខរសចេញមកពីស្លឹមដើមឈើ)

libérable *a.* សេរីការីយ, អាចធ្វើសេរីការបាន, អាចរំដោះបាន; អាចដោះលែងបាន; ដិតចេញពីទាហាន (ឧ. militaire libérable)

libéral,e,aux *a.* ដែលមានចិត្តទូលាយ; ស្របខាងសេរីភាព (ឧ. idées libérales) ។ arts libéraux សិល្បៈសេរី (ឧ. វិចិត្រកម្ម. ម្ហូកម្ម (ចម្លាក់) ។ profession libérale វិជ្ជាជីវៈសេរី (ឧ. មេធាវី,គ្រូពេទ្យ,វិស្វករប្រឹក្សា ។ ល ។) ។ *n.m.* អ្នកសេរីនិយម (អ្នកនិយមសេរីភាពឯកត្តជនក្នុងនយោបាយនិងសេដ្ឋកិច្ច)

libéralement *adv.* ដោយមានចិត្តទូលាយ, ដោយសទ្ធាចិត្ត; ដោយសេរីនិយម (ឧ. interpréter libéralement une loi)

libéralisation *n.f.* សេរីកម្ម (ការធ្វើឲ្យមានសេរីភាពជាងមុន)

libéraliser *v.t.* ធ្វើសេរីកម្ម (ធ្វើឲ្យមានសេរីភាពជាងមុន) (ឧ. libéraliser un régime)

libéralisme *n.m.* សេរីនិយម។ *Par ext.* ការយល់ឃើញធ្លាយទូលាយ

libéralité *n.f.* ចិត្តទូលាយ (ឧ. agir avec libéralité); សទ្ធាទាន, អំណោយដោយសទ្ធា (ឧ. faire des libéralités)

libérateur,trice *n.* & *a.* សេរីការី-រីនី, អ្នករំដោះ (ឧ. Moïse fut le libérateur des Hébreux)

libération *n.f.* សេរីការ, ការដោះលែង (ឧ. libération d'un condamné); ការឲ្យចេញពីទាហាន (ឧ. libération du contingent) ។ *Dr.* ការសងបំណុល

libératoire *a.* ដែលឲ្យរួចបំណុល (ឧ.

le pouvoir libératoire de l'argent)

libéré,e *a.* ដែលរួចពីបំណុល - ពីកិច្ចសន្យា ឬ ពីទណ្ឌកម្ម

libérer *v.t.* ធ្វើសេរីការ, ឲ្យរួចខ្លួន (ឧ. libérer quelqu'un d'une dette); ដោះលែង (ឧ. libérer un prisonnier); ឲ្យមានសេរីភាព (ឧ. libérer les échanges économiques); ឲ្យចេញពីទាហាន (ឧ.libérer une classe); រំដោះ។ libérer par anticipation ធ្វើសេរីការមុនពេលកំណត់ ។

se libérer *v.pr.* សងបំណុល; បំពេញភារកិច្ច; ដោះខ្លួន

libérien,enne *a.* *Bot.* សឺបែរ (ឧ. fibres libériennes)។ faisceau libérien ម.ព. faisceau និង liber

liberté *n.f.* សេរីភាព (ឧ. engager sa liberté); ភាពគ្មានគេបង្ខំ; ភាពមិនរអែងចិត្ត (ឧ. parler en toute liberté) ។

mettre en liberté ដោះលែង (ឲ្យរួចខ្លួនពីឃុំឃាំង - ពីខ្ញុំគេ ឬ ពីការជិះជាន់) ។ prendre la liberté de ហ៊ាន (ហ៊ានប្រើសិទ្ធិ) (ឧ. prendre la liberté de contredire quelqu'un) ។ liberté civile សេរីភាពពលរដ្ឋ។ liberté de conscience ម.ព. conscience ។ liberté individuelle សេរីភាពឯកត្តជន ។ liberté naturelle សេរីភាពធម្មជាតិ(សិទ្ធិដែលបើកឲ្យមនុស្សប្រព្រឹត្តបានដោយគ្មានគេបង្ខំ) ។ liberté politique សេរីភាពនយោបាយ ។ liberté de la presse សេរីភាពបោះពុម្ពផ្សាយ។ en liberté ដោយសេរីភាព។

*pl.*ការរួចពន្ធ(ឧ.libertés municipales); ការហ៊ានពេក (ការមិនរអែងចិត្ត)(ឧ. prendre des libertés avec quelqu'un)(ព.ផ. esclavage, servitude)

liberticide *a.* សេរីឃាត (ដែលបំផ្លាញសេរីភាព) (ឧ. loi liberticide)

libertin,e *a.&n.*សេរីចារី, ដែលប្រព្រឹត្តខុសសីលធម៌; ដែលមិនជឿសាសនា; មនុស្សខិលខូច

libertinage *n.m.* សេរីចារ្យ,ការប្រព្រឹត្តខុសសីលធម៌; ការមិនជឿសាសនា

libidineux,euse *a.* ម.ព. lascif

libido *n.f. Psych.* កាមតម្រេក

libouret *n.m.* ខ្សែសន្ទូច

libraire *n.* បណ្ណវិក្កយិក យើញ, អ្នកលក់សៀវភៅ ។ libraire-éditeur បណ្ណវិក្កយិកបោះពុម្ពផ្សាយ (អ្នកលក់សៀវភៅផង ទទួលបោះពុម្ពផ្សាយសៀវភៅផង) (*pl.* des libraires-éditeurs)

librairie *n.f.* បណ្ណាគារ;បណ្ណពាណិជ្ជ, ជំនួញសៀវភៅ

libre *a.* សេរី (ឧ. l'homme se sent libre); មិនចំណុះគេ (ឧ. pays libre; il entend rester libre et ne veut prendre aucun engagement); លីវ (ឧ. cette jeune personne est libre) ; មានសេរីភាព, គ្មានគេបង្ខំ; គ្មានរអែងចិត្តគេ (ឧ. on est libre dans cette maison); ទំនេរ (មិនរវល់, មិនខ្វល់) (ឧ. avoir l'esprit libre)។

Par ext. សេរី (ឧ. commerce libre); ទំនេរ, គ្មានឧបសគ្គ (ឧ. voie libre)។ libre de គ្មានជាប់ជំពាក់នឹង (ឧ. libre de tout préjugé) ។ libre d'accepter ou de refuser មានសេរីភាព (ឬ អាច) ទទួល ឬ បដិសេធ ។ *imp.* libre à vous de លោកមានសេរីភាពនឹង, លោកអាច ។ avoir le champ libre មានសេរីភាពនឹងប្រតិបត្តិការតាមចិត្ត ។ avoir ses entrées libres chez quelqu'un មានសេរីភាពចូលបានតាមចិត្ត (គ្មានទើសទាល់) ។ chansons libres ចម្រៀងអាសគ្រាម ។ entrée libre ចូលឥតយកថ្លៃ ។ papier libre ក្រដាសគ្មានត្រា ។ place libre កន្លែងទំនេរ ។ traduction libre ការប្រែតាមចិត្ត(មិនជាប់ឡើងតាមអត្ថបទដើម)។ libre penseur អ្នកមិនជឿសាសនា ។ libre arbitre ម.ព. arbitre ។

Pol. monde libre លោកសេរី (ផ្ទុយពីលោកកុម្មុយនិស្ត ឬ មូលធននិយម) ។

avoir le ventre libre មិនទល់លាមក

libre-échange *n.m.* សេរីបរិវត្តន៍ (ជំនួញរវាងប្រជាជាតិដោយមិនហាមឃាត់ នឹងគ្មានពន្ធគយ) (ព.ផ. pro-

tectionnisme)

libre-échangiste *n.* អ្នកសេរីបរិវត្តិនិយម (ឧ. Cobden fut le chef des libre-échangistes) ។ *a.* សេរីបរិវត្តនិយម (ឧ. politique libre-échangiste) (ព.ផ. protectionniste)

librement *adv.* ដោយសេរី (ឧ. vivre librement); ដោយស្មោះត្រង់ (ឧ. parler librement)

libre-service *n.m.* សេរីសេវា, ការបម្រើដោយខ្លួនឯង (ក្នុងភោជនាគារខ្លះ) (*pl.* des libres-services)

liçage *n.m* ម.ព. lissage

liée *n.f.* កំពែង; ធ្លាមានកំពែងព័ទ្ធជុំវិញ (សម្រាប់ប្រយុទ្ធ ឬ ហាត់) ។ *Par ext.* កន្លែងប្រយុទ្ធ ។ *Fig.* entrer en lice ចូលប្រឡូក, ចូលជជែកគ្នា

lice *n.f.* មេឆ្កែប្រដេញ

lice ឬ **lisse** *n.f.* គង្កៀ (ប្រដាប់សម្រាប់ថ្ករត្បាញ)

licence *n.f.* អលជ្ជីភាព, ការប្រព្រឹត្តតាមចិត្ត (ដោយមិនគោរព, ដោយឥតគួរសម) (ឧ. prendre des licences avec quelqu'un)។ *Ens.* បរិញ្ញាប័ត្រ ។ *Com.* អាជ្ញាប័ណ្ណ (លិខិតអនុញ្ញាតពិសេស) ។ licence d'importation អាជ្ញាប័ណ្ណអាហរណកម្ម ឬ អាហរណអាជ្ញាប័ណ្ណ, អាជ្ញាប័ណ្ណនាំចូល

licencié,e *n.* អ្នកបរិញ្ញា, អ្នកមានបរិញ្ញាប័ត្រ ។ licencié en droit អ្នកបរិញ្ញាខាងនីតិសាស្ត្រ ។ licencié ès sciences អ្នកបរិញ្ញាខាងវិទ្យាសាស្ត្រ

licenciement *n.m.* ការបញ្ឈប់លែងឲ្យធ្វើការ (ឧ. licenciement de personnel)

licencier *v.t.* បញ្ឈប់ (លែងឲ្យធ្វើការ)

licencieusement *adv.* ដោយខុស ឬ ប្រាសចាកសីលធម៌; ដោយអលជ្ជី

licencieux,euse *a.* ខុសសីលធម៌ (ឧ. conduite licencieuse); អលជ្ជី; អាសគ្រាម (ឧ. vers licencieux)

lichen [-kèn] *n.m.* ករកាប្យ [កៈ-រៈ-កាប]

licher *v.t.* *Pop.* ផឹក (ឧ. licher du lait)

licheur,euse *n.* *Pop.* អ្នកផឹក

licitation *n.f.* *Dr.* អភាគិយវិក្កយ [អៈ-ភា-គិយៈ-វិក-កៃ] (ឧ. vendre une maison par licita-

tion)

licite *a.* នៃលច្បាប់អនុញ្ញាត (ឧ. un moyen licite)

licitement *adv.* ដោយច្បាប់អនុញ្ញាត

liciter *v.t.* លក់ដោយអភាគិយវិក្ក័យ

licou ឬ **licol** *n.m.* ប្រទេះ្សូ ក

licorne *n.f.* លីគ័ន (សត្វក្នុងរឿងល្បើក មានខ្លួនជាសេះ ហើយមានស្នែងមួយដុះ ចំកណ្ដាលថ្ងាស)

licou *n.m.* ម.ព. licol

lie *n.f.* កាក, កករ ។ *Fig.* boire le calice jusqu'à la lie ទ្រាំទាល់តែផុត ។ la lie du peuple អន្តជន (ជនថោកទាប)

lie-de-vin *a.inv.* ស្វាយខ្ចី(ពណ៌)

liège *n.m.* ត្បាញ្ជ [ត្បូក-សា] (សំបកឈើម្យ៉ាងស្រាលខ្ចបស្ពោសម្រាប់ធ្វើឆ្នុកដប)

liégé,e *a.* មានត្បាញ្ជ [ត្បូក-សា]

liégeux,euse *a.* ដូចត្បាញ្ជ [ត្បូក-សា]

liement *n.m.* ការចង

lien *n.m.* សម្ព័ន្ធ, ចំណង។ *pl.* ច្រវាក់ (សម្រាប់ដាក់អ្នកទោស)។ *Fig.* សម្ព័ន្ធ (ឧ. les liens du sang) ។ liens culturels សម្ព័ន្ធវប្បធម៌

lier *v.t.* ចង (ឧ. lier un fagot); ភ្ជាប់ (ឧ. le ciment lie les pierres); ធ្វើឲ្យខាប់ (ឧ. lier une sauce) ។ *Fig.* ចងសម្ពន្ធ (ឧ. lier amitié avec quelqu'un); បង្រួបបង្រួម (ឧ. l'intérêt nous lie) ។ lier les idées ភ្ជាប់គំនិត (រកពាក្យបន្ថែមធ្វើឲ្យគំនិតទាក់ទងគ្នា)។ lier conversation ផ្ដើមសន្ទនា ។ lier les mains ចងដៃ; មិនឲ្យធ្វើអ្វីកើត ។ lier la langue ចងមាត់; មិនឲ្យនិយាយបាន ។

se lier *v.pr.* ចងសម្ពន្ធមិត្រ (ឧ. se lier avec quelqu'un); បង្ខំខ្លួនឯង (ឧ. se lier par un serment)

lierre *n.m.* លីយែរ (វល្លិជាតិម្យ៉ាង)(ឧ. le lierre peut vivre plusieurs siècles)

liesse *n.f.* ការសប្បាយទាំងក្រុម (ឧ. une foule en liesse)

lieu *n.m.* កន្លែង (ឧ. deux corps ne peuvent occuper le même lieu en même temps); កន្លែង, ដំបន់(ឧ. lieu charmant); កន្លែងគួរ, កាលគួរ (ឧ. ce n'est pas le lieu de parler de

cela) ។ *Math.* ស្ថាន ។ lieu géométrique ស្ថានរេខាគណិត ។ lieu d'asile កន្លែងជ្រកកោស្រ័យ។ mauvais lieu កន្លែងមិនល្អ: ផ្ទះប្រព្រឹត្តអនាចារ ។ avoir lieu de គួរតែ (ឧ. il a lieu de se féliciter) ។ il y a lieu de ត្រូវតែ, គួរតែ (ឧ. il y a lieu de se réjouir) ។ avoir lieu មានឡើង, កើតឡើង ។ donner lieu បើកឱកាស ។ tenir lieu ជំនួស ។ en temps et lieu ក្នុងកាលនឹងកន្លែងនិគួរ ។ n'avoir ni feu ni lieu ក្រណាស់, ជាមនុស្សអនាថា ។

pl. les Lieux saints សត្ថស្ថាន (ជាឡែស្ទីនៈ គឺកន្លែងដែលព្រះយេស៊ូវស៊េនៅ)។ lieux communs គំនិតសាំមញ្ញ ។ lieux d'aisance បង្គន់ ។

Loc. adv. en premier lieu ទី១ ។ en second lieu ទី២ ។ au lieu de *loc. pré.* ជាង, ត្រង់កន្លែងដែលថា ។ au lieu (ឬ en lieu) et place de *loc. pré.* ជាជំនួស, តាងនាម។ au lieu que *loc. conj.* ក្នុងពេលដែល, រីឯ

lieue *n.f.* ការុត, លីយើ (រង្វាស់ប្រវែងចម្ងាយ ៤គ.ម.)

lieur *n.m.* អ្នកចងកណ្ដាប់ស្រូវ

lieuse *n.f.* ម៉ាស៊ីនចងកណ្ដាប់ស្រូវ

lieutenance *n.f.* សក្តិអនុសេនីយទោ; មុខងារជាភូឈួយ (ឧ.acheter une lieutenance)

lieutenant *n.m.* អនុសេនីយទោ; ភូឈួយ ។ lieutenant général ឧត្តមសេនីយទោ(សក្តិក្នុងទ័ពបូរាណ)។ lieutenant de vaisseau អនុនាវីឯក

lieutenant-colonel *n.m.* វរសេនីយទោ (*pl.* des lieutenants-colonels)

lièvre *n.m* ទន្សាយព្រៃ (ញីហៅថា hase) (cri: le lièvre vagit)។ *Fig.* courir deux lièvres à la fois ចាប់នេះចាប់នោះ មិនឆ្ពោះត្រង់ណា (ចាប់ការច្រើនមុខតែម្ដង) ។ lever un lièvre លើកបញ្ហា ។ mémoire de lièvre ស្មារតីតិច, ឆាប់ភ្លេច

liftier *n.m.* ឆ្មាំជណ្ដើរយន្ត

ligament *n.m.* សរសៃចង (សរសៃគន្លឹងត្រង់សន្លាក់ ឬ ចងទប់អាការៈ

ផ្សេងៗ) (ឧ. ligaments suspenseurs du cristallin)

ligamenteux,euse *a.* ដូចសរសៃចង (ឧ. tissu ligamenteux)

ligature *n.f.* ការចង; ចំណង; របៀបចងផ្អាប; ការរុំបំពៅមែកឈើ

ligaturer *v.i.* ចងរុំ (ឧ. ligaturer une artère)

lige *a. Fig.* homme lige មនុស្សស៊ូប្ដូរនឹងចៅហ្វាយនាយ

lignage *n.m.* ចំនួនបន្ទាត់បោះពុម្ព

lignard *n.m. Pop.* ទាហានថ្មើរជើង (មុន គ.ស. ១៩១៤)

ligne *n.f.* រេខា, ខ្សែបន្ទាត់ (ឧ. un point qui se déplace engendre une ligne); គន្លង, មគ៌ា (ឧ. aller en droite ligne); បន្ទាត់ (អក្សរ)។ aller à la ligne ចុះបន្ទាត់។ ជួរ (ឧ. une ligne de forts)។ ligne et angle រេខានិងមុំ។ ligne brisée បន្ទាត់កាច់។ ligne courbe បន្ទាត់កោង។ ligne droite ឧជុរេខា ឬ បន្ទាត់ត្រង់។ ligne horizontale បន្ទាត់នភាបទឬផ្ដេក។ ligne oblique បន្ទាត់បញ្ឆៀង។ ligne verticale បន្ទាត់បញ្ឈរ។

Mil. ជួរទ័ព។ monter en ligne ទៅកាន់ស្នាមប្រយុទ្ធ។ en première ligne នៅមុខគេ (ក្នុងសង្គ្រាម)។

ខ្សែសន្ទូច; បន្ទាត់ខ្សែ (សម្រាប់វាយបន្ទាត់) (ឧ. ligne de charpentier, de maçon, etc...)។ ligne équinoxiale ឬ ligne ភូមធ្យរេខា។ *Bx-arts.* រេខានកាយ។

Fig. ជួរ (ញាតិ)។ ligne collatérale ជួរសាខាញាតិ (អ្នកកើតចេញពីគោត្រជាមួយគ្នា តែបែកទៅជាមែកដទៃ ដូចយ៉ាងបងប្អូនបង្កើត, មាមីងនឹងក្មួយ, បងប្អូនជីដូនមួយ, ជីទួតមួយចុះរៀងទៅ)។ ligne directe ជួរញាតិផ្ទាល់ (អ្នកដែលកើតតគ្នាពីមួយទៅមួយ តាមលំដាប់គឺឪពុក, កូន, ចៅ, ចៅទួត ។ល។ រហូតដល់ជាន់ទី៧)។

Fam. avoir de la ligne រាងស្រឡះ, រាងសម។ ligne de conduite ចរិយាបថ

lignée *n.f.* ពូជ (ឧ. laisser une lignée pure)។ *Agr.* lignée pure ពូជសុទ្ធ

ligner *v.t. Constr.* វាយបន្ទាត់ (ឧ. ligner des planches)

ligneul *n.m.* ខ្សែក្រចង

ligneux,euse *a.* ជាជាតិឈើ (ឧ. tige ligneuse); នៃជាតិឈើ (ឧ. fibre ligneuse)

lignicole *a.* ដែលនៅអាស្រ័យក្នុងឈើ (ឧ. insectes lignicoles)

lignifier (se) *v.pr.* ទៅជាឈើ

lignite *n.m.* ធ្យូងថ្មម្យ៉ាង (ឧ. la lignite contient un pourcentage d'hydrocarbures plus élevé que le charbon ordinaire)

ligotage *n.m.* ការចងរឹត

ligoter *v.t.* ចងរឹត

ligue *n.f.* សម្ព័ន្ធ, ការរួមជាបក្ស (ឧ. ligue des droits de l'homme)។ ligue arabe សម្ព័ន្ធអារ៉ាប់

liguer *v.t.* បញ្ចូលក្នុងសម្ព័ន្ធ ។ se liguer *v.pr.* រួមគ្នាជាសម្ព័ន្ធ, ពួកផ្ដិត

ligueur,euse *n.* សមាជិកសម្ព័ន្ធ

liliacées *n.f.pl.* បណ្ដាពួកល [ប៉ះ-ឡាន-ឌះ-]

lilliputien,enne *a.&n.* តូចណាស់ (មកពី Lilliput ប្រទេសមួយក្នុងរឿងព្រេងដែលមានមនុស្សតូចៗ)

limace *n.f.* ខ្យងម្យ៉ាងសំបកតូច

limaçon *n.m.* ខ្យងសោក

limage *n.m.* ការដូស; របៀបដូស

limaille *n.f.* អាចម៍ដែកអង្រួស (រសៈ ម្សៅដែកអង្រួស) (ឧ. limaille de fer)

limbaire *a. Bot.* នៃតួស្លឹក

limbe *n.f.* ហាមនៃតារា។ *Bot.* តួស្លឹក; តួត្របកផ្កា។ *Fig.* ភាពស្រពិចស្រពិល (ឧ. les limbes de la pensée)

lime *n.f.* ដែកអង្រួស

lime ឬ **limette** *n.f.* ក្រូចឆ្មារម្យ៉ាងផ្លែតូច

limer *v.t.* ដូស ។ *Fig.* កែសម្រួច (ឧ. limer des vers)

limettier *n.m.* ដើមក្រូចម្យ៉ាង

limeur,euse *n. & a.* ដែលកាន់ដែកអង្រួស

limicole *a.* ដែលនៅអាស្រ័យក្នុងភក់

limier *n.m.* ឆ្កែប្រមាញ់ធំ ។ *Fig. & Fam.* ភ្នាក់ងារនគរបាល

liminaire *a.* ខាងដើម (ចំពោះសៀវភៅ; កាព្យកាព្យ) (ឧ. pensée liminaire)

liminal,e,aux *a.* ដំបូង (ឧ. la psy-

chologie étudie l'excitation liminale)

limitable *a.* អាចកំណត់ព្រំដែនបាន; ដែលកំណត់បាន

limitatif,ive *a.* ដែលកំណត់ព្រំដែន (ឧ. clause limitative)

limitation *n.f.* ការកំណត់ព្រំដែន (ឧ. obtenir un congé sans limitation de temps); ការដាក់កំហិត; កំណត់

limite *n.f.* ព្រំដែន (ឧ. limite de la mer); ព្រំប្រទល់ ។ *Fig.* toute puissance a des limites អានុភាពតែងមានព្រំដែន ។ limite de la souveraineté ព្រំដែននៃអធិបតេយ្យ ។ *a.* លើសទៀតមិនកើត (ឧ. prix limite)

limité,e *a.* ដែលមានកំណត់ព្រំដែន , ដែលមានកំណត់ (ឧ. congé limité)

limiter *v.t.* កំណត់ព្រំដែន ឬ ព្រំប្រទល់ (ឧ. limiter un pays); ជាព្រំដែននៃ (ឧ. le Phnom Dangrêk limite le Cambodge au Nord) ។ *Fig.* រឹតត្បិត (ឧ. limiter ses dépenses)

limitrophe *a.* ដែលនៅត្រង់ព្រំប្រទល់

limogeage *n.m. Fam.* ការដកពីមុខតំណែង

limoger *v.t. Fam.* ដកពីមុខតំណែង

limon *n.m.* ដីល្បប់ (ឧ. le riche limon du Mékong est déposé lors des crues)

limon *n.m.* ក្រូចឆ្មារម្យ៉ាងមានទឹកច្រើន

limonade *n.f.* ទឹកលីម៉ូណាត

limonadier,ère *n.* អ្នកលក់ភេសជ្ជៈរាយ

limonage *n.m.* ការដាក់ដីល្បប់ (ថា limonement ក៏បាន)

limoneux,euse *a.* ដែលមានល្បប់(ឧ. terrain limoneux)

limonier *n.m.* ដើមក្រូចឆ្មារម្យ៉ាង

limonière *n.f.* ទូករទេះ

limono-sableux,euse *a.* ល្បាយខ្សាច់

limousin,e *a.&n.* នៃស្រុកលីម៉ូស ឬ លីមូស័ង ។ *n.m.* ជាងបាយអ

limpide *a.* ថ្លាឆ្វង់(ឧ.une eau limpide); ថ្លា (ឧ. œil limpide) ។ *Fig.* ច្បាស់, ងាយយល់ (ឧ. style limpide)

limpidité *n.f.* ភាពថ្លាឆ្វង់ (ឧ. limpidité de l'eau, du regard)

limule *n.m.* ប្រឡាំងកាស (សត្វសមុទ្រ)

lin *n.m.* ដើមធ្មៃ; ធ្មៃ; សំពត់ធ្មៃ

linacé,e *a.* ដូចធ្មៃ

linceul *n.m.* ស្បង ។ *Par ext.* អ្វីៗដែលគ្របដណ្ដប់ (ឧ. un linceul de neige)

linéaire *a.* នៃបន្ទាត់, ដែលធ្វើដោយគូសបន្ទាត់ ។ mesures linéaires រង្វាស់ប្រវែង ។ feuilles linéaires ស្លឹកតូចវែង

linéal,e,aux *a.* នៃបន្ទាត់ក្នុងត្រកូល

linéament *n.m.* ប្រណិតភាពនៃមុខ ។ *Par ext.* អាការៈដែលបាននិងដំបូងនៃសត្វ; ស្នាមដំបូង (ឧ. les linéaments d'un dessin)

liner [laï-neur] *n.m.* នាវាដើរផ្លូវឆ្ងាយ

linette *n.f.* គ្រាប់ធ្មៃ

linge *n.m.* គោរំខ្លួនស្រួ,សំពត់ ។ linge d'office សំពត់ជូត

linger,ère *n.&a.* អ្នកធ្វើឬលក់សំពត់ ។ *n.f.* គោរិក, ស្រីអ្នកយោកលាងសំពត់

lingerie *n.f.* គោរំខ្លួនកាណិជ្ជកម្ម [គោ-រំខ-តៈ-], ជំនួញសំពត់; គោរំខ្លួនខ្លាន [គោ-រំខ-ត័ត-],កន្លែងទុកសំពត់;សំពត់ (សំលៀកបំពាក់) (ឧ. porter de la lingerie fine)

lingot *n.m.* ដុំលោហធាតុសិត (ឧ.lingot d'or) ។ argent en lingot ប្រាក់ណែន .

lingotière *n.f.* ពុម្ពសិតដុំលោហធាតុ

lingual,e, aux *a.* នៃអណ្ដាត (ឧ. muscle lingual) ។ consonne linguale ឬ linguale *n.f.* ម្ធូង: (ឧ. អក្សរ: d, t, l, n, r, ន, ឋ, ឌ, ល, ណ, រ, ឡ ជាម្ធូងៈ) (ម.ព. cérébral ផង)

linguiforme *a.* ដែលមានរាងដូចអណ្ដាត

linguiste *n.* ភាសាវិទូ, អ្នកប្រាជ្ញខាងភាសា

linguistique *a.* នៃភាសាប្រវត្តិ (ឧ. travaux linguistiques) ។ *n.f.* ភាសាប្រវត្តិ

linier,ère *a.* នៃធ្មៃ (ឧ. industrie linière) ។ *n.f.* ចំការធ្មៃ

liniment *n.m.* ថ្នាំរែក

linteau *n.m.* មេទ្វារ-បង្អួចខាងលើ

lion, lionne *n.* សិង្ហ, រោ (cri: le lion rugit) ។ *Fig.* សីហៈ, មនុស្សក្លាហាន ។ la part du lion ចំណែកធំ (ប្រើនិងរេចាំងអស់) ។ *Astr.* សីហរាសី ។

Loc. adv. coudre la peau du renard à celle du

lion ផ្សែកលល្បិចនឹងកម្លាំងកាយ ។ *Prov.* à l'ongle (ឬ à la griffe) on reconnaît le lion ម.ព. griffe

lionceau *n.m.* កូនសិង្ហ ឬ តោ

lipide *n.m.* គេលិក (ជាតិខ្លាញ់)

lipoïde *a.* ដូចគេលិក

liposoluble *a.* ដែលរលាយក្នុងខ្លាញ់ ឬ ប្រេង (ឧ. vitamines liposolubles)

lipothymie *n.f.* ដំណើរសន្លប់មួយភ្លែត

lipovaccin *n.m.* ថ្នាំបង្ការរោគរលាយក្នុងខ្លាញ់ ឬ ប្រេង

lippe *n.f.* បបូរមាត់ក្រោម ។ *Fam.* faire la lippe ពេបមាត់; ក្ដិច, ងឿកង

lippée *n.f.* ចំនួនមួយម៉ាត់ ។ *Fam.* franche lippée អាហារឆ្ងាញ់ហើយគ្មានចាយប្រាក់

lippu,e *a.* ដែលមានបបូរមាត់ក្រោមក្រាស់

liquéfaction *n.f.* ដំណើរក្លាយជាទឹក (ឧស្ម័ន)

liquéfiable *a.* អាចធ្វើឲ្យក្លាយជាទឹកបាន

liquéfiant,e *a.* សម្រាប់ធ្វើឲ្យក្លាយជាទឹក

liquéfier *v.t.* ធ្វើឲ្យក្លាយជាទឹក ។ se liquéfier *v.pr.* ក្លាយជាទឹក

liqueur *n.f.* ទឹក; ភេសជ្ជៈ ។ vin de liqueur ស្រាខ្សោយហើយផ្អែម

liquidable *a.* អាចជម្រះបញ្ជីបាន

liquidateur,trice *n.&a.* សម្រាប់ជម្រះបញ្ជី ។ service liquidateur ក្រុមជម្រះបញ្ជី

liquidatif,ive *a.* ដែលជម្រះបញ្ជី (ឧ. un acte liquidatif de société)

liquidation *n.f.* ការជម្រះបញ្ជី; ការទូទាត់; ការសងបំណុល; ការលក់ចោលដោយថោកៗ ។ liquidation des dépens ការកំណត់សោហ៊ុយក្ដី ។ liquidation de l'impôt ការកំណត់ពន្ធ ។ *Par ext.* ការដោះស្រាយ (ឧ. liquidation d'un problème)

liquide *a.* រាវ, រាវ ។ *n.m.* វត្ថុរាវ-ធាតុ, ធាតុរាវ; ភេសជ្ជៈ

liquide *a.* ស្អាត, គ្មានជាប់ជំពាក់ទាក់ទិន (ឧ.une créance liquide) ។ argent liquide សាច់ប្រាក់ (ប្រាក់ដែលអាចចាយបានភ្លាមៗ)

liquider *v.t.* ជម្រះបញ្ជី (ឧ.liquider un compte); ជម្រះ, ផាត់ ឬ ទូទាត់

(ឧ. liquider une affaire) ; ចំណាយចោល ឬ លក់ចោលអោយហើយ ។ *Par ext.* ដោះស្រាយ (ឧ. liquider une situation difficile) ។ *Fam.* កំចាត់, លោស់ចោល (ឧ. liquider un importun)

liquidien *a. m.* នៃរំលីនធាតុ (ឧ. épanchement liquidien de la plèvre)

liquidité *n.f.* ការអាចដូរប្រែបញ្ចៀន (ចំពោះសហក្រាសដែលមានមូលនិធិគ្រប់គ្រាន់អាចសងបំណុលខ្លួនបានភ្លាមៗ)

liquoreux,reuse *a.* ខ្សោយ (ចំពោះស្រា)

liquoriste *n.m.* អ្នកធ្វើឬលក់គេសង្ឃឹះ

lire *n.f.* លៀរ (រូបិយវត្ថុអ៊ីតាលី)

lire *v.t.* អាន (ឧ. enfant qui lit couramment; lire une lettre); អានឲ្យស្តាប់ (ឧ. lire une pièce dans une assemblée) ។ *Fig.* យល់, យល់ធ្លុះ (ឧ. lire dans la pensée)

lis ឬ **lys** *n.m.* លីស (ផ្កាម្យ៉ាងសព្រម្យប) ។ teint de lis ពណ៌សស្គុស

lise *n.f.* ខ្សាច់ហូរនៅមាត់សមុទ្រ

liseron *n.m.* ត្រកួន

lisette *n.f.* ត្រីស្រីធ្លាក

liseur,euse *n.*អ្នកចូលចិត្តអាន;អ្នកយល់

lisibilité *n.f.* ភាពងាយអាន

lisible *a.* ងាយអាន (ឧ. écriture lisible)

lisiblement *adv.* ដោយងាយអាន (ឧ. une lettre écrite lisiblement)

lisière *n.f.* ជាយ; រនះ, មាត់ (ព្រៃ) (ឧ. la lisière d'un champ)

lissage *n.m.* ការខាត់; ការខាត់ស្អាត

lissage ឬ **liçage** *n.m.Techn.*ការធ្វើរ

lisse *a.* រលីង

lisse *n.f. Mar.* បង្កាន់ដៃស្គាទូក

lisse ឬ **lice** *n.f.* គង្ក

lissé,e *a.* ដែលគេខាត់រលីង

lisser *v.t.* ខាត់, រលីង (ឧ. lisser du papier); អ៊ុត (ឧ lisser un faux col)

lisseuse *n.f.* ម៉ាស៊ីនខាត់រលីង

lissier ឬ **licier** *n.m.* អ្នកធ្វើរ.អ្នកចងគង្ក

lissoir *n.m.* ប្រដាប់ខាត់រលីង

liste *n.f.* បញ្ជី ។ liste civile ចំនួនប្រាក់ថ្វាយព្រះករុណាទុកចំណាយផ្ទាល់ព្រះអង្គ ។ liste électorale បញ្ជីអ្នក

ចោះឆ្នោត។ liste noire បញ្ជីស្បែកខ្មៅ (បញ្ជីកត់ឈ្មោះជន ឬ គ្រឹះស្ថានដែលមានឈ្មោះអាក្រក់)

lit *n.m.* គ្រែ; កន្លែងអាចដេកបាន (ឧ. lit de gazon)។ *Par ext.* អាពាហ៍ពិពាហ៍។ enfant de premier lit កូនប្រពន្ធដើម។ enfant du second lit កូនប្រពន្ធចុង។ lit de camp ក្ដារគ្រៀ។ faire le lit រៀបចំគ្រែ។ garder le lit ដេកជាប់ (ដោយមានជម្ងឺ)។ être au lit de mort ហៀបនឹងស្លាប់។ *Fig. Géogr.* ពោះ (ត្រលង ឬ ប្រឡាយនៃទន្លេ,ស្ទឹង,បឹង។ល។)។ lit majeur ពោះតម្លើង។ lit mineur ពោះសម្រក។ ស្រទាប់ (ឧ. lit de sable, de cailloux)។

Mar. lit du vent ទិសខ្យល់បក់

litanie *n.f. Fam.* ការរៀបរាប់មិនចេះចប់ (ឧ. une litanie de réclamations)។ c'est toujours la même litanie សំដីស្រីដែលនាំឲ្យធុញទ្រាន់

litchi, li-tchi ឬ **letchi** *n.m.* ម.ព. letchi

liteau *n.m.* ជម្រកខ្លាព្រៃក្នុងពេលថ្ងៃ

litée *n.f.* សំបុក (ចំនួនសត្វដែលនៅក្នុងជម្រកជាមួយគ្នា ; ចំនួនកូនសត្វដែលកើតម្តងពីមេមួយ) (ឧ. une litée de marcassins)

liter *v.t.* តម្រៀបត្រីជាស្រទាប់ (ក្នុងការធ្វើទឹកត្រីជាដើម)

literie *n.f.* ប្រដាប់ប្រដាគ្រែ

litham *n.m.* លីថាម (សំពត់គ្របមុខនៃស្ត្រីកាន់សាសនាអ៊ីស្លាមជាដើម)

lithiase *n.f.Méd.* ដំណើរកក្រួស (ក្នុងប្រមាត់ឬក្នុងក្រពះនោម)។ lithiase urinaire ប្រមេះគ្រាប់ (ម.ព. gravelle ផង)

lithiasique *a.* នៃដំណើរកក្រួស (ឧ. affection lithiasique)។ *a. & n.* ដែលមានកក្រួស (ក្នុងប្រមាត់ ឬ ក្នុងក្រពះនោម)

lithographe *n.m. Arts graph.* អ្នកសិលាលេខ

lithographie *n.f. Arts graph.* សិលាលេខ , ការបោះពុម្ពដោយប្រើថ្ម (ឧ. la lithographie fut découverte en 1796, par Senefelder)

lithographier *v.t.* បោះពុម្ពដោយ

សិលាលេខ

lithographique *a.* នៃសិលាលេខ (ឧ. pierre lithographique)

lithologie *n.f.* សិលាវិទ្យា, វិទ្យាសាស្ត្រខាងថ្ម

lithophage *a.* សិលាសី , ដែលស៊ីថ្ម (ឧ. coquillages lithophages)

litige *n.m.* វិវាទ (ឧ. point en litige)

litière *n.f.* ចំបើងក្រាលឲ្យសត្វដេក ; គ្រែស្នែង

litigieux,euse *a.* ជាប់វិវាទ (ឧ. point litigieux); ដែលចូលចិត្តប្រកែក(ឧ. esprit litigieux)

litre (l.) *n.m.* លីត្រ (ល.)

litsam *n.m.* ម.ព. litham

littéraire *a.* នៃអក្សរសាស្ត្រ (ឧ. journal littéraire) ។ le monde littéraire លោកអក្សរសាស្ត្រ, អ្នកអក្សរសាស្ត្រទាំងឡាយ

littérairement *adv.* ខាងអក្សរសាស្ត្រ

littéral,e,aux *a.* ត្រឹមត្រូវតាមព្យញ្ជនៈឬតាមន័យរបស់ពាក្យ(ឧ. traduction littérale d'un auteur)

littéralement *adv.* តាមព្យញ្ជនៈ (ឧ. traduire littéralement) ។ *Fam.* មែនទែន (ឧ. il est littéralement incapable)

littérateur *n.m.* អ្នកអក្សរសាស្ត្រ

littérature *n.f.* អក្សរសាស្ត្រ; វិជ្ជាជីវៈខាងអក្សរសាស្ត្រ (ឧ. se lancer dans la littérature)

littoral,e,aux *a.* នៃមាត់សមុទ្រ (ឧ. montagnes littorales) ។ *n.m.* ស្រុកក្បែរមាត់សមុទ្រ

livide *a.* ខៀវជាំ ; ស្លាំង (ឧ. teint livide)

lividité *n.f.* ភាពស្លាំង (ឧ.la lividité cadavérique de la peau)

living-room [li-ving-roum] *n.m.* បន្ទប់ទទួលភ្ញៀវ (*pl.* des living-rooms)

livrable *a.* អាចប្រគល់បាន

livraison *n.f.* ការប្រគល់ (ឧ. la livraison constitue l'obligation du vendeur dans le contrat de vente)

livre *n.m.* សៀវភៅ; វត្ថុដែលបង្រៀន; សៀវភៅ ឬ បញ្ជី (ឧ. avoir un livre d'adresses) ។ *Com.* grand livre ម.ព. grand-livre ។ livre de caisse សៀវភៅបេឡា ។ livre de compte សៀវភៅ

គណនី ។ livre journal សៀវភៅប្រចាំថ្ងៃ ។ *Mar.* livre de bord សៀវភៅនាវា (សៀវភៅសម្រាប់នាយនាវាកត់ហេតុការណ៍សព្វគ្រប់ដែលកើតមានក្នុងនាវា) ។ livre classique សៀវភៅសិក្សា (ម.ព. classique ផង)។ livre d'or សៀវភៅសុវណ្ណវិចិត្រ ។ à livre ouvert *loc. adv.* ដោយបើកសៀវភៅអាន, ដោយគ្មានប្រុងប្រៀបជាមុន (ឧ. traduire à livre ouvert)

livre *n.f.* នាឡិ; សំនង់ទម្ងន់អង់គ្លេស (០,៤៥៣គីឡូក្រាម); លីវ្រ៍ , រូបិយវត្ថុអង់គ្លេស (livre sterling)

livrée *n.f.* សំលៀកបំពាក់ដោយឡែកនៃអ្នកបម្រើក្នុងផ្ទះ; ក្រុមទាសកម្មករ ។ porter la livrée ធ្វើជាទាសកម្មករ ។ ពេមសត្វខ្លះ

livrer *v.t.* ប្រគល់ (ឧ. livrer une commande); បោះបង់ (ឧ. livrer une ville au pillage); ប្រគល់ឲ្យដោយក្បត់ (ឧ. livrer une place à l'ennemi) ។ livrer bataille ចូលប្រយុទ្ធ ។ livrer à la justice ដាក់ឲ្យតុលាការជំរះ។ se livrer *v.pr.* បណ្ដោយខ្លួន (ឧ. se livrer à la joie); ផ្ចង់ចិត្ត (ឧ. se livrer à l'étude); ប្រព្រឹត្ត(ឧ. se livrer à la pêche)

livresque *a.* ដែលបានមកពីសៀវភៅ (ឧ. science livresque)

livret *n.m.* សៀវភៅតូច; បញ្ជីកាយឈ្មោះរបស់ ។ livret de caisse d'épargne សៀវភៅបេឡាសញ្ចយ ឬ ហិបសំចៃ ។ livret de famille សៀវភៅគ្រួសារ (សម្រាប់ទុកលិខិតអត្រានុកូលដ្ឋានផ្សេងៗនៃគ្រួសារ) ។ livret ouvrier សៀវភៅកម្មករ។ livret scolaire សៀវភៅសិក្សាធិការ

livreur,euse *n.* អ្នកប្រគល់ទំនិញដល់ទីលំនៅ; រថយន្តដឹកទំនិញប្រគល់ឲ្យអ្នកទិញ

lobe *n.m.Anat.* កំពក (ភាគពកមូលនៃអាការៈណាមួយ) (ឧ. les lobes du cerveau, des poumons)។ lobe de l'oreille ទងត្រចៀក

local,e,aux *a.* អាយ, ដោយឡែកសម្រាប់ទីកន្លែងណាមួយ (ឧ. coutume locale)។ heure locale ម៉ោងក្នុងស្រុក ។ នៃកន្លែងណាមួយ (ឧ. douleur locale) ។ *Litt. & Bx-*

arts couleur locale លក្ខណៈពិសេសនៃស្រុកទេស (ការពិពណ៌នាឬរូបដែលចាប់យកលក្ខណៈពិសេសនៃទំនៀមទម្លាប់, សំលៀកបំពាក់ ។ល។ នៃស្រុកទេសណាមួយ)។ *n.m.* កន្លែង ឬបន្ទប់ពិសេសសម្រាប់ធ្វើអ្វីមួយ (ឧ. local commercial)

localement *adv.* តែមួយកន្លែង

localisation *n.f.* ឋានបរិច្ឆេទ (ការកំណត់កន្លែង; ដំណើរមានកន្លែងប្រាកដ) (ឧ. la localisation des perceptions visuelles dans les lobes occipitaux du cerveau)

localiser *v.t.* ធ្វើឋានបរិច្ឆេទ (រកកន្លែង ឧ. localiser une sensation; កំណត់កន្លែង, មិនឲ្យចេញពីព្រំដែន ឧ. localiser un incendie) ។ se localiser *v.pr.* មានកន្លែងប្រាកដ

localité *n.f.* ដំបន់

locataire *n.* អ្នកជួលដីឬផ្ទះ ។ locataire principal អ្នកជួលដើម ។ sous-locataire អ្នកជួលត

locateur,trice *n.* អ្នកដាក់ឈ្នួល

locatif,ive *a.* នៃការជួល; នៃអ្នកជួល ។ réparations locatives ការជួសជុលដែលជាបន្ទុកនៃអ្នកជួល ។ valeur locative តម្លៃជួល

locatif *n.m.* សត្តមីវិភត្តិ, វិភត្តិទី ៧

location *n.f.* ការជួល (ឧ. location d'un logement); ឈ្នួល, តម្លៃជួល (ឧ. location fort chère)

locatis *n.m.Fam.* សេះ-រទេះ ឬ ផ្ទះ ឈ្នួល

loch [lok] *n.m.Mar.* ឡុក (ប្រដាប់ស្ទង់ល្បឿននាវា)

locomobile *a.* ដែលចេះកម្រើកនឹងផ្លាស់ប្ដូរកន្លែង

locomoteur,trice *a.* ចលករ [ចៈ-លៈ-] (ដែលឲ្យកម្រើក) (ឧ. machine locomotrice; នៃការកម្រើក(ឧ.ataxie locomotrice)

locomotion *n.f.* ចលកម្ម (អំពើកម្រើកទៅ, ការផ្លាស់ប្ដូរកន្លែង)

locomotive *n.f.* ក្បាលអយស្ម័យយាន (ម៉ាស៊ីនអូស) (ឧ. Stephenson construisit la première locomotive)

locotracteur *n.m.* ឡូកូត្រ័កទ័រ, ម៉ាស៊ីនអូស

locution *n.f.* ភាវិលាស ។ locution adverbiale ភាវិលាស-

កិរិយាវិសេសន៍ ។ locution conjonctive ឃ្លាវិសេសសន្ធាន។ locution prépositive ឃ្លាវិសេសអាយតនិបាត ។ locution proverbiale ឃ្លាវិសេសភាសិត

lœss [leuss] *n.m.* ល៊ឿស្ស (ល្បប់ម៉ដ្ឋ) (ឧ. le lœss de la Chine du Nord, qui s'étend sur d'immenses surfaces est en partie d'origine éolienne)

lof *n.m. Mar.* ខាងត្រូវខ្យល់ (នាវា) ។ venir au lof បែរកទិសខ្យល់

logarithme *n.m. Math.* មេលេខដំបើន (ឧ. l'emploi des logarithmes permet de simplifier les calculs)

logarithmique *a.* នៃមេលេខដំបើន (ឧ. calcul logarithmique)

loge *n.f.* លំនៅគេហបាល; ឡូស, បន្ទប់ខណ្ឌ (ក្នុងទស្សនីយភាព) (ឧ. louer une loge) ។ *Fig. & Fam.* être aux premières loges បានកន្លែងស្រួល(សម្រាប់មើលអ្វីមួយ) (ពាក្យសាមញ្ញថា: អង្គុយថ្នាក់ឡូស) ។ បន្ទប់ស្លៀកពាក់ (សម្រាប់តួល្ខោន)

logeable *a.* អាចនៅបានដោយស្រួល (ឧ. maison logeable)

logement *n.m.* និវេសនដ្ឋាន, លំនៅ (ឧ. politique du logement)។ logement garni ឬ meublé និវេសនដ្ឋានមានគ្រឿង

loger *v.i.* នៅ (ឧ. où logez-vous) ។ *Fig. & Fam.* loger à la belle étoile ដេកកណ្ដាលវាល ។ *v.t.* ឲ្យលំនៅ, ឲ្យសំចត (ឧ. loger des soldats)។ *Par ext.* ដាក់, បញ្ចូល (ឧ. loger une balle dans la cible) ។

se loger *v.pr.* នៅ, សំចត

logette *n.f.* កូនបន្ទប់

logeur,euse *n.* អ្នកជួលផ្ទះមានគ្រឿង

logicien *n.* តក្កវិញ្ញូ (អ្នកចេះតក្កវិជ្ជា) (ឧ. Stuart Mill fut un logicien de valeur)

logisme *n.m.* តក្កនិយម (ទ្រឹស្ដីទស្សនវិជ្ជាដែលនិយមថាតក្កវិជ្ជាសំខាន់ជាងគេ)

logique *n.f.* តក្កវិជ្ជា (វិជ្ជាត្រិះរិះពិចារណារកហេតុផល) (ឧ. Aristote a formulé les principes de la logique); តក្កសាស្ត្រ (ក្បួន

តក្កវិជ្ជា)។ *a.* ត្រឹមត្រូវតាមតក្កវិជ្ជា; សមហេតុសមផល

logiquement *adv.* ដោយត្រឹមត្រូវតាមតក្កវិជ្ជា; ដោយសមហេតុសមផល

logis *n.m.* លំនៅ, ផ្ទះ (ឧ. rentrer au logis); ផ្ទះសំណាក់។ corps du logis ផ្ទះធំ។ *Fig.&Fam.* la folle du logis មនោគតិ

logisticien *n.m.* តក្កវិញ្ញូខាងគណិតសាស្ត្រ

logistique *n.f.* វិជ្ជាដឹកនាំ (ដឹកនាំពស្តុភារនិងដឹកនាំទ័ព)។ *Philos.* តក្កវិជ្ជាគណិតសាស្ត្រ។ *a.* នៃវិជ្ជាដឹកនាំ (ឧ. les bases sont les supports logistiques des armées en campagne)

logogriphe *n.m.* បណ្តាំឡប៉ាង (ឲ្យរកពាក្យដោយផ្លាស់អក្សរ ឧ. ក្នុងពាក្យ « បំណាក់ » គេអាចរកឃើញពាក្យ « កំណាប់ »)។ *Fig.&Fam.* សំដីស្តាប់មិនបាន

loi *n.f.* ច្បាប់ (ឧ. se soumettre à une loi; promulguer une loi)។ nul n'est censé ignorer la loi ម.ព. censé។ ធម្មតា (ឧ. les lois de la chute des corps)។ la loi ancienne លទ្ធិយូអ៊ីស។ la loi nouvelle សាសនាព្រះយេស៊ូ។ loi morale ច្បាប់សីលធម៌។ loi de finances ច្បាប់ហិរញ្ញវត្ថុ។ loi civile ច្បាប់បវេណី។ loi martiale ច្បាប់អាជ្ញាសឹក។ loi de la guerre ច្បាប់សង្គ្រាម (ច្បាប់ស្តីអំពីការរក្សាអ្នករបួស, ឈ្លើយសង្គ្រាម។ល។)។ loi divine ច្បាប់អាទិទេព។ loi naturelle ច្បាប់ធម្មជាតិ។ loi de l'offre et de la demande ច្បាប់ធម្មជាតិលក់ទិញ។ loi en vigueur ច្បាប់ជាធរមាន។ se faire une loi តាំងចិត្ត (ដាក់កំហិតខ្លួនឯង)។ n' avoir ni foi ni loi មិនប្រព្រឹត្តតាមសាសនាឬតាមយុត្តិធម៌សោះ។ *Philos.* ធម៌

loi-cadre *n.f.* ច្បាប់ក្របខ័ណ្ឌ (*pl.* des lois-cadres)

loin *adv.* ឆ្ងាយ (ឧ.arme qui porte loin); ឆ្ងាយ (យូរ) (ឧ. remonter bien loin dans l'histoire)។

aller loin ទៅឆ្ងាយ, បើកយូរ (ឧ. héritage qui n'ira pas loin)។ aller plus loin ធ្វើ

លើស ។ *Fig* aller trop loin ធ្វើហួសពេក (ឧ. c'est aller trop loin)។ voir loin ឃើញឆ្ងាយ ។ *Fam.* ne voir pas plus loin que son nez មើលមិនឃើញឆ្ងាយ; គំនិតខ្លីណាស់ ។ il y a loin de នៅឆ្ងាយ (ឧ. il y a loin de Paris à Mouscou ប៉ារីសនៅឆ្ងាយពីមូស្គូ); *au fig.* ខុសគ្នាឆ្ងាយ (ឧ. il y a souvent loin de ce qu'on dit à ce qu'on pense) ។ il ne la portera pas bien loin វាមិនរួចខ្លួនទេ(គង់តែថ្ងៃណាមួយនឹងត្រូវទោស) ។

Loc. adv. de loin ពីចម្ងាយ (ឧ.appeler de loin)។ revenir de loin ត្រឡប់មកពីចម្ងាយ(ទៅឆ្ងាយហើយទើបត្រឡប់មកវិញ); *au fig.* ដូចកើតម្ដងទៀត (ដើបពីឈឺធ្ងន់; រួចពីគ្រោះថ្នាក់ធំឬពីស្ថានការណ៍ពិបាក)។ être parents de loin ជាបងប្អូនឬសាច់ញាតិឆ្ងាយ។ ne connaître quelqu'un ni de près ni de loin មិនដែលស្គាល់សោះ។ au loin ឯទីឆ្ងាយ, ទៅឆ្ងាយ ។ de loin en loin ឆ្ងាយៗពីគ្នា ។ plus loin ឆ្ងាយទៅទៀត; យូរទៅទៀត ។

Loc. pré. loin de ឆ្ងាយពី (ឧ. loin de Phnom-Penh) ; *au fig.* គ្មានប្រាថ្នានឹង (ឧ. être loin de s'énorgueillir);មិន... ទៅជា (ឧ. certains défauts, loin de nuire, servent គុណវិបត្តិខ្លះមិនឲ្យទោស ទៅជាមានប្រយោជន៍វិញ) ។ loin de là ខុសឆ្ងាយ ។ être loin de son compte គិតខុសឆ្ងាយ ។ être loin de compte ខុសគ្នាឆ្ងាយ, មិនត្រូវគ្នាសោះ ។ non loin de មិនឆ្ងាយពី (ឧ. non loin du fleuve) ។

Prov. pas à pas on va loin ឬ qui va doucement va loin ក្នុងកាងដើកផ្លូវ ស្ទូវៗនិល់ខ្ទះ។ à beau mentir qui vient de loin ម.ព. beau ។ loin des yeux loin du cœur ឃ្លាតកាយណាយចិត្ត ។ il y a loin de la coupe aux lèvres ម.ព. coupe

lointain,e *a.* ដែលនៅឆ្ងាយ (ឧ. un pays lointain); យូរមកហើយ (ឧ. une époque loin-

taine) ។ *n.m.* ទីឆ្ងាយ, ដំបន់ឆ្ងាយ (ឧ. apercevoir une lumière dans le lointain)

loisible *a.* អាចនឹង (ឧ. il vous est loisible de partir)

loisir *n.m.* ពេលសំរែ; ពេលគ្រប់គ្រាន់ (ឧ. j'ai tout le loisir de répondre) ។ à loisir *loc. adv.* ដោយមិនប្រញាប់

lombago *n.m.* ម.ព. lumbago

lombaire *a.* នៃចង្កេះ (ឧ. région lombaire)

lombalgie *n.f.* រោគចុកចង្កេះ

lombes *n.m. pl.* ចង្កេះ (ផ្នែកខាងក្រោយពោះ)

lombric *n.m.* ជន្លេន

lombricoïde *a.* ដូចជន្លេន (ឧ. ver lombricoïde)

londonien,enne *a.* នៃក្រុងឡុងដ្រ៏ ។ *n.* ជននៅក្រុងឡុងដ្រ៏

long,longue *a.* វែង (ឧ. un pont long de cent mètres); យូរ (ឧ. un long voyage); វែង (ឧ. un discours long); យឺត (ឧ. il est long à comprendre) ។ *n.m.* បណ្ដោយ, ប្រវែង (ឧ. une table de deux mètres de long) ។ tomber de tout son long ដួលទាំងដំហរ ។

Adv. en savoir long ចេះឬដឹងច្រើន; ចេះល្បិចច្រើន ។

Loc. adv. au long ឬ tout du long ចប់ចុងចប់ដើម (ឧ. raconter au long, ce qu'on a vu) ។ à la longue យូរៗទៅ (ឧ. tout s'use à la longue) ។ de long en large គ្រប់ទិស ។ le long de តាមបណ្ដោយ (ឧ. le long de la rivière)

longanimité *n.f.* ភាពចិត្តធ្ងន់

longanier *n.m.* ដើមមៀន

long-courrier *a.&n.m.* ដែលដើរផ្លូវឆ្ងាយ (ឧ. paquebot long-courrier) (*pl.* des longs-courriers)

longe *n.f.* ខ្សែបង្ហៀរសេះ; ខ្សែបន្លាយ

longer *v.t.* ដើរបណ្ដោយ; សៀរតាម (ឧ. longer la rivière); នៅបណ្ដោយ (ឧ. le bois longe la côte)

longévité *n.f.* ទីឃាយុភាព, អាយុវែង

longimétrie *n.f.* វិធីវាស់ចម្ងាយ

longitude *n.f.* អាយាមន្តរ (រយៈបណ្ដោយ) (ម.ព. méridien, latitude, bureau ផង)

longitudinal,e,aux *a.* អាយាមិក, បណ្ដោយ (ឧ. fibres longitudinales)

longitudinalement *adv.* តាមបណ្ដោយ (ឧ. fendre longitudinalement un tronc d'arbre)

longtemps *adv.* យូរ (ឧ. attendre longtemps)

longuement *adv.* យ៉ាងយូរ(ឧ.parler longuement);ដោយហ្មត់ចត់

longuet,ette *a.Fam.* យូរបន្តិច; វែងបន្តិច (ឧ. discours longuet) ។ *n.m.* នំប៉័ងតូចវែង

longueur *n.f.* បណ្ដោយ; ប្រវែង; រយៈពេល (ឧ. longueur des jours et des nuits) ។ *Fig.* ការពន្យារ ឬ យូរ (ឧ. l'affaire traîne en longueur); ការវែង (ឧ.des longueurs dans un ouvrage)។ **en longueur** តាមបណ្ដោយ។ tirer en longueur ធ្វើឲ្យយឺតយូរ, មានរយៈពេលយូរ (ឧ procès qui tire en longueur) ។ longueur d'onde ប្រវែងរលកធាតុអាកាស

longue-vue *n.f.* កែវយឹត (*pl.* des longues-vues)

looping *n.m.* *Aéron.* ការហោះផ្កាប់ផ្ងារ

lopin *n.m.* ដុំ, ភាគ (ដី)

loquace *a.* ដែលនិយាយច្រើន

loquacité *n.f.* ការនិយាយច្រើន; ទំលាប់និយាយច្រើន (ឧ. loquacité féminine)

loque *n.f.* ចំរៀកសំពត់ (ឧ.un vêtement qui tombe en loques)។ *Fig.* មនុស្សទន់ខ្សោយ

loquet *n.m.* ខ្នុកទ្វារ

loqueteau *n.m.* ខ្នុកតូច

loqueteux, euse *a.* ដែលស្លៀកពាក់រយីករយាក (ឧ. un mendiant loqueteux)

lord *n.m.* ល័រដ៍ ។ premier lord de l'Amirauté រដ្ឋមន្ត្រីកងនាវាអង់គ្លេស ។ premier lord de la mer នាយសេនាធិការកងនាវាអង់គ្លេស

lord-maire *n.m.* ចៅហ្វាយក្រុងឡុងដ្រ៍ (*pl.* des lords-maires)

lordose *n.f.* ភាពខ្នងផែនសើ

lorgner *n.m.* មើលចុងភ្នែក, ឆ្លុះកែវយឹត (ឧ. lorgner le public) ។ *Fig.* & *fam.* ប៉ងប្រាថ្នាដោយស្ងាត់កំបាំង (ឧ. lorguer une place)

lorgnette *n.f.* កែវយឹតតូច ។ *Fig.* regarder par le petit bout de la lorgnette មើលឃើញវត្ថុធំៗ (ធំជាងពិត) ។ regarder par le gros bout de la lorgnette មើលឃើញរបស់តូចៗ(តូចជាងពិត) (*ill.* jumelles)

lorgneur,euse *n.Fam.* អ្នកមើលចុងភ្នែក

lorgno *n.m.* វ៉ែនតាក្ដៀបក្ដោងច្រមុះ (ហៅ binocle ក៏បាន)

lorrain,e *a.&n.* នៃខេត្តឡូរ៉ែន

lorry *n.m.* *Ch. de f.* ឡូរី (កូនទូអយ-ស្ម័យយានដឹកប្រដាប់ធ្វើនឹងថែទាំផ្លូវ)

lors *adv.* កាលនោះ ។ pour lors *loc. adv.* ដូច្នេះ។ dès lors *loc. adv.* តាំងពីនោះមក, ដោយហេតុនោះ (ឧ. dès lors il me prit en amitié) ។ dès lors que *loc. adv.* ដោយហេតុថា ។ lors de *loc pré.* ក្នុងពេល, ក្នុងឱកាស (ឧ. lors de son mariage)។ lors même que *loc. pré.* ថ្វីបើ, ទោះជា (ឧ. cela sera ainsi, lors même que vous ne le voudriez pas)

lorsque *conj.* កាល, កាលដែល, កាលបើ, នាកាល

losange *n.m.* ចតុរស្ស, ផ្ទៃបួនជ្រុងញាយស្មើ

lot *n.m.* ឡូ, ចំណែក (ឧ. distribuer des lots); រង្វាន់ឆ្នោត (ឧ. le gros lot) ។ *Fig.* វាសនា (ឧ. la richesse est son lot)

loterie *n.f.* ឆ្នោត ។ loterie nationale ឆ្នោតជាតិ ។ *Fig.* របស់មិនទៀង(ព្រោះសម្រេចនៅលើវាសនា) (ឧ. les biens de ce monde sont une véritable loterie)

loti,e *a.* ដែលចែក, ដែលបានទទួលការអនុគ្រោះ (ឧ.être bien, mal loti dans un partage)

lotion *n.f.* ការលាង, ការស្រប់ ។ *Par ext.* ទឹកសម្រាប់លាង

lotionner *v.t.* លាង

lotir *v.t.* ចែកជាឡូ (ឧ. lotir un terrain pour le vendre); ឲ្យ

ជាចំណែក

lotissement *n.m.* ការចែកជាឡូ ; ដីដែលចែកជាឡូ

loto *n.m.* ល្បែងឡូតូ

lotus ឬ **lotos** *n.m.* ឈូក

louable *a.* គួរសរសើរ

louage *n.m.* ការជួល; ប្រាក់ឈ្នួល

louange *n.f.* ការសរសើរ (ឧ. dire quelque chose à la louange de quelqu'un); ពាក្យសរសើរ (ឧ. combler de louanges)

louanger *v.t.* សរសើរ

louangeur,euse *a.* ដែលសរសើរ (ឧ. poésie louangeuse) ។ *n.* អ្នកចូលចិត្តសរសើរ

louche *a.* ស្រលៀង (ភ្នែក) (ឧ. enfant louche); ល្អក់, ស្រអាប់ (មិនសូវមានស្នើ) (ចំពោះពណ៌, ទឹក ។ល។) (ឧ. couleur louche; perle louche) ។ *Fig.* គួរមន្ទិល, គួរសង្ស័យ (ឧ. conduite louche)។ *n.m.* អ្វីដែលគួរឲ្យមន្ទិល(ឧ. il y a du louche dans cette affaire)

louche *n.f.* វែក, ចោយ (វែកត្រឡោក)

louchement *n.m.* ការធ្វើភ្នែកស្រលៀង (ក្នុងន័យនេះជា loucherie ក៏បាន); ការឡើងល្អក់ (ទឹក) (ក្នុងន័យនេះជា louchissement ក៏បាន)

loucher *v.i.* មានភ្នែកស្រលៀង ។ *Fig.&Fam.* សំឡឹងចង់បាន (ឧ. loucher sur quelque chose)

louchet *n.m.* ចបជីកម្យ៉ាង

loucheur,euse *n.* មនុស្សភ្នែកស្រលៀង

louchon *n.m.* ក្មេងភ្នែកស្រលៀង

louer *v.t.* សរសើរ (ឧ. louer un poète) ។ se louer *v.pr.* se louer de សប្បាយនឹងខ្លួនឯងដោយ (ឧ. n'avoir qu'à se louer de quelqu'un)

louer *v.t.* ជួល (ឧ. louer une maison, un garçon de ferme)

loufoque *a.&.n.m. Pop.* ឆ្កួត, ចំកួត

loufoquerie *n.f. Pop.* អំពើ ឬ សំដីឆ្កួត

louis *n.m.* លួី (រូបិយវត្ថុបុរាណបារាំង)

loulou *n.m.* ឆ្កែម្យ៉ាងមាឌតូចរោមវែង

loup *n.m.* វៃសុនខ [វៃ-ន: សុ-ណក់], ឆ្កែព្រៃ (cri: le loup hurle) ។ loup de mer *Fig.* ពលទាហានទឹកជើងចាស់ ។ *Fig.*

marcher à pas de loup ដើរលបៗ ។ hurler avec le loup ចូលស្ទឹងតាមបត់ (គឺធ្វើតាមគេតាមឯង) ។ entre chien et loup ពេលព្រលប់ ។ être connu comme le loup blanc មានគេស្គាល់គ្រប់គ្នា ។ froid de loup រងាខ្លាំងណាស់ ។

Prov. les loups ne se mangent pas entre eux ពាលច្រើនតែយោគយល់ពាលដូចគ្នា

loup-cervier *n.m.* ស្វាន ។ *Fig.* នាយទុនលោភលន់(*pl.* des loups-cerviers)

loupe *n.f.* ពក (ពកសាច់ ឬ ពកឈើ); កែវហើម

louper *v.i. Pop.* មិនចូលចិត្តធ្វើការ; ធ្វើការខ្ជីខ្ជា; ទៅមិនទាន់, ខក (ឧ. louper un train)

loupiot *n.m. Pop.* ក្មេង

lourd,e *a.* ធ្ងន់ (ឧ. lourd fardeau) ។ *Fig.* ធ្ងន់, ពិបាក (ឧ. lourde tâche); ធ្ងន់(ឧ.lourde faute); មិនសូវរហ័សវៃ (ឧ. esprit lourd); ឆ្គង (ឧ. plaisanterie lourde) ។ temps lourd អាកាសអួអាប់ ។ aliment lourd អាហាររឹង (ក្រលាយ)

lourdaud,e *n.&a. Fig.* មនុស្សឆ្គង

lourdement *adv.* យ៉ាងធ្ងន់ (ឧ. tomber lourdement sur le sol) ។ *Fig.* se tromper lourdement ច្រឡំយ៉ាងធ្ងន់

lourdeur *n.f.* ភាពធ្ងន់ (ឧ. la lourdeur d'un fardeau) ។ *Fig.* ភាពមិនសូវរហ័សវៃ (ឧ. la lourdeur de l'esprit)

loustic *n.m. Fam.* មនុស្សកំប្លែង

loutre *n.f.* ភេ

louve *n.f.* នេសុនខី [រ:-ន:-សុ:-ណក់-ខី]. ឆ្កែព្រៃញី; ចិងជងគ្រី

louvetau *n.m.* កូនឆ្កែព្រៃ; កាយរឹទ្ធិក្មេង

louveter *v.i.* កើតកូន (ចំពោះឆ្កែព្រៃ)

louveterie *n.f.* ការបាញ់ឆ្កែព្រៃ

louvoiement *n.m.* ការបើកទារ (ក្ដោង); ការភេង

louvoyer *v.i. Mar.* បើកទារ (ក្ដោង)។ *Fig.* ដើរភេង

lover *v.t. Mar.* ញាយ (ឧ. lover un câble) ។ se lover *v.pr.* ពេន (ឧ. le serpent se love pour s'élancer)

loyal,e,aux *a.* ស្មោះត្រង់, ភក្តី (ឧ. un homme loyal; une conduite loyale)

loyalement *adv.* ដោយស្មោះត្រង់

loyalisme *n.m.* នីតិភក្តីភាព, ភក្តីភាពចំពោះរដ្ឋាភិបាល

loyaliste *a.&n.* នីតិភក្តី, ភក្តីចំពោះរដ្ឋាភិបាល

loyauté *n.f.* ភក្តីភាព, សេចក្តីស្មោះត្រង់

loyer *n.m.* ប្រាក់ឈ្នួលផ្ទះ ឬ ដី (ឧ. payer un loyer élevé); ពេលត្រូវបង់ប្រាក់ឈ្នួល ។ loyer de l'argent ការប្រាក់

lubie *n.f.Fam.* បំណងចម្លែក

lubricité *n.f.* ដំណើរងប់នឹងកាមគុណ

lubrifiant,e *a.* ដែលធ្វើឱ្យរអិល(ដើម្បីឱ្យម៉ាស៊ីនដើរបានស្រួល) ។ *n.m.* ប្រេងម៉ាស៊ីន

lubrification *n.f.* ការដាក់ប្រេងម៉ាស៊ីន

lubrifier *v.t.* ដាក់ប្រេងម៉ាស៊ីន

lubrique *a.* ងប់នឹងកាមគុណ

lubriquement *adv.* ដោយងប់នឹងកាមគុណ

lucarne *n.m.* សត្វកញ្ចៀ

lucarne *n.f.* បង្អួចដំបូល

lucide *a.* ឈ្លាសវៃ (ឧ. esprit lucide) ។ intervalle lucide ពេលដឹងខ្លួនត្រូវម្តងៗ(ចំពោះមនុស្សឆ្កួត)

lucidement *adv.* ដោយឈ្លាសវៃ

lucidité *n.f.* សេចក្តីឈ្លាសវៃ

lucifuge *a.* ដែលខ្លាចពន្លឺ, ដែលជៀសពន្លឺ

lucilie *n.f.* រុយខៀវ, រុយចង្រៃ

lucimètre *n.m.* រង្វាស់ពន្លឺ, ប្រដាប់វាស់ពន្លឺ

luciole *n.f.* អំពិលអំពែកម្យ៉ាង

lucratif,ive *a.* រកកម្រៃ, ដែលឱ្យកម្រៃច្រើន (ឧ. emploi lucratif)

lucrativement *adv.* ដោយឱ្យកម្រៃច្រើន

lucre *n.m.* កម្រៃ (ឧ. l'amour du lucre)

luette *n.f.* កន្ទើត(ឧ. en touchant la luette, on provoque le vomissement ou la nausée)

lueur *n.f.* មន្ទប្រភា, ពន្លឺព្រឹមៗ (ឧ. les premières lueurs de l'aube)។ *Fig.* ដំណើរមានតែមួយភ្លែត (ឧ. une lueur de raison)

luge *n.f.* លុហ្សឺ, កូនរទេះរអិលលើទឹកកក

luger *v.i.* ជិះលុហ្សឺ (ជិះកូនរទេះរអិលលើទឹកកក)

lugeur,euse *n.* អ្នកកីឡាជិះលុយហ្ស

lugubre *a.* ស្រពាប់ស្រពោន(ឧ. mine lugubre); គួរអាណោចអាធ័ម (ឧ. des plaintes lugubres)

lugubrement *adv.* ដោយស្រពាប់-ស្រពោន; ដោយអាណោចអាធ័ម

lui *pr. per.* លោក,គាត់,វា; ដល់លោក, ដល់គាត់, ដល់វា

luire *v.i.* បញ្ចេញពន្លឺ , ប៉ភ្លឺ (ឧ. le soleil luit) ; ឆ្លុះពន្លឺ (ឧ. arme qui luit) ។ *Fig.* un espoir luit មានសង្ឃឹមបន្តិច

luisance *n.f.* ភាពភ្លឺ

luisant,e *a.* ដែលបញ្ចេញពន្លឺ, ភ្លឺ ។ vers luisant អំពិលអំពែក

lumbago *n.m.* ជម្ងឺពុកចង្កេះ

lumière *n.f.* រស្មី, ពន្លឺ; ទៀន, ចង្កៀង; រន្ធអុជឆ្នួនកាំភ្លើងធំ ។ *Fig.* រស្មីឬពន្លឺ (ឧ. la lumière de la raison); វិជ្ជា, តម្រិះ (ឧ. ses lumières sont petites) ។ អ្នកប្រាជ្ញដ៏ឆ្នើម (ឧ. c'est la lumière de son siècle) ; voir la lumière កើត(ឃើញពន្លឺព្រះអាទិត្យ)។ perdre la lumière ខ្វាក់ ។ mettre en lumière ផ្សាយ; ឲ្យការណ៍

lumignon *n.m.* ប្រឆេះទៀនឆេះ;កន្ទុយទៀន; ពន្លឺតិច

luminaire *n.f.* ប្រទីបភ្លាណ (ទៀនចង្កៀង ឬ គោមអុជពេលបុណ្យ) (ឧ. l'éclat du luminaire)

luminescence *n.f.* ដំណើរបញ្ចេញពន្លឺត្រជាក់ (ឧ. la fluorescence et la phosphorescence sont des cas particuliers de luminescence)

luminescent,e *a.* ដែលបញ្ចេញពន្លឺត្រជាក់

lumineusement *adv.* ដោយភ្លឺ

lumineux,euse *a.* ដែលមានពន្លឺ, ដែលប៉ភ្លឺ (ឧ.corps lumineux)។ *Fig.* ច្បាស់, ពិតណាស់ (ឧ. idée lumineuse)

luminosité *n.f.* រស្មីភាព, ភាពមានពន្លឺ

lunaire *a.* នៃព្រះចន្ទ; ដូចព្រះចន្ទ; ចន្ទគតិ (ឧ. mois lunaire)

lunaison *n.f.Astr.* ខែចន្ទគតិ(ចន្លោះពេលពីខ្នើតមួយ ទៅខ្នើតមួយ)

lunatique *a.&n.* ដែលមានគតិមិនទៀង

lunch *n.m.* អាហារព្រឹក; ការលៀងនំ

luncher *v.i.* លៀងនំ

lundi *n.m.* ថ្ងៃចន្ទ

lune *n.f.Astr.* ព្រះចន្ទ ។ មុខមូលដូចព្រះចន្ទ ។ *Fig.* être dans sa bonne lune កំពុងតែស្រួលចិត្ត។ être dans sa mauvaise lune កំពុងតែមិនស្រួលចិត្ត ។ clair de lune ខែភ្លឺ (ពន្លឺព្រះចន្ទ)។ lune de miel ពេលទើបនឹងរៀបអាពាហ៍ពិពាហ៍ហើយ ។ lune d'eau ល្ពក ស ។ *Fig.* vouloir la lune ចង់បានរបស់ហួសវិស័យ ។ demander la lune ទាររបស់ហួសវិស័យ ។ promettre la lune សន្យារបស់ហួសវិស័យ ។ faire un trou à la lune រត់ (គេចខ្លួនមិនសងបំណុល)។ être dans la lune កំពុងភាំង (មានអារម្មណ៍អណ្តែតអណ្តូង)

luné,e *a.* ជាកងអឌ្ឍចន្ទ ។ *Fam.* être bien luné កំពុងតែមានអារម្មណ៍ល្អ ។ être mal luné កំពុងតែមានអារម្មណ៍មិនល្អ

lunetier,ère *a.* នៃការធ្វើវ៉ែនតា (ឧ. industrie lunetière) ។ *n.m.* អ្នកធ្វើឬឈ្មួញវ៉ែនតា

lunette *n.f.* កែវឆ្លុះ ។ lunettes astronomique កែវយឹតតារាសាស្ត្រ ។ lunette d'approche ឬ longue vue កែវយឹត។ *Fig.* regarder par le gros bout de la lunette មើលឃើញរបស់តូចៗ (តូចជាងពិត) ។ *pl.* វ៉ែនតា (រ.ស. ស្នូងព្រះនេត្រ) ។ serpent à lunettes ម. ព. serpent ។ ពោងក្លែកសេះ

lunetterie *n.f.* ជំនួញវ៉ែនតា

lunettier *n.m.* ម.ព. lunetier

luneviller *v.t.* ប៉ាក់និន

luni-solaire *a. Astr.* ចន្ទគតិនឹងសុរិយគតិ, នៃព្រះចន្ទនឹងព្រះអាទិត្យ ។ année luni-solaire ឆ្នាំចន្ទគតិនឹងសុរិយគតិ

lunule *n.f.* បណ្តូលក្រចក

lupanar *n.m.* ពេស្យដ្ឋាន (បនស់និង)

lurette *n.f.* il y a belle lurette យូរណាស់មកហើយ

luron,onne *n.Fam.* មនុស្សកាយបើកិត (មនុស្សមិនទេះព្រួយ); ស្ត្រីមិនខេះខ្មាច

lustrage *n.m.* ការខាត់ឲ្យភ្លឺ ; ភាពភ្លឺ (រលោង)

lustral,e,aux *a.* នៃលជម្រះ (ឲ្យបរិសុទ្ធ)។ eau lustrale ទឹកមន្ត

lustre *n.m.* ពន្លឺ; ភាពរលោង (ឧ. le lustre du vernis) ; ជើងទៀន

មានសាខាច្រើន ។ *Fig.* មុខមាត់ (កេរ្តិ៍ឈ្មោះដោយសំអាងដោយសមត្ថភាព ។ល។)(ឧ. cette fonction lui donne un certain lustre)

lustre *n.m.* រយៈពេល ៥ ឆ្នាំ

lustré,e *a.* រលោង (ព្រោះប្រើប្រាស់ ឬ ព្រោះកកិតគ្នា) (ឧ un veston lustré)

lustrer *v.t.* ខាត់ឲ្យភ្លឺរលោង

lustrerie *n.f.* កន្លែងធ្វើចង្កៀង

luth *n.m.* ពិណម្យ៉ាង ។ *Zool.* អណ្តើកសមុទ្រម្យ៉ាង

luthéranisme *n.m.* លុទែរនិយម (លទ្ធិរបស់លុទែរ)

lutherie *n.f.* ការធ្វើគ្រឿងភ្លេងខ្សែ

luthérien,enne *n.* អ្នកកាន់លទ្ធិលុទែរ។ *a.* លុទែរនិយម (ឧ. religion luthérienne)

luthier *n.m.* អ្នកធ្វើគ្រឿងភ្លេងខ្សែ

lutin *n.m.* បិសាច, ព្រេញគង្វាល ។ *Par anal.* ក្មេងប៉ប៉ិលប៉ប៉ូច

lutin,e *a.* កំរើក, ប៉ប៉ិលប៉ប៉ូច(ឧ. figure lutine)

lutiner *v.t.* ជិទ្ធជិទ្ធេញ

lutte *n.f.* ចំបាប់ ។ *Fig.* ការប្រយុទ្ធ (ឧ. entrer en lutte avec quelqu'un); ចំបាំង (ឧ. luttes politiques); ការប្រឆាំងគ្នា (ឧ. la lutte du devoir contre la passion)។ lutte de classes ការប្រឆាំងវណ្ណៈ ។ de haute lutte ដោយប្រើកំឡាំង ឬ ប្រើអំណាច

lutter *v.i.* ចំបាប់គ្នា ។ *Par ext.* ប្រយុទ្ធ ។ *Fig.* ប្រឆាំង, ពុះពារ (ឧ. lutter contre la tempête)

lutteur,euse *n.* អ្នកលេងចំបាប់; អ្នកប្រយុទ្ធ

luxation *n.f.* ដំណើរភ្លាត់ឆ្អឹង

luxe *n.m.* ប្រណិតភាព (ឧ. le luxe de la table) ។ *Fig.* ភាពបរិបូណ៌ (ឧ.un grand luxe de précautions)

luxer *v.t.* ធ្វើឲ្យភ្លាត់ឆ្អឹង

luxueusement *adv.* ដោយប្រណិត, យ៉ាងឆើតឆាយ

luxueux,euse *a.* ប្រណិត, ឆើតឆាយ (ឧ. ameublement luxueux)

luxure *n.f.* កាមមុច្ឆា,ដំណើរងប់ក្នុងកាម

luxuriance *n.f.* ភាពគ្រសុំគ្រសាយ

luxuriant,e *a.* គ្រសុំគ្រសាយ (ឧ. végétation luxuriante)

luxurieux,euse *a.* ដែលងប់នឹងកាមគុណ (*tt.* lascif, sensuel, voluptueux)

lycanthrope *n.m.* មនុស្សឆ្កួតដែលថាខ្លួនជាឆ្កែព្រៃ

lycanthropie *n.f.* រោគឆ្កួតដែលអ្នកជម្ងឺថាខ្លួនឯងជាឆ្កែព្រៃ

lycée *n.m.* វិទ្យាល័យ

lycéen,enne *n.* សិស្សវិទ្យាល័យ

lycopode *n.f. Bot.* លីកូពាទ

lycopodinées *n.m.pl.* លីកូពាទជាតិ

lymphatique *a.* នៃលសិកា

lymphe *n.m.* លសិកា (ធាតុទឹកពណ៌លឿង ឬ ឥតពណ៌ដែលជ្រាបចេញពីឈាម)

lynchage *n.m.* ប្រជាទណ្ឌ, ការដាក់ទោសដោយមហាជន

lyncher *v.t. Par ext.* ធ្វើប្រជាទណ្ឌ

lyonnais,e *a.&n.* នៃក្រុងលីយ៉ុង

lyre *n.f.* ពិណបុរាណ ។ *Fig.* ទេពកោសល្យខាងកវីនិពន្ធ

lyrique *a.* នៃសិល្បៈខាងកវីនិពន្ធ; ដែលធ្វើឲ្យអណ្ដែតអណ្ដូងឬឲ្យរំភើបចិត្ត

lyrisme *n.m.* សំដីដែលធ្វើឲ្យអណ្ដែតអណ្ដូង ឬ ឲ្យរំភើបចិត្ត

lys *n.m.* ម.ព. lis



MAISON FLOTTANTE
ព្រះរាជនិវាសន៍ជល

m *n.m.* អក្សរទី ១៣នៃអក្ខរក្រមឡាតាំង។ M (លេខរ៉ូម៉ាំង)មួយពាន់។ *m.* (ពាក្យបំព្រួញនៃ mètre) ម.(ម៉ែត្រ)។ M. (ពាក្យបំព្រួញនៃ Monsieur)លោក

ma *pr. pers. f.* របស់ខ្ញុំ, របស់អញ

maboul,e *a.&n.Pop.* ឆ្កួត

maboulisme *n.m.Pop.* កេតឆ្កួត

macabre *a.* នៃខ្មោច; ដែលធ្វើឲ្យព្រឺយខ្លាំង (ឧ. plaisanterie macabre)

macadam *n.m.* ថ្មក្រាល (ថ្មដែលគេកិនក្រាលផ្លូវ)

macadamisage *n.m.* ឬ **macadamisation** *n.f.* ការកិនថ្ម(ក្រាលផ្លូវ)

macadamiser *v.t.* កិនថ្មក្រាលផ្លូវ

macaque *n.m.* ស្វាខាវ។ *Fig.*មនុស្សរូបអាក្រក់

macaron *n.m.* នំកឹង

macaroni *n.m.* ម៉ាការ៉ូនី

macchabée *n.m. Pop.* សាកសព, ខ្មោច

macédonien,enne *a.&n.*នៃប្រទេសម៉ាសេដ្វាន

macérateur *a.m.* ដែលត្រាំ

macération *n.f.* ការត្រាំ(ឲ្យចេញជាតិដែលរលាយ)។ *pl.Fig.* ការដាក់ទណ្ឌកម្មខ្លួនឯង (មានការធ្វើបាបខ្លួនឯង, ការអត់បាយ, ការកាន់វត្តប្រតិបត្តិតឹងរ៉ឹង។ល។ ដើម្បីលុបលាងទោស)

macérer *v.t.* ត្រាំ (ឧ.macérer des roses dans l'alcool); ធ្វើទោសខ្លួនឯង (ខាងផ្លូវសាសនា)(ឧ. macérer sa chair par le jeûne)

mâchefer *n.m.* អាចម៍ដែក

mâchelier,ère *a.* សម្រាប់ទំពា ។ *n.f.* ថ្គាម

mâchement *n.m.* ការទំពា; ការខាំធ្មេញ

mâcher *v.t.* ទំពា; កាត់មិនដាច់ត្រឹមស្អាត (ចំពោះប្រដាប់កាត់) (ឧ. outil qui mâche le bois) ។ *Fig.* mâcher la besogne à quelqu'un រៀបចំការងារឲ្យ ។ mâcher les mots en parlant និយាយខាំធ្មេញ ។ ne pas mâcher ses mots មាត់ឆៅ, និយាយមិនញញើតមាត់

machiavélique [-kya-] *a.* នៃម៉ាគីយ៉ាវែល (ឧ. politique machiavélique) ។ *Fig.* វៀចវេរ, គ្មានអាសង្កា (ឧ. habileté machiavélique)

machiavélisme [-kya-vé-lism'] *n.m.* ម៉ាគីយ៉ាវែលនិយម, របៀបនយោបាយនៃម៉ាគីយ៉ាវែល(នយោបាយប្រកបដោយកលល្បិចគ្រប់យ៉ាង ដើម្បីសម្រេចផលប្រយោជន៍) ។ *Fig.* សេចក្ដីវៀចវេរ

machin,e *n. Pop.* ស្អីនោះ

machinal,e,aux *a.* ដែលធ្វើដោយគ្មានគិត

machinalement *adv.* ដោយគ្មានគិត (ឧ. secouer machinalement sa tête)

machinateur *n.m.* អ្នកប្រើឧបាយទុច្ចរិត

machination *n.f.* កូដិប្រព័ន្ធ, ឧបាយទុច្ចរិត

machine *n.f.* ម៉ាស៊ីន; ប្រដាប់គ្រឿងយន្ត; ប្រជុំអាការៈដាក់កាយ(មនុស្ស, សត្វ) ។ *Fig.* មនុស្សដែលចាំតែស្ដាប់បង្គាប់គេ ។ machine à vapeur ម៉ាស៊ីនប្រើចំហាយទឹក ។ machine à écrire ម៉ាស៊ីនអង្គុលីលេខ ។ faire machine arrière ថយថយ

machine-outil *n.f.* ម៉ាស៊ីនឧបករណ៍ (ម៉ាស៊ីនលើកដាក់ឧបករណ៍ជំនួសមនុស្ស) (*pl.* des machines-outils)

machiner *v.t.* ល្បួចគិត (ឧ. machiner une trahison)

machinerie *n.f.* យន្តការ; យន្តសាពេន, គ្រឿងយន្តទាំងឡាយ; កន្លែងដាក់ម៉ាស៊ីន

machinisme *n.m.* យន្តវិជ្ជា; ការរៀបចំគ្រឿងយន្ត; យន្តនិយម, ការប្រើម៉ាស៊ីន

(ឧ. le machinisme a transformé l'industrie moderne) ។ *Fig.* ម៉ាស៊ីន (អង្គការដែលប្រព្រឹត្តទៅដូចគ្រឿងយន្ត); ការងារដែលធ្វើដោយគ្មានគិត ។ *Philos.* យន្តនិយម(លទ្ធិយល់ថាសត្វជាម៉ាស៊ីន) (ឧ. Descartes a défendu le machinisme)

machiniste *n.m.* យន្តការី

mâchoire *n.f.* ឆ្អឹងថ្គាម; ដែកឆ្កាប់ ។ jouer ឬ travailler des mâchoires បរិភោគ

mâchonnement *n.m.* ការអង្កៀម

mâchonner *v.t.* អង្កៀម (ឧ. mâchonner une cigare) ។ *Fig.* និយាយមិនច្បាស់ (ឧ. mâchonner des injures)

mâchurer *v.t.* ប្រឡាក់ពណ៌ខ្មៅ, ហែកកំទេច (ឧ. mâchurer son mouchoir)

maclage *n.m.* ការកូរកែវក្នុងឡ

macle *n.f.* ដើមក្រចាប់

macler *v.t.* កូរកែវក្នុងឡ

mâcon *n.m.* ម៉ាកុង(ស្រាទំពាំងបាយជូរធ្វើនៅម៉ាកុង) (ឧ. une bouteille de mâcon)

maçon *n.m.* ជាងបាយអ (ជួនកាលគេហៅសំដៅទៅ franc-maçon)

maçon,onne *a.* ដែលចេះធ្វើសំបុកដោយដី-ក្រួស ។ល។ (ឧ. abeille maçonne)

maçonnage *n.m.* ការងារជាងបាយអ

maçonner *v.t.* សង់ឬជួសជុលដោយឥដ្ឋបាយអ (ឧ. maçonner une fenêtre)

maçonnerie *n.f.* សំណង់បាយអ; ផ្ទះថ្ម (ជួនកាលគេប្រើជាពាក្យបំប្រួញនៃ franc-maçonnerie)

maçonnique *a.* នៃសមាគមហ្វ្រង់ម៉ាសុង

macre ឬ **macle** *n.f.* ម.ព. macle

macrocéphale *a.* ដែលមានក្បាលធំ

macropode *n.m.&a.* ដែលមានជើងក្រោយឬទងវែងៗ; ត្រីក្រឹមក្រោយវែង

maculage *n.m.* ឬ **maculation** *n.f.* ការប្រឡាក់; ភាពប្រឡាក់

maculature *n.f.* ក្រដាសពោះពុម្ពខូច

macule *n.f.* មន្ទិល, ភាពប្រឡាក់ (ឧ. papier couvert de macule)

maculer *v.t.* *Arts graph.* លាបខ្មៅ ។ *Par ext.* ធ្វើឲ្យប្រឡាក់ ។ *v.i.* ប្រឡាក់ (ឧ. ce papier macule)

madame (Mme) *n.f.* ស្ត្រីដែលមានប្ដីហើយ; អ្នកស្រី, លោកស្រី។ *Fam.* jouer à la madame វាយឫកជាលោកស្រី (*pl.* mesdames)

madécasse *a.&n.* នៃម៉ាដាហ្គាស្ការ(ឧ. la population madécasse) (ជា malgache ក៏បាន)

mademoiselle (Mlle) *n.f.* ស្ត្រីក្រមុំ, នាងកញ្ញា(*pl.* mesdemoiselles)

madère *n.m.* ស្រាទំពាំងបាយជូរកោះម៉ាឌែរ

madone *n.f.* រូបសំណាកមាតាព្រះយេស៊ូ ។ la Madone មាតាព្រះយេស៊ូ

madre *n.m.* ឈើម្យ៉ាងសាច់ឡាយ

madré,e *a.* ឡាយ; ដែលមានកលល្បិច (ឧ. c'est un madré compère)

madrier *n.m.* ក្ដារក្រាស់វែង

madrigal *n.m.* កំណាព្យទំនើសស្នេហា (ឧ. débiter des madrigaux)

madrilène *a.&n.* នៃក្រុងម៉ាឌ្រីដ

madrure *n.f.* ក្រឡាកន្លាញ់(សាច់ឈើ); បង្គង់ (រោមសត្វ)

maestria *n.f. Par ext.* ការធ្វើបានសម្រេចដោយរហ័សនឹងដោយប្រសប់

maestro *n.m.* គ្រូភ្លេងល្បីល្បាញ (*pl.* des maestros)

maffia ឬ **mafia** *n.f.* ម៉ាហ្វីយ៉ា (សមាគមសម្ងាត់នៃមនុស្សខូច)

mafflu,e *a.& n. Fam.* ដែលមានថ្ពាល់ធំៗ

magasin *n.m.* អគ្គស្រូវ,ភណ្ឌាគារ,ឃ្លាំង (ឧ. magasin à blé); ហាង (ឧ. magasin d'épicerie)។ magasin général ឃ្លាំងទូទៅ(ឃ្លាំងដែលអ្នកជំនួញទាំងឡាយផ្ញើទំនិញទុក)

magasinage *n.m.* ការដាក់ក្នុងឃ្លាំង; ការបិទនៅក្នុងឃ្លាំង; ពន្ធឃ្លាំង

magasinier *n.m.* ឆ្មាំឃ្លាំង

magazine *n.m.* ទស្សនាវដ្ដីរូបភាព

mage *n.m.* អ្នកបួសជាតិប៉ែរ ឬ ជាតិខែល្ប; ហោរ

magicien,enne *n.* គ្រូមន្តអាគម ។ *Par ext.* អ្នកធ្វើអ្វីៗដ៏ប្លែកអស្ចារ្យ (ឧ. ce musicien est un vrai magicien)

magie *n.f.* មន្តអាគម។ magie noire ការហៅខ្មោចបិសាច។ *Fig.* ផលប្លែកអស្ចារ្យ; កម្លាំងនៃការទាក់ចិត្ត (ឧ. la magie des mots)

magique *a.* នៃមន្តអាគម; ទិព្វ (ឧ. pouvoir magique) ។ *Fig.* អស្ចារ្យ(ឧ. spectacle magique)។

formules magiques); មន្តអាគម ។ signes magiques យ័ន្ត

magiquement *adv.* ដោយមន្តអាគម; ដោយអស្ចារ្យ

magister *n.m.* គ្រូបង្រៀន (ក្នុងបុរាណកាល) ។ *Fam.* មនុស្សអួតចំណេះ (ឧ. faire le magister) (*pl.* des magisters)

magistère *n.m.* *Alch.* ធាតុផ្សំម្យ៉ាងមានអានុភាពអស្ចារ្យ ។ *Fig.* អំណាចគ្រប់យ៉ាង (ឧ. exercer un magistère)

magistral,e,aux *a.* នៃគ្រូ; ដាច់ខាត, ម៉ឺងម៉ាត់ (ឧ. ton magistral); ប្រសើរអស្ចារ្យ (ឧ. une œuvre magistrale)

magistralement *adv.* ដោយដាច់ខាត, ដោយម៉ឺងម៉ាត់ (ឧ. parler magistralement)

magistrat *n.m.* អ្នកកាន់អំណាចតុលាការ (ចៅក្រម) - អំណាចរដ្ឋបាល (ចៅហ្វាយក្រុង, ចៅហ្វាយខេត្ត។ល។) ឬអំណាចនយោបាយ (ប្រធានាធិបតី, រដ្ឋមន្ត្រី។ល។) (ឧ. les commissaires de police, les consuls, les conseillers d'état, les conseillers à la cour des comptes, etc ... sont des magistrats de l'ordre juridictionnel et de l'ordre administratif)

magistrature *n.f.* ស័ក្តិយសឬមុខងារនៃចៅក្រម; រយៈពេលដែលចៅក្រមបំពេញមុខងាររបស់ខ្លួន; តុលាការ ។ magistrature assise ចៅក្រមអង្គុយ ។ magistrature debout ចៅក្រមឈរ

magma *n.m.* ដុំល្អិតខាប់ ។ *Fig.* ការលាយបញ្ចូលគ្នា

magnan *n.m.* ដង្កូវនាង (ពាក្យប្រើនៅប៉ែកខាងត្បូងនៃប្រទេសបារាំង)

magnanarelle *n.f.* ស្រីអ្នកចិញ្ចឹមនាង

magnanerie *n.f.* រោងចិញ្ចឹមនាង; សិល្បៈចិញ្ចឹមនាង

magnanier,ère *n.* អ្នកចិញ្ចឹមនាង

magnanime *a.* មហាស្រ័យ (ដែលមានចិត្តសប្បុរស ឧ. vainqueur magnanime; ថ្លៃថ្នូរ ឧ. cœur magnanime)

magnanimement *adv.* ដោយមហាស្រ័យ (ដោយសប្បុរស, ដោយថ្លៃថ្នូរ ឧ. traiter magnanimement

un vaincu)

magnanimité *n.f.* មហាស្រយភាព (ចិត្តធំប្រសើរ, ចិត្តសប្បុរស)

magnat *n.m.* មហទ្ធន [មៈ-ហ័ត-ធៈ-] (មូលធនិកដែលមានអំណាច)

magnésie *n.f.* ម៉ាញេស៊ី (វត្ថុម្យ៉ាងដូចដីសប្រើជាថ្នាំបញ្ចុះ)

magnésien,enne *a.* ដែលមានម៉ាញេស៊ីយ៉ូម (ឧ. sel magnésien)

magnésium *n.m.* ម៉ាញេស៊ីយ៉ូម (លោហធាតុម្យ៉ាងស្រាលឆុតឆេះ)

magnétique *a.* ចុម្ពិត [ចុំ-ពិត] (នៃលោហកាន្ត, នៃមេដែក; ដែលមានលក្ខណៈដូចមេដែក) (ឧ. corps magnétique; champ magnétique) ។ méridien magnétique ម.ព. méridien ។ *Fig.* ដែលមានអំណាចខ្លាំង (ដូចជាមានមេដែកស្រូប) (ឧ.regard magnétique)

magnétisable *a.* ចុម្ពិតីយ (អាចបញ្ចុះមេដែកបាន); អាចសណ្ដំបាន (ឧ.sujet magnétisable)

magnétisant,e *a.* ដែលបញ្ចុះមេដែក (ឧ. champ magnétisant); ដែលសណ្ដំ (ឧ. vertu magnétisante)

magnétisation *n.f.* ចុម្ពិតកម្ម, ការបញ្ចុះមេដែក

magnétiser *v.t.* បញ្ចុះមេដែក (ឧ. magnétiser une barre de fer) (ff. aimanter); សណ្ដំ ។ *Fig.* មានអំណាចខ្លាំង (ដូចមានមេដែកស្រូប) (ឧ.l'orateur magnétisait la foule)

magnétiseur *n.m.* អ្នកសណ្ដំ

magnétisme *n.m.* ចុម្ពិតពល, លក្ខណៈមេដែក ។ magnétisme animal ចុម្ពិតពលសត្វ (ការសណ្ដំដោយវាសដៃ) ។ magnétisme terrestre ចុម្ពិតពលដី ។ *Fig.* អំណាចធ្វើឲ្យគេចូលចិត្ត

magnéto *n.f.* ម៉ាញេតូ (ពាក្យបំប្រួញនៃ machine magnéto-électrique)

magnéto-électrique *a.* ចុម្ពិតអគ្គិសនី ។ machine magnéto-électrique ម៉ាស៊ីនចុម្ពិតអគ្គិសនី (ពាក្យសាមញ្ញថា ម៉ាញេតូ)

magnétomètre *n.m.* ចុម្ពិតមាត្រ

magnétométrie *n.f.* ចុម្ពិតមាត្រវិធី

magnétophone *n.m.* ចុម្ពិតសព្ទ,

ប្រឆាំបថតនឹងផ្សាយសំឡេង

magnificience *n.m.* អធិកភាព (ភាពរុងរឿងឬឆើតឆាយ) (ឧ. la magnificience d'un palais) ; ចិត្តខ្វះឈាយ (ឧ. une magnificience ruineuse)

magnifier *v.t.* សរសើរ, លើកតម្កើង (ឧ. magnifier un exploit)

magnifique *a.* អធិក, រុងរឿង, ឆើតឆាយ, ប្រសើរលើសលប់ (ឧ. palais magnifique); ល្អណាស់ (ឧ. temps magnifique) ។ *Fig.* ប្រកបដោយកិត្តិគុណ (ឧ. titre magnifique)

magnifiquement *adv.* យ៉ាងរុងរឿង (ឧ. traiter magnifiquement ses hôtes)

magot *n.m.* ស្វាអង្គុ; មនុស្សរូបអាក្រក់

magot *n.m.* *Fam.* ប្រាក់លាក់ទុក (ឧ. chercher le magot)

maharajah ឬ **maharadja** *n.m.* មហារាជ (*f.* maharani)

maharani *n.f.* មហារានី

mahatma *n.m.* មហាត្មា

mahométan,e *a.&n.* នៃសាសនាមហាម៉ូត, ដែលកាន់សាសនាមហាម៉ូត

mah-jongg *n.m.* ម.ព. ma-jong

mahométisme *n.m.* សាសនាមហាម៉ូត

mai *n.m.* (ខែ) ឧសភា; មៃ (ដើមឈើម្យ៉ាងគេដាំនៅថ្ងៃទី ១ ខែឧសភា ជាកិត្តិយសដល់ជនណាមួយ)

maigre *a.* ស្គម; មិនសូវមានខ្លាញ់; គ្មានសាច់ ឬ គ្មានខ្លាញ់ (ឧ. des aliments maigres) ។ *Par ext.* អត្តខាត់, មិនសូវបរិបូណ៌; មិនសូវឆ្ងាញ់ (ឧ. un maigre repas); មិនសូវមានជីជាតិ (ឧ. terre maigre)។ jours maigres ថ្ងៃតមសាច់ ។ *Fig.* មិនពិស្តារ (ឧ. maigre développement littéraire) ។ *n.m.* សាច់សុទ្ធ (ឧ. servez-moi du maigre);ម្ហូបគ្មានសាច់ ឬ គ្មានខ្លាញ់ (ឧ. le maigre n'exclut pas le gibier d'eau) ។ faire maigre តមសាច់នៅថ្ងៃដែលត្រូវកាន់គ្រឹស្តសាសនា

maigrelet,ette *a.* ស្គមបន្តិច

maigrement *adv.* យ៉ាងអត្តខាត់ (ឧ. dîner maigrement)

maigreur *n.m.* ភាពស្គម។ *Fig.* ភាព

អត្តខាត់, ភាពមិនបរិបូណ៌; ភាពមិនសូវមានជីជាតិ (ឧ. maigreur d'un sol); ភាពមិនពិស្តារ(ឧ. maigreur d'un sujet)

maigrichon,onne ឬ **maigriot,otte** *a. Fam.* ស្គមបន្តិច

maigrir *v.i.* ចុះស្គម ។ *v.t.* ធ្វើឲ្យស្គម ឬឲ្យឃើញដូចជាស្គម

mail [may'] *n.m.* ម៉ៃ (ល្បែងវាយដុំឈើ ; និងវាយដុំឈើក្នុងល្បែងម៉ៃ); ឈានដើរលេង

maille *n.f.* ក្រឡាចាក់; ក្រឡាសំណាញ់; ក្រវិលប្រវាក់ ។ *Bot.* ពន្លក

maille *n.f.* ម៉ៃយ (រូបិយវត្ថុបុរាណធ្វើអំពីស្ពាន់)(ឧ. n'avoir ni sou ni maille) ។ avoir maille à partir ប្រឈ្លោះគ្នាដោយហេតុបន្តិចបន្តួច; មានរឿងនឹង

maillechort *n.m.* កុលម៉ុង (ឬ កាំរ៉ូបី) (លោហធាតុស្រដៀងប្រាក់)

mailler *v.i.* ចាក់ក្រឡា (ឧ. mailler un filet) ។ *Mar.* mailler une chaîne ភ្ជាប់ប្រវាក់ដោយបង្ហាប់ក្រវិល ។ *v.t.* ចេញពន្លក (ឧ. le raisin commence à mailler)

maillet *n.m.* អន្លូងក្បាលស្វា

mailloche *n.f.* អន្លូងក្បាលស្វាធំ; អន្លូងក្បាលម្ខាង (ដូចជាអន្លូងនេគ)

maillon *n.m.* ក្រឡាសំណាញ់ល្អិត; ក្រវិលឬកងប្រវាក់

maillot *n.m.* កន្ទបទារក; អាវយឺត (ឧ. maillot de bain) ។ *Fig.* ទារកភាព

maillotin *n.m.* ឃ្នាបអូលីវ; អាវុធកាងជាអន្លូង

maillure *n.f.* ស្នាមសាច់ឈើ

main *n.f.* ប្រអប់ដៃ (ពីកដៃទៅក្រោម);ដៃ (អ្វីៗដែលមានរាងដូចដៃ) (ឧ. les Romains harponnaient les vaisseaux ennemis avec des mains de fer); ដៃ (ការប៉ិនប្រសប់នៃដៃ) (ឧ. se gâter la main); ដៃ (ស្នាដៃ) (ឧ. la main de l'homme gâte bien plus souvent qu'elle n'embellit); ដៃ (ភ្នាក់ងារ, ប្រដាប់) (ឧ. le gouvernement ne saurait être injuste sans avoir des mains qui exercent ses injustices); ដៃ, កម្លាំង (ឧ. il y a des masses trop pesantes pour la main des hommes); ដៃ, កណ្ដាប់ដៃ

(ឧ. l'avenir est dans la main du maître d'école) ។

Loc. div. agir sous main ប្រព្រឹត្តដោយសម្ងាត់ ។ à main armée អាវុធនៅដៃ ។ avoir le cœur sur la main ចិត្តល្អណាស់ ។ avoir la haute main បញ្ជា ។ avoir la main heureuse ធ្វើអ្វីច្រើនកប ។ avoir les mains liées ធ្វើអ្វីមិនកើត (ដូចគេចងដៃជាប់) ។ avoir sous la main មាននៅជិតដៃ ។ avoir une belle main សរសេរអក្សរល្អ ។ battre des mains ទះដៃ ។ de la main à la main ផ្ទាល់ដៃ (គ្មានអ្នកណាជួយទទួល) ។ de main de maître យ៉ាងប្រសប់ ។ de main en main ពីម្នាក់ទៅម្នាក់ ។ demander la main ស្ដីដណ្ដឹង ។ obtenir la main ស្ដីដណ្ដឹងបាន ។ donner à pleines mains ឲ្យពេញដៃ, ឲ្យយ៉ាងច្រើន ។ en main propre ផ្ទាល់ដៃសាមីខ្លួន ។ en un tour de main មួយភ្លែត ។ en venir aux mains ចូលវាយ, ចូលប្រឡូក ។ coup de main ម.ព. coup ។ être en bonnes mains ត្រូវប្រគល់ទល់ដៃអ្នកពេះ ។ faire main basse លួច; ប្លន់; សម្លាប់ ។ forcer la main ចាប់ដៃបង្ខំ ។ se laver les mains d'une chose ប្រកាសថា គ្មានបានចូលរួមធ្វើអ្វីមួយ (យករួចខ្លួន, មិនទទួលខុសត្រូវ) ។ lever la main លើកដៃស្បថ (ចំពោះតុលាការ) ។ lever la main sur quelqu'un យារដៃវាយ ។ main courante បង្កាន់ដៃជណ្ដើរ ។ main de papier ជុំក្រដាស ២៥ សន្លឹក ។ mettre la dernière main ធ្វើបង្ហើយ, សម្រេច ។ mettre la main à l'œuvre ចាប់ធ្វើ ។ mettre la main à la pâte ធ្វើការខ្លួនឯង ។ n'y pas aller de main morte វាយយ៉ាងធំណាំ ។ petite main ស្រីរៀនដេរ ។ première main ដៃលេខមួយ (ជាងលេខមួយក្នុងផ្ទះកាត់ដេរ) ។ prendre en main ទទួលបន្ទុក (កាន់ពេញដៃ) ។ tendre la main សុំទាន (លូកដៃសុំ) ។ tenir de première main បានពីម្ចាស់ដើម ឬ ពីប្រភពដើម

mainate *n.m.* សារិកាកែវ

mainbour ឬ **mainbourg** [min-bour'] *n.m.* អ្នកអាណាព្យាបាល។ *Par ext.* ឆ្មាំ, អ្នកយាម

mainbournie [min-bour-ni] *n.f.* *Dr.* អាណាព្យាបាល ។ *Par ext.* ការឧបត្ថម្ភ

mainbournir *v.t.* ធ្វើជាអ្នកអាណាព្យាបាល; ឧបត្ថម្ភ

main-d'œuvre *n.f.* ហត្ថពល, ការងារ; ហត្ថពលិក, ក្រុមកម្មករនៃរោងធ្វើការអ្វីមួយ; ហត្ថមូល, ឈ្នួលជាង (ឧ. payer une main-d'œuvre élevée) (*pl.* des mains-d'œuvre)

main-forte *n.f.* ជំនួយ ។ prêter main-forte ជួយ

mainlevée *n.f.* ការលើកលែង (ឧ. donner mainlevée de...)។ mainlevée des marchandises អនុញ្ញាតយកទំនិញ (ការអនុញ្ញាតឲ្យយកទំនិញចេញពីឃ្លាំងគយ ក្រោយបានបង្ហាញបង្កាន់ដៃបង់ពន្ធ)

mainmettre *v.t.* *Féod.* ឲ្យរួចជាអ្នកជា (ឧ. mainmettre un serf)

mainmise *n.f.* *Féod.* ការឲ្យរួចជាអ្នកជា (ឧ. la mainmise d'un serf); ការរឹបអូស (ឧ. il y avait mainmise par défaut de foi et hommage); ការល្មោភនៃកូល (ឧ. mainmise de quelqu'un sur une société) ។ *Fam.* user de mainmise រំលោភ

mainmorte *n.f.* ការមិនអាចលក់ ឬផ្លាស់ម្ចាស់បាន; គរុភណ្ឌ ។ taxe de mainmorte អាករគរុភណ្ឌ

maint,e *a.* ច្រើន (ឧ. maintes fois; en maintes occasions)

maintenant *adv.* ឥឡូវនេះ ។ maintenant que *loc. conj.* ឥឡូវនេះហើយ

mainteneur *n.m.* អ្នកទប់; អ្នករក្សាទុក; អ្នកការពារ

maintenir *v.t.* ទប់ (ឲ្យនឹង ឬ ឲ្យជាប់) (ឧ. poutre qui maintient la charpente)។ *Fig.* រក្សាទុក; ថែទាំ, ការពារ (ឧ. maintenir les lois existantes); អះអាង; ប្រកាន់ (ឧ. je maintiens que cela est vrai)។ se maintenir *v.pr.* នៅនឹង, នៅនៃល; រក្សាខ្លួន (ឧ. se maintenir en bonne santé)

maintien *n.m.* ការរក្សា (ឧ. le maintien de l'ordre); អាកប្បកិរិយា (ឧ. maintien modeste) ។ perdre son maintien ស្លន់ ។ maintien dans les lieux អនុញ្ញាតឲ្យនៅតទៅទៀត (ការអនុញ្ញាតឲ្យអ្នកជួលផ្ទះនៅតទៅទៀត ពិតមែនតែម្ចាស់ផ្ទះមិនចង់ឲ្យនៅ) (*ut.* attitude, contenance, prestance, tenue)

maire *n.m.* មេឃុំ; ចៅហ្វាយក្រុង

mairesse *n.f.* ភរិយាមេឃុំ ឬ ចៅហ្វាយក្រុង

mairie *n.f.* សាលាឃុំ; សាលាក្រុង; ភជិការក្រុង; មុខងារជាមេឃុំ ឬ ជាចៅហ្វាយក្រុង

mais *adv.* n'en pouvoir mais ទៅទៀតលែងរួច (ឧ. je n'en peux mais, tant j'ai couru)

mais *conj.* ប៉ុន្តែ

maïs *n.m.* ពោត

maïserie *n.f.* រោងចក្រពោត

maison *n.f.* គេហដ្ឋាន, ផ្ទះ, គ្រឹះស្ថានជំនួញ (ឧ. maison de vin en gros); គេហកិច្ច; គ្រឿងតាំងក្នុងផ្ទះ; មនុស្សដែលនៅជាមួយគ្នា, វង្ស, ពូជ (ឧ. la maison des Bonaparte) ។ de bonne maison ពូជល្អ (ពូជខ្ពង់ខ្ពស់ហើយមានទ្រព្យ) ។ maison d'arrêt ម.ព. arrêt ។ maison de santé មន្ទីរសុខភាព; មន្ទីរពេទ្យល្អូល ។ maison de tolérance ពេស្យដ្ឋាន ។ garder la maison មិនចេញពីផ្ទះ ។ faire maison nette បណ្ដេញជាវក្រាវចោលអស់ (*ut.* demeure, domicile, logis, résidence)

maisonnée *n.f. Fam.* មនុស្សមួយផ្ទះ

maisonnette *n.f.* ផ្ទះតូច

maitre *n.m.* មេ, នាយ, ចៅហ្វាយ (ឧ. un maitre sévère); ម្ចាស់ (ឧ. le maitre de la maison); គ្រូបង្រៀន (ឧ. suivre les leçons d'un savant maitre); សាស្តា, អាចារ្យ, គ្រូ (ឧ. s'inspirer des maitres) ។ passer maitre បានជាគ្រូគេ; *au fig.* ប៉ិនប្រសប់ក្នុងការអ្វីមួយ ។

ដែលមានអំណាចលើ (ឧ. maitre de ses passions); ដែលមានសេរីភាពនឹង (ជាម្ចាស់លើខ្លួនឯង)

(ឧ. maître de choisir sa carrière)។ maître d'armes គ្រូគុនដាវ ។

maître d'école គ្រូបង្រៀន។ maître d'hôtel មេសណ្ឋាគារ ។ *Mar.* maître principal នាយបព្រាបាល [ចក-ព្រះ-] ។ premier maître បព្រាបាលឯក ។ second maître បព្រាបាលទោ ។ quartier maître បព្រាបាលរងទោ។ quartier maître chef បព្រាបាលរងឯក ។ maître de forge នាយរោងបព្រស្មែក ។

a. ប្រសប់, ប៉ិន; ស្ទាហាប់; ពូកែ (ឧ. un maître fripon)។

Prov. le temps est un grand maître ពេលវេលាជាគ្រូធំ (ធ្វើអ្វីកុំធ្វើដោយប្រញាប់ពេក ព្រោះពេលវេលាជាទកាសនាំឲ្យយើងមានពិសោធន៍; ពេលវេលាជាទកាសអាចដោះស្រាយរឿងទាំងឡាយបានដោយស្រួល)

maître-à-danser *n.m.* ដែកឈានម្យ៉ាង (*pl.* des maîtres-à-danser)

maîtresse *n.f.* នាយស្រី ម្ចាស់ស្រី; អ្នកគ្រូ; ស្រីសហាយ ។ maîtresse de maison ស្ត្រីមេផ្ទះ ។ *a.* សំខាន់; ធំ (ឧ. poutre maîtresse)។ maîtresse femme ស្ត្រីមានៈ

maîtrisable *a.* អាចបង្ក្រាបបាន (ឧ. passion peu maîtrisable)

maîtrise *a.* អំណាចនាយ - ម្ចាស់ - គ្រូ; ការរក្សាស្មារតី; ការមិនស្លុត (ឧ. conserver sa maîtrise dans une situation périlleuse); សាលាបង្រៀនចម្រៀងនិងភ្លេងសាសនា ។ *Ens.* ឋានៈគ្រូ ។ maîtrise de l'air ការមានប្រៀបខាងអាកាស។ maîtrise de la mer ការមានប្រៀបខាងសមុទ្រ

maîtriser *v.t.* បង្ក្រាប (ឧ. maîtriser un animal furieux) ។ *Fig.* គ្រុត, ទប់ (ឧ. maîtriser ses passions) ។ se maîtriser *v.pr.* អត់សង្កត់ចិត្ត, ទប់ចិត្ត

majesté *n.f.* អានុភាពដ៏អស្ចារ្យ (ឧ. la majesté divine); សីហវិលាស, ភាពសំបើមគួរឲ្យគោរព (ឧ allure pleine de majesté) ។ Sa Majesté (S.M.) ព្រះករុណា (បុរិសសព្ទនាមចំពោះស្តេចហោយភក្ស)។

Sa Majesté Très Chrétienne ព្រះមហាក្សត្រទេសបារាំង ។ Sa Majesté Catholique ព្រះមហាក្សត្រទេសអេស្ប៉ាញ

majestueusement *adv.* ដោយសីហារិលាស

majestueux,euse *a.* ប្រកបដោយសីហារិលាស (ឧ.démarche majestueuse)

majeur,e *a.* ធំជាង, ច្រើនជាង (ឧ. la majeure partie); ពេញការ (ឧ. fille majeure); សំខាន់ (ឧ. affaire majeure) ។ cas de force majeure ករណីប្រធានសក្តិ ។ *n.m.* ម្រាមចង្អុលកណ្តាល

ma-jong *n.m.* ល្បែងបៀក្អក

major *n.m.* នាយទាហានជាន់ខ្ពស់អ្នកគ្រប់គ្រងកងវរសេនាធំ ។ major général ឧត្តមសេនីយទោ ។ *Arg. scol.* សិស្សច្បង (សិស្សលេខមួយក្នុងមួយជំនាន់)

majoration *n.f.* ការតម្លើងថ្លៃ (ឧ. des majorations de prix)

majordome *n.m.* នាយជាវព្រាវ

majorer *v.t.* តម្លើងថ្លៃ (ឧ. majorer des prix, des produits)

majoritaire *a.&n.* ខាងភាគច្រើន; ដែលផ្អែកលើភាគច្រើន (ឧ.gouvernement majoritaire) ។ *a.* ដែលនិយមភាគច្រើន

majorité *n.f.* នីតិភាព, ភាពពេញការ (ឧ. la majorité civile et civique est de 21 ans, celui de la majorité pénale est de 18 ans); ភាគច្រើន (ឧ. la majorité des blessés survivent) ។ majorité absolue ភាគច្រើនដាច់ខាត(ចំនួនសម្លេងលើសពីពាក់កណ្តាលនៃសម្លេងដែលបានបោះឆ្នោត) ។ majorité constitutionnelle ភាគច្រើនតាមរដ្ឋធម្មនុញ្ញ (ភាគច្រើនដាច់ខាតតាមចំនួនសមាជិកវរដ្ឋសភា មិនមែនតាមចំនួនសម្លេងដែលបោះឆ្នោតទេ) ។ majorité relative ឬ simple ភាគច្រើនធៀប

majuscule *n.f. & a.* អក្សរធំ

mal *n.m.* អំពើអាក្រក់ (ឧ. rendre le bien pour le mal); អកុសល; ហេតុអាក្រក់, ការខូចខាត (ឧ. les maux de la guerre); អគ្គទោស (ឧ. le mal est qu'il s'absen-

te souvent);សេចក្ដីឈឺចាប់,ឆឺ, រោគ (ឧ. mal de dents); ការលំបាក (ឧ. on a trop de mal ici) ។ aller de mal en pis កាន់តែខូចពីបទៅ ។ dire du mal de quelqu'un និយាយអាក្រក់ពីគេ។ prendre ឬ tourner une chose en mal យល់ន័យខាងអាក្រក់; ប្រកាន់ចិត្តខឹង (ឧ.tourner en mal une plaisanterie) ។

Méd. mal de cœur និរណើរពេលក្អួត(កើតកំណើតពីក្រពះ)។mal de mer និរណើរពុលរលក ។ mal des montagnes ឬ mal de l'altitude និរណើរពុលអាកាស(រោគបណ្ដាលពីខ្យល់អ្នកឡើងខ្ពស់នៅទីខ្ពស់) ។ mal de Naples រោគស្វាយ ។ mal de Pott រោគរបេងឆ្អឹងខ្នង។ mal sacré, mal divin, mal caduc ឬ haut mal រោគឆ្កួតជ្រូក (ម.ព. épilepsie ផង) ។ mal de l'été រោគឈឺក្បាល(ត្រង់ថ្ងាស) ។ mal du pays ការរឭកស្រុកកំណើត ។

Prov. de deux maux il faut choisir le moindre ចំពោះហេតុអាក្រក់ពីរ យើងត្រូវរើសយកហេតុមិនសូវអាក្រក់ ។ chacun sent son mal មនុស្សម្នាក់ៗស្គាល់ទុក្ខរបស់ខ្លួន (មនុស្សម្នាក់ៗស្គាល់ជាងអ្នកដទៃនូវទុក្ខដែលខ្លួនបានរង)។ aux grands maux les grands remèdes ជំងឺធ្ងន់ត្រូវប្រើថ្នាំខ្លាំង។ qui veut mal, mal lui tourne អ្នកណាឲ្យទុក្ខគេអ្នកនោះនឹងទទួលទុក្ខវិញ

mal,e *a.* អាក្រក់, ចង្រៃ ។ bon an, mal an ទុកពេលល្អនឹងអាក្រក់ (ឆ្នាំកសិឡើងនឹងកសិចុះ)។ bon gré, mal gré ម.ព. gré ។ *Fam.* n'être pas mal មិនអន់ទេ,មានរូបរាងល្អ

mal *adv.* អាក្រក់ (ឧ. écrire mal)។ *Fam.* pas mal ច្រើនគួរសម ។ se trouver mal avec quelqu'un មិនសូវត្រូវនឹងអ្នកណាមួយ ។ être bien mal ឬ au plus mal មានគ្រោះដល់ស្លាប់។prendre mal une chose ប្រកាន់ទោសចំពោះរឿងអ្វីមួយ ។ trouver mal ឃើញអាក្រក់,មិនពេញចិត្ត។se trouver mal d'une chose ទទួល

ទោសពីរបស់អ្វីមួយ

malabre *a.&n.* នៃប្រទេសម៉ាឡាបារ (ឧ.la côte malabre est malsaine)។ *n.m. Arg.* ធំ, ខ្លាំង

malade *a.* ឈឺ។ *Fig.* ទុនទាប (ឧ. industrie malade); មិនស្រួល(ខាងផ្លូវបញ្ញា ឬ ខាងផ្លូវចិត្ត) (ឧ. esprit malade)។ *n.* រោគី (អ្នកជំងឺ)

maladie *n.f.* ជំងឺ, រោគ (ឧ.contracter une maladie); ការខូច(ឧ. maladie du vin)។

maladie aiguë រោគក្លាខ្លាំង។ maladie chronique រោគរ៉ាំរ៉ៃ។ maladie cryptogamique រោគបជិក្ខុជាត។ maladie endémique រោគប្រាំព្រែង។ maladie épidémique រោគរាតត្បាត។ maladie héréditaire រោគបិតាគត, រោគជិរ។ maladie parasitaire រោគបរាសិត។ maladie professionnelle រោគវិជ្ជាជីវៈ (រោគបណ្តាលពីបំពេញវិជ្ជាជីវៈ)។

Fig. ការងប់, ការរក (ឧ. il a la maladie de collectionner les papillons)។ *Fig.& Fam.* faire une maladie de ធំញើរើមទ្រូងដោយ, ពិបាកចិត្តដោយ

maladif,ive *a.* ឈឺច្រើន, ហៃឈឺ (ឧ.tempérament maladif)។ *Fig.* ដែលងប់, ដែលរក (ឧ. curiosité maladive)

maladivement *adv.* ដោយឈឺច្រើន; ដោយងប់

maladrerie *n.f.* មន្ទីរពេទ្យឃ្លង់ (ក្នុងយុគកណ្តាល)

maladresse *n.f.* ភាពឆ្គង (ឧ. maladresse d'un chasseur); អំពើឆ្គង (ឧ. commettre des maladresses)

maladroit,e *a.&n.* ឆ្គង (ឧ. ouvrier maladroit)។ *Fig.* មិនប្រសប់ (ឧ. un flatteur maladroit)

maladroitement *adv.* ដោយឆ្គង; ដោយមិនប្រសប់ (ឧ. intriguer maladroitement)

malaire *a.* នៃថ្ពាល់ (ឧ. os malaire)

malais,e *a.* នៃប្រទេសជ្វា។ *n.* ជនជាតិជ្វា។ *n.m.* ភាសាជ្វា

malaise *n.m.* ដំណើររសាប់រសល់។ *Fig.* ដំណើរទាល់ប្រាក់; វិបត្តិសេដ្ឋកិច្ច, ការព្រួយបារម្ភ

malaisé,e *a.* ពិបាក, មិនងាយ, មិនស្រួល, ក្រ

malaisément *adv.* ដោយពិបាក

malandre *n.f.* រោគសន្លាក់ជើងសេះ; ភ្នែកឈើស្អុយ

malandreux,euse *a.* ដែលឈឺសន្លាក់ជើង(សេះ) (ឧ.cheval malandreux); ដែលស្អុយភ្នែក (ឈើ) (ឧ. bois malandreux)

malandrin *n.m.* *Par ext.* ចោរ; មនុស្សប្រឡៃប្រកោ

malappris,e *a.&n.* គម្រោល, គ្មានការអប់រំ (ឧ. un enfant malappris)

malard ឬ **malart** *n.m.* ទាឈ្មោល

malaria *n.f.* គ្រុនចាញ់

malavisé,e *a.&n.* ពព្រាក់ពព្រើ, មិនដឹងខុសត្រូវ

malaxage *n.m.* ឬ **malaxation** *n.f.* ការច្របាច់ឲ្យទន់

malaxer *v.t.* ច្របាច់ ឬ ដំឲ្យទន់

malaxeur *a.&n.m.* ប្រដាប់សំរាប់កិបច្របល់

malchance *n.f.* ដំណើរខាតលាភ, អភ័ព្វ

malchanceux,euse *a.* អភ័ព្វ, ស៊យ

mâle *a.* ឈ្មោល ។ fleur mâle ផ្កាឈ្មោល ។ *Fig.* មាំមួន, ស្វាហាប់ (ឧ. une voix mâle) ។ *Techn.* ដំណាប់ឈ្មោល (ពន្លួញ ឬ អណ្ដាតត្ដួយពីដំណាប់ដែលដោតខាងញី)។ *n.m.* សត្វឈ្មោល

malédiction *n.f.* បណ្ដាសា ។ *Fig.* អពមង្គល, អភ័ព្វ (ឧ. la malédiction est sur moi)

maléfice *n.m.* អំពើអំពាន់ ។ jeter un maléfice ធ្វើអំពើ

maléfique *a.Astrol.* សោយ, ជ្រែក (ដែលឲ្យទោស)

malemort *n.f.* ដំណើរស្លាប់តាយហោង (ឧ. mourir de malemort)

malencontreusement *adv.* ដោយគាំឡើខាន; ដោយខុសពេល

malencontreux,euse *a.* ដែលគាំឡើខាន; ដែលមកខុសពេល(ឧ.circonstance malencontreuse)

malendurant,e *a.* មិនអំណត់, មិនធន់

mal-en-point *loc. adv. inv.* កំពុងតែមិនស្រួលខ្លួន (ឧ. voici un blessé bien mal-en-point) (សរសេរ mal en point ក៏បាន); កំពុងតែជុនជាប

malentendu *n.m.* សំដី ឬ អំពើយល់

ប្រឡំ (ឧ. faire cesser un malentendu)

malfaçon *n.f.* ការដែលធ្វើមិនបានល្អ (ដោយល្ងង់ ដោយធ្វេសប្រហែស ឬ ដោយមានបំណងអាក្រក់)

malfaire *v.t.* ប្រព្រឹត្តបទអាក្រក់

malfaisance *n.f.* អកុសលកម្ម; ការចូលចិត្តប្រព្រឹត្តបទអាក្រក់

malfaisant,e *a.* ដែលចូលចិត្តប្រព្រឹត្តបទអាក្រក់; ចង្រៃ (ឧ. animaux malfaisants); ដែលឲ្យទោសដល់សុខភាព

malfaiteur,trice *n.* មនុស្សខូច ឬ ប្រព្រឹត្តបទអាក្រក់

malfamé,e *a.* ដែលមានកេរ្តិ៍ឈ្មោះអាក្រក់ (ឧ. maison, rue malfamée)(សរសេរ mal famé ក៏បាន)

malformation *n.f.* វិរូបភាព

malgache ឬ **madécasse** *a.* នៃកោះម៉ាដាហ្គាស្ការ។ *n.* ជនជាតិម៉ាដាហ្គាស្ការ

malgracieux,euse *a.* មិនពិរោះគួរសម, ច្រូតោះ

malgré *pré.* ខុសទំនើងចិត្ត; ខុសឆន្ទៈ (ឧ. faire quelque chose malgré soi) ; ថ្វីបើ (ឧ. sortir malgré la pluie) ។

Loc. div. malgré tout ទុកជាយ៉ាងណាក៏ដោយ ។ malgré vents et marée ទុកជាមានភ្លៀងខ្យល់ក៏ដោយ (ចំពោះនាវាដែលតយុទ្ធនឹងខ្យល់ព្យុះ); *au fig.* ទុកជាមានឧបសគ្គយ៉ាងណាក៏ដោយ

malhabile *a.* មិនប្រសប់, ឆ្គង; ល្ងង់ (ឧ. ouvrier malhabile)

malhabilement *adv.* ដោយមិនប្រសប់, ដោយឆ្គង

malheur *n.m.* អភ័ព្វ (ឧ. triompher du malheur); ទុក្ខ (ឧ. il lui est arrivé un malheur) ។ jouer de malheur ជាមនុស្សអភ័ព្វ ។ porter malheur នាំឲ្យអភ័ព្វ, នាំឲ្យចង្រៃ ។ malheur à . . . ! ឲ្យ . . . វេទនា (ពាក្យបណ្ដាសា) ។ par malheur *loc. adv.* ដោយអភ័ព្វ; ជួនជាគ្រោះកាច

malheureusement *adv.* ដោយអភ័ព្វ, ជួនជាគ្រោះកាច; ដោយគួរឲ្យស្ដាយ

malheureux,euse *a.* អភ័ព្វ, ដែលមានទុក្ខ (ឧ. un enfant malheureux); អកុសល; ចង្រៃ (ឧ. une entreprise malheu-

reuse) ; កំសត់, គួរឲ្យអាណិត (ឧ. situation malheureuse) ; ស្រពាប់ស្រពោន (ឧ. un air malheureux); ចង្រៃ, ដែលឲ្យមានទុក្ខ (ឧ. jour malheureux); ដែលឲ្យគេស្អប់(ឧ.physionomie malheureuse); គ្មានតម្លៃ, មិនសំខាន់ (ឧ. un malheureux coin de terre) ។

avoir la main malheureuse ធ្វើអ្វីមិនកើត; សយ; កាន់របស់អ្វី ខូចរបស់នោះ (ដៃភ្លើងជើងមាន់) ។ malheureux comme les pierres វេទនាខ្លាំងណាស់ ។

n.m. មនុស្សកំសត់ទុគ៌ត(ឧ. soulager les malheureux) ; មនុស្សកំណាច ឬ ថោកទាប

malhonnête *a.&n.* ទុច្ចរិត ។ *Par ext.* ឥតច្បាប់ (ឧ. enfant malhonnête); អាសគ្រាម (ឧ. livre malhonnête)

malhonnêtement *adv.* ដោយទុច្ចរិត (ឧ. se conduire malhonnêtement)

malhonnêteté *n.f.* ទុច្ចរិត; សេចក្ដីឥតគួរសម

malice *n.f.* ព្យាបាទ (ឧ. il a un fonds de malice) ។ *Par ext.* ការចូលចិត្តធ្វើអំពើរប៉ិលរប៉ូច (ឧ. la malice est fréquente chez l'enfant); ការចំអកចំអន់លេង (ឧ. faire des malices)

malicieusement *adv.* ដោយចំអកចំអន់លេង

malicieux,euse *a.&n.* ដែលចង់ព្យាបាទ; រប៉ិលរប៉ូច; ដែលចំអកចំអន់លេង

malignement *adv.* ដោយកំណាច

malignité *n.f.* ភាពអាក្រក់ (ឧ. la malignité du péché); ការចូលចិត្តធ្វើ-តិត ឬ និយាយអាក្រក់ (ឧ. la malignité des hommes); អំពើកំណាចថោកទាប (ឧ. la malignité publique); អំពើឬសំដីប្រកបដោយព្យាបាទ

malin,igne *a.* រប៉ិលរប៉ូច (ឧ. un enfant malin); ដែលចំអកចំអន់លេង (ឧ. un sourire malin); ឆ្លាត, ប្រសប់ (ឧ. il est trop malin pour agir ainsi) ។ *Fam.* ce n'est pas malin មិនពិបាកទេ ។ l'esprit malin បិសាច ។ *n.* មនុស្សឆ្លាត(មានកលល្បិច) (ឧ. quel

malin !) ។ *n.m.* បិសាច

malingre *a.* ទុព្វល, ខ្សោយ (ឧ. enfant malingre)

malintentionné,e *a.&n.* ប្រកបដោយបំណងអាក្រក់

mal-jugé *n.m.* ការវិនិច្ឆ័យខុស (ឧ. il y a eu mal-jugé)

malle *n.f.* ហិបឈើ ។ faire sa malle ឬ ses malles រៀបចំនឹងចេញ

malléabilisation *n.f.* បធីយកម្ម(ការធ្វើឲ្យទន់ អាចដែ ឬ កិនជាសន្លឹកបាន) (ឧ.la malléabilisation confère aux fontes blanches des propriétés voisines de celles de l'acier)

malléabilité *n.f.Techn.* បធីយភាព, ភាពទន់អាចដែ ឬ កិនជាសន្លឹកបាន (ឧ. la malléabilité du plomb)

malléable *a. Techn.* បធីយ, អាចដែ ឬ កិនជាសន្លឹកបាន ។ *Fig.* ទន់, អាចដឹកនាំបាន (ឧ. caractère malléable)

malle-poste *n.f.* ហិបប្រៃសណីយ៍(រថដឹកសំបុត្រ) (*pl.* des malles-postes)

mallette *n.f.* កូនហិបឈើ

malmener *v.t.* ធ្វើបាបដោយកាយ ឬ វាចា (ឧ. on ne doit malmener personne); ធ្វើឲ្យខកខាន, ធ្វើឲ្យមិនបានសម្រេច (ឧ. malmener l'ennemi)

malodorant,e *a.* ដែលមានក្លិនអាក្រក់

malotru,e *a.&n.* ដែលមានរូបរាងអាក្រក់; កម្រោល; ឥតច្បាប់

malpropre *a.&n.* អសុចិ, កខ្វក់, ស្មោកគ្រោក (ឧ. des mains malpropres); មិនស្អាត (ឧ. travail malpropre) ។ *Fig.* អាសគ្រាម (ឧ. propos malpropres); វៀច, ខុសគន្លងធម៌ (ឧ. conduite malpropre)

malproprement *adv.* ដោយកខ្វក់, ដោយមិនស្អាត; ដោយវៀច (ឧ. se tenir, se conduire malproprement)

malpropreté *n.f.* អសុចិភាព, ភាពកខ្វក់; សេចក្ដីស្មោកគ្រោក ។ *Fig.* ភាពវៀច, ភាពទុច្ចរិត

malsain,e *a.* មិនសុខសប្បាយ; មិនឲ្យសុខសប្បាយ (ឧ. air malsain)។ *Fig.* អកុសល, ប្រកបដោយគ្រោះ-

ថ្លាក់ (ឧ. livre malsain)

malséance *n.f.* ទុក្ករធម៌; ភាពមិនគួរសម

malséant,e *a.* ទុក្ករិយ, មិនគួរសម

malsonnant,e *a.* ទុក្ខសី, មិនពីរោះ, គ្រោះ (ឧ. paroles malsonnantes)

malthusianisme *n.m.* និប្បូលនិយម (ឧ. malthusianisme économique)

malthusien,enne *a.&n.* នៃនិប្បូលនិយម

maltose *n.m.* យញ្ជធុ [យ៉ក.ធុ]

maltraiter *v.t.* ប្រមាថ, ធ្វើបាប, ធ្វើទុក្ខ

malveillamment *adv.* ដោយទុដ្ឋិត

malveillance *n.f.* ទុដ្ឋិតភាព, ព្យាបាទ (ឧ. incendie attribué à la malveillance); សំអប់ (ឧ. la malveillance d'un examinateur)

malveillant,e *a.&n.* ទុដ្ឋិត, ប្រកបដោយព្យាបាទ

malvenant,e *a.* ដែលដុះមិនល្អ (ឧ. bois malvenants)

malvenu,e *a.* គ្មានសិទ្ធិនឹងធ្វើអ្វីមួយ (ឧ. héritier malvenu à se plaindre) (ថា mal venu ក៏បាន)

malversation *n.f.* ការគៃបន្លំ

malverser *v.i.* គៃបន្លំ

maman *n.f.* ម៉ែ, ម៉ាក់

mamellaire *a.* នៃដោះ

mamelle *n.f.* ស្តន [ស្តន់], ដោះ (រ.ស. ព្រះស្តន) ។ enfant à la mamelle ក្មេងនៅបៅដោះ

mamelon *n.m.* សណ្តាន់ដោះ ។ *Par ext.* ប៉ូក-ទួល ឬ កំពូលរាងដូចដោះ

mamelonné,e *a.* ដែលមានកំពូក, ដូចដំបូក

mamelu,e *a. Pop.* ដែលមានដោះធំ

m'amie *n.f.* (ពាក្យបំព្រួញនៃ ma amie ដែលគេច្រើនសរសេរថា ma mie)

mammaire *a.* នៃដោះ (ឧ. glandes mammaires)

mammalogie *n.f.* ថនិកវិទ្យា, វិទ្យាសាស្ត្រស្តីអំពីថនិកសត្វ

mammifère *a.* ថនិក, ដែលមានដោះ ។ *n.m. pl.* ថនិកសត្វ, សត្វចិញ្ចឹមកូនដោយដោះ

mammouth *n.m.* ម៉ាំមុត, ដំរីបុរាណ

mam'selle ឬ **mam'zelle** *n.f.* (ពាក្យបំព្រួញនៃ mademoiselle)

manager *n.m.* ចាងហ្វាងសកេក្រាស

manant *n.m.* *Autref.* អ្នកស្រែ ។ *Péjor.* មនុស្សកម្រោល,មនុស្សថ្លឹង

manche *n.m.* ដង (ឧ. manche de couteau); យាមនង្គ័ល ។ jeter le manche après la cognée ម.ក. cognée ។ manche à balai ដៃបង្កួតឡើងចុះនៃយន្តហោះ

manche *n.f.* ដៃអាវ ។ manche à air បំពង់ខ្យល់ (បំពង់ធ្វើអំពីសំពត់សម្រាប់ចង្អុលទិសខ្យល់ ក្នុងអាកាសយានដ្ឋាន; បំពង់បញ្ចូលខ្យល់ក្នុងនាវា)។ *Géogr.* ដៃសមុទ្រ ។ avoir quelqu'un dans sa manche មានឥទ្ធិពលលើ ។ tirer la manche à quelqu'un អង្វោកអង្វាល ។ *Fam.* c'est une autre paire de manches ជារឿងខុសគ្នា

mancheron *n.m.* យាមនង្គ័ល, ដៃអាវ

manchette *n.f.* ដៃអាវ; បំណងជើងធំៗនៃកាសែត ។ *pl. Par iron.* ខ្នោះដៃ

manchon *n.m.* *Techn.* ស្រោមដំណ; សំបុកចង្កៀងម៉ង់ស៊ុង

manchot,e *a.&n.* កំបុតដៃម្ខាង។*Fig.* n'être pas manchot ប្រសប់, ខ្លាំង ។ *n.m.* បក្សីម្យ៉ាងនៅសមុទ្រទឹកកកខាងត្បូង

mancie *n.f.* ការទាយ

mandant,e *n.* អាណត្តិទាយក (អ្នកប្រគល់អាណត្តិ) (ឧ. un député et ses mandants)

mandarin *n.m.* មន្ត្រី

mandarinat *n.m.* ឋានៈជាមន្ត្រី

mandarine *n.f.* ក្រូចឃ្វិច

mandarinier *n.m.* ដើមក្រូចឃ្វិច

mandat *n.m.* អាណត្តិ, លិខិតប្រគល់សិទ្ធិឬអំណាចដំណាង; ដីកា ។ mandat d'amener ដីកានាំខ្លួន ។ mandat d'arrêt ដីកាចាប់ខ្លួន។ mandat de comparution ដីកាចូលខ្លួន។ mandat de dépôt ដីកាឃុំខ្លួន ។ mandat-poste អាណត្តិប្រៃសណីយ ។ mandat de paiement អាណត្តិបើកប្រាក់ ។ mandat de trésorerie អាណត្តិរតនាគារ ។ mandat de virement អាណត្តិបង្វែរ

mandataire *n.* អាណត្តិគាហក (អ្នកទទួលអាណត្តិ) (ឧ. être le mandataire de quelqu'un)

mandat-carte *n.m.* អាណត្តិប័ណ្ណ

(*pl.* des mandats-cartes)

mandat-contributions *n.m.* ប័ណ្ណបរិវិសទាន [ប៉ៈ-រ៉ិ-វិ-ស៉ៈ—]

mandatement *n.m.* អាណត្តិកិច្ច, ការធ្វើអាណត្តិបើកប្រាក់ (ឧ. mandatement d'une somme)

mandater *v.t.* ធ្វើអាណត្តិបើកប្រាក់; ប្រគល់អាណត្តិ

mandat-lettre *n.m.* អាណត្តិលិខិត (*pl.* des mandats-lettres)

mandement *n.m.* លិខិតបង្គាប់

mander *v.t.* បង្គាប់តាមលិខិត; ហៅ (ឧ. mander quelqu'un)

mandibulaire *a.* នៃឆ្អឹងថ្គាមក្រោម

mandibule *n.f.* ឆ្អឹងថ្គាមក្រោម; ផ្នែកនិមួយៗនៃចំពុះបក្សី; ថ្គាមសត្វល្អិត

mandoline *n.f.* ម៉ង់ដូលីន (ចាប៉ីប្រាំង)

mandoliniste *n.* អ្នកលេងម៉ង់ដូលីន

mandrin *n.m.* *Techn.* ក្រឡុប (ប្រដាប់ចាក់ខ្យងនក្រឡឹង) ; ប្រដាប់ចោះម៉ែ ឬ ស្មុល

manducation *n.f.* ការបរិភោគ

manège *n.m.* ការបង្ហាត់សេះ; កន្លែងបង្ហាត់សេះ ។ *Fig.* កលល្បិច (ឧ. je me méfie de ce manège)

manéger *v.t.* បង្ហាត់ (ឧ. manéger un cheval)

mânes *n.m. pl.* វិញ្ញាណក្ខន្ធ

maneton *n.m.* នៃម្ហូលតូច

manette *n.f.* នៃម្ហូលខ្នាឬក្បាលម៉ាស៊ីន

manganèse *n.m.* ម៉ង់ហ្គាណែស

mangeable *a.* អាចបរិភោគបាន

mangeaille *n.f.* ចំណីសត្វខ្លះ ។ *Fam.* អាហារ

mangeoire *n.f.* ស្នូកដាក់ចំណីសត្វ

mangeotter *v.t.* បរិភោគមិនសូវឆ្ងាញ់

manger *v.t.* បរិភោគ, ស៊ី (ឧ. manger du pain) ; ស៊ី (ឧ. la rouille mange le fer) ។ *Fig.* បង្ហិន (ឧ. manger son bien) ។ manger des yeux សម្លឹងចង់បាន ។ manger ses mots អានពាក្យមិនច្បាស់ ។ manger de la vache enragée វេទនាខ្វះខាតច្រើន ។ *Fam.* manger la consigne ភ្លេចសេចក្តីបង្គាប់ ។ il y a à boire et à manger ទាំងពីរ; *au fig.* មានទោសមានគុណ ។

n.m. ភោជន [ភោ-ជន់] , ម្ហូបដែលគេបរិភោគ (ឧ. le boire et le manger) ។ *Fig.* perdre

le boire et le manger បរិភោគជាយទឹកមិនបាន (ដោយរវល់ ឬ ដោយព្រួយខ្លាំងពេក)

mangerie *n.f.Fam.* ការបរិភោគច្រើន

mangeur,euse *n.* អ្នកស៊ី;អ្នកស៊ីច្រើន; អ្នកបង្ហិន

mangoustan *n.m.* ផ្លែមង្ឃុត

mangoustanier *n.m.* ដើមមង្ឃុត

mangouste *n.f.* ស្កា

mangue *n.f.* ផ្លែស្វាយ

manguier *n.m.* ដើមស្វាយ

maniabilité *n.f.* ភាពស្រួលកាន់ ឬ ស្រួលប្រើ

maniable *a.* ស្រួលកាន់, ស្រួលប្រើ (ឧ. instrument maniable)។ *Fig.* ងាយដឹកនាំ (ឧ. cet homme n'est pas maniable)

maniaque *a.* & *n.* ឆ្កួត, រឹក, ដែលមាន ទម្លាប់ប្លែក (ឧ. quel maniaque)

manie *n.f.* ដំណើររឹកឬឆ្កួត; ទម្លាប់ប្លែក (ឧ. il a la manie de se regarder dans la glace)

maniement *n.m.* ការកាន់, ការប្រើ (ឧ. le maniement d'un outil)។ *Fig.* ការដឹកនាំ; ការត្រួត; ការគ្រប់គ្រង (ឧ. le maniement des esprits, des affaires)

manier *v.t.* ស្ទាប, កាន់ (ឧ. manier une étoffe); កាន់កាប់, ប្រើ (ឧ. bien manier l'épée, la parole)។ *n.m.* សម្ផស្ស ។ au manier ដោយស្ទាប

manière *n.f.* យ៉ាង, របៀប, បែប ។ manière de servir របៀបធ្វើការ។ manière de voir យោបល់។ manière de penser មតិ។ c'est une manière de parler គ្រាន់តែពាក្យសំដីខ្លាំងពេក ។ *pl.* ឫក, ឫកពា, បែបបទ (ឧ. avoir des manières rudes) ។ *Fam.* faire des manières à ធ្វើឫក ។

Loc.pré. de manière à ដើម្បីនឹង ។ à la manière de តាមរបៀប។ de manière que ឬ de telle manière que *loc. conj.* យ៉ាងណាឲ្យតែ (ឧ. il agit de manière que l'on voit (ឬ voie) ses intentions)

maniéré,e *a.* មាយា, ដែលធ្វើឫក (ឧ. femme maniérée) ។ *Fig.* ខ្លស់ពេក (ឧ. style maniéré)

maniérisme *n.m.* ការមិនធម្មជាតិ (សិល្បៈ, អក្សរសាស្ត្រ)

manieur *n.m.* អ្នកកាន់ (ពាក្យនេះប្រើតែសម្រាប់បន្តុះបង្អាប់ក្នុងសំនួនសេចក្តី manieur d'argent អ្នកកាន់ប្រាក់គំហោរញ៉ាក)

manifestant,e *n.* ជាតុករ, អ្នកធ្វើជាតុកម្ម

manifestation *n.f.* ជាតុកម្ម, ការសំដែង

manifeste *a.* បច្ចុប្ប [ជាំប-ជាក់], ជាក់ស្តែង (ឧ. erreur manifeste)

manifeste *n.m.* និវេទន៍, សេចក្តីថ្លែង។ *Mar.* និវេទនប័ណ្ណ (បញ្ជីរាយឈ្មោះរបស់ទុកក្នុងនាវា)

manifestement *adv.* ដោយបច្ចុប្ប, ដោយជាក់ស្តែង

manifester *v.t.* សំដែង (ឧ. manifester sa joie)។ *v.i.* ធ្វើជាតុកម្ម ។ se manifester *v.pr.* បញ្ចេញឲ្យឃើញ (ឧ. Dieu se manifeste par ses œuvres)

manigance *n.f. Fam.* ឧបាយសម្ងាត់

manigancer *v.t. Fam.* ប្រើឧបាយសម្ងាត់

manille *n.m.* ស៊ីហ្គារមកពីម៉ានីល(ហ្វីលីពីន); ម្លូកបច្ចុតម្សៅង។ chanvre de Manille ឫ.ព. abaca

manioc *n.m.* ក្តួច ឬ ដំឡូងឈើ

manipulateur *n.m.* អ្នកលាយឱសថ (ឧ. un manipulateur de produits chimiques)

manipulation *n.f.* សហត្ថការណ៍ (ការកាន់, ការលាយ; ការរៀបចំ) (ឧ. la manipulation de la dynamite est dangereuse) ។ *Fig.* ឧបាយបញ្ឆោត (ឧ. manipulation électorale)

manipuler *v.t.* កាន់, លាយ; រៀបចំ (ឧ. manipuler des drogues; manipuler un appareil)

manitou *n.m.* ម៉ានីទូ (អាទិទេពតាមជំនឿនៃអន្តាក្រាមនៅអាមេរិកខាងជើង)

manivelle *n.f. Techn.* ដៃរ៉ៃ

manne *n.f.* ម្លូបទិព ។ *Par ext.* បំណើបរិបូណ៌ហើយជោក

manne *n.f.* កញ្ជ

mannée *n.f.* ចំនួនមួយកញ្ជ

mannequin *n.m.* ជាលតូចវែង

mannequin *n.m.* រូបសំណាក, ទីងមោង ; ស្ត្រីអ្នកបង្ហាញសំលៀកបំពាក់បែបថ្មី ។ *Fig.* មនុស្សទីងមោង (ឲ្យ

គេដឹកនាំបានតាមចិត្ត)

manette *n.f.* កូនកញ្ចៀ

manœuvrabilité *n.f.* សុចលនភាព, ភាពស្រួលបើកបរ (ឧ. la manœuvrabilité d'un avion)

manœuvrable *a.* ស្រួលបើកបរ

manœuvre *n.f.* ការធ្វើឲ្យគ្រឿងយន្ត (ឧ. manœuvre d'une pompe); ហត្ថកិច្ច, ការសមយុទ្ធ (ឧ. un général habile à la manœuvre)។ *Mar.* ការបើកនាវា ។ *Fig.* កលល្បិច, ឧបាយ (ឧ. déjouer les manœuvres d'un adversaire)។ faire fausse manœuvre ធ្វើខុស (មិនទំនង)។ manœuvres électorales កលល្បិចបោះឆ្នោត។ manœuvres frauduleuses កលល្បិចបន្លំ (ដើម្បីឲ្យគេទុកចិត្ត) ។ *n.m.* ហត្ថករ (កម្មករធ្វើការដោយកម្លាំង) ។ manœuvre spécialisé ហត្ថករឯកទេស

manœuvrer *v.t.* បើកបរ (ឧ. manœuvrer un navire, ធ្វើម៉ាស៊ីនឲ្យដើរ (ឧ. manœuvrer une pompe)។ *Fig.* ដឹកនាំដើម្បីឲ្យបានសម្រេច ។ *v.i.* សមយុទ្ធ (ឧ. la troupe a bien manœuvré)។ *Fig.* ប្រើកលល្បិចដើម្បីឲ្យបានសម្រេច (ឧ. manœuvrer sourdement)

manœuvrier *n.m.* អ្នកពូកែខាងបើកបរនាវា ឬ ពូកែខាងសមយុទ្ធ ។ *Par ext.* អ្នកប៉ិនកលល្បិច

manoir *n.m.* ផ្ទះធំមានសួនដីជុំវិញ; ផ្ទះ

manomètre *n.m.* *Techn.* សម្ពាធមាត្រ (ប្រដាប់ស្ទង់កម្លាំងចំហាយទឹក ឬ ឧស្ម័ន) (ឧ. manomètre métallique)

manométrique *a.* នៃសម្ពាធមាត្រ (ឧ. capsule manométrique)

manquant,e *n.&a.* ដែលខ្វះ (ឧ. remplacer les manquants)

manque *n.m.* ការខ្វះ (ឧ. manque d'argent); អ្វីៗដែលខ្វះ ។ manque à gagner ការខានបានចំណេញ ។ *Pop.* à la manque មិនល្អ ។ manque de *loc. pré.* ដោយខ្វះ

manqué,e *a.* ខូច, មិនល្អ (ឧ. ouvrage manqué); មិនគ្រប់លក្ខណៈ (ឧ. projet, avocat manqué)

manquement *n.m.* កំហុស, បទល្មើស

(ឧ.manquement à la morale)

manquer *v.i.* ខ្វះ (ឧ. les vivres manquaient) ។ *Par ext.* ស្លាប់, បាត់ខ្លួន (ឧ. s'il venait à manquer, sa famille serait ruinée); ខ្វះ, មិនឃើញមក (ឧ. plusieurs élèves manquent aujourd'hui) ។ *Impers.* ខ្វះ (ឧ. il manque dix élèves) ។ *v.t.* ខ្វះ, ថ្លោន (ឧ. les forces lui manquaient); ខកខាន, មិនបំពេញ, ប្រព្រឹត្តខុស (ឧ. manquer à son devoir, à sa parole); មិនមក (ឧ. manquer à une séance); មិនគោរព (ឧ. manquer à un supérieur) ។ le pied lui a manqué គាត់ភ្លាត់ជើងកក្រល់ខ្លួន។ ខ្វះ (ឧ. manquer d'argent); ភ្លេះ, ស្ទើរតែ (ឧ. il a manqué de se noyer ឬ il a manqué se noyer)។ne pas manquer de កុំភ្លេច, មិនភ្លេច (ឧ. je ne manquerai pas de le lui dire) ។ *v.t.* មិនបានសម្រេច (ឧ.manquer une affaire); ខកឱកាសទៅ (ឧ. manquer une occasion); បាញ់ខុស (ឧ. manquer un lièvre); ខាន, មិនបានជួប (ឧ. manquer un rendez-vous, un ami)

mansarde *n.f.* ស្អាកក្រោមដំបូល

mansuétude *n.f.* ចិត្តស្លូតបូត, ចិត្តល្អ

mante *n.f.* អាវក្លាធំដែលសម្រាប់ស្ត្រី ។ *Zool.* កណ្តូបសេះ (ពាក្យធម្មតាហៅថា mante religieuse, mante prie Dieu)

manteau *n.m.* អាវក្រៅខ្លាយ។ sous le manteau *loc. adv. Fig.* ដោយលួចលាក់, ដោយស្ងាត់កំបាំង

mantelet *n.m.* អាវក្រៅខ្លីសម្រាប់ស្ត្រី

mantille *n.f.* កន្សែងខ្លួរសម្រាប់ស្ត្រី

mantique *n.f.* សិល្បៈខាងទាយ

manucure *n.* អ្នកថែដៃ

manuel,elle *a.* ជំនិតដៃ; ដែលធ្វើដោយដៃ។ *a.&n.* ហត្ថកម្មករ, ដែលធ្វើការដោយដៃ (ឧ. travailleur manuel)។ travail manuel ការហត្ថកម្ម។ *n.m.* សៀវភៅ, គម្រា, ក្បួនតូច ។ manuel scolaire សៀវភៅសិក្សា

manuellement *adv.* ដោយដៃ

manufacturable *a.* អាចធ្វើក្នុងកម្មន្ត-

សាលបាន (ឧ. produit manufacturable)

manufacture *n.f.* កម្មន្តសាល (ឧ. manufacture de tabac)

manufacturer *v.t.* ធ្វើនៅក្នុងកម្មន្តសាល (ឧ. manufacturer des tissus)

manufacturier,ère *n.* ម្ចាស់កម្មន្តសាល ។ *a.* នៃកម្មន្តសាល (ឧ. industrie manufacturière)

manuscrit,e *a.* ដែលសរសេរដោយដៃ (ឧ. pièce manuscrite) ។ *n.m.* សៀវភៅសរសេរដោយដៃ(ផ្ទុយពីសៀវភៅបោះពុម្ព)

manutention *n.f.* ហត្ថក្រោះ, ការលើកដាក់; ការរៀបចំទំនិញ; ហត្ថគ្រឹះ; ហត្ថកោបនា; រោងគ្រឿងហារ

manutentionnaire *n.* អ្នកលើកដាក់; ការរៀបចំទំនិញ

manutentionner *v.t.* ធ្វើ - លើកដាក់ ឬរៀបចំទំនិញ

mappemonde *n.m.* ផែនទីសកលលោក ។ mappemonde céleste ផែនទីនភាកាស, ផែនទីមេឃប្រកបដោយតារានិករ

maquereau *n.m.* ត្រីស្បៃកា

maquette *n.f.* សំណាក

maquettiste *n.* ជាងធ្វើសំណាក

maquignon *n.m.* អស្សពាណិជ, ឈ្មួញសេះ។ *Fig.* ជើងសារជំនួញប៉ិនប្រសប់

maquignonnage *n.m.* អស្សពាណិជ្ជកម្ម; ជំនួញសេះ ។ *Fig.* ឧបាយកលជើងសារជំនួញ

maquignonner *v.t.* ប្រើឧបាយកលលាក់គុណវិបត្តិសេះ ។ *Fig.* ប្រើឧបាយកលដើម្បីឲ្យបានសម្រេច

maquillage *n.m.* ការលាបមុខ; ការក្លែង

maquiller *v.t.* លាបមុខ, ផាត់ម្សៅ (ឧ. maquiller son visage)។ *Fig.* ក្លែង (ឧ.maquiller les faits)។ se maquiller *v.pr.* លាបមុខខ្លួនឯង

maquilleur,euse *n.* អ្នកផាត់ម្សៅឲ្យតួល្ខោន

maquis *n.m.* គុម្ពោត ។ prendre le maquis ចូលពួនព្រៃ។*Par anal.* ព្រៃសម្រាប់ពួនគេច; ក្រុមអ្នកពួនព្រៃ ។ *Fig.* ភាពស្មុគស្មាញ (ឧ. le maquis de la procédure)

maquisard *n.m.* អ្នកពួនព្រៃ (ដើម្បីគេច)

marabout *n.m.* អាចារ្យសាសនាអ៊ីស្លាម; កូនវិហារអ៊ីស្លាម ; កំសៀវទឹកម្យ៉ាង; ត្រដក់; ស្វាបត្រដក់

maraîcher,ère *n.* អ្នកដាំបន្លែ ។ *a.* នៃការដាំបន្លែ (ឧ. culture maraîchère)

marais *n.m.* ឧទកដ្ឋាន, ទំនាបបឹង; ដីដាំបន្លែ ។ marais salants ស្រែអំបិល

marasme *n m.* ភាពស្គមកំព្រឹង; ភាពអស់កម្លាំងទឹកចិត្ត; ភាពចុះដុនដាប (ឧ. le commerce est dans le marasme)

marâtre *n.f.* ម្ដាយចុង ។ *Par ext.* ម្ដាយចិត្តអាក្រក់

maraud,e *n.* ជនគួរឲ្យមើលងាយ

maraudage *n.m.* ឬ **maraude** *n.f.* ការលួចបន្លែ ផ្លែឈើ ។ taxi en maraude តាក់ស៊ីដែលស្វែងរកអ្នកជិះ

marauder *v.i.* ដើរលួចបន្លែ-ផ្លែឈើ; លួចរបស់បន្តិចបន្តួច

maraudeur,euse *n.* ចោរលួចបន្លែ-ផ្លែឈើ; អ្នកបើកតាក់ស៊ីស្វែងរកអ្នកជិះ

marbre *n.m.* ម៉ាក, ថ្មកែវ; របស់ធ្វើអំពីថ្មកែវ ។ cœur de marbre ចិត្តរឹងដូចថ្ម (គ្មានមេត្តា)

marbré,e *a.* ដូចថ្មកែវ (ឧ. figure marbrée par le froid); ដែលមានសាច់ឡាយដូចថ្មកែវ (ឧ. livre dont les plats sont marbrés)

marbrer *v.t.* លាបត្រួតធ្វើជាសាច់ថ្មកែវ

marbrerie *n.f.* សិល្ប ឬរោងជាងថ្មកែវ

marbreur,euse *n.* ជាងលាបធ្វើជាសាច់ថ្មកែវ

marbrier,ère *a.* នៃថ្មកែវ ។ *n.m.* ជាងថ្មកែវ ។ *n.f.* កន្លែងយកថ្មកែវ

marbrure *n.f.* សាច់ឡាយដូចថ្មកែវ

marc *n.m.* កាកផ្លែឈើដែលគេច្របាច់យកទឹកជម្រួចហើយ (ឧ. marc de raisin); កាក (របស់ដែលដុង) (ឧ. marc de café)

marcassin *n.m.* កូនជ្រូកព្រៃ

marcescence *n.f.* ភាពស្រពោន (ផ្កា, ដើមឈើ)

marcescent,e *a.Bot.* ស្រពោន

marcescible *a.Bot.* អាចស្រពោនបាន

marchand,e *n.* ឈ្មួញ ។ *Fig.* être le mauvais marchand d'une chose ជួញតែទុក្ខ (ធ្វើការរឿមិនបានចំណេញ បែរជាបានទុក្ខទៅវិញ) ។ *a.* នៃពាណិជ្ជកម្ម (ឧ la valeur marchande d'un objet) ។ den-

rée marchande គ្រឿងបរិភោគងាយលក់ ។ marine marchande កងនាវាជំនួញ (ផ្ទុកទំនិញ) ។ navire ឬ vaisseau marchand នាវាជំនួញ(ផ្ទុកទំនិញ)។ prix marchand តម្លៃរវាងឈ្មួញ (តម្លៃដែលឈ្មួញលក់ឲ្យឈ្មួញដូចគ្នា)។ qualité marchande គុណភាពជំនួញ(គុណភាពសាមញ្ញ)។ville marchande ក្រុងជំនួញ

marchandage *n.m.* ការតថ្លៃ;ការម៉ៅឈ្នួលផាង (ឧ. le marchandage est interdit par la loi, car il constitue une exploitation de l'ouvrier par le marchandeur)

marchander *v.t.* តថ្លៃ (ឧ. marchander du drap);អ្នកម៉ៅឈ្នួលផាង ។ *Fig.* ឲ្យដោយត្បិតត្បៀត ។ marchander des éloges សរសើរដោយមិនស្មោះ

marchandeur,euse *n.* អ្នកតថ្លៃច្រើន ។ *n.m. Constr.* ម៉ៅឈ្នួលផាង

marchandise *n.f.* ទំនិញ (ឧ. un magasin rempli de marchandises) ។ *Fig.* faire valoir sa marchandise បើះបង្ហាញឲ្យគេចូលចិត្ត

marchant,e *a.* ដែលដើរ (ឧ. l'aile marchante d'une troupe)

marche *n.f.* ការដើរ, ដំណើរ (ឧ. ralentir sa marche); រយៈពេលដើរ (ឧ. village situé à une heure de marche); ឋលនាទ័ព (ឧ. les marches savantes de Turenne) ។ marche forcée ដំណើរបង្ខំ (លើសពីរយៈពេលត្រូវឈប់សំចត)។ ដំណើរ (ឧ. la marche de la lune, d'un navire, d'une horloge); ភ្លេងដើរ (ឧ. jouer une marche)។*Fig.* ដំណើរ, ការចំរើន (ឧ.la marche de la science, d'une affaire)

marche *n.f. Constr.* កាំជណ្ដើរ ។ *Techn.* ឈ្នាន់; ថ្នាក់

marché *n.m.* អាបណដ្ឋាន, ផ្សារ (ឧ. marché aux légumes); របស់ដែលទិញ (ឧ. faire son marché); អាបណសញ្ញា, កិច្ចសន្យាទិញ-លក់ (ឧ.maché avantageux)។ marché de gré à gré អាបណ-

សញ្ញាព្រមព្រៀង ។ marché ferme កេបណសញ្ញាហើយ ។ marché à prime កេបណសញ្ញាមានបុព្វលាភ ។ marché de fournitures អាបណសញ្ញាគ្រឿងផ្គត់ផ្គង់ ។ កិច្ចសន្យា (ឧ. rompre un marché) ។ marché noir ផ្សារងងឹត ។ bon marché ថោក ។ faire bon marché de មិនស្ដាយ, មិនគិតពិច័យ ។ faire bon marché de sa vie មិនគិតពិច័យដល់ជីវិតខ្លួនឯង ។ mettre le marché à la main (ឬ en main) ទុកឲ្យសម្រេចអំពីកិច្ចសន្យា (គួរយល់ព្រមឬបដិសេធ) ។ par-dessus le marché ថែមទៀត

marchepied *n.m.* ជណ្ដើរខ្ទី; ឈ្នាន់ (រទេះយន្ត) ។ *Fig.* មធ្យោបាយឡើងកាន់តំណែងខ្ពស់ (ឧ. cet emploi lui a servi de marchepied)

marcher *v.i.* ដើរ (ឧ. marcher rapidement); ដើរជាន់ (ឧ. marcher sur les doigts de quelqu'un); ដើរឬប្រព្រឹត្តទៅតាមធម្មតា (ឧ. cette montre marche) ។ marcher à pas de loup ដើរលបៗ (មិនឲ្យឮសូរ) ។ *Fig.* ចម្រើន (ឧ. affaire qui marche) ។ *Fam.* ជឿដោយឆោត ។ marcher droit ប្រព្រឹត្តតាមគន្លង ។ marcher sous quelqu'un នៅក្រោមបង្គាប់ ។ marcher sur les pas de quelqu'un ត្រាប់ ។ marcher sur les pieds de quelqu'un ដើរជាន់ជើង; ប្រមាថ, មើលងាយ ។

v.t. ជាន់ (ឧ. marcher l'argile à potier) ។

n.m. ដំណើរ; ដីដែលគេជាន់ដើរ

marcheur,euse *n.&a.* ដែលដើរ, អ្នកពូកែដើរ (ឧ. marcheur infatigable) ។ *n.f.* ស្រីយាវហ (គ្មាននិយាយស្ដី)

marcottage *n.m.* ការផ្សាំ (ដោយបង្កប់មែកក្នុងដី)

marcotte *n.f.* មែកផ្សាំ (ដោយបង្កប់ក្នុងដីឲ្យចាប់ឫស) (ម.ព. bouture, greffe ផង)

marcotter *v.t.* ផ្សាំ (ដោយបង្កប់មែកក្នុងដី)

mardi *n.m.* ថ្ងៃអង្គារ

mare *n.f.* ស្រះ, ត្រពាំង ។ *Par ext.*

une mare de sang ថ្លុកឈាម

marécage *n.m.* វាលភក់ល្បាប់

marécageux,euse *a.* ពាសពេញដោយភក់ល្បាប់, ដែលជាវាលភក់ល្បាប់ (ឧ. contrée marécageuse)

maréchal *n.m.* សេនាប្រមុខ។ maréchal des logis ពលបាល (ខាងទ័ពសេះ, ខាងកងតម្រួតទាហាន)។ maréchal des logis - chef ពលបាលទោ។ maréchal des logis-major ពលបាលឯក

maréchalat *n.m.* ឋានៈជាសេនាប្រមុខ

maréchale *n.f.* ភរិយាសេនាប្រមុខ; ត្បូងថ្មម៉្យាង

maréchalerie *n.f.* មុខរបរឬរោងជាងដោះក្រចកសេះ

monométallisme *n.m.* ឯកលោហនិយម (របបរូបិយវត្ថុដែលនិយមប្រើលោហធាតុតែមួយ ទុកជាមានតុល្យភាពដោះដំណាក់ដោយគតព្រំដែន ហើយដែលដោះដាយបានដោយសេរី) (ផ្ទុយនឹង bimétallisme)

monométalliste *a.* នៃឯកលោហនិយម។ *n.* អ្នកឯកលោហនិយម

monomoteur *a.* ដែលមានម៉ាស៊ីនតែមួយ (អាកាសយាន)

monoplace *a.* ដែលមានកន្លែងតែមួយ (ឧ. voiture monoplace)

monoplan *n.m.* *Aéron.* អាកាសយានស្លាបមួយជាន់

monoplégie *n.f.* ដំណើរស្លាប់អវយវៈតែមួយ

monopole *n.m.* ឯកាធិភាព, ដំណើរផ្តាច់មុខ (ឧ. l'état possède le monopole des tabacs et allumettes) ។ monopole de pavillon ឯកាធិភាពនៃនាវា(ដំណើរ

ផ្តាច់មុខនៃតាវ៉ារបស់ជាតិ ក្នុងទឹកដីជាតិណាមួយវៀរលែងតែមានអនុញ្ញាតទើបតាវ៉ាជាតិដទៃចូលបាន) ។ *Fig.* ដំណើរផ្តាច់មុខ (មានតែម្នាក់ឯង) (ឧ. s'attribuer le monopole de la vertu)

monopolisation *n.f.* ឯកាធិកម្ម, ការធ្វើឬទទួលផ្តាច់មុខ

monorail *a.&n.m.* ឯករេណាបថ

monorime *a.* ដែលមានរគុងចួនតែមួយ

monosépale *a.* ដែលមានត្របកក្រៅតែមួយស្រទាប់ (ឧ. fleur monosépale)

monopoliser *v.t.* ធ្វើឬទទួលផ្តាច់មុខ។ *Fam.* ប្រមូលតែម្នាក់ឯង

monosyllabe *n.m.* ពាក្យឯកព្យាង្គ

monosyllabique *a.* ឯកព្យាង្គ (ឧ. mot monosyllabique); ដែលមានសុទ្ធតែពាក្យឯកព្យាង្គ (ឧ. vers monosyllabique)

monosyllabisme *n.m.* ភាពឯកព្យាង្គ, ភាពភាសាដែលមានពាក្យឯកព្យាង្គ (ឧ. le monosyllabisme chinois)

monothéisme *n.m.* ឯកាទិទេពនិយម, ការនិយមជឿថាមានអាទិទេពតែមួយ (ឧ. le monothéisme juif)

monothéiste *a.* ឯកាទិទេពនិយម ។ *n.* អ្នកឯកាទិទេពនិយម

monotone *a.* ឯកសព្ទ (ឧ. chant monotone) ។ *Fig.* ដដែលៗ (គ្មានប្រែប្រួល) (ឧ. style monotone)

monotonie *n.f.* ឯកតាន (ភាពមានសម្លេងតែមួយគឺសម្លេងស្មើឥតប្រែប្រួល) ។ *Fig.* ភាពដដែលៗ (ឥតប្រែប្រួល)

monseigneur *n.m.* សម្តេច (*pl.* messeigneurs, nosseigneurs)

monsieur *n.m.* លោក។ un vilain monsieur ជនអាក្រក់ម្នាក់ ។ faire le monsieur ធ្វើឫកលោក (ធ្វើឫកជាអ្នកធំ) (*pl.* messieurs)

monstre *n.m.* វិរូបកាយ, សត្វចំឡែក (ឧ. les frères siamois sont des monstres doubles); សត្វដែលមានតែក្នុងរឿងព្រេង; មនុស្សខុសគេ (ឧ. épouser un monstre); របស់ឬសត្វធំសំបើម (ឧ. les monstres marins) ។

a. Fam. អស្ចារ្យ; ធំសំបើម (ឧ. dîner monstre)

monstrueusement *adv.* យ៉ាងអស្ចារ្យ, យ៉ាងសំបើម

monstrueux,euse *a.* វិរូប, ចំឡែក (ឧ. enfant monstrueux); អស្ចារ្យ, សំបើម (ឧ. grosseur monstrueuse) ។ *Fig.* ក្រៃពេក (ឧ prodigalité monstrueuse); គួរឲ្យខ្លាច (ឧ. crime monstrueux)

monstruosité *n.f.* វិរូបភាព, ភាពចំឡែក ឬ អស្ចារ្យ: អ្វីៗធំអាក្រក់សំបើម-គួរឲ្យខ្លាច (ឧ. ce meurtre est une monstruosité)

mont *n.m.* ភ្នំ ។ *Fig.* promettre monts et merveilles សន្យាហួសហេតុ ។ par monts et par vaux *loc. adv.* គ្រប់ទិស

montage *n.m.* ការយោងឡើង ។ *Techn.* ការតម្លើង (ឧ. le montage d'une machine) ។ *Cin.* ការតម្លើងខ្សែភាពយន្ត (ការជ្រើសរើសនឹងការផ្គុំរឿងខ្សែភាពយន្តដែលបានថតជាប់ៗពីគ្នា)

montagnard,e *n.&a.* អ្នកស្រុកភ្នំ

montagne *n.f.* ភ្នំ ។ *Par anal.* ភ្នំ, គំនរធំ (ឧ. une montagne de livres) ។ chaîne de montagne ម. chaîne ។ montagne russe កន្លែងមានខ្ពស់ទាបច្រើនសម្រាប់ជិះការរអិលលេង ។

Prov. & loc. prov. la montagne a enfanté une souris ការធំឲ្យផលស្ដួច ។ il n'y a que les montagnes qui ne se rencontrent jamais កង់ព្រាចកង់ជួប ។ chaque montagne a sa vallée ឬ pas de montagne sans vallée ភ្នំតែងតែមានជ្រលង; របស់នីមួយៗតែងមានល្អមានអាក្រក់

montagneux,euse *a.* ដែលមានភ្នំច្រើន

montant *n.m.* មេបញ្ឈរ; មេជណ្ដើរ; ចំនួនទឹកប្រាក់, តម្លៃ (ឧ. le montant d'une note d'hôtel); ក្ងូនមុត

montant,e *a.* ដែលឡើង (ឧ. marée montante); ដែលឡើងចោត

mont-de-piété *n.m.* សន្ធិណាគារ (*pl.* des monts-de-piété)

monte *n.f.* ការជិះសេះ; របៀបជិះសេះ; ការពាក់គ្នា (សត្វពាហនៈខ្លះ); ការឡើងទំឃ្លាប (ដង្កូវនាង)

monté,e *a.* ដែលមាន (ឧ.être bien monté en vêtements) ។

être bien monté មានសេះល្អ ។ être mal monté មានសេះមិនល្អ ។ soldat monté ទាហានដែលប្រតិបត្តិការដោយជិះសេះ ។ coup monté ការធ្វើអ្វីដោយប្រុងប្រៀបមុនយ៉ាងសម្ងាត់ ។ être monté ខឹង

monte-charge *n.m.* ប្រដាប់យោង (យោងអីវ៉ាន់ពីថ្នាក់ក្រោមឡើងទៅថ្នាក់លើ)

montée *n.f.* ការឡើង; ជម្រាល, ដីដែលឡើងកាន់តែខ្ពស់ (ឧ. gravir une montée); ផ្លូវឡើង; ជំនន់ទឹក

monténégrin,e *a.&n.* នៃប្រទេសម៉ុងតេណេគ្រូ

monte-pente *n.m. inv.* ប្រដាប់យោងឡើងជោត (ឧបករណ៍កីឡានៃសិសិររដូវ) (ដូច remonte-pente ក៏បាន)

monte-plats *n.m. inv.* ប្រដាប់យោងចាន

monter *v.i.* ឡើង (ឧ. monter sur un arbre); ឡើងជិះ (ឧ. monter en avion, à cheval); មានកំពស់ (ឧ. la tour Eiffel monte à plus de trois cents mètres); ឡើង, ជន់ (ឧ. la rivière a monté de plusieurs centimètres); កាន់តែខ្ពស់ (ឧ. le terrain monte); ឡើងគ្រលួច (ឧ. la voix monte par tons et demi-tons) ។

Fig. ឡើង (ឋានន្តរស័ក្តិ) (ឧ. monter en grade); ឡើងថ្លៃ (ឧ. le blé monte); មានចំនួនទឹកប្រាក់ (ឧ. la dépense monte à mille riels) ។

monter sur le trône ឡើងសោយរាជ្យ ។ monter sur les planches ចូលលេងល្ខោន ។

v.t. ឡើង (ឧ. monter un escalier); យោង, យកឡើង (ឧ. monter du foin au grenier); តម្លើង (ឧ. monter une machine); មួលឡាន (ឧ. monter un ressort); ជិះ (ឧ. monter un cheval); រៀបចំ (ឧ. monter sa maison); ដាំ (ត្បូង) (ឧ. monter un diamant) ។

Fig. រៀបចំ, បង្កើត (ឧ. monter une entreprise) ។ monter la tête សម្រើប ។ monter la garde យាម ។ *Fam.* monter

le coup à une personne បំពាន ។

se monter *v.pr.* ផ្គត់ផ្គង់ខ្លួនឯង (ឧ. se monter en linge)។ se monter la tête ស្រើប (*lit.* escalader, gravir, grimper)

monte-sacs *n.m. inv* ប្រដាប់យោងបាវ

monteur,euse *n.* ជាងអ្នកតម្លើង; ជាងធ្វើពេជ្រ

montgolfière *n.f.* ប៉េងប៉ោះ

monticole *a.* ដែលរស់នៅឬដុះលើភ្នំ

monticule *n.m.* ទួលភ្នំ, ទំពូក

montoir *n.m.* ដុំថ្មឬដុំឈើសម្រាប់ជាន់ឡើងជិះសេះ ។ côté montoir ខាងឆ្វេង (សេះ)

montrable *a.* អាចបង្ហាញបាន (ឧ. ma figure n'est pas montrable)

montre *n.f.* នាឡិកាដៃ ។ montre à répétition នាឡិកាដែលមានភ្លេងរោទ៍

montre *n.f.* ទំនិញតាំង, ទូតាំងទំនិញ (ឧ. mettre un article en montre)។ *Fig.* faire montre de បញ្ចេញឲ្យគេឃើញ (ឧ. faire montre de son érudition)

montre-bracelet *n.f.* នាឡិកាបង់ដៃ (*pl.* des montres-bracelets)

montrer *v.t.* បង្ហាញ, តាំង (ឧ. montrer ses bijoux); ចង្អុល (ឧ. montrer du doigt) ។ *Fig.* សំដែង, បញ្ចេញ (ឧ. montrer du courage); បង្ហាញ, សឲ្យឃើញ(ឧ. montrer qu'on a raison) ។ montrer des dents បញ្ចេញធ្មេញ; សំដែងការគំរាម ។ montrer les talons រត់ ។ montrer quelqu'un au doigt ឬ du doigt ម.ព. doigt ។

v.i. ind. (à) បង្ហាញ, បង្រៀន (ឧ. montrer à quelqu'un à écrire) ។

se montrer *v.pr.* សំដែងឲ្យគេឃើញច្បាស់

montreur,euse *n.* អ្នកបង្ហាញអ្វីៗឲ្យសាធារណជនមើល (ឧ. montreur d'ours, de marionnettes)

montueux,euse *a.* ខ្ពស់ទាប, មានភ្នំ (ឧ. terrain montueux)

monture *n.f.* ជំនិះ ។ *Techn.* ដង, ជើង(ឧ. monture d'une scie);

ព្រោប់ (សំរាប់ពាប់ត្បូង) (ឧ. monture en or); ក្បាលជាំ (ឧ. la monture vaut, à elle seule, 3.000 riels)

monument *n.m.* បូជនីយស្ថាន ។ monument public បូជនីយស្ថានសាធារណៈ ។ Monument de l'Indépendance បូជនីយស្ថានឯករាជ្យ ។ *Fig.* ស្នាដៃដ៏ល្អទុកឲ្យកូនចៅជាន់ក្រោយ (ឧ. les œuvres d'Homère sont les plus beaux monuments de l'Antiquité)

monumental,e,aux *a.* នៃបូជនីយស្ថាន (ឧ. plan monumental de Paris); ធំសំបើម (ឧ. une statue monumentale)។ *Par anal.&fam.* សំបើម, ចំឡែក (ឧ. il est d'une bêtise monumentale)

moque *n.f.* ពោយ (គ្រឿងឡាក ឬកំប៉ុងមានដង)

moquer (se) *v.pr.* ចំអក(ឧ. Molière s'est moqué des précieuses); មិនរវល់ (មិនធ្វើជាដឹង); មិនខ្វាយ, ពុះ-ពារ (ឧ. se moquer du qu'en-dira-t-on); និយាយលេង (ឧ. c'est se moquer que de...)

moquerie *n.f.* ការចំអក; សំដី ឬ អំពើចំអក (ឧ. de fines moqueries)

moquette *n.f.* ផ្លាក់ (បក្សី)

moquette *n.f.* កម្រាល, ព្រំ

moqueur,euse *n.&a.* អ្នកចំអក; ដែលចំអក (ឧ. sourire moqueur)

moqueusement *adv.* ដោយចំអក

moracées *n.f pl.* ខ្ទុម្ពជាតិ

morailles *n.f.* ដង្កាប់ចាប់ច្រមុះសេះដែលគេបោះក្រចក

moraillon *n.m.* សន្ទះសោ

moraine *n.f.* ដុំថ្មដោយកាមក់នៅទឹកកក

moral,e,aux *a.* ខាងចរិយា (ឧ. le progrès moral); ត្រឹមត្រូវតាមសីលធម៌ (ឧ. vie morale); ដែលទូន្មានឲ្យប្រព្រឹត្តល្អ (ឧ. livre moral); ដែលមានចរិយាល្អ (ឧ. homme moral); ខាងផ្លូវចិត្ត (ឧ. rapport moral) ។

n.m. ទឹកចិត្ត (ឧ. le physique influe sur le moral); relever le moral de quelqu'un)

morale *n.f.* សីលធម៌ (វិជ្ជាសាស្ត្រសម្រាប់ទូន្មានឲ្យធ្វើអំពើល្អហើយឲ្យគម

អំពើអាក្រក់); ការស្តីបន្ទោស (ឧ. faire la morale à un enfant); ដំបូន្មាន (ឧ. la morale d'une fable)

moralement *adv.* តាមសីលធម៌; ខាងផ្លូវចិត្ត (ឧ. être moralement sûr d'un fait)

moralisateur,trice *a.* សម្រាប់ទូន្មាន (ឧ. récit moralisateur)

moralisation *n.m.* ការទូន្មាន

moraliser *v.t.* ធ្វើឲ្យត្រឹមត្រូវតាមសីលធម៌ ។ *Fam.* ទូន្មាន; ស្តីបន្ទោស (ឧ. moraliser un enfant) ។ *v.i.* ថ្លែងអំពីសីលធម៌

moraliseur,euse *n.* អ្នកហៃទូន្មាន

moralisme *n.m.* សីលធម៌និយម (ឧ. le moralisme de J.-J. Rousseau)

moraliste *n.&a.* អ្នកសីលធម៌និយម(ឧ. la sobriété est regardée par tous les moralistes comme la mère de la santé) ។ *Fam.* អ្នកចូលចិត្តទូន្មាន (ឧ. me préserve le ciel de m'ériger en moraliste)

moralité *n.f.* ធម្មចរិយា, ការទាក់ទងនៃចរិយានឹងសីលធម៌ (ឧ. un homme d'une moralité irréprochable); ដំបូន្មាន (ឧ. la moralité d'un conte)

moratoire *a.* intérêt moratoire ការប្រាក់ដែលសងយឺត

moratoire *n.m.* សាលក្រមពន្យារពេល

morbide *a.* នៃភាពមានរោគ; ដែលឲ្យឃើញជាឈឺ (ឧ. état morbide) ។ *Fig.* ខូចសតិ

morbide *a.* *Bx-arts* ប្រណិត

morbidesse *n.f.* ភាពប្រណិតនៃសាច់ (ក្នុងរូបគំនូរ ឬ រូបចម្លាក់)

morbidité *n.f.* ភាពឈឺ, រោគប្បមាណ (ការគមនុស្សឈឺក្នុងចំនួនប្រជាពលរដ្ឋ)

morbifique *a.* ដែលធ្វើឲ្យឈឺ, ដែលបង្ករោគ (ឧ. humeur, virus morbifique)

morbilleux,euse *a.* *Méd.* នៃរោគកញ្ជ្រិល (ឧ. fièvre morbilleuse)

morbleu! *int.* យ៉ាអើ ! (សំដែងកំហឹងជាដើម)

morceau *n.m.* ដុំ, កំណាត់, ភាគ, កង់ (ឧ. morceau de pain; morceau de terre); របស់(ឧ. c'est un morceau de choix គឺជា

របស់សម្រាំង ឬ ជម្រើស); អត្ថបទសម្រាំង (ឧ. un recueil de morceaux choisis); បទភ្លេង (ឧ. morceau de musique)។ aimer les bons morceaux ចូលចិត្តម្ហូបឆ្ងាញ់។ *Fam.* manger un morceau ស្រស់ស្រូប ។ emporter le morceau ខាំស្ទើរដាច់សាច់, ខាំខ្លាំង; *au fig.* និយាយ ឬ ប្រព្រឹត្តយ៉ាងខ្លាំង ។ être fait de pièces et de morceaux យកមកប៉ះប៉ុន; គ្មានឯកភាព។ *Pop.* manger le morceau ប្រាប់រឿងស្ងាត់កំបាំង

morceler *v.t.* ចែកជាដុំ-ជាកង់-ជាកំណាត់-ជាភាគ (ឧ. morceler un héritage)

morcellement *n.m.* ការចែកជាដុំ-ជាកង់-ជាកំណាត់-ជាភាគ (ឧ. morcellement d'un domaine)

mordache *n.f.* បន្ទះស្តាន់ ឬ សំណប្រាប់មាត់អន្លុំ

mordacité *n.f.* ចេះខនភាព, ភាពស៊ី ឬ កាត់ (ឧ. la mordacité de l'eau-forte)។ *Fig.* ភាពសំដីមុត

mordançage *n.m.* ការភ្ជាប់ពត៌ដោយជាតិអ្វីមួយដែលកាត់

mordancer *v.t.* ភ្ជាប់ពត៌ដោយជាតិអ្វីមួយដែលកាត់

mordant,e *a.* ដែលខាំ; ដែលកាត់ (ទឹកក្រក) (ឧ. acide mordant)។ *Par ext.* មុត (សំដី) (ឧ. voix mordante)។ *Fig.* ដែលរិះគន់ (ឧ. esprit, écrivain mordant)។ *n.m.* ហោធាតុមានសន្ធឹក។ *Fig.* ការរិះគន់ (ឧ. le mordant de Molière); ដំណើររហ័សរហួន (ឧ. troupe qui a du mordant)

mordication *n.f.* ដំណើរឈឺចៀបៗ

mordicus *adv.* យ៉ាងស្វិតស្វាញ, យ៉ាងស្វិ (ឧ. soutenir une opinion mordicus)

mordillage *n.m.* ការញញ, ការខាំស្រាលៗ

mordiller *v.t.* ញញ, ខាំស្រាលៗ

mordoré,e *a.* & *n.m* ដែលមានពន្លឺលោកខ្លួមាស (ឧ. des souliers mordorés)

mordorer *v.i.* ធ្វើមានពន្លឺលោកខ្លួមាស

mordorure *n.f.* ពណ៌មានពន្លឺលោកខ្លួមាស

mordre *v.t.* ខាំ, ខឹក; ចាប់យ៉ាងជាប់ (ឧ. tenailles qui mordent le fer); ឆាប, ស៊ូស, ធ្វើឲ្យជាប់-ឲ្យសឹក (ឧ. la lime mord l'acier)។ mordre la poussière ស៊ីដី; ស្លាប់ក្នុងពេលប្រយុទ្ធ; ត្រូវដួលក្នុងពេលចំបាប់គ្នា ។

v.i. mordre à ឬ mordre dans ខាំស៊ី (ឧ. mordre dans son pain); កាត់, ស៊ី ។ *Mar.* ថ្កក់ជាប់ (យុថ្កា) ។ *Méc.* ស៊ី, ខាំ (ឧ. pignon qui ne mord pas assez) ។

v.t. ind. Fig. mordre à រៀន ឬ យល់ដោយរ៉ែករាយ (ឧ. mordre au latin)។ mordre sur លយនុតតែម (ឧ. ardoises qui mordent les unes sur les autres) ។

se mordre *v.pr.* s'en mordre les doigts ស្ដាយក្រោយ

more *a.* ម.ព. maure

moreau,elle *a.* ខ្មៅស្រិល, ខ្មៅរលើប (ឧ une jument morelle)

moresque *a.* & *n.* ម.ព. mauresque

morfil *n.m.* មុខ (មុខកាំបិតដែលទេីបនឹងសំលៀងហើយ)

morfondre *v.t.* ធ្វើឲ្យរងាញាក់ (ឧ. la pluie l'a morfondu) ។ se morfondre *v.pr.* ត្រូវរងា ។ *Fig.* អន្សុកដោយចាំ (ឧ.se morfondre à la porte de quelqu'un)

morfondure *n.f.* រោគគឹងច្រមុះសេះ

morganatiquement *adv.* ដោយខុសវណ្ណៈ (ចំពោះអាពាហ៍ពិពាហ៍ ឧ. se marier morganatiquement)

morganatique *a.* នៃអាពាហ៍ពិពាហ៍រវាងក្សត្រនឹងស្ត្រីវណ្ណៈទាប

morgue *n.f.* ឫកក្អេង (ឧ. montrer de la morgue)

morgue *n.f.* ផរគ្រឹះ, ផ្ទះសព

moribond,e *a.*&*n.* ជិតស្លាប់ (ឃើ. agonisant, mourant)

moricaud,e *a.*&*n.* សម្បុរខ្មៅដែង

morigéner *v.t.* ស្ដីបន្ទោស (ឧ. morigéner un enfant)

morillon *n.m.* ទំពាំងបាយជូរខ្មៅម្យ៉ាង; ទាព្រៃម្យ៉ាង។ *pl.* ត្បូងមរកតមិនទាន់ច្នៃ

morne *a.* ទ្វុំទ្វ, ស្រពាប់ស្រពោន (ឧ.

morne silence) ។ temps morne មេឃខ្ទឹម

morne *n.f.* ចង្កៀស្រោបមុខលំពែង

morné,e *a.* ដែលមានស្រោបចង្កៀ

mornifle *n.f. Pop.* ការទះកមុខដោយខ្នងដៃ

morose *a.* ក្រញូវ (ឧ. air morose) (*syn.* maussade, renfrogné)

morosité *n.f.* ភាពក្រញូវ

morphine *n.f.* ម័រហ្វីន, ឱសថមានជាតិអាភៀន

morphinisme *n.m.* ជំងឺពុលម័រហ្វីន

morphinomane *a.&n.* ដែលញៀនម័រហ្វីន

morphinomanie *n.f.* ការញៀនម័រហ្វីន

morphologie *n.f.* រូបសាស្ត្រ (វិទ្យាសាស្ត្រខាងអាការៈក្រៅ)

morphologique *a.* នៃរូបសាស្ត្រ

morphopsychologie *n.f.* រូបចិត្តសាស្ត្រ (ចិត្តសាស្ត្រដែលសំអាងលើរូបសាស្ត្រ)

mors *n.m.* បង្ហៀ (គ្រឿងបង្ហៀសេះ) ។ *Fig.& Fam.* ការទំងប្រឡោត ។ *Techn.* មាត់ដង្កាប់ ឬ អន្ទាក់

morse *n.m.* ម៉ូស, អក្សរទូរលេខ

morsure *n.f.* ដំបៅឬស្នាមខាំ-ចឹក ។ *Fam.* ពិសពុលក្រាំ (ឧ. les morsures de la calomnie)

mort *n.f.* មរណភាព,អនិច្ចធម្ម,អនិច្ចកម្ម, សេចក្ដីស្លាប់ (ឧ. périr de mort violente); ទោសដល់ជីវិត(ឧ. être condamné à mort); ការឈឺចាប់ខ្លាំង(ឧ.souffrir mille morts)។ *Fig.* ការកើតទុក្ខធំ (ឧ. avoir la mort dans l'âme);គ្មានអ្វីកម្រើក (ឧ. un désert qui n'est que silence et mort); សេចក្ដីវិនាស, សេចក្ដីសាបសូន្យ (ឧ. mort du petit commerce); ហេតុនៃសេចក្ដីវិនាស (ឧ. le monopole est la mort de l'industrie); និមិត្តរូបនៃសេចក្ដីស្លាប់ ។

être à la mort, à deux doigts de la mort, à l'article de la mort ឬ à son lit de mort ហៀបនឹងស្លាប់ ។ être entre la vie et la mort ស្ទើរស្លាប់ស្ទើររស់ (មានគ្រោះថ្នាក់ដល់ស្លាប់) ។ mort de l'âme ឬ mort éternelle ការ

ផុតផ្លូវសួគ៌ (ចុះនរកហ្មត់) ។ mort civile ការប្រាសចាកសិទ្ធិពលរដ្ឋ ។

Loc. adv. à mort ដល់ស្លាប់ (ឧ. blessé à mort); *int.* ប្រយ័ត្នស្លាប់! ។ à la mort ក្រៃពេក, ស្មើរស្លាប់ (ឧ. haïr à la mort) ។ à la vie et à la mort យាវជីវ៍, ជាបដល់អស់ជីវិត (ឧ. être amis à la vie et à la mort)

mort,e *a.* ស្លាប់, ទទួលអនិច្ចធម្ម (បព្ជិត), ទទួលមរណភាព(នាម៉ឺន), ទទួលអនិច្ចកម្ម (មនុស្សធម្មតា) ។ mort pour la patrie មរណៈដើម្បីមាតុភូមិ ។ mort en service commandé មរណៈដោយសេវាបញ្ជា ។ mort au champ d'honneur មរណៈក្នុងរណរង្គ ។ *Fig.* être plus mort que vif ភ័យស្មើរស្លាប់ ។ ដែលវិនាស, ដែលរលត់ (ឧ. espérances mortes); គ្មានសកម្មភាព (ឧ. une ville morte) ។ langue morte ភាសាស្លាប់ (ម.ព. langue ផង) ។ eau morte ទឹកនឹង (មិនហូរ) ។ nature morte របស់គ្មានវិញ្ញាណ (ចំពោះគំនូរ) ។ point mort ចំណុចអសកម្ម (គ្រឿងចក្រ) ។ temps mort ពេលអសកម្ម (ពេលគ្មានសកម្មភាព) ។

n. សព, ខ្មោច (ឧ. prier pour les morts) ។ faire le mort ពុតធ្វើស្លាប់; ពួនមិនបង្ហាញខ្លួន

mortaise *n.f.* ដំណាប់

mortaiser *v.t.* ដាប់ដំណាប់ (ឧ. mortaiser une poutre)

mortaiseuse *n.f.* ប្រដាប់ដាប់ដំណាប់

mortalité *n.f.* មតប្បមាណ [មៈ-ត័ប-ប៉ៈ—], មរណប្បមាណ [មៈ-រៈ-ណ័ប-ប៉ៈ—]

mort-aux-rats *n.f.* ថ្នាំបំពុលកណ្ដុរ

mort-bois *n.m.* ឈើគ្មានតម្លៃ

morte-eau *n.f.* រដូវជំនោរតូច

mortel,elle *a.* ដែលលុះក្នុងសេចក្ដីស្លាប់ (ឧ. nous sommes tous mortels); ដែលបណ្ដាលឲ្យស្លាប់ (ឧ. blessure mortelle) ។ dépouilles mortelles ឬ restes mortels សព ។ ennemi mortel សត្រូវធំណាស់ ។ péché mortel អំពើបាបដែលព្រះប្រោសមិនរួច ។ *Fig.* ខ្លាំងហួសពេក (ឧ. douleur mortelle) ។ *Fam.* ដែលឲ្យធុញទ្រាន់ (ឧ. vacances mortelles) ។

n. មនុស្ស (ឧ. heureux mortels)

mortellement *adv.* ដល់ស្លាប់ (ឧ. blessé mortellement)។ *Fig.* ក្រៃពេក (ឧ. discours mortellement ennuyeux)

morte-saison *n.f.* រដូវអសកម្ម, រដូវមិនសូវមានសកម្មភាព (*pl.* des mortes-saisons)

mortier *n.m.* *Constr.* បាយអ។ *Par ext.* ក្ដុដែលមានសណ្ឋានដូចបាយអ; ត្បាល់បុក ។ *Mil.* កាំភ្លើងត្បាល់ ។ *Just.* មួកចៅក្រមសាលាវិនិច្ឆ័យនឹងសាលាឧទ្ធរណ៍

mortifère *a.* ដែលបណ្ដាលឲ្យស្លាប់ (ឧ. plante mortifère)

mortifiant,e *a.* ដែលធ្វើកាយនឹងចិត្តឲ្យស្ងប់ (ឧ. pratiques mortifiantes) ។ *Fig.* ដែលបង្អាប់មុខ (ឧ. refus mortifiant)

mortification *n.f.* អត្តកិលមថកម្ម (ការប្រព្រឹត្តកាន់វត្តយ៉ាងតឹង ដើម្បីធ្វើកាយនឹងចិត្តឲ្យស្ងប់) (ឧ. les mortifications des ascètes) ។ *Fig.* ការអាប់មុខ (ឧ. subir une cruelle mortification) ។ *Art cul.* ការបាក់សាច់ ។ *Méd.* ដំណើរស្លាប់(នៃផាលិកាឬសរីរាង្គណាមួយ)

mortifier *v.t.* ធ្វើឲ្យបាក់សាច់។ *Fig.* ប្រព្រឹត្តអត្តកិលមថកម្ម (ឧ. mortifier son corps); បង្អាប់មុខ; ធ្វើឲ្យអន់ចិត្ត (ឧ. votre refus m'a mortifié)

mortinalité *n.f.* ភាពប្រសូតមកស្លាប់ (ទារក)

mort-né,e *a.&n.* ដែលប្រសូតមកស្លាប់ (ទារក) (ឧ. enfant mort-né) ។ *a. Fig.* ដែលស្អុនការតាំងពីដំបូងដៃ (ឧ. projet mort-né) (*pl.* mort-nés, mort-nées)

mortuaire *a.* នៃបុណ្យខ្មោច (ឧ. drap mortuaire)។ maison mortuaire ផ្ទះនៃសព (ផ្ទះនៃបុគ្គលទោះទទួលមរណភាព) ។ registre mortuaire បញ្ជីមរណភាព (បញ្ជីឈ្មោះមនុស្សស្លាប់)។ extrait mortuaire សេចក្ដីស្រង់មរណភាព

morue *n.f.* ត្រីម៉ូរុយ

morutier *a.&n.m.* នាវានេសាទត្រីម៉ូរុយ; អ្នកនេសាទត្រីម៉ូរុយ

morve *n.f.* រោគហៀរសំបោរ (ចំពោះសេះ, លា) (ឧ. les animaux

atteints de morve doivent être abattus);សំបោរ(ឧ. avoir la morve au nez)

morveux,euse *a.* cheval morveux សេះកើតសំបោរ។ ដែលកើតសំបោរ (ឧ.enfant morveux)។ *Prov.* qui se sent morveux se mouche មានឈាមខ្លួនមានប្រហុកពង ឬ ស៊ីសៀតអៀនខ្លួន ។

n. ក្មេងកើតសំបោរ (ឧ. un petit morveux)។ *Fam.* ក្មេងតូច (ដែលគេនៅញើសសំបោរឡើ), ជន ដែលគេគួរទុកខ្លួនជាក្មេងតូច (ឧ. ce sont de beaux morveux) ។

Prov. les morveux veulent moucher les autres អ្នកណាឯងតូចឯងមិនប្រែះ បង់ណាងតូចគេ

mosaïque *n.f.* គំនូរវិចិត្រដោយផ្គុំរូបតូចៗ

mosaïque *a.* នៃម៉ូអ៊ីស (ឧ. loi mosaïque)

mosaïquer *v.t.* វិចិត្រដោយផ្គុំរូបតូចៗ

mosaïsme *n.m.* ច្បាប់របស់ម៉ូអ៊ីស

mosaïste *a.&n.* ជាងគំនូរវិចិត្រដោយផ្គុំរូបតូចៗ

moscouade *n.f.* ស្ករអសិទ្ធ (មិនទាន់ម្ចាស់)

moscovite *a.&n.* នៃក្រុងម៉ូស្គូ ។ *Par ext.* នៃប្រទេសរុស្ស៊ី

mosellan,e *a.&n.* នៃខេត្រម៉ូសែល

mosquée *n.f.* វិហារអ៊ិស្លាម

moss *n.m.* ម៉ូស្ស (រង្វាស់ស្រាបិយែរ បំណុះ ២ ល.)

mot *n.m.* សព្ទ, ពាក្យ (ឧ. un mot de plusieurs syllabes); ម៉ាត់ (ឧ. dire un mot à l'oreille; écrire un mot à quelqu'un); សំដី; ភាសិត, សំដីគួរចាំ (ឧ. beau mot de Socrate); សំដីឥតសព្ទ ឥតសារ(ឧ.se payer de mots)។

Gram. mot composé សមូហសព្ទ។ mot exceptionnel អញ្ញត្រសព្ទ ។ mot invaraible អព្យយសព្ទ។ mot propre ពាក្យចំ, ពាក្យត្រូវ ។ mot simple ឯកសព្ទ។

bon mot សំដីប្រាជ្ញ ។ mot-clé ពាក្យគោល (ពាក្យដែលគេប្រើជាន បើគេយល់ន័យពាក្យនេះ ទើបគេយល់សេចក្ដីអក្សរ)។ mots couverts សំដីបិទមុខ ។ mots croisés ពាក្យខ្វែង ។ le fin mot និម្រៅ ឬ ន័យកំបាំង (នៃរបស់អ្វីមួយ)។ grand

mot ពាក្យប៉ៃ ។ gros mot សំដីថ្លោស (សំដីគម្រោះគម្រើយ, ពាក្យជេរ) ។ mot d'une énigme ឈ្មោះវត្ថុនៃបណ្ដៅ។ mot d'ordre សព្ទសញ្ញា (សម្រាប់ឲ្យស្គាល់គ្នា) ។ mot de ralliement ពាក្យស្របគ្នា ។

avoir le dernier mot ឈ្នះ (ម.ព. dernier ផង) ។ se donner le mot មត់ពាក្យសំដីគ្នា ។ jouer sur les mots ម.ព. jouer ។ manger ses mots ម.ព. manger ។ ne dire ឬ ne souffler mot គ្មាននិយាយមួយម៉ាត់ ។ prendre au mot សុខចិត្តតាម ។ trancher le mot ថាឲ្យចំៗមិនបញ្ឈិតបញ្ជៀង ។ entendre à demi mot យល់ដោយមិនជាចំនិយាយអស់សេចក្ដី។

Loc.adv. en un mot ដោយខ្លីទៅ ។ mot à mot ដោយផ្ដិត, ដោយគ្មានល្អៀង(ឧ. traduire mot à mot) ។ au bas mot យ៉ាងថោកបំផុត, យ៉ាងទាបបំផុត ។

mot à mot *n.m.* ការប្រែផ្ដិត

motard *n.m. Fam.* អ្នកជិះម៉ូតូ

moteur,trice *a.* ចលករ (នែលឲ្យករម្រើក) (ឧ. force motrice ម.ព. force ផង) ។

n.m. ចលករ (ធាតុជាគ្រឿងធ្វើឲ្យយន្តដើរ ដូចជាទឹក,ខ្យល់,ចំហាយទឹក។ល។); ម៉ាស៊ីន ។ moteur à combustion interne ម៉ាស៊ីនឥន្ធនកម្មក្នុង ។ moteur à explosion ម៉ាស៊ីនផ្ទុះ។ moteur flottant ម៉ាស៊ីនបណ្ដែត (ភ្ជាប់ដោយចំណងធូរ)។ moteur à réaction ម៉ាស៊ីនប្រតិកម្ម ។

Fig. អ្នកដើមគំនិត (ឧ. être le moteur d'une entreprise); គ្រឿងធ្វើឲ្យដើរ (ឧ. l'enthousiasme, ce moteur de l'âme)

motif *n.m.* ហេតុ (ឧ. un motif louable; se fâcher sans motif)។ *Bx-Arts* ប្រធានក្បាច់

motilité *n.f.* ភាពងាយករម្រើក

motion *n.f.* ញត្តិ

motivation *n.f.* ការប្រាប់ហេតុផល; ការដឹងហេតុផល

motiver *v.t.* ប្រាប់ហេតុផល; ធ្វើឲ្យសមហេតុផល (ឧ. rien ne motive cette mesure)

moto *préf.* (បុព្វបទសំគាល់ថាមានប្រើយន្ត) ។ *n.f. Fam.* ម៉ូតូ (កោបព្រះយានយន្ត)

motobécane *n.f.* ម៉ូតូបេកាន,កោបព្រះយានយន្តតូច

motoculteur *n.m.* យន្តរៀបការ, យន្តភ្ជួររីធុនស្រាល

motoculture *n.f.* យន្តរៀបកម្ម

motocyclete *n.f.* ម៉ូតូ, កោបព្រះយានយន្តធំ

motocycliste *n.* អ្នកជិះម៉ូតូ, អ្នកជិះកោបព្រះយានយន្ត

motonautique *a.* យន្តកិរិយ

motonautisme *n.m.* យន្តកិរិយណ៍

motopompe *a.* ស្នប់យន្ត (ឧ. motopompe d'incendie)

motorisation *n.f.* យន្តកម្ម, ការផាក់ឡើងដោយគ្រឿងយន្ត (ឧ. la motorisation de l'agriculture)

motoriser *v.t.* ធ្វើយន្តកម្ម, ផាក់ឡើងដោយយន្ត ; ផ្តល់នូវគ្រឿងយន្ត (ឧ. motoriser une division d'infanterie) ។ troupe motorisée ម.ព. troupe

motor-ship *n.m.* (ព.អ.) នាវាយន្ត (សរសេរបំព្រួញ: M.S.)

motrice *n.f.* ទេសម្រាប់ទាញ-អូស

mots-croisiste *n.m.* អ្នកលេងពាក្យខ្វែង

motte *n.f.* អាចម៍បំណះ ។ motte de beurre ដុំបឺរសម្រាប់លក់រាយ

motter (se) *v.pr.* ពួនក្រោយអាចម៍បំណះ (សត្វ)

motteux *n.m.* បក្សីម្យ៉ាងចូលចិត្តទំលើអាចម៍បំណះ

motus ! [— tuss] *int.* កុំមាត់ ! (កុំប្រាប់ឲ្យគេដឹង)

mou ឬ **mol,molle** *a.* ទន់, ស្រាយ (ឧ. cire, poire molle) ។ temps mou អាកាសក្តៅហើយសើម ។ *Fig.* ខ្សោយ (ឧ. cheval mou); ទន់ខ្លួនស្រើ; ស្រណុកពេក (ឧ. vie molle) ។

n.m. អ្វីៗដ៏ទន់ (ឧ. le mou et le dur) ។ donner du mou ធូរ (ខ្សែ) ។ សួត (សួតសត្វដែលគេបរិភោគ) (ឧ. mou de veau)

mouchage *n.m.* ការញើសសំបោរ

mouchard *n.m. Fam. & Péj.* អ្នកស៊ើបការសម្ងាត់ ។ *Par ext.* អ្នកចាក់រុក; ប្រដាប់ពិនិត្យត្រួត

mouchardage *n.m. Fam.* ការអុនអាល,ការចាក់រុក (ល្ងួចប្តឹងអំពីគេ)

moucharder *v.t.&Fam.* អុនអាល, ចាក់រុក,លួចប្តឹងពីគេ(ឧ.moucharder un camarade)

mouche *n.f.* រុយ ។ mouche à miel ឃ្មុំ ។ *Par ext.* សម្បុរអុជៗ (លើកេមសត្វផងនេះ) ។ *Par anal.* អ្នកស៊ើបការសម្ងាត់ (ឧ. une de ces mouches que l'on tient sans cesse à mes trousses); អ្នកស៊ីតាមសារគេ; អ្នកទំនេរ; ចំណុចខ្មៅត្រង់កណ្តាលរង្វង់ចាញ់ ។ *Fig.* កំហឹង (ឧ. la mou h t t d'un coup à la tête vous monte!) ។ *Arg.* អាព្រាក់មើល ។ *Escr.* ស្បែកស្រោបដាវ ។

mouche d'escadre នាវាតូច ឬ យន្តហោះឈ្លបយកការណ៍ ឬ បញ្ជូនសារ ។ faire la mouche du coche ធ្វើឡេមឡើម ។ faire mouche បាញ់ត្រូវចំណុចខ្មៅ (កណ្តាលរង្វង់) ។ fine mouche មនុស្សឆ្លាតណាស់ ។ pattes de mouche អក្សរល្អិតហើយមិនច្បាស់ ។ prendre la mouche ខឹងខុសបមិ ។ *Fam.* quelle mouche le pique? ហេតុអ្វីបានជាគេខឹង? ។

Prov. on prend ឬ on attrape plus de mouches avec du miel qu'avec du vinaigre ឬ avec une cuillerée de miel qu'avec cent tonneaux de vinaigre ពាក្យពិរោះ មនុស្សច្រើនស្ម័គ្រ ពាក្យអប្រិយ គេច្រើនខ្ពើម ; អន្ទង់ក្រជាក់ត្រីច្រើនកុម ។ à cheveaux maigres vont les mouches អ្នកខ្សោយសត្រូវជោម

moucher *v.t.* ញើសស៊ាំងារ; ផ្ដះកញ្ចមប្រេង ។ *Fam.* ដាក់ទណ្ឌកម្ម

moucheron *n.m.* សុច,មមង់ ។ *Pop.* កូនក្មេងតូច; មនុស្សកញ្ចកញ្ចក់

moucheronner *n.m.* កញ្ចមប្រេង

moucheronner *v.i.* លោតចាប់សត្វល្អិត (ចំពោះត្រី)

moucheté,e *a.* អុជៗ ។ fleuret moucheté ដាវស្រោបចុង

moucheter *v.t.* ធ្វើឲ្យជិតអុជៗ (ឧ. moucheter du satin)

mouchette *n.f.* ដែកឈូសលញ់ ។ *n.f. pl.* កន្ត្រៃកាត់កញ្ចមប្រេង

moucheture *n.f.* ស្នាមអុជៗ (ឧ. les mouchetures de la panthère)

mouchoir *n.m.* កន្សែងដៃ

mouchure *n.f.* សំបោរដែលគេញើស

moudre *v.t.* កិនជាម្សៅ (ឧ.moudre du maïs)

moue *n.f.* ការបួញមាត់ ។ faire la moue បួញមាត់; ក្ដិច

mouette *n.f.* សត្វកេត

moufle *n.f.* ឆ្នាំងដីចំហុយ; ឬស្នូត-សំឡូន

moufle *n.f.* ស្រោមដៃធំ

mouillage *n.m.* ការសើម; ការលាយទឹកបន្ទំ (ចំពោះភេសជ្ជៈ) (ឧ. le mouillage est rigoureusement interdit)។ *Mar.* កន្លែងចត (ឧ. mouillage abrité); ការចតនាវ; ការរាយគ្រាប់បែកក្នុងទឹក

mouille *n.f.Mar.* ការខូចខាតដោយសើម

mouillement *n.f.* ការសើម

mouiller *v.t.* សើម, ជ្រលក់ (ឧ. mouiller du linge); លាយទឹក (ឧ. mouiller du vin)។ mouiller l'ancre ឬ mouiller បោះយុថ្កា (ឧ. mouiller au large)។ mouiller des mines រាយគ្រាប់បែកនៅតាមសមុទ្រ (ព្រ.humecter, imbiber, tremper.– ព.ផ. sécher)

mouillère *n.f.* ដីសើមជាធម្មតា

mouillette *n.f.* បំណិតនំប៉័ងវែងហើយស្តើង

mouilleur *n.m.* ប្រដាប់សើម។ *Mar.* ប្រដាប់បោះយុថ្កា ; ប្រដាប់រាយគ្រាប់បែក ។ mouilleur de mines នាវារាយគ្រាប់បែក

mouilloir *n.m.* ភាជន៍ដាក់ទឹកសម្រាប់ជ្រលក់សើម

mouillure *n.f.* ការសើម; ភាពសើម

mouise *n.f. Pop.* ភាពគោកយ៉ាក

moujik *n.m.* អ្នកស្រែជាតិរុស្ស៊ី

moulage *n.m.* ការសិត (ដាក់លោហធាតុក្នុងពុម្ព) (ឧ. le moulage d'une statue); ការផ្តិតពុម្ព; ពុម្ពដែលផ្តិតអំពីរូប; ការដាក់ពុម្ព

moulage *n.m.* ការកិនជាម្សៅ

moule *n.f.* ពុម្ព ។ fait au moule ល្អដូចដាក់ពុម្ព (ដែលធ្វើបានល្អ)

moule *n.f.* គ្រុំ ។ *Fig. & fam.* មនុស្សល្ងីល្ងើ (ឧ. quelle moule!)

moulé,e *a.Fig.* ល្អ, សម (ឧ. un homme moulé) ។ lettre moulée តួអក្សរពុម្ព ។ écriture moulée អក្សរច្បាស់ល្អ ។

n.m. អក្សរពុម្ព (ឧ. ne lire que le moulé)

mouler *v.t.* សិត (ឧ. mouler une statue); ផ្តិតពុម្ព (ឧ. mouler un bas-relief); យកទម្រង់តាម (ឧ. corsage qui moule le buste)។ *Fig.* ឲ្យយកគម្រូតាម (ឧ. mouler le caractère de son fils sur le sien)។

se mouler *v.pr.* រឹតព័ទ្ធនឹងខ្លួន; យកគម្រាប់តាម

mouleur *n.&a.m.* ជាងសិត

moulière *n.f.* កន្លែងចិញ្ចឹមគ្រុំ

moulin *n.m.* ត្បាល់កិន, ម៉ាស៊ីនកិន ។ moulin à huile ម៉ាស៊ីនកិនប្រេង ។ moulin à vent ម៉ាស៊ីនកិនប្រើខ្យល់ (មានកង្ហារ)។ moulin à café ត្បាល់កិនកាហ្វេ; កំភ្លើងយន្ត។ moulin à foulon ម៉ាស៊ីនកិនសំពត់ (ឲ្យជិតសាច់) ។ *Fig.* moulin à paroles ពហុភាសកៈ, មនុស្សនិយាយច្រើន

moulinage *n.m.* ការគួប (ការប្រូតសរសៃសូត្រ)

mouliner *v.t.* គួប (ប្រូតសរសៃសូត្រ); ស៊ីឈើ (ដង្កូវ)

moulinet *n.m.* កង្ហារត្បាល់កិន; ទ្វារវិល; សំទង់ល្បឿនទឹកហូរ ។ faire le moulinet យីគុន, គ្រវីដាវ ឬ ដំបងជុំវិញខ្លួន

moulineur ឬ **moulinier** *n.m.* ជាងគួប (ជាងប្រូតសរសៃសូត្រ)

moulu,e *a.* ទ្រម (ឧ. avoir le corps moulu) ។ or moulu មាសម្សៅ

moulure *n.f.* ក្បាច់ខ្សែ

moulurer *v.t.* លំអដោយក្បាច់ខ្សែ

mourant,e *a.* ជិតស្លាប់; ដែលធ្វើឲ្យនឹងជាជិតស្លាប់; កំពុងតែអន្តរាយ ។ *Fig.* ដែលសង្រេងសង្រែ (ឧ. regards mourants) ។ voix mourante សំឡេងល្ហើយហើយបន្លូស ។ *n.* មនុស្សជិតស្លាប់

mourir *v.i.* ស្លាប់ (ឧ. mourir de vieillesse)។ mourir de sa belle mort ស្លាប់ដោយស្រួល ។ *Par exag.* រងទុក្ខខ្លាំង; រំខានខ្លាំង (ឧ. mourir de faim ឃ្លានស្ទើរស្លាប់)។ mourir de peur ភ័យ

ស្ទើរស្លាប់ ។ mourir de rire សើចក្អាកក្អាយ ។ វិនាស, ខូច (ឧ. la gelée a fait mourir ces fleurs) ។ *Fig.* ស្លាប់, រលាយ (ឧ. les empires naissent et meurent); អន្តរធាន; កាន់តែខ្សោយទៅ (ឧ. les vagues venaient mourir sur la grève) ។ à mourir ក្រៃពេក ។ se mourir *v.pr.* ជិតស្លាប់

mousquet *n.m.* មូស្គេ (កាំភ្លើងប្រើក្នុងសតវត្សទី ១៦ និង ១៧)

mousquetade *n.m.* ការបាញ់មូស្គេ

mousquetaire *n.Autref.* ទាហានកាន់មូស្គេ; មូស្គែទែរ(អភិជន)

mousqueterie *n.f.* ការបាញ់កាំភ្លើងបម្រុះ

moussaillon *n.m.* កម្មករនាវាតូច

mousqueton *n.m.* មូស្គេតុង(កាំភ្លើង)

mousse *n.m.* កម្មករនាវាក្មេង (អាយុ១៥ ឆ្នាំ)

mousses *n.f. pl.* ស្លែ

mousse *n.f.* ពពុះ

mousse *a.* ទាល(ឧ. lame mousse)

mousseline *n.f.* មូស្សឺលីន (ស្បៃម្យ៉ាងទន់-ស្រាល) (ឧ. mousseline de soie, de coton) ។ *a. inv.* verre mousseline កែវសាប៉ុន្ទ

mousser *v.i.* ឡើងពពុះ(ឧ. le champagne mousse) ។ *Fig.* & *fam.* faire mousser quelqu'un ឬ quelque chose អួតអំពី (ឧ. faire mousser ses amis)

mousseux,euse *a.* ដែលឡើងពពុះ(ឧ. bière mousseuse)

moussoir *n.m.* ឈើវាយម្យ៉ាងឬស្លាបព្រា (ឲ្យឡើងពពុះ)

mousson *n.f.* ខ្យល់រដូវ(ឧ. la mousson d'été est humide)

moussu,e *a.* ដែលដុះស្លែ (ឧ. pierre moussue)

moustache *n.f.* ពុកមាត់(មនុស្ស,សត្វ) (ឧ. les moustaches du chat)

moustachu,e *a.* ដែលមានពុកមាត់ក្រាស់ (ឧ. soldat moustachu); ដែលមានពុកមាត់ (ឧ. une femme moustachue)

moustiquaire *n.f.* មុង

moustique *n.m.* មូស

moût *n.m.* ស្រាមិនទាន់ឡើង; ទឹកផ្អែមសម្រាប់ធ្វើស្រា (មានទឹកត្នោតជាដើម)

moutard *n.m.* *Fam.* កូនក្មេង

moutarde *n.f.* កៃឡាត់ ។ *Fig.* la moutarde lui monte au nez គាត់ក្ដៅក្នុងក្រអុះហើយ

mouton *n.m.* ចៀម (cri: le mouton bêle); សាច់ចៀម (ឧ. manger du mouton); ស្បែកចៀម (ឧ. une reliure de mouton)។ *Pop.* ពួក។ *Fig.* មនុស្សស្លូតងាយដឹកនាំ (ឧ. c'est un mouton)។ *Arg.* អ្នកល្បួងយកការណ៍ពីមនុស្សទោស។ revenons à nos moutons ចូរយើងត្រឡប់មកនិយាយពីរឿងយើងវិញ ។ moutons de Panurge អ្នកតាមគេដោយឥតពិចារណា ។ រូបិយវត្ថុមាសបុរាណ ។ *Méc.* ដុំដែកឬឈើសម្រាប់បុកជើងសសរ ។

pl. Mar. រលកផ្កាត្រែង

moutonné,e *a.* រួញខ្ញិចរោមចៀម

moutonnement *n.m.* ដំណើរបោកបែកផ្កាត្រែង (ឧ. le moutonnement des vagues)

moutonner *v.t.* ធ្វើឲ្យមានអង្កាញ់ខ្ញិចរោមចៀម; អ៊ុត (ឧ. moutonner une chevelure) ។ *v.i. Mar.* បោកបែកផ្កាត្រែង (រលក) (ឧ. les vagues moutonnent)

moutonnerie *n.f.* លក្ខណៈនៃសត្វចៀម; គំនិតធ្វើតាមគេ

moutonneux,euse *a.* ដែលបោកបែកផ្កាត្រែង (ឧ. mer moutonneuse)

moutonnier,ère *a.* នៃសត្វចៀម; ដែលធ្វើតាមតែគេ (ដូចសត្វចៀម) (ឧ. la foule est moutonnière)

mouture *n.f.* ការកិនម្សៅ

mouvant,e *a.* ដែលកម្រើក, ដែលរអិល (ឧ. sable mouvant; terre mouvante) ។ *Fig.* មិនឋិតថេរ (ឧ. situation mouvante)

mouvement *n.m.* ចលនា, ការកម្រើក (ឧ. le mouvement d'un balançoire) ។ *Mil.* faire mouvement ធ្វើចលនា, ដើរ (ទ័ព)។ *Fig.* ដំណើរឡើងចុះនៃតម្លៃ។ *Pol.* ចលាចល, ការច្របូកច្របល់ (ឧ. les esprits sont en mouvement) ។ mouvement de colère កំហឹងមួយឆាប ។ agir de son propre mouvement ប្រព្រឹត្តដោយចិត្តឯង (ដោយគំនិតខ្លួនឯង) ។ *Mus.* ចលនា ។ mouvement du sol ភាពខ្ពស់ទាបនៃដី

mouvementé,e *a.* ខ្ពស់ទាប (ដី) ។

Fig. ប្រកបដោយចលាចល (ឧ. séance mouvementée)

mouvementer *v.t.* ធ្វើឲ្យអ៊ូអរឬឲ្យមានចលនា (ឧ. mouvementer un récit, une action scénique)

mouvoir *v.t.* ធ្វើឲ្យកម្រើក (ឧ. mouvoir une pierre) ។ *Fig.* ញុំាងឲ្យប្រព្រឹត្ត (ឧ. être mû par l'intérêt) ។ *v.i.* កម្រើក ។ se mouvoir *v.pr.* កម្រើក (ឃ. actionner, animer, porter)

moxa *n.m.* (ព. ជប៉ុន) ការអុជ (របៀបព្យាបាលរោគ)

moyen, enne *a.* មធ្យម (ឧ. un homme de taille moyenne); មធ្យម, ធម្មតា, សាមញ្ញ (ឧ. intelligence moyenne); ដំណើរ ។ Moyen Age យុគកណ្ដាល ។ cours moyen មធ្យមដ្ឋាន (ម.ព. cours ផង)

moyen *n.m.* មធ្យោបាយ (ឧ. moyens légitimes); ការឧបត្ថម្ភ (ឧ. arriver à un emploi par le moyen de quelqu'un) ។ *pl.* ធនធាន (ឧ. vivre selon ses moyens); សម្បទា (ឧ. cet élève manque de moyens) ។ au moyen de ឬ par le moyen de *loc. pré.* ដោយ (ដោយប្រើមធ្យោបាយ) ។ moyen de subsistance មធ្យោបាយចិញ្ចឹមជីវិត ។ moyen de transport មធ្យោបាយដឹកនាំ

moyennâgeux, euse *a.* នៃយុគកណ្ដាល (ឧ. un costume moyennâgeux)

moyen-courrier *n.m.* & *a.* *Aér.* មធ្យមហារីយ (អាកាសយានដឹកនាំសម្រាប់ហោះចម្ងាយមធ្យម គឺ តិចជាង ២០០០គ.ម.) (*pl.* des moyen-courriers)

moyennant *pré.* ដោយ; លុះតែបាន... (ឧ. moyennant cette somme) ។ moyennant que *loc. conj.* លុះណាតែ

moyenne *n.f.* មធ្យមភាគ ។ en moyenne ជាមធ្យមភាគ

moyennement *adv.* យ៉ាងមធ្យម

moyeu *n.m.* ដុំរទេះ

moyeu *n.m.* ជាតិលឿងនៃស៊ុត

M.P.C. (Mathématiques, Physique, Chimie គណិតសាស្ត្រ,

រូបនិយម, តីម)

M.T.S. (Mètre, Tonne, Seconde ម៉ែត្រ, តោន, វិនាទី)

muche-pot (à) *loc. adv.* ម.ព. musse-pot (à)

mucosité *n.f.* ជាតិរំអិល (ឧ. les mucosités nasales)

mucus *n.m.* សំបោរ, រំអិល។ glande à mucus ម.ព. glande

mue *n.f.* ការកោរ (ជម្រុះរោម ឬ ស្លាប); ពេលកោរ; ការសក; សំណក; ពេលសក; ទ្រុងក្រុងមេមាន់និងកូន; កន្លែងបំប៉នបក្សី; ដំណើរឡើងសំឡេងគ្រាវ (ពេលឡើងខ្លួន)

muer *v.i.* កោរ, សក (ឧ. les serpents muent régulièrement); ឡើងសំឡេងគ្រាវ ។ se muer *v.pr.* ប្រែ, ក្លាយ (ឧ. sympathie qui se mue en amitié)

muet,ette *a.* គ (ឧ.homme muet); ដែលនិយាយមិនរួច(ដោយស្ងន់ជាដើម) (ឧ. être muet de terreur); ដែលមិនចេញស្តី (ឧ. les grandes douleurs sont muettes) ។ *Théât.* jeu muet ការលេងគ (លេងដោយធ្វើដៃធ្វើជើងគ្មាននិយាយ)។ *n.* មនុស្សគ។ *n.f.* អក្សរគ (គ្មានសំឡេង) ។ à la muette *loc. adv.* ដោយធ្វើដៃធ្វើជើង(គ្មាននិយាយ)

mufle *n.f.* ចុងច្រមុះសត្វ (ឧ. une mufle de bœuf, de lion) ។ *Fig.&Fam.* មនុស្សកម្រោល

muflerie *n.f. Fam.* អំពើកម្រោល

mugir *v.i.* គោ៎ ។ *Fig.* លាន់ឮ (ដូចសំឡេងគោ៎) (ឧ. les vents mugissent)

mugissant,e *a.* ដែលគោ៎ (ឧ. bœuf mugissant); ដែលលាន់ឮ (ឧ. vents mugissants)

mugissement *n.m.* សំឡេងគោ៎; ឮសន្ធឹក (ដូចសំឡេងគោ៎) (ឧ. le mugissement des flots)

mulâtre *n.&a.* កូនកាត់ជនជាតិស្បែកសនិងស្បែកខ្មៅ ។ *f.* mulâtresse

mule *n.f.* សេះទេសញី ។ être têtu comme une mule ចចេសណាស់

mulet *n.m.* សេះទេសឈ្មោល

muletier,ère *a.* នៃសេះទេស (ឧ. chemin muletier) ។ *n.m.* អ្នកបរសេះទេស

mulsion *n.f.* ការរឹតទឹកដោះ

multicellulaire *a.* ពហុកោសិកា

multicolore *a.* ចម្រុះពណ៌ច្រើន

multicouche *a.* ច្រើនជាន់ (ឧ. revêtement multicouche)

multifilaire *a.* ច្រើនសរសៃ (ឧ. câble multifilaire)

multiflore *a.* ដែលមានផ្កាច្រើន

multiforme *a.* ពហុសណ្ឋាន (ឧ. la vérité est multiforme)

multimillionnaire *n.&a.* អ្នកមានប្រាក់ច្រើនលាន

multipare *a.&n.f.* ដែលកើតកូនច្រើនក្នុងមួយលើកៗ (ឧ. laie multipare); ដែលមានកូនច្រើន (ស្រី)

multiparité *n.f.* ការកើតកូនច្រើនក្នុងមួយលើកៗ (ឧ. la multiparité est commune chez les rongeurs)

multiple *a.* ពហុគុណ; សន្ធឹកសន្ធាប់ ។ *n.m. Math.* ពហុគុណ (ឧ. 8 est un multiple de 2); រង្វាស់ពហុគុណ ។ sou-smultiple រង្វាស់អនុពហុគុណ

multipliable *a.* អាចគុណបាន

multiplicande *n.m.Math.* តំណាងគុណ

multiplicateur *a.&n.m.* គុណការី, ដែលគុណ។ *Math.* មេគុណ

multiplicatif,ive *a.* ដែលគុណ

multiplication *n.f.* គុណកម្ម, ការគុណលេខ; ការកើនចំនួន (ឧ. la multiplication des êtres) ។ *Math.* លេខគុណ ។ table de multiplication មេលេខគុណ

multiplicité *n.f.* អនេកគុណ, ចំនួនច្រើន (ឧ. la multiplicité des étoiles)

multiplier *v.t.Math.* គុណលេខ; បង្កើនចំនួន (ឧ. multiplier les formalités) ។ *v.i.* បង្កើតកូន, ផ្សាយកូន (ឧ. croissez et multipliez) ។ se multiplier *v.pr.* *Fig.* ខំប្រឹងធ្វើការច្រើនកន្លែង (ឧ. sauveteur qui se multiplie); កើតគរគ្នា

multitude *n.f.* ពហុភាព, ចំនួនច្រើន (ឧ. multitude de lièvres); ហ្វូងមនុស្ស (ឧ. la multitude emplissait les rues); ជនសាមញ្ញ

munichois,e *a.* នៃក្រុងមុយនិច

municipal,e,aux *a.* នៃកិច្ចការក្រុង,

នៃក្រុមមឿង (ឧ. loi municipale)។ conseil municipal ក្រុមប្រឹក្សាភិបាលក្រុង

municipalité *n.f.* ទីភពិបាលក្រុង, ក្រុមមឿង

munificence *n.f.* ចាគបេគតា [ចា-គះ-បេ-គះ-តា] (គំនិតដែលឥតចិត្តឲ្យមានការលះបង់) (ឧ. agir avec munificence) (*lit.* largesse, prodigalité)

munificent,e *a.* សប្បុរស

munir *v.t.* ផ្គត់ផ្គង់របស់ចាំបាច់; បំពេញ (ឧ. munir d'argent)។ se munir *v.pr.Fig.* se munir de patience ប្រុងខ្លួនចាំទ្រាំ

munition *n.f.* ស្បៀង; គ្រាប់រំសេវ

munitionner *v.t.* ផ្តល់ស្បៀង ឬ គ្រាប់រំសេវ

muqueux,euse *a.* សេម្ហៈ [សេ-ម្ហៈ] (ឧ. sécrétion muqueuse)។ membranes muqueuses ឬ muqueuses *n.f.* សេម្ហកលា [សេ-ម្ហះ-កះ-ឡា] (ម.ព. membrane ផង)។ fièvre muqueuse គ្រុនសន្និបាត

mur *n.m.* ជញ្ជាំង។ *Fig.* អ្វីៗដែលរាំងមិនឲ្យទៅរួច (ឧ. heurter à un mur)។ mur mitoyen ម.ព. mitoyen។ mur bahut ជញ្ជាំងទាប (មិនខ្ពស់ជាងកៅអី)។ mur d'assaut ជញ្ជាំងឡើង (សម្រាប់ហាត់ប្រាណ)។ mur d'airain ឧបសគ្គពុំអាចនឹងពុះពារបាន។ sauter le mur ឬ faire le mur លួចផ្លោះរបង; ចេញដោយខុសច្បាប់, លួចចេញ។ mettre quelqu'un au pied du mur បង្ខំឲ្យសម្រេចចិត្ត; ធ្វើមិនឲ្យធ្វើរបួច។ les murs ont des oreilles ជញ្ជាំងមានត្រចៀក (អាចមានគេលួចស្តាប់)។ mur de chaleur ជញ្ជាំងកំដៅ (កម្រិតល្បឿនគម្រូវឲ្យអាកាសយានបើកដើម្បីកុំឲ្យក្តៅហួស)។ mur du son ជញ្ជាំងសូរ។

n.m.pl. កំពែងក្រុង; *par ext.* ទីក្រុង (ឧ. depuis quand êtes-vous dans nos murs?)

mûr,e *a.* ទុំ (ឧ. banane mûre)។ *Fig.* âge mûr វ័យចាស់។ esprit mûr គំនិតចាស់។ projet mûr សេចក្តីព្រាង ឬ គំរោងការដែលបានពិចារណាយ៉ាងហ្មត់ចត់។ abcès

mûr ហួសទុំ (និតណាយ)

murage *n.m.* ការហ៊ុំជញ្ជាំង; ការនៅក្នុងជញ្ជាំង

muraille *n.f.* កំពែង (ជញ្ជាំងក្រាស់ហើយខ្ពស់)។ *Mar.* កែមនាវា (ពីត្រឹមទឹកមកលើ); ការក្រៅនៃក្របកសេះ។ *pl.* កំពែង, របង

mural,e, aux *a.* ដែលដុះលើជញ្ជាំង (ឧ. plante murale); ដែលព្ធួរឬព្យួរនៅជញ្ជាំង (ឧ. carte murale)

mûre *n.f.* ផ្លែមន ។ mûre sauvage ផ្លែរពាក់

mûrement *adv.* ដោយជានតិ ហ្មត់ចត់ (ឧ. réfléchir mûrement à un projet)

murer *v.t.* ស្ទះ, សន្ទប់ (ដោយបៀកជាយអ) (ឧ. murer une porte); ហ៊ុំជញ្ជាំង, បិទដោយជញ្ជាំង; បង្ខាំងក្នុងជញ្ជាំង

muret ឬ **muretin** *n.m.* កូនជញ្ជាំង

murette *n.f.* កូនជញ្ជាំង

mûrier *n.m.* ដើមមន

mûrir *v.t.* ធ្វើឲ្យទុំ, បន្ទុំ (ឧ. le soleil murit les fruits)។ *Fig.* ធ្វើឲ្យចាស់គំនិត, គិតយ៉ាងហ្មត់ចត់ (ឧ. mûrir un projet)។ *v.i.* ឡើងទុំ (ឧ. les raisins mûrissent en automne)។ *Fig.* ឡើងចាស់ (គំនិត) (ឧ son esprit a mûri); ទុកចាំឱកាសស្រួល (ឧ. laisser mûrir cette affaire)

mûrissage ឬ **mûrissement** *n.m.* ការទុំ

mûrissant,e *a.* ស្រគាល (ដែលជិតនឹងទុំ) (ឧ. fruits mûrissants)

murmurant,e *a.* ដែលបន្លឺសូរហ៊ឹម (ឧ. source murmurante)

murmure *n.m.* សូរហ៊ឹម (សូរទឹកហូរ, សូរខ្យល់បក់ស្លឹកឈើ)។ *Fig.* សំដីរអ៊ូរទាំ (ឧ. apaiser les murmures de la foule)

murmurer *v.i.* បន្លឺសូរហ៊ឹម (ឧ. les eaux murmurent); និយាយរអ៊ូរទាំ (ឧ. murmurer entre ses dents)។ *v.t.* ខ្សឹប (ឧ. murmurer un secret)

musard,e *a.&n.Fam.* ដែលលេងឥតការ (ឧ. un écolier musard)

musarder *v.i.Fam.* ខាតពេល; លេងឥតការ (ut. flâner, muser)

musardise *n.f.* ការឬទម្លាប់លេងឥតការ

musc *n.m.* ល្មុស; គ្រឿងក្រអូបធ្វើអំពី

ទំរកាមសត្វល្អិស

muscinées *n.f. pl.* សេវិលជាតិ [សេ-វ៉-ល៉ះ—]

muscle *n.m.* សាច់ដុំ

musclé,e *a.* ដែលមានសាច់ដុំ

musculaire *a.* នៃសាច់ដុំ (ឧ. force musculaire)

musculature *n.f.* សរុបសាច់;ដុំគ្រោង

musculeux,euse *a.* ដែលមានសាច់ដុំច្រើន (ឧ. partie musculeuse)

muse *n.f.* ទេវតាខាងអក្សរសាស្ត្រកាព្យឃ្លោង-ករនិពន្ធ

museau *n.m.* ច្រមុះ-មាត់សត្វ(ឧ.museau de chien)។ *Pop.* មុខ

musée *n.m.* ភណ្ឌាគារ[ភ័ណ-ឌៈ-គា-រ], សារមន្ទីរ ។ musée scolaire សារមន្ទីរសិក្សា ។ Musée National សារមន្ទីរជាតិ

museler *v.t.* ឃ្លុំមាត់សត្វ (ឧ. museler un chien)។*Fig.&Fam.* ឃ្លុំមាត់, បំបិទមាត់(មិនឲ្យនិយាយ) (ឧ. museler la presse)

muselière *n.f.* ឃ្លុំ

musellement *n.m.* ការឃ្លុំ

muséologie *n.f.* ភណ្ឌាគារវិទ្យា [ភ័ន-ឌៈ គា-រៈ-វិ-]

muser *v.i.* លេងឥតការ; ដើរត្រេតត្រត

muserolle *n.f.* ព្រំវ៉ិតច្រមុះ (បង្ហៀរ)

musette *n.f.* ខែនម្យ៉ាង ; ថង់ស៊ពត់

muséum *n.m.* វិជ្ជាភណ្ឌាគារ [វិ-វិ-ជៈ-ភ័ន-ឌ័ត-ឋាន] (សម្រាប់សិក្សា) (ឧ. muséum d'histoire naturelle) (*pl.* des muséums)

musical,e,aux *a.* នៃតន្ត្រី (ឧ. art musical); ដែលមានប្រគំភ្លេង (ឧ. soirée musicale)។ *Par ext.* ពីរោះ

musicalement *adv.* ខាងភ្លេង; តាមរបៀបភ្លេង

musicalité *n.f.* គំរណើមានសម្លេងសុខ (ខ្វួចសម្លេងដើម) (ចំពោះវិទ្យុទទួលសម្លេង) (*ill.* fidélité)

music-hall [—hòl] *n.m.* (ព អ.) រោងមានភ្លេង; សាលតន្ត្រី (*pl.* des music-halls)

musicien,enne *n.* វាទកៈ-ទិកា, អ្នកវាទកៈ-ទិកា ភ្លេង

musicographe *n.* អ្នកនិពន្ធអំពីភ្លេង

musicologie *n.f.* វិទ្យាសាស្ត្រ (វិទ្យាសាស្ត្រខាងប្រវត្តិនៃភ្លេង)

musicologue *n.* អ្នកវិទ្យាសាស្ត្រ (អ្នកស្រាវជ្រាវរកប្រវត្តិភ្លេង)

musicomanie *n.f.* ភិទ្យុម្មាទ, ការចូលចិត្តភ្លេងហួសពេក

musique *n.f.* តន្ត្រី, ភ្លេង; វិទ្យាទ្រឹស្តី (ទ្រឹស្តីភ្លេង) (ឧ. apprendre la musique) ; ភិទនកម្ម (ការលេងភ្លេង)(ឧ.faire de la musique); ក្រុមភ្លេង (ឧ. musique d'un régiment) ។ musique de chambre ភ្លេងប្រើគ្រឿងតិច ។ musique instrumentale ឧបករណតន្ត្រី (ភ្លេងប្រើគ្រឿង)។ musique vocale ឧស្សតន្ត្រី(ភ្លេងច្រៀង)។ musique légère ភ្លេងងាយ, ភ្លេងសម្រើប ឬ ឲ្យរីករាយ ។ *Fam.* connaître la musique ដឹងស្មៀតអស់

musiquer *v.i.* លេងភ្លេង ។ *v.t.* ដាក់ជាបទភ្លេង

musiquette *n.f.* ភ្លេងខ្លីៗងាយៗ

musoir *n.m.* ចុងទំនប់ឬផែ(រីកធំហើយមូល)

musqué,e *a.* ក្រអូប, ប្រហើរ (ឧ. poires musquées)

musse-pot (à) *loc.adv.* ដោយលួចលាក់, ដោយស្ងាត់កំបាំង (ដូចពាក្យ គេថា à muche-pot)

musser (se) *v.pr.* ពួន

mussitation *n.f.* ការនិយាយខ្សឹបមាត់ (បណ្ដាលពីរោគ)

mustang [-tan] *n.m.* សេះព្រៃ(នៅអាមេរិកខាងត្បូង)

musulman,e *a.* អ៊ីស្លាម(ឧ.religion musulmane) ។ *n.* អ្នកកាន់សាសនាអ៊ីស្លាម

mutabilité *n.f.* បរិវត្តភាព, ភាពងាយនឹងប្រែប្រួល (ឧ. la mutabilité des choses humaines) សម្បទាខាងប្រែប្រួល

mutage *n.m.* ការផ្លាស់, ការប្ដូរ

mutation *n.f.* បរិវត្តន៍, ការផ្ទេរសិទ្ធិ; ការប្ដូរ, ការផ្លាស់ (ឧ. mutation de personnel) ; droits de mutation អាករសោធបរិវត្តន៍ (អាករលើការលក់ ឬ ផ្ទេរសិទ្ធិ)

mutationnisme *n.m.* បរិវត្តនិយម

mutationniste *a.* បរិវត្តនិយម ។ *n.* អ្នកបរិវត្តនិយម

muter *v.t.* បរិវត្ត, ផ្លាស់, ប្ដូរ

mutilant,e *a.* ដែលបណ្ដាលឲ្យកាត់អវយវៈ(ឧ.opération mutilante)

mutilateur *n.m.* អ្នកធ្វើឲ្យខូច(ឧ.les mutilateurs des œuvres d'art

sont de véritables vandales)

mutilation *n.f.* កាយវិកលកម្ម, ការកាត់អវយវៈណាមួយចេញ; ការកាត់ ឬធ្វើឲ្យខូចការខ្លះ; ការធ្វើឲ្យខូច (ឧ. mutilation d'une statue)

mutilé,e *n.* កាយវិកល, អ្នកដែលគេកាត់អវយវៈណាមួយចេញ

mutiler *v.t.* ធ្វើកាយវិកលកម្ម, កាត់អវយវៈណាមួយចេញ។ *Par ext.* កាត់ការខ្លះ (ឧ. mutiler un monument); ធ្វើឲ្យខូច (ដោយដកចេញខ្លះ ឬ បន្ថែម) (ឧ. mutiler un ouvrage)

mutin,e *a.* ប៉ិប៉ុលប៉ប៉ូច (ឧ. air mutin)។ *n.m.* អ្នករឹងរូស, អ្នកបះបោរ, (ឧ. châtier des mutins)

mutiner (se) *v.pr.* បះបោរមិនព្រមស្ដាប់បង្គាប់; ធ្វើសង្កុបកម្ម, បះបោរ (ឧ. l'armée se mutina)

mutinerie *n.f.* សង្កុបកម្ម, ការបះបោរ

mutisme *n.m.* ភាពមនុស្សគ (ឧ. l'apoplexie amène souvent le mutisme)។ *Fig.* ភាពអ្នកមិនចង់និយាយឬនិយាយមិនរួច

mutité *n.f.* ម.ព. mutisme

mutualiste *a.* ជាអញ្ញមញ្ញភាព (ឧ. une société mutualiste)។ *n.* សមាគមអញ្ញមញ្ញសង្គ្រោះ

mutuel,elle *a.* អញ្ញមញ្ញ, ទៅវិញទៅមក (ឧ. estime mutuelle)។ *n.f.* សមាគមអញ្ញមញ្ញសង្គ្រោះ

mutualité *n.f.* អញ្ញមញ្ញភាព, ភាពមានទៅមានមក; សមាគមអញ្ញមញ្ញសង្គ្រោះ (សមាគមសង្គ្រោះគ្នាទៅវិញទៅមក)

mutuellement *adv.* ជាអញ្ញមញ្ញ, ទៅវិញទៅមក (ឧ. s'instruire mutuellement)

myalgie *n.f.* ដំណើរឈឺសាច់ដុំ

mycologie *n.f.* កពកសាស្ត្រ [ក:-ព:-ក:—] (វិទ្យាសាស្ត្រខាងផ្សិត)

mycologique *a.* នៃកពកសាស្ត្រ

mycologue *n.* កពកវិទូ (អ្នកប្រាជ្ញខាងផ្សិត)

mycose *n.f.* កពករោគ [ក:-ព:-ក:—] (រោគបណ្ដាលអំពីផ្សិត)

myélite *n.f.* រោគរលាកមិញ្ញាឆ្អឹងខ្នង; រោគរលាកមិញ្ញាឆ្អឹង

myocarde *n.m.* សាច់ដុំបេះដូង

myologie *n.f.* *Anat.* វិទ្យាសាស្ត្រខាងសាច់ដុំ

myome *n.m.* ដំណើរដុំសាច់ដុំ

myopathie *n.f.* រោគសាច់ដុំ

myope *n. & a.* ទូរន្ទ [ទូ-រន់], ងងឹតឆ្ងាយ

myopie *n.f.* ទូរន្ទភាព, ភាពងងឹតឆ្ងាយ

myosine *n.f.* ម្យូស៊ីន

myriade *n.f.* អនេកប្បមាណ; ចំនួនច្រើនអនេក (ឧ. des myriades d'étoiles)

myriapodes *n.m.pl.* ម.ព. mille-pattes

myrmidon *n.m.* មនុស្សមានតួចកញ្ច្រិក; *au fig.* មនុស្សតូចតាច (មានយសសក្តិតូច)

myriapodes *n.m.pl.* ពហុប្បាទសត្វ

mystère *n.m.* គោល ឬ ហេតុនៃសាសនា ដែលពុំអាចយល់បានដោយវិចារណញ្ញាណ; អាថ៌កំបាំង (ឧ. les mystères de la politique); ការពង្វាង; ការប៉ប៉ិចប៉ប៉ាំង (មិនឲ្យគេដឹងសុះសាយ) (ឧ. parler avec mystère) ។ faire mystère de លាក់បំបាំង

mystérieusement *adv.* យ៉ាងស្ងាត់; ជាអាថ៌កំបាំង

mystérieux,euse *a.* ជាអាថ៌កំបាំង; ដែលគេពុំអាចដឹងឬពុំអាចស្គាល់បាន(ឧ. un homme mystérieux)

mysticité *n.f.* ភាពតឹងរ៉ឹងក្នុងសាសនា

mystifiable *a.* អាចបញ្ឆោតលេងបាន

mystificateur,trice *a. & n.* ដែលចូលចិត្តបញ្ឆោតលេង

mystification *n.f.* ការបញ្ឆោតលេង; របស់គ្មានខ្លឹមសារ-គ្រាន់តែបញ្ឆោត

mystifier *v.t.* បញ្ឆោតលេង

mystique *a.* ដែលកាន់សាសនាយ៉ាងតឹង ។ *n.f.* វិទ្យាសាស្ត្រខាងកាន់សាសនាតឹងរ៉ឹង

mythe *n.m.* ទេវកថា, អព្ភូតកថា; រឿងលើក (ឧ. les mythes de la Grèce) ។ *Fig.* វត្ថុមិនពិតឬព្រេង (ឧ. le Phénix des Anciens est un mythe)

mythique *a.* នៃទេវកថា (ឧ. la période mythique de la Grèce)

mythographe *n.m.* អ្នកនិពន្ធខាងទេវកថា

mythologie *n.f.* ទេវកថាវិទ្យា (រឿងអាទិទេពនិងវីរបុរសក្នុងបុរាណកាល)

mythologique *a.* នៃទេវកថាវិទ្យា

mythologue *n.m.* ទេវកថាវិទូ

mythomane *a. & n.* អព្ភូតុម្មត្ត, ដែលនិយាយមិនពិត

mythomanie *n.f.* អភូតុម្ពុទ, ទម្លាប់ខាងនិយាយមិនពិត

mytiliculteur *n.m.* សិប្បីវប្បករ, អ្នកចិញ្ចឹមគ្រុំ

mytiliculture *n.f.* សិប្បីវប្បកម្ម, ការចិញ្ចឹមគ្រុំ

n *n.m.* អក្សរទី ១៤ នៃអក្ខរក្រមឡាតាំង

nabab *n.m.* អ្នកមានទ្រព្យស្ដុកស្ដម្ភ,សេដ្ឋី

nabot,e *n.* មនុស្សកន្ដុញ,រមុកមិក-កញ្ចឹកកញ្ចុក

nacarat *a.inv.* ក្រហមខ្ចី (ឧ. soie nacarat) ។ *n.m.* ពណ៌ក្រហមខ្ចី (ឧ.étoffe d'un beau nacarat)

nacelle *n.f.* ទូកគ្មានក្ដោង; ទូក ។ *Aéron.* ជាលគោមហោះ(សម្រាប់ជិះ)

nacre *n.f.* ខ្យងជាំ

nacré,e *a.* ដែលមានសភាពដូចខ្យងជាំ (ឧ. teint nacré)

nacrer *v.t.* ធ្វើឲ្យមានសភាពដូចខ្យងជាំ (ចំពោះត្បូងក្លែងក្លាយធ្វើអំពីកែវ)

nævus [né-vuss] *n.m.* ប្រជ្រុយ(*pl.* des nævi)

naga *n.m.* នាគ

nage *n.f.* ការហែលទឹក ។ *Mar.* ការអុំឬចែវទូក។ à la nage ដោយហែល (ឧ. se sauver à la nage) ។ se jeter à la nage លោតទឹក (ដើម្បីហែល) ។ *Fig.* être tout en nage បែកញើសដូចគេងូត

nagée *n.f.* សំទុះហែល (ចម្ងាយដែលហែលបានក្នុងពេលដែលភាសជើង ឬ ដៃម្ដងៗ)

nageoire *n.f.* ព្រុយត្រី ។ nageoire abdominale ព្រុយពោះ ។ nageoire anale ព្រុយគូទ ។ nageoire caudale ព្រុយកន្ទុយ ។

nageoire dorsale ព្រុយខ្នង ។ nageoire pectorale ព្រុយទ្រូង។ បន្ទះក្តារ ឬ ស្លឹកដែលគេបណ្តែតក្នុងទឹក ដោតកុំឱ្យក្រឡុក

nager *v.i.* ហែលទឹក; អណ្តែត (ឧ. le bois nage sur l'eau)។ *Par ext.* ហែល (នៅក្នុងវត្ថុរាវអ្វីមួយ) (ឧ. ce poisson nage dans le beurre) ។ *Mar.* អុំ ឬ ចែវទូក ។ *Fig.* nager dans l'opulence មានទ្រព្យស្តុកស្តម្ភ ។ nager dans le sang ប្រឡាក់ឈាមពេញខ្លួន ។ nager entre deux eaux យោគយល់ទាំងសងខាង ។ *Fam.* ហែលគោក; មិនដឹងធ្វើខ្លួនម្តេច; មិនយល់ ។ *v.t.* ហែល (តាមបែបណាមួយ) (ឧ. nager le crawl)

nageur,euse *n.* អ្នកហែលទឹក

naguère *adv.* ក្នុងពេលថ្មីៗនេះ: (គេសរសេរជា naguères ក៏បាន)

naïf,ïve *a.* ពីកំណើត; ត្រង់ (ឧ. les grâces naïves de l'enfance); ដែលនិយាយពីការពិត-ពីធម្មជាតិ (ឧ. un style naïf); គ្មានពិសោធន៍; កញ្ជាត (ឧ. réponse naïve)

nain,naine *a.* តឿ ។ *n.* មនុស្សតឿ (ព.ផ. géant)

naissance *n.f.* ប្រសូតិកម្ម, ការកើត; កំណើត(ឧ.naissance illustre); គល់ (ឧ.naissance de l'épine dorsale) ។ *Fig.* ដើមកំណើត (ឧ. naissance du monde)។donner naissance បណ្តាល,ឱ្យមាន; បង្កើត ។ prendre naissance ចាប់ផ្តើមឡើង, ចាប់មានឡើង ។ de naissance តាំងពីកំណើត; តាំងពីមុនកើត (ឧ. aveugle de naissance) ។ acte de naissance សំបុត្រកំណើត

naissant,e *a.* ដែលកើត; ដែលចាប់កំណើត; ដែលទើបនឹងលេចឡើង (ឧ. jour naissant)

naitre *v.i.* ប្រសូត, កើត; មានដើមកំណើត (ឧ. le Mékong nait dans le Thibet); កើតមាន (ឧ. les fleurs naissent au printemps); មានកោសល្យពីកំណើត (ការប៉ិនប្រសប់) (ឧ. naître poète)។ *Fig.* មកពី, បណ្តាលពី (ឧ. les guerres naissent des guerres)។ faire naître បង្កើត; បណ្តាលឱ្យមាន

naïvement *adv.* ដោយឆោត, ដោយត្រង់

naïveté *n.f.* មទ្ទភាព, សេចក្ដីត្រង់ (ឧ. la naïveté d'un enfant); សេចក្ដីឆោត ឬ ល្ងង់ខ្លាំង (ឧ. être d'une grande naïveté); សំដីកញ្ញាត (ឧ. dire des naïvetés)

naja *n.m.* ពស់វែក (ឧ. le cobra est une espèce de naja de l'Inde) (ធម្មតាគេហៅ serpent à lunettes)

nanan *n.m.* បង្អែម (ពាក្យក្មេង) ។ *Fig.* វត្ថុប្រណីតឬឆ្ងាញ់ពិសា

nandou *n.m.* ណង់ឌូ (បក្សីប្រភេទមួយរស់នៅនាទ្វីបអាមេរិកខាងត្បូង)

nanisme *n.m.* ភាពនៃមនុស្សតឿ

nankin *n.m.* សំពត់ណង់កាំង (សំពត់សើបហើយសាច់ជិតក្បាញដោយអំបោះពណ៌(ឧ.pantalon de nankin)

nansouk *n.m.* សំពត់ណង់ស៊ុក (សំពត់អំបោះស្រាលទន់សើបដូចព្រៃ)

nantir *v.t.* ដាក់បញ្ចាំ ។ *Par ext.* ឲ្យ, ផ្ដល់ (ឧ. nantir de provisions)។se nantir *v.pr.* បម្រុងទុក (ឧ. se nantir d'argent)

nantissement *n.m.* តំណាំង; សច្ចាការ, ការបញ្ចាំ; សិទ្ធិតបញ្ចាំ; វត្ថុដាក់បញ្ចាំ

napalm *n.m.* ណាប៉ាល់ (ប្រេងសាំងកកសម្រាប់ធ្វើគ្រាប់បែកឆេះ)

naphtaline *n.f.* ឬ **naphtalène** *n.m.* ណាហ្វតាលីន, ថ្នាំស្អុយដាក់កុំឲ្យសត្វល្អិតកាត់ខោអាវ

naphte *n.m.* ប្រេងកាតអសុទ្ធ (ប្រេងកាតមិនទាន់ចម្រាញ់)

napoléon *n.m.* កាក់ណាប៉ូឡេអុង (កាក់មាសមានរូបណាប៉ូឡេអុងទីមួយឬទីបី តម្លៃ ២០ ហ្វ្រង់)

napoléonien,enne *a.* នៃកាក់ណាប៉ូឡេអុង; នៃណាប៉ូឡេអុងទីមួយ

napolitain,e *a.* &*n.* នៃក្រុងណាប ។ *n.f.* សំពត់ខណ្ឌាម័យ

nappage *n.m.* កម្រាលតុនិងកន្សែងដៃ

nappe *n.f.* កម្រាលតុ (ឧ. mettre la nappe) ។ nappe d'autel កម្រាលអង្គ ឬ គ្រែព្រះធម៌ ។ *Par anal.* nappe d'eau ផលស្លាប (ទឹកដក់លើដីឬក្នុងដី) ។ nappe phréatique ផលស្លាបក្នុងស្តូក (ទឹកដក់ក្នុងស្រទាប់ដីហើយចេញជាប្រភព)។ nappe souterraine ផលស្លាបក្នុងដី ។ *Par ext.* nappe de

gaz ឧស្ម័នស្តារ ។ ទឹកធ្លាក់ (ដូចកម្រាល); ផ្ទៃទឹក។ nappe de feu អគ្គីស្តារ (ទីធំដែលមានភ្លើងឆេះពេញ)

napper *v.t.* ក្រាលកម្រាលតុ

napperon *n.m.* កម្រាលតូច (សម្រាប់ទ្រាប់ពីលើកម្រាលតុធំកុំឲ្យប្រឡាក់)

narcisse *n.m.* ដើមផ្កាម្យ៉ាង ។ *Fig.* មនុស្សអត្តស្នេហា (ស្រឡាញ់ខ្លួនឯង)

narcissisme *n.m.* អត្តស្នេហានិយម (ការស្រឡាញ់ងប់នឹងខ្លួនឯង)

narcolepsie *n.f.* *Méd.* សេចក្ដីងងុយដេកខ្លាំង (ទប់មិនបាន)

narcose *n.f.* ដំណើរដេកលក់ដោយថ្នាំសណ្ដំ

narcotine *n.f.* ណាកូទីន (ជាតិអាភៀន)

narcotique *a.* ដែលធ្វើឲ្យងងុយដេក; ដែលសណ្ដំ ។ *n.m.* ថ្នាំសណ្ដំ, ថ្នាំងងុយដេក (*ff.* somnifère, soporifique)

narguer *v.t.* ចំអកដោយមើលងាយ; ជំទះដោយមើលងាយ; ប្រសើរជាងច្រើន

narguilé [-ghi-] ឬ **narghileh** *n.m.* ខ្សៀជក់ទឹក

narine *n.f.* រន្ធច្រមុះ

narquois,e *a.* ឡកឡឺយ ; ដែលមានឧបាយកល (ឧ. un air narquois)

narquoisement *adv.* ដោយឡកឡឺយ; ដោយឧបាយកល

narrateur,trice *n.* អ្នកនិទានរឿង

narratif,ive *a.* នៃរឿងនិទាន (ឧ. style narratif)

narration *n.f.* និទានកថា; រឿងដំណាល; ការរៀបរាប់តែងសេចក្ដី

narrer *v.t.* និទាន, ដំណាលរឿង (ឧ. narrer une bataille)

nasal,e,aux *a.* នៃច្រមុះ ។ fosses nasales រន្ធច្រមុះ ។ *Gram.* consonne, voyelle nasale ឬ nasale *n.f.* នាសិកជៈ (វេយ្យាករណ៍)(ដែលមានសម្លេងកើតត្រង់ច្រមុះ)

nasalement *adv.* ដោយនាសិកជៈ, ដោយមានសម្លេងកើតត្រង់ច្រមុះ

nasalisation *n.f.* នាសិកជកម្ម, ការនិយាយបញ្ចេញសម្លេងពីច្រមុះ ; ភាពសម្លេងនិយាយតាមច្រមុះ

nasaliser *v.t.* និយាយបញ្ចេញសម្លេងពីច្រមុះ (ឧ. nasaliser une voyelle)

nasalité *n.f.* នាសិកជភាព, ភាពសម្លេងកើតត្រង់ច្រមុះ

nasarde *a.* ការបួតច្រមុះ ។ *Fig.*

& *Fam.* ការប្រមាថ, ការចាក់ដោត (ឧ. recevoir des nasardes)

naseau *n.m.* រន្ធច្រមុះសត្វ (មានសេះ, គោជាដើម)

nasillarde *v.i.* ក្ងួរ, ដែលចេញពីច្រមុះ (ឧ. voix nasillarde)

nasillement *n.m.* ការនិយាយក្ងួរ; គុណវិបត្តិនៃអ្នកនិយាយក្ងួរ

nasiller *v.i.* និយាយក្ងួរ; យំ(ទា, ជ្រូកព្រៃ)

nasilleur,euse *n.* អ្នកនិយាយក្ងួរ

nasonnement *n.m.* សម្លេងក្ងួរ

nasse *n.f.* វឡូកណ្ដ (នេសាទឧបករណ៍ដែលធ្វើដោយឫស្សីជាដើមដូចអង្រុត, លប, ទ្រូ); លប់(សំណាញ់ទាក់បក្សី)។ *Fig.* ស្ថានភាពអាក្រក់ ; អន្ទាក់ ឬ ឧបាយកល (ឧ. tomber dans la nasse)

natal,e,als *a.* នៃស្រុក ឬ ថ្ងៃកំណើត (ឧ. pays natal)

natalité *n.f.* ជាតប្បមាណ (ភាគកំណើតក្នុងចំនួនប្រជាពលរដ្ឋ)

natation *n.m.* ឧទកកីឡា, ការហែលទឹក; សិល្បៈខាងហែលទឹក

natatoire *a.* នៃការហែលទឹក, សម្រាប់ហែលទឹក (ឧ. appareil natatoire) ។ vessie natatoire ប្លោកខ្យល់ (នៃត្រី)

natif,ive *a.* ដែលមានស្រុកកំណើតនៅ (ឧ. être natif de Takèo)។ *Fig.* ដែលមានពីកំណើត (ឧ. vertu native) ។ or, argent, cuivre natif រ៉ែមាស-ប្រាក់-ស្ពាន់ កំណើត (ដែលគេឃើញមាននៅក្នុងដីជាលោហធាតុស្រាប់) ។ *n.* អ្នកកើត (នៅស្រុកណាមួយ) (ឧ. un natif de Pursat)

nation *n.f.* ប្រជាជាតិ ។ *pl. Relig.* អ្នកទ្រុស្តសាសនា (ឧ. saint Paul, l'Apôtre des nations)

national,e,aux *a.* ជាតិ (របស់ប្រជាជាតិ)(ឧ.caractère national)។ *n.m. pl.* អ្នកទេសជាតិ (ឧ. les consuls défendent les intérêts de leurs nationaux)

nationalisation *n.f.* ជាតូបនីយកម្ម, ការដាក់ជារបស់ជាតិ

nationaliser *v.t.* ធ្វើជាតូបនីយកម្ម, ដាក់ជារបស់ជាតិ

nationalisme *n.m.* ជាតិនិយម

nationaliste *a.* ជាតិនិយម ។ *n.* អ្នកជាតិនិយម

nationalité *n.f.* សញ្ជាតិ

national-socialisme *n.m.* ជាតិ-សង្គមនិយម (ជា nazisme ក៏បាន)

national-socialiste *a.* នៃជាតិសង្គមនិយម ។ *n.* អ្នកជាតិសង្គមនិយម (ជា nazi ក៏បាន)

nativement *adv.* ពីកំណើត

nativité *n.f.* បុណ្យខួបកំណើតព្រះយេស៊ូគ្រិស្ត ។ *Absol.* Nativité បុណ្យណូអែល

N.A.T.O.(North Atlantic Traity Organization)ម.ព. O.T.A N.

nattage *n.m.* ការត្បាញកន្ទេល;ការក្រង

natte *n.f.* កន្ទេល; កម្រងសក់; កម្រង

natter *v.t.* ត្បាញកន្ទេល; ក្រង; ក្រាលកន្ទេល

nattier,ère *n.* អ្នកធ្វើកន្ទេល

naturalisation *n.f.* សញ្ជាតូបនីយកម្ម, ការអនុញ្ញាតឲ្យចូលជាតិ; ការផ្សាំធាតុអាកាស; ការធ្វើឲ្យមានភាពក្រៀមដូចជារស់; ការបញ្ចូលជាពាក្យជាតិ

naturalisé,e *n.* អ្នកចូលជាតិ (ឧ. les naturalisés jouissent des mêmes droits que les nationaux)

naturaliser *v.t.* ធ្វើសញ្ជាតូបនីយកម្ម, អនុញ្ញាតឲ្យចូលជាតិ; ផ្សាំធាតុអាកាស; បញ្ចូលជាពាក្យជាតិ (ឧ. naturaliser un mot); ធ្វើឲ្យមានសភាពក្រៀមដូចរស់

naturalisme *n.m.* ភាពជាធម្មជាតិ ។ *Littér.* ធម្មជាតិនិយម

naturaliste *n.* ធម្មជាតិវិទូ , អ្នកវិទ្យាសាស្ត្រធម្មជាតិ (ឧ. Aristote, Pline et Buffon ont été de grands naturalistes); អ្នករៀបចំសត្វដើម្បីរក្សាទុក;អ្នកធម្មជាតិនិយម។ *a.* នៃលវិន្ទកលើធម្មជាតិ

nature *n.f.* ធម្មជាតិ (ឧ. les trois règnes de la nature); រូបលោក [រូ-ប៉ះ-] (លោកដែលមានរូប) (ឧ.les harmonies de la nature); ប្រភេទ (ឧ. nature divine, humaine); ចរិត (ឧ. une nature bilieuse); សភាព(ឧ.nature indolente);វត្ថុ(មានផលដំណាំជាដើមជំនួសឲ្យប្រាក់) (ឧ. payer en nature); មុខ,ប្រភេទ (ឧ. objets de différente nature) ។ nature des marchandises ប្រភេទទំនិញ។ état de nature ភាពនៅជាធម្មជាតិ (ភាពមុនសុីវិល័យ) ។ forcer **la nature** ធ្វើហួសកម្លាំង ឬ ហួស

សមត្ថភាព ។ payer le tribut à la nature បង់ពន្ធដី; ស្លាប់។ nature morte *Peint.* សត្វងាប់ (រូប); *par ext.* របស់គ្មានវិញ្ញាណ ។ *a. inv.* សុទ្ធ, គ្មានលាយនឹងអ្វី (ឧ.bœuf nature; café nature) ។ *Fam.* ធម្មតា, មិនធ្វើឫកពា (ឧ. personne très nature)

naturel,elle *a.* ធម្មជាតិ (ឧ.loi naturelle); ដែលមានពីកំណើត (ឧ. bonté naturelle); ជាធម្មតា (ឧ. il est naturel de...); សុទ្ធ,មិនលាយ, មិនក្លាយ(ឧ. vin naturel); ដែលមានក្នុងធម្មជាតិ (ឧ. gaz naturel) ។ enfant naturel ម.ព. enfant) ។ mort naturelle ស្លាប់តាមធម្មតា (ដោយជម្ងឺ ឬ ដោយចាស់)។ sciences naturelles វិទ្យាសាស្ត្រធម្មជាតិ ។ histoire naturelle សត្វវិទ្យាសាស្ត្រ ។ loi naturelle ម.ព. loi

obscurcir *v.t.* ធ្វើឲ្យងងឹត (ឧ. les hautes maisons obscurcissent la rue)។ *Fig.* ធ្វើឲ្យពិបាកយល់ (ឧ. quelquefois, un commentaire obscurcit un texte) ។

s'obscurcir *v.pr.* ឡើងស្រទំ, ឡើងងងឹត (ឧ. le temps s'obscurcit) ។ *Fig.* ឡើងស្រអាប់, បាត់ស្មើ(ឧ. sa gloire s'est obscurcie)

obscurcissement *n.m.* ដំណើរចេញពន្លឺ, ភាពងងឹត (ឧ. obscurcissement du soleil)។ *Fig.* ការឡើងស្រអាប់-ឱយស្មើ(ឧ.l'obscurcissement d'une réputation)

obscurément *adv.* ដោយងងឹត ; ដោយមិនច្បាស់ ; ដោយពិបាកយល់ ; ដោយគ្មានគេស្គាល់ច្រើន (ឧ. finir obscurément sa vie)

obscurité *n.f.* ភាពងងឹត (ឧ. l'obscurité de la nuit) ។ *Fig.* ទីងងឹត; ភាពមិនសូវច្បាស់, ភាពពិបាកយល់(ឧ.obscurité de langage); ភាពគេមិនសូវស្គាល់(ឧ.l'obscurité du passé); ស្ថានភាពមិនរុងរឿង; ដំណើរបាត់កិត្តិសព្ទ(ឧ.vivre dans l'obscurité)

obsécration *n.f.* ការបួងសួង

obsédant,e *a.* ដែលរំខានឬរំអុក (ឧ. une insistance obsédante)

obsédé,e *a.&n.* ដែលមានកង្វល់ចិត្ត; ដែលមានគំនិតមមៃ

obséder *v.t.* រំខាន, រំអុក (ឧ. être obsédé par des solliciteurs); ធ្វើឲ្យខ្វល់ចិត្ត;ធ្វើឲ្យនឹកមមៃ(ឧ. cette idée m'obsède)(*syn.*ennuyer, persécuter, tracasser)

obsèques *n.f. pl.* បុណ្យខ្មោច

obséquieusement *adv.* ដោយគោរពហួសប្រមាណ (ឧ. saluer obséquieusement)

obséquieux,euse *a.* ដែលយកចិត្តទុកដាក់-ភប់អានឬគោរពហួសប្រមាណ (ឧ. des manières obséquieuses)

obséquiosité *n.f.* ចរិតអ្នកគោរពហួសប្រមាណ

observable *a.* អាចសង្កេតបាន (ឧ. éclipse aisément observable)

observance *n.f.* ការប្រតិបត្តិតាមបញ្ញត្តិសាសនា, បញ្ញត្តិសាសនា

observateur,trice *n.* អ្នកប្រតិបត្តិតាមច្បាប់ (ឧ. observateur des commandements de Dieu); អ្នកសង្កេត (ឧ. un écrivain doit être un observateur attentif); អ្នកសង្កេតការណ៍ (ឧ. se faire représenter par un observateur à une conférence internationale); អ្នកចាំមើល ។ *a.m.* ដែលសង្កេត, ដែលចេះសង្កេត (ឧ esprit observateur)

observation *n.f.* ការប្រតិបត្តិតាម; ការកាន់ (ឧ. l'observation d'un règlement) ; ការសង្កេត, កំណត់សំគាល់ (ឧ observation d'un phénomène)។ esprit d'ob-

servation ការចេះសង្កេត ។ observation aérienne ការឈ្លបយកការណ៍ដោយអាកាសយាន ។ observation armée ការសង្កេតដោយឧបករណ៍ (តាមរបៀបវិទ្យាសាស្ត្រ)។ ការតិះទៀន; ការបន្ទោស(ឧ. faire une observation à un enfant)។ être ឬ se tenir en observation ឈ្លប ឬ ឃ្លាំមើល ។ mettre un malade en observation សង្កេតអាការៈរោគ ។ corps d'observation ទ័ពឈ្លប

observatoire *n.m.* ឧលោកនដ្ឋាន [អុ-ឡោ-កៈ-ណ័ត-], កន្លែងសង្កេត; កន្លែងឈ្លបមើលសត្រូវ

observer *v.t.* កាន់, ប្រតិបត្តិតាម (ឧ. observer les convenances); សង្កេត (ឧ. observer le cours des astres); ក្តោល; ឃ្លាំមើល; ឈ្លប (ឧ. on nous observe) ។ s'observer *v.pr.* ប្រុងប្រយ័ត្ន (ឧ. cet homme s'observe en société); ឃ្លាំគ្នាទៅវិញទៅមក (ឧ. les deux armées s'observent)

obsession *n.f.* ការរំខាន ។ *Fig.* ការគិតមមៃ ។ *Psychol.* គំនិតមមៃ (ឧ. l'obsession est une névrose)

obsessionnel,elle *a.* ដែលឲ្យគិតមមៃ (រោគ) (ឧ. une névrose obsessionnelle)

obsolète *a.* ដែលគេលែងប្រើ (ឧ. mot obsolète)

obstacle *n.m.* ឧបសគ្គ (ឧ. obstacle infranchissable)

obstétrical,e,aux *a.* នៃគព្ភបរិហារវិទ្យា [គ័ប-ភៈ-ប៉-រិ-ហារៈ-] (ការសម្រាលកូន)

obstétrique *n.f.* គព្ភបរិហារវិទ្យា [គ័ប-ភៈ-ប៉-រិ-ហារៈ-], វិជ្ជាសម្រាលកូន

obstination *n.f.* ការចចេស(ឧ. vaincre l'obstination de quelqu'un)

obstiné,e *a.&n.* ចចេស (ឧ. enfant obstiné) ។ *Fig.* ឧហាត, ស៊ក (ឧ. travail obstiné)

obstinément *adv.* ដោយចចេស, ដោយរឹងរូស (ឧ. s'en tenir obstinément à la première opinion)

obstiner(s') *v.pr.* ចចេស(ឧ. s'ob-

stiner dans son opinion)

obstructif,ive *a.* ដែលឲ្យស្ទះ

obstruction *n.f.* *Méd.* ឧបរោធន៍, ដំណើរស្ទះ (ឧ. obstruction intestinale)។ *Fig.* ការបន្ទប់ (ឧ. faire de l'obstruction) ។ *Sports* ការបន្ទប់បង្អាក់

obstructionnisme *n.m.* ឧបរោធនិយម, បន្ទប់និយម (លទ្ធិនយោបាយប្រើឧបាយបន្ទប់បង្អាក់).

obstructionniste *a.* ឧបរោធនិយម, បន្ទប់និយម ។ *n.* អ្នកឧបរោធនិយម, អ្នកបន្ទប់និយម

obstruer *v.t.* ធ្វើឧបរោធន៍, ធ្វើឲ្យស្ទះ; បន្ទប់ (*iff.* barrer, embarrasser, fermer, obturer)

optempérer (à) *v.i.* ស្ដាប់បង្គាប់; សុខចិត្ត (ឧ. obtempérer à un ordre)

obtenir *v.t.* បាន (ឧ. obtenir une faveur) (*iff.* acquérir, gagner, remporter)

obtention *n.f.* ការបាន

obturateur,trice *a.* សម្រាប់បិទឬចុក (ឧ. plaque obturatrice) ។ *n.m.* វត្ថុសម្រាប់បិទឬចុក; សន្ទះ

obturation *n.f.* ការបិទឬចុក; ភាពស្ទះ

obturer *v.t.* បិទ; ចុក, ធ្វើឲ្យស្ទះ

obtus,e *a.* ទាល ។ *Math.* angle obtus មុមញាយ ។ *Fig.* esprit obtus ប្រាជ្ញាអាប់

obtusangle *a.* ដែលមានមុមញាយ (ចំពោះត្រីកោណ)

obus [-bu] *n.m.* គ្រាប់បែកបាញ់

obusier *n.m.* កាំភ្លើងបាញ់គ្រាប់បែក

obvenir *v.i.* *Dr.* ធ្លាក់បានមក

obvier (à) *v.i.* បង្ការ (ឧ. obvier à un inconvénient)

occasion *n.f.* ឱកាស (ឧ. profiter d'une occasion); ឱកាស, ជើងពេល; ហេតុ (ឧ. occasion de dispute) ។

d'occasion *loc.adv.* ដោយគាប់ជួន; ជំនំ (ដែលគេប្រើប្រាស់ខ្លះហើយ) (ឧ. voiture d'occasion)។ à l'occasion *loc.adv.* បើមានឱកាស ។ par occasion *loc.adv.* ដោយពេល, ដោយជួន

occasionnalisme *n.m.* *Phil.* ឱកាសនិយម (ឧ. occasionnalisme de Malebranche)

occasionnel,elle *a.* ដែលបើកឱកាស;

ដែលជាឱកាស (ឧ. circonstance occasionnelle) ។ *Phil.* cause occasionnelle ហេតុជាឱកាស

occasionnellement *adv.* ដោយពេល, ដោយចួន

occasionner *v.t.* បណ្ដាល, នាំឲ្យ (ឧ. une chute occasionna sa mort) (*syn.* amener, causer, créer, déterminer, entraîner, susciter)

occident *n.m.* បស្ចិម, ទិសខាងលិច; បស្ចិមប្រទេស

occidental,e,aux *a.* បស្ចិម, ខាងលិច ។ *n.m. pl.* ជនជាតិបស្ចិមប្រទេស

occipital,e,aux *a.* នៃកញ្ចឹងក (ឧ. muscles occipitaux)

occiput *n.m.* កញ្ចឹងក

occire *v.t.* សម្លាប់

occlure *v.t.* បិទខ្ទ, ស្ទះ

occlusif,ive *a.* ធ្វើឲ្យស្ទះ

occlusion *n.f.* ការបិទ; ដំណើរស្ទះ ។ *Méd.* occlusion intestinale រោគស្ទះពោះវៀន

occultation *n.f. Astr.* ការបាំង (ដំណើរដែលតារាណាមួយមានតារាមួយទៀតបាំង)

occulte *a.* ដែលជាអាថ៌កំបាំង (ឧ. pouvoir occulte) ។ sciences occultes រហស្សវិទ្យាសាស្ត្រ [រៈ-ហ័ស-សៈ-] (វិជ្ជាមន្តអាគម)

occultisme *n.m.* រហស្សសាស្ត្រ (វិជ្ជាមន្តអាគម)

occultiste *a.* នៃរហស្សសាស្ត្រ ។ *n.* អ្នករហស្សសាស្ត្រ

occupant,e *a.&n.* ដែលកាន់កាប់ (ឧ. les forces occupantes) ។ *Dr.* premier occupant អ្នកកាន់កាប់មុនគេ ។ occupant de bonne foi អ្នកកាន់កាប់ដោយសុទ្ធចិត្ត

occupation *n.f.* ការដណ្ដើមយក; ការកាន់កាប់; ធុរៈ, កិច្ចការ (ឧ. avoir de nombreuses occupations); កន្លែងធ្វើការ, របរ (ឧ. ce genre d'occupation lui convient bien)

occupé,e *a.* ដែលមានកិច្ចការ, ដែលមានគេកាន់កាប់; មិនទំនេរ

occuper *v.t.* យកកន្លែង (ឧ. le lit occupa toute la place); យកពេល (ឧ. cette discussion a

occupé toute la séance);កាន់កាប់, នៅ (ឧ. occuper un logement); ឲ្យទ័ពកាន់កាប់ (ឧ. occuper une ville); ឲ្យធ្វើការ (ឧ. occuper des ouvriers) ។ occuper un emploi ប្រកបការងារ ។ *Fig.* occuper ses loisirs à ប្រើពេលសំរាកធ្វើ ។ ធ្វើឲ្យរវល់ (ឧ. son travail l'occupe beaucoup) ។

v.i. Dr. កាន់រឿងក្តី (ឧ. occuper pour le demandeur)។

s'occuper *v.pr.* ធ្វើ; គិតគូរ; រវល់ (ឧ.s'occuper de chimie)

occurrence *n.f.* ការជួបប្រទះ; ការគាប់ជួន (ឧ. agir selon l'occurrence) ។ en l'occurrence ចំពោះរឿងឬហេតុនេះ; ក្នុងវេលាៈកាលៈនេះ

océan *n.m.* មហាសមុទ្រ, មហាសាគរ (ឧ. les océans et les mers couvrent les sept dizièmes de la surface de la Terre)។ *Fig.* ផ្ទៃធំ (ឧ. un océan de verdure)

océanide *n.f.Myth.* ទេវតា [ទេ-វៈ-ត្បា] (ទេពធីតារក្សាសមុទ្រ)

océanien,enne *a.&n.*នៃមហាសមុទ្រ អូសេអានី

océanique *a.* នៃមហាសមុទ្រ

océanographe *n.* សាគរសាស្ត្រិន, អ្នកសាគរសាស្ត្រ

océanographie *n.f.* សាគរសាស្ត្រ (វិទ្យាសាស្ត្រខាងមហាសមុទ្រ)

océanographique *a.* នៃសាគរ-សាស្ត្រ (ឧ. recherches océanographiques); សាគរលេខ

ocelle *n.m.* ភ្នែកឯកត្ត-អន្លិជាទិកសត្វ ។ ល ។; ក្រ, ពណ៌មូលនៅស្លាបមេ-អំបៅស្លាបបក្សី-កេឌសត្វ

ocellé,e *a.* ផាកងភ្នែក(មូល); ដែលមានពណ៌មូល (ឧ. ailes ocellées)

ocre *n.f.* ដីឥដ្ឋពណ៌លឿង-ទង់ដែង ឬក្រហម ។ *a.inv.* ពណ៌ត្នោត (ឧ. papiers ocres)

ocrer *v.t.* ត្រលាក់ពណ៌ត្នោត

ocreux,euse *a.* ដូចដីឥដ្ឋក្រហម; ពណ៌ត្នោត (ឧ. un trait ocreux)

octa *n.m.* អដ្ឋា

octacorde *a. Mus.* អដ្ឋតន្ត្រ, ដែលមានខ្សែប្រាំបី(ឧ. lyre octacorde)

octaèdre *n.m. Math.* អដ្ឋតល [អ័ត-ឋៈ-ត័ល], ប្រលេពស្រុងប្រាំបី

octaédrique *a.* ជាភាងអដ្ឋគ័ល

octante *a. num.* ប៉ែតសិប

octave *n.f. Mus.* ការអដ្ឋ

octavier *v.i.* ឮស្រួតការអដ្ឋ (ឧ. le hautbois est sujet à octavier)

octavo *a.* ១៨

octobre *n.m.* តុលា (ខែ)

octogénaire *a.&n.* ដែលមានអាយុ ៨០ ឆ្នាំ

octogonal,e,aux *a.* ជាអដ្ឋកោណ (ឧ. pyramide à base octogonales)

octogone *n.m. Math.* អដ្ឋកោណ ។ octogone régulier អដ្ឋកោណស្មើជ្រុង ។ *a.* figure octogone រូបអដ្ឋកោណ

octopode *a.* អដ្ឋបាទ, ដែលមានអវយវៈប្រាំបី ។ *n.m. pl.* អដ្ឋបាទសត្វ

octopus *n.m.* អដ្ឋករ

octostyle *a.* អដ្ឋស្តម្ភ, ដែលមានសសរប្រាំបី . (ឧ. façade octostyle)

octosyllabe *a.&n.m.* ឬ **octosyllabique** *a.* អដ្ឋព្យាង្គ, ដែលមាន ៨ ព្យាង្គ (កាព្យ)

octroi *n.m.* ការឲ្យ (ឧ. l'octroi des lettres de noblesse)

octroyer *v.t.* ឲ្យ (ឧ. octroyer une grâce)

octuple *a.* អដ្ឋគុណ, ធំជាង ៨ ដង

oculaire *a.* នៃភ្នែក (ឧ. globe oculaire) ។ *Fig.* témoin oculaire ពសិណដែលបានឃើញនឹងភ្នែក

oculiste *n.&a.* ចក្ខុពេទ្យ, ពេទ្យភ្នែក (*ល.* ophtalmologiste)

oculus *n.m. Arch.* បង្អួចភ្នែកគ្រាប (បង្អួចមូល) (ម.ព. œil-de-bœuf ផង)

odeur *n.f.* គន្ធ, ក្លិន; គន្ធជាតិ, ទឹកអប់ (ឧ. odeur agréable, fétide)

odieusement *adv.* ដោយគួរឲ្យស្អប់; ដោយអាក្រក់ណាស់ (ឧ. être odieusement calomnié)

odieux,euse *a.* គួរឲ្យស្អប់ (ឧ. les méchants sont odieux à tout le monde) ។ *Par exag.* អាក្រក់ណាស់ (ឧ. personne odieuse) ។

n.m. មនុស្សអាក្រក់, មនុស្សគួរឲ្យស្អប់ (ឧ. l'odieux d'une action)

odomètre *n.m.* ប្រដាប់វាស់ចម្ងាយ

odontalgie *n.f.* ទន្តរោគ, ឈឺធ្មេញ

odontalgique *a.* នៃទន្តរោគ

odontologie *n.f. Anat. &Pathol.* ទន្តសាស្ត្រ (វិជ្ជាសាស្ត្រខាងធ្មេញ)

odorant,e *a.* ដែលការយក្លិន, ក្រអូប (ឧ. le jasmin est très odorant)

odorat *n.m.*ឃានវិញ្ញាណ

odorer *v.t.&i.* ហិតក្លិន; ការយក្លិន

odoriférant,e *a.* ក្រអូប (ឧ. prairie odoriférante)

odyssée *n.f.* ឈ្មោះកំណាព្យហូមែរ ។ *Fig.* ដំណើរផ្សងព្រេង; ព្រឹត្តិការណ៍ចំឡែកៗ (ឧ. sa vie fut une extraordinaire odyssée)

œcuménicité *n.f.* សាកលភាព

œcuménique [é-] *a.* សាកល

œdémateux.euse [é-] *a.* នៃលហើម

œdème [é-] *n.m.* ដំណើរហើម (មានហើមស្លុតជាដើម)

œdipe [é-] *n.m.* អ្នកឆាប់យល់អាថ៌កំបាំង

œil *n.m.* (*pl.* yeux) ចក្ខុ, ភ្នែក (ឧ. la prunelle de l'œil)។ jeter les yeux sur ចោលភ្នែកមើល ។ ប្រដាប់ប្រើជំនួសភ្នែក (ឧ. œil de verre); ទឹកល្អង(ឧ. cette perle a un bon œil);ពៅឬប្អូក(ប្រហោងផ្លែប៉ាវ៉េ ឬ ផ្លែនឹងសម្រាប់បញ្ចុះផង); ភ្នែក (ពន្លកឈើ) ; ប្រហោង (នំប៉័ង, នំកេក) ។ *Mar.* ក្រវិលពួងខ្សែ ។

Anat. œil à facettes ភ្នែកមុខខៃ ។

coup d'œil ទិដ្ឋភាព (ឧ. rade qui présente un magnifique coup d'œil); ការចោលភ្នែក (ឧ. jeter un coup d'œil sur quelqu'un, sur quelque chose); ការយល់យ៉ាងរហ័ស (ឧ. avoir le coup d'œil sûr) ។ entre quatre yeux ប្រទល់ភ្នែក , ប្រទល់មុខ ។ *Fam.* pour les beaux yeux de quelqu'un ដោយគប់អានចំពោះអ្នកណាមួយ (ដោយមិនប្រាថ្នាប្រយោជន៍)។ faire de l'œil ញាក់ភ្នែក (ជាសញ្ញា) ។ l'œil du maître ភ្នែកម្ចាស់(ម្ចាស់តែងមើលរបស់អ្វីដោយម៉ត់ចត់ជានិច្ច) (ឧ. il n'est pour voir que l'œil du maître) ។ *Fam.* avoir l'œil américain ឆាប់ឃើញ។ en un clin d'œil ក្នុងមួយប៉ព្រិចភ្នែក ។ être tout

yeuxមើលដោយព្រងប្រយ័ត។ avoir l'œil ប្រយ័ត។ avoir l'œil sur quelqu'un ឃ្លាំមើលអ្នកណាមួយ ។ ouvrir l'œil បើកភ្នែក (ឃើញ របស់អ្វី ដែលខ្លួនមិនបានឃើញដោយ ភ្លាមខ្លួន) ។ ouvrir de grands yeux បើកភ្នែកធំ (ដោយងល់) ។ voir tout par ses yeux មើល ដោយភ្នែកឯងទាំងអស់ ។ couver ឬ dévorer des yeux សម្លឹង បង់បាន ។ fermer les yeux sur បិទភ្នែក, ធ្វើជាមិនឃើញ។ ne pouvoir fermer les yeux ដេកមិន លក់ ។ fermer les yeux de quelqu'un ជួយបិទភ្នែកឲ្យ (ជួយ នៅពេលផុតដង្ហើម) ។ avoir un bandeau sur les yeux វិនិច្ឆ័យ ដោយសំអៀង។ avoir bon pied, bon œil ស្វាហាប់ហើយចេះប្រុង ប្រយ័ត។ avoir le coup d'œil juste ឆាប់យល់ ។ cela saute aux yeux ឬ crève les yeux ភស្តុតាងណាស់ ។ n'avoir pas froid aux yeux មានសេចក្តីក្លាហាន។ ne pas avoir les yeux dans sa poche យល់ច្បាស់; ឆាប់ឃើញ ។ avoir le compas dans l'œil ចូលស្ទាបដោយភ្នែក (ថ្លឹងភេពស់) ។ voir avec les yeux de la foi ជឿព្រួចភ្នែក(ជឿ ដោយមិនយល់ - ដោយមិនឃើញ) ។ *Pop.* se rincer l'œil លៀង ភ្នែក (លួចមើលអ្វីដែលឲ្យសប្បាយ) ។ *Fam.* taper dans l'œil ត្រូវ ភ្នែក , ជាប់ភ្នែក ។ *Pop.* s'en battre l'œil មិនយកចិត្តទុកដាក់ នឹង ។ *Pop.* à l'œil ១១៩ , ដោយ ឥតថ្លៃ ។

Prov. les yeux sont le miroir de l'âme ភ្នែកជាកញ្ចក់ ឆ្លុះមើលចិត្ត ។ quatre yeux voient mieux que deux ភ្នែក បួនមើលច្បាស់ជាងភ្នែកពីរ ។ loin des yeux, loin du cœur ម.ព. cœur ឬ loin។ l'œil du maître engraisse le cheval ឬ l'œil du fermier vaut fumier ម.ព. cheval ។ les ministres sont les yeux des princes មន្ត្រី ស្នងព្រះនេត្រព្រះមហាក្សត្រ ។ œil pour œil, dent pour dent ភ្នែកសងភ្នែក, ធ្មេញសងធ្មេញ (ច្បាប់

កាលយ៉ុងតម្រូវថា ទោសត្រូវឲ្យសមនឹងកំហុស)។ quand on a mal aux yeux, il n'y faut toucher que du coude គេមិនត្រូវពាល់ភ្នែកឈឺឲ្យសោះ

œil-de-bœuf *n.m.* បង្អួចភ្នែកព្រាប (បង្អួចមូល) (*pl.* des œils-de-bœuf)

œil-de-chat *n.m.* ត្បូងភ្នែកឆ្មា (*pl.* des œils-de-chat)

œil-de-perdrix *n.m.* ផ្លែស្រាមជើង; សាច់ជាប់ភ្នែកមាន់

œil-de-serpent *n.m.* ពេជ្រ (*pl.* des œils-de-serpent)

œillade *n.f.* ការពោលភ្នែក (បង្ហាញឲ្យដឹងចិត្ត) (ឧ. jeter une œillade)

œillard *n.m.* ប្រហោះត្បាល់កិន (រណ្ដៅបញ្ចូលស្រូវត្បាល់កិន)

œillère *n.f.* របាំងភ្នែក ។ *Fam.* avoir des œillères ចង់ឃើញតែទិដ្ឋភាពម្ខាងនៃរបស់មួយ; ជាប់ចិត្តខ្លាំងទៅលើអ្នកណាមួយ

œillet *n.m.* អិយេ (ផ្កាម្យ៉ាង); រន្ធស៊កខ្សែស្បែកជើង; ក្រវិល

œilleton *n.m.* លំពង់គល់; វង់តម្រង់កាំភ្លើង

œilletonnage *n.m.* ការក្តិចលំពង់គល់ចោល; ការបំបែកគុម្ព

œilletonner *v.t.* ក្តិចលំពង់គល់ចោល; បំបែកគុម្ព

œkoumène [é–] *n.m.* ផ្ទៃដីអាស្រ័យនៅបាន

œnanthique [é–] *a.* នៃស្រាទំពាំងបាយជូរ

œnilisme [é–] *n.m.* រោគស្រា

œnolique [é–] *a.* ដែលផ្សំដោយស្រា

œnologie [é–] *n.f.* សុរាវិទ្យា

œnologique [é–] *a.* នៃសុរាវិទ្យា

œnomètre [e–] *n.m.* សុរាមាត្រ

œnométrie [é–] *n.f.* សុរាមាត្រវិធី, វិធីស្ទង់ជាតិសុរា

œnométrique [é–] *a.* នៃសុរាមាត្រវិធី (ឧ. procédé œnométrique)

œnophile [é–] *a.* ដែលចូលចិត្តស្រា; នៃសុរា; នៃការផឹកស្រា ។ société œnophile ក្រុមហ៊ុនជួញស្រា ។
n. អ្នកចូលចិត្តស្រា

œnophobe [é–] *a.* ដែលស្អប់សុរា

œnophobie [é–] *n.f.* ការស្អប់សុរា

œnotechnie ឬ **œnotechnique** [é–] *n.f.* បច្ចេកទេសសុរា (ការធ្វើ, ការរក្សាស្រា។ល។)

œnotechnique *a.* នៃបញ្ញាធ្វើស្រា (ឧ. laboratoire œnotechnique)

œsophage [é—] *n.m.* បំពង់អាហារ

œsophagien,enne ឬ **œsophagique** [é—] *a.* នៃបំពង់អាហារ (ឧ. les contractions œsophagiennes)

œsophagite [é—] *n.m.* រោគរលាកបំពង់អាហារ

œsophagroscope [é—] *n.m.* *Méd.* ប្រដាប់ឆ្លុះបំពង់អាហារ

œstre [é—] *n.m.* រុយម្យ៉ាង

œuf *n.m.* អណ្ដូ, ស៊ុត, ពង។ *Fig.* ការបង្កដំបូង (ឧ. écraser une révolution dans l'œuf)។ plein comme un œuf ពេញណែន ។ œuf à la coque ស៊ុតស្រស់ ។ œuf dur ស៊ុតឆ្អិន ។ se ressembler comme deux œufs ដូចគ្នាបេះបិទ

œufrier *n.m.* ឆ្នាំងស្ងោរស៊ុត; ចានដាក់ស៊ុតស្ងោរ

œuvé,e *a.* ដែលមានពង (បំពោះត្រី)

œuvre *n.f.* ការ (ឧ. se mettre à l'œuvre ចាប់ធ្វើការ); ស្នាដៃ (ឧ. la science est l'œuvre des siècles); និពន្ធ, សៀវភៅ (ដែលតែង) (ឧ. publier ses œuvres); អំពើ (ឧ. le mérite des bonnes œuvres) ។ mettre en œuvre ដាក់ប្រើ ។ mettre à l'œuvre ឲ្យចាប់ធ្វើការ ។ faire œuvre de ការធ្វើយ៉ាងជាង។ œuvre de bienfaisance សមាគមសង្គ្រោះ ។ œuvres vives ផ្នែកលិចទឹក (នៃនាវា) ។ œuvres mortes ផ្នែកលើទឹក (នៃនាវា) ។ l'exécuteur des hautes œuvres ពេជ្ឈឃាត ។

n.m. ស្នាដៃទាំងឡាយនៃសិល្បការម្នាក់ (ឧ. l'œuvre gravé de Raphaël) ។ gros œuvre ជញ្ជាំងសំខាន់នៃផ្ទះមួយ ។

Loc. adv. Archit. en sous-œuvre ពីក្រោមគ្រឹះ (មិនជាប់នឹងផ្ទះ) ។ dans œuvre ពីក្នុង (ក្នុងផ្ទះ) (ឧ. escalier dans œuvre)។ hors d'œuvre ពីក្រៅ (ក្រៅផ្ទះ) (ឧ. escalier hors d'œuvre)។ à pied d'œuvre នៅរៀបការខ្លួន

œuvrer *v.t.* ធ្វើការ (ឧ. œuvrer pour le bien public)

OFENET (Office des Entreprises d'Etat មន្ទីរជ្រើសរហគ្រាស)

offensant,e *a.* ដែលប្រមាថ, ដែលមើលងាយ (ឧ. des propos offensants)

offense *n.f.* ការប្រមាថឬមើលងាយ (ឧ. venger une offense); កំហុស; បាប (ឧ. Seigneur, pardonnez-nous nos offenses) (*ttt.* affront, camouflet, injure, insulte, outrage)

offensé,e *a.&n.* ដែលត្រូវគេប្រមាថ ឬ មើលងាយ; ដែលអាក់អន់ចិត្ត, ដែលខឹង

offenser *v.t.* ប្រមាថ, មើលងាយ (ឧ. il n'a pas dit cela pour vous offenser); ធ្វើឲ្យអាក់អន់ចិត្ត ឬ ឲ្យខឹង; ធ្វើឲ្យស្រពង់; ធ្វើឲ្យមានរបួស; ប្រព្រឹត្តកន្លងច្បាប់ ។ offenser Dieu ធ្វើបាបកម្ម ។

s'offenser *v.pr.* អន់ចិត្ត, ខឹង (ឧ. s'offenser d'un rien)

offenseur *n.m.* អ្នកប្រមាថ, អ្នកមើលងាយ

offensif,ive *a.* ដែលវាយលុក; ដែលសម្រាប់វាយលុក (ឧ. arme offensive) ។ alliance offensive et défensive សម្ពន្ធភាពវាយលុកនិងការពារ ។ *n.f.* ការវាយលុក

offensivement *adv.* ដោយវាយលុក

office *n.m.* ការណ៍យកិច្ចជាពិសេស ; តំណែង; ការ (ឧ. remplir l'office de secrétaire)។ rendre un bon office យកអាសា ។ bons offices ការជួយ(ឧ recourir aux bons offices de quelqu'un); ការជួយផ្សះផ្សា (ឧ. puissance qui offre ses bons offices pour hâter la conclusion d'un traité de paix), មន្ទីរ, ការិយាល័យ (ឧ. diriger un office de publicité)។ office des entreprises d'état មន្ទីរជ្រើសរហគ្រាស (ម.ព. OFENET ផង) ។ office national des changes ជាតិមន្ទីរប្តូរប្រាក់ ។ office du crédit populaire មន្ទីរបេងការសម្រាប់ប្រជាជន ។ office des étudiants cambodgiens មន្ទីរសង្គហនិស្សិតខ្មែរ ។ office de riz មន្ទីរស្រូវ ។

d'office *loc. adv.* ដោយបញ្ញត្តិ (ដោយមិនបាច់សុំ មិនបាច់ពឹងរក-មិនបាច់ប្រឡង។ល។) (ឧ. être admis d'office à un emploi)

office *n.f.* បន្ទប់គ្រៀមម្ហូប (ឧ. une office claire)

official *n.m.* វិន័យធរ, ចៅក្រមបព្វជិត (*pl.* des officiaux)

officialité *n.f.* ចៅសភា, សាលាជម្រះអធិករណ៍បព្វជិត

officiel,elle *a.* ជាផ្លូវការ (នៃការចេញពីរដ្ឋាភិបាល, ជារបស់រដ្ឋាភិបាល)(ឧ. réponse officielle; acte officiel) ។ personnage officiel ឬ un officiel ពិស្សរជនផ្លូវការ ។ journal officiel ម.ព. journal

officiellement *adv.* តាមផ្លូវការ, ពីរដ្ឋាភិបាល (ឧ. nouvelle officiellement confirmée)

officier *n.m.* សេនានី, នាយទាហាន។ officier subalterne អនុសេនានី។ officier supérieur វរសេនានី ។ officier général ឧត្តមសេនានី ។ officier de liaison នាយទាហានសម្ពន្ធ ។ officier d'ordonnance ម.ព. ordonnance ។ officier de réserve នាយទាហានបម្រុង ។ officier de police នាយក្រុមនគរបាល ។ មន្ត្រី ។ officier de santé មន្ត្រីសុខាភិបាល។ officier de l'état civil ម.ព. état civil

officieusement *adv.* តាមក្រៅផ្លូវការ

officieux,euse *a.* ក្រៅផ្លូវការ (ឧ. cette communication n'est encore qu'officieuse)

officinal,e,aux *a.* plantes officinales រុក្ខជាតិប្រើជាឱសថ, ឈើថ្នាំ

officine *n.f.* ឱសថស្ថាន ។ *Fig.* កន្លែងលួចធ្វើការអ្វីមួយ (ឧ. officine de fausses nouvelles)

offrande *n.f.* ជំនូន, ជង្វាយ, ចង្ហាន់, ទាន, បណ្ណាការ

offrant *n. & a.m.* អ្នកជូន, អ្នកថ្វាយ, ទាយក, អ្នកប្រគេន, អ្នកវេរ; អ្នកឲ្យថ្លៃ ។ au plus offrant ចំពោះអ្នកហ៊ានថ្លៃច្រើនជាងគេ

offre *n.f.* ការជូន, ការថ្វាយ, ការប្រគេន, ការវេរ, ទេយ្យទាន; ការបូជា; ការស្នើ (ឧ. accepter une offre

avantageuse)។ offre d'emploi ការរកមនុស្សធ្វើការ ។ loi de l'offre et de la demande ម.ក. loi

offrir *v.t.* ជូន, ថ្វាយ, ប្រគេន, ធ្វើ (ឧ. offrir un sacrifice) ; ស្នើ (មានស្នើលក់ជាដើម) (ឧ. offrir des marchandises) ។ *Fig.* បញ្ចេញឲ្យឃើញ (ឧ. la campagne offre un bel aspect) ។ offrir son bras à quelqu'un ហុចដៃឲ្យ (ដើម្បីជួយទប់ ឬ ជាសេចក្ដីគួរសម) ។

s'offrir *v.pr.* ជូនបន្ថា; បង្ហាញខ្លួន; សុំខ្លួនធ្វើ; សុំយកអាសា

offset *n.m.inv.* អុហ្វសិត (របៀបបោះពុម្ពម្យ៉ាង)។ *a.&n.f.* ម៉ាស៊ីនអុហ្វសិត

offusquer *v.t.* បាំង, ធ្វើឲ្យស្រវាំង (ឧ. le soleil m'offusque les yeux) ។ *Fig.* ធ្វើឲ្យអន់ចិត្ត ឬ ឲ្យទាស់ចិត្ត (ឧ. tout l'offusque)

ogre, ogresse *n.* យក្ស, យក្ខិនី ។ *Fig.* មនុស្សកំណាច; អ្នកល្មោភស៊ី

oh! *int.* យី!

ohé! *int.* អេ្ហ! (សម្រាប់ស្រែកហៅ)

oie *n.f.* ក្ងានញី(ក្ងានឈ្មោលហៅ jars) (cri: l'oie criaille, siffle, cocarde)។ *Fam.* មនុស្សល្ងើ ។ oie blanche ក្មេងស្រីកញ្ញោក

oignon ឬ **ognon** *n.m.* ខ្ទឹមក្រហម; មើម; ផ្លែដើង ។ en rang d'oignon *loc. adv.* ជាមួយជួរ

oignonnade *n.f.* ម្ហូបប្រើខ្ទឹមច្រើន

oignonière *n.f.* ចំការខ្ទឹម

oindre *v.t.* លាបប្រេងឬខ្លាញ់, ស្រឡាបប្រេង(ឧ. autrefois, on oignait les athlètes pour la lutte)

oing *n.m.* ខ្លាញ់លាប ។ vieux oing ខ្លាញ់លាបភ្លៅរទេះ

oiseaux *n.m.* បក្សី, សត្វស្លាប ។ oiseau de basse cour បសុបក្សី ។ oiseau de bon augure អ្នកនាំដំណឹងល្អ ។ oiseau de mauvais augure អ្នកនាំដំណឹងអាក្រក់ ។ être comme l'oiseau sur la branche មិននឹងនៅជាយ៉ាងណា, មិនបាននៅយូរ ។

à vol d'oiseau *loc. adv.* តាមចក្សីបរ (តាមបន្ទាត់ត្រង់)។

Prov. petit à petit l'oiseau fait son nid ចក់ៗពេញបំពង់ ។ à petit oiseau petit

nid ទ្រព្យតិចផ្ទះតូច ; ទូកតូចក្តោងតូច ។ le bon oiseau se fait de lui-même ម.ព. faire ។ vilain oiseau que celui qui salit son nid មនុស្សដែលនិយាយអាក្រក់ពីប្រទេសខ្លួន ឬ ពីគ្រួសារខ្លួនជាមនុស្សអាក្រក់

oiseau-mouche *n.m.* ម.ព. colibri (*pl.* des oiseaux-mouches)

oiseler *v.t.* បង្រៀនហើរ ។ *v.i.* ទាក់បក្សី

oiselet *n.m.* បក្សីតូច, សត្វស្លាបតូច

oiseleur *n.m.* បក្សីលុទ្ទកៈ, ព្រានទាក់បក្សី

oiselier *n.m.* បក្សីវប្បករ, អ្នកចិញ្ចឹមបក្សី; ឈ្មួញបក្សី

oisellerie *n.f.* ជំនួញបក្សី; កន្លែងលក់បក្សី

oiseusement *adv.* ដោយឥតប្រយោជន៍

oiseux,euse *a.* ឥតប្រយោជន៍ (ឧ. paroles oiseuses)

oisif,ive *a.&n.* អកម្មិក, ដែលមិនធ្វើការ (ឧ. homme oisif)។ *a.* ទំនេរ (ឧ. vie oisive)។ argent oisif ប្រាក់ទំនេរ (ដែលឥតប្រើប្រាស់)

oisillon *n.m.* កូនបក្សី, កូនចាប

oisivement *adv.* ដោយអកម្មិក, ដោយឥតធ្វើការ

oisiveté *n.f.* អកម្មិកភាព, ភាពឥតធ្វើការ។ *Prov.* l'oisiveté est la mère de tous les vices ភាពទំនេរជាមេបាបធម៌គ្រប់យ៉ាង

oison,onne *a.* កូនក្ងាន ។ *Fig. & Fam.* មនុស្សប្រាជ្ញាអាប់

o-k! [o-ké] *int.* ហ្នឹងហើយ!, ល្អហើយ!

oléagineux,euse *a.* ជាជាតិប្រេង (ឧ. liquide oléagineux); ដែលឱ្យប្រេង (ឧ. plante oléagineuse)

oléfiant,e *a.* ដែលឲ្យប្រេង

oléiculture *n.f.* ការដាំអូលីវ

oléifère *a.* ដែលឱ្យប្រេង, ដែលគ្រាប់មានប្រេង (ឧ. plantes oléifères)

oléiforme *a.* ដូចប្រេង

oléine *n.f.* *Chim.* អូឡេអ៊ីន (ជាតិប្រេង

olfactif,ive *a.* នៃឃានវិញ្ញាណ (ឧ. nerf, sens olfactif)

olfaction *n.f.* ឃានសម្ផស្ស.ការដឹងក្លិន

oligarchie *n.f.* អប្បជនាធិបតេយ្យ (របៀបគ្រប់គ្រង ដែលអំណាចធ្លាក់ក្នុងកណ្តាប់នៃជនភាគតិច) ។ *Par ext.* oligarchie financière អប្ប-

ជនាធិបតេយ្យហោញ៉ូក

oligarchique *a.* អប្បជនាធិបតេយ្យ; ដែលគ្រប់គ្រងដោយជនភាគតិច (ឧ. Sparte était une cité oligarchique)

oligarque *n.m.* អ្នកអប្បជនាធិបតេយ្យ; សមាជិកជនាធិបតេយ្យ

oligurie *n.f. Pathol.* ភេគនោមតិច

olivacé,e *a.* ស៊ីលៀប(លឿងបៃតងកាវ)

olivaie ឬ **oliveraie** *n.f.* ចំការអូលីវ (ធ. olivette)

olivaison *n.f.* ការបេះអូលីវ; រដូវបេះអូលីវ

olivâtre *a.* ស្មើរបៃតងកាវ (ឧ. teint olivâtre)

olive *n.f.* អូលីវ(ផ្លែឈើម្យ៉ាងមានប្រេង)។ *Par anal.* ក្តោងខ្ចូលអូលីវ (មូលទ្រវែង)។ *Arch.* ក្បាច់តងក្រពើ។ *a. inv.* ស៊ីលៀប (ពណ៌)(ឧ.étoffe olive)

oliveraie *n.f.* ម.ព. olivaie

olivette *n.f.* ធ. នៃ olivaie; ផ្លែទំពាំងបាយជូរកងទ្រវែង (ដូចផ្លែអូលីវ)

olivier *n.m.* ដើមអូលីវ (ឧ. l'olivier croît dans les pays méditerranéens)

olographe *a.* សរសេរដោយដៃឯង (ចំពោះមតកសាសន៍)

olympe *n.m. Mythol.* អូឡាំ, ឋាន អាទិទេព (ឧ. les dieux de l'Olympe); អាទិទេពទាំងឡាយ (ឧ. l'Olympe assemblé, réuni)។ *Fig.* មជ្ឈដ្ឋាននយោបាយជាន់ខ្ពស់(ឧ. Olympe politique) ។ *Poét.* មេឃ (ឧ. le jour s'approche et l'Olympe blanchit)

olympiade *n.f.* រយៈពេលបួនឆ្នាំ

olympien,enne *a.* នៃអ្នកនៅអូឡាំ ។ *Fig.* ប្រកបដោយសិរីហោស (ឧ. regard olympien)

olympique *a.* jeux Olympiques ល្បែងអូឡាំពិក (ការប្រកួតកីឡាអន្តរជាតិ) ។ សម្រាប់ល្បែងអូឡាំពិក (ឧ. stade olympique); ត្រឹមតាមច្បាប់ល្បែងអូឡាំពិក (ឧ. piscine olympique)

ombelle *n.f.* ឧក្ខត្តបុស្ប [អ៊ុប-ឆ័ត-តៈ-បុស](ឧ. on distingue des ombelles simples et des ombelles composées)

ombellé,e *a.* ឧក្ខត្តបុស្ប [អ៊ុប-ឆ័ត-តៈ-បុស] (ឧ. fleur ombellée)

ombelliféracées *n f. pl.* ឧម្ពេត្តជាតិ [អុំប-ឆ័ត-តៈ-ជាតិ]

ombellifère *a. Bot.* ឧម្ពេត្ត [អុំប-ឆ័ត] ។ *n.f.* ឧម្ពេត្តកុល [អុំប-ឆ័ត-តៈ-កុល]

ombelliforme *a.* ឧម្ពេត្តសណ្ឋាន [អុំប-ឆ័ត-តៈ—]

ombilic *n.m.* ផ្ចិត, ផ្ចិត ។ *Fig.* ផ្ចិត (ប៉ែកដែលនៅចំកណ្ដាល)។ ombilic de la terre ផ្ចិតផែនដី

ombilical,e,aux *a.* នៃផ្ចិត, នៃផ្ចិត ។ cordon ombilical ទងផ្ចិត

ombiliqué,e *a.* ដែលមានផ្ចិត

ombrage *n.m.* មែកនិងស្លឹកឈើដែលឡម្លប់; ឆាយា, ម្លប់ ។ *Fig.* porter ឬ faire ombrage ធ្វើឲ្យជារអ្ន ។ prendre ombrage ព្រួយ, ជារអ្ន

ombragé,e *a.* ដែលមានម្លប់ (ឧ. un lieu ombragé)

ombrageant,e *a.* ដែលឡម្លប់

ombrager *v.t.* គ្របដោយម្លប់; បាំង, ឡម្លប់ (ឧ. les arbres qui ombragent la cour)

ombrageux,euse *a.* ភ្ញើល, ងាយបន្ទាច; ដែលខ្លាចស្រមោលឯង (ឧ. cheval ombrageux) ។ *Fig.* ដែលចេះតែសង្ស័យ, ដែលចេះតែជារអ្ន (ឧ. esprit ombrageux)

ombrant,e *a. Peint.* សម្រាប់ស្រាប់ស្រមោល (គូរស្រមោល) (ឧ. des émaux ombrants)

ombre *n.f.* ឆាយា, ស្រមោល (ឧ. l'ombre d'un arbre)។ *Fig.* ស្រមោល, អ្វីៗដែលមានតែបន្តិចបន្តួច (ឧ. il n'y a pas l'ombre d'un doute); ព្រលឹង (ឧ. l'ombre d'Achille)។

l'empire des ombres ឋានខ្មោច ។ courir après une ombre សង្ឃឹមឥតប្រយោជន៍(ដូចគេដេញចាប់ស្រមោល)។ les ombres de la mort ស្រមោលនៃសេចក្ដីស្លាប់ (សេចក្ដីស្លាប់ដែលជិតមកដល់)។ les ombres de la nuit ភាពងងឹត ។ ombres chinoises ណាំង, រោងស្បែក ។ passer comme une ombre មាន ឬ ឡឃើញតែមួយភ្លែត (ដូចស្រមោល) ។ vivre dans l'ombre រស់នៅតែម្នាក់ឯងដោយគ្មានគេស្គាល់ ។

Peint. ស្រមោល (ប៉ែកផាត់ពណ៌ខ្មៅដូចស្រមោល) ។

Fig. & fam. il y a une ombre au tableau មានអ្វីមួយគួរឲ្យតារអ្ន ។

à l'ombre de *loc. adv.* នៅក្រោមម្លប់(ឧ. à l'ombre d'un toit); *au fig.* ក្រោមការឧបត្ថម្ភ (ឧ. à l'ombre de ton bras) ។ sous l'ombre ឬ sous ombre *loc. adv.* ដោយអាងថា, ដោយអាងលេស

ombré,e *a. Peint.* ដែលមានផាត់ស្រមោល (ឧ. dessin ombré)

ombrelle *n.f.* ការងយូ; ឆ័ត្រតូច

ombrer *v.t.* ផាត់ស្រមោល (គំនូរ)

ombreux,euse *a. Poét.* ដែលឲ្យម្លប់ (ឧ. forêt ombreuse)

oméga *n.m.* អូមេហ្គា (អក្សរចុងក្រោយបំផុតនៃអក្ខរក្រមក្រិក) ។ *Fig.* l'alpha et l'oméga ដើមដំបូងនិងចុងក្រោយបំផុត

omelette *n.f.* ស៊ុតចៀន

omettre *v.t.* ខាន; ភ្លេច (ឧ.omettre une formalité) (*w.* oublier, négliger)

omission *n.f.* ការខាន; ការភ្លេច; របស់ភ្លេច (ឧ. omission involontaire)

omnibus *n.m.* រទេះសេះធ្យូង ។ *a.* សម្រាប់ប្រើគ្រប់យ៉ាងជាសាធារណៈ ។ train omnibus ម.ក. train

omnicolore *a.* គ្រប់ពណ៌

omnipotence *n.f.* សព្វានុភាព (ឧ. l'omnipotence divine) ។ *Par ext.* អំណាចផ្ដាច់ការ; អំណាចខ្ពស់បំផុត

omnipotent,e *a.* ដែលមានសព្វានុភាព; ដែលមានអានុភាពអស្ចារ្យ; ដែលមានអំណាចផ្ដាច់ការ (ឧ. monarque omnipotent)

omniprésence *n.f.* សព្វន្និភាព, ភាពមាននៅគ្រប់កន្លែង

omniprésent,e *a.* ដែលមានសព្វន្និភាព, ដែលមាននៅគ្រប់កន្លែង

omniscience *n.f.* សព្វញ្ញុភាព, ការចេះឬដឹងគ្រប់

omniscient,e *a.* សព្វញ្ញូ, ដែលចេះឬដឹងគ្រប់

omnium *n.m. Sports* ការប្រណាំងកង់ដែលប្រយានមានវិញ្ញាសាច្រើន ។ *Turf.* ការប្រណាំងសេះចម្រុះ (មានសេះគ្រប់ប្រភេទ) ។ *Fin.* សព្វការីសមាគម

omnivore *a.* សព្វាសី (ដែលបរិភោគអាហារគ្រប់យ៉ាង ត្រានសាច់, រុក្ខជាតិ ។ល។) (ឧ.l'homme est omnivore)

omophagie *n.f.* ទម្លាប់បរិភោគសាច់ឆៅ

omoplate *n.f* ឆ្អឹងស្មាបប្រចៀ។ *Par ext.* ស្មា

O.M.S.(Organisation Mondiale de la Santé អង្គការពិភពលោកខាងសុខភាព)

on *pr.ind.* គេ (ឧ. on a souvent besoin d'un plus petit que soi)

once *n.f.* កូនជញ្ជីងយាក់ងទម្ងន់ ៣០,៥៩៤ ក្រ.; កូនជញ្ជីងអង់គ្លេសទម្ងន់២៨,៣៥ក្រ.។ *Fig. & Fam.* ចំនួនតិចណាស់

once *n.f.* ឆ្មាព្រៃមានធំ

oncle *n.m.* ពូ, មា, ឪពុកធំ (ឧ oncle parternel, oncle maternel)។ រ.ស. ព្រះមាតុលា (មា ឬ ឪពុកធំខាងមាតា),ព្រះបិតុលា(មាឬឪពុកធំខាងបិតា)

onction *n.f.* ការលាបប្រេង ឬ ខ្លាញ់; ការស្រឡាប; ពិធីលាបប្រេងប្រសិទ្ធី (ឧ. les rois de France recevaient l'onction du sacre)។ *Fig.* ភាពផ្អែមល្ហែមអស្ចារ្យ (ឧ. parler avec onction)

onctueusement *adv.* យ៉ាងរអិល

onctueux,euse *a.* រអិល (ឧ. liquide onctueux); ផ្អែមឆ្ងាញ់ (ឧ.un chocolat onctueux)។ *Fig.* ផ្អែមល្ហែមអស្ចារ្យ (ឧ. sermon onctueux)

onctuosité *n.f.* ភាពរអិល; ភាពផ្អែមឆ្ងាញ់

onde *n.f.* មណ្ឌលរលកទឹក(រលកទឹកជារង្វង់មូលៗដែលមានឡើងនៅពេលគេប៉ះទឹក); រលក(ពន្លឺ) (ឧ. onde d'une moire)។*Poét.* គង្គា, ទឹក (ឧ. voguer sur l'onde) ។ *Phys.* រលក ។ onde courte រលកខ្លី(ធាតុអាកាស)។ onde moyenne រលកមធ្យម (ធាតុអាកាស) ។ grande onde រលកធំ (ធាតុអាកាស)

ondé,e *a.* រលក (ឧ.moire ondée); កង្ហាញ់ (ឧ. cheveux ondés)

ondée *n.f.* ភ្លៀងធាប់ធាត់ (ឧ. les ondées d'avril)

ondin,e *a.* មេខលា [មេ-ខៈ-ឡា](ទេវតាក្រោសមុទ្រ)

on-dit *n.m.inv.* ពាក្យបរម្បរា [ប៉ះ-កុំ-

ប៉ះ-ក៏], ពាក្យចចាមអារ៉ាម (ឧ. n'écoutez pas les on-dit)

ondoiement *n.m.* កន្ត្រាញ់រលក (ឧ. l'ondoiement des vagues)

ondoyant,e *a.* ដែលបក់កន្ត្រាញ់ (ខ្លះ ពាប) (ឧ.cheveux ondoyants)។ *Fig.* ដែលប្រែប្រួល (ឧ l'homme, a dit Montaigne, est ondoyant et divers)

ondoyer *v.i.* បក់កន្ត្រាញ់ (ឧ. moissons qui ondoient)

ondulant,e *a.* ដែលបក់កន្ត្រាញ់

ondulation *n.f.* រលក; កន្ត្រាញ់រលក (ឧ. les ondulations des vagues) ។ *Par ext.* សភាព កន្ត្រាញ់ (ឧ. les ondulations d'un champ de paddy); ការ អ៊ុតសក់; ផ្នត់កន្ត្រាញ់ (នៃសក់)

ondulatoire *a.* ដែលមានភាពកន្ត្រាញ់ (ឧ. mouvement ondulatoire); ដែលមានភាពជារលក (ឧ. nature ondulatoire de la lumière)

ondulé,e *a.* កន្ត្រាញ់ (ឧ. chevelure ondulée); រយាករយោក

onduler *v.t.* បក់កន្ត្រាញ់ (ឧ. les moissons ondulent) ។ *v.t.* អ៊ុតឡក់កន្ត្រាញ់ (ឧ. onduler les cheveux)

onduleux,euse *a.* ដែលរលកកន្ត្រាញ់, ដែល បត់បែន (ឧ. replis onduleux)

O.N.E. (Œuvre National d'Entraide ក្រុមសង្គហជាតិ)

onéraire *a.* ដែលកាន់មុខងារ; ដែល មាននិលែណងពិត (ផ្ទុយពី honoraire)

onéreusement *adv.* ដោយថ្លៃ, ដោយមានថ្លៃ

onéreux,euse *a.* ថ្លៃ, ដែលមានថ្លៃ (ឧ. séjour onéreux)។ à titre onéreux ដោយថ្លៃ, ដោយមានថ្លៃ (ឧ.acquérir une terre à titre onéreux)

ongle *n.f.* ក្រចក ។ *Fig.* rogner les ongles à កាប់ចុង; បន្ថយ កម្រៃអំណាច។ donner sur les ongles ពិក់វល្លកម្ម, ស្តីបន្ទោស។ avoir l'esprit jusqu'au bout des ongles ឈ្លាសវៃ ណាស់។ savoir sur l'ongle ចេះស្ទាត់; ដឹងឬយល់ច្បាស់

onglé,e *a.* ដែលមានក្រចក

onglée *n.f.* និលេវាស្ពឹកចុងក្រមដៃ

(ដោយក្រចាក់ខ្លាំង)

onglet *n.m.* អណ្ដាតក្រដាស (សម្រាប់បិទសន្លឹកក្រដាស,រូបឬផែនទីក្នុងសៀវភៅ; ចង្អូរផ្លែកាំបិត (សម្រាប់ចុចបើកផ្លែកាំបិត) ។ *Techn.* boîte à onglet ពែងប្រមុំ

onglette *n.f.* ទិតតូច (ពន្លាកឆ្លាក់តូច)

onglier *n.m.* ប្រដាប់ថែក្រចក ។ *n.m. pl.* កន្ត្រៃកាត់ក្រចក

onguent *n.m.* ឧសថក្រអូប; ទឹកអប់ (ឧ.les momies étaient enveloppées de bandelettes chargés d'onguents); ឧសថប្រេង(សម្រាប់លាប) ។

Prov. dans les petites boîtes (ឬ petits pots) les bons onguents ម.ក. boîte

onguicule *n.m.* ក្រចកតូច

onguiculé,e *a.* ដែលមានក្រចកគ្រប់ម្រាម (ចំពោះសត្វ)

ongulé,e *a.* ខុរ ។ *n.m. pl.* ខុរង្គសត្វ (មានសេះ, គោសជាដើម)

onguligrade *a.* ខុរង្គ,ដែលដើរដោយក្រចក (ឧ. les éléphants sont onguligrades)

onirique *a.* នៃសុបិន (ឧ. délire onirique)

onirisme *n.m. Psych.* ការនិមិត្តឃើញភ្លាកស្រស់

onirologie *n.f.* សុបិនវិទ្យា [សុ-បិនៈ-]

oniromancie *n.f.* សុបិនព្យាករណ៍ [សុ-បិនៈ-], ការកាត់សប្ដិ

oniromancien,enne *a.* នៃសុបិនព្យាករណ៍ ។ *n.* សុបិនព្យាការី [សុ-បិនៈ-]

onomastique *a.* នៃអសាធារណនាម ។ *n.f.* អសាធារណនាមសាស្ត្រ

onomatologie *n.f.* នាមសាស្ត្រ

onomatopée *n.f.* ពាក្យត្រាប់ (ពាក្យកើតដោយត្រាប់); ការបង្កើតពាក្យត្រាប់

ontologie *n.f. Phil.* ប្រាណវិទ្យា (ឧ. l'ontologie se confond avec la métaphysique)

ontologique *a.* នៃប្រាណវិទ្យា

ontologiquement *adv.* តាមប្រាណវិទ្យា

O.N.U. អ.ស.ប. (Organisation des Nations Unis)

onychophagie *n.f.* ទម្លាប់កកេរក្រចក

onyx *n.m.* ត្បូងនិលដៀម

onze *a.num.* ដប់មួយ; ទី ១១ ។ *n.m.* លេខ ១១; ថ្ងៃទី ១១

onzième *a.num.ord.* ឯកាទសមៈ, ទី ១១ ។ *n.* អ្នកលេខ ១១ ។ *n.m.* ភាគ ១១

onzièmement *adv.* ទី១១; ជាគំរប់១១

oosphère *n.f.Bot.* អណ្ឌកោល(ដុំមូលនៅក្នុងបុប្ផាណ្ឌ)

opacifier *v.t.* ធ្វើឲ្យស្រអាប់ឬឲ្យឃ្នើក ។ s'opacifier *v.pr.* ឡើងស្រអាប់ឬឃ្នើក

opacité *n.f.* ភាពស្រអាប់, ភាពឃ្នើក

opale *n.f.* តេតោបល [រៈ-តៈ-ណោ-បុល] (ពេជ្រម្យ៉ាង)

opaque *a.* ស្រអាប់, ឃ្នើក (ឧ. corps opaque)។ *Fig.* ចូលមិនចុះ(ព.ផ. transparent, diaphane)

opéra *n.m.Mus.* អូប៉េរ៉ា; រោងកំអូប៉េរ៉ា

opérable *a.* អាចវះកាត់បាន; អាចប្រតិបត្តិបាន

opérateur,trice *n.* អ្នកវះកាត់; ការី, ការិនី (ឧ. opérateur de cinéma)

opération *n.f.* ប្រតិបត្តិការ (ឧ. opération financière)។ opération des changes ប្រតិបត្តិការប្តូរប្រាក់ ។ *Chir.* ការវះកាត់ ។ *Math.* លេខ; វិធីលេខ; ការធ្វើលេខ ។ les quatre opérations ចតុវិធលេខ។ *Mil.* ប្រតិបត្តិការ (ឧ. les opérations de débarquement)។ théâtre d'opération ម. ព. théâtre។ *Fam. & iron.* par l'opération du Saint-Esprit ដោយមធ្យោបាយសម្ងាត់

opérationnel,elle *a.* នៃប្រតិបត្តិការ (ខាងយុទ្ធសាស្ត្រយោធា)

opératoire *a.* នៃការវះកាត់ (ឧ. médecine opératoire)។ bloc opératoire ម.ព. bloc

operculaire *a.* នៃគ្របស្រកី (ឧ. valve operculaire)

opercule *n.f.* សន្ទះគម្របវន្ទ; គ្របស្រកី

operculé,e *a.* ដែលមានសន្ទះគម្រប(ឧ. coquille operculée)

opéré,e *n.&a.* ដែលបានទទួលការវះកាត់

opérer *v.t.* ប្រតិបត្តិ; ធ្វើ, បំពេញ (ឧ. opérer des miracles); ធ្វើលេខ (ឧ. opérer une addition)។ opérer un mélange លាយ។ *Chir.* វះកាត់ (ឧ. opérer un malade); ឲ្យផល (ឧ le re-

mède commence à opérer)

opérette *n.f.* អូប៉េរ៉ែត

ophidien,enne *a.* នៃសប្បៈ [ស័ប-ប៉ៈ], នៃពស់, ដូចពស់ ។ *n.m. pl.* សប្បសត្វ (ពួកសត្វពស់)

ophiolatrie *n.f.* សប្បសក្ការៈ, ការគោរពពស់ (ឧ. l'ophiolatrie existe encore dans l'Inde)

ophiologie ឬ **ophiographie** *n.f.* សប្បសាស្ត្រ [ស័ប-ប៉ៈ–], ការពិពណ៌នាអំពីពស់

ophtalmie *n.f.* ចក្ខុរោគ, ជម្ងឺភ្នែក

ophtalmique *a.* នៃចក្ខុ, នៃភ្នែក

ophtalmologie *n.f.* ចក្ខុរោគសាស្ត្រ

ophtalmologique *a.* នៃចក្ខុរោគសាស្ត្រ (ឧ. clinique ophtalmologique)

ophtalmologiste ឬ **ophtalmologue** *n.m.* ចក្ខុពេទ្យ, ពេទ្យភ្នែក (ឃ. oculiste)

ophtalmomètre *n.m.* ចក្ខុមាត្រ, ប្រដាប់វាស់សណ្ឋានកោងនៃកញ្ចក់ភ្នែក

ophtalmoscope *n.m.* ចក្ខុទស្សន៍, ប្រដាប់ឆ្លុះមើលខាងក្នុងភ្នែក

ophtalmoscopie *n.f.* ចក្ខុទស្សនា, ការឆ្លុះមើលខាងក្នុងភ្នែក

opiacé,e *a.* ដែលមានជាតិអាភៀន (ឧ. médicament opiacé)

opilions *n.m. pl.* ទាក់មេ្យ (ជាពពួកសត្វពួកពីងពាង) (ម.ព. faucheux ផង)

opimes *a. f. pl.* dépouilles opimes អាវុធយកបានពីឧត្តមសេនីយបច្ចាមិត្ត ស្លាប់ដោយដៃឧត្តមសេនីយរ៉ូម៉ាំង; *au fig.* គុណប្រយោជន៍ច្រើន

opiner *v.i.* សំដែងមតិ ។ *Fam.* opiner du bonnet ងក់ក្បាលយល់ស្របជានិច្ច

opiniâtre *a.* រឹង (ឧ. enfant opiniâtre) ។ travail opiniâtre ការងារខ្ជាប់ខ្ជួន ។ haine opiniâtre សំអប់មិនស្រាក ។ combat opiniâtre ការប្រយុទ្ធដោយមានះ ឬដោយស៊ូ ។ fièvre opiniâtre គ្រុនរឹង (ដាក់ថ្នាំមិនដល់)

opiniâtrement *adv.* យ៉ាងរឹង

opiniâtrer *v.t.* គាំទ្រដោយមានះ ។ s'opiniâtrer *v.pr.* មានះ, ចចេស (ឧ. s'opiniâtrer dans son erreur)

opiniâtreté *n.f.* មានភាព [មា-នៈ–]

ការរឹងត្អឹង (ឧ. soutenir une erreur avec opiniâtreté); ការខ្ជាប់ខ្លួន (ឧ. travailler avec opiniâtreté) (ម. acharnement, entêtement, obstination, ténacité)

opinion *n.f.* មតិ, យោបល់ (ឧ. donner son opinion) ។ avoir une bonne opinion de យល់ឃើញថាល្អ ។ avoir une mauvaise opinion de យល់ឃើញថាអាក្រក់ ។ l'opinion publique ឬ *absol.* l'opinion មតិសាធារណៈ ។ partage d'opinions មតិខ្វែងគ្នា ។ sondage d'opinion ការស្ទង់មតិ

opiomane *n.&a.* អ្នកញៀនអាភៀន

opium *n.m.* អាភៀន ។ *Fig.* ហេតុនាំឲ្យខូចចរិយា

opportun,e *a.* កាលានុវត្ត [កា-ឡា-នុ-វ័ត], គួរដល់កាល (ឧ. une circonstance opportune)។ temps opportun កាលគួរ

opportunément *adv.* ដោយកាលានុវត្ត, ដោយគួរដល់កាល

opportunisme *n.m.* កាលានុវត្តនិយម [កា-ឡា-នុ-វ័ត-ត:-]

opportuniste *n.* អ្នកកាលានុវត្តនិយម ។ *a.* កាលានុវត្តនិយម (ឧ. politique opportuniste)

opportunité *n.f.* កាលានុវត្តភាព [កា-ឡា-នុ-វ័ត ត:—], ការគួរដល់កាល (ត្រូវតាមកាលទេសៈ) (ឧ. l'opportunité d'une démarche)

opposabilité *n.f.* *Dr.* ការអាចជំទាស់បាន

opposable *a.* អាចផ្ទាក់ឈមមុខបាន (ឧ. l'homme a le pouce opposable aux autres doigts); អាចទប់បាន (ឧ. digue opposable à une inondation); អាចតទល់បាន (ឧ. forces opposables à l'ennemi)។

Par ext. អាចជំទាស់ ឬ ប្រឆាំងបាន (ឧ. raison opposable à d'autres raisons)

opposant,e *a.* ដែលជំទាស់ ។ *n.* អ្នកជំទាស់, អ្នកប្រឆាំង

opposé,e *a.* ឈម; ទល់មុខគ្នា (ឧ. rives opposés); ផ្ទុយគ្នា, ប្រឆាំងគ្នា (ឧ. intérêts opposés) ។

Math. ឈម ។ nombres

opposés មុំទួលឈម ។ angles opposés par le sommet ម.ព. angle ។

n.m. របស់ផ្ទុយ (ឧ. le bien est l'opposé du mal) ។ à l'opposé *loc. adv.* ដោយផ្ទុយទៅវិញ ។ à l'opposé de *loc. pré.* ជាផ្ទុយនឹង (សំ. adverse, antagoniste, contradictoire, inverse)

opposer *v.t.* ដាក់ទប់ (ឧ. opposer une digue aux flots); *au fig.* ដាក់ប្រឆាំង (ឧ. opposer la force à la force); ដាក់ប្រឈម ឬ ប្រទល់មុខ (ឧ. opposer deux motifs d'ornementation) ។ *Fig.* ផ្ទឹម (ឧ. opposer les Anciens aux Modernes); ដាក់តទប់ (ឧ. opposer une grande résistance តស៊ូយ៉ាងខ្លាំង); ជំទាស់ (ឧ. opposer de bonnes raisons) ។

s'opposer *v.pr.* ជំទាស់, ប្រឆាំង, រាំង (ឧ. s'opposer à un mariage)

opposite *n.m.* របស់ផ្ទុយ ។ à l'opposite *loc.pré.&adv.* ខាងមុខ (ឧ. le miroir se plaçait toujours à l'opposite); *au fig.* ដោយផ្ទុយទៅវិញ

opposition *n.f.* ការទប់, ការតទល់ (ឧ. mettre opposition à quelque chose); ភាពផ្ទុយគ្នា (ឧ. opposition de couleurs) ។ *Dr.* ការជំទាស់ (ឧ. opposition à mariage, à paiement); ការប្តឹងជំទាស់; ការប្រឆាំង; បក្សពួកប្រឆាំង

oppresser *v.t.* សង្កត់; ធ្វើឲ្យថប់ដង្ហើម (ឧ. l'asthme oppresse) ។ *Fig.* ធ្វើឲ្យតឹងទ្រូង (ឧ. ce souvenir m'oppresse)

oppresseur *a.&n.m.* អ្នកសង្កត់សង្កិន

oppressif,ive *a.* សម្រាប់សង្កត់សង្កិន (ឧ. lois oppressives)

oppression *n.f.* ការសង្កត់; ភាពថប់ដង្ហើម ។ oppression de poitrine ការតឹងទ្រូង ។ *Fig.* ការសង្កត់សង្កិន (ដោយរំលោភអំណាច); ភាពត្រូវសង្កត់សង្កិន (ឧ. oppression d'un peuple)

opprimant,e *a.* ដែលសង្កត់សង្កិន

opprimé,e *a.* ដែលត្រូវគេសង្កត់សង្កិន

opprimer *v.t.* សង្កត់សង្កិន (ឧ. les puissants oppriment les faibles) (ព.ដ. asservir, assujettir, soumettre, subjuguer, tyranniser)

opprobre *n.m.* ទុយ៌ស (ឧ. vivre dans l'opprobre) ។ être l'opprobre de sa famille ជាទុយ៌សនៃគ្រួសារខ្លួន, ធ្វើឲ្យគ្រួសារខ្លួនខ្មាសគេ

optatif,ive *a.* ដែលសំដែងសេចក្ដីប្រាថ្នា (ឧ. formule optative)

opter *v.i.* រើសយក (ឧ. l'enfant né au Cambodge de parents étrangers peut, à sa majorité, opter pour la nationalité cambodgienne)

opticien *n.m.* អ្នកធ្វើ ឬ លក់ទស្សនភ័ណ្ឌ (គ្រឿងកែវឆ្លុះ-គ្រឿងវែនតា)

optime *adv. Fam.* ល្អណាស់

optimisme *n.m.* សុទិដ្ឋិនិយម (ព.ផ. pessimisme)

optimiste *a.* សុទិដ្ឋិនិយម ។ *n.* អ្នកសុទិដ្ឋិនិយម (ដែលយល់ឃើញជាសុទ្ធតែល្អ ឬ សុទ្ធតែត្រូវ)

optimum *n.m.* ភាពប្រសើរបំផុត (ឧ. l'optimum de dimensions d'une entreprise industrielle) (*pl.* des optimums ឬ des optima)

option *n.f.* ការរើសយក ។ *Dr.* សិទ្ធិជ្រើសរើស (ឧ. avoir une option sur un terrain) ។ levée d'option ការទុកសិទ្ធិជ្រើសរើស (ក្នុងកិច្ចសន្យា)

optique *a.* ទស្សនៈ, នៃការមើល (ឧ. apparence optique); នៃភ្នែក ។ angle optique ឬ angle de vision មុមចក្ខុវិស័យ ។ nerf optique ចក្ខុបសាទ, ប្រសាទភ្នែក ។ *n.f.* អាការិទ្យា; ទស្សនភណ្ឌ

opulemment *adv.* យ៉ាងស្តុកស្តម្ភ

opulence *n.f.* ភាពមានស្តុកស្តម្ភ (មានទ្រព្យសម្បត្តិច្រើន)(ឧ. vivre dans l'opulence)(ព.ផ. dénuement, gêne, indigence, misère, pauvreté)

opulent,e *a.* ដែលមានស្តុកស្តម្ភ

opuscule *n.m.* សៀវភៅតូច

or *n.m.* មាស, រូបិយវត្ថុមាស (ឧ. être payé en or); សុវណ្ណមយ (គ្រឿង

មាស)។ valeur or តម្លៃជាមាស។ *Fig.* មាសប្រាក់, ទ្រព្យសម្បត្តិ (ឧ. la soif de l'or)។ adorer le veau d'or គិតតែពីមានបាន ។ affaire ឬ marché d'or រឿង ឬ អាបណសញ្ញាឲ្យគុណប្រយោជន៍ច្រើន។ âge d'or ម.ព. âge ។ c'est de l'or en barres តម្លៃនេះប្រាកដណាស់។ cœur d'or ចិត្តវិសេស។ être cousu d'or ឬ rouler sur l'or មានថ្លឹងមាស; មានស្តុកស្តម្ភ ។ payer au poid de l'or សង ឬ បង់យ៉ាងថ្លៃ ។ livre d'or ម.ព. livre ។ parler d'or និយាយពីការប្រសើរបំផុត

or *conj.* រីឯ, តែថា

oracle *n.m.* ទំនាយដោយបួល (ចម្លើយរបស់អាទិទេពចំពោះសំនួរមនុស្សលោក) (ឧ. les oracles étaient souvent rédigés en termes ambigus); អាទិទេព (ឧ. consulter l'oracle);បំណងអាទិទេព; សេចក្តីសម្រេចនៃអ្នកធំ(អ្នកមានអំណាច, អ្នកប្រាជ្ញ) (ឧ. les oracles de la Faculté); អ្នកធំ (ឧ. il était l'oracle de son parti)។parler comme un oracle និយាយត្រូវណាស់ ។ ton d'oracle សម្លេងម៉ឺងម៉ាត់

orage *n.m. Météor.* អសនីបាត [អៈ-សៈ-ណី-], ព្យុះភ្លៀង (ឧ. les orages sont fréquents en été)។ orage magnétique ព្យុះចុម្ពិត (ដំណើរមិនស្រួលនៃស្នាមចុម្ពិតដោយសកម្មភាពនៃព្រះអាទិត្យ)។*Fig.* ព្យុះ (ភ័យ, ទោសទុក្ខ, គ្រោះកាច) (ឧ. orages de la vie); ចលាចល; ការរំជើបរំជួល (ឧ. les orages du cœur)

orageusement *adv.* ដោយមានខ្យល់ព្យុះ; ដោយរំជើបរំជួល

orageux,euse *a.* ដែលមានព្យុះញឹកញយ (ឧ. les pays de montagne sont très orageux);ដែលមានខ្យល់ព្យុះ (ឧ. temps orageux)។ *Fig.* រំជើបរំជួល (ឧ. séance orageuse)

oraison *n.f.* ការសូត្រធម៌។ oraison funèbre វិប្បយោគកថា (សុន្ទរកថាថ្លែងជាកិត្តិយសចំពោះសពអ្នកមានកិត្តិនាម)

oral,e,aux *a.* នៃមាត់ (ឧ. cavité

orale); ដែលផ្សាយពីមាត់មួយទៅមាត់មួយ (ឧ.tradition orale); ដែលធ្វើដោយវាចា-ដោយមាត់ទទេ (ឧ. déposition orale) ។ calcul oral ម.ព. calcul ។ épreuve orale ម.ព. épreuve ។

n.m. ការសួរមាត់ទទេ (ក្នុងការប្រឡង), ការនិយាយប្រយោគ (ឧ. échouer à l'oral)

oralement *adv.* ដោយវាចា, ដោយមាត់ទទេ

orange *n.f.* ផ្លែក្រូចពោធិ៍សាត់ ។ *n.m.* ពណ៌លឿងទុំ, ពណ៌ស្វាទុំ (ឧ. un orange clair) ។ *a.inv.* លឿងទុំ, ស្វាទុំ(ពណ៌) (ឧ.étoffes orange)

orangé,e *a.* ហង្សបាទ [ហង់-ស្បាត], លឿងការ ។ *n.m.* ពណ៌ហង្សបាទ

orangeade *n.f.* ទឹកក្រូច (ដាក់ស្ករ)

orangeat *n.m.* នំណាប់សំបកក្រូច

oranger *n.m.* ដើមក្រូចពោធិ៍សាត់

oranger *v.t.* ជ្រលក់ឬលាបពណ៌លឿងទុំ

orangerie *n.f.* ចំការក្រូចពោធិ៍សាត់

orangerie *n.f.* ទីដាំដើមក្រូចពោធិ៍សាត់ក្នុងសិសិររដូវ

orangette *n.f.* ផ្លែក្រូចពោធិ៍សាត់ (សម្រាប់ធ្វើនំណាប់)

orant,e *n.&a.* រូបចម្លាក់មនុស្សលុតជង្គង់ (សូត្រធម៌) (ព.ផ.gisant)

orang-outan ឬ **orang-outang** *n.m.* ស្វាធំម្យ៉ាង

orateur, trice *n.* វាគ្មិន-គ្មិនី [វា-] អ្នកស្ទាត់សុន្ទរកថា; អ្នកមានវោហារ (ឧ. c'est un orateur)

oratoire *a.* នៃវាគ្មិន [វា-] (ឧ. un traité sur l'art oratoire)

orbicole *a.* ដែលមានពេញដី(គ្រប់កន្លែង) (ឧ. plante orbicole)

orbiculaire *a.* ជារង្វង់មូល (ឧ. mouvement orbiculaire)

orbitaire *a.* នៃរង្វង់ភ្នែក (ឧ. nerfs orbitaires)

orbital,e,aux *a.* នៃគ្រហបថ [គ្រះ-ហ-បត់] (គោចរ) (ឧ. mouvement orbital d'une planète)

orbite *n.f.* គន្លងជារង្វង់មូល (ឧ. l'orbite des électrons autour du noyau dans un atome) ។ *Astr.* គ្រហបថ [គ្រះ-ហះ-បត់], គោចរ [គោ-ច-] ។ *Anat.* រណ្ដៅភ្នែក

orchestral,e,aux *a.* នៃវង់ភ្លេង (ឧ. musique orchestrale)

orchestration *n.f.* ការរៀបចំវង់ភ្លេងតាមសម្លេងគ្រឿង

orchestre *n.m.* វង់ភ្លេង; កន្លែងវង់ភ្លេង (ក្នុងរោងល្ខោន) ។ orchestre de chambre វង់ភ្លេងសម្រាប់លេងក្នុងបន្ទប់តូច ។ orchestre à cordes តូរិយាង្គ, វង់ភ្លេងខ្សែ

orchestrer *v.t.* រៀបចំវង់ភ្លេងតាមសម្លេងគ្រឿង

orchidacées [—ki—] *n.f. pl.* បិនសីឥកូល [ប៊ិន-ស៊ី-ឥ:-]

orchidée [-ki-] *n.f.* កេសរ ។ *n.f. pl.* កេសរកូល

orchite [—kit'] *n.f.* អណ្ឌរោគ, រោគប

ordalité *n.f.* ការស្បថ (ឲ្យលូកសំណ ឬកូលភ្លើងដូចនាងសីតាក្នុងរឿងរាមកេរ្តិ៍ ជាដើម)

ordinaire *a.* ធម្មតា (ឧ. nourriture ordinaire); សាមញ្ញ, អន់ (ឧ. esprit ordinaire) ។ *n.m.* ម្ហូបធម្មតា (ឧ. un bon ordinaire) ។ à l'ordinaire ឬ comme à l'ordinaire តាមទម្លាប់, ដូចធម្មតា។ d'ordinaire ឬ pour l'ordinaire ជាធម្មតា (ឧ. on se repent d'ordinaire d'avoir trop parlé) ។ contre l'ordinaire ខុសពីធម្មតា

ordinairement *adv.* ជាធម្មតា (ឧ. le ciel de Londres est ordinairement brumeux)

ordinal,e,aux *a.* បូរណសំខ្យា, ដែលប្រាប់របៀប-ប្រាប់ថ្នាក់ (ឧ. premier លេខ ១; deuxième លេខ ២)

ordonnance *n.f.* ការរៀបចំ (ឧ. ordonnance d'un poème); បញ្ញត្តិ ។ ordonnance royale រាជបញ្ញត្តិ ។ ដីកា ។ ordonnance de référé ដីកាបណ្តោះអាសន្ន ។ ordonnance de renvoi ដីកាបញ្ជូនរឿងជាមធ្យម ។ ordonnance de transmission ដីកាបញ្ជូនរឿងជាឧក្រិដ្ឋ ។ *Méd.* វេជ្ជបញ្ញត្តិ (ឧ. suivre rigoureusement une ordonnance) ។ *Fin.* អាណាប័ណ្ណ ។ *Mil.* បម្រើ (កូនទាហានសម្រាប់បម្រើនាយទាហានម្នាក់) ។ officier d'ordonnance នាយទាហានបម្រើ (អង្គរក្ស)

ordonnancement *n.m.* អាណាប័ណ្ណ, ការបញ្ជាចំណាយ (ឧ. tout ordonnancement doit être

visé par le contrôleur des dépenses engagées)

ordonnancer *v.t.* ធ្វើអាណាប័ណ្ណ, បញ្ជាចំណាយ

ordonnateur,trice *n.* អាណាប័កបិក [ឆាក់-ប៉ុក]; អ្នកបង្គាប់, អ្នករៀបចំ (ឧ. ordonnateur d'un festin) ។ *n.m. Fin.* អាណាប័ក [-ឆាក់], អ្នកបញ្ជាចំណាយ ។ ordonnateur délégué អាណាប័កប្រតិភូ, អ្នកបញ្ជាប្រតិភូ ។ ordonnateur du budget អាណាប័កថវិកា, អ្នកបញ្ជាចំណាយថវិកា

ordonné,e *a.* ដែលមានសណ្ដាប់ធ្នាប់ (ឧ. élève ordonné; maison ordonnée)

ordonnée *n.f. Math.* យាមក (ម.ព. coordonnée ផង)

ordonner *v.t.* រៀបចំ (ឧ. ordonner sa maison); បង្គាប់ (ឧ. ordonner à quelqu'un de se taire) ។ *Méd.* បញ្ជា (បង្គាប់ឲ្យប្រើឱសថ) (ឧ. le médecin leur a ordonné des bains, la diète, etc . . .)

ordre *n.m.* ការរៀបចំ (ឧ. mettre des papiers en ordre), ដំណើរស្រួល (ឧ. mettre de l'ordre dans ses affaires); សេចក្ដីរៀបរយ (ឧ. l'ordre règne partout; របៀប, សណ្ដាប់ធ្នាប់ (ឧ. avoir de l'ordre); លំដាប់ (ឧ. développer l'ordre des batailles) ។ ordre chronologique លំដាប់កាល (ឧ. respecter l'ordre chronologique) ។ ការរៀងគ្នា ។ numéro d'ordre លេខរៀង ។

គណៈ ។ ordre des avocats គណៈមេធាវី ។ ordre mahanikay គណៈមហានិកាយ ។ ordre dhammayuttikanikay គណៈធម្មយុត្តិកនិកាយ ។ ក្រុម (តិរច្ឆានយស) ។

Par ext. ឋានន្តរក្រុម, លំដាប់សក្តិ; ឋានៈ (ឧ. un savant, un écrivain de premier ordre) ។

បញ្ជា, សេចក្ដីបង្គាប់ (ឧ. les ordres du maître) ។

Loc. div. mettre ឬ donner ordre à ធ្វើឲ្យមានដំណើរ

ស្រួល ឬ ឲ្យមានរបៀបរៀបរយ។ être ឬ se mettre aux ordres de quelqu'un ត្រៀមខ្លួនចាំទទួលបង្គាប់។ jusqu' à nouvel ordre លុះតែមានបង្គាប់ជាថ្មី។ par ordre (p.o.) ដោយទទួលបង្គាប់ (ឧ. avis inséré par ordre dans tous les journaux)។ ordre de mission បញ្ជាបេសកកម្ម។ ordre de service សេវាបញ្ជា។ ដីកា។ ordre de paiement ដីកាបើកប្រាក់។ ordre de recette ដីកាចំណូល។ ordre de versement ដីកាឲ្យបង់ប្រាក់។

Mil. បញ្ជា, បង្គាប់ការ (ឧ. un ordre doit être clair et précis); ពេលទទួលបញ្ជា (ពេលម៉ោងដែលត្រូវមកទទួលបញ្ជាអំពីចៅហ្វាយនាយ) (ឧ. aller à l'ordre)។ mot d'ordre ម.ព. mot។ ordre d'écrou បញ្ជាឲ្យដាក់គុក។ ordre d'élargissement បញ្ជាឲ្យដោះលែង។ ordre du jour ភារបញ្ជា [ភា-រៈ—] (ខាងទាហាន)។ porter un militaire à l'ordre du jour សរសើរជាសាធារណៈ។

Pol. ordre du jour របៀបភារៈ។ passer à l'ordre du jour ផ្ដើមរបៀបភារៈថ្មី (ឈប់ជជែកអំពីរឿងមួយ ដើម្បីលើកយករឿងមួយទៀតមកពិភាក្សា)។ rappel à l'ordre ការរំឭកឲ្យមានរបៀប

ordure *n.f.* សម្រាម (ឧ. boîte aux ordures)។ *Fig.* ពាក្យអាសគ្រាម (ឧ. dire des ordures)

ordurier,ère *a.* ដែលមានពាក្យអាសគ្រាម (ឧ. livre ordurier); ដែលចូលចិត្តប្រើពាក្យអាសគ្រាម (ឧ. homme, écrivain ordurier)

oréade *n.f. Myth.* បព្វតទេវតា, ទេពធីតានៅភ្នំ, អ្នកតាភ្នំ

orée *n.f.* មាត់ព្រៃ, រនះព្រៃ

oreillard,e *a.* ដែលមានត្រចៀកវែងជាក់ (ឧ. cheval oreillard)។ *n.m.* ប្រចៀវម្យ៉ាង (ត្រចៀកវែង)

oreille *n.f.* សោត, ត្រចៀក (ឧ. avoir l'oreille bien faite); ត្រចៀក (សោតវិញ្ញាណ) (ឧ. avoir l'oreille fine មានត្រចៀកវៃ); ត្រចៀក (ការចេះស្ដាប់សម្លេងពីរោះ) (ឧ. avoir l'oreille); ក្ដាងខ្លួនត្រចៀក (ឧ.

écrou à oreilles); ឆ្នុកព្រឹស សៀរកោ ។ *Mar.* លៀងយុថ្កា ។

Fig. à l'oreille ដោយខ្សឹបដាក់ត្រចៀក (ឧ. dire un secret à l'oreille)។ avoir l'oreille basse ដាក់ត្រចៀកខ្ទប; អាម៉ាស់មុខ ។ avoir l'oreille de quelqu'un មានអ្នកណាម្នាក់ស្ដាប់ (ធ្វើការ) ។ échauffer les oreilles ធ្វើឲ្យក្ដៅត្រចៀក; ធ្វើឲ្យខឹង។ frotter ឬ tirer les oreilles de quelqu'un ញឹងត្រចៀក; ផ្ចាល ។ ouvrir les oreilles ស្ដាប់ដោយយកចិត្តទុកដាក់។ prêter l'oreille ផ្ទៀងត្រចៀក ។ se faire tirer l'oreille ឲ្យគេអង្វរឬឲ្យគេបង្ខំដើម្បីធ្វើអ្វីមួយ ។ laisser passer ឬ montrer le bout de l'oreille ឲ្យគេស្គាល់ពោះវៀន

oreiller *n.m.* ខ្នើយ

oreillette *n.f.* ហឫទយកណ្ណ [ហៈ-ឫ:-យៈ-ក័ន] (បន្ទប់បេះដូងសម្រាប់ទទួលឈាមខ្មៅ)។ oreillette droite ហឫទយកណ្ណស្ដាំ ។ oreillette gauche ហឫទយកណ្ណឆ្វេង

oreillons *n.m pl.* ស្រឡៀវទន; ជ៉ន អ្នកគ្រប់ត្រចៀក

ores *adv.* ឥឡូវនេះ ។ d'ores et déjà *loc. adv.* តាំងពីឥឡូវនេះទៅហើយ

orfèvre *n.m.* រតនពាណិជ, ឈ្មួញគ្រឿងមាសប្រាក់; ជាងទង ។ être orfèvre en la matière ប្រសប់ឬជំនាញក្នុងរឿងមួយ

orfèvrerie *n.f.* សិល្បៈខាងគ្រឿងមាសប្រាក់ ; ជំនួញគ្រឿងមាសប្រាក់; រតនម័យ, គ្រឿងមាសប្រាក់ (ឧ. acheter de l'orfèvrerie)

orfraie *n.f.* ព្យាឧបក្សីអ្យាំង (ឧ. on a souvent confondu à tort l'orfraie avec l'effraie)

organe *n.m.* សរីរាង្គ [សៈ-រី-រ៉ាង] (ឧ.les jambes sont les organes qui suffisent pour marcher)។ organe broyeur សរីរាង្គសម្រាប់កិន ។ organe de l'équilibration សរីរាង្គនៃតុល្យការ។ organe génital អង្គជាតិ។ អាយតនៈ ។ organe de la vue ចក្ខាយតនៈ។ organe de l'ouïe សោតាយតនៈ។ organe de l'odorat ឃានាយតនៈ។ organe

du goût ជិវ្ហាយតនៈ ។ organe du toucher កាយាយតនៈ ។

Spécial. សម្លេង (ឧ. avoir un bel organe មានសម្លេងល្អ) ។

Fig. គ្រឿង (ឧ. la langue est devenue l'organe de la dissimulation) ; អង្គការ (ឧ. journal qui est l'organe de l'opposition) ។ *Par ext.* កាសែត (ឧ. les organes de l'opposition) ។

Comptab. organes comptables អង្គគណនេយ្យ (ឧ. les organes comptables sont le journal, le grand livre et la balance)

organicisme *n.m.* សរីរាង្គនិយម [សៈ-រី-រ៉ាង-គៈ—] (*Méd.* លទ្ធិនិយម ជារោគបណ្ដាលមកអំពីការខូចសរីរាង្គ ; *Phil.* លទ្ធិនិយមថា ជីវិតមានអំពីដំណើរនៃសរីរាង្គ)

organique *a.* នៃសរីរាង្គ (ឧ. maladie organique) ។ chimie organique គីមីសរីរាង្គ ។ fonctions organiques មុខងារនៃសរីរាង្គ (មុខងារនៃរោគសញ) ។ loi organique ច្បាប់រៀបចំអង្គការ (ឧ. les lois électorales sont des lois organiques)

organiquement *adv.* ដោយសរីរាង្គ

organisable *a.* អាចរៀបចំបាន

organisateur, trice *a.&n* អ្នករៀបចំ; អ្នកប្រសប់រៀបចំ; អ្នកចាត់ចែង

organisation *n.f.* ការរៀបចំ (ឧ. organisation du corps humain) ។ *Fig.* ការចាត់ចែង (organisation d'une fête) ។ organisation sociale scolaire ការរៀបចំសង្គមសិក្សា ។ អង្គការ ។ Organisation Mondiale de la Santé អង្គការពិភពលោកខាងសុខភាព (ម.ព. O.M.S. ផង) ។ Organisation des Nations Unies អង្គការសហប្រជាជាតិ (ម.ព. O.N.U. ផង) ។ Organisation Scientifique du Travail (O.S.T.) អង្គការវិទ្យាសាស្ត្រខាងការងារ ។ ingénieur en organisation វិស្វករខាងអង្គការ

organisé, e *a.* ដែលមានសរីរាង្គ (ឧ. les végétaux sont des corps organisés) ។ *Fig.* ដែលមានរបៀប

រៀបរយ (ឧ. maison de commerce bien organisée) ។ tête bien organisée ក្បាលខ្ទរល្អ

organiser *v.t.* រៀបចំ (ឧ. organiser un ministère); ជាត់ចែង (ឧ. organiser une partie de plaisir) ។ s'organiser *v.pr.* មានទម្រង់ត្រឹមត្រូវ

organisme *n.m.* សព៌ាង្គកាយ [សារ-ពាង្គ—] (សរីរាង្គទាំងឡាយ)(ឧ. l'organisme humain) ។

Fig. អង្គការ។ organisme constitutionnel អង្គការរដ្ឋធម្មនុញ្ញ ។ organisme sanitaire អង្គការសុខភាព ។ la Fédération Nationale des Organismes de Sécurité Sociale សហព័ន្ធជាតិនៃអង្គការនិរភ័យក្នុងសង្គម

organsin *n.m.* សូត្រត្រវៀរ

organsinage *n.m.* ការត្រវៀរ

organsiner *v.t.* ត្រវៀរ

orgasme *n.m.* ទីបំផុតនៃតម្រេក (ពេលបញ្ចេញទឹកកាម)

orge *n.f.* ធញ្ញជាតិមួយយ៉ាង

orgelet *n m.* ពកៃភ្នែ (ភេគកើតនៅភ្នែក)

orgiaque *a.* នៃការស៊ីផឹកហួសប្រមាណ (ឧ. débauches orgiaques)

orgie *n.f.* ការស៊ីផឹកហួសប្រមាណ (ឧ. faire une orgie) ។ *Par ext.* ភាពលើស, ភាពសម្បូរពេក (ឧ. orgie de lumière, de fleurs)

orgueil *n.m.* អភិមានះ, សេចក្ដីឡើង ឬ ក្រអឺតក្រអោង (ឧ. l'orgueil se nourrit de l'ignorance) ។ *En bonne part* សេចក្ដីថ្លៃថ្នូរ (ឧ. un légitime orgueil) (*ut.* fatuité, hauteur, morgue, présomption, prétention, suffisance, vanité)

orgueilleusement *adv.* ដោយអភិមានះ, យ៉ាងឡើង, ដោយក្រអឺតក្រអោង

orgueilleux,euse *a.* ឡើង, ដែលកាន់ឫក, ក្រអឺតក្រអោង (ឧ. réponse orgueilleuse)

oribus *n.m.* ទៀនជ័រ

orient *n.m.* បូព៌, ទិសខាងកើត; ខ្លះនៃពេជ្រ; បូព៌ាប្រទេស (ឧ. voyage en Orient) ។ Moyen Orient មជ្ឈិមបូព៌ាប្រទេស ។ Extrême Orient ចុងបូព៌ាប្រទេស

orientable *a.* អាចបំបែរបាន (ឧ. phare orientable)

oriental,e,aux *a.&n.* នៃទិសបូព៌ ។ *n.m. pl.* ជនជាតិបូព៌ាប្រទេស

orientalisme *n.m.* វិជ្ជាខាងបូព៌ាប្រទេស(ភាសា, ប្រវត្តិសាស្ត្រ. ទំនៀមទម្លាប់ ។ ល ។ នៃបូព៌ាប្រទេស)

orientaliste *n.* អ្នកសិក្សាវិជ្ជាខាងបូព៌ាប្រទេស (អ្នកសិក្សាភាសានិងអារ្យធម៌បូព៌ាប្រទេស)

orientation *n.f.* អនុស្ថាប័ន, ការរកទិស (ឧ. l'orientation est facile au moyen de la boussole); ភាពឈមមុខ(រកទិស)។ *Fig.* ការដឹកនាំ (ឧ. l'orientation de la politique) ។ orientation professionnelle អនុស្ថាប័នខាងវិជ្ជាជីវៈ(ការជួយណែនាំក្មេងឲ្យរើសវិជ្ជាជីវៈដែលសមនឹងសមត្ថភាពផង សមនឹងសេចក្ដីត្រូវការផង)

orientement *n.m.* ការបំបែររកទិស

orienter *v.t.* បំបែររកទិស(ឧ. orienter un édifice); ដឹកនាំ, បង្ហាញផ្លូវ (ឧ.orienter le public vers la sortie)។ *Fig.* ជួយណែនាំឲ្យរើសវិជ្ជាជីវៈ ។

s'orienter *v.pr.* រកទិស; តម្រង់ឆ្ពោះទៅ

orienteur,trice *n.* អ្នកជួយណែនាំឲ្យរើសវិជ្ជាជីវៈ

orifice *n.m.* ជំរុំ, រន្ធ, ប្រហោង

oriflamme *n.f.* ទង់សុវណ្ណជ្វាលា

originaire *a.* ដែលមានដើមកំណើតពី (ឧ. plante originaire d'Amérique)

originairement *adv.* ពីដើមកំណើត

original,e,aux *a.* ដើម (ដែលមានមុនគេបង្អស់) (ឧ. un tableau, un texte original); ប្លែក (មិនដែលឃើញ, មិនដែលឮ) (ឧ. pensée originale); ចំឡែក, ល្ងើយ (ឧ. caractère original) ។

n.m. ច្បាប់ដើម, សំណៅដើម។ *n.* មនុស្សល្ងើយ (ខុសគេ)

originalement *adv.* យ៉ាងប្លែក

originalité *n.f.* ភាពប្លែក; ចរិតប្លែក (ឧ. se faire remarquer par son originalité)

origine *n.f.* ឧប្បត្តិស្ថាន; ដើមកំណើត (ឧ. l'origine du monde); ដើមហេតុ (ឧ. origine d'une maladie); ដើមកំណើត, មូល, ឫស(ឧ. l'origine d'un mot) ។ dans l'origine ឬ à l'origine *loc.*

adv. ដើមដំបូង

originel,elle *a.* ដែលមានតាំងពីដើម កំណើតមក

originellement *adv.* តាំងពីដើម កំណើត (ឧ. contrat originellement vicié)

orillon *n.m.* ត្រចៀក (ចាន, ថាស) (ឧ. les orillons d'une écuelle)

orin *n.m.* *Mar.* ខ្សែពោង

oripeau *n.m.* ស្លាន់ក្រាប ។ *Par ext.* សំលៀកបំពាក់ដែលមានពន្លឺភ្លឺ

orme *n.m.* រុក្ខ (ដើមឈើម្យ៉ាង) ។ *Prov.* attendez moi sous l'orme ម.ព. attendre

ornement *n.m.* គ្រឿងតុបតែង

ornemental,e,aux *a.* នៃគ្រឿងតុបតែង (ឧ. style ornemental); សម្រាប់តុបតែង (ឧ. plantes ornementales)

ornementation *n.f.* វិជ្ជាខាងតុបតែង

ornementer *v.t.* បន្ថែមគ្រឿងតុបតែង (ឧ.ornementer un panneau)

orner *v.t.* តុបតែង (ឧ. orner un salon de tableaux) ។ *Fig.* ធ្វើឲ្យបរិបូរ (ឧ.la lecture orne l'esprit)

ornière *n.f.* ផ្លូវរទេះ ។ *Fig.* ទម្លាប់ចាស់ (ឧ. sortir de l'ornière)

ornithologie *n.f.* បក្សីសាស្ត្រ (វិទ្យាសាស្ត្រខាងសត្វស្លាប)

ornithologiste ឬ **ornithologue** *n.* បក្សីសាស្ត្រិន, អ្នកបក្សីសាស្ត្រ

ornithomancie *n.f.* សកុណទាយវិទ្យា, វិជ្ជាទាយដោយមើលសត្វហើរ ឬ ស្ដាប់សត្វយំ

ornithorynque *n.m.* អ៊ីធឺតូរ៉ាំង (ថនិកបក្សីប្រភេទមួយនៅកោះអូស្ត្រាលី)

orogenèse *n.f.* កំណើតនៃផ្នំភ្នំ

orogénie *n.f.* ដំណើរលាយនៃសំបកផែនដី

orogénique *a.* នៃដំណើរលាយសំបកផែនដី

orographie *n.f.* គីរីភូមិសាស្ត្រ (វិទ្យាសាស្ត្រខាងផ្លូវរស់ភ្នំ)

orographique *a.* នៃគីរីភូមិសាស្ត្រ (ឧ. carte orographique)

orpaillage *n.m.* ការរែងមាស

orpailleur *n.m.* អ្នករែងមាស

orphelin *n.&a.* កំព្រា (ឧ. être orphelin de père)

orphelinat *n.m.* គ្រឹះស្ថានក្មេងកំព្រា

កំព្រា

orteil *n.m.* ម្រាមជើង ។ *Spécial.* ឬ gros orteil មេជើង

orthodoxe *a.* គន្លងនិយម (ត្រូវតាមច្បាប់សាសនា, ដែលជាសម្មាមតិ) (ឧ. une opinion qui n'est pas orthodoxe)

orthodoxie *n.f.* គន្លងនិយម, សម្មាមតិ (ឧ. défendre l'orthodoxie)

orthogonal,e,aux *a.* ឧជុកោណ, ដែលកាត់ជាមុំកែង

orthogonalement *adv.* ជាឧជុកោណ, ជាមុំកែង (ឧ. plans qui se coupent orthogonalement)

orthographe *n.f.* អក្ខរាវិរុទ្ធ (ឧ. apprendre l'orthographe); អក្សរ (ឧ. mauvaise orthographe)

orthographier *v.t.* សរសេរត្រឹមត្រូវតាមអក្ខរាវិរុទ្ធ

orthographique *a.* នៃអក្ខរាវិរុទ្ធ (ឧ. signes orthographiques)

orthopédie *n.f.* ការកែទម្រង់កាយ (ការធ្វើឲ្យជាត់ផ្ទៀងស្មា ឬ ឲ្យជាត់រៀបឆ្អឹងខ្នងជាដើម)

orthopédique *a.* សម្រាប់កែទម្រង់កាយ (ឧ. appareil orthopédique)

orthopédiste *a.&n.* អ្នកកែទម្រង់កាយ (ឧ. chirurgien orthopédiste)

orthoptères *n.m. pl.* ឧជុបត្តសត្វ (ជាណាកសត្វពួកកណ្ដូប, ចង្រិត)

ortie *n.f.* ដើមកន្ទួបរោល

ortolan *n.m.* អ័រតូឡង់ (ជាបម្យ៉ាងដែលមកដល់ប្រទេសយើងក្នុងខេត្តព្រវែង)

os *n.m.* អដ្ឋិ, ឆ្អឹង ។ os compact ឆ្អឹងតាន់, ឆ្អឹងណែន ។ os spongieux ឆ្អឹងស្គោត ។ *Fig.* en chair et en os ដោយខ្លួនឯង, ទាំងរូប ។ jusqu'à la moelle des os ដល់ឆ្អឹង, យ៉ាងជ្រៅ ។ n'avoir que les os et la peau មានតែស្បែកនឹងឆ្អឹង ។ avoir la peau collée aux os មានតែស្បែកដណ្ដប់ឆ្អឹង (ស្គមណាស់) ។ donner un os à ronger à quelqu'un ឲ្យឆ្អឹងអង្គៀម (ឲ្យធនធានគ្រាន់នោះទាល់) ។ ne pas faire de vieux os ខានចាស់, ស្លាប់ពីក្មេង

oscar *n.m.* អូស្ការ, រង្វាន់ធំនៃខ្សែភាព-

យន្ត (ម៉ោងជាប្រុងម្រាក់ដែលកលំផ្ទាំនៅហ្សីរ៉ូត) ។ *Par ext.* ម៉ោង

oscillant,e [os-si-lan] *a.* ដែលយោល

oscillateur [os-si-ឬ os-sil-] *n.m.* គ្រឿងយោល (គ្រឿងអគ្គិសនី)

oscillation [os-si-ឬ os-sil-] *n.f.* ការយោល (ឧ. les oscillations du pendule); ការប្រែប្រួល

oscillatoire [os-si-ឬ os-sil-] *a.* យោល (ឧ. mouvement oscillatoire)

osciller [os-si-lé] *v.i.* យោល ។ *Fig.* ប្រែប្រួល; រេរា, រារែក

osé,e *a.* ហ៊ាន (ឧ. tentative osée; vous êtes bien osé)

oser *v.i.* ហ៊ាន (ឧ. c'est un homme à tout oser)

oseraie *n.f.* ចំការអូស៊ីយេរ (ដើមស្រល់ម្យ៉ាង)

oseur,euse *a.* ហ៊ាន ។ *n.* អ្នកហ៊ាន

osier *n.m.* អូស៊ីយេរ (ដើមស្រល់ម្យ៉ាងដែលគេយកមែកធ្វើកន្ត្រក, ល្អីខ្សែ ។ល។)

osiériculture *n.f.* ការដាំអូស៊ីយេរ

osmologie *n.f.* គន្ធសាស្ត្រ(វិទ្យាសាស្ត្រខាងក្លិន)

osmologique *a.* នៃគន្ធសាស្ត្រ (ឧ. essais osmologiques)

osmomètre *n.m.* អាសារណមាត្រ [-រ៉ៈ-ណៈ-]

osmose *n.m.* អាសារណ៍

osmotique *a.* អាសារណ៍ (ឧ. pression osmotique)

ossature *n.f.* ឆ្អឹងទាំងខ្លួន, គ្រោងឆ្អឹង (ឧ. homme d'une solide ossature); ឆ្អឹង (ឧ. ossature en fer d'une voûte)

osséine *n.f.* អដ្ឋិជាតិ, ជាតិឆ្អឹង

osselet *n.m.* ឆ្អឹងតូច ។ chaîne des osselets ម.ព. chaîne

ossements *n.m. pl.* ឆ្អឹងស្ងួត

osseux,euse *a.* នៃឆ្អឹង ។ tissu osseux ជាលិកាឆ្អឹង ។ ដែលឃើញឆ្អឹងរពោង (ឧ. main osseuse)

ossification *n.f.* អដ្ឋិរូបករណ៍, ការក្លាយជាឆ្អឹង

ossifier *v.t.* ក្លាយជាឆ្អឹង

ossu,e *a.* ដែលមានឆ្អឹងធំៗ (ឧ. une femme ossue)

ossuaire *n.m.* ចេតិយឆ្អឹង; កន្លែងគរឆ្អឹង

O.S.T. (Organisation Scien-

tifique du Travail) ម.ក. organisation

ostéalgie *n.f.* ការឈឺឆ្អឹង

ostéalgique *a.* នៃការឈឺឆ្អឹង(ឧ.douleur ostéalgique)

ostéite *n.f.* រោគរលាកឆ្អឹង

ostensible *a.* ដែលសំញែង(ឧ.porter une insigne d'une manière ostensible)

ostensiblement *adv.* ដោយសំញែង (ឧ. montrer ostensiblement ses préférences)

ostentateur,trice *a.* ដែលចូលចិត្តសំញែង

ostentation *n.f.* ការសំញែង(ឧ.faire ostentation de ses richesses) (ព្រ.étalage, montre,parade)

ostentatoire *a.* ដែលចង់សំញែង (ឧ. une attitude ostentatoire)

ostéoblaste *n.m.* អដ្ឋិកោសិក, កោសិកានៃឆ្អឹង

ostéogenèse *n.f.* ម.ក. ossification

ostéographie *n.f.* អដ្ឋិសាស្ត្រ

ostéolithe *n.m.* អដ្ឋិសិលា, ឆ្អឹងដែលក្លាយជាថ្ម

ostéologie *n.f.* អដ្ឋិវិទ្យា (វិទ្យាសាស្ត្រខាងឆ្អឹង)

ostéologique *a.* នៃអដ្ឋិវិទ្យា

ostéomalacie *n.f.* រោគបណ្ដាលឲ្យឆ្អឹងទន់

ostéomyélite *n.f.* រោគរលាកឆ្អឹងនិងមិញ្ជាឆ្អឹង

ostéoplastie *n.f.* ការជួសឆ្អឹង (ដោយបំណែកឆ្អឹង)

ostéosarcome *n.m.* រោគហើមឆ្អឹង

ostéosynthèse *n.f.* អដ្ឋិសំយោគ, ការផ្គុំឆ្អឹង (សល្យសាស្ត្រ)

ostéotomie *n.f.* អដ្ឋិច្ឆេទនា [អ័ត-ថិច-ឆេ-ទៈ-ណា], ការកាត់ឆ្អឹងចេញខ្លះ

ostracisme *n.m.* ការនិរទេស ១០ ឆ្នាំ (ទំនៀមទម្លាប់ជនជាតិអាតែន)។ *Par ext.* ការបណ្ដេញចេញ (ឧ. être victime d'un ostracisme)

ostréicole *a.* នៃសិប្បិវប្បកម្ម (ឧ. industrie ostréicole)

ostréiculteur *n.m.* សិប្បិវប្បករ, អ្នកចិញ្ចឹមគ្រុំ

ostréiculture *n.f.* សិប្បិវប្បកម្ម, ការចិញ្ចឹមគ្រុំ (ឧ. Marennes est un centre d'ostréiculture)

ostrogoth ឬ **ostrogot,e** *a.&n.* *Par*

ext. អនាឡូ។ *Fam.* ព្រៃ, មិនចេះគួរសម

otage *n.m.* មនុស្សឬស្រុកដាក់ធានា(ក្នុងកិច្ចសន្យាឬសន្ធិសញ្ញា)(ឧ. prendre, échanger des otages); ចំណាប់ខ្មាំង (មនុស្ស ឬ អ្វីៗ ដែលខ្មាំងចាប់យកទៅឃុំឃាំងទុកយកថ្លៃ)

O.T.A.N.(Organisation du Traité de l'Atlantique Nord អង្គការសន្ធិសញ្ញាអាត្លង់ទិកខាងជើង)

otalgie *n.f.* ការឈឺត្រចៀក

O.T.A.S.E. (Organisation du Traité de l'Asie du Sud-Est អង្គការសន្ធិសញ្ញាអាស៊ីភាគអាគ្នេយ៍)

ôté *part. passé* លើកលែង (ឧ. ouvrage excellent, ôté deux ou trois chapitres)

ôter *v.t.* ដកចេញ, យកចេញ (ឧ. ôter un objet de la table); សម្រាតចេញ, ដោះចេញ (ឧ. ôter son manteau); ហូត(ឧ. ôter deux de quatre) ។ *Fig.* ដក,ហូត,យកចេញ (ឧ. ôter son emploi à quelqu'un; ôtez-lui cette idée de l'esprit); បំបាត់ចោល, កំចាត់ (ឧ. ôter la fièvre) ។

s'ôter *v.pr.* ថយចេញ (ឧ. ôtez-vous de là) (សទ. défalquer, extirper, extraire, prélever, soustraire, supprimer)

otique *a.* នៃត្រចៀក

otite *n.f.* អំបៅអំបែក(ឧ.otite aiguë)

otologie *n.f.* សោតវិទ្យា (ការសិក្សាអំពីត្រចៀកនិងរោគត្រចៀក)

oto-rhino-laryngologie *n.f.* សោត-ឃាន-កណ្ឋរោគសាស្ត្រ [សោ-តៈ-ឃា-នៈ-ក័ណ-ឋៈ-រោគៈ—]

oto-rhino-laryngologiste *n.* សោត-ឃាន-កណ្ឋពេទ្យ [សោ-តៈ-ឃា-នៈ-ក័ណ-ឋៈ—]

otorrhagie *n.f.* ដំណើរចេញឈាមពីត្រចៀក

otorrhée *n.f.* ដំណើរហូរខ្ទុះពីត្រចៀក

otoscope *n.m.* សោតទស្សន៍ (ប្រដាប់ពិនិត្យរន្ធត្រចៀក)

ottoman,e *a.&n.* នៃជនជាតិទួរគី ។ *n.m.* សំពត់អន្លូងសូត្រជាប់អំបោះ ។ *n.f.* កៅអីវែងប្រែតម្យ៉ាង

ou *conj.* ឬ

où *adv.* ដែល (បន្ទុលទី, កន្លែង ឧ. la maison où j'habite; បន្ទុល

ពេល ឧ. le jour où je vous ai rencontré); ឯណា (សំនួរ ឧ. où courez-vous)។ là où នៅទីដែល ។ où que នៅទីណាដែល ។ d'où ពីទីណា (ពុំថា c'est là où je veux aller, ត្រូវថា c'est là que...)

ouaille *n.f.* ចៀម ។ *Fig.* អ្នកនៅក្រោមនិងបព្វជិតមួយរូប (ឧ.ce curé a soin de ses ouailles)។ *Par ext.* អ្នកនៅក្រោមការឧបត្ថម្ភ (ឧ. Pauvres gens (les maris) qui n'ont pas l'esprit De garder du loup leur ouaille)

ouais ! *int.Fam.* អៃយ៉ា!(ឧ.ouais! vous le prenez de bien haut)

ouate *n.f.* សំឡីកប្បាស

ouater *v.t.* ដាក់សំឡី; ទ្រាប់សំឡី

ouatine *n.f.* សំពត់កប្បាសសម្រាប់ទ្រាប់

ouatiner *v.t.* ទ្រាប់សំពត់កប្បាស

oubli *n.m.* ការភ្លេច (ឧ.l'oubli d'un fait important); ការធ្វេស, ការភ្លេច (ឧ.réparer un oubli); ការភ្លេងមួយភ្លែត (ឧ. commettre une faute dans un moment d'oubli) ។ oubli de soi ការមិនគិតដល់ខ្លួនឯង (ការលះបង់សិទ្ធិនិងប្រយោជន៍ផ្ទាល់ខ្លួន)

oubliable *a.* អាចភ្លេចបាន

oublie *n.f.* នំប៉ុពង់

oublier *v.t.* ភ្លេច (ឧ. oublier une date); បំភ្លេច (ឧ.oublions le passé) ។ oublier ses amis ភ្លេចមិត្តភក្តិខ្លួន ។

s'oublier *v.pr.* ភ្លេង(ភ្លេចការគួរពីខ្លួន) (ឧ. il s'est oublié au point de répondre incorrectement) ។ *Fam.* ប្រព្រឹត្តស្មោះគារ; លែងគិតដល់ខ្លួនឯង (ឧ. s'oublier, c'est penser aux autres)

oubliette *n.f.* គុកងងឹត; រំលុងយន្ត (រំលុងគ្របមានគន្លឹះ)

oublieux,euse *a.* ដែលភ្លេច (ឧ. écolier oublieux)

ouche *n.f.* ចំការដើងភូមិ

oued *n.m.* អូរ៉ែត (ស្ទឹងនៅភលខ្សាច់) (*pl.* des oueds)

ouest *n.m.* បស្ចិម, ទិសខាងលិច (ឧ. marcher vers l'ouest) ។ *Par ext.* បស្ចិមប្រទេស; បច្ចិមការនៃប្រទេសណាមួយ (ឧ. voyager

dans l'ouest) (ក.ធ. est, levant, orient)

ouf! *int.* អុ! (សូរលាន់មាត់ក្រោយពីមានការលំបាក)

oui *adv.* មែន, បាទ, អើ ។ *Fam.* oui-da អើហ្នឹងហើយ (ប្រើនប្រើដោយចំអក) ។ *n.m. inv.* ការព្រម (ឧ. tout se résout par des oui ou par des non) ។ dire ឬ prononcer le grand oui ជាព្រម (រៀបអាពាហ៍ពិពាហ៍) ។ se fâcher pour un oui, pour un non ខឹងឥតរឿង

ouiche ! *int.Pop.* អើមែនហើយ !

ouï-dire *n.m. inv.* បរម្បូក, ពាក្យនិយាយតៗគ្នា (ឧ. il ne faut pas s'arrêter aux ouï-dire) ។ par ouï-dire *loc. adv.* ដោយឮគេថា

ouïe *n.f.* សោតវិញ្ញាណ (ឧ. les chiens ont l'ouïe fine) ។ *pl.* ស្រកី

ouïr *v.t.* ឮ (ឧ. j'ai ouï dire que . . .) ។ *Dr.* ស្ដាប់ (ស្ដាប់ចម្លើយឲ្យការណ៍) (ឧ. ouïr les experts)

oupille *n.f.* គប់

ouragan *n.m.* ព្យុះភក, ព្យុះសង្ឃរា ។ *Fig.* ការជ្រួលច្របល់ខ្លាំង (ឧ. ouragan politique) ។ arriver comme un ouragan មកដល់យ៉ាងលឿន (ដូចព្យុះ)

ouralien,enne *a.* នៃភ្នំអ៊ូរ៉ាល (នៅប្រទេសរុស្ស៊ី) (ឧ. les populations ouraliennes)

ourdir *v.t.* អន្ទង (ត្បាញ) ។ *Fig.* លួចគិត (ក្បត់) (ឧ. ourdir une trahison)

ourdissage *n.m. ind.* ការអន្ទង

ourdisseur,euse *n.* អ្នកអន្ទង

ourdissoir *n.m.* ម៉ាស៊ីនអន្ទង

ourler *v.t.* លើន, ប៉ំ

ourlet *n.m.* ជាយសំពត់លើន

ourlien,enne *a.* នៃស្រឡទែន (ឧ. orchite ourlienne)

ours *n.m.* ខ្លាឃ្មុំ (cri: l'ours gronde, grogne) ។ *Fig.* មនុស្សចូលចិត្តនៅម្នាក់ឯង ។ ours mal léché មនុស្សកន្ទ្រលកន្ទ្រល; មនុស្សឫកអាក្រក់

ourse *n.f.* ខ្លាឃ្មុំញី ។ *Astr.* Grande Ourse et Petite Ourse ផ្កាយ

ព្រាពើ (Grande Ourse ជាផ្នែកពាក់កណ្ដាលខ្លួនក្រោយ, Petite Ours ជាផ្នែកពាក់កណ្ដាលខ្លួនមុខ ហើយមានផ្កាយមេរុ (étoile polaire) នៅក្នុងប្រមុះ)

oursin *n.m.* សត្វសមុទ្រមួយក្រាងខ្លួនមូល មានបន្លា; ស្បែកខ្លាឃ្មុំជាប់រោម (ឧ. un bonnet d'oursin)

ourson *n.m.* កូនខ្លាឃ្មុំ

oust ! ឬ ouste! *int. Fam.* ចៀស!

outil *n.m.* ឧបករណ៍, ប្រដាប់ប្រដា (ឧ. outil de menuisier)

outillage *n.m.* ហត្ថបករណ៍; ប្រដាប់ប្រដាមួយគ្រឿង; គ្រឿងឧបករណ៍មួយគ្រឿង ។ outillage national ហត្ថបករណ៍ជាតិ (ធនធាននៃប្រទេសជាតិ ដូចជាផ្លូវ, ព្រែកជីក, អាយស្ម័យយាន, កំពង់ផែ ។ ល ។)

outillé,e *a.* ប្រដាប់ដោយឧបករណ៍ (ឧ. apprenti qui est bien outillé)

outiller *v.t.* ផ្គត់ផ្គង់ឧបករណ៍, ផ្គត់ផ្គង់ប្រដាប់ប្រដា (ឧ. outiller un ouvrier) ។ *Fig.* ផ្ដល់មធ្យោបាយចាំបាច់ (ឧ. outiller un jeune homme pour lutter dans la vie) ។

s'outiller *v.pr.* រកឧបករណ៍(សម្រាប់ខ្លួនឯង)

outlaw [aout'-lô] (ក.*n.*) ជនក្រៅច្បាប់ (ឧ. toute personne avait le droit de mettre à mort un outlaw)

outrage *n.m.* ការប្រមាថជាធ្ងន់ (ឧ. accabler quelqu'un d'outrages) ។ *Fig.* ការបំពាន (ឧ. outrage à la raison, à la vérité) ។

Dr. outrage aux bonnes mœurs ការប៉ះពាល់សមាចារ (មានការផ្សាយសៀវភៅរូបថតអាសគ្រាមជាដើម) ។ outrage public à la pudeur ការប៉ះពាល់ជាសាធារណៈដល់កេរ្តិ៍ខ្មាស ។

Poét. កំហុស, ការខូចខាត (ឧ. les outrages du sort) ។ les outrages du temps ជរាកាល

outrageant,e *a.* ដែលប្រមាថជាធ្ងន់ (ឧ. paroles outrageantes)

outrager *v.t.* ប្រមាថជាធ្ងន់, ជេរ (ឧ. outrager un supérieur)

outrageusement *adv.* ហួសហេតុ

(ឧ. outrageusement bète)

outrageux,euse *a.* ដែលប្រមាថ

outrance *n.f.* ការបំផ្លើស; ភាពហួសប្រមាណ; ក្ដីហួសប្រមាណ (ឧ.l'outrance de ses paroles, de ses opinions) ។ à outrance *loc.adv.* ហួសប្រមាណ; គ្មានឈប់ឈរ (ឧ.poursuivre à outrance)

outrancier,ère *a.* ដែលបំផ្លើស;ហួសប្រមាណ

outre *n.f.* ស្បែកពពែដេរសម្រាប់ដាក់ទឹក (ឧ. une outre pleine d'eau)

outre *pré.* ឯនាយ ។ outre-mer ឯនាយសមុទ្រ ។ ក្រៅពី (ឧ. apporter, outre les témoignages, des preuves écrites) ។

adv. passer outre ធ្វើរំលង, មិនរើសនឹង (ឧ. il a passé outre à ces observations) ។

Loc. adv. outre mesure ដោយហួសប្រមាណ ។ en outre ម្យ៉ាងទៀត ។ d'outre en outre ពីម្ខាងទៅម្ខាង (ឧ. un coup d'épée l'a percé d'outre en outre)។ outre que *loc.conj.* ក្រៅពី

outré,e *a.* បំផ្លើស, ហួសហេតុ (ឧ. pensée outrée); ក្ដៅក្រហាយ(ឧ. je suis outré de tant d'impertinence)

outre-atlantique *loc.adv.* ឯនាយមហាសមុទ្រអាត្លង់ទិក(ចំពោះទ្វីបអឺរ៉ុប)

outrecuidance *n.f.* អភិមានះ, ការប្រកាន់ថាខ្លួនឯងប្រសើរហួសពេក; ភាពវាយឫក, ភាពឡឹក (ឧ. parler avec outrecuidance)

outrecuidant,e *a.* អភិមានះ, វាយឫក, ឡឹក (ឧ. personnage outrecuidant)

outre-manche *loc. adv.* ឯនាយសមុទ្រម៉ង់ស្ស (ចំពោះប្រទេសបារាំង)

outremer *n.m.* មរកត, ពណ៌មេឃ

outre-mer *loc.adv.* ឯនាយសមុទ្រ (ឧ. s'établir outre-mer; les peuples d'outre-mer)

outre-monts *loc adv.* ឯនាយភ្នំ (ជាពិសេសចំពោះភ្នំអាល្ប) (ឧ. les pays d'outre-monts)

outrepasser *v.t.* រំលង; ប្រព្រឹត្តហួស (ឧ. outrepasser ses pouvoirs)

outrer *v.t.* ធ្វើហួសប្រមាណ; បំផ្លើស (ឧ. outrer la vérité); ប្រមាថជាទម្ងន់; ធ្វើឲ្យទ្រាំមិនបាន (ឧ. vos paroles l'ont outré)

outre-Rhin *loc.adv.* ឯនាយទន្លេរ៉ាំង

outre-tombe *loc.adv.* ក្រោយពេលស្លាប់

ouvert,e *a.* ដែលបើក, ដែលចំហ ។ pays ouvert ប្រទេសចំហ (គ្មានបន្ទាយឬគ្មានអ្វីការពារនៅព្រំប្រទល់) ។ ville ouverte ក្រុងចំហ(ក្រុងដែលគេមិនការពារ) ។ port ouvert កំពង់ផែចំហ(កំពង់ផែដែលនាវាបរទេសចូលចតបានដោយសេរី) ។ rade ouverte ជំរកសមុទ្រចំហ (កន្លែងចតកណ្ដាលសមុទ្រគ្មានអ្វីការពារនឹងខ្យល់ឬនឹងសត្រូវ) ។ lettre ouverte សំបុត្រចំហ ។

à cœur ouvert ដោយស្មោះត្រង់ ។ à bras ouverts ដោយរាក់ទាក់ (ឧ. recevoir un ami à bras ouverts) ។ à livre ouvert ដោយគ្មានប្រុងប្រៀបជាមុន ។ tenir table ouverte ទទួលឥតរើសមុខ

ouvertement *adv.* ដោយស្មោះត្រង់; ដោយចេញមុខ (ឧ. déclarer ouvertement ses intentions)

ouverture *n.f.* ប្រហោង, រន្ធ; រង្វះ (ឧ. faire une ouverture dans un mur); ការបើក (ឧ. l'ouverture d'un coffre) ។ *Fig.* ការបើក, ការសម្ពោធ (ឧ. ouverture d'une séance, d'un magasin); ការស្នើធ្វើកិច្ចចរចា ឬ ធ្វើជំនួញ (ឧ. faire des ouvertures de paix) ។

Géom. ouverture d'un angle រង្វះនៃមុំ ។ ouverture d'un compas រង្វះនៃដែកឈាន ។

Dr. ការបើកចំណាយ ។ loi portant ouverture de crédits ច្បាប់បើកឥណទាន (ម.ព. crédit ផង) ។ ouverture d'une succession ឱកាសបើកសិទ្ធិទទួលមរតក ។

Mil. ouverture de tir ការផ្ដើមបាញ់ (ព.ផ. fermeture)

ouvrable *a.* អាចធ្វើការបាន (ឧ. une matière ouvrable) ។ jour ouvrable ថ្ងៃធ្វើការ(ម.ព.jourផង)

ouvrage *n.m.* ដំណើរធ្វើការ; ការ (ឧ.

se mettre à l'ouvrage); ការ្យ, របស់ដែលធ្វើ (ឧ. un ouvrage de menuiserie; un sac à ouvrage); សៀវភៅ(ឧ. publier un ouvrage; un ouvrage relié) ។ ouvrage d'art ការ្យសិល្បៈ (សំណង់ដោយដែក ឬ ស៊ីម៉ង់ តាមមាត់ថ្នល់ថ្នល់មានស្ពានជាដើម)

ouvragé,e *a.* ម.ព. ouvré

ouvrager *v.t.* ធ្វើដោយផ្ចិតផ្ចង់ (ឧ. ouvrager une pièce d'orfèvrerie)

ouvrant,e *a.* ដែលគេបើកបាន (ឧ. voiture à toit ouvrant)

ouvré,e ឬ **ouvragé,e** *a.* រចនា, ដែលធ្វើដោយផ្ចិតផ្ចង់ (ឧ. fer ouvré) ។ linge ouvré សំពត់លើកគោម ឬ ផ្កា (ផ្ទុយនឹង uni ឈាត)

ouvreau *n.m. Ind.* រន្ធក្រុងកែវរលាយ (ក្នុងឡដុតកែវ)

ouvre-boites *n.m. inv.* ប្រដាប់បើកប្រអប់

ouvrer *v.i.* ធ្វើការ ។ *v.t.* ត្បាញលើកគោម; ធ្វើការ(ឧ.ouvrer du bois)

ouvreur,euse *n.* អ្នកបើក (ផ្ទុយពីបិទ)។ *n.f.* ស្ត្រីអ្នកនាំអ្នកមើលទៅអង្គុយ (ក្នុងរោងល្ខោនឬរោងភាពយន្ត)

ouvrier,ère *n.* កម្មករ (ឧ. ouvrier à la journée)។ ouvrier spécialisé (O.S.) កម្មករឯកទេស ។ ouvrier qualifié ឬ professionnel (P.) កម្មករមានសមត្ថភាព ឬ បេះវិជ្ជាជីវៈ ។ ouvrier hautement qualifié កម្មករមានសមត្ថភាពយ៉ាងឧត្តម ។

a. la classe ouvrière វណ្ណៈកម្មករ ។ cheville ouvrière ម.ព.cheville

ouvriérisme *n.m.* កម្មករនិយម (ការនិយមថាមានតែកម្មករទេដែលអាចដឹកនាំចលនាសង្គមនិយមបាន)

ouvrir *v.t.* បើក, ចំហ (ឧ. ouvrir une armoire; ouvrir un chemin); បើកទ្វារ (ឲ្យចូល) (ឧ. ouvrir sa maison aux pauvres); ចោះ, កាត់ (ឧ.ouvrir une veine, un pâté) ។

Fig. បើក, សម្ពោធ, ផ្ដើម (ឧ. ouvrir un bal); បើក, ស្ថាបនា, សង់ (ឧ. ouvrir une école)។ ouvrir l'appétit ធ្វើឲ្យឆ្ងាញ់បាយ។ ouvrir la chasse កំណត់

សម័យបរោញ ។ ouvrir son cœur à quelqu'un សាស័ព្ទប្រាប់សុខទុក្ខ ។ ouvrir les yeux បើកភ្នែក(លែងវង្វេងស្មារតី) ។ ouvrir les yeux de quelqu'un បំភ្លឺ ។ ouvrir l'esprit បង្រៀនឲ្យអាចយល់បាន ។ ouvrir l'oreille ឬ les oreilles ផ្ទៀងត្រចៀកស្ដាប់ ។ ouvrir un passage à quelqu'un បើកផ្លូវឲ្យ ។ ouvrir la maison à ទទួលដោយរាក់ទាក់ ។ ouvrir la bourse à ឲ្យប្រាក់ ។

Com. ouvrir un compte à quelqu'un បើកគណនីឲ្យ ។ ouvrir un crédit à អនុញ្ញាតឲ្យបើកប្រាក់ ។ *Fam.* ouvrir un emprunt ខ្ចីប្រាក់ (បំពោះផ្លាកិពាល) ។

Gram. ouvrir une parenthèse បើកវង់ក្រចក ។

Mar. ouvrir un port ឬ une baie ឃើញច្រកចូលកំពង់ផែ ឬ ឆកសមុទ្រ (នៅពេលនែលចូលកាន់តែបកជិត); បើកឲ្យចូលកំពង់ផែ ឬ ឆកសមុទ្រ (អនុញ្ញាតឲ្យចូល) ។ ouvrir un port au commerce បើកកំពង់ផែ (អនុញ្ញាតឲ្យចូលឬធ្វើច្រកចូលឲ្យស្អាត) ។

Mil. ouvrir le feu ផ្ដើមបាញ់ ។

v.i. បើកទៅរក (ឧ.cette porte ouvre sur le jardin); បើកទ្វារ (ឧ. magasin qui ouvre le dimanche); បើកផ្លូវ ។

s'ouvrir *v.pr.* ផ្ដើម (ឧ. l'année s'ouvre avec un grave événement); បែរមុខទៅ; បើក; រីក ។ s'ouvrir à quelqu'un ប្រាប់គំនិត

ovaire *n.m.* អណ្ដាស័យ

oval *a.* មូលពងក្រពើ, មូលទ្រវែង ។ en oval *loc. adv.* ជារាងពងក្រពើ

ovaliser *v.t.* ធ្វើឲ្យជារាងពងក្រពើ (ឧ. cylindre ovalisé)

ovariectomie *n.f.* អណ្ដាស័យច្ឆេទតា [អវ៉-តា-សៈ-យ៉ុប-ឆេទៈ—], ការកាត់អណ្ដាស័យចោល

ovarien,enne *a.* នៃអណ្ដាស័យ

ovarité *n.f.* រោគរលាកអណ្ដាស័យ

ovation *n.f.* សព្ទសាទរ, សម្រែកសាទរ

ovationner *v.t.* ស្រែកសាទរ (ឧ.

ovationner un orateur)

ové,e *a.* ជារាងស៊ុត (ឧ. fruit ové)

oviducte *n.m.* អណ្ឌប្រណាលី

oviforme *a.* អណ្ឌសណ្ឋាន, ដែលមានរាងដូចស៊ុត

ovipare *a.&n.* អណ្ឌជ:, ដែលកើតអំពីស៊ុត

oviparité *n.f.* អណ្ឌជកំណើត

ovoïde *a.* អណ្ឌសណ្ឋាន(ដែលមានរាងជាស៊ុត) (ឧ. fruit ovoïde)

ovovipare *n.&a.* សត្វដែលពងញាស់ក្នុងផ្ទៃ (ឧ. la vipère est ovovipare)

ovule *n.m.* បព្ភាណ្ឌ [ចាប់-ផាន]

ovulaire *a.* នៃបព្ភាណ្ឌ [ចាប់- ផាន]

oxacide ឬ **oxyacide** *n.m.Chim.* អុក្សាស៊ីដ

oxydable *a.* អាចច្រែះចាប់បាន

oxydant,e *a.&n.m.* អុក្ស៊ីដសម្បត្តិ, ដែលធ្វើឲ្យច្រែះចាប់

oxydation *n.f.* អុក្ស៊ីដកម្ម, ការធ្វើឲ្យច្រែះចាប់; ការច្រែះចាប់

oxyde *n.m.* អុក្ស៊ីដ។ oxyde basique អុក្ស៊ីដបាស

oxyder *v.t.* ធ្វើឲ្យច្រែះចាប់។ s'oxyder *v.pr.* ច្រែះចាប់ (ឧ. le minium empêche le fer de s'oxyder)

oxygénation *n.f.* ការលាយនឹងអុក្ស៊ីហ្សែន

oxygène *n.m.* អុក្ស៊ីហ្សែន

oxygéné,e *a.* ដែលមានអុក្ស៊ីហ្សែន (ឧ. les composés oxygénés de l'azote)

oxygéner *v.t.* លាយនឹងអុក្ស៊ីហ្សែន

oxygénothérapie *n.f.* ការព្យាបាលដោយស្រូបអុក្ស៊ីហ្សែន

oxyure *n.f.* ពៀន



p *n.m.* អក្សរទី១៦នៃអក្ខរក្រមឡាតាំង។ *Adm.* p. (ពាក្យបំព្រួញនៃ pour) ជ. (ជំនួស)។ *Relig.* P. (ពាក្យបំព្រួញនៃ Père)

pacage *n.m.* គិណភូមិ [គិ-ណៈ-ភូម], វាលស្មៅចិញ្ចឹមសត្វ (ឧ. mettre des bestiaux au pacage)

pacager *v.t.* ឲ្យស្មៅស៊ី (ឧ. pacager des troupeaux dans les montagnes)

pacha *n.m.* ប៉ាចា, ចៅហ្វាយខេត្តក្នុងប្រទេសទួរគី

pachiderme [-chi-] *a.&n.* ពហលចម្មី [ពៈ-ហៈ-ឡៈ-ច័ម-មី] (សត្វានសត្វស្បែកក្រាស់មានដំរី-រមាសជាដើម)។ *n.m. pl.* ពហលចម្មីសត្វ

pacificateur,trice *a.&n.* សន្តិការ-ករ-ការិនី, ដែលធ្វើឲ្យមានសន្តិភាព

pacification *n.f.* សន្តិការកម្ម, ការធ្វើឲ្យមានសន្តិភាព - ឲ្យក្សេមក្សាន្ត ។ *Fig.* ការធ្វើឲ្យស្ងប់ (ឧ. pacification des esprits)

pacifier *v.t.* សន្តិការក្រិត, ធ្វើឲ្យមានសន្តិភាព, ធ្វើឲ្យក្សេមក្សាន្ត(ឧ. pacifier un pays) ។ *Fig.* ធ្វើឲ្យស្ងប់ (ឧ. pacifier les esprits)

pacifique *a.* ដែលស្រឡាញ់សន្តិភាព (ឧ. homme pacifique);ប្រកបដោយសន្តិភាព (ឧ. règne pacifique); ជាសន្តិវិធី (ឧ. moyen

pacifique)(Syn. calme, doux, paisible, placide, tranquille) (ព.ផ. belliqueux)

pacifiquement *adv.* ដោយសន្តិវិធី

pacifisme *n.m.* សន្តិនិយម (លទ្ធិនិយមថា ត្រូវដោះស្រាយអធិករណ៍រវាងប្រជាជាតិដោយសន្តិវិធី គឺការចរចា)

pacifiste *n.& a.* អ្នកសន្តិនិយម

pacotille *n.f.* លហុភណ្ឌ, ទំនិញដែលកម្មករនាវា ឬ អ្នកដំណើរមានសិទ្ធិយកតាមខ្លួន។ *Par dénigr.* ទំនិញថោកអន់

pacte *n.m.* កតិកាសញ្ញា (ឧ. faire, rompre un pacte)។ Pacte fédéral កតិកាសញ្ញាសហព័ន្ធ (រដ្ឋធម្មនុញ្ញនៃប្រទេសស៊ុីស្ស)

pactiser *v.i.* ធ្វើកតិកាសញ្ញា ។ *Par ext.* ចូលដៃ (ឧ. il ne faut point pactiser avec les scélérats); សម្រប

Pactole *n.pr.Géogr.* ឈ្មោះស្ទឹងមួយសម្បូរមាស ។ *n.m.* ប្រភពនៃធនធាន (ឧ. commerce qui est un pactole pour ceux qui le font)

paddy *n.m.* ស្រូវ

padiatrie *n.f.Méd.* ម.ក.pédiatrie

paf! *int.* ផ្ទាំង (គ្រាប់ស្វាហាយ); ផ្លុង (គ្រាប់ស្បូវធ្លាក់) ។ *n.m. Pop.* ស្បែកជើង; ស្រា។ *a. Pop.* ស្រវឹង (ឧ. vous avez été joliment paf hier)

pagaïe,pagaille ឬ **pagaye** *n.f.* *Fam.* ការច្របូកច្របល់ ។ en pagaille ដោយច្របូកច្របល់

paganiser *v.i.* កាន់សែយសាសន៍ [–សៃ-យ៉ះ-សាសា] ។ *v.t.* បញ្ចូលសែយសាសន៍ (ឧ. paganiser un peuple)

paganisme *n.m.* សែយសាសននិយម [សៃ-យ៉ះ-សា-សៈ-និះ-],(លទ្ធិអ្នកគោរពអាទិទេពច្រើន ផ្ទុយនឹងគ្រិស្តសាសនាដែលគោរពអាទិទេពតែមួយ; ភាពអ្នកមិនកាន់គ្រិស្តសាសនា)

pagayer *v.i. & t.* អុំ, ចែវ

pagayeur,euse *n.* អ្នកអុំ, អ្នកចែវ

page *n.f.* ទំព័រ (ឧ. une page blanche)។ *Par ext.* ក្បួនសន្លឹក (ឧ. déchirer une page); ទំព័រ (អត្ថបទមួយទំព័រ) (ឧ. apprendre une page par cœur); និពន្ធ (ផ្នែកអក្សរសាស្ត្រ ឬ ភ្លេង) (ឧ. les

plus belles pages de Racine) ។ *Arts graph.* belle page ទំព័រខាងស្ដាំ (នៃសៀវភៅ) ។ fausse page ទំព័រខាងឆ្វេង (នៃសៀវភៅ) ។

Fig. អំពើ; សម័យ (ឧ. les plus belles pages de l'histoire du Cambodge)។ *Fam.* être à la page ដឹងរឿងគ្រប់

page *n.m.* ប៉ាហ្ស (កុមារត្រកូលអភិជន ដែលចូលរៀនការ) ។ effronté comme un page ហ៊ានឥតអៀនខ្មាស

pageot *n.m. Pop.* គ្រែ

pagination *n.f.* លេខទំព័រសៀវភៅ

paginer *v.i.* បង់លេខទំព័រសៀវភៅ (*ill.* folioter)

pagne *n.m.* សំពត់ប៉ឹង

pagnoter (se) *v.pr. Pop.* ដេក

pagode *n.f.* វត្ត, វិហារ, រូបយក្សមាស នៃឥណ្ឌៀ ។ *a. inv.* manche pagode ដៃអាវទូលាយត្រង់កដៃ

pagodite *n.f.* ថ្មកែវម្យ៉ាង

pagodon *n.m.* វិហារតូច

pagure *n.f. m.* ខ្យងខ្ចៅប្រាណ (ម.ព. bernard-l'ermite ផង)

paie ឬ **paye** *n.f.* បៀវត្ស, ឈ្នួល (ឧ. la paie des officiers, des ouvriers); ការបើកប្រាក់ (ឧ. jour de paie)។ bulletin ឬ feuille de paie ព្រឹត្តិប័ត្រឬប័ណ្ណបើកប្រាក់។ livre de paie សៀវភៅបើកប្រាក់ ។ កូនបំណុល

paiement ឬ **payement** *n.m.* ការសងប្រាក់ (ឧ. suspendre ses paiements); ចំនួនប្រាក់សង ។ *Fig.* ការតបស្នង

païen,enne *a.* ដែលគោរពអាទិទេពច្រើន (ផ្ទុយនឹងគ្រិស្តសាសនា ដែលគោរពអាទិទេពតែមួយ)។ *Par ext.* ពាហិរជន, ជនក្រៅសាសនា (ឧ. les philosophes païens); អ្នកមិនជឿសាសនា (ឧ. jurer comme un païen)

paierie *n.f.* មន្ទីរបើកប្រាក់

paillage *n.m.* ការញាត់ចំបើង

paillard,e *a.&n.* ដែលដេកលើចំបើង; អនាចារ

paillardise *n.f.* អំពើអនាចារ; សំដីអាសអាភាស

paillasse *n.f.* ពូកញាត់ចំបើងឬស្លឹកឈើ

paillasson *n.m.* ទ្រនាប់ជូតជើង ។

Pop. មនុស្សអនាថា; ស្រីបើក; អ្នកការពារស្រីពេស្យា។ *Constr.* ចំបើងទ្រនាប់ ។ *Hort.* ចំបើងគ្របដំណាំ

paillassonnage *n.m. Hort.* ការគ្របដំណាំ; របៀបគ្របដំណាំ

paillassonner *v.t.* ក្រាប់ចំបើង ។ *Hort.* គ្របចំបើង (ឧ. paillassonner des semis)

paille *n.f* ចំបើង។ *Techn.* ស្នាមស្អុប (ស្នាមជាំនៃលោហធាតុដែលសិតមិនជិតសាច់) ។ paille de fer ចំឡៀរដែក (សម្រាប់ដុសខាត់រាបផ្ទះ) ។ être sur la paille ក្រណាស់ ។ feu de paille ភ្លើងចំបើង ឬ ភ្លើងសម្រាម; ចិត្ត ឬ ការប្រឹងប្រែងដែលមិនបានយូរ ។ homme de paille មនុស្សពោលម្សៀត; អ្នកឈរឈ្មោះ ។ tirer à la courte paille បួល(ដោយហូតចំបើង)(ម.ព. courte paille ក្នុងពាក្យ court ផង) ។ rompre la paille រំលោយកិច្ចសញ្ញា; ទាស់គ្នា។ *a. inv.* លឿងព្រលែត(ដូចចំបើង)(ឧ. ruban paille)

paillé *n.m.* ក្រដាំចំបើង, ដីចំបើងមិនទាន់ស្អុយ

paillé,e *a.* លឿងព្រលែត (ដូចចំបើង); ស្អុប(ដែលសិតមិនបានជិតស្និទ្ធ) (ឧ. fonte paillée)

pailler *n.m.* កន្លែងដាក់ចំបើង

pailler *v.t.* ក្រាលចំបើង; គ្របចំបើង (ឧ.pailler des semis); រុំ ឬញាត់ចំបើង (ឧ. pailler une chaise)

pailletage *n.m.* ការប្រោះកំទេចមាស

pailleté,e *a.* ដែលមានប្រោះកំទេចមាស (ឧ. habit pailleté)

pailleter *v.t.* ប្រោះកំទេចមាស (ឧ. pailleter une jupe de danseuse); មានសភាពដូចប្រោះកំទេចមាស (ឧ. les grains de jais qui paillettent un corsage)

pailleteur *n.m.* អ្នករែងមាស(ក្នុងស្ទឹង)

paillette *n.f.* កំទេចមាសលាយនឹងខ្សាច់ស្ទឹង ឬ ទន្លេ; កំទេចលោហធាតុ ឬ កែវដែលគេប្រោះបន្ថែមលើសំពត់

pailleux,euse *a.* ស្អុប, មិនជិតស្និទ្ធ (លោហធាតុសិត) (ឧ. métal pailleux) ។ *Agr.* fumier pailleux ក្រដាំចំបើង

paillis *n.m.* ចំបើងក្រាលជើង (ចំបើងសម្រាប់ក្រាលទ្រផ្លែឈើផងឲ្យដីត្រជាក់ផង)

paillon *n.m.* កំទេចមាសគ្រាប់ធំ ។ *Pop.* ការផិតក្បត់ ។ *Com.* ព្រួលចំបើងស្រោបដបស្រា ។ *Techn.* កំទេចស្ពាន់ប្រោះបន្ទំលើសំពត់ (ឡាភ្ញី)

paillot *n.m.* ទ្រនាប់គ្រែទារក

paillote *n.f.* ផ្ទះស្បូវ, ផ្ទះស្លឹក; ស្បូវ, ស្លឹក

pain *n.m.* នំប៉័ង ។ *Par ext.* បាយ, អាហារ (ឧ. gagner son pain à la sueur de son front) ។ *Par anal.* ដុំ, ផែន (ឧ. pain de sucre, de cire, de savon) ។ *Fig.* អាហារ (ខាងផ្លូវចិត្ត) (ឧ. l'espérance est le pain du malheureux) ។

Loc. div. pain quotidien ការចិញ្ចឹមជីវិតរាល់ថ្ងៃ (ឧ. demander au travail son pain quotidien) ។ pain sec នំប៉័ងទទេ ឬនំប៉័ងសាប (ទណ្ឌកម្មដាក់ឲ្យក្មេងស៊ីនំប៉័ងគ្មានម្ហូប) ។ *Fig.* pain cuit ការផែលគេធ្វើបម្រុងទៅអនាគតកាល ។ avoir son pain cuit ឬ du pain sur la planche មានបាយពេញឆ្នាំង; លែងភ័យអំពីការអត់ឃ្លាន ។ *Fig.* morceau de pain បាយមួយចាន; តម្លៃតិចណាស់ (ឧ. donner une terre pour un morceau de pain) ។ long comme un jour sans pain យូរហើយអផ្សុកពេក ។ bon comme le pain ល្អពេកណាស់ ។ demander ឬ mendier son pain សុំបាយគេស៊ី ។ mettre le pain à la main de quelqu'un ឲ្យបាយស៊ី ។ ôter le pain de la main de quelqu'un ដេះបាយពីមាត់ ។ s'ôter le pain de la bouche pour quelqu'un ដេះបាយពីមាត់ឯងឲ្យទៅគេ ។ promettre plus de beurre que de pain សន្យាហួសហេតុ ។ il ne vaut pas le pain qu'il mange ពិស៊ីបង់បាយ (ខ្ជិលណាស់, គ្មានបានការអ្វីសោះ) ។ manger un pain trempé de larmes ស៊ីបាយស្រួបទឹកភ្នែក (រងទុក្ខខ្លាំង) ។ pain d'amertume ហេតុឲ្យកើតទុក្ខ (ឧ. la vérité n'est plus pour eux qu'un pain d'amertume) ។ faire passer ឬ faire perdre le goût du pain à

quelqu'un សម្លាប់ ។ manger son pain à la fumée du rôt មើលគេលេងសប្បាយ (ប៉ុន្តែមិនបានលេងខ្លួនឯង) ។ manger de plus d'un pain ធ្លាប់ម្ហូប; ធ្វើឡើងប្លែក ។ emprunter un pain sur la fournée ឡប់ព្រួញណាមុនរៀបរកពាហ៍ពិពាហ៍ ។

Dr. cout. être pain de père et de mère ឬ être en pain នៅក្រោមអំណាចបិតា ។ être hors pain ផុតអំពីអំណាចបិតា ។

Mar. pain de sucre ស្លោក (ពេលសមុទ្ររំខ្ទល)

pair,paire *a.* ស្មើ, ដូច (ឧ.être pair et compagnon avec quelqu'un) ។ *Math.* គត់គូ ។ nombre pair ចំនួនគត់គូ (ម.ព. nombre សេស) ។

n.m. តម្លៃស្មើគ្នានៃរូបិយវត្ថុរបស់ប្រទេសពីរ; តម្លៃរូបិយវត្ថុ ។ être au pair dans une maison ធ្វើការយកតែបាយនឹងទីណែកក្នុងផ្ទះមួយ ។

n.m. pl. អ្នកស្មើសក្តិគ្នា (ឧ. être jugé par ses pairs) ។

Loc.adv. de pair ព្រមគ្នា; ជាមួយគ្នា; ស្មើមុខគ្នា ។ hors de pair ឬ hors pair ពេប្រដូចមិនបាន, គ្មានស្មើ

paire *n.f.* គូ (ឧ. une paire d'amis; une paire de pigeons); នឹម (ឧ. une paire de bœufs) ។ une paire de ciseaux កន្ត្រៃមួយ

pairement *adv.* ដោយស្មើ ឬ ដូចគ្នា

paisible *a.* ស្លូត; ស្ងប់ (ឧ. homme paisible); ក្សេមក្សាន្ត, សុខសាន្ត (ឧ. vie paisible) ។ *Dr.* គ្មានគេអំពល់ (ឧ.paisible possesseur d'un héritage) (ព.ផ. agité, perturbé, troublé)

paisiblement *adv.* យ៉ាងស្លូត,ដោយសុខសាន្ត (ឧ. jouir paisiblement de sa fortune)

paissance *n.f.* ការស៊ីស្មៅ (សត្វ) (ឧ. troupeaux trouvés en paissance dans une forêt)

paisseau *n.m.* ម.ព. échalas

paître *v.t.* ស៊ី (ស្មៅ) (ឧ. paître l'herbe) ។ *v.i.* បង្វាស្មៅ (ឧ. mener paître; faire paître) ។ *Fig. & Fam.* envoyer quelqu'un paître បណ្ដេញចេញ

ដោយចោះចោក (ទ្ធិបនើញសត្វ) ។

se paître *v.pr.* ស៊ី (ឧ. les aigles se paissent de viande) ។ *Fig.* ស៊ី (គិតការកើតប្រយោជន៍) (ឧ. se paître de chimères) (ម.ព. se repaître ផង)

paix *n.f.* សន្តិភាព; សន្ធិសញ្ញាសន្តិភាព (ឧ. ratifier la paix); ការស្រុះស្រួលនឹងគ្នា (ឧ. vivre en paix avec ses voisins); ភាពសុខសាន្ត(គ្មានគេបៀតបៀន)(ឧ. laisser en paix); ភាពស្ងប់; ភាពស្ងាត់ (ឧ. paix des champs); ភាពស្ងប់ក្នុងចិត្ត (ឧ. être en paix avec sa conscience) ។ paix armée សន្តិភាពដោយប្រុងប្រៀបចំពាំង។ faire la paix ជានឹងគ្នាវិញ ។

Int. ស្ងៀម! (ពាក្យស្រែកឃាត់កុំឲ្យនិយាយ)

pal *n.m.* ឈើអណ្តោត (ឈើសម្រួច); ទោសដោតដោយឈើសម្រួច (*pl.* des pals)

palabre *n.f.* សន្និសីទជាមួយនឹងនាយជនជាតិស្បែកខ្មៅ; សន្ទនាឬជាជំពាក់ជារឿង

palabrer *v.i.* ធ្វើសន្និសីទជាមួយនឹងនាយជនជាតិស្បែកខ្មៅ; សន្ទនា, ជជែកគ្នាលេង

palace *n.m.* មហាសណ្ឋាគារ

palais *n.m.* វាំង, វិមាន, គេហស្ថានល្អវិសេស; សាលាជម្រះក្តី; មន្ទីរសភា ។ palais de justice យុត្តិវិមាន, វិមានតុលាការ ។ palais nationaux ជាតិវិមាន

palais *n.m.* ពាលុ, ក្រអូមមាត់, ពិតានមាត់ ។ *Fig.* ការដឹងរសជាតិ (ឧ. avoir le palais fin)

palan *n.m.* រ៉ក, កៅឡាក់, ប្រដាប់យោងអីវ៉ាន់ឡើងចុះ

palanche *n.f.* ដងរ៉ែក

palançon *n.m.* ឈើមេជញ្ជាំងគោម័យ (ជាយអាចម៍គោលាយដីនឹងចំបើង)

palangre *n.f.* ខ្សែរនេងសន្ទូច

palanque *n.f. Fortif.* របងបម្រុង (សម្រាប់ការពារសត្រូវ)

palanquée *n.f. Mar.* ហិបឬទំនិញដែលលើកដោយរ៉ក

palanquer *v.t.Mar.* លើកដោយរ៉ក។ *Fortif.* បោះរបងបម្រុង (ឧ. palanquer une porte).

palanquin *n.m.* អង្រឹងស្នែង

palatal,e,aux *a.* ពាលុជៈ (ចំពោះ

សម្លេងដែលកើតត្រង់ពិតានមាត់)

palatin,e *a.* ដែលមាននុខងារក្នុងវាំង។ *n.m.* ឧបរាជប្រទេសហុងគ្រី; ចៅហ្វាយខេត្តនៅប្រទេសប៉ូឡូញ

palatin,e *a.* នៃក្រអូមមាត់ (ឧ. voûte palatine)

pale *n.f.* ស្លាបព្រាវ, ស្លាបចែវ; ស្លាប ស្លាបចក្រ; ស្លាបកង្ហារ; សន្ទះបិទទឹក

pâle *a.* ស្លាំង (ឧ. figure pâle); ស្រអាប់ (មិនសូវមានរស្មី) (ឧ. le soleil est pâle en hiver); ព្រលែត (ឧ. jaune pâle) (ម្យ. blafard, blême, incolore, livide, terne)

palée *n.f.* ជួរបង្គោល, ជួរបង្រឹង

palefrenier *n.m.* អស្សបាល [អះ-ស្សះ-], អ្នកថែទាំសេះ

palefroi *n.m.* សេះមហាក្សត្រិយ៍ សម្រាប់ក្បួនពល

paléographe *a.&n.* បុរាណលេខវិទូ, អ្នកវិទ្យាសាស្ត្រខាងអានអក្សរបុរាណ

paléographie *n.f.* បុរាណលេខសាស្ត្រ, វិទ្យាសាស្ត្រខាងអានអក្សរបុរាណ

paléographique *a.* នៃបុរាណលេខសាស្ត្រ, នៃវិទ្យាសាស្ត្រខាងអានអក្សរបុរាណ

paléontologie *n.f.* បាសាណភូតវិទ្យា [ប៉ា-]

paléontologique *a.* នៃបាសាណភូតវិទ្យា [ប៉ា-]

paléontologiste ឬ **paléontologue** *a.&n.* បាសាណភូតវិទូ [ប៉ា-]

paléozoïque *n.m.& a.* បឋមស័ក (ម្យ. ère primaire)

paleron *n.m.* *Bouch.* សាច់ស្មា (គោ, ជ្រូក)

palestinien,enne *a.&n.* នៃប្រទេសប៉ាឡេស្ទីន

palestre *n.f.* ទីហាត់ប្រាណជាសាធារណៈ (ក្នុងបុរាណកាល); វិធីហាត់ប្រាណ

palet *n.m.* កាស, មេហាប៉ុក

paletot *n.m.* អាវពុក

palette *n.f.* បន្ទះក្តារ ឬ ចានសម្រាប់លាយថ្នាំពណ៌; បន្ទះក្តារ (សម្រាប់កូរវក់ជាដើម); ស្លាបកង្ហារ ឬ រហាត់ទឹក។ *Bouch.* ស្មា (នៃចៀម, ជ្រូក)

palétuvier *n.m.* ដើមកោងកាង

pâleur *n.f.* សម្បុរស្លាំង-ព្រលែត (ឧ. pâleur du teint)

pali *n.m.* មគធភាសា, ភាសាបាលី

palier *n.m.* ថ្នាក់ជណ្តើរ; ទ្រូងផ្លូវ ។

Fam. ជាន់, ថ្នាក់ (ឧ. procéder par paliers)។ *Aéron.* vol en palier ការហោះនឹងកំពស់(ស្មើកំពស់)

palière *a.f.* *Constr.* marche palière កាំលើនៃជណ្ដើរ

palingénésie *n.f.* ការរស់ឡើងវិញ

palingénégique *a.* នៃការរស់ឡើងវិញ (ឧ. théorie palingénégique)

palinodie *n.f.* ការប្រែកក; ការដកពាក្យសំដី; ការផ្លាស់មតិ (ឧ. une lamentable palinodie)។ chanter la palinodie បដិសេធឬមិនទទួលស្គាល់សំដីរបស់ខ្លួន

pâlir *v.i.* ឡើងស្លាំង (ឧ. pâlir de colère); ឡើងស្រអាប់ (ឧ. la lumière pâlit)។ *Fig.* ខ្វះជាតិតម្លៃ (ឧ. son œuvre pâlit à côté de la vôtre)។ pâlir sur ses livres រៀនគ្មានឈប់ឈរ។ son étoile pâlit រាសីធាត់ចុះហើយ (ជិតអស់លាភ)។ faire pâlir ធ្វើឲ្យខ្មាស; *au fig.* បំបិទបំបាំង, លាក់ (មិនបញ្ចេញ)

palis [-li] *n.m.* បង្គោល; របងបង្គោល

palissade *n.f.* របងបង្គោល

palissader *v.t.* ព័ទ្ធរបងបង្គោល (ឧ. palissader un jardin); ការធ្វើរបងបង្គោល (ឧ. palissader une haie)

palissage *n.m.* ការចងមែកឈើភ្ជាប់នឹងជញ្ជាំង

pâlissant,e *a.* ដែលឡើងស្លាំង; ដែលស្រទំ

palisser *v.t.* ចងមែកឈើភ្ជាប់នឹងជញ្ជាំង

palisson *n.m.* ប្រដាប់បន្ទន់ស្បែក

palissonner *v.t.* បន្ទន់ស្បែក

palissonneur *n.&a. m.* ជាងបន្ទន់ស្បែក

palladium [-dyom] *n.m.* *Fig.* គ្រឿងធានា; គ្រឿងការពារ (ឧ. les lois sont le palladium de la société)

palladium *n.m.* (គ.ស.) ប៉ាឡាដ្យូម (លោហធាតុពណ៌ស)

palliatif,ive *a.* ដែលឲ្យធូរស្បើយមិនបានជាសះស្បើយ (ឧ. remède palliatif); ជាបណ្ដោះអាសន្ន។ *n.m.* ឧបាយជាការបណ្ដោះអាសន្ន (ឧ. un emprunt n'est jamais qu'un palliatif)

pallier *v.t.* កែក្លែង (ទោសកំហុសមិនល្អ); អត់ទោស (ឧ. essayer de pallier

une faute) ; ធ្វើឲ្យស្រាកឬបង្ហន់ ឬបន្ថយគ្រា (ឧ. pallier un mal); ទប់ទល់ (ឧ. pallier un inconvénient) (ខ្លះកាលគេប្រើ pallier à)

palma-christi *n.m.* ល្ហុងខ្មែរ (ពាក្យសាមញ្ញ)

palmaire *a.* នៃបាតដៃ (ឧ. muscle palmaire)

palmarès *n.m.* ព្រហ្មទេយ្យ, បញ្ជីអ្នកបានរង្វាន់

palmarium *n.m.* ទីសួនតាលជាតិ (នៅប្រទេសត្រជាក់)

palmature *n.f.* ភាពម្រាមដៃជាប់គ្នា

palme *n.f.* តាលប័ត្រ, ស្លឹកត្នោត; ត្នោត (ឧ. vin de palme); ប្រដាប់ពាក់ជើងហែលទឹក (ឧ. les palmes permettent la nage sans l'aide des bras)។ *Fig.* remporter la palme ឈ្នះក្នុងការប្រយុទ្ធឬក្នុងការដណ្ដើម ។ la palme du martyre ការស្លាប់ដោយជំនឿ ។ *Mil.* តាលប័ត្រ (បន្ទោងគ្រឿងឥស្សរិយយស)។ palme de l'Académie តាលប័ត្រនៃបណ្ឌិតសភា

palmé,e *a.Bot.* ដែលមានស្លឹក ឬ ម្រាមដៃស្លឹកដូចតាលប័ត្រ។ *Zool.* ដែលមានម្រាមជាប់គ្នា (ដូចទា-ក្ងាន។ល។)

palmer *v.t.* *Techn.* ដំក្បាលម្ជុលឲ្យ សំប៉ែត (មុននឹងចោះរន្ធ)

palmeraie *n.f.* តាលវ័ន, កន្លែងដាំត្នោត

palmette *n.f.* ភ្ញីតាលប័ត្រ

palmier *n.m.* តាលព្រឹក្ស [តា-ល៉ះ-]។ palmier à sucre ដើមត្នោត ។ *n.m. pl.* តាលកុល [តា-ល៉ះ-] (សន្តានត្នោត-ដូង ។ល។)

palmipède *a.* តាលបាទ (ដែលមានម្រាមជើងជាប់គ្នាដូចទា - ក្ងាន) ។ *n.m. pl.* តាលបាទបក្សី (សន្តានបក្សីមានម្រាមជើងជាប់គ្នាដូចទា-ក្ងាន)

palmiste *n.m.* ដើមឈើពួកដូង-ស្លា ។ល។

palmite *n.m.* ពមត្នោត

palmure *n.f.* ស្បែកចង្កេះជើងបក្សី

palombeឬ**palonne** *n.f.* កំប្រុក, ពពូល

pâlot,otte *a.* ស្លាំង ឬ ព្រលែតបន្តិច

palpable *a.* អាចស្ទាបបាន ។ *Fig.* ច្បាស់លាស់(ឧ. preuves solides et palpables)

palpation *n.f.* ការស្ទាប (ឧ. la palpation est l'une des principales investigations

de l'examen clinique)

palpébral,e,aux *a.* នៃត្របកភ្នែក (ឧ. artères palpébrales)

palper *v.t.* ស្ទាប, ពិនិត្យដោយដៃ ។ *Fig.* & *Fam.* ទទួលប្រាក់

palpitant,e *a.* ញាប់ញ័រ (ឧ. avoir le cœur palpitant) ។ *Fig.* & *Fam.* គួរឲ្យចាប់អារម្មណ៍ក្រៃពេក, ដែលគួរឲ្យរំភើប (ឧ. roman palpitant d'intérêt) ។ *n.m. Pop.* បេះដូង

palpitation *n.f.* ដំណើរញាប់ញ័រ, ដំណើរញ័របេះដូង (ឧ. être sujet aux palpitations)

palpiter *v.t.* ញាប់ញ័រ; កម្រើក(បេះដូង) (ឧ. tant que le cœur palpite, on n'est pas mort); ញាក់ (សាច់សត្វដែលគេទើបនឹងសម្លាប់) ។ *Fig.* រំភើបខ្លាំង (ឧ. palpiter de joie)

palplanche *n.f.* ក្ដារទប់ដី (ក្នុងអណ្ដូងរ៉ែជាដើម)

paltoquet *n.m. Fam.* មនុស្សព្រៃ, មនុស្សកម្រោល; មនុស្សចោលម្សៀត

paludarium [—ryom] *n.m.* ផើង ឬកន្លែងចិញ្ចឹមមណ្ឌុកសត្វ

paludéen,enne *a.* នៃជលដ្ឋាន [-ជល់-ល័ត—] (នៃដីទំនាបដក់ទឹក) (ឧ. plante paludéenne) ។ fièvre paludéenne គ្រុនចាញ់

paludier *n.m.* កម្មករស្រែអំបិល

paludisme *n.m.* ជម្ងឺគ្រុនចាញ់ (*ut.* malaria)

palustre *a.* ដែលរស់នៅ ឬ ដុះក្នុងជលដ្ឋាន-ក្នុងទីទឹកដក់ (ឧ. coquillages palustres); នៃគ្រុនចាញ់ (ឧ. fièvre palustre)

pâmer (se) *v.pr.* ស្លុត, ចំប្រប់, ខ្ទត់ ។ se pâmer de rire, de joie សើច ឬ សប្បាយហួសពេក

pâmoison *n.f.* ដំណើរស្លុតឬខ្ទត់; ភាពស្លុតឬខ្ទត់ (ឧ. tomber en pâmoison)

pampa *n.f.* វាលស្មៅធំ (នៅអាមេរិកខាងត្បូង)

pamphlet *n.m.* និពន្ធន៍ដៀលត្មះ (ច្រើន ប្រើខាងនយោបាយឬសាសនា)

pamphlétaire *n.m.* អ្នកនិពន្ធដៀលត្មះ

pampille *n.f.* ព្យួចខ្សែរសយ

pamplemousse *n.m.* ឬ *f.* ក្រូចថ្លុង

pamplemoussier *n.m.* ដើមក្រូចថ្លុង

pampre *n.m.* បង្កាមស្លឹកនិងផ្លែទំពាំង-

ជាយធ្លរ។ *Archit.* ក្បឹងទំពាំងជាយធ្លរ

pan *n.m.* ជាយ, ផ្ទាំង

pan! *int.* ប៉ុង!(ខទាតសព្ទ)

panacée *n.f.* ឱសថសព្វគុណ [-សប់-ពៈ-]. ថ្នាំព្យាបាលគ្រប់យ៉ាង

panachage *n.m.* ការលំអដោយសំណុំស្លាប; ការលាយឡំ

panache *n.m.* សំណុំស្លាបបក្សី; អ្វីៗដែលបក់រំភើយ (ដូចសំណុំស្លាប) (ឧ. panache de fumée)។*Fig.*អ្វីៗដែលរើត (ឧ. aimer le panache)។ faire panache ព្រឡប់ (រថយន្ត)

panaché,e *a.* វណ្ណរឹកគិ,ដែលចម្រុះពណ៌ (ឧ.rose panachée)។*Fam.*រឹកគិ, ដែលលាយឡំ (ឧ. style panaché)។ *Culs.* glace panachée ទឹកកកចម្រុះក្លិន។ légumes panachés បន្លែលាយចម្រុះ

panacher *v.t.* តែងលំអដោយសំណុំស្លាប(ឧ.panacher un casque); លំអដោយពណ៌ចម្រុះ (ឧ.panacher des œillets)។*Fig.* បញ្ចូលចម្រុះលើប័ណ្ណតែមួយនូវឈ្មោះបេក្ខជនគណបក្សខុសគ្នា។se panacher *v.pr.* មានពណ៌ចម្រុះ

panachure *n.f.* បន្ទះពណ៌ផាក់លើផ្ទៃពណ៌ខុសគ្នា

panade *n.f.* បបរនំប៉័ង ប៉ុរីងទឹកដោះគោ។ *Pop.* ភាពក្រខ្សត់

panama *n.m.* មួកប៉ាណាម៉ា (មួករបេកម្យ៉ាង)

panaméricain,e *a.* នៃប្រទេសអាមេរិកទាំងពីរ

panaméricanisme *n.m.* លទ្ធិហាមមិនឲ្យជនជាតិដទៃ លូកដៃក្នុងកិច្ចការប្រទេសអាមេរិក

panarabisme *n.m.* អារ៉ាបនិយម(លទ្ធិរួបរួមប្រទេសប្រើភាសាអារ៉ាប)

panard,e *a.* ដែលមានជើងកែក (សម្លេះមកក្រៅ)(ឧ.jument panarde)។ *n.m. Pop.* ជើង

panaris [-ri] *n.m.* ដំបៅព្រចកជើងឬព្រចកដៃ ។ *Par ext.* ដំបៅម្រាម

panca,panka ឬ **punka** [pon –] *n.m.* ផ្ទាំងសំពត់ព្យួរទាញធ្វើជាផ្លិត

pancalisme *n.m.* *Phil.* សោភ័ណនិយម

pancarte *n.f.* ការប្រកាស; ប័ណ្ណប្រកាស, ប័ណ្ណសញ្ញា

pancosmisme *n.m.* លោកធាតុនិយម

pancrace *n.m.* វិធីហាត់ប្រាណចម្រុះចំបាប់នឹងប្រដាល់

pancratiaste *n.m.* អ្នកកីឡាហាត់ចម្រុះចំបាប់នឹងប្រដាល់

pancréas *n.m.* លំពែង (អាការៈក្នុងខ្លួន)

pancréatique *a.* នៃលំពែង

pancréatite *n.f.* រោគរលាកលំពែង

pandèmes *n.f. pl.* បុណ្យមានជប់-លៀងជាសាធារណៈ

pandémie *n.f.* ការឆ្លងរោគអស់មួយទ្វីប ឬ អស់ទាំងផែនដី

pandémonium *n.m.* ឋានទីជានរក។ *Fig.* នរក (ទីដែលមានតែការពុករលួយនឹងការប្រឡូកប្រឡល់)

pandit *n.m.* បណ្ឌិត

pandore *n.m.Fam.* អាវុធហត្ថ

pandour *n.m.Fig.* មនុស្សកម្រោល; ចោរ

pané,e *a.* ដែលស្បាត់លំអិតនំប៉័ង (ឧ. cotelette panée)

panégyrique *n.m.* បសំសាកថា [ប៉ៈ-ស័ង-សៈ—], សុន្ទរកថាសរសើរ ។ *Par ext.* ការសរសើរហួសហេតុ (ឧ. faire le panégyrique d'un ami)

panégyriste *n.m.* អ្នកសរសើរ

paner *v.t.* ស្បាត់ដោយលំអិតនំប៉័ង

panerée *n.f.* បំណុះកញ្ជើ ឬ កញ្ចែ (ឧ. une panerée de fruits)

paneterie *n.f.* កន្លែងចែកនំប៉័ង

panetier *n.m.* អ្នកចែកនំប៉័ង

panetière *n.f.* កូនបញ្ញាកស្ពាយ; ទូនំប៉័ង

paneton *n.m.* កញ្ច្រែងដាក់ម្សៅនំប៉័ង

pangermanisme *n.m.* អាល្លឺម៉ង់-និយម (លទ្ធិប្រមូលជនជាតិអាល្លឺម៉ង់)

pangermaniste *a.* នៃអាល្លឺម៉ង់និយម, នៃលទ្ធិប្រមូលជនជាតិអាល្លឺម៉ង់។ *n.* អ្នកអាល្លឺម៉ង់និយម (អ្នកកាន់លទ្ធិប្រមូលជនជាតិអាល្លឺម៉ង់)

pangolin *n.m.* ពង្រូល

panicule *n.f. Bot.* ចង្កោម, ភួរ

paniculé,e *a Bot.* ជាចង្កោម, ជាភួរ

panier *n.m.* កញ្ចែ, កញ្ច្រែង, កញ្ជើ, ល្អី, កន្ត្រក; អ្វីៗដែលដាក់ក្នុងកញ្ចែ-កញ្ច្រែង ។ល។ (ឧ. panier de fruits); កញ្ច្រែង (កីឡាបាល់បោះ)។ faire un panier បោះបាល់ចូលមួយ ។ panier à ouvrage កញ្ច្រែងដេរ (សម្រាប់ដាក់ប្រដាប់ដេរពាក់) ។ *Fig.&Fam.* le dessus du panier អ្វីៗដែលប្រសើរបំផុត ។ panier percé កញ្ជើធ្លុះ (មនុស្ស

កញ្ចះកញ្ច្រែយ)។ panier de crabes ក្រុមអ្នកព្យាបាទគ្នា

panifiable *a.* អាចធ្វើនំប៉័ងបាន (ឧ. farine panifiable)

panification *n.f.* ការធ្វើនំប៉័ង (ធ្វើម្សៅឡើងទៅជានំប៉័ង)

panifier *v.t.* ធ្វើនំប៉័ង (ធ្វើម្សៅឡើងទៅជានំប៉័ង)

panique *a.* អហេតុកភ័យ (ឧ.terreur panique) ។ *n.f.* អហេតុកភ័យ (ឧ. jeter la panique)

panislamisme *n.m.* អ៊ីស្លាមនិយម (លទ្ធិរួបរួមជនជាតិកាន់សាសនាអ៊ីស្លាម)

panka *n.m.* ម.ព. panca

panne *n.f.* សាច់ខ្លាញ់ជ្រូក

panne *n.f.* ទាញស្បែក (ស្បែកជ្រូក ឬ ស្បែកសត្វផ្សេងៗ)

panne *n.f.Mar.* ក្ដោងនាវា។ mettre en panne ទាញក្ដោងរបស់នាវា ។ panne de nuages ផ្ទាំងពពកនាជើងមេឃ ។ និរណ៍ខូច ឬ គាំង (គ្រឿងយន្ត) (ឧ. tomber en panne)។ être dans la panne កំពុងតែក្រលំបាក

panne *n.f.Techn.* មុខញញួរ (ម៉ែកខាងសម្រាប់គំ)។ *Constr.* ធ្នឹម, ប្រឡង

panné,e *a.&n.Pop.* ដែលគ្មានប្រាក់ ឬគ្មានធនធាន

panneau *n.m.* បន្ទះ; ចម្រៀកសំពត់ (សម្រាប់ប៉ះពង្រីកសំលៀកបំពាក់) (ឧ. panneau de jupe)។ panneau de signalisation ផ្ទាំងសញ្ញា; បន្ទះ (សម្រាប់ទាក់ទន្សាយជាដើម) ។ *Fig.* tomber ឬ donner dans le panneau ជាប់អន្ទាក់គេ (ឲ្យគេបោកបញ្ឆោតបាន)

panneautage *n.m.* ការដាក់បន្ទះ (ឧ. le panneautage est un délit)

panneauter *v.t.* ដាក់បន្ទះ

panneauteur *n.m.* អ្នកដាក់បន្ទះ

panneton *n.m.Techn.* ធ្មេញកូនសោ (កាតកូនសោដែលបង្វិលគន្លឹះសោ)

panoplie *n.f.* អាវុធតាំងនៅជញ្ជាំង។ *Par ext.* ប្រដាប់លេងដាក់លើផ្ទាំងក្រដាសក្រាស់

panorama *n.m.* ទិដ្ឋទស្សន៍, ទេសភាពធំទូលាយ

panoramique *a.* នៃទិដ្ឋទស្សន៍, នៃទេសភាពធំទូលាយ; ដែលឲ្យមើលឃើញធំទូលាយ (ឧ. vue panoramique)

panoufle *n.f.* បន្ទះស្បែកចៀមទាំងរោម (សម្រាប់ធ្វើខ្សែស្បែកជើងឈើ)

pausage *n.m.* ការប្រោសសំអាតរោមសត្វ (ឲ្យជ្រះថ្លាល); ការថែទាំសត្វ

panse *n.f.* ក្រពះធំ (ក្រពះទី១នៃសត្វទំពាអៀង) ។ *Fam.*ពោះ, កំប៉េង (សណ្ឋានពោងនៃផបអក្សរខ្លះ មានអក្សរ a , b, p, q ជាដើម)

pansement *n.m.* ការរុំដំបៅ (ឧ. les pansements doivent être faits avec une propreté minutieuse)

panser *v.t.* រុំដំបៅ, រុំរបួស; ប្រោសសំអាតសត្វ; ថែទាំសត្វ (ឧ. panser un cheval, une vache)

panslavisme *n.m.* លទ្ធិចង់បញ្ចូលពួកជាតិស្លាវមកក្នុងប្រទេសរុស្ស៊ី

panslaviste *n.* អ្នកកាន់លទ្ធិចង់បញ្ចូលពួកជាតិស្លាវមកក្នុងប្រទេសរុស្ស៊ី ។ *a.* នៃលទ្ធិចង់បញ្ចូលពួកជាតិស្លាវមកក្នុងប្រទេសរុស្ស៊ី

pansu,e *a.&n.* ដែលមានពោះកំប៉ោង; កំប៉ោង (ឧ. bouteille pansue)

pantagruélique *a.* សំបើម (ឧ. repas pantagruélique)

pantalon *n.m.* ខោវែង

pantalonnade *n.f.* ការកំប្លែង ។ *Par ext.* ឧបាយបោះខ្លួនដ៏គួរឲ្យអស់សំណើច

pante *n.m. Arg.* មនុស្ស, ជន

pantelant,e *a.* ស្ទើតស្ទក់, ញាប់ញ័រ, ប៉ិត្តិតប៉ិត្តក់ ។ chair pantelante សាច់រងាល (សាច់សត្វទើបនឹងសម្លាប់នៅញ័រនៅឡើយ)

pantenne ឬ **pantène** *n.f. Chass.* ម.ព. pantière ។ en pantenne *loc. adv. Mar.* ដោយប្រប៉ូកប្រប៉ល់ ។ vergues en pantenne សាកែ្តងលើកឡើងជាមរណសញ្ញា

panteler *v.i.* ញាប់ញ័រខ្លាំង

panthéon *n.m.* ទេវហាន (គ្រឹះស្ថានឧទ្ទិសចំពោះអាទិទេព); វិមានសម្រាប់បញ្ចុះសពវីរបុរស; អាទិទេព (របស់ជនជាតិ ឬ សាសនាមួយ) (ឧ. panthéon védique)

panthère *n.f.* ខ្លារខិន

pantière *n.f.* សប់ (ជាក់បញ្ឆោតទាក់បក្សីហើរ)

pantin *n.m.* រូបអាយ៉ង, តុក្កតា ។ *Fig.* អ្នកនិយាយធ្លាក់ធ្លាជើង (គួរឲ្យអស់សំណើច); មនុស្សសាក់

pantographe *n.m.* ប្រដាប់គូសចម្លងពង្រីកឬពង្រួមគំនូរ

pantoire *n.f.Mar.* ខ្សែទំពក់ (សម្រាប់ផ្ទុកលើកអីវ៉ាន់)

pantois,e *a.* ស្រឡាំងកាំង, ភាំងកាំង (ឧ. rester tout pantois)

pantomètre *n.m.* ប្រដាប់វាស់មុមនឹងគូសបន្ទាត់សំយ៉ុងលើផែនដី

pantomime *n.f.* មូកាសា, កាសាត; ការធ្វើដៃធ្វើជើង; ការលេងរឿងដោយគ្មាននិយាយ (គ្រាន់តែធ្វើដៃជើង)

pantomimer *v.t.* ធ្វើដៃធ្វើជើង

pantouflard *n.m.* *Fam.* អ្នកមិនសូវចេញពីផ្ទះ, អ្នកចូលចិត្តនៅតែផ្ទះ

pantoufle *n.f.* ស្បែកជើងផ្ទាត់, ស្បែកជើងពាក់ក្នុងផ្ទះ ។ en pantoufles ដោយពាក់ស្បែកជើងផ្ទាត់ (ឧ. sortir en pantoufles); ដោយប្រកាន់ឥរិយាបថស្រួល, ដោយមិនរវែងខ្លួន (ឧ. faire son métier en pantoufles)

pantouflier,ère *n.* អ្នកធ្វើ ឬ លក់ស្បែកជើងផ្ទាត់

panure *n.f.* កំទេចនំប៉័ងរោយលើសាច់

panzer *n.m.* (ព.អាល្លឺម៉ង់) រថក្រោះ ។ panzerdivision កងពលរថក្រោះ

paon [pan] *n.m.* មយូរ, ក្ងោកឈ្មោល (cri: le paon criaille, braille); មនុស្សអួតស្ងាបអុតៗ (ដូចស្ទាបក្ងោក) ។ *Fig.* មនុស្សឆ្មើងកំអួត ។ se parer des plumes du paon យករបស់គេមកអួត

paonne [pan'] *n.f.* មយូរី, ក្ងោកញី

paonneau [pa-nô] *n.m.* កូនក្ងោក

paonner *v.i.* ពង់; សំញែង; កែងខ្លួន

papa *n.m.* ប៉ា, ឪ (ឪពុក) ។ *Fam.* មនុស្សចាស់ ។ à la papa គ្មានរវែង, មិនប្រញាប់, តាមធម្មតា

papal,e,aux *a.* នៃប៉ាប (ឧ. autorité papale)

papalin *n.m.* ទាហានរបស់ប៉ាប

papas [-pass] *n.m.* បព្វជិតកាតូលិកសាសនិក

papauté *n.f.* ឋានន្តរជាប៉ាប; រយៈពេលដែលប៉ាបម្នាក់អភិបាល; អភិបាលនៃប៉ាប

papaver [-ver] *n.m.* ដើមអាភៀន (ពាក្យវិទ្យាសាស្ត្រ)

papavéracées *n.f. pl.* សន្តានដើមអាភៀន

papaye *n.f.* ផ្លែល្ហុង

papayer *n.m.* ដើមល្ហុង

pape *n.m.* ប៉ាប (ប្រមុខនៃសាសនា

កាតូលិក)

papegai [-ghè] ឬ **papegeai** [-jè] *n.m.* សេក; សំណាកបក្សីជាគោលបាញ់

papelard,e *a.* ដែលសំដែងការលាក់ពុត (ឧ. voix papelarde)។ *n.m.* ធម្មិកក្លែង (អ្នកក្លែងធ្វើជាស៊ប់ខ្លួនចំពោះសាសនា)

papelardise *n.f.* ការលាក់ពុត

paperasse *n.f.* ក្រដាស ឬ លិខិតគ្មានតម្លៃ

paperasserie *n.f.* គំនរក្រដាសឬគំនរលិខិតគ្មានតម្លៃ (ឧ. paperasserie administrative)

paperassier,ère *n.* អ្នកចូលចិត្ត-អ្នកប្រើ ឬ អ្នករើគំនរលិខិតឥតតម្លៃ

papesse *n.f.* ប៉ាបស្រី

papeterie *n.f.* រោងធ្វើក្រដាស; ជំនួញក្រដាសនិងរបស់ប្រើប្រាស់ក្នុងការិយាល័យ; ប្រអប់ដាក់គ្រឿងសរសេរ

papetier,ère *n.* អ្នកធ្វើឬលក់ក្រដាស

papier *n.m.* ក្រដាស; លិខិត (សរសេរ ឬបោះពុម្ព) (ឧ. un papier compromettant); លិខិត ឬសៀវភៅសរសេរដៃ; ឯកសារ (ឧ. lire un papier); អត្ថបទសម្រាប់រៀបពុម្ពកាសែត; ធនបត្រ, ភណ្ឌបត្រ (ឧ. refuser le papier d'un commerçant) ។ papier autographique ក្រដាសផ្តិតគំនូរ ។ papier bible ឬ papier indien ក្រដាសប៊ីប (ក្រដាសស្តើងសម្រាប់បោះពុម្ពសៀវភៅ) ។ papier buvard ម.ព. buvard ។ papier à calquer ក្រដាសផ្តាប់ចម្លង ។ papier carbone ក្រដាសធ្យូង ។ papier chiffon ក្រដាសប្រណិតធ្វើអំពីកន្ទប ។ papier à cigarette ក្រដាសមូរបារី, ក្រដាសជក់ ។ papier cristal ក្រដាសផលិក (ភ្លឺថ្លុះ) ។ papier-émeri ក្រដាសខាត់ដែក ។ papier écolier ក្រដាសកូនសិស្ស, ក្រដាសសំរាប់សរសេរដៃ ។ papier-filtre ក្រដាសតម្រង ។ papier hygiénique ក្រដាសខ្ចិត ។ papier joseph ព.ម. joseph ។ papier journal ក្រដាសកាសែត ។ papier kraft ក្រដាសខ្ចប់អីវ៉ាន់ពណ៌ត្នោត ។ papier peint ឬ papier-tenture ក្រដាសពាសជញ្ជាំង ។ papier pelure ក្រដាសស្តើង (សម្រាប់អង្គុលីលេខ) ។ papier-pierre ក្រដាសការតុង

រឹង។ papier sensible ក្រដាសផ្តិតរូបថត ។ papier vélin ក្រដាសប្រណិតរលីងហើយរលើប ។ papier timbré ក្រដាសបិទតែមប្រើបោះត្រា។ papier libre ក្រដាសលាត (គ្មានបិទតែមប្រើ) ។ papier végétal, papier à calquer ឬ papier calque ក្រដាសផ្ទាប់ចម្លង ។ papier de verre ឬ papier verré ក្រដាសខាត់ ។ *Mar.* papiers de bord ឯកសារនាវា ។ *Fig.&Fam.* être dans les petits papiers de quelqu'un ជាទីស្រឡាញ់នៃអ្នកណាមួយ ។

pl. លិខិតឆ្លងដែន; អត្តសញ្ញាណប័ណ្ណ (ឧ. avez-vous vos papiers?); សារព័ត៌មាន, កាសែត

papier-monnaie *n.m.* ធនប័ត្រ ក្រដាសប្រាក់

papillaire [-pil-lèr-] *a.* ដែលមានបិណ្ឌិកា

papille [-piy'] *n.f.* បិណ្ឌិកា (កន្ទួលតូចៗនៃអណ្តាត) (ឧ. papilles gustatives)

papilleux,euse *a.* ដែលមានបិណ្ឌិកាពាសពេញ

papillifère [-pil-li] *a.* ដែលមានបិណ្ឌិកា

papilliforme [-pil-li-] *a.* ដែលមានសណ្ឋានជាបិណ្ឌិកា

papillome [-pil-lom-] *n.m.* *Méd.* កន្ទួលដំ

papillon *n.m.* មេអំបៅ ។ *Fig.* ចរិតសាវ៉ា; ប័ណ្ណប្រកាសតូចៗ(ឧ. coller des papillons); សន្លឹកក្រដាសស៊កក្នុងសៀវភៅ ។

a. ដែលមានទ្រង់ទ្រាយដូចមេអំបៅ (ឧ. nœud papillon)

papillonner *v.i.* *Fam.* ហើរពីរបស់មួយទៅរបស់មួយឬពីម្នាក់ទៅម្នាក់

papillotage *n.m.* ការញាក់ត្របកភ្នែក (កម្រើកទាក់ដោយឥតបំណង); ដំណើរអស់កម្លាំងដោយឃើញវត្ថុភ្លឺពេក ឬ ឃើញពណ៌ឆើតពេក

papillotant,e *a.* ដែលឲ្យញាក់ភ្នែក ឬ ឲ្យអស់កម្លាំង (ឧ. lumières papillotantes)

papillote *n.f.* ក្រដាស ឬ កំណាត់សំពត់រុំសក់ឲ្យរួញ; ស្ករគ្រាប់ខ្ចប់ក្រដាសជ្រួញៗ; ក្រដាសលាបខ្លាញ់ខ្ចប់សាច់ដើម្បីអាំង (ឧ. cotelettes en papillotes)

papillotement *n.m.* ពន្លឺព្រាយដែលឲ្យស្រវាំងភ្នែក

papilloter *v.i.* ញាក់ត្របកភ្នែក

papion *n.m.* ស្វាក្បាលវែង(ដូចក្បាលឆ្កែ)

papotage *n.m.Fam.* ការនិយាយលេងឥតប្រយោជន៍

papoter *v.i. Fam.* និយាយលេងឥតប្រយោជន៍, និយាយប៉ាច់ប៉ោច

paprika *n.m.* ម្ទេសម្ទុក

papule *n.f.* ពងផ្លូត (ពងក្រហមលើស្បែក)

papuleux,euse *a.* នៃពងក្រហមលើស្បែក (ឧ. lésion papuleuse)

pâque *n.f.* បុណ្យប៉ាក (បុណ្យនៃជាតិហេប្រឺរំឭកពេលចាកចេញពីប្រទេសអេហ្ស៊ីប)

paquebot *n.m.* នាវាសមុទ្រ

pâques *n.m. pl.* បុណ្យប៉ាកសាសនាគ្រិស្ត (បុណ្យរំឭកថ្ងៃដែលព្រះយេស៊ូ-គ្រិស្តរស់ឡើងវិញ)

paquet *n.m.* កញ្ចប់, បង្វេច (ឧ. un paquet de linge) ។ *Fig.* & *Fam.* faire son paquet វេចបង្វេច; ចាកចេញ ។ *Mar.* paquet de mer រលកដែលបោកបាចមកលើកម្រាលនាវា ។ recevoir son paquet ទទួលសំដីធ្ងន់ៗឆ្លើយមិនរួច

paquetage *n.m.* ការខ្ចប់, ការវេច; ប្រដាប់ប្រដាររបស់ទាហានម្នាក់ៗ

paqueter *v.t.* ខ្ចប់, វេច

paqueteur,euse *n.* អ្នកជំនាញខាងធ្វើកញ្ចប់ ឬវាយឡាំង

par *pré.* តាម (ប្រាប់ទីកន្លែងដែលទៅ ឧ. passer par Takèo); ដោយ (ប្រាប់ទេសកាលៈ ឧ. voyager par mer calme; ប្រាប់មធ្យោបាយ ឧ. arriver par bateau; ប្រាប់ហេតុ ឧ. agir par intérêt; ប្រាប់អ្នកធ្វើ ឧ. Gandhi fut tué par un journaliste); ពី (ប្រាប់របៀប ឧ. commencer par la fin); ក្នុងមួយ (ប្រាប់កំឡុងពេល ឧ. gagner mille riels par mois) ។

de par *loc.pré.* នៅតំបន់ខ្លះ (ឧ. nous avons des parents inconnus de par le monde); តាម (តាមបញ្ជានៃ) (ឧ. de par la volonté du peuple); ក្នុងនាមនៃ ។ par conséquent *loc.adv.* ដោយហេតុនេះ

parabellum *n.m.* ប៉ារ៉ាបែលុម

(កាំភ្លើងនៃប្រ៉ាង)

parabole *n.f.* អធិប្បាយជារូបាធិដ្ឋាន ។ *Fam.* parler par paraboles និយាយពុំច្បាស់លាស់

parabole *n.f. Math.* បន្ទាត់ពត់

parabolique *a.* នៃការអធិប្បាយជារូបាធិដ្ឋាន(ឧ.sens parabolique)

parabolique *a. Math.* នៃបន្ទាត់ពត់; ជាភាងប៉ោង (ឧ. miroir parabolique)

paraboliquement *adv.* ជារូបាធិដ្ឋាន

paracentèse *n.f. Chir.* ការចាក់ប្រមុះ (ឧ. paracentèse du tympan)

parachevable *a.* អាចបង្ហើយបាន

parachèvement *n.m.* ការបង្ហើយ, ការសម្រេច; វិសុទ្ធិភាព, ភាពបង្ហើយស្រេច

parachever *v.t.* បង្ហើយ, សម្រេច (ពវ.finir, parfaire, perfectionner, terminer)

parachronisme *n.m.* បរកាលភាព, ការដាក់ព្រឹត្តិការណ៍អ្វីមួយក្រោយពេលដែលកើតមានឡើង

parachutage *n.m.* ការទម្លាក់ដោយឆត្រយោង

parachute *n.m.* ឆត្រយោង

parachuter *v.t.* ទម្លាក់ដោយឆត្រយោង

parachutisme *n.m.* កីឡាឆត្រយោង (ឧ. le parachutisme est l'objet de compétitions)

parachutiste *n.m.* អ្នកលោតឆត្រយោង; ទាហានឆត្រយោង

parade *n.f.* ការទប់ ។ cheval sûr à la parade សេះដែលឈប់ភ្លាម-បរ ឬ ទឹកបានដោយងាយ ។ *Escr.* ការកាត់ឬរង; ស្នៀតកាត់ឬរង (ឧ. escrimeur prompt à la parade); ការកំប្លែងដើម្បីប្រមូលអ្នកមើល (ឧ. les clowns sont les acteurs habituels de la parade) ។ de parade ជាលំអឬជាការសំញែង (ឧ. cheval de parade) ។ faire parade de សំញែង ។ lit de parade គ្រែដំកល់សពពិស្សដេន (សម្រាប់អ្នកផងទៅមើល)

parader *v.i.* បរ (ឧ. parader un cheval); សំញែង (ឧ. parader des troupes) ។ *Fig.* ដើរកាច់កង (ឧ. parader dans un salon)

paradeur *n.m.* អ្នកចូលចិត្តដើរកាច់កង

paradigme *n.m.* គំរូ (ឧ. les ver-

bes «aimer», «finir», «rendre» sont les trois paradigmes des conjugaisons françaises)

paradis *n.m.* ឋានសួគ៌ ។ *Fig.* រមណីយប្បទេស, ប្រទេសសប្បាយ; រមណីយភាព, ភាពសប្បាយបំផុត; ថ្នាក់លើបំផុតនៃនានិសាល

paradisiaque *a.* នៃឋានសួគ៌ (ឧ. bonheur paradisiaque)

parados *n.m.* *Fortif.* បរក្រាណ [ប៉ៈ-រ៉ៈ—], រនាំងខ្នង (ពំនូកដីការពារខាងក្រោយខ្នង) (ឧ. parados de tranchée)

paradoxal,e,aux *a.* នៃបរមតិ, [ប៉ៈ-រ៉ៈ—], ផ្ទុយនឹងមតិធម្មតា, ប្លែក (ឧ. opinion paradoxale)

paradoxalement *adv.* ដោយបរមតិ, ដោយផ្ទុយនឹងមតិធម្មតា; ដោយប្លែក

paradoxe *n.m.* បរមតិ, មតិផ្ទុយនឹងមតិធម្មតា

parafe *n.m.* ម.ព. paraphe

parafer *v.t.* ម.ព. parapher

paraffinage *n.m.* ការលាបប្រេងប៉ារ៉ាហ្វីន

paraffine *n.f.* ប្រេងប៉ារ៉ាហ្វីន (ប្រេងមួយយ៉ាងសម្រាប់ធ្វើទៀន)(ឧ. la paraffine sert à la fabrication de bougies)

paraffiner *v.t.* លាបប្រេងប៉ារ៉ាហ្វីន

parafiscal,e,aux *a.* នៃសមូហការ

parafiscalité *n.f.* សមូហការ (ប្រជុំពន្ធនឹងអាករ)

parafoudre *n.m.* បការន្ទះ (គ្រឿងការពារន្ទះ)

parage *n.m.* អម្បូរ, កំណើត, ពូជ (ឧ. dame de haut parage)

parage *n.m.* តំបន់មួយនៃសមុទ្រ (ឧ. les parages que fréquentent les pirates)។ *pl.* កន្លែង, តំបន់, ភូមិភាគ (ឧ. que faites-vous dans ces parages?)

parage *n.m.Vitic.* ការភ្ជួរបំការទំពាំងបាយជូរមុនសិសិររដូវ

paragraphe *n.m.* កថាខណ្ឌ; សញ្ញាកថាខណ្ឌ

paragrêle *a.* បការព្រឹល (ប្រដាប់ការពារកុំឲ្យធ្លាក់ព្រឹល) (ឧ. fusée paragrêle)

paraître *v.i.* លេចចេញ(ឧ. dès que l'aurore paraît); ហាក់ដូចជា, ដូចជា(ឧ. il paraît souffrant);

ចេញ (ត្រូវបោះពុម្ពឆ្នាំទៅ) (ឧ. ce livre a paru l'an dernier)។ *Fig.* ចេញមុខ (ឧ. chercher à paraître); មាន, បង្ហាញ (ឧ. son orgueil paraît dans toutes ses actions) ។

v.imp. il paraît que ដូចជា, ប្រហែលជា។ il y paraît គេឃើញច្បាស់ (ឧ. il a été longtemps malade, mais il n'y paraît plus)

parallèle *a.* ស្រប។ plans parallèles ផ្ទៃស្រប។ marché parallèle ផ្សារសម្ងាត់ ។ *Fig.* ស្របគ្នា, ដូចគ្នា (ឧ. mener une action parallèle) ។

n.f. ខ្សែស្រប (ឧ. tirer une parallèle) ។

n.m. ការផ្ទឹមគំនិត ឬសុន្ទរកថា, ការផ្ទឹមមនុស្ស ឬវត្ថុ ។ *n.m.* ខ្សែស្រប (មណ្ឌលស្របនឹងផ្លូវព្រះអាទិត្យ)

parallèlement *adv.* ដោយស្របគ្នា

parallélépipède ឬ **parallélipipède** *n.m.* ឆៀងទ្រវែង [ឆៈ-ឡុង]

parallélisme *n.m.* ភាពស្រប ។ *Fig.* ទិសស្រប ។ *Psych.* ស្របនិយម

paralléliste *a.&n.* *Psych.* អ្នកស្របនិយម

parallélogramme *n.m.* ចតុរស្សញាយស្រប, ផ្ទៃបួនជ្រុងញាយស្រប

paralogisme *n.m.* បរិតក្ក [ប៉ៈ-រ៉ៈ-រិ-តុក], ការត្រិះរិះខុសដោយឥតចេតនា (ព.ដ. sophisme)

paralysant,e *a.* ដែលធ្វើឲ្យខ្វិនឬឲ្យស្ពន់

paralysé,e *a.* ខ្វិន ។ *n.* មនុស្សខ្វិន

paralyser *v.t.* ធ្វើឲ្យខ្វិន; ធ្វើឲ្យស្ពន់ ។ *Fig.* បង្អាក់, បង្អាំង, ញុំាងមិនឲ្យធ្វើអ្វីកើត (ឧ. paralyser les efforts de quelqu'un)

paralysie *n.f.* ភេទស្លាប់អវយវៈ, ភេទខ្វិន; ការស្ពន់។ *Fig.* ការធ្វើអ្វីមិនកើត; ដំណើរគាំង (ឧ. paralysie de l'économie)

paralytique *a.* ខ្វិន (ឧ. un vieillard paralytique) ។ *n.* មនុស្សខ្វិន (ឧ. un paralytique)

paramagnétique *a.* *Electr.* បក-ពុម្ពិត

paramilitaire *a.* យោធាប្រតិព័ទ្ធ, ដែលមានលំនាំជាកងទ័ព (ឧ. formation paramilitaire)

paramnésie *n.f.* រោគខួរក្បាលបណ្ដាលឲ្យយករឿងកើតថ្មីថាជារឿងចាស់;ការច្រឡំថាដូចជាធ្លាប់បានឃើញហើយ

parangon *n.m.* គំរូ, សំណាក (ឧ. Mao Svet est le parangon des avares); ពេជ្រ ឬ ត្បូងល្អឥតខ្ចោះ

parangonnage *n.m. Arts graph.* ការរៀបអក្សរទំហំខុសគ្នាក្នុងជួរបន្ទាត់តែមួយ

parangonner *v.t. Arts graph.* រៀបអក្សរទំហំខុសគ្នាក្នុងជួរបន្ទាត់តែមួយ

parapet *n.m.* ជញ្ជាំងពួនបាញ់; បង្កាន់ដៃ (ឧ. parapet d'un pont)

paraphe ឬ **parafe** *n.m.* ហត្ថលេខាសង្ខេប; អាទិសង្កេត

parapher ឬ **parafer** *v.t.* ចុះហត្ថលេខាសង្ខេប; ចុះអាទិសង្កេត

paraphernal,e,aux *a.* នៃទ្រព្យរបស់ប្រពន្ធ (ក្រៅអំពីចំណងដៃ) (ឧ. la femme a l'administration de ses biens paraphernaux)

paraphrase *n.f.* បរប្រយោគ, សេចក្ដីបកស្រាយ ឬ ពន្យល់ទូលំទូលាយនៃអត្ថបទមួយ ។ *Par ext.* អធិប្បាយវែងហើយសាំញ៉ាំ

paraphraser *v.t.* ធ្វើបរប្រយោគ, បកស្រាយ ឬ ពន្យល់យ៉ាងទូលាយ ; បកស្រាយ។ *Fig.* បន្លាយ,ពង្រីក, បំផ្លើស

paraphraseur,euse *n.* បរភិទី-ទិនី, អ្នកនិយាយបំផ្លើស

paraphrastique *a.* នៃការបំផ្លើស(ឧ. traduction paraphrastique)

paraplégie *n.f.* ដំណើរខ្វិនជើងទាំងពីរ

paraplégique *a.&n.* អ្នកខ្វិនជើងទាំងពីរ ។ *a.* ដែលមានលំនាំដូចខ្វិនជើង

parapluie *n.m.* ឆត្រ

parasélène *n.f.* ខែចាំងឆត្រ (រង្វង់ភ្លឺជុំវិញព្រះចន្ទ)

parasitaire *a.* បរាសិត [ប៉ៈ-រ៉ា-], នៃមនុស្សឬសត្វផ្ញើប្រាណ (មនុស្សឬសត្វដែលរស់នៅដោយសារគេ); នៃបញ្ញើក្អែក ។ *Méd.* ដែលបណ្ដាលអំពីបរាសិត (ឧ. maladie parasitaire)

parasite *n.m.* បរាសិត [ប៉ៈ-រ៉ា-], មនុស្សឬសត្វផ្ញើប្រាណ (មនុស្សឬសត្វដែលរស់នៅដោយសារគេ) ។ *pl.* សម្លេងព្រៃ (វិទ្យុ) ។ *a.* plante parasite រុក្ខជាតិផ្ញើប្រាណ (ឧ. បញ្ញើក្អែក, ប៉ប្រក, វល្លិមាស ។ល។)

parasiter *v.t.* ផ្ញើប្រាណ (ចូលទៅអាស្រ័យក្នុងរុក្ខជាតិ ឬ ក្នុងខ្លួនសត្វ)

parasiticide *a.* បរាសិតឃាតី

parasitique *a.* បរាសិត, ដែលរស់នៅដោយសារគេ (ឧ. mœurs parasitiques)

parasitisme *n.m.* បរាសិតភាព [ប៉ៈ-រ៉ា-សិតៈ–]

parasitologie *n.f.* បរាសិតសាស្ត្រ [ប៉ៈ-រ៉ា-សិតៈ–]

parasol *n.m.* ក្លស់, តាំងយូ

parasoleil *n.m.* ជាំងពន្លឺថ្ងៃ (ប្រដាប់ថតរូប)

paratonnerre *n.m.* បរាសនី [ប៉ៈ-រ៉ា-សៈ-ន៉ី], គ្រឿងស្រូបផ្គរ ឬ រន្ទះ

parâtre *n.m.* ឪពុកចុង (ច្រើនសំដៅឪពុកចិត្តអាក្រក់)

paratyphique *a.* នៃគ្រុនសន្ធំស្រាល

paratyphoïde *a.&n.f.* គ្រុនសន្ធំស្រាល

paravent *n.m.* ឡប់ឡែ, ជាំងខ្យល់

parc *n.m.* ឧទ្យានសាធារណ៍, ក្រោលសត្វ; កន្លែងទុកស្បៀង ឬ គ្រឿងទ័ព (ឧ. parc aérien); បំណគារ

parcage *n.m.* ការដាក់ក្រោល; ការបង្ខាំង

parcellaire *a.* ដែលធ្វើតាមក្បាលដីតូចៗ (ឧ. en France, le cadastre est parcellaire); ដែលបែកជាភាគ, ដែលបែកជាក្បាលដី (ឧ. plan parcellaire)

parcelle *n.f.* ភាគតូច; ក្បាលដី

parce que *loc.conj.* ពីព្រោះ, ដោយហេតុ, ដោយសារតែ (ឧ. on se chauffe parce qu'on a froid)

parchemin *n.m.* ស្បែកសរសេរ ។ *pl. Fig. & Fam.* សញ្ញាប័ត្រ (ឧ. être fier de ses parchemins)

parcheminé,e *a.* ដូចស្បែកសរសេរ (ឧ. visage parcheminé)

parcheminer *v.t.* ធ្វើឲ្យដូចស្បែកសរសេរ (ឧ. l'huile parchemine le papier)

parchemineux,euse *a.* ជាស្បែកសរសេរ ; ដូចស្បែកសរសេរ

parcimonie *n.f.* ការសន្សំ, ការត្បិតត្បៀត (ស. avarice, ladrerie)

parcimonieusement *adv.* ដោយសន្សំ, ដោយត្បិតត្បៀត (ឧ. distribuer parcimonieusement des éloges)

parcimonieux,euse *a.* ត្បិតត្បៀត,

រឹតត្បិត

parcourir *v.t.* ដើរសុសសព្វ (ឧ. parcourir une route ដើរមួយចប់ផ្លូវ ; parcourir une ville ដើរមើលសុសសព្វក្រុង); អានក្រួសៗ (ឲ្យតែចប់) (ឧ. parcourir un livre)

parcours *n.m.* រយៈផ្លូវ(ឧ. effectuer un parcours); ផ្លូវ(សម្រាប់រថយន្តសាធារណៈ) (ឧ. parcours d'un autobus)

pardessus *n.m.* អាវក្រៅ

pardi! pardieu! *int.* មែនហើយ, ពិតហើយ

par-devant *loc.pré.* ចំពោះមុខ; ដោយមានជំនួយអំពី

pardon *n.m.* ការអភ័យទោស (ឧ. obtenir son pardon); ពាក្យសុំអភ័យទោស (ឧ. je vous demande de pardon ខ្ញុំសូមលោកអភ័យទោស)

pardonnable *a.* អាចអភ័យទោសបាន (ឧ. faute pardonnable); គួរអភ័យទោស (ឧ. enfant pardonnable)

pardonner *v.t.* អភ័យទោស, លើកទោស, អត់ទោស (ឧ. pardonner une offense) ; អត់ឱនឲ្យ (មិនប្រណែន (ឧ. on ne lui pardonne pas ses succès) ។

v.t. ind. (à) លើកទោសឲ្យ (ឧ. pardonner à un écolier puni); សំចៃ, លស់លា (ឧ. la mort ne pardonne à personne) ។ maladie qui ne pardonne pas ជម្ងឺផ្តាច់ជីវិត។ pardonnez-moi សុំទោស (*III.* absoudre, acquitter, excuser) (ព.ផ. condamner, reprendre, réprimander, réprouver, stigmatiser)

paré,e *a.* អលង្ការ, ដែលតែងលំអ (ឧ. jardin paré de mille fleurs)

pare-balle *n.m. inv.* បាំងគ្រាប់, ជម្រកគ្រាប់កាំភ្លើង

pare-boue *n.m. inv.* បាំងភក់

pare-brise *n.m. inv.* បាំងខ្យល់ (កញ្ចក់មុខរថយន្ត)

pare-chocs *n.m. inv.* បង្ការទង្គិច (បន្ទះដែកការពាររថយន្តនឹងការប៉ះទង្គិច)

pare-clous *n.m. inv.* បង្ការដែកគោល (បន្ទះកៅស៊ូទ្រាប់ពោះវៀនកង់

កុំឲ្យមុតដែកគោល)

pare-éclats *n.m. inv.* ជាំងបំណែកគ្រាប់បែក (ពំនូកដី ឬ សំណង់ផ្សេងៗ សម្រាប់ការពារបំណែកគ្រាប់បែក)

pare-étincelles *n.m. inv.* ជាំងផ្កាភ្លើង (ដែកជាំងកុំឲ្យផ្កាភ្លើងហើរ)

pare-feu *n.m. inv.* ជាំងភ្លើង (រឿង សម្រាប់ការពារកុំឲ្យភ្លើងឆេះរាលដាល; ផ្នែកព្រៃដែលគេកាប់ឲ្យរលស ដើម្បីការពារអគ្គិភ័យ)

pare-fumée *n.m. inv.* ជាំងផ្សែង (ក្នុងអយស្ម័យយាន)

parégorique *a.* élixir parégorique ថ្នាំចុកពោះនឹងការូស

pareil,eille *a.* ដូច (ឧ. des livres pareils); ដូច្នេះ (ឧ. en pareil cas)។ sans pareil ឥតមានដូច, ប្រសើរជាងគេ (ឧ. une mémoire sans pareille)។

n. il n'a pas son pareil គ្មានអ្នកណាដូច។ vos pareils ជនបែបអ្នក ។

n.f. rendre la pareille តបវិញឲ្យដូចគ្នា

pareillement *adv.* ដូចគ្នា (តាមរបៀបដូចគ្នា); ដែរ (ឧ. je le désire pareillement)

parement *n.m.* ជាន់ស័ក្តិដៃអាវ; គ្រឿងតែងលំអ

parementer *v.t.* ដាក់គ្រឿងលំអ (ឧ. parementer un mur)

parémiologie *n.f.* ក្បួនភាសិត

parent,e *n.* ញាតិ, បងប្អូន (ឧ. un parent éloigné)។ *n.m. pl.* ឪពុកម្តាយ, ជីដូនជីតា (ឧ. issu de parents illustres)។ nos premiers parents បឋមញាតិ (តាមអ្នកកាន់គ្រិស្តសាសនា គឺអាដាំនិងអេវ)

parentales ឬ **parentalies** *n.f. pl. Antiq.* ទក្ខិណានុប្បទាន, បុណ្យឧទ្ទិសចំពោះបុគ្គលទៅកាន់បរលោកហើយ (ដូចបុណ្យភ្ជុំបិណ្ឌក្នុងប្រទេសយើង)

parenté *n.f.* ញាតិភាព; ញាតិវង្ស។ degré de parenté ថ្នាក់ញាតិវង្ស។ ligne de parenté ជួរញាតិវង្ស។ parenté en ligne collatérale ញាតិវង្សជួរសាខា។ parenté en ligne directe ញាតិវង្សជួរផ្ទាល់ ។ parenté en ligne directe ascendante ញាតិវង្ស

ខ្សែផ្ទាល់ជាបុព្វជន ។ parenté en ligne directe descendante ញាតិវង្សខ្សែផ្ទាល់ជាបច្ឆាជន ។

Fig. ការដូចគ្នា (ឧ. parenté de deux opinions) (*Cf.* affinité, analogie, conformité, similitude)

parentèle *n.f.* ក្រុមញាតិ

parenthèse *n.f.* វង់ក្រចក (ឃ្លាក្នុងវង់ក្រចក គឺ ឃ្លាបន្ទាប់បន្សំមានន័យដោយឡែកពីឃ្លាក្នុងអត្ថបទ; សញ្ញា () (ឧ. mettre entre parenthèses) ។ *Par ext.* ouvrir une parenthèse បើកវង់ក្រចក គឺ អធិប្បាយក្រៅរឿង ។ entre parenthèses ឬ par parenthèse *loc. adv.* ជាបន្ទាប់បន្សំ, ជាក្រៅរឿង (ឧ. par parenthèse, je tiens à vous dire que...)

paréo *n.m.* សៀអខ្លីនៃស្រីកោះតាហ៊ីទី

parer *v.t.* តែងលំអ, ស្អិតស្អាង (ឧ. parer un autel, une mariée) (*Cf.* arranger, embellir, enjoliver, garnir, orner); បញ្ចៀស, រង, ការ (ឧ. parer un coup) ។

Cuis. parer la viande សំអាតសាច់ (ដោយយកស្បែក-សរសៃនិងខ្លាញ់ឥតប្រយោជន៍ចេញ) ។ parer des légumes, des fruits សំអាតបន្លែ-ផ្លែឈើ (ដោយយកភាគដែលបរិភោគមិនកើតចេញ) ។

Mar. ប្រុងស្រប (ឧ. parer une ancre) ។

v.t. ind. (à) បង្ការ, ការពារ (ឧ. parer à un danger, à un inconvénient) ។

se parer *v.pr.* ស្អិតស្អាងខ្លួន; ឡើងល្អ (ឧ. la terre se pare au printemps) ។ *Fig.* អួតខ្លួន (ឧ. se parer de son ascendance)

parère *n.m.* ប្រតិក្រមលិខិត (លិខិតបញ្ជាក់ដែលនេតិបណ្ឌិតបរទេសចេញឲ្យ ស្ដីអំពីវិធានច្បាប់ជំនួញ)

parésie *n.f.* ភាពស្លាប់អវយវៈខ្លះ

pare-soleil *n.m.* របាំងថ្ងៃ (ក្នុងរថយន្ត)

paresse *n.f.* សេចក្ដីខ្ជិល (ឧ. la paresse engendre la misère); ការល្ហើយ, ការព្រួស, ការយឺត (ឧ. accuser quelqu'un de paresse) ។ paresse d'esprit ប្រាជ្ញាយឺត (ព្រយល់, ព្រគិតឃើញ);

ការខ្ជិលគិតឲ្យជ្រៅ

paresser *v.i. Fam.*–បណ្ដោយខ្លួនឲ្យខ្ជិល, ធ្វើជាអ្នកខ្ជិល

paresseusement *adv.* ដោយខ្ជិលច្រអូស (ឧ. s'étendre paresseusement au soleil)

paresseux,euse *a.&n.* ខ្ជិល, កំជិល (ឧ. un écolier paresseux); ដែលដើរមិនស្រួល (ឧ. estomac paresseux ព្រោះរំលាយអាហារយឺត)

pareur,euse *n.m.* កម្មករសំអាតបង្ហើយ

parfaire *v.t.* សម្រេច, បង្ហើយ (ឧ. parfaire un ouvrage); បង្គ្រប់, បំពេញ (ឧ. parfaire une somme)

parfait,e *a.* សុក្រិត, ឥតខ្ចោះ (ឧ. beauté parfaite) គ្រប់លក្ខណ៍ (ឧ. nul homme n'est parfait); ពេញលេញ, បរិបូរ (ឧ. tranquillité parfaite) ។ *Mus.* accord parfait ម.ព. accord (ស. accompli, excellent, idéal, impeccable, supérieur)

parfaitement *adv.* ដោយសុក្រិត, ដោយឥតខ្ចោះ, ដោយពេញលេញ; មែនហើយ, បាទ (voudriez-vous? — parfaitement)

parfilage *n.m.* ការហូតសរសៃមាស ឬប្រាក់ពីសំពត់

parfiler *v.t.* ហូតសរសៃមាស ឬ ប្រាក់ពីសំពត់; បន្សុំពណ៌ (ក្លូលក្នុងកៃរជាដើម)

parfois *adv.* ជួនកាល

parfum *n.m.* គន្ធជាតិ, ក្លិនក្រអូប (ឧ. parfum des roses); ទឹកអប់ (ឧ. aimer les parfums) ។ *Fig.* អ្វីៗដែលឲ្យនឹកឃើញអនុស្សាវរីយ៍ឬរឿងល្អ (ឧ. parfum du bonheur)

parfumer *v.t.* លាបទឹកអប់, ប្រោះទឹកអប់

parfumerie *n.f.* សុគន្ធរស, ទឹកអប់; សុគន្ធដ្ឋាន, កន្លែងលក់ទឹកអប់; ជំនួញទឹកអប់

parfumeur,euse *n.* អ្នកធ្វើ ឬ លក់ទឹកអប់

pari *n.m.* ការភ្នាល់ (ឧ. engager ឬ faire un pari); ប្រយាតំណាង (ប្រាក់ឬវត្ថុដាក់ភ្នាល់) (ឧ. toucher un pari) ។ pari mutuel ល្បែងប្រណាំងសេះ (មានច្បាប់អនុញ្ញាត)

paria *n.m.* សូទ្រ (ជនក្នុងវណ្ណៈទី ៤ នៃប្រទេសឥណ្ឌា); អ្នកងារ ។ *Par ext.* មនុស្សដែលគេមិនចូលចិត្តគ្រប់គ្នា

pariade *n.f.* ការជាន់ញី (បក្សី); ខ្ទើរ

បក្សីជាន់ញី; ជួបញី

paridigitidé *a.& n.m.* យុគង្គុលី [យុ-គ័ង-គុ-], ដែលមានម្រាមជើងពត់គូនៅជើងនីមួយៗ (ដូចយ៉ាងគោ, ជ្រូកជាដើម)

parier *v.t.* ភ្នាល់

pariétal,e,aux *a. Anat.* នៃឆ្អឹងចំហៀងលលាដ៍ក្បាល

parieur,euse *n.* អ្នកភ្នាល់

parisianisme *n.m.* ប៉ារីសនិយម(ការនិយមឫកពាអ្នកក្រុងប៉ារីស)

parisien,enne *a.* នៃក្រុងប៉ារីស ។ *n.* អ្នកក្រុងប៉ារីស

paritaire *a.* យុគល [យុ-គៈ-លៈ ឬ យុ-គល់], ដែលមានចំពួកស្មើគ្នា

parité *n.f.* យុគភាព [យុ-គៈ-](ភាពស្មើគ្នា ឧ. parité entre les salaires masculins et féminins;ភាពគូគ្នា ឧ. parité d'un nombre)។ *Com.* យុគភាព (ការធៀបតម្លៃប្រាក់; ការធៀបគ្នា) (ឧ. établir une parité)

parjure *n.m.* សម្បថបំពាន; ការប្រព្រឹត្តក្នុងសម្បថ (ឧ. commettre un parjure)។ *n.&a.* អ្នកស្បថបំពាន; អ្នកប្រព្រឹត្តក្នុងសម្បថ (ឧ. ami parjure)

parjurer (se) *v.pr.* ប្រព្រឹត្តក្នុងសម្បថ; ស្បថបំពាន

parking [-kin'g] *n.m.* ចំណតរថយន្ត

parlando *n.m. Mus.* របៀបច្រៀងស្រដៀងនឹងនិយាយ

parlant,e *a.* ដែលចេះនិយាយ ។ film parlant ភាពយន្តនិយាយ។ *Fig.* ដូចបេះបិទ (ឧ. portrait parlant) ។ généralement parlant *loc. adv.* ដោយនិយាយទូទៅ

parlé,e *a.* ដែលនិយាយ (ឧ. l'anglais parlé diffère beaucoup de l'anglais écrit) ។ *n.m.* អ្វីៗដែលគេនិយាយ (ឧ. dans l'opéra comique, il y a du parlé et du chanté)

parlement *n.m.* សភា, ទីប្រជុំ

parlementaire *a.* នៃសភា (ឧ. usages parlementaires); អាស្រ័យរដ្ឋសភា ។ régime parlementaire របបគ្រប់គ្រងអាស្រ័យរដ្ឋសភា (រដ្ឋមន្ត្រីទទួលខុសត្រូវចំពោះរដ្ឋសភា) (ឧ. les Etats-Unis

d'Amérique ne pratiquent pas le régime parlementaire)។ សមរម្យក្នុងសភា; *par ext.* សមរម្យ (បេះរកមធ្យោបាយនិយាយឲ្យបានការកុំឲ្យគេខឹង) (ឧ. expression, procédé peu parlementaire); ទង់ន្ទិសភា(ឧ. drapeau, pavillon parlementaire); ដែលមានសភា។

n.m. អ្នកចរចាជាមួយនឹងគូសត្រូវ (ក្នុងសង្គ្រាម) (ឧ. se présenter en parlementaire); សមាជិកសភា; តំណាង

parlementairement *adv.* ដោយសមរម្យ (បេះរកមធ្យោបាយនិយាយឲ្យបានការកុំឲ្យគេខឹង)(ឧ. s'exprimer peu parlementairement)

parlementarisme *n.m.* សភានិយម (របៀបគ្រប់គ្រងអាស្រ័យសភា គឺរដ្ឋមន្ត្រីទទួលខុសត្រូវចំពោះរដ្ឋសភា)

parlementer *v.i.* ចរចា; ស្តាប់ពាក្យស្នើសម្រុះសម្រួល (ឧ. parlementer avec l'ennemi)។ *Par ext.* ជជែកសម្រុះសម្រួល (ឧ. parlementer avant de céder)

parler *v.i.* និយាយ(ឧ. enfant qui commence à parler); និយាយ (ត្រាប់សម្លេងការមនុស្ស)(ឧ. faire parler un perroquet); និយាយ (បញ្ចេញយោបល់ដោយភាសា) (ឧ. parler en termes corrects); និយាយ (ឧ. parler à un ami); និយាយ, សូត្រសុន្ទរកថា (ឧ. parler en public); និយាយដោយកាយវិការ (ឧ. les muets parlent par signes)។

Fig. បញ្ជា, បង្គាប់ (ឧ. l'honneur parle)។

Loc. adv. faire parler de soi ឲ្យគេនិយាយពីខ្លួន (មានកេរ្តិ៍ឈ្មោះល្អ ឬ អាក្រក់)។ parler d'abondance និយាយគិតគ្រោងទុក។ parler en l'air និយាយឲ្យរួចតែពីមាត់ (គិតបានការ)។ parler au cœur ធ្វើឲ្យទន់ចិត្ត, ធ្វើឲ្យរំភើប។ parler en maître និយាយដោយប្រើអំណាច។ parler d'or និយាយត្រូវណាស់, ប្រសប់និយាយ, ពូកែនិយាយ។ trouver à qui parler មានអ្នកប្រឆាំង។ *Pop.* tu parles! ឬ vous

parlez! ខ្ញុំឮហើយ ។ parler haut និយាយខ្លាំងៗ; និយាយឮគេ គេតក្រង ។

v.t. ind. (de) និយាយអំពី (ឧ. parler de ses maîtres) ។ parler bien de quelqu'un និយាយល្អអំពី (សរសើរ) ។ parler mal de quelqu'un និយាយអាក្រក់អំពី (រិះគន់ឬនិយាយដើម) ។ parler de la pluie et du beau temps និយាយលេងពីនេះពីនោះ ។

v.t. parler raison និយាយត្រូវ (ដោយអាងហេតុផល)។ និយាយ(ភាសាណាមួយ) (ឧ parler le cambodgien); និយាយអំពី (ឧ. parler politique; parler affaire) ។

se parler *v.pr.* ប្រើ; មានគេនិយាយ(ភាសា) (ឧ. l'anglais se parle partout); និយាយគ្នា (ឧ. des amis brouillés qui ne se parlent plus)។ sans parler de *loc.pré.* ដោយមិនគិតដល់, ក្រៅអំពី (*ttt.* causer, conférer, converser, deviser, discourir, pérorer) ។

Prov. trop gratter cuit, trop parler nuit ម.ព. cuire

parler *n.m.* ភាសា; របៀបនិយាយ(ឧ. le parler doux); គ្រាមភាសា (ឧ. le parler de Siemreap)

parole *n.f.* ការបេះនិយាយ (ឧ. l'homme seul a la parole); វាចា, សំដី(ឧ. avoir la parole douce); ពាក្យ (ឧ. s'expliquer en peu de paroles); ភាសិត (ឧ. parole mémorable); ពាក្យសន្យា (ឧ. donner sa parole)។

amuser quelqu'un de belles paroles បញ្ឆោត (ដោយមិនកាន់តាមពាក្យសន្យា) ។ n'avoir qu'une parole និយាយទៀង ។ droit de parole សិទ្ធិនិយាយ ឬ ជជែក (ក្នុងការប្រជុំ) ។ homme de parole មនុស្សនិយាយទៀង (មិនក្រឡាស់សំដី)។ le don de la parole វោហារកោសល្យ ។ ma parole ឬ parole d'honneur ពាក្យសច្ចាពាក្យសត្យ (ខ្ញុំហ៊ានស្បថ, ពិតហើយ) ។ avoir la parole មានសិទ្ធិនិយាយ ។ demander

la parole សុំនិយាយ ។ prendre la parole ចាប់និយាយ។ porter la parole នាំពាក្យ, និយាយក្នុងនាមជនច្រើនរូប ។ perdre la parole គ, លែងនិយាយរួច។ couper la parole និយាយកាត់សំដី ។ adresser la parole à quelqu'un និយាយទៅកាន់ ។ avoir deux paroles ក្រឡាស់សំដី, មិនកាន់ពាក្យសំដី, និយាយមិនទៀង។ sur parole តាមសំដី, តាមវាចា (ឧ. juger sur parole); តាមពាក្យនិយាយ (យកពាក្យនិយាយជាសំអាង) (ឧ. croire quelqu'un sur parole) ។

pl. ទំនុកច្រៀង (ឧ. faire la musique et les paroles)

paroli *n.m. Jeux* ការបក (ការដាក់ទ្វេក្នុងល្បែងស៊ីសង គឺកាលណាឈ្នះគេដាក់ទាំងប្រាក់ដើម ទាំងប្រាក់ឈ្នះទៅវិញ) (ឧ. faire paroli)

parolier *n.m.* អ្នកនិពន្ធទំនុកច្រៀង

paronomase *n.f.* ការប្រើជាឧបមេយ្យនូវពាក្យមានសំឡេងដូចគ្នាតែមានន័យខុសគ្នា (ឧ. qui vivra verra; qui se ressemble s'assemble)

parleur,euse *n.&a.* អ្នកនិយាយច្រើន។ beau parleur អ្នកប្រសប់និយាយ (និយាយពីរោះស្តាប់)

parloir *n.m.* សាលសន្ទនា (ក្នុងគ្រឹះស្ថានខ្លះ)

parlote *n.f. Fam.* ការហាក់និយាយ (ពួកស្នាក្តី); ការសំណេះសំណាល (ការនិយាយលេងឥតការណ៍)

parmi *pré.* ក្នុងចំណោម, បណ្តា (ឧ. parmi les honnêtes gens; parmi la foule)

parnasse *n.m.* ភ្នំប៉ារណាស់ (សម្រាប់អាប៉ូល្លុងនិងទេពកវី) ។ *Fig.* កវីនិពន្ធ; កវី

parnassien *a.* នៃភ្នំប៉ារណាស់ (ឧ. cimes parnassiennes); ដែលនៅភ្នំប៉ារណាស់ (ឧ. nymphes parnassiennes)

parodie *n.f.* ការត្រាប់កំប្លែងនូវនិពន្ធត្រឹមត្រូវ។ *Par ext.* ការត្រាប់កំប្លែង (ទូទៅ)

parodier *v.t.* ត្រាប់កំប្លែងនូវនិពន្ធ (ឧ. parodier une tragédie) ។ *Fig.* ត្រាប់ (ឧ. parodier quelqu'un)

parodiste *n.m. &a.* អ្នកនិពន្ធ

គ្រាប់កាំភ្លើង

paroi *n.f.* ជញ្ជាំងទំណប, ផ្ទៃក្នុង (នៃធុង ឬបំពង់)។ *Par anal.* អ្វីៗដែលដូចជញ្ជាំង (ឧ. paroi de rochers)។ *Anat.* ស្រោម, តែម (ឧ. les parois du crâne, de l'estomac)

paroisse *n.f.* ប៉ារ៉ូស, តំបន់ចំណុះគូរ៉េម្នាក់; ក្រុមសាសនិកចំណុះគូរ៉េម្នាក់ (ឧ. convoquer toute la paroisse); វិហារប៉ារ៉ូស (ឧ. aller à la paroisse)

paroissial,e,aux *a.* នៃប៉ារ៉ូស (ឧ. église paroissiale)

paroissien,enne *n.m.* បណ្ដាជនក្នុងប៉ារ៉ូស ។ *Fam.* ជនខូចទៅ (ឧ. quel drôle de paroissien!)។ *n.m.* សៀវភៅធម៌សម្រាប់សូត្រក្នុងវិហារ

paronyme *n.m.* ឃ្លីទិសនាម, ឃ្លីទិសសព្ទ [អ៊ុ-ទិ-សះ–] (ពាក្យស្រដៀងគ្នាដោយទ្រង់ទ្រាយ-ដោយអក្ខរាវិរុទ្ធ ឬដោយសំឡេង) (ឧ. conjecture នឹង conjoncture; collision នឹង collusion)

paronymie *n.f.* ឃ្លីទិសភាព

paronymique *a.* ឃ្លីទិស

paroptique *a.* ឆ្ងាយពីភ្នែក

parotide *n.* & *a.f.* ឧបកណ្ណ (អកា:សម្រាប់បញ្ចេញទឹកមាត់) (ឧ. les oreillons sont une inflammation des parotides) ។ glande parotide គ្រន្ថិឧបកណ្ណ

parotidien,enne *a.* នៃឧបកណ្ណ

parotidite *n.f.* ឧបកណ្ណរោគ [អ៊ុ-ប៉ះ-ក័ន-ណះ–]

paroxysme *n.m.* អតិវេគភាព, ភាពលើសលុប; ទីបំផុត (ឧ. au paroxysme de la colère)

parquement *n.m.* ការបង្ខាំង; ការដាក់ក្រោល

parquer *v.t.* ដាក់ក្រោល (ឧ. parquer des bœufs); បង្ខាំង (ឧ. parquer dans un camp de concentration) ។ *v.i.* ជាប់ក្រោល (ឧ. les bœufs parquent)

parques *Myth.* យមបាល

parquet *n.m.* *Just.* parquet général មហាអយ្យការ ។ *Constr.* ក្ដារក្រាល ។ parquet d'élevage ទ្រុងមាន់

parquetage *n.m.* *Constr.* ការក្រាលក្ដារ; ក្ដារក្រាល

parqueter *v.t.* ក្រាលក្តារ (ឧ. parqueter une chambre)

parqueterie *n.f.* សិល្បៈខាងធ្វើក្តារក្រាលនិងខាងក្រាលក្តារ

parqueteur *a.&n.m.* ជាងក្រាលក្តារ

parqueur,euse *n.* អ្នកថែរក្សាសត្វក្នុងក្រោល; អ្នកចិញ្ចឹមត្រី (ជា parquier *n.m.* ក៏បាន)

parrain *n.m.* ឪពុកធម៌

parrainage *n.m.* ភាព ឬ នាទីនៃឪពុកធម៌ ឬ ម្ដាយធម៌

parrainer *v.t.* ទទួលធ្វើជាឪពុកធម៌ឲ្យ

parricide *a.&n.* បិតុឃាតកៈ-តិកា (អ្នកសម្លាប់បិតាមាតាឬជីដូនជីតា)។ *n.m.* បិតុឃាតកម្ម (ការសម្លាប់បិតាមាតា) (ឧ. commettre un parricide)

parsec *n.m.* *Astr.* ប្រមាណរង្វាស់ចម្ងាយតារា (៣.០៨០.០០០ កោដិគីឡូម៉ែត្រ)

parsemer *v.t.* រាយពាយ (ឧ. parsemer un chemin de fleurs); នៅរាយរដាស (ឧ. les étoiles parsèment le ciel)(*Syn.* éparpiller, jeter, joncher, répandre, semer)

part *n.m.* *Dr.* កូនង៉ែត ។ suppression de part (ឬ d'enfant) ការបំបាត់ភស្តុតាងកំណើតកូន (ដោយលុបឈ្មោះចោលពីបញ្ជីកំណើត) ។ supposition de part (ឬ d'enfant) ការដាក់ថាមានកូន (ដាក់ក្លែងថាស្ត្រីនោះមានកូន ឬ យកកូនគេមកដាក់ជាកូននាងនោះ) ។ ការកើតកូន (សត្វ) (ឧ. un part laborieux)

part *n.f.* ភាគ (ឧ. faire quatre parts d'un gâteau); ចំណែក (ឧ. c'est un honneur dont je veux avoir ma part); ចំណែកមត៌ក, ចំណែកដើមទុន (ហ៊ុន); ទី, កន្លែង (ឧ. je l'ai vu quelque part) ។

Fig. & Fam. avoir part au gâteau បានចំណែកកម្រៃក្នុងរឿងអ្វីមួយ ។ part de fondateur ចំណែកជនកសមាជិក [-ជិៈ-នៈ-កៈ-]។ part indivise ចំណែកអវិភាគ។ la part du lion ភាគ ឬ ចំណែកធំជាងគេ ។ faire part de ឲ្យដំណឹងអំពី។ billet ឬ lettre de faire part លិខិតជូនដំណឹង(ក្នុងអាពាហ៍ពិពាហ៍ឬមរណភាព) (ជា faire part *n.m.inv.*

ក៏បាន) ។ faire la part d'une chose ពិតពិល, យកមកពិត (ឧ. faire la part du hasard) ។ *Fig.* faire la part du feu ឧ.ក. feu ។ prendre part à ធ្វើសហការ, ចូលដៃ, ចូលហ៊ុន (ឧ. prendre part à une entreprise); រីករាយជាមួយ, ចូលរួមជាមួយ (ឧ. prendre part à la joie de quelqu'un) ។ prendre en bonne part យល់ឃើញជាល្អ; ទុកជាល្អ (ឧ. il a pris en bonne part ce que vous lui avez dit) ។ prendre en mauvaise part យល់ឃើញជាអាក្រក់; ទុកជាអាក្រក់ (ឧ. ce mot se prend tantôt en bonne, tantôt en mauvaise part) ។

de part en part *loc. adv.* ពីម្ខាងទៅម្ខាង ។ de toutes parts *loc. adv.* ពីគ្រប់ទិស ។ de part et d'autre *loc. adv.* ទាំងសងខាង ។ à part *loc. adv.* ដោយឡែក (ឧ. étudier à part chaque question); ខុសគេ, ពិសេស (ឧ. un fait, un être à part) ។ à part moi ក្នុងចិត្តខ្ញុំ ។ à part lui ក្នុងចិត្តគាត់ ។ à part *loc.pré.* លើកលែងតែ, ក្រៅពី (ឧ. à part sa nonchalance, c'est un bon garçon) ។ de la part de ក្នុងនាមនៃ, ពីសំណាក់នៃ ។ pour ma part *loc. adv.* ចំណែកខាងខ្ញុំ

partage *n.m.* ការចែក, ការបែងការ (ឧ. faire le partage d'un héritage); ចំណែក (ឧ. cette ferme m'est échue en partage) ។ *Fig.* អ្វីៗដែលជានិស្ស័យ ឬដែលជាចំណែកនៃ (ឧ. la fourberie est le partage des lâches); លទ្ធភាពយចំណែក; សមភាព (ភាពស្មើគ្នា) (ឧ. cent voix d'un côté, cent voix de l'autre, il y a partage) ។ partage d'opinions មតិខ្វែងគ្នា ។

Géogr. ligne de partage des eaux បន្ទាត់ចែកទឹក (ទីដែលទឹកហៀរហូរទៅសងខាង)

partageable *a.* អាចបែងការបាន, អាចចែកបាន (ឧ. biens partageables)

partageant *n.m.* អ្នកទទួលចំណែក

partager *v.t.* ចែក, ចែកភាគ (ឧ. partager des terres); ចែកគ្នា (មានជាមួយគ្នា) (ឧ. partager le pouvoir)។ *Fig.* ជួយរំលែក; ជួយរង (ឧ. partager la joie, ជួយត្រេកអរ; partager la douleur ជួយរំលែកទុក្ខ); អនុគ្រោះ, ផ្តល់ឲ្យ (ឧ. la nature l'a bien partagé)។ partager l'opinion យល់ស្រប។

v.i. បានចំណែក

partageux,euse *n.&a.Péjor.* អ្នកទាមទារចំណែកទ្រព្យសម្បត្តិ

partance *n.f.* ពេលក្រោយបំផុត(មុននឹងចេញដំណើរ)។ en partance ហៀបនឹងចេញដំណើរ, ត្រូវចេញដំណើរ (ឧ. navire en partance)

partant *n.m.* អ្នកចេញដំណើរ

partant *conj.* ដូច្នេះ, ហេតុនេះ (ឧ. plus d'argent, partant plus d'amis) (ឬ. aussi, c'est pourquoi, donc)

partenaire *n.* ដៃគូ។ *Par ext.* អ្នកចូលហ៊ុន

parterre *n.m.* បុប្ផាកម [បុប-ផា-កម] (ផ្នែកសួនច្បារសម្រាប់ដាំផ្កា); បុប្ផាសនៈ [បុប-ផា-សៈ-នៈ] (ផ្នែកល្ខោនខាងក្រោយកៅអីមានភ្ជាប់ដៃ); អ្នកអង្គុយមើលនៅបុប្ផាសនៈ (ឧ. les applaudissements du parterre)

parti *n.m.* បក្ស, ពួក, គណៈបក្ស (ឧ. un chef de parti); ការសម្រេចចិត្ត (ឧ. prendre un parti); កម្រៃ(ឧ.un bon parti de...); អ្នកដែលគេអាចយកជាប្តី ឬ ជាប្រពន្ធបាន (ឧ. excellent parti)។ prendre parti រៀបអាពាហ៍ពិពាហ៍, យកប្តី ឬប្រពន្ធ។ parti pris ការប្រកាន់ចិត្តជាប់ជាមុន (ដោយលែងប្រែប្រួល)។ esprit de parti ការប្រកាន់បក្សពួក។ prendre le parti de quelqu'un កាន់ជើង។ prendre son parti សុខចិត្តទ្រាំ។ faire un mauvais parti à quelqu'un ធ្វើបាប។ prendre parti សម្រេចចិត្ត។

Mil. កងទាហានតូច (ដែលទៅបំពេញបេសកកម្មមួយ) (ឧ. un parti de cavalerie)

partiaire *a.* colon partiaire អ្នកទទួលប្រវាស់ដី (ចែកផលដំណាំជា

មួយនឹងម្ចាស់គឺ)

partial,e,aux *a.* អគតិគាមិ, ដែលកាន់ជើងម្ខាងៗ, ដែលលំអៀង (ឧ. juge partial)

partialement *adv.* ដោយអគតិ, ដោយលំអៀង

partialité *n.f.* អគតិ, សេចក្ដីលំអៀង (ឧ.montrer de la partialité)

participant,e *n.&a.* ភាគិន-គិនី, អ្នកចូលរួម (ឧ. les participants à une réunion)

participation *n.f.* ភាគកម្ម, ការចូលរួម (ឧ. participation à un crime) ។ association en participation សមាគមជាភាគកម្ម (ក្នុងជំនួញ)។ pour participation ដើម្បីភាគកម្ម, ដើម្បីរួមធ្វើ

participer (à) *v.t.ind.* មានចំណែកក្នុង (ឧ. participer aux bénéfices d'une entreprise); ធ្វើសហប្រតិបត្តិការ, ជួយ (ឧ. participer à la disgrâce de quelqu'un); ចូលរួម (ឧ. participer à la joie de quelqu'un), ទទួលនិតែកងរន្ធមន្ត្រី(ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន ឬដើម្បីគណៈបក្សខ្លួន) ។

participer de ភាគយកពី (ឧ. le mulet participe de l'âne et du cheval)

particularisation *n.f.* វិសេសកម្ម, ការបញ្ជាក់ដោយច្បាស់លាស់

particulariser *v.t.* បញ្ជាក់ដោយច្បាស់លាស់ (ឧ. particulariser les moindres circonstances d'un fait)

particularisme *n.m.* ប្រយោជន៍ដោយឡែក, ប្រយោជន៍ផ្ទាល់ខ្លួន (ឧ. le particularisme l'emporte souvent sur l'intérêt général) ។

Hist. វិសេសនិយម (ការនិយមរក្សាប្រពៃណីដោយឡែករបស់ខ្លួន)

particulariste *n.m. Hist.* អ្នកវិសេសនិយម ។ *a.* វិសេសនិយម (ឧ. idées particularistes)

particularité *n.f.* វិសេសភាព, (ឧ. les particularités d'un événement); អាការពិសេស; ព្រឹត្តិការណ៍ដោយឡែក

particule *n.f.* ចុណ្ណភាគ, ភាគតូចល្អិត-ល្អា (ឧ. les particules

d'un corps)

particulier,ère *a.* ដោយឡែក (ឧ. plante particulière à un climat); ផ្ទាល់ខ្លួន (ឧ. l'intérêt particulier doit s'effacer devant l'intérêt général); ល្អិតល្អន់, ពិស្ដារ (ឧ. rappeler les circonstances particulières d'un fait); ពិសេស (ឧ avoir un talent particulier pour la musique); ដោយឡែក, ដាច់ពីគេ (ឧ. chambre particulière); ឯកជន(មិនមែនសាធារណ៍); ផ្ទាល់ (ឧ. secrétaire particulier, conversation particulière) ។

n.m. ឯកជន (ឧ. c'est un simple particulier) ។ en son particulier ក្នុងចិត្តខ្លួន ។ en particulier *loc. adv.* ដោយឡែក, ជាពិសេស

particulièrement *adv.* ដោយអាការពិសេស, ដោយឡែក, ជាពិសេស (ឧ. il réussit particulièrement en poésie); យ៉ាងប្លែក (ឧ. il vous honore particulièrement)

partie *n.f.* ភាគ (ឧ. les cinq parties du monde; les différentes parties d'une machine); មុខរបរដោយឡែក; វិជ្ជាពិសេស (ឧ. être très fort dans sa partie) ។ *Jeux* ក្ដារ (លេងមួយលើកៗ) (ឧ. une partie de cartes; une partie de football); ការលំហែ, ការកំសាន្ត (ឧ. une partie de chasse) ។ *Comptab.* comptabilité en partie double ម.ព. comptabilité ។

Dr. ភាគី ។ partie adverse ភាគីប្រឆាំង ។ partie belligérante ភាគីយុទ្ធការី (ម.ព. belligérant ផង) ។ partie civile ភាគីបរណី, តោទក៍ខាង បទបរណី ។ partie contractante ភាគីគូសញ្ញា ។ haute partie ឧត្ដមភាគី ។

avoir affaire à forte partie មានរឿងនឹងគូប្រឆាំងពូកែ ។ la partie n'est pas égale មិនស្មើកម្លាំងគ្នា, មានប្រៀបម្ខាង ។

Fig. prendre quelqu'un à partie ចាប់ថ្នាក់ ។ quitter la partie បោះបង់ចោល, លែងលេង ។

n.f. pl. Anat. parties nobles អវយវៈចាំបាច់ដល់ជីវិត(មាន បេះដូង-សួត-ថ្លើម-ខួរក្បាលជាដើម) ។

Absol. អង្គជាត ។

en partie *loc. adv.* ខ្លះ, ដោយភាគ(ឧ. l'assistance était composée en partie d'étrangers) ។ en tout ou en partie ទាំងស្រុង (ឬទាំងអស់) ឬ តែភាគខ្លះ ។

Prov. qui quitte la partie la perd ប្រហែសបាត់ប្រយោជន៍ ។ il ne faut pas remettre la partie au lendemain ធ្វើអ្វីធ្វើឲ្យហើយ កុំទុកឡើយបង្អែកពេល; កុំទុកក្អែងស្អែកស្អួញទៅ ព្រែកនេះដល់យូរ ទៅខាតខូចអស់ការ

partiel,elle *a.* នៃភាគខ្លះ(ឧ. produit partiel); ដែលមានតែមួយភាគ, មិនពេញ (ឧ. éclipse partielle; élections partielles)

partiellement *adv.* ដោយភាគ, ខ្លះ, ដោយអន្ទើ

partir *v.i.* ចេញទៅ, ចេញដំណើរ (ឧ. partir pour Phnom-Penh); រត់ចេញឬហើរចេញ (ឧ. le lièvre partit comme un trait); ស្ទុះចេញ, ខ្ទាតចេញ (ឧ. le bouchon est parti); ផ្ទុះ; ដើរ (គ្រឿងយន្ត) (ឧ. faire partir un coup de feu; moteur qui part difficilement); ចេញ (ឧ. trois routes partent de Angtassom) ។

Fig. យកជាដើមទី (ឧ. il faut partir de cette hypothèse); ចេញពី, មកពី (ឧ. cela part d'un bon cœur) ។

v.t. avoir maille à partir avec quelqu'un មានរឿងនឹង, មានការណ៍នឹង ។

à partir de *loc. pré.* តាំងពី... ទៅ (ឧ. à partir d'aujourd'hui); ចាប់ពី... ទៅ (ឧ. à partir d'ici)

partisan,e *n.&a.* បក្សពួក; អ្នកកាន់ចិត្ត; អ្នកជឿឬកាន់តាម (ឧ. les partisans de César) (គេប្រើនប្រើ គុណនាមស្ត្រីលិង្គថា : partisante ក្នុងការ

និយាយស៊ូទូស្ទាល)។

n.m. ជាវទីសង់ (គាហានជំនួយ) (ឧ. corps de partisans)។

a. នៃការប្រកាន់បក្សពួក (ឧ. querelles partisanes)

partiteur *n.m.* ប្រដាប់បែកទឹក (ក្នុងព្រែកបង្ហូរទឹកដាក់ស្រែ)

partitif,ive *a.* & *n.m.* នៃលំបង្គួលកាត (ឧ. article partitif)

partner *n.m.* ដៃគូ (ក្នុងល្បែង)

partout *adv.* នៅគ្រប់កន្លែង, ពាសពេញ។ de partout *loc. adv.* ពីគ្រប់ទិស

parturiente *n.f.* ស្ត្រីកំពុងសម្រាលកូន

parturition *n.f.* ការសម្រាលកូន; ការកើតកូន (សត្វ)

parulie *n.f.* កក់ធ្មេញ

parure *n.f.* គ្រឿងលំអ (ឧ. aimer la parure); អលង្ការ (មានកង, ការ, ខ្សែក ជាដើម) (ឧ. une parure de diamants); សំលៀកបំពាក់ក្នុង (ខោទាប់) នៃស្ត្រី; កាត់នៃលប៉ះចេញឬចៀរចេញ (ឧ. les parures d'une peau)

parurerie *n.f.* អលង្ការក្លែងមនោរម័ត (ធ្វើតាមតែនឹកឃើញ)

parurier,ère *n.* អ្នកធ្វើ ឬ លក់គ្រឿងមនោរម័ត សម្រាប់សំលៀកបំពាក់ស្ត្រី (មានអលង្ការ-ខ្សែក្រវាត់ជាដើម)

parution *n.f.* ការផ្សាយតាមបណ្ណាគារ (សៀវភៅ)

parvenir *v.i.* ដល់ (ឧ parvenir au haut d'une montagne); ដល់ (ចំពោះវត្ថុ) (ឧ. ma lettre lui est parvenue)។

Fig. បានដល់ (ឧ. parvenir aux honneurs)។ *Absol.* កើតការលាភលាភគុណ (មានសម្បត្តិ) (ឧ. que de peines pour parvenir!)

parvenu,e *n.* អ្នកមានថ្មី (ទើបនឹងមានសម្បត្តិហួសឋានៈខ្លួន)

parvis *n.m.* ទីមុខទ្វារវិហារកាតូលិក ។ parvis célestes ឋានសួគ៌

pas *n.m.* ជំហាន (ឧ. marcher à petit pas); ដានជើង (ឧ. distinguer le pas d'un cheval de celui d'un bœuf); ដំណើរ (ឧ. aller bon pas); ល្បឿនសេះដើរ (ឧ. passer du trot au pas); ជំហាន(ឧ tirer à trente pas); ច្រកចង្អៀតហើយពិបាក (ច្រកភ្នំ) (ឧ. le pas de Susse); នៃ

សមុទ្រ (ឧ. pas de Calais); កាំជណ្ដើរ; ធរណីទ្វារ (ឧ. être sur le pas de sa porte) ។

à deux pas ជិតបង្កើយ ។ à pas comptés មួយៗ, យ៉ាងយឺត ។ à grands pas យ៉ាងលឿន ។ à pas de loup ដោយលបៗ, ដោយឥតឮសូរ ។ mauvais pas ច្រកដែលមានគ្រោះថ្នាក់; ស្ថានការពិបាក ។ faire un faux pas ភ្លាត់ជើង; ភ្លាត់បំណាប់ (ធ្វើខុស) ។ pas accéléré ដំណើរបន្ទំ ។ pas de charge ដំណើរយ៉ាងលឿន ។ pas cadencé ដំណើរត្រូវចង្វាក់ (ត្រូវជើងគ្នា) ។ pas gymnastique ការរត់ត្រូវចង្វាក់ ។ pas de course ការរត់ត្រឹកៗ ។ pas de route ដំណើរធម្មតា ។ marquer le pas ម.ព. marquer ។ faire les cent pas ដើរទៅដើរមក ។ marcher à pas de géant ជានបំរើនយ៉ាងរហ័ស ។ marcher sur les pas de quelqu'un ធ្វើតាមលំអានគេ ។ mettre quelqu'un au pas បង្ខំឲ្យធ្វើករណីយកិច្ច ឬ កិច្ចការខ្លួន ។ franchir le pas ឬ sauter le pas កាត់ចិត្តធ្វើ ។ faire les premiers pas រៀនដើរ; ផ្ដើមទាក់ទងមុន ។ pas d'engrenage ចន្លោះធ្មេញស្ដី ។ pas de porte ប្រាក់ទឹកតែ (ក្នុងការជួលផ្ទះ) ។

Loc. adv. de ce pas ក្នុងពេលឥឡូវនេះ, ភ្លាម ។ pas à pas មួយៗ ។

Prov. il n' y a que le premier pas qui coûte មានតែជំហានដំបូងដែលពិបាក, ការទាំងឡាយពិបាកបំផុតនៅពេលចាប់ធ្វើ ។ pas à pas on va bien loin ម.ព. loin ។ la peur a bon pas អ្នកខ្លាចដើរលឿន

pas *adv.* ទេ ។ pas d'argent គ្មានប្រាក់ទេ ។ pas un, pas une គ្មានមួយ, គ្មានសោះ (ឧ. pas un nuage au ciel) ។ *Fam.* pas vrai? មែនឬទេ ? ។ un pas grand' chose ម ព. gand' chose

pascal,e,als ឬ **aux** *a.* នៃបុណ្យប៉ាក (ឧ. communion pascale) ។ agneau pascal កូនចៀមសម្រាប់

ប្ញជាយញ្ញាក្នុងពិធីបុណ្យជាក

pasquin *n.m.* ត្លុក (ឧ. le pasquin de la troupe)

pasquinade *n.f.* ករិតពន្ធន៍ធៀលត្រះ ដោយកំប្លែង

passable *a.* ដែលគ្រាំទ្របាន; មធ្យម; ល្មមប្រើបាន

passablement *adv.* ជាមធ្យម, បង្គួរ, ល្មមនឹង (ឧ. une plaisanterie passablement risquée)

passade *n.f.* បំណាក់មួយឆាប

passage *n.m.* ការឆ្លង (ឧ. le passage des Alpes par Bonaparte); ពេលឆ្លង ឬទៅ (ឧ. attendre quelqu'un au passage); ផ្លូវ (កន្លែងឆ្លង ឬ ទៅ) (ឧ. ôtez-vous du passage); ការឆ្លងសមុទ្រ (ឧ. passage de Toulon à Alger); អាករ ឬ ថ្លៃឆ្លង (ឧ. payer un passage élevé); សិទ្ធិឆ្លងកាត់ (លើដីអ្នកដទៃ) (ឧ. la servitude de passage est légale en cas d'enclave, contractuelle dans les autres cas); ផ្លូវឆ្លង (ក្នុងទីក្រុង)។ *Fig.* អ្វីៗដែលមិនបិតថេរ (ឧ. la vie n'est qu'un passage); ដំណើរឆ្លង; ដំណើរផ្លាស់ (ឧ. le passage du jour à la nuit); សង្កាត់ (នៃសៀវភៅដែលគេយកមកថ្លែង) (ឧ. un beau passage de Bossuet)។ oiseaux de passage បក្សីដែលឆ្លងកាត់ (បក្សីដែលផ្លាស់អាកាសធាតុ)។

Ch. de fer. passage à niveau ថ្នល់កាត់ផ្លូវអយស្ម័យយាន។ passage supérieur ថ្នល់កាត់ពីលើផ្លូវអយស្ម័យយាន ។ passage inférieur ថ្នល់កាត់ពីក្រោមផ្លូវអយស្ម័យយាន។ passage clouté ផ្លូវបោះដែកគោល (សម្រាប់ដើរឆ្លងវិថី)

passager,ère *a.* មិននៅយូរ (ឧ. un hôte passager)។ *Fig.* មិនបិតថេរ (ឧ. beauté passagère)។

n. យាន្តបុរ (អ្នកដំណើរតាមយាន) (ម. éphémère, fugace, fugitif, momentané, provisoire, temporaire)

passagèrement *adv.* ដោយមិននៅយូរ; ដោយមិនបិតថេរ

passant,e *a.* ដែលគេទៅមកច្រើន (ផ្លូវ) (ឧ. rue très passante) (កុំជា

passagère) ។ *n.* អ្នកដើរតាមផ្លូវ (ឧ. arrêter les passants) ។

en passant *loc. adv.* តាមខ្ទាប់ម៉ឺ; ដោយឥតឈប់, ដោយមិនទទួប

passation *n.f.* ការប្រគល់ (តំណែង, អំណាច ។ ល ។); ការចុះ ឬ ធ្វើលិខិតគតិយុត្ត (ឧ. passation d'un contrat ការចុះកិច្ចសន្យា) ។ passation d'écriture ការចុះលេខា (ការចុះវិធីលេខក្នុងសៀវភៅគណនី)

passavant *n.m.* តវនប័ត្រ [តៈ-មៈ-នៈ-] (លិខិតអនុញ្ញាតឱ្យនាំចេញចូលក្នុងដែនគយ ចំពោះទំនិញដែលបង់ពន្ធរួច ឬ ដែលរួចពន្ធ)

passe *n.f.* ការឆ្លងកាត់ (ឧ. une passe de pigeons ramiers); លិខិតអនុញ្ញាតឆ្លងកាត់ (ឧ. en temps de blocus, il faut une passe pour s'embarquer) ។

Arg. ម៉ាស៊ីនកាត់ក (ឧ. gerber (condamner) à la passe) ។

passe d'armes *Fig.* ការលេងសំដី (ឧ. à Paris on aime les passes d'armes parlementaires) ។

Mar. ច្រកចង្អៀត ។

Théâtr. ដំណើរកាត់ឆាក (ដំណើរដែលតួដើរកាត់ឆាកពីម្ខាងទៅម្ខាង) ។

Sports ការឲ្យបាល់ (ការបញ្ជូនបាល់ឲ្យគ្នាឯង)។

Loc. adv. mot de passe សព្ទសញ្ញា (សព្ទសម្រាប់ឲ្យសមាជិកនៃសមាគមមួយស្គាល់គ្នា)។ être en passe de មានលក្ខណសម្បត្តិដើម្បី, ល្មមនឹង (ឧ. il est en passe de réussir)។ bonne passe ឱកាសល្អ ។ être dans une belle passe នៅក្នុងស្ថានភាពល្អ ។ mauvaise passe ស្ថានភាពពិបាកឬស្មុគស្មាញ

passé,e *a.* ដែលកន្លងទៅហើយ (ឧ. les événements passés); លើស, ហួស (ឧ. il est dix heures passées)។

n.m. អតីតកាល, កាលកន្លងទៅហើយ (ឧ. songer avec regret au passé) ។

Gram. អតីតកាល

passé *pré.* ក្រោយ (ឧ. passé dix heures ក្រោយម៉ោង ១០)

passe-balles *n.m.* ព្យាសមាត្រ (ក្ដារតោះប្រហោងសម្រាប់វាស់ព្យាសគ្រាប់កាំភ្លើង)

passe-droit *n.m.* ការអនុគ្រោះខុសច្បាប់ ឬ ខុសទំនៀមទម្លាប់ (*pl.* des passe-droits)

passée *n.f.* ពេលបក្សីចេញពីព្រៃ (ឧ. l'heure de la passée): ពិនសត្វ (លើដី)

passefiler *v.t.* ស្រែះ

passe-lacet *n.m.* ម្ជុលនេរយារ, ម្ជុលហុតខ្សែ (*pl.* des passe-lacets)

passement *n.m.* ជាយខ្សែសយ

passementer *v.t.* តែងលំអដោយជាយខ្សែសយ (ឧ. passementer une jupe)

passementerie *n.f.* សិល្បៈឬជំនួញខ្សែសយ

passementier,ère *a.&n.* អ្នកធ្វើ ឬ លក់ជាយខ្សែសយ

passe-montagne *n.m.* កាត់បត្រប ពស់គ្រាបៀកនឹងក (*pl.* des passe-montagnes)

passe-partout *n.m. inv. &a.* កូនសោចាក់ត្រូវមេច្រើន ; ក្របរូបថតបើកដាក់រូបពីក្រោយ; រណារកន្ទុយត្រី; អ្វីៗប្រើការបានច្រើនមុខ

passe-passe *n m. inv.* tour de passe-passe លែ្បងប៉ិនប្រសប់; *au. fig.* ការបញ្ឆោត; ពុតអាក្រក់

passepoil *n.m.* សំពត់ចំ (ឧ. poche à passepoil)

passeport *n.m.* លិខិតឆ្លងដែន ។ demander ឬ recevoir ses passeports សុំចេញ ឬ ត្រូវបង្ខំឲ្យចេញ (ចំពោះទូតក្នុងករណីមានវិបត្តិខាងនយោបាយ)

passer *v.i.* ទៅ(ឧ. passer à Kep); ឆ្លង (ឧ passer les prés); ចូល, ទៅកាន់ (ឧ. passer chez le boulanger; passer à la caisse) ។

Fig. អស់, អន្តរធាន (ឧ. la beauté passe); ផុត (ផុតពីភ្លើមពីស្លាប់) (ឧ. il vient de passer); ស្លាប់ (មុខងារ); ឡើងឋានន្តរស័ក្តិ (ឧ. il est ឬ a passé inspecteur); ទៅ; ផ្សាយ (ឧ. passer de bouche en

bouche); ចូល (ឧ. ce mot passe dans notre langue); ផ្លាស់ (ប្តូរ, របៀប, ការ ។ ល។) (ឧ. passer du plaisant au sérieux); ឡើងស្រអាប់, ហើរពណ៌ (ឧ. cette étoffe, cette couleur passera) ។

Théâtr. យកមកលេង (រឿងល្ខោន); យកមកបញ្ចាំង (ខ្សែភាពយន្ត) ។

cela lui a passé par la tête គាត់នឹកឃើញ ។ cela peut passer មិនអ្វីទេ ។ cette mode passera ម៉ូតនោះឆាប់សាប ។ en passer par សុខចិត្តទ្រាំ ។ laisser passer ទុកផ្លោះ, មិនពិតាស់, មិនថាអ្វី, មិនកែ (ឧ. laisser passer des erreurs) ។ passer par de rudes épreuves រងទុក្ខទោសគ្រប់យ៉ាង ។ passer par-dessus les difficultés ពុះពារឧបសគ្គ ។ passer pour ល្បី, កេរ្តិ៍ឈ្មោះថា ។ passer sur អត់ទោស (ឧ. passer sur une faute); មិនរើសនឹង (ឧ. passer sur les défauts d'un ouvrage) ។

y passer រលាយអស់, ចាយអស់, ប្រើអស់ (ឧ. toute sa fortune y a passé); ទទួលរង (ទុក្ខទោស, អំពើលំបាក) (ឧ. il nous a fallu y passer) ។ passer chez quelqu'un ទៅ ឬ ចូលសួរ ។ passer à l'ennemi រត់ចូលខាងសត្រូវ ។

v.t. ឆ្លង (ឧ. passer une rivière); ចម្លង (ឧ. bac qui passe des voyageurs); បញ្ចូល ឬ ទទួល (ឧ. passer de la contrebande); ហុចឲ្យ (ឧ. passer un objet à son voisin); ស្លៀក, ពាក់ (ឧ. passer un vêtement); រែង, ត្រង ឧ. passer un bouillon); ហួស (ឧ. passer le but); ឈ្នះ (ឧ. passer quelqu'un à la course); ហួស (ឧ. cela passe mes forces) ។

passer le temps ប្រើពេល ។ passer un contrat, un marché ចុះកិច្ចសន្យា, ចុះអាបណ-សញ្ញា [អា-ប៉ៈ-ណៈ-] ។ passer un article en compte ត្រា

បញ្ចី ។ passer un examen ប្រឡង ។ passer une envie បំពេញចំណង់ ។ passer un fait ភ្លេចការណ៍មួយ ។ passer une faute អត់ទោសកំហុស ។ passer quelqu'un par les armes បាញ់ចោល ។ passer au fil de l'épée កាប់សម្លាប់ ។ passer condamnation ទទួលសារភាពកំហុស ។ passer l'éponge អត់ទោស ។ passer en revue ពិនិត្យមួយម្ដងៗ (ឧ. passer en revue tous les arguments, toutes les preuves) ។

en passant *loc.adv.* ដោយគ្រាន់តែរំឭក; ដោយមិនទទូច ។

se passer *v.pr.* កន្លងទៅ (ឧ. le temps se passe quelquefois à ne rien faire); មាន, មានឡើង (ឧ. la scène se passe au Cambodge; il se passe d'étranges choses); វៀស (មិនត្រូវការ) (ឧ. se passer de vin)។

Loc. prov. il faut passer par là ou par la porte ត្រូវតែចុះចាញ់ ឬដើរចេញខ្លួនឯង។ la chose a passé à fleur de corde នៅតែមួយសរសៃសក់នឹងប៉ះ។ passer comme une chandelle ផុតដោយស្រួល (ស្លាប់ដោយស្រួលដូចទៀនរលត់)។ le temps passe et la mort vient ពេលទើបអាយុក្ស័យ

passereaux *n.m. pl.* រំកបក្សី [រ:-និ:-ក:-], ពពួកបក្សីសត្វចាប (*au sing.* un passereau)

passerelle *n.f.* ស្ពានតូច

passe-rivière *n.m.* ខ្សែសន្ទូងសម្រាប់ឆ្លង (ខ្សែចងសន្ទូងនឹងបង្គោល ឬដើមឈើសម្រាប់ស្ទូងឆ្លងកាត់ឧបសគ្គ)

passe-temps *n.m.inv.* ល្បែងឬការធ្វើលំហែ

passe-thé *n.m.inv.* កូនចានឆុងតែ

passeur,euse *n.* អ្នកចម្លង; អ្នកលួចចម្លងព្រំដែន

passible *a.* អាចទទួលវេទនារម្មណ៍បាន (ឧ. le corps humain, dans son état naturel, est passible); គួរទទួល (ឧ. tout coupable est passible d'une peine)

passif,ive *a.* អកម្មៈ ដែលទទួលរង (ឧ. nous sommes à la fois actifs et passifs)។ obéissance passive ការស្តាប់បង្គាប់ឬធ្វើតាមទាំងភ្លេចភ្នែក(ដោយឥតពិចារណា)។

Dr. dette passive ម.ព. dette។ passif exigible បំណុលអកម្ម (ពេលទារបានភ្លាម)។

n.m. សរុបបំណុល

passion *n.f.* តណ្ហា (ឧ. réprimer ses passions); ការងប់ (ឧ.avoir la passion du jeu); អ្វីៗដែលគេស្រឡាញ់ងប់ (ឧ. l'étude est sa passion); សេចក្តីក្រេវក្រោធ (ឧ. n'agissez jamais dans la passion); ការលំអៀង (ឧ. jugez avec passion)។

Spécial. ស្នេហាខ្លាំង (ឧ. déclarer sa passion)។

Dr. ពាល្យ។ abus des passions d'un mineur ទុរុបយោគលើពាល្យនៃអនីតិជន

passionnant,e *a.* គួរជាទីចាប់អារម្មណ៍យ៉ាងខ្លាំង (ឧ. d scussion passionnante)

passionné,e *a.* ដែលមានតណ្ហាខ្លាំង; ដែលងប់; ដែលស្រឡាញ់ណាស់ (ឧ. passionné pour la gloire); ដែលបណ្តាលមកពីសេចក្តីក្រេវក្រោធ ឬសេចក្តីលំអៀង (ឧ. langage passionné)

passionnel,elle *a.* នៃកាមតណ្ហា ឬស្នេហាងប់ (ឧ. crime passionnel)

passionnément *adv.* ដោយរំជួលចិត្ត; ដោយក្លៀវក្លា; ដោយចូលចិត្តខ្លាំង

passionner *v.t.* ឲ្យចូលចិត្តខ្លាំង (ឧ. roman qui passionne beaucoup de lecteurs); ធ្វើឲ្យចាប់អារម្មណ៍ខ្លាំង (ឧ. passionner une discussion)។

se passionner (pour) *v.pr.* ស្រឡាញ់ងប់

passionnette *n.f.Fam.* ស្នេហាមិនឋិតថេរ

passivement *adv.* ជាអកម្ម, ដោយឥតតបវិញ

passivité *n.f.* អកម្មភាព, ភាពអ្នកទទួលរងដោយមិនតបវិញ

passoire *n.f.* តម្រង

pastel *n.m.* ប៉ាស្តែល (ដីពណ៌សម្រាប់គូរ); គំនូរប៉ាស្តែល (ឧ. les pastels

de La Tour)

pasteller *v.t.* គូរដោយប៉ាស្តែល

pastelliste *n.* ជាងគំនូរប៉ាស្តែល

pastèque *n.f.* ឪឡឹក

pasteur *n.m.* គង្វាល (ឧ. des moutons et leur pasteur)។ *Fig.* អភិបាល ។ les pasteurs des peuples ប្រជាភិបាល (ព្រះរាជា)។ *Relig.* ប៉ាស្ទ័រ (អាចារ្យខាងសាសនាប្រូតេស្តង់)។ *Spécial.* le Bon Pasteur ព្រះយេស៊ូ

pasteurien ឬ **pastorien,enne** *a.* នៃប៉ាស្ទ័រ, តាមវិធីរបស់ប៉ាស្ទ័រ (ឧ. les méthodes pasteuriennes)

pasteurisation *n.f.* ការកំដៅរម្ងាប់មេរោគ (តាមវិធីរបស់ប៉ាស្ទ័រ)

pasteuriser ឬ **pastoriser** *v.t.* កំដៅរម្ងាប់មេរោគ (តាមវិធីរបស់ប៉ាស្ទ័រ)

pastiche ឬ **pastichage** *n.m.* សៀវភៅឬគំនូរដោយត្រាប់របៀបគេ

pasticher *v.t.* ត្រាប់របៀប (ខាងអក្សរសាស្ត្រ ឬ គំនូរ) (ឧ. pasticher Hugo)

pasticheur,euse *n.* អ្នកត្រាប់របៀបគេ

pastillage *n.m.* ស្កររូប (នំស្ករសូទជារូប); រូបដីឥដ្ឋ

pastille *n.f.* ស្ករគ្រាប់ ; ថ្នាំគុលិកា ; ដុំដីដុតអប់

pastis *n.m.* (គ្រាមភាសាស្រុកខែត្រប្រូវ៉ង់) ម្យៀ; ការណាយ ។ *Fig.* & *Fam.* ការច្របូកច្របល់

pastoral,e,aux *a.* នៃគង្វាលចៀម; នៃស្រែចំការ (ឧ. chant pastoral; vie pastorale); ដែលថ្លែងអំពីជីវភាពនៅស្រែចំការ (ឧ. poésie pastorale)។ *Fig.* នៃប៉ាស្ទ័រ; *spécial.* នៃអេវ៉ែក (ឧ tournée, croix pastorale)

pastorale *n.f.* រឿងល្ខោនថ្លែងអំពីគង្វាលចៀម

pastoralement *adv.* តាមរបៀបអ្នកគង្វាលចៀម (ឧ. vivre pastoralement)

pastorat *n.m.* នាទីជាប៉ាស្ទ័រ (អាចារ្យខាងសាសនា)

pastoriser *v.t.* ម.ក. pasteuriser

pastoureau *n.f.* ក្មេងប្រុសគង្វាលចៀម

pastourelle *n.f.* ក្មេងស្រីគង្វាលចៀម

pat *a.m.* *Echecs* អប្ប (ល្បែងចត្រង្គ)

patache *n.f.* រទេះបុរាណ; *par ext.* ឡានមិនល្អ: កប៉ាល់តយ

patachon *n.m.* *Mar.* អ្នកបើកកប៉ាល់

គយ ។ *Fam.* mener une vie de patachon គិតតែស៊ីផឹក (ដូច អ្នកបើករទេះគយដែលចេះតែដើរជានិច្ចហើយគិតតែស៊ីផឹកសប្បាយ)

patafioler *v.t. Fam.* que le bon Dieu te patafiole សុំឲ្យព្រះលោកជួយឯង ។ que le diable te patafiole (ដូចកាលគេថែម et te rapatafiole) សុំឲ្យខ្មោចបិសាចបំផ្លាញឯង

patapouf *n.m. Fam.* មនុស្សកំប៉េះកំប៉ោង

patate *n.f.* ដំឡូង

patatras! *int.* ក្លាំង! (សូរគ្រាប់របស់ធ្លាក់ឮខ្លាំង)

pataud,e *n.&a.* កូនឆ្កែជើងធំ ។ *Fam.* មនុស្សក្រួល

pataugeage ឬ **pataugement** *n.m.* ការលុយភក់

patauger *v.i.* លុយភក់ ។ *Fig.& Fam.* ហែលគោក, ប្រទះការលំបាក (ឧ. patauger dans une traduction)

pataugeur,euse *n.* អ្នកលុយភក់

pâte *n.f.* ម្សៅច្របាច់លាយទឹក ម្សៅស្អិត (ឧ. pâte de papier); ដំណាប់ផ្លែឈើក្រៀម (ឧ. pâte de fruits)។ pâte alimentaire ម្សៅធញ្ញជាតិ ។

Fig.& Fam. រូបរាង (ឧ. vous êtes d'une pâte à vivre cent ans)។ mettre la main à la pâte ម.ព. main។ comme un coq en pâte ដូចមាន់រាងលើស្រូវ (នៅក្នុងស្ថានភាពរុងរឿង)

pâté *n.m.* សាច់ប៉ាតេ, ប្រហិត។ *Fig.* ដំណក់ទឹកខ្មៅលើក្រដាស ។ pâté de maison ផ្ទះមួយក្រុម

pâtée *n.f.* ចំណីបំប៉នសត្វ; បាយលាយឲ្យឆ្កែ-ឆ្មា ។ល។

patelin *n.m.Pop.* ភូមិ

patelin,e *a.* ល្អកល្អិន (ឧ. air patelin) ។ *n.* អ្នកមានឫកឫកពាល្អកល្អិន

patelinage *n.m.* ឬ **patelinerie** *n.f.* ឫកល្អកល្អិន

pateliner *v.i* ប្រើឫកល្អកល្អិន ។ *v.t.* ផ្គាប់ចិត្តដោយល្អកល្អិន

patelle *n.f.* ជាតខ្យង

patelliforme *a.* ជារាងជាតខ្យង

patenôtre *n.f.* ធម៌សូត្របន់ស្រន់ (ឧ. marmotter des patenôtres)។

Par ext. សំដីស្រាំដែលគិតជាមុន

patent,e *a.* ជាក់ស្ដែង (ឧ. fait patent)។ lettre patente រាជសារទៅសភា

patentable *a.* ដែលត្រូវជាប់ពន្ធប៉ាតង់ (ឧ. commerçant patentable)

patente *n.f.* ប៉ាតង់ (ពន្ធចំពោះម្យ៉ាងគម្រូវឲ្យពាណិជ្ជករ, ឧស្សាហករ និង អ្នកកាន់វិជ្ជាជីវៈខ្លះបង់); សន្លឹកប៉ាតង់; (ឧ. montrer sa patente)។

Mar. patente de santé វិញ្ញាបនប័ត្រសុខភាព(វិញ្ញាបនប័ត្រពេទ្យចេញឲ្យនាវាដែលត្រូវចេញដំណើរ)

patenté,e *n.* & *a.* ដែលមានប៉ាតង់, ដែលមានឋានន្តរ (ឧ. défenseur patenté d'une institution); ដែលបង់ពន្ធប៉ាតង់ (ឧ. commerçant patenté)

patenter *v.t.* ដាក់ពន្ធប៉ាតង់ (ឧ. on patente toutes les formes de commerce); ចេញសន្លឹកប៉ាតង់ឲ្យ (ឧ. patenter un inventeur)

patère *n.f.* ដៃកៅ (សម្រាប់ពាក់ព្យួរ)

paternalisme *n.m.* បិតុនិយម(លទ្ធិសង្គមនិយម ដែលថាមានតែនាយម្នាក់ទេជាអ្នកមានអំណាចបង្កើតនឹងជាក់ចែងការសង្គមទាំងឡាយក្នុងសហគ្រាស)

paternaliste *a.* បិតុនិយម

paterne *a.* ស្លូតល្អ (ឧ. un ton paterne)

paternel,elle *a.* នៃឪពុក (ឧ. domicile paternel; autorité paternelle); ខាងឪពុក (ឧ. grands-parents paternels); ប្រកបដោយព្រហ្មវិហារធម៌ (ឧ. ton paternel)។

n.m. Pop. ឪ

paternellement *adv.* ដូចឪពុក; ដោយព្រហ្មវិហារធម៌

paternité *n.f.* បិតុភាព, ភាពជាបិតា។ paternité légitime បិតុភាពពេញច្បាប់។ paternité naturelle បិតុភាពក្រៅច្បាប់។ paternité adoptive បិតុភាពចិញ្ចឹម។

Fig. បិតុភាព, ការបង្កើតមុនគេ (ឧ. revendiquer la paternité d'une invention)

pâteux,euse *a.* ស្អិត (ជាប់មាត់) (ឧ. fruit pâteux); ខាប់ (ឧ. encre pâteuse); ស្រអាប់។ avoir la bouche ឬ la langue pâteuse

ស្ងៀតមាត់, មិននឹងស្រដី

pathétique *a.* ដែលនាំឲ្យរំភើបចិត្ត (ឧ. discours, ton pathétique)

pathétiquement *adv.* ដោយឲ្យរំភើបចិត្ត

pathétisme *n.m.* ភាពឲ្យរំភើបចិត្ត

pathogène *a.* ដែលបង្កជម្ងឺ (ឧ. microbe pathogène)

pathogénie *n.f.* រោគសមុដ្ឋាន

pathogénique *a.* នៃរោគសមុដ្ឋាន(ឧ. recherches pathogéniques)

pathognomonique *a.* ដែលឲ្យស្គាល់រោគ

pathologie *n.f.* រោគសាស្ត្រ

pathologique *a.* នៃរោគសាស្ត្រ (ឧ. anatomie pathologique)

pathologiquement *adv.* តាមរោគ-សាស្ត្រ

pathologiste *n.&a.m.* រោគសាស្ត្រិន, ពេទ្យខាងរោគសាស្ត្រ

pathos [-toss] *n.m.* *Fam.* សំដីសាំញ៉ាំ

patibulaire *a.* នៃឈើឆ្កាង (ឧ. fourches patibulaires) ។ *Fig.* mine, air patibulaire មុខមនុស្សហាក់ឃោរឃៅ(មនុស្សគួរខ្លាច ឬ គួរស្អប់)

patiemment *adv.* ដោយអត់ធ្មត់, ដោយអំណត់ (ឧ. supporter patiemment une injure)

patience *n.f.* ខន្តី, សេចក្ដីអត់ធ្មត់, អំណត់ (ឧ. la patience vient à bout de tout)។ prendre patience រង់ចាំដោយឥតរអ៊ូ។ prendre en patience ទ្រាំដោយគ្មានត្អូញ (ឧ. prendre son mal en patience) ។ perdre patience ទ្រាំលែងបាន ។ patience! *int.* ទ្រាំបន្តិច! (ឧ. patience! nous arrivons); ចាំមើល! (ឧ. patience! j'aurai mon tour) (ctr. calme, sang-froid, tranquillité)

patient,e *a.* *Phil.* ដែលទទួលរា-ម្មណ៍ (ឧ. l'être est agent ou patient); ដែលចេះអត់ធ្មត់ ។ *n.* អ្នកទទួលរងការវះកាត់ ឬ រងទារុណកម្ម

patienter *v.i.* អត់ធ្មត់, ទ្រាំ

patin *n.m.* ស្បែកជើងរំអិល ។ patins à roulettes ស្បែកជើងរំអិលមានកង់

patinage *n.m.* ការជិះរំអិល (ឧ.

le patinage est un sport très agréable)

patine *n.f.* ស្នឹមទង់ដែង ។ *Par anal.* ដំណើរឡើងពណ៌នៃរបស់ទុកយូរ

patiner *v.i.* ដើររអិល; រអិល (បំពោះរថយន្តដែលបត់) (ឧ. roue qui patine sur le sol) ។

v.t. ធ្វើឲ្យឡើងពណ៌ស្លួបរបស់ទុកយូរ

patinette *n.f.* ម.ព. trottinette

patineur,euse *n.* អ្នកដើររអិល

patinoire *n.f.* កន្លែងដើររអិល

patio [– ti –] *n.m.* ធ្លាក្នុងផ្ទះ

pâtir *v.i.* ឈឺចាប់ (ឧ. les bons pâtissent pour les méchants)

patiras *n.m.Fam.* អ្នកដែលគេធ្វើបាប

pâtis *n.m.* កន្លែងឲ្យសត្វស៊ីស្មៅ

pâtissant,e *a.* ដែលឈឺចាប់

pâtisser *v.t.* កិនម្សៅធ្វើនំ (ឧ. pâtisser la farine) ។ *v.t.* ធ្វើនំ (ឧ. femme qui pâtisse bien)

pâtisserie *n.f.* នំផ្អែមធ្វើពីម្សៅ (ឧ. manger de la patisserie); ឬហាន, កន្លែងធ្វើឬលក់នំ

pâtissier,ère *n.* អ្នកធ្វើឬលក់នំផ្អែម

patissoire *n.f.* តុលាយម្សៅ

patoche *n.f. Fam.* ប្រអប់ដៃធំ; ការវាយបាតដៃ

patois *n.m.* គ្រាមភាសា, សំដីដោយឡែកតាមតំបន់

patois,e *a.* នៃគ្រាមភាសា (ឧ. locution patoise)

patoiser *v.i.* និយាយគ្រាមភាសា

pâton *n.m.* ដុំម្សៅ, ដុំដីសម្រាប់ធ្វើផែរ គ្របៀកកាជ៌ន

patouillard *n.m. Fam.* តាភ្លុកធូន (បើកស៊េរមិនរួច)

patouille *n.f. Fam.* ម្សៅស៊ីរខាប់ ស៊ីរកក

patouiller *v.i.Fam.* ល្បុយភក់

patraque *n.f.Fam.* គ្រឿងម៉ាស៊ីនដែលគម្លើងដោយខ្ចីខ្លាឬដែលសឹករស់ ។ *a.Fam.* ដែលដើរមិនស្រួល(ម៉ាស៊ីន) (ឧ. cette montre est une vraie patraque) ។ *Fig. & Fam.* កំសោយ, ឈឺប្រើន (ឧ. se sentir un peu patraque)

pâtre *n.m.* គង្វាលសត្វ

patriarcal,e,aux *a.* នៃព្រឹទ្ធាចារ្យ(ឧ. simplicité patriarcale) ។ *Sociol.* នៃបេត្តិយាក [ប៉េត-តៃ-យ៉ះ-

ក] (ឧ. régime patriarcal)

patriarcalement *adv.* ជាព្រឹទ្ធាចារ្យ (ឧ. vivre patriarcalement)

patriarcat *n.m. Sociol.* បេត្តិយ្យក [ប៉េត-តៃ-យ៉ៈ-ក] (របបគ្រួសារដែលឪបិតាមានអំណាចលើសមាជិកឯទៀត) (ឧ. le patriarcat a succédé au matriarcat)

patriarche *n.m. Fig.* ព្រឹទ្ធាចារ្យ

patricien,enne *n.&a. Par ext.* អភិជន (ឧ.famille patricienne)

patrie *n.f.* មាតុភូមិ , បិតុប្រទេស ; ប្រទេស ឬ ស្រុកកំណើត ។ mère patrie ម.ព. mère ។ céleste patrie ឋានសួគ៌ (នៃពួកគ្រិស្ទៀង)

patrimoine *n.m.* បេតិកភ័ណ្ឌ [ប៉េ-តិ-កៈ-] (កេរ្តិ៍ពីឪពុកឬពីម្ដាយ; *au fig.* កេរ្តិ៍ដំណែលរួមគ្នា ឧ. la science est le patrimoine des hommes d'étude)

patrimonial,e,aux *a.* ដែលជាបេតិកភ័ណ្ឌ, ដែលជាកេរ្តិ៍ពីឪពុកម្ដាយ (ឧ. terre patrimoniale)

patrimonialement *adv.* ជាបេតិកភ័ណ្ឌ

patriotard,e *a. Fam.* អ្នកបញ្ចេញឫកស្រឡាញ់មាតុភូមិ

patriote *n.& a.* អ្នកស្នេហាបិតុប្រទេស ឬ មាតុភូមិ

patriotique *a.* ស្នេហាមាតុភូមិ (ឧ. sentiments patriotiques)

patriotiquement *adv.* ដោយស្នេហាមាតុភូមិ

patriotisme *n.m.* ស្នេហាមាតុភូមិ

patron,onne *n.* បរិបាល [ប៉ៈ-រិ-បាល], នាយសហគ្រាស, ម្ចាស់, ថៅកែ ។ *Relig.* បរិបាល, ឧបត្ថម្ភក (ឧ. sainte Geneviève, patronne de Paris)

patron *n.m.* គំរូកាត់ខោអាវ; ក្រដាសរំហោកសម្រាប់ផាត់ពណ៌

patronage *n.m.* បរិបាលកិច្ច, ការឧបត្ថម្ភ

patronal,e,aux *a.* នៃបរិបាល (នាយសហគ្រាសឬថៅកែ) (ឧ. syndicat patronal)

patronat *n.m.* បរិបាលភាព, សិទ្ធិ ឬ អំណាចនាយ; បរិបាលក, ពួកនាយ

patronner *v.t.* ឧបត្ថម្ភ (ឧ. patronner un candidat); បោះពុម្ពដោយប្រើក្រដាសរំហោក; កាត់ដោយប្រើក្រដាសគំរូ (ឧ. patronner

une jupe)

patronyme *n.m. lit.* nom patronymique

patronymique *a.* nom patronymique គោត្រនាម

patrouillage *n.m. Fam.* ការល្បាត; អំពើផ្ដេសផ្ដាសប្រព្រឹត្តក្នុងពេលល្បាត

patrouille *n.f.* ការល្បាត (ឧ. exécuter une patrouille)។ *Par ext.* ទ័ពល្បាត (ឧ. la patrouille a perdu trois hommes)

patrouiller *v.i. Fam.* លុយភក់, រាក្រឡុកទឹកភក់ ។ *Mil.* ល្បាត

patrouilleur *n.m.* ទាហាន-ភាគ ឬ អាកាសយានល្បាត

patte *n.f.* ជើង (សត្វ, របស់) (ឧ. les insectes ont trois paires de pattes)។ patte articulée ជើងមានសន្លាក់ ។ *Fam.* ដៃ ឬ ជើង (មនុស្ស)។ *Fig. & fam.* ដៃ (ការប៉ិនប្រសប់) (ឧ. la patte d'un peintre) ។ patte blanche ដៃស្អាត (គ្មានសៅហ្មង) (ឧ. montrez-moi patte blanche) ។ ជើង (កែវ) (ឧ. un verre à patte)។ *Cout.* ជាន (បន្ទះសំពត់ឬស្បែកសម្រាប់ភ្ជាប់)។ patte d'épaule ជានស្មា (បន្ទះសំពត់ភ្ជាប់លើអាវ) ។

Loc. div. pattes de mouche អក្សរឆ្វារហើយកព្រក់ ។ *Pop.* pattes d'araignée ការចាក់ក្រឡេក ។ pattes de lapin អមគាងខ្លី (ពុកចង្កាដុះត្រង់ថ្ពាល់) ។ pattes de velours ជើងឆ្មាដែលលាក់ក្រចក, *au fig.* ការលាក់ពុត; ដៃស្រាល, ការធ្វើអ្វីដោយថ្នម។ coup de patte ការរិះគន់ ។ se servir de la patte du chat pour tirer les marrons du feu ញុះគេឲ្យធ្វើការលំបាកជំនួសខ្លួន (ម.ព. chat ផង) ។ graisser la patte à quelqu'un យកជើង, សូក ។ marcher à quatre pattes វារ; *au fig.* ពុះពោររាបខ្លួនសត្វ ។ mettre la patte sur ចាប់បាន; រកឃើញ, ឆយ ; ធ្វើបាប ។ être entre les pattes de quelqu'un នៅក្នុងកណ្ដាប់ដៃ ។ tomber sous la patte de quelqu'un ធ្លាក់ក្នុងកណ្ដាប់ដៃគេ (ដូចកណ្ដុរដែលឆ្មាចាប់បាន)។ sortir, se tirer ឬ

s'échapper des pattes de quelqu'un រួចផុត ឬ រួចអំពីកណ្ដាប់ដៃ ។ tenir quelqu'un sous sa patte មានអ្នកណាម្នាក់នៅក្នុងកណ្ដាប់ដៃខ្លួន ។ retomber sur ses pattes មិនធ្លាក់ចំណាប់, បានរួចខ្លួន (ម.ព. chat ផង) ។ ne pouvoir remuer ni pied ni patte កម្រើកខ្លួនមិនរួច,ធ្វើអ្វីមិនកើត។

Loc. adv. Fam. à patte ដោយជើង

patte-d'oie *n.f.* ផ្លូវប្រសព្វគ្នាច្រើន,កន្លែងផ្លូវបែកច្រើន ។ *Fig.* ស្នាមជ្រួញកន្ទុយភ្នែក (*pl.* des pattes-d'oie)

pattu,e *a.* ដែលមានជើងធំ (ឧ. chien pattu); ដែលមានរោមនៅក្នុងជើង (បក្សី) (ឧ. pigeon pattu)

pâturable *a.* អាចឲ្យសត្វស៊ីស្មៅបាន (ឧ. plaines pâturables)

pâturage *n.m.* កន្លែងសត្វស៊ីស្មៅ (ឧ. les pâturages alpestres); ការឲ្យសត្វស៊ីស្មៅ; សិទ្ធិឲ្យសត្វស៊ីស្មៅ

pâture *n.f.* ចំណីសត្វ; វាលស្មៅសត្វ (ឧ. bœuf mis en pâture) ។ *Fam.* ចំណីមនុស្ស ។

Fig. ចំណី (ឧ. cet incident a servi de pâture aux journaux)

pâturer *a.* ស៊ីចំណី (សត្វ), ស៊ីស្មៅ

paturon *n.m.* កកែងសេះ (កជើងសេះ)

pauciflore *a.* ដែលមានផ្កាតិច

paume *n.f.* បាតដៃ ។ *Jeux* ប៉ូម (កីឡាវាយបាល់មួយបែប)

paumer *v.t. Arg.* ទះ (ឧ. paumer la figure de quelqu'un); ចាប់ (ឧ. paumer un voleur) ។ paumer marron ចាប់ដាក់ស្លុង ។

Pop. វង្វេងដៃ; បាត់ ។

se paumer *v.pr.* វង្វេង; ទះគ្នា

paupérisation *n.f.* ការធ្វើឲ្យបណ្ដាក្រព្រ

paupérisme *n.m.* ក្រនិយម; ភាពបណ្ដាក្រព្រពោកយ៉ាក

paupière *n.f.* ត្របកភ្នែក ។ ouvrir les paupières បើកភ្នែក; ភ្ញាក់ ។ fermer la paupière បិទភ្នែក; ដេក; ស្លាប់ ។ fermer les paupières à quelqu'un បិទភ្នែកឲ្យ (ជួយនៅពេលផុតដង្ហើម)

pause *n.f.* ការផ្អាក, ការឈប់សំកាំង (ឧ. voyageur, lecteur qui fait une pause) ។ *Mus.* បង្អង់ ។ *Sports* ការឈប់សម្រាកបន្ទោះទឹក (ក្នុងកីឡាហែលទឹក)

pauser *v.t.* ផ្អាក, ឈប់សំកាំង

pauvre *a.* ក្រ (ឧ. une famille pauvre; pays pauvre); អន់ (ឧ. un pauvre orateur); តិច, មិនគ្រប់គ្រាន់ (ឧ. un pauvre budget); កំសត់, គួរឱ្យអាណិតអាសូរ (ឧ. le pauvre homme!) ។

Loc. div. pauvre de អប្ប, មិនគ្រប់គ្រាន់ (ឧ. pauvre d'esprit) ។ pauvre en ដែលខ្វះ, មិនបរិបូរ (ឧ. pauvre en minerais) ។ pauvre diable មនុស្សកំសត់ ។ être pauvre comme Job ក្រណាស់ (គ្មានអ្វីបន្តិចសោះ) ។ pauvre sire ឬ pauvre hère មនុស្សអន់ (គ្មានគេរាប់អាន, គ្មានគុណូបការ) ។ langue pauvre ភាសាមិនគ្រប់គ្រាន់ (ខ្វះសព្ទនិយាយ) ។ ne pas dire un pauvre mot មិនចេញស្តីមួយម៉ាត់

n.m. អ្នកក្រ (ឧ. faire l'aumône à un pauvre) (ព.ផ. aisé, cossu, fortuné, riche)

pauvrement *adv.* ដោយក្រលំបាក (ឧ. vivre pauvrement)

pauvresse *n.f.* ស្រីអ្នកក្រ; ស្មូម, យាចិកា (ឧ. secourir une pauvresse)

pauvret,ette *a.* ក្រ (សព្ទនេះមានសំដែងសេចក្តីអាណិត)

pauvreté *n.f.* ភាពក្រ (ឧ. pauvreté n'est pas vice) (ឃ. besoin, dénuement, gêne, indigence, nécessité, pénurie)

pavage ឬ **pavement** *n.m.* កម្រាលថ្ម (ឧ. pavage en grès); ការក្រាលថ្ម

pavaner (se) *v.pr.* ដើរបញ្ចេញកង (ដូចក្ងោកពង់)

pavé *n.m.* ថ្មក្រាល; កាតក្រាលថ្មនៃវិថី ។ battre le pavé ម.ព. battre ។ être sur le pavé គ្មានលំនៅ, គ្មានរបរ ។ tenir le haut du pavé នៅមុខគេ

pavement *n.m.* ម.ព. pavage

paver *v.t.* ក្រាលថ្ម (ឧ. paver une

avenue)

paveur *n.&a.m.* អ្នកក្រាលថ្ម

pavillon *n.m.* ពន្លា, មណ្ឌប, ផ្ទះតូច (ឧ. pavillon de chasse; pavillon de banlieue) ។ *Poét.* មេឃ (ឧ. le pavillon d'azur)។

Loc. fam. baisser pavillon ឬ mettre pavillon bas devant quelqu'un សុំញ៉ម, ចុះចាញ់ ។

Acoust. មាត់រីកនៃបំពង់បំពងសម្លេង ។

Anat. pavillon de l'oreille ស្លឹកត្រចៀក ។

Mar. ទង់, មេលើម។ hisser pavillon បង្ហូតទង់ ។ mettre un pavillon en berne បង្ហូតទង់លស់ (បង្ហូតពាក់កណ្ដាលដងទង់)។ rentrer son pavillon ទម្លាក់ទង់ ។ amener son pavillon សុំចាញ់ ។ នាវា (ឧ. la part du pavillon anglais dans le commerce du monde est considérable)

pavillonnerie *n.f.* កន្លែងធ្វើទង់; កន្លែងរក្សាទង់

pavimenteux,euse *a. Techn.* សម្រាប់ក្រាលថ្នល់ (ថ្ម)

pavois *n.m. Autref.* ខែលធំ ។ *Fig.* élever sur le pavois ប្រគល់អំណាចក្សត្រ (តាមទំនៀមទម្លាប់ជនជាតិហ្សេរម៉ាំងនឹងហ្វ្រង់ គេតែងលើកដាក់លើខែលសែង នូវក្សត្រដែលទើបនឹងជ្រើសតាំង); *au fig.* លើកតម្កើង ។ monter sur le pavois ឡើងសោយរាជសម្បត្តិ; ឡើងឋានៈខ្ពស់ ។ tomber du pavois ធ្លាក់ពីរាជសម្បត្តិ; ចុះឋានៈ

pavoisement *n.m.* ការតែងលំអដោយទង់

pavoiser *v.t.* តែងលំអដោយទង់។ *Fig. & Fam.* សប្បាយរីករាយណាស់

pavot *n.m.* ដើមអាភៀន

payable *a.* ដែលត្រូវបង់ថ្លៃ; ដែលត្រូវសង

payant,e *a.* ដែលបង់ថ្លៃ (ឧ. spectateurs payants); ដែលមានថ្លៃ (ឧ. spectacle payant) ។ *Fam.* ដែលឲ្យផល (ឧ. une affaire payante) ។

n. អ្នកបង់ថ្លៃ (ឧ. les invités et les payants)

paye *n.f.* ម.ព. paie

payement ម.ព. paiement

payer *v.t.* សង; បង់ថ្លៃ; បង់ពន្ធ; បើកប្រាក់ឲ្យ(ឧ.payer des ouvriers); ឲ្យរង្វាន់; តបគុណ (ឧ. payer généreusement un service) ។ *Fig.* បានដោយបង់ខាត (ឧ. payer cher une victoire ឈ្នះដោយខូចខាតច្រើន; សងលាងទោសដោយទទួលទណ្ឌកម្ម (ឧ. payer son crime); ខ្ញុំសធុលសោហ៊ុយ (ឧ. je n'ai pas été payé de mes efforts) ; ធ្វើទោស (ឧ. on l'a payé de son insolence) ។ payer d'audace បញ្ចេញសេចក្ដីអង់អាច ។ payer d'ingratitude រមិលគុណ ។ payer de sa personne ប្រថុយខ្លួនឲ្យរងគ្រោះថ្នាក់; ប្រព្រឹត្តដោយខ្លួនឯង ។ payer de retour សងវិញ, តបគុណវិញ ។ payer pour les autres ទទួលទោសជំនួសគេ ។ payer le tribut à la nature បង់ពន្ធដី, ស្លាប់ ។ il me payera ខ្ញុំនឹងសងសឹកវិញ ។

v.i. Fam. ឲ្យផល(ឧ.commerce qui paie) ។

se payer *v.pr.* ទទួលប្រាក់; ទទួលរង្វាន់; ទទួលទោស ។ se payer un objet ទិញ ។ se payer un voyage ធ្វើដំណើរ (ដោយចេញប្រាក់ខ្លួនឯង) ។ se payer de បានតែ (ឧ. se payer de paroles បានតែសំដី)

payeur,euse *n.* អ្នកសង; អ្នកបើកប្រាក់ (ឧ. trésorier-payeur général)

pays *n.m.* ស្រុក, ប្រទេស (ឧ. pays chauds) ; ប្រជាជាតិ (ឧ. pays civilisé) ។ pays de cocagne ម.ព. cocagne ។ មាតុភូមិ, ស្រុកកំណើត (ឧ. quitter son pays) ។ mal du pays ការនឹកស្រុក ។ pays perdu ស្រុកឆ្ងាយដាច់សង្វែង ។ voir du pays ដើរមើលស្រុក, ធ្វើដំណើរ ។ être en pays de connaissance នៅក្នុងចំណោមអ្នកស្គាល់ ។ *Fam.* អ្នកស្រុក (ឧ. tiens, voilà mon pays (*f.* payse) ។ pays sous développé ប្រទេសឧនាភិវឌ្ឍ [—អ៊ូ-ណា-ភិ-វ័ត]

paysage *n.m.* ទេសភាព (ឧ. admirer le paysage); គំនូរទេសភាព (ឧ. Corot a laissé de magnifiques paysages)

paysagiste *n.m.* & *a.* ជាងគំនូរទេសភាព

paysan,anne *n.* អ្នកស្រែ-ចំការ, អ្នកជនបទ ។ paysan du Danube មនុស្សគម្រោងហើយមាត់ដៅ

paysannerie *n.f.* ភាព-ឋានៈ ឬ ក្រុមអ្នកស្រែចំការ; សៀវភៅរឿងអ្នកស្រែចំការ (ឧ.les paysanneries de George Sand)

payse *n.f.* ម.ព. pays

P.C.B. *n.m.* (ពាក្យបំព្រួញនៃ certificat d'études Physiques, Chimiques et Biologiques)

péage *n.m.* ពន្ធចតឆ្លង (ពន្ធលើសង្កាត់ផ្លូវ, ស្ពាន ។ ល ។)

péager,ère *n.* អ្នកហូតពន្ធចតឆ្លង

peau *n.f.* ចម្ម, ស្បែក; សំបក (ឧ. une peau de banane) ។ peau d'âne សញ្ញាបត្រ ។ n'avoir que la peau et les os មានតែស្បែកនឹងឆ្អឹង (ស្គមណាស់) ។ se mettre dans la peau de quelqu'un ធ្វើខ្លួនជាអ្នកណាមួយ ។ vendre cher sa peau ការពារខ្លួនយ៉ាងអង់អាចមុននឹងស្លាប់ ។ faire peau neuve ផ្លាស់ឥរិយា-បថ-យោបល់ ឬសំលៀកបំពាក់ជាថ្មី

peausserie *n.f.* ចម្មពាណិជ្ជ; ចម្មដ្ឋាន; ជំនួញ ឬ កន្លែងសម្លាប់ស្បែក

peaussier *n.&a. m.* ចម្មការី; ចម្ម-ពាណិជ; ជាងសម្លាប់ស្បែក; ឈ្មួញស្បែក

pébrine *n.f.* ទ្រនិចរុយ (រោគដង្កូវនាងបណ្ដាលឲ្យមានស្នាមខ្មៅៗ ប៉ុនគ្រាប់ម្រេច)

pécari *n.m.* ជ្រូកព្រៃម្យ៉ាង (នៅអាមេរិក)

peccabilité *n.f.* ការអាចធ្វើបាបកម្ម ឬធ្វើខុសបាន

peccable *a.* អាចធ្វើបាបកម្ម ឬ ធ្វើខុសបាន (ឧ. tout homme est peccable)

peccadille *n.f.* កំហុសស្រាល

pêche *n.f.* ប៉ែស (ផ្លែឈើម្យ៉ាង)

pêche *n.f.* ការនេសាទ (ឧ. aller à la pêche); ត្រីនេសាទបាន (ឧ. vendre sa pêche)

péché *n.m.* *Relig.* បាប, បាបកម្ម (ឧ. confesser ses péchés) ។

péché mignon ទម្លាប់អាក្រក់ដែលគេមិនចង់លះបង់ (ឧ. la gourmandise est un péché mignon)។ *pl.* péchés capitaux មេបាបកម្ម (បាបកម្មដែលជាមេនាំឲ្យកើតបាបកម្មឯទៀត) (ឧ. les sept péchés capitaux sont l'orgueil, l'envie, l'avarice, la luxure, la gourmandise, la colère et la paresse)

pécher *v.i.* ធ្វើបាបកម្ម។ *Fig.* ធ្វើខុស (ឧ. pécher contre la politesse); មានខ្វះ

pécher *n.m.* ដើមប៉ែស (ឈើម្យ៉ាង)

pêcher *v.t.* នេសាទ (ឧ. pêcher des truites)។ *Fig. & fam.* យកពី, ស្រង់ពី(ឧ. où a-t-il pêché cette nouvelle?)។ pêcher en eau trouble ម.ព. eau

pêcherie *n.f.* កន្លែងនេសាទ, ឡូត៍នេសាទ (ឧ. les pêcheries du Tonlé Sap)

pécheur,eresse *n.* អ្នកធ្វើបាបកម្ម ឬធ្វើខុស; អ្នកមានបាប; អ្នកចូលចិត្តធ្វើបាបកម្ម

pêcheur,euse *n.* នេសាទ

pécore *n.f. Fam.* មនុស្សភ្លើ

pecque *n.f. Fam.* ស្រីល្ងង់ហើយក្រអឺតក្រទម

pectoral,e,aux *a.* នៃទ្រូង(ឧ. muscles pectoraux)។ nageoires pectorales ម.ព. nageoire ។ សម្រាប់ទ្រូង(ឧ. pâte pectorale)។ *n.m. Pop.* ពោះ, ក្រពះ ។ s'humecter le pectoral ផឹក។ *Armur.* គ្រោះទ្រូង

péculat *n.m.* និកត្យហោរ [និ-កៈ-ត្យ-រៈ-ហោ], ការគៃបន្លំប្រាក់រាជការ

pécule *n.m.* សញ្ចយធន [ស័ញ-ចៈ-យៈ-], ប្រាក់សំចៃ (ឧ. amasser un petit pécule); ប្រាក់បន្ថែមក្នុងបៀវត្ស

pécune *n.f.* ប្រាក់កាស

pécuniaire *a.* នៃប្រាក់កាស(ឧ. ennui pécuniaire); ជាប្រាក់កាស (ឧ. intérêt pécuniaire; peine pécuniaire)

pécuniairement *adv.* ដោយប្រាក់កាស (ឧ. être condamné pécuniairement)

pécunieux,euse *a.* ដែលមានប្រាក់កាសច្រើន

pédagogie *n.f.* គរុកោសល្យ [គៈ-រុ-កោ-សល់]

pédagogique *a.* នៃគរុកោសល្យ (ឧ. méthode pédagogique) ។ musée pédagogique ភណ្ឌាទិ-ភេគន៍គរុកោសល្យ ។ service pédagogique ក្រុមគរុកោសល្យ ។ *n.f.* គរុកោសល្យ

pédagogiquement *adv.* ដោយគរុ-កោសល្យ

pédagogue *n.m.* អ្នកគរុកោសល្យ, គ្រូអាចារ្យ (ពាក្យមើលងាយ); អ្នកវាយឫកពាក្រអឺត; អ្នកប្រដៅឬរិះគន់គេ

pédale *n.f. Techn.* ឈ្នាន់ (ឧ. pédale de débrayage) ។ *Par ext.* កីឡាទោចក្រយាន (ឧ. les fervents de la pédale)

pédaler *v.i.* ជាន់ឈ្នាន់, ធាក់ឈ្នាន់ ។ *Par ext.* ជិះទោចក្រយាន

pédaleur,euse *n. Fam.* អ្នកជិះទោចក្រយាន

pédalier *n.m. Techn.* គ្រឿងឈ្នាន់

pédant,e *n.* អ្នកវាយឫកបេះ; អ្នកសំដីខ្ពស់; អ្នកប្រដៅឬរិះគន់គេ

pédanterie *n.f.* ឬ **pédantisme** *n.m.* សំដីឬឫកពាជាអ្នកវាយឫកបេះ

pédantesque *a.* ដែលបញ្ចេញចំណេះ (ឧ. discours pédantesques)

pédéraste *n.m.* អ្នកលេងកូនជិង

pédérastie *n.f.* ការលេងកូនជិង

pédestre *a.* ដែលធ្វើដោយជើង(ដំណើរ) (ឧ. voyage pédestre)។ statue pédestre រូបចម្លាក់ឬរូបស្មិតមនុស្សឈរ

pédestrement *adv.* ដោយជើង (ឧ. regaguer pédestrement sa demeure)

pédiatre *n.m.* ពេទ្យកុមារ

pédiatrie *n.f.* វិជ្ជាពេទ្យកុមារ

pédicelle *n.f.Bot.* ទងតូច

pédicellé,e *a.Bot.* ដែលមានទងតូច

pédiculaire *a.* នៃចៃ

pédieux,euse *a.* នៃជើង (ឧ.artère pédieuse)

pedigree [-gré] *n.m.* បញ្ជីពូជសត្វ (សេះ, ឆ្កែ ។ល។)

pédologie ឬ **paidologie** *n.f.* កុមារចិត្តសាស្ត្រ

pédologie *n.f.* ធរណីសាស្ត្រ, វិទ្យា-សាស្ត្រខាងដី

pédologue *n.m.* អ្នកកុមារចិត្តសាស្ត្រ

pédonculaire *a.Bot.* នៃទង

pédoncule *n.m.* ទង(នៃផ្កាឬផ្លែ)

pédonculé,e *a.* ដែលមានទង

pégase *n.m. Ichtyol.* ត្រីហើរ (ត្រីមានស្លាប) ។ *Myth.* សេះមានស្លាប

pegmatite *n.f.* ប៉ូលកណាស៊ីលា [ប៉ូ-លៈ-កៈ-ណៈ-]

pègre *n.f.* បនតោរ; ក្រុមមនុស្សខូច

peignage *n.m.Ind.* ការសិតអំបោះ; កន្លែងសិតអំបោះ

peigne *n.m.* ស្និត, ក្រាស, ប្រែង

peignée *n.f. Ind.* ចំនួនអំបោះមួយប្រែង ។ *Fam.* ការវាយឬប្រវាយគ្នា

peigner *v.t.* សិត; ធ្វើឬថែទាំដោយផ្ចិតផ្ចង់ ។ se peigner *v pr.* សិតសក់; កាត់សក់

peigneur,euse *a.&n.* ដែលសិតអំបោះ (ឧ. ouvrier peigneur) ។ *n.f.* ម៉ាស៊ីនសិតអំបោះ

peignier *n.m.* អ្នកធ្វើ ឬ លក់ក្រាស ឬ ស្និត (សម្រាប់សិតសក់)

peignoir *n.m.* អាវពាក់សិតសក់; អាវស្រីពាក់នៅផ្ទះ (ក្នុងឡប់ឲ)

peignures *n.f.pl.* សក់សិត

peille *n.f.* កន្ទបសម្រាប់ធ្វើក្រដាស

peinard,e *a.Pop.* ស្រណុក,មិនតៀម

peindre *v t.* វិចិត្រ, គូរ (ឧ. peindre un homme, un paysage); ផាត់ពណ៌; លាបពណ៌ (ឧ. peindre un mur) ។ *Fig.* ពណ៌នា (ឧ. peindre des personnages)

peine *n.f.* ទោស (ឧ. proportionner la peine à la faute); សេចក្ដីលំបាក, ទុក្ខទោស (ឧ. les peines du cœur, de l'esprit); ការនឿយហត់, ការប្រឹងប្រែង (ឧ. se donner beaucoup de peine); ខបសគ្គ, ការពិបាក (ឧ. avoir de la peine à marcher; réussir sans peine); សេចក្ដីទំលប្រ (ឧ. laisser quelqu'un dans la peine) ។

donnez-vous la peine de... សុំមេត្តា... ។ être en peine de មានសេចក្ដីលំបាកនឹង (ឧ. j'étais en peine de ce qu'il était devenu) ។ faire de la peine à ធ្វើឲ្យពិបាកចិត្ត ។ homme de peine ម.ព. homme ។ mourir à la peine ស្លាប់ដោយនឿយហត់ ។ perdre sa peine បំបង់កម្លាំង (ធ្វើការឥតប្រយោជន៍) ។ valoir la peine

ធ្ងរធ្វើ (សំខាន់ធ្ងរលើសគេ) ។ peines accessoires អនុទោស ។ peine principale មូលទោស ។ peine complémentaire ទោសបំពេញ ។

à peine *loc. adv.* ទើបនឹង (ឧ. à peine était-il parti...); ស្ទើរតែមិន (ឧ. savoir à peine lire អានស្ទើរតែមិនដាច់) ។ peine afflictive ឬ infamante ទោសអត្តទណ្ឌកម្ម ឬ ទុយ៌ស ។ peine capitale ទោសដល់ជីវិត ។ peine correctionnelle ទោសមជ្ឈិម ។ à grand-peine *loc. adv.* ដោយពិបាក (*ff.* affliction, désolation, douleur, tourment)

peiné,e *a.* ព្រួយ, ដែលកើតទុក្ខ (ឧ. je suis très peiné de cette résolution)

peiner *v.t.* ធ្វើឲ្យព្រួយ, ធ្វើឲ្យកើតទុក្ខ (ឧ.les enfants peinent quelquefois leurs parents); ធ្វើឲ្យអស់កម្លាំង ។

v.i. អន់ចិត្ត, អស់កម្លាំង ; ខំប្រឹងប្រែង(ឧ. peiner pour réussir)។ se peiner *v.pr.* ព្រួយចិត្ត (*ff.* affliger, attrister, chagriner, désoler)

peintre *n.m.* វិចិត្រករ; ជាងលាបថ្នាំ ។ *Fig.* អ្នកនិពន្ធដែលរៀបរាប់ពណ៌នាឲ្យឃើញច្បាស់នឹងភ្នែក (ឧ. Molière est un grand peintre des vices et des travers de l'humanité)

peintre-graveur *n.m.* វិចិត្រករឆ្លាក់ (*pl.* des peintres-graveurs)

peintresse *n.f. Fam. &Péjor.* វិចិត្រការិនី (ពាក្យបន្តុះបង្អាប់)

peinture *n.f.* វិចិត្រកម្ម (ឧ. des peintures sur bois); រូបវិចិត្រ; ថ្នាំលាប ។ *Fig.* សេចក្ដីពណ៌នា(ឧ. la peinture des mœurs)

peinturer *v.t.* លាបថ្នាំ (ឧ. peinturer un lambris)

peinturlurer *v.t. Fam.* លាបពណ៌ផ្សេងៗ

péjoratif,ive *a.* ដែលបន្តុះបង្អាប់

péjorativement *adv.* ដោយបន្តុះបង្អាប់

péjoration *n.f.* ការធ្វើឲ្យកាន់តែអាក្រក់; ការធ្លាក់ចុះថយថោក

pékin ឬ **péquin** *n.m. Fam.* អសេនិក (ព.ផ. militaire)

pékiné *n.m.* សំពត់ឆ្នូតបណ្ដោយសាច់

pékinois *a.&n.* នៃក្រុងប៉េកាំង។ *n.m.* ប៉េគីណ្វា (ឆ្កែតូចរោមវែងក្បាលធំ)

pelade *n.f.* រោគជ្រុះរោម ឬ សក់ដោយអន្ទើរ (ឧ. la pelade est une maladie organique non contagieuse)

pelage *n.m.* រោម (ឧ. le lion a le pelage fauve); ការបក ឬ ការលាត់ស្បែក (ឧ. le pelage d'une peau)

pélagien,enne *a.* នៃកណ្ដាលសមុទ្រ

pélagique *a.* នៃសមុទ្រ (ឧ. faune pélagique)

pelard *a.m.* bois pelard ឈើដែលគេស្ទោះសំបកយកទៅសម្លាប់ស្បែក

pelé,e *a.* ដែលជ្រុះសក់ ឬ ជ្រុះរោមអស់ (ឧ. crâne pelé); ដែលគេបកសំបកចេញ (ឧ. des fruits pelés); ដែលគេលាតស្បែកចេញ ។ *Fig.* គ្មានដំណាំ ឬ គ្មានរុក្ខជាតិដុះ (ដី) (ឧ. campagne pelée); ក្រងាល ។ *n.* ទំពែក (ឧ. un vieux pelé)

pélécypodes *n.m.pl.Zool.* ម.ក. lamellibranches

pêle-mêle *n.m. inv.* ការច្របូកច្របល់ (ឧ. le pêle-mêle de la foule); ច្របល់ជាក់រូបចិតច្រើន ។ *Loc. adv.* ដោយច្របូកច្របល់ (ឧ. mettre tout pêle-mêle)

peler *v.t.* កោសរោមចេញ (ឧ. peler des peaux); បកឬសកសំបក ។ *v.i.* របកស្បែក (ឧ. dos qui pèle après un coup de soleil) ។

se peler *v.pr.* ឡើងក្រងាល

pèlerin,e *n.* បូជនីយសក ; អ្នកដំណើរ។ *Zool.* កណ្ដូបម្យ៉ាង

pèlerinage *n.m.* បូជនីយសចរណ៍ (ឧ. aller en pèlerinage); បូជនីយស្ថាន (ឧ. le pèlerinage de Lourdes)

pèlerine *n.f.* អាវក្លោប

pélican *n.m.* ទុង (បក្សី)

pelle *n.f.* ប៉ែល, ចបជួក ។ pelle mécanique ប៉ែលយន្ត។ *Fig.& fam.* remuer l'argent avec la pelle មានណាស់ (ចូកប្រាក់ដោយប៉ែល)។ *Pop.* ramasser

une pelle ភ្លាត់, ដួល; *au fig.* មិនបានសម្រេច ។ *Mar.* ស្លាបច្រវ៉ា (ភាគសំប៉ែតនៃច្រវ៉ា)

pelle-pioche *n.f. Mil.* ប៉ែលចប (*pl.* des pelles-pioches)

pelletage *n.m. Techn.* ការចូក ឬ ដឹកដោយប៉ែល

pelletée *n.f.* ចំនួនមួយប៉ែល ។ *Fig.* ចំនួនច្រើន (ឧ. des pelletées d'injures)

pelleter *v.t.* ដឹក, ចូក (ដោយប៉ែល) (ឧ. pelleter du sable)

pelleterie *n.f.* សិល្បៈសម្លាប់ស្បែកមានរោម; ស្បែកផាប់រោម (ឧ. de précieuses pelleteries); ជំនួញស្បែកផាប់រោម (ឧ. s'enrichir dans la pelleterie)

pelleteur *n.m.* កម្មករប្រើប៉ែល

pelleteuse *n.f. Trav.publ.* ម៉ាស៊ីនចូកដី

pelletier,ère *a.&n.* ជាងសម្លាប់ស្បែកផាប់រោម; ឈ្មួញស្បែកផាប់រោម

pelliculaire *a.* ដែលមានសភាពដូចធរី

pellicule *n.f.* ធរី, ស្បែកស្ដើង ។ *Path.* អង្គែ

pelliculeux,euse *a.* ដែលមានធរី; ដែលមានអង្គែ

pellucide *a.* ថ្លា (ឧ. la membrane pellucide de l'œuf ferme la chambre à air)

pelotage *n.m.* ការមូរឬហុង (អំបោះ); ការធ្វើជាដុំ

pelote *n.f.* ហុង (អំបោះ), ដុំ, ប្រមូរ, រុំ, មូរ, សំណុំ; កូនខ្នើយដោតម្ជុល។ *Zool.* ស្នាប់ជើង ។ *Fig. & fam.* faire sa pelote បានកម្រៃ

peloter *v.t.* មូរ, ហុង (ឧ. peloter de la ficelle) ។ *Pop.* ស្ទាបអង្អែល; *au fig.* បញ្ជោរ (ឧ. peloter un homme influent); ធ្វើបាប (ដោយកាយ ឬ ដោយវាចា)

peloteur,euse *a.&n.* អ្នកមូរ ឬ ហុង

peloton *n.m.* ដុំ ឬ មូរតូច, ហុងតូច ។ *Mil.* ពួកទាហាន (ឧ. le peloton est en principe commandé par un lieutenant)។ peloton muletier សិទ្ធពាឌីយោធា, ពួកទាហានសេះទេស។ ហ្វូង(បណ្ដាកជាតិ) (ឧ. peloton de chenilles, d'abeilles); ក្រុម (អ្នករត់ប្រណាំង) (ឧ. le peloton de tête) ។ peloton d'exécution ពួកទា-

ហាត់ពេទ្យហាង

pelotonnement *n.m.* ការមូរជាហុងតូច; ការរៀន

pelotonner *v.t.* មូរជាហុងតូច (ឧ. pelotonner du fil); ផ្តុំ ។

se pelotonner *v.pr.* រៀន

pelouse *n.f.* ដីជាស្មៅ, កម្រាលស្មៅ, ស្លាប់ស្មៅ

peltaste *n.m. Antiq.* ខ្មាន់ខែល

pelte *n.m. Antiq.gr.* ខែលតូចរាងអឌ្ឍចន្ទ

pelu,e *a.* ស្រមូរ (ដែលមានរោមពេញ)

peluche *n.f.* សំពត់ម្យ៉ាងម្ខាងរលោងម្ខាងទៀតមានរោម

peluché,e *a.* ដែលមានរោម (សំពត់ ឬ ដើមឈើ) (ឧ. tissu peluché)

pelucher *v.t.* ឬ **se pelucher** *v.pr.* ប្រឡាក់រោមដែលរបោចអំពីសំពត់ (ឧ. étoffe qui peluche ឬ se peluche)

pelucheux,euse *a.* ជាប់រោម

pelure *n.f.* សំបកផ្លែឈើឬបន្លែ (ឧ. pelure de pêche, d'oignon)។ papier pelure ក្រដាសស្តើង (ម.ព. papier ផង)

pelvien,enne *a.Anat.* នៃត្រគាក

pelvis *n.m.Anat.* មើ. bassin

pemmican *n.m.* ការធ្វើសាច់ងៀត

pénal,e,aux *a.* ព្រហ្មទណ្ឌ (នៃទណ្ឌកម្ម, ដែលដាក់ទោស, ដែលពិន័យ) ។ code pénal ម.ព. code ។ loi pénale ច្បាប់ព្រហ្មទណ្ឌ

pénalement *adv.* តាមច្បាប់ព្រហ្មទណ្ឌ (តាមបទពិន័យ)

pénalisation *n.f.* ការដាក់ទណ្ឌកម្ម, ពិន័យ

pénaliser *v.t.* ដាក់ទណ្ឌកម្ម, ពិន័យ

pénalité *n.f.* ទោសបញ្ញត្តិ; ទោស

penalty *n.m.* ប៉េណាល់ទី (ពិន័យក្នុងកីឡាបាល់ទាត់)

pénates *n.m. pl.* ម្ចាស់ផ្ទះ ។ *Fig.* លំនៅ, ផ្ទះ (ឧ. regagner ses pénates)

penaud,e *a.* ស្រមេះ, អៀនអន់, អឹម-អៀម (ឧ. rester penaud)

penchant,e *a.* ផ្អៀង, ទ្រេត ។ *Fig.* ដែលលំអៀង ។

n.m. ជម្រាល (ឧ. penchant d'une colline) ។ *Fig.* ការលំអៀង (ឧ. les bons, les mauvais penchants)

pencher *v.t.* ងាក, ផ្អៀង (ឧ. pencher

la tête)។

v.i. ទ្រេត (ឧ. ce mur penche) ។ *Fig.* សំអៀង (ឧ. pencher à l'indulgence) ។

se pencher *v.pr.* ឱន, បន្ទន់ខ្លួន ។ *Fig.* se pencher sur យកចិត្តទុកដាក់នឹង (ឧ. se pencher sur un problème)

pendable *a.* ដាច់ទោស, គួរព្យួរក (ឧ. bandit pendable); គួរឱ្យវាស់ទោស ព្យួរក (ឧ. cas pendable) ។ tour pendable ល្បិចអាក្រក់ណាស់

pendaison *n.f.* ការព្យួរ (ឧ. pendaison de crémaillère); ការព្យួរក; ទោសព្យួរក (ការសម្លាប់ដោយចងខ្សែត្រូវព្យួរបញ្ឈរក)

pendant,e *a.* ធ្លាក់ (ត្រចៀក) (ឧ. oreilles pendantes); ស្រយាក; ដែលព្យួរ; យារ ។

Dr. fruits pendants par branches et par racines ម.ព. fruit ។ *Fig.* មិនទាន់ជម្រះ (ឧ. la cause est encore pendante)

pendant *n.m.* គូ (សំណង់វត្ថុសម្រាប់តាំងជាគូ) (ឧ. un buste et son pendant) ។ *Fig.* គូ (របស់ផ្ទួចគ្នា ឬស្មើគ្នា) (ឧ. l'un est le pendant de l'autre) ។ pendants d'oreilles ការ, ឃោ

pendant *pré.* ក្នុងកំឡុង, ក្នុងរយៈពេល ។

pendant que *loc. conj.* ក្នុងពេលដែល, រីឯ

pendard,e *n.* *Fam.* មនុស្សពោលម្ញៀក; មនុស្សឆោតោក

pendeloque *n.f.* ពេជ្របន្តោងឃោ ។ *pl.* ផលិក [ផៈ-លិក] បន្តោងជើងទៀន

pendentif *n.m.* បន្តោង (គ្រឿងអលង្ការបន្តោងនៅក)

penderie *n.f.* កន្លែងព្យួរសំលៀកបំពាក់

pendiller *v.i.* សំយាក, ព្យួរយោង

pendillon *n.m.* *Techn.* ដងប៉ោលនាឡិកា

pendoir *n.m.* ខ្សែ ឬ ទំពក់ព្យួរសាច់ (កន្លែងលក់សាច់)

pendouiller *v.i.* *Pop.* ព្យួរតែកពោក

pendre *v.t.* ព្យួរ (ឧ. pendre des jambons au plafond); ព្យួរក (ធ្វើទោសចងក) (ឧ. pendre un criminel) ។ être pendu à យកចិត្តទុកដាក់យ៉ាងខ្លាំង (ឧ. tous étaient pendus à ses paro-

les) ។

Loc. div. à pendre ឬ bon à pendre គួរព្យួក។ *Fig.* pendre au croc ព្យួរទោល, ទោះបង់, ទោល (ឧ. pendre son épée au croc)។ pendre la crémaillère ម.ក. crémaillère។ dire pis que pendre de quelqu'un និយាយអាក្រក់យ៉ាងច្រើនអំពីអ្នកណាមួយ ។

Prov. les grands voleurs pendent les petits ចោរធំព្យួកចោរតូច (អ្នកធ្វើទោសចោរ ច្រើនតែជាចោរធំៗខ្លួនឯង) ។

v.i. ព្យួរ (ជាប់ដោយគេព្យួរ ឬ ដូចគេព្យួរ)(ឧ.les fruits pendent aux arbres)។ *Fig.* បម្រុងនឹងធ្លាក់លើ, បម្រុងនឹងឲ្យទោស (ឧ. une espèce de prédiction du malheur qui pendait sur sa tête) ; សំយាក (ឧ. robe qui pend d'un côté)។ *Par anal.* ធ្លាក់យោក (ឧ. des joues qui pendent)។ *Fig.* នៅអន្តែង-អន្តែ. មិនទាន់ជាប់ស្រេច (ឧ. procès qui pend depuis longtemps)។

Loc. div. être pendu haut et court ត្រូវព្យួកនៅឈើខ្ពស់ ។ *Fig.* être toujours pendu au cou de quelqu'un ចេះតែឱបកមិនឈប់ être pendu aux oreilles de quelqu'un ធ្វើជានិយាយនឹងអ្នកណាមួយមិនឈប់។ être pendu aux côtés, à la ceinture de quelqu'un ឬ auprès de quelqu'un តាមជាប់, មិនឃ្លាត ។ avoir la langue bien pendue និយាយសំដីរអិល; និយាយមិនឈប់ ។

se pendre *v.pr.* ប្រពោង; ចងកសម្លាប់ខ្លួនឯង ។ *Par exag.* il y a de quoi se pendre របស់នេះពិបាកទ្រាំណាស់ ។ il n'y a pas de quoi se pendre រឿងនេះមិនធ្ងន់ទេ ឬ មិនសំខាន់ទេ ។ après cela il faut se pendre រួចហើយចងកសម្លាប់ខ្លួនឯងទៅ(ស្តាយណាស់ដោយខាតឱកាសល្អ) ។ se pendre à la sonnette អង្រួនកណ្ដឹងមិនឈប់

pendu,e *n.* អ្នកចងកសម្លាប់ខ្លួន; អ្នកត្រូវព្យួក(ឧ. décrocher un pendu)។

Prov. avoir de la corde de pendu dans sa poche; il ne faut pas parler de corde dans la maison d'un pendu ម.ក. corde

pendulaire *a.* នៃនាឡិកាយោល, នៃយោល (ឧ. mouvement pendulaire)

pendule *n.m.* យោល(ឧ.les petites oscillations d'un pendule sont isochrones)

pendule *n.f.* នាឡិកាយោល ។ pendule à répétition នាឡិកាយោលវាយម៉ោង

pendulette *n.f.* កូននាឡិកាយោល

pêne *n.m.* ពន្លូញសោ

pénéplaine *n.f.* ស្មើរាល

pénétrabilité *n.f.* ភាពអាចចោះបាន; ភាពអាចចូលធ្លុះ; ភាពអាចយល់បាន

pénétrable *a.* អាចចោះបាន (ឧ. le diamant est malaisément pénétrable) ; អាចចូលបាន ។ *Fig.* អាចយល់បាន , អាចទាយត្រូវ (ឧ.mystère peu pénétrable)

pénétrant,e *a.* ដែលចូល (ឧ. projectile pénétrant); មុត, ឈ្លាសវៃ(ឧ. esprit pénétrant) ។ *n.f.* ផ្លូវចូលជ្រៅ

pénétration *n.f.* ការចូល, ការមុត (ឧ. puissance de pénétration d'un obus) ។ *Fig.* ការឈ្លាសវៃ (បញ្ញាមុត); សេចក្ដីឈ្លាសវៃ

pénétré,e *a.* ដែលជឿជាក់ (ឧ. un homme pénétré de son importance)

pénétrer *v.t.* ចោះ; ធ្លុះ; ចូល; ជ្រាបចូល (ឧ. l'huile pénètre les étoffes); ចូល ឬ មុតជ្រៅ (ឧ. le coup a pénétré les chairs) ។ *Fig.* ឃើញ, យល់ (ឧ. pénétrer les intentions d'autrui); ធ្វើឲ្យរំភើបខ្លាំង(ឧ. sa douleur me pénètre le cœur); ជឿជាក់ ។

v.i. ចូល (ឧ. l'arme a pénétré jusqu'à l'os) ។

se pénétrer *v.pr.* លាយគ្នា, ចូលគ្នា; ស្គាល់គ្នា; យល់ចិត្ត ឬ គំនិតគ្នា; យល់ច្បាស់ (ឧ. se pénétrer d'une vérité)

pénible *a.* លំបាក (ឧ. travail pénible); ដែលឲ្យពិបាកចិត្ត (ឧ.

nouvelle pénible)

péniblement *adv.* ដោយលំបាក (ឧ. avancer péniblement)

péniche *n.f.* នាវាល្បាត; នាវាដឹកទំនិញធំៗតាមទន្លេ

pénicilline *n.f.* ប៉េនីស៊ីលីន (ឧសថម្យ៉ាង)

péninsulaire *a.* នៃឧបទ្វីប [អ៊ុ-ប៉ៈ—]; នៃបណ្ដាជនក្នុងឧបទ្វីប

péninsule *n.f.* ឧបទ្វីប [អ៊ុ-ប៉ៈ—]

pénis *n.m.Anat.* អង្គជាត (ម. verge)

pénitence *n.f. Relig.* អនុតាប (ការក្ដៅក្រហាយចិត្តដោយនឹកស្ដាយក្រោយរឿយៗ); បរិភាសកម្ម (ឧ. accomplir sa pénitence); ទណ្ឌកម្ម (ឧ. mettre un enfant en pénitence)

pénitencier *n.m.* បព្វជិតអ្នកជម្រះបាបកម្ម; គុកសម្រាប់ដាក់មនុស្សទោស

pénitent,e *a.&n. Relig.* អ្នកទទួលបរិភាសកម្ម (ឧ. pécheur pénitent) ។ *n.* អ្នកសារភាពទោសខ្លួន

pénitentiaire *a.* នៃពន្ធនាគារ, នៃការដាក់ពន្ធនាគារ (ឧ. régime pénitentiaire)

pénitentielles *a.pl.* នៃបរិភាសកម្ម (ឧ. œuvres pénitentielles)

penne *n.f.* ស្លាបវែង (ស្លាបវែងនៃស្លាប ឬកន្ទុយបក្សី); ស្លាបព្រួញ

penné,e *a. Bot.* ដែលដុះជារបៀបស្លាបបក្សី

penniforme *a.* ជារាងស្លាប (ឧ. feuille penniforme)

penny *n.m.* ប៉ិនី (រូបិយវត្ថុអង់គ្លេស)

pénombre *n.f.* កឡុកន, ស្រមោលព្រិលៗ; ពន្លឺព្រិលៗ ។ *Fig.* ការគ្មានកិត្តិគុណ; ភាពគ្មានគេស្គាល់

pensant,e *a.* ដែលគិត, ដែលចេះគិត (ឧ. l'homme, a dit Pascal, est un roseau pensant) ។ bien pensant *a.&n.* សម្មាចិត្ត, ដែលមានគំនិតត្រូវ ។ mal pensant *a.&n.* មិច្ឆាចិត្ត, ដែលមានគំនិតខុស

pensée *n.f.* ចិត្ត, គំនិត (ឧ. la dignité de l'homme réside dans la pensée; saisir la pensée d'un auteur); វិចារៈ (ឧ. les «Pensées» de Pascal)

penser *v.i.* គិត, នឹក (ខ. il parle sans penser); មានគំនិត (ខ. penser finement) ។

v.t. គិត (បម្រុងនឹង) (ខ. nous pensons partir bientôt); គិតថា (សង្ឃឹម) (ខ. je pense réussir); ជឿ, យល់ឃើញ (ខ. qu'en pensez-vous?) ។

v.t. ind. (à) នឹក (ខ. penser aux absents); គិត, មានបំណង (ខ. penser à s'établir); ប្រុងប្រយ័ត (ខ. vous avez des ennemis, pensez à vous) ។ penser à mal គិតព្រាង្គអាក្រក់ (ខ. dire une chose sans penser à mal)

penser *n.m. Poét.* គំនិត (ខ. il faut chasser ce triste penser)

penseur *n.m.* បិណ្ឌបណ្ឌិត; អ្នកមានគំនិតជ្រៅ; អ្នកធ្លាប់គិត ។ libre penseur អ្នកមិនជឿសាសនា

pensif,ive *a.* សញ្ជប់សញ្ជឹង (ខ. rester pensif)

pension *n.f.* សោធន (ប្រាក់ឈ្នួលស្នាក់នៅនិងអាហារ)(ខ. payer sa pension); កន្លែងទទួលឲ្យនៅនិងឲ្យបរិភោគ(ខ. pension de famille); អគារអប់រំ (ខ. mettre son fils en pension); សិស្សក្នុងអគារអប់រំ (ខ. la pension est en promenade) ។

Dr. pension alimentaire សោធនអាហារណីយ, អាហារកិច្ច ។ pension d'ancienneté de services សោធនអតីតកាលនៃសេវា ។ pension de guerre សោធនសង្គ្រាម ។ pension d'invalidité សោធនពិការភាព ។ pension proportionnelle សោធនសមាមាត្រ ។ pension de retraite សោធននិវត្តន៍ ។ pension de revision សោធនបុនរាព្រឹត្តិ [ប៊ុន:-ព៊-] ។ pension temporaire សោធនកាលិក ។ pension de veuve សោធនមេម៉ាយ ។

mettre en pension ដាក់បញ្ចាំ; ដាក់ឲ្យចិញ្ចឹម ។ prendre en pension ទទួលបញ្ចាំ; ទទួលចិញ្ចឹម

pensionnaire *a.* អ្នកចេញឈ្នួលស្នាក់នៅនិងអាហារ (ខ. prendre des pensionnaires pour la table); សិស្សក្នុងអគារអប់រំ

pensionnat *n.m.* អគារអប់រំ; សិស្សទាំងឡាយក្នុងអគារអប់រំ

pensionné,e *a.& n.* សោធនលាភី

pensionner *v.t.* ចេញសោធនឲ្យ (ឧ. pensionner un soldat)

pensivement *adv.* ដោយសញ្ជប់សញ្ជឹង

pensum [pin-som] *n.m.* កិច្ចការជាទណ្ឌកម្ម (សម្រាប់សិស្ស) ។ *Par ext.* កិច្ចការសរសេរដែលឲ្យធុញទ្រាន់ (*pl.* des pensums)

pentacle [pin—] *n.m.* រូបផ្កាយបញ្ចសាខា

pentacorde [pin—] *n.m.* ពិណខ្សែប្រាំ (ពិណបុរាណ)

pentadactyle [pin—] *a.* បញ្ចង្គុលី, ដែលមានម្រាមប្រាំ

pentadécagone [pin—] *n.m.* & *a. Math.* បញ្ចទសកោណ (ពហុកោណមានជ្រុង ១៥)

pentaèdre [pin—] *n.m. Math.* បញ្ចតល, ប្រសព្វជ្រុងប្រាំ (ឧ. une pyramide quadrangulaire est un pentaèdre)

pentagonal,e,aux [pin—] *a.* & *n. m. Math.* បញ្ចកោណ, ដែលមានរាងជាបញ្ចកោណ

pentagone [pin—] *n.m.* & *a.* បញ្ចកោណ ។ *n.m. Pop.* le Pentagone បញ្ចកោណ (មន្ទីរមន្ត្រីការពារប្រទេសនៃសហរដ្ឋអាមេរិក ព្រោះអគារនេះមានរាងបញ្ចកោណ)

pentamètre [pin—] *n.m.* កាព្យបញ្ចបាទ

pentapétale [pin—] *a.* ដែលមានត្របកប្រាំ (ផ្កា)

pentapole [pin—] *n.f. Antiq.* តំបន់មានក្រុងសំខាន់ប្រាំ (ឧ. la pentapole de Libye)

pentarchie [pin—] *n.f.* បញ្ចនាធិបតេយ្យ (របៀបគ្រប់គ្រងដោយមានប្រមុខប្រាំនាក់នៅរដ្ឋក្រិកសម័យបុរាណ)

pente *n.f.* ដំរាល, ជើងទេរ ។ *Fig.* être sur la mauvaise pente សំអៀងទៅខាងខូច

pentecôte *n.f.* បុណ្យប៉ង់តិកូត

pénultième *a.* បន្ទាប់ចុងបំផុត ។ *n.f.* ព្យាង្គបន្ទាប់ព្យាង្គក្រោយបំផុត

pénurie *n.f.* ការខ្វះ (ឧ. pénurie d'argent; pénurie de main-d'œuvre); ការក្រ (ឧ. vivre dans une grande pénurie)

pépère *n.m.* តា (ពាក្យក្មេង) ។ *Fam.* តា (ពាក្យស្និទ្ធស្នាល) ។ *a. Fam.* ស្ងប់

pépettes *n.f. pl. Pop.* ប្រាក់ ។ avoir des pépettes មានទ្រព្យ

pépie *n.f.* គាន (រោគកើតនៅចុងអណ្ដាតបក្សី បណ្ដាលឲ្យស៊ីចំណីមិនបានតែនៅផឹកទឹកបាន) ។ *Fig.& Fam.* avoir la pépie ស្រេកខ្លាំង

pépiement *n.m.* ការយំ; សំឡេងយំ (កូនបក្សី)

pépier *n.m.* យំ (កូនបក្សី)

pépin *n.m.* គ្រាប់ផ្លែឈើ ។ *Fam.* ឆ័ត្រ ។ *Pop.* ស្នេហាមិនបើកបើរ; គ្រោះថ្នាក់; កង្វល់ (ឧ. avoir un pépin)

pépinière *n.f.* កូនឈើបណ្ដុះដាំ; ថ្នាលបណ្ដុះ, ថ្នាល ។ *Fig.* ថ្នាលបណ្ដុះ, អគារហ្វឹកហ្វឺនវិជ្ជាជីវៈ (ឧ. le Conservatoire est une pépinière d'artistes)

pépiniériste *n.* ថ្នាលការីក, អ្នកថែទាំថ្នាល

pépite *n.f.* ដុំមាស ឬ លោហធាតុ (ពីកំណើត)

pépon *n.m.* ឬ **péponide** *n.f.* ផ្លែត្រឡាច; ផ្លែល្ពៅ

pepsine *n.f.* ប៉ិបស៊ីន [ប៉ិ–] (សេម្យ៉ាងនៃក្រពះ ជួយរំលាយអាហារ)

peptone *n.f.* ប៉ិបតូន [ប៉ិ–] (អាហារទើបកើតពីសាច់រលាយដោយធាតុប៉ិបស៊ីន)

péquin *n.m.* ម.ព. pékin

perçage *n.m.* ឆិទ្ទកម្ម, ការចោះ-ទម្លុះ ឬ ទម្លាយ

percaline *n.f.* ពែរកាលីន (សំពត់អំបោះស្ដើងរលោងសម្រាប់ធ្វើទ្រនាប់)

perçant,e *a.* មុត (ឧ. froid perçant; yeux perçants); គ្រលួច (សម្លេង) (ឧ. voix perçante) ។ vue perçante ភ្នែកមុត (មើលឃើញរបស់តូចៗដែលនៅឆ្ងាយ) ។ esprit perçant បញ្ញាមុត (ឈ្លាសវៃ)

perce *n.f.* ដែកចោះ; ដែកកណ្ដារ; រន្ធគ្រឿងភ្លេងផ្លុំ ។ en perce ដោយចោះ (ចំពោះធុងដែលគេចោះបង្ហូរយកវត្ថុដែលនៅក្នុងនោះ)

percé,e *a.* ដែលមានប្រហោង, ធ្លាយ, ធ្លុះ; ឈឺពើត; មានទ្វារបង្អួច (ផ្ទះ)

percé *n.m.* ***ill.*** នៃ percée

percée *n.f.* ឬ **percé** *n.m.* ប្រហោង; ផ្លូវកាត់ព្រៃ

percement *n.m.* ការចោះ (ឧ. le percement de l'isthme de

Suez); ប្រហោងនោះ

percepteur,trice *n.* សុង្កការី-នី, ភ្នាក់ងារទារពន្ធ

perceptibilité *n.f.* សញ្ញាណីយភាព

perceptible *a.* សញ្ញាណីយ, អាចនឹងដោយវិញ្ញាណ (ឧ. objet perceptible à la vue វត្ថុអាចមើលឃើញ; objet perceptible à l'ouïe វត្ថុអាចស្ដាប់ឮ) (ល. apparent, manifeste, ostensible, visible) ។

Fin. អាចទារបាន (ពន្ធ)

perceptiblement *adv.* ដោយសញ្ញាណីយ

perceptif,ive *a. Phil.* នៃសញ្ញា (ឧ. faculté perceptive)

perception *n.f. Fin.* ការទារពន្ធ(ឧ. la perception d'une taxe); មុខងារសុង្កការី,សុង្កស្ថាន(ឧ. obtenir une perception) ។

Phil. សញ្ញា ។ *Fig.* ការនឹងឬយល់ដោយវិញ្ញាណ (ឧ. la perception des couleurs, des odeurs)

perceptionnisme *n.m. Phil.* សញ្ញាណនិយម

percer *v.t.* ចោះ, ចម្លាយ (ឧ. percer une planche); ចោះ(ឧ. percer une porte); ដើរកាត់; ច្រៀកហ្វូង (ឧ. percer la foule); ចាក់ (ធ្វើឱ្យរបួស, សម្លាប់) (ឧ. percer quelqu'un de coups); ពិចាក់ (ឧ. la lumière perce les ténèbres) ។

Fig. ស្រាយ (អាថ៌កំបាំង); រកឃើញ(ឧ.percer un mystère)។ percer le cœur ធ្វើឱ្យខ្លោចចិត្ត (ឧ. ces plaintes me percent le cœur) ។ crier à percer les oreilles ស្រែកស្ទើរបែកត្រចៀក, ស្រែកដោយសម្លេងគ្រលួច ។

v.i. ធ្លាយ (ឧ. l'abcès a percé) ។ *Fig.* ចេញឱ្យគេឃើញ (ឧ. sa méchanceté perce dans tous ses discours); ល្បីល្បាញ (ឧ. cet artiste commence à percer) (ល. forer, perforer, transpercer, trouer)

percerette *n.f.* នៃកខួង

perceur,euse *a.&n.* អ្នកចោះ, អ្នក

រូង។ *n.f. Techn.* ម៉ាស៊ីនចោះឬខួង

percevable *a.* អាចទារបាន (ពន្ធ) (ឧ. taxe difficilement percevable)

percevoir *v.t.* ទារ (ពន្ធ) (ឧ. percevoir les impôts) ។ *Fig.* ដឹងដោយវិញ្ញាណ (ឧ. percevoir un son ឮសម្លេង)

perche *n.f.* ត្រីម្យ៉ាង

perche *n.f.* ឈើវែង (ឈើស្នួ; ផ្លោល, ឈើសារ ។ល។) (ឧ. étendre du linge sur une perche)។ *Fig. & Fam.* មនុស្សខ្ពស់បង្គោង ។ tendre la perche à quelqu'un ជួយស្រោចស្រង់, ជួយយឹតយោង។ *Pêch.* ដងសន្ទូច។ *Vénér.* ស្នែងក្តាន់ ។ *Sports* saut à la perche ការលោតផ្លោល

perchée *n.f.* បង្គូរ (សម្រាប់ដាំគល់ទំពាំងបាយជូរ)

percher *v.i.* ឬ **se percher** *v.pr.* ទំ (ចំពោះបក្សី) ។ *Fig. & Fam.* នៅ (ឧ. où perche-t-il ?) ។ *v.t.* ដាក់នៅទីខ្ពស់

percheron,onne *n.* ជនជាតិពែរ្យ។ *a.* នៃប្រទេស ឬ ជនជាតិពែរ្យ (ឧ. race percheronne) ។ cheval percheron ឬ percheron *n.m.* សេះពែរ្យ

percheur,euse *a.* ដែលទំ (ចំពោះបក្សី) (ឧ. l'alouette n'est pas percheuse)

perchoir *n.m.* ទ្រនំ

perclus,e *a.* ខ្វិន

perçoir *n.m. Techn.* ប្រដាប់ចោះ

percussion *n.f.* ការបុក, ការទង្គិច។ *Mus.* instruments de percussion គ្រឿងភ្លេងវាយ (ឧ. ស្គរ, ឃ្មោះ, គង ។ល។) ។ *Méd.* ការគោះស្តាប់

percutant,e *a.* ដែលទង្គិច ។ projectile percutant គ្រាប់ផ្ទុះ (គ្រាប់ដែលផ្ទុះដោយប៉ះទង្គិច) ។ tir percutant ការបាញ់គ្រាប់ផ្ទុះ ។ *Fig.* ដែលធ្វើឲ្យស្រឡាំងកាំង (ឧ. argument percutant)

percuter *v.t.* វាយ (ឧ. le chien de fusil percute l'amorce)។ *Méd.* គោះស្តាប់ (វិធីពេទ្យវិនិច្ឆ័យ) (ឧ. percuter le dos) ។ *v.i.* ជល់, បុក, ទង្គិច (ឧ. la voiture a percuté contre

un arbre)

percuteur *n.m.* ដៃគុទ៌, ពន្លួញបុកឲ្យផ្ទុះរំសេវគ្រាប់កាំភ្លើង

perdable *a.* អាចបាត់បាន

perdant,e *a.* ដែលចាញ់; ដែលខុស (ឆ្នោត) (ឧ. billets perdants)។

n. អ្នកចាញ់ (ក្នុងល្បែង) (ឧ. tout gagnant suppose un perdant តែមានអ្នកឈ្នះ តោងមានអ្នកចាញ់)

perdition *n.f.* ការមានគ្រោះថ្នាក់ធ្ងន់ (បំពោះនាវាដែលកំពុងលិច) ។ *Fig.* ដំណើរហិនហោច; ភាពអ្នកប្រាសចាកផ្លូវសុខ

perdre *v.t.* បាត់ (ឧ. perdre sa place; perdre son mouchoir); ប្រាសចាក (ព្រោះស្លាប់)(ឧ. perdre son père); ចាញ់ (ឧ. perdre un procès, une bataille); ខូច (ឧ. perdre un bras); ធ្វើឲ្យខូច (ឧ. la pluie a perdu mon chapeau); ជ្រុះ (ឧ. les arbres perdent leurs feuilles en automne) ។

perdre haleine ហត់ស្ទើរដាច់ខ្យល់ ។ perdre la vie បាត់បង់ជីវិត, ស្លាប់ ។ perdre la tête ត្រូវគេកាត់កសម្លាប់; ឆ្កួត; ស្វន់។

Fig. ធ្វើឲ្យវិនាស (ឧ. le jeu le perdra); នាំឲ្យខូច (ឧ. les mauvaises fréquentations perdent la jeunesse); ធ្វើឲ្យហិនហោច; បង្ខូចកិត្តិយស (ឧ. vous allez me perdre) ។ perdre son temps ខាតពេល ។ perdre l'occasion ខូចឱកាស។ perdre la piste បាត់ដាន។ perdre une habitude ចោល ឬ លះបង់ទម្លាប់ ។ perdre la carte, le nord ឬ la tramontane ស្វន់, ឡប់ស្មារតី។ perdre pied ផុតជើង (ឈរជើងលែងដល់ដីក្នុងទឹកជ្រៅ ; *au fig.* លែងដឹងធ្វើដូចម្ដេច ឬ ជាដូចម្ដេច) ។ perdre du terrain ថយ ។ perdre de vue ភ្លេច (ឧ. ne perdez pas de vue vos devoirs) ; លែងទាក់ទងជាមួយ (ឧ. perdre de vue des amis d'enfance); លែងគិត (ឧ. perdre de vue une affaire) ។ vous ne perdez rien pour attendre អ្នកឯងគង់តែឃើញទេ, អ្នកឯង

គង់តែត្រូវការនោះ ។ perdre le fil d'un discours ឡប់ (ភ្លេចដំណើររឿង) ។

v.i. ពុះបើក, ខូចតម្លៃ (ឧ. les grains perdent en vieillissant); ខាត (ឧ. perdre sur une marchandise)។ la mer perd ទឹកនាច ។ navire qui perd នាវាដែលឡើងក្រោយទឹកមិនរួចឬដែលបើកបាត់នាវាដទៃ ។

se perdre *v.pr.* វង្វេង (ឧ. se perdre dans un bois); កប់បាត់, ប្រឡំបាត់ (ឧ. se perdre dans la foule); លិចលង់ (នាវា) (ឧ. ce bâtiment s'est perdu sur une côte) ។

Fig. ខូច, ប្រព្រឹត្តខុសគន្លងធម៌ (ឧ jeune homme qui se perd); ត្រូវគេលែងនិយម (ឧ. cette mode se perd) ។ je m'y perds ខ្ញុំមិនយល់បន្តិចសោះ

perdreau *n.m.* ទទាកូនទង់ (ឧ. le perdreau est un gibier très estimé)

perdrix *n.f.* ទទា

perdu,e *a.* ដែលបាត់; ដែលស្លាប់; ដែលមើលមិនឃើញ; ដែលធ្លាក់ស្លុង (ឧ être perdu dans ses réflexions, dans sa douleur); ឆ្ងាយដាច់ស្រយាល (ឧ. pays perdu); អស់សង្ឃឹម (ឧ. malade perdu); ដែលវិនាស (ឧ. homme perdu)។ temps perdu ខាតពេល, ពេលអសារឥតការ ។ peine perdue ខាតកម្លាំង, ការនឿយហត់ឥតអំពើ ។

n. courir comme un perdu រត់លឿនណាស់ ។

Loc.adv. aux moments perdues នៅពេលទំនេរ។ à corps perdu ដោយកម្លាំងកាយ, យ៉ាងខ្លាំងក្លា

père *n.m.* បិតា, ឪពុក (ឧ. honorez votre père) ។ père adoptif ឪពុកចិញ្ចឹម។ père légitime ឪពុកពេញច្បាប់។ père naturel ឪពុកក្រៅច្បាប់ ។ père nourricier ប្ដីរបស់មេដោះ។ បិតា, អ្នកបង្កើត (ឧ. Corneille est le père de la tragédie française) ។ *Fam.* តា (សម្រាប់ហៅមនុស្សចាស់ណាស់) (ឧ. le père François)។ *Relig.* ព្រះ (សម្រាប់

ហៅបព្វជិតកាតូលិកខ្លះ) ។ père éternel អាទិទេព ។ le Saint-Père ប៉ាប(សង្ឃធំក្នុងសាសនាគ្រិស្ត) ។ *Théâtr.* père noble តួឪពុក ។

pl. ជីដូនជីតា(ឧ. nos pères)។ de père en fils *loc.adv.* តពីឪពុកទៅដល់កូន ។

Prov. tel père tel fils ផ្លែឈើមិនដែលជ្រុះឆ្ងាយពីគល់ ។ on ne peut pas contenter tout le monde et son père គេមិនអាចនឹងបំពេញចិត្តមនុស្សទាំងអស់គ្នាបានទេ; ប្អូសដោយវត្តចិត្តដោយខ្លួន

pérégrination *n.f.* អន្តានគមន៍, ដំណើរទៅកាន់ប្រទេសឆ្ងាយ

péremption *n.f.* ការផុតវេលា(ចំពោះនីតិវិធីដែលមិនបានប្រើក្នុងរយៈពេលកំណត់ទុក)

péremptoire *a.* ដែលឆ្លើយតបវិញមិនរួច; ដាច់ខាត (ឧ. réponse péremptoire; preuve péremptoire); នៃការផុតវេលា (ឧ. exception péremptoire) (ប្រ. décisif, dogmatique, tranchant).

péremptoirement *adv.* ដោយមិនឲ្យតបវិញរួច; ដោយដាច់ខាត (ឧ. répondre péremptoirement à une objection)

pérennant,e *a.* *Bot.* ដែលរស់នៅបានច្រើនឆ្នាំ

pérenniser *v.t.* ចិរស្ថិត [ចេរ:—], ធ្វើឲ្យឋិតថេរ

pérennité *n.f.* ចិរកាល [ចេរ:—] (ឧ. la pérennité de certains usages)

péréquation *n.f.* ការចែកឲ្យស្មើ

perfectibilité *n.f.* ភាពគួរដល់សុក្រឹត

perfectible *a.* គួរដល់សុក្រឹត

perfection *n.f.* សុក្រឹតភាព, ភាពល្អឥតខ្ចោះ (ឧ. atteindre à la perfection)។ à la perfection យ៉ាងសុក្រឹត, យ៉ាងវិសេស (ឧ. elle chante à la perfection)

perfectionnement *n.m.* វិក្រឹតការ

perfectionner *v.t.* ធ្វើឲ្យវិក្រឹត, ធ្វើឲ្យកាន់តែល្អឡើង (ឧ. on perfectionne chaque jour les modes de locomotion)

perfide *a.* & *n.* វង្កៈ [វុង-ក.], វៀចវេរ; មិនទៀង (ដែលមិនកាន់សច្ចៈ) (ឧ.

ami perfide ក្លែមិត្ត) ។

a. ដែលក្បត់; មិនស្មោះ (ឧ. louanges perfides) (ម៉្យ. félon, infidèle, traître)

perfidement *adv.* ដោយវៀចវេរ; ដោយមិនស្មោះ

perfidie *n.f.* ក្លែក, ក្លែកាច, សេចក្ដីវៀចវេរ; ការក្បត់ (ឧ. la perfidie est un vice détestable) (ព.ផ. droiture, franchise, loyauté, sincérité)

perforage *n.m.* ការចោះ

perforant,e *a.* ដែលចោះ (ឧ. projectile perforant)

perforateur,trice *a.* សម្រាប់ចោះ ។ *n.f. Trav. publ.* ម៉ាស៊ីនចោះឬខួងថ្ម (សម្រាប់ជីកផ្លូវ) (ឧ. on se sert de perforatrices pour le percement de tunnels)

perforation *n.f.* ការចោះ ។ *Méd.* ដំណើរធ្លាយ (ធ្លាយពោះវៀន, ក្រពះ ។ ល ។)

perforer *v.t.* ចោះ, ខួង

perforeuse *n.f.* ម៉ាស៊ីនចោះ

performance *n.f.* លទ្ធផលក្នុងកីឡា ឬ ក្នុងការប្រណាំង ។ *Par ext.* ស្នាដៃពិសេស

perfusion *n.f. Méd.* ការបញ្ចូលសេរ៉ូម (បញ្ចូលថ្នាំឬឈាមក្នុងខ្លួន)

pergole ឬ **pergola** *n.f.* ព្រឹង

péricarde *n.m.* ហទយកោស [ហៈ-ទៈ-យៈ-]

péricardite *n.f.* ហទយកោសរោគ [ហៈ-ទៈ-យៈ-កោសៈ-]

péricarpe *n.m.* សំបកផ្លែ (ម៉្យ. peau, écorce)

péricliter *v.i.* មានហានិភ័យ; ចុះដុនដាប (ឧ. entreprise qui périclite)

périgée *n.m. Astr.* សមីសង្គត (ព.ផ. apogée)

péril *n.m.* ហានិភ័យ, គ្រោះថ្នាក់ (ឧ. braver le péril ឬ les périls) ។ au péril de ដោយប្រថុយ, ដោយមិនខ្លាចខាតបង់ (ឧ. au péril de sa vie) ។ à ses risques et périls ដោយទទួលខុសត្រូវលើខ្លួនទាំងអស់ ។ péril en la demeure ការខូចប្រយោជន៍បណ្ដាលមកពីដំណើរយឺត ។ il n'y a pas péril en la demeure

គ្មានវាគញ្ញើដោយរង់ចាំទេ

périlleusement *adv.* ដោយមានហានិភ័យ, ដោយមានគ្រោះថ្នាក់

périlleux,euse *a.* ដែលមានហានិភ័យ, ដែលមានគ្រោះថ្នាក់ (ឧ.entreprise périlleuse) ។ saut périlleux ម.ព. saut

périmer(se) *v.pr.* ឬ **être périmé** *v.passif* អស់តម្លៃ ឬ ផុតលេត (ដោយផុតរយៈពេល)

périmètre *n.m. Math.* បរិមាត្រ ។ បរិវេណ (ឧ. le périmètre d'une ville)

période *n.f.* ប្រវត្តិកាល, កាលសម័យ (ឧ. les grandes périodes de l'histoire) ។ *Géol.* période glaciaire ម.ព. glaciaire ។ *Méd.* កាល, សម័យ (ឧ.la période d'invasion, de déclin)។ *pl. Méd.* រដូវ (ស្ត្រី)

périodicité *n.f.* សាមយិកភាព [សា-ម៉ៈ-យិ-កៈ–] (ឧ. la périodicité des comètes)

périodique *a.* សាមយិក [សា-ម៉ៈ–], ទៀងកំណត់ពេល(ឧ.mouvement périodique; publication périodique) ។

n.m. សាមយិកប័ត្រ (ទស្សនាវដ្ដី - សារពត៌មានដែលផ្សាយទៀងកំណត់ពេល)

périodiquement *adv.* ដោយសាមយិក, ដោយទៀងកំណត់ពេល

périoste *n.m.* សំបកឆ្អឹង

périostite *n.f.* រោគរលាកសំបកឆ្អឹង

péripétie *n.f.* លហុបរិវត្តន៍, ឧប្បត្តិហេតុក្នុងរឿងប្រលោមលោក - ក្នុងដំណើរ (ឧ. les péripéties d'une guerre) (ព្រ. aventure, épisode, événement, incident)

périphérie *n.f.* បរិមណ្ឌល (បរិមាត្រនៃវណ្ឌមណ្ឌល, ខ្សែក្រៅ)

périphérique *a.* នៃបរិមណ្ឌល (ឧ. ligne périphérique)

périphrase *n.f.* បរិប្រយោគ [ប៉ៈ-រិ-ប្រ-យោគ], ពាក្យ ឬ សេចក្ដីពង្វាង (ឧ. គេថា la messagère du printemps ដើម្បីថា hirondelle)

périphraser *v.t.* និយាយតាមបរិប្រយោគ, និយាយតាមសេចក្ដីពង្វាង

périphrastique *a.* នៃបរិប្រយោគ (ឧ. expression périphrasti-

que); សម្បូរដោយបរិប្រយោគ

périple *n.m.* បរិចរណ៍ (ដំណើរជុំវិញសមុទ្រ-កោះឬប្រទេសមួយ) ។ *Par ext.* ដំណើរទេសចរ

périr *v.i.* ស្លាប់ដោយហោង (ឧ. périr dans un incendie); លិចលង់ (នាវា) (ឧ. le vaisseau a péri sur les récifs) ។ *Fig.* រលាយ, វិនាស (ឧ. les plus grands empires ont péri); ទ្រាំមិនបាន (ឧ. périr d'ennui អផ្សុកស្ទើរស្លាប់) (*ut.* s'éteindre, expirer, succomber, trépasser) ។

se périr *v.pr.* សម្លាប់ខ្លួន

périscolaire *a.* បរិសិក្សា (សម្រាប់ថែមបំពេញការសិក្សាមែនទែន) (ឧ. activités périscolaires)

périscope *n.m.* បរិទស្សន៍ (ប្រដាប់ឆ្លុះមើលវិលងខបសត្ត)

périscopique *a.* នៃបរិទស្សន៍ (ឧ. objectif périscopique)

périssable *a.* អាចខូចខាតបាន ។ denrées périssables គ្រឿងឧបភោគបរិភោគទុកមិនបាន (ដូចជាផ្លែឈើ, បន្លែ ។ល។)

périssodactyles *n.m. pl.* វិសមង្គុលី [វិ-សៈ-ម៉ុង-គុ-]

périssoire *n.f.* ទូកម្យ៉ាងតូចវែង

péristyle *n.m. Arch.* បរិស្តម្ភ (របៀបផ្ទះដែលបាំងដោយជួរសសរម្ខាងជញ្ជាំងម្ខាង ឧ. le péristyle de la Madeleine ; ជួរសសរលើអមុខគេហដ្ឋាន ឧ. péristyle du Panthéon)

perle *n.f.* មុក្តា, គជ់ ។ *Fig.* កំពូល, អ្វីៗដ៏ប្រសើរបំផុត (ឧ. c'est la perle des honnêtes gens) ; ដំណក់ទឹកថ្លាដូចពេជ្រ (ឧ. les perles de la rosée)

perlé,e *a.* ដូចគជ់; ដែលតាំគជ់ (ឧ. tissu perlé) ។ *Fig.* ផ្ចិតផ្ចង់ណាស់ , ពិរោះ (ឧ. travail perlé) ។ riz perlé អង្ករសម្រិត ។ grève perlée ម.ព. grève

perler *v.i.* ស្រក់ (ជាដំណក់តូចៗ) (ឧ. la sueur lui perle au front) ។ *v.t.* ធ្វើផ្ចិតផ្ចង់, ធ្វើឲ្យល្អពិរោះ: (ឧ. perler un ouvrage); ស្រិត (អង្ករ)

perlier,ère *a.* ដែលមានគជ់; ដែលឲ្យគជ់ (ឧ huîtres perlières)

perlot *n.m.* ងាវតូចម្យ៉ាង ។ *Pop.*

ថ្នាំដក់

permanence *n.f.* និច្ចភាព, អចិន្ត្រៃយភាព; និច្ចកាល (ឧ. la permanence du pouvoir entre les mêmes mains): ក្រុមអចិន្ត្រៃយ (ឧ. permanence électorale); ស្នងការដ្ឋានកណ្តាល ។ principe de permanence គោលការណ៍នៃអចិន្ត្រៃយភាព។ en permanence ជាអចិន្ត្រៃយ

permanent,e *a.* ជានិច្ច, អចិន្ត្រៃយ (ឧ. spectacle permanent; cinéma permanent) ។

n.m. សមាជិកអចិន្ត្រៃយ ។

n.f. សក់អ៊ុត

permanganate *n.m.* ពែរម៉ង់ក្កាណាត

perméabilité *n.f.* ភាពជ្រាបទឹក, ភាពអាចជ្រាបចូលបាន

perméable *a.* ដែលជ្រាបទឹក, អាចជ្រាបចូលបាន (ឧ. le papier buvard est perméable à l'eau) ។ *Fig.* អាចបញ្ចុះបញ្ចូលបាន (ឧ. perméable à certaines opinions)

permettre *v.t.* អនុញ្ញាត (ឧ. faire ce que les lois permettent); បើកដៃ, បើកឱកាស។

se permettre *v.pr.* ប្រព្រឹត្តតាមអំពើចិត្តខ្លួន; ហ៊ាន (ឧ. elle s'est permis de tenir ce langage)

permis *n.m.* លិខិតអនុញ្ញាត។ permis-chef លិខិតអនុញ្ញាតរួម ។ permis de chasse លិខិតអនុញ្ញាតប្របាញ់។ permis de conduire លិខិតអនុញ្ញាតបើកបរ ។ permis de navigation លិខិតអនុញ្ញាតនាវាចរណ៍ ។ permis de transit លិខិតអនុញ្ញាតនាំកាត់

permission *n.f.* អនុញ្ញាត; អនុញ្ញាតឲ្យឈប់សម្រាក

permissionnaire *n.* អនុញ្ញាតគាហក, អ្នកបានអនុញ្ញាតឲ្យឈប់សម្រាក

permutabilité *n.f.* ភាពអាចប្តូរបាន

permutable *a.* អាចប្តូរបាន (ប្តូរមុខងារ-កន្លែង ឬ ដំណែង) (ឧ. lettres permutables)

permutant,e *n.* អ្នកប្តូរ

permutation *n.f.* ការប្តូរ (ការប្តូរមុខងារ; ការប្តូរដំណែង; ការប្តូរកន្លែង)

permuter *v.t.* ប្តូរ (ប្តូរមុខងារ, ប្តូរ

ដំណែង; ប្តូរកន្លែង) (ឧ. permuter des emplois) ។

v.t. ប្តូរដំណែង; ប្តូរកន្លែង (ឧ. permuter avec un collègue)

permuteur *n.m.* អ្នកប្តូរ, អ្នកប្តូរមុខ-ងារឬដំណែង

pernicieusement *adv.* ដោយឲ្យទោស; ដោយចង្រៃ

pernicieux,euse *a.* ដែលឲ្យទោស, ដែលឲ្យមានគ្រោះថ្នាក់ (ឧ. l'alcool est pernicieux à la santé); ចង្រៃ, ដែលឲ្យវិនាស (ឧ. invention pernicieuse) ។ fièvre pernicieuse គ្រុនចាញ់ធ្ងន់

perniciosité *n.f.* ភាពចង្រៃ; ភាពឲ្យទោស

péroné *n.m.* ឆ្អឹងស្មងជើង

péronnelle *n.f.Fam.* ស្ត្រីល្ងង់ហើយមាត់ច្រើន

péroraison *n.f.* និគមវចនៈ [និ-គៈ-មៈ-វៈ-ចៈ-នៈ], ពាក្យសានបទនៃសុន្ទរ-កថា (ឧ. la péroraison résume d'une manière rapide et émouvante les principaux arguments du discours)

pérorer *v.i.* និយាយវែងហើយដោយបំប៉ោងហោរ

perpendiculaire *a.* ដែលកាត់កែង ។ *Math.* droite perpendiculaire ឬ perpendiculaire *n.f.* បន្ទាត់កាត់កែង

perpendiculairement *adv.* ដោយកាត់កែង, ដោយសំយុង

perpétration *n.f.Péjor.* ការប្រព្រឹត្តបទឧក្រិដ្ឋ (ឧ. la perpétration d'un crime)

perpétrer *v.t.Péjor.* ប្រព្រឹត្ត (ប្រព្រឹត្តបទឧក្រិដ្ឋ) (ឧ. perpétrer un assassinat)

perpette(à) *loc.adv.Pop.* មិនចប់, ជាអចិន្ត្រៃយ

perpétuation *n.f.* ការធ្វើឲ្យឋិតថេរជានិច្ច (ឧ. la perpétuation des espèces vivantes)

perpétuel,elle *a.* ជានិច្ច, រហូត, មិនដាច់ (ឧ. printemps perpétuel); អស់មួយជីវិត (ឧ. bannissement perpétuel); មិនឈប់ឈរ; រឿយៗ (ឧ. combats perpétuels) ។ secrétaire perpétuel និច្ច-

ពោខានិការ (*id.* continu, continuel, fréquent, incessant, permanent)

perpétuellement *adv.* ជានិច្ច, ជានិកប, ជារឿយៗ

perpétuer *v.t.* ធ្វើឲ្យឋិតថេរជានិច្ច (ឧ. perpétuer une rente, un usage)

perpétuité *v.t.* និច្ចកាល (ឧ. la perpétuité de la religion)។ à perpétuité *loc. adv.* ជានិច្ចកាល (ឧ. travaux forcés à perpétuité)

perplexe *a.* អល់អែក (ឧ. situation perplexe)

perplexité *n.f.* ការអល់អែក

perquisition *n.f.* ការរុករកដោយហ្មត់ចត់;ការឆែកឆេរតាមបង្គាប់តុលាការ

perquisitionner *v.i.* រុករកដោយហ្មត់ចត់; ឆែកឆេរតាមបង្គាប់តុលាការ

perré *n.m. Trav. publ.* ខឿនទប់ដី

perron *n.m. Constr.* ខឿនជណ្ដើរ

perroquet *n.m.* សេកសោម, សេកមានធំ ។ *Fig.* សេក, អ្នកនិយាយឬធ្វើតាមគេដោយឥតពិចារណា

perruche *n.f.* សេកអាត់, សេកមាឌតូច; សេកញី

perruque *n.f.* សក់ក្លែង ។ *Fig. & Fam.* tête à perruque ឬ vieille perruque អ្នកប្រកាន់ជំនឿហួសសម័យ

perruquier *n.m.* ជាងកាត់សក់

pers,e *a.* ដែលមានពណ៌ពងក្រួក

persan,e *a.&n.* នៃប្រទេសពែរ្ស (ឧ. les rois perses)។
n.m. ភាសាពែរ្ស

persécutant,e *a.* ដែលធ្វើទុក្ខបុកម្នេញ; ដែលឲ្យរំខាន

persécuté,e *n.&a.* វិហេឋិ, ដែលត្រូវគេធ្វើទុក្ខបុកម្នេញ; ដែលត្រូវគេរំខាន

persécuter *v.t.* ធ្វើវិហេឋការ [វិ-ហេ-ឋិ:-], ធ្វើទុក្ខបុកម្នេញ (ឧ. Néron persécuta les chrétiens) ។ *Par ext.* ធ្វើបាប, រំខាន (ឧ. être persécuté par des créanciers)

persécuteur,trice *n.&a.* វិហេឋក:-កា, អ្នកធ្វើទុក្ខបុកម្នេញ (ឧ. être livré à ses persécuteurs)។ *Par ext.* អ្នកធ្វើបាប, អ្នករំខាន (ឧ. enfants persécuteurs)

persécution *n.f.* វិហេឋការ [វិ-ហេ-

ឋិៈ-], ការធ្វើទុក្ខបុកម្នេញ ។ *Par ext.* ការធ្វើបាប, ការរំខាន (ឧ. accabler quelqu'un de ses persécutions)

persévérance *n.f.* អធិយោគ, ព្យាយាម, សេចក្ដីខ្ជាប់ខ្ជួន

persévérant,e *a.* ដែលមានអធិយោគ, ខ្ជាប់ខ្ជួន

persévérer *v.i.* ព្យាយាម, មានសេចក្ដីខ្ជាប់ខ្ជួន (ឧ. il persévère dans l'étude); ឋិតនៅយូរ (ឧ. fièvre qui persévère)

persienne *n.f. Contsr.* ស្លាបព្រិល

persiflage *n.m.* ការចំអកពេបជ្រាយ

persifler *v.t.* ចំអកពេបជ្រាយ

persifleur,euse *a.&n.* ដែលចំអកពេបជ្រាយ

persil *n.m.* ភ្លៅកង្កែប (បន្លែម្យ៉ាង) (ឧ. le persil s'emploie comme condiment)

persique *a.* នៃប្រទេសពែរ្សបុរាណ

persistance *n.f.* មានះ, ការស៊ូ (ឧ. mettre de la persistance à faire quelque chose); ភាពឋិតនៅយូរ (ឧ. persistance du mauvais temps)

persistant,e *a.* មានះ, ដែលស៊ូ (ឧ. plaideur persistant); រឹង, ឋិតនៅយូរ (ឧ. fièvre persistante) ។ *Bol.* មិនរបេះជ្រុះ (ឧ. feuillage persistant)

persister *v.i.* មានមានះ, ស៊ូ (ឧ. persister dans la résolution); ឋិតនៅយូរ, មិនបាត់ (ឧ. douleur qui persiste)

persona grata ស្វាគមបុគ្គល (ខាងទូតគឺតំណាងជនដែលរដ្ឋត្រូវខ្លួនទៅនោះទទួលដោយរីករាយ; *par ext.* ជនដែលគេគាប់ចិត្ត)

personnage *n.m.* កិត្តិមជន (ជនប្រកបដោយកិត្តិនាម) (ឧ. les grands personnages de l'Antiquité); ជន (សំដៅយកចរិយា)(ឧ. un triste personnage); តួ (ក្នុងរឿងល្ខោន ឬ ប្រលោមលោក (ឧ. les personnages de Corneille) ។ personnage allégorique តួរូបាទិដ្ឋាន(តួតំណាងជំរើជំនះ កេរ្តិ៍ឈ្មោះ ។ល។)

personnaliser *v.t.* ធ្វើឲ្យដូចជាមនុស្ស (ឧ. personnaliser un vice)

personnalisme *n.m.* បុគ្គលនិយម (ការទ្រឹស្ដីទស្សនវិជ្ជា និយមថាតម្លៃធំបំផុតនៅលើរូបមនុស្សទាំងមូល)

personnalité *n.f.* បុគ្គលិកលក្ខណៈ, ចរិតមនុស្ស, ចរិតរបស់ជនម្នាក់ (ឧ. respecter la personnalité humaine; un homme qui a de la personnalité); ឥស្សរជន (ឧ. il y avait à cette cérémonie beaucoup de personnalités); ការជៀមដាម(ឧ. se permettre des personnalités); បច្ចេកលក្ខណៈ; បច្ចេកភាព។ personnalité juridique បុគ្គលិកលក្ខណៈគតិយុត្ត ។ personnalité morale បុគ្គលិកលក្ខណៈសីលធម៌ ។ dédoublement de personnalité(ម.ព.dédoublement)

personne *n.f.* អ្នក (បុរស ឬ ស្ត្រី) (ឧ. quelles sont ces personnes?); បុគ្គល (ឧ. le bonheur tient surtout à la personne); រូប, ខ្លួន (ឧ. être bien fait de sa personne); ជីវិត(ឧ. on a attenté à sa personne)។

Loc. adv. grande personne មនុស្សធំ (ទីទៃពីកូនក្មេង) ។ jeune personne ស្រីក្រមុំ; ពីន ក្មេង (ទាំងពីរភេទ) (ឧ. il serait bien à souhaiter que les jeunes personnes des deux sexes fussent toujours éclairées)។ dans la personne de លើរូប (ឧ. il n'y a de nation libre que celle où chacun se sent offensé dans la personne de l'opprimé) ។ en personne ដោយខ្លួនឯង (ឧ. général en chef qui prend en personne la direction d'un assaut); *au fig.* ជាតួអង្គ (ជារូបរាង) (ឧ. c'est l'honneur, c'est l'avarice en personne) ។ acception de personne ការយល់មុខ (ឧ. celui qui, dans un jugement, fait acception de personnes pèche contre la droiture et la bonne foi) ។ sans acception de personnes ដោយឥតយល់មុខ ។

être bonne personne ស្លូត (មានអារម្មណ៍ល្អហើយស្លូត)។aimer sa personne ស្រឡាញ់ខ្លួន, ពួលចិត្តទុកស្រឡាញ់ខ្លួន ។ répondre de la personne de quelqu'un ធានាចំពោះរូបអ្នកណាមួយ,ទទួលខុសត្រូវចំពោះរូបអ្នកណាមួយ ។ de sa personne ខ្លួនឯង ។ payer de sa personne ប្តូរស្លាប់រស់; បំពេញករណីយកិច្ចលំបាកដោយក្លាហាន; ប្រថុយគ្រោះ, ប្រថុយរូបកាយ (ឧ. la femme qui accepte d'un homme des présents contracte une dette qu'elle s'expose à payer de sa personne) ។ être bien fait de sa personne មានរូបល្អ (សម) ។ s'assurer de la personne de quelqu'un ចាប់ខ្លួន, ឃុំខ្លួន ។

Dr. personne civile និតិភាពបុគ្គល ។ personne juridique គតិបុត្តបុគ្គល ។ personne morale នីតិបុគ្គល ។ personne physique រូបវន្តបុគ្គល ។ personne humaine មនុស្ស ។ personne internationale អន្តរជាតិបុគ្គល ។ personne privée ឯកជនបុគ្គល ។ personne publique សាធារណបុគ្គល (អ្នកបំពេញមុខងារសាធារណៈ) ។

Gram. បុរិស: ។ première personne បឋមបុរិស: ។ deuxième personne ទុតិយបុរិស:។ troisième personne តតិយបុរិស:

personne *pr.ind.m.sing.* អ្នកណាមួយ (ឧ. personne osera-t-il nier ?); គ្មានម្នាក់ (ឧ. hier personne n'est venu)

personnel,elle *a.* ជាតិបុគ្គល [ប៉ឺ-តិ–], ផ្ទាល់ខ្លួន (ឧ. affaire personnelle), នៃជនម្នាក់ៗ (ឧ. qualités personnelles) ។ contribution personnelle វិភាគទាននៃជនម្នាក់ៗ ។

Gram. pronom personnel បុរិសសព្វនាម ។

n.m. បុគ្គលិក (ឧ. le personnel enseignant; le personnel d'une imprimerie)

personnellement *adv.* ដោយខ្លួនឯង (ឧ. répondre personnel-

lement)

personnificateur,trice *n.* បដិរូបករ (ឧ. Plutarque, en personnificateur de l'histoire, peint plus qu'il ne raconte)

personnification *n f.* បដិរូបកម្ម(ការកំណត់ឲ្យមានចិត្ត - គំនិត ឬ សំដីដូចមនុស្ស) (ឧ. les personnifications sont fréquentes en poésie); តួអង្គ; តំរូតតខ្មោះ

personnifier *v.t.* ធ្វើបដិរូបកម្ម(កំណត់ឲ្យមានចិត្ត - គំនិត ឬ សំដីដូចមនុស្ស) (ឧ. Boileau, dans le «Lutrin», a plaisamment personnifié la Mollesse); ជាតួអង្គ (ឧ. Néron personnifie la cruauté)

perspectif,ive *a.* ជាទស្សនវិស័យ (ឧ. dessin plan perspectif)

perspective *n.f.* ទស្សនវិស័យ, នេត្រាទស្សន៍ (គំនូរតាមឃើញពីចម្ងាយ, ភាពវត្ថុឃើញពីចម្ងាយ) (ឧ. les lois de la perspective; voilà un coteau qui fait une belle perspective) ។

Fig. ការប្រមើលអនាគត (ឧ. avoir la perspective d'un bel avenir); ភាពឆ្ងាយ, ភាពប្រយោល (ឧ. manquer de perspective pour juger un événement) ។

Econ. pol. perspective économique ទស្សនវិស័យសេដ្ឋកិច្ច ។

en perspective *loc. adv.* ពីចម្ងាយ;ក្នុងអនាគតកាល (ឧ. avoir une belle situation en perspective)

perspectivisme *n.m.* ទស្សនវិសយនិយម [ទ័ស-សៈ-ន៉ៈ-វី-សៈ-យ៉ៈ—]

perspicace *a.* មុត, វាងវៃ (ឧ. un esprit perspicace)

perspicacité *n.f.* ប្រាជ្ញាមុត, សេចក្ដីវាងវៃ (ឧ. la perspicacité féminine)(ប្រ. acuité, clairvoyance, finesse, lucidité, sagacité)

perspiration *n.f.* ដំណើរបែកញើសតិច ៗ

persuadant,e *a.* ដែលបញ្ចុះបញ្ចូល (ឧ. argument persuadant)

persuader *v.t.* បញ្ចុះបញ្ចូល, អន្ទង (ឧ.

on l'a persuadé ឬ on lui a persuadé de se marier) ។

se persuader *v.pr.* ស្មាន (ឧ. ils se sont persuadés qu'on les trompait)

persuasible *a.* អាចបញ្ចុះបញ្ចូលបាន

persuasif,ive *a.* ដែលបញ្ចុះបញ្ចូល (ឧ. un ton persuasif)

persuasion *n.f.* ការបញ្ចុះបញ្ចូល (ឧ. don de persuasion); ជំនឿជាក់ (ឧ. j'ai la persuasion que vous réussirez)

persuasivement *adv.* ដោយបញ្ចុះ-បញ្ចូល

perte *n.f.* ការបាត់; ការខូច (ឧ. perte de la vue ការខូចភ្នែក គឺខ្វាក់); បរាភព; ការវិនាស (ឧ. la perte d'un ami; il a juré sa perte); ការខាត (ឧ. ce commerçant a éprouvé de grandes pertes)។ perte sèche ការខាតទទេ (គ្មានបានអ្វីមកទប់ទល់)។ ការចាញ់ (ក្នុងល្បែងឬក្នុងការប្រយុទ្ធ) (ឧ. perte d'une bataille) ។ perte de temps ការខាតពេល ។

Aéron. perte de vitesse ការអន់ល្បឿន ។

Pl. Mil. ការខូចខាត (នៃទ័ពក្នុងការប្រយុទ្ធ) (ឧ. les pertes se composent de la somme des tués, des blessés, des prisonniers, des disparus et des malades) ។

Loc. adv. avec perte ដោយចាញ់ ។ à perte ដោយខាត ។ à perte de vue ផុតកន្ទុយភ្នែក (ឧ. plaine qui s'étend à perte de vue) ។ en pure perte ដោយឥតប្រយោជន៍

pertinemment *adv.* ដោយមានសមត្ថភាព; ដោយជាក់ច្បាស់; ត្រូវ; ដោយសមហេតុផល (ឧ. parler pertinemment)

pertinence *n.f.* ភាពសមហេតុផល; ភាពត្រូវ

pertinent,e *a.* សមហេតុផល, ចំ (ឧ. fournir des raisons pertinentes)

pertuis *n.m.* ច្រកចង្អៀត

pertuisane *n.f.* លំពែងមានទៀង

perturbateur,trice *a.&n.* ដែលបង្កវិបរិត

perturbation *n.f.* វិបរិត (ឧ. jeter la perturbation dans une réunion)

perturber *v.t.* ធ្វើឲ្យមានវិបរិត (ឧ. perturber l'ordre public)

péruvien,enne *a.&n.* នៃប្រទេសប៉េរូ

pervers,e *a. &n.* កំណាច(ឧ. homme pervers)។ ***Fig. a.*** ខូច(ឧ. goûts pervers)

perversement *adv.* ដោយកំណាច

perversion *n.f.* ដំណើរខូច (ឧ. la perversion des mœurs)។ *Méd.* ដំណើរខូចអាការណាមួយក្នុងខ្លួន

perversité *n.f.* ការប្រព្រឹត្តិលខូច; អំពើកំណាច

pervertir *v.t.* នាំខូច (ឧ. pervertir la jeunesse); ធ្វើឲ្យខូច (ឧ.pervertir le goût)។

se pervertir *v.pr.* ទៅជាខូច

pervertissement *n.m.* ការនាំខូច ; ការបង្ខូច; ភាពខូច

pervertisseur,euse *a.&n.* ដែលនាំខូច (ឧ.romans pervertisseurs)

pesade *n.f.* ការលើកឈរដោយជើងក្រោយ (សេះ)

pesage *n.m.* ការថ្លឹង; កន្លែងថ្លឹងអ្នកជិះសេះប្រណាំង

pesamment *adv.* យ៉ាងធ្ងន់; យ៉ាងស្ពុយ; យឺតយ៉ាវ (ឧ. marcher pesamment)

pesant,e *a.* ធ្ងន់ (ឧ. un fardeau pesant); ស្ពុយ; យឺត (ឧ. allure pesante)។ *Fig.* ពិបាកទ្រាំ (ឧ. un joug pesant); យឺត (ឧ. esprit pesant); គ្មានសោភណភាព (ឧ. style pesant)។

n.m. ទម្ងន់ ។ valoir son pesant d'or មានគុណូបការ, មានតម្លៃច្រើន (ដូចមាសទឹកដប់)

pesanteur *n.f.* ភាពធ្ងន់ (ឧ. pesanteur d'un fardeau); ភាពស្ពុយ; ភាពយឺត (ឧ. pesanteur de la marche); ដំណើរមិនស្រួល (ឧ. pesanteur d'estomac)។

Fig. ភាពយឺត (ឧ. pesanteur de l'esprit)។

Phys. ភូរិពល (កម្លាំងស្រូបវត្ថុទាំងឡាយមកស្ទូលផែនដី)

pèse-acide *n.m.* សម្ទង់អាស៊ីដ (*pl.* des pèse-acides)

pèse-bébé *n.m.* ជញ្ជីងថ្លឹងកូនខ្ចី(*pl.* des pèse-bébés)

pesée *n.f.* របៀបថ្លឹង;ការថ្លឹង(ឧ.faire la pesée d'une marchandise); វគ្គថ្លឹងមួយលើក (ឧ. une pesée de 50 kilogrammes)។ *Par ext.* ការប្រឹង (ទាញខ្សែយោង ឬ សង្កត់ដងថ្លឹង)

pèse-esprit *n.m.* សម្ទង់វត្ថុរាវស្រាលជាងទឹក (*pl.* des pèse-esprits)

pèse-lait *n.m.* សម្ទង់ទឹកដោះ (*pl.* des pèse-laits)

pèse-moût *n.m.* ម.ព.glucomètre

pèse-lettre *n.m.* ជញ្ជីងថ្លឹងសំបុត្រ (*pl.* des pèse-lettres)

peser *v.t.* ថ្លឹង។ *Fig.* ថ្លឹង, ពិនិត្យយ៉ាងហ្មត់ចត់ (ឧ. peser le pour et le contre) ។ peser mûrement les choses ពិនិត្យពិច័យដោយហ្មត់ចត់ ។ peser ses paroles ថ្លឹងពាក្យសំដី(និយាយដោយប្រុងប្រយ័ត្ន)។ រំខាន(ឧ. sa présence me pèse) ។

v.i. មានទម្ងន់(ឧ.le platine pèse plus lourd que l'or); សង្កត់(ឧ. peser sur un levier); ឲ្យទុក្ខព្រួយ; ដាក់បន្ទុកលើ ។ peser sur l'estomac ធ្វើឲ្យក្រពះពិបាករំលាយអាហារ

pèse-sel *n.m.* សម្ទង់ជាតិប្រៃ (*pl.* des pèse-sels)

pèse-sirop *n.m.* សម្ទង់ស៊ីរ៉ូ (*pl.* des pèse-sirops)

peseta [pé-zé–] *n.f.* ប៉េសេតា(រូបិយវត្ថុប្រទេសអេស្ប៉ាញ) (*pl.* des pesetas)

pesette *n.f.* ជញ្ជីងថ្លឹងមាស

peseur,euse *n.* អ្នកថ្លឹង

peso *n.m.* ប៉ឺសូ (រូបិយវត្ថុនៃអាមេរិកឡាទីន)

peson *n.m.* ប៉ឺសុង (ប្រដាប់ថ្លឹងមិនសូវទៀង ប៉ុន្តែស្រួលប្រើ) (ឧ. peson à ressort, à contrepoids)

pessimisme *n.m.* ទុទិដ្ឋិនិយម (ព.ផ. optimisme)

pessimiste *n.* អ្នកទុទិដ្ឋិនិយម ។ *a.* ប្រកបដោយទុទិដ្ឋិនិយម (ឧ. esprit pessimiste)

peste *n.f.* រោគប៉េស្ត, រោគពិស។ *Fig.* មនុស្ស ឬ សត្វចង្រៃ (ឧ. les flat-

teurs, l'intolérance sont une peste)។ *Fig.* ក្មេងប៉ប៉ុល-ប៉ប្រ៉ោ។ peste soit de...ឬ peste de... អាប៉េស្តកើត, អាប៉ែលកេប

pester *v.i.* និយាយរអ៊ូរទាំ; ជេរប្រទេច (ឧ. pester contre la nature humaine)

pesteux,euse *a.* នៃរោគពិស

pestiféré,e *a.&n.* ដែលកើតជម្ងឺប៉េស្ត ឬ កើតពិស

pestilent,e *a.* នៃរោគប៉េស្ត (ឧ. fièvre pestilente)

pestilentiel, elle *a.* ដូចជារោគប៉េស្ត (ឧ. maladie pestilentielle); ដែលពុំក្លិនអាក្រក់ (ឧ. air pestilentiel)

pet *n.m.* ផោម

pétale *n.m. Bot.* ទលី [ទៈ-លី], ត្របកផ្កា (ត្របកនីមួយៗ)

pétaloïde *a. Bot.* ដូចទលី [ទៈ-លី]

pétarade *n.m.* សូរផ្ទុះ ឬ លាន់បន្តៗគ្នា (ដូចអុជផាវ)

pétarader *v.i.* បន្លឺសូរបន្តៗគ្នា (ដូចអុជផាវ)

pétard *n.m.* ផាវ; ធ្នូដាក់ឲ្យផ្ទុះបំបែក។ *Fig. & Fam.* សូរ, រឿងដែលឲ្យគេនិយាយតៗគ្នា (ឧ. nouvelle qui fait pétard)។ tirer un pétard អុជផាវ; *au fig.* ធ្វើឲ្យជំពើងជាទីចាប់អារម្មណ៍យ៉ាងខ្លាំង

pétaudière *n.f. Fam.* កន្លែងដែលគ្មានអ្នកណាស្ដាប់បង្គាប់អ្នកណា

péter *v.t.* ផោម; ផ្ទុះ (ឧ. le bois vert pète dans le feu)។ *Fam.* ផ្ទុះ, បែក

pète-sec *n.m. &a. inv. Fam.* អ្នកបង្គាប់បញ្ជាដោយម៉ឺងម៉ាត់(គ្មាននិយាយលេង)

péteur,euse *Fam. n.* អ្នកបោរផោម

péteux,euse *n. Fam.* មនុស្សកម្សាប ឬ កំសាក

pétillant,e *a.* ដែលផ្ទុះ (ឧ. feu pétillant); ភ្លឺ, ដែលព្រាយចេញ, ដែលឆេះ; វៃ(ឧ. esprit pétillant)

pétillement *n.m.* ការផ្ទុះ, ការព្រាយចេញ (ឧ. le pétillement du bois vert dans le feu)

pétiller *v.i.* ផ្ទុះ (ឧ. bois, charbon qui pétille); ចេញពពុះ (ឧ. le champagne pétille)។ *Fig.* ភ្លឺ (ឧ. des yeux qui pétillent)។ pétiller d'ardeur

ពុះពោរដោយសេចក្ដីក្លាហាន ។ pétiller d'esprit មានប្រាជ្ញាវៃ

pétiole *n.m.* ទងស្លឹក

pétiolé,e *a.* ដែលមានទង (ស្លឹកឈើ)

pétiot,e *a. &n. Fam.* ប្រមក់ (តូច)

Loc. div. donner un petit poisson pour en avoir un gros ឲ្យតិចដើម្បីប្រាថ្នាច្រើន ។ il avalerait la mer et les poissons ផឹកច្រើន, ស៊ីច្រើន ។ il boirait la mer et ses poissons ម.ក. boire។ *Fig.* ne savoir à quelle sauce manger son poisson ទុញទុះខ្លាំង, ជាប់ជុះខ្លាំង ។ la sauce fait manger ឬ fait passer le poisson ការបន្ទាប់បន្សំធ្វើឲ្យស្រួលការធំ។ muet comme un poisson គ្មានហើបមាត់, ស្ងាត់ស្ងៀមព្រៀមស្ងប់ (មិននិយាយសោះ) ។ ni chair ni poisson មិនច្បាស់លាស់; យោបល់មិនប្រាកដ ។ petit poisson deviendra grand មនុស្សប្រុសក្មេងទាំងឡាយត្រូវតែធំ គង់ ខែមេសា។ poisson d'avril ម.ក. avril។ être comme le poisson dans l'eau សប្បាយណាស់, ស្រួលណាស់, មិនរអែងខ្វល់។ finir en queue de poisson ល្អខាងដើម អន់ខាងចុង ។

Prov. les gros poissons mangent les petits ត្រីធំស៊ីបង្គា អ្នកធំជាន់ជិះអ្នកតូចតាច ។ jeune chair et vieux poisson ស៊ីប្រហិត និង បញ្ចៀសការស្ងួតស្ងោស៊ីត្រីឡើរកត្រីចាស់

poissonnerie *n.f.* ផ្សារត្រី, កន្លែងលក់ត្រី

poissonneux,euse *a.* ដែលមានត្រីច្រើន, សម្បូរត្រី (ឧ. les eaux du Cambodge sont très poissonneuses)

poissonnier,ère *n.* អ្នកលក់ត្រី ។ *n.f.* ប្រដាប់ចំហុយត្រី

poitrail *n.m.* ទ្រូងសេះ

poitrinaire *a.&n.* ដែលកើតរោគសួត; ដែលកើតរោគក្អករបេង

poitrine *n.f.* ឧរ, ទ្រូង; ដោះស្ត្រី, សួត (ឧ. maladie de poitrine រោគសួត (របេង); ពិធីរលេច (ព្រានព្រឹក

ពីទ្រូងសាច់) (ឧ poitrine de mouton)

poivrade *n.f.* ទឹកម្រេច

poivre *n.m.* ម្រេច។ *Fam.* poivre et sel ប្រផេះ

poivré,e *a.* ដែលដាក់ម្រេច ។ *Fig.* អាសគ្រាម (ឧ récit poivré) ។ *Pop.* ថ្លៃពេក

poivrer *v.t.* ដាក់ម្រេច

poivrier *n.m.* ដើមម្រេច; ប្រអប់ម្រេច

poivrière *n.f.* ចំការម្រេច ; ប្រអប់ដាក់ម្រេច; កិនម្រេច

poivron *n.m.* ផ្លែម្ទេស

poivrot *n.m.* *Pop.* ប្រមឹក

poix *n.f.* ជ័រស្អិត, ជ័រពុង

poker [−kèr] *n.m.* ដែកគ្វះលើកភ្លើង; ល្បែងប៉ូកែរ, បៀផែ

polaire *a.* នៃអក្សសាន (ឧ. mers, terres polaires)។ étoile polaire ម.ព. étoile ។ *Electr.* នៃក្បាលថ្មពិល ឬ មេដែក

polariser *v.t.* *Fig.* ទទួលរងអំពើរិះគន់នៃសាធារណជន

polatouche *n.m.* ឆ្មាបា

polder *n.m.* (ព. ហូឡង់ដេ) ប៉ុលឌែរ (ដីនដីបានដោយទប់សមុទ្រឬ ទំនាបបឹង)

pôle *n.m.* អក្សសាន, ប៉ូល (ឧ. les pôles sont couverts de glaces)។ pôle terrestre អក្សសានភូគោល។ ក្បាលថ្មពិល(ឧ.dans une pile, le courant va du pôle négatif au pôle positif)។ pôle nord អក្សសានឧត្តរ។ pôle sud អក្សសានទក្សិណ ។ *Fig.* ពាក្យផ្ទុយគ្នា (ឧ. l'erreur et la vérité sont deux pôles)។ pôle d'attraction គ្រឿងទាញ

polémarque *n.m.* មេទ័ពក្រិក (ក្នុងសម័យបុរាណ)

polémique *n.f.* សង្គ្រាមដីកា ។ *a.* នៃសង្គ្រាមដីកា(ឧ.une critique polémique)

polémiquer ឬ **polémiser** *v.i.* ធ្វើសង្គ្រាមដីកា

polémiste *n.m.* អ្នកធ្វើសង្គ្រាមដីកា

polémologie *n.f.* សង្គ្រាមសាស្ត្រ (វិទ្យាសាស្ត្រខាងសង្គ្រាម)

poli,e *a.* រលោង, រលើង (ឧ. du marbre poli) ។ *Fig.* គួរសម (ឧ. homme poli) ។ *n.m.* ភាព

ភ្លឺរលោង (ឧ. vaisselle d'un beau poli)(ព្រ. affable, civil, courtois, galant, gracieux)

police *n.f.* ប៉ូលីស (ក្រុមមនុស្សដែលធ្វើឲ្យមានរបៀបរៀបរយសាធារណៈ) (ឧ. organiser la police d'un Etat); ប៉ូលីស, ក្រុមនគរបាល (កងការ កាន់កាប់របៀបរៀបរយ) (ឧ. dénoncer quelqu'un à la police); ភ្នាក់ងារប៉ូលីស ។ police correctionnelle ប៉ូលីសមជ្ឈឹម ។ police criminelle ប៉ូលីសឧក្រិដ្ឋ ។ police judiciaire ប៉ូលីសតុលាការ ។ police spéciale ប៉ូលីសពិសេស ។ police urbaine ប៉ូលីសក្រុង ។ police nationale ក្រុមនគរបាលជាតិ ។ tribunal de simple police សាលាលហុ (ម.ព. tribunal ផង)

police *n.f.* បណ្ណសន្យា ។ police d'abonnement បណ្ណជាវប្រចាំ ។ police d'assurance បណ្ណសន្យារ៉ាប់រង

policeman *n.m.* ភ្នាក់ងារប៉ូលីសអង់គ្លេស (*pl.* des policemen)

policer *v.t.* ធ្វើឲ្យមានអរិយធម៌; ឲ្យប្រើច្បាប់ត្រឹមត្រូវល្អ (ឧ. Pierre 1er essaya de policer la Russie) ។ route policée ផ្លូវថ្នល់មានការការពាររៀបរយ ។

se policer *v. pr.* មានអរិយធម៌

polichinelle *n.m.* អាយ៉ង ។ *Fig.* មនុស្សគ្មានបត់ ឬ គ្មានសេចក្ដីថ្លៃថ្នូរ ។ secret de polichinelle ម.ព. secret

policier,ère *a.* នៃប៉ូលីស (ឧ. mesures policières); ដែលចេញពីក្រុមប៉ូលីស ។ *n.m.* មន្ត្រីប៉ូលីស (ឧ. les policiers)

poliment *adv.* ដោយគួរសម (ឧ. éconduire poliment un solliciteur)

poliomyélite *n.f.* គ្រុនស្លាប់អវយវៈ

poliomyélitique *a.* នៃរោគគ្រុនស្លាប់អវយវៈ ។ *a.&n.* ដែលកើតរោគគ្រុនស្លាប់អវយវៈ

poliorcétique *a.* នៃសិល្បៈឡោមក្រុង ។ *n.f.* សិល្បៈឡោមក្រុង

polir *v.t.* ខាត់ (ឧ. polir un métal) ។ *Fig.* អប់រំ (ឧ. polir l'esprit, les mœurs); សម្រិត-

សម្រាំង, កែឲ្យល្អ (ឧ. polir un discours)

polissable *a.* អាចខាត់បាន (ឧ. le marbre est polissable)

polissage ឬ **polissement** *n.m.* ការខាត់

polisseur,euse *n.* អ្នកខាត់

polissoir *n.m.* ប្រដាប់ខាត់

polisson,onne *n.* ក្មេងស្មោកគ្រោក; ក្មេងរនាថា (ឧ.les polissons de la rue); ក្មេងខិល ។ *a.* អាសគ្រាម (ឧ. une chanson polissonne)

polissonner *v.i.* ប្រព្រឹត្តអំពើខិលខូច; ប្រើសំដីអាសគ្រាម

polissonnerie *n.f* អំពើ ឬ សំដីខិលខូច; សំដីអាសគ្រាម

polissure *n.f.* ការខាត់; ភាពរលីង

politesse *n.f.* សេចក្ដីគួរសម; អំពើគួរសម (ឧ. faire une politesse) ។

Loc. div. politesse de marchand សេចក្ដីគួរសមប្រាថ្នាប្រយោជន៍ ។ brûler la politesse ចាកចេញឥតលា; មិនទៅកាន់ទីណាត់ ។

All. hist. l'exactitude est la politesse des rois ពិសោធន៍ទៀងពេល ជាសេចក្ដីគួរសមនៃព្រះរាជា (ភាសិតនៃព្រះចៅល្វីទី១៨)

politicard,e *n.&a. Péjor.* អ្នកនយោបាយថោកទាប

politicien,enne *n. Péjor.* អ្នកនយោបាយ

politique *a.* នយោបាយ (នៃការគ្រប់គ្រងរដ្ឋ) (ឧ. institutions politiques) ។ droits politiques សិទ្ធិនយោបាយ ។ économie politique ម.ក. économie ។ homme politique អ្នកនយោបាយ ។

n.m. អ្នកនយោបាយ (ឧ. Richelieu fut un habile politique)

politique *n.f.* នយោបាយ (ឧ. une politique prévoyante; parler politique); នយោបាយសាស្ត្រ; អ្នកនយោបាយ; អ្នកប៉ិនប្រសប់ ។ politique intérieure នយោបាយក្នុងប្រទេស ។ politique extérieure នយោបាយក្រៅប្រទេស

politiquement *adv.* តាមវិធីនយោបាយ ។ *Fig.* ដោយប៉ិនប្រសប់

politiquer *v.i.* ពិភាក្សាពីរឿងនយោបាយ

politisation *n.f.* នយោបាយកម្ម, ការឲ្យមានលក្ខណៈនយោបាយ (ឧ. la politisation des syndicats)

politiser *v.t.* ធ្វើនយោបាយកម្ម, ឲ្យមានលក្ខណៈនយោបាយ

polka *n.f.* ប៉ុលកា (របាំប៉ូឡូញមានពីរកង្វាក់)

pollen *n.m.Bot.* លំអងផ្កា (ឧ. transporté par le vent ou par les insectes, le pollen germe sur le stigmate du pistil)។ sac à pollen ថង់លំអងផ្កា

pollinique *a.* នៃលំអងផ្កា (ឧ. sac pollinique; tube pollinique)

pollinisation *n.f.* ដំណើរលំអងផ្កាកោយ; ផ្ទេរលំអងផ្កាកោយ

polluer *v.t.* ធ្វើឲ្យសាបរលាប (ឧ. polluer un temple); ធ្វើឲ្យប្រឡាក់ឬឲ្យកខ្វក់ (ឧ. polluer une rivière)

pollution *n.f.* ការធ្វើឲ្យសាបរលាប; ការធ្វើឲ្យកខ្វក់ (ឧ. la pollution d'une source)

polo *n.m.* ល្បែងប៉ូឡូ (ល្បែងកូនគោលលេងជិះសេះ)

polochon *n.m.Pop.* ខ្នើយឱប

polonais,e *a.* នៃប្រទេសប៉ូឡូញ ។ *n.* ជនជាតិប៉ូឡូញ ។ *n.m.* ភាសាប៉ូឡូញ

poltron,onne *a.&n.* កំឡាច, កំសាក (ករ. couard, lâche, peureux, pleutre, pusillanime, timoré)

poltronnerie *n.f.* កំឡាច, កំសាក

polyandre *a.* ពហុស្វាមី (ដែលមានប្ដីច្រើន) ។ *Bot.* ដែលមានទងកេសរច្រើន

polyandrie *n.f.* ពហុស្វាមិភាព (ភាពស្ត្រីមានប្ដីច្រើន) ។ *Bot.* ភាពរុក្ខជាតិមានទងកេសរច្រើន

polychroïsme *n.m.* ពហុវណ្ណលក្ខណ៍ (អាការនៃវត្ថុថ្លាដែលគេមើលឃើញពណ៌ផ្សេងៗតាមទំនងពន្លឺដែលបាំង)

polychrome *a.* ពហុវណ្ណ, ចម្រុះពណ៌ (ដែលមានពណ៌ច្រើន) (ឧ. statue polychrome)

polychromie *n.f.* ពហុវណ្ណភាព

polyclinique *n.f.* មន្ទីរពេទ្យពហុរោគ (មន្ទីរពេទ្យរោគច្រើនបែប)

polycopie *n.f.* វិធីផ្ដិតចម្លង

polycopier *v.t.* ផ្ដិតចម្លង

polyculture *n.f.* ពហុវប្បកម្ម, របៀបដាំដំណាំច្រើនមុខលើដីមួយកន្លែង

polyèdre *a &n. Math.* ពហុតល [ពៈ-ហ៊ុ-តល], ប្រុសព្ទក្រុងច្រើន

polyédrique *a.* ពហុតល

polygame *a.&n.* ពហុពន្ធ [ពៈ-ហ៊ុ-ពន់], បុរសប្រពន្ធច្រើន, ស្ត្រីប្ដីច្រើន (ក្នុងន័យនេះគេអាចប្រើពាក្យ polyandre បាន)។ *a. Bot.* ដែលមានផ្កាញីនិងផ្កាឈ្មោលលើដើមតែមួយ

polygamie *n.f.* ពហុពន្ធភាព, ភាពមានប្រពន្ធឬប្ដីច្រើន ។ *Bot.* ភាពរុក្ខជាតិមានផ្កាឈ្មោលនិងញីលើដើមតែមួយ

polyglotte *a.* ពហុភាសា (ដែលចេះនិយាយច្រើនភាសា) (ឧ. un interprète polyglotte); ដែលសរសេរជាច្រើនភាសា

polygonal,e,aux *a.* នៃពហុកោណ; ដែលមានរាងជាពហុកោណ

polygonation *n.f.* ពហុកោណកម្ម

polygone *n.m. Math.* ពហុកោណ ។ polygone irrégulier ពហុកោណមិនស្មើគ្រុង ។ polygone régulier ពហុកោណស្មើគ្រុង ។ *Mil.* ទីលានបាញ់កាំភ្លើងធំ

polymorphe *a.* ពហុសណ្ឋាន (ដែលឡើងក្រោមដោយមានសណ្ឋានផ្សេងៗ)

polynôme *n.m. Math.* ពហុធា(សព្ទនៃពីជគណិត ដែលមានឯកធាច្រើនតួបូកគ្នាឬសងគ្នា)

polynucléaire *a.* ពហុនយស៊ី [ពៈ-ហ៊ុ-នៈ-យស់] (ដែលដូចជាមាននយស៊ីច្រើន) ។ *n.m.* ពហុនយស៊ី

polype *n.m.* រូបហស៊ីលាប្រាណ [រ-ប៉ះ-ស៊ិ-ឡា-]

polypeux,euse *a.* នៃរូបហស៊ីលាប្រាណ; ដូចរូបហស៊ីលាប្រាណ

polyphone *a.* ដែលមានសម្លេងច្រើន (អក្សរ)

polysoc *a.* ដែលមានផាលច្រើន(នង្គ័ល)

polysyllabe ឬ **polysyllabique** *a.* ពហុព្យាង្គ

polytechnicien *n.m.* និស្សិតពហុបច្ចេកទេស

polytechnique *a.* ពហុបច្ចេកទេស ។ enseignement polytechnique ពហុបច្ចេកទេសសិក្សា ។ école polytechnique សាលាពហុបច្ចេកទេស

polythéisme *n.m.* ពហុទេពនិយម (លទ្ធិនិយមអាទិទេពច្រើន) (ព.ផ. monothéisme)

polythéiste *a.* ពហុទេពនិយម ។ *n.* អ្នកពហុទេពនិយម

polyurie *n.f.* ពហុបស្សាវរោគ, រោគនោមច្រើន (ឧ. la polyurie accompagne souvent le diabète)

polyurique *a.* ពហុបស្សាវរោគ ។ *a.&n.* ពហុបស្សាវរោគី, ដែលកើតពហុបស្សាវរោគ

polyvalent,e *a.* ដែលត្រូវច្រើនមុខ (ឱសថ)

pommade *n.f.* ប៉ូម៉ាត, ឱសថក្រមួន។ *Fig.* & *Fam.* passer de la pommade à quelqu'un បញ្ជោរ

pommader *v.t.* លាបប៉ូម៉ាត (ឱសថក្រមួន)

pomme *n.f.* ផ្លែប៉ោម ។ pomme d'une canne គោលដំបង (រាងដូចផ្លែប៉ោម)។ pomme d'amour ប៉េងប៉ោះ ។ pomme cannelle ទៀប ។ pomme de terre ដំឡូងបារាំង ។ pomme rose ផ្លែជម្ពូ ។ *Anat.* pomme d'Adam ក្រាប់ពោន (ឆ្អឹងខ្ចីត្រង់បំពង់កមនុស្ស) ។ pomme d'arrosoir ក្បាលបំពង់ស្រោចទឹក (រាងដូចផ្លែឈូក) ។ *Fig.* pomme de discorde ហេតុជំលោះឬឲ្យបែកបាក់គ្នា ។ *Pop.* tomber dans les pommes សន្លប់

pommé,e *a.* មូលខ្ទបផ្លែប៉ោម ។ chou pommé ស្ពៃក្តោប (ម.ព. chou ផង) ។ *Fig.* & *Fam.* ពេញទី (ឧ. sottise pommée)

pommeau *n.m.* គោលដំបង; គោលដងដាវ (ត្រង់ត្រមោង)

pommelé,e *a.* ពពាល (ប្រផេះនឹងស) (ឧ. cheval pommelé)

pommeraie *n.f.* ចំការប៉ោម (ដីដាំដើមប៉ោម) (ឧ. les pommeraies normandes)

pommette *n.f.* ខ្ពង់ថ្ពាល់ (ភាគថ្ពាល់ដែលទុលឡើង)

pommier *n.m.* ដើមប៉ោម

pompage *n.m.* ការសប់, ការបូម (ឧ. station de pompage)

pompe *n.f.* *Techn.* ស្នប់ ។ pompe aspriránte ស្នប់បឺត, ម៉ាស៊ីនបូមទឹក (ដោយស្រូប)។ pompe foulante កាំភ្លោះ, ស្នប់បាញ់, ម៉ាស៊ីនបាញ់ទឹក (ដោយជម្រុញ) (ម.ព. foulant ផង)។ pompe aspirante et foulante ស្នប់បឺតបាញ់, កាំព្រួច ។ pompe à incendie កាំផ្លោចលត់ភ្លើង

pompe *n.f.* ក្បួនអធិកអធម។ pomme

funèbre ក្បួនហែសព ។ *Relig.* សេចក្ដីសប្បាយឥតខ្លឹមសារ (ឧ. renoncer au monde et à ses pompes)

pompéien,enne *a. & n.* នៃក្រុងប៉ុមប៉េអ៊ី (ឧ. vase pompéien); ជាកូនក្រុងប៉ុមប៉េអ៊ី

pomper *v.t.* សប់, បូម, បឺត ។ *Par ext.* ស្រូប (ឧ. le soleil pompe les eaux)។ *Pop.* បូម, ផឹកច្រើន (ស្រា); ធ្វើឲ្យអស់កម្លាំង

pompette *a. Fam.* ស្រវឹងស្រៀងៗ

pompeusement *adv.* ដោយអធិកអធម

pompeux,euse *a.* អធិកអធម (ឧ. entrée pompeuse)

pompier *n.m.* អ្នកលត់អគ្គិភ័យ (មើ. sapeur - pompier); អ្នកធ្វើឬលក់ស្នប់ ។

a. Fam. សាមញ្ញ; ដែលបំភ្លៃ (ឧ. style pompier)

pompiste *n.m.* អ្នកបូមប្រេងសាំង ។ *Mar.* អ្នកកាន់កាប់ស្នប់ (ក្នុងនាវាប្រេងកាត)

pompon *n.m.* ភួ (សំណុំសក់, រោម, សរសៃអ្វីៗសម្រាប់ប្រើជាគ្រឿងរយោល)។ *Fam.* avoir le pompon ល្អះគេ ។ avoir son pompon ស្រវឹងស្រៀងៗ

pomponner *v.t.* លំអដោយភួ (ឧ. pomponner une coiffure) ; តែងខ្លួនឲ្យ (ឧ. pomponner une mariée) ។

se pomponner *v.pr.* តែងខ្លួនយ៉ាងស្អាត

ponant *n.m.* មើ. នៃ occident

ponantais,e *a. & n.* ជនជាតិបស្ចិមប្រទេស

ponçage *n.m.* ខាត់រលីងដោយថ្ម

ponce *n.f.* ម.ព. pierre ponce

ponceau *n.m.Trav.publ.* កូនស្ពាន

ponceau *n.m.* ដើមអាភៀនព្រៃ។ *a. inv.* ក្រហម (ឧ. des rubans ponceau)

poncer *v.t.* ខាត់រលីងដោយថ្ម (ឧ. poncer du cuir)

ponceux,euse *a.* ដូចថ្មខាត់ ។ *n.f.* ម៉ាស៊ីនខាត់

poncho [pon-tcho] *n.m.* ប៉ុងឆូ (អាវរងាមួយបែបប្រើនៅប្រទេសអាមេរិកខាងត្បូង)

ponction *n.f.* ការបូមខ្ទុះ (វេជ្ជវិទ្យា) ។ *Fig.* ការហូត, ការយកចេញ (ឧ.

ponction faite au budget)

ponctionner *v.t.* បូមខ្ទុះ(វេជ្ជវិទ្យា) (ឧ. ponctionner une pleurésie)

ponctualité *n.f.* អាការទៀងពេល (ឧ. arriver à son travail avec ponctualité) (សរ. exactitude, régularité)

ponctuation *n.f.* វិធីប្រើវណ្ណយុត្ត ។ signes de ponctuation វណ្ណយុត្ត

ponctué,e *a.* ដែលដាក់វណ្ណយុត្ត (ឧ. page mal ponctuée); ចុចៗ (ឧ. ligne ponctuée); អុចៗ (ឧ. plumage ponctué)

ponctuel,elle *a.* ទៀងពេល (ឧ. un écolier ponctuel); ជាចំណុចមួយ (ឧ. image ponctuelle)

ponctuellement *adv.* ដោយទៀងពេល

ponctuer *v.t.* ដាក់វណ្ណយុត្ត ។ *Fig.* សង្កត់ពាក្យ(ឧ.ponctuer chaque mot d'un geste)

pondaison *n.f.* ការពង; រដូវបញ្ចេញពង

pondérable *a.* អាចថ្លឹងបាន, ដែលមានជុំ (ឧ. fluide pondérable)

pondéral,e,aux *a.* នៃទម្ងន់

pondérateur,trice *a.* ដែលថ្លឹង,ដែលធ្វើឲ្យមានតុល្យភាព (ឧ. pouvoir pondérateur)

pondération *n.f. Méc.* តុល្យភាព (កើតកើយកម្លាំងផ្ទុយគ្នា)។ pondération des pouvoirs តុល្យភាពនៃអំណាច ។ *Fig.* ការចេះប្រមាណ; ភាពស្ងប់,ភាពនឹងនួន(មិនប្រាស់ប្រាស់) (ឧ. agir avec pondération) (សរ. placidité, sérénité, tranquillité ។ ព.ផ. agitation, déséquilibre, fébrilité, nervosité)

pondéré,e *a.* នឹងនួន (ឧ. esprit pondéré)

pondérer *v.t.* ថ្លឹងឲ្យស្មើ; ធ្វើឲ្យមានតុល្យភាព

pondéreux,euse *a.* ធ្ងន់ណាស់ (ឧ. transporter par eau des produits pondéreux)។ *n.m. pl.* ទំនិញធ្ងន់ណាស់(ធ្ងន់លើសពីមួយតោនក្នុងមួយម៉ែត្រគីប)

pondeur,euse *a.&n.* ដែលពង។ *Fig. & fam.* ដែលបង្កើតឬតែងបានច្រើន (ឧ. un infatigable pondeur de prose)

pondoir *n.m.* សំបុកដាក់ឲ្យមាន់ពង

pondre *v.t.* ពង (ឧ. les animaux qui pondent sont dits «ovipares»។ *Fig. & fam.* បង្កើត(ធ្វើ, តែង) (ឧ. pondre des vers)

poney *n.m.* សេះតូច

pont *n.m.* ស្ពាន។ *Mar.* នាវាភូមិ,រនាបនាវា ។ pont aérien ស្ពានអាកាស (ការធ្វើគមនាគមន៍តាមផ្លូវអាកាសនៅមណ្ឌលដែលធ្វើគមនាគមន៍តាមផ្លូវគោក ឬផ្លូវទឹកមិនកើត)។ pont bascule ជញ្ជីងស្ពាន។ pont de bateaux ស្ពានទូក (ស្ពានធ្វើដោយបង់ទូកផ្គោបគ្នា)។ pont élévateur ស្ពានលើក (គ្រឿងកាប់លើករថយន្តដើម្បីលាងប្រេង)។ pont tournant ស្ពានវិល ។ pont suspendu ស្ពានព្យួរ (ស្ពានគ្មានសសរ) ។ pont essieu ខ្នល់ភ្លៅ ។ pont arrière ភ្លៅក្រោយនៃរថយន្ត។ ponts et chaussées អភិបាលស្ពាននឹងថ្នល់។ ingénieur des ponts et chaussées ម.ព. ingénieur ។ tête de pont ក្បាលស្ពាន (ក្បាលកងទ័ពដែលបានឡើងទៅត្រើយម្ខាងហើយ) (ម.ព. tête ផង)។ *Jeux* couper dans le pont កាប់បៀចំកន្លែងដែលគេពត់បំណក់; *au fig.* លាញ់ល្បិចគេ ។ *Fig.* faire le pont ឈប់ភ្ជាប់ (ឈប់ថ្ងៃចន្លោះនៃថ្ងៃឈប់ពីរ) ។ pont aux ânes *Fig. & fam.* បញ្ហាពិបាកចំពោះមនុស្សឆោត

pontage *n.m.* , គំបូលតូចនៅក្បាល ឬកន្សៃទូក

ponte *n.f.* ការពង; វេលាបញ្ចេញពង;ចំនួនស៊ុតដែលពងបាន (ឧ. une ponte abondante)

ponté,e *a.* ដែលមានក្ដារក្រាល (នាវា) (ឧ.embarcation pontée)

ponter *v.t. Mar.* ក្រាលក្ដារ (នាវា)

pontife *n.m.* បព្វជិតមានសមណសក្តិ (ឧ. les évêques sont des pontifes)។ souverain pontife ប៉ាប ។ *Fig. & fam.* អ្នកធ្វើឫក (ឧ. les pontifes de la critique)

pontifical,e,aux *a.* នៃសមណសក្តិ (ជាពិសេសគឺសមណសក្តិរបស់ប៉ាប) (ឧ. siège pontifical)

pontificat *n.m.* មហាសមណសក្តិ; សមណសក្តិជាប៉ាប(សាសនាកាតូលិក); រយៈកាលនៃអំណាចប៉ាបមួយរូប (ឧ. le

pontificat de Léon X)

pontifier *v.i. Fam.* ធម្មើងឫក

pont-levis *n.m.* ស្ពានយោង (ដែលលើកដាក់បាន) (*pl.* des ponts-levis)

ponton *n.m.* ស្ពានបណ្តែត, ស្ពានផែ

pontonnier *n.m.* ទាហានសង់ស្ពាន

pool [poul] *n.m.* ពូល (កិច្ចព្រមព្រៀងកំណត់ផលិតផល)

popeline *n.f.* ប៉ូពឺលីន (សំពត់)

poplité,e *a.* នៃគន្លាក់អាប់ម (ឧ. muscle poplité)

popote *n.f.Fam.* ម្ហូប (ឧ. faire la popote) ; ភោជនីយដ្ឋាន ។ *a. Fam.* សាមញ្ញ, មិនថ្លៃថ្នូរ

populace *n.f.* រាស្ត្រថោកទាប (ព. បន្ទោក)

populacier,ère *a.* នៃរាស្ត្រថោកទាប

populaire *a.* នៃរាស្ត្រ, នៃប្រជារាស្ត្រ (ឧ. les classes populaires); សម្រាប់រាស្ត្រ (ឧ.quartier populaire); ប្រជាប្រិយ (ដែលរាស្ត្ររាប់អាន, ដែលរាស្ត្រស្រឡាញ់) (ឧ. ministre populaire); សាមញ្ញ (ឧ. style populaire)។

Pol. ប្រជាមានិត ។ front populaire រណសិរ្សប្រជាមានិត [រៈ-ណៈ-សេរ-] ។ démocratie populaire ប្រជាធិបតេយ្យប្រជាមានិត ។ agitation populaire ប្រជាកោលាហល

populairement *adv.* ដោយប្រជាប្រិយ

populariser *v.t.* ធ្វើឲ្យរាស្ត្ររាប់អាន ; ធ្វើឲ្យរាស្ត្រស្គាល់; ផ្សាយ (ឧ. populariser une idée)

popularité *n.f.* ប្រជាប្រិយភាព(ដំណើររាស្ត្រស្រឡាញ់រាប់អាន) (ឧ. jouir d'une large popularité)

population *n.f.* ប្រជាជន, ប្រជាពលរដ្ឋ។ population active ប្រជាជនសកម្ម ។ ក្រុម (មនុស្ស, សត្វ ឬ រុក្ខជាតិ)

populeux,euse *a.* ដែលមានប្រជាជនច្រើន (ឧ. quartier populeux)

populisme *n.m.* ប្រជានិយម (លទ្ធិអ្នកតែងប្រលោមលោកស្តីអំពីប្រជារាស្ត្រ)

populiste *a.&n.* ប្រជានិយម

populo *n.m. Pop.* រាស្ត្រថោកទាប; ពួកមនុស្ស

poquer *v.i.* បោះផ្តាក់

porc *n.m.* ជ្រូក (cri: le porc grogne); សាច់ជ្រូក (ឧ. manger du porc) ។ porc frais សាច់ជ្រូក

ស្រស់ ។ *Fig.* មនុស្សស្មោកគ្រោកឬល្មោភ

porcelaine *n.f.* ចានថ្មខៀវ (ភាជនដីសាប់ម្ហត់)

porcelainier,ère *a.* នៃចានថ្មខៀវ (ឧ. industrie porcelainière) ។ *n.m.* អ្នកធ្វើចានថ្មខៀវ

porcelet *n.m.* កូនជ្រូក

porc-épic *n.m.* ប្រមា

porchaison *n.f.Véner.* រដូវជ្រូកព្រៃធាត់

porche *n.m.* ខ្លោងទ្វារ

porcher,ère *n.* គង្វាលជ្រូក

porcherie *n.f.* ទ្រុងជ្រូក

porcin,e *a.* សុករសាទិស, នៃជ្រូក (ឧ. race porcine) ។ *n.m. pl.* សុករសាទិសសត្វ

pore *n.m. Anat.* រន្ធញើស, លោមកូប [លោ-មៈ-], រន្ធក្លកោម ។ *Bot.* មុខប្រេះ (ផ្លែឈើ)

poreux,euse *a.* ដែលមានរន្ធ (ឧ. l'argile sèche est très poreuse); ប្រហោក, ស្ពោត

poricide *a.* ម.ក. déhiscent

pornographe *a.&n.* អ្នកកាមសាស្ត្រ (អ្នកនិពន្ធរឿងអាសគ្រាម)

pornographie *n.f.* កាមសាស្ត្រ (អក្សរសាស្ត្រអាសគ្រាម)

pornographique *a.* ជាកាមសាស្ត្រ

porosité *n.f.* ភាពមានរន្ធ (ឧ. la porosité de la pierre ponce); ភាពប្រហោក ឬ ស្ពោត

porphyre *n.m.* ប្រភិឡសិលា [ប្រ-ភិឡៈ-]

port *n.m.* កំពង់; កំពង់ផែ; ក្រុងផែ (ក្រុងនៅជិតកំពង់ផែ) (ឧ. habiter un port de mer) ។ port fluvial កំពង់ផែទន្លេ ។ port maritime កំពង់ផែសមុទ្រ ។ port d'attache កំពង់លំនៅ (កំពង់ដើមកំណើត, ទីលំនៅរបស់នាវា) ។ port autonome កំពង់ផែស្វយ័ត [ស្វៈ-យ៉ាត់] ។ port franc កំពង់ផែរួចពន្ធ ។

Fig. ត្រើយ; ទីសប្បាយ; ស្ថានភាពស្រួល (ឧ. s'assurer un port dans la tempête) ។ arriver à bon port ទៅដល់ដោយសុវត្ថិភាព ។ faire naufrage au port លិចកំពង់លង់ទូក (ខូចការណ៍ក្នុងពេលដែលកៀបនឹងសំរេច)

port *n.m.* ប្រាក់ផ្ញើតាមរទេះ (នៅប្រទេស

យាក់ង)

port *n.m.* ការស្ទៀកពាក់; ការកាន់-សែង-លី-ដឹកនាំ; តម្លៃដឹកនាំ-លី-សែង (ឧ. payer le port d'un colis); ទ្រង់ទ្រាយនៃដើមឈើ;ដំណើរ;របៀប; ឫកពា (ឧ. un port noble et majestueux) ។

frais de port សោហ៊ុយដឹកនាំ ។ port d'armes ការឬសិទ្ធិកាន់អាវុធ

portable *a.* អាចស្ទៀកពាក់បាន; អាចលើកដាក់បាន

portage *n.m.* ការលើក (ឧ. le portage des marchandises); ការលី, ការព្រនាក់

portail *n.m.* ពោរណៈ, ខ្លោងទ្វារធំ

portant *n.m.* ត្រចៀកហិប

portant,e *a.Techn.* ដែលលើកឬទ្រ ។ être bien portant សុខសប្បាយ (ដែលមានសុខភាពល្អ)។ être malportant មិនសុខសប្បាយ ។

à bout portant *loc. adv.* ផ្ទុក(បាញ់ពីទីជិតពេកស់) (ម.ព.bout ដង)

portatif,ive *a.* ងាយលើកដាក់ (ឧ. table portative)

porte *n.f.* ទ្វារ ។ fausse porte ទ្វារបញ្ឆោត ។ *Fig.* ទ្វារ, ផ្លូវទៅកាន់ (ឧ. la vertu est la porte du bonheur) ។

Loc. div. à la porte ឬ aux portes de ជិតជិត, ទៀប ។ mettre à la porte ដេញចេញទៅ។ enfoncer une porte ouverte ម.ព. enfoncer ។ refuser sa porte មិនឲ្យចូលផ្ទះ ។ porte de derrière ទ្វារក្រោយ; ល្បិចដោះខ្លួន។ *Fam.* prendre la porte ថយខ្លួន, ក្មះចេញ ។ mettre clef sous la porte ម.ព. clef ។ ouvrir la porte បើកទ្វារ;ចំហ,បណ្ដាលឲ្យ(ឧ.ceci ouvre la porte à toutes les hypothèses) ។ de porte en porte *loc. adv.* ពីផ្ទះមួយទៅផ្ទះមួយ

porte-affiches *n.m. inv.* ក្ដារបិទប័ណ្ណប្រកាស (ច្រើនមានរនាំងជាល្អស សំណាញ់)

porte-aiguille *n.m. inv.Techn.* ដើងទ្រម្ជុល (បង្គោលក្ជាប់ទ្រម្ជុលម៉ាស៊ីន)

porte-aiguilles *n.m. inv.* ថើ ឬ ក្លាក់ម្ជុល (ប្រអប់ម្ជុល)

porte-allumettes *n.m.inv.* ប្រអប់ឈើគូស

porte-assiette *n.m. inv.* ចានល្បឬ ល្បាក់ប្រទាប

porte-avions *n.m. inv.* នាវាផ្ទុក យន្តហោះ

porte-bagages *n.m. inv.* រានដាក់ អីវ៉ាន់ (នៅខាងក្រោយយាន)

porte-bannière *n. inv.* ខ្មាន់ទង់

porte-billets *n.m.inv.* សំពៀត ដាក់ក្រដាសប្រាក់

porte-bonheur *n.m.inv.* វត្ថុដែល ឲ្យចម្រុងចម្រើនឬដែលឲ្យសុភមង្គល

porte-bouquet *n.m.inv.* ថូផ្កា

porte-bouteilles *n.m. inv.* ប្រអប់ តម្រៀបដប

porte-brancard *n.m.inv.* ខ្សែ យោងនឹងកររទេះ

porte-cartes *n.m.inv.* កូនសំពៀត ដាក់បណ្ណ

porte-chapeaux *n.m.inv.* ប្រដាប់ ពាក់មួក, ដៃព្យួរមួក

porte-cigare, porte-cigarette *n.m. inv.* កន្ទុយបារី (ខ្សៀដាក់បារី)

porte-cigares, porte-cigarettes *n.m.inv.* ប្រអប់បារី

porte-clefs *n.m. inv.* ខ្មាន់កូនសោ ពន្ធនាគារ; ប្រវ៉ែងដាក់កូនសោ

porte-couteau *n.m.inv.* កំណល់ កាំបិត

porte-crayon *n.m. inv.* បំពង់ដាក់ ខ្មៅដៃ

porte-drapeau *n.m. inv.* ខ្មាន់ ទង់ជ័យ

portée *n.f.* សំបុក (ចំនួនកូនសត្វដែល កើតក្នុងមួយលើក); ចម្ងាយ(ដែលបាញ់ ដល់-ដែលលូកដល់-ដែលមើលឃើញ- ដែលស្តាប់ឮ) (ឧ.objet à portée de la main)។

Fig. វិស័យ, សមត្ថភាព (ខាង គំនិតប្រាជ្ញា) (ឧ. cela est hors de sa portée); អានុភាព, តម្លៃ, សារៈសំខាន់ (ឧ. ce raisonnement a une grande portée)។ à portée ឬ à portée de អាចលូកដល់(ឧ. laisser un livre à portée (ឬ à la portée) d'un enfant); *au fig.* ល្មមនឹង(ប្រាជ្ញា) (ឧ. je vous demanderai si ce livre est à portée de mon intelligence)។ à portée de *Fig.* អាចនឹង (ឧ. je ne suis pas

encore à portée de recevoir cette joie)

porte-enseigne *n.m. inv.* ខ្មាន់ទង់ជាតិ

porte-épée *n.m. inv.* ខ្សែបន្តោកដាវ

porte-étendard *n. m. inv.* ខ្មាន់ទង់ជ័យ (ក្នុងកងទ័ពសេះឬកងកម្លាំងធំ)

portefaix *n.m.* អ្នកលីសែង

porte-fanion *n.m. inv.* ខ្មាន់ទង់ឧត្តមសេនីយ

porte-fenêtre *n.f.* ទ្វារបង្អួច (សម្រាប់ប្រើជាទ្វារផងជាបង្អួចផង) (*pl.* des portes-fenêtres) (ហៅ porte-croisée ក៏បាន) (*pl.* des portes-croisées)

portefeuille *n.m.* ស៊ីផៀត (ដាក់លិខិតឬបិយវត្ថុ) ។ *Fig.* តំណែងរដ្ឋមន្ត្រី

porte-fort *n.m. inv. Dr.* អ្នកធានា

porte-greffe ឬ **porte-greffes** *n. m. Bot.* មេផ្សាំសាប (ដើមដែលទទួលសាបផ្សាំ)

porte-malheur *n.m. inv.* កាឡ-កិណី [កាល-កិ-ណី], មនុស្ស ឬ វត្ថុ ដែលឲ្យទោស; មនុស្សចង្រៃឬវត្ថុចង្រៃ

portemanteau *n.m.* ណាគទន្ត, ដៃកែវ (ប្រដាប់ព្យួរសំលៀកបំពាក់); កា-លីសម្ប៉ាក (ឧ. portemanteau de voyage)

porte-mine *n.m. inv.* ពីតប៊ិច, ឃ្ញុចស្លាបខ្មៅដៃ

porte-monnaie *n.m.inv.* ថង់ប្រាក់

porte-montre *n m. inv.* ប្រអប់នាឡិកា

porte-musc *n.m. inv.* ឈ្លូស (សត្វបក្សាទន្សាយពួកសំពោចមានទឹកកាបប្រើរាយធ្វើទឹកអប់)

porte-outil *n.m. inv. Techn.* គ្រឿងទ្រឧបករណ៍

porte-parapluies *n.m.inv.* កន្លែងដាក់ឆ័ត្រ

porte-parole *n.m.inv.* អ្នកនាំពាក្យ

porte-plat *n.m. inv.* ជាសដាក់ម្ហូបក្ដៅ

porte-plume *n.m.* ដងប៉ាកកា

porter *v.t.* លើក (ឧ. porter un verre à ses lèvres) ។ porter sur l'épaule លី ។ porter sur la tête ទូល ។ porter sur le bras បី, ត្រកង ។ porter sur un seul bras កង ។ porter à la main កាន់ ។ porter à la main, le bras pendant

ឈ្លូរ ។ porter sous l'aisselle តៀតនឹងក្លៀក ។ porter sur la hanche កណ្ដៀត ។ porter au bout d'un bâton ព្នង។ porter à la palanche រែក ។ porter à plusieurs សែង ។ porter en bandoulière ស្ពាយ ។ porter en sautoir ម.ក. sautoir ។ porter sur le dos ព្រនរ, ព្រនាក់។ porter à la gueule ឬ au bec ពាំនឹងមាត់ឬនឹងចំពុះ ។ porter à la ceinture សៀតនឹងចង្កេះ ។

porter des habits ស្លៀកពាក់ ។ porter une bague ពាក់ចិញ្ចៀន ។ porter une veste ពាក់អាវ។ porter un pantalon ស្លៀកខោ។ porter les cheveux longs ទុកសក់វែង ។

ដឹកនាំ, ដឹកនាំ (ឧ. porter des denrées au marché); មានជាប់នឹងខ្លួន (ឧ. porter une somme d'argent)។ មាន, ឱ្យផល (ឧ. un arbre qui porte de beaux fruits) ។

porter la gaieté sur son visage មានទឹកមុខរីករាយ ។

porter le deuil កាន់បរិពោ-សញ្ញា; កាន់ទុក្ខ។ porter la tête haute ងើបក្បាល ។ porter ses regards បោះភ្នែក, ក្រឡេកមើល។ argent qui porte intérêt ប្រាក់មានធុងការ ។

Fig. ញុះញង់ (ឧ. porter quelqu'un au mal) ។

Loc.div. porter bonheur ឱ្យសុខ, ចម្រើន ។ porter malheur ឱ្យទុក្ខ, នាំឱ្យចង្រៃ ។ porter un article sur un registre ចុះរបស់អ្វីមួយក្នុងបញ្ជី ។ porter un beau nom ជាអ្នកត្រកូលខ្ពស់ ។ porter bien son âge នៅមាំពិតមែនតែចាស់; ដូចជាមិនចាស់ ។ porter bien son vin ពូកែផឹក (ផឹកស្រាច្រើនមិនស្រវឹង) ។ porter envie ចង់បាន, ប្រណែន ។ porter l'épée ជានាយទាហាន ។ porter la robe ជាចៅក្រម ។ porter la soutane បួស, ជាអ្នកបួស។ porter les armes ជាទាហាន។ porter la livrée ជាអ្នកបម្រើគេ ។ porter la main sur quelqu'un វាយអ្នក

ណាមួយ ។ porter quelqu'un aux nues លើកអ្នកណាមួយទើសពេកពេល(អួតសរសើរខ្លាំងពេក)។ porter en terre យកទៅកប់, កប់ ។ porter la parole ចាំពាក្យ ។ porter parole នាំពាក្យអ្នកណាមួយ(ហើយមកនិយាយ)។ porter ses pas en un lieu ទៅកាន់ទីណាមួយ ។ porter la peine d'une faute ទទួលទោសនៃកំហុស។ porter le poids des affaires ទទួលភារៈជាធំការតែម្នាក់ឯង ។ porter un toast ផឹកជូនពរ ។ l'un portant l'autre ឬ le fort portant le faible ដើរយកទូទាត់ម្នាទៅ (ប.គ. fort ពិត)។ porter plainte ប្ដឹង ។ porter bâteau អាចបើកនាវាបាន (ជ្រៅទឹក) ។ porter le poids du jour et de la chaleur ប.គ. poids ។ porter bien l'eau អាចលាយទឹកបាន (ស្រា)។ porter les chausses ឬ porter la culotte ជាស្រីគ្រប់គ្រងលើប្ដី ។. porter des cornes ជាប្ដីដែលប្រពន្ធពិត។ porter des fers ជាប់ច្រវាក់; *au fig.* ជាអ្នកប្រឡាញ់គេ (ជាប់បំណងស្នេហា) ។ la gent qui porte crête មាន់ (មាន់ញី, មាន់ឈ្មោល)។ porter le nez au vent ធ្វើប្រកែត។ le porter haut អួតខ្លួន ។ porter la main au chapeau លើកមួកគំនាប់ ។ porter la main à l'épée ហូតដាវប្រយុទ្ធ។

Fig. porter un coup បង្ខូច(ឧ. cela a porté un coup à sa réputation) ។ porter coup បានពិស; ធ្វើឲ្យកើបឬឲ្យជាប់អារម្មណ៍ ។ porter amitié à quelqu'un ស្រឡាញ់រាប់អានអ្នកណាមួយ ។ porter respect à quelqu'un គោរពអ្នកណាមួយ ។ porter la mine de មានទឹកមុខជា, ហាក់ដូចជា ។ porter quelqu'un dans son cœur ស្រឡាញ់ណាស់ (ជាបណ្ដាលចិត្ត) ។ porter quelqu'un sur les épaules *fig.* ធុញទ្រាន់នឹងអ្នកណាមួយ ។ porter témoignage ធ្វើជាសាក្សី ។ ce fruit porte son sucre ផ្លែនេះផ្អែម (មិនបាច់ដាក់ស្ករ)។

Mar. នាំ (ឧ. le courant

porte au large)។ porter de la toile មានក្ដោងច្រើន ។

Prov. chacun porte sa croix en ce monde មនុស្សគ្រប់រូបតែងមានទុក្ខ ។ argent comptant porte médecine ប្រាក់ជាគ្រូពេទ្យមួយ (ប្រាក់អាចសម្រាលទុក្ខបានខ្លះ) ។

v.i. ផ្ទល់លើ, ទ្រដោយ (ឧ. tout l'édifice porte sur une colonne); មានគភ៌ឬដើម (ក្នុងរយៈពេល) (ឧ. la chatte porte huit semaines); បាញ់បានចម្ងាយ (ឧ. carabine qui porte à 500 mètres); ឮដល់ (ឧ. voix qui porte loin); ឃើញដល់ (ឧ. vue qui porte loin); សំដៅ (ឧ. sur quoi porte votre critique ?) ។

Loc. div. porter sur ប៉ះ, ទង្គិច (ឧ sa tête a porté sur le trottoir); *au fig.* ទាក់ទងនឹង; ស្ដីអំពី (ឧ. examen qui porte sur les sciences) ។ porter à la tête ធ្វើឲ្យឆាប់ស្រវឹង; *au fig.* ធ្វើឲ្យរវើរវាយ ។ porter sur les nerfs ធ្វើឲ្យក្ដាញ់ ។ *Pop.* porter à la peau សម្រើប (រាងកាយ) ។ porter à faux មិនស៊ីបស្លូន ។ *Mar.* porter plein ឬ bon plein កាច់ចង្កូតឲ្យក្ដោងដក់ខ្យល់ ។ porter plein la voile *Fig.* ម.ក. plein ។ laisser porter sur la terre បើកសំដៅដី ។

se porter *v.pr.* ដើរឆ្ពោះ, ដើរតម្រង់ទៅ (ឧ. la foule se porte à tel endroit)។ *Fig.* មានសុខភាព (ឧ. se porter bien មានសុខភាពល្អ, ស្រួលខ្លួន; se porter mal មានសុខភាពមិនល្អ, មិនស្រួលខ្លួន); ប្រព្រឹត្ត (ឧ. se porter à des voies de fait) ។ ក្លែងជា (ឧ. une duègne qui se portait pour gouvernante); ពាក់ (ឧ. la redingote ne se porte plus) ។ *Fig.* កើតមានលើ (ឧ. les soupçons se porteront sur eux)។ se porter candidat aux élections ធ្វើជាបេក្ខជនឲ្យគេបោះឆ្នោត។ se porter fort pour quelqu'un ទទួល

ខុសក្រិតវិន័យអ្នកលេងណាមួយ

porter [–tèr] *n.m.* (ព.អ.) ពាំរទេះ (បៀរអង់គ្លេស)

porte-respect *n.m.inv.* អាវុធការពារខ្លួន; សញ្ញាដែលឲ្យគេគោរព

porterie *n.f.* លំនៅឆ្មាំទ្វារ

porte-serviettes *n.m.inv.* កន្លែងព្យួរកន្សែងជូតខ្លួន

porteur,euse *n.* អ្នកសែង-លី; អ្នកដឹកនាំ ។ porteur de germes អ្នកមានមេរោគក្នុងខ្លួន (អ្នកកើតរោគឆ្លង មិនរើកខ្លួន ហើយជើងចម្លងរោគនេះ) ។ *n.m.* អ្នកនាំសំបុត្រ (ឧ. réponse au porteur); អ្នកនាំពាក្យ, អ្នកឲ្យដំណឹង ។ *Com.* ពាហក [–ហ៊ក់] ។ au porteur ចំពោះពាហក

porte-veine *n.m.* ម.ព. porte-bonheur

porte-voix *n.m. inv.* បំពង់បំពងសម្លេង (ឧ. le porte-voix sert beaucoup aux marins)

portier,ère *n.&a.* ទ្វារបាល, ឆ្មាំទ្វារ

portière *n.f.* ទ្វាររថ; ទ្វារ

portière *a.f.* ដល់អាយុមានកូន (ចំពោះបសុសត្វញីដែលដល់អាយុល្មមមានកូន) (ឧ. brebis portière)

portillon *n.m.* ទ្វារតូច

portion *n.f.* ភាគ, ចំណែក

portionnaire *a.&n. Dr.* ភាគិយ, អ្នកត្រូវបានចំណែកមរតក

portique *n.m.* រោងថែវទទឹងខ្លោងទ្វារ

portland *n.m.* ស៊ីម៉ងត៍ប្រើក្នុងទឹក

portrait *n.m.* រូបភាព, រូបថត ។ *Fig.* ភាពដូចស្ទួសភាព (ឧ. cet enfant est le portrait de son père); ពិពណ៌នា, សេចក្តីពណ៌នាអំពីរូបភាព (ឧ. les portraits de la Bruyère); សេចក្តីពណ៌នាយ៉ាងដូច

portraitiste *n.m.* រូបការី

portraiturer *v.t.* គូររូប ឬ ពណ៌នាអំពីរូបភាព

portuaire *a.* នៃកំពង់ផែ (ឧ. des installations portuaires)

portugais,e *a.* នៃប្រទេសព័រទុយហ្គាល់ ។ *n.* ជនជាតិព័រទុយហ្គាល់ ។ *n.m.* ភាសាព័រទុយហ្គាល់

posada *n.f.* ប៉ូសាដា (ភោជនាល័យនៅប្រទេសអេស្ប៉ាញ)

posage *n.m.* ការដាក់

pose *n.f.* ការដាក់ឲ្យត្រូវកន្លែង (ឧ. la pose d'un tapis); ឥរិយាបថ (ឧ. une pose indolente) ។

Phot. ការឈរឬអង្គុយថត ។ *Fig.* ការធ្វើឫកពា (ខ. parler sans pose)

posé,e *a.* នឹងធឹង, រម្យទម (ខ. homme posé; maintien posé) ។ à main posée ម្ដងៗ, ដោយប្រិតប្រៀប

posément *adv.* ម្ដងៗ, ដោយមិនប្រញាប់ (ខ. lire, parler posément)

posemètre *n.m.* ប្រដាប់ស្ទង់រយៈពេលថតរូប

poser *v.t.* ដាក់ (ខ. poser un plat sur la table); ដាក់ចុះ; ទុក (ខ.poser son fusil); រៀបចំ(ខ. poser des draperies)។poser les fondements d'un édifice ចាក់ឫសគ្រឹះ ។ *Fig.* poser un principe តាំងគោលការណ៍ ។ poser quelqu'un លើកដំកើង (ខ. le moindre succès pose un auteur)។poser une question ចោទ, សួរ ។ សន្មត (ខ. posons qu'il en soit ainsi...)។

Loc. div. Fig. poser le masque បើកមុខ, ប្រព្រឹត្តដោយចេញមុខ ។ *Pop.* poser un lapin ម.ព. lapin ។ poser culotte បត់ជើង (បន្ទោបង់) ។*Arg.* poser sa chique លាក់មាត់ម៉ឹង គេញុក ។

Arithm. poser les chiffres តាំងលេខ ។

Art mil. poser les armes ដាក់អាវុធ; *au fig.* ចុះចាញ់ ; លែងប្រយុទ្ធ ។ poser des sentinelles ដាក់អ្នកយាម(ឲ្យយាមតាមកន្លែងដែលត្រូវការ) ។

Ch. de f. poser une voie ដាក់ផ្លូវដែក ។

Abs.Constr. poser à sec សង់គ្មានបាយអ ។ poser à cru សង់មិនចាក់ឫស ។

v.i. ទង (ខ. poutre qui pose sur un mur)។*Fig.* មានហេតុ, សំអាង (ខ. notre crainte (de la mort) ne pouvant poser sur rien de certain...); ឈរ-អង្គុយឲ្យគេគូរ ឬថត (ខ.poser pour un portrait)។

Fig. ធ្វើឫកពា (ខ.l'homme pose jusque dans la dou-

leur)។ poser pour អ្នកអាងខាង (ឧ. poser pour les belles relations) ។ faire poser ធ្វើឲ្យគេរង់ចាំ ។

se poser *v.pr.* ទំ (ឧ. hirondelle qui se pose sur un fil télégraphique)។ *Fig.* បានរុំញ៉ាំង (ឧ. artiste qui a eu bien de la peine à se poser); កោទសួរខ្លួនឯង(ឧ. l'enfant ne se pose pas de problème)។ se poser en តាំងខ្លួនជា (ឧ. se poser en censeur); ដាក់ (ឧ. les bouteilles de vin se posent couchées)

poseur,euse *a.&n.* អ្នកធ្វើឫកពា (ឧ. les poseurs sont insupportables) ។ *n.m.* អ្នករៀប (ឧ. poseur de parquet)

positif,ive *a.* វិជ្ជមាន, បតិដ្ឋាន, ពិត, ទៀង (ឧ. fait positif) ។ homme positif អ្នកគិតតែខាងមានប្រយោជន៍ ។

n.m. អ្វីៗ ដែលផ្តល់ប្រយោជន៍ (ឧ.n'estimer que le positif) (ហ៊ី. certain, concret, effectif, flagrant, formel, réel, tangible, vrai)

position *n.f.* កន្លែង (ឧ. la position d'une ville); ឥរិយាបថ (ឧ. la position du corps) ។ *Fig.* ស្ថានភាព (ឧ. position critique); មុខងារ(ឧ. avoir une belle position) ។ position statique ស្ថានភាពមិនកន្លែងឬស្ថិតនៅ ។ *Mil.* ទីតាំង ។ *Mus.* ដំណរ ។ prendre position ប្រកាន់ស្ថានភាព, ប្រកាន់ឥរិយាបថ

positivement *adv.* ដោយដាក់លាក់, យ៉ាងច្បាស់លាស់ (ឧ. être positivement sûr d'une chose)

positivisme *n.m.* បតិដ្ឋាននិយម,វិជ្ជមាននិយម

positiviste *a.& n.* អ្នកបតិដ្ឋាននិយម; អ្នកវិជ្ជមាននិយម (ឧ. Littré fut positiviste)

positivité *n.f* បតិដ្ឋានភាព,វិជ្ជមានភាព (ឧ. la positivité d'un fait)

positon *n.m. Phys.* ប៉ូស៊ីតុង

posologie *a.&n.* វិធីប្រើឱសថ

possédé,e *a.* ដែលជាប់ (ឧ. possédé de la passion du jeu) ។ *n.*

មនុស្សខ្មោចចូល (ឧ. exorciser un possédé)

posséder *v.t.* មាន (ឧ. posséder une maison) ។ *Fig.* ចេះច្បាស់ (ឧ. posséder les mathématiques); ធ្វើឲ្យវង្វេង ឬ ឲ្យរាក់ (ឧ. la fureur le possède) ។

se posséder *v.pr.* ទប់ចិត្ត

possesseur *n.m.* ម្ចាស់ (របស់) (ឧ. le possesseur d'un objet mis en gage n'en a pas la propriété) ។ *Dr.* ភោគី

possessif *n.& a.m.Gram.* សាមីសម្ពន្ធ

possession *n.f.* ការមាន,ការកាន់កាប់; ភាពជាម្ចាស់ (ឧ. une possession légitime); សម្បត្តិ ។ *Dr.* ភោគ ។ prendre possession de ចូលកាន់កាប់ឬកាន់ដំណែង; ដំណើរយក។ *Psych.* ភាពខ្មោចចូល ។ délire de possession ការរាំឬខ្មោចចូល

possessionnel,elle *a. Dr.* នៃភាពជាម្ចាស់ (ឧ. démarches possessionnelles)

possessoire *a.Dr.* ដើម្បីបាន(ជាម្ចាស់) (ឧ. intenter une action possessoire)។ *n.m.* សិទ្ធិជាម្ចាស់ (ឧ. contester le possessoire)

possibilité *n.f.* លទ្ធភាព, ដំណើរអាចធ្វើបាន (ឧ. possibilité d'un accord)

possible *a.* អាចធ្វើបាន , អាចមាន (ឧ. il a éprouvé tous les malheurs possibles) ។

n.m. កិច្ចអាចធ្វើបាន។ faire son possible ធ្វើតាមដែលអាចធ្វើបាន ។

adv. ប្រហែលជាពិតមែន, ខ្ញុំមិនប្រកែកទេ។au possible *loc.adv.* ដល់កំណត់,ក្រៃពេក (ឧ. avare au possible)

postage *n.m.* ការយកទៅដាក់ប្រៃសណីយ ; ការធ្វើតាមប្រៃសណីយ (ឧ. faire le postage pour un paquebot en partance)

postal,e,aux *a.* នៃប្រៃសណីយ (ឧ. convention postale)

postdate *n.f.* បញ្ជាកាលបរិច្ឆេទ(ក្រោយកាលបរិច្ឆេទពិត)

postdater *v.t.* ចុះបញ្ជាកាលបរិច្ឆេទ (ឧ. postdater un chèque constitue un délit)

poste *n.f.* *Autr.* ត្រាំ(រយៈផ្លូវគឺដំណាក់ពីមួយៗទៅមួយសម្រាប់ឲ្យសត្វសម្រាក)។ *Auj.* ប្រៃសណីយ៍; រថយន្តដឹកសំបុត្រប្រៃសណីយ៍ (ឧ. la poste vient de partir)។ poste aérienne ប្រៃសណីយ៍អាកាសយាន ។ poste restante ម.ព. restant ។ les postes et télécommunications ប្រៃសណីយ៍និងទូរគមនាគមន៍។ les postes, télégraphes et téléphones(P.T.T.)ប្រៃសណីយ៍, ទូរលេខនិងទូរសព្ទ។ *Fig.& fam.* courir la poste ដើរយ៉ាងលឿន; ធ្វើដោយប្រញាប់ប្រញាល់

poste *n.m.* កន្លែងបំពេញមុខការ (ឧ. mourir à son poste); ដំណែង (ឧ. occuper un poste important); ភារោល, កងទាហានអ្នកយាម ឬ ឃ្លាំ; ប៉ុស្តិ៍។ poste d'incendie ប៉ុស្តិ៍អគ្គិភ័យ (កន្លែងរៀបចំប្រយុទ្ធនឹងអគ្គិភ័យ)(មើrobinet arméក៏បាន)។ poste de police ប៉ុស្តិ៍ប៉ូលីស ។ poste de secours ប៉ុស្តិ៍សង្គ្រោះ។ *Mil.* poste de commandement (P.C.) ប៉ុស្តិ៍បញ្ជាការ ។ poste de surveillance ប៉ុស្តិ៍ឃ្លាំ (សម្រាប់ឃ្លាំមើលនិងបង្ការដំណើរសត្រូវ)។ តំបន់។ poste administratif តំបន់រដ្ឋបាល ។ poste de contrôle តំបន់ត្រួតត្រា

poster *v.t.* ដាក់តាមកន្លែង, ដាក់ឲ្យចាំ-ឲ្យយាម-ឲ្យឃ្លាំ (ឧ. poster des sentinelles); ផ្ញើតាមប្រៃសណីយ៍ (ឧ. poster un courrier) ។

se poster *v.pr.* ចាំឃ្លាំ (ឧ. se poster sous une porte)

postérieur,e *a.* បច្ឆាគត [ប៉ាច់-ឆា-គត់] (ក្រោយ, ដែលនៅខាងក្រោយ) (ឧ. testament annulé par un testament postérieur); ខាងក្រោយ (ឧ. la partie postérieure de la tête) ។

n.m. *Fam.* គូទ (ឧ. tomber sur le postérieur) (មើ. ultérieur ។ ព.ផ. antérieur)

postérieurement *adv.* ទៅបច្ឆាគត, ក្រោយ, តអំពី

posteriori (a) *loc. adv.* ម.ព. **a** posteriori

postériorité *n.f.* បច្ឆាភាព, ភាពជាខាងក្រោយ

postérité *n.f.* បច្ឆាសន្តាន (ឧ. la

postérité de Ta Trasak Paèm); បច្ឆាជនតា, ជំនាន់ក្រោយ (ឧ. transmettre son nom à la postérité) (ម៉ើ. descendance, progéniture)

postface *n.f.* បច្ឆិមបទ (ព.ផ. préface)

posthume *a.* បច្ឆាមរណៈ (ក្រោយស្លាប់)។ enfant posthume កូនបច្ឆាមរណៈ។ livre posthume សៀវភៅបច្ឆាមរណៈ។ à titre posthume ជាកិច្ចបច្ឆាមរណៈ

postiche *a.* ធ្វើឬថែមជាខាងក្រោយ (ឧ. ornement postiche); ជំនួស; ក្លែង (ឧ. cheveux postiches)។ *n.m.* សក់ធ្វើដោយសិប្បនិម្មិត (ឧ. un postiche en cheveux blonds)

postier *n.m.* ភ្នាក់ងារប្រៃសណីយ

postillon *n.m.* អ្នកបររថ (ឧ.le postillon d'une diligence)។ *Fam.* ក៏ទាតទឹកមាត់នៅពេលកំពុងនិយាយ

postopératoire *a.* ក្រោយការវះកាត់ (ឧ. soins postopératoires)

postposer *v.t.* តិតក្រោយ (ទុកជាបន្ទាប់បន្សំ) (ឧ. Mlle X... ne connaissant que la passion présente et y postposant tout)

postridien,enne *a.* នៃថ្ងៃស្អែក

postscolaire *a.* បច្ឆាសិក្សា (ក្រោយការសិក្សានៅសាលា) (ឧ. instruction postscolaire)

post-scriptum (P.-S.) *n.m. inv.* បច្ឆាលិខិត(សេចក្ដីសំបុត្របន្ថែមក្រោយហត្ថលេខា)

postulant,e *n.* អ្នកសុំតំណែង

postulat *n.m.* ឧបធារណ៍ (ឧ. le postulat d'Euclide) (ពី postulatum ក៏បាន)(*pl.* postulata)

postulation *n.f.* ការសុំ

postuler *v.t.* សុំ (ឧ. postuler un emploi)។ *Phil.* ដាក់ជាឧបធារណ៍ (ឧ. la preuve ontologique postule l'existence de Dieu au lieu de la démontrer)

postural,e,aux *a. Psych.* ដែលជាប់នឹងឥរិយាបថ (ឧ. la sensibilité posturale)

posture *n.f.* អាកប្បកិរិយា, ឥរិយាបថ (ឧ. posture naturelle)។ *Fig.*

សណ្ឋាន, ស្ថានភាព (ឧ. être en bonne posture)

pot *n.m.* ប៉ូ, ផើង, កាជិន; ចំនួនមួយប៉ូ-មួយផើង ។

Loc. div. pot à ប៉ូ (ផើង ឬ កាជិន) សម្រាប់ (ឧ. pot à eau ប៉ូទឹក; pot à fleur ផើងផ្កា) ។ pot à feu គោម ។ pot de កាជិន (ឧ. pot de lait កាជិនទឹកដោះ; pot de vin កាជិនស្រា) ។ pot de vin *Fig.* ម.ព. pot-de-vin ។ pot au noir *Fig.* ស្ថានភាពស្មុគ-ស្មាញ ; ព្រឹត្តិការណ៍អាក្រក់ ; *par ext.* gare le pot au noir ! ប្រយ័ត្ន! ។ pot à moineaux សំបុកចាបស្រុក (សំបុកដែលគេព្យួរទុកឲ្យចាបស្រុកនៅ) ។ *Fig.* pot à deux anses ហេតុឲ្យគេចាប់ភ្ជាក់ (ឧ. la raison est un pot à deux anses, qu'on peut saisir à droite et à gauche (Montaigne) ។ faire le pot à deux anses ច្រត់ដៃនៅចង្កេះ; កៀកស្ត្រីពីរនាក់ ។ *Fig.* c'est un pot sans anses, on ne sait par où le prendre ពុំជា មនុស្សពិបាកស្ដាប់ហើយប្រកាន់ច្រើន ។ *Fig.* pot à tabac មនុស្សកន្ទិលកន្ទុល ។ à la fortune du pot ការបរិភោគដោយម្ចាស់ផ្ទះមិនដឹងខ្លួនជាមុន ។ pot de chambre កន្ថោរនោម (ហៅ vase de nuit ក៏បាន) ។ être sourd comme un pot ថ្លង់ដូចត្រចៀកពាង (ថ្លង់មែនទែន) ។ *Fig.* faire bouillir le pot ធ្វើឲ្យគ្រួសារបានសម្បូរសប្បាយ ។ mettre la poule au pot រស់នៅដោយសម្បូរសប្បាយ, មានធនធានគ្រាន់បើ ។ être au pot de quelqu'un នៅជាមួយឬរស់នៅដោយសារអ្នកណាមួយ ។ faire son pot ឬ son petit pot à part មិនឲ្យគេហ៊ុនជាមួយ ។ être dans un pot à part មិនដូចគេសោះ ។ découvrir le pot aux roses រកឃើញអាថ៌ប្រស្នា ។ *Fig.* payer les pots cassés សាប់មិនបានស៊ីយកឆ្អឹងព្យួរក ។ être à pot et à rôt ស្និទ្ធស្នាលនឹងគ្នាណាស់ ។ tourner autour du pot និយាយពង្វាងសេចក្ដី ។ ce n'est pas par là que le pot s'enfuit

ព្រោះថ្នាក់មិនមែនទៅត្រង់គុះទេ។

Jeux ខ្ទាប់ ។

Prov. on fait de bonne soupe dans un vieux pot របស់ចាស់ឬមនុស្សចាស់នៅតែមានប្រយោជន៍ដែរ ។ un pot fêlé dure longtemps កំពាក់កំពុកអាយុវែង (មនុស្សពិការ ឬ ឈឺច្រើនអាចរស់នៅបានយូរ)

pot [pot'] *n.m.* ចំនួនប្រយោគតំណាង

potable *a.* អាចផឹកបាន, សម្រាប់ផឹក (ឧ. eau potable) ។ *Par ext.* & *fam.* ល្មមផឹកបាន, បង្គួរ (ឧ. vin potable) ។ *Fig.* & *fam.* បង្គួរ (ឧ. un roman potable)

potache *n.m.Fam.* សិស្សវិទ្យាល័យ ឬ អនុវិទ្យាល័យ

potage *n.m.* បបរ ។ patage gras បបរដាក់សាច់ ។ potage maigre បបរគ្មានសាច់ ។ pour tout potage តែ... ប៉ុណ្ណោះ (ឧ. joueur décavé qui n'a plus que cent riels pour tout potage)

potager,ère *a.* ដែលដាំបន្លែ; ដែលបរិភោគបាន។ *n.m.* ច្បារបន្លែ, ចំការបន្លែ; ជើងក្រានឥដ្ឋតម្រៀង

potard *n.m.Pop.* ឱសថការី

potasse *n.f.* ក្បុង

potasser *v.t.Fam.* ទំរៀន

potassique *a.* នៃក្បុង (ឧ. engrais potassique)

potassium *n.m.* ប៉ូតាស្យូម

pot-au-feu *n.m.inv.* ស៊ុបសាច់គោ; សាច់គោស្ងោរស៊ុប; ឆ្នាំងស្ងោរស៊ុប ។ *a.* ដែលស្រឡាញ់ជើងក្រាន(ដែលស្រឡាញ់កិច្ចការក្នុងផ្ទះ) (ឧ. une femme pot-au-feu)

pot-bouille *n.f. Pop.* ដំណើរធម្មតានៃគេហកិច្ច (ឧ. le cabaret nuit à la pot-bouille) ។ faire pot-bouille avec quelqu'un ចូលហ៊ុននឹងអ្នកណាមួយ

pot-de-vin *n.m.* ប្រាក់ស៊ីប (ម្ខាងក្រៅ); កម្រៃអាថ៌កំបាំង (ឧ. toucher un pot-de-vin) (*pl.* des pots-de-vin)

pote *n.m.Pop.* ពួកម៉ាក, គ្លើ

poteau *n.m.* បង្គោល។ poteau indicateur បង្គោលចង្អុល (មានចង្អុលប្រាប់ផ្លូវជាដើម) ។ poteau télégraphique បង្គោលទូរលេខ

potée *n.f.* ចំនួនមួយថូ-មួយឆ្នាំង ឬ មួយ

ភាជន៍; ស្មៅខាត់ម្យ៉ាង ។ *Ind.* ដីធ្វើកុម្ភស្មិត

potelé,e *a.* កញ្ចាំង, កន្ធក (ឧ. enfant potelé)

potence *n.f.* ឈើឬដែកសម្រាប់ទ្រ ឬ ព្យួរ; ឈើគ្នោក; ទោសគ្នោក (ឧ. condamné à la potence) ។ *Fig.* gibier de potence មនុស្សល្បាលខូច(គួរគ្នោក)។ ប្រដាប់ភស់កំពស់

potentat *n.m.* មហាចក្រពត្រាធិរាជ ។ *Fig.* មនុស្សភ័យឫកឡើត

potentialité *n.f. Phil.* សក្តានុភាព

potentiation *n.f. Math.* សក្តិកម្ម

potentiel,elle *a.* សក្តានុភូត, មិនទាន់ឃើញស្តែង ។ *n.m.* សក្តានុពល (កម្លាំងដែលអាចប្រើបាន)(ឧ. le potentiel militaire d'une nation)

poterie *n.f.* កុម្ភការភណ្ឌ [កុំ-ភៈ-កា-រៈ-ភ័ន], គ្រឿងបានឆ្នាំងដី; កុម្ភការដ្ឋាន [—កាត-ឋាន], កន្លែងធ្វើបានឆ្នាំងដី; សិល្បៈស្មូនឆ្នាំង (ឧ. poterie d'étain)

potiche *n.f.* ភាជន៍ម្យ៉ាង

potier *n.m.* កុម្ភការី, ស្មូនឆ្នាំង; អ្នកលក់គ្រឿងបាន

potin *n.m. Fam.* សំដីអេះអូច; ស្ទួរក្តុងក្តាំង

potiner *v.i. Fam.* និយាយរាប្រាក់ពីគេ

potinier,ère *a. Fam.* ដែលនិយាយរាប្រាក់ពីគេ

potion *n.f.* ឱសថទឹក (ឧ. potion calmante)

potiron *n.m.* ល្ពៅ

potron-jaquet ឬ **potron-minet** *n.m.* dès potron-jaquet ឬ dès potron-minet តាំងពីព្រឹកស្រាងៗ

pott (mal de) របេងឆ្អឹងខ្នង

pou *n.m.* ចៃ ។ chercher des poux à quelqu'un រករឿងនឹងអ្នកណាមួយ

pouacre *a.&n. Fam.* កខ្វក់

pouah ! *int.* អ៊ិក! (សំដែងសេចក្តីខ្ពើម)

pouce *n.m.* មេដៃ; មេជើង; មួយធ្នាប់មេដៃ, មួយមេដៃ (រង្វាស់បុរាណប្រវែងមួយមេដៃ; រង្វាស់បារាំងប្រវែង ២៧,០៧ម.ម; រង្វាស់អង់គ្លេសប្រវែង ២៥,៤ម.ម) ។

Fig. ប៉ុនមេដៃឬប៉ុនមួយធ្នាប់(បន្តិចបន្តួច) (ឧ. ne pas céder un pouce de territoire) ។

Loc. div. pas un pouce de terrain ឬ de terre *Fig.* គ្មានអ្វីបន្តិចសោះ ។ et le pouce មានអ្វីខ្លះទៀត (ឧ. il a mangé mille riels.— Oui, et le pouce !) ។ manger sur le pouce បរិភោគដោយប្រញាប់ប្រញាល់-ដោយមិនបាច់អង្គុយ ។ lire du pouce អានព្រួសៗ (ដោយគ្រាន់តែបើកទំព័រយ៉ាងរហ័ស) ។ *Fig.* tourner ses pouces អង្គុយកេះក្របក (នៅស្ងៀមមិនធ្វើការអ្វី) ។ serrer les pouces à quelqu'un គៀបមេដៃ (ទារុណកម្ម); *au fig.* គម្រាមឲ្យនិយាយ ។ *Fig.* se mordre les pouces ស្ដាយក្រោយណាស់ (អ្នកដែលធ្វើអ្វីខុសហើយស្ដាយក្រោយជ្រើនញេញមេដៃខ្លួនឯង) ។ *Fig.* mettre les pouces ទទួលចាញ់, ចុះចាញ់ក្រោយដែលបានតស៊ូ ។ *Fig.* jouer du pouce រាប់ប្រាក់ ។ *Fig* sucer son pouce សប្បាយដោយភាន់ព្រឿ ។ *Fig.* se lécher les pouces de លិទ្ធមាត់ (ឆ្ងាញ់ណាស់ ទាល់តែលិទ្ធដៃលិទ្ធជើង) ។ y mettre les quatre doigts et le pouce បរិភោគរឡិបរឡប់; *au fig.* ប្រព្រឹត្តដោយគ្មានរអែង; ធ្វើអ្វីដោយមិនញញើតញញើម ។ être malade du pouce សំអាងជាឈើ (ចំពោះអ្នកដែលមិនធ្វើការដោយសំអាងជាឈើ) ។ *Fam.* donner le coup de pouce ច្របាច់ក,សម្លាប់; *au fig.* បន្ថើម (ឧ.donner le coup de pouce à un tableau) ។

Prov. si on lui en donne un pouce, il en prendra long comme le bras បើគេឲ្យតែមួយធ្នាប់ គាត់យកដល់មួយហ្វូក

poucettes *n.f. pl.* ខ្នោះមេដៃ

poucier *n.m.* ស្រោមមេដៃ

poudrage ឬ **poudrement** *n.m.* ការរោយម្សៅ

poudre *n.f.* ធូលី, ម្សៅ, ធង់, សំអិត; រសេវ ។ *Fig.* jeter de la poudre aux yeux បំភាន់ភ្នែក ; ធ្វើឲ្យជឿការមិនពិត ; ធ្វើឲ្យគេវង្វេង ។ mettre le feu aux poudres យកភ្លើងទៅដុត ; អុជអាលឲ្យតែឈ្លោះគ្នា, ធ្វើឲ្យបែករឿងធំ ។ prendre la poudre d'escampette ម. ព. escampette ។

n'avoir pas inventé la poudre មិនសូវឆ្លាត

poudrer *v.t.* រោយម្សៅ, លាបម្សៅ

poudrerie *n.f.* កន្លែងធ្វើរំសេវ

poudrette *n.f.* ផង់លាមក (ប្រើជាជី)

poudreux,euse *a.* ប្រឡាក់ធូលី, មានធូលីច្រើន (ឧ. route poudreuse) ។ *n.f.* ម៉ាស៊ីនរោយម្សៅឃា-ណាកឃាត

poudrier *n.m.* អ្នកធ្វើរំសេវ; ប្រអប់ម្សៅ

poudrière *n.f.* ឃ្លាំងរំសេវ

poudrin *n.m.* ម.ព. embrun

poudroiement *n.m.* ដំណើរហុយជាធូលី

poudroyer *v.i.* ហុយជាធូលី (ឧ. le sable poudroyait); មានធូលីច្រើន (ឧ. la route poudroie)។ *v.t.* ធ្វើឲ្យប្រឡាក់ធូលី

pouf ! *int.* ខ្លាក!, ពុប! (ត្រាប់សូរធ្លាក់) (ឧ. pouf ! le voilà par terre)។ *n.m.* កៅអីប៉ោង

pouffer *v.i.* pouffer de rire សើចទប់មិនឈ្នះ

pouh ! *int.* អ៊ឹក ! (សំដែងសេចក្ដីខ្ពើម, សេចក្ដីមើលងាយ)

pouillard *n.m.* ទារាំទង

pouillerie *n.f.* *Pop.* ភាពគោកយ៉ាក; កន្លែងមិនស្អាត

pouilles *n.f pl.* chanter pouilles ជេរ

pouilleux,euse *a.* ដែលមានចៃ; គ្មានជីជាតិ (ឧ. Champagne pouilleuse) ។ *Fam.* កខ្វក់; រហេមរហាម (ឧ. quartier pouilleux)។ *n.m.* មនុស្សក្ររហេមរហាម

poulailler *n.m.* ទ្រុងមាន់; ឈ្មួញបសុបក្សី; ស្ពាក (ថ្នាក់ខ្ពស់បំផុតនៃរោងល្ខោន)

poulaillerie *n.f.* កន្លែងលក់បក្សី

poulain *n.m.* កូនសេះឈ្មោល (អាយុមិនទាន់ដល់៣ ឆ្នាំ)។ *Techn.* ស្ពានទេរសម្រាប់ប្រមៀលធុងទម្លាក់ពីទីខ្ពស់

poularde *n.f.* មាន់ជំទង់ដែលគេបំប៉នបំណើ

poule *n.f.* មាន់ញី, មេមាន់ (cri: la poule glousse មេមាន់ធ្វើក្រុកៗ; caquette ក្ដត); ញី (បក្សី) ។ poule d'eau ឬ poule des marais មាន់ទឹក ។ poule sultane ទោម ។

Fam. ស្ត្រី(ពាក្យទំលើ)។ *Pop.* ស្ត្រី(សហាយ); ស្ត្រីសាវ៉ា ។

Loc.div. poule mouillée ឬ

cœur de poule មនុស្សកំសាក ។ poule laitée មនុស្សទន់ជ្ញិចស្រី ។ fils de poule blanche មនុស្សដែលមានភ័ព្វគ្រប់យ៉ាង ។ chair de poule សម្បុរតីង្គក់(ជំពើរព្រឺខ្លួន)(ឧ. le froid, la peur donnent la chair de poule) ។ avoir la chair de poule ឡើងសម្បុរតីង្គក់។ cul de poule ការពេបមាត់។ *Fig.* plumer la poule លួច;រំបផាន់។ plumer la poule sans la faire crier រំបផាន់ដោយប៉ុនប្រសប់ (មិនឲ្យមានរឿង) (អូសទូកមិនឲ្យល្អាន ចាប់ត្រីបានមិនឲ្យល្អក់ទឹក)។ courir la poule លួចបន្លែឬផ្លែឈើ។ être empêtré comme une poule qui n'a qu'un poussin ធ្វើទទឹមទទាមដោយហេតុបន្តិចបន្តួច។ être comme une poule qui a couvé des œufs de cane ភ្ញាក់ព្រើត ។ vendre la poule au renard យកពងមាន់ទៅផ្ញើនឹងខ្លែក។ il veut aller garder les poules de monsieur le curé គាត់ជិតស្លាប់ហើយ, គាត់ជិតពូលក្ដារមឈូសហើយ ។ tuer la poule aux œufs d'or កាប់ដល់បេះផ្លែ (ធ្វើឲ្យខូចប្រភពធនធាន ព្រោះបង់មានះហ៊ុសពេក) ។

Prov. les poules pondent par le bec មាន់ពងដោយសារចំពុះ (បើឲ្យស៊ីច្រើនពាក់សំភារតែពងពាក់)។ quand le sort est sur les poules, le diable ne les ferai pas pondre បើមាន់មិនទាន់ដល់ពេលពង គ្មានមធ្យោបាយអ្វីនឹងធ្វើឲ្យវាពងទេ ។ un bon renard ne mange jamais les poules de son voisin ចោរឆ្លាតបេះចោលជើង (មនុស្សឆ្លាតដែលចង់ប្រព្រឹត្តអំពើអាក្រក់ ត្រូវវៀសវាងកន្លែងដែលគេស្គាល់ខ្លួន) ។ la poule ne doit pas chanter devant le coq ម.ព. coq ។ qui naît poule aime à gratter មាន់ឡើងក្រោក ទាស្មោកក្រោកដេកផ្ទាល់ដី

poule *n.f.* ប្រយាតំណាំងទាំងអស់ (ឧ. gagner la poule)

poulet *n.m.* មាន់ជំទង់ (cri: le poulet piaule)។ *Fig.* សំបុត្រស្នេហ៍ (ឧ. écrire un poulet)

poulette *n.m.* មាន់ញីជំទង់; ពាក្យទំលើហៅក្មេងស្រី

pouliche *n.f.* កូនសេះញី (រហូតដល់ទាល់ពេញ ៣ ឆ្នាំ)

poulie *n.f.* រ៉ក, កៅឡាក់

pouliner *v.i.* កើតកូន (សេះ)

poulinière *n.&a.f.* មេសេះបង្កាត់កូន

poulot,otte *n.* ពាក្យទំលើហៅកូនក្មេង

poulpe *n.m.* ម.ព. pieuvre

poulpican *n.m.* បិសាចបញ្ចាក់ក្នុងរឿងព្រេងនិទានប្រ៊េតាញ

pouls [pou] *n.m.* ជីពចរ (ឧ. pouls fréquent, filiforme) ។ *Fig.& fam.* tâter le pouls à quelqu'un ស្ទង់ចិត្ត ឬ គំនិត ។ se tâter le pouls ស្ទង់កម្លាំងខ្លួនមុននឹងធ្វើអ្វីមួយ

poumon *n.m.* សួត ។ poumons d'acier សួតដែក (ម៉ាស៊ីនសម្រាប់ឲ្យអ្នកជំងឺខ្វះពិកដកដង្ហើម)

pound [pa-ound] *n.m.* ផោន (រង្វាស់ទម្ងន់អង់គ្លេសស្មើនឹង ៤៥៣,៥៩ ក.)

poupard,e *a.&n.* កន្ទួល (ធាត់ស្រលុក) (ឧ. physionomie pouparde)

poupe *n.f.* *Mar.* កន្សៃនាវា ។ *Fig.* avoir le vent en poupe កំពុងត្រូវក្ដោង (កំពុងមានភ័ព្វ - មានសម្បត្តិ) (ព.ផ. proue)

poupée *n.f.* រូបកូនក្រមុំ (សម្រាប់ក្មេងលេង); រូបសំពោក (ក្នុងផ្ទះកាត់ដេរ); រូបសម្រាប់ហាញ់ (ឧ. casser une poupée) ។ *Fam.* សំពត់ក្រោមរបស់ ។ *Arg.* ប្រដាប់ផ្ដិតក្ដួរលោ ។ *Fig.* មនុស្សមាឌតូចតែងខ្លួនណាស់ (ឧ. c'est une vraie poupée); មនុស្សល្ងេល្ងើបន្តិចៗ ។ *Techn.* ត្រឡប់ (ប្រដាប់ក្រឡឹង)

poupin,e *a.* ស្រស់, មានពណ៌ (ឧ. figure poupine)

poupon,onne *n.* ទារក, កូនង៉ែត; ក្មេងមុខក្រមប់

pouponner *v.i.* *Fam.* ថែកូនង៉ែត

pouponnière *n.f.* មន្ទីររក្សាទារក

poupoule *n.f.* *Pop.* មាន់ (ពាក្យស្និទ្ធស្នាលសម្រាប់និយាយទៅកាន់ស្ត្រី)

pour *pré.* ជំនួស (ឧ. mot qui s'emploie souvent pour tel autre); ជាថ្នូរ, ជាតម្លៃ (ឧ. ne rien payer pour le blé fourni); ដូរ (ឧ. changer ses billets pour de la monnaie); ជំនួស, ក្នុងនាមនៃ (ឧ. je vous

réponds pour lui de son obéissance (Racine); តបវិញ (ឧ. rendre le bien pour le mal; œil pour œil, dent pour dent ប.ព. œil ផង); សម្រាប់(ឧ. ce n'est pas un spectacle pour jeune fille); ទៅ (ឧ. partir pour la campagne); សម្រាប់ ពេល,នៅពេល(ឧ. ce sera pour Pâques); ដើម្បី (ឧ. travailler pour la gloire);ដើម្បីជាប្រយោជន៍ ពីល (ឧ.mourir pour la patrie; quêter pour les pauvres); ព្រោះតែ (ឧ. être puni pour sa paresse); ពិតមែនតែ (ឧ. Ah! pour être dévot, je n'en suis pas moins homme(Molière); ទោះបី,ទុកជា(ឧ. pour sages que soient les hommes, ils ne sont point infaillibles(Saint-Simon); អស់រយៈពេល (ឧ. il est chez moi pour un an ou deux) ។

Loc. div. être pour សម្រាប់ (ឧ. ce spectacle n'est pas pour amuser vos yeux (Boileau); ហៀបនឹង (ឧ. il était pour venir) ។ en être pour រលំ,ខាត(ឧ. en être pour cent mille riels; en être pour sa peine) ។ pour le moins យ៉ាង តិច ។ être pour beaucoup dans មានចូលដៃឬចូលរួមច្រើនក្នុង។ être pour peu dans មានចូល ដៃ ឬ ចូលរួមតិចក្នុង ។ n'y être pour rien គ្មានចូលដៃ ឬ ចូលរួម សោះ ។ pour toujours, pour jamais ជានិច្ច ។ et pour cause ដោយសមហេតុ ។ pour ainsi parler ឬ pour ainsi dire បើ ដូច្នេះ ។ vous me prenez pour un autre លោកដូចជាមិនស្គាល់ខ្ញុំ (លោកមិនសមបើប្រព្រឹត្តដូច្នេះចំពោះ ខ្ញុំសោះ) ។

Loc. adv. pour lors កាលនោះ, ដូច្នោះ ។

Loc.conj. pour peu que ម.ព. peu ។ pour que ដើម្បីនឹង (ឧ.pour qu'on vous obéisse, obéissez aux lois (Voltaire)។

n.m. គុណប្រយោជន៍ (ឧ. peser le pour et le contre

រឿងពុលភពនឹងទោស)

pourboire *n.m.* ទឹកតែ, កម្រៃក្រៅ (ឧ. le pourboire constitue légalement un élément du salaire)

pourceau *n.m.* ជ្រូក *Fig.* pourceau d'Epicure មនុស្សងប់ក្នុងកាមភព

pour-cent *n.m. inv.* ភាគរយ, ការប្រាក់ក្នុងដើម ១០០រ. (ឧ. à quel pour-cent avez vous placé)

pourcentage *n.m.* ចំនួនភាគរយ; ការកំរិតភាគរយឬកំរិតការប្រាក់

pourchasser *v.t.* ដេញតាម (ដោយទំប្រឹងខ្លាំង) (ឧ. pourchasser un voleur)

pourchasseur *n.m.* អ្នកដេញតាម; អ្នកស្វែង (ឧ. les pourchasseurs de dots)

pour-compte ឬ **pourcompte** *n.m. inv.* ការជួយលក់ឲ្យ (កិច្ចសន្យាដែលអ្នកជំនួញទទួលជួយលក់ទំនិញពុំអស់)

pourfendeur, euse *n.&a.* ដែលពុះផាកាំតែមួយដាវ (ឧ. les bras des antiques pourfendeurs de la chevalerie(G.Sand)។ *Fig.* អ្នករិះគន់ (ឧ une pourfendeuse de préjugés)។ un pourfendeur de géants មនុស្សក្អេងក្អាង (ពាក្យចំអក)

pourfendre *v.t.* ពុះផាកាំតែមួយដាវ; ពុះក្បាល (ឧ. Don Quichotte cherchait des géants à pourfendre)។se pourfendre *v.pr.* ពុះក្បាលគ្នាទៅវិញទៅមក

pourlèchement *n.m.* ការលិទ្ធជុំវិញ

pourlécher *v.t.* លិទ្ធជុំវិញ; លិទ្ធញយៗ (ឧ. pourlécher ses doigts) ។ *Fam.* លិទ្ធមាត់ ។ *Fig.* បញ្ចេញអង្កេល, ធ្វើដោយផ្ចិតផ្ចង់ (ដូចគេលិទ្ធមាត់) (ឧ. pourlécher un dessin) ។

se pourlécher *v.pr.* លិទ្ធមាត់ ។ *Fig.* & *fam.* s'en pourlécher les babines លិទ្ធកាត់លិទ្ធក (បរិភោគឆ្ងាញ់ពេកស់ឬចង់បរិភោគខ្លាំងពេកស់)

pourparlers *n.m. pl.* សំសន្ទនា [ស័ង-សន់-ទៈ-នា] (សន្តិសិទបំពោះរឿងអ្វីមួយ) (ឧ. engager des pourparlers)

pourpoint *n.m.* អាវរឹបបង្កេះម្យ៉ាង(ប្រើ

ក្នុងសាតរាក្យទី១៧)

pourpre *n.f.* ជាតិក្រហមយកពីសំបក ខ្យងម្យ៉ាង (ឧ. la pourpre de Tyr était la plus estimée) ; សំពត់ជ្រលក់ក្រហម (ឧ. manteau de pourpre) ; ពណ៌ក្រហមខ្លាំងណាស់ ។

n.m. ពណ៌ក្រហមស្មើស្អាយ (ឧ.manteau d'un beau pourpre)។*Fig.* ពណ៌ក្រហម(ឧ.sentir le pourpre monter à son visage ឡើងមុខក្រហម) ។

a. ក្រហមឆ្អៅ

pourpré,e *a.* ក្រហម (ឧ. robe pourprée) ។ fièvre pourprée ម.ព. urticaire

pourquoi *conj.& adv.* ម្តេច, ហេតុអ្វីក៏ម្តេច, ហេតុអ្វី (ឧ. on se fâche sans savoir pourquoi)។ c'est pourquoi ហេតុនេះ ។

n.m. inv. ហេតុ (ឧ. le pourquoi de toutes choses) ; សំនួរ (ឧ. il n'est pas facile de répondre à tous les pourquoi)

pourri,e *a.* ពុក, រលួយ (ឧ. fruit pourri); ស្អុយ(ឧ.viande pourrie) ។ temps pourri អាកាសសើមហើយនាំឲ្យមិនស្រួលខ្លួន ។

n.m. ក្លិនស្អុយ (ឧ. cela sent le pourri)

pourrir *v.i.* ពុក, រលួយ ។ *Fig.* ប៉ិតនៅក្នុងគុក (ឧ. pourrir en prison); នៅត្រាំត្រែង (ឧ conflit, guerre qui pourrit) ។

v.t. ធ្វើឲ្យពុក ឬ ឲ្យរលួយ (ឧ. l'eau pourrit le bois)

pourrissable *a.* អាចពុករលួយបាន

pourrissage *n.m. Ind.* ការត្រាំ (សំពត់ឬវត្ថុផ្សេងៗសម្រាប់ធ្វើក្រដាស)

pourrissoir *n.m.Ind.* កន្លែងត្រាំ

pourriture *n.f.* ភាពពុករលួយ

poursuite *n.f.* ការប្រដេញ ។ *Fig.* ឧស្សាហ៍, ការខំស្វែង, ការបន្ត (ឧ. s'obstiner à la poursuite d'un emploi)។

pl. Dr. ការប្តឹង (ឧ.entamer des poursuites contre un débiteur)

poursuivant,e *n. Dr.* អ្នកប្តឹង ។ *a.* ដែលប្តឹង(ឧ.la partie poursuivante)

poursuiveur *n.m.* អ្នកប្រដេញ; អ្នកតាម

poursuivre *v.t.* ប្រដេញ (ឧ. le chien poursuit le gibier)។ *Fig.* ធ្វើនបេក្រត, ស្វែងរក, ចង់ឲ្យបានសេចក្ដី (ឧ. poursuivre un but); បន្ត (ឧ. poursuivre une entreprise)។

Dr. ប្ដឹង (ពីរឿងក្ដីកម្ម) (ឧ. poursuivre un débiteur)។ ធ្វើឲ្យត់ព្រួយ (ឧ. l'ennui poursuit le désœuvré)

pourtant *adv.* ប៉ុន្តែ (ឧ. cette aventure est surprenante, elle est pourtant vraie) (មើ. cependant, mais, néanmoins, toutefois)

pourtour *n.m.* ជុំវិញ, រង់ជុំវិញ (ឧ. le pourtour d'une place)

pourvoi *n.m.Dr.* ប្ដឹងតវ៉ា។ pourvoi en revision ប្ដឹងតវ៉ាឲ្យពិនិត្យក្ដី (ការប្ដឹងឲ្យសើបអង្កេតឡើងវិញ)

pourvoir *v.i.* ផ្គត់ផ្គង់ (ឧ. vos parents pourvoient à vos besoins)។ *v.t.* ផ្គត់ផ្គង់, ឲ្យមាន (ឧ. pourvoir un soldat de munitions); ផ្ដល់ផ្គត់ផ្គង់ (ឧ. pourvoir ses enfants)។ *Fig.* ប្រទាន, ឲ្យមាន (ឧ. la nature l'a pourvu de grandes qualités)។

se pourvoir *v.pr.* បម្រុង, ផ្គង់ទុកប្រុង (ឧ. se pourvoir d'argent)។ *Dr.* ធ្វើប្ដឹងតវ៉ា (ឧ. se pourvoir en cassation)

pourvoyeur,euse *n.* អ្នកផ្គត់ផ្គង់, អ្នកផ្គត់ផ្គង់ស្បៀង។ *n.m.* ទាហានប្រកគ្រាប់

prévôté *n.f.* ក្រុមតម្រួត; ដំណែង-នីតិកម្មឬមន្ទីរនាយតម្រួតទាហាន។ prévoté militaire Khmer(P.M.K.) ក្រុមតម្រួតទាហានខ្មែរ

prévoyance *n.f.* ការពេះប្រមាណ; សន្តិច័យ។ prévoyance sociale សន្តិច័យសង្គម (សង្គ្រោះ)

prévoyant,e *a.* ដែលពេះប្រមាណ ឬពេះគ្រោងទុកជាមុន

prié,e *a.* ដែលគេអញ្ជើញតាមផ្លូវការ (ឧ. repas prié)

prie-dieu *n.m. inv.* ធម្មាសនៈ (អាសនៈសម្រាប់អង្គុយសូត្រធម៌ តាមសាសនាកាតូលិក)

prier *v.t.* សូត្រធម៌; បន់ (ឧ. prier Dieu)។ *Par ext.* សូម, អង្វរ (ឧ. prier un vainqueur de se montrer clément) ; អញ្ជើញ (ឧ. prier quelqu'un à dîner) ។

Loc. div. prier comme le bon Dieu ឬ prier à mains jointes សំពះអង្វរ (អង្វរដោយទទូច)។ je vous prie ឬ je vous en prie សុំលោកមេត្តា (ឧ. ne recommencez pas, je vous en prie)។ je prie Dieu que ខ្ញុំបន់ព្រះសំពះទេវតាសុំឲ្យ ។ se faire prier ចាំឲ្យគេអង្វរ (ទាល់តែគេអង្វរទើបធ្វើ ឬ ឲ្យ) ។ ne pas se faire prier ធ្វើភ្លាមៗ (មិនចាំឲ្យគេអង្វរ) ។

Loc.prov. il ne prie pas comme il joint les mains ចិត្តជាទេវទត្ត មាត់ជាទេវតា (ជាមនុស្សលាក់ពុត ពីមានរាកអារៈក្រៅល្អ ប៉ុន្តែចិត្តអាក្រក់) ។ la viande ne prie pas les gens ម្ហូបនេះមិនឲ្យពាក់បរិភោគសោះ ។

v.i. ឧទ្ទិស ឬ ធ្វើបុណ្យកុសល (ឧ. prier pour les morts)

(មើ. adjurer, conjurer, implorer, invoquer, supplier)

prière *n.f.* ការស្មូត្រធម៌; ធម៌; បំណន់; សំណូម; ពាក្យអង្វរ (ឧ. prière de ne pas fumer សូមកុំជក់បារី)

primage *n.m.* ការឲ្យមានតម្លៃ; ការឲ្យកោសលាភ [កោ-សះ–] ឬ រង្វាន់។ *Com.* រង្វាន់ភាគរយ។ *Particul.* រង្វាន់លើទំនិញ (រង្វាន់សម្រាប់នាវិកប្រមុខ)

primaire *a.* បឋម ។ cycle primaire បឋមភូមិ (ម.ព. cycle ផង) ។ école primaire សាលាបឋមសិក្សា ។ enseignement primaire ម.ព. enseignement ។ *Géol.* ère primaire ម.ព. ère។ *Fam. & péjor.* អ្នកមានវិជ្ជាតិច

primarité *n.f.* បឋមភាព

primata *n.m.* បឋមតា [ប៉ះ-ឋះ-ម៉ះ-តា]

primates *n.m. pl.* ពិនរសត្វ

primauté *n.f.* ភាពប្រសើរជាងគេ, លេខ១ (ឧ. cet homme veut avoir la primauté partout)

prime *n.f.* បុព្វលាភ [បុប-ព:–] ។ prime d'assurance បុព្វលាភធានារ៉ាប់រង (ប្រាក់ដែលត្រូវបង់ឲ្យអ្នកធានារ៉ាប់រង) ។

កោសលាភ [កោ-សះ–], រង្វាន់លើកទឹកចិត្តសម្រាប់ឲ្យធ្វើអ្វីមួយ ។ prime pédagogique កោសលាភគរុកោសល្យ ។ *Fig.* faire prime មានគេត្រូវការច្រើន (ឧ. l'or fait prime sur le marché des monnaies)

prime *a.* ទី១, លេខ១; ក្បៀសមួយ (') (ឧ. «b'» s'énonce «b prime»)។ prime jeunesse ភាពក្មេងខ្ចី (វ័យក្មេងបំផុត)។

Loc.adv. de prime abord តាំងពីដំបូងជាដំបូង ។ de prime ដៃមួយរំពេច (ភ្លាមៗ, គ្មានត្រូវការថ្នាក់) (ឧ. arriver de prime saut

au faîte des honneurs)។ de prime face តាំងពីឃើញជាដំបូង ។

n.f. ដំណើរទើបនឹងរះ (ព្រះអាទិត្យ ឬ ព្រះចន្ទ)។ la lune est en prime ព្រះចន្ទទើបនឹងរះ

primer *v.t.* ល្អះ, ប្រសើរជាង (ឧ. sagesse prime richesse); ឲ្យរង្វាន់ (ក្នុងការប្រណាំងប្រជែង) (ឧ. primer un animal dans un concours)។

v.i. ល្អះគេ; នៅលើគេ; ធំជាងគេ (ឧ. la comtesse est une femme brusque qui aime à primer, à gouverner... (Marivaux)

primesautier,ère *a.* ដែលធ្វើអ្វីតាមតែនឹកឃើញ (ដោយឥតគិតជាមុន)(ឧ. esprit primesautier)

primeur *n.f.* ភាពរបស់ទើបនឹងកើតថ្មី (ឧ. lire un livre, voir une pièce dans sa primeur);ចម្លូក (អ្វីៗមានផ្លែឈើជាដើម ដែលកើតមុនរដូវ)

primeuriste [—risst'] *n.m.* អ្នកដាំបន្លែឬផ្លែចម្លូក

primipare *a.* ដែលមានកូនជាដំបូង

primitif,ive *a.* ជាដំបូង, មុនគេបំផុត (ឧ. forme primitive; état primitif);នៃយុគដំបូង(សម័យដែលមនុស្សទើបនឹងកើត) (ឧ. mœurs primitives)។ couleurs primitives មូលវណ្ណៈ,ពណ៌ដើម(ពណ៌សម្រាប់លាយឲ្យបានជាពណ៌ដទៃ គឺស្វាយ, ចុះ, ខៀវ,បៃតង, លឿង,ហង្សបាទ (លឿងភាវនឹងក្រហម)។

*Gram.*mot primitif មូលសព្ទ [មូ-លៈ-ស័ប] (សព្ទដើម, សព្ទដែលជាដើមកំណើតនៃពាក្យឯទៀត)។

n.m. ជនដែលមានអារ្យធម៌អន់ថយ

primitivement *adv.* ពីដើមកំណើត, ពីដើមដំបូង

primo *adv.* ទី ១

primogéniture *n.f.* ជេដ្ឋភាព, ភាពជាច្បង

primo-infection ឬ **primo** *n.f.* ដំណើរជាប់ដំបូង (ចំពោះរោគរូករបេង)

primordial,e,aux *a.* នៃសម្ភពដ្ឋាន, ដែលជាដើមកំណើត; ចាស់ជាងគេបំផុត (ឧ. état primordial du globe); សំខាន់ (ឧ. rôle primordial)

prin *a.* de prin saut ឬ de prin-

saut ឬ d'un prinsaut តាំងពីដំបូងតែ (មើល de prime ឬ de prime saut ឬ de plein saut)

prince *n.m.* ព្រះអង្គម្ចាស់, ក្សត្រ, មហាក្សត្រិយ៍, ស្ដេច (ឧ. tout prince sage doit souhaiter de n'être que l'exécuteur des lois); រាជាធិរាជ (ឧ. Charlemagne fut un grand prince)។ prince consort ម.ព. consort។ prince impérial ព្រះអង្គម្ចាស់រជ្ជទាយាទនៃរាជាធិរាជ ។ prince royal ព្រះអង្គម្ចាស់រជ្ជទាយាទនៃមហាក្សត្រិយ៍ ។ prince de sang ម.ព. sang ។ le prince des ténèbres ម.ព. ténèbres ។

Par ext. ឯកអគ្គបុរស (ឧ. les princes de la littérature) ។

Loc. div. en prince ជារបៀបក្សត្រ ។ vivre en prince រស់នៅយ៉ាងរុងរឿង ។ être bon prince ជាអ្នកស្រួលទាក់ទង ។ être heureux comme un prince សប្បាយណាស់ ។ vêtu comme un prince ស្លៀកពាក់យ៉ាងឆើត ។

Dr. fait du prince រាជសម្ពាធ (ខមួយនៃប្រធានសក្ដិដែលបណ្ដាលមកអំពីសេចក្ដីសម្រេចនៃរដ្ឋាភិបាល)។

Prov. les princes ont les bras longs, les mains longues អំណាចក្សត្រទូលាយណាស់

princeps *a.* édition princeps ការបោះពុម្ពផ្សាយលើកដំបូង

princesse *n.f.* ព្រះអង្គម្ចាស់ក្សត្រី, មហាក្សត្រិយានី ។ faire la princesse កាន់ឫកធំ ។ aux frais de la princesse សោហ៊ុយលើរាជការ ឬ ចៅហ្វាយនាយ

princier,ère *a.* នៃក្សត្រ, នៃខត្តិយ, នៃព្រះអង្គម្ចាស់ (ឧ. famille princière ខត្តិយត្រកូល); ឆើតឆាយ

princièrement *adv.* ជារបៀបក្សត្រ, យ៉ាងឆើតឆាយ (ឧ. recevoir princièrement)

principal,e,aux *a.* សំខាន់បំផុត, ធំ (ឧ. le rôle principal); ដើម (ឧ.principal locataire អ្នកជួលដើម (អ្នកជួលដើម្បីយកទៅដាក់ជួលបន្ត); ដើមអាទិ៍ (ឧ. auteur principal អ្នកប្រព្រឹត្តជាដើមអាទិ៍)។ ដើមខ្សែ (ឧ. professeur principal

សៅស្រុកហាឫស៊ើមខ្មែរ) ។

Dr. demande principale ម.ព. demande ។

n.m. វត្ថុ ឬ ការសំខាន់បំផុត (ឧ. vous oubliez le principal) ; ប្រាក់ដើម (ក្នុងបំណុល) (ឧ. rembourser le principal et les intérêts); នាយកអនុវិទ្យាល័យ

principalat *n.m.* តំណែងនាយកអនុវិទ្យាល័យ

principalement *adv.* ជាពិសេស, ជាដើម, ច្រើនតែ

principat *n.m.* ឋានៈជារាជ្យត្រ

principauté *n.f.* រាជ្យត្រប្រទេស (រដ្ឋដែលមានព្រះអង្គម្ចាស់ជាប្រមុខ)(ឧ. la principauté de Monaco); រាជ្យត្រភាព (ភាពជារាជ្យត្រ) (ឧ. accorder à un duc la principauté)

principe *n.m.* ដើមកំណើត, ដើមដំបូង (ឧ. remonter jusqu'au principe de toutes choses)។ dès le principe ពីដំបូង ។

Par ext. គោលការណ៍ ។ accord de principe ការយល់ព្រមខាងគោលការណ៍ (ការយល់ព្រមត្រង់ចំណុចសំខាន់ ប៉ុន្តែនៅមានការបញ្ជាក់ថែមទៀត) ។ en principe តាមគោលការណ៍ ។ poser un principe ម.ព poser ។ *pl.* principes de justice គោលការណ៍ខាងយុត្តិធម៌ ។ principes politiques គោលការណ៍ខាងនយោបាយ ។

Absol. គោលសីលធម៌ (ឧ. un homme sans principes est un homme sans caractère, car s'il était né avec du caractère il aurait senti le besoin de se créer des principes) (Chamfort) (មើល. loi, norme, système)

printanier,ère *a.* នៃនិទាឃរដូវ (ឧ. fleur printanière) ។ *Fig.* ក្មេង,នៃបឋមវ័យ (ឧ. grâce printanière)

printemps *n.m.* និទាឃរដូវ (រាប់ពីថ្ងៃ ២១ មីនា ដល់ ២១ មិថុនា) ។ *Fig.* បឋមវ័យ (ឧ. printemps de la vie)។ *Poét.* ឆ្នាំ (ឧ. avoir vécu seize printemps)

priori (a) *loc. adv.* តាំងពីដំបូង, ក្នុងអាទិកាល(មុនពិសោធ)(ឧ. a priori,

il ne m'est pas sympathique) ។

a.&n. inv. អនុពិសោធ (ឧ. vous avez des idées a priori)

prioritaire *a.* ដែលមានអាទិភាព (ដែលមានសិទ្ធិធ្វើមុនគេ) (ឧ. industries prioritaires)

priorité *n.f.* អាទិភាព, សិទ្ធិនិយាយ-សិទ្ធិបានមុនគេឬ ធ្វើមុនគេ ។ priorité absolue អាទិភាពដាច់ខាត

pris,e *a.* ដែលយក (ឧ. mot pris du latin) ។ pris de fièvre ដែលគ្រុន ។ *Fig.* ដែលស្រឡាញ់; ដែលកក (ឧ. fleuve pris)។ pris de vin ស្រវឹងស្រា។ pris pour dupe ដែលចាញ់បោកគេ ។ taille bien prise រាងសម

prise *n.f.* ការចាប់; ការកាន់; ការដណ្ដើមយក, ការវាយយក (ឧ. prise de Longvêk par les Siamois); របស់ ឬ មនុស្សចាប់បាន ឬ ដែលដណ្ដើមឬចាប់យកបាន)(ឧ. une bonne prise); ស្នៀតចាប់ (ឧ. une prise de judo); កន្លែងចាប់(ឬខ្សែទាញឬកសម្រាប់ចាប់ពោងឡើងភ្នំ);ការប្រកាន់;ជម្លោះ(ឧ. il y a souvent des prises violentes à la chambre des députés); ហិត (ចំនួនសម្រាប់ហិតម្ដង) (ឧ. une prise de tabac ថ្នាំមួយហិត) ។

Loc. div. Fig. & Fam. prise de bec ការឈ្លោះប្រកែកគ្នា ។ prise en charge ការទទួលបន្ទុក ។ prise d'habit, prise de voile ការចូលកាន់ផ្នួស។ donner prise ម.ព. donner ។ lâcher prise លែង (អ្វីៗដែលគេចាប់ឬកាន់); *au fig.* សងអើញ; ឈប់, លែងដេញ, លែងតាម ។ en venir aux prises ចូលប្រឡូកគ្នា។ être aux prises ប្រយុទ្ធគ្នា ។ être aux prises avec ប្រយុទ្ធនឹង; ខ្វល់នឹង; ជួបប្រទះ (ឧ. être aux prises avec l'adversité) ។ mettre aux prises ដាក់ឲ្យប្រយុទ្ធគ្នា, ប្រជល់គ្នា(ឧ.mettre deux coqs aux prises) ។ avoir prise sur quelqu'un មានមធ្យោបាយធ្វើអ្វីលើអ្នកណាមួយ (ចាប់ ឬ ធ្វើឲ្យស្លាប់បង្ខាប់) ។ *Pop.* pren-

dre une prise ហិតថ្នាំស្ដុយ ។

Dr. prise de corps ការចាប់ខ្លួន (ដោយដីកាតុលាការ); ការសម្រេចឲ្យចាប់ខ្លួន (ឧ. il y a prise de corps contre lui) ។ prise à parti ការប្ដឹងពីចៅក្រម ។ prise de possession ការទទួលដំណែង; ការចូលកាន់កាប់; ការទទួលភោគ ។

Jeu. Echecs កូនដែលគេស៊ី (បម្រុង)(ឧ.cavalier en prise)។

Mar. នាវាដែលគេចាប់បាន ។ part de prise ចំណែកអ្នកចាប់បាន ។ droit de prise សិទ្ធិចាប់ (សិទ្ធិចាប់នាវាជំនួញរបស់បច្ចាមិត្ត) ។

Mil. អ្វីៗដែលចាប់បានអំពីបច្ចាមិត្ត ។ prise d'arme ពិធីអាវុធគ្រាស ។

Techn. prise de son ការថតសម្លេង។ prise de vues ការថតរូប ។

Phil. prise de conscience ការដឹងខ្លួន, ការភ្ញាក់ខ្លួន

prisée *n.f.* ការវាយតម្លៃរបស់ឈ្មួញ

priser *v.t.* វាយតម្លៃ; ចូលចិត្ត (ឧ. priser un orateur)

priser *v.t.* ហិត (ឧ. priser du tabac)

priseur,euse *n.* អ្នកហិតថ្នាំ (ថ្នាំផង់) (ឧ. une vieille priseuse)

priseur,euse *n.* អ្នកវាយតម្លៃ

prismatique *a.* ជារាងអាក់ (ឧ.corps prismatique); ដែលមានអាក់ (ឧ. jumelle prismatique) ។

Phys. couleurs prismatiques ពណ៌ឃើញក្នុងអាក់

prisme *n.m.Math.* អាក់(ឧ.prisme triangulaire)។ *Fig.* អ្វីៗដែលឲ្យគេយល់ខុស ។ voir les choses à travers un prisme យល់ខុសព្រោះអគតិ

prison *n.f.* ពន្ធនាគារ, គុក (ឧ. mettre en prison); ការដាក់គុក (ឧ. condamné à six mois de prison) ។

Fig. ទីងងឹតហើយមិនសប្បាយ

prisonnier,ère *a.* ដែលជាប់គុក ។ *n.* អ្នកទោស(អ្នកជាប់គុក)។prisonnier de guerre ឈ្លើយសង្គ្រាម (ឧ. les prisonniers de guerre sont protégés par la Convention de Genève) ។

Fig. ដែលជាប់ជំពាក់ (ឧ.

prisonnier de ses passions)

privatif,ive *a.&n.m.Gram.* បដិសេធនិបាត (និបាតសព្ទសម្រាប់បដិសេធដូចជាន ក្នុងនត្ថិ, អ ក្នុងអកុសល)

privation *n.f.* ដំណើរខ្វះ;ដំណើរព្រាសបាក(ឧ.la privation des droits civils); ការអត់,ការតម (ឧ.la privation volontaire d'un plaisir); ភាពគ្មាន (ឧ. la privation des rudesses me tiendrait bien lieu d'amitié en un besoin) (Mme de Sévigné); ការខ្វះខាត, ការមិនបានដូចបំណង(ឧ. vivre dans les privations) ។ vivre de privations រស់ដោយខ្វះខាត ។ privation de l'ouïe ដំណើរខូចត្រចៀក (ភាពថ្លង់) ។ privation de la vue ដំណើរខូចភ្នែក (ភាពខ្វាក់)

privativement *adv.* ដោយអបរិយាប័ន្ន,ដោយចំពោះ,ដោយយល់មុខ(ដោយបដិសេធអ្នកឯទៀត) (ឧ. le pain, désormais, n'appartiendra privativement à personne)

privauté *n.f.* សេចក្ដីស្និទ្ធស្នាលហួសពេក (ឧ. permettre des privautés)

privé,e *a.* ឯកជន (ដែលគ្មានជំពាក់សាធារណ: ឧ. homme privé; នៃជនពិសេស; ក្នុងគ្រួសារ ឧ. vie privée; សម្រាប់ជនខ្លះ; មិនមែនសាធារណ: ឧ. séance privée) ។ droit privé នីតិឯកជន ។

n.m. ជីវភាពក្នុងគ្រួសារ (ឧ. être différent en public et dans le privé)

priver *v.t.* ដកហូត (ឧ. priver un homme de ses droits civils); បង្អត់,បំបាត់ (មិនឲ្យមាន)(ឧ.priver un enfant de récréation) ។

se priver (de) *v.pr.* អត់, តម (ឧ. se priver de vin) ។ *Abs.* សុខចិត្តអត់ឃ្លាន (ឧ. cette mère s'est privée pour élever ses enfants)(ហ៊. arracher, enlever, frustrer)

privilège *n.m.* ឯកសិទ្ធិ (សិទ្ធិជាប់នឹងស្ថានភាពខ្លះ ឧ. le privilège de la noblesse; អត្ថប្រយោជន៍ពិសេស ឬ ផ្ទាល់ខ្លួន ឧ. obtenir un privilège; សិទ្ធិ, បុព្វសិទ្ធិ ឧ. présider par privilège d'âge; អត្ថ-

ប្រយោជន៍ត្រូវបានទទួលសំណងមុនអ្នកឯទៀត ឧ. les frais de justice sont l'objet d'un privilège។ *Fig.* និស្ស័យ ឧ. la raison est un privilège de l'homme)។ privilège juridictionnel ឯកសិទ្ធិនៃយុត្តាធិការ

privilégié,e *n.&a.* ឯកសិទ្ធិ-ទ្ធិន,ដែលមានឯកសិទ្ធិ (ឧ. les classes privilégiées) ។ créancier privilégié ម្ចាស់បំណុលមានឯកសិទ្ធិ (ដែលត្រូវបានទទួលសំណងមុនអ្នកឯទៀត)

privilégier *v.t.* ឲ្យឯកសិទ្ធិ

prix *n.m.* តម្លៃ(ឧ. c'est la concurrence qui met un juste prix aux marchandises)។

Fig. ការខាតបង់ (ដើម្បីបានអ្វីមួយ) (ឧ. nombre de gens veulent parvenir à quelque prix que ce soit); តម្លៃ (ឧ. on ne comprend généralement le prix d'une bonne réputation qu'après l'avoir perdue) ។

ព្រហ្មទេយ្យ, រង្វាន់ (ឧ. recevoir le prix de ses services, de son dévouement; distribution des prix); អ្នកបានរង្វាន់(ឧ. peintre qui est un premier prix de Rome)។ prix d'excellence រង្វាន់ឯក ។ prix d'honneur រង្វាន់កិត្តិយស។

ទោស, ទណ្ឌកម្ម (ឧ. c'est le juste prix de son forfait)។

Loc. div. de prix ដែលមានតម្លៃ (ឧ. cheval de prix) ។ au prix de ជាតម្លៃ (ឧ. vendre sa maison au prix de cent mille riels); បើធៀបនឹង (ឧ. la fortune n'est rien au prix de la santé); ដោយអស់, ដោយបង់ខាត, ដោយប្រើ (ឧ. achever un travail au prix de grands efforts) ។ à prix d'argent ដោយបង់ប្រាក់ ។ à prix d'or ដោយថ្លៃណាស់ ។ prix pour prix បើគិតជាតម្លៃ (ឧ. prix pour prix, votre drap est plus cher que mon velours)។ à tout prix ទុកជាយ៉ាងណាក៏ដោយ។ hors de

prix ថ្លៃហួសពេក ។ prix fait តម្លៃត្រូវហើយ។ prix fixe ដាច់ថ្លៃ (ដោយមិនចេញថ្លៃ) (ឧ. vendre à prix fixe) ។ remporter le prix ឈ្នះគេ, បានរង្វាន់ ។ partager le prix ស្មើគ្នា (ចែករង្វាន់គ្នា) ។ mettre la tête d'un homme à prix កាត់ថ្លៃមនុស្សម្នាក់ (សន្យាថាឲ្យរង្វាន់ដល់អ្នកណាដែលសម្លាប់ ឬ ចាប់មនុស្សនោះបាន)។ valoir son prix ឬ avoir son prix មានតម្លៃខ្លះ ។ n'avoir point de prix ឬ être sans prix មានតម្លៃណាស់ ។ cela vaut toujours son prix របស់នេះនៅតែមានតម្លៃ ។

Com. prix de fabrique ម.ក. fabrique ។ prix réel តម្លៃពិត ។ prix courant ម.ក. courant ។ vendre à non prix លក់ថោកជាងតម្លៃពិត ។ vendre à tout prix លក់ឲ្យខាងតែដាច់ ។ prix de revient ម.ក. revient ។

Prov. chacun vaut son prix គ្មានគំនិតណាលោលឡៀតទេ

probablisme *n.m.* ភវនិយម (លទ្ធិនិយមជាធម្មតា មតិតែងតែមានត្រូវខ្លះខុសខ្លះ)

probabliste *a.* ភវនិយម ។ *n.* អ្នកភវនិយម

probabilité *n.f.* ភវិយភាព (ដំណើរសមជាពិត, ការគួរមាន - គួរជឿ) (ឧ. examiner les probabilités)

probable *a.* ភវិយ, គួរជាពិត, គួរមាន, គួរជឿ (ឧ. succès probable)

probablement *adv.* ប្រហែលជា, ទំនងជា, គួរតែមែន

probant,e *a.* ដែលបង្ហាញពស្តុតាង (ឧ. raison probante) ; ដែលជាពស្តុតាង (ឧ. pièce probante) *Pratiq.* en forme probante ដោយទម្រង់ត្រឹមត្រូវតាមច្បាប់

probatoire *a.* សម្រាប់ជាពស្តុតាង (ឧ. faits probatoires) ។ *Ens.* examen probatoire ការប្រឡងសាក

probe *a.* ទៀងត្រង់ (ឧ. on ne doit pas s'énorgueillir d'être probe) (ព.ផ. malhonnête, véreux)

probité *n.f.* សេចក្ដីទៀងត្រង់ (ឧ.

un homme d'une grande probité)(ម៉. honnêteté, intégrité, vertu)

problématique *a.* មិនទៀង,មិនប្រាកដ (ឧ. un succès problématique); គួរឲ្យមន្ទិល (ឧ. conduite problématique)

problématiquement *adv.* ដោយមិនទៀត ឬ មិនប្រាកដ ; ដោយគួរឲ្យមន្ទិល (ឧ. affaire problématiquement conçu)

problème *n.m.* ប៉ះណោទ (ឧ. problème de géométrie)។ *Par anal.* បញ្ហា ។ problème politique បញ្ហានយោបាយ ។ problèmes sociaux បញ្ហាសង្គម ។ cet homme est un problème មនុស្សនេះមើលមិនយល់

proboscidiens *n.m. pl.* សោណ្ឌីសត្វ (សត្វសន្ធានដំរី) (*sing.* un proboscidien)

procédé *n.m.* របៀប, បែប,វិធីធ្វើឬប្រើ

procéder *v.i.* បណ្ដាលមកអំពី (ឧ. nombre de maladies procèdent d'une mauvaise hygiène) ។ *Fig.* ធ្វើ, ប្រព្រឹត្ត (ឧ. procéder avec ordre) ។

v.t. ind. (à) ជាធ់នីតិវិធី (ឧ. procéder à l'ouverture d'un testament)។ *Par ext.* ជាត់បែង (ឧ. procéder à la démobilisation des troupes) ។

Loc. div. procéder militairement ធ្វើទាំងកញ្ជ្រោល (ដោយមិនតាមទម្រង់ការធម្មតានៃតុលាការ) ។

Dr. ប្ដឹង (ឧ. procéder au civil) ។

Fam. tant fut procédé ឬ tant a été procédé que ទើបប្រឹងទាល់តែ.., រឿងបកពិលាំងក់...

procédure *n.f.* និតិក្រម, នីតិវិធី ។ code de procédure en matière civile ក្រមនីតិវិធីខាងរដ្ឋប្បវេណី ។ code de procédure en matière pénale ក្រមនីតិវិធីខាងបទព្រហ្មទណ្ឌ

procédurier, ère *n.&a.* ដែលរវះនីតិវិធី (ឧ. un avoué procédurier); ដែលចូលចិត្តក្ដី (ឧ. on dit les Normands procéduriers); ដែលបន្តនីតិវិធី (ឧ. formalités procédurières)

procès *n.m.* ក្ដី (រឿងក្ដី) (ឧ. intenter un procès) ។ *Anat* ពុង (ឬរបស់ដែលបត់) ។

Fig. sans forme de procès ដោយគ្មានទីតិវិធី (ឧ. aux Etats-Unies, on lynche parfois un Nègre sans forme de procès); *au fig.* sans autre forme de procès ដោយមិនយាប់ជ្រួសមច្រើន, ដោយមិនបាច់រវល់ច្រើន ។ gagner un procès ឈ្នះក្ដី; *au fig.* ឈ្នះ, មានជោគជ័យ ។ perdre un procès ចាញ់ក្ដី; *au fig.* គ្មានជោគជ័យ, ចាញ់ ។ faire un procès à ប្ដឹងនឹង (មានរឿងក្ដីជាមួយនឹង) (ឧ. faire le procès à un escroc); *au fig.* ថោះ, បន្ទោស ។ mettre les parties hors de cour et de procès មិនជំនុំជម្រះក្ដីឡើយ ។

Prov. gagne assez qui sort de procès អ្នកមិនក្ដីទុកជាឈ្នះ (ចាញ់បានជាព្រះ ឈ្នះបានជាមារ) ។ un mauvais arrangement vaut mieux qu'un bon (ឬ que le meilleur) procès ការត្រូវត្រូវស្រួលគ្នាដោយខាតបង់ខ្លះក្រៃលែងជាងឈ្នះក្ដី

processif,ive *a.* ដែលចូលចិត្តក្ដី

procession *n.f.* ក្បួនហែ (ខាងសាសនា) ។ *Fig. & fam.* មនុស្សដើរជាប់គ្នា

processionnel,elle *a.* នៃក្បួនហែ (ឧ. marche processionnelle)

processionnellement *adv.* ជាក្បួនហែ (ឧ. s'avancer processionnellement)

processionner *v.i.* ហែ

processus *n.m.* អភិក្រម, ដំណើរ (ឧ. le processus d'une maladie); ការលូតលាស់, ការចម្រើន (ឧ. le processus de l'évolution intellectuelle)

procès-verbal *n.m.* កំណត់ហេតុ (លិខិតបញ្ជាក់ហេតុ ឬ បទល្មើស ឧ. dresser procès-verbal contre un chasseur sans permis; សេចក្ដីសង្ខេបជាលាយលក្ខអក្សរនៃការនិយាយ-ធ្វើឬសម្រេច ឧ. procès-verbal d'une séance) ។ procès-verbal de saisie កំណត់ហេតុរឹបអូស

Fig. dresser un procès-verbal ធ្វើកំណត់ហេតុ (ឧ. dresser un procès-verbal de carence) (*pl.* des procès-verbaux)

prochain,e *a.* ជិត (ឧ. la ville prochaine); ជិត, ផ្ទាល់ (ឧ. la cause prochaine de nos erreurs); មុខ (ដែលជិតបង្អស់) (ឧ le mois prochain)។

n.m. មនុស្សជិតគ្នា; អ្នកជិត (ឧ. on doit assister son prochain)

prochainement *adv.* បន្តិចទៀត, មិនយូរប៉ុន្មាន, ថ្ងៃមុខ

proche *a.* ជិត (ឧ. ces deux maisons sont proches l'une de l'autre; parent proche)។

n.m. pl. ញាតិ (ឧ. nos proches)

proclamateur,trice *n.* អ្នកប្រកាស

proclamation *n.f.* ការប្រកាស (ឧ. la proclamation d'un résultat); សេចក្ដីប្រកាស (ឧ. afficher une proclamation)

proclamer *v.t.* ប្រកាស (ឧ.proclamer un verdict; proclamer la vérité) (មើ. annoncer, déclarer, dévoiler, manifester)។

se proclamer *v.pr.* ប្រកាសខ្លួន

proconsul *n.m.* ប្រូកុងស៊ុល (ទេសាភិបាលរាជការខេត្តដែលរាជការបោកកាន)។

Fig. អ្នកកាន់អំណាចផ្ដាច់ការ (ឧ. les conventionnels en mission étaient de véritables proconsuls)

proconsulaire *a.* នៃប្រូកុងស៊ុល (ឧ. autorité proconsulaire)

proconsulat *n.m.* តំណែងប្រូកុងស៊ុល; រយៈពេលកាន់តំណែងប្រូកុងស៊ុល

procréateur,trice *a.&n.* ជាតិការី-នី, ដែលបង្កើត

procréation *n.f.* ជាតិកម្ម, ការបង្កើត

procréer *v.t.* ធ្វើជាតិកម្ម, បង្កើត

procurateur *Ant. rom.* អ្នកទារសារពើពន្ធ: ប្រមុខខេត្ត

procuration *n.f.* សិទ្ធិប្រទាន (ការប្រគល់អំណាច - ប្រគល់សិទ្ធិ; លិខិតប្រគល់អំណាច - ប្រគល់សិទ្ធិ) (ឧ. dresser une procuration)។

donner procuration ប្រគល់

សិទ្ធិប្រទាន ។ par procuration ដោយសិទ្ធិប្រទាន

procuratrice *n.f.* អាជ្ញាសាលាស្រី

procurer *v.t.* ផ្តល់ឲ្យ, រកឲ្យ (ឧ. procurer un emploi à quelqu'un); ជាហេតុ (ឧ. cet événement nous a procuré bien des ennuis)

procureur *n.m.* អ្នកប្រព្រឹត្តដោយសិទ្ធិប្រទាន ។ procureur du roi ឬ procureur ព្រះរាជអាជ្ញា

prodigalité *n.f.* ការកញ្ជះកញ្ជាយ ; ភាពអ្នកកញ្ជះកញ្ជាយ ។ prodigalité excessive ការកញ្ជះកញ្ជាយហួសពេក

prodige *n.m.* មហស្ចារ្យ, ហេតុអស្ចារ្យ (ឧ. les Romains croyaient aux prodiges) ; វត្ថុ ឬ មនុស្សអស្ចារ្យ (ឧ. cet homme est un prodige de savoir; les prodiges de la science) ។

a. enfant prodige ក្មេងអស្ចារ្យ

prodigieusement *adv.* យ៉ាងអស្ចារ្យ

prodigieux,euse *a.* អស្ចារ្យ ; សំបើមណាស់ (ឧ. une prodigieuse sottise)

prodigue *n.&a.* ដែលកញ្ជះកញ្ជាយ, ដែលឲ្យឬចាយឥតគិត (ឧ. les prodigues peuvent être pourvus d'un conseil judiciaire) ។ *Fig.* ដែលមិនសំចៃ (ឧ. prodigue de compliments) ។ Enfant prodigue កូនកញ្ជះកញ្ជាយ (រឿងនិទានក្នុងគម្ពីរព្រះយេស៊ូ ថាកូនកញ្ជះកញ្ជាយនេះ ចេញអំពីគ្រួសារខ្លួនទៅប្រព្រឹត្តអនាចារ លុះប្រទះនឹងសេចក្តីលំបាកគ្រប់យ៉ាង ទើបត្រឡប់មកកាន់គ្រួសារវិញ) ។

Prov. à père avare, enfant prodigue ឪពុកកំណាញ់ កូនកញ្ជះកញ្ជាយ (មនុស្សកំណាញ់ច្រើនមានកូនកញ្ជះកញ្ជាយ)

(ព.ផ. avare, économe)

prodiguer *v.t.* កញ្ជះកញ្ជាយ, ចាយវាយឥតគិត (ឧ. prodiguer son argent); មិនសំចៃ (ឧ. prodiguer des éloges) (ស៊ី. dilapider, dissiper, gaspiller) (ព.ផ. économiser, épargner)

pro doma sua *loc.lat.* សម្រាប់ខ្លួនឯង

prodrome *n.m.* បឋមហេតុ, ភាពសង្កេតសង្គាញ់មុនចាប់ជម្ងឺអ្វីមួយ (ឧ. les prodromes de la fièvre typhoïde); *par ext.* ហេតុជាប្រផ្នូល

produceur [--dyou-seur] *n.m.* (ព.អ.) *Cin.* ផលិតករខ្សែភាពយន្ត

producteur,trice *a.&n.* ផលិតករ, អ្នកបង្កើតផល។ *n. Cin.* អ្នកធ្វើឬផលិតខ្សែភាពយន្ត

productible *a.* ផលិតីយ, អាចបង្កើតបាន (ឧ. marchandises productibles)

productif,ive *a.* ផលិត, ដែលឲ្យផល; ដែលឲ្យផលច្រើន (ឧ. sol productif)

production *n.f.* ផលិតកម្ម; ការបង្កើតផល; ផលិតផល (ឧ. les productions du sol); ការបង្ហាញ (ឧ. la production d'un acte de naissance); ផលិតវណ្ណ

productivisme *n.m.* ផលិតនិយម (លទ្ធិនិយមបង្កើតផលិតកម្មជានិច្ច)

productivité *n.f.* ផលិតភាព; ដំណើរឲ្យផល; ភាពវត្ថុដែលឲ្យផល (ឧ. productivité d'une terre)

produire *v.t.* ផលិត, បង្កើត (ឧ. chaque animal produit son semblable); ឲ្យផល (ឧ. pays qui produit beaucoup de paddy); ធ្វើ (ឧ. produire des automobiles)។

Fig. ឲ្យផល (ឧ. cette charge produit tant par an); បង្កើត, ឲ្យមាន (ឧ. la guerre produit de grands maux); បង្ហាញ (ឧ. produire des titres, des pièces); នាំចូល (ឧ. produire quelqu'un dans une société); មាន (ឧ. la France a produit beaucoup de grands hommes); បង្កើត (ឧ. l'art produit des merveilles)។

se produire *v.pr.* បង្ហាញខ្លួន, ធ្វើឲ្យគេស្គាល់ខ្លួន (ឧ. se produire dans les salons); មានឡើង (ឧ. un grand silence se produit immédiatement)

produit *n.m.* ផលិតផល, ផល (ឧ. vivre du produit de sa terre); កូន (ឧ. les produits d'une jument)។

produits agricoles ផលិតផលកសិកម្ម ។ produits dérivés ផលិតផលនិស្សន្ទវត្ថុ ។ produits industriels ផលិតផលឧស្សាហកម្ម ។ produits manufacturés ផលិតផលកម្មន្តសាល ។ produits finis ផលិតផលសិទ្ធ ។ produits semi-finis ផលិតផលអឌ្ឍសិទ្ធ

proème *n.m.* អារម្ភកថា

proéminence *n.f.* ភាពពក; ពក

proéminent,e *a.* ដែលពក, ខ្ពស់ (ឧ. front proéminent)

profanateur,trice *a.&n.* ដែលប្រមាថសរណវត្ថុ

profanation *n.f.* បមាថកម្ម, ការប្រមាថសរណវត្ថុ (ឧ. profanation d'un temple) ។ *Fig.* ការធ្វើឲ្យខូច, ការប្រមាថ (ឧ. la profanation du génie)

profane *a.* មិនមែនក្នុងសាសនា, មិនមែនជាវត្ថុសរណៈ (ឧ. tout profane exercice est banni de son temple); ដែលមិនគោរពសរណវត្ថុ(ឧ.conduite profane)។ *n.* អ្នកក្រៅ(សាសនាឬសមាគម) (ឧ. éloigner les profanes)។ *Par ext.* អ្នកមិនចេះ(វិទ្យាសាស្ត្រ, សិល្បៈ)(ឧ. les artistes sont impitoyables pour les profanes qui osent juger leurs œuvres); ពិតៈជន [អ៊ិ-ត:-ជ:–], ប្រថុជ្ជន ។

n.m. វត្ថុសាមញ្ញ (ក្រៅសាសនា, មិនពិសិដ្ឋ) (ឧ. mêler le profane au sacré)

profanement *n.m.* ប.ព. profanation

profaner *v.t.* ប្រមាថសរណវត្ថុ (ឧ. profaner les autels, un temple)។ *Par ext.* ប្រមាថ,មិនគោរព (ឧ. la royauté a été profanée) (Bossuet) ។ ធ្វើឲ្យសាបរលាបនូវសរណវត្ថុ។ *Fig.* បន្ថោក(ឧ. c'est profaner son talent, que de le mettre au service d'une mauvaise cause)

profectif,ive *a.Dr.* ដែលមកអំពីបុព្វញាតិ (ឧ.biens profectifs)

proférer *v.t.* បន្លឺពាក្យ (ឧ. ne pas proférer une parole)។ proférer des injures ជេរខ្លាំង

professable *a.* អាចបង្រៀនបាន (ឧ.

une matière peu professable)

professer *v.t.* ថ្លែង, ទទួលស្គាល់ជាសាធារណៈ (ឧ. professer des opinions démocratiques); ប្រកបវិជ្ជាជីវៈខាង (ឧ. professer la médecine); បង្រៀន (ឧ. professer l'histoire)

professeur *n.* សាស្ត្រាចារ្យ (ឧ. professeur d'anglais); អ្នកផ្សាយ (ពស. enseignant, maître)

profession *n.f.* ការប្រកាសជាសាធារណៈ (ឧ. faire profession d'athéisme) ។ profession de foi ការប្រកាសជំនឿ ។ *Fam.* faire profession de អួតខ្លួន ។ វិជ្ជាជីវៈ (ឧ. profession de médecin) ។

Loc.adv. de profession ដោយវិជ្ជាជីវៈ (ឧ. un savant de profession); ជាទម្លាប់ (ឧ. un ivrogne de profession) ។ profession libérale ម.ព. libéral

professionnalisme *n.m.* វិជ្ជាជីវនិយម (សកម្មភាពអ្នកធ្វើអ្វីដោយវិជ្ជាជីវៈ)

professionnel,elle *a.* ខាងវិជ្ជាជីវៈ (ឧ. enseignement professionnel) ។ école professionnelle សាលាវិជ្ជាជីវៈ ។

n. អ្នកកាន់មុខការអ្វីជាវិជ្ជាជីវៈ (ផ្ទុយនឹង amateur)

professionnellement *adv.* ជារបៀបវិជ្ជាជីវៈ

professoral,e,aux *a.* នៃសាស្ត្រាចារ្យ (ឧ. ton professoral)

professorat *n.m.* ដំណែងសាស្ត្រាចារ្យ; រយៈពេលកាន់ដំណែងសាស្ត្រាចារ្យ

profil *n.m.* គំនូសកាត់ (ទ្រង់ទ្រាយមុខ ឬវត្ថុមើលពីចំហៀង) ។ profil d'équilibre គំនូសកាត់សមតា [សៈ-ម៉ៈ-តា] ។ profil en long គំនូសកាត់បណ្ដោយ ។ profil en travers គំនូសកាត់ទទឹង

profilé,e *a.* ដែលមានគំនូសកាត់ (ឧ. carosserie bien profilée)

profiler *v.t.* គូរគំនូសកាត់ (គូរទ្រង់ទ្រាយពីចំហៀង) (ឧ. profiler une tour); បញ្ចាំងទ្រង់ទ្រាយពីចំហៀង ។

se profiler *v.pr.* បង្ហាញខ្លួនពីចំហៀងមុខ; បញ្ចាំងស្រមោល

profit *n.m.* គុណប្រយោជន៍, កម្រៃ (ឧ.

tirer profit d'une affaire)។ profit brut គុណប្រយោជន៍ពុំល។ profit net គុណប្រយោជន៍សុទ្ធ។

Loc. adv. mettre à profit ប្រើឲ្យមានប្រយោជន៍, ឆ្លៀត (យកប្រយោជន៍) (ឧ. mettre à profit l'occasion)។ faire le profit de ឆ្លៀតយកប្រយោជន៍ពី(ឧ. faites votre profit des leçons de l'expérience)។trouver son profit à បានកម្រៃពី(ឧ. quiconque déclame contre la liberté, trouve son profit à l'esclavage) (Boiste)។ c'est tout profit មានតែពីចំណេញ ។ être fait à profit ឬ à profit de ménage ប្រើបានយូរ ។

Com. profits et pertes ចំណេញនិងខាត(ឧ. compte des profits et pertes) ។

au profit de *loc. pré.* ដាក់ប្រែចំពោះ, ជាគុណប្រយោជន៍ចំពោះ (ព.ផ. perte)

profitable *a.* ដែលឲ្យគុណប្រយោជន៍, ដែលឲ្យកម្រៃ

profitablement *adv.* ដោយបានគុណប្រយោជន៍ឬកម្រៃ

profitant,e *a. Fam.* ដែលប្រើចំណេញ (ឧ. étoffe profitante)

profiter *v.t. ind.* profiter de ឆ្លៀត (ទាញគុណប្រយោជន៍) (ឧ. profiter du temps)។profiter à ផ្ដល់គុណប្រយោជន៍ដល់ (ឧ. ce commerce lui a bien profité); បានច្រើន (ឧ. bien mal acquis ne profite jamais ម.ព. bien ផង) ។

v.i. ឡើងធំ(ឧ. cet enfant profite à vue d'œil)

profiteur,euse *n.&a.* អ្នកឆ្លៀត, អ្នកទាញគុណប្រយោជន៍ពីការអ្នកដទៃ

profond,e *a.* ជ្រៅ (ឧ. puits profond; blessure profonde)។ *Fig.* ជ្រៅ (ឧ. nuit profonde); ជម្ពូរ, ជ្រាលជ្រៅ, សុខុម (ឧ. des vérités profondes; esprit profond); ស្ងួន (ឧ. une ignorance profonde); ឈឹង, ជ្រងំ(ឧ. profond silence); ពន់ពេក, ខ្លាំងណាស់ (ឧ. un profond ennui; une profonde douleur); ពេញ

ទី (ឧ. un profond scélérat); វែង (ឧ. un profond soupir); ចាស់ (ឧ. bleu profond) ។

profonde révérence ការគំនាប់យ៉ាងទាប ។ voix profonde សម្លេងប៉ុងប៉ាត់ ។

n.m. បាត (ឧ. tomber jusqu'au profond de l'abîme) ។ *Fig.* ជម្រៅ (ឧ. laisser voir le profond de son cœur) ។

n.f. *Arg.* ហោប៉ៅ (ឧ. tirer un surin de sa profonde) ; ភូមិគ្រឹះ (បន្ទប់ក្នុងដីក្រោមផ្ទះ)

profondément *adv.* យ៉ាងជ្រៅ (ឧ. creuser profondément la terre, une question); យ៉ាងខ្លាំង, យ៉ាងធ្ងន់; យ៉ាងទាប (ឧ. saluer profondément)

profondeur *n.f.* ជម្រៅ (ឧ. profondeur d'une rivière); ជម្រៅ ឬ បណ្ដោយ (ឧ. cette cour a 20 mètres de largeur et 30 de profondeur) ។

Fig. គម្ភីរភាព, ជម្រៅ (នៃវិជ្ជា, នៃគំនិត) (ឧ. profondeur des idées); សុខុមភាព (ឧ. la profondeur des mystères)

pro forma (ព. ឡាតាំង) ជាទម្រង់ (ឧ. faire une demande pro forma) ។ facture pro forma ប.ត. facture

profus,e *a.* *Méd.* ច្រើន (ឧ. sueurs profuses)

profusément *adv.* យ៉ាងច្រើន (ឧ. lumière profusément jetée par le soleil)

profusion *n.f.* បរិបូណ៌ភាព, ភិយ្យោភាព, ភាពច្រើន; ភាពខ្ជះខ្ជាយ (ឧ. ses profusions l'ont ruiné) ។ à profusion យ៉ាងច្រើន (ឧ. donner à profusion) (មើ. largesse, munificence, prodigalité)

progéniture *n.f.* កូន (កូនទាំងឡាយនៃបុគ្គលម្នាក់ឬសត្វមួយ) ។ *Fam.* កូន (ឧ. conduire sa progéniture au théâtre)

programmation *n.f.* ការរៀបចំកម្មវិធី

programme *n.m.* កម្មវិធី (ឧ. programme d'un concert; programme de l'enseignement) ។ *Fig.* បំណង (ឧ. on

est souvent obligé de changer son programme) ។ menteur comme un programme ដែលសន្យាឲ្យរួចតែពីមាត់

programmer *v.t.* រៀបចំកម្មវិធី

progrès *n.m.* វឌ្ឍនធម៌, សភាពចម្រើន, សភាពលឿន

progresser *v.i.* ទៅមុខ (ឧ. les troupes progressent)។ *Fig.* មានវឌ្ឍនធម៌, ចម្រើន, លឿន (ឧ. l'humanité progresse sans cesse) ។

progressibilité *n.f.* វឌ្ឍនីយភាព, ភាពអាចចម្រើនបាន

progressif, ive *a.* ដែលចំរើន ឬ លឿន ជាលំដាប់ (ឧ. la marche progressive de la science) ។ impôt progressif ពន្ធកើន ។

n. វឌ្ឍនជន, អ្នកទៅមុខ, អ្នកចម្រើន (ឧ. il n'y a que trois classes d'hommes: les rétrogrades, les stationnaires et les progressifs)

progression *n.f.* ការទៅមុខ (ឧ. la progression d'une troupe)។ *Fig.* វឌ្ឍនកម្ម, ការចម្រើន, ការលឿន (ឧ. progression des idées)។ *Math.* ដំណើន ។ progression arithmétique ដំណើនលេខគណិត (ដំណើនដោយបូកឬសងនឹងចំនួនពីដែលហៅថា raison de progression មេដំណើន) (ឧ. progression croissante(ដំណើនឡើង)-:-1 4 7 10 13... (មេដំណើន+៣); progression décroissante(ដំណើនចុះ) ÷ 17 13 9 5 1... (មេដំណើន_៤)។ progression géométrique ដំណើនធរណីមាត្រ (ដំណើនដោយគុណ ឬ ចែក) (ឧ. ÷ 5 10 20 40... (មេដំណើន ២)

progressisme *n.m.* វឌ្ឍននិយម (លទ្ធិនិយមការចម្រើន)

progressiste *n.&a.* អ្នកវឌ្ឍននិយម (អ្នកនិយមការចម្រើន ។ *Auj.* អ្នកដែលមានគំនិតខាងនយោបាយនឹងខាងសង្គមលឿនទៅមុខ)

progressivement *adv.* កាន់តែកើនឡើងជាលំដាប់

progressivité *n.f.* វឌ្ឍនភាព (ភាពនៃអ្វីៗដែលចម្រើនជាលំដាប់;ភាពនៃអត្រាពន្ធដែលឡើងតាមទឹកប្រាក់ពន្ធ)(ឧ. le taux de progressivité de la

surtaxe varie pour chaque tranche de revenu considérée) (ព.ផ. proportionnalité)

prohibé,e *a.* អាយ័ត [–យ៉ាត់], ដែលហាមឃាត់។ temps prohibé កាលអាយ័ត(ពេលហាមមិនឲ្យធ្វើអំពើខ្លះ (ឧ. chasser en temps prohibé)។ degré prohibé ថ្នាក់អាយ័ត (ថ្នាក់ញាតិវង្សដែលច្បាប់ហាមមិនឲ្យយកគ្នាជាប្ដីប្រពន្ធ) ។ armes prohibées អាវុធអាយ័ត(អាវុធដែលច្បាប់ហាមមិនឲ្យកាន់) (ព.ផ. autorisé)

prohiber *v.t.* អាយ័ត [អា-យ៉ាត់], ហាមឃាត់ (ឧ. prohiber l'exportation des grains)។ prohiber le mariage អាយ័តមិនឲ្យរៀបអាពាហ៍ពិពាហ៍ (ស្រ. défendre ព.ផ. admettre, autoriser, permettre)

prohibitif,ive *a.* អាយ័ត, ដែលហាមឃាត់ (ឧ. une loi prohibitive); ហួសពេក (ឧ. des prix prohibitifs); អាយ័ត (សម្រាប់បំបិទឬបន្ថយជំនួញ, ឧស្សាហកម្ម) (ឧ. tarif de douane prohibitif)

prohibition *n.f.* អាយតកម្ម, ការហាមឃាត់ (ឧ. la prohibition de la pêche à certaines époques)

prohibitionnisme *n.m.* អាយតនិយម [–យ៉ះ-តះ–] (លទ្ធិនិយមហាមឃាត់ផលិតផលខ្លះដូចជាស្រា)

prohibitionniste *a.* អាយតនិយម(ឧ. mesures prohibitionnistes)។ *n.* អ្នកអាយតនិយម

proie *n.f.* រំពា (ឧ. l'aigle fond sur sa proie)។ *Fig.* វត្ថុដែលគេដណ្ដើមយកបាន (ឧ. la Gaule fut la proie des Barbares)។ être la proie de ជាចំណីនៃ, ត្រូវអន្តរាយដោយ (ឧ. cette maison a été la proie des flammes)។ être en proie à ត្រូវច្របល់ដោយ, ខ្វល់ដោយ (ឧ. être en proie au remords)។ oiseau de proie បក្សីរំពា (បក្សីដែលស៊ីសាច់សត្វដទៃជាអាហារ)

projecteur *n.m.* ប្រដាប់បញ្ចាំងពន្លឺ

projectile *n.m.* វត្ថុដែលគេបោះឬបាញ់ទៅឆ្ងាយ, គ្រាប់ (ឧ. un projectile explosif)។

a. ដែលបោះឬបាញ់ទៅឆ្ងាយ (ឧ. force projectile)

projection *n.f.* ការចោល ឬ បាញ់(ឧ. projection de pierres, d'eau, de vapeur); ការបញ្ចាំង; រូបបញ្ចាំង; ការបញ្ចាំងភាពយន្ត

projet *n.m.* បំណង (ឧ. projet qui échoue); សេចក្ដីព្រាង (ឧ. ce n'est encore qu'un projet; un projet de contrat) ។ projet de loi សេចក្ដីព្រាងច្បាប់ (ពស. but, dessein, entreprise)

projeter *v.i.* ចោលទៅមុខ (ឧ. corps qui projette son ombre); មានបំណង; ព្រាង, គ្រោងការ (ឧ. projeter un voyage) ។ *Cin.* បញ្ចាំង

prolétaire *n.m.* ពលជីវី [ពៈ-លៈ-—] (អ្នកក្រ, អ្នករស់នៅដោយកម្លាំងកាយ)

prolétariat *n.m.* វណ្ណៈពលជីវីៈ (វណ្ណៈអ្នករស់នៅដោយកម្លាំងកាយ)

prolétarien,enne *a.* ពលជីវីៈ

prolétarisation *n.f.* ពលជីវីកម្ម

prolétariser *v.t.* ធ្វើពលជីវីកម្ម, ធ្វើឲ្យមានលក្ខណៈជាពលជីវី

prolifération *n.f. Par ext.* ដំណើរសាយកូន

prolifère *a.* ដែលសាយកូន

proliférer *v.i.* សាយកូន

prolifique *a.* ដែលសាយកូន (ឧ. les lapins sont très prolifiques) ។ *Fig.* ដែលមានស្នាដៃច្រើន (អ្នកនិពន្ធ)

prolixe *a.* សំញ៉ាំ, វែងពេក (ឧ. discours prolixe); ដែលអធិប្បាយវែងពេក (ឧ. orateur prolixe)

prolixement *adv.* ដោយវែងពេក

prolixité *n.f.* ភាពសំញ៉ាំ ឬ វែងពេក (ឧ. la prolixité est un insupportable défaut)

prologue *n.m.* បុរេកថា [បុ-រេ-កៈ-ថា]; ការផ្ដើម (ឧ. cette réception servit de prologue à la conférence) (ព.ផ. épilogue)

prolongation *n.f.* ការបន្ត ឬ ពន្យារពេល (ឧ. la prolongation d'un congé, d un match)

prolongement *n.m.* ការបន្តឲ្យវែង; អ្វីៗដែលបន្ត (ឧ. le prolongement d'une rue) ។ *Fig.* ផល (ឧ. les prolongements d'une affaire)

prolonger *v.t.* បន្តឲ្យវែង (ឧ. prolonger une route); បន្ត (ឧ. prolonger une séance) ។

Mar. prolonger une côte បើកសៀរតាមច្រាំង ។ prolonger une ligne de navires បើកបណ្ដោយតាមផ្លូវនាវា ។

se prolonger *v.pr. Fig.* នៅក (មិនសាបសូន្យ) (ឧ. nous aimons à nous prolonger dans nos enfants); នៅមានត ទៅទៀត (ឧ. la guerre s'est prolongée plus qu'on ne pensait) (សរ. agrandir, allonger, augmenter, étendre)(ព.ផ. abréger, diminuer, écourter, raccourcir)

promenade *n.f.* ការដើរលេង; កន្លែងដើរលេង (ឧ.la promenade des Anglais, à Nice)

promener *v.t.* នាំដើរលេង (ឧ. promener un malade) ។ *Fig.* promener ses regards ចោលភ្នែកមើល (ឧ. promener ses regards sur la foule)។ *Particul.* នាំអ្នកអាន (ឧ. Dumas père promène ses lecteurs par toute l'histoire) ។

se promener *v.pr.* ដើរលេង ។ *Fig.* ទៅកន្លែងនេះបន្តិច កន្លែងនោះបន្តិច, បត់ទៀតបត់ចុះ (ឧ. Ruisseau qui... Dans un pré plein de fleurs lentement se promène) (Boileau); ទៅពីមួយទៅមួយ (ឧ. imagination qui se promène d'un objet à l'autre) ។

Fig. & fam. envoyer promener ឬ se promener បណ្ដេញ (ដោយខឹង); លែងរវល់ ។ allez vous promener! ទៅឲ្យឆ្ងាយទៅ! ។ qu'il aille se promener! ឲ្យវាទៅឲ្យឆ្ងាយទៅ!; លែងរវល់នឹងវាទៅ!

promeneur, euse *n.* អ្នកនាំដើរលេង ។ (ឧ. un promeneur d'étrangers); អ្នកដើរលេង(ឧ.d'élégantes promeneuses)។

Fig. & fam. ដើលរៀបរាប់ច្រើនពេក ; ដើលមិនកាន់ពាក្យសន្យា (ឧ. envoyons promener les promeneurs)

promenoir *n.m.* សាលាដើរលេង

promesse *n.f.* ការសន្យា; ពាក្យសន្យា (ឧ. tenir ses promesses) ។

Fig. ភាពក្លូវឲ្យសង្ឃឹម (ឧ. jeune homme plein de promesses)។ promesse de mariage ការកំដាប់ពាក្យ ។ se ruiner en promesses សន្យាច្រើនតែមិនកាន់។ *n.f. pl.* ជំនួន (ក្នុងពិធីលើក ស្លាកំដាប់ពាក្យ)

prometteur,euse *a.&n.* អ្នកដែលសន្យាឲ្យរួចតែពីមាត់។ *a.* គួរឲ្យសង្ឃឹមច្រើន (ឧ. sourire prometteur)

promettre *v.t.* សន្យា(ឧ.promettre une récompense)។ *Fig.* ឲ្យដំណឹង (ឧ. le temps promet la pluie)។ *Abs.* ឲ្យសង្ឃឹម (ឧ. la vigne promet beaucoup)។

Loc. div. se ruiner à promettre et s'enrichir à ne rien donner សន្យាច្រើនប៉ុន្តែមិនកាន់ ។

Prov. promettre et tenir sont deux មិនដំត្រង់សន្យាទេ (ធ្វើនការបេតេមិនកាន់ពាក្យសន្យាទេ) ។

se promettre *v.pr.* សង្ឃឹម (ឧ. la jeunesse se promet tout d'elle-même)(Fénelon); សម្រេចចិត្ត (ឧ. il s'était bien promis de garder le silence); សន្យាគ្នា (ឧ. amies qui se sont promis de s'écrire)

promis,e *a.* ដែលសន្យា (ឧ. une chose promise)។terre promise ដីសន្យា (ដីនៃពេលកានដែលអាទិទេពសន្យា ប្រទានឲ្យពួកហេប្រឺនៅប្រទេសជាឡេស្ទីន); *par anal.* ដីមានដីជាតិល្អ; កន្លែងដែលគេរករបស់ត្រូវការបានគ្រប់យ៉ាង (ឧ. un pays qui est la terre promise du chasseur); *au fig.* របស់ដែលគេប្រាថ្នាតែរកមិនបាន (ឧ. le bonheur, pour la plupart des hommes, reste toujours la terre promise) ។

Prov. chose promise: chose due ពាក្យសន្យាពាក្យសត្យ, វត្ថុដែលសន្យាហើយត្រូវតែឲ្យ ។

n. គូកំណាន់ចិត្ត (ឧ. un promis et sa promise)

promiscue *a. f. Dr.* ប្រឡូកប្រឡំ (ឧ. réunion promiscue); រួមគ្នា (ឧ. possession promiscue)

promiscuité *n.f.* ភាពប្រឡូកប្រឡំ (ឧ. il règne dans l'Asie

musulmane une grande promiscuité de langage) (Renan); ភាពមនុស្សនៅលាយឡំប្រឡូកប្របល់ (ភេទខុសគ្នា, ឋានៈខុសគ្នា, សញ្ជាតិខុសគ្នា ។ ល ។) (ឧ. la promiscuité de la ville d'eaux ou de la plage)

promission *n.f.* terre de promission ម.ព. terre promise ក្នុង ព. promis

promontoire *n.m.* ជ្រោយខ្ពស់ (ឧ. Gibraltar est bâtie sur un promontoire)

promoteur,trice *n.* អាទិករ, អ្នកផ្ដើមធ្វើមុន (ឧ. le promoteur d'une loi, d'une réforme)

promotion *n.f.* ការលើកឋានន្តរស័ក្តិ (ឧ. la nouvelle de sa promotion est arrivée en sept jours) ។ *Par ext.* ជំនាន់ (ក្រុមអ្នកបានឡើងឋានន្តរស័ក្តិ ឬ បានចូលសាលាខ្ទះជំនាន់គ្នា) (ឧ. des officiers de la même promotion); ការតែងតាំងក្នុងមុខងារ ឬ ឋានន្តរស័ក្តិខ្ពស់

promouvoir *v.t.* លើកឋានន្តរស័ក្តិ ។ *Fig.* ប្រតិបត្តិ (ឧ. promouvoir une politique de progrès)

prompt,e *a.* រហ័ស (ឧ. une prompte répartie; un esprit prompt); ឆាប់ខឹង ។

Loc. div. avoir la main prompte ងាយដៃ (ចូលចិត្តវាយដោយរឿងបន្តិចបន្តួច) ។ *Pratiq.* droit de prompte expédition ឬ prompte *n.f.* សំពូកឡរហ័ស

promptement *adv.* យ៉ាងរហ័ស

promptitude *n.f.* ភាពរហ័ស (ឧ. obéir avec promptitude); ភាពរហ័សយល់ (ឧ. la promptitude de l'esprit); ភាពឆាប់ខឹង (ឧ. je tâcherai d'apaiser une partie de mon impatience et de ma promptitude naturelle) (Mme de Sévigné) (ព្ទ. célérité, diligence, hâte, prestesse, rapidité, vélocité, vitesse)

promu,e *a.&n.* ដែលបានឡើងឋានន្តរស័ក្តិ

promulgation *n.f.* ការប្រកាសឲ្យ

ប្រើ ។ promulgation de loi ការប្រកាសឲ្យប្រើច្បាប់

promulguer *v.t.* ប្រកាសឲ្យប្រើ (ច្បាប់) (ឧ. promulguer une loi)

prône *n.m. Relig.* ការបង្រៀនដោយស្និទ្ធស្នាល (សាសនា) (ឧ. faire le prône)។recommander quelqu'un au prône *Fig.* ប្ដឹងទៅអ្នកធំ (ឲ្យធ្វើទោស)

prôner *v.t.* បង្រៀនដោយស្និទ្ធស្នាល; អួត (ឧ. il nous la prône comme une héroïne)។

v.i. ស្ដីបន្ទោស ។

se prôner *v.pr.* អួតខ្លួនឯង; អួតគ្នាទៅវិញទៅមក

prôneur,euse *n.* អ្នកអួតហួសហេតុ។ *Fam.* អ្នកហៃស្ដីបន្ទោស (ឧ. une prôneuse insupportable)។ petit faiseur et grand prôneur អ្នកបានតែជា (រស់តែពាក្យ ត្រពាក់ស្លាប់ឈឹង)។

n.m. អ្នកបង្រៀនសាសនាដោយស្និទ្ធស្នាល

pronom *n.m. Gram.* សព្វនាម ។ pronom démonstratif និយមសព្វនាម ។ pronom indéfini អនិយមសព្វនាម ។ pronom personnel បុរិសសព្វនាម

pronominal,e,aux *a.* នៃសព្វនាម

pronominalement *adv* ជាសព្វនាម

prononçable *a.* អាចថា ឬ អានបាន (ឧ. ce nom n'est pas prononçable)

prononcé,e *a.* ច្បាស់(ដែលមានច្បាស់, ដែលឃើញច្បាស់) (ឧ. traits prononcés; goût prononcé pour les arts) ។

n.m. ការសូត្រ(សេចក្ដីសម្រេច) (ឧ. le prononcé d'un jugement)

prononcer *v.t.* ថា,អាន(ឧ.prononcer les lettres, les mots); សូត្រ (ឧ. prononcer un discours); សូត្រ (សេចក្ដីសម្រេច) (ឧ. prononcer un arrêt)

v.i. សម្រេច ។

se prononcer *v.pr.* ថ្លែងបំណង ឬ គំនិតខ្លួន (សរ. décider, juger, statuer)

prononciation *n.f.* ការថា;ការអាន (ឧ. la prononciation anglaise); ការសូត្រ (សេចក្ដីសម្រេច)

(ឧ. la prononciation d'un arrêté)

pronostic *n.m.* ការទាយ - ស្មាន ឬ ប៉ាន់ (ឧ. se tromper dans ses pronostics); ប្បុរេនិមិត្ត, សញ្ញាសម្រាប់ទាយ-ស្មាន ឬ ប៉ាន់ (ឧ. fâcheux pronostic)

pronostiquer *v.t.* ទាយ, ស្មាន, ប៉ាន់ (ឧ. pronostiquer le temps)

pronostiqueur,euse *n.* អ្នកទាយ-ស្មាន ឬ ប៉ាន់

propagande *n.f.* ឃោសនា

propagandiste *n.&a.* ឃោសនិកនិកា, អ្នកឃោសនា

propagateur,trice *n.&a.* អ្នកផ្សាយ (ឧ. propagateur d'idées nouvelles)

propagation *n.f.* ការបង្កើតឲ្យបានច្រើនឡើង (ឧ. la propagation du genre humain)។ *Fig.* ការផ្សាយ (ឧ. propagation des idées); ដំណើររាលឆ្លង (ឧ. propagation du feu)

propager *v.t.* បង្កើតឲ្យបានច្រើនឡើង, សាយ។ *Fig.* ផ្សាយ (ឧ. propager de fausses nouvelles)។

se propager *v.pr.* រាលដាល (*šf.* colporter, diffuser, divulguer, proclamer, publier, révéler)

propédeutique *n.f.* សិក្សាត្រៀម។ *a.* សិក្សាត្រៀម។ année propédeutique ឆ្នាំសិក្សាត្រៀម។ classe propédeutique ការសិក្សាត្រៀម (ដំណាក់សាស្ត្រាចារ្យ)។ cours propédeutique សិក្ខាប័ទសិក្សាត្រៀម

propension *n.f.* ឧបនិស្ស័យ (ដំណើរលំអៀងឬបែរទៅរកកន្លែងណាមួយ)។ *Fig.* សេចក្ដីលំអៀង (ឧ. propension au bien)

propharmacien,enne *a.&n.* ឧ-ភេសជការី

prophète,prophétesse *n.* ព្យាការី-ការិនី; អ្នកទាយ (ឧ. le prophète Isaïe)។

Loc. adv. le Roi Prophète ព្រះចៅដាវីដ (មហាក្សត្រប្រទេសអ៊ីស្រាអែលសម័យមុនព្រះយេស៊ូគ្រិស្ត)។ *Absol.* le Prophète មហាម៉ាត់។ faux prophète អ្នកទាយក្លែង; អ្នកទាយខុស (ទាយមិន

ក្រើ) ។ prophète de malheur អ្នកទាយតែរឿងទុក្ខ ឬ រឿងអាក្រក់ ។ chapeau de prophète មួកគ្រូប ។ la loi et les prophètes ក្បួនច្បាប់អ៊ីស្រាអែលនឹងទំនាយ; *au fig.* voici la loi et les prophètes របស់នេះទុកជាគ្រូ ។ être prophète comme une vache មិនយល់អ្វីសោះ (មិនចេះទាយឬស្មានសោះ) ។

Prov. nul n'est prophète dans son pays តាមធម្មតា គេមិនសូវទទួលស្គាល់កិត្តិនាមនៃមនុស្សនៅក្នុងស្រុកឯងទេ

prophétie *n.f.* ព្យាករណ៍; ទំនាយ (ឧ. ses prophéties se sont trouvées démenties)

prophétique *a.* នៃអ្នកទាយ, នៃទំនាយ (ឧ. langage prophétique); ដែលចេះទាយ

prophétiquement *adv.* ជាអ្នកទាយ

prophétiser *v.t.* ព្យាករ, ទាយ (ឧ. prophétiser un événement)

prophylactique *a. Méd.* សម្រាប់បង្ការរោគ (ឧ. mesures prophylactiques)

prophylaxie *n.f.* រោគនិវារណ៍; វិធីបង្ការរោគ (ឧ. Pasteur fit progresser la prophylaxie)

propice *a.* ដែលបើអនុគ្រោះ, ល្អ (ឧ. circonstances propices à une entreprise) (ត.ផ. contraire, défavorable, néfaste)

proportion *n.f.* សមាមាត្រ (ឧ. observer les proportions) ។ *pl.* ខ្នាត (ឧ. cela sort des proportions ordinaires); ទំហំ (ឧ. ce désastre a pris des proportions considérables) ។

Loc. adv. à proportion ឬ en proportion ជាសមាមាត្រ, ទៀសមតាមមាត្រ ឬ តាមចំនួន ។ à proportion de ឬ en proportion de ឬ avec *loc. pré.* ដោយប្រៀបធៀបនឹង, ដោយយល់ដល់ (ឧ. la valeur morale de l'homme est en proportion de sa faculté d'admirer) ។ à proportion que *loc.conj.* ក្នុងលំដាប់ដែល (ឧ. on n'est curieux qu'à proportion qu'on est instruit) ។ proportion ឬ toute

proportion gardée ដោយគិតតាមសមាមាត្រ

proportionnaliste *n.&a. Pol. & Sociol.* សមាមាត្រនិយម(ដែលនិយមឲ្យមានតំណាងជាសមាមាត្រក្នុងការបោះឆ្នោត)

proportionnalité *n.f.* សមាមាត្រភាព (ព.ធ. progressivité)

proportionné,e *a.* ត្រូវ, ដែលមានសមាមាត្រ, សមមាត្រ (ឧ. corps bien proportionné)

proportionnel,elle *a.* ជាសមាមាត្រ។ *Math.* moyenne proportionnelle មធ្យមសមាមាត្រ។ quatrième proportionnelle ចតុត្ថសមាមាត្រ

proportionnellement *adv.* ដោយសមាមាត្រ, ដោយប្រៀបធៀប

proportionner *v.t.* ធ្វើឲ្យមានសមាមាត្រ; ថែឲ្យសម (ឧ. proportionner vos dépenses à vos ressources)

propos *n.m.* ការគិតបម្រុង; សេចក្តីសម្រេច (ឧ. se confesser ses péchés avec un ferme propos de n'y plus retomber)។ de propos délibéré ដោយចេតនា, ដោយសំរៀង ។

បំណង, គំនិត (ឧ. suivons notre propos) ។ mettre sur le propos de បំបែរគំនិតទៅរក ។

សំដីសន្ទនា (ឧ. tenir de joyeux propos); ការនិយាយដើម (និយាយអាក្រក់) (ឧ. tenir des propos sur quelqu'un) ។ propos interrompus ការសន្ទនាពីនេះពីនោះ ។ *Fig.* jouer aux propos interrompus ស្តាប់គ្នាមិនបានសោះ ។

Loc. div. à propos ត្រូវកាល, ត្រូវពេលវេលា (ឧ. tout le secret de la politique consiste à mentir à propos) (Mme de Pompadour) ។ à propos de ទៅនឹករស, ចំពោះរឿង (ឧ. s'égorger à propos d'un arpent de terre) ។ à tout propos រាល់ពេល, ជារឿយៗ ។ à quel propos ឬ à propos de quoi ចំពោះហេតុ ឬ រឿងអ្វី ។ à ce propos ចំពោះរឿងនេះ។ juger à propos de យល់ថាគួរតែ

(ឧ. je juge à propos de n'en rien dire) ។ hors de propos ក្រៅរឿង (ឧ. vous m'interrompez par des histoires hors de propos) ។ mal à propos ដោយខុសកាល, ដោយឥតហេតុ (ឧ. se fâcher mal à propos) ។ à propos de rien ដោយហេតុបន្តិចបន្តួច

proposable *a.* គួរស្នើបាន (ឧ. arrangement proposable)

proposer *v.t.* ដាក់ចំពោះមុខ (ឧ. voilà les véritables spectateurs que nous devons nous proposer); ស្នើ (ឧ. proposer un amendement); បង្ហាញជាគំរូ ។

v.i. ប្រាថ្នា ។

Prov. l'homme propose et Dieu dispose មនុស្សប្រាថ្នាតែការសម្រេចនៅលើភគវា (ជួនកាលការងារដែលយើងធ្វើ មិនបានសម្រេចតាមសេចក្ដីប្រាថ្នារបស់យើងឡើយ) ។

se proposer *v.pr.* មានបំណង, បម្រុងនឹង (ឧ. se proposer de passer l'été à Boko); ប្រាថ្នា, មានគោលបំណង (ឧ. se proposer le bien de l'Etat); សុំធ្វើ (ឧ. se proposer comme chauffeur)

proposition *n.f.* សេចក្ដីស្នើ, សំណើ (ឧ. faire une proposition à une assemblée); សេចក្ដីអះអាង (ឧ. presque toutes les propositions sont à la fois vraies et fausses); ការសុំ (ពេលសុំធ្វើការជាដើម) ។

proposition de loi សេចក្ដីស្នើច្បាប់ ។ sur la proposition de តាមសេចក្ដីស្នើនៃ ។ pour étude et proposition ម.ព. étude ។

Gram. វាក្យសម្ពន្ធ

propre *a.* ដោយឡែក, ចំពោះខ្លួន, ផ្ទាល់ខ្លួន (ឧ. chaque être a ses caractères propres); ឯង(ជារបស់ខ្លួន) (ឧ. écrire de sa propre main សរសេរដោយដៃឯង; avoir vu de ses propres yeux បានឃើញនឹងភ្នែកឯង; voici ses propres paroles នេះគឺសំដីគាត់ (ដែលនិយាយខ្លួនឯង); សម្រាប់ (ឧ.

bois propre à la construction)។ propre à ប្រសប់ខាង (ឧ. homme propre aux affaires) ។

Par ext. ស្អាត (ឧ. habit propre)។ *Fig.* ស្អាត, បរិសុទ្ធ (ឧ. homme dont la conduite n'est pas propre)។

Loc. div. nom propre ម.ព. nom។ sens propre ម.ព. sens ។ terme propre សព្ទត្រូវប្រាំ។ en main propre ផ្ទាល់ដៃ (ឧ. remettre en main propre)។

Prov. qui est propre à tout n'est propre à rien ប៉ះនេះប៉ះនោះមិនខ្លះត្រង់ណា (អ្នកប៉ះប្រើនមុខពោកពុំអាចជំនាញក្នុងវិជ្ជាណាមួយឡើយ) ។

n.m. លក្ខណៈពិសេស (ឧ. l'admiration est le propre des grandes âmes (Montesquieu) ។ en propre ជាទ្រព្យផ្ទាល់ខ្លួន (ឧ. posséder en propre une ferme)។ propre à rien មនុស្សមិនបានការអ្វីសោះ ។ អ្វីៗដែលស្អាត (ឧ. le propre ne l'est jamais trop) ។

n.m. pl. Dr. propres (ឬ biens propres) ទ្រព្យដើម (ទ្រព្យផ្ទាល់របស់ស្វាមីឬភរិយា)(ឧ. dans le régime de la communauté légale, les immeubles apportés par les époux sont des propres)

proprement *adv.* ដោយពិត, ដោយឡែក (ឧ.voilà proprement ce qu'il a dit)។ proprement dit,e មែនទែន (ឧ. l'Angleterre proprement dite)។ *Fig.* យ៉ាងស្អាត (ឧ. manger proprement); ដោយសមគួរ, ដោយសមរម្យ (ឧ. mis proprement)

propret,ette *a.* ស្អាតបាត (ស្អាតហើយល្អផង) (ឧ. une petite chambre proprette)

propreté *n.f.* ភាពស្អាត (ឧ. la propreté du corps) (សរ. netteté ។ ព.ផ. crasse, malpropreté, saleté)

propriétaire *n.* កម្មសិទ្ធិករ, អ្នកមានកម្មសិទ្ធិ, ម្ចាស់កម្មសិទ្ធិ

propriété *n.f.* កម្មសិទ្ធិ(ឧ.propriété foncière; propriété mobilière)។ *Spécial.* របស់ជាកម្មសិទ្ធិ; អសង្ហារិម, អចលនទ្រព្យ (ឧ. une propriété bien entretenue); គុណភាព (ឧ. propriété de l'aimant)។

Gram. ន័យចំ, ន័យត្រូវ (ឧ. la propriété des termes)។

propriété artistique et littéraire កម្មសិទ្ធិខាងសិល្បៈនិងអក្សរសាស្ត្រ(សិទ្ធិផាច់មុខនៃសិល្បករឬអ្នកនិពន្ធព្រមទាំងទាយាទរបស់ខ្លួនត្រូវទទួលគុណប្រយោជន៍អំពីស្នាដៃខ្លួន)។ propriété commerciale ពាណិជ្ជកម្មសិទ្ធិ (សិទ្ធិរបស់អ្នកជំនួញត្រូវបានបន្តកិច្ចសន្យាជួលផ្ទះឬបានបំណាច់ការណ្ដេញចេញ)។ propriété industrielle ឧស្សាហកម្មសិទ្ធិ (សិទ្ធិផាច់មុខខាងទាញយកផលអំពីម៉ាកោ, ម៉ាក, ប្រកាសនីយប័ត្រ ។ល។)

propulser *v.t.* ធ្វើឲ្យទៅមុខៗ, រុញឬច្រានទៅមុខៗ

propulseur *n.m. Méc.* ប្រដាប់រុញ ឬ ច្រានទៅមុខៗ (ដូចយ៉ាងស្លាបបក្រ កាងើត)។

a. ដែលរុញទៅមុខៗ

propulsif,ive *a.* សម្រាប់រុញ ឬ ច្រានទៅមុខៗ (ឧ. fusée propulsive)

propulsion *n.f.* ការរុញឬច្រានទៅមុខៗ (ឧ. la propulsion par réaction)

propylée *n.m.* ខ្លោងទ្វារធំ

prorata *n.m. inv.* ចំណែកឬភាគជាសមាមាត្រ (ឧ. recevoir son prorata)។

au prorata *loc. adv.* ឬ au prorata de *loc. pré.* ជាសមាមាត្រ (ឧ. percevoir des bénéfices au prorata de sa mise de fonds)

prorogatif,ive *a.* ដែលពន្យារ (ឧ. acte prorogatif)

prorogation *n.f.* ការពន្យារ

proroger *v.t.* ពន្យារ (ឧ. proroger une échéance)។ *Par ext.* បន្ត (ឧ. proroger un traité)។ prorogé par... ដែលត្រូវដាក់ឲ្យអនុវត្តបន្តដោយ...

prosaïque *a.* ដូចពាក្យរាយពេក (ឧ. vers prosaïques)។ *Fig.* មិនថ្លៃថ្នូរ; គ្មានឧត្តមគតិ (ឧ. une vie

prosaïque)

prosaïquement *adv.* ដោយមិនថ្លៃថ្នូរ, ដោយគ្មានឧត្តមគតិ (ឧ. vivre très prosaïquement)

prosaïsme *n.m.* លំនាំរំណរកាព្យគ្មានលក្ខណៈជាករីនិពន្ធ ។ *Fig.* ភាពសាមញ្ញ; ភាពមិនថ្លៃថ្នូរ ឬគ្មានឧត្តមគតិ (ឧ. le prosaïsme de certaines existences)

prosateur *n.m.* អ្នកនិពន្ធជាពាក្យរាយ (ឧ. Bossuet est le plus grand prosateur du XVIIe s.)

proscripteur *n.m.* អ្នកបំបរបង់ (ឧ. tous les temps et tous les régimes ont eu des proscripteurs)

proscription *n.f. Ant. rom.* ការសម្លាប់ដោយគិតជំនុំជម្រះ; ការដាក់ក្រៅច្បាប់; ការបំបរបង់ (ឧ. toutes les lois de proscription sont des lois essentiellement révolutionnaires (E. de Girardin) ។

Fig. បដិសេធ, ការហាម, ការលុបចោល (ឧ. la proscription d'un usage)

proscrire *v.t.* សម្លាប់ដោយគិតជំនុំជម្រះ (តាមទម្លាប់ជនជាតិរ៉ូម៉ាំង) (ឧ. Sulla proscrivit trois ou quatre mille citoyens) ។

Par ext. ធ្វើឃាត, សម្លាប់ (ឧ. Mais il pense proscrire un prince sans appui (Racine); បំបរបង់ (ឧ. il fut proscrit de sa patrie) ។

Par ext. & fam. បដិសេធ, បណ្ដេញចេញ (ឧ. proscrire quelqu'un de sa société) ។ *Fig.* បដិសេធ, ហាមមិនឲ្យប្រើ, លុបចោល (ឧ. proscrire un mot)

(ផ្ទ. bannir, exclure, exiler)

proscrit,e *n.* អ្នកត្រូវទោសប្រហារជីវិត; អ្នកត្រូវបំបរបង់ (ឧ. la mort des poscrits était suivie de la confiscation de leurs biens) ។

Loc. div. figure ឬ mine de proscrit មុខដូចគេយកទៅសម្លាប់; មុខមិនគួរឲ្យគេចូលចិត្តសោះ ។ avoir un jeu ឬ des dés de proscrit លេងស៊ៀតខូច ។

a. ដែលត្រូវហាមឃាត់ ឬ ត្រូវ

បដិសេធ

prose *n.f.* ពាក្យរាយ (ផ្ទុយនឹងពាក្យកាព្យ) (ឧ. la belle prose est comme un fleuve majestueux qui roule ses eaux (Montesquieu) ។ prose rythmée ពាក្យកម្រង,រ៉ៃយកែ (ពាក្យរាយដែលមានលំនាំជួនគ្នាម្ដងៗ) ។ *Fam.* សំដី; សំព្រូ (ឧ. je n'ai cure de votre prose)

prosodie *n.f.* ឆន្ទវិទ្យា

prosodique *a.* នៃឆន្ទវិទ្យា

prospecter *v.t.* រកអណ្ដូងរ៉ែ ។ *Par ext.* ពិនិត្យដោយហ្មត់ចត់ ។ *Fig.* រករៀបផ្សាយដំណឹង

prospecteur *n.m.* ប្រូសេ [ប៉ុ-ប៉េ–] អ្នករកអណ្ដូងរ៉ែ

prospectif,ive *a.* សម្រាប់អនាគត(ឧ. on a donc inventé la critique d'avenir, la critique prospective) (Th. Gautier)

prospection *n.f.* ប្រូសេនា [ប៉ុ-ប៉េ-សេះ-ទាំ], ការរកអណ្ដូងរ៉ែ ។ *Com.* ការរកបញ្ជោរបាយបង្កើនអតិថិជន

prospectus *n.m.* *Proprem.* ការឃើញអនាគត ។ *Com.* បរិយាយបណ្ណ (លិខិតផ្សាយប្រាប់គោលរឿងនិពន្ធឬដំណើរអ្វីមួយ)

prospère *a.* ចម្រើន, រុងរឿង, ថ្កុំថ្កើង (ឧ. maison prospère)

prospérer *v.i.* បានរុងរឿង, បានចម្រើន,បានថ្កុំថ្កើង (ឧ. son commerce prospère)

prospérité *n.f.* វិបុលភាព, ភាពរុងរឿងឬថ្កុំថ្កើង, ភាពចម្រើន (ឧ. période de prospérité)

prosternation *n.f.* ឬ **prosternement** *n.m.* ការក្រាបថ្វាយបង្គំ;ការឱនលំទោន

prosterner *v.t.* ធ្វើឲ្យក្រាបថ្វាយបង្គំ (ឧ. le repentir prosterne le coupable) ។

se prosterner *v.pr.* ក្រាបថ្វាយបង្គំ (ឧ. se prosterner devant l'autel) ។ *Fig.* ឱនលំទោន. (ឧ. se prosterner devant les puissants)

prostituée *n.f.* ស្ត្រីពេស្យា (ស្ត្រីខូច) ,

prostituer *v.t.* នាំធ្វើជាស្ត្រីពេស្យា ។ *Fig.* បន្ថោក (ឧ. prostituer son talent)

prostitution *n.f.* ពេស្យាចារ, ការ

ធ្វើជាស្ត្រីពេស្យា ។ *Fig.* ការបន្ទាប ឬ បន្ថោក

prostration *n.f.* ការក្រាបបង្គំ (ឧ: les génuflexions, les prostrations et les autres actions et cérémonies extérieures (Bossuet) ។ *Fig.* ភាពអស់ខ្លាំងណាស់(កម្លាំង) (ឧ.la prostration des forces)

prostré,e *a.* អស់កម្លាំងណាស់

protagoniste *n.m.* តួឯក ។ *Fig.* ប្រធានគំនិត, អ្នកនាំមុខ (ឧ.c'est le protagoniste de l'affaire)

protecteur,trice *n.* ឧបត្ថម្ភកៈ-ម្ភិកា, អ្នកឧបត្ថម្ភ, អ្នកការពារ (ឧ.un protecteur des pauvres) ។

a. សម្រាប់ឧបត្ថម្ភ, សម្រាប់ការពារ (ឧ. muraille, puissance protectrice); នៃអ្នកឧបត្ថម្ភ; កោង, ឡើត (ឧ. air protecteur)

protection *n.f.* ឧបត្ថម្ភ, ការការពារ, ការគាំពារ (ឧ.solliciter la protection de quelqu'un); អ្នកឧបត្ថម្ភ (ឧ. arriver par les protections) ។

protection sanitaire de la mère et de l'enfant ការរក្សាសុខភាពមាតានិងកុមារ ។ prendre la protection ឧបត្ថម្ភ ឬ ការពារ ។ prendre sous sa protection ឬ en sa protection ម.ព. prendre ។ prendre un air de protection ធ្វើឫកធំ, ធ្វើឫកឡើត (សទិ. aide, appui, défense, garantie, secours ។ ព.ផ. oppression, tyrannie, hostilité)

protectionnisme *n.m.* ឧបត្ថម្ភនិយម [ភ្រ៊ុ-ត៉ិក-ស៊ិម-ភ:-],(លទ្ធិនិយមឧបត្ថម្ភកសិកម្ម ពាណិជ្ជកម្ម ឬ ឧស្សាហកម្មនៃប្រទេសមួយ ប្រឆាំងនឹងការប្រជែងពីបរទេស ដោយវិធានការផ្សេងៗ មានកម្រិតការនាំចូល ជ្រោមជ្រែងការនាំចេញនិងត្រួតត្រាការផ្លាស់ប្តូររូបិយវត្ថុជាដើម) (ព.ផ. libre-échange)

protectionniste *a.* ឧបត្ថម្ភនិយម ។ *n.m.* អ្នកឧបត្ថម្ភនិយម

protectorat *n.m. Pol.* មុខងារនៃឧបត្ថម្ភកៈ (ឧ. le protectorat de Cromwell); របបការពារអាណាព្យាបាល; រដ្ឋក្នុងអាណាព្យាបាល (ឧ. la Tu-

nisie et le Maroc ont été des protectorats français)

protée *n.m.* ជនដែលផ្លាស់របៀប ឬ ផ្លាស់មតិមិនឈប់ឈរ

protégé,e *n.* ជននៅក្នុងឧបត្ថម្ភ (ឧ. les protégés du ministre)

protéger *v.t.* ឧបត្ថម្ភ, ទំនុកបម្រុង (ឧ. protéger les faibles; protéger un candidat); ការពារ (ឧ. des forts nombreux protégeaient Paris) ។

se protéger *v.pr.* ការពារឬទំនុកបម្រុងគ្នាទៅវិញទៅមក (ឧ. Etats amis et alliés qui s'engagent à se protéger réciproquement)

(ស៊ី. défendre, garantir, immuniser, préserver ។ ព.ផ. agresser, assaillir, attaquer)

protestable *a. Dr.* អាចធ្វើវិរុទ្ធភាពបាន, អាចតវ៉ាឬប្រកែកបាន (ឧ. effet protestable)

protestant,e *n.* អ្នកកាន់សាសនាប្រូតេស្តង់ ។ *a.* ប្រូតេស្តង់ (ឧ. religion protestante)

protestantisme *n.m.* សាសនាប្រូតេស្តង់

Prov. ta chemise ne sache ta guise ត្រូវបិទលាក់គំនិតខ្លួនកុំឲ្យអ្នកដទៃដឹង ។ ce que trois personnes savent est public អ្វីដែលមានបីនាក់ដឹង លែងស្ងាត់ហើយ ។

v.i. ចេះ, មានពិសោធន៍ (ឧ. si jeunesse savait); ដឹងច្បាស់ (ឧ. si je savais, je ...) ។

savoir *n.m.* វិជ្ជា, ចំណេះ (ឧ. homme de grand savoir) (មើ. culture, érudition, instruction)

savoir-faire *n.m.* ការប៉ិនប្រសប់

savoir-vivre *n.m.* សុជីវធម៌,សុជីវភាព (ឧ. les règles du savoir-vivre)

savoisien,enne *a.&n.* ប.ក. savoyard

savon *n.m.* សាប៊ូ; ដុំសាប៊ូ; ការលាងដោយសាប៊ូ(ឧ. donner un savon à du linge) ។ *Fig. & Fam.* ការជេរស្តី (ឧ. passer un savon à quelqu'un)

savonnage *n.m.* ការដុសសាប៊ូ

savonner *v.t.* ដុសសាប៊ូ ; លាបពពុះសាប៊ូ ។ *Fig.&Fam.* ជេរស្តី ។

se savonner *v.pr.* ដុសសាប៊ូខ្លួនឯង

savonnerie *n.f.* ការធ្វើសាប៊ូ; កន្លែងធ្វើសាប៊ូ

savonnette *n.f.* សាប៊ូក្រអូប ។ montre à savonnette នាឡិកាមានគម្របពុចបើក

savonneux,euse *a.* ដែលមានសាប៊ូ (ឧ. eau savonneuse); នៃជាតិសាប៊ូ; រអិលដូចសាប៊ូ (ឧ. argile savonneuse)

savonnier, ère *a.* សាប៊ូ (នៃសាប៊ូ; នៃការធ្វើសាប៊ូ; នៃជំនួញសាប៊ូ) (ឧ. industrie savonnière; marchand savonnier) ។

n.m. អ្នកធ្វើសាប៊ូ

savourer *v.t.* ព្រាបរសជាតិ (ឧ. savourer une tasse de café) ។ *Fig.* ត្រេកអរ (ឧ. savourer les honneurs)

savoureusement *adv.* ដោយព្រាបរសជាតិ; ដោយមានឱជារស

savoureux,euse *a.* ដែលមានឱជារស (ឧ. mets très savoureux) ។ *Fig.* គាប់ប្រសើរ(ឧ.plaisanterie

savoureuse)

savoyard,e *a.&n.* នៃប្រទេសសាវ័រ

saxatile *a.* សិលាស្រ័យ, ដែលដុះ ឬរស់នៅលើថ្ម(ឧ.fleurs saxatiles)

saxicole *a.* សិលាស្រ័យ, ដែលរស់នៅ ឬ ដុះលើថ្ម (ឧ. plante saxicole)

saxon,onne *a.&n.* នៃប្រទេសស័ក្ស

saxophone *n.m.* ស័ក្សូហ្វូន (ត្រែម្យ៉ាង)

saynète *n.f.* ឆាកកំប្លែង

sbire *n.m.* *Péjor.* ប៉ូលីស (ភ្នាក់ងារប៉ូលីស)

scabieux,euse *a.* ដូចកម (ឧ. éruption scabieuse)

scabreux,euse *a.* រដិបរដុប (ឧ. chemin scabreux)។ *Par ext.* ទ្រគោះ(ឧ. un style scabreux); ប្រកបដោយគ្រោះថ្នាក់ (ឧ. entreprise scabreuse) ; ដែលឆ្ងល់ (ឧ. question scabreuse); អាសគ្រាម (ឧ. conte scabreux)

scalène *a.Math.* triangle scalène ត្រីកោណវិសមបាត(មិនស្មើជ្រុង)

scalp *n.m.* សក់ជាប់នឹងស្បែកក្បាល (ដែលជនស្បែកក្រហមនៃទ្វីបអាមេរិកឧទ្ធរយកពីសត្រូវដែលគេសម្លាប់បាន)

scalpel *n.m.* កាំបិតវះកាត់

scalper *v.t.* បកស្បែកលលាដ៍ក្បាល

scandale *n.m.* *Relig.* ទាកាសធ្វើជាបកម្មឬធ្វើកំហុស (ឧ. malheur à ceux par qui le scandale arrive !) ។ *Par ext.* រឿងអាស្រូវ

scandaleusement *adv.* យ៉ាងអាស្រូវ (ឧ. vivre scandaleusement); យ៉ាងអាក្រក់ក្រៃលែង (ឧ. être scandaleusement riche)

scandaleux,euse *a.* អាស្រូវ (ឧ. conduite scandaleuse)

scandaliser *v.t.* នាំឲ្យប្រព្រឹត្តកំហុស (ឧ. scandaliser un enfant par ses exemples) ; នាំឲ្យអាស្រូវ,នាំឲ្យគេខឹង (ឧ. sa conduite scandalise tout le monde) ។

se scandaliser *v.pr.* ខឹង, ទាស់ចិត្ត (*វ៉ា.* blesser, choquer, froisser, indigner, offenser)

scander *v.t.* សូត្រកាប់ព្យាង្គកាព្យ ។ *Par ext.* សង្កត់ពាក្យ (ឧ. scander certains passages d'un discours)

scandinave *a. & n.* នៃប្រទេសស្កង់ឌីណាវី

scansion *n.f.* ការ ឬ របៀបសូត្ររាប់ព្យាង្គកាព្យ

scaphandre *n.m.* ស្រោមពាក់មុជទឹក

scaphandrier *n.m.* អ្នកមុជទឹកដោយប្រើស្រោមម្យ៉ាង

scarabée *n.m.* កំភេម-កំពោង ឬកញ្ចែ

scarification *n.f.* ការឆូតស្បែក

scarifier *v.t.* ឆូតឲ្យមុត (ឧ. scarifier la peau)

scarlatine *n.f.* អុតក្ដាម

scarlatiniforme *a.* ដូចអុតក្ដាម

scatophile *a.* ដែលចូលចិត្តលាមក (ដែលរស់នៅឬដុះលើលាមក)

scatologie *n.f.* សំដីលាមក

sceau,scel *n.m.* ត្រា (ឧ. le sceau de l'Etat): ការបោះត្រា (ឧ. pièce soumise au sceau); មុខងារអ្នកកាន់ត្រា (ឧ. donner le sceau à quelqu'un ឲ្យអ្នកណាម្នាក់កាន់ត្រា) ។ *Fig.* លក្ខណៈប្លែក (ឧ. cet ouvrage porte le sceau du génie) ។ sceau commun ត្រាសាទិស (ត្រាដែលមានរូបស្រដៀងគ្នា) ។ confier quelque chose sous le sceau du secret ប្រាប់រឿងអ្វីមួយលុះត្រាតែបេះលាក់ការសម្ងាត់

scélérat,e *a.* ដែលជាប់បទឧក្រិដ្ឋ; មិនខកនឹងប្រព្រឹត្តបទឧក្រិដ្ឋ; ដែលជាបទឧក្រិដ្ឋ (ឧ. actes scélérats); ដ៏លាមក (ឧ. conduite scélérate) ។

n. លាមកជន, អ្នកបានប្រព្រឹត្តបទឧក្រិដ្ឋ, អ្នកហ៊ានប្រព្រឹត្តបទឧក្រិដ្ឋ។ *Par ext.* វិល (ពាក្យចំអន់សម្រាប់ហៅអ្នកប្រព្រឹត្តកំហុសតិចតួច) (ឧ. petit scélérat)

scélératesse *n.f.* អំពើ ឬ សំដីលាមក

scellage *n.m.* ការបោះត្រា; ការបិទបោះត្រា

scellement *n.m. Technol.* ការបញ្ចុះដុំឈើ ឬ ដុំដែកក្នុងជញ្ជាំង; ភាគនៃសោដែលបញ្ចុះទៅក្នុងជញ្ជាំង

sceller *v.t.* បោះត្រា (ឧ. sceller une lettre; sceller un acte en cire rouge); បិទបោះត្រា (ឧ. sceller la porte d'un logement); បញ្ចុះដុំឈើ ឬ ដុំដែកក្នុងជញ្ជាំង; បិទជិតស្អិត; ភ្ជាប់; ពង្រឹង ។ *Fig.* បញ្ជាក់, យកធ្វើជាបន្ទាល់ (ឧ.

sceller une promesse de son sang)

scellés *n.m.pl.* ផ្លាំងក្រដាស ឬ សំពត់ ភ្ជាប់ដោយអាចម៍ល័ខ មានបោះត្រា

scénario *n.m.* នាដកថា (ការបែកជាឈុត, គ្រោងការនៃរឿង)

scénariste *n.* អ្នកតែងនាដកថា (នៃខ្សែភាពយន្ត)

scène *n.f.* វិការដ្ឋាន (ទីនៃការធ្វើឲ្យប្លែក, កន្លែងនៃការផ្លាស់ប្តូរ) (ឧ. la scène est à Rome); ឆាក (ភនដែលល្ខោនសំដែងរឿង; ភាគនៃឈុត; គំនូរបំពួនមួយសង្កាត់រឿង) (ឧ. changement de scène; troisième scène du premier acte ឆាកទីបីនៃឈុតទីមួយ); សិល្បៈខាងល្ខោន (ឧ. avoir une parfaite connaissance de la scène) ។

Fig ទស្សនីយភាព (ឧ. scène attendrissante); វិការដ្ឋាន, កន្លែង (ឧ. la scène du crime) ។ *Fam.* ការទាំងប្រទេ្បាត, ការឈ្លោះគ្នា (ឧ. faire une scène à quelqu'un) ។ paraître sur la scène ចូលលេងល្ខោន ។ mettre en scène រៀបចំរឿងល្ខោន ឬ ថតភាពយន្ត ។ mettre sur la scène ឬ porter à la scène តែងជារឿង (ល្ខោន ឬ រឿងភាពយន្ត) ។ scène muette រឿងគ្មាននិយាយ (អ្នកលេងធ្វើតែកាយវិការ)

scénique *a.* នៃល្ខោន (ឧ. art scénique; jeu scénique)

scéniquement *adv.* តាមរឿង (ល្ខោន ឬភាពយន្ត)

scénologie *n.f.* សិល្បៈរៀបចំឆាក

scepticisme *n.m.* មន្ទិលជាគុនិយម, ការមិនជឿតាមមតិខ្លួនទៅ (ឧ. accueillir une nouvelle avec scepticisme)

sceptique *n.* & *a.* មន្ទិលជាគុនិយម, ដែលចេះតែសង្ស័យ (ឧ. esprit sceptique) (ហ៊. incrédule, incroyant, irréligieux) ។

sceptiquement *adv.* ដោយចេះតែសង្ស័យ

sceptre *n.m.* រាជទណ្ឌ, ដំបងរាជ្យ (ឧ. le sceptre des rois de France figurait une main) ។ *Fig.* រាជសម្បត្តិ (ឧ. ambitionner le sceptre); ភាពឧត្តម ។ sceptre de fer របបផ្តាច់ការ

schah, shah ឬ **chah** *n.m.* ព្រះចៅសាហ៍ (មហាក្សត្រប្រទេសពែរ្ស)

schako *n.m.* ម.ព. shako

schéma ឬ **schème** *n.m.* ចិត្ររូប, គំនូរបំព្រួញ; គ្រោងសៀវភៅ

schématique *a.* នៃចិត្ររូប, នៃគំនូរបំព្រួញ, ដែលធ្វើដោយគំនូរបំព្រួញ (ឧ. croquis schématique)។ *Par ext.* បំព្រួញបំផុត (ឧ. exposé schématique d'une doctrine)

schématiquement *adv.* ដោយបំព្រួញ

schématiser *v.t.* គូរបំព្រួញ

schématisme *n.m.* ការបំព្រួញ

schérif [ché-] *n.m.* ម.ព. chérif

schilling *n.m.* ស៊ីលីញ(រូបិយវត្ថុប្រទេសអូទ្រីស)

schismatique *a.* & *n.* ដែលប្រព្រឹត្តធម្មភេទ

schisme [chism'] *n.m.* ធម្មភេទ, ដំណើរបែកចេញនៃសាសនា។ *Fam.* ដំណើរបែកមតិ

schiste *n.m.* សុកាដ, ថ្មស្រទាប់

schisteux,euse *a.* ដែលជាសុកាដ

schistoïde *a.* ដូចសុកាដ (ឧ. roche schistoïde)

schistosité *n.f.* ភាពជាស្រទាប់ស្តើងៗ

sciable *a.* អាចអារបាន

sciage *n.m.* ការអារ; ឈើដែលអារហើយ

scialytique *a.* ដែលមិនឲ្យមានស្រមោល (ឧ. lampe scialytique)

scie *n.f.* *Techn.* រណារ ។ trait de scie បន្ទាត់ផ្លូវរណារ ។ *Fam.* មនុស្ស ឬ វត្ថុដែលធ្វើឲ្យគេធុញទ្រាន់ ។ *Zool.* ឆ្លាម

sciemment *adv.* ដោយគិតទុក, ដោយដឹងខ្លួន

science *n.f.* វិទ្យាសាស្ត្រ ។ sciences économiques វិទ្យាសាស្ត្រសេដ្ឋកិច្ច។ sciences expérimentales វិទ្យាសាស្ត្រពិសោធ ។ sciences humaines វិទ្យាសាស្ត្រមនុស្សជាតិ។ sciences naturelles វិទ្យាសាស្ត្រធម្មជាតិ ។ sciences occultes រហស្សវិទ្យាសាស្ត្រ (ម.ព. occulte ផង)។ sciences paramédicales វិទ្យាសាស្ត្រវេជ្ជប្រតិព័ទ្ធ ។ sciences physiques វិទ្យាសាស្ត្ររូបនិយម ។ sciences sociales វិទ្យាសាស្ត្រខាងសង្គម (មានប្រវត្តិសាស្ត្រ, ភូមិសាស្ត្រ, សីលធម៌, លោកនីតិ ។ល។)។

Loc. div. science du

monde វិជ្ជាប្ចូរលោក ។ demi-science វិជ្ជាស្ទាក់ស្ទើរ ឬ វិជ្ជាស្ទើរភ្លើង ។ de sciences certaines ដោយដឹងការណ៍ច្បាស់។avoir plus d'heur que de science ហេងជាងចេះ (បានជោគជ័យដោយភព្វស័ណាងជាងដោយប៉ិនប្រសប់) ។

Prov. science sans conscience n'est que ruine de l'âme វិទ្យាសាស្ត្រឥតសម្បជញ្ញៈនាំឲ្យវិនាសអាត្មន។ expérience passe science ការពិសោធប្រសើរជាងចំណេះទទេ; អ្នកចេះជំប់មិនស្មើនឹងអ្នកប្រសប់មួយ

scientifique *a.* នៃវិទ្យាសាស្ត្រ ។ esprit scientifique គតិវិទ្យាសាស្ត្រ(គុណសម្បត្តិសម្រាប់អ្នកប្រាជ្ញគឺសេចក្តីសុចរិត,សេចក្តីសុភាព,សណ្តាប់ធ្នាប់, ការចេះសង្កេត, ជំនឿលើវិទ្យាសាស្ត្រ ។ល។)

scientifiquement *adv.* តាមរបៀបវិទ្យាសាស្ត្រ

scientisme *n.m.* វិទ្យាសាស្ត្រនិយម

scientiste *a.* វិទ្យាសាស្ត្រនិយម។ *n.* អ្នកវិទ្យាសាស្ត្រនិយម (អ្នកស្រាវជ្រាវក្នុងសាខាមួយនៃវិទ្យាសាស្ត្រ, អ្នកធ្វើការខាងវិទ្យាសាស្ត្រ)

scier *v.t.* អារ ។ scier le dos à quelqu'un ធ្វើឲ្យធុញទ្រាន់ដោយនិយាយស្រំដែល

scierie *n.f.* រោងអារឈើ ។ scierie mécanique រោងម៉ាស៊ីនអារឈើ

scieur *n.&a.m.* អ្នកអារ ។ scieur de long អ្នកអារបណ្តោយ

scieuse *n.f. ind.* រណារយន្ត

scindement *n.m.* ការបែក, ការបំបែក; ភាពបំបែក

scinder *v.t.* បែក, បំបែក (ឧ. scinder une question) ។

se scinder *v.pr.* បែក (ឧ. parti politique qui s'est scindé en deux groupes)

scintillant,e *a.* ភ្លឺផ្លេក

scintillation *n.f.* ឬ**scintillement** *n.m.* ដំណើរភ្លឺផ្លេកៗ; ភាពភ្លឺផ្លេក

scintiller *v.i.* ភ្លឺផ្លេកៗ (ឧ. les étoiles scintillent) (*vi.* briller, éclairer, étinceler)

scion *n.m.* ល្ងាស់; មែកសម្រាប់ផ្សាំ សាប; ពុងដឹងសន្ទូច

sciotte *n.m.* រណារអារថ្ម

scissile *a. Minér.* អាចពុះបាន (ឧ.

roche scissile)

scission *n.f.* ការបាក់បែកគ្នា (ក្នុងសភា ឬក្នុងគណៈបក្សនយោបាយ); ការបែកមតិ (ក្នុងការប្រជុំ)

scissionniste *a.&n.* ដែលរករឿងបំបែកបំបាក់

scissure *n.f.* *Anat.* រន្ធសរីរាង្គ

sciure *n.f.* អាចម៍រណារ (ឧ. sciure de bois)

scléreux,euse *a.* សាញ (ឧ. tissu scléreux)

sclérose *n.f.* ដំណើរឡើងរឹងនៃសាច់

sclérosé,e *a.* ដែលឡើងរឹង

scléroser (se) *v.pr.* ឡើងរឹង (លែងទន់ភ្លន់); លែងប្រែប្រួល (ឧ.se scléroser dans ses habitudes)

sclérotique *n.f.* *Anat.* ទរកោស [ទ:- រ៉:-], ស្រោមរឹងនៃភ្នែក

scolaire *a.* សិក្ខាគារិក, សម្រាប់សិក្សា, នៃសាលា ។ âge scolaire អាយុសិក្សា ។ année scolaire ឆ្នាំសិក្សា ។ livret scolaire ម.ព. livret ។ *n.m.* សៀវភៅសិក្សា

scolarisation *n.m.* សិក្សាក្នុងសាលា, ការបង្រៀនក្នុងសាលា; ការទៅកាន់សាលារៀន

scolarité *n.f.* សិក្ខាគារិកភាព; រយៈពេលសិក្សា

scolastique *a.* តាមរបៀបសិក្សាក្នុងសាលា (ឧ. enseignement scolastique) ; នៃរបៀបសិក្សាយុគកណ្ដាល (ឧ. la philosophie de Descartes rompt avec la tradition scolastique) ។ *n.f.* សិក្សាទស្សនវិជ្ជានាយុគកណ្ដាល

scoliose *n.f.* ដំណើរវៀចឆ្អឹងខ្នង

scolopendre *n.f.* *Zool.* ក្អែប

scooter [scou-teur] *n.m.* ស្កូទ័រ (ទោចក្រយានយន្តម៉្យាង)

scootériste *n.* អ្នកជិះស្កូទ័រ

scorbut *n.m.* រាក់ធ្មេញ

scorbutique *a.* នៃរាក់ធ្មេញ (ឧ. affection scorbutique) ។ *n.* អ្នកកើតរាក់ធ្មេញ

score *n.m.* ចំនួនពិន្ទុ (នៃអ្នកប្រកួតនិមួយៗ ឬ ក្រុមនិមួយៗក្នុងកីឡា)

scorie *n.f.* *Ind.* អាចម៍លោហធាតុរលាយ

scorpion *n.m.* ខ្ទួយ, ខ្យាដំរី ។ *Astr.* វិច្ឆិករាសី ឬ ព្រឹស្ចិករាសី

scout *n.m.* ម.ព boy-scout ។ *a.*

នៃកាយរឹទ្ធ (ឧ.fraternité scoute)

scout-car *n.m.* ឡានចរ, រថមើលការជាមុន

scoutisme *n.m.* អង្គការកាយរឹទ្ធ

scraper [-peur] *n.m.* *Trav. publ.* ម.ព. décapeuse

scribe *n.m.* អ្នកចម្លង

scribouillard *n.m.* *Fam.* &*Péj.* ស្មៀនស្មេរ

scripteur *n.m.* អ្នកសរសេរ

scrupule *n.m.* អាសង្កា, ការនឹករអែង (ឧ.avoir des scrupules); ការធ្វើអ្វីដោយហ្មត់ចត់ ។ avoir scrupule ញញើត ។ se faire un scrupule de quelque chose មិនសូវហ៊ានធ្វើដោយខ្លាចឃ្លាតច្បាប់

scrupuleusement *adv.* ដោយពិតល្អិត, យ៉ាងហ្មត់ចត់ (ឧ. compte scrupuleusement exact)

scrupuleux,euse *a.* ដែលមានអាសង្កា (ឧ. conscience scrupuleuse) ។ *Fig.* ហ្មត់ចត់ (ឧ. apporter une attention scrupuleuse)

scrutateur *a.* ដែលពិនិត្យពិច័យ, (ឧ. regard scrutateur) ។ *n.m.* អ្នកពិនិត្យពិច័យ; អ្នកពិនិត្យសន្លឹកឆ្នោត

scruter *v.t.* ពិនិត្យពិច័យ; រិះរក; ស្ទង់ (ឧ. scruter les intentions de quelqu'un) (ម.ស. examiner, sonder)

scrutin *n.m.* ការបោះឆ្នោត (ឧ. dépouiller le scrutin)

sculpté,e *a.* ឆ្លាក់ (ឧ. bois sculpté)

sculpter *v.t.* ឆ្លាក់ (ឧ. sculpter du marbre)

sculpteur *n.m.* ជាងចម្លាក់

sculptural,e,aux *a.* ខាងចម្លាក់ (ឧ. art sculptural); គួរឆ្លាក់ទុក (ឧ. beauté sculpturale)

sculpture *n.f.* ចម្លាក់ (ឧ. la sculpture grecque); រូបចម្លាក់ (ឧ. une belle sculpture)

scutiforme *a.* ជារាងខែល

se *pr. pers.* ខ្លួនឯង

séance *n.f.* សម័យប្រជុំ, ពេលប្រជុំ; ការប្រជុំ (ឧ. ouvrir, suspendre, lever la séance); សិទ្ធិចូលប្រជុំ ។ *Par ext.* ពេលអង្គុយឲ្យគេគូរ (ឧ. faire un portrait en trois séances) ។ *Fig.* séance plénière ការប្រជុំពេញអង្គ ។

séance tenante ក្នុងពេលប្រជុំ, ភ្លាមៗ, មិនចាំពេលក្រោយ

séant,e *a.* ដែលនៅ (ក្នុងបច្ចុប្បន្នកាល); សមរម្យ (ឧ. il n'est pas séant à votre âge de...) ។

n.m. être ឬ se mettre sur son séant អង្គុយ ។ *Pop.* គូទ

S.E.A.P. Games (ពាក្យបំព្រួញនៃ South East Asia Peninsula Games ល្បែង (កីឡា) នៅឧបទ្វីបអាស៊ីទិសអាគ្នេយ៍)

S.E.A.T.O. (South East Asia Traity Organization) ម.ព. O.T.A.S.E.

seau *n.m.* ធុង, ពើង (សម្រាប់ដាក់ទឹក)។ *Fam.* il pleut à seaux ភ្លៀងដូចគេចាក់ទឹក

sébacé,e *a.* រំសា, ដូចខ្លាញ់ ។ glande sébacée ម.ព. glande

sébile *n.f.* ត្បាក់, កាដិនឈើ (ឧ. la sébile d'un aveugle)

sec,sèche *a.* ស្ងួត (ឧ. terrain sec); ក្រៀម (ឧ. noix sèche) ។ *Par ext.* ស្គម (ឧ. homme grand et sec); ឥតឈាមទឹក ។ *Fig.* ស្ងួត, គ្មានលំអ, សោះកក្រោះ, គ្មានកំប្លុកកំប្លែង (ឧ. style sec); កំបុតកំបុយ, គគ្រោះគគ្រើល (ឧ. refus tout sec); សោះអង្គើយ, មិនរាក់ទាក់ (ឧ. manières sèches); ឥតមេត្តា (ឧ. cœur sec) ។ *Pop.* ស្លាប់ ។

Loc. pop. il fait sec មានគ្រោះថ្នាក់ ។ consultation sèche ការពិគ្រោះជម្ងឺទទេ (ឥតយកថ្លៃ) ។ *Arg. scol* rester sec នៅស្ងៀម (ទាល់, មិនចេះ, មិនដឹងជាដូចម្ដេច) ។

Loc. div. Fig. fruit sec ក្មេងត្រក (ក្មេងដែលឈប់រៀនដោយរៀនមិនចេះ) ។ coup sec ការវាយយ៉ាងរហ័ស (វាយរួចដកដៃភ្លាម)។ bruit sec សូរស្រួយ។ argent sec ប្រាក់ដល់ដៃ។ argent liquide et sec ទឹកប្រាក់ដល់ដៃ (សងជាប្រាក់ភ្លាមៗ)។ œil sec ភ្នែកស្ងួត (គ្មានទឹកភ្នែក); *au fig.* ភាពឥតមេត្តា, ភាពព្រងើយកន្តើយ (ឧ. regarder d'un œil sec les maux d'autrui សម្លឹងមើលអ្នកដទៃដោយព្រងើយកន្តើយ) ។ orage sec ព្យុះគ្មានភ្លៀង ។ *Fig. & Fam.* perte sèche ម.ព. perte ។ sec comme une

allumette ស្ងួតក្រោះ (ធម្មតាឈើគូសតែសើមគូសមិនឆេះទេ)។ à pied sec ដោយឥតទទឹកជើង (ឧ. passer une rivière à pied sec ឆ្លងស្ទឹងដោយឥតទទឹកជើង (ឆ្លងនៅពេលស្ទឹងរីងស្ងួត)។ *Fig.* tout sec ទទេ, តែប៉ុណ្ណឹង (ដោយគ្មានបន្ថែមអ្វីទៀត) (ឧ. un merci tout sec)។ pain sec នំប៉័ងទទេ។ être sec comme un pendu ស្គមកំប្រេវ, ស្គមខ្សល់បករលំ ។ avoir le gosier sec ស្ងួតបំពង់ក, ស្រេកទឹក ។

Loc. fam. régler ឬ liquider en cinq sec សម្រេចយ៉ាងរហ័ស ។

n.m. ភាពស្ងួត (ឧ. l'humidité et le sec)៖ អ្វីដែលស្ងួតឬក្រៀម (ឧ. mettre un cheval à sec ឲ្យសេះស៊ីស្មៅស្ងួត) ។ *Fam.* employer le vert et le sec ប្រើបច្ចោបាយគ្រប់យ៉ាង (ដូចគេឲ្យសេះស៊ីស្មៅស្រស់ផង ស្មៅស្ងួតផង) ។

adv. ដោយកំរុតកំបុយ, យ៉ាងទ្រគោះ (ឧ. répondre sec à quelqu'un)។ boire sec ផឹកស្រាសុទ្ធ (ស្រាឥតលាយទឹក)។ *Fig.* tout sec គត់ (ឧ. emploi qui vaut, tout sec, trente mille riels par an) ។

Loc. adv. à sec ស្ងួត(គ្មានទឹក) (ឧ. puits à sec); *fam.* ស្ងួត(គ្មានប្រាក់) (ឧ. se trouver à sec); *au fig.* ទាល់ប្រាជ្ញ, ទាល់គំនិត (ឧ. poète à sec) ។ mettre à sec ស្រង់ពីទឹក; *au fig.* ឈ្នះយកប្រាក់អស់ (ក្នុងល្បែង)។ *Constr.* poser à sec ម.ព. poser

sécable *a.* អាចកាត់បាន

sécant,e *a.* ដែលកាត់ផ្ទៃ ឬបន្ទាត់ (ឧ. plan sécant)

sécante *n.f. Math.* បន្ទាត់កាត់

sécateur *n.m.* កន្ត្រៃកាត់មែកឈើ

sécession *n.f.* អបគមន៍ [អៈ-ប៉ៈ-គំ], ការដកខ្លួនចេញពីបក្សពួក

sécessionniste *a.&n.* អបគមនិយម, ដែលចេញខ្លួនពីបក្សពួក, ដែលនាំយកបែក

séchage *n.m.* ការហាល, ការសំងិល (ឧ. le séchage des foins)

sèche-cheveux *n.m. inv.* ប្រដាប់ធ្វើសក់ឲ្យស្ងួត

sèchement *adv.* យ៉ាងគំរោះគំរើល (ឧ.

répondre sèchement)

sécher *v.t.* ធ្វើឲ្យស្ងួត, ហាល, សំងិល (ឧ. le vent sèche les chemins) ។ *Fig.* sécher les larmes ជួយលួង ។ *Arg. scol.* រេះ (មិនចូលរៀន) (ឧ. sécher un cours) ។

v.i. ឡើងស្ងួត, ឡើងក្រៀម (ឧ. ces fleurs ont séché); រីង ។ *Fig.* sécher sur pied សស្រង-សស្រែ ។ *Arg. scol.* ចាល់, ឆ្លើយមិនរួច (ចំពោះសិស្សដែលឆ្លើយនឹងសំនួរគ្រូមិនរួច) ។

se sécher *v.pr.* ឡើងស្ងួត

sécheresse *n.f.* ភាពស្ងួត (ឧ. la sécheresse de la terre nuit à la végétation); ភាពរាំង, ដំណើរគ្មានភ្លៀង (ឧ. il y eut une grande sécheresse cette année-là) ; រដូវប្រាំង ។ *Fig.* សេចក្ដីគគ្រោះគគ្រើម (ឧ. répondre avec sécheresse ឆ្លើយដោយគគ្រោះគគ្រើម); ភាពគ្មានមេត្តា (ឧ. sécheresse de cœur) ; ភាពសោះកក្រោះ (ឧ. sécheresse de style)

sécherie *n.f.* កន្លែងហាល (ឧ. sécherie de poissons).

sécheur *n.m.*, **sécheuse** *n.f.* ប្រដាប់ហាល

séchoir *n.m.* បន្ទប់ហាល (ឧ. séchoir électrique); រនា-ប្រពាស ឬ ដែប សម្រាប់ហាល ·

second,e *a.* ទី២ (ឧ. la seconde place); រង; ផ្សេង, ថ្មី, មួយទៀត (ឧ. c'est un second Alexandre)

n.m. ជាន់ទី២ (ឧ. monter au second) ។ *n.* អ្នកបន្ទាប់, អ្នករង (ឧ. être le second) ។ *Mar.* second maître ម.ព. maître ។ en second *loc. adv.* រង (ឧ. capitaine en second) ។ en second lieu ជាបន្ទាប់

secondaire *a.* បន្ទាប់បន្សំ, រាយរង (ឧ. motifs secondaires) ។ enseignement secondaire មធ្យមសិក្សា ។ *Géol.* ère secondaire ឬ le secondaire ម.ព. ère

secondairement *adv.* ជាបន្ទាប់បន្សំ

seconde *n.f.* ថ្នាក់ទី២ (ឧ. élève de seconde); វិនាទី ។ *Par ext.* មួយវិនាទី (កំណត់ពេលយ៉ាងខ្លី) (ឧ.

attendez une seconde)

secondement *adv.* ទី ២, ជាគំរប់ ២

seconder *v.t.* ជួយ (ឧ. son secrétaire le seconde dans son travail); ជួយជាធាយរង; ជួយអនុគ្រោះ (មើល. aider, assister, collaborer, coopérer, participer, servir)

secouement *n.m.* ការអង្រួន, ការជីជុះ

secouer *v.t.* អង្រួន (ឧ. secouer un arbre); ជីជុះ (ឧ secouer la poussière de ses vêtements) ។ *Fig.* រើខ្លួន, ដោះខ្លួនអំពី (ឧ. le Nord entier secoue le joug du fanatisme (Voltaire) ។ *Absol.* រលាក់ (ឧ. cette voiture secoue beaucoup) ។ *Fig.* ធ្វើឲ្យរងទុក្ខ, ធ្វើឲ្យពិបាកចិត្ត (ឧ. cette maladie, cette nouvelle l'a bien secoué); ដាស់តឿន (ឧ. il faut secouer l'âme quand elle est abattue (Voltaire) ។ *Fam.* ស្ដីប្រដៅ (ឧ. secouer un écolier paresseux) ។

Loc. div. Fig. secouer la poussière de ses pieds ឬ de ses souliers ក្រោកចេញដោយសំដែងកំហឹង (ដោយគ្រវីជើង) ។ secouer la tête គ្រវីក្បាល; មិនយល់ព្រម ។ secouer le joug រើខ្លួនអំពីនឹម; ដោះខ្លួនអំពីការជិះជាន់ ។ *Fam.* secouer l'oreille ឬ les oreilles សំដែងអាការមិនយល់ព្រម ដោយមើលងាយ ។ secouer les oreilles à ឬ secouer ញីក ត្រចៀក; ស្ដីបន្ទោស, ប្រដៅ ។ ne faire qu'en secouer les oreilles មិនស្ញប់ភ័យនឹងហេតុការណ៍អាក្រក់ ។ secouer les puces វាយ ឬ បន្ទោសយ៉ាងខ្លាំង ។

se secouer *v.pr.* រលាស់ដៃជើង (ឲ្យបាត់ស្រពន់); ហាត់ប្រាណ (ឧ. allons, secouez-vous); *au fig.* មិននៅស្ងៀម, មិនអស់សង្ឃឹម (ឧ. secouez-vous, occupez-vous (Voltaire)

secourable *a.* អាចជួយបាន (ឧ. ville qui n'est secourable que par mer); ដែលជួយ; ដែលចូលចិត្តជួយ (ឧ. soyez secourable à tout le monde) ។ tendre

une main ឬ des mains secourables ជួយសង្គ្រោះ

secourir *v.t.* ជួយ, សង្គ្រោះ (ក្នុងពេលអាសន្ន ឧ. la ville fut secourue à temps; ក្នុងពេលត្រូវការ ឧ. secourir les pauvres)

secours *n.m.* ជំនួយ, ការសង្គ្រោះ (ឧ. mourir faute de secours) ។ poste de secours ម.ព. poste។ *pl.* ជំនួយ, អ្វីៗដែលឲ្យជាជំនួយ (ឧ. des secours en espèce, en nature) ។ របស់ជាជំនួយ; ជំនួយបម្រុងការ ។ secours scolaires ជំនួយសិក្សា ។ *Mil.* ទ័ពជំនួយ

secousse *n.f.* ការរញ្ជួយ (ឧ. donner une secousse ធ្វើឲ្យរញ្ជួយ); ដំណើររញ្ជួយដែលមាន។ *Fig.* ការស្លុត; ដំណើរខូចសុខភាពឬខ្វះបៀតបៀនរាងកាយ; ចលាចល (ឧ. cette maladie a été pour lui une terrible secousse) ។ sans secousse ដោយគ្មានរញ្ជួយ, យ៉ាងស្ងប់, យ៉ាងសន្សឹម។ se donner une secousse រលាស់ខ្លួនលាស់ដើង (ឲ្យឈាមរត់ស្រួល) ។ *Pop.* faire une chose à la secousse ធ្វើការកញ្ឆក់កញ្ឆែង (ធ្វើរហ័សហើយមិនល្អ)។ donner une secousse ធ្វើការដោយព្យាយាម ។ n'en pas faire ឬ ficher une secousse មិនខ្វល់ធ្វើអ្វី, ខ្ជិលច្រអូស

secret,ète *a.* សម្ងាត់ (ឧ. négociation secrète); សម្ងាត់, កំបាំង (ឧ. escalier secret; porte secrète); ដែលលាក់ទុក, ដែលមិនបញ្ចេញមុខ (ឧ. ennemis secrets) ; ដែលបេះលាក់ ។

Loc. div. maladie secrète រោគស្ត្រី (រោគស្វាយប្រមេះ)។ remèdes secrets ឱសថសម្ងាត់ (ដែលគេលាក់) ។ comité secret គណៈកម្មាធិការសម្ងាត់ ។

Loc. fam. être secret comme un coup de canon ឬ comme un coup de tonnerre មិនចេះលាក់អាថ៌កំបាំងសោះ។

Fin. fonds secrets មូលនិធិសម្ងាត់

secret *n.m.* ការសម្ងាត់, អាថ៌កំបាំង (ឧ. confier un secret à quelqu'un); ការលាក់អាថ៌កំបាំង។ *Particul.* គន្លឹះសម្ងាត់ (ឧ. le secret d'une serrure) ; កន្លែងដោយ

ខ្សែក្នុងពន្ធនាគារ (ឧ. mettre au secret un criminel) ។ mise au secret ការហាមមិនឲ្យទាក់ទងនឹងអ្នកឯណានោះ ។ *Par ext.* ការនៅឆ្ងាយពីគេ ។ *Par anal.* អ្វីដ៏សម្ងាត់ ឬ ដ៏កំបាំង (ឧ. la mort a découvert le secret de ses affaires (Bossuet); ន័យសម្ងាត់ (ឧ. pour entendre le secret de ces expressions); មធ្យោបាយសម្ងាត់ (ឧ. le secret d'ennuyer est de tout dire (Voltaire) ។

Loc. dlv. secret d'Etat ការសម្ងាត់របស់រដ្ឋ ។ secret de polichinelle ឬ secret de la comédie ការសម្ងាត់ដែលគេដឹងគ្រប់គ្នា។ être du secret ឬ être dans le secret ជាអ្នកដឹងការសម្ងាត់ដែលគេកំពុងធ្វើ ។ avoir le secret de quelqu'un ដឹងការសម្ងាត់របស់អ្នកណាម្នាក់។ c'est mon secret គឺការសម្ងាត់របស់ខ្ញុំ (ខ្ញុំប្រាប់រឿងនេះមិនបានទេ) ។ dire une chose sous le secret ឬ en grand secret ប្រាប់រឿងអ្វីដោយផ្ដាំថាកុំប្រាប់អ្នកឯណាទៀតឲ្យសោះ ។ n'avoir point de secret pour quelqu'un និយាយអស់ពីពោះ, គ្មានលាក់អ្វីចំពោះអ្នកណាម្នាក់ ។

Loc.adv. en secret ដោយសម្ងាត់, ដោយគ្មានសាក្សី (ឧ. voir quelqu'un en secret); ដោយលាក់គំនិត

secrétaire *n.* លេខាធិការ-ការី, ស្មៀន។ secrétaire d'ambassade លេខាធិការនៃស្ថានឯកអគ្គរាជទូត ។ secrétaire d'Etat រដ្ឋលេខាធិការ ។ secrétaire général អគ្គលេខាធិការ ។ secrétaire particulier លេខាធិការផ្ទាល់ ។

n.m. តុសរសេរ

secrétairerie *n.f.* លេខាធិការដ្ឋាន; លេខាធិការទាំងឡាយ

secrétariat *n.m.* មុខងារនៃលេខាធិការ; លេខាធិការដ្ឋាន; លេខាធិការទាំងឡាយ ។ secrétariat d'Etat រដ្ឋលេខាធិការដ្ឋាន ។ secrétariat général អគ្គលេខាធិការដ្ឋាន។ secrétariat particulier លេខាធិការដ្ឋានផ្ទាល់

secrètement *adv.* ដោយសម្ងាត់ (ឧ.

avertir quelqu'un secrètement)

secréter *v.t.* ធ្វើរសមោចនា (បញ្ចេញ) (ឧ. le foie secrète la bile)

secréteur, teuse ឬ **trice** *a. Physiol.* ដែលធ្វើរសមោចនា (ដែលបញ្ចេញ) (ឧ. les organes sécréteurs de la salive)

secrétion *n.f. Physiol.* រសមោចនា [រ:-ស:-]

secrétoire *a.Physiol.* នៃរសមោចនា (ឧ. organe, appareil secrétoire)

sectaire *a.&n.* និកាយិក (ដែលប្រកាន់និកាយ, គំនិតខ្លី) (ឧ. esprit sectaire)

sectarisme *n.m.* និកាយនិយម

secte *n.f.* និកាយ ។ *Fig.* faire secte ប្រមូលជាក្រុមដោយឡែក

secteur *n.m. Math.* ផ្ទៃចន្លោះកាំ ។ *Mil.* តំបន់ ។ sous-secteur តំបន់រង ។ *Fig.* ផ្នែក (ឧ. secteur économique)

section *n.f.* ការកាត់; មុខកាត់ (ឧ. la section des tendons); ចំណិត; ផ្នែក ។ section d'un tribunal ផ្នែកនៃសាលាក្ដី ។ section civile ផ្នែករដ្ឋប្បវេណី ។ section correctionnelle ផ្នែកមជ្ឈិម ។ section de simple police ផ្នែកលហុ ។ section d'identité judiciaire ផ្នែកអត្តសញ្ញាណតុលាការ ។ *Mil.* កងអនុសេនាតូច

sectionnement *n.m.* ការកាត់ជាកំណាត់; ការចែកជាផ្នែក

sectionner *v.t.* កាត់ជាកំណាត់; ចែកជាផ្នែក (ឧ. sectionner une administration) (ប្រ. fractionner, fragmenter, scinder, séparer)

séculaire *a.* ដែលមានរាល់តែសតវត្ស (ឧ. fête séculaire); សតាយុ, ដែលមានអាយុរាប់រយឆ្នាំ (ឧ. chêne séculaire); ចាស់ណាស់ (ឧ. préjugé séculaire) ។ année séculaire ឆ្នាំចុងសតវត្ស

séculairement *adv.* រាល់តែសតវត្ស, ពីសតវត្សមួយទៅសតវត្សមួយ (ឧ. tradition séculairement fortifiée)

sécularisation *n.f.* ការលែងជាប់ជាសាសនភណ្ឌ (ឧ. la sécularisa-

tion des biens ecclésiastiques)

séculariser *v.t.* លែងដាក់ជាសាសនសម្បត្តិ; រឹបអូស, ផ្ទេរកាន់មកអាណាចក្រ; ប្រែ, ឲ្យកាន់ភេទគ្រហស្ថវិញ

séculier,ère *a.* ដែលចូលចិត្តការសប្បាយក្នុងលោក (ឧ. une vie séculière); ខាងអាណាចក្រ (ឧ. tribunaux séculiers)។ bras séculier អំណាចតុលាការខាងអាណាចក្រ (ឧ. livrer un ecclésiastique au bras séculier)។

n.m. គ្រហស្ថ

secundo *adv.* ទី២, ជាគំរប់ ២

sécurité *n.f.* សន្តិសុខ, និរភ័យ ។ sécurité sociale និរភ័យក្នុងសង្គម (អង្គការរ៉ាប់រងអ្នកធ្វើការនៅពេលគ្មានការធ្វើ,ពេលមានរោគ, ពេលមានគ្រោះថ្នាក់។ល។)

sédatif,ive *a. & n.* ដែលធ្វើឲ្យអន់ឈឺចាប់ (ឧ.potion sédative)

sédation *n.f.* ដំណើរត្រឡប់ដើរស្រួលវិញ

sédentaire *a.* និសិន្ន (ដែលអង្គុយជាធម្មតា ឧ. être trop sédentaire; ដែលមិនសូវចេញដើរ ឧ. en vieillissant on devient sédentaire; ដែលនៅនឹងមួយកន្លែង ឧ. vie, emploi sédentaire) ។ service sédentaire ក្រុមនិសិន្ន

sédentairement *adv.* ដោយនិសិន្ន (ឧ. vivre sédentairement)

sédentarité *n.f.* និសិន្នភាព

sédiment *n.m.* អវសាទ (កណ្ដក, កករ ឬអ្វីៗដែលពូនគុះឡើងបន្តិចម្ដងៗ)

sédimentaire *a.* ជាអវសាទ (ជាកណ្ដក,ជាកករ ឬអ្វីៗដែលពូនគុះឡើងបន្តិចម្ដងៗ)។ roches sédimentaires ម.ព. roche

sédimentation *n.f.* អវសាទកម្ម (ដំណើររងនៃកករ, ដំណើរពូនគុះឡើងបន្តិចម្ដងៗ)

séditieusement *adv.* ដោយបះបោរ

séditieux,euse *a.&n.* ដែលបំបះបំបោរ (ឧ.discours séditieux); ដែលបះបោរ; ដែលសំរៀងទៅរកការបះបោរ (ឧ. esprit séditieux)

sédition *n.f.* ចលាចល, ការបះបោរ

séducteur,trice *n. & a.* ដែលប្រលោម; អ្នកបំបែង ។ l'esprit séducteur ព្រាយបញ្ចុលចិត្ត

séduction *n.f.* ការប្រលោម,ការបំបែង; ការទាក់ចិត្ត (ឧ. les séductions

de la richesse)

séduire *v.t.* ប្រលោម (ឧ. séduire les témoins); ធ្វើឲ្យចូលចិត្ត, ធ្វើឲ្យទាក់ចិត្ត (ឧ. ses manières m'ont séduit) (ម៉ើ. attirer, captiver, enchanter, envoûter, ravir, subjuguer)

séduisant,e *a.* គួរឲ្យស្រឡាញ់ (ឧ. homme séduisant); គួរឲ្យចូលចិត្ត (ឧ. offre séduisante)

segment *n.m. Math.* ខណ្ឌភាគ ។ segment de cercle ខណ្ឌភាគនៃមណ្ឌល។ segment de droite ខណ្ឌភាគនៃខត្ថិត (បន្ទាត់ត្រង់) ។ segment orienté ខណ្ឌភាគបែរ។ segment sphérique ខណ្ឌភាគនៃគោល

segmentaire *a.* ដែលជាខណ្ឌភាគ

segmentation *n.f.* ខណ្ឌករណ៍, ការបែកជាខណ្ឌភាគ

segmenter *v.t.* បែកជាខណ្ឌភាគ

ségrégatif,ive *a.* ដែលបំបែក; ដែលញែកបែក

ségrégation *n.f.* វិយោគកម្ម (ការបំបែកចេញ; ការដាក់ដោយឡែក; ការបំបែកពួកដែលមានដើមកំណើត-ជាតិពន្ធ ឬ សាសនាខុសគ្នា) ។ ségrégation raciale វិយោគកម្មជាតិពន្ធ

seiche ឬ **sèche** *n.f.* ត្រីមឹក,ត្រីមៀវហ៊ី

seigle *n.m.* ធញ្ញជាតិមួយយ៉ាង

seigneur *n.m.* សេដ្ឋី, អភិជន; ម្ចាស់ (ឧ. être maître et seigneur chez soi ជាចៅហ្វាយនិងម្ចាស់ក្នុងផ្ទះខ្លួន) ។ le Seigneur អាទិទេព ។ Notre-Seigneur ព្រះយេស៊ូ ។ le Grand Seigneur ព្រះចៅស៊ុលតង់។ vivre en seigneur រស់នៅយ៉ាងរុងរឿង។ faire le seigneur ក៏យឫកធំ។ le seigneur et maître d'une femme ស្វាមី, ប្ដី ។

Prov. à tout seigneur tout honneur ម.ព. honneur។ tant vaut le seigneur tant vaut la terre ម្ចាស់តម្លៃយ៉ាងណាដីតម្លៃយ៉ាងនោះ

seigneuriage *n.m.* សិទ្ធិរបស់សេដ្ឋី; សិទ្ធិលើការបោះប្រាក់ (របស់ព្រះរាជា)

seigneurial,e,aux *a.* នៃសេដ្ឋី (ឧ. terre seigneuriale)

seigneurie *n.f.* អំណាចសេដ្ឋី; ដែនដីសេដ្ឋី

seille *n.f.* ថាំងឈើ

seillon *n.m.* ផាំងឈើតូចរាក់

seime [sèm'] *n.f.* ស្នាមប្រេះនៃក្រចកជើងសេះ

sein *n.m.* ដោះ ។ *Par ext.* ទ្រូង (ឧ.presser quelqu'un contre son sein); ទ្រូងស្ត្រី; ដោះស្ត្រី (ឧ. donner le sein à un enfant); គភ៌, ផ្ទៃ (ឧ. elle l'a porté dans son sein) ។ *Par ext.* ភាគខាងក្នុង (ឧ. dans le sein de la terre) ។

Fig. ប្រភព (ឧ. vivre au sein des grandeurs) ; ចិត្ត, គំនិត (ឧ. déposer un secret dans le sein d'un ami) ។ le sein de Dieu ឋានសួគ៌

seine ឬ **senne** *n.f.* អញ្ចូង

seing *n.m.* ហត្ថលេខាសញ្ញា, សញ្ញាជំនួសហត្ថលេខា; ហត្ថលេខាបញ្ជាក់ (ជាលិខិតត្រឹមត្រូវតាមច្បាប់) (ឧ. apposer son seing)។ sous seing privé រវាងឯកជន (មិនបានធ្វើចំពោះមុខអ្នករាជការ) ។ blanc-seing ម.ព. blanc seing

séisme *n.m.* ភូមិចាល,ការរញ្ជួយប្រឹថពី

séismique *a.* ម.ព. sismique

séismographie *n.m.* ម.ព. sismographie

seizaine *n.f.* សោឡសកៈ, ចំនួន ១៦; ចំនួនប្រមាណជា១៦; ខ្សែចងខ្ចប់អីវ៉ាន់

seize *a.num.* ដប់ប្រាំមួយ (ឧ. seize personnes); ទី ១៦ (ឧ. Louis XVI) ។

n.m. ថ្ងៃទី ១៦ (ឧ. le seize juillet)

seizième *a. num. ord.* ទី ១៦ ។ *n.* អ្នកឬរបស់ទី ១៦ (ឧ. être le seizième) ។

n.m. ភាគ ១៦

seizièmement *adv.* ទី ១៦; ជាគំរប់ ១៦

séjour *n.m.* ការស្នាក់អាស្រ័យ, ការសំចត; ទីសំណាក់ (ឧ. séjour enchanteur) ។ frais de séjour ម.ព. frais

séjourner *v.i.* ស្នាក់អាស្រ័យ, សំចត (ឧ. séjourner à Bok Ko)

sel *n.m.* អំបិល។ sel gemme អំបិលដី (ដែលគេជីកយកពីក្នុងដី)។ sel gris ឬ sel de cuisine អំបិលខ្មៅ ។ sel marin អំបិលសមុទ្រ ។

Chim. សែល ។

Fig. រស (ន័យដ៏ល្អិតល្អន់ ឬ ដ៏ជ្រៅ)(ឧ.goûter le sel d'une plaisanterie)

sélect *a.Fam.* លេខមួយ, អស់ជម្រើស (ឧ. des réunions sélects)

sélecteur *n.m.* គ្រឿងសម្រាប់សម្រាំង

sélectif,ive *a.* ដែលជ្រើសរើស, ដែលស្រាស់យកតែល្អ

sélection *n.f.* ការសម្រាំង, ការស្រាស់យកតែល្អ(ឧ.faire une sélection parmi des candidats); ជំរើស; មនុស្សទាំងឡាយដែលស្រាស់ជ្រើស ។ sélection naturelle ការសម្រាំងនៃធម្មជាតិ ។ sélection professionnelle ការសម្រាំងខាងវិជ្ជាជីវៈ (ការស្រាស់ជ្រើសបេក្ខជនសម្រាប់វិជ្ជាជីវៈមួយ)

sélectionné,e *a.&n.* សម្រាំង, ដែលគេស្រាស់ជ្រើស (ក្នុងកីឡា)

sélectionner *v.t.* ជ្រើសរើស,សម្រាំង, ស្រាស់ជ្រើស

sélectionneur,euse *n.* អ្នកសម្រាំង, អ្នកស្រាស់ជ្រើស

sélénographie *n.f.* ចន្ទ្រពិពណ៌នា

sélénographique *a.* នៃចន្ទ្រពិពណ៌នា

self-government [sèlf-gheu-vèrn'-mèn] (ព.អ.) *n.m.* អត្តាភិបាល, ការគ្រប់គ្រងដោយខ្លួនឯង

sellage *n.m.* ការឬរបៀបបង់កែបសេះ

selle *n.f.* កែបសេះ; កែបទោចក្រយាន។ cheval de selle សេះជិះ(សម្រាប់ជិះ); បង្គន់ (ឧ. aller à la selle); ការបន្ទោបង់ឧច្ចារៈ; លាមក(ឧ. selles abondantes); ទ្រនាប់ចម្លាក់ ។ *Fig.* être bien en selle បានរឹងមាំ (ក្នុងមុខងារ, ក្នុងនាទី)

seller *v.t.* បង់កែបសេះ (ឧ. seller sa monture)

seller *v.i.* ឬ **se seller** *v.pr.* ឡើងរឹងមុខលើ (ដី)

sellerie *n.f.* ជំនួញ ឬ ឧស្សាហកម្មកែបសេះ; កន្លែងដាក់កែបសេះ

sellette *n.f.* កៅអីឈើសម្រាប់អ្នកត្រូវចោទអង្គុយ ។ tenir quelqu'un sur la sellette ឈ្លបសួរ ។ កូនតុទ្រនាប់ចម្លាក់; កូនកែប

sellier *n.&a.m.* ជាងធ្វើកែបសេះនិងគ្រឿងបង្ហៀរសេះ

selon *pré.* តាម (ឧ. selon leur témoignage); ដោយយល់ដល់ (ឧ. selon ses forces); តាមយោបល់ (ឧ. la philosophie selon

Epicure) ។ c'est selon គឺតាមកាលៈទេសៈ ។ selon que *loc. conj.* តាមដែល

semaille *n.f.pl.* ការសាបព្រោះ (ឧ. les semailles se font en automne et au printemps); របៀបធ្វើ, រដូវសាបព្រោះ

semaine *n.f.* សប្ដាហៈ, អាទិត្យ (ឧ. le dimanche est le premier jour de la semaine); ការធ្វើក្នុងមួយអាទិត្យ; ឈ្នួលអាទិត្យ (ឈ្នួលក្នុងមួយអាទិត្យ) (ឧ. toucher sa semaine); ប្រាក់អាទិត្យ (ប្រាក់សម្រាប់ចាយក្នុងមួយអាទិត្យ) ។ prêter à la petite semaine ឲ្យខ្ចីយកការរាល់អាទិត្យ ។ semaine anglaise សប្ដាហៈអង់គ្លេស (ការនិយមឈប់ល្ងាចថ្ងៃសៅរ៍បន្ថែមលើថ្ងៃអាទិត្យតាមរបៀបអង់គ្លេស) ។ être de la semaine ទទួលវេនអាទិត្យ, ទទួលការប្រចាំអាទិត្យ

semainier,ère *n.* អ្នកវេនសប្ដាហៈ, អ្នកទទួលការប្រចាំអាទិត្យ

sémantique *a.* នៃនិយណ្ដសាស្ត្រ, នៃអត្ថន័យ (ឧ. la valeur sémantique d'un mot) ។

n.f. និយណ្ដសាស្ត្រ

sémaphore *n.m.* សញ្ញាករ (*Ch. de fer* សញ្ញាសំគាល់ថាផ្លូវអោយស្ទួយយានបិទ ឬ បើក ; *Mar.* បង្គោលតាមឆ្នេរសមុទ្រ ឬតាមកំពង់ផែ សម្រាប់ធ្វើសញ្ញាដល់នាវា)

sémaphorique *a.* នៃសញ្ញាករ (ឧ. poste sémaphorique)

semblable *a.* ដូចគ្នា, ដូចនេះ, ដូច (ទ. ne tenez pas de semblables discours) ។

n.m. សមរូប [សៈ-មិៈ—]; ឯកត្តកាយ; មនុស្សឬសត្វដូចគ្នា (ឧ. aimer son semblable) (មើល. analogue, pareil, similaire, tel)

semblablement *adv.* យ៉ាងដូចគ្នា; ដូចគ្នាដែរ

semblant *n.m.* អាការៈក្រៅ (ឧ. un semblant d'amitié) ។ faire semblant ធ្វើហាក់ដូចជា ។ *Fam.* ne faire semblant de rien ធ្វើហាក់ដូចជាមិនដឹងអ្វីសោះ ។ faux semblant ឧបាយកល, ការលាក់ពុត, ការបញ្ឆោត

sembler *v.i.* ដូចជា, មានទំនងជា (ឧ. ce vin me semble trouble) ។

v.impers. il me semble que ខ្ញុំហាក់ដូចជា, ខ្ញុំស្មានថា ។ ce me semble តាមខ្ញុំ, តាមយោបល់ខ្ញុំ ។ si bon vous semble បើលោកយល់ថាត្រូវ, បើលោកពូលចិត្ត ។ que vous en semb'e ? តើលោកយល់ដូចម្តេច ?

séméiologie *n.f. Méd.* រោគសញ្ញាសាស្ត្រ (ថា séméiotique ឬ sémiologie ក៏បាន) ។ *Philos.* សញ្ញាសាស្ត្រ (ការសិក្សាអំពីអភិវឌ្ឍន៍នឹងមុខងារនៃសញ្ញានានាដ៏វិភាពក្នុងសង្គម)

séméiologique *a.* នៃសញ្ញាសាស្ត្រ (ឧ. théorie séméiologique)

séméiologue *n.m.* អ្នករោគសញ្ញាសាស្ត្រ

semelle *n.f.* បាតស្បែកជើង; ទ្រនាប់បាតជើង; ប្រវែងបាតស្បែកជើង (ឧ. rompre d'une semelle) ។ battre la semelle យកជើងទោះបង្ហាត់ (កុំឲ្យរងា) ។ *Fig.* ne pas avancer d'une semelle គ្មានបម្រើនសោះ ។ ne pas reculer d'une semelle មិនព្រមថយសោះ

semence *n.f.* គ្រាប់ពូជ; ដែកគោលតូចក្បាលសំប៉ែត ។ *Fig.* បុព្វហេតុ

semer *v t.* សាប, ព្រោះ, បណ្ដុះ (ឧ. semer des céréales); ពង្រាយ (ឧ. semer des clous sur la route); ដាក់កាយ, បាច (ឧ. semer un chemin de fleurs) ។ *Fig.* ធ្វើឲ្យកើតមាន (ឧ. semer la discorde, l'erreur) ។ semer de l'argent ចាយប្រាក់ខ្ជះខ្ជាយ ។

Fig. សាបព្រោះ, ធ្វើទុក (ដើម្បីយកផលទៅអនាគត) (ឧ. semer dans la jeunesse pour récolter dans l'âge mûr) ។ *Pop.* រលាស់ចោល, គេចចេញពី (ឧ. semer un importun)

semestre *n.m.* ឆមាស, រយៈពេលប្រាំមួយខែ (ឧ. pension payée par semestre) ។ *Par ext.* ប្រាក់ឆមាសិក (ធនលាភ, បៀវត្សដែលបើកប្រាំមួយខែម្តង) (ឧ. toucher son semestre)

semestriel,elle *a.* ឆមាស, ដែលមានប្រាំមួយខែម្តង (ឧ. composition semestrielle); ឆមាសិក, ដែលមានរយៈពេលប្រាំមួយខែ (ឧ. congé semestriel)

semestriellement *adv.* តាមឆមាស, ប្រាំមួយខែម្តង

semeur,euse *n.* វប្បការ-ការី, អ្នកសាបព្រោះ។ *Fig.* អ្នកផ្សាយ (ឧ. semeur de faux bruits)។

n.f. ប្រដាប់សាបព្រោះ

semi-automatique *a.* អឌ្ឍស្វ័យប្រវត្ត។ *Mil.* arme semi-automatique អាវុធអឌ្ឍស្វ័យប្រវត្ត

semi-fini,e *a.* produit semi-fini ម.ព. produit

sémillant, e *a.* រហ័សរហួនហើយសប្បាយ (ឧ. enfant sémillant; esprit sémillant)

séminaire *n.m.* សិក្ខាសាលា; សិស្សសិក្ខាសាលាទាំងឡាយ (ឧ. tout le séminaire est sorti); រយៈពេលរៀនក្នុងសិក្ខាសាលា (ឧ. il finit son séminaire)

séminal,e,aux *a* នៃគ្រាប់ពូជ

séminariste *n.m.* សិស្សសិក្ខាសាលា

sémination *n.f.* ដំណើរជ្រុះរាយភាយនៃគ្រាប់ពូជ

semi-nomade *a.&n.* អឌ្ឍចរកជន

semi-nomadisme *n.m.* អឌ្ឍចរនិយម (របៀបរស់នៅដោយកសិកម្មខ្លះ ដោយការត្រាច់ចរចិញ្ចឹមសត្វខ្លះ)

semi-œuvré,e *a.* អឌ្ឍក្រិត

sémiologie ឬ **sémiotique** *n.f.* ម.ព. séméiologie

semi-public,ique *a.* អឌ្ឍសាធារណៈ

semis *n.m.* ពង្រោះ; ការប្ញូររៀបសាបព្រោះ (ឧ. les plantes annuelles ne se multiplient guère que par semis); វប្បដ្ឋាន, ថ្នាល, កន្លែងសាបព្រោះ (ឧ. marcher dans un semis); សំណាប, កូនឈើ

sémite *n.* អម្បូរសេមីត (ជនក្នុងអម្បូរដែលជាប់ពីជាតិអារ៉ាប, ជាតិជ្វីហ្វ, ជាតិស៊ីរី)

sémitique *a.* នៃអម្បូរសេមីត។ langues sémitiques អម្បូរភាសាសេមីត

sémitisme *n.m.* លក្ខណកជនអម្បូរសេមីត

semi-voyelle *n.f.* ស្រះពេញតួ

semoir *n.m.* ថង់ដាក់ពូជ; ម៉ាស៊ីនសាបព្រោះ

semonce *n.f.* ការស្តីប្រដៅ

semoncer *v.t.* ស្តីប្រដៅ

sempiternel,elle *a.* ជានិច្ច, មិនឈប់ឈរ (ឧ. des remontrances

sempiternelles) (ពើ. continuel, éternel)

sempiternellement *adv.* ជានិច្ច

sen [sèn] *n.m.* សេន (លុយយួន)

sénat *n.m.* ព្រឹទ្ធសភា

sénateur *n.m.* សមាជិកព្រឹទ្ធសភា ។ *Loc. fam.* train de sénateur ដំណើរអ្នកធំ (ដំណើរយឺត ឬ រៀបទម)

sénatorial,e,aux *a.* នៃសមាជិកព្រឹទ្ធសភា (ឧ. la dignité sénatoriale)

sénatorien,enne *a.* នៃសមាជិកព្រឹទ្ធសភារ៉ូម៉ាំង (ឧ. famille sénatorienne)

sénégalais,e *a.* នៃប្រទេសសេណេហ្កាល់

sénescence *n.f. Pathol.* ជរាភេទ

senestre *a.* ដែលងាកទៅឆ្វេង (ឧ. enroulement senestre) ។ *Blas.* នៃឆ្វេង (ព.ផ. dextre)

sénile *a.* ជរា, ចាស់ជរា

sénilité *n.f.* ជរាភាព, ភាពចាស់ជរា

senior *n.m. Sports* បច្ចុប (អ្នកកីឡាដែលមានអាយុលើសពី ១៨ ឆ្នាំ)

senne *n.f.* ម.ព. seine

sens *n.m.* វិញ្ញាណ (ឧ. les cinq sens វិញ្ញាណទាំងប្រាំ): វិនិច្ឆ័យ (ឧ. avoir du sens មានវិនិច្ឆ័យ; ការដឹង, ការស្គាល់ (ឧ. celui qui ment toujours perd le sens du vrai); យោបល់, មតិ, របៀបយល់, របៀបវិនិច្ឆ័យ (ឧ. la voie la plus correcte pour arriver à la faveur des grands est d'entrer toujours dans leur sens (Fléchier); សតិ; អត្ថន័យ (ឧ. paroles à double sens); បែក, ខាង, អន្លើ (ឧ. retourner un objet en tous sens ប្រែត្រឡប់របស់មួយសព្វអន្លើ); ទិស ។ aller dans le sens du courant ទៅតាមបណ្តោយទឹក ។

Loc. div. sixième sens វិញ្ញាណទីប្រាំមួយ, មនោវិញ្ញាណ ។ bon sens សុភនិច្ឆ័យ (ការពិចារណាដោយត្រឹមត្រូវ, ការដឹងខុសដឹងត្រូវ) (ឧ. le bon sens est la chose du monde la mieux partagée (Descartes) ។ gros bon sens សុភនិច្ឆ័យពីកំណើត (សុភនិច្ឆ័យដែលនាំឲ្យដឹងថាអ្វីជាពិត ជាយុត្តិធម៌ ដោយមិនបាច់មាន

ចំណេះវិជ្ជា) ។ en dépit du bon sens ដោយផ្ទុយនឹងសុភនិច្ឆ័យ ។ être dans son bon sens ត្រូវតាមសុភនិច្ឆ័យ ។ sens commun សាទិសនិច្ឆ័យ (សុភនិច្ឆ័យម្យ៉ាង គឺពន្លឺសាមញ្ញដែលជនច្រើនគ្នាមាន) (ឧ. le sens commun est la chose la moins commune du monde (Port-Royal) ។ avoir le sens commun មានសាទិសនិច្ឆ័យ (ចេះវិនិច្ឆ័យឲ្យសមតាមមតិមនុស្សទាំងពួង) (ឧ. cela n'a pas le sens commun) ។ sens esthétique សោភណនិច្ឆ័យ (ការយល់, ការស្គាល់របស់ល្អនឹងអាក្រក់) ។ sens moral សីលនិច្ឆ័យ (សម្បជញ្ញៈដឹងល្អនឹងអាក្រក់ខាងសីលធម៌) ។ sens pratique បដិបត្តិនិច្ឆ័យ (ការយល់របស់ប្រតិបត្តិឬងាយប្រើ,ការប្រសប់)។sens figuré អត្ថបដិរូប ។ sens propre អត្ថានុរូប។ sens de la circulation ទិសចរាចរ ។ sens interdit ទិសហាម ។ sens obligatoire ទិសតម្រូវ ។ sens unique ឯកទិស ។

Loc. adv. sens dessus dessous ត្រឡប់ត្រឡិន (ឧ. renverser un objet sens dessus dessous); ច្របូកច្របល់ (ឧ. ma bibliothèque est sens dessus dessous) ; ច្រួលច្របល់ (ឧ. assister à un accident qui vous met tout sens dessus dessous)។ sens devant derrière ត្រឡប់ពីមុខទៅក្រោយ ។

Prov. qui perd le sien perd le sens ការបង់ទ្រព្យតាំងឲ្យខូចសតិ (ផ. នឹងសុភាសិតខ្មែរថា: ខ្លួនរស់ របស់កើត)

sensation *n.f.* វេទនារម្មណ៍, ការដឹងដោយវិញ្ញាណ (ឧ. sensation tactile) ។ *Fig.* avoir la sensation que ហាក់ដូចជាយល់ថា (ដឹងដោយវិញ្ញាណថា) ។ faire sensation ធ្វើឲ្យចាប់អារម្មណ៍ខ្លាំង (ក្នុងចំណោម) ។ nouvelle à sensation ដំណឹងដែលធ្វើឲ្យរំភើប

sensationnel,elle *a.* ដែលឲ្យរំភើប

sensé,e *a.* ដែលមានសុភនិច្ឆ័យ (ឧ. une personne sensée); សមតាមសុភនិច្ឆ័យ (ឧ.discours sen-

sé)

sensément *adv.* ដោយសមតាមសុ·ភនិច្ឆ័យ (ឧ. parler, agir sensément)

sensibilisateur *n.m.* វេទយិតករ [វេ-ទៈ-យិត-តៈ-] (ឧ. sensibilisateur photographique)

sensibilisation *n.f.* វេទយិតកម្ម

sensibiliser *v.t.* ធ្វើឲ្យវេទយិត-ឲ្យងាយរំភើប ឬ ឲ្យឆាប់ជាប់រូប

sensibilité *n.f.* វេទយិតភាព (ភាពងាយនឹងមានវេទនារម្មណ៍ ឧ. sensibilité cutanée; ភាពងាយនឹងជាប់អារម្មណ៍ខាងផ្លូវចិត្ត); ភាពឆាប់ជាប់រូប (ក្នុងការថតរូប)។ *Fig.* ភាពឆាប់រំភើប (ឧ. personne d'une grande sensibilité); មនុស្សធម៌; ភាពមានមេត្តា;ភាពមិនស្លឹក (រហ័ស)

sensible *a.* វេទយិត (ដែលមានវេទនារម្មណ៍ ឧ. être sensible au froid; ដែលឆាប់ជាប់អារម្មណ៍ខាងផ្លូវចិត្ត ឧ. être sensible aux éloges សប្បាយចិត្តនឹងពាក្យសរសើរ); ឆាប់រំភើប, មានមេត្តា (ឧ. cœur sensible); ច្បាស់, ស្តែង; ដែលអាចដឹងបានដោយវិញ្ញាណ (ឧ. progrès sensible)។ *Mus.* គនវេទយិត។ côté sensible អ្វីៗដែលធ្វើឲ្យអាណិតអាសូរ (ប្រ. compatissant, généreux, humain, tendre ។ ព.ផ. cruel, dur, impitoyable, inhumain)

sensiblement *adv.* យ៉ាងស្តែង (ឧ. le flux monte sensiblement): ដោយរំភើប

sensiblerie *n.f.* វេទយិតភាពក្លែង ឬ ហួសហេតុ

sensitif,ive *a.* ដែលមានវិញ្ញាណ, នៃវិញ្ញាណ (ឧ. nerf sensitif): ខាងវេទនារម្មណ៍ (ឧ. faculté sensitive)

sensitive *n.f.* ព្រះខ្លប (ឧ. la sensitive est dite aussi «mimosa») ។ *Fig.* មនុស្សឆាប់ភ័យ ឬ ឆាប់ខ្លាច

sensoriel,elle *a.* ខាងវិញ្ញាណ (ឧ. les phénomènes sensoriels)

sensualité *n.f.* កាមគត, សេចក្តីត្រេកក្នុងកាមគុណ (ឧ. vivre avec sensualité; austérité qui condamne toutes les sensualités)

sensuel,elle *a.&n.* កាមភគី, ដែលត្រេកក្នុងកាមគុណ (ឧ. homme sensuel); ខាងកាមភគ (ឧ. plaisir sensuel)

sente *n.f.* ផ្លូវដើរ

sentence *n.f.* ភាសិត(មើ.maxime, précepte); យោបល់ ។ *Dr.* ក្រមកាដី(សេចក្ដីវិនិច្ឆ័យ) (ឧ. sentence de mort)

sentencieusement *adv.* ជាភាសិត (ឧ. parler sentencieusement)

sentencieux,euse *a.* ដែលថ្លែងជាភាសិត (ឧ. homme sentencieux); ដែលមានភាសិត (ឧ. langage sentencieux); ដែលជាភាសិត, ដែលមានលំនាំជាភាសិត (ឧ. phrase sentencieuse); ដែលក្លែងធ្វើជារម្យទម (ឧ. ton sentencieux)

senteur *n.f.* វិលេបនៈ, ក្លិន (ឧ. la senteur d'un mets)(មើ. arôme, bouquet, odeur, parfum)

senti,e *a.* ដែលយល់ហើយថ្លែងយ៉ាងច្បាស់(ឧ.paroles bien senties)

sentier *n.m.* ផ្លូវដើរ ។ *Fig.* មាគ៌ា (ឧ. les sentiers de l'honneur)

sentiment *n.m.* វេទនា (ការដឹងអារម្មណ៍ជាសុខ ឬ ទុក្ខ); ការដឹង, ដំណើរអានស្មារតីដឹងខ្លួន (ឧ. avoir le sentiment de sa force); មនោសញ្ចេតនា (ឧ. être animé de nobles sentiments; montrer les sentiments d'un père)

sentimental,e,aux *a.* ដែលបញ្ចេញមនោសញ្ចេតនា (ឧ. ton sentimental); ដែលធ្វើឫកជារំភើប (ឧ. un jeune homme sentimental)

sentimentalement *adv.* ដោយបញ្ចេញមនោសញ្ចេតនា

sentimentalisme *n.m.* សញ្ចេតនិយម (ការនិយមប្រព្រឹត្តតាមមនោសញ្ចេតនា) (ឧ. le sentimentalisme de Rousseau)

sentimentalité *n.f.* សញ្ចេតនភាព, ការបញ្ចេញមនោសញ្ចេតនា

sentinelle *n.f.* អ្នកយាម ។ sentinelle perdue អ្នកយាមកន្លែងឆ្ងាយហើយប្រកបដោយគ្រោះថ្នាក់ ។ faire sentinelle យាម, ឃ្លាំមើល

sentir *v.t.* ដឹង (ដោយវិញ្ញាណ) (ឧ. sentir le froid, la faim); មាន

រសជាតិយខ្សែក (ឧ. ce vin sent son terroir); ធុំក្លិន (ឧ. ce tabac sent la violette); ហិត, ហើប (ឧ. sentir une rose); ស្ទាប, ពាល់ (ឧ. je la sens du doigt) ។

Fig. ស្គាល់, ឃើញ, យល់ (ឧ. sentir les beautés d'un ouvrage); មានមនោសញ្ចេតនា (ឧ. sentir du chagrin ព្រួយចិត្ត; sentir de la joie សប្បាយចិត្ត; sentir de l'affection pour quelqu'un ស្រឡាញ់អ្នកណាម្នាក់); ដឹងខ្លួន (ឧ. je sens que j'ai commis une faute); រំភើបចិត្តនឹង (ឧ. sentir plus vivement les maux que les biens); មានគុណភាព; មានទំនងជា (ឧ. cela sent le pédant); បង្ហាញឲ្យឃើញ ។

Loc. div. faire sentir ធ្វើឲ្យដឹង, បញ្ចេញឲ្យឃើញ (ឧ. faire sentir son autorité) ។ se faire sentir ចេញឲ្យដឹងឬឲ្យឃើញ (ឧ. vers dans lesquels le travail se fait trop sentir) ។ sentir de loin ដឹងមុន, ព្រាងទុកមុន; *au fig.* sentir de loin quelqu'un ស្គាល់ថាជាអ្នកណា ។ sentir quelqu'un de loin ស្គាល់ពោះវៀន, ដឹងចំណង់របស់អ្នកណាម្នាក់ ។ - ne rien sentir pour គ្មានចិត្តអ្វីបន្តិចចំពោះ, មិនស្រឡាញ់សោះ ។ *Fam.* ne pouvoir sentir quelqu'un ឃើញមុខមិនបានសោះ (ស្អប់ខ្លាំងណាស់) ។ sentir le corps de garde ជាមនុស្សឆ្គងផង; ឥតអៀនខ្មាស ។ sentir le fagot ដូចជាមានអញ្ញទិដ្ឋិ (ក្នុងសម័យបុរាណគេដុតអញ្ញទិដ្ឋិកជនទាំងរស់); ដូចជាចំឡែក ។ sentir le gibet ឬ la potence គួរពោក, គួរធ្វើទារុណកម្មយ៉ាងធ្ងន់ ។ *Pop.* sentir le sapin ធុំក្លិនអុសក្តួ, ធុំក្លិនជាតិប (ជិតស្លាប់) ។ sentir l'huile ម.ព. huile ។ sentir son bien មានរបៀបជាអ្នកមានពូជ ។ sentir le terroir មានរសដោយខ្សែក (តាមដីដែលដាំ) (ឧ. vin qui sent le terroir); *au fig.* មានគុណវិបត្តិនៃអ្នកស្រុករបស់ខ្លួន (មានគុណវិបត្តិដូចអ្នកដែលនៅស្រុកជាមួយ) ។ faire sentir la force de son bras បញ្ចេញគេជដៃ, ធ្វើឲ្យដឹងគេជដៃ ។

v.i. ធុំក្លិន, កាយក្លិន (ឧ. ce

bouquet sent bon); *en part.* ធុំអាក្រក់, ធុំស្អុយ (ឧ. ce poisson sent); ក្រោងទុកមុន (ឧ. sentir de loin)។

se sentir *v.pr.* ដឹងខ្លួន (ឧ. se sentir fort; se sentir malade) ។ je ne me sens pas bien ខ្ញុំធ្លាប់ជាមិនស្ងប់ស្រួលខ្លួន ។

Loc. div. commencer à se sentir ដឹងខ្លួនថាមានកម្លាំង ឬមានគុណូបការ (ឧ. jeune talent qui commence à se sentir); កំពុងឡើងខ្លួន ។ se sentir de ទទួលផលនៃ (ឧ. se sentir d'une blessure ឈឺកន្លែងរបួស (ឈឺក្រោយពីត្រូវរបួស) ។ ne se sentir pas ភ្លេចខ្លួន (ដោយសប្បាយ) (ឧ. A ces mots, le corbeau ne se sent pas de joie (La Fontaine) ។ se sentir du cœur pour une chose ចូលចិត្តអ្វីមួយ។ *Fig. & Fam.* se sentir les coudes ពួកដៃគ្នា, ធ្វើការស្រុះគ្នា

seoir *v.i.* (ប្រើជា séant, sis, sise) អង្គុយ

seoir *v.t.* សម (មិនខាសភ្នែក) (ឧ. cette coiffure ne vous sied pas) ។ *Impers.* il vous sied mal de parler ainsi លោកមិនសមជានិយាយដូច្នេះសោះ

sep *n.m.* ផ្ទៀង (នង្គ័ល)

sépale *n.m. Bot.* ត្របកផ្កា

sépaloïde *a.* ជាភាងត្របកផ្កា

séparable *a.* អាចបែកពីគ្នាបាន

séparateur,trice *a.* ដែលបំបែក, ដែលចែក

séparatif,ive *a.* ដែលបំបែក; ដែលសំគាល់ការបែកញែក

séparation *n.f.* ការបំបែកគ្នា; ការបែកគ្នា; របស់ដែលញែក ឬ ដែលចែកខណ្ឌ; ការប្រាសនិកស។ *Dr.* séparation de biens ការចែកទ្រព្យ (របបអាពាហ៍ពិពាហ៍ដែលស្វាមី និង ភរិយារក្សាហើយគ្រប់គ្រងទ្រព្យរៀងខ្លួន គ្រាន់តែជួយចេញសោហ៊ុយចំណាយក្នុងផ្ទះ) ។ séparation de biens conventionnelle ការចែកទ្រព្យជាអនុសញ្ញាក (ដោយព្រមព្រៀងគ្នាមុនអាពាហ៍ពិពាហ៍) ។ séparation de biens judiciaire ការចែកទ្រព្យដោយតុលាការ (ដោយមានការសម្រេចពីតៅក្រម) ។ séparation de

corps ការបង់ឃ្លាតខ្លួន, ការពង្រាត់ខ្លួន (ការសម្រេចរបស់តុលាការឲ្យស្វាមីភរិយាទៅបែកគ្នា) ។ séparation des patrimoines ការបែកមរតកភណ្ឌ ។ séparation des pouvoirs ម.ព. pouvoir

séparatisme *n.m.* ភេទនិយម (ការនិយមធ្វើដែនដីមួយ ឲ្យបែកចេញអំពីរដ្ឋដែលដែនដីនេះធ្លាប់រួម)

séparatiste *a.&n.* អ្នកភេទនិយម

séparé,e *a.* ផ្សេង, ដោយឡែក (ឧ. ils ont des intérêts séparés) ។ *Dr.* ដែលឃ្លាតខ្លួន, ដែលព្រាត់ខ្លួន

séparément *adv.* ដោយបែកគ្នា (ឧ. vivre séparément)

séparer *v.t.* កាត់ចេញ (ឧ. séparer la tête du corps); ដាក់ផ្សេងគ្នា, រើសចេញ (ឧ. séparer l'ivraie du bon grain); ញែក, វែក (ឧ. séparer ses cheveux sur le front); បែក (ឧ. séparer une chambre en trois); ខណ្ឌ (ឧ. la mer sépare la France de l'Angleterre); បំបែក, ធ្វើឲ្យឃ្លាតពីគ្នា (ឧ. le vent sépara les deux flottes); ឃាត់មិនឲ្យវាយគ្នា (ឧ. séparer des combattants) ។ *Fig.* ពិនិត្យដោយឡែក (ឧ. séparer une question de l'ensemble d'un problème); ពង្រាត់បង្រាស។

se séparer *v.pr.* បែកគ្នា។ *Dr.* se séparer de corps et de biens ឃ្លាតខ្លួននឹងបែកទ្រព្យ (ព្រ. disjoindre, disloquer, dissocier, isoler, partager)

sépia *n.f.* សេប្យា (ទឹកមឹកសម្រាប់ប្រើក្នុងគំនូរ, ទឹកពណ៌ខ្មៅការ); គំនូរសេប្យា (ដោយទឹកមឹក) (ឧ. une belle sépia) (*pl.* des sépias)

sept *a.num.* សប្ត, ប្រាំពីរ (ឧ. les sept jours de la semaine); ទី ៧ (ឧ. Charles sept)។

n.m.inv. លេខ ៧; ថ្ងៃទី ៧ (ឧ. le sept Juillet)

septante *a.num.* ចិតសិប

septembral,e,aux *a.* នៃខែកញ្ញា ។ la purée septembrale ស្រាទំពាំងបាយជូរ

septembre *n.m.* កញ្ញា (ខែ)

septembrisades *n.f.pl.* ការសម្លាប់អ្នកជាប់ទោសនយោបាយ ក្នុងពន្ធនាគារ

ពីថ្ងៃ ទី ២ ទៅទី ៦ កញ្ញា ១៧៩២

septembriseur *n.m.* អ្នកសម្លាប់អ្នកជាប់គុកនយោបាយក្នុងខែកញ្ញា១៧៩២

septénaire *a.* ដែលមាន ៧ ថ្ងៃឬ ៧ឆ្នាំ ។ parlement septénaire សប្តវស្សសភា (សភាដែលឋិតនៅ ៧ ឆ្នាំ) ។

n.m. សប្តទិន, រយៈពេល ៧ ថ្ងៃ (រោគ) (ឧ. le premier, le second septénaire)

septennal,e,aux *a.* ដែលមាន ៧ ឆ្នាំម្តង; ដែលឋិតនៅ ៧ ឆ្នាំ (ឧ. période septennale)

septennalité *n.f.* សប្តវស្សភាព, ភាពឋិតនៅ ៧ ឆ្នាំ

septennat *n.m.* សប្តវស្ស (អំណាចនយោបាយដែលឋិតនៅ ៧ ឆ្នាំ)

septentrion *n.m.* ទិសឧត្តរ, ទិសខាងជើង ។ au septentrion de ខាងជើងនៃ

septentrional,e,aux *a.* ខាងឧត្តរ, ខាងជើង (ឧ. Amérique septentrionale; les pays septentrionaux) ។

n.m. pl. les septentrionaux ជនជាតិខាងជើង

septicémie *n.f.* បូតិករោគ, រោគបង្កដោយមេរោគចូលក្នុងឈាម

septicémique *a.* នៃបូតិករោគ, ដែលបង្កដោយមេរោគចូលក្នុងឈាម (ឧ. affection septicémique)

septicité *n.f.* បូតិករភាព, ភាពបង្ករោគ

septidi *n.m.* សប្តមទិន (ថ្ងៃទី ៧ នៃទសទិន)

septième *a. num.* សប្តមៈ, ទី ៧ ។ être au septième ciel បានសុភមង្គលគ្មានល្អក់ (ម.ព. ciel ផង) ។

n. សប្តមៈ, មនុស្ស ឬ របស់ទី៧ ។ *n.m.* ភាគ ៧ ។ *n.f.* ថ្នាក់ទី៧ (ឧ. finir sa septième)

septièmement *adv.* ទី៧, ជាគម្រប់ ៧

septimo *adv.* ទី ៧

septique *a.* បូតិករ, ដែលបង្ករោគ (ឧ. microbes septiques); ដែលបង្កដោយមេរោគ ។ fosse septique រណ្តៅបូតិករ

septuagénaire *a.* & *n.* ដែលមានអាយុ ៧០ ឆ្នាំ

septuple *a.* សប្តគុណ (ឧ. nombre septuple) ។ *n.m.* ចំនួនសប្តគុណ (ច្រើនជាង ៧ ដង)

septupler *v.t.* សប្តគុណ, ធ្វើឲ្យចំរើន ៧ ដង (ឧ. septupler son

revenu)។

v.i. ចម្រើន ៧ ដង (ឧ. revenu qui a septuplé)

sépulcral,e,aux *a.* នៃផ្នូរខ្មោច (ឧ. inscription sépulcrale) ។ *Fig.* voix sépulcrale សម្លេងដូចជាចេញពីផ្នូរ

sépulcre *n.m.* ស្តូប, ផ្នូរខ្មោច ។ le saint sépulcre ស្តូបព្រះយេស៊ូ (នាជេរុយសាឡែម)

sépulture *n.f.* សុសាន, ស្មសាន, ទីបញ្ចុះសព (ឧ. Saint-Denis était la sépulture des rois de France); ការបញ្ចុះសព (ឧ. recevoir les honneurs de la sépulture)

séquelle *n.f.* ពួកខ្ញុំកញ្ជះគេ (ពួកជនថោកទាបសម្រាប់បម្រើបក្សពួក ឬ ជនណាម្នាក់) (ឧ. on l'a chassé, lui et sa séquelle); អ្វីៗដែលមានច្រើនតគ្នា (ឧ. une séquelle d'injures ការជេរច្រើន) ។

pl. Pathol. សំណល់រោគ

séquence *n.f.* រូបរៀងៗ, ឈុតរៀងៗដែលផ្សំជារៀងមួយ

séquestration *n.f.* វិសុណ្ឌាបនកម្ម, ការផ្ញើទុកនូវវត្ថុដែលកើតវិវាទ; ភាពវត្ថុកើតវិវាទដែលផ្ញើទុក; ការបង្ខាំងមនុស្សដោយខុសច្បាប់; ការទៅនៅឆ្ងាយពីគេ

séquestre *n.m.* វិសុណ្ឌាប័ន, ការផ្ញើវត្ថុដែលកើតវិវាទនៅដៃអាជ្ញាកណ្ដាលម្នាក់ (ឧ. mettre un bien sous séquestre) ។ séquestre judiciaire វិសុណ្ឌាប័នតុលាការ (វត្ថុកើតវិវាទដែលផ្ញើទុក)

séquestre *n.m.* វិសុណ្ឌាបនិក, អ្នកទទួលទុកនូវបញ្ញើកើតវិវាទ

séquestrer *v.t.* វិសុណ្ឌាបនា, ផ្ញើទុកនូវវត្ថុដែលកើតវិវាទ (ឧ. séquestrer des biens); បង្ខាំងមនុស្សដោយខុសច្បាប់ (ឧ. séquestrer une personne constitue un délit ou un crime suivant que l'infraction a duré moins ou plus de dix jours) ។

se séquestrer *v.pr.Fig.* ទៅនៅឆ្ងាយពីគេ; រស់នៅតែម្នាក់ឯង

sérail *n.m.* សេរ៉ៃ, វាំងនៃក្សត្រអ៊ីស្លាម

sérançage *n.m.* ការហែកសរសៃធ្មៃ ឬ ក្រចៅ

sérancer *v.t.* ហែកសរសៃធ្មៃ ឬក្រចៅ

séranceur *n.&a.m.* អ្នកហែកសរសៃធ្មៃ ឬ ក្រចៅ

serein,e *a.* ស្រឡះ (អាកាស), ស្ងប់ (ឧ. temps serein)។ *Fig.* ស្ងប់ (ឧ. passer des jours sereins; visage serein)

sérénade *n.f.* សេរ៉េណាត (ភ្លេងនិងចំរៀងលេងវេលាយប់នៅក្រោមបង្អួចអ្នកឯណាម្នាក់ ដើម្បីជាទីគោរពពិសំអ្នកនោះ)

sérénité *n.f.* ភាពស្រឡះ; ភាពស្ងប់(ឧ. la sérénité de l'âme)

séreux,euse *a.* ដូចទឹករងៃ, ដែលចេញទឹករងៃ

serf,serve *a.* & *n.* សេវ៉ក, ដែលជាទាសៈ

sorge *n.f.* សែក (សំពត់ខណ្ឌម៉យប៉ាំង)

sergent *n.m.* ពលបាលត្រី។ sergent-chef ពលបាលទោ (*pl.* des sergents-chefs)។ sergent-major ពលបាលឯក (*pl.* des sergents-majors) ។ sergent de ville ឬ gardien de la paix ម.ព. gardien

séricicole *a.* ខាងកោសេយ្យវិប្បកម្ម (នៃការធ្វើសូត្រ) (ឧ. industrie séricicole)

sériciculteur *n.m.* កោសេយ្យវិប្បករ, អ្នកចិញ្ចឹមនាង, អ្នកធ្វើសូត្រ

sériciculture *n.f.* កោសេយ្យវិប្បកម្ម, ការចិញ្ចឹមនាង, ការធ្វើសូត្រ

série *n.f.* អ្វីៗដែលបន្តគ្នា(ឧ. série de difficultés ការលំបាកបន្តគ្នា) ។ *Par ext.* អ្វីៗដែលបន្តគ្នាមិនឈប់ (ឧ. poser une série de questions ចោទសួរមិនរេរះឈប់) ; មាលា , ឈុត (របស់ដែលប្រមូលរួមរួលជាមួយពួក, ជាមួយគ្រឿង) (ឧ. ranger les objets par série)។ en série ដោយច្រើន (ចំពោះរបស់ដែលធ្វើដោយឧស្សាហកម្ម) ។ hors série ដោយឡែក, ជាពិសេស (ចំពោះរបស់ដែលធ្វើខុសពីគេ); *au fig.* ខុសគេ, ចំឡែក(ឧ. destin hors série) ។ *Hist. nat.* ចំពួក (ឧ. série zoologique)។ *Ens.* ផ្នែក (ម.ព. baccalauréat ផង)

sérier *v.t.* ដាក់ ឬ រៀបចំជាពួក (ឧ. sérier les questions)

sérieusement *adv.* មែនទែន (មិនលេង), យ៉ាងប្រាកដប្រជា (ឧ.parler

sérieusement) : យ៉ាងមធ្យ័ត, ដោយយកចិត្តទុកដាក់(ឧ. travailler sérieusement à un examen); យ៉ាងធ្ងន់ (រោគ) (ឧ. être sérieusement malade)

sérieux,euse *a.* ប្រាកដប្រជា, រម្យទម, មធ្យ័ត, នឹងធឹង (ឧ. homme sérieux) ; មិនលេងសើច (ឧ. air sérieux); ប្រាកដ, ពិត, ស្មោះ (ឧ. promesses sérieuses) ; ធ្ងន់ (ឧ. maladie sérieuse) ។

n.m. សេចក្ដីប្រាកដប្រជា; ភាពរម្យទម ឬ នឹងធឹង (ឧ. prendre son sérieux); រឿងមិនកំប្លែង ។ prendre au sérieux ជឿជាពិត (ជឿជាប្រាកដប្រជា)

serin,e *n.* ចាបញ៉ាំងសម្បុរលឿង ។ *Fig.&Fam.* មនុស្សកញ្ចោក (ឧ. c'est un serin)

seriner *v.t.* បង្រៀនចាប ។ *Fig.& Fam.* បង្រៀនដោយឲ្យទន្ទេញដដែលៗ (ឧ. seriner une règle à un écolier)

seringage *n.m.* ការស្រោចដោយបាញ់ទឹកជាគ្រាប់ល្អិតៗ

seringue *n.f.* កន្ត្រួចសម្រាប់បាញ់ខ្យល់ ឬ ទឹក; ម្ជុលចាក់ថ្នាំ

serment *n.m.* សំបថ, ការស្បថ (ឧ. le faux serment prêté devant un tribunal constitue un délit) ។ *Par ext.* ពាក្យស្បថ (ឧ. oublier ses serments) ។ *Fam.* serment d'ivrogne សំបថមិនគួរជឿ ។ *Dr.* serment décisoire ម.ព. décisoire

sermon *n.m.* ធម្មទេសនា ។ *Fam.* ការស្ដីប្រដៅយ៉ាងយូរ

sermonnaire *n.m.* ធម្មកថិក, អ្នកសំដែងធម៌; កម្រងធម្មទេសនា

sermonner *v.t.* ស្ដីប្រដៅ (ឧ. sermonner un jeune homme) ។

v.i. ទេសនា, ធ្វើសុន្ទរកថា

sermonneur,euse *a.* ដែលចូលចិត្តស្ដីប្រដៅ

sérosité *n.f.* អាបោធាតុម្យ៉ាងសម្រាប់រំអិលអាការៈដែលកកិតគ្នា, ទឹករងៃ

serpe *n.f.* កាំបិតព្រា ។ *Fig.&Fam.* ouvrage fait à la serpe ឬ à coups de serpe ការធ្វើដោយខ្ជីខ្ជា (គម្រោងថៃត)

serpent *n.m.* ពស់(cri: le serpent

siffle)។ *Fig.* របស់ដែលបត់បែនដូចពស់; មនុស្សកំណាចវៀចវេរ ។ serpent à lunettes ពស់វែកព្រើ។ serpent à sonnettes ពស់វែកបង្កង (ម.ព. crotale ផង) ។ langue de serpent មនុស្សមាត់អាក្រក់ , មនុស្សហៃនិយាយអាក្រក់ពីគេ ។ réchauffer un serpent dans son sein ចិញ្ចឹមខ្លា (ធ្វើល្អលើមនុស្សរមិលគុណ, ដែលប្រទូស្តតបវិញ ។

n.m. pl. សប្បុរស

serpentaire *n.m.* បក្សីម្យ៉ាងស៊ីពស់

se solidifier *v.p.* កក, ឡើងរឹង

solidité *n.f.* ភាពមាំ-ជាប់ធ្ងន់ (ឧ. la solidité d'une étoffe, d'une argumentation)

solifluxion ឬ **solifluction** *n.f.* ដំណើររអិលស្រុតរបស់ដីលើ

soliloque *n.m.* សំដីនិយាយនឹងអាត្មាឯង (និយាយម្នាក់ឯង)

soliloquer *v.i.* និយាយនឹងអាត្មាឯង (និយាយម្នាក់ឯង)

solipède *a.* ដែលមានស្រោមឬមានក្រចកជើងតែមួយ (ដូចសេះ) ។

n.m. pl. អស្សកុល (សត្វានសត្វសេះ, លា ។ល។)

soliste *n.* អ្នកលេងភ្លេងទោល

solitaire *a.* ទោល; ដែលចូលចិត្តនៅតែម្នាក់ឯង; ដែលនៅឆ្ងាយពីគេ (ឧ. hameau solitaire) ។ *Bot.* ទោល

(ផ្កា) ។ ver solitaire ព្រូនវែង ។ *n.m.* អ្នកបួសដែលនៅតែម្នាក់ឯង; អ្នកនៅឆ្ងាយពីគេ ; ជ្រូកព្រៃឈ្មោល ; ពេជ្រដាំតែមួយគ្រាប់

solitairement *adv.* តែម្នាក់ឯង, ឆ្ងាយពីគេ

solitude *n.f.* ភាពអ្នករស់នៅតែម្នាក់ឯង ឬ ឆ្ងាយពីគេ (ឧ. charmes de la solitude); កន្លែងឆ្ងាយពីគេ (ឧ. se retirer dans la solitude)

solive *n.f. Constr.* រនូត

soliveau *n.m.* រនូតតូច ។ *Fig.& Fam.* មនុស្សមិនបានការ (ឧ. ce n'est qu'un soliveau)

solleret *n.m.* ម.ព. soleret

sollicitation *n.f.* ការសុំ, ការទទួចសុំ (ឧ. c'est à votre sollicitation que...)

solliciter *v.t.* សុំ (ឧ. solliciter une audience); ទទួចសុំ (ឧ. solliciter quelqu'un de faire quelque chose) ។ *Fig.* ទាញ, ធ្វើឲ្យ (ឧ. solliciter l'attention ធ្វើឲ្យគេចាប់ភ្នែកមកលើ) (ប្រ. postuler, quémander)

solliciteur,euse *n.* អ្នកសុំ(សុំដីហែង, សុំទោស)

sollicitude *n.f.* ការថ្នាក់ថ្នម; ការប្រោសប្រណី (ឧ. sollicitude maternelle)

solo *n.m.* ភ្លេងចៀវ (ឧ. faire un solo) (*pl.* des solos)

solubiliser *v.t.* ធ្វើឲ្យអាចរលាយក្នុងទឹកបាន

solubilité *n.f.* ភាពអាចរលាយក្នុងទឹកបាន (ឧ. la solubilité varie avec la température)

soluble *a.* អាចរលាយក្នុងទឹកបាន (ឧ. le sucre est soluble dans l'eau) ។ *Fig.* អាចដោះស្រាយបាន; អាចរកឃើញ (ឧ. problème soluble)

soluté *n.m.* ឧសថរាវ; ធាតុរលាយ

solution *n.f.* ការដោះស្រាយ (ឧ. solution d'un rébus); ការឆ្លើយ (បំណោទ); សេចក្ដីសម្រេច (ឧ. affaire qui demande une prompte solution.); ទឹកដែលមានធាតុរលាយ (ដូចយ៉ាងទឹកស្ករជាដើម) ។ solution de continuité ម.ព. continuité

solutionner *v.t.* ឆ្លើយ; ដោះស្រាយ

(ឧ. solutionner un problème)

solvabilité *n.f.* សាធនភាព , ភាពអ្នកមានប្រាក់សង ឬ បង់ (ឧ. la solvabilité d'un commerçant) ។ certificat de solvabilité វិញ្ញាបនប័ត្រសាធនភាព

solvable *a.* សាធនីយ,ដែលមានប្រាក់សង ឬ បង់ (ឧ. locataire solvable)

solvant *n.m.* ទឹកសម្រាប់រំលាយវត្ថុដទៃ

soma *n.m.Biol.* កាយ (អាការៈទាំងពួងនៃសត្វលោកដែលវិនាសអស់ទៅក្រោយពេលស្លាប់ ផ្ទុយនឹង germen ដែលបន្តពូជទៅទៀត)

somatique *a.* នៃកាយ (ឧ. affection somatique)

sombre *a.* ងងឹត(មិនសូវភ្លឺ)(ឧ. maison sombre); ចាស់(ពណ៌) (ឧ. couleur sombre); ងងឹត (មើលអ្វីមិនឃើញ)(ឧ. nuit sombre)។ *Fig.* ស្រងូតស្រងាត់, មិននិយាយស្តី, ព្រួយ (ឧ. caractère sombre); គួរឲ្យស្បើម; គួរឲ្យពេញចិត្ត (ឧ. sombre avenir) ។ les sombres bords ឬ le sombre empire ឋាននរក

sombrer *v.i.Mar.* លង់, លិច (នាវា) (ឧ. navire qui sombre) ។ *Fig.* ធ្លាក់ចុះ (ឧ. sombrer dans le vice) ; វិនាស (ឧ. fortune qui sombre)

sombrero *n.m.* (ព.អេស្ប៉ាញ៉ុល) មួកសំបុកហាមធំ(*pl.* des sombreros)

sommaire *a.* ខ្លី, សង្ខេប (ឧ. analyse sommaire); រហ័ស, មិនចាំបាច់មានទម្រង់ការណ៍ច្រើន (ឧ. justice sommaire) ។

n.m. សេចក្តីសង្ខេប (ររ. bref, concis, court, élémentaire, rudimentaire, succinct ។ ព.ផ. diffus, long)

sommairement *adv.* យ៉ាងខ្លី, យ៉ាងសង្ខេប; យ៉ាងរហ័ស

sommation *n.f. Dr.* ដីកាបង្ខំ, ដីកាតឹងរ៉ឹង ។ sommation sans frais ដីកាតឹងរ៉ឹងឥតពិន័យ ។ sommation avec frais ដីកាតឹងរ៉ឹងមានពិន័យ ។ *Mil.* ការស្ទាក់ (ការហៅឲ្យឈប់ក្នុងការប្រយុទ្ធ; ការស្រែកប្រាប់ឲ្យបែកគ្នាក្នុងការប្រជុំឥតច្បាប់) ។ *Math.* ការបូករួម

somme *n.f.Math.* ចំនួនបូករួម; ផល-

ប្បមាណ, ហិរញ្ញប្បមាណ, ចំនួនប្រាក់, ទឹកប្រាក់ ។ *Fig.* ចំនួនរួម, សរុប (ឧ. la somme des biens et des maux) ។ somme toute ឬ en somme *loc.adv.* ក្នុងទីបំផុត, ដោយសង្ខេបទៅ

somme *n.f.* bête de somme សត្វពាហនៈ ។ *Fig.* អ្នកទទួលបន្ទុកការច្រើនពេក

somme *n.m.Fam.* ល្បក់ (ពេលមួយទំហឹងដេកលក់)

sommeil *n.m.* ការដេកលក់ (ឧ. être plongé dans le sommeil ដេកលក់)៖ ដំណើរងងុយដេក (ឧ. avoir sommeil ងងុយដេក) ។ *Fig.* ដំណេក (ភាពឥតកម្រើក) (ឧ. l'hiver est le sommeil de la nature) ។

Loc. div. demi-sommeil ដំណើរលក់រលីវៗ, ដំណេកស្ទើរលក់ ។ tomber de sommeil ងងុយដេកខ្លាំង ។ sommeil de mort ដំណេកលក់ដូចស្លាប់ ។ sommeil de plomb ដំណេកលក់ដូចគេសណ្ដំ ។ sommeil de la mort ឬ sommeil du trépas ឬ sommeil de la tombe ឬ sommeil éternel ឬ dernier sommeil ឬ sommeil ទីឃនិទ្រា, ភាពស្លាប់ (ឧ. il dort du dernier sommeil ឬ d'un sommeil éternel គាត់ស្លាប់) ។ sommeil du juste ដំណេកលក់ស្រួល; ភាពស្លាប់ស្រួល (ឥតវេទនា) (ឧ. s'endormir ឬ dormir du sommeil du juste) ។ maladie du sommeil និទ្រារោគ, រោគងងុយដេក (បង្កដោយរុយម្យ៉ាងឈ្មោះត្សេត្សេទាំ) ។ mettre en sommeil បង្អន់សកម្មភាព

sommeiller *v.t.* ដេកលក់រលីវៗ ។ *Fig.* គ្មានសកម្មភាព; ស្ងប់ (ឧ. passions qui sommeillent)

sommelier *n.m.* អ្នកបម្រើស្រា (ក្នុងភោជនីយដ្ឋាន)

sommellerie *n.f.* មុខការអ្នកបម្រើស្រា

sommer *v.t.* គំរាម, បង្ខំ; ចេញដីកាបង្ខំ ឬ ដីកាតឹងរ៉ឹង (ឧ. sommer un débiteur d'avoir à s'exécuter) ។ sommer une place សង្កាប់ ឬ បង្ខំស្រុកឲ្យចុះចាញ់ (ស្រុកដែលគេឡោមព័ទ្ធ)

sommer *v.t.* បូក (ឧ. sommer les

termes d'une série)

sommet *n.m.* កោណគ្គ [- ណាគ់], កំពូល (ឧ. sommet d'une montagne); ចុង ។ *Math.* sommet d'un angle កំពូលមុម ។ sommet d'un cône កំពូលសាជីមូល ។ *Fig.* កំពូល (ថ្នាក់ខ្ពស់បំផុត) (ឧ. sommet des grandeurs)។ conférence au sommet សន្និសិទកំពូល (សន្និសិទរវាងប្រមុខរដ្ឋ)

sommier *n.m.* មេព្រុំស្ប៉ា ។ sommier élastique ពូកស្ប៉ា ។

sommier *n.m.* ក្រាំង, បញ្ជីចំណូល, បញ្ជីចុះទឹកប្រាក់, សៀវភៅបញ្ជីធំ ។ sommier judicière ក្រាំងកត់ទោស

sommité *n.f.* កំពូល, ចុងមែក ឬ ចុងដើមផ្កា ។ *Fig.* ឯកទគ្គបុគ្គល

somnambule *n.&a.* ដែលបមើ (ដែលនិយាយ, ដើរ ឬ ធ្វើអ្វីក្នុងវេលាកំពុងដេកលក់)

somnambulisme *n.m.* ការបមើ; អំពើដែលធ្វើក្នុងពេលដេកលក់

somnifère *a.* ដែលឲ្យងងុយដេក, ដែលឲ្យដេកលក់ (ឧ. le pavot est un somnifère) ។ *Fam.* គួរឲ្យងងុយ; ដែលឲ្យធុញទ្រាន់ (ឧ. lecture somnifère)

somnolence *n.f.* ភាពលក់ស្មា, ភាពស្ទើរលក់ស្ទើរភ្ញាក់ ។ *Fig.* ដំណើរគ្មានសកម្មភាព; ភាពទន់ព្រៃពេក

somnolent,e *a.* ដែលលក់ស្មា, ដែលស្ទើរលក់ស្ទើរភ្ញាក់ (ឧ. état somnolent) ។ *Fig.* គ្មានសកម្មភាព

somnoler *v.i.* លក់ស្មា, តាម្ងៃស្ទើរលក់ស្ទើរភ្ញាក់

somptuaire *a.* នៃចំណាយ (ឧ. réformes somptuaires) ។ lois somptuaires ច្បាប់បន្ថយចំណាយ

somptueusement *adv.* យ៉ាងអធ្យ-ត្តម, យ៉ាងឆើតឆាយ; ដោយចាយច្រើន (ឧ. vivre somptueusement)

somptueux,euse *a.* អធ្យត្តម [អ័ត-ធ្យត-ដំ], ឆើតឆាយ (ឧ. festin somptueux); ដែលចាយច្រើន (ព្រ. éclatant, magnifique, pompeux, splendide)

somptuosité *n.f.* អធ្យត្តមភាព [អ័ត-ធ្យត-តមៈ-], ភាពចាយច្រើន; ភាពឆើតឆាយ

son,sa,ses *a. pos.* របស់គាត់, របស់វា

son *n.m.* ស័ព្ទ, ស្វរ, សំឡេង (ឧ. son aigu; son grave)

son *n.m.* កន្ទក់ (ឧ. le son contient la plupart des vitamines) ។ *Fam.* tache de son ស្នាមប្រហោម ,

sonar *n.m. Mar.* ប្រដាប់រកនាវាមុជទឹក (ដោយប្រើសំឡេង)

sondage *n.m.* ការស្ទង់; លទ្ធផលនៃការស្ទង់ (ឧ. sondage d'un terrain; sondage de l'opinion)។ sondage aérologique ការស្ទង់រកទិសខ្យល់ (ដោយប្រើបាល់ឡុងស្ទង់)។contrôle par sondage ការពិនិត្យត្រួតដោយស្ទង់ ។,enquête par sondage ការអង្កេតដោយស្ទង់

soude *n.f. Mar.* ប្រដាប់ស្ទង់ (ជម្រៅទឹក); បង្រប់, ដែកចំពុះទុង ។ *Min.* ប្រដាប់ខួងមើលដី.

souder *v.t.* ស្ទង់ ។ *Fig.* ស្ទង់ (ពិនិត្យត្រួត, ធ្វើអង្កេត); ស្ទង់ចិត្ត ឬ យោបល់ (ឧ. sonder quelqu'un) ។ sonder le terrain ស្ទង់ស្ថានការណ៍

sondeur *n.m.* អ្នកស្ទង់; ប្រដាប់ស្ទង់ (ស្ទង់ជម្រៅទឹក ឬ កំពស់អាកាសយាន) (ឧ. sondeur à ultra-sons)

sondeuse *n.f.* ដែកខួងដី(ជាក់ភ្ជាប់នឹងរថយន្តសម្រាប់ខួងអណ្ដូងទឹករាក់ៗ)

songe *n.m.* សុបិននិមិត្ត,ការយល់សប្ដិឬយល់សួង ។ *Fig.* ការគិតខុស, ការសង្ឃឹមខុស (ឧ. faire de beaux songes); វត្ថុឥតខ្លឹមសារ (ឧ. la plus éclatante fortune n'est qu'un songe flatteur (Fénelon)។

Loc. div. en songe ក្នុងពេលដេកលក់; ក្នុងសុបិននិមិត្ត (ឧ. voir en songe un monstre)។ sembler un songe ឬ avoir l'air d'un songe ឬ être comme un songe ដូចជាយល់សប្ដិ, មិនច្បាស់, ស្រពេចស្រពិល ៗ។

Mythol. សុបិនទេព (ទេវតាខាងសុបិន)។

Prov. tout songe est mensonge សុបិនមិនមែនជាការពិត ។ mal passé n'est que songe ទុក្ខកន្លងហួសទៅហើយ ទុកដូចជាសុបិន, គេតែងតែភ្លេចបាត់នូវសេចក្ដីទុក្ខសោកដែលកន្លងទៅហើយ ។ mal d'autrui n'est que songe

ទុក្ខរបស់អ្នកដទៃ ទុកដូចជាសុបិន, យើងឥតឈឺចាប់ចំពោះទុក្ខសោករបស់អ្នកដទៃឡើយ

songe-creux *n.m. inv.* មនុស្សគំនិតរវើរវាយ

songer (à) *v.t. ind.* មានបំណងនឹង (ឧ. songer à se marier) ។ songer à quelqu'un នឹកដល់អ្នកណាម្នាក់ ។

v.i. គិតរវើរវាយ, គិតដល់ (ឧ. songer à l'avenir)

songerie *n.f.* គំនិតរវើរវាយ

songeur,euse *n,m.* អ្នកគិតច្រើន, អ្នកគិតរវើរវាយ ។

a. ដែលសញ្ជប់សញ្ជឹង (ឧ. air songeur)

sonique *a.* នៃស្នូរ, នៃសម្លេង (ឧ. vitesse sonique)

sonnaille *n.f.* បង្ក្រង់

sonnailler *n.m.* មេខ្លាង (សត្វនាំមុខហ្វូងហើយមានបង្ក្រង់ចងនៅក)

sonnailler *v.i.* បន្លឺស្នូរញយៗឥតការណ៍

sonnant,e *a.* ដែលវាយ (ឲ្យឮស្នូរ) (ឧ. horloge sonnante) ។ à huit heures sonnante នៅម៉ោងប្រាំបីគត់ ។ espèces sonnantes ប្រាក់ (រូបិយវត្ថុមាស ឬ ប្រាក់)

sonné,e *a.* ដែលឲ្យដំណឹងដោយស្នូរជួង (ឧ. il est midi sonné); ស្រេច, ពេញលេញ (ឧ. il a cinquante ans sonnés)

sonner *v.i.* វាយ (ឲ្យឮស្នូរ) (ឧ. les cloches sonnent); គោះ, ទូង, ផ្លុំ (ឲ្យឮស្នូរ) (ឧ. sonner du cor); ឲ្យសញ្ញាដោយស្នូរ (ឧ. la messe sonne) ។ *Fig.* ដល់ហើយ (ពេល, សម័យ) (ឧ. la dernière heure sonne pour tout le monde) ។ *Gramm.* faire sonner une lettre អានបញ្ចេញសំឡេងអក្សរណាមួយ ។

Arg. សុំទាន ។

Loc. div. faire sonner ផ្លុំ, ទូង, វាយ (ឲ្យឮស្នូរ); *au fig.* ទទូច ; អួតហួសហេតុ (ឧ. faire sonner une victoire) ។ ce mot sonne mal ពាក្យនេះទាស់ត្រចៀក ។ sonner creux ឮតែទូងៗដូចស្គរ (ប្រហោងក្នុង) ។

v.t. វាយ (ឲ្យឮស្នូរ) (ឧ. sonner les cloches) ។ *Pop.* សំពងក្បាល, ធ្វើឲ្យវិលមុខ; អង្រួន ឬ

កុបកណ្ដឹងហៅ (ឧ. sonner le planton);ឲ្យដំណឹងដោយស្នូរ (ឧ. sonner la retraite): ភិយ (ឲ្យឮស្នូរ) (ឧ. sonner le tocsin) ។

Loc. div. sonner le fêlé ឮស្នូរស្រាំ ។ sonner le creux ឮស្នូរប្រហោងក្នុង ។ ne sonner mot គ្មាននិយាយមួយម៉ាត់, នៅស្ងៀម ។

Prov. on ne saurait sonner les cloches et aller à la procession (ឬ dire la messe) គេមិនអាចធ្វើការម្ដងពីរមុខៗ ដុំយប្បាបានឡើយ

sonnerie *n.f.* ស្នូរជួងច្រើនភិយព្រមគ្នា; ស្នូរកណ្ដឹងទូរសព្ទ; ជួងទាំងអស់ក្នុងវិហារមួយ; កណ្ដឹងរោទ៍ (នាឡិកា) (ឧ. la sonnerie d'un réveil dérangée); បទផ្លុំត្រែនៃកងវរសេនាធំ ។ sonnerie électrique កណ្ដឹងអគ្គិសនី

sonnet *n.m.* កវីនិពន្ធមាន ១៤ បាទ

sonnette *n.f.* កណ្ដឹង, បង្កង់ ។ *Trav. publ.* ម៉ាស៊ីនលើកដុំដែកបុកបួសសសរ ។ serpent à sonnette ប.ព. serpent និង crotale

sonneur *n.m.* អ្នកភិយជួង; អ្នកផ្លុំស្នែង

sonomètre *n.m.* សព្ទមាត្រ [ស័ប-ទ:-], ប្រដាប់ភិស័ននឹងថ្លឹងស្នូរ

sonore *a.* សព្ទន [ស័ប-ទាន់], ដែលមានស្នូរ (ឧ. corps sonore); ពីកកង (ឧ. voix sonore); ខ្ទរ (ឧ. amphithéâtre sonore); film sonore ខ្សែភាពយន្តមាននិយាយ (ស៊ី. bruyant, retentissant, tonitruant, vibrant)

sonorisation *n.f.* ការថតសំឡេងបញ្ចូលខ្សែភាពយន្ត: ការធ្វើឲ្យឮស្នូរ

sonoriser *v.t.* ថតសំឡេងបញ្ចូល (ឧ. sonoriser un film); ដាក់ប្រដាប់បំពងសម្លេង (ឧ. sonoriser une église)

sonorité *n.f.* ភាពឮស្នូរពីកកង;ភាពមានសំឡេងពីរោះ (ឧ. sonorité d'un violon): ភាពខ្ទរ

sonothèque *n.f.* សព្ទាល័យ [ស័ប-ទា-ល៉ៃ] (កន្លែងរក្សាខ្សែ ឬ ថាសថតសំឡេងផ្សេងៗ)

sophisme *n.m.* វិរុទ្ធនិទស្សន៍, របៀបពិចារណាបំភាន់

sophiste *n.m.* វិរុទ្ធនិទស្សនវិទូ, ទស្សន-

វិទូខាងវោហារជំនាន់បុរាណ ។ *Par ext.* អ្នកតែងរៀបពិចារណាបំភាន់

sophistication *n.f.* ការក្លែង, ការលាយបន្ថំ (ភេសជ្ជៈ ឬ ឱសថទឹក)

sophistique *a.* នៃរបៀបពិចារណាបំភាន់ (ឧ. raisonnement sophistique) ។

n.f. របៀបទស្សនវិជ្ជាជាន់បុរាណ (ជាតិក្រិក)

sophistiqué,e *a.* គ្មានលំនាំធម្មតា (ដោយទំពាក់តែងហួសពេក) (ឧ. une beauté sophistiquée)

sophistiquer *v.i.* ក្លែង; ពិចារណាបំភាន់; ក្លែងភេសជ្ជៈឬឱសថ (ដោយលាយបន្ថំ)

soporatif,ve *a.* ដែលធ្វើឲ្យដេកលក់ ។ *n.m.* ថ្នាំដេកលក់

soporifique *a.* ដែលនាំឲ្យដេកលក់ ។ *Fig.* ដែលឲ្យធុញទ្រាន់ (ឧ. livre soporifique) ។

n.m. ថ្នាំដេកលក់

soprano *n.m.* សំឡេងឆ្មារនៃស្ត្រី ឬ ក្មេងតូច; អ្នកច្រៀងសំឡេងឆ្មារ

sorbet *n.m.* ភេសជ្ជៈម្យ៉ាងធ្វើអំពីទឹកដមផ្លែឈើលាយស្ករនឹងស្រា

sorbonnard *n.m.* *Fam.* និស្សិតនឹងសាស្ត្រាចារ្យនៅសរបោន

sorcellerie *n.f.* ល្បិច-អំពើ ឬ របរនៃអ្នកធ្មប់ឬមេអាប(ឧ. la sorcellerie était considérée au Moyen Age comme un crime) ។ *Par ext.* ល្បិចអស្ចារ្យ

sorcier,ère *a.&n.* អ្នកធ្មប់, មេអាប ។ *Fig.& Fam.* មនុស្សប្រសប់ណាស់ ឬ ឆ្លាតណាស់ (ឧ. il faut être sorcier pour lire ce grimoire) ។ cela n'est pas sorcier ការនេះមិនពិបាកអ្វីទេ ។ ដែលឲ្យគប់ ឬ ឲ្យជាប់ចិត្តខ្លាំង (ឧ. à l'infâme sorcier qui charme vos esprits (Corneille) ។ *Fam.* vieux sorcier, vieille sorcière ចាស់កំណាច ។

Loc. div. cet homme n'est pas sorcier ឬ n'est pas un grand sorcier អ្នកនេះមិនសូវមានប្រាជ្ញា - មិនសូវប្រសប់ ឬ មិនសូវឆ្លាតទេ ។ il ne faut pas être grand sorcier pour... មិនចាំបាច់មានប្រាជ្ញាច្រើន ឬ ឆ្លាតណាស់ទេដើម្បី.. ។ être sorcier comme une vache គ្មានការវិនិច្ឆ័យ ឬ គ្មាន

ការភិតកៃរហៈ

sordide *a.* កខ្វក់, គួរឲ្យខ្ពើម (ឧ. vêtements sordides) ។ avarice sordide សេចក្ដីកំណាញ់ស្ទូរជិន

sordidement *adv.* យ៉ាងកខ្វក់;ដោយគួរឲ្យខ្ពើម

sordidité *n.f.* ភាពកខ្វក់,ភាពគួរឲ្យខ្ពើម

sornette *n.f.* សំដីឥតខ្លឹមសារ; របស់ឥតតម្លៃ (ច្រើនតែប្រើជាពហុវចនៈ)

sort *n.m.* ជោគវាសនា (ឧ. se plaindre de son sort);ទេសកាល,ការចាប់ឆ្នោត(ឧ. le sort en a décidé); ស្ថានភាព; សម្បុកទ្រយុក; ស្ថានភាពធនទ្រព្យ (មានឬក្រ) (ឧ. faire un sort heureux à quelqu'un); ការសំរេចដោយចាប់ឆ្នោត (បូល) (ឧ. beaucoup de magistrats d'Athènes étaient choisis par le sort); អំពើធ្មប់ឬអាប (ឧ. jeter un sort sur quelqu'un)

Loc. div. terminer le sort de quelqu'un សម្លាប់ ។ terminer son sort ស្លាប់ ។ il y a un sort ឬ il faut qu'il y ait un sort មានវាសនាអាក្រក់តាមជាប់ជានិច្ច,សំយជានិច្ច។ le sort des armes វាសនានៃសង្គ្រាម (ឧ. tenter le sort des armes) ។ le sort en est jeté វាស្រេចទៅហើយ ; សម្រេចចិត្តរួចទៅហើយ ។ tirage au sort ការចាប់ឆ្នោត ឬបូល។ faire un sort à quelque chose ឲ្យឬលើកតម្លៃរបស់អ្វីមួយ; *fam.* យករបស់នោះមកប្រើជាប្រយោជន៍ខ្លួន(សរ. chance, destin, état, fatalité)

sortable *a.* សមរម្យ (ឧ. vêtement sortable)

sortant,e *a.* ដែលចេញ (ឧ. gouverneur sortant); ដែលផុតអាណត្តិ (ឧ députés sortants) ។

n.m. អ្នកចេញ (ឧ. les entrants et les sortants)

sorte *n.f.* ប្រភេទ (ឧ. toutes sortes de bêtes); យ៉ាង, បែប (ឧ. un homme de la sorte); របៀប (ឧ. s'y prendre de telle ou telle sorte ធ្វើរបៀបនេះឬរបៀបនោះ) ។

Loc.div. une sorte de មួយយ៉ាង(ឧ. le palanquin est une sorte de chaise à porteurs)។

faire en sorte de ឬ que ខំយ៉ាង ណាកាល់តែ (ឧ. faites en sorte qu'on ne vous croit pas malheureux) ។ de bonne sorte ឬ de la bonne sorte *loc. adv.* ដោយសមរម្យ ; ដោយ ត្រឹមត្រូវ (ឧ. tout s'est-il, ces deux jours, passé de bonne sorte? (Molière); *fam.* យ៉ាង ប៉ុនម៉ាត់, យ៉ាងតឹងរ៉ឹង , យ៉ាងខ្លាំង (ឧ. tancer quelqu'un de la bonne sorte)។ de sorte que, en sorte que ឬ de telle sorte que *loc. conj.* យ៉ាងណាកាល់តែ ឬ ត្រាតែ (ឧ. il a travaillé de telle sorte qu'on a fini par le congédier)។ de la sorte ឬ en la sorte ដូច្នេះ,តាមរបៀបនេះ។ en quelque sorte គឺជា, គឺដា (ឧ. la femme est en quelque sorte la conscience de la famille)

sortie *n.f.* ការចេញ (ឧ. faire sa première sortie après une maladie);ទី-ផ្លូវ-ទ្វារឬច្រកចេញ(ឧ. cette maison a deux sorties) ; ការចេញពីឆាក (ឧ. acteur qui fait une fausse sortie) ; ការចេញប្រតិបត្តិការ (អាកាសយាន ចំបាំង) (ឧ. le 6 Juin 1941 l'aviation alliée effectua plus de douze mille sorties); ការ ភាយទម្លុះ (នៃការឡោមព័ទ្ធ); ការ តាំចេញ (ឧ. droit de sortie) ។ *Fig.* ការដោះខ្លួន (អំពីការពិបាកអ្វី មួយ) (ឧ. se ménager une sortie);ការទឹកព្រឡោត (ឧ. je ne m'attendais pas à cette sortie) ។

Loc.div. sortie de bain សំលៀកបំពាក់ងូតទឹក ។ à la sortie de *loc. pré.* ទៅពេលចេញពី (ឧ. à la sortie du spectacle)

sortilège *n.m.* អំពើអំពាន់ (ឧ. avoir recours aux sortilèges); មព្រៀឈយព្យាទ

sortir *v.i.* ចេញ (ឧ. sortir de chez soi); ចេញដើរលេង (ឧ. jeune fille qui ne sort pas seule) ; ដុះចេញ (ឧ. le riz qui sort de terre); កាយចេញ; ផ្សាយ ចេញ (ឧ. une douce odeur

sort de ces fleurs) ។

Fig. ចេញផុតពី (ពីផ្លូវមួយទៅផ្លូវមួយ, ពីស្ថានភាពមួយទៅស្ថានភាពមួយ) (ឧ. sortir de l'hiver, de l'esclavage); ផុត, ចេញពី (ឧ. sortir de maladie, d'inquiétude); ឃ្លាតពី, ងាកពី (ឧ. sortir du sujet); ដោះខ្លួនពី (ឧ. sortir d'embarras); មកពី (ឧ. sortir de bonne famille); ចេញពី (អតីតនិស្សិតនៃ) (ឧ. sortir de l'Ecole Royale d'Administration); មកពី (ឧ. comptable qui sort d'une grande usine); កើតមកពី (ឧ. cheval qui sort d'un bon haras); របូតចេញ, ភ្លាត់ចេញ (ឧ. porte qui sort de ses gonds); លយ ឬ លៀនចេញ (ឧ. pierre qui sort du mur); បែកចេញ (ឧ. cette pensée ne sort pas assez); លេចចេញ, ដុះចេញ (ឧ. les canines sortent au dixième mois); បន្លឺ (ឧ. les mots ne sortent point)។

Loc. div. sortir à peine de la coquille ទើបនឹងញាស់(នៅក្មេងណាស់) ។ sortir du monde ស្លាប់ ។ sortir des mains de quelqu'un ទទួលការអប់រំអំពីសំណាក់អ្នកណាម្នាក់ ។ sortir de la mémoire ឬ de l'esprit de ភ្លេច ។ sortir de la tête de នឹកមិនឃើញ ។ sortir de soi-même បំភ្លេចខ្លួនឯង, មិនគិតដល់ខ្លួនឯង ។ sortir les pieds en avant ឬ les pieds devant ម.ព. devant ។ les yeux lui sortent de la tête គាត់ខឹងប្រឡេត ។ le feu lui sort par les yeux ភ្នែកគាត់ឡើងក្រហម (ដោយខឹង ឬ ដោយកេត) ។ ne pas sortir de នៅតែនឹងមាត់, និយាយមិនដាច់អំពីមាត់ (ឧ. jamais on ne le voit sortir du grand seigneur (Molière) ។ ne pas sortir de là ប្រកាន់ដាច់ (មិនព្រមបោលពាក្យ ឬ យោបល់ខ្លួន)។ je sors d'en prendre ខ្ញុំលែងត្រូវការទៀតហើយ, ខ្ញុំធុញទ្រាន់ណាស់ (ឧ. M'engagez? Merci je sors d'en prendre!) ។

sortez de là ចូរអ្នកដោះខ្លួនទៅ, ចូរអ្នកចេញទៅ។ d'où sortent-ils អ្នកណាកម្លោះ? ពីណាមកក្មេង? (ពាក្យមើលងាយ)។ d'où sortez-vous? តើអ្នកទើបនឹងមកពីណា (បានជាមិនដឹងរឿងនេះដែលគេដឹងគ្រប់គ្នា) ។ sortir des bornes ចេញហួសព្រំដែន ។ sortir de la vie ស្លាប់។ sortir des gonds ម.ព. gond ។ sortir de son caractère ទឹងខុសពីធម្មតា ។

v.t. ដឹកចេញ, នាំចេញ, បញ្ចេញ (ឧ. sortir les bœufs de l'étable); ទាញចេញពី, ជួយឲ្យរួចអំពី (ឧ. sortir quelqu'un d'embarras) ។ *Fam.* បណ្ដេញចេញ (ឧ. sortir un importun); បញ្ចេញលក់ (របស់ថ្មី) (ឧ. sortir un livre) ។ *v.imp.* កាយចេញ ។

au sortir de *loc. pré.* នៅពេលចេញ, នៅពេលផុត (ឧ. au sortir de l'école)

sortir *v.t. Dr.* មាន, បាន (ឧ. cette sentence, sortira son plein et entier effet)

S.O.S. *n.m.* (ព. បំប្រួញនៃ Save Our Souls = ជួយសង្គ្រោះអាយុយើងផង) ជួយផង (សញ្ញាដែលនាវា ឬយន្តហោះមានភ័យអាសន្នផ្ញើតាមវិទ្យុខ្សែលេខ) ។

Fam. demander un «S.O.S.» ឬ lancer un «S.O.S.» សុំគេជួយ

sosie *n.m.* អ្នកដែលដូចបេះបិទនឹងអ្នកណាមួយ

sot,sotte *a.* ភ្លីភ្លើ ។ *Par ext.* ស្រឡាំងកាំង (ឧ. il reste tout sot); គួរឲ្យស្ដាយ; គួរឲ្យអស់សំណើច (ឧ. sotte affaire) ។

n. មនុស្សភ្លីភ្លើ

sot-l'y-laisse *n.m. inv.* កន្ទុយមាន់ (?)

sottement *adv.* ដោយភ្លីភ្លើ

sottise *n.f.* ភាពភ្លីភ្លើ (ឧ. la vanité marque la sottise); អំពើ ឬ សំដីភ្លីភ្លើ (ឧ. ne faire que des sottises); ពាក្យជេរ (ឧ. il m'a dit des sottises)

sou *n.m.* សេន។ *Loc.div.* mettre sou sur sou សន្សំមួយសេនម្ដងៗ; សន្សំពីបន្តិចបន្តួច ។ sou à sou ឬ sou par sou មួយសេនម្ដងៗ, បន្តិច

ម្ដងៗ (ឧ. payer sou à sou)។ les quatre sous de ទ្រព្យបន្តិចបន្តួចរបស់... (ឧ. manger ses quatre sous) ។ n'avoir pas le sou ឬ être sans le sou ឬ sans un sou vaillant ឬ n'avoir ni sous ni maille គ្មានមួយសេន (គ្មានប្រាក់សោះ)។ n'avoir pas un sou de dette គ្មានជំពាក់អ្នកណាមួយសេនសោះ ។ n'avoir pas un sou de bien គ្មានទ្រព្យសម្បត្តិអ្វីបន្តិចសោះ ។ n'avoir pas un sou de ឬ pas pour un sou de គ្មានបន្តិចសោះ (ឧ. il n'a pas pour un sou de talent); មិនបានកម្រៃមួយសេនសោះអំពី... (ឧ. il n'aura pas un sou de ce tableau) ។ n'avoir pas le premier sou គ្មានមួយសេនផ្ដើមធ្វើការអ្វីមួយ ។ un sans le sou មនុស្សរហេម-រហាម (ឧ. se marier à un sans le sou) ។ ne pas valoir un sou គ្មានតម្លៃសោះ ។ ne pas rapporter un sou មិនបានផលមួយសេនសោះ ។ valoir... comme un sou មានតម្លៃ...រាប៉ូរ (ឬល្អប)ណាស់ទៅហើយ (ឧ. valoir mille riels comme un sou ថ្លៃ ១០០០រ ល្អបណាស់ទៅហើយ) ។ faire de cent sous quatre livres, et de quatre livres rien ខ្ជះខ្ជាយអស់, បំផ្លាញអស់ ។ au sou la livre ម្នាក់ៗបានតាមបំណុលដែលខ្លួនត្រូវបាន ។ *Fam.* être près de ses sous កំណាញ់មិនរះមួយសេន ។ être propre ឬ net comme un sou neuf ស្អាតរលីង

soubassement *n.m.* ជើងកោល, ផ្នែកខាងក្រោមនៃផ្ទះ

soubresaut *n.m.* ការផ្លោះ (សត្វ), ការភ្ញាក់ប្រឡេត (ឧ. le cheval fit un soubresaut) ។ *Fig.* ការញាប់ញ័រ, ការរើបក្ដាប់

soubrette *n.f.* កំលៀង (ក្នុងរឿងល្ខោន) (ឧ. les soubrettes jouent un grand rôle dans les pièces de Marivaux) ។ *Par ext.* ស្រីបម្រើក្នុងបន្ទប់

souche *n.f.* ជង្គត់ឈើ; ជើងជង់; មេសន្តតិវង្ស (ឧ. Robert de cler-

mont, sixième fils de Saint Louis, est la souche des Bourbons)។ *Fig.&Fam.* មនុស្សស្ពឹក (ដូចជង្គត់ឈើ); គល់ (បង្កាន់ដៃ) (ឧ. carnet à souches); ដើមកំណើត (ឧ.mot à souche indo-européenne)។

Loc. div. faire souche ៖ សន្តតិវង្ស, មានកូនចៅតវង្សត្រកូល។ être comme une souche ឬ ne pas se remuer plus qu'une souche នឹងដូចជង្គត់ឈើ (មិនកម្រើកសោះ)

souchon *n.m.* កូនជង្គត់

souchong ឬ **sou-chong** *n.m.* ស៊ូចុង (តែខ្មៅមកពីប្រទេសចិន)

souci *n.m.* បារម្ភ (ឧ. vivre sans souci); កង្វល់, របស់ជាទីគាប់ចិត្តដែលនាំឲ្យរវល់ (ឧ. mon fils est mon unique souci) ។ c'est là le moindre (ឬ le cadet) de mes soucis ខ្ញុំគ្មានបារម្ភនឹងរបស់នោះសោះ (ល៊ី. ennui, obsession, préoccupation, tourment, tracas)

soucier *v.t.* ធ្វើឲ្យបារម្ភ ។

se soucier *v.pr.* បារម្ភ, កើតទុក្ខ; យកចិត្តទុកដាក់ (ឧ. je ne m'en soucie guère)

soucieusement *adv.* ដោយបារម្ភ(ឧ. réfléchir soucieusement à l'avenir)

soucieux,euse *a.* ដែលបារម្ភ, ដែលព្រួយ (ឧ.mère soucieuse); ដែលយកចិត្តទុកដាក់ (ឧ. peuple soucieux de sa liberté); ដែលមានបារម្ភ (ឧ. air soucieux)

soucoupe *n.f.* ចានទ្រនាប់

soudable *a.* អាចផ្សារ ឬ ភ្ជាប់បាន

soudage *n.m.* ការផ្សារ, ការភ្ជាប់

soudain,e *a.* រហ័សណាស់ (ឧ. mort soudaine) ។ *adv.* ភ្លាម (ឧ. il apparut soudain)(ល៊ី. immédiat, instantané, prompt, rapide, subit)

soudainement *adv.* ភ្លាម

soudaineté *n.f.* ភាពរហ័សណាស់; ដំណើរមានឡើងភ្លាមៗ (ឧ. la soudaineté d'une attaque)

soudanais,e ឬ **soudanien,enne** *a.* នៃប្រទេសស៊ូដង់។ *n.* ជនជាតិស៊ូដង់

soudard *n.m.* *Autref.* ទាហាន ។

Arg. មនុស្សកម្រោល

soude *n.f.* ក្បុង

souder *v.t.* ផ្សារភ្ជាប់គ្នា, តភ្ជាប់គ្នា ។ *Fig.* រួបរួមគ្នា, មូលគ្នា (ឧ. ils étaient soudés autour de leur chef) ។

se souder *v.pr.* លាយជាប់គ្នា, ដុះជាប់គ្នា (ឧ. deux os qui se soudent)

soudeur,euse *n.* អ្នកផ្សារ ឬ ភ្ជាប់

soudier,ère *a.* នៃក្បុង (ឧ. industrie soudière) ។

n.m. អ្នកធ្វើក្បុង ។ *n.f.* រោងចក្រធ្វើក្បុង

soudoyer *v.t.* ជួល (ឲ្យជួយធ្វើអំពើមិនល្អ) ។ soudoyer des assassins ជួលឃាតកជន

soudure *n.f.* ទឹកបន្សារ; ការផ្សារ; បន្សារ; ឬទបន្សារ; កិច្ចការផងផ្សារ ។ *Fig.* ការជួប; ការប្រជុំវត្ថុទុសគ្នា ។ faire la soudure ធ្វើសន្ធិ, សំចៃទុកឲ្យប្រើគ្រប់គ្រាន់ដល់ពេលមានមកថ្មីទៀត ។ période de soudure សន្ធិសម័យ

soue *n.f.* ទ្រុងជ្រូក

soufflage *n.m.* ការផ្លុំ; របៀបផ្លុំធ្វើកែវ

souffle *n.m.* ខ្យល់ផ្លុំ (ឧ. éteindre une bougie avec son souffle); ដំណើរបក់នៃខ្យល់ (ឧ. le souffle des vents); សំទុះខ្យល់ (បណ្ដាលអំពីការផ្ទុះអ្វីមួយ)(ឧ. l'effet de souffle d'une explosion atomique est considérable); អស្សាសៈ, ខ្យល់ដកដង្ហើមចេញ (ឧ. écouter le souffle d'un malade); ការភាយចេញ; ក្លិន (ដែលភាយចេញ) (ឧ. souffles empoisonnés des marécages); ការដកដង្ហើម (ឧ. reprendre son souffle) ។ *Méd.* សូរខុសពីធម្មតា (នៃអាការៈដែលដើរមិនស្រួល) (ឧ. souffle cardiaque) ។ *Fig.* គំនិតដែលផុសឡើង (ឧ. le souffle du génie) ។

Loc. div. manque de souffle ដំណើរហត់ហេបៗ (ស្ទើរផុតដង្ហើមឬដកដង្ហើមមិនដល់គ្នា) ។ n'avoir plus que le souffle នៅតែដង្ហើមផ្ដួង (ជិតស្លាប់) ។ ne tenir qu'à un souffle ខ្យល់បក់រលំ, មិនមាំមួន

soufflement *n.m.* ការផ្លុំ, ការបក់

souffler *v.i.* បក់ (ខ្យល់)(ឧ. la bise souffle); ផ្លុំ (ឧ. souffler dans ses doigts); ដកដង្ហើមដោយលំបាក (ឧ.souffler comme un bœuf); សម្រាក (ឲ្យបាត់ហត់) (ឧ. laisser les chevaux souffler) : ថ្ងូច (ប្រើ) ។

v.t. សប់, ផ្លុំ (ឲ្យឆេះ)(ឧ.souffler le feu); លត់ (ភ្លើង)(ឧ.souffler la chandelle); ប្រាប់,បណ្ដោ, ឲ្យយោបល់ (ឧ. souffler une bonne idée à quelqu'un); ខ្សឹបប្រាប់ (ឧ. souffler à quelqu'un sa leçon);ផ្លុំបញ្ចូលខ្យល់; សប់ស្នប់ ។

Loc. div. souffler le verre ផ្លុំកែវ ។ souffler la discorde ញុះញង់ឲ្យទាស់ទែងគ្នា ។ ne pas souffler mot គ្មាននិយាយមួយម៉ាត់។ *Fam.* souffler un emploi à quelqu'un ដណ្ដើមយកដំណែងអ្នកណាម្នាក់

soufflerie *n.f.* គ្រឿងស្នប់

soufflet *n.m.* ស្នប់

soufflet *n.m.* ការទះកំភ្លៀង ។ *Fig.* ការប្រមាថ (ឧ. il a reçu un rude soufflet)

souffleter *v.t.* ទះកំភ្លៀង ។ *Fig.* ប្រមាថ, មើលងាយ

souffleur,euse *n.* អ្នកខ្សឹបប្រាប់ (ក្នុងល្ខោន) ។ *n.m.* ជាងផ្លុំកែវ

soufflure *n.f.* ប្រហោងក្នុងវត្ថុសិតម្ពុត (មានកែវជាដើម)

souffrance *n.f.* ការឈឺចាប់ (ក្នុងកាយ ឬក្នុងចិត្ត); ភាពអ្នកឈឺចាប់ (ឧ. être dur à la souffrance) (មើ. affliction, mal, peine, tourment) ។ *Fig.* en souffrance អនិច្ឆ័យ, ដែលគេមិនទាន់សម្រេច ឬមិនទាន់បាត់ការ (ឧ. affaire en souffrance) ; ដែលមិនទាន់មានគេស្គាល់ (ឧ. colis en souffrance)

souffrant,e *a.* ដែលឈឺ, មិនស្រួលខ្លួន (ឧ. personne infirme et souffrante); ដែលចេះអត់ធ្មត់

souffre-douleur *n.m.* អ្នកដែលគេធ្វើបាបជានិច្ច

souffreteux,euse *a.* ដែលឈឺជាធម្មតា; ស្គម (ឧ. un enfant souffreteux)

souffrir *v.t.* អត់ទ្រាំ, ធន់, ទ្រាំ (ឧ. il ne peut souffrir le men-

songe); អនុញ្ញាត (ឧ. souffrez que je vous parle); អាចនឹង, បណ្ដោយឲ្យ (ឧ. cela ne souffre aucun retard) ។ souffrir le martyre ឈឺចាប់ខ្លាំង។ ne pouvoir souffrir une personne ស្អប់អ្នកណាម្នាក់, ឃើញមុខមិនបាន ។ souffrir la faim ទ្រាំឃ្លាន ។ souffrir la soif ទ្រាំស្រេក។

Prov. le papier souffre tout ក្រដាសមិនចេះប្រកែក ឬ មិនចេះរា (គេអាចសរសេរអ្វីគ្រប់យ៉ាងលើក្រដាសបាន ទុកជាត្រូវក្ដី, ខុសក្ដី,ល្អក្ដី, អាក្រក់ក្ដី) ។

v.i. ឈឺចាប់(ក្នុងកាយឬក្នុងចិត្ត) (ឧ. il est malade et souffre beaucoup) ។ souffrir de ឈឺត្រង់ (កន្លែងណាមួយ) (ឧ. souffrir de la tête ឈឺក្បាល); កើតទុក្ខដោយ (ឧ. souffrir de la faim); ខូចខាតដោយ (ឧ. les vignes ont souffert de la grêle) ។

se souffrir *v.pr.* ទ្រាំនឹងខ្លួនឯង(ឧ. si l'homme se connaissait, il ne pourrait se souffrir);ទ្រាំឬអត់គ្នាទៅវិញទៅមក (ឃ.accepter, endurer, pâtir, subir, supporter)

soufrage *n.m.* ការជ្រលក់ស្ពាន់ធ័រ (គ្រាប់ឈើគូស);ការបាញ់ម្សៅស្ពាន់ធ័រ (លើរុក្ខជាតិ) (ឧ. le soufrage de la vigne prévient l'oïdium)

soufre *n.m.* ស្ពាន់ធ័រ

soufrer *v.t.* ជ្រលក់ស្ពាន់ធ័រ (ឧ. soufrer des allumettes);រោលផ្សែងស្ពាន់ធ័រ (ឧ. soufrer des laines) ។ soufrer un tonneau ដុតស្ពាន់ធ័រក្នុងធុងឈើ (ដើម្បីសម្លាប់មេរោគ)

soufreur,euse *n.* អ្នកបាញ់ម្សៅស្ពាន់-ធ័រ ។ *n.f.* ប្រដាប់បាញ់ម្សៅស្ពាន់ធ័រ

soufrière *n.f.* កន្លែងយកស្ពាន់ធ័រ

soufroir *n.m. Ind.* បន្ទប់បោកសំអាតសំលៀកបំពាក់(ដោយប្រើស្ពាន់-ធ័រ)

souhait *n.m.* សេចក្ដីប្រាថ្នា, ពរ (ឧ. des souhaits de bonheur) ។ à vos souhaits ស្បើយ! (ពាក្យសម្រាប់ពោល កាលណាអ្នកណាម្នាក់កណ្ដាស់)។ à souhait *loc.adv.* ដូចសេចក្ដីប្រាថ្នា, ដូចបំណង (ឧ.

tout lui réussit à souhait)

souhaitable *a.* គួរប្រាថ្នា,គួរបង់បាន

souhaiter *v.t.* បង់បាន, ប្រាថ្នា (ឧ. souhaiter du bien à tous) ; ប្រសិទ្ធពរ (ឧ. souhaiter la bonne année)។ je vous en souhaite អ្នកមិនបានដូចប្រាថ្នាទេ

souillard *n.m.* រន្ធចាក់ទឹក (រន្ធនៅជញ្ជាំង ឬ នៅរនាបសម្រាប់ចាក់ទឹក)

souillarde *n.f.* កន្លែងបោកខោអាវ

souille *n.f.* ភ្លាបជ្រូកព្រៃ។ *Mar.* ស្នាមនាវាកៀនក្នុងភក់; ស្នាមគ្រាប់បែកធ្លាក់លើដី

souiller *v.t.* ធ្វើឲ្យមានមន្ទិល, ធ្វើឲ្យប្រឡាក់។ *Fig.* បង្ខូច(កិត្តិយសឬកិត្តិនាម) (ឧ. souiller sa réputation)។ souiller les mains de sang ប្រព្រឹត្តឃាតកម្ម

souillon *n. Fam.* មនុស្សកខ្វក់ (ឧ. un petit souillon)

souillure *n.f.* មន្ទិល, អ្វីៗដែលធ្វើឲ្យប្រឡាក់; ស្នាមប្រឡាក់; ភាពប្រឡាក់ (ឧ. vêtement couvert de souillures)។ *Fig.* ដំណើរសៅហ្មង(ឧ. la souillure du péché)

souk *n.m.* (ព.អារ៉ាប់) ផ្សារ,ហាងអារ៉ាប់

soûl,e *a.* ស្រវឹង។ *Fig.* être soûl de... ឆ្អែតឆ្អន់នឹង, ធុញនឹង។

n.m. Fam. en avoir tout son soûl តាមចិត្ត

soulagement *n.m.* ដំណើរធូរ-ស្បើយ ឬ ស្រាក (ខាងផ្លូវកាយនិងផ្លូវចិត្ត) (ឧ. apporter du soulagement)

soulager *v.t.* ជួយសំរាលបន្ទុក(ឧ.soulager un porteur trop chargé)។ *Fig.* ធ្វើឲ្យធូរ-ឲ្យស្បើយ ឬ ឲ្យស្រាក (ឧ. soulager la douleur); ជួយដោះទុក្ខ (ឧ. soulager les malheureux); សម្រាលការ (ឧ. la machine a-t-elle soulagé l'ouvrier?) ។ *Techn.* សម្រាល,បន្ថយបន្ទុក (ឧ. soulager une poutre qui fatigue)។

se soulager *v.pr.* បានធូរ, បានស្បើយ ។ *Fam.* បន្ទោបង់ (ព៏. alléger, apaiser, calmer)

soûlard,e *n. & a.Pop.* ស្រវឹងខ្លួប(ឧ. un vieux soûlard)

soûlaud,e *n.&.a. Pop.* ស្រវឹងខ្លួប

soûler *v.t. Pop.* បញ្ឆ្លកកេសដ្ឋៈ, ធ្វើឲ្យស្រវឹង ។ se soûler *v.pr. Pop.* ស្រវឹង; ឆ្អែត, ស្កប់ (ឧ. il se soûle

de phrases vides de sens)

soulèvement *n.m.* ការរំជួល (ឧ. soulèvement des flots) ។ soulèvement de cœur ការឆ្អើម ។ ការងើបឡើងឬហើបឡើង ។ *Géol.* ដំណើររញ្ជួយផែនដី ។ *Fig.* កុប្បកម្ម [កុប-ប៉ះ-], ការបះបោរ

soulever *v.t.* លើក (ឧ. soulever un fardeau); បង្ហុយ (ឧ. soulever la poussière) ។ *Fig.* ធ្វើឲ្យខឹង ឬ ឲ្យអាក់អន់ចិត្ត (ឧ. son insolence souleva l'assemblée) ; បង្កកុប្បកម្ម, នាំបះបោរ (ឧ. soulever le peuple) ។ soulever une question លើករឿងមកជជែក, បង្កើតបញ្ហា ។ soulever le cœur នាំឲ្យឆ្អើម។ soulever un voile បង្ហាញតែភាគខ្លះ ។

se soulever *v.pr.* *Fig.* ធ្វើកុប្បកម្ម, បះបោរ ។ le cœur se soulève ឆ្អើម, រអើម

soulier *n.m.* ស្បែកជើង; (រ.ស.) ព្រះសុពណ៌បាទ ។ *Fig.* & *Fam.* n'avoir pas de souliers ក្រណាស់ (គ្មានអ្វីបន្តិចសោះ) ។ être dans ses petits souliers កំពុងតែបង្អៀតចិត្ត (ដោយស្ថានភាពពិបាក)

soulignement *n.m.* ការដឹកបន្ទាត់ពីក្រោម

souligner *v.t.* គូសពីក្រោម, ដឹកបន្ទាត់ពីក្រោម (ឧ. souligner un mot); ទាញសម្បជញ្ញៈ (ឧ. il est inutile de souligner ce que vous voulez dire)

soulographie *n.f.Fam.* ភាពស្រវឹងខ្លប, ការស៊ីផឹកហួសប្រមាណ

soulte *n.f.* ប្រាក់បន្ថែម (ឲ្យស្មើតម្លៃគ្នាក្នុងការដូររបស់អ្វីមួយជាដើម)

soumettre *v.t.* ធ្វើអនុកូល, ដាក់ក្រោមអំណាចខ្លួន; បង្ក្រាប, ពង្រាប (ឧ. soumettre des rebelles) ; បង្ក្រាប, ជំនះ (ឧ. soumettre ses passions) ។ *Fig.* soumettre à ដាក់ជូនពិនិត្យ (ឧ. je vous soumets un projet, une demande) ។

se soumettre *v.pr.* ចុះចូល, ប្រតិបត្តិតាម (ឧ. je me soumets à sa décision)

soumis,e *a.* ចំណុះចុះចូល, ដែលចេះស្តាប់បង្គាប់, មិនរឹងរូស (ឧ enfant soumis; air soumis ទំនងជា

មិនរឹងរូស, ទំនងជាពេះស្តាប់បង្គាប់)

soumission *n.f.* អនុកូលភាព, ប្រតិ-ពាទន៍ (ការពេះស្តាប់បង្គាប់ ឧ. soumission parfaite ; ការស្តាប់បង្គាប់, ការចុះចូល ឧ. cette ville a fait sa sovmission; កិច្ចសន្យាទទួលការ)

soumissionnaire *n.m.* អនុកូលជន, ប្រតិបាទី (អ្នកចុះកិច្ចសន្យាទទួលការ)

soumissionner *v.t.* ប្រតិបាទ (ចុះកិច្ចសន្យាទទួលការ)

soupape *n.f.* ស៊ូប៉ាប, សន្ទះស្ទប់

soupçon *n.m.* អាសង្កា, សេចក្ដីឬការសង្ស័យ (ឧ. conduite exempte de tout soupçon); ការមន្ទិល(ឧ. j'ai quelque soupçon que c'est lui); អាការៈក្រៅ ឬហេតុភេទបន្តិចបន្តួច(ដែលនាំឲ្យសង្ស័យ) (ឧ. il n'y a pas le moindre soupçon d'hypocrise dans sa conduite) ។ *Fam.* បំនួនស្តួចស្តើង(តិចណាស់) (ឧ.un soupçon de vin)

soupçonnable *a.* គួរសង្ស័យ (ឧ. sa conduite est soupçonnable)

soupçonner *v.t.* មានអាសង្កា,សង្ស័យ (ឧ. soupçonner quelqu'un de fraude) ; មន្ទិល, ស្មាន (ឧ. je soupçonne une ruse de sa part) (ពវ. se douter, flairer, pressentir, suspecter)

soupçonneusement *adv.* ដោយអាសង្កា, ដោយសង្ស័យ

soupçonneux,euse *a.* ដែលមិនទុកចិត្ត, ដែលពេះតែសង្ស័យ (ឧ. esprit soupçonneux)

soupe *n.f.* ស៊ុប, បបរ ។ *Fam.* អាហារទាហាន (ឧ. aller à la soupe); ស្មៅជ្រលក់ទឹកដើម្បីបញ្ចូកសត្វ ។ *Fam.* marchand de soupe នាយភោជនីយដ្ឋាន ។ soupe au lait *n.f.* អ្នកចិត្តស្រាល, អ្នកឆាប់ខឹង ។ soupe de perroquet នំប៉័ងជ្រលក់ស្រាទំពាំងបាយជូរ ។

Loc. div. tremper la soupe ជ្រលក់ស៊ុប (នំប៉័ង)។ *Fig. & Pop.* tremper une soupe à quelqu'un វាយអ្នកណាម្នាក់ ។ dès la soupe តាំងពីទើបនឹងបាប់បរិភោគ ។ venez manger ma soupe ឬ la soupe avec moi អញ្ជើញមកពិសាបាយផ្ទះខ្ញុំ ។ sa sou-

pe est bien maigre ម្ហូបគាត់មិនឆ្ងាញ់សោះ។ quelqu'un lui a mangé sa soupe ឬ le dessus de sa soupe គាត់មួម៉ៅ(មិនសប្បាយចិត្ត)។ soupe populaire កន្លែងចែកអាហារជាសាធារណ៍ ។

Loc. prov. tremper comme une soupe ទទឹកជោក។ s'emporter comme une soupe au lait ចិត្តស្រាលណាស់,ឆាប់ខឹងណាស់ ។ ivre comme une soupe ទទឹកស្រាជោក; ស្រវឹង ។ la soupe fait le soldat ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ ។ il faut mesurer sa soupe à sa bouche ដាំដើងក្រានឲ្យប្រមាណនឹងឆ្នាំង; ត្រូវលៃចំណាយឲ្យល្មមនឹងធនធានខ្លួន

souper *n.m.* អាហារពេលល្ងាច; អាហារពេលយប់ជ្រៅ; ម្ហូបពេលល្ងាច (ឧ. il y avait un bon souper)

souper *v.i.* បរិភោគអាហារពេលល្ងាច ឬ ពេលយប់ជ្រៅ ។ *Pop.* avoir soupé d'une chose ធុញទ្រាន់នឹងរបស់អ្វីមួយ

soupeser *v.t.* ថ្លឹងនឹងដៃ

soupeur, euse *n.* អ្នកធ្លាប់បរិភោគយប់ជ្រៅ (ក្រោយពីមើលល្បែងកំសាន្ត)

soupier, ère *a. Fam.* ដែលចូលចិត្តស៊ុប

soupière *n.f.* ចានស៊ុប

soupir *n.m.* ការដកដង្ហើមធំ(ឧ. pousser de profonds soupirs) ។ *Poét.* សំឡេងពីរោះគួរឲ្យស្រងេះស្រងោច (ឧ. les soupirs du vent dans les bois) ។ *Mus.* ដង្ហើម។ jusqu'au dernier soupir រហូតដល់ស្លាប់ ។ rendre le dernier soupir ផុតដង្ហើម(ស្លាប់)

soupirail *n.m.* បង្អួចបន្ទប់ក្នុងដី (*pl.* des soupiraux)

soupirant *n.m.* អ្នកចង់បានប្រពន្ធ (ឧ. écarter les soupirants)

soupirer *v.i.* ដកដង្ហើមធំ។ soupirer d'amour pour quelqu'un ស្នេហាលើអ្នកណាម្នាក់, ស្រឡាញ់អ្នកណាម្នាក់ ។

v.t. ind. (après) *Fig.* ចង់បានខ្លាំង (ឧ. soupirer après une place)

souple *a.* សុពប:, ទន់ (ឧ. osier, étoffe souple); ទន់ភ្លន់ (ឧ.

la gymnastique rend souple) ។ *Fig.* សុពចះ, មិនរឹងរូស, ងាយដឹកនាំ (ឧ. avoir un caractère souple) ។ avoir l'échine souple ឬ les reins souples ម.ព. échine

souplement *adv.* យ៉ាងទន់ភ្លន់

souplesse *n.f.* សុពចភាព, ភាពទន់ភ្លន់ ។ *Fig.* ភាពងាយពត់ · ងាយស្ដីប្រដៅ ឬងាយដឹកនាំ; ភាពចេះសំរបតាមកាលៈទេសៈ និងតាមបំណងអ្នកដទៃ (ឧ. manquer de souplesse)

souquenille *n.f.* អៀមជ្រោមប៉ាង ។ *Par ext.* សំលៀកបំពាក់សឹក

souquer *v.t. Mar.* ចងក្រៀក, ចងត្រដែង(ឧ.souquer une amarre) ។

v.i. ទំប្រឹង (ឧ. souquer aux avirons)

source *n.f.* ប្រភព (កន្លែងទឹកផុសចេញពីក្នុងដី) ។ *Fig.* ប្រភព (កន្លែងយកវត្ថុអ្វីមួយ ឧ. le Moyen-Orient est une source de pétrole; ដើមហេតុ ឧ. le travail est une source de richesse;ឯកសារដើម ឧ. les nombreuses sources de l'histoire contemporaine) ។ eau de source ទឹកប្រភព។ source souterraine ប្រភពក្នុងដី ។

Loc. div. sources de la vie ប្រភពនៃជីវិត (អាការៈជាសារវន្តនៃជីវិត) ។ tenir une nouvelle de bonne source បានដំណឹងពីប្រភពច្បាស់ការណ៍ (បានដំណឹងពីអ្នកដឹងការណ៍ច្បាស់)។ *Fig.* chose qui coule de source វត្ថុដែលកើតឡើងដោយងាយ ។

Loc.adv. de source ដោយងាយ,ដោយឥតប្រឹង(ឧ.éloquence qui coule de source)

sourcier,ère *n.* អ្នករកប្រភពទឹក(ដោយប្ញលចង្កឹះ)

sourcil [– si] *n.m.* ចិញ្ចើម; រ.ស.ភម្ញ: រោមចិញ្ចើម(ឧ.avoir les sourcils très fournis) ។ *Fig.* froncer le sourcil ចងចិញ្ចើម (សំដែងកំហឹង ឬសេចក្ដីមិនសប្បាយចិត្ត)

sourcilier,ère *a.* នៃចិញ្ចើម (ឧ. l'arcade sourcilière)

sourciller *v.i.* ញាក់ចិញ្ចើម; ចងចិញ្ចើម

(សំដែងអំពីការអន់ចិត្តឬសេចក្ដីធ្ងន់) ។ *Fig.* sans sourciller ឬ ne pas sourciller គ្មានព្រើម (ឧ. entendre sans sourciller la décision des juges)

sourcilleux,euse *a.* ដែលបង្កិតចិញ្ចើម (ដោយខ្ញើង) (ឧ. il se montre à votre égard très sourcilleux) ។ front sourcilleux ក្រអឺតក្រអោង

sourd,e *a.* ថ្លង់, ត្រចៀកធ្ងន់ (ឧ. devenir sourd); ឥតមេត្តា (ឧ. sourd à la pitié); ខ្សោយ (សំឡេង) (ឧ. voix sourde); ខ្ទរហ៊ឹង (ស្អូ) (ឧ. bruit sourd); មិនច្បាស់, មិនប្រាកដ (ឧ. une rumeur sourde se répand); ដោយស្ងាត់ (គ្មានអ្នកណាដឹងឮ) (ឧ. guerre sourde) ។ *Fig.* មិនស្ដាប់, មិនចង់ដឹង, មិនចង់ឮ (ឧ. sourd aux avis, à la vérité)។

Loc. div. Fam. sourd comme un pot ឬ comme une pioche ឬ comme une bécasse ឬ sourd à ne pas entendre Dieu tonner ម.ព. pot ។ faire la sourde oreille ធ្វើថ្លង់, ធ្វើជាមិនឮ ឬ មិនយល់ ។ lime sourde ដែកអង្រុសមុត(មិនឮស្អូ) ។ lanterne sourde ម.ព. lanterne ។

— *n.* មនុស្សថ្លង់ (ឧ. un sourd de naissance) ។ frapper comme un sourd វាយដោយឥតមេត្តា ។ crier comme un sourd ស្រែកបណ្ដាល ។ autant vaudrait parler à un sourd និយាយនឹងអ្នកនេះឥតបានការអ្វីសោះ (ព្រោះមិនព្រមស្ដាប់)។

Prov. il n'est pire sourd que celui qui ne veut pas entendre ថ្លង់អ្វីមិនស្មើនឹងអ្នកមិនចង់ស្ដាប់

sourdement *adv.* យ៉ាងខ្ទរហ៊ឹង (យ៉ាងថ្លង់) (ឧ. le tonnerre grondait sourdement); យ៉ាងស្ងាត់ (លួចលាក់) (ឧ. agir sourdement)

sourdine *n.f.* ប្រដាប់ដាក់គ្រឿងភ្លេងកុំឲ្យឮខ្លាំងពេក។ *Fig.* mettre une sourdine à ធ្វើកុំឲ្យឮស្មុសស្មាយពេក; ធ្វើកុំឲ្យចេញស្ដែងពេក (ឧ. mettre une sourdine à ses

prétentions) ។ à la sourdine ឬ en sourdine *loc.div.* តិចៗ (ស្ងួរ): យ៉ាងស្ងាត់កំបាំង, ដោយលួចលាក់

sourd-muet, sourde-muette *n.* មនុស្សថ្លង់គ, មនុស្សថ្លង់ផងគផង (*pl.* des sourds-muets; des sourdes muettes)

sourdre *v.i.* ហូរចេញពីក្នុងដី ។ *Fig.* មានលទ្ធផល; ចេញ, មាន, កើត (ឧ. à côté de l'idée de puissance commence à sourdre l'idée de justice)

souriant,e *a.* ដែលញញឹម (ឧ. un visage souriant)

souriceau *n.m.* កូនកណ្ដុរ

souricier *n.m.* ដែលចាប់ ឬ ស៊ីកណ្ដុរ (ឧ. le hérisson est un excellent souricier)

souricière *n.f.* អន្លប់កណ្ដុរ ។ *Fig.* កន្លែងដែលក្រុមប៉ូលីសស្ទាក់ចាំចាប់មនុស្សខូច; *par ext.* អន្ទាក់; អន្លប់ (ឧ. se jeter dans une souricière)

souriquois,e *a. Fam.* le peuple souriquois កណ្ដុរទាំងឡាយ

sourire *v.i. & t.* ញញឹម ។ *Fig.* ញញឹមរក (ភេទភាពគួររីករាយ ឧ. tout sourit à la jeunesse; អនុគ្រោះ (ឧ. la fortune lui sourit); ត្រូវចិត្ត, ឲ្យចូលចិត្ត (ឧ. cette affaire me sourit)

sourire *n.m.* ការញញឹម (ឧ. sourire engageant)

souris *n.m.* ការញញឹមបន្តិចៗ

souris *n.f.* កណ្ដុរ ។ on entendrait trotter une souris ស្ងាត់ជ្រៀប (ទាល់តែឮសម្រឹបជើងកណ្ដុរ)

sournois,e *a.* ដែលលាក់គំនិត (ឧ. homme sournois); ដែលលាក់ពុត (ឧ. un air sournois) (ស្រ. dissimulé, faux, fourbe, hypocrite)

sournoisement *adv.* ដោយលាក់គំនិត ឬ លាក់ពុត (ឧ. desservir sournoisement un concurrent)

sournoiserie *n.f.* ការលាក់ពុត (ព.ផ. franchise)

sous *pré.* ក្រោម (ឧ. mettre un oreiller sous sa tête); ក្នុង (ក្នុងពេល) (ឧ. sous le règne du roi Ang Duong ក្នុងរជ្ជកាលនៃ

ព្រះបាទអង្គខ្លួន) ; នឹង (សំគាល់មធ្យោបាយ) (ឧ. écraser un serpent sous ses pieds); ដោយ (សំគាល់ហេតុ) (ឧ. agir sous l'empire de la colère ប្រព្រឹត្តដោយអំណាចកំហឹង); ខាង (សំគាល់ទស្សនៈ) (ឧ. voir les choses sous un mauvais jour ឃើញរបស់ទាំងឡាយតែខាងអាក្រក់); ក្រោម (សំគាល់លក្ខខ័ណ្ឌ) (ឧ. sous votre responsabilité); ក្រោម (សំគាល់ការទាក់ទង, ភាពចំណុះ) (ឧ. il a cent hommes sous ses ordres) ។

Loc. div. sous peu បន្តិចទៀត។ sous ce rapport ចំពោះរឿងនេះ ។ sous prétexte de ដោយអាងលេសថា ។ être sous clef ជាប់សោ, ត្រូវគេចាក់សោទុក ។ sous peine de ដោយមានទោស (ប្រសិនជាប្រព្រឹត្តរំលង) (ឧ. sous peine de mort; sous peine d'amende) ។ être sous les drapeaux បម្រើក្រោមទង់ជាតិ, ធ្វើទាហាន ។ être sous les armes កាន់អាវុធត្រៀមខ្លួន; បម្រើក្នុងកងទ័ព។ avoir sous la main មាននៅជិតដៃ (ល្មមលូកដល់ ឬត្រូវការបានភ្លាម)។ agir sous main ប្រព្រឹត្តដោយសម្ងាត់ ។ passer sous silence ម.ព. silence ។ regarder quelqu'un sous le nez ឈ្ងោកមើលជិតមុខ (ឈ្ងោកមើលជិតដោយចង់ដឹង)

sous-acquéreur *n.m.* អ្នកជាវត, អ្នកទិញត

sous-agent *n.m.* ភ្នាក់ងាររង

sous-aide *n.m.* អ្នកជំនួយ

sous-alimentation *n.f.* ឱនាហារូបត្ថម្ភ (ការទទួលអាហារមិនគ្រប់គ្រាន់)

sous-alimenter *v.t.* ឱនាហារូបត្ថម្ភ, ឲ្យអាហារមិនគ្រប់គ្រាន់

sous-ambassade *n.f.* តំណែងឯកអគ្គរាជទូតរង (បេសកកម្មក្រោមឱ្វការទទួលអំពីឯកអគ្គរាជទូត)

sous-ambassadeur *n.m.* ឯកអគ្គរាជទូតរង (ប្រតិភូក្រោមឱ្វការនៃឯកអគ្គរាជទូត)

sous-amendement *n.m.* ការកែប្រែផ្ទួន (កែប្រែលើការកែប្រែមុន) (*pl.* des sous-amendements)

sous-arbrisseau *n.m.* អនុគុម្ពព្រឹក្ស

sous-archiviste *n.m.* អ្នករក្សាឯកសាររង

sous-bail *n.m.* កិច្ចសន្យាជួលបន្ត(*pl.* des sous-baux)

sous-bailleur,euse *n.* អ្នកជួលបន្ត

sous-barbe ឬ **soubarbe** *n.f. inv.* *Fam.* ការដាល់ស៊ើយបង្កា

sous-bibliothécaire *n.* បណ្ណារក្សរង (*pl.* des sous-bibliothécaires)

sous-bois *n.m.* រុក្ខជាតិរប (កូនឈើដែលដុះក្រោមឈើធំៗ ក្នុងព្រៃ); រូបគំនូរក្នុងព្រៃ

sous-bourgeon *n.m.* ខ្នែងរាប

sous-brigadier *n.m.* ត្រួតរង(*pl.* des sous-brigadiers)

sous-chef *n.m.* នាយរង ។ sous-chef de bureau នាយការិយាល័យរង ។ sous-chef d'Etat-major នាយសេនាធិការរង (*pl.* des sous-chefs)

sous-clavier,ère *a.Anat.* ក្រោមឆ្អឹងដងកាំបិត (ឧ. veine sous-clavière)

sous-commissaire *n.m.Mar.* អនុស្នងការ

sous-commission *n.f.* អនុគណៈកម្មការ

sous-comptoir *n.m.* អនុគណកនីយដ្ឋាន

sous-conjonctival,e,aux *a.Anat.* ក្រោមយុជា (ឧ. glandes sous-conjonctivales)

sous-consommation *n.f.* ឱនបរិភោគ (បរិភោគតិចជាងបរិភោគមធ្យម ឬ បរិភោគអប្បបរមា; បរិភោគតិចជាងការត្រូវការ)

sous-costal,e,aux *a.* ក្រោមឆ្អឹងជំនីរ

souscripteur *n.m.* បរិសករ [ប៉ះ-រ៉ិ-រិ-សះ-] (អ្នកយល់ព្រមតាមផលប័ត្រ ឧ. le souscripteur d'une lettre de change; ការចូលហ៊ុន; ការចុះកិច្ចសន្យា ឧ. les souscripteurs à un emprunt)

souscription *n.f.* បរិសកម្ម [ប៉ិះ-រ៉ិ-រិ-សះ-] (ការចុះហត្ថលេខាខាងក្រោមលិខិតដើម្បីយល់ព្រមតាមលិខិតនោះ ; ការចុះកិច្ចសន្យាចូលហ៊ុនក្នុងសហគ្រាសមួយ ឬ ទិញសៀវភៅកំពុងបោះពុម្ព); បរិសទាន (ចំនួនប្រាក់ដែលអ្នកចុះកិច្ចសន្យាត្រូវបង់) ។ droit de souscription សិទ្ធិបរិសកម្ម (ឯកសិទ្ធិ

ដែលឲ្យអ្នកចូលហ៊ុនមានអាទិភាពគម្លើង មូលធន)

souscrire *v.t.* ធ្វើបរិវិសកម្ម (ចុះហត្ថលេខាខាងក្រោមលិខិតដើម្បីយល់ព្រមតាមលិខិតនោះ ឧ. souscrire une obligation) ។ *v.t. ind.* (à) យល់ព្រម, ទទួល (ឧ. souscrire à un arrangement) ។

v.i. ធ្វើបរិវិសកម្ម ឬ បរិវិសទាន (ចូលហ៊ុន; ចុះកិច្ចសន្យាចូលក្នុងសហគ្រាសមួយ ឧ. souscrire pour un monument; ចុះកិច្ចសន្យាទិញសៀវភៅកំពុងបោះពុម្ព)

sous-cutané,e *a.* ក្រោមស្បែក (ឧ. injection sous-cutanée)

sous-délégation *n.f.* ម.ព. subdélégation

sous-délégué *n.m.* ម.ព.subdélégué

sous-déléguer *v.t.* ម.ព. subdéléguer)

sous-développé,e *a.* ឧនាភិវឌ្ឍ [អូ-នា-ភិ-វ័ឌ], រាភិវឌ្ឍមិនគ្រប់គ្រាន់ ។ pays sous-développé ប្រទេសឧនាភិវឌ្ឍ (ប្រទេសដែលឋានៈជីវភាពនៃអ្នកស្រុកនៅទាប ដោយហេតុអាជីវកម្មនៃផលទុនខាងកសិកម្មនិងខាងរ៉ែនៅតិច និងអភិវឌ្ឍន៍ខាងឧស្សាហកម្មមិនទាន់គ្រប់គ្រាន់)

sous-directeur *n.m.* នាយករង ឬ ចាងហ្វាងរង

sous-directrice *n.f.* នាយិកា ឬ ចាងហ្វាងស្ត្រីរង

sous-dominante *n.f.* *Mus.* គាន សំខាន់ក្រោម

sous-économe *n.m.* អគ្គារូបដ្ឋាករង (*pl.* des sous-économes)

sous-embranchement *n.m.* *Hist. nat.* សាខារង

sous-emploi *n.m.* ឩននិយោជន៍ [អូ-នៈ-]

sous-entendre *v.t.* ថ្លែងដោយបេយ្យាលន័យ; ធ្វើឲ្យយល់ដោយមិនបាច់សំដែងឡើង ។ *Fig.* មានជាលក្ខណ៍ (ឧ. l'anarchie sous-entend la faiblesse du gouvernement)

sous-entendu *n.m.* បេយ្យាលន័យ, ន័យដែលគេមិនបាច់សំដែងឡើង (ឧ. parler par sous-entendu)

sous-entrepreneur *n.m.* អនុសហគ្រិន (សហគ្រិនដែលទទួលការបន្តពី

សហគ្រិនមួយទៀត)

sous-enveloppe *n.f.* ស្រោមក្នុង (ស្រោមដែលនៅក្នុងស្រោមមួយទៀត)

sous-épidermique *a.* ក្រោមអធិតច, ក្រោមស្បែកសើ (ឧ. tissu sous-épidermique)

sous-équipé, e *a.* ឱនបរិក្ខារវត្ថុ (ដែលមានបរិក្ខារខាងឧស្សាហកម្មមិនគ្រប់គ្រាន់)

sous-estimer ឬ **sous-évaluer** *v.t.* ដាក់តម្លៃខុស, ប្រមាណខ្វះ ។ *Fig.* មើលងាយ

sous-exposer *v.t.* បើកឲ្យពន្លឺចូលមិនគ្រប់គ្រាន់ (ក្នុងការថតរូប)

sous-faite *n.m.* មេដំបូល (*pl.* des sous-faites)

sous-fifre *n.m. Fam.* កូនរម (មនុស្សដែលកាន់មុខងាររយោង, ដែលរងពីគេមក) (*pl.* des sous-fifres)

sous-frutescent,e *a.* ដូចអនុគុម្ពព្រឹក្ស (ឧ. plante sous frutescente)

sous-garde *n.f.* រណាំងកៃ (ដែកសម្រាប់ការពារកៃកាំភ្លើង) (*pl.* des sous-gardes)

sous-genre *n.m. Hist. nat.* អនុប្រភេទ (*pl.* des sous-genres)

sous-gorge *n.f.inv.* ខ្សែព័ទ្ធក្រោមបង្កា (គ្រឿងបង្ហៀរ)

sous-gouverneur *n.m.* ទេសាភិបាលរង (*pl.* des sous-gouverneurs)

sous-ingénieur *n.m.* វិស្វកររង (*pl.* des sous-ingénieurs)

sous-inspecteur *n.m.* អធិការរង

sous-intendant *n.m.* នាយក្រុមភស្តុការរង (*pl.* des sous-intendants)

sous-jacent,e *a.* ដែលនៅពីក្រោម (ឧ. muscles sous-jacents)

sous-lieutenant *n.m.* អនុសេនីយត្រី (*pl.* des sous-lieutenants)

sous-locataire *n.* អ្នកទទួលជួលផ្ទះបន្ត (*pl.* des sous-locataires)

sous-location *n.f.* ការជួលផ្ទះបន្ត (*pl.* des sous-locations)

sous-louer *v.t.* ជួលផ្ទះបន្ត; ទទួលជួលបន្ត (ឧ. sous-louer un appartement)

sous-main *n.m. inv.* ក្រដាសទ្រទាប់ដៃ ។ en sous-main *loc. adv. Fig.* ដោយលួចលាក់

sous-maitre *n.m. Ens.* គ្រូបង្រៀន

រង ។ *Mil.* នាយរង

sous-maîtresse *n.f. Ens.* អ្នកគ្រូបង្រៀនរង

sous-marin,e *a.* ក្រោមសមុទ្រ (ឧ. volcan sous-marin) ។ *Mar.* navigation sous-marine នាវាចរណ៍មុជទឹក ។

n.m. នាវាមុជទឹក (*pl.* des sous-marins)

sous-marinier *n.m.* អ្នកដើរនាវាមុជទឹក (*pl.* de sous-mariniers)

sous-maxillaire *a.* ក្រោមថ្គាម (ឧ. glandes sous-maxillaires)

sous-mentonnière *n.f.* ក្រពាត់បង្កា (ខ្សែចងមួកពាក់នឹងចង្កា)

sous-multiple *a.* អនុពហុគុណ ។ *n.m.* រង្វាស់អនុពហុគុណ

sous-nappe *n.f.* ទ្រនាប់កម្រាលតុ (*pl.* des sous-nappes)

sous-œuvre *n.m. Techn.* ឫសសំណង់ ។ en sous-œuvre ពីក្រោម (ពីក្រោមឫសសំណង់ ដោយមិនប៉ះសំណង់ចាស់) (ឧ. reprendre en sous-œuvre); បន្តទៅទៀត (ដើម្បីបំពេញភាពខ្វះ) (ឧ. reprendre un travail en sous-œuvre) ។ *Fig.* ពីក្រោម; ពីក្នុង (ឧ. ses passions qui travaillent en sous-œuvre (Caraccioli)

sous-off *n.m. Fam.* (ពាក្យបំព្រួញនៃ sous-officier)

sous-officier *n.m.* នាយទាហានរង (*pl.* des sous-officiers)

sous-ordre *n.m. inv.* អ្នកក្រោមបង្គាប់ ។ *Hist. nat.* អនុលំដាប់ ។ en sous-ordre *loc. adv.* ក្រោមបង្គាប់; បន្ទាប់; បន្ត ។ créancier en sous-ordre ម្ចាស់បំណុលបន្ត (ម្ចាស់បំណុលរបស់ម្ចាស់បំណុលមួយទៀត) (*pl.* des sous-ordres)

sous-palan *loc.adv.* ដល់ដៃ (ចំពោះទំនិញដែលគេប្រគល់ដល់ដៃបាតែដញ្ញូនដាក់នាវា)

sous-préfecture *n.f.* ផ្នែករងនៃខេត្ត (ប្រទេសបារាំង) (*pl.* des sous-préfectures)

sous-préfet *n.m.* នាយផ្នែករងនៃខេត្ត (ប្រទេសបារាំង) (*pl.* des sous-préfets)

sous-production *n.f.* អនុផលិតកម្ម

sous-produit *n.m.* អនុផល; អនុផលិត-

ផល (ឧ. le goudron est un des sous-produits de la distillation de la houille)

sous-secrétaire *n.m.* អនុលេខាធិការ ។ sous-secrétaire d'Etat អនុរដ្ឋលេខាធិការ (*pl.* des sous-secrétaires)

sous-secrétariat *n.m.* មុខងារអនុលេខាធិការ; អនុលេខាធិការដ្ឋាន ។ sous-secrétariat d'Etat តំណែងអនុរដ្ឋលេខាធិការ ; អនុរដ្ឋលេខាធិការដ្ឋាន (*pl.* des sous-secrétariats)

sous-seing *n.m.* (ឬ acte sous seing privé) សារលិខិតរវាងឯកជន ។ sous-seing privé រវាងឯកជន (ម.ព. seing ផង)

soussigné,e *n.* &*a.* ដែលចុះឈ្មោះខាងក្រោម; ដែលចុះហត្ថលេខាខាងក្រោម (ឧ. le soussigné déclare...)

sous-sol *n.m.* អនោប្រថពី, ស្រទាប់ដីខាងក្រោម (ឧ. un sous-sol sablonneux); ផ្នែកផ្ទះនៅក្នុងដី (*pl.* des sous-sols)

sous-station *n.f.* ស្ថានីយរង (*pl.* des sous-stations)

sous-tangente *n.f.* *Math.* អនុផុគ្គរេខា (*pl.* des sous-tangentes) .

sous-tendante *n.f.* បន្ទោះ (ខ្សែធ្នូ ឬ ស្ពាន)

sous-tendre *v.t.* ចងបន្ទោះ ។ *Math.* ដឹកខ្សែបន្ទោះ (ឧ. corde qui sous-tend un arc de cercle)

sous-tension *n.f.* ភាពធូរជាងធម្មតា (*pl.* des sous-tensions)

sous-titre *n.m.* អនុមាតិកា ; ចំណងជើងរង ។ *Cin.* អនុមាតិកា, ចំណងជើងរឿង (សេចក្ដីប្រែសង្ខេបនៃសំដីរបស់តួ ក្នុងខ្សែភាពយន្ត) (*pl.* des sous-titres)

sous-titrer *v.t.* ដាក់អនុមាតិកា ឬ ចំណងជើងរង

soustractif,ive *a.Math.* ដែលដក ឬ ហូត; ដែលត្រូវហូត (ឧ. terme soustractif)

soustraction *n.f.* ការលួចដក ឬ ហូត (ឧ. soustraction frauduleuse) ។ *Math.* លេខសង

soustraire *v.t.* លួច, លួចដក, លួចហូត (ឧ. soustraire des pa-

piers) ; ធ្វើឲ្យផុតអំពី, ធ្វើឲ្យរួចអំពី (ឧ. rien ne peut le soustraire à ma vengeance) ។ *Math.* ធ្វើលេខសង; ដក, ហូត, សង។

se soustraire *v.pr.* គេចខ្លួន (ឧ. se soustraire au châtiment) (សំ. déduire, défalquer, escamoter, ôter, subtiliser)

sous-traitant *n.m.* អនុសន្និសញ្ញីក, អ្នកទទួលការតអំពីគេ (*pl.* des sous-traitants)

sous-traité *n.m.* អនុសន្និសញ្ញា (*pl.* des sous-traités)

sous-traiter *v.t.* ធ្វើអនុសន្និសញ្ញា (ប្រគល់អាជីវកម្មសញ្ញាដែលខ្លួនទទួលឲ្យម្នាក់ទៀតធ្វើ; ទទួលការតអំពីគេ)

sous-ventrière *n.f.* ខ្សែពុង (ខ្សែចងរឹតពោះសត្វ) (*pl.* des sous-ventrières)

sous-verge *n.m.* *inv.* *Fam.* ភូឈ្លួយ

sous-vêtement *n.m.* សំលៀកបំពាក់ក្នុង (*pl* des sous-vêtements)

soutane *n.f.* អាវអ្នកបួសសាសនាកាតូលិក (ឧ. les évêques portent la soutane violette) ; ផ្នួស (ឧ. renoncer à la soutane សឹកជាកផ្នួស)

soute *n.f.* *Mar.* ឃ្លាំងជាតនាវា (ឧ. soute à charbon)

soutenable *a.* អាចទ្រាំទ្របាន (ឧ. joug qui n'est pas soutenable) ។ *Fig.* អាចគាំទ្រ ឬ ការពារបាន (ឧ. opinion soutenable)

soutenance *n.f.* soutenance d'une thèse ការការពារនិក្ខេបបទ

soutenant *n.m.* អ្នកការពារ(និក្ខេបបទ)

soutènement *n.m.* ការគាំទ្រ, ការការពារ ។ *Trav.pub.* mur de soutènement ជញ្ជាំងទប់ (សម្រាប់ទប់ដី ឬ ទប់ទឹក)

souteneur *n.m.* អ្នកគាំទ្រ; អ្នកការពារ

soutenir *v.t.* ទ្រ, ទល់ទ្រ (ឧ. colonnes qui soutiennent les voûtes) ។ *Fig.* ជួយ ; គាំទ្រ (ឧ. soutenir une famille); គាំពារ (ឧ. soutenir des troupes); ការពារ (ឧ. soutenir l'innocence) ; តស៊ូនឹង (ឧ. soutenir une attaque តស៊ូនឹងការវាយ

ប្រហារ); អះអាង (ឧ. je vous soutiens que...) ។

Loc. div. soutenir la conversation នាំសំណេះសំណាល (មិនឲ្យនៅស្ងៀម)។ soutenir une épreuve តស៊ូនឹងការសាកល្បង ឬ ទ្រាំទ្រវេទនាដោយក្លាហាន។ soutenir son rang រស់នៅឲ្យសមតាមឋានៈខ្លួន ។ soutenir sa réputation ការពារកិត្តិនាម (ធ្វើឲ្យសមតាមកិត្តិនាម) ។ soutenir une thèse ការពារនិក្ខេបបទ ។ soutenir la voix បន្លឺសំឡេង (ឲ្យនៅស្មើ) ។ soutenir une gageure សុខចិត្តភ្នាល់ ។

se soutenir *v.pr.* ទប់ខ្លួនឈរ (ឧ. ne pouvoir se soutenir sur ses jambes); ទប់គ្នាទៅវិញទៅមក ។ *Fig.* នៅមានបន្ត (ឧ. l'intérêt d'un bon roman se soutient jusqu'au bout); ជួយគ្នាទៅវិញទៅមក (សរ. épauler, étayer, garantir, protéger)

soutenu,e *a.* ថ្លៃថ្នូរជានិច្ច (ឧ. style soutenu); មិនពេះពុះ, មិនរេះរអ៊ុយ, ស្មើ (ឧ. intérêt soutenu; efforts soutenus)

souterrain,e *a.* ក្នុងដី (ឧ. chemin souterrain)។ *Fig.* voies souterraines ឧបាយកលសម្ងាត់ដើម្បីសម្រេចបំណង ។

n.m. រូងក្នុងដី

souterrainement *adv.* ក្នុងដី។ *Fig.* ដោយសម្ងាត់

soutien *n.m.* អ្វីៗដែលគាំទ្រ ឬ គាំពារ។ unités de soutien កងឯកភាពគាំពារ ។ soutien de famille អ្នកគាំទ្រគ្រួសារ ។ *Fig.* អ្នកការពារ; ពំនឹង

soutien-gorge *n.m.* ស្ដួនព្រ្កា, អាវទ្រដោះ (*pl.* des soutiens-gorge)

soutirage *n.m.* ការសម្រិត (សិតទឹកផ្ទេរកុំឲ្យដោយកករ)

soutirer *v.t.* សម្រិត (សិតទឹកផ្ទេរកុំឲ្យដោយកករ) ។ *Fig.* បាន (ដោយឧបាយកល, ដោយប៉ិនប្រសប់) (ឧ. soutirer de l'argent à quelqu'un; soutirer un secret)

soûtra *n.m.* ព្រះសូត្រ(គម្ពីរបែនៈបំណែក

មួយផាភោហារ ប្រាប់ពន្យល់ពីបុណ្យ បាប, គុណ, ទោសជាដើម)

souvenance *n.f.* អនុស្សាវរីយ៍ដ៏យូរយារ, ការនឹកឃើញ (ចំពោះរឿងដែលមានយូរមកហើយ)

souvenir *n.m.* អនុស្សាវរីយ៍, ការនឹកឃើញ (ឧ. échapper au souvenir)

souvenir (se) *v.pr.* នឹកឃើញ (ឧ. souvenez-vous des leçons du passé) ។ je m'en souviendrai ខ្ញុំមិនភ្លេចទេ, ខ្ញុំនឹងសងសឹកវិញ (ព.ផ. oublier)

souvent *adv.* ញយ, ញឹកញយ (ពរ. fréquemment)

souventefois ឬ **souventes fois** *adv.* ញយដង

souverain,e *a.* ខ្ពស់បំផុត, ធំបំផុត (ឧ. le souverain bien) ; ប្រសើរបំផុត,រកអ្វីផ្ទឹមគ្មាន(ឧ. une souveraine habilité);អធិបតី(ដែលគ្មានអ្នកឯណាត្រួតត្រា, ដែលមានស្វ័យភាព) (ឧ. une puissance souveraine); ជាទីបំផុត (ឧ. souverain mépris) ; ស័ក្តិសិទ្ធិណាស់ (ឧ. remède souverain ឱសថស័ក្តិសិទ្ធិណាស់) ។ le souverain pontife ប៉ាប ។ cour souveraine តុលាការខ្ពស់បំផុត ។

n. & a. អធិបតី (ដែលកាន់អធិបតេយ្យ) (ឧ. le peuple souverain); អធិបៈ, មហាក្សត្រ។

n.m. សូវ៉ឺរ៉ាំង (រូបិយវត្ថុមាសអង់គ្លេស)

souverainement *adv.* យ៉ាងខ្ពស់បំផុត; ជាទីបំផុត (ឧ. souverainement bon; *par ext.* livre souverainement ennuyeux); ដោយអធិបតេយ្យ (ឧ.commander souverainement) ; ដោយគ្មានឧទ្ធរណ៍ (ឧ. la Cour de cassation juge souverainement)

souveraineté *n.f.* អធិបតេយ្យ (អំណាចធំបំផុត (ឧ. souveraineté du peuple; អំណាចរបស់រដ្ឋអាចបញ្ជានឹងបង្ខំបាន; អំណាចនយោបាយរបស់រដ្ឋឬអង្គការដែលគ្មានរដ្ឋឬអង្គការណាមួយត្រួត); ដែនដីនៃមហាក្សត្រ ។ souveraineté externe អធិបតេយ្យខាងក្រៅ ។ souveraineté intérieure ឬ interne អធិបតេយ្យខាងក្នុង ។ souveraineté natio-

nale អធិបតេយ្យជាតិ

soviet *n.m.* សូវៀត (ក្រុមប្រឹក្សាប្រតិភូនៃកម្មករ, អ្នកស្រែនិងទាហាននៅប្រទេសរុស្ស៊ី)

soviétique *a.* នៃសូវៀត។ *Par ext.* នៃសហភាពរុស្ស៊ី (ឧ. l'économie soviétique) ។

n. សូវៀត(ពលរដ្ឋសហភាពរុស្ស៊ី)

soviétisation *n.f.* ការឲ្យយករបបសូវៀត

soviétiser *v.t.* ឲ្យយករបបសូវៀត

sovkhoze *n.m.* (ព. រុស្ស៊ី) សូវខូស (មហាកសិដ្ឋានគំរូនៅសហភាពសូវៀត)

soya *n.m.* ម.ព. soja

soyer,ère *a.* នៃផលិតកម្មសូត្រ (ឧ. industrie soyère)

soyeux,euse *a.* នៃសូត្រ (ឧ.matière soyeuse); ដូចសូត្រ (ឆ្អារហើយទន់ដូចសូត្រ) (ឧ. laine soyeuse)។

n.m. អ្នកធ្វើសូត្រ, ឧស្សាហករធ្វើសូត្រ(ឧ.un soyeux de Lyon)

spacieusement *adv.* យ៉ាងទូលាយ (ឧ.être logé spacieusement)

spacieux,euse *a.* ទូលាយ (ឧ. jardin spacieux) (ព.ផ. petit, étroit, resserré)

spadassin *n.m.* អ្នកកាប់ចាក់ (ឧ. un spadassin à gages)

spahi *n.m.* ស្ប៉ាហ៊ី(អ្នកជិះសេះជាតិទួរគី, ទាហានជិះសេះនៅអាហ្វ្រិកខាងជើង)

sparadrap *n.m.* បន្ទះសំពត់ ឬ ក្រដាសមានលាបជ័រសម្រាប់បិទ

spartéine *n.f.* ស្ប៉ារតេអ៊ីន (ថ្នាំបេះដូង)

spartiate *a.&n.* នៃប្រទេសស្ប៉ារតឺ ។ *Fig.* តឹងរ៉ឹង ឬ ម៉ឺងម៉ាត់ដូចជនជាតិស្ប៉ារតឺ ។ à la spartiate យ៉ាងតឹងរ៉ឹង

spasme *n.m.* ដំណើរកន្ត្រាក់ ឬ ញាក់សាច់ដុំ (ឧ. les spasmes des muscles des organes creux produisent de violentes douleurs paroxystiques)

spasmodique *a.* នៃដំណើរកន្ត្រាក់ ឬ ញាក់សាច់ដុំ ។ *Fig.* រញាក់រញើរ

spath *n.m.* ស្ប៉ាត ។ spath d'Islande ស្ប៉ាតអ៊ីស្លង់

spatial,e,aux *a.* នៃអវកាស

spatialité *n.f.* អវកាសភាព (ភាពអ្វីដែលជាអវកាស)

spatio-temporel,elle *a.* នៃអវកាសកាល (ដែលទាក់ទងនឹងអវកាសផងនឹងកាលផង) (ឧ. l'univers spatio-

temporel)

spatulé,e *a.* ស្ទឹក

S.P.C.N. (Sciences Physiques, Chimiques, Naturelles) *f.t.* គ.ធ. (វិទ្យាសាស្ត្ររូបនិយម, គីមី, ធម្មជាតិ)

speaker [spi-keur], **speakerine** *n.* អ្នកនិយាយវិទ្យុ

spécial,e,aux *a.* ឯកទេស, ពិសេស, ដោយឡែក (ឧ. aptitude, autorisation spéciale) ។ armes spéciales អាវុធពិសេស (អាវុធគីមី, បេត្រាណូនិងបរមាណូ) (ព.ផ. armes classiques អាវុធគន្លី)

spécialement *adv.* ជាពិសេស (ឧ. s'intéresser spécialement à une science)

spécialisation *n.f.* ឯកទេសកម្ម (ការបង្អួលជាពិសេស; ការបម្រុងខ្លួនជាអ្នកឯកទេស)(ឧ. dans l'industrie, la spécialisation abusive nuit à la qualification)

spécialisé,e *a.* ឯកទេស (ដែលធ្វើការមួយដែលតម្រូវជាចាំបាច់ឲ្យហាត់ឲ្យថ្នឹកឲ្យហ៊ឹកហ៊ឺនខាងវិជ្ជាជីវៈ ឲ្យមានការប្រតិបត្តិគ្រប់គ្រាន់ ប៉ុន្តែមិនបាច់ឲ្យហាត់រៀនមែនទែនទេ)

spécialiser *v.t.* បង្អួលជាពិសេស (ឧ. bien spécialiser ce qu'on veut) ។

se spécialiser *v.pr.* បម្រុងខ្លួនជាអ្នកឯកទេស (ឧ. se spécialiser dans l'histoire romaine)

spécialiste *a.&.n.* ឯកទេសី, អ្នកឯកទេស

spécialité *n.f.* ឯកទេសភាព; វត្ថុឯកទេស; វិជ្ជាឯកទេស (ឧ. le paysage est la spécialité de ce peintre) ។ *Dr.* spécialité administrative ឯកទេសភាពនៃរដ្ឋបាល (នីតិសាស្ត្រសាធារណៈ) ។ *Méd.* spécialité médicale វិជ្ជាឯកទេសខាងពេទ្យ

spécieusement *adv.* ដោយបំភាន់ (ឧ. défendre spécieusement une théorie)

spécieux,euse *a.* ដែលបំភាន់ (គ្រាន់តែដូចជាពិត ឬ ដូចជាយុត្តិធម៌) (ឧ. raisonnement spécieux) ។

n.m. អ្វីៗដែលបំភាន់ (ឧ. le spécieux d'un prétexte)

spécification *n.f.* បរិច្ឆេទកម្ម, ការបញ្ជាក់ដោយឡែក

spécificité *n.f.* បរិច្ឆេទភាព, ភាពដោយឡែកតាមពួក (ឧ. spécificité d'un microbe)

spécifier *v.t.* បញ្ជាក់ដោយឡែក ឬដោយល្អិត (ឧ. la loi ne peut pas spécifier tous les cas de délit)

spécifique *a.* បរិច្ឆិន្ន [ប៉ះ-រ៉ិច-ឆិន]; យថាប្រភេទ, ដោយឡែកតាមពួក ។ droits spécifiques ពន្ធយថាប្រភេទ, ពន្ធតាមមុខរបស់ (ផ. នឹង droits ad valorem) ។ *Phys.* poids spécifique ម.ព. poids ។ *n.m.* ឱសថពិសេស (ឧ. la quinine est un spécifique de la fièvre paludéenne)

spécifiquement *adv.* ជាបរិច្ឆិន្ន; ជាយថាប្រភេទ; ជាពិសេស

spécimen *n.m.* បដិរូប, តួយ៉ាង, គំរូ (*pl.* des spécimens)

spéciosité *n.f.* ភាពបំភាន់ (ឧ. la spéciosité d'un argument)

spectacle *n.m.* ទស្សនីយភាព (អ្វីៗដែលគួរឲ្យចង់មើល ឧ.le spectacle de la nature: របាំ, ល្ខោន, ភាពយន្ត ។ ល ។ ឧ. aimer le spectacle) ។ être en spectacle, servir de spectace ឬ se donner en spectacle សំដែងអាការៈឲ្យគេមើល ឬ ឲ្យគេរិះគន់

spectaculaire *a.* ទស្សនីយម័ត្ត, គួរឲ្យគេចង់មើល (ឧ. match spectaculaire) ។ *Par ext.* សំបើម, អស្ចារ្យ (ឧ. résultats spectaculaires)

spectateur,trice *n.* អ្នកទស្សនា, អ្នកមើល, អ្នកឃើញ

spectral,e,aux *a.* ឆាយាភូត, ដូចខ្មោច (ដែលលង) (ឧ. vision spectrale) ។ *Phys.* ឆាយាភូត (ឧ. analyse spectrale)

spectre *n.m.* ខ្មោច (ដែលលង) ។ *Fig.* ស្រមោល (ឧ. le spectre de la faim ស្រមោលនៃការអត់ឃ្លាន) ។ *Fig. & fam.* មនុស្សបង្គ្រោង (មនុស្សខ្ពស់ស្គមហើយស្លាំងដូចខ្មោច) (ឧ. c'est un véritable spectre): អ្វីៗដែលគួរខ្លាច (ឧ. le spectre de la guerre) ។ *Phys.* ឆាយាភូត, អ្វីៗគ្រាន់តែឃើញប៉ុន្តែចាប់មិនបាន

spéculateur,trice *n.* បរិកប្បី [ប៉ះ-រ៉ិ-ក័ប-ប៉ី], អ្នកទ្រឹស្ដី; អ្នកកេងកម្រៃ (ពាក្យនេះ ប្រើឥតប្រើសម្រាប់បន្ទាប់)

spéculatif,ive *a.* ខាងបរិកប្ប (ដែលគិតតែខាងទ្រឹស្ដី,មិនរវល់នឹងការប្រតិបត្តិ ឧ. esprit spéculatif; នៃការកេងចំណេញ ឧ. des manœuvres spéculatives)

spéculation *n.f.* បរិកប្ប [ប៉ះ-រ៉ិ-ក័ប] (ការពិនិត្យឬការសិក្សាខាងទ្រឹស្ដី; ទ្រឹស្ដី (ផ្ទុយនឹងការប្រតិបត្តិ); ការកេងឲ្យបានប្រាក់ចំណូលចំណេញច្រើន ឧ. spéculation boursière)

spéculativement *adv.* ដោយបរិកប្ប

spéculer *v.i.* ធ្វើបរិកប្ប (ពិចារណាអំពីទ្រឹស្ដី ឧ. spéculer sur la métaphysique; កេងចំណេញ; រកងើប ឧ. spéculer sur la faiblesse d'un adversaire)

speech [spitch'] *n.m. Fam.* សុន្ទរ-កថា (ឧ faire un speech)

spéléologie *n.f.* គុហាវិទ្យា (វិទ្យាសាស្ត្រខាងពិនិត្យនិងសិក្សាពីរូងភ្នំនិងទឹកក្នុងដី) (ឧ. Martel a été le fondateur de la spéléologie)

spéléologue ឬ **spéléologiste** *n.m.* គុហាវិទូ (អ្នកជំនាញខាងគុហាវិទ្យា)

spencer [spèn-sèr] *n.m.* ស្ប៉ែនស៊ែរ (សម្លៀកបំពាក់ប្រ៉ុង)

spermatique *a.* នៃទឹកកាម

sperme *n.m.* ទឹកកាម, ទឹកសុក្កៈ, ទឹកអសុចិ

sphère *n.f.* គោល ។ sphère céleste គោលនភាកាស ។ *Fig.* ដែន (ឧ. étendre la sphère des connaissances humaines ពង្រីកដែនវិជ្ជានៃមនុស្សលោក)។ sphère d'activité ដែនសកម្មភាព ។ sphère d'attributions ដែនមុខការ (ឧ. le fonctionnaire qui sort de sa sphère d'attributions commet un excès de pouvoir justiciable du Conseil d'Etat)

sphéricité *n.f.* គោលភាព (ឧ. la sphéricité de la Terre n'est pas absolue)

sphérique *a.* ជាគោល (ឧ. figure sphérique) ។ *Math.* នៃគោល ។ *n.m.* ពាល់មូល

sphéroïdal,e,aux *a.* ដូចគោល (ឧ. forme sphéroïdale)

sphéroïde *n.m.* ដុំដែលមានរាងដូចគោល (ឧ. la Terre est un sphéroïde)

sphéromètre *n.m.* គោលមាត្រ (ប្រដាប់សម្រាប់វាស់ភាពកោងនៃគោល)

sphinx *n.m.* ស្ហ្វាំង (បំពោះជនជាតិអេហ្ស៊ីប គឺសត្វមួយក្នុងរឿងព្រេងមានខ្លួនជាសិង្ហ មានក្បាលជាមនុស្ស) ។ *Fig.* មនុស្សដែលគេមិនអាចនឹងយល់គំនិតបាន; អ្នកប្រសប់ខាងដោះបញ្ហាពិបាកៗ

spinal,e,aux *a.* នៃឆ្អឹងខ្នង

spinelle *n.m.* ត្បូងទទឹមក្រហមខ្ចី ។ *a.* ក្រហមខ្ចី (ឧ. rubis spinelle)

spinule *n.f.* បន្លាតូច

spiral,e,aux *a.* ហៀនគួចខ្យង។ *n.m.* ខ្បាន (រមូរដែកមានសណ្ឋានជាបម្រៀក ឬ ជាបន្ទះតូច កាលណាមូលរឹតឲ្យតឹងមានកម្លាំងប្រឹងរលាររិតចេញ សម្រាប់ញុំាងគ្រឿងចក្រឲ្យដើរ)(ឧ. le spiral d'une montre)

spirale *n.f.* ក្បាច់ហៀន។ en spirale ជាក្បាច់ហៀន ។ ressort en spirale ម.ព. ressort

spiralé,e *a.* ដែលមូរជាហៀនគួចខ្យង

spire *n.f.* ហៀនគួចខ្យង (បន្ទាត់វិលវៀននៃគួចខ្យង)

spirite *n.* អ្នកភូតនិយម (អ្នកបេះទាក់ទងនឹងភូត)

spiritisme *n.m.* ភូតនិយម (លទ្ធិដែលបេះធ្វើឲ្យឃើញភូត ជាពិសេសឲ្យឃើញព្រលឹងមនុស្ស ដែលស្លាប់ទៅហើយ ហើយអាចនិយាយគ្នាបាន)

spiritualisation *n.f.* ចេតូបនីយកម្ម

spiritualiser *v.t.* ធ្វើឲ្យមានចិត្ត ឬ ឲ្យមានព្រលឹង (ឧ. spiritualiser la matière) ; ធ្វើឲ្យមានលក្ខណៈជាសាសនា; ធ្វើឲ្យនៅជាវិរតី (ឧ. spiritualiser l'amour); បកស្រាយខាងផ្លូវសាសនា (ឧ. spiritualiser un texte)

spiritualisme *n.m.* ចេតោនិយម(លទ្ធិទស្សនវិជ្ជាដែលនិយមថាមានចិត្ត ឬ ព្រលឹង) (ឧ. le spiritualisme de Leibniz)(ផ្ទ.នឹង matérialisme)

spiritualiste *n.&a* អ្នកចេតោនិយម។ *a.* ចេតោនិយម

spiritualité *n.f.* ចេតភាព, ភាពជាចិត្ត (ឧ. la spiritualité de l'âme)

spirituel,elle *a.* ដែលជាចិត្ត;ដែលមានប្រាជ្ញា (ឧ. vie spirituelle); ខាងសាសនា (ឧ. exercices spiri-

tuels; pouvoir spirituel); ឆ្លាត, វៃ (ឧ. homme spirituel; réponse spirituelle) ។ *n.m.* សាសនចក្រ, អំណាចខាងសាសនា (ឧ. le spirituel et le temporel)

spirituellement *adv.* យ៉ាងឆ្លាត (ឧ. répondre spirituellement); ដោយចិត្ត (ឧ. communier spirituellement avec le prêtre); ដោយផ្លូវចិត្ត

spiritueux,euse *a.* ដែលមានជាតិស្រា ។ *n.m.* គ្រឿងស្រវឹង

spiroïdal,e,aux *a.* ដែលវិលវៀនដូចក្ងូវខ្យង

spiromètre *n.m.* អស្សាសបស្សាសមាត្រ, ប្រដាប់ស្ទង់កម្លាំងសួត

spleen [splinn] *n.m.* (ព.អ.) ការធុញទ្រាន់ណាយនឹងវត្ថុគ្រប់យ៉ាង; ការធុញនឹងជីវិត

splendeur *n.f.* វិភោបន៍ (ពន្លឺត្រចះត្រចង់ ឧ. la splendeur du soleil ។ *Fig.* កិត្តិនាមដ៏រុងរឿង ឧ. la splendeur de son nom; ភាពរុងរឿង)

splendide *a.* ត្រចះត្រចង់ (ឧ. un soleil splendide); រុងរឿង, ល្អដើត (ឧ. palais splendide)

splendidement *adv.* ដោយវិភោបន៍, យ៉ាងត្រចះត្រចង់, យ៉ាងរុងរឿង

splénectomie *n.f.* ការកាត់ផាលចោល (ផាល គឺ អវយវៈនៅត្រង់ពុងឆ្អឹងជំនីរមនុស្ស)

splénique *a.* នៃផាល (ឧ. artère splénique)

splénite *n.f.* រោគរលាកផាល

spoliateur,trice *n.&a.* ដែលជិះជាន់ (យកធនធាន) (ឧ. une mesure spoliatrice)

spoliation *n.f.* ការជិះជាន់ (យកធនធាន)

spolier *v.t.* ជិះជាន់ (យកធនធាន)

spongieux,euse *a.* ស្ពោត, ផុស, ស្រូបពពុះទឹក (ឧ. tissu spongieux); ដែលជក់ទឹក (ឧ.sol spongieux)

spongiosité *n.f.* ភាពស្ពោត - ផុស ឬជក់ទឹក

spontané,e *a.* សយម្ភូត [សៈ-យុំម-ភូត], ដែលប្រព្រឹត្តដោយឯកឯង (ឧ. les mouvements du cœur sont spontanés); ដែលធ្វើដោយខ្លួនឯង (ពិតគេបង្ខំ) (ឧ. action

spontanée) ។ *Bot.* ដែលដុះឯង (ឥតគេដាំ) ។ génération spontanée ប.ព. génération

spontanéité *n.f.* សយម្ភូតភាព [សៈ-យ៉ុម-ភូតៈ-], ដំណើរធ្វើដោយឯកឯង

spontanément *adv.* ដោយសយម្ភូត, ដោយឯកឯង (ឧ. faire spontanément une concession)

sporadicité *n.f.* ភាពមានដាច់ៗពីគ្នា

sporadique *a.* ដែលមានដាច់ៗពីគ្នា, ដែលមិនជុំគ្នា (ឧ. résistance sporadique) ។ *Path.* maladie sporadique រោគដែលចាប់មនុស្សម្នាក់ៗ (ផ. នឹង maladie épidémique រោគរាតត្បាត)

sporadiquement *adv.* ដោយមិនជុំគ្នា, ដោយដាច់ៗពីគ្នា (ឧ. maladie qui sévit sporadiquement)

sport *n.m.* កីឡា ។ sport athlétique កីឡាអត្តពលិក [-អ័ត-តៈ-ពៈ-] *a.* កីឡា (ឧ. costume sport សំលៀកបំពាក់កីឡា)

sportif,ive *a.* នៃកីឡា (ឧ. épreuve sportive); ដែលចូលចិត្តកីឡា ។ *n.* អ្នកកីឡា

sportivement *adv.* ជាអ្នកកីឡា, ដោយស្មោះត្រង់ (ឧ. reconnaître sportivement sa défaite)

sportivité *n.f.* កីឡាភាព; ភាពស្មោះត្រង់

sportsman [sports-man'] ឬ **sportman** *n.m.* កីឡាករ, អ្នកកីឡាប្រុស

sportswoman [sports-ou-man'] ឬ **sportwoman** *n.f.* កីឡាការិនី, អ្នកកីឡាស្ត្រី

spoutnik *n.m.* (ព. រុស្ស៊ី) ស្ពូតនិក (ផ្កាយរណបសិប្បនិម្មិតដែលសហភាពសូវៀតបាញ់បង្ហោះ)

sprint [sprin't] *n.m.* ការរត់សាប់ (ជិតដល់ទី)

sprinter [sprin'-teur] *n.m.* អ្នករត់សាប់

sprinter [sprin' té] *v.i.* រត់សាប់, រត់បង្ហិតដល់ទី

sprumescent,e *a.* ដូចពពុះ ; ដែលបញ្ចេញពពុះ

sprumeux,euse *a.* ដែលមានពពុះស្កុល

sprumosité *n.f.* ភាពមានពពុះស្កុល (ឧ. la sprumosité de la bière)

sputation *n.f. Pathol.* រោគខាក, មិនដាច់

squale [skoual'] *n.m.* ឆ្លាម

squame [skouam'] *n.f. Pathol.* ស្រកា (ដំណើររបេះស្បែកបន្តិចៗជាក្រឡាៗ): ក្រមរ

squamelle [skouamèl'] *n.f.* ស្រកា ឬ ក្រមរតូច

squameux, euse [skoua–] *a. Pathol.* ដែលរបកស្រកា (ឧ. peau squameuse) ។ *Anat.* ដែលជាស្រកា (ឧ. la portion squameuse du temporal) ។ *Zool.* ដែលមានស្រកា (ឧ. insecte squameux); ដូចស្រកា (ឧ. plumes squameuses); ជាកងស្រកា

squamifère [skoua–] *a. Bot.* ដែលមានស្រកា

squamule [skoua–] *n.m.* ស្រកាល្អិត

square [skouar'] *n.m.* សួនច្បារសាធារណៈមានបំណារជុំវិញ

squelette *n.m.* អដ្ឋិសង្ខលិក, អដ្ឋិសង្ខាត, គ្រោងឆ្អឹង (ឧ. le squelette féminin se compose de 208 os) ។ *Par exag. & fam.* មនុស្សស្គមកំព្រឹង (ឃើញតែឆ្អឹង) (ឧ. c'ést un vrai squelette) ។ *Fig.* គ្រោងការសង្ខេប (នៃសៀវភៅ) (ឧ. le squelette d'un roman, d'une tragédie) ។ *Mar.* squelette d'un navire គ្រោងនាវា

squelettique *a.* នៃអដ្ឋិសង្ខលិក, នៃគ្រោងឆ្អឹង (ឧ. les pièces squelettiques) ។ maigreur squelettique ភាពស្គមកំព្រឹង ។ *Fig.* សង្ខេបពេក

squelettisation *n.f.* ដំណើរធ្វើឲ្យនៅសល់តែគ្រោងឆ្អឹង

squelettiser *v.t. Fam.* ធ្វើឲ្យស្គមកំព្រឹង (ឃើញតែឆ្អឹង) ។

se squelettiser *v.pr. Fam.* ទៅជាស្គមកំព្រឹង

st (stère) ស្ទ (ស្ទែរ)

stabilisateur,trice *a.* ស្ថិរករ [ស្ថិ-រៈ–] (ដែលធ្វើឲ្យនឹង) ។

n.m. ស្ថិរករ, ប្រដាប់ធ្វើឲ្យមានស្ថិរភាព ឬ ឲ្យនឹង

stabilisation *n.f.* ស្ថិរកម្ម, ការធ្វើឲ្យមានស្ថិរភាពឬឲ្យនឹង (ឧ. stabilisation de la monnaie)

stabiliser *v.t.* ធ្វើឲ្យមានស្ថិរភាព ឬ ឲ្យនឹង (ឧ. stabiliser les prix)

stabilité *n.f.* ស្ថិរភាព, ភាពនឹង (ឧ. vérifier la stabilité d'un pont) ។ *Fig.* stabilité d'un Etat ស្ថិរភាពនៃរដ្ឋ

stable *a.* ស្ថិរវន្ត, នឹង, មិនប្រែប្រួល (ឧ. édifice stable; *au fig.* paix stable)

stabulation *n.f.* ការដាក់ក្នុងក្រោល (សត្វ) ។ *Par ext.* ការប្រោះត្រី ។ *Méd.* ការឲ្យសម្រាកលើគ្រែ

stade *n.m.* កីឡាឋាន, កីឡាមណ្ឌល ។ *Fig.* ដំណាក់, កំរិត (ឧ. les différents stades d'une évolution)

stage *n.m.* កម្មសិក្សា, ពេលរៀនធ្វើការ; ស្ថានភាពបណ្ដោះអាសន្ន

stagiaire *n.* កម្មសិក្សាការី, អ្នករៀនធ្វើការ, មន្ត្រីបម្រុងរាជការ (ឧ. avocat stagiaire) ។

a. នៃកម្មសិក្សា, នៃពេលរៀនធ្វើការ (ឧ. période stagiaire)

stagnant,e *a.* នឹង, មិនហូរ (ឧ. eaux stagnantes) ។ *Fig.* គ្មានបម្រើន (ឧ. l'état stagnant des affaires)

stagnation *n.f.* ស្ថិរតា, ភាពនឹង ឬ មិនហូរ ។ *Fig.* ភាពនៅស្ងៀម; ភាពគ្មានបម្រើនសោះ

stagner *v.i.* នៅនឹង, មិនហូរ ។ *Fig.* គ្មានបម្រើន

stalactite *n.f.* អាចុតសិលា (ថ្មដែលដុះច្រូងច្រាងនៅពិតានរូងភ្នំដោយទឹកភ្លៀងជ្រោះបុណ្ណីសិលា)

stalag *n.m.* (ព.អាល្លឺម៉ង់) ជំរំឈ្លើយសង្គ្រាម (សម្រាប់នាយទាហានរងនិងកូនទាហាន)

stalagmite *n.f.* និចុតសិលា (ថ្មដែលដុះច្រូងច្រាងនៅបាតរូងភ្នំ ដោយទឹកភ្លៀងជ្រោះបុណ្ណីសិលា)

stalagmomètre *n.m.* ពិន្ទុមាត្រ (ប្រដាប់ស្ទង់ទម្ងន់ ឬ ទំហំតំណក់)

stalinien,enne *a.&n.* អ្នកកាន់ជើងស្តាលីន

stalinisme *n.m.* ស្តាលីននិយម(សារព័ន្ធទ្រឹស្ដីនិងរបៀបរបស់ស្តាលីន)

stalle *n.f.* កៅអីមានលេខ (ក្នុងរោងល្ខោន);បន្ទប់សេះមួយ(ក្នុងក្រោលសេះ)

stance *n.f.* គាថា

stand *n.m.* វេទិកាមើលប្រណាំងសេះ; កន្លែងបាញ់រ៉ង់; ស្ដាន ឬ រោងតាំង(ក្នុងពិពណ៌)

standart *n.m.* &*a.* បមាណី [ប៉ះ-ម៉ា-

នី]; គំរូ, កម្រិត ។ *n.m.* បមាណីយ, ស្តង់ដារ ។ standard de vie បមាណីយនៃជីវភាព (កម្រិតជីវភាព)

standardisation *n.f.* បមាណីយកម្ម [–នីយៈ–], ការធ្វើតាមគម្រូតែមួយ

standardiser *v.t.* ធ្វើបមាណីយកម្ម, ធ្វើតាមគម្រូតែមួយ

standardiste *n.* អ្នកកាន់បមាណីយ, អ្នកកាន់ស្តង់ដារទូរស័ព្ទ

standing *n.m.* ដំណើរជីវភាព, របៀបរស់នៅ; ផាសុកភាព, ប្រណីតភាព (ឧ. standing d'un appartement)

stanifère *a.* ដែលមានសំណប៉ាហាំង

staphilocoque *n.m.* មេរោគម្យ៉ាងបង្កឲ្យមានខ្ទុះលើស្បែក

star *n.f.* តារាភាពយន្ត

starie *n.f.* ម.ព. estarie

starlette *n.f.* ស្រីទើបនឹងចូលលេងក្នុងភាពយន្ត

starter [–teur] *n.m.* *Sports* អ្នកឲ្យសញ្ញារត់ (ក្នុងកីឡារត់ប្រណាំង); អ្នកឲ្យសញ្ញាចេញដំណើរ (អាកាសយានដ្ឋាន, ស្ថានីយ៍អយស្ម័យយាន) ។ *Mécan.* ស្តាទ័រ (ប្រដាប់ធ្វើឲ្យម៉ាស៊ីនឆាប់ឆេះ)

stase *n.f.* ដំណើរមិនស្រួលនៃអាកាធាតុ (ក្នុងខ្លួន)

station *n.f.* កិរិយាឈរ, របៀបឈរ (ឧ. station verticale); ការឈប់, ការសំចត (ឧ. faire une longue station à l'arrêt de l'autobus); ចំណតរថ, កន្លែងឈប់(កន្លែងរថយន្ត, អយស្ម័យយាន ។ល។ ឈប់ផាក់មនុស្ស); ឋាន, កន្លែង ។ station d'émission ឋានផ្សាយ ។ station expérimentale ឋានពិសោធ ។ station horticole ឋានសាកវប្បកម្ម ។ station météorologique ឋានឧតុនិយម ។

ស្ថានីយ, កន្លែងឈប់សំចត, កន្លែងសំណាក់ ។ station balnéaire ស្ថានីយងូតទឹក ។ station thermale ស្ថានីយឧណ្ហោទក

stationnaire *a.* ដែលនៅនឹង(មិនបម្រើន, មិនថយ; មិនឡើងថ្លៃ, មិនចុះថ្លៃ; មិនប្រែប្រួល)(ឧ. état stationnaire; ondes stationnaires) ។

n.m. នាវាល្បាតមាត់ច្រកដៃ

stationnement *n.m.* ការចត, ការសំចត (ឧ. interdiction de stationnement)

stationner *v.i.* ចត, សំចត

station-service *n.f.* ហាងសេវា (កន្លែងសម្រាប់ថែរក្សានិងទោបព្រយានយន្ត ដាក់ប្រេងសាំង ដាក់ប្រេងម៉ាស៊ីន ដាក់ទឹក ឬ ប្ដូរខ្យាញ់ដាញ់ប្រេង) (*pl.* des stations-service)

statique *a.* ឋិតវន្ត (ដែលទាក់ទងនឹងសមតានៃកម្លាំង;ដែលនៅនឹងមួយកន្លែង) (ផ្ទ. នឹង dynamique ថាមវន្ត) ។

n.f. Math. ឋិតពល

statiquement *adv.* ដោយឋិតវន្ត, ដោយនៅនឹង

statisticien *n.m.* ស្ថិតិលេខក:, អ្នកស្ថិតិ

statistique *n.f.* ស្ថិតិ។ statistique de natalité ស្ថិតិនៃកំណើត ។

a. នៃស្ថិតិ (ឧ. rapports statistiques)

statuaire *a.* នៃបដិមាករ (ឧ. l'art statuaire) ; សម្រាប់ធ្វើបដិមាករ, សម្រាប់ឆ្លាក់រូប ។

n.m. បដិមាការី, ជាងឆ្លាក់រូប ។

n.f. សិល្ប:ខាងឆ្លាក់រូប

statue *n.f.* បដិមាករ, រូបចម្លាក់ ។ *Fig.* មនុស្សធ្មឹងធ្មើយ; មនុស្សមឹះៗ

statuer *v.t.* អារកាត់ (ឧ. statuer sur un litige) ។ *v.i.* សម្រេចសេចក្ដី

statuette *n.f.* បដិមាករតូច, រូបចម្លាក់តូច

statufier *v.t. Fam.* ឆ្លាក់បដិមាករជូន, ឆ្លាក់រូបតំណាងជូន

statu quo *n.m.* ស្ថានភាពដូចដើម (ឧ. maintenir le «statu quo»)

stature *n.f.* មាឌ (ឧ. il est d'une haute stature)

statut *n.m.* លក្ខន្តិក:។ statut commun សហលក្ខន្តិក: ។ statut juridique លក្ខន្តិក:គតិយុត្ត ។ statut personnel លក្ខន្តិក:បុគ្គលិក

statutaire *a.* ត្រូវតាមលក្ខន្តិក:; ដែលជ្រើសតាំងតាមលក្ខន្តិក: (ឧ. gérant statutaire)

statutairement *adv.* ដោយត្រូវតាមលក្ខន្តិក:

steamer *n.m.* កប៉ាល់ (ដើរដោយចំហាយទឹក)

stéarine *n.f.* ស៊េរិកា [ស៊េ-]

stéarinerie *n.f. Ind.* ស៊េរិកាគារ, កន្លែងធ្វើស៊េរិកា

steeple-chase [stipl'-tchèze] *n.m.* (ព.អ.) ការប្រណាំងសេះផ្លោះឧបសគ្គគ្រប់យ៉ាង (*pl.* des

steeple-chases)

stèle *n.f.* សិលាស្តម្ភ; សិលាចារឹក

stellaire *a.* នៃផ្កាយ; ជារាងផ្កាយ (ឧ. disposition stellaire)

stencil *n.m.* ស្តង់ស៊ីល (ក្រដាសស្រលក់ក្រមួនសម្រាប់ប្រើជាពុម្ពចម្លង)

stenciliste *n.&a.* អ្នកវាយស្តង់ស៊ីល (អ្នកវាយអង្គុលីលេខដោយស្តង់ស៊ីល)

sténodactylographe ឬ **sténodactylo** *n.* អ្នកជវអង្គុលីលេខ

sténodactylographie *n.f.* ជវអង្គុលីលេខ [ជៈ-វៈ-]

sténographe *n.* អ្នកជវលេខ [ជៈ-វៈ-]

sténographie *n.f.* ជវលេខ (របៀបសរសេរឲ្យទាន់សំដីនិយាយ)

sténographier *v.t.* សរសេរជវលេខ

sténographique *a.* នៃជវលេខ

sténographiquement *adv.* ដោយជវលេខ

sténose *n.f.* ដំណើររួម ឬ ខ្ទប (ឧ. sténose du pylore)

sténotype *n.f.* ម៉ាស៊ីនជវលេខ

sténotypie *n.f.* ជវលេខដោយម៉ាស៊ីន

sténotypiste *n.* អ្នកប្រើម៉ាស៊ីនជវលេខ

stentor *n.m.* មនុស្សសម្លេងធំ ។ voix de stentor សម្លេងធំ

steppe *n.f.* វាលស្មៅធំ (នៅប្រទេសរុស្ស៊ី)

stepper (ព.អ.) ឬ **steppeur** *n.m.* សេះលុន

steppique *a.* ជាវាលស្មៅធំ

stère (st) *n.m.* ស្ទែរ(ស្ទ) (រង្វាស់ឧស ១ ម៉ែត្រគីប)

stéréoscope *n.m.* ឧត្តទស្សន៍, គ្រឿងឆ្លុះឲ្យឃើញក្រឡោត

stéréoscopique *a.* នៃឧត្តទស្សន៍ (ឧ. vue stéréoscopique)

stérer *v.t.* វាស់ជាស្ទែរ (ឧ. stérer du bois)

stérile *a.* វញ្ឈៈ, ឥតផល, ឥតផ្លែ (ឧ. arbre stérile); ឥតជីជាតិ (ឧ. terre stérile); អា (ឥតកូន) (ឧ. femme stérile) ។ *Bactér.* និម្មល (គ្មានមេរោគ) ។ *Fig.* ឥតបានការ, គ្មានបង្កើតអ្វី (ឧ. esprit stérile); ឥតបានផល, ឥតប្រយោជន៍ (ឧ. discussion stérile)

stérilement *adv.* ដោយវញ្ឈៈ

stérilisant,e *a.* ដែលសម្លាប់មេរោគ

stérilisateur *n.m.* ប្រដាប់សម្លាប់មេរោគ

stérilisation *n.f.* វញ្ឈកម្ម (ការធ្វើឲ្យឥតផល ឬ ឥតផ្លែ; ការធ្វើមិនឲ្យមាន

ពូជ); និក្ខោសកម្ម, ការរម្លាប់មេរោគ

stérilisé,e *a.* និក្ខោសី, ដែលរម្លាប់មេរោគហើយ (ឧ. lait stérilisé)

stériliser *v.t.* ធ្វើវញ្ញកម្ម(ធ្វើឲ្យឥតផល ឬ ឥតផ្លែ; ធ្វើឲ្យអា); រម្លាប់មេរោគ (ឧ. stériliser une eau)

stérilité *n.f.* វញ្ញភាព (ភាពឥតផល ឬ ឥតផ្លែ; ភាពឥតជីជាតិ ឧ. la stérilité du sol; ភាពអា; *fig.* ភាពឥតបានការ; ភាពមិនសូវមានហេតុការណ៍; ភាពអធិប្បាយមិនបានវែង ឧ. stérilité d'un sujet)

sterling *n.m.inv.* ស្ទែរលើញ។ livre sterling លីវ្រ៍ស្ទែរលើញ (រូបិយវត្ថុគណនីនៃប្រទេសអង់គ្លេស)

sternal,e,aux *a.* នៃឆ្អឹងសន្ទះទ្រូង

sterne *n.f.* ត្របៀកកាំសមុទ្រ

sternum *n.m.* ឆ្អឹងសន្ទះទ្រូង

sternutation *n.f.* ការកណ្ដាស់

sternutatoire *a.* ដែលធ្វើឲ្យកណ្ដាស់ (ឧ. poudre sternutatoire)

stéthoscope *n.m.* ឧភទស្បូន៍, ប្រដាប់ពិនិត្យទ្រូង

steward [sti-ouard'] *n.m.* មេសណ្ឋាគារ; អ្នកបម្រើ (ក្នុងយន្តហោះ, ក្នុងនាវា ។ល។)

stick *n.m.* រំពាត់ទន់, ដំបងទន់ ។ *Mil.* ក្រុមអ្នកលោតឆ័ត្រយោងពីយន្តហោះជាមួយគ្នា

stigmate *n.m.Autref.* ស្នាមដោយដែកដុត (ឧ. la peine des stigmates); ស្នាម(ដំបៅ, អុត) (ឧ. les stigmates de la petite vérole) ។ *Fig.* ស្នាម ឬ សញ្ញាទុយ៉ស (ឧ. les stigmates du vice) ។ *Bot.* ទ្វារស្បូនផ្កា ។ *Zool.* រន្ធដង្ហើម (ចំពោះបាណកសត្វ)

stigmatisation *n.f.* ការបោះសញ្ញាដោយដែកដុត ។ *Fig.* ការជៀលត្ថុះចំពោះសាធារណៈ

stigmatiser *v.t.* បោះសញ្ញាដោយដែកដុត។*Fig.* ជៀលត្ថុះចំពោះសាធារណៈ (ឧ. stigmatiser le vice)

stillation *n.f.* ដំណើរស្រក់តក់ៗ

stillatoire *a.* ដែលស្រក់តក់ៗ

stilligoutte *n.m.* បំពង់ដំណក់ (មើ. compte-gouttes)

stimulant,e *a.* ឧទ្ទីប [អ៊ុត-ទីប], ដែលលើកកម្លាំង ឬ លើកទឹកចិត្ត (ឧ. potion stimulante) ។ *n.m.* ឧទ្ទីបក [អ៊ុត-ទី-ប៉ាក់] (ឧ. faire usage de stimulants)។

Fig. ថ្នាំដាស់ (អ្វីៗដែលធ្វើឲ្យក្លៀវក្លា ឬ ឲ្យខំស្វាហាប់) (ឧ. sa paresse a besoin d'un stimulant)

stimulateur,trice *a.* ដែលធ្វើឲ្យក្លៀវក្លា

stimulation *n.f.* ឧទ្ទីបកម្ម (ការលើកកម្លាំងឬលើកទឹកចិត្ត; កម្លាំងដែលមានដោយសារឱសថ ។ *Méd.* ការលើកកម្លាំងដោយឱសថ ។ ការបណ្ដុះបណ្ដាល)

stimuler *v.t.* ឧទ្ទីប, ដាស់តឿន, ដាស់សតិ (ឧ. stimuler un enfant); លើកកម្លាំង ។ *Fig.* លើកទឹកចិត្ត; បណ្ដុះបណ្ដាល (ឧ stimuler l'industrie) (ស៊ី. animer, encourager, exhorter, inciter)

stimuline *n.f.* ឧទ្ទីបរស (ជាតិក្នុងខ្លួនដែលធ្វើឲ្យគ្រឿងខ្លះដើរស្រួល)

stipe *n.m.* ដើមឈើគ្មានមែក (ដូចយ៉ាងដើមត្នោតជាដើម)

stipendié,e *a.* ដែលគេជួល (ឲ្យធ្វើអំពើអាក្រក់) (ឧ. espion stipendié)

stipendier *v.t.* ជួល(ឲ្យធ្វើអំពើអាក្រក់) (ឧ. stipendier des assassins)

stipulant *n.m.* *Dr.* បដិញ្ញ (ដែលទាមទារអ្វីមួយដោយអនុសញ្ញា)

stipulation *n.f.* បដិញ្ញា (ខដែលមានចែងក្នុងកិច្ចសន្យា) ។ stipulation pour autrui បដិញ្ញាតាងបរជន

stipule *n.f.* *Bot.* ដំយារ (ស្លឹកតូចដែលដុះនៅគល់ទងស្លឹក)

stipuler *v.t.* បដិញ្ញាត (ចែងលក្ខខណ្ឌឬចុះខក្នុងកិច្ចសន្យា) (ឧ. stipuler une garantie) ។ *Par ext.* ត្រូវគ្នា(អំពីរឿងអ្វីមួយ)

stock *n.m.* ស្តុក្ក, សន្និធិ

stockage *n.m.* ការទុកជាស្តុក្ក ឬ ជាសន្និធិ; ទំនិញក្នុងសន្និធិ

stocker *v.t.* ទុកជាស្តុក្ក ឬ ជាសន្និធិ; ទុកក្នុងឃ្លាំង

stoïcien,enne *a.&n.* នៃលទ្ធិទស្សនវិជ្ជារបស់លោកសេណុង ។ *Par ext.* មិនទម្រន់, មិនរន្ធត់

stoïcisme *n.m.* លទ្ធិទស្សនវិជ្ជារបស់លោកសេណុង ។ *Fig.* សេចក្ដីមិនទម្រន់ឬមិនរន្ធត់(ឧ.supporter ses malheurs avec stoïcisme)

stoïque *a.& n.* មិនទម្រន់, មិនរន្ធត់ (ឧ. un stoïque)

stoïquement *adv.* ដោយមិនទម្រន់, ដោយមិនរន្ធត់ (ឧ. affronter

stoïquement la mort)

stomacal, e, aux *a.* នៃក្រពះ (ឧ. digestion stomacale)

stomachique *a.* ដែលធ្វើឲ្យក្រពះដើរស្រួល ។ *n.m.* ឱសថក្រពះ(ដែលធ្វើឲ្យក្រពះដើរស្រួល)

stomatique *a.* មុខោសថ, ឱសថសម្រាប់រោគក្នុងមាត់

stomatite *n.f.* មុខរោគ, រោគមាត់

stomatologie *n.f.* មុខសាស្ត្រ (ការសិក្សាអំពីរោគមាត់និងធ្មេញ)

stomatologiste *n.* មុខពេទ្យ (ពេទ្យព្យាបាលរោគមាត់និងធ្មេញ)

stomascope *n.m.* មុខទស្សន៍ (ប្រដាប់បើកមាត់ដើម្បីពិនិត្យ)

stop ! *int.* ឈប់!

stoppage *n.m.* ការប្រេះ

stopper *v.t.* ប្រេះ (ប៉ះសំពត់ធ្លុះដោយដេរធ្នាក់)

stopper *v.i.* បញ្ឈប់ (ឧ. stopper une machine; stopper une offensive)

stoppeur,euse *n.& a.* អ្នកប្រេះ(មើ. rentrayeur,euse)

store *n.m.* រនាំង

stoupâ ឬ **stupâ** *n.m.* ស្តូប, ចេតិយ,

stout [staout`] *n.m.* ស្តោត៍ (ប៊ីយែរអង់គ្លេស)

strabisme *n.m.* ភាពស្រលៀង (ឧ. strabisme convergent, divergent)

strangulation *n.f.* ការច្របាច់ក ។ mort par strangulation ដំណើរស្លាប់ដោយច្របាច់ក

strass *n.m.* ត្បូងស្ល ។ *Fig.* អ្វីៗដែលភ្លឺក្លែង

strasse *n.f.* អាចម៍សូត្រ

stratagème *n.m.* យុទ្ធោបាយ, រណោបាយ, ឧបាយសឹក ។ *Par ext.* ការប៉ិនប្រសប់ ; ការលេងកល (ឧ. plaisant stratagème)

strate *n.f.* *Géol.* ស្តក (ស្រទាប់នៃសិលា)

stratège *n.m.* អ្នកយុទ្ធសាស្ត្រ

stratégie *n.f.* យុទ្ធសាស្ត្រ; យុទ្ធកោសល្យ

stratégique *a.* នៃយុទ្ធសាស្ត្រ (ឧ. objectif, bombardement stratégique)

stratégiquement *adv.* តាមយុទ្ធសាស្ត្រ

stratégiste *n.m.* អ្នកយុទ្ធសាស្ត្រ

stratification *n.f.Géol.* ស្តរកម្ម (ដំណើរសិលាដែលមានជាស្រទាប់ៗ)

stratifié,e *a.* & *n.m.* ស្តរិក

stratifier *v.t.* ដាក់ឬរៀបជាស្រទាប់ៗ

stratigraphie *n.f.* ស្តរសាស្ត្រ (ផ្នែកនៃភូគព្ភសាស្ត្រ ដែលសិក្សាអំពីស្រទាប់នៃផែនដី)

stratigraphique *a.* នៃស្តរសាស្ត្រ

stratosphère *n.f.*ផ្នែកអាកាសខាងលើ

stratus *n.m.* អន្លាំព្យុ ឬ អន្លង់ៗ, ពពកជាន់ទាប

streptococcie *n.f.*រោគបណ្តាលដោយស្ត្រិបតូកុក

streptocoque *n.m.* ស្ត្រិបតូកុក(មេរោគម្យ៉ាងមានច្រើនទៅក្នុងវត្ថុដែលរលួយ)

striation *n.f.* ការឆូត (ធ្វើឲ្យមានឆ្នូត); ភាពឆូត (មានឆ្នូត)

strict,e *a.* ត្រឹមត្រូវ (ឧ. devoir strict);ប្រិតប្រៀប (ឧ.un professeur très strict)

strictement *adv.* យ៉ាងត្រឹមត្រូវ; យ៉ាងប្រិតប្រៀប

striction *n.f. Méd.* ការបង្ខំប, ការបង្កបង្រួមរាង់ឲ្យតូច

stridence *n.f.* ស្វរគ្រលួច (ធ្វើឲ្យសង្កៀរត្រចៀក)

strident,e *a.* គ្រលួច (ធ្វើឲ្យសង្កៀរត្រចៀក) (ឧ. bruit strident)

stridulant,e *a.* ដែលបញ្ចេញសម្លេងគ្រលួច (ឧ. insectes stridulants)

stridulation *n.f.* ការបញ្ចេញសម្លេងគ្រលួច

striduler *v.i.* បញ្ចេញសម្លេងគ្រលួច

striduleux,euse *a.* គ្រលួចបន្តិច

strie *n.f.* ឆ្នូត

strié,e *a.* ដែលមានឆ្នូត

strier *v.t.* ឆូត, ធ្វើឲ្យមានឆ្នូត (ឧ. le sable strie le verre)

strigidés *n.m.pl.* ខ្ញុកកូល [អ៊ឹ-ខ្ញុ-កៈ-], ត្រកូលមៀម-ទីទុយ

striure *n.f.* ភាពមានឆ្នូត; ឆ្នូត

strophe *n.f.* បទ

structural,e,aux *a.* នៃរចនាសម្ព័ន្ធ

structure *n.f.* រចនាសម្ព័ន្ធ (របៀបសង់ ឬ ផ្គុំ;រូបរាង; គ្រោង)(ឧ. structure agraire d'un pays; structure du corps humain) ។ structure de la moelle épinière រចនាសម្ព័ន្ធខួរឆ្អឹងខ្នង ។ structure de l'os រចនាសម្ព័ន្ធអដ្ឋិ

structurer *v.t.* ឲ្យមានរចនាសម្ព័ន្ធ

strume *n.m.* ម.ព. goitre

strumeux,euse *a.* ដែលពក ក

strychnine *n.f.* ស្ទ្រិចនីន (ថ្នាំពុលជាតិស្លែង)

studieusement *adv.* ដោយឧស្សាហ៍

studieux,euse *a.* ឧស្សាហ៍រៀនសូត្រ; ឧស្សាហ៍ (ឧ. écolier studieux)

studio *n.m.* ស្ទូឌីយោ (រោងការនៃសិល្បករ; កន្លែងធ្វើការ, បន្ទប់ថតរូបភាពយន្ត)

stupéfaction *n.f.* ការឆ្ងល់ស្រឡាំង-កាំង(ឧ. être frappé de stupéfaction)

stupéfait,e *a.* ឆ្ងល់ស្រឡាំងកាំង (ឧ. il resta stupéfait)

stupéfiant,e *a.* ដែលធ្វើឲ្យស្ពឹក ឬ ឲ្យស្រវឹង (ឧ. la morphine est stupéfiante) ។ *Fig.* ដែលធ្វើឲ្យស្រឡាំងកាំង (ឧ. nouvelle stupéfiante) ។

n.m. ថ្នាំស្ពឹក ឬ ថ្នាំស្រវឹង(ដែលធ្វើឲ្យស្ពឹក ឬ ឲ្យស្រវឹង (ដូចអាភៀន)

stupéfier *v.t.* ធ្វើឲ្យស្ពឹក ឬ ឲ្យស្រវឹង (ឧ. l'opium stupéfie les fumeurs qui en usent)។*Fig.* ធ្វើឲ្យស្រឡាំងកាំង(ឧ. cette nouvelle m'a stupéfié)

stupeur *n.f.* ភាពស្ពឹកឬស្រវឹង ។ *Fig.* ភាពស្រឡាំងកាំង(ឧ. rester muet de stupeur)

stupide *a.&n.* សំពឹក (ឧ. il est si stupide qu'on ne peut rien faire de lui) ។ *a.* ភ្លើ (ឧ. air stupide)

stupidement *adv.* ដោយភ្លើ (ឧ. répondre stupidement)

stupidité *n.m.* ភាពភ្លើឬល្ងង់ល្ងើ;សំដី ឬ អំពើភ្លើ (ឧ. dire une stupidité)

stupre *n.m.* អំពើអនាចារ; អំពើទុយំស

style *n.m.* ដែកចារ; របនាបថ, បែបនិពន្ធ (ឧ. soigner son style); បែបដោយឡែក (នៃសិល្បករម្នាក់ ឬ សម័យមួយ) (ឧ. style gothique)។*Bot.* បំពង់ស្បូនផ្កា

styler *v.t.* បង្រៀនរបៀប ឬ បែបបទ (ឧ. styler un domestique)

stylet *n.m.* ព្រួស, កាំបិតស្នៀតវែងតូច; ដែកចារ

stylisation *n.f.* របនាបថកម្ម, ការប្ដូរ ឬ របនាលំអ

styliser *v.t.* ប្ដូរឬរបនាលំអ (ឧ. styliser une fleur)

stylisme *n.m.* របៀបចនិយម (ការនិយមយកចិត្តទុកដាក់នឹងរបៀបនិពន្ធ)

styliste *n.* អ្នករបៀបចនិយម

stylistique *n.f.* របៀបចនិវិទ្យា

stylo ឬ **stylographe** *n.m.* ស្ទីឡូ (ដងប៉ាកកាស្រូបទឹកខ្មៅ)

stylographique *a.* សម្រាប់ស្ទីឡូ (ឧ. encre stylographique)

su *n.m.* ការបានដឹង ។ au vu et au su de quelqu'un ដោយមានអ្នកណាម្នាក់បានឃើញនឹងបានដឹង

suaire *n.m.* ស្បៃ ។ le saint suaire សន្តស្បៃ, ស្បៃហោសពព្រះយេស៊ូ

suant,e *a.* ដែលបែកញើស; ដែលស្រាបទឹក

suave *a.* គួរត្រេកត្រអាល, រមណីយ(ឧ. parfum, musique suave) (សរ. délicieux, doux, exquis ។ ព.ផ. désagréable, pénible, rude)

suavement *adv.* ដោយគួរត្រេកត្រអាល

suavité *n.f.* ភាពគួរត្រេកត្រអាល (ឧ. un goût, des parfums d'une grande suavité; la suavité du visage, du regard)

subaigu,ë *a.* ស្រួចគួរសម; ខ្លាំងល្មមគួរសម(រោគ)(ឧ. maladie subaiguë)

subalpin,e *a.*ជិតភ្នំអាល្ប,ដែលនៅជើងភ្នំអាល្ប (ឧ. lacs subalpins)

subalterne *a.&n.* ដែលនៅក្រោមបង្គាប់;ថ្នាក់ទាប ។ cadre subalterne ម.ព. cadre ។ officier subalterne ម.ព. officier ។ *a.* រាយរង, បន្ទាប់បន្សំ (ឧ. emploi subalterne)

subconscience *n.f.Phil.* អន្លូសម្បជញ្ញៈ

subconscient,e *a.* ដែលដឹងខ្លួនបន្តិចៗ ។ *n.m.* អន្លូសម្បជញ្ញៈ (ឧ. selon la psychanalyse, certains désirs sont refoulés dans notre subconscient)

subdélégation *n.f.* ការបាត់ប្រតិភូបន្ត; អនុគណៈប្រតិភូ

subdélégué *n.m.* អនុប្រតិភូ, អ្នកតំណាងរង

subdéléguer *v.t.* បែងអំណាចបន្ត; បាត់អនុប្រតិភូ

subdiviser *v.t.* បែងចែកបន្ត; ចែកជាផ្នែករង

subdivision *n.f.* ផ្នែករង

subdivisionnaire *a.* នៃផ្នែករង

subir *v.t.* ទទួលរង (ឧ. subir un interrogatoire); ទទួលការល្បង; ទទួល, រង (ឧ. subir des tortures); ត្រាំ (ឧ. subir une conversation ennuyeuse) ។ *Fig.* subir un changement ត្រូវគេផ្លាស់ប្តូរ ។ subir un examen ចូលប្រឡង(ធ្វើវិញ្ញាសាប្រឡង)។ subir son jugement ទទួលទោសតាមសាលក្រម(មើ.éprouver, essuyer, pâtir, souffrir)

subit,e *a.* ភ្លាម, រហ័សណាស់ (ឧ. changement subit)

subitement *adv.* ភ្លាម

subito *adv. Fam.* ភ្លាម

subjacent,e *a.* ម.ព. sous-jacent

subjectif,ive *a.* ជាអញ្ញជាវត្ត,ដែលនៅតែក្នុងគំនិត (ផ. នឹង objectif យថាវត្ត) ។ *Par ext.* ជាអញ្ញជាវត្ត (ដែលប្រែប្រួលទៅតាមការវិនិច្ឆ័យ, តាមការចូលចិត្ត, តាមទម្លាប់នៃជនម្នាក់) ។

n.m. អញ្ញជាវត្ត, អ្វីៗដែលមាននៅតែក្នុងគំនិត

subjectivement *adv.* ដោយអញ្ញជាវត្ត

subjectivisme *n.m. Phil.* អញ្ញជានិយម (ឧ. le subjectivisme est une forme de l'idéalisme)

subjectiviste *a.* អញ្ញជានិយម ។ *n.* អ្នកអញ្ញជានិយម

subjectivité *n.f.* អញ្ញជាភាព, ភាពមាននៅតែក្នុងគំនិត

subjuguer *v.t.* បង្ក្រាប (ឧ. subjuguer un peuple) ។ *Fig.* មានអំណាចលើ (ឧ. subjuguer les esprits)

sublimation *n.f.* ការធ្វើវត្ថុរឹងឡើងទៅជាចំហុយ ; ការធ្វើចំហុយឡើងទៅជាវត្ថុរឹង (ឧ. sublimation de l'iode) ។ *Fig.* មហោឡារកម្ម (ឧ. la sublimation d'une passion)

sublime *a.* មហោឡារ, ឧត្តមណាស់, ប្រសើរណាស់, ថ្លៃថ្នូរណាស់ (ឧ. éloquence sublime ; être sublime de dévouement) ។

n.m. សេចក្តីល្អវិសេស; អំពើវិសេសបំផុត

sublimé *n.m. Chim.* ធាតុចំហុយដែលកករឹងជាដុំ

sublimement *adv.* យ៉ាងមហោឡារ, យ៉ាងប្រសើរ

sublimer *v.t.* រំលាយវត្ថុរឹងជាចំហុយ;

ធ្វើឧស្ម័នឲ្យទៅជាវត្ថុរឹង ; ធ្វើឲ្យបានប្រសើរឬឲ្យវិសេសបំផុត (ឧ. l'art permet de sublimer les tendances)

sublimité *n.f.* មហោឡារភាព, ភាពប្រសើរ ឬវិសេសបំផុត(ឧ. la sublimité du style)

sublingual [–gou-al]**,e,aux** *a.* ក្រោមអណ្ដាត (ឧ. les glandes sublinguales produisent une salive très visqueuse)

sublunaire *a. Astr.* ក្រោមព្រះចន្ទ (ឧ. région sublunaire) ។ *Par plaisant.* le monde sublunaire ផែនដី

submerger *v.t.* ពន្លិច, ធ្វើឲ្យលិចក្នុងទឹក។ *Fig.* លិចលង់, ធ្វើឲ្យសាបសូន្យ (ឧ. Etat submergé par l'anarchie)

submersible *a.* អាចពន្លិចទឹកបាន ។ *n.m.* នាវាមុជទឹក

submersion *n.f.* ការពន្លិចទឹក; ភាពលិចទឹក; ភាពត្រូវជ្រមុជទឹក

subodorer *v.t.* ស្រង់ក្លិនពីចម្ងាយ ។ *Fig.* ពីភាល់, សង្ស័យ(ថាមានការណ៍អ្វីមួយ) (ឧ. je subodore quelque vilain projet)(ប្រ.flairer pressentir, soupçonner)

subordination *n.f.* អធីនភាព, ភាពនៅក្នុងចំណុះគេ

subordonné,e *a.* អធីន, ចំណុះគេ

subordonner *v.t.* ដាក់ក្នុងចំណុះ ។ *Fig.* លៃតាម (ឧ. subordonner sa réponse à une nouvelle demande)

subornation *n.f.* ការនាំខូច, ការញុំាងឲ្យប្រព្រឹត្តកន្លងករណីយកិច្ច (ឧ. la subornation des témoins est punie des mêmes peines que le faux témoignage)

suborner *v.t.* នាំខូច, ញុំាងឲ្យប្រព្រឹត្តកន្លងករណីយកិច្ច (ឧ. suborner des témoins)

suborneur,euse *a.* ដែលនាំខូច,ដែលញុំាងឲ្យប្រព្រឹត្តកន្លងករណីយកិច្ច ។ *n.* អ្នកល្បួងលោមបញ្ឆោតស្ត្រី

subreptice *a.* ដែលធ្វើដោយលាក់លៀម ឬដោយខុសច្បាប់ (ឧ. pacte subreptice)

subrepticement *adv.* ដោយលាក់លៀម (ឧ. dérober subrepticement des objects) ; ដោយ

ខុសច្បាប់

subreption *n.f.* ការប្រើមធ្យោបាយខុសច្បាប់ (ឧ. obtenir une faveur par subreption)

subrogateur *a.m.Dr.* ឧបាទេស, ដែលតែងតាំងជំនួស។ acte subrogateur លិខិតឧបាទេស (លិខិតដែលតែងតាំងអ្នកនាំការណ៍ម្នាក់ជំនួសអ្នកនាំការណ៍ម្នាក់ទៀត ឬ អ្នកព្យាបាលម្នាក់ជំនួសអ្នកព្យាបាលម្នាក់ទៀត) ។

n.m. Dr. ឧបាទេស (ចៅក្រមដែលត្រូវតែងតាំងជំនួសគេ ក្នុងឋានៈជាអ្នកនាំការណ៍)

subrogatif,ive *a.* ដែលជាឧបាទេសកម្ម

subrogation *n.f.* ឧបាទេសកម្ម, ការតែងតាំងជំនួស, ការដាក់ជំនួស ។ subrogation personnelle ឧបាទេសកម្មជាតិបុគ្គល (ការដាក់មនុស្សជំនួស) ។ subrogation réelle ឧបាទេសកម្មភណ្ឌិក (ការដាក់របស់ជំនួស ក្នុងសេចក្ដីរាយការណ៍ខាងគុណការ)

subrogatoire *a.Dr.* ឧបាទេសករ (ឧ. acte subrogatoire)

subrogé,e *a.* ឧបាទេសិក។ subrogé tuteur អព្យាបកឧបាទេសិក (អ្នកដែលក្រុមប្រឹក្សាគ្រួសារតាំងជំនួសអ្នកព្យាបាល)

subroger *v.t. Dr.* ធ្វើឧបាទេសកម្ម, តែងតាំងជំនួស, ដាក់ជំនួស

subséquemment *adv.* ជាក្រោយ, តទៅទៀត

subséquent,e *a.* ក្រោយ (ឧ. un testament subséquent annule le premier)

subside *n.m.* ពន្ធជំនួយ; ប្រាក់ជំនួយ; ជំនួយ។

subsidiaire *a.* ដែលឲ្យជាជំនួយ; បន្ទាប់បន្សំ (ឧ. raison subsidiaire) (ព.ផ. capital, essentiel, primordial, principal)

subsidiairement *adv.* ជាជំនួយ; ជាបន្ទាប់បន្សំ

subsistance *n.f.* ជីវព្រឹត្តិ (អាហារនិងការថែទាំ; ការចិញ្ចឹម ឧ. pourvoir à la subsistance de sa famille ផ្ដល់ជីវព្រឹត្តិចំពោះគ្រួសារ (ផ្ដល់អាហារនិងរបស់គ្រប់យ៉ាងដែលត្រូវការសម្រាប់ចិញ្ចឹមជីវិតចំពោះគ្រួសារ) ។

pl. ស្បៀង។ *Mil.* service des subsistances ក្រុមជីវព្រឹត្តិ (ក្រុម

អាយុត្តកដ្ឋានខាងអាហារ ដែលមាន បេសកកម្មផ្តល់អ្វីៗជាការចាំបាច់សម្រាប់ អាហារនៃកងទ័ព)

subsistant,e *a.* ជីវព្រឹត្ត, ដែលគង់នៅ។ *n.m.* ជីវព្រឹត្ត

subsister *v.i.* នៅមានជីវិត, ឋិតនៅ, គង់នៅ (ឧ. cet ancien édifice subsiste de nos jours); នៅជាធរមានបញ្ញត្តិ (ឧ. cette loi subsiste); រស់នៅ (ឧ. ne subsister que d'aumônes) (មើល. durer, persister, rester)

subsolaire *a.* ក្រោមព្រះអាទិត្យ

substance *n.f.* សារជាតិ (*Phil.* អ្វីៗដែលនៅឋិតថេរក្នុងវត្ថុដែលប្រែប្រួល ; អ្វីៗដ៏ប្រសើរបំផុត, ដ៏មានរសជាតិបំផុត ឧ. les plantes tirent leur substance de la terre); ធាតុ (ឧ.substance dure, molle)។ *Fig.* ខ្លឹមសារ, សេចក្តីសង្ខេប (ឧ. rapporter la substance d'un discours) ។ en substance ដោយសង្ខេប

substantialisme *n.m.* សារជាតិនិយម (លទ្ធិទស្សនវិជ្ជាដែលជឿថាមានសារជាតិ) (មើល. réalisme ។ ព.ផ. idéalisme)

substantialiste *a.* សារជាតិនិយម។ *n.* អ្នកសារជាតិនិយម (ឧ. Descartes et Spinoza sont des philosophes substantialistes)

substantialité *n.f.* សារជាតិភាព

substantiel,elle *a.* សារជាតិវន្ត (ដែលជាខ្លឹមសារ) (ឧ. idée substantielle); ដែលមានរសជាតិ (ឧ.aliment substantiel); សំខាន់ (ឧ.extraire d'un livre ce qu'il y a de plus substantiel)

substantiellement *adv.* ជាសារជាតិវន្ត

substantif,ive *a. Gramm.* ដែលជានាមសព្ទ ។ *n.m.* នាមសព្ទ

substantivement *adv.* ជានាមសព្ទ (ឧ. adjectif utilisé substantivement)

substituer *v.t.* ធ្វើអាទេសកម្ម, ដាក់ជំនួស, ផ្លាស់ (ឧ. substituer un enfant, un mot à un autre)។ se substituer *v.pr.* ជំនួស

substitut *n.m.* អាទេសី, អ្នកជំនួសគេ; ព្រះរាជអាជ្ញារង

substitution *n.f.* អាទេសកម្ម, ការដាក់

ជំនួស,ការផ្លាស់ (ឧ. substitution d'enfant)

subterfuge *n.m.* បុញ្ញទោភាយ,ឧបាយប្រាកះខ្លួន (ឧ. user de subterfuges) (មើ. échappatoire, faux-fuyant, ruse)

subtil,e *a.* សុខុម,ល្អិតល្អន់ (ឧ. question subtile); វៃ, ប្រសប់ (ឧ. esprit subtil)

subtilement *adv.* យ៉ាងប្រសប់, (ឧ. se tirer subtilement d'une affaire); យ៉ាងសុខុម,យ៉ាងល្អិតល្អន់ (ឧ. raisonner subtilement)

subtilisation *n.f.* សុខុមកម្ម, ការធ្វើឲ្យសុខុម ឬល្អិតល្អន់

subtiliser *v.t.* ធ្វើឲ្យសុខុមឬល្អិតល្អន់(ឧ. subtiliser une substance) ។ *Pop.* បោកដោយប៉ិនប្រសប់ (ឧ. subtiliser un client); លួចដោយប៉ិនប្រសប់ (ឧ. subtiliser une montre) ។

v.i. គិត ឬ ប្រព្រឹត្តដោយល្អិតល្អន់ពេក

subtilité *n.f.* សុខុមភាព (ភាពល្អិត, ឆ្លាតឬប្រាជ្ញយ៉ាងរហ័ស ឧ.la subtilité des atomes échappe à toute division; គំនិតល្អិតល្អន់ ឧ. trop de subtilité nuit; ការញែកដោយល្អិតល្អន់ពេក; ឧបាយយ៉ាងប្រសប់; អ្វីៗដ៏ល្អិតល្អន់)

subtropical,e,aux *a.* ឧបត្រូពិក (ឧ. les régions subtropicales)

subulé,e *a.* ស្រួចពុង (ឧ. antenne subulée)

suburbain,e *a.* ជិតទីក្រុង (ឧ. la population suburbaine)

subvenir *v.i.* ផ្គត់ផ្គង់, ជួយ (ឧ. subvenir aux besoins de quelqu'un)

subvention *n.f.* ឧបត្ថម្ភកធន, ប្រាក់ជំនួយ

subventionnel,elle *a.* ដែលជាឧបត្ថម្ភកធន

subventionner *v.t.* ផ្ដល់ឧបត្ថម្ភកធន, ឲ្យប្រាក់ជំនួយ(ឧ. subventionner un théâtre, une industrie)

subversif,ive *a.* វិទ្ធង្សក, សម្រាប់បំផ្លាញ ឬបង្ខិនបង្ខោច (ឧ. propos subversifs)

subversion *n.f.* វិទ្ធង្សនា, ការបំផ្លាញ ឬ បង្ខិនបង្ខោច

subversivement *adv.* ដោយវិទ្ធង្សក

suc *n.m.* រស (ទឹកដមសាប់, រុក្ខជាតិ ។ល។; វត្ថុរាវដែលហូរចេញ ឬ ដែលគេគាបយកពីសរីរកាយ)។ suc digestif រសជីរណោក ។ suc gastrique រសក្រពះ ។ suc intestinal រសពោះវៀន ។ suc pancréatique រសលំពែង ។ *Fig.* រស (ខ្លឹមសារនៃពាក្យប្រៀន) (ឧ. le suc de la science)

succédané,e *a.* & *n.m.* ឧត្តរវត្ថុ, ឱសថ ឬ របស់ជំនួស (ឧ. les succédanés de l'opium)

succéder *v.i.* បន្ត (ឧ. la nuit succède au jour) ; ធ្វើឧត្តរាធិការ; សោយរាជ្យត, ស្នង, ជំនួស (ឧ. S. M. Sisowath succéda à S.M. Norodom) ។

se succéder *v.pr.* បន្តគ្នា (ឧ. les victoires se sont succédé)

succès *n.m.* ជោគជ័យ(ឧ. le succès d'une entreprise)(ស៊ី. avantage, réussite, triomphe, victoire)

successeur *n.m.* ឧត្តរាធិការី, អ្នកស្នង, អ្នកជំនួស

successibilité *n.f.* ឧត្តរាធិការភាព

successible *a.* ឧត្តរាធិការីយ៍, អាចស្នងបាន(ឧ. parents successibles)

successif,ive *a.* ដែលបន្តគ្នាមិនដាច់ (ឧ. l'ordre successif des jours et des nuits) ។ *Dr.* នៃឧត្តរាធិការ(ឧ le droit successif)

succession *n.f.* ឧត្តរាធិការ (ឧ. succession de rois); ដំណើរបន្តគ្នាមិនដាច់ (ឧ. succession d'idées) ។ *Dr.* ឧត្តរាធិការ (ការបែកនឹងទទួលមរតក; ទ្រព្យមរតក) ។ ordre de succession លំដាប់នៃឧត្តរាធិការ ។ droits de succession ពន្ធនៃឧត្តរាធិការ

successivement *adv.* ជាបន្តគ្នា; ជាលំដាប់

successoral,e,aux *a.* នៃឧត្តរាធិការ (ឧ. loi successorale)

succinct,e *a* ខ្លី; សង្ខេប (ឧ. récit succinct) ។ *Par ext.* ខ្លី, មិនបរិយាយឲ្យវែង(ឧ succinct dans ses réponses) ។ *Fam.* អត្តខាត់, មិនសូវសម្បូណ៌ (ឧ. repas succinct)(ព.ផ.diffus, prolixe, verbeux)

succinctement *adv.* យ៉ាងខ្លី យ៉ាងសង្ខេប

succion *n.f.* ការជញ្ជក់(ឧ.pratiquer la succion d'une plaie)

succomber *v.i.* ធន់មិនបាន, ទ្រមិនរួច; ស្លាប់ (ឧ. le malade a succombé); ចាញ់(ក្នុងការប្រយុទ្ធ, ក្នុងរឿងក្ដី ។ ល ។) ។

v.t. ind. (à) *Fig.* ទប់មិនឈ្នះ, ទប់មិនបាន (ឧ. succomber à la tentation)

succulence *n.f.* ឱជារស

succulent,e *a.* ដែលមានឱជារស (ឧ. viande succulente)

succursale *n.f.* សាខា (គ្រឹះស្ថានជំនួញ) (ឧ. société à succursales multiples)

sucement *n.m.* ការជញ្ជក់

sucer *v.t.* ជញ្ជក់ (ឧ. sucer un bonbon, un crayon); ស្រូបជញ្ជក់ ។ sucer avec le lait ទទួលតាំងពីក្មេង (តាំងពីនៅបៅដោះ)។ sucer son pouce ម.ព. pouce

sucette *n.f.* ក្បាលដោះសម្រាប់ជញ្ជក់

suceur,euse *a.&n.* ដែលជញ្ជក់

suçoir *n.m.Zool.* ប្រមោយសត្វល្អិត (សម្រាប់ជញ្ជក់)

suçon *n.m. Fam.* ស្នាមជញ្ជក់

suçoter *v.t.* ជញ្ជក់ច្រើនដង

sucrage *n.m.* ការបង់ស្ករ (ឧ. le sucrage des moûts augmentent la teneur du vin en alcool)

sucrant,e *a.* ដែលធ្វើឲ្យផ្អែម (ឧ.pouvoir sucrant)

sucre *n.m.* ស្ករ ។ sucre candi ស្ករតាំងម៉ែ ។ sucre raffiné ស្ករស ។ pain de sucre ដែនស្ករស។ *Par ext.* en pain de sucre ជាដែន ឬ រាងសាជី ។ casser du sucre sur le dos de quelqu'un និយាយដើមពីអ្នកណាម្នាក់ ។ ce fruit porte sucre ផ្លែនេះផ្អែមណាស់ (មិនបាច់ដាក់ស្ករ)

sucré,e *a.* ផ្អែម ។ *Fig.* ផ្អែមល្ហែម (ដោយលាក់ពុត) (ឧ. langage sucré) ។

n.f. faire la sucrée ធ្វើជាផ្អែមល្ហែម; ក្លែងជាស្លូត

sucrer *v.t.* បង់ស្ករ (ឧ. sucrer des fruits) ។

se sucrer *v.pr.* *Pop.*

យកចំណែកធំបំផុត

sucrerie *n.f.* កន្លែងធ្វើស្ករ ។ *pl.* បង្អែម (ឧ. aimer les sucreries)

sucrier,ère *a.* នៃការធ្វើស្ករ (ឧ. industrie sucrière) ។ *n.m.* ក្អមស្ករ; អ្នកធ្វើស្ករ

sucrin *n.&a. m.* ត្រសក់ស្រូវផ្អែម

sud *n.m.* ទក្សិណ, ទិសខាងត្បូង; ដំបន់ខាងត្បូង, ទក្សិណប្រទេស

sud-africain,e *a.&n.* នៃប្រទេសអាហ្វ្រិកខាងត្បូង (*pl.* des Sud-Africains)

sud-américain,e *a.* នៃប្រទេសអាមេរិកខាងត្បូង។ *n.* ជនជាតិអាមេរិកាំងខាងត្បូង (*pl.* des Sud-Américains)

sudation *n.f.* ដំណើរបែកញើស (ឧ. provoquer une abondante sudation)

sudatoire *a.* ដែលបានបែកញើសជាប្រោយ

sud-est *a.* អគ្នេយ៍ (ឧ. la région sud-est du Cambodge) ។
n.m. ដំបន់ខាងអគ្នេយ៍

sudiste *n.m.* អ្នកទក្សិណ (បក្សពួកនៃរដ្ឋខាងត្បូងសហរដ្ឋអាមេរិក ក្នុងសង្គ្រាម ១៨៦១-១៨៦៥)

sudorifique *a.* ដែលធ្វើឲ្យបែកញើស (ឱសថ) ។ *n.m.* ភេសជ្ជៈ,ឱសថដែលធ្វើឲ្យបែកញើស

sudoripare ឬ **sudorifère** *a.* សេទៈ, ដែលបញ្ចេញញើស ។ glande sudoripare សេទគ្រន្ថិ (ប.ព. glande ដិង)

sud-ouest *a.* និរតី (ឧ. la région sud-ouest de l'Asie) ។
n.m. ដំបន់ខាងនិរតី

suédois,e *a.* នៃប្រទេសស៊ុយអែដ ។ *n.* ជនជាតិស៊ុយអែដ ។ *n.m.* ភាសាស៊ុយអែដ

suée *n.f.* ដំណើរបែកញើស; ការធ្វើឲ្យបែកញើស ។ *Fig.&Pop.* ដំណើរភ័យបែកញើស (ភ័យភ្លាមៗយ៉ាងខ្លាំង)

suer *v.i.* បែកញើស ។ *Fig. & pop.* faire suer quelqu'un ធ្វើឲ្យបែកញើស; ធ្វើឲ្យហត់; ធ្វើឲ្យធុញណាយ (ដោយនិយាយច្រើន) ។ ជ្រាប ឬ ស្រក់ទឹក (ឧ. les murs suent par les temps humides) ។
v.t. Fam. suer sang et eau ខំប្រឹងបែកញើសតាំងទឹក ។ suer l'ennui អផ្សុកក្រៃពេក ។

suer la peur ខ្លាចព្រៃពេក (ទាល់តែបែកញើស)

suette *n.f.* សេទកេត, រោគបែកញើសច្រើន

sueur *n.f.* ញើស; ដំណើរបែកញើស (ឧ. être en sueur)។ *Par ext.* ញើស (កិច្ចការលំបាក) (ឧ. vivre de la sueur du peuple)។ à la sueur de son front ដោយបែកញើសដាបថ្ងាស (ដោយធ្វើការយ៉ាងលំបាកហើយដោយព្យាយាម)

suffire *v.i. ind.* អាចបំពេញបាន (ឧ. suffire à ses obligations); គ្រប់គ្រាន់ (ឧ. cette somme lui suffira pour payer ses dettes)។ *Abs.* cela suffit, il suffit ឬ suffit គ្រាន់ហើយ, ល្មមហើយ។ **il suffit de** គ្រាន់តែ។ il suffit que គ្រាន់តែឲ្យ។

se suffire ***v.pr.*** មានគ្រប់គ្រាន់ខ្លួនឯង; មិនត្រូវការឲ្យគេជួយ

suffisamment *adv.* យ៉ាងគ្រប់គ្រាន់

suffisance *n.f.* ចំនួនគ្រប់គ្រាន់ (ឧ. avoir sa suffisance de pain); សមត្ថភាពគ្រប់គ្រាន់; សេចក្ដីឡើត (ឧ. sotte suffisance)។ à suffisance ឬ en suffisance *loc. adv.* ដោយគ្រប់គ្រាន់

suffisant,e *a.* ជិតដល់, គ្រប់គ្រាន់ (ឧ. somme suffisante)។

a. & n. ឡើត (ឧ. ton suffisant)

suffixation *n.f.* ការបង្កើតសព្ទដោយបច្ច័យ

suffixe *a. & n.m.* បច្ច័យ

suffocant,e *a.* ដែលធ្វើឲ្យឈ្លក់ ឬ ឲ្យថប់ដង្ហើម

suffocation *n.f.* ដំណើរឈ្លក់ ឬ ថប់ដង្ហើម

suffoquer *v.t.* ធ្វើឲ្យឈ្លក់, ធ្វើឲ្យថប់ដង្ហើម (ឧ. les sanglots le suffoquent)។ *Fam.* ធ្វើឲ្យរំភើបខ្លាំង។

v.i. ឈ្លក់, ថប់ដង្ហើម, ស្ទះដង្ហើម (ឧ. suffoquer de colère)

suffrage *n.m.* ការបោះឆ្នោត; សម្លេង (ក្នុងការបោះឆ្នោត) (ឧ. refuser son suffrage មិនបោះឆ្នោតឲ្យ); ការយល់ព្រម (ឧ. enlever tous les suffrages du public)។ suffrage capacitaire ការបោះឆ្នោតតាមសមត្ថភាព។ suffrage direct ការបោះឆ្នោតចំពោះ។ suffrage

indirect ការបោះឆ្នោតមិនចំពោះ ។ suffrage restreint ការបោះឆ្នោតអសកល ។ suffrage universel ការបោះឆ្នោតសកល

suffragette *n.f.* ស្ត្រីអ្នកទាមទារសិទ្ធិបោះឆ្នោតសម្រាប់ស្ត្រី (នៅប្រទេសអង់គ្លេស)

suffumigation *n.f.* ការបាញ់ផ្សែង (កំចាត់រុយស្អុយ)

suggérer *v.t.* បណ្ដែ, ណែនាំ, ឲ្យយោបល់, ទូន្មាន (ឧ. suggérer une solution)

suggestibilité *n.f.* ភាពស្រួលណែនាំ, សម្បទាខាងទទួលការណែនាំ

suggestif,ive *a.* ដែលណែនាំ, ដែលទូន្មាន; ដែលធ្វើឲ្យនឹកឃើញដល់

suggestion *n.f.* ការណែនាំ,ការទូន្មាន; សេចក្ដីណែនាំ; ការធ្វើឲ្យនឹកឃើញដល់ (ឧ. faire une suggestion) (ស្រ. avis, conseil, insinuation)

suggestionner *v.t.* ធ្វើឲ្យនឹកឃើញដល់

suggestivité *n.f.* លក្ខណៈខាងណែនាំ

suicide *n.m.* អត្តឃាតកម្ម, ការសម្លាប់ខ្លួនឯង

suicidé,e *n* អត្តឃាតកៈ-តិកា, អ្នកសម្លាប់ខ្លួនឯង

suicider (se) *v.pr.* ធ្វើអត្តឃាតកម្ម, សម្លាប់ខ្លួនឯង ។ *Fig.* បំផ្លាញខ្លួនឯង

suidés *n.m. pl.* សូករសត្វ (សត្វសន្តានជ្រូក, ជ្រូកព្រៃ ។ ល ។)

suie *n.f.* ម្រែងភ្លើង (ឧ. comme engrais, la suie nourrit l'herbe et tue la mousse)

suif *n.m.* ខ្លាញ់គោ ឬ ពពែ (សម្រាប់ធ្វើទៀន)។suif végétal ប្រេងរុក្ខជាតិ។ *Pop.* ការស្ដីបន្ទោស

suiffer *v.t.* លាបខ្លាញ់គោ

suiffeux,euse *a.* ប្រកខ្លាញ់គោ

suint [suin] *n.m.* ខ្លាញ់រោមចៀម; អាចម៍ញើសលាយ (ក្នុងន័យខាងក្រោមនេះសរសេរថា suin ក៏បាន)

suintement *n.m.* ការជ្រាប; ដំណើរចេញទឹករងៃ (ឧ. suintement d'une plaie)

suinter *v.i.* ជ្រាប (ឧ.l'eau suinte à travers les rochers); ជ្រាបទឹក (ឧ. ce mur suinte); ចេញទឹករងៃ

suisse *a.* នៃប្រទេសស្វីស្ស

suisse,suissesse *n.* ជនជាតិស្វីស្ស

suisse *n.m.* ឆ្មាំការ (នៃព្រះវិហារធំ)។

n.m. pl. ទាហានជាតិស្វីស្ស(ដែលបម្រើក្នុងកងទ័ពបរទេស) ។ faire suisse បរិភោគដោយគ្មានអញ្ជើញគេ

suite *n.f.* បរិវារ, បរិពារ,ក្រុមអ្នកហែហម (ឧ. suite d'un prince); ក្រុមមនុស្សដែលបន្តគ្នា ; អ្វីៗដែលត (ឧ. pour comprendre ce passage, il faut lire la suite) ; ភាគបន្ត(ឧ. suite d'un roman); ការបន្ត ; ដំណើរមានបន្តគ្នា (ឧ. suite de succès) ; របស់បន្តគ្នា (ឧ. suite de mots); ផល (ឧ. cette affaire aura des suites graves); ដំណើរហូរហែ; ដំណើរមានរបៀប (ឧ raisonnements sans suite) ។

droit de suite សិទ្ធិបន្ត(ម.ព. droit ផង) ។ esprit de suite គំនិតខ្ជាប់ខ្ជួន, ការមិនប្រែប្រួលគំនិត។ avoir de la suite dans les idées មានសេចក្ដីព្យាយាម ។

Loc. adv. de suite មិនដាច់, គ្មានឈប់ (ឧ. faire dix kilomètres de suite) ។ tout de suite ភ្លាម (ឧ.obéissez tout de suite) ។ par suite *loc. adv. & pré.* ដោយហេតុនេះ,ដូច្នេះ។ *Loc. pré.* à la suite de ពីក្រោយ (ឧ. marcher à la suite de quelqu'un) ។ *Loc. div.* pour suite ដើម្បីចាត់ការ។ pour suite demandée ដើម្បីចាត់ការតាមសុំ

suivant *pré.* តាម (ឧ. marcher suivant l'axe d'une vallée; suivant le mérite); តាមមតិ(ឧ. suivant Bossuet) ។ suivant que *loc. conj.* ដោយយោលតាម

suivant,e *a.* បន្ទាប់, ដែលតទៅទៀត (ឧ. au chapitre suivant) ។ *n.m. pl.* បរិវារ , អ្នកហែហម ។ *n.f.* កំលៀង

suiveur *n.m.* អ្នកតាម(ក្នុងការប្រណាំងទោចក្រយាន)

suivi,e *a.* ហូរហែ (ឧ. raisonnement bien suivi); ខ្ជាប់ខ្ជួន ។ théâtre suivie ល្ខោនដែលមានគេមើលច្រើន

suivre *v.t.* តាម (ឧ. suivre quelqu'un pas à pas); អនុចរ, តាមក្រោយ ; ហែហម ; តាមឃ្លាំ (ឧ. il faut suivre cet homme-là);

ដើរបណ្ដោយតាម (ខ. suivre la lisière d'un bois); ដើរតាម(ខ. suivre un chemin); ដេញតាម (ខ. suivre un cheval au galop) ។ *Fig.* តាម (ខ. cet image me suit partout); តាម, ធ្វើតាម (ខ. suivre une mode); តាមសង្កេត (ខ. suivre les progrès des négociations); តាម, យល់តាម, ធ្វើតាម (ខ. suivre Descartes); ស្ដាប់ (ដើម្បីឲ្យយល់) (ខ. suivre un discours); ដល់ក្រោយ (ខ. le printemps suit l'hiver); មានកម្រិតល្មម (រៀនបានទាន់គេ)(ខ. suivre sa classe) ។

suivre une affaire ពិតគួរ អំពីរឿងមួយដោយប្រាកដប្រជា។ suivre un cours ទៅរៀនដោយទៀងទាត់ ។ suivre ses goûts ធ្វើតាមការចូលចិត្តរបស់ខ្លួន ។ suivre une méthode ប្រតិបត្តតាមវិធីមួយ ។ suivre un parti ចូលគណបក្សមួយ ។ suivre une profession ប្រកបវិជ្ជាជីវៈមួយ ។

v.i. តាម (ខ. c'est à vous de suivre) ។

v. impers. il s'en suit que ដោយហេតុនេះបានជា ។

se suivre *v.pr.* បន្ត (ខ. les jours se suivent); តគ្នា(ខ. numéros qui se suivent); ទាក់ទងគ្នាល្អ (ខ. ces raisonnements se suivent)

sujet,ette *a.* ដែលស្ថិតនៅក្នុងអំណាច (ខ. nous sommes tous sujets aux lois); ដែលតែងតែ, ដែលជៀសមិនរួចអំពី (ខ. les hommes sont sujets à la mort, à l'erreur); ដែលត្រូវតែ, ដែលជាប់ពន្ធកិច្ច (ខ. être sujet à l'impôt foncier); ដែលចូលចិត្ត (ខ. être sujet à boire); ដែលច្រើនតែឈឺ (ខ. être sujet à la migraine); ប្រកបដោយ (ខ. entreprise sujette à bien des difficultés); ដែលតាំងឲ្យ, ដែលគេអាច (ខ. passage sujet à plusieurs interprétations) ។

Loc. div. être sujet à l'heure, au coup de marteau, de cloche ឬ de son-

nette ត្រូវតែទៅកន្លែងណាមួយ; ត្រូវតែមានម៉ោងមានពេល, ត្រូវតែទៅធ្វើការឲ្យទៀងពេល; ត្រូវតែទៅពេលចៅហ្វាយនាយត្រូវការ ។ sujet à caution មិនគួរទុកចិត្ត

sujet,ette *n.* អាណាប្រជារាស្ត្រ, អ្នកនៅក្នុងអំណាចបញ្ជា (ឧ. Louis XIV a banni trois millions de sujets. (B. Constant) ។ sujet de droit អ្នកមានសិទ្ធិ ។ *Fam.* il est bon prince, il ne foule guère ses sujets ហាក់នេះស្រួលណាស់ មិនបេះបិះជាន់ទេ ។ *Econ. pol.* sujet économique បុគ្គលសេដ្ឋកិច្ច

sujet *n.m.* ហេតុ, រឿង(ឧ. quereller quelqu'un sans sujet); ប្រធាន (ឧ. sujet de la rédaction, d'examen; le sujet d'un verbe); មនុស្សឬវត្ថុ(ដែលគេសិក្សាឬពិសោធ) (ឧ. les cadavres servent de sujets pour le sétudes anatomiques) ។

Loc. pré. au sujet de ឬ sur le sujet de អំពី ។ bon sujet មនុស្សល្អ ។ mauvais sujet មនុស្សអាក្រក់

sujétion *n.f.* ភាពនៅក្នុងអំណាច; ភាពនៅក្នុងការជិះជាន់ (ឧ. vivre dans la sujétion); ការបង្ខំ, ការបៀតបៀនមិនរួច (ឧ. certaines habitudes deviennent des sujétions)

sulcature *n.f.* ស្នាមជារាងគន្លង

sulciforme *a.* ជារាងគន្លង

sulfamide *n.m.* ស៊ុលហ្វាមីដ

sulfatage *n.m.* ការបាញ់ស៊ុលហ្វាត (ឧ.le sulfatage de la vigne)

sulfate *n.m.* *Chim.* ស៊ុលហ្វាត

sulfaté,e *a.* ដែលមានស៊ុលហ្វាត (ឧ. eau sulfatée)

sulfater *v.t.* បាញ់ស៊ុលហ្វាត (ឧ. sulfater les vignes)

sulfurer *v.t.* លាយនឹងស្ពាន់ធ័រ

sulfureux,euse *a.* ដូចស្ពាន់ធ័រ; ដែលមានលាយស្ពាន់ធ័រ (ឧ. eau sulfureuse)

sultan *n.m.* ស៊ុលតង់ (ក្សត្រប្រទេសទួរគី, ក្សត្រសាសនាអ៊ិស្លាម)

sultanat *n.m.* ឋានៈស៊ុលតង់; រាជ្យស៊ុលតង់

sultane *n.f.* ស៊ុលតាន (ក្សត្រិយានីនៃ

ប្រទេសទួរគី); អាវវែងម្យ៉ាង

summum [som-mom] *n.m.* កំពូល, កម្រិតខ្ពស់បំផុត (ឧ.le summum d'une civilisation)

su-nan *n.m.Art.culin.* ចានឆាក់

sunna , sounna ឬ **souna** *n.f.* សុណ្ណា (កម្រងសិក្ខាបទអ៊ីស្លាម; *par ext.* គន្លងនីតិអ៊ីស្លាម)

supé,e *a.* ដែលជាប់ក្នុងភក់ (ឧ. navire supé)

superbe *a.* ខ្ពស់, សំបើម (ឧ. des tours superbes); ល្អសំបើម (ឧ. ville superbe; superbe poème); ធើតឆាយ (ឧ. costume superbe); ល្អណាស់ (មេឃ); ដែលមានតេជានុភាពគួរឲ្យស្ញើម (ឧ. vainqueur superbe); ស្វាហាប់ (ឧ. grenadier superbe) ។ *En mauv. part.* ឆ្មើងកន្ត្រើង (ឧ. Cette femme superbe entre le front levé. (Racine); ពោង (ឧ. affecter des airs superbes) ។

n.f. សេចក្ដីឆ្មើង, ភាពឡូត ។ (ទិរ. admirable, extraordinaire, merveilleux, prodigieux, splendide, sublime)

superbement *adv.* យ៉ាងសំបើម; យ៉ាងឡូត

supercarburant *n.m.* ប្រេងសាំងវិសេស

supercherie *n.f.* ការបោក (ឧ. user de supercherie); ការបន្លំ (ឧ. une supercherie littéraire)

superciment *n.m.* ស៊ីម៉ងត៍វិសេស

superfétation *n.f.* របស់បន្ថែមឥតប្រយោជន៍

superfétatoire *a.* ដែលបន្ថែមឥតប្រយោជន៍

superficie *n.f.* ផ្ទៃ ។ *Fig.* ចំណេះស្លាក់ស្ទើរ, ចំណេះសើ (ឧ. s'arrêter à la superficie)

superficiel,elle *a.* សើ (ឧ. plaie superficielle) ។ *Fig.* សើ, រាក់ (ឧ. esprit superficiel); ស្លាក់ស្ទើរ (ឧ. connaissance superficielle)

superficiellement *adv.* សើ; យ៉ាងស្ទើរ; យ៉ាងរាក់

superfin,e *a.* ល្អិតល្អន់ណាស់; សុទ្ធណាស់; វាងវៃណាស់

superflu,e *a.* លើស (ឧ. orne-

ment superflu); ឥតប្រយោជន៍ (ឧ. regrets superflus) ។

n.m. អ្វីៗដែលលើសឬដែលសល់ (ឧ. donner un peu de son superflu)

superfluité *n.f.* ភាពលើស (ឧ. superfluité de paroles) ។ *pl.* របស់លើស, របស់ឥតប្រយោជន៍ (ឧ. que de superfluités !)

supérieur,e *a.* ឧត្តម, ខ្ពស់, លើ (ឧ. étage supérieur); លើស (ឧ. température supérieure à la normale)។ *Fig.* ឧត្តុង្គឧត្តម, ប្រសើរជាងគេ, លើសគេ (ឧ. talent supérieur) ។ cours supérieur ម.ត. cours ។ officier supérieur ម.ត. officier ។ être supérieur aux événements មិនតក់ស្លុតនឹងព្រឹត្តិការណ៍ ។

n. ចៅហ្វាយនាយ, មេ (ឧ. obéir à ses supérieurs); ប្រធានអាវាស

supérieurement *adv.* យ៉ាងឧត្តម, យ៉ាងខ្ពស់, យ៉ាងប្រសើរ (ឧ. être supérieurement doué); ដោយឥតខ្ចោះ

supériorité *n.f.* ឧត្តមភាព, ភាពខ្ពស់ ឬ ប្រសើរលើសគេ (ឧ. supériorité de mérite); ភាពជាប្រធានអាវាស។ supériorité aérienne ឧត្តមភាពខាងអាកាស ។ supériorité navale ឧត្តមភាពខាងនាវា (ស៊ី. avantage, prééminence, prépondérance, primauté, suprématie)

superlatif,ive *a. Gramm.* អតិវិសេស ។ adjectif superlatif អតិវិសេសគុណនាម ។

n.m. អតិវិសេសភាព។ *Fam.* au superlatif *loc. adv.* ក្រៃលែង (ឧ il est bête au superlatif)

superlativement *adv.* ក្រៃលែង

supermarché *n.m.* ផ្សារវិសេស (ហាងធំដែលមានលក់អាហារគ្រប់យ៉ាង)

superposable *a.* អាចដាក់ត្រួតគ្នាបាន (ឧ. deux carrés superposables)

superposer *v.t.* ដាក់ត្រួតគ្នា ។ se superposer *v.pr.* ត្រួតគ្នា

superposition *n.f.* ការដាក់ត្រួតគ្នា; ភាពនៅត្រួតគ្នា

superproduction *n.f.* ខ្សែភាពយន្តធ្វើអស់តម្លៃច្រើន

supersonique *a.* លឿនជាងសូរ

superstitieusement *adv.* តាមជំនឿឆ្វេង (ជំនឿក្រៅសាសនា); ដោយទៀងទាត់ហួសហេតុ

superstitieux,euse *a.* ដែលជឿឆ្វេង (ក្រៅពីសាសនា) (ឧ.crainte superstitieuse) ។

n. អ្នកជឿឆ្វេង (ក្រៅសាសនា)

superstition *n.f.* ជំនឿឆ្វេង(ជំនឿក្រៅសាសនា; ជំនឿប្រឆាំងនឹងខ្លួនជាពស់ល្អនកាត់ផ្លូវជាដើម) ។ *Fig.* ការប្រកាន់ហួសហេតុ; ការចូលចិត្តហួសហេតុ(ឧ. avoir la superstition du passé)

superstructure *n.f.* ឧបរិបនាសម្ព័ន្ធ (*Constr.*ផ្នែកខាងលើនៃសំណង់,នៃអគារ ។ *Fig.* អ្វីៗដែលត្រួតពីលើ)

superviser *v.t.* ពិនិត្យត្រួតត្រាលើ (លើកិច្ចការដែលធ្វើរួចហើយ)

supination *n.f.* ភាពអ្នកផើកផ្ងារ; ភាពដៃផ្ងារ; ចលនាបង្វិលផ្ងារដៃ (ព.ផ. pronation)

supplanter *v.t.* ដណ្ដើមកន្លែងគេ (ឧ. supplanter un rival); ប្ដូរ (វត្ថុអ្វីមួយ)

suppléance *n.f.* ការឬសិទ្ធិជំនួសគេ; មុខងារអ្នកជំនួសគេ(ជាបណ្ដោះអាសន្ន) (ឧ. une suppléance vacante)

suppléant,e *a.* ដែលជំនួសគេ (ជាបណ្ដោះអាសន្ន) (ឧ. juge suppléant) ។ membre suppléant ម.ក. membre ។

n.m. អ្នកជំនួសគេ

suppléer *v.t.* ថែមបង្គ្រប់, បំពេញ (ឧ. si vous ne pouvez réunir toute la somme, je suppléerai le reste); ជំនួស (ជាបណ្ដោះអាសន្ន) (ឧ. suppléer un professeur)

v.t. ind. (à) ជំនួស (វត្ថុដែលខ្វះ) (ឧ. la valeur supplée au nombre)

supplément *n.m.* វត្ថុបន្ថែម (ឧ.supplément de solde); អ្វីៗដែលគេថែម

supplémentaire *a.* បន្ថែម (សម្រាប់បន្ថែម ឧ. crédit supplémentaire; ដែលធ្វើបន្ថែម ឧ. heures supplémentaires) ។ *Econ. pol.* biens supplémentaires

របស់ទ្រព្យបន្ថែម

supplémentarité *n.f. Econ. pol.* ភាពបន្ថែម

supplétif,ive *a.* បូរណ៍,ដែលបំពេញ។ *n.m.* ពាក្យបូរណ៍, ពាក្យបំពេញ;ទាហានបំពេញ

supplétoire *a.Dr.* serment supplétoire សម្បថបំពេញ (ដោយភស្តុតាងមិនគ្រប់គ្រាន់)

suppliant,e *a.& n.* ដែលអង្វរករ (ឧ. une mère suppliante) ។ *a.* ដែលបង្ហាញសេចក្ដីអង្វរករ (ឧ. voix suppliante)

supplication *n.f.* ការអង្វរករ

supplice *n.m.* ការផ្ដន្ទាទោស (លើរូបកាយ) (ឧ. supplice de la roue ការភិយក័រ);ការឈឺចាប់ដោយរាងកាយ។ *Par ext.*ការឈឺចាប់ខ្លាំង(ដោយរាងកាយ) (ឧ. le mal de dent est un supplice) ។ *Fig.* អ្វីៗដែលឲ្យមានទុក្ខព្រួយឬឲ្យឈឺចាប់ខ្លាំង(ខាងផ្លូវចិត្ត) (ឧ. sa vue est pour moi un supplice) ។ le dernier supplice ទោសដល់ជីវិត ។ être au supplice ឈឺចាប់, រងទុក្ខ ។ supplices éternels ការរងទុក្ខក្នុងនរក(គ្មានទីបញ្ចប់) ។ supplice de Tantale ការរងទុក្ខដោយមិនបានសម្រេចតាមបំណង(ព្រោះរបស់ឃើញហើយប៉ុន្តែលូកយកមិនបាន)

supplicié,e *n.m.* អ្នកទទួលទោស (ដោយរូបកាយ)

supplicier *v.t.* ប្រហារជីវិត (ឧ. supplicier un condamné); ផ្ដន្ទាទោស។ *Fig.* ធ្វើឲ្យឈឺចាប់,ធ្វើឲ្យរងទុក្ខ

supplier *v.t.* អង្វរករ (ឧ. je vous supplie de me croire)។ *Par ext.* ទទូចសុំ,ទទូចអង្វរ(ឧ. laissez-moi partir, je vous en supplie)

supplique *n.f.* លិខិតសុំទោស ឬ សុំអនុគ្រោះ

support *n.m.* បង្គល់ (ឧ. les supports d'une voûte); ។ *Fig.* ពំនឹង

supportable *a.* អាចទ្រាំបាន (ឧ. douleur supportable) ; អាចអត់អាស្រ័យបាន , អាចអត់ឱនឲ្យបាន (ឧ. cela n'est pas supportable)

supporter [–tèr ឬ –teur] *n.m.*

អ្នកគាំទ្រ (ខាងកីឡា)

supporter *v.t.* ទ្រ (ឧ. piliers qui supportent une voûte) ។ *Fig.* ទ្រាំទ្រនឹង (ឧ. supporter le froid); ទ្រាំ (ទទួលរងដោយអំណត់ទ្រាំ) (ឧ. supporter un malheur); បណ្ដោយឲ្យ (ឧ: il ne faut pas supporter que les enfants soient insolents) ; ទទួលបន្ទុក (ឧ. supporter les frais d'un procès); ធន់ (ឧ. ce livre ne supporte pas l'examen); ទ្រាំ (ឧ. supporter quelqu'un) ។ se supporter *v.pr.* ទ្រាំនឹងគ្នាទៅវិញទៅមក

supposable *a.* អាចសន្មតបាន; អាចស្មានបាន

supposé,e *a.* ក្លែង (ឧ. nom supposé); ដែលគេសន្មត (ឧ. cette circonstance supposée...)។ supposé *pré.* ម.ព. excepté ។ supposée que *loc. conj.* សន្មតថា, ឧបមាថា

supposer *v.t.* សន្មត, ឧបមា (ឧ. supposons que cela soit vrai); តម្រូវឲ្យមាន (ឧ. les droits supposent les devoirs) ; ស្មានខុស; ក្លែង

supposition *n.f.* សម្មតិ; ការស្មាន; ការប្រមាណ (ឧ. une supposition gratuite) ។ supposition de part ឬ d'enfant ការសន្មតិជាកូន (ម.ព. part ផង) (ឧ la supposition d'enfant peut être punie de réclusion) ។ *Pop.* une supposition que ឧបមាថា

suppositoire *n.m.* ឱសថស៊កតាមទ្វារធាត

suppôt *n.m.* អ្នកគាំទ្រ (ក្រុមអ្នកប្រព្រឹត្តបទអាក្រក់) (ឧ. les suppôts d'un parti) ។ suppôts de Satan យមទូត; *par ext.* មនុស្សកំណាច។ suppôt de Bacchus មនុស្សប្រមឹក

suppression *n.f.* ការលុបចោល, ការបំបិទចោល, ការបំបាត់ចោល, ការដកចោល (ឧ. suppression des privilèges) ; ភាគម្ខាងដែលគេបំបិទចោល ។ suppression de part ឬ d'enfant ម.ព. part

supprimer *v.t.* លុបចោល, បំបាត់

ចោល (ឧ. supprimer des emplois inutiles); បំបិទចោល (ឧ. supprimer un journal); ពិក ចោល (ឧ. supprimer une phrase) (ពិ. abolir, abroger, annuler, exterminer, ôter, retirer)

suppurant,e *a.* ដែលធ្លាយខ្ទុះ

suppuratif,ive *a. &n.* ដែលធ្វើឲ្យធ្លាយខ្ទុះ (ឧ. un cataplasme suppuratif)

suppuration *n.f.* ដំណើរកខ្ទុះ; ដំណើរធ្លាយខ្ទុះ

suppurer *v.i.* កខ្ទុះ; ធ្លាយខ្ទុះ (ឧ. abcès qui suppure)

supputation *n.f.* ការថាន់, ការប្រមាណ, ការគិតរកចំនួន (ដោយស្មានៗ) (ឧ. la supputation des dates)

supputer *v.t.* ថាន់, ប្រមាណ (គិតរកចំនួនដោយស្មានៗ) (ឧ. supputer une dépense)

supra *adv. lat.* ខាងលើនេះ (ព.ផ. infra)

supranational,e,aux *a.* លើរដ្ឋ (ចំពោះអង្គការណាមួយដែលមានអំណាចលើរដ្ឋាភិបាលនៃប្រទេសមួយៗ)

suprasensible *a.* លើវិញ្ញាណ; ពុំអាចដឹងបានដោយវិញ្ញាណ

supraterrestre *a.* បរលោក

suprématie *n.f.* អគ្គោត្តមភាព, ភាពឧត្តមបំផុត (ឧ. prétendre à la suprématie)

suprême *a.* អគ្គោត្តម, ឧត្តមបំផុត (ឧ. dignité suprême); សំខាន់បំផុត (ឧ. voici l'instant suprême)។ l'Etre suprême អគ្គោត្តមសត្វ, អាទិទេព។ moment ឬ heure suprême មរណវេលា, ពេលស្លាប់។ volontés suprêmes ឆន្ទៈបុគ្គលដែលជិតស្លាប់។ cour suprême តុលាការខ្ពស់បំផុត ។ pouvoir suprême អំណាចខ្ពស់បំផុត។ honneurs suprêmes ឈាបនកិច្ច (កិត្តិយសធំបំផុត) ។ au suprême degré យ៉ាងប្រសើរបំផុត

suprêmement *adv.* យ៉ាងឧត្តម-ខ្ពស់ ឬ សំខាន់បំផុត

sur *pré.* លើ (ឧ. monter sur le toit); នា (នៅនា) (ឧ. la clef est sur la porte); ខាង (ឧ. aller sur la gauche ទៅខាងឆ្វេង);

សំដៅ (ឧ. revenir sur Phnom-Penh ត្រឡប់ (សំដៅ) មកភ្នំពេញវិញ); តាម (ឧ. sur ma recommandation); ប្រមាណជា, ប្រហែលជា, រវាង (ឧ. sur le soir; elle va sur ses dix ans); ក្នុង (ឧ. cinq mètres sur huit); អំពី (ឧ. écrire sur l'histoire); លើ (ឧ. peindre sur la porcelaine); តាម (ឧ. juger sur les apparences) ។ sur ce ជា ឬ ធ្វើដូច្នេះហើយ (ឧ. sur ce, je vous quitte)

sur,e *a.* ជូរ, ចត់ (ឧ. des pommes sures)

sûr,e *a.* គួរទុកចិត្ត (ឧ. ami sûr); ល្អ (ឥតគ្រោះថ្នាក់) (ឧ. route sûre); ប្រាកដ, ជាក់ (ឧ. le fait est sûr); ដែលដឹងច្បាស់ (ឧ. j'en suis sûr); ប្រាកដជាមាន (ឧ. bénéfice sûr); ស័ក្តិសិទ្ធិ (ឧ. remède sûr) ។

Loc. div. avoir le coup d'œil sûr ប្រមាណដោយភ្នែកមិនខុស ។ avoir la main sûre មិនញ័រដៃ ។ avoir le pied sûr មិនភ្លាត់ជើង, មិនដំពប់ ។ avoir le goût sûr បេះស្គាល់ម្ហូបឆ្ងាញ់; បេះស្គាល់របស់ល្អឬអាក្រក់ ។ le temps n'est pas sûr មេឃអាចមានព្យុះខ្យល់ ។ mettre quelqu'un en lieu sûr ដាក់អ្នកណាម្នាក់នៅកន្លែងស្រួល (កន្លែងដែលឥតឲ្យអ្នកនោះភ័យបារម្ភ ឬ ដែលអ្នកនោះពុំអាចរត់រួច) ។ bien sûr? ពិតឬ? ។ jouer à coup sûr ពិតជាបានសម្រេច ។ parier à coup sûr ពិតជាភ្នាល់បានឈ្នះ ។ faire sûr បានសុខ (ទីណាមួយ) (ឧ. il ne fait pas sûr, la nuit, dans toutes les rues) ។ le plus sûr ប្រសើរបំផុត (ឧ. le plus sûr est de ne compter que sur soi) ។ être sûr de son fait ឬ de son coup ឬ être sûr de soi ទុកចិត្តជាបានសម្រេច, ទុកចិត្តលើខ្លួនឯង ។ être sûr de quelqu'un ទុកចិត្តលើអ្នកណាម្នាក់ ។ *Fam.* être sûr de son bâton ទុកចិត្តជាបានសម្រេច ។

Loc. adv. à coup sûr ឬ pour sûr ប្រាកដជា, ប្រាកដ (ព.ផ. douteux, incertain)

surabondamment *adv.* ដោយ

បរិបូណ៌; ហួសពីគ្រប់គ្រាន់ (ឧ. démontrer surabondamment)

surabondance *n.f.* បរិបុណ្ណភាព, ភាពសម្បូណ៌ពេក

surabondant,e *a.* បរិបូណ៌, សម្បូណ៌ពេក (ឧ. récolte surabondante); លើស (ឧ. détails surabondants) (ដ. excessif, inutile, superflu, vain)

surabonder *v.t.* មានបរិបូណ៌, មានសម្បូណ៌ពេក

suractivité *n.f.* អតិសកម្មភាព, សកម្មភាពដ៏លើសលុប

surah *n.m.* (ព.ហិណ្ឌូ) ស៊ូរ៉ា (សំពត់ស្តើងហើយទន់ធ្វើនៅប្រទេសឥណ្ឌា)

suraigu,ë *a.* ស្រួចខ្លាំងណាស់ (រោគ)

surajouter *v.t.* បន្ថែមទៀត (ឧ. surajouter des preuves)

suralimentation *n.f.* អត្យាហារូបត្ថម្ភ, ការឲ្យអាហារលើសធម្មតា (ឧ. traiter un malade par la suralimentation)

suralimenter *v.t.* ឲ្យអាហារលើសធម្មតា (ឧ. suralimenter un malade)

suranné,e *a.* ចាស់ហួសសម័យ (ឧ. vêtement ឬ cérémonial suranné) (ដ. demodé, périmé)

surarbitre *n.m.* អាជ្ញាកណ្តាលបន្ថែម (សម្រាប់សម្រេចក្នុងករណីដែលអាជ្ញាកណ្តាលមុនសម្រេចមិនស្របគ្នា)

surbaissé,e *a.* ទាបពេក

surbaissement *n.m.* *Archit.* ភាពទាបពេក

surbaisser *v.t.* ធ្វើឲ្យទាបពេក (ឧ. surbaisser une voûte)

surcharge *n.f.* បន្ទុកលើស; ទម្ងន់លើស ។ *Fig.* បន្ទុកហួស (ហួសកម្លាំង ឬ ហួសចំនួនប្រាក់) (ឧ. surcharge des programmes scolaires); ពាក្យត្រៀត; ពាក្យសរសេរត្រួត (ឧ. en comptabilité les surcharges sont interdites)

surcharger *v.t.* ផ្ទុកធ្ងន់ពេក, ឲ្យធ្វើការច្រើនពេក (ឧ. surcharger un cheval) ។ *Fig.* ដាក់បន្ទុកធ្ងន់ពេក (ឧ. surcharger d'impôts); សរសេរត្រៀត ឬ សរសេរត្រួត

surchauffe *n.f.* ការកំដៅខ្លាំងពេក

surchauffer *v.t.* កំដៅខ្លាំងពេក

surchauffeur *n.m.* ប្រដាប់បង្កើនកំដៅចំហាយទឹក

surchoix *n.m.* ភាពល្អលេខមួយ, ភាពល្អអស់ជម្រើស ។ objet de surchoix របស់ល្អអស់ជម្រើស

surclasser *v.t.* ឈ្នះបណ្ដាច់ (ក្នុងកីឡា)

surcompression *n.f.* ការសង្កត់ ឬ កៀបបន្ថែម

surcomprimé,e *a.* ដែលសង្កត់ ឬ កាបបន្ថែម

surcomprimer *v.t.* សង្កត់ ឬ កៀបបន្ថែម .

surcostal,e,aux *a.* លើឆ្អឹងជំនីរ (ឧ. muscle surcostal)

surcot *n.m.* អាវក្រៅ (ពាក់ក្នុងយុគកណ្ដាល)

surcroît *n.m.* ការបន្ថែម (ឧ. surcroît de travail) ។ de surcroît ឬ par surcroît ប៉ុន្មានទៀត, ថែមទៀត

surdent *n.f.* ធ្មេញព្រៃដែលមិនព្រមបាក់; ធ្មេញសេះដែលលូតវែងជាងគេ

surdi-mutité *n.f.* ភាពថ្លង់គ, ភាពថ្លង់ផងគផង

surdité *n.f.* ភាពថ្លង់ (ឧ. surdité complète) ។ *Psychol.* surdité psychique ភាពថ្លង់ដោយវិកលចរិត

surdos *n.m.* ខ្សែពាក់ខ្នងសេះ

surélévation *n.f.* ការលើក ឬ បន្តឲ្យខ្ពស់ទៀត; ការតម្លើងថែមទៀត; ការតម្លើងខ្លាំងពេក; ភាគដែលលើស; ភាគបន្ថែម

surélever *v.t.* លើកឬបន្តឲ្យខ្ពស់ទៀត (ឧ. surélever un mur)

sûrement *adv.* ដោយនិរន្តរាយ, ដោយគ្មានភ័យនឹងអន្តរាយ (ឧ. argent sûrement placé); ប្រាកដជា, ជាក់ជា, ពិតជា (ឧ. il sera déjà sûrement arrivé)

suréminent,e *a.* ឧត្តមបំផុត (ឧ. la dignité suréminente du pape)

surémission *n.f.* ការផ្សាយឬបញ្ចេញច្រើនពេក

surenchère *n.f.* ការឲ្យថ្លៃលើស (លើសគេឬលើសថ្លៃកម្រិត); ការដេញតម្លើងថ្លៃ ។ *Fig.* ការសន្យាប្រកួតប្រជែងគ្នា (ឧ. surenchère électorale)

surenchérir *v.i.* ឲ្យថ្លៃលើស (លើស

គេ ឬ លើសថ្លៃកម្រិត); ដេញតម្លើងថ្លៃ

surenchérissement *n.m.* ការឡើងថ្លៃលើស; ការដេញតម្លើងថ្លៃ

surenchérisseur,euse *n.&a.* អ្នកឡើងថ្លៃលើស; អ្នកដេញតម្លើងថ្លៃ

surentraînement *n.m. Sports* ការហាត់ហួស (កីឡា)

surentraîner *v.t.Sports* ហាត់ហួស (កីឡា)

suréquipé,e *a.* អតិបរិក្ខារវត្ត, ដែលមានបរិក្ខារហួសសេចក្ដីត្រូវការ (សេដ្ឋកិច្ច)

surérogation *n.f.* ការដែលធ្វើហួសពីសេចក្ដីសន្យា

surérogatoire *a.* ហួសពីសេចក្ដីសន្យា

surestarie *n.f.Mar.* ថ្លៃលើស (លើសកំណត់ពេលដែលត្រូវដឹកនាំ ហើយដែលត្រូវបង់សោហ៊ុយឲ្យនាវាអ្នកទទួលដឹកនាំ)

surestimation *n.f.* ការដាក់តម្លៃច្រើនពេក; ប្រមាណលើស

surestimer *v.t.* ដាក់តម្លៃច្រើនពេក; ប្រមាណលើស

suret,ette *a.* ជូរបន្តិចៗ

sûreté *n.f.* និរន្តរាយ, ដំណើរគ្មានភ័យនឹងអន្តរាយ (ឧ. voyager en sûreté); ការមិនភាន់ (ឧ. sûreté de coup d'œil); ប្រយ័ត្ន (ឧ. prendre ses sûretés)។ *Dr.* ប្រាតិភោគ (ក្នុងច្បាប់ផ្លូវរដ្ឋប្បវេណី គឺរបស់ ឬ បុគ្គលជាធានា) (ឧ. l'hypothèque constitue une sûreté réelle, la caution une sûreté personnelle) ។ sûreté conventionnelle និរន្តរាយអនុសញ្ញា ។ sûreté individuelle និរន្តរាយឯកត្តជន ។ sûreté légale និរន្តរាយនីត្យានុកូល (តាមផ្លូវច្បាប់) ។ sûreté nationale ឬ la Sûreté ក្រុមព្រះនគរបាល ។ serrure de sûreté សោមិនងាយកាច់ ។

Loc. div. en sûreté ដោយនិរន្តរាយ, នៅកន្លែងឥតគ្រោះថ្នាក់; នៅកន្លែងដែលមិនអាចរត់ចេញរួច; ក្នុងគុក ។ lieu de sûreté កន្លែងនិរន្តរាយ, ជម្រក; កន្លែងឥតភ័យជាអាទិ ។ mettre quelqu'un en lieu de sûreté ធ្វើមិនឲ្យគេចោទប្រកាន់អ្នកណាម្នាក់បាន ។ en sûreté de conscience ដោយគ្មានស្ដាយក្រោយ, ដោយត្រង់

surévaluer *v.t.* ដាក់តម្លៃខ្ពស់ពេក

surexcitable *a.* អាចញុះញង់បាន; អាចឲ្យខ្លាំងក្លាបាន; អាចឲ្យមានតម្រេកខ្លាំងបាន

surexcitation *n.f.* ការញុះញង់; ការធ្វើឲ្យខ្លាំងក្លា; ការមានតម្រេកខ្លាំង ។ *Par anal.* ការជ្រួលច្របល់ខ្លាំង

surexciter *v.t.* ញុះញង់; ធ្វើឲ្យខ្លាំងក្លា; ធ្វើឲ្យមានតម្រេក; ធ្វើឲ្យជ្រួលច្របល់ខ្លាំងពេក

surexposition *n.f. Phot.* ការបើកឲ្យពន្លឺចូលច្រើនពេក (រូបថត)

surfaçage *Technol.* ការខាត់ផ្ទៃ (ដោយប្រើម៉ាស៊ីន)

surface *n.f.* ផ្ទៃក្រៅ, ប៉ែកខាងក្រៅនៃវត្ថុមួយ។ *Math.* ផ្ទៃ (ឧ. surface de la terre) ។ surface développable ផ្ទៃលាតបាន ។ surface gauche ផ្ទៃលាតមិនបាន។ surface de niveau ផ្ទៃរាបស្មើ (គ្មានកន្លែងត្រង់ណាខ្ពស់ឬទាប)។ surface latérale ផ្ទៃលាត។ surface totale ផ្ទៃទាំងមូល។ *Mar.* faire surface ងើប (នាវាមុជទឹក) ។ *Fig.* អាការៈក្រៅ (ឧ. ne pas s'arrêter à la surface des choses); គ្រឿងបញ្ចាំ ឬ គ្រឿងធានា (ជាមានប្រាក់សង)(ឧ. avoir de la surface)

surfacer *v.t.&i. Technol.* ខាត់ផ្ទៃ (ដោយម៉ាស៊ីន)

surfaire *v.t.&i.* កាត់ថ្លៃខ្ពស់ពេក (ឧ. surfaire un objet) ។ *Fig.* អួតខ្លាំងពេក (ឧ. surfaire un écrivain)

surfait,e *a.* ដែលគេយកតម្លៃហួស

surfaix *n.m.* ខ្សែរុក (ខ្សែចងរឹបកែបសេះ)

surfil *n.m.* ថ្នេរជាន់ជិត

surfilage *n.m.* ការវេញបន្ថែម; ការជាន់ជិត

surfiler *v.t.* វេញបន្ថែម; ជាន់ជិត

surfin,e *a.* ល្អវិសេស

surfusion *n.f. Phys.* បរិវើន, ភាពនៅរលាយក្នុងកំដៅស្ទើរ

surgeon *n.m.* លំពង់, ខ្នែងរុក្ខជាតិដុះចេញពីគល់ឈើ

surgir *v.i.* ងើបឡើង, លេចចេញ (ឧ. une voile surgit à l'horizon)។ *Fig.* ផុសឡើង; ដុះឡើង; មានភ្លាម; ចេញភ្លាម (ឧ. de nouvelles difficultés surgissent)

(ស. émerger, paraître, poindre, sortir, survenir)

surgissement *n.m.* ការផើបឡើង; ការលេចចេញ; ការផុសឡើង

surglacer *v.t.* ពង្រាំ

surhaussé,e *a.* ខ្ពស់ពេក (ព.ផ. surbaissé,e)

surhaussement *n.m.* ការលើកឲ្យខ្ពស់ទៀត; ការធ្វើឲ្យខ្ពស់ពេក

surhausser *v.t.* លើកឲ្យខ្ពស់ទៀត (ឧ. surhausser un mur); ធ្វើឲ្យខ្ពស់ពេក ។ *Fig.* តម្លើងថ្លៃថែមទៀត (ចំពោះរបស់ដែលមានតម្លៃខ្ពស់ណាស់ទៅហើយ)

surhomme *n.m.* ឧត្តមមនុស្ស, មនុស្សវិសេសលើសធម្ម:

surhumain,e *a.* ហួសវិស័យមនុស្ស (ឧ. effort surhumain)

surimposer *v.t.* ដាក់ពន្ធធ្ងន់ពេក (ឧ. l'alcool est surimposé)

surimposition *n.f.* ការដាក់ពន្ធធ្ងន់ពេក

surimpression *n.f.* ការថតត្រួតគ្នា (ឧ. les scènes de rêve au cinéma s'obtiennent par surimpression)

surin *n.m.Arg.* កាំបិត

suriner *v.t.Arg.* កាប់ដោយកាំបិត

surinfection *n.f.* ការកើតរោគថែមទៀត

surintendance *n.f.* មុខងារឧត្តមាយុត្តក:; ឧត្តមាយុត្តកដ្ឋាន, ការិយាល័យឧត្តមាយុត្តក:

surintendant *n.m.* ឧត្តមាយុត្តក:, នាយទាហានក្រសួងការត្រួតលើអាយុត្តក:

surintendante *n.f.* ភរិយាឧត្តមាយុត្តក:; ស្ត្រីព្រះមហាក្សត្រិយានី; នាយិកាសាលាអប់រំ

surintensité *n.f. Electr.* អតិប្រពលភាព, ចរន្តអគ្គិសនីហួសកម្លាំង

surir *v.i.* ឡើងជូរ

surjet *n.m.* ថ្នេរផិត

surjeter *v.t.* ដេរផិត (ឧ. couture surjetée)

surlendemain *n.m.* ថ្ងៃខានស្អែក

surmenage *n.m.* រោគធ្លាក់កម្លាំង (រោគកើតអំពីធ្វើការហួសកម្លាំង) ។ surmenage nerveux ភាពធ្លាក់កម្លាំងសរសៃប្រសាទ

surmener *v.t.* ធ្លាក់កម្លាំង, ធ្វើការហួសកម្លាំង; ឲ្យធ្វើការហួសកម្លាំង (ឧ. surmener des écoliers)

surmontable *a.* អាចជំនះឬពុះពារបាន

(ឧ. difficulté aisément surmontable)

surmonter *v.t.* ឡើងខ្ពស់ជាង (ឧ. l'eau surmontait les maisons); បន្តួតពីលើ (ឧ. statue qui surmonte une colonne)។ *Fig.* ជំនះ, តុះតាំ (ឧ. surmonter les obstacles)

surmoulage *n.m.* ពុម្ពផ្តិតពីរូបស្មិត

surmoule *n.m.* ពុម្ពផ្តិតពីរូបស្មិត

surmouler *v.t.* ផ្តិតពុម្ពពីរូបស្មិត

surnager *v.t.* អណ្តែតលើទឹក ។ *Fig.* នៅសល់ (ឧ. de cette époque, il ne surnage que quelques souvenirs)

surnaturel,elle *a.* អធិធម្មជាត, ហួសវិស័យធម្មជាតិ (ឧ. pouvoir surnaturel); ដែលមានតែក្នុងជំនឿ (ឧ. vérités surnaturelles)។ *Par exagér.* អស្ចារ្យ (ឧ. adresse surnaturelle) ។

n.m. អធិធម្មជាតិ, អំពើអស្ចារ្យ

surnaturellement *adv.* ដោយអធិធម្មជាត, ដោយអស្ចារ្យ

surnom *n.m.* សម្មតិនាម, ឈ្មោះក្រៅ

surnombre *n.m.* ចំនួនលើស

surnommer *v.t.* ដាក់សម្មតិនាម, ឲ្យឈ្មោះក្រៅ

surnuméraire *a.* លើស (ពីចំនួនកំរិត) (ឧ. avoir un doigt surnuméraire)

suroffre *n.f.* ការឲ្យថ្លៃលើស (លើសពីថ្លៃឲ្យលើកមុន)

suroît *n.m.* ខ្យល់ទិសបស្ចិម; មួកកម្មករនាវា (មិនជ្រាបទឹក)

suros *n.m.* ពកជើងសេះ

suroxyder *v.t.* ធ្វើឲ្យព្រះបាប់ខ្លាំង

suroxygéné,e *a.* ដែលមានអុកស៊ីសែនច្រើនពេក

surpasser *v.t.* មានកំពស់ជាង (ឧ. surpasser son voisin de toute la tête)។ *Fig.* ហួស, លើស (ឧ. cela surpasse ses moyens); ឈ្នះ, មានលើស (ឧ. surpasser ses rivaux en talent) ។ *Fam.* ធ្វើឲ្យធ្ងល់ខ្លាំង (ឧ. cet événement me surpasse)។

se surpasser *v.pr.* ធ្វើបានល្អជាងប្រក្រតី

surpaye *n.f.* រង្វាន់បន្ថែម (លើប្រាក់ឈ្នួល); ប្រាក់បន្ថែម (លើតម្លៃ)

surpayer *v.t.* ចេញប្រាក់លើស; ចេញ

ប្រាក់បន្ថែម; ទិញថ្លៃពេក

surpeuplé,e *a.* មានបណ្ដាជនលើសលុប

surpeuplememt *n.m.* អតិប្រជាភិវឌ្ឍន៍, ដំណើរមានបណ្ដាជនលើសលុប (ឧ. le surpeuplement chinois)

surplomb *n.m.* ភាពផ្អៀង ឬ ទ្រេត

surplombement *n.m.* ដំណើរទ្រេត ឬ ផ្អៀង (ឧ. le surplombement d'un mur)

surplomber *v.i.* ទ្រេត, ផ្អៀង (ឧ. ce mur surplombe) ។ *v.t.* ទ្រេតទៅលើ, គ្របពីលើ (ឧ. les rochers surplombent le ravin)

surplus [--ply] *n.m.* អតិរេក, វត្ថុលើស; ចំនួនលើស (ឧ. vendre le surplus de sa récolte) ។ *n.m. pl.* សម្ភារៈសឹកដែលសល់ពីចំបាំង (ឧ. les surplus américains) ។ au surplus *loc. adv.* ម្យ៉ាងទៀត

surpopulation *n.f.* អធិកប្រជាជន; ប្រជាជនច្រើនពេក (ក្នុងប្រទេសមួយ)

surprenant,e *a.* ដែលឲ្យឆ្ងល់ (ឧ. nouvelle surprenante)

surprendre *v.t.* ទាន់· (ឃើញកំពុងធ្វើអ្វីមួយ) (ឧ. surprendre un voleur); មកដល់ដោយមិនដឹងខ្លួន (ឧ. la pluie nous a surpris); ឆ្មក់; លួចល្បាក់ (ឧ. j'irai vous surprendre un jour) ។ *Fig.* ធ្វើឲ្យឆ្ងល់ (ឧ. cette nouvelle m'a surpris); បំភាន់, បញ្ឆោត (ឧ. surprendre la crédulité); ចាប់បាន (ឧ. surprendre une lettre, un secret)

surpression *n.f.* ការសង្កត់ ឬ កៀបខ្លាំងពេក

surprime *n.f.* អតិកោសលាភ, ប្រាក់ធានារ៉ាប់រងបន្ថែម

surprise *n.f.* វិស្ម័យ, ការទាន់; ការឆ្មក់, ការលួចល្បាក់ (ឧ. s'emparer d'un pont par surprise); មកដល់ដោយមិនដឹងខ្លួន; ការឆ្ងល់ (ឧ. causer une grande surprise); ការសប្បាយដោយមិនដឹងខ្លួនមុន; រង្វាន់ ឬ ជំនូនឲ្យដោយមិនដឹងខ្លួនមុន (ឧ. faire une surprise à quelqu'un le jour de sa fête)

surprise-party (ព.អ.) ឬ **surprise-**

partie *n.f.* ការប្រជុំភ្នាក់លេង

surproduction *n.f.* បរិផលិតកម្ម, ផលិតកម្មលើសពីសេចក្ដីត្រូវការ (ឧ. les crises générales de surproduction résultent souvent d'une insuffisance du pouvoir d'achat des consommateurs)

surproduire *v.t.* បរិផលិត, បង្កើតផលិតកម្មច្រើនពេក

surrection *n.f.* ដំណើរលេចឡើង, ដំណើរងើបឡើង

surréel *n.m.* អ្វីៗដែលហួសពីសេចក្ដីពិត

surénal,e,aux *a.* លើតម្រងនោម

sursalaire *n.m.* ប្រាក់បន្ថែមលើប្រាក់ឈ្នួល

sursaturation *n.f.* អធិតិត្ថិកម្ម, ការធ្វើឲ្យឆាប់ហួសពេក ; អធិតិត្ថិភាព, ភាពឆាប់ហួសពេក

sursaturer *v.t.* ធ្វើឲ្យឆាប់ហួសពេក ។ *Fig.* ធ្វើឲ្យឆ្អែតស្កល់ពេក

sursaut *n.m.* ការភ្ញាក់ព្រើត ។ en sursaut *loc. adv.* ប្រញាប់ប្រញាល់ (ឧ. s'éveiller en sursaut)

sursauter *v.i.* ភ្ញាក់ព្រើត (ឧ. sursauter à une mauvaise nouvelle)

surséance *n.f.* រយៈពេលផ្អាក (ក្នុងការជំនុំជំរះ)

sursemer *v.t.* សាបឬព្រោះគ្រាប់លើគ្នា

surseoir (à) *v.t. ind.*ពន្យារពេល, ផ្អាក, លើកពេល (ឧ. surseoir à des poursuites)

sursis *n.m.* ការពន្យារពេល ; ការលស់លា ; ការព្យួរទោស (ឧ. la peine infligée à un condamné qui bénéficie des sursis est annulée si, dans les cinq années suivantes, l'intéressé n'encourt aucune condamnation pour un délit de droit commun) ។ sursis à statuer សេចក្ដីសម្រេចលើកពេលជំនុំជំរះ ។ sursis d'incorporation ការពន្យារពេលចូលធ្វើទាហាន (សម្រាប់ឲ្យសាមីខ្លួនបន្តការសិក្សា)

sursitaire *n.* អ្នកទទួលការពន្យារពេលចូលធ្វើទាហាន

surtaux *n.m.* អត្រាធិក

surtaxe *n.f.* អធិការ, អាករពន្លើស

surtaxer *v.t.* ពន្លើសអាករ, បង្កើនអាករ (ឧ. surtaxer les produits

de luxe)

surtension *n.f. Electr.* ដំណើរឡើងបរិមាណអគ្គិសនី

surtondre *v.t.* កាត់ពុករោមចៀម

surtonte *n.f.* ការកាត់ពុករោមចៀម

surtout *adv.* ជាដើម, ជាពិសេស

surtout *n.m.* អាវក្រៅម្យ៉ាងស៊ីលធំបុរស (ឧ. surtout de chasse)

surveillance *n.f.* អនុរក្ស, ការត្រួតត្រា; ការថែទាំ; ការឃ្លាំមើល (ឧ. exercer une surveillance active)។ sous la surveillance de ក្រោមការត្រួតត្រានៃ (ឧ. être sous la surveillance de la police)

surveillant,e *a.&n.* អនុរក្ស; អ្នកត្រួតត្រា; អ្នកថែទាំ។ surveillant général អគ្គានុរក្ស

surveiller *v.t.* អនុរក្ស; ត្រួតត្រា; ឃ្លាំមើល (ឧ. surveiller les travaux des élèves, des prisonniers); ថែទាំ

survenance *n.f. Dr.* អាគន្តុកបន្ទ, ការមកដល់ ឬ មានក្រោយការ (ឧ. survenance d'un enfant après donation faite)

survenir *v.i.* អាគន្តុកម, មកដល់ ឬ មានដោយខ្លួន; មកដល់ ឬ មានក្រោយកាល

survente *n.f.* ការលក់យកចំណេញហួសពេក

survenue *n.f.* ការមកដល់ដោយខ្លួន

survie *n.f.* ឧត្តរជីព, ឧត្តរជីវិត (ភាពអ្នកនៅរស់យូរជាងម្នាក់ទៀត; ដំណើរនៅមានឈ្មោះក្រោយស្លាប់; ជីវិតក្នុងបរលោក)។ *Dr.* gains ឬ droits de survie លាភ ឬសិទ្ធិនៃឧត្តរជីព (គុណប្រយោជន៍ដែលត្រូវបានដល់អ្នករស់នៅលើសពីកិច្ចសន្យា)

survivance *n.f.* ឧត្តរជីវៃ (ការរួចជីវិត; ដំណើរនៅរស់យូរជាងអ្នកណាម្នាក់; ឯកសិទ្ធិដែលព្រះរាជាប្រគល់ឲ្យដើម្បីរើសឧត្តរាធិការីរបស់ខ្លួន)។ *Fig.* អ្វីដែលនៅសល់ (ឧ. c'est une survivance d'une époque révolue); គំនិត ឬ ទំនៀមទម្លាប់ដែលនៅសល់ (ឧ. le duel est une survivance)

survivant,e *n.&a.* ឧត្តរជីវី, ដែលនៅរស់យូរជាងអ្នកណាម្នាក់ (ឧ. le survivant des époux; l'époux survivant)

survivre *v.i. &t. ind.* នៅរស់យូរ

ជាងអ្នកណាម្នាក់ ។ *Fig.* មាននៅឬរស់នៅក្រោយ (ឧ. survivre à son honneur) ។

se survivre *v.pr.* នៅមានជីវិត (កាយេរើរបស់ឯទៀតហិនហោចអស់ទៅហើយ)

survol *n.m.* ការហោះឬហើរពីលើ

survoler *v.t.* ហោះឬហើរពីលើ។*Fig.* ពិនិត្យគ្រួសៗ (ឧ. survoler une question)

survoltage *n.m. Elect.* ដំណើរឡើងកម្លាំងចរន្តអគ្គិសនី (ឬហៅ surtension វិញ)

survolté,e *a.* lampe survoltée បង្កៀងទទួលចរន្តខ្លាំងពេក ។ *Fig.* ដែលជ្រួលច្រាល់ខ្លាំង(ឧ. auditoire survolté)

survolter *v.t.* បង្កើនកម្លាំងចរន្តអគ្គិសនី

survolteur *n.m. Elect.* ម៉ាស៊ីនបង្កើនចរន្តអគ្គិសនី

survolteur-dévolteur *n.m.Elect.* ម៉ាស៊ីនបង្កើននឹងបន្ថយចរន្តអគ្គិសនី

sus [suss ឬ su] *pré.* លើ ។ courir sus à quelqu'un តាមព្យាបាទ។ en sus *loc. adv.* ថែមទៀត ។ en sus de *loc.pré.* ក្រៅពី ។ *int.* ទ! (ឧ. sus, mes amis, sus donc!)

susceptibilité *n.f.* ភាពឆាប់អន់ចិត្ត

susceptible *a.* អាចទទួលអំពើគ្រប់យ៉ាងបាន (ឧ.la cire est susceptible de plusieurs formes ក្រមួនអាចធ្វើឲ្យទៅជារូបរាងផ្សេងៗបាន ; enfant susceptible de s'améliorer ក្មេងអាចទៅជាល្អបាន) ។ *Fig.* ងាយធ្វើឲ្យឈឺចាប់; ចិត្តស្រាល, ឆាប់អន់ចិត្ត (ឧ.homme susceptible) (ពាក្យ. chatouilleux, irascible, irritable, ombrageux)

susciter *v.t.* បង្កើត, បង្ក (ឧ. susciter une querelle) (ពាក្យ. déclancher, provoquer)

suscription *n.m.* ពំណា (អាសយដ្ឋានការលើស្រោមសំបុត្រ)

susdit,e *n.* & *a.* ដែលមាននិយាយខាងលើ

sus-dominante *n.f. Mus.* ពាយសំខាន់លើ

sus-hépatique *a.* លើថ្លើម

sus-maxillaire *a.* ឆ្អឹងថ្គាមលើ។ *n.m.*

ផ្ដឹកថ្លាមលើ

susmentionné,e *a.* ដែលមានថ្លែងខាងលើ

susnommé,e *a.* ដែលមានឈ្មោះខាងលើ(ឧ. entre les susnommés, il a été convenu)

suspect,e *a.* ដែលគេសង្ស័យ (ឧ. témoignage suspect); គួរឲ្យមន្ទិល (ឧ. vin suspect) ។ suspect de ដែលគេសង្ស័យពី, គួរឲ្យសង្ស័យពី (ឧ. suspect de partialité) ។ *n.m.* ជនដែលគេសង្ស័យ ឬ ដែលគួរឲ្យសង្ស័យ

suspecter *v.t.* សង្ស័យ, មន្ទិល (ឧ. suspecter l'honnêteté de quelqu'un)

suspendre *v.t.* ព្យួរ (ឧ. suspendre un lustre) ។ *Fig.* ពន្យារពេល, ផ្អាក (ឧ. suspendre l'exécution des arrêts); បញ្ឈប់ (ឧ. suspendre la marche); ហាមឃាត់(ដោយមានកំណត់ពេល(ឧ. suspendre un journal); ព្យួរងារ (មន្ត្រី)

suspendu,e *a.* ដែលគេព្យួរ; ដែលត្រូវពន្យារពេល; ដែលត្រូវបញ្ឈប់; ដែលត្រូវហាមឃាត់ (ដោយមានកំណត់ពេល); ព្យួរ ។ pont suspendu ស្ពានសង្រែក

suspens *a.* ដែលគេព្យួរងារ ។ en suspens *loc.adv.* មិនទាន់ដាច់ស្រេច, មិនហើយ (ឧ. laisser une affaire en suspens)

suspenseur *a. m. Anat.* ប្រគោង (ឧ. ligament suspenseur)

suspensif,ive *a. Dr.* ដែលផ្អាក (សម្រាប់ផ្អាកសេចក្ដីសម្រេចតុលាការ) (ឧ. appel suspensif; condition suspensive) ។ *Gramm.* points suspensifs បុច្ឆា-សញ្ញា, សញ្ញាពងត្រី

suspension *n.f.* ការព្យួរ; ភាពព្យួរ (ឧ. la suspension du peudule); គោមព្យួរ (ឧ. suspension en bronze); ការផ្អាក (ឧ. suspension de paiements); សង្រែកព្យួរ ។ suspension de fonction ការព្យួរងារ ។ *Mil.* suspension d'armes ការផ្អាកសង្គ្រាម ។ *Gramm.* points de suspension ម.ព. point ។ *Chim* ដំណើរមិនរលាយអស់ ។ *Phil.* sus-

pension du jugement ការមិនទាន់វិនិច្ឆ័យ (ដោយមិនទាន់យល់ច្បាស់) (ឧ. le doute cartésien est une suspension du jugement)

suspensoir *n.m.* ស្នាប់ទ្រ (សម្រាប់ទ្រសរីរាង្គណាមួយ)

suspente *n.f. Aéron.* ខ្សែព្យួរ (នៃគោមបង្ហោះ)។ *Mar.* ខ្សែផងក្ដោង

suspiscion *n.f.* សង្ស័យ, មន្ទិល (ឧ. juste suspiscion)។ *Dr.* suspiscion légitime សេចក្ដីមន្ទិលត្រូវច្បាប់ (គូក្ដីមានសិទ្ធិមន្ទិលខ្លាចក្រែងតុលាការសម្រេចសេចក្ដីឲ្យខ្លួន ពុំដោយត្រឹមធម៌ ហើយបើសេចក្ដីមន្ទិលនោះសមហេតុផល គេអាចសម្រេចឲ្យជម្រះឡើងវិញបាន ដោយតុលាការថ្មីមានសមត្ថកិច្ចស្មើគ្នា) (មើល. défiance, soupçon)

sustentation *n.f.* ការទ្រទ្រង់កម្លាំងដោយអាហារ; ភាពនៅកល់លើវត្ថុដទៃ

sustenter *v.t.* ទ្រទ្រង់កម្លាំងដោយអាហារ (ឧ. sustenter un malade)។ *Fig.* ទ្រទ្រង់ (ឧ. la lecture sustente l'esprit)។ se sustenter *v.pr.* ចិញ្ចឹមជីវិត; នៅកល់លើគេ

sus-tonique *n.f. Mus.* ញាណកលើ

susurrement *n.m.* ស្សូរខ្សឹប; ស្សូរខ្សៀកៗ (ខ្យល់បក់ស្លឹកឈើ) (ឧ. le susurrement du vent dans les feuilles); ស្សូរហ៊ឹមៗ

susurrer *v.i.* ខ្សឹប។ *v.t.* បន្លឺស្សូរខ្សៀកៗ(ដូចខ្យល់បក់ស្លឹកឈើ) ឬ ស្សូរហ៊ឹមៗ

suttée, suttie ឬ **sâti** *n.f.* សាទី (ពលីកម្មស្ត្រីមេម៉ាយប្រទេសហិណ្ឌូដែលលោតចូលក្នុងភ្លើងដុតខ្លួនជាមួយសពប្ដី)

sutural, e, aux *a.* នៃមុខតំណ(របួស, ឆ្អឹង)

suture *n.f.* ការដេរភ្ជិតមុខរបួស (ឧ. suture au fil de lin)។ *Anat.* មុខតំណនៃឆ្អឹង (សណ្ឋានដូចធ្មេញរណារ) (ឧ. les sutures du crâne)

suturer *v.t.* ដេរភ្ជិត (មុខរបួស) (ឧ. suturer une plaie)

suzerain,e *n.& a.* អធិរាជ (ឧ. le suzerain devait aide au vassal)

suzeraineté *n.f.* អធិរាជភាព; សិទ្ធិអធិរាជលើប្រទេសចំណុះ

svastika *n.m.* ស្វស្តិកៈ

svelte *a.* រៀវ, ស្រាវ, តូចស្តើង, ខ្ពស់ស្រឡះ (ឧ. une taille svelte)

sveltesse *n.f.* បរៀ្យវ, ភាពរៀវ, ភាពស្រាវ, ភាពតូចស្តើង, ភាពខ្ពស់ស្រឡះ

S.V.P. ពាក្យបំព្រួញនៃ s'il vous plait ពាក្យគួរសមមានន័យថា: «សូមអភ័យទោស» ឬ «បើលោកអ្នកពុំយល់ទាស់ទេ»

sweater [soui-teur] *n.m.* (ព.អ.) អាវដាក់ដោយរោមសត្វ

sweating-system *n.m.* (ព.អ.) របៀបបន្ថោកថ្លៃកម្មករ (ដើម្បីឲ្យខ្លួនបានកម្រៃច្រើន ដូចយ៉ាងគឺថ្លៃឈ្នួលឲ្យបានថោកបំផុតជាដើម)

sweepstake [souip's-tèk'] *n.m.* (ព.អ.) ការបាប់ឆ្នោតសេះប្រណាំង

swing [souing] *n.m.* (ព.អ.) ការដាល់ពោក ។ *Mus.* ស្វីញ (បង្វាក់ភ្លេង) ។

a. សៀង

sycophante *n.m.* *Par ext.* អ្នកប្ដឹង, អ្នកបរិហារ; អ្នកបង្កាច់

syénite *n.f.* ថារសៀណេ [ថា-រ:-]

syllabaire *n.m.* សៀវភៅរៀនអាន

syllabe *n.f.* ព្យាង្គ (ឧ. «Paris» a deux syllabes) ។ ne répondre une syllabe មិនឆ្លើយមួយម៉ាត់សោះ

syllabique *a.* នៃព្យាង្គ

syllabus [-buss] *n.m.* បញ្ជីជាបកម្ម (ដែលជាប់ហាមឃាត់)

sylphe *n.m.* អាកាសទេព (ទេព្តានៃខ្យល់)

sylphide *n.f.* អាកាសទេពី ។ *Fig.* ស្រីល្អហើយរហ័សរហួន

sylvains *n.m.pl.* វនទេព (ទេព្តានៃព្រៃ)

sylve *n.f.* វន, ព្រៃ

sylvestre *a.* ដែលដុះក្នុងព្រៃ (ឧ. pin sylvestre)

sylvicole *a.* នៃវនវប្បកម្ម, នៃការដាំព្រៃ (ឧ. industrie sylvicole); ដែលរស់នៅក្នុងព្រៃ

sylviculteur *n.m.* វនវប្បករ, អ្នកបណ្តុះនិងរក្សាព្រៃ

sylviculture *n.f.* វនវប្បកម្ម, ការដាំព្រៃ; វិជ្ជាសាស្ត្រខាងដាំព្រៃ

symbole *n.m.* និមិត្តការណ៍; និមិត្តរូប (ឧ. le chien est le symbole de la fidélité; la balance est le symbole de la justice)

symbolique *a.* ជានិមិត្តរូប (ឧ. le glaive symbolique de la loi) ។ *Par ext.* ដែលគ្រាន់តែជានិមិត្តរូប, ដែលមានតែអាការៈក្រៅ (មិនពិត) (ឧ. offrande symbolique)

symboliquement *adv.* ជានិមិត្តរូប

symbolisation *n.f.* និមិត្តរូបកម្ម, ការសំដែងដោយនិមិត្តរូប

symboliser *v.t.* ធ្វើជានិមិត្តរូប (ឧ. l'olivier symbolise la paix)

symbolisme *n.m.* និមិត្តរូបនិយម

symboliste *a.* និមិត្តរូបនិយម (ឧ. mouvement symboliste) ។ *n.* អ្នកនិមិត្តរូបនិយម

symétrie *n f.* សមប្បមាណ (ឧ. symétrie architecturale)

symétrique *a.* ដែលមានសមប្បមាណ (ឧ. deux constructions symétriques)

symétriquement *adv.* ដោយសមប្បមាណ

sympathie *n.f.* សមានចិត្ត [សៈ-ម៉ា-នៈ–], បសាទចិត្ត [ប៉ៈ-សា-ទៈ–] (ឧ. éprouver de la sympathie pour quelqu'un)

sympathique *a.* ប្រកបដោយសមានចិត្ត, គួរឲ្យចូលចិត្ត (មនុស្ស) (ឧ. personne sympathique) ។ encre sympathique ទឹកខ្មៅសម្ងាត់ (ទឹកខ្មៅនេះគេសរសេរមើលមិនឃើញអក្សរទេ លុះតែដាក់ថ្នាំទើបមើលឃើញ)

sympathiquement *adv.* ដោយសមានចិត្ត (ឧ. accueillir sympathiquement un visiteur)

sympathisant,e *n.* បសាទិកៈ; ដែលសំដែងសមានចិត្ត

sympathiser (avec) *v.i.* មានសមានចិត្ត (ចំពោះ); ចងមិត្តភាព (ជាមួយ) (ឧ. sympathiser avec un camarade)

symphonie *n.f.* មហោរី

symphonique *a.* នៃមហោរី

symphoniquement *adv.* ដោយមហោរី

symphoniste *n.* អ្នកនិពន្ធ ឬ អ្នកលេងមហោរី

symplectique *a.* ដែលរឹតរួបជាមួយនឹងអង្គមួយទៀត

symptomatique *a.* ដែលជាលក្ខណៈនៃរោគ ។ *Fig.* ដែលបង្ហាញសភាព ឬ សន្តានចិត្ត

symptomatologie *n.f.* រោគលក្ខណសាស្ត្រ (មើ. séméiologie)

symptôme *n.m.* រោគលក្ខណៈ (ឧ. des symptômes d'anémie)។ *Fig.* និមិត្តហេតុ (ឧ. des symptômes de rébellion)

synagogue *n.f.* វិហារយ៉ូហ្វ

synallagmatique *a.* contrat synallagmatique អញ្ញមញ្ញកិច្ចសន្យា (កិច្ចសន្យាទៅវិញទៅមក)

synapse *n.f.* ទីប្រសព្វ (នៃសរសៃវិញ្ញាណពីរ)

synarchie *n.f.* សហរាជាធិបតេយ្យ (របៀបគ្រប់គ្រងដោយក្សត្រិយ៍ច្រើនអង្គក្នុងរដ្ឋតែមួយ)

synarthrose *n.f.Anat.* សន្លាក់រឹងនៃឆ្អឹង (ឥតកម្រើកបាន) (ឧ. les sutures sont des synarthroses)

synchrone *a.* សមកាល, ស្មើកាលគ្នា

synchronique *a.* ដែលមានឡើងក្នុងពេលជាមួយ

synchronisation *n.f.* សមកាលកម្ម (ការធ្វើឲ្យប្រព្រឹត្តទៅស្មើកាលគ្នា)

synchroniser *v.t.* ធ្វើសមកាលកម្ម (ធ្វើឲ្យប្រព្រឹត្តទៅស្មើកាលគ្នា)

synchroniseuse *n.f.* សមកាលូបករណ៍ (ប្រដាប់ធ្វើឲ្យប្រព្រឹត្តទៅស្មើកាលគ្នា)

synchronisme *n.m.* សមកាលភាព (ភាពមានឡើងស្មើកាលគ្នា ឧ. synchronisme de deux pendules ; ដំណើរមានឡើងត្រូវពេលគ្នាក្នុងប្រវត្តិសាស្ត្រ)

synclinal,e,aux *a.* & *n.m.* *Géol.* អព្ភលី, ភាគផតនៃផ្ទៃដី (ព.ផ. anticlinal)

syncopal,e,aux *a.* នៃខ្យល់គរ

syncope *n.f.* ខ្យល់គរ (ឧ. tomber en syncope)។ *Mus.* ជិន្នសព្ទ

syndactyle *a.* ដែលមានម្រាមជាប់គ្នា

syndic *n.m.* សហបតិភាគ, អ្នកតំណាងសហជីព

syndical,e,aux *a.* នៃសហជីព (ឧ. l'action syndicale)

syndicalisme *n.m.* សហជីពនិយម; អំពើនៃសហជីព; ប្រជុំសហជីព

syndicaliste *n.&a.* អ្នកសហជីពនិយម; អ្នកចូលក្នុងសហជីព

syndicat *n.m.* សហជីព។ syndicat professionnel សហជីពវិជ្ជាជីវៈ

syndicataire *n.* អ្នកចូលក្នុងសហជីព

នាយទុន ។

a. នៃសហជីព, ដែលទាក់ទង ដោយសហជីព

syndiqué,e *a.&n.* អ្នកចូលក្នុងសហ- ជីព

syndiquer *v.t.* រៀបចំជាសហជីព (ឧ. syndiquer une profession)។

se syndiquer *v.pr.* ប្រមូលគ្នាធ្វើសហជីព; ចូលក្នុងសហជីព

syndrome *n.m.* សហនិមិត្តហេតុ, អា- ការៈនៃរោគមួយ (ឧ. syndrome infectieux)

synodal,e,aux *a.* នៃសង្ឃសភា

synode *n.m.* សង្ឃសភា

synodique *a.* ដែលចេញពីសង្ឃសភា

synonyme *a.* វេវចនៈ។ *n.m.* វេវចន- សព្ទ

synonymie *n.f.* វេវចនភាព

synonymique *a.* នៃវេវចនភាព

synoptique *a.* អាចឲ្យក្រឡេកទៅឃើញទាំងអស់ (ឧ. tableau synoptique)

synovial,e,aux *a.* នៃទឹកសន្លាក់

synovie *n.f.* ទឹកសន្លាក់

syntactique *a.* នៃវាក្យសម្ពន្ធ ។ *n.f.* វាក្យសម្ពន្ធសាស្ត្រ

syntaxe *n.f.* វាក្យសម្ពន្ធ (វេយ្យាករណ៍)

syntaxique *a.* នៃវាក្យសម្ពន្ធ

synthèse *n.f.* សំយោគ, ការរួបរួម ។

synthèse mathématique សំ- យោគគណិតសាស្ត្រ

synthétique *a.* សំយោគី (ដែលធ្វើដោយប្រើវិធីសំយោគ) (ឧ. méthode synthétique; caoutchouc synthétique)

synthétiquement *adv.* ដោយវិធីសំយោគ

synthétiser *v.t.* ធ្វើសំយោគ (ឧ. synthétiser les faits)

syntonisation *n.f.* របៀបថ្លឹងសម្លេងប៉ុស្តិ៍វិទ្យុ

syphilis *n.f.* រោគស្វាយ

syphilitique *a.* នៃរោគស្វាយ ។ *n.* អ្នកកើតរោគស្វាយ

syriaque *a.&n.m.* ភាសាប្រទេសស៊ីរីជាន់ដើម

syrien,enne *a.* នៃប្រទេសស៊ីរី ។ *n.* ជនជាតិស៊ីរី ។ *n.m.* ភាសាស៊ីរី

systématique *a.* ប្រពន្ធិក (នៃប្រព័ន្ធ ឬ របៀបមួយ); ដាច់អហង្ការ (ទុកស្មើលទ្ធិ) (ឧ. doute systématique) ។ esprit systéma-

tique គំនិតប្រព័ន្ធិក ។ homme systématique អហង្ការិនបុគ្គល។

n.f. ប្រព័ន្ធវិជ្ជា; យថាក្រម

systématiquement *adv.* ជាប់អហង្ការ [អៈ-ហ័ង-ការ]

systématisation *n.f.* ប្រព័ន្ធកម្ម, ការរៀបចំជាប្រព័ន្ធ; ការនិយមតាមលទ្ធិ

systématiser *v.t.* រៀបចំជាប្រព័ន្ធ, និយមតាមលទ្ធិ ,

système *n.m.* ប្រព័ន្ធ; របៀប (របៀបធ្វើ ឬ ធ្គុំ; របៀបជាក់លែង ១. système de Taylor ; របៀបគ្រប់គ្រង; របៀបបោះឆ្នោត ១. systèmes électoraux); លទ្ធិគ្រប់គ្រង។

par système *loc. adv.* ដោយសំអៀង ។ esprit de système ការចូលចិត្តរៀបចំជារបៀប; ការប្រព្រឹត្តដោយសំអៀង ។ système D របៀបដោះកុខ ឬ ឈ្លុសឈ្លុល ។ système métrique មាត្រាប្រព័ន្ធ (របៀបរង្វាស់រង្វាល់យកម៉ែត្រជាមាត្រា) ។ système numéral ប្រព័ន្ធសំខ្យា ។ système nerveux ប្រព័ន្ធប្រសាទ ។ système sympathique ប្រព័ន្ធសហានុភូត ។ *Dr.* បែបបទ ។ système de publication des lois បែបបទនៃការផ្សាយច្បាប់

t *n.m.* អក្សរទី ២០ នៃអក្ខរក្រមឡាតាំង។ en T ជាអក្សរ T ។ *t.* (ពាក្យបំព្រួញនៃ tonne) ត. (តោន)

ta *a.pos.f.* (ឥត្ថីលិង្គនៃពាក្យ ton) របស់ឯង

tabac *n.m.* ដើមថ្នាំ; ថ្នាំ (ថ្នាំជក់ឬបុក); គៀមថ្នាំ ។ *Fig.* passer à tabac ធ្វើបាប, វាយដំ។ c'est le même tabac ជាដដែលៗ, ដូចតែគ្នា ។ pot à tabac មនុស្សទាបកន្ទ្រល ។

a. ពណ៌ថ្នាំ (ក្រហមក្រមៅ) (ឧ. une étoffe tabac)

tabagie *n.f.* សាលជក់ថ្នាំ (ជាសាធារណៈ)

tabagisme *n.m.* ម.ព.nicotinisme

tabatière *n.f.* ប្រអប់ថ្នាំ; ប្រអប់បារី ។ fenêtre ឬ chassis à tabatière កូនបង្អួចនៅជិបូល

tabellaire *a.* ជាភាងបន្ទះ ។ impression tabellaire ការបោះពុម្ពដោយក្តារបន្ទះឆ្លាក់

tabernacle *n.m.* ទូតាំងគ្រឿងសក្ការបូជា (ក្នុងគ្រិស្តសាសនា)

table *n.f.* តុ (ឧ. la table sert principalement à servir les repas); អាហាររៀបលើតុ (ឧ. avoir une table frugale); តារាង, បញ្ជី ។ table de logarithmes តារាងមេដំរៀន ។ table de multiplication តារាងមេគុណ, មេលេខគុណ ។ table des matières សារបាន, បញ្ជីរឿង ។

table de nuit តុដំណេក ។ table ronde តុមូល (ការប្រជុំជាផ្លូវការដើម្បីសម្រេចរឿងអ្វីមួយ)។ *Fig.* mettre ឬ dresser la table រៀបតុ (រៀបចំម្ហូបអាហារលើតុ) ។ se mettre à table ចូលតុ (អង្គុយបរិភោគអាហារនៅតុ); *au fig. & pop.* ធ្វើយទទួលសារភាព ។ aimer la table ចូលចិត្តម្ហូបឆ្ងាញ់។ tenir table ouverte ទស្សហ៊ាលៀងអាហារ ។ table d'hôte អាហារប្រចាំពេល ។ faire table rase ម.ព. ras

tableau *n.m.* ក្ដារខៀន (សម្រាប់សិស្សរៀន); ផ្ទាំងគំនូរ; បញ្ជី, តារាង (ឧ. tableau des avocats) ។ *Fig.* ទេសភាព (ឧ. de cette hauteur, on découvre un tableau magnifique); ការពិពណ៌នា (ឲ្យឃើញហាក់ដូចជានៅច្បាស់នឹងភ្នែក) (ឧ. faire un tableau fidèle des événements) ។ tableau d'honneur តារាងកិត្តិយស ។ tableau d'avancement តារាងឡើងឋានន្តរសក្ដិ

tableautin *n.m. Peint.* ផ្ទាំងគំនូរតូច

tablée *n.f.* ក្រុមអ្នកអាស្រ័យរួមតុជាមួយ

tabler (sur) *v.t. ind.* យកជាគោល, ទុកជាគោល (ឧ. tabler sur un événement hypothétique) (ទើរ. attendre, compter (sur), escompter, espérer)

tabletier, ère *n.* អ្នកធ្វើនិងលក់គ្រឿងបគ្រង្គ - រែក ។ ល ។

tablette *n.f.* តុដំកល់ក្រដាសនិងសៀវភៅ; ដុំ, បន្ទះ (បំណី) (ឧ. tablettes de chocolat): ក្រដាសកំណត់ ។ *Fig.* mettez cela sur vos tablettes សុំលោកកុំភ្លេចការណ៍នេះ។ rayer cela de vos tablettes កុំសង្ឃឹមលើការណ៍នេះឲ្យសោះ

tabletterie *n.f.* របរអ្នកធ្វើគ្រឿងបគ្រង្គ

tablier *n.m.* អៀមពាក់ធ្វើការ (សម្រាប់ពាក់ពីមុខកុំឲ្យប្រឡាក់សំលៀកបំពាក់)។ *Fig. & Fam.* rendre son tablier លាឈប់ពីមុខជំនែង ។ ក្ដារស្ពាន; សន្ទះហ៊ិបរថយន្ត; ក្ដារបគ្រង្គ (ប៉ែកខាងមានគូសក្រឡាសម្រាប់លេង)

tabou *n.m.* ពិសិទ្ធកម្ម (ការលើកមនុស្ស ឬ របស់មួយជាពិសិទ្ធហើយហាមលែងឲ្យប៉ះពាល់ ឬ យកមកប្រើប្រាស់) (ឧ.

jeter un tabou sur un lieu)។

a. ពិសិដ្ឋ, ប៉ះពាល់មិនបាន (ឧ. un mot tabou)

tabouret *n.m.* ជើងម៉ា; កំណល់ជើង

tabulaire *a.* ដាក់ជាតុ, រាបស្មើ (ដូចតុ) (ឧ. relief tabulaire)

tac *n.m.* តិក (សម្លេងគ្រាប់ស្វារ)។ *Fig.* répondre du tac au tac ឆ្លើយសំដីម៉ាត់ទៅម៉ាត់មក

tache *n.f.* ស្នាមប្រឡាក់ (ឧ. tache de graisse); ខ្នើ, ស្នាមដូចប្រឡាក់នៅស្បែកមនុស្ស (ឧ. taches de rousseur); ពពាល (ពណ៌ដូចប្រឡាក់នៅរោមសត្វ)។ *Astr.* ស្នាមខ្មៅ (ភាគងងឹតផ្ទុំៗនៅផ្ទៃព្រះអាទិត្យ) ។ *Fig.* ភាពខ្មោះ (ក្នុងរៀងចិត្ត); ដំណើរសៅហ្មង (ក្បើតល្មោភ:) (ឧ. une vie sans tache) ។ faire tache រាល, ជាំ; ធ្វើឲ្យសៅហ្មង (ឧ. cet homme fait tache dans cette société) ។ *Théol.* ផលកម្ម (ឧ. tache originelle) ។ L'Agneau sans tache ព្រះយេស៊ូគ្រិស្ត

tâche *n.f.* ការិយការ [-រ៉ុយ៉ៈ-] (ការដែលត្រូវប្រតិបត្តិក្នុងរយៈពេលតែមួយ)។ *Fig.* កិច្ចការចាំបាច់; ការ ។ prendre à tâche de ប្រឹងប្រែង ។ à la tâche តាមសាច់ការ (តម្លៃឈ្នួល) (ឧ. travailler à la tâche)

tachéographe [-ké-] *n.m.* ប្រដាប់ធ្វើផែនទី

tachéomètre [-ké-] *n.m.* *Techn.* ប្រដាប់ស្ទង់ផ្ទៃដី

tachéométrie *n.f.* វិធីស្ទង់ផ្ទៃដី

tacher *v.t.* ធ្វើឲ្យប្រឡាក់, ធ្វើឲ្យជាំ ។ *Fig.* ធ្វើឲ្យសៅហ្មង (ឧ. tacher sa réputation)

tâcher (de) *v.t. ind.* ប្រឹងប្រែង (ឧ. tâcher de terminer ce travail) ។

v.t. tâcher que ធ្វើត្រាតែ (ព្ទ. chercher (à), s'efforcer (de), essayer (de), s'évertuer (à)

tâcheron *n.m.* ការិយការី, កម្មករយកឈ្នួលតាមសាច់ការ

tacheter *v.t.* ធ្វើឲ្យប្រឡាក់ផ្ទុំៗ, ធ្វើឲ្យប្រឡាក់អុជៗ

tachycardie [-ki-] *n.f.* ជំងឺបេះដូងដើរញាប់

tachymètre *n.m.* *Techn.* សម្ទង់

ស្ញៀន

tacite *a.* តុណ្ហី, ដែលស្ងៀម (ឧ. consentement tacite)។ *Dr.* tacite reconduction ម.ព. reconduction

tacitement *adv.* ដោយតុណ្ហីភាព, ស្ងៀម

taciturne *a.* ដែលនិយាយតិច, មិនចេញវាចា

taciturnité *n.f.* ភាពនិយាយតិច

tacot *n.m. Fam.* ឡានកញ្ចាស់

tact *n.m.* ផស្សៈ, កាយវិញ្ញាណ។ *Fig.* សេចក្ដីឆ្លាតឬវាងវៃ (ឧ. manquer de tact)

tacticien *n.m.* អ្នកកលយុទ្ធ

tactile *a.* អាចប៉ះពាល់ត្រូវ (ឧ. corps tactile); នៃកាយវិញ្ញាណ

tactique *n.f. Milit.* កលយុទ្ធ (ឧ. tactique d'infanterie)។ *Fig.* ស្ទៀត(មធ្យោបាយឲ្យបានសម្រេចការ) (ឧ. changer de tactique)។ *a.* នៃកលយុទ្ធ (ឧ. l'emploi tactique des blindés)

tael *n.m.* តម្លឹង

tænia *n.m.* ម.ព. ténia

taffetas *n.m.* សំពត់សូត្រម៉្យាង

taïaut! ឬ **tayaut!** *int. Véner.* អា! (សម្លេងពន្យុះឆ្កែឲ្យដេញសត្វ)

taie *n.f.* ស្រោមខ្នើយ; ស្នាមសនៅកញ្ចក់ភ្នែក

taillable *a.* ដែលជាប់ពន្ធខ្លួន (នៅប្រទេសបារាំងជាន់ដើម) (ឧ. le serf était taillable et corvéable à merci)

taillade *n.f.* ស្នាមរយះ, ស្នាមឆ្លូតសាច់; ស្នាមរហែកបណ្ដោយសំពត់

taillader *v.t.* ធ្វើឲ្យរយះ, កាត់ឆ្លូតសាច់ (ឧ. se taillader le visage); រហែកបណ្ដោយសំពត់

taillage *n.m. Techn.* ការបន្ស៊ីធ្មេញ (ឧ. le taillage d'une roue d'engrenage)

taillanderie *n.f. Techn.* របរសស្ត្រការី

taillandier *n.m. Techn.* សស្ត្រការី (ជាងធ្វើគ្រឿងអារ-ច្រូត-កាប់-កាត់ ដូចជារណារ, កណ្ដៀវ, កាំបិត ។ល។)

taillant *n.m.* មុខ (មុខកាំបិត-ពូថៅ ។ល។)

taille *n.f.* មុខដាវ; ការកាត់, ការចិត; វិធីកាត់, វិធីចិត; ការក្រី, ការលះមែកឈើ (ឧ. la taille des arbres)។

taille d'entretien ការព្រឹក្សា ។ taille de formation ការព្រឹចំរើន ។ ល្បាស់ឈើ (ដែលទើបនឹងលាស់ពីពេលដែលគេកាត់) (ឧ. taille de deux ans); មាឌ (ឧ. homme de grande taille); ផឹងខ្លួន (ឧ. taille svelte) ។ tour de taille បង្កេះ (ប្រវែងមួយជុំបង្កេះ) ។ ទំហំ; ឈើព្រឹត (បំណាំបំនួនបំណុល); ពន្ធខ្លួន (អាករចំពោះលើរូបមនុស្សនៅប្រទេសបារាំងក្នុងសម័យបុរាណ)(ឧ.être exempt de la taille) ។

sortir en taille ចេញដើរខ្លួនទទេ ។ pierre de taille ថ្មរឹង (សម្រាប់សង់ផ្ទះ) ។ frapper d'estoc et de taille ម.ព. estoc ។ être de taille à អាចនឹង

taillé,e *a.* រៀបចំរួចស្រេច (ឧ. voilà votre besogne taillée) ។ homme bien taillé មនុស្សមានឧធំហើយសមល្អ

taille-crayon *n.m.* ប្រដាប់ចិតខ្មៅដៃ

taille-douce *n.f.* *Arts graph.* ចម្លាក់លើលោហធាតុ (ឆ្លាក់ដោយដែកមិនប្រើទឹកថ្នាំបង្ខាត់)

tailler *v.t.* កាត់, ចិត; របោះឡើងជា; ព្រឹ, លះមែកឈើ(ឧ.tailler un arbre); ច្នៃ (ត្បូង) ។ *Fig.* tailler en pièces une armée កំទេចទ័ពមួយ ។ tailler des croupières à quelqu'un ម.ព. croupière (ពាក់. couper, découper, hacher, sectionner, trancher, tronçonner)

taillerie *n.f.* សិល្បៈច្នៃត្បូង ; រោងជាងច្នៃត្បូង (ឧ. taillerie de diamants)

tailleur *n.m.* អ្នកកាត់, អ្នកចិត (ឧ. tailleur de pierre); ជាងកាត់ដេរ; សំលៀកបំពាក់ ។ costume tailleur ឬ tailleur តៃយ័រ (សំលៀកបំពាក់ស្ត្រីម្យ៉ាង)

tailleuse *n.f.* ស្ត្រីអ្នកកាត់ដេរ

taillis *n.m.* ព្រៃល្បាស់(ព្រៃដែលគេកាប់ទុកឲ្យលាស់ឡើងវិញ) (ឧ. couper un taillis)

tailloir *n.m.* ថ្នៀញក្រាប់កាត់សាច់ ។ *Archit.* ក្បាលសសរ

tain *n.m.* ថ្នាំលាបកញ្ចក់ (ឡេផ្ទះស្រមោល)

taire *v.t.* មិននិយាយ, លាក់ (ឧ. taire la vérité) ។

se taire *v.pr.* នៅស្ងៀម, មិនបញ្ចេញស្តី, នៅស្ងាត់ស្ងៀម; លាក់អាថ៌កំបាំង ។ se taire sur (ឬ de) មិននិយាយបរិយាយពី ។ faire taire បំបិទមាត់ (មិនឲ្យនិយាយ) ។ *Fig.* faire taire le ressentiment ទប់កំហឹង។ faire taire le canon ធ្វើឲ្យឈប់បាញ់

talaire *a.* ដែលធ្លាក់ដល់កែងជើង (ឧ. robe talaire)

talapoin *n.m.* ព្រះសង្ឃ (នៅប្រទេសសៀម)

talc *n.m.* ត័ល (ម្សៅ)

talé,e *a.* ជាំ (ផ្លែឈើ)(ឧ. poires talées)

talent *n.m.* រូបិយវត្ថុក្រិកបុរាណមួយបែប ។ *Fig.* កោសល្យ, ការប៉ិន (ឧ. le talent de la parole); អ្នកប៉ិន (ឧ. c'est un talent de premier ordre)។ne forçons point notre talent ល្ងង់កុំចង់ធ្វើប្រាជ្ញ

talentueusement *adv.* ដោយប៉ិន

talentueux,euse *a.* *Fam.* ប៉ិន

talion *n.m.* ទណ្ឌកម្មធ្ងន់នឹងកំហុស ។ loi du talion ច្បាប់តាលីយ៉ុង (ច្បាប់បញ្ញត្តិឲ្យដាក់ទណ្ឌកម្មឲ្យធ្ងន់នឹងកំហុស)

talisman *n.m.* វត្ថុស័ក្តិសិទ្ធ (មានយ័ន្តជាដើម) ។ *Fig.* អ្វីៗដែលមានអានុភាពខ្លាំង (ឧ. l'or est un puissant talisman)

talismanique *a.* នៃវត្ថុស័ក្តិសិទ្ធិ

taloche *n.f.* *Fam.* ការទះក្បាល។ *Techn.* ក្តារបាតបាយអ

talocher *v.t.* ទះក្បាល (ឧ. talocher un enfant)

talon *n.m.* កែងជើង; កែងស្បែកជើង; កន្ទុយ (ឧ. talon de pain); សន្លឹកបៀដែលសល់ពីចែក; គល់បញ្ជី; បាតនាវាខាងក្រោយ ។ montrer ឬ tourner le talon រត់ ។ marcher sur les talons de តាមប្រកិត ។ talon d'Achille ចំណុចខ្សោយ

talonner *v.t.* គោះកែង; ដាក់ដោយព្រនាប់ (សេះ) (ឧ. talonner un cheval); ដេញតាមប្រកិត (ឧ. talonner un ennemi)។*Fig.* បង្ខំខ្លាំង (ឧ. être talonné par

ses créanciers) ។

v.i. Mar. កើលបាត (នាវា) (ឧ. navire qui talonne) (ល៏. pourchasser, poursuivre, tourmenter, traquer)

talonnette *n.f.* ស្នាប់កែង (ទ្រនាប់កែងស្បែកជើង)

talus *n.m.* ដីជំរាល, ជើងទេរ, ភ្លឺ ។ couper ឬ tailler en talus កាត់បញ្ឆិត

taluter *v.t. Techn.* សង់ជំរាល; ពូនជើងជញ្ជាំង

talweg ឬ **thalweg** *n.m.* ផ្លូវបាតជ្រោះ

tamarin *n.m.* អម្ពិល; ផ្លែអម្ពិល

tamarinier *n.m.* ដើមអម្ពិល

tambouille *n.f. Pop.* ជើងក្រាន

tambour *n.m.* ស្គរ; អ្នកវាយស្គរ; ក្រសាល់ខ្សែ ឬ ប្រភក់ ។ *Fig.& Fam.* mener quelqu'un tambour battant ធ្វើជាបខ្លាំង ។ battre du tambour វាយស្គរ ។ sans tambour ni trompette ស្ងាត់ឈឹង; ដោយសម្ងាត់ (ឧ. partir sans tambour ni trompette)

tambourin *n.m.* សំភោរ

tambourinage ឬ **tambourinement** *n.m.* ការវាយស្គរ

tambouriner *v.i.* វាយស្គរ; គ្រាប់សម្លេងស្គរ (ឧ. la pluie tambourine sur les vitres); វាយញយៗ (វាយច្រើនដង) (ឧ. tambouriner sur la porte) ។

v.t. ជាំគែងខ្លួនភៅ, ស្រែកប្រកាសដោយវាយស្គរ ។ *Fig.* ផ្សាយពាសពេញ (ឧ. tambouriner une nouvelle)

tambourineur *n.m.* អ្នកវាយសំភោរ

tambour-major *n.m.* នាយស្គរ (នាយទាហានដែលជាមេគ្រូតស្គរ ឬ ជាមេភ្លេងទាហាន) (*pl.* des tambours-majors)

tamis [-mi] *n.m.* កញ្ច្រែងរែង, កន្ត្រង, កាតៅ ។ *Fig.* passer au tamis ពិនិត្យដោយហ្មត់ចត់

tamisage *n.m.* ការរែង, ការត្រង

tamiser *v.t.* រែង, ត្រង (ឧ. tamiser de la farine) ។ *Par ext.* ត្រង (បញ្ចេញបន្តិចៗ) (ឧ.vitraux qui tamisent la lumière) ។

v.i. លេចឬជ្រុះចេញពីកញ្ច្រែង។ *Mar.* voile qui tamise ក្ដោង

ហាស់ផ្ទះ

tamiseur,euse *n.* អ្នករែង ឬ ត្រង

tamoul ឬ **tamil** *n.m.* តាមីល(ភាសាតាមីល)

tampon *n.m.* ឆ្នុក; ដុំសំពត់សម្រាប់ជូតសខាត់; សំឡីជូតឈាមដំបៅ; ត្រា; ទ្រនាប់, បន្ទាស, គ្រឿងការពារការប៉ះទង្គិច ។ pays tampon ប្រទេសទ្រនាប់(ប្រទេសដែលនៅចន្លោះប្រទេសពីរ ហើយអាចរាំងកុំឲ្យប្រទេសពីរនោះទាស់ទែងគ្នា) ។ *Pop.* coup de tampon ការជល់

tamponnement *n.m.* ការប៉ះឬទង្គិចខ្លាំង; ដំណើររថយន្តបុកគ្នា (ចំពោះរថយន្តដែលបើកទៅសំដៅទិសជាមួយគ្នា); ការចុក (ឧ.tamponnement des fosses nasales en cas d'épistaxis)

tamponner *v.t.* ចុក; បោះដញ្ជាំងញាត់ឈើដើម្បីបោះដែកគោល; ប៉ះ, ទង្គិច (ឧ. train qui en tamponne un autre); បោះត្រា (ស. choquer, emboutir, heurter, télescoper)

tamponnoir *n.m.* ប្រដាប់បោះដញ្ជាំង (សម្រាប់ញាត់ឈើបោះដែកគោល)

tam-tam *n.m.* រគាំង, ឃ្មោះ, ស្គរ; ស្គរគោះលើដែក ។ *Fam.* ការផ្សាយ (ឧ. faire du tam-tam à propos d'un roman) (*pl.* des tam-tams)

tan *n.m.* សំបកឈើកិនសម្រាប់សម្លាប់ស្បែក

tancer *v.t.* ស្តីបន្ទោស (ឧ. tancer un enfant)

tandem [-dèm] *n.m.* ទោចក្រយានជិះពីរនាក់

tandis que *loc.conj.* ក្នុងពេលដែល, កាន់ (ឧ. travaillons tandis que nous sommes jeunes); ចំណែកខាង, រីឯ

tangage *n.m.* ការយោលទៅមុខទៅក្រោយ (ផ្ទុយនឹង roulis ការយោង)

tangence *n.f. Math.* ផុស្គភាព, ភាពប៉ះប្រផិតប្រផើយ ។ point de tangence ចំណុចផុស្គភាព (ចំណុចដែលបន្ទាត់ពីរ ឬ ផ្ទៃពីរប៉ះគ្នា)

tangent,e *a.* ផុស្គៈ, ដែលប៉ះប្រផិតប្រផើយ(ឧ. droite tangente à un cercle) ។ *Fam.* ប្រផិតប្រផើយ, ហៀបនឹងបានសម្រេច

tangente *n.f.Math.* ផុស្គរេខា ។ *Fig.*

& Fam. s'échapper par la tangente ឬ prendre la tangente ដោះសាដោយប៉ិនប្រសប់ ។ *Arg. scol.* ត្រូតម្រូត (ក្នុងពេលប្រឡង)

tangentiel,elle *a. Math.* នៃផ្ចិតប៉ះ

tangentiellement *adv.* ដោយប៉ះប្រផិតប្រផើយ

tangibilité *n.f.* ផុសនីយភាព, ភាពអាចស្ទាបបាន; ភាពជាក់ស្ដែង

tangible *a.* ផុសនីយ, ដែលអាចស្ទាបបាន (ឧ. les corps tangibles) ។ *Par ext.* ជាក់ស្ដែង, ពិត (ឧ. un signe tangible)

tangiblement *adv.* ដោយផុសនីយ, ដោយអាចស្ទាបបាន; ដោយជាក់ស្ដែង

tango *n.m.* តង់ហ្គោ (របាំម្យ៉ាង) ។ *a. inv.* លឿងទុំ (ឧ. des étoffes tango)

tanguer *v.i.* យោលពីមុខទៅក្រោយ

tanière *n.f.* រូង, ជម្រកសត្វព្រៃ (ឧ. la tanière du lion) ។ *Par anal.* ផ្ទះរយីករយាក; ផ្ទះនៅដាច់សង្វែង

tanin ឬ **tannin** *n.m.* ថ្នាំសម្លាប់ស្បែក

tank *n.m.* អាងនាវាដឹកសាំង; ដលដ្ឋាន (សម្រាប់បាញ់ទឹកបញ្ចូលស្រែនៅប្រទេសឥណ្ឌា)); រថក្រោះ (ប.ព. char ផង)

tanker *n.m.* (ព.អ.) នាវាដឹកប្រេងសាំង

tannage *n.m.* ការសម្លាប់ស្បែក

tannant,e *a.* សម្រាប់សម្លាប់ស្បែក (ឧ. écorces tannantes) ។ *Fig. & Fam.* ដែលធុញទ្រាន់, ដែលធ្វើឲ្យអស់កម្លាំង

tanne *n.f.* មុន (រោគកើតគ្រង់មុខ)

tanné,e *a.* ដែលសម្លាប់ហើយ (ស្បែក) (ឧ. peau tannée); ដាំដែង (ពណ៌ដូចថ្នាំសម្លាប់ស្បែក) (ឧ. visage tannée par le soleil) ។

n.m. ពណ៌ដាំដែង (ពណ៌ថ្នាំសម្លាប់ស្បែក)

tannée *n.f.* កាកថ្នាំសម្លាប់ស្បែក

tanner *v.t.* សម្លាប់ស្បែក ។ *Fig. & Fam.* ធ្វើឲ្យទ្រាន់

tannerie *n.f.* កន្លែងសម្លាប់ស្បែក; ឧស្សាហកម្មសម្លាប់ស្បែក

tanneur *a.&n.m.* អ្នកសម្លាប់ស្បែក; អ្នកលក់ស្បែកសម្លាប់

tannique *a.* ដែលមានជាតិថ្នាំសម្លាប់ស្បែក

tan-sad *n.m.* កៅអីព្រនាក់ (កៅអីដាក់ខាងក្រោយសម្រាប់ព្រនាក់គ្នា)

tant *adv.* ច្រើនយ៉ាងនេះ (ឧ. il a tant

d'amis que...); ប៉ុណ្ណេះ (ឧ. il y aura tant pour vous); ទាល់តែ, ត្រាតែ (ឧ. il a mangé tant que...); ឮរណាស់ (ឧ. j'ai tant marché); ដរាបណា (ឧ. tant que je vivrai); ឆ្ងាយត្រឹម (ឧ. tant que la vue peut s'étendre ភ្នែកមើលឃើញដល់ត្រឹមណា...); ធំយ៉ាងនេះ; ញឹកយ៉ាងនេះ; ណាស់ទៅ (ឧ. tant va la cruche à l'eau qu'à la fin elle se casse ម.ព.cruche ផង)។

Loc. adv. tant mieux សាធុ! ល្អហើយ! (សម្តែងសេចក្តីរីករាយ)។ tant pis ដូចម្តេចក៏ដោយចុះ (សម្តែងកំហឹង)។ tant et plus ច្រើន។ tant soit peu ឬ un tant soit peu ទោះជាបន្តិចបន្តួចក្តី។ *Loc. conj.* tant s'en faut que ឆ្ងាយណាស់ទៅ។ si tant est que ប្រសិនជា, បើមាន។ en tant que តាមតែលសម្រេចបាន; ក្នុងឋានៈជា។ tant pour cent កំណត់ភាគរយ។ tant que ដរាបណា... ដរាបនោះ, ល្មមណា។ faire tant ធ្វើត្រាតែឬទាល់តែ

tante *n.f.* ម្តាយមីង, ម្តាយធំ។ tante à la mode de Bretagne មីងក្រៅពីមីងបង្កើត (បងប្អូនជីដូនមួយស្រីរបស់ឪពុកឬម្តាយ)។ *Pop.* ma tante ផ្ទះរុកស៊ីបញ្ចាំ

tantième *a.* នៃចំនួនតូច; ចំនួនបែងភាគ (ឧ. soit à trouver la tantième partie d'un tout)។ *n.m.* ភាគប្រាក់ចំណេញ (ដែលបែកឡើងទៅអភិបាលក្រុមហ៊ុន)

tantine *n.f. Fam.* មីង (ព.ទំលើមកពី tante)

tantinet *n.m. Fam.* បន្តិច (ចំនួនតិចតួចណាស់) (ឧ. un tantinet de pain)។ un tantinet *loc. adv.* បន្តិច (ឧ. il est un tantinet malin)

tantôt *adv.* បន្តិចទៀត (ក្នុងពេលបន្តិចទៀត) (ឧ. j'irai tantôt); ទើបនឹង (ឧ. je l'ai vu tantôt); ជួនកាល, ម្តង... ម្តង... (ឧ. tantôt il est d'un avis, tantot il est d'un autre ម្តងជាយ៉ាងនេះម្តងជាយ៉ាងនោះ)។ à tantôt សូមលាសិន (បន្តិចទៀតនឹងជួបគ្នាវិញ)។

n.m. le tantôt ថ្ងៃរសៀល

taoïsme *n.m.* លទ្ធិតាវ(នៅប្រទេសចិន)

taoïste *a.&n.* អ្នកកាន់លទ្ធិតាវ; នៃលទ្ធិតាវ

taon [tan] *n.m.* របោម

tapage *n.m.* សូរទះ ឬ វាយ ។ *Par ext.* សូរអ៊ូអែ ឬ ក្ដុងក្ដាំង (ឧ. faire du tapage); សូរសុសសាយ (ពវ. brouhaha, fracas, tintamarre, vacarme)

tapager *v.i.* បន្លឺសូរអ៊ូអែ, ធ្វើឲ្យឮសូរអ៊ូអែ; ដែលធ្វើក្ដុងក្ដាំង; ធ្វើឲ្យឮសុសសាយ

tapageur,euse *a.* & *n.* ដែលធ្វើក្ដុងក្ដាំង; ដែលហៃធ្វើក្ដុងក្ដាំង (ឧ. un enfant tapageur) ។ *a. Fig.* ឆើតពេក (ឧ. luxe tapageur; toilette tapageuse)

tapageusement *adv.* ដោយអ៊ូអែ; ដោយក្ដុងក្ដាំង

tapant,e *a.* គត់ (ឧ. midi tapant)

tape *n.f.* ការទះ; ដុក ។ *Mar.* បន្ទះដែក ឬ ក្ដារបិទប្រហោង

tapé,e *a.* ដែលក្រៀបហើយឆ្អើរ (ឧ. poire tapée) ។ *Fam.* c'est bien tapé ល្អហើយ, សមហើយ

tape-à-l'œil *a. Fam.* ក្រឡែត(ដែលឲ្យឃើញច្បាស់)

tapée *n.f. Fam.* ចំនួនច្រើន,ហ្វូង (ឧ. une tapée d'enfants)

taper *v.t.* ទះ, វាយ, គោះ ។ *Fam.* ខ្ចីប្រាក់; វាយ(ម៉ាស៊ីនអង្គុលីលេខ) ។ *v.i.* taper du វាយឬគោះនឹង (ឧ. taper du pied) ។ *Fam.* taper dans l'œil ត្រូវភ្នែក, ស្រឡាញ់ (ពវ. batire, frapper)

tapette *n.f.* ប្រដាប់វាយ; ការវាយផ្ទប់នឹងជញ្ជាំង (កីឡាវាយកូនឃ្លី)។ *Fam.* សំដី (ឧ. avoir une fière tapette)

tapeur,euse *n.* អ្នកហៃខ្ចីប្រាក់

tapinois (en) *loc. adv.* ដោយលួចលាក់

tapin *n.m. Fam.* ក្មេងអ្នកវាយស្គរ

tapioca *n.m.* ម្សៅក្ដួចឬដំឡូងឈើ

tapir (se) *v.pr.* ក្រាបពួន

tapis *n.m.* កម្រាល, ព្រំ ។ *Par ext.* កម្រាល (អ្វីៗមានសណ្ឋានដូចកម្រាល) (ឧ. tapis de gazon) ។ *Fig.* tapis vert តុល្បែង; *par ext.* តុសន្និសីទ ។ amuser le tapis និយាយកំប្លែង។ être sur le tapis

ត្រូវគេយកមកពិភាក្សា ឬ យកមកពិនិត្យ ។ mettre une affaire sur le tapis ដាក់ស្នើឲ្យពិនិត្យរឿងមួយ

tapis-franc *n.m.* គៀមស្រាគគ្រក់ (ដែលមានភ្ញៀវល្អៈអាក្រក់)

tapisser *v.t.* ក្រាល; បិទលំអដោយគ្រឿងជាំក់ (ឧ. tapisser une chambre) ។ *Par ext.* គ្របដណ្ដប់

tapisserie *n.f.* គ្រឿងជាំក់, គ្រឿងកម្រាល, គ្រឿងព្រំ; កម្រាល ។ *Fig.* faire une tapisserie អង្គុយមើលគេរាំ

tapissier,ère *n.* អ្នកធ្វើ-លក់ ឬ ដាក់គ្រឿងតុបតែងគេហស្ថាន

tapon *n.m. Fam.* ដុំកសំពត់

taponner *v.t.* ធ្វើជាកងដុំកសំពត់ (ឧ. taponner les cheveux)

tapotage ឬ**tapotement** *n.m.* ការទះតិចៗ ឬ បន្លើ១ៗ

tapoter *v.t.* ទះតិចៗ, ទះបន្លើ១ៗ

taquer *v.t. Arts graph.* កលំអក្សរ

taquet *n.m.* កំណល់ ។ *Mar.* ឈើ ឬ ដែកសម្រាប់ចងនាវា ។ *Techn.* taquet d'arrêt កំណល់ទប់

taquin,e *a. & n.* ដែលចូលចិត្តជិន្ទជន្ទេញ; ដែលចូលចិត្តចំអន់

taquiner *v.t. & i.* ជិន្ទជន្ទេញ, ចំអន់

taquinerie *n.f.* ការជិន្ទជន្ទេញ, ការចំអន់

taquoir *n.m. Arts graph.* កំណល់អក្សរ

tarabiscot *n.m.* លំហូត (ក្បាច់លកចន្លោះក្បាច់ខ្សែ); ល្បាក (ដែកសម្រាប់ល្បូសលកលំហូត)

tarabiscoter *v.t.* ល្បាកលំហូត; លំអហួសពេក (ឧ. décoration tarabiscotée)

tarabuster *v.t. Fam.* រាំនមិនឈប់ឈរ

tarage *n.m.* ការដាក់សំបក

tarare *n.m.* ក្បាលបក់ (បក់សំអាតគ្រាប់ស្រូវ)

taratata ! *int. Fam.* យីអើ! (សូរលាន់មាត់សំដែងសេចក្ដីមើលងាយ, សេចក្ដីមិនជឿ, សេចក្ដីធុញ)

taraud *n.m.Mécan.*ដែកធ្វើស្ពីឡោស

taraudage *n.m.* ការធ្វើស្ពីឡោស

tarauder *v.t. Mécan.* ធ្វើស្ពីឡោស

taraudeuse *n.f.Mécan.* ម៉ាស៊ីនធ្វើស្ពីឡោស

tarbouch ឬ **tarbouche** *n.m.* ភាគីប ជនជាតិទួរគីនិងក្រិក

tard *adv.* យឺត (ឧ. la raison vient tard aux hommes); យូរ (ថ្ងៃខ្ពស់ ឬ យប់ជ្រៅ) (ឧ. se coucher tard ក្រោកពីគេង) ។ tôt ou tard មិនយូរប៉ុន្មានឆាប់, ក្នុងថ្ងៃណាមួយ ។

n.m. sur le tard យប់ជ្រៅ; *au fig.* ដល់ពេលចាស់ (ជិតស្លាប់) (ឧ. s'assagir sur le tard)

tarder *v.i.* មកយឺត (ក្រមកដល់) (ឧ. pourquoi avez-vous tant tardé ?) ។

v.t. ind. (à) ស្ទាក់ (ឧ. ne tardez pas à remplir un devoir) ។

v.imp. il me tarde de... ខ្ញុំចង់តែ...ឆាប់ ។

tardif,ive *a.* យឺត (ឧ. regret tardif); ក្រកើត, ក្រខ្ញុំដឹង (ឧ. esprit tardif); ទុំ, ក្រឡេងទុំ (ឧ.fruits tardifs)។ riz tardif ម.ព. riz

tardillon,onne *n. Fam.* កូនពៅ (កើតមកក្រោយគេយូរ)

tardivement *adv.* ដោយយឺត

tardiveté *n.f. Jard.* ភាពទុំ, ភាពក្រលូតលាស់

tare *n.f.* និស្សារ, ទម្ងន់សំបក ឬ កញ្ចប់ (ឧ. la tare ajoutée au poids net, fournit le poids brut)។ faire la tare ថ្លឹងវត្ថុមួយឲ្យស្មើទម្ងន់ ។ *Fig.* និស្សារ (គុណវិបត្តិ, វិកលកាយ ឬ ចរិត)

taré,e *a.* ខូច, សៅហ្មង

tarente *n.f.* តុកកែ (ម.ព. gecko ផង)

tarentelle *n.f.* តារ៉ង់តែល (របាំម្យ៉ាងនៅប្រទេសអ៊ីតាលី)

tarer *v.t.* កាត់សំបក

targe *n.f.* ខែលតូចមួយបែបប្រើក្នុងយុគកណ្ដាល

targette *n.f.* កូនរនុកទ្វារ ឬ បង្អួច

targuer(se) *v.pr.* អួតខ្លួន (ឧ. se targuer de ses richesses)

taricheute [-keut'] *n.m.* (ព.ក្រិក) អ្នកធ្វើសាកសពឲ្យទុកបានយូរ

tarière *n.f. Techn.* ដែកខួង ។ *Hist. nat.* ទ្រនិច (សម្រាប់សត្វល្អិតញីខួងដី ឬ ឈើ កប់ពង) (មើ. oviscapte)

tarif *n.m.* តារាងតម្លៃ; តម្លៃ ។ tarif autonome តារាងតម្លៃស្វយ័ត ។

tarif conventionnel តារាងតម្លៃអនុសញ្ញា ។ double tarif តារាងតម្លៃទ្វេ

tarifaire *a.* នៃតារាងតម្លៃ

tarifer *v.t.* កម្រិតតម្លៃ; ធ្វើតារាងតម្លៃ

tarification *n.f.* ការកម្រិតតម្លៃ; ការធ្វើតារាងតម្លៃ

tarir *v.t.* ពង្រីង (ឧ. la sécheresse tarit les puits) ។ *Fig.* បំបាត់ (ឧ. tarir les larmes) ។ *v.i.* រីង (ឧ. la source a tari tout à coup) ។ *Fig.* ឈប់, បាត់ (ឧ. ses pleurs ne tarissent pas) ។ ne pas tarir sur និយាយមិនអស់មិនហើយពី (ឧ. ne pas tarir d'éloges sur quelqu'un សរសើរអ្នកណាម្នាក់មិនអស់មិនហើយ)

tarissable *a.* អាចរីង ឬ ឈប់បាន

tarissement *n.m.* ដំណើររីង, ដំណើរស្ងួត

tarlatane *n.f.* (ព.ហ៊ិណ្ឌូ) សំពត់អំបោះទន់ស្តើង

tarmacadam *n.m.* ថ្នល់ចាក់កៅស៊ូ

taro *n.m.* ត្រាវ

tarpan *n.m.* សេះព្រៃម្យ៉ាង(ដែលពីដើមជាពូជសេះស្រុក)

tarse *n.m.* កជើង; ឆ្អឹងជើង (ជាណាក-សព្ទ)

tarsectomie *n.f.* ការកាត់ឆ្អឹងកជើង

tarsien,enne *a.* នៃកជើង (ឧ. os tarsiens)

tartan *n.m.* (ព.អ.) សំពត់ឧណ្ណាម៉យក្រឡា

tartane *n.f.* នាវានេសាទម្យ៉ាង

tartarinage *n.f.* *Fam.* អំនួត

tartine *n.f.* ចំណិតនំប៉័ងដាក់ប៊ឺរ ។ *Fig. & Fam.* អត្ថបទវែង

tartiner *v.t.* ដាក់ប៊ឺរលើចំណិតនំប៉័ង

tartre *n.m.* ក្អាំង; ក្រមរជើងធ្មេញ

tartreux,euse *a.* ជាជាតិក្អាំងឬក្រមរ

tartufe *n.m.* មនុស្សលាក់ពុត

tatuferie *n.f.* ការលាក់ពុត

tas *n.m.* គំនរ,ពំនូក,ដង់;ហ្វូង(មនុស្ស)។ apprentissage sur le tas ការរៀនធ្វើការក្នុងរោងជាង ។ grève sur le tas ម.ព. grève ។ *Fig. & Fam.* un tas de មួយគំនរ, ច្រើន (ឧ. un tas de mensonges, de fripons)

tasse *n.f.* ពែង; បំណុះពែង (ឧ. une tasse de thé)

tassement *n.m.* ភាពហាប់, ភាពស្រុត

tasser *v.t.* គរ,ពូន;បង្ហាប់ (ឧ. tasser de la paille); ញាត់ ។

v.i. Jard. បែកគុម្ព, ដុះឡើងក្រាស់ (ឧ. le riz commence à tasser) ។

se tasser *v.pr.* ឡើងហាប់, ស្រុញ, ស្រុត (ឧ. le mur se tasse) ។ *Fig. & Fam.* ស្រាក, ធូរថយ (ប្រើចំពោះតែវត្ថុ)

tassette *n.f.* ក្រោះភ្លៅ

tassili *n.m.* ភ្នំ (ក្នុងភាសាខ្សាច់សាហារ៉ា) (ឧ. le tassili des Adjers)

tâter *v.t.* ស្ទាប (ឧ. tater une étoffe) ។ tâter le pouls ចាប់ជីពចរ ។ *Fig. Fam.* tâter le terrain ស្ទង់ស្ថានការណ៍ ឬ ចិត្តមុន (ឧ. tâter quelqu'un) ។ *v.t. ind.* (de ឬ à) ស្ទង់ចិត្ត, ភ្លក់, ល, ល្បង (ឧ.tâter d'un métier) ។

se tâter *v.pr.* ស្ទង់ចិត្តខ្លួន; សាញ, រួញរា

tâte-vin *n.m.inv.* បំពង់បឺតស្រា(ដើម្បីភ្លក់); ពែងភ្លក់ស្រា

tatillon,onne *a.&n. Fam.* អ្នកប្រិតប្រៀបសព្វបើការកំប៉ិកកំប៉ុក

tatillonner *v.i. Fam.* ប្រិតប្រៀបសព្វបើការកំប៉ិកកំប៉ុក

tâtonnement *n.m.* ការស្ទាប ។ *Fig.* ការរាវរក

tâtonner *v.i.* ស្ទាប (ឧ. on tâtonne dans l'obscurité) *Fig.* រាវ (ឧ. savant qui tâtonne dans ses recherches)

tâtons (à) *loc. adv.* ដោយស្ទាបៗ (ក្នុងទីងងឹត) ។ *Fig.* ដោយស្មាន; ដោយរាវ; ឥតរបៀប

tatouage *n.m.* ការសាក់; សាក់

tatouer *v.t.* សាក់

tatoueur *a.&n.m.* អ្នកសាក់

taud *n.m.* ឬ **taude** *n.f.* រនាំងតំបូលទូក (សម្រាប់គ្របទូកកាលណាភ្លៀង)

taudis *n.m.* លំនៅគោកយ៉ាក, លំនៅស្មោកគ្រោក

taupe *n.f.* កំពីងដូង (សត្វ) ។ noir comme une taupe ខ្មៅងងឹត, ខ្មៅណាស់ ។ *Fam.* aller au royaume des taupes ស្លាប់ ។ *Arg.scol.* ថ្នាក់រៀនប្រឡងចូលសាលាពហុបច្ចេកទេស ។

Prov. lynx envers les au-

tres et taupe envers soi-même ទោសខ្លួនឯងមើលមិនយល់ ទោសគេតូចសោតសល់ មើលយល់ប៉ុនទាំងភ្នំ

taupé,e *a.* ខ្លីកោមក៏ពីងខ្លុង (ឧ. feutre taupé)

taupe-grillon *n.m.* ខ្ទុល(ព.សាមញ្ញ) (*pl.* des taupes-grillons)

taupier *n.m.* អ្នកចាប់កំពឹះខ្លុង

taupière *n.f.* អន្ទាក់ ឬ អន្លប់កំពឹងខ្លុង

taupin *n.m.* អ្នកទម្លុះនិញ្ជាំងក៏ពែងក្រុងដែលឡោមព័ទ្ធ

taupin *n.m.* *Arg. scol.* បេក្ខជនប្រឡងចូលសាលាពហុបច្ចេកទេស

taupinière ឬ **taupinée** *n.f.* ពំនូកដីដែលសត្វកំពឹងខ្លុងកាយ ; សំណង់បន្ទាប់បន្សំ

taure *n.f.* គោញី (មិនទាន់ដែលមានកូន)

taureau *n.m.* ឧសភៈ, ព្រឹសភៈ, គោឈ្មោល (cri: le taureau mugit)។ *Fig.* មនុស្សខ្លាំង ។ de taureau ធំណាស់, ខ្លាំងណាស់។ *Astr.* ឧសភៈរាសី ឬ ព្រឹសភរាសី

taurides *n.f.pl.* ទេពផ្កាយដែលហាក់ដូចជាធ្លាក់មកពីឧសភតារា

taurillon *n.m.* គោឈ្មោលជំទង់

taurin,e *a.* នៃគោឈ្មោល

tauromachie *n.f.* ការប្រយុទ្ធនឹងគោឈ្មោល; ការប្រណាំងគោឈ្មោល

tautologie *n.f.* ការប្រើពាក្យស្ទួន (ឧ. « au jour d'aujourd'hui » est une tautologie) (ម.*f.* pléonasme)

tautologique *a.* នៃការប្រើពាក្យស្ទួន

taux *n.m.* អត្រា; កម្រិតការប្រាក់១០០ក្នុងមួយឆ្នាំ(ឧ. prêter au taux de 5%)។ *Par ext.* កម្រិតភាគរយ (ឧ. taux d'invalidité); កម្រិតប្រាក់ឈ្នួល; កម្រិតពន្ធ

taveler *v.t.* ប្រឡាក់ជាំៗ, ពពាលចុះៗ

tavelure *n.f.* ភាពពពាលចុះៗ

taverne *n.f.* *Autref.* ភៀងស្រា,ស្ថានការ ឬស្ថានក្រឹះ។ *Auj.* ភោជនីយដ្ឋាន

tavernier,ère *n.* អ្នកកាន់កាប់ភោជនីយដ្ឋាន

taxateur *n.&a.m.* អ្នកកម្រិតតម្លៃ; អ្នកដាក់អាករ (ឧ. juge taxateur)

taxatif,ive *a.* អាចជាប់អាករ

taxation *n.f.* ការកម្រិតអាករ ; ការដាក់អាករ

taxe *n.f.* តម្លៃកម្រិត ។ *Par ext.* អាករ(ឧ.taxe proportionnelle

sur les revenus)។ taxe additionnelle អាករបន្ថែម ។ taxe de circulation អាករចរាចរណ៍ ។ taxe de consommation អាករលើបរិភោគ ។ taxe de débarquement អាកររំលៀង ។ taxe indirecte អាករមិនចំពោះ ។ taxe journalière ទិវាករ ។ taxe sur les chiffres d'affaires អាករលើផលរបរ។ taxe de séjour អាករស្នាក់អាស្រ័យ

taxer *v.t.* កម្រិតតម្លៃ, តាំងអាករ (ឧ. taxer les produits de luxe)។ *Fig.* ចោទថា (ឧ. taxer quelqu'un d'avarice)

taxi *n.m.* (ព. បំព្រួញនៃ taxi auto) តាក់ស៊ី, រថយន្តឈ្នួល

taxidermie *n.f.* សិល្បៈខាងញាត់គរសត្វមានឆ្អឹង

taximètre *n.m.* តាក់ស៊ីមាត្រ (ប្រដាប់បង្អុលរយៈផ្លូវ ឬ តម្លៃរថយន្តឈ្នួល)

taxiphone *n.f.* តាក់ស៊ីទូរស័ព្ទ (បន្ទប់ទូរសព្ទឈ្នួល

aylorisation *n.f.* របៀបធ្វើការតាមលោកតៃល័រ

ayloriser *v.t.* ធ្វើការតាមលោកតៃល័រ

taylorisme *n.m.* តៃល័រនិយម (ការធ្វើការ ឲ្យបានចម្រើនតាមរបៀបតៃល័រ)

tcharchaf *n.m.* ស្បៃរុំមុខ (របស់ស្រីជាតិទួរគី)

tchécoslovaque *a.* & *n.* នៃប្រទេសឆេកូស្លូវ៉ាគី

tchèque *n.m.* ភាសាឆែក(នៃប្រទេសឆេកូស្លូវ៉ាគី)

tchernoziom *n.m.* (ព. រុស្ស៊ី) ដីខ្មៅនៅប្រទេសរុស្ស៊ីខាងត្បូងនិងនៅស៊ីបេរី

tchervonetz *n.m.* ប្រភេទរូបិយវត្ថុនៅប្រទេសរុស្ស៊ី (*pl.* tchervontsi)

te *pr. pos.* ឯង (ម.ព. tu)

tea-room [ti-roum] *n.m.* (ព.អ.) សាលតែ

technicien *n.m.* អ្នកបច្ចេកទេស

technicité *n.f.* បច្ចេកទេសភាព

technique *a.* បច្ចេកទេស (ឧ. collège technique អនុវិទ្យាល័យបច្ចេកទេស) ។ *n.f.* បច្ចេកទេសវិជ្ជា

techniquement *adv.* តាមបច្ចេកទេស (ឧ. définir techniquement)

technocrate *n.* អ្នកបច្ចេកាធិបតេយ្យ

technocratie *n.f.* បច្ចេកាធិបតេយ្យ

(លទ្ធិគ្រប់គ្រងដែលផ្អែកលើអ្នកបច្ចេកទេស)

technologie *n.f.* បច្ចេកវិជ្ជា; សរុបពាក្យបច្ចេកទេស ។ technologie agricole បច្ចេកវិជ្ជាកសិកម្ម ។ technologie forestière បច្ចេកវិជ្ជារុក្ខា ។ technologie industrielle បច្ចេកវិជ្ជាឧស្សាហកម្ម ។ technologie de pêche បច្ចេកវិជ្ជានេសាទ

technologique *a.* នៃបច្ចេកវិជ្ជា; នៃពាក្យបច្ចេកទេស (ឧ. dictionnaire technologique)

teck ឬ **tek** *n.m.* ម៉ៃសាក់

teckel *n.m.* ឆ្កែតឿ, ឆ្កែម្យ៉ាងខ្លួនវែងតាបជើងខ្លីនិងកោងខ្លីៗ

tectonique *n.f.* រចិតវិវត្តន៍ [រៈ. ចិតៈ-វិ-វ័ត]

tectrice *a.* & *n.f.* រោមស្លាបប្រវែងមធ្យមនៃបក្សី

tégénaire *n.f.* ពីងពាងផ្ទះ (ពីងពាងក្នុងគេហដ្ឋាន)

tégument *n.m.* *Anat.* អាការៈដែលគ្របដណ្ដប់ខ្លួនមនុស្សនិងសត្វ (ស្បែក, រោម, ស្លាប, ស្រកា) ។ *Bot.* លលាដ៍គ្រាប់ផ្លែ

tégumentaire *a.* នៃអាការៈដែលគ្របដណ្ដប់ខ្លួនមនុស្ស-សត្វ (ឧ. lésion tégumentaire)

teigne *n.f.* មេអំបៅម្យ៉ាង; អង្គែ ។ *Fig. & Fam.* មនុស្សកំណាច

teigneux,euse *a.&n.* ដែលកើតអង្គែ

teillage ឬ **tillage** *n.m.* ការកិនយកសរសៃក្រចៅ

teille ឬ **tille** *n.f.* សំបកក្រចៅ

teiller ឬ **tiller** *v.t. Ind.* កិនយកសរសៃក្រចៅ

teilleur,euse *n.* អ្នកកិនយកសរសៃក្រចៅ ។ *n.f.* ម៉ាស៊ីនកិនយកសរសៃក្រចៅ

teindre *v.t.* ជ្រលក់ពណ៌ (ឧ.teindre des étoffes); ឲ្យជាប់ពណ៌ ។ teindre sa main ឬ son bras du (ឬ dans le) sang de quelqu'un សម្លាប់ ឬ ធ្វើឲ្យមានរបួសដល់អ្នកណាម្នាក់

teint *n.m.* ឆវី, សម្បុរមុខ (ឧ. teint bronzé) ; ពណ៌ (ពណ៌ដែលគេជ្រលក់) (ឧ. teint solide)។ bon teint ពណ៌ជាប់ (មិនហើរ, មិនសាក)

teint,e *a.* ដែលជ្រលក់ពណ៌ (ឧ. étoffe teinte)

teinte *n.f.* ពណ៌ (ឧ. teinte grise)។ demi-teinte ពណ៌ភារី ។ teinte plate ពណ៌លាប (ពណ៌តែមួយ) ។ *Fig.* ភាពស្រាល, បន្តិចបន្តួច (ឧ. teinte d'ironie) (មើ. carnation, coloration, coloris, couleur)

teinté,e *a.* ដែលលាបពណ៌ស្តើង (ឧ. verres teintés)

teinter *v.t.* ជ្រលក់ពណ៌ ។ *Par ext.* លាប ឬ ជ្រលក់ពណ៌ស្តើង (ឧ. teinter de l'eau avec du vin)

teinture *n.f.* ថ្នាំជ្រលក់, ថ្នាំលាប; ការជ្រលក់ឬលាបពណ៌; ពណ៌ (នៃវត្ថុដែលជ្រលក់ ឬ លាប) (ឧ. drap d'une belle teinture) ។ *Fig.* វិជ្ជាបន្តិចបន្តួច (ឧ. avoir une teinture de latin)

teinturerie *n.f.* រោងជ្រលក់ពណ៌; សិល្បៈខាងជ្រលក់ពណ៌

teinturier,ère *n.* ជាងជ្រលក់ពណ៌

tel,telle *a.* ប្រហែលនេះ, បែបនេះ (ឧ. on ne verra plus de tels hommes); នេះ (ឧ. tel est mon avis); ខ្លះ (ឧ. telle page était griffonnée, telle autre était tachée d'encre); ដូច្នេះ ។ tel... tel យ៉ាងណា... យ៉ាងនោះ ដែរ (ឧ. tel père, tel fils) ។ tel que ដូចម្តេច... ដូច្នោះ (ឧ. voir les hommes tel qu'ils sont); ដ៏ណាស់ទៅទាល់តែ (ឧ. son pouvoir est tel que tout lui obéit) ។ tel quel ដូចដើម, ដដែល (ឧ. je vous rends votre livre tel quel) ។

Pr. ind. អ្នកណា (ឧ. tel rit aujourd'hui qui pleurera demain) ។ *Pr. & a.* នេះ (ឧ. tel fut le résultat de ses efforts) ។ à telle enseigne que ឬ à telles enseignes que *loc. conj.* ម.ព. enseigne

télamon *n.m. Archit.* តៃកា (មើ. atlante)

télautographe *n.m.* ទូរលិខនភ.ម្ភ, ប្រដាប់បញ្ជូនអក្សរនិងគំនូរទៅឆ្ងាយ

télécinématographe *n.m.* ទូរភាពយន្ត, ប្រដាប់បញ្ជូនភាពទូរទស្សន៍ទូរលេខភាពយន្ត (ជា télécinéma ក៏បាន)

télécommande *n.f.* ទូរបញ្ជា (ប្រដាប់បញ្ជាពីចម្ងាយ)

télécommander *v.t.* ទូរបញ្ជា

télécommunication *n.f.* ទូរគមនាគមន៍

télédynamie *n.f.* ទូថាមពលកម្ម, ការបញ្ជូនកម្លាំងអគ្គិសនីទៅឆ្ងាយ

télédynamique *a.* នៃទូរថាមពលកម្ម, ដែលបញ្ជូនកម្លាំងអគ្គិសនីទៅឆ្ងាយ (ឧ. câble télédynamique)

téléférique *a.* & *n.m.* ម.ព. téléphérique

télégramme *n.m.* ទូរលេខ

télégraphe *n.m.* ទូរលេខ ។ télégraphe direct ទូរលេខរំហូត។ télégraphe omnibus ទូរលេខបន្ត

télégraphie *n.m.* ទូរលេខសាស្ត្រ ។ télégraphie sans fil (T.S.F.) វិទ្យុទូរលេខសាស្ត្រ

télégraphier *v.i.* វាយទូរលេខ ។ *v.t.* ផ្ញើទូរលេខ

télégraphique *a.* នៃទូរលេខសាស្ត្រ (ឧ. signes télégraphiques) ។ dépêche télégraphique សារទូរលេខ

télégraphiquement *adv.* ដោយទូរលេខសាស្ត្រ (ឧ. appeler télégraphiquement)

télégraphiste *n.m.* ទូរលេខិកៈ [-លេ-ខិ-កៈ], អ្នកទូរលេខ

téléguidage *n.m.* ទូរណាត្ត, ការបើកបរពីចម្ងាយ

téléguider *v.t.* ទូរណាត្ត, បើកបរពីចម្ងាយ (ឧ. téléguider une fusée)

téléimprimeur *n.m.* ទូរពុម្ពភណ្ឌ, ប្រដាប់បោះពុម្ពពីចម្ងាយ (*pl.* des téléimprimeurs)

télémécanicien *n.m.* អ្នកបច្ចេកទេសខាងទូរគមនាគមន៍

télémécanique *n.f.* សិប្ប.ខាងទូរបញ្ជា

télémesure *n.f.* ទូរប្រមាណ

télémètre *n.m.* ទូរមាត្រ (ប្រដាប់វាស់ពីចម្ងាយ)

télémétreur *n.m.* អ្នកបច្ចេកទេសខាងទូរមាត្រ

téléobjectif *n.m.* កែវថតពីចម្ងាយ

télépathe *a.*&*n.* អ្នកទូរវេទន៍ ឬ ទូរចិត្ត; រូបអារក្ស

télépathie *n.f.* ទូរវេទន៍, ទូរចិត្ត

télépathique *a.* នៃទូរវេទន៍ ឬ ទូរចិត្ត

téléphérage *n.m.* ទូរយាន; ការដឹកនាំ

តាមទូរយាន

téléphérique *n.m.* ទូរយានិក ។ *a.* នៃទូរយាន

téléphone *n.m.* គ្រឿងទូរសព្ទ ។ *Fam.* coup de téléphone ការនិយាយទូរសព្ទ

téléphoner *v.i.* និយាយទូរសព្ទ។ *v.t.* និយាយទូរសព្ទប្រាប់

téléphonie *n.f.* ទូរសព្ទ

téléphonique *a.* នៃទូរសព្ទ (ឧ. appel téléphonique)

téléphoniquement *adv.* តាមទូរ-សព្ទ

téléphoniste *n.* ទូរសព្ទិក, អ្នកទូរសព្ទ

téléphotographie *n.f.* ទូរឆាយាកម្ម (ការបញ្ជូនរូបថតទៅឆ្ងាយ)

téléradiocommunication *n.f.* ទូរវិទ្យុគមនាគមន៍

téléradiographie *n.f.* ទូរវិទ្យុឆាយា-កម្ម, ការឆ្លុះរស្មីអ៊ិចពីចម្ងាយ

télescopage *n.m.* ដំណើរទង្គិចគ្នា(នៃអយស្ម័យយានពីរ); ដំណើរទង្គិចគ្នា

télescope *n.m.* *Astr.* កែវយឺត (សម្រាប់សង្កេតតារា)

télescoper *v.t.* បុក, ទង្គិច (ឧ. train qui en télescope un autre)។

se télescoper *v.pr.* ទង្គិចមូរនប (ទង្គិចខ្លាំងដល់ប្រមូលចូលផ្ទាប់គ្នា)

télescopique *a.* ដែលប្រើកែវយឺត (ឧ. observations télescopiques); ដែលអាចមើលឃើញតែដោយកែវយឺត (ឧ. planète télescopique); ដែលប្រមាក់ចូលគ្នា (ឧ. pied télescopique)

téléscripteur *n.m.* ម៉ាស៊ីនទូរចារិក

télespectateur,trice *n.* ទូរទស្សនិក, អ្នកមើលទូរទស្សន៍

télévisé,e *a.* ដែលផ្សាយតាមទូរទស្សន៍ (ឧ. journal télévisé)

téléviser *v.t.* ផ្សាយតាមទូរទស្សន៍

téléviseur *n.&a.m.* ប្រដាប់ទទួលទូរទស្សន៍

télévision *n.f.* ទូរទស្សន៍

tellement *adv.* យ៉ាងណា ។ tellement que ទាល់តែ

tellurique ឬ **tellurien,enne** *a.* នៃដី (ឧ. courant tellurique)

tellurisme *n.m.* ឥទ្ធិពលដីលើមនុស្ស (លើអាកាស, ចរិត ។ល។)

téméraire *a.* ព្រហើន, ក្លាហានហួសប្រមាណ (ឧ. homme témé-

raire) ។ jugement téméraire ការវិនិច្ឆ័យដោយគ្មានភស្តុតាងគ្រប់គ្រាន់

témérairement *adv.* ដោយព្រហើន, ដោយក្លាហានហួសប្រមាណ

témérité *n.f.* ភាពព្រហើន,ភាពក្លាហានហួសប្រមាណ; អំពើព្រហើន

témoignage *n.m.* សក្ខីកម្ម, ការធ្វើជាសាក្សី (ឧ. être appelé en témoignage); ចម្លើយសាក្សី (ឧ. recueillir des témoignages)។

Fig. សក្ខីភាព ; សក្ខីសញ្ញា, សញ្ញាខាងក្រៅ; ភស្តុតាង (ឧ. témoignage d'amitié សក្ខីភាពនៃមិត្តភាព) ។

Loc. div. faux témoignage ចម្លើយកុហករបស់សាក្សី ។ ne s'en rapporter qu'au témoignage de ses yeux ជឿតែភ្នែកឯង, ជឿតែអ្វីដែលខ្លួនបានឃើញដោយភ្នែក។ rendre témoignage de ឆ្លើយអំពី (ចំពោះសាក្សី) (ឧ. le témoin ne doit rendre témoignage que de ce qu'il sait sûrement) ។ rendre témoignage à quelque chose ទទួលស្គាល់ និងទទួលគោរពរបស់អ្វីមួយ ។ rendre témoignage à quelqu'un ធ្វើជាកសិណឲ្យអ្នកណាម្នាក់ ។ porter témoignage ម.ព. porter ។ témoignage de satisfaction សក្ខីភាពនៃសោមនស្ស

témoigner *v.t.* បង្ហាញ ឬ បញ្ចេញឲ្យឃើញ (ឧ. témoigner de la joie) ។

v.i. ធ្វើជាកសិណ (ឧ. témoigner contre quelqu'un en justice)

témoin *n.m.* កសិណ, សាក្សី, បន្ទាល់ (ឧ. les témoins prêtent le serment de dire la vérité); អ្នកបានឃើញ-បានដឹង ឬ បានឮ (ឧ. être témoin d'un accident); ភស្តុតាង (ឧ. ce temple est un témoin de la piété de nos aïeux) ។

Loc. div. témoin auriculaire សាក្សីដែលបានឮដោយត្រចៀកឯង ។ témoin oculaire សាក្សីដែលបានឃើញដោយភ្នែកឯង ។ témoin à charge កសិណខាង

ទោទក៌ ។ témoin à décharge កសិណខាងចម្លើយ ។ prendre quelqu'un à témoin យកអ្នកណាម្នាក់ជាកសិណ

tempe *n.f.* សៀតផ្កា

tempérament *n.m.* អធ្យាស្រ័យ, ចរិត ។ vente à tempérament លក់កាត់យកថ្លៃបន្តិចម្តងៗ

tempérance *n.f.* មត្តញ្ញុតា, ការបេះប្រមាណ; ការបេះប្រមាណក្នុងបរិភោគ ។ société de tempérance សមាគមខាងមត្តញ្ញុតា(សមាគមប្រឆាំងនឹងការសេពសុរា)

tempérant,e *a.&n.* មត្តញ្ញូ, អ្នកបេះប្រមាណ

température *n.f.* សីតុណ្ហភាព; ចំហាយក្តៅ ។ avoir la température គ្រុន (ក្តៅខ្លួន)

tempéré,e *a.* បមាណយុត្ត (មិនក្តៅពេក មិនត្រជាក់ពេក) (ឧ. climat tempéré)

tempérément *adv.* ដោយបមាណយុត្ត; ដោយបន្ធូរ

tempérer *v.t.* បន្ធូរ, បង្អន់ (ឧ. tempérer la sévérité)

tempête *n.f.* ព្យុះ ។ *Fig.* ព្យុះសង្ឃរា (ការផ្ទុះចេញខ្លាំងនៃកំហឹង; ការរំជួលចិត្ត; ការឈ្លោះប្រកែកខ្លាំង; ការជ្រួលច្របល់ក្នុងប្រទេស)

tempêter *v.i.* ស្រែកឡូឡា (ដោយកំហឹង); ឈ្លោះ (ឧ. il ne fait que crier et tempêter)

tempétueusement *adv.* ដោយខ្លាំង; ជាព្យុះ

tempétueux,euse *a.* ដែលបង្កើតព្យុះ (ឧ. vent tempétueux); ដែលមានព្យុះច្រើន (ឧ. mer tempétueuse)

temple *n.m.* វិហារ

temporaire *a.* កាលិក, មិនឋិតថេរ; បណ្ដោះអាសន្ន (ឧ. pouvoir temporaire) (ព.ផ. constant, durable, permanent)

temporairement *adv.* ជាកាលិក, ជាបណ្ដោះអាសន្ន (ឧ. s'éloigner temporairement d'un lieu)

temporal,e,aux *a.* នៃសៀតផ្កា (ឧ. os temporal) ។ *n.m. pl.* temporaux ឆ្អឹងសៀតផ្កា

temporalité *n.f. Phil.* លោកិយភាព

temporel,elle *a.* លោកិយ (ផ.ពឹង

éternel) (ឧ. l'existence temporelle de l'homme) ; ខាងអាណាចក្រ (ព. ផ. spirituel) ។ pouvoir temporel ម.ព. pouvoir ។

n.m. អាណាចក្រ (ឧ. le temporel et le spirituel)

temporellement *adv.* ក្នុងមួយពេល; ក្នុងអាណាចក្រ

temporisateur, trice *a.&n.* ដែលពន្យារពេល, ដែលផ្អាក (ឧ. général temporisateur)

temporisation *n.f.* ការពន្យារពេល, ការផ្អាក (ចាំឱកាសល្អ)

temporiser *v.i.* ពន្យារពេល, ផ្អាក (ចាំឱកាសល្អ) (ស៊ី. ajourner, atermoyer, lanterner, remettre, renvoyer, retarder, surseoir)

temps *n.m.* កាល, ពេល, វេលា (ឧ. bien employer son temps); ឱកាស (ឧ. c'était le bon temps); រដូវ, សម័យ (ឧ. le temps des vendanges); អាកាស (ឧ. temps humide); មេឃ (ឧ. il fait beau temps) ។

Loc. div. un temps ពេលខ្លី (ឧ. la jeunesse n'a qu'un temps) ។ au temps jadis ឬ dans le temps កាលពីដើម ។ temps historiques ម.ព. historique) ។ le bon vieux temps សម័យដូនតាយើង, សម័យសប្បាយ ។ en son temps នៅកាលគួរ, នៅឱកាសល្អ (ឧ. faites chaque chose en son temps) ។ en temps ordinaire ក្នុងកាលធម្មតា ។ dans le cours ឬ dans la suite des temps តទៅខាងមុខ, ទៅអនាគត ។ par le temps qui court ក្នុងឥឡូវនេះ, ក្នុងបច្ចុប្បន្នកាល ។ jeune temps កាលនៅក្មេង ។ temps d'arrêt ពេលឈប់, ពេលមានរអាក់រអួល (ឧ. affaire qui subit un temps d'arrêt) ។ temps dur ម.ព. dur ។ gros temps ពេលព្យុះ (ក្នុងសមុទ្រ) ។ laps de temps រយៈពេល ។ temps haut ពពកខ្ពស់ ; *au fig.* être haut comme le temps ធ្ងើងណាស់ ។ couleur du temps ពណ៌ខៀវ

(ក្នុងកាព្យឃ្លោង); *au fig.* កាលៈ-ទេសៈ (ឧ. consulter pour agir, la couleur du temps មើលកាលៈទេសៈមុននឹងធ្វើអ្វីមួយ)។ signe du temps ឬ des temps សញ្ញានៃព្រឹត្តិការណ៍ធំៗ ; សញ្ញានៃកាល (លក្ខណៈនៃទំនៀមទម្លាប់ ក្នុងសម័យនោះ) ។ berceau ឬ source des temps ដើមកំណើតនៃពិភពលោក ។ dans la nuit des temps យូរយារណាស់មកហើយ ។ être de son temps ប្រូលស្ទឹងតាមបត់ ប្រូលស្រុកតាមប្រទេស ប្រូលទូកតាមកំពង់។ tuer ឬ passer le temps កែអផ្សុក, បំភ្លេចពេល ។ perdre son temps គ្មានធ្វើអ្វី; ធ្វើការឥតប្រយោជន៍ ។ perdre du temps ឬ perdre le temps ខាតពេល (គ្មានបានការអ្វី) ។ il n'y a pas de temps à perdre មិនត្រូវបាត់ទេ, ត្រូវធ្វើយ៉ាងប្រញាប់ ។ sans perdre de temps ដោយឥតយឺតយ៉ាវ, ភ្លាមៗ។ temps perdu ពេលដែលខាត (ឧ. c'est temps perdu de prêcher un joueur) ។ réparer ឬ rattraper le temps perdu ខំប្រឹងដើម្បីសងពេលដែលខាត ។ gagner du temps ពន្យារពេល (ដើម្បីឲ្យមានឱកាសល្អ) ។ avoir le temps មានពេល (មិនប្រញាប់) ។ prendre du temps ម.ព. prendre ។ prendre son temps ធ្វើដោយមិនប្រញាប់ (ម.ព. prendre ផង) ។ prendre bien son temps ធ្វើត្រូវពេល ។ prendre mal son temps ធ្វើខុសពេល ។ prendre le temps comme il vient ត្រូវអនុលោមតាមទេសៈកាលៈ។ se donner du bon temps លេងសប្បាយ; រស់នៅដោយសប្បាយ ។ profiter du temps ឆ្លៀតឱកាស ។ avoir fait son temps ចប់មុខការ; អស់ទោស (ឧ. condamné qui a fait son temps) ; បានសប្បាយគ្រប់គ្រាន់ហើយ; ហួសសម័យ (ឧ. la force a fait son temps); ហួសសម័យ, ប្រើការលែងកើត (ឧ. habit qui a fait son temps) ។ il est temps de ដល់ពេល...ហើយ (ឧ. il est temps de partir)។ il est temps que ពិត្យូវនេះត្រូវតែ (ឧ.

il est temps que vous pensiez à vos affaires) ។ il est temps ឬ il est grand temps ល្មមពេលហើយ (តែចាប់គិតទៀតយូរពេលហើយ)។ un temps viendra où គង់តែនឹងដល់ពេលមួយដែល ។ le temps passe កាលរេះតែកន្លងទៅ ឬ ទើបទៅ (យើងត្រូវតែប្រញាប់) ។

Loc. adv. à temps ទាន់ឬត្រូវពេល (ឧ. arriver à temps); ដោយមានពេលកំណត់ (ឧ. travaux forcés à temps)។ en tout temps ឬ de tout temps ជានិច្ច (ឧ. on maintient certains abus parce qu'ils ont existé de tout temps)។ en même temps ឬ au même temps ឬ tout d'un temps ជាមួយគ្នា, ព្រមគ្នា ។ de temps en temps ឬ de temps à autre ម្ដងកាល, យូរៗម្ដង ។ en temps et lieu នៅពេលនិងទីដ៏គួរ ។ avant le temps មុនពេល, ឆាប់ពេក ។ la plupart du temps ឬ les trois quarts du temps ច្រើនតែ ។ avec le temps យូរទៅ ។ depuis le temps តាំងពីពេលនោះមក (ឧ. depuis le temps il s'est passé bien des choses)។ entre temps ក្នុងចន្លោះពេល ។

Loc. conj. dans le temps que ឬ dans le temps où នៅពេលដែល ។ en même temps que នៅពេលជាមួយគ្នានឹង។

emploi du temps ម.ព. emploi ។

Mus. ចង្វាក់ (ភ្លេង)។ temps faible ចង្វាក់ខ្សោយ។ temps fort ចង្វាក់ខ្លាំង ។

Prov. autre temps, autres mœurs ទំនៀមទម្លាប់ផ្លាស់ប្ដូរតាមកាល ។ le temps dévore tout យូរទៅរបស់ទាំងឡាយតែងវិនាស។ le temps est un grand maître ពេលជាគ្រូធំ (អ្នកធ្លាប់ធ្វើការយូរមកហើយ រមែងមានពិសោធន៍ច្រើន)។ le temps perdu ne revient point ឬ ne se rattrape pas ពេលកន្លងទៅហើយមិនដែលត្រឡប់មកវិញទេ។ le temps,

c'est l'argent(សុភាសិតអង់គ្លេស) ពេលជាប្រាក់(ពេលមានតម្លៃណាស់)។ il viendra un temps où les chiens auront besoin de leur queue ទ្រព្យសំរប់គង់មានប្រយោជន៍ក្នុងថ្ងៃណាមួយ។ qui a temps (ឬ terme) ne doit rien ម.ព. devoir ។ qui a temps a vie ឲ្យតែមានពេលគ្រប់គ្រាន់គេនឹងអាចដោះខ្លួនរួច ។ il y a temps pour tout របស់នីមួយៗ ត្រូវធ្វើតាមពេលរបស់វា ។ tout vient à temps pour qui sait attendre ម.ព at-tendre ។ après bon temps, on se repent ការសប្បាយនាំឲ្យស្ដាយក្រោយ

tenable *a.* អាចនៅតទៅទៀតបាន (ឧ. la place n'étant pas tenable pour un jaloux, il sortit furieux (Montesquieu); អាចការពារបាន (ច្រើនប្រើតែក្នុងពាក្យបដិសេធ) (ឧ. le poste n'est pas tenable)

tenace *a.* ស្អិត(ឧ. la poix est tenace): ស្វិត, ជាប់ (ឧ. métal tenace) ។ *Fig.* មានះ, ស្វិតស្វាញ (ដែលប្រកាន់គំនិតខ្លួន) (ឧ. personne tenace); ព្យាយាម, ស្វិតស្វាញ, មិនងាយបោះបង់ (ឧ. solliciteur tenace): ស៊ូ; ពិបាកកំចាត់ (ឧ. les préjugés sont tenaces) ។ mémoire tenace ស្មារតីល្អហើយចាំបានយូរ

ténacité *n.f.* ភាពស្អិត; ភាពស្វិតឬជាប់។ *Fig.* មានះ, ភាពស្វិតស្វាញ; សេចក្ដីស៊ូ

tenaille *n.f.* ឬ **tenailles** *n.f. pl.* ដង្កាប់; ញេញចាស់ (ដង្កាប់ឈើ)

tenaillement *n.m.* ការក្ដៀបនឹងដង្កាប់ដុត ។ *Fig.* ការធ្វើឲ្យឈឺចាប់; ការធ្វើឲ្យកើតទុក្ខ

tenailler *v.t.* ក្ដៀបដោយដង្កាប់ដុត ។ *Fig.* ធ្វើឲ្យខ្លោចផ្សា (ធ្វើឲ្យឈឺចាប់ក្នុងកាយ ឬ ក្នុងចិត្ត) (ឧ. la faim le tenaillait); ធ្វើឲ្យកើតទុក្ខ (ឧ. être tenaillé par le remords)

tenancier,ère *n.* អ្នកទទួលជួលដី; អ្នកកាន់កាប់អគារ

tenant,e *a.* séance tenante ម.ព. séance ។

n.m. អ្នកបបួលគេប្រយុទ្ធ ។ d'un seul tenant តែមួយដុំ (ជាប់គ្នារហូត) (ឧ. une propriété de vingt hectares d'un seul

tenant) ។ *pl.* អ្នកកាន់កាប់ (ឧ. les tenants d'un régime) ។ les tenants et les aboutissants d'une terre ជើងនិងចុងនៃដីមួយ (ទីតាំងឡាយដែលជាប់នឹងដីនោះ) ។ connaître les tenants et les aboutissants d'une affaire ដឹងរឿងមួយចប់ចុងចប់ដើម (ដឹងតាំងពីដើមរហូតដល់ទីបញ្ចប់)

tendance *n.f.* និន្នាការ (អាការទោរទន់ទៅរក; ដំណើរឆ្ពោះទៅរក ឧ. tendance des corps vers la terre; *fig.* ការលំអៀងទៅរក, ការចូលចិត្ត ឧ. tendance au mensonge)

tendancieux,euse *a.* ដែលមាននិន្នាការ, ដែលមានបំណងស្ងាត់កំបាំង (ឧ. un récit tendancieux)

tendancieusement *adv.* ដោយនិន្នាការ; ដោយមានបំណងស្ងាត់កំបាំង

tendant,e *a.* ដែលលំអៀងទៅរក; ដែលមានគោលបំណង (ឧ. requête tendant à...)

tendelle *n.f.* ដង់ប្រៀង

tender [tan-dèr] *n.m. Ch. de f.* ឧបរថ [អ៊ុ-ប៉ះរត់] (រថភ្ជាប់នឹងក្បាលរថភ្លើងសម្រាប់ដាក់ទឹកនិងអុស)

tenderie *n.f.* ការដាក់ដង់; កន្លែងដាក់ដង់

tendeur *n.m.* អ្នកដាក់ (ឧ. tendeur de pièges); អ្នកទាញសន្ទឹង; ប្រដាប់ទាញសន្ទឹង

tendoir *n.m.* ស្ដៀង, ស្បៀង, ស្នូ

tendon *n.m.* សរសៃចុងសាច់ដុំ ។ tendon d'Achille សរសៃកែង

tendre *a.* ទន់ (ឧ. pierre tendre); ផុយ (ឧ. viande tendre); ខ្ចី (ឧ. herbe tendre) ។ pain tendre នំប៉័ងថ្មី (ទើបនឹងចេញពីឡ) ។

Fig. ទន់ (ឧ. cœur tendre ចិត្តទន់); ស្រទន់, ផ្អែមល្ហែម (ឧ. paroles tendres); ស្រទន់, ពីរោះលះឡាច (ឧ. air tendre); ខ្ចី, ក្មេង (ឧ. dès l'âge tendre); អន់, ស្រទន់, ខ្ចី (ឧ. rose tendre) ។

n.m. ស្នេហា ។ pays du tendre ស្នេហប្រទេស (ប្រទេសនៃសេចក្ដីស្នេហា)

tendre *v.t.* ទាញសន្ទឹង (ឧ. tendre une corde); យឹត (ធ្នូ) (ឧ. tendre un arc); ដាក់ (អន្ទាក់) (ឧ. tendre un piège); លូក

ហុច (ឧ. tendre la main);តម្លើង (ឧ. tendre une tente); ពាស, ក្រាល(ឧ. tendre une chambre de papier bleu) ។

Loc.div. tendre la main លូកដៃជួយ, ជួយ;លូកដៃសុំ, សុំទាន។ tendre le dos ហុចខ្នងឲ្យ, ប្រុងខ្នងឲ្យគេវាយ ។ *Fig.* tendre son esprit ប្រុងគំនិត, ទំគិត ។

v.t.ind. (à) ទៅរក; សំដៅ, ប្រាថ្នា (ឧ. à quoi tendent vos démarches ?; tendre à la perfection)

tendrement *adv.*ដោយស្នេហា; ដោយថ្នាក់ថ្នម (ឧ. embrasser tendrement); ដោយស្រទន់

tendresse *n.f.* ស្នេហា (ឧ. la tendresse d'une mère) ។ *pl.* សេចក្ដីថ្នាក់ថ្នម, ការបញ្ចោសអង្អែល(ឧ. combler de caresses) ; សំដីស្រទន់ ឬ ផ្អែមល្ហែម

tendreté *n.f.* ភាពទន់ ឬ ឆ្អិយ (សាច់)

tendron *n.m.Fam.* ស្រីក្រមុំក្មេង ។ *pl.* ឆ្អឹងជំនីរខ្ចី (ឧ. des tendrons de veau)

tendu,e *a.* ដែលក្រាល; ដែលហុច; តឹង; តឹងតែង (ឧ. rapports tendus); ដែលប្រឹងគិតខ្លាំង (ឧ.esprit tendu); តឹងណាស់ (ឧ. situation tendue)

ténèbres *n.f. pl.* អន្ធការ; អន្ធភាព (ភាពងងឹតសូន្យ ឧ. marcher dans les ténèbres) ។ *Fig.* ភាពល្ងង់ (ងងឹតសូន្យ)។ l'ange, le prince ឬ l'esprit des ténèbres ពាមិច្ឆា(បិសាច,អារក្ស)។l'empire des ténèbres អន្ធពាមិច្ឆា , លោកន្តរ (ឋានអាកងងឹតសូន្យ)

ténébreusement *adv.*ដោយអន្ធការ, ដោយវៀចវេរ (ឧ. intriguer ténébreusement)

ténébreux,euse *a.* អន្ធការ, ងងឹតសូន្យ (ឧ. prison ténébreuse); ងងឹត, ខ្មៅ (ឧ. les sapins ténébreux)។ *Fig.* លួចលាក់, វៀចវេរ (ឧ. des projets ténébreux); ពិបាកយល់ (ឧ. philosophe ténébreux)

teneur *n.f.* សេចក្ដី (នៃលិខិត, នៃកិច្ចសន្យា) (ឧ. la teneur d'un traité); ចំនួន (នៃវត្ថុដែលលាយចូលនៅក្នុងវត្ថុមួយ) (ឧ. teneur en al-

cool)

teneur,euse *n.* អ្នកកាន់ ។ teneur de livre បញ្ជិកាវិ-ទី, អ្នកកាន់បញ្ជី

ténia ឬ **tænia** *n.m. Méd.* ព្រូនដែរ

ténifuge *a.* ដែលឲ្យធ្លាក់ព្រូន ។ *n.m.* ថ្នាំព្រូន (ឧ. l'écorce de grenadier est un ténifuge)

tenir *v.t.* កាន់ (ឧ. tenir un livre); នៅកន្លែង,ជំនួស(ឧ. tenir la place de quelqu'un) ; ឃុំឃាំង (ឧ. tenir en prison);ថែទាំ(ឧ. tenir en bon état);មានចំណុះ(ឧ. cette carafe tient un litre); ទុកជា (ឧ. je tiens cette affaire faite); ចូលលុក (នៅក្នុងអំណាចនៃ) (ឧ.quand la colère le tient); កាន់, គោរព (ឧ. tenir ses promesses); ទប់ (ឧ.il faut savoir tenir sa langue); ដឹកនាំដោយជំនាញ (ឧ. tenir une classe); បានដោយសារ (ជំពាក់គុណ) (ឧ. je tiens tout de vous); កាន់កាប់ (ឧ. tenir un hôtel) ។

Loc. div. tenir une chose de quelqu'un ដឹងរឿងអំពីអ្នកណាម្នាក់ ។ tenir sa parole កាន់ពាក្យសត្យ ។ tenir une promesse កាន់ពាក្យសន្យា ។ tenir un parti កាន់ជើង, ជួយគាំទ្របក្សពួក ។ tenir secret លាក់បំបាំង (មិនឲ្យបែកធ្លាយឮ សុសសាយ) ។ tenir table ouverte ម.ព. table ។ *Mil.* tenir garnison តាំងយោធភូមិ, នៅក្នុងយោធភូមិ ។ *Mar.* tenir la mer ដើរសមុទ្រ ។ *Autom.* tenir la route រត់នឹងល្អ (រថយន្តដែលបើកលឿនបានមិនធ្លាក់ក្រៅផ្លូវបត់) ។ *Comptab.* tenir la caisse កាន់បេឡា ។ tenir les livres កាន់បញ្ជី ។ tenir des propos, des discours និយាយ ។ tenir son rang កាន់ឋានៈខ្លួន, ប្រព្រឹត្តឲ្យសមតាមឋានៈខ្លួន ។ tenir compte d'une chose គិតដល់, យកមកគិត ។ tenir tête ម.ព. tête ។ tenir la main à une chose ប្រុងប្រយ័ត្ន ។ tenir en haleine ធ្វើឲ្យចង់ ឬ ឲ្យស្រួលចិត្ត ។ *Fig. & Fam.* tenir la queue de la poêle ម.ព. poêle ។ tenir conseil ពិគ្រោះ ។ *Absol.* tiens! យី!, យីអើ! ។

v.t. ind. ដូច, កាត់ទៅខាង (ឧ. il tient de son père) ។ *Fig.* ចូលចិត្ត, ស្រឡាញ់ (ឧ. tenir à quelqu'un, à sa réputation); ជាកូនកាត់, មានលាយឈាម (ឧ. le mulet tient de l'âne et du cheval); មកអំពី (ឧ. cela tient à plusieurs raisons); ចង់ខ្លាំង (ឧ. il tient à vous voir) ។

v.i. ជាប់ពី, ជាប់នឹង (ឧ. ma maison tient à la sienne); ចង, ជាប់ (ឧ. la corde tient au mur); ឋិតនៅ, គង់នៅ (ឧ. cette mode ne tiendra pas); មានក្នុងទីមួយ (ឧ. on tient huit à cette table) ។

Loc. div. tenir bon ឬ ferme តស៊ូ, មិនព្រមឱយ ។ cela ne tient qu'à un fil របស់នេះមិនមាំទេ ។ tenir pour ចូលដៃខាង ។ *Fam.* en tenir pour ចាប់ចិត្តស្រឡាញ់ ។

v. impers. qu'à cela ne tienne មិនថ្វីទេ ។ il ne tient qu'à moi ស្រេចនៅលើខ្ញុំ ។

se tenir *v.pr.* ឋិត, នៅ (ឧ. tenez-vous là) ។

Loc. div. se tenir droit ឈរឬអង្គុយឲ្យត្រង់ខ្លួន ។ tenez-vous bien សូមឈរ ឬ អង្គុយឲ្យស្រួល; សូមប្រយ័ត្ន ។ s'en tenir à une chose ចង់បានតែរបស់មួយ; គិតតែអំពីរបស់មួយ ។ se tenir à peu de chose នៅសល់តែបន្តិចទៀត, ហៀបនឹងចុះសម្រុងគ្នា ។ se tenir les bras croisés ឈរឱបដៃ, នៅស្ងៀម

tennis *n.m.* តិន្នីស, កីឡាវាយបាល់ ។ tennis de table (ឬ ping-pong) កីឡាវាយបាល់លើតុ ឬ ពីងប៉ុង

tenon *n.m. Techn.* ពន្លួញ (ទូនឹង mortaise ដំណាប់)

tenor *n.m. Mus.* សម្លេងធំនៃមនុស្សប្រុស; អ្នកច្រៀងសម្លេងធំ

ténoriser *v.i.* ច្រៀងសម្លេងធំ

tensiomètre *n.m.* អាយតមាត្រ [–យ៉ះ តះ–]

tension *n.f.* អាយតភាព [–យ៉ះ-តះ–] (ភាពវត្ថុដែលទាញតឹងឧ. la tension d'un ressort; ភាពនៃសាច់ដុំខ្លះដែលឡើងរឹង ឧ. la tension des muscles; *Phys.* ភាពខ្សែនដែល

ណែន; *Electr.* កម្លាំងចរន្តនៅក្នុងអគ្គិសនី (ឧ. tension de 110 volts)។ *Méd.* tension artérielle ឬ tension សម្ពាធឈាមនៃសរសៃឈាម (ម.ព. hypertension និង hypotension ផង)។ *Fig.* tension d'esprit ការប្រឹងគិតខ្លាំង។ ភាពតានតឹង (ភាពមិនត្រូវគ្នារវាងរដ្ឋ, វណ្ណៈ, បក្សនយោបាយ)

tentaculaire *a.* នៃហត្ថាការ (ឧ. appendices tentaculaires); ដូចហត្ថាការ។ *Fig.* ដែលរីករាលដាល (ដូចហត្ថាការ)(ឧ. ville tentaculaire)

tentacule *n.m.* ហត្ថាការ (អវយវៈនៃសត្វខ្លះសម្រាប់ប្រើដូចដៃ)(ឧ. tentacules des pieuvres)

tentant,e *a.* ដែលឲ្យកើតបំណងចិត្ត, ដែលឲ្យមានចំណង់

tentateur,trice *a.&n.* ដែលទាញទៅរកបទអាក្រក់។ l'esprit tentateur ព្រាយបញ្ឆោតចិត្តឲ្យធ្វើអាក្រក់

tentation *n.f.* ជាប់ចិត្ត, ចំណង់ទៅខាងបទអាក្រក់(ឧ. résister à la tentation); ចំណង់ (ឧ. tentation de voyager)

tentative *n.f.* ការប៉ុនប៉ង (ឧ. tentative d'assassinat ការប៉ុនប៉ងធ្វើឃាត); ការល្បង (ម.ស. essai)

tente *n.f.* តង់, ខ្ទម្រក្រណាត់, ដំបូលសំពត់។ *Fig.* se retirer sous sa tente លែងរវល់នឹងការអ្វីមួយ (ដោយខឹង)។ *Poét.* ទេយ។

Loc. div. être ឬ vivre sous sa tente នៅកន្លែងណាមួយជាបណ្ដោះអាសន្ន។ lever ses tentes លើកកញ្ចើដើរ; ចេញពីកន្លែងណាមួយ

tente-abri *n.f.* ដំបូលសំពត់តូច (*pl.* des tentes abris)

tenter *v.t.* ប៉ុនប៉ង, ល្បង (ឧ. tenter une expérience), ល្បង (ធ្វើការពិបាក)(ឧ. tenter une expédition); បញ្ឆោតចិត្ត (ឧ. le serpent tenta Eve); ធ្វើឲ្យចង់ (ឧ. ce fruit me tente)។ tenter Dieu • ខំប្រឹងធ្វើការហួសកម្លាំងមនុស្ស។ *v.t.ind.* (de) ល្បង, ខំប្រឹង

tenture *n.f.* សំពត់ ឬ ក្រដាសពណ៌ពាសជញ្ជាំង (ឧ. tenture de velours); កម្រាលដែលគត្លា

tenu,e *a.* ដែលគេថែរក្សា, ដែលគេបីបាច់ (ឧ. enfant bien tenu); ដែល

មានរបៀប (ឧ. maison bien tenue); ដែលត្រូវតែ(ដែលចៀសមិនរួច ឬ គានមិនបាន) (ឧ. être tenu à); នឹង, ប្រាកដ (ឧ. valeurs tenues)

ténu,e *a.* ឆ្មារ, តូច, ល្អិត (ឧ. les fils ténus d'un ver à soie)

tenue *n.m.* ពេលប្រជុំ (ឧ tenue des assises); ការកាន់កាប់; របៀបថែទាំ(ឧ.tenue d'une maison); របៀបស្លៀកពាក់ ; ចរិយា (របៀប, សណ្ដាប់ធ្នាប់, សំលៀកបំពាក់) (ឧ. bonne, mauvaise tenue) ។

Loc. div. Mil. tenue militaire យោធចរិយា (របៀប, សណ្ដាប់ធ្នាប់ឬសំលៀកបំពាក់ទាហាន)។ grande tenue ឯកសណ្ឋានធំ (សំលៀកបំពាក់សម្រាប់ពិធីអ្វីមួយ) ។ en tenue ជាឯកសណ្ឋាន ។ *Comptab.* tenue de livres ការកាន់បញ្ជី។ *Autom.* tenue de route ដំណើរនឹងល្អ (រថយន្ត) ។ *Equit.* avoir de la tenue ជិះជាប់ (ជិះសេះមិនធ្លាក់) ។ tout d'une tenue ឬ d'une seule tenue *loc. adv.* ជាប់គ្នាទាំងអស់, មិនដាច់

ténuité *n.f.* ភាពឆ្មារ, ភាពតូច ឬ ល្អិត

ter *adv.* បីដង; លើកទីបី

tératologie *n.f.* វិរូបកាយវិទ្យា (ផ្នែកវិទ្យាសាស្ត្រស្ដីអំពីសត្វមានរូបបំឡែក)

tératologique *a.* នៃវិរូបកាយវិទ្យា(ឧ. anatomie tératologique)

tercer ឬ **terser** *v.t.* ម.ក. tiercer

tercet *n.m.* គាថាមានបីបាទ .

térébrant,e *a.* ដែលចោះ (ចោះរន្ធ) (ឧ. insectes térébrants) ។ *Fig.* douleur térébrante ឈឺចាក់ដោត (ដូចគេចាក់ឆ្កៀល)

térébration *n.f.* ការចោះ (ចោះរន្ធ)

tergal,e,aux *a.* នៃខ្នង

tergal *n.m.* ទែរហ្គាល (សំពត់ម្យ៉ាងធ្វើនៅប្រទេសបារាំង)

tergiversation *n.f.* ទ្វេតាលភាព, ការនិយាយពង្វាង; ការរារែក

tergiverser *v.i.* ពង្វាង;ប្រើកល; រារែក(ស. biaiser, hésiter, louvoyer)

terme *n.m.* ទីបំផុត (ឧ. terme d'une course, de la vie); កាលកំណត់ (ដែលត្រូវបង់ប្រាក់) (ឧ. le terme est échu) ។ à court

terme ក្នុងកាលកំណត់ខ្លី។ à long terme ក្នុងកាលកំណត់វែង ។ *Par ext.* ប្រាក់ដែលត្រូវបង់នៅកាលកំណត់ (ឧ. payer son terme)។ vente à terme ការលក់បណ្ដាក់ ។

Méd. ពេលគ្រប់ខែ(កាលកំណត់សម្រាលកូនជាធម្មតា) (ឧ. enfant né avant terme កូនកើតមិនគ្រប់ខែ) ។

Gram. សព្ទ, ពាក្យ (ឧ. choisir ses termes) ។ terme propre ម.ព. propre ។ terme royal រាជស័ព្ទ ។ terme technique ស័ព្ទបច្ចេកទេស។ *Math.* ស័ន្ធន (ឧ. termes d'une fraction) ។

pl. ការទាក់ទងចំពោះ (ឧ. en quels termes êtes-vous avec lui ?)

terminaison *n.f.* ភាពចប់, ភាពអស់ (ឧ. la terminaison d'une maladie); ចុងស័ព្ទ, អវសានសព្ទ (ផ.ឹង radical)

terminal,e,aux *a. Bot.* ដែលនៅចុង (ឧ. bourgeon terminal ត្រួយ); ដែលបញ្ចប់ (ឧ. classes terminales)

terminer *v.t.* បញ្ចប់ (ឧ. terminer ses études); បង្ហើយ (ឧ. peintre qui ne termine pas ses tableaux) ។

se terminer *v.pr.* ចប់,ផុត

terminologie *n.f.* វិជ្ជាយល់សព្ទ[-យ៉ុគ ក:—], ប្រជុំស័ព្ទបច្ចេកទេស

terminus *n.m.* ចុងខ្សែ

termite *n.f.* កណ្ដៀរ

termitière *n.f.* ដំបូកកណ្ដៀរ

ternaire *a.* ដែលមានបី (ឧ. nombre ternaire); ដែលចែកជាបី (ឧ. division ternaire)

terne *n.m.* លេខសួនបី, លេខដូចគ្នាបីដែលចេញជាមួយគ្នា(ឆ្នោត ឡូកឡាក់)

terne *a.* ស្រអាប់, មិនភ្លឺ (ឧ.œil terne) ។ *Fig.* ស្រអាប់, មិនត្រចះត្រចង់; គ្មានល្អ (ឧ. style terne) (ព.ផ. brillant, éclatant)

ternir *v.t.* ធ្វើឲ្យស្រអាប់ (ឧ. ternir une étoffe) ។ *Fig.* ធ្វើឲ្យស្រអាប់, ធ្វើឲ្យមានមន្ទិល (ឧ.ternir sa réputation) (ព.ផ. polir)

ternissement *n.m.* ការធ្វើឲ្យស្រអាប់

ternissure *n.f.* ភាពស្រអាប់ (ឧ.

la ternissure d'une glace)

terrain *n.m.* ដី; ទីដី (ឧ. occuper un vaste terrain); ដី (សាច់ដី) (ឧ. terrain argileux, couvert, boisé) ។ terrain vague ដីទំនេរក្នុងក្រុង (គ្មានផ្ទះឬគ្មានដំណាំ) ។ accident de terrain ភាពដីខ្ពស់ទាប។ *Méd.* ភាពនៃសរីរៈ (ដែលទទួលឬមិនទទួលរោគ) ។

Mil. organisation du terrain ការរៀបចំដី(ដើម្បីការពារ)។ terrain d'aviation លានយន្តហោះ (កន្លែងយន្តហោះចុះឬឡើង) ។ véhicule tout terrain យានសម្រាប់ដីគ្រប់យ៉ាង (យានដែលអាចបើកលើថ្នល់ឬលើដីគ្រប់បែបយាង) ។ *Sports* ផ្លាក់ឡ ។ aller sur le terrain ចូលប្រយុទ្ធគ្នាតទ្វី ។

Fig. ស្ថានភាព, ស្ថានការណ៍; ចិត្ត, គំនិត ។ sonder le terrain ស្ទង់ស្ថានការណ៍ ; ស្ទង់ចិត្តគំនិត ។ connaître le terrain ដឹងស្ថានការណ៍, ស្គាល់មនុស្សដែលគេត្រូវទាក់ទង ។ gagner du terrain ម.ព. gagner ។ disputer le terrain ការពារមតិខ្លួន ។ être sur son terrain នៅក្នុងទីខ្លួន; និយាយអំពីអ្វីដែលខ្លួនចេះច្បាស់ ។ se placer sur un bon terrain ការពារបុព្វហេតុល្អ; មានប្រៀបលើគេ ។ se placer sur un mauvais terrain ការពារបុព្វហេតុមិនល្អ; ចាញ់ប្រៀបគេ

terrasse *n.f. Constr.* លាន, ដំបូលរាបស្មើ ។ champ en terrasse ចំការជាថ្នាក់នៅជំរាលភ្នំ

terrassement *n.m.* ការជីកលើកដី; ដីលើក (ឧ. les terrassements d'une voie ferrée)

terrasser *v.t.* លើកដីទប់ (ឧ. terrasser un mur) ; យោកផ្តួល (ឧ. terrasser un adversaire) ។ ឈ្នះ (ឧ. terrasser l'ennemi)។ ធ្វើឱ្យស្លុត (ឧ. cette nouvelle l'a terrassé) (ល៊ី. abattre renverser)

terrassier *n.& a.m.* កម្មករលើកដី

terrasson *n.m.* ភាគទួលនៃដំបូលរាបស្មើ

terre *n.f.* ពសុធា, ផែនដី (ក្នុងន័យនេះ សរសេរជាអក្សរធំ); ដី (ឧ. terre glaise ដីឥដ្ឋ); ដី, ប្រទេស (ឧ. mourir en terre étrangère);

ដី, ផ្នូរ (ឧ. porter en terre); ដី (ដីជាតិដំណាំ, ស្រែ, ចំការ) (ឧ. vivre dans ses terres); បណ្ដាញដីនៅលើផែនដី ។

Loc. div. toute la terre ទាំងផែនពសុធា, ទាំងផែនដី (ឧ. être connu de toute la terre)។ à ឬ par terre នៅដី (ឧ. ramasser un livre tombé à terre; se jeter par terre) ។ *Fig.* jeter ឬ porter par terre ផ្ដួល, រលំ, បំផ្លាញ (ឧ. il vous a porté par terre) ។ être à terre រលំ, វិនាស, ធ្លាក់គោកយ៉ាក (ឧ. nos espérances sont souvent à terre)។ *Fig.* tomber à terre ឬ par terre ដួល, រលំ (ឧ. ta tyrannie n'a pas été plus solide que ma république, elle est tombée à terre (Fénelon) ។ ne pas tomber à terre មិនអសារបង់ (ឧ. les promesses qu'on nous fait ne tombent pas à terre) ។ courir ventre à terre រត់អស់ទំហឹង ។

donner du nez à terre ដួលផ្កាប់មុខ; *au fig.* ទក, មិនបានសម្រេច។ battre quelqu'un à terre វាយមនុស្សដែលដួលស្រាប់, វាយអ្នកដែលមិនអាចការពារខ្លួនបាន ។ terre à terre ជិតច្រាំង (ឧ. naviguer terre à terre); *au fig.* គ្មានបម្រើន; មិនថ្លៃថ្នូរ; *n.m.* របៀបរស់នៅជាសាមញ្ញ (គ្មានគំនិតថ្លៃថ្នូរ) (ឧ. le terre à terre a parfois du bon); *a.* សាមញ្ញ, ទាប, មិនថ្លៃថ្នូរ (ឧ. avoir des goûts terre à terre) ។

sous terre ក្រោមដី; *au fig.* ដោយស្ងាត់កំបាំង (ឧ. le père Le Tellier qui faisait tout sous terre. (Saint Simon) ។ être sous terre, នៅក្នុងដី, ស្លាប់ ។ vouloir être à cent pieds sous terre ចង់ប្រុលទៅក្នុងក្នុងដី, អៀនអន់ណាស់ ។ de dessous terre ពីទីស្ងាត់ ឬ គ្មានអ្នកឯណាស្គាល់ ។ entre deux terres ក្រោមដីបន្តិច (ឧ. couper un arbre entre deux terres) ។

biens de la terre ផលព្រះ

ធរណី, ទ្រព្យដែលកើតអំពីដី; *au fig.* ទ្រព្យលោកិយ (ផ.នឹង biens spirituels)។ fruits de la terre ផលដី ។ fonds de terre ឬ fonds មូលនិធិជាដី, ដីជាកម្មសិទ្ធិ ។ terre cuite ដីដុត; របស់ធ្វើដោយដីដុត ។ *Agr.* terre forte ឬ terre grasse ដីស្អិត (មានជីជាតិ) ។ terre à foulon ម.ព. foulon ។ terre végétale ម.ព. végétal ។ terre vierge ម.ព. vierge ។ terre volcanique ដីភ្នំភ្លើង ។ *Bx.Arts* terre de pipe ដីឥដ្ឋស ។ *Hist. relig.* terre promise ប្រទេសកាណាន (ម.ព. promis ផង) ។ terre ferme ឬ grande terre ទ្វីប (ឬដីគោកផ្ទុយនឹងកោះ)។ armée de terre ទ័ពជើងគោក (ផ. នឹង armée de mer) ។ les terres ឬ l'intérieur des terres ដីខាងក្នុង (ឆ្ងាយពីច្រាំងសមុទ្រ)។ être sur terre ឬ sur la terre ឬ sur cette terre នៅរស់ ។ mesurer la terre វាស់ដី (ដួល) ។ baiser ឬ raser la terre ហើរប៉ប្រះដី (ឧ. l'hirondelle rase souvent la terre); *au fig.* មិនខ្ពង់ខ្ពស់ ។ perdre terre មើលច្រាំងលែងឃើញ; ជុតជើង (ឈរមិនដល់បាតព្រោះទឹកជ្រៅពេក)។ prendre terre ចូលចត ។ reprendre terre ចូលចតវិញ; *au fig.* មានកម្លាំងឡើងវិញ ។ chercher quelqu'un par mer et par terre រកអ្នកណាម្នាក់គ្រប់ច្រកល្ហក។ *Fig.* chasser sur les terres d'autrui ម.ព. chasser ។ n'avoir pas un pouce de terre គ្មានដីមួយដុំសោះ ។ remuer de la terre កាប់គាស់ដី, ជីកដី ឬ លុបដី ។ remuer ciel et terre ម.ព. ciel ។ mettre ឬ porter en terre យកទៅបញ្ចុះ ឬ កប់ (ក្នុងដី)។ sentir la terre ជុំក្លិនដី (ជិតស្លាប់)។ quitter la terre pour le cens បោះអង្ករ យកអង្កាម, បោលសាប់ស្រាវក្ដឹង ។ il vaut mieux en terre qu'en pré ចាត់នេះស្លាប់ល្អជាងនៅរស់ ។

Mar. à terre លើគោក (ឧ. laisser quelques hommes à terre) ។ descendre à terre

ឡើងគោក (ព្រះពីនាវទៅកាន់ដីគោក) ។ être sous la terre បើកនាវជិតដី ។ chasser la terre បើកនាវទៅរកដី ។ gagner la terre កាប់បង្ហួតទៅរកដី ។

Prov. qui terre a guerre a ម.ព guerre។ bonne terre, mauvais chemin ម.ព. chemin ។ six pieds de terre suffisent au plus grand homme មនុស្សធំបំផុតត្រូវការតែដីបួនហត្ថប៉ុណ្ណោះ (មនុស្សដែលស្លាប់ទៅត្រូវការដីបួនហត្ថដួបគ្នាសម្រាប់កប់)

terreau *n.m.* ដីចុណ្ណមីស្ស, ដីជី (ដីលាយជីសត្វនឹងដីរុក្ខជាតិ) (ឧ. le terreau sert à amender le sol ordinaire)

terreautage *n.m.Hortic.* ការលាយដីចុណ្ណមីស្ស

terreauter *v.t.* ដាក់ដីចុណ្ណមីស្ស

terre-neuve *n.m.inv.* ទែរណើវ (ឆ្កែម្យ៉ាងរោមវែង)

terre-plein *n.m. Trav. publ.* ដីទៀន, ដីលើក (*pl.* des terre-pleins)

terrer *v.t.* ពូនដី (គល់ឈើ) (ឧ. terrer un arbre); លុបដី (ឧ. terrer des semis) ។

v.i. នៅក្នុងរូងដី ។

se terrer *v.pr.* ពួនក្នុងរូងដី (ទន្សាយ) ។ *Fig.* ពួនមុខ

terrestre *a.* នៃផែនដី ។ le globe terrestre ម.ព. globe ។ ឋលោកស, ដែលរស់នៅលើគោក(ឧ. les animaux, les plantes terrestres) ។ *Fig.* លោកិយ (ផ្ទ. នឹង spirituel) (ឧ. les joies terrestres)

terreur *n.f.* ភេរវកម្ម, អំពើគួរឲ្យខ្លាច; ភ័យខ្លាំង (ឧ. inspirer la terreur); ភេរវជន (ឧ. être la terreur d'un pays)

terreux,euse *a.* ជាជាតិដី; លាយដី; ប្រឡាក់ដី (ឧ. avoir les mains terreuses)។*Fig.* ស្លាំង;ស្រអាប់។ visage terreux មុខស្លេកស្លាំង ។ couleur terreuse ពណ៌ស្រអាប់

terri *n.m.* ម.ព. terril

terrible *a.* ភេរវ, ដែលឲ្យភ័យខ្លាំង, គួរខ្លាច(ឧ.homme terrible)។*Fig.* ខ្លាំងសំបើម (ឧ. vent terrible)។ *Péjor.* អស្ចារ្យ, ចំឡែក (ឧ. un

terrible bavard)(ម.affreux, atroce, effrayant, effroyable, épouvantable, redoutable, tragique)

terriblement *adv.* ដោយគួរឲ្យភ័យខ្លាំង ។ *Fam.* យ៉ាងសំបើម (ឧ. manger terriblement)

terricole *a.* ថលាស័យ, ដែលអាស្រ័យនៅក្នុងដី (ឧ. amibe terricole)

terrien,enne *a.* ដែលនៅលើដែនដី; ដែលមានដីច្រើន (ឧ propriétaire terrien) ។

n. ម្ចាស់ដី, អ្នកមានដី។ *Fam.* អ្នកនៅលើគោក (ផ. នឹង marin)(ឧ. le matelot a un certain mépris pour le terrien) ។

terrier *n.m.* រូងសត្វ (ក្នុងដី) (ឧ. le furet atteint les lapins dans leur terrier); ឆ្កែប្រដេញសត្វក្នុងរូង; ឆ្កែប្រមាញ់ម្យ៉ាង

terrifier *v.t.* ធ្វើភេរវកម្ម, បន្លាច, ធ្វើឲ្យភ័យខ្លាំង(ឧ.terrifier une région)

terril ឬ **terri** *n.m.Ind.* គំនរអាចម៍រ៉ែ

terrine *n.f.* ផើង, ភាជន៍; ឆ្នាំងដែក; ចំនួនមួយផើងឬមួយភាជន៍ (ឧ. boire une terrine de lait)

terrinée *n.f.* ចំនួនមួយផើងឬមួយភាជន៍

terrir *v.i.* ឡើងពងលើគោក(ឧ.saison où les tortues terrissent)

territoire *n.m.* ដែនដី, អាណាខេត្ត (ឧ.le territoire cambodgien; le territoire d'un khum)

territorial,e,aux *a.* នៃដែនដី, នៃអាណាខេត្ត (ឧ. impôt territorial) ។

n.m. ទាហានជើងគោក

territorialement *adv.* តាមដែនដី, តាមអាណាខេត្ត

territorialité *n.f.* ភាពជាដែនដី ឬ ជាអាណាខេត្តនៃរដ្ឋមួយ

terroir *n.m.* ដី (ស្រែចំការ) (ឧ. terroir fertile) ។ goût de terroir រសពិសេស (នៃស្រាទំពាំងបាយជូរខ្លះ)។ sentir le terroir ម.ព. sentir

terroriser *v.t.* ធ្វើភេរវកម្ម, ធ្វើឲ្យភ័យខ្លាំង

terrorisme *n.m.* ភេរវនិយម (ភេរវកម្មទាំងឡាយរបស់ក្រុមបដិវត្តន៍; របបនយោបាយនៃរដ្ឋដែលប្រើភេរវកម្ម)

terroriste *a. &n.* ភេរវជន, អ្នកធ្វើភេរវកម្ម (ឧ. groupe terroriste)

tertiaire *a.* ទី៣ ។ *Géol.* ère tertiaire ឬ le tertiaire *n.m.* តតិយយុគ (ឧ. l'ère tertiaire a duré environ 70 millions d'années)

tertio *adv.* ទ៣; ទី៣; ជាគម្រប់ ៣

tertre *n.m.* ទួល, គោក (ទួលកណ្ដាលវាល ឬ កណ្ដាលវាលស្រែ) ។ tertre funéraire ផ្នូរខ្មោច

tes *a. pos.* របស់ឯង (ពហុវចនៈនៃពាក្យ ton, ta)

tesson *n.m.* អំបែង (ថាន, ពាង, ដប, កែវ) (ឧ. tesson de bouteille)

test [tèst] *n.m.* សំបកខ្ចៅខ្យង

test *n.m.* បរិក្សា [ប៉ៈ-រ៉ិក-សា], ការពិសោធចង់ដឹង

testacé,e *a. Zool.* ជាសំបកខ្ចៅខ្យង; ដែលមានសំបក (ឧ. mollusque testacé)

testament *n.m.* មតកសាសន៍ (លិខិតដែលមនុស្សម្នាក់សំដែងឆន្ទៈចុងក្រោយបំផុតរបស់គេ ហើយចាត់ចែងទ្រព្យសម្បត្តិរបស់គេ សម្រាប់ពេលដែលគេស្លាប់ទៅ; លិខិតបញ្ជាមរណៈដែលអ្នកតែងថ្លែងអំពីទស្សនៈ ឬ គ្រោងការរបស់ខ្លួន)

testamentaire *a.* នៃមតកសាសន៍(ឧ. disposition testamentaire) ។ exécuteur testamentaire ម. ក. exécuteur

testateur,trice *n.* អ្នកធ្វើមតកសាសន៍

tester *v.i.* ធ្វើមតកសាសន៍

tester *v.t.* ធ្វើបរិក្សា, ពិសោធចង់ដឹង (ឧ. tester des écoliers)

testicule *n.m.* អណ្ឌៈ, ពងស្វាស, ពងអង្គជាតបុរស

testimonial, e, aux *a.* preuve testimoniale ភស្តុតាងដោយករណីសាក្សី

tétanie *n.f.* ឬ **tétanisme** *n.m.* ដំណើរប្រកាច់

tétanique *a.* នៃតេតាណូស (ឧ. convulsions tétaniques)

tétaniser *v.t.* ធ្វើឲ្យប្រកាច់

tétanos *n.m.* តេតាណូស(រោគប្រកាច់)

têtard *n.m.* កូនក្អុក, កូនកៀក

tête *n.f.* ក្បាល (ឧ. lever, baisser la tête);(រ.ស.)សិរសា;ត្បូង;ក្បាល (លលាដ៍ក្បាល) (ឧ. fendre, casser la tête à quelqu'un):ក្បាល(សក់) (ឧ. une tête soignée, frisée) ។ *Fig.* មនុស្ស(ឧ. j'ignore

le destin d'une tête si chère (Racine); ក្បាល(សត្វមួយៗ); ម្នាក់ៗ, ផិនមួយរូបៗ (ឧ. donner, payer tant par tête); ជីវិត (ឧ. payer de sa tête son imprudence); ក្បាល, បញ្ញា (ឧ. le cœur sent, la tête compare (Chateaubriand); គំនិត (ឧ. j'ai dans la tête certaine petite vengeance); ក្បាល (មានះ, ការបះបេស) (ឧ. une tête de fer); វិញ្ញាណញាណ (ឧ. un homme de tête); ស្មារតី (ឧ. il faut conserver toute sa tête dans le péril) ។

Fig. កំពូល (ឧ. couper la tête d'un arbre); ក្បាល (ឧ. tête d'une épingle); ក្បាល (នៃទ័ព, ក្បួនហែ) (ឧ. la tête d'une colonne en marche, d'un convoi); ខាងដើម (ភាគខាងមុខនៃសៀវភៅ) (ឧ. préface placée en tête d'un ouvrage); ដើម (ភាគខាងលើ) (ឧ. être en tête d'une liste de souscription); ទីមួយ, នាយក; ហិនៈនាយក (ឧ. être à la tête d'une administration) ។

Loc. div. tête pelée ឬ chauve ក្បាលទំពែក; មនុស្សក្បាលទំពែក ។ tête naissante សក់ទើបនឹងដុះ ។ tête dure ក្បាលស្ពឹក, បញ្ញាអាប្ប ។ tête carrée វិញ្ញាណញាណមោះមុត ; ក្បាលរឹង (មនុស្សបះបេស) ; មនុស្សមិនសូវមានបញ្ញា ។ tête sans cervelle, éventée ឬ tête à l'évent, tête de linotte ឬ tête légère មនុស្សរឡើករឡក់-ពាយងាយ ឬ ឆើក ។ tête chaude មនុស្សចិត្តស្រាល (ឆាប់ខឹង) ។ tête froide មនុស្សចិត្តធ្ងន់ ។ tête à perruque ឬ tête រូបក្បាលមនុស្ស (សម្រាប់រៀនធ្វើសក់) ; *au fig.* មនុស្សចាស់ល្ងង់ហើយបះបេស ។ se faire une tête រៀបចំទឹកមុខ ។ avoir de la tête បេះវិនិច្ឆ័យ; មានស្មារតី; បះបេស ។ bonne tête ការវិនិច្ឆ័យត្រឹមត្រូវ; វិញ្ញាណញាណល្អ (ឧ. tout chef doit avoir bonne tête); *fam.* មុខគួរឲ្យអស់សំណើច (ឧ. Monsieur Prudhomme, quelle bonne tête!) ។ mauvaise

tête ក្បាលអាប្រក់ (មនុស្សរបឹងរឹងរូស, គ្មានវិន័យ); គំនិតពាយងាយ ។ mauvaise tête et bon cœur គំនិតពាយងាយតែចិត្តល្អ ។ forte tête បរិតរឹង(មិនចុះក្ដូល) ឬ គិតច្រើន; មេដឹកនាំធំ ។ homme de tête មនុស្សមានសមត្ថភាពនឹងមានស្មារតី ។ tête couronnée ព្រះមហាក្សត្រ (ដែលទ្រង់មកុដ) ។ tête de Turc រូបក្បាលសម្រាប់ហោតដាល់; *au fig.* មនុស្សដែលគេធ្វើបាប ឬ លេងគ្រក់គ្រើញ ។ se payer la tête de quelqu'un បញ្ឆោតអ្នកណាម្នាក់លេង ។ tête d'âne, de mulet ឬ de bœuf មនុស្សល្ងង់ហើយចចេស។ tête de mort ក្បាលខ្មោច។

Fig. tête de clou អក្សរមិនច្បាស់ ។ mal de tête រោគឈឺក្បាល ។ coup de tête អំពើធ្វើដោយគិតពិចារណា ។ martel en tête ការកើតទុក្ខជាប់ជានិច្ច។ la tête la première ក្បាលទៅមុន (ឧ. se jeter à l'eau la tête la première); ភ្លាមៗ; ដោយគ្មានពិចារណា (ឧ. se jeter dans une affaire la tête la première) ។ de la tête aux pieds ពីក្បាលដល់ចុងជើង (ឧ. toiser les gens de la tête aux pieds) ។ sur la tête de ក្នុងបន្ទុកនៃ; ក្នុងនាមនៃ(ឧ. mettre tous ses biens sur la tête de sa femme); ឡែកាប់ក (ក្នុងសំបថ) (ឧ. je jure sur la tête de mes enfants ខ្ញុំស្បថឲ្យវត្តសក្តិសិទ្ធិកាប់កកូនខ្ញុំ) ; ពីលើក្បាល, ល្អបះលើ (ឧ. enfin il fit si bien qu'il se trouva sur la tête de tout le monde (Retz) ។ avoir tant d'années sur sa tête មានអាយុប៉ុណ្ណោះទៅហើយ ។ deux têtes dans un bonnet ម.ព. bonnet ។ lever la tête ងើបក្បាល ; *au fig.* ងើបក្បាល (ហ៊ានឡើងវិញ,បញ្ចេញកម្លាំងឬអំណាចឡើងវិញ) (ឧ. ce parti n'ose plus lever la tête) ។ tête levée ដោយងើបក្បាល; ដោយអង់អាច; ដោយគិតខ្មាស (ឧ. le crime va la tête levée, la vertu rougit et se cache. (Massillon)។ baisser la tête ឱក

មុខ, សំយុងមុខ; *au fig.* សំយុងមុខ ដោយអៀនខ្មាស (ឧ. le cynique ne baisse pas la tête)។ *Fig.* tête baissée សម្រុកក្បាល (ដោយគ្មានគិតដល់គ្រោះថ្នាក់) (ឧ. se précipiter tête baissée au milieu des rangs ennemis); ដោយគ្មានគិត (ឧ. donner tête baissée dans le panneau)។ courber la tête ឱនក្បាល; *au fig.* ចុះចាញ់ ។ courber la tête sous le joug ទ្រាំទទួលនឹម (សុខចិត្តទទួលអំណាចជិះជាន់)។ *Très fam.* tomber cul par-dessus tête ធ្លាក់ចាក់ទឹង ឬ ដាំទឹង (ធ្លាក់ក្បាលចុះក្រោម ជើងឡើងលើ) ។ faire sa tête ធ្វើឫកធំ ។ *Pop.* faire la tête ធ្វើមុខក្រញូវ, កកកុក ។ faire une tête ធ្វើឡឹងឡោង; ទឹងប្រឡេត ។ avoir la tête dans les épaules មានករួញ (កខ្លី) ។ avoir la tête lourde ធ្ងន់ក្បាល ។ avoir quelque chose en tête គិតមមៃដល់; គិតពីរឿងអ្វីមួយជាប់ជានិច្ច ។ avoir en tête de បង់បានយ៉ាងខ្ជាប់ខ្ជួន ។ se mettre dans la tête de ឬ que បង់បានយ៉ាងខ្ជាប់ខ្ជួន; គិតថា; យល់ថា (ឧ. mettez-vous dans la tête que je vous vaux bien)។ se mettre en tête មានបំណង។ mettre en tête នាំឲ្យគិតដល់; នាំឲ្យចង់ធ្វើ (ឧ. la belle saison nous met en tête les voyages) ។ avoir du travail ឬ des affaires par-dessus la tête មានការលើសលុប (លើសកម្លាំងដែលធ្វើបាន) ។ en avoir par-dessus la tête ធុញនឹង (របស់អ្វីមួយ ឬ អ្នកណាម្នាក់)។ ne savoir où donner de la tête មិនដឹងចាប់ធ្វើអ្វីមុន; មិនដឹងជាទៅជាយ៉ាងណា; មិនដឹងជាគិតដូចម្ដេច ។ avoir quelque chose en tête មានរបស់អ្វីមួយ ឬ អ្នកណាម្នាក់នាំឲ្យពិបាកចិត្ត (ឧ. il avait en tête un général si puissant (Bossuet); គិតមមៃដល់អ្នកណាម្នាក់ ។ faire tête à បែរមុខទៅ; តទល់នឹង (ឧ. sanglier qui fait tête aux chiens) ។ *Fig.* donner de la tête contre

les murs ឬ contre un mur គិតធ្វើអ្វីដែលធ្វើមិនកើត ។ porter, donner ឬ monter à la tête ធ្វើឲ្យវិលមុខ (ឧ. vin qui porte ឬ qui monte à la tête)(ម.ព. porter ផឹក) ។ laver la tête à quelqu'un ស្ដីឲ្យយ៉ាំងខ្លាំង ។ crier ឬ chanter à pleine tête, à tue tête ឬ du haut de sa tête ស្រែក ឬ ច្រៀងអស់សម្លេង។ jeter à la tête លើកឲ្យ, ឲ្យដោយប្រញាប់ប្រញាល់(ឧ. il y a des mères qui vous jettent leurs filles à la tête); លើកយកមកស្ដីថា (ឧ. jeter à la tête d'un candidat ses anciennes opinions)។ se jeter à la tête de quelqu'un បើកដៃឲ្យភ្លួសហេតុ ។ tenir tête à quelqu'un តស៊ូ ឬ ជំទាស់នឹងអ្នកណាម្នាក់។ tenir la tête ឈ្នះ, បានសម្លេងច្រើនជាង (ក្នុងការបោះឆ្នោត)។ perdre la tête ត្រូវគេកាត់ក្បាល (ឧ. être condamné à perdre la tête); *au fig.* ស្លន់; ទៅជាឆ្កួត ។ avoir toute sa tête មានស្មារតីរឹងប៉ឹង,មិនភ្លេចស្មារតី។ mettre une tête à prix កាត់ថ្លៃក្បាលមនុស្សម្នាក់ (សន្យាថាឲ្យរង្វាន់ដល់អ្នកណាដែលសម្លាប់មនុស្សនោះបាន) ។ fendre ឬ briser la tête à quelqu'un ធ្វើឲ្យវឹងស៊ុំ (ដោយសរៃប្រេក ឬ ស្វាសន្លឹក)។ la tête me fend ខ្ញុំឈឺក្បាលស្ទើរបែក ។ rompre la tête à quelqu'un រំខានអ្នកណាម្នាក់ ។ se rompre la tête គិតស្ទើរបែកក្បាល ។ monter ឬ échauffer la tête à quelqu'un សម្រើបមនោគតិ; ធ្វើឲ្យខឹង។ avoir la tête félée ឬ avoir un coup de hache ឬ un coup de marteau à la tête លេលា, ឆ្កួតបន្តិចៗ ។ tourner ឬ faire tourner la tête à quelqu'un ធ្វើអ្នកណាម្នាក់ឲ្យវិលខួរ; *particul.* ធ្វើឲ្យអ្នកណាម្នាក់ស្រឡាញ់ឆ្កួត ។ la tête lui tourne គាត់នេះវិលមុខហើយ; គាត់នេះវិលខួរហើយ (ឡប់ស្មារតីហើយ; គាត់នេះឆ្កួតហើយ) ។ agir de tête ប្រព្រឹត្តដោយគ្មានគត់ស្លុត ហើយដោយខ្ជាប់ខ្លួន ។ mettre son cœur dans sa tête ធ្វើឲ្យ

ចិត្តទៅក្នុងអំណាចវិញ្ញាណញ្ញាណ ។ avoir la tête près du bonnet ម.ព. bonnet ។ j'y mettrais, je donnerais ma tête à couper ឬ je parierais ma tête ខ្ញុំហ៊ានភ្នាល់ឲ្យកាត់ក្បាលខ្ញុំ ។ ce qu'il a à la tête, il ne l'a pas aux pieds ឬ au talon របស់អ្វីដែលគាត់ចង់បាន គាត់ជំនះទាល់តែបាន ។

Loc. pré. à la tête de ខាងដើម; ជាមេ, ជានាយក (ខ. à la tête d'une armée, d'une affaire) ។ *loc. adv.* tête à tête គូ, តែពីរនាក់ (ខ. causer tête à tête) ។ de tête ដោយចាំមាត់; តាមមនោគតិ (ខ. répéter de tête tout un discours) ។

Escrim. avoir de la tête ចេះបញ្ឆោតនឹងចេះផាត់ ។ *Mil.* tête de pont ម.ព. pont ។ *Mar.* faire tête au vent ឬ au courant បែរមុខទៅរកខ្យល់ឬរកទឹកហូរ ។ tête de vent ខ្យល់ដែលទើបនឹងបក់ ។

Natat. piquer une tête លោតផ្កាំខ្លួនក្នុងទឹក (លោតសំយុងក្បាលទៅក្នុងទឹក) ។

Prov. mal de tête veut paître បើឈឺក្បាលឲ្យបរិភោគ ។ tête de fou ne blanchit pas មនុស្សឆ្កួតមិនស្កូវសក់ (មនុស្សឆ្កួតគ្មានកង្វល់អ្វីនាំឲ្យស្កូវសក់) ។

tête-de-moineau *n.f.* ម.ព. gailletin (*pl.* des têtes-de-moineau) .

tête-à-queue *n.m. inv.* ការប្រះ (ការដែលសេះទីមគេបងាកពីផ្លូវ)

tête-à-tête *n.m. inv.* ការជួបសន្ទនាតែពីរនាក់; កៅអីអង្គុយពីរនាក់; ភាជនភណ្ឌសម្រាប់ពីរនាក់

tête-bêche *loc.adv.* ដោយក្រោសគ្នា (ចំពោះមនុស្សពីរនាក់ ឬ របស់ពីរដែលដេកឬដាក់ផ្ទុយគ្នា ពីក្បាលទៅជើងពីគល់ទៅចុង)

tête-de-loup *n.f.* អំពោសស្លាបសត្វគិះវែង (*pl.* des têtes-de-loup)

tête-de-nègre *n.m.&a. inv.* ពណ៌ក្រមៅ

tétée *n.f.* ការបៅដោះ; ចំនួនទឹកដោះបៅម្ដង

téter *v.t.* បៅដោះ (ខ. enfant qui

ne tête plus)

têtière *n.f.* ប្រាក់ក្បាល (គ្រឿងបង្ហៀរ)

tétin *n.m.* សណ្ដាន់ដោះ

tétine *n.f.* ដោះសត្វ; សណ្ដាន់ដោះកៅស៊ូ

téton *n.m. Fam.* ដោះ

tétracorde *n.f.Mus.* ចតុរាក្សត្រ

tétradactyle *a. Zool.* ដែលមានម្រាមបួន

tétraèdre *n.m.* ចតុផល, ប្រសព្វជ្រុងបួន

tétraédrique *a.* នៃចតុផល; ដោកដងចតុផល

tétragone *a. & n.m.* ចតុកោណ (គេប្រើនហៅ quadrilatère ជាង)

tétramère *a.* ដែលចែកជាបួនភាគ

tétrapode *a.* ចតុប្បទ, ដែលមានជើងបួន

tétraptère *a.* ចតុបក្ខ, ដែលមានស្លាបពីរគូ(ស្លាប ៤)

tétrasyllabe ឬ **tétrasyllabique** *a.* ចតុព្យាង្គ, ដែលមានបួនព្យាង្គ

tétrodon *n.m.* ត្រីពត

tette *n.f.* សណ្ដាន់ដោះសត្វ

têtu,e *a.* មុទាំង, ចចេស, មានះ (ឧ. un enfant têtu) (*ព្ន.* buté, entêté, obstiné, opiniâtre, tenace ។ ព.ផ. docile, obéissant, soumis)

teuf-teuf តេតទ (ស្នូរម៉ាស៊ីន) ។ *n.m. inv. Par ext. & Fam.* ឡាន (រថយន្ត)(ឧ. un vieux teuf-teuf)

texte *n.m.* អត្ថបទ [អ័ត-ថៈ-បត់] (ឧ. citer un texte) ។ restituer un texte ផ្គុំអត្ថបទឡើងវិញ ។ revenir à son texte វិលមកនិយាយពីការដែលត្រូវនិយាយវិញ

textile *a.* វាយនីយ, ដែលត្បាញបាន; នៃវាយនភណ្ឌ (ឧ. industrie textile) ។

n.m. វាយនភណ្ឌ ; សរសៃសម្រាប់ត្បាញ

textuaire *a.* នៃអត្ថបទ

textuel,elle *a.* ត្រឹមត្រូវតាមអត្ថបទ (ឧ.citation textuelle)

textuellement *adv.* តាមអត្ថបទ(គ្មានល្អៀង)(ឧ. citer textuellement un passage)

texture *n.f.* វាយភាព (ភាពជារបស់ត្បាញ; ភាពប្រទាក់គ្នានៃភាគផ្សេងៗ ឧ. texture de la peau; texture d'un roman)

thaï,thaïe *a.* ថៃ (សៀម) ។ *n.m.* ភាសាថៃ

thallophytes *n.f. pl.* សុត្តកូតតាម

thé *n.m.* តែ (ឧ. boire du thé); ការលៀងតែ (ភេសជ្ជៈ) (ឧ. inviter quelqu'un à un thé)

théâtral,e,aux *a.* នៃល្ខោន (ឧ action théâtrale) ។ *Par ext.* ដែលសម្ដែង (ឧ. attitude théâtrale); បំផ្លើស (ដូចលេងល្ខោន)

théâtralement *adv.* ដោយសម្ដែង

théâtre *n.m.* រោងល្ខោន; ល្ខោន (ឧ. aller au théâtre); ល្ខោន, វិធីតែងរឿងល្ខោន (ឧ. les règles du théâtre); ល្ខោន (រឿងល្ខោនទាំងពួងនៃប្រទេសមួយ ឬ នៃអ្នកនិពន្ធម្នាក់) (ឧ. le théâtre grec; le théâtre de Corneille); របរអ្នកលេងល្ខោន (ឧ. se destiner au théâtre)។ *Fig.* កន្លែង (ដែលមានហេតុអ្វីមួយ (ឧ. cette ville fut le théâtre d'un grand événement) ។

Loc. div. coup de théâtre ម.ព. coup ។ théâtre d'opérations យុទ្ធភូមិ, រណរង្គ [រៈ-ណៈ-រង់] (ទីចំបាំង) ។ théâtres d'opérations extérieures (T.O.E.) យុទ្ធភូមិខាងក្រៅ

théâtreuse *n.f.* តួស្រីធុនអន់

thébaïde *n.f.* ភាពស្ងាត់ជ្រងំ (ឧ. vivre dans une thébaïde)

thébaïque *a.* នៃអាភៀន

thébaïsme *n.m.* រោគញៀនអាភៀន

théier *n.m.* ដើមតែ

théière *n.f* ប៉ាន់តែ

théine *n.f.* តែរស, ជាតិជ័រតែ

théïsme *n.m.* ទេវនិយម

théïste *a.* ទេវនិយម។ *n.* អ្នកទេវនិយម

thème *n.m.* វិទ្យានិពន្ធ, រឿងដែលត្រូវតែង (ឧ. traiter un thème ingrat); សកបរិវត្តន៍, ការប្រែភាសាកំណើតជាភាសាដែលរៀន។ fort en thème ឧស្សាហ៍ហើយចេះចាំប៉ុន្តែមិនសូវមានបញ្ញា (ចំពោះកូនសិស្ស)

théocrate *n.m.* អ្នកទេវាធិបតេយ្យ

théocratie *n.f.* ទេវាធិបតេយ្យ

théocratique *a.* នៃទេវាធិបតេយ្យ (ឧ. pouvoir théocratique)

théocratiquement *adv.* ដោយទេវាធិបតេយ្យ

théologie *n.f.* ទេវវិទ្យា [ទេ-វៈ-] (វិទ្យាសាស្ត្រខាងសាសនា, ខាងរឿងអាទិទេព ឧ. la théologie catholique;

ការសិក្សាអំពីអាទិទេព ឧ. faire sa théologie)

théologien *n.m.* ទេវវិទូ (ឧ. saint Thomas reste le plus grand des théologiens catholiques du Moyen Age); សិស្សខាងទេវវិទ្យា

théologique *a.* ខាងទេវវិទ្យា (ឧ. discussion théologique)

théologiquement *adv.* ដោយទេវវិទ្យា

théorématique *a.* ខាងទ្រឹស្ដីបទ (ឧ. sciences théorématiques)

théorème *n.m.* ទ្រឹស្ដីបទ ។ théorème réciproque ទ្រឹស្ដីបទបដិការ

théoricien,enne *n.* អ្នកទ្រឹស្ដី

théorie *n.f.* ទ្រឹស្ដី (ឧ. théorie atomique; théorie politique); មេរៀនខាងវិជ្ជាសឹក (ឧ. écouter une théorie)

théorie *n.f.* ក្បួនហែ (ពួកជនដែលដើរជាថ្នា)

théorique *a.* ខាងទ្រឹស្ដី (ផ.នឹង pratique) (ឧ. discussion purement théorique)

théoriquement *adv.* តាមទ្រឹស្ដី,តាមបរិយត្ត

thérapeute *n.* អ្នកព្យាបាលរោគ

thérapeutique *a.* ខាងតិកិច្ឆា, ខាងវិធីព្យាបាលរោគ (ឧ. agent thérapeutique) ។

n.f. តិកិច្ឆា, វិធីព្យាបាលរោគ

thérapie *n.f.* ម.ព.thérapeutique

thermal,e,aux *a.* នៃឧណ្ហភារ (ឧ. source, station thermale)

thermalité *n.f.* ឧណ្ហភាព (ធម្មជាតិឬគុណសម្បត្តិនៃទឹកទន់និងក្ដៅ)

thermique *a.* នៃកំដៅ (ឧ. l'énergie thermique)

thermochimie *n.f.* ឧណ្ហគីមី

thermodynamique *n.f.* ឧណ្ហកម្លា

thermo-électricité *n.f.* ឧណ្ហអគ្គិសនី

thermo-électrique *a.* នៃឧណ្ហអគ្គិសនី

thermogène *a.* ដែលបង្កើតកំដៅ

thermographe *n.m.* ប្រដាប់ស្ទង់ដំណើរប្រែប្រួលនៃកំដៅ

thermologie *n.f.* ឧណ្ហសាស្ត្រ (វិទ្យាសាស្ត្រខាងកំដៅ)

thermomètre *n.m.* ឧណ្ហមាត្រ (ប្រដាប់ស្ទង់កំដៅ)

thermométrie *n.f.* ឧណ្ហមាត្រា (ការ

ស្ទង់កំដៅ)

thermométrique *a.* នៃឧណ្ហមាត្រា (ឧ. échelle thermométrique)

thermonucléaire *a.* ឧណ្ហបរមាណូ។ bombe thermonucléaire ឬ bombe à hydrogène គ្រាប់បែកឧណ្ហបរមាណូ ឬ គ្រាប់បែកអ៊ីដ្រូសែន

thermos *n.f.* ទែរម៉ូស (ប្រដាប់រក្សាទឹកក្ដៅ ឬ ត្រជាក់)

thermothérapie *n.f.* ឧណ្ហតិកិច្ឆា, ការព្យាបាលរោគដោយប្រើកំដៅ

thésaurisation *n.f.* រតនតិធិការ, ការប្រមូលប្រាក់ទុក

thésauriser *v.i.* ធ្វើរតនតិធិការ, ប្រមូលប្រាក់ទុក (សរ. économiser entasser, épargner)

thésauriseur,euse *a.&n.* រតនតិធិក-កា, អ្នកប្រមូលប្រាក់ទុក; អ្នកចូលចិត្តប្រមូលប្រាក់ទុក

thèse *n.f.* និក្ខេបបទ(ឧ.une pareille thèse ne peut se défendre)

thon *n.m.* ធុន (ត្រីសមុទ្រម្យ៉ាង)

thoracique *a.* ឧរិក, នៃទ្រូង។ cage thoracique ឆ្អឹងឧរិក ។ canal thoracique ប.ព. canal

thorax *n.m.* ឧរ, ទ្រូង

tiare *n.f.* មកុដ។ *Fig.* ឋានៈជាប៉ាប (ឧ. recevoir la tiare)

tibétain,e *a.* នៃប្រទេសទីបេ។ *n.m.* ភាសាទីបេ

tibia *n.m.* ឆ្អឹងស្មងជើង

tibial,e,aux *a.* នៃឆ្អឹងស្មងជើង (ឧ. nerfs tibiaux)

tic *n.m.* និរណ៍ញាក់សាច់មុខ ។ *Fig.* ទម្លាប់អាក្រក់ (ឧ. il a le tic de commencer ses phrases par «eh bien !»

ticket *n.m.* ប័ណ្ណ, ខ្ទង់

tic tac [tik tak] ទិកតាក់ (សូរ) (ឧ. la pendule fait tic tac) ។ *n.m. inv.* សូរទិកតាក់ (ឧ. le tic tac d'un moulin)

tictaquer *v.i.* ឮសូរទិកតាក់

tiède *a.* ឧណ្ហ, សង្ហូន (ក្ដៅបន្តិច) ។ *a.&n. Fig.* ព្រងើយកន្តើយ, មិនស្និទ្ធស្នាល (ឧ. amitié tiède) ។ *adv.* boire tiède ផឹកក្ដៅឧណ្ហ១

tièdement *adv.* ដោយក្ដៅឧណ្ហ១; ដោយព្រងើយកន្តើយ

tiédeur *n.f.* ឧណ្ហភាព (ភាពក្ដៅតិចៗ) (ឧ. la tiédeur de l'eau) ។ *Fig.* ឧបេក្ខា, សេចក្ដីព្រងើយកន្តើយ, ដំណើរមិនស្វះស្វែង (ឧ. la tiédeur des sentiments)

tiédir *v.i.* ឡើងក្ដៅឧណ្ហៗ ។ *v.i.* ធ្វើឲ្យក្ដៅឧណ្ហៗ

tiédissement *n.m.* ឧណ្ហការ, ការធ្វើឲ្យក្ដៅឧណ្ហៗ; ដំណើរឡើងក្ដៅឧណ្ហៗ

tien,enne *a.pos.* ជារបស់ឯង (ឧ. le bien que tu sais tien) ។

Pron. pos. le tien, la tienne របស់ឯង (ឧ. j'ai mes chagrins, tu as les tiens) ។

n.m. របស់ឯង (ឧ. le tien et le mien engendrent de nombreux procès) ។

n.m.pl. les tiens បងប្អូនឯង, ញាតិឯង (ឧ. ne compte absolument sur personne, pas même sur les tiens) ។

Loc. div. y mettre du tien ចេញប្រាក់ឯង (ឧ. tu ne passeras pas pour généreux sans y mettre du tien); បន្ធូរបន្ថយខ្លះ (ឧ. si tu veux aboutir, mets-y du tien); បំផ្លើស, បញ្ចេញបញ្ចូល (ឧ. si tu veux toujours être cru, n'y mets jamais du tien) ។ faire des tiennes ធ្វើអំពើផ្ដេសផ្ដាស

tiercelet *n.m.* ឈ្មោល (បក្សីពាដែលតូចជាងញីបីដង)។ *Fig.* មនុស្សទុនអន់

tiercement *n.m.* ការភ្ជួរជាគម្រប់ ៣ ដង

tiercer *v.t. Agric.* ភ្ជួរជាគម្រប់៣ដង (ឧ. tiercer un champ) (ថា tercer ក៏បាន)

tiers *n.m.* តតិយភាគ, ភាគ៣ (ឧ. le tiers d'une pomme); តតិយជន (ជនទីបីគឺជនដែលគ្មានទាក់ទងក្នុងរឿងជាមួយ) (ឧ. avoir recours à un tiers) ។ *Fam.* le tiers et le quart អ្នកទាំងពួង (ឧ. chacun médit du tiers et du quart)។

Dr. fait d'un tiers អំពើតតិយជន (អំពើបង្កដោយជនដែលមិនទាក់ទងក្នុងរឿងជាមួយ) ។ tiers acquéreur ឬ sous-acquéreur តតិយលទ្ធជន, អ្នកទិញត ។

Loc. div. en tiers ជាតតិយជន (ជាជនទី៣ក្នុងបណ្ដាគ្នា៣នាក់)

(ឧ. être en tiers dans une société)

tiers,tierce *a.* តតិយៈ,ទីបី,ជាគម្រប់បី (ឧ. une tierce personne; un tiers parti)

tiers-point *n.m.* *Techn.* ដែកឆាប ឬ ដែកអារជ្រុងសមុខបី។ *Mar.* ក្តោងបីជ្រុង (*pl.* des tiers-points)

tige *n.f.* ដើម។ tige aérienne ដើមក្រៅដី(ផ.នឹង tige souterraine)។ tige herbacée ដើមជាស្មៅ។ tige ligneuse ដើមជាឈើ។ tige rampante ដើមជាវល្លិ៍។ tige souterraine ដើមក្នុងដី (ផ.នឹង tige aérienne)។ *Fam.* vieille tige អ្នកបើកយន្តហោះជើងចាស់

tigelle *n.f.* *Bot.* ពន្លកដើម (ដែលទើបនឹងដុះចេញពីគ្រាប់)

tiglon *n.m.* ម.ព. tigron

tignasse *n.f.* *Fam.* សក់កន្ទ្រើង(សក់មិនសិតសំអាត)។ *Par anal.* មែកប្រគេងប្រងាង

tigre,esse *n.* ខ្លាធំ, ខ្លាធំបង (cri: le tigre feule, rauque, râle)។ *Fig.* មនុស្សកាចឃោរឃៅ។ jaloux comme un tigre ប្រណែន ឬ ប្រច័ណ្ឌក្រៃពេក

tigré,e *a.* ពាក់បង្កង់(ពពាលឆ្នូតដូចខ្លាធំ) (ឧ. cheval, chat tigré)

tigresse *n.f.* ខ្លាញី (ម.ព. tigre ផង)

tigrer *v.t.* គូរឆ្នូត, គូរបង្កង់(ដូចជាស្បែកខ្លាធំ)

tigron ឬ **tiglon** *n.m.* កូនកាត់ខ្លាសិង្ហ

tilbury *n.m.* រទេះសេះម្យ៉ាងគ្មានដំបូល (*pl.* des tilburys)

timbale *n.f.* ពាំហាល (ស្គរពាស់ស្បែកម្ខាង); ពែង (ធ្វើដោយលោហធាតុ)។ *Fig.* décrocher la timbale បានរង្វាន់

timbalier *n.m.* អ្នកវាយពាំហាល

timbrage *n.m.* ការបិទតែម

timbre *n.m.* កណ្តឹង, ជួង (ឧ. timbre d'une pendule); សម្លេងដោយឡែក; កំពូលមួក។ *Fig.* avoir le timbre fêlé ខួបខ្វរ, ឆ្កួតលេលា។ តែម។ timbre fiscal តែមសារពើពន្ធ

timbré,e *a.* papier timbré ក្រដាសពុម្ព, ក្រដាសតែម។ *Fam.* ដែលខួបខ្វរ, លេលា។ voix timbrée សម្លេងស្រួយល្អ

timbre-poste *n.m.* តែមប្រៃសណីយ៍

(*pl.* des timbres-poste)

timbre-quittance *n.m. inv.* តែមបង្កាន់ដៃ (*pl.* des timbres-quittance)

timbrer *v.t.* បិទតែម (ឧ. timbrer du papier, une lettre)

timide *a.&n.* មង្កុភូត, ខ្មាសៗ, អៀនប្រៀន (ឧ. enfant timide)

timidement *adv.* ដោយខ្មាសៗ, ដោយអៀនប្រៀន

timidité *n.f.* មង្កុភាព, ភាពខ្មាសៗ, ភាពអៀនប្រៀន (ឧ. timidité d'une réponse) (ពាក្យ. embarras, gêne, pudeur ។ ព.ផ. audace, effronterie, hardiesse)

timon *n.m.* ទូករទេះ ។ *Mar.* ចង្កូត

timonerie *n.f. Mar.* កណ្ណដ្ឋាន, កន្លែងដាក់ប្រដាប់សម្រាប់កាច់ចង្កូតនាវា

timonier *n.m. Mar.* កណ្ណធារ [ក័ន-ណា:-], អ្នកកាន់ចង្កូតនាវា

timoré,e *a.* ញញើតញញើម (ពាក្យ. apeuré, craintif)

tinctorial,e,aux [tink-] *a.* សម្រាប់ធ្វើជាថ្នាំជ្រលក់ (ឧ. plante tinctoriale); នៃវិធីជ្រលក់ពណ៌

tine *n.f.* ប្រអប់ ឬ ធុងដែក, ចោត

tinette *n.f.* ធុងលាមក

tintamarre *n.m.Fam.* សូរអឺអរ

tintement *n.m.* សូរកណ្តឹង ឬ ជួង ។ tintement d'oreilles សូរហ៊ឹងត្រចៀក

tinter *v.t.* អង្រួនឬវាយកណ្តឹង ឬ ជួង។ *v.i.* ឮសូរម៉ុងៗ (ឧ. la cloche tinte) ។ *Par anal.* ហ៊ឹង (ឧ. les oreilles me tintent)

tintinnabuler *v.i.* ធ្វើឲ្យឮសូរឌិបព្រោក

tintouin *n.m. Fam.* កង្វល់ (ឧ. affaire qui donne beaucoup de tintouin)

tipule *n.f.* មូសម្យ៉ាងមិនបេះខាំមនុស្ស

tique *n.m.* ឆ្កែ (សត្វល្អិត)

tiquer *v.i.* មានឆ្កៃខាំ ។ *Fig. & fam.* សំដែងអាការភ្ញាក់; បញ្ចេញទឹកមុខមិនសប្បាយចិត្ត

tiqueté,e *a.* ដែលមានសម្បុរអុជៗ (ឧ. oiseau tiqueté)

tiqueture *n.f.* ភាពមានសម្បុរអុជៗ (ឧ. les tiquetures d'un œillet)

tiqueur,euse *n.* អ្នកមានទម្លាប់អាក្រក់

tir *n.m.* ការបាញ់; វិធីបាញ់; កន្លែងហាត់បាញ់ (ឧ. aller au tir) ។

ligne de tir ខ្សែបន្ទាត់បាញ់ ។ angle de tir មុមបាញ់ ។ champ de tir ទីបាញ់; កន្លែងបាញ់រង់ ។ tir à bras francs ការបាញ់ដោយគ្មានផ្អឹងដៃ ។ tir d'enfilade ការបាញ់បណ្ដោយជួរ ។ tir de plein fouet ការបាញ់យកទំហឹង (ឲ្យត្រូវយ៉ាងខ្លាំង) ។ tir plongeant ម.ព. plongeant ។ tir de barrage ម.ព. barrage ។ tir de préparation ម.ព. préparation

tirage *n.m.* ការបាញ់;ការទាញ;ការហូត (លួស) (ឧ. tirage de métaux); ការស្រាវ (ឧ. tirage de la soie); ការចេញ (ឆ្នោត) (ឧ. tirage d'une loterie) ។ tirage au sort ម.ព. sort ។ *Arts graph.* ការផ្ដិតពុម្ព ។ *Phot.* ការផ្ដិតរូបថត ។ *Comm.* បយារ៍ណ ។ droit de tirage ម.ព. droit ។ *Fig.* ការពិបាកដែលត្រូវពុះពារ (ឧ. il y aura du tirage)

tiraillement *n.m.* ការប្រទាញប្រទង់; ដំណើររមួល (ឧ. tiraillement d'estomac ដំណើររមួលពោះ) ។ *pl. Fig. & fam.* ការមិនស្រុះស្រួលគ្នា (ឧ. tiraillement à l'intérieur d'un parti)

tirailler *v.t.* ប្រទាញប្រទង់ (ឧ. les jeunes chiens tiraillent tout ce qu'ils peuvent saisir) ។ *Fig.* ទទូចតៀ (ឧ. se faire longtemps tirailler avant d'acorder quelque chose); នាំឲ្យខ្វល់ចិត្ត (ឧ. une demi douzaine d'affaires très désagréables me tiraillent de tous côtés (Voltaire) ។

v.i. បាញ់រប៉ើសរប៉ស (បាញ់ញយៗហើយឥតបានការ) (ឧ. chasseurs qui ne font que tirailler) ។

se tirailler *v.pr.* ប្រទាញប្រទង់គ្នា (ឧ. enfants qui se tiraillent)

tiraillerie *n.f.* ការបាញ់រប៉ើសរប៉ស

tirailleur *n.m.* *Mil.* ទាហានតាំមុខ; ទាហាន (ក្នុងជំនាន់អាណាព្យាបាលបារាំង) ។ *Fig.* អ្នកធ្វើអ្វីតែម្នាក់ឯងមុនគេ

tirant *n.m.* ខ្សែរូត ។ *Constr.* ធាត់សង (គ្រឿងដំបូល) ។ tirant d'eau

តម្រៅស៊ីទឹក (នាវា) ។ tirant d'air កំពស់ហួសពីទឹក (ស្ពាន)

tirasse *n.f.* បង្គឹងក្រួប

tire *n.f.* vol à la tire ការលួចឆក់ ។ voleur à la tire ចោរឆក់

tiré,e *a.* ស្លក់ (ដោយហត់) (ឧ.figure tirée) ។ être tiré à quatre épingles ស្លៀកពាក់ស្អាតបាត ។ tiré par les cheveux មិនស្រួលបួល, មិនស្រូវទំនង ។

n.m.Comm. បព្វារិត [ប៉ៈ—] ។ tiré d'une lettre de change បព្វារិតរូបិយាណត្តិ ។ *Chass.* សត្វដែលបាញ់បាន; ព្រៃប្រមាញ់ (ព្រៃកំពស់ដំហរមនុស្សសម្រាប់បាញ់សត្វ) (ឧ. les tirés de la forêt de Rambouillet)

tire-au-flanc *n.m.inv.Pop.* មនុស្សកំជិលគេះ; មនុស្សមានពុត

tire-bonde *n.m.* ប្រដាប់ដកឆ្នុកធុង (*pl.* des tire-bondes)

tire-botte *n.m.* ប្រដាប់ដោះស្បែកជើង (*pl.* des tire-bottes)

tire-bouchon *n.m.* ខួងឆ្នុកដប; សក់រួញរមូរ ។ en tire-bouchon រមួលខ្វង់ (ឧ. les vrilles de la vigne sont contournés en tire-bouchon) (*pl.* des tire-bouchons)

tire-bouchonner *v.t.* រុំឡើងខ្វង់ (ដូចខួងឆ្នុកដប) (ឧ. tire-bouchonner un fil de fer) ។

se tire-bouchonner *v.pr.* ស្មើររមួលខ្លួន

tire-boucles *n.m.inv.* ប្រដាប់រំលើងពំណាប់

tire-bouton *n.m.* ប្រដាប់ពាក់ឡេវ (*pl.* des tire-boutons)

tire-braise *n.m.inv.* ប្រដាប់ការរងើកភ្លើង

tire-clou *n.m.* ស្នែងពាស់ដែកគោល (*pl.* des tire-clous)

tire d'aile *n.m.inv.* ការហើរលឿន ។ à tire d'aile *loc. adv.* យ៉ាងលឿន (ឧ.voler à tire d'aile)

tire-laine *n.m.inv.* ឬ **tireur de laine** *n.m. Autref.* អ្នកលួចអាវ (ឧ. le Pont-Neuf, à Paris, fut jadis le rendez-vous des tire-laine)

tire-lait *n.m.inv.* ប្រដាប់បឺតទឹកដោះ

tire-larigot (à) *loc. adv. Fam.*

ច្រើន (ឧ. boire à tire-larigot)

tire-liard *n.m.* ស្វាជិន , មនុស្ស កំណាញ់រឹតត្បិតតិតខ្លាស (*pl.* des tire-liards)

tire-ligne *n.m.* ប្រដាប់ដឹកបន្ទាត់ (*pl.* des tire-lignes)

tirelire *n.f.* បំពង់ឬប្រអប់សន្សំប្រាក់

tire-l'œil *n.m. inv. Fam.* របស់ទាញភ្នែក (របស់ដែលបណ្ដាលឲ្យគេមើល)

tire-moelle [-mo-èl'] *n.m. inv.* ប្រដាប់គ្លុះខួរឆ្អឹង ។ *Arg.* កូនកន្សែង (សម្រាប់ញើសសំពោរ)

tire-monde (Madame) *Pop.* យាយមីប

tire-pointe *n.m. inv. Techn.* ដែកចាក់ប្រហោង (*pl.* des tire-pointes)

tirer *v.t.* ទាញ (ឧ. tirer une corde); អូស (ឧ. cheval qui tire une voiture); ដឹក (ឧ. tirer un cheval par la bride); បញ្ចេញ, យកចេញ (ឧ. tirer l'argent de sa poche); ស្រង់, រើស (ឧ. tirer ses exemples); សៀន (ឧ. tirer la langue); ដឹក(បន្ទាត់)(ឧ. tirer une ligne) ; ផ្ដិត, បោះពុម្ព (ឧ. tirer une estampe); ផ្ដិត(រូបថត)(ឧ. tirer une épreuve); បាញ់ (ឧ. tirer un coup de canon); ហូត(ទាញជាល្វស) (ឧ. tirer l'or ហូតមាស); ហូត, ដក (ឧ. tirer l'épée du fourreau); ស្រាវ ។ *Fig.* ផឹក, បឺត (ឧ. souliers qui tirent l'eau) ។ *Particul.* ចាប់ឆ្នោត (ឧ. tirer les billets, les numéros) ។ *Par ext.* tirer une loterie ចេញឆ្នោត ។

Loc. div. tirer ses bas ក្បិតស្រោមជើង(កុំឲ្យជ្រួញ)។ tirer une chose en longueur ពន្យឺត, ធ្វើឲ្យបានវែង,ធ្វើឲ្យបានយូរ។ *Absol.* tirer à la ligne អធិប្បាយឲ្យវែង (ពីតប្រយោជន៍)។ tirer avantage de យកអត្ថប្រយោជន៍អំពី; បកស្រាយដើម្បីជាអត្ថប្រយោជន៍ខ្លួន (ឧ. on tire avantage de la perversité d'autrui pour se justifier soi-même) ។ tirer parti de យកកម្រៃអំពី ។ tirer de son côte បំបែរជាប្រយោជន៍ខ្លួន ។ *Fig.*

tirer quelqu'un à quatre ទទូចឲ្យអ្នកណាម្នាក់ធ្វើអ្វីមួយ ។ se faire tirer ឲ្យគេអង្វរ ។ tirer quelqu'un de prison ដោះអ្នកណាម្នាក់ចេញពីពន្ធនាគារ(ចេញពីគុក)។ tirer un an de prison ជាប់គុកមួយឆ្នាំ។ *Fig.* tirer quelqu'un d'embarras ឬ d'un mauvais pas ជួយដោះកង្វល់, ជួយដោះក្ដុន ។ tirer une épine du pied ជួយពិបាក្លា; ជួយដោះទុក្ខ ។ tirer son épingle du jeu ដោះខ្លួនដោយប៉ិនប្រសប់ ។ être tiré à quatre épingles ម.ព. épingle ។ tirer les larmes des yeux ធ្វើឲ្យស្រក់ទឹកភ្នែក, ធ្វើឲ្យយំ ។ tirer quelqu'un de l'oubli ធ្វើឲ្យគេស្គាល់អ្នកណាម្នាក់វិញ (មិនឲ្យគេភ្លេច) ។ tirer quelqu'un de la poussière ឬ de la boue ស្រង់អ៊ីពីភក់; ស្រង់អ៊ីពីសេចក្ដីលំបាក ឬ សេចក្ដីវេទនា ។ tirer l'échelle après une personne ឬ une chose ម.ព. échelle ។ tirer les marrons du feu ម. ព. marron ។ tirer sa source ឬ tirer son origine មានប្រភពពី, មានដើមកំណើតពី; ផលិតពូជពង្សពី ។ tirer du sang à ធ្វើឲ្យចេញឈាម, ជញ្ជក់ឈាម ។ tirer les yeux ធ្វើឲ្យរឹងភ្នែក។ faire tirer la langue à quelqu'un ឬ lui faire tirer la langue d'un pied de long បង្អត់របស់ដែលត្រូវការ ។ tirer l'épée ហូតដាវ;ចាប់អាវុធ, ប្រុងប្រៀបនឹងប្រយុទ្ធ។ tirer l'épée comme saint Georges ពូកែគុនដាវណាស់ ។ tirer le cordon ជាគេហបាល ។ tirer le poil à une étoffe សិតសំពត់ឲ្យឡើងរោម ។ tirer sa révérence à quelqu'un គំនាប់អ្នកណាម្នាក់; ឱនខ្លួន, មិនព្រម ។ tirer les vers du nez ស៊ូរធ, ឈ្លបសួរដោយប៉ិនប្រសប់ ។ tirer l'horoscope ទាយតាមផ្នូងផតា ។ tirer les cartes ទាយដោយប៉ូលបៀ ។ tirer raison ឬ satisfaction បង្ខំឲ្យសុំទោស (ឧ. tirer raison d'un insolent) ។ tirer vengeance de សងសឹក។ tirer vanité យកមកអួត។ tirer

une affaire au clair បំភ្លឺរឿងមួយ (បង្ហាញឲ្យយល់ច្បាស់) ។

Arg.mil. tirer son congé ចូលធ្វើទាហានតាមកំណត់ពេល ។ tirer une bordée ឈប់ដោយគ្មានអនុញ្ញាត ។

Comm. tirer une lettre de change បោះរូបិយាណត្តិ ។

Econ. rur. tirer une vache រឹតទឹកដោះគោ។ tirer race បង្កាត់សេះមេ ។

Mar. ស៊ីជម្រៅ (ឧ. un navire qui tire quatorze pieds d'eau) ។ tirer des bordées ម.ព. louvoyer ។ tirer un navire sur terre ទាញនាវាឡើងគោក ។

Loc. prov. il tirerait de l'huile d'un mur គាត់នេះពិតតែពីបំណេញជីរាប ។ on tirerait plutôt de l'huile d'un mur បើបម្រាញ់ប្រេងពីជញ្ជាំងស្រួលជាង (គេះជា ការពិបាកបំផុតក៏នៅតែស្រួលជាងការនេះ)។ *Pop.* on tirerait plutôt un pet d'un âne mort, qu'un sou de sa bourse គាត់នេះកំណាញ់មិនងាយរបេះមួយសេនទេ ។

v.i. ទាញ, ញាក់ (ឧ. tirer sur la bride, sur la corde); ឡើងតឹង, ឡើងរឹង (ឧ. la peau me tire); បាញ់ (ឧ. tirer sur quelqu'un à bout portant); ហាត់បាញ់ (ឧ. tirer de l'arc, de l'arquebuse); រត់(ភៀសខ្លួន) (ឧ. nous sommes découverts, tirons de ce côté (Molière) ។

Par ext. ស្មើរ, ប្រហែល, ស្រដៀង (ពណ៌,សម្បុរ) (ឧ. tirer sur le blanc; *au fig.* des espèces d'émotions tirant à fièvre (Boileau) ។

Loc. div. Fig. tirer sur quelqu'un ពេបជ្រាយឬចំអកឡកអ្នកណាម្នាក់; និយាយដើមពីអ្នកណាម្នាក់។ tirer de long, tirer de large ដើរគ្មានឈប់ (សត្វ); *Par anal.* រត់, គេចខ្លួន ។ en tirant vers ឬ sur ដោយងាកខាង, ដោយតម្រង់ទៅខាង (ឧ. à vingt lieues de la ville en tirant sur la gauche) ។ tirer en lon-

gueur ទៅអន្លាយ (វែងពេក, យូរពេក) (ឧ. cette affaire tire en longueur) ។ tirer à la courte paille ម.ព. paille ។ tirer au flanc ម.ព. flanc (ម.ព. *Arg. mil.* ខាង ក្រោមនេះ)។ tirer à sa fin ម.ព. fin ។ tirer à conséquence ម.ព. conséquence ។ tirer sur ses propres troupes ឬ sur ses gens បាញ់ពួកគ្នាឯង; រក រឿងពួកគ្នាឯង ។ tirer sur quelqu'un à boulets rouges រក រឿងយ៉ាងខ្លាំង។ tirer juste បាញ់ ត្រង់ (ឧ. ce fusil tire juste) ។ il y a encore bien à tirer pour en arriver là នៅមាន ការធ្វើច្រើនមុននឹងដល់ទីបញ្ចប់។ tirer au sort ប្រថុយតាមព្រេងសំណាង។

Arg. mil. tirer au grenadier (ឬ au flanc, au renard ឬ au cul) គេចខ្លួនមិនធ្វើ ការងារ ។

Chass. tirer au vol ឬ tirer en volant បាញ់សត្វកំពុង ហើរ ។ tirer au jugé (ឬ au juger) បាញ់ស្មាន ។

Prov. le vin est tiré, il faut le boire ម.ព. boire ។

se tirer *v.pr.* ប៉ះពាល់ (ឧ. il s'est bien tiré de son rôle);ចេញ (ឧ. se tirer d'un trou) ; ដកខ្លួន, ដោះខ្លួន (ឧ. se tirer d'une situation délicate)។ se tirer arrière ដកថយខ្លួន (ឧ. au lieu de me tirer arrière de l'accusation, je m'y enfonce (Montaigne)។

Loc. div. se tirer d'affaire ម.ព. affaire ។ s'en tirer ឬ s'en bien tirer ជាសះ ស្បើយ, អស់ជំងឺ; រួចពីការពិបាក ។ il se tirerait d'un puits គាត់នេះប្រសប់ដោះកូនណាស់ (ទុក ជាគេទម្លាក់ក្នុងអណ្ដូងក៏ចេញរួចដែរ)

tire-sou *n.m. Pop.* អ្នកទារពន្ធ; អ្នក យកការប្រាក់ហួសប្រមាណ; អ្នកចង់បាន ហួសហេតុ (*pl.* des tire-sous)

tiret *n.m.* រន្ធសញ្ញា, ខ្សែបន្ទាត់ខ្លី

tirette *n.f.* ខ្សែរូត; ក្ដារបិទ (សន្លឹកក្ដារ ស៊កនឹងតុ-ទូ ដែលអាចទាញចេញរុញ ចូលបាន)

tireur,euse *n.* អ្នកបាញ់ (ឧ. un bon, un mauvais tireur); អ្នកទាញ; អ្នកអូស; អ្នកក្លែង (ឧ. tireur d'or អ្នកក្លែងមាស) ។ tireur ឬ tireuse de cartes អ្នកទាយដោយប្លុយបៀ។ *Comm.* បញ្ហើរ[ប៉ះ-ហា-ក៏ក់]។ tireur d'une lettre de change បញ្ហើរបូរិយាបណ្ណ ។ *Mines* tireur de mines កម្មករអណ្ដូងរ៉ែ ។ *Arg.* ចោរឆក់ (ឧ. un adroit tireur) ។

tireur de laine ម.ក. tire-laine ។ tireur au flanc ឬ au grenadier អ្នកគេចខ្លួនមិនធ្វើទាហាន; អ្នកគេចខ្លួនពីការតពួកិច្ច

tiroir *n.m.* ប្រអប់ថត (ថតតុ-ទូដែលទាញចេញចូលបាន)

tisane *n.f.* ថ្នាំជាតិឈើ (ដែលគេត្រាំ, ដាំ ឬ ស្ងោរ) (ឧ. les tisanes se font par macération, infusion ou décoction)

tisanerie *n.f.* កន្លែងធ្វើថ្នាំជាតិឈើ

tison *n.m.* អង្គត់អុស, កន្ទុយអុស (ឧ. éteindre un tison) ។ *Fig.* មេភ្លើង, អ្នកនាំភ្លើង, អ្នកញុះញង់, អ្នកនាំគេឲ្យឈ្លោះគ្នា ។

Loc. div. tison d'enfer មនុស្សគួរនឹងភ្លើងនរក(មនុស្សកំណាច)។ tison (ឬ Brandon) de discorde មេនាំភ្លើង, អ្នកដើមហេតុជម្លោះ ។ garder les tisons, être toujours sur les tisons ឬ avoir toujours le nez sur les tisons នៅតែជិតភ្លើង (យាមកន្ទុយអុស, ឈ្លោកតែភ្លើង) ។ prendre le tison par où il brûle កាន់កន្ទុយអុសពីខាងឆេះ (ចាប់ពស់ពីកន្ទុយ; ចាប់ធ្វើការដោយមធ្យោបាយប្រកបដោយគ្រោះថ្នាក់បំផុត)

tisonné,e *a.* ដែលមានសម្បុរខ្មៅជ្រុំ (សេះ)

tisonner *v.i.* &*t.* បង្កំភ្លើង, ឆ្កឹះភ្លើង(ឲ្យឆេះ) (ឧ. se plaire à tisonner; tisonner le feu)

tisonneur,euse *n.* អ្នកបង្កំភ្លើង, អ្នកឆ្កឹះភ្លើង (ឲ្យឆេះ)

tisonnier *n.m.* ដែកឆ្កឹះភ្លើង

tissage *n.m.* ការត្បាញ (ឧ. le tissage de la toile) ; ពិយនាគារ, រោងត្បាញ (ឧ.un tissage mécanique)

tisser *v.t.* ត្បាញ (ឧ. tisser de la

laine, du coton); ត័ទ្ន (បង់ពីង-ពាង)

tisserand *n.&a.m.* ជាងតម្បាញ

tisserin *n.m.* ចាបព្រៃ

tisseur *n.&a.m.* អ្នកត្បាញ

tissu *n.m.* សំពត់ (ដែលកើតអំពីការត្បាញ); សាច់ (សំពត់) (ឧ. étoffe d'un tissu lâche)។ *Fig.* ភាពប្រទាក់ធ្លាក់គ្នា, ភាពទាក់ទងគ្នាភូរហៃ (ឧ. tissu de mensonges) ។ *Histol.* ជាលិកា ។ tissu adipeux ជាលិកាខ្លាញ់ ។ tissu conjonctif ជាលិកាសន្ធាន (ម.ព. conjonctif ផង)។ tissu nerveux ជាលិកាប្រសាទ ។ tissu osseux អដ្ឋិជាលិកា

tissu,e *a. Fig.* ឈាយ, ផ្សំ ។ dès jours tissus d'or et de soie ជីវភាពសម្បូរសប្បាយ (ដេកលើគំនរមាសគំនរព្រៃ)

tissu-éponge *n.m.* សំពត់សាច់ស្ពោត (*pl.* des tissus-éponges)

tissulaire *a. Histol.* នៃជាលិកា

tissure *n.f.* សាច់ត្បាញ (ការប្រទាក់គ្នានៃអំពោះត្បាញ) (ឧ. tissure serrée)

titan *n.m.* យក្ស (មនុស្ស ឬ របស់ធំសំបើម)។ de titan ធំសំបើម

titanesque ឬ **titanique** *a.* នៃយក្ស, សំបើម (ឧ. effort titanesque)

titi *n.m.Pop.* ទីទី (ក្មេងនៅក្រុងប៉ារីស)

titillation *n.f.* ការអង្អែល; ការធ្វើឲ្យរសើបបន្តិចៗ

titiller *v.t.* អង្អែល; ធ្វើឲ្យរសើបបន្តិចៗ (ឧ. ce vin titille agréablement le palais)។

v.i. រសើបបន្តិចៗ

titrage *n.m.* ការកម្រិតចំនួនវត្ថុធាតុដែលលាយចូល (ឧ. le titrage des alcools)

titre *n.m* បំណងជើង (ឧ. un bon titre); មាតិកា (ភាគនៃសៀវភៅ ឧ. titre IV du code civil); ឋានន្តរ [ថា-ន័ន-ដរ] (ឧ. titre de prince) ។ titre universitaire ឋានន្តរមហាវិទ្យាល័យ ។ ឋានៈ (ឧ. le titre de père); ងារ (ឧ. recevoir son titre de notaire); គោរមងារ ។

Par ext. ប័ណ្ណ (ឧ. titre de rente) ។ titre d'identité អត្តសញ្ញាណប័ណ្ណ ។ titre de

permission ប័ណ្ណអនុញ្ញាត។ *Fin.* មូលប័ត្រ (ឧ. titres négociables)។ ទឹក (មាស, ប្រាក់)។

titre d'alliage ទឹកលោហធាតុបញ្ចូល, កំណត់លោហធាតុសុទ្ធ។

Loc. div. en titre ពេញឋានៈ (ឧ. professeur en titre)។ titre de paiement ប័ណ្ណឲ្យបើក។ à juste titre ដោយយុត្តិធម៌, ចំ, ត្រូវ (គេថា à bon titre ដែរ)។ à titre de *loc. pré.* ក្នុងឋានៈជា (ឧ. recevoir quelqu'un à titre d'ami); ក្នុងស្ថានជា, ដោយគិតជា (ឧ. donner l'argent à titre de prêt)។ à titre d'office ដោយអាស្រ័យងារ (ឧ. présider à titre d'office)។ à titre gratuit ដោយមុធា, ដោយគ្មានថ្លៃ, ទទេ។ à titre onéreux ដោយមូល, ដោយមានថ្លៃ។ sur titre តាមគុណសម្បទ (ដោយមិនបាច់ប្រឡងប្រជែង ព្រោះមានគុណសម្បទគ្រប់គ្រាន់)

titré,e *a.* ដែលមានឋានន្តរ (អភិជនភាព ឬ កិត្តិយស) (ឧ. personnage titré)

titrer *v.t.* ដាក់ឋានន្តរ, ដាក់ងារ (ឧ. titrer un homme); កំណត់ទឹកលោហធាតុ; កម្រិតចំនួនវត្ថុធាតុដែលលាយ។

se titrer *v.pr.* ដាក់ឋានន្តរខ្លួនឯង; ដាក់ងារខ្លួនឯង (ឧ. se titrer marquise)

titubant,e *a.* ទ្រេតទ្រោត

titubation *n.f.* ដំណើរទ្រេតទ្រោត, ដំណើរញ័រជើង

tituber *v.i.* ដើរទ្រេតទ្រោត, ញ័រជើង (ឧ. ivrogne qui titube)

titulaire *n.& a.* សាមីជន, ជនជាម្ចាស់; អ្នកកាន់ដំណែង; អ្នកមានវិញ្ញាបនប័ត្រ។ titulaire de livret à coupon សាមីជននៃខណ្ឌប័ណ្ណ។ membre titulaire ម.ព. membre

titularisation *n.f.* ការតាំងស៊ប់ក្នុងដំណែង

titulariser *v.t.* តាំងស៊ប់ក្នុងដំណែង (ឧ. titulariser un fonctionnaire suppléant)

titus [-tuss] **(à la)** *loc. adv.* ខ្លីស្មើ (របៀបកាត់សក់)

toast ឬ **toste** *n.m.* តូស្ត, ការលើកកែវប្រសិទ្ធពរ (ឧ. porter un toast);

នំប៉័ងចៀនដាក់ប៊ឺរ

toaster ឬ **toster** *v.t.* លើកកែវប្រសិទ្ធពរ

toasteur *n.m.* ក្ដូនខ្នះចៀននំប៉័ង

toboggan *n.m.* ជាររអិលបញ្ជាំង ។ *Par ext.* ផ្លូវរអិល (សម្រាប់ទម្លាក់ទំនិញ); ពន្លូររំអិល(សម្រាប់ក្មេងលេង)

toc *onom.* តុក(សូរ) (ឧ. faire toc toc) ។

n.m. Fam. ការកាឡៃ (ការធ្វើឲ្យដូចមាសឬដូចរបស់បុរាណ) (ឧ. bijou en toc)

tocante *n.f.* ម.ព. toquante

tocard,e *a. Pop.* អាក្រក់, គម្រក់ ។ *n.m. Fam.* សេះប្រណាំងគម្រក់

tocsin *n.m.* សូរជួងជាភេរវសញ្ញា; ជួង

T.O.E. (ពាក្យបំព្រួញនៃ Théâtres d'Opérations Extérieures) ម.ព. théâtre

toge *n.f.* អាវផាយ (សម្រាប់ចៅក្រមមេធាវី ឬ សាស្ត្រាចារ្យ)។*Relig.* ចីពរ

tohu-bohu *n.m. inv.* សូរអ៊ូអែខ្លាំង

toi *pr. pers.* ឯង

toilage *n.m.* ផ្ទៃដី

toile *n.f.* សំពត់ (សំពត់អំបោះ គឺធ្វើអំពីធ្មៃ, ក្រចៅ, កប្បាសក្រៅអំពីសូត្រ); សំពត់(សម្រាប់គូរគំនូរ) ។ *Par ext.* ផ្ទាំងគំនូរ (ឧ. des toiles de Rubens) ។ *Mar.* porter de la toile ម.ព. porter ។ toile d'araignée មងពីងពាង

toilerie *n.f.* កន្លែងធ្វើសំពត់; ជំនួញសំពត់; សំពត់អំបោះ

toilette *n.f.* តុទូសំអាងខ្លួន;ការសំអាត; ការស្អិតស្អាងខ្លួន;កន្លែងលាងដៃ(ក្នុងទីសាធារណៈ); ទីបន្ទោរបង់។ cabinet de toilette បន្ទប់សំអាងខ្លួន ។ marchande à la toilette ស្ត្រីអ្នកលក់គ្រឿងសំអាងខ្លួន ។ គ្រឿងតែងខ្លួន (សម្រាប់ស្ត្រី) (ឧ. aimer la toilette) ។ *Par ext.* សំលៀកបំពាក់ស្ត្រី (ឧ. toilette d'été; toilette de mariée); ចិងដាក់ខោអាវ (សម្រាប់ជាងដេរយកខោអាវទៅប្រគល់ឲ្យគេ)

toiletter *v.t.* សំអាតឲ្យ(ឧ. toiletter un chien)

toilier,ère *n.* អ្នកលក់ឬអ្នកធ្វើសំពត់។ *a.* នៃការធ្វើសំពត់

toise *n.f.* ព្យាម (រង្វាស់បុរាណប្រើនៅប្រទេសបារាំងប្រវែង ១,៩៤៩ម.) (ឧ. mesurer à la toise ឬ avec

la toise); ប្រដាប់វាស់កំពស់មនុស្ស។ *Fig.* ខ្នាត, រង្វាស់ ។ long d'une toise វែងមួយព្យាម, វែងណាស់ (ឧ. des mots longs d'une toise)។ mesurer les hommes à la toise វិនិច្ឆ័យមនុស្សតាមរូបរាង(គិតតែពីមាឌនិងរូបរាង ជាងតម្លៃពិតនៃមនុស្សនោះ) ។ mesurer à sa toise វិនិច្ឆ័យដោយផ្ទឹមនឹងខ្លួនឯង ។ se mesurer à sa toise វិនិច្ឆ័យខ្លួនឯងតាមតម្លៃពិត (មិនពន្លើសគុណូបការរបស់ខ្លួន)

toisé *n.m.* ការវាស់(ការគិតតម្លៃសំណង់ដោយវាស់) (គេប្រើនជា métré ជាង)

toisement *n.m.* ការសម្លឹតសម្លក់

toiser *v.t.* វាស់ ។ *Fig.* & *Fam.* toiser quelqu'un សម្លឹតសម្លក់អ្នកណាម្នាក់ (មើលដោយប្រុងប្រយ័ត្ន ឬ ដោយមើលងាយ)

toison *n.f.* រោមចៀម ។ *Par ext.* រោមសត្វ ។ *Fam.* សក់

toit *n.m.* *Constr.* ដំបូល (ឧ. toit de chaume)។ *Par ext.* ដំបូល, ផ្ទះ (ឧ. le toit paternel); រោង។ *Fig.* crier sur les toits ស្រែកអាក្រាស, ប្រកាសសុសសាយ

toiture *n.f.* *Constr.* គ្រឿងដំបូល; ដំបូល

tôle *n.f.* ដែកបន្ទះ ។ tôle ondulée ដែកបន្ទះកង្កាញ់ ។ *Pop.* គុក

tolérable *a.* គួរអត់ទន

tolérance *n.f.* ការអត់ទន (ឧ. dans la vie sociale, la vertu la plus utile est la tolérance)។ tolérance religieuse ការអត់ទនខាងសាសនា។ *Par ext.* សេចក្ដីត្រាប្រណី (ឧ. ce n'est pas un droit, c'est une tolérance); ភាពទទួល (ភាពនៃសរីរាង្គដែលអាចទទួលវត្ថុខ្លះដោយគ្មានឈឺ) (ឧ. la tolérance aux barbituriques est très variable selon les sujets); ការអត់អាស្រ័យ ,(ដោយមានការខ្វះខាត ឬ លើសលស់) (ឧ. la tolérance dans les monnaies est minime)។ maison de tolérance ពេស្យាស្ថាន, ផ្ទះបន

tolérant,e *a.* ដែលអត់ទន; ដែលត្រាប្រណី

tolérer *v.t.* អត់ទន (ឧ. tolérer des abus); ត្រាប្រណី; ទ្រាំ ឬ បណ្ដោយ

ឲ្យនៅ ឬ ឲ្យធ្វើ (ឧ. tolérer quelqu'un chez soi) (ន័. accepter, endurer, souffrir)

tôlerie *n.f.* ឧស្សាហកម្មដែកបន្ទះ; របស់ធ្វើដោយដែកបន្ទះ

tôlier *n.&a.* ជាងធ្វើដែកបន្ទះ

tollé *n.m.* សម្រែកកំហឹង (ឧ. soulever un tollé général)(*pl.* des tollés)

tomadon *n.m.* ជន្ទ្រញ

tomahawk [to ma·âk] *n.m.* មោង; ពូថៅចំបាំង

tomate *n.f.* ប៉េងប៉ោះ (ដើមប៉េងប៉ោះ; ផ្លែប៉េងប៉ោះ ឧ. la tomate sert à faire des sauces) (ន័. pomme d'amour)

tombac *n.m.* មាសក្លែង (មានលាយស្ពាន់និងស័ង្កសី)

tombale *a.f.* នៃផ្នូរខ្មោច (ឧ. pierre tombale)

tombant,e *a.* ដែលធ្លាក់, ដែលសំយោរចុះ (ឧ. cheveux tombant); ដែលជិតយប់ ។

Loc. div. nuit tombante ព្រលប់ (វេលាជាខាងដើមយប់) ។ jour tombant ក្បាលព្រលប់ (វេលាដែលថ្ងៃទើបអស់ទៅ ហើយយប់ទើបមកដល់) ។

Fig. à la tombante ភ្លាមៗ (ឧ. je ne puis vous donner une réponse à la tombante) (មិនសូវប្រើ)

tombe *n.f.* ផ្នូរ ។ *Par ext.* កន្លែងកប់សាកសព ។ *Fig. & poét.* មរណភាព (ឧ. verser un pleur sur sa tombe ។

Loc.div. descendre dans la tombe ចុះរណ្ដៅ, ស្លាប់ ។ avoir un pied dans la tombe ឈានជើងចូលរណ្ដៅ, ជិតស្លាប់ ។ être au bord de la tombe នៅមាត់រណ្ដៅ, ជិតស្លាប់

tombeau *n.m.* ផ្នូរ (ឧ. tombeau de marbre) ។ *Par ext.* ផ្នូរ, កន្លែងមនុស្សស្លាប់ (ឧ. Cassino fut pendant la dernière guerre le tombeau de nombreux soldats); ទីងងឹត-ស្ងាត់ឬគួរឲ្យព្រួយ (ឧ. une prison est un tombeau)។ *Fig.* មរណភាព, សេចក្ដីស្លាប់ (ឧ. rester fidèle jusqu'au tombeau); កន្លែងឬ

ភាពដែលគ្មានគេស្គាល់ខ្លួនសោះ ដែលគេភ្លេចខ្លួនឈឹង ឬដែលគេបោះបង់ខ្លួន (ឧ. l'isolement est un tombeau) ។

Loc. div. nuit du tombeau មរណភាព, សេចក្តីស្លាប់ ។ portes ឬ porte du tombeau ភាពជិតចុះរណ្តៅ, ភាពជិតស្លាប់ ។ descendre au tombeau ចុះរណ្តៅ, ស្លាប់ ។ *Fig.* se creuser un tombeau ជីកកប់ខ្លួនឯង, ធ្វើឲ្យហិនហោចខ្លួនឯង ។ suivre quelqu'un au tombeau ស្លាប់តាមអ្នកណាម្នាក់, កាន់មរណភាពបន្ទាប់ពីអ្នកណាម្នាក់ ។ mettre ឬ conduire au tombeau ធ្វើឲ្យស្លាប់ ។ tirer quelqu'un du tombeau ជួយឲ្យរួចពីសេចក្តីស្លាប់ ។ courir ឬ rouler à tombeau ouvert រត់ឬបើករថយន្តអស់ល្បឿន (មិនខ្លាចគ្រោះថ្នាក់)។ le tombeau des secrets មនុស្សមាត់ជិតណាស់

tombée *n.f.* ដំណើរធ្លាក់ ។ à la tombée de la nuit នៅពេលព្រលប់, នៅពេលថ្ងៃលិច ។ à la tombée du jour នៅថ្ងៃល្ងាច

tombelle *n.f.* ធ្មឹ

tomber *v.i.* ដួល (ឧ. tomber de haut); ធ្លាក់ (ឧ. tomber de cheval); រលំ (ឧ. maison qui tombe en ruine); រលាយ (ឧ. tomber en poussière); សំរោកចុះ, សំយាកចុះ (ឧ. fruits, cheveux qui tombent); ស្ងប់ (ឧ. le vent tombe); អន់, ស្រាក (ឧ. la fièvre tombe); ចុះអន់ថយ (ឧ. sa puissance tombe); លិច (ឧ. le jour tombe); អស់ (ឧ. faire tomber les difficultés)។

tomber dans ហូរចាក់ (ឧ. le Stung de Pursat tombe dans le Grand Lac)។ tomber sur រលំលើ (ឧ. l'armoire tomba sur lui)។ les regards tombent sur lui ភ្នែកគេទាំងអស់សម្លឹងមើលគាត់ ។ un grand malheur est tombé sur lui គាត់មានទុក្ខធ្ងន់ ។

Loc. div. tomber à plat ដួលផ្កាប់មុខ; *au fig.* ដួល; មិនបានសម្រេច ។ tomber à rien នៅ

សល់តែបន្តិចៗខ្លួច ។ ne pas tomber à terre ឬ par terre ឬ ne pas tomber dans l'oreille d'un sourd មិនមែនឥតគ្មានគេឮទេ។ tomber aux pieds, aux genoux de quelqu'un ឬ à genoux devant quelqu'un ក្រាបទៀបជាទអ្នកណាម្នាក់ ឬ លុតជង្គង់ចំពោះមុខអ្នកណាម្នាក់ (ដោយគោរព ឬ ដោយស្នេហា ដើម្បីអង្វរ) ។ tomber du ciel ម.ព. ciel ។ tomber des nues ម.ព. nue។ tomber de son haut ព.ម. haut ។ les bras m'en tombent ម.ព. bras ។ tomber de fièvre en chaud mal, de la poêle dans la braise, de mal en pis ឬ de Charybde en Scylla កាន់តែធ្លាក់ធុនដាបទៅ។ *Fig.* tomber du côté où l'on penche ទ្រេតទៅខាងណា រលំទៅខាងនោះ; ទទួលផលតែកំហុសរបស់ខ្លួន។ faire tomber les armes des mains ទម្លាក់អាវុធពីដៃ ។ faire tomber la plume des mains à quelqu'un ធ្វើឲ្យប្រុះនិងចាកកាពីដៃ; ដឹកនាំឲ្យលែងនិពន្ធ ។ *Fig.* livre qui tombe des mains សៀវភៅដែលគេទម្លាក់ចោល (លែងអានព្រោះខាស់ចិត្តគេ)។ tomber du haut mal ឆ្កួតជ្រូក។ tomber mort ឬ raide mort ដួលស្លាប់ភ្លាម ។ tomber les quatre fers en l'air ម.ព. fer។ *Triv.* faire tomber son enfant រលូតកូន ។ *Fig.* tomber dans la nasse ចូលស៊ាំង , ចូលអន្ទាក់ ។ tomber dans le sens ឬ dans le sentiment de quelqu'un ស្របតាមយោបល់អ្នកណាម្នាក់ ។ cela tombe sous le sens របស់នោះច្បាស់ណាស់ ។ tomber en désuétude ផុតសម័យ, គេលែងប្រើហើយ។ tomber dans l'indigence ធ្លាក់ទាល់ក្រ។ tomber en disgrace ខូចប្ដីគាប់, ធ្លាក់បុណ្យ ។ tomber dans un piège ឬ dans les filets de quelqu'un ចូលក្នុងអន្ទាក់អ្នកណាម្នាក់ ។ tomber malade ធ្លាក់ខ្លួនឈឺ។ tomber dans le mépris អស់អំណាច (ន. les lois, sans

le secours des armes, tombent dans le mépris): ត្រូវគេមើលងាយ ។ tomber dans l'oubli ត្រូវគេភ្លេច ។ tomber en lambeaux រយះរយាយ ។ tomber en pièces ធ្លាក់បែក; រហែករហេក។ tomber en ruine ធ្លាក់បែក, ទ្រុឌទ្រោម ។ faire tomber quelqu'un en confusion ធ្វើឲ្យអ្នកណាម្នាក់អៀនអន់។ tomber sur le corps à quelqu'un ឬ tomber sur la friperie de quelqu'un និយាយអាក្រក់ពីអ្នកណាម្នាក់; ធ្វើឲ្យអាក្រក់ៗ។ tomber sur ses pieds ឬ tomber debout ដើរៈរួចបានខ្លួន; មិនភ្លាត់ចំណាប់(ម.ព chat និងត្រង់«être comme le chat, qui retombe sur ses pattes») ។ tomber sur les bras de quelqu'un ធ្លាក់លើបន្ទុកអ្នកណាម្នាក់ ។ laisser tomber ទម្លាក់បោល;មិនយកៈ និយាយបញ្ចេញសំដីលេងៗ (ឧ. laisser tomber ses paroles); *au fig.* មិនយកចិត្តទុកដាក់, មិនរវល់ (ឧ.sans cela, laissez les (mes causeries) tomber. (Mme de Sévigné)។ laisser tout tomber លែងរវល់ទាំងអស់។ *Fig. & fam.* laisser tomber quelqu'un លែងរវល់នឹងអ្នកណាម្នាក់ (លែងទាក់ទង)។ laisser tomber un regard sur quelqu'un ងៀកមើលដោយមានមនោសញ្ចេតនាអ្វីម្យ៉ាង (ឧ. laisser tomber sur un malheureux un regard de pitié ងៀងមើលមនុស្សកំសត់ដោយអាណិត) ។ faire tomber la conversation sur នាំនិយាយអំពី ។ tomber sur la poitrine ជាលដល់សួត (ចំពោះរោគក្អកខ្លាំង) ។ tomber au sort ជាប់ឆ្នោតត្រូវខ្លួន។ tomber sous la main de ធ្លាក់ក្រោមអំណាចដៃ ។ tomber sous la main, sous la patte ឬ sous la coupe de quelqu'un ម.ព. patte។ tomber sous la dent ឲ្យគេស៊ីខ្លួន។ tomber bien មកដល់ត្រូវពេលល្អ; យល់ត្រូវ (ពាក្យចំអក) ។ tomber mal មកដល់ខុសពេល; យល់ខុស ។ tomber d'accord ព្រះសម្រុងគ្នា។

tomber dans l'erreur ប្រព្រឹត្តភាន់ច្រឡំ ។ tomber en faute ប្រព្រឹត្តខុស ។

v.t. Fam. ទម្លាក់, បោះពោល។ *Fig.* ផ្តួល, ឈ្នះ (ឧ. tomber son adversaire)

(ស. s'abattre, s'affaisser, s'affaler, choir, dégringoler, s'écrouler)

tomber *n.m.* ល្អប៉ះដី (ក្នុងចំបាប់) (ឧ. gagner par tomber)

tombereau *n.m.* រទេះកប់ ; រទេះ (ចំនួន ឬ ទម្ងន់ដែលល្មមផ្ទុកមួយរទេះ តាន) (ឧ. un tombereau de sable)

tombeur *n.& a.m.Fam.* អ្នកយោកផ្ដួល (ក្នុងកីឡាចំបាប់)

tombola *n.f.* ឆ្នោតវត្ថុ

tome *n.m.* កណ្ឌ

tomenteux, euse *a. Bot.* ដែលដុះរោម (ឬ មមិះ)

tomer *v.t.* ចែកជាកណ្ឌ។ tomer les feuilles បង់លេខកណ្ឌលើសន្លឹកក្រដាស

tommy *n.m.* កូនទាហានអង់គ្លេស (*pl.* des tommies)

tom-pouce *n.m. inv.* តូមពូស (អនុល្បមាឧត្តម)។ *Fam.* ឆ័ត្រ

ton, ta, tes *a. pos.* របស់ឯង

ton *n.m.* សម្លេង (ឧ. jouer dans un ton grave, aigu) ; សំដី (របៀបនិយាយឬសរសេរ) (ឧ. ton noble) ។ *Mus.* តាន ។ *Peint.* ពណ៌ ។ changer de ton ផ្លាស់គំនិត របៀប ឬ សំដី ។ donner le ton តាំងអាទិ៍ ឬ ឲ្យគម្រប់ខាងទម្លាប់ ឬ របៀប ។ bon ton ភាសា ឬ សណ្ដាប់ធ្នាប់អ្នកមានពូជ ។ se donner un ton ធ្វើឫក

tonal, e, als *a. Mus.* នៃសំនៀង

tonalité *n.f.* សំនៀង (ស្ទួរសម្លេង, ទឹកសម្លេង, រសសម្លេង); ពណ៌, សម្បុរ

tondage *n.m.* ការកាត់រោម (ឧ. le tondage des chevaux; le tondage des draps)

tondaille *n.f.* ការកាត់រោមសត្វ; ពិធីកាត់រោមសត្វ

tondaison *n.f.* ម.ព. tonte

tondeur, euse *n.* អ្នកកាត់ ។ *n.f.* គុងដី (កន្ត្រៃកាត់សក់ម៉ាស៊ីន; ប្រដាប់កាត់ស្មៅ ឬ កាត់រោមសត្វ)

tondre *v.t.* កាត់ត្រគិល , កាត់ឡីល,

កាត់រាបគល់ឈើ (ឧ. tondre les buis); កាត់ (ឧ. toudre la laine) ។ *Fig. & Fam.* ឆក់ពន្ធធ្ងន់ហួសពេក (ឧ. tondre les contribuables); កោរ (ឆ្មៀតយកប្រយោជន៍ច្រើនពេក) (ឧ. usurier qui toud ses victimes) ។

Loc.div. se laisser tondre la laine sur le dos ព្រមឲ្យគេធ្វើស្រេចលើខ្លួន; ព្រមឲ្យគេជិះជាន់ ។ il tondrait un œuf កំណាញ់ស្វិតស្វាញ; សក់មួយសរសៃកាត់ប្រៀកជាពីរ ។

Prov. il faut tondre les brebis, et non pas les écorcher គ្រាន់តែកាត់យករោមចៀមបានហើយ កុំឲ្យពន្លាត់ស្បែកវា (កុំបង្ខំអ្នកណាម្នាក់ឲ្យធ្វើហួសពីកម្លាំងខ្លួន) ។ à brebis tondue Dieu mesure le vent ឫ.ព. Dieu

tondu, e *a.* ដែលគេកាត់សក់ (ឬរោម) អស់ ។ pré tondu វាលស្មៅទើបនឹងកាត់ហើយ ។

n. អ្នកដែលគេកាត់សក់ត្រងិល (ឧ. quel est cet affreux tondu?) ។ le Petit Tondu ព្រះបាទណាប៉ូឡេអុងទី ១

tonicardiaque *a.* ដែលធ្វើឲ្យបេះដូងដើរស្រួល

tonicité *n.f.* អាយតពលភាព (ភាពនៃសាច់ដុំដែលមានអាយតពល)

tonifiant,e *a.* ដែលធ្វើឲ្យមានកម្លាំង

tonifier *v.t.* ធ្វើឲ្យមានកម្លាំង (ឧ. les lotions froides tonifient la peau)

tonique *a.* តានិក, ដែលមានសម្លេង (ឧ. syllabe tonique) ។

n.f. Mus. តានិក ។

a. & n.m. ថ្នាំលើកកម្លាំង (ឧ. le quinquina est un tonique)

tonitruant,e *a.* ដែលឮសូរដូចរន្ទះ (ឧ. voix tonitruante)

tonitruer *v.i. & t.* ស្រែកបណ្ដាល (ពិ. brailler, s'égosiller, tonner, vociférer)

tonkinois,e *a.&n.* នៃប្រទេសតុងកឹង

tonnage *n.m. Mar.* ចំណុះ ឬទម្ងន់នាវា

tonnant,e *a.* ដែលលាន់ដូចរន្ទះ ។ voix tonnante សម្លេងលាន់ដូចរន្ទះ

tonne *n.f.* ធុងឈើធំ; ចំណុះធុងឈើធំ;

តោន (១០០០ គ.ក)

tonneau *n.m.* ធុងឈើ; បំពង់ធុងឈើ (ឧ. un tonneau d'huile) ។ *Mar.* តោណូ (រង្វាស់បំពង់នាវាមាន ២,៨៣ ម³) (ឧ. bateau de 1.400 tonneaux); រទេះឡានកង់ពីរ; ការប្រមៀលខ្លួន (ឧ. faire le tonneau) ។ *Aéron.* ការបង្វិលខ្លួន (យន្តហោះ)

tonnelage *n.m.* រឿងដែលទាក់ទងនឹងការធ្វើធុងឈើ

tonnelet *n.m.* ធុងឈើតូច

tonnelier *n.m.* ជាងធ្វើ ឬ ជួសជុលធុងឈើ

tonnellerie *n.f.* របរជាងធុងឈើ ; កន្លែងធ្វើធុងឈើ

tonner *v.imp.* លាន់ស្នូរផ្គរ (ឧ. il tonne assez souvent en été) ។

v.i. បន្លឺស្នូរផ្គរ (ឧ. l'homme croit volontiers que c'est pour lui que Dieu tonne (Michelet) ។ *Par ext.* ឮស្នូរដូចរន្ទះ (ឧ. le canon tonne); និយាយដោយសម្លេងដូចរន្ទះ (ឧ. Mirabeau tonnait à la tribune) ។ *Fig.* សង្កាប់ឡូ, និយាយឡូឡាក (ឧ. tonner contre les abus) ។

Prov. on n'entendrait pas Dieu tonner ស្នូរខ្លះល្អុបស្នូរផ្គរទៀត ។ tant tonne qu'il pleut ផ្គរលួចភ្លៀង; ពុម្រមរួបប្រាកដជាច់ ។

v.t. ច្រៀយជំណឹង (ដោយស្នូរដូចផ្គរ) (ឧ. Et vous, nobles canons qui tonnez la victoire... (De Vigny)

tonnerre *n.m.* ផ្គរ ។ *Par ext.* រន្ទះ (ឧ. le tonnerre tombe d'ordinaire sur les lieux élevés); ស្នូរលាន់ដូចផ្គរ (ឧ. un tonnerre d'applaudissements) ។ coup de tonnerre ព្រឹត្តិការណ៍ចម្លែក ឬ ដែលគេមិនអាចដឹងមុន ។ voix de tonnerre សម្លេងពេញដូចរន្ទះ

tonsure *n.f.* ពិធីកោរសក់ (បួសបួស)

tonsuré, e *a.*& *n.* ដែលកោរសក់ (បួសបួស)

tonsurer *v.t.* កោរសក់បំបួស (ឧ. tonsurer un clerc)

tonte ឬ **tondaison** *n.f.* ការកាត់រោម

ចៀម; រោមចៀមដែលកាត់បាន; រដូវកាត់រោមចៀម

tontine *n.f.* តុងទីន, ហួយ; ប្រាក់ការតុងទីន

tontine *n.f.* ស្លឹកក្ដោបគល់កូនឈើដែលគេយកទៅដាំ

tonton *n.m. Fam.* ពូ, មា

tonture *n.f.* ការកាត់រោមសត្វ; រោមដែលគេកាត់ (ជា tonte ក៏បាន) ។ *Hortic.* ការកាត់ស្មៅ, ការកាត់ដើមឈើ

tonus *n.m.* អាយតពល (ឧ. le tonus règle les attitudes du corps dans les différentes positions)

topaze *n.f.* ត្បូងថៃលឿង

toper *v.i.* ព្រម (ក្នុងការភ្នាល់) (ឧ. il topait partout)។ *Fam.* ព្រម (ឧ. il propose son prix, on y tope (Diderot) ។ tope! ឬ tope-là! ព្រមហើយ ! ។ *Onom.* ទះដៃជាសញ្ញាយល់ព្រម

topette *n.f.* កូនបំពង់ (ឧ. renverser l'encre d'une topette); ចំនួនមួយកូនបំពង់ (ឧ. boire une topette)

top-lever [–lé-veur] *n.m.* (ព. អ.) កាំភ្លើងកាប់ប្រក

topo *n.m. Fam.* ផែនទី (ឧ. le topo d'une maison); ផែនការ; សុន្ទរកថា, សេចក្ដីថ្លែង (ឧ. un long topo)

topographe *n.m.* អ្នកឋានលេខា

topographie *n.f.* ឋានលេខា (ពិពណ៌នាឬផែនទីកន្លែងណាមួយ; វិទ្យាសាស្ត្រខាងធ្វើផែនទី)

topographique *a.* នៃឋានលេខា (ឧ. signes topographiques)

topographiquement *adv.* តាមឋានលេខា

topologie *n.f.* ឋានវិជ្ជា (វិជ្ជាខាងពិនិត្យសណ្ឋានដី និងក្បួនខ្នាតនៃសណ្ឋានដី) (ឧ. la topologie et la topométrie sont les deux éléments de la topographie)

topométrie *n.f.* ឋានគណិត (ការវាស់វែងកន្លែងសម្រាប់ធ្វើផែនទី) (ឧ. la topométrie est l'élément fondamental de la topographie)

toponymie ឬ **topomastique** *n.f.* ឋាននាមវិទ្យា

toquade *n.f. Fam.* ចិត្តសាវ៉ា; ទម្លាប់ប្លែក

toquante *n.f. Pop.* នាឡិកា

toquard,e *a. & n.* ម.ព. tocard

toque *n.f.* កាតិប (សម្រាប់ចៅក្រម ឬ មេចារី)(ឧ. toque de magistrat)

toqué,e *a.&n. Fam.* ដែលងប់ (ឧ. toqué de politique); លលា, ស្ទើរឆ្កួត

toquer *v.t. Fam.* ពាក់កាតិប ។ se toquer de *v.pr. Fam.* ងប់នឹង (ឧ. se toquer d'une personne)

toquet *n.m.* កូនកាតិប ។ *loc. adv.* en avoir dans le toquet ស្រវឹង

torche *n.f.* ចន្លុះ; រនុក (ពី troche ក៏បាន); កន្ទបជូត ។ *Fig.* ភ្លើង (រឿងហេតុនាំឲ្យទាស់ទែងគ្នា) (ឧ. allumer les torches de la guerre civile)

torcher *v.t.* ជូតសំអាត ។ *Pop.* ប្រឡិមប្រឡុំ

torchère *n.f.* កាជើងដាក់ប្រេងអុជ

torchette *n.f.* កូនកន្ទបជូត ។ *Loc. fam.* net et clair comme torchette ស្អាតដូចកន្ទបជូតក្តារ (កខ្វក់ណាស់; សំញ៉ាំណាស់)

torchis *n.m.Constr.* គោម័យ(លាយអាចម៍គោលាយដីឥដ្ឋនឹងចំបើង)

torchon *n.m.* កន្ទបជូត ។ *Fam.* ស្ត្រីកខ្វក់ (ឧ. c'est un vrai torchon) ។

Loc. div. être fait comme un torchon ស្លៀកពាក់យ៉ាងកខ្វក់ ។ le torchon brûle មានការទាស់ទែងគ្នាក្នុងគ្រួសារ ។ *Pop.* se mettre dans ses torchons ដេក ។ se flanquer un coup de torchon ប្រវាយគ្នា

torchonner *v.t.* ជូត (ដោយកន្ទប) (ឧ. torchonner la vaisselle)។ *Fig. & Pop.* ធ្វើប្រឡិមប្រឡុំ, ធ្វើដោយខ្ជីខ្ជា

tordage *n.m. Ind.* ការក្រវៀរសូត្រ

tordant,e *a. Fam.* ចំឡែក; កំប្លែង

tordeur,euse *n.* អ្នកក្រវៀរ (សូត្រ ឬ អំបោះ) ។ *n.f.* ម៉ាស៊ីនវេញពួរ

tord-nez *n.m. inv.* ប្រដាប់មួលច្រមុះសេះ

tordoir *n.m.* កូន(ឬមេ) កំព្រា (កំណាត់ឈើ ឬ កំណាត់ឬស្សីសម្រាប់រឹតក្រវែង

ខ្សែ)

tordre *v.t.* វេញ (ឧ. tordre du fil)។ មួរ; ពួត (ឧ. tordre du linge); មួល (ឧ. tordre le bras à quelqu'un)។ *Fig.* មួលបង្កាច់; បកស្រាយខុស (ឧ. ils tordent une phrase d'Hippocrate (Voltaire) ។

Loc. div. tordre le cou ឬ la vis មួលក,កាច់ក (ឧ. tordre le cou à un poulet)។ *Pop.* tordre le cou à une négresse ផឹកស្រាទំពាំងបាយជូរក្រហមមួយដប ។ tordre l'échine លុតក្រាប ។ ne faire que tordre et avaler ស៊ីរឡេបរឡប់ ។

se tordre *v.pr.* រមួលខ្លួន (ឧ. il se tord convulsivement; serpent qui se tord)។

Loc. div. se tordre les mains ឬ les bras កាច់ដៃខ្លួនឯង (ដោយអស់សង្ឃឹម) ។ *Pop.* rire à se tordre les côtes ឬ à se tordre សើចរមួលខ្លួន, សើចទន់ខ្លួន

toréador *n.m.* អ្នកប្រយុទ្ធនឹងគោ (ពាក្យអេស្ប៉ាញ៉ុលថា torero)

toréer *v.i.* ធ្វើជាអ្នកប្រយុទ្ធនឹងគោ

toreutique *n.f.* ចម្លាក់ (លើឈើ,ភ្លុក, លោហធាតុ)

torgniole ឬ **torgnole** *n.f. Pop.* ការទះ, ការដាល់ (ឧ. recevoir une torgniole ត្រូវមួយដៃ គឺត្រូវគេទះ ឬ ត្រូវគេដាល់មួយដៃ)

torii *n.m.* តូរី (ខ្លោងទ្វារវិហារជប៉ុន)

toril *n.m.* កន្លែងបង្ខាំងគោជាមុនពេលប្រយុទ្ធ

tornade *n.f.* បក្រាភិត,ព្យុះសង្ឃរា

toron *n.m.* ធ្លុង (ខ្សែ) (ឧ. la réunion de plusieurs torons forment un cordage)

toronneuse *n.f.* ម៉ាស៊ីនត្រដាញ់ធ្លុងខ្សែ

torpédo *n.f.* ទ័រប៉េដូ (រថយន្តដែលបើកដំបូល)

torpeur *n.f.* ភេតស្ពុល, ភាពស្រយុតស្រយង់ (ឧ. tomber dans la torpeur) ។ *Par ext.* ភាពស្ពុលនៃចិត្ត (ឧ. tirer un homme de sa torpeur) (*ftf.* assoupissement, léthargie, somnolence)

torpide *a.* ស្ពុល, ស្រយុតស្រយង់ (ឧ.

la pluie les a rendus torpides (V. Jacquemin)

torpillage *n.m.* ការបាញ់គ្រាប់បែកពុក (ឧ. le torpillage d'un cuirassé); ការបំផ្លាញគ្រោងការ

torpille *n.f. Art. mil.* គ្រាប់បែកពុក

torpiller *v.t.* បង្កប់គ្រាប់បែក (ឧ. torpiller une rade); បាញ់គ្រាប់បែកពុក (ឧ. torpiller un navire) ។ *Fig.* បំផ្លាញគ្រោងការ (ឧ. torpiller un projet de loi)

torpilleur *n.m.* នាវាបាញ់គ្រាប់បែកពុក (*a.* bateau torpilleur); អ្នកបាញ់គ្រាប់បែកពុក (*a.* marin torpilleur)

torque *n.f.* បង្ហាយល្អួស

torréfacteur *n.m.* ប្រដាប់លីង (ឧ. torréfacteur à café)

torréfaction *n.f.* ការលីង

torréfier *v.t.* លីង (ឧ. torréfier du café)

torrent *n.m.* ជលវេគ, ជ្រោះ; ខ្សែទឹកហូរខ្លាំង ។ *Fig.* ដំណើរហូរខ្លាំង (ឧ. torrent de larmes)

torrentiel,elle *a.* នៃជ្រោះ (ឧ. des eaux torrentielles); នៃខ្សែទឹកហូរខ្លាំង; ដែលធ្លាក់ខ្លាំង (ឧ. pluie torrentielle)

torrentiellement *a.* ដូចទឹកជ្រោះ

torrentueux,euse *a.* ខ្លាំង(ដូចជ្រោះ) (ឧ. rivière torrentueuse)

torride *a.* ក្តៅហែង (ឧ. climat torride)

tors, e *a.* រមួល (ឧ. fil tors); វៀចវង់ (ឧ. des jambes torses) ។ *n.m.* ការវេញ

torsade *n.f. Techn.* រវេរាលរមួល; របស់អ្វីដែលរមួល

torsader *v.t.* វេញ (ឧ. torsader des brins d'osier)

torse *n.m.* ដងខ្លួន; បញ្ឈាក់ ឬ ចំនួនដងខ្លួន

torsion *n.f.* ការមួរ, ការគា, ការវេញ; ការរមួល

tort *n.m.* កំហុស (ឧ. tous les torts sont de son côté)។ avoir tort ខុស ។ faire tort à ធ្វើឲ្យខូចខាតដល់; លួចសិទ្ធិ; បន្តោក។ faire tort de quelque chose ធ្វើឲ្យខាត, ធ្វើឲ្យបាត់បង់ (ឧ. ne pas faire tort d'un sou à quelqu'un) ។ បំពាត់ ឬ ដកហូតដោយអយុត្តិធម៌ ។

Loc. div. donner tort à quelqu'un ឲ្យអ្នកណាម្នាក់ខុស (ប្រកាសថាអ្នកនោះប្រព្រឹត្តខុស) ។ se donner des torts ប្រព្រឹត្តខុស ។ mettre quelqu'un dans son tort ធ្វើឲ្យអ្នកណាម្នាក់ទទួលខុសជំនួសខ្លួន ។

Loc. adv. à tort ដោយខុស, ដោយមិនត្រូវ, ដោយអយុត្តិធម៌ (ឧ. c'est à tort que vous vous effrayez) ។ à tort et à droit ម.ព. droit ។ à tort ou à raison ដោយខុសក្តីត្រូវក្តី ។ à tort et à travers ទទឹងទទែង, ប្រទេងប្រទាង (ឧ. parler à tort et à travers) ។

Prov. les absents ont toujours tort អ្នកមិននៅចាំតែខុស

torticolis *n.m.* កប៉ាក់

tortillage *n.m.* ការក្រញួញ ។ *Fig. & Fam.* ការនិយាយមិនច្បាស់លាស់, ការនិយាយពង្វាង

tortillard *n.m. Fam.* អយស្ម័យយានតូច (សម្រាប់បើកតាមផ្លូវបត់បែន)

tortille *n.f.* ផ្លូវបត់បែន (ក្នុងសួន) (ថា tortillère ក៏បាន)

tortillement *n.m.* ការក្រញួញ; ភាពក្រញាញ់

tortiller *v.t.* ក្រញួញ (ឧ. tortiller une corde) ។

v.i. ពង្វាង; ប្រើឧបាយកល ។ tortiller des hanches ពត់បង្កេះ (ក្នុងដំណើរ) ។

se tortiller *v.pr.* ពេន (ពស់); រមួលខ្លួន

tortillère *n.f.* ម.ព. tortille

tortillon *n.m.* របស់រមួល (ឧ. un tortillon de cheveux); រង្វេល, ភ្នួន; ទំកង ។ *Techn.* ប្រដាប់អុតសក់; រមូរក្រដាសសម្រាប់ផាត់ពណ៌

tortionnaire *a.* សម្រាប់ធ្វើទារុណកម្ម (ឧ. appareil tortionnaire) ។ *Dr.* ដែលជាទារុណកម្ម (ឧ. emprisonnement tortionnaire) ។

n.m. ពៅក្រមអ្នកបង្គាប់ឲ្យធ្វើទារុណកម្ម (ឧ. les tortionnaires de l'Inquisition) ។ *Par ext.* អ្នកធ្វើទារុណកម្ម

tortionnairement *adv.* ជាទារុណកម្ម

tortis *n.m.* ខ្សែវេញ (ឧ. un tortis de chanvre)

tortois,e *a.* ដែលមានភាពដូចអណ្ដើក (ឧ. tente tortoise)

tortu,e *a.* វៀច (ឧ. arbre tortu); កោង (ឧ. nez tortu); ខូច ។ bois tortu ដើមទំពាំងបាយជូរ ។ *Fig.* វៀចវេរ (ឧ. esprit tortu)

tortue *n.f.* អណ្ដើក ។ *Fig.* à pas de tortue ដើរដូចអណ្ដើក, យ៉ាងយឺតៗ

tortuer *v.t.* ពត់, មួល (ឧ. tortuer une aiguille)

tortueusement *adv.* ដោយបត់បែនៗ *Fig.* ដោយវៀចវេរ (ឧ. agir tortueusement)

tortueux,euse *a.* បត់បែន, ក្រវិចក្រវៀន (ឧ. sentier tortueux)។ *Fig.* វៀចវេរ (ឧ. conduite tortueuse) (ក.ផ. droit)

tortuosité *n.f.* ភាពវៀច ឬ កោង ។ *Fig.* ភាពវៀចវេរ

torturant,e *a.* ដែលធ្វើទារុណកម្ម

torture *n.f.* ទារុណកម្ម ។ *Fig.* ការកើតទុក្ខខ្លាំង ។ se mettre l'esprit à la torture ធ្វើអ្វីមួយដោយយកចិត្តទុកដាក់ខ្លាំង ។ mettre quelqu'un à la torture ធ្វើឲ្យពិបាក ឬ ឲ្យអន្ទះសា

torturer *v.t.* ធ្វើទារុណកម្ម (ឧ. torturer un accusé) ។ *Fig.* ធ្វើឲ្យខ្វល់ខ្លាំង (ឧ. la jalousie torture l'homme); ពង្វាងសេចក្ដី ឬ ពង្វាងន័យខ្លាំង (ឧ. torturer un texte)

torve *a.* ដែលសម្លក់

tory *n.m.&a.* តូរី, អ្នកអភិរក្សនិយម(នៅប្រទេសអង់គ្លេស)(*pl.* des tories)

torysme *n.m.* អភិរក្សនិយម (នៅប្រទេសអង់គ្លេស)

tôt *adv.* ឆាប់, រហ័ស (ឧ. se coucher tôt) ។ tôt ou tard មិនយូរមិនឆាប់, ក្នុងថ្ងៃណាមួយ ។ plus tôt que plus tard យ៉ាងប្រញាប់, គួរតែប្រញាប់

total,e,aux *a.* ទាំងស្រុង, បូករួម, សរុប ។ *n.m.* ចំនួនសរុប ។ total des notes ពិន្ទុសរុប ។ au total ដោយសរុប (ឧ. au total, c'est une bonne affaire) (*tif.* complet, entier)

totalement *adv.* ទាំងស្រុង, ទាំងអស់, រលីង

totalisateur ឬ **totaliseur** *n.m.*

ប្រដាប់បូកសរុប

totalisation *n.f.* ការបូកសរុប

totaliser *v.t.* រកចំនួនសរុប, បូកសរុប (ឧ. totaliser des chiffres)

totalitaire *a.* សមគ្គនិយម [សៈ-ម៉ៈ-គ្គៈ-] (នៃលទ្ធិផ្តាច់ការ)

totalitarisme *n.m.* សមគ្គនិយម (លទ្ធិផ្តាច់ការ)

totalité *n.f.* ចំនួនសរុប, ចំនួនទាំងមូលឬទាំងស្រុង (ឧ. la presque totalité des hommes)។ en totalité ទាំងអស់

totem *n.m.* តូតិម (សត្វដែលជាដើមសន្តតិវង្ស)

totémique *a.* នៃតូតិម

totémisme *n.m.* តូតិមនិយម (និយមជឿតូតិម)

toto *n.m.* *Arg. mil.* ចៃ

toton *n.m.* អាចៀង។ *Fig.* faire tourner quelqu'un comme un toton បង្វិលអ្នកណាម្នាក់ដូចអាចៀង (តាមតែប្រើឲ្យធ្វើអ្វីក៏ធ្វើតាមទាំងអស់)

touage *n.m.* *Mar.* ការអូសនាវ; ថ្លៃអូសនាវ

touaille *n.f.* ប្រដាប់ជូតដៃ

toubib *n.m.* *Pop.* គ្រូពេទ្យ

toucan *n.m.* កេងកង (បក្សី)

touchant *pré.* ចំពោះរឿង, ដែលទាក់ទងដល់ (ឧ. touchant vos intérêts)

touchant,e *a.* ដែលឲ្យរំភើបចិត្ត, ស្រងោច(ឧ.discours touchant)

touchau ឬ **toucheau** *n.m.* ប្រដាប់សាកមាសប្រាក់ (ស្លាកជាផ្កាយធ្វើអំពីមាសឬប្រាក់ ត្រង់និមួយៗមានទឹកមាសឬ ប្រាក់ខុសៗគ្នា)

touche *n.f.* ការស្ទាប, ការពាល់; រំពាត់ដេញគោ (បាក់ឲ្យគោដើរលឿន)។ *Pop.* ទំនង, ភាព, រូប (ឧ. une drôle de touche); ផ្ទៃព្រួច (គ្រឿងភ្លេង-ម៉ាស៊ីនអង្គុលីលេខ); ការសាកមាស។ pierre de touche ថ្មសម្រាប់សាកមាសនឹងប្រាក់; *fig.* គ្រឿងពិសោធ(ឧ. l'adversité est la pierre de touche de l'amitié)។ *Peint.* របៀបដាក់ពណ៌ (ឧ.touche légère)។ *Par anal.* របៀបថ្លែងយោបល់(នៃអ្នកនិពន្ធម្នាក់)។ *Sports* ព្រំខាងនៃធ្លាទាត់បាល់; ដំណើរបាល់ចេញហួសព្រំធ្លា។ *Escr.* ការបាក់ត្រូវបច្ចាមិត្រ (ក្នុងគុនដាវ)។

La Sainte-Touche ថ្ងៃបើកប្រាក់

touche-à-tout *n.m. inv. Fam.* អ្នកធ្វើគ្រប់មុខ; អ្នកចូលលូកទ្បុកនឹងការគ្រប់មុខ

toucher *v.t.* ស្ទាប,ពាល់ (ឧ. toucher un objet du doigt) ។ *Escr.* ចាក់ត្រូវ(ឧ. toucher son adversaire) ។ toucher les bœufs ចាក់ (ឲ្យគោដើរលឿន) ។ នៅជិតគ្នា, នៅជាប់គ្នា (ឧ. ma maison touche la vôtre); ទទួល; បើកប្រាក់ (ឧ. toucher de l'argent) ។ *Fig.* ទាក់ទងនឹង (ឧ. cela ne me touche en rien); ធ្វើឲ្យរំភើប; ធ្វើឲ្យយកចិត្តទុកដាក់ពល់ (ឧ. son sort me touche); ជាញាតិ (ឧ. il me touche de près គាត់ជាញាតិជិតនឹងខ្ញុំ) ។ *Fam.* ថា, ប្រាប់, និយាយ (ឧ. je lui en toucherai un mot) ។

v.t. ind. (à) ចាប់, កាន់, ពាល់ (ឧ. cet enfant touche à tout); ពល់,ទើស,ប៉ះ (ឧ. toucher au plafond); ហៀបនឹងពល់,ហៀបនឹងសម្រេច(ឧ. toucher au port, à sa fin); នៅជិត (ឧ. sa maison touche à la mienne); ពាល់ (អាស្រ័យ)(ឧ. il n'a pas touché à son déjeuner); កែប្រែ (ឧ. toucher à un règlement) ។ n'avoir pas l'air d'y toucher ធ្វើសោះអង្គើយ, ធ្វើខ្លី, មិនរវល់នឹង; លាក់គំនិត (សរ. palper, tâter, tâtonner, attendrir, bouleverser, impressionner) ។

n.m. toucher កាយវិញ្ញាណ, ផោដ្ឋព្វៈ; វិធីលេង (គ្រឿងភ្លេង)

touchette *n.f.* ខ្ទង់ (ចាប៉ី)

toucheur *n.m.* អ្នកបរសត្វ

touée *n.f. Mar.* ប្រវែងខ្សែសណ្ដោង; ប្រវែងខ្សែយុថ្កា (ដែលទម្លាក់ចុះទៅក្នុងទឹក)

touer *v.t. Mar.* សណ្ដោង; អូស

toueur,euse *a.&n.* សម្រាប់សណ្ដោងឬអូសនាវា(ឧ. un bateau toueur)

touffe *n.f.* ចុម្ព,ជង្គុំ (ឧ. une touffe d'herbe); ជុំ (ឧ. une touffe de cheveux)

touffeur *n.f.* បំហាយក្ដៅកាយមកលើមុខ (កាលណាគេចូលទៅក្នុងទីក្ដៅ)

touffu,e *a.* ក្រាស់,ញឹក,ស៊ុបទ្រុប,ដុក (ឧ. bois touffu; arbre touf-

fu)" *Fig.* សាញ៉ាំ (ឧ. discours touffu)

touillage *n.m.* ការលាយ, ការច្របល់

touiller *v.t.* លាយ, ច្របល់ (ឧ. touiller la fécule)

toujours *adv.* ជានិច្ច; ជាដរាប (ឧ. il est toujours prêt à faire son devoir); ជានិច្ច, ដដែល(នៅមានក្នុងបច្ចុប្បន្នកាល) (ឧ.il l'aime toujours); សិនទៅ (ឧ. payer toujours, nous verrons après); យ៉ាងណាក៏ (ឧ.toujours est il que...) ។ pour toujours ជាស្ថាពរ, ជាដរាបរៀងទៅ

toundra *n.f.* ទុនដ្រា (ប្រជុំភូតតាមនៅប្រទេសមានអាកាសធាតុត្រជាក់) (មើ. barren grounds)

toupet *n.m.* ផ្សុក, កំប៉ោយ ។ *Fig.* & *Fam.* avoir du toupet ហ៊ាន, ព្រហើន

toupie *n.f.* ខ្វី ។ *Techn.* ដែកល្បូសលកកន្លួត (ហៅ toupilleuse ក៏បាន)

toupiller *v.i.* វិល (ដូចខ្វី) ។ *v.t.* *Techn.* លកកន្លួត

toupilleuse *n.f.* ម៉ាស៊ីនលកកន្លួត (មើ. toupie)

toupillon *n.m.* សំណុំ (រោម ឬ ស្លាប) (ឧ. toupillon de barbe); បញ្ចុំមែកឈើ

touque *n.f.* ធ៉ោក (ឧ. une touque de pétrole)

tour *n.f.* ប៉ម, ណេន ។ *Aéron.* tour de contrôle ណេនត្រួតពិនិត្យ ។ tour de garde ណេនយាម ។ *Jeux.* ទូក (កូនប្រគ្គ)

tour *n.m.* ជុំ (ឧ. tour de roue; faire le tour de la ville) ។ *Par ext.* ការដើរលេង (ឧ. faire un tour); កង, ខ្សែក (ឧ. un tour du cou); អំពើទាំងឡាយដែលប្រើកំឡាំង ប្រើការប៉ិនប្រសប់ ឬការហ៊ាសរហ្វូន (ឧ. tour de bateleur) ។ *Fig.& Fam.* ល្បិច (ឧ. jouer un bon tour); អាការៈក្រៅ, លំនាំ (នៃកិច្ចការអ្វីមួយ) (ឧ. cette affaire prend un mauvais tour); របៀបថ្លែងយោបល់ (ឧ. tour original); វេន (ឧ. parler à son tour); ជើងក្រឡឹង ។

Loc. div. jouer un bon

tour លេង។ jouer un mauvais tour ធ្វើបាប, បោកប្រាស់ ។ à tour de bras ដោយអស់ទំហឹងដៃ។ en un tour de main ឬ en un tournemain ក្នុងមួយភ្លែត ។ tour de main ការប៉ិនប្រសប់ (ដោយថ្នឹក) ។ tour de bâton កម្រៃខុសច្បាប់ ។ tour de force ការពិបាកដែលធ្វើបានដោយប្រឹងប្រែងខ្លាំង ។ tour de reins ការរញ្ជួះត្រគាក ។ tour de vis ការមួលរឹតខ្ចៅ ។ *Fig.* fait au tour ដែលធ្វើបានល្អ ។ tour à tour *loc. adv.* ម្ដងម្នាក់, ដោយផ្លាស់វេនគ្នា

touraille *n.f.* ឡសម្ងួតគ្រាប់ធញ្ញជាតិ (កុំឲ្យដុះ)៖ គ្រាប់សម្ងួតក្នុងឡ

touraillon [–ra-yon] *n.m.* ពន្លកព្រៀម (ដោយពេលសម្ងួតក្នុងឡ) (ឧ. le touraillon s'emploie comme engrais et pour la nourriture du bétail)

tourbe *n.f.* ឥន្ធនសិលា, ធ្យូងថ្មខៅ (ធ្យូងថ្មដែលមានផ្សែងនឹងឆេះច្រើន)

tourbe *n.f.* បន (ជនថោកទាប) (ឧ. la tourbe des intrigants)

tourbeux, euse *a.* ដែលមានឥន្ធនសិលា (ធ្យូងថ្មខៅ) (ឧ. marais tourbeux)

tourbier *n.m.* កម្មករកោលឥន្ធនសិលា (ធ្យូងថ្មខៅ)

tourbière *n.f.* ឥន្ធនសិលាដ្ឋាន,កន្លែងយកធ្យូងថ្មខៅ

tourbillon *n.m.* ខ្យល់កំបុតត្បូង, ខ្យល់កួច; ទឹកកួច; វត្ថុដែលហុយកួចឡើង (ឧ. tourbillon de fumée)។ *Fig.* កង្វល់ (អ្វីៗដែលនាំមនុស្សឲ្យរវល់ខ្វល់)(ឧ. le tourbillon des affaires)

tourbillonnant,e *a.* ដែលកួច, ដែលវិល

tourbillonnement *n.m.* ដំណើរកួចឬវិល ។ *Fig.* ដំណើររំជួលខ្លាំង, ដំណើររវល់ខ្វល់

tourbillonner *v.i.* កួច, វិល (ឧ. eau qui tourbillonne)។*Fig.* រំជួលខ្លាំង, រវល់ខ្វល់

tourdille *a.* ឆ្នូក (ប្រផេះលាយលឿងការមានទង់ដែងរុងរឿង) (ប្រើជាមួយនឹងពាក្យ gris) (ឧ. un cheval gris tourdille)

tourelle *n.f.* ប៉ម

tourillon *n.m.* ពន្លួញ, ស្នូល (សម្រាប់បង្វិល)

touret *n.m. Techn.* គ្រឿងបក្រ (មានកង់ធំ នឹង កង់តូចឲ្យវិលញាប់); រហាត់ធ្វើញខ្សែ ឬ ពួរ (រហាត់រវៃវេញខ្សែ); កន្ត្រឡង (ប្រដាប់ទ្រឡងបង្វិលខ្លួ)

tourier, ère *a. & n. Autref.* អ្នកយាមប៉ម (ក្នុងអាភិស) (ឧ. frère tourier)។ sœur tourière ដូនជីអ្នកទាក់ទងនឹងជនក្រៅអាភិស

tourisme *n.m.* ទេសចរណ៍ (ឧ. le tourisme international permet aux peuples de se mieux connaître); បញ្ហាទេសចរណ៍

touriste *n.* ទេសចរ

touristique *a.* ជាទេសចរណ៍ (ឧ. voyages touristiques); ដែលទាញទេសចរ (ឧ. villes touristiques)

tourment *n.m.* ទារុណកម្ម, ដំណើរឈឺចាប់ខ្លាំងលើរាងកាយ (ឧ. souffrir d'affreux tourments)។ *Fig.* កង្វល់, រវល់, ការតប់ប្រមល់, សេចក្ដីព្រួយខ្លាំង (ឧ. cette affaire lui a donné bien du tourment)

tourmentant,e *a.* ដែលធ្វើឲ្យឈឺចាប់ ឬឲ្យខ្វល់; ដែលពួលចិត្តធ្វើឲ្យឈឺចាប់ ឬឲ្យខ្វល់

tourmente *n.f.* ព្យុះខ្លាំង (តែឆាប់ស្ងប់)។ *Fig.* ចលាចល, ដំណើរជ្រួលច្របល់ (ឧ. tourmente révolutionnaire)

tourmenté,e *a.* រពើតរពើង, មិនរាបស្មើ (ដី) (ឧ. sol tourmenté)។ *Fig.* ជើតឆាយពេក (ឧ. style tourmenté)

tourmenter *v.i.* ធ្វើទារុណកម្ម, ធ្វើឲ្យឈឺចាប់ខ្លាំង (ឧ. la goutte le tourmente); ធ្វើឲ្យជ្រួលខ្លាំង (ឧ. le vent tourmente le navire)។ *Fig.* ធ្វើឲ្យព្រួយបារម្ភ, ធ្វើឲ្យខ្វល់, ធ្វើឲ្យតប់ប្រមល់ (ឧ. son procès le tourmente); រំខាន (ឧ. ses créanciers le tourmentent)។

se tourmenter *v.pr.* ព្រួយបារម្ភ, តប់ប្រមល់; ទំព្រើង (ម៉ើ. harceler, inquiéter, obséder, persécuter, préoccuper, tenailler, torturer)

tourmenteur, euse *n.& a.* អ្នករំខាន

tournage *n.m.* ការក្រឡឹង; ការថតភាពយន្ត (ឧ. tournage d'un film)

tournant, e *a.* ដែលវិល (ឧ. pont tournant) ។ mouvement tournant ចលនាវាង (ការវាងទ័ពសត្រូវ)

tournailler *v.i. Fam.* ដើរទៅមកឥតការ; ដើរក្រឡឹង

tournant *n.m.* ផ្លូវបត់; របត់ព្រែក ។ *Fig.* ពេលប្រែប្រួល; ពេលសំខាន់ (ឧ. les tournants de l'histoire)

tourné, e *a.* ដែលទៅជា (ឧ. bien tourné ទៅជាល្អ; mal tourné ទៅជាអាក្រក់); ដែលក្លាយ; ដែលជូរ; ដែលខូច (ឧ. lait; vin tourné)

tourne-à-gauche *n.m. inv. Techn.* ប្រដាប់មួល ឬ ពត់; ដែកពត់ធ្មេញរណារ; ប្រដាប់ធ្វើធ្មេញឡោស៊ី

tournebouler *v.t. Fam.* ធ្វើឲ្យភ័យខ្លាំង

tournebroche *n.m.* ប្រដាប់បង្វិលប្រទូក; អ្នកបង្វិលប្រទូក

tourne-disque *n.m.* ជាលភមន៍, ម៉ាស៊ីនបង្វិលថាស

tournedos *n.m.* សាច់ចំឡកគោហាន់ជាបន្ទះក្រាស់ៗ

tournée *n.f.* ទស្សនាការ, ទស្សនាចរ។ frais de tournée ម.ព. frais។ *Fam.* ជុំ (ភេសជ្ជៈ ឬស្រាដែលជនម្នាក់ចេញថ្លៃឲ្យផឹកទាំងអស់គ្នា)

tourne-feuille *n.m.* ប្រដាប់ត្រឡប់សន្លឹកសៀវភៅភ្លេង (*pl.* des tourne-feuilles)

tournemain *n.m.* en un tournemain ក្នុងមួយភ្លែត ឬ មួយរំពេច

tourner *v.t.* បង្វិល (ឧ. tourner une roue); ងាក, បែរ (ឧ. tourner la tête); ត្រឡប់ (ឧ. tourner une page d'un livre); បែរ, ចោល (ភ្នែក) (ឧ. tourner les yeux vers quelqu'un បែរមើលអ្នកណាម្នាក់); វាង, ចៀស (ឧ. tourner une montague); ក្រឡឹង (ឧ. tourner un pied de table) ។ *Fig.* រៀបចំសេចក្តី (ឧ. bien tourner une lettre); ពិនិត្យពិច័យ (ឧ. tourner une affaire en tout sens); កាត់យល់ (ន័យ) (ឧ. tour-

ner en bien កាត់យល់ទៅខាងល្អ; tourner en mal កាត់យល់ទៅខាងអាក្រក់); បំបាត់, ដោះស្រាយ (ការពិបាក) (ឧ. tourner une difficulté) ។ *Cin.* ថត (ភាពយន្ត) (ឧ. tourner un film) ។

Loc. div. tourner ses souliers ធ្វើឲ្យខូចកែងស្បែកជើង ។ tourner casaque ផ្លាស់បក្សពួក (ម.ព. casaque ផង) ។ tourner le dos à quelqu'un បែរខ្នងឲ្យអ្នកណាម្នាក់, ដើរចេញ; *fig.* មើលងាយ ។ tourner les talons ចេញធ្លាយ ។ tourner bride ត្រឡប់វិលវិញ ។ tourner ses pouces ម.ព. pouce ។ tourner la tête à quelqu'un ធ្វើឲ្យចូលចិត្ត, ធ្វើឲ្យស្រឡាញ់ ។ touner en ridicule ចំអកឲ្យបានសើច ។ *Fam.* tourner le sang (ឬ les sens) à ធ្វើឲ្យរំភើបខ្លាំង ។ tourner quelqu'un à son gré ដឹកនាំតាមអំពើចិត្ត ។

v.i. វិល (ឧ. la terre tourne autour du soleil); ផ្លាស់ទិស (ខ្យល់) (ឧ. le vent a tourné au nord); ងាក (ឧ. tourner à droite, à gauche); លេង (ដើរតួ) (ក្នុងខ្សែភាពយន្ត); ក្លាយ, ជ្ជូរ, ខូច (ឧ. le lait, le vin a tourné) ។ *Fig.* ទៅជា (ល្អ ឬ អាក្រក់) (ឧ. l'affaire a bien ឬ mal tourné); បែរជា (ល្អ ឬ អាក្រក់), ប្រែជា (ល្អ ឬ អាក្រក់) (ឧ. ce jeune homme a bien ឬ mal tourné); បានជាល់ខ្មាស, ផ្តល់ឡើងកិត្តិយស (ឧ. cela tournera à sa honte ឬ à sa gloire) ។

Loc. div. la chance a tourné ភ័ព្វសំណាងប្រែត្រឡប់ (ងាកទៅគេឯទៀតវិញ); ក្លាយ ។ tourner rond វិល ឬ ដើរល្អ (ម៉ាស៊ីន); *fig.* បានចម្រើន (កិច្ចការ) ។ tourner à tout vent ងាកបេតាមខ្យល់; ហៃផ្លាស់មតិឬយោបល់ ។ tourner du côté de quelqu'un ចូលខាង, កាន់ខាង ។ la tête lui tourne គាត់វិលមុខហើយ ។ tourner autour du pot ម.ព. pot ។ tourner court វត់ដោយយកទីខ្លី; *fig.* ឈប់ ឬ ផ្លាស់ភ្លាមៗ ។ *Fam.* tourner de l'œil សន្លប់, បាត់ស្មារតី

tournerie *n.f.* រោងជាងក្រឡឹង

tournesol *n.m.* ផ្កាឈូករត្ន

tournette *n.f.* រហាត់(មានភ្លៅ); ទ្រុងកំប្រុក (វិលហាន)

tourneur *n.m.* ជាងក្រឡឹង។ *a.* ដែលក្រឡឹង; ដែលបង្វិលខ្លួន (ឧ. derviche tourneur)

tournevis *n.m.* ទួរណឺវីស, ប្រដាប់មួលខ្ចៅ

tourniole *n.f.* ដំបៅក្រចក

tourniquer *v.i. Fam.* ដើរត្រេតត្រត; ដើរក្រវែល

tourniquet *n.m.* ទ្វារកង្ហារ, ទ្វារវិល; កង្ហារស្រួច; ដែកបង្គួលបង្អួច(រាងដូច S); ល្បែងបង្វិលលេខ។ *Fam.* passer au tourniquet ឡើងតុលាការសឹក (មានរឿងត្រូវតុលាការសឹកជំរះ)។ *Chir.* ប្រដាប់កៀបសរសៃឈាម

tournoi *n.m.* ពិធីប្រយុទ្ធ (ក្នុងសម័យបុរាណ)។ *Sports* ការប្រកួត (ជាមិត្តភាពហើយឥតឲ្យរង្វាន់)(ឧ. tournoi de tennis)

tournoiement *n.m.* ដំណើរវិលជុំវិញខ្លួន; ដំណើរក្បួច

tournoyant,e *a.* ដែលវិលជុំវិញខ្លួន; ដែលក្បួច

tournoyer *v.i.* វិលជុំវិញខ្លួន; ក្បួច; ហើរក្រឡឹង, ហើរវៀល

tournure *n.f.* ភាព, រាងកាយ (ឧ. cette femme a une jolie tournure)។ *Fig.* ឫក, គតិ (ឧ. tournure d'esprit agréable); ដំណើរការ (ឧ. l'affaire prend une bonne tournure); របៀបរៀបប្រយោគ(ឧ.tournure d'une phrase); កំទេចលោហធាតុក្រឡឹង (ព្រ. expression, formule, idiotisme, locution)

tourte *n.f. Fig.* &. *Fam.* មនុស្សល្ងើ

tourteau *n.m.* នំប៉័ងមូល; កាកប្រេង (កាកគ្រាប់ ឬ ផ្លែឈើដែលគេគាបយកប្រេង) (ឧ. tourteau d'olive)

tourtereau *n.m.* កូនលលក (នៅក្នុងសំបុក)។ *pl. Fig.* យុវជនដែលស្រឡាញ់គ្នាខ្លាំង

tourterelle *n.f.* លលក (cri: la tourterelle gemit, roucoule លលកយំ ឬ ក្រោល)

toussaint *n.f.* បុណ្យខួបឆ្លង (ក្នុងសាសនាគ្រិស្ត)

tousser *v.i.* ក្អក

tousserie *n.f. Fam.* ការក្អក

tousseur, euse *n. Fam.* អ្នកហែក្អក

toussoter *v.i.* ក្អកញយៗ ឬ តិចៗ

tout [tou], **toute**, *pl.m.* **tous** [tou ឬ touss] *a.qual.* ទាំងមូល, ទាំងអស់, ទាំងស្រុង (ឧ. toute la ville); ពេញ (ឧ. veiller toute la nuit មិនដេកទើសភ្លឺ(ពេញមួយយប់)។

Adj. ind. រាល់, ប្រប់តែ (ឧ. toute peine mérite salaire); គ្រប់ (ឧ. en toute occasion ។

Loc. div. tous deux ឬ tous les deux ទាំងពីរ (ជាមួយគ្នា, ដូចគ្នា) ។ tout un អស់មួយ (ឧ. manger tout un pain)។ tout autre អ្នកណាម្នាក់ទៀត។ à toute minute គ្រប់ពេល, ញយណាស់ ។ tout à បម្រើពេញបន្ទុក (ឧ. je suis tout à vous ខ្ញុំរង់ចាំបម្រើលោកពេញបន្ទុក) ។ tout à tous បំពេញចិត្តគ្រប់គ្នាទាំងអស់ (ឧ. il est tout à tous)។ de tout point ទោះយ៉ាងណាក៏ដោយ, គ្រប់បែប ។ une fois pour toutes តែម្តងឲ្យស្រេច, ជាស្ថាពរ។ tous les (ប្រើជាមួយនឹងនាមសព្ទ)រាល់,គ្រប់(ឧ.prendre une leçon toutes les semaines) ។ tous les... (ប្រើជាមួយនឹងលេខ) ក្នុង...ម្តង (ឧ. il m'écrit tous les deux jours គាត់សរសេរមកខ្ញុំក្នុងពីរថ្ងៃម្តង)។ tout le monde ទាំងអស់គ្នា,គ្រប់គ្នា (ឧ. tout le monde est mortel); អ្នកឯង,ទេឯងគ្រប់គ្នា(ឧ.s'habiller comme tout le monde) ។ tout ce qu'il y a de ទាំងអស់ (ឧ. tout ce qu'il y a d'honnêtes gens មនុស្សសុចរិតទាំងអស់) ។ en tout bien, tout honneur ដោយសុទ្ធចិត្ត ។ tous yeux ផិតភ្នែក (មើល)។ tous oreilles ផិតត្រចៀក(ស្តាប់)។ ce sont tous ឬ ce sont toutes សុទ្ធតែជា (ឧ.ce sont tous contes à dormir debout) ។

pr. ind. ទាំងអស់គ្នា (ឧ. tous sont venus); ទាំងអស់(គ្មានសល់) (ឧ. tout est dit); អ្វី (វត្ថុនិមួយៗ) (ឧ. tout ce qui naît meurt) ។

Loc. div. tous ទាំងអស់គ្នា (មនុស្សទាំងអស់ទូទៅ ឬ មនុស្សទាំងអស់ក្នុងក្រុមមួយ)(ឧ.être approu-

vé par tous)។ tous tant que ទាំងអស់គ្នាដែលជា (ឧ. tous tant que nous sommes)។ tout ou partie ទាំងអស់ ឬ តែមួយភាគ ។ après tout ក្នុងទីបំផុត; ដោយគិតឲ្យហ្មត់ចត់ទៅ ។ comme tout ម.ព. comme។ en tout ទាំងអស់ (ឧ. cela fait mille riels en tout) ។ en tout et partout គ្រប់មុខ និង គ្រប់កាល ។ tout compte fait បើគិតឲ្យស្រួលទៅ ។ c'est tout តែប៉ុណ្ណោះ (គ្មានអ្វីទៀតទេ) ។ ce n'est pas tout មិនទាន់អស់ទេ ; នៅមានអ្វីទៀត ។ à tout prendre ដោយសរុបទៅ ។ avoir réponse à tout មិនចេះទាល់, គ្មានអ្វីមកពាក់ពាន ។ c'est tout dire សព្វគ្រប់អស់ហើយ(គ្មានអ្វីជាថែមទៀតឬគ្មានអ្វីខ្វះសំខាន់ទៀត)។ avoir tout de ពេញទី (មានលក្ខណៈអាក្រក់សព្វគ្រប់ទាំងអស់)(ឧ. il a tout du singe) ។

tout *adv.* ដោយពេញលេញ (ឧ. elle est tout heureuse) ។ tout... que ទោះជា...ក្តី (ឧ. tout savant qu'il est, il a fait une bévue) ។ tout en ដើរ (ឧ. dire à quelqu'un ses vérités tout en riant) ; ...បណ្តើរ... បណ្តើរ (ឧ. parler tout en marchant និយាយបណ្តើរដើរបណ្តើរ) ។ tout comme ដូចបេះបិទ ។ tout le premier មុនគេបង្អស់; លើគេបង្អស់ ។ tout un ដូចគ្នាសុទ្ធសាធ ។ c'est tout un គឺដដែល, ដូចតែគ្នា (ឧ. rester, partir, c'est tout un pour moi)។

Loc. adv. tout à fait ម.ព. fait ។ tout à coup ម.ព. coup ។ tout d'un coup ម.ព. coup ។ tout de go ម.ព. go ។ tout à l'heure ឥឡូវ, ភ្លាម (ឧ. je veux de l'argent tout à l'heure (Molière); បន្តិចទៀត។ tout autant ដូចតែគ្នា (ឧ. Mettez une pierre à la place, Elle vous rendra tout autant (La Fontaine)។ tout plein ច្រើន (ឧ. j'ai tout plein de projet en tête) ។ tout juste ល្មមតែ (ឧ. il y a tout juste de quoi vivre); *fam.* ពិតហើយ

(ឧ. c'est votre mari? — tout juste!) ។ tout d'un temps តែម្តង (បន្តជាប់គ្នារហូត) ។ tout de même ក៏នៅតែ (ឧ. je suis mal portant, mais j'irai vous voir tout de même) ។ tout au plus យ៉ាង ច្រើនណាស់ទៅ ។ à tout le moins យ៉ាងហោចណាស់ទៅ, យ៉ាង តិចណាស់ (ឧ. l'Eglise ordonne de communier à tout le moins une fois l'an) ។ tout doux ដោយតិចៗ, ដោយថ្នាក់ថ្នម(ឧ. prenez le tout doux, ne l'irritez pas) ។ tout doux! តិចៗ!, ល្មមៗ! (ឧ. tout doux! ne nous fâchons point) ។ du tout ទេ, សោះ ។ tout à fait ពេញទី ។ en tout ទាំងអស់ (សរុបទាំងអស់)។du tout au tout ទាំងស្រុង (ឧ. différer du tout au tout)

tout *n.m.* វត្ថុទាំងមូល (ឧ. le tout est plus grand que la partie) ។

Loc. div. le tout ទាំងអស់នោះ (ឧ.ferme et chateau, j'ai acheté le tout); ការសំខាន់ (ឧ le tout est de réussir) ។ risquer le tout pour le tout ប្រថុយចំណេញ ឬខាតទាំងស្រុង ។ le tout ensemble ទាំងអស់ (រួមគ្នា) ។ ce n'est pas le tout មិនទាន់គ្រប់សព្វទេ (មានអ្វីទៀតទៀត) (ឧ. ce n'est pas le tout, il me faut de l'argent) ។ ce n'est pas le tout que des choux, il faut encore de la graisse យើងធ្វើប៉ុណ្ណេះមិនទាន់គ្រប់សព្វទេ

toutefois *adv.* ប៉ុន្តែ; ប្រសិនជា (ឧ. si toutefois il veut venir)។ (ម្រ. cependant, en revanche, mais, néanmoins)

toute-puissance *n.f.* អនន្តានុភាព, ឥទ្ធិពលខ្លាំង; អំណាចផ្តាច់ការ(ឧ. aspirer à la toute-puissance)

toutou *n.m.* ឆ្កែ (ភាសាក្មេង)

tout-puissant, toute-puissante *a.* ដែលមានអនន្តានុភាព (ដែលមានឥទ្ធិពលខ្លាំង ឬ អំណាចផ្តាច់ការ) (ឧ.ministre tout-puissant) ។

n.m. le Tout-Puissant អាទិទេព។ (*pl.* tout-puissants, toutes-puissantes)

tout-venant *n.m. ind.* ធ្យូងថ្មរយ (មិនបានរើសសម្រាំង) ។ *Agr.* ពូជរយ ។ *Par ext.* របស់រយ (អ្វីៗដែលមិនបានរើសហ្មត់ចត់)

toux *n.f.* ក្អក

toxémie *n.f.* គ្រោះថ្នាក់បណ្ដាលអំពីជាតិពុលក្នុងឈាម

toxicité *n.f.* វិសភាព, ភាពពុល (ឧ. la toxicité de l'arsenic); ចំនួនជាតិពុលដែលបណ្ដាលឲ្យស្លាប់បាន

toxicologie *n.f.* វិសសាស្ត្រ, វេជ្ជវិទ្យាខាងជាតិពុល

toxicologique *a.* ខាងវិសសាស្ត្រ, នៃវេជ្ជវិទ្យាខាងជាតិពុល (ឧ. expertise toxicologique)

toxicologue *n.m.* អ្នកវិសសាស្ត្រ, ពេទ្យខាងជាតិពុល

toxicomane *a.&n.* វិសព័ន្ធ, វិសបដិព័ន្ធ (អ្នកញៀនជាតិពុល មានអាភៀនជាដើម)

toxicomanie *n.f.* វិសពន្ធន៍ (ការញៀនជាតិពុល មានអាភៀនជាដើម)

toxine *n.f.* វិសករស, ជាតិពុលដែលបង្កើតដោយអតិសុខុមប្រាណ

toxique *n.f.* វិសៈ, ជាតិពុល។ *a.* ពុល (ឧ. substance toxique)

trabe *n.f.* ដងទង់

trac *n.m.* ប្រាប ។ avoir le trac ប្រាបជាន់ ។ *Fam.* tout à trac *loc. adv.* ភ្លាមៗ, ឥតគិត

traçage *n.m.* ការដឹកបន្ទាត់

traçant,e *a.* racine traçante ឫសសើដី ។ balle traçante ម.ព. balle

tracas *n.m. Fam.* សេចក្ដីព្រួយ, កង្វល់ (ឧ. les tracas d'un père) (មើល. contrariété, ennui, obsession, préoccupation, tourment)

tracasser *v.t.* ធ្វើឲ្យខ្វល់, ធ្វើឲ្យព្រួយ, ធ្វើឲ្យបារម្ភ (ឧ. sa santé me tracasse)

tracasserie *n.f.* ការរំខាន; កង្វល់, អំពល់, សេចក្ដីព្រួយ, បារម្ភ

tracassier,ière *n. & a.* ដែលនាំអំពល់, ដែលចូលចិត្តធ្វើឲ្យខ្វល់ឬឲ្យព្រួយ

tracassin *n.m. Fam.* វិតក្កចរិត, ចរិតព្រួយ

trace *n.f.* ដាន, ស្នាម (ឧ. suivre

une biche à la trace); សម្លាក (ឧ. la trace d'une brûlure)។ *Fig.* ស្នាម(ឧ.cette aventure a laissé des traces profondes en lui); ស្នាម; សំណល់, ស៊ំអាន (ឧ. on ne trouve pas trace de cet événement chez les historiens);បំនួនស្តួចស្តើង(ឧ. des traces d'albumine dans les urines) ។ marcher sur les traces de quelqu'un តាមស៊ំអាន, យកគម្រាប់តាម ។ à la trace តាមស៊ំអាន, តាមដាន

tracé *n.m.* បន្ទាត់, គំនូស (ឧ. faire le tracé d'une figure); ផ្លូវ (ឧ. le tracé du Métropolitain)

tracement *n.m.* ការដឹកបន្ទាត់

tracer *v.t.* ដឹកបន្ទាត់; គូរ, សរសេរ (ឧ. tracer des lettres)។ *Fig.* រ៉ាយរ៉ាប់ (ឧ. tracer un tableau sinistre) ; ណែនាំឲ្យប្រព្រឹត្តតាម, បង្គាប់ (ឧ. tracer à quelqu'un sa conduite) ។ tracer le chemin à quelqu'un ប្រាប់ផ្លូវអ្នកណាម្នាក់; ឲ្យដាក់រូ ។

v.i. សាយទៅខាង (ឫស ឬ មែកឈើ)

traceret *n.m.* ដែកគូស (ហៅ traçoir ក៏បាន)

traceur,euse *n.* អ្នកដឹកបន្ទាត់

trachéal [–ké-al], **e,aux** *a.* នៃ បំពង់ខ្យល់ (សួត)

trachée *n.f.* (ពាក្យបំប្រួញនៃ trachée-artère)

trachée-artère *n.f.* បំពង់ខ្យល់ (នៃ សួត) (*pl.* des trachées-artères)

trachéen,enne [–ké–] *a.* នៃបំពង់ ខ្យល់ (សួត) (ឧ. la respiration trachéenne des insectes)

trachéite [–ké-it'] *n.f.* រោគរលាក បំពង់ខ្យល់ (សួត)

trachéotomie [– ké –] *n.f.* ការ វះកាត់បំពង់ខ្យល់ (សួត)

trachome [–ko–] *n.m.* កណរោគ, ត្រាកូម (រោគដែលមានអាការៈដាំពងៗ ក្នុងត្របកភ្នែក)

trachyte [–ki–] *n.m.* ពពួកសិលា

traçoir *n.m.* ម.ព. traceret

tract *n.m.* ខិតប័ណ្ណ

tractation *n.f.* ការតថ្លៃខាងផ្លូវចិត្តញ

(ប្រើនិយាយក្នុងន័យអាក្រក់)

tracté,e *a.* ដែលទាញ ឬ អូសដោយត្រាក់ទ័រ

tracteur *n.m.* ត្រាក់ទ័រ (ម៉ាស៊ីនអូស) (ឧ. un tracteur agricole)

tractif,ive *a.* ដែលអូស, ដែលទាញ (ឧ. force tractive)

traction *n.m.* ការទាញ, ការអូស (ឧ. traction d'un wagon) ។ traction avant ឬ traction រថយន្តបង្វិលកង់មុខ

trade-union ឬ **trade union** *n.f.* សហជីពកម្មករ (នៅប្រទេសអង់គ្លេស) (*pl.* des trade-unions ឬ trade unions)

tradition *n.f.* ប្រពៃណី (ឧ. la tradition est le lien du passé avec le présent)។ *Spécial.* ច្បាប់ប្រពៃណី (ក្នុងសាសនា); ទម្លាប់ជាប្រពៃណី (ឧ. les traditions d'une province) ។ *Dr.* ការប្រគល់បណ្ណទ្រព្យម្ចាស់ថ្មី

traditionalisme *n.m.* ប្រពៃណីនិយម

traditionaliste *n.&a.* អ្នកប្រពៃណីនិយម

traditionnel,elle *a.* តាមប្រពៃណី (ឧ. défilé traditionnel); ជាប្រពៃណី

traditionnellement *adv.* តាមប្រពៃណី

traducteur *n.m.* ភាសាបរិវត្តកៈ-ក, អ្នកប្រែភាសា

traduction *n.f.* ភាសាបរិវត្តន៍, ការប្រែភាសា (ឧ. la traduction d'un discours); សេចក្តីប្រែ, សៀវភៅប្រែ (ឧ. lire une traduction d'Homère) ។ *Par ext.* ការបកស្រាយ (ឧ. traduction de la pensée de quelqu'un)

traduire *v.t.* ធ្វើភាសាបរិវត្តន៍, ប្រែភាសា (ឧ. traduire du pali en cambodgien) ។ *Par ext.* បញ្ចេញឲ្យដឹង(គំនិត)(ឧ. nos yeux traduirent nos sentiments)។ traduire en justice ប្តឹងឲ្យតុលាការជំនុំជំរះ ។

se traduire *v.pr.* សំដែងចេញ (ឧ. sa douleur se traduisait par des cris)

traduisible *a.* អាចប្រែបាន (ភាសា)

trafalgar *n. pr. Fam.* coup de

trafalgar គ្រោះថ្នាក់ខ្ទប់ហើយមិនដឹងខ្លួនមុន

trafic *n.m.* វិក្រយ, ជំនួញ (ឧ. le trafic des cuirs) ; ជំនួញលួចលាក់; វិក្រយបលគា (បលគារថយន្ត-អយស្ម័យយាន ។ល។) (ឧ. trafic ferroviaire; trafic routier) ។ *Fig.* យោគវិក្រយ, ការប្រកបដោយមិនសុចរិត ។ trafic d'influence វិក្រយអំណាច

trafiquant,e ឬ **trafiqueur,euse** *n.* វិក្រយបលគ្គ; ឈ្មួញមិនសុចរិត

trafiquer *v.i.* ធ្វើជំនួញខុសច្បាប់ ឬ លួចលាក់; រកប្រាក់ដោយឧបាយទុច្ចរិត

tragédie *n.f.* សោកនាដកម្ម, រឿងល្ខោនដែលមានឆាកសោក ។ *Fig.* ព្រឹត្តិការណ៍អាក្រក់ (ឧ. sanglante tragédie)

tragédien,enne *n.* សោកនាដក,អ្នកសំដែងរឿងល្ខោនដែលមានឆាកសោក។ *Fig.* កម្រុះរឿងមធ្យ័តនឹងរឿងកំប្លែង

tragi-comédie *n.f.* សោកហាសនាដកម្ម, រឿងល្ខោនដែលមានឆាកសោកលាយនឹងឆាកកំប្លែង (*pl.* des tragi-comédies)

tragi-comique *a.* សោកហាសក្តី,ដែលមានឆាកសោកលាយនឹងឆាកកំប្លែង

tragique *a.* ប្រកបដោយទុក្ខភ័យ (ឧ. situation tragique); ដែលនាំឲ្យមានភ័យ-ឲ្យមានអន្តរាយ ឬឲ្យវិនាស (ឧ. fin tragique) ។

n.m. សោកនាដ, បែបរឿងល្ខោនដែលមានឆាកសោក;សោកនាដភាព, ភាពរឿងដែលនាំឲ្យភ័យ ឬ ឲ្យវិនាស (ឧ. le tragique de certaines situations); សោកនាដនិពន្ធ, អ្នកនិពន្ធរឿងល្ខោនដែលមានឆាកសោក (ឧ. les tragiques grecs)។ prendre une chose au tragique ក៏យល់ពីរឿងអ្វីមួយ ។ tourner au tragique ក្លាយទៅជារឿងទុក្ខ ឬ អន្តរាយ

tragiquement *adv.* ដល់នូវអន្តរាយ (ឧ. aventure qui finira tragiquement)

tragus [–guss] *n.m.* កូនត្រចៀក

trahir *v.t.* ក្បត់ (ឧ. trahir sa patrie) ។ *Fig.* និយាយ ឬ ប្រព្រឹត្តបំពាន ឬ ខ្ពុយនឹង, មិនប្រព្រឹត្តតាម (ឧ. trahir ses serments); បរិហារ (ឧ. trahir un secret);

ធ្វើឲ្យក្លាយ, បំប្លែង (ឧ. trahir la pensée de quelqu'un) ; មិនទ្រទ្រង់ (ឧ. ses forces l'ont trahi) ។ trahir les intérêts de quelqu'un បង្ខូចប្រយោជន៍អ្នកណាម្នាក់ ។

se trahir *v.pr.* ចេញឲ្យឃើញ

trahison *n.f.* អំពើក្បត់, ការក្បត់, (ម្រ. déloyauté, félonie, forfaiture, traîtrise)

train *n.m.* ល្បឿន (នៃសត្វជិះឬសត្វអូសរទេះ) (ឧ. cheval qui va bon train); ល្បឿន (ទូទៅ) (ឧ. marcher grand train) ។ mener le train នាំមុខ (ក្នុងការប្រណាំង) ។

Fig.&Fam. សូរអ៊ូអែរ (ឧ. faire du train) ។

Aéron. train d'atterrissage គ្រឿងសម្រាប់អាកាសយានចុះដី ។ *Autom.* train avant គ្រឿងភ្លៅមុខ ។ train arrière គ្រឿងភ្លៅក្រោយ (នៃរថយន្តសម័យថ្មី) ។ *Ch. de f.* ខ្សែរថ, ខ្សែអយស្ម័យរថ ។ train de ceinture ខ្សែរថព័ទ្ធក្រុង ។ train express ឬ train direct ខ្សែរថបង្ហួត (ដែលឈប់តែត្រង់ជំណាក់ធំៗ) ។ train facultatif ខ្សែរថឥតបង្ខំ ។ train léger ខ្សែរថស្រាល ។ train de marchandise ខ្សែរថទំនិញ ។ train mixte ខ្សែរថចម្រុះ (មានទូសម្រាប់មនុស្សជិះ នឹង សម្រាប់ដឹកទំនិញ) ។ train omnibus ខ្សែរថសព្វហាន (ដែលឈប់គ្រប់ជំណាក់) ។ train de plaisir ខ្សែរថតម្លៃថោក ។ train rapide ខ្សែរថលឿន ។ train régulier ខ្សែរថនិយ័ត ។ train de secours ខ្សែរថសង្គ្រោះ ។ train de service ខ្សែរថសេវា ។

train de bois ក្បូនឈើ ។ train de péniches ក្បូនទូកសណ្ដោង (ទូកដែលគេបងសណ្ដោងទៅជាមួយគ្នា) ។

Mil. ខ្សែរថ ។ train blindé ខ្សែរថក្រោះ ។ train sanitaire ខ្សែរថខាងសុខាភិបាល ។ រថយន្តទ័ព ។ train de combat រថយន្តប្រយុទ្ធ (រថយន្តទាំងឡាយនៃកងវរសេនាតូច សម្រាប់ដឹកស្បៀង, សម្ភារៈដែលកងទ័ពត្រូវការជាប្រញាប់ នៅ

សមរភូមិ)។ train régimentaire រថយន្តនៃកងវរសេនាធំ (រថយន្តទាំងឡាយនៃកងវរសេនាធំ សម្រាប់ដឹកស្បៀង) ។

Techn. train d'engrenages គ្រឿងចក្រ ។ train de devant ស្មាសេះ (ភាគខាងមុខនៃខ្លួនសេះ)។ train de derrière ត្រគាកសេះ (ភាគខាងក្រោយនៃខ្លួនសេះ) ។ **train de pneus** គ្រឿងកង់ (ក្នុងរថយន្តមួយ)។

Fig. train de vie ដំណើរជីវភាព (របៀបរស់នៅ)។ train de maison ក្រុមអ្នកបម្រើក្នុងផ្ទះមួយ ។ mettre une affaire en train ផ្ដើមកិច្ចការ, ជាប់ធ្វើ ។ être en train កំពុងស្រួលចិត្ត ។ être en train de កំពុងតែ ។ à fond de train ដោយរស់ល្បឿន ។ train de sénateur ដំណើរអ្នកធំ (ដំណើរយឺតហើយវែងវែង) ។ *Fam.* être dans le train នៅក្នុងក្រុម

trainant,e *a.* អូសដី (ឧ. robe trainante) *Fig.* បង្អូស;ស្របរុតស្រយង់; ជំជែលៗ (ឧ. voix trainante)

trainard,e *n. Fam.* អ្នកនៅក្រោយគេ (តាមគេមិនទាន់)។ *Par ext.* មនុស្សយឺតយ៉ាវ

trainasser *v.t. Fam.* ធ្វើ ឬ ទុកឲ្យយឺតយ៉ាវ (ឧ. trainasser une affaire) ។

v.i. Fam. ក្រធ្វើ; ដើរត្រេតត្រត

traine *n.f.* ការអូស; រំកាយអាវ; ជាប់អូសបង្អូសដោយគាវ ។ bateau à la traine ទាកបង្អូស (ទាក់ដែលគេអូស) ។ *Fig. & Fam.* à la traine ដោយរាត់រាយ (ឧ. le désordonné laisse ses affaires à la traine) ។

Fam. être à la traine យឺត, នៅក្រោយគេឆ្ងាយ។ *Pêcher.* អួន

traineau *n.m.* គាវ;អួន(គ្រឿងនេសាទ)

trainée *n.f.* វត្ថុរាយតាមផ្លូវ(ឧ.trainée de poudre); កម្លាំងទប់ (កម្លាំងអាកាសទប់វត្ថុអ្វីមួយ កុំឲ្យស្ទុះលឿនទៅបាន) (ឧ. la trainée est une force qu'on diminue en affinant les formes) ។ *Fam.* ស្ត្រីគំនិតរាយមាយ

traine-malheur ឬ **traine-misère** *n.m. inv. Fam.* មនុស្សរហេមរហាម

trainement *n.m.* ការអូស, ការទាញ

trainer *v.t.* អូស, ទាញ ។ trainer les pieds ដើរមិនលើកជើង ។ trainer la jambe ដើរអូសជើង (ដោយអស់កម្លាំង ឬ ដោយត្រូវរបួស)។ យកតាម, នាំតាម (ឧ. il traine avec lui toute sa famille)។ *Fig.* រស់នៅដោយវេទនា (ឧ. trainer une misérable existence)។ trainer une affaire en longueur ផ្អាកការឡើយត ។ trainer ses paroles និយាយបង្អូសសំដី, និយាយយឺតៗ។ trainer quelqu'un dans la boue ពន្លិចក្នុងភក់; បង្ខូចកិត្តិនាម ។

v.i. អូសដី (ឧ. son manteau traine); ស្រយុតស្រយង់ (ឧ. il traine depuis longtemps); នៅរាត់រាយ (ឧ. tout traine dans cette maison); ដើរលេងឥតគោលដៅ ។

se trainer *v.pr.* លូនទៅដី, ដើរដោយលំបាក

trainerie *n.f.* ការទុកឡូយឺតយ៉ាវ

traineur,euse *n.* អ្នកអូស,អ្នកទាញ។ traineur de sabre អ្នកស្ពាយដាវ, ទាហាន (ដែលធ្វើឫកព្រហើនព្រហាង) ;

trainglot *n.m. Fam.* ទាហានក្នុងរទេះភ្លើង(សរសេរជាtringlotក៏បាន)

train-trainឬ**tran-tran** *n.m.Fam.* ការងប់ក្នុងទម្លាប់; ដំណើរធម្មតា (នៃជីវិត, នៃការណ៍)

traire *v.t.* រឹតទឹកដោះ

trait *n.m.* ការអូសរទេះ (ឧ. bêtes de trait សត្វសម្រាប់អូស): ខ្សែលយ: អាវុធសម្រាប់ពួយ (មានលំពែង, ស្នារ, ព្រួញ,ពីគលង់ជាដើម);ខ្សែបន្ទាត់; គំនូរគ្មានដាក់ពណ៌ (ឧ. dessiner au trait) ។ *Fig.* អំពើ (ដែលធ្វើឲ្យចូលចិត្ត ឬ មិនចូលចិត្ត) (ឧ. trait de satire, d'amitié); អំពើប្រពៃ (ឧ. trait de vertu); ប្រាជ្ញាវៃ (ឧ. trait d'esprit); លក្ខណៈ (ដែលចេញឡើយញប្លែកពីគេ) (ឧ. c'est un trait de notre époque) ; ការទាក់ទងដល់ (ឧ. cela a trait à ce qu'on vient de dire) ។

pl. ភៈមុខ (ឧ. traits fins, grossiers) ។ trait de scie ផ្លូវមុខរណារ ។

Loc. div. avaler d'un trait លេបមួយក្អឹក ។ avoir trait à មានការទាក់ទងនឹង ។ partir comme un trait ទៅលឿនដូចព្រួញ ។ copier trait pour trait ចម្លងផ្ចិត (ដូចសុទ្ធ) ។ trait d'union វគ្គសញ្ញា, សមាសញ្ញា; អ្វីៗ សម្រាប់ភ្ជាប់ ឬ សម្រាប់បញ្ចូលគ្នា

trait,e *a. Techn.* ដែលហូតជាលួស (ឧ. de l'or trait)

traitable *a.* អាចអភិប្រាយឬអត្ថាធិប្បាយបាន (ឧ. sujet facilement traitable); ស្លូត, ងាយទាក់ទង (ចរិត)

traitant *a.* médecin traitant ពេទ្យព្យាបាល

traite *n.f.* ការរីតទឹកដោះ; ល្បើក, រយៈផ្លូវដែលទៅបានគ្មានឈប់ (ឧ. longue traite) ។ tout d'une traite ឬ d'une seule traite រំហូត, ឥតឈប់, ឥតផ្អាក ។

Dr. រូបិយាណត្តិ (ហៅថា lettre de change ក៏បាន) ។ traite documentaire រូបិយាណត្តិដោយឯកសារ ។ traite domiciliée រូបិយាណត្តិកសេត ។ traite négociée រូបិយាណត្តិវិក្កណិត ។ traite tirée រូបិយាណត្តិបហារិត ។

ពាណិជ្ជកម្ម ។ traite des esclaves, traite des Noirs ឬ des Nègres ទាសពាណិជ្ជកម្ម ។ traite des blanches ពេស្យពាណិជ្ជកម្ម (ការដឹកនាំស្រីស្បែកសឲ្យធ្វើពេស្យា)

traité *n.m.* អភិប្រាយ, ក្បួន (ឧ. traité de mathématiques) ។ traité de droit civil អភិប្រាយនៃនីតិសាស្ត្របវេណី ។ *Pol.* សន្ធិសញ្ញា (រវាងរដ្ឋ) ។ traité de commerce សន្ធិសញ្ញាពាណិជ្ជកម្ម ។ traité de paix សន្ធិសញ្ញាសន្តិភាព

traitement *n.m.* បដិសណ្ឋារកិច្ច, ការទទួល; បៀវត្ស; រោគព្យាបាល (វិធីព្យាបាលរោគ) (ឧ. traitement chirurgical) ។ *Ind.* ការចែក (រ៉ែ); ការយករូបធាតុដើមទៅធ្វើ ។ *pl.* ប្រព្រឹត្តកម្ម ។ mauvais traitements ការវាយដំ, ការធ្វើបាប

traiter *v.t.* ប្រព្រឹត្តទៅលើ (ឧ. traiter

les vaincus avec humanité); ប្រព្រឹត្ត (ឧ. bien traiter les animaux ប្រព្រឹត្តល្អចំពោះសត្វ); ធ្វើបដិសណ្ឋារកិច្ច, ទទួល (ឧ. il nous a traités splendidement); អភិប្រាយ; វាយការណ៍; ដំណើរ(រកខុសត្រូវ) (ឧ. traiter une question); ព្យាបាល (ឧ. traiter un malade); ទុកជា, ចាត់ជាជា, សំគាល់ជា (ឧ. traiter quelqu'un de voleur); ចម្រាញ់ (ឧ. traiter un minerai ចម្រាញ់រ៉ែ) ។

v.t. ind. (de) សរសេរអំពី, អត្ថាធិប្បាយអំពី (ឧ. traiter de la paix)

traiteur *n.m.* អ្នកលក់អាហារ

traître,esse *a.* ដែលក្បត់; ដើម្បីក្បត់; ដែលលាក់ពុត (ឧ. les chats sont traîtres) ។ ne pas dire un traître mot មិនហើបមាត់សោះ (មិននិយាយ មួយម៉ាត់សោះ) ។

n. អ្នកក្បត់ ។ en traître *loc. adv.* ដោយក្បត់

traîtreusement *adv.* ដោយក្បត់

traîtrise *n.f.* ការក្បត់; ការលាក់ពុត, ឧបាយទុច្ចរិត

trajectoire *v.t.* គន្លងគ្រាប់ (ផ្លូវរបស់គ្រាប់កាំភ្លើងជាដើម)

trajet *n.m.* ចម្ងាយផ្លូវ; ផ្លូវ (ដែលត្រូវដើរ) (ឧ. notre trajet fut difficile) ។ accident de trajet គ្រោះថ្នាក់តាមផ្លូវ (ចំពោះកម្មករដែលមានគ្រោះថ្នាក់នៅពេលទៅធ្វើការ ឬ ត្រឡប់ពីធ្វើការហើយដែលត្រូវបានទទួលបំណាច់)

tralala *n.m. Fam.* ភាពអ៊ឹកធឹក (ឧ. faire du tralala)

tram *n.m.* (ពាក្យបំព្រួញនៃ tramway)

tramail ឬ **trémail** *n.m.* មងត្រឡាកបីជាន់ (ឧ. pêcher au tramail)

trame *n.f. Techn.* អំពោះបាក់; ក្រឡាលើកញ្ចក់ (ប្រើក្នុងគ្រឿងសេរូបថត) ។ *Fig.* គ្រោងរឿង (ឧ. trame d'une tragédie); ដំណើរប្រទាក់ក្រឡាក់; ដំណើរប្រឡូកប្រឡល់ (ឧ. la trame des événements) ។ *Poét.* la trame de nos jours កំឡុងជីវិត

tramer *v.t. Techn.* បាក់ (ក្បាញ) ។ *Fig.* គិតក្បត់ (ឧ. tramer une conspiration) ។

se tramer *v.pr.* មានគេ

គិត (ការក្បត់)

trameur, euse *n.* អ្នកការអំពោះ សម្រាប់ធាក់ ។ *n.f.* ប្រដាប់ការអំពោះធាក់

traminot *n.m.* កម្មករអយស្ម័យអគ្គិសនី

tramontane *n.f.* ទាងជើង (នៅតំបន់មេឌីទែរ៉ាណេ) ; ផ្កាយមេរុ (ក្នុងប្រមុះផ្កាយប្រពើ ; ខ្យល់ត្រជាក់ម្យ៉ាង ។ perdre la tramontane វង្វេង; ឡប់, លែងដឹងថាគេធ្វើអ្វី ឬ និយាយអ្វី

tramp *n.m.* (ព.អ.) *Mar.* នាវាបន្ទុកដែលគ្មានផ្លូវកំណត់

tramping *n.m.* *Mar.* ការដឹកនាំតាមនាវាបន្ទុក (ដែលគ្មានផ្លូវកំណត់)

tramway ឬ **tram** *n.m.*(ព.អ.)អយស្ម័យអគ្គិសនី (*pl.* des tramways)

tranchage *n.m.* ការកាត់; ការព្រៀកបន្ទះក្តារ

tranchant,e *a.* មុត(ឧ. épée tranchante)។*Fig.* ton tranchant សំដីម៉ាត់ៗ ។ couleurs tranchantes ពណ៌ដើតខ្លាំង ។

tranchant *n.m.* មុខ(កាំបិត, ដាវ)។ *Fig.* à deux tranchants មុខពីរ; អាចឲ្យផលពីរផ្ទុយគ្នា (ឧ. argument à deux tranchants)

tranche *n.f.* ចំណិត,បន្ទះ,ពង្រៀក(ឧ. tranche de jambon) ; បន្ទារ, បន្ទារសៀវភៅ; ខ្ទង់លេខ; លើក (ក្នុងការបោះពុម្ពប្រាក់ ឬ ពេញឆ្នោត)

tranché,e *a.* *Fig.*ច្បាស់ដាច់គ្នា,ដាច់ពីគ្នា (ឧ. deux couleurs bien tranchées); សម្រេចហើយ

tranchée *n.f.* ស្នាមភ្លោះ ។ *Mil.* លេណដ្ឋាន ។ *Trav. publ.* រណ្តៅ (សំរាប់គ្រឹះស្ពានសង់ឬដាំឈើ) ។ *pl.* *Méd.* រោគចុកពោះខ្លាំង

tranchefile *n.f.* រឹមខ្នងសៀវភៅ

tranchefiler *v.t.* ដាក់រឹមខ្នងសៀវភៅ

tranchelard *n.m.* កាំបិតប៉ុងតោ (សម្រាប់ប្រើក្នុងផ្ទះបាយ)

tranche-montagne *n.m.* អ្នកក្អេងក្អាង; អ្នកអំនួត(*pl.* des tranche-montagnes)

trancher *v.t.* កាត់ផ្តាច់; ចិត; ពុះជាចំរៀក ។ *Fig.* សម្រេច; ដោះស្រាយ (ឧ. trancher une question, une difficulté) ។ trancher le mot និយាយម៉ឺងម៉ាត់ ។

v.i. សម្រេចដោយក្លាហាន (ឧ. trancher sur tout) ។ *Fig.*

លេចចេញច្បាស់(ឧ. ces couleurs ne tranchent pas assez)(ព្ទ. couper, découper, sectionner)

tranchet *n.m.* *Techn.* ប្រដាប់កាត់ស្បែក (ប្រដាប់របស់ជាងដេរស្បែកជើង)

trancheur *n.m.* អ្នកកាត់, អ្នកចិត

tranchoir *n.m.* ជ្រញ់; កាំបិតបាន់; ត្រីម្យ៉ាង

tranquille [kil'] *a.* ស្ងប់ (ឧ. rue tranquille); នឹង (ទឹក) (ឧ. eau tranquille); សុខសាន្ត, ឥតភ័យ-បារម្ភ(ឧ.conscience tranquille)

tranquillement *adv.* ដោយស្ងប់; ដោយគ្មានរំភើប ឬ មិនឲ្យភ័យ (ឧ. répondre tranquillement)

tranquillisant,e *a.* ដែលឲ្យស្ងប់, ដែលមិនឲ្យបារម្ភ (ឧ. nouvelle tranquillisante); ឱសថធ្វើឲ្យស្ងប់ ឬ ឲ្យបាត់ព្រួយ

tranquilliser *v.t.* ធ្វើឲ្យស្ងប់ ; ធ្វើមិនឲ្យរំភើបឬមិនឲ្យភ័យ (ឧ. tranquilliser l'esprit) ។

se tranquilliser *v.pr.* បាត់ព្រួយ, បាត់រំភើប (ព.ផ. alarmer, troubler)

tranquillité *n.f.* ភាពនឹង, ភាពស្ងប់ (ឧ. tranquillité de la mer); ឧបសន្តភាព, ភាពសុខសាន្ត,ភាពស្ងប់, អភ័យ (ឧ. tranquillité des esprits) (ព្ទ.calme, paix, quiétude, sécurité, sérénité)

transaction *n.f.* កិច្ចការជំនួញ, ការលក់ដូរ (ឧ. un certain courant de transaction a été observé sur les valeurs du comptant); ការស្រុះស្រួលគ្នា (ឧ. une médiocre transaction est préférable à un bon procès); កិច្ចសម្រុះសម្រួល, ការសម្រុះសម្រួល, ការចរចា

transactionnel,elle *a.* ដែលជាកិច្ចសម្រុះសម្រួល (ឧ. proposition transactionnelle)

transafricain,e *a.* ដែលកាត់ប្រទេសអាហ្វ្រិក (ឧ. chemin de fer transafricain)

transalpin,e [-zal -] *a.* ឯនាយភ្នំអាល្ប

transatlantique [– za –] *a.* ឯនាយមហាសមុទ្រអាត្លង់ទិក ។ *n.m.*

នាវាឆ្លងមហាសមុទ្រអាត្លង់ទិក; កៅអីសំពត់បត់ប្យ៉ាង

transbordement *n.m.* ការផ្ទេរ (ផ្លាស់បន្ទុកនាវា ឬ យាន)

transborder *v.t.* ផ្ទេរ(ផ្លាស់បន្ទុកនាវា ឬ យាន)

transbordeur *n. & a.m.* ប្រដាប់ផ្ទេរបន្ទុកនាវា

transcaspien,enne *a.* ឯនាយសមុទ្រកាស្ពៀន

transcaucasien,enne *a.* ឯនាយភ្នំកូកាស

transcendance *n.f.* អតិសេដ្ឋភាព (ការវិសេសវិសាល, ភាពឧត្តម ។ *Phil.* ភាពឈោងមិនដល់, ភាពគិតមិនដល់ ឧ. Kant affirme la transcendance de la chose en soi par rapport à la connaissance humaine) (ព.ផ. immanence)

transcendant,e *a.* អតិសេដ្ឋ (វិសេសវិសាល,ឧត្តម,ជំនាញក្នុងមុខងារខ្លួន ឧ. esprit transcendant ។ *Phil.* ដែលឈោងមិនដល់ ឬ គិតមិនដល់) (ឧ. selon certains philosophes, le réel est transcendant à la pensée) (ព.ផ. immanent)

transcendantal,e,aux *a. Phil.* ដែលគិតឃើញមុនពិសោធ (ឧ. d'après Kant, l'espace et le temps sont deux concepts transcendantaux) (កុំច្រឡំនឹង ព. transcendant); សញ្ញាតិសុខុមល្អិតណាស់ ; កំបាំងណាស់ ; ពិបាកនិយាយប្រាប់

transcender *v.t. Phil.* ហួស (ហួសវិស័យមនុស្សគិត) ។ *v.i. Par ext. & Fam.* ដារអតិសេដ្ឋ

transcontinental,e,aux *a.* ដែលកាត់ទ្វីប ។ *n.m.* ផ្លូវអយស្ម័យយានកាត់ទ្វីបអាមេរិក

transcripteur *n.m.* អ្នកចម្លង, អ្នកប្រែភាសា

transcription *n.f.* ប្រតិចារឹក, ប្រតិលេខ; ការចម្លង; សេចក្ដីចម្លង

transcrire *v.t.* ធ្វើប្រតិចារឹកឬប្រតិលេខ; ចម្លង; ប្រែភាសា

transe *n.f.* ភ័យចំប្រប់, សេចក្ដីខ្លាចខ្លាំង ។ transe médiumnique ដំណើរខ្មោចចូល (មើ. affres, angoisse, anxiété)

transfèrement *n.m.* ការផ្ទេរ (ការនាំយកមនុស្សពីទីមួយទៅទីមួយ) (ឧ. transfèrement cellulaire)

transférer *v.t.* ផ្ទេរ (នាំយកពីទីមួយទៅទីមួយ ឧ.transférer un prisonnier, une préfecture, d'une ville dans une autre; ពីម្នាក់ទៅម្នាក់ ឧ. transférer une inscription de rente); ដឹកនាំ

transfert *n.m.* ការផ្ទេរ (ការផ្លាស់បន្ទុកពីម្នាក់ទៅម្នាក់) ។ transfert de pouvoirs ការផ្ទេរអំណាច ។ លិខិតផ្ទេរកម្មសិទ្ធិ (ឧ. transfert de propriété); ការប្រគល់; ការដឹកនាំ (ឧ. transfert de reliques)

transfiguration *n.f.* ការផ្លាស់ភេទ; ការផ្លាស់រូបរាង ឬ ទ្រង់ទ្រាយ

transfigurer *v.t.* ផ្លាស់ភេទ; ផ្លាស់រូបរាង ឬ ទ្រង់ទ្រាយ

transfiler *v.t. Mar.* លើក ឬ ដោតបន្តគ្នា (ឧ. transfiler les tentes)

transformable *a.* ដែលផ្លាស់ទ្រង់ទ្រាយបាន; អាចប្រែប្រួលបាន

transformateur, trice *a.* ដែលផ្លាស់ទ្រង់ទ្រាយ ។

n.m.Electr. ប្រដាប់កែកម្លាំងបន្តអគ្គិសនី

transformation *n.f.* រូបបរិវត្តន៍, ការផ្លាស់ទ្រង់ទ្រាយ; ការប្រែប្រួល; ការប្លែងភាព

transformer *v.t.* រូបបរិវត្ត, ប្លែងភាព, ធ្វើឲ្យក្លាយ(ឧ.Circé transforma les compagnons d'Ulisse en pourceaux); ប្រែ (ប្រែឲ្យបម្រើន, ឲ្យល្អឡើង)(ឧ. ce séjour à la montagne l'a transformé); ផ្លាស់ទ្រង់ទ្រាយ, ធ្វើឲ្យក្លាយ។

se transformer *v.pr.* ក្លាយ (ឧ. la chenille se transforme en papillon); ប្រែប្រួលចរិត (ជាល្អ ឬ ជាអាក្រក់) (ឧ. cet enfant s'est bien transformé) (មើ. convertir, muer)

transformisme *n.m.* រូបបរិវត្តនិយម

transformiste *n.* អ្នករូបបរិវត្តនិយម។ *a.* រូបបរិវត្តនិយម (ឧ. théorie transformiste)

transfuge *n.m.* អ្នករត់ចូលខាងសត្រូវ។ *Fig.* អ្នករត់ចូលខាងបក្សប្រឆាំង; អ្នកកាន់មតិ ឬ យោបល់ផ្ទុយ (ផ្ទុយនឹងយោបល់ខ្លួនពីដើម)

transfuser *v.t.* ផ្ទេរ (រំគ្នារ); ចាក់

បញ្ចូលឈាម

transfusion *n.f.* ការចាក់បញ្ចូលឈាម (ឧ. la transfusion ne réussit qu'entre individus de groupes sanguins déterminés)

transgresser *v.t.* ល្មើស; ប្រព្រឹត្តកន្លង; បំពាន (សរ. enfreindre, violer)

transgresseur *n.m.* អ្នកល្មើស; អ្នកបំពាន

transgressif,ive *a.* ដែលបំពាន

transgression *n.f.* អជ្ឈាចារ, ការប្រព្រឹត្តកន្លង; ការបំពាន ។ transgression marine ដំណើររាតនៃសមុទ្រ (ដំណើរសមុទ្ររសាយមកលើភាគខ្លះនៃទ្វីប ដោយភាគដីនោះស្រុតចុះ ឬដោយទឹកសមុទ្រជោរឡើង) (ព.ផ. régression)

transhumance *n.f.* ការឃ្វាលចៀមលើភ្នំ (ក្នុងវស្សានរដូវ)

transhumant,e *a.* នៃហ្វូងសត្វដែលគេឃ្វាលនៅលើភ្នំ

transhumer *v.i.* ទៅស៊ីលើភ្នំក្នុងវស្សានរដូវ (ចៀម)

transi,e *a.* ញាក់ (ដោយខ្លាច, ដោយរងា) (ឧ. transi de froid)

transiger *v.i.* សម្រុះសម្រួលគ្នា (ឧ. il vaut mieux transiger que plaider); អត់អាស្រ័យឲ្យ ។ *Fig.* transiger avec son devoir មិនបំពេញការណីយកិច្ចខ្លួនដោយហ្មត់ចត់ ។ transiger avec sa conscience មិនប្រព្រឹត្តតាមជំនឿ ឬយោបល់ខ្លួន (សរ. s'accorder, composer, s'entendre)

transir [–sir ឬ zir] *v.t.* ធ្វើឲ្យរងា (ឧ. le vent du nord nous transit) ។ *Fig.* ធ្វើឲ្យញាក់(ដោយខ្លាចជាដើម) ។

v.i. ញាក់ (ដោយរងា ឬ ខ្លាច)

transistor *n.m.*(ព.អ.) ត្រង់ស៊ីស្ទ័រ

transit [– zit'] *n.m.* ការកាត់ឆ្លង; ការនាំកាត់ (ការនាំឆ្លងប្រទេសដោយគ្មានបង់ពន្ធ) (ឧ. les marchandises en transit sont dispensées du paiement des droits de douane)

transitaire [-zi-] *a.* ដែលនាំឆ្លងកាត់ (ដែលអនុញ្ញាតឲ្យឆ្លងប្រទេសដោយគ្មានបង់ពន្ធ) (ឧ. commerce transitaire); ដែលមានទំនិញឆ្លងកាត់ (ឧ. la France est un pays transitaire) ។

n.m. ពាណិជនាំឆ្លងកាត់, អ្នកនាំទំនិញឆ្លងប្រទេសដោយគ្មានបង់ពន្ធ

transiter [-zi-] *v.t.* នាំឆ្លងកាត់, នាំឆ្លងប្រទេសដោយគ្មានបង់ពន្ធ (ឧ. transiter des marchandises) ។

v.i. កាត់, ឆ្លងប្រទេសដោយគ្មានបង់ពន្ធ; សំចត

transitif,ve *a.* verbe transitif សកម្មកិរិយា

transition *n.f.* ស្ពាន, អន្តរភាព (ភាពជាចន្លោះ) (ឧ. passer sans transition de l'état féodal à la démocratie moderne); វិធី ឬការភ្ជាប់រឿង (ឧ. habile transition); ការឆ្លង (ឧ. une brusque transition)

transitivement *adv.* ជាសកម្ម

transitivité *n.f.* ភាពជាសកម្ម

transitoire [-zi-] *a.* អន្តរៈ, មិនឋិតថេរ (ឧ. loi transitoire); បណ្ដោះអាសន្ន, ជាស្ពាន (ឧ. règne transitoire) ។ disposition transitoire អន្តរបញ្ញត្តិ

transitoirement *adv.* ដោយមិនឋិតថេរ ជាបណ្ដោះអាសន្ន

transjuran,e *a.* ឯនាយភ្នំហ្ស៊ូរ៉ា

translatif,ive *a.* សម្រាប់បង្វែរ (កម្មសិទ្ធិ) (ឧ. acte translatif de propriété)

translation *n.f.* ការបង្វែរ; ការរំកិល; ការផ្លាស់កន្លែង (ឧ. la translation des cendres de Napoléon 1er)

translucide *a.* ថ្លាល្មៀង (ឧ. les verres dépolis sont translucides)

translucidité *n.f.* ភាពថ្លាល្មៀង

transmetteur *n.&a.m.* ប្រដាប់បញ្ជូនទូរលេខ

transmettre *v.t.* បញ្ជូន (ឧ. transmettre un ordre); ប្រគល់, ផ្ទេរ (ឧ. transmettre une propriété) ។ *Fig.* បង្អំ (ឧ. transmettre ses vertus à son fils); ចែកបព្វយទាន

transmigration *n.f.* វត្តប្រវេសន៍ (ដំណើរប្រជាជនចេញពីប្រទេសមួយទៅប្រទេសមួយ) ។ transmigration des âmes វដ្តសង្សារ, ដំណើរអន្តោលវិលកើតវិលស្លាប់

transmigrer *v.i.* ធ្វើវត្តប្រវេសន៍ (ប្រជា-

ដិខ); ទៅពីទីមួយទៅទីមួយឬពីប្រទេសមួយទៅប្រទេសមួយ; ជាប់កំណើតថ្មី, ជាប់បដិសន្ធិ

transmissibilité *n.f.* ភាពអាចបញ្ជូនបាន-អាចផ្ទេរបាន ឬ ចម្លងបាន

transmissible *a.* អាចបញ្ជូនបាន; អាចប្រគល់បាន; អាចផ្ទេរបាន; អាចចម្លងបាន (ឧ. tares transmissibles)

transmission *n.f.* បេសនា, ការបញ្ជូន; ការបញ្ជូនសារ; ការប្រគល់; ការផ្ទេរ (ឧ. transmission d'un droit) ។ transmission des pouvoirs ការប្រគល់អំណាច ។ transmission de pensée ម.ព. télépathie ។

pl. កង ឬ គ្រឿងបញ្ជូនសារ (ក្នុងកងទ័ព) (ឧ. service des transmissions)

transmuable ឬ **transmutable** *a.* អាចប្រែក្លាយបាន

transmuer ឬ **transmuter** *v.t.* ធ្វើឲ្យប្រែក្លាយ

transmutabilité *n.f.* ភាពអាចប្រែក្លាយបាន

transmutation *n.f.* ដំណើរប្រែក្លាយ (ឧ. transmutation des métaux)

transmuter *v.t.* ប្រែក្លាយ

transocéanique *a.* ឯនាយមហាសមុទ្រ; កាត់មហាសមុទ្រ

transparaître *v.i.* លេចចេញពីក្រោយរបស់ភ្លឺ ។ *Fig.* ឲ្យគេយល់, ឲ្យគេឃើញ (ឧ. laisser transparaître ses intentions)

transparence *n.f.* ភាពថ្លាធ្លុះ

transparent,e *a.* ថ្លាធ្លុះ (ឧ. le verre est transparent) ។ *Fig.* ដែលឲ្យយល់ (ចំពោះន័យកំបាំង) (ឧ. allusion transparente) ។

n.m. ក្រដាសបន្ទាត់ (សម្រាប់ផ្ទាប់ពីក្រោមក្រដាសណាត់ដើម្បីសរសេរតាមបន្ទាត់នោះ)

transpercer *v.t.* ទម្លុះពីម្ខាងទៅម្ខាង (ឧ. transpercer le mont Cenis); ជ្រាបចូល (ឧ. la pluie ne peut transpercer un vêtement imperméable)

transpirable *a.* *Méd.* អាចបញ្ចេញចោលតាមញើសបាន

transpiration *n.f.* ដំណើរបែកញើស (ឧ. être en transpiration)

transpirer *v.i.* បែកញើស ។ *Fig.*

បែកការណ៍, លេចឮ (ឧ. laisser transpirer un secret)

transplantable *a.* អាចលើកយកទៅដាំបាន

transplantation *n.f.* ការដាំ, ការលើកយកទៅដាំ (ជា transplantement ក៏បាន)។ transplantation en motte ការដាំភ្ជាប់ដី។ transplantation à racine nue ការដាំឫសលាត

transplanter *v.t.* ដាំ, លើកយកទៅដាំ (ឧ. transplanter des arbres)។ *Fig.* ផ្ទេរ, ដឹកនាំ (ឧ. transplanter une colonie)

transport *n.m.* ការដឹកនាំ (ឧ. transport de marchandises); ពាហនយាន (ក្នុងកងទ័ព); កិច្ចប្រគល់អរូបីវត្ថុ។ *Fig.* ចិត្តស្មុះស្មា; ការស្មុះស្មា, ការរំភើបចិត្តខ្លាំង (ឧ. transport de joie)។

transport commun ពាហនយាន ឬ ការដឹកនាំសាធារណៈ។ transport direct ការដឹកនាំរហូត។ transport de justice ដំណើរចៅក្រមទៅពិនិត្យដល់កន្លែងកើតរឿងហេតុ។ transport de force ការដឹកនាំកម្លាំងអគ្គិសនី (តាមខ្សែ)។ *pl.* មធ្យោបាយដឹកនាំ (ឧ. la coordination des transports)

transportable *a.* អាចដឹកនាំបាន (ឧ. blessé transportable)

transportation *n.f.* ទោសត្រូវធ្វើការដោយបង្ខំ ឬ ត្រូវបង្ខាំងនៅក្រៅប្រទេស (ឧ. en France la transportation à la Guyane a été supprimée en 1938)

transporter *v.t.* ដឹកនាំ (ឧ. transporter des voyageurs); បញ្ចូល (ឧ. transporter sur la scène un fait historique); ផ្ទេរ (ដោយលិខិត) (ឧ. transporter une créance)។ *Fig.* ធ្វើឲ្យស្មុះស្មាឬឲ្យរំភើបខ្លាំង (ឧ. la fureur le transporte)។

se transporter *v.pr.* ទៅកាន់កន្លែងណាមួយ; គិតដល់ (ឧ. transportez-vous dans le passé) (*tt.* déménager déporter, transiter, véhiculer, voiturer)

transporteur *n.&a.m.* ប្រដាប់ដឹក

នាំដោយស្វ័យប្រវត្តិ; អ្នកដឹកនាំ (ឧ. un transporteur routier)

transposable *a.* អាចផ្លាស់កន្លែងបាន ។ *Mus.* អាចផ្លាស់សម្លេងបាន

transposer *v.t.* ផ្លាស់កន្លែង (ឧ. transposer un mot, une lettre) ។ *Mus.* ផ្លាស់សម្លេង (តន្ត្រី)

transpositeur *a. Mus.* instrument transpositeur ប្រដាប់ផ្លាស់សម្លេង

transposition *n.f.* ការផ្លាស់កន្លែង។ *Mus.* ការផ្លាស់សម្លេង

transpyrénéen,enne *a.* ឯនាយភ្នំពីរ៉េណេ; ដែលកាត់ភ្នំពីរ៉េណេ

transrhénan,e *a.* ឯនាយទន្លេរ៉ែន

transsaharien,enne *a.* ដែលកាត់វាលខ្សាច់សាហារ៉ា

transsibérien,enne *a.* ឯនាយដែនស៊ីបេរី; ដែលកាត់ស៊ីបេរី (ឧ. chemin de fer transsibérien)

transsonique *a.* ទៀបល្បឿនសម្លេង

transsudation *n.f.* ដំណើរជ្រាប (ឧ. la transsudation de l'eau)

transsuder *v.i.* ជ្រាប

transvasement *n.m.* ការផ្ទេរភាជន៍

transvaser *v.t.* ផ្ទេរភាជន៍ (ឧ. transvaser du vin)

transverbérer *v.t.* ទម្លាយ (បេះដូង)

transversal,e, aux *a.* វិភ្លោក, ទទឹង, ជៀង (ឧ. ligne transversale)។ *n.f. Math.* វិភ្លោករេខា, បន្ទាត់ពុះ

transversalement *adv.* ដោយទទឹង, ដោយជៀង

transverse *a.* ជៀង ។ *Anat.* ទទឹង (ឧ. artère transverse)

transvider *v.t.* ផ្ទេរឲ្យអស់លើង

tran-tran *n.m.* ម.ព. train-train

trapèze *n.m.* ចតុរស្សព្នាយកោក ។ trapèze isocèle ចតុរស្សព្នាយកោកទ្វេសមបាត ។ trapèze rectangle ចតុរស្សព្នាយកោកកែង ។ *Sports.* ទោង (ប្រៀងហាត់ប្រាណ)។ *Anat.* សាច់ដុំខ្នង (ឧ. le trapèze rapproche l'omoplate de la colonne vertébrale)

trapéziste *n.m.* អ្នកកីឡាយោលទោង

trapézoèdre *n.m.* ចតុតលព្នាយកោក (មើ. rhomboèdre)

trapézoïdal,e, aux *a.* ជាចតុរស្សព្នាយកោក

trappe *n.f.* ឃ្នាប (ទ្វារបិទប្រហោងពោះនោម; ប្រហោងពោះទៅរនាប); ទ្វារ ឬបង្អួចរូត; អន្ទាក់ (ដាក់ពីលើរណ្តៅ)

trappeur *n.m.* ព្រានអង្គប់

trappillon [-you] *n.m.* គន្លឹះបិទរបួប ឬ អង្គប់

trapu,e *a.* ក្រអាញ, កន្លាញ, កន្លា (ឧ. homme trapu)

traque *n.f.* ការលើកសត្វ, ការកៀងសត្វ

traquenard *n.m.* អន្ទាក់សត្វចាប់ស្រៀ ។ *Fig.* ឧបាយកល (ឧ. tomber dans un traquenard)

traquer *v.t.* លើកសត្វ (ឧ. traquer un cerf) ; ដេញតាមព្រួតក (ឧ. traquer un voleur)

traqueur,euse *n.* អ្នកលើកសត្វ

traumatique *a.* នៃដំបៅ, នៃរបួស (ឧ. hémorragie traumatique)

traumatisme *n.m.* ជម្ងឺបណ្ដាលអំពីដំបៅ ឬ របួស

travail, *pl.* **travaux** *n.m.* ការងារ (ឧ. travail manuel; travail intellectuel) ; ការ (ដែលត្រូវធ្វើ) (ឧ. distribuer le travail aux ouvriers); វិធី ឬ របៀបធ្វើ (ឧ. bijou d'un beau travail); ដំណើរបោរ ឬ ស្រក (ឧ. le travail des bois produit souvent des fentes) ។ le travail កម្លាំងកិត, ដំណើរស្បែនរីកត្បូក ក្នុងពេលស្ត្រីឆ្លងទន្លេ (ឧ. femme en travail) ។ *Phys.* កម្លាំង ។

accident de travail គ្រោះថ្នាក់ក្នុងការងារ ។ homme de travail អ្នកចិញ្ចឹមជីវិតដោយធ្វើការងារធ្ងន់ ។ maison de travail ផ្ទះសម្រាប់អ្នកទោសធ្វើការងារ ។ travail manuel ការហត្ថកម្ម ។ travaux forcés ទោសឲ្យធ្វើការដោយបង្ខំ ។ travaux publics សាធារណការ

travail *n.m.* ឡើងបង្ក្រៀកសត្វ (*pl.* des travails)

travaillé,e *a.* ដែលធ្វើដោយផ្ចិតផ្ចង់ (ឧ. ouvrage travaillé; style travaillé) ។ *Fig.* ដែលនឹកមមៃ (ឧ. travaillé par une idée); ដែលធ្វើឲ្យខ្វល់ឬធ្វើឲ្យឈឺចាប់ (ឧ. travaillé par la maladie)

travailler *v.i.* ធ្វើការ (ឧ. travailler dans l'imprimerie) ; ខំប្រឹង (ឧ. travailler à perdre quelqu'un) ។ *Fig.* បោរឬស្រក (ឧ. le bois vert travaille); កើតផល (ឧ. faire travailler son ar-

gent); ឡើង ឬ ក្លាយ (ឧ. le vin nouveau travaille) ។

travailler pour quelqu'un ធ្វើការឲ្យអ្នកណាម្នាក់, ជួយយកអាសា ។ travailler contre quelqu'un ធ្វើការប្រឆាំងនឹងអ្នកណាម្នាក់ ។

v.t. ទំនិតទំនង់ (ឧ. travailler le style) ។ *Fig.* ធ្វើឲ្យខ្វល់ ឬ ឲ្យឈឺចាប់ (ឧ. la fièvre le travaille) ។ travailler le fer ដំដែក ។ travailler les esprits បញ្ចុះបញ្ចូល; នាំអុជអាល

travailleur,euse *a.* ដែលស្រឡាញ់ការងារ ។ *n.* កម្មករ, អ្នកធ្វើការ; អ្នកស្រឡាញ់ការងារ ។ *n.f.* តុធ្វើការ ។ *pl.* ក្រុមអ្នកធ្វើការ (កម្មករ) (ឧ.les législations sociales ont pour objet de protéger les travailleurs)

travaillisme *n.m.* កម្មករនិយម

travailliste *n.m.* អ្នកកម្មករនិយម

traveau *n.m.* ឬ **travette** *n.f.* រនូត

travée *n.f.* ល្វែង; ចន្លោះរនូត; ជួរជើងម៉ា (ឧ. les travées d'une assemblée)

travelage *n.m.* ប្រឡោះផ្លូវអយស្ម័យយាន (ប្រឡោះពីដែកមួយទៅដែកមួយ)

travers *n.m.* ទទឹង (ឧ.un travers de doigt); ទិសខុស; អំពើដែលខុស; គុណវិបត្តិ; ភាពចម្លែក (ឧ. travers d'esprit) ។

en travers *loc. adv.* កាត់ទទឹង ។ à tort et à travers *loc. adv.* ទទឹងទទែង, ផ្តេសផ្តាស ។ de travers *loc. adv.* ពីចំហៀង; ទទឹងទិស ។ regarder de travers សម្លក់ (ដោយខឹង) ។ entendre de travers ស្តាប់ខុស, ស្តាប់ភាន់ ។ à travers *loc. pré.* កាត់ (ឧ. à travers champs); ពីក្រោយ (ឧ. à travers sa bonhomie s'aperçoit son intransigeance) ។ au travers de *loc. pré.* កាត់; ពុះទម្លាយ (ឧបសគ្គ) (ឧ. au travers de l'ennemi)

traversable *a.* អាចឆ្លងកាត់បាន (ឧ. rivière traversable)

traverse *n.f.* ឈើទទឹង; ធ្នឹម; ផ្លូវកាត់ (ឧ. chemin de traverse); កំណល់ (ផ្លូវអយស្ម័យយាន) ។ se

mettre à la traverse ភាគខ្ទីរ; បង្កើតឧបសគ្គ ។

pl. ឧបសគ្គ, អន្តរាយ (ឧ. rencontrer bien des traverses sur son chemin)

traversée *n.f.* ការឆ្លងកាត់; សមុទ្រយាត្រា; ការឆ្លងសមុទ្រ; ចម្ងាយឆ្លងសមុទ្រ; ដំណើរតាមសមុទ្រ; ដំណើរកាត់ប្រទេស។ traversée de voie កន្លែងផ្លូវដែកយានយន្តកាត់គ្នា

traverser *v.t.* ឆ្លងកាត់ (ឧ. traverser une forêt, la rue); កាត់ទម្លុះ,ទម្លាយ,ជ្រាបចូល (ឧ. la pluie a traversé mes habits); កាត់ (ឧ. des allées traversent le jardin)។ *Fig.* ឆ្លងកាត់, រស់នៅក្នុងពេល... (ឧ. traverser des temps malheureux)

traversier,ère *a.* សម្រាប់ឆ្លងកាត់ (ឧ. barque traversière)

traversin *n.m.* ខ្នើយឧប ។ *Techn.* សន្លឹកក្តារបាតធុង; ដងជញ្ជីង

traversine [-vèr-] *n.f.* ធ្នឹម

travesti *n.m.* សំលៀកបំពាក់សម្រាប់ក្លែង; តួអ្នកក្លែង (ល្ខោន) (ឧ. jouer les traverstis)

travestir *v.t.* ក្លែង ។ *Fig.* បំប្លែង (ប្រែសៀវភៅរបស់ទេព្យ ដោយប្រើពាក្យគ្រោតគ្រាត); ក្លែង (បកស្រាយខុស) (ឧ. travestir une pensée) ។

se travestir *v.pr.* ស្លៀកពាក់ក្លែងខ្លួន

travestissement *n.m.* ការក្លែង, ការស្លៀកពាក់ក្លែងខ្លួន; ការបំប្លែង

traviole (de) *loc. adv. Pop.* ពីចំហៀង; ទទឹងទិស

trayeur,euse *n.* អ្នករឹតទឹកដោះគោ ។

n.f. ប្រដាប់រឹតទឹកដោះគោ

trayon [trè-yon] *n.m.* សណ្តាន់ដោះគោ

trébuchant,e *a.* ធ្ងន់, ដែលធ្វើឲ្យប៉ះជញ្ជីង (រូបិយវត្ថុប្រាក់ ឬ មាស) (ឧ. espèces sonnantes et trébuchantes)

trébucher *v.i.* ជំពប់ (ឧ.trébucher sur une pierre); មិនទឹងជំហរ; ដាក់ឲ្យប៉ះជញ្ជីង (ឧ. quand on pèse une monnaie d'or il faut qu'elle trébuche)។ *Fig.* ភាំងភ្លាត់ (ឧ. la raison humaine trébuche souvent)។

v.i. ថ្លឹងនឹងជញ្ជីងត្រាជូ (ឧ.

trébucher des pièces d'or)

trébuchet *n.m.* ជង់; ជញ្ជីងក្រាជ្ញ

tréfilage *n.m.* ការហូតលួស

tréfiler *v.t.* ហូតលួស

tréfilerie *n.f.Ind.* រោងចក្រហូតលួស

tréfileur *n.m.* អ្នកហូតលួស; ឧស្សាហករហូតលួស

tréfonds *n.m.* បាតដី ។ *Fig.* ការសម្ងាត់បំផុត (ឧ. savoir le fond et le tréfonds d'une affaire)

treillage *n.m.* ប្រដឹស; ទ្រើង

treiller *v.t.* ដាក់ប្រដឹស; ធ្វើទ្រើង

treillageur *n.m.* អ្នកធ្វើប្រដឹស

treille *n.f.* ទំពាំងបាយជូរឡើងទ្រើង ។ le jus de la treille ស្រាទំពាំងបាយជូរ

treillis *n.m.* របងប្រដឹស; ប្រដឹស; ក្រើយ(សំលោះខ្មៅនៅ) (ឧ. pantalon de treillis)។ *Par ext.* សំលៀកបំពាក់ក្រើយ (សម្រាប់ធ្វើការឬសម្រប់ហាត់)(ឧ.se mettre en treillis)

treillisser *v.t.* ដាក់ប្រដឹស(ឧ. treillisser une fenêtre)

treizaine *n.f.* ត្រីទសកៈ, ចំនួន ១៣, ប្រមាណជា ១៣

treize *a.num.* ដប់បី ។ treize à la douzaine ការឲ្យល្អាប់(ការប្រគល់វត្ថុ ១៣ បើគេទិញតែ ១២); ទី១៣ (ឧ. Louis treize) ។

n.m. ចំនួន ១៣; ថ្ងៃទី ១៣

treizième *a.num.ord.* ទី ១៣, លេខ ១៣ ។ *n.* អ្នកទី១៣ ។ *n.m.* ភាគ ១៣

treizièmement *adv.* ទី ១៣

tréma *n.m.* ត្រេម៉ា (ចំណុចពីរដាក់លើអក្សរ e, i, u,)

trémail *n.m.* ម.ព. tramail

trématage *n.m.* ការដែង ។ droit de trématage សិទ្ធិទៅមុនគេ (ចំពោះនាវិកខ្លះ)

trémater *v.i.* ដែង (នាវា)

trématodes *n.m. pl.* ព្រូនសត្វ(រាងសំប៉ែត) (*sing.* un trématode)

tremblant,e *a.* ដែលញ័រ (ឧ. main, voix tremblante);ដែលរញ្ជួយ។ *Fig.* ដែលខ្លាចញាក់(ខ្លាចខ្លាំង)(ឧ. il était tout tremblant)

tremblante *n.f.* រោគញាក់ (ជម្ងឺសត្វចៀម)

tremblé,e *a.* écriture tremblée អក្សរសរសេរដោយញ័រដៃ ។ sons tremblés សម្លេងញ័រ

tremblement *n.m.* ការញ័រ (ឧ. tremblement de main); ការរញ្ជួយ ។ *Mus.* បង្ហាក់ញាប់ (តន្ត្រី) ។ tremblement de terre ភូមិចាល, ការរញ្ជួយដី

trembler *v.i.* ញ័រ, រញ្ជួយ (ឧ. le plancher tremble); ញាក់ (ឧ. trembler de froid)។ *Fig.* ខ្លាចញ័រ; ខ្លាច (ឧ. je tremble qu'il n'apprenne trop vite cette malheureuse nouvelle) (ពៅ. frémir, frissonner, grelotter)

trembleur,euse *n.* អ្នកខ្លាច, អ្នកម្ងូរម្ងុៗ

tremblotant,e *a.* ដែលញ័រ (ឧ. voix tremblotante; lumière tremblotante)

tremblote *n.f. Pop.* avoir la tremblote ញ័រ, ខ្លាច

tremblotement *n.m. Fam.* ការញ័រតិចៗ

trembloter *v.i. Fam.* ញ័រតិចៗ

trémolo *n.m.* សម្លេងស្ទួនញាប់ (ឧ. le trémolo est utilisé par les instruments à arche)

trémoussement *n.m.* ការកម្រើក; ការទទះ (ឧ. trémoussement d'ailes); ការលោត

trémousser (se) *v.pr.* កម្រើក; លោតអន្ទើល ។ *Fig.&Fam.* ទំប្រឹងខ្លាំង

trempage *n.m.* ការជ្រលក់ទឹក

trempe *n.f. Ind.* ការលត់ដែក; ភាពដែកលត់ ។ *Fig.* ភាពរឹង (ចរិត) (ឧ. âme de forte trempe) ។ *Fam.* ទណ្ឌកម្មធ្ងន់, ការស្តីប្រដៅច្រើន (ឧ. recevoir une trempe)

tremper *v.t.* ជ្រលក់ទឹក; ជ្រលក់ (ឧ. tremper sa plume dans l'encre); ផ្សើម (ឧ. tremper son mouchoir de larmes); លត់ដែក ។

tremper la soupe ដាក់ស៊ុបលើនំប៉័ង ។ tremper le vin លាយទឹកស្រា ។ être trempé ទទឹកជោក ។ *Fig.* tremper ses mains dans le sang ធ្វើមនុស្សឃាត, សមគំនិតក្នុងឃាតកម្ម ។

v.i. នៅត្រាំទឹក។ *Fig.* tremper dans un crime ឬ dans un complot ចូលដៃ ឬ សមគំនិតក្នុងបទឧក្រិដ្ឋ ឬ ក្នុងការក្បត់

trempette *n.f. Fam.* នំប៉័ងជ្រលក់

ស៊ុប (ឬ ត្រលក់ទឹកផ្សេងៗ) ។ *Fam.* ងូតទឹកដោយប្រញាប់ប្រញាប់

trempeur *n. & a. m.* ជាងលត់ដែក (ឧ. trempeur d'acier); ជាងត្រលក់ (ឧ. trempeur de papier)

tremplin *n.m.* ឈ្នាន់លោត (ក្ដារស្ពានសម្រាប់លោតទឹក) ។ *Fig.* បតិដ្ឋាន, មធ្យោបាយ(សម្រាប់ប្រើឲ្យបានសម្រេច)

trémulation *n.f.* ដំណើរញាក់

trench-coat [trènch-kôt] *n.m.* (ព.អ.)អាវភ្លៀង(*pl.* des trench-coats)

trentaine *n.f.* តិង្សកៈ, ចំនួន ៣០, ប្រមាណជា ៣០; អាយុ៣០ឆ្នាំ

trente *a.num.* សាមសិប; ទី ៣០ (ឧ. page trente) ។

n.m. ចំនួន៣០; ថ្ងៃទី ៣០ (ឧ. le trente janvier) ។ *Fam.* se mettre sur son trente et un ស្លៀកពាក់ល្អ

trente-et-quarante *n.m. inv.* ល្បែងបៀម្យ៉ាង

trentenaire *a.* តិង្សវ័យ, ដែលមិតនៅ ៣០ឆ្នាំ (ឧ.la possession trentenaire opère la prescription)

trentième *a. num.ord.* ទី ៣០ ។

n. អ្នកលេខ ៣០ (ឧ. être le ឬ la trentième) ។

n.m. ភាគ ៣០

tréou *n.m. Mar.* ក្ដោងបួនជ្រុងស្មើ (ប្រើក្នុងពេលមានព្យុះ)

trépan *n.m.* ប្រដាប់ខួងឆ្អឹង(ឆ្អឹងលលាដ៍ក្បាល) ។ *Par ext.* ការខួងឆ្អឹង ។

Techn. ដែកខួងវត្ថុរឹង; ប្រដាប់ខួងដី

trépanation *n.f.* ការខួងឆ្អឹង; ការខួង

trépaner *v.t.* ខួងឆ្អឹង (ឧ. trépaner un blessé) ; ខួង

trépas *n.m.* មរណភាព (ប្រើក្នុងកាព្យឃ្លោង)។ *Fam.* passer de vie à trépas ស្លាប់

trépassé,e *n.* មនុស្សស្លាប់(ឧ. prier pour les trépassés)។ le jour ឬ la fête des trépassés ថ្ងៃទី ២ វិច្ឆិកា (បុណ្យរំឭកអ្នកស្លាប់)

trépasser *v.i.* ស្លាប់

trépidant,e *a.* ចំប្រប់, រំពើក ។ allure trépidante ដំណើររំពើក

trépidation *n.f.* ដំណើរញ័រអរិយាបថៈឬញ័រសរសៃ; ដំណើរញ័រ(ឧ.la tripi-

dation des vitres)

trépider *v.i.* ញ័រញ៉ូប ឬ រំពើក

trépied *n.m.* ត្រីជាទក៏ឈ្នា, ជើងក្រាង ជើង ៣; កៅអីជើង ៣

trépignée *n.f.* *Pop.* ការវាយខ្លាំង

trépignement *n.m.* ការគន្រ្ទឹ, ការប្រំជើង

trépigner *v.i.* គន្រ្ទឹ (ឧ. trépigner de colère) (ម៉ើ.piaffer, piétiner); ប្រំជើង

trépointe *n.f.* *Techn.* បន្ទះស្បែកទ្រនាប់ (សម្រាប់ទ្រាប់បន្ទះស្បែកប្រាស់ពីរ)

très *adv.* ណាស់, ក្រៃពេក, ក្រៃលែង ។ très bien ល្អណាស់ ។ très mal អាក្រក់ណាស់

trésor *n.m.* រតនសម្បត្តិ, វត្ថុដែលមានតម្លៃឬមានប្រយោជន៍(ឧ.découvrir un trésor caché); រតនាគារ; កំណប់(ឧ.trouver un trésor) ។ *Fig.* សម្បត្តិ (វត្ថុមានតម្លៃ - ប្រសើរ ឬ មានប្រយោជន៍ច្រើន) (ឧ. la santé est un trésor); មនុស្ស ឬ វត្ថុដែលគេស្រឡាញ់ខ្លាំង ។ les trésors de Cérès ម.ព. cérès ។ les trésors de Bacchus ទំពាំងបាយជូរ ។ les trésors de l'automne ក្រូចផល(ផ្លែឈើ) ។ trésor général អគ្គរតនាគារ ។ trésor national រតនសម្បត្តិជាតិ; រតនាគារជាតិ

trésorerie *n.f.* រតនាគារភិបាល; ក្រុមរតនាគារ; ប្រាក់ដែលគេអាចចាយវាយបានភ្លាម (ឧ.les valeurs mobilières et les effets de commerce aisément négociables sont considérés comme des éléments de la trésorerie); រតនាគារិកដ្ឋាន; ហេរញ្ញិកដ្ឋាន; ហិរញ្ញវត្ថុដ្ឋាន; ក្រសួងហិរញ្ញវត្ថុ(នៅប្រទេសអង់គ្លេស) (ឧ. les lords de la Trésorerie) ។ trésorerie nationale រតនាគារជាតិ

trésorier, ère *n.* ហេរញ្ញិក-កា ។ trésorier général អគ្គហេរញ្ញិក ។ trésorier-payeur ហេរញ្ញិកបើកប្រាក់ (*pl.* des trésoriers-payeurs) ។ trésorier-payeur général អគ្គហេរញ្ញិកបើកប្រាក់ (*pl.* des trésoriers-payeurs généraux) ។

n.f. ហេរញ្ញិកា

tressage *n.m.* ការក្រង, ការត្បាញ

tressaillement *n.m.* ការញាក់; ការព្រឺ; ការភ្ញាក់

tressailli *a.m.* nerf — tendon tressailli សរសៃភ្លាត់(ដោយខំប្រឹងខ្លាំង)

tressaillir *v.i.* ញាក់; ព្រឺ; ភ្ញាក់ (ឧ. tressaillir de joie)

tressaut *n.m.* ការភ្ញាក់

tressauter *v.i.* ភ្ញាក់ (ដោយភ័យខ្លាច ជាដើម) (ឧ. tressauter devant un danger)

tresse *n.f.* កន្ទ្រង; ខ្សែក្រងសំប៉ែត

tresser *v.t.* ក្រង (ឧ. tresser des cheveux); ត្បាញ

tresseur,euse *n.* អ្នកក្រង, អ្នកត្បាញ

tréteau *n.m.* ជើងម៉ា ។ monter sur les tréteaux ចូលលេងល្ខោន

treuil *n.m.* កង្ហារ; ប្រដាប់ទាញ

trêve *n.f.* បទឈប់ស្រប, ការផ្អាកសង្គ្រាម; ការផ្អាក; ដំណើរស្រាកស្រាន្ត (ឧ. son mal ne lui donne pas de trêve) ។ n'avoir ni trêve ni repos គ្មានស្រាកស្រាន្ត; គ្មានសម្រាកសោះ ។ trêve de plaisanteries ការឈប់និយាយលេង

tri *n.m.* ការស្រាស់ជ្រើស (ឧ. le tri des lettres)

triade *n.f.* ការប្រជុំវត្ថុ ៣ ឬមនុស្ស ៣ នាក់

triage *n.m.* ការស្រាស់ជ្រើស (ឧ. le triage de la houille); វត្ថុស្រាស់ជ្រើស

triangle *n.m.* ត្រីកោណ ឬត្រីប្រង្ស ។ triangle équilatéral ត្រ.ស. équilatéral ។ triangle isocèle ត្រីកោណទ្វេសមបាទ ។ triangle rectangle ត្រីកោណកែង ។ triangle scalène ម.ស. scalène

triangulaire *a.* ជាត្រីកោណ (ឧ. lame triangulaire); ដែលមានបាតជាត្រីកោណ (ឧ. pyramide triangulaire) ។ *Fig.* រវាង ៣ ក្រុម (ឧ. tournoi triangulaire de bridge) ។ — *n.m.* ឈ្មោះស្អាប់ធ្មុំខ្លះដែលមានរាងជាត្រីកោណ

triangulairement *adv.* ជាត្រីកោណ

triangulation *n.f.* ត្រីកោណវិធី (វិធីបែងផែនដីជាត្រីកោណដើម្បីគូរផែន-

ទី) ។ triangulation générale ត្រីកោណវិធីទូទៅ ។ triangulation subsidiaire ត្រីកោណវិធីបន្ទាប់បន្សំ

trianguler *v.t.* ធ្វើត្រីកោណវិធី

triatomique *a.* ត្រីបរមាណូ, ដែលមានបរមាណូ ៣

tribal,e *a.* នៃកុលសម្ពន្ធ ។ organisation tribale អង្គការកុលសម្ពន្ធ (អង្គការដែលមានកុលសម្ពន្ធជាមូលដ្ឋាន)

triballe *n.f.* ដែកដំស្បែកឲ្យទន់

triballer *v.t.* ដំស្បែកឲ្យទន់

tribart *n.m.* ណែងណង (សម្រាប់បំពាក់កសត្វកុំឲ្យរត់ឬកាត់របងរួច)

tribasique *a.* ត្រីបាស, ដែលមានបាស៣

tribo-électricité *n.f.* អគ្គិសនីកើតអំពីការកកិតគ្នា

tribométrie *n.f.* វិទ្យាសាស្ត្រខាងកម្លាំងកកិតគ្នា

tribord *n.m.* *Mar.* ខែមស្តាំនៃនាវា (មើលពីកន្សៃទៅក្បាល)(ឧ. le feu du tribord est vert) (ព.ផ. babord)

tribordais *n.m.* អ្នកយាមខែមស្តាំនៃនាវា

triboulet *n.m.* *Techn.* ខ្នាតវង់ចិញ្ចៀន

tribu *n.f.* កុលសម្ពន្ធ

tribulation *n.f.* ទុក្ខព្រួយ(ខាងផ្លូវចិត្ត) (ឧ.il a passé par de nombreuses tribulations)

tribun *n.m.* មន្ត្រីការពារសិទ្ធិនិងប្រយោជន៍រាស្ត្រ

tribunal *n.m.* តុលាការ (ឧ. comparaître devant le tribunal); សាលាក្តី; ចៅក្រម (ឧ.le tribunal se déclare suffisamment éclairé) ។ *Fig.* អ្វីៗដែលអាចសម្រេចសេចក្តីបាន (ឧ. le tribunal de la conscience) ។ le tribunal de la pénitence ម.ព. confessionnal ។ tribunal administratif សាលាក្តីរដ្ឋបាល ។ tribunal civil សាលាក្តីរដ្ឋប្បវេណី ។ tribunal de commerce សាលាក្តីពាណិជ្ជកម្ម ។ tribunal des conflits សាលាក្តីសង្ឃ័ជ ។ tribunal correctionnel សាលាមជ្ឈិម ។ tribunal d'exception សាលាក្តីអសាមញ្ញ ។ tribunal judiciaire

សាលាក្ដីតុលាការ ។ tribunal militaire សាលាក្ដីយោធា។tribunal ordinaire ou de droit commun សាលាក្ដីធម្មតាឬបទសាមញ្ញ។ tribunal de première instance សាលាដំបូង ។ tribunal répressif សាលាក្ដីនិគ្រោះ ។ tribunal martial សាលាក្ដីអាជ្ញាសឹក

tribunat *n.m.* ដំណែងមន្ត្រីអ្នកការពារសិទ្ធិនឹងប្រយោជន៍រាស្ត្រ

tribune *n.f.* វេទិកា ។ éloquence de la tribune វោហារខាងផ្នែកផ្លូវនយោបាយ ។ tribune libre វេទិកាសេរី

tribut *n.m.* សួយសារ, សួយសារអាករ, ពន្ធ, អាករ ។ *Fig.* អ្វីៗដែលគេត្រូវបង់ឲ្យធ្វើ-ឡើង ឬ ឲ្យឲ្យ (ឧ. payer tribut à la tradition)។ payer le tribut à la nature ស្លាប់

tributaire *a.* សុង្គ្រាយក, ដែលត្រូវឡើងសួយសារអាករ ឬ ត្រូវបង់អាករ ។ *Fig.* ដែលនៅក្នុងអំណាច ឬ ក្រោមអំណាច (ឧ. être tributaire de l'étranger pour le charbon); ដែលហូរធ្លាក់ទៅក្នុងទន្លេមួយទៀតឬទៅក្នុងសមុទ្រ (ទន្លេ) ។ *n.* សុង្គ្រាយក

tricennal,e,aux *a.* ដែលមានរយះពេល ៣០ ឆ្នាំ

tricentenaire *n.m.* ត្រីសតវស្សាយុក; ត្រីសតវស្សពិធី

tricéphale *a* ត្រីសិរ, ដែលមានក្បាល ៣ (ឧ. monstre tricéphale)

triceps *n.m.* សាច់ដុំដែលមានសរសៃរយោង ៣ (ឧ. triceps brachial)

triche *n.f. Fam.* ការបន្លំ (ឧ. obtenir quelque chose à la triche)

tricher *v.t. & i.* បន្លំ (ក្នុងល្បែង) ។ *Par ext.* បន្លំ

tricherie *n.f.* ការបន្លំ (ក្នុងល្បែង)

tricheur,euse *n.* អ្នកបន្លំ

trichine [-kin' ឬ chin'] *n.f.* ដង្កូវនៅក្នុងសាច់ជ្រូក

trichinose *n.f.* រោគបណ្ដាលអំពីដង្កូវក្នុងសាច់

tricoises *n.f. pl.* ដង្កាប់ដាងគោះក្រចកសេះ

tricolore *a.* ត្រីពណ៌, ដែលមានពណ៌ ៣ ។ le drapeau tricolore ទង់ជាតិបារាំង

tricorne *a.* ដែលមានជ្រុង ៣ ដាក់ស្នែង ។ *n.m.* មួកក្រុមអាវុធហត្ថ (មានជ្រុង ៣)

tricot *n.m.* សំពត់ចាក់; អាវយឺត

tricotage *n.m.* ការចាក់; សំពត់ចាក់

tricoter *v.t.* ចាក់ (សំពត់) ។ *v.i.* ធ្វើអាវយឺត ។ *Pop.* ដើរយ៉ាងលឿន

tricoteur,euse *n.* អ្នកចាក់ ។ *n.f.* ម៉ាស៊ីនចាក់

tricouni *n.m.* ដែកបោះបាតស្បែកជើងអ្នកឡើងភ្នំ

tricuspide *a.* ដែលមានចុង ៣ (ឧ. valvule tricuspide)

tricycle *n.m.* ត្រីចក្រយាន, រទេះកង់បី

tridactyle *a.* ដែលមានម្រាមបី

trident *n.m.* ត្រីសូល, លំពែងមុខបី; ឈ្នក

tridenté,e *a.* ដែលមានផ្នែកបី (ស្លឹកឈើ) (ឧ. feuille tridentée)

triduum *n.m.* ធម៌សូត្រ ៣ ថ្ងៃ

trièdre *n.m.* *Math.* ត្រីទ្រល[-តល់], ប្រសព្វប្លង់បី

triennal,e,aux *a.* ត្រីវស្ស, ដែលប្រព្រឹត្តទៅបីឆ្នាំ, សម្រាប់បីឆ្នាំ (ឧ. plans d'équipement triennaux); ដែលមានបីឆ្នាំម្ដង

triennat *n.m.* ត្រីវស្ស, រយៈពេលបីឆ្នាំ; ការបំពេញមុខងារអស់រយៈពេលបីឆ្នាំ

trier *v.t.* ស្រាល់ជ្រើស (ឧ. trier des graines) ។ *Fig.* trier sur le volet ស្រាល់ជ្រើសដោយហ្មត់ចត់ (ម.ស. classer, sélectionner)

trieur,euse *n.* អ្នកស្រាល់ជ្រើស ។ *n.m.* ម៉ាស៊ីនស្រាល់ជ្រើសគ្រាប់; ម៉ាស៊ីនផ្ដួចភោមបៀម

trifide *a.* *Hist. nat.* ដែលបែកជា ៣ ភាគ (ឧ. graine trifide)

triflore *a.* ត្រីបុប្ផា, ដែលមានផ្កាបី

trifolié,e *a.* ត្រីបត្រ, ដែលមានស្លឹកតូចបីៗ

trifouiller *v.i.* *Fam.* រុករើកាត់រាយ

trigémellaire *a.* ត្រីគភ៌, ដែលមានទារក ៣ (ផ្ទៃ)

trigéminé,e *a.* ជាបីៗ

trigone *a.* ត្រីកោណ, ដែលមានមុមបី (ឧ. fontaine trigone)

trigonométrie *n.f.* *Math.* ត្រីកោណមាត្រសាស្ត្រ

trigonométrique *a.* នៃត្រីកោណមាត្រសាស្ត្រ

trigonométriquement *adv.* តាមត្រីកោណមាត្រសាស្ត្រ

trihebdomadaire *a.* ត្រីសប្តាហ៍,

ដែលមាន ៣ ជីងក្នុងមួយអាទិត្យ,ដែលចេញបីដងក្នុងមួយអាទិត្យ

trilatéral,e,aux *a.* ដែលមានបីខាង

trilingue *a.*ត្រីភាសា,ដែលចេះបីភាសា; ដែលសរសេរជាបីភាសា (ឧ. inscription trilingue)

trilitère ឬ **trilittère** *a. Gramm.* ដែលប្រកបដោយព្យញ្ជនៈបី

trillion *n.m.* មួយសែនកោដិ (មាន ១៨ សូន្យ)

trilobé,e *a.Archit.* ដែលមានកំពូកបី

triloculaire *a.* ដែលចែកជាបីបន្ទប់ (ឧ. ovaire triloculaire)

trimard *n.m.Arg.* ផ្លូវឆ្ងាយ

trimarder *v.i. Arg.* ដើរចរព្រាប់ (ឥតគោល)

trimardeur *n.m.Arg.*អ្នកដើរចរព្រាប់ (ដើរឥតគោល)

trimbalage ឬ **trimbalement** *n.m. Pop.* ការយកជាប់នឹងខ្លួនជានិច្ច

trimbaler *v.t. Fam.* យកជាប់នឹងខ្លួនជានិច្ច (ឧ. trimbaler ses valises)

trimer *v.i.* ធ្វើការធ្ងន់; ទំប្រឹងខ្លាំង

trimestre *n.m.* ត្រីមាស; ប្រាក់បង់ប្រចាំត្រីមាស;មុខងារកំឡុងមួយត្រីមាស

trimestriel,elle *a.* ត្រីមាស; ប្រចាំត្រីមាស, ដែលមានក្នុងមួយត្រីមាសម្ដង (ឧ. bulletin trimestriel ព្រឹត្តិប័ត្រត្រីមាស ឬ ព្រឹត្តិប័ត្រប្រចាំត្រីមាស)

trimestriellement *adv.* រាល់ត្រីមាស (ឧ. revue qui paraît trimestriellement)

trimoteur *a.&n.* ត្រីយន្ត (យន្តហោះបីម៉ាស៊ីន)

trinervé,e *a.* ដែលមានសរសៃ ៣

tringle *n.f.* ចម្រូតកំរងនន; បន្ទាត់គូសដោយខ្សែ ។ *Arg.* កាំភ្លើង; លំពែង

tringler *v.t.* គូសខ្សែបន្ទាត់ (លើឈើបម្រុងនឹងអារ)

tringlot *n.m.* ម.ព. trainglot

trinité *n.f.* ត្រីមូរ្តិ [ត្រិ-មូរ]

trinôme *n.m. Math.* ត្រីធា

trinquart *n.m.* ត្រង់ការ(នាវានេសាទម្យ៉ាងសម្រាប់នេសាទត្រីហារ៉ង់)

trinquer *v.i.* ទង្គិចកែវគ្នា (មុនផឹក) ។ *Fam.* ផឹក ។ *Pop.* ខូចខាត; មានកង្វល់

trinqueur *n.m.* អ្នកចូលចិត្តទង្គិចកែវ; អ្នកចូលចិត្តផឹក (ឧ. un rude trinqueur)

trio *n.m. Mus.* បទភ្លេងមានគ្រឿង

បី; បទភ្លេងមានបម្រៀងបី; ប្រជុំមនុស្ស បីនាក់ ឬ វត្ថុបី

triomphal,e,aux *a.* នៃវិជ័យ (ឧ. char triomphal); អ៊ឹកអធឹក (ឧ. accueil triomphal

triomphalement *adv.* ដោយវិជ័យ (ឧ. entrer triomphalement dans une ville)។ *Fam.* យ៉ាង អ៊ឹកអធឹក

triomphant,e *a.* វិជ័យ, ដែលមានជ័យជំនះ; ដែលសប្បាយរីករាយ (ឧ. air triomphant); ដែលគេឆ្លើយតបមិនរួច (ឧ. argument triomphant)

triomphateur,trice *a.* ដែលគេទទួលដោយអ៊ឹកអធឹក (ឧ. général triomphateur)។

a. ដែលមានជ័យជំនះ (ឧ. nation triomphatrice)។

n.m. អ្នកមានជ័យជំនះ

triomphe *n.m.* វិជ័យ (ជ័យជំនះធំ)(ឧ. les triomphes d'Alexandre)។ *Fig.* ជោគជ័យប្រសើរ (ឧ. c'est un jour de triomphe pour lui)។ en triomphe ដោយអ៊ឹកអធឹក។ porter quelqu'un en triomphe បញ្ជិះជាកិត្តិយស; *au fig.* សរសើរខ្លាំង

triompher *v.i.* មានវិជ័យ, មានជ័យជំនះធំ។ *Fig.* សប្បាយរីករាយ (ឧ. le jeune vainqueur triomphait)។

v.t.ind.(de)ឈ្នះ(ឧ.triompher d'un adversaire)។*Fig.* ជំនះ, បង្ក្រាប (ឧ. triompher de ses passions); ឡើងអំនួត (ឧ. triompher du gain d'un procès); ពេញចិត្តនឹង, សប្បាយចិត្តនឹង (ឧ.triompher du malheur d'autrui)

tripaille *n.f. Chass.* ពោះវៀនសត្វ

tripale *a.* ដែលមានស្លាបបី (ស្លាបប្រា) (ឧ. hélice tripale)

triparti,e ឬ **tripartite** *a.m. & f.* ដែលចែកជាបីភាគ (ឧ. feuille tripartite); ត្រីភាគី (ដែលមាន ៣ ក្រុម ឬ ៣ គណបក្សប្រជុំគ្នា, រាក់គ្នាបីនាក់) (ឧ.gouvernement tripartite; accord tripartite)

tripartisme *n.m.* ត្រីភាគីនិយម (ការប្រជុំធារគ្នាកាលដោយគណបក្សបី)

tripartition *n.f.* ការចែកជាបីភាគស្មើ

tripatouillage *n.m. Fam.* ការកែប្រែសៀវភៅដោយឥតអនុញ្ញាតអំពីអ្នករៀបរៀង

tripatouiller *v.t. Fam.* កែប្រែសៀវភៅដោយឥតអនុញ្ញាតអំពីអ្នករៀបរៀង; ធ្វើ ឬ ប្រើប្រាស់ដោយក្លែង ឬ ដោយឥតលាក់លៀម

tripe *n.f.* ក្រពះឬពោះវៀនសត្វ។ *Fam.* ពោះវៀនមនុស្ស ; ភាគខាងក្នុងនៃបារីស៊ីហ្គា ។ *pl.* ម្ហូបក្រពះឬពោះវៀនសត្វ

triperie *n.f.* កន្លែងលក់ក្រពះនឹងពោះវៀនសត្វ; ជំនួញក្រពះនឹងពោះវៀនសត្វ

tripette *n.f. Pop.* cela ne vaut pas tripette វាគ្មានតម្លៃអ្វីសោះ, វាឥតប្រយោជន៍សោះ

tripétale ឬ **tripétalé,e** *a.* ដែលមានត្របកបី (ផ្កា)

triphtongue *n.f.* ព្យាង្គត្រីស្វរ (ដែលមានសម្លេង៣បេញជាមួយគ្នា) (ឧ. il n'y a pas de triphtongues proprement dites en français)

triphylle *a.* ដែលមានស្លឹកតូចៗបីៗជាមួយគ្នា

tripier,ère *n.* អ្នកលក់ក្រពះនឹងពោះវៀនសត្វ

triplace *a.* ដែលមានកន្លែងបី

triplan *n.m.* យន្តហោះស្លាបបីជាន់

triple *a.* ត្រីគុណ, ដែលមានបីដង ឬ បីជាន់ (ឧ. un bâtiment à triple étage); អស្ចារ្យ (ខ្លាំង) (ឧ. triple idiot)។

n.m. ត្រីគុណ (ឧ. neuf est le triple de trois)

triplement *adv.* ត្រីគុណ, ៣ ដង

triplement *n.m.* ការគុណនឹងបី; ការបង្កើន ៣ ដង

tripler *v.t.* គុណនឹងបី (ឧ. tripler un nombre) ។

v.i. កើនបីដង

triplette *n.f.* កែបបី(ទោចក្រយានមានកន្លែងជិះបី)

triplicata *n.m. inv.* តតិយតា (សេចក្ដីចម្លងទីបី)

tri-porteur ឬ **triporteur** *n.m.* ត្រីចក្រយានម្យ៉ាង(សម្រាប់ដឹកអីវ៉ាន់)

tripot *n.m.* ផ្ទះល្បែង ។ *Par ext.* បនមនុស្សទុច្ចរិត

tripotage *n.m.* ការកាន់; ការល្បាយអង្អែល ; ការបាត់បែង ។ *Fam.* ការប្រឡូក (ឧ. aimer le tri-

potage); របស់ហាយមិនស្អាតទាញ់ ។ *Fig. & Fam.* ការប្រឡូកប្រឡល់; កលល្បិច (ឧ. les tripotages de la politique); ការកេងកម្រៃ, ការទិញលក់មិនស្អាតស្អំ (ឧ. des tripotages de Bourse)

tripotée *n.f. Fam.* ការវាយច្រើន (ឧ. recevoir une tripotée ត្រូវគេវាយច្រើន) ។ *Pop.* ហ្វូង, ពួកច្រើន (ឧ. une tripotée d'enfants)

tripoter *v.t. Fam.* ស្ទាប, កាន់ (ឧ. tripoter de la viande); ស្ទាបអង្អែល (ឧ. tripoter sa chaîne de montre) ។ *Fig.* ចាត់ចែង, គិតគូរ (ឧ. tripoter une affaire); រៀបចំ (ឧ. tripoter un mariage) ។ tripoter l'argent d'autrui, កេងកម្រៃលើប្រាក់គេ ។

v.i. ប្រឡូក (ឧ. les enfants aiment à tripoter dans l'eau) ។ *Fig. & Fam.* ប្រព្រឹត្តអំពើមិនស្អាតស្អំ; កេងកម្រៃ (ឧ. tripoter sur le maïs); រើករាយ (ឧ. tripoter dans ses tiroirs, dans sa malle)

tripoteur,euse *n.Fam.* អ្នកកាន់; អ្នកចាត់ចែង; អ្នកគិតគូរ; អ្នកកេងកម្រៃ

tripotier,ère *a.* ដែលកាន់; ដែលចាត់ចែង; ដែលគិតគូរ; ដែលកេងកម្រៃ ។

n. មេល្បែង, អ្នកបើកផ្ទះល្បែង

triptyque *n.m.* ផ្ទាំងគំនូរបីផ្ទាំង

trique *n.f. Fam.* ព្រនង់

triqueballe *n.m.* រទេះដឹកកាំភ្លើងធំ ឬ ឈើហុប (ហៅថា trinqueballe ក៏បាន)

triquer *v.t.* សំពង, វាយដោយព្រនង់ (ឧ. triquer un âne) ។ triquer des bois ស្រាស់ជ្រើសឈើហុប (ស្រាយឈើហុបចេញពីគំនរ ហើយដាក់ឈើល្អនឹងឈើអាក្រក់ដោយឡែកពីគ្នា)

triquet *n.m.* ជិងវាយកូនបាល់ម្យ៉ាង ។ *Techn.* ជើងម៉ៃរបត់

triquetrac *n.m.* សូរទង្គិចគ្នាប្រឡូកប្រឡល់

triquètre *a.* ដែលមានមុខ ឬ ជ្រុងបី

trirectangle *a. Math.* ដែលមានមុំកែងបី (ឧ. trièdre trirectangle)

trisaïeul *n.m.* ជីតាលួត (*pl.* des trisaïeuls)

trisaïeule *n.f.* ជីដូនលួត (*pl.* des

trisaïeules)

trisannuel,elle *a.* ត្រីសំវច្ឆរៈ, ត្រីសំវត្ស, បីឆ្នាំម្តង (ឧ. fête trisannuelle); ដែលឋិតនៅបីឆ្នាំ

trisecteur,trice *a.* ដែលចែកមុំជាបី

trisection *n.f. Math.* ការចែកជាបីភាគស្មើ (ឧ. la trisection d'un angle est un problème insoluble)

trisépale *a.Bot.* ដែលមានត្របកបី(ផ្កា)

trisoc *n.m.* នង្គ័លផាលបី

trisperme *a. Bot.* ដែលមានគ្រាប់បី

trisser *v.i.* ស្រែក (ត្រចៀកកាំ)

trisser *v.t.* ឲ្យធ្វើឡើងវិញបីដង (ឧ. on a trissé la sérénade) ។

se trisser *v.pr.Pop.* ដើរចេញយ៉ាងរហ័ស

triste *a.* ព្រួយ (ឧ.il est triste de la mort de son ami); ស្រងូតស្រងាត់ (ឧ. il est triste de son naturel); អាប្រក់; គួរឲ្យមើលងាយ; ថោកទាប (គុណនាមនេះត្រូវដាក់ពីមុខនាម) (ឧ. c'est un triste personnage); លន្លង់លន្លោច, ស្រពេះស្រពោច (ឧ. un air triste); ដែលឲ្យព្រួយ (ឧ. une triste nouvelle); កំសត់, គោកយ៉ាក (ឧ.mener une triste existence); គួរឈឺចាប់, គួរពិបាកចិត្ត (ឧ. il est triste de se voir accuser quand on est innocent); ងងឹត (ឧ. chambre triste); ស្រអាប់ (ឧ. couleurs tristes) ។

avoir triste mine ឬ triste figure មានទឹកមុខស្រពាប់ស្រពោន ឬ ស្រងូតស្រងាត់ ។ faire triste mine ឬ triste figure ធ្វើទឹកមុខស្រពាប់ស្រពោន ឬ ស្រងូតស្រងាត់, មានទឹកមុខព្រួយ ឬ មិនសប្បាយចិត្ត ។ faire triste mine à quelqu'un ធ្វើមុខក្រញូវដាក់អ្នកណាម្នាក់; ទទួលដោយមិនសប្បាយចិត្ត ។ triste repas ពេលបាយដែលគេបរិភោគមិនសូវឆ្ងាញ់ (ប.ស. funèbre, lugubre, morne) ។

tristement *adv.* ដោយព្រួយ, ដោយស្រងូតស្រងាត់; ដោយលន្លង់លន្លោច; យ៉ាងអាប្រក់; យ៉ាងថោកទាប

trisyllabe *a.&n.m.* ត្រីព្យាង្គ, ដែលមានបីព្យាង្គ

trisyllabique *a.* នៃត្រីព្យាង្គ

tristesse *n.f.* សេចក្តីព្រួយ (ឧ. som-

brer dans la tristesse)

triturable *a.* អាចកិនល្អិតបាន

triturateur *n.m.* ប្រដាប់កិនល្អិត

trituration *n.f.* ការកិនល្អិត

triturer *v.t.* កិនល្អិត (ឧ.les dents triturent les aliments)

triumvir [tri-om'–] *n.m.* ត្រីជន (អ្នកកាន់ការចំនួន ៣ រូបនៃក្រុងរ៉ូម ដែលទទួលភារៈគ្រប់គ្រងសាខាមួយនៃរដ្ឋាភិបាល)

triumviral,e,aux [tri-om' –] *a.* នៃត្រីជន

triumvirat [tri-om' –] *n.m.* ត្រីជនាភិបាល, អភិបាលនៃត្រីជន

trivalve *a.* ត្រីប៊ូន [–ប៊ុក]

trivial,e,aux *a.* ថោកទាប, ជាគម្រៀរ (ឧ. expression triviale) ។ *n.m.* របស់ ឬ អំពើថោកទាប

trivialement *adv.* ដោយថោកទាប

trivialiser *v.t.* ធ្វើឲ្យថោកទាប

trivialité *n.f.* ភាពថោកទាប; គំនិត ឬ សំដីជាគម្រៀរ

troc *n.m.* ការដូរ (ឧ. le troc fut sans doute la première forme du commerce)។ troc pour troc ដូរគ្នា, ដូរមួយទៅមួយ មក (គ្មានថែមថយ)

trochée *n.f.* កញ្ចុំខ្នងដែលដុះចេញពីជង្គង់

trochet *n.m.* បង្កោម, ស្នូង (ផ្កា ឬ ផ្លែ)

trochille *n.m.* ម.ព. colibri

troglodyte *n.m.* គុហាវាសី, ជនរស់នៅក្នុងគុហា

troglodytique *a.* នៃគុហាវាសី ។ habitation troglodytique គុហាវាសន៍, ការរស់នៅក្នុងគុហា

trogne *n.f.* *Fam.* មុខក្រហម ។ *Spécial.* មុខបំប្រុង

trognon *n.m.* បណ្តូល (នៃផ្លែឈើ ឬ បន្លែ)(ឧ. un trognon de chou)

troïka *n.f.* ត្រូយកា (គារុស្ស៊ីទឹមសេះបី)

trois *a. num.* បី (ឧ. trois hommes); ទីបី (ឧ. Henri trois) ។ *n.m.* លេខបី; ថ្ងៃទីបី (ឧ. le 3 Janvier) ។ *Math.* règle de trois ម.ព. règle

troisième *a. num. ord.* ទីបី (ឧ. le troisième jour); ភាគបី(ឧ. la troisième partie de 21 est 7) ។ *n.m.* ជាន់ទីបី ។ *n.f.* ថ្នាក់ទីបី (នៃវិទ្យាល័យ ឬ អនុវិទ្យាល័យ)។ *n,*

អ្នកទី ៣

troisièmement *adv.* ទីបី, ជាគំរប់បី

trois-mâts *n.m.* នាវាមានដងក្ដោងបី (ឧ. trois-mâts goélette)

trois-pieds *n.m.* ម.ព. trépied

trôler *v.t. Pop.* យកជាប់នឹងខ្លួនជានិច្ច (ឧ. il trôle partout des moutards) ។

v.i. ដើរព្រួលព្រួល (ឧ. ne faire que trôler)

troll *n.m.* ព្រេញគង្វាល (នៃជនជាតិស្កង់ឌីណាវី)

trolley [tro-lé] *n.m.* (ព.អ.) ត្រូលេ (យានម៉ាស៊ីនរត់បណ្ដោយតាមខ្សែកាប៊្លែ)

trombe *n.f.* ខ្យល់ស្ដម្ភ (ខ្ទឹកក្បួរដោយខ្យល់កំបុតត្បូង) ។ *Fig. & Fam.* arriver en trombe មកដល់យ៉ាងរហ័ស ហើយដោយមិនដឹងខ្លួនមុន

trombine *n.f. Pop.* មុខ

tromblon *n.m.* កាំភ្លើងត្រំបួង (កាំភ្លើងម្យ៉ាងមាត់ត្រីក) ។ *Pop.* មួកម្យ៉ាងរីកខាងលើ

trombone *n.m.* ត្រែត្រុំបោន

tromboniste *n.m.* អ្នកផ្លុំត្រុំបោន

trompe *n.f.* ស្នែងផ្លុំ (ក្នុងការបរបាញ់)។ *Zool.* ប្រមោយ (នៃដំរី, ខ្យង, ជាណាក-សត្វ) ។ *Anat.* ប្រមោយ (បំពង់សរីរៈកង់ខ្លួនប្រមោយ)។ trompe d'Eustache ប្រមោយអឺស្តាស (នៅក្នុងត្រចៀក)

trompe-la-mort *n. inv. Fam.* មនុស្សយមបាលមិនត្រូវការ (មនុស្សដែលឈឺធ្ងន់ណាស់ ហើយជាវិញ ឬមនុស្សដែលចាស់ណាស់ហើយ នៅតែមិនទាន់ស្លាប់)

trompe-l'œil *n.m. inv.* រូបបំភាន់ភ្នែក (គំនូរដែលមើលពីចម្ងាយឃើញដូចរូបមែនទែន) ។ *Fig.* អាការៈក្រៅបំភាន់

tromper *v.t.* បំភាន់, នាំឲ្យភាន់ (ឧ. l'intérêt particulier nous trompe); បោក, បញ្ឆោត (ឧ. Ne m'allez pas tromper, je vous prie (Molière); បន្លំ (ឧ. marchands qui trompent leurs clients); ផិត (ឧ. tromper sa femme) ។

Par ext. ធ្វើឲ្យខក (ឧ. tromper les espérances, les calculs de quelqu'un); បញ្ឆោត, បង្វែរ (ឧ. tromper la vigilance de ses gardes); បញ្ឆោត, បំភ្លេច (ឧ.

tromper la faim, l'ennui) ។ tromper le temps កែអផ្សុក (លេងសប្បាយបន្ធូរបំភើញកុំឲ្យធុញថប់ព្រួយពេក)។ tromper le chemin បន្ធូរកុំឲ្យធុញថប់ផ្លូវឆ្ងាយ(ដោយនិយាយលេងជាដើម) ។

se tromper *v.pr.* ច្រឡំ, ភាន់ច្រឡំ (ឧ. rien n'est plus commun que de se tromper); បំភាន់ខ្លួនឯង (ឧ. Et l'amour-propre engage à se tromper soi-même (Molière); បំភាន់·បន្លំ ឬ បោកគ្នា (ឧ. les hommes ne se lient que pour se tromper mutuellement (Massillon); ដឹកញាក់ ។

Loc. div. se tromper à son avantage ច្រឡំចូល (ធ្វើជាច្រឡំដើម្បីឲ្យបានចំណេញខ្លួនឯង) ។ s'y tromper ច្រឡំឬយល់ខុសអំពី។ c'est à s'y tromper ងាយនឹងច្រឡំ,ដូចណាស់ទាល់តែនាំឲ្យតែច្រឡំ ។ si je ne me trompe បើខ្ញុំមិនច្រឡំទេ។ se tromper de ច្រឡំ (ឧ. se tromper de rue ច្រឡំផ្លូវ)

(ស៊ី.abuser, berner, décevoir, duper, mystifier, tricher)

tromperie *n.f.* ប្រវ័ញ្ចន៍,ការបន្លំ បំភាន់ ឬ បញ្ឆោត

trompeter *v.i.* ផ្លុំត្រែ; យំ(សត្វឥន្ទ្រី)។

v.t. Fam. ផ្សាយ, ស្រែកប្រកាស (ឧ. trompeter une nouvelle)

trompeteur *n.* & *a.* អ្នកផ្លុំត្រែ

trompette *n.f.* ត្រុំប៉ែត ។ *Mil.* ត្រែ ។ *Fig.* អ្នកដើរផ្សាយ, អ្នកដើរនិយាយ (ឧ. le bavard est une vraie trompette) ។ *Pop.* មុខ; ឬ មុះ; មាត់ ។.

Loc. div. Fig. emboucher la trompette ប្រើសំដីក្អេង ។ sonner de la trompette ឬ faire sonner la trompette ស្រែកប្រកាស; ធ្វើអ្វីដោយឲ្យគេដឹងឮគ្រប់គ្នា ។ déloger sans trompette ចេញដោយស្ងាត់ ។ sans tambour ni trompette ម.ព. tambour ។ nez en trompette ច្រមុះកោង

trompettiste *n.m.* អ្នកកាន់ត្រុំប៉ែត

trompeur,euse *a.* ដែលបន្លំឬបញ្ឆោត (ឧ. discours trompeur) ។ *n.* អ្នកបន្លំ ឬ បញ្ឆោត

trompeusement *adv.* ដោយបញ្ឆោត (ឧ. promettre trompeusement)

tronc *n.m.* ដើម(ដើមឈើពីគ្រឹមឫសឡើងទៅទល់នឹងមែកក្រោម)(ឧ. le tronc des palmiers est très élancé)។ *Anat.* ដងខ្លួនមនុស្ស។ *Archit.* សសរ ។ *Fig.* ដើមហេតុឬម (ឧ. toutes les affections ont pour tronc la sympathie (L'abbé Bautain); ហុងគល់(ញាតិវង្សពុងខ្សែទៅខាងលើ)។ *Math.* tronc de cône សាជីមូលកាត់

tronche ឬ **tronce** *n.f.* *Arg.* ក្បាលមនុស្ស

tronchet *n.m.* គ្រញ់ជើងបី

tronçon *n.m.* កំណាត់វែង (ឧ. tronçon d'épée); គ្រញ់កង់(ធ្វើដោយកំណាត់ដើមឈើ); គល់កន្ទុយសេះ ។ *Fig.* កំណាត់ (ឧ. tronçon de route)

tronconique *a.* ជារាងសាជីកាត់

tronçonnage *n.m.* ការកាត់ជាកំណាត់; ភាពកាត់ជាកំណាត់

tronçonner *v.t.* កាត់ជាកំណាត់ (ឧ. tronçonner une anguille)

tronçonneuse *n.f.* ម៉ាស៊ីនកាត់

trône *n.m.* រាជបល្ល័ង្ក ។ *Fig.* រាជសម្បត្តិ (ឧ. aspirer au trône)

trôner *v.t.* ធ្វើឫកគ្រាន់បើក្នុងកណ្ដាលចំណោម (ឧ. trôner dans un salon)

tronqué,e *a.* ដែលគេកាត់(ឧ. ouvrage tronqué); កំបុត(ឧ. colonne tronquée) ។ *Math.* កាត់ (ឧ. cône tronqué)

tronquer *v.t.* កាត់ឲ្យកំបុត; យកមួយចំណែកចេញ (ឧ. tronquer une statue, un texte)

trop *adv.* ពេក, ហួសពេក (ឧ. il est trop exigeant) ។ ne... pas trop មិនសូវទេ (ឧ. cela n'est pas trop sûr ការណ៍នេះមិនសូវប្រាកដទេ) ។ *Fam.* par trop ពិតជាច្រើនហួស; ពិតជាហួសពេក (ឧ. voilà qui est par trop fort) ។ de trop លើស, ហួស ។ en trop លើស (ឧ. recevoir cent riels en trop) ។ pas

trop ឬ trop មិនសូវ (ឧ. je ne vous crois pas trop ឬ je ne sais trop)។ trop peu តិចពេក, មិនគួរគប្បី ។ c'est trop que ឬ de គឺទៅជាហួសពេកដែល ។ c'en est trop ហួសពេកហើយ ។

n.m. ចំនួនលើស (ឧ. en tout, le trop ne vaut rien)។

Prov. trop est trop អ្វីដែលហួសពេកមិនល្អទេ ។ trop et trop peu n'est pas mesure ច្រើនពេកក៏មិនល្អ តិចពេកក៏មិនល្អ ។ trop parler nuit, trop gratter cuit ម.ព. cuire ។ qui trop embrasse mal étreint ម.ព. embrasser ។ rien de trop កុំឲ្យហួសប្រមាណឡើយ៖

trophée *n.m.* ជយភ័ណ្ឌ (វត្ថុដែលយកបានពីសត្រូវ) (ឧ. les trophées de la victoire); ផ្ទាំងរាវុធគាំងលំអ។ *Par ext.* របស់បង្ហាញជាប់(ឧ. trophée de drapeaux)។ *Fig.* ជយសញ្ញា, ស្នាមឬអនុស្សាវរីយ៍នៃជ័យជំនះ (ឧ. s'énorgueillir de ses trophées)

trophique *a.* នៃពោសនា (ការចិញ្ចឹមកាយដោយអាហារ) (ឧ. troubles trophiques)

tropical,e,aux *a.* និវត្ត (នៃខណ្ឌប្រទេស, នៃប្រទេសក្តៅ) (ឧ. climat tropical)

tropicalisation *n.f.* និវត្តកម្ម (ការធ្វើឲ្យសម្ភារៈផ្សេងៗ ធន់នឹងអាកាសធាតុនិវត្តបាន)

tropicalisé,e *a.* ដែលទទួលនិវត្តកម្មហើយ

tropique *n.m.* និវត្តន៍ (ខណ្ឌប្រទេស, ប្រទេសក្តៅ) ។ tropique du Cancer កក្កដនិវត្តន៍ ។ tropique du Capricorne មករនិវត្តន៍ ។

a. នៃនិវត្តន៍

trop-perçu *n.m.inv.* ប្រាក់បើកលើស (ឧ. rembourser le trop-perçu) (*pl.* des trop-perçus)

trop-plein *n.m.* ចំនួនដែលហៀរហូរចេញ (ឧ. le trop-plein d'un réservoir); របៀបបង្ហៀរ (*pl.* des trop-pleins)

troquer *v.t.* ប្តូរ (ឧ. troquer un meuble contre un cheval)។

Loc. prov. troquer son cheval borgne contre un

cheval aveugle ពាក់អង្ករយក អង្កាម

troqueur,euse *n. Fam.* អ្នកប្តូរ, អ្នកហៃប្តូរ

trot *n.m.* ដំណើរលុន (ឧ. prendre le trot)។ *Fig. & Fam.* au trot យ៉ាងរហ័ស, ដោយរួសរាន់

trottade *n.f.* ការជិះសេះ ឬ ជិះរទេះ កំសាន្ត

trotte *n.f. Fam.* ល្បឿក, ចម្ងាយដែលត្រូវដើរ (ឧ. trotte de cinq lieues) ។ tout d'une trotte គ្មានឈប់

trotte-menu *a.inv.* ដែលលុនតិចៗ។ la gent trotte-menu កណ្ដុរ

trotter *v.i.* លុន (ឧ. cheval qui trotte bien)។ *Fam.* ដើរ (លឿន ហើយយ៉ាងឆ្ងាយ) (ឧ.trotter toute une journée)។ *Fig.* trotter par (ឬ dans) la cervelle ឬ la tête de quelqu'un ធ្វើឲ្យអ្នកណាម្នាក់ខ្វល់ជាប់ជានិច្ច ។

se trotter *v.pr. Pop.* រត់ (ភៀសខ្លួន)

trotteur,euse *a.&n.* សេះលុន, សេះដែលគេបង្ហាត់ឲ្យលុន; អ្នកដើរលឿន។ *n.f.* ទ្រនិចវិនាទី (នាឡិកា)

trottin *n.m. Fam.* ស្ត្រីអ្នករត់ការ

trottinement *n.m.* ដំណើរលុនជំហានខ្លីៗ

trottiner *v.i.* លុនជំហានខ្លី; ដើរញាប់ជើង (ដើរញាប់រន្ទាន់)

trottinette *n.f.* ត្រូតទីណែត (ទោចក្រយានសម្រាប់ក្មេងជិះឈរជើងម្ខាង រុញជើងម្ខាង)

trotting [-tin'g] *n.m.* ការចិញ្ចឹមសេះលុន

trottoir *n.m.* ចិញ្ចើមថ្នល់។ trottoir cyclable ចិញ្ចើមថ្នល់សម្រាប់ទោចក្រយាន

trou *n.m.* ប្រហោង, រន្ធ, រូង (ឧ. un trou de souris)។ trou d'air អន្តរភាគ, ថ្លុកអាកាស ។ *Fig.* សំណៅ បង្អៀតបង្អល់ ។ *Fam.* ដំបន់តូចតាច។

boucher un trou បុករន្ធ; សងបំណុល ។ faire son trou មានរបរជាប់លាប់។ faire un trou à la lune គេចមិនសងបំណុល ។

Loc. prov. on le ferait passer dans (ឬ par) le trou d'une aiguille គេនាំឲ្យចូលរូងក្តាមក៏បាន

troublant,e *a.* ដែលធ្វើឲ្យរឹករ៉ៃ ឬ ឲ្យខ្វល់ (ឧ. inquiétude troublante)

trouble *n.m.* ការល់អក់; ការរំខាន (ឧ. son arrivée causa quelque trouble dans l'assistance); ការរឹករ៉ៃ, ការទាស់ទែងគ្នា (ឧ.mettre du trouble dans une famille); កង្វល់, បារម្ភ (ឧ. rougeur qui trahit le trouble) ។ trouble mental មានសតិវិកល[មា-នៈ សតៈ វិ-កល់] (វិកលប្រាជ្ញាស្មារតី) ។

pl. ចលាចល (ឧ. fomenter des troubles)

trouble *n.f.* ម.ព. truble

trouble *a.* ល្អក់ (ឧ. eau trouble)។ *Fig.* មិនច្បាស់ (ឧ. tout ceci reste trouble); សៅហ្មង (ឧ. joie trouble devant l'échec d'autrui); រឹករ៉ៃ ។ pêcher en eau trouble ម.ព. eau

trouble-fête *n. inv.* អ្នកល់អក់ពណ៌, អ្នករំខានក្នុងការប្រជុំសប្បាយ, អ្នកធ្វើអ្មុកឡុក (ឧ. cette femme est une trouble-fête)

troubler *v.t.* ល់អក់, ធ្វើឲ្យល្អក់ (ឧ. troubler l'eau); ធ្វើមិនឲ្យច្បាស់, ធ្វើឲ្យស្រវាំង (ឧ. troubler la vue) ។ *Fig.* ធ្វើឲ្យខ្វល់, ធ្វើឲ្យរំខាន(ឧ. cette pensée ne peut que le troubler); ធ្វើអ្មុកឡុក, ធ្វើឲ្យរឹករ៉ៃ, ធ្វើឲ្យមានចលាចល (ឧ. troubler la paix publique); ធ្វើឲ្យទាស់ទែងគ្នា; ធ្វើឲ្យវ្វឹប (ឧ. troubler la raison); រំខាន, កាត់ (ឧ. troubler un entretien); ធ្វើឲ្យស្ងន់ ឬ ឲ្យវ្វឹបស្មារតី(ឧ. votre présence le trouble) ។

se troubler *v.pr.* ឡើងល្អក់; វ្វឹបស្មារតី (ឧ. l'orateur se troubla)(ពិ. brouiller, dérégler, désorganiser, détraquer, perturber)

trouée *n.f.* ប្រឡោះ (ក្នុងរបង, ក្នុងព្រៃ ។ល។)

trouer *v.t.* ចោះប្រហោង

troufion *n.m. Pop.* កូនទាហាន

trouille *n.f. Pop.* ភ័យ, សេចក្ដីខ្លាច

troupe *n.f.* ក្រុម; ហ្វូង(មនុស្ស, សត្វ); បន (ឧ. troupe de voleurs); ក្រុមល្ខោន; កងពល ។ troupe

motorisée កងយន្តគត [–យន់-តៈ-គត់]

troupeau *n.m.* ហ្វូង (សត្វ) (ឧ. un troupeau de moutons)។ *Fig.* ហ្វូង (មនុស្ស)(ពាក្យមើលងាយ) (ឧ. un misérable troupeau fuyant devant nous) ។

Prov. il ne faut qu'une brebis galeuse pour infester un troupeau ត្រីមួយក្រកស្អុយតែមួយ ស្អុយទាំងអស់

troupier *n.m.Fam.* ទាហាន

troussage *n.m.* ការធ្វើ (មាន់ ឬ ទា) សម្រាប់អាំង

trousse *n.f.* បាច់ (ឧ.une trousse de foin); ប្រអប់ឬថង់ប្រដាប់ប្រដា (ឧ.trousse de chirurgien)។

pl. ខោជើងវែង ។ aux trousses de ដេញតាម(ឧ.avoir les gendarmes à ses trousses មានអាវុធហត្ថដេញតាមខ្លួន)

troussé,e *a.Fam.* ដែលតែងខ្លួន ឬ ស្លៀកពាក់ (ឧ. Notre laitière ainsi troussée... (La Fontaine); ដែលមានរូបរាង (ឧ. voilà un gaillard bien troussé!); ដែលគេរៀបចំឬតាក់តែង (ឧ. c'était un repas bien troussé) ។ troussé à la diable ឬ à la turque ដែលគេធ្វើតាមតែបាន

trousseau *n.m.* បាច់, បណ្តុំ (ឧ. un trousseau de clefs);គ្រឿងសំលៀកបំពាក់(របស់ស្រីរៀបអាពាហ៍-ពិពាហ៍ ឬ ក្មេងចូលសាលា) (ឧ. le trousseau d'une mariée, d'un collégien)

trousse-pied *n.m. inv.* ខ្សែព្យួរជើងសត្វ (ខ្សែសម្រាប់ចងព្យួរជើងសត្វឲ្យវាបត់)

trousse-queue *n.m. inv.* ក្រពាត់ (គ្រឿងបង្ហៀរដែលពាក់តាមកន្ទុយ)

trousser *v.t.* ណាត់, សើយ(ឧ. trousser sa jupe)។ trousser quelqu'un ណាត់ ឬ លើកខោអាវឲ្យ ។ *Fig.* trousser une femme ចាប់ស្រី (ដោយសុខចិត្តក្តី មិនសុខចិត្តក្តី)។ *Fig.* សម្រេះសម្រួល-រៀបចំឬបាត់ការដោយរួសរាន់ (ឧ.trousser une affaire) ។ *Par ext. & fam.* ធ្វើឲ្យឆាប់ស្លាប់ ។ trousser bagage រៀបចំខោអាវ; ចាកចេញទៅភ្លាមៗ ។ trousser un poulet

ញើមាត់ (សម្រាប់រាំង)។

se trousser *v.pr.* ណាត់, សើយ (សំលៀកបំពាក់)

troussis *n.m.* ផ្លិតបត់ឡើង (សំលៀកបំពាក់)

trouvable *a.* អាចរកបាន

trouvaille *n.f.* អលភ្យលាភ [អៈ-លៈ-ភ្យៈ-], ការរកឃើញ (ឧ. faire une bonne trouvaille); វត្ថុរកឃើញ (ឧ. une riche trouvaille)

trouvé,e *a.* ដែលរកឃើញ ។ tout-trouvé ដែលមានមក ឬ រកឃើញឯងៗ។ enfant trouvé ក្មេងរើសបាន

trouver *v.t.* រកឃើញ; រកបាន (ឧ. trouver un appartement); ជួប, ឃើញ, ប្រទះ, រើសបាន (ឧ. trouver un porte-feuille); ចាប់បាន (ឧ. trouver une faute)។ *Fig.* រកឃើញ (ឧ. trouver un procédé); មាន (មនោសញ្ចេតនា) (ឧ. trouver du plaisir សប្បាយចិត្ត); ឃើញ (ឧ. je vous trouve bonne mine ខ្ញុំឃើញទឹកមុខលោកស្រស់); យល់ឃើញ, វិនិច្ឆ័យ (ឧ. trouver un ouvrage bien fait) ។

Loc. div. trouver la mort ស្លាប់ ។ trouver bon យល់ឃើញថាល្អ: យល់ព្រមតាម ។ trouver mauvais យល់ឃើញថាមិនល្អ;មិនយល់ព្រមតាម ។ trouver à dire ឬ à redire មានការបន្ទោស ។ la trouver mauvaise យល់ឃើញថារបៀបនេះមិនល្អ។ aller trouver quelqu'un ទៅរកជួបអ្នកណាម្នាក់ ។ trouver le temps long អផ្សុក។ trouver son compte មានប្រយោជន៍នឹង ។ trouver moyen de រកផ្លូវឃើញ (រកមធ្យោបាយឃើញ) ។ *Fig.* trouver quelqu'un sur son chemin មានអ្នកណាម្នាក់មករាំងរា ។ trouver son maître ជួបអ្នកណាម្នាក់ដែលគ្រាន់បើជាងខ្លួន។ trouver le mot de l'énigme រកឃើញការសម្ងាត់ដែលគេរកយូរហើយ។ qui me cherche me trouve អ្នកណារករឿងនឹងខ្ញុំគង់តែនឹងឃើញវិញទេ ។

Prov. &loc.prov. prendre son bien où on le

trouve ឆ្អិនក្បាលស៊ីក្បាលឆ្អិនកន្ទុយស៊ីកន្ទុយ ។ cherchez et vous trouvez តែរកមុខជានឹងឃើញ ។

se trouver *v.pr.* មាននៅ; មានគេជួប, មានគេឃើញ, ទៅ, មក (ឧ. trouvez-vous ici demain); នៅ (ឧ. je me trouve en ce moment à Phnom Penh) ។ *Fig.* ជួបប្រទះ, យល់ឃើញខ្លួនឯងថា, សំគាល់ខ្លួនឯងថា (ឧ. il se trouve fort spirituel) ។ il se trouve embarrassé គាត់កំទេញគុះ ។

v.impers. មាន (ឧ. il s'est trouvé des poitrines et des têtes bretonnes plus dures que le fer de l'étranger (Michelet); ជួនជា (ឧ. il se trouva que la voiture était partie) ។

Loc. div. se trouver bien យល់ឃើញជាស្រួល (ឧ. je me trouve bien chez moi); ស្រួលខ្លួន (ឧ. je me trouve bien depuis hier) ។ se trouver mal យល់ឃើញជាមិនស្រួល; មិនស្រួលខ្លួន; ឡប់ជាប់ ។ se trouver bien de សប្បាយចិត្តដោយ (ឧ. il se trouve bien d'avoir suivi mes conseils); se trouver mal de មានទុក្ខព្រួយ (ឬមានការពិបាក) ព្រោះ ។

Loc. fam. il ne s'était jamais trouvé à telle fête ឬ à telle noce គេមិនដែលទទួលគាត់ភក់ទាក់យ៉ាងនេះទេ; *par antiphrase* គាត់មិនដែលត្រូវគេភិយប្រើនយ៉ាងនេះទេ; គាត់មិនដែលទទួលយ៉ាងនេះទេ

trouveur,euse *n.* អ្នកឃើញ, អ្នករើសបាន; អ្នករកឃើញ; អ្នកបង្កើត

truand,e *n.* មនុស្សអនាថា, ស្មូម ។ *Auj.* យុវ្ហូម, ក្មេងពាល

truanderie *n.f.* របរពួកស្មូម; ក្រុមមនុស្សអនាថា ឬ ស្មូម

truble ឬ **trouble** *n.f.* ឆ្នុង (គ្រឿងនេសាទ)

troublion *n.m.* អ្នករំខាន, អ្នកធ្វើអុកឡុក, អ្នកធ្វើឲ្យរឹករា

truc *n.m.Fam.* ការប៉ិនប្រសប់, ល្បិច (ឧ. les trucs d'un métier); ស្នឹ (ពាក្យហៅវត្ថុ ឬ មនុស្សដែលគេ

មិនយំឈ្មោះ ; របស់គ្មានឈ្មោះច្បាស់លាស់) (ឧ. un truc pour ouvrir les boîtes)

truc ឬ **truck** *n.m. Ch. de f.* ទូលាត (ទូរទេះភ្លើងយានតបស្មើ សម្រាប់ដាក់របស់ព្រួតធ្ងន់ៗប្រវែងវែងហើយធ្ងន់)

trucage ឬ **truquage** *n.m.* កល (ការ ឬ វិធីបន្លំ ឬ ក្លែងក្នុងរបៀបលេងភាពយន្តជាដើម) ; ការប្រើឧបាយបញ្ឆោត (ដោយមិនប្រសប់); ល្បិច

truchement *n.m.* អ្នកកណ្ដាល (ឧ. agir par le truchement de quelqu'un); អ្នកប្រែភាសា; វត្ថុសម្រាប់ឲ្យយល់ ឬ ឲ្យស្គាល់វត្ថុមួយទៀត

trucider *v.t. Fam.* សម្លាប់ (ពាក្យកំប្លែង)

truculence *n.f.* បរិតសាហាវ; ភាពស្រស់; ភាពអាសគ្រាម

truculent,e *a.* កញ្ច្រោល, សាហាវ (ឧ. le caractère barbare et truculent du Gaulois primitif (Th. Gautier) ; ស្រស់ (ឧ. visage truculent); អាសគ្រាម (ឧ. langage truculent)

truelle *n.f.* ស្លាបព្រាបាយអ

truellée *n.f.* ចំនួនមួយស្លាបព្រាបាយអ

truffe *n.f.* ផ្សិតទ្រុហ្វ ។ *Pop.* ច្រមុះទ្រមឹង (ច្រមុះធំហើយមូល); ច្រមុះ ។ *Zool.* ច្រមុះឆ្កែ

truffer *v.t.* ញាត់ផ្សិត (ឧ. truffer une volaille) ។ *Fig.* បំពេញ, ញាត់ (ឧ. truffer un discours de citations)

truffier,ère *a.* នៃផ្សិតទ្រុហ្វ ; ដែលមានផ្សិតទ្រុហ្វ (ឧ. région truffière); សម្រាប់រកផ្សិតទ្រុហ្វ (ឧ. chien truffier)

truffière *n.f.* កន្លែងមានផ្សិតទ្រុហ្វ

truie *n.f.* ជ្រូកញី

trumeau *n.m.* សាច់ជញ្ជាំងចនោះបង្អួច; ភ្លៅគោ

truquage *n.m.* ម.ព. trucage

truquer *v.t.* ក្លែង (ឧ. truquer un bijou); បន្លំ; បន្លំលក់របស់ថ្មីថាជារបស់ចាស់ ; ប្រើកល , ប្រើឧបាយបញ្ឆោតដោយមិនប្រសប់

truqueur,euse *n.* អ្នកក្លែង; អ្នកបន្លំ

trusquin ឬ **troussequin** *n.m* ប្រដាយស្រប

trusquiner *v.t.* គូសបន្ទាត់ដោយប្រដាយស្រប

trust [treust] *n.m.* ត្រឹស្ត (សហ-ជីពពួកផលិតករដើម្បីតម្លើងថ្លៃទំនិញ ; *Par ext.* សហគ្រាសប្រមូលផ្តុំ; នៅសហភាពសូវៀតពីសារព័ន៌សហគ្រាសឬដែលមានទីបាត់ការតែមួយ)

truster [treus-té] *v.t.* ប្រមូលផ្តុំជាត្រឹស្ត; ប្រមូលទំនិញ (ដើម្បីតម្លើងថ្លៃ)

trusteur *n.m.* អ្នកបាត់ចែងត្រឹស្ត

trypanosomiase *n.f.* រោគងងុយដេក

tsar *n.* ត្សារ (អធិរាជប្រទេសរុស្ស៊ី)

tsarévitch *n.m.* ត្សារ៉េវិត (រាជបុត្រអធិរាជប្រទេសរុស្ស៊ី)

tsarine *n.f.* ត្សារីន (អធិរាជិនីប្រទេសរុស្ស៊ី)

tsarisme *n.m.* ត្សារនិយម (លទ្ធិនយោបាយនៅប្រទេសរុស្ស៊ី ក្នុងរជ្ជកាលអធិរាជ)

tsariste *a.&n.* អ្នកត្សារនិយម

tsé-tsé *n.f.* ត្សេត្សេ (រុយម្យ៉ាងបង្កើតរោគងងុយដេក)

T.S.F. (ពាក្យបំប្រួញនៃ Télégraphie ឬ Téléphonie Sans Fil)

T.S.V.P. (ពាក្យបំប្រួញ មានន័យថា Tournez S'il Vous Plaît)

tu,toi,te *pr. pers. sing.* ឯង ។ *Fam.* être à tu et à toi avec quelqu'un ហៅគ្នាអាមីងទៅវិញទៅមក (ស្និទ្ធស្នាលនឹងគ្នាណាស់)

tuable *a.* អាចសម្លាប់បាន, គួរសម្លាប់

tuant,e *a. Fam.* ពិបាក, ហត់ណាស់

tub [teub] *n.m.* បាតត្លាំធំសម្រាប់ងូតទឹក; ការងូតទឹកក្នុងបាតត្លាំ

tubage *n.m.* ការបញ្ចូលបំពង់ក្នុងបំពង់ក (ដើម្បីកុំឲ្យស្ទះដង្ហើមឬដើម្បីពិនិត្យធាតុក្នុងក្រពះ)

tube *n.m.* ទ័ម្ពៈ [ទុម-ភៈ], បំពង់។ tube digestif បំពង់ដំណើរការ

tuber *v.t. Trav. publ.* ដាក់បំពង់ (ឧ. tuber un puits)

tuber [teu-bé] *v.t.* លាងក្នុងបាតត្លាំធំ

tubercule *n.m.* មើម ។ *Anat.* ភាគកំពីកកំពកនៃឆ្អឹង ។ *Path.* ពកក្នុងសាច់ (ជាសញ្ញានៃរោគរបេង)

tuberculeux,euse *a.* ជាមើម (ឧ. racine tuberculeuse); នៃរោគរបេង ។

n. មនុស្សរបេង (អ្នកកើតរោគរបេង)

tuberculination ឬ **tuberculinisation** *n.f.* ការចាក់ថ្នាំសាករោគរបេង

tuberculine *n.f.* ជាតិពិសនៃមេរោគរបេង

tuberculiner ឬ **tuberculiniser** *v.t.* ចាក់ថ្នាំសាកមេរោគរបេង (ឧ. tuberculiner une génisse)

tuberculisation *n.f.* ដំណើរបុះ(កជាមើម)

tuberculiser *v.t.* បុះ (បង្កើតជាមើម)

tuberculose *n.f.* របេង

tubéreuse *n.f.* បន្ទុំ [ប័ន-ទុំ]

tubéreux,euse *a.* ដែលបង្កើតជាមើម (ឧ. racine tubéreuse)

tubérisation *n.f.* ដំណើរកើតជាមើម

tubérisé,e *a.* ដែលកើតជាមើម (ឧ. racine tubérisée)

tubicole *a.* ទ្រុងស័យ, ដែលរស់នៅក្នុងបំពង់ (ឧ.annélides tubicoles)

tubulaire *a.* ដែលមានរាងជាបំពង់ ។ pont tubulé ស្ពានធ្វើដោយបំពង់ដែកតាំងគ្នា

tubulé,e *a.* ជារាងបំពង់; ដែលមានប្រហោងស៊កបំពង់

tubuleux,euse *a.* ជារាងបំពង់ (ឧ. corolle tubuleuse)

tubuliflore *a.* ដែលមានផ្កាជារាងបំពង់

tubulure *n.f.* ប្រហោងប្រហោកបំពង់; បំពង់ចាំងឡាយ; រន្ធ

tue-mouches *a.* papier tue-mouches ក្រដាសលាបថ្នាំបំពុលរុយ

tuer *v.t.* សម្លាប់; បំផ្លាញ (ឧ. la gelée tue les plantes) ។ *Fig.* បន្ថយសុខភាព (ឧ. ses excès le tuent); សម្លាប់,ធ្វើឲ្យរំខានខ្លាំង (ឧ. il me tue avec ses compliments);ធ្វើឲ្យរលំ ឬ ឲ្យហិនហោច។ tuer le temps ដែកឥឡូក (ដោយធ្វើកិច្ចការអ្វីមួយលេងកំសាន្ត) ។

se tuer *v.pr.* សម្លាប់ខ្លួន; បន្ថយសុខភាពខ្លួន (ឧ.se tuer au travail) (មើ. abattre, assassiner, assommer, décimer, exterminer, massacrer, occire, supprimer)

tuerie *n.f.* ការសម្លាប់លំអិត; ទីសត្តឃាត

tue-tête(à) *loc.adv.* crier à tue-tête ស្រែករស់សម្លេង (ស្រែកយ៉ាងខ្លាំង)

tueur,euse *n.* ឃាតកៈ-កា, អ្នកសម្លាប់ ។ *n.m.* ពណាឃាតកៈ, អ្នកសម្លាប់សត្វ

tuile *n.f.* ក្បឿង (ឧ. maison

couverte de tuiles) ។ *Fig. & fam.* ព្រឹត្តិការណ៍អាក្រក់

tuileau *n.m.* កំទេចក្បឿង

tuilerie *n.f Ind.* ឧស្សាហកម្មធ្វើក្បឿង

tuilier *n. & a.m.* អ្នកធ្វើក្បឿង; ឈ្មួញក្បឿង

tulle *n.f.* ស្បៃ

tullerie *n.f.* ជំនួញស្បៃ; រោងតម្បាញស្បៃ

tullier,ère *a.* នៃស្បៃ (ឧ. industrie tullière)

tulliste *n.* ជាងត្បាញស្បៃ

tuméfaction *n.f. Méd.* ដំណើរហើម; ភាពហើម

tuméfié,e *a.* ដែលហើម ; ដែលពក (ដោយគេវាយ) (ឧ. visage tuméfié)

tuméfier *v.t.* ធ្វើឲ្យហើមឬឲ្យទុលឡើង

tumescence *n.f.* ភាពហើម

tumescent,e *a.* ដែលហើម

tumeur *n.f.* ដុំពក (រោគ)

tumulaire *a.* នៃម៉ុង, នៃផ្នូរខ្មោច (ឧ. pierre tumulaire)

tumulte *n.m.* ដំណើរជ្រួលច្របល់ ឬ អ៊ូអែ (ឧ. apaiser un tumulte) ។ *Fig.* ដំណើរច្របូកច្របល់ (ឧ. le tumulte des affaires) ។

en tumulte *loc.adv.* ដោយច្របូកច្របល់ (ឧ. se rassembler en tumulte)

tumultuaire *a.* ជ្រួលច្របល់, ច្របូកច្របល់

tumultueusement *adv.* ដោយច្របូកច្របល់, ដោយជ្រួលច្របល់ (ឧ. écoliers qui sortent de la classe tumultueusement)

tumultueux,euse *a.* ជ្រួលច្របល់, អ៊ូអែ (ឧ. assemblée tumultueuse)

tumulus [–luss] *n.m.* ពំនូកដី; ផ្នូរខ្មោច

tunique *n.f.* អាវវែងម្យ៉ាង; សំបក

tunisien,enne *a.* នៃប្រទេសទុយនីស៊ី (ឧ. bazar tunisien) ។ *n.* ជនជាតិទុយនីស៊ី ។

n.m. ភាសាទុយនីស៊ី

tunisois,e *a.* នៃក្រុងទុយនីស ។ *n.* អ្នកក្រុងទុយនីស

tunnel *n.m.* ឧមង្គ, ផ្លូវក្រោមដី (ឧ. tunnel de chemin de fer)

turban *n.m.* ឈ្នួត

turbidité *n.f.* ភាពល្អក់ (ទឹក)

turbin *n.m. Pop.* ការ

turbine *n.f. Méc.* ទួរប៊ីន (កង់មានស្លាប សម្រាប់បង្វិលគ្រឿងចក្រ)

turbiné,e *a. Hist. nat.* ជាកង់រួ (ឧ. coquille turbinée)

turbiner *v.i. Pop.* ធ្វើការដោយប្រឹងប្រែង

turbulence *n.f.* ភាពរពឹស; ការកួរ-វឹកយ៉ាងខ្លាំង; ដំណើរកជាខ្យល់កួច

turbulent,e *a.* រពឹស (ឧ. enfant turbulent); ដែលចូលចិត្តបង្កចលាចល (ឧ. esprit turbulent)

turc,turque *a.* នៃប្រទេសទួរគី ។ *n.* ជនជាតិទួរគី ។ **à la turque** តាមរបៀបទួរគី; *fig.* ដោយតឹងរ៉ឹង ។ fort comme un Turc ខ្លាំងណាស់ ។ tête de Turc ម.ព. tête ។ traiter quelqu'un de Turc à Maure ធ្វើបាបគ្មានប្រណី ។

n.m. ភាសាទួរគី

turcophile *n. & a.* ដែលស្រឡាញ់ជនជាតិទួរគី

turf *n.m.* វាលរង់, វាលប្រណាំងសេះ; អស្សកីឡា, កីឡាប្រណាំងសេះ

turfiste *n.* អ្នកចូលចិត្តកីឡាប្រណាំងសេះ

turlupin *n.m.* អ្នកកំប្លែងផ្ដេសផ្ដាស

turlupinade *n.f.* ការកំប្លែងផ្ដេសផ្ដាស

turlupiner *v.t. Fam.* ធ្វើឲ្យរំខាន (ឧ.cette idée me turlupine)

turlutaine *n.f. Fam.* ពាក្យដែលគេទន្ទេញមិនដាច់ពីមាត់; ទម្លាប់អាក្រក់; ចំណង់ចម្លែក

turlututu *n.m. Fam.* ខ្លុយ

turne *n.f. Pop.* ផ្ទះ; បន្ទប់

turpitude *n.f.* អំពើថោកទាប (ឧ. turpitude des traîtres); អំពើអាស្រូវ (ឧ. commettre des turpitudes)

turquerie *n.f.Fam.* អំពើឃោរឃៅ; ភាពកំណាញ់ស្អុរជន; រូប ឬ សៀវភៅស្ដីអំពីជីវភាពជនជាតិទួរគី

turquet *n.m.* ពោត; ផ្លែពៀមប៉ាង

turquin *a.m.* bleu turquin ខៀវចាស់ ។ *n.m.* ថ្មកែវខៀវ

tussor ឬ **tussore** *n.m.* ទុស្ស័រ, សំពត់សូត្រម្យ៉ាង

tutélaire *a.* ដែលទំនុកបម្រុង, ដែលរក្សា (ឧ. dieu tutélaire) ។ *Par anal.* ដែលអនុគ្រោះ (ឧ. puissance tutélaire) ។ *Dr.*

អាណាព្យាបាល (ឧ. gestion tutélaire)

tutelle *n.f.* ព្យាបាលភាព (ការពិភក្តិរក្សាអនីតិជន ព្រមទាំងគ្រប់គ្រងទ្រព្យនៃជននេះ)។ *Fig.* អាណាព្យាបាល (ការគ្រប់គ្រងរក្សា, ការទំនុកបម្រុង ឧ. la tutelle des lois; ការត្រួត ឧ. se mettre en tutelle)។

conseil de tutelle ក្រុមប្រឹក្សាព្យាបាល (អង្គការព្យាបាលអនីតិជន); ក្រុមប្រឹក្សាអាណាព្យាបាល (អង្គការរបស់ អ.ស.ប. សម្រាប់ត្រួតរបៀបគ្រប់គ្រងនៃអាណាព្យាបាល)។ territoire sous tutelle ដែនដីក្រោមអាណាព្យាបាល

tuteur,trice *n.m.* អធ្យាប៉ក-បិកា, [-ប៉ុក;-ប៉ិកា], អាណាព្យាបាល (អ្នកគ្រប់គ្រងរក្សា)។ subrogé tuteur ប.ព. subrogé ។

n.m Arbor. ជន្ទល់។ tuteur vivant ជន្ទល់រស់។ tuteur mort ជន្ទល់ងាប់

tuteurage *n.m.* ការដាំជន្ទល់

tuteurer *v.t.Arbor.* ដាំជន្ទល់

tutoiement *n.m.* ការហៅអា មឹង ឬ អញ ឯង (ការប្រើពាក្យ tu, toi)

tutoyer *v.t.* ហៅអា-មឹង ឬ អញ-ឯង (ប្រើពាក្យ tu, toi)

tuyau *n.m.* បំពង់ (ឧ. tuyau de cheminée)។ tuyau d'arrosage បំពង់ស្រោចទឹក។ *Fam.* dire quelque chose dans le tuyau de l'oreille ខ្សឹបដាក់ត្រចៀក។ ដំណឹងសម្ងាត់, ល្បិចសម្ងាត់

tuyautage *n.m.* ការបត់ផាភងបំពង់ (ឧ. tuyautage du linge)

tuyauter *v.i.* បត់ផាភងបំពង់ (សំលៀកបំពាក់)។ *Fam.* ប្រាប់ដំណឹង ឬ ល្បិចសម្ងាត់

tuyauterie *n.f.Techn.* បំពង់បង្ហូរ ឬ បញ្ចេញ (ឧ. tuyauterie de vapeur)

tympan *n.m.Anat.* ក្រដាសត្រចៀក។ *Fig.* briser le tympan à quelqu'un ស្រែកបំបែកក្រដាសត្រចៀក, ស្រែកខ្លាំងណាស់

tympanique *a.* នៃក្រដាសត្រចៀក

tympaniser *v.t.* ស្រែក ឬ ប្រាប់យ៉ាងខ្លាំង (ឧ. c'est lui qui, dans les vers, vous a tympanisées)

tympanisme *n.m.* ដំណើរហើមពោះ

type *n.m.* ពុម្ព (សម្រាប់សិតឡើងរបស់

ឱ្យបញ្ញា); តួយ៉ាង (ឧ. Harpagon est le type de l'avare); បែបផែន, គំរូ (ឧ. type anglais) ។ *Fam.* មនុស្សចំឡែក (ឧ. c'est un type) ។ *Pop.* មនុស្ស (ឧ. quel est ce type-là? អ្នកណាហ្នឹង?) (ក្នុងន័យនេះ: *f.* typesse)

typhique *a.* នៃគ្រុនសន្និ; នៃពិសក្តៅ (ឧ. affection typhique)

typhogène *a.* ដែលឲ្យគ្រុន

typhoïde *a.* ដែលសន្និ ។ fièvre typhoïde គ្រុនសន្និ

typhoïdique *a.* នៃគ្រុនសន្និ

typhon *n.m.* ព្យុះសង្ឃរា (ក្នុងមហាសមុទ្រឥណ្ឌា)

typhose *n.f.* ភាពគ្រុនសន្និ; រោគបញ្ជើ

typhotoxine *n.f.* ពិសមេរោគគ្រុនសន្និ

typhus exanthématique *n.m.* គ្រុនសន្និពោល

typique *a.* ជាតួយ៉ាង, ជាបែបផែន (ឧ. cas typique)(មើ. caractéristique)

typiquement *adv.* ជាតួយ៉ាង, ជាបែបផែន

typo *n.m. Fam.* (ពាក្យបំប្រួញនៃ typographe *f.* typote) ។ *n.f.* (ពាក្យបំប្រួញនៃ typographie)

typochromie *n.f.* ការបោះពុម្ពជាពណ៌

typographe *n.* អ្នករៀបអក្សរពុម្ព

typographie *n.f.* មុទ្ទវិទ្យា, វិធីរៀបអក្សរបោះពុម្ព

typographique *a.* នៃមុទ្ទវិទ្យា, នៃវិធីរៀបអក្សរបោះពុម្ព

typomètre *n.m.* មុទ្ទមាត្រ, ម៉ែត្រប្រើក្នុងការបោះពុម្ព

typophotographie *n.f.* ឆាយាមុទ្ទវិទ្យា, វិធីថតអក្សរផ្តិតពុម្ព

tyran *n.m.* ប្រជាហិង្សក [-ហឹង], ក្សត្រិយ៍កាន់អំណាចផ្តាច់ការ (ឧ. Néron fut un tyran) ។ *Par ext.* អ្នករំលោភដោយអំណាច

tyrannicide *n.m.* ប្រជាហិង្សឃាត, ការធ្វើឃាតប្រជាហិង្សក ។ *n.* ប្រជាហិង្សឃាតក:, អ្នកធ្វើឃាតប្រជាហិង្សក

tyrannie *n.f.* ប្រជាហិង្សា, អំណាចផ្តាច់ការ; ការរំលោភ; ការសង្កត់សង្កិន; អំពើកំណាច

tyrannique *a.* ប្រជាហិង្ស, នៃការរំលោភ ឬ សង្កត់សង្កិន (ឧ. loi, pouvoir tyrannique) ។ *Fig.* ដែលទប់មិនបាន: (ឧ. le charme tyrannique de la beauté)

tyranniquement *adv.* ដោយរំលោភ; ដោយសង្កត់សង្កិន

tyranniser *v.t.* សង្កត់សង្កិន (ឧ. tyranniser ses sujets) ។ *Par ext.* រំលោភលើ (ឧ. tyranniser sa femme, ses enfants) ។ *Fig.* សង្កត់សង្កិន(ដោយផ្លូវចិត្ត) (ឧ. tyranniser les consciences) (បើ. asservir, assujettir, opprimer, soumettre, subjuguer)

tzar, tzarine, tzarévitch ម.ព. tsar, tsarine, tsarévitch



u *n.m.* អក្សរទី ២១ នៃអក្ខរក្រមឡាតាំង

ubiquiste [– kuist'] *n. & a.* *Fam.* ដែលបេះបែងភាគ, ដែលគេឃើញនៅច្រើនកន្លែងក្នុងពេលជាមួយគ្នា

ubiquité [– kui-té] *n.f.* ការបែងភាគ, ការធ្វើឲ្យគេឃើញនៅច្រើនកន្លែងក្នុងពេលជាមួយគ្នា ។ je n'ai pas le don d'ubiquité ខ្ញុំមិនចេះបែងភាគទេ

udomètre *n.m.* ម.ព. pluviomètre

ukase ឬ **oukase** *n.m.* អ៊ុយកាស (ព្រះរាជបញ្ញត្តិនៃអធិរាជប្រទេសរុស្ស៊ី) (ឧ. ukase impérial) ។ *Par ext.* ការសម្រេចដោយអំណាច

ukrainien,enne ឬ **ukranien,enne** *a.&n.* នៃប្រទេសអ៊ុយក្រែន

ulcératif,ive *a.* ដែលបង្កដំបៅរលួយ

ulcération *n.f.* ការបង្កដំបៅរលួយ; ដំបៅរលួយ

ulcère *n.m.* ដំបៅរលួយ; ដំបៅដើមឈើ

ulcéré,e *a.* ដែលកើតដំបៅរលួយ ។ conscience ulcérée សតិសម្បជញ្ញៈប្រកបដោយវិប្បដិសារ, ដំណើរខ្លោចផ្សាចិត្តដោយស្ដាយក្រោយ ។ cœur ulcéré ចិត្តនៅខឹងគំ

ulcérer *v.t.* បង្កដំបៅរលួយ ។ *Fig.* ធ្វើឲ្យឈឺចាប់ខ្លាំងក្នុងចិត្ត, ធ្វើឲ្យខឹងគំ (ឧ. vos critiques l'ont ulcéré) (ព្ទ. blesser, choquer, froisser, offenser, offusquer, vexer)

ulcéreux,euse *a.* ដែលជាដំបៅរលួយ

(ឧ. plaie ulcéreuse): ដែលកើតដំបៅ លួយពាសពេញ

ulcéroïde *a.* ដូចដំបៅរលួយ

uliginaire ឬ **uligineux,euse** *a.* ដែលដុះនៅទីសើម (រុក្ខជាតិ) (ឧ. plantes uliginaires ឬ uligineuses)

ultérieur,e *a.* បច្ឆាកាល, ដែលមានក្រោយ (ផ្ទ. នឹង antérieur) (ឧ. nouvelle ultérieure) (ប្រៀ. consécutif, postérieur, suivant)

ultérieurement *adv.* នៅបច្ឆាកាល, នៅពេលក្រោយ, ជាខាងក្រោយ (ឧ. nous examinerons cela ultérieurement)

ultimatum *n.m.* ឧសានវាទ (ល័ក្ខខ័ណ្ឌដែលមិនអាចបដិសេធបាន; ពាក្យចុងក្រោយ)

ultime *a.* ចុងក្រោយ (ឧ. c'est mon ultime condition)

ultimo *adv.* ក្នុងទីបំផុត

ultra ណាស់, លើសលុប ។ *n.m.* អ្នកប្រកាន់យោបល់តឹងហួសពេក

ultramontain,e *a. & n.* ឯនាយភ្នំ: ឯនាយភ្នំអាល្ប (ចំពោះប្រទេសបារាំង) (ឧ. pays ultramontains)

ultrapression *n.f.* អតិសម្ពាធ (ការសង្កត់ខ្លាំងណាស់)

ultravirus *n.m.* អតិវិសាណូ

ululation *n.f.* ឬ **ululement** *n.m.* សម្រែកបក្សីក្រៀល

ululer ឬ **hululer** *v.i.* យំ (បក្សីក្រៀល) ។ *Par anal.* ស្រែកថ្ងូរ

un,une *a. num.* មួយ ។ un à un មួយម្តង, ម្នាក់ម្តង ។ pas un គ្មានមួយ, គ្មានម្នាក់, គ្មានសោះ ។ ne faire qu'un ដូចគ្នាសុទ្ធសាធ; ដូចខ្លួនមួយ; ជិតស្និទ្ធខ្លាំង ។ *Fam.* ne faire ni une ni deux មិនស្ទាក់ស្ទើរ, គ្មានច្រឹមច្រម ។

a. ord. ទី១ (ឧ. page un) ។

a. qual. ឯកភូត (ដែលបែកមិនបាន) (ឧ. la souveraineté est une et indivisible) ។

art. ind. ម្នាក់ (ឧ. un Ancien a dit) ។

pr. ind. ម្នាក់ (ផ្ទ. នឹង l'autre ម្នាក់ទៀត) ។ l'un l'autre ទៅវិញទៅមក ។

n.m. មួយ (ឧ. un et un font deux): លេខមួយ (ឧ. un «un» mal tracé)

unanime *a.* ជាឯកច្ឆន្ទ (ដែលព្រមចិត្តគ្នា) (ឧ. un consentement unanime)។ *pl.* ដែលមានមតិឬបំណងត្រូវគ្នា (ឧ. nous avons été unanimes sur cette question)

unanimement *adv.* ដោយឯកច្ឆន្ទ, ដោយព្រមចិត្តគ្នា (ឧ. cette décision a été unanimement approuvée)

unanimisme *n.m.* ឯកច្ឆន្ទនិយម [ឯ-ក័ច ឆ័ន-ទ:-] (លទ្ធិខាងអក្សរសាស្ត្រមួយ)

unanimiste *a.* ឯកច្ឆន្ទនិយម

unanimité *n.f.* ឯកច្ឆន្ទ, បំណងតែមួយ (ឧ. il fut élu à l'unanimité)

unciforme *a.* ជាងទំពក់

unciné,e *a.* ដែលមានទំពក់

U.N.E.S.C.O. ពាក្យបំប្រួញនៃ United Nations Educational, Scientific and Cultural Organization អង្គការសហប្រជាជាតិផ្នែកខាងការអប់រំ, វិទ្យាសាស្ត្រនិងវប្បធម៌

unguéal,e,aux [on-ghu–] *a.* នៃក្រចក

unguifère [on-ghui–] *a.* ដែលមានក្រចកមួយ

uni,e *a.* រាបស្មើ (ឧ. chemin uni); ណាត (គ្មានរូប ភាពឬផ្កា) (ឧ. linge uni)។ *Fig.* ដដែលៗ, គ្មានប្លែក (ឧ. vie unie)។

n.m. របស់រាបស្មើ; សំពត់ណាត (ឧ. porter de l'uni)

unicellulaire *a.* ឯកកោសិក [ឯ-ក:-កោ–], ដែលមានកោសិកាតែមួយ (ឧ. organisme unicellulaire)

unicité *n.f.* ភាពមានតែមួយ

unicolore *a.* ឯកពណ៌, ដែលមានពណ៌តែមួយ

unicorne *a.* ដែលមានស្នែងតែមួយ

unificateur,trice *n.* អ្នកធ្វើឯកសមោធាន, អ្នកប្រមូលរួបរួមឲ្យមានតែមួយ

unification *n.f.* ឯកសមោធាន, ការប្រមូលរួបរួមឲ្យមានតែមួយ

unifier *v.t.* ធ្វើឯកសមោធាន, ប្រមូលរួបរួមឲ្យមានតែមួយ (ឧ. unifier un pays)។

s'unifier *v.pr.* រួបរួមគ្នាជាមួយ

unifilaire *a.* ដែលមានខ្សែតែមួយ

unifolié,e *a.* ដែលមានស្លឹកតែមួយ

uniforme *a.* ឯកសណ្ឋាន, ដូចគ្នា, ដែលមានរាងដូចគ្នា (ឧ. des maisons uniformes); ដដែល, គ្មានប្លែក (ឧ.aspect, style uniforme); គ្មានប្រែប្រួល (ឧ. vie, conduite uniforme) (ព.ផ. accidenté, changeant, divers, nuancé, varié)

uniforme *n.m.* (ពាក្យបំព្រួញនៃ habit uniforme) ឯកសណ្ឋាន ។ endosser l'uniforme ចូលធ្វើទាហាន (ស្លៀកពាក់ឯកសណ្ឋាន) ។ quitter l'uniforme ចេញពីទាហាន (លែងស្លៀកពាក់ឯកសណ្ឋាន)

uniformément *adv.* យ៉ាងស្មើ, យ៉ាងនឹង (ឧ. mouvement uniformément accéléré)

uniformisation *n.f.* ឯកសណ្ឋានកម្ម, ការធ្វើឲ្យដូចគ្នា ; ឯកសណ្ឋានភាព, ភាពទៅជាដូចគ្នា

uniformiser *v.t.* ធ្វើឲ្យដូចគ្នា

uniformité *n.f.* ឯកសណ្ឋានភាព, ភាពដូចគ្នា

unijambiste *n.m.* អ្នកមានជើងតែម្ខាង

unilatéral,e,aux *a.* ដែលនៅតែម្ខាង (ឧ. stationnement unilatéral); ឯកតោភាគី (ឧ. engagement unilatéral)

unilatéralement *adv.* ជាឯកតោភាគី

uniment *adv.* យ៉ាងរាបស្មើ; ស្មើដៃ (ឧ. toile travaillée uniment) ។ *Fig.* tout uniment យ៉ាងងាយ, គ្មានបញ្ចេញបញ្ចូល (ឧ. voilà tout uniment ce que j'ai vu)

uninominal,e,aux *a.* ឯកនាម, ដែលមានឈ្មោះតែមួយ (ឧ. scrutin uninominal)

union *n.f.* សហភាព; សមាយោគ, ការរួបរួមគ្នា, ការបញ្ចូលរបស់ផ្សេងជារបស់តែមួយ (ឧ.l'union de l'âme et du corps); សមគ្គសង្វាស (ការនៅរួមសុខរួមទុក្ខរបស់ស្វាមីភរិយា, អាពាហ៍ពិពាហ៍) ។ *Fig.* ការរួមកម្លាំង, ការចងបាច់ (ឧ. l'union fait la force ការចងបាច់ជាកម្លាំង) ; ការចូលហ៊ុនគ្នា ។

union douanière សហភាពគយ ។ union postale សហភាពប្រៃសណីយ (សរ. accord, affinité, alliance, concert, entente, intelligence)

unionisme *n.m.* សហភាពនិយម

unioniste *n.* អ្នកសហភាពនិយម

uni-ovulé,e *a.* ឯកបញ្ញាណ

unipare *a.* ឯកបុត្ត, ដែលកើតកូនតែមួយ (ឧ. femelle unipare)

unipolaire *a.* ឯកប្រភាគ

unique *a.* ឯក, ដែលមានតែម្នាក់ ឬតែមួយ (ឧ.fils unique; son unique souci) ។ *Par ext.* ឯក (លើសគេ, ឈ្នះគេ) (ឧ. talent unique) ; ប្លែក, ឆ្នើយ (ព.ផ. multiple)

uniquement *adv.* តែមួយ, តែម្យ៉ាង (ឧ. penser uniquement au devoir)

unir *v.t.* បញ្ចូលគ្នា, ភ្ជាប់គ្នា (ឧ. unir deux communes); លាយគ្នា ។ *Fig.* បង្រួបបង្រួម (ឧ. unir deux familles par un mariage); ផ្សំផ្គុំ; ពង្រាបឲ្យស្មើ (ឧ. unir une allée) ។

s'unir *v.pr.* ចូលហ៊ុនគ្នា; រួបរួមគ្នា; រួមកម្លាំងគ្នា; ចងស្ពានមេត្រី; រួមសង្វាស; ឡើងរាបស្មើ

unisexuel, elle ឬ **unisexué,e** *a.* *Bot.* ដែលមានភេទតែមួយ (រុក្ខជាតិ)

unisson *n.f.* *Mus.* ឯកសព្ទ, ភាពត្រូវសម្លេងគ្នា (ឧ. chanter à l'unisson) ។ *Fig.* ការព្រមព្រៀងគ្នា; ដំណើរត្រូវគ្នា (ចិត្ត, គំនិត) ; អំពើស្មើស្មើគ្នា (ឧ. se mettre à l'unisson des circonstances)

unitaire *a.* ឯកភូត, មួយៗ ។ *n.m.* *Pol.* អ្នកឯកភាពនិយម ។ *Relig.* អ្នកឯកកាយនិយម

unitarisme *n.m.* *Pol.* ឯកភាពនិយម ។ *Relig.* ឯកកាយនិយម

unité *n.f.* ចំនួនរាយ (ឧ. colonne des unités); មាត្រា, មានទណ្ឌ (ខ្នាតរង្វាស់ដូចយ៉ាងម៉ែត្រជាដើម) ។ unité de capacité មាត្រាចំណុះ ។ unité de longueur មាត្រាប្រវែង ។ unité de poids មាត្រាទម្ងន់ ។

ឯកភាព (ភាពមានតែមួយ ផ.នឹង pluralité ឧ. unité du pouvoir; ភាពសុខដុម; ភាពស៊ីគ្នា ឧ. ce roman manque d'unité); ភាពព្រមព្រៀងគ្នា, ភាពស្រុះស្រួលគ្នា (ឧ. il n'y a pas d'unité entre eux) ។ unité de vue ឯកភាពនៃទិដ្ឋិ ។

Littér. unité d'action

ឯកភាពនៃអំពើ ។ unité de lieu ឯកភាពនៃឋាន(កន្លែង) ។ unité de temps ឯកភាពនៃពេល ។

Ind. ឯកដ្ឋាន ។ unité de production ឯកដ្ឋាននៃផលិតកម្ម។

Mil. កងឯកភាព ។ petite unité កងឯកភាពតូច ។ grande unité កងឯកភាពធំ ។ unité de feu ឯកភាពនៃគ្រាប់សេរ(ចំនួនគ្រាប់សេរជាមូលដ្ឋានសម្រាប់ផ្គត់ផ្គង់ទ័ព) ។ unité d'essence ឯកភាពប្រេងសាំង (ចំនួនប្រេងសាំងជាមូលដ្ឋានសម្រាប់ផ្គត់ផ្គង់ទ័ព)

unitif,ive *a.* ដែលភ្ជាប់ (ឧ. fibres unitives du cœur)

univalve *a.* ឯកបួត [ឯកៈ–បួត]

univers *n.m.* សកលលោក; ផែនដី; កន្លែងរស់នៅ (ឧ. sa chambre est son univers) ។ *Fig.* វិស័យ (ខាងសម្ភារៈ,ខាងបញ្ញានឹងខាងផ្លូវចិត្ត) (ឧ. faire de ses études tout son univers)

universalisation *n.f.* សកល្យូបនីយកម្ម, ការផ្សាយគ្រប់កន្លែង

universaliser *v.t.* ធ្វើសកល្យូបនីយកម្ម, ផ្សាយគ្រប់កន្លែង (ឧ. universaliser un principe)

universalisme *n.m.* សកលនិយម

universaliste *n.&a.* អ្នកសកលនិយម

universalité *n.f.* សកលភាព (ភាពទូទៅ, ភាពទាំងអស់ ឧ. l'universalité des êtres; ភាពមានចំណេះគ្រប់មុខ ឧ. universalité d'esprit)

universel,elle *a.* សាកល;គ្រប់គ្រប់មុខ (ឧ.remède universel);គ្រប់គ្នា, នៃជនគ្រប់រូប (ឧ. consentement universel); ដែលមានចំណេះគ្រប់មុខ (ឧ. homme universel) ។ *Dr.* légataire universel អច្ចយលាភីសាកល ។ *Phys.* attraction universelle ម.ព. attraction

universellement *adv.* ជាសាកល (ឧ. universellement connu)

universitaire *a.* នៃសាកលវិទ្យាល័យ ។

n.m. សាស្ត្រាចារ្យសាកលវិទ្យាល័យ

université *n.f.* សាកលវិទ្យាល័យ ។ Université Royale Khmère សាកលវិទ្យាល័យខេមរភូមិន្ទ

uppercut *n.m.* ការតប់បង្កា (ក្នុង

ប្រដាល់)

uranifère *a.* ដែលមានអ៊ុយរ៉ានីយ៉ូម (ឧ. terrain, roche uranifère)

uranique *a.* នៃអ៊ុយរ៉ានីយ៉ូម

uranium *n.m.* អ៊ុយរ៉ានីយ៉ូម (លោហធាតុម្យ៉ាង)

urbain,e *a.* & *n.* នៃទីក្រុង, នៃនគរ

urbanisation *n.f.* នគរូបនីយកម្ម, ការដាក់ឲ្យមានលក្ខណៈជាទីក្រុង

urbaniser *v.t.* ដាក់ឲ្យមានលក្ខណៈជាទីក្រុង

urbanisme *n.m.* នគរូបនីយវិទ្យា, វិជ្ជា ឬ វិធីតុបតែងទីក្រុង ។ comité d'urbanisme et d'habitat ម.ព. comité

urbaniste *n.m.* អ្នកតុបតែងទីក្រុង ។ *a.* នៃការតុបតែងទីក្រុង

urbanité *n.f.* នគរភាព, សេចក្ដីគួរសម (ឧ. accueillir un visiteur avec urbanité)

urbi et orbi *loc. lat.* នៅគ្រប់កន្លែង

urée *n.f.* ឧដ្ឋីវជាតិ

uretère *n.m.* បំពង់មូត្រ

urétérite *n.f.* រោគរលាកបំពង់មូត្រ

urétral,e,aux *a.* នៃបំពង់មូត្រ

urètre *n.m.* បស្សាវមគ្គ, ទ្វារមូត្រ, ទ្វារតូច (ទ្វារនោម)

urgence *n.f.* ការប្រញាប់ ។ état d'urgence ម.ព. état ។ d'urgence *loc. adv.* យ៉ាងប្រញាប់ (ឧ. prendre un parti d'urgence)

urgent,e *a.* ប្រញាប់, បន្ទាន់ (ឧ. une affaire urgente)(ពិ. instant, pressant)

urinaire *a.* នៃមូត្រ ឬ ទឹកនោម

urinal *n.m.* បស្សាវភាជន៍, ភាជន៍នោម (*pl.* des urinaux)

urine *n.f.* បស្សាវៈ, មូត្រ, ទឹកនោម

uriner *v.i.* បន្ទោបង់បស្សាវៈ ឬ មូត្រ, បត់ជើងតូច, នោម

urinifère *a.* ដែលនាំមូត្រ ឬ ទឹកនោម (ឧ. tubes urinifères des reins)

urinoir *n.m.* បស្សាវដ្ឋាន, បង្គន់នោម (សម្រាប់បុរស)

urne *n.f.* ផ្តិល; ហិបឆ្នោត ។ urne cinéraire ឬ urne កោដ្ឋ (ភាជន៍ដាក់ធាតុ)

uro-génital,e,aux *a.* ម.ព. génito-urinaire

urologie *n.f.* បស្សាវវិទ្យា, វិជ្ជាខាងរោគ

ផ្លូវមូត្រ

urologue *n.* បស្សាវវិទូ

uromètre ឬ **uréomètre** *n.m.* បស្សាវមាត្រ

uropygial,e,aux *a.* នៃកន្ទុយក្លៀកបក្សី

U.R.S.S. ពាក្យបំប្រួញនៃ Union des Républiques Socialistes Soviétiques សហភាពនៃសាធារណរដ្ឋសង្គមនិយមសូវៀត

urticacées *n.f.pl.* កក្ខជាតិ [កំប-ផ្ទុ—]

urticaire *n.f.* កន្ទាលព្រអាក

urticant,e *a.* ដែលរមាស(សត្វ,រុក្ខជាតិ)

us *n.m.pl.* ទម្លាប់ (ឧ. les us et les coutumes)

U.S.A. ពាក្យបំប្រួញនៃ United States of America សហរដ្ឋអាមេរិក

usable *a.* អាចធ្វើឲ្យរិល ឬ ឲ្យសឹកបាន

usage *n.m.* ការប្រើ (ឧ. le bon usage des richesses); របៀបប្រើ; ទំនៀមទម្លាប់ (ឧ. aller contre l'usage établi); សិទ្ធិប្រើ (សិទ្ធិប្រើរបស់គេ) ។

usage du monde ទំនៀមទម្លាប់ក្នុងសង្គម, របៀបធ្វើ ឬ និយាយក្នុងសង្គមមនុស្ស ។ à l'usage de សម្រាប់ (ឧ. livres à l'usage de la jeunesse) ។ faire de l'usage ឬ faire un bon usage ប្រើឲ្យបានយូរ ។ faire usage de ប្រើ ។

usagé,e *a.* ដែលប្រើហើយ, ចាស់ (ឧ. vêtements usagés)

usager,ère *a.* សម្រាប់ប្រើប្រាស់ធម្មតា ។ effets usagers ប្រដាប់សម្រាប់ប្រើប្រាស់ធម្មតា(រួបពន្ធគយ)។

n. អ្នកប្រើប្រាស់ (ឧ. les usagers de la route)។ *n.m.* អ្នកមានសិទ្ធិប្រើប្រាស់ (ឧ. les usagers du rail)

usé,e *a.* ចាស់ (ឧ. vêtement usé); រិល, សឹក ។ *Fig.* ខ្សោយ (ឧ. homme usé); សាមញ្ញ (ឧ. sujet usé)

user (de) *v.t.* ប្រើ (ឧ. user d'une permission) ។ en user bien avec quelqu'un ប្រព្រឹត្តល្អចំពោះអ្នកណាម្នាក់។ en user mal avec quelqu'un ប្រព្រឹត្តមិនល្អចំពោះអ្នកណាម្នាក់ ។

v.t. ប្រើ(ធ្វើឲ្យខូច,ធ្វើឲ្យសឹក)(ឧ. user ses vêtements); ពន្រិល,

ស៊ីក (ឧ. le grès use le fer) ។ *Fig.* ធ្វើឲ្យខ្សោយឬបំផ្លាញបន្តិចម្ដងៗ (ឧ. user sa santé) ។

s'user *v.pr.* រិល, ស៊ឹក (ឧ. cette étoffe s'use vite)

user *n.m.* ការប្រើ; ដំណើរធន់នឹងការប្រើ

usinage *n.m.Ind.* ការធ្វើក្នុងរោងចក្រ

usine *n.f.* រោងចក្រ ។ usine d'Etat រោងចក្ររដ្ឋ

usiner *v.t. ind.* ធ្វើក្នុងរោងចក្រ

usinier,ère *a.* នៃរោងចក្រ ។ *n.m.* ម្ចាស់រោងចក្រ

usité,e *a.* ដែលគេប្រើ (ចំពោះសព្ទ) (ឧ. terme usité depuis peu)

ustensile *n.m.* ឧបភោគភណ្ឌ (គ្រឿងប្រើប្រាស់ប្រចាំជីវភាពធម្មតាជាពិសេសសម្រាប់ផ្ទះបាយ)

usuel,elle *a.* ដែលគេប្រើញឹកញាប់ (ឧ. termes, mots usuels) ។

n.m. សៀវភៅដែលគេប្រើញឹកញាប់

usuellement *adv.* ជាញឹកញាប់

usufructuaire *a.* ដែលឲ្យតែផលុបភោគ

usufruit *n.m. Dr.* ផលុបភោគ, សិទ្ធិអាស្រ័យផល (ឧ. la durée de l'usufruit ne peut excéder la durée de la vie de son bénéficiaire)

usufruitier,ère *n. Dr.* ផលុបភោគី, អ្នកមានសិទ្ធិអាស្រ័យផល

usuraire *a.* ដែលយកការប្រាក់ហួសប្រមាណ

usurairement *adv.* ដោយយកការប្រាក់ហួសប្រមាណ

usure *n.f.* វឌ្ឍិកម្ម, ដំណើរយកការប្រាក់ហួសប្រមាណ; កម្រៃច្រើនហួសប្រមាណ ។ avec usure ដោយលើសលុប, ដោយលើសពីគេទទួល

usure *n.f.* សំណឹក, ភាពសឹក (ឧ. l'usure des chaussures); ភាពរិល ។ *Fig.* ភាពចុះទន់ខ្សោយ, ភាពចុះអន់ថយ ។ guerre d'usure ចំបាំងពង្រោះពង្រិល (ចំបាំងដើម្បីឲ្យកម្លាំងសត្រូវចុះទន់ខ្សោយ ដោយប្រើពេលយូរ)

usurier,ère *n.* វឌ្ឍិករ, អ្នកយកការប្រាក់ហួសប្រមាណ

usurpateur,trice *a.&n.* អ្នកដណ្ដើម (ឧ. pouvoir usurpateur) ។ *Spécial.* អ្នកដណ្ដើមរាជ្យ

usurpation *n.f.* ការដណ្ដើម (ដោយប្រើកម្លាំង ឬ ប្រើឧបាយកល) (ឧ. usurpation de fonctions publiques) ។ *Par ext.* របស់ដណ្ដើមបាន

usurpatoire *a.* ដែលមានលក្ខណៈជាការដណ្ដើម

usurper *v.t.* ដណ្ដើម (ដោយប្រើកម្លាំង ឬ ប្រើឧបាយកល) (ឧ. usurper le pouvoir) ។

v.i. ទន្ទ្រាន (ឧ. il usurpe sur mon domaine)

utérin,e *a.* &*n.* សហោទរ, រួមឧទរ, សហមាតា ។ *a.* នៃស្បូន (ឧ. muqueuse utérine)

utérus *n.m.* ស្បូន (ព្រ. matrice)

utile *a.* មានប្រយោជន៍ (ឧ. travaux utiles) ។ en temps utile នៅកាលដ៏គួរ ។

n.m. របស់មានប្រយោជន៍ (ឧ. joindre l'utile à l'agréable)

utilement *adv.* ដោយមានប្រយោជន៍

utilisable *a.* អាចប្រើប្រាស់បាន

utilisateur,trice *n.* អ្នកប្រើប្រាស់ (ឧ. les utilisateurs du gaz)

utilisation *n.f.* ការប្រើប្រាស់

utiliser *v.t.* ប្រើប្រាស់ ; ទាញយកប្រយោជន៍

utilitaire *a.* ដែលប្រាថ្នាប្រយោជន៍ (ឧ. politique utilitaire) ។

n. អ្នកប្រាថ្នាប្រយោជន៍

utilitarisme *n.m.* ប្រយោជននិយម

utilitariste *a.* ប្រយោជននិយម ។ *n.* អ្នកប្រយោជននិយម

utilité *n.f.* ប្រយោជន៍, អត្ថប្រយោជន៍។ utilité publique ប្រយោជន៍សាធារណៈ ។ *Théât.* តួរាយរង

utopie *n.f.* ការហួសវិស័យ; គំនិតហួសវិស័យ (មិនអាចធ្វើឲ្យសម្រេចបាន)

utopique *a.* ហួសវិស័យ

utopiste *a.* អបិន្ដបុគ្គល, ដែលមានគំនិតហួសវិស័យ

uval,c,aux *a.* នៃទំពាំងបាយជូរ (ឧ. cure uvale)



v *n.m.* អក្សរទី ២២ នៃអក្ខរក្រមឡាតាំង។ V (លេខរ៉ូម៉ាំង) ៥

va *Int.* ទៅ! ប្រឹង! ប្រយ័ត្ន! ។ *Fam.* va pour យកចុះថ្លៃ...(ខ្ញុំព្រមថ្លៃ...) (ឧ. va pour dix riels)

vacance *n.f.* ភាពទំនេរ (កន្លែង, មុខងារ) (ឧ. vacance d'un siège épiscopal)។ *pl.* វិស្សមកាល [វិស-សៈ-មៈ-] ។ vacances parlementaires វិស្សមកាលនៃសភា ។ vacances scolaires វិស្សមកាលនៃការសិក្សា

vacancier *n.m.* អ្នកឈប់សម្រាកនៅជនបទ

vacant,e *a.* ទំនេរ (កន្លែង, មុខងារ) (ឧ. appartement vacant) (ប្រៀ. disponible)

vacarme *n.m.* សូរកងរំពង

vacation *n.f.* វេលាការ, ថ្ងៃការ (ឧ. vacation d'un expert, d'un notaire) ។ *Par ext.* ប្រាក់វេលាការ ។ *pl.* វិស្សមកាលតុលាការ

vaccin *n.m.* ថ្នាំបង្ការរោគ

vaccinable *a.* អាចចាក់បង្ការរោគបាន

vaccinal,e,aux *a.* នៃថ្នាំបង្ការរោគ

vaccinateur *n.&a.m.* បសុព្យាបាល [ប៉ៈ-សុ-]; អ្នកចាក់ថ្នាំបង្ការរោគ

vaccination *n.f.* ការចាក់ថ្នាំបង្ការរោគ ។ vaccination antivariolique ការដោះអុត ឬ ការបណ្ដុះអុត

vaccine *n.f.* រោគអុតគោ

vacciner *v.t.* ដាក់ថ្នាំបង្ការរោគ ។ *Fig.* & *fam.* ធ្វើឲ្យធុតអំពី

vaccinogène *a.* ដែលបង្កើតថ្នាំបង្ការរោគ

vaccinoïde *a.* ដូចរោគអុតគោ (ឧ. éruption vaccinoïde)

vaccinothérapie *n.f.* ការព្យាបាលដោយថ្នាំបង្ការរោគ

vache *n.f.* មេគោ,គោញី (ឧ. du lait de vache); សាច់គោញី (ឧ. manger de la vache); ស្បែកគោញី (ឧ. des souliers en vache) ។ vache à lait មេគោទឹកដោះ, គោញីចិញ្ចឹមដើម្បីយកទឹកដោះ; *au fig.* មនុស្ស ឬ របស់ដែលឲ្យប្រយោជន៍ជានិច្ច ។

a. Pop. រឹងរូំង (ឧ. se montrer vache)

vacher,ère *n.* គង្វាលគោញី

vacherie *n.f.* ក្រោលគោញី; កន្លែងរីតទឹកដោះ; កន្លែងលក់ទឹកដោះគោ ។

Pop. អំពើកំណាច

vachette *n.f.* ស្បែកកូនគោ

vacillant,e *a.* ទន្រេតទន្រោត; ញ័រ (ឧ. la flamme vacillante d'une bougie) ។ *Fig.* សាញ; ប្រែប្រួល (ឧ. esprit vacillant)

vaccillation *n.f.* ដំណើរផ្អៀងចុះផ្អៀងឡើង; ដំណើរយោង (ឧ. vacillation d'une barque) ។ *Fig.* ការសាញ (ឧ. vacillation dans les opinions)

vacillement *n.m.* ដំណើរផ្អៀងចុះផ្អៀងឡើង

vaciller *v.i.* ផ្អៀងចុះផ្អៀងឡើង, យោង; មានដំណើរទ្រេតទ្រោត (ឧ. vaciller sur ses jambes); ញ័របព្ភិបវ (ឧ. la lumière vaccille) ។ *Fig.* សាញ, រួញរា (ឧ. vaciller dans ses réponses) (*ឋ.* papilloter, tituber, trembler, trembloter)

vacuité *n.f.* សុញ្ញភាព, ភាពទទេ (គ្មានអ្វីនៅក្នុង)

vacuum [–ku-om'] *n.m.* អ្វីៗដែលទទេ

vade-mecum [–dé-mék-om'] *n.m.* របស់ដែលគេយកជាប់នឹងខ្លួនជាធម្មតា

vadrouille *n.f. Mar.* ជុំសំពត់សម្រាប់ជូតឈាង ។ *Pop.* ការដើរលេង

vadrouiller *v.i.Pop.* ដើរលេង

vadrouilleur,euse *n. Pop.* អ្នកដើរលេង

va-et-vient *n.m.inv.* ដំណើរទៅមក

vagabond,e *a.* អនាថា, ដែលឥតទីពឹង, ឥតពំនាក់; ដែលដើរបរប្រាប់ ។ *Fig.* គ្មានសណ្ដាប់ធ្នាប់ (ឧ. imagination vagabonde) ។
n.m. ជនអនាថា

vagabondage *n.m.* ភាពអនាថា, (ឧ. le vagabondage est un délit)

vagabonder *v.i.* ធ្វើជាជនអនាថា; ដើរបរប្រាប់ (ប្រ. rôder, vaguer)

vagin *n.m.* យោនី (អង្គជាតស្ត្រី), ទ្វារមាស

vaginal,e,aux *a.* នៃយោនី, នៃទ្វារមាស (ឧ. muqueuse vaginale)

vaginité *n.f.* រោគរលាកយោនី

vagir *v.i.* ស្រែកយំ (ទារក) (ឧ. nouveau-né qui vagit) ; ស្រែក (ទន្សាយ ឬ ក្រពើ)

vagissant,e *a.* ដែលស្រែកយំ

vagissement *n.m.* សំស្រែកយំ (ទារកទើបនឹងកើត) ។ *Par ext.* សំស្រែក (ទន្សាយ ឬ ក្រពើ)

vagon *n.m.* ម.ក. wagon

vague *a.* មិនជាក់, មិនប្រាកដ (ឧ. promesse vague) ។ *Peint.* មិនច្បាស់, ព្រិលៗ (ឧ. couleur vague); រវើរវាយ (គំនិត) ។
n.m. អាកាសល្ហល្ហេវ; អ្វីៗដែលមិនជាក់ ឬ មិនប្រាកដ (ឧ. rester dans le vague) ។ le vague de l'âme សេចក្ដីលង្វង់លង្វោច (ប្រ. flou, incertain, indécis, indéfini, indéterminé, obscur)

vague *a.* terrain vague ដីទំនេរ, ដីភល (ក្នុងក្រុង)

vague *n.f.* រលក ។ *Par ext.* អ្វីៗដែលមានសណ្ឋាន ឬ មានដំណើរដូចរលក; សា, លើក (ឧ. une vague d'assaut, de chars) ។ *Fig.* ដំណើរមានភ្លាមៗ (ឧ. vague de froid)

vaguelette *n.f.* រលកតូច

vaguement *adv.* ដោយមិនជាក់ ឬ មិនប្រាកដ, រហិបរហៀង; ស្រពេចស្រពិល

vaguemestre *n.m.* លេខាការី

vaguer *v.i.* ដើរបរប្រាប់ (ឧ. vaguer par les champs) ។ *Fig.*

បណ្តោយតាម(ឧ. laisser vaguer son imagination)

vaicya *n.m.* វេស្យៈ (វណ្ណៈអ្នកជំនួញ, កសិករ ។ល។)

vaillamment *adv.* ដោយក្លាហាន, យ៉ាងអង់អាច (ឧ. lutter vaillamment)

vaillance *n.f.* សេចក្ដីក្លាហាន, សេចក្ដីអង់អាច (មើ. bravoure, courage, hardiesse)

vaillant,e *a.* ក្លាហាន,អង់អាច ។ *adv.* n'avoir pas un sou vaillant គ្មានមួយសេនសោះ (គ្មានទ្រព្យ, គ្មានប្រាក់) (ព.ផ. lâche, peureux, poltron)

vain,e *a.* វញ្ឈៈ [វ័ញ-ឈៈ], អសារ, ឥតប្រយោជន៍ (ឧ. vains efforts; vaines excuses); ឥតបានការ, ខុស (ឧ. vain espoir); ឡឹត (ឧ. esprit vain); ឥតខ្លឹមសារ (ឧ. vains plaisirs) ។ vaine pâture វាលឲ្យសត្វស៊ីស្មៅទទេ (ឥតយកថ្លៃ) ។ en vain *loc. adv.* ឥតប្រយោជន៍, ឥតអំពើ

vaincre *v.t.* អបរាជ័យ , ឈ្នះ (ឧ. vaincre ses rivaux); ជំនះ (ឧ. vaincre un obstacle; vaincre sa peur) ។

se vaincre *v.pr.* អត់សង្កត់ចិត្ត (មើ. anéantir, battre, culbuter, défaire, écraser, surmonter)

vaincu,e *a.* បរាជិត, ដែលបរាជ័យ, ចាញ់គេ ។ *n.* បរាជិត, អ្នកបរាជ័យ, អ្នកចាញ់ (ឧ. les vaincus ont toujours tort)

vainement *adv.* ឥតប្រយោជន៍, អសារឥតការ (ឧ. vous alléguez vainement cent raisons)

vainqueur *n.m.* អបរាជិត, អ្នកអបរាជ័យ, អ្នកឈ្នះ ។ *a.* អបរាជិត, ដែលឈ្នះ ។ air vainqueur ឫកសំបើម, ឫកឡឹត

vaisseau *n.m.* នាវា (ដើរសមុទ្រ) ។ enseigne, lieutenant, capitaine de vaisseau ម.ព. enseigne, lieutenant, capitaine) ។ officier de vaisseau សេនានាវា, នាយនាវី ។ vaisseau amiral នាវាឧត្ដមនាវី។ vaisseau de l'Etat នាវារដ្ឋ ។

Anat. នហារូ (សរសៃឈាម)។

vaisseau chylifère នាឡូរគ្គលសី [អន់-គ:-ល:-សី] ។ *Bot.* សរសៃដឹរ

vaisselier *n.m.* ទូចាន

vaisselle *n.f.* ភាជនភ័ណ្ឌ, ចានឆ្នាំង

vaissellerie *n.f.* ឧស្សាហកម្មធ្វើចានឆ្នាំង

val *n.m.* ជ្រលងធំ ។ par monts et par vaux ពីគ្រប់ទិស (*pl.* des vaux ឬ des vals)

valable *a.* គួរយកជាការបាន (ឧ. quittance valable) ។ *Par ext.* គួរទទួលបាន (ឧ. interlocuteur valable); សមហេតុ (ឧ. excuse valable); មានតម្លៃគួរសម (ឧ. œuvre valable)

valablement *adv.* ដោយគួរយកជាការបាន (ឧ. alléguer valablement une excuse)

valet *n.m.* អ្នកបម្រើ, ខ្ញុំកំដរ ។ valet de chambre អ្នកបម្រើក្នុង, អ្នកបម្រើសំលៀកបំពាក់ ។ valet de pied អ្នកបម្រើក្រៅ, អ្នកដើរតាមបម្រើ ។ *Par ext.* កញ្ជះគេ (អ្នកផ្គាប់ចិត្តគេដោយថោកទាបដើម្បីយកប្រយោជន៍)។ *Jeux.* ប៉ោយ (បៀជាក់ង)

valetaille *n.f.* ក្រុមអ្នកបម្រើ (ពាក្យបន្អាប់)

valétudinaire *a. & n.* ដែលឈឺច្រើន, ដែលមានសុខភាពមិនល្អ

valeur *n.f.* តម្លៃ (ឧ. objet de valeur របស់មានតម្លៃ); គុណសម្បត្តិ (ឧ. homme de peu de valeur); សេចក្ដីក្លាហាន (ឧ. soldats d'une rare valeur)។ valeur extrinsèque តម្លៃពាហិរ ។ valeur intrinsèque តម្លៃសង្ឃ-គ្គិក (ម.ព. intrinsèque ផង) ។

Comm. តម្លៃ ។ valeur d'échange តម្លៃដូរ ។ valeur or តម្លៃជាមាស ។ valeur en portefeuille តម្លៃក្នុងសំពៀត ។ valeur résiduelle តម្លៃកាក ។ valeur à revenu fixe តម្លៃប្រតិលាភឥតប្រែប្រួល ។ valeur à revenu variable តម្លៃប្រតិលាភប្រែប្រួល ។ valeur d'usage តម្លៃប្រើប្រាស់ ។ valeur vénale តម្លៃជាតិក ។

ភាពឡើងផល (ឧ. mettre une terre en valeur) ។ *Fig.* សារៈសំខាន់ (ឧ. attacher de la valeur à un propos)។ mettre

en valeur ឬ donner de la valeur បញ្ចេញឲ្យឃើញ (ឧ. mettre ses talents en valeur) ។

Mus. រយៈពេល

valeureusement *adv.* យ៉ាងក្លាហាន

valeureux,euse *a.* ក្លាហាន (ឧ. de valeureux soldats) (បវ. hardi, héroïque, intrépide, vaillant)

valgus *a.* កែក, ដែលស្បៀងចេញក្រៅ (ជើង) (ព.ផ. varus)

validation *n.f.* សុពលកម្ម, ការធ្វើឲ្យបានការ ការប្រកាសថាបានការ (ឧ. la validation d'une élection)

valide *a.* សុពល, អរោគ (ឧ. homme valide) ។ *Fig.* បានការ (ឧ. contrat valide)

validement *adv.* ដោយសុពល, ដោយបានការ

valider *v.t.* ធ្វើសុពលកម្ម, ធ្វើឲ្យប្រើការបាន,ធ្វើឲ្យបានការ; ប្រកាសថាបានការ (ឧ. valider une élection)

validité *n.f.* សុពលភាព, ភាពប្រើការបាន (ឧ. validité d'un billet de chemin de fer); ភាពបានការ

valise *n.f.* វ៉ាលីស, ហិប ។ valise diplomatique ហិបអ្នកការទូត

vallée *n.f.* ជ្រលងភ្នំ

vallon *n.m.* ជ្រលងតូច

vallonnement *n.m.* ភាពជួបជ្រលងភ្នំ

vallonné,e *a.* ជួបជ្រលងភ្នំ (ឧ. une région vallonnée)

vallonner *v.t.* ជីកជាជ្រលង

valoir *v.i.* មានតម្លៃ (ឧ. montre qui vaut dix mille riels); មានន័យថា; ស្មើនឹង, ជំនួស (ឧ. une blanche, en musique, vaut deux noires) ។ *Fig.* មានគុណូបការ (ឧ. homme qui sait ce qu'il vaut); គួរតែ, ល្មមតែ (ឧ. ce paysage vaut une visite); មានប្រយោជន៍ ។ valoir la peine de ឬ que ល្មមនឹង ។ valoir bien ល្មមបាន ។ valoir mieux គួរជាង ។ autant vaut ដូចតែគ្នា ។ cette liqueur ne vaut rien ភេសជ្ជៈនេះឲ្យទោសដល់សុខភាព។ ne rien faire qui vaille គ្មានបានការអ្វីសោះ។ faire valoir ធ្វើឲ្យមានផល, ទាញយក

ប្រយោជន៍ ។ se faire valoir បញ្ចេញគុណសម្បត្តិខ្លួន; ធ្វើឲ្យគេស្គាល់តម្លៃខ្លួន; សំអាងសិទ្ធិខ្លួន; *en mauv. part.* សំអាងគុណសម្បត្តិពេលខ្លួនគ្មាន ។

v.t. ផ្ដល់, នាំមកឲ្យ (ឧ. la gloire que ses exploits lui ont value) ។

v. impers. il vaut mieux គួរតែ... ជាង ។ autant vaudait គប្បីដែរ ។ vaille que vaille *loc. adv.* ទោះជាយ៉ាងណាក៏ដោយ ។

n.m. un rien-qui-vaille មនុស្សឥតបានការសោះ

valorem (ad) *loc. lat.* ម.ព. ad valorem

valorisation *n.f.* ការបង្កើនតម្លៃ, ការធ្វើឲ្យមានតម្លៃ

valoriser *v.t.* ធ្វើឲ្យមានតម្លៃ

valse *n.f.* របាំវ៉ាល់ស៍ (រាំបង្វិលខ្លួន); ភ្លេងវ៉ាល់ស៍

valser *v.i.* រាំវ៉ាល់ស៍ ។ *v.t.* រាំតាមភ្លេងវ៉ាល់ស៍

value *n.f.* moins-value ម.ព. moins-value ។ plus-value ម.ព. plus-value

valvaire *a.* នៃបូត [ប៉ូត]

valve *n.f.* បូត [ប៉ូត] (ផ្នែកនីមួយៗនៃសំបកគ្រុំ, លៀសឬសំបកផ្លែឈើ); ក្បាលវ៉ាល់វ៍ (សន្ទះទប់ខ្យល់) (ឧ. valve de chambre à air)

valvé,e *a.* ដែលផ្សំដោយវ៉ាល់វ៍

valvulaire *a.* ដែលមានសន្ទះ; នៃសន្ទះ

valvule *n.f.* សន្ទះ (សន្ទះដែលទប់មិនឲ្យឈាមហូរថយជាដើម) ។ valvule pylorique សន្ទះក្លួនក្រពះ

vampire *n.m.* ខ្មោចហុតឈាមមនុស្ស។ *Fig.* អ្នករឹបជាន់យកធ្វើមាន; ជ្រិងវ៉ែមពៀរ (សត្វជ្រិងម្យ៉ាងនៅទ្វីបអាមេរិក)

vampirisme *n.m.* ជំនឿថាមានខ្មោចហុតឈាមមនុស្ស; ការបំផ្លាញនៃជ្រិងវ៉ែមពៀរ ។ *Fig.* លោភៈ (ការជិះជាន់គេយកធ្វើមាន)

van *n.m.* ចង្អេរ

van *n.m.* រទេះដឹកនាំសេះ

vandale *n.m.* អ្នកបំផ្លាញវត្ថុសិល្បៈនិងរបស់ល្អៗ

vandalisme *n.m.* ការនិយមបំផ្លាញវត្ថុសិល្បៈនិងរបស់ល្អៗ

vanille *n.f.* វ៉ានីយ៍ (ផ្លែឈើម្យ៉ាង)

vanillé,e *a.* អប់ក្លិនវ៉ានីយ៍

vanillerie ឬ **vanillière** *n.f.* ចំការ

វ៉ានីយ៉

vanillier *n.m.* ដើមវ៉ានីយ៉ (ឧ. le vanillier est cultivé aux Antilles)

vanilline *n.f.* ជាតិក្លិនវ៉ានីយ៉

vanité *n.f.* វិជ្ជភាព, តុច្ឆភាព, ភាពឥតខ្លឹមសារ; របស់ឥតខ្លឹមសារ; អំនួត, សេចក្ដីអួត ។ tirer vanité de យកមកអួត; ឡើងឡឹកដោយ ។ sans vanité ឥតអួតទេ

vaniteusement *adv.* ដោយឡឹក

vaniteux,euse *n. & a.* មនុស្សអួត, ឡឹក (ឧ. un vaniteux grotesque)

vannage *n.m.* សារពន្ធសន្ទះទប់ទឹក

vannage *n.m.* ការអុំ (ដោយចង្អេរ)

vanne *n.f.* សន្ទះទប់ទឹក; ស្លាបធំៗនៃស្លាបបក្សី

vanner *v.t. Techn.* ដាក់សន្ទះទប់ទឹក

vanner *v.t.* អុំ (ដោយចង្អេរ) (ឧ. vanner le riz) ។ *Pop.* ធ្វើឲ្យហត់ខ្លាំង

vannerie *n.f.* របរអ្នកធ្វើកញ្ច្រែងល្អី; កញ្ច្រែងល្អី

vanneur *n. & a.m.* អ្នកអុំ

vanneuse *n.f.* ត្បាល់បក់

vannier *n.m.* អ្នកធ្វើកញ្ច្រែង-ល្អី

vannure ឬ **vannée** *n.f.* សំដី,កំទេចចេញពីត្បាល់បក់

vantail,aux *n.m.* ផ្ទាំងទ្វារ (*pl.* des vantaux)

vantard,e *n. & a.* មនុស្សអំនួត (ឧ. les chasseurs sont souvent vantards)

vantardise *n.f.* អំនួត

vanter *v.t.* អួត (ឧ. vanter le temps passé) ។

se vanter *v.pr.* អួតខ្លួន (ឧ. il n'y a que les sots pour se vanter sans cesse) ។ se vanter de អួតខ្លួនអំពី (ឧ. se vanter de sa force); អួតខ្លួនថា (ឧ. il se vante de réussir)

vanterie *n.f.* ការអួតខ្លួន ; ទម្លាប់នៃមនុស្សអំនួត

va-nu-pieds *n.m.inv.Fam.* មនុស្សតោកយ៉ាក (គ្មានស្បែកជើងពាក់)

vapeur *n.f.* ចំហាយ, ចំហាយ (ឧ. vapeur d'eau) ។ machine, bateau à vapeur ម៉ាស៊ីន, កប៉ាល់ដើរដោយចំហាយទឹក ។ à la ឬ à toute

vapeur យ៉ាងលឿន ។

Fig. របស់ឥតខ្លឹមសារ ។

pl. Fig. ជាតិស្រវឹង (ឧ. les vapeurs du vin) ; ការស្រវឹងដោយតណ្ហា

vapeur *n.m. Mar.* កប៉ាល់

vaporeusement *adv.* ជាចំហាយ

vaporeux,euse *a.* ដែលមានចំហាយ (ឧ. ciel vaporeux); ស្រអាប់ (ដោយចំហាយ) (ឧ. lumière vaporeuse)។ *Fig.* សាភ៌; មិនច្បាស់។ tissu vaporeux ស្បៃស្តើងហៀ

vaporisage *n.m.* ការបន្ទុំដោយចំហាយ (ដើម្បីឲ្យពណ៌ជាប់ល្អជាដើម)

vaporisateur *n.m.* ប្រដាប់ព្រួសទឹក

vaporisation *n.f.* ការព្រួសទឹក; ដំណើរក្លាយជាចំហាយ

vaporiser *v.t.* ព្រួសទឹក; ធ្វើឲ្យទៅជាចំហាយ ។ se vaporiser *v.pr.* ក្លាយទៅជាចំហាយ

vaporiseur *n.m.* ម.ព. vaporisateur

vaquer *v.i.* នៅទំនេរ (កន្លែង ឬមុខងារ); ឈប់ក្នុងវិស្សមកាល (ឧ. les tribunaux vaquent) ។

v.t. ind. vaquer à ធ្វើដោយផ្ចិតផ្ចង់ (ឧ. vaquer à ses affaires)

varaigne *n.f.* ផ្លូវបញ្ចូលទឹកសមុទ្រទៅស្រែអំបិល

varech *n.m.* សារាយ

vareuse *n.f.* ក៏រ៉ុស(អាវធ្វើការនៃកម្មករនាវា; អាវម្យ៉ាង)

variabilité *n.f.* វិបរិណាមភាព (ឧ. variabilité du temps) ។ *Gram.* ភាពជាព្យយសព្ទ

variable *a.* វិបរិណាម, អាចផ្លាស់ប្តូរ ឬអាចប្រែប្រួលបាន ។ *Gram.* ព្យយសព្ទ

variablement *adv.* ដោយវិបរិណាម, ដោយអាចផ្លាស់ប្តូរ ឬប្រែប្រួលបាន

variant,e *a.* ដែលផ្លាស់ប្តូរញយ

variante *n.f.* រូបន្តរ [រូ-ប៉ន់-តរ], អ្វីៗដែលទីទៃពីគ្នា, ដែលផ្សេងពីគ្នា

variation *n.f.* វិបរិណាម, ដំណើរផ្លាស់ប្តូរ ។ *pl.* ដំណើរប្រែប្រួល (ឧ. les variations d'une doctrine)

varice *n.f. Pathol.* ដំណើរយឺត ឬរីកសរសៃឈាម

varicelle *n.f.* អុតស្វាយ, អុតតូច

varié,e *a.* វិជ, ផ្សេងគ្នា(ឧ. couleurs variées)។ mouvement varié

វិធបលតា (ដែលមានល្បឿនមិនស្មើ)

varier *v.t.* ផ្លាស់ប្តូរ (ឧ. varier son alimentation); ធ្វើឲ្យផ្សេងគ្នា, ធ្វើឲ្យប្លែកគ្នា ។

v.i. ប្រែប្រួល (ឧ. ses réponses varient); ប្រែ, ប្លែកគ្នា (ឧ. les mœurs varient d'un pays à l'autre): ផ្លាស់យោបល់, មានយោបល់ខុសគ្នា(ឧ.les auteurs varient sur ce point)។ *Math.* ផ្លាស់តម្លៃ

variété *n.f.* ដំណើរផ្លាស់ប្តូរញយៗ(ឧ. la variété d'occupations) ; បែប, មុខៗ (ភាពប្លែកគ្នានៃវត្ថុមួយយ៉ាង) (ឧ. une grande variété de plantes): វិធភាព; ភាពផ្សេងគ្នា, ភាពខុសគ្នា (ឧ. la variété des opinions)

varietur (ne) *loc. lat.* អវិបរិណាម, ដើម្បីកុំឲ្យប្រែប្រួល ឬ ផ្លាស់ប្តូរបាន (ឧ. faire parapher un acte, un document, ne varietur); ឥតប្រែប្រួល (ឧ. une édition ne variatur)

variole *n.f.* អុតព្រៃ,អុតធំ(ហៅ. petite vérole)

variolé,e *a.* អុត (ដែលមានស្លាកអុត)

varioleux,euse *a.* នៃអុតធំ ។ *n.* អ្នកកើតអុត

variolique *a.* នៃអុតធំ (ឧ. pustule variolique)

variolisation *n.f.* ការបណ្តុះអុត(របៀបយកមេអុតស្រាលទៅបង្កងដើម្បីចៀសវាងអុតកាច)

varioloïde *n.f.* អុតធំស្រាល

variqueux,euse *a.* នៃរោគយឺតសរសៃឈាម; ដែលបណ្តាលអំពីដំណើរយឺតសរសៃឈាម (ឧ. ulcère variqueux)

varlope *n.f. Techn.* ដែកឈូសវែង

varloper *v.t.* ឈូស (ដោយដែកឈូសវែង)(ឧ.varloper une planche)

varron *n.m.* ដង្កោ

varus [– russ], *f.* **vara** *a.* (ព. ឡាតាំង) ជង្គង់សោក, កែងចូលក្នុង (ឧ. pied bot varus; coxa vara) (ព.ផ. valgus)

vasard,e *a.* ដែលមានភក់ (ឧ. côte vasarde) ។ *n.m.* បាតមានភក់

vasculaire ឬ **vasculeux,euse** *a.* នៃនហារូ, នៃសរសៃឈាម (ឧ. membrane vasculaire); ដែល

មានតែសរសៃឈាម (ឧ. tissus vasculeux)

vascularisation *n.f.* លំនាំសរសៃ ភបក្នុងសរីរាង្គ (ឧ. la vascularisation du foie)

vascularisé,e *a.* ដែលមាននហារូ (សរសៃឈាម)

vase *n.f.* ភក់; កករ

vase *n.m.* ភាជន៍, ផើង

vaseline *n.f.* វ៉ាស៊ីលីន

vaseux,euse *a.* ដែលមានភក់, ដែលមានតែភក់ (ឧ. fond vaseux) ។ *Fig. & pop.* អស់កម្លាំង, ល្ងើយ; ពិបាកយល់(ឧ.un article vaseux)

vasière *n.f.* កន្លែងមានភក់; មេទឹកស្រែអំបិល (កន្លែងទុកទឹកសម្រាប់បង្ហូរដាក់ស្រែអំបិល)

vasistas [-zis-tass] *n.m.* ទ្វារ ឬ បង្អួចទល់

vaso-constricteur *a.m.* ដែលរួបសរសៃឈាម

vaso-dilatateur *a.m.* ដែលពង្រីកសរសៃឈាម

vaso-moteur,trice *a.* nref vaso-moteur ម.ព. nerf

vasque *n.f.* អាងតម្រងទឹកម៉ាស៊ីន(មូលហើយរាក់); កែវ ឬ ពានតាំង (សម្រាប់តាំងលើតុ)

vassal,e,aux *n.* សាមន្តរាជ, ប្រទេសរាជ, អ្នកចំណុះគេ ។ *a.* ចំណុះ

vassalité *n.f.* ឬ **vasselage** *n.m.* ភាពនៅក្នុងចំណុះ ។ *Fig.* ទាសភាព (ល៊ី. assujettissement, dépendance, esclavage, servitude, subordination)

vassiveau *n.m.* កូនចៀម (អាយុមិនទាន់ដល់ពីរឆ្នាំ)

vaste *a.* ធំ (ឧ. une vaste plaine); ទូលាយ ។ *Fig.* ធំ (ឧ. une vaste entreprise; de vastes projets); ទូលំទូលាយ, ជ្រៅជ្រះ (ឧ. une vaste érudition)

vastement *adv.* យ៉ាងធំ,យ៉ាងទូលាយ

vaticane *a.f.* នៃវ៉ាទីកង់ (វិមានប៉ាប) (ឧ. politique vaticane)

vaticinateur,trice *n.* ហោរ

vaticination *n.f.* ការទាយ (ទាយអនាគត)

vaticiner *v.i.* ទាយ (ទាយអនាគត) (ច្រើនតែប្រើខាងផ្លូវអាក្រក់)

va-tout *n.m. inv.* ការដាក់ទាំងអស់ (ក្នុងល្បែងបៀ ដាក់អស់ប្រាក់ពីមុខខ្លួន

រលឹង) ។ *Fig.* risquer son va-tout ប្រថុយលើកក្រោយ ; ប្រថុយទាំងអស់

vaudeville *n.m. Autref.* បម្រៀងកំប្លែង ។ *Auj.* ល្ខោនកំប្លែង

vaudevillesque *a.* ត្រូវនឹងល្ខោនកំប្លែង

vaudevilliste *n.m.* អ្នកនិពន្ធល្ខោនកំប្លែង

vaudou *n.m.* វូឌូ (សាសនាជនជាតិអាហ្វ្រិកស្បែកខ្មៅ ដែលនាំចូលទៅក្នុងប្រទេសអាមេរិក)

vau-l'eau (à) *loc.adv.* បណ្ដោយទឹក, ដែលរសាត់តាមទឹក(ឧ. barque qui s'en va à vau-l'eau); រពាត់-រពាយ។ *Fig.* aller à vau-l'eau មិនបានសម្រេច (ឧ. l'affaire est allée à vau-l'eau)

vaurien,enne *n. & a.* មនុស្សពាលម្សៀត

vautour *n.m.* ត្មាត ។ vautour cendré, vautour moine ឬ arrian ត្មាតជេះ ។ vautour fauve ឬ griffon ត្មាតភ្លើង ។ *Fig.* ត្មាត, មនុស្សលោភ

vautrer (se) *v.pr.* ននៀល (នៅដី ឬ នៅភក់) (ឧ. se vautrer sur l'herbe ននៀលលើស្មៅ) ។ *Par ext.* បង្អប់ខ្លួនក្នុង; ដេក (ឧ. se vautrer dans un fauteuil, sur un lit)

vau-vent (à) *loc. adv.* បណ្ដោយខ្យល់, ពីក្រោមខ្យល់ ។ chasser à vau-vent លបបាញ់ពីក្រោមខ្យល់ ។ aller à au-vent រត់បណ្ដោយខ្យល់ (សត្វដែលគេដេញ)

vauvert ។ aller au diable vauvert ឬ c'est au diable vauvert ដើរឆ្ងាយ; ទៅនៅទីឆ្ងាយដាច់ស្រយាល (ម.ព. diable ផង)

veau *n.m.* កូនគោឈ្មោល (កូនគោញី: génisse); សាច់កូនគោ (ឧ. un rôti de veau); ស្បែកកូនគោ (ឧ. soulier en veau mégis) ។ tuer le veau gras ជប់លៀងធំ ។ faire le veau ឬ s'étendre comme un veau ទម្លាក់ខ្លួនដេក (ដោយបណ្ដោយខ្លួនទៅទាំងស្រុងពិតៗ) ។ veau marin ផ្សោត ។ *Fig.* adorer le veau d'or ស្រឡាញ់ធនធាន (ស្មើសាសនា) ។ *Loc. div.* pleurer com-

me un veau ម.ព. pleurer

vecteur *n.m.Math.* ទិសយុត្តិ

vectoriel,elle *a. Math.* ទិសយុត្ត ។ analyse vectorielle វិភាគទិសយុត្ត ។ grandeur vectorielle ទំហំទិសយុត្ត

vedette *n.f. Autref.* អ្នកជិះសេះយាមល្បាត។ *Mar.* នាវាល្បាត; ទូកដែក (កប៉ាល់ល្បឿនតូច)។ *Fig.* តួឯក (ឧ. vedette de cinéma)។ mettre en vedette ធ្វើឱ្យគេស្គាល់ ; បញ្ចេញឱ្យឃើញច្បាស់, ធ្វើឱ្យលេចធ្លោ។ *Arts graph.* en vedette ក្រឡោត (អក្សរពុម្ព)

Védas *n.propre* វេទ (គម្ពីរសំដែងបែប ឬ របៀបផ្សេងៗខាងសាសនាព្រាហ្មណ៍)

védique *a.* នៃវេទ ។ *n.m.* ភាសាប្រើក្នុងវេទ

védisme *n.m.* វេទនិយម

végétal *n.m.* រុក្ខជាតិ (*pl.* des végétaux)

végétal,e,aux *a.* នៃរុក្ខជាតិ (ឧ. règne végétal); ដែលយកមកពីរុក្ខជាតិ (ឧ. rouge végétal); terre végétale ម.ព. terre ។ formation végétale ផន្តុំរុក្ខជាតិ (ឧ. la forêt est une formation végétale où l'arbre domine)

végétalisme *n.m.* សាកជាតិនិយម (ការបរិភោគតែបន្លែនិងផ្លែឈើសុទ្ធ គមអ្វីគ្រប់យ៉ាងដែលកើតអំពីសត្វ)

végétarien,enne *a.&n.* សាកាហារី, អ្នកបរិភោគតែបន្លែ

végétarisme *n.m.* សាកាហារនិយម (ការតមតែសាច់សុទ្ធ)

végétatif,ive *a.* ជារុក្ខជាតិ(ឧ. principe végétatif); នៃសត្វមានជីវិត (ឧ. fonctions végétatives)។ *Fig.* ដែលបន្ថយ, ដែលមានត្រឹមតែល្មមរស់ជីវិត (ឧ. vie végétative) ។ appareil végétatif បរិជាតាហារ (គ្រឿងសម្រាប់ឱ្យរុក្ខជាតិចិញ្ចឹមជីវិត ម៉ាងឫស, ដើមនិងស្លឹក ជាដើម) ។ multiplication végétative ការផុះអំពីបរិជាតាហារ (គឺផុះពីឫស,ដើម,ស្លឹក ។ល។)

végétation *n.f.* ភោហណា, ដំណើរលូតលាស់នៃរុក្ខជាតិ; រុក្ខជាតិ (ឧ. la végétation des tropiques) ។ *Pathol.* ភោហណា, ដំណើរផុះខុស

ធម្មតា

végéter *v.t.* ដុះ, លូត ; រស់នៅតែមួយកន្លែង (ដោយគ្មានសកម្មភាព, ដោយមិនបានចម្រើន); រស់នៅរហេមរហាម (ដោយគ្មានគេស្គាល់) (ឧ. végéter dans un emploi subalterne)

véhémence *n.f.* សូរភាព, សេចក្ដីក្លៀវក្លា, សេចក្ដីខ្លាំងក្លា (ឧ. parler avec véhémence) (មើ. impétuosité, violence)

véhément,e *a.* ខ្លាំងក្លា (ឧ. orateur véhément)

véhémentement *adv.* ដោយខ្លាំងក្លា; ដោយខ្លាំងណាស់; យ៉ាងច្រើន (ឧ. discourir véhémentement)

véhicule *n.m.* យាន, គ្រឿងដឹកនាំ (តាមជើងគោក, ជើងទឹក ឬ ជើងអាកាស) (ឧ. véhicules industriels) ; គ្រឿងដឹកនាំ (ឧ. l'air est le véhicule du son)។ *Fig.* យាន, មធ្យោបាយទាក់ទងគ្នា (ឧ. l'imprimerie est le véhicule de la pensée)។ langue véhicule ភាសាយាន (ភាសាដែលប្រើសម្រាប់រៀនវិជ្ជាមួយ)

véhiculer *v.t.* ដឹកនាំដោយយាន; ដឹក។

Fig. បញ្ជូន

veille *n.f.* ដំណើរអត់ងងុយ (ឧ. les longues veilles altèrent la santé); ការនៅភ្ញាក់ (មិនបានដេក); ថ្ងៃម្សិល, ថ្ងៃមុន (មុនមួយថ្ងៃ) (ឧ. la veille de Pâques)។

pl. កិច្ចការធ្វើក្នុងវេលាយប់; ការខំសិក្សា (ឧ. c'est le fruit de ses veilles); អនិទ្រា, ដំណើរដេកមិនលក់។

Loc. div. être à la veille de ជិតដល់, ហៀបនឹង (ឧ. être à la veille de son départ)។ lit de veille គ្រែអ្នកយាមជម្ងឺ

veillée *n.f.* ពេលព្រលប់ (ពីពេលបាយល្ងាចដល់ពេលចូលដំណេក); ការប្រជុំគ្នាពេលព្រលប់

veiller *v.i.* អត់ងងុយ, មិនដេក (ឧ. veiller jusqu'au jour); យាម (ឧ. le concierge veille à la sortie de l'établissement); រឭក (នៅក្នុងសភាពដេកមិនលក់) (ឧ. Ne sens-je pas bien que je veille? Ne suis-je dans mon bon sens? (Molière))។

v.t. ind. (à ឬ sur) *Fig.*

ប្រុងប្រយ័ត (ឧ. seuls, veillons sur nos pensées; en famille, sur notre honneur; en société, sur notre langue (Mme de Staël); ថែទាំ (ឧ. veiller sur les jours de quelqu'un)។ veiller au grain ប្រយ័តខ្យល់ព្យុះ; *au fig.* ប្រយ័តការណ៍។

v.t. យាម ។ veiller un malade យាមជំងឺ ។ veiller un mort យាមខ្មោច

veilleur,euse *n.* អ្នកមិនដេក។ *n.m.* អ្នកយាម (ឧ. veilleur de nuit អ្នកយាមយប់)

veilleuse *n.f.* ចង្កៀងដំណេក ។ *Fig.* mettre en veilleuse មួល ប្រឆេះចង្កៀងឡូតូច; បន្ថយសកម្មភាព

veillotte *n.f.* គូនជ្រីមចំបើង

veinard,e *n.* អ្នកមានសំណាង ។ *a.* ហេង (ឧ. un joueur veinard)

veine *n.f.* ធមនី , សរសៃឈាមខ្មៅ (ឈាមចូលបេះដូង) ។ veine cave លេណធមនី ។ veine pulmonaire ធមនីបញ្ញាសិក ។

ឡាយ (សាច់ឆ្នូតៗនៃអ៊ែឈើ ឬ ថ្មកែវ) ។ *Min.* ខ្សែរ៉ែ (ឧ. tomber sur une veine importante) ។ veine poétique ការទេពកោសល្យ (ទេពកោសល្យខាងកវីនិពន្ធ) ។ *Fam.* សំណាង (ឧ. avoir de la veine au jeu)

veiné,e *a.* ដែលមានឡាយ (មានឆ្នូត) (សាច់ឈើ ឬ ថ្មកែវ) (ឧ. marbre veiné); ពព្រាក់

veiner *v.t.* លាបព្រាប់ឡាយឈើ ឬ ថ្មកែវ

veinette *n.f.* ជក់សំប៉ែតសម្រាប់លាប ធ្វើព្រាប់ឡាយឈើ ឬ ថ្ម

veineux,euse *a.* នៃធមនី (សរសៃឈាមខ្មៅ) (ឧ. système veineux) ។ sang veineux ឈាមធមនី, ឈាមខ្មៅ (ដែលចូលបេះដូងវិញ) ។ ដែលមានឡាយ (សាច់ឈើ, ថ្មកែវ) (ឧ. bois veineux)

veinule *n.f.* អនុធមនី,សរសៃឈាមតូច

veinure *n.f.* ឡាយ (ក្រឡាអង្កាញ់នៃសាច់ឈើ ឬ ថ្មកែវ).

vélage ឬ **vêlement** *n.m.* ការកើតកូន (មេគោ)

vélaire *a.* & *n.f.* កណ្ឋជៈ (អក្សរដែលមានសម្លេងកើតជិតក្រអូមមាត់)

vêlement *n.m.* ម.ព. vêlage

vêler *v.i.* កើតកូន (មេគោ)

vélin *n.m.* ស្បែកកូនគោសម្លាប់; ក្រដាសម៉ដ្ឋល្អមួយ (ឧ. vélin teinté) ។

a. នៃក្រដាសម៉ដ្ឋ ។ papier vélin ម.ព. papier

vêlique *a.Mar.* នៃក្ដោង

vélivole *n.&a.* អ្នកចូលចិត្តហោះបណ្ដែតតាមខ្យល់

velléitaire *a.&n.* ដែលគ្រាន់តែប៉ង

velléité *n.f.* ឆន្ទន្ទ [អូ.ន័ប.ធ័ន] (បំណងខ្សោយ, ការគ្រាន់តែប៉ង) (ឧ. avoir des velléités de résistance)

vélo *n.m.Fam.* រទេះកង់(ទោចក្រយាន)

véloce *a.* រហ័ស

vélocipède *n.m.* ទោចក្រយាន(ពាក្យជាន់ដើម)

vélocité *n.f.* ដំណើរលឿន ឬ រហ័ស (សរ. célérité, diligence, hâte, prestesse, promptitude, rapidité ។ ព.ផ. lenteur, longueur, mollesse)

vélodrome *n.m.* វិលវង់ប្រណាំងទោចក្រយាន

vélomoteur *n.m.* ទោចក្រយានយន្តតូច

velot *n.m.* ស្បែកកូនគោ(កើតមកស្លាប់)

velours *n.m.* កម្មី ។ *Par anal.* អ្វីៗដែលទន់ល្មើយ(ឧ. le velours d'une pêche) ។ patte de velours ម.ព. patte ។ *Fig.* faire patte de velours លាក់ក្រចក (លាក់ពុត)។ *Fam.* sur le velours ដោយគ្មានទំប្រឹង

velouté,e *a.* ដូចកម្មី (ឧ. papier velouté); ទន់ល្មើយ (ឧ.peau veloutée) ។

n.m. ភាពទន់ល្មើយ (ឧ. le velouté d'un fruit)

veloutement *n.m.* ការធ្វើឲ្យមានសភាពជាកម្មី; ការធ្វើឲ្យទន់ល្មើយ

velouter *v.t.* ធ្វើឲ្យមានសភាពជាកម្មី ។ *Fig.* ធ្វើឲ្យឡើងទន់ល្មើយ

velouteux,euse *a.* ដែលមានរោមទន់ល្មើយ

veloutier *n.m.* ជាងត្បាញកម្មី

veloutine *n.f.* វីលូទីន (សំពត់អំបោះកោសឲ្យឡើងរោមដូចកម្មី)

velu,e *a.* ស្រមូវ, ដែលមានរោមពាសពេញ (ឧ. bras velus; fruit velu)

venaison *n.f.* សាច់សត្វព្រៃ(សាច់ជ្រូក

ព្រៃ, រមាំង ។ល។ ផងដើម)

vénal,e,aux *a.* ដែលត្រូវបង់ថ្លៃ (ឧ. une charge vénale) ។ *Fig.* ដែលទិញដោយប្រាក់បាន; ដែលគិតតែពីប្រាក់; ដែលគិតតែប្រយោជន៍; ដែលគេខ្ជួលឲ្យធ្វើអំពើអកុសលគ្រប់មុខបាន (ឧ.un homme vénal) ។ *Com.* ជានិក ។ valeur vénale ម.ព. valeur

vénalement *adv.* ដោយគិតតែពីប្រាក់; ដោយគិតតែប្រយោជន៍ខ្លួន

vénalité *n.f.* ភាពត្រូវបង់ថ្លៃ (ឧ. la vénalité des charges); ជានិកភាព; ភាពទិញដោយប្រាក់បាន ។ *Fig.* ភាពអ្នកគិតតែប្រយោជន៍ខ្លួន

venant,e *a.* ដែលមក ។ bien venant ប្រកបដោយវិឡនផល ។

n.m. អ្នកមក (ឧ. les allants et les venants) ។ tout venant ម.ព. tout-venant ។ à tout venant គ្រប់គ្នា, ជាមិនប្រែប្រួល

vendable *a.* វិក្រាយិក, អាចលក់បាន (ឧ. marchandises vendables)

vendange *n.f.* ការបេះទំពាំងបាយជូរ (ឧ. faire la vendange); ផ្លែទំពាំងបាយជូរ(ដែលគេបេះ) (ឧ.porter la vendange à la cuve); រដូវបេះទំពាំងបាយជូរ (ឧ. se louer pour les vendanges)

vendangeoir *n.m.* កញ្ច្រែងបេះទំពាំងបាយជូរ

vendanger *v.t.* បេះទំពាំងបាយជូរ (ឧ. vendanger une vigne) ។

v.i. បេះទំពាំងបាយជូរ(ឧ. vendanger de bonne heure)

vendangerot *n.m.* កន្ត្រកបេះទំពាំងបាយជូរ

vendangette *n.f.* ម.ព. grive

vendangeur,euse *n.* អ្នកបេះទំពាំងបាយជូរ

vendéen,enne *a.&n.* នៃខេត្តវ៉ង់ដេ

vendetta [–dèt-ta] *n.f.* វ៉ង់ដែតា (របៀបសងសឹកគ្នាតពូជនៅកោះគ័រស៍)

vendeur,euse *n.* វិក្រយិក-យិកា, អ្នកលក់ (ឧ. une vendeuse de magasin ស្រីអ្នកលក់ក្នុងហាង) ។ *Dr.* vendeur, venderesse អ្នកលក់ (អ្នកធ្វើលិខិតលក់)

vendre *v.t.* លក់ (ឧ. vendre sa maison), លក់, ក្បត់ (ឧ. vendre

des tissus) ។ *Fig.* លក់ (ចំពោះវត្ថុដែលមិនត្រូវលក់បាន មានការទទួលសំណូកជាដើម) (ឧ. vendre sa conscience); លក់ (ក្បត់ដើម្បីយកប្រាក់) (ឧ. vendre ses complices) ។

Loc. div. vendre une chose chat en poche ម.ព. chat ។ *Fig. & Fam.* vendre la mèche ប្រាប់ការណ៍សម្ងាត់ ។ vendre chèrement sa vie ម.ព. chèrement ។ vendre son honneur លក់កេរ្តិ៍លក់ឈ្មោះ (សុខចិត្តធ្វើអំពើថោកទាប)។ vendre la peau de l'ours ប្រើប្រាស់វត្ថុដែលមិនទាន់បាន។ j'y vendrai ma chemise ខ្ញុំប្រថុយលក់ខោអាវ (លក់ឲ្យអស់ពីខ្លួនដើម្បីឲ្យបានសម្រេច) ។ il vendrait jusqu'à sa chemise គាត់លក់ខោលក់អាវអស់ពីខ្លួន, គាត់ចាយ ឬ លេងអស់ពីខ្លួន ។ être à quelqu'un à vendre et à dépendre ត្រៀមចាំបម្រើជានិច្ច, ធ្វើតាមបំណងជានិច្ច ។

Prov. ce n'est pas tout de vendre, il faut livrer ត្រូវប្រតិបត្តិតាមពាក្យសន្យាផង

vendredi *n.m.* ថ្ងៃសុក្រ ។ vendredi saint ថ្ងៃខួបនៃមរណភាពព្រះយេស៊ូ ។

Prov. qui rit vendredi, dimanche pleurera ម.ព. dimanche និង rire

vendu,e *a.* ដែលលក់ខ្លួន; ដែលគេល្បួងបានដោយប្រាក់ (ឧ. homme vendu à un pays étranger) ។

n. អ្នកលក់ខ្លួន, អ្នកដែលគេល្បួងបានដោយប្រាក់

venelle *n.f.* ផ្លូវតូច

vénéneux,euse *a.* ពុល (ឧ. champignon vénéneux) ។ animaux vénéneux សត្វពុល (កុំប្រឡំនឹង animaux venimeux សត្វមានពិស) (ឧ. les moules sont quelquefois vénéneuses)

vénérable *a.* គួរធ្វើសក្ការៈ, គួរគោរព

vénérablement *adv.* ដោយគួរធ្វើសក្ការៈ, ដោយគួរគោរព

vénération *n.f.* សក្ការៈ, សេចក្តីគោរព (ឧ. il a beaucoup de vénération pour son père)

vénérer *v.t.* គោរព (ឧ. vénérer un bienfaiteur); ធ្វើសក្ការៈ (ឧ. vénérer des reliques) (ព្រ. adorer, honorer, révérer)

vénerie *n.f.* ការប្រដេញសត្វ

vénérien, enne *a.* នៃមេថុនកម្ម ។ maladie vénérienne រោគស្ត្រី (រោគស្វាយ, ប្រមេះ)

venette *n.f. Fam.* សេចក្ដីខ្លាច, ជំណើរភ័យ

veneur *n.m.* អ្នកនាំឆ្កែប្រដេញសត្វ។ grand veneur នាយព្រានប្រមាញ់

vénézuélien, enne *a. & n.* នៃប្រទេសវេណេស៊ុយអេឡា

vengeance *n.f.* ពៀរពិរោធ, ការសងសឹក

venger *v.t.* សងសឹក (ឧ. venger une offense)។ venger quelqu'un សងសឹកជួសអ្នកណាម្នាក់ ។
se venger (de) *v.pr.* សងសឹក

vengeur, eresse *n. & a.* ដែលសងសឹក, ដែលធ្វើទោស (ឧ. un bras vengeur)

véniel, elle *a.* ។ péché véniel បាបកម្មស្រាល (ផ្ទ. នឹង péché mortel) ។ *Par ext.* ស្រាល (ឧ. faute vénielle)

véniellement *adv.* យ៉ាងស្រាល (ឧ. pécher véniellement)

venimeux, euse *a.* ដែលមានពិស (ឧ. la vipère est un animal venimeux) ។ *Fig.* កំណាច, ដែលប្រកបដោយអសុទ្ធចិត្ត (ឧ. critique venimeuse)

venimosité *n.f.* ភាពមានពិស

venin *n.m.* ពិស (ពិសសត្វ) (ឧ. le venin de la vipère) ។ *Fig.* ពិស (អំពើកំណាច) (ឧ. le venin de la calomnie)

venir *v.i.* មក (ឧ. venez que je vous parle); មកដល់ (ដោយគិតនឹងខ្លួនមុន) (ឧ. la mort vient sans qu'on s'en doute); មកអំពី (ធ្លងពី) (ឧ. cette maladie vient de famille); មកដល់, ដល់ត្រឹម, លូកដល់ (ឧ. il me vient à l'épaule); បានដល់, បានសម្រេច; មកអំពី (មានអាគតស្ថាន, មានដើមកំណើត) (ឧ. ce thé vient de Ceylan); ចេញ, ហូរ, ស្រក់ (ឧ. ce vin vient goutte à goutte); មកដល់ (ដោ

បន្ទាប់)(ឧ. le printemps vient après l'hiver; quand viendra l'heure!);មកអំពី(ក្លាយមកពី) (ឧ. ce mot vient du pali); មានឡើង, កឡើង, កើតឡើង (ឧ. il lui est venu une tumeur): ចេញមកពី, បានមកពី (ឧ. le pouvoir vient du pleuple); លូត លាស់, ដុះ (ឧ. cet arbre vient bien) ។

Loc. div. faire venir ហៅមក, អញ្ជើញមក (ឧ. faire venir le médecin);បង្គាប់ឲ្យយកមក,បញ្ជូនវិញ(ឧ. faire venir des provisions de la campagne)។ en venir à (ឬ jusqu'à) ហៅន ដល់,ដល់ទៅ។ vouloir en venir មានបំណង(ដោយកាយឬដោយវាចា)។ venir au monde កើត ។ en venir aux mains ប្រវាយគ្នា ។ venir à bout de លុះ, មាន ជោគជ័យ ។ venir à bien បាន សម្រេច ។ venir à rien ចុះឱន- ថយ; *au fig.* គ្មានជោគជ័យសោះ ។ venir de ទើបនឹង (ឧ. il vient de partir) ។ se faire bien venir ធ្វើឲ្យស្រឡាញ់ ។ laisser venir ឬ voir venir ចាំកឲ្យមក, រង់ចាំ ។ voir venir quelqu'un ដឹងបំណងមុន ។ ne faire qu'aller et venir នៅមិនស្ងៀម សោះ; គ្រាន់តែទៅដល់មកវិញភ្លាម (ឧ. attendez-moi, je ne fais qu'aller et venir) ។ à venir ក្រោយ, ទៅអនាគត (ដែល នឹងមកដល់នៅពេលក្រោយ) (ឧ. les siècles à venir)។ venir après បន្ទាប់ ។ ceux qui viendront après nous កូនចៅយើងក្រោយៗ។ venir à បើសិនជា(ដោយមិនដឹងខ្លួន) (ឧ. s'il venait à mourir, ses enfants seraient bien malheureux) ។ venir à une chose សម្រេចធ្វើអ្វីមួយ (ឧ. un jour il y viendra) ។ venir bien à ត្រូវចិត្ត ។ venir ឬ en venir à ses fins បានសម្រេច ។ venir à la maturité ទុំ ។ venir au secours ជួយ ។ venir à une succession ទទួលមត៌ក ។ venir à compte រាប់ ។ venir à partage ចែក ។ venir à

composition សម្របសម្រួលគ្នា។ venir à la traverse de បង្អាក់ ឧបសគ្គ, យកជើងកទឹក ។ venir comme de cire មកដល់ត្រូវទេសកាល។ venir comme tambourin à noce ឬ comme violon en danse មកដល់ត្រូវកាល(នៅពេលត្រូវការ) ។ s'en aller comme on est venu មកឥតបានការអ្វី (ឥតមានការប្រែប្រួលអ្វី ឬ ឥតយកចិត្តទុកដាក់លើអ្វី) ។ qu'il y vienne! ឲ្យគាត់ធ្វើទៅ! (ពាក្យគម្រាម)។ vienne បើមាន, បើសិនជាមានមកដល់ភ្លាមៗ, កាលណាឱកាសហុចឲ្យ (ឧ. vienne un nouveau gouvernement, il sera le premier à acclamer) ។ qui vient ក្រោយ (ដែលនឹងមកដល់) (ឧ. l'année qui vient) ។ venir de l'autre monde គ្មានដឹងអ្វីសោះ ។ d'où venez-vous? ឬ de quel pays venez-vous? លោកទើបនឹងមកពីណា? (បានជាមិនដឹងអ្វីសោះ) ។

Prov. les maladies viennent à cheval et s'en retournent à pied រោគចាប់រហ័សណាស់ តែជាវិញដោយយឺតបំផុត (រោគអាចកើតឡើងភ្លាមៗ តែស្រះជាទៅវិញណាស់)

vénitien,enne *n.* & *n.* នៃក្រុងវ៉េនីស

vent *n.m.* ខ្យល់ (ឧ. faire du vent avec un éventail បក់ដោយផ្លិត); ខ្យល់ (ឧស្ម័នដែលមានក្នុងខ្លួនមនុស្ស ឬ សត្វ) (ឧ. avoir des vents) ។ *Mar.* être sous le vent d'un navire នៅក្រោមនាវាមួយ (ក្រោមខ្យល់) ។ avoir bon vent ត្រូវខ្យល់ (ត្រូវក្តោង) ។ ក្លិនសត្វ; ខ្យល់ (សំរុះ) ។

Loc. div. mettre flamberge au vent ហូតដាវ ។ le nez au vent អើតមើលឆាយអាយ។ en plein vent ជំនះខ្យល់, កណ្ដាលវាល។ des quatre vents ពីគ្រប់ទិស,ពីគ្រប់ស្រុក។ avoir vent de quelque chose ដឹងក្លិន, ដឹងដំណឹង ។ au vent បក់ ឬ អណ្តែតតាមខ្យល់ ។ jeter la plume au vent ម.ព. plume ។ mettre fleurette au vent និយាយចែចង់ ។ jeter ឬ envoyer aux

vents ពោលភត់ភាយ ។ être logé aux quatre vents ជ្រកនៅក្នុងផ្ទះដែលខ្យល់ចូលបានពីគ្រប់ទិស ។ donner vent à un tonneau ឬ donner vent au vin បើកប្រហោងក្នុងស្រាទំពាំងបាយជូរ (ដើម្បីឲ្យខ្យល់ចូល) ។ prendre du vent ឡើងជូរ (ស្រាទំពាំងបាយជូរដែលត្រូវខ្យល់) ។ aller selon le vent បើកតាមខ្យល់ (នាវា); *fig.* តម្រូវតាមទេសកាល ។ aller comme le vent ឬ plus vite que le vent ឬ fendre le vent ទើរ ឬ រត់យ៉ាងលឿន ។ flotter au gré du vent ឬ à la merci du vent រសាត់តាមខ្យល់ (នាវា); បក់តាមខ្យល់ ។ tourner ឬ virer à tout vent ឬ à tous les vents ឬ au moindre vent ប្រែប្រួលជានិច្ច, មិននឹងនួន (បរិយា) ។ regarder de quel côté vient le vent មើលនេះមើលនោះ (មិនច្បាស់ជាមើលអ្វី) ; *fig.* មើលទេសកាល (ដើម្បីប្រតិបត្តិតាម)។ n'avoir ni vent ni nouvelles ឬ ni vent ni voix de quelque chose ឥតបានទទួលដំណឹងអំពីអ្វីមួយសោះ។ autant en emporte le vent ដូចរសាត់តាមខ្យល់ (ចំពោះពាក្យសន្យា ដែលគេមិនកាន់តាម ឬ គម្រោងការដែលមិនបានសម្រេច) ។ vendre du vent et de la fumée សន្យាឥតបានការ ។ avoir du vent plein son sac និយាយច្រើនឥតបានការ ។ quel bon vent vous amène? ខ្ញុំសប្បាយចិត្តណាស់ដោយបានលោកមក។ être vent dessus vent dedans ស្រវឹង ។ *Fam.* il y a du vent dans les voiles ស្រវឹងទ្រេតទ្រោត ។ être au vent de sa bouée បានចំណេញច្រើន ឬ បានផលច្រើន ។ aller contre vent et marée ទំលុះបញ្ចាញ (ទោះជាមានឧបសគ្គយ៉ាងណាក៏ដោយ) ។ lier le vent ចាប់ខ្លាយលើមេឃ (ធ្វើការដែលពុំអាចសម្រេចបាន) ។

Mar. force du vent កម្លាំងខ្យល់បក់ ។ vent fait ខ្យល់នឹង (មិនផ្លាស់ទិស) ។ vent forcé ខ្យល់ខ្លាំងពេក ។ vents d'amont ឬ vents de mer

ខ្យល់សមុទ្រ(ខ្យល់បក់ពីសមុទ្រមកដី)។ vents d'aval ឬ vents de terre ខ្យល់ដី (ខ្យល់បក់ពីដីទៅសមុទ្រ)។ vents variables ខ្យល់ប្រែប្រួល (ប្រែទាំងទិស ទាំងកម្លាំង) ។ avoir bon vent ទៅបណ្ដោយខ្យល់ ។ avoir vent contraire ទៅប្រាសខ្យល់ ។ vent piquant ខ្យល់ត្រដាក់មុខ ។ vent portant ខ្យល់ត្រូវល្អ។ saute de vent ដំណើរផ្លាស់ទិសភ្លាមៗនៃខ្យល់ ។ vent de demoiselle ខ្យល់ត្រសៀក (ខ្យល់ខ្សោយណាស់) ។ vent à rafales ខ្យល់បក់ខ្លាំងៗម្ដងៗ ។ le vent tombe ខ្យល់ស្រាក (អន់)។ le vent tourne ខ្យល់ផ្លាស់ទិស។

Mus. instruments à vent គ្រឿងផ្លុំ (ភ្លេង) ។

Véner. & Chasse prendre le vent ស្រង់ក្លិន ។ chasser au vent ឬ aller dans le vent ដើរក្រោមខ្យល់ (ប្រដេញសត្វ) ។ avoir le vent ធុំក្លិនសត្វ ។ être à bon vent ដើរប្រាសខ្យល់ ។

Prov. petite pluie abat grand vent ម.ព. abattre ។ selon le vent, la voile ដាំដើមក្រានឲ្យប្រមាណឆ្នាំង ។ on va de tout vent à un même endroit ដើរផ្លូវផ្សេងគ្នាតែបានដល់ដូចគ្នា ។ à brebis tondue Dieu mesure le vent ម.ព. Dieu ។ il pleut à tous vents យើងអាចមានទុក្ខភ័យគ្រប់ពេល ។ il faut laisser courir le vent par dessus les tuiles ត្រូវបេះទ្រាំហេតុការណ៍ , ដែលជៀសពុំរួច

ventage *n.m.* ការអុំ ឬ ស្លៃ (សំអាតគ្រាប់ធញ្ញជាតិ)

ventaison *n.f.* រាគបណ្ដាលអំពីត្រូវខ្យល់ពេក (រោគធញ្ញជាតិ)

vente *n.f.* ការលក់ (ឧ. contrat de vente); ដំណើរលក់ដាច់ (ឧ. marchandise de bonne vente); ដំនួញ (ឧ. la vente du lait); ភាគព្រៃដែលទើបនឹងកាប់ ។ vente au détail ការលក់រាយ ។ vente en gros ការលក់ដុំ ។ vente au comptant ការលក់ដល់ដៃ (ឲ្យប្រាក់ភ្លាម) ។ vente

à crédit ការលក់បណ្ដាក់។ vente à tempérament ការលក់សង រំលស់ (សងបន្តិចម្ដងៗ)

venté,e *a.* ដែលខ្យល់បក់ត្រូវ

venteaux *n.m. pl.* ខ្នុខ្យល់ (ប្រហោងមានសន្ទះបិទសម្រាប់ឲ្យខ្យល់ ចូលក្នុងស្នប់)

venter *v.impers.* បក់ (ខ្យល់)

venteux,euse *a.* ដែលមានខ្យល់ (ឧ. pays venteux); ដែលបង្កខ្យល់ ក្នុងខ្លួន (ឧ. légume venteux)

ventilateur *n.m.* យន្តផែផៃ, ផ្លិតយន្ត

ventilation *n.f.* ការបក់បញ្ចូលខ្យល់។ ventilation pulmonaire ដំណើរខ្យល់ចេញចូលក្នុងសួត

ventilation *n.f.* ការចែកមុខៗ (ប្រាក់ចំណាយ ឬ ចំណូល) (ឧ. ventilation des frais généraux)

ventiler *v.t.* បញ្ចូលខ្យល់ (ឧ. ventiler un tunnel)

ventiler *v.t.* ចែក (ចំពោះតម្លៃវត្ថុដែលរួមគ្នា); ចែកមុខៗ (ចំណាយឬចំណូល)

ventis *n.m. pl.* ឈើរលំដោយខ្យល់

ventosité *n.f.* ដំណើរកខ្យល់ក្នុងពោះវៀន

ventouse *n.f.* កែវផឹប; អាការៈសម្រាប់ តោង (នៃសត្វខ្លះ: ឆ្លូចជាឈើង ឬ ដឹងបក់ ។ ល ។)។ *Techn.* រន្ធខ្យល់

ventral,e,aux *a.* នៃពោះ។ face ventrale ខាងពោះ (ផ្ទ.នឹង face dorsale ខាងខ្នង)

ventre *n.m.* ខ្ទ,ផ្ទៃ,ពោះ(មើល.abdomen)។ *Par ext. Techn.* ក្បេង (ភាគកំប៉េងនៃក្អម,ខ្ទាង ។ ល ។) (ឧ. le ventre d'une bouteille); ក្បេង (ភាគនាឋិត្រង់កំប៉េងកណ្ដាល)។ *Fig.* ការចូលចិត្តម្ហូបឆ្ងាញ់ (ឧ. ne songer qu'à son ventre)។

Loc. div. ventre de biche ពណ៌លឿងខ្ចី ។ dès le ventre de sa mère តាំងពីនៅក្នុងផ្ទៃមាតា ឬ តាំងពីកំណើតមក ។ lâcher le ventre ធ្វើឲ្យស្រួលពោះ(ឧ.les pruneaux lâchent le ventre)។ sur le ventre ឬ à plat ventre ឬ ventre à terre ឬ ventre contre terre ពោប (ផ្កាប់មុខ)។ *Fig.* à plat ventre ក្រាបឃ្លាលដល់ដី(គោរពដោយ ហេីកទាប) (ឧ. se tenir à plat ventre devant le pouvoir)។ ventre à terre លឿនណាស់។

avoir le ventre plein ពោះឆ្អែត ។ à ventre déboutonné ច្រើនហួសពេក (ស៊ី ឬ ផឹកច្រើនទាល់តែបន្ធូរខ្សែក្រវាត់) (ឧ. boire à ventre déboutonné); អស់ចំហ៊ាង (ឧ. rire à ventre déboutonné); អស់ពីពោះ (ដោយស្មោះ) (ឧ. parler à ventre déboutonné)។ avoir ឬ prendre du ventre ធំពោះ ឬ ឡើងក្បាលពោះ។ battre quelqu'un dos et ventre វាយខ្លាំង ។ *Fig.* taper sur le ventre à quelqu'un ស៊ិទ្ធស្និទ្ធហួសពេកជាមួយនឹងអ្នកណាម្នាក់ (អាចទះពោះគ្នាលេងបាន) ។ mettre le cœur au ventre ធ្វើឲ្យក្លាហាន ។ remettre le cœur au ventre ធ្វើឲ្យក្លាហានឡើងវិញ ។ mettre le feu sous le ventre de quelqu'un ធ្វើឲ្យខឹង, ធ្វើឲ្យរឹតតែខឹង ។ faire rentrer les paroles dans le ventre à quelqu'un ធ្វើឲ្យអ្នកណាម្នាក់ស្ដាយក្រោយដោយនិយាយហួស; ធ្វើឲ្យឈប់និយាយ ។ avoir dans le ventre រស់នៅបាន ; បិតនៅបាន (ឧ. c'est un homme qui n'a tout au plus que six mois dans le ventre (Molière): អាចធ្វើបាន (ឧ. cet écrivain n'avait que cet ouvrage dans le ventre) ។ savoir ce que quelqu'un a dans le ventre ស្គាល់ពោះវៀន (ដឹងគំនិត ឬ ដឹងតម្លៃអ្នកណាម្នាក់)។ se remplir le ventre ឬ avoir le ventre plein ស៊ីឆ្អែត; ឆ្អែត ។ se faire bon ventre ស៊ីផឹកលក់(ស៊ីទាល់តែឆ្អែតខ្លាំង)។ se faire une carrelure de ventre ស៊ីច្រើន ។ se faire un dieu de son ventre គោរពការស៊ីផឹក, ចូលចិត្តស៊ីជាជាងធ្វើអ្វីទាំងអស់ ។ avoir les yeux plus grands que le ventre ចាប់អួបច្រើនហួសពេក (ទាល់តែស៊ីមិនអស់) ។ être sujet à son ventre ស៊ីតាមឃ្លាន (ស៊ីឥតប្រមាណ)។ être le dos au feu, le ventre à table អង្គុយស៊ីយ៉ាងស្រួល (សម្រួលឥរិយាបថដើម្បីបរិភោគ) ។ bouder contre son ventre

ឬ bouder son ventre មិនព្រមស៊ី ; *au fig.* ងៀកង៉រ (មិនព្រមទទួលយកវត្ថុដែលគេត្រូវការ ឬដែលគេចង់បានណាស់) ។ tant que le cœur me battra dans le ventre ដរាបណាខ្ញុំនៅរស់... ។ c'est le ventre de ma mère, je n'y retournerai jamais ឬ c'est le ventre de ma mère ខ្ញុំលែងធ្វើការបែបនេះទៀតហើយ ។ passer sur le ventre ខ្ទួល ។

Prov. tout fait ventre អ្វីក៏អាចចិញ្ចឹមជីវិត (ឬ ពោះ) បានដែរ (អាហារផុតអន់ក៏អាចចិញ្ចឹមជីវិតបានដូចអាហារប្រសើរដែរ) ។ ventre affamé n'a point d'oreille ពោះឃ្លានគ្មានត្រចៀក (មនុស្សឃ្លានគេនិយាយអ្វីក៏មិនស្តាប់ដែរ) ។ à ventre soûl cerices amères ពោះឆ្អែតបដិសេធចំណី , ឆ្អែតលែងឆ្ងាញ់ (ស្របនឹងពាក្យទំនៀមខ្មែរថា ឃ្លានឆ្ងាញ់ស្រឡាញ់ល្អ) ។ grain à grain la poule remplit son ventre គក់ៗពេញបំពង់ (ប្រាក់ ឬ វត្ថុសន្សំបន្តិចម្តងៗអាចធ្វើឲ្យមានបាន)

ventrée *n.f. Fam.* ចំនួនកូនមួយលើក (សត្វ); ពោះ(អាហារមួយចំអែត)

ventriculaire *a.* នៃហទយោទរ

ventricule *n.m.* ហទយោទរ [ហៈ-ទៈ-យោ-ទ], បន្ទប់បេះដូងខាងក្រោម។ ventricule droit ហទយោទរស្តាំ ។ ventricule gauche ហទយោទរឆ្វេង

ventrière *n.f.* ខ្សែពុង (ខ្សែចងរឹតពោះសត្វ)

ventriloque *a.&n.* អ្នកបេះនិយាយតាមដើមបំពង់ក(ធ្វើឲ្យដូចសម្លេងចេញពីក្នុងពោះ)

ventriloquie *n.f.* វិធីនិយាយតាមដើមក

ventripotent,e ឬ **ventru,e** *a. Fam.* ដែលមានពោះកំប៉ោង

ventru,e *a.* ម.ព. ventripotent ។ *Fig.* មូល, កំប៉ោង (ឧ. une potiche ventrue)

venu,e *a.* ដែលធ្វើបានសម្រេច ឬ បានល្អ (ឧ. estampe bien venue) ។ être bien venu ត្រូវគេទទួលដោយរាក់ទាក់ ។ être mal venu ត្រូវគេទទួលដោយមិនរាក់ទាក់ ។

n. le premier venu, la

première venue មនុស្សណាក៏ដោយ (មិនរើសមុខ) (ឧ. écouter le premier venu) ។

n.&a. nouveau venu, nouvelle venue អាគន្តុកៈ, អ្នកទើបមកដល់ថ្មី

venue *n.f.* ការមកដល់ ។ *Fig.* ការលូតលាស់, ដំណើរដុះ (ឧ. arbre d'une belle venue) ។ tout d'une venue ស្មើរហូត; *fig.* ពិតរៀបរយ ។

pl. allées et venues ការទៅមកញឹកញាប់

Vénus *n.propre Astr.* ផ្កាយសុក្រ។ *Mythol.* ព្រះនាងកាមទេព ។ *n.f.* ខ្យងសមុទ្រម្យ៉ាង

vénusté *n.f.* ភាពសមសួន

vêpre *n.m.* ល្ងាច

ver *n.m.* កិមិជាតិ, ដង្កូវ ។ver blanc ដង្កូវខ្លួង ។ ver luisant អំពិលអំពែក ។ ver solitaire ព្រូនវែង ។ ver à soie ដង្កូវនាង ។ ver de terre ជន្លេន ។ *Fam.* avoir le ver solitaire បរិភោគច្រើន (ដូចមនុស្សកើតព្រូន) ។ tirer les vers du nez de quelqu'un ទាំឲ្យនិយាយប្រាប់រឿងអស់ (ម.ព. tirer ផង) ។ tuer le ver ផឹកពិសេ, ផឹកលុបអរុណ

véracité *n.f.* សច្ចសីលភាព [ស័ច-ចះ-សី-លះ-], ការកាន់ខ្ជាប់នូវការណ៍ពិត; ការចូលចិត្តតែការណ៍ពិត (ឧ. la véracité d'un hitorien); ភាពសមនឹងការណ៍ពិត, ភាពត្រឹមត្រូវតាមការណ៍ពិត (ឧ. la véracité d'un témoignage) (ស្រ. franchise, sincérité)

véraison *n.f.* ភាពស្រពាល (ភាពផ្លែឈើមានទំពាំងពាយផ្ការជាដើមដែលជិតទុំ)

véranda *n.f.* រានហាល

verbal,e,aux *a.* ដែលធ្វើដោយវាចា (ដោយនិងលាយលក្ខអក្សរ) (ឧ.promesse verbale)។ location verbale កិច្ចសន្យាជួលផ្ទះឥតកំណត់ពេល (ធ្វើដោយលាយលក្ខអក្សរ) ។ note verbale លិខិតទូត (ឥតមានចុះហត្ថលេខា) ។ *Gramm.* នៃកិរិយាសព្ទ (ឧ. forme verbale)។ adjectif verbal គុណសព្ទដែលកើតមកអំពីកិរិយាសព្ទ

verbalement *adv.* ដោយវាចា,ដោយ

មាត់ទទេ

verbalisation *n.f.* ការធ្វើកំណត់ហេតុ

verbaliser *v.t.* ធ្វើកំណត់ហេតុ (ឧ. verbaliser contre un chasseur sans permis)

verbalisme *n.m.* វាទនិយម (ការនិយមថាសំដីសំខាន់ជាងគំនិត)

verbe *n.m.* វាចា, សំឡេង, សំដី (ឧ. avoir le verbe haut មានសំឡេងខ្លាំង, និយាយសំដីធំ) ។ *Gramm.* កិរិយាសព្ទ (ឧ. conjuguer un verbe ធ្វើកិរិយាវិភាគ, បំបែកកិរិយាសព្ទ)។ verbe auxiliaire កិរិយាសព្ទជំនួយ ។ verbe actif កត្តុវាចកកិរិយាសព្ទ ។ verbe passif កម្មវាចកកិរិយាសព្ទ ។ verbe intransitif អកម្មកិរិយាសព្ទ។ verbe transitif សកម្មកិរិយាសព្ទ។ verbe pronominal សព្វនាមិកកិរិយាសព្ទ

verbeux,euse *a.* សម្ដីរដោយសំដីឥតប្រយោជន៍ (ឧ. orateur verbeux)

verbiage *n.m.* ដំណើរសម្ដីរដោយសំដីឥតប្រយោជន៍; សំដីឥតប្រយោជន៍

verboquet *n.m.* ខ្សែញាក់, ខ្សែទាញវត្ថុដែលគេចងលើកដើម្បីកុំឲ្យវិល ឬ កុំឲ្យទង្គិច

verbosité *n.f.* ភាពសម្ដីរដោយសំដីឥតប្រយោជន៍; សំដីឥតប្រយោជន៍

ver-coquin *n.m.* រោគវិលមុខនៃសត្វ (បណ្ដាលអំពីដង្កូវក្នុងខួរក្បាល); ដង្កូវក្នុងខួរក្បាល (*pl.* des vers-coquins)

verdage *n.m.* ការកប់រុក្ខជាតិស្រស់ធ្វើជី

verdagon *n.m.* ស្រាទំពាំងបាយជូរស្រស់ (នៅជូរខ្លាំងមិនទាន់ល្មមផឹក)

verdâtre *a.* បៃតងភាវ

verdelet,ette *a.* vin verdelet ស្រាទំពាំងបាយជូរនៅជូរបន្តិចៗ

verdet *n.m.* ស្នឹមស្ពាន់ (ពណ៌បៃតង) (ឧ. le verdet est employé, en bouillies, au traitement des maladies cryptogamiques des plantes)

verdeur *n.f.* ភាពឈើស្រស់; ភាពខ្ចី (ផ្លែឈើ); ភាពស្រាទំពាំងបាយជូរស្រស់ (នៅជូរមិនទាន់ល្មមផឹក) ។ *Fig.* កម្លាំង, វ័យក្មេង (ឧ. la verdeur de l'âge); ភាពទ្រគោះ; ភាពរម៉ាំងរមោក (សំដី) (ឧ. la verdeur de ses propos)

verdict *n.m.* និន្ន័យ, ការវិនិច្ឆ័យ (ឧ.

le verdict de l'opinion publique)

verdir *v.t.* ធ្វើឲ្យឡើងបៃតង (ឧ. la lumière verdit les feuilles)។ *v.i.* ឡើងបៃតង

verdissage *n.m.* ការធ្វើឲ្យឡើងបៃតង; ការលាបពណ៌បៃតង

verdissement *n.m.* ការធ្វើឲ្យឡើងបៃតង; ការលាបពណ៌បៃតង

verdoiement *n.m.* ដំណើរឡើងបៃតង

verdoyant,e *a.* ដែលឡើងបៃតង

verdoyer *v.i.* ឡើងបៃតង (ឧ. la campagne verdoie)

verdunisation *n.f.* ការលាយទឹកហ្សាវែលក្នុងទឹកផឹក

verduniser *v.t.* លាយទឹកហ្សាវែលក្នុងទឹកផឹក

verdure *n.f.* ហរិតជាតិ, ពណ៌បៃតងនៃរុក្ខជាតិ (ឧ. la verdure des prés); ស្មៅ ឬ ស្លឹក(ពណ៌បៃតង)(ឧ. se coucher sur ឬ sous la verdure); បន្លែ (ដែលគេអាស្រ័យស្លឹក) (ឧ. la verdure est rafraîchissante)

verdurier,ère *n.* អ្នកលក់ស្មៅ-បន្លែ។ល។

véreux,euse *a.* ដែលមានដង្កូវ (ឧ. fruit véreux)។ *Fig.* អាក្រក់,គួរឲ្យមន្ទិល (ឧ. affaire véreuse); ទុច្ចរិត (ឧ. banquier véreux)

verge *n.f.* រំពាត់; ដំបងយុត្តិ; ដំបងដញ្ជីងខ្លះ។ *Anat.* ម.ព. penis

vergeoise *n.f.* ស្ករកាក (ស្ករធ្វើពីកាកស្ករដែលគេចម្រាញ់ហើយ)

verger *n.m.* ផលារាម [ផៈ-លា-រ៉ាម], ច្បារឬចំការផលព្រឹក្ស, សួនឈើមានផ្លែ

vergeté,e *a.* ដែលមានស្នាម ឬ ដែលប្រឡាក់ពាសពេញ (ឧ. peau, figure vergetée)

vergetier,ère *n.* អ្នកធ្វើរំពាត់នឹងច្រាស

vergette *n.f.* រំពាត់;ច្រាសជូតសំលៀកបំពាក់

vergetures *n.f. pl.* ស្នាមប្រេះសាច់ (ក្នុងពេលមានផ្ទៃពោះ ឬ មានជម្ងឺខ្លះ)

verglacé,e *a.* ដែលមានហិមានី, គ្របដណ្ដប់ដោយទឹកកកក្ដាំង (ឧ. route verglacée)

verglacer *v. imp.* ធ្លាក់ហិមានី, ធ្លាក់ទឹកកកក្ដាំង

verglas *n.m.* ហិមានី [ហិ-មា-នី], ទឹកកកក្ដាំង (ស្រទាប់ទឹកកកស្ដើងគ្រប

លើដី)

vergogne *n.f.* ហិរិ,សេចក្ដីអៀនខ្មាស។ sans vergogne ដោយឥតអៀនខ្មាស

vergue *n.f. Mar.* សារក្ដោង

véridicité *n.f.* សច្ចការ ; សច្ចភាព, ភាពត្រូវនឹងសេចក្ដីពិត

véridique *a.* សច្ចៈ, ធ្លាប់ពោលតែពាក្យពិត (ឧ. homme véridique); ត្រឹមត្រូវតាមសេចក្ដីពិត (ឧ. témoignage véridique)

véridiquement *adv.* ដោយសច្ចៈ; ដោយត្រឹមត្រូវតាមសេចក្ដីពិត (ឧ. rapporter véridiquement un fait)

vérifiable *a.* អាចពិនិត្យឲ្យដឹងខុសត្រូវបាន

vérificateur *n. & a.m.* អ្នកពិនិត្យបញ្ជាក់, អ្នកមើលបញ្ជាក់ (ឧ. vérificateur des poids)

vérificatif,ive *a.* សម្រាប់ពិនិត្យបញ្ជាក់, សម្រាប់មើលបញ្ជាក់ (ឧ. contrôle vérificatif)

vérification *n.f.* ការពិនិត្យបញ្ជាក់, ការមើលបញ្ជាក់ (ឲ្យដឹងខុសត្រូវ, មែន ឬ មិនមែន) (ឧ. vérification d'un compte)។ vérification d'écriture ការពិនិត្យបញ្ជាក់លិខិត (ក្នុងតុលាការ)។ vérification des pouvoirs ការពិនិត្យបញ្ជាក់អំណាច (ការពិនិត្យអំណាចនៃអ្នកចូលរួមក្នុងទីប្រជុំ ឬ សមាគម; ការពិនិត្យមើល តើការបោះឆ្នោតរើសសមាជិកសភាត្រឹមត្រូវតាមច្បាប់ ឬ មិនត្រឹមត្រូវ)

vérifier *v.t.* ពិនិត្យបញ្ជាក់, មើលបញ្ជាក់ (ឲ្យដឹងខុសត្រូវ, មែន ឬ មិនមែន) (ឧ. vérifer un compte, une citation); បញ្ជាក់ថែម (ឧ.l'événement a vérifié sa prédiction) (ត្រ. confirmer, constater, contrôler, corroborer, justifier)

vérin *n.m. Mécan.* ប្រដាប់លើក ឬ ដាក់វត្ថុធ្ងន់ (ដូចជាប្រដាប់ទល់លើករថយន្តដើម្បីប្ដូរកង់ជាដើម)

vérine ឬ **verrine** *n.f.* ព្យួរមានទំពក់ (សម្រាប់ទាញប្រកាក់នាវា)

véritable *a.* មែនទែន, ពិត (ឧ. histoire véritable); ពិតប្រាកដ (ឧ. or véritable); ពិត (សមតាមពាក្យគេហៅ) (ឧ. un ami véritable)

véritablement *adv.* ដោយមែនទែន,

ដោយពិតប្រាកដ (ឧ. être véritablement heureux)

vérité *n.f.* សច្ចៈ, សត្យៈ, សេចក្ដីពិត; ការពិត; របស់ពិត (ឧ. jurer de dire la vérité); សុទ្ធចិត្ត (ឧ. parler avec l'accent de la vérité) ។ *Peint. & sculpt.* ភាពដូចសុទ្ធសាធ, ភាពដូចណាស់ (ឧ. portrait d'une grande vérité រូបដូចសុទ្ធសាធ) ។ *Fam.* dire à quelqu'un ses vérités និយាយបើកកកាយកំហុសទាំងអស់ឲ្យស្ដាប់ ។

Loc. adv. en vérité ដោយពិត (ឧ. en vérité cela est étrange) ។ à la vérité ពិតមែន, ត្រូវហើយ (ឧ. à la vérité, je l'ai frappé, mais il m'avait provoqué) ។ à dire vérité បើនិយាយតាមពិតទៅ ។

Prov. toutes vérités ne sont pas bonnes à dire ពាក្យពិតមិនសុទ្ធតែគួរយកមកនិយាយទេ ។ il n'y a que la vérité qui offense (ឬ qui blesse) ពាក្យពិតរែងតែស្វែង (ពាក្យពិតតែងតែជួរចត់)

verjus *n.m.* ទឹកជូរផ្លែទំពាំងបាយជូរខ្ចី

verjuté,e *a.* ដែលដាក់ទឹកជូរទំពាំងបាយជូរខ្ចី (ឧ. sauce verjutée); ជូរ (ដូចទឹកជូរទំពាំងបាយជូរខ្ចី) (ឧ. vin blanc verjuté)

vermée *n.f.* ការនេសាទដោយនុយជន្លេន

vermeil,eille *a.* ក្រហមដូចឈាម (ឧ. lèvres vermeilles) ។ *n.m.* ប្រាក់កាឡៃ (ស្រោលទឹកមាស)

vermicelier,ère *n.* អ្នកធ្វើចាំងហ៊ុន-គុយទាវ ។ ល ។

vermicelle *n.m.* នំបញ្ចុក, ចាំងហ៊ុន, គុយទាវ ។ ល ។

vermicellerie *n.f.* កន្លែងធ្វើចាំងហ៊ុន-គុយទាវ ។ ល ។; ការធ្វើមីសួ-គុយទាវ ។ ល ។

vermicide *a.* ដែលសម្លាប់ជន្លេន

vermiculaire *a.* ដូចជន្លេន (ឧ. appendice vermiculaire)

vermiculé,e *a. Achit.* ដូចស្នាមជន្លេនវារ (ក្បាច់)

vermiculure *n.f.* ក្បាច់ជន្លេនវារ

vermidiens *n.m. pl.* សត្វសណ្ឋានជន្លេន

vermiforme *a.* ដូចដង្កូវ (ដែលមានសណ្ឋានដូចដង្កូវ)

vermifuge *a.* ដែលសម្លាប់ព្រូន ។ *n.m.* ថ្នាំព្រូន

vermiller *v.i.* ឈូសដី (ដើម្បីរកជន្លេនស៊ី) (ជ្រូក)

vermillon *n.m.* ពណ៌ក្រហមឆេះ

vermillonner *v.i.* ឈូសដីរកមើមឈើ (សត្វស្វា)

vermine *n.f.* សត្វល្អិតស្មោកគ្រោកហើយចង្រៃ (ឧ. mendiant dévoré de vermine)។ *Fig.* អ្វីៗដែលបំផ្លាញបន្តិចម្តងៗ; ជនថោកទាប (ឧ. toute la vermine du quartier)

vermineux,euse *a.Méd.* ដែលបង្កដោយព្រូន (រោគ); ដែលមានចៃពាសពេញ

vermisseau *n.m.* ជន្លេនតូច; សត្វល្អិតល្អោច (សត្វល្អិតរស់នៅដោយវេទនា) (ឧ. l'homme n'est qu'un vermisseau, en face de la nature)

vermivore *a.* កិមិស័យ, ដែលស៊ីដង្កូវ

vermouler (se) *v.pr.* ស្អុយ, ឡើងពុក (ដោយដង្កូវស៊ី)

vermoulu,e *a.* ពុក (ដែលដង្កូវស៊ី) (ឈើ); អន់ថយ

vermoulure *n.f.* ស្នាមដង្កូវស៊ី; អាចម៍កន្ធង់ (កំទេចឈើសត្វស៊ី)

vermouth [– moutt] *n.m.* ស្រាទំពាំងបាយជូរ ស ដែលគេអប់

vernaculaire *a.* សម្រាប់ប្រទេសមួយ (ឧ. langue vernaculaire)

vernal,e,aux *a.* នៃនិទាឃរដូវ (ឧ. équinox vernal)

vernir *v.t.* លាបវ៉ែរនី ។ *Pop.* être verni មានសំណាង

vernis *n.m.* វ៉ែរនី (ថ្នាំលាបឲ្យរលោង ឬ ការពារអ្វីមួយកុំឲ្យខូចដោយធាតុអាកាស)។ *Fig.* អាការៈក្រៅបិញ្ចប-បិញ្ចែង (ឧ. un vernis d'élégance)

vernissage *n.m.* ការលាបវ៉ែរនី; ភាពលាបវ៉ែរនី

vernissé,e *a.* ដែលមានលាបវ៉ែរនី; ភ្លឺរលោង (ដូចលាបវ៉ែរនី)

vernisser *v.t.* ដាក់វ៉ែរនី (ភាជនភណ្ឌ)

vernisseur,euse *n.* អ្នកធ្វើវ៉ែរនី; ជាងលាបវ៉ែរនី

vernix caséosa *a.* រអិលប្រឡាក់ខ្លួនទារកនៅពេលដែលកើតមក (សន្លិចម្សៅ)

vérole *n.f.* ម.ព. syphilis ។ petite vérole ម.ព. variole

verrat *n.m.* ជ្រូកឈ្មោល

verre *n.m.* កែវ (កែវដាក់ភេសជ្ជៈ): កែវ (វត្ថុក្នុងកែវ) (ឧ. un verre de vin ស្រាមួយកែវ); កញ្ចក់, របស់ធ្វើដោយកែវ (ឧ. un verre de montre): កែវនែឡិកា ។ verre en cristal កែវផលិក ។ maison de verre ផ្ទះដែលគ្មានអាថ៌កំបាំង។ petit verre កែវតូច (ស្រាដែលគេដាក់ក្នុងកែវតូចៗផឹក) (ឧ. boire un petit verre)

verré,e *a.* ដែលមានលាយលំអិតកែវ (ឧ. papier verré)

verrerie *n.f.* វិជ្ជាធ្វើកែវ; រោងចក្រធ្វើកែវ; គ្រឿងកែវ (ឧ. un magasin de verrerie)

verrier *n.m.* អ្នកធ្វើឬលក់កែវ; កន្ត្រកដាក់កែវ ។ *a.* peintre verrier ជាងគូរលើកញ្ចក់

verroterie *n.f.* របស់តូចៗធ្វើអំពីកែវពណ៌ (មានអង្កាំជាដើម)

verrou *n.m.* *Techn.* រនុកទ្វារ ។ sous les verrous ជាប់គុក ។ porter l'épée en verrou ឬ en verrouil កាន់ដាវសណ្ដូកត្រង់

verrouillage *n.m.* ការបិទរនុក

verrouiller *v.t.* បិទរនុក (ឧ. verrouiller sa porte): បង្ខាំង (ឧ. verrouiller un prisonnier)។ se verrouiller *v.pr.* នៅក្នុងបន្ទប់បិទ

verrue *n.f.* ប្រឡេះ។ *Fig* គុណវិបត្តិ: ជាបន្ទ

verruqueux,euse *a.* ដែលមានប្រឡេះពាសពេញ (ឧ. mains verruqueuses)

vers *n.m.* កំណាព្យ, ជាទ (ឃ្លាសង្កាត់ជាពិកាព្យឃ្លោង) ។ vers blancs កំណាព្យរាយ (គ្មានចុងចួន)

vers *pré.* ឯ, ឆ្ពោះ, សំដៅ (ឧ. aller vers la fenêtre); ប្រមាណជា (ឧ. vers la fin de la journée)

versant *n.m.* ជំរាលភ្នំ

versatile *a.* សាវ៉ា (ឧ. homme versatile)

versatilité *n.f.* ភាពសាវ៉ា (ឧ. versatilité des opinions)

verse (à) *loc. adv.* ដូចគេចាក់ទឹក, យ៉ាងច្រើន (ភ្លៀង) (ឧ. il pleut à verse)

verse *n.f.* ការចាក់; ដំណើរផ្ទួល (ស្រូវមិនទាន់ច្រូត) (ឧ. la verse est souvent produite par le piéton)

versé,e *a.* ម.ព. renversé

versé,e *a.* ពូក, ចេះជ្រៅជ្រះ (ឧ. versé dans les sciences)

verseau *n.m.* កុម្ភសី (រាសីកុម្ភ)

versement *n.m.* ការបង់ប្រាក់; ការចេញប្រាក់ (ឧ. payer en plusieurs versements); ការបរិច្ចាគ

verser *v.t.* ចាក់ (ឧ. verser de l'eau sur les mains); ផ្ទេរ,ចាក់ (ពីភាជន៍មួយទៅក្នុងភាជន៍មួយទៀត) (ឧ. verser du vin dans un verre); ផ្ទួល (ស្រូវ) (ឧ. l'orage a versé les blés); បំភ្លូក. ធ្វើឲ្យក្រឡាប់ (រថ); បង់ប្រាក់ (ឧ. verser une cotisation); បរិច្ចាគ។ verser du sang បង្ហូរឈាម; សម្លាប់។ verser son sang បូជាជីវិត ។ verser des larmes បង្ហូរទឹកភ្នែក, យំ ។

v.i. ក្រឡាប់ (រថ); ផ្ទួល (ស្រូវ)

verset *n.m.* គាថា

verseur *n.m.* អ្នកចាក់ (បង្ហូរចេញ) ។ *a.m.* សម្រាប់ចាក់ (បង្ហូរចេញ) (ឧ. bouchon verseur)

verseuse *n.f.* ចាន់ (ប្រដាប់មានចំពួយសម្រាប់ចាក់ទឹកក្ដៅ)

versicolore *a.* ដែលមានពណ៌ច្រើន (ឧ. ruban versicolore)

versiculet *n.m.* កំណាព្យខ្លី

versificateur *n.m.* អ្នកតែងកាព្យ

versification *n.f.* របៀបតែងកាព្យ (ឧ. traité de versification); លំនាំកំណាព្យ (ឧ. versification élégante)

versifier *v.i.* តែងកាព្យ ។ *v.t.* លើកជាកំណាព្យ (ឧ. versifier une fable)

version *n.f.* សកបរិវត្តន៍ [ស:-ក:-ប៉:-រ៉ិ-វ័ត] (ការប្រែពីភាសាបរទេស មកជាភាសាកំណើត) (ផ្ទុយនឹង thème); របៀបនិទានរឿង ; របៀបបកស្រាយ (ឧ. il y a sur cet accident différentes versions)

vers-libriste *n.* & *a.* អ្នកតែងកាព្យរាយ ; អ្នកចូលចិត្តខាងកំណាព្យរាយ (*pl.* des vers-libristes)

verso *n.m.* ទំព័រខ្នង (ផ្ទុយនឹង recto) (*pl.* des versos)

versoir *n.m.* ផ្លៀងនង្គ័ល(ហៅ.oreille)

vert,e *a.* បៃតង; ស្រស់(ឈើឬបន្លែស្រស់) (ឧ. des pois verts); ស្រស់ (ស្រើម, មិនទាន់ស្ងួត) (ឧ. du bois vert); ខ្ចី (ឧ. du raisin vert) ។

Fig. ដែលនៅខ្លាំង (ពិតមែនតែចាស់) (ឧ. vieillard encore vert): ព្រោះ; ធ្ងន់; ខ្លាំង (ឧ. une verte réprimande) ។ *Ellipt. & Fam.* អាសអាភាស(ឧ. en raconter de vertes) ។

vin vert ស្រាទំពាំងបាយជូរស្រស់ (នៅជូរនៅឡើយមិនទាន់ល្មមអាស្រ័យ)។ café vert កាហ្វេស្រស់ (មិនទាន់លីង) ។ langue verte ភាសាដោយឡែក ។ volée de bois vert ការវាយច្រើន ។

n.m. ពណ៌បៃតង (ឧ. aimer le vert); ស្មៅស្រស់ ។ se mettre au vert ទៅសម្រាកនៅស្រុកស្រែ ។ prendre sans vert ធ្វើឬចាប់ដោយមិនដឹងខ្លួន (តាមទំនៀមទម្លាប់បារាំងនៅសតវត្សទី ១៣, ១៤ និង ១៥ ក្នុងខែឧសភា គេត្រូវកាន់មែកឈើស្រស់មួយជាប់នឹងខ្លួន បើពុំដូច្នោះទេ អ្នកឯទៀតនឹងជះទឹកលើក្បាល)

vert-de-gris *n.m.* ស្នឹមស្ពាន់

vert-de-grisé,e *a.* ដែលមានស្នឹម (ស្ពាន់) (ឧ. bronze vert-de-grisé)

vertébral,e,aux *a.* នៃបិដ្ឋាដ្ឋិ, នៃឆ្អឹងខ្នង(ឧ. la colonne vertébrale)

vertèbre *n.f.* បិដ្ឋាដ្ឋិ [ប៉ិត-ថ្អាត់ ឋិ]. ឆ្អឹងខ្នង

vertébré,e *a.* បិដ្ឋាដ្ឋិកៈ [ប៉ិត-ថ្អាត់-ឋិ-កៈ] ។ *n.m. pl.* បិដ្ឋាដ្ឋិកសត្វ, សត្វដែលមានឆ្អឹងខ្នង

vertement *adv.* យ៉ាងខ្លាំង (ឧ. relever vertement une inconvenance)

vertical,e,aux *a.* បញ្ឈរ (សំយុងចុះក្រោមតាមលំនាំខ្សែកូនប្រយោល) ។ *Mil.* tir vertical ម.ព. tir ។

n.f. បន្ទាត់បញ្ឈរ

verticalement *adv.* ដោយបញ្ឈរ (សំយុងចុះក្រោម ឬ ត្រង់ឡើងលើ) (ឧ. dresser verticalement un piquet)

verticalité *n.f.* ភាពបញ្ឈរ (សំយុងចុះក្រោម ឬ ត្រង់ឡើងលើ)(ឧ.la verticalité d'un mur)

vertige *n.m.* ដំណើរវិលមុខ ។ *Fig.*

ភាពវេងវេង

vertigineux,euse *a.* ដែលឲ្យវិលមុខ (ឧ. hauteur vertigineuse); វិលមុខ (ឧ. affection vertigineuse ជម្ងឺវិលមុខ)

vertu *n.f.* គុណធម៌ (ចរិយានាំឲ្យធ្វើអំពើល្អ និងវៀរភាងអំពើអាក្រក់) (ឧ. pratiquer la vertu); គុណសម្បត្តិពិសេស (ឧ. il a tous les vices et aucune vertu); ព្រហ្មចារីយភាព; ភាពស័ក្តិសិទ្ធិ (ឧ. vertu des plantes) ។ en vertu de *loc. pré.* ដោយអាស្រ័យអំណាចនៃ (ឧ. en vertu d'un jugement)

vertueusement *adv.* ដោយគុណធម៌

vertueux,euse *a.* ប្រកបដោយគុណធម៌ (ឧ. homme vertueux); តាមគុណធម៌(ដែលបណ្ដាលមកពីគុណធម៌) (ឧ. action vertueuse)

vertugadin *n.m.* ប្រដាប់បំប៉ោងអៀម (ប្រដាប់ពាក់ក្នុងអៀមឲ្យប៉ោង); អៀមប៉ោង (ដោយប្រដាប់ពាក់ពីក្នុង)

verve *n.f.* សន្ទុះចិត្តឬគំនិត; ទឹករេហរ (ឧ. être en verve)

vervelle *n.f.* ក្រវិលបក្សី (កងដែលគេបំពាក់នៅជើងបក្សី ដើម្បីចំណាំវា)

verveux *n.m.* មងមួយបែបសណ្ឋានឆ្វាឈាយ; កញ្ជ្រែនាក់លើខ្នងសត្វ (ដើម្បីដាក់បន្លែផ្លែឈើ)

vésanie *n.f.* ដំណើរខូចសតិបញ្ញា(រោគ)

vésical,e,aux *a.* នៃថង់ឬប្លោក (អាការៈក្នុងខ្លួន)(ឧ. calcul vésical)

vésicant,e *a.* *Méd.* ដែលបណ្ដាលឲ្យកើតពងទឹករងៃ (ឧ. l'ortie est vésicante)

vésication *n.f.* ដំណើរបង្កពងទឹករងៃ

vésicatoire *n.f.* ឱសថធ្វើឲ្យពងសើស្បែក។ *a.* ដែលនាំឲ្យពងស្បែក (ឧ. topique vésicatoire)

vésicule *n.f.* ថង់ (អាការៈក្នុងខ្លួនមានសណ្ឋានជាប្លោកតូច) ។ vésicule biliaire បិត្តាស័យ, ថង់ប្រមាត់ ។ vésicule pulmonaire ថង់បប្ផាសួត ។ *Pathol.* ពងទឹករងៃសើស្បែក

vésiculeux,euse *a.* ដូចប្លោក; ដូចថ្លុក

vesou *n.m.* ទឹកអំពៅ (ដែលគេគាប)

vespasienne *n.f.* បង្គន់នោមសាធារណៈ (សម្រាប់តែប្រុស)

vespéral,e,aux *a.* នៃពេលល្ងាច (ឧ. clarté vespérale)

vespertilion *n.m.* ប្រចៀវម្យ៉ាងនៅប្រទេសបារាំង

vesse *n.f.* *Pop.* ផោម (គតឮសូរ)

vesser *v.t.* *Pop.* ផោម (ដោយគតឮសូរ)

vessie *n.f.* មុត្រាស័យ, ប្លោកមូត្រ, ក្រពះនោម; ប្លោក ។ vessie natatoire ប្លោកខ្យល់នៃត្រី(សម្រាប់ឲ្យត្រីមុជ ឬអើបក្នុងទឹក) ។ *Fig.&Fam.* prendre des vessies pour des lanternes ភាន់ច្រឡំយ៉ាងខ្លាំង

vestale *n.f.* *Fig.* កញ្ញាបរិសុទ្ធណាស់

veste *n.f.* អាវ។ រ.ស. ព្រះភូសា។ *Fam.* ដំណើរខកការ (ឧ. ramasser une veste) ។ *Fam.* retourner sa veste ផ្លាស់មតិ; ផ្លាស់បក្សពួក

vestiaire *n.m.* កន្លែងទុកអាវ (ក្នុងទីសាធារណៈ)

vestibulaire *a.* *Anat.* នៃរន្ធត្រចៀកក្នុង

vestibule *n.m.* ល្វែងក្រៅ ។ *Anat.* រន្ធត្រចៀកក្នុង

vestige *n.m.* ដានជើង; ស្នាម; ដំណែល (សំណល់អ្វីៗដែលរលុបរលាយទៅ) (ឧ. les vestiges d'une civilisation)

vestimentaire *a.* នៃសំលៀកបំពាក់

veston *n.m.* អាវក្រុត (អាវក្រៅសម្រាប់មនុស្សប្រុស)

vêtement *n.m.* សំលៀកបំពាក់ (ស.រ. accoutrement, costume, habit, tenue)

vétéran *n.m.* ទាហានចាស់ឆ្នាំ; អ្នកជើងចាស់(អ្នកនៅយូរជាងគេក្នុងក្រសួងមួយ ឬ ក្នុងមុខរបរមួយ) (ឧ. un vétéran de l'enseignement) ; កូនសិស្សចាស់ឆ្នាំក្នុងថ្នាក់; ទាហានចាស់(នៅសហរដ្ឋអាមេរិក)។*Sports.* ចំណាស់

vétérance *n.f.* ភាពចាស់ឆ្នាំ, ភាពអ្នកជើងចាស់

vétérinaire *a.* នៃបសុព្យាបាល [ប៉ះ-សុ–] (ឧ. médecine vétérinaire) ។

n.m. បសុពេទ្យ, ពេទ្យសត្វ

vétillard,e *a.&n.* ម.ព. vétilleur

vétille *n.f.* ការប៉ិចប៉ុ, ការឥតប្រយោជន៍

vétiller *v.t.* ចូលចិត្តការប៉ិចប៉ុ, ចូលចិត្តការឥតប្រយោជន៍; រិះគន់លើការឥតប្រយោជន៍; រិះគន់លេងឥតការ

vétilleur,euse *n.* អ្នកជជែកពីការ

រប៉ិចរប៉ុ

vétilleux,euse *a.* ដែលចូលចិត្តការរប៉ិចរប៉ុ (ឧ. esprit vétilleux)

vêtir *v.t.* ស្លៀកពាក់ឲ្យ, ផ្ដល់សំលៀកបំពាក់ឲ្យ (ឧ. vêtir les pauvres)។

se vêtir *v.pr.* ស្លៀកពាក់ (ខ្លួនឯង)

veto *n.m.* ទំនាស់, ការជំទាស់ ។ *Par ext.&Fam.* ការប្រឆាំង, ការមិនយល់ព្រម (ឧ. père qui met son veto à un mariage)

vêture *n.f.* ពិធីបំបួស (ពិធីប្រគល់សំលៀកបំពាក់បព្វជិត ដល់អ្នកបួសក្នុងសាសនាគ្រិស្ត)

vétuste *a.* ទ្រុឌទ្រោម (ឧ. mobilier vétuste)

vétusté *n.f.* ភាពទ្រុឌទ្រោម

veuf *n. & a. m.* ពោះម៉ាយ

veuve *n.&a.f.* មេម៉ាយ

veule *a. Fam.* ខ្សោយ, ទន់ (មិនស្វាហាប់)

veulerie *n.f.* ភាពខ្សោយ, ភាពទន់ (មិនស្វាហាប់)

veuvage *n.m.* ភាពពោះម៉ាយ, ភាពមេម៉ាយ (មើ. viduité ភាពមេម៉ាយ)

vexant,e *a.* ដែលធ្វើឲ្យទោមនស្ស, ដែលធ្វើឲ្យអន់ចិត្ត

vexateur,trice *a.* ដែលបណ្ដាលឲ្យអន់ចិត្ត (ឧ. mesure vexatrice)

vexation *n.f.* ទោមនស្សកម្ម, ការធ្វើឲ្យអន់ចិត្ត (ព្រោះរំលោភអំណាច)

vexatoire *a.* ដែលនាំឲ្យអន់ចិត្ត (ឧ. impôt vexatoire)

vexer *v.i.* ធ្វើឲ្យទោមនស្ស,ធ្វើឲ្យអន់ចិត្ត (ឧ. il ne faut vexer personne) ។

se vexer *v.pr.* ទោមនស្ស, អន់ចិត្ត (ឧ. les gens susceptibles se vexent facilement)

via *pré.* តាម (ផ្លូវ), ដោយកាត់តាម (ឧ. train pour Battambang via Pursat)

viabilité *n.f.* ភាពអាចរស់នៅបាន

viabilité *n.f.* ភាពល្អ (ភាពផ្លូវអាចធ្វើគមនាគមន៍បានស្រួល)

viable *a.* អាចរស់នៅបាន (ឧ. enfant viable) ។ *Fig.* អាចសម្រេចបាន, អាចប្រព្រឹត្តទៅបាន(ឧ. projet viable)

viaduc *n.m.* វីយ៉ាឌុច, ស្ពានថ្មោង(ស្ពានសង់កាត់ពីលើផ្លូវ ឬ កាត់ជ្រលងភ្នំ)

viager,ère *a.* យាវជីវ, អស់មួយជីវិត។

rente viagère ម.ព. rente ។ n.m. ប្រតិលាភយាវជីព ។ en viager *loc. adv.* ជាធនលាភយាវជីព (ឧ. vendre sa maison en viager)

viagèrement *adv.* ជាយាវជីព, អស់មួយជីវិត

viande *n.f.* សាច់ (សាច់សម្រាប់ជាអាហារ) (ឧ. il ne faut pas s'alimenter exclusiment de viande) ។ viande blanche សាច់ស (សាច់កូនគោ, ទន្សាយ, មាន់, ៗ) ។ viande noire សាច់ខ្មៅ (សាច់ជ្រូកព្រៃ, ប្រចៀវ ។ល។) ។ viande rouge សាច់ក្រហម (សាច់គោ, ចៀម)

viander *v.i.* ស៊ីស្មៅ (សត្វព្រៃ)

viatique *n.m.* ប្រាក់ឬស្បៀង (សម្រាប់ដើរផ្លូវ) ។ *Fig.* មធ្យោបាយសម្រាប់ឲ្យបានសម្រេច

vibices *n.f.pl.* ស្នាមជាំនៅស្បែក

vibrage *n.m.* ដំណើរញ័រ ។ vibrage du béton ការរលាក់បេតុង (ឲ្យស្អិតសាច់)

vibrant,e *a.* ដែលញ័រ (ឧ. lame vibrante) ។ *Fig.* ដែលឲ្យរំភើប, ដែលឲ្យស្រើប (ឧ. discours vibrant)

vibratile *a.* អាចញ័របាន

vibration *n.f.* ដំណើរញ័រ ។ *Fig.* ការរំភើប ។ *Mus.* ការរលាក់(សំឡេង)

vibrato *n.m. Mus.* ដំណើររលាក់ (*pl.* des vibratos)

vibratoire *a.* ដែលញ័រ (ឧ. mouvement vibratoire)

vibrer *v.i.* ញ័រ ។ *Fig.* រំភើប, ស្រើប ។ faire vibrer ធ្វើឲ្យរំភើប ។ *Mus.* រលាក់ (សំឡេង)

vibreur *n.m.* ម៉ាស៊ីនរលាក់ (ម៉ាស៊ីនប្រើចរន្តអគ្គិសនី)

vibrion *n.m.* មេរោគ (ដែលមានខ្លួនខ្ទប)(ឧ. le vibrion du choléra)

vibrisse *n.f.* រោមច្រមុះ; រោមបក្សី

vicaire *n.m.* អ្នកជំនួសគេ; វីគែរ (បព្វជិតរងគួរេ)

vice *n.m.* បាបធម៌; គុណវិបត្តិ; វិការ (ឧ. vice de conformation ម.ព. conformation); អំពើអាក្រក់ (ឧ. flétrir le vice); ដំណើរខ្វះ; អំពើទំលខូច (ឧ. croupir dans le vice) ។

Dr. អធម៌ (ភាពខុសខាង

ច្បាប់) ។ vice de consentement អធម៌ក្នុងសេចក្ដីព្រមព្រៀង ។ vice de forme អធម៌ខាងទម្រង់, ដំណើរខុសទម្រង់ ។

Prov. l'oisiveté est la mère de tous les vices ម.ព. oisiveté (ព.ផ. vertu)

vice-amiral *n.m.* ឧត្តមនាវីទោ (*pl.* des vice-amiraux)

vice-chancelier *n.m.* អធិការបតីរង (*pl.* des vice-chanceliers)

vice-consul *n.m.* កុងស៊ុលរង (*pl.* des vice-consuls)

vice-consulat *n.m.* ដំណែងកុងស៊ុលរង (*pl.* des vice-consulats)

vice-gérant *n.m.* បណ្ណាធិការរង

vicennal,e,aux *a.* វីសំវត្សរ៍, សម្រាប់ម្ភៃឆ្នាំ; ដែលមានម្ភៃឆ្នាំម្ដង

vice-présidence *n.f.* ដំណែង ឬ ឋានន្តរជាអនុប្រធាន-អនុប្រធានាធិបតី-ឧបនាយកឬចាងហ្វាងរង (*pl.* des vice-présidences)

vice-président *n.m.* អនុប្រធាន ។ vice-président de l'Assemblée Nationale អនុប្រធានរដ្ឋសភា ។ អនុប្រធានាធិបតី ។ vice-président des Etats-Unis d'Amérique អនុប្រធានាធិបតីនៃសហរដ្ឋអាមេរិក ។ ឧបនាយក ។ vice-président du conseil des ministres ឧបនាយករដ្ឋមន្ត្រី ។ ចាងហ្វាងរង(*pl.* des vice-présidents)

vice-roi *n.m.* ឧបរាជ (*pl.* des vice-rois)

vice-royauté *n.f.* ឧបរាជ្យ (*pl.* des vice-royautés)

vicésimal,e, aux *a.* ដែលមាន ២០ ជាមូលដ្ឋាន

vice versa [vi-sé] *loc. adv.* ទៅវិញទៅមក

viciable *a.* អាចធ្វើឲ្យខូចបាន

viciateur,trice *a.* ដែលធ្វើឲ្យខូច

viciation *n.f.* ការធ្វើឲ្យខូច (ឧ. la respiration d'un grand nombre de personnes dans une salle close produit une rapide viciation de l'air)

vicier *v.t.* ធ្វើឲ្យខូច (ឧ. vicier le sang) ។ *Dr.* ធ្វើឲ្យយកជាការមិនបាន (ឧ. erreur qui vicie un acte) ។

se vicier *v.pr.* ឡើងខូច; មានគុណវិបត្តិ

vicieusement *adv.* ដោយខុស, ដោយទិលខូច (ឧ. parler vicieusement)

vicieux,euse *a.* ខូច, ខុស (ឧ. inclination vicieuse); ទិលខូច(ឧ. homme vicieux); ដែលព្រាញ (សេះ, លា ។ល។) (ឧ. mule vicieuse) (ព្រ. corrompu, dépravé, pervers, sadique)

vicinal,e,aux *a.* ដែលភ្ជាប់ភូមិជិតខាង (ផ្លូវ)

vicinalité *n.f.* ភាពផ្លូវភ្ជាប់ភូមិជិតខាង។ chemin de grande vicinalité ផ្លូវគមនាគមន៍ពីភូមិមួយទៅភូមិមួយ

vicissitude *n.f.* វិបរិយាស, ដំណើរប្រែត្រឡប់ (ផ្លាស់ពីល្អទៅអាក្រក់ ពីអាក្រក់ទៅល្អ) (ឧ. vicissitudes des saisons); ដំណើរប្រែប្រួល (ឧ. les vicissitudes de la fortune)

vicomtal,e,aux *a.* នៃវីកុងត៍ (ឧ. couronne vicomtale)

vicomte *n.m.* វីកុងត៍, ឋានន្តរសក្តិជនបន្ទាប់កុងត៍

vicomté *n.m.* ឋានន្តរនៃវីកុងត៍

vicomtesse *n.f.* ភរិយាវីកុងត៍

victimaire *n.m.* អ្នកពិឃាតមនុស្សឬសត្វសម្រាប់បូជា

victime *n.f.* មនុស្សឬសត្វដែលគេយកទៅបូជា ។ *Fig.* អ្នករងអំពើលោភឬអំពើអយុត្តិធម៌ (ឧ. être victime d'une intrigue); អ្នករងគ្រោះ (ឧ. être victime de son dévouement)

victoire *n.f.* អបរាជ័យ, ជ័យ, ជំនះ។ chanter ឬ crier victoire អួតពីជ័យជំនះខ្លួន

victoria *n.f.* វិចតូរិយ៉ា, រទេះសេះម្យ៉ាងកង់បួនឥតដំបូល

victoriene,nne *a.* នៃមហាក្សត្រិយានីវិចតូរីយ៉ាឬសម័យព្រះអង្គ (ឧ. l'art victorien)

victorieusement *adv.* ដោយមានជ័យជំនះ (ឧ. combattre victorieusement)

victorieux,euse *a.* ដែលមានជ័យជំនះ (ឧ. les troupes victorieures); ដែលឲ្យមានជ័យជំនះ; មិនអាចប្រកែកបាន (ឧ. preuve victorieuse); ក្រអឺតក្រអោង(ដោយមានជ័យជំនះ) (ឧ. avoir un air

victorieux) (ប្រ. triomphateur, vainqueur)

victuailles *n.f.pl.Fam.* ស្បៀង (គ្រឿងបរិភោគចិញ្ចឹមជីវិត)

vidage *n.m.* ការស្តារ, ការយកចេញឲ្យអស់

vidange *n.f.* ការយកចេញឲ្យអស់; ការស្តារបង្គន់; ភាពធុងទទេ ។

pl. លាមកដែលគេស្តារចេញពីបង្គន់

vidanger *v.t.* យកទឹកចេញឲ្យអស់ពីក្នុងធុង; ស្តារបង្គន់

vidangeur *n. & a.m.* អ្នកស្តារបង្គន់

vide *a.* ទទេ (គ្មានអ្វីសោះ) (ឧ. bourse vide); ទទេ (មានតែខ្យល់) (ឧ. espace vide); ទទេ (គ្មានមនុស្សនៅ) (ឧ. salle vide); ទទេ(ដែលគេយករបស់ចេញអស់) (ឧ. maison vide); ទំនេរ, គ្មានអ្នកកាន់កាប់ (ឧ. poste vide) ។ *Fig.* ខ្វះ (ឧ. un esprit vide d'idées) ។

Loc.div. les mains vides ដៃទទេ (គ្មានកាន់អ្វី; ពុំបានផលប្រយោជន៍អ្វី) (ឧ. bien peu de politiciens se retirent les mains vides) ។ *Fam.* avoir des chambres vides dans la tête លាយជំណើប (ឆ្កួតបន្តិចៗ) ។ cœur vide បេះដូងទំនេរ (គ្មានជាប់ជំពាក់នឹងស្នេហា) ។ tête vide ក្បាលទទេ (អ្នកគ្មានបញ្ញា) ។ vide de គ្មាន ។

n.m. *Phys.* សុញ្ញកាស (កន្លែងទទេ) (ឧ. faire le vide)។ *Constr.* ប្រហោង (ទ្វារបង្អួចនៅជញ្ជាំង) ។ កន្លែងទំនេរ (ឥតអ្នកកាន់កាប់) (ឧ. combler les vides dans une administration)។ *Fig.* ភាពរហេងរហាង (ហាក់ដូចជានៅម្នាក់ឯងឥតពំនាក់) (ឧ. sa mort fait un grand vide); ភាពឥតខ្លឹមសារ, សុញ្ញភាព (ឧ. sentir le vide de toutes choses) ។

Loc. div. faire le vide autour de quelqu'un បោះបង់អ្នកណាម្នាក់ ឬ ទុកឲ្យនៅតែឯង ។

à vide *loc. adv.* ទទេ (គ្មានបន្ទុក) (ឧ. la voiture est partie à vide); ទទេ (ឥតឲ្យផលអ្វី) (ឧ. moteur qui tourne à vide)

vide-bouteille *n.m.* ចំពួយជិប (ឆ្នុកមានឡូតសម្រាប់បញ្ច្រូបសិតទឹកចេញ

ពីដបដោយមិនបាច់បើកឆ្នុក) (*pl.* des vide-bouteilles)

vide-cave *n.m. inv.* ម៉ាស៊ីនបូមទឹកចេញពីលេណ

vide-citron *n.m.* ប្រដាប់ច្របាច់ក្រូច

videlle *n.f.* សម្រែះ (ចេសដែលស្រែះភ្ជិតប្រហោង) ; ប្រដាប់រៀលផ្លែឈើ (ដើម្បីធ្វើតំណាប់); ប្រដាប់កាត់ម្សៅ

vide-gousset *n.m.* ចោរ

vide-ordures *n.m. inv.* បំពង់ទម្លាក់សម្រាម (ទម្លាក់សម្រាមពីផ្ទះជាយទៅក្នុងធុងសម្រាមឯភិល)

vide-poches *n.m. inv.* កន្ត្រក,ក្ដូនទូ (សម្រាប់ទុកអីវ៉ាន់ដែលគេច្រើនដាក់ក្នុងហោប៉ៅ)

vider *v.t.* យកចេញឲ្យអស់ (ឧ. vider un tonneau); ផឹកបង្ហើយ (ឲ្យអស់ពីដប) (ឧ. vider une bouteille); ចាកចេញ,ចេញ (ឧ. vider les lieux); ឲ្យចេញអស់(ឧ. vider une salle) ។ *Fig.* បញ្ចប់រឿង, ដោះស្រាយ (ឧ. vider une querelle) ។

Loc.div. vider sa bourse ចាយហ្មត់ (ចាយអស់រលីង) ។ vider ses comptes ទូទាត់គ្នាអស់ (លែងមានជំពាក់គ្នា) ។ *Fam. & Fig.* vider son sac ម.ព. sac ។ vider le plancher ថយចេញ ។ vider une volaille ឬ vider un poisson ធ្វើ (វះសំអាតពោះ) បក្សី, ត្រី ។ *Dr.* vider un délibéré កាត់សេចក្ដី (ក្រោយពីបានពិគ្រោះគ្នា) ។

se vider *v.pr.* អស់; នៅទទេ (ឧ.les poumons ne se vident jamais d'air) ។ *Arg.* ស្លាប់ ។ *Fig.* ត្រូវដោះស្រាយរួច (ឧ. querelle qui ne put se vider amicalement) ។ vider les arçons ធ្លាក់ពីខ្នងសេះ

videur,euse *n.* អ្នកធ្វើ (វះសំអាតពោះបក្សី,ត្រី ។ល។) (ឧ. videur de volailles)

vidimer *v.t.* ផ្ទៀងហើយបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម

vidimus [–muss] *n.m.* សេចក្ដីបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម (ឧ. délivrer un vidimus)

vidoir *n.m.* កន្លែងចាក់ចោល

vidrecome *n.m.* កែវធំសម្រាប់ផឹក

viduité *n.f.* វិធវភាព[វិ-ធៈ-វៈ–], ភាព

មេម៉ាយ (និយាយចំពោះតែស្ត្រី) ។ délai de viduité វិធវេលា,រយៈពេលវិធវភាព(រយៈពេលដែលស្ត្រីលែងប្ដី ឬប្ដីស្លាប់ត្រូវនៅមេម៉ាយ)(ឧ. le délai de viduité qui, en principe, est de 300 jours, peut être abrégé)

vidure *n.f.* អ្វីៗដែលគេយកចោលចេញ (ពោះវៀនសត្វជាដើម)

vie *n.f.* ជីវិត (ដំណើររស់នៅ) (ឧ. les conditions nécessaires à la vie); ជីវិត(រយៈពេលដែលរស់នៅ)(ឧ. vie courte) ; របៀបបរិភោគ (ឧ. régime de vie des vieillards va mal aux jeunes gens); អាហារ (ឧ. mendier sa vie); ជីវភាព (ឧ.mener joyeuse vie); តម្លៃជីវភាព (តម្លៃម្ហូបអាហារ) (ឧ. la vie est chère); ជីវប្រវត្តិ (ឧ. les vies de Plutarque); ជីវភាព, វិជ្ជាជីវៈ (ឧ. embrasser la vie religieuse); សកម្មភាព(ឧ.style plein de vie) ។

Loc. div. vie de garçon ជីវភាពឥតព្រួយ។ vie d'artiste ជីវភាពមិនស្មើ(ខ្លះកាលមានខ្លះកាលក្រ)។ vie de bohème ជីវភាពពិបាក ។ *Fam.* vie de Polichinelle ឬ vie de patachon, de bâton de chaise ជីវភាពរាយមាយ ។ vie de chien ជីវភាពតោកយ៉ាក (ម.ព. vivre en chien ក្នុង ព. chien ផង)។ femme de mauvaise vie ស្ត្រីចរិយាអាក្រក់ ។ être en vie នៅរស់។ n'avoir qu'un filet ឬ qu'un souffle de vie ជិតដ្ហើមហួត, ខ្សោយណាស់, ស្ទើរស្លាប់ ។ sa vie ne tient qu'à un fil ជិតស្លាប់ណាស់ហើយ ។ avoir la vie dure ជីវិតថ្ងៃ; ក្រស្លាប់ , មិនងាយនឹងស្លាប់ (ឧ. le chat a la vie très dure) ។ donner ឬ laisser la vie à quelqu'un ឬ lui faire grâce de la vie ទុកជីវិតឲ្យ ។ donner la vie à quelque chose ធ្វើឲ្យរស់រវើក (ឧ. l'industrie donne la vie à toute une contrée) ។ demander la vie សុំរួចជីវិត ។ la vie ! សូមទុកជីវិតខ្ញុំ! សូមកុំសម្លាប់ខ្ញុំ ។ devoir la vie à quel-

qu'un កើតពី, ជាកូនគេ (ឧ. les parents auxquels nous devons la vie) ; រួចជីវិតដោយអ្នកណាម្នាក់ (ឧ. je dois la vie à ce médecin)។ donner la vie à quelqu'un បង្កើតអ្នកណាម្នាក់។ rendre la vie dure à quelqu'un ធ្វើបាប, ធ្វើឲ្យវេទនា ។ passer de vie à trépas ម.ព. trépas ។ faire bonne vie អាស្រ័យឆ្ងាញ់។ faire mauvaise vie អាស្រ័យមិនឆ្ងាញ់ ។ être de grande vie ស៊ីធំ(ចាយសម្រាប់ម្ហូបអាហារច្រើន) ។ être de petite vie ស៊ីតូច (ចាយសម្រាប់ម្ហូបអាហារតិច) ។ la vie future ជាតិក្រោយ ។ entre la vie et la mort ស្ទើរស្លាប់ស្ទើររស់ (ឈឺធ្ងន់ណាស់) ។ redonner ឬ rendre la vie à quelqu'un ធ្វើឲ្យទុកចិត្តវិញ; ធ្វើឲ្យបាត់ភ័យ ។ de la vie, de ma vie, etc... អស់មួយជីវិត ។faire la vie គិតតែសប្បាយ ។ vivre sa vie សប្បាយឲ្យអស់ចិត្ត ។ *loc. adv.* à vie អស់មួយជីវិត(ឧ. pension à vie)។ à la vie, à la mort ឬ pour la vie អស់មួយជីវិត, ជានិច្ច ។ niveau de vie ម.ព. niveau ។ standard de vice ម.ព. standard ។ ni à la vie ni à la mort ទោះរស់ក្តីស្លាប់ក្តី (មិន... សោះ) ។ pour la vie អស់មួយជីវិត; យូរអង្វែង (ឧ. c'est une fameuse étoffe, vous en aurez pour la vie) ។ de la vie ឬ de ma vie ឬ de sa vie ឬ jamais de la vie មិនដែល...សោះ (ឧ. de la vie on n'a vu pareil spectacle) ។ la vie durant ក្នុងមួយជីវិត ។

Prov. & loc.prov. vie de cochon, courte et bonne ប្រព្រឹត្តអនាចារនាំឲ្យអាយុខ្លី, សប្បាយខុសគន្លងនាំឲ្យអាយុខ្លី ។ il faut faire vie qui dure ត្រូវចេះសំចៃទុកប្រើឲ្យបានយូរ។nous n'avons que notre vie en ce monde ស្លាប់ហើយមិនយកទ្រព្យទៅផងទេ(ត្រូវតែចេះស៊ីចាយ) ។ telle vie telle mort ឆ្នាក់ខ្លួយទៀននៅតែទៀន (គេពុំអាចផ្លាស់ចរិយាបានឡើយ) ។ qui

a temps a vie បើមានពេលគិត គេអាចជៀសផុតពីសេចក្ដីវិនាសបាន(ម.ព. temps ផង) ។ qui méprise sa vie est maître de celle d'autrui អ្នកមិនខ្លាចស្លាប់ មិនខ្លាចនឹងសម្លាប់គេទេ

vieil *a. m.* ម.ព. vieux

vieillard *n.m.* មនុស្សចាស់ (ប្រុស)។ *pl.* ចាស់ៗ (ក្រុមមនុស្សចាស់ទាំងពីរភេទ)

vieillerie *n.f.* សំលៀកបំពាក់ចាស់; ឥវ៉ាន់ចាស់ ។ *Fig.* គំនិតចាស់ (ដែលគេធ្លាប់ដឹង) (ឧ.ne dire que des vieilleries)

vieillesse *n.f.* វ័យចាស់; មនុស្សចាស់ (ឧ. la vieillesse est impitoyable); ភាពចាស់ (ឧ. la vieillesse améliore le vin) ។ bâton de vieillesse អ្នកគាំទ្រមនុស្សចាស់

vieilli,e *a.* ដែលឡើងចាស់ (ឧ. retrouver bien vieilli un ami ancien); ចាស់ (ដែលមានយូរមកហើយ, ហួសសម័យ) (ឧ. préjugé vieilli; mode vieillie)

vieillir *v.i.* ទៅជាចាស់ (ឧ. il est pénible de vieillir); ឡើងចាស់ (ឧ. il vieillit depuis quelque temps); នៅ ឬ ធ្វើការយូរក្នុង (ឧ. vieillir dans l'Administration); ចាស់, ពុះទន់ខ្សោយ; បាត់សម្រស់ (ឧ. les femmes vieillissent souvent plus vite que les hommes ស្ត្រីច្រើនតែឆាប់ចាស់ជាងបុរស)។*Fig.* ចាស់ហួស, ហួសសម័យ (ឧ. cette mode vieillit; ce roman a vieilli) ។

v.t. ធ្វើឲ្យចាស់, ធ្វើឲ្យដូចចាស់ (ឧ. cette toilette vous vieillit)។

se vieillir *v.pr.* ក្លែងជាចាស់; តាំងខ្លួនថាចាស់

vieillissant,e *a.* ដែលឡើងចាស់

vieillissement *n.m.* ភាពឡើងចាស់; ភាពហួសសម័យ

vieillot,otte *a.* ចាស់បន្តិច, ដូចជាចាស់បន្តិច(ឧ. une femme vieillotte)

vierge *n.f.* កញ្ញា, ស្ត្រីព្រហ្មចារី ។ la Sainte Vierge សន្តកញ្ញា, មាតាព្រះយេស៊ូ ។

a. ព្រហ្មចារី, បរិសុទ្ធ (ឧ. un jeune homme vierge) ។ *Fig.* ស្អាត;ថ្មី,មិនទាន់ប្រើប្រាស់ (ឧ. page vierge); មិនទាន់សៅហ្មង, មិនទាន់ប៉ះពាល់ (ឧ. réputation vierge)។ forêt vierge ព្រៃស្មោង (ព្រៃដែលមិនទាន់មានគេរុករាន) ។ terre vierge ដីថ្មី, ដីដែលមិនទាន់មានគេដាំដំណាំ ។ film vierge ហ្វីល្មថ្មី, ហ្វីល្មមិនទាន់ថត ។

Astr. កញ្ញារាសី

vieux,vieil,vieille *a.* ព្រឹទ្ធ,ចាស់ (ឧ. un vieux paysan; un vieil homme; une vieille femme); ចាស់ (អាយុច្រើនជាង) (ឧ. je suis plus vieux que vous); ចាស់ (ក្នុងមុខដំណែង) (ឧ. un vieux professeur); ចាស់ (យូរមកហើយ) (ឧ. vieil ami); ចាស់ (ដែលមានយូរហើយ; ដែលមិនមែនជាទំនើប) (ឧ. vieux meuble); ចាស់ (ដែលគេប្រើយូរមកហើយ) (ឧ. un vieux chapeau); ចាស់ (ដែលគេលែងប្រើ) (ឧ. vieille expression) ។

Loc. div. se faire vieux ឡើងចាស់; តាំងខ្លួនជាចាស់ ។ les vieux jours វ័យចាស់ ។ *Fam.* ne pas faire de vieux os ខានចាស់,មិនរស់នៅយូរ, មិននៅយូរ។ être vieux avant l'âge ចាស់មុនអាយុ ។

n.m. របស់ចាស់, វត្ថុចាស់ (ឧ. le vieux vaut le neuf)។

n. មនុស្សចាស់ (ឧ. les jeunes et les vieux) ។ mon vieux, ma vieille តាប៉ុ, យាយប៉ុ (ពាក្យស្និទ្ធស្នាលហៅក្មេងៗ ក៏បាន) (ឧ. écoute, mon vieux! dis donc, ma vieille!); តា, យាយ (ពាក្យស្និទ្ធស្នាលហៅឪពុកម្ដាយ) (ឧ. personne ne vous gâtera jamais comme votre vieux ou votre vieille) ។ faire le vieux ធ្វើឫកចាស់ (ប្រើសំដី ឬ កិរិយាបថដូចមនុស្សចាស់) (ព.ផ. jeune, neuf, nouveau)

vif,vive *a.* ទាំងរស់ (ឧ. être brûlé vif) ។ *Fig.* រហ័សរហួន (ឧ. enfant vif) ; ឆាប់ខឹង (ឧ. vif comme la poudre); រហ័ស, វៃ (ឧ. une imagination vive);

ដែលនៅរស់; រស់រវើក; ឆើត, បិញ្ចាច (ឧ. couleur vive) ; ស្វាហាប់; រហ័ស (ឧ. attaque vive); ធ្ងន់; ខ្លាំង;ទ្រគោះ(ឧ.vifs reproches)។

Loc. div. eau vive ទឹកហូរ; ទឹកប្រភព (ទឹកដែលហូរចេញពីប្រភព) ។ *Mar.* vives eaux ទឹកជំនោរ (នៅថ្ងៃពេញបូណ៌មី) ។ haie vive ម.ព. haie ។ chaux vive ម.ព. chaux ។ bois vif ឈើរស់ ។ foi vive ជំនឿស៊ប់ ។ arête vive ជ្រុងស្រួច ។ roc vif ថ្មរឹង (ផ្ទុយនឹងដី, ខ្សាច់ ឬ វត្ថុផ្សេងៗ ដែលផុយៗ) ។

n.m. សាច់ស្រស់(សាច់មនុស្ស ឬសត្វរស់) (ឧ. trancher dans le vif); កូនត្រីរស់ (សម្រាប់ធ្វើនុយ) ។ *Dr.* មនុស្សរស់ (ឧ. donation entre vifs)។ *Fig.* អ្វីៗដែលសំខាន់ជាងគេ (ឧ. le vif d'une question) ។

Loc.div. couper ឬ trancher dans le vif កាត់ឫសកែ (កាត់ភាគសំខាន់); កាត់ចិត្តលះបង់អ្វីដែលគេស្រឡាញ់ណាស់); ចាត់វិធានការម៉ឺងម៉ាត់ ។ trancher au vif ចាប់ចំចំណុចខ្សោយ ។ prendre sur le vif ធ្វើត្រាប់ដូចសុទ្ធសាធ ។ piquer au vif ធ្វើឲ្យអន់ចិត្តខ្លាំង ។

Loc. adv. de vive voix ដោយវាចា។ de vive force ដោយប្រើកម្លាំងឃោរឃៅ (ឧ. enlever quelqu'un de vive force)។ à vive jauge យ៉ាងជ្រៅ (ភ្ជួរដី) (ឧ. labourer à vive jauge)

vif-argent *n.m.* បារត (ឬ បារទ ។ avoir du vif-argent dans les veines រហ័សរហួន

vigesimo *adv.* ទី ២០, ជាគម្រប់ ២០

vigie *n.f. Mar.* អ្នកយាមនៅជិតក្ដោង (កម្មករនាវា); អ្នកយាមសមុទ្រនៅមាត់ច្រាំង (ឧ. installer une vigie); ប៉មអ្នកយាមសមុទ្រ; បន្ទប់យាមខ្សែអយស្ម័យយាន

vigilamment *adv.* ដោយអប្បមាទ, ដោយប្រុងប្រយ័ត

vigilance *n.f.* អប្បមាទ, ការមិនធ្វេស, ការប្រុងប្រយ័ត្ន (ឧ. redoubler de vigilance) (មើ. application, diligence, soin)

vigilant,e *a.* អប្បមាទ, មិនធ្វេស, ប្រុងប្រយ័ត (ឧ. gardien vigilant)

vigile *n.f.* ថ្ងៃមុនបុណ្យធំ (ក្នុងសាសនាកាតូលិក)

vigile *n.m.* អ្នកយាមយប់ (នៅក្រុងរ៉ូម)

vigne *n.f.* ដើមទំពាំងបាយជូរ ; ចំការទំពាំងបាយជូរ ។ feuille de vigne ស្លឹកពោធិ៍, បាប៉ុង(គ្រឿងប្រដាប់ស្រដៀងនឹងស្លឹកពោធិ៍ សម្រាប់បិទបាំងខ្មាស) ។ *Fig.* être dans les vignes du Seigneur ស្រវឹង

vigneron,onne *n.* អ្នកដាំទំពាំង.បាយជូរ

vignette *n.f.* លតាប័ត្រ, ភ្ញីវល្លិ, ក្បាច់អម (ក្បាច់លំអក្របសៀវភៅ-ក្រដាសសរសេរសំបុត្រ-កូនកន្សែង ។ល។) vignette de validité លតាប័ត្របានការ

vignettiste *n.* អ្នកគូរ ឬ ឆ្លាក់លតាប័ត្រ

vigneture *n.f.* ភ្ញីស្លឹកទំពាំងបាយជូរ

vignoble *n.m.* ចំការទំពាំងបាយជូរ (ឧ. le vignoble de Bourgogne); ទំពាំងបាយជូរ (ឧ. des coteaux couverts de vignobles) ។

a. ដែលមានដំណាំទំពាំងបាយជូរ (ឧ. pays vignoble)

vigoureusement *adv.* យ៉ាងខ្លាំង, យ៉ាងមាំ

vigoureux,euse *a.* ខ្លាំង, មាំ (ឧ. vieillard encore vigoureux); ខ្លាំង (ឧ.attaque vigoureuse); ដិត,ឆើត (ឧ.coloris vigoureux)

vigueur *n.f.* ពលសម្បទ,កម្លាំងកាយ(ឧ. la vigueur de la jeunesse); កម្លាំងកាយ ឬ កម្លាំងចិត្ត (ប្រើធ្វើការអ្វីមួយ)(ឧ. agir avec vigueur); សេចក្ដីខ្លាំងក្លា(នៃគំនិត)(ឧ.vigueur de l'imagination); អានុភាព ។ être en vigueur នៅក្នុងធរមាន-បញ្ញត្តិ (ចំពោះច្បាប់ដែលនៅប្រើ)

vil,e *a.* ថោក (ឧ. acheter à vil prix) ។ *Fig.* ថោកទាប, អប្រិយ (ឧ. homme vil)

vilain,e *a.* ទុច្ចរិត; ថោកទាប (គួរឲ្យមើលងាយ) (ឧ. vilaine action); កាច,អាក្រក់ (ឧ.un vilain monsieur); អាក្រក់ (ឧ. vilain temps); អាក្រក់មើល (ឧ. vilain pays) ។

n.m. Autref. អ្នកស្រែ ។ *Pop.* ជម្លោះ; រឿងអប្រិយ (ឧ. il y a eu du vilain)

vilainement *n.m.* ដោយទុច្ចរិត;យ៉ាង

អាក្រក់មើល; យ៉ាងកខ្វក់; ដោយខ្ជីខ្ជា

vilebrequin *n.m. Techn.* ដែកស្វាន; វីឡីប្រ៊ីកឹង (គ្រឿងចំព្រ)

vilement *adv.* យ៉ាងថោកទាប

vilenie *n.f.* ហីនកម្ម, អំពើថោកទាប (ឧ. il est capable de toutes les vilenies); ពាក្យអសុរស, ពាក្យជេរ (ឧ. dire toutes sortes de vilenies)

vileté *n.f.* ហីនភាព, ភាពថោកទាប, ភាពគ្មានតម្លៃ; សេចក្ដីថោកទាប

vilipender *v.t.* ប្រកាសថាថោកទាប-ថាគួរមើលងាយ; មើលងាយ

villa *n.f.* ភូមិគ្រឹះ (ផ្ទះល្អនៅជនបទ ឬនៅមាត់សមុទ្រ; ផ្ទះដាច់ពីគេមានរបងព័ទ្ធជុំវិញ)

village *n.m.* ភូមិ; ជនក្នុងភូមិ

villageois,e *n.* ភូមិកជន, ជនក្នុងភូមិ។ *a.* នៃភូមិ (ឧ. manières villageoises)

villanelle *n.f.* កំណាព្យថ្លែងពីជនបទ; របាំមានចម្រៀង

ville *n.f.* ក្រុង, ទីក្រុង; ជនក្នុងទីក្រុង (ឧ. la ville est en liesse); ជីវភាពក្នុងទីក្រុង (ឧ. préférer la ville à la campagne) ។ la ville éternelle ក្រុងរ៉ូម ។ la ville sainte ក្រុងជេរុយសាឡែម, ក្រុងមេឌីន, ក្រុងឡាមិចក៏, ក្រុងឡាសា, ក្រុងរ៉ូម (តាមសាសនា) ។ à la ville នៅទីក្រុង (ផ. នឹង à la campagne) ។ en ville នៅផ្សារ (ផ.នឹង chez soi នៅផ្ទះ); ក្នុងក្រុង (សរសេរបំព្រួញ E.V.)

villégiateur *n.m.* អ្នកសំណាក់នៅជនបទ ឬនៅមាត់សមុទ្រ (ដែលមិនមែននៅផ្ទះខ្លួន)

villégiature *n.f.* ការសំណាក់នៅជនបទ

villeux,euse [vil-leû,eûz'] *a.* ស្រមូវ (ដែលមានរោមវែងដុះ) (ឧ. insecte villeux)

villosité [vil-lo-zi-té] *n.f.* ភាពមានរោមស្រមូវ; រោមស្រមូវ ។

Anat. ស្រាំង, ភាពគគ្រើម (ឧ. villosités intestinales ស្រាំងពោះវៀន)

vin *n.m.* ស្រាទំពាំងបាយជូរ; ឱសថលាយជាតិស្រាទំពាំងបាយជូរ (ឧ. vin de quinquina) ។

Loc. div. vin de palme ទឹកត្នោតជូរ ។ être pris de vin

ស្រវឹងស្រា ។ être entre deux vins ស្រវឹងស្រៀងៗ ។ sac à vin មនុស្សប្រមឹក ។ couver son vin ដេកលក់ទាំងស្រវឹង ។ vin d'honneur ស្រាជប់លៀង ។ grands vins ស្រាល្បីល្បាញ ។ vin bâtard ឬ de buffet ស្រាហោយទឹក (lit. abondance) ។ vin bleu ស្រាធុនធម្មតា ។ vin bourru ស្រាមិនទាន់ជូរល្មម ។ vin doux ស្រាខ្សោយ (មិនទាន់ជូរល្មម); ស្រាផ្អែម ។ vin nouveau ស្រាថ្មី (ធ្វើក្នុងឆ្នាំថ្មី) ។ vin de liqueur ស្រាផ្អែមមុត ។ vin de paille ស្រាចំបើង (ស្រាធ្វើពីទំពាំងបាយជូរទុំដោរដែលគេហាលលើចំបើង) ។ vin bouté ស្រាខូចក្នុងធុង ។ vin brûlé ស្រាលាយស្ករកំដៅ ។ vin de coupage ស្រាសម្រាប់លាយ (មានពណ៌ដិត) ។ vin de Brétigny ឬ vin à faire danser les chèvres ស្រាជូរល្អែម ។ vin de deux, de trois ឬ de quatre feuilles ស្រាពីរ-បី ឬ បួនឆ្នាំ ។ vin de singe ស្រាជាប់ស្រវឹង ។ vin du cru ស្រាក្នុងស្រុក (ធ្វើពីទំពាំងបាយជូរដាំក្នុងស្រុក) ។ vin en cercle ស្រាធុង (ផ. នឹងស្រាដប) ។ vin fumeux ស្រាឆួល (ធ្វើឲ្យក្ដៅដល់ក្បាល) ។ vin frais ស្រាខ្សោយ ។ esprit de vin ស្រា ។ vin de derrière les fagots ស្រាជម្រើស (ដែលគេជ្រើសទុកដោយឡែក) (ម.ព. fagot ផង) ។ pointe de vin ការជាប់ស្រវឹងស្រៀងៗ ។ avoir un vin d'agneau ស្រវឹងស្រាល ។ avoir un vin d'âne ស្រវឹងខ្លាំង ។ avoir un vin de cerf ស្រវឹងឆ្កួល ។ avoir un vin de lion ក្លាហានដោយត្រូវស្រា ។ avoir un vin de pie ស្វាហាប់ដោយត្រូវស្រា ។ avoir un vin de pourceau ស្រវឹងដួលខ្ទៀលដី ។ porter mal son vin ស្រវឹងកាច, ស្រវឹងផ្ដេសផ្ដាស; មិនពូកែផឹក ។ bien porter le vin ស្រវឹងស្លូត; ពូកែផឹក ។ avoir son vin ហើបមាត់មិនរួច, គេដេញដើងទាន់ ។ boire le vin du marché ផឹកជាមួយគ្នាក្រោយពេលដែលពិតការបានសម្រេច ។ faire jambes de vin ផឹកយកកម្លាំង

ផើរ ។

Fig. mettre de l'eau dans son vin ប្រែជាស្លូត ឬ ជាស្រួល; ទន់ចិត្ត, រសាយ, អន់ទឹក។ *Fig.* s'enivrer de son vin ចរចេសតាមគំនិតខ្លួន ។ le vin lui sort par les yeux ស្រវឹងផុល (ស្រវឹងក្រហមភ្នែក) ។

Prov. quand le vin est tiré, il faut le boire ម.ព. boire ។ vin versé n'est pas avalé ព្រឹត្តិការណ៍ដែលគួរកើតឡើង អាចនឹងមិនកើតទៅវិញបាន (ឧ. រឿងទន្សាយនឹងត្រីរស់ដែលគេចាប់បានហើយ អាចរួចទៅវិញបាន) ។ un verre de vin avise bien un homme គួរផឹកស្រាមួយកែវឲ្យភ្លាត់គំនិត ។ à bon vin point d'enseigne អ្វីដែលល្អមិនបាច់អួតទេ ។ chaque vin a sa lie អ្វីក៏ដោយសុទ្ធតែមានអត្ថទោស ឬ មានប៉ែកខាងអាក្រក់ជានិច្ច

vinage *n.m.* ការលាយស្រានឹងស្រាទំពាំងបាយជូរ (ដើម្បីឲ្យខ្លាំង)

vinaigre *n.m.* ទឹកខ្មេះ ។ *Fam.* faire vinaigre បង្វិលខ្លួនយ៉ាងរហ័ស (ក្នុងល្បែងលោតអន្ទាក់); *par ext.* ប្រញាប់

vinaigré,e *a.* ដែលមានដាក់ទឹកខ្មេះ

vinaigrer *v.t.* ដាក់ទឹកខ្មេះ (ឧ.vinaigrer une salade)

vinaigrerie *n.f.* កន្លែងធ្វើទឹកខ្មេះ

vinaigrette *n.f.* ទឹកគ្រឿងដាក់ទឹកខ្មេះ; ដបទឹកខ្មេះ (ដបកែវ)

vinaigrier *n.m.* អ្នកធ្វើនឹងលក់ទឹកខ្មេះ

vinaire *a.* នៃស្រាទំពាំងបាយជូរ (ឧ. matériel vinaire)

vinasse *n.f. Fam.* ស្រាខ្សោយហើយសាប; ស្រាកាក

vindicatif,ive *a.* ដែលចងគំនុំ, ដែលចូលចិត្តសងសឹក (ឧ. caractère vindicatif)

vindicativement *adv.* ដោយចងគំនុំ

vindicte *n.f.* vindicte publique ការចោទប្រកាន់ទោស ដោយសាធារណជន (ក្នុងនាមនៃសង្គមមនុស្ស)

vinée *n.f.* ផលស្រាទំពាំងបាយជូរ (ឧ. une bonne vinée); បន្ទប់ទំពាំងបាយជូរកាត់ដោយទាំងផ្លែ

viner *v.t.* លាយស្រានឹងស្រាទំពាំងបាយជូរ (ដើម្បីឲ្យខ្លាំង)

vineux,euse *a.* ខ្លាំង (ដែលមានជាតិស្រាច្រើន)(ស្រាទំពាំងបាយជូរ); ដែលមានរស ឬមានក្លិនដូចស្រាទំពាំងបាយជូរ (ឧ. pêche vineuse); ដូចស្រាទំពាំងបាយជូរ (ពណ៌) (ឧ. rouge vineux); ដែលផ្តល់ស្រាទំពាំងបាយជូរច្រើន (ឧ. la vineuse Bourgogne)

vingt *a.num.* ម្ភៃ (ឧ. vingt riels)។ ទី ២០ (ឧ. page vingt)។ vingt-quatre heures ម្ភៃបួនម៉ោង, ពេញមួយថ្ងៃ ។

n.m. ចំនួន ២០; លេខ ២០; ថ្ងៃទី ២០ (ត្រូវថា: vingt et un, vingt-deux ។ល។)។ vingt-et-un ល្បែងបៀ

vingtaine *n.f.* វីសកៈ, ចំនួនម្ភៃ; ប្រមាណជាម្ភៃ

vingtième *a. num. ord.* ទីម្ភៃ ។ *n.* អ្នកលេខម្ភៃ ។ *n.m.* ភាគ ២០ (ឧ. un vingtième)

vingtièmement *adv.* ទី ២០ .

vingtuple *a.* ម្ភៃគុណ ។ *n.m.* ចំនួនម្ភៃគុណ

vingtupler *v.t.* គុណនឹងម្ភៃ

vinicole *a.* ដែលដាំទំពាំងបាយជូរ (ឧ. pays vinicole); ដែលធ្វើស្រាទំពាំងបាយជូរ (ឧ. société vinicole) (មើល. viticole)

viniculture *n.f.* ការដាំទំពាំងបាយជូរ; ការធ្វើស្រាទំពាំងបាយជូរ

vinifère *a.* ដែលផ្តល់ស្រាទំពាំងបាយជូរ (ឧ. terrain vinifère)

vinification *n.f.* វិធីធ្វើស្រាទំពាំងបាយជូរ

vinique *a.* ដែលមកអំពីស្រាទំពាំងបាយជូរ

vinosité *n.f.* ភាពវត្ថុមានរស ឬ ក្លិនដូចស្រាទំពាំងបាយជូរ

viol *n.m.* អំពើកំហែងចាប់ចង់; ការប្រមាថ (ការធ្វើឲ្យសៅហ្មងដល់វត្ថុដែលគួរគោរព)

violabilité *n.f.* ភាពអាចប្រព្រឹត្តល្មើសបាន

violable *a.* អាចប្រព្រឹត្តល្មើសបាន

violacé,e *a.* ស្ទើរស្វាយ (ឧ. des mains violacées)

violacer *v.i.* ឡើងអុជៗពណ៌ស្វាយ, ឡើងពណ៌ស្វាយ

violateur,trice *n.* អ្នកកំហែងចាប់ចង់; អ្នកល្មើសច្បាប់

violation *n.f.* អជ្ញាចារ, វីតិក្រម, ការរំលង ឬ ល្មើសច្បាប់, ការបំពានច្បាប់;

ការប្រមាថសន្តិវត្ត ។ violation de domicile ការរុករកទ្រព្យនៅក្នុងលំនៅ ។ violation du secret des lettres ការមិនគោរពការសម្ងាត់នៃលិខិត (ការលួចបើក ឬ បំបាត់សំបុត្រអ្នកដទៃ)

violâtre *a.* ស្វាយភាវ

viole *n.f.* វីយ៉ូល, ទ្រម្យ៉ាងខ្សែបី

violemment [—la-man] *adv.* យ៉ាងខ្លាំង, យ៉ាងឃោរឃៅ (ឧ. repousser violemment)

violence *n.f.* ភាពខ្លាំង (ឧ. violence des vents, des passions); ការធ្វើទុក្ខទោស; អំពើកម្រោល, អំពើឃោរឃៅ ។

Dr. ការបំពាបំពាន; ការគម្រាម (ដើម្បីបង្ខំឲ្យធ្វើអ្វីមួយ) (ឧ. la violence est une cause de nullité du contrat) ។

Pol. ហិង្សា ។ non-violence អហិង្សា ។

faire violence à la loi មួលបង្កាប់ច្បាប់ (ឲ្យន័យខុស) ។ se faire violence បង្ខំខ្លួន (ស៊ី.brutalité, emportement, fougue, impétuosité, véhémence)

violent,e *a.* ខ្លាំង (ឧ. tempête violente); ឆាប់ខឹង; កម្រោល, ឃោរឃៅ (ឧ. homme violent) ។ *Fig.* ខ្លាំង (ឧ. sentiment violent); ហួសពេក (ឧ. c'est un peu violent de se voir ainsi traité) ។ mort violente ដំណើរស្លាប់តាមរបោង (ស៊ី. emporté, fougueux, impétueux)

violenter *v.t.* បង្ខំ

violer *v.t.* កំហែងចាប់ចង; ប្រមាថ (សន្តិវត្ត); បំពាបំពាន; មិនគោរព, មិនប្រព្រឹត្តតាម (ឧ. violer la loi, un serment) ។ violer le domicile de quelqu'un រុករកទ្រព្យនៅលំនៅអ្នកណាម្នាក់

violet,ette *a.* ស្វាយ (ពណ៌) ។ *n.m.* ពណ៌ស្វាយ

violeter *v.t.* ជ្រលក់ស្វាយ, លាបស្វាយ

violette *n.f.* វីយ៉ូឡែត (ផ្កាម្យ៉ាងពណ៌ស្វាយក្រអូបឈ្ងុល)

violine *a.* ស្វាយដាំ (ស្វាយលាយក្រហម)

violiste *n.m.* អ្នកកាន់វីយ៉ូល (ទ្រខ្សែបី)

violon *n.m.* ទ្រ; អ្នកកូតទ្រ ។ *Fig.* គុក (នៅនឹកកន្លែងឃុំ) ។ violon d'Ingres របរបន្ទាប់បន្សំ (ដែល

គេភ្លឹកជំនាញ) ។ payer les violons ចេញថ្លៃ, ចេញសោហ៊ុយ

violoncelle *n.m.* វីយ៉ូឡុងសែល (ទ្រប៉ុងវីយូឡូន ធំជាងទ្រធម្មតា)

violoncelliste *n.* អ្នកកាន់វីយ៉ូឡុងសែល (ទ្រវីយូឡូន)

violoneur ឬ **violoneux** *n.m.* *Fam.* អ្នកមិនប្រសប់កូតទ្រ

violoniste *n.m.* អ្នកកូតទ្រ

vipère *n.f.* ពស់វែក ។ *Fig.* មនុស្សកំណាច ។ langue de vipère ម.ព. langue

vipereau *n.m.* កូនពស់វែក

vipéridés *n.m. pl.* សន្តានពស់វែក

vipérin,e *a.* នៃពស់វែក ។ *Fig.* langue vipérine មនុស្សអាក្រក់; មនុស្សមាត់អាក្រក់ (ដូចពស់វែក) ។

n.f. ពស់សម្លាប់កង្កែប (ដូចពស់វែក)

virage *n.m.* ការបត់; របត់, ផ្លូវបត់ (ឧ. un virage relevé)។ *Fig.* ការងាក, ការបែរ (ឧ. politique qui prend un virage dangereux)

virago *n.f.* *Fam.* ស្ត្រីដែលមានមាឌ ឬ មានឫកដូចបុរស

viral,e *a.* នៃវីរាណូ (មេរោគ) (ឧ. la grippe est une affection virale)

virée *n.f.* *Fam.* ការដើរលេង (ឧ. faire une virée)

virement *n.m.* ការបង្វែរ

virer *v.i.* បែរ,ងាក;ហើរពណ៌ ។ virer de bord បត់; ផ្លាស់គណៈបក្ស ។

v.t. ind. (à) ប្រែពណ៌ (ឧ. le noir vire souvent au jaunâtre) ។

v.t. បង្វែរ (ឧ. virer une somme)

vireux,euse *a.* ពុល ; អសោច (ឧ. odeur vireuse)

vire-vire *n.m.* ឬ **virevaude** *n.f.* របត់ (នាវិចរ)

virevolte *n.f.* ការបង្វិលខ្លួន (សេះ)

virevolter *v.i.* បង្វិលខ្លួន

virginal,e,aux *a.* នៃស្ត្រីព្រហ្មចារី ; សម្រាប់ស្ត្រីព្រហ្មចារី (ឧ. voile virginal) ។ *Fig.* ព្រហ្មចារី, បរិសុទ្ធ, ឥតមន្ទិល

virginité *n.f.* ព្រហ្មចរិយភាព ។ *Fig.* ភាពបរិសុទ្ធ, ភាពឥតមន្ទិល

virgule *n.f.* កណ្ដាក់សញ្ញា,ក្បៀស(,) ។

point-virgule ម.ព. point ។ ba-cille virgule ។ ណ្ណាណ្ណអាសន្នរោគ

virguler *v.t.* ដាក់កណ្ដក់សញ្ញា, ក្បៀស

viril,e *a.* នៃប្រុស; រឹង ។ âge viril អាយុ ឬ វ័យពេញប្រុស ។ membre viril ស្វាស, អង្គជាតប្រុស ។ *Fig.* សមនឹងប្រុស; ក្លាហាន (ឧ. action virile) (ព្រ.courageux, éner-gique, ferme)

virilement *adv.* ដោយខ្លាំងក្លា, ដោយក្លាហាន (ដូចប្រុស)

viriliser *v.t.* ឲ្យមានលក្ខណៈដូចប្រុស; ធ្វើឲ្យក្លាហាន

virilisme *n.m.* បុរិសវិបល្លាស [ប៉ុ-រិ.ស:-វិ-ប៉ាល់-ឡាស], ដំណើរក្លាយជាប្រុស (រោគបណ្ដាលឲ្យស្រីមានលក្ខណៈជាប្រុស ដូចយ៉ាងដុះពុកមាត់, មានសម្លេងធំជាដើម)

virilité *n.f.* បុរិសលក្ខណៈ (អ្វីៗដែលសំគាល់ភេទប្រុស ឧ.les attributs de la virilité; សមត្ថភាពបង្កើតកូន ឧ. donner des preuves de sa virilité; អាការៈគ្រៀដូចប្រុស); វ័យពេញប្រុស ។ *Par ext.* បុរសទាំងឡាយ ។ *Fig.* បុរិសភាព (ចរិតសមនឹងប្រុស, កម្លាំងខ្លាំងក្លាដូចប្រុស)

virolage *n.m.* ការដាក់បង្គំ ឬ មៀន

virole *n.f.* បង្គំ, មៀន

viroler *v.t.* ដាក់បង្គំ ឬ មៀន

virtualité *n.f.* អនុត្តពលភាព (ភាពអាចកើតមានទៅខាងមុខ) (ឧ. la virtualité, pour exister, doit être actualisée)

virtuel,elle *a.* អនុត្តពល, អាចកើតមានទៅខាងមុខ, មិនទាន់មានឥលក្នុងបច្ចុប្បន្ន

virtuellement *adv.* ដោយអនុត្តពល, ដោយអាចកើតមានទៅខាងមុខ (ឧ. armée virtuellement défai-te)

virtuose *n.* អគ្គសិល្បិន (អ្នកជំនាញខាងភ្លេង; *par ext.* អ្នកជំនាញខាងសិល្បៈណាមួយ)

virtuosité *n.f.* អគ្គសិល្បភាព, សេចក្ដីជំនាញខាងសិល្បៈណាមួយ(ឧ. la virtuosité d'un pia-niste)

virulence *n.f.* វិសាណុភាព (ភាពបណ្ដាលដោយវិសាណូ ឧ.la viru-lence des humeurs); ភាពរហ័សរាលដាល (រោគ) (ឧ. la

virulence d'un microbe) ។ *Fig.* ភាពខ្លាំង (ឧ. critique pleine de virulence)

virulent,e *a.* វីសាណុជាត, ដែលបង្កើត ដោយវីសាណូ (ឧ. maladie virulente); រហ័សរាលដាល (ឧ. microbe virulent) ។ *Fig.* ខ្លាំង (ឧ. satire virulente)

virus *n.m.* វីសាណូ (មេរោគ) (ឧ. le virus de la fièvre typhoïde) ។ *Fig.* មេរោគ, មេព្រួច (ប្រភព ដែលនាំឲ្យខូចខាងផ្លូវចិត្ត) (ឧ. le virus de l'anarchie)

vis *n.f.* វីស, ខ្នៅ (សម្រាប់មួល) ។ escalier à vis ជណ្ដើរវៀន ។ pas de vis ធ្មេញខ្នៅ ។ *Fig.* serrer la vis រឹត (ប្រព្រឹត្តឲ្យតឹងរ៉ឹង លើសមុន) ។ vis de pression ខ្នៅរឹប ។ vis de rappel ខ្នៅរឹត ឬ បន្ធូរ

visa *n.m.* ទិដ្ឋាការ ។ pour visa ដើម្បីទិដ្ឋាការ

visage *n.m.* មុខមនុស្ស; មនុស្ស; មុខ (ទឹកមុខ) (ឧ. visage riant); ទិដ្ឋភាព ។

Loc. div. changer de visage ស្លាំងទឹកមុខ ។ trouver visage de bois មិនជួបអ្នកដែលទៅចង់រក ។ à visage découvert ដោយបើកមុខ, ដោយឥត លាក់មុខ, ដោយឥតក្លែង ។ visage nouveau ឬ nouveau visage ឬ visage neuf មនុស្សថ្មី (ដែលគេមិនធ្លាប់ស្គាល់) ។ visage d'excommunié ឬ de déterré, visage de l'autre monde, visage de bois flotté មុខស្លេកស្លាំង ។ visage de cuir bouilli មុខអាក្រក់ (គួរឲ្យអស់សំណើច ។ visage de Raminagrobis មុខធ្លាធង់, មុខស្រស់ប៉ប្រិមប៉ប្រៃ ។ visage allongé មុខស្ងួត, មុខអស់សង្ឃឹម ។ visage de pleine lune មុខមូលក្រឡង់ (ដូចព្រះចន្ទពេញវង់) ។ visage cousu មុខជ្រួញ (ស្គមក្រៀង) ។ bon visage មុខស្រស់ (ដោយមានសុខភាពល្អ) ។ mauvais visage មុខស្រៀម (ដោយសុខភាពមិនស្រួល) ។ se composer le visage រៀបចំទឹកមុខ (ដើម្បីលាក់គំនិតខ្លួន) ។ à deux visages ក្បាលពីរ (មិនត្រង់) (ឧ. un hom-

me à deux visages) ។ n'avoir rien d'humain que le visage ជាមនុស្សព្រៃ, ជាមនុស្សកំណាច (មានតែមុខដូចមនុស្ស ប៉ុន្តែចិត្តជាតិរច្ឆាន) ។ un visage ឬ un plaisant visage! មុខល្អណាស់! (ជាចំពោះមនុស្សដែលគេស្អប់ ឬ ដែលគួរចំអកឡ) ។ tourner le visage បែរមុខចេញ ។ épouser un visage ទទួលយកធ្វើប្រពន្ធដោយឃើញមុខល្អ ។ *Pop.* visage sans nez ខាងក្រោយ (ផ.នឹងមុខ)

visagiste *n.m.* អ្នកបញ្ចូកទេសខាងថែមុខ

vis-à-vis *loc.adv.* ខាងមុខ, មុខ (ឧ. nous étions placés vis-à-vis) ។

n.m. Fam. អ្នកអង្គុយមុខ; ដៃគូ; កៅអីចំណុះពីរនាក់

vis-à-vis de *loc. pré.* ចំពីមុខ, ចំពោះមុខ; បើប្រៀបធៀបនឹង

viscéral,e,aux *a.* នៃអន្តរការៈ, នៃអាការៈក្នុង (ឧ. cavité viscérale) ។

viscère *n.m.* អន្តរការៈ [អន់-តៈ-រ៉ា–], អាការៈក្នុង (ដូចជាខួរក្បាល, សួត, ពោះវៀន ។ល។)

viscosimètre *n.m.* ប្រដាប់ស្ទង់ភាពអន្ទិល

viscosité *n.f.* ភាពអន្ទិល ឬ ខាប់

visée *n.f.* ទិស (ដែលតោលភ្នែកមើល); ការតម្រង់កាំភ្លើង (ឧ. faire une bonne visée) ។ *pl. Fig.* ប្រណិធាន, ប្រាថ្នា, បំណង (អ្វីៗដែលគេប្រាថ្នាឲ្យបានសម្រេច) (ឧ. des visées ambitieuses); ការតម្រង់ផ្តោះ (ព្រ. but, dessein, intention, projet)

viser *v.t.* តម្រង់ ។ *Fig.* ប្រាថ្នា (ឧ. viser les honneurs); សំដៅ; សម្លឹង ។

v.t. ind. ប្រាថ្នា (ឧ. viser à l'effet ម.ព. effet)

viser *v.t.* ចុះទិដ្ឋាការលើ (ឧ. viser un passeport)

viseur,euse *n.m.* ប្រដាប់តម្រង់ (ឧ. viseur de tir aérien)

Vishnu ឬ **Vichnu** *n.pr.* វិស្ណុ ឬ ពិស្ណុ (ព្រះនារាយណ៍)

visibilité *n.f.* ទិស្សមានភាព [ទិស-សៈ-ម៉ានៈ–], ភាពអាចមើលឃើញ (ឧ. tournant sans visibilité)

visible *a.* ទិស្សមាន [ទិស.សៈ-ម៉ាន],

អាចមើលឃើញ (ឧ. un objet visible à l'œil nu)។ *Fam.* ដែលគេអាចទៅជួបបាន, ដែលព្រមទទួលភ្ញៀវ។ *Fig.* ស្តែង, ច្បាស់ទែង (ឧ. injustice visible) (សរ. apparent, manifeste, ostensible, perceptible)

visiblement *adv.* ដោយអាចមើលឃើញ; ដោយស្តែង

visière *n.f.* ក្បាំងមួក។ *Fig.* rompre en visière ប្រឆាំងឬនិយាយនឹងគាស់យ៉ាងដាច់ខាតហើយចំពោះមុខ

vision *n.f.* ចក្ខុសម្ផស្ស, ការឃើញ (ឧ. trouble de la vision); ចក្ខុនិមិត្ត, ការឃើញរបស់មិនពិត (ឧ. avoir des visions); ចក្ខុវិស័យ។ champ de vision ដែនចក្ខុវិស័យ។ *Fig.* គំនិតរវើរភ័យ

visionnaire *n.&a.* អ្នកឃើញរបស់ដែលអ្នកឯទៀតមើលមិនឃើញ។ *Fig.* អ្នកមានគំនិតរវើរភ័យ

visionner *v.t.* ឆ្លុះមើល, មើលក្នុងប្រដាប់ឆ្លុះ (ឧ. le public va voir le film mais après que le technicien l'aura visionné)

visionneuse *n.f.* ប្រដាប់ឆ្លុះរូប

visite *n.f.* ការទៅលេង; ការទៅសួរ (ការទៅផ្ទះគេ ដើម្បីមានការអ្វីម្យ៉ាង) (ឧ. faire une visite de condoléance ទៅសួរដើម្បីសំដែងសមានទុក្ខ); ការដើរមើល (ឧ. visite d'un musée); ភ្ញៀវ, អ្នកទៅសួរ, អ្នកដើរមើល; ការពិនិត្យជម្ងឺ (ចំពោះគ្រូពេទ្យ); ការពិនិត្យ, ការត្រួតត្រា (ឧ. faire la visite d'un navire); ទស្សនការ ។

visite domiciliaire ការពិនិត្យដល់លំនៅ ; ទស្សនាការដល់លំនៅ (ការស៊ើបអង្កេតពីបទល្មើស ឬអំពីបទឧក្រិដ្ឋដល់លំនៅ) ។ visite d'Etat ទស្សនាការជាផ្លូវរដ្ឋ ។ visite officielle ទស្សនាការជាផ្លូវការ ។ visite privée ទស្សនាការជាឯកជន ។

Loc. div. rendre visite, rendre sa visite à quelqu'un ម.ព. rendre

visiter *v.t.* ទៅលេង; ទៅសួរ (ឧ. visiter un malade); ដើរមើល (ឧ. visiter un monument); ពិនិត្យ; ត្រួតត្រា; ធ្វើទស្សនាការ (សរ. examiner, inspecter, scru-

ter, souder)

visiteur,euse *n.* អាគន្តុកៈ-កា, ភ្ញៀវ; អ្នកចូលចិត្តដើរលេងផ្ទះគេ; អ្នកត្រួតត្រា

vison *n.m.* សំពោចម្យ៉ាង

visqueux,euse *a.* អន្ទិល, ១ន់ (ឧ. une peau visqueuse)

vissage *n.m.* ការមួលខ្ចៅភ្ជាប់

visser *v.t.* មួលខ្ចៅភ្ជាប់; មួលភ្ជាប់ ។ *Fig.&fam.* រឹតត្បិត

visserie *n.f.* គ្រឿងខ្ចៅ

visualiser *v.t.* ធ្វើឲ្យមើលឃើញ

visuel,elle *a.* នៃចក្ខុវិញ្ញាណ, នៃភ្នែក (ឧ. acuité visuelle) ។ mémoire visuelle ម.ព. mémoire

visuellement *adv.* ដោយចក្ខុវិញ្ញាណ, ដោយភ្នែក

vital,e,aux *a.* ជីវិតសម្ពន្ធ, នៃជីវិត, សម្រាប់ជីវិត (ឧ. les fonctions vitales) ។ *Fig.* ជីវិតសម្ពន្ធ, ដែលជាអាយុជីវិត (ឧ. forces vitales d'un pays); សំខាន់ដល់ជីវិត (ឧ. question vitale)

vitaliser *v.t.* ឲ្យមានកម្លាំងឡើងវិញ

vitalisme *n.m.* ជីវិតនិយម (លទ្ធិខាងជីវសាស្ត្រដែលនិយមថា មានជីវិតមួយដោយឡែកអំពីព្រលឹង និងសពាង្គកាយ)

vitalité *n.f.* ជីវិតសម្ពន្ធភាព (កម្លាំង, បរិភាពនៃជីវិត) ; កម្លាំងឡើងវិញ (ឧ. il est doué d'une grande vitalité)

vitamine *n.f.* ជីវជាតិ

vitaminé,e *a.* ដែលមានជីវជាតិ

vite *a.* លឿន (ឧ. les coureurs les plus vites); រហ័ស ។ *adv.* យ៉ាងលឿន(ឧ. parler vite)

vitement *adv.* យ៉ាងលឿន

vitesse *n.f.* ល្បឿន; ភាពរហ័ស ។ grande vitesse ល្បឿនខ្លាំង ។ petite vitesse ល្បឿនខ្សោយ ។ en vitesse យ៉ាងលឿន

viticole *a.* នៃផលិតវប្បកម្ម, នៃការដាំទំពាំងបាយជូរ (ឧ. congrès viticole)

viticulteur *n.m.* ផលិតវប្បករ, អ្នកដាំទំពាំងបាយជូរ

viticulture *n.f.* ផលិតវប្បកម្ម, ការដាំទំពាំងបាយជូរ

vitrage *n.m.* ការដាក់កញ្ចក់; កញ្ចក់សព្វយ៉ាងក្នុងគេហស្ថាន ; ទ្វារកញ្ចក់; វាំងននបង្អួច

vitrail *n.m.* បង្អួចកញ្ចក់គំនូរផាត់ពណ៌; គំនូរផាត់ពណ៌ (*pl.* des vitraux)

vitre *n.f.* កញ្ចក់ (កញ្ចក់បង្អួច,កញ្ចក់ទូ)។ *Par ext.* បង្អួចកញ្ចក់ (ឧ. ouvrir ឬ fermer la vitre) ។ *Pop.* ភ្នែក (ឧ. crever une vitre à quelqu'un) ។ carreaux de vitre វ៉ែនតា ។ *Fig. & fam.* casser les vitres បើកកកាយខ្សែអស់; ធ្វើឲ្យខូចខាយ ឬ ឲ្យអាស្រូវ

vitré,e *a.* ថ្លាដូចកញ្ចក់; ដែលមានដាក់កញ្ចក់

vitrer *v.t.* ដាក់កញ្ចក់, ដំកញ្ចក់

vitrerie *n.f.* ការធ្វើកញ្ចក់; ការដាក់កញ្ចក់; ជំនួញកញ្ចក់

vitreux,euse *a.* ដូចកញ្ចក់ ។ les yeux vitreux ភ្នែកស្ញែ (ភ្នែកល្អក់ដូចភ្នែកខ្មោច)

vitrier *n.m.* អ្នកធ្វើកញ្ចក់; ជាងដាក់កញ្ចក់; ឈ្មួញកញ្ចក់

vitrifiable *a.* អាចធ្វើជាកែវបាន (ឧ. sable vitrifiable)

vitrification *n.f.* ការរំលាយធ្វើកែវ; ការស្លកែវ

vitrifier *v.t.* រំលាយធ្វើកែវ, ស្លកែវ (ឧ.vitrifier du sable)

vitrine *n.f.* ទូកញ្ចក់

vitupérateur,trice *a.* ដែលបន្ទោស

vitupération *n.f.* ការបន្ទោស

vitupérer *v.t.* ឬ *v.t. ind.* (contre) បន្ទោស (ឧ. vitupérer quelqu'un)

vivace *a.* អាចរស់បានយូរ ។ *Fig.* ដែលឋិតនៅយូរ (ឧ. les préjugés sont vivaces); រស់រវើក

vivacité *n.f.* ភាពរហ័សរហួន (ឧ. la vivacité de la jeunesse) ។ *Fig.* សេចក្ដីឈ្លាសវៃ (ឧ. vivacité d'esprit); ភាពឆាប់ខឹង; ភាពឆាប់រំភើប; ភាពស្រស់ (ឧ. vivacité des couleurs)

vivandier,ère *n.* អ្នកលក់ចំណីនិងស្រាឲ្យទាហាន

vivant,e *a.* ជីព, ជីវន្ត, ដែលមានជីវិត, រស់ (ឧ.les animaux vivants)។ être vivant ជីវន្តលោក, សត្វមានជីវិត។ *Fig.* រស់រវើក; ដូចជារស់ពិតៗ (ឧ. roman vivant); អ៊ូអែ (ឧ. quartier vivant) ។ langue vivante ម.ព. langue ។ portrait vivant រូបភាពដូចសុទ្ធសាធ។ une bibliothèque vivante

សព្វវិទូ [សប់-ពៈ-] (អ្នកចេះចំណេះគ្រប់យ៉ាង ដែលអាចឆ្លើយបញ្ហាផ្សេងៗបានដោយ មិនបាច់បើកក្បួន) ។

n.m. មនុស្សរស់ (ឧ. les vivants et les morts)។ bon vivant មនុស្សរីករាយជាធម្មតា ។ du vivant de ឬ en son vivant កាលនៅរស់នៅឡើយ(ឧ.plusieurs hommes devenus célèbres sont restés inconnus de leur vivant)

vivat! *int.* ជយោ!។ *n.m.* ជយស័ព្ទ, ជយឃោស (សម្រែកអបអរសាទរ) (ឧ. pousser de joyeux vivats)

vive *int.* ជយោ! (ឧ. vive le Cambodge !)

vivement *adv.* យ៉ាងរហ័សរហួន (ឧ. marcher vivement); យ៉ាងខ្លាំង (ឧ. vivement touché)

viveur *n.m.* មនុស្សគិតតែពីសប្បាយ (មនុស្សខិលខូច)

vivier *n.m.* កន្លែងស្រោះត្រី

vivifiant,e *a.* ដែលធ្វើឲ្យមានកម្លាំង (ឧ. air vivifiant)

vivificateur,trice *a.* ដែលធ្វើឲ្យមានកម្លាំង

vivification *n.f.* ការធ្វើឲ្យមានកម្លាំង

vivifier *v.t.* ធ្វើឲ្យមានកម្លាំង (ឧ. le soleil vivifie la nature)

vivipare *n. & a.* ជលាពុជៈ(សត្វដែលកើតជាគភ៌) (ផ. នឹង ovipare)

viviparité *n.f.* ជលាពុជៈកំណើត [ជៈ-លា-ពុ-ជៈ-] .

vivoter *v.i.* *Fam.* រស់នៅដោយឱនថយ

vivre *v.i.* រស់ (មានជីវិត) (ឧ. les corbeaux vivent très longtemps); នៅ (ឧ. vivre à la campagne); រស់នៅ (ឧ. vivre seul);រស់នៅ (ប្រព្រឹត្ត,កាន់អារយាទ) (ឧ.vivre saintement); ឋិតនៅ, គង់វង្សនៅ (ឧ.sa gloire vit éternellement) ។

vivre de រស់ដោយ, ចិញ្ចឹមជីវិតដោយ (ឧ. vivre de ses rentes) ។ vivre sur ចិញ្ចឹមជីវិតដោយ ។ vivre pour រស់ដើម្បី (គោលបំណងនៃជីវិតគឺ) (ឧ. vivre pour l'art) ។ ne pas vivre រស់តែកើតទុក្ខ(មិនបានសប្បាយដោយរស់នៅ) ។ être facile à vivre ស្រួល, មិនរើសត្រើស ។ savoir

vivre បេះស៊ូជីវធម៌ (ឧ. voilà une personne qui sait vivre); (ម.ព. savoir-vivre ផង) ។ vivre au jour le jour ម.ព. jour ។ vivre avec សេពគប់ ឬ ទាក់ទងនឹង ។ *Fam.* apprendre à vivre à quelqu'un ស្ដីប្រដៅ; ធ្វើទោស ។ qui vive ? ម.ព. qui vive ។ vive, vivent ជយោ ។

v.t. vivre sa vie រស់នៅតាមប្រាថ្នារបស់ខ្លួន, ប្រព្រឹត្តតាមប្រាថ្នារបស់ខ្លួន ។

n.m. ការរស់នៅ; ការសប្បាយដោយរស់នៅ

vivre *n.m.* អាហារ (ឧ. le vivre et le vêtement) ។ *pl.* ស្បៀង (ឧ. s'approvisionner en vivres) ។ couper les vivres à quelqu'un ផ្ដាច់ស្បៀង; លែងជួយ; រាំងរាមិនឲ្យបានសម្រេច

vivrier,ère *a.* ដែលជាអាហារ (ឧ. cultures vivrières) ។ *n.m.* អ្នកផ្គត់ផ្គង់ស្បៀង(ក្នុងកងទ័ព)

vizir *n.m.* វីសៀរ (រដ្ឋមន្ត្រីនៃក្សត្រអ៊ីស្លាម) ។ grand vizir រដ្ឋមន្ត្រីទីមួយ (នៃប្រទេសទួរគី)

vizirat *n.m.* ឋានៈវីសៀរ

vlan! ឬ v'lan! *int.* ផ្លុង! (ឧទានស័ព្ទ) (ឧ. vlan! en plein visage ផ្លុង! ចំមុខ)

vocable *n.m.* ពាក្យ (ឧ. tous les vocables d'une langue)

vocabulaire *n.m.* វាក្យស័ព្ទ

vocal,e,aux *a.* នៃសម្លេង (ឧ. les cordes vocales); ដែលបញ្ចេញសម្លេង (ឧ. prière vocale) ។ *Mus.* musique vocale ព.ម. musique

vocalement *adv.* ដោយសម្លេង

vocalique *a.* ដែលទាក់ទងនឹងសម្លេង (ឧ. les modifications vocaliques)

vocalisateur,trice *n.* អ្នកហាត់ច្រៀងបទភ្លេងទទេ (គ្មានទំនុក) (ថា vocaliste ក៏បាន)

vocalisation *n.f.* ប្រព័ន្ធស្រះ (របៀបប្រើស្រះនៃភាសាមួយ) ។ *Par ext.* ការបញ្ចេញសម្លេងស្រះ ។ *Gram.* ការផ្លាស់ព្យញ្ជនៈជាស្រះ ។ *Mus.* ការហាត់ច្រៀងបទភ្លេងទទេ (គ្មានទំនុក)

vocalise *n.f.* របៀបច្រៀងបទភ្លេងទទេ

vocaliser *v.i.* ហាត់ច្រៀងបទភ្លេងទទេ (គ្មានទំនុក) ។ *Fig.* ថ្លាស់ររបៀបសរសេរ; ថ្លាស់គំនិត ។
v.t. ច្រៀងដោយគ្មានទំនុក; ផ្លាស់ជាស្រៈ (ឧ. vocaliser une consonne)

vocalisme *n.m. Gramm.* ទ្រឹស្តីនៃស្រៈ, របៀបប្រើស្រៈនៃភាសាមួយ; ប្រព័ន្ធស្រៈ, ស្រៈទាំងអស់នៃពាក្យមួយ

vocaliste *n.m.* ម.ព. vocalisateur

vocatif *n.m.* អាលបនៈ [អា-ល័ៈ-ប៉ៈ-នៈ]

vocation *n.f.* ឧបនិស្ស័យ, ការចូលចិត្តទៅនឹងវិជ្ជាអ្វីមួយ ។ *Rel.* ការបម្រុងខ្លួនចូលបួស (មើ. goût, inclination, propension, tendance)

vociférant,e *a.* ដែលស្រែកសន្ធាប់

vociférateur,trice *n.* អ្នកហៅស្រែកសន្ធាប់

vociférations *n.f.pl.* សម្រែកសន្ធាប់ (ឧ. les vociférations de la foule)

vociférer *v.i.* ឬ *v.t.ind.* (contre) ស្រែកសន្ធាប់ឲ្យ (ឧ. vociférer contre quelqu'un) ។
v.t. ស្រែក (ឧ. vociférer des injures ស្រែកជេរ)

vodka *n.f.* វ៉ុតកា [វ៉ុត-កា] (ស្រានៃប្រទេសរុស្ស៊ីធ្វើអំពីពោត ឬ ស្រូវសាលី)

vœu *n.m.* សច្ចាធិដ្ឋាន, ការសច្ចា (ឧ. faire le vœu d'aller en pélerinage); ការតាំងចិត្ត (ឧ. vœu de pauvreté; je fis vœu de toujours lui obéir); ឆន្ទៈ, បំណង (ឧ. le vœu de la nation); ពរ (ឧ. former des vœux pour quelqu'un)

vogue *n.f.* អ្នកអុំ (ឬ អ្នកចែវ) ទូកមួយ; របៀបអុំ ឬ ចែវ ។ mener la vogue គោះចង្វាក់ (ឲ្យអុំ ឬ ចែវស្រះគ្នា) ។ *Fig.* ការរាប់អាន, ការចូលចិត្ត ។ en vogue ដែលគេរាប់អាន, ដែលគេចូលចិត្ត (ឧ. auteur, livre en vogue)

voguer *v.i.* អណ្តែតលឿនលើទឹក(ដោយអុំ ឬ ដោយបើកក្ដោង) ។ *Par ext.* ហែល (ឧ. on a remarqué qu'ordinairement les dauphins voguaient contre le vent (Lacépède) ។ *Fig.* អណ្តែតត្រសែត (ឧ. ainsi voguaient mes pensées (Cha-

teaubriand) ។ *Fig. & fam.* vogue la galère! បណ្ដោយតាមយថាកម្ម!

voici *pré.* នេះ

voie *n.f.* មាគ៌ា, បថ, ផ្លូវ ។ voie de communication ផ្លូវគមនាគមន៍។ voie aérienne អាកាសបថ, ផ្លូវអាកាស ។ voie ferrée អយស្ម័យបថ, ផ្លូវដែក។ voie fluviale ជលបថ, ផ្លូវទឹក ។ voie publique ផ្លូវសាធារណៈ ។ voie terrestre ថលបថ, ផ្លូវគោក ។ voie navigable ផ្លូវនាវាចរ (ផ្លូវនាវាអាចបើកបាន) ។ voie non navigable ផ្លូវអនាវាចរ (ផ្លូវនាវាបើកពុំបាន)។ *Ch. de fer* poser une voie ម.ព. poser ។ *Mar.* voie d'eau មុខទឹក (កន្លែងធ្លាយដែលធ្វើឲ្យទឹកហូរចូលក្នុងនាវា)។ *Fig.* ផ្លូវ, មធ្យោបាយ (ឧ. la voie de la persuation); មាគ៌ា (ឧ. suivre la voie de l'honneur) ។

Dr. voie d'accommodement ផ្លូវផ្សះផ្សា; ការផ្សះផ្សា ។ voie d'action ផ្លូវបណ្ដឹង ។ voies de droit ផ្លូវច្បាប់, ការប្ដឹងតុលាការ ។ voie d'exception ផ្លូវអញ្ញត្រកម្ម។ voie d'exécution ផ្លូវប្រតិបត្តិ (របៀបធ្វើឲ្យបានសម្រេចសាលក្រម ឬ ដីកា) ។ voie de fait អំពើបំពានបំពាន (ឧ. cracher au visage constitue une voie de fait) ។ voie de recours ផ្លូវឧបាស្រ័យ (របៀបប្ដឹងតក៏ទៅសាលាឧទ្ធរណ៍ ឬ សាលាវិនិច្ឆ័យ) ។

Loc. div. être en bonne voie កំពុងតែមានដំណើរស្រួល (បម្រុងបានសម្រេច) ។ être en voie de ជិតនឹង, របៀបនឹង (ឧ. il est en voie de réussir)។ mettre quelqu'un sur la voie ជួយតម្រែតម្រង់អ្នកណាម្នាក់ ។

Anat. ផ្លូវ ។ voie urinaire ផ្លូវនោម ។ voie réspiratoire ផ្លូវដង្ហើម ។ *Astr.* voie lactée ម.ព. lacté ។

pl. voies et moyens មាគ៌ានិងមធ្យោបាយ (ធនធាននៃរដ្ឋ)

voilà *pré.* នោះ

voilage *n.m.* គម្របសំពត់ភ្ញី

voile *n.m.* វត្ថុបិទបាំង, គម្របសំពត់ (ឧ.

statue couverte d'un voile): សំពត់បាំងមុខ (សម្រាប់ស្ត្រី) (ឧ. baisser, relever son voile): សំពត់ស្តើង ។ *Par ext.* គម្រប, របាំង(ឧ.un voile de nuages)។ *Anat.* voile du palais ស្បែកក្រអូមមាត់ (ស្បែកក្នុងមាត់ដែលបិទរន្ធច្រមុះ ។

Fig. លេស, ហេតុអាង (ឧ. sous le voile de l'amitié): អ្វីៗដែលសម្រាប់លាក់បំបាំង (ឧ. le voile de l'anonymat) ។ mettre le voile ឬ jeter le voile លាក់បំបាំង។ prendre le voile បួសបួស(ជាដូនជី)។ le voile de la nuit ភាពងងឹត(វេលាយប់)

voile *n.f.* ក្ដោង; នាវា (ឧ. signaler une voile à l'horizon): កំឡា នាវាក្ដោង។ faire voile ចេញនាវា; ចេញដំណើរ ។ mettre à la voile ចុះនាវា។ *Pop.* mettre les voiles ចាកចេញ ។ à pleines voiles, porter plein la voile ម.ព. plein

voilé,e *a.* ដែលមានអ្វីគ្របឬបាំង; កោង, ពោរ(ឧ. planche, roue voilée)។ voix voilée សំឡេងខ្សាវ ។ regard voilé ភ្នែកងាស(ស្រអាប់)

voilement *n.m.* ដំណើរពោរ

voiler *v.t.* គ្របដោយសំពត់, ឃ្លុំ; បាំង (ឧ. la lune est voilée ce soir); ពត់, ធ្វើឲ្យពោរ (ឧ. voiler sa roue de bicyclette) ; ដាក់ក្ដោង ។ *Fig.* បិទបាំង, លាក់ (ឧ. voiler ses desseins) ។

v.i. & se voiler *v.pr.* ទៀងពោរ

voilerie *n.f.* រោងធ្វើក្ដោង,រោងទុកក្ដោង

voilette *n.f.* សំពត់ស្តើងសម្រាប់បាំងមុខ (គ្រឿងតែងខ្លួនស្ត្រី)

voilier *n.m. Mar.* ជាងធ្វើក្ដោង; នាវាក្ដោង(ឧ. un fin voilier) ; បក្សីម្យ៉ាង

voilure *n.f. Mar.* ក្ដោងទាំងឡាយនៃនាវាមួយ។ *Aéron.* ស្លាបយន្តហោះ។ *Mécan.* ភាពពោរ

voir *v.t.* ឃើញ (ឧ. heureux celui qui n'a jamais vu la guerre); មើល ; ពិនិត្យ (ឧ. voyez ce tableau); មើល, សួរ (ឧ. aller voir un ami); ឃើញ, ជួប (ឧ. je l'ai vu par hasard); មើល,

ព្យាបាល (ឧ. voir un malade); ទៅរក (ឲ្យជួយ) (ឧ.voir un médecin); មើល,ចង់ដឹង,ចង់ឃើញ(ឧ. je vais voir s'il est rentré); មើល (ដោយពិនិត្យពិច័យ)(ឧ. voir au microscope); មើល, ដើរមើល (ឧ. voir du pays); ឃើញ; សេពគប់; ទទួល (ឧ. voir beaucoup de monde); លមើល (ឧ. voyez si ce vêtement vous va) ។

Fig. ឃើញ, សំគាល់ឃើញ (ឧ. voyez comme il est à plaindre); ឃើញ, ស្គាល់ (ឧ. Dieu voit le fond des cœurs); ឃើញ, យល់ (ឧ. je vois sa ruse); ឃើញ, រកឃើញ (ឧ. je ne vois pas quel parti prendre); មើល,ពិនិត្យឲ្យម៉ត់ចត់(ឧ.voir tout par soi-même); វិធីជួយ (ឧ. tout homme a sa manière de voir) ។

Loc.div. faire voir បង្ហាញ, ធ្វើឲ្យឃើញ។ laisser voir បង្ហាញ, បញ្ចេញឲ្យឃើញ ។ voir le jour ឃើញពន្លឺព្រះអាទិត្យ, កើតឡើង; មានឡើង; ត្រូវបោះពុម្ពផ្សាយ ។ voir de bon œil អនុគ្រោះ, សប្បាយចិត្ត។ voir de mauvais œil មិនអនុគ្រោះ, មិនសប្បាយចិត្ត ។ voir venir quelqu'un ស្គាល់បំណងអ្នកណាម្នាក់ ។

v.t. voir de loin មើលឃើញឆ្ងាយ (បេះប្រយ័តមុន)។ pour voir លមើល ។ voir à ce que ប្រយ័តឲ្យ ។

se voir *v.pr.* ឃើញគ្នា; សេពគប់គ្នា ។ ne point se voir ឃើញមុខគ្នាមិនបាន,មិនត្រូវគ្នា។ cela se voit tous les jours របស់នោះមានញឹកញយ (*ល.* apercevoir, aviser, entrevoir, observer, surprendre)

voire *adv.* មែនទែន ។ voire même ឬ voire តែមយ៉ាង,ទៀតផង(ឧ. Mazarin était habile, voire retors)

voirie *n.f.* សារពើផ្លូវ, ផ្លូវទាំងឡាយ (ឧ. la grande et la petite voirie); ក្រុមវិថីបាល (ក្រុមធ្វើ,ថែទាំនិងគួសគុលផ្លូវ); កន្លែងចាក់សម្រាម

voisin,e *a.* ជិតខាង (ឧ. pays voi-

sin); ដែលនៅជិត; ជិត (ឧ.voisin de la mort); ប្រហែល, ស្រដៀង (ឧ. son projet est très voisin du mien) ។

n. អ្នកជិតខាង (ឧ. il est mon voisin); អ្នកឯទៀត ។

Prov. un bon renard ne mange jamais la poule de son voisin ម.ព. poule

voisinage *n.m.* ភាពជាអ្នកជិតខាង (ឧ. le voisinage de ces gens est insupportable); ទីជិតខាង, ដំបន់ជិតខាង (ឧ. il demeure dans le voisinage); ការទាក់ទងរវាងអ្នកជិតខាង (ឧ. des relations de bon voisinage); អ្នកជិតខាងទាំងឡាយ

voisiner *v.i.* នៅជិត (ឧ. sur sa table les livres voisinaient avec un reste de repas); សេពគប់អ្នកជិតខាង (ឧ. à Phnom Penh on voisine très peu)

voiturage *n.m.* ការដឹកនាំដោយរថ

voiture *n.f.* រថ, រទេះ; អ្នកជិះរថជាមួយគ្នា (ឧ. toute la voiture jetait les hauts cris); ដឹក, បន្ទុកមួយរទេះ (ឧ.voiture de paddy); ការដឹកនាំ; ថ្លៃដឹកនាំ ។ voiture automotrice រថស្វ័យគត [—ស្វៃ-គត់] ។ voiture-bar ម.ព. wagon-bar ។ voiture-lit ម.ព. wagon-lit ។ voiture-restaurant ម.ព. wagon-restaurant

voiturée *n.f.* បន្ទុករថ

voiturer *v.t.* ដឹកនាំដោយរថ (ប្រើបំពោះតែទំនិញ)

voiturette *n.f.* រទេះតូច, រថយន្តតូច

voiturier *n.&a.m.* សារថី, អ្នកដឹកនាំ

voix *n.f.* សម្លេង (ឧ. voix harmonieuse; la voix du perroquet) ។ *Spécial.* សម្លេងច្រៀង (ឧ. avoir une voix de ténor) ។ voix musicale សម្លេងតន្ត្រី (ពីរោះដូចភ្លេង) ។ voix pleine សម្លេងក្រអួន ។

Fig. ឧភិទ; ការព្រមាន; ការអំពាវនាវ (ឧ. écouter la voix d'un ami); មនោសញ្ចេតនា; សម្លេង (ក្នុងការបោះឆ្នោត)(ឧ. donner sa voix à tel candidat បោះឆ្នោតឲ្យបេក្ខជននេះ); សម្លេង (ឬសម្រែកក្នុង ដូចពាក្យថា "ឈាមស្រែកស្បែក

ហើរ") (ឧ. la voix du sang, de la conscience) ។

Loc. div. avoir voix au chapitre មានសិទ្ធិថ្លែងយោបល់ខ្លួន ។ de vive voix ដោយវាចា, ផ្ទាល់មាត់ ។ donner de la voix ស្រែក (ចំពោះឆ្កែប្រមាញ់); និយាយខ្លាំងៗ ។ sans voix ដោយឥតនិយាយ, ដោយនៅស្ងៀម។ voix du peuple សម្លេងប្រជារាស្ត្រ (មតិទូទៅ) ។

Prov. la voix du peuple est la voix de Dieu ម.ព. Dieu និង peuple

vol *n.m.* ការហើរ, ការហោះ; ចម្ងាយមួយល្បើកសត្វហើរ; ចំនួនបក្សីដែលហើរជាមួយគ្នា (ឧ. un vol de perdrix); សំទុះ, ចលនាល្បឿន, ទំហឹងល្បឿន (ឧ. le vol des flèches) ។

Loc. div. au vol ក្នុងពេលហើរ, ឮដ៏អាកាស; យ៉ាងរហ័ស ។ saisir l'occasion au vol ឆក់យកឱកាស ។ à vol d'oiseau *loc. adv.* ម.ព. oiseau ។ prendre son vol ហើរ, ហោះ

vol *n.m.* អទិន្នាទាន, ការលួច (ឧ. commettre un vol) ; អទិន្នាភណ្ឌ, របស់ដែលលួចបាន ។ vol qualifié ម.ព. qualifié

volable *a.* អាចលួចបាន

volage *a.* សាវ៉ា (ឧ. esprit, cœur volage)

volaille *n.f.* បសុបក្សី (ឧ. engraisser de la volaille)

volailler *n.m.* ឈ្មួញបសុបក្សី (ឬនកាលគេថា volailleur); កន្លែងចិញ្ចឹមបសុបក្សី

volant *n.m.* សី; ល្បែងសី; បន្តួតរបិយន្ត; ស្លាបកង្ហារ។ *Fig.* ប្រាក់បម្រុង (ឧ. volant de sécurité)

volant,e *a.* ដែលហើរ, ដែលហោះ (ឧ. poisson volant); ដែលធ្វើដំណើរបានរហ័ស (ឧ. brigade volante) ។ feuille volante សន្លឹកក្រដាសរាយ (មិនដេរភ្ជាប់គ្នា) ។ fusée volante កាំជ្រួចហោះ ។ pont volant ស្ពានស្រួលលើកដាក់ ។ table volante តុស្រួលលើកដាក់

volatil,e *a.* ហើរ, ដែលហុយជាផ្សែងបានដោយងាយ

volatile *n.m.* សត្វហើរ (សត្វដែលបេះហើរ); បក្សបក្សី

volatilisable *a.* អាចហើរបាន, អាចហុយជាផ្សែងបាន

volatilisation *n.f.* ការធ្វើឲ្យហុយជាផ្សែង

volatiliser *v.t.* ធ្វើឲ្យហើរ, ធ្វើឲ្យហុយជាផ្សែង (ឧ. volatiliser du soufre) ។ *Fam.* បំបាត់; លួច (ឧ. volatiliser un portefeuille)។

se volatiliser *v.pr.* ហើរ, ហុយជាផ្សែង ។ *Fig. & fam.* បាត់

volatilité *n.f.* ភាពហើរ(ហុយជាផ្សែង) (ឧ. la volatilité de l'éther)

volcan *n.m.* ភ្នំភ្លើង (ឧ. le Vésuve est un volcan) ។ *Fig.* មនុស្សក្លៀវក្លា; ភ្នំភ្លើង (គ្រោះថ្នាក់កំបាំងដែលបម្រុងនឹងផ្ទុះ) (ឧ. être sur un volcan)

volcanique *a.* នៃភ្នំភ្លើង (ឧ. éruption volcanique) ។ *Min.* roches volcaniques សិលាភ្នំភ្លើង ។ *Fig.* ក្លៀវក្លា

volcaniser *v.t.* ធ្វើឲ្យមានសភាពជាសិលាភ្នំភ្លើង ។ *Fig.* ធ្វើឲ្យក្លៀវក្លា។

se volcaniser *v.pr.* មានសភាពជាសិលាភ្នំភ្លើង ។ *Fig.* ក្លៀវក្លាណាស់ (ឧ. la jeunesse se volcanise aisément)

volcanisme *n.m.* វិជ្ជាខាងភ្នំភ្លើង

volée *n.f.* ការហើរ; ការហោះ; ល្បឿនសត្វហើរ (ចម្ងាយសត្វហើរបានគ្មានឈប់ ឧ. une hirondelle traverse la Méditerranée d'une seule volée); ហ្វូងសត្វ (ដែលហើរជាមួយគ្នា)(ឧ. volée de moineaux); ការបាញ់បម្រុះ (ឧ. volée d'obus); ការវាយច្រើន (ឧ. recevoir une volée); រំពងជួង (ស្គរជួងដែលគេអង្រួន) (ឧ. sonner à toute volée)។

Sports. ការវាយបាល់ដែលមិនទាន់ធ្លាក់ដល់ដី ។ demi-volée ការវាយបាល់ដែលទើបនឹងលោតផុតពីដី ។ à la volée *loc. adv.* កំពុងលោត (ឧ. saisir une balle à la volée); *fig.* យ៉ាងរហ័ស (ឧ. saisir une allusion à la volée) ។ prendre sa volée ចេញហើរដោយស្លាបឯង (ចេញពីអាណាព្យាបាល)

voler *v.t.* ហើរ,ហោះ; បោលយ៉ាងលឿន

(ឧ. il lui fait voler son épée) ។ *Fig.* រត់លឿនណាស់ (ដូចគេហោះ) (ឧ. ce cheval vole); កន្លងទៅយ៉ាងរហ័ស (ឧ. le temps vole); សាយភាយយ៉ាងរហ័ស ។ voler de ses propres ailes ហើរដោយស្លាបឯង (ធ្វើខ្លួនឯង) ។

v.t. ហើរដេញ (ឧ. cet oiseau vole le héron)

voler *v.t.* លួច ។ ne l'avoir pas volé សមនឹងទទួលអំពើដែលធ្លាក់លើខ្លួន ។

Prov. qui vole un œuf vole un bœuf លួចគេកន្លាប់ដៃ, អ្នកហ៊ានលួចរបស់តូចមុខតែហ៊ានលួចរបស់ធំ (មើ. cambrioler, déposséder, dépouiller, dérober, détourner, dévaliser, extorquer, piller)

volerie *n.f. Fam.* ការលួចបន្តិចបន្តួច (ឧ. il s'est enrichi par ses voleries)

volet *n.m.* បង្អួចបន្ទះ; បន្ទះសម្ភបបាន; កូនតុសម្រាប់រើសរបស់ល្អិត ។ *Fig.* trier sur le volet រើសយ៉ាងហ្មត់ចត់ (ឧ. trier ses invités sur le volet)

voleter *v.i.* ហើរជិតៗ

volettement *n.m.* ការហើរជិតៗ

voleur,euse *n.* អទិន្នហារី-រិនី, ចោរ ។

Prov. les grands voleurs pendent les petits ម. ព. pendre

volière *n.f.* ទ្រុងធំសម្រាប់ចិញ្ចឹមបក្សី

volitif,ive *a.* ដែលសំដែងឆន្ទៈ (ឧ. phénomènes volitifs)

volition *n.f.* ការសំដែងឆន្ទៈ

volley-ball *n.m.* វ៉ូលេប៉ូល, កីឡាបាល់ទះ

volleyeur,euse *n.* អ្នកកីឡាបាល់ទះ

volontaire *a.* ស្ម័គ្រ, ប្រកបដោយឆន្ទៈ (ឧ. acte volontaire); ដែលធ្វើតែតាមចិត្តឯង (ឧ. enfant volontaire) ។

n.m. ទាហានអាសា, ទាហានស្ម័គ្រចិត្ត (ឧ. bataillons de volontaires); អ្នកស្ម័គ្រចិត្ត

volontairement *adv.* ដោយស្ម័គ្រ (ឧ. obéir volontairement); ដោយចេតនា

volontariat *n.m.* ការចូលធ្វើទាហានដោយស្ម័គ្រ

volontarisme *n.m. Philos.* ឆន្ទនិយម (លទ្ធិនិយមថាឆន្ទៈជាប្រធានក្នុងការវិនិច្ឆ័យ) (ព.ផ. intellectualisme)

volontariste *Philos. a.* ឆន្ទនិយម ។ *n.* អ្នកឆន្ទនិយម

volonté *n.f.* ឆន្ទៈ, ចេតនា, បំណង (ឧ. agir contre la volonté de quelqu'un): ឆន្ទៈ, សេចក្ដីម៉ឺងម៉ាត់(ឧ.volonté inflexible); សេចក្ដីស្ម័គ្រ ។ volonté nationale ឆន្ទៈរបស់ប្រជាជាតិ ។ bonne volonté សុឆន្ទៈ, ឆន្ទៈល្អ ។ mauvaise volonté ទុច្ឆន្ទៈ, ឆន្ទៈអាក្រក់ ។

*pl.*ឆន្ទៈ,ទំនើងចិត្ត(ឧ.soumettre tout le monde à ses volontés)។ dernières volontés អវសានឆន្ទៈ, បំណងចុងក្រោយបង្អស់ (បំណងដែលសំដែងនៅពេលជិតស្លាប់); មតកសាសន៍ ។ *Fam.* faire ses quatre volontés ធ្វើតាមទំនើងចិត្តខ្លួន ។ à volonté *loc. adv.* តាមចិត្ត (ឧ. vous en aurez à volonté); តាមបំណង (ឧ. billet payable à volonté)

volontiers *adv.* ដោយរីករាយ

voltaire *n.m.* កៅអីវ៉ុលទែរ,កៅអីមួយប្រភេទមានបង្អែកខ្ពស់

volte *n.f.* ការឲ្យសេះរត់វង់ ; ការគេចដោយបង្វិលខ្លួន

volte-face *n.f. inv.* ការបែរមុខត្រឡប់ (ឧ. faire volte-face) ។ *Fig.* ការប្រែត្រឡប់ (ការផ្លាស់មតិ ឬផ្លាស់របៀបភ្លាមៗ)

volter *v.i.* បង្វិលខ្លួន ។ *Manèg.* បំបរសេះជារង្វង់មូល។ *Mar.* បត់(នាវា)

voltige *n.f.*ខ្សែស្វា,ខ្សែសម្រាប់ស្វា; កីឡាយោលទោង (ឧ.exceller dans la voltige); កីឡាលោតជិះសេះ

voltigement *n.m.* ការហើរហើរ

voltiger *v.i.* ហើរហើរ (ដូចមេអំបៅ) (ឧ. les abeilles voltigent de fleur en fleur): រត់យ៉ាងលឿនដោយងាកខាងនេះបន្តិចខាងនោះបន្តិច; អណ្ដែតតាមខ្យល់; ស្វាខ្សែ ។ *Fig.* មានចរិតសាវ៉ា

voltigeur *n.m.* អ្នកយោលទោង (សៀក); ទាហានសម្រាំង (ពី គ.ស. ១៨០៤ ទៅ ១៨៧០)។ *Auj.* ទាហានទំពស្រួច (ថា grenadier voltigeur ក៏បាន)

volubile *a.Bot.* ដែលតោងព័ទ្ធ (វល្លិ-ជាត) (ឧ. les liserons sont volubiles)។ *Fig.* រឡាញ (ដែលនិយាយច្រើនហើយញាប់)

volubilis *n.m.Bot.* ម.ព. convolvulus

volubilité *n.f.* សំដីរឡាញ (ឧ. parler avec volubilité)

volume *n.m.* ក្បាល (សៀវភៅ) (ឧ. ouvrage en deux volumes); មាឌ, ទំហំ (ឧ. le volume d'un bloc de pierre); ទំហំ(នៃស្សូរ ឬ សំឡេង)

volumétrique *a.* នៃការវាស់ទំហំ (ឧ. analyse volumétrique)

volumineux,euse *a.* ធំ (ឧ.paquet volumineux); ដែលមានមាឌធំ, ក្រាស់

volumique *a.* យថាមាឌ ។ poids volumique ម.ព. poids

volupté *n.f.* កាមរតី [កា-មៈ-រ-តី], គយ្រេហ(ឧ.boire avec volupté); សេចក្ដីត្រេកអរ (ឧ. les voluptés du travail, de l'étude)

voluptuaire *a.* សម្រាប់តែសប្បាយ, សម្រាប់របស់ប្រណិត(ចំពោះចំណាយ)

voluptueusement *adv.* ដោយត្រេកត្រអាល

voluptueux,euse *a.* ដែលត្រេកត្រអាលនឹងកាមរតី ។ *n.* អ្នកត្រេកត្រអាលនឹងកាមរតី

volute *n.f. Arch.* ក្បាច់ហៀន ។ *Par ext.* អ្វីៗដែលព័ទ្ធពេន ឬ វិលវង់ (ឧ. des volutes de fumée)

volvacé,e *a.* ដូចចិង

vomi *n.m.* ការក្អួត; កំអួត

vomique *a.* noix vomique គ្រាប់ស្លែង

vomiquier *n.m.* ដើមស្លែង

vomir *v.t.* ក្អួត (ឧ. vomir son déjeuner) ។ *Par ext.* ព្រួស, ខ្ជាក់(ឧ. les canons vomissent le feu et la mort) ។ *Fig.* ស្រែកយ៉ាងខ្លាំង (ដោយកំហឹង) ។ vomir des injures ស្រែកជេរ

vomissement *n.m.* ការក្អួត (ឧ. l'épica provoque le vomissement)

vomissure *n.f.* កំអួត

vomitif,ive *a.* ដែលឲ្យក្អួត ។ *n.m.* ថ្នាំឲ្យក្អួត (ឧ. l'émétique et l'ipécacuanat sont les vo-

mitifs les plus usités)

vomito ឬ **vomito negro** *n.m.* (ព.អេស្ប៉ាញ៉ុល) គ្រុនលឿង

vorace *a.* ដែលស៊ីដោយល្មោភ (ឧ. le brochet est très vorace); ដែលត្រូវការម្ហូបច្រើន (ឧ. appétit vorace)

voracement *adv.* ដោយល្មោភ (ស៊ី)

voracité *n.f.* ការល្មោភស៊ីហួសប្រមាណ (ឧ. la voracité des loups)។ *Fig.* ល្មោភហួសប្រមាណ

vos *a.pos.* (ពហុវចនៈនៃ votre)

votant,e *a.* ដែលបោះឆ្នោត; ដែលមានសិទ្ធិបោះឆ្នោត ។ *n.* អ្នកបោះឆ្នោត

votation *n.f.* ការបោះឆ្នោត (ឧ. mode de votation)

vote *n.m.* ការបញ្ចេញមតិ,ការបោះឆ្នោត (ឧ. exécuter un vote)។ vote secret វិធីបញ្ចេញមតិសម្ងាត់, ការបោះឆ្នោតសម្ងាត់ ។ ឆ្នោត (មតិបញ្ចេញដោយបោះឆ្នោត) (ឧ. compter les votes)

voter *v.i.* បោះឆ្នោត ។ *v.t.* អនុម័ត, បញ្ចេញមតិបំពោះ (ឧ. voter une loi)

votif,ive *a.* នៃបំណន់;ដើម្បីឧទ្ទិសឬបួងសួង ។ fête votive ពិធីបួងសួង

votre *a.pos.sing.* ដ៏របស់អ្នក(ឬរបស់លោក) (ឧ. votre patrie)(*pl.* vos)

vôtre *pr. pos.* របស់អ្នក, របស់លោក (ឧ. mon père et le vôtre)។

n.m. le vôtre ទ្រព្យរបស់អ្នក (ឬរបស់លោក); ខ្ញុំបម្រើអ្នក (ឬលោក) (ស៊ូប្តូរនឹងលោក) (ឧ. je suis tout vôtre) ។

n.m. pl. les vôtres បងប្អូន-មិត្ត-ពួកអ្នក (ឬលោក)

vouer *v.t.* ថ្វាយ; បន់; បួងសួង; ឧទ្ទិស (ឧ. vouer un temple à Dieu); ថ្វាយខ្លួន (ឡើងយាក្សា) (ឧ. vouer son enfant à la vierge); សច្ចា (ឧ. l'amitié que je lui ai vouée); ប្រុងនឹង (ឧ. entreprise qui est vouée à l'échec) ។

se vouer *v.pr.* អធិដ្ឋានខ្លួន ។ ne savoir à quel saint se vouer មិនដឹងធ្វើដូចម្តេច

vouge *n.m.* លំពែងម្យ៉ាង (ប្រើក្នុងសតវត្សទី ១៣ ដល់ទី១៦); ផ្កាក់លះមែកឈើ

vouloir *v.t.* មានឆន្ទៈ, ចង់(ឧ. partez si vous voulez); ចង់បាន(ដោយអំណាច) (ឧ. je veux de meilleures copies); ចង់បាន, ត្រូវការ (ឧ. vous aurez tout ce que vous voudrez); ចង់បាន (ឧ. que veut-il de moi? តើគាត់ចង់បានអ្វីពីខ្ញុំ); ចង់បាន, កាត់ថ្លៃ (ឧ. vouloir tant de sa maison); ខំ (ឧ. enfant qui veut faire le grand garçon); ចង់ថា, ពោលអះអាងថា (ឧ. il veut que je sois paresseux) ។

Loc. div. vouloir bien ព្រម ។ vouloir du bien à quelqu'un ប្រាថ្នាល្អចំពោះអ្នកណាម្នាក់ (ឧ. ce regard voulait du bien à tout l'univers) ។ vouloir du mal à quelqu'un ប្រាថ្នាអាក្រក់ចំពោះអ្នកណាម្នាក់ (ឧ. il lui veut force mal) ។ se faire bien vouloir បានអ្នកណាម្នាក់ស្រឡាញ់ ។ se faire mal vouloir ធ្វើឲ្យអ្នកណាម្នាក់ស្អប់ (រករឿងប្រទូស) ។ vouloir dire ចង់ថា(ឧ. avant de parler il faut savoir ce qu'on veut dire); មានន័យថា (ឧ. vertu veut dire force) ។ faire de quelqu'un ce qu'on veut មានអំណាចខ្លាំងលើអ្នកណាម្នាក់ (អាចធ្វើអ្វីបានតាមចិត្ត) ។ être à bouche que veux-tu មានអ្វីគ្រប់យ៉ាងបរិបូរហូរហៀរ; បានអ្វីដូចបំណងទាំងអស់ ។ sans le vouloir ដោយអចេតនា, ដោយគ្មានបំណង ។

Prov. vouloir, c'est pouvoir តែចង់មុខជាបាន (បើគេប្រាថ្នាអ្វីដោយម៉ឺងម៉ាត់ គេមុខជានឹងបានសម្រេច) ។

v.t. ind. (de) ព្រម, ទទួល (ឧ. ne t'impose pas à ceux qui ne veulent pas de ton amitié) ។

v.t. en vouloir à ទាស់, គុំគួន (ឧ. l'envieux en veut à tout le monde); ប្រាថ្នា, ចង់បាន (ឧ. tout marchand en veut à notre bourse)

vouloir *n.m.* ឆន្ទៈ, បំណង(ឧ. votre vouloir est le mien); បំណង; ចេតនា (ឧ. mauvais vouloir)

vous *pr. pers.* (ពហុវចនៈនៃ tu) អ្នកទាំងអស់គ្នា; លោក; លោកទាំងអស់គ្នា

voussoiement *n.m.* ម.ព. vouvoiement

voûte *n.f.* ក្លោង ។ *Poét.* voûte azurée, étoilée ឬ céleste មេឃ

voûté,e *a.* ជាកង់ក្លោង (ឧ. une cave voutée) ។ *Par ext.* កោង ។ dos vouté ខ្នងកំពីស, ខ្នងកោង

voûter *v.t.* ធាក់ក្លោង (ឧ. vouter un souterrain) ។ *Par ext.* ធ្វើឲ្យទៀងកោង ។

se voûter *v.pr.* មានសណ្ឋានជាក្លោង; ទៀងកោងខ្នង

vouvoiement ឬ **voussoiement** *n.m.* ការហៅគ្នាលោក-អ្នក

vouvoyer,vousoyer ឬ **voussoyer** *v.t.* ហៅគ្នាលោក-អ្នក (និយាយទៅកាន់ដោយប្រើពាក្យ vous, មិនប្រើ tu, toi)

voyage *n.m.* ចរនាការ, ដំណើរ ។ voyage interplanétaire ចរនាការអន្តរភព។ faire le voyage de l'autre monde ឬ le grand voyage សុគត, បែកស្ពាន (ស្លាប់)

voyager *v.i.* ធ្វើដំណើរ ។

Prov. qui veut voyager loin ménage sa monture សន្សំមកុំបំពោល ព្រែកពុំដល់ខ្លួនប្រាជ្ញា

voyageur,euse *n.* អ្នកដំណើរ ។ voyageur de commerce អ្នកដើរសាវជំនួញ ។

a.m. commis voyageur ស៊ីប៊ិការពាណិជ

voyance *n.f.* ការបេះយ៉ាតមើលអតីតកាលនិងអនាគតកាល

voyant,e *a.* ដែលមើលឃើញ; ឆើត; ឆេប (ឧ. couleur voyante) ។

n. គ្រូបេះយ៉ាតមើលអតីតកាលនិងអនាគតកាល (ឧ. consulter une voyante) ។

n.m. អ្វីសម្រាប់មើលឃើញពីចម្ងាយ

voyelle *n.f.* ស្រៈ ។ voyelle inhérente វគ្គស្រៈ

voyer *n.m.* វិថីបាល, អ្នកថែទាំផ្លូវ ។

a. m. agent voyer ភ្នាក់ងារវិថីបាល .

voyou *n.m.* យូហ្គូម, ក្មេងអនាថា;មនុស្សពាល (*f.* voyoute)

vrac (en) *loc.div.* រាត់រាយ, រយ៉ក-

រយោក, ឥតខ្ចប់(ទំនិញ) (ឧ. expédier en vrac) ។ *Par ext.* រាត់រាយ

vrai,e *a.* ពិត, ស័ត្យ (ឧ. rien n'est vrai dans ce qu'il dit) ; ពិត, មែនទែន (មិនក្លែង) (ឧ. un vrai diamant); សម; សមគួរ; មែនទែន (ឧ. voilà sa vraie place) ។

n.m. សច្ចៈ, សេចក្ដីពិត (ឧ. aimer le vrai) ។

Loc. adv. à vrai dire ឬ à dire vrai តាមការពិត ។

Loc.div. au vrai ពិតមែន។ pour de vrai មែនទែន ។ au vrai, pour vrai ឬ dans le vrai ពិត (ស្រ. authentique, avéré, effectif, exact, juste, positif, réel, tangible, véridique, véritable)

vraiment *adv.* មែនទែន (ឧ. une aventure vraiment extraordinaire)

vraisemblable *a.* សមជាពិត, ទំនងជាពិត ។ *n.m.* អ្វីដែលសមជាពិត

vraisemblablement *adv.* ដោយសមជាពិត, ដោយទំនងជាពិត

vraisemblance *n.f.* ភាពសមជាពិត

vrillage *n.m.* ការរមួល (ភាពអម្បោះវេញ, ភាពខ្នាញ់ពេក)

vrille *n.f. Bot.* ដៃ (ទំពក់វល្លិ) ។ *Techn.* ដែកខួង, ដែកកណ្ដារ (ឧ. percer des trous avec une vrille) ។ *Filat.* ការរមួល, ការរលា (ចំពោះអម្បោះដែលគេវេញ រួចទុកឲ្យវាលាខ្លួនឯង) ។

Fig. yeux en vrille ភ្នែកតូចណាស់

vrillé,e *a.* *Bot.* ដែលមានដៃ (រុក្ខជាតិ) (ឧ. tige vrillée) ។ *Techn.* ដែលគេខួង ។ *Filat.* រួញរមួល (ឧ. ficelle vrillée par l'humidité)

vriller *v.t.* ខួង, ចារ (ឧ. vriller une planche) ។

v.i. ហោះបង្វិលខ្លួន (យន្តហោះ); ឡើងរមួល (ដោយរួញ) (ឧ. corde qui vrille)

vrombir *v.i.* បន្លឺស្នូរហ៊ូងៗ

vrombissement *n.m.* ស្នូរហ៊ូងៗ (ឧ. le vrombissement d'un moteur)

vu,e *a.* បានឃើញ ។ *Adm.* vu et accordé បានឃើញហើយព្រមឲ្យ ។

vu et approuvé. បានឃើញហើយយល់ព្រម ។ vu et autorisé បានឃើញហើយអនុញ្ញាត ។ vu et certifié exact បានឃើញហើយបានបញ្ជាក់ថាត្រឹមត្រូវ ។ vu, bon à payer បានឃើញហើយបើកប្រាក់ឲ្យចុះ ។ vu, bon à tirer បានឃើញហើយបោះពុម្ពចុះ ។ *Com.* vu, bon à virer បានឃើញហើយបង្វែរចុះ ។ vu, pour attache ម.ព. attache ។

Fig. être bien vu មានគេរាប់អាន ។ être mal vu គ្មានគេរាប់អាន (ឧ. être mal vu à cause de ses opinions) ។

pré. ដោយបានឃើញ (ឧ. vu la difficulté) ។

n.m. ទស្សនៈ, ការឃើញ (ឧ. au vu et au su de tout le monde) ។ vu que *loc. conj.* ដោយហេតុថា

vue *n.f.* ចក្ខុវិញ្ញាណ; ភ្នែក (ឧ. une vue perçante ភ្នែកមុត; détourner la vue de... ងាកភ្នែកចេញពី..); ការមើល (ឧ. regardez ces merveilles, la vue n'en coûte rien); ការពិនិត្យ, ការឃើញ (ឧ. à la vue de l'ennemi); ការមើលឃើញ; ទិដ្ឋភាព; ទេសភាពដែលគេឃើញពីកន្លែងមួយ (ឧ. cette maison a une belle vue); គំនូរទេសភាព ឬ រូប (ឧ. une vue du Phnom) ។ *Fig.* ការយល់ឃើញ; ការគិតារណា; គោលបំណង ។ *Dr.* បង្អួច (សម្រាប់មើលទីដីខាងក) (ឧ. le code réglemente les vues sur les propriétés voisines) ។

Loc. div. prise de vue ការថតភាពយន្ត ។ connaître de vue ស្គាល់តែមុខ (ដោយបានឃើញ) ។ à vue d'œil ស្រួតៗ, យ៉ាងរហ័ស (ឧ. cet enfant grandit à vue d'œil) ។ *Fam. & par plaisant.* à vue de nez ប្រាន់តែប្រមាណ ។ à perte de vue ជាប់កន្ទុយភ្នែក ។ perdre de vue លែងឃើញ; លែងមានការទាក់ទង; *fig.* ភ្លេច (ឧ. ne perdez pas de vue ce détail) ។ ne pas perdre de vue តាមឃ្លាំមើលឲ្យជាប់ ។ garder à vue ឃុំកក់ក្នុង

ឲ្យមើលឃើញជានិច្ច ។ garder quelqu'un à vue ឃ្លាំមើល ។ vue courte ឬ basse ការមើលឃើញជិត; ដំណើរមិនវាងវៃ ។ vue longue ការមើលឃើញឆ្ងាយ ។ à la première vue ឬ à première vue គ្រាន់តែឃើញម្ដង(នៅពេលឃើញដំបូង, មិនទាន់ពិនិត្យ) ។ point de vue ម.ព. point ។ au point de vue de តាមន័យ, តាម ។ être en vue ជាទីឲ្យគេមើលឃើញ;ជាទីឲ្យគេស្គាល់; មានគេរាប់អានច្រើន ។ dessin à vue គំនូរតាមទស្សនៈ ឬ តាមមើលឃើញ ។

en vue de *loc. pré.* ដើម្បីនឹង ។

pl. ទស្សនៈ, គ្រោងការ (ឧ. avoir des vues sur)

vulcanisation *n.f.* ការបញ្ចូលស្ពាន់ធ័រក្នុងកៅស៊ូ (ដើម្បីឲ្យជាប់)

vulcaniser *v.t.* បញ្ចូលស្ពាន់ធ័រក្នុងកៅស៊ូ (ដើម្បីឲ្យជាប់)

vulcanologie *n.f.* វិជ្ជាខាងភ្នំភ្លើង

vulcanologiste ឬ **vulcanologue** *n.* អ្នកប្រាជ្ញខាងភ្នំភ្លើង

vulgaire *a.* ទូទៅ,សាមញ្ញ(ឧ. esprit vulgaire) ; គម្រាំង, កម្រោល, គ្មានគួរសម (ឧ. manières vulgaires) ។ langue vulgaire ភាសាសាមញ្ញ (ភាសាដែលនិយាយជាធម្មតា ផ្ទុយនឹងភាសាសរសេរ ឬ ភាសាត្រឹមត្រូវ) ។

n.m. ប្រជាជន, មនុស្សសាមញ្ញ

vulgairement *adv.* តាមភាសាឬតាមរបៀបសាមញ្ញ; ដោយកម្រោល ឬ គ្មានគួរសម (ឧ. s'exprimer vulgairement)

vulgarisateur,trice *n.* ទូទៅការីការី, អ្នកផ្សាយចំណេះឬផ្សាយរបស់ថ្មី (ឧ. une encyclopédie est un merveilleux instrument de vulgarisation)

vulgarisation *n.f.* ទូទៅកម្ម, ការផ្សាយចំណេះឬរបស់ថ្មី ។ vulgarisation agricole ទូទៅកម្មខាងកសិកម្ម

vulgariser *v.t.* ធ្វើទូទៅកម្ម, ធ្វើឲ្យទៅជាសាមញ្ញ; ផ្សាយ (ឧ. vulgariser une science, un procédé)

vulgarisme *n.m.* របស់សាមញ្ញ; សំដី

សាមញ្ញ; គំនិតសាមញ្ញ

vulgarité *n.f.* ឧក្តានភាព, សាមញ្ញ-ភាព, ភាពសាមញ្ញ (ឧ. la vulgarité des manières)

vulgo *adv. Fam.* តាមភាសា ឬ របៀបសាមញ្ញ

vulnérabilité *n.f.* ភេទនីយភាព, ភាពអាចធ្វើឲ្យរបួសបាន

vulnérable *a.* ភេទនីយ៍, អាចធ្វើឲ្យរបួសបាន ។ *Fig.* អាចរិះគន់បាន, ដែលមានកំហុស; សៅហ្មង (ឧ. position vulnérable)

vulnéraire *a.* សម្រាប់ព្យាបាលរបួស ។ *n.m.* ថ្នាំរបួស

vultueux,euse *a.* ហើមឡើងក្រហម (មុខ)

vultuosité *n.f.* ភាពមុខហើមឡើងក្រហម

vulve *n.f.* យោនី (អង្គជាតស្ត្រីឬសត្វញី)

vulvite *n.f.* រោគរលាកយោនី



w *n.m.* អក្សរទី ២៣ នៃអក្ខរក្រមឡាតាំង

wagage *n.m.* ល្បប់ (សម្រាប់ប្រើជាដី)

wagnérien,enne *a. Mus.* នៃលោកវ៉ាគនែរ (អ្នកភ្លេងជាតិអាល់ឡឺម៉ង់) (ឧ. thème wagnérien) ។
n. បក្សពួកវ៉ាគនែរ

wagnérisme *n.m.* វ៉ាគនែរនិយម

wagon *n.m. Ch. de fer* ទូ,រថ(អយស្ម័យយាន) ។ wagon à marchandises ទូទំនិញ ។ wagon à voyageurs ទូជិះដើរ

wagon-bar *n.m.* រថមង្គាគារ, រថភៀមស្រា(គេប្រើជា voiture-bar ផង) (*pl.* des wagons-bars)

wagon-citerne *n.m.* ព.ម. wagon-réservoir (*pl.* des wagons-citernes)

wagon-foudre *n.m.* រថភេសជ្ជៈ (*pl.* des wagons-foudres)

wagon-lit *n.m.* រថគេងលក(គេប្រើជា voiture-lit ផង) (*pl.* des wagons-lits)

wagonnée *n.f.* ចំណុះទូ (អយស្ម័យយាន)

wagonnet *n.m.* កូនទូ (កូនទូអយស្ម័យយានសម្រាប់ដឹកដី)

wagonnette *n.f.* រថកង់បួនម៉្យាងតូចទាប

wagonnier *n.m.* កម្មកររុញកូនទូ

wagon-poste *n.m.* រថប្រៃសណីយ៍

(*pl.* des wagons-poste)

wagon-réservoir *n.m.* រថដឹកវត្ថុរាវ (*pl.* des wagons-réservoirs)

wagon-restaurant *n.m.* រថភោជនាគារ, រថអាហារ(គេប្រើនឹង voiture-restaurant ផង) (*pl.* des wagons-restaurants)

wagon-tombereau *n.m.* ម.ព. truc

walk-over *n.m.* ការត់ម្នាក់ឯង; អ្នកឈ្នះឯង(ដោយគូប្រកួតសុំញ៉មជាដើម) (ឧ. gagner par walk-over) (ពាក្យបំប្រួញ : W-O.)

warrant [va-ran] *n.m.* អធិប័ត្រ ។ warrant agricole អធិប័ត្រកសិកម្ម ។ warrant hôtelier អធិប័ត្រសណ្ឋាគារ ។ warrant industriel អធិប័ត្រឧស្សាហកម្ម ។ warrant pétrolier អធិប័ត្រប្រេងកាត

warrantage *n.m.* ការចេញអធិប័ត្រ

warranté,e *a.* ដែលធានាអធិប័ត្រ

warranter *v.t.* ចេញអធិប័ត្រ

water-closet [oua-tèr-clo-zèt] *n.m.* វច្ចកុដិ, បង្គន់ (ពាក្យបំប្រួញ W.-C.) (*pl.* des water-closets)

water-polo *n.m.* វ៉ាទ័រប៉ូឡូ (កីឡាបាល់លេងក្នុងទឹក)

waterproof *n.m.* អាវភ្លៀង

watt [ouat'] *n.m.* វ៉ាត់ (មាត្រាបរិវត្ត-អគ្គិសនី)

w.-c. (ពាក្យបំប្រួញនៃ water-closet)

week-end [ouik-ènd'] *n.m.* ពេលសម្រាកចុងសប្តាហ៍

whisky *n.m.* វីស្គី (ស្រា)

X

x [iks] *n.m.* អក្សរទី ២៤ នៃអក្ខរក្រមឡាតាំង (ឧ. le «x» est une consonne double) ។ X (លេខរ៉ូម៉ាំង) ១០ ។ rayons X ម.ព. rayon

xénon *n.m.* សេណុង (ឧស្ម័នម្យ៉ាង)

xénophile *a.* ដែលចូលចិត្តជនបរទេស

xénophilie *n.f.* ការចូលចិត្តជនបរទេស

xénophobe *a.* ដែលស្អប់ជនបរទេស

xénophobie *n.f.* ការស្អប់ជនបរទេស

xylographe *n.* ជាងឆ្លាក់ឈើ

xylographie *n.f.* សិល្បៈខាងឆ្លាក់ឈើ; ការបោះពុម្ពដោយផ្ទាំងឈើ

xylographique *a.* នៃសិល្បៈខាងឆ្លាក់ឈើ; នៃរបៀបបោះពុម្ពដោយផ្ទាំង

ឈើ

xylométrie *n.f.* ការកំស់ឈើជាម៉ែត្រគីប

xylophage *a. & n.* ដែលស៊ីឈើ (ពាណកសត្វ)

xylophone *n.m.* រនាត

Y

y *n.m.* អក្សរទី ២៥ នៃអក្ខរក្រមឡាតាំង

y *adv.* នៅទីនោះ ។ il y a មាន ។ *pr. pers.* ដល់នោះ, ដល់មនុស្សនោះ (ឧ. ne vous y fiez pas)

yacht *n.m.* នាវាកំសាន្ត

yachting *n.m.* ផលកីឡា, ការបើកនាវាកំសាន្ត

yachtsman *f.*, **yachtswoman** *n.* អ្នកបើកនាវាកំសាន្ត (*pl.* des yachtsmen; des yachtswomen)

yack ឬ **yak** *n.m.* ពាមរី (បុរាណហៅចៀមពាមរី)

yankee *n.* យ៉ង់គី, ជនជាតិអាមេរិក ។ *a.* នៃជនជាតិអាមេរិក (ឧ. mœurs yankees)

yaourt *n.m.* ម.ព. yogourt

yard *n.m.* យ៉ារ (រង្វាស់អង់គ្លេសប្រវែង ០,៩១៤ម.

yatagan *n.m.* យ៉ាតាហ្គង់ (ដាវឬកាំបិតស្នៀតនៃជនជាតិទួរគី)

yen *n.m.* យ៉េន (រូបិយវត្ថុជប៉ុន)

yersin (bacille de) ទណ្ឌាណូយែរស័ង (មេរោគប៉េស្តដែលយែរសាំងរកឃើញ)

yeux *n.m. pl.* (ពហុវចនៈនៃពាក្យ œil) ភ្នែក

ylang-ylang [i-lan-i-lan] *n.m.* ម.ព. ilang-ilang

yoga *n.m.* យោគ (ការបម្រើនកម្មដ្ឋាន)

yogi [yo-gui] *n.m.* យោគីឬយោគិន (អ្នកបម្រើនកម្មដ្ឋាន)

yogourt *n.m.* ទធិ, យ៉ាអួរ, ទឹកដោះជូរ

yole *n.f.* យ៉ូល (ទូកតូចវែងស្រាល) (ឧ. yole à plusieurs rameurs)

youga *n.f.* យុគ (អាយុពិភពលោក)

yougoslave *a.&n.* នៃប្រទេសយូហ្គូស្លាវី

youpin,e *a.&n.Pop.&péjor.* ជនជាតិស៊ីហ្វ

youyou *n.m.* យូយូ (ទូកម៉្យាង)

yoyo *n.m. inv.* យ៉ូយ៉ូ (ល្បែងម៉្យាង)

ysopet *n.m.* កម្រងរឿងល្បើក (នៅយុគកណ្ដាល) (ឧ. les ysopets de Marie de France)

Z

z *n.m.* អក្សរទី ២៦ នៃអក្ខរក្រមឡាតាំង

zagaie ម.ព. sagaie

zain *a.m.* ដែលគ្មានរោមសសោះ (សេះ ឬ ឆ្កែ)

zèbre *n.m.* សេះបង្កង់។ *Pop.* មនុស្ស (ឧ. quel drôle de zèbre!)។ *Fam.* courir comme un zèbre រត់លឿនដូចសេះ

zébré,e *a.* ដែលមានបង្កង់; ឆ្នូត (ឧ. étoffe zébrée)

zébrer *v.t.* គូសឆ្នូត (ឧ. zébrer une couverture de voyage); គូសក្រវេមក្រវាម (ឧ. les éclairs zèbrent un ciel d'orage)

zébrure *n.f.* បង្កង់, ឆ្នូតនៅស្បែក

zébu *n.m.* ឧសភៈ [អ៊ុ-សះ-ភៈ], គោមានបូក

zélateur,trice *n.&a.* ដែលធ្វើការដោយរឿសរវៃ

zèle *n.m.* យតិភាព, ការខ្នះខ្នែង, ការរឿសរវៃ។ *Fam.* faire du zèle ធ្វើជាខ្នះខ្នែង (សរ. application, ardeur, émulation, enthousiasme, entrain)

zélé,e *a.* ខ្នះខ្នែង, រឿសរវៃ

zénith *n.m.* មណ្ឌលមេឃនៅចំពីលើក្បាល ។ *Fig.* កំពូល (ឧ. sa gloire est au zénith) (ព.ផ. nadir)

zéophage *n.&a.* វារកភក្ស [វា-រៈ-កៈ–], ដែលបរិភោគពោតជាអាហារ

zéphyr ឬ **zéphyre** *n.m.* ខ្យល់ល់ហើយ; ព្រះពាយ; សំពត់ស្តើង

zéphyrien,enne *a.* ស្រាលដូចខ្យល់ (ឧ. danse zéphyrienne)

zéphyrine *n.f.* សំពត់ពណ៌

zeppelin *n.m.* ប៉័ល្លុងហោះមានឆ្អឹងដែក

zéro *n.m.* លេខសូន្យ; សូន្យ ។ *Fig.* មនុស្សមិនបានការ (ឧ. c'est un zéro); សូន្យ, ភាពគ្មានអ្វីសោះ (ឧ. fortune réduite à zéro) ។

a. សូន្យ, គ្មានសោះ (ឧ. zéro faute; zéro riels)

zérotage *n.m.* ការកម្រិតសូន្យ (សីតុណ្ហមាត្រ)

zest *n.m.* entre le zist et le zest មិនល្អមិនអាក្រក់

zeste *n.m.* សំបកក្រូច ។ *Fig.* របស់គ្មានតម្លៃ (ឧ. cela ne vaut pas

un zeste)

zester *v.t.* ចិតស្បែកក្រូច

zieuter *v.t. Pop.* មើល, ចោលភ្នែក

zig ឬ **zigue** *n.m. Pop.* មនុស្ស (ឧ. un bon zig)

zigouiller *v.t. Pop.* កាប់សម្លាប់

zigzag *n.m.* បន្ទាត់ក្ងិចក្ងក់ ។ en zigzag ក្ងិចក្ងក់

zigzagué,e *a.* ក្ងិចក្ងក់ (ឧ. éclair zigzagué)

zigzaguer *v.i.* ធ្វើក្ងិចក្ងក់; ដើរក្ងិចក្ងក់

zinc *n.m.* ស័ង្កសី; យន្តហោះ

zincage *n.m.* ម.ព. zingage

zincifère *a.* ដែលមានជាតិស័ង្កសី (ឧ. minerai zincifère)

zincographie ឬ **zincogravure** *n.f.* ការបោះពុម្ពដោយប្រើស័ង្កសី

zingage ឬ **zincage** *n.m.* ការពាសស័ង្កសី; ភាពពាសស័ង្កសី

zingibéracé,e *a.* នៃខ្ញី ។ *n.f. pl.* សន្តានខ្ញី (ឬ រមៀត)

zinguer *v.t.* ប្រក់ស័ង្កសី(ឧ. zinguer un toit); ពាសស័ង្កសី (ឧ. zinguer du fer)

zingueur *n. & a. m.* ជាងស័ង្កសី

zinguerie *n.f.* ជំនួញស័ង្កសី; កន្លែងធ្វើស័ង្កសី

zircon *n.m.* ពេជ្រថៃ

zizanie *n.f.* ស្មៅតែលលក (ភាសាក្នុងគម្ពីរគ្រិស្តសាសនា)។ *Fig.* ការបែកបាក់គ្នា, ការទាស់ទែងគ្នា (ឧ. semer la zizanie)(ប្រ. brouille, désaccord, mésentente, mésintelligence)

zist *n.m. inv.* ម.ព. zest

zizyphe *n.m. Bot.* ម.ព. jujubier

zodiacal,e, aux *a.* នៃរាសីចក្រ (ឧ. étoile zodiacale)

zodiaque *n.m. Astr.* រាសីចក្រ

zonal,e, aux *a. Hist nat.* ដែលមានបង្កង់ពណ៌ (ឧ. spondyle zonal)

zone *n.f.* មណ្ឌល (ឧ. zone frontière)។ *Hist. nat.* ស្នាមមណ្ឌល ។ *Fig.* មណ្ឌល (ឧ. zone d'influence) ។

zoné,e *a.* ដែលមានស្នាមមណ្ឌល (ឧ. colline zonée)

zonier,ère *a.* នៃមណ្ឌលព្រំដែន

zoo *n.m.* (ពាក្យបំព្រួញនៃ jardin zoologique ម.ព. jardin)

zoobiologie *n.f.* សត្វជីវវិទ្យា

zoogéographie *n.m.* សត្តភូមិសាស្ត្រ (ការសិក្សាអំពីរបៀបបែកសត្វលើផែនដី)

zoolâtre *n.&a.* អ្នកសត្តនមស្សនា, អ្នកធ្វើសក្ការៈដល់សត្វ

zoolâtrie *n.f.* សត្តនមស្សនា [ស័ត-តៈ-នៈ-ម័ស-សៈ-នា], ការធ្វើសក្ការៈដល់សត្វ (ឧ. l'Egypte pratiquait la zoolâtrie)

zoologie *n.f.* សត្តវិទ្យា (ឧ. Cuvier a renouvelé la zoologie)

zoologique *a.* នៃសត្តវិទ្យា ។ jardin zoologique ម.ព. jardin

zoologiquement *adv.* តាមសត្តវិទ្យា

zoologiste ឬ **zoologue** *n.m.* សត្តវិទូ

zoomorphisme *n.m.* ការធ្វើឲ្យមានរាងជាសត្វ

zoonomie *n.f.* សត្តសាស្ត្រ (ច្បាប់ធម្មជាតិទាំងឡាយដែលគ្រប់គ្រងជីវិតសត្វ)

zoophage *a.* សត្តភក្ស (ដែលស៊ីសាច់សត្វ)

zoophagie *n.f.* សត្តភក្សា (ការស៊ីសាច់សត្វ)

zoophobie *n.f.* ការខ្លាចសត្វខ្លះ

zoophyte *n.m.* សត្តភូតគាម (សត្វដែលមានរូបរាងជារុក្ខជាតិ)

zoopsie *n.m.* *Méd.* ការមមាលឃើញសត្វ (ឧ. les zoopsies sont fréquentes chez les alcooliques)

zootechnicien,enne *n.* ការចិញ្ចឹមសត្វ (សម្រាប់ប្រើការអ្វីម្យ៉ាង)

zootechnie *n.f.* ការចិញ្ចឹមសត្វ (សម្រាប់ប្រើការអ្វីម្យ៉ាង) (ឧ. la zootechnie est une branche importante de l'agriculture)

zoothérapeutique *a.* នៃការព្យាបាលសត្វ

zoothérapie *n.f.* ការព្យាបាលសត្វ

zouave ឬ **zouzou** *n.m.* ហ្ស៊ូអាវ (ទាហានកងទ័ពបារាំងនៅអាល់ហ្សេរី)

zut ! *int.* *Pop.* ហ្ស៊ុត (ឧទានស័ព្ទសំដែងសេចក្តីមើលងាយ, សេចក្តីព្រងើយកន្តើយ)

zygote *n.m.* ម.ព. œuf

Achevé d'imprimer
sur les presses de l'imprimerie
OUK-MEY-KOL
12 R Vithei Pasteur prolongé
en Avril 1964.
Tirage 5.000 exemplaires.
Dépôt légal 2e trimestre 1964